## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន កម្រិតបរិញ្ញាបត្រ

# មុខវិជ្ជា៖

# ប្រវត្តិសាស្ត្រសាកលលោក

**កញ្ចប់សមត្ថភាពទី១**

**ចំណេះដឹងឯកទេសបរិញ្ញាបត្រ**



# មុខវិជ្ជា៖
# ប្រវត្តិសាស្ត្រសកលលោក

កញ្ចប់សមត្ថភាពទី ១
ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

**លទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុកទី ១៖

លទ្ធផលសិក្សារំពឹងទុកទី ២៖

លទ្ធផលសិក្សារំពឹងទុកទី ៣៖

លទ្ធផលសិក្សារំពឹងទុកទី ៤៖

លទ្ធផលសិក្សារំពឹងទុកទី ៥៖

**របាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

**កិច្ចការគ្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖

កិច្ចការទី ២៖

កិច្ចការទី ៣៖

កិច្ចការទី ៤៖

កិច្ចការទី ៥៖

# អារម្ភកថា

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន តាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃចន្ទ ៦រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ប៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អឌ្ឍារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សូត្រ** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក ភារម៉េរ៉ាន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់អឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាតិ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត វិសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន គឹមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ូ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ីម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ឡៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អឌ្ឍារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ម៉ៅ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

## ៤. ការរីកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ារ៉ាឌី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **ឌន សំណាង** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់-ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសរូបវិទ្យាប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសប្រវត្តិវិទ្យាកម្រិតបរិញ្ញាបត្រ**

- ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ
- ប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប
- ទ្រឹស្តីប្រវត្តិសាស្ត្រ
- ប្រវត្តិសាស្ត្រពិភពលោក
- ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍
- ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- សន្ទឹកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា

**(២) ចំណេះដឹងវិធីគរុកោលស្យ សាស្ត្របង្រៀន និងការអប់រំប្រវត្តិវិទ្យាកម្រិតមធ្យមសិក្សា**

- វិធីសាស្ត្របង្រៀន
- វិធីសាស្ត្រវង្វាយតម្លៃ
- ការស្រាវជ្រាវប្រតិបត្តិ
- ប្រឹក្សាគរុកោសល្យ
- បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោលស្យ និងការអនុវត្តជាក់ស្តែង**

- អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ការអនុវត្តកម្មវិធីស្វ័យសិក្សារូបវិទ្យា ពីទីថ្នាក់៧-ទី១២
- របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្ហឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនប្រវត្តិវិទ្យាប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនរូបវិទ្យា និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

## កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្តោតលើបណ្តុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្តងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្តែងកន្លងមក ។

| បណ្តុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្តុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ | ៣ |
| | ប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប | ៣ |
| | ទ្រឹស្តីប្រវត្តិសាស្ត្រ | ៣ |
| | ប្រវត្តិសាស្ត្រពិភពលោក | ៣ |
| | ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |

| | | |
|---|---|---|
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និង ការអប់រំមធ្យមសិក្សា (២០%) | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ* | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សា គរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រ សហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹងវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។


ការចាប់ផ្តើមនៃប្រវត្តិសាស្ត្រ
ឧទ្ទេសដោយ៖ សាស្ត្រាចារ្យជំនួយ គួង គានី


ប្រវត្តិសាស្ត្រ
សម័យបុរេប្រវត្តិសាស្ត្រ
សម័យប្រវត្តិសាស្ត្រ
អតីតកាល
បច្ចុប្បន្ន
កំណត់ត្រា


Homo habilis
Homo erectus
Homo neanderthalensis
Homo sapiens


Denisova Cave
Admixture between Denisovans and H. erectus
Neanderthal admixture
Admixture with archaic African hominins
Admixture with Denisovan-like population or H. erectus
Wallace's phenotypic boundary
Possible ranges of archaic forms
Neanderthals
Denisovans
H. erectus
Archaic African hominins



## បុរេប្រវត្តិសាស្ត្រ

- បុរេប្រវត្តិសាស្ត្រ៖ ចាប់ពីពេលដែលមនុស្សកើតឡើងដំបូងរហូតដល់ការចេះកត់ត្រា។
- បុរេប្រវត្តិសាស្ត្រត្រូវបានសិក្សាតាមរយៈសំណល់បុរាណវិទ្យា។
- ជាទូទៅបុរេប្រវត្តិសាស្ត្រត្រូវបានគេបែងចែកជា ៣ យុគ។








| យុគថ្មបំបែក | យុគថ្មរំលីង | យុគលោហៈ |
|---|---|---|

## យុគថ្មបំបែក



- សេដ្ឋកិច្ចគ្រួសារ៖ បរបាញ់, នេសាទ, ប្រមូលក្នុងព្រៃ។
- ឧបករណ៍៖ មានលក្ខណៈធម្មជាតិដែលធ្វើពីថ្ម, ឈើ, ឆ្អឹង
- ការរស់នៅ៖ ជាលក្ខណៈគ្រួសារ ឬហ្វូង។
- ផ្លាស់ទីពីមួយកន្លែងទៅមួយកន្លែង
- ជំនឿ៖ ជីវចលនិយម



## យុគថ្មរំលីង



- សេដ្ឋកិច្ចគ្រួសារ៖ ដាំដុះ, ចិញ្ចឹមសត្វ, ត្បាញ, សិប្បកម្ម...
- ឧបករណ៍ប្រើប្រាស់៖ ឧបករណ៍ធ្វើពីថ្មរំលីង, ភាជន៍, ក្រណាត់...
- ទីលំនៅ៖ រស់នៅក្នុងផ្ទះ
- រស់នៅមួយកន្លែងក្បែរប្រភពទឹក។
- រស់នៅជាភូមិ
- ជំនឿ៖ ជីវចលនិយម, ព្រលឹងដូនតា។



## កសិកម្ម

- ដាំដុះ៖ ស្រូវមីយេ, ស្រូវសាលី, ស្រូវអង្ករ, ដំណាំមើម, បន្លែ, ផ្លែឈើ។
- ចិញ្ចឹមសត្វ៖ ឆ្កែ, ជ្រូក, គោ-ក្របី។





## ការផលិតភាជន៍

- សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និង សម្រាប់រក្សាទុកចំណីអាហារ។
- ចេះពីរបៀបគ្រប់គ្រងភ្លើង។








## យុគលោហៈ

- សេដ្ឋកិច្ចគ្រួសារ៖ ស្មិតលោហៈ, ផ្លោះប្តូរ, ការងារជំនាញ, អ្នកគ្រប់គ្រង, បព្វជិត។
- ឧបករណ៍ប្រើប្រាស់៖ ឧបករណ៍ធ្វើពីទង់ដែង, លង្ហិន, និងដែក។
- ទីលំនៅ៖ ភូមិស្រុកស្អាញ និងទីក្រុង
- ចំណីលើស
- ផ្លោះប្តូរទំនិញ

## ភូមិកសិកម្ម

- គ្រួសារតិច
- ភាគច្រើនជាកសិករ



## ភូមិស្មុកស្មាញ

- គ្រួសារច្រើន
- ការងារចម្រុះ៖ កសិករ, កម្មករជំនាញ, ពាណិជ្ជករ




## ទីក្រុង

- មជ្ឈមណ្ឌលនយោបាយ, វប្បធម៌, និងសេដ្ឋកិច្ច។
- សេដ្ឋកិច្ចលែងពឹងលើកសិកម្ម។






## បុរី-រដ្ឋ

- ទីក្រុងមួយហ៊ុំព័ទ្ធជុំវិញដោយភូមិកសិកម្ម។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ
ប្រភពហិរញ្ញប្បទាន៖ គម្រោងកែលម្អការអប់រំចំណេះទូទៅ

# ប្រវត្តិសាស្ត្រពិភពលោក




រៀបរៀងដោយ៖
គួច គានី


2022

CAMBODIA
RESEARCH CREATIVITY INNOVATION


គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# ប្រវត្តិសាស្ត្រពិភពលោក

រៀបរៀងដោយ៖
គួង គានី
2022

ឧបត្ថម្ភការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
# មហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ
# ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

## គណៈកម្មការនិពន្ធ

១. លោក **គួង គានី** — សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

## គណៈកម្មការត្រួតពិនិត្យ

១. លោកបណ្ឌិត **វង់ សុជាវ៉ា** — ប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
២. លោក **ណុប សុខា** — អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
៣. លោក **ធូ រេណូ** — ប្រធានការិយាល័យស្រាវជ្រាវ

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ 1998 កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ 8% ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ 53% នៅឆ្នាំ 2004 មកនៅទាបជាង 10% នៅឆ្នាំ 2019 ។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ 2050 ។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី 4 និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ 44% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការ វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវ ជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូនិងអាហ្វ្រិក មានប្រមាណ 5% នៃការវិនិយោគ ទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង 2 នេះមានប្រជាជនប្រមាណ20% នៃប្រជាជន ពិភពលោក។ ប្រទេសចំនួន 6 ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ 70% នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី 4 នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជាត្រូវ

ក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ 2002 នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labor and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំគឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែក លើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និង

តម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង 2,2 លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន 440 ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន 305 ពាន់ និងប្រទេសរុស្ស៊ីមាន 120 ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-19 ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថល ដែលមានភាពសម្បូរបែប ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ 2020 ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន3 រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម 4.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី 21 (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ 2020 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណ

ភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

1. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
2. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជាកម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
3. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
4. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច 2 ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់

## របស់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរ និងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# អារម្ភកថា

សៀវភៅនេះត្រូវបានរៀបរៀងឡើងក្រោមការឧបត្ថម្ភគាំទ្ររបស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ សម្រាប់ទុកជាសៀវភៅសិក្សាគោលដើម្បីបម្រើឱ្យការរៀន និងបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រពិភពលោកក្នុងដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃមហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សៀវភៅនេះ ផ្តល់ជូនអ្នកសិក្សានូវចំណេះដឹងស្តីអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងពិភពលោកចាប់តាំងពីសម័យបុរាណរហូតដល់សម័យទំនើប ដែលអាចសមល្មមឱ្យអ្នកសិក្សាប្រវត្តិសាស្ត្រទាំងឡាយមានមូលដ្ឋានគ្រឹះរឹងមាំក្នុងការសិក្សាបន្ត ឬស្រាវជ្រាវបន្ថែម ឬក្នុងការប្រកបការងារផ្សេងៗក្នុងវិជ្ជាជីវៈរបស់ខ្លួន។ មិនតែប៉ណ្ណោះ សៀវភៅនេះក៏អាចចាត់ទុកជាឯកសារពិគ្រោះសម្រាប់អ្នកស្នេហាប្រវត្តិសាស្ត្រផងដែរ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ គួង គានី ជាសាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃមហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាអ្នករៀបរៀងសៀវភៅសិក្សាដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រពិភពលោក"។ ខ្ញុំបាទសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងសូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ថវិកាមកក្រសួងអប់រំ ដើម្បីបង្កើតជាមូលនិធិសម្រាប់គាំទ្រដល់ការសរសេរសៀវភៅសិក្សាសម្រាប់កម្រិតឧត្តមសិក្សារបស់ខ្ញុំបាទនេះ។

- ក្រសួងអប់រំ យុវជន និងកីឡា ដែលមានឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ជួន ណារ៉ុន ជាប្រមុខ ដែលលោកបានដឹកនាំបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ឡើង ដើម្បីគាំទ្រទាំងស្រុងដល់ដំណើរការសរសេរសៀវភៅនេះ ដែលជាចំណែកមួយក្នុងបេសកកម្មកំណែទម្រង់វិស័យអប់រំឧត្តមសិក្សា។

- ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលក្នុងនាមលោកជាតំណាងមូលនិធិ លោកបានយកអស់កម្លាំងការចិត្ត ជួយចាត់ចែងនិងជ្រោមជ្រែងយ៉ាងពេញទំហឹង ព្រមទាំងផ្តល់ជាអនុសាសន៍និងដំណោះស្រាយនានា ដើម្បីជំនះនូវរាល់ឧបសគ្គដែលកើតមានក្នុងដំណើរការសរសេរសៀវភៅនេះ។

- ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានយកអស់កម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មមាញឹកនិងមានតម្លៃរបស់លោកក្នុងការជួយលើកទឹកចិត្ត ជួយខ្នះ ខ្នែងដោះស្រាយ និងផ្តល់អនុសាសន៍ដ៏ត្រឹមត្រូវ ក៏ដូចជាបង្កលក្ខណៈងាយស្រួលនានា ទាំងផ្នែករដ្ឋបាល និងទាំងផ្នែកបច្ចេកទេស ដើម្បីឲ្យដំណើរការរៀបរៀងសៀវភៅនេះបានប្រព្រឹត្តទៅដោយរលូនរហូតចប់ចុងចប់ដើម។

- លោក លួន ពេជ្របូរី និង អស់លោក-លោកស្រី ជាក្រុមការងារសម្របសម្រួលទាំងអស់របស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានយកអស់កម្លាំងកាយចិត្ត ជួយឈឺឆ្អាលក្នុងការដោះស្រាយបញ្ហាប្រឈមនានាយ៉ាងសស្រាក់សស្រាំជាទីបំផុត ដោយមិនត្អូញត្អែរ និងមិនខ្លាចនឿយហត់ ដើម្បីឲ្យការសរសេរសៀវភៅនេះប្រព្រឹត្តទៅដោយរលូន។

- ឯកឧត្តមបណ្ឌិត ស្រ៊ីវ ថារិទ្ធ អ្នកសម្របសម្រួលសាលាក្រោយឧត្តម និងលោកបណ្ឌិត សុខ សិរី អនុប្រធានការិយាល័យស្រាវជ្រាវ ដែលតែងជួយឈឺឆ្អាល ជួយសម្របសម្រួល និងផ្តល់សេវាសម្រាប់ការប្រជុំបច្ចេកទេសនានាតាមអនឡាញតាំងពីដើមរៀងមក។

- អស់លោក-លោកស្រី ជាសមាជិក-សមាជិកាគណៈកម្មការអភិវឌ្ឍសៀវភៅសិក្សា ក៏ដូចជាគណៈកម្មការត្រួតពិនិត្យសៀវភៅសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយផ្តល់ធាតុចូលដល់សៀវភៅនេះឲ្យកាន់តែមានគុណភាពប្រសើរថែមទៀត។

- ជាចុងក្រោយ និងជាពិសេស លោក ធូ រេណូ ប្រធានការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលតែងជួយផ្តល់ធាតុចូលចំពោះរាល់ឯកសារការងារ ទាំងផ្នែករដ្ឋបាលនិងទាំងផ្នែកបច្ចេកទេស លោកថែមទាំងជួយសម្រួលរាល់បញ្ហាប្រឈមនានាយ៉ាងជិតដល់បំផុត ដោយមិនប្រកាន់ពេលវេលា និងដោយចិត្តជ្រះថ្លារហូតការសរសេរសៀវភៅនេះទទួលបានជោគជ័យជាស្ថាពរ។

# មាតិកា

**បុព្វកថា** ..... i
**សេចក្តីបញ្ជាក់** ..... vi
**អារម្ភកថា** ..... vii
**សេចក្តីថ្លែងអំណរគុណ** ..... viii
**មាតិកា** ..... ix
**ជំពូក 1 ៖ សេចក្តីផ្តើម** ..... 1
មេរៀនទី 1 ៖ សារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ..... 1
1. និយមន័យរបស់ប្រវត្តិសាស្ត្រ ..... 1
2. ប្រវត្តិសាស្ត្រជាវិទ្យាសាស្ត្រ ឬជាសិល្បៈ? ..... 2
3. តម្លៃនៃប្រវត្តិសាស្ត្រ ..... 3
4. ប្រវត្តិសាស្ត្រ និងមុខវិជ្ជាផ្សេងៗ ..... 5
មេរៀនទី 2 ៖ ប្រវត្តិសាស្ត្រពិភពលោក និងដែនកំណត់របស់វា ..... 8
1. តម្រូវការនៃការសិក្សាប្រវត្តិសាស្ត្រពិភពលោក ..... 8
2. ការកំណត់រយៈកាលនៃប្រវត្តិសាស្ត្រពិភពលោក ..... 9
3. វប្បធម៌ និងអរិយធម៌ ..... 9
4. កត្តាដែលនាំឱ្យលេចឡើង និងការអភិវឌ្ឍវប្បធម៌ ..... 10
មេរៀនទី 3 ៖ មនុស្សសម័យបុរេប្រវត្តិសាស្ត្រ ..... 13
1. ដើមកំណើត និងជីវិតនៃផែនដី ..... 13
2. មនុស្សដំបូងបំផុត ..... 13
3. យុគថ្មចាស់ (ថ្មីបំបែក) ..... 14
4. ការធ្វើចំណាកស្រុករបស់ក្រុមអម្បូរមនុស្ស ..... 14
5. យុគថ្មថ្មី (ថ្មរំលីង) ..... 15
6. សិល្បៈថ្មរំលីង ..... 15
7. យុគលោហៈ ..... 16
8. អម្បូរនៃមនុស្សជាតិ ..... 16
មេរៀនទី 4 ៖ ការសិក្សាពីប្រវត្តិសាស្ត្រ និងមនុស្សដំបូង ..... 18
1. ការយល់ដឹងពីអតីតកាល ..... 18
2. ប្រភពឯកសារដើម និងឯកសារទី 2 ..... 18
3. មនុស្សដំបូងគឺជាអ្នកបរបាញ់ និងបេះផ្លែឈើ ..... 19

4. ការអភិវឌ្ឍឧបករណ៍ប្រើប្រាស់ និងវប្បធម៌ ..... 20
5. ការចាប់ផ្តើមឡើងនៃកសិកម្ម ..... 21
មេរៀនទី 5 ៖ សហគមន៍ដំបូង ..... 23
1. ការតាំងទីលំនៅដំបូង ..... 23
2. ភូមិសាមញ្ញាបានវិវត្តកាន់តែស្មុគស្មាញ ..... 24
**ជំពូក 2 ៖ មេសូប៉ូតាមី និងដែនដីអឌ្ឍចន្ទប្រកបដោយជីជាតិ** ..... 26
មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រមេសូប៉ូតាមីសម័យបុរាណ ..... 26
1. ទឹកដីនៅចន្លោះទន្លេពីរ ..... 26
2. ការគ្រប់គ្រងទឹកដោយប្រព័ន្ធធារាសាស្ត្រ ..... 26
3. ទឹកដីដែលមានធនធានតិចតួច ..... 27
មេរៀនទី 2 ៖ អរិយធម៌ដំបូង ..... 29
1. ការលេចឡើងនៃអរិយធម៌ ..... 29
2. បុរី-រដ្ឋរបស់ពួកស៊ូម៉ែរ ..... 29
3. សង្គមរបស់ពួកស៊ូម៉ែរ ..... 31
4. ការភិវឌ្ឍវិទ្យាសាស្ត្ររបស់ពួកស៊ូម៉ែរ ..... 31
មេរៀនទី 3 ៖ ចក្រភពនៃដែនដីអឌ្ឍចន្ទប្រកបដោយជីជាតិ ..... 33
1. អ្នកស្ថាបនាចក្រភពដំបូង ..... 33
2. ពួកអាស៊ីរី និងឆាលឌៀន ..... 34
3. ពួកពៃក្យត្រួតត្រាអាស៊ីខាងលិច ..... 35
**ជំពូក 3 ៖ ព្រះរាជាណាចក្ររបស់ពួកហេព្រើរ** ..... 38
មេរៀនទី 1 ៖ ដើមកំណើតពួកហេព្រើរ ..... 38
1. ប្រជាជនហេព្រើរនៅកាណាន ..... 38
2. ពីកាណានទៅកាន់អេហ្ស៊ីប និងត្រឡប់មកវិញ ..... 39
3. ត្រឡប់ទៅកាន់ទឹកដីសន្យា ..... 40
មេរៀនទី 2 ៖ ព្រះរាជាណាចក្រ និងការជាប់ឃុំឃាំង ..... 41
1. ព្រះរាជាណាចក្ររបស់អ៊ីស្រាអែល ..... 41
2. ការបែងចែកព្រះរាជាណាចក្រ ..... 42
3. ពួកជ្វីបដែលគេនិរទ្ទេសត្រឡប់មកកាន់យូដាវិញ ..... 43
មេរៀនទី 3 ៖ ការរីកសាយភាយនៃយូដានិយម ..... 45
1. ដឹកនាំគ្រប់គ្រងដោយបរទេស ..... 45

2. ស្ថិតក្រោមការត្រួតត្រារបស់រ៉ូម ..... 45
3. យូដានិយម-ជំនឿដែលស្ថិតស្ថេរ ..... 47
**ជំពូក 4៖ ប្រទេសអេហ្ស៊ីប និងគូសបុរាណ** ..... 48
មេរៀនទី 1 ៖ អំណោយនៃទន្លេនីល ..... 48
1. ទីតាំងភូមិសាស្ត្រនៃអេហ្ស៊ីបបុរាណ ..... 48
2. ទឹកដីដែលបរិបូរណ៍ ..... 49
3. ទីតាំងភូមិសាស្ត្របង្កើតទម្រង់រស់នៅរបស់ប្រជាជនអេហ្ស៊ីប ..... 50
មេរៀនទី 2 ៖ ជីវិតរស់នៅក្នុងប្រទេសអេហ្ស៊ីបបុរាណ ..... 52
1. ការងារ និងគ្រួសារ ..... 52
2. ការពង្រីកចំណេះដឹង ..... 54
3. ជំនឿ និងសាសនា ..... 55
មេរៀនទី 3 ៖ អ្នកស្ថាបនាប្រាសាទពីរ៉ាមីត ..... 57
1. ព្រះរាជាណាចក្រចាស់ ..... 57
2. ប្រាសាទពីរ៉ាមីតធំរបស់ស្ដេចឃូហ្វូ ..... 58
3. ព្រះរាជាណាចក្រកណ្ដាល ..... 59
មេរៀនទី 4 ៖ ព្រះរាជាណាចក្រថ្មី និងព្រះរាជាណាចក្រគូស ..... 61
1. ផារ៉ូសស្រី ..... 61
2. ស្ដេចផារ៉ូសធ្វើកំណែទម្រង់មួយអង្គ ..... 62
3. ស្ដេចផារ៉ូសដ៏មានឥទ្ធិពល ..... 62
4. នូប៊ី និងអរិយធម៌គូស ..... 63
**ជំពូក 5៖ ប្រទេសឥណ្ឌាសម័យបុរាណ** ..... 66
មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រ និងជីវភាពរស់នៅរបស់ពួកឥណ្ឌា ..... 66
1. ទីតាំងភូមិសាស្ត្រនៃប្រទេសឥណ្ឌា ..... 66
2. ទីក្រុងនៅតាមច្រលងទន្លេឥណ្ឌូស ..... 66
3. វប្បធម៌ហារ៉ាប៉ា ..... 68
4. ចុងបញ្ចប់នៃវប្បធម៌ជ្រលងទន្លេឥណ្ឌូស ..... 69
មេរៀនទី 2 ៖ ដើមកំណើតហិណ្ឌូនិយម ..... 71
1. ពួកអារ្យ៉ែនធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា ..... 71
2. ផ្លាស់ប្ដូរការរស់នៅក្នុងប្រទេសឥណ្ឌា ..... 71
3. ហិណ្ឌូនិយម៖ សាសនារបស់ឥណ្ឌា ..... 72

មេរៀនទី 3 ៖ ពុទ្ធសាសនា និងយុគមាសនៅឥណ្ឌា ..... 74
1. ការលេចឡើងនៃពុទ្ធសាសនា ..... 74
2. ចក្រភពមោរ្យា ..... 75
3. យុគមាសនៃកុប្តៈ ..... 76
មេរៀនទី 4 ៖ កេរ្តិ៍តំណែលរបស់ឥណ្ឌា ..... 79
1. កេរ្តិ៍តំណែលសាសនារបស់ឥណ្ឌា ..... 79
2. កេរ្តិ៍តំណែលសិល្បៈរបស់ឥណ្ឌា ..... 79
3. កេរ្តិ៍តំណែលគណិតវិទ្យារបស់ឥណ្ឌា ..... 81
**ជំពូក 6 ៖ ប្រទេសចិនសម័យបុរាណ** ..... 82
មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រចិនបុរាណ ..... 82
1. ទម្រង់នៃទីតាំងភូមិសាស្ត្ររបស់ចិន ..... 82
2. សន្តតិវង្សសាង ..... 83
3. រាជវង្សចូវ ..... 84
មេរៀនទី 2 ៖ ទស្សនវិជ្ជាចិនបុរាណ ..... 86
1. នីតិនិយម ..... 86
2. ខុងជឺនិយម ..... 86
3. តាវនិយម ឬលិទ្ធិតាវ ..... 88
មេរៀនទី 3 ៖ សន្តតិវង្សឈិន និងហាន ..... 90
1. សន្តតិវង្សឈិនបង្រួបបង្រួមប្រទេសចិន ..... 90
2. សន្តតិវង្សហាន ..... 91
3. ជីវិតរស់នៅក្នុងសម័យរាជវង្សហាន ..... 92
មេរៀនទី 4 ៖ កេរ្តិ៍តំណែលចិនសម័យបុរាណ ..... 94
1. ផ្លូវសូត្រ ..... 94
2. ឥទ្ធិពលនៃទស្សន និងជំនឿ ..... 95
3. ការបង្កើត និងការរកឃើញរបស់ចិន ..... 95
**ជំពូក 7 ៖ ប្រទេសក្រិកបុរាណ** ..... 97
មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រប្រទេសក្រិក ..... 97
1. ទីតាំងភូមិសាស្ត្របង្កើតទម្រង់រស់នៅរបស់ក្រិក ..... 97
2. ពាណិជ្ជកម្មធ្វើឱ្យក្រិករុងរឿង ..... 98
3. ពួកក្រិកដំបូងបំផុត ..... 99

មេរៀនទី 2 ៖ ជីវិតរស់នៅរបស់ប្រជាជនក្រិកបុរាណ ....101
1. អាទិទេពរបស់ក្រិក និងទេវកថា ....101
2. ការផ្ដល់កិត្តិយសដល់អាទិទេព ....102
3. អក្សរសិល្ប៍ក្រិកដំបូង ....103
មេរៀនទី 3 ៖ បុរី-រដ្ឋ និងប្រជាធិបតេយ្យ ....105
1. ការកកើតឡើងនៃបុរី-រដ្ឋ ....105
2. ទម្រង់នៃរដ្ឋាភិបាល ....106
3. បុរីអាតែនស្ថាបនាប្រជាធិបតេយ្យមានកម្រិតមួយ ....107
មេរៀនទី 4 ៖ បុរីស្ប៉ាត និងអាតែន ....111
1. រដ្ឋយោធារបស់បុរីស្ប៉ាត ....111
2. របៀបនៃការរស់នៅនៅអាតែន ....112
3. សង្គ្រាមជាមួយពួកពែក្ស ....113
**ជំពូក 8 ៖ ក្រិកសម័យរុងរឿង** ....115
មេរៀនទី 1 ៖ ប្រជាធិបតេយ្យនៅអាតែន និងសង្គ្រាម ....115
1. ពេរីក្លេសដឹកនាំអាតែន ....115
2. ការពង្រីកចក្រភព ....116
3. ការកែលម្អបុរីអាតែន ....117
4. សង្គ្រាមប៉េឡូប៉ូនេសៀន ....118
មេរៀនទី 2 ៖ អាឡិចសាន់ឌឺដ៏អស្ចារ្យ ....121
1. ស្ដេចនៃម៉ាសេដូនៀ ....121
2. អាឡិចសាន់ឌឺព្យាយាមនៅក្នុងការកាន់កាប់ពិភពលោក ....122
3. កេរ្តិ៍ដំណែលរបស់អាឡិចសាន់ឌឺ ....123
មេរៀនទី 3 ៖ យុគមាសនៅក្នុងប្រទេសក្រិក ....125
1. សិល្បៈ និងស្ថាបត្យកម្ម ....125
2. ប្រជាធិបតេយ្យ, ប្រវត្តិវិទ្យា, និងទស្សនវិទ្យា ....127
3. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ....128
**ជំពូក 9 ៖ ចក្រភពរ៉ូមសម័យបុរាណ** ....130
មេរៀនទី 1 ៖ សាធារណៈរដ្ឋរ៉ូម ....130
1. ការចាប់ផ្ដើមឡើងដំបូងនៃចក្រភពរ៉ូម ....130
2. ទីតាំងភូមិសាស្ត្ររបស់រ៉ូម និងជីវភាពរស់នៅដំបូង ....130

3. ការលេចឡើងនៃសាធារណរដ្ឋ ....132
4. ការពង្រីកសាធារណរដ្ឋ ....133
មេរៀនទី 2 ៖ រ៉ូមក្លាយជាចក្រភពមួយ ....135
1. ជម្លោះនៅក្នុងប្រទេស ....135
2. ជូលីស សេសា ....135
3. អធិរាជដឹកនាំរ៉ូម ....137
មេរៀនទី 3 ៖ ជីវភាពរស់នៅប្រចាំថ្ងៃរបស់រ៉ូម ....140
1. គ្រួសារ និងសង្គម ....140
2. ជំនឿរបស់ពួករ៉ូម ....141
3. ជីវិតរស់នៅក្នុងទីក្រុងរបស់ពួករួម ....141
មេរៀនទី 4 ៖ ការអភិវឌ្ឍឡើងនៃសាសនាគ្រីស្ត ....144
1. ឫសគល់នៃសាសនាគ្រីស្តរបស់ពួកជ្វីប ....144
2. ជីវិតរស់នៅរបស់ព្រះយេស៊ូ ....144
3. ការសុគត់របស់ព្រះយេស៊ូ ....145
4. គ្រីស្តសាសនាដំបូង ....146
5. ប៉ូលសាយភាយគ្រីស្តសាសនា ....147
**ជំពូក 10 ៖ ការធ្លាក់ចុះនៃចក្រភពរ៉ូម និងកេរ្តិ៍ដំណែល** ....149
មេរៀនទី 1 ៖ រ៉ូម និងសាសនាគ្រីស្ត ....149
1. គោលនយោបាយរបស់រ៉ូមចំពោះសាសនាគ្រីស្ត ....149
2. ការផ្លាស់ប្តូរសាសនារបស់ខុនស្ទេនទីន ....150
3. ការចាប់ផ្តើមឡើងនៃព្រះវិហាររ៉ូម៉ាំងកាតូលិក ....151
មេរៀនទី 2 ៖ ការធ្លាក់ចុះ និងការដួលរលំនៃចក្រភពរ៉ូម ....153
1. ការចុះខ្សោយនៃចក្រភព ....153
2. រ៉ូមបានបែងចែកទៅជារ៉ូមខាងកើត និងរ៉ូមខាងលិច ....154
3. ការដួលរលំនៃចក្រភពខាងលិច ....155
មេរៀនទី 3 ៖ ចក្រភពប៊ីហ្សង់ទីន ....157
1. ចក្រភពដែលបន្តមានវត្តមាន ....157
2. ការបែងចែកគ្រីស្តសាសនាជាពីរផ្សេងគ្នា ....158
3. ការដួលរលំនៃចក្រភពប៊ីហ្សង់ទីន ....159
មេរៀនទី 4 ៖ កេរ្តិ៍ដំណែលរបស់រ៉ូម ....160

1. វប្បធម៌រ៉ូម ...160
2. ស្ថាបត្យកម្ម និងវិស្វកម្ម ...161
3. សាសនា និងច្បាប់...162
**ជំពូក 11 ៖ ការលេចឡើងនៃសាសនាអ៊ីស្លាម** ...164
មេរៀនទី 1 ៖ សាសនាអ៊ីស្លាម និងមហាម៉ាត់ ...164
1. វប្បធម៌តំបន់វាលខ្សាច់...164
2. ចំណុចប្រសព្វគ្នានៃទ្វីប 3 ...165
3. ជីវិតរស់នៅ និងការបង្រៀនរបស់មហាម៉ាត់...166
4. ជំនឿ, ការប្រតិបត្តិ, និងច្បាប់អ៊ីស្លាម ...167
មេរៀនទី 2 ៖ ការពង្រីកអំណាចរបស់ពួកម៉ូស្លីម...170
1. មេដឹកនាំម៉ូស្លីមថ្មីលេចឡើង ...170
2. ការបែកខ្ញែកនូវសាសនាអ៊ីស្លាម ...172
3. អ៊ូម៉ាយយាដ្ស...173
មេរៀនទី 3 ៖ យុគសម័យមាសរបស់ពួកម៉ូស្លីម...175
1. ការរីកចម្រើន និងការធ្លាក់ចុះរបស់អាបបាស៊ីដ ...175
2. ពួកម៉ូស្លីមដឹកនាំអេស្ប៉ាញ...177
3. ការអភិវឌ្ឍរបស់អេស្ប៉ាញម៉ូស្លីម...177
**ជំពូក 12 ៖ អរិយធម៌អាហ្វ្រិក**...180
មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រ និងប្រជាជនអាហ្វ្រិក ...180
1. ភូមិសាស្ត្រចម្រុះនៃអាហ្វ្រិក...180
2. ការធ្វើអន្តោប្រវេសន៍របស់ពួកបានទូ ...181
3. ជីវិតរស់នៅនៅអាហ្វ្រិក...181
មេរៀនទី 2 ៖ ចក្រភពនៃអាហ្វ្រិកភាគខាងលិច...183
1. ការលូតលាស់នៃចក្រភពហ្គាណា...183
2. ម៉ាលីស្ថាបនាឡើងលើគ្រឹះរបស់ហ្គាណា...184
3. ចក្រភពសុងហៃ ...185
មេរៀនទី 3 ៖ អរិយធម៌ពាណិជ្ជរបស់អាហ្វ្រិក...187
1. ការរះឡើងនៃអាក់សាំ ...187
2. ស្នាដៃរបស់អាក់សាំ ...187
3. អាហ្វ្រិកភាគខាងកើត និងអ៊ីស្លាម...188

4. សូណា និងមហាហ្ស៊ីមបាវេ ........189
5. កុងហ្គោ និងព័រទុយហ្គាល់ ........190
**ជំពូក 13 ៖ អរិយធម៌ទ្វីបអាមេរិក** ........192
មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រនៃទ្វីបអាមេរិក ........192
1. រូបសណ្ឋានភូមិសាស្ត្រនៃទ្វីអាមេរិក ........192
2. ភូមិសាស្ត្រអង់ដេស ........193
3. ភូមិសាស្ត្រតំបន់មេសូអាមេរិក ........193
មេរៀនទី 2 ៖ អាមេរិកកណ្ដាល និងអាមេរិកខាងជើង ........195
1. អូលមេច ........195
2. ម៉ាយ៉ា ........195
3. ពួកអាសទិក ........197
4. ពួកអ៊ីនកា ........198
មេរៀនទី 3 ៖ ប្រជាជននៅអាមេរិកខាងជើង ........200
1. អរិយធម៌ដំបូង ........200
2. សង្គមជនជាតិដើមអាមេរិកលូតលាស់ ........200
**ជំពូក 14 ៖ សន្តតិវង្សនៅក្នុងប្រទេសចិន** ........204
មេរៀនទី 1 ៖ ការបង្រួបបង្រួមប្រទេសចិន ........204
1. ការដួលរលំនៃសន្តតិវង្សហាន ........204
2. ការផ្លាស់ប្ដូរប្រព័ន្ធជំនឿ ........204
3. សន្តតិវង្សស្វយ និងសន្តតិវង្សតាងបង្រួបបង្រួមប្រទេសចិន ........206
មេរៀនទី 2 ៖ ការរីកចម្រើននៅក្នុងសម័យថាំង និងសុង ........209
1. ការស្ដាបនារដ្ឋចក្រពត្តិ ........209
2. ភាពរុងរឿងពីការធ្វើពាណិជ្ជកម្ម និងការដាំដុះ ........210
3. ពេលវេលានៃភាពជោគជ័យដ៏អស្ចារ្យ ........211
មេរៀនទី 3 ៖ ចក្រភពម៉ុងហ្គោល ........214
1. ការឈ្លានពានរបស់ម៉ុងហ្គោល ........214
2. រដ្ឋាភិបាលម៉ុងហ្គោល ........215
3. ការបើកប្រទេសចិនទៅកាន់ពិភពលោក ........216
មេរៀនទី 4 ៖ ការត្រឡប់ទៅរកការគ្រប់គ្រងរបស់ចិនវិញ ........218
1. ការទម្លាក់ពួកម៉ុងហ្គោល ........218

2. ពាណិជ្ជកម្ម និងដំណើរក្រៅប្រទេស ....................219
3. សន្តតិវង្សចុងក្រោយ ....................220
**ជំពូក 15៖ អរិយធម៌នៅអាស៊ី**....................221
មេរៀនទី 1 ៖ អរិយធម៌ជប៉ុន ....................221
1. ដែនដីព្រះអាទិត្យរះ ....................221
2. វប្បធម៌ជប៉ុន ....................222
3. ការលេចឡើងនៃសង្គមយោធាមួយ....................224
មេរៀនទី 2 ៖ ប្រទេសកូរ៉េ និងអាស៊ីអាគ្នេយ៍....................226
1. កូរ៉េឯករាជ្យ ....................226
2. ចក្រភពខ្មែរ....................227
3. ព្រះរាជាណាចក្ររបស់វៀតណាម ....................228
មេរៀនទី 3 ៖ ចក្រភពម៉ុងហ្គោល់នៅឥណ្ឌា ....................230
1. ប្រវត្តិសាស្ត្រដំបូងរបស់ម៉ុងហ្គោល់ ....................230
2. យុគមាសរបស់អាកបា ....................231
3. អ្នកបន្តតំណែងពីអាកបា ....................232
4. ការធ្លាក់ចុះនៃចក្រភពម៉ុងហ្គោល់ ....................234
មេរៀនទី 4 ៖ ចក្រភពអូតូម៉ង់ ....................235
1. ការលេចឡើងនៃអំណាច ....................235
2. ការពង្រីកចក្រភព....................236
3. ជីវិតរស់នៅក្នុងចក្រភពអូតូម៉ង់ ....................236
**ជំពូក 16៖ សក្តិភូមិ និងចុងមជ្ឈិមសម័យនៅអឺរ៉ុប**....................238
មេរៀនទី 1 ៖ សក្តិភូមិនិយមក្នុងមជ្ឈិមសម័យនៅអឺរ៉ុប ....................238
1. ការលេចឡើងនៃមជ្ឈិមសម័យនៅអឺរ៉ុប ....................238
2. សហគមន៍គ្រីស្តសាសនារីកចម្រើន និងរីកសាយភាយ....................238
3. សក្តិភូមិនិយម៖ សណ្តាប់ធ្នាប់សង្គមថ្មីមួយ....................239
4. ប្រព័ន្ធភូមិគ្រឹះ ....................240
5. យុគសម័យជីវ៉ាល់រី....................241
6. ការរីកលូតលាស់នៃទីប្រជុំជន ....................242
មេរៀនទី 2 ៖ ព្រះវិហារគ្រីស្តសាសនា និងបូជនីយកិច្ច....................243
1. អំណាចរបស់ព្រះវិហាររ៉ូម៉ាំងកាតូលិក....................243

2. ព្រះវិហារគ្រីស្តសាសនា, នយោបាយ, និងសង្គម ....243
3. បូជនីយកិច្ចចាប់ផ្តើម....245
4. ម៉ូស្លីមទទួលជ័យជំនះ និងបរាជ័យ ....245
មេរៀនទី 3 ៖ ជំងឺប៉េស្ត និងសង្គ្រាមរាប់រយឆ្នាំ ....248
1. ជំងឺប៉េស្ត....248
2. សង្គ្រាមរាប់រយឆ្នាំ ....249
3. អឺរ៉ុបសម័យទំនើបដំបូងលេចឡើង ....249
មេរៀនទី 4 ៖ ការចាប់ផ្តើមឡើងនៃរដ្ឋាភិបាលសម័យទំនើប....251
1. រដ្ឋាភិបាលអង់គ្លេស....251
2. ស្ថាប័នតំណាង ....252
3. ការលេចឡើងនៃគំនិតប្រជាធិបតេយ្យសម័យទំនើប....252
**ជំពូក 17 ៖ បុនសម័យ និងការធ្វើកំណែទម្រង់** ....254
មេរៀនទី 1 ៖ បុនសម័យនៅអ៊ីតាលី....254
1. ការប្រែប្រួលសង្គមអឺរ៉ុប....254
2. វិធីក្នុងការគិតថ្មី ....254
3. បុនសម័យចាប់ផ្តើមនៅអ៊ីតាលី ....256
4. ការរីចម្រើនផ្នែកសិល្បៈ ....257
មេរៀមទី 2 ៖ បុនសម័យរីកសាយភាយ ....259
1. បុនវុឌ្ឍធ្វើដំណើរទៅភាគខាងជើង ....259
2. វិចិត្រករ និងអ្នកនិពន្ធ ....260
3. ភាពជឿនលឿនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា....261
4. ជីវិតរស់នៅអំឡុងបុនសម័យ....262
មេរៀនទី 3 ៖ ការចាប់ផ្តើមធ្វើកំណែទម្រង់....264
1. ការបែកខ្ញែកដ៏ធំ....264
2. ការរិះគន់លើព្រះវិហារគ្រីស្តសាសនា....265
3. លូធ័រប្រឈមជាមួយព្រះវិហារគ្រីស្តសាសនា....266
មេរៀនទី 4 ៖ ការកែប្រែសាសនា និងប្រតិកម្ម ....268
1. ការកើនឡើងនៃកែប្រែសាសនា ....268
2. ការប្រឈមជាមួយការកែប្រែសាសនា....269
3. បេសកទូតសាសនាសាយភាយសហគមន៍គ្រីស្តសាសនា ....270

4. កេរ្តិ៍ដំណែលនៃការកែប្រែសាសនា.....271
**ជំពូក 18៖ បដិវត្តវិទ្យាសាស្ត្រ និងយុគសម័យនៃការរុករក**.....273
មេរៀនទី 1 ៖ បដិវត្តវិទ្យាសាស្ត្រ.....273
1. ប្រវត្តិគំនិតវិទ្យាសាស្ត្រ.....273
2. ភាពរីកចម្រើននៃវិទ្យាសាស្ត្រ.....275
3. វិធីសាស្ត្របែបវិទ្យាសាស្ត្រ.....277
មេរៀនទី 2 ៖ យុគសម័យនៃការរុករក.....278
1. ព័ទ្ធ័យហ្គាលនាំផ្លូវ.....278
2. បច្ចេកវិទ្យា និងការរុករក.....278
3. កូឡុំប៊ីសទៅដល់អាមេរិក.....279
4. ការរុករកបន្ទាប់ពីកូឡុំប៊ីស.....280
មេរៀនទី 3 ៖ អាណានិគមនិយម និងការផ្លាស់ប្តូរ.....283
1. ការផ្លាស់ប្តូរទំនិញ និងគំនិត.....283
2. ការប្រកួតប្រជែងសម្រាប់អាណានិគម.....284
3. ការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់អឺរ៉ុប.....285
**ជំពូក 19៖ ពិភពអាត្លង់ទិក 1492-1800**.....287
មេរៀនទី 1 ៖ អេស្ប៉ាញស្ថាបនាចក្រភពអាមេរិកមួយ.....287
1. ការធ្វើដំណើររបស់កូឡុំប៊ីស.....287
2. អេស្ប៉ាញដណ្តើមកាន់កាប់ម៉ិកស៊ិកកូ.....289
3. អេស្ប៉ាញដណ្តើមកាន់កាប់ប៉េរូ.....290
4. ការពង្រីកឥទ្ធិពលរបស់អេស្ប៉ាញ.....291
5. ការប្រឆាំងជាមួយនឹងការគ្រប់គ្រងរបស់អេស្ប៉ាញ.....292
មេរៀនទី 2 ៖ប្រទេសនៅអឺរ៉ុបតាំងទីលំនៅអាមេរិកខាងជើង.....294
1. ការប្រកួតប្រជែងគ្នាដើម្បីកាន់កាប់អាមេរិកខាងជើង.....294
2. អង់គ្លេសមកដល់អាមេរិកខាងជើង.....295
3. ការតស៊ូសម្រាប់អាមេរិកខាងជើង.....296
4. ជនជាតិដើមអាមេរិកឆ្លើយតប.....297
មេរៀនទី 3 ៖ពាណិជ្ជកម្មទាសករនៅអាត្លង់ទិក.....300
1. មូលហេតុនៃទាសភាពអាហ្វ្រិក.....300
2. ទាសភាពរីកសាយភាយពាសពេញអាមេរិក.....301

3. ដំណើរផ្សងព្រេងដោយការបង្ខំ....................302
4. ទាសភាពនៅអាមេរិក....................303
5. ហេតុបច្ច័យនៃពាណិជ្ជកម្មទាសករ....................303
មេរៀនទី 3 ៖ ការផ្ដោះប្ដូរកូឡុំបៀ និងពាណិជ្ជកម្មសកល....................305
1. ការផ្ដោះប្ដូរកូឡុំបៀន....................305
2. ពាណិជ្ជកម្មសកល....................306
3. ការកើនឡើងនៃការស្វែងរកប្រាក់ចំណេញនិយម....................307
**ជំពូក 20 ៖ រាជាធិបតេយ្យផ្ដាច់ការនៅអឺរ៉ុប 1500-1800**....................309
មេរៀនទី 1 ៖ ចក្រភពអេស្ប៉ាញ និងលទ្ធិផ្ដាច់ការនៅអឺរ៉ុប....................309
1. ចក្រភពអេស្ប៉ាញដ៏មានអំណាចមួយ....................309
2. យុគមាសនៃសិល្បៈ និងអក្សរសិល្ប៍អេស្ប៉ាញ....................310
3. ចក្រភពអេស្ប៉ាញចុះខ្សោយ....................311
4. ហូឡង់ឯករាជ្យរុងរឿង....................312
5. លិទ្ធិផ្ដាច់ការនៅអឺរ៉ុប....................313
មេរៀនទី 2 ៖ រាជរបស់ព្រះអង្គម្ចាស់ល្វីទី 14....................315
1. សង្គ្រាមសាសនា និងការប្រជែងអំណាច....................315
2. អ្នកនិពន្ធត្រឡប់ឆ្ពោះទៅរកសង្ស័យនិយម....................316
3. ព្រះអង្គម្ចាស់ល្វីទី 14 ឡើងកាន់អំណាច....................317
4. រចនាបថដ៏អស្ចារ្យរបស់ព្រះមហាក្សត្រព្រះអាទិត្យ....................318
5. ព្រះអង្គម្ចាស់ល្វីវាយប្រយុទ្ធនៅក្នុងសង្គ្រាមដ៏មហន្តរាយ....................319
មេរៀនទី 3 ៖ ព្រះមហាក្សត្រនៅអឺរ៉ុបកណ្ដាលប៉ះទង្គិចគ្នា....................322
1. សង្គ្រាម 30 ឆ្នាំ....................322
2. ទម្រង់រដ្ឋនៅអឺរ៉ុបកណ្ដាល....................323
3. ព្រូសប្រជែងជាមួយអូទ្រីស....................325
មេរៀនទី 4 ៖ មេដឹកនាំផ្ដាច់ការនៅរុស្ស៊ី....................327
1. ស្ដេចហ្សាដំបូង....................327
2. ព្រះអង្គម្ចាស់ពីទ័រដ៏អស្ចារ្យឡើងកាន់អំណាច....................328
3. ព្រះអង្គម្ចាស់ពីទ័រដឹកនាំបែបផ្ដាច់ការ....................329
មេរៀនទី 5 ៖ សភាកម្រិតអំណាចព្រះមហាក្សត្រនៅអង់គ្លេស....................331
1. ព្រះមហាក្សត្របង្កហេតុជាមួយសភាតំណាងរាស្ត្រ....................331

2. សង្គ្រាមស៊ីវិលនៅអង់គ្លេស ....................332
3. ការស្តារឡើងវិញ និងបដិវត្ត ....................333
4. ការកម្រិតអំណាចរបស់ព្រះរាជា ....................334
**ជំពូក 21 ៖ សករាជពន្លឺ និងបដិវត្ត 1550-1789** ....................336
មេរៀនទី 1 ៖ បដិវត្តវិទ្យាសាស្ត្រ ....................336
1. ឫសគល់នៃវិទ្យាសាស្ត្រសម័យទំនើប ....................336
2. បដិវត្តគំរូនៃចក្រវាមួយ ....................337
3. វិធីសាស្ត្របែបវិទ្យាសាស្ត្រ ....................339
4. ញូវតុនពន្យល់ពីច្បាប់ទំនាញផែនដី ....................340
5. ការរីកសាយភាយនៃបដិវត្តវិទ្យាសាស្ត្រ ....................340
មេរៀនទី 2 ៖ សករាជពន្លឺនៅអឺរ៉ុប ....................342
1. ទស្សនពីរអំពីរដ្ឋាភិបាល ....................342
2. ទស្សនវិទូតស៊ូមតិអំពីហេតុផល ....................343
3. ស្ត្រី និងសករាជពន្លឺ ....................345
4. កេរ្តិ៍ដំណែលនៃសករាជពន្លឺ ....................346
មេរៀនទី 3 ៖ សករាជពន្លឺរីកសាយភាយ ....................348
1. ពិភពនៃទស្សនមួយ ....................348
2. រចនាបថសិល្បៈថ្មី ....................349
3. សករាជពន្លឺ និងរាជាធិបតេយ្យ ....................349
មេរៀនទី 4 ៖ បដិវត្តនៅអាមេរិក ....................352
1. អង់គ្លេស និងដែនដីអាណានិគមអាមេរិករបស់ពួកគេ ....................352
2. អាមេរិកទទួលបានឯករាជ្យ ....................353
3. ជោគជ័យសម្រាប់ពួកអាណានិគម ....................354
4. អាមេរិកបង្កើតសាធារណរដ្ឋមួយ ....................355
**ជំពូក 22 ៖ បដិវត្តនៅបារាំង និងណាប៉ូឡេអុង 1789-1815** ....................357
មេរៀនទី 1 ៖ ការចាប់ផ្តើមឡើងនៃបដិវត្តនៅបារាំង ....................357
1. សណ្តាប់ធ្នាប់ចាស់ ....................357
2. កម្លាំងនៃការផ្លាស់ប្តូរ ....................358
3. ដើមដំបូងនៃបដិវត្ត ....................359
4. ភាពភ័យខ្លាចដ៏អស្ចារ្យមួយបោកបក់មកលើប្រទេសបារាំង ....................360

មេរៀនទី 2 ៖ បដិវត្តនាំមកនូវការធ្វើកំណែទម្រង់ និងភេរវកម្ម.....362
1. សភាធ្វើកំណែទម្រង់ប្រទេសបារាំង.....362
2. ការអភិវឌ្ឍនៃការបែងចែក.....363
3. សង្គ្រាម និងការសម្លាប់.....364
4. ភេរវកម្មឱបក្រសោបបារាំង.....365
5. ការបញ្ចប់នៃអំពើភេរវកម្ម.....366
6. ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងដណ្តើមអំណាច.....367
មេរៀនទី 3 ៖ ណាប៉ូឡេអ៊ុងបង្កើតចក្រភពមួយ.....368
1. ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងគ្រប់គ្រងប្រទេសបារាំង.....368
2. អធិរាជណាប៉ូឡេអ៊ុងបង្កើតចក្រភព.....370
មេរៀនទី 4 ៖ ចក្រភពរបស់អធិរាជណាប៉ូឡេអ៊ុងដួលរលំ.....372
1. កំហុសដ៏ធំរបស់អធិរាជណាប៉ូឡេអ៊ុង.....372
2. ការដួលរលំរបស់អធិរាជណាប៉ូឡេអ៊ុង.....374
មេរៀនទី 5 ៖ សន្និបាទនៃទីក្រុងវីយែន.....376
1. ផែនការរបស់មេតឋ៌រនិចសម្រាប់អឺរ៉ុប.....376
2. ការផ្លាស់ប្តូរនយោបាយបន្ទាប់ពីសន្និបាទទីក្រុងវីយែន.....377
**ជំពូក 23 ៖ បដិវត្តជាតិនិយមបោកបក់នៅភាគខាងលិច 1789-1900**.....380
មេរៀនទី 1 ៖ ប្រជាជនអាមេរិកឡាទីនទទួលបានឯករាជ្យ.....380
1. សង្គមអាណានិគមបែងចែក.....380
2. បដិវត្តនៅអាមេរិក.....380
3. ពួកក្រេអូលេសនាំមុខក្នុងការទាមទារឯករាជ្យ.....381
4. ម៉ិកស៊ិកកូបញ្ចប់ការគ្រប់គ្រងរបស់អេស្ប៉ាញ.....383
5. រាជវង្សអ្នករំដោះប្រទេសប្រេស៊ីល.....384
មេរៀនទី 2 ៖ អឺរ៉ុបប្រឈមជាមួយការធ្វើបដិវត្ត.....385
1. ការប៉ះទង្គិចផ្នែកទស្សនវិជ្ជា.....385
2. ជាតិនិយមរីកចម្រើន.....385
3. អ្នកជាតិនិយមប្រកួតប្រជែងអំណាចជាមួយពួកអភិរក្សនិយម.....386
4. ក្រុមជ្រុលនិយមផ្លាស់ប្តូរប្រទេសបារាំង.....387
5. កំណែទម្រង់នៅប្រទេសរុស្ស៊ី.....388
មេរៀនទី 3 ៖ ជាតិនិយម.....390

1. ជាតិនិយម៖ កម្លាំងដើម្បីឯកភាពជាតិ ឬការបំបែកបំបាក់ ....390
2. ជាតិនិយមអង្រួនចក្រភពចាស់ៗ ....390
3. លោកការវួរបង្រួបបង្រួមអ៊ីតាលី ....391
4. ប៊ីស្មាក់បង្រួបបង្រួមប្រទេសអាល្លឺម៉ង់ ....392
5. ការផ្លាស់ប្តូរអំណាច ....394
មេរៀនទី 4 ៖ បដិវត្តសិល្បៈ ....396
1. ចលនារ៉ូមែនទិច ....396
2. ការផ្លាស់ប្តូរទៅរកភាពប្រាកដនិយមក្នុងសិល្បៈ ....398
3. អ្នកអារម្មណ៍និយមប្រតិកម្មប្រឆាំងនឹងពិតប្រាកដនិយម ....399
**ជំពូក 24 ៖ បដិវត្តឧស្សាហកម្ម 1700-1900** ....400
មេរៀនទី 1 ៖ ការចាប់ផ្តើមឡើងនៃបដិវត្តឧស្សាហកម្ម ....400
1. បដិវត្តឧស្សាហកម្មចាប់ផ្តើមដំបូងនៅចក្រភពអង់គ្លេស ....400
2. ការបង្កើតថ្មីនាំទៅដល់ឧស្សាហូបនីយកម្ម ....402
3. ការរីកចម្រើននៃគមនាគមន៍ ....403
4. យុគសម័យផ្លូវដែកបានចាប់ផ្តើមឡើង ....404
មេរៀនទី 2 ៖ ឧស្សាហូបនីយកម្ម ....406
1. ឧស្សាហូបនីយកម្មផ្លាស់ប្តូរជីវិតរស់នៅ ....406
2. ជម្លោះវណ្ណៈបានកើនឡើង ....408
3. ឥទ្ធពលវិជ្ជមាននៃបដិវត្តឧស្សាហកម្ម ....408
មេរៀនទី 3 ៖ ឧស្សាហូបនីយកម្មរីកសាយភាយ ....410
1. ការអភិវឌ្ឍឧស្សាហកម្មនៅសហរដ្ឋអាមេរិក ....410
2. ឧស្សាហូបនីយកម្មនៅទ្វីបអឺរ៉ុប ....412
3. ឥទ្ធិពលនៃឧស្សាហូបនីយកម្ម ....413
មេរៀនទី 4 ៖ការធ្វើកំណែទម្រង់ឧស្សាហកម្មនៅលើពិភពលោក ....415
1. ទស្សនៈស្តីអំពីឧស្សាហបនីយកម្ម ....415
2. ការរីកឡើងនៃសង្គមនិយម ....416
3. ម៉ាក្សនិយម៖សង្គមនិយមជ្រុល ....417
4. សហជីពការងារ និងច្បាប់កំណែទម្រង់ ....419
5. ចលនាកំណែទម្រង់រីកសាយភាយ ....420
**ជំពូក 25 ៖ យុគសម័យនៃប្រជាធិបតេយ្យ និងភាពជឿនលឿន 1815-1914** ....423

មេរៀនទី 1 ៖ កំណែទម្រង់ប្រជាធិបតេយ្យ និងសកម្មនិយម ......423
1. ការធ្វើកំណែទម្រង់នៅអង់គ្លេស ......423
2. ស្ត្រីទទួលបានសិទ្ធិបោះឆ្នោត ......425
3. បារាំង និងប្រជាធិបតេយ្យ ......425
មេរៀនទី 2 ៖ ការទាមទារឯករាជ្យរបស់ប្រទេសដែលស្ថិតនៅក្រោមអាណានិគមរបស់អង់គ្លេស ......427
1. ការទាមទារឯករាជ្យរបស់កាណាដា ......427
2. ប្រទេសអូស្ត្រាលី និងញូវហ្សេឡែន ......428
3. ពួកអៀកឡង់ទទួលជ័យជំនះក្នុងការគ្រប់គ្រងប្រទេស ......430
មេរៀនទី 3 ៖ សង្គ្រាមដើម្បីពង្រីងដែនដីនៅសហរដ្ឋអាមេរិក ......433
1. អាមេរិកពង្រីកទៅភាគខាងលិច ......433
2. សង្គ្រាមស៊ីវិលសាកល្បងពីប្រជាធិបតេយ្យ ......434
3. សេដ្ឋកិច្ចក្រោយសង្គ្រាម ......436
មេរៀនទី 4 ៖ ភាពជឿនលឿននៅសតវត្សរ៍ទី 19 ......437
1. ការបង្កើតថ្មីធ្វើឱ្យជីវិតកាន់តែងាយស្រួល ......437
2. គំនិតថ្មីអំពីឱសថ ......438
3. គំនិតថ្មីអំពីវិទ្យាសាស្ត្រ ......438
4. វិទ្យាសាស្ត្រសង្គមស្រាវជ្រាវពីឥរិយាបថ ......440
5. ការរីកឡើងនៃទម្រង់វប្បធម៌ ......441
**ជំពូក 26 ៖ យុគសម័យចក្រពត្តិនិយម 1850-1914** ......443
មេរៀនទី 1 ៖ ដំណើរទៅកាន់ទ្វីបអាហ្វ្រិក ......443
1. អាហ្វ្រិកមុនការក្របដណ្តប់របស់ពួកអឺរ៉ុប ......443
2. កម្លាំងដែលជម្រុញឱ្យមានចក្រពត្តិនិយម ......444
3. ការបែងចែកអាហ្វិក ......446
4. បីក្រុមប៉ះទង្គិចគ្នាដើម្បីដណ្តើមដែនដីអាហ្វ្រិចខាងត្បូង ......447
មេរៀនទី 2 ៖ ចក្រពត្តិនិយម ......449
1. យុគសម័យថ្មីនៃចក្រពត្តិនិយម ......449
2. ការតស៊ូប្រឆាំងរបស់ពួកអាហ្វ្រិក ......451
3. កេរ្តិ៍ដំណែលនៃការគ្រប់គ្រងអាណានិគម ......452
មេរៀនទី 3 ៖ ពួកអឺរ៉ុបដណ្តើមកាន់កាប់ដែនដីរបស់ពួកម៉ូស្លីម ......454
1. ចក្រភពអូតូម៉ង់បាត់បង់អំណាច ......454

2. ការក្រសោបយកដែនដីរបស់ពួកអឺរ៉ុប ....454
3. ការចាប់ផ្តើមការធ្វើកំណែទម្រង់នៅអេហ្ស៊ីប ....456
4. ពៃក្សវង់សម្លាតឱ្យមានការផ្លាស់ប្តូរ ....457
មេរៀនទី 4 ៖ ចក្រពត្តិនិយមអង់គ្លេសនៅឥណ្ឌា....459
1. អង់គ្លេសពង្រីកការគ្រប់គ្រងលើប្រទេសឥណ្ឌា....459
2. កងទ័ពរបស់ឥណ្ឌាធ្វើការបះបោរ....460
3. ជាតិនិយមលេចឡើងនៅឥណ្ឌា....462
មេរៀនទី 5 ៖ ចក្រពត្តិនិយមនៅតំបន់អាស៊ីអាគ្នេយ៍ ....463
1. មហាអំណាចអឺរ៉ុបឈ្លានពានតំបន់ជាយប៉ាស៊ីហ្វិក....463
2. សៀមបន្តរក្សាឯករាជ្យ ....464
3. ចក្រពត្តិនិយមអាមេរិកនៅដែនកោះប៉ាស៊ីហ្វិក ....465
**ជំពូក 27 ៖ ការផ្លាស់ប្តូរជាសកល 1800-1914** ....467
មេរៀនទី 1 ៖ ចិនតស៊ូប្រឆាំងជាមួយឥទ្ធិពលពីខាងក្រៅ....467
1. ចិន និងពួកបច្ចិមប្រទេស ....467
2. ការកើនឡើងនៃបញ្ហាផ្ទៃក្នុង ....468
3. ការកើនឡើងនៃឥទ្ធិពលបរទេស ....469
4. ការកញ្ច្រៀលឡើងនៃគំនិតជាតិនិយមរបស់ប្រជាជនចិន....470
មេរៀនទី 2 ៖ ទំនើបកម្មក្នុងប្រទេសជប៉ុន....472
1. ជប៉ុនបញ្ចប់ភាពឯកកោររបស់ខ្លួន ....472
2. ចក្រពត្តិជប៉ុន ....473
មេរៀនទី 3 ៖ សេដ្ឋកិច្ចបែបចក្រពត្តិនិយមរបស់សហរដ្ឋអាមេរិក....476
1. អាមេរិកឡាទីនបន្ទាប់ពីទទួលបានឯករាជ្យ....476
2. ការកើនឡើងនៃសេដ្ឋកិច្ចស្ថិតក្រោមឥទ្ធិពលបរទេស....477
3. ចក្រភពអាមេរិកឡាទីនមួយ....478
មេរៀនទី 4 ៖ ភាពចលាចល និងការផ្លាស់ប្តូរនៅម៉ិកសិកកូ ....481
1. សាន់តា អានណា និងសង្គ្រាមម៉ិកសិកកូ....481
2. លោកជូរេស និងការធ្វើកំណែទម្រង់ ....482
3. លោកប៉ូហ្វីរីអូ ដៃហ្ស "សណ្តាប់ធ្នាប់ និងភាពជឿនលឿន" ....484
4. ការធ្វើបដិវត្ត និងសង្គ្រាមស៊ីវិល ....485
**ជំពូក 28 ៖ សង្គ្រាមលោក 1914-1918** ....487

មេរៀនទី 1 ៖ ដំណើរឆ្ពោះទៅរកសង្គ្រាម....487
1. ការលេចឡើងនៃជម្លោះនៅអឺរ៉ុប....487
2. សម្ព័ន្ធមិត្តដ៏ស្មុកស្មាញ....488
3. វិបត្តិនៅតំបន់បាល់កង់....489
មេរៀនទី 2 ៖ អឺរ៉ុបលិចលង់ដោយសង្គ្រាម....492
1. សង្គ្រាមលោកចាប់ផ្តើម....492
2. សង្គ្រាមដ៏បង្ហូរឈាមមួយចាប់ផ្តើមនៅទ្រឹង....493
3. ការប្រយុទ្ធគ្នានៅសមរភូមិខាងកើត....494
មេរៀនទី 3 ៖ ជម្លោះជាសកលមួយ....496
1. សង្គ្រាមជះឥទ្ធិពលដល់ពិភពលោក....496
2. ការចូលរួមសង្គ្រាមរបស់សហរដ្ឋអាមេរិកបានជះឥទ្ធិពលលើសមរភូមិមុខនៅអឺរ៉ុប....498
3. ក្រុមសម្ព័ន្ធមិត្តឈ្នះសង្គ្រាម....499
4. កេរ្តិ៍ដំណែលនៃសង្គ្រាម....500
មេរៀនទី 4 ៖ សន្តិភាពដ៏ផុយស្រួយមួយ....502
1. ក្រុមសម្ព័ន្ធមិត្តជួយប្រជុំ និងជជែកគ្នា....502
2. សន្ធិសញ្ញាមួយដែលបង្កឱ្យមានបញ្ហា....503
**ជំពូក 29 ៖ ការធ្វើបដិវត្តន៍ និងគំនិតជាតិនិយម 1900-1939**....505
មេរៀនទី 1 ៖ បដិវត្តនៅក្នុងប្រទេសរុស្ស៊ី....505
1. ស្តេចហ្សាររុស្ស៊ីប្រឆាំងជាមួយការផ្លាស់ប្តូរ....505
2. បដិវត្តន៍ឧស្សាហកម្មនៅក្នុងប្រទេសរុស្ស៊ី....505
3. វិបត្តិនៅក្នុង និងក្រៅប្រទេស....507
4. បដិវត្តខែមីនា....508
5. បដិវត្តបូលសេវិក....509
6. លេនីនរៀបចំសណ្តាប់ធ្នាប់ឡើងវិញ....510
7. ស្តាលីនក្លាយជាជនផ្តាច់ការ....511
មេរៀនទី 2 ៖ លទ្ធិផ្តាច់ការ....513
1. រដ្ឋាភិបាលមួយដែលគ្រប់គ្រងអំណាចទាំងស្រុង....513
2. ស្តាលីនស្ថាបនារដ្ឋប្រកាន់របបផ្តាច់ការមួយ....514
3. ស្តាលីនដណ្តើមការគ្រប់គ្រងសេដ្ឋកិច្ច....516
4. ជីវភាពរស់នៅប្រចាំថ្ងៃក្រោមស្តាលីន....517

5. ការសម្រេចការគ្រប់គ្រងទាំងមូល ....518
មេរៀនទី 3 ៖ ចក្រភពចិនដួលរលំ ....519
1. ពួកអ្នកជាតិនិយមទម្លាប់រាជវង្សឈីង ....519
2. គណបក្សកុំម្មុយនីស្តនៅក្នុងប្រទេសចិន ....520
3. សង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅក្នុងប្រទេសចិន ....521
មេរៀនទី 4 ៖ ជាតិនិយមនៅក្នុងប្រទេសឥណ្ឌា និងអាស៊ីអាគ្នេយ៍ ....523
1. ការកើនឡើងនៃគំនិតជាតិនិយមនៅក្នុងប្រទេសឥណ្ឌា ....523
2. យុទ្ធសាស្ត្របែបអហិង្សារបស់គន្ធី ....524
3. អង់គ្លេសប្រគល់សិទ្ធិគ្រប់គ្រងដោយខ្លួនឯងដែលមានកម្រិត ....525
**ជំពូក 30 ៖ ទសវត្សរ៍នៃវិបត្តិ 1919-1939** ....528
មេរៀនទី 1 ៖ ការប្រែប្រួលក្រោយសង្គ្រាម ....528
1. បដិវត្តថ្មីក្នុងវិស័យវិទ្យាសាស្ត្រ ....528
2. អក្សរសិល្ប៍នៅទសវត្សឆ្នាំ 1920 ....529
3. បដិវត្តសិល្បៈ ....530
4. សង្គមប្រជែងជាមួយអនុសញ្ញា ....531
5. បច្ចេកវិទ្យាជឿនលឿនធ្វើអោយជីវិតប្រសើរឡើង ....531
មេរៀនទី 2 ៖ វិបត្តិសេដ្ឋកិច្ចជាសកល ....533
1. អឺរ៉ុបក្រោយសង្គ្រាម ....533
2. សាធារណរដ្ឋវីម៉ា ....533
3. ការប៉ុនប៉ងធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព ....534
4. ការដួលរលំផ្នែកហិរញ្ញវត្ថុ ....535
5. មហាវិបត្តិសេដ្ឋកិច្ច ....536
6. ពិភពលោកប្រឈមមុខនឹងវិបត្តិ ....537
មេរៀនទី 3 ៖ ហ្វាស៊ីសនិយមលេចឡើងនៃអឺរ៉ុប ....539
1. ហ្វាស៊ីសនិយមលេចឡើងនៅអ៊ីតាលី ....539
2. ហ៊ីត្លែរឡើងកាន់អំណាចនៅប្រទេសអាល្លឺម៉ង់ ....540
3. ហ៊ីត្លែរក្លាយជាអធិការបតី ....541
4. ប្រទេសផ្សេងៗទៀតធ្លាក់ទៅក្នុងរបបផ្តាច់ការ ....542
មេរៀនទី 4 ៖ អ្នកឈ្លានពានធ្វើការឈ្លានពានលើប្រទេសជាតិនានា ....544
1. ជប៉ុនសម្លឹងទៅរកការបង្កើតចក្រភពមួយ ....544

2. ក្រុមអ្នកឈ្លានពានអឺរ៉ុបកំពុងធ្វើដំណើរ....545
3. ប្រទេសប្រជាធិបតេយ្យព្យាយាមរក្សាសន្តិភាព....546
**ជំពូក 31 ៖ សង្គ្រាមលោកលើកទី 2 1939-1945**....549
មេរៀនទី 1 ៖ ហ៊ីត្លែបញ្ឆេះសង្គ្រាម....549
1. អាឡឺម៉ង់បញ្ឆេះសង្គ្រាមថ្មីមួយនៅអឺរ៉ុប....549
2. បារាំងដួលរលំ....550
3. សមរភូមិនៅអង់គ្លេស....551
4. សមរភូមិសមុទ្រមេឌីទែរ៉ាណេ និងអឺរ៉ុបខាងកើត....552
5. សហរដ្ឋអាមេរិកផ្តល់ជំនួយដល់សម្ព័ន្ធមិត្ត....555
មេរៀនទី 2 ៖ យុទ្ធនាការរបស់ប្រទេសជប៉ុននៅតំបន់ប៉ាស៊ីហ្វិក....556
1. ការវាយប្រហារដ៏គួរឱ្យភ្ញាក់ផ្អើរលើកំពង់ផែភើល ហារប៊ឺរ....556
2. ជប៉ុនទទួលជ័យជំនះ....557
3. សម្ព័ន្ធមិត្តវាយបក....557
4. ការវាយលុករបស់សម្ព័ន្ធមិត្ត....559
មេរៀនទី 3 ៖ ហូឡូខូស( ការសម្លាប់ដោយប្រើភ្លើង )....561
1. ហូឡូខូសចាប់ផ្តើមឡើង....561
2. "ដំណោះស្រាយចុងក្រោយ"....562
មេរៀនទី 4 ៖ ជ័យជំនះរបស់ក្រុមសម្ព័ន្ធមិត្ត....565
1. ការត្រឡប់ស្ថានការណ៍លើសមរភូមិពីរ....565
2. ការប្រឈមក្នុងប្រទេសរបស់ពួកសម្ព័ន្ធមិត្ត....567
3. ជ័យជំនះនៅអឺរ៉ុប....568
4. ជ័យជំនះនៅតំបន់ប៉ាស៊ីហ្វិក....570
មេរៀនទី 5 ៖ អឺរ៉ុប និងជប៉ុនស្ថិតក្នុងវិនាសកម្ម....572
1. ការបំផ្លិចបំផ្លាញនៅអឺរ៉ុប....572
2. រដ្ឋាភិបាល និងនយោបាយក្រោយសង្គ្រាម....573
3. ប្រទេសជប៉ុនក្រោយសង្គ្រាម....574
4. ការកាន់កាប់បាននាំមកនូវការប្រែប្រួលដ៏ខ្លាំងក្លា....575
**ជំពូក 32 ៖ ការស្ថាបនាពិភពលោកវិញក្រោយសង្គ្រាម 1945-បច្ចុប្បន្ន**....576
មេរៀនទី 1 ៖ សង្គ្រាមត្រជាក់៖ ការប្រឈមដាក់គ្នារវាងមហាអំណាច....576
1. សម្ព័ន្ធក្លាយជាសត្រូវ....576

2. វាំងននដែករបស់អឺរ៉ុបខាងកើត ....577
3. សហរដ្ឋអាមេរិកព្យាយាមនៅក្នុងការហ៊ុំព័ទ្ធសហភាពសូវៀត ....578
4. សង្គ្រាមត្រជាក់បែងចែកពិភពលោក....579
មេរៀនទី 2 ៖ កុំម្មុយនីស្តឡើងកាន់អំណាចនៅក្នុងប្រទេសចិន....582
1. ពួកកុំម្មុយនីស្តទល់ជាមួយពួកជាតិនិយម ....582
2. ប្រទេសចិនទាំងពីរជះឥទ្ធិពលដល់សង្គ្រាមត្រជាក់ ....583
3. ពួកកុំម្មុយនីស្តផ្លាស់ប្តូរប្រទេសចិន ....584
មេរៀនទី 3 ៖ សង្គ្រាមនៅក្នុងប្រទេសកូរ៉េ និងវៀតណាម ....587
1. សង្គ្រាមនៅក្នុងប្រទេសកូរ៉េ....587
2. សង្គ្រាមផ្ទុះឡើងនៅវៀតណាម ....589
3. សហរដ្ឋអាមេរិកចូលរួម....590
4. អាស៊ីអាគ្នេយ៍ក្រោយសង្គ្រាម ....591
មេរៀនទី 4 ៖ សង្គ្រាមត្រជាក់បែងចែកពិភពលោក....593
1. ការវាយប្រយុទ្ធសម្រាប់លោកទីបី ....593
2. ការប្រឈមមុខដាក់គ្នានៃអាមេរិកឡាទីន ....593
3. ការប្រឈមមុខដាក់គ្នានៅមជ្ឈិមបូព៌ា ....596
មេរៀនទី 5 ៖ សង្គ្រាមត្រជាក់រលាយ ....598
1. គោលនយោបាយសូវៀតនៅអឺរ៉ុបខាងកើត និងប្រទេសចិន....598
2. ពីគោលនយោបាយប្រឈមមុខដាក់គ្នាឆ្ពោះទៅរកការបញ្ចប់ជម្លោះ....599
3. ការដួលរលំនៃគោលនយោបាយបញ្ចប់ជម្លោះ ....601
**ជំពូក 33 ៖ ដែនដីអាណានិគមក្លាយជាប្រទេសថ្មី**....603
មេរៀនទី 1 ៖ ឧបទ្វីបឥណ្ឌាទទួលបានសេរីភាព....603
1. ចលនាឆ្ពោះទៅរកឯករាជ្យ ....603
2. សេរីភាពនាំមកនូវភាពចលាចល....603
3. ប្រទេសឥណ្ឌាសម័យទំនើប ....605
4. ប៉ាគីស្ថានតស៊ូដើម្បីសេរីភាព ....606
5. ការតស៊ូរបស់បង់ក្លាដែស និងស្រីលង្កា....607
មេរៀនទី 2 ៖ ប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យ....609
1. ហ្វីលីពីនទទួលបានឯករាជ្យ ....609
2. ដែនដីអាណានិគមអង់គ្លេសទទួលបានឯករាជ្យ ....611

3. ឥណ្ឌូនេស៊ីទទួលបានឯករាជ្យពីហូឡង់ ....612
មេរៀនទី 3 ៖ ប្រជាជាតិថ្មីនៅអាហ្វ្រិក ....615
1. ការទទួលបាននូវឯករាជ្យ ....615
2. ប្រទេសហ្គាណានាំមុខ ....616
3. ការតស៊ូដើម្បីសេរីភាព ....616
4. សង្គ្រាមស៊ីវិលនៅកុងហ្គោ និងអង់ហ្គោឡា ....618
មេរៀនទី 4 ៖ ជម្លោះនៅមជ្ឈិមបូព៌ា ....620
1. អ៊ីស្រាអែលក្លាយជារដ្ឋមួយ ....620
2. អ៊ីស្រាអែល និងរដ្ឋអារ៉ាប់កើតមានជម្លោះ ....621
3. ការបាត់បង់សន្តិភាព ....624
មេរៀនទី 5 ៖ ការតស៊ូនៅអាស៊ីកណ្តាល ....627
1. សេរីភាពនាំមកនូវការប្រឈមថ្មី ....627
2. អាហ្វហ្គានីស្ថាន និងពិភពលោក ....628
**ជំពូក 34 ៖ ការតស៊ូដើម្បីប្រជាធិបតេយ្យ** ....631
មេរៀនទី 1 ៖ ប្រជាធិបតេយ្យ ....631
1. គោលដៅប្រជាធិបតេយ្យ ....631
2. ករណីសិក្សាប្រទេសប្រេស៊ីល៖ របបផ្តាច់ការ និងលទ្ធិប្រជាធិបតេយ្យ ....631
3. ករណីសិក្សាប្រទេសម៉ិកស៊ិកកូ៖ ការគ្រប់គ្រងដោយបក្សតែមួយ ....633
4. ករណីសិក្សាប្រទេសអាហ្សង់ទីន៖ វិបត្តិនយោបាយ និងសេដ្ឋកិច្ច ....635
មេរៀនទី 2 ៖ បញ្ហាប្រឈមនៃលទ្ធិប្រជាធិបតេយ្យនៅអាហ្វ្រិក ....637
1. ពួកអាណានិគមកម្រិតលទ្ធិប្រជាធិបតេយ្យ ....637
2. សង្គ្រាមស៊ីវិលនៅនីហ្សេរីយ៉ា ....637
3. ការកសាងជាតិប្រទេសនីហ្សេរីយ៉ាឡើងវិញ ....638
4. អាហ្វ្រិកខាងត្បូងក្រោមរបបប្រកាន់ពូជសាសន៍ ....640
5. ការតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ ....641
មេរៀនទី 3 ៖ ការដួលរលំនៃសហភាពសូវៀត ....643
1. ហ្គោបាឆេវធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ....643
2. កំណែទម្រង់សេដ្ឋកិច្ច និងនយោបាយ ....643
3. សហភាពសូវៀតប្រឈមមុខនឹងភាពចលាចល ....644
4. ប្រទេសរុស្ស៊ីក្រោមការដឹកនាំរបស់លោកបូរីស យ៉េលស៊ីន ....646

5. ប្រទេសរុស្ស៊ីក្រោមការដឹកនាំរបស់លោកវ្ល៉ាឌីមៀរ ពូទីន....647
មេរៀនទី 4 ៖ ការផ្លាស់ប្តូរនៅអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត....649
1. កំណែទម្រង់នៅប៉ូឡូញ និងហុងគ្រី....649
2. អាល្លឺម៉ង់បង្រួបបង្រួមគ្នាឡើងវិញ....650
3. លទ្ធិប្រជាធិបតេយ្យរីករាលដាលនៅឆេកូស្លូវ៉ាគី....652
4. ការដួលរលំនៅប្រទេសរ៉ូម៉ានី....653
5. ការបែកបាក់នៃយូហ្គោស្លាវី....654
មេរៀនទី 5 ៖ ប្រទេសចិន, កំណែទម្រង់ និងប្រតិកម្ម....656
1. កេរ្តិ៍ដំណែលរបស់ម៉ៅ....656
2. ប្រទេសចិន និងលោកខាងលិច....656
3. ការសម្លាប់រង្គាលនៅទីលានធានអានមេន....657
4. ប្រទេសចិនឈានចូលសហស្សវត្សរ៍ថ្មី....658
5. ប្រទេសចិនក្រោយឆ្នាំ 2000....660
ឯកសារពិគ្រោះ....661

# ជំពូក 1 ៖ សេចក្តីផ្តើម

## មេរៀនទី 1 ៖ សារៈសំខាន់នៃការសិក្សាប្រវត្តិសាស្រ្ត

ជនជាតិក្រិកបុរាណគឺជាមនុស្សដំបូងគេបំផុតដែលបានស្វះស្វែងរកនូវចំណេះដឹង និងឧត្តមគតិ។ នៅក្នុងនោះមុខវិជ្ជាសំខាន់មួយក្នុងចំណោមមុខវិជ្ជាសំខាន់នានាដែលបានបញ្ចូលទៅក្នុងចំណេះដឹង និងឧត្តមគតិរបស់ពួកគេគឺមុខវិជ្ជាប្រវត្តិសាស្ត្រ។ នៅក្នុងភាសាអង់គ្លេសពាក្យថា "ប្រវត្តិសាស្ត្រ" ត្រូវបានទាញចេញមកពីភាសាក្រិកថ្នាក់ជានាមសព្ទថា "Historia"។ "ប្រវត្តិសាស្ត្រ" ឬ "Historia" មានន័យយ៉ាងសាមញ្ញថា "ការស៊ើបអង្កេត ឬការស្រាវជ្រាវ"។ ប្រវត្តិសាស្ត្រគឺជាការសិក្សាតាមរយៈការស៊ើបអង្កេតអំពីអតីតកាលរបស់មនុស្សជាតិ ដែលក្រោយមកត្រូវបានអភិវឌ្ឍទៅជាមុខវិជ្ជាបង្រៀនមួយដោយប្រវត្តិវិទូជនជាតិក្រិកបុរាណចំនួន 2 រូប គឺលោកហេរ៉ូដូទឹស និងលោកធូសាយឌីដេស។

លោកហេរ៉ូដូទឹស ដែលត្រូវបានគេទទួលស្គាល់ជាទូទៅថា "បិតាប្រវត្តិសាស្ត្រ" បានសរសេរអំពីសង្គ្រាមរវាងពួកក្រិក និងពែក្ស ដែលស្នាដៃនេះបានផ្ទុកនូវបណ្តុំនៃព័ត៌មានមួយ ដោយក្នុងនោះរួមបញ្ចូលទាំងព័ត៌មានដែលជាប់ទាក់ទងទៅនឹងពួកអេហ្ស៊ីប និងពួកពែក្សបុរាណផងដែរ។ លោកធូសាយឌីដេសបានធ្វើការអភិវឌ្ឍន៍មុខវិជ្ជានេះដោយឈរលើមាគ៌ាបែបវិទ្យាសាស្ត្រ។ លោកបានសរសេរអំពីសង្គ្រាមភេឡូពេនេសៀនដោយពឹងផ្អែកទាំងស្រុងទៅលើមូលដ្ឋានគ្រឹះនៃភស្តុតាង និងបានបង្ហាញលម្អិតអំពីទំនាក់ទំនងរវាងហេតុ និងផល។

### 1. និយមន័យរបស់ប្រវត្តិសាស្ត្រ

ចាប់តាំងពីពេលនោះមក ទម្រង់នៃការសរសេរប្រវត្តិសាស្ត្របានផ្លាស់ប្តូរ ហើយគោលគំនិតសំខាន់នៅក្នុងអត្ថបទនីមួយៗត្រូវបានសរសេរឡើង ដោយឆ្លុះបញ្ចាំងតាមរយៈចំណាប់អារម្មណ៍របស់ប្រវត្តិវិទូ។ នៅក្នុងនិយមន័យរបស់ប្រវត្តិសាស្ត្រមួយចំនួន ដែលបានឆ្លុះបញ្ចាំងអំពីអ្វីទៅជាប្រវត្តិសាស្ត្រ គឺអាស្រ័យទៅលើប្រវត្តិវិទូនីមួយៗជាអ្នកកំណត់។ មាននិយមន័យដ៏គួរឱ្យចាប់អារម្មណ៍មួយចំនួន ដែលនិស្សិតដែលចង់ដឹងអំពីមុខវិជ្ជានេះមិនអាចមើលរំលងបាន។

លោកថូម៉ាស ខាលីឡេដែលជាប្រវត្តិវិទូដ៏ល្បីល្បាញមួយរូប ដោយលោកបានសរសេរសៀវភៅមួយស្តីអំពី "បដិវត្តន៍បារាំង" បានឱ្យនិយមន័យប្រវត្តិសាស្ត្រសកលលោកថាជា "ជីវប្រវត្តិរបស់មនុស្សល្បីល្បាញ"។ លោកអ៊ី. អេជ. ខារនៅក្នុងចំណោមប្រវត្តិវិទូនានា បានកំណត់និយមន័យប្រវត្តិសាស្ត្រថា "ជាការពិភាក្សាដែលមិនចេះចប់មិនចេះហើយមួយរវាងបច្ចុប្បន្ន និងអតីតកាល"។ លោកសាស្ត្រាចារ្យរេនីយេ៍បានធ្វើការគូសបញ្ជាក់ទៅលើតួនាទីរបស់ប្រវត្តិសាស្ត្រនៅក្នុងសង្គម ហើយបានកំណត់និយមន័យវាថា "ជាការចងចាំនៃសង្គម"។ លោកវីលឌូរេនត៍ដែលជាប្រវត្តិវិទូដ៏ល្បីល្បាញមួយរូបនៅលើសកលលោក បានផ្តល់នូវនិយមន័យយ៉ាងច្បាស់លាស់មួយ ដោយបាននិយាយថាវាគឺជា "ការអត្ថាធិប្បាយមួយអំពីអ្វីដែលមនុស្សស៊ីវិល័យបានគិត ឬបានធ្វើកាលពីអតីតកាល"។ យោងទៅតាមនិយមន័យខាងលើ មនុស្សទាំងឡាយអាចសន្និដ្ឋានបានយ៉ាងងាយស្រួលអំពីចរិត និងគោលបំណង

នៃប្រវត្តិសាស្ត្រ។ វាគឺជាការអត្ថាធិប្បាយមួយអំពីព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីអតីតកាល ដែលបានបង្កើតដោគវាសនារបស់មនុស្សជាតិ។

## 2. ប្រវត្តិសាស្ត្រជាវិទ្យាសាស្ត្រ ឬជាសិល្បៈ?

តើប្រវត្តិសាស្ត្រជាវិទ្យាសាស្ត្រ ឬជាសិល្បៈ? នេះគឺជាសំណួរមួយដែលកំពុងតែមានការជជែកវែកញែកគ្នាយ៉ាងខ្លាំងក្លា ដើម្បីស្វែងរកចម្លើយមួយដែលស្រមស្របៗ តួនាទីរបស់ប្រវត្តិសាស្ត្រគឺ ធ្វើការកត់ត្រា និងពន្យល់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីអតីតកាលឱ្យបានត្រឹមត្រូវតាមតែអាចធ្វើទៅបាន។ ប៉ុន្តែរាល់ព័ត៌មានអំពីព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងកាលពីអតីតកាល គឺស្ថិតនៅពីក្រោយការចងចាំឡើងវិញរបស់នណាម្នាក់ ហេតុដូច្នេះ វាមិនបានទៅដល់កម្រិតនៃបទដ្ឋានមួយដែលកំណត់ដោយវិទ្យាសាស្ត្រឡើយ។ យ៉ាងណាក៏ដោយ លោកខូលលីង្វូដយល់ឃើញថាតួនាទីរបស់ប្រវត្តិសាស្ត្រស្រដៀងគ្នាទៅនឹងវិទ្យាសាស្ត្រ ដោយលោកបាននិយាយថា "វិទ្យាសាស្ត្រគឺជាការស្វែងយល់នូវអ្វីៗទាំងឡាយ ហើយតាមរយៈគំនិតនេះ ប្រវត្តិសាស្ត្រគឺជាវិទ្យាសាស្ត្រ"។ ដោយសារតែវាបានស្វែងរកផតឈប់ឈរសម្រាប់ការពិត។ ទាំងបានអភិវឌ្ឍវិធីសាស្ត្រផ្ទាល់របស់ពួកគេ និងបានឈានទៅដល់ការសន្និដ្ឋាន ឬបញ្ញត្តិមួយចំនួន។ ខណៈពេលដែលវិទ្យាសាស្ត្របានអនុវត្តវិធីសាស្ត្រសំខាន់ៗមួយចំនួន ដូចជាការអង្កេត, សម្មតិកម្ម, និងការពិសោធន៍ដើម្បីទទួលបានបញ្ញត្តិវិទ្យាសាស្ត្រ ការសរសេរប្រវត្តិសាស្ត្របានចូលរួមនៅក្នុងការប្រមូលនូវប្រភពឯកសារ, ពិនិត្យបញ្ជាក់អំពីភាពពិត និងត្រឹមត្រូវនៃប្រភពឯកសារ, ធ្វើការចាត់ថ្នាក់ប្រភពឯកសារ, ធ្វើការញែកចេញពីគ្នា ឬផ្គុំចូលគ្នា, អត្ថាធិប្បាយអំពីលទ្ធផល, ហើយចុងក្រោយធ្វើការទិតៀន។ បញ្ញត្តិវិទ្យាសាស្ត្រគឺការពិត ប៉ុន្តែចំណេះដឹងប្រវត្តិសាស្ត្រដែលជាប់ទាក់ទងជាមួយសកម្មភាពរបស់មនុស្សកាលពីអតីតកាល មិនទាន់គ្រប់លក្ខណៈសម្រាប់ការពិតឡើយ។ ដោយចំណេះដឹងមួយចំនួនមិនបានកើតឡើងដោយពិតឡើយ ប៉ុន្តែវាបានមកពីការគិតពិចារណាតែប៉ុណ្ណោះ។ ដូច្នេះសំណួរបានលេចឡើង ថាតើប្រវត្តិសាស្ត្រអាចត្រូវបានចាត់ថ្នាក់ចូលទៅក្នុងសិល្បៈ ឬអត់។

ដូចដែលបានបង្ហាញរួចមកហើយថា ប្រវត្តិវិទូមួយរូបត្រូវតែប្រើប្រាស់នូវទេពកោសល្យផ្ទាល់ខ្លួនរបស់គេ ដើម្បីធ្វើការបង្ហាញពីកិច្ចការស្រាវជ្រាវរបស់គេនៅក្នុងវិធីមួយប្រកបដោយការច្នៃប្រឌិត។ ខុសគ្នាពីវិទ្យាសាស្ត្រដែលធ្វើការភាគច្រើនទាក់ទងជាមួយវិធីដែលមិនមានការច្នៃប្រឌិត ប្រវត្តិវិទូមួយរូបធ្វើការទាក់ទងជាមួយចំណាប់អារម្មណ៍របស់ពួកគេទៅលើស្ថានភាពរបស់មនុស្សកាលពីអតីតកាល។ ប្រសិនបើគេមិនអាចបន្ថែមសាច់, ឈាម, និងវិញ្ញាណទៅលើគ្រោងឆ្អឹងនៃភាពពិតរបស់ប្រវត្តិសាស្ត្រទេនោះ រឿងរ៉ាវនៃអតីតកាលរបស់គាត់នឹងបង្ហាញពីភាពមិនពិតប្រាកដ។ ដូច្នេះ គាត់ត្រូវតែប្រើមនោគតិរបស់គាត់ដើម្បីធ្វើឱ្យអតីតកាលមានលក្ខណៈពិតប្រាកដ និងគួរជឿបានសម្រាប់អ្នកអានរបស់គាត់។ វិធីនៃការធ្វើបទបង្ហាញបែបនេះ ជាដំណើរការមួយដែលគេស្គាល់ថាការសរសេរប្រវត្តិសាស្ត្រ គឺហាក់ដូចជាស្ថិតនៅក្រោមសិល្បៈជាជាងវិទ្យាសាស្ត្រ។ ជារួម ប្រវត្តិសាស្ត្រអាចត្រូវបានគេចាត់ទុកថាជាវិទ្យាសាស្ត្រមួយ ដោយសារតែវាបានប្រើប្រាស់នូវវិធីសាស្ត្របែបវិទ្យាសាស្ត្រ និងចាត់ទុកថាជាសិល្បៈមួយ

ដោយសារតែវិធីសាស្ត្រនៃការបង្ហាញ និងតាក់តែងសេចក្ដីរបស់វា។ ប្រវត្តិវិទូជាច្រើនបានចាត់ទុកប្រវត្តិសាស្ត្រ ថាជាមុខវិជ្ជាមនុស្សសាស្ត្រដែលចាស់ជាងគេ។

### 3. តម្លៃនៃប្រវត្តិសាស្ត្រ

មុខវិជ្ជានីមួយៗដែលគេយកមកបង្រៀននៅតាមសាលា ឬតាមសាកលវិទ្យាល័យនានា ត្រូវបានគេជឿថា គឺដើម្បីជួយដល់និស្សិតក្នុងការក្រេបជញ្ជក់នូវតម្លៃពិតប្រាកដនានារបស់វា។ តើមានតម្លៃអ្វីខ្លះដែលយើងអាចទាញយកចេញមកពីការសិក្សាប្រវត្តិសាស្ត្រ?

អស់រយៈពេលជាយូរមកហើយលោកហេរ៉ូដូទឹស បានសរសេរប្រវត្តិសាស្ត្រជាមួយគោលបំណងបញ្ជាក់យ៉ាងច្បាស់ថា សកម្មភាពនានារបស់ក្រិកកាលពីសម័យបុរាណ "នឹងមិនត្រូវបានបំភ្លេចដោយអ្នកជំនាន់ក្រោយឡើយ"។ ប្រវត្តិសាស្ត្រសំដៅទៅលើសកម្មភាពរបស់ព្រះមហាក្សត្រ និងមនុស្សអស្ចារ្យនៅក្នុងរយៈកាលផ្សេងៗគ្នា ដោយហេតុនេះវាបានបន្ថែមឱ្យមនុស្សទាំងឡាយនូវចំណេះដឹងអំពីមនុស្ស។ ជាថ្មីម្ដងទៀត ប្រវត្តិសាស្ត្រមិនមែនគ្រាន់តែជាបញ្ជីរាយឈ្មោះសកម្មភាពទាំងឡាយរបស់មនុស្សឡើយ ប៉ុន្តែវាបានពន្យល់អំពីហេតុផលនៅពីក្រោយសកម្មភាពទាំងអស់នោះនៅក្នុងវិធីដ៏គួរឱ្យចាប់អារម្មណ៍មួយ ឬតាមបែបមនុស្សសាស្ត្រ។ ជាឧទាហរណ៍ នៅក្នុងសៀវភៅបដិវត្តន៍បារាំង របស់លោកខាលីឡេ លោកបានពិពណ៌នាមិនត្រឹមតែពីសកម្មភាពនៅក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញពីវិចារណញ្ញាណនៅពីក្រោយសកម្មភាពរបស់វាផងដែរ។

ប្រវត្តិសាស្ត្រក៏អាចជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងផងដែរ។ ការតស៊ូជាច្រើនរបស់ពួកយើងទាំងដើម្បីឯករាជ្យ ឬដើម្បីប្រឆាំងជាមួយការកេងប្រវ័ញ្ច ឬប្រឆាំងជាមួយការសង្កត់សង្កិន អាចធ្លាប់ជាបទពិសោធន៍មួយដែលធ្លាប់បានធ្វើរួចមកហើយកាលពីអតីតកាល។ ភាពដូចគ្នានៃប្រវត្តិសាស្ត្រគឺមានច្រើន។ អំឡុងពេលនៃការតស៊ូសម្រាប់សេរីភាព លោកមហាត្មៈ គន្ធីតែងតែទទួលយកការទូន្មាននានា តាមរយៈការអានសៀវភៅស្ដីអំពីការកេងប្រវ័ញ្ចទៅលើអ្នកប្រយុទ្ធដើម្បីសេរីភាពនៅក្នុងប្រទេសអ៊ីតាលីកាលពីអតីតកាល។ ដូចគ្នានេះផងដែរ ជាមួយនឹងការតស៊ូដើម្បីសេរីភាព មនុស្សជាច្រើនបានធ្វើការប្រៀបធៀបគ្នារវាងលោកហ្គាន្ធីជី ជាមួយនឹងលោកម៉ាហ្ស៊ីនីរបស់ប្រទេសអ៊ីតាលី, លោកការ៉ូ ជាមួយលោកនេរុ, និងលោកសាប់ហាស់ ចាន់ដ្រា ប៉ូស ជាមួយនឹងលោកហ្គារីបាលឌី។ អំឡុងពេលនៃការតស៊ូដើម្បីសេរីភាព ភាពស្រដៀងគ្នាតិច ឬច្រើននៃបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេបានលេចឡើង។

តម្លៃសំខាន់មួយដែលទាញចេញមកពីការសិក្សាប្រវត្តិសាស្ត្រគឺថា វាបានជួយយើងនៅក្នុងការភ្ជាប់ទំនាក់ទំនងរបស់យើងជាមួយនឹងអតីតកាលរបស់យើង។ វប្បធម៌ និងអរិយធម៌របស់យើងមានដើមកំណើតរបស់វាកាលពីអតីតកាល។ ទំនាក់ទំនងរបស់យើងជាមួយអតីតកាលបានចាក់ឫសយ៉ាងជ្រៅ ហើយសូម្បីតែយើងចង់បំបែកវាចេញពីគ្នាក៏វាមិនអាចធ្វើទៅបានឡើយ។ ជាឧទាហរណ៍ ដូចជាអំពើឃោរឃៅក្នុងសង្គមនានា ដែលមានដូចជា ភាពមិនអាចជ្រាបចូលបាន ឬការធ្វើទុក្ខបុកម្នេញលើពួកវណ្ណៈក្រៅសង្គមនៅឥណ្ឌាជាដើម។ រឿងទាំងនេះវាសុទ្ធតែមានឫសគល់របស់វាកាលពីអតីតកាល។

ការសិក្សាប្រវត្តិសាស្ត្រមួយអាចជាតម្លៃដ៏ធំមហិមា ជាពិសេសចំពោះអ្នកវិទ្យាសាស្ត្រសង្គមដែលជាប់ទាក់ទងជាមួយនឹងការស្រាវជ្រាវ។ វាអាចនឹងផ្តល់ឱ្យពួកគេនូវការយល់ច្បាស់មួយអំពីបញ្ហានានាដែលពួកគេកំពុងសិក្សា។ វាក៏ប្រហែលជានឹងផ្តល់នូវទិន្នន័យចាំបាច់មួយចំនួនសម្រាប់ការស៊ើបអង្កេតទៅលើបាតុភូតសង្គម ឬសេដ្ឋកិច្ចផងដែរ។ សង្គមវិទូម្នាក់ធ្វើការស្រាវជ្រាវទៅលើការបង្កើតប្រព័ន្ធបែងចែកវណ្ណៈ ឬអ្នកវិទ្យាសាស្ត្រនយោបាយម្នាក់ធ្វើការទៅលើប្រព័ន្ធនយោបាយបែបសភានិយម ឬចិត្តវិទូម្នាក់ធ្វើការស្រាវជ្រាវទៅលើអំពើហិង្សារបស់ហ្វូងមនុស្ស, អ្នកទាំងអស់គ្នា ត្រូវតែស្វែងរកនូវប្រភពឯកសាររបស់ពួកគេឱ្យបានទូលំទូលាយពីវិមានដ៏មហាសាលនៃប្រវត្តិសាស្ត្រ។ មិនមានអ្វីគួរឱ្យងឿងឆ្ងល់ឡើយ ប្រវត្តិសាស្ត្រត្រូវបានគេហៅថាមន្ទីរពិសោធន៍នៃវិទ្យាសាស្ត្រសង្គម។

ការសិក្សាប្រវត្តិសាស្ត្រអាចជារង្វាន់ដ៏ធំមួយសម្រាប់បញ្ញវន្តជាច្រើន, អ្នកនយោបាយ, និងរដ្ឋាភិបាល, ឧត្តមសេនីយ៍យោធា, អ្នកវិទ្យាសាស្ត្រ, និងអ្នករដ្ឋបាល។ ព្រះអង្គម្ចាស់ណាប៉ូឡេអុងអាចសម្រេចបានជោគជ័យដ៏ប្រសើរនៅក្នុងកិច្ចការរបស់ទ្រង់ តាមរយៈប្រាជ្ញាឆ្លាតវៃអំពីប្រវត្តិសាស្ត្ររបស់ទ្រង់។ ការសិក្សាអំពីប្រវត្តិសាស្ត្រអាចបង្កើនប្រាជ្ញាវាងវៃដល់មនុស្សអស្ចារ្យមួយចំនួននាសម័យបច្ចុប្បន្ន ក្នុងនោះមានដូចជាលោកចាវ៉ាហាឡាលនេរុ និងលោកប្រធានាធិបតីសហរដ្ឋអាមេរិកលោកចន អេហ្វ កេណឺឌី។ ចំណេះដឹងប្រវត្តិសាស្ត្រ បានជះឥទ្ធិពលទៅលើគំនិតយល់ដឹងរបស់ពួកគេ។ ពួកគេបានដោះស្រាយបំណុលរបស់គេចំពោះប្រវត្តិសាស្ត្រតាមរយៈការចែករំលែកនូវស្នាដៃដែលមិនអាចកាត់ថ្លៃបានរបស់ពួកគេ ដោយក្នុងនោះលោកនេរុ បានសរសេរសៀវភៅ "ទស្សនីយភាពនៃប្រវត្តិសាស្ត្រពិភពលោក" និងលោកកេណឺឌី បានសរសេរសៀវភៅ "ទម្រង់នៃសេចក្តីក្លាហាន" ។

នៅក្នុងប្រវត្តិសាស្ត្ររបស់ជាតិនីមួយៗ សង្គមរបស់ពួកគេបានបន្តជួបប្រទះវិបត្តិជាច្រើន។ មេដឹកនាំរបស់គេសង្ឃឹមយ៉ាងក្លៀវក្លានៅក្នុងការគ្រប់គ្រងទៅលើវិបត្តិទាំងអស់នោះ និងឈានទៅរកការបញ្ចប់នូវបញ្ហាទាំងនោះ។ នៅក្នុងការវិនិច្ឆ័យរបស់ពួកគេ ប្រវត្តិសាស្ត្របានដើរតួនាទីជាមគ្គុទ្ទេសក៍មួយ ឬជាភ្លើងនាំផ្លូវមួយ។ ប្រវត្តិសាស្ត្រនាំផ្លូវសង្គមមួយឆ្ពោះទៅរកគោលដៅរបស់វាដោយសុវត្ថិភាព។ នៅពាក់កណ្តាលសតវត្សរ៍ទី 19 ប្រជាជនអាមេរិកជាច្រើនបានជឿជាក់ទៅលើអ្វីដែលពេលនោះគេបានហៅវាថា "ជោគវាសនាជាក់ស្តែង"។ ពួកគេជឿជាក់ថា ជាតិរបស់ពួកគេត្រូវបានញ៉ាំងឱ្យប្រព្រឹត្តសកម្មភាពដោយសារជោគវាសនា ដើម្បីពង្រីកដែនដីទៅកាន់ឆ្នេរប៉ាស៊ីហ្វិក។ ដូច្នេះលោកអាលលេន នេវីន្សបានមើលឃើញថា ប្រវត្តិសាស្ត្រមិនមែនគ្រាន់តែជាការពិពណ៌នាមួយអំពីអតីតកាលតែប៉ុណ្ណោះទេ ប៉ុន្តែវាជា "ស្ពានមួយតភ្ជាប់អតីតកាលទៅនឹងបច្ចុប្បន្ន និងចង្អុលបង្ហាញផ្លូវទៅអនាគត"។

ចំណេះដឹងដ៏ខ្លាំងក្លាមួយនៃប្រវត្តិសាស្ត្រ អាចជួយឱ្យនិស្សិតយល់ដឹងពីព្រឹត្តិការណ៍នាពេលបច្ចុប្បន្នបានយ៉ាងប្រសើរ។ ព្រឹត្តិការណ៍មួយចំនួនអាចនឹងធ្លាប់ត្រូវបានព្យាករណ៍ដោយមនុស្សអស្ចារ្យមួយចំនួនកាលពីអតីតកាល។ ឧទាហរណ៍ លោកឡេអូណាដូ ដា វីនស៊ី បានគិតឃើញពីការបង្កើតគ្រឿងហោះហើរដោយខ្លួនឯងនៅដើមសតវត្សរ៍ទី 16 ។ ការធ្វើដំណើរក្នុងលំហសម័យទំនើបត្រូវបានព្យាករណ៍តិចច្រើនដោយប្រវត្តិវិទូនានា ដូចជាលោកអេជ.ជី. វែល្ស និងលោកជូលេស វែរនែជាដើម។ ដូចគ្នានេះដែរ ការធ្វើដំណើរក្នុងលំហ ឬក៏ការធ្វើដំណើរតាមសមុទ្ទនាពេលបច្ចុប្បន្ន អាចនឹងមានទំនាក់ទំនងជាមួយនឹងការធ្វើដំណើរតាមសមុទ្រនានារបស់អ្នករុករកដំបូងៗមួយ

ចំនួន ក្នុងនោះមានដូចជាលោកកូឡុំបឹស, លោកវ៉ាស្កូ ដឺ ហ្គាម៉ា, ឬលោកម៉ាហ្សេឡង់ជាដើម។ ជាមួយនឹងការយល់ដឹងពីប្រវត្តិសាស្ត្រ វាមិនមានការលំបាកសម្រាប់និស្សិតម្នាក់ឡើយក្នុងការយល់ដឹងពីព្រឹត្តិការណ៍ភាគច្រើននាពេលបច្ចុប្បន្ន ដែលកើតឡើងនៅក្នុងប្រទេសរបស់ពួកគេ ឬនៅក្រៅប្រទេស។

វាជាការចំបាច់ណាស់នៅក្នុងការគូសបញ្ជាក់ថា ប្រវត្តិសាស្ត្របានការពារ និងថែរក្សានូវតម្លៃទំនៀមទម្លាប់ប្រពៃណី និងវប្បធម៌របស់ជាតិមួយ។ ប្រវត្តិវិទូបានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការរំឭកយ៉ាងខ្ជាប់ខ្ជួនដល់ជនរួមជាតិរបស់ពួកគេ អំពីតួនាទីដ៏សំខាន់មួយនៃជាតិរបស់ពួកគេក្នុងប្រវត្តិសាស្ត្រសាកលលោក។ ប្រវត្តិវិទូអាឡឺម៉ង់គាំទ្រ និងដុតបញ្ឆេះគំនិតជាតិនិយមប្រឆាំងជាមួយការសង្កត់សង្កិនរបស់ព្រះអង្គម្ចាស់ណាប៉ូឡេអុងនៅដើមសតវត្សរ៍ទី 19 ។ លោកហ៊ីត្លែ ត្រូវបាននាំទៅកាន់ផ្លូវខុសដោយគំនិតរបស់ប្រវត្តិវិទូនៅដើមដំបូង ដោយបានគិតថាជនជាតិអាឡឺម៉ង់គឺជាពួកជាតិសាសន៍ខ្ពង់ខ្ពស់មួយ ដូច្នេះត្រូវតែគ្រប់គ្រងទៅលើមនុស្សជាតិទាំងមូល។

តម្លៃផ្សេងៗទៀត បើទោះបីជាវាមិនត្រូវបានចែងច្បាស់ក៏ដោយ ប្រវត្តិសាស្ត្របានបណ្តុះគំនិតក្នុងចំណោមនិស្សិតអំពីសេចក្តីស្រលាញ់, សេចក្តីមេត្តាករុណា, និងការចេះអធ្យាស្រ័យ។ ខណៈពេលដែលពួកគេអានសៀវភៅប្រវត្តិសាស្ត្រទាំងឡាយ មនុស្សម្នាក់បានដឹងពីភាពឈឺចាប់ដែលមិនអាចនិយាយបានរបស់ទាសករ និងគ្រីស្ទបរិស័ទនៅក្នុងអាណាចក្ររ៉ូម។ នៅក្នុងសម័យទំនើប ការឈឺចាប់របស់ពួកជ្វីបនៅក្រោមដៃរបស់ពួកណាហ្ស៊ីអាឡឺម៉ង់ និងស្ថានភាពរបស់ជនភៀសខ្លួនប៉ាឡេស្ទីន និងប៉ង់ក្លាដេស បានរំឭកនៅក្នុងអារម្មណ៍របស់យើងអំពីសេចក្តីមេត្តាករុណា។

## 4. ប្រវត្តិសាស្ត្រ និងមុខវិជ្ជាផ្សេងៗ

### 4.1. ប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យា

តើមានវិទ្យាសាស្ត្រមួយណាដែលអាចអនុញ្ញាតិឱ្យប្រវត្តិវិទូ អាចក្តោបយកអតីតកាលដែលមិនទាន់មានកំណត់ត្រា (សម័យបុរេប្រវត្តិសាស្ត្រ)? ដោយមិនចាំបាច់សង្ស័យគឺបុរាណវិទ្យា។ មុខវិទ្យានេះគឺជាការសិក្សាបែបវិទ្យាសាស្ត្រមួយអំពីសំណល់កាលពីអតីតកាល។ តំបន់ប្រវត្តិសាស្ត្រ, វត្ថុបុរាណ, បូជនីយស្ថាន, កាក់, អក្សរចារឹក, និងស្នាដៃសិល្បៈផ្សេងៗទៀត ទាំងអស់នេះបានអនុញ្ញាតិឱ្យបុរាណវិទូធ្វើការស្ថាបនាប្រវត្តិសាស្ត្រឡើងនៅក្នុងវិធីសមហេតុផលបំផុតមួយ។ វាគឺជារឿងទូទៅមួយដែលថា អរិយធម៌តាមជ្រលងទន្លេឥណ្ឌូស ត្រូវបានលាតត្រដាងតាមរយៈការធ្វើកំណាយរបស់បុរាណវិទូឥណ្ឌា (1921-22)។

### 4.2. ប្រវត្តិសាស្ត្រ និងភូមិវិទ្យា

ខណៈពេលដែលមានការពិភាក្សាគ្នាថាមួយណាកើតមុនរវាងភូមិវិទ្យា និងប្រវត្តិសាស្ត្រ ទស្សនវិទូជនជាតិអាឡឺម៉ង់លោកកានត៍ បាននិយាយថា "ភូមិវិទ្យាគ្របពីលើពីមូលដ្ឋានគ្រឹះនៃប្រវត្តិសាស្ត្រ" ចំណែកឯលោកហ័រឌ័របាននិយាយថា "ប្រវត្តិសាស្ត្រគឺជាបណ្តុំនៃសកម្មភាពភូមិវិទ្យា"។ មានអ្នកដទៃទៀត ដូចជាលោកអែលស្វ័សហានទីងតុន និងលោកអាលលេន សេមផល អ្នកដែលបានចាត់ទុកសារៈសំខាន់នៃអាកាសធាតុថាបានជះឥទ្ធិពលយ៉ាងសំខាន់ទៅលើដំណើរការនៃប្រវត្តិសាស្ត្រ ក៏ដូចជាជះឥទ្ធិពលទៅលើនិស្ស័យរបស់ជាតិសាសន៍នីមួយៗ។ វាគឺ

ជាការពិតដែលកត្តាភូមិសាស្រ្តនានាដូចជា អាកាសធាតុ, ដី, ទន្លេ, ភ្នំ, សមុទ្ទ, ឆ្នេរ, និងធនធានក្នុងដី បានជួយដល់ការអភិវឌ្ឍនៃវប្បធម៌តាមជ្រលងទន្លេនានា ដូចជានៅ អេហ្ស៊ីប, មេសូប៉ូតាមី, ឥណ្ឌា, និងចិន។ លោកហេរ៉ូដូទឹស ប្រវត្តិវិទូជនជាតិក្រិចសម័យបុរាណ បានពិពណ៌នាថា "អេហ្ស៊ីបគឺជារង្វាន់មួយដែលទទួលបានពីទន្លេនីល"។ ប្រជាជនក្រិកបុរាណបានធ្វើដំណើរចេញទៅខាងក្រៅក៏ដូចជាធ្វើដំណើរតាមសមុទ្រ ដោយសារកត្តាភូមិសាស្រ្តជាច្រើនមានដូចជា ដីឥតមានជីជាតិ, ស្ថិតនៅជិតសមុទ្រ, និងឆ្នេរសមុទ្រដែលមិនល្អ។

នៅក្នុងដំណើរការនៃការបង្កើតឡើងនៃទម្រង់ជីវិត និងប្រវត្តិរបស់មនុស្ស អ្វីៗក៏ដោយអាចធ្លាប់ត្រូវបានរងឥទ្ធិពលដោយសារកត្តាភូមិសាស្រ្តនានាៗ ដូច្នេះមនុស្សម្នាក់គួរតែប្រុងប្រយ័ត្នឱ្យបានគ្រប់គ្រាន់ ដោយមិនត្រូវធ្វើទូទៅនីយកម្មឡើយ។ ជាមួយនឹងពេលវេលាកន្លងផុតទៅ មនុស្សទទួលបាននូវចំណេះដឹងផ្សេងៗអំពីការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធ្វើឱ្យសមស្របជាមួយតម្រូវការរស់នៅរបស់ពួកគេ។ តួយ៉ាងដូចជាប្រជាជនអ៊ីស្រាអែលសម័យទំនើប បានប្រែក្លាយតំបន់វាលខ្សាច់របស់ពួកគេឱ្យក្លាយទៅជាតំបន់ដែលអាចរស់នៅបាន ដូច្នេះពួកគេទៅនោះមិនរងឥទ្ធិពលពីភូមិសាស្រ្តឡើយ។ ដូច្នេះវាគួរតែកម្រិតឱ្យបានត្រឹមត្រូវនូវការអធិប្បាយអំពីឥទ្ធិពលនៃភូមិសាស្រ្តមកលើការប្រតិបត្តិរបស់មនុស្ស ឬមកលើប្រវត្តិរបស់ពួកគេ។

### 4.3. ប្រវត្តិសាស្រ្ត និងវិទ្យាសាស្រ្តសង្គមផ្សេងៗទៀត

ដែននៃប្រវត្តិសាស្រ្តត្រូវបានគេពង្រីកយ៉ាងទូលំទូលាយនៅក្នុងសម័យទំនើប ដោយបានបញ្ចូលនូវរាល់សកម្មភាពទាំងឡាយរបស់មនុស្សកាលពីអតីតកាល។ កាលពីអតីតកាល ប្រវត្តិសាស្រ្តត្រូវបានគេចាត់ទុកថាជាមុខវិជ្ជាមនុស្សសាស្រ្តតែមួយគត់។ ប៉ុន្តែ ក្រុមប្រឹក្សាស្រាវជ្រាវវិទ្យាសាស្រ្តសង្គមថ្មីមួយដែលត្រូវបានបង្កើតឡើងនៅសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ 1924 បានបញ្ចូលប្រវត្តិសាស្រ្តទៅក្នុងមុខវិជ្ជាវិទ្យាសាស្រ្តសង្គម។ ការធ្វើបែបនេះគឺដើម្បីលើកកម្ពស់ដល់វិធីសាស្រ្តនៃការបណ្តុះបណ្តាលរួមគ្នារវាងការស្រាវជ្រាវ និងការអប់រំ។ កិច្ចសហប្រតិបត្តិការមួយរវាងប្រវត្តិវិទូ ជាមួយអ្នកវិទ្យាសាស្រ្តសង្គមនឹងធ្វើដំណើរតាមផ្លូវដ៏វែងឆ្ងាយមួយជាមួយនឹងការយល់ដឹង និងការបង្រៀនឱ្យប្រសើរឡើងនូវមុខវិជ្ជាវិទ្យាសាស្រ្តសង្គម។

នរវិទ្យាជាមួយនិងប្រវត្តិសាស្រ្តគឺមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និត។ អតីតកាលអនុញ្ញាតឱ្យប្រវត្តិវិទូមួយរូបយល់ដឹងពីទម្រង់វប្បធម៌ និងឥរិយាបថរបស់មនុស្សសម័យដើមដែលស្ថិតនៅក្នុងអម្បូរផ្សេងៗគ្នា។ ដូច្នេះ ចំណេះដឹងដែលប្រវត្តិវិទូមួយរូបទទួលបានអំពីមុខវិជ្ជានេះ នឹងធ្វើដំណើរតាមផ្លូវដ៏វែងឆ្ងាយមួយជាមួយនឹងការពន្យល់ពីទម្រង់ឥរិយាបថ, ប្រពៃណី, និងសង្គមជំនាន់មុន និងបច្ចុប្បន្ន។ ប្រវត្តិវិទូពិតប្រាកដមួយរូប អាចគូសចេញនូវដំណើរការវិវត្តន៍នៃសង្គម និងវប្បធម៌នៅក្នុងសម័យបុរេប្រវត្តិសាស្រ្ត និងសម័យប្រវត្តិសាស្រ្ត។ ពួកគេនឹងធ្វើបានត្រឹមត្រូវទៅលើចំណុចនេះតាមរយៈចំណេះដឹងនរវិទ្យារបស់ពួកគេតែមួយគត់។

ប្រវត្តិវិទ្យាបានជួយដល់ការយល់ដឹងអំពីមុខវិជ្ជាវិទ្យាសាស្រ្តសង្គមផ្សេងៗទៀតផងដែរ ដែលក្នុងនោះមានដូចជាវិទ្យាសាស្រ្តនយោបាយ, សេដ្ឋកិច្ច, និងចិត្តវិទ្យា។ ដំណើរការស្វែងរកគ្មានទីបញ្ចប់នៃអំណាច និងរដ្ឋាភិបាលដែលមានសណ្តាប់ធ្នាប់មួយ នឹងអាចទទួលបានជោគជ័យទៅបានអាស្រ័យលើចំណេះដឹងប្រវត្តិនយោបាយ។ ជា

ថ្មីម្ដងទៀត ដំណើរការស្វែងរកគ្មានទីបញ្ចប់នៃជីវភាពរស់នៅ និងរបស់របរប្រើប្រាស់ដ៏ប្រសើរ ត្រូវពឹងផ្អែកលើចំណេះដឹងប្រវត្តិសេដ្ឋកិច្ច។ ប្រវត្តិសាស្ត្រក៏ទាក់ទងជាមួយនឹងឥរិយាបថរបស់ក្រុមផងដែរ និងបានផ្ដល់ការពន្យល់បកស្រាយ ឬវិភាគទៅលើព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដូចជា ការធ្វើបដិវត្តន៍, ចលនារបស់ប្រជាជន, អំពើហិង្សា, ឬប្រតិកម្មរបស់ហ្វូងមហាជន។ និស្ស័យរបស់ប្រវត្តិសាស្ត្រគឺការវិភាគ។ ដូច្នេះ ប្រវត្តិសាស្ត្រ និងមុខវិជ្ជាវិទ្យាសាស្ត្រសង្គមផ្សេងៗទៀតមានតួនាទីនៅក្នុងការបកស្រាយពន្យល់យ៉ាងទូលំទូលាយអំពីឥរិយាបថ និងស្ថានភាពផ្សេងៗរបស់មនុស្ស។ ចំណេះដឹងនៃមុខវិជ្ជាទាំងពីរអនុញ្ញាតិឱ្យវរជនដឹកនាំទាំងអស់អាចរៀបចំគម្រោង និងធ្វើការដើម្បីអនាគតដ៏ប្រសើរមួយ។ ប្រវត្តិសាស្ត្របានសិក្សាពីចរិតលក្ខណៈរបស់មនុស្សអស់រយៈកាលជាច្រើនសតវត្សរ៍មកហើយ ដូច្នេះមុខវិទ្យានេះស្ថិតនៅក្នុងតំណែងមួយនៅក្នុងការលើកស្ទួយសន្តិភាព និងសុភមង្គលសម្រាប់មនុស្សជាតិ។

# មេរៀនទី 2៖ ប្រវត្តិសាស្ត្រពិភពលោក និងដែនកំណត់របស់វា

គោលបំណងរបស់ប្រវត្តិសាស្ត្រពិភពលោក គឺដើម្បីផ្តោតលើការយកចិត្តទុកដាក់របស់និស្សិតទៅលើស្នាដៃជាច្រើនរបស់មនុស្សជាតិទាំងឡាយ ចាប់តាំងពីការកកើតឡើងនៃប្រវត្តិសាស្ត្រដំបូងរហូតមកដល់សម័យបច្ចុប្បន្ន។ ដូច្នេះ សកម្មភាពទាំងអស់នេះស្ថិតនៅក្នុងដំណើរការដ៏វែងឆ្ងាយមួយ ដែលបង្កើតឡើងដោយសង្គមនីមួយៗ ហើយសកម្មភាពទាំងនេះបានចូលរួមចំណែកដល់ការកកើតឡើងនៃអរិយធម៌ពិភពលោក។

ដើម្បីធ្វើវាឱ្យកាន់តែច្បាស់ ប្រវត្តិសាស្ត្រពិភពលោកបានយកចិត្តទុកដាក់ទៅលើដើមកំណើត និងការវិវត្តរបស់មនុស្សដំបូងដែលជាអម្បូរមនុស្សជាតិ, អន្តរកម្មរបស់មនុស្សជាមួយនឹងបរិស្ថានរបស់ពួកគេ, ការតាំងទីលំនៅរបស់ពួកមនុស្សដំបូងនៅតាមជ្រលងទន្លេ, ការបង្កើតសាសនា, សិល្បៈ និងស្ថាបត្យកម្ម, អក្សរសាស្ត្រ, ឧស្សាហ៍កម្ម, កសិកម្ម, ជំនួញ, និងពាណិជ្ជកម្ម។

ប្រទេសលោកខាងលិចនានាបានឈានចូលទៅក្នុងសម័យកាលថ្មីមួយ ដែលវាបានកត់សំគាល់ដោយការអនុវត្តនូវរបបរាជអត្តាធិបតេយ្យ, បុនសម័យ, ការស្រាវជ្រាវភូមិសាស្ត្រ, និងការស្រាវជ្រាវវិទ្យាសាស្ត្រ, និងការបង្កើតរបស់ថ្មីៗ។ បដិវត្តឧស្សាហកម្មនៅលោកខាងលិច បាននាំឱ្យប្រទេសជាតិជាច្រើនរបស់ពួកគេធ្វើដំណើរស្វែងរកការដាក់អាណានិគមនៅក្នុងទ្វីបអាមេរិក, អាហ្វ្រិក, និងអាស៊ី។ វាចំណាយអស់រយៈពេលដ៏យូរមួយសម្រាប់ប្រជាជនដែលស្ថិតនៅក្រោមអាណានិគម នៅក្នុងការផ្តាច់ខ្លួនពួកគេចេញពីនឹមអាណានិគមរបស់ពួកចក្រព័ត្តិនិយមលោកខាងលិច និងលេចចេញនូវឯករាជ្យមួយ។ ដូច្នេះ ប្រវត្តិសាស្ត្រពិភពលោក មិនត្រឹមតែយកចិត្តទុកដាក់ទៅលើដំណើរការរបស់មនុស្សជាតិតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានយកចិត្តទុកដាក់ទៅលើការតស៊ូរបស់មនុស្សប្រឆាំងជាមួយទម្រង់នៃការគាបសង្កត់ទាំងឡាយ។ ការចាប់កំណើតនៃអង្គការសហប្រជាជាតិដើម្បីជួយសង្គ្រោះពិភពលោកពីសង្គ្រាមនុយក្លេអ៊ែរ និងភាពអនាធិបតេយ្យ ដែលវាគឺជាបំណងប្រាថ្នារួមមួយរបស់មនុស្សជាតិនាសម័យបច្ចុប្បន្ន។

## 1. តម្រូវការនៃការសិក្សាប្រវត្តិសាស្ត្រពិភពលោក

ហេតុអ្វីបានជាយើងត្រូវសិក្សាពីប្រវត្តិសាស្ត្រពិភពលោក? សំណួរមួយនេះមានចម្លើយជាច្រើន។ ទីមួយ៖ ពិភពលោកបានក្លាយជាទីកន្លែងតូចមួយ ដោយអរគុណចំពោះការធ្វើបដិវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ប្រទេសជាតិតូចធំទាំងឡាយនឹងត្រូវរស់នៅជាមួយគ្នាដោយសន្តិភាព។ ការរស់នៅជាមួយគ្នាដោយសន្តិភាពអាចនឹងសម្រេចបានតាមរយៈមេត្រីភាព និងការយោគយល់គ្នាទៅវិញទៅមកក្នុងចំណោមបណ្តាប្រទេសទាំងឡាយ។ ដូច្នេះ គោលបំណងរួមមួយក្នុងចំណោមប្រជាជនទាំងឡាយ គឺការស្គាល់គ្នាទៅវិញទៅមក។ នៅត្រង់ចំណុចទាំងអស់នេះ ការសិក្សាប្រវត្តិសាស្ត្រពិភពលោកបានបំពេញនូវតម្រូវការរបស់ពួកគេ។ ទីពីរ៖ ប្រវត្តិសាស្ត្រពិភពលោកបានដើរតួនាទីជាគ្រូបង្រៀនម្នាក់ តាមរយៈការពន្យល់ពីបញ្ហា និងគ្រោះថ្នាក់នានាដែលប្រឈមជាមួយមនុស្សជាតិ។ ប្រសិនបើបញ្ហាទាំងអស់នេះមិនត្រូវបានដោះស្រាយឱ្យមានប្រសិទ្ធភាពទេ នោះការផ្ទុះឡើងនៃសង្គ្រាមលោកលើកទី 3 អាចនឹងកើតមានឡើងជាក់ជាពុំខាន។ ទីបី៖ ការសិក្សាប្រវត្តិសាស្ត្រពិភពលោកបានពង្រីកគំនិត និងទស្សនវិស័យរបស់មនុស្សម្នាក់។ វាបានអនុញ្ញាតឱ្យពួកគេមើលឃើញពីបញ្ហានៅក្នុងវិធីមួយដោយមិនមានកង្វល់ ដែលវាគឺជា

គន្លឹះមួយដើម្បីជោគជ័យនៅក្នុងជីវិត។ ចុងក្រោយ ការសិក្សាប្រវត្តិសាស្ត្រពិភពលោក អនុញ្ញាតឱ្យនិស្សិតទទួលបាននូវគុណភាពនៃបញ្ញា, គំនិតត្រាប្រណី, គំនិតប្រជាពលរដ្ឋ, និងភារៈកិច្ច។

## 2. ការកំណត់រយៈកាលនៃប្រវត្តិសាស្ត្រពិភពលោក

ប្រវត្តិសាស្ត្រនៃមនុស្សជាតិ ជាទូទៅត្រូវបានបែកចែកជា 2 ផ្នែក ដែលក្នុងនោះរួមមានសម័យបុរេប្រវត្តិសាស្ត្រ (ចាប់ពីឆ្នាំ 1000000 មុនគ.សរហូតដល់ឆ្នាំ 5000 មុនគ.ស) និងសម័យប្រវត្តិសាស្ត្រ (ចាប់ពីឆ្នាំ 5000 មុនគ.សរហូតដល់បច្ចុប្បន្ន)។ បុរាណវិទូបានធ្វើការបែងចែកប្រវត្តិសាស្ត្ររបស់មនុស្សជាតិទៅជាយុគផ្សេងៗគ្នា ដោយធ្វើការគិតពិចារណាទៅលើឧបករណ៍ប្រើប្រាស់ផ្សេងៗគ្នាដែលមនុស្សទាំងនោះបានប្រើ។ ឧទាហរណ៍ យើងបានឮអំពីយុគថ្មបំបែក ឬយុគថ្មបំបែកក្លាយ, យុគថ្មរំលីង, យុគទង់ដែង, យុគលង្ហិន, យុគដែក, និងសម័យទំនើប។

ដូចដែលភាគច្រើននៃការសិក្សារបស់យើងផ្តោតសំខាន់ទៅលើសម័យប្រវត្តិសាស្ត្រ ប្រវត្តិវិទូមានបែងចែកសម័យនេះទៅជា៖ សម័យបុរាណ (ឆ្នាំ 5000 មុនគ.ស រហូតដល់ឆ្នាំ 500 នៃគ.ស) សម័យកណ្តាល (ឆ្នាំ 500 នៃគ.សដល់ឆ្នាំ 1500 នៃគ.ស) និងសម័យទំនើប (ឆ្នាំ 1500 នៃគ.សដល់បច្ចុប្បន្ន)។ មូលហេតុដែលនាំឱ្យមានការបែងចែកសម័យកាលខាងលើនេះ គឺដើម្បីគូសបញ្ជាក់អំពីរបៀបនៃការរស់នៅរបស់មនុស្សនៅក្នុងពេលវេលាផ្សេងៗគ្នា។ សៀវភៅប្រវត្តិសាស្ត្រពិភពលោកមួយដែលមិនបាននាំទៅរកការយល់ដឹងរបស់និស្សិតនូវរបៀបផ្សេងៗគ្នានៃការរស់នៅរបស់មនុស្ស បានបង្កើតឲ្យមានចន្លោះដ៏ធំមួយនៅក្នុងចំណេះដឹងរបស់ពួកគេ។ ហេតុនេះទើបមានការគូសបញ្ជាក់ទៅលើការកំណត់រយៈកាលនៃប្រវត្តិសាស្ត្រពិភពលោក។

ព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ជាទូទៅត្រូវបានចុះការបរិច្ឆេទតាមប្រតិទិនគ្រឹស្តសាសនា។ ការចាប់កំណើតនៃព្រះយេស៊ូគ្រឹស្ត បាននាំមកនូវសករាជដ៏សំខាន់មួយដល់គ្រឹស្តសាសនិក។ ដូច្នេះ គេបានចាប់ផ្តើមរាប់ឆ្នាំទាំងមុនគ្រឹស្តសករាជ (BC) និងនៃគ្រឹស្តសករាជ (AD)។ គ្រឹស្តសករាជត្រូវបានចុះការបរិច្ឆេទ 4 ឆ្នាំ បន្ទាប់ពីការចាប់កំណត់របស់ព្រះយេស៊ូ។ មនុស្សគ្រប់រូបគួរដឹងថាព្រះយេស៊ូគ្រឹស្តបានចាប់កំណើតនៅថ្ងៃទី 25 ខែ ធ្នូ ឆ្នាំ 4 មុនគ្រឹស្តសករាជ។

## 3. វប្បធម៌ និងអរិយធម៌

និស្សិតប្រវត្តិសាស្ត្រម្នាក់ ជាធម្មតាគួរតែស្គាល់ច្បាស់ជាមួយនូវអត្ថន័យនៃពាក្យមួយចំនួន ជាពិសេសពាក្យវប្បធម៌ និងអរិយធម៌។ ពាក្យថា "វប្បធម៌" ជាសាមញ្ញមានន័យថា វិធីនៃការរស់នៅមួយរបស់មនុស្សមួយក្រុម។ វារួមបញ្ចូលនូវតម្រូវការប្រចាំថ្ងៃរបស់មនុស្ស ដែលមានដូចជា ចំណីអាហារ, សំលៀកបំពាក់ និងទីជម្រក រួមទាំងទំនៀបទម្លាប់របស់ពួកគេ, ទម្លាប់, ឫកពា, អាកប្បកិរិយា, គំនិត, និងសម្បជញ្ញៈ។ ម្យ៉ាងវិញទៀត ការចូលរួមរបស់មនុស្សនៅក្នុងសកម្មភាពនានានៅក្នុងសង្គមមួយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវជោគវាសនារបស់ពួកគេនៅក្នុងផ្នែកជាច្រើនបានកើតឡើងនៅក្រោមវប្បធម៌។ ចំណាប់អារម្មណ៍របស់ពួកគេទៅលើសិល្បៈ, ស្ថាបត្យកម្ម អក្សរសាស្ត្រ, ការសិក្សា, តន្ត្រី, ទស្សនៈវិជ្ជា, និងរបស់ផ្សេងៗទៀតដែលពួកគេបានធ្វើ ដើម្បីធ្វើឱ្យជីវិតរបស់ពួកគេសប្បាយរីករាយទាំងអស់នេះរួមបញ្ចូលនៅក្នុងវប្បធម៌។

អរិយធម៌បានបង្ហាញពីភាពជឿនលឿននៃវប្បធម៌។ សង្គមដ៏ធំមួយទទួលបានតំណែងនេះតាមរយៈការធ្វើបដិវត្តនៅក្នុងវង្វង់ ឬទិដ្ឋភាពនីមួយៗនៃវប្បធម៌។ គេនិយាយថា នៅពេលដែលសង្គមមួយបង្កើតរបស់ប្រើប្រាស់, ការសរសេរ, និងប្រតិទិនមួយ សង្គមនោះទទួលបាននូវជំហានដ៏ធំមួយនៅក្នុងដំណើរឆ្ពោះទៅរកអរិយធម៌។ លោកមេកអ៊ីវ៉ែបាននិយាយថា "វប្បធម៌របស់យើងគឺជាអ្វីដែលយើងមាន អរិយធម៌របស់យើងគឺជាអ្វីដែលយើងប្រើ"។

## 4. កត្តាដែលនាំឱ្យលេចឡើង និងការអភិវឌ្ឍវប្បធម៌

### 4.1. កត្តាភូមិសាស្ត្រ

វាមានសារៈសំខាន់ណាស់ នៅក្នុងការពិភាក្សាអំពីកត្តាដែលបានរួមចំណែកនាំឱ្យលេចឡើងនៃវប្បធម៌។ យោងទៅតាមលោកអ៊ែលស្វ័សហានទីងតុនកត្តាដែលមានសារៈសំខាន់បំផុតគឺសមាសភាពភូមិសាស្ត្រ ដែលមានដូចជាអាកាសធាតុ និងដី។ មិនមានវប្បធម៌មានតម្លៃណា ដែលនឹងលេចឡើងនៅក្នុងបរិស្ថានមិនអំណោយផលមួយឡើយ។ ធនធានទ្រទ្រង់ជីវិតមួយក្រុមរួមមានទឹក, ដី, អាកាសធាតុ, របាំងធម្មជាតិ, និងសភាវៈគតិនៃការពារខ្លួន។ កត្តាភូមិសាស្ត្រទាំងអស់នេះបាននាំឱ្យលេចឡើងនូវអរិយធម៌ដំបូងនៅក្នុងប្រទេសអេហ្ស៊ីប, មេសូប៉ូតាមី, ឥណ្ឌា, និងចិន។

### 4.2. ការច្នៃប្រឌិតរបស់ក្រុមភាគតិច

នៅក្នុងកិច្ចការដ៏សំខាន់មួយរបស់គាត់ ការសិក្សាប្រវត្តិសាស្ត្រ ប្រវត្តិវិទូដ៏ល្បីល្បាញមួយរូបលោកអាណូដជេ. តូយ្នប៊ីបានគូសចេញនូវកត្តាផ្សេងៗទៀតក្រៅពីកត្តាភូមិសាស្ត្រ។ លោកបានគូសបញ្ជាក់ទៅលើតួនាទីជាថាមវន្តនៃការច្នៃប្រឌិតរបស់ក្រុមភាគតិចនៅក្នុងសង្គមនីមួយៗ។ នៅក្នុងវប្បធម៌នីមួយៗ វណ្ណៈបញ្ញាវន្តបានបង្កើតស្ថានការណ៍ដែលអំណោយផលដល់ការរីកចម្រើន។ ពួកគេកាន់កាប់កន្លែងសំខាន់នៅក្នុងផ្នែករដ្ឋបាលស៊ីវិល និងយោធារបស់ប្រទេស។ កត្តាផ្សេងទៀត ដែលលោកបានអះអាងថាមានសារៈសំខាន់ចំបាច់សម្រាប់ការការពារវប្បធម៌គឺការពុះពារនានា។ វប្បធម៌ដែលបានកើតឡើងថ្មីមួយបានសឲ្យឃើញពីការពុះពារនានា ហើយភាពរស់រានរបស់វាពឹងផ្អែកទៅលើការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។ វាភាគច្រើនកើតឡើងនៅក្នុងទម្រង់នៃសង្គ្រាម ឬសង្គ្រាមស៊ីវិលមួយ ឬការបះបោរមួយ ឬការរញ្ជួយដីមួយ ឬគ្រោះអត់ឃ្លានមួយ។ ប្រសិនបើប្រភេទនៃបរិស្ថានមិនអំណោយផលនេះមិនត្រូវបានពុះពារតាមរយៈការឆ្លើយតបដោយប្រសិទ្ធភាព វប្បធម៌មួយនឹងសាបសូន្យ ឬចុះចាញ់ចំពោះឥទ្ធិពលវប្បធម៌បរទេស។ នៅក្នុងពិភពលោក និងលោកខាងលិច លោកតូយ្នប៊ីបានសំដៅទៅលើផលប៉ះពាល់នៃវប្បធម៌ខ្ពង់ខ្ពស់មួយទៅលើវប្បធម៌តូចទាបមួយផ្សេងទៀត។

### 4.3. សុខុមាលភាពសេដ្ឋកិច្ច និងសេរីភាព

វប្បធម៌មួយអាចស្លាប់បាន ប្រសិនបើមិនបានថែរក្សាវាឱ្យបានល្អប្រសើរតាមរយៈសកម្មភាពដែលប្រកបដោយការច្នៃប្រឌិតនានា។ នៅក្នុងសង្គមមួយ ភាពក្រីក្រអាចដើរតួជាសត្រូវមួយរបស់សកម្មភាពដែលប្រកបដោយការច្នៃប្រឌិតនានា។ មនុស្សនៅក្នុងសង្គមនោះ នឹងត្រូវរវៃខានដោយសារតម្រូវការចាំបាច់ប្រចាំថ្ងៃសម្រាប់ជីវិត។ ដូច្នេះ

វាប្រហែលជាមិនមានសេរីភាពសម្រាប់ពួកគេ នៅក្នុងការបញ្ចូលខ្លួនគេទៅក្នុងសកម្មភាពដែលប្រកបដោយការច្នៃប្រឌិតនានាឡើយ។ ដូច្នេះ កម្រិតជាក់លាក់មួយនៃសុខុមាលភាពសេដ្ឋកិច្ច អាចនឹងសឲ្យឃើញពីលទ្ធផលនៃការលេចឡើង និងការអភិវឌ្ឍនៃវប្បធម៌។ លោកអាលហ្វេដ អ៊ែល. ក្រូប័រនៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា រូបសណ្ឋាននៃវប្បធម៌ និងលោកស៊ី. អ៊ី. អឹម. ចូដនៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថាអ្វីទៅជាអរិយធម៌? ដោយបានគូសបញ្ជាក់ពីសារៈសំខាន់នៃសកម្មភាពដែលប្រកបដោយការច្នៃប្រឌិត។

### 4.4. ភាពលំអៀងនៃវប្បធម៌នៅតាមទីក្រុង

ជាទូទៅ វប្បធម៌បានរីកឡើងនៅក្នុងទីក្រុង។ នៅក្នុងទីក្រុងមនុស្សបានផ្លាស់ប្តូរគំនិត និងការគិតរបស់ពួកគេ។ នៅក្នុងទីក្រុង មណ្ឌលបណ្តុះបណ្តាលទទួលបានការឧបត្ថម្ភគាំទ្រ។ មណ្ឌលទាំងនេះដើរតួជាភ្នាក់ងារសម្រាប់ចែកចាយវប្បធម៌។ នៅក្នុងប្រទេសក្រិកនៅសម័យបុរាណ អាតែនបានដើរតួនាទីជាមណ្ឌលវប្បធម៌ដ៏សំខាន់មួយ និងបានទាក់ទាញនិស្សិតនានាមកពីប្រទេសជិតខាងឱ្យមានទទួលការបណ្តុះបណ្តាលនៅមណ្ឌលរបស់គេ។ ដូច្នេះ វប្បធម៌ទទួលបានការចិញ្ចឹមបីបាច់ និងរីកលូតលាស់នៅក្នុងទីក្រុង។

### 4.5. ពាណិជ្ជកម្ម

សុខុមាលភាពសេដ្ឋកិច្ច និងការលូតលាស់នៃទីក្រុងគឺពឹងផ្អែកទៅលើការរីកដុះដាលនៃពាណិជ្ជកម្ម។ ទីក្រុង និងតំបន់ជាច្រើនបានរីកលូតលាស់ដោយពឹងផ្អែកទៅលើផ្លូវពាណិជ្ជកម្មនៅអំឡុងយុគកណ្តាល (មជ្ឈិមសម័យ)។ បន្ទាប់ពីសង្គ្រាមរវាងពួកអ្នកកាន់សាសនាគ្រឹស្ត និងពួកអ្នកកាន់អ៊ីស្លាមមក អ៊ីតាលីទទួលបាននូវសិទ្ធិផ្តាច់មុខនៅក្នុងការធ្វើពាណិជ្ជកម្មនៅតំបន់មេឌីទែរ៉ានេ។ ទីក្រុងរបស់គេបានក្លាយជាទីក្រុងរុងរឿងបំផុត។ ក្រុមពាណិជ្ជករមានទ្រព្យស្តុកស្តម្ភរបស់គេបានផ្តល់នូវកម្លាំងរុញច្រានគ្រប់គ្រាន់ការចាប់បដិសន្ធិជាថ្មីនូវវប្បធម៌ថ្មីមួយ-បុនសម័យនៅក្នុងសតវត្សរ៍ទី 15 ។

### 4.6. ការលូតលាស់នៃវប្បធម៌ ជាមួយចំណេះដឹង និងគំនិតថ្មី

វប្បធម៌មួយគួរតែអាចសម្របខ្លួនគេមិនត្រឹមតែជាមួយបរិស្ថានថ្មីមួយប៉ុណ្ណោះទេ ប៉ុន្តែស្វាគមន៍នូវចំណេះដឹង និងគំនិតថ្មីៗ។ បន្ទាប់ពីទស្សនកិច្ច និងការកើនរំលឹករបស់ឧត្តមនាវីផ័រី ជប៉ុនមិនអាចបន្តរក្សាការបិទទ្វាររបស់គេដើម្បីរារាំងដល់ការចូលមកនៃវប្បធម៌បរទេសឡើយ។ ប្រតិកម្មរបស់គេមិនមែនជាការតស៊ូប្រឆាំងឡើយ ប៉ុន្តែគឺជាការព្រមទទួលយក។ រដ្ឋាភិបាលថ្មីស្ថិតនៅក្រោមអធិរាជជប៉ុន បានលើកទឹកចិត្តដល់ដំណើរការនៃបស្ចិមនីយកម្ម។ ភាពប្រសើរបំផុតរបស់ពួកបស្ចិមប្រទេសស្ថិតនៅលើចំណេះដឹងដ៏ឧត្តុងឧត្តមរបស់គេឧទាហរណ៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ជប៉ុនទទួលយកយ៉ាងច្រើននូវចំណេះដឹងទាំងនោះ និងបានក្លាយជាមហាអំណាចមួយ។

### 4.7. ភាពរឹងមាំនយោបាយ និងបរិយាកាសសង្គម

នៅក្នុងកថាខ័ណ្ឌមុន សេចក្តីបញ្ជាក់មួយបានបង្កើតឡើងចំពោះរដ្ឋ-បរិបាលកិច្ច។ ដូច្នេះ វាមានសារៈសំខាន់ក្នុងការដឹងថា វប្បធម៌មួយបានលូតលាស់នៅក្នុងនយោបាយ និងបរិយាកាសសង្គមរឹងមាំមួយ។ រដ្ឋ និង

សង្គមមួយគួរតែអនុញ្ញាតឱ្យមនុស្សគ្រប់រូប "គិតដោយសេរី និងថ្មី" ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់ពួកគេ។ មនុស្សល្បីល្បាញជាច្រើនទាំងបុរស និងស្ត្រី ដូចជា សេក្រេតេស, យេស៊ូគ្រីស្ទ, ចូន អប់ អាជ, មហាត្មៈគន្ធីបានរងទុក្ខជាទម្ងន់ដោយសារការតស៊ូដ៏ខ្លាំងក្លារបស់ពួកគេ។

ជាសង្ខេប ការលេចឡើង និងការលូតលាស់នៃវប្បធម៌មួយពឹងផ្អែកទៅលើកត្តាមួយចំនួនដូចជាកត្តាភូមិសាស្ត្រ និងសង្គម, ការច្នៃប្រឌិតរបស់ក្រុមភាគតិច, ការឆ្លើយតបដោយប្រសិទ្ធភាពចំពោះបញ្ហា, សុខុមាលភាពសេដ្ឋកិច្ច និងសេរីភាពរបស់វា, ពាណិជ្ជកម្ម, ចំណេះដឹង និងគំនិត និងភាពរឹងមាំនៃនយោបាយ និងបរិយាកាសសង្គម។

# មេរៀនទី 3៖ មនុស្សសម័យបុរេប្រវត្តិសាស្ត្រ

វាជាការចាប់អារម្មណ៍មួយ ក្នុងស្វែងយកអំពីរបៀបដែលមនុស្សក្រុបដណ្តប់នៅលើផែនដី និងជីវិតរស់នៅរបស់មនុស្សសត្វរាប់លាននាក់នៅលើភពផែនដីអំឡុងយុគនានា។ ជាជំហានដំបូង វាជាការចាំបាច់ក្នុងការយល់ដឹងអំពីរបៀប និងពេលវេលាដែលភពផែនដីរបស់យើងលេចឡើង និងផ្តល់កំណើតដល់មនុស្សសត្វរាប់កោដិ។

## 1. ដើមកំណើត និងជីវិតនៃផែនដី

ភូគព្ភវិទូបាននិយាយថា ផែនដីបានកើតឡើងប្រហែលជា 4,600 លានឆ្នាំកន្លងមកហើយ។ ទ្រឹស្តីល្បីល្បាញមួយនៅក្នុងចំណោមអ្នកវិទ្យាសាស្ត្រ បាននិយាយថា ផែនដីដំបូងលេចឡើងដូចជាបាល់ពណ៌ក្រហមដ៏ក្តៅមួយដែលពេញទៅដោយផ្សែងនៃចំហះឧស្ម័ន។ វាបានចាប់ផ្តើមចុះកម្តៅបន្ទាប់ពីប៉ុន្មានរយលានឆ្នាំកន្លងទៅ ដូច្នេះវាធ្វើឲ្យមានជីវិតលេចឡើង។ សមុទ្ទ, ផ្ទៃដី, និងភ្នំបានចាប់ផ្តើមលេចជារូបរាងឡើង។ ប៉ុន្តែរបៀបដែលជីវិតចាប់ផ្តើមឡើងនៅតែជាអាថ៌កំបាំងសម្រាប់អ្នកវិទ្យាសាស្ត្ររហូតមកដល់បច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ ជីវិតបានលេចឡើងភ្លាមៗ ប្រហែលជាតាមរយៈឧបទ្ទេវហេតុនៅក្នុងទឹកមួយកោដិឆ្នាំកន្លងមក។ កោសិកាជីវិតដ៏តូចនេះ (វារីជាតិ) បានចាប់ផ្តើមកើនឡើង, អភិវឌ្ឍ, និងលេចឡើងនៅក្នុងទម្រង់នានានៅក្នុងរយៈការដ៏យូរមួយ។ រុក្ខជាតិ និងសត្វមួយចំនួនរស់នៅនៅក្នុងទឹករាក់ៗ។ ពួកគេបានចាប់ផ្តើមសម្របទៅនឹងបរិស្ថាននៅលើដី។

នៅក្នុងប្រវត្តិសាស្ត្រនៃផែនដី យុគកណ្តាល ត្រូវបានគេស្គាល់សាជាយុគដែលសំបូរទៅដោយសត្វល្មូនជាច្រើនដូចជា ដាយណូស័រ ដែលដើរនៅលើដី។ ថនិកសត្វក៏បានលេចឡើងដែលពួកវាចិញ្ចឹមកូនដោយទឹកដោះ។ នៅពេលដែលផែនដីចាប់ផ្តើមចុះត្រជាក់ដែលជារយៈកាលឈានទៅរកយុគទឹកកក ជីវិតរាប់លានបានចាប់ផ្តើមវិនាសស្ទើរទាំងស្រុង ដែលរួមទាំង ដាយណូស័រ និងជីវិតផ្សេងៗទៀត។ មានតែថនិកសត្វប៉ុណ្ណោះដែលនៅរស់។ ក្រុមថ្មីៗបានចាប់ផ្តើមលេចចេញឡើង។ ផែនដីបានឆ្លងកាត់នូវយុគទឹកកក 4 ដងយោងទៅតាមភូគព្ភវិទូ។

## 2. មនុស្សដំបូងបំផុត

យើងមិនមានចំណេះដឹងគ្រប់គ្រាន់អំពីមនុស្សដំបូងបំផុត ដែលលេចឡើងនៅលើភពនេះឡើយ។ លោកដាវីនបានគូសបញ្ជាក់ពីដើមកំណើតនៃមនុស្សដំបូងទៅលើស្វាធំៗ ដែលលោកបានធ្វើការត្រិះរិះពិចារណាយ៉ាងច្រើន។ 80 ឆ្នាំកន្លងមក បណ្ឌិតជាតិហូល្លង់ម្នាក់ ដែលមានឈ្មោះថាឌូបូស បានធ្វើការរុករកសំណល់របស់មនុស្សដំបូងបំផុតនៅលើផែនដី-មនុស្សជ្វា។ សំណល់គ្រោងឆ្អឹងរបស់មនុស្សដំបូងបំផុតក៏ត្រូវបានរកឃើញនៅប៉េកាំង និងហៃដេលបឺកផងដែរ។ មនុស្សជ្វា និងមនុស្សប៉េកាំងគួរតែបានរស់នៅលើភពរបស់យើងប្រហែលមួយលានឆ្នាំកន្លងមក។ ពួកគេមានរូបរាងប្រសើរជាងស្វាធំៗ និងដើរដោយឈរត្រង់ទៅលើ។

នៅច្រលងនានដឺថាលនៅក្នុងប្រទេសអាឡឺម៉ង់ ស្លាក់ស្នាមនៃភាពខុសគ្នាមួយនៃអំបូរនៃមនុស្សប្រុស និងមនុស្សស្រីនៅសម័យបុរេប្រវត្តិសាស្ត្រត្រូវបានរកឃើញ។ ពួកគេគួរតែបានរស់នៅរវាងឆ្នាំ 100000 ដល់ឆ្នាំ 50000 មុនគ.ស។ មនុស្សនានដឺថាល មានដើមកំណើតដំបូងជាមួយនឹងដងខ្លួនក្រាស់ ថ្ងាស់តូច និងថ្គាម

លយទៅមុខ។ ប៉ុន្តែ ពួកគេហាក់ដូចជារីកចម្រើនជាងបុព្វការីរបស់ពួកគេ។ ក្រុមចុងក្រោយបំផុតនៃមនុស្សបុរេប្រវត្តិសាស្ត្រទាំងនេះគឺក្រូ-ម៉ាកណ្យុនដែលបានរស់នៅក្នុងរូងភ្នំនៅក្នុងប្រទេសបារាំងប្រហែល 20,000 ឆ្នាំកន្លងមក។ ពួកវាខ្ពស់ រូបរាងសមរម្យ និងស៊ីវីល័យជាមុន។

## 3. យុគថ្មចាស់ (ថ្មីបំបែក)

នរវិទូ និងបុរាណវត្ថុវិទូសម័យទំនើបបានធ្វើការសិក្សាអំពីជីវិតរស់នៅ និងរបស់របរប្រើប្រាស់ដោយមនុស្សនៅក្នុងសម័យបុរេប្រវត្តិសាស្ត្រ។ ប្រវត្តិសាស្ត្រដ៏វែងនៃមនុស្សបុរេប្រវត្តិសាស្ត្រយ៉ាងងាយ ត្រូវបានបានបែងចែកទៅជា យុគថ្មបំបែក និងយុគថ្មរលីង។ យុគថ្មបំបែកត្រូវបានគេមើលឃើញថាចាប់ផ្តើមឡើងអស់រយៈកាលដ៏យូរមួយ នៅពេលដែលមនុស្សចាប់ផ្តើមរបស់របរប្រើប្រាស់មិនទាន់រំលីង អាវុធសម្រាប់បរបាញ់សត្វ និងឧបករណ៍ប្រើប្រាស់ធ្វើពីថ្មសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅ។ ប្រហែលជាជោគជ័យដ៏សំខាន់បំផុតរបស់ពួកគេ អាចត្រូវបានកត់សំគាល់ទៅលើការរៀនរបស់ពួកគេអំពីរបៀបនៅក្នុងការបង្កើតពូថៅដៃ, លំពែង, និងភ្លើង។ របស់ទាំងអស់នេះអនុញ្ញាតិឱ្យពួកគេអាចរស់នៅជាមួយហ្វូងសត្វកាចសាហាវដ៏គ្រោះថ្នាក់បាន។ មនុស្សអំឡុងពេលនោះមិនទាន់មានទីអាស្រ័យជាក់លាក់ឡើយ។ ពួកគេធ្វើដំណើរពីមួយកន្លែងទៅមួយកន្លែងទៀតដើម្បីស្វែងរកអាហារនៅក្នុងព្រៃ។ ពួកគេបរបាញ់ និងសម្លាប់សត្វបានយ៉ាងងាយស្រួល និងបានបរិភោគសាច់របស់វា។ ពួកគេចាប់ផ្តើមប្រើប្រាស់ស្បែកសត្វសម្រាប់គ្របដណ្តប់ខ្លួនប្រាណរបស់ពួកគេ។ មនុស្សនានដឺថាលក៏បានប្រើប្រាស់រូងភ្នំសម្រាប់ការពារខ្លួនគេពីភាពត្រជាក់អំឡុងរដូវរងារ។ ពួកគេបានដឹងពីរបៀបក្នុងការបង្កើតភ្លើង និងបំភ័យសត្វជាមួយនឹងអណ្តាតភ្លើង។ ពួកគេបានធ្វើទំនាក់ទំនងទៅកាន់គ្នាគេតាមរយៈសម្រែក និងការគ្រហឹម។ នៅពេលដែលគ្នាគេស្លាប់ពួកគេបានកប់វា។

មនុស្សនានដឺថាល បានចាប់ផ្តើមបាត់រូបរាងនៅពេលដែលមនុស្សក្រូ-ម៉ាកណ្យុនបានធ្វើដំណើរទៅកាន់ភាគខាងជើង។ រឿងនេះត្រូវបានកើតឡើងប្រហែល 30,000 ឆ្នាំកន្លងមក។ មនុស្សក្រូ-ម៉ាកណ្យុនប្រើប្រាស់នូវរបស់របរ និងអាវុធសម្រាប់បរបាញ់ប្រសើរជាងមុន ដែលមានដូចជាសំពែងសម្រាប់ចោល, ធ្នូ និងព្រួញ, និងស្ទូ (សម្រាប់នេសាទ)។ មនុស្សស្រីបានធ្វើសំលៀកបំពាក់ពីស្បែកសត្វ។ មនុស្សក្រូ-ម៉ាកណ្យុនក៏បានបង្ហាញពីសមត្ថភាពសិល្បៈរបស់ពួកគេ តាមរយៈគំនូររូបភាពនៅលើជញ្ជាំងក្នុងរូងភ្នំ ដែលត្រូវបានគេរកឃើញនៅក្នុងប្រទេសបារាំង និងអេស្ប៉ាញ។ មនុស្សក្រូ-ម៉ាកណ្យុនអាចត្រូវបានពិពណ៌នាថាស្ថិតនៅក្នុងអំបូររបស់ពួកយើង-ហូម៉ូសាព្យ៉ាង។

## 4. ការធ្វើចំណាកស្រុករបស់ក្រុមអម្បូរមនុស្ស

ដូចដែរបានបង្ហាញនៅដើមដំបូង ផែនដីបានឆ្លងកាត់យុគទឹកកក ឬសម័យផ្ទាំងទឹកកកចំនួន 4 ដង។ យុគចុងក្រោយប្រហែលជាត្រូវបានបញ្ចប់ 11,000 ឆ្នាំកន្លងមកហើយ។ ផ្នែកដ៏ធំទូលាយនៃអឺរ៉ុបភាគខាងជើង, អាស៊ី និងកាណាដាគ្របដណ្តប់ដោយទឹកកក។ ដូច្នេះ មនុស្សនៅក្នុងយុគថ្មចាស់ត្រូវតែស្វែងរកការតាំងទីលំនៅ

នៅក្នុងតំបន់ដែលមានអាកាសធាតុកក់ក្ដៅ។ ដូច្នេះ ពួកគេបានរស់នៅរាយប៉ាយ។ មនុស្សជាតិត្រូវបានចាត់ថ្នាក់ទៅជាអម្បូរមនុស្សជាតិមួយចំនួន ដូចជាកៅកាសូអ៊ីត, ម៉ុងហ្គោឡូអ៊ីត, មេឌីទែរ៉ានៀន, និងនេក្រូអ៊ីត។

**5. យុគថ្មថ្មី (ថ្មរំលីង)**

យុគថ្មថ្មីចាប់ផ្ដើមឡើងប្រហែលឆ្នាំ 10000 មុនគ.ស ដែលបានបង្ហាញប្រាប់ឱ្យដឹងពីសករាជថ្មីមួយនៃជីវិតរស់នៅរបស់មនុស្ស។ ជីវិតរស់នៅដោយបម្លាស់ទីរបស់មនុស្សដើម្បីស្វែងរកអាហារត្រូវបានបញ្ចប់។ ដោយជំនួស ពួកគេបានរៀនពីរបៀបផលិតចំណីអាហារ។ ជាធម្មតា វាបាននាំទៅរករបៀបនៃការតាំងទីលំនៅកាន់តែច្រើន។ បុរាណវត្ថុវិទូបានរុករកឃើញតិចតួចពីការតាំងទីលំនៅនៅក្នុងប្រទេសមួយចំនួនដូចជា ស្វីស, អ៊ីតាលី, បារាំង, រុស្ស៊ី, ស្កុតលែន និងអាមេរិកខាងជើង។ មនុស្សយុគថ្មីរំលីងបានចាក់ចេញពីព្រៃភ្នំ និងបានចាប់ផ្ដើមរស់នៅតំបន់វាលរាប ជាពិសេសតំបន់ច្រាំងទន្លេ។

ដើម្បីជួយដល់ពួកគេក្នុងការធ្វើកសិកម្ម សត្វត្រូវបានគេយកមកផ្សាំង។ សត្វគោឈ្មោលត្រូវបានយកមកជួយពួកគេធ្វើកសិកម្ម។ សត្វគោមេ និងពពែបានផ្ដល់ទឹកដោះដល់ពួកគេ។ សត្វឆ្កែ និងសេះបានក្លាយជាសត្វដែលមានប្រយោជន៍នៅក្នុងសកម្មភាពមួយចំនួន។ ជាមួយនឹងស្បែករបស់ចៀម ពួកគេទទួលបានសំលៀកបំពាក់ធ្វើពីឡែន។ ពេលខ្លះមនុស្សប្រុសធ្វើការបរបាញ់ និងស្ត្រីមើលថែចំការរបស់ពួកគេ ដែលបានដាំដុះដើមកប្បាស, ស្រូវបាឡេ, និងស្រូវសាលី។

**6. សិល្បៈថ្មរំលីង**

មនុស្សយុគថ្មរំលីងបានបង្កើតសំលៀកបំពាក់ពីសរសៃអំបោះ និងកប្បាស។ ពួកគេបានរៀនពីសិល្បៈនៃការវេ និងត្បាញ និងដេរប៉ាក់សំលៀកបំពាក់។ ពួកគេបានប្រើប្រាស់នូវរបស់របរប្រើប្រាស់, ឧបករណ៍, និងអាវុធធ្វើពីថ្មរំលីង។ ហេតុនេះ វាបានធ្វើឱ្យយុគនេះត្រូវបានគេស្គាល់ថា យុគថ្មថ្មី។ ពួកគេក៏បានអភិវឌ្ឍសិល្បៈមួយចំនួន មានដូចជាគ្រឿងកុលាបភាជន៍, កញ្ច្រែង, កន្ទេស, ទូក, ខ្ទមធ្វើពីឈើ, និងតុ និងកៅអីឈើ។ នៅក្នុងរយៈពេលដ៏ខ្លី មនុស្សយុគថ្មីរំលីងបានធ្វើរបស់របរពីឈើ, ថ្ម, និងភ្លុកជាច្រើន។ ជីវិតរបស់ពួកគេចាប់ផ្ដើមងាយស្រួលនៅពេលដែលពួកគេបង្កើត រ៉ក, ពូថៅ, ម្ជុល, ជណ្ដើរ, ផ្លែសន្ទូច, ថ្មសំលៀងកំបិត, រហាត់ ។ល។ ប្រហែលជាការបង្កើតជាប្រវត្តិសាស្ត្រនៅពេលនោះគឺ កង់ ដែលបានបង្ហាញពីដំណើរវិវត្តទៅមុខរបស់ពួកគេ។

មនុស្សយុគថ្មរំលីងស្ទើតែមិនមានពេលក្នុងការបង្កើតគំនូរដូចជាបុព្វការីជនរបស់ពួកគេគឺ មនុស្សក្រូម៉ាកណូន្យ។ ប៉ុន្តែ ពួកគេបានតុបតែងភាជន៍របស់ពួកគេជាមួយការរចនាមួយចំនួន ដោយបានបង្កើតរូបចម្លាក់ពីដីឥដ្ឋ ឬឈើ និងរចនាសំលៀកបំពាក់ភ្លឺរលោង។ ភាសារបស់ពួកគេបានអភិវឌ្ឍន៍។ ការច្រៀង និងរាំកំឡុងពិធីបុណ្យនានាត្រូវបានគេនិយម។

### 7. យុគលោហៈ

មនុស្សនៅអាស៊ីខាងលិចបានរកឃើញទង់ដែងនៅចន្លោះឆ្នាំ 4000 មុនគ.ស ហើយបានបង្កើតជារបស់របរប្រើប្រាស់ និងអាវុធនានា មានដូចជា កាំបិតស្នៀត, កាំបិត, ពូថៅ, និងញញួរ។ ដូចដែលលោហៈមានភាពទន់ គែមនៃរបស់របរប្រើប្រាស់ និងអាវុធទាំងអស់នេះតែងតែរេចរិល។ មនុស្សមួយចំនួនបានរកឃើញសំណប៉ាហាំង រំលាយវា និងលាយបញ្ចូលវាជាមួយលោហៈទង់ដែង។ ការរួមបញ្ចូលគ្នានេះបានបង្កើតលោហៈដ៏រឹងមាំមួយ ដែលបច្ចុប្បន្នត្រូវបានគេស្គាល់ថាលង្ហិន (ឆ្នាំ 3000 មុនគ.ស) ។ ប៉ុន្តែយុគទង់ដែង និងយុគលង្ហិននៅក្នុងប្រវត្តិសាស្ត្របានចាប់ផ្ដើមដំបូងនៅអាស៊ីខាងលិច និងដើមបូព៌ា។ បន្តិចម្ដងៗ របកកំហើញ និងការប្រើប្រាស់របស់ពួកគេបានរីករាលដាលទៅកាន់តំបន់ផ្សេងទៀតនៅក្នុងពិភពលោក។ នៅជម្លោះឆ្នាំ 2000 មុនគ.ស ការប្រើប្រាស់លោហៈដ៏រឹងមាំមួយគឺដែក ត្រូវបានចាប់ផ្ដើមស្គាល់នៅអាស៊ីខាងលិច។ គេជឿជាក់ថា ប្រជាជនមេសូប៉ូតាមី គឺជាមនុស្សដំបូងបំផុតដែលប្រើប្រាស់លោហៈនេះ។ យុគលោហៈត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយនៃដំណើរការឆ្ពោះទៅមុខដ៏វែងឆ្ងាយរបស់មនុស្ស។

### 8. អម្បូរនៃមនុស្សជាតិ

មុនពេលដែលយើងឈានទៅសិក្សាពីសម័យប្រវត្តិសាស្ត្រ វាជាការចាំបាច់ណាស់នៅក្នុងការយល់ដឹងពីរបៀបដែលមនុស្សជាតិត្រូវបានគេបែងចែក យោងទៅតាមការកំណត់ត្រឹមត្រូវអំពីអម្បូរ។ នៅក្នុងពិភពលោកសព្វថ្ងៃមនុស្សជាច្រើនស្ថិតនៅក្នុងអម្បូរលាយបញ្ចូលគ្នាមួយ។ នៅក្នុងប្រទេសឥណ្ឌា មានអម្បូរលាយបញ្ចូលគ្នារវាងពួកអារ្យ៉ន និងដ្រាវិឌ។ ស្រដៀងគ្នានេះដែរ យើងមើលឃើញពីការលាយបញ្ចូលគ្នានៃអម្បូរនៅក្នុងទ្វីបអាមេរិក។ បើគិតទៅលើពណ៌សំបុល និងទម្រង់រូបរាង មនុស្សជាតិនាពេលបច្ចុប្បន្នត្រូវបានគេបែងចែកជាទូទៅទៅជា 3 អម្បូរ៖ (1) ពួកស្បែកខ្មៅ ឬ ជនជាតិស្បែកខ្មៅ, (2) ពួកស្បែកលឿង ឬម៉ុងហ្គោល, និង (3) ពួកស្បែកស ឬ (កៅកាសៀន) ។

(1) អ្នកទាំងឡាយដែរស្ថិតនៅក្នុងអបូរជនជាតិស្បែកខ្មៅ មានស្បែកពណ៌ខ្មៅ សក់រួញ ច្រមុះធំ និងបបូរមាត់ក្រាស។ នៅក្នុងចំណោមអម្បូរជនជាតិស្បែកខ្មៅ មានក្រុមពីរសំខាន់ៗ។ ក្នុងនោះរួមមាន ក្រុមជនជាតិស្បែកខ្មៅទាប ដែលគេអាចរកឃើញនៅ ម៉ាឡាយ៉ា, ហ្វីលីពិន, និងតំបន់មួយចំនួននៅអូស្ត្រាលី, និងក្រុមជនជាតិស្បែកខ្មៅធម្មតា ដែលគេអាចរកឃើញនៅអាហ្វ្រិចកណ្ដាល និងអាហ្វ្រិចខាងលិច។

(2) ប្រជាជននៅទីបេ, នេប៉ាល់, ឥណ្ឌូចិន, ជប៉ុន, ហ្វ័រម៉ូសា ស្ថិតនៅក្នុងអំបូរស្បែកលឿង ឬម៉ុងហ្គោល។ ពួកគេមានស្បែកពណ៌លឿង មុខរាបស្មើជាមួយនឹងឆ្អឹងថ្ពាល់ខ្ពស់ និងភ្នែកទ្រេត។ សូម្បីតែប្រជាជនឥណ្ឌាអាមេរិកក៏ស្ថិតនៅក្នុងសាខាមួយនៃអំបូរម៉ុងហ្គោលផងដែរ។ រួមទាំង ពួកអេស្គីម៉ូស ដែលស្ថិតនៅអាមេរិកខាងជើងក្នុងតំបន់អាក់តិច និងឥណ្ឌាអាមេរិកនៅអាមេរិកខាងត្បូងផងដែរ។

(3) ភាគច្រើននៃប្រជាជនដែលរស់នៅអឺរ៉ុប, អាហ្វ្រិចខាងជើង, អារ៉ាប់, ដែនកោះមួយចំនួននៅប៉ាស៊ីហ្វិច, ញ៉ូវហ្ស៊ីឡែន, ឥណ្ឌាខាងត្បូង និងសេរីលង្កាស្ថិតនៅក្នុងអម្បូរស្បែកស។ អម្បូរស្បែកសរមានច្រើនក្រុម ក្នុងនោះ

មានដូចជាន័រដិច, បាល់ទិចខាងកើត, អាលពីន និងមេឌីទែរ៉ានៀន។ ពួកន័រដិចខ្ពស់, ក្បាលវែង, ភ្នែកពណ៌ទង់ដែង និងពណ៌ខៀវ។ ពួកបាល់ទិចខាងកើតទាបជាមួយនឹងក្បាលមូល និងមុខមូល។ ពួកមេឌីទែរ៉ានៀន មានស្បែកពណ៌ខ្មៅ, ភ្នែកពណ៌ខ្មៅ, សក់វែង, និងក្បាលវែង។ ពួកទាសករភាពច្រើននៅក្នុងប្រទេសរូស្ស៊ីស្ថិតនៅក្នុងក្រុមអាលពីន។

វាជាការសំខាន់នៅក្នុងការកត់សំគាល់ថា យើងទាំងអស់គ្នាស្ទើតែមិនមាននណាម្នាក់មកពីអម្បូរសុទ្ធមួយណាឡើយ ឬអម្បូរដែលធ្វើអន្តោប្រវេសន៍ពីតំបន់មួយទៅកាន់តំបន់មួយទៀត។ ជាងនេះទៅទៀត វាត្រូវបានអះអាងថាគ្នាវប្បធម៌មួយណានាពេលបច្ចុប្បន្ននេះត្រូវបានគេភ្ជាប់ជាមួយអម្បូរជាក់លាក់មួយណាឡើយ។

# មេរៀនទី 4៖ ការសិក្សាពីប្រវត្តិសាស្ត្រ និងមនុស្សដំបូង

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកអាចនឹងដឹងថាតើឪពុកម្ដាយ ឬជូនតារបស់យើងមកពីទីកន្លែងណា និងយល់ដឹងខ្លះៗអំពីរឿងរ៉ាវនៃជីវិតរស់នៅរបស់ពួកគាត់។ រឿងរ៉ាវនៃគ្រួសាររបស់អ្នក អាចជួយអ្នកឱ្យយល់ដឹងច្បាស់អំពីប្រវត្តិផ្ទាល់ខ្លួនរបស់អ្នក។ ឥឡូវនេះ អ្នកកំពុងតែសិក្សាពីអ្វីដែលប្រវត្តិវិទូប្រើដើម្បីជួយដល់អ្នកក្នុងការស្វែងយល់ពីអតីតកាល។

## 1. ការយល់ដឹងពីអតីតកាល

សំណួរគន្លឹះ៖ ហេតុអ្វីបានជាគេរៀនប្រវត្តិសាស្ត្រ ហើយព្យាយាមសិក្សាកាន់តែស៊ីជម្រៅអំពីអតីតកាល?

មនុស្សធ្វើការស៊ើបអង្កេតពីប្រវត្តិគ្រួសាររបស់ពួកគេ ដើម្បីស្វែងរកឱ្យឃើញនូវបុព្វការីជនរបស់ពួកគេ។ ដូច្នេះនៅក្នុងដំណើរនេះ ពួកគេក៏នឹងអាចស្វែងយល់ខ្លួនគេផងដែរ។ យើងសិក្សាពីប្រវត្តិសាស្ត្រពិភពលោកក៏យ៉ាងដូច្នេះដែរ។ ហេតុអ្វីសិក្សាប្រវត្តិសាស្ត្រពិភពលោក? អ្វីដែលកើតមានចំពោះមនុស្សម្នាក់ គ្រួសារមួយ ឬសង្គមមួយនៅអតីតកាលអាចនឹងមានឥទ្ធិពលដល់អ្វីដែលនឹងកើតឡើងនាអនាគត។ ប៉ុន្តែប្រវត្តិសាស្ត្រលើសពីអ្វីដែលគ្រាន់តែរៀបរាប់ និងសិក្សាពីព្រឹត្តិការណ៍ពីអតីតកាល។ ការវិភាគលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយក៏តម្រូវឱ្យមានការសិក្សាពីវប្បធម៌, សាសនា, នយោបាយ, និងសេដ្ឋកិច្ចរបស់សង្គមមួយផងដែរ។ អ្វីដែលប្រវត្តិវិទូធ្វើការវិភាគពីព្រឹត្តិការណ៍ពីអតីតកាល ពួកគេព្យាយាមនៅក្នុងការស្វែងរកទម្រង់នានា។ អ្វីដែលសំខាន់ ប្រវត្តិវិទូព្យាយាមក្នុងការយល់ដឹងពីអតីតកាលតាមរយៈមនុស្សដែលធ្លាប់ឆ្លងកាត់ព្រឹត្តិការណ៍នោះ។ ដើម្បីធ្វើដូច្នេះ ពួកគេស្វែងយល់ឱ្យកាន់តែច្បាស់ពីធម្មជាតិនៃមនុស្ស ហើយផ្តល់នូវចម្លើយសម្រាប់សំណួរប្រវត្តិសាស្ត្រសំខាន់ៗ។

## 2. ប្រភពឯកសារដើម និងឯកសារទី 2

ប្រវត្តិវិទូចាប់ផ្តើមការសិក្សារបស់ពួកគេពីអតីតកាលដោយការសួរសំណួរ។ ពួកគេប្រើភស្តុតាងដើម្បីឆ្លើយសំណួររបស់ពួកគេ។ ភស្តុតាងទាំងនោះជាទូទៅត្រូវបានគេបែងចែកជាប្រភពឯកសារដើម និងប្រភពឯកសារទី 2 ។ ប្រភពឯកសារដើមមួយគឺជាអ្វីដែលសរសេរ ឬបង្កើតដោយមនុស្សដែលឆ្លងកាត់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនោះដោយផ្ទាល់។ ឯកសារប្រភពដើមអាចរួមមាន កំណត់ត្រាយោធា, ប័ណ្ណអាពាហ៍ពិពាហ៍, កំណត់ហេតុ, និងសំបុត្រផ្ទាល់ខ្លួន។ មិនមែនប្រភពឯកសារដើមទាំងអស់សុទ្ធតែជាសរសេរទាំងអស់នោះទេ ។ វត្ថុសិល្បៈនានា ដូចជាវត្ថុមួយចំនួនដែលរុករកឃើញដោយបុរាណវត្ថុវិទូក៏អាចរាប់បានថាជាប្រភពឯកសារដើមផងដែរ។ សំណង់ប្រាសាទស្នាដៃសិល្បៈ និងវត្ថុប្រើប្រាស់គឺជាឧទាហរណ៍នៃវត្ថុសិល្បៈដែលជាប្រភពឯកសារដើម។ ប្រភពឯកសារដើមមួយចំនួនទៀតគឺជាការនិយាយ។ ប្រវត្តិសាស្ត្រផ្ទាល់មាត់កើតចេញមកពីការនិយាយអំពីព្រឹត្តិការណ៍។ វារួមបញ្ចូលអំពីរឿងរ៉ាវ, ទំនៀមទម្លាប់, និងចម្រៀងដែលមានកន្លងផុតជាច្រើនឆ្នាំ។

ប្រភេទនៃភស្តុតាងផ្សេងទៀតគឺប្រភពឯកសារទី 2 គឺជាស្នាដៃការងារអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយរបស់មនុស្សដែលមិនបានឆ្លងកាត់ព្រឹត្តិការណ៍នោះ។ កាសែត, សៀវភៅ, និងឯកសារបោះពុម្ពជាទូទៅត្រូវបានគេចាត់

ទុកថាជាប្រភពឯកសារទី 2 ។ ប្រវត្តិសាស្ត្រផ្ទាល់មាត់ពេលខ្លះក៏អាចជាប្រភពឯកសារទី 2 ផងដែរ។ ប្រភពឯកសារទី 2 មួយអាចនឹងផ្ទុកនូវភាពស៊ីជម្រៅមួយអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលប្រភពឯកសារដើមមិនមាន។ ឧទាហរណ៍ ប្រភពឯកសារទី 2 អំពីលោកកូឡុំប៊ីស អាចនឹងកត់ត្រាថា លោកមិនបានធ្វើដំណើរតាមនាវាមកកាន់អាស៊ីទេ ជាអ្វីដែលលោកកូឡុំប៊ីស ខ្លួនលោកផ្ទាល់មិនដែលបាននិយាយ។

ហេតុអ្វីបានជាប្រវត្តិប្រែប្រួល៖ ប្រវត្តិវិទូវិភាគយ៉ាងយកចិត្តទុកដាក់ទៅលើរាល់ភស្តុតាងដែលពួកគេបានប្រមូល។ ពួកគេពេលខ្លះមានព័ត៌មានច្រើនជាងអ្វីដែលពួកគេអាចប្រើវាបាន។ ពួកគេពិនិត្យត្រួតៗអំពីព័ត៌មានទាំងអស់នោះ ហើយធ្វើការជ្រើសរើសព័ត៌មានដែលសំខាន់ និងត្រឹមត្រូវបំផុត។ ហេតុផលមួយដែលប្រវត្តិសាស្ត្រប្រែប្រួលគឺដោយសារប្រវត្តិវិទូផ្សេងៗគ្នាអាចនឹងប្រើប្រាស់ភស្តុតាងផ្សេងៗគ្នា។ នៅពេលដែលពួកគេស្វែងរកឃើញ និងវិភាគទៅលើភស្តុតាងប្រវត្តិវិទូធ្វើការបកស្រាយពីវា។ ការបកស្រាយអាចមានទម្រង់ផ្សេងៗគ្នា ដោយក្នុងនោះមានដូចជា អត្ថបទសៀវភៅ និងការតាំងបង្ហាញក្នុងសារមន្ទីរ។ ជាញឹកញយប្រវត្តិវិទូមានទំនាស់នៅក្នុងការបកស្រាយ។ ប្រវត្តិវិទូពេលខ្លះទាញសេចក្ដីសន្និដ្ឋានផ្សេងគ្នាចេញពីភស្តុតាងដូចគ្នា។

ចុងក្រោយ ការរុករកឃើញភស្តុតាងថ្មីអាចនឹងនាំឱ្យប្រវត្តិវិទូគូសចេញនូវសេចក្ដីសន្និដ្ឋានថ្មីមួយអំពីអតីតកាល។ ឧទាហរណ៍ នៅក្នុងឆ្នាំ 1799 ទាហានបារាំងបានរកឃើញថ្មរ៉ូសេតតា។ ថ្មរ៉ូសេតតាត្រូវបានគេដាក់ឈ្មោះតាមទីក្រុងមួយនៅអេហ្ស៊ីប ជាទីកន្លែងមួយដែលគេបានរកឃើញថ្មនោះ ថ្មនេះគឺជាប្រភពឯកសារដើមមួយរបស់អេហ្ស៊ីបុរាណ។ ព័ត៌មាននៅលើថ្មនេះបានពិពណ៌នាឡើងជា 3 ភាសា៖ អក្សររូបជាទម្រង់សរសេរបែបអេហ្ស៊ីបបុរាណ, ទម្រង់អក្សររូបសរសេរជាប់គ្នា, និងអក្សរក្រិច។ នៅក្នុងឆ្នាំ 1822 អ្នកប្រាជ្ញបារាំងមួយរូប ចុងក្រោយបានបំបែកកូដនៃអក្សររូប។ ការបំបែកនេះផ្ដល់នូវគន្លឹះក្នុងការអានអក្សររូប ដែលប្រវត្តិវិទូ និងអ្នកប្រាជ្ញបានព្យាយាមធ្វើអស់រយៈពេលជាង 1,000 ឆ្នាំ។ ប្រវត្តិវិទូចុងក្រោយអាចអានអក្សរអេហ្ស៊ីបបុរាណ ហើយធ្វើការបកប្រែអក្សរដែលសរសេរនៅតាមបូជនិយដ្ឋាន និងផ្នូរនានា។ ពួកគេអាចរៀនសូត្របានកាន់តែច្រើនពីអេហ្ស៊ីបបុរាណ។

ការធ្វើឱ្យប្រែប្រួល៖ ពន្យល់ថាហេតុអ្វីបានជាមនុស្សសិក្សាពីប្រវត្តិសាស្ត្រ និងអតីតកាល

### 3. មនុស្សដំបូងគឺជាអ្នកបរបាញ់ និងបេះផ្លែឈើ

សំណួរគន្លឹះ៖ តើមនុស្សដំបូងសម្របទៅនឹងបរិស្ថានដោយរបៀបណា?

ការសន្និដ្ឋានរបស់ប្រវត្តិវិទូអំពីមនុស្សដំបូងបានផ្លាស់ប្ដូរជាប្រចាំ ដោយសារតែភស្តុតាងថ្មីៗត្រូវបានរកឃើញ។ ប្រវត្តិវិទូយល់ស្របថា មនុស្សដំបូងគឺជាបរបាញ់ និងបេះផ្លែឈើ។ ពួកគេបរបាញ់សត្វ និងបេះផ្លែឈើនៅក្នុងព្រៃដើម្បីធ្វើជាចំណីអាហារ។ នៅពេលដែលការបរបាញ់ និងបេះផ្លែឈើមិនអាចផ្ដល់ឱ្យពួកគេហូបចុកគ្រប់គ្រាន់ពួកគេផ្លាស់ទីទៅកន្លែងផ្សេងទៀត។

ការសម្របទៅនឹងបរិស្ថាន៖ មនុស្សដំបូងពឹងផ្អែកការតាំងទីលំនៅរបស់ពួកគេទៅតាមធនធានធម្មជាតិ។ ក្រុមមនុស្សខ្លះរស់នៅតាមរូងភ្នំ និងរូងថ្ម។ ក្រុមមនុស្សដែលរស់នៅតំបន់វាលទំនាប ឬនៅតំបន់វាលខ្សាច់អាចនឹង

ចេះធ្វើទីលំនៅពីមែកឈើ សំបកឈើ ឬស្បែកសត្វដែលពួកគេបរបាញ់បាន។ ពួកបរបាញ់ និងបេះផ្លែឈើរស់នៅជាមួយគ្នាជាក្រុមតូចមួយ ដែលក្រុមតូចនីមួយៗអាចបង្កើតឡើងដោយគ្រួសារមួយចំនួន។ ទំហំនៃក្រុមមួយ (ប្រហែលជាមានសមាជិក 30 នាក់) ឆ្លុះបញ្ចាំងអំពីចំនួនមនុស្សដែលអាចរស់នៅបានអាស្រ័យលើរុក្ខជាតិ និងសត្វនៅក្នុងតំបន់នោះ។ បុរសជាអ្នកបរបាញ់ និងនេសាទ។ ស្ត្រីជាអ្នកស្វែងរកចំណីអាហារ ដូចជាផ្លែឈើ និងមើមរុក្ខជាតិដែលដុះនៅក្នុងព្រៃ ហើយនិងមើលថែកូន។

ការផ្លាស់ទីរបស់មនុស្សដំបូង៖ ពួកអ្នកបរបាញ់ និងបេះផ្លែឈើគឺជាអ្នកបម្លាស់ទី ពួកគេផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។ ការធ្វើដំណើររបស់ពួកគេជាទូទៅគឺមានដែនកំណត់ ហើយក្រុមមនុស្សទាំងនោះត្រឡប់មកកាន់កន្លែងចាស់វិញទៅតាមរដូវកាលផ្លាស់ប្តូរ។ មនុស្សដំបូងក៏ធ្វើដំណើរទៅកាន់កន្លែងថ្មី និងឆ្ងាយៗផងដែរ។ សកម្មភាពដែលពួកផ្លាស់ប្តូរពីកន្លែងមួយទៅតាំងទីលំនៅនៅកន្លែងមួយផ្សេងទៀតត្រូវបានគេហៅថា ការធ្វើអន្តោប្រវេសន៍។ ការធ្វើអន្តោប្រវេសន៍អាចបណ្តាលមកពីមនុស្សធ្វើដំណើរតាមបរបាញ់សត្វ។ ត្រឹមចន្លោះឆ្នាំ 13000 មុនគ.ស ក្រុមអ្នកបរបាញ់ និងបេះផ្លែឈើបានធ្វើអន្តោប្រវេសន៍ស្ទើរពាសពេញពិភពលោក។ ពួកគេអាចនឹងធ្វើដំណើរឆ្លងកាត់ស្ពានដីមួយដែលភ្ជាប់ពីតំបន់ស៊ីបេរីទៅអាឡាស្កា។ តាមផ្លូវនេះ ពួកគេបានចូលទៅកាន់អាមេរិក។ ការមកដល់នៃក្រុមអ្នកធ្វើអន្តោប្រវេសន៍នៅក្នុងទឹកដីរបស់ក្រុមមនុស្សផ្សេងទៀតអាចនាំទៅដល់ផលល្អ និងអាក្រក់។ មនុស្សទាំងអស់នឹងទទួលបានប្រយោជន៍នៅពេលដែលចំណេះដឹង និងឧបករណ៍ប្រើប្រាស់ត្រូវបានចែករំលែក។ ប៉ុន្តែ មនុស្សទាំងអស់នេះពេលខ្លះបង្កទៅជាហឹង្សានៅពេលដែលពួកគេគិតថា ពួកគេត្រូវបានគំរាមកំហែងដែលក្រុមអ្នកមកដល់ថ្មី ដោយពួកគេគិតថាពួកគេអាចជាអ្នកព្យាយាមដណ្តើមទឹកដីរបស់ខ្លួន។ ពេលខ្លះពេកគេអាចនឹងខ្លាចពួកអ្នកមកដល់ថ្មីដោយមូលហេតុគ្រាន់តែពួកគេមានលក្ខណៈខុសគ្នា។

សង្ខេប៖ ពន្យល់អំពីវិធីដែលមនុស្សដំបូងសម្របខ្លួនគេជាមួយបរិស្ថាន។

## 4. ការអភិវឌ្ឍឧបករណ៍ប្រើប្រាស់ និងវប្បធម៌

សំណួរគន្លឹះ៖ អ្វីជាធាតុសំខាន់នៃវប្បធម៌បុរេប្រវត្តិសាស្ត្រ?

បច្ចេកវិទ្យា៖ រួមបញ្ចូលនូវវិធីដែលមនុស្សប្រើប្រាស់នូវចំណេះដឹង ឧបករណ៍ប្រើប្រាស់ និងការបង្កើតថ្មីដើម្បីទទួលបាននូវអ្វីដែលពួកគេត្រូវការ។ បច្ចេកវិទ្យាចាប់ផ្តើមឡើងតាំងពីមនុស្សដំបូងមកម្លេះ។ ពួកគេដឹងពីការប្រើប្រាស់ឧបករណ៍ដើម្បីធ្វើឱ្យការងារកាន់តែងាយស្រួល។

ការអភិវឌ្ឍបច្ចេកវិទ្យា៖ យ៉ាងហោចណាស់ 2 លានឆ្នាំកន្លងទៅ មនុស្សបានបង្កើតឧបករណ៍ធ្វើពីថ្មដើម្បីកាត់របស់។ មនុស្សដំបូងក៏ចេះបង្កើតកាបូបដាក់របស់ ពូថៅដៃធ្វើពីថ្ម ដែកខៃ(ឧបករណ៍សម្រាប់ចោះរន្ធនៅលើស្បែក ឬឈើ)។ បន្ទាប់មក មនុស្សបានអភិវឌ្ឍឧបករណ៍កាន់តែស្មុគស្មាញ ដែលមានដូចជាធ្នូធ្វើពីឈើសម្រាប់បរបាញ់ជាដើម។ ពួកគេរៀនបង្កើតក្បាលព្រួញ និងឧបកណ៍ប្រើប្រាស់ធ្វើពីលោហៈ។ មនុស្សដំបូងប្រើប្រាស់ឧបករណ៍ដើម្បីបរបាញ់ និងសម្លាប់ សត្វ និងសាងសង់ទីជម្រកមានទម្រង់សាមញ្ញ។ បច្ចេកវិទ្យា(ឧបករណ៍ប្រើប្រាស់ថ្មីទាំងអស់នេះ) នាំឱ្យមនុស្សអាចគ្រប់គ្រងបានកាន់តែច្រើនទៅលើបរិស្ថាន។

ការប្រើប្រាស់ភ្លើង៖ នៅរវាង 500,000 ឆ្នាំកន្លងមក មនុស្សដំបូងបានរៀនប្រើប្រាស់ និងគ្រប់គ្រងភ្លើង។ ភ្លើងបានផ្តល់នូវកម្តៅ និងពន្លឺ ហើយវាអនុញ្ញាតឱ្យមនុស្សចម្អិនអាហារ។ ភ្លើងអាចជួយការពារពីការវាយប្រហារពីសំណាក់សត្វកាចសាហាវ។ មនុស្សដំបូងប្រើប្រាស់ភ្លើងស្ងួរលោហៈធ្វើឧបករណ៍ប្រើប្រាស់។

វប្បធម៌មនុស្សដំបូង៖ មនុស្សដំបូងបានបង្កើតវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ។ បុគ្គលិកលក្ខណៈនេះហើយដែលបានញែកមនុស្សឱ្យដាច់ដោយឡែកពីសត្វលោកដ៏ទៃទៀត។ សិល្បៈ ភាសា និងសាសនាគឺជាចំណុចរួមនៅមនុស្សទាំងអស់។ ភាសារបស់មនុស្សប្រហែលជាត្រូវបានអភិវឌ្ឍឡើងដោយសារតម្រូវសម្រាប់មនុស្សក្នុងការធ្វើការជាមួយគ្នា។ ទ្រឹស្តីមួយបានស្នើថា តម្រូវការក្នុងការសហការគ្នាអំឡុងពេលនៅការបរបាញ់បានជម្រុញឱ្យមានការអភិវឌ្ឍឡើងនៃភាសា។ ទ្រឹស្តីផ្សេងទៀតបានស្នើថា តម្រូវការនៃការសហការគ្នាដើម្បីជួបជុំ និងចែករំលែកចំណីអាហារបាននាំទៅដល់ការអភិវឌ្ឍភាសា។

សាសនា៖ គឺជាការគោរពបូជាព្រះជាម្ចាស់ ឬព្រលឹង។ មនុស្សដំបូងប្រហែលជាមានជំនឿលើធម្មជាតិទាំងឡាយ ដូចជាថ្ម ដើមឈើ និងសត្វ ថាមានព្រលឹង។ បុរាណវត្ថុវិទូមួយចំនួនជឿថា គំនូរសត្វក្នុងរូងភ្នំដំបូង គឺធ្វើឡើងដើម្បីផ្តល់កិត្តិយសដល់ព្រលឹងសត្វនានាដែលពួកគេបានសម្លាប់ដើម្បីយកមកបរិភោគ។ សិល្បៈដំបូងបានផ្តល់ឱ្យយើងនូវការយល់ដឹងដ៏ស៊ីជម្រៅមួយអំពីជីវិតរស់នៅ និងជំនឿរបស់មនុស្ស។ មនុស្សដំបូងបង្កើតសិល្បៈនៅក្នុងទីលំនៅរបស់ពួកគេក្នុងរូងភ្នំ និងផ្ទាំងថ្មនៅពាសពេញពិភពលោក។ ស្ថានីយ៍សិល្បៈក្នុងរូងភ្នំដំបូងច្រើនជាង 200 ត្រូវបានគេរុករកឃើញនៅប្រទេសបារាំង និងអេស្ប៉ាញ។ គំនូរក្នុងរូងភ្នំអាយុកាលរាប់ពាន់ឆ្នាំបានបង្ហាញពីរូបសត្វគោ, សេះ, និងគោព្រៃ។ សិល្បៈមនុស្សដំបូងលេចឡើងនៅអាហ្វ្រិក, អាស៊ី, អឺរ៉ុប អូស្ត្រាលី, និងអាមេរិក។ មនុស្សដំបូងក៏បានបង្កើតសិល្បៈដែលពួកគេអាចនាំយកតាមពួកគេបាន។ គ្រឿងអលង្ការ និងរូបចម្លាក់គឺជាឧទាហរណ៍នៃសិល្បៈដែលអាចយកតាមខ្លួនបាន។ មនុស្សដំបូងអាចនឹងពាក់វត្ថុទាំងអស់នេះ។ វត្ថុផ្សេងទៀតអាចនឹងមានអត្ថន័យទាក់ទងនឹងសាសនា ឬព្រលឹង។ សិល្បៈក៏រួមបញ្ចូលផងដែរនូវតន្ត្រី, របាំ, និងរឿងល្ខោន( សិល្បៈដែលអាចសម្តែងបានគ្រប់ទីកន្លែង )។

ស្វែងរកគោលគំនិត៖ កំណត់អំពីធាតុសំខាន់ៗនៃវប្បធម៌សម័យបុរេប្រវត្តិសាស្ត្រ។

## 5. ការចាប់ផ្តើមឡើងនៃកសិកម្ម

សំណួរគន្លឹះ៖ តើបទពិសោធន៍បរបាញ់ និងបេះផ្លែឈើបានជួយដោយរបៀបណាដល់មនុស្សដំបូងក្នុងការដាំដុះដាំណាំ និងផ្សាំងសត្វ?

មនុស្សដំបូងគឺជាពួកពនេចរ។ ពួកគេធ្វើដំណើរគ្រប់ទីកន្លែងដើម្បីស្វែងរកចំណីអាហារ។ នៅត្រឹមឆ្នាំប្រហែល 8000 មុនគ.ស ពួកគេបានរៀនអំពីវិធីកែច្នៃបរិស្ថានតាមរយៈការដាំដុះដំណាំ និងចិញ្ចឹមសត្វ។

ការប្រែប្រួលអាកាសធាតុ៖ ការកើនឡើងនៃសីតុណ្ហភាពបណ្តាលឱ្យផ្ទាំងទឹកកករលាយ។ ការរលាយនៃផ្ទាំងទឹកកកនេះនាំឱ្យមនុស្សដំបូងអាចផ្លាស់ទីទៅកាន់កន្លែងផ្សេងទៀតបាន។ ដូចដែលសីតុណ្ហភាពកើនឡើង រដូវ

កាលដាំដុះដំណាំមានរយៈពេលវែងជាងមុន។ ស្មៅព្រៃចាប់ផ្តើមដុះឡើងច្រើន ហើយមនុស្សចាប់ផ្តើមដាំដុះ និងបង្កាត់ពូជវា។ ជំនាញនេះបានផ្តល់ឱ្យមនុស្ស និងសត្វនូវចំណីអាហារកាន់តែច្រើន។

ការផ្សាំងសត្វ៖ មនុស្សដំបូងក៏យល់ដឹងផងដែរថា សត្វខ្លះអាចចាប់ និងធ្វើឱ្យសាំងបាន។ ចំណេះដឹងជំនាញរបស់អ្នកបរបាញ់ស្តីអំពីសត្វព្រៃប្រហែលជាដើរតួនាទីសំខាន់មួយនៅក្នុងការផ្សាំងសត្វ។ អំឡុងពេលនៃការបរបាញ់ពួកគេប្រហែលជាគៀងហ្វូងសត្វឱ្យចូលក្នុងជ្រលងភ្នំដើម្បីចាប់និងសម្លាប់ពួកវា។ គំនិតនៅក្នុងការគៀងហ្វូងសត្វចូលទៅក្នុងរបងហ៊ុំព័ទ្ធដោយមនុស្ស អាចនឹងត្រូវបានអភិវឌ្ឍចេញមកពីរឿងនេះ។ សត្វដែលស្ថិតនៅក្នុងរបងហ៊ុំព័ទ្ធអាចត្រូវបានគេរក្សាទុកដើម្បីធ្វើជាចំណីអាហារទៀងទាត់មួយ ហើយជាយថាហេតុពួកគេបានចិញ្ចឹមសត្វទាំងនោះ។ មនុស្សដំបូងបានរៀនចិញ្ចឹមសត្វដំបូងបំផុតនៅរង្វង់ឆ្នាំ ១០០០០ មុនគ.ស។ ការចិញ្ចឹមសត្វបានផ្តល់នូវប្រភពចំណីអាហារ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀតទៀងទាត់។ មនុស្សដំបូងប្រើប្រាស់ស្បែកសត្វដើម្បីធ្វើសំលៀកបំពាក់ និងទីជម្រក។ ពួកគេផលិតស្នូ ម្ជុល និងឧបករណ៍ប្រើប្រាស់ផ្សេងៗទៀតពីឆ្អឹងសត្វ។ សត្វមួយចំនួនដូចជាសេះ, លា, និងអូដ្ឋ ត្រូវបានគេប្រើសម្រាប់ជាមធ្យោបាយក្នុងការដឹកជញ្ជូនមនុស្ស និងទំនិញ។ មនុស្សប្រហែលជាចិញ្ចឹមសត្វឆ្កែដើម្បីជួយពួកគេក្នុងការបរបាញ់សត្វព្រៃ។ ដោយសារតែមនុស្សដំបូងពឹងផ្អែកលើសត្វ និងផលិផលធ្វើពីសត្វ នៅក្នុងជីវភាពរស់នៅរបស់ពួកគេ ការចេះចិញ្ចឹមសត្វទាំងនោះគឺជារឿងមានប្រយោជន៍យ៉ាងខ្លាំង។

បដិវត្តកសិកម្ម៖ ក៏ដូចជាចំណេះដឹងរបស់ពួកបរបាញ់អំពីសត្វព្រៃដែលនាំឱ្យពួកគេអាចផ្សាំងសត្វទាំងអស់នោះដែរ ការយល់ដឹងអំពីរុក្ខជាតិរបស់អ្នកប្រមូលចំណីអាហារប្រហែលជានាំទៅដល់ការអភិវឌ្ឍឡើងនូវការធ្វើស្រែចំការ។ អ្នកប្រមូលចំណីអាហារអាចនឹងកំណត់ចំណាំថា គ្រាប់ធុញ្ញជាតិដុះចេញមកពីគ្រាប់រុក្ខជាតិដែលទុំ។ ចុងក្រោយ មនុស្សទទួលបាននូវគំនិតអំពីកសិកម្ម ឬការដាំដុះគ្រាប់ពូជដើម្បីបង្កើនគ្រប់ធុញ្ញជាតិ។ បដិវត្តកសិកម្មគឺជាឈ្មោះដែលគេដាក់ដើម្បីសំដៅទៅលើការផ្លាស់ប្តូរពីការដើរប្រមូលចំណីអាហារ ទៅជាការដាំដុះចំណីអាហារ។ កសិកម្មប្រហែលជាចាប់ផ្តើមនៅអាស៊ីរង្វង់ឆ្នាំ ៨០០០ មុនគ.ស។ នៅក្នុងរយៈពេលប្រហែល 5 ពាន់ឆ្នាំ អរិយធម៌នៅអាហ្រិក, អាស៊ី, និងអាមេរិកបានត្រឡប់ទៅរកកសិកម្ម។ ការដាំដុះចាប់ផ្តើមរីកសាយភាយទៅកាន់តំបន់ជុំវិញ។ បដិវត្តកសិកម្មបាននាំមកនូវការផ្លាស់ប្តូរឧបករណ៍ប្រើប្រាស់ និងបច្ចេកវិទ្យា។ មនុស្សបានបង្កើតចបកាប់ដើម្បីជ្រោយដី, នង្គ័លដើម្បីជួយដល់ការដាំដុះគ្រាប់ពូជ, និងកន្ត្រៃដើម្បីប្រមូលផលគ្រាប់ធុញ្ញជាតិ។ ដូចដែលបច្ចេកវិទ្យា និងវិធីសាស្ត្រធ្វើស្រែត្រូវបានធ្វើឱ្យប្រសើរឡើង កសិកម្មបានក្លាយជាប្រភពនៃធនធានចំណីអាហារដ៏សំខាន់បំផុតរបស់មនុស្ស។ ការដាំដុះនៅលើដីក្នុងតំបន់មួយអាចផ្តល់នូវចំណីអាហារច្រើនជាងការបរបាញ់ និងបេះផ្លែឈើនាំឱ្យមានការកើនឡើងនូវចំនួនប្រជាជន និងឱកាសក្នុងការតាំងទីលំនៅនៅមួយកន្លែង។

គូសបង្ហាញសេចក្តីសន្និដ្ឋាន៖ តើបទពិសោធន៍បរបាញ់ និងបេះផ្លែឈើបានជួយដោយរបៀបណាដល់មនុស្សដំបូងក្នុងការដាំដុះដាំណាំ និងផ្សាំងសត្វ?

# មេរៀនទី 5៖ សហគមន៍ដំបូង

ភ្ជាប់ទៅនិងអ្វីដែលបានដឹង៖ នៅក្នុងប្រទេសរបស់អ្នក តើអ្នករស់នៅក្នុងទីក្រុង ទីប្រជុំជន ឬទីជនបទ? កាលពីអតីតកាលដ៏យូរលង់មកហើយ ភូមិកសិកម្មធម្មតាបានអភិវឌ្ឍអស់រយៈពេលរាប់ពាន់ឆ្នាំឱ្យក្លាយជាភូមិកាន់តែស្មុគស្មាញ ហើយចុងក្រោយបានអភិវឌ្ឍក្លាយជាទីក្រុង។

## 1. ការតាំងទីលំនៅដំបូង

សំណួរគន្លឹះ៖ តើការធ្វើស្រែចំការនាំឱ្យវិធីរស់នៅរបស់មនុស្ស មានការផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះ?

មនុស្សរៀននៅក្នុងការធ្វើស្រែចំការឱ្យកាន់តែប្រសើរ ដូចដែលឧបករណ៍ប្រើប្រាស់របស់ពួកគេមានភាពជឿនលឿន។ ក្រុមមនុស្សជាទូទៅបន្តរស់នៅកន្លែងដដែលជាជាងធ្វើដំណើរវិលចុះឡើងជារៀងរាល់ឆ្នាំ។ ពួកគេបានអភិវឌ្ឍទីលំនៅធំជាងមុន និងជាអចិន្ត្រៃ។

ភូមិកសិកម្មអភិវឌ្ឍនៅពាសពេញពិភពលោក៖ ការអភិវឌ្ឍវិស័យកសិកម្មដំបូងធ្វើឡើងនៅតាមតំបន់ដែលមានប្រភពទឹកប្រើប្រាស់ ក្នុងនោះមានដូចជាជ្រលងទន្លេជាដើម។ ប្រព័ន្ធបង្ហូរទឹកគឺជាការបញ្ចូលទឹកទៅកន្លែងដីស្ងួតដោយប្រើបណ្តាញប្រឡាយ, បំពង់, និងអូរ។ តំបន់ដីដែលសំបូរជីជាតិ ធ្វើឱ្យទិន្នផលបានច្រើន និងប្រសើរផងដែរ ដែលវាបានទាក់ទាញកសិករ។ ប្រជាកសិកររស់នៅក្នុងភូមិធំៗ និងធ្វើដំណើរទៅកាន់ដីស្រែចំការរបស់ពួកគេដើម្បីធ្វើការងារ។ នៅក្នុងភូមិចំនួនប្រជាជនបានកើនឡើងរហូតដល់រាប់ពាន់នាក់។ ជីវិតរស់នៅក្នុងភូមិបានផ្តល់ផលប្រយោជន៍ជាច្រើន។ ចំណីអាហារកាន់តែមានភាពសម្បូរបែប។ មនុស្សរស់នៅជុំគ្នាជាក្រុមធំ អាចមានភាពងាយស្រួលនៅក្នុងការការពារពីការវាយប្រហាររបស់ពួកក្រុមពនេចរផ្សេងៗទៀត។ ជីវិតរស់នៅក្នុងភូមិក៏មានគុណវិបត្តិផងដែរ ដោយក្នុងនោះមានហានិភ័យនៃអគ្គីភ័យ, ជំងឺ, និងទឹកជំនន់។

ការអភិវឌ្ឍភាពលើស៖ ដូចដែលបច្ចេកទេសកសិកកម្មកើនឡើង កសិករជាទូទៅបានផលិតទិន្នផលលើស។ ភាពលើសគឺជាអ្វីដែលច្រើនជាងអ្នកត្រូវការដើម្បីរស់រាន។ ឧទាហរណ៍ កសិករដាំដុះដំណាំធុញ្ញជាតិច្រើនជាងអ្វីដែលគ្រួសារ ឬភូមិរបស់គេត្រូវការ។ គ្រាប់ធុញ្ញជាតិដែលនៅសល់គឺជាការកើនឡើងនៃសេដ្ឋកិច្ច។ ភាពលើសនៅក្នុងភូមិកសិកម្មដំបូងមិនមែនលើសតែទិន្នផលកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែភាពលើសនោះក៏រួមបញ្ចូលវត្ថុធាតុដើមសម្រាប់ផលិតសំលៀកបំពាក់ និងផលិផលផ្សេងៗទៀត។ ឧទាហរណ៍ អ្នកចិញ្ចឹមសត្វចៀម មានភាពលើសនៃរោមចៀម។ ភាពលើសនៃទិន្នផលនៅក្នុងរដូវល្អជួយដល់អ្នកភូមិឲ្យរស់បាននៅរដូវមិនល្អ។ នៅពេលដែលភូមិកាន់តែរុងរឿង ពួកគេអាចផ្គត់ផ្គង់មនុស្សបានកាន់តែច្រើន។ ដូច្នេះចំនួនប្រជាជនកើនឡើង។ សេដ្ឋកិច្ចនៅក្នុងភូមិកាន់តែមានភាពចម្រុះ ដូចដែលមនុស្សចាប់ផ្តើមអភិវឌ្ឍជំនាញពិសេស។

មនុស្សអភិវឌ្ឍជំនាញផ្សេងៗគ្នា៖ ដូចដែលកសិករចាប់ផ្តើមផលិតលើស មិនមែនមនុស្សគ្រប់រូបតម្រូវឱ្យដាំដុះចំណីអាហារទៀតទេ។ មនុស្សចាប់ផ្តើមហាត់រៀននូវជំនាញឯកទេសផ្សេងៗទៀត។ ឯកទេសកម្មគឺជាជំនាញនៅក្នុងការធ្វើការងារអ្វីមួយ។ អ្នកស្មូន និងអ្នកតម្បាញប្រហែលជាជំនាញឯកទេសដំបូងគេបំផុត។ ពួកគេផលិតនូវ

ផលិតផលដែលមនុស្សគ្រប់គ្នាអាចប្រើប្រាស់បាន។ អ្នកស្មូនផលិតភាជន៍សម្រាប់ដង និងដាក់ទឹក និងដាក់ចំណីអាហារ។ អ្នកតម្បាញបង្កើតសំលៀកបំពាក់ពីសរសៃកប្បាស, រោមចៀម, និងដើមក្រចៅ។ អ្នកស្មូន និងអ្នកតម្បាញដោះដូរផលិតផលរបស់ពួកគេជាមួយចំណីអាហារ។ មនុស្សមួយចំនួននៅក្នុងសហគមន៍មួយត្រូវបានគេចាត់ទុកថាមនុស្សពិសិដ្ឋ។ មនុស្សពិសិដ្ឋទាំងនេះតែងតែត្រូវបានគេហៅថាសាម៉ាន ធ្វើការបកស្រាយអំពីព្រឹត្តិការណ៍ធម្មជាតិនានាដូចជាភ្លៀង និងភ្លើងជាដើម។ ពួកគេពន្យល់អំពីមូលហេតុនៃការប្រមូលផលបានល្អ ឬមិនល្អ។ ពួកគេក៏ជាអ្នកព្យាបាលតាមរយៈការធ្វើទំនាក់ទំនងជាមួយពិភពព្រលឹង។ មនុស្សមួយចំនួនចាប់ផ្តើមវិវត្តខ្លួនទៅជាបព្វជិកនៅក្នុងទីក្រុង។វីធីនៅក្នុងការរស់នៅក្នុងភូមិគឺមានលក្ខណៈថ្មី និងមានភាពខុសប្លែកគ្នា។ អ្នកបរបាញ់ និងប្រមូលផល រស់នៅជាលក្ខណៈពនេចរ ធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។ មនុស្សនៅក្នុងភូមិតាំងទីលំនៅនៅមួយកន្លែង ហើយមិនបន្តពឹងអាស្រ័យលើការរកចំណីអាហារដោយការបរបាញ់ និងប្រមូលហេតុទៀតឡើយ។ ផ្ទុយទៅវិញ កសិករធ្វើការដើម្បីផលិតចំណីអាហារគ្រប់គ្រានសម្រាប់មនុស្សនៅក្នុងភូមិទាំងមូល។ ការធ្វើការងារចាប់ផ្តើមកាន់តែជំនាញ ហើយអ្នកមិនមែនកសិករប្តូរទំនិញ និងសេវារបស់គេជាមួយចំណីអាហារ។

គូសបង្ហាញសេចក្តីសន្និដ្ឋាន៖ ពន្យល់ថាតើការដាំដុះដំណាំបានផ្លាស់ប្តូរដូចម្តេចខ្លះដល់ជីវិតរស់នៅរបស់មនុស្សដំបូង។

## 2. ភូមិសាមញ្ញបានវិវត្តកាន់តែស្មុគស្មាញ

សំណួរគន្លឹះ៖ តើជីវិតរស់នៅក្នុងភូមិកាន់តែស្មុគស្មាញមានលក្ខណៈដូចម្តេច?

ភាពលើស និងឯកទេសកម្មនាំទៅដល់ការរីកលូតលាស់នៃភូមិ។ ជីវិតរស់នៅចាប់ផ្តើមស្មុគស្មាញនៅក្នុងភូមិមួយចំនួនដោយសារតែភូមិទាំងនោះបានអភិវឌ្ឍ។ ទំនាក់ទំនងសង្គមក៏មានលក្ខណៈកាន់តែស្មុគស្មាញ ដូចដែលមនុស្សនៅក្នុងភូមិកាន់តែមានចំនួនច្រើន។

ការផ្លាស់ប្តូរវិធីក្នុងការរស់នៅ៖ ភាពលើសនៃចំណីអាហារ និងទំនិញផ្សេងៗទៀតមានន័យថា មនុស្សកាន់តែច្រើនអាចរស់នៅជាមួយគ្នាបាន។ នៅក្នុងវិធីនេះ ភាពលើសបានជំរុញឱ្យមានការរីកធំនៃភូមិ និងចំនួនប្រជាជនកើនឡើង។ ភាពលើសក៏បាននាំទៅដល់ការកើនឡើងនៃការផ្លោះប្តូរទំនិញ។ មនុស្សនៅក្នុងភូមិអាចនឹងប្តូរចំណីអាហារលើសរបស់ពួកគេជាមួយនឹងឧបរណ៍ប្រើប្រាស់លើសរបស់មនុស្សនៅក្នុងភូមិផ្សេងទៀត។ កសិកម្មបានអនុញ្ញាតឱ្យភូមិកាន់តែច្រើនអាចផលិតនូវទិន្នផលលើស និងឯកទេសកម្ម វិធីដែលមនុស្សទាក់ទងគ្នាចាប់ផ្តើមផ្លាស់ប្តូរ។ អ្នកស្មូន, អ្នកតម្បាញ, និងក្រុមអ្នកហត្ថកម្មផ្សេងទៀតបានចំណាយពេលជាច្រើនឆ្នាំដើម្បីរៀនជំនាញរបស់ពួកគេ។ មនុស្សដែលបណ្តុះបណ្តាលជំនាញ និងហត្ថកម្ម ត្រូវបានគេហៅថាសិប្បករ។ ជាងឈើ អ្នកផលិតឧបករណ៍ប្រើប្រាស់ អ្នកផលិតសំលៀកបំពាក់ និងអ្នកស្មូនទាំងនេះគឺជាសិប្បករ។ មនុស្សដែលមានជំនាញដូចគ្នានេះ បានអភិវឌ្ឍទៅជាមុខរបរមួយ។ នៅក្នុងវិធីនេះ ឯកទេសកម្មបាននាំទៅដល់ការអភិវឌ្ឍវណ្ណៈសង្គម។ វណ្ណៈសង្គម គឺជាមនុស្សមួយក្រុមដែលមានទំនៀមទម្លាប់, សាវតា, ការបណ្តុះបណ្តាល, និងចំណូលប្រហាក់ប្រហែលគ្នា ក្នុងនោះមានដូចជាកសិករ, សិប្បករ, បព្វជិក, និងមេដឹកនាំ។ ដូចដែលសហគមន៍បុរាណបានអភិវឌ្ឍទៅជាភូមិ

ធំៗ មនុស្សត្រូវការច្បាប់ និងមេដឹកនាំដើម្បីរក្សាសណ្តាប់ធ្នាប់ និងដំណោះស្រាយបញ្ហា។ មនុស្សបានអភិវឌ្ឍទម្រង់ដំបូងនៃរដ្ឋាភិបាល ដែលជាវិធីនៅក្នុងការរក្សាសណ្តាប់ធ្នាប់ និងផ្តល់ការដឹកនាំ។ មនុស្សដំបូងបង្កើតច្បាប់ ដើម្បីធ្វើឱ្យសហគមន៍របស់ពួកគេមានសុវត្ថិភាព និងស្ថេរភាព។

ជីវិតរស់នៅក្នុងភូមិស្មុគស្មាញ៖ ភូមិស្មុគស្មាញមួយមានមនុស្សរស់នៅច្រើនជាភូមិធម្មតា ដែលមនុស្សទាំងអស់រស់នៅជិតៗគ្នា។ មនុស្សច្រើននៅក្នុងភូមិនាំឱ្យមានភាពសំបូរបែបនៃជំនាញ, គំនិត, និងតម្រូវការ។ ជាលទ្ធផល ជីវិតរស់នៅក្នុងភូមិស្មុគស្មាញមានភាពចម្រុះ និងស៊ាំញ៉ាំជាភូមិធម្មតា។ ភូមិស្មុគស្មាញមិនដូចជាទីក្រុងនាពេលបច្ចុប្បន្នទេ។ បើទោះបីជាភូមិស្មុគស្មាញមួយអាចមានមនុស្សរស់នៅរហូតដល់ 8,000 នាក់ក៏ដោយ ក៏វានៅតូចជាបទដ្ឋាននៃទីក្រុងនានាបច្ចុប្បន្ន។ ប៉ុន្តែ កាលពីរាប់ពាន់ឆ្នាំមុន ភូមិមួយដែលមានប្រជាជនរស់នៅ 8,000 នាក់ គឺជាភូមិដែលធំខ្លាំងណាស់។ ភូមិកសិកម្មភាពច្រើនមានអ្នកតាំងទីលំនៅតែប៉ុន្មានរយនាក់ប៉ុណ្ណោះ។ បច្ចេកវិទ្យាបន្តស្ថិតនៅដំណាក់កាលដំបូងដដែល។ អគ្គីសនី, ការដឹកជញ្ជូនល្បឿនលឿន, ប្រព័ន្ធលូរទឹក និងសំណង់រឹងមាំនានាបានជួយគាំទ្រដល់មនុស្សដ៏ច្រើននៅក្នុងទីក្រុងនាពេលបច្ចុប្បន្ន។ នៅក្នុងសម័យបុរាណ ឧបករណ៍ប្រើប្រាស់ និងបច្ចេកវិទ្យាទាំងនេះមិនទាន់ត្រូវបានគេបង្កើតឡើងឡើយ។

ឆាតថាលហ៊ូយូក៖ តាមរយៈការសិក្សាពីសំណល់ដែរសេសសល់ បុរាណវត្ថុវិទូអាចរៀនអំពីជីវិតរស់នៅក្នុងភូមិស្មុគស្មាញ។ ឆាតថាលហ៊ូយូកគឺជាឧទាហរណ៍នៃភូមិស្មុគស្មាញ។ មានទីតាំងនៅក្នុងប្រទេសតួគី ស្ថានីយ៍នេះមានអាយុកាលយ៉ាងតិច 9,000 ឆ្នាំ ហើយមានប្រជាជនរស់នៅប្រហែល 8,000 នាក់។ ឆាតថាលហ៊ូយូកគ្របដណ្តប់លើផ្ទៃដីប្រហែល 32 អាឃើ(មួយអាឃើស្មើ 0.25 ហិចតា)។ វាគឺជាភូមិកសិកម្មដែលផ្ទៃដីមានជីជាតិដែលដាំដុះដំណាំធុញ្ញជាតិដូចជាស្រូវសាលី, ស្រូវបាឡេ, និងសណ្តែកបារាំង។ អ្នកភូមិក៏ចិញ្ចឹមសត្វផងដែរ។ ទិន្នផលកសិកម្មលើសរបស់ឆាតថាលហ៊ូយូកបានផ្គត់ផ្គង់ដល់មនុស្សនៅក្នុងភូមិ។

បើទោះបីជាឆាតថាលហ៊ូយូកមានចំនួនប្រជាជនតិចក៏ដោយ ក៏ទីតាំងរបស់ភូមិនេះបានបង្ហាញភស្តុតាងអំពីជីវិតរស់នៅស្មុគស្មាញរបស់ប្រជាជន។ តាមរយៈសំណល់នៅក្នុងភូមិបានបង្ហាញថា ប្រជាជនរស់នៅជាក្រុមនៅក្នុងសំណង់អាគារអចិន្ត្រៃ។ លំនៅដ្ឋានប្រហែល 1,000 ដែលមានលក្ខណៈដូចគ្នាត្រូវបានសាងសងនៅក្នុងភូមិ។ បុរាណវត្ថុវិទូជឿជាក់ថា មនុស្សនៅឆាតថាលហ៊ូយូកកប់សពអ្នកដែលស្លាប់នៅក្រោមផ្ទះរបស់ពួកគេ។ ពួកគេក៏បានរកឃើញផ្ទាំងគំនូរដ៏ស្រស់ស្អាតដែលគូរនៅលើជញ្ជាំងផ្ទះជាច្រើន។ ផ្ទាំងគំនូរទាំងនេះជាទូទៅបង្ហាញពីសត្វព្រៃ និងរូបភាពអ្នកបរបាញ់។ វាហាក់ដូចជាទាក់ទងជាមួយការបញ្ចុះសព គេសន្និដ្ឋានថា គំនូរទាំងនេះមានជាប់ទាក់ទងទៅនឹងសាសនា។ មនុស្សនៅឆាតថាលហ៊ូយូកបានអភិវឌ្ឍជំនាញឯកទេស ដែលរួមមានដូចជាការផលិតឧបករណ៍ប្រើប្រាស់ និងរបស់ប្រណិតៗ។ ពួកគេផលិតសំលៀកបំពាក់, ទូកឈើ, និងភាជន៍ធម្មតា។ ឆាតថាលហ៊ូយូក បានក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្ម វប្បធម៌ និងឥទ្ធិពល។

ស្វែងរកគោលគំនិត៖ ពន្យល់ថាតើជីវិតរស់នៅក្នុងភូមិមានភាពស្មុកស្មាញមានលក្ខណៈដូចម្តេច?

# ជំពូក 2 ៖ មេសូប៉ូតាមី និងដែនដីអឌ្ឍចន្ទប្រកបដោយជីជាតិ

## មេរៀនទី 1 ៖ ទីតាំងភូមិសាស្រ្តមេសូប៉ូតាមីសម័យបុរាណ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖  គិតដល់ពេលមួយដែលអ្នកបានឃើញរូបភាពទឹកជំនន់នៅលើទូរទស្សន៍ ឬនៅក្នុងការសែត។ ទឹកជំនន់បណ្តាលឱ្យវិនាសអន្តរាយ ដោយហូរនាំយកនូវវត្ថុផ្សេងៗទៅជាមួយ។ តើអ្នកគិតថា ទឹកជំនន់ក៏អាចមានផលល្អផងដែរ ?

### 1. ទឹកដីនៅចន្លោះទន្លេពីរ

សំណួរគន្លឹះ៖ តើទឹកដីចន្លោះទន្លេទីគ្រីហ្ស និងអឺផ្រាតបានជួយអ្វីខ្លះដល់ការដាំដុះ ?

ទន្លេទីគ្រីហ្ស  និងទន្លេអឺផ្រាតស្ថិតនៅតំបន់អាស៊ីភាគនិរតី។ វាចាប់ផ្តើមហូរមកពីតំបន់ភ្នំដែលបច្ចុប្បន្នស្ថិតនៅប្រទេសទួគី  និងខឺឌីស្ថាន។  វាហូរពីទីនោះឆ្លងកាត់ប្រទេសអ៊ីរ៉ាក់  និងឆ្ពោះទៅកាន់ភាគអាគ្នេយ៍ចាក់ចូលទៅក្នុងឈូងសមុទ្រពែក្ស ។

មេសូប៉ូតាមី៖ តំបន់ដែលទន្លេទាំងពីរនេះហូរកាត់គឺត្រូវបានគេហៅថាមេសូប៉ូតាមី ។ ឈ្មោះនេះមានន័យថា "ទឹកដីចន្លោះទន្លេ"។  ដីនេះភាគច្រើនមិនរាបស្មើទេ  និងសម្បូរទៅដោយដើមស្រ្តប៊ី។  ទន្លេបានផ្តល់នូវទឹកប្រើប្រាស់  និងការធ្វើដំណើរ។  នៅសម័យបុរាណ  វាមានភាពងាយស្រួលនៅក្នុងការធ្វើដំណើរតាមទូកជាជាងការធ្វើដំណើរតាមផ្លូវគោក។ ទូកអាចនាំយកទំនិញធ្ងន់ៗ ហើយចរន្តទឹកហូររបស់ទន្លេបានជួយដល់ការផ្លាស់ទីទូកដែលធ្វើដំណើរតាមបណ្តោយទន្លេ។ នៅពេលនោះ មានផ្លូវគោកតិចតួចណាស់។

ដីមានជីជាតិ៖  ស្ទើរតែរាល់ឆ្នាំ  ទឹកភ្លៀង  និងការរលាយនៃទឹកកកនៅលើភ្នំបានបណ្តាលឱ្យទឹកទន្លេហក់ឡើង។ ដូចដែលទឹកហូរចុះមកពីលើភ្នំ វាបាននាំយកនូវដីភក់មកជាមួយ។ នៅពេលដែលទឹកទន្លេហូរមកដល់តំបន់ទំនាប ទឹកចាប់ផ្តើមលិចលង់លើតំបន់ទំនាបទាំងនោះ  ដែលដីទំនាបទាំងនោះស្ថិតនៅជាប់តាមច្រាំងទន្លេ។  ដូចដែលទឹកទន្លេបានលិចលង់លើតំបន់ទំនាប ដីភក់ដែលវាបាននាំយកមកបានធ្លាក់នៅលើដីទំនាប។ ដីភក់ដ៏ល្អដែលបាននាំយកមកដោយទឹកទន្លេនោះត្រូវបានគេហៅថា ដីល្បាប់។ ដីល្បាប់សម្បូរជីជាតិ ដែលល្អសម្រាប់ការដាំដុះដំណាំ។

អាកាសធាតុស្ងួតហែង៖ ជារៀងរាល់ឆ្នាំនៅភាគខាងត្បូងមេសូប៉ូតាមីទំហំទឹកភ្លៀងមានតិចជាង 10 អ៊ិញ ហើយនៅរដូវប្រាំងអាកាសធាតុក្តៅខ្លាំង។ អាកាសធាតុប្រភេទនេះត្រូវបានគេហៅថាស្ងួតហែង។ បើទោះបីជាតំបន់ទាំងមូលរាំងស្ងួតក៏ដោយ មនុស្សសម័យបុរាណនៅតែអាចដាំដុះដំណាំបានដោយ សារតែទឹកទន្លេ និងដីល្បាប់ដែលសម្បូរជីជាតិ។ ត្រឹមឆ្នាំ 3500 មុនគ.ស ភូមិកសិកម្មបានរីកសាយភាពនៅពាសពេញតំបន់មេសូប៉ូតាមីខាងត្បូង។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ថាតើផ្ទៃដីនៅចន្លោះទន្លេទីគ្រីហ្ស និងអឺផ្រាតបានជួយយ៉ាងដូចម្តេចដល់ការដាំដុះ។

### 2. ការគ្រប់គ្រងទឹកដោយប្រព័ន្ធធារាសាស្រ្ត

សំណួរគន្លឹះ៖ ហេតុអ្វីបានជាប្រព័ន្ធធារាសាស្រ្តមានសារៈសំខាន់ចំពោះប្រជាកសិករ ?

ការងាររបស់ប្រជាកសិករក៏មានភាពលំបាក។ ដំណាំត្រូវការបរិមាណទឹកគ្រប់គ្រាន់ដើម្បីរីកលូតលាស់។ ទឹកជំនន់ និងអាកាសធាតុស្ងួតហែងនៅតំបន់មេសូប៉ូតាមីនាំឱ្យកសិករជាញឹកញយជួបប្រទះទាំងបរិមាណទឹកលើស និងបរិមាណទឹកខ្វះ។

ទឹកជំនន់ និងរាំងស្ងួត៖ ទឹកជំនន់នៃទន្លេទីគ្រីហ្ស និងអឺផ្រាតគឺមិនអាចទាយដឹងជាមុនឡើយ។ គ្មាននរណាម្នាក់ដឹងច្បាស់ថាទឹកជំនន់នឹងកើតឡើងឬក៏អត់ទេ។ ជាទូទៅទឹកជំនន់នឹងមកដល់នៅខែមេសា ឬក៏វាមិនមានរហូតដល់ខែមិថុនា បន្ទាប់ពីកសិករបានដាំដុះដំណាំរបស់គេរួចរាល់។ ទំហំនៃទឹកជំនន់គឺអាស្រ័យលើការរលាយនៃទឹកកកនៅលើភ្នំនៅនិទាឃរដូវ និងអាស្រ័យទៅលើចំនួនទឹកភ្លៀង។ ទឹកភ្លៀងធ្លាក់ខ្លាំង និងទឹកកករលាយខ្លាំងបណ្ដាលឲ្យមានទឹកជំនន់ខ្លាំងដែលបានហូរនាំយកអ្វីៗទាំងអស់ទៅជាមួយ។ ប៉ុន្តែផ្ទុយទៅវិញ ភ្លៀងតិច និងទឹកកករលាយតិច នឹងមិនបណ្ដាលឲ្យមានទឹកជំនន់ឡើយ។ នៅពេលដែលមានភ្លៀងតិចតួចអស់រយៈកាលជាយូរត្រូវបានគេហៅថា រាំងស្ងួត។ នៅតំបន់ស្ងួតហែងមួយចំនួនដូចជាមេសូប៉ូតាមី រាំងស្ងួតគឺជាបញ្ហាដែលតែងតែកើតមានឡើង។ អំឡុងពេលនៃភាពរាំងស្ងួត កម្រិតទឹកទន្លេទីគ្រីហ្ស និងអឺផ្រាតនឹងធ្លាក់ចុះ ដែលនាំឱ្យមានផលលំបាកសម្រាប់ប្រជាកសិករក្នុងការប្រើប្រាស់ទឹកសម្រាប់ស្រោចដំណាំរបស់ពួកគេ។ ប្រសិនបើដំណាំរបស់ពួកគេងាប់ ប្រជាជននៅមេសូប៉ូតាមី និងជួបគ្រោះអត់ឃ្លាន។

ប្រព័ន្ធធារាសាស្ត្រ៖ នៅដើមឆ្នាំ 6000 មុនគ.ស ប្រជាកសិករនៅមេសូប៉ូតាមីចាប់ផ្ដើមឈានទៅដល់ការគ្រប់គ្រងការផ្គត់ផ្គង់ទឹកដើម្បីប្រើប្រាស់។ ពួកគេស្ថាបនាជញ្ជាំងដីនៅតាមច្រាំងទន្លេដោយឃាំងទឹកកុំឱ្យហូរចូលទៅក្នុងទន្លេវិញ។ ពួកគេក៏បានស្ថាបនាប្រឡាយដើម្បីនាំយកទឹកពីទន្លេទៅកាន់ដីស្រែរបស់ពួកគេ។ ប្រព័ន្ធដែលគេប្រើដើម្បីនាំយកទឹកទៅកាន់តំបន់ដែលស្ងួតគ្មានទឹកត្រូវបានគេហៅថា ប្រព័ន្ធធារាសាស្ត្រ។ ទឹកដែលបានមកពីទន្លេទីគ្រីហ្ស និងអឺផ្រាតមានភាពល្អក់ និងសម្បូរភក់ដែលជាញឹកញយនាំឲ្យស្ទះប្រឡាយ។ ដើម្បីធ្វើឱ្យប្រឡាយស្អាត និងទឹកអាចហូរបានគឺជាឧបសគ្គមួយសម្រាប់ប្រជាកសិករមេសូប៉ូតាមី។

គូសបង្ហាញពីសេចក្ដីសន្និដ្ឋាន៖ បរិយាយអំពីសារៈសំខាន់នៃប្រព័ន្ធធារាសាស្ត្រចំពោះកសិករ។

### 3. ទឹកដីដែលមានធនធានតិចតួច

សំណួរគន្លឹះ៖ តើប្រជាជនមេសូប៉ូតាមីដោះស្រាយដោយរបៀបណាចំពោះកង្វះខាតធនធាន?

មនុស្សជាទូទៅតែងតែដោះស្រាយបញ្ហាដែលកើតមាននៅជុំវិញខ្លួនរបស់ពួកគេ។ បញ្ហាខ្លះបណ្ដាលមកពីកង្វះខាងធនធាន។ ឧទាហរណ៍ មេសូប៉ូតាមីមិនមានព្រៃឈើដែលអាចផ្ដល់ឈើដើម្បីប្រើប្រាស់ឡើយ។ នៅតំបន់នេះក៏មានថ្មតិចតួច និងខ្វះខាតធនធានរ៉ែនានា ដូចជារ៉ែទង់ដែងជាដើម។

ផ្ទះធ្វើពីដើមត្រែង និងដីឥដ្ឋ៖ ដោយសារតែកង្វះខាតធនធាន ប្រជាជនមេសូប៉ូតាមីបុរាណមានសម្ភារៈតិចតួចសម្រាប់សាងសង់សំណង់។ នៅពេលដែលប្រជាជនមេសូប៉ូតាមីមិនអាចសាងសង់សំណង់ពីឈើ ឬថ្ម ពួកគេប្រើប្រាស់នូវអ្វីដែលពួកគេអាចប្រើប្រាស់បានគឺដើមត្រែង និងភក់។ ពួកគេចងរុំដើមត្រែងធ្វើជាសរសរ និងបញ្ចូល

វាទៅក្នុងរណ្ដៅនៅលើដី។ ពួកគេទាញសសរដើមត្រែងទាំងនោះភ្ជាប់គ្នា ដែលបង្កើតបានជាដំបូល។ ពួកគេបិទជញ្ជាំងជាមួយនឹងភក់ដើម្បីធ្វើឱ្យវារឹងមាំ។ ប្រជាជនមេសូប៉ូតាមីក៏បានលាយបញ្ចូលគ្នារវាងភក់ និងចំបើងជាមួយគ្នាដើម្បីធ្វើឥដ្ឋ។ ពួកគេធ្វើឱ្យឥដ្ឋរឹងដោយដាក់វាហាលក្រោមកំដៅថ្ងៃ។ សំណង់នានាដែលស្ថាបនាជាមួយនឹងឥដ្ឋនេះមានភាពរឹងមាំជាងសំណង់ដែលសាងសង់ដោយដើមត្រែង និងភក់។ បើទោះបីដូច្នេះក៏ដោយ សំណង់ទាំងពីរប្រភេទនេះងាយនឹងខូចខាតនៅពេលដែលមានអាកាសធាតុអាក្រក់ ហើយត្រូវការជួសជុលជាប្រចាំ។

កំពែងឥដ្ឋ៖ ដោយសារកង្វះខាងធនធាននាំឲ្យកើតមានបញ្ហាផ្សេងៗទៀតសម្រាប់ប្រជាជននៅមេសូប៉ូតាមី។ តំបន់នេះមានភាពងាយស្រួលនៅក្នុងការឈ្លានពានពីព្រោះតំបន់នេះមិនមានភ្នំ ឬរបាំងធម្មជាតិព័ទ្ធជុំវិញឡើយ។ ជាលទ្ធផល មនុស្សពីតំបន់ផ្សេងៗទៀតតែងតែធ្វើដំណើរមកឆក់ប្លន់ ឬឈ្លានពានប្រជាជនមេសូប៉ូតាមី។ ប្រជាជនមេសូប៉ូតាមីចង់ការពារខ្លួនគេ។ ប៉ុន្តែ ពួកគេមិនមានដើមឈើ ឬដុំថ្មសម្រាប់ស្ថាបនារបាំងការងារដ៏រឹងមាំឡើយ។ ដូច្នេះ ពួកគេស្ថាបនាកំពែងឥដ្ឋជុំវិញទីក្រុង ឬភូមិរបស់ពួកគេ។ នៅជុំវិញទីក្រុងធំៗ ជញ្ជាំងពេលខ្លះមានកំពស់ 25 ហ្វីត។ ជញ្ជាំងមានតួប៉មយាមការពារនៅតាមចន្លោះដាក់លាក់មួយចំនួនអាស្រ័យលើប្រវែងនៃជញ្ជាំង។ ក្នុងការបន្ថែម ជាទូទៅជញ្ជាំងព័ទ្ធជុំវិញដោយប្រឡាយ ឬគូរទឹក។ ការធ្វើដូច្នេះវាបានជួយការពារយ៉ាងមានប្រសិទ្ធភាពដល់ការឈ្លានពានរបស់សត្រូវ។

ការធ្វើពាណិជ្ជកម្មដើម្បីធនធាន៖ ប្រជាជនមេសូប៉ូតាមីទទួលបានថ្ម ឈើ និងទង់ដែង និងសំណតាមរយៈការធ្វើពាណិជ្ជកម្មជាមួយប្រជាជននៅក្នុងតំបន់អាស៊ីនិរតីទាំងមូល។ ពួកគេក៏ធ្វើពាណិជ្ជកម្មដើម្បីរបស់ប្រណិតដែលមានដូចជាមាស, ត្បូង, ឈើខ្មៅ, និងត្បូងមានតម្លៃ។ ដើម្បីទទួលបានទំនិញទាំងអស់នេះ ពាណិជ្ជករមេសូប៉ូតាមីបានដោះដូរគ្រាប់ធុញ្ញជាតិ ល្មើរ និងផលិតផលកសិកម្មផ្សេងៗទៀត។ រឿងនេះវាអាចទៅរួចដោយសារប្រជាជនមេសូប៉ូតាមីបានដាំដុះដំណាំដែលបានផ្ដល់ទិន្នផលលើស។ ទិន្នផលលើស មានន័យថាពួកគេទទួលបានទិន្នផលលើសពីអ្វីដែលពួកគេត្រូវការ។

ការងារដូចជាការធ្វើពាណិជ្ជកម្ម, ជីកប្រឡាយ, ស្ថាបនាកំពែង, និងដាំដុះដំណាំត្រូវធ្វើឡើងជាប្រចាំ។ មេដឹកនាំនៅក្នុងសហគមន៍ ចាប់ផ្ដើមរៀបចំក្រុមមនុស្សដើម្បីធ្វើការងារទាំងអស់នេះឲ្យត្រូវនឹងពេលវេលា។ មេរៀនបន្ទាប់នឹងពន្យល់លម្អិតអំពីរចនាសម្ព័ន្ធនៃសង្គមមេសូប៉ូតាមី។

វិភាគពីឥទ្ធិពល៖ ពន្យល់ថាតើប្រជាជនមេសូប៉ូតាមីដោះស្រាយដោយរបៀបណាចំពោះកង្វះខាងធនធានធម្មជាតិ។

# មេរៀនទី 2 ៖ អរិយធម៌ដំបូង

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងទីក្រុងសព្វថ្ងៃមានវប្បធម៌ដ៏សម្បូរបែប។ មនុស្សនៅក្នុងទីក្រុងរីករាយទៅនឹងលេងកីឡា, កន្លែងកំសាន្តអារម្មណ៍, សារមន្ទីរ, រោងកុន, និងភោជនីយដ្ឋាន។ ទីក្រុងក៏បានផ្តល់ឱកាសក្នុងការសិក្សា ឬការងារ។ អ្វីដែលអ្នកនឹងអាន សូម្បីតែនៅក្នុងទីក្រុងដំបូងបំផុតក៏ជាកន្លែងដែលផ្តល់ឱកាស និងសម្បូរវប្បធម៌ផងដែរ។

## 1. ការលេចឡើងនៃអរិយធម៌

សំណួរគន្លឹះ៖ តើអរិយធម៌នៅតំបន់ស៊ូម៉ែរអភិវឌ្ឍឡើងដោយរបៀបណា?

ដូចដែលអ្នកបានដឹងមកហើយ មនុស្សចាប់ផ្តើមក្លាយជាកសិករជំនាញ ហើយពួកគេរស់នៅក្នុងភូមិធំៗ។ បន្តិចម្តងៗ ភូមិទាំងនេះបានរីកធំឡើង។ ជាយថាហេតុ ភូមិមួយចំនួនបានក្លាយជាទីក្រុង។ មេដឹកនាំនៅក្នុងទីក្រុងចាប់ផ្តើមរៀបចំក្រុមការងារដើម្បីដោះស្រាយបញ្ហាដែលកើតមាននៅក្នុងទីក្រុង ក្នុងនោះមានដូចជាក្រុមអ្នកសាងសងអគារ និងសម្អាតប្រឡាយបង្ហូរទឹកជាដើម។ ជាលទ្ធផល សង្គម និងវប្បធម៌ចាប់ផ្តើមមានភាពស្មុគស្មាញជាងមុន។ ការប្រែប្រួលនេះបាននាំទៅដល់ទម្រង់នៃភាពជឿនលឿននៃវប្បធម៌ ដែលគេហៅថាអរិយធម៌។ ប្រវត្តិវិទូជាច្រើនជឿជាក់ថា អរិយធម៌ដំបូងលេចឡើងនៅឆ្នាំប្រហែល 3300 មុនគ.ស នៅតំបន់ស៊ូម៉ែរដែលជាតំបន់មួយស្ថិតនៅភាគខាងត្បូងមេសូប៉ូតាមី។

សង្ខេប៖ ពន្យល់ថាតើអរិយធម៌នៅតំបន់ស៊ូម៉ែរអភិវឌ្ឍឡើងដោយរបៀបណា។

## 2. បុរី-រដ្ឋរបស់ពួកស៊ូម៉ែរ

សំណួរគន្លឹះ៖ តើជីវិតរស់នៅក្នុងបុរី-រដ្ឋរបស់ពួកស៊ូម៉ែរមានលក្ខណៈដូចម្តេច?

ទីក្រុងរបស់ពួកស៊ូម៉ែរគឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម សិក្សា និងសាសនា។ មនុស្សភាគច្រើនបន្តរស់នៅតាមទីជនបទ។ ប៉ុន្តែ បន្តិចម្តងៗទីក្រុងបានចាប់ផ្តើមគ្រប់គ្រងតំបន់ និងភូមិនៅជុំវិញ។ សហគមន៍ដែលរួមបញ្ចូលទីក្រុង និងតំបន់ដែលព័ទ្ធជុំវិញ ត្រូវបានគេហៅថាបុរី-រដ្ឋ។ ត្រឹមឆ្នាំ 3000 មុនគ.ស នៅតំបន់ស៊ូម៉ែរ មានបុរី-រដ្ឋយ៉ាងតិច 12 ។ បុរី-រដ្ឋដែលល្បីល្បាញជាងគេរួមមាន បាប៊ីឡូន, គីស, នីពពួរ, និងអ៊ួរ។ ដូចដែលផែនទីខាងក្រោមបានបង្ហាញ ភាគច្រើននៃបុរី-រដ្ឋទាំងនេះមានទីតាំងស្ថិតនៅតាមមាត់ទន្លេទីគ្រីស និងអឺផ្រាត។ ដីដំបន់នោះគឺជាដីដែលសម្បូរទៅដោយជីជាតិ។ ដូច្នេះ ប្រជាកសិករអាចដាំដុះដំណាំបានទិន្នផលច្រើនបានច្រើន។ ភាពលើសនៃស្បៀងអាចផ្គត់ផ្គង់ដល់មនុស្សច្រើននាក់។

ទីក្រុងរបស់ពួកស៊ូម៉ែរ៖ ទីក្រុងរបស់ពួកស៊ូម៉ែរបានរីកចម្រើនបន្តិចម្តងៗ ដូច្នេះវាមើលទៅមិនដូចជាទីក្រុងផ្សេងៗនាពេលបច្ចុប្បន្នឡើយ។ ផ្ទុយពីបណ្តោយផ្លូវក្នុងទីក្រុងបច្ចុប្បន្នដែលធំៗ ផ្លូវនៅក្នុងទីក្រុងរបស់ពួកស៊ូម៉ែរតូចចង្អៀត។ ដូចដែលអ្នកបានរៀននៅផ្នែកទី 1 ទីក្រុងមានកំពែងព័ទ្ធជុំវិញ។ ភ្លោងទ្វានៅតាមកំពែងអនុញ្ញាតឱ្យមនុស្សចេញចូល។ ប្រជាជនស្ថាបនាផ្ទះរបស់ពួកគេពីដើមត្រែង និងភក់ ឬឥដ្ឋ។ ជញ្ជាំងផ្ទះនីមួយៗគេធ្វើក្រាស់ៗ

ដើម្បីការពារកម្តៅ។ ផ្ទះមួយមានបន្ទប់ជាច្រើននៅក្នុងនោះ។ នៅក្នុងផ្ទះគ្របពីលើដោយដំបូលប្រក់ស្លឹកត្នោតនៅពីលើបន្ទះក្តារ។ ក៏ដូចជាជញ្ជាំងដែរ ដំបូលត្រូវបានរចនាឡើងដើម្បីធ្វើឲ្យផ្ទះត្រជាក់។

ហ្ស៊ីកគូរ៉ាតចំណុចស្នូលនៃទីក្រុង៖ រចនាសម្ព័ន្ធដែលធំ និងសំខាន់បំផុតនៅក្នុងទីក្រុងនានារបស់ពួកស៊ូម័រគឺហ្ស៊ីកគូរ៉ាត។ ហ្ស៊ីកគូរ៉ាតត្រូវបានស្ថាបនាឡើងដំបូងនៅក្នុងឆ្នាំប្រហែល 2200 មុនគ.ស។ ហ្ស៊ីកគូរ៉ាតស្ថិតនៅចំកណ្តាលសំណង់ប្រាសាទដ៏ធំមួយ។ សំណង់ប្រាសាទនេះមានមុខងារដូចជាសាលាក្រុង។ ដោយសារតែទីនេះពួកបព្វជិតបានរៀបចំចាត់ចែងប្រព័ន្ធបង្ហូរទឹក និងផ្នែកសំខាន់ៗផ្សេងទៀតនៅក្នុងទីក្រុង។ ប្រជាជនធ្វើដំណើរមកកាន់សំណង់ប្រាសាទដើម្បីបង់ឱ្យបព្វជិតនូវគ្រាប់ធញ្ញជាតិ និងរបស់របរផ្សេងៗសម្រាប់សេវាកម្មរបស់ពួកគេ។ ដូច្នេះ ពួកបព្វជិតបានរៀបចំកន្លែងទុកដាក់គ្រាប់ធុញ្ញជាតិលើស និងត្រួតត្រាភាគច្រើនទៅលើទ្រព្យសម្បត្តិនៅក្នុងទីក្រុង។

បព្វជិតក្លាយជាអ្នកដឹកនាំ៖ ដូចដែលអ្នកទើបតែបានអាន ពួកបព្វជិតបានដើរតួនាទីនយោបាយយ៉ាងសំខាន់មួយនៅស៊ូម័រ។ ប្រជាជនស៊ូម័រក៏ត្រូវការពួកបព្វជិតទាំងនោះទាក់ទងទៅកាន់អាទិទេពដើម្បីជួយដល់ពួកគេ។ ពួកបព្វជិតបានផ្តល់យោបល់ដល់ប្រជាជនថាតើពួកគេត្រូវធ្វើយ៉ាងដូចម្តេចខ្លះដើម្បីផ្គាប់ចិត្តអាទិទេព។ ពួកស៊ូម័រមានជំនឿទៅលើអាទិទេពជាច្រើន ជំនឿមួយដែលគេហៅថាពហុទេពនិយម។ យោងទៅតាមសាសនារបស់ពួកស៊ូម័រ អាទិទេពសំខាន់ៗ 4 ដែលបង្កើត និងដឹកនាំពិភពលោក៖ អាទិទេពមេឃ, ខ្យល់, ភ្នំ, និងទឹក។ បុរី-រដ្ឋនីមួយៗគោរពបូជាអាទិទេពផ្ទាល់ខ្លួនរបស់ពួកគេ។ ក្នុងការបន្ថែម ពួកស៊ូម័រមានអាទិទេពតូចតាចរាប់ពាន់ផ្សេងទៀត។ ពួកស៊ូម័រជឿជាក់ថាអាទិទេពរបស់ពួកគេអាចការពារកុំឲ្យកើតគ្រោះអាក្រក់នានា។ ដូច្នេះដើម្បីការពារខ្លួនគេ និងទីក្រុងរបស់ពួកគេ ពួកស៊ូម័រព្យាយាមនៅក្នុងការផ្គាប់ចិត្តអាទិទេព។ អាទិទេពនីមួយៗមានបព្វជិតជាច្រើន។ ពួកបព្វជិតធ្វើការដើម្បីបំពេញចិត្តអាទិទេពទាំងនោះ ហើយការអះអាងរបស់ពួកបព្វជិតមានឥទ្ធិពលលើការជួយរបស់អាទិទេព។ ដោយសារតែការអះអាងដែលមានឥទ្ធិពលនេះហើយ មនុស្សទៅទូចាត់ទុកពួកបព្វជិតជាមេដឹកនាំរបស់ពួកគេ។

មេដឹកនាំថ្មីនៅស៊ូម័រ៖ នៅវង្វង់ឆ្នាំ 3000 មុនគ.ស ដូចដែលប្រជាជននៅក្នុងបុរី-រដ្ឋបានចាប់ផ្តើមអភិវឌ្ឍកាន់តែមានទ្រព្យច្រើន មនុស្សក្រុមផ្សេងទៀតចាប់ផ្តើមធ្វើការវាយប្រហារពួកគេ ដើម្បីដណ្តើមយកទ្រព្យរបស់ពួកគេ។ ពួកអ្នកវាយប្រហារមួយចំនួនធ្វើដំណើរមកពីទីឆ្ងាយ។ ក្រុមអ្នកវាប្រហារមួយចំនួនទៀតមកពីបុរី-រដ្ឋជិតខាង។ ស្ថិតនៅក្នុងកាលៈទេសៈដ៏គ្រោះថ្នាក់នេះ ប្រជាជននៅក្នុងបុរី-រដ្ឋតែងតែស្នើអ្នកមានអំណាចម្នាក់ដើម្បីដឹកនាំពួកគេ និងការពារទីក្រុង។ នៅដើមដំបូង មេដឹកនាំមួយចំនួនដឹកនាំបុរី-រដ្ឋតែអំឡុងពេលកើតមានសង្គ្រាមប៉ុណ្ណោះ។ ជាយថាហេតុ ពួកគេបានក្លាយជាអ្នកត្រួតត្រាទីក្រុងជាអចិន្ត្រៃន៍តែម្តង។ មេដឹកនាំថ្មីនេះទទួលយកការងារមួយចំនួនរបស់ពួកបព្វជិត។ ពួកគេថែទាំប្រឡាយ រៀបចំគ្រប់គ្រងធុញ្ញជាតិលើស និងដើរតួនាទីជាអ្នកកាត់ក្តី។ បន្តិចម្តងៗ មេដឹកនាំប្រភេទថ្មីនេះបានក្លាយជាស្តេចដែលជាមេដឹកនាំជាន់ខ្ពស់បំផុតនៅក្នុងទីក្រុង។ តំបន់ដែលស្តេចដឹកនាំត្រូវបានគេហៅថា ព្រះរាជាណាចក្រ។ នៅត្រឹមឆ្នាំ 2375 មុនគ.សស៊ូម័របានក្លាយជាព្រះរាជាណាចក្រដែលដឹកនាំដោយស្តេច។ ពួកបព្វជិតនៅតែដើរតួនាទីសំខាន់ដដែល ដោយសារកិច្ចការងាររបស់ពួកគេគឺផ្គាប់ចិត្ត

របស់អាទិទេព និងបណ្តេញគ្រោះអាក្រក់ចេញឲ្យឆ្ងាយ។ ប្រជាជនស៊ូម៉េរជឿជាក់ថាអាទិទេពគឺជាអ្នកបញ្ជូនស្តេចមកដើម្បីដឹកនាំពួកគេ។

សង្ខេប៖ ពិពណ៌នាអំពីជីវិតរស់នៅក្នុងបុរី-រដ្ឋរបស់ពួកស៊ូម៉េរ។

### 3. សង្គមរបស់ពួកស៊ូម៉េរ

សំណួរគន្លឹះ៖ តើមានវណ្ណៈសង្គមអ្វីខ្លះនៅក្នុងសង្គមរបស់ពួកស៊ូម៉េរ?

ដូចដែលសង្គមរបស់ពួកស៊ូម៉េរកាន់តែមានលក្ខណៈស្មុគស្មាញ វាបានបែងចែកទៅជាវណ្ណៈសង្គមជាច្រើនក្រុម។ ប្រព័ន្ធវណ្ណៈត្រូវបានគេកំណត់ដោយយោងទៅលើនរណាដែលមានអំណាច និងនរណាខ្លះដែលធ្វើការងារដែលគេមិនឱ្យតម្លៃ។

វណ្ណៈសង្គម៖ ស្តេច និងបព្វជិតគឺស្ថិតនៅកំពូលនៃវណ្ណៈសង្គមនៅស៊ូម៉េរ។ ពួកស៊ូម៉េរមានជំនឿថាស្តេចរបស់ពួកគេ និងពួកបព្វជិតមានទំនាក់ទំនងជាមួយអាទិទេព ដូច្នេះពួកគេមានឥទ្ធិពលយ៉ាងសំខាន់លើប្រជាជនទូទៅ។ វណ្ណៈខ្ពង់ខ្ពស់ផ្សេងទៀតក៏រួមបញ្ចូលទាំងម្ចាស់កម្មសិទ្ធិដីធ្លី, មន្ត្រីរាជការ, និងពាណិជ្ជករមានទ្រព្យច្រើន។ វណ្ណៈកណ្តាលរួមបញ្ចូលមនុស្សមានសេរីភាពទាំងអស់។ ភាគច្រើននៃប្រជាជនស៊ូម៉េរគឺស្ថិតនៅក្នុងក្រុមនេះ។ ដោយក្នុងនោះរួមមាន ប្រជាកសិករ និងសប្បករ។ ទាសករស្ថិតនៅក្នុងវណ្ណៈទាបបំផុតនៅក្នុងសង្គម ប៉ុន្តែពួកគេនៅមានសិទ្ធិមួយចំនួន។ ពួគទាសករអាចធ្វើជំនួញ និងខ្ចីប្រាក់បាន។ ពួគគេក៏អាចទិញសេរីភាពរបស់ពួកគេបានផងដែរ។

តួនាទីរបស់ស្ត្រី៖ នៅគ្រប់កម្រិតនៃវណ្ណៈសង្គមទាំងអស់ក៏រួមបញ្ចូលស្ត្រីនៅក្នុងនោះផងដែរ ដូច្នេះឋានៈក្នុងសង្គមរបស់ពួគគេមានភាពទូលំទូលាយ។ ជាទូទៅ ស្ត្រីនៅក្នុងសង្គមស៊ូម៉េរដំបូងមានសិទ្ធិច្រើនជាងអ្វីដែលគេមាននៅពេលក្រោយមកទៀត។ ស្ត្រីនៅវណ្ណៈជាន់ខ្ពស់មួយចំនួនមានក្លាយជាបព្វជិត ដែលជាឋានៈដែលគេឱ្យតម្លៃ។ ស្ត្រីដែលមានសេរីភាពអាចមានសិទ្ធិកាន់កាប់ដីធ្លី ហើយពួកគេអាចធ្វើការងារជាពាណិជ្ជករ និងសិប្បករ ដែលក្នុងនោះមានដូចជា អ្នកតម្បាញជាដើម។ ក៏ប៉ុន្តែ តួនាទីសំខាន់របស់ស្ត្រីភាគច្រើនគឺចិញ្ចឹមបីបាច់កូនៗរបស់ពួកគេ។

ធ្វើការបែងចែក៖ កំណត់អំពីប្រព័ន្ធវណ្ណៈនៅក្នុងសង្គមរបស់ពួគស៊ូម៉េរ។

### 4. ការអភិវឌ្ឍវិទ្យាសាស្ត្ររបស់ពួកស៊ូម៉េរ

សំណួរគន្លឹះ៖ តើពួកស៊ូម៉េរបានអភិវឌ្ឍវិទ្យាសាស្ត្រអ្វីខ្លះ?

ពួកស៊ូម៉េរមានភាពប៉ុនប្រសព្វនៅក្នុងការដោះស្រាយបញ្ហា។ ពួកគេបង្កើតឧបករណ៍ប្រើប្រាស់ និងអភិវឌ្ឍជំនាញពិសេសដើម្បីបង្កើនជីវភាពរស់នៅរបស់ពួកគេ។ ពួកគេគឺជាមនុស្សដំបូងដែលបានបង្កើតរបស់របរដែលយើងប្រើប្រាស់សព្វថ្ងៃ។

ការបង្កើតដំបូង៖ ប្រវត្តិវិទូជឿជាក់ថា ពួកស៊ូម៉េរបានបង្កើតនង្គ័លនៅវង្វង់ឆ្នាំ 6000 មុនគ.ស និងកង់រទេះនៅវង្វង់ឆ្នាំ 3500 មុនគ.ស។ ការបង្កើតទាំងអស់នេះបានជួយយ៉ាងច្រើនដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកស៊ូម៉េរ។

នង្គ័លគឺជាឧបករណ៍សំខាន់ដំបូងមួយដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់កសិករ។ នង្គ័លដំបូងជាទូទៅមានលក្ខណៈជាចបជីកដែលមានដែកាន់។ ដំបូងវាអាចប្រើដោយការរុញ ឬទាញដោយមនុស្ស ក្រោយមកគេប្រើសត្វម្តង។ នង្គ័លអាចបំបែកដីរឹង ដែលនាំឲ្យការដាំដុះមានលក្ខណៈងាយស្រួល។ ពួកស៊ូម៉ែរប្រើប្រាស់កង់រង្វង់ក្នុងវិធីជាច្រើន ក្នុងនោះមានដូចជា ប្រើជាកង់រទេះដើម្បីដឹកទំនិញ។ កង់រង្វង់ដែលពិសេសជាងគេគឺកង់រង្វង់របស់អ្នកស្មូន។ កង់រង្វង់នេះអាចអនុញ្ញាតឲ្យពួកស៊ូម៉ែរផលិតភាជន៍មានគុណភាពល្អ និងលឿន។ ពាងគឺជាកន្លែងរក្សាទុកស្បៀងអាហារលើសដ៏សំខាន់មួយ។ ពាងទាំងអស់នេះក៏ជាវត្ថុដែលពួកស៊ូម៉ែរអាចធ្វើពាណិជ្ជកម្មផងដែរ។

គណិតវិទ្យា៖ ពួកស៊ូម៉ែរបានអភិវឌ្ឍគណិតសាស្ត្រដើម្បីកត់ត្រាអំពីទិន្នផលកសិកម្ម និងទំនិញរបស់ពួកគេ។ ប្រព័ន្ធលេខរបស់ពួកគេគឺយក 60 ធ្វើជាមូលដ្ឋាន។ ដូច្នេះបច្ចុប្បន្ន ក្នុងមួយនាទីយើងមាន 60 វិនាទី និងក្នុងមួយម៉ោងយើងមាន 60 នាទី។ មួយជុំរង្វង់មាន 360 ដឺក្រេ។ ដោយថាហេតុ ការវាស់ពេលវេលាបានជួយដល់ការបង្កើតប្រតិទិន។

ភាសាសរសេរ៖ ត្រឹមឆ្នាំ 3000 មុនគ.ស ពួកស៊ូម៉ែរបានបង្កើតប្រព័ន្ធសំណេរដើម្បីបំពេញនូវតម្រូវការនៅក្នុងការធ្វើជំនួញរបស់ពួកគេ។ ដូចដែលពាណិជ្ជកម្មបានរីកធំ ពួកពាណិជ្ជករត្រូវការកត់ត្រាអំពីការដោះដូររបស់ពួកគេ។ ពួកគេក៏ត្រូវការបិទស្លាកសំគាល់ទំនិញរបស់ពួកគេ។ ដូច្នេះ ពួកគេគូសនិមិត្តសញ្ញា នៅខាងក្រៅប្រអប់ទំនិញរបស់ពួកគេដើម្បីសំគាល់ផលិតផលនៅខាងក្នុង។ និមិត្តសញ្ញាទាំងនោះត្រូវបានគេស្គាល់ថាវត្ថុលេខនាដែលមានន័យថា "សំណេររូបភាព"។ ក្រោយមកទៀតពួកស៊ូម៉ែរចាប់ផ្តើមគូរវត្ថុលេខនានៅលើបន្ទះដីឥដ្ឋ។ ដំបូងវត្ថុលេខនាបង្ហាញពីរូបវត្ថុពិតៗ។ ក្រោយមកទៀត ពួកវាបង្ហាញអំពីគំនិត និងសំលេង។ តាមរយៈការផ្តុំសំលេង ពួកគេអាចសរសេរបានច្រើន។ ក្រោយមកទៀតពួកស៊ូម៉ែរឈប់ប្រើប្រាស់រូបភាព ហើយចាប់ផ្តើមប្រើប្រាស់និមិតសញ្ញាមានរូបសណ្ឋានជ្រុង។ ការសរសេរអក្សរនិមិត្តសញ្ញាជ្រុងនេះត្រូវបានគេហៅថាអក្សរមានសណ្ឋានជ្រុង។ ប្រព័ន្ធសំណេរគឺមានលក្ខណៈស្មុកស្មាញ និងមាននិមិត្តសញ្ញាប្រហែល 600 ផ្សេងៗគ្នា។ ការសិក្សាពីនិមិតសញ្ញាទាំងអស់នោះត្រូវការរយៈពេលរាប់ឆ្នាំ។ ជាលទ្ធផល មានមនុស្សតិចតួចប៉ុណ្ណោះដែលអាចអាន និងសរសេរបាន។

មនុស្សដែលមានជំនាញនៅក្នុងការសរសេរត្រូវបានគេហៅថាស្មេរ។ ពួកគេគឺជាជំនាញនៅក្នុងការសរសេរកំណត់ត្រានានា។ មនុស្សផ្សេងៗទៀតនៅក្នុងសង្គមស៊ូម៉ែរគោរពពួកគេយ៉ាងខ្លាំង។ ដំបូងឡើយ ពួកស៊ូម៉ែរប្រើប្រាស់ការសរសេររបស់ពួកគេសម្រាប់គោលបំណងក្នុងការធ្វើជំនួញប៉ុណ្ណោះ។ ក្រោយមក ពួកគេបានចាប់ផ្តើមសរសេរអំពីសង្គ្រាម ទឹកជំនន់ និងកំណត់ត្រាអំពីស្តេច។ កំណត់ត្រាទាំងអស់នេះហើយគឺកំណត់ត្រាប្រវត្តិសាស្ត្ររបស់ស៊ូម៉ែរ។

សង្ខេប៖ កំណត់អំពីការអភិវឌ្ឍវិទ្យាសាស្ត្រសំខាន់ៗដែលបង្កើតឡើងដោយពួកស៊ូម៉ែរ។

# មេរៀនទី 3៖ ចក្រភពនៃដែនដីអឌ្ឍចន្ទប្រកបដោយជីជាតិ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើប្រទេសដែលអ្នកកំពុងរស់នៅមានទំហំប៉ុណ្ណា? តើនៅក្នុងទីក្រុងរបស់អ្នកមានសកម្មភាពអ្វីខ្លះ? ភាគច្រើននៃបុរី-រដ្ឋនៅមូសូប៉ូតាមីមានទំហំតូចជាងប្រទេសដែលអ្នកកំពុងរស់នៅ។ ប៉ុន្តែបុរី-រដ្ឋទាំងអស់នោះក៏ជាមជ្ឈមណ្ឌលវប្បធម៌ និងអំណាចផងដែរ។

## 1. អ្នកស្ថាបនាចក្រភពដំបូង

សំណួរគន្លឹះ៖ តើចក្រភពមួយណាដែលគ្រប់គ្រងនៅតំបន់ដែនដីអឌ្ឍចន្ទមានជីជាតិ?

ចាប់ពីឆ្នាំប្រហែល 3000 ទៅ 2000 មុនគ.ស ស្តេចដែលមានមហិច្ឆិតាមួយចំនួននៅបុរី-រដ្ឋស៊ូម៉េរធ្វើសង្គ្រាមដើម្បីពង្រីកទឹកដីរបស់ពួកគេ។ ទឹកដីមានលក្ខណៈរាបស្មើ និងមានភាពងាយស្រួលនៅក្នុងការឈ្លានពាន។ កាន់កាប់ផ្ទៃដីច្រើនបានផ្តល់ឲ្យស្តេចនូវទ្រព្យសម្បត្តិ និងអំណាចកាន់តែច្រើន។ ប៉ុន្តែ នៅអំឡុងពេលនោះ គ្មានស្តេចណាអាចគ្រប់គ្រងបុរី-រដ្ឋទាំងអស់នៅមេសូប៉ូតាមីតែម្នាក់ឯងបានឡើយ។

ចក្រភពអាកាដៀន៖ នៅរង្វង់ឆ្នាំ 2371 មុនគ.ស មេដឹកនាំមានអំណាចមួយរូបព្រះនាមសាហ្គោនអាកាដបានគ្រប់គ្រងតំបន់ទាំងមូល។ សាហ្គោនអាកាដត្រូវបានគេស្គាល់ថាជាអ្នកបង្កើតចក្រភពដំបូងនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។ ចក្រភពមួយបង្រួមបញ្ចូលគ្នានៃផ្ទៃដី និងប្រជាជនផ្សេងៗគ្នាឲ្យស្ថិតនៅក្រោមមេដឹកនាំតែម្នាក់។ មេដឹកនាំដែលគ្រប់គ្រងចក្រភពត្រូវបានគេហៅថាអធិរាជ។ ចក្រភពរបស់សាហ្គោនអាកាដត្រូវបានគេហៅថាចក្រភពអាកាដៀន។ ដាយថាហេតុ សាហ្គោនអាកាដបានគ្រប់គ្រងលើផ្ទៃដីដែលលាតសន្ធឹងពីឈូងសមុទ្រពែក្សកាត់តាមតំបន់មេសូប៉ូតាមីរហូតដល់សមុទ្រមេឌីទែរ៉ានេ។ តំបន់នេះត្រូវបានគេហៅថាដែនដីអឌ្ឍចន្ទមានជីជាតិ ជាដែនដីសម្បូរទៅដោយដីដែលមានជីជាតិ និងទឹក ដែលធ្វើឱ្យតំបន់នេះមានភាពល្អប្រសើរសម្រាប់ការធ្វើកសិកម្ម។

ការបង្កើតចក្រភពមួយគឺជាទិដ្ឋភាពមួយដែលកើតមានឡើងដដែលៗនៅក្នុងប្រវត្តិសាស្ត្រ។ ចក្រភពមានសារៈសំខាន់ណាស់ ដោយសារវាបានផ្លាស់ប្តូរវិធីដែលមនុស្សរស់នៅ។ វាបាននាំមកនូវសន្តិភាពដល់ប្រជាជនដែលរស់នៅទីនោះ។ វាជំរុញឲ្យមានសកម្មភាពពាណិជ្ជកម្ម ដែលនាំឲ្យមានទំនិញសំបូរបែប។ ចក្រភពជាទូទៅបានរួមបញ្ចូលប្រជាជនដែលមានវប្បធម៌ផ្សេងៗគ្នា។ គំនិត, បច្ចេកវិទ្យា, និងទំនៀមទម្លាប់នៃមនុស្សផ្សេងៗគ្នាត្រូវបានចែករំលែកឱ្យគ្នាទៅវិញទៅមក។

ចក្រភពបាប៊ីឡូន និងហាមូរ៉ាប៊ី៖ ចក្រភពអាកាដមានអាយុកាលប្រហែល 200 ឆ្នាំ។ មូលហេតុនៃការដួលរលំនៃចក្រភពនេះគឺដោយសារតែការវាយប្រហារពីសំណាក់មនុស្សខាងក្រៅ។ នៅរង្វង់ឆ្នាំ 2000 មុនគ.ស ប្រជាជនដែលគេស្គាល់ថាអាម៉ូរីតបានវាយប្រហារ និងគ្រប់គ្រងបុរី-រដ្ឋនានារបស់ពួកស៊ូម៉េរ។ ពួកគេបានជ្រើសរើសទីក្រុងបាប៊ីឡូនដែលស្ថិតនៅជាប់ដងទន្លេអឺប្រាដធ្វើជារាជធានីរបស់ពួកគេ។ ចាប់ពីឆ្នាំ 1792 មុនគ.ស ដល់ 1750 មុនគ.សស្តេចមានអំណាចមួយអង្គព្រះនាមហាមូរ៉ាប៊ីបានដឹកនាំចក្រភពបាប៊ីឡូន។ ទ្រង់ជឿជាក់ថា ក្រមនៃច្បាប់មួយអាចជួយទ្រង់នៅក្នុងការគ្រប់គ្រងដែនដីទាំងមូលរបស់ទ្រង់។ ក្រមនៃច្បាប់ គឺជាបណ្តុំនៃសំណេរច្បាប់សម្រាប់

ឱ្យប្រជាជនធ្វើតាម។ ហាមូរ៉ាប៊ីបានត្រួតពិនិត្យឡើងវិញនូវច្បាប់ទាំងឡាយដែលមាននៅក្នុងចក្រភពរបស់ទ្រង់។ បន្ទាប់មកទ្រង់បានគូសចេញនូវក្រមច្បាប់មួយដែលបង្ហាញនៅលើសរសរដ៏ធំមួយនៅបាប៊ីឡូន។

គោលបំណងនៃក្រមនេះគឺដើម្បីនាំមកនូវយុត្តិធម៌ ឬការអនុវត្តស្មើគ្នាចំពោះប្រជាជនទាំងឡាយនៅក្នុងចក្រភព។ វាកំណត់បង្ហាញអំពីសកម្មភាពណាដែលខុសឆ្គង និងទណ្ឌកម្ម។ ក្រមហាមូរ៉ាប៊ីបានបង្កើតគំនិតដែលថា សង្គមត្រូវតែដំណើរការដោយការគោរពច្បាប់។ នេះមានន័យថា ច្បាប់ត្រូវបានអនុវត្តសម្រាប់មនុស្សទាំងអស់ មិនមែនអនុវត្តសម្រាប់តែមនុស្សមួយចំនួនតូចប៉ុណ្ណោះទេ។ តាមរយៈការដាក់បង្ហាញក្រមនេះ ហាមូរ៉ាប៊ីក៏បានបង្កើតគំនិតដែលថា មនុស្សមានសិទ្ធិនៅក្នុងការដឹងអំពីច្បាប់ និងទោសទណ្ឌនៅពេលដែលពួកគេល្មើសទៅនឹងច្បាប់នោះ។

សង្ខេប៖ កំណត់បង្ហាញអំពីចក្រភពដំបូងៗដែលគ្រប់គ្រងនៅដែនដីជីជាតិ

## 2. ពួកអាស៊ីរី និងឆាលឌៀន

សំណួរគន្លឹះ៖ តើពួកពួកអាស៊ីរី និងពួកឆាលឌៀនអាចស្ថាបនាចក្រភពបានដោយរបៀបណា?

ចក្រភពបាប៊ីឡូនដួលរលំនៅវង្វង់ឆ្នាំ 1500 មុនគ.ស។ ប្រហែល 200 ឆ្នាំក្រោយមក ចក្រភពមួយផ្សេងទៀតដែលមានឈ្មោះថាអាស៊ីរីបានលេចឡើងដើម្បីគ្រប់គ្រងដែនដីជីជាតិ។ អាស៊ីរីមានទីតាំងស្ថិតនៅភាគខាងជើងមូសូប៉ូតាមី ជាតំបន់មួយដែលហ៊ុំព័ទ្ធជុំវិញទៅដោយភ្នំ។ ដើម្បីការពារទឹកដីរបស់ពួកគេ មេដឹកនាំអាស៊ីរីបានស្ថាបនាកងទ័ពដ៏ខ្លាំងក្លាមួយ ហើយចាប់ផ្តើមធ្វើការឈ្លានពានទឹកដីរដ្ឋជិតខាងរបស់ខ្លួន។

ចក្រភពដ៏ខ្លាំងក្លាមួយ៖ កងទ័ពអាស៊ីរីប្រើប្រាស់អាវុធដែលគេបង្កើតថ្មីសម្រាប់ធ្វើសង្គ្រាម។ ពួកគេកាន់ដាវធ្វើពីដែក និងលំពែងដែក។ សត្រូវរបស់ពួកគេតិចតួចណាស់ដែលមានអាវុធធ្វើពីដែក។ ពួកអាស៊ីរីវាយប្រហារកំពែងទីក្រុងដោយប្រើប្រដាប់បុកទម្លាយ។ ពួកគេប្រើប្រាស់ជណ្តើរដើម្បីឡើងកំពែងទីក្រុង។ ពួកគេក៏ជីករូងក្រោមកំពែងទីក្រុងដើម្បីឲ្យកងទ័ពអាចចូលទៅក្នុងទីក្រុងបាន។ បន្តិចម្តងៗ អាស៊ីរីបានដណ្តើមកាន់កាប់ដែនដីជាច្រើន។ ពួកគេបានបញ្ចូលស៊ីរី, បាប៊ីឡូន, អេហ្ស៊ីប, ផូនីសៀ, និងប៉ាឡេស្ទីនទៅក្នុងចក្រភពរបស់ពួកគេ។ អាស៊ីរីបានឈានដល់ដំណាក់កាលកំពូលនៃអំណាចរបស់ខ្លួន នៅក្នុងរាជ្យរបស់ស្តេចអាស៊ូបានីប៉ាលដែលដឹកនាំចាប់ពីឆ្នាំ 668 ដល់ឆ្នាំ 627 មុនគ.ស ដែលមានរាជធានីស្ថិតនៅនីនេវេញទ្រង់គ្រប់គ្រងដែនដីស្ទើរតែទាំងស្រុងនៃដែនដីអឌ្ឍចន្ទមានជីជាតិ។ អាស៊ីរីគ្រប់គ្រងដែនដីដែលពួកគេដណ្តើមកាន់កាប់ តាមរយៈការជ្រើសរើសមេដឹកនាំម្នាក់ចេញមកពីដែនដីនោះ ដើម្បីគ្រប់គ្រងនៅទីនោះទៅតាមការបញ្ជារបស់ពួកគេ។ មេដឹកនាំនីមួយៗត្រូវបញ្ជូនសួយសារអាករទៅកាន់អធិរាជអាស៊ីរី។ នេះមានន័យថាមេដឹកនាំទាំងនោះត្រូវតែបង់ថ្លៃការពារដល់កងទ័ពអាស៊ីរី។ ប្រសិនបើមេដឹកនាំណាមិនបានបញ្ជូនសួយសារអាករមកទេ កងទ័ពអាស៊ីរី និងកម្ទេចទីក្រុមនានារបស់បុរីនោះ។ មនុស្សនៅក្នុងដែនដីទាំងនោះ ជាទូទៅត្រូវបានគេនិរទ្ទេសដោយបង្ខំ ឬបណ្តេញចេញពីទឹកដីកំណើតរបស់ពួកគេទៅកាន់តំបន់ឆ្ងាយៗ។

ការដួលរលំនៃអាស៊ីរី៖ នៅក្នុងឆ្នាំ 609 មុនគ.ស ចក្រភពអាស៊ីរីបានដួលរលំ។ សត្រូវរបស់គេមានពីរ គឺពួកមេដេស និងពួកឆាលឌៀន បានចូលរួមកម្លាំងជាមួយគ្នាដើម្បីយកជ័យជំនះលើអាស៊ីរី។ កងទ័ពរបស់មេដេស និងឆាលឌៀនបានវាយកម្ទិចទីក្រុងនីនេវេញទាំងស្រុង ដោយដុតទីក្រុងនេះរាបដល់ដី។ អស់រយៈកាលប៉ុន្មានសតវត្សរ៍ក្រោយមក នៅទីនោះនៅសល់តែពំនូកដីប៉ុណ្ណោះដែលបានគូសបញ្ជាក់ថាទីតាំងនេះធ្លាប់ជាទីក្រុងដ៏អស្ចារ្យ។

ចក្រភពបាប៊ីឡូនថ្មី៖ បន្តិចម្តងៗ រដ្ឋជិតខាងរបស់អាស៊ីរី គឺពួកឆាលឌៀនបានគ្រប់គ្រងភាគច្រើននៃអតីតទឹកដីរបស់ចក្រភពអាស៊ីរី។ ទីក្រុងបាប៊ីឡូនបានក្លាយជារាជធានីរបស់ចក្រភពថ្មីឆាលឌៀន។ យើងនៅចាំបានថាបាប៊ីឡូនធ្លាប់ជារាជធានីរបស់បាប៊ីឡូនដំបូង។ ដូច្នេះ ពេលខ្លះឆាលឌៀនត្រូវបានគេហៅថាបាប៊ីឡូនថ្មី។ ចក្រភពឆាលឌៀនបានរីកចម្រើនដល់កម្រិតកំពូលក្រោមការដឹកនាំរបស់ស្តេចនេប៊ូឆាដនេហ្សាទី 2 ដែលដឹកនាំចាប់ពីឆ្នាំ 605 ដល់ 562 មុនគ.ស។ ទ្រង់បានស្ថាបនាទីក្រុងបាប៊ីឡូនឡើងវិញ។ ដើម្បីផ្គាប់ចិត្តមហេសីរបស់ទ្រង់ស្តេចនេប៊ូឆាដនេហ្សាទី 2 បានបន្ថែមនូវភ្នំសិប្បនិមិត្តមួយដែលក្របដណ្តប់ទៅដោយដើមឈើ និងរុក្ខជាតិ។ វាត្រូវបានគេហៅថា សួនព្យួរនៅបាប៊ីឡូន។ សួននេះត្រូវបានស្ថាបនាឡើងនៅក្នុងវិធីមួយដែលមើលទៅហាក់ដូចជាអណ្តែតឡើងនៅលើគោក។ សួននេះបានក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោកមួយក្នុងចំណោមប្រាំពីរ។

ក៏ដូចជាអាស៊ីរីដែរ ពួកឆាលឌៀនជាអ្នកដឹកនាំដែលឃោឃៅ។ ឧទាហរណ៍ នៅក្នុងឆ្នាំ 587 មុនគ.ស ស្តេចនេប៊ូឆាដនេហ្សាទី 2 បានដណ្តើមកាន់កាប់ជេរ៉ូសាលឹមដែលជារាជធានីរបស់ពួកហេព្រើរ។ ពួកគេបានចាប់ខ្លួនពួកឈ្លើយសឹកហេព្រើររាប់ពាន់នាក់យកមកទីក្រុងបាប៊ីឡូនអស់រយៈពេល 50 ឆ្នាំ។ (អ្នកនឹងសិក្សាអំពីពួកហេព្រើរនៅក្នុងជំពូកបន្ទាប់)។ មេដឹកនាំដែលបន្តរាជ្យពីស្តេចនេប៊ូឆាដនេហ្សាទី 2 មានភាពទន់ខ្សោយ។ មេដឹកនាំម្នាក់បានធ្វើឱ្យប្រជាជនឆាសឌៀនអាក់អន់ចិត្ត ដោយសារទ្រង់ព្យាយាមនៅក្នុងការផ្លាស់ប្តូរអាទិទេពសំខាន់របស់ពួកគេគឺម៉ាឌូក។ អ្នកគោរពដើមតាមម៉ាឌូកអាចជាអ្នកជួយដល់ស៊ីរូសរបស់ពែក្សក្នុងការឈ្លានពានបាប៊ីឡូន។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ថាតើពួកអាស៊ីរី និងពួកឆាសឌៀនអាចកសាងចក្រភពរបស់ខ្លួនបានដោយរបៀបណា?

### 3. ពួកពែក្សត្រួតត្រាអាស៊ីខាងលិច

សំណួរគន្លឹះ៖ តើអ្នកប្រៀបធៀបយ៉ាងដូចម្តេចចំពោះរាជ្យរបស់ស្តេចស៊ីរូស និងដារូស?

ភាគខាងកើតដែនដីដីជាតិគឺជាដែនដីរបស់ពួកមេដេសដែលគេហៅថាមេឌៀ។ ពួកមេដេសត្រួតត្រាដែនដីជាទីកន្លែងដែលពួកពែក្សរស់នៅ។ តំបន់នេះហ៊ុំព័ទ្ធទៅដោយជួរភ្នំ។ ជួរភ្នំទាំងនោះរួមមានហ្សាក្រូស, កៅកាស៊ូស, និងហិណ្ឌូគូសបច្ចុប្បន្នភាគច្រើនស្ថិតនៅក្នុងប្រទេសអ៊ីរ៉ង់។ ពួកពែក្ស អ្នកជាចរកជនមកពីតំបន់វាលទំនាបអាស៊ីកណ្តាល បានមកដល់មេឌៀនៅវង្វង់ឆ្នាំ 1000 មុនគ.ស។ ពួកគេបានបង្កើតព្រះរាជណាចក្រតូចៗជាច្រើនដែលរីកលូតលាស់តាមរយៈការធ្វើពាណិជ្ជកម្ម។ ព្រះរាជាណាចក្រទាំងអស់នេះចាប់ផ្តើមកើនអំណាច និងគំរាមកំហែងដល់ការត្រួតត្រារបស់ពួកមេដេសលើតំបន់នោះ។

ស៊ីរូសស្ថាបនាចក្រភពពែក្ស៖ ពួកមេដេសគ្រប់គ្រងពួកពែក្សរហូតដល់ពួកគេក្លាយជារដ្ឋរីកចម្រើនមួយ ស្តេចពែក្សមានអំណាចមួយរូបព្រះនាមស៊ីរូសបានត្រួតត្រានៅពែក្ស។ ទ្រង់ត្រូវបានគេស្គាល់ថាស៊ីរូសដ៏អស្ចារ្យ។ ស៊ីរូសមានទស្សនៈវិស័យមួយនៅក្នុងការឈ្លានពានទឹកដីនានានៅជុំវិញពែក្ស ហើយបង្រួបបង្រួមដែនដីទាំងអស់នេះឱ្យក្លាយជាចក្រភពដ៏ធំមួយ។ ទ្រង់ចាប់ផ្តើមធ្វើសកម្មភាពនានាដើម្បីសម្រេចគោលដៅរបស់ទ្រង់។ ដំបូងស៊ីរូសឈ្លានពានតំបន់អាណាតូលីដែលស្ថិតនៅភាគខាងលិច។ បន្ទាប់មកនៅរវាងឆ្នាំ 550 ដល់ 539 មុនគ.ស ទ្រង់បានឈ្លានពានដែនដីដែលធ្លាប់ត្រួតត្រាដោយពួកអាស៊ីរី និងពួកឆាសឌៀន។ ចក្រភពរបស់ទ្រង់ធំបហិមា។ ស៊ីរូសត្រូវការវិធីជាច្រើនក្នុងការត្រួតត្រាដែនដីដែលពោរពេញទៅដោយមនុស្សផ្សេងៗគ្នា។ ផ្ទុយពីពួកអាស៊ីរី ដែលដឹកនាំតាមរយៈភាពឃោរឃៅ ស៊ីរូសបង្កើតគោលនយោបាយអត់ឱនមួយ។ គោលនយោបាយនេះអនុញ្ញាតឱ្យប្រជាជនរក្សានូវទំនៀមទម្លាប់ប្រពៃណី និងជំនឿរបស់ពួកគេ។ ស៊ីរូសអនុញ្ញាតឱ្យប្រជាជនបន្តគោរពបូជាអាទិទេពផ្ទាល់ខ្លួនរបស់ពួកគេ, និយាយភាសាផ្ទាល់ខ្លួនរបស់ពួកគេ, និងអនុវត្តរបៀបរបបរស់នៅផ្ទាល់របស់ពួកគេ។ ប៉ុន្តែ ពួកគេត្រូវបង់សួយសារអាករ។ គោលនយោបាយអត់ឱនរបស់ស៊ីរូសធ្វើឱ្យការគ្រប់គ្រងចក្រភពមានភាពងាយស្រួល។ មានការបះបោរតិចតួចប៉ុណ្ណោះ ហើយប្រជាជនរស់នៅក្នុងសន្តិភាព។

ដារូសពង្រីកចក្រភព៖ ស៊ីរូសបានស្ថាបនាចក្រភពដែលមនុស្សច្រើនមួយឲ្យមានស្ថេរភាពតាមរយៈគោលនយោបាយអត់ឱនរបស់ទ្រង់។ អ្នកបន្តតំណែងពីស៊ីរូស កាំប៊ីសេសបានពង្រីកចក្រភព ប៉ុន្តែទ្រង់ដឹកនាំតាមរយៈភាពឃោរឃៅ។ នៅពេលដែលទ្រង់សុគត ចលនាបះបោរបានងើបឡើងនៅពាសពេញចក្រភព។ បន្ទាប់មកមេដឹកនាំដ៏ខ្លាំងមួយរូបព្រះនាមដារូសបានឡើងកាន់អំណាច។ ដារូសបានចំណាយពេលមួយឆ្នាំដំបូងនៃរាជ្យរបស់ទ្រង់ នៅក្នុងដោះស្រាយជាមួយការបះបោររបស់ប្រជាជន។ បន្ទាប់ពីទ្រង់បង្ក្រាបការបះបោររួចហើយ ទ្រង់បានពង្រីកដែនដីរបស់ចក្រភពទ្រង់។ បន្តិចម្តងៗទ្រង់បានឈ្លានពានទឹកដីរហូតដល់ឥណ្ឌា។ ស្ថិតនៅក្រោមការដឹកនាំរបស់ទ្រង់ចក្រភពពែក្សបានរីកធំយ៉ាងខ្លាំង ដែលពីកើតទៅលិចមានប្រវែង 2,800 ម៉ាយ។ (ចម្ងាយពីទីក្រុងញ៉ូយកទៅឡូអានជ័រឡេសមានប្រវែងប្រហែល 2,500 ម៉ាយ)។ ចក្រភពមានទំហំធំដូច្នេះ ដារូសបានបន្ថែមគោលនយោបាយថ្មីមួយពីលើគោលនយោបាយចាស់ដែលបង្កើតឡើងដោយស៊ីរូស។ ដារូសបានបែងចែកចក្រភពទៅជា 20 ខេត្ត។ ខេត្តនីមួយៗ ដែលជាដែនដីដូចទៅនឹងរដ្ឋមួយ មានរដ្ឋាភិបាលក្នុងតំបន់។ ដារូសបង្កើតមេដឹកនាំរដ្ឋាភិបាលដែលហៅថាសាត្រាប ដើម្បីអនុវត្តបទបញ្ជារបស់ទ្រង់នៅតាមខេត្តនីមួយៗ និងដើម្បីប្រមូលពន្ធ។ ទ្រង់បានតែងតាំងមេដឹកនាំយោធាមួយរូបនៅតាមសាត្រាបនីមួយៗ។ ទ្រង់ក៏បានបង្កើតក្រុមចារកិច្ចដែលគេហៅថា "ភ្នែក និងត្រចៀករបស់ស្តេច" ដើម្បីច្បាស់ថាសាត្រាបរបស់ទ្រង់ស្តាប់តាមបញ្ជារបស់ទ្រង់។ គោលនយោបាយទាំងនេះអនុញ្ញាតឱ្យទ្រង់អាចត្រួតត្រាបានយ៉ាងល្អប្រសើរលើដែនដីទាំងឡាយនៅក្នុងចក្រភពរបស់ទ្រង់។

គោលនយោបាយខេត្តនីមួយៗដឹកនាំដោយសាត្រាបគឺគ្រាន់តែជាវិធីមួយក្នុងការបង្រួបបង្រួមចក្រភពរបស់ដារូសប៉ុណ្ណោះ។ ទ្រង់បានស្ថាបនាផ្លូវមួយឈ្មោះថាផ្លូវភូមិន្ទ ឬផ្លូវសម្រាប់គោលដៅរដ្ឋាភិបាល។ ផ្លូវភូមិន្ទមានប្រវែង 1775 ម៉ាយ។ ចុងបញ្ចប់នៃផ្លូវភាគខាងកើតគឺនៅស៊ូសាស្ថិតនៅបាប៊ីឡូន ហើយចុងផ្លូវភាគខាងលិចស្ថិតនៅសាឌីសស្ថិតនៅអាណាតូលី។ រាជសារត្រូវបានបញ្ជូនតាមផ្លូវនេះដោយក្រុមអ្នកបញ្ជូនសារបណ្តាក់គ្នា។ កង

យោធា និងសំបុត្រក៏បានធ្វើដំណើរតាមផ្លូវនេះពាលពេញចក្រភពផងដែរ។ ដារ្យូសប្រើប្រាស់មធ្យោបាយផ្សេងទៀតដើម្បីបង្រួបបង្រួមចក្រភព។ ទ្រង់បានបង្កើតក្រមច្បាប់មួយដោយយោងលើគំរូក្រមច្បាប់ហាមូរ៉ាប៊ី។ ទ្រង់បានគំនិតមួយក្នុងការបង្កើតកាក់តាមពួកលីដៀនដែលជាដែនដីមួយដែលទ្រង់ដណ្តើមកាន់កាប់។ កាក់នេះត្រូវបានបង្កើតដោយរដ្ឋាភិបាលដែលជាលុយផ្លូវការ ជួយលើកកម្ពស់សកម្មភាពជំនួញ និងងាយស្រួលនៅក្នុងការប្រមូលពន្ធ។ ដារ្យូសមានគម្រោងនៅក្នុងការឈ្លានពានលើពួកបះបោរនៅអេហ្ស៊ីបនៅក្នុងឆ្នាំ 486 មុនគ.ស ប៉ុន្តែទ្រង់ក៏បានសុគតនៅក្នុងឆ្នាំនោះ។ រាជបុត្ររបស់ទ្រង់ព្រះនាមហ្សេរសេសត្រូវដោះស្រាយបញ្ហានានាជាមួយអេហ្ស៊ីប។ អ្នកនឹងអានអំពីអេហ្ស៊ីបនៅក្នុងជំពូក 5 ។ ហ្សេរសេស ក៏នឹងត្រូវដោះស្រាយជាមួយក្រិកផងដែរ។ អ្នកនឹងអានរឿងនេះនៅក្នុងជំពូក 8 ។

ប្រៀបធៀប៖ ប្រៀបធៀបគោលនយោបាយរបស់ស៊ីរូស និងដារ្យូសដែលដាក់ចេញនៅអំឡុងរាជ្យរបស់ទ្រង់ទាំងពីរ។

# ជំពូក 3 ៖ ព្រះរាជាណាចក្ររបស់ពួកហេព្រើរ

## មេរៀនទី 1 ៖ ដើមកំណើតពួកហេព្រើរ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកនឹកគិតឡើងវិញ តំបន់ដែលគេស្គាល់ថាដែនដីជីជាតិសម្បូរទៅដោយផ្ទៃដីដែលសម្បូរជីជាតិ និងទឹកដែលផ្តល់ភាពល្អប្រសើរសម្រាប់ការធ្វើស្រែចំការ។ នៅមុនឆ្នាំប្រមាណ 1800 មុនគ.ស មនុស្សមួយក្រុមដែលគេហៅថាហេព្រើរបានធ្វើដំណើរមកកាន់តំបន់នេះ។ ដីតំបន់នេះបានផ្តល់ឱ្យពួកគេនូវវាលស្មៅសម្រាប់ចិញ្ចឹមហ្វូងសត្វពពែ និងចៀមរបស់ពួកគេ។

### 1. ប្រជាជនហេព្រើរនៅកាណាន

សំណួរគន្លឹះ៖ អ្វីទៅជាជំនឿស្នូររបស់ពួកហេព្រើរ ?

សៀវភៅ 5 ក្បាលដំបូងនៃគម្ពីប៊ិបរបស់ពួកហេព្រើរត្រូវបានគេហៅថាតូរេះ។ ពួកហេព្រើរជឿថាសៀវភៅ ឬរូបចម្លាក់ដ៏ពិសិដ្ឋទាំងនេះត្រូវបានប្រគល់ឱ្យពួកគេដោយព្រះជាម្ចាស់។ គម្ពីតូរេះបានសរសេរនូវប្រវត្តិសាស្ត្រ, ច្បាប់, និងជំនឿរបស់ពួកហេព្រើរ។ សៀវភៅទាំងនោះរួមមានជេនេស៊ីស, អេហ្សូឌូស, លេវីទីគូស, ណាំប័រ, និងដឺតេរ៉ូណូមី។ ក្រោមមកគម្ពីតូរេះត្រូវបានគេបានធ្វើការអត្ថាធិប្បាយ ឬបកប្រែ។

ពីអ៊ួរទៅកាណាន៖ នៅក្នុងគម្ពីតូរេះ បាននិយាយថាព្រះជាម្ចាស់បានជ្រើសរើសព្យាការីមួយរូបដែលមានឈ្មោះថាអាប្រាហាំ ដែលជាអ្នកបង្កើតប្រជាជនហេព្រើរ។ អាប្រាហាំរស់នៅអ៊ួរដែលជាទីក្រុងមួយនៅមេសូប៉ូតាមីភាគខាងត្បូង។ យោងទៅតាមសៀវភៅជេនេស៊ីស ព្រះជាម្ចាស់បានផ្តល់យោបល់ឲ្យអាប្រាហាំចាកចេញពីអ៊ួរ ហើយធ្វើដំណើរទៅកាណាន។ អាប្រាហាំជឿជាក់ថា ប្រសិនបើលោកធ្វើដំណើរទៅកាន់កាណាន នោះដែនដីនេះនឹងក្លាយជាកម្មសិទ្ធិរបស់បច្ឆាជនរបស់លោក ដោយសារព្រះជាម្ចាស់បានសន្យាជាមួយគាត់។ ដោយសារតែហេតុនេះ ពួកហេព្រូសបានគិតថាកាណាមគឺជាដែនដីសន្យា។ ដូច្នេះ នៅវង្វង់ឆ្នាំ 1800 មុនគ.សអាប្រាហាំ និងគ្រួសាររបស់លោក និងហ្វូងសត្វចិញ្ចឹមបានធ្វើដំណើរមកកាន់ទឹកដីកាណាន។

យូដានិយម និងឯកទេពនិយម៖ នៅពាសពេញពិភពលោកនាសម័យបុរាណ ប្រជាជនភាគច្រើនគឺជាអ្នកដែលជឿលើពហុទេពនិយម។ មានន័យថាពួកគេគោរពបូជាលើអាទិទេពច្រើន។ ផ្ទុយទៅវិញ ពួកហេព្រើរជឿលើអាទិទេពតែមួយប៉ុណ្ណោះ ព្រះជាម្ចាស់ដែលមានអំណាចទាំងអស់និយាយទៅកាន់អាប្រាហាំ និងបានផ្តល់ការអប់រំសំខាន់ៗដល់គាត់។ ជឿលើព្រះជាម្ចាស់តែមួយត្រូវបានគេហៅថាឯកទេពនិយម។ យូដានិយមសព្វថ្ងៃគឺជាបច្ឆាជនរបស់សាសនាពួកហេព្រើរសម័យបុរាណ។ ឈ្មោះនេះបានមកពី ក្រុមកុលសម្ព័ន្ធយូដា ដែលជាកុលសម្ព័ន្ធមួយក្នុងចំណោមកុលសម្ព័ន្ធទាំង 12 ដែលជាបច្ឆាជនរបស់អាប្រាហាំ។

គម្ពីតូរេះបាននិយាយថា ពួកហេព្រើរបានរក្សាជំនឿរបស់ពួកគេលើព្រះជាម្ចាស់នៅអំឡុងពេលដែលពួកគេជួបភាពរីករ។ ពួកគេជឿថាមានកិច្ចសន្យា ឬកិច្ចព្រមព្រៀងមួយដែលបង្កើតឡើងរវាងព្រះជាម្ចាស់ និងអាប្រាហាំ

និងបច្ឆាជនរបស់គាត់។ អាប្រាហាំសន្យាក្នុងការស្តាប់តាមព្រះជាម្ចាស់។ ក្នុងការឆ្លើយតប ព្រះជាម្ចាស់នឹងផ្តល់ការការពារដល់អាប្រាហាំ និងបច្ឆាជនរបស់លោក និងផ្តល់ឱ្យពួកគេនូវទឹកដីកំណើតមួយ។

សង្ខេបៈ កំណត់អំពីជំនឿស្នូលរបស់ពួកហេព្រើរ។

## 2. ពីកាណាននៅកាន់អេហ្ស៊ីប និងត្រឡប់មកវិញ

សំណួរគន្លឹះៈ មូលហេតុអ្វីខ្លះដែលធ្វើឱ្យពួកហេព្រើរជឿថាព្រះជាម្ចាស់បានអនុវត្តកិច្ចសន្យារបស់ទ្រង់ជាមួយពួកគេ?

អស់រយៈកាលកន្លងទៅពួកហេព្រើរនៅកាណាន បានទទួលឈ្មោះថ្មីមួយគឺអ៊ីស្រាអែល។ ឈ្មោះរបស់ពួកគេបានមកពីចៅរបស់អាប្រាហាំគឺយ៉ាកុប។ យោងទៅតាមគម្ពីតូរ៉ាៈគាត់ក៏ត្រូវបានគេហៅថាអ៊ីស្រាអែលផងដែរ។ យ៉ាកុបមានកូនប្រុស 12 នាក់។ កូនប្រុស 10 នាក់ក្នុងចំណោម 12 នាក់នេះ និងចៅប្រុសពីរនាក់ គឺជាស្ថាបនិកនៃកុលសម្ព័ន្ធទាំង 12 នៅអ៊ីស្រាអែល។

ម៉ូសេសដឹកនាំអ៊ីស្រាអែលៈ គម្ពីតូរ៉ាៈបានប្រាប់អំពីគ្រោះអត់ឃ្លានបានកើតឡើងនៅទឹកដីកាណាន។ ពួកអត់ឃ្លានអ៊ីស្រាអែលបានធ្វើដំណើរទៅកាន់អេហ្ស៊ីប ដែលជាទីកន្លែងដែលកូនប្រុសរបស់យ៉ាកុបឈ្មោះចូសេពបម្រើការងារជាប្រមុខទីប្រឹក្សារបស់ស្តេចផារ៉ូសអេហ្ស៊ីប។ នៅដំបូងឡើយ ពួកអ៊ីស្រាអែលត្រូវបានគេផ្តល់កន្លែងរស់នៅដែលមានកិត្តិយសនៅអេហ្ស៊ីប។ ប៉ុន្តែ ក្រោយមកទៀតស្តេចផារ៉ូសថ្មីមួយអង្គបានឡើងកាន់អំណាច។ ទ្រង់បានយកពួកអ៊ីស្រាអែលធ្វើជាទាសករ និងបង្ខំឱ្យពួកគេធ្វើការលើគម្រោងសាងសង់របស់ទ្រង់។ គម្ពីតូរ៉ាៈបានប្រាប់ពីវិធីដែលព្រះជាម្ចាស់ផ្តល់យោបល់ដល់ម៉ូសេស ឱ្យដឹកនាំពួកអ៊ីស្រាអែលចាកចេញពីអេហ្ស៊ីប។ ការធ្វើអន្តោប្រវេសន៍របស់ពួកអ៊ីស្រាអែលចាកចេញពីអេហ្ស៊ីបត្រូវបានគេស្គាល់ថាអេហ្សូឌូស។ បន្ទាប់ពីចាកចេញពីអេហ្ស៊ីប ពួកអ៊ីស្រាអែលបានវសាត់អណ្តែតនៅតំបន់វាលខ្សាច់ស៊ីណៃអស់រយៈពេល 40 ឆ្នាំ។ យោងទៅតាមគម្ពីតូរ៉ាៈ លោកម៉ូសេសបានឡើងទៅលើភ្នំស៊ីណៃ ដែលជាទីកន្លែងដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោក។ ម៉ូសេសបានចុះពីលើភ្នំជាមួយនឹងបន្ទះថ្មពីរដុំដែលព្រះជាម្ចាស់បានសសេរបទបញ្ញាទាំង 10 ។ បទបញ្ញាទាំងនេះបានក្លាយជាមូលដ្ឋាននៃច្បាប់របស់ពួកអ៊ីស្រាអែល។ បទបញ្ញាទាំងនេះក្រោយមក បានក្លាយជាផ្នែកដ៏សំខាន់មួយនៃសីលធម៌ និងក្រមសីលធម៌នៃអរិយធម៌បស្ចិមលោក ដែលជាវប្បធម៌របស់ពួកអឺរ៉ុប និងអាមេរិកខាងជើង។

ការអនុវត្តកិច្ចព្រមព្រៀងមួយៈ ពួកអ៊ីស្រាអែលជឿថាការផ្តល់ឱ្យពួកគេនូវសេចក្តីបញ្ញាទាំងនេះ គឺជាការអនុវត្តកិច្ចព្រមព្រៀងរបស់ពួកគេជាមួយនឹងព្រះជាម្ចាស់។ ពួកគេគិតថា ព្រះជាម្ចាស់នឹងជួយការពារពួកគេ។ ក្នុងការផ្តល់ត្រឡប់ ប្រជាជនទាំងអស់ត្រូវស្គាល់តាមបទបញ្ញារបស់ទ្រង់។ ពួកគេជឿជាក់ថាព្រះជាម្ចាស់បានបង្កើតច្បាប់សីលធម៌សម្រាប់មនុស្សលោកទាំងអស់តាមរយៈបទបញ្ញារបស់ទ្រង់។

វាយតម្លៃៈ ពន្យល់អំពីអ្វីទៅដែលបានធ្វើឱ្យពួកហេព្រើរជឿជាក់ថាព្រះជាម្ចាស់អនុវត្តកិច្ចព្រមព្រៀងរបស់ទ្រង់ជាមួយពួកគេ។

### 3. ត្រឡប់ទៅកាន់ទឹកដីសន្យា

សំណួរគន្លឹះ៖ តើចៅក្រមដើរតួនាទីជាអ្វីនៅអ៊ីស្រាអែលសម័យបុរាណ?

ម៉ូសេសបានជ្រើសរើសចូសាវដើម្បីដឹកនាំពួកអ៊ីស្រាអែលត្រឡប់ទៅកាន់ដែនដីកាណានវិញ។ គិតត្រឹមពេលដែលពួកគេត្រឡប់មកវិញ ពួកគេបានចាកចោលកន្លែងនេះអស់ជាច្រើនឆ្នាំ។ មានក្រុមផ្សេងទៀតបានរស់នៅទីនោះ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេដឹកនាំមានអំណាចនានា ដែលបុរី-រដ្ឋរបស់ពួកគេមានកំពែងព័ទ្ធជុំវិញ។

ពួកកុលសម្ព័ន្ធទាំង 12 របស់អ៊ីស្រាអែល៖ ដូចដែលអ្នកបានរៀនរួចមកហើយ ពួកអ៊ីស្រាអែលបានត្រឡប់មកកាន់ដែនដីកាណាន ត្រូវបានរៀបចំទៅជា 12 ក្រុមកុលសម្ព័ន្ធ។ បុរសនៅក្នុងកុលសម្ព័ន្ធទាំងនេះបានក្លាយជាកងទ័ពរបស់ចូសាវ។ ពួកគេបានបង្កើតជាកងកម្លាំងវាយប្រយុទ្ធមួយ ដោយគោលបំណងរបស់ពួកគេគឺទាមទារមកវិញនូវទឹកដីកាណានពីពួកមេដឹកនាំតាមបុរី-រដ្ឋនានា។ បុរី-រដ្ឋដំបូងដែលធ្លាក់ក្រោមការគ្រប់គ្រងរបស់ចូសាវគឺជេរីចូ។ ប៉ុន្តែ មេដឹកនាំផ្សេងៗទៀតនៅទឹកដីកាណាន នៅតែបន្តវាយប្រយុទ្ធជាមួយពួកអ៊ីស្រាអែល។ ពួកអ៊ីស្រាអែលចំណាយពេលអស់ប្រមាណ 200 ឆ្នាំ ដើម្បីយកទឹកដីកាណានត្រឡប់មកវិញ។ នៅពេលដែលសង្គ្រាមបានបញ្ចប់ កងកម្លាំងរបស់អ៊ីស្រាអែលបានក្លាយជាប្រជាកសិករ និងអ្នកចិញ្ចឹមហ្វូងសត្វ។ ពួកកុលសម្ព័ន្ធទាំង 12 បានបែងចែកដែនដីរបស់ពួកគេរៀងៗខ្លួន។ កុលសម្ព័ន្ធខ្លះទទួលបានទឹកដីនៅតំបន់ភ្នំ។ កុលសម្ព័ន្ធមួយចំនួនទៀតបានតាំងទីលំនៅនៅតាមតំបន់វាលទំនាប។ កុលសម្ព័ន្ធដែលរស់នៅជិតគ្នាបានចងសម្ព័ន្ធមិត្តជាមួយគ្នាដោយសារតែពួកគេមានជំនឿ, បញ្ហា, និងសត្រូវដូចគ្នា។

ចៅក្រមដឹកនាំពួកអ៊ីស្រាអែល៖ អំឡុងពេលនៃសង្គ្រាមរយៈពេល 200 ឆ្នាំ មិនមានមេដឹកនាំណាមានអំណាចគ្រប់គ្រងពួកអ៊ីស្រាអែលតែម្នាក់ឯងបានឡើយ។ ផ្ទុយទៅវិញ ពួកគេបានស្វះស្វែងរកការប្រឹក្សាយោបល់ពីមេដឹកនាំផ្សេងៗគ្នាដែលគេហៅថាចៅក្រម ដែលជាមនុស្សគេគោរពខ្លាំងនៅក្នុងសហគមន៍។ ចៅក្រមដំបូងដើរតួនាទីជាមេដឹកនាំយោធា។ ក្រោយមកចៅក្រមផ្តល់ការប្រឹក្សាយោបល់លើកិច្ចការច្បាប់ និងជួយដោះស្រាយទំនាស់។ ចៅក្រមដូចជាជីដេអន, សាំសុន, និងសាមូអែលទទួលបានកិត្តិនាមល្បីល្បាញពាសពេញកាណាន ដោយសារភាពរឹងមាំ និងឧត្តមគតិរបស់ពួកគេ។ ដេបូរ៉ោះ គឺជាចៅក្រមដ៏ល្បីល្បាញបំផុតម្នាក់។ ភាពជាអ្នកដឹកនាំរបស់គាត់គឺមានលក្ខណៈពិសេសសម្រាប់ស្ត្រីហេព្រើរ។ ជាទូទៅ ភារៈកិច្ចដ៏សំខាន់បំផុតរបស់ស្ត្រីហេព្រើរគឺចិញ្ចឹមបីបាច់ថែរក្សាកូនចៅ និងផ្តល់ការអប់រំសីលធម៌ដល់ពួកគេ។ ប៉ុន្តែ ដេបូរ៉ោះបានបង្កើតកងកម្លាំងវាយប្រយុទ្ធតូចមួយយកជ័យជំនះលើកងកម្លាំងដ៏ច្រើនរបស់កាណាអានីតែនៅជិតភ្នំតាបូ។ ចៅក្រមដើរតួនាទីសំខាន់មួយនៅក្នុងរក្សាការរួបរួមនៃកុលសម្ព័ន្ធទាំង 12 ។ នៅពេលដែលពួកអ៊ីស្រាអែលខ្វះខាតមេដឹកនាំដែលជាចៅក្រមខ្លាំង ក្រុមកុលសម្ព័ន្ធផ្សេងៗទៀតចាប់ផ្តើមឈប់គោរពទៅលើសាសនាដែលជាទំនៀមទម្លាប់។ ពួកចៅក្រមបាននិយាយប្រឆាំងទៅនឹងសកម្មភាពនេះ។ ដូចដែលអ្នកនឹងរៀននៅមេរៀនបន្ទាប់ ពួកគេក៏ជួយនៅក្នុងការជ្រើសរើសមេដឹកនាំថ្មីដែលមានភាពខ្លាំង ដែលមេដឹកនាំនោះក្រោយមកជាអ្នកបង្រួបបង្រួមអ៊ីស្រាអែល។

ស្វែងរកគំនិតសំខាន់៖ ពិភាក្សាអំពីតួនាទីរបស់ចៅក្រមនៅអ៊ីស្រាអែលសម័យបុរាណ។

# មេរៀនទី 2 ៖ ព្រះរាជាណាចក្រ និងការជាប់ឃុំឃាំង

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកបានសិក្សារួចមួយហើយថាពួកអ៊ីស្រាអែលបានត្រឡប់ពីប្រទេសអេហ្ស៊ីបមកកាន់ទឹកដីកាណានវិញ។ បន្ទាប់ពីពួកគេវាយប្រយុទ្ធដើម្បីដណ្តើមយកដែនដីមកត្រួតត្រាវិញ ពួកអ៊ីស្រាអែលបានបះទង្គិចគ្នាជាមួយក្រុមផ្សេងៗទៀតនៅក្នុងតំបន់។

## 1. ព្រះរាជាណាចក្ររបស់អ៊ីស្រាអែល

សំណួរគន្លឹះ៖ ហេតុអ្វីបានជាពួកអ៊ីស្រាអែលសម្រេចចិត្តជ្រើសរើសស្តេចមួយអង្គ?

ពួកអ៊ីស្រាអែលមានជំនឿទៅលើព្រះជាម្ចាស់តែមួយអង្គគត់ ហើយការប្រតិបត្តិសាសនារបស់ពួកគេបានញែកពួកគេឱ្យដាច់ចេញពីក្រុមផ្សេងៗទៀតនៅក្នុងតំបន់។ ពួកគេធ្វើពាណិជ្ជកម្មជាមួយក្រុមផ្សេងៗទៀតនៅក្នុងតំបន់កាណាន ហើយរស់នៅលាយលំគ្នាជាមួយពួកគេ ប៉ុន្តែមិនបានទទួលយកវប្បធម៌ និងជំនឿរបស់ពួកគេឡើយ។ ពេលខ្លះពួកអ៊ីស្រាអែលទទួលរងការគំរាមកំហែងពីសំណាក់ក្រុមទាំងអស់នេះ។ ស្ថិតនៅក្នុងបរិយាកាសបែបនេះ ចៅក្រមបានស្នើឱ្យមានការបង្រួបបង្រួមក្នុងចំណោមកុលសម្ព័ន្ធទាំងឡាយរបស់អ៊ីស្រាអែល និងវាយប្រយុទ្ធជាមួយក្រុមទាំងនោះ។

ពួកភីលីស្ទីន៖ នៅវង្វង់ឆ្នាំ 1029 មុនគ.ស ពួកអ៊ីស្រាអែលបានប្រឈមមុខជាមួយពួកភីលីស្ទីន ដែលជាមនុស្សមួយក្រុមដែលធ្វើដំណើរមកពីតំបន់ក្បែរនោះដែលហៅឈ្មោះថាភីលីស្ទា។ ពួកភីលីស្ទីនបានឈ្លានពាន និងដណ្តើមកាន់កាប់ដែនដីរបស់ពួកអ៊ីស្រាអែល។ ពួកអ៊ីស្រាអែលបានយល់ស្របនៅក្នុងការបង្រួមបង្រួមឱ្យស្ថិតនៅក្រោមការដឹកនាំរបស់ស្តេចមួយអង្គ ដើម្បីវាយប្រយុទ្ធជាមួយពួកភីលីស្ទីនបើទោះជាពួកអ៊ីស្រាអែលភាគច្រើនមានការព្រួយបារម្ភថា ស្ថិតក្រោមការដឹកនាំរបស់ស្តេចតែមួយអង្គ នឹងនាំឱ្យទ្រង់មានអំណាចច្រើនហួសហេតុ។ ចៅក្រមមួយរូបឈ្មោះសាមូអែលមានការព្រួយបារម្ភពីបញ្ហានេះដូចគ្នា ប៉ុន្តែលោកបានជួយនៅក្នុងការជ្រើសរើសស្តេចដំបូងពីអង្គរបស់អ៊ីស្រាអែល។

សូល និងដាវីឌ៖ ពួកអ៊ីស្រាអែលបានជ្រើសរើសសូលដែលជាតំណាងមេដឹកនាំយោធាម្នាក់ ធ្វើជាស្តេចដំបូងរបស់ពួកគេនៅក្នុងឆ្នាំ 1020 មុនគ.ស។ ស្ថិតនៅក្រោមការដឹកនាំរបស់សូល ពួកអ៊ីស្រាអែលបានវាយប្រយុទ្ធគ្នាជាមួយពួកភីលីស្ទីន។ សមរភូមិនេះបានបង្ខំឱ្យពួកភីលីស្ទីនបោះបង់ការគ្រប់គ្រងរបស់ខ្លួនលើដែនដីអ៊ីស្រាអែល។ បន្ទាប់ពីសូលសោយទីវង្គត់ ពួកអ៊ីស្រាអែលបានសម្លឹងរកមេដឹកនាំថ្មីមួយរូបទៀត។ យោងទៅតាមគម្ពីប៊ីបរបស់ហេព្រើរ សាមូអែលបានជ្រើសរើសបុរសវ័យក្មេងមួយរូប ដែលមានឈ្មោះថា ដាវីឌឱ្យធ្វើជាស្តេចបន្ទាប់។ ជម្រើសនេះគឺប្រកបទៅដោយគតិបណ្ឌិត។ នៅក្នុងឆ្នាំប្រហែល 1000 មុនគ.ស ដាវីឌ និងពួកអ៊ីស្រាអែល បានបណ្តេញពួកភីលីស្ទីនចេញពីដែនដីកាណាន។ ដាវីឌមានទទួលជោគជ័យក្នុងការគ្រប់គ្រងដែនដីជេរ៉ូសាលឹមហើយបានយកដែនដីនេះធ្វើជារាជធានីរបស់ទ្រង់។

សូឡូម៉ុន៖ ដាវិឌបានបង្កើតខ្សែរាជវង្សមួយ។ ទ្រង់បានជ្រើសរើសរាជបុត្រារបស់ទ្រង់ព្រះនាមសូឡូម៉ុនឱ្យឡើងស្នងរាជ្យបន្តពីទ្រង់។ សូឡូម៉ុនបានក្លាយជាស្តេចទីបីរបស់អ៊ីស្រាអែលនៅប្រហែលឆ្នាំ 962 មុនគ.ស។ ដូចជាបិតារបស់ទ្រង់ដែរ សូឡូម៉ុនគឺជាស្តេចដ៏ខ្លាំងក្លាមួយអង្គ។ អំឡុងពេលនៃការគ្រប់គ្រងរបស់សូឡូម៉ុន អ៊ីស្រាអែលបានក្លាយជារដ្ឋដ៏ខ្លាំងមួយ។ សូឡូម៉ុនបានពង្រឹងទំនាក់ទំនងពាណិជ្ជកម្មរវាងផូនីសៀជាមួយនិងអ៊ីស្រាអែល ដែលដំបូងឡើយបានបង្កើតឡើងដោយស្តេចដាវិឌ។ ទ្រង់ក៏បានបង្កើតសម្ព័ន្ធភាពពាណិជ្ជកម្មថ្មីមួយផងដែរ។

សូឡូម៉ុនបានដឹកនាំគម្រោងស្ថាបនាជាច្រើន។ គម្រោងស្ថាបនាដែលល្បីល្បាញបំផុតរបស់ទ្រង់គឺ ប្រាសាទនៅយេរ៉ូសាឡឹម។ ប្រាសាទនេះហ៊ុំព័ទ្ធដោយថ្មពីខាងក្រៅ ចំណែកឯជញ្ជាំងនៅខាងក្នុងត្រូវបានស្ថាបនាឡើងដោយដើមឈើសេដា(ដើមគ្រីស្មាស) ដែលស្រោបទៅដោយមាស។ ប្រាសាទរបស់សូឡូម៉ុន បានក្លាយជាមជ្ឈមណ្ឌលសាសនាសម្រាប់ពីអ៊ីស្រាអែល។ ប្រជាជនពីគ្រប់ផ្នែកទាំងអស់នៃព្រះរាជាណាចក្របានធ្វើដំណើរមកកាន់ទីនេះដើម្បីធ្វើការអធិដ្ឋាន និងផ្តល់ដង្វាយ។ មនុស្សជាច្រើនក៏បានធ្វើដំណើរមកទីនេះដើម្បីស្នើសុំព្រះមហាក្សត្រជួយដោះស្រាយទំនាស់របស់ពួកគេផងដែរ។

វិភាគអំពីដើមហេតុ៖ ពន្យល់ពីមូលហេតុដែលពួកអ៊ីស្រាអែលសម្រេចចិត្តនៅក្នុងការជ្រើសរើសស្តេចមួយអង្គ។

## 2. ការបែងចែកព្រះរាជាណាចក្រ

សំណួរគន្លឹះ៖ តើមានអ្វីកើតឡើងបន្ទាប់ពីកើតមានជម្លោះផ្ទៃក្នុងរបស់ពួកអ៊ីស្រាអែល?

ប្រឈមទៅនឹងការគំរាមកំហែងពីការវាយប្រហារ កុលសម្ព័ន្ធនានារបស់អ៊ីស្រាអែលបានបង្រួមបង្រួមគ្នាបង្កើតបានជាព្រះរាជាណាចក្រអ៊ីស្រាអែល។ នៅពេលដែលការគំរាមកំហែងបានបញ្ចប់ ព្រះរាជាណាចក្របានបែងចែក។

អ៊ីស្រាអែល និងយូដា៖ ប្រាសាទរបស់សូឡូម៉ុនតម្រូវឲ្យមានការបង់ពន្ធខ្ពស់។ នៅពេលដែលសូឡូម៉ុនសុគតនៅឆ្នាំប្រមាណ 922 មុនគ.ស រាជបុត្រារបស់ទ្រង់ព្រះនាមរេហូប៊ាមបានក្លាយជាស្តេច។ ប៉ុន្តែក្រុមកុលសម្ព័ន្ធភាគខាងជើងបានបដិសេធក្នុងសន្យាអំពីភក្តីភាពរបស់ពួកគេ លុះត្រាណាតែទ្រង់យល់ព្រមកាត់បន្ថយការបង់ពន្ធរបស់ពួកគេ និងបញ្ចប់ការយកពួកគេទៅធ្វើការនៅក្នុងគម្រោងស្ថាបនានានា។ នៅពេលដែលទ្រង់បដិសេធសំណើរនេះ ពួកកុលសម្ព័ន្ធទាំងនោះបាននាំគ្នាបះបោរ។ មានតែកុលសម្ព័ន្ធយូដា និងបេនយ៉ាមីនតែប៉ុណ្ណោះដែលនៅបន្តមានភក្តីភាពជាមួយរេហូប៊ាម។ អ៊ីស្រាអែលបានបែកចេញជាព្រះរាជាណាចក្រពីរផ្សេងគ្នា។ ផ្នែកភាគខាងជើងនៅតែបន្តហៅថាអ៊ីស្រាអែល។ ចំណែកឯកុលសម្ព័ន្ធពីរនៅភាគខាងត្បូងដែលរួមបញ្ចូលទាំងរាជធានីជេរ៉ូសាលឹមផងនោះ ត្រូវបានគេហៅថាយូដា។ ពាក្យយូដានិយម និងជ្វីបបានមកពីឈ្មោះយូដា។ ព្រះរាជាណាចក្រទាំងពីរនេះបានដាច់ចេញពីគ្នាប្រហែល 2 សតវត្សរ៍។ នៅអំឡុងពេលនៃការបែកចេញពីគ្នានេះជេរ៉ូសារឹម នៅតែជាមជ្ឈមណ្ឌលសាសនាដ៏សំខាន់មួយ។

ពួកអាស៊ីរី និងបាប៊ីឡូនដណ្តើមយកដី៖ ត្រឹមឆ្នាំ 738 មុនគ.ស ព្រះរាជាណាចក្រទាំងពីរប្រឈមទៅនឹងការគំរាមកំហែងជាថ្មីទៀតចំពោះឯករាជ្យរបស់ពួកគេពីសំណាក់ពួកអាស៊ីរី។ ពួកអាស៊ីរីបានបង្ខំឱ្យពួកអ៊ីស្រាអែល

និងយូដា បង់សួយសាអាករដល់ពួកគេ។ នៅក្នុងឆ្នាំ 722 មុនគ.ស អាស៊ីរីបានឈ្លានពាន និងដណ្តើមកាន់កាប់អ៊ីស្រាអែល ដែលពេលនោះកងទ័ពរបស់អ៊ីស្រាអែលមានកម្លាំងខ្សោយ។ ពេលនោះព្រះរាជាណាចក្រអ៊ីស្រាអែលត្រូវបានបញ្ចប់។ នៅរង្វង់ឆ្នាំ 612 មុនគ.ស ចក្រភពអាស៊ីរីបានដួលរលំធ្លាក់ក្រោមការគ្រប់គ្រងរបស់បាប៊ីឡូន។ អស់រយៈកាលជាច្រើនឆ្នាំស្តេចនេប៊ូឆាដនេហ្សរ៍បានដឹកនាំបាប៊ីឡូន។ នៅក្នុងឆ្នាំ 586 មុនគ.សស្តេចនេប៊ូឆាដនេហ្សរ៍បានដណ្តើមកាន់កាប់យេរ៉ូសាឡឹម។ នៅពេលដែលមេដឹកនាំរបស់យូដាប្រឆាំងជាមួយនឹងការគ្រប់គ្រងរបស់ទ្រង់ ពួកបាប៊ីឡូនបានវាយកម្ទេចប្រាសាទរបស់សូឡូម៉ុននៅយេរ៉ូសាលឹម។ ពួកគេបានចាប់យកពួកជ្វីបរាប់ពាន់នាក់ធ្វើជាឈ្លើយសឹកហើយនាំយកទៅកាន់បាប៊ីឡូន។

វិភាគអំពីឥទ្ធិពល៖ បង្ហាញថាតើមានរឿងអ្វីកើតឡើងបន្ទាប់ពីកើតមានជម្លោះផ្ទៃក្នុងរបស់ពួកអ៊ីស្រាអែល។

### 3. ពួកជ្វីបដែលគេនិរទ្ទេសត្រឡប់មកកាន់យូដាវិញ

សំណួរគន្លឹះ៖ តើសេចក្តីសង្ឃឹម និងជំនឿអ្វីខ្លះដែលបានជួយដល់ពួកជ្វីបដែលគេនិរទ្ទេស?

ពួកអ៊ីស្រាអែលដែលត្រូវបាននិរទ្ទេសចេញពីយូដា ចំណាយពេលអស់ប្រហែល 50 ឆ្នាំរស់នៅបាប៊ីឡូន។ ក្នុងរយៈពេល 50 ឆ្នាំនេះត្រូវបានគេស្គាល់ថា ការជាប់ឃុំឃាំងនៅបាប៊ីឡូន។ អំឡុងពេលនោះ ពួកអ៊ីស្រាអែលត្រូវបានស្គាល់ថាជ្វីប។

ជំនឿអំឡុងពេលនៃការជាប់ឃុំឃាំងនៅបាប៊ីឡូន៖ អំឡុងពេលនៃការរស់នៅរបស់ពួកគេនៅបាប៊ីឡូន ពួកជ្វីបបានតស៊ូក្នុងការរក្សានូវអត្តសញ្ញាណរបស់ពួកគេ។ ពួកគេបន្តអនុវត្តច្បាប់សាសនា, ប្រារព្ធថ្ងៃពិសិដ្ឋ, និងគោរពបូជាដូចដែលអ្វីដែលពួកគេធ្លាប់ធ្វើនៅយូដា។ ពួកគេសង្ឃឹមថា ថ្ងៃណាមួយពួកគេនឹងត្រឡប់ទៅកាន់ទឹកដីកំណើតរបស់ពួកគេវិញនៅយូដា និងស្ថាបនាប្រាសាទនៅយេរ៉ូសាលឹមឡើងវិញ។ ជំនឿនេះបានគាំទ្រ ឬជួយទ្រទ្រង់ដល់ស្មារតីរបស់ពួកអ៊ីស្រាអែលអំឡុងពេលនៃការចាប់ឃុំឃាំង។ ពួកអ្នកត្រូវបានគេនិរទ្ទេស ក៏បានសម្លឹងឆ្ពោះទៅរកពេលវេលាមួយដែលពួកគេនឹងមានស្តេចរបស់ពួកគេផ្ទាល់ម្តងទៀត។ មុនពេលនិរទ្ទេស មេដឹកនាំហេព្រើរត្រូវបានគេជុសខាត់ ឬក៏មានប្រេងពិសេសចាកពីលើក្បាលរបស់ពួកគេ នៅពេលដែលពួកគេឡើងចូលកាន់តំណែង។ ពាក្យរបស់ហេព្រើរមីសៃមានន័យថា "ការជុសខាត់" អ្នកដែលជាប់ពាក់ព័ន្ធជាមួយភារៈកិច្ច ឬការដឹកនាំ។ ឆ្លងកាត់ការគ្រប់គ្រងរបស់បរទេសអស់ជាច្រើនសតវត្សរ៍ ប្រជាជនអ៊ីស្រាអែលនៅតែរក្សាសេចក្តីសង្ឃឹមរបស់ពួកគេក្នុងការមានស្តេចផ្ទាល់របស់ពួកគេ។ ពួកអ៊ីស្រាអែលសង្ឃឹមថានឹងមានទាយាទមួយរូបឡើងស្នងរាជ្យបន្តពីដាវីឌ ដែលជាអ្នកជួយសង្គ្រោះ ឬអ្នករំដោះ-មីសៃ។

អំឡុងពេលនៃការលំបាក ទាំងនៅយូដា និងបាប៊ីឡូន ប្រជាជនជ្វីបបានត្រឡប់ទៅគោរពលើមេដឹកនាំព្រលឹងដែលគេហៅថា ព្យាការីដើម្បីណែនាំពួកគេ។ ព្យាការីទាំងនេះ គឺជាមនុស្សប្រុស ឬស្រីដែលគេគិតថាមានសមត្ថភាពពិសេសមួយនៅក្នុងការបកប្រែសម្តីរបស់ព្រះជាម្ចាស់។ ពួកគេបានដាស់តឿនដល់ប្រជាជន នៅពេលដែលពួកគេងាកចេញពីក្រមប្រតិបត្តិរបស់ជ្វីប។ ពួកគេរិះគន់ដល់មេដឹកនាំទាំងឡាយណា ដែលមិនបានរស់នៅស្របទៅតាមច្បាប់របស់ព្រះជាម្ចាស់។ ព្យាការីក៏ជាអ្នកលើកទឹកចិត្តប្រជាជនផងដែរនៅពេលដែលពួកគេជួបប្រទះបញ្ហា។

ប្រាសាទត្រូវបានស្ថាបនាឡើងវិញ៖ នៅក្នុងឆ្នាំ 539 មុនគ.ស ពួកពែក្សបានដណ្តើមកាន់កាប់បាប៊ីឡោន។ ដូចដែលអ្នកអាននៅក្នុងជំពូក 2 ស្តេចពែក្សព្រះនាមស៊ីរូសបានបង្កើតគោលនយោបាយត្រាប្រណីដល់សាសនានៅក្នុងចក្រភពរបស់ទ្រង់។ ខុសពីពួកអ្នកឈ្លានពាននានា ស៊ីរូសជឿជាក់លើការផ្តល់តម្លៃដល់ទំនៀមទម្លាប់ និងសាសនាក្នុងតំបន់។ ជំនួសដោយការវាយកម្ទេចប្រាសាទនៅក្នុងតំបន់ ស៊ីរូសបែរជាលុតជង្គង់នៅទីនោះដើម្បីបន់ស្រន់ទៅវិញ។ នៅក្នុងឆ្នាំ 538 មុនគ.ស ស៊ីរូសបានដោះលែងពួកអ្នកនិរទេសជ្វីបពីឃុំឃាំង និងអនុញ្ញាតឱ្យពួកគេត្រឡប់ទៅកាន់ទឹកដីកំណើតរបស់ពួកគេនៅយូដាវិញ។ ពួកអ្នកនិរទេសប្រមាណ 4 ម៉ឺននាក់បានត្រឡប់មកកាន់យូដាវិញ។ ប៉ុន្តែ ពួកជ្វីបជាច្រើននៅបន្តរស់នៅបាប៊ីឡោន។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពែក្ស ពួកជ្វីបបានស្ថាបនាជេរ៉ូសាឡឹមឡើងវិញ។ ពួកជ្វីបតែងតែដឹងគុណស៊ីរូសជារៀងរហូត អ្នកដែលពួកគេចាត់ទុកថាជាមិត្តភ័ក្តិ និងជាអាណាព្យាបាលមួយរូប។

ភ្លាមៗបន្ទាប់ពីពួកនិរទេសភាគច្រើនត្រឡប់មកកាន់យូដា ពួកគេចាប់ផ្តើមស្ថាបនាប្រាសាទនៅយេរ៉ូសាឡឹមឡើងវិញ។ សំណង់ប្រាសាទដ៏ស្រស់ស្អាតរបស់សូឡូម៉ុនត្រូវបានកម្ទេចរាបដល់ដី។ ស្មៅបានដុះនៅតាមចន្លោះស្នាមប្រេះនៃកំពែង។ កម្មករបានបញ្ចប់ការស្ថាបនាប្រាសាទថ្មីនៅរង្វង់ឆ្នាំ 515 មុនគ.ស។ កំពែងនៅយេរ៉ូសាឡឹមត្រូវបានស្ថាបនាឡើងវិញនៅក្នុងឆ្នាំ 445 មុនគ.ស។ នៅក្នុងមេរៀនទី 3 អ្នកនឹងរៀនអំពីអ្វីដែលនឹងក្លាយជាប្រាសាទទីពីរ និងទឹកដីកំណើតរបស់ជ្វីប។

គូសបង្ហាញពីសេចក្តីសន្និដ្ឋាន៖ ពិពណ៌នាពីសេចក្តីសង្ឃឹម និងជំនឿដែលបានជួយទ្រទ្រង់ដល់ពួកជ្វីបអំឡុងពេលនិរទេស។

# មេរៀនទី 3៖ ការរីកសាយភាយនៃយូដានិយម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ពួកជ្វីបបានត្រឡប់មកកាន់ទឹកដីយូដាវិញបន្ទាប់ពីបាននិរទ្ទេសទៅកាន់បាប៊ីឡូនអស់រយៈពេលជាយូរមក។ ដូចដែលពួកគេចាប់ផ្តើមដឹកនាំគ្រប់គ្រងដោយខ្លួន សម័យកាលដែលពួកគេទទួលបានឯករាជ្យនោះជាទូទៅតែងតែញាំញីដោយការឈ្លានពានពីសំណាក់ពួកបរទេស។

## 1. ដឹកនាំគ្រប់គ្រងដោយបរទេស

សំណួរគន្លឹះ៖ ហេតុអ្វីបានជាពួកជ្វីបបះបោរប្រឆាំងជាមួយពួកស៊ីរី?

ទឹកដីយូដា ស្ថិតនៅលើកន្លងផ្លូវនៃការឈ្លានពានរបស់ពួកកងទ័ពបរទេសដែលបានធ្វើដំណើរឆ្លងកាត់ឆ្នេរភាគខាងកើតសមុទ្រមេឌីទែរ៉ានេ។ អស់រយៈពេលជាច្រើនឆ្នាំ ក្រុមផ្សេងៗជាច្រើន ដោយរួមមានទាំងស៊ីរី និងរ៉ូមផងបានត្រួតត្រាតំបន់នេះ។

ពួកស៊ីរីគ្រប់គ្រងតំបន់យូដា៖ នៅក្នុងឆ្នាំ 198 មុនគ.ស ស៊ីរីបានដណ្តើមគ្រប់គ្រងតំបន់យូដា។ មេដឹកនាំស៊ីរីបានឱ្យតម្លៃទៅលើវប្បធម៌របស់ក្រិច និងបាននាំយកជំនឿរបស់ពួកក្រិចមកផ្សព្វផ្សាយដល់ពួកជ្វីប។ ពួកជ្វីបមួយចំនួនបានទទួលយកជំនឿនេះ។ ប៉ុន្តែ ប្រជាជនជ្វីបមួយចំនួនទៀតនៅតែបន្តប្រតិបត្តិ ឬដើរតាមជំនឿរបស់ពួកជ្វីប។ មេដឹកនាំស៊ីរីដំបូងដែលគ្រប់គ្រងនៅយូដាបានអនុញ្ញាតឱ្យពួកជ្វីបប្រតិបត្តិសាសនារបស់ពួកគេ។ នៅក្នុងឆ្នាំ 175 មុនគ.ស មេដឹកនាំថ្មីរបស់ស៊ីរីបានបញ្ជាឱ្យបព្វជិតជ្វីបរៀបចំពិធីបូជាថ្វាយដល់អទិទេពរបស់ក្រិច។ នៅពេលដែលពួកជ្វីបបដិសេធ មេដឹកនាំស៊ីរីបានដាក់បដិមាអទិទេពក្រិចនៅក្នុងប្រាសាទនានានៅយេរ៉ូសាលឹម។ មេដឹកនាំស៊ីរីបានចាត់ទុកការប្រតិបត្តិច្បាប់ជ្វីប ឬការសិក្សាពីកម្ពីរតូរេះថាជាបទឧក្រិដ្ឋ។ ពួកជ្វីបមួយចំនួនបានរត់គេចទៅកាន់លើភ្នំ ជាទីកន្លែងដែលពួកគេបានរៀបចំដើម្បីត្រៀមវាយបកលើពួកស៊ីរីវិញ។

ការបះបោរវាយប្រយុទ្ធជាមួយស៊ីរី៖ បព្វជិតជ្វីបមួយរូបបានបញ្ចេះឱ្យមានចលនាបះបោរដើម្បីបណ្តេញពួកស៊ីរីចេញ។ កូនម្នាក់នៅក្នុងចំណោមកូនប្រុសទាំង 5 អ្នករបស់លោក ឈ្មោះយូដាម៉ាកាប៊ីបានដឹកនាំការបះបោរនេះ។ យូដាម៉ាកាប៊ីមានភារៈកិច្ចដ៏លំបាកមួយ។ កងកម្លាំងដ៏តិចតួចរបស់លោក ដែលគេហៅថាម៉ាកាប៊ីបានប្រឈមជាមួយនឹងកងទ័ពដ៏ច្រើន និងបានអាវុធទំនើបៗ។ ប៉ុន្តែចំណេះដឹងរបស់យូដាម៉ាកាប៊ីអំពីទីជនបទ បានផ្តល់ឱ្យក្រុមលោកមានប្រៀប។ បន្ទាប់ពីការវាយប្រយុទ្ធគ្នា កងទ័ពបះបោរបានយកជ័យជំនះទៅលើកងទ័ពស៊ីរី។ ឆ្នាំ 164 មុនគ.ស កងទ័ពម៉ាកាប៊ីបានដណ្តើមត្រួតត្រាទីក្រុងយេរ៉ូសាលឹមឡើងវិញ។

វិភាគអំពីបុព្វហេតុ៖ ពន្យល់ថាហេតុអ្វីបានជាពួកជ្វីបបះបោរប្រឆ្នាំជាមួយពួកស៊ីរី។

## 2. ស្ថិតក្រោមការត្រួតត្រារបស់រ៉ូម

សំណួរគន្លឹះ៖ អ្វីទៅជាផលប៉ះពាល់នៃការគ្រប់គ្រងរបស់រ៉ូម?

ឯករាជ្យភាពរបស់ជ្វីបមិនស្ថិតស្ថេរបានយូរអង្វែងឡើយ។ បន្ទាប់ពីគ្រប់គ្រងដោយខ្លួនឯងអស់រយៈពេលប្រហែលមួយសតវត្សរ៍មក មហាអំណាចបរទេសមួយផ្សេងទៀតបានត្រួតត្រាលើពួកជ្វីប។

ពួករ៉ូមដណ្តើមកាន់កាប់យូដា៖ នៅក្នុងឆ្នាំ 63 នៃគ.ស ពួករ៉ូមបានដណ្តើមកាន់កាប់យូដា ដែលពេលនោះពួកគេបានហៅទឹកដីនេះថាយូឌា។ មេដឹកនាំរ៉ូមបានគ្រប់គ្រងយ៉ាងតឹងរឹងលើទឹកដីយូឌានេះ។ ពួកជ្វីបត្រូវបានអនុញ្ញាតឱ្យមានស្តេច និងមេដឹកនាំសាសនាជាជនជាតិជ្វីប ប៉ុន្តែស្តេច និងមេដឹកនាំសាសនាទាំងនេះត្រូវជ្រើសតាំងដោយរ៉ូម។ នៅក្នុងឆ្នាំ 66 នៃគ.ស ពួកជ្វីបមួយក្រុមដែលគេស្គាល់ថាហ្សេឡូតបានដឹកនាំចលនាបះបោរមួយនៅយូឌាដើម្បីប្រឆាំងជាមួយអាជ្ញាធររ៉ូមនៅតាមខេត្ត។ ពួកគេបានដណ្តើមកាន់កាប់បន្ទាយម៉ាសាដាពីពួករ៉ូម ហើយប្រើប្រាស់វាធ្វើជាមូលដ្ឋានកងទ័ពរបស់ខ្លួន។

ការតស៊ូប្រយុទ្ធជាមួយនឹងមេដឹកនាំរ៉ូម៖ មេដឹកនាំរ៉ូមបានឆ្លើយតប ដោយបញ្ជូនឧត្តមសេនីយ៍វេស្ពាសៀនដើម្បីបង្ក្រាបការបះបោរនេះ។ ពួកជ្វីបមួយចំនួនមានការភ័យខ្លាចថាពួករ៉ូមនឹងវាយកម្ទិចប្រាសាទរបស់ពួកគេ។ ជាលទ្ធផល គ្រូបង្រៀនម្នាក់មានឈ្មោះថាយ៉ូហាណាន បេន ហ្សាក់កៃ ប្រញាប់ប្រញាលធ្វើដំណើរទៅកាន់ជំរុំរបស់វេស្ពាសៀន។ លោកស្នើឱ្យឧត្តមសេនីយ៍វេស្ពាសៀន បង្កើតតំបន់ដាច់ដោយឡែកមួយសម្រាប់អ្នកប្រាជ្ញជ្វីបធ្វើការសិក្សារៀនសូត្រ។ សាលាដែលយ៉ូហាណាន បេន ហ្សាក់កៃ បង្កើតឡើងគឺដើម្បីរក្សានូវទំនៀមទម្លាប់របស់ពួកជ្វីបឱ្យគង់វង្ស។ នៅពេលដែលវេស្ពាសៀនបានក្លាយជាអធិរាជរបស់រ៉ូមនៅក្នុងឆ្នាំ 69 នៃគ.ស ទ្រង់បានដាក់រាជ្យបុត្រារបស់ទ្រង់ព្រះនាមទីទូសឱ្យទទួលបន្ទុកគ្រប់គ្រងកងទ័ពរ៉ូមនៅទឹកដីយូដា។ នៅក្នុងឆ្នាំ 70 នៃគ.សទីទូសបានបង្ក្រាបការបះបោរ។ កងទ័ពរ៉ូមបានវាយប្រហារលើទីក្រុងយេរ៉ូសាលឹម និងបានវាយកម្ទេចប្រាសាទជាលើកទី 2 ។ អ្វីដែលនៅសេះសល់គឺជញ្ជាំងផ្នែកខាងលិចនៃប្រាសាទ ដែលបច្ចុប្បន្នគឺជាស្ថូបដ៏ពិសិដ្ឋបំផុតរបស់ពួកជ្វីប។ កងទ័ពរបស់ហ្សេឡូតនៅបន្តគ្រប់គ្រងនៅម៉ាសាដារហូតដល់ឆ្នាំ 73 នៃគ.ស ប៉ុន្តែចុងបញ្ចប់បន្ទាយនេះត្រូវបានដណ្តើមកាន់កាប់ដោយពួករ៉ូម។ ពួកជ្វីបដែលនៅសេះសល់ក្នុងបន្ទាយប្រហែលជិតមួយពាន់នាក់ បានជ្រើសរើសយកការធ្វើអត្តឃាតខ្លួនឯងជាជាងត្រូវបានពួករ៉ូមចាប់ខ្លួន។ នៅក្នុងការបះបោរនេះពួកជ្វីបប្រហែលកន្លះលាននាក់ត្រូវបានសម្លាប់។ ពួកជ្វីបបានព្យាយាមជាថ្មីម្តងទៀតដើម្បីឯករាជ្យពីពួករ៉ូមនៅក្នុងឆ្នាំ 132 នៃគ.ស។ ពួកគេមានការខឹងសម្បា នៅពេលដែលអធិរាជរ៉ូមហាឌ្រានបានប្រកាសអំពីផែនការនៃការស្ថាបនាទីក្រុងយេរ៉ូសារឹមឡើងវិញឱ្យក្លាយជាទីក្រុងរបស់រ៉ូម។ ពួកជ្វីបប្រមាណ 85 ម៉ឺននាក់ទៀតបានស្លាប់នៅអំឡុងនៃការវាយប្រយុទ្ធគ្នារយៈពេល 3 ឆ្នាំ។ បន្ទាប់ពីការបះបោរត្រូវបានបង្ក្រាប ហាឌ្រៀនបានហាមឃាត់ពួកជ្វីបមិនឱ្យចូលទីក្រុងជេរ៉ូសាលឹម។

ការរាយពាយ៖ ការបំផ្លិចបំផ្លាញប្រាសាទទី 2 និងទីក្រុងយេរ៉ូសាលឹមដោយពួករ៉ូមនៅក្នុងឆ្នាំ 70 នៃគ.ស បានបន្តដោយការនិរទ្ទេស និងចលនាអស់ជាច្រើនសតវត្សរ៍។ ចលនារបស់ពួកជ្វីបនេះត្រូវបានគេស្គាល់ថាដៃស្ព៉ា ជាភាសាក្រិចដែលមានន័យថា "រាយពាយ"។ ពួករ៉ូមបានបញ្ជូនពួកជ្វីបជាច្រើនទៅកាន់ទីក្រុងរ៉ូមដើម្បីធ្វើជាទាសករ។ ពួកជ្វីបមួយចំនួនបន្តរស់នៅជិតទីក្រុងយេរ៉ូសារឹម។ មួយចំនួនទៀតបានរត់គេចទៅកាន់តំបន់នានានៅលើពិភព

លោក ដោយរួមមានទាំងអឺរ៉ុបផងដែរ។ ជាលទ្ធផលនៃការរាយប៉ាយ រដ្ឋរបស់ពួកជ្វីបបានផ្អាកដំណើរការប្រមាណ 1800 ឆ្នាំ។ មិនមានរដ្ឋជ្វីបទេចាប់ពីពេលនោះមករហូតដល់ការបង្កើតឡើងវិញនៃរដ្ឋអ៊ីស្រាអែលនៅក្នុងឆ្នាំ 1948 ។

វិភាគអំពីឥទ្ធិពលៈ ពិភាក្សាអំពីឥទ្ធិពលនៃការគ្រប់គ្រងរបស់ពួករ៉ូម។

### 3. យូដានិយម-ជំនឿដែលស្ថិតស្ថេរ

សំណួរគន្លឹះៈ តើពួកជ្វីបបន្តរក្សាសាសនារបស់ពួកគេឱ្យបន្តស្ថិតស្ថេរបានដោយរបៀបណាអំឡុងពេលដែលពួកគេត្រូវបាននិរទ្ទេស ?

បើទោះបីជាពួកជ្វីបត្រូវបានធ្វើឱ្យរាយពាយនៅពាលពេញចក្រភពរ៉ូបក៏ដោយ ពួកគេជាច្រើននៅតែមានជំនឿទៅលើសាសនារបស់ពួកគេដដែល។ ថ្វីបើពួកគេខ្ចាត់ខ្ចាយគ្នាមែន ប៉ុន្តែពួកគេបន្តប្រតិបត្តិគោលគំនិតនៅក្នុងគម្ពីរសាសនាគ្រឹស្តស្តីអំពីភាពត្រឹមត្រូវ និងយុត្តិធម៌។

គ្រូបង្រៀន និងច្បាប់ៈ បន្ទាប់ពីការបំផ្លិចបំផ្លាញប្រាសាទទី 2 និងការរាយពាយមក ពួកជ្វីបជាច្រើនមានការព្រួយបារម្ភថា ពួកគេនឹងបាត់បង់អត្តសញ្ញាណរបស់ពួកគេ។ មេដឹកនាំសាសនា និងគ្រូបង្រៀនមួយចំនួនដែលគេហៅថារ៉ាប៊ីសបានព្យាយាមនៅក្នុងការធ្វើឱ្យច្បាស់ថា រឿងនេះមិនអាចកើតមានបានឡើយ។ ដឹកនាំដោយរ៉ាប៊ីស យូហាណាន បេន ហ្សាក់កៃ ពួកគេបានស្ថាបនាទីកន្លែងសម្រាប់ការសិក្សា, អធិដ្ឋាន, និងគោរពបូជានៅគ្រប់ទីកន្លែងដែលមានពួកជ្វីបរស់នៅ។ ទីកន្លែងដែលគេបង្កើតឡើងសម្រាប់គោរពបូជាទាំងនេះត្រូវបានគេហៅថាស៊ីណាហ្គូហ្គិស។ នៅស៊ីណាហ្គូហ្គិស មនុស្សបានប្រមូលផ្តុំគ្នាដើម្បីស្តាប់រ៉ាប៊ីសអានគម្ពីរតូរ៉ោះ និងបកប្រែ ឬអត្ថាធិប្បាយគម្ពីរនោះ។ នៅក្នុងវិធីនេះ ពួកជ្វីបទាំងឡាយបានរក្សាវិធីស្រដៀងគ្នានៅក្នុងការគោរពបូជា បើទោះបីជាពួកគេរស់នៅទីណាក៏ដោយ។

ពួកជ្វីបក៏បានរក្សានូវសច្ចៈភាពរបស់ពួកគេតាមរយៈការប្រតិបត្តិដោយយកចិត្តទុកដាក់នូវច្បាប់ និងសង្កេតមើលទៅលើប្រពៃណីនៃសាសនារបស់ពួកគេ។ ពួកគេបានបង្កើតសាលារៀន ដែលកុមារជ្វីបបានសិក្សាពីគម្ពីរតូរ៉ោះ និងរៀនពីការអធិដ្ឋាននូវសច្ចៈភាពរបស់ពួកគេ។ ការអនុវត្តរបស់ពួកជ្វីបទាំងនេះបានជះឥទ្ធិពលលើមនុស្សដែលរស់នៅក្នុងសហគមន៍គ្រីស្ទៀនទាំងនោះ។ ប្រពៃណីនៃសាសនាទាំងពីរនេះបានផ្តល់នូវមូលដ្ឋានគ្រឹះដ៏សំខាន់មួយនៃអរិយធម៌លោកខាងលិច។

សង្ខេបៈ ប្រាប់ពីវិធីដែលពួកជ្វីបរក្សានូវសាសនាឱ្យស្ថិតស្ថេរអំឡុងពេលនៃការនិរទ្ទេស។

# ជំពូក 4 ៖ ប្រទេសអេហ្ស៊ីប និងគូសបុរាណ

## មេរៀនទី 1 ៖ អំណោយនៃទន្លេនីល

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹងៈ តើអ្នកធ្លាប់ទទួលបានអំណោយដែលមានសារៈសំខាន់បំផុតសម្រាប់អ្នក? ទន្លេនីលមានសារៈសំខាន់ណាស់សម្រាប់ប្រទេសអេហ្ស៊ីប ដែលកាលពី 2,500 ឆ្នាំកន្លងទៅប្រវត្តិវិទូជនជាតិក្រិកមួយរូបបានហៅអេហ្ស៊ីបថា "អំណោយនៃទន្លេនីល"។

### 1. ទីតាំងភូមិសាស្ត្រនៃអេហ្ស៊ីបបុរាណ

សំណួរគន្លឹះ៖ តើទឹកជំនន់ជារៀងរាល់ឆ្នាំនៃទន្លេនីលបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អេហ្ស៊ីប?

ប្រវត្តិវិទូជនជាតិក្រិចបានដឹងអំពីអ្វីដែលគាត់បាននិយាយ។ ទន្លេនីលជាដង្ហើមនៃអរិយធម៌អេហ្ស៊ីបដែលរយៈពេលជាង 5,000 ឆ្នាំ។

ទន្លេដែលវែងជាងគេ៖ ទន្លេនីលមានប្រវែង 4,160 ម៉ាយ ដែលជាទន្លេវែងជាងគេនៅលើពិភពលោក។ វាហូរចេញមកពីតំបន់ជិតខ្សែអេក្វាទ័រនៃទ្វីបអាហ្វ្រិក និងហូរមកភាគខាងជើងឆ្ពោះទៅកាន់សមុទ្រមេឌីទែរ៉ាណេ។ នៅភាគខាងត្បូងទន្លេនេះសំបូរទៅដោយល្បាក់។ ល្បាក់គឺជាទឹកធ្លាក់។ នៅជិតសមុទ្រទន្លេនីលបានបែកខ្នែកបង្កើតបានជាតំបន់ដីសណ្តរមួយ។ តំបន់ដីសណ្តគឺជាតំបន់ដែលស្ថិតនៅជិតមាត់ទន្លេដែលទឹកទន្លេបាននាំយកដីមានជីជាតិដែលគេហៅថាល្បាប់។ នៅតំបន់ដីសណ្ត ទន្លេនីលបានបែកខ្នែកជាច្រើនខ្សែ។ ទន្លេនេះចាប់ផ្តើមហូរចេញពីភាគខាងត្បូង និងហូរមកកាន់ភាគខាងជើងចាក់ចូលសមុទ្រមេឌីទែរ៉ានេ។ សម្រាប់ហេតុផលនេះ ទន្លេនីលភាគខាងលើគឺស្ថិតនៅភាគខាងត្បូង និងទន្លេនីលភាគខាងក្រោមស្ថិតនៅភាគខាងជើង។ អស់រយៈពេលជាច្រើនសតវត្សរ៍ ភ្លៀងធ្លាក់ដ៏ច្រើននៅតំបន់វាលទំនាបអេត្យូពីបានបណ្តាលឱ្យទន្លេនីលជន់លិចជារៀងរាល់រដូវក្តៅ។ ទឹកជំនន់បាននាំមកនូវដីដែលសម្បូរជីជាតិនៅតាមច្រាំងសងខាងនៃទន្លេនីល។ ដីទាំងនេះសម្បូរទៅដោយជីជាតិដែលអំណោយផលដល់ការដាំដុះដំណាំផ្សេងៗ។ ជាកាពិត តំបន់នេះគឺជាតំបន់ដែលដីសម្បូរជីជាតិជាងគេនៅក្នុងទ្វីបអាហ្វ្រិក។ ជាសំណាងសម្រាប់ប្រជាកសិករអេហ្ស៊ីប ទឹកជំនន់ទន្លេនីលជន់លិចក្នុងរយៈពេលប្រហាក់ប្រហែលគ្នាជារៀងរាល់ឆ្នាំ ដូច្នេះប្រជាកសិករអាចប៉ាន់ស្មានអំពីពេលវេលាដែលពួកគេអាចដាំដុះដំណាំរបស់ពួកគេបាន។

ដីខ្មៅ និងដីក្រហម៖ ប្រជាជនអេហ្ស៊ីបបុរាណរស់នៅប្រមូលផ្តុំនៅតាំងច្រាំងសងខាងនៃទន្លេនីល។ ពួកគេហៅតំបន់នេះថាតំបន់ដីខ្មៅ ដោយសារតែតំបន់នេះសម្បូរទៅដោយដីមានជីជាតិដែលនាំយកមកដោយទឹកជំនន់។ តំបន់ដីក្រហមគឺជាតំបន់ដីខ្សាច់ដែលស្ថិតនៅជាប់តំបន់ដីសម្បូរជីជាតិ។

អាកាសធាតុនៅអេហ្ស៊ីបតែងតែមានលក្ខណៈដូចគ្នាជាប្រចាំ។ ក្នុងមួយឆ្នាំ 8 ខែគឺជារដូវក្តៅ។ 4 ខែគឺជារដូវរំហើយ។ តំបន់ភាគច្រើនមានភ្លៀងធ្លាក់ត្រឹមតែមួយអ៊ីញប៉ុណ្ណោះក្នុងមួយឆ្នាំ។ តំបន់ដែលមិនស្ថិតនៅជិតទន្លេនីលភាគច្រើនគឺជាវាលខ្សាច់។ តំបន់វាលខ្សាច់ដ៏ធំបានដើរតួជារបាំងមួយការពារអេហ្ស៊ីបពីការវាយប្រហារពីសត្រូវ។ តំបន់

ឆ្នេរសមុទ្រមេឌីទែរ៉ាណេជាតំបន់ដែលសម្បូរដោយវាលភក់ ហើយមានកំពង់ផែល្អៗតិចតួច។ សម្រាប់ហេតុផលនេះ ប្រជាជនអេហ្ស៊ីបភាគច្រើនមិនបានធ្វើដំណើរចេញឆ្ងាយពីផ្ទះឡើយ។

សង្ខេប៖ កំណត់អំពីអត្ថប្រយោជន៍នៃជំនន់ទន្លេនីលសម្រាប់ប្រជាជនអេហ្ស៊ីប។

## 2. ទឹកដីដែលចរិចូរណ៍

សំណួរកន្លឹះ៖ តើប្រជាជនអេហ្ស៊ីបប្រើប្រាស់ដីនៅជុំវិញទន្លេនីលដោយរបៀបណា?

ជារៀងរាល់ឆ្នាំ ប្រជាកសិករអេហ្ស៊ីបតែងតែពិនិត្យមើលសត្វស្លាបសដែលគេហៅថាអាយប៊ីសដែលបានហោះមកពីភាគខាងត្បូង។ នៅពេលដែលសត្វស្លាបសមកដល់ ទឹកជំនន់ប្រចាំឆ្នាំនឹងមកដល់ក្នុងពេលឆាប់ៗ។ នៅពេលដែលទឹកជំនន់ស្រក់វិញ ប្រជាកសិករអាចដាំដំណាំរបស់ពួកគេនៅលើដីជីជាតិ។

បច្ចេកវិទ្យាកសិកម្ម៖ ការគ្រប់គ្រងទឹកជំនន់ប្រចាំឆ្នាំរបស់ទន្លេនីលសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្មគឺជារឿងសំខាន់មួយសម្រាប់សហគមន៍។ ដើម្បីប្រើប្រាស់ទឹកទន្លេបាន ប្រជាកសិករអេហ្ស៊ីបត្រូវធ្វើការជាមួយគ្នា។ ភាគច្រើនពួកគេត្រូវជីកដី។ ប្រព័ន្ធប្រឡាយបង្ហូរទឹកត្រូវបានគេជិកឡើងដើម្បីនាំយកទឹកទៅកាន់តំបន់ស្ងួតគ្មានទឹក។ អាងស្តុបទឹក ជាតំបន់ដែលទឹកត្រូវបានគេទប់ដើម្បីប្រើប្រាស់នៅពេលដែលទឹកជំនន់ស្រក។ ដីភាគច្រើនដែលគេជីកយកចេញពីប្រឡាយ និងអាងស្តុបទឹកអាចយកទៅស្ថាបនាខឿនទំនប់ដើម្បីការពារកុំឱ្យទឹកជន់លិចតំបន់ផ្សេងៗទៀត។ ក្រោយមក នៅរង្វង់ឆ្នាំ 1600 មុនគ.ស ឧបករណ៍ប្រើប្រាស់មួយដែលគេហៅថាសាដូហ្វត្រូវបានគេនាំយកពីអាស៊ីភាគនិរតី។ ប្រជាកសិករអេហ្ស៊ីបប្រើប្រាស់វាដើម្បីដងទឹកពីទន្លេនីលដាក់ក្នុងប្រឡាយ និងពីប្រឡាយដាក់ក្នុងអាងស្តុបទឹក ឬពីអាងស្តុបទឹកដាក់ក្នុងស្រែ។ សាដូហ្វបានបង្កើនសមត្ថភាពពួកអេហ្ស៊ីបក្នុងការប្រើប្រាស់ទឹកយ៉ាងមានប្រសិទ្ធភាព។

ដំណាំរបស់ប្រជាជនអេហ្ស៊ីប៖ ប្រជាជនអេហ្ស៊ីបបុរាណបានដាំដុះនូវដំណាំជាច្រើនប្រភេទ។ គ្រាប់ធុញ្ញជាតិដូចជាស្រូវសាលី និងស្រូវបាឡេ គឺជាដំណាំចំបងរបស់ប្រជាជនអេហ្ស៊ីប។ ពួកគេគឺជាមនុស្សដំបូងដែលមានកិនស្រូវសាលីទៅជាម្សៅ និងលាយម្សៅជាមួយមេដំបែ និងទឹកដើម្បីបង្កើតបានជានំប៉័ង។ ពួកគេបានដាំដុះបន្លែជាច្រើនប្រភេទក្នុងនោះមានដូចជាសាឡាត់, ផៃថាវ, ខ្ទឹមបារាំង, និងត្រសក់។ ផ្លែឈើ រួមមានល្មើល, ល្វា, និងទំពាំងបាយជូរជាដើម។ ពួកអេហ្ស៊ីបក៏ដាំដុះវត្ថុធាតុដើមនានាសម្រាប់ផលិតសំលៀកបំពាក់របស់ពួកគេផងដែរ។ ពួកគេជាមនុស្សដំបូងដែលបានត្បាញសសៃអំបោះដែលបានមកពីដើមកប្បាសឱ្យទៅជាក្រណាត់ ដែលគេហៅថាទ្បែន។ សំលៀកបំពាក់ធ្វើពីទ្បែនដែលមានទម្ងន់ស្រាលគឺមានភាពសាកសមសម្រាប់អាកាសធាតុក្តៅនៅអេហ្ស៊ីប។ បុរសៗរុំក្រណាត់ទ្បែនជុំវិញចង្កេះរបស់ពួកគេ។ ស្ត្រីភាគច្រើនពាក់សំលៀកបំពាក់របស់ពួកគេដែលមានភាពរលុងៗ។ ប្រជាជនអេហ្ស៊ីបក៏ត្បាញស្មៅធ្វើជាស្បែកជើងផងដែរ។

ផ្ទះរបស់ពួកអេហ្ស៊ីប៖ ប្រជាជនអេហ្ស៊ីបសាងសង់ផ្ទះដោយប្រើឥដ្ឋដែលធ្វើឡើងពីដីភក់ដែលបានមកពីទន្លេនីលលាយជាមួយជញ្ជ្រាំស្មៅ។ ពួកគេដាក់បង្អួចតូចៗនៅតាមជញ្ជាំងដើម្បីកាត់បន្ថយពន្លឺព្រះអាទិត្យ។ ពួក

អេហ្ស៊ីបតែងតែងគូរជញ្ជាំងរបស់ពួកគេពណ៌សដើម្បីទប់ទៅនឹងរលកកម្តៅ។ ពួកគេត្បាញស្លឹកត្នោតជាមួយបែកឈើដើម្បីធ្វើដំបូលផ្ទះ។ នៅខាងក្នុងផ្ទះគេក្រាលកម្រាលដើមត្រែងនៅពីលើដី។ ភាគច្រើននៃប្រជាជនអេហ្ស៊ីបដេកនៅលើកម្រាលដើមត្រែងជាមួយនឹងក្រណាត់ទ្បែន។ ប្រជាជនមានទ្រព្យសម្បត្តិស្តុកស្តម្ភដេកនៅលើគ្រែ និងពូកខ្នើយ។ ពួកអភិជនអេហ្ស៊ីបមានផ្ទះគួរឱ្យចង់នៅ ដោយមានដើមឈើហ៊ុំព័ទ្ធទីធ្លាមុខផ្ទះ។ ផ្ទះមួយចំនួនមានស្រះទឹកដែលមានដាំផ្កាឈូក និងចិញ្ចឹមត្រី។ ប្រជាជនអេហ្ស៊ីបក្រីក្រជាទូទៅតែងតែឡើងទៅដេកលើដំបូលផ្ទះរបស់ពួកគេបន្ទាប់ពីថ្ងៃលិច។

សង្ខេប៖ ពន្យល់ពីការប្រើប្រាស់ដីផ្សេងៗគ្នារបស់ប្រជាជនអេហ្ស៊ីបនៅតាមច្រាំងទន្លេនីល។

## 3. ទីតាំងភូមិសាស្ត្របង្កើតទម្រង់រស់នៅរបស់ប្រជាជនអេហ្ស៊ីប

សំណួរគន្លឹះ៖ សកម្មភាពសេដ្ឋកិច្ចអ្វីខ្លះដែលបានអភិវឌ្ឍឡើងនៅអេហ្ស៊ីប?

សេដ្ឋកិច្ចរបស់អេហ្ស៊ីបពឹងផ្អែកលើការធ្វើកសិកម្ម។ ប៉ុន្តែ ប្រជាជនអេហ្ស៊ីបក៏ប្រើប្រាស់ធនធានធម្មជាតិផ្សេងៗដើម្បីផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់ពួកគេ និងអភិវឌ្ឍទៅជាសកម្មភាពសេដ្ឋកិច្ច។

ការជីករ៉ែ៖ ប្រជាជនអេហ្ស៊ីបជីករ៉ែលោហៈ និងគាស់យកថ្មជាច្រើនប្រភេទដើម្បីបម្រើឱ្យវិស័យផ្សេងៗជាច្រើនដែលមានសារៈសំខាន់សម្រាប់សង្គមរស់នៅរបស់ពួកគេ។ ឧទាហរណ៍ ពួកគេជីករករ៉ែទង់ដែងនៅប្រហែលឆ្នាំ 4000 មុនគ.ស ហើយប្រើវាធ្វើជាឧបករណ៍ប្រើប្រាស់ និងអាវុធ។ ក្រោយមក ដោយសារតែដែកមានភាពរឹងមាំជាង ពួកគេបានជ្រើសរើសយកលោហៈនេះដើម្បីប្រើប្រាស់វិញម្តង។ ទង់ដែង និងដែកត្រូវបានគេជីកនៅតំបន់វាលខ្សាច់ភាគខាងកើត និងនៅតំបន់ឧបទ្វីបស៊ីណៃ។ មាសក៏ត្រូវបានគេជីកនៅតំបន់ដែលក្តៅខ្លាំង និងយ៉ាប់យឺននេះផងដែរ។ គុណភាពនៃមាសរបស់ប្រជាជនអេហ្ស៊ីបមានកម្រិតខ្ពស់ ហើយការធ្វើគ្រឿងអលង្ការរបស់ពួកគេ គឺស្ថិតនៅក្នុងចំណោមអ្នកធ្វើគ្រឿងអលង្កាល្អបំផុតនៅសម័យបុរាណ។ ភាសាអេហ្ស៊ីបហៅមាសថានូប។ ជាលទ្ធផល ពួកគេហៅតំបន់នៅភាគខាងត្បូងល្បាក់ទី 2 នៅទន្លេនីល (តំបន់ដែលសំបូរទៅដោយរ៉ែមាស) ថានូប៊ី។

ត្បូងជាច្រើនប្រភេទត្រូវបានគេកែច្នៃនៅពាសពេញអេហ្ស៊ីបផងដែរ។ ប្រជាជនអេហ្ស៊ីបប្រើប្រាស់ថ្មកំបោរពណ៌សដ៏ប្រណិតម្យ៉ាង ដែលត្រូវបានគាស់នៅជិតតំបន់មេមភីស ដើម្បីប្រើប្រាស់លើគម្រោងសំខាន់ៗ ដូចជាធ្វើជញ្ជាំងប្រាសាទ និងផ្នូរជាដើម។ ភាគខាងជើងបន្តិចនៃល្បាក់ទីមួយ ថ្មក្រានិតត្រូវបានគេគាស់នៅតំបន់អាស្វាន។ កម្មករបានដាក់វានៅលើទូកដើម្បីដឹកជញ្ជូនវាមកកាន់មជ្ឈមណ្ឌលសាសនា និងសិល្បៈសំខាន់ៗ ដូចក្នុងនោះមានដូចជាថេបេស ឬមេមភីសជាដើម។ វាគឺជាវត្ថុធាតុដើមដ៏សំខាន់មួយសម្រាប់ក្រុមអ្នកស្ថាបនា និងជាងចម្លាក់។ ប្រជាជនអេហ្ស៊ីបក៏ជីកត្បូងមានតម្លៃផងដែរ។ ពួកគេប្រហែលជាមនុស្សដំបូងនៅលើលោកដែលបានជីកថ្មកែវ។ ថ្មកែវ និងត្បូងមានតម្លៃផ្សេងមួយប្រភេទទៀត-ត្បូងមរកតត្រូវបានគេជីកនៅតំបន់វាលខ្សាច់ភាគខាងកើត។ ត្បូងមានតម្លៃទាំងពីរប្រភេទនេះត្រូវបានគេប្រើធ្វើជាគ្រឿងអលង្កាសម្រាប់ខ្សែរាជវង្ស និងពួកអភិជន។

ការនេសាទ និងបរបាញ់៖ ទន្លេសម្បូរដោយត្រី និងសត្វព្រៃផ្សេងៗទៀតដែលជាតម្រូវការរបស់ប្រជាជនអេហ្ស៊ីប។ ដើម្បីធ្វើដំណើរលើទឹកទន្លេ ប្រជាជនអេហ្ស៊ីបបានផលិតក្បូនដែលបង្កើតឡើងដោយការចង់ភ្ជាប់ដើមត្រែង។ ពួកគេប្រើប្រាស់ឧបករណ៍គ្រប់បែបយ៉ាង រាប់ចាប់ពីសំណាញ់រហូតដល់ស្នដើម្បីចាប់ត្រី។ គំនូរបុរាណមួយបានបង្ហាញថា បុរសម្នាក់បម្រុងនឹងវាយត្រីជាមួយនឹងញញួរឈើរបស់គាត់។ ក្រុមអ្នកប្រម៉ាញ់ផ្សងព្រេងជាច្រើនបានបានប្រើលំពែងរបស់ពួកគេដើម្បីចាក់សត្វដំរីទឹក និងក្រពើនៅតាមដងទន្លេនីល។ ប្រជាជនអេហ្ស៊ីក៏បានប្រើប្រាស់សំណាញ់ដើម្បីចាប់សត្វក្រួចផងដែរ។ ពួកគេប្រើប្រាស់ដំបងកោងដើម្បីកប់ទម្លាក់សត្វទា និងក្ងានដែលហើរ (ដំបងកោងគឺជាឈើដែលគេពត់ឱ្យកោង ហើយវាវិលត្រឡប់មកកាន់កន្លែងដើមវិញនៅពេលដែលយើងចោលវា)។

ការដឹកជញ្ជូន និងពាណិជ្ជកម្ម៖ ជាយថាហេតុ ប្រជាជនអេហ្ស៊ីប បានភ្ជាប់ក្ដោង និងចង្វាជាមួយទូកដើមត្បែងរបស់ពួកគេ ហើយទន្លេនីលបានក្លាយជាផ្លូវធ្វើដំណើរដ៏សំខាន់មួយ។ ចរន្តទឹកហើយនៅទន្លេនីលមានលក្ខណៈយឺត ដូច្នេះអ្នករត់ទូកប្រើចង្វាដើម្បីបង្កើនល្បឿននៅពេលដែលពួកគេធ្វើដំណើរទៅភាគខាងជើងតាមខ្សែទឹកហូរ។ ធ្វើដំណើរទៅខាងត្បូង ពូកគេទម្លាក់ក្ដោងដើម្បីឱ្យខ្យល់ជួយរុញច្រានទូក។ ទន្លេនីលបានផ្ដល់ភាពល្អប្រសើរសម្រាប់ប្រជាជនអេហ្ស៊ីប ដែលជាទូទៅពួកគេតែងទទួលបានភាពលើសនូវស្បៀងអាហារ ឬទំនិញដែលពួកគេត្រូវការ។ ពួកគេចាប់ផ្ដើមធ្វើពាណិជ្ជកម្មជាមួយគ្នាទៅវិញទៅមក។ អេហ្ស៊ីបបុរាណមិនប្រើប្រាស់លុយទេ ដូច្នេះប្រជាជនដោះដូរនូវទំនិញលើសរបស់ពួកគេ។ វិធីសាស្ត្រនៃការធ្វើពាណិជ្ជកម្មនេះត្រូវបានគេហៅថា ប្ដូរទំនិញ។ ពួកគេក៏ធ្វើពាណិជ្ជកម្មជាមួយក្រុមមនុស្សជិតខាងផងដែរ។ ពួកគេធ្វើពាណិជ្ជកម្មជាមួយពួកនូប៊ី ដោយនាំយកមកនូវសត្វកម្រ, មាស, ភ្លុក, និងធូបមកកាន់អេហ្ស៊ីប។ អេហ្ស៊ីបក៏ធ្វើពាណិជ្ជកម្មជាមួយតំបន់ភាគឦសានឆ្លងសមុទ្រមេឌីទែរ៉ានេដែលបច្ចុប្បន្នស្ថិតនៅឡេបានុន និងស៊ីរី។ ប្រជាជនអេហ្ស៊ីបស្វែងរកវិធីនានាដើម្បីកែច្នៃរបស់របរនៅជុំវិញខ្លួនរបស់ពួកគេ។ ភាពវៃឈ្លាតនៅក្នុងការសម្របខ្លួនរបស់ពួកគេទៅនឹងបរិស្ថានជុំវិញបានអនុញ្ញាតឱ្យពួកគេអាចស្ថាបនាសង្គមស្មុគស្មាញមួយ ដែលអ្នកនឹងបានឃើញនៅមេរៀនបន្ទាប់។

សង្ខេប៖ ពន្យល់ពីសកម្មភាពសេដ្ឋកិច្ចដែលបានអភិវឌ្ឍឡើងនៅអេហ្ស៊ីប។

# មេរៀនទី 2 ៖ ជីវិតរស់នៅក្នុងប្រទេសអេហ្ស៊ីបបុរាណ

ភ្ជាប់ទៅនឹងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានដឹងមកហើយ អេហ្ស៊ីបមានភាពរុងរឿងតាមដងទន្លេនីល។ ភាពរុងរឿងនេះបានធ្វើឲ្យជីវិតរស់នៅមានលក្ខណៈងាយស្រួល និងបានផ្តល់នូវឱកាសដ៏ល្អប្រសើរសម្រាប់ប្រជាជនអេហ្ស៊ីបទាំងឡាយ។

## 1. ការងារ និងគ្រួសារ

សំណួរគន្លឹះ៖ តើការងារ និងតួនាទីសង្គមបានជះឥទ្ធិពលយ៉ាងដូចម្តេចមកលើប្រជជនអេហ្ស៊ីបបុរាណ?

នៅពេលដែលប្រជាកសិករផលិតស្បៀងអាហារលើស សេដ្ឋកិច្ចនៅក្នុងសង្គមចាប់ផ្តើមរីកធំ។ ទីក្រុងបានលេចឡើង ដែលជាមជ្ឈមណ្ឌលវប្បធម៌ និងអំណាច ហើយប្រជាជនហាត់រៀនធ្វើការងារផ្សេងៗដែលមិនជាប់ពាក់ព័ន្ធជាមួយវិស័យកសិកម្ម។ ឧទាហរណ៍ ប្រជាជនអេហ្ស៊ីបបុរាណមួយចំនួនបានហាត់រៀនដើម្បីក្លាយជាអ្នកសរសេរ ដែលការងាររបស់ពួកគេគឺសរសេរ និងរក្សាកំណត់ត្រា។

ការងារជំនាញ៖ ដូចដែលអរិយធម៌អេហ្ស៊ីបកើនឡើងកាន់តែស្មុកស្មាញ ប្រជាជនអេហ្ស៊ីបចាប់ផ្តើមចាប់យកការងារផ្សេងៗទៀតជាជាងធ្វើជាកសិករ ឬអ្នកសរសេរ។ វិចិត្រករជំនាញមួយចំនួនរៀបថ្ម ឬឥដ្ឋធ្វើផ្ទះ ឬប្រាសាទ។ វិចិត្រករផ្សេងទៀតបានអភិវឌ្ឍជំនាញផ្ទាល់របស់ពួកគេ។ ពួកគេផលិតភាជន៍, កន្ទេល, គ្រឿងសង្ហារឹម, សំលៀកបំពាក់ទ្បែន, ស្បែកជើង, ឬគ្រឿងអលង្ការ។ ប្រជាជនអេហ្ស៊ីបមួយចំនួនតូចបានធ្វើដំណើរទៅកាន់ទន្លេនីលខាងលើ ដើម្បីធ្វើពាណិជ្ជកម្មជាមួយពួកអាហ្វ្រិកផ្សេងទៀត។ ពួកពាណិជ្ជករទាំងនេះបាននាំយកនូវផលិតផលរបស់អេហ្ស៊ីបដែលមានដូចជារមូលក្រដាស, ក្រណាត់ទ្បែន, មាស, និងគ្រឿងអលង្ការជាដើម។ ពួកគេនាំយកត្រឡប់មកវិញនូវឈើកម្រ, ស្បែកសត្វ, និងសត្វរស់។

មេដឹកនាំ និងបព្វជិត៖ ដូចដែលសង្គមអេហ្ស៊ីបរីកធំ ដូច្នេះវាត្រូវការការរៀបចំសណ្តាប់ធ្នាប់។ ប្រជាជនអេហ្ស៊ីបបានបង្កើតរដ្ឋាភិបាលមួយដែលបានបែងចែកចក្រភពជា 42 ខេត្ត។ មន្ត្រីជាច្រើនបានធ្វើការងារដើម្បីធ្វើឱ្យខេត្តរបស់ពួកគេដំណើរការរលូន។ អេហ្ស៊ីបក៏បានបង្កើតកងទ័ពដើម្បីការងារខ្លួនផងដែរ។ ការងារដែលមានតំណែងខ្ពស់ជាងគេនៅអេហ្ស៊ីបគឺបព្វជិក។ បព្វជិតប្រារព្ធក្បួនពិធីទូទៅ និងមើលថែទាំប្រាសាទ។ មុនពេលចូលទៅកាន់ប្រាសាទបព្វជិតម្នាក់ត្រូវលាងជម្រះកាយ និងស្លៀកសំលៀកបំពាក់ធ្វើពីទ្បែន និងពាក់ស្បែកជើងពណ៌ស។ បព្វជិតសំអាតបដិមាស័ក្តសិទ្ធនៅក្នុងប្រាសាទ ផ្លាស់ប្តូរសំលៀកបំពាក់ និងរៀបចំចំណីអាហារដល់បដិមាទាំងនោះ។

ទាំងបព្វជិត និងមេដឹកនាំប្រារព្ធពិធីដើម្បីផ្គាប់ចិត្តដល់អាទិទេព។ ប្រជាជនអេហ្ស៊ីបជឿជាក់ថា ប្រសិនបើអាទិទេពខឹងសម្បា ទន្លេនីលនឹងមិនជន់លិចឡើយ។ ជាលទ្ធផល ដំណាំនឹងមិនអាចដាំដុះបាន ហើយប្រជាជនទាំងអស់នឹងស្លាប់។ ដូច្នេះមេដឹកនាំ និងបព្វជិតបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការធ្វើយ៉ាងណាឱ្យអាទិទេពពេញចិត្តជាមួយពួកគេ។ តាមរយៈការធ្វើដូច្នេះ ពួកគេសង្ឃឹមថាអាចរក្សាសណ្តាប់ធ្នាប់សង្គម និងនយោបាយផងដែរ។

ទាសករ៖ ទាសករស្ថិតនៅក្នុងចំណោមវណ្ណៈក្រោមគេនៅក្នុងសង្គម។ នៅក្នុងប្រទេសអេហ្ស៊ីប ទាសករភាគច្រើនគឺជាឈ្លើយសឹក។ មួយចំនួនគឺជាទាហានដែលគេចាប់បាន និងមួយចំនួនទៀតគឺជាប្រជាជនដែលមិនមានសំណាងស្ថិតនៅភាគីខាងចាញ់សង្គ្រាម។ ភាគច្រើននៃមនុស្សដែលគេចាប់មកធ្វើទាសករទាំងនេះ ធ្វើការនៅក្នុងគំរោងសំណង់សាធារណៈ ដែលមានដូចជាការសាងសងប្រាសាទពីរ៉ាមីតជាដើម។ ដោយសារតែការងារសាងសង់ប្រាសាទនេះមានលក្ខណៈលំបាក ទាសករភាគច្រើនចូលចិត្តធ្វើការងារនៅកន្លែងជីករ៉ែ និងគាស់ថ្មនៅតំបន់វាលខ្សាច់ភាគខាងកើត និងនៅតំបន់ស៊ីណៃជាង។ បញ្ហាលំបាកសម្រាប់ទាសករនៅតំបន់ជីករ៉ែ និងគាស់ថ្មទាំងនេះជាទូទៅគឺ ពួកទាសករភាគច្រើនមិនដែលបានធ្វើដំណើរត្រឡប់មកផ្ទះវិញទេ។ កង្វះខាតទាសករដើម្បីធ្វើការងារបង្កការលំបាកកាន់តែខ្លាំងឡើងៗ។ ដោយហេតុនេះ នៅពេលដែលស្តេចផារ៉ូសរ៉ាមសេសទី 2 ត្រូវការកម្លាំងពលកម្មសម្រាប់គម្រោងស្ថាបនាសំណង់ដ៏ធំមួយរបស់ទ្រង់ ទ្រង់បានបញ្ជូនទាហានទៅកាន់តំបន់វាលខ្សាច់ភាគខាងលិចដើម្បីចាប់ពួកលីប៊ី។ (អ្នកនឹងអានលម្អិតអំពីស្តេចរ៉ាមសេសនៅក្នុងមេរៀនបន្ទាប់)

ទាសករដែលត្រូវបានយកមកធ្វើជាអ្នកបម្រើនៅតាមផ្ទះ គឺជាអ្នកសំណាងបើប្រៀបធៀបជាមួយទាសករផ្សេងៗទៀត។ ពួកគេធ្វើការនៅក្នុងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់តិចតួច រស់នៅក្នុងផ្ទះដែលមានផាសុខភាព និងបរិភោគចំណីអាចបានច្រើន និងមានលក្ខណៈល្អប្រសើរ។ ពួកគេក៏អាចត្រូវបានចាត់ទុកថាជាមនុស្សដែលមានតួនាទីសំខាន់នៅក្នុងផ្ទះផងដែរ។

ស្ត្រី និងកុមារ៖ អេហ្ស៊ីគឺជាទីកន្លែងដែលល្អប្រសើរបំផុតនៅសម័យបុរាណសម្រាប់ស្ត្រី។ ខុសពីវប្បធម៌របស់ប្រទេសអាហ្វ្រិកផ្សេងៗទៀត នៅក្នុងសង្គមអេហ្ស៊ីបស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា។ ឧទាហរណ៍ ទាំងបុរស និងស្ត្រីអាចកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិបានដូចគ្នា។ ការងារចំបងរបស់ស្ត្រីភាគច្រើនគឺមើលថែទាំងកូន និងផ្ទះសំបែងរបស់ពួកគេ ប៉ុន្តែស្ត្រីមួយចំនួនក៏ធ្វើការងារផ្សេងៗទៀតផងដែរ។ ស្ត្រីមួយចំនួនត្បាញសម្លៀកបំពាក់។ ស្ត្រីមួយចំនួនធ្វើការជាមួយស្វាមីរបស់ពួកគេនៅស្រែចំការ និងកន្លែងការងារផ្សេងៗទៀត។

កុមារនៅអេហ្ស៊ីបលេងសម្ភារៈកុមារដូចជា កូនតុក្កតា រូបសត្វ អុក/រ៉េក និងកូនឃ្លីជាដើម។ ឪពុកម្តាយរបស់ពួកគេធ្វើសម្ភារៈលេងទាំងនេះពីឈើ ឬដីឥដ្ឋ។ កុមារប្រុស និងស្រីក៏លេងល្បែងកីឡាជាមួយនឹងបាល់ដែលធ្វើឡើងពីស្បែក ឬដើមត្បែង។ កុមារប្រុស និងស្រីមួយចំនួនដែលមកពីគ្រួសារមានទ្រព្យសម្បត្តិស្តុកស្តម្ភ ទៅសាលារៀនដែលបើកដំណើរការដោយអ្នកសរសេរ ឬបព្វជិក។ ភាគច្រើននៃកុមារសិក្សារៀនសូត្រពីការងាររបស់ឪពុកម្តាយពួកគេ។ ស្ទើតែទាំងស្រុងនៃប្រជាជនអេហ្ស៊ីបរៀបអាពាហ៍ពិពាហ៍នៅពេលដែលពួកគេស្ថិតនៅយុវវ័យ។

សត្វចិញ្ចឹម៖ ប្រជាជនអេហ្ស៊ីបចិញ្ចឹមសត្វច្រើនប្រភេទផ្សេងៗគ្នា។ សត្វឆ្កែត្រូវបានគេចិញ្ចឹមដើម្បីធ្វើដំណើរទៅបរបាញ់ ដូចដែលពេលខ្លះវាបានបន្តធ្វើមកដល់បច្ចុប្បន្ន។ ក៏មានផងដែរនូវការបង្កាត់ពូជឆ្កែ (ខ្លួនវែងជើងខ្លី) ដែលពេញនិយមនៅអេហ្ស៊ីប។ ប៉ុន្តែ ឆ្មាគឺជាសត្វចិញ្ចឹមដែលពេញនិយមបំផុតនៅអេហ្ស៊ីប។ ក៏មានផងដែរនូវអាទិទេពឆ្មាបាស្តេត។ ពាក្យរបស់អេហ្ស៊ីបហៅឆ្មាថាមីវដែលហៅតាមសំលេងឆ្មាស្រែក។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពន្យល់អំពីតួនាទីរបស់មនុស្សតាមកម្រិតវណ្ណៈផ្សេងៗគ្នានៅក្នុងសង្គមអេហ្ស៊ីបបុរាណ។

## 2. ការពង្រីកចំណេះដឹង

សំណួរគន្លឹះ៖ តើការសិក្សារៀនសូត្រនៅអេហ្ស៊ីបបុរាណរីកចម្រើនដោយរបៀបណា?

ក៏ដូចជាសង្គមផ្សេងៗទៀតនាសម័យបុរាណ ចំណេះដឹងភាគច្រើននៅអេហ្ស៊ីបបានមកពីការសិក្សារៀនសូត្ររបស់បព្វជិតពីពិភពលោកដើម្បីស្វែងរកវិធីនានាផ្គាប់ចិត្តអាទិទេព។ ការអភិវឌ្ឍផ្សេងទៀតបានមកពីការអនុវត្តការស្រាវជ្រាវរុករក។

សំណេរ៖ ចាប់ផ្តើមដំបូងនៅអំឡុងឆ្នាំ 3000 មុនគ.ស ពួកអេហ្ស៊ីបបានអភិវឌ្ឍប្រព័ន្ធសំណេរមួយដោយប្រើប្រាស់អក្សររូប។ អក្សររូបគឺជារូបភាពដែលតំណាងឱ្យពាក្យ ឬសំលេងផ្សេងគ្នា។ ប្រជាជនអេហ្ស៊ីបដំបូងបានបង្កើតប្រព័ន្ធរូបភាពមួយដែលមានអក្សររូបប្រមាណ 700 រូបភាព។ ក្រោយមកទៀត ប្រព័ន្ធនេះបានរីកចម្រើនរហូតដល់ការបង្កើតបាននិមិត្តសញ្ញាប្រមាណ 6,000 និមិត្តសញ្ញា។ ប្រជាជនអេហ្ស៊ីបក៏បានអភិវឌ្ឍសម្ភារៈម្យ៉ាងដូចក្រដាស់សរសេរដែលគេហៅថាប៉ាពីរ៉ូស ដែលបង្កើតឡើងពីប្រភេទដើមត្រែងម្យ៉ាងមានឈ្មោះថាប៉ាពីរ៉ូស។ ប្រជាជនអេហ្ស៊ីបកាត់ដើមត្រែងជាបន្ទះៗរួចសង្កត់វា ហើយដាក់ហាលវាឱ្យស្ងួតដែលគេអាចមូលវាជារមូលបាន។ រមូលប៉ាពីរ៉ូសមានទម្ងន់ស្រាល និងងាយស្រួលនៅក្នុងការយកតាមខ្លួន។ តាមរយៈការប្រើប្រាស់រមូលនេះ ប្រជាជនអេហ្ស៊ីបជាអ្នកបង្កើតសៀវភៅដំបូងនៅលើពិភពលោក។

គណិតវិទ្យា និងវិទ្យាសាស្ត្រ៖ ប្រជាជនអេហ្ស៊ីបានអភិវឌ្ឍធរណីមាត្រដំបូងគេបំផុត។ ជារៀងរាល់ឆ្នាំទឹកជំនន់ទន្លេនីលបានលុបព្រំប្រទល់ដីរបស់ពួកគេបាត់។ ដើម្បីស្តាបនាព្រំប្រទល់ឡើងវិញ ក្រុមអ្នកពិនិត្យមើលបានវាស់វែងដីដោយប្រើខ្សែដែលគេចងក្ងចពីចន្លោះមួយទៅចន្លោះមួយមានប្រវែងស្មើគ្នា។ ទម្រង់ធរណីមាត្រដូចជាការេ និងត្រីកោណគឺមានលក្ខណៈពិសិដ្ឋសម្រាប់ប្រជាជនអេហ្ស៊ីប។ ស្ថាបត្យករប្រើប្រាស់វាដើម្បីរចនាប្រាសាទ និងរាជបូជនីយស្ថាននានា។ បព្វជិតអេហ្ស៊ីសិក្សាអំពីមេឃដែលជាផ្នែកមួយនៃសាសនារបស់ពួកគេ។ ប្រហែលជា 5,000 ឆ្នាំកន្លងមក ពួកគេគត់សំគាល់ថា ផ្កាយមួយដែលបច្ចុប្បន្នត្រូវបានគេហៅថាស៊ីរូស នឹងលិចឡើងភ្លាមៗបន្ទាប់ពីទឹកទន្លេនីលចាប់ផ្តើមជន់លិច។ ផ្កាយនឹងត្រឡប់ទៅកាន់ទីតាំងដើមវិញក្នុងរយៈពេល 365 ថ្ងៃ។ យោងតាមនេះ ប្រជាជនអេហ្ស៊ីបបានអភិវឌ្ឍប្រតិទិនដំបូងគេបំផុតលើលោក។

ឱសថសាស្ត្រ៖ ពេទ្យនៅអេហ្ស៊ីបតែងតែរៀបចំសាកសពសម្រាប់បញ្ចុះ ដូច្នេះពួកគេដឹងច្បាស់អំពីផ្នែកផ្សេងៗនៃរាងកាយមនុស្ស។ ចំណេះដឹងនេះបានជួយដល់ពួកគេនៅក្នុងការអនុវត្តការវះកាត់ដំបូងបំផុតនៅលើលោក។ ឧទាហរណ៍ រមូលប៉ាពីរ៉ូសមួយបានបង្ហាញពីរបៀបដេរមុខថ្មេរះកាត់ធំៗ។ ជាការគួរឱ្យភ្ញាក់ផ្អើល អត្ថបទផ្សេងទៀតបានប្រាប់ពីរបៀបប្រើប្រាស់ផ្សិតនំប៉័ងពោយលើមុខរបួសទៀតផង។ ផេនីស៊ីលីនគឺជាអង់ទីប៊ីយូតិចដែលត្រូវបានគេប្រើប្រាស់នៅក្នុងឱសថនាពេលបច្ចុប្បន្ន ដែលវាត្រូវបានបង្កើតឡើងដោយផ្សិត។ វេជ្ជបណ្ឌិតអេហ្ស៊ីបក៏ប្រើប្រាស់សំ

បកឈើម៉្យាងដើម្បីកាត់បន្ថយការឈឺចាប់យ៉ាងមានប្រសិទ្ធិភាពផងដែរ។ ការវិភាគបានបង្ហាញថាសំបកឈើនេះមានផ្ទុកនូវសារជាតុម្យ៉ាងស្រដៀងគ្នាទៅនឹងអាស្ពីរីន។

សង្ខេប៖ រាយបញ្ជី និងពន្យល់អំពីភាពរីកចំរើននៃចំណេះដឹងរបស់ពួកអេហ្ស៊ីប។

## 3. ជំនឿ និងសាសនា

សំណួរគន្លឹះ៖ តើជំនឿសាសនាអ្វីដែលប្រជាជនអេហ្ស៊ីគោរពជឿ ?

យើងបានដឹងតាមរយៈការសរសេរ និងតាមរយៈសិល្បៈរបស់ពួកគេថា ជាទូទៅពួកអេហ្ស៊ីបមានទស្សនវិស័យវិជ្ជមានអំពីជីវិតរស់នៅ។ ដីពណ៌ខ្មៅបានផ្តល់ឱ្យពួកគេនូវរាល់តម្រូវការទាំងឡាយ។ ជាលទ្ធផល ពួកគេពុំចាំបាច់តស៊ូពុះពារនៅក្នុងការរស់នៅឡើយ។

ជីវិតរស់នៅបន្ទាប់ពីការស្លាប់៖ ទស្សនៈវិជ្ជមានជាទូទៅរបស់ប្រជាជនអេហ្ស៊ីបបានបង្កើតទម្រង់នៃជំនឿរបស់ពួកគេ ហើយបាននាំពួកគេឱ្យជឿជាក់ថាអាទិទេពបានអនុគ្រោះដល់ពួកគេ។ ប្រជាជនអេហ្ស៊ីបបានជឿជាក់ថា មិនត្រឹមតែស្តេចផារ៉ូស និងពួកអភិជនតែប៉ុណ្ណោះទេដែលគិតអំពីជីវិតរស់នៅបន្ទាប់ពីការស្លាប់។ វាបានក្លាយជាជំនឿទូទៅដែលថា ភាពរុងរឿងរបស់មនុស្សម្នាក់អាចបន្តរស់នៅដោយរីករាយនៅជីវិតបន្ទាប់។ ជីវិតបន្ទាប់គឺជាជីវិតមួយដែលគេជឿថាកើតឡើងបន្ទាប់ពីការស្លាប់។ ពួកអេហ្ស៊ីបមានការយល់ឃើញផ្សេងៗគ្នាអំពីអ្វីដែលនាំឱ្យពួកគេរីករាយនៅជីវិតបន្ទាប់។ ឧទាហរណ៍ ប្រជាកសិករនៅជនបទ រីករាយជាមួយនឹងភាពស្ថិតស្ថេរនៃដីកសិកម្មដែលទទួលបានទិន្នផលល្អ, មិនមានការឈឺចាប់ និងរងរបួស, មនុស្សទាំងឡាយទទួលបានផ្ទៃដីដាំដុះស្មើៗគ្នា។ មិនមែនគ្រប់វប្បធម៌សម័យបុរាណទាំងអស់មានជំនឿដូចពួកអេហ្ស៊ីបឡើយ។ ឧទាហរណ៍ ពួកស៊ូម័របានគិតថាជីវិតបន្ទាប់គឺពិបាក។

អាទិទេពច្រើន៖ ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក 3 ពហុទេពនិយម គឺជាជំនឿលើអាទិទេពច្រើន។ ពួកអេហ្ស៊ីបគោរពអាទិទេពទាំងឡាយដែលជាប់ទាក់ទងទៅនឹងជីវិតបន្ទាប់ និងធម្មជាតិ ដែលមានដូចជាព្រះអាទិត្យ និងទន្លេជាដើម។ អាទិទេពជាច្រើនត្រូវបានគេគោរពបូជាតាមតំបន់សំខាន់ៗមួយចំនួនប៉ុណ្ណោះ។ អាទិទេពអាម៉ូនដំបូងឡើយគឺជាអាទិទេពក្នុងតំបន់-ប្រមុខអាទិទេពនៅតំបន់ថេបេសតែប៉ុណ្ណោះ។ ប៉ុន្តែ ក្រោយមកអាម៉ូនបានក្លាយជាអាទិទេពសំខាន់ នៅពេលដែលគ្រួសារមួយរបស់ពួកថេបេសបានជាប់ខ្សែស្រឡាយជាមួយស្តេចផារ៉ូស។ អាទិទេពសំខាន់ៗផ្សេងទៀតរបស់ពួកៈអេហ្ស៊ីប បង្ហាញនៅតារាងខាងស្តាំ។

ការធ្វើម៉ុមី៖ ប្រជាជនអេហ្ស៊ីបអប់សាសពរបស់មនុស្សស្លាប់មុនពេលដែលពួកគេបញ្ចុះនៅក្នុងផ្នូរ។ អប់សពមានន័យថាគឺជាការរក្សាសាសពរបស់នណារម្នាក់បន្ទាប់ពីស្លាប់។ ដំណើរការនៃការអប់សពមានភាពខុសប្លែកគ្នាពីសម័យកាលមួយទៅសម័យកាលមួយ ប៉ុន្តែការអនុវត្តមួយចំនួនមានលក្ខណៈដូចគ្នា។ ដំបូងអ្នកអប់សពបានវះយកគ្រឿងក្នុងទាំងអស់របស់សពចេញ លើកលែងតែបេះដូង។ ដោយចំឡែក ខួរក្បាលត្រូវបានគេគិតថាមិនមានសារៈសំខាន់ឡើយ។ ខណៈពេលដែលគ្រឿងក្នុងផ្សេងៗត្រូវបានគេរក្សាទុក និងគោរព ខួរក្បាលត្រូវបានគេយក

ចេញ និងបោះចោល។ គ្រឿងក្នុងផ្សេងៗក្រៅពីខួរក្បាល ត្រូវបានគេសម្អាត និងដាក់នៅក្នុងថូផ្សេងៗគ្នា។ ក្រុមអ្នកអប់សពលាង និងសំអាតសាកសពដែលវះយកគ្រឿងក្នុងចេញ។ ក្រោយមកពួកគេញាត់ និងលាបពីលើសាកសពជាមួយណាត្រូនជាសារធាតុធម្មជាតិម្យ៉ាងសម្រាប់សម្ងួត និងសម្លាប់មេរោគ ដែលមានផ្ទុកនូវសារធាតុអំបិលជាច្រើន។ ការសម្ងួតដោយប្រើណាត្រូន បានប្រែក្លាយសាកសពទៅជាមុំាមីមួយ។ មុំាមីគឺជាសាកសពមួយដែលត្រូវបានគេសម្ងួតដូច្នេះវាមិនរលួយទេ។ ដុំក្រណាត់ទ្បេន ឬសូម្បីតែអាចម៍រណាត្រូវបានគេប្រើដើម្បីញាត់ចូលទៅក្នុងរន្ធពោះសាសព។ មុំាមីត្រូវបានគេរុំជាមួយក្រណាត់ទ្បេនរាប់រាយយ៉ាត។ ដំណើរទាំងមូលនៃការអប់សព និងការរុំ ត្រូវចំណាយពេលប្រហែល 70 ថ្ងៃ។ ការអប់សពគឺមានតម្លៃថ្លៃ ហើយមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែមានលទ្ធភាពឡើយ។

ផ្នូររបស់ពួកអេហ្ស៊ីប៖ របៀបនៃការថែទាំសាកសព និងរបស់របរផ្សេងៗដែលដាក់នៅក្នុងផ្នូរបានបង្ហាញថាប្រជាជនអេហ្ស៊ីបមានជំនឿអំពីជីវិតបន្ទាប់ពីការស្លាប់ដែលនឹងបន្តពីជីវិតរបស់នៅជំបូងរបស់ពួកគេ។ នៅក្នុងផ្នូរផ្ទុកទៅដោយឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃដែលមនុស្សទាំងឡាយត្រូវការ ដែលក្នុងនោះមានដូចជាស្បៀងអាហារ, ទឹក, ឧបករណ៍ប្រើប្រាស់, សំលៀកបំពាក់, និងគ្រឿងសង្ហារឹមជាដើម។ សាច់ញាតិរបស់សាកសពតម្រូវឱ្យយកចំណីអាហារថ្មីៗ និងទឹកទៅកាន់ផ្នូររបស់សពជារៀងរាល់ថ្ងៃ។ តាមពិតទៅ គ្រួសារអ្នកមានទ្រព្យស្តុកស្តម្ភមួយចំនួនបានជួលជំនួយការដើម្បីបំពេញភារៈកិច្ចទាំងនេះ។ ពីរ៉ាមីតដែលជាផ្នូររបស់ស្តេចផារ៉ូសបានក្លាយជានិមិត្តរូបនៃអេហ្ស៊ីបបុរាណដ៏ល្បីល្បាញបំផុត។ អ្នកនឹងរៀនអំពីវា និងស្តេចផារ៉ូសដែលជាអ្នកស្ថាបនាផ្នូរទាំងនេះនៅក្នុងមេរៀនទី 3 ។

សង្ខេប៖ សង្ខេបអំពីជំនឿសាសនារបស់ពួកអេហ្ស៊ីប។

# មេរៀនទី 3 ៖ អ្នកស្ថាបនាប្រាសាទពីរ៉ាមីត

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកបានអានមេរៀនដែលទាក់ទងទៅនឹងទន្លេនីលលើ និងទន្លេនីលក្រោម។ នៅទីនោះមានព្រះរាជាណាចក្រពីរ ដែលគេហៅថា អេហ្ស៊ីបលើ និងអេហ្ស៊ីបក្រោម។ ព្រះរាជាណាចក្រទាំងពីរនេះបានបង្រួបបង្រួមគ្នាក្លាយជាចក្រភពដ៏ខ្លាំងក្លាមួយ។

## 1. ព្រះរាជាណាចក្រចាស់

សំណួរគន្លឹះ៖ តើរដ្ឋាភិបាលប្រភេទអ្វីដែលគ្រប់គ្រងនៅអេហ្ស៊ីបបន្ទាប់ពីវាត្រូវបានបង្រួបបង្រួម?

រឿងព្រេងបានមួយនិយាយថា ព្រះមហាក្សត្រមួយអង្គព្រះនាមណាមើបានបង្រួបបង្រួមអេហ្ស៊ីបលើ និងអេហ្ស៊ីបក្រោម។ ប្រវត្តិវិទូមួយចំនួនបានគិតថាណាមើមែនទែនទៅតំណាងឱ្យស្តេចជាច្រើនដែលបានចូលរួមនៅក្នុងបង្រួបបង្រួមទឹកដីទាំងពីរនេះ។ ការរួបបញ្ចូលគ្នារវាងអេហ្ស៊ីបលើ និងអេហ្ស៊ីបក្រោមបានកើតឡើងនៅអំឡុងឆ្នាំប្រហែល 3100 មុនគ.ស។ ប្រវត្តិវិទូនានាបានបែងចែកប្រវត្តិសាស្ត្រអេហ្ស៊ីបសម័យបុរាណជា 3 សម័យកាលគឺ ព្រះរាជាណាចក្រចាស់, ព្រះរាជាណាចក្រកណ្តាល, និងព្រះរាជាណាចក្រថ្មី។ នៅអំឡុងសម័យព្រះរាជាណាចក្រចាស់ ដែលចាប់ផ្តើមឡើងនៅអំឡុងឆ្នាំ 2575 មុនគ.ស ប្រាសាទពីរ៉ាមីតដែលមនុស្សជាច្រើនបានភ្ជាប់វាជាមួយអេហ្ស៊ីប ត្រូវបានស្ថាបនាឡើង។

សន្តតិវង្សដំបូង៖ សន្តតិវង្សដំបូងរបស់ចក្រភពអេហ្ស៊ីបបានចាប់ផ្តើមឡើងនៅពេលដែលប្រទេសនេះបានបង្រួបបង្រួមគ្នា។ សន្តតិវង្សរបស់អេហ្ស៊ីប 3 ដំបូងចាប់ផ្តើមឡើងមុនសម័យព្រះរាជាណាចក្រចាស់។ សន្តតិវង្សគឺជាខ្សែស្រឡាយអ្នកដឹកនាំដែលស្ថិតនៅក្នុងរាជវង្សតែមួយ។ នៅពេលព្រះមហាក្សត្រសុគត រាជបុត្ររបស់ទ្រង់ជាទូទៅឡើងគ្រប់គ្រងតំណែងបន្តពីទ្រង់។ របៀបដែលសមាជិកគ្រួសាររាជវង្សទទួលបានការស្នងតំណែងបន្តពីអតីតព្រះមហាក្សត្រគេហៅថា ការស្នងរាជបល្ល័ង្ក។ មានសន្តតិវង្សច្រើនជាង 30 គ្រប់គ្រងនៅអេហ្ស៊ីបសម័យបុរាណ។

ការដឹកនាំរបស់ស្តេចផារ៉ូស៖ ស្តេចរបស់អេហ្ស៊ីបត្រូវបានគេស្គាល់ថាផារ៉ូស។ ផារ៉ូសមានន័យថា "ផ្ទះធំ" ហើយដំបូងឡើយវាត្រូវបានគេប្រើដើម្បីបរិយាយអំពីរាជវាំងរបស់ព្រះមហាក្សត្រ។ ហើយក្រោយមកវាបានក្លាយជាឋានន្តរនាមរបស់ព្រះមហាក្សត្រតែម្តង។ ស្តេចផារ៉ូសដឹកនាំដឹកនាំនៅអេហ្ស៊ីប ដែលមានរាជធានីស្ថិតនៅមេមភីស។

ប្រជាជនអេហ្ស៊ីបបុរាណគិតថាស្តេចផារ៉ូសគឺជារាជបុត្ររបស់អាទិទេព ហើយពួកគេចាត់ទុកទ្រង់ថាជាអាទិទេពរបស់ពួកគេ។ ប្រជាជនអេហ្ស៊ីបជឿថា ប្រសិនបើស្តេចផារ៉ូស និងប្រជានុរាស្ត្ររបស់ទ្រង់គោរពដល់អាទិទេព ជីវិតរស់នៅរបស់ពួកគេនឹងរីករាយ។ ប្រសិនបើប្រទេសអេហ្ស៊ីបជួបរងទុក្ខគ្រោះលំបាកអស់រយៈដ៏វែងមួយ ប្រជាជននឹងបន្ទោសស្តេចផារ៉ូសដែលជាអ្នកធ្វើឱ្យអាទិទេពខឹងសម្បា។ នៅក្នុងករណីមួយចំនួន គូរប្រជែងរបស់ស្តេចផារ៉ូសអាចនឹងបណ្តេញទ្រង់ចេញពីអំណាច ហើយចាប់ផ្តើមសន្តតិវង្សមួយថ្មីទៀត។ ដោយសារតែស្តេចផារ៉ូសត្រូវបានគេចាត់ទុកថាជាអាទិទេពមួយអង្គ នៅប្រទេសអេហ្ស៊ីបសម័យបុរាណ សាសនា និងរដ្ឋាភិបាលមិនត្រូវបានគេញែកចេញពីគ្នាឡើយ។ បព្វជិតមានអំណាចច្រើននៅក្នុងជួររដ្ឋាភិបាល។ មន្ត្រីជាន់ខ្ពស់ជាច្រើនគឺជាពួកបព្វជិត។

វាយតម្លៃ៖ ពន្យល់ពីប្រភេទនៃរដ្ឋាភិបាលអេហ្ស៊ីបបន្ទាប់ពីវាត្រូវបានបង្រួបបង្រួម។

## 2. ប្រាសាទពីរ៉ាមីតធំរបស់ស្តេចឃូហ្វូ

សំណួរគន្លឹះ៖ តើស្តេចផារ៉ូសឃូហ្វូបង្ហាញពីភាពរុងរឿងរបស់ទ្រង់ដោយរបៀបណា?

មេដឹកនាំដំបូងៗរបស់អេហ្ស៊ីបជាទូទៅតែងតែត្រូវបានគេបញ្ចុះសពនៅក្នុងផ្នូរក្រោមដី ដែលគ្របពីលើដោយដុំឥដ្ឋ។ បន្ទាប់មកស្តេចមានគំនិតចង់បង្កើតឱ្យមានបូជនីយស្ថានអចិន្ត្រៃនានា។ ពួកគេបានស្ថាបនាប្រាសាទពីរ៉ាមីតតូចៗជំនួសដុំឥដ្ឋវិញ ដែលប្រាសាទនេះអាចសាងសងពីដីឥដ្ឋ ឬថ្ម។ ពីរ៉ាមីតគឺជាទម្រង់នៃទ្រង់ទ្រាយមួយដែលស្រដៀងគ្នាទៅនឹងត្រីកោណ ដែលជ្រុងទាំង 4 ជួបប្រជុំគ្នានៅចំណុចតែមួយ។ ប្រហែលឆ្នាំ 2630 មុនគ.ស ស្តេចចូស័របានស្ថាបនាប្រាសាទពីរ៉ាមីតដ៏ធំមួយនៅពីលើផ្នូររបស់ទ្រង់។ វាត្រូវបានគេហៅថា ប្រាសាទពីរ៉ាមីតថ្នាក់ៗដោយសារនៅចុងជ្រុងរបស់វាត្រូវបានស្ថាបនាជាថ្នាក់ៗទៅលើ។ វាគឺជាសំណង់ប្រាសាទដែលធ្វើពីថ្មចាស់ និងធំជាងគេនៅលើពិភពលោក។

ប្រាសាទពីរ៉ាមីតធំ៖ បន្ទាប់ពីការស្ថាបនាប្រាសាទពីរ៉ាមីតថ្នាក់ៗរបស់ស្តេចចូស័រ 80 ឆ្នាំក្រោយមក ស្តេចផារ៉ូសមួយអង្គព្រះនាមឃូហ្វូ បានសម្រេចចិត្តថាទ្រង់ចង់បានបូជនីយស្ថានមួយ ដែលអាចបង្ហាញពិភពលោកអំពីភាពអស្ចារ្យរបស់ទ្រង់។ ទ្រង់បានបញ្ជារឱ្យគេស្ថាបនាប្រាសាទពីរ៉ាមីតដ៏ធំមួយដែលមិនធ្លាប់ត្រូវបានស្ថាបនាកន្លងមកទេ។ តាមជ្រុងនីមួយៗមានប្រវែងប្រមាណ 760 ហ្វីត។ ប្រាសាទនេះត្រូវបានស្ថាបនាឡើងដោយប្រើថ្មចំនួន 2.3 លានដុំ។ ការស្ថាបនាប្រាសាទពីរ៉ាមីតធំគឺជាកិច្ចការងារដ៏លំបាក។ ក្រុមអ្នកជីកថ្ម បានកាត់ថ្មជាដុំធំៗ ដោយប្រើរណាទង់ដែង និងពន្លាក។ ឧបករណ៍ប្រើប្រាស់ទាំងនេះ មានលក្ខណៈទន់ជាងឧបករណ៍ធ្វើពីដែក (ដែលគេបង្កើតក្រោយមកទៀត) ឆ្ងាយណាស់ ដូច្នេះការងារមានលក្ខណៈយឺតយ៉ាវ និងលំបាក។ ក្រុមកម្មករផ្សេងៗទៀតទាញដុំថ្មឡើងតាមជម្រាលទៅកាន់ទីតាំងដែលដុំថ្មនីមួយៗត្រូវប្រើដើម្បីស្ថាបនាប្រាសាទ។ កម្មករទាញដុំថ្មធំៗឡើងទៅលើរាប់រយហ្វីត ហើយបន្ទាប់មកដាក់វាទៅតាមកន្លែងរបស់វា។

នៅអំឡុងរដូវដែលទឹកទន្លេនីលជន់លិច ប្រជាកសិករតម្រូវឱ្យអូសថ្មយកទៅធ្វើប្រាសាទ ដែលការងារនេះជាការងារដ៏លំបាកមួយ។ អ្នកជំនាញកាត់ថ្ម និងអ្នកមើលការខុសត្រូវធ្វើការរាប់សិបឆ្នាំនៅទីនោះ។ ប្រាសាទពីរ៉ាមីតធំត្រូវចំណាយពេលប្រមាណជិត 20 ឆ្នាំដើម្បីសាងសងរួច។ ក្នុងការប៉ាន់ប្រមាណមានកម្មករអេហ្ស៊ីបប្រមាណ 2 ម៉ឺននាក់ចូលរួមនៅក្នុងការស្ថាបនាប្រាសាទនេះ។ ទីក្រុងមួយឈ្មោះថាហ្គីហ្សាត្រូវបានស្ថាបនាឡើងសម្រាប់កម្មករ និងប្រជាជនដែលរៀបចំចំណីអាហារ, សំលៀកបំពាក់ និងផ្ទះសម្រាប់កម្មករទាំងនោះ។

ចោរលួចគាស់ផ្នូរ៖ ជាយថាហេតុប្រជាជនអេហ្ស៊ីបបានបញ្ឈប់ការស្ថាបនាប្រាសាទពីរ៉ាមីត។ មូលហេតុមួយដែលសំខាន់គឺថា ប្រាសាទពីរ៉ាមីតនានាបាននាំដល់ការចាប់អារម្មណ៍ទៅនឹងផ្នូរនៅក្នុងប្រាសាទនោះ។ ពួកចោរបានលួចគាស់ចូលទៅក្នុងផ្នូរទាំងនោះ ដើម្បីលួចទ្រព្យសម្បត្តិមានតម្លៃនានាដែលគេដាក់កប់ជាមួយស្តេចផារ៉ូស។ ពេលខ្លះពួកគេក៏លួចមាំមីផងដែរ។ ប្រជាជនអេហ្ស៊ីបជឿថា ប្រសិនបើផ្នូរត្រូវបានគេលួចគាស់ មនុស្សដែលគេកប់នៅក្នុងផ្នូរនោះមិនអាចសប្បាយរីករាយនៅជីវិតបន្ទាប់ឡើយ។ អំឡុងនៃសម័យព្រះរាជាណាចក្រថ្មី ស្តេច

ផារ៉ូសបានចាប់ផ្តើមស្ថាបនាផ្នូរសម្ងាត់នៅក្នុងតំបន់មួយដែលគេហៅថា ច្រលងនៃស្តេច។ បន្ទាប់បញ្ចុះសាកសព ត្រូវបានគេលាក់បំបាំងនៅក្នុងរូងភ្នំនានានៅជិតទន្លេនីល។ នៅក្នុងវិធីនេះ ស្តេចផារ៉ូសសង្ឃឹមនៅក្នុងការការពារ សាកសព និងទ្រព្យសម្បត្តិមានតម្លៃនានារបស់ទ្រង់ពីក្រុមចោរ។

បើទោះបីជាស្តេចផារ៉ូសព្យាយាមនៅក្នុងការលាក់បាំងសាកសពយ៉ាងណាក៏ដោយ ក្រុមចោរនៅតែលួចគាស់យកទ្រព្យសម្បត្តិស្ទើរតែគ្រប់ផ្នូរទាំងអស់។ មានតែផ្នូររបស់ស្តេចផារ៉ូសមួយគត់ដែលស្ថិតនៅក្នុងសម័យព្រះរាជាណាចក្រថ្មីដែលមានគេចផុតពីក្រុមចោរលួចគាស់ផ្នូរ គឺផ្នូររបស់ស្តេចផារ៉ូសទូតានខាមេន។ ផ្នូរនេះត្រូវបានគេស្រាវជ្រាវរុករកឃើញនៅក្នុងឆ្នាំ 1922 ។ ទ្រព្យសម្បត្តិដ៏ចម្លែកចញ្ចាំងត្រូវបានគេរកឃើញនៅក្នុងផ្នូរ ដែលបានបង្ហាញពីចំនួនទ្រព្យសម្បត្តិដែលស្តេចផារ៉ូសបានត្រៀមសម្រាប់ជីវិតបន្ទាប់របស់ទ្រង់។

សង្ខេប៖ ពន្យល់ពីរបៀបដែលស្តេចផារ៉ូសឃូហ្វូបង្ហាញពីភាពរុងរឿងរបស់ទ្រង់។

### 3. ព្រះរាជាណាចក្រកណ្តាល

សំណួរគន្លឹះ៖ តើស្តេចផារ៉ូសអាមេនេមហេតទី 1 ធ្វើអ្វីខ្លះដើម្បីពង្រីកអំណាចគ្រប់គ្រងរបស់ទ្រង់ ?

ត្រឹមឆ្នាំប្រមាណ 2160 មុនគ.សអំណាចកណ្តាលរបស់ស្តេចផារ៉ូសចាប់ផ្តើមបែកខ្ញែក។ ភាពបាក់បែក, សង្គ្រាមស៊ីវិល, និងការឈ្លានពានបានញាំញីអេហ្ស៊ីបអស់ប្រមាណជាង 100 ឆ្នាំ។ ការឡើងគ្រប់គ្រងអំណាចរបស់ស្តេចផារ៉ូសមេនទូហូទេពទី 2 នៅក្នុងឆ្នាំ 2055 មុនគ.សបាននាំមកនូវស្ថេរភាពខ្លះៗ។ សម័យកាលដែលបន្តពីនេះត្រូវបានគេហៅថាសម័យព្រះរាជាណាចក្រកណ្តាល។

ភ្ជាប់ទៅនឹងប្រពៃណី៖ បើទោះបីជាស្តេចផារ៉ូសមេនទូហូទេពទី 2 អាចបង្រួបបង្រួមអេហ្ស៊ីបក៏ដោយ ក៏ចំណុចនៃភាពលេចធ្លោរបស់ព្រះរាជាណាចក្រកណ្តាលចាប់ផ្តើមឡើង 70 ឆ្នាំក្រោយមកទៀត។ ស្តេចផារ៉ូសអាមេនេមហេត 1 បានបង្កើតសន្តតិវង្សទី 12 នៅក្នុងឆ្នាំ 1985 មុនគ.ស។ ទ្រង់មិនមែនជាសមាជិកនៃគ្រួសាររាជវង្សទេ ដូច្នេះការឡើងគ្រប់គ្រងរាជ្យបល្ល័ង្ករបស់ទ្រង់បង្កឱ្យមានអស្ថេរភាព។ អាមេនេមហេតទី 1 អះអាងអំពីការព្យាករណ៍ពីសម័យបុរាណមួយគាំទ្រដល់ការឡើងគ្រងរាជ្យរបស់ទ្រង់។ ទ្រង់បានផ្សព្វផ្សាយអំពីការព្យាករណ៍របស់នេហ្វីទី ដែលសរសេរឡើងនៃអំឡុងរាជ្យរបស់ផារ៉ូសស្នេហ្វ្រូដែលជាស្តេចផារ៉ូសដែលគេគោរពខ្លាំងបំផុតនៅក្នុងសន្តតិវង្សទី 4 ។ ការព្យាករណ៍បានដឹងជាមុនថានឹងមានស្តេចផារ៉ូសមួយអង្គព្រះនាមអាមេនី ដែលនឹងជួយសង្គ្រោះអេហ្ស៊ីបពីភាពចលាចល។ តាមការពិតអាមេនេមហេតទី 1 បានសរសេររឿងនេះដោយខ្លួនទ្រង់ផ្ទាល់ដើម្បីភ្ជាប់ខ្លួនទ្រង់ទៅនឹងស្នេហ្វ្រូ ហើយចង់បង្ហាញថាការឡើងស្នងរាជ្យរបស់ទ្រង់គឺជារឿងត្រឹមត្រូវ។ ទ្រង់ដឹកនាំអេហ្ស៊ីប 29 ឆ្នាំ ហើយសន្តតិវង្សទី 12 គ្រប់គ្រងអេហ្ស៊ីបប្រមាណជាង 200 ឆ្នាំ។

ភាពខ្លាំងក្លា និងរុងរឿង៖ ស្តេចផារ៉ូសនានានៅក្នុងសន្តតិវង្សទី 12 បានប្រើប្រាស់កងទ័ពរបស់ទ្រង់ដើម្បីពង្រីកដែនដីរបស់អេហ្ស៊ីបទៅភាគខាងត្បូង។ ពួកគេចង់គ្រប់គ្រងធនធាននៅនូប៊ី ជាពិសេសគឺមាសនៅទីនោះ។ ពង្រីកទឹកដីឆ្ពោះទៅកាន់ភាគខាងត្បូង ស្តេចផារ៉ូសបានត្រួតត្រារហូតដល់ល្បាក់ទី 2 ត្រឹមឆ្នាំ 1800 មុនគ.ស។

បន្ទាប់ពីទទួលបានជ័យជំនះលើការដណ្តើមកាន់កាប់ បន្ទាយត្រូវបានគេស្ថាបនាឡើងដើម្បីរក្សាការត្រួតត្រាលើទឹកដីថ្មី នឹងជួយសម្រួលដល់ការនាំយកមាសមកកាន់រតនាគារបស់អេហ្ស៊ីប។ កសិកម្មបានកើនឡើងយ៉ាងខ្លាំងនៅក្នុងសម័យព្រះរាជាណាចក្រកណ្តាល។ ភាគខាងត្បូង និងខាងលិចសាការ៉ា គឺជាតំបន់វាភក់ដែលជាទូទៅតំបន់នេះគេស្គាល់ថាហ្វៃយូ។ ស្តេចផារ៉ូសនានាបានធ្វើការងារដើម្បីសម្ងួតតំបន់វាលភក់នេះ ដើម្បីប្រែក្លាយវាទៅជាតំបន់ដែលអាចដាំដុះបាន។ ពួកគេសម្ងួតតំបន់នេះដោយជីកប្រឡាយ និងធ្វើទំនាប់ដើម្បីប្តូរទិសទឹកដែលនឹងហូរមកប្រមូលផ្តុំគ្នានៅទីនេះ។ គម្រោងនេះបានបង្កើនផ្ទៃដីដាំដុះបានប្រមាណ 15 ម៉ឺនអេក្រ៍។ ការកើនឡើងនៃការផលិតស្បៀងអាហារនាំឱ្យអេហ្ស៊ីបកាន់តែខ្លាំងក្លាថែមទៀត។ ជាទូទៅ នៅអំឡុងនៃការគ្រប់គ្រងរបស់សន្តតិវង្សទី 12 នាសម័យព្រះរាជជាណាចក្រកណ្តាលប្រទេសអេហ្ស៊ីបបានរីកចម្រើនជឿនលឿនយ៉ាងខ្លាំង។ សិល្បៈ(ជាពិសេសអក្សរសិល្ប៍) បានរីកចម្រើន, ពាណិជ្ជកម្មបានពង្រីកនៅពាសពេញតំបន់មេឌីទែរ៉ានេ និងភាគខាងកើតឆ្ពោះទៅអាស៊ី, និងការឡើងស្នងរាជ្យរបស់ស្តេចផារ៉ូសមានស្ថេរភាព និងតាមលំដាប់។

ការធ្លាក់ចុះ និងការផ្តួលរំលំ៖ ការដឹកនាំរបស់សន្តតិវង្សទី 13 មានភាពអន់ខ្សោយជាខ្លាំង។ អំឡុងនៃសម័យកាលនេះ ប្រជាជនមកពីតំបន់ភាគខាងកើតនៃឧបទ្វីបស៊ីណៃ ដែលនៅក្នុងភាសាអេហ្ស៊ីបហៅថា "អាស៊ីតិច" (ប្រជាជនមកពីអាស៊ី) បានចាប់ផ្តើមធ្វើអន្តោប្រវេសន៍មកកាន់ភាគខាងកើតនៃតំបន់ដីសណ្តទន្លេនីល។ ចុងក្រោយក្រុមមួយដែលប្រជាជនហៅថាហ៊ីកសូសបានឈ្លានពានអេហ្ស៊ីបពីតំបន់ប៉ាឡេស្ទីន និងស៊ីរី។ ពួកគេបានដណ្តើមកាន់កាប់មួយភាគធំនៃទឹកដីអេហ្ស៊ីបក្រោមត្រឹមឆ្នាំ 1630 មុនគ.ស ដោយសារតែពួកគេមានអាវុធទំនើប និងរទេះសេះ ដែលមិនធ្លាប់មាននៅក្នុងប្រទេសអេហ្ស៊ីប។ បន្ទាប់ពីការឈ្លានពានប្រមាណ 100 ឆ្នាំ ពួកអេហ្ស៊ីបបានបណ្តេញពួកហ៊ីកសូសចេញ និងចាប់ផ្តើមសម័យព្រះរាជាណាចក្រថ្មី។ អ្នកនឹងសិក្សាអំពីសម័យកាលនេះនៅក្នុងមេរៀនបន្ទាប់។

កំណត់អំពីបញ្ហា៖ ពន្យល់អំពីមធ្យោបាយដែលស្តេចផារ៉ូសអាមេនេមហេតទី 1 ពង្រឹងអំណាចរបស់ទ្រង់។

# មេរៀនទី 4 ៖ ព្រះរាជាណាចក្រថ្មី និងព្រះរាជាណាចក្រចុងក្រោយ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានអានមេរៀនមុន ស្ដេចផារ៉ូសមានអំណាចមួយចំនួនចូលចិត្តស្ថាបនាបូជនីយស្ថានធំៗ។ សម័យព្រះរាជាណាចក្រថ្មីមានស្ដេចផារ៉ូសមានអំណាចមួយចំនួន ដែលទ្រង់នៅបន្តលំនាំបែបនេះដដែល។

## 1. ផារ៉ូសស្រី

សំណួរគន្លឹះ៖ អ្វីទៅជាចំណុចសំខាន់នៃការគ្រប់គ្រងរបស់ម្ចាស់ក្សត្រីហាតសេពស៊ូត?

សម័យព្រះរាជាណាចក្រកណ្ដាល រួមមានមេដឹកនាំមានអំណាចមួយចំនួនរបស់អេហ្ស៊ីប។ ស្ដេចផារ៉ូសទាំងនេះបានបង្កើតរាជធានីថ្មីមួយនៅថេបេសចម្ងាយ 450 ម៉ាយភាគខាងត្បូងរាជធានីចាស់នៅមេមភីស។ ពួកគេពង្រឹងអំណាចរបស់អេហ្ស៊ីបដោយធ្វើការពង្រីកទឹកដីចក្រភព។

ការឡើងគ្រប់គ្រងអំណាច៖ ម្ចាស់ក្សត្រីហាតសេពស៊ូត គឺជាស្ត្រីដំបូងដែលទទួលតំណែងជាស្ដេចផារ៉ូសនៅអេហ្ស៊ីប។ ទ្រង់គឺជាមហេសីរបស់ស្ដេចផារ៉ូសដែលបានសោយទីវង្គត់បន្ទាប់ពីបានឡើងគ្រងរាជ្យមួយរយៈពេលខ្លីមក។ បន្ទាប់មកម្ចាស់ក្សត្រីហាតសេពស៊ូត និងរាជបុត្រធម៌របស់ទ្រង់ព្រះនាមធូតម៉ូសេទី 3 បានដឹកនាំអេហ្ស៊ីបបន្ត។ នៅក្នុងឆ្នាំ 1472 មុនគ.ស ទ្រង់បានប្រកាសថាទ្រង់តែមួយអង្គគត់ដែលជាមេដឹកនាំនៅអេហ្ស៊ីប។ ទ្រង់ពាក់ពុកចង្កាក្លែងក្លាយមួយដែលគេរក្សាទុកសម្រាប់តែស្ដេចផារ៉ូសប៉ុណ្ណោះ។

ការរីកចម្រើននៃពាណិជ្ជកម្ម៖ ស្ដេចផារ៉ូសភាគច្រើននៅក្នុងសម័យព្រះរាជាណាចក្រកណ្ដាលពង្រីកដែនដីអេហ្ស៊ីបតាមរយៈការធ្វើសង្គ្រាម។ ស្ដេចផារ៉ូសប្រើប្រាស់វិធីសាស្ត្រផ្សេងទៀតដើម្បីពង្រីកឥទ្ធិពលរបស់អេហ្ស៊ីប។ ទ្រង់ចង់ធ្វើឱ្យប្រទេសអេហ្ស៊ីបក្លាយជាប្រទេសអ្នកមានតាមរយៈការធ្វើពាណិជ្ជកម្ម។ ការពង្រីកការធ្វើពាណិជ្ជកម្មដ៏ធំរបស់ទ្រង់ចាប់ពីតំបន់វាលខ្សាច់ភាគខាងកើតដល់សមុទ្រក្រហម។ នាវាធំៗបានធ្វើដំណើរទៅភាគខាងត្បូងឆ្ពោះទៅកាន់តំបន់អាហ្វ្រិកមួយដែលគេហៅថាប៉ុន។ ពួកពាណិជ្ជករបាននាំយកត្រឡប់មកវិញជាមួយពួកគេនូវស្លឹករុក្ខជាតិកម្រ, គ្រឿងទេស, ឈើក្រអូប, សត្វស្វា, និងដើមឈើម្យ៉ាងសម្រាប់ធ្វើធូប។

កេរ្តិ៍តំណែលរបស់ ហាតសេពស៊ូត៖ ក៏ដូចជាផារ៉ូសផ្សេងៗទៀតដែរ ហាតសេពស៊ូត ស្រេកឃ្លាននៅក្នុងការបង្ហាញពីភាពរុងរឿងរបស់ទ្រង់។ បូជនីយស្ថានមួយប្រភេទដែលទ្រង់បានបង្កើតឡើងគឺសសរអូបេលីស។ សសរអូបេលីសគឺជាសសរបួនជ្រុងមួយដែលមានទម្រង់រាងពីរ៉ាមីតនៅខាងលើ។ ម្ចាស់ក្សត្រីហាតសេពស៊ូតមានសសរអូបេលីសខ្ពស់ៗដែលបានដាប់ចេញមកពីផ្ទាំងសិលាក្រានិតពណ៌ក្រហម។ នៅលើសសរអូបេលីសវិចិត្រករបានសរសេរអក្សររូបដើម្បីកត់ត្រាអំពីស្នាដៃដ៏អស្ចារ្យរបស់ទ្រង់។

បន្ទាប់ពីគ្រប់គ្រងអស់រយៈពេល 15 ឆ្នាំ ម្ចាស់ក្សត្រីហាតសេពស៊ូត បានបាត់រូបរាង។ ទ្រង់អាចសុគត់ដោយស្ងប់ស្ងាត់ ឬអាចត្រូវបានធ្វើឃាតដោយធូតម៉ូសេទី 3 ។ បន្ទាប់ពីការសោយទីវង្គត់របស់ទ្រង់ ធូតម៉ូសេទី 3 បានក្លាយជាស្ដេចផារ៉ូស ហើយព្យាយាមនៅក្នុងការកម្ទិចកំណត់ត្រាទាំងឡាយនៅក្នុងរាជ្យរបស់ម្ចាស់ក្សត្រីហាតសេព

ស៊ូត។ យើងស្គាល់ទ្រង់ដោយសារតែក្រុមអ្នកបុរាណវិទ្យាបានជួសជុលឡើងវិញនូវប្រាសាទ និងផ្នូររបស់ទ្រង់ដែលទទួលរងការខូចខាត។

វិភាគអំពីឥទ្ធិពល៖ ពន្យល់អំពីឥទ្ធិពលនៃការគ្រប់គ្រងរបស់ម្ចាស់ក្សត្រីហាតសេពស៊ូតមកលើប្រទេសអេហ្ស៊ីប។

## 2. ស្ដេចផារ៉ូសធ្វើកំណែទម្រង់មួយអន្ត

សំណួរគន្លឹះ៖ តើស្ដេចផារ៉ូសអាខេណាតុនប្រើវិធីសាស្ត្រអ្វីដើម្បីផ្លាស់ប្ដូរសាសនារបស់ពួកអេហ្ស៊ីប?

ដូចដែលអ្នកបានអាននៅដើមដំបូង ប្រជាជនអេហ្ស៊ីបជឿជាក់ថា ការខឹងសម្បារបស់អាទិទេពនឹងនាំទៅដល់គ្រោះចង្រៃ។ បើទោះជាដូច្នេះក៏ដោយ មានស្ដេចផារ៉ូសមួយអង្គមានភាពក្លាហាននៅក្នុងការប្រឈមជាមួយអាទិទេពទាំងឡាយ។

ជំនឿថ្មីមួយ៖ នៅពេលដែល អាខេណាតុន បានក្លាយជាស្ដេចផារ៉ូសនៅក្នុងឆ្នាំ 1353 មុនគ.ស ទ្រង់បានលើកតម្កើនអាទិទេពព្រះអាទិត្យដែលគេហៅថាអាតុនឱ្យស្ថិតនៅក្នុងឋានៈខ្ពស់បំផុត។ ពេលនោះទ្រង់បានបិទទ្វាប្រាសាទរបស់អាទូទេពទាំងឡាយ។ នៅក្នុងវិធីនេះ ទ្រង់ជាក្សត្រដំបូងដែលលើកតម្កើនឱ្យមានការគោរពទៅលើអាទិទេពតែមួយនៅក្នុងប្រវត្តិសាស្ត្រអេហ្ស៊ីប។ បព្វជិតដែលបម្រើឱ្យអាទិទេពផ្សេងបានបាត់បង់អំណាចរបស់ខ្លួន។ ពួកគេក៏មានការព្រួយបារម្ភណ៍ផងដែរថា សកម្មភាពរបស់ស្ដេចផារ៉ូសនាំឲ្យអាទិទេពចាស់ៗខឹងសម្បា។

ជំនឿថ្មីរបស់ស្ដេចផារ៉ូសអាខេណាតុនបានជះឥទ្ធិពលដល់សិល្បៈ។ កាលពីសម័យបុរាណ ការងារសិល្បៈរបស់អេហ្ស៊ីបជាទូទៅ តែងតែព្យាយាមនៅក្នុងការបង្ហាញពីបដិមាដ៏ស្រស់ស្អាតរបស់ស្ដេចផារ៉ូស។ នៅក្នុងសម័យព្រះរាជាណាចក្រកណ្ដាល ជំហានទៅរកភាពប្រាកដនិយមបានលេចឡើងបន្តិច។ ប៉ុន្តែ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាខេណាតុន ស្ដេចផារ៉ូសមួយរូបត្រូវបានបង្ហាញយ៉ាងពិតប្រាកដជាលើកដំបូង។ ឧទាហរណ៍ រូបចម្លាក់របស់អាខេណាតុនបានបង្ហាញពីក្បាលពោះធំរបស់ទ្រង់។

ការធ្វើកំណែទម្រង់បញ្ចប់៖ សាសនាថ្មីរបស់អាខេណាតុនមិនមានរយៈកាលយូរអង្វែងឡើយ។ 3 ឆ្នាំបន្ទាប់ពីការសោយទីវង្គត់របស់ទ្រង់ សាច់ញាតិវ័យក្មេងមួយអង្គរបស់ទ្រង់ព្រះនាមទូតានខាមេនបានក្លាយជាស្ដេចផារ៉ូសនៅក្នុងឆ្នាំ 1333 មុនគ.ស។ ក្សត្រវ័យក្មេងមួយអង្គនេះជឿលើទីប្រឹក្សាដើម្បីជួយទ្រង់ក្នុងការគ្រប់គ្រងអំណាចនៅអេហ្ស៊ីប។ ពួកទីប្រឹក្សាទាំងនេះបានបញ្ចុះបញ្ចូលស្ដេចផារ៉ូសទូតានខាមេនឲ្យបដិសេធសាសនាថ្មី ហើយគោរពអាទិទេពចាស់វិញ។

សង្ខេប៖ សង្ខេបអំពីការធ្វើកំណែទម្រង់សាសនារបស់ទូតានខាមេន។

## 3. ស្ដេចផារ៉ូសដ៏មានឥទ្ធិពល

សំណួរគន្លឹះ៖ តើវិធីសាស្ត្រអ្វីដែលស្ដេចផារ៉ូសរ៉ាមសេសទី 2 ប្រើដើម្បីពង្រីកឥទ្ធិពលរបស់អេហ្ស៊ីប?

នៅក្នុងឆ្នាំ 1279 មុនគ.សស្តេចផារ៉ូសរ៉ាមសេសទី 2 បានឡើងគ្រប់គ្រងអំណាច។ ទ្រង់ឡើងគ្រងរាជ្យ 66 ឆ្នាំដែលស្ថិតនៅក្នុងចំណោមរាជ្យវែងជាងគេនៅក្នុងប្រវត្តិសាស្ត្រ។

អ្នកស្ថាបនាចក្រភព៖ ខុសពីម្ចាស់ក្សត្រីហាតសេពស៊ូត ស្តេចផារ៉ូសរ៉ាមសេសទី 2 ក៏ត្រូវបានគេហៅថារ៉ាមសេសដ៏អស្ចារ្យ មានបំណងចង់ធ្វើឱ្យប្រទេសអេហ្ស៊ីបមានអំណាចខ្លាំងតាមរយៈការធ្វើសង្គ្រាម។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចផារ៉ូសរ៉ាមសេសទី 2 ប្រទេសអេហ្ស៊ីបបានពង្រីកទឹកដីឆ្ពោះទៅកាន់ភាគខាងត្បូងដល់ព្រះរាជាណាចក្រនូប៊ី។ ចក្រភពក៏សាតសន្ធឹងទៅភាគខាងកើតឆ្វេរសមុទ្រមេឌីទែរ៉ានេដែលមានព្រំប្រទល់ជាប់ជាមួយចក្រភពហ៊ីទីត។ ពួកអេហ្ស៊ីប និងពួកហ៊ីទីតគឺជាសត្រូវជាមួយគ្នាអស់រយៈកាលជាយូរមកហើយ។ ភ្លាមៗបន្ទាប់ពីទ្រង់ក្លាយជាស្តេចផារ៉ូស រ៉ាមសេស បានដឹកនាំកងទ័ពវាយប្រយុទ្ធគ្នាជាមួយពួកហ៊ីទីត។ មិនមានភាគីណាឈ្នះសង្គ្រាមនេះឡើយ នៅពេលនោះមានការចចារគ្នាពួកហ៊ីទីត ដែលជាទូទៅត្រូវបានគេស្គាល់ថាជាសន្ធិសញ្ញាសន្តិភាពលើដំបូងនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។ រ៉ាមសេសលើកតម្កើនខ្លួនទ្រង់ផ្ទាល់យ៉ាងខ្លាំង។ ទ្រង់បានស្ថាបនាទីក្រុងមួយឈ្មោះថា ពី-រ៉ាមសេស ឬផ្ទះរបស់រ៉ាមសេស នៅក្នុងដីសណ្តភាគខាងកើត។ នៅអាប៊ូស៊ីមបេលភាគខាងត្បូងល្បាក់ទី 1 រូបបដិមាស្តេចផារ៉ូសរ៉ាមសេសកម្ពស់ 66 ហ្វូតចំនួន 4 ឈរយាមនៅមុខប្រាសាទរបស់ទ្រង់។ គ្រាន់តែត្រចៀករបស់រូបបដិមាមានប្រវែងជាង 3 ហ្វូត។ ខុសពីអាខេណាតុន ស្តេចផារ៉ូសរ៉ាមសេសមិនចង់ឱ្យរូបបដិមារបស់ទ្រង់បង្ហាញពីរូបរាងពិតរបស់ទ្រង់ឡើង។ ទ្រង់ចង់ឱ្យរូបបដិមារបស់ទ្រង់មានលក្ខណៈដូចជាអាទិទេព។ ស្តេចផារ៉ូសរ៉ាមសេសបន្តសោយរាជ្យរហូតដល់ឆ្នាំ 1213 មុនគ.ស នៅពេលដែលទ្រង់មានព្រះជន្មជាង 90 ព្រះវស្សា។ ធ្វើជាមេដឹកនាំអស់រយៈពេល 66 ឆ្នាំ ទ្រង់បានធ្វើឱ្យរដ្ឋាភិបាលអេហ្ស៊ីបមានស្ថេរភាព។ សម័យកាលនៃការគ្រប់គ្រងរបស់ទ្រង់ក៏ជារយៈពេលនៃសន្តិភាពផងដែរ។ បន្ទាប់ពីចុះសន្ធិសញ្ញាជាមួយពួកហ៊ីទីត មិនមានសត្រូវណាគំរាមកំហែងដល់ប្រទេសអេហ្ស៊ីបទៀតឡើងអំឡុងពេលនៃការគ្រប់គ្រងរបស់រ៉ាមសេស។

ការធ្លាក់ចុះនៃអេហ្ស៊ីប៖ ប្រទេសអេហ្ស៊ីបមិនដែលធ្លាក់ចុះដូចអ្វីដែលបានកើតឡើងក្រោយការសោយទីវង្គត់របស់រ៉ាមសេសឡើយ។ ជាទូទៅអំណាចរដ្ឋាភិបាលកណ្តាលចុះខ្សោយ។ បន្ទាប់ពីឆ្នាំប្រមាណ 1070 មុនគ.ស មហាអំណាចបរទេសបានចូលមកគ្រប់គ្រងប្រទេសអេហ្ស៊ីបជាបន្តបន្ទាប់អស់រយៈពេលប្រមាណ 1,000 ឆ្នាំ។ ពួកពែក្សបានឈ្លានពានកាន់កាប់អេហ្ស៊ីបនៅក្នុងឆ្នាំ 525 មុនគ.ស។ ក្រោយមកនៅក្នុងឆ្នាំ 332 មុនគ.ស អាឡិចសាន់ដឺដ៏អស្ចារ្យនៃម៉ាសេដូនៀបានកាន់កាប់អេហ្ស៊ីប ដោយបានដាក់អេហ្ស៊ីបឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រិកអស់រយៈពេល 300 ឆ្នាំ។ (អ្នកនឹងអានអំពីអាឡិចសាន់ដឺដ៏អស្ចារ្យនៅក្នុងជំពូក 8 )។ ប៉ុន្តែ មុនការឈ្លានពានរបស់ពែក្ស និងក្រិក, ព្រះរាជាណាចក្រនូប៊ីគូសក៏បានគ្រប់គ្រងអេហ្ស៊ីបផងដែរ។

សង្ខេប៖ ពិពណ៌នាពីវិធីសាស្ត្រដែលស្តេចផារ៉ូសរ៉ាមសេសទី 2 ពង្រីកឥទ្ធិពលរបស់អេហ្ស៊ីប។

## 4. នូប៊ី និងអរិយធម៌គូស

សំណួរគន្លឹះ៖ តើអេហ្ស៊ីប និងគូសភ្ជាប់ទំនាក់ទំនងគ្នាដោយរបៀបណា?

អេហ្ស៊ីត្រួតត្រាផ្នែកខ្លះនៃនូប៊ីចាប់ពីឆ្នាំប្រហែល 2000 មុនគ.សរហូតដល់ឆ្នាំ 1000 មុនគ.ស។ ដូចដែលអំណាចកណ្ដាលរបស់អេហ្ស៊ីបដួលរលំនៅចុងសម័យព្រះរាជាណាចក្រកណ្ដាល ក្រុមមេដឹកនាំនានាបានបែកខ្វែកគ្នាក្នុងការគ្រប់គ្រងនៅអេហ្ស៊ីបក្រោម និងអេហ្ស៊ីបលើ។ មេដឹកនាំដែលមានអំណាចតិចតួចទាំងអស់នេះមិនអាចគ្រប់គ្រងនៅតំបន់នូប៊ីបានទេ។ នៅពេលនោះ ព្រះរាជាណាចក្រនូប៊ីមួយដែលគេហៅថាគូស បានក្លាយជាព្រះរាជាណាចក្រខ្លាំងក្លានៅក្នុងតំបន់។

ទំនាក់ទំនងវប្បធម៌រវាងអេហ្ស៊ីប និងគូស៖ នៅអំឡុងពេលដែលអេហ្ស៊ីបគ្រប់គ្រងនូប៊ីបាននាំដល់ការផ្លាស់ប្ដូរវប្បធម៌គ្នា។ អេហ្ស៊ីបបានជះឥទ្ធិពលសិល្បៈដល់នូប៊ី ដោយរួមមានទាំងពួកគូសផងដែរ។ ពួកអភិជនគូសក្មេងៗបានធ្វើដំណើរទៅអេហ្ស៊ីបដើម្បីសិក្សារៀនសូត្រភាសាអេហ្ស៊ីប។ ពួកគេទទួលយកទំនៀមទម្លាប់ និងរបៀបនៃការស្លៀកពាក់របស់ពួកអេហ្ស៊ីប ហើយបាននាំយកព្រះរាជក្បួនពិធី និងប្រព័ន្ធសរសេរអក្សររូបត្រឡប់ទៅកាន់គូសវិញ។ ពីរ៉ាមីតរបស់ពួកអេហ្ស៊ីបក៏ត្រូវបានចម្លងតាមនៅគូសផងដែរ ហើយពួកនូប៊ីគោរពអាទិទេពមួយចំនួនដែលពិសិដ្ឋសម្រាប់ពួកអេហ្ស៊ីប។

ការរីកឡើងនៃអំណាចរបស់ពួកគូស៖ នៅពេលដែលឥទ្ធិពលរបស់អេហ្ស៊ីបលើនូប៊ីបានធ្លាក់ចុះនៅអំឡុងឆ្នាំ 1000 មុនគ.ស ការគោរពអាទិទេពអាមូននៅតែបន្តធ្វើនៅរាជធានីណាប៉ាតារបស់ពួកគូស។ ត្រឹមឆ្នាំប្រហែល 750 មុនគ.ស អេហ្ស៊ីបស្ថិតនៅចន្លោះកណ្ដាលនៅក្នុងការប្រជែងគ្នារវាងមហាអំណាចនានានៅក្នុងតំបន់។ កងកម្លាំងដែលត្រួតត្រានៅតំបន់ដីសណ្ដភាគខាងលិចចាប់ផ្ដើមគំរាមកំហែងដល់តំបន់អេហ្ស៊ីខាងលើ។ មេដឹកនាំនៅថេបេស ដែលជាមជ្ឈមណ្ឌលនៃការគោរពដល់អាមូន បានអញ្ជើញស្ដេចរបស់គូសព្រះនាមពីយេ (ពី) ឱ្យមកជួយការពារពួកគេ។ ស្ដេចពីយេ និងកងទ័ពរបស់ទ្រង់បានធ្វើដំណើរតាមទន្លេនីលឡើងទៅកាន់ថេបេស ដែលពេលទៅដល់ទីនោះទ្រង់ត្រូវបានគេប្រកាសថាជាស្ដេចផារ៉ូស។ ពេលនោះទ្រង់បានបន្តដំណើរទៅកាន់អេហ្ស៊ីបក្រោមនៅភាគខាងជើង ដោយយកជ័យជំនះលើសត្រូវទាំងឡាយរបស់ទ្រង់នៅតាមផ្លូវឆ្ពោះទៅកាន់មេមផីស។ បន្ទាប់ពីសង្គ្រាមដ៏យូរអង្វែងមក ទ្រង់បានគ្រប់គ្រងអេហ្ស៊ីបទាំងស្រុង។

ទំនាក់ទំនងនយោបាយ និងពាណិជ្ជកម្មជាមួយអេហ្ស៊ីប៖ ស្ដេចពីយេបានបង្រួបបង្រួមអេហ្ស៊ីប និងគូស។ នូប៊ីបានបង្កើតសន្តតិវង្សរបស់ពួកគេផ្ទាល់ដើម្បីគ្រប់គ្រងរាជ្យបល្ល័ង្កនៅអេហ្ស៊ីប។ ពីយេត្រូវបានគេប្រកាសថាជាស្ដេចផារ៉ូសរបស់អេហ្ស៊ីប។ រាជ្យរបស់ទ្រង់គឺជាចំណុចចាប់ផ្ដើមនៃសន្តតិវង្សទី 20 របស់អេហ្ស៊ីប។ បើទោះបីទ្រង់ជាស្ដេចផារ៉ូសក៏ដោយពីយេមិនបានគង់នៅក្នុងប្រទេសអេហ្ស៊ីបឡើយ។ ផ្ទុយទៅវិញ ទ្រង់បានជ្រើសរើសការគង់នៅណាប៉ាតា ដែលជារាជធានីរបសគូស។ ណាប៉ាតាមានទីតាំងស្ថិតនៅជងផ្លូវមួយដែលគេប្រើសម្រាប់ដឹកទំនិញនានាដើម្បីវាងល្បាក់នៅទន្លេនីល។ ពាណិជ្ជកររប្រើប្រាស់ផ្លូវនេះនៅពេលដែលទូកដឹកទំនិញមិនអាចឆ្លងកាត់ទឹកទន្លេទៅកាន់ផ្នែកម្ខាក់ទៀតនៃទន្លេ។ ផ្លូវនេះជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមដងទន្លេនីល។ ណាប៉ាតាគឺជាមជ្ឈមណ្ឌលចាកចេញទំនិញ និងវប្បធម៌អេហ្ស៊ីបទៅកាន់ដៃគូរពាណិជ្ជកម្មផ្សេងៗទៀតរបស់គូស។

ការធ្លាក់ចុះនៃព្រះរាជាណាចក្រគូស៖ នៅក្នុងឆ្នាំ 704 មុនគ.ស កងកម្លាំងគូសអេហ្ស៊ីបបានវាយប្រយុទ្ធគ្នាជាមួយពួកអាស៊ីរីនៅប៉ាឡេស្ទីន។ ពួកអេហ្ស៊ីបគាំទ្រមេដឹកនាំមួយរូបដែលងើបឡើងប្រឆាំងជាមួយការគ្រប់គ្រងរបស់ពួកអាស៊ីរី។ ពួកអាស៊ីរីដែលមានអាវុធធ្វើពីដែករឹងមាំជាងអាវុធធ្វើពីលង្ហិនរបស់ពួកគូស បានយកជ័យជំនះលើសមរភូមិនេះ។ ភាគីទាំងពីរនៅតែបន្តវាយប្រយុទ្ធគ្នាអស់រយៈពេលជាច្រើនឆ្នាំ ដូចដែលពួកអេហ្ស៊ីបនៅតែបន្តគាំទ្រមេដឹកនាំបរទេសផ្សេងទៀតដែលប្រឆាំងជាមួយការគ្រប់គ្រងរបស់ពួកអាស៊ីរី។ នៅក្នុងឆ្នាំ 671 មុនគ.ស ពួកអាស៊ីរីបានឈ្លានពាន និងកាន់កាប់អេហ្ស៊ីប។ ការឈ្លានពាននេះបញ្ចប់ការគ្រប់គ្រងរបស់ពួកគូសលើអេហ្ស៊ីប។

ស្វែងរកគំនិតសំខាន់៖ ពន្យល់អំពីវិធីដែលពួកអេហ្ស៊ីប និងគូសភ្ជាប់ទំនាក់ទំនងគ្នាតាមរយៈប្រវត្តិសាស្ត្ររបស់ពួកគេ។

# ជំពូក 5 ៖ ប្រទេសឥណ្ឌាសម័យបុរាណ

## មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រ និងជីវភាពរស់នៅរបស់ពួកឥណ្ឌា

ភ្ជាប់ទៅនឹងអ្វីដែលអ្នកបានដឹង៖ តើអ្នកធ្លាប់បានធ្វើដំណើរទៅទស្សនាផ្នែកណាមួយនៃសហរដ្ឋអាមេរិកដែលមានអាកាសធាតុខុសគ្នាដែរឬទេ? តំបន់ខ្លះនៃសហរដ្ឋអាមេរិកមានភ្លៀងធ្លាក់ច្រើនជាងតំបន់ផ្សេងៗ។ ដូចដែលអ្នកនឹងត្រូវរៀន ប្រទេសឥណ្ឌាមានរដូវពីរផ្សេងពីគ្នា៖ រដូវវស្សា និងរដូវប្រាំង។

### 1. ទីតាំងភូមិសាស្ត្រនៃប្រទេសឥណ្ឌា

សំណួរគន្លឹះ៖ តើភ្នំ និងខ្យល់រដូវបង្កើតអាកាសធាតុនៅឥណ្ឌាដោយរបៀបណា?

ឥណ្ឌាគឺជាឧបទ្វីបមួយ ដែលជាផ្ទៃដីដ៏ធំល្វឹងល្វើយមួយជាប់ជាមួយផ្ទៃដីទ្វីប ប៉ុន្តែវាត្រូវបានគេចាត់ទុកថាជាតំបន់ដាច់ដោយឡែក។ ឧបទ្វីបរួមបញ្ចូល ប្រទេសបច្ចុប្បន្នបង់ក្លាដេស, ប៊ូតាន, ឥណ្ឌា, នេប៉ាល់, និងមួយភាគធំនៃប៉ាគីស្ថាន។ ជាទូទៅវាត្រូវបានគេសំដៅទៅលើអាស៊ីខាងត្បូង។ ឧបទ្វីបឥណ្ឌាដែលមានរាងដូចខ្លែងធ្លាប់ជាតំបន់ដែលមានផ្ទៃដីដាច់ដោយឡែកពីដីទ្វីប។ ឧបទ្វីបនេះវារលាត់អណ្តែតបន្តិចម្តងៗឆ្ពោះទៅភាគខាងជើងរហូតទៅទល់នឹងអាស៊ី។ នៅពេលដែលតំបន់ទាំងពីរនេះជួបគ្នា វាបានរុញទង្គិចគ្នានាំឲ្យលេចចេញជួរភ្នំ។

ជួរភ្នំ និងផ្លូវទឹក៖ ភ្នំជាច្រើនផ្តុំគ្នាបង្កើតបានជាជួរភ្នំ ដោយរួមមានជួរភ្នំឥណ្ឌូគូស និងជួរភ្នំហិម៉ាល័យដែលជាភ្នំដែលខ្ពស់ជាងគេនៅលើពិភពលោក។ ជួរភ្នំទាំងនេះសាតសន្ធឹងនៅភាគខាងជើងប្រទេសឥណ្ឌា ដែលញែកឥណ្ឌាពីប្រទេសចិន និងអាស៊ី។ ទន្លេនៅឧបទ្វីបនេះរួមមាន ទន្លេគង្គា និងទន្លេឥណ្ឌូស។ ទន្លេទាំងពីរនេះបាននាំទឹកសម្រាប់ប្រព័ន្ធធារាសាស្ត្រ។ ដីល្បាប់ដែលទន្លេបាននាំយកមកធ្វើឱ្យដីសម្បូរជីជាតិ។ នៅសម័យបុរាណ តំបន់ទន្លេសារ៉ាស្វាទីគឺជាតំបន់ដែលមានទីក្រុងធំៗ។ ប៉ុន្តែ ទន្លេនេះបានរីងស្ងួត ប្រហែលដោយសារការរញ្ជួយដីមួយ។ សមុទ្រអារ៉ាប់, មហាសមុទ្រឥណ្ឌា, និងឈូងសមុទ្របេងហ្គាល់ព័ទ្ធជុំវិញប្រទេសឥណ្ឌា។ ប្រជាជនឥណ្ឌាបុរាណធ្វើដំណើរតាមផ្លូវទឹកនេះទៅកាន់តំបន់ផ្សេងៗទៀតដើម្បីធ្វើពាណិជ្ជកម្ម។

អាកាសធាតុ៖ ភ្នំខ្ពស់ៗជួយដល់រាំងដល់ខ្យល់ត្រជាក់ដែលបក់មកពីភាគខាងជើងមិនឱ្យធ្វើដំណើរមកកាន់ឥណ្ឌា។ ជាលទ្ធផល សីតុណ្ហភាពជាទូទៅមានលក្ខណៈក្តៅល្មមនៅឥណ្ឌា។ ជាមួយគ្នានេះ ប្រព័ន្ធខ្យល់រដូវដែលគេហៅថាម៉ូសុងបានបង្កើតជាទម្រង់អាកាសធាតុនៅឥណ្ឌា។ ខ្យល់រដូវនេះបង្កើតបានជារដូវភ្លៀង និងរដូវប្រាំងនៅក្នុងតំបន់, ពេលខ្លះមានភ្លៀងធ្លាក់យ៉ាងច្រើន។ ខ្យល់ម៉ូសុងរដូវក្តៅបានផ្តល់នូវទឹកភ្លៀងសម្រាប់ការដាំដុះនៅឥណ្ឌា ប៉ុន្តែទឹកភ្លៀងនេះក៏អាចបង្កឲ្យមានទឹកជំនន់ធ្ងន់ធ្ងរផងដែរ។

សង្ខេប៖ ពិពណ៌នាអំពីរបៀបដែលភ្នំ និងខ្យល់បង្កើតទម្រង់អាកាសធាតុនៅឥណ្ឌា។

### 2. ទីក្រុងនៅតាមច្រលងទន្លេឥណ្ឌូស

សំណួរគន្លឹះ៖ ហេតុអ្វីបានជាអរិយធម៌ដំបូងរបស់ឥណ្ឌាចាប់ផ្តើមឡើងនៅជិតទន្លេឥណ្ឌូស?

ពំនូកដីទួលដ៏ធំលេចឡើងនៅតាមជ្រលងទន្លេឥណ្ឌូស។ នៅជិតពំនូកដីទួលនោះ គេឃើញមានដុំឥដ្ឋ និងដុំថ្មតូចៗដែលមានសរសេរអក្សរចម្លែកនៅលើនោះ។ ការរកឃើញនេះនាំទៅដល់ការស្រាវជ្រាវរុករកពំនូកដីទាំងនោះ។ ក្រុមអ្នកបុរាណវត្ថុវិទូធ្វើកំណាយនៅតំបន់បាក់បែកទាំងនេះដែលជាអរិយធម៌បុរាណមួយ។

ការតាំងទីលំនៅដំបូងៈ ប្រវត្តិសាស្ត្រនៅតំបន់ច្រលងទន្លេឥណ្ឌូសលេចឡើងមានទម្រង់លក្ខណៈដូចគ្នាទៅនឹងពួកស៊ូម៉េរ និងអេហ្ស៊ីប។ ក៏ដូចជាតំបន់ផ្សេងៗទៀតដែរ អរិយធម៌តាមច្រលងទន្លេឥណ្ឌូសចាប់ផ្តើមជាមួយកសិកម្ម។ ប្រជាកសិករដំបូងដាំដុះស្រូវសាលី និងស្រូវបាឡេ។ ត្រឹមឆ្នាំ 3000 មុនគ.ស ពួកគេដាំដុះដំណាំកប្បាស និងបានផលិតវាទៅជាក្រណាត់ ដែលជាមនុស្សដំបូងនៅក្នុងទ្វីបអាស៊ីដែលបង្កើតក្រណាត់។ ពួកគេចិញ្ចឹមសត្វគោ, ចៀម, ពពែ, និងមាន់។ ពួកគេចេះពីវិធីផលិតឧបករណ៍ធ្វើពីទង់ដែង និងលង្ហិនផងដែរ។ ប្រជាជននៅក្នុងភូមិផ្លោះប្តូរទំនិញជាមួយតំបន់ដទៃទៀត។ បន្តិចម្តងៗ ប្រជាជននៅជ្រលងទន្លេឥណ្ឌូសចាប់ផ្តើមធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រជាជនដែលស្ថិតនៅក្នុងតំបន់ឆ្ងាយៗ។ ទ្រព្យសម្បត្តិដែលពួកគេទទួលបានពីការធ្វើពាណិជ្ជកម្មបានជួយដល់ពួកគេនៅក្នុងការអភិវឌ្ឍវប្បធម៌ដ៏ស្មុកស្មាញមួយ។

ទីក្រុងដ៏ធំៈ ត្រឹមឆ្នាំ 2500 មុនគ.ស ភូមិខ្លះបានរីកចម្រើនក្លាយជាទីក្រុងដ៏ធំ។ នៅតាមជ្រលងទន្លេឥណ្ឌូស និងសារ៉ាស្វាទីមានទីក្រុងរាប់រយ។ យ៉ាងហោចណាស់មានប្រជាជនចំនួន 35,000 នាក់រស់នៅក្នុងទីក្រុងដែលធំ និងល្បីល្បាញជាងគេ ម៉ូហេនចូ-ដារ៉ូ និងហារ៉ាប៉ា។ ហារ៉ាប៉ាត្រូវបានគេយកមកធ្វើជាឈ្មោះសម្រាប់វប្បធម៌នៃតំបន់ទាំងមូល។ បច្ចុប្បន្ន វប្បធម៌បុរាណដែលបានអភិវឌ្ឍឡើងនៅតាមជ្រលងទន្លេឥណ្ឌូសត្រូវបានគេហៅថា អរិយធម៌ហារ៉ាប៉ា។ អរិយធម៌នេះរួមបញ្ចូលទីក្រុងដែលមានការរៀបចំ ដែលទីក្រុងនេះស្ថាបនាឡើងតាមរយៈការរចនា។ ស្ថាបត្យករបានសាងសងកំពែងឥដ្ឋយ៉ាងរឹងមាំការពារជុំវិញទីក្រុងទាំងនេះ។ ផ្លូវក្នុងទីក្រុងកាត់ខ្វែងគ្នាយ៉ាងមានរបៀបរៀបរយជាមួយនឹងទម្រង់រាងការេ។ នៅតាមផ្លូវមានផ្ទះ ហាងទំនិញ និងរោងចក្រ។ នៅក្នុងទីក្រុងក៏មានសំណង់អាគារសាធារណធំៗ ដែលអាចគេប្រើប្រាស់សម្រាប់មុខងាររដ្ឋាភិបាល និងសាសនា។ ទីក្រុងហារ៉ាប៉ាគឺជាគំរូដ៏ប្រសើរមួយនៃទីក្រុងដែលមានការរៀបចំនេះ។ ផ្នែកខ្លះនៃទីក្រុងត្រូវបានស្ថាននាឡើងពីលើសំណង់កម្រាលដុំឥដ្ឋដើម្បីការពារពីទឹកជំនន់។ មានកំពែងឥដ្ឋក្រាសៗប្រវែងប្រមាណ 3.5 ម៉ាយព័ទ្ធជុំវិញ។ នៅខាងក្នុងគឺជាបន្ទាយប្រាការដែលផ្តល់ការការពារដល់គ្រួសាររាជវង្ស និងដើរតួនាទីជាប្រាសាទផងដែរ។ ផ្លូវដែលស្ថិតនៅក្នុងប្រព័ន្ធខ្វែងគ្នាត្រង់ដែលមានទំហំប្រមាណ 30 ហ្វីត។ កំពែងបានបែងចែកសង្កាត់នានាចេញពីគ្នា។ ផ្ទះមានទំហំផ្សេងៗគ្នា។ ផ្លូវតូចៗបានញែកជួរផ្ទះជាប្លុកៗ។

ដំណោះស្រាយចំពោះបញ្ហាៈ ប្រជាជននៅក្នុងទីក្រុងធំតែងតែត្រូវដោះស្រាយជាមួយបញ្ហានៃការយកចេញនូវកាកសំណល់របស់មនុស្ស។ នៅក្នុងទីក្រុងបុរាណភាគច្រើនប្រជាជនយកទឹកមកពីទន្លេ ឬក៏អណ្តូងរួមមួយ។ ពួកគេបញ្ចេញកាកសំណល់តាមប្រព័ន្ធប្រឡាយបង្ហូរមួយ ឬដឹកវាទៅបោះចោលក្រៅក្រុង។ ផ្ទុយទៅវិញ ទីក្រុងនានានៅហារ៉ាប៉ាគឺមានលក្ខណៈជឿនលឿននៅក្នុងការគ្រប់គ្រងកាកសំណល់នេះ។ ស្ទើតែគ្រប់ផ្ទះទាំងអស់មានបន្ទាប់

ទឹក និងបង្គន់មួយ។ ប្រព័ន្ធលូក្រោមដីមាននាំយកនូវកាកសំណល់ទៅឆ្ងាយ។ មិនមានអរិយធម៌ណាអាចធ្វើបានដល់កម្រិតអស្ចារ្យបែបនេះទេនាសម័យបុរាណ រហូតដល់ទសវត្សឆ្នាំ 1800 ។

វាត្រូវការផែនការ និងការរៀបចំដោយយកចិត្តទុកដាក់បំផុតដើម្បីស្ថាបនាទីក្រុងដ៏ស្មុកស្មាញបែបនេះ។ ដោយហេតុនេះ ប្រវត្តិវិទូជឿជាក់ថា ប្រជាជនហារ៉ាប៉ាសម័យបុរាណអាចនឹងមានមេដឹកនាំដ៏មានឥទ្ធិពល។ គេមិនបានដឹងថាជាបព្វជិត ឬជាស្តេច ឬក៏ទាំងពីរដែលដឹកនាំនៅហារ៉ាប៉ា ប៉ុន្តែប្រព័ន្ធរដ្ឋាភិបាលរបស់ពួកគេគួរតែមានលក្ខណៈខ្លាំងក្លាមួយ។

ស្វែងរកគោលគំនិត៖ ពន្យល់អ្វីមូលហេតុដែលនាំឱ្យអរិយធម៌ឥណ្ឌាអភិវឌ្ឍឡើងតាមដងទន្លេឥណ្ឌូស។

### 3. វប្បធម៌ហារ៉ាប៉ា

សំណួរគន្លឹះ៖ អ្វីទៅជាទម្រង់នៃអរិយធម៌ហារ៉ាប៉ា ?

ទម្រង់ដ៏ចម្លែកនៃប្រព័ន្ធសំណេរនៅពីលើត្រាថ្មត្រូវបានគេរកឃើញក្នុងគំនរបាក់បែកនៃទីក្រុង។ ក្នុងចំណោមនោះ មានត្រាមួយចំនួនជាត្រាដែលបង្ហាញអំពីប្រភេទនៃទំនិញពាណិជ្ជកម្ម។ អ្នកប្រាជ្ញមួយចំនួនបានគិតថាអក្សររូប ឬរូបសញ្ញាចំនួន 500 នៅក្នុងប្រព័ន្ធសំណេររបស់ពួកហារ៉ាប៉ាគឺតំណាងឱ្យពាក្យ, សំលេង, ឬទាំងពីរ។ ប៉ុន្តែពួកគេមិនបានដឹងច្បាស់ទេ។ រហូតមកដល់ពេលនេះ មិនទាន់មាននណារម្នាក់អាចអានតួអក្សរនៃអរិយធម៌ហារ៉ាប៉ានបាននៅឡើយទេ។ នៅពេលនេះយើងអាចរៀនអំពីអរិយធម៌ហារ៉ាប៉ាបានគឺអាស្រ័យទៅលើការសិក្សាលើវត្ថុសិល្បៈប៉ុណ្ណោះ។

សាសនារបស់ពួកហារ៉ាប៉ា៖ ក្រុមអ្នកបុរាណវត្ថុវិទូមិនទាន់បានកំណត់ឱ្យជាក់លាក់អំពីទីតាំងនៃប្រាសាទណាមួយសម្រាប់គោរពបូជាអាទិទេពឡើយ ប៉ុន្តែពួកគេបានរកឃើញភស្តុតាងនានាសម័យវិស័យសាសនា។ ទីក្រុងម៉ូហេនចូ-ដារ៉ូមានអាងមុជទឹកសាធារណៈដ៏ធំមួយដែលធ្លាប់ត្រូវបានគេប្រើសម្រាប់ពិធីក្បួនសាសនា។ បុរាណវត្ថុវិទូបានរកឃើញរូបសត្វនានា ដែលក្នុងនោះមានសត្វគោ ដែលប្រជាជនឥណ្ឌានៅតែចាត់ទុកថាជាសត្វពិសិដ្ឋរហូតដល់សព្វថ្ងៃ។ ពួកគេក៏បានរកឃើញរូបធ្វើពីដីដុតដែលអាចសម្រាប់គោរពបូជាអាទិទេព ឬរូបកូនក្រមុំធម្មតា។ បព្វជិតទំនងជាបន់ស្រន់សម្រាប់ភាពល្អប្រសើរនៃការប្រមូលភោគផល និងសុវត្ថិភាពពីគ្រោះទឹកជំនន់។ វត្ថុបែបសាសនានានាបានបង្ហាញពីទំនាក់ទំនងទៅនឹងវប្បធម៌សាសនាហិណ្ឌូនាពេលបច្ចុប្បន្ន។ រូបរាងនៃរូបចម្លាក់ទាំងនោះមើលទៅដូចជារូបបដិមានព្រះសិវៈដំបូងបង្អស់ ដែលជាអាទិទេពសំខាន់មួយនៅក្នុងសាសនាហិណ្ឌូ។ រូបចម្លាក់មួយចំនួនទៀតទាក់ទងទៅនឹងមាតាអាទិទេពមួយអង្គ និងគោរពដល់សត្វគោ។ ក្រោយមក រូបចម្លាក់ទាំងអស់នេះបានក្លាយជាផ្នែកមួយនៃអរិយធម៌របស់ឥណ្ឌា។

ការរីកសាយភាយ និងភាពរុងរឿងនៃវប្បធម៌៖ ប្រជាជននៅពាលពេញតំបន់ដ៏ធំមួយមានវប្បធម៌ហារ៉ាប៉ារួម។ ទីក្រុងហារ៉ាប៉ាសាយភាយនៅពាសពេញតំបន់មួយដែលមានផ្ទៃក្រឡាប្រហែល 50 ម៉ឺនម៉ាយការេ។ តំបន់នេះមាន

ទំហំធំជាងរដ្ឋតិចសាសបច្ចុប្បន្នប្រហែលជាពីរដង។ បើទោះបីជាធំដូច្នេះក៏ដោយ ទីក្រុងទាំងអស់នេះមានការរចនាដូចៗគ្នា។ ការរចនាដូចៗគ្នានេះបានបង្ហាញពីកម្រិតនៃការរីកសាយភាយនៃវប្បធម៌។

វប្បធម៌ និងពាណិជ្ជកម្ម៖ ប្រជាជនហារ៉ាប៉ាប្រើប្រាស់បទដ្ឋានសម្រាប់ថ្លឹងទម្ងន់ និងវាល់ប្រវែង។ នៅពាសពេញតំបន់ ពួកគេផលិតរូបចម្លាក់ធ្វើពីលង្ហិន និងគ្រឿងលេងធ្វើពីដីដុតស្រដៀងគ្នា។ រូបសិល្បៈទាំងអស់នេះបានបង្ហាញថា ប្រជាជនហារ៉ាប៉ាអាចបង្កើតបាននូវអ្វីៗដែលលើសពីតម្រូវការធម្មតា។ ប្រជាជនហារ៉ាប៉ាបង្កើតទ្រព្យសម្បត្តិរបស់ពួកគេពីការធ្វើកសិកម្ម និងពាណិជ្ជកម្ម។ បុរាណវត្ថុវិទូបានរកឃើញត្រាចាប់ពីតំបន់ជ្រលងទន្លេឥណ្ឌូសដល់តំបន់មេសូប៉ូតាមី។ ត្រាទាំងអស់នេះធ្វើឡើងពីថ្ម ដែលប្រហែលជាប្រើប្រាស់ដោយពាណិជ្ជករនៅឥណ្ឌាដើម្បីកំណត់សំគាល់ទំនិញរបស់ពួកគេ។ ពួកហារ៉ាប៉ាធ្វើពាណិជ្ជកម្មឈើហុប, ភ្លុក, និងអង្កាំ។ មេសូប៉ូតាមីលក់ឱ្យពួកហារ៉ាប៉ានូវប្រាក់, ទង់ដែង, និងសំលៀកបំពាក់ធ្វើពីឡែន។ ពាណិជ្ជកម្មចាប់ផ្តើមដំបូងនៅក្នុងរាជ្យរបស់ស្តេចសាហ្គុនអាកាដនៅរង្វង់ឆ្នាំ 2370 មុនគ.ស ហើយបន្តអស់រយៈពេលជាច្រើនឆ្នាំទៅមុខទៀត។

សង្ខេប៖ ពិពណ៌នាអំពីទម្រង់នៃអរិយធម៌ហារ៉ាប៉ា។

## 4. ចុងបញ្ចប់នៃវប្បធម៌ជ្រលងទន្លេឥណ្ឌូស

សំណួរគន្លឹះ៖ ហេតុអ្វីបានជាអរិយធម៌ជ្រលងទន្លេឥណ្ឌូសធ្លាក់ចុះ?

នៅរង្វង់ឆ្នាំ 1700 មុនគ.ស គុណភាពនៃសំណង់នៅតាមទីក្រុងនានានៅជ្រលងទន្លេឥណ្ឌូសមានការធ្លាក់ចុះ។ បន្តិចម្តងៗ ទីក្រុងធំៗបានក្លាយជាពុកផុយ។ តើមានអ្វីកើតឡើង? ប្រវត្តិវិទូមួយចំនួនគិតថា ទឹកទន្លេឥណ្ឌូសប្តូរទិសដៅ ដូច្នេះទឹកជំនន់មិនបានបង្កើតជីជាតិដល់ផ្ទៃដីដាំដុះនៅជិតទីក្រុងទៀតឡើយ។ អ្នកប្រាជ្ញមួយចំនួនទៀតយល់ឃើញថាប្រជាជនត្រូវបានគេបណ្តេញចេញពីដីដែលនៅជាតាមជ្រលង។ អរិយធម៌ច្រលងទន្លេឥណ្ឌូសប្រឈមទៅនឹងបញ្ហាបរិស្ថានជាច្រើន ក្នុងចំណោមបញ្ហាទាំងនោះរួមមានកត្តាដូចខាងក្រោម៖

1. ទឹកជំនន់ប្រចាំឆ្នាំនៅជ្រលងទន្លេឥណ្ឌូសគឺមិនអាចប៉ាន់ប្រមាណដឹងជាមុន។
2. ទន្លេពេលខ្លះផ្លាស់ប្តូរទិសដៅ។
3. រដូវនៃរដូវប្រាំង និងរដូវវស្សាដែលនាំយកមកដោយខ្យល់មូសុងគឺមិនអាចប៉ាន់ប្រមាណដឹងជាមុន។

ដំណោះស្រាយភាពអាថ៌កំបាំង?៖ ការដួលរលំនៃទីក្រុងនៅតែជាអាថ៌កំបាំងរហូតដល់ទសវត្សឆ្នាំ 1970 ។ ពេលនោះរូបភាពពីលើអាកាសស្តីអំពីឧបទ្វីបឥណ្ឌា បានបង្ហាញភស្តុតាងអំពីចលនានៃសំបកផែនដីកាលពីសម័យបុរាណ។ ចលនានេះប្រហែលជាបង្កឱ្យមានគ្រោះរញ្ជួយដី និងទឹកជំនន់។ ចលនានេះក៏ប្រហែលជានាំឱ្យចរន្តទឹកទន្លេឥណ្ឌូសផ្លាស់ប្តូរផងដែរ។

ឥទ្ធិពលនៃគ្រោះមហន្តរាយ៖ ទីក្រុងមួយចំនួននៅតាមទន្លេយ៉ាងជាក់ច្បាស់ប្រាកដជារងគ្រោះដោយគ្រោះមហន្តរាយទាំងនេះ ប៉ុន្តែនៅមានរូបរាង។ ចំណែកឯទីក្រុងផ្សេងទៀតត្រូវបានកម្ទិច។ ការផ្លាស់ប្តូរនេះអាចបង្កបញ្ហាដល់ទន្លេផ្សេងទៀត គឺទន្លេសារ៉ាស្វាទី បានរីងស្ងួត។ ការធ្វើពាណិជ្ជកម្មតាមទន្លេនេះគឺមិនអាចធ្វើបានទៀត

ឡើយ ហើយទីក្រុងចាប់ផ្តើមដួលរលំ។ កសិកម្មនៅហារ៉ាប៉ាក៏នឹងរងឥទ្ធិពលពីព្រឹត្តិការណ៍ទាំងនេះផងដែរ។ វាហាក់ដូចជាថាការផ្លាស់ប្តូរទាំងនេះបានរារាំងដល់ការផលិតស្បៀងអាហារក្នុងបរិមាណច្រើន។ ហេតុផលនេះ វាបានបង្ខំឱ្យប្រជាជនចាប់ផ្តើមចាកចេញពីទីក្រុងដើម្បីជានាអំពីការរស់រានរបស់ពួកគេ។

ឥទ្ធិពលរបស់ពួកចរកជនៈ មានកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលមកលើឧបទ្វីបឥណ្ឌា។ ក្រុមមនុស្សចរកជនមួយក្រុមធ្វើដំណើរមកពីភាគខាងជើងតំបន់ជួរភ្នំហិណ្ឌូគូស ចូរមកកាន់តំបន់ជ្រលងទន្លេឥណ្ឌូសនៅរង្វង់ឆ្នាំ 1500 មុនគ.ស។ អរិយធម៌ឥណ្ឌាអាចនឹងរីកចម្រើនម្តងទៀតដោយស្ថិតនៅក្រោមឥទ្ធិពលនៃក្រុមចរកជនទាំងនេះ ដូចដែលអ្នកនឹងសិក្សានៅមេរៀនបន្ទាប់។

វិភាគអំពីមូលហេតុៈ ពន្យល់ពីមូលហេតុដែលនាំឱ្យអរិយធម៌ជ្រលងទន្លេឥណ្ឌូសធ្លាក់ចុះ។

# មេរៀនទី 2 ៖ ដើមកំណើតហិណ្ឌូនិយម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅជំពូកមុន អ្នកបានសិក្សាពីវិធីដែលពួកអេហ្ស៊ីបបុរាណប្រយុទ្ធគ្នាជាមួយពួកហ៊ីទីត។ ពួកហ៊ីទីតគឺស្ថិតនៅក្នុងក្រុមប្រជាជនដែលនិយាយគ្រាមភាសាមួយដែលគេហៅថាឥណ្ឌូ-អឺរ៉ុប។ អ្នកប្រាជ្ញជឿជាក់ថា ពួកឥណ្ឌូ-អឺរ៉ុបអាចមានដើមកំណើតមកពីតំបន់អាស៊ីកណ្តាល។

## 1. ពួកអារ្យ៉ុនធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា

សំណួរគន្លឹះ៖ តើពួកអារ្យ៉ុនជានណារ?

ភាគច្រើននៃពួកឥណ្ឌូ-អឺរ៉ុបគឺជាពួកពនេចរ។ ពួកគេរស់នៅជាក្រុមៗ ឬកុលសម្ព័ន្ធ ហើយចិញ្ចឹមសត្វគោ, ចៀម, និងពពែ។ ពួកគេក៏ជាអ្នកប្រយុទ្ធ ដោយជំនាញខាងជិះរទេះសេះ។ ពួកគេវាយប្រយុទ្ធជាមួយនឹងធ្នូ និងគ្រាប់ព្រួញវែងៗ និងពូថៅអ្វីអំពីលង្ហិន។

ពួកឥណ្ឌូ-អឺរ៉ុបធ្វើអន្តោប្រវេសន៍៖ នៅរង្វង់ឆ្នាំ 2000 មុនគ.ស មានហេតុការណ៍មួយបានបណ្តាលឱ្យពួកឥណ្ឌូ-អឺរ៉ុបចាកចេញពីទឹកដីកំណើតរបស់ពួកគេ ដោយធ្វើអន្តោប្រវេសន៍ទៅកាន់តំបន់ផ្សេង។ ប្រវត្តិវិទូមិនបានដឹងច្បាស់អំពីមូលហេតុនៃការធ្វើអន្តោប្រវេសន៍នេះឡើង ថាវាបណ្តាលមកពីមូលហេតុអ្វីឱ្យពិតប្រាកដ វាអាចមកពីគ្រោះរាំងស្ងួត ឬជំងឺឆ្លង (ប៉េស្ត) ឬការឈ្លានពានដែលនាំឱ្យពួកគេចាកចេញពីទីនោះ។ មានក្រុមផ្សេងៗគ្នាបានចាកចេញទៅកាន់តំបន់ផ្សេងៗគ្នា។ ពួកហ៊ីទីតបានធ្វើដំណើរទៅកាន់អាស៊ីភាគនីរតី ហើយពួកឥណ្ឌូ-អឺរ៉ុបជាច្រើនទៀតបានទៅរស់នៅផ្នែកខ្លះនៃទ្វីបអ៊ឺរ៉ុប។

ពួកអារ្យ៉ុនធ្វើអន្តោប្រវេសន៍៖ នៅប្រហែលឆ្នាំ 1500 មុនគ.ស ពួកអារ្យ៉ុន ដែលស្ថិតនៅក្នុងក្រុមឥណ្ឌូ-អឺរ៉ុបត្រូវបានគេជឿថាបានធ្វើអន្តោប្រវេសន៍មកកាន់ឧបទ្វីបឥណ្ឌា។ ផ្ទុយទៅនឹងពួកហារ៉ាប៉ាដែលរស់នៅក្នុងទីក្រុង ពួកអារ្យ៉ុនគឺជាក្រុមអ្នកចិញ្ចឹមសត្វដែលរស់នៅក្នុងផ្ទះសាមញ្ញ។ ពួកគេនិយាយភាសាឥណ្ឌូ-អឺរ៉ុបមួយដែលគេហៅថាសំស្ក្រឹត។

តើពួកអ្នកប្រយុទ្ធជិះលើរទេះសេះអារ្យ៉ុនបានកាន់កាប់ទីក្រុង និងបង្ខំឱ្យពួកហារ៉ាប៉ារត់ទៅកាន់ភាគខាងត្បូង? អស់រយៈពេលជាច្រើនឆ្នាំកន្លងមក សៀវភៅប្រវត្តិសាស្ត្រនានាបាននិយាយអំពីដូច្នេះ។ ប៉ុន្តែ ការស្រាវជ្រាវថ្មីបានបង្ហាញពីរឿងរ៉ាវខុសពីនេះ។ 200 ឆ្នាំមុនការមកដល់នៃពួកអារ្យ៉ុន ទីក្រុងនានារបស់ពួកហារ៉ាប៉ាបានខ្ទេចខ្ទីរួចទៅហើយ។ វិនាសកម្មនេះអាចបណ្តាលមកពីគ្រោះរញ្ជួយដី ឬទឹកជំនន់។

សង្ខេប៖ កំណត់អំពីពួកអារ្យ៉ុន។

## 2. ផ្លាស់ប្តូរការរស់នៅក្នុងប្រទេសឥណ្ឌា

សំណួរគន្លឹះ៖ តើសង្គមអារ្យ៉ុនមានលក្ខណៈដូចម្តេច?

ពួកអារ្យ៉ែនចូលមកកាន់ប្រទេសឥណ្ឌាបន្តិចម្តងៗ។ ពួកគេប្រតិបត្តិសាសនាមួយដែលពួកដ្រាវិឌជាច្រើនបានចាប់អារម្មណ៍ (ដ្រាវិឌគឺជាប្រជាជនដែលកំពុងរស់ក្នុងប្រទេសឥណ្ឌានៅពេលដែលពួកអារ្យ៉ែនមកដល់)។ ជាលទ្ធផលសាសនា និងភាសារបស់ពួកអារ្យ៉ែនបានរីកសាយភាយ។ ក្នុងការតបស្នង ពួកដ្រាវីឌបានបង្រៀនពួកអារ្យ៉ែនអំពីជីវិតរស់នៅបែបទីក្រុង។ ដោយសារតែទំនាក់ទំនងគ្នាទៅវិញទៅមកនេះហើយ ដែលនាំឱ្យប្រទេសឥណ្ឌាអភិវឌ្ឍវប្បធម៌ចម្រុះ និងស្មុកស្មាញ។

រចនាសម្ព័ន្ធសង្គម៖ សង្គមរបស់អារ្យ៉ែនត្រូវបានរៀបចំទៅតាមថ្នាក់៖ អ្នកប្រយុទ្ធ, បព្វជិត, និងប្រជាជនសាមញ្ញ។ ដូចដែលសង្គមឥណ្ឌាកាន់តែមានលក្ខណៈស្មុកស្មាញ ថ្នាក់ទាំងនេះក្រោយមកបានអភិវឌ្ឍទៅជាប្រព័ន្ធមួយដែលគេហៅថាប្រព័ន្ធវណ្ណៈ។ វណ្ណៈ គឺជាឋានៈក្នុងសង្គមមួយ ដែលមនុស្សស្ថិតនៅក្នុងឋានៈនេះតាមរយៈកំណើតរបស់ពួកគេ។ វណ្ណៈទាំងនេះចាប់ផ្តើមជាប់ទាក់ទងជាមួយនឹងការបែងចែកការងារផ្សេងៗគ្នា។ ជាទូទៅ ក្រុមទាំងនេះត្រូវបានគេរៀបចំទៅជា 4 ក្រុម។ ស្ថិតនៅក្នុងវណ្ណៈព្រាហ្ម មានបព្វជិត, អ្នកប្រាជ្ញ, និងគ្រូបង្រៀន។ វណ្ណៈក្សត្រ រួមមានមេដឹកនាំ, អភិជន, និងអ្នកប្រយុទ្ធ។ វណ្ណៈវៃស្យ រួមមានធនាគារិក, កសិករ, និងពាណិជ្ជករ។ ពួកសូទ្រ រួមមានពួកវិចិត្រករ និងកម្មករ។ ច្រើនសតវត្សរ៍ក្រោយមក មានក្រុមមួយផ្សេងទៀតបានអភិវឌ្ឍឡើង ដែលត្រូវបានគេចាត់ទុកថាស្ថិតនៅវណ្ណៈក្រោមគេបង្អស់។ ក្រុមនេះត្រូវបានគេហៅថា ក្រុមគ្មានវណ្ណៈ។ ពួកគេធ្វើការងារដែលគ្មាននណារចង់ធ្វើ ក្នុងនោះមានដូចជាយកសាកសពទៅបោះចោលជាដើម។

ជំនឿរបស់ពួកអារ្យ៉ែន និងព្រហ្មញ្ញសាសនា៖ សាសនាដំបូងរបស់ពួកអារ្យ៉ែន បច្ចុប្បន្នត្រូវបានគេហៅថាព្រហ្មញ្ញសាសនា យោងទៅតាមឈ្មោះរបស់បព្វជិតអារ្យ៉ែន ឬព្រាហ្ម។ ពួកអារ្យ៉ែនគោរពបូជាអាទិទេពធម្មជាតិជាច្រើន។ ពួកព្រាហ្មធ្វើពីធីបូជាដល់អាទិទេពទាំងនោះតាមរយៈការថ្វាយនូវសត្វទៅក្នុងភ្លើងពិសិដ្ឋ។ បន្តិចម្តងៗ ពិធីបុណ្យនេះចាប់ផ្តើមកាន់តែស្មុកស្មាញទៅៗ។ ពិធីខ្លះមានរយៈពេលរាប់ថ្ងៃ ឬក៏រហូតដល់រាប់ខែក៏មាន។ ក្បួនពិធីនៅក្នុងសាសនារបស់ពួកអារ្យ៉ែន និងចម្រៀងថ្វាយអាទិទេពជាច្រើនត្រូវបានគេរកឃើញនៅក្នុងគម្ពីរពិសិដ្ឋសរសេរជាភាសាសំស្ក្រឹត ដែលគេហៅថាវេទ។ គម្ពីរវេទគឺបណ្តុំនៃពាក្យឧទ្ទិស និងការអប់រំក្បួនពិធីនានា ដែលគេបែងចែកជា 4 ផ្នែក។ ផ្នែកដែលសំខាន់ជាងគេគឺរិកវេទ។ ដូចដែលពេលវេលាកន្លងទៅ ប្រជាជនឥណ្ឌាចាប់ផ្តើមមានចម្ងល់ថាតើពិភពលោកកើតឡើងដោយរបៀបណា? ចម្ងល់នេះបាននាំទៅដល់ការផ្លាស់ប្តូរគំនិតនៅក្នុងសាសនា។ ការផ្លាស់ប្តូរមួយដែលសំខាន់គឺ ពួកគេជឿថាអាទិទេពទាំងឡាយគឺបែងភាគចេញមកពីអាទិទេពតែមួយ។ ក្រោយមកពួកឥណ្ឌាបានសរសេរប្រវត្តិសាស្ត្របុរាណរបស់ពួកគេនៅក្នុងសៀវភៅមួយចំនួន ដូចជាមហាភារតដែលជារឿងនិយាយអំពីទេវកថាជាច្រើន។ ភាគវគិតជាផ្នែកមួយនៅក្នុងសៀវភៅមហាភារត។

បែងចែក៖ ពិពណ៌នាអំពីរចនាសម្ព័ន្ធសង្គមរបស់ពួកអារ្យ៉ែន។

### 3. ហិណ្ឌូនិយម៖ សាសនារបស់ឥណ្ឌា

សំណួរគន្លឹះ៖ តើសាសនាហិណ្ឌូអភិវឌ្ឍឡើងដោយរបៀបណា?

ភាកវគិតគីជាគម្ពីដ៏សំខាន់មួយនៅក្នុងសាសនាហិណ្ឌូ។ សាសនាហិណ្ឌូ គឺជាឈ្មោះសម័យទំនើបសម្រាប់ហៅសាសនាសំខាន់ជាងគេហៅក្នុងប្រទេសឥណ្ឌា ដែលសាសនានេះបានអភិវឌ្ឍចេញមកពីព្រហ្មញ្ញសាសនា។

អាទិទេពច្រើន៖ ពួកហិណ្ឌូគោរពបូជាអាទិទេពច្រើន។ បើទោះបីជាពួកគេជឿលើអាទិទេពច្រើនក៏ដោយ ពួកហិណ្ឌូទទួលស្គាល់ថាមានតែអាទិទេពកំពូលតែមួយអង្គគត់។ ពួកហិណ្ឌូចាត់ទុកថាអាទិទេពផ្សេងៗទៀតគឺជាផ្នែកនៃអាទិទេពកំពូលតែប៉ុណ្ណោះ។ អាទិទេពដែលសំខាន់ជាងគេ 3 អង្គ គឺ ព្រះព្រហ្មជាអទិទេពបង្កើត, ព្រះវិស្ណុះជាអាទិទេពការពារ, និងព្រះសិវៈជាអាទិទេពបំផ្លាញ (ព្រះសិវៈបំផ្លាញចក្រវាំ ហើយទ្រង់ក៏ជាអ្នកបង្កើតថ្មីមកវិញផងដែរ)។

ជីវិតច្រើន៖ ពួកហិណ្ឌូមានជំនឿទៅលើការចាប់ជាតិ ដែលមានន័យថារាល់មនុស្សទាំងអស់មានជីវិតច្រើន។ អ្វីដែលមនុស្សធ្វើនៅក្នុងជីវិតរស់នៅរបស់ពួកគេជាតិនេះ នឹងកំណត់ទៅលើអ្វីដែលពួកគេនឹងទទួលបាននៅជីវិតបន្ទាប់ យោងទៅតាមជំនឿមួយដែលគេហៅថា កម្ម។ នៅក្នុងសាសនាហិណ្ឌូ នេះគឺជាជំនឿដែលថាផលនៃទង្វើរបស់មនុស្សនៅក្នុងជាតិនេះនឹងកំណត់ផលកម្មរបស់ពួកគេនៅជីវិតបន្ទាប់។ ការចាប់ជាតិឡើងវិញបង្កើតបានជាវដ្តនៃជីវិត កើត, ស្លាប់, និងកើតឡើងវិញ។ វដ្តនេះចាប់នៅពេលដែលមនុស្សម្នាក់សម្រេចជោគជ័យក្នុងការភ្ជាប់ខ្លួនជាមួយអាទិទេព។ ដើម្បីសម្រេចជោគជ័យនេះ មនុស្សម្នាក់ត្រូវធ្វើយ៉ាងណាឱ្យព្រលឹងរបស់គេ និងព្រលឹងរបស់អាទិទេពគឺតែមួយ។

មាគ៌ាជាច្រើនទៅកាន់អាទិទេព៖ ពួកហិណ្ឌូជឿថា ពួកគេអាចភ្ជាប់ទំនាក់ទំនងជាមួយអាទិទេពតាមរយៈការដើរតាមមាគ៌ារបស់ពួកគេរៀងៗខ្លួន។ ផ្នែកមួយនៃមាគ៌ាគឺជាប់ទាក់ទងជាមួយការងារ ដែលជាប់ទាក់ទងជាមួយប្រព័ន្ធវណ្ណៈ។ អ្នកជំនឿស៊ុបលើសាសនាហិណ្ឌូ ត្រូវតែប្រតិបត្តិនូវរាល់ភារៈកិច្ចរបស់ពួកគេដោយស្មោះត្រង់។ ពួកហិណ្ឌូមានជម្រើសជាច្រើននៅក្នុងការប្រតិបត្តិខាងផ្លូវអារម្មណ៍ផ្សេងៗ ដើម្បីភ្ជាប់ខ្លួនពួកគេឱ្យកាន់តែជិតអាទិទេព។ មានជម្រើសចំនួន 2 ដែលពេញនិយមសម្រាប់អ្នកមិនមែនហិណ្ឌូនិយម។ ការតាំងសម្មាធិគឺជាការអនុវត្តន៍ដើម្បីឱ្យមានអារម្មណ៍ស្ងប់។ យូហ្គាគឺជាការអនុវត្តដ៏ស្មុកស្មាញមួយ ដោយរួមមានការធ្វើលំហាត់ប្រាណ, បច្ចេកទេសដកដង្ហើម, និងរបបអាហារ។ នៅក្នុងមេរៀនបន្ទាប់ អ្នកនឹងសិក្សាអំពីសាសនាសំខាន់ផ្សេងទៀតនៅក្នុងប្រទេសឥណ្ឌា។

បង្កើតគំនិតទូទៅ៖ ពិពណ៌នាអំពីការអភិវឌ្ឍសាសនាហិណ្ឌូក្នុងប្រទេសឥណ្ឌា។

# មេរៀនទី 3 ៖ ពុទ្ធសាសនា និងយុគមាសនៅឥណ្ឌា

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានដឹងមកហើយ សាសនាហិណ្ឌូគឺជាឈ្មោះសម័យបច្ចុប្បន្ន សម្រាប់ហៅសាសនាសំខាន់ដែលគេគោរពនៅប្រទេសឥណ្ឌា។ សាសនាផ្សេងៗទៀតក៏មានប្រភពដើមចេញមក ពីប្រទេសឥណ្ឌាផងដែរ។ ក្នុងចំណោមសាសនាទាំងនេះ គឺសាសនាជេន។ ជេនបង្រៀនពីអហឹង្សា។ អ្នកកាន់ សាសនាជេនប្រតិបត្តិអហឹង្សាយ៉ាងតឹងរឹងបំផុត។ ពួកគេជឿថា រាល់ជីវិតទាំងអស់សុទ្ធតែមានព្រលឹង ហើយមិន ត្រូវធ្វើឲ្យពួកគេឈឺចាប់ឡើយ។ អ្នកកាន់សាសនាជេនមួយចំនួនថែមទាំងបានពាក់ម៉ាស់ទៀតផង ដើម្បីជៀសវាង ការដកដង្ហើមចូលសត្វល្អិត។

## 1. ការលេចឡើងនៃពុទ្ធសាសនា

សំណួរគន្លឹះ៖ អ្វីទៅជាមូលដ្ឋានគ្រឹះនៃការអប់រំរបស់ពុទ្ធសាសនា?

សាសនាដែលសំខាន់នៅលើពិភពលោកមួយទៀត ដែលគេហៅថាពុទ្ធសាសនា ក៏ចាប់ផ្ដើមឡើងនៅប្រទេស ឥណ្ឌាផងដែរ។ ពុទ្ធសាសនា គឺផ្ដោតសំខាន់ទៅលើការអប់រំទូន្មានរបស់សិទ្ធត្ថគោតម។ ព្រះអង្គគឺជាព្រះអង្គម្ចាស់ មួយអង្គដែលបានលះបង់ទ្រព្យសម្បត្តិ និងតំណែងរបស់ទ្រង់ ដើម្បីព្យាយាមនៅក្នុងការស្វែងយល់អំពីនិយមន័យ ជីវិត។ ក្រោយមក នៅពេលដែលទ្រង់ចាប់ផ្ដើមបង្រៀននូវអ្វីដែលទ្រង់បានរៀនសូត្រចេះដឹង ទ្រង់ត្រូវបានគេហៅ ថាពុទ្ធ ឬ អ្នកត្រាស់ដឹង ។

ជីវិតរស់នៅរបស់ព្រះពុទ្ធ និងការបង្រៀន៖ សិទ្ធត្ថបានកើតក្នុងគ្រួសាររាជវង្សដែលកាន់សាសនាហិណ្ឌូ។ បព្វជិតមួយរូបបានទស្សន៍ទាយថា ទ្រង់នឹងក្លាយជាមនុស្សត្រាច់ចរដ៏ពិសិដ្ឋម្នាក់។ ដើម្បីការពាររឿងនេះ បិតា របស់សិទ្ធត្ថបានបិទបាំងទ្រង់។ សិទ្ធត្ថមិនបានឃើញមនុស្សចាស់, មនុស្សឈឺ, មនុស្សស្លាប់, ឬមនុស្សក្រីក្រ ឡើយ រហូតដល់ទ្រង់មានព្រះជន្ម 29 ព្រះវស្សា។ ចុងក្រោយ នៅពេលដែលទ្រង់បានឃើញពីភាពលំបាកផ្សេងៗ វាបានធ្វើឱ្យទ្រង់មិនសប្បាយចិត្ត។ ទ្រង់បានរត់ចេញពីរាជតំណាក់ដើម្បីស្វែងរកសន្តិភាពនៅក្នុងពិភពនៃការឈឺ ចាប់។ អស់រយៈពេល 6 ឆ្នាំ សិទ្ធត្ថបង្អត់អាហារខ្លួនឯង ប៉ុន្តែការបូជានេះមិនបានជួយទ្រង់នៅក្នុងការស្វែងរក ឃើញចម្លើយដែលទ្រង់កំពង់ស្វែងរកឡើយ។ បន្ទាប់មកទ្រង់បានគង់នៅក្នុងក្រោមដើមពោធិ៍មួយដើម និងធ្វើ សម្មាធិរហូតដល់ទ្រង់ស្វែងរកឃើញការត្រាស់ដឹង។ ការត្រាស់ដឹងនេះបានធ្វើឱ្យទ្រង់យល់ច្បាស់អំពីសច្ចៈភាព ដែលគេហៅថា អរិយសច្ចៈទាំង 4 ។ ទីមួយ ជីវិតរស់នៅរមែងមានការឈឺចាប់។ ទីពីរ ការឈឺចាប់ទាំងនេះកើត ឡើងដោយសារតែពួកគេចង់បាននូវអ្វីដែលពួកគេមិនមាន ឬចង់បានជីវិតរស់នៅដែលខុសពីអ្វីដែលពួកគេមាន។ ទីបី មនុស្សអាចបំបាក់ការឈឺចាប់របស់ពួកគេបានតាមរយៈការលប់បំបាត់ចំណង់។ ទីបួន មនុស្សអាចបញ្ឈប់ ចំណង់របស់ពួកគេបានតាមរយៈមាគ៌ាទាំង 8 ។

មាគ៌ាទាំង 8 រួមមានការគិតត្រូវ, ចំណង់, ការនិយាយ, សកម្មភាព, ការងារ, ការព្យាយាម, ការតាំងចិត្ត, និង ការធ្វើសម្មាធិ។ ផ្លូវនេះអាចនាំទៅដល់ឋាននិព្វាន ដែលជាឋានចុងបញ្ចប់នៃការឈឺចាប់។ ការធ្វើដំណើរទៅដល់

ឋានិព្វានអាចបញ្ចប់នូវវដ្តនៃការកើតចាស់ឈឺស្លាប់។ ព្រះពុទ្ធជឿទៅលើការប្រតិបត្តិអហឹង្សា ប៉ុន្តែទ្រង់មិនគោរពបូជាលើអាទិទេពនៅក្នុងសាសនាហិណ្ឌូឡើយ។ បន្ទាប់ពីព្រះពុទ្ធសុគត់ទៅ អ្នកដើរតាមទ្រង់ប្រមូលផ្តុំពាក្យអប់រំរបស់ទ្រង់ដើម្បីបង្រៀនទៅកាន់អ្នកដទៃ។ ការប្រមូលផ្តុំចងក្រងពាក្យអប់រំទាំងនេះត្រូវបានគេហៅថាធម្ម ដែលមានន័យថាធម្មជាតិពិតនៃជីវិត។ ធម្មជាជាទូទៅត្រូវបានគេបង្ហាញដូចជាកង់រទេះមួយ។

សង្ខេប៖ ពិពណ៌នាអំពីមូលដ្ឋានគ្រឹះនៃការអប់រំរបស់ពុទ្ធសាសនា។

## 2. ចក្រភពមោរ្យ

សំណួរគន្លឹះ៖ អ្វីទៅជាស្នាដៃសំខាន់ៗរបស់ស្តេចអាសោកនៅអំឡុងពេលនៃការគ្រប់គ្រងរបស់ទ្រង់នៅក្នុងចក្រភពមោរ្យ ?

ហេតុផលមួយដែលនាំឱ្យពុទ្ធសាសនាមានឥទ្ធិពលខ្លាំងគឺដោយសារស្តេចដ៏ល្បីល្បាញមួយអង្គរបស់ឥណ្ឌាដឹកនាំប្រទេសតាមរយៈការអប់រំរបស់ពុទ្ធសាសនា។ ដូចដែលអ្នកបានអាន ទ្រង់គឺជាស្តេចទី 3 នៃសន្តិវង្សមោរ្យដែលបានបង្រួបបង្រួមប្រទេសឥណ្ឌា។

បង្រួបបង្រួមឥណ្ឌា៖ អស់រយៈពេលជាច្រើនឆ្នាំ ព្រះរាជាណាចក្រអារ្យនផ្សេងៗបានវាយប្រយុទ្ធគ្នាទៅវិញទៅមក។ នៅរវាងឆ្នាំ 550 មុនគ.ស មគធៈព្រះរាជាណាចក្រមួយស្ថិតនៅភាគឦសាន ចាប់ផ្តើមពង្រីកអំណាចរបស់ខ្លួន។ នៅឆ្នាំប្រហែល 321 មុនគ.ស ចន្ទ្រាគុប្តៈមោរ្យាបានឡើងធ្វើជាស្តេចនៅមគធៈ។ ទ្រង់បានឈ្លានពានដណ្តើមកាន់កាប់ដែនដីជាច្រើន។ ចន្ទ្រាគុប្តៈមានធ្វើដំណើរទៅកាន់ភាគពាយព្យ ដណ្តើមកាន់កាប់ដែនដីទាំងអស់ដែលស្ថិតនៅចន្លោះចាប់ពីមគធៈទៅដល់ជ្រលងទន្លេឥណ្ឌូស។ ចក្រភពមោរ្យរបស់ទ្រង់យ៉ាងឆាប់ហើសបានគ្របដណ្តប់មួយភាគធំលើដែនដីឧបទ្វីបឥណ្ឌា។ ចន្ទ្រាគុប្តៈគ្រប់គ្រងចក្រភពរបស់ទ្រង់តាមរយៈការប្រើប្រាស់ចារកិច្ចដើម្បីសិក្សាពីអ្វីដែលប្រជាជនបានធ្វើ និងប្រើប្រាស់កងទ័ពដើម្បីរក្សាសណ្តាប់ធ្នាប់។ កងទ័ពដ៏ច្រើនរបស់ទ្រង់ រួមមានកងទ័ពថ្មើរជើង 60 ម៉ឺននាក់, កងទ័ពសេះ 3 ម៉ឺននាក់, និងដំរី 9 ពាន់ក្បាល់។ មានមន្ត្រីរាជការជាច្រើនធ្វើការនៅក្នុងជួររដ្ឋាភិបាល។ ដើម្បីចំណាយទៅលើមន្ត្រីរាជការទាំងអស់នេះ ចន្ទ្រាគុប្តៈបានហូតពន្ធលើដីធ្លី និងទន្និផលកសិកម្មយ៉ាងធ្ងន់ធ្ងរ។ តាមរយៈរឿងព្រេង បាននិយាយថា នៅចុងបញ្ចប់នៃជីវិតរបស់ទ្រង់ ទ្រង់បានក្លាយជាព្រះសង្ឃអហឹង្សានៃសាសនាជេន។

ព្រះបាទអសោក, ស្តេចពុទ្ធសាសនិក៖ ស្តេចដែលល្បីល្បាញបំផុតនៅក្នុងសន្តតិវង្សមោរ្យាគឺ ចៅប្រុសរបស់ចន្ទ្រាគុប្តៈព្រះនាមអសោកដែលបានឡើងគ្រង់រាជ្យនៅក្នុងឆ្នាំ 272 មុនគ.ស។ នៅដើមដំបូងនៃរាជ្យរបស់ទ្រង់ទ្រង់បានធ្វើសង្គ្រាមដ៏បង្ហូរឈាមមួយ និងធ្វើការឈ្លានពានដណ្តើមកាន់កាប់ព្រះរាជាណាចក្រជិតខាងមួយ។ បន្ទាប់មក ព្រះបាទអសោកក៏សម្រេចចិត្តធ្វើការដឹកនាំប្រទេសតាមរយៈពាក្យទូន្មានរបស់ពុទ្ធសាសានា។ ទ្រង់បានលះបង់ការធ្វើសង្គ្រាម។ ទ្រង់បានព្យាយាមនៅក្នុងគ្រប់គ្រងដោយសន្តិភាពតាមរយៈការប្រើប្រាស់ច្បាប់។ ព្រះបាទអសោកបានឆ្លាក់គោលនយោបាយរបស់ទ្រង់នៅលើផ្ទាំងថ្ម និងសរសេរស្តម្ភនានា។ ផ្ទាំងថ្មដែលនៅសះសល់តាំងពីរាជ្យ

របស់ទ្រង់ បានណែនាំឱ្យមនុស្សទៀងទ្រង់ និងករុណា។ មានផ្ទាំងថ្មមួយចំនួនជម្រុញឱ្យមនុស្សមិនត្រូវសម្រាប់ជីវិតសត្វឡើយ។

ជាលទ្ធផល តាមរយៈបរិបាលកិច្ចរបស់ព្រះបាទអសោក ពុទ្ធសាសនាបានទាក់ទាញមនុស្សឱ្យចូលរួមធ្វើជាសាមណៈសង្ឃ។ ព្រះបាទអសោក និងមេដឹកនាំដែលជាពុទ្ធសាសនិកមួយចំនួនទៀតដែលសោយរាជ្យបន្តពីទ្រង់បានបញ្ជូនបេសកទូតដើម្បីផ្សព្វផ្សាយពីពុទ្ធសាសនា។ នៅក្នុងពេលជាមួយគ្នានោះ ទ្រង់បានអនុញ្ញាតឱ្យប្រជាជនដែលមានជំនឿលើសាសនាផ្សេងទៀតអាចគោរពបូជាសាសនារបស់ពួកគេបានដោយសេរី។ មន្ត្រីរបស់ព្រះបាទអសោកដាំដើមឈើ, ជីកអណ្តូង, បង្កើតមន្ទីរពេទ្យ, និងស្ថាបនាសាលាសំណាក់នៅតាមផ្លូវ។ ការអភិវឌ្ឍនេះបានអនុញ្ញាត្តិឱ្យប្រជាជនអាចធ្វើដំណើរបានងាយស្រួលជាងមុន។ ស្ថានភាពនៅក្នុងការធ្វើដំណើរកាន់តែប្រសើរបានជួយសម្រួលដល់ពួកពាណិជ្ជករ និងមន្ត្រីរាជការ។ សកម្មភាពមួយចំនួនបានបង្ហាញពីការយកចិត្តទុកដាក់របស់ព្រះបាទអសោកចំពោះសុខុមាលភាពរបស់ប្រជានុរាស្ត្រទ្រង់។ ដោយសារតែការអនុវត្តគោលនយោបាយរបស់ទ្រង់ពួកអភិជនបរាជ័យនៅក្នុងការគ្រប់គ្រងចក្រភពរួមគ្នា បន្ទាប់ពីការសោយទិវង្គត់របស់ព្រះបាទអសោកនៅក្នុងឆ្នាំ 230 មុនគ.ស។

ការផ្លាស់ប្តូរទៅសាសនាហិណ្ឌូ៖ ដោយសារប្រជាប្រិយភាពរបស់ពុទ្ធសាសនា បណ្តាលឱ្យមនុស្សតិចតួចប៉ុណ្ណោះដែលគោរពបូជាអាទិទេពក្នុងសាសនាហិណ្ឌូ។ សាសនាហិណ្ឌូដំបូងមានពិធីបូជាយញ្ញដ៏ស្មុកស្មាញ ដែលមានតែពួកបព្វជិតតែប៉ុណ្ណោះដែលអាចប្រតិបត្តិបាន។ ពួកគេអនុវត្តក្បួនពិធីនៅក្នុងគម្ពីរភាសាសំស្រ្កឹត ដែលមានមនុស្សតិចតួចប៉ុណ្ណោះដែលចេះភាសានេះ។ ហេតុផលនេះហើយ ដែលនាំឱ្យប្រជាជនមានអារម្មណ៍ហាក់ដូចជានៅឆ្ងាយពីអាទិទេព។ មានមនុស្សជាច្រើនបានប្រែត្រឡប់ទៅជឿលើពុទ្ធសាសនាវិញ។ មេដឹកនាំដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ពុទ្ធសាសនាបានលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរនេះ។

បន្ទាប់មកពួកហិណ្ឌូបានចាប់ផ្តើមគិតអំពីការផ្លាស់ប្តូររបស់ខ្លួន។ កវីចាប់ផ្តើមសរសេរកំណាព្យសម្រាប់បព្វជិតសូត្រថ្វាយអទិទេពវិស្ណុ និងសិវៈ។ កំណាព្យទាំងនេះត្រូវបានសរសេរឡើងជាភាសាដែលមនុស្សទូទៅនិយាយជាជាងសរសេរជាភាសាសំស្រ្កឹត។ កំណាព្យចាប់ផ្តើមមានប្រជាប្រិយភាពនៅពាលពេញប្រទេសឥណ្ឌា។ ជាលទ្ធផលប្រជាជនឥណ្ឌាចាប់ផ្តើមចាប់អារម្មណ៍សារជាថ្មីទៅលើអាទិទេពក្នុងសាសនាហិណ្ឌូរបស់ពួកគេ។ ការចាប់អារម្មណ៍សារជាថ្មីទៅលើសាសនាហិណ្ឌូនេះកើតឡើងតំណាលគ្នាជាមួយនឹងការធ្លាក់ចុះនៃពុទ្ធសាសនា។ ជាយថាហេតុពុទ្ធសាសនាបានបាត់បង់អ្នកគាំទ្រស្ទើតែទាំងស្រុងនៅក្នុងប្រទេសឥណ្ឌា។ ប៉ុន្តែ នៅពេលនោះ ពុទ្ធសាសនាបានរីកសាយភាយទៅកាន់ប្រទេសជាច្រើននៅអាស៊ី។

ស្វែងរកគំនិតសំខាន់៖ កំណត់អំពីស្នាដៃសំខាន់របស់ព្រះបាទអសោក។

### 3. យុគមាសនៃគុប្តៈ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាសម័យនៃការគ្រប់គ្រងរបស់គុប្តៈគឺជាយុគមាសនៅឥណ្ឌា?

ភ្លាមៗបន្ទាប់ពីព្រះបាទអសោកសុគត ចក្រភពមោរ្យាបានដួលរលំ ដោយសារមេដឹកនាំខ្សោយ និងការឈ្លានពានពីសត្រូវ។ ជម្លោះកើតឡើងជាបន្តបន្ទាប់អស់រយៈពេល 5 សតវត្សរ៍ រហូតដល់រាជវង្ស កុប្តៈគ្រប់គ្រង។

ចក្រភពកុប្តៈ៖ ក៏ដូចជារាជវង្សមោរ្យាដែរ រាជវង្សកុប្តៈចាប់ផ្តើមក្លាយជាមេដឹកនាំនៅមគធៈ ។ ចន្ទ្រាកុប្តៈទី 1 បានក្លាយជាស្តេចនៅក្នុងឆ្នាំ 320 នៃគ.ស។ (ទ្រង់មិនជាប់ទំនាក់ទំនងជាមួយចន្ទ្រាកុប្តៈមោរ្យាឡើយ)។ ភ្លាមៗ ទ្រង់បានរៀបអភិសេកជាមួយរាជបុត្រីមួយអង្គរបស់ស្តេច និងទទួលបានទឹកដីថ្មីដើម្បីគ្រប់គ្រង។ ក្រោយមក រាជបុត្រារបស់ទ្រង់បានពង្រីកចក្រភពតាមរយៈការធ្វើសង្គ្រាម។ ប៉ុន្តែ ចៅប្រុសរបស់ចន្ទ្រាកុប្តៈ ព្រះនាមចន្ទ្រាកុប្តៈទី 2 គឺជាមេដឹកនាំល្បីល្បាញជាងគេនៅក្នុងរាជវង្ស។ នៅអំឡុងរាជរបស់ទ្រង់ (375 ដល់ 415 នៃគ.ស) ប្រទេសឥណ្ឌាឆ្លងកាត់នូវយុគមាស ដែលជាពេលវេលាដែលសម្រេចជោគជ័យដ៏អស្ចារ្យ។

សិល្បៈ និងអក្សរសាស្ត្រ៖ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ចន្ទ្រាកុប្តៈទី 2 សិល្បៈរបស់ឥណ្ឌាចាប់ផ្តើមរីកចម្រើន។ ស្ថាបត្យករបានស្ថាបនាប្រាសាទដែលរចនាឡើងយ៉ាងល្អប្រសើរ។ វិចិត្រករគូរគំនូរនៅលើជញ្ជាំង និងឆ្លាក់រូបបដិមា។ រូបគំនូរនៅលើជញ្ជាំង និងរូបចម្លាក់ជាច្រើនជាប់ទាក់ទងជាមួយសាសនា។ វីរកថាជាភាសាសំស្ក្រឹតសម័យបុរាណ មហាភារតបានក្លាយជាមូលដ្ឋានគ្រឹះនៃអ្នកនិពន្ធល្ខោននៅក្នុងសម័យកុប្តៈ។ កវីនិពន្ធក៏រីកចម្រើនផងដែរនៅក្នុងសម័យនេះ។

គណិតវិទ្យា និងវិទ្យាសាស្ត្រ៖ គណិតវិទ្យារបស់ឥណ្ឌាស្ថិតនៅក្នុងចំណោមប្រទេសដែលជឿនលឿនបំផុតនៅលើពិភពលោក។ អ្នកប្រាជ្ញឥណ្ឌាបានបង្កើតប្រព័ន្ធលេខដែលយើងប្រើប្រាស់សព្វថ្ងៃ។ ពួកគេក៏បានអភិវឌ្ឍប្រព័ន្ធទសភាគ និងលេខសូន្យផងដែរ។ (ពួកម៉ាយ៉ានៅអាមេរិកកណ្តាលក៏អះអាងថាជាអ្នកមានគំនិតបង្កើតលេខសូន្យដូចគ្នា)។ គណិតវិទូមួយរូបបានគិតចេញអំពីថេរវេលាក្នុងមួយឆ្នាំ។ លោកក៏បានប៉ាន់ប្រមាណអំពីតម្លៃនៃភីដែលអ្នកនឹងរៀននៅពេលដែលអ្នករៀនធរណីមាត្រ។ ភីគឺជាលេខដែលប្រើសម្រាប់គណនាអំពីប្រវែងនៃរង្វង់ដែលគេហៅថាបរិមាត្រ។

អំឡុងសម័យចក្រភពកុប្តៈ ចំណេះដឹងអំពីតារាសាស្ត្របានកើនឡើង។ ស្ទើតែ 1,000 ឆ្នាំមុន កូប៉ឺនីសតារាវិទូឥណ្ឌាបានបង្ហាញថាផែនដីមានរាងមូលតាមរយៈការអង្កេតច័ន្ទគ្រាស។ អំឡុងពេលនៃច័ន្ទគ្រាស ស្រមោលនៃផែនដីលុបពីលើពន្លឺព្រះច័ន្ទ។ ពួកតារាវិទូបានកត់សំគាល់ថា ស្រមោលរបស់ផែនដីមានរាងកោង ដែលចង្អុលបង្ហាញថាផែនដីគឺមានរាងមូល។

វេជ្ជបណ្ឌិតបានបន្ថែមបច្ចេកទេសថ្មីបន្ថែមទៀត ទៅលើការអនុវត្តបែបបុរាណតាមក្បួនគម្ពីរវេជ្ជសាស្ត្រអាយុវេទ។ វាបានលើកកម្ពស់សុខភាពតាមរយៈរបបអាហារ និងលំហាត់ប្រាណ។

កិច្ចការទាក់ទងនឹងលោហៈ៖ វិចិត្រករឥណ្ឌាបានអភិវឌ្ឍវិធីសាស្ត្រជឿនលឿនមួយនៅក្នុងការលោហស្សាកម្ម (កិច្ចការទាក់ទងនឹងលោហៈ)។ នៅខាងក្រៅទីក្រុងឌេលីសរសរស្តម្ភធ្វើពីដែកមួយត្រូវបានសាងសងឡើងនៅអំឡុងឆ្នាំ 400 នៃគ.ស ដែលមានកម្ពស់ជាង 20 ហ្វីត (ជាង 6 ម៉ែត្រ)។ មិនមានមនុស្សណាដែលអាចផលិតបំពង់ដែលដ៏ធំបែបនេះឡើយ រហូតដល់យ៉ាងហោចណាស់ 1,000 ឆ្នាំក្រោយមកទៀត។ ខុសពីដែកផ្សេងៗទៀត សរសរ

ស្តម្ភបានតស៊ូជាមួយនឹងច្រេះចាប់អស់រយៈពេល 16 សតវត្សរ៍។ មានការពន្យល់មួយថា ដោយសារតែសរសរដែកនេះមានផ្ទុកនូវសារធាតុផូសស្វ័រច្រើនជាងដែកដែលគេផលិតបច្ចុប្បន្ន។ ជាលទ្ធផល ស្រទាប់ការពារមួយបានលេចឡើងនៅលើផ្ទៃសរសរស្តម្ភនោះ។

ការរីកសាយភាយនៃពាណិជ្ជកម្ម និងវប្បធម៌៖ រាជវាំងរបស់រាជវង្សគុប្តៈគឺជាកន្លែងមួយដែលមានភាពអស្ចារ្យ និងរីកចម្រើន។ ប្រជាជនឥណ្ឌាគោរពស្តេចដោយសារតែភាពអង់អាចក្លាហានរបស់ទ្រង់។ ព្រះមហាក្សត្របង្ហាញពីភាពអង់អាចក្លាហាននេះតាមរយៈការពង្រីកទឹកដីរបស់ចក្រភព ដែលបានអនុញ្ញាតឱ្យចក្រភពគុប្តៈរបស់ឥណ្ឌាអាចពង្រីក និងទទួលផលចំនេញច្រើនពីការធ្វើពាណិជ្ជកម្មអន្តរជាតិ។ពួកពាណិជ្ជករលក់ទំនិញឥណ្ឌា ដែលមានដូចជាកប្បាស និងភ្លុកឱ្យទៅពាណិជ្ជករបរទេស។ ពាណិជ្ជករឥណ្ឌាបានទិញទំនិញពីប្រទេសចិន ដែលមានដូចជាសូត្រជាដើម។ ពួកគេយកទំនិញនេះទៅលក់បន្តឱ្យពាណិជ្ជករដែលធ្វើដំណើរទៅភាគខាងលិច។

ទាំងពាណិជ្ជករ និងបេសកទូសាសនាបានពង្រីកវប្បធម៌ និងជំនឿរបស់ឥណ្ឌា។ សាសនាហិណ្ឌូបានរីកសាយភាយនៅផ្នែកមួយចំនួននៃអាស៊ីអាគ្នេយ៍។ ពុទ្ធសាសនាបន្តិចម្តងៗបានរីកសាយភាយនៃអាស៊ីកណ្តាល, ស្រីលង្កា(ពីមុនមកគេហៅសីឡុន), ចិន, និងអាស៊ីអាគ្នេយ៍។ ដោយថាហេតុ ឥទ្ធិពលនៃសាសនាហិណ្ឌូបានធ្លាក់ចុះនៅអាស៊ីអាគ្នេយ៍ ប៉ុន្តែ វានៅបន្តជាសាសនាគ្របដណ្តប់នៅក្នុងប្រទេសឥណ្ឌា។ ចំណែកពុទ្ធសាសនាវិញរីកចម្រើននៅអាស៊ីអាគ្នេយ៍ តែមិនពេញនិយមនៅប្រទេសឥណ្ឌាទេ។ នៅក្នុងមេរៀនបន្ទាប់ស្តីអំពីកេរ្តិ៍ដំណែលរបស់ឥណ្ឌា អ្នកនឹងបានឃើញពីសមិទ្ធផលរបស់ឥណ្ឌា ដែលជះឥទ្ធិពលទៅកាន់តំបន់នានានៅលើពិភពលោក។ ក្នុងចំណោមនោះមានសាសនា, អក្សរសាស្ត្រ, ល្ខោន, សិល្បៈ, ចម្លាក់, និងស្ថាបត្យកម្ម។

ស្វែងរកគំនិតសំខាន់៖ ពិភាក្សាពីមូលហេតុដែលនាំឱ្យគេចាត់ទុកសម័យនៃការគ្រប់គ្រងរបស់ចក្រភពគុប្តៈថាជាយុគមាសនៅឥណ្ឌា។

# មេរៀនទី 4 ៖ កេរ្តិ៍តំណែលរបស់ឥណ្ឌា

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅសម័យបុរាណ ពាណិជ្ជកម្មបានបានធ្វើឱ្យសាសនា និងសិល្បៈរបស់ឥណ្ឌារីកសាយភាយទៅកាន់ផ្នែកផ្សេងៗទៀតនៅក្នុងទ្វីបអាស៊ី។ វប្បធម៌របស់ឥណ្ឌាបានបន្តជះឥទ្ធិពលមកលើពិភពលោកនាពេលបច្ចុប្បន្ន។

## 1. កេរ្តិ៍តំណែលសាសនារបស់ឥណ្ឌា

សំណួរគន្លឹះ៖ តើសាសនារបស់ឥណ្ឌាជះឥទ្ធិពលយ៉ាងដូចម្តេចទៅលើវប្បធម៌របស់ប្រទេសដ៏ទៃ ?

យូហ្គាមានវ័យចំណាស់តាំងពីភគវគិត ហើយបច្ចុប្បន្នវាគឺជាមុខវិជ្ជាមួយដែលគេបង្រៀននៅក្នុងក្លឹបសុខភាព។ ភាពរុងរឿងរបស់វាបានបង្ហាញថា សាសនាប្រពៃណីបុរាណរបស់ឥណ្ឌាគឺនៅតែមានឥទ្ធិពលរហូតមកដល់បច្ចុប្បន្ន។

សាសនាហិណ្ឌូ និងពុទ្ធសាសនានាពេលបច្ចុប្បន្ន៖ មនុស្ស 4 នាក់ក្នុងចំណោម 5 នាក់ដែលរស់នៅប្រទេសឥណ្ឌាបច្ចុប្បន្នគឺជាអ្នកជឿលើសាសនាហិណ្ឌូ។ អ្នកកាន់សាសនាហិណ្ឌូមួយចំនួនស្ថិតនៅក្នុងប្រទេសនេប៉ាល់, ស្រីលង្កា, ម៉ាឡេស៊ី, និងប្រទេសជាច្រើនទៀត។ មានប្រជាជនប្រមាណមួយលាននាក់នៅសហរដ្ឋអាមេរិកគឺជាអ្នកប្រតិបត្តិសាសនាហិណ្ឌូ។ ពុទ្ធសាសនាមិនមានអ្នកជឿច្រើនទេនៅប្រទេសឥណ្ឌានាពេលបច្ចុប្បន្ន។ មានប្រជាជនឥណ្ឌាមិនដល់មួយភាគរយផងដែលជាពុទ្ធសាសនិក។ ប៉ុន្តែសាសនានេះមានប្រជាប្រិយភាពខ្លាំងនៅក្នុងទ្វីបអាស៊ី, អឺរ៉ុបខាងលិច, និងសហរដ្ឋអាមេរិក។

ឥទ្ធិពលនៃសាសនាហិណ្ឌូ និងពុទ្ធសាសនា៖ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1900 មេដឹកនាំឥណ្ឌា មហាត្មិៈ គន្ធីបានប្រើប្រាស់ធម៌អហឹង្សាប្រឆាំងជាមួយពួកអង់គ្លេសដើម្បីទាមទារឯករាជ្យឱ្យប្រទេសឥណ្ឌា។ នៅក្នុងជីវិតរស់នៅរបស់លោក លោកបានបំផុសឱ្យមេដឹកនាំសិទ្ធិស៊ីវិលអាមេរិកលោកម៉ាទីន លូជឺខីង ជេអ. ដឹកនាំការបាតុកម្មអហឹង្សាដើម្បីទាមទារសិទ្ធិសម្រាប់ប្រជាជនអាមេរិកស្បែកខ្មៅ។ បច្ចុប្បន្នឥទ្ធិពលនៃសាសនាហិណ្ឌូ និងពុទ្ធសាសនានៅតែបន្ត។ ឧទាហរណ៍ មានមនុស្សជាច្រើនលាននាក់ដែលមកពីសាសនាផ្សេងៗ ធ្វើសមាធិក និងអនុវត្តយូហ្គា។

ស្វែងរកគំនិតសំខាន់៖ ពិពណ៌នាអំពីរបៀបដែលសាសនារបស់ឥណ្ឌាជះឥទ្ធិពលលើវប្បធម៌ដ៏ទៃ។

## 2. កេរ្តិ៍តំណែលសិល្បៈរបស់ឥណ្ឌា

សំណួរគន្លឹះ៖ តើសមិទ្ធផលសំខាន់ៗនៃសិល្បៈរបស់ឥណ្ឌាមានអ្វីខ្លះ ?

សិល្បៈរបស់ឥណ្ឌាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើពិភពលោក។ ឥទ្ធិពលនេះយើងអាចឃើញមាននៅលើអក្សរសិល្ប៍, សិល្បៈ និងចម្លាក់, និងស្ថាបត្យកម្ម។

អក្សរសិល្ប៍៖ អ្នកនិពន្ធដ៏ល្បីល្បាញបំផុតរបស់ឥណ្ឌាគឺលោកកាលីដាសា។ លោកអាចជាកវីប្រចាំរាជវាំងរបស់ស្តេចចន្ទ្រាកុប្តៈទី 2 ។ ស្នាដៃដ៏ល្បីល្បាញបំផុតរបស់លោកកាលីដាសាគឺល្ខោនរឿងសាគុណាតាឡា។ វាបានប្រាប់ពីរឿងរ៉ាវនៃស្ត្រីដ៏ស្រស់ស្អាតមួយរូបដែលបានធ្លាក់ក្នុងអន្លង់ស្នេហ៍ និងបានរៀបអភិសេកជាមួយស្តេចវ័យ

កណ្ដាលមួយអង្គ។ បន្ទាប់ពីសាគុណតាឡា និងស្វាមីរបស់នាងបែកបាក់គ្នា ពួកគេមានភាពឈឺចាប់ក្រៃលែង ដោយសារតែបណ្ដាសាមួយដែលបានរារាំងស្ដេចមិនឱ្យចំណាំមហេសីរបស់ទ្រង់ឡើងនៅពេលដែលទ្រង់ជួបនាងម្ដងទៀត។ ប្រជាជនជំនាន់ថ្មីនៅក្នុងប្រទេសឥណ្ឌានៅតែបន្តស្ងើចសរសើរស្នាដៃល្ខោននានារបស់លោកកាលីដាសាដោយសារតែល្ខោនទាំងនោះសរសេរឡើងដោយភាពប៉ុនប្រសព្វ និងរំជួលអារម្មណ៍។ ឥណ្ឌាខាងត្បូងក៏សម្បូរទៅដោយអក្សរសិល្ប៍ប្រពៃណីផងដែរ។ នៅក្នុងឆ្នាំ 100 នៃគ.ស ទីក្រុងម៉ាឌូរៃដែលស្ថិតនៅភាគខាងត្បូងប្រទេសឥណ្ឌា បានក្លាយជាតំបន់សម្រាប់ការសរសេរវិជ្ជាជាន់ខ្ពស់។ មានកំណាព្យជាភាសាតាមិលច្រើនជាង 2,000 នៅក្នុងសម័យនោះ បន្តមានវត្តមានរហូតដល់បច្ចុប្បន្ន។

ល្ខោន៖ បន្ថែមពីលើអក្សរសិល្ប៍ ល្ខោនមានភាពពេញនិយមយ៉ាងខ្លាំងនៅក្នុងប្រទេសឥណ្ឌានាសម័យបុរាណ។ នៅឥណ្ឌាភាគខាងត្បូង តួអង្គល្ខោនបានធ្វើដំណើរទៅសំដែងពីទីក្រុងមួយទៅកាន់ទីក្រុងមួយនៅពាសពេញតំបន់។ ស្ត្រីក៏ដូចជាបុរសដែល បានចូលរួមនៅក្នុងការសំដែងទាំងនេះផងដែរ ដោយបានរួមបញ្ចូលគ្នាទាំងល្ខោន និងរបាំ។ ទម្រង់នៃរបាំសម័យបុរាណជាច្រើនរបស់ឥណ្ឌានាពេលបច្ចុប្បន្នគឺឈរលើមូលដ្ឋាននៃបច្ចេកទេស ដែលបានពន្យល់នៅក្នុងសៀវភៅមួយដែលសរសេរឡើងនៅអំឡុងសម័យនោះ។ នៅក្នុងបណ្ដាលប្រទេសជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រជាជនសម្ដែងល្ខោនដោយឈរលើមូលដ្ឋាននៃទេវកថាជាភាសាសំស្ក្រឹតសម័យបុរាណមហាភារតៈ។ គម្ពីភគវគិតត្រូវបានបកប្រែទៅជាភាសាផ្សេងៗ ហើយវាត្រូវបានគេអាចនៅពាសពេញពិភពលោក។

សិល្បៈ និងចម្លាក់៖ សិល្បៈ និងចម្លាក់ឥណ្ឌាបានជះឥទ្ធិពលលើសិល្បៈរបស់ប្រទេសដ៏ទៃទៀត។ ទាំងសិល្បៈសាសនាហិណ្ឌូ និងពុទ្ធសាសនាមានសារៈសំខាន់នៅក្នុងការអភិវឌ្ឍសិល្បៈនៅក្នុងប្រទេសឥណ្ឌា។ ភាពខុសគ្នាដ៏សំខាន់រវាងសិល្បៈពុទ្ធសាសនា និងសិល្បៈសាសនាហិណ្ឌូនៅក្នុងប្រទេសឥណ្ឌាគឺប្រធានបទរបស់វា។ សិល្បៈពុទ្ធសាសនាជាទូទៅគឺគំនូរស្ដីអំពីព្រះពុទ្ធ ឬសាវៈនានារបស់ព្រះពុទ្ធ។ អាទិទេពក្នុងសាសនាហិណ្ឌូ មានដូចជាព្រះវិស្ណុ និងព្រះហ្គីនេសគឺជាប្រធានបទសំខាន់នៅក្នុងសិល្បៈហិណ្ឌូ។ នៅពីក្រោយនៃភាពខុសគ្នានៃប្រធានបទ ជំនឿបែបហិណ្ឌូ និងពុទ្ធ មានឥទ្ធិពលតិចតួចមកលើរចនាបថសិល្បៈឥណ្ឌា។ ឧទាហរណ៍ ចម្លាក់បែបសាសនាហិណ្ឌូ និងចម្លាក់បែបពុទ្ធសាសនាបង្កើតឡើងក្នុងពេលតំណាលគ្នា ហើយមានរចនាបថដូចគ្នា។ តាមពិតទៅ ជាទូទៅវិចិត្រក៏តែម្នាក់ ប៉ុន្តែបានបង្កើតស្នាដៃសិល្បៈទាំងបែបសាសនាហិណ្ឌូ និងបែបពុទ្ធសាសនា។

ស្ថាបត្យកម្ម៖ ឥទ្ធិពលនៃជំនឿបែបហិណ្ឌូ យើងអាចឃើញនៅក្នុងស្ថាបត្យកម្មឥណ្ឌា។ ទម្រង់ស្ថាបត្យកម្មជាច្រើនចាប់ផ្ដើមឡើងនៅក្នុងសម័យកុប្តៈ។ ទម្រង់ស្ថាបត្យកម្មទាំងនេះរួមមាន ការស្ថាបនាសំណង់ជាមួយនឹងថ្មជាជាងការធ្វើពីឈើ, សាងសងលើទីខ្ពស់, ដំបូលលើរាងពីរ៉ាមីតជំនួសដំបូលរាបស្មើ, និងចម្លាក់លម្អនៅលើដំបូល។ ឥទ្ធិពលនៃស្ថាបត្យកម្មឥណ្ឌាបានរីកសាយភាយនៅពាសពេញតំបន់អាស៊ីអាគ្នេយ៍ ដោយរួមមាន ប្រទេសភូមា, ថៃ, ឡាវ, វៀតណាម, និងកម្ពុជា។

នៅភាគឦសាននៃប្រទេសកម្ពុជា ស្ថាបត្យករសម័យបុរាណបានសាងសង់សំណង់ប្រាសាទសាសនាហិណ្ឌូដ៏ធំមួយដែលគេហៅថាអង្គរវត្ត។ ទម្រង់ស្ថាបត្យកម្មដែលចាប់ផ្ដើមនៅក្នុងសម័យកុប្តៈត្រូវបានប្រើប្រាស់នៅក្នុង

សំណង់ប្រាសាទនេះ ដែលបានសាងសង់ឡើងនៅក្នុងទសវត្សរ៍ឆ្នាំ 1100 នៃគ.ស។ វាគឺជាសំណង់ប្រាសាទសាសនាដែលធំជាងគេនៅលើពិភពលោក ហើយក៏ត្រូវបានគេចាត់ទុកថាជាស្នាដៃស្ថាបត្យកម្មមួយក្នុងចំណោមស្នាដៃស្ថាបត្យកម្មដែលល្អបំផុតនៅលើពិភពលោក។ វាត្រូវបានស្ថាបនាឡើងជាភ្នំសប្បនិមិត្តមួយដើម្បីឧទ្ទិសដល់អាទិទេពក្នុងហិណ្ឌូគឺព្រះវិស្ណុ។ ប៉ុន្តែ ប៉ុន្មានសតវត្សរ៍ក្រោយមកប្រាសាទមួយនេះ ត្រូវបានប្រែក្លាយជាប្រាសាទពុទ្ធសាសនា។ ឥទ្ធិពលរបស់ឥណ្ឌាត្រូវបានគេមើលឃើញនៅក្នុងរចនាបទរបស់ប្រាសាទអង្គរវត្ត។ ឧទាហរណ៍សំណង់ប្រាសាទនេះមានដំបូលរាងពីរ៉ាមីត។ ប្រាសាទនេះធ្វើអំពីថ្ម ដែលតែងលម្អដោយចម្លាក់នៅលើដំបូល និងជញ្ជាំង។ សំណង់ប្រាសាទនេះគ្របដណ្តប់លើផ្ទៃដីជិតមួយម៉ាយការ៉េ។

ស្វែងរកគោលគំនិតរួម៖ ពិភាក្សាអំពីស្នាដៃសិល្បៈសំខាន់ៗមួយចំនួនរបស់ឥណ្ឌា។

### 3. កេរ្តិ៍តំណែលគណិតវិទ្យារបស់ឥណ្ឌា

សំណួរគន្លឹះ៖ តើចំណេះដឹងគណិតសាស្ត្ររបស់ឥណ្ឌាបុរាណជះឥទ្ធិពលយ៉ាងដូចម្តេចមកលើជីវភាពរស់នៅរបស់យើងនាពេលបច្ចុប្បន្ន?

ប្រព័ន្ធលេខត្រូវបានប្រើប្រាស់ដំបូងនៅក្នុងប្រទេសឥណ្ឌា។ ប្រជាជននៅក្នុងប្រទេសឥណ្ឌាធ្លាប់បានប្រើប្រាស់លេខ 1 ដល់ 9 អស់រយៈពេលជាង 2 ពាន់ឆ្នាំមកហើយ។ ពាណិជ្ជករអារ៉ាប់បាននាំយកលេខនេះទៅកាន់ភាគខាងលិច ជាលទ្ធផល ពួកខាងលិចជាញឹកញ៉ាយតែងតែហៅលេខទាំងនេះថា លេខអារ៉ាប់។ ប៉ុន្តែ នៅក្នុងការប្រើប្រាស់នៅសម័យទំនើបគេនិយមហៅលេខនេះថាលេខហិណ្ឌូ-អារ៉ាប់។

ប្រព័ន្ធលេខនេះដំបូងអភិវឌ្ឍដំបូងនៅប្រទេសឥណ្ឌា ហើយក្រោយមកត្រូវបានគេប្រើប្រាស់ទូទាំងពិភពលោកនាពេលបច្ចុប្បន្នត្រូវបានគេហៅថាប្រព័ន្ធទសភាគ។ ឈ្មោះនេះបានមកពីភាសាឡាតាំងដេសេមដែលមានន័យថា "10"។ នៅក្នុងលេខមួយចំនួនដូចជា 5555 លេខនីមួយៗមានតម្លៃ 10 ដងច្រើនជាងលេខដែលស្ថិតនៅខាងស្តាំរបស់វា។ ខ្ទង់នៃលេខនីមួយៗ ដែលមានរាយ, ដប, រយ និងបន្តបន្ទាប់ បានប្រាប់យើងពីតម្លៃនៃលេខទាំងនោះ។

ប្រព័ន្ធទសភាគនឹងមិនអាចប្រើប្រាស់បានទេប្រសិនបើគ្មានលេខសូន្យ។ វានឹងមិនអាចទៅរួចទេប្រសិនបើយើងសរសេរលេខដូចជា 504 ដោយមិនបានបង្ហាញថាខ្ទង់ 10 គឺទទេ។ នៅក្នុងប្រទេសឥណ្ឌា ពួកគេប្រើប្រាស់លេខសូន្យតាំងពីប្រមាណ 1,400 ឆ្នាំមុនម្ល៉ះ។

សង្ខេប៖ ពិពណ៌នាអំពីឥទ្ធិពលនៃគណិតសាស្ត្ររបស់ឥណ្ឌាបុរាណមកលើជីវភាពរស់នៅរបស់យើងនាពេលបច្ចុប្បន្ន។

# ជំពូក 6 ៖ ប្រទេសចិនសម័យបុរាណ

## មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រចិនបុរាណ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្វីទៅដែលធ្វើឲ្យតំបន់ដែលអ្នករស់នៅក្លាយជាកន្លែងល្អប្រសើរមួយសម្រាប់ការរស់នៅ? គិតអំពីរូបសណ្ឋាននៃភូមិសាស្ត្រនៅក្នុងតំបន់របស់អ្នកដែលមានឥទ្ធិពលលើការរស់នៅនៅទីនោះ។

### 1. ទម្រង់នៃទីតាំងភូមិសាស្ត្ររបស់ចិន

សំណួរគន្លឹះ៖ តើទីតាំងភូមិសាស្ត្រនៃប្រទេសចិនបានជះឥទ្ធិពលអ្វីខ្លះដល់ការអភិវឌ្ឍរបស់ពួកគេនៅដើមដំបូង?

ទម្រង់នៃជ្រលងទន្លេដែលអ្នកបានសិក្សានៅមេសូប៉ូតាមី, អេហ្ស៊ីប, និងជ្រឡងទន្លេឥណ្ឌូស គឺមានលក្ខណៈដូចគ្នាទៅនឹងប្រទេសចិនដែរ។ អរិយធម៌ចិនបានអភិវឌ្ឍឡើងដោយសារតែទន្លេពីរដែលបាននាំយកទឹក និងដីជាតិដែលនាំឱ្យមានភាពងាយស្រួលដល់ការដាំដុះ។ ទីក្រុងនានាបានលេចឡើងនៅតាមច្រាំងសងខាងនៃទន្លេ។

ការដាច់ចេញពីគេដោយរបាំង៖ មានទីតាំងស្ថិតនៅភាគខាងកើតនៃទ្វីបអាស៊ី ប្រទេសចិនមានចម្ងាយខាងជើងខ្សែអេក្វាទ័រប្រហែលគ្នាទៅនឹងសហរដ្ឋអាមេរិក។ ប្រទេសចិនមានព្រំប្រទល់ភាគខាងកើតជាប់នឹងសមុទ្រលឿង, សមុទ្ទចិនខាងកើត, និងមហាសមុទ្ទប៉ាស៊ីហ្វិច។ តំបន់វាលខ្សាច់ស្ថិតនៅជាយខាងជើង និងខាងលិច។ ស្ថិតនៅភាគខាងជើងគឺតំបន់វាលខ្សាច់ហ្គោប៊ី និងស្ថិតនៅភាគខាងលិចគឺតំបន់វាលខ្សាច់តាគ្លីម៉ាកាន។ ជួរភ្នំប៉ាមី, ធានសាន, និងហិម៉ាឡៃផ្តុំគ្នាបានជាបន្ទាត់កោងមួយ ដែលបង្កើតបានជាព្រំដែនភាគខាងលិច។ ខុសពីតំបន់ទន្លេនីស និងដែនដីជីជាតិ ដែលជាទូទៅអរិយធម៌មានទំនាក់ទំនងជាមួយគ្នា ប្រទេសចិនមានទីតាំងភូមិសាស្ត្រដាច់ចេញពីគេ។ ជួរភ្នំធំៗ និងវាលខ្សាច់ និងផ្ទៃទឹកដ៏ល្វឹងល្វើយបានដើរតួនាទីជាធ្វើរបាំងរវាងចិនជាមួយទឹកដីផ្សេងៗទៀត។ ហេតុផលនេះហេតុដែលនាំឱ្យការរីកសាយភាយនៃគំនិត និងទំនិញរបស់ចិនមានការលំបាក។ ជាលទ្ធផលអរិយធម៌ចិនអភិវឌ្ឍឡើងដាច់ឆ្ងាយពីគេ។ មានឥទ្ធិពលពីខាងក្រៅតិចតួចបំផុតដែលបានជះមកលើវប្បធម៌របស់ចិន។

ប្រព័ន្ធទន្លេពីរ៖ ទន្លេសំខាន់ៗពីរដែលហូរឆ្ពោះទៅកាន់មហាសមុទ្រប៉ាស៊ីហ្វិច។ ទន្លេឆាងជាំង ឬទន្លេយ៉ងសេស្ថិតនៅចិនភាគកណ្តាល។ ទន្លេហ័ងហ័រស្ថិតនៅភាគខាងជើង ដែលជាទូទៅគេស្គាល់ថាទន្លេលឿង។ នៅសម័យបុរាណ ប្រជាកសិករចិនភាគច្រើនបានដាំដុះនៅលើផ្ទៃដីដែលសម្បូរដីជាតិនៅចន្លោះទន្លេឆាងជាំង និងហ័ងហ័រ។ ទឹកជំនន់របស់ទន្លេទាំងពីរនេះបានផ្តល់នូវដីល្បាប់ពណ៌លឿងដែលនាំឱ្យដីមានជីជាតិ។ ដីនៅតំបន់នេះត្រូវបានគេហៅថា តំបន់វាលទំនាបចិនខាងជើង ដែលជាមជ្ឈមណ្ឌលនៃអរិយធម៌ចិន។

អាកាសធាតុចម្រុះ៖ ប្រទេសចិនមានអាកាសធាតុចម្រុះ ដែលស្រដៀងគ្នាទៅនឹងសហរដ្ឋអាមេរិក។ នៅចិនភាគខាងលិច មានភាពរាំងស្ងួតដូចជាភាគខាងលិចសហរដ្ឋអាមេរិកដែរ។ ដោយសារតែតំបន់នេះភាគច្រើនជាវាលខ្សាច់ និងជួរភ្នំ នៅទីនោះមិនសូវមានមនុស្សរស់នៅច្រើនទេ ហើយតំបន់នោះមានផ្ទៃដីដែលអាចដាំដុះតិចតួចបំផុត។ នៅភាគឦសាននៃប្រទេសចិនមានរដូវកាលដូចជាអង់គ្លេសថ្មីដែលមានរដូវរំហើយត្រជាក់ និងរដូវ

ក្តៅ។ ផ្ទុយទៅវិញ នៅតំបន់ភាគអាគ្នេយ៍គឺដូចគ្នាទៅនឹងតំបន់ភាគខាងត្បូងនៃសហរដ្ឋអាមេរិក ដែលមានរដូវរំហើយ និងក្តៅ, និងរដូវភ្លៀង។ អាកាសធាតុខុសគ្នានេះអនុញ្ញាតឱ្យប្រទេសចិនអាចផលិតនូវគ្រាប់ធញ្ញជាតិបានចម្រុះ។ ស្រូវអង្ករត្រូវបានដាំដុះនៅតំបន់សើមភាគខាងត្បូង ខណៈពេលដែលស្រូវសាលី, សណ្តែកសៀង, និងស្រូវមីយេត្រូវបានគេដាំដុះនៅតំបន់ស្ងួតភាគខាងជើង។

វិភាគអំពីឥទ្ធពល៖ ពន្យល់អំពីការជះឥទ្ធិពលនៃទីតាំងភូមិសាស្ត្រ លើការអភិវឌ្ឍដំបូងរបស់ប្រទេសចិន។

## 2. សន្តតិវង្សសាង

សំណួរគន្លឹះ៖ តើភាសាចិនអភិវឌ្ឍដោយរបៀបណា?

នៅអំឡុងឆ្នាំ 2000 មុនគ.ស ក្រុមប្រជាកសិករដែលតាំងទីលំនៅនៅតាមដងទន្លេហ័ងហ័របានចាប់ផ្តើមរីកចម្រើនក្លាយជាទីក្រុង។ អរិយធម៌ដំបូងចាប់ផ្តើមអភិវឌ្ឍឡើងនៅទីនេះ ហើយវប្បធម៌ចិននាពេលបច្ចុប្បន្នបានអភិវឌ្ឍចេញមកពីអរិយធម៌បុរាណដំបូងនេះ។ ប្រវត្តិវិទូចាត់ទុកថាចិនគឺជាប្រទេសដែលមានអរិយធម៌និរន្តរចំណាស់បំផុតនៅលើពិភពលោក។

ស្តេចសាង៖ នៅអំឡុងឆ្នាំ 1766 មុនគ.ស គ្រួសាររាជវង្សសាងចាប់ផ្តើមគ្រប់គ្រងទីក្រុងមួយចំនួន។ ពួកគេបានបង្កើតសន្តតិវង្សមួយដែលគ្រួសារមួយ ឬក្រុមមួយដែលដឹកនាំបន្តបន្ទាប់គ្នាជាច្រើនជំនាន់។ ស្តេចទទួលបន្ទុកចំពោះសកម្មភាពសាសនា។ ពួកគេអះអាងអំពីការគ្រប់គ្រងរបស់ពួកគេជាមួយនឹងការអនុញ្ញាតរបស់អាទិទេព។ ស្តេចសាងត្រួតត្រាតំបន់ភាគកណ្តាលនៃវាលទំនាបចិនខាងជើង សាច់ញាតិរបស់ពួកគេគ្រប់គ្រងនៅតំបន់ផ្សេងៗទៀត។ ពួកសាងប្រើប្រាស់រទេះសេះដើម្បីការពារពួកគេពីការវាយប្រហាររបស់ពួកចរកជនដែលរស់នៅភាគខាងជើង និងភាគខាងលិច។ ពួកគេធ្វើសង្គ្រាមជាមួយក្រុមចរកជននានា ដូចជាពួកចូវជាដើម។

រាជវង្សសាង៖ នៅក្នុងវប្បធម៌របស់សាង ការគោរពចំពោះឪពុកម្តាយ ឬបុព្វការីជនគឺជារឿងសំខាន់។ គ្រួសារមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយសាសនា។ ពួកប្រជាជនជនជឿថាព្រលឹងរបស់ដូនតាពួកគេអាចនាំយកលាបសំណាងដល់ពួកគេ។ គ្រួសារទាំងមូលគោរពដល់បុព្វការីជនខាងឪពុក តាមរយៈការបូជាយញ្ញសត្វដើម្បីជាការផ្តល់កិត្តិយសដល់ពួកគេ។ បុរសគឺជាអ្នកគ្រប់គ្រងគ្រួសារ។

ការអភិវឌ្ឍភាសា៖ ស្តេចសាងត្រូវបានអះអាងថាអាចទទួលឥទ្ធពលពីអាទិទេព។ ពួកគេទទួលសារពីអាទិទេពតាមរយៈឆ្អឹងទំនាយ។ វាគឺជាឆ្អឹងសត្វនានាដែលបព្វជិតរបស់រាជវង្សសាងយកមកសរសេរដើម្បីសួរសំណួរទៅកាន់អាទិទេព។ បន្ទាប់ពីសរសេរសំណួររួច ពួកគេដាក់ដុំថ្មក្តៅលើឆ្អឹងនោះដើម្បីឱ្យវាប្រេះ ហើយធ្វើការបកស្រាយអំពីស្នាមប្រេះនោះ។ បន្ទាប់មកពួកគេសរសេរចម្លើយនៅលើឆ្អឹងនោះ។អក្សរសរសេរនៅលើឆ្អឹងទំនាយនេះគឺជាទម្រង់អក្សរដំបូងរបស់ចិន។ ក៏ដូចជាប្រជាជនសម័យបុរាណផ្សេងៗទៀតដែរ ពួកសាងបានអភិវឌ្ឍប្រព័ន្ធសំណេររបស់ពួកគេជាមួយនឹងអក្សររូប ដែលជាការគូររូបទូទៅដែលតំណាងឱ្យពាក្យ ឬគំនិត។ ដូចដែលអ្នកអាចមើលឃើញនៅក្នុងតារាងនៅខាងស្តាំ អក្សររូបចិនសម័យបុរាណមានលក្ខណៈស្រដៀងគ្នាទៅនឹងតួអក្សរចិនសម័យទំ

នើប។ ប្រព័ន្ធសំណេររបស់ចិនប្រើប្រាស់នូវនិមិត្តសញ្ញាយ៉ាងច្រើន។ ដើម្បីអាចអាន និងសរសេរអក្សរចិនបាន មនុស្សម្នាក់ត្រូវស្គាល់យ៉ាងហោចណាស់តួអក្សរចិនចំនួន 1,500 ។ មនុស្សដែលទទួលបានការអប់រំអាចស្គាល់តួអក្សរចិនយ៉ាងហោចណាស់ចំនួន 1 ម៉ឺនតួអក្សរ។ ផលប្រយោជន៍នៃប្រព័ន្ធសំណេររបស់ចិនគឺថា អ្នកអាចអានអក្សរចិនបានដោយមិនចាំបាច់ចេះនិយាយភាសាចិន។ ប្រជាជននៅក្នុងប្រទេសចិនទាំងមូលអាចរៀនសរសេរតួអក្សរចិនបាន បើទោះបីជាពួកគេមានភាសាផ្សេងៗគ្នាក៏ដោយ។ ប្រព័ន្ធតួអក្សរនេះជួយដល់ការបង្រួបបង្រួមដែនដីដែលធំ និងចម្រុះរបស់ចិន។

សង្ខេប៖ ពន្យល់អំពីរបៀបដែលភាសាចិនអភិវឌ្ឍឡើង

## 3. រាជវង្សចូវ

សំណួរគន្លឹះ៖ តើគោលគំនិត "អាណត្តិនៃឋានសួគ៌" បានជួយរាជវង្សចូវយ៉ាងដូចម្តេចដើម្បីយកជ័យជំនះលើរាជវង្សសាង?

ប្រជាជនចូវបានធ្វើដំណើរមកពីតំបន់ភាគពាយព្យ។ ពួកគេតែងតែបះទង្គិចគ្នាជាមួយពួកសាងជាញឹកញាប់។ នៅរង្វង់ឆ្នាំ 1027 មុនគ.ស មេដឹកនាំចូវម្នាក់ឈ្មោះវ៉ីវ៉ាំងបានដឹកនាំកម្លាំងទ័ពវាយប្រយុទ្ធយកជ័យជំនះលើពួកសាង។ ពួកចូវយកលំនាំតាមគំរូជាច្រើនរបស់ពួកសាង ដូច្នេះជ័យជំនះរបស់ពួកចូវមិនបណ្តាលឱ្យមានការផ្លាស់ប្តូរវប្បធម៌ឡើយ។ ប៉ុន្តែ មេដឹកនាំចូវនៅតែនាំយកនូវគំនិតថ្មីមកប្រើក្នុងអរិយធម៌ចិន។

រាជវង្សចូវ និងវដ្តនៃសន្តតិវង្ស៖ ស្តេចចូវបង្កើតសន្តតិវង្សថ្មីមួយនៅក្នុងប្រទេសចិន។ សន្តតិវង្សរបស់ចិនរីកចម្រើន និងធ្លាក់ចុះតាមលំនាំមួយ។ ប្រវត្តិវិទូនានាបានហៅលំនាំនៃការរីកចម្រើន និងការធ្លាក់ចុះនៃសន្តតិវង្សនៅក្នុងប្រទេសចិននេះថាវដ្តនៃសន្តតិវង្ស។ ពិនិត្យមើលដ្យាក្រាមខាងលើដើម្បីមើលឃើញពីលំនាំនេះ។ ក៏ដូចជាអេហ្ស៊ីបបុរាណដែរ ស្តេចចូវគិតថាបញ្ហានឹងកើតមានឡើងប្រសិនបើមេដឹកនាំបាត់បង់ការអនុគ្រោះពីឋានសួគ៌។ ដើម្បីដោះសារចំពោះការឈ្លានពានរបស់ពួកគេ មេដឹកនាំចូវបានប្រកាសថា ស្តេចចុងក្រោយនៃរាជវង្សសាងគឺជាមេដឹកនាំខ្សោយមួយរូប។ ពួកគេអះអាងថា អាទិទេពបានដកហូតយកសិទ្ធិរបស់រាជវង្សសាងនៅក្នុងការដឹកនាំ ហើយយកមកប្រគល់ឱ្យរាជវង្សចូវវិញ។ ដោយថាហេតុ គំនិតដែលថា មេដឹកនាំល្អមួយត្រូវតែទទួលបានការយល់ស្របពីអាទិទេព បានក្លាយជាផ្នែកមួយនៃវប្បធម៌ចិន។ នៅពេលដែលមេដឹកនាំអាក្រក់ និងល្ងីល្ងើ ប្រជាជនជឿថា អាទិទេពបានដកយកការយល់ព្រមរបស់ទ្រង់ពីមេដឹកនាំនោះ។ គំនិតនេះត្រូវបានគេហៅថា អាណត្តិនៃឋានសួគ៌។ ប្រជាជនចិនជឿថា បញ្ហាដែលកើតមានឡើង ដូចជាការបះបោររបស់ប្រជាកសិករ, ការឈ្លានពាន, ទឹកជំនន់, ឬគ្រោះរញ្ជួយដី ឆ្លុះបញ្ចាំងថា អាណត្តិនៃឋានសួគ៌ត្រូវបានដកហូត។ ពេលនោះគឺជាពេលដែលត្រូវមានមេដឹកនាំថ្មី ហើយអាណត្តិនៃឋានសួគ៌ត្រូវប្រគល់ឱ្យរាជវង្សមេដឹកនាំថ្មីនោះ។

រដ្ឋាភិបាលរបស់រាជវង្សចូវ៖ ក៏ដូចជារាជវង្សសាងដែរ អំណាចកណ្តាលនៃរដ្ឋាភិបាលរាជវង្សចូវមិនខ្លាំងក្លាឡើយ។ ស្តេចតែងតែដាក់សាច់ញាតិ និងមនុស្សដែលទុកចិត្តផ្សេងៗឱ្យទទួលបន្ទុកគ្រប់គ្រងនៅតាមតំបន់នានា។ មេដឹកនាំ ឬស្តេចត្រាញ់នៅក្នុងតំបន់ទាំងនោះបានផ្តល់នូវភក្តីភាព និងសេវាយោធាដល់ស្តេចកណ្តាល។ ជាថ្នូរ

ស្តេចកណ្តាលសន្យាក្នុងការជួយការពារទឹកដីរបស់ពួកគេពីការឈ្លានពាន។ នៅពេលដែលទីប្រជុំជនរបស់ពួកគេបានអភិវឌ្ឍក្លាយជាទីក្រុង ស្តេចត្រាញ់ចាប់ផ្តើមកើនអំណាចខ្លាំង។ ស្តេចត្រាញ់ចាប់ផ្តើមវាយក្រុមផ្សេងៗកាន់តែច្រើនដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ។ ការពឹងផ្អែករបស់ស្តេចត្រាញ់លើស្តេចកណ្តាលថយចុះបន្តិចម្តងៗ។ ពួកស្តេចត្រាញ់ចាប់ផ្តើមវាយប្រយុទ្ធគ្នាទៅវិញទៅមកក្នុងចំណោមក្រុមរបស់ពួកគេ និងវាយជាមួយក្រុមដ៏ទៃផ្សេងទៀត។ ផ្ទៃដីដែលពួកគេបញ្ចូលបន្ថែមក្នុងការគ្រប់គ្រងរបស់ពួកគេ នាំដល់ការពង្រីកទឹកដីចិនឱ្យកាន់តែធំ។

សម័យការនៃសង្គ្រាមរវាងរដ្ឋនិងរដ្ឋ៖ ការឈ្លានពានទឹកដីចិនគឺតែងតែកើតមានជានិច្ចនៅក្នុងប្រវត្តិសាស្រ្តចិន។ បន្ទាប់ពីឆ្នាំ 800 មុនគ.ស ពួកចរកេជនមកពីភាគខាងជើង និងខាងលិចបានឈ្លានពានប្រទេសចិន។ នៅក្នុងឆ្នាំ 771 មុនគ.ស ក្រុមអ្នកឈ្លានពានបានវាយកម្ទេចរាជធានីហាវ និងសម្លាប់ស្តេច។ គ្រួសាររាជវង្សបានរត់គៀសខ្លួនទៅកាន់លូយ៉ាង និងបង្កើតរាជធានីថ្មីនៅទីនោះ។ ដោយសារតែការគ្រប់គ្រងរបស់ស្តេចអន់ខ្សោយធ្វើឱ្យស្តេចត្រាញ់នានាវាយប្រយុទ្ធគ្នាជាញឹកញាប់។ ដូចដែលអំណាចរបស់ពួកគេកើនឡើង ស្តេចត្រាញ់ទាំងនេះបានអះអាងខ្លួនឯងជាស្តេចនៅក្នុងដែនដីដែលពួកគេគ្រប់គ្រង។ សកម្មភាពនេះនាំទៅដល់សម័យកាលមួយដែលគេហៅថា សង្គ្រាមរវាងរដ្ឋនិងរដ្ឋ ដែលបានចាប់ផ្តើមឡើងនៅវង្វង់ឆ្នាំ 403 មុនគ.ស។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពន្យល់ពីរបៀបដែលគោលគំនិតអាណត្តិនៃឋានសួគ៌ ជួយដល់រាជវង្សចូវក្នុងការដណ្តើមអំណាចពីរាជវង្សសាង។

# មេរៀនទី 2 ៖ ទស្សនវិជ្ជាចិនបុរាណ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅមេរៀនមុនអ្នកបានសិក្សាអំពីសម័យកាលសង្គ្រាមរវាងរដ្ឋ និងរដ្ឋនៅក្នុងប្រទេសចិន។ នៅអំឡុងពេលនោះ សង្គមរបស់ចិនជួបប្រទះទៅនឹងបញ្ហាស្មុកស្មាញជាច្រើន។ ស្តេចត្រាញ់ និងស្តេចវាយប្រយុទ្ធគ្នាទៅវិញទៅមកដើម្បីដណ្តើមកាន់កាប់ទឹកដី។ អ្នកប្រាជ្ញចាប់ផ្តើមគិតថាតើអ្វីទៅដែលអាចនាំឱ្យមានសន្តិភាពនៅក្នុងតំបន់របស់ពួកគេ។ ពួកគេបានអភិវឌ្ឍគំនិតចំនួន 3 ៖ នីតិនិយម, ខុងជឺនិយម, និងតាវនិយម។ គំនិតនីមួយៗគឺជាទស្សនៈវិជ្ជា ឬការសិក្សាបែបតក្កមួយអំពីមូលដ្ឋានគ្រឹះនៃសច្ចៈរបស់ចំណេះដឹង, តម្លៃ, និងពិភពលោក។

## 1. នីតិនិយម

សំណួរគន្លឹះ៖ តើនីតិនិយមណែនាំយ៉ាងដូចម្តេចចំពោះការគ្រប់គ្រងសង្គម?

ទស្សនៈវិជ្ជាមួយគឺនីតិនិយម ឬជំនឿមួយដែលថារដ្ឋាភិបាលដែលខ្លាំងក្លា និងមានប្រសិទ្ធភាព និងមានប្រព័ន្ធច្បាប់តឹងរឹងមួយគឺជាគន្លឹះក្នុងការរក្សាសណ្តាប់ធ្នាប់សង្គម។ អ្នកនីតិនិយមមានការភ័យខ្លាចចំពោះបញ្ហាស្មុកស្មាញនៃសង្គម។ ពួកគេបានសម្រេចថា រដ្ឋាភិបាលរឹងមាំមួយដែលអនុវត្តច្បាស់តឹងរឹងនឹងស្តារឡើងវិញនូវសណ្តាប់ធ្នាប់ និងដោះស្រាយបញ្ហារបស់ប្រទេសចិន។

ច្បាប់តឹងរឹង និងទណ្ឌកម្មធ្ងន់ធ្ងរ៖ អ្នកនីតិនិយមជឿថា ធម្មជាតិនៃមនុស្សគឺអាក្រក់ឃោឃៅ។ ដូច្នេះ ពួកគេគិតថាមនុស្សធ្វើអំពើល្អនៅពេលណាដែលគេបង្ខំឱ្យធ្វើតែប៉ុណ្ណោះ។ អ្នកនីតិនិយមគិតថា រដ្ឋាភិបាលគួរតែអនុម័តច្បាប់តឹងរឹងនានាដើម្បីគ្រប់គ្រងរបៀបដែលមនុស្សប្រព្រឹត្ត។ ពួកគេទទូចថា ទណ្ឌកម្មធ្ងន់ធ្ងរត្រូវតែប្រើ ដើម្បីធ្វើឱ្យមនុស្សកោតខ្លាច ជៀសវាងប្រព្រឹត្តខុស។

ការបង្កើនការត្រួតត្រារបស់រដ្ឋាភិបាល៖ ពួកនីតិនិយមបានបង្រៀនថា មេដឹកនាំគួរតែផ្តល់រង្វាន់ដល់ជនណាដែលអ្នកអនុវត្តករណីយកិច្ចរបស់ពួកគេបានល្អ។ ប៉ុន្តែ នៅក្នុងការអនុវត្ត អ្នកនីតិនិយម សង្កត់ធ្ងន់ទៅលើការដាក់ទណ្ឌកម្មជាជាងការផ្តល់រង្វាន់។ សាងយ៉ាងអ្នកគាំទ្រនីតិនិយមមួយរូប ចង់បង្ខំឱ្យមនុស្សរាយការណ៍អំពីអ្នកប្រព្រឹត្តខុសច្បាប់។ តាមការពិត លោកគិតថាមនុស្សអ្នកដែលមិនបានរាយការណ៍អំពីអ្នកប្រព្រឹត្តខុសច្បាប់អ្នកនោះនឹងត្រូវប្រហារជីវិត។ អ្នកនីតិនិយមមិនចង់ឱ្យមនុស្សរិះគន់រដ្ឋាភិបាល ឬសួរសំណួរអំពីការប្រព្រឹត្តរបស់រដ្ឋាភិបាលឡើយ។ ពួកគេចង់ឱ្យមានការចាប់ខ្លួនជនណាដែលសួរសំណួររដ្ឋាភិបាល ឬបង្រៀនពីគំនិតផ្សេងដែលប្រឆាំងជាមួយរដ្ឋាភិបាល។ ពួកគេក៏បង្រៀនផងដែរថា មេដឹកនាំគួរតែដុតសៀវភៅនានាដែលសរសេរអំពីទស្សនៈ ឬគំនិតផ្សេងពីនីតិនិយម។

ស្វែងរកគោលគំនិត៖ ពន្យល់ពីរបៀបដែលនីតិនិយមស្នើឡើងដើម្បីគ្រប់គ្រងសង្គម។

## 2. ខុងជឺនិយម

សំណួរគន្លឹះ៖ តើសកម្មភាពអ្វីខ្លះដែលខុងជឺជឿថាអាចនាំសណ្តាប់ធ្នាប់ដល់ប្រទេសចិន?

ខុងជឺរស់នៅចាប់ពីឆ្នាំ 551 ដល់ 479 មុនគ.ស នៅអំឡុងពេលដែលជម្លោះ និងភាពចលាចលកើតឡើងច្រើននៅក្នុងប្រទេសចិន។ ក៏ដូចជាអ្នកនីតិនិយមដែរ លោកចង់ស្តារឡើងវិញនូវសណ្តាប់ធ្នាប់នៅក្នុងសង្គមរបស់លោកដូចគ្រាមុន។ ប៉ុន្តែ លោកបានអភិវឌ្ឍគំនិតផ្សេងពីពួកនីតិនិយម អំពីវិធីបញ្ចប់ជម្លោះ និងមានសន្តិភាពនៅគ្រប់រាល់ទំនាក់ទំនងទាំងអស់។ យោងទៅតាមខុងជឺ ការគោរពដល់អ្នកដ៏ទៃគឺជាតម្រូវការចាំបាច់បំផុតសម្រាប់សន្តិភាព និងសណ្តាប់ធ្នាប់។ មេដឹកនាំរដ្ឋាភិបាលគួរតែបង្កើតគំរូល្អមួយ ដូច្នេះប្រជាជននឹងមើលឃើញថាអ្វីទៅជាភាពត្រឹមត្រូវ។ សិស្សរបស់ខុងជឺបានប្រមូលចងក្រងគំនិតរបស់លោក ហើយកត់ត្រាវានៅក្នុងសៀវភៅមួយដែលគេហៅថាអក្សរសាស្ត្រជ្រើសរើស។ សៀវភៅនេះបានប្រាប់ពីការបង្រៀនផ្សេងៗរបស់ខុងជឺ ដែលការរួមបញ្ចូលគ្នាទាំងអស់នេះបង្កើតបានជាប្រព័ន្ធជំនឿមួយដែលគេស្គាល់ថាខុងជឺនិយម ឬលិទ្ធិខុងជឺ។

ទំនាក់ទំនងទាំង 5 ៖ ខុងជឺបានបង្រៀនអំពីក្រមនៃការប្រព្រឹត្តត្រឹមត្រូវ ឬក្រមសីលធម៌សម្រាប់មនុស្ស។ នៅក្នុងលិទ្ធិខុងជឺ មានមូលដ្ឋានគ្រឹះនៃទំនាក់ទំនង 5 ។ ប្រភេទនៃទំនាក់ទំនងនីមួយៗ មានករណីយកិច្ច និងក្រមនៃការប្រព្រឹត្តត្រឹមត្រូវរបស់វារៀងៗខ្លួន។ ខាងក្រោមនេះគឺជាទំនាក់ទំនងទាំង 5 ៖

1. ទំនាក់ទំនងរវាងឪពុក និងកូន
2. ទំនាក់ទំនងរវាងបងប្រុស និងប្អូនប្រុស
3. ទំនាក់ទំនងរវាងប្តី និងប្រពន្ធ
4. ទំនាក់ទំនងរវាងមិត្តភ័ក្ត និងមិត្តភ័ក្ត
5. ទំនាក់ទំនងរវាងមេដឹកនាំ និងប្រជានុរាស្ត្រ

ត្រូវចង់ចាំថា ទំនាក់ទំនងនេះត្រូវបានបែងចែកជាពីរប្រភេទសំខាន់ៗ៖ ការប្រព្រឹត្តត្រឹមត្រូវនៅក្នុងគ្រួសារ និងការប្រព្រឹត្តត្រឹមត្រូវនៅក្នុងសង្គម។

ការប្រព្រឹត្តត្រឹមត្រូវ៖ ខុងជឺជឿថា ការប្រព្រឹត្តល្អ និងការគោរពត្រូវចាប់ផ្តើមដំបូងគេនៅក្នុងផ្ទះ។ ប្តីត្រូវតែប្រព្រឹត្តល្អដាក់ប្រពន្ធរបស់ពួកគេ។ ប្រពន្ធត្រូវតែធ្វើតាមរាល់សេចក្តីសម្រេចចិត្តរបស់ប្តី។ បងប្រុសត្រូវតែចិត្តល្អចំពោះប្អូនប្រុស ប៉ុន្តែប្អូនប្រុសត្រូវតែអនុវត្តតាមបំណងប្រាថ្នារបស់បងប្រុស។ គំនិតសំខាន់បំផុតមួយដែលខុងជឺបានបង្រៀនគឺ ករណីយកិច្ចក្នុងការគោរព និងស្រឡាញ់ឪពុកម្តាយ ឬការប្រព្រឹត្តចំពោះឪពុកម្តាយដោយសេចក្តីគោរព។ ប្រភពឯកសារដើមខាងលើគឺករណីយកិច្ចក្នុងការគោរព និងស្រឡាញ់ឪពុកម្តាយ។ ខុងជឺក៏មានទំនាក់ទំនងជាមួយឥរិយាបថរបស់មនុស្សនៅក្នុងសង្គមផងដែរ។ អាជ្ញាធរគួរតែត្រូវបានគេគោរព។ ទំនួលខុសត្រូវរបស់មេដឹកនាំ គឺរស់នៅដោយត្រឹមត្រូវ និងប្រព្រឹត្តចំពោះប្រជានុរាស្ត្ររបស់ពួកគេដោយសេចក្តីគោរព។ ប្រសិនបើមេដឹកនាំម្នាក់ដឹកនាំក្នុងផ្លូវត្រូវតាមបែបសិលធម៌ ករណីយកិច្ចរបស់ប្រជានុរាស្ត្រគឺត្រូវធ្វើតាម។ ប្រសិបបើឥរិយាបថទាំងនេះត្រូវបានគេអនុវត្តតាម វានឹងនាំឱ្យមានសន្តភាពនៅក្នុងសង្គម។

ឥទ្ធិពលនៃលិទ្ធិខុងជឺ៖ ខុងជឺនិយម ឬលិទ្ធិខុងជឺបង្ហាញយ៉ាងច្បាស់ពីតួនាទីរបស់គ្រួសារ និងសង្គម។ ដោយអនុវត្តតាមតួនាទីនេះ ប្រជាជនចិនរកឃើញពីវិធីនៅក្នុងការជៀសវាងជម្លោះ និងរស់នៅដោយសុខសន្តិភាព។

មេដឹកនាំមួយចំនួនធំបានព្យាយាមនៅក្នុងការប្រព្រឹត្តតាមគំរូរបស់ខុងជឺដើម្បីក្លាយជាមេដឹកនាំល្អមួយរូប។ តាមរយៈការគូសបញ្ជាក់ពីសារៈសំខាន់នៃការអប់រំ ខុងជឺបានបង្ហាញពីមូលដ្ឋានគ្រឹះមួយសម្រាប់បង្រៀនឱ្យមន្ត្រីរដ្ឋាភិបាលមានយុត្តិធម៌ និងជំនាញ។

សង្ខេប៖ ពន្យល់ពីអ្វីខ្លះដែលខុងជឺបានបង្រៀនដើម្បីនាំសណ្តាប់ធ្នាប់ដល់ប្រទេសចិន។

## 3. តាវនិយម ឬលិទ្ធិតាវ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាលិទ្ធិតាវបង្រៀនថាមនុស្សម្នាក់ៗត្រូវស្វែងរកវិធីផ្ទាល់ខ្លួនដើម្បីអនុវត្តក្នុងជីវិតរស់នៅរបស់ពួកគេ?

ទស្សនៈវិជ្ជាចិនបុរាណទី 3 នេះ ត្រូវបានគេនិយាយថាបានចាប់ផ្តើមជាមួយនិងឡាវហ្សឺ។ មិនមាននណារម្នាក់ដឹងពិតប្រាកដថាលោកមានរូបរាងពិតប្រាកដឬទេ ប៉ុន្តែមនុស្សមួយចំនួនបាននិយាយថាលោករស់នៅអំឡុងទសវត្សរ៍ឆ្នាំ 500 មុនគ.ស។ ឈ្មោះឡាវហ្សឺ មានន័យថា "គ្រូចាស់"។ សៀវភៅដែលលោកបានបង្រៀនគឺសៀវភៅតាវតេជីង(សៀវភៅនៃផ្លូវគុណធម៌)។ ការបង្រៀនរបស់ឡាវហ្សឺត្រូវបានគេហៅថាតាវនិយម។ ទស្សនៈតាវនិយមមានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំងពីទស្សនៈនីតិនិយម និងខុងជឺនិយម។

ផ្លូវ៖ ឡាវហ្សឺ ជឿថាកម្លាំងសកលមួយដែលហៅថា តាវ ឬផ្លូវ ដឹកនាំគ្រប់អ្វីៗទាំងអស់។ គ្រប់ជីវិតទាំងអស់លើកលែងតែមនុស្ស រស់នៅជាមួយនឹងសុខដុមជាមួយនឹងកម្លាំងនេះ។ មនុស្សទាំងឡាយជជែកគ្នាអំពីអ្វីខុសអ្វីត្រូវ។ យោងទៅតាម ឡាវហ្សឺ ការជជែកគ្នាមួយចំនួនគ្មានប្រយោជន៍អ្វីទាំងអស់។ ដើម្បីភ្ជាប់ទំនាក់ទំនងទៅនឹងធម្មជាតិ និងរវាងគ្នានិងគ្នា មនុស្សម្នាក់ៗត្រូវតែស្វែងរកផ្លូវ ឬតាវផ្ទាល់ខ្លួន ដើម្បីដើរតាម។ មនុស្សម្នាក់ៗត្រូវរៀនពីការរស់នៅបែបសុខដុម ឬចុះសម្រុងនឹងគ្នាជាមួយនឹងធម្មជាតិ និងជាមួយនឹងអារម្មណ៍ខាងក្នុងរបស់គេ។ ឡាវហ្សឺនិងអ្នកដើរតាមគាត់យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសណ្តាប់ធ្នាប់ធម្មជាតិជាជាងសណ្តាប់ធ្នាប់សង្គម។ យោងទៅតាមការអប់រំរបស់តាវនិយម ប្រសិនបើមនុស្សម្នាក់ៗអាចស្វែងផ្លូវផ្ទាល់ខ្លួនរបស់គេ ហើយរៀនរស់នៅដោយសុខដុមជាមួយនឹងធម្មជាតិ នោះសណ្តាប់ធ្នាប់សង្គមនឹងកើតមានឡើងតាមក្រោយ។ ដូចដែល ឡាវហ្សឺបានលើកឡើងថា "មនុស្សនឹងពេញចិត្តជាមួយនឹងភាពសាមញ្ញរបស់ពួកគេ ក្នុងជីវិតរស់នៅប្រចាំថ្ងៃដោយសុខដុម និងដោយគ្មានចំណង់"។

ការដើរតាមផ្លូវ៖ អ្នកតាវនិយមមិនជជែកពីអ្វីល្អ ឬអាក្រក់នោះទេ ហើយពួកគេមិនបានព្យាយាមនៅក្នុងការផ្លាស់ប្តូរអ្វីៗទាំងអស់។ ពួកគេទទួលយកនូវអ្វីដែលពួកគេមាន។ ខុសពីអ្នកដើរតាមនីតិនិយម និងខុងជឺនិយម ពួកគេមិនចង់ជាប់ពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាលឡើយ។ ផ្ទុយទៅវិញ ពួកគេគិតថា រដ្ឋាភិបាលគួរតែទុកឱ្យប្រជាជននៅដាច់ដោយឡែក។ អ្នកតាវនិយមព្យាយាមនៅក្នុងការស្វែងយល់ពីធម្មជាតិ និងរស់នៅដោយសុខដុមជាមួយនឹងដំណើរការរបស់វា។ នៅក្នុងនោះរួមមានគំនិតអំពី យីង និងយ៉ាង ឬរបស់ពីរដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងតំណាងឱ្យដំណើរជាធម្មជាតិរបស់ជីវិត។ យីង(ខ្មៅ) តំណាងឱ្យអ្វីៗដែលត្រជាក់, ងងឹត, និងអាថ៌កំបាំង។ យ៉ាង(ស) តំណាងឱ្យអ្វីៗដែលក្តៅ, ភ្លឺ, និងមើលឃើញ។ កម្លាំងទាំងពីរនេះបំពេញឱ្យគ្នា

ទៅវិញទៅមក។ កម្លាំងទាំងពីរនេះតែងតែផ្លាស់ប្តូរ និងវិវត្ត។ ការយល់ដឹងអំពី យើង និង យ៉ាង ជួយមនុស្សម្នាក់ឱ្យយល់ដឹងពីរបៀបដែលធ្វើឱ្យគេត្រូវគ្នាជាមួយពិភពដែលគេរស់នៅ។ ក្នុងការស្វែងរកចំណេះដឹង និងស្វែងយល់របស់ពួកគេពីធម្មជាតិ អ្នកតាវនិយមសិក្សាតាមបែបវិទ្យាសាស្ត្រ។ ពួកគេបានចូលរួមចំណែកយ៉ាងសំខាន់ដល់វិទ្យាសាស្ត្រលើវិស័យមួយចំនួនដូចជា តារាសាស្ត្រ និងឱសថសាស្ត្រ។ នៅមេរៀនបន្ទាប់ អ្នកនឹងបានសិក្សាពីរបៀបដែលទស្សនៈទាំង 3 នេះមានឥទ្ធិពលទៅលើវិធីដែលមេដឹកនាំចិនគ្រប់គ្រងដែនដីរបស់ពួកគេ។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពន្យល់ពីមូលហេតុដែលតាវនិយមបង្រៀនមនុស្សនីមួយៗឱ្យស្វែងរកផ្លូវផ្ទាល់ខ្លួនរបស់ពួកគេដើម្បីដើរ។

# មេរៀនទី 3៖ សន្តតិវង្សឈិន និងហាន

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅចុងបញ្ចប់នៅសម័យរាជវង្សចូវរដ្ឋជាច្រើននៅបន្តមានសង្គ្រាមជាមួយគ្នា។ ដូចដែលអ្នកបានដឹង ប្រជាជនចិនជឿលើអាណត្តិនៃឋានសួគ៌។ យោងទៅតាមជំនឿនេះ សង្គ្រាម និងបញ្ហាផ្សេងៗដែលកើតមានឡើងគឺជាសញ្ញាបង្ហាញថា រាជវង្សកាន់អំណាចបានបាត់បង់ការអនុគ្រោះពីឋានសួគ៌។ ពួកចិនយល់ថាពីគេត្រូវការមេដឹកនាំថ្មីមួយរូប។

## 1. សន្តតិវង្សឈិនបង្រួបបង្រួមប្រទេសចិន

សំណួរគន្លឹះ៖ តើរាជវង្សឈិនបង្រួបបង្រួមប្រទេសចិនដោយរបៀបណា?

មេដឹកនាំថ្មីរបស់ចិនមកពីរដ្ឋឈិន។ អ្នកប្រាជ្ញមួយចំនួនយល់ថា ឈ្មោះនៃប្រទេសចិនបច្ចុប្បន្នគឺបានមកពីពាក្យឈិននេះ។ អធិរាជថ្មីទទួលគោរមងារថាសីហ័ងទី។ ទ្រង់បានបង្រួមបង្រួម និងពង្រីកអំណាចរបស់ចិន។

មេដឹកនាំបែបនីតិនិយម៖ នៅក្នុងឆ្នាំ 221 មុនគ.ស មេដឹកនាំសីហ័ងទីបានចាប់ផ្តើមបញ្ចប់ជម្លោះផ្ទៃក្នុងរបស់រដ្ឋនានានៅក្នុងប្រទេសចិន។ ក្រោយមកទ្រង់បានឈ្លានពានដណ្តើមកាន់កាប់រដ្ឋនានាដែលជាសត្រូវ និងបានបណ្តេញពួកចរកជនចេញពីទឹកដីចិន។ ប្រទេសចិនពេលនោះបានពង្រីកធំជាងកាលពីសម័យរាជវង្សចូវ។ សីហ័ងទីជាអ្នកជឿលើនីតិនិយម ហើយទ្រង់យកវិធីរបស់នីតិនិយមមកដឹកនាំប្រទេស។ ទ្រង់ព្យាយាមនៅក្នុងការលុបបំបាត់ចោលខុងជឺនិយម។ ទ្រង់បានសម្លាប់អ្នករិះគន់ និងអ្នកខុងជឺនិយមអស់ចំនួន 460 នាក់។ ទ្រង់ក៏បានបញ្ជាឱ្យគេដុតសៀវភៅនានាដែលសរសេរពីទស្សនៈដែលទ្រង់មិនពេញចិត្ត។

ការបង្រួបបង្រួមប្រទេសចិន៖ សីហ័ងទីចង់ឱ្យមានរដ្ឋាភិបាលកណ្តាលមួយដែលមានអំណាចខ្លាំង។ ដើម្បីទទួលបានអំណាច ទ្រង់ព្យាយាមនៅក្នុងការធ្វើឱ្យអន់ថយនៃអំពីរបស់គ្រួសារអភិជននៅក្នុងប្រទេសចិន។ ទ្រង់បានរឹបអូសយកដីធ្លីរបស់ពួកអភិជន និងបានបង្ខំឱ្យពួកគេទៅរស់នៅក្នុងរាជធានី ដូច្នេះទ្រង់អស់តាមដានពួកគេបាន។ សកម្មភាពទាំងនេះបានជួយពង្រឹងអំណាចរបស់អធិរាជ។ សីហ័ងទីចាប់ផ្តើមបង្រួបបង្រួមប្រទេសចិនឱ្យស្ថិតនៅក្រោមកាតត្រួតត្រារបស់ទ្រង់។ ដើម្បីភ្ជាប់ទឹកដីជាមួយគ្នា ទ្រង់បង្កើតគម្រោងស្ថាបនាផ្លូវធំៗ និងប្រព័ន្ធធារាសាស្ត្រ។ ទ្រង់បានបង្ខំឱ្យប្រជាកសិករធ្វើការនៅក្នុងគម្រោងទាំងនេះ និងបានបង្កើនពន្ធអាករកាន់តែខ្ពស់ដើម្បីចំណាយលើគម្រោងទាំងនោះ។ ទ្រង់ក៏បានបង្កើតបទដ្ឋានទម្ងន់, ខ្នាតវាស់, កាក់, និងប្រព័ន្ធសំណេររបស់រដ្ឋាភិបាល ដែលធ្វើឱ្យមានភាពងាយស្រួលដល់ការធ្វើជំនួញគ្រប់ទីកន្លែងនៅក្នុងប្រទេសចិន។

មហាកំផែង៖ សីហ័ងទីចង់ឱ្យមានកំពែងដ៏វែងមួយតាមបណ្តោយព្រំដែនរបស់ប្រទេសចិនភាគខាងជើងដើម្បីការពារការឈ្លានពានរបស់ពួកចរកជន។ ទ្រង់បានរៀបចំគម្រោងស្ថាបនាមហាកំផែង ដែលជាការតភ្ជាប់គ្នារវាងកំពែងតូចៗដែលបានស្ថាបនាឡើងអំឡុងសម័យសង្គ្រាមរវាងរដ្ឋនិងរដ្ឋនៅក្នុងប្រទេសចិន។ កំពែងដំបូងបំផុតស្ថាបនាឡើងដោយដី។ ក្រោយមក ថ្ម និងឥដ្ឋត្រូវបានគេប្រើដើម្បីស្ថាបនា។ សីហ័ងទី បានបង្ខំឱ្យប្រជាកសិករ និងអ្នកជាប់ទោសរាប់សែននាក់ស្ថាបនាមហាកំផែងនេះ។ មានកម្មករជាច្រើនបានស្លាប់ដោយសារធ្វើ

ការងារធ្ងន់ធ្ងរពេក។ ការស្លាប់នាំឲ្យមានការមិនសប្បាយចិត្តពីសំណាក់ប្រជាជន។ សន្តតិវង្សក្រោយៗមកទៀតបានជួសជុល និងពង្រីកមហាកំផែងនេះជាបន្តបន្ទាប់។

ចុងបញ្ចប់នៃសន្តតិវង្សឈិន៖ ស៊ីហ័ងទីសុគតនៅក្នុងឆ្នាំ 210 មុនគ.ស ទ្រង់ត្រូវបានគេបញ្ចុះនៅក្នុងផ្នូរដ៏ធំមួយ។ កងទ័ពដែលធ្វើពីដីឥដ្ឋពណ៌ខ្មៅត្រូវបានគេបញ្ចុះនៅក្បែរផ្នូររបស់ទ្រង់ដើម្បីការពារទ្រង់។ ពួកអ្នកបុរាណវត្ថុវិទ្យាបានជីករកឃើញកងទ័ពទាំងនេះនៅក្នុងឆ្នាំ 1974 ។

សង្ខេប៖ ពន្យល់ពីរបៀបដែលរាជវង្សឈិនបង្រួបបង្រួមប្រទេសចិន។

## 2. សន្តតិវង្សហាន

សំណួរគន្លឹះ៖ តើរាជវង្សហានដឹកនាំប្រទេសចិនដោយរបៀបណា?

រាជបុត្រារបស់ស៊ីហ័ងទីគឺជាមេដឹកនាំអន់ខ្សោយជាងបិតារបស់ទ្រង់។ អំឡុងពេលនៃការគ្រប់គ្រងរបស់ទ្រង់ ការបះបោរ ហើយក្រោយមកសង្គ្រាមស៊ីវិលបានផ្ទុះឡើង។ ឧត្តមសេនីយ៍យោធាមួយរូបឈ្មោះលីបាងបានបញ្ចប់សង្គ្រាមស៊ីវិល និងបង្រួបបង្រួមប្រទេសចិនឡើងវិញ។ នៅក្នុងឆ្នាំ 202 មុនគ.ស ទ្រង់បានបង្កើតរាជវង្សហាន។ រាជវង្សហានបន្តរហូតដល់ប្រហែលឆ្នាំ 202 នៃគ.ស សម័យកាលដំណាលគ្នាជាមួយនឹងចក្រភពរ៉ូម។

រដ្ឋាភិបាលហាន៖ លីបាងរក្សានូវគោលនយោបាយរបស់ឈិនស្ដីអំពីរដ្ឋាភិបាលកណ្ដាលដែលមានអំណាចខ្លាំង ប៉ុន្តែបានបញ្ចុះតម្លៃពន្ធអាករ។ ទ្រង់បានបន្ថយការដាក់ពិន័យឱ្យធូរស្រាលជាងមុន។ នៅក្នុងសម័យហានប្រជាកសិករប្រុសៗត្រូវជាប់កាតព្វកិច្ចធ្វើការងារឱ្យរដ្ឋាភិបាលរយៈពេលមួយខែក្នុងមួយឆ្នាំ ទៅលើគម្រោងសាធារណៈនានារបស់អធិរាជ។ លីបាង បានដាក់ប្រជាកសិករឲ្យធ្វើផ្លូវ, ជីកប្រឡាយ, និងគម្រោងប្រព័ន្ធធារាសាស្ត្រ។

មេដឹកនាំហានបានបង្កើតប្រព័ន្ធការិយាធិបតេយ្យមួយ ដែលជាប្រព័ន្ធមួយដែលការិយាល័យនានាត្រូវទទួលបន្ទុកកិច្ចការងាររបស់រដ្ឋាភិបាល។ នៅក្នុងគ្រប់គ្រងបែបនេះ មន្ត្រីនានាត្រូវបានជ្រើសរើសដោយមេដឹកនាំដើម្បីគ្រប់គ្រងការិយាល័យ។ មន្ត្រីទាំងនេះជួយដល់ការអនុវត្តការគ្រប់គ្រងរបស់អធិរាជ។ ពួកមេដឹកនាំហានបានដាក់សមាជិកគ្រួសាររបស់ពួកគេ និងមនុស្សដែលគេជឿទុកចិត្តនៅក្នុងតំណាងមន្ត្រីរដ្ឋាភិបាលក្នុងតំបន់។ បន្តែក្រោយមក ជំនាញរបស់មនុស្សចាប់ផ្ដើមដើរតួនាទីសំខាន់នៅក្នុងជ្រើសរើសមន្ត្រីធ្វើការនៅក្នុងជួររដ្ឋាភិបាល។ មេដឹកនាំហានបានបង្កើតប្រព័ន្ធមួយដើម្បីស្វែងរកមនុស្សដែលមានការអប់រំ និងមានសីលធម៌ខ្ពស់សម្រាប់ធ្វើការនៅក្នុងការិយាល័យរបស់រដ្ឋ។ ពួកគេសាកល្បងចំណេះអំពីទស្សនខុងជឺរបស់មនុស្សទាំងនោះ។ ប្រព័ន្ធនៃជំនឿបានក្លាយជាមូលដ្ឋានគ្រឹះនៃរដ្ឋាភិបាលចិន។

ក្សត្រីគ្រប់គ្រងអំណាច៖ នៅពេលដែលលីបាងសុគតនៅក្នុងឆ្នាំ 195 មុនគ.ស មហេសីរបស់ទ្រង់ម្ចាស់ក្សត្រីលីគ្រប់គ្រងអំណាចជាមួយរាជបុត្រវ័យក្មេងរបស់ទ្រង់។ ម្ចាស់ក្សត្រីលីរស់នៅជាមួយរាជបុត្រារបស់ទ្រង់ និងបន្តដាក់ទារកឱ្យឡើងគ្រងរាជ្យ។ ការធ្វើដូច្នេះអាចអនុញ្ញាតឱ្យទ្រង់អាចរក្សាអំណាច ដោយសារទារកមានវ័យ

ក្មេងណាស់មិនអាចដឹកនាំរាជកិច្ចបានទេ។ នៅពេលដែលទ្រង់សុគតនៅក្នុងឆ្នាំ 180 មុនគ.ស អ្នកដែកស្មោះស្ម័គ្រនឹងលីបាងបានប្រហារជីវិតសមាជិកគ្រួសារទាំងអស់របស់ម្ចាស់ក្សត្រីលី។

ការពង្រីក និងការបង្រួបបង្រួមចក្រភពឡើងវិញ៖ ចាប់ពីឆ្នាំ 141 ដល់ 87 មុនគ.ស បច្ឆាជនរបស់លីបាងមានព្រះនាមថាវូទីបានដឹកនាំចក្រភពហាន។ ទ្រង់ត្រូវបានគេហៅថាអធិរាជសឹកសង្គ្រាម ដោយសារតែទ្រង់ប្រើប្រាស់ការធ្វើសង្គ្រាមដើម្បីពង្រីកប្រទេសចិន។ វូទីធ្វើការឈ្លានពានដណ្ដើមកាន់កាប់ជាច្រើនលើកច្រើនសារទៅលើរដ្ឋនានា ។ ទ្រង់បានវាយយកខេត្តភាគខាងត្បូង, វៀតណាមខាងជើង, និងកូរ៉េខាងជើងដាក់ឱ្យស្ថិតនៅក្រោមការត្រួតត្រារបស់ទ្រង់។ ទ្រង់បានវាយបណ្ដេញពីក្រុមឈ្លានពានចរកជនចេញពីចិនភាគខាងជើង។ នៅចុងបញ្ចប់នៃការគ្រប់គ្រងរបស់ទ្រង ប្រទេសចិនបានរីកធំយ៉ាងខ្លាំង ដែលមានទំហំប្រហែលទៅនឹងប្រទេសនាពេលបច្ចុប្បន្ន។

ដើម្បីបង្រួបបង្រួងចក្រភពដ៏ធំ និងចម្រុះនេះ រដ្ឋាភិបាលចិនបានជម្រុញឱ្យប្រជជនជនដែលពួកគេដណ្ដើមកាន់កាប់ជ្រួតជ្រាប ឬទទួលយកវប្បធម៌របស់ចិន។ ដើម្បីធ្វើដូច្នេះ រដ្ឋាភិបាលបានបញ្ជូនកសិករចិនទៅតាំងលំនៅនៅដែនដីអាណានិគមន៍ថ្មី។ វាបានជម្រុញឱ្យប្រជាកសិករចិនរៀបអាពាហ៍ពិពាហ៍ជាមួយប្រជាជនដែលពួកគេដណ្ដើមកាន់កាប់ ដើម្បីជួយដល់ការសាយភាយនៃវប្បធម៌ចិន។ មន្ត្រីរដ្ឋាភិបាលបានបង្កើតសាលារៀនជាច្រើនដើម្បីបង្រៀនប្រជាជនក្នុងតំបន់អំពីទស្សនខុងជឺ។ បន្ទាប់មកពួកគេចាត់តាំងអ្នកប្រាជ្ញក្នុងតំបន់ឱ្យធ្វើជាមន្ត្រីរដ្ឋាភិបាល។

បើទោះបីជារាជវង្សហានប្រឈមជាមួយនឹងការបះបោរ, កុបកម្មរបស់ប្រជាកសិករ, ទឹកជំនន់, គ្រោះអត់ឃ្លាន, និងមហន្តរាយសេដ្ឋកិច្ច។ ប៉ុន្តែ ដោយសារតែរដ្ឋាភិបាលមានអំណាចរឹងមាំ និងការបង្រួបបង្រួមប្រជាជនបានជួយឱ្យរាជវង្សនេះគ្រប់គ្រងអំណាចបានបន្តទៀត។ រាជវង្សហានគ្រប់គ្រងប្រទេសចិនរហូតដល់ឆ្នាំ 220 នៃគ.ស។

ស្វែងរកគោលគំនិត៖ ពន្យល់ពីរបៀបដែលរាជវង្សហានគ្រប់គ្រងប្រទេសចិន។

## 3. ជីវិតរស់នៅក្នុងសម័យរាជវង្សហាន

សំណួរគន្លឹះ៖ តើជីវិតរស់នៅក្នុងសម័យរាជវង្សហានមានលក្ខណៈដូចម្ដេច?

ប្រជាជនចិនជាច្រើននាពេលបច្ចុប្បន្នហៅខ្លួនឯងថា ប្រជាជនហាន។ ពួកគេមានលក្ខណៈដូចគ្នាយ៉ាងខ្លាំងទៅនឹងបុព្វការីជនរបស់ពួកគេកាលពីសម័យបុរាណ។ ពួកហានគឺជាមនុស្សឧស្សាហ៍ព្យាយាម ដែលអរិយធម៌របស់ពួកគេបានរុងរឿងអស់ជាច្រើនទសវត្សរ៍។

ជីវិតរស់នៅក្នុងសម័យរាជវង្សហាន៖ សង្គមរបស់ហានមួយភាគធំមានមុខរបរជាប្រជាកសិករ។ ប្រជាកសិកររស់នៅក្នុងភូមិក្បែរដីដាំដុះរបស់ពួកគេ។ ពួកគេភាគច្រើនរស់នៅក្នុងផ្ទះផ្ទាល់ដី ឬមួយជាន់ដែលធ្វើឡើងពីដីភក់។ ជង្រុកស្រូវ, ទ្រុងជ្រូក, និងឃ្លាំងដាក់ទំនិញក៏មានទីតាំងស្ថិតនៅក្បែរផ្ទះរបស់ពួកគេផងដែរ។ ប្រជាកសិករដែលមានទ្រព្យសម្បត្តិច្រើនប្រហែលជាអាចមានគោមួយ ឬពីរដើម្បីជួយដល់ការភ្ជួរដី។ ប្រជាកសិករក្រីក្រត្រូវភ្ជួរដោយប្រើកម្លាំងខ្លួនឯង។ ទាំងអ្នកមាន និងអ្នកក្រមានសម្ភារៈប្រើប្រាស់សាមញ្ញមួយចំនួនដើម្បីបម្រើដល់ការងារដាំដុះ

របស់ពួកគេឱ្យកាន់តែងាយស្រួល។ ប្រជាកសិករចិនស្លៀកសំលៀកបំពាក់ និងស្បែកជើងសាមញ្ញ ដែលប្រហាក់ប្រហែលទៅនឹងសំលៀកបំពាក់នាពេលបច្ចុប្បន្ន។ សម្រាប់ខែត្រជាក់ សំលៀកបំពាក់របស់ពួកគេបិទជិតដូចជាកម្រាលព្រំ។ ប្រជាកសិករនៅភាគខាងជើងដាំដុះស្រូវសាលី ឬស្រូវបីយេ។ ប្រជាកសិករនៅភាគខាងត្បូងដាំដុះស្រូវអង្ករ។ គ្រួសារនីមួយៗមានសួនបន្លែផ្ទាល់ខ្លួនសម្រាប់ធ្វើម្ហូបអាហារ។ ត្រី និងសាច់អាចស្វែងរកទិញបាន ប៉ុន្តែមានតម្លៃថ្លៃ។ ជាលទ្ធផល ប្រជាជនភាគច្រើនញ៉ាំសាច់ និងត្រីតិចតួចប៉ុណ្ណោះ។

ជីវិតរស់នៅក្នុងទីក្រុង៖ មិនមែនមនុស្សទាំងអស់សុទ្ធតែរស់នៅទីជនបទទេ។ នៅក្នុងប្រទេសចិននាសម័យរាជវង្សហានក៏មានទីក្រុងផងដែរ។ ទីក្រុងជាមជ្ឈមណ្ឌលពាណិជ្ជកម្ម, អប់រំ, និងរដ្ឋាភិបាល។ ពាណិជ្ជករ, សិប្បករ, និងមន្ត្រីរដ្ឋាភិបាលរស់នៅទីនេះ។ ពេលខ្លះ ទីក្រុងនៅពេលនោះមិនមានអ្វីខុសគ្នាច្រើនពីទីក្រុងនាពេលបច្ចុប្បន្នឡើយ។ នៅក្នុងទីក្រុងមានមនុស្សកុះករ និងមានការសម្តែងជាច្រើនប្រភេទ ដោយរួមមាន ការសម្តែងតន្ត្រី, សៀក, និងកាយវប្បកម្ម។ យោងទៅតាមអ្នកនិពន្ធមួយចំនួន នៅក្នុងទីក្រុងក៏មានក្រុមអ្នកលេងតាមដងផ្លូវផងដែរ។ នៅក្នុងមេរៀនបន្ទាប់ អ្នកនឹងបានសិក្សាអំពីកេរ្តិ៍តំណែលរបស់រាជវង្សហាន។

ស្វែងរកគោលគំនិត៖ ពិពណ៌នាអំពីជីវិតរស់នៅរបស់ប្រជាជនចិននៅក្នុងសម័យរាជវង្សហាន។

# មេរៀនទី 4 ៖ កេរ្តិ៍តំណែលចិនសម័យបុរាណ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ពាណិជ្ជកម្មបានបង្កើតជីវិតមួយផ្នែករបស់ប្រជាជនចិន។ បើទោះបីជាមានរបាំងភូមិសាស្ត្រដែលញែកប្រទេសចិនពីភាគខាងលិចក៏ដោយ ក៏ពាណិជ្ជកម្មបាននាំឱ្យប្រទេសចិនមានទំនាក់ទំនងជាមួយតំបន់ផ្សេងដើម្បី។

## 1. ផ្លូវសូត្រ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាផ្លូវសូត្រមានសារៈសំខាន់សម្រាប់អរិយធម៌ចិន?

អំឡុងសម័យរាជវង្សហាន មានតែជនជាតិចិនមួយគត់ដែលបានដឹងពីវិធីផលិតសូត្រ។ វាមានការពេញចិត្តយ៉ាងខ្លាំងពីសំណាក់ទាំងជនជាតិចិន និងជនជាតិផ្សេងៗទៀតនៅក្រៅប្រទេសចិន ដោយសារវាជាក្រណាត់ដែលល្អប្រណិត។ សូត្រចិនមានសារៈសំខាន់នៅក្នុងបើកផ្លូវពាណិជ្ជកម្មទៅកាន់ភាគខាងលិច។

ប្រកភ្ជាប់ទំនាក់ទំនងអឺរ៉ុប-អាស៊ី៖ ការធ្វើពាណិជ្ជកម្មតាមផ្លូវគោកត្រូវបានគេហៅថា ផ្លូវសូត្រ ដោយសារតែពាណិជ្ជករបាននាំយកសូត្រ និងទំនិញផ្សេងៗទៀតតាមផ្លូវលំជាក្រុមៗ។ ផ្លូវលំលាតសន្ធឹងឆ្ពោះទៅភាគខាងលិចចាប់ពីប្រទេសចិនកាត់តាមអាស៊ីកណ្តាលទៅដល់មេសូប៉ូតាមី និងអឺរ៉ុប ដែលមានចម្ងាយដីប្រហែល 5,000 ម៉ាយដោយសារផ្លូវលំនេះឆ្លងកាត់ទ្វីបពីរអឺរ៉ុប និងអាស៊ី វាត្រូវបានគេហៅថា ប្រកអឺរ៉ុប-អាស៊ី។ ប្រទេសចិននៅពេលនោះគឺជាផ្នែកដ៏ធំមួយនៃបណ្តាញពាណិជ្ជកម្មសកល។ ត្រឹមឆ្នាំ 100 មុនគ.ស ផ្លូវសូត្រត្រូវបានគេរៀបចំបានយ៉ាងល្អប្រសើរ។ ពាណិជ្ជករស្វែងរកប្រាក់ចំណេញតាមរយៈការនាំយកទំនិញទៅមក ដោយឆ្លងកាត់តំបន់ដែលមានដីរដិបរដុបតាមក្បួនធ្វើដំណើរដោយសត្វអូដ្ឋ។ ការធ្វើដំណើរនេះអាចចំណាយពេលរាប់ឆ្នាំ។ ទីក្រុងនានានៅតាមផ្លូវសូត្របានផ្តត់ផ្គង់នូវចំណីអាហារ, ទឹក, និងទីកន្លែងស្នាក់នៅ ក៏ដូចជាទំនិញមួយចំនួនសម្រាប់ការធ្វើពាណិជ្ជកម្ម។ ទំនិញដែលគេដឹកចេញពីប្រទេសចិនរួមមាន សូត្រ, ក្រដាស់, ថ្មយក់, និងភាជន៍។ ទំនិញដែលគេផ្លោះប្តូរមកពីអឺរ៉ុបរួមមាន គ្រាប់ និងប្រេងល្ង, លោហៈ, និងត្បូងមានតម្លៃ។ ទំនិញពាណិជ្ជកម្មមួយដែលប្រជាជនឱ្យតម្លៃខ្លាំងជាងគេគឺសត្វសេះមកពីអាស៊ីកណ្តាល។

ការសាយភាយនៃវប្បធម៌៖ ការធ្វើពាណិជ្ជកម្មទំនិញមិនមែនជារបស់តែមួយដែលឆ្លងកាត់តាមផ្លូវសូត្រឡើយ។ ទស្សន និងវប្បធម៌ទំនៀមទម្លាប់នានាបានធ្វើដំណើរតាមផ្លូវសូត្រផងដែរ។ ការរីកសាយភាយនៃទស្សន និងទំនៀមទម្លាប់នេះត្រូវបានគេហៅថា ការសាយភាយនៃវប្បធម៌។ ការសាយភាយនៃវប្បធម៌ អាចកើតមានឡើងនៅពេលដែលមនុស្សមួយក្រុមធ្វើដំណើរមកធ្វើទំនាក់ទំនងជាមួយមនុស្សមួយក្រុមទៀត។ ដូចដែលអ្នកបានរៀននៅក្នុងមេរៀនមុន របាំងភូមិសាស្ត្របានផ្តាច់ប្រទេសចិនឱ្យឯកកោ ដែលមានន័យថា ការអភិវឌ្ឍវប្បធម៌របស់ពួកគេមានឥទ្ធិពលមកពីខាងក្រៅតិចតួចប៉ុណ្ណោះ។ ប៉ុន្តែ ផ្លូវសូត្រដែលសសៀរតាមតំបន់វាលខ្សាច់តាកលីម៉ាកាន និងឆ្លងកាត់តំបន់ប៉ាមីបានអនុញ្ញាឱ្យទំនិញ, ទស្សន, និងទំនៀមទម្លាប់ថ្មីៗចូលមកកាន់ប្រទេសចិន។ ឧទាហរណ៍

សម្ភារៈឃោជាមកពីអាស៊ីកណ្តាល, ការអប់រំបែបពុទ្ធសាសនា, និងរចនាបថវប្បធម៌អ៊ីរ៉ុបបានចូលមកដល់ប្រទេសចិន។ ប្តូរទៅវិញ សិល្បៈចិន, សូត្រ, និងភាជន៍បានជះឥទ្ធិពលលើវប្បធម៌របស់ពួកខាងលិច។

ការរីកសាយភាយនៃពុទ្ធសាសនា៖ នៅក្នុងមេរៀនមុនស្តីពីឥណ្ឌា អ្នកបានសិក្សាអំពីការចាប់កំណើតឡើងដំបូងនៃពុទ្ធសាសនានៅក្នុងប្រទេសឥណ្ឌា។ នៅអំឡុងសម័យរាជវង្សហាន បេសកទូតពុទ្ធសាសនាបានចូលមកកាន់ប្រទេសចិនតាមរយៈផ្លូវសូត្រ និងបានផ្សព្វផ្សាយសាសនានេះទៅកាន់ប្រជាជនចិន។ នៅគ្រាដំបូង ទស្សនរបស់បរទេសនេះទាក់ទាញអ្នកដើរតាមបានតិចតួចប៉ុណ្ណោះ។ ប៉ុន្តែ នៅអំឡុងឆ្នាំនៃភាពជ្រួលច្របល់បន្ទាប់ពីការធ្លាក់ចុះនៃរាជវង្សហាន ការសន្យារបស់ពុទ្ធសាសនាអំពីការចាកផុតពីសេចក្តីឈឺចាប់បានក្លាយជាចំណាប់អារម្មណ៍របស់ប្រជាជនជាច្រើន។ ពុទ្ធសាសនិកចិនបានកែប្រែពុទ្ធសាសនាឱ្យត្រូវទៅនឹងទំនៀមទម្លាប់ប្រពៃណីរបស់ពួកគេ។ ពុទ្ធសាសនាបានរីកសាយភាយពីប្រទេសចិនទៅកាន់ប្រទេសជប៉ុន និងប្រទេសកូរ៉េ។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីមូលហេតុដែលផ្លូវសូត្រមានសារៈសំខាន់សម្រាប់អរិយធម៌ចិន។

## 2. ឥទ្ធិពលនៃទស្សន និងជំនឿ

សំណួរគន្លឹះ៖ តើខុងជឺនិយម, តាវនិយម, និងពុទ្ធសាសនាមានសារៈសំខាន់យ៉ាងដូចម្តេច?

ទស្សនរបស់ចិនបុរាណបានបន្តជះឥទ្ធិពលនៅក្នុងប្រទេស និងលើពិភពលោក។ បទដ្ឋានដែលបង្កើតឡើងដោយខុងជឺនិយមនៅបន្តមានសារៈសំខាន់នៅក្នុងជួររដ្ឋាភិបាល និងការអប់រំនៅក្នុងប្រទេសចិន។ បច្ចុប្បន្ន ទស្សនរបស់ខុងជឺអំពីកាតព្វកិច្ចសង្គមនៅតែមានសារៈសំខាន់នៅក្នុងសង្គមចិន។ ខុងជឺនិយមក៏បានក្លាយជាទស្សនវិជ្ជាដែលមានឥទ្ធិពលបំផុតមួយនៅក្នុងប្រទេសជប៉ុន, ប្រទេសកូរ៉េ, និងប្រទេសវៀតណាម។ តាវនិយមមានឥទ្ធិពលខ្លាំងក្លានៅក្នុងប្រទេសចិន។ ត្រឹមឆ្នាំ 500 នៃគ.ស វាបានក្លាយជាសាសនាមួយដែលមានបព្វជិត, ក្បួនពិធី, និងបណ្តុំនៃសៀវភៅ។ ខុសពីខុងជឺនិយម តាវនិយមនៅតែជាប្រព័ន្ធជំនឿគោលរបស់ចិន។ ជាមួយគ្នា ពុទ្ធសាសនា, តាវនិយម, និងខុងជឺនិយមបានបង្កើតបានជាសាសនា ឬប្រព័ន្ធសីលធម៌សំខាន់ 3 ដែលមានឥទ្ធិពលលើជីវិតរស់នៅរបស់ប្រជាជនចិន។ ជំនឿរបស់ប្រជាជនភាគច្រើនរួមបញ្ចូលធាតុនៃទស្សនៈទាំង 3 នេះ។ ប្រាសាទរបស់តាវ និងពុទ្ធសាសនាត្រូវបានគេឃើញមាននៅពាសពេញប្រទេសចិន។ បច្ចុប្បន្ន ប្រព័ន្ធជំនឿទាំង 3 នេះមានអ្នកដើរតាមនៅពាសពេញពិភពលោក។ ពុទ្ធសាសនាគឺជាសាសនាមួយដែលមានការរីកសាយភាយខ្លាំងជាងគេ ដែលមានអ្នកប្រតិបត្តិប្រមាណ 379 លាននាក់នៅក្នុងប្រទេសចំនួន 130 ។ នៅក្នុងការបន្ថែម មានប្រជាជនប្រមាណ 6.5 លាននាក់ជាអ្នកខុងជឺនិយម និងប្រហែល 2.7 លាននាក់ជាអ្នកតាវនិយមនៅពាសពេញពិភពលោក។

សង្ខេប៖ ពន្យល់អំពីសារៈសំខាន់យូរអង្វែងនៃខុងជឺនិយម, តាវនិយម, និងពុទ្ធសាសនា។

## 3. ការបង្កើត និងការរកឃើញរបស់ចិន

សំណួរគន្លឹះ៖ តើទិដ្ឋភាពនៃជីវិតរស់នៅរបស់ប្រជាជនចិនមួយណាដែលរាជវង្សហានបានអភិវឌ្ឍឡើងយ៉ាងល្អប្រសើរ។

ប្រទេសចិនត្រូវចិញ្ចឹមប្រជាជនដ៏ច្រើន និងកើនឡើងយ៉ាងឆាប់រហ័ស។ ប្រជាជនចិនចាត់ទុកថាការធ្វើដាំដុះគឺមានសារៈសំខាន់បំផុត និងជាការងារដែលមានកិត្តិយស។ ដោយសារតែកសិកម្មមានសារៈសំខាន់ខ្លាំងនៅក្នុងប្រទេសចិន ការបង្កើតថ្មីៗជាច្រើននៅក្នុងវិស័យកសិកម្មបានកើតឡើងនៅអំឡុងពេលនោះ។

ការអភិវឌ្ឍកសិកម្ម៖ ការបង្កើតថ្មីរបស់ចិនបានធ្វើឱ្យជីវិតរស់នៅរបស់ប្រជាកសិករកាន់តែងាយស្រួល និងផលិតបាននូវទិន្នផលគ្រាប់ធុញ្ញជាតិកាន់តែច្រើនសម្រាប់ធ្វើពាណិជ្ជកម្ម។ ឧទាហរណ៍ ប្រជាជនចិនបានអភិវឌ្ឍនង្គ័លដែលមានប្រសិទ្ធភាពខ្លាំងមួយ ដោយសារតែនង្គ័លនេះមានផ្លែពីរ។ ការធ្វើឱ្យប្រសើរឡើងនៃនង្គ័ល បូករួមជាមួយសម្ភារៈកសិកម្មល្អៗដែលធ្វើពីដែក បានជួយបង្កើនទិន្នផលកសិកម្ម។ ការអភិវឌ្ឍបច្ចេកវិទ្យាមួយទៀតគឺស្រងកសេះ។ ការបង្កើតថ្មីនេះ បានអនុញ្ញាតឱ្យសេះអាចអូសទាញនូវរបស់ធ្ងន់ៗជាងស្រងកដែលប្រើប្រាស់នៅអឺរ៉ុបនាសម័យនោះ។ ជនជាតិចិនក៏បានបង្កើតរទេះរុញ ដែលធ្វើឱ្យមានលក្ខណៈងាយស្រួលសម្រាប់ប្រជាកសិករក្នុងការផ្លាស់ទីរបស់ធ្ងន់ៗដោយប្រើប្រាស់ដៃរុញ។ ប្រជាជនចិនចាប់ផ្តើមប្រើប្រាស់ឧបករណ៍សម្រាប់កិនដោយប្រើកម្លាំងទឹក ដោយគេប្រើប្រាស់កម្លាំងទឹកហូរដើម្បីកិនគ្រប់ធុញ្ញជាតិ។ ភាគច្រើននៅក្នុងតំបន់ដែលប្រមូលផ្តុំទៅដោយប្រជាកសិករ គេឃើញមានការប្រើប្រាស់ឧបករណ៍សម្រាប់កិនដោយប្រើកម្លាំងទឹកនេះ។

ក្រដាស៖ នៅក្នុងឆ្នាំ 105 នៃគ.ស ក្រដាសត្រូវបានបង្កើតឡើងនៅក្នុងប្រទេសចិន។ មុនពេលការបង្កើតក្រដាស សៀវភៅត្រូវបានគេធ្វើឡើងពីសូត្រ ដែលមានតម្លៃថ្លៃ។ ក្រដាសថ្មីដែលមានតម្លៃថោកនេះបង្កើតឡើងពីការលាយបញ្ចូលគ្នានូវកម្ទិចក្រណាត់ចាស់, សសៃសំបកដើមមន, និងសសៃដើមក្រចៅ។ ក្រដាសដែលមានតម្លៃថោក បានបង្កើតឱ្យមានសៀវភៅជាច្រើននៅក្នុងប្រទេសមួយដែលឱ្យតម្លៃខ្ពស់ទៅលើការសិក្សា។ ការបង្កើតឡើងនៃក្រដាស់ថ្មីនេះក៏ជះឥទ្ធិពលលើរដ្ឋាភិបាលចិនផងដែរ។ កាលពីមុន រាល់ឯកសាររដ្ឋាភិបាលទាំងអស់ត្រូវបានគេកត់ត្រានៅលើបន្ទះឈើ។ ការប្រើប្រាស់ក្រដាសសម្រាប់កត់ត្រាធ្វើឱ្យមានភាពងាយស្រួលជាង។ ក្រដាសគឺជាការបង្កើតថ្មីដែលមានសារៈសំខាន់សម្រាប់រដ្ឋាភិបាលបែបការិយាធិបតេយ្យ ដែលជាទូទៅត្រូវការរក្សាទុកកំណត់ត្រាច្រើន។

សូត្រ៖ សូត្រគឺមានលក្ខណៈស្រស់ស្អាត និងស្ថិតស្ថេរបានយូរអង្វែង។ គេអាចជ្រលក់វាបានជាច្រើនពណ៌។ ប្រហែលជា 3,000 ឆ្នាំមុន មានតែជនជាតិចិនប៉ុណ្ណោះដែលបានដឹងពីអាថ៌កំបាំងនៃការផលិតសូត្រ។ ដោយសារតែវាកម្រ វាបានក្លាយជាទំនិញពាណិជ្ជកម្មដ៏ល្អប្រសើរមួយ។ សូត្របានអនុញ្ញាតឱ្យចិនទទួលបាននូវប្រាក់ និងមាសពីតំបន់នានាដែលស្ថិតនៅភាគខាងលិចប្រទេសចិន។ មានពេលមួយនោះ សូត្រទម្ងន់មួយផោនមានតម្លៃស្មើនឹងមាសមួយផោន។ ការទទួលបានមាស និងប្រាក់មានសារៈសំខាន់ណាស់សម្រាប់ប្រទេសចិន ដោយសារតែប្រទេសនេះមិនសូវសំបូរធនធានរ៉ែក្រោមដីឡើយ។

ធ្វើចំណាត់ថ្នាក់៖ រាយបញ្ជីពីទម្រង់រស់នៅរបស់ប្រជាជនចិនដែលរាជវង្សហានបានអភិវឌ្ឍឡើងយ៉ាងល្អប្រសើរ។

# ជំពូក 7 ៖ ប្រទេសក្រិកបុរាណ

## មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រប្រទេសក្រិក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើធ្លាប់មានការស្ពាបនាសំណង់ ឬឧបទ្ទវហេតុណាមួយដែលបានរាំងស្ទះដល់ផ្លូវដែលគ្រួសារអ្នកចង់ធ្វើដំណើរដែរឬទេ? តើអ្នកដោះស្រាយបញ្ហានេះដោយរបៀបណា? ជួរភ្នំបានរារាំងដល់ពួកក្រិកបុរាណមិនអាចធ្វើដំណើរតាមផ្លូវគោកបានឡើយ។ នៅក្នុងមេរៀននេះនឹងពន្យល់ពីវិធីសាស្ត្រនៃការធ្វើដំណើរផ្សេងៗទៀត ជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះចំពោះជីវភាពរស់នៅជនជាតិក្រិកបុរាណ។

### 1. ទីតាំងភូមិសាស្ត្របង្កើតទម្រង់រស់នៅរបស់ក្រិក

សំណួរគន្លឹះ៖ តើជួរភ្នំជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះជីវិតរស់នៅរបស់ប្រជាជនក្រិក?

ក្រិចផ្នែកខាងដីគោកលយចេញទៅក្នុងសមុទ្រមេឌីទែរ៉ានេ។ វាគឺជាឧបទ្វីបមួយ ដែលជាដីមួយស្ទើរតែហុំព័ទ្ធជុំវិញទៅដោយទឹក។ ប្រទេសក្រិចក៏រួមបញ្ចូលដោយកោះរាប់ពាន់ផងដែរ។

ឈូងដែលលយចូលស្ទើរតែផ្តាច់ឧបទ្វីបក្រិកជាពីរផ្នែក។ តំបន់ចុងភាគខាងត្បូងដែលបង្កើតបានជាឧបទ្វីបទីពីរត្រូវបានគេហៅថាប៉េឡូប៉ូនេស៊ូស។ ផ្ទៃដីតូចមួយត្រូវបានគេហៅថាអ៊ីសម៉ូសបានភ្ជាប់តំបន់ប៉េឡូប៉ូនេស៊ូសជាមួយនឹងតំបន់ផ្សេងៗទៀតរបស់ក្រិក។

ផ្ទៃដី និងអាកាសធាតុ៖ ជួរភ្នំគ្របដណ្តប់ស្ទើរពាសពេញប្រទេសក្រិក ដែលបានបែងចែកផ្ទៃដីទៅជាច្រើនតំបន់ផ្សេងៗគ្នា។ ប្រទេសនេះមិនមានទន្លេធំៗទេ។ ផ្ទៃដីមិនរាបស្មើ និងកង្វះខាងទន្លេធំៗធ្វើឱ្យមធ្យោបាយធ្វើដំណើរមានការលំបាកសម្រាប់ប្រជាជនក្រិកនាសម័យបុរាណ។ ផ្ទៃដីរដេបរដុបក៏នាំឱ្យមានភាពលំបាកសម្រាប់ក្រិចក្នុងការបង្រួបបង្រួមគ្នាឱ្យស្ថិតនៅក្រោយរដ្ឋាភិបាលតែមួយ។ នៅក្រិចមានអាកាសធាតុមិនក្តៅពេកមិនត្រជាក់ពេក, រដូវរំហើយមានភ្លៀងធ្លាក់ និងក្តៅ, និងរដូវក្តៅស្ងួត។ ក្នុងតំបន់ភាគច្រើនក្នុងប្រទេសក្រិក អាកាសធាតុមានចន្លោះប្រហែល 50°F នៅរដូវរំហើយ ដល់ 80°F នៅរដូវក្តៅ។ អាកាសធាតុក្តៅល្មមបានអនុគ្រោះដល់ជីវិតរស់នៅខាងក្រៅផ្ទះ នៅក្នុងប្រទេសក្រិកនាសម័យបុរាណ។ ឧទាហរណ៍ ការប្រកួតប្រជែងអត្តពលិកនៅកណ្តាលវាលដូចជាការរត់ប្រណាំង គឺជាផ្នែកដ៏សំខាន់មួយនៃវប្បធម៌របស់ក្រិក។

កសិកម្ម៖ ផ្ទៃដីនៅក្នុងប្រទេសក្រិចសម្បូរទៅដោយថ្ម ដូច្នេះមានតែផ្ទៃដីមួយភាគតូចប៉ុណ្ណោះដែលអំណោយផលដល់ការដាំដុះ។ បើទោះបីជាដូច្នេះក៏ដោយ ជាងពាក់កណ្តាលនៃប្រជាជនក្រិកគឺជាប្រជាកសិករ ឬអ្នកចិញ្ចឹមសត្វ។ ការដាំដុះភាគច្រើនធ្វើឡើងនៅតាមជ្រលងភ្នំដែលស្ថិតនៅចម្លោះជួរភ្នំ។

នៅក្នុងសង្គមក្រិក ម្ចាស់កម្មសិទ្ធិដីធ្លី ស្ថិតនៅក្នុងវណ្ណៈជាន់លើ។ ជាទូទៅ មានតែបុរសទេដែលមានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ។ មនុស្សម្នាក់ដែលមានដីធ្លីកាន់កាប់អាចផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគេបានដោយខ្លួនឯង។ ពួកគេមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីចំណាយទៅលើគ្រឿងបរិក្ខារនានា ដូចជា មួកដែក, ខែលការពារ,

និងដារ។ កាលនេះ បានអនុញ្ញាតឱ្យពួកគេអាចចូលបម្រើការនៅក្នុងកងទ័ព និងការពារទឹកដីរបស់ពួកគេ។ ជាលទ្ធផល ម្ចាស់កម្មសិទ្ធិដីធ្លី មានឋានៈខ្ពស់នៅក្នុងសង្គមជាងពាណិជ្ជករ ឬប្រជាជនក្រីក្រ។ ដើម្បីទទួលបានផ្ទៃដីសម្រាប់ដាំដុះបានកាន់តែច្រើន ក្រិកបានដាក់អាណានិគមលើតំបន់ផ្សេងៗទៀត។ តំបន់ខាងលិចអាណាតូលីមានតំបន់វាលទំនាប និងមានទន្លេច្រើន។ ក្រិកបានដាក់អាណានិគមលើតំបន់ជាច្រើននៅទីនោះ។

ធនធាន៖ កង្វះខាងផ្ទៃដីសម្រាប់ធ្វើកសិកម្មមិនមែនជាបញ្ហាតែមួយសម្រាប់ក្រិកឡើយ។ ប្រទេសក្រិកក៏មានបញ្ហាទាក់ទងទៅនឹងកង្វះខាងធនធានធម្មជាតិនានា ដូចជាលោហៈធាតុមានតម្លៃនានា។ ហេតុដូច្នេះ ក្រិកត្រូវស្វែងរកធនធានទាំងនោះនៅក្នុងតំបន់ផ្សេងៗទៀត។ បើទោះបីជាដូច្នេះក៏ដោយ ប្រទេសក្រិកក៏មានធនធានសំខាន់ៗពីរផងដែរ។ ទីមួយគឺ ភាពសំបូរបែបនៃថ្មសម្រាប់ស្ថាបនាសំណង់។ ទីពីរគឺឆ្នេរសមុទ្រដែលសម្បូរទៅដោយតំបន់ល្អសម្រាប់សាងសង់កំពង់ផែ។

វិភាគពីឥទ្ធិពល៖ ពិពណ៌នាអំពីឥទ្ធិពលនៃជួរភ្នំលើជីវភាពរស់នៅរបស់ប្រជាជនក្រិក។

## 2. ពាណិជ្ជកម្មធ្វើឱ្យក្រិករុងរឿង

សំណួរគន្លឹះ៖ តើសមុទ្រជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះសេដ្ឋកិច្ចរបស់ក្រិច?

ក៏ដូចជាទន្លេដែលជះឥទ្ធិពលលើវប្បធម៌បុរាណនានា សមុទ្រក៏បានជះឥទ្ធិពលលើជីវិតរស់នៅក្នុងប្រទេសក្រិកនាសម័យបុរាណផងដែរ។ ប្រទេសក្រិកមានតំបន់ឆ្នេរសមុទ្រវែង ហើយតំបន់ភាគច្រើននៅក្នុងប្រទេសក្រិកមានចម្ងាយមិនលើសពី 100 ម៉ាយពីឆ្នេរសមុទ្រឡើយ។ ដូច្នេះ ទីក្រុងជាច្រើនត្រូវបានស្ថាបនាផ្ទាល់នៅនឹងកំពង់ផែតែម្តង។

ប្រជាជនសមុទ្រ៖ សមុទ្រច្រើនបានដើរតួនាទីសំខាន់មួយនៅក្នុងជីវិតរស់នៅរបស់ប្រជាជនក្រិកសម័យបុរាណ។ សមុទ្រដែលធំជាងគេគឺសមុទ្រមេឌីទែរ៉ានេដែលស្ថិតនៅភាគខាងត្បូង។ សមុទ្រអាយអូនៀន និងសមុទ្រអេជៀនគឺជាសាខានៃសមុទ្រមេឌីទែរ៉ានេ។ សមុទ្រអាយអូនៀនស្ថិតនៅភាគខាងលិចក្រិក និងសមុទ្រអេជៀនលាតសន្ធឹងនៅភាគខាងកើត។ ផ្លូវទឹកទាំងនេះបានភ្ជាប់ផ្នែកនានានៃប្រទេសក្រិកជាមួយគ្នា។ ប្រជាជនក្រិកប្រើប្រាស់សមុទ្រធ្វើជាផ្លូវគមនាគមន៍ ហើយពួកគេបានក្លាយជាអ្នកជំនាញខាងដើរសមុទ្រ និងផលិតនាវា។ ពួកគេស្ថាបនាទូកចាវសម្រាប់ធ្វើសង្គ្រាម និងស្ថាបនាទូកក្ដោងសម្រាប់ធ្វើពាណិជ្ជកម្ម។ នាវាចម្បាំងមួយចំនួនមានច្រវា 2 ឬ 3 ជាន់នៅសងខាងនៃនាវា។ ភាគច្រើននៃទូកក្ដោងមានដងក្ដោង និងក្ដោងតែមួយប៉ុណ្ណោះ។ សមុទ្រអាយអូនៀន និងសមុទ្រអេជៀន មិនសូវជាមានទំហំធំប៉ុន្មានទេ។ ទូកតូចៗដែលធ្វើដំណើរនៅជុំវិញវាបានដោយធ្វើដំណើរពីតំបន់ឆ្នេរមួយទៅតំបន់មួយទៀតនៅក្បែរនោះ ឬធ្វើដំណើរពីកោះមួយទៅកោះមួយទៀត។ នៅពេលដែលពួកក្រិកដឹងពីផ្លូវទឹកនេះច្បាស់ហើយ ពួកគេអាចធ្វើដំណើរទៅកាន់តំបន់ផ្សេងៗទៀតបាន។ សមុទ្របានផ្ដល់នូវធនធានត្រីដែលជាផ្នែកដ៏សំខាន់មួយនៃចំណីអាហាររបស់ប្រជាជនក្រិច។ ពួកក្រិកធ្វើពាណិជ្ជកម្មត្រីស្រស់ដែលនេសាទបានមកពីសមុទ្រតាមកំពង់ផែផ្សេងៗនៅតាមតំបន់ឆ្នេរ។ ពួកគេក៏បានប្រឡាក់ងៀតនូវប្រភេទត្រីមួយចំនួន ដូច្នេះពួកគេអាចដឹកជញ្ជូនវាទៅកាន់តំបន់ឆ្ងាយៗបាន។

ពាណិជ្ជកម្ម និងជំនួញ៖ ពួកក្រិកមិនអាចផលិតគ្រាប់ធញ្ញជាតិបានច្រើនទេ ប៉ុន្តែតំបន់មួយចំនួនផលិតនូវប្រេងអូលីវ, ស្រា, រោមចៀម, ភាជន៍ ដែលមានចំនួនលើសពីតម្រូវការ។ បុរី-រដ្ឋនានារបស់ក្រិកបាននាំយក និងលក់នូវផលិតផលលើសរបស់ពួកគេឱ្យគ្នាទៅវិញទៅមក។ ជាងនេះទៅទៀត ពួកក្រិកបានធ្វើដោះដូររបស់របរទាំងអស់នេះជាមួយនឹងតំបន់ផ្សេងៗនៅជុំវិញសមុទ្រខ្មៅ និងសមុទ្រមេឌីទែរ៉ានេ ដោយរួមបញ្ចូលទាំងអេហ្ស៊ីប និងអ៊ីតាលីផងដែរ។ ទំនិញសំខាន់ៗដែលពួកក្រិកបាននាំចូលរួមមាន គ្រាប់ធុញ្ញជាតិ, ឈើហ៊ុបសម្រាប់សំណង់, ស្បែកសត្វ, និងទាសករ។ ពួកក្រិកក៏នាំចូលផងដែរនូវសណ្តែកដី, ល្ងា, ឈើស, និងកប្បាសសម្រាប់ផលិតក្រណាត់ទ្បែន។

វិភាគពីឥទ្ធិពល៖ កំណត់អំពីវិធីដែលសមុទ្រជះឥទ្ធិពលលើសេដ្ឋកិច្ចរបស់ក្រិក។

## 3. ពួកក្រិកដំបូងបំផុត

សំណួរគន្លឹះ៖ តើពាណិជ្ជកម្មបានជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះវប្បធម៌របស់ក្រិក?

វប្បធម៌នៃការធ្វើដំណើរតាមផ្លូវទឹក និងការធ្វើពាណិជ្ជកម្មរបស់ពួកក្រិកបានអភិវឌ្ឍឡើងរាប់ពាន់ឆ្នាំមកហើយ។ ប្រជាជនក្រិកដំបូងបំផុតបានធ្វើដំណើរមកកាន់ឧបទ្វីបក្រិកនៅអំឡុងឆ្នាំប្រមាណ 2000 មុនគ.ស។

អរិយធម៌មែសេនៀន៖ អរិយធម៌ដំបូងរបស់ក្រិកត្រូវបានស្ថាបនានៅប៉េឡូប៉ូនេស៊ូស។ ឈ្មោះនៃអរិយធម៌នេះត្រូវបានដាក់តាមឈ្មោះទីក្រុងដ៏សំខាន់មួយដែលមានឈ្មោះថាមែសេនេ។ ទីក្រុងដែលមានទីតាំងនៅចន្លោះកូនភ្នំដែលហ៊ុំព័ទ្ធជុំវិញដោយកំពែងសម្រាប់ការពារសត្រូវ។ បន្ទាយនេះអាចទប់ទល់ទៅនឹងការវាយប្រហារនានា។ នៅតាមទីក្រុងនីមួយៗរបស់មែសេនៀននៅក្រិកមានស្តេចមួយអង្គគ្រប់គ្រង និងមានភូមិ និងផ្ទៃដីដាំដុះនៅជុំវិញ។

ពួកអភិជនដែលរស់នៅក្នុងបន្ទាយនៅមែសេនៀន ភាគច្រើនរស់នៅតាមបែបប្រណិតភាព។ ពួកគេរីករាយជាមួយនឹងពិធីជប់លៀងសំខាន់ៗនៅក្នុងសាលបរិភោគអាហារដ៏ធំ។ ពួកគេប្រើប្រាស់ពែងមាសសម្រាប់ផឹក និងប្រើប្រាស់អាវុធធ្វើពីសំរិទ្ធដ៏រឹងមាំ។ ប្រជាជនសាមញ្ញភាគច្រើននៅមែសេនៀន ធ្វើឧបករណ៍ប្រើប្រាស់ពីធនធានដែលមិនសូវមានតម្លៃមួយចំនួនដូចជា ថ្ម និងឈើជាដើម។

ពួកមែសេនៀនក៏ជាពាណិជ្ជករផងដែរ។ វប្បធម៌ដែលសំខាន់របស់ពួកគេរួមមាន ការសរសេរ, គ្រឿងអលង្កាធ្វើពីមាស, អាវុធធ្វើពីសំរិទ្ធ, និងគ្រឿងកុលាលភាជន៍ប្រណិតៗ។ អរិយធម៌របស់ពួកគេដួលរលំនៅអំឡុងឆ្នាំ 1200 មុនគ.ស ប្រហែលដោយសារតែការឈ្លានពានពីពួកខាងក្រៅ។ បន្ទាប់ពីការដួលរលំនៃពួកមែសេនៀន វប្បធម៌ក្រិកបានធ្លាក់ចុះ។ ប្រជាជនមិនបានបន្តរក្សាទុកកំណត់ត្រាផ្សេងៗ ទៀតឡើយ។ ដោយសារគ្មានកំណត់ត្រា ប្រវត្តិវិទូបានដឹងតិចតួចអំពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងប្រទេសក្រិកចន្លោះពីឆ្នាំ 1200 មុនគ.ស ដល់ 750 មុនគ.ស។

ការអភិវឌ្ឍថ្មីនៃវប្បធម៌ក្រិក៖ ក្រោយមកវប្បធម៌របស់ក្រិកបានចាប់ផ្តើមរីកចម្រើនឡើងជាថ្មីម្តងទៀត។ ហេតុផលមួយនៃការរីកចម្រើនឡើងវិញនេះគឺដោយសារតែប្រជាជនក្រិករៀនសូត្រពីអ្នកដ៏ទៃ ដូចជាផូនីសៀនជាដើម។ ពួកផូនីសៀនគឺជាក្រុមពាណិជ្ជករដ៏សំខាន់មួយដែលរស់នៅតំបន់ឆ្នេរមេឌីទែរ៉ានេភាគខាងកើត។ ក្នុងនាមជាពាណិជ្ជករ ពួកផូនេសៀនត្រូវការវិធីមួយដើម្បីកត់ត្រាអំពីការធ្វើពាណិជ្ជកម្មរបស់ពួកគេឱ្យបានច្បាស់ និងឆាប់

រហ័ស។ ដូចដែលអ្នកបានសិក្សាមកហើយ ពួកគេបានបង្កើតប្រព័ន្ធសំណេរមួយដោយប្រើនិមិត្តសញ្ញាចំនួន 22 ដែលតំណាងឱ្យសំលេង។ ប្រព័ន្ធនិមិត្តសញ្ញាមួយនេះត្រូវបានគេហៅថាអាផាបេត។ តាមរយៈការធ្វើពាណិជ្ជកម្មជាមួយនឹងប្រជាជនផ្សេងទៀត ពួកផូនីសៀនបានសាយភាយប្រព័ន្ធសំណេររបស់ពួកគេ។ ពួកក្រិកបានជ្រើរើសយកអាផាបេតរបស់ផូនីសៀនមកប្រើនៅចន្លោះរវាងឆ្នាំ 900 មុនគ.ស ដល់ឆ្នាំ 800 មុនគ.ស។ ពួកគេបានផ្លាស់ប្តូរតួអក្សរមួយចំនួនដើម្បីធ្វើឱ្យវាស៊ីគ្នាជាមួយភាសារបស់ពួកគេ។ អាផាបេតរបស់ក្រិកក្រោយមកបានអភិវឌ្ឍទៅជាអាផាបេត 26 តួ ដែលប្រទេសភាគច្រើននៅអឺរ៉ុបប្រើប្រាស់រហូតដល់សព្វថ្ងៃ។

ពួកក្រិកក៏បានរៀនធ្វើកាក់ពីការធ្វើពាណិជ្ជកម្មជាមួយប្រជាជនផ្សេងៗផងដែរ។ កាក់ត្រូវបានបង្កើតឡើងដំបូងនៅក្នុងឆ្នាំ 650 មុនគ.ស នៅតំបន់អាណាតូលី។ ត្រឹមឆ្នាំ 500 មុនគ.សស្ទើរតែគ្រប់ផ្នែកទាំងអស់នៅក្រិកបានបង្កើតកាក់របស់គេរៀងៗខ្លួន។ ដោយថាហេតុ ក្រិកក៏បានអភិវឌ្ឍទម្រង់ថ្មីនៃអក្សរសិល្ប៍ និងរដ្ឋាភិបាល។ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីការអភិវឌ្ឍទាំងនេះនៅក្នុងមេរៀនបន្ទាប់។

វិភាគពីឥទ្ធិពល៖ កំណត់អំពីការជះឥទ្ធិពលនៃពាណិជ្ជកម្មមកលើវប្បធម៌របស់ក្រិក។

# មេរៀនទី 2 ៖ ជីវិតរស់នៅរបស់ប្រជាជនក្រិកបុរាណ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ក៏ដូចជាប្រជាជនសម័យបុរាណផ្សេងៗទៀតដែរ ប្រជាជនក្រិកបុរាណជឿលើអទិទេពជាច្រើន។ ជំនឿលើអាទិទេពច្រើននេះគេហៅថាពហុទេពនិយម។ ប៉ុន្តែអ្នកមិនបានឃើញអទិទេពដែលមានក្បាលជាសត្វនៅក្នុងប្រទេសក្រិក ដូចដែលអ្នកធ្លាប់បានឃើញនៅក្នុងប្រទេសអេហ្ស៊ីបឡើយ។ អទិទេពនៅក្រិកមានលក្ខណៈដូចជាមើលទៅដូចជាមនុស្សធម្មតា ប៉ុន្តែមានអំណាច និងស្រស់ស្អាតជាងមនុស្សធម្មតា។

## 1. អាទិទេពរបស់ក្រិក និងទេវកថា

សំណួរគន្លឹះ៖ តើទេវកថា និងសាសនារបស់ក្រិកមានទំនាក់ទំនងយ៉ាងដូចម្ដេចជាមួយគ្នា?

សម្រាប់ប្រជាជនក្រិក អាទិទេពមិនស្ថិតនៅឆ្ងាយពីមនុស្សលោកយើងឡើយ។ ពួកគេចូលរួមជាមួយនឹងការរស់នៅរបស់មនុស្សលោក ហើយប្រជាជនក្រិកចូលចិត្តប្រាប់អំពីរឿងរ៉ាវរបស់អទិទេពទាំងនោះ។ រឿងរ៉ាវដែលពិពណ៌នាអំពីភាពអស្ចារ្យនៃអាទិទេពទាំងនេះ ដែលបង្ហាញពីភាពថ្លៃថ្នូរ ឬគតិបណ្ឌិត ប៉ុន្តែក៏បង្ហាញពីភាពកាចសាហាវ និងអាត្មានិយមផងដែរ។

អាទិទេពរបស់ក្រិក៖ អាទិទេពរបស់ក្រិកមានទាំងលក្ខណៈបែបទេវតា និងមនុស្សលោក។ ឧទាហរណ៍ អាទិទេពទាំងនោះមានអំណាចខ្លាំង និងអាចរៀបចំព្រឹត្តិការណ៍នានាឱ្យកើតលើមនុស្ស។ ប៉ុន្តែ អាទិទេពទាំងនេះមានមនោសញ្ចេតនាមួយចំនួនដូចមនុស្សដែរ ដោយក្នុងនោះរួមមាន សេចក្តីស្រលាញ់, ខឹង, និងច្រណែន។ អាទិទេព និងទេវធីតារបស់ក្រិកតែងតែប្រជែងជាមួយគ្នាទៅវិញទៅមកជាប្រចាំ។ ហ្ស៊ូសគឺជាមេដឹកនាំរបស់អាទិទេពទាំងឡាយ។ ពួកក្រិកជឿថា ទ្រង់ និងអាទិទេព-ទេពធីតាសំខាន់ៗចំនួន 11 អង្គទៀតគង់នៅលើកំពូលភ្នំអូលីមពូសដែលជាភ្នំដែលខ្ពស់ជាងគេបំផុតនៅក្រិក។ ពួកក្រិកក៏គោរពបូជាអាទិទេពមិនសូវសំខាន់ៗជាច្រើនទៀតផងដែរ។ តាមទីក្រុងនីមួយៗមានអាទិទេព ឬទេពធីតាពិសេសមួយសម្រាប់ការពារ។ ឧទាហរណ៍ ទេពធីតាអាថេណា (អាទិទេពមួយអង្គក្នុងចំណោមអាទិទេពទាំង 12 អង្គដែលរស់នៅលើកំពូលភ្នំអូលីមពូស) គឺជាអ្នកការពារទីក្រុងអាតែន។ ទ្រង់គឺជាទេពធីតានៃសេចក្តីសង្ឃឹម, ទេពធីតានៃអ្នកប្រយុទ្ធ, និងទេពធីតានៃសិប្បកម្ម ដែលមានដូចជាតម្បាញជាដើម។

ទេវកថាក្រិក៖ ទេវកថាគឺជារឿងរ៉ាវដែលមនុស្សនិយាយឡើងដើម្បីពន្យល់ពីជំនឿរបស់ពួកគេអំពីពិភពដែលពួកគេរស់នៅ។ ទេវកថាជាទូទៅចាប់ផ្តើមដំបូងជាមួយការនិយាយផ្ទាល់មាត់។ ក្រោយមកពួកគេសរសេរវាឡើង។ ពួកក្រិកបានអភិវឌ្ឍទេវកថាដើម្បីពន្យល់អំពីការបង្កើតពិភពលោក និងជីវិតមនុស្សជាតិ។ ទេវកថាមួយបាននិយាយអំពីប៉ាន់ដូរ៉ាជាស្ត្រីដំបូងនៅលើពិភពលោក។ ហ្ស៊ូសបានប្រគល់ឱ្យប៉ាន់ដូរ៉ានូវក្រឡបិទជិតមួយ ប៉ុន្តែបានប្រាប់នាងថាកុំឱ្យបើកក្រឡនោះ។ បើទោះបីជាមានការប្រមានពីហ្ស៊ូសក៏ដោយ នាងបានបើកក្រឡនោះ ដែលបានដោះលែង សេចក្តីឈឺចាប់, ភាពលោភលន់, និងសេចក្តីអាក្រក់ផ្សេងៗទៀតមកក្នុងផែនដី។ ព្រលឹងមួយដែលបន្តស្ថិតនៅក្រឡនោះគឺ៖ សេចក្តីសង្ឃឹម។

ទេវកថាជាច្រើនបានពិពណ៌នាអំពីអាទិទេព និងទេពធីតា និងបង្ហាញពីរបៀបដែលពួកគេធ្វើទំនាក់ទំនងជាមួយគ្នា និងជាមួយមនុស្សលោក។ ឧទាហរណ៍៖ ទេវកថានៃប្រូមេថឺសបាននិយាយអំពីវិធីដែលគាត់បានលួចភ្លើងពីអាទិទេព និងប្រគល់វាឱ្យមនុស្សលោក។ ហ្ស៊ូសបានដាក់ទណ្ឌកម្មគាត់ ដោយជប់ឱ្យគាត់ក្លាយជាថ្ម។ ជារៀងរាល់ពេលថ្ងៃ សត្វឥន្ទ្រីមួយបានហោះមកចឹកស៊ីថ្លើមរបស់គាត់ ដែលថ្លើមនោះនឹងដុះមកវិញជារៀងរាល់យប់។ ទេវកថាផ្សេងទៀតបានពិពណ៌នាអំពីវីរៈបុរស និងវីរៈនារីក្រិក។ ទេវកថាមួយបានពិពណ៌នាអំពីនាងអាតាឡានតា អ្នកដែលធំដឹងក្តីឡើងដោយការចិញ្ចឹមរបស់សត្វខ្លាឃ្មុំញីមួយក្បាល និងក្រោយមកត្រូវបានអ្នកបរបាញ់យកទៅចិញ្ចឹម។ ដោយហេតុនេះ នាងបានក្លាយជាអ្នកជំនាញខាងបរបាញ់ និងរត់។

សង្ខេប៖ ពន្យល់ពីរបៀបដែលទេវកថា និងសាសនារបស់ក្រិកមានទំនាក់ទំនងជាមួយគ្នា។

## 2. ការផ្តល់កិត្តិយសដល់អាទិទេព

សំណួរគន្លឹះ៖ តើប្រជាជនក្រិកផ្តល់កិត្តិយសដល់អាទិទេពរបស់ពួកគេដោយរបៀបណា?

ក៏ដូចជាប្រជាជនសម័យបុរាណផ្សេងៗទៀតដែរ ប្រជាជនក្រិកជឿថា វាមានសារៈសំខាន់ណាស់នៅក្នុងការផ្តល់កិត្តិយសដល់អាទិទេព។ នៅពេលណាដែលអាទិទេពមានកំហឹង ដែលបណ្តាលឱ្យមានគ្រោះកើតឡើង។ ពួកក្រិកបានបង្កើតបដិមារបស់អាទិទេពនានា និងបានស្ថាបនាប្រាសាទសម្រាប់ធ្វើជាទីលំនៅរបស់អាទិទេពទាំងនោះ។ ពួកគេក៏រៀបចំព្រឹត្តិការណ៍ពិសេសៗដើម្បីផ្តល់កិត្តិយសដល់អាទិទេពទាំងនោះផងដែរ។

ពិធីបុណ្យពិសិដ្ឋ៖ នៅក្នុងខែនីមួយៗមានថ្ងៃខ្លះជាថ្ងៃពិសិដ្ឋសម្រាប់អាទិទេព និងទេពធីតាផ្សេងៗគ្នា ឬសម្រាប់លក្ខណៈពិសេសនៃធម្មជាតិ។ ប្រជាជនប្រារព្ធពិធីនៅថ្ងៃពិសិដ្ឋជាមួយនឹងការសែនព្រេន និងពិធីបុណ្យសាធារណៈ។ មានពិធីបុណ្យសំខាន់ជាច្រើនធ្វើឡើងដើម្បីផ្តល់កិត្តិយសដល់អាទិទេពទាំង 12 អង្គដែលគង់នៅទីក្រុងអូឡាំព្យាន។ ឧទាហរណ៍៖ មានពិធីបុណ្យដ៏ធំមួយដើម្បីផ្តល់កិត្តិយសដល់ទេពធីតាអាថេណា។ សំលៀកបំពាក់ថ្មីត្រូវបានគេដេរឡើងសម្រាប់បំពាក់ដល់បដិមាទ្រង់ដែលគេតំកល់នៅក្នុងប្រាសាទធំ។ ពិធីបុណ្យនេះក៏រួមបញ្ចូលការហែក្បួន, ការរត់ប្រណាំង, និងល្បែងអត្តពលកម្មផ្សេងៗទៀត, និងការសូត្រកំណាព្យ។

កីឡាអូឡាំពិក៖ នៅក្នុងប្រទេសក្រិក ល្បែងជាទូទៅគឺជាផ្នែកនៃពិធីបុណ្យសាសនា។ ល្បែងដែលធំ និងមានការយកចិត្តទុកដាក់ជាងគេគឺ ល្បែងកីឡាអូឡាំពិក។ អូឡាំពិកគឺជាល្បែងដែលប្រារព្ធឡើងជារៀងរាល់ 4 ឆ្នាំម្តងដែលជាផ្នែកនៃពិធីបុណ្យដ៏សំខាន់មួយដែលផ្តល់កិត្តិយសដល់ហ្ស៊ូស។ វាត្រូវបានគេរៀបចំឡើងនៅពហុកីឡាដ្ឋានមួយដែលស្ថាបនាឡើងនៅក្នុងទីក្រុងអូឡាំព្យា។ មានតែបុរសទេដែលប្រគួតប្រជែងនៅក្នុងល្បែងនេះ។

កំណត់ត្រាចាស់បំផុតនៃជ័យលាភីនៅកីឡាអូឡាំពិកចុះការបរិច្ឆេទនៅក្នុងឆ្នាំ 776 មុនគ.ស ប៉ុន្តែល្បែងនេះអាចនឹងចាប់ផ្តើមច្រើនសតវត្សមុននេះ។ កីឡាអូឡាំពិកដំបូងមានតែការរត់ប្រណាំងរយៈចម្ងាយជិតតែមួយគត់។ ក្រោយមក ការរត់ប្រណាំងរយៈចម្ងាយឆ្ងាយ និងព្រឹត្តិការណ៍ផ្សេងៗទៀតត្រូវបានគេបញ្ចូល។ ព្រឹត្តិការណ៍ទាំងនោះរួមមានកីឡាបោកចំបាប់, ការលោតចម្ងាយ, ការបោលលំពែង, និងបោលថាស។ ល្បែងនេះបានប្រឡង

ប្រជែងសាកល្បងជំនាញដែលមានតម្លៃសម្រាប់ការចូលបម្រើកងទ័ព។ ពិធីបុណ្យដែលផ្ដល់កិត្តិយលដល់ទេពធីតាហេរ៉ាដែលជាមហេសីរបស់អាទិទេពហ្ស៊ូស ត្រូវបានគេប្រារព្ធឡើងក្នុងពេលដំណាលគ្នាជាមួយកីឡាអូឡាំពិក។ នៅក្នុងពិធីនោះ ស្ត្រីដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ត្រូវបានគេអនុញ្ញាតឱ្យចូលរួមប្រកួតរត់ប្រណាំរយៈចម្ងាយជិត។ ការរត់ប្រណាំងនេះរៀបចំជា 3 ប្រភេទអាយុផ្សេងៗគ្នា ដែលធ្វើឡើងនៅក្នុងពហុកីឡាដ្ឋានអូឡាំពិក។

ធ្វើចំណាត់ថ្នាក់៖ ពិពណ៌នាអំពីរបៀបដែលពួកក្រិកផ្ដល់កិត្តិយសដល់អាទិទេពរបស់ពួកគេ។

### 3. អក្សរសិល្ប៍ក្រិកដំបូង

សំណួរគន្លឹះ៖ ហេតុអ្វីបានជាអក្សរសិល្ប៍ដំបូង ដូចជាវីរកថារបស់ហូមឺមានសារៈសំខាន់?

ក្នុងការបន្ថែមទៅលើរឿងរ៉ាវស្ដីអំពីអាទិទេព ពួកក្រិកបាននិយាយរឿងរ៉ាវអំពីវីរបុរសសម័យបុរាណរបស់ពួកគេ។ ភាពច្រើននៃអ្វីដែលយើងបានដឹងពីក្រិកនៅដើមដំបូងគឺបានមកពីរឿងរ៉ាវដែលនិយាយបន្តពីមួយជំនាន់ទៅមួយជំនាន់ និងដឹងពីកំណាព្យវែងៗដែលបានបង្ហាញពីរឿងរ៉ាវកាលពីអតីតកាល។ កំណាព្យដ៏វែងនេះត្រូវបានគេហៅថាវីរកថា។ យោងទៅតាមប្រវត្តិសាស្ត្របែបប្រពៃណី មានបុរសពិការភ្នែកម្នាក់ឈ្មោះថា ហូមឺ បានតាក់តែងនូវកំណាព្យវីរកថាដ៏ល្បីល្បាញបំផុត។ កំណាព្យទាំងនោះនៅតែត្រូវបានគេចាត់ទុកថាជាស្នាដៃឯកនៃអក្សរសិល្ប៍។

វីរកថារបស់ហូមឺ៖ វីរកថាពីរដ៏អស្ចារ្យរបស់ហូមឺគឺអ៊ីលៀដ និងអូឌីសី។ រឿងរ៉ាវនៅពីក្រោយកំណាព្យទាំងពីរនេះគឺសង្គ្រាមនៅត្រួយ។ សង្គ្រាមចាប់ផ្ដើមឡើងដោយសារតែជនជាតិត្រួយមួយរូបបានលួចមហេសីរបស់ស្ដេចក្រិក។ ពួកក្រិចបានប្រមូលផ្ដុំកងទ័ពដ៏ច្រើនសន្ធឹកសន្ធាប់ និងបានធ្វើដំណើរតាមផ្លូវទឹកទៅកាន់ទីក្រុងរបស់ពួកត្រួយ។ ពួកក្រិចបានឡោមព័ទ្ធទីក្រុង និងបានចំណាយពេលជាង 9 ឆ្នាំដើម្បីប្រយុទ្ធជាមួយពួកត្រួយ និងព្យាយាមនៅក្នុងការដណ្ដើមកាន់កាប់ទីក្រុងរបស់ពួកគេ។

រឿងអ៊ីលៀដមានភាពល្បីល្បាញដោយសារតែការពិពណ៌នាអំពីវីរបុរសនានា ជាពិសេសអ្នកប្រយុទ្ធជនជាតិក្រិកឈ្មោះថាអាឈីលែស។ នៅពេលគាត់នៅក្មេង ម្ដាយរបស់គាត់បានកាន់កែងជើងរបស់គាត់ និងបានជ្រលក់គាត់ទៅក្នុងទឹកទន្លេពិសិដ្ឋមួយ។ គ្រប់ទីកន្លែងដែលប៉ះជាមួយទឹកត្រូវបានការពារពីការរងរបួស។ អាឈីលែសត្រូវបានគេមើលឃើញថាជាមនុស្សម្នាក់ដែលមិនអាចយកឈ្នះបាននៅក្នុងសមរភូមិ។ ប៉ុន្តែនៅពេលដែលមានព្រួញមួយហោះមកបុកជាមួយចំណុចខ្សោយរបស់គាត់ (កែងជើង) គាត់ក៏ស្លាប់ទៅ។ អស់រយៈពេលជាច្រើនសតវត្សមកហើយ មនុស្សគិតថាសង្គ្រាមនៅត្រួយគឺជារឿងប្រឌិត។ ប៉ុន្តែនៅអំឡុងឆ្នាំ 1870 ពួកអ្នកបុរាណវត្ថុវិទូបានស្រាវជ្រាវរកឃើញសំណល់នៅទីក្រុងរបស់ពួកត្រួយ។ សង្គ្រាមពិតប្រាកដអាចកើតមាននៅទីនោះ ប៉ុន្តែមិនបានកើតឡើងតាមអ្វីដែលពិពណ៌នានៅក្នុងរឿងអ៊ីលៀដឡើយ។

វីរកថាដែលសំខាន់មួយផ្សេងទៀតរបស់ហូមឺគឺអូឌីសី។ វាបានពិពណ៌នាអំពីដំណើរផ្សងព្រេងរបស់វីរៈបុរសក្រិកម្នាក់ឈ្មោះអូឌីសឺស។ នៅអំឡុងនៃការធ្វើដំណើរត្រឡប់មកក្រិកវិញបន្ទាប់ពីការធ្វើសង្គ្រាមជាមួយពួកត្រួយ អូឌីសឺសបានប្រឆាំងជាមួយប៉ូសីដុនដែលជាអាទិទេពសមុទ្ររបស់ក្រិក។ នៅក្នុងការសងសឹក អាទិទេពបានធ្វើឱ្យ

ដំណើររបស់អូឌីស៊ីស ត្រូវចំណាយពេល 10 ឆ្នាំ។ នៅអំឡុងពេលនោះ អូឌីស៊ីស និងកងទ័ពរបស់គាត់បានធ្វើដំណើរកាត់តាមដែនដីចម្លែកៗ និងអាថ៌កំបាំង និងជួបប្រទះទៅនឹងគ្រោះថ្នាក់ជាច្រើន។ អូឌីស៊ីសបានប្រើប្រាស់ប្រាជ្ញា និងល្បិចដើម្បីរស់រាននៅអំឡុងពេលនៃការធ្វើដំណើរដ៏វែងឆ្ងាយនេះ។ រឿងបុរាណទាំងអស់នេះនៅតែមានឥទ្ធិពលដល់ការនិយាយ និងសិល្បៈនាពេលបច្ចុប្បន្ន។ ឧទាហរណ៍៖ ពាក្យថា "កែងជើងរបស់អាឈីលេស" ត្រូវបានគេប្រើសំដៅទៅលើចំណុចខ្សោយរបស់មនុស្សម្នាក់។ ពាក្យថាអូឌីស៊ីត្រូវបានគេប្រើដើម្បីពិពណ៌នាអំពីការដំណើរផ្សងព្រេង។

រឿងព្រេងរបស់អ៊ីសូព៖ រឿងព្រេងគឺជាការនិទានរឿងខ្លីមួយ ដែលជាទូទៅមានការចូលរួមពីសត្វនានា ដែលបង្រៀនពីមេរៀនសីលធម៌មួយ។ រឿងព្រេងជាច្រើនដែលនិទាននាពេលបច្ចុប្បន្នបានផ្តល់កិត្តិយសដល់ជនជាតិក្រិកម្នាក់ឈ្មោះអ៊ីសូព។ ប្រវិត្តិវិទូសម័យបុរាណមួយចំនួនបានពិពណ៌នាអ៊ីសូពថាជាទាសករម្នាក់ដែលបានរស់នៅក្នុងប្រទេសក្រិក និងបានសរសេររឿងព្រេង។ ប៉ុន្តែ អ្នកប្រាជ្ញសម័យទំនើបជឿជាក់ថា ទំនងជាមិនមានឈ្មោះអ៊ីសូពនេះពិតប្រាកដឡើយ។ ប្រហែលជាឈ្មោះនេះត្រូវបានបង្កើតឡើងដើម្បី ធ្វើជាឈ្មោះអ្នកនិពន្ធរឿងព្រេងសម័យបុរាណ។

រឿងព្រេងមួយដែលល្បីល្បាញបំផុតរបស់អ៊ីសូពគឺ "សត្វទន្សាយ និងអណ្តើក"។ នៅក្នុងរឿងព្រេងនេះ សត្វទន្សាយមួយក្បាលបានសើចចំអកដល់សត្វអណ្តើកមួយក្បាលដែលធ្វើដំណើរយឺត។ សត្វអណ្តើកបានប្រកួតប្រជែងជាមួយសត្វទន្សាយនៅក្នុងរត់ប្រណាំង។ សត្វទន្សាយគិតថាការប្រកួតប្រជែងនេះជារឿងគួរឱ្យអស់សំណើច។ ទន្សាយមានភាពជឿជាក់ខ្លួនឯងយ៉ាងខ្លាំងថានឹងឈ្នះ ដូច្នេះទន្សាយបានទម្រេតខ្លួនដេកមួយស្របក់។ ផ្ទុយទៅវិញ សត្វអណ្តើកមិនបានបញ្ឈប់ការធ្វើដំណើររបស់ខ្លួនឡើង ដោយធ្វើដំណើរយឺតៗ មួយជំហានម្តងៗរហូតដល់ទីផ្តាច់ព្រ័ត។ នៅពេលដែលទន្សាយភ្ញាក់ឡើង ទន្សាយបានដឹងថាយឺតពេលទៅហើយក្នុងការបង្កើនល្បឿនដើម្បីយកជ័យជំនះ ហើយអណ្តើកដែលដើរយឺតៗទទួលជ័យជំនះក្នុងការរត់ប្រណាំងនេះ។ មនុស្សនាពេលបច្ចុប្បន្ននេះនៅតែលើកឡើងពីមេរៀននៅក្នុងរឿងព្រេងនេះ ដើម្បីលើកទឹកចិត្តដល់មនុស្សនានាឱ្យធ្វើការងារបន្តិចម្តងៗ បើទោះបីជាការងារទាំងអស់នោះហាក់ដូចជាការងារដែលពិបាកនឹងសម្រេចជោគជ័យក៏ដោយ។

ស្វែងរកគោលគំនិត៖ ពន្យល់ពីសារៈសំខាន់នៃវីរកថារបស់ហូមឺ។

# មេរៀនទី 3 ៖ បុរី-រដ្ឋ និងប្រជាធិបតេយ្យ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានអាននៅក្នុងមេរៀនមុន អរិយធម៌មែសេនៀន ដួលរលំនៅអំឡុងឆ្នាំប្រហែល 1200 មុនគ.ស។ បន្ទាប់ពីការធ្លាក់ចុះ វប្បធម៌របស់ក្រិកបានចាប់ផ្តើមអភិវឌ្ឍឡើងវិញបន្តិចម្តងៗ។ កាលនេះនាំទៅដល់ការកកើតឡើងនៃអរិយធម៌ក្រិក។ ក៏ដូចជាពួកស៊ូមីបុរាណដែរ ប្រទេសក្រិកគឺជាតំបន់មួយដែលប្រជាជនមានភាសា និងជំនឿរួមគ្នា។ បើទោះបីជាមានភាពរួមគ្នានៃវប្បធម៌ក៏ដោយ ពួកក្រិកមានប្រព័ន្ធនយោបាយផ្សេងៗគ្នា។

## 1. ការកកើតឡើងនៃបុរី-រដ្ឋ

សំណួរគន្លឹះ៖ តើពួកក្រិករៀបចំប្រព័ន្ធនយោបាយរបស់ពួកគេដោយរបៀបណា?

អ្នកធ្លាប់បានសិក្សារួចមកហើយអំពីទីតាំងភូមិសាស្ត្ររបស់ក្រិក ដែលបានបែងចែកពួកក្រិកទៅជាតំបន់តូចៗដាច់ដោយឡែកពីគ្នា។ ដោយសារតែហេតុនេះ ទម្រង់សំខាន់នៃរដ្ឋាភិបាលនៅក្នុងប្រទេសក្រិកនៅពេលនោះគឺបុរី-រដ្ឋ។ បុរី-រដ្ឋគឺជារដ្ឋមួយដែលបង្កើតឡើងដោយទីក្រុងមួយនិងផ្ទៃដីដែលនៅហ៊ុំព័ទ្ធជុំវិញវា។ ជាទូទៅវាបានរួមបញ្ចូលភូមិជាច្រើន។ តំបន់ដែលក្រិកបានដាក់អាណានិគមនៅជុំវិញសមុទ្រមេឌីទែរ៉ាណេក៏មានប្រព័ន្ធនយោបាយជាបុរី-រដ្ឋផងដែរ។

បុរី-រដ្ឋរបស់ក្រិក៖ បុរី-រដ្ឋបានចាប់ផ្តើមឡើងនៅក្នុងប្រទេសក្រិកនៅអំឡុងឆ្នាំប្រហែល 700 មុនគ.ស។ នៅក្នុងភាសាក្រិក ពាក្យដែលគេហៅបុរី-រដ្ឋគឺប៉ូលីស។ បុរី-រដ្ឋភាគច្រើនមានទំហំតូច។ លក្ខណៈនៃទីតាំងភូមិសាស្ត្រដូចជាជួរភ្នំជាដើមបានកម្រិតទំហំរបស់បុរី-រដ្ឋទាំងនោះ។ អាតែន និងស្ប៉ាតគឺជាបុរី-រដ្ឋក្រិកដែលធំជាងគេបំផុត។ ទំហំផ្ទៃដីនៃបុរី-រដ្ឋទាំងពីរនេះបានរួមបញ្ចូលតំបន់វាលទំនាបដែលនៅព័ទ្ធជុំវិញទីក្រុងនៅកណ្តាល។ ភាគច្រើននៃបុរី-រដ្ឋរបស់ក្រិកគ្រួតត្រាលើផ្ទៃដីចន្លោះពី 50 ទៅ 500 ម៉ាយការ៉េ និងមានប្រជាជនតិចជាង 2 ម៉ឺននាក់។ ដោយសារតែបែបផែននៃបុរី-រដ្ឋមានលក្ខណៈតូចចង្អៀត ប្រជាជនដែលរស់នៅក្នុងបុរី-រដ្ឋនោះបានបង្កើតជាសហគមន៍ជិតស្និតគ្នាមួយ។

ការរចនាទីក្រុង៖ មជ្ឈមណ្ឌលសំខាន់នៃទីក្រុងស្ថិតនៅអាហ្គូរ៉ាដែលជាទីកន្លែងសាធារណៈមួយដែលមនុស្សធ្វើជំនួញ និងជួបប្រជុំគ្នាជាសាធារណៈនៅទីនោះ។ ប្រជាជនប្រុសៗបានជួបប្រជុំគ្នានៅទីនោះដើម្បីពិភាក្សាអំពីរឿងនយោបាយ។ ពិធីបុណ្យ និងការប្រកួតប្រជែងអត្តពលិកត្រូវបានគេប្រារព្ធនៅទៅនោះ។ បដិមា, ប្រាសាទ, និងសំណង់សាធារណៈផ្សេងៗទៀតត្រូវបានគេស្ថាបនាឡើងនៅជុំវិញអាហ្គូរ៉ា។

ទីក្រុងជាច្រើនមានបន្ទាយប្រាការនៅលើកូនភ្នំតូចមួយដែលគេហៅថាអាក្រូប៉ូលីស។ ពាក្យនេះមានន័យថា "ទីក្រុងខ្ពស់"។ ដំបូងឡើយ ប្រជាជនប្រើប្រាស់អាក្រូប៉ូលីសក្នុងហេតុផលយោធាជាចំបង ដោយសារទីកន្លែងខ្ពស់មានភាពងាយស្រួលក្នុងការការពារសត្រូវ។ ក្រោយមកប្រជាជនក្រិកស្ថាបនាប្រាសាទ និងរាជវាំងនៅលើផ្ទៃរាបនៃកំពូលភ្នំនោះ។ ផ្ទះប្រជាជនសាមញ្ញត្រូវគេស្ថាបនាឡើងនៅតាមជម្រាលភ្នំ។

សង្ខេប៖ ពន្យល់ពីរបស់ដែលពួកក្រិករៀបចំប្រព័ន្ធនយោបាយរបស់ពួកគេ។

## 2. ទម្រង់នៃរដ្ឋាភិបាល

សំណួរគន្លឹះ៖ តើប្រព័ន្ធនយោបាយអ្វីខ្លះដែលមាននៅក្នុងបុរី-រដ្ឋរបស់ក្រិក?

បុរី-រដ្ឋនីមួយៗរបស់ក្រិកមានភាពឯករាជ្យពីគ្នា។ ប្រជាជននៅក្នុងបុរី-រដ្ឋនីមួយៗរបស់ក្រិកគិតគូរអំពីប្រភេទរដ្ឋាភិបាលណាដែលមានភាពល្អប្រសើរសម្រាប់ពួកគេ។ ជាលទ្ធផលបុរី-រដ្ឋនីមួយៗ មានប្រព័ន្ធនយោបាយផ្សេងៗគ្នា។ បុរី-រដ្ឋខ្លះរក្សាប្រព័ន្ធរដ្ឋាភិបាលដដែលៗរាប់សតវត្សរ៍។ ចំណែកបុរី-រដ្ឋខ្លះទៀតបានផ្លាស់ប្តូរពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀត។

ព្រះមហាក្សត្រ និងអភិជន៖ ទម្រង់រដ្ឋាភិបាលដំបូងបំផុតនៅក្នុងប្រទេសក្រិកគឺ រាជាធិបតេយ្យ។ ព្រះរាជាគឺជាស្តេច ឬក្សត្រីមួយអង្គដែលមានអំណាចកំពូល។ រាជាធិបតេយ្យគឺជាប្រព័ន្ធរដ្ឋាភិបាលដែលស្តេច ឬក្សត្រីគ្រប់គ្រងអំណាច។ ភាគច្រើននៃបុរី-រដ្ឋនៅក្នុងប្រទេសក្រិកចាប់ផ្តើមប្រព័ន្ធរដ្ឋាភិបាលដំបូងបែបរាជាធិបតេយ្យ ប៉ុន្តែក្រោយមកបានផ្លាស់ប្តូរទៅទម្រង់រដ្ឋាភិបាលផ្សេងទៀត។

អភិជនាធិបតេយ្យ៖ គឺជាប្រព័ន្ធរដ្ឋាភិបាលមួយដែលដឹកនាំដោយវណ្ណៈកំពូលនៃសង្គម ឬដោយវណ្ណៈអភិជន។ នៅក្នុងប្រទេសក្រិក ពួកអភិជនគឺជាក្រុមមនុស្សដែលជាប់ខ្សែស្រឡាយបន្តពីបុព្វការីជនរបស់ពួកគេ។ ពួកអភិជនមួយចំនួនបានអះអាងថា បុព្វការីជនរបស់ពួកគេគឺជាវីរៈបុរសនៅក្នុងទេវកថា។

បុរី-រដ្ឋរបស់ក្រិកឈ្មោះថាកូរីនចាប់ផ្តើមប្រព័ន្ធរដ្ឋាភិបាលដំបូងបែបរាជធិបតេយ្យ។ ក្រោយមក បុរី-រដ្ឋនេះត្រូវបានដឹកនាំបែបអភិជនាធិបតេយ្យវិញ។ បុរី-រដ្ឋផ្សេងៗជាច្រើនទៀតរបស់ក្រិចបានផ្លាស់ប្តូរដូចកូរីនដែរ។ ត្រឹមទសវត្សរ៍ឆ្នាំ 700 មុនគ.ស ភាគច្រើននៃប្រព័ន្ធរដ្ឋាភិបាលរបស់បុរី-រដ្ឋនៅក្រិកបានផ្លាស់ប្តូរពីប្រព័ន្ធរាជាធិបតេយ្យមកអភិជនាធិបតេយ្យ។

អប្បជនាធិបតេយ្យ៖ បុរី-រដ្ឋមួយចំនួនបានអភិវឌ្ឍប្រព័ន្ធនយោបាយមួយ ដែលគេហៅថា អប្បជនាធិបតេយ្យ។ អប្បជនាធិបតេយ្យមានន័យថា "ដឹកនាំដោយមនុស្សតិចតួច"។ វាស្រដៀងគ្នាទៅនឹងអភិជនាធិបតេយ្យ ដោយសារតែប្រព័ន្ធរដ្ឋាភិបាលទាំងពីរនេះ មានក្រុមមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលមានអំណាចគ្រប់គ្រងរដ្ឋាភិបាល។

ភាពខុសគ្នាដែលសំខាន់រវាងប្រព័ន្ធអភិជនាធិបតេយ្យ និងអប្បជនាធិបតេយ្យគឺ មូលដ្ឋាននៃអំណាចរបស់ពួកអ្នកគ្រប់គ្រង។ នៅក្នុងប្រព័ន្ធអភិជនាធិបតេយ្យ ពួកអភិជនអាចឡើងគ្រប់គ្រងអំណាចបានដោយសារតែពួកគេស្ថិតនៅក្នុងវណ្ណៈដែលបន្តមកពីបុព្វការីជនរបស់ពួកគេ។ នៅក្នុងប្រព័ន្ធអប្បជនាធិបតេយ្យ ពួកគេអាចឡើងគ្រប់គ្រងអំណាចបានដោយសារតែពួកគេមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬកាន់កាប់ដីធ្លីច្រើន។ នៅក្នុងបុរី-រដ្ឋមួយចំនួនរបស់ក្រិក ប្រព័ន្ធអប្បជនាធិបតេយ្យបានជំនួសប្រព័ន្ធអភិជនាធិបតេយ្យ។ នៅក្នុងបុរី-រដ្ឋមួយចំនួនទៀតពួកអភិជន និងអប្បជនគ្រប់គ្រងអំណាចរួមគ្នា។

របបផ្តាច់ការ៖ ប្រជាជនក្រីក្រមិនមែនជាផ្នែកនៃរដ្ឋាភិបាលនៅក្នុងប្រព័ន្ធរាជធិបតេយ្យ, អភិជនាធិបតេយ្យ, ឬអប្បធនាធិបតេយ្យឡើយ។ ជារឿយៗ ប្រជាជនក្រីក្រមិនសប្បាយចិត្តជាមួយនឹងការផាត់ចេញពីអំណាចនេះ ហើយពេលខ្លះពួកគេបានបង្ហាញពីការមិនពេញចិត្តរបស់ពួកគេតាមរយៈការបះបោរប្រឆាំង។

នៅពេលខ្លះអ្នកមានទ្រព្យសម្បត្តិមួយរូបដែលចង់កាន់កាប់អំណាច បានប្រើប្រាស់អ្នកដែលមិនសប្បាយចិត្តទាំងអស់នោះ។ គេបានស្នើឱ្យប្រជាជនក្រីក្រគាំទ្រដល់គេដើម្បីក្លាយជាមេដឹកនាំ។ មេដឹកនាំមួយចំនួនត្រូវបានគេហៅថាមេដឹកនាំកាន់អំណាចផ្តាច់ការ។ នៅក្នុងប្រទេសក្រិក មេដឹកនាំផ្តាច់ការមួយរូបគឺជាបុគ្គលដែលឡើងគ្រប់គ្រងអំណាចដោយវិធីខុសច្បាប់។ បច្ចុប្បន្នពាក្យថាផ្តាច់ការមានន័យថាមេដឹកនាំកាចសាហាវ។ សម្រាប់ប្រជាជនក្រិក មេដឹកនាំផ្តាច់ការមួយរូប គឺជាមេដឹកនាំសាមញ្ញដែលឡើងគ្រប់គ្រងអំណាចជាស្តេចដោយមិនបានជាប់ខ្សែស្រឡាយរាជវង្សឡើយ។ មេដឹកនាំផ្តាច់ការក្រិកធ្វើការងារដើម្បីជួយដល់ប្រជាជនក្រីក្រ ឬបង្កើតកម្មវិធីសាងសង់នានាដើម្បីបង្កើតការងារ។ មេដឹកនាំមួយចំនួនទៀតបង្កើតច្បាប់លុបចោលបំណុលដែលប្រជាជនក្រីក្រជំពាក់អ្នកមានទ្រព្យសម្បត្តិ។ មេដឹកនាំផ្តាច់ការបានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការអភិវឌ្ឍការគ្រប់គ្រងតាមរយៈអំណាចប្រជាជន។ ពួកគេជួយដល់ការទម្លាក់ពួកអប្បជន។ ពួកគេក៏បានបង្ហាញផងដែរថា ប្រសិនបើប្រជាជនសាមញ្ញរួបរួមគ្នាក្រោមមេដឹកនាំមួយរូប ពួកគេអាចទទួលបានអំណាចដើម្បីធ្វើការផ្លាស់ប្តូរ។

ធ្វើការប្រៀបធៀប៖ ពិពណ៌នាអំពីប្រព័ន្ធនយោបាយដែលបានអភិវឌ្ឍឡើងនៅក្នុងបុរី-រដ្ឋនានារបស់ក្រិក។

### 3. បុរីអាតែនស្ថាបនាប្រជាធិបតេយ្យមានកម្រិតមួយ

សំណួរគន្លឹះ៖ តើក្លេស្តេនេសផ្លាស់ប្តូរប្រព័ន្ធរដ្ឋាភិបាលនៅអាតែនដោយរបៀបណា?

តាមរយៈការជួយពួកមេដឹកនាំផ្តាច់ការឱ្យឡើងកាន់អំណាច ប្រជាជនស្ថិតនៅក្នុងវណ្ណៈជាន់ទាបបានដឹងច្បាស់ថាពួកគេអាចមានឥទ្ធិពលលើរដ្ឋាភិបាល។ ដោយហេតុដូចនេះ ពួកគេចាប់ផ្តើមទាមទារអំណាចនយោបាយកាន់តែច្រើនជាងមុន។

ភាពជាប្រជាពលរដ្ឋ៖ កេរ្តិ៍ដំណែលដ៏សំខាន់បំផុតមួយរបស់ប្រទេសក្រិកបុរាណនោះគឺ គំនិតស្តីអំពីភាពជាប្រជាពលរដ្ឋ ដែលត្រូវបានបង្កើតឡើងដោយពួកក្រិក។ នៅក្នុងពិភពលោកនាសម័យបច្ចុប្បន្ន ប្រជាពលរដ្ឋម្នាក់គឺជាមនុស្សម្នាក់ដែលមានភក្តីភាពចំពោះប្រទេសជាតិមួយ និងជាអ្នកដែលទទួលបានសិទ្ធិនៅក្នុងការការពារពីរដ្ឋាភិបាលនៅក្នុងប្រទេសដែលពួកគេរស់នៅ។ នៅក្នុងសង្គមក្រិកកាលពីសម័យបុរាណ មានតែបុរសពេញវ័យប៉ុណ្ណោះដែលអាចក្លាយជាប្រជាពលរដ្ឋ។ លក្ខខ័ណ្ឌផ្សេងៗដែលកំណត់អំពីភាពជាប្រជាពលរដ្ឋមានលក្ខណៈខុសប្លែកគ្នាទៅតាមបុរី-រដ្ឋនីមួយៗ។ បុរី-រដ្ឋខ្លះកម្រិតភាពជាប្រជាពលរដ្ឋត្រឹមតែម្ចាស់កម្មសិទ្ធិដីធ្លីប៉ុណ្ណោះ។ បុរី-រដ្ឋខ្លះទៀតតម្រូវឱ្យមានឪពុកម្តាយជាប្រជាពលរដ្ឋមានសេរីភាព។

នៅក្នុងបុរី-រដ្ឋនានានៅក្រិកសម័យបុរាណ ប្រជាជនទាំងវណ្ណៈលើ និងវណ្ណៈក្រោមសុទ្ធតែជាប្រជាពលរដ្ឋ ប៉ុន្តែមានតែប្រជាពលរដ្ឋវណ្ណៈលើប៉ុណ្ណោះដែលក្តោមក្តាប់អំណាច។ តាមរយៈការទាមទារអំណាចនយោបាយ

ប្រជាពលរដ្ឋវណ្ណៈក្រោមបានស្នើឱ្យមានការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងសង្គមរស់នៅរបស់ពួកគេ។ ការផ្លាស់ប្តូរនេះមិនបានកើតមានឆាប់រហ័សឡើយ។ អំឡុងទសវត្សរ៍ឆ្នាំ 500 មុនគ.ស មេដឹកនាំពីររូបនៅបុរីអាថែនបានធ្វើកំណែទម្រង់បន្តិចម្តងៗដើម្បីធ្វើឲ្យប្រជាជនមានអំណាចច្រើនជាងមុន។ មេដឹកនាំទាំងពីររូបនោះគឺសូឡូននិងក្លេស្ថេនេស។

សូឡូន៖ នៅក្នុងទសវត្សរ៍ឆ្នាំ 500 ភាពរឹករវបានកើតមានឡើងនៅក្នុងបុរីអាតែន។ ប្រជាកសិករក្រីក្រជាច្រើនបានជំពាក់បំណុល ដូច្នេះពួកគេត្រូវបានបង្ខំឱ្យធ្វើការដាំដុះនៅលើដីធ្លីរបស់ពួកគេដើម្បីប្រមូលផលឱ្យអ្នកដ៏ទៃ ឬក៏ក្លាយជាទាសករ។ ពួកវណ្ណៈក្រោមបានកើនកំហឹងជាមួយមេដឹកនាំរបស់ពួកគេ។

ប្រហែលឆ្នាំ 594 មុនគ.ស ពួកអភិជនបានបោះឆ្នោតតែងតាំងសូឡូនឱ្យក្លាយជាមេដឹកនាំនៅបុរីអាតែន។ លោកបានធ្វើកំណែទម្រង់មួយចំនួន ដែលបានជួយការពារដល់ការបះបោររបស់ប្រជាជនក្រីក្រ។ ដំបូងទ្រង់បានផ្តល់សេរីភាពដល់មនុស្សទាំងឡាយដែលបានក្លាយជាទាសករដោយសារតែបំណុល។ លោកបានបង្កើតច្បាប់មួយដែលថាគ្មានប្រជាពលរដ្ឋណាត្រូវបានគេយកធ្វើជាទាសករបានឡើយ។ សូឡូនក៏បានរៀបចំប្រជាពលរដ្ឋទៅជា 4 កម្រិតដោយផ្អែកទៅលើទ្រព្យសម្បត្តិរបស់ពួកគេ ដោយមិនផ្អែកលើកំណើតរបស់ពួកគេឡើយ។ អ្នកដែលមានទ្រព្យសម្បត្តិច្រើនជាងគេមានអំណាចច្រើនជាងគេ។ បើទោះបីជាដូច្នេះក៏ដោយ វាក៏ជាប្រព័ន្ធមួយដែលប្រសើរជាងប្រព័ន្ធចាស់ ដែលផ្តល់អំណាចឲ្យតែពួកអ្នកមានដើមកំណើរមកពីគ្រួសារអភិជនដែរ។

ការផ្លាស់ប្តូរដែលបង្កើតឡើងដោយសូឡូន បានអនុញ្ញាតឱ្យប្រជាពលរដ្ឋទាំងអស់អាចបម្រើការនៅក្នុងសភាដែលជាស្ថាប័នបង្កើតច្បាប់ និងជួយដល់ការបោះឆ្នោតជ្រើសរើសមេដឹកនាំ។ លោកក៏បានធ្វើកំណែទម្រង់ច្បាប់មួយចំនួនដើម្បីកាត់បន្ថយភាពធ្ងើងឆ្ងៃរបស់ពួកគេ។

ក្លេស្ថេនេស៖ នៅវង្វង់ឆ្នាំប្រហែល 500 មុនគ.ស ក្លេស្ថេនេស បានបង្កើនអំណាចដល់ប្រជាពលរដ្ឋបុរីអាតែនដែលមិនធ្លាប់មានពីមុនមក។ លោកបានធ្វើរៀបចំសភាឡើងវិញ ដើម្បីដកយកអំណាចពីពួកអភិជន។ លោកបានរៀនចំប្រជាពលរដ្ឋជា 10 ក្រុម ដែលគេស្គាល់ថា កុលសម្ព័ន្ធ។ ការបែងចែកកុលសម្ព័ន្ធនីមួយៗផ្អែកទៅលើទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋ មិនមែនផ្អែកលើទ្រព្យសម្បត្តិ ឬខ្សែស្រឡាយគ្រួសារឡើយ។ លោកក្លេស្ថេនេសបានបង្កើតក្រុមមួយដែលមានមេបញ្ជាការ 10 រូបដើម្បីដឹកនាំវិស័យយោធា។ កុសម្ព័ន្ធនីមួយៗធ្វើការបោះឆ្នោតជ្រើសរើសមេបញ្ជាការមួយរូប ដែលត្រូវធ្វើការក្នុងអណត្តិមួយឆ្នាំ។ លោកក្លេស្ថេនេសក៏បានធ្វើកំណែទម្រង់ក្រុមប្រឹក្សាដែលជួយដល់សភាដើម្បីគ្រប់គ្រង។ វាត្រូវបានគេស្គាល់ថា ក្រុមប្រឹក្សា 500 ។

ប្រជាធិបតេយ្យដោយផ្ទាល់៖ ក្រុមប្រឹក្សា 500 ត្រូវបានបង្កើតឡើងដោយបុរស 500 នាក់ ដោយជ្រើសរើស 50 នាក់មកពីកុលសម្ព័ន្ធនីមួយៗ។ ប្រជាពលរដ្ឋទាំងឡាយដែលមានអាយុលើសពី 30 ឆ្នាំមានគុណវុឌ្ឍគ្រប់គ្រាន់សម្រាប់ជ្រើសរើសជាសមាជិក។ កុលសម្ព័ន្ធនីមួយៗជ្រើសរើសតំណាងរបស់ខ្លួនតាមរយៈប្រព័ន្ធសមាមាត្រ ឬដោយចៃដន្យ ដើម្បីបម្រើការក្នុងអាណត្តិមួយឆ្នាំ។ សមាជិកក្នុងប្រឹក្សាអាចត្រូវបានគេបោះឆ្នោតជ្រើសរើសឱ្យបម្រើ

ការឡើងវិញបានតែម្តងគត់។ ការធ្វើដូច្នេះ បានអនុញ្ញាតឱ្យចំនួនប្រជាពលរដ្ឋបុរីអាតែនកាន់តែច្រើនអាចចូលរួមនៅក្នុងជួររដ្ឋាភិបាលរបស់ពួកគេ ក្នុងតំណែងកម្រិតខ្ពស់។

គម្រោងរបស់ក្លេស្តេនេស បានអនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សា 500 អាចស្នើច្បាប់ដើម្បីឱ្យសភាធ្វើការពិភាក្សាដេញដោល និងអនុម័ត។ ក្រុមប្រឹក្សាផ្តល់យោបល់ដល់សភា។ ច្បាស់ត្រូវបានអនុម័តដោយសំលេងភាគច្រើននៅក្នុងសភា។ ការផ្លាស់ប្តូរនេះបាននាំបុរីអាតែនឆ្ពោះទៅរកទម្រង់ដំបូងបំផុតនៃប្រជាធិបតេយ្យ។ ប្រជាធិបតេយ្យគឺជាប្រព័ន្ធរដ្ឋាភិបាលមួយដែលប្រជាពលរដ្ឋធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយដោយផ្ទាល់ ឬតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរបស់ពួកគេ។ ទម្រង់នៃប្រជាធិបតេយ្យរបស់ពួកអាតែនត្រូវបានគេហៅថាប្រជាធិបតេយ្យដោយផ្ទាល់។ នៅក្នុងប្រព័ន្ធមួយដែលប្រជាពលរដ្ឋទាំងអស់ជួបប្រជុំគ្នាដើម្បីពិភាក្សាដេញដោលច្បាប់។ ប្រជាធិបតេយ្យមិនផ្ទាល់ ដែលប្រជាជនបោះឆ្នោតជ្រើសរើសតំណាងដើម្បីធ្វើច្បាប់ មានលក្ខណៈទូទៅនាពេលបច្ចុប្បន្ន (ឧទាហរណ៍សហរដ្ឋអាមេរិក)។

ប្រជាធិបតេយ្យមានកម្រិត និងការបណ្តេញចេញ៖ បើទោះបីជាបុរីអាតែនបានបង្កើតប្រព័ន្ធប្រជាធិបតេយ្យដោយផ្ទាល់ក៏ដោយ អត្ថប្រយោជន៍របស់ប្រព័ន្ធនេះនៅមានកម្រិត។ រដ្ឋាភិបាលមិនបានបញ្ចូលមនុស្សទាំងអស់ដែលរស់នៅក្នុងបុរី-រដ្ឋទៅក្នុងរដ្ឋាភិបាលឡើយ។ មានតែបុរសពេញវិញមានសេរីភាពដែលជាប្រជាពលរដ្ឋប៉ុណ្ណោះដែលអាចចូលរួមក្នុងរដ្ឋាភិបាលបាន។ ស្ត្រី, ប្រជាជនដែលគេយកមកធ្វើជាទាសករ, ជនបរទេស មិនអាចចូលរួមក្នុងរដ្ឋាភិបាលបានឡើយ។ ប្រជាជនដែលមិនមែនជាប្រជាពលរដ្ឋនៅក្នុងបុរីអាតែន មិនត្រូវបានគេអនុញ្ញាតឱ្យក្លាយជាប្រជាពលរដ្ឋឡើយ។ ប្រព័ន្ធប្រជាធិបតេយ្យនៅអាតែនរួមបញ្ចូលប្រព័ន្ធមួយដែលគេហៅថាការបណ្តេញចេញ។ នៅក្នុងប្រព័ន្ធនេះ សមាជិកទាំងឡាយនៅក្នុងសភាដែលបានយល់ថាជនណាម្នាក់អាចបង្កគ្រោះថ្នាក់ដល់បុរី-រដ្ឋ គេអាចបញ្ជូនឈ្មោះបុគ្គលនោះទៅសភាដើម្បីធ្វើការបោះឆ្នោត។ ប្រសិនបើបុគ្គលនោះទទួលបានសំលេងបោះឆ្នោតដើម្បីបណ្តេញចេញច្រើន ពេលនោះជននោះនឹងត្រូវបានគេបណ្តេញចេញពីបុរី-រដ្ឋរយៈពេល 10 ឆ្នាំ។

ទំនួលខុសត្រូវរបស់ប្រជាពលរដ្ឋ៖ ប្រជាពលរដ្ឋអាតែនមានទំនួលខុសត្រូវជាច្រើន។ ពួកគេត្រូវចូលបម្រើការនៅក្នុងវិស័យយោធា នៅពេលណាដែលបុរី-រដ្ឋត្រូវការកម្លាំងយោធា។ ស្ថិតនៅក្រោមការកែប្រែរបស់ក្លេស្តេនេស កុលសម្ព័ន្ធនីមួយៗនៅក្នុងចំណោមកុលសម្ព័ន្ធទាំង 10 តម្រូវឱ្យផ្តល់ប្រជាពលរដ្ឋសម្រាប់បម្រើការនៅក្នុងវិស័យយោធា។ ប្រជាពលរដ្ឋអាឱ្យត្រូវបានបណ្តុះបណ្តាលឱ្យចេះធ្វើចម្បាំង និងត្រូវបានកោះហៅឱ្យចូលរួមប្រយុទ្ធនៅពេលណាដែលមានសង្គ្រាម។

ប្រជាពលរដ្ឋអាតែនក៏បម្រើការនៅក្រុមប្រឹក្សាតុលាការផងដែរ។ ដើម្បីអាចជ្រើសតាំងឱ្យបម្រើការងារនេះបាន ប្រជាពលរដ្ឋមួយរូបត្រូវបានអាយុយ៉ាងតិច 30 ឆ្នាំ។ ក្នុងការជំនំជម្រះទោសរបស់ក្រុមប្រឹក្សាតុលាការជាទូទៅមានប្រជាជនរាប់រយនាក់ចូលរួមស្តាប់ការវិនិច្ឆ័យទោសរបស់ជនណាម្នាក់។ នៅក្នុងបុរីអាតែន ប្រជាពលរដ្ឋទាំងអស់ស្មើភាពគ្នាចំពោះមុខច្បាប់។ មិនមានមេធាវីជំនាញវិជ្ជាជីវៈ ឬចៅក្រមឡើយនៅពេលនោះ។ ប្រជាពលរដ្ឋ

បញ្ជាក់ហេតុផលដោយផ្ទាល់នៅចំពោះមុខក្រុមប្រឹក្សាតុលាការ។ នៅពេលនោះសមាជិកក្រុមប្រឹក្សាតុលាការធ្វើការបោះឆ្នោតដើម្បីសម្រេចថាជនណាម្នាក់មានទោសឬក៏អត់។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីវិធីដែលក្លេស្ថេនេសជួយផ្លាស់ប្តូរប្រព័ន្ធរដ្ឋាភិបាលនៅបុរីអាតែន។

# មេរៀនទី 4៖ បុរីស្ពាត និងអាតែន

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកបានសិក្សាពីបុរីអាតែន។ គូរប្រជែងដែលសំខាន់បំផុតរបស់បុរីអាតែន គឺបុរីស្ពាត ដែលជាបុរី-រដ្ឋដ៏ធំមួយនៅតំបន់ប៉េឡូប៉ូនេស៊ូស។ ជីវិតរស់នៅក្នុងបុរីស្ពាតមានលក្ខណៈខុសប្លែកគ្នាយ៉ាងខ្លាំងពីជីវិតរស់នៅក្នុងបុរីអាតែន។

## 1. រដ្ឋយោធារបស់បុរីស្ពាត

សំណួរគន្លឹះ៖ តើការអប់រំនៅក្នុងបុរីស្ពាតជួយគាំទ្រយ៉ាងដូចម្ដេចដល់វិស័យយោធា?

នៅក្នុងឆ្នាំប្រហែល 715 មុនគ.ស ពួកស្ពាតបានធ្វើការឈ្លានពានតំបន់នៅជិតខាងរបស់ខ្លួនដើម្បីពង្រីកផ្ទៃដី។ ពួកស្ពាតបានបង្ខំឱ្យប្រជាជនដែលចាញ់សង្គ្រាមធ្វើជាទាសករ ដែលគេហៅថាហេឡូត។ ពួកទាសករទាំងអស់នោះភាគច្រើនធ្វើការលើដីស្រែចំការ ហើយត្រូវប្រគល់ទិន្នផលពាក់កណ្ដាលឱ្យទៅពួកស្ពាត។ ពួកហេឡូតតែងតែធ្វើការបះបោរជាច្រើនលើក។ បើទោះបីជាពួកគេមានចំនួនច្រើនជាងពួកស្ពាត និងខំប្រឹងវាយប្រយុទ្ធយ៉ាងណាក៏ដោយ ពួកស្ពាតតែងតែបង្ក្រាបការបះបោរទាំងនេះ។ ដោយមានការព្រួយបារម្ភអំពីការបះបោរនេះ ពួកស្ពាតបានអភិវឌ្ឍខ្លួនឯងឱ្យក្លាយជារដ្ឋមួយ ដែលផ្តោតសំខាន់ទៅលើការស្ថាបនាវិស័យកងទ័ពឱ្យមានភាពខ្លាំងក្លា។

រដ្ឋាភិបាល និងសង្គម៖ ពួកស្ពាតមានរដ្ឋាភិបាលមួយដែលមួយផ្នែកបែបរាជាធិបតេយ្យ មួយផ្នែកទៀតបែបអភិជនាធិបតេយ្យ និងមួយផ្នែកទៀតបែបប្រជាធិបតេយ្យ។ មានស្ដេចពីរអង្គគ្រប់គ្រងនៅក្នុងបុរីស្ពាតនិងទីប្រឹក្សាចំនួន 5 រូបដែលត្រូវបានបោះឆ្នោតជ្រើសរើសដើម្បីដឹកនាំរដ្ឋាភិបាល។ ក្រុមប្រឹក្សាចាស់ទុំ ដែលត្រូវបានបង្កើតឡើងដោយប្រជាពលរដ្ឋចាស់ទុំចំនួន 30 នាក់ជាអ្នកស្នើច្បាប់។ ប្រជាពលរដ្ឋទាំងអស់របស់ស្ពាតគឺជាសមាជិករបស់សភា ដែលធ្វើការបោះឆ្នោតជ្រើសរើសមន្ត្រីរាជការ និងអនុម័តច្បាប់ដែលស្នើឡើងដោយក្រុមប្រឹក្សាចាស់ទុំ។

នៅក្នុងសង្គមស្ពាតគេបែងចែកមនុស្សជា 3 ក្រុម ដោយក្នុងនោះរួមមាន ប្រជាពលរដ្ឋ, មិនមែនប្រជាពលរដ្ឋប៉ុន្តែមានសេរីភាព, និងពួកហេឡូត។ ប្រជាពលរដ្ឋគឺជាបុព្វការីជនរបស់អ្នកតាំងទីលំនៅដើមនៅក្នុងតំបន់នេះ។ ពួកគេរស់នៅក្នុងទីក្រុង និងចំណាយពេលរបស់ពួកគេនៅក្នុងការបណ្ដុះបណ្ដាលកងទ័ព។ ប៉ុន្តែ ពួកមិនមែនប្រជាពលរដ្ឋមានសេរីភាព, មិនមានសិទ្ធិនយោបាយ, និងរស់នៅក្នុងភូមិជិតៗទីក្រុង។ ក្រុមដែលស្ថិតនៅក្រោមគេបំផុតគឺពួកហេឡូត។ ពួកគេប្រឹងប្រែងធ្វើការងារដើម្បីចិញ្ចឹមពួកស្ពាត ដើម្បីអាចឱ្យពួកគេមានសេរីភាពក្លាយជាកងយោធាពេញសិទ្ធិមួយរូបរបស់ស្ពាត។

ការអប់រំ៖ គោលបំណងរបស់ស្ពាតគឺចង់មានកងយោធាដ៏ខ្លាំងក្លាមួយ។ នៅពេលដែលមានអាយុ 7 ឆ្នាំ កុមារប្រុសៗត្រូវបានគេផ្លាស់ឱ្យទៅនឹងផ្ទះទាហានដែលគេហៅថា បន្ទាយទាហាន។ ការអប់រំរបស់ពួកគេគឺផ្តោតទៅលើ បទវិន័យ, កាតព្វកិច្ច, ភាពខ្លាំងក្លា, និងជំនាញយោធា។ កុមារទាំងនេះរៀនអានអក្សរបន្តិចបន្តួចប៉ុណ្ណោះ។

ប្រជាពលរដ្ឋប្រុសទាំងអស់ចូលបម្រើការងារជាកងទ័ពនៅពេលដែលពួកគេមានអាយុ 20 ឆ្នាំ និងបម្រើការងាររហូតដល់ពេលដែលពួកគេមានអាយុ 60 ឆ្នាំ។ បើទោះបីជាបន្ទាប់ពីបុរសទាំងនោះរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ ពួកគេត្រូវតែទៅរស់នៅក្នុងបន្ទាយយោធាដែលពួកបម្រើការងារ។

តួនាទីរបស់ស្រ្តី៖ ពួកស្ប៉ាតសង្ឃឹមថាស្រ្តីនៅក្នុងសង្គមរបស់ពួកគេជាអ្នកបណ្តុះបណ្តាលទាំងផ្នែកចិត្តសាស្រ្ត និងរូបរាងកាយ។ ម្តាយទាំងឡាយតែងតែប្រាប់ទៅកាន់កូនប្រុសរបស់ពួកគេថា "នាំយកខែលនេះមកវិញដោយខ្លួនឯង ឬក៏ចង់ឱ្យខែលនេះជាអ្នកនាំកូនមកវិញ" (ពួកស្ប៉ាតនាំយកសាកសពអ្នកធ្វើសង្គ្រាមត្រឡប់មកផ្ទះវិញដោយដាក់នៅលើខែលរបស់ពួកគេ។ ការអប់រំសម្រាប់ស្រ្តីនៅក្នុងបុរីស្ប៉ាតផ្តោតសំខាន់ទៅលើការធ្វើឱ្យរូបរាងការរបស់ពួកគេរឹងមាំ។ ពួកគេទទួលការបណ្តុះបណ្តាលផ្នែកខាងអត្តពលកម្ម និងរៀនអំពីរបៀបការពារខ្លួនដោយខ្លួនឯង។

ការយកចិត្តទុកដាក់តែទៅលើវិស័យយោធា ធ្វើឱ្យជីវិតគ្រួសារនៅក្នុងបុរីស្ប៉ាតមិនសូវមានសារៈសំខាន់ប៉ុន្មានទេ បើប្រៀបធៀបជាមួយបុរី-រដ្ឋផ្សេងៗទៀត។ នៅក្នុងបុរីស្ប៉ាត ប្តី និងប្រពន្ធរស់នៅភាគច្រើនបែកគ្នា។ ស្រ្តីមានសិទ្ធិសេរីភាពច្រើន។ ពួកគេត្រូវបានអនុញ្ញាតឱ្យកាន់កាប់ទ្រព្យសម្បត្តិ។ ប្រពន្ធត្រូវបានគេរំពឹងថានឹងមើលការខុសត្រូវលើទ្រព្យសម្បត្តិរបស់ប្តី ប្រសិនណាបើប្តីកំពុងធ្វើសង្គ្រាម។

សង្ខេប៖ ពន្យល់ថាតើការអប់រំនៅបុរីស្ប៉ាតបានជួយគាំទ្រយ៉ាងដូចម្តេចដល់យោធា។

## 2. របៀបនៃការរស់នៅនៅអាតែន

សំណួរគន្លឹះ៖ តើស្រ្តីនៅបុរីអាតែនមានតួនាទីអ្វីខ្លះ?

ដូចដែលអ្នកបានរៀនរួមមកហើយនៅក្នុងមេរៀនទី 3 ពួកអាតែនបន្តិចម្តងៗបានអភិវឌ្ឍប្រព័ន្ធនយោបាយបែបប្រជាធិបតេយ្យដោយផ្ទាល់មួយ។ ប្រជាពលរដ្ឋទាំងអស់របស់អាតែនជួបប្រជុំគ្នាដើម្បីធ្វើការបោះឆ្នោតអនុម័តច្បាប់នានា។ ប៉ុន្តែ ប្រជាធិបតេយ្យនៅមានកម្រិត ដោយសារតែមានតែបុរសដែលមានសេរីភាពប៉ុណ្ណោះដែលគេចាត់ទុកថាជាប្រជាពលរដ្ឋ។

សង្គមរបស់អាតែន៖ ប្រជាជនដែលរស់នៅក្នុងបុរីអាតែន ត្រូវបានគេបែងចែកទៅជា 4 វណ្ណៈធំៗ ដោយក្នុងនោះរួមមាន ប្រជាពលរដ្ឋ, ស្រ្តី, មិនមែនប្រជាពលរដ្ឋប៉ុន្តែមានសេរីភាព, និងទាសករ។ ប៉ុន្តែនៅក្នុងវណ្ណៈនីមួយៗមានវណ្ណៈតូចៗនៅក្នុងនោះទៀត។ ឧទាហរណ៍ នៅក្នុងវណ្ណៈប្រជាពលរដ្ឋរួមបញ្ចូលប្រជាពលរដ្ឋជាច្រើនកម្រិតដែលជាទូទៅផ្អែកទៅលើទ្រព្យសម្បត្តិរបស់ពួកគេ។ ប្រជាជនដែលជាទាសករ មានចំនួន 1/3 នៃចំនួនប្រជាជនសរុប។ ជាទូទៅ ពួកទាសករនៅបុរីអាតែនភាគច្រើនជាឈ្លើយសឹកដែលគេចាប់បានមកពីសង្គ្រាម។ កូនរបស់ទាសករក៏ជាទាសករផងដែរ។ ទាសករនៅក្នុងបុរីអាតែនធ្វើការងារនៅក្នុងផ្ទះ, កសិកម្ម, សិប្បកម្ម, និងជីករ៉ែ ហើយជាទូទៅធ្វើការអមជាមួយចៅហ្វាយរបស់ពួកគេ។ ទាសករមួយចំនួនអាចទទួលបានប្រាក់ខែ និងអាចសូម្បីតែទិញសេរីភាពរបស់ពួកគេ។

ការអប់រំ៖ នៅក្នុងបុរីអាតែនការអប់រំត្រូវបានរចនាឡើងដើម្បីរៀបចំកុមារ៉ាឱ្យក្លាយជាប្រជាពលរដ្ឋល្អ។ កុមារ៉ាដែលមកពីគ្រួសារអ្នកមានទ្រព្យសម្បត្តិចាប់ផ្តើមចូលរួមនៅអាយុ 6 ឬ 7 ឆ្នាំ។ ពួកគេសិក្សាអំពីតក្កវិទ្យា និងការនិយាយនៅសាធារណៈដើម្បីជួយដល់ពួកគេក្នុងការពិភាក្សាដេញដោល ដូចដែលមនុស្សពេញវ័យធ្វើនៅក្នុងសភា។ ពួកគេក៏សិក្សាអំពីការអាន, សរសេរ, កំណាព្យ, គណិតវិទ្យា, និងតន្ត្រី។ អត្តពលកម្មបានជួយដល់ពួកគេអភិវឌ្ឍភាពរឹងមាំ និងសហការគ្នា។

តួនាទីរបស់ស្ត្រី៖ ស្ត្រីមិនបានចូលរួមនៅក្នុងរដ្ឋាភិបាលអាតែនទេ។ ពួកអាតែនរំពឹងថាស្ត្រីគឺជាប្រពន្ធ និងម្តាយដ៏ល្អមួយរូប។ តួនាទីនេះត្រូវបានគេគោរព និងឱ្យតម្លៃ ដោយសារតែស្ត្រីបានជួយដល់ការថែរក្សាគ្រួសារ និងសង្គមឱ្យរឹងមាំ។ ជាងនេះទៅទៀត ស្ត្រីមួយចំនួនបានដើរតួនាទីសំខាន់នៅក្នុងវិស័យសាសនា ដោយធ្វើការជាបព្វជិតនី (ស្ត្រី) នៅក្នុងប្រាសាទ។ បើទោះបីជាស្ត្រីនៅអាតែនមានសារៈសំខាន់ចំពោះសង្គមក៏ដោយ ក៏ស្ត្រីនៅអាតែនមានសេរីភាពតិចតួចជាងស្ត្រីនៅបុរីស្ប៉ាត។ ស្ត្រីអាចអាចទទួលមរតកបានលុះត្រាណាតែគ្រួសាររបស់ពួកគេគ្មានកូនប្រុស។ ស្ត្រីមិនបានទៅសាលារៀនទេ។ ស្ត្រីរៀនសូត្រពីរបៀនធ្វើកិច្ចការផ្ទះពីម្តាយរបស់ពួកគេ។ មានស្ត្រីបន្តិចបន្តួចប៉ុណ្ណោះដែលរៀនពីការអាន និងសរសេរ។

ស្វែងរកគំនិតសំខាន់៖ ពិពណ៌នាអំពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គមអាតែន។

### 3. សង្គ្រាមជាមួយពួកពែក្ស

សំណួរគន្លឹះ៖ តើសង្គ្រាមជាមួយពួកពែក្សជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះបុរី-រដ្ឋនានារបស់ក្រិក?

ដូចដែលអ្នកបានដឹងមកហើយថា ពួកពែក្សបានឈ្លានពានដណ្តើមកាន់កាប់មួយភាគធំនៃអាស៊ីនិរតី។ នៅក្នុងទសវត្សរ៍ឆ្នាំ 500 មុនគ.ស ពួកពែក្សបានឈ្លានពានកាន់កាប់តំបន់អាណាតូលី ដែលជាតំបន់មួយដែលមានដែនដីអាណានិគមជាច្រើនរបស់ពួកក្រិក។ នៅក្នុងឆ្នាំ 499 មុនគ.ស ដែនដីរបស់ក្រិកមួយចំនួននៅអាណាតូលីបានងើបឡើងបះបោរប្រឆាំងជាមួយនឹងការគ្រប់គ្រងរបស់ពួកពែក្ស។ បុរីអាតែនបានបញ្ជូននាវាចម្បាំង និងកងទ័ពទៅជួយពួកគេ។ ការបះបោរនោះបរាជ័យ ប៉ុន្តែពួកពែក្សបានសម្រេចចិត្តក្នុងការដាក់ពិន័យដល់ពួកអាតែនដែលបានចូលជ្រៀតជ្រែកនៅការបះបោរនេះ។ នៅក្នុងឆ្នាំ 490 មុនគ.ស ពួកពែក្សបានធ្វើដំណើរមកដល់ជិតអាតែននៅតំបន់វាលទំនាបមួយឈ្មោះថាម៉ារ៉ាតុន។ ពួកអាតែនបានបញ្ជូនអ្នករត់ម្នាក់ទៅស្នើសុំជំនួយពីពួកស្ប៉ាត ប៉ុន្តែពួកស្ប៉ាតមកជួយយឺតពេល។ ពួកអាតែនមានចំនួនកងទ័ពតិច ដូច្នេះពួកគេត្រូវតែប្រើប្រាស់ផែនការឆ្លាតវៃមួយ។ ដំបូងពួកគេបានបញ្ឆោតពួកពែក្សឱ្យធ្វើដំណើរទៅដល់ចំណុចកណ្តាលនៃទឹកដីរបស់ក្រិក។ ពេលនោះពួកក្រិកឡោមព័ទ្ធពួកគេ និងធ្វើការវាយប្រហារ។ នៅក្នុងការប្រយុទ្ធគ្នានៅជិត ដាវរបស់ពួកក្រិកមានប្រសិទ្ធភាពជាងព្រួញរបស់ពួកពែក្ស។ ពួកពែក្សបានបាត់បង់ជីវិតកងទ័ពអស់ 6,400 នាក់។ ចំណែកពួកក្រិកបានបាត់បង់ជីវិតអស់តែ 192 នាក់ប៉ុណ្ណោះ។ មានរឿងព្រេងមួយបានិយាយថា ទាហានម្នាក់ដែលរត់ពីម៉ារ៉ាតុនមកកាន់អាតែនដែលមានចម្ងាយផ្លូវប្រមាណ 25 ម៉ាយដើម្បីប្រាប់ពីជ័យជំនះ។ បន្ទាប់ពីទាហាននោះមកដល់អាតែនជាមួយនឹងព័ត៌មានពី

ជ័យជំនះនេះ ទាហាននោះក៏បានដួល និងស្លាប់បាត់ទៅ។ កីឡាម៉ារ៉ាតុនសម័យទំនើបគឺផ្អែកទៅលើចម្ងាយរត់ដ៏វែងរបស់ទាហាននោះ។

ជ័យជំនះរបស់ពួកក្រិក៖ នៅក្នុងឆ្នាំ 480 មុនគ.ស ពួកពែក្សបានមកឈ្លានពានក្រិកម្តងទៀត។ បើទោះបីជាពីមុនមកជម្លោះជាមួយគ្នាក៏ដោយបុរី-រដ្ឋមួយចំនួនរបស់ក្រិកបានរួបរួមគ្នាដើម្បីប្រឆាំងជាមួយពួកពែក្ស។ កងទ័ពរបស់ស្ពាត 300 នាក់ចាំការពារនៅច្រកចូលតូចមួយនៅតំបន់ថឺម៉ូពីលីដើម្បីរាំងកងទ័ពរបស់ពែក្សកុំឱ្យធ្វើដំណើរទៅកាន់អាតែន។ ពួកកងទ័ពស្ពាតទប់ទល់ជាមួយពួកពែក្សបាន 2 ថ្ងៃ មុនពេលដែលពួកគេទាំងអស់ត្រូវបានកងទ័ពពែក្សសម្លាប់។ ការលះបង់របស់ពួកគេបានផ្តល់ពេលឱ្យពួកអាតែនមានពេលរៀបចំដើម្បីត្រៀមវាយប្រយុទ្ធ។ ពួកអាតែនបានចាក់ចេញពីទីក្រុងរបស់ពួកគេដើម្បីវាយប្រយុទ្ធនៅក្នុងសមរភូមិផ្លូវទឹកប្រឆាំងជាមួយពួកពែក្ស។ សមរភូមិនេះធ្វើឡើងនៅតំបន់ដែលមានផ្លូវទឹកតូចចង្អៀត ដែលនាវាធំៗរបស់ពែក្សមិនអាចធ្វើចលនាបានលឿន។ នាវាតូចៗ និងធ្វើចលនាលឿនរបស់ក្រិកបានវាយកម្ទិចនាវាធំៗរបស់ពែក្សប្រមាណ 300 គ្រឿង។ សង្គ្រាមចុងក្រោយបានបញ្ចប់នៅក្នុងឆ្នាំ 479 មុនគ.ស។ អ្នកនឹងបានសិក្សាបន្ថែមពីប្រទេសក្រិកបន្ទាប់ពីសង្គ្រាមនៅមេរៀនបន្ទាប់ទៀត។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីការជះឥទ្ធិពលនៃសង្គ្រាមជាមួយពែក្សលើបុរី-រដ្ឋនានានៅក្រិក។

# ជំពូក 8៖ ក្រិកសម័យរុងរឿង

## មេរៀនទី 1៖ ប្រជាធិបតេយ្យនៅអាតែន និងសង្គ្រាម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងមេរៀនមុខអ្នកបានសិក្សាពីរបៀបដែលលោកសូឡុន និងក្លេស្តេនេស បង្កើនអំណាចនយោបាយដល់ប្រជាពលរដ្ឋនៅបុរីអាតែន។ ត្រឹមឆ្នាំប្រមាណ 500 មុនគ.ស អាតែនបានក្លាយជាបុរីប្រកាន់យកប្រព័ន្ធប្រជាធិបតេយ្យមួយ។ អ្នកក៏នឹងសិក្សាអំពីភាពខុសគ្នារវាងបុរីអាតែន និងបុរីស្ប៉ាត ដែលជាបុរី-រដ្ឋមួយផ្តោតសំខាន់ទៅលើអំណាចយោធា។

### 1. ពេរីក្លេសដឹកនាំអាតែន

សំណួរគន្លឹះ៖ តើជំហានអ្វីខ្លះដែលពេរីក្លេសបានប្រើដើម្បីធ្វើឱ្យរដ្ឋាភិបាលអាថែនកាន់តែមានប្រជាធិបតេយ្យ?

បន្ទាប់ពីសង្គ្រាមពែក្សដែលអ្នកបានអាននៅក្នុងមេរៀនមុនបានបញ្ចប់ មេដឹកនាំដ៏ខ្លាំងក្លាបំផុតមួយរូបរបស់អាតែន ឈ្មោះថាពេរីក្លេសបានឡើងកាន់កាប់អំណាច។ ពេរីក្លេសត្រូវបានគេចាត់ទុកថាជាអ្នកនិយាយសាធារណដ៏ល្អបំផុតម្នាក់នៅពេលនោះ។ លោកក៏ទទួលបានកិត្តិនាមផងដែរដោយសារតែភាពទៀងត្រង់ និងមានក្រមសីលធម៌ខ្ពស់។

ត្រឹមឆ្នាំ 460 មុនគ.ស ពេរីក្លេស បានក្លាយជាមេដឹកនាំដ៏ខ្លាំងក្លាបំផុតនៅអាតែន។ ត្រង់បន្តធ្វើជាមេដឹកនាំនៅក្នុងបុរី-រដ្ឋរហូតដល់ទ្រង់សុគត បន្ទាប់ពីទ្រង់គ្រប់គ្រងអស់រយៈពេល 31 ឆ្នាំ។ អ្វីដែលជាស្នាដៃនៅអំឡុងពេលនៃការគ្រប់គ្រងរបស់លោក គឺមានសារៈសំខាន់ណាស់ ដែលនៅពេលនោះនៅក្នុបុរីអាតែនជាទូទៅត្រូវបានគេហៅថាយុគនៃពេរីក្លេស។ ពេរីក្លេសមានគោលបំណងសំខាន់ៗ 3 សម្រាប់បុរីអាថែន។ ដំបូងគេគឺពង្រឹងប្រជាធិបតេយ្យនៅអាតែន។ ទី 2 គឺពង្រីកអំណាចរបស់អាតែនទៅកាន់ពិភពខាងក្រៅ។ ទី 3 គឺរៀបចំកែលម្អទីក្រុង។ សមត្ថភាពនិយាយពិសេសរបស់ពេរីក្លេស បានជួយដល់លោកក្នុងការបញ្ចុះបញ្ចូលប្រជាជននៅអាតែនឱ្យគាំទ្រការធ្វើកំណែទម្រង់របស់លោក។

ពេរីក្លេសពង្រឹងប្រជាធិបតេយ្យ៖ ត្រូវចងចាំថាមុនពេរីក្លេស មេដឹកនាំមុនៗនៅក្នុងបុរីអាតែនបានចាប់ផ្តើមពង្រីកប្រជាធិបតេយ្យ។ ពេរីក្លេសគាំទ្រការធ្វើកំណែទម្រង់ដើម្បីពង្រីកប្រជាធិបតេយ្យទាំងនោះ។ ប៉ុន្តែ លោកចង់បានតុល្យភាពនៃអំណាចរវាងអ្នកមាន និងអ្នកក្រ។ បើទោះបីជាពេរីក្លេសមកពីគ្រួសារមានទ្រព្យសម្បត្តិស្តុកស្តម្ភក៏ដោយ លោកគិតថាពួកអ្នកមាន ហាក់ដូចជាមានអំណាចច្រើនពេក។ នៅឆ្នាំប្រមាណ 430 មុនគ.ស ពេរីក្លេសបានបង្ហាញពីការយល់ឃើញរបស់លោកចំពោះប្រជាធិបតេយ្យ នៅក្នុងសន្ទរកថាមួយដើម្បីផ្តល់កិត្តិយលដល់កងទ័ពអាតែនដែលបានស្លាប់នៅក្នុងសង្គ្រាម។ លោកបាននិយាយថា "មនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់"។ អ្វីដែលសំខាន់នៅក្នុងការបម្រើការងារសាធារណ "មិនមែនដោយសារតែពួកគេជាសមាជិកនៅក្នុងវណ្ណៈជាក់លាក់ណាមួយឡើយ ប៉ុន្តែផ្តោតសំខាន់ទៅលើសមត្ថភាពជាក់ស្តែងដែលពួកគេមាន"។

ដើម្បីក្លាយជាប្រជាពលរដ្ឋម្នាក់ បុគ្គលម្នាក់ត្រូវតែជាបុរសដែលមានសេរីភាពមានអាយុលើសពីអាយុ 18 ឆ្នាំ នៅជាកូនប្រុសរបស់ប្រជាពលរដ្ឋអាតែន។ ពេរីក្លេសបានផ្លាស់ប្តូរច្បាប់ចាស់ដែលតម្រូវឱ្យមានទាំងឪពុក និងម្តាយជាប្រជាពលរដ្ឋអាតែន។ ច្បាប់ចាស់នេះបានរារាំងដល់អ្នកមានទ្រព្យសម្បត្តិនៅក្នុងបុរីអាតែនកុំឱ្យភ្ជាប់ទំនាក់ទំនងជាមួយអ្នកមានទ្រព្យសម្បត្តិនៅក្នុងបុរី-រដ្ឋផ្សេងទៀត តាមរយៈការរៀនអាពិហ៍ពិពាហ៍។

ការផ្តល់ប្រាក់ខែដល់មន្ត្រីសាធារណៈ ដើម្បីបែងចែកអំណាចឱ្យកាន់តែមានភាពស្មើគ្នា ពេរីក្លេសបានផ្លាស់ប្តូរច្បាប់ដែលទាក់ទងទៅនឹងការងារការិយាល័យសាធារណ។ មុនការគ្រប់គ្រងរបស់ពេរីក្លេស មន្ត្រីសាធារណភាគច្រើន មិនទទួលបានប្រាក់ខែសម្រាប់ការងាររបស់ពួកគេឡើយ ដូច្នេះមានតែអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភប៉ុណ្ណោះដែលអានមានលិទ្ធភាពបម្រើការនៅក្នុងរដ្ឋាភិបាលអាតែន។ ពេរីក្លេសបានបង្កើនចំនួនមន្ត្រីសាធារណដែលមន្ត្រីទាំងនោះនឹងទទួលបានប្រាក់ខែសម្រាប់ការធ្វើការងាររបស់ពួកគេ។ ជាមួយនឹងការទទួលបានប្រាក់ខែសូម្បីតែប្រជាពលរដ្ឋក្រីក្រក៏អាចចូលធ្វើការងារក្នុងរដ្ឋាភិបាលបានផងដែរ ប្រសិនណាបើពួកគេត្រូវបានបោះឆ្នោតជ្រើសរើសជាមន្ត្រីសារធារណ ឬត្រូវបានគេជ្រើសរើសឱ្យធ្វើការនៅក្នុងក្រុមប្រឹក្សាតុលាការ។

ប្រជាធិបតេយ្យដោយផ្ទាល់៖ ទម្រង់នៃប្រជាធិបតេយ្យដែលអនុវត្តនៅអាតែនមិនមែនជាទម្រង់ដែលអនុវត្តនៅក្នុងសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្នឡើយ។ ទម្រង់ដែលគេប្រើនៅក្នុងបុរីអាថែនគឺប្រជាធិបតេយ្យដោយផ្ទាល់មានន័យថារាល់ប្រជាពលរដ្ឋទាំងអស់ចូលរួមដោយផ្ទាល់នៅក្នុងរដ្ឋាភិបាល។ ឧទាហរណ៍ ប្រជាពលរដ្ឋអាតែនណាម្នាក់ក៏បាន អាចស្នើច្បាប់ថ្មីមួយ ឬអាចបោះឆ្នោតអនុម័តដោយផ្ទាល់ទៅលើច្បាប់នានា។

បើធ្វើការប្រៀបធៀប សហរដ្ឋអាមេរិកមានទម្រង់ប្រជាធិបតេយ្យតំណាង ឬមានទម្រង់បែបសាធារណរដ្ឋមួយ។ ប្រជាពលរដ្ឋសហរដ្ឋអាមេរិក ទាំងប្រុសទាំងស្រី ធ្វើការបោះឆ្នោតជ្រើសរើសតំណាងរបស់ដើម្បីធ្វើការនៅក្នុងជួររដ្ឋាភិបាល។ តំណាងប្រជាពលរដ្ឋទាំងនេះស្នើច្បាប់ និងបោះឆ្នោតអនុម័តច្បាប់ទាំងឡាយ។ សិក្សាពីតារាងនៅក្នុងទំព័រនេះដើម្បីស្វែងយល់ពីភាពខុសគ្នាផ្សេងទៀតរវាងប្រជាធិបតេយ្យដោយផ្ទាល់ និងប្រជាធិបតេយ្យតំណាង។

សង្ខេប៖ ពិពណ៌នាអំពីជំហាននានាដែលពេរីក្លេសបានធ្វើឡើងដើម្បីធ្វើឱ្យរដ្ឋាភិបាលនៅអាតែនកាន់តែមានប្រជាធិបតេយ្យ។

## 2. ភាពរុងរឿងនៃចក្រភព

សំណួរគន្លឹះ៖ តើបុរីអាតែនមានអំណាចកាន់តែខ្លាំងដោយរបៀបណា?

ទ្រព្យសម្បត្តិរបស់ក្រិកគឺអាស្រ័យទៅលើការពារពាណិជ្ជកម្មឯនាយសមុទ្រ។ អាតែនយកចិត្តទុកដាក់យ៉ាងខ្លាំងលើការការពារពាណិជ្ជកម្មឯនាយសមុទ្រ និងក្នុងស្រុករបស់ពួកគេ។ នៅចុងបញ្ចប់នៃសង្គ្រាមពែក្ស បុរី-រដ្ឋនានារបស់ក្រិកបានបង្កើតសម្ព័ន្ធមួយដើម្បីការពារគ្នាទៅវិញទៅមក។ សម្ព័ន្ធនេះត្រូវបានគេហៅថាសម្ព័ន្ធដេលៀន។

សម្ព័ន្ធដេលៀន៖ បុរីអាថតែនជាអ្នកជួយរៀបចំសម្ព័ន្ធនេះ។ វាត្រូវបានគេហៅថាសម្ព័ន្ធដេលៀន ដោយសារតែមូលដ្ឋាន និងរតនាគារបស់សម្ព័ន្ធនេះស្ថិតនៅលើកោះមួយដែលមានឈ្មោះថាដេឡូស។ បុរី-រដ្ឋមួយចំនួនបានផ្តល់

កងទ័ព និងនាវាសម្រាប់បម្រើការនៅក្នុងជួរកងទ័ពរបស់សម្ព័ន្ធ។ សមាជិកបុរី-រដ្ឋផ្សេងៗបានបង់ជាប្រាក់ជំនួសឱ្យការផ្តល់កងទ័ព។ ពេរីក្លេសបានប្រើប្រាស់លុយ, កងទ័ព, និងនាវារបស់សម្ព័ន្ធដើម្បីស្ថាបនាកងទ័ពដ៏ខ្លាំងក្លាមួយរបស់អាតែន។ នៅពេលនោះ កងនាវារបស់អាតែន មាននាវាចម្បាំងយោងហោចណាស់ចំនួន 300 គ្រឿង។

អាតែនគ្រប់ដណ្តប់លើសម្ព័ន្ធដេលៀន៖ កងនាវារបស់អាតែនគឺជាងកងនាវាដែលខ្លាំងជាគេបំផុតនៅតំបន់មេឌីទែរ៉ានេ។ ដោយសារតែអាតែនគឺជាអ្នកត្រួតត្រាលើកងទ័ពជើងទឹកដ៏ខ្លាំងក្លា ពួកគេបានក្លាយជាអ្នកមានឥទ្ធិពលគ្រប់ដណ្តប់លើសម្ព័ន្ធដេលៀន។ មានបុរី-រដ្ឋមួយចំនួនព្រួយបារម្ភថាទ្រព្យមហាសាលដែលមាននៅក្នុងរតនាគាររបស់សម្ព័ន្ធ អាចនឹងមិនមានសុវត្ថភាពគ្រប់គ្រាន់ពីការវាយប្រហាររបស់ពួកពែក្ស ឬសត្រូវផ្សេងៗទៀត។ នៅក្នុងឆ្នាំ 454 មុនគ.ស រតនាគាររបស់សម្ព័ន្ធដេលៀនត្រូវបានផ្លាស់ប្តូរទៅអាតែន។ ការផ្លាស់ប្តូររតនាគាររបស់សម្ព័ន្ធដេលៀនបានជួយពង្រឹងអំណាចរបស់អាតែនមួយកម្រិតទៀត។ បុរីអាតែនចាប់ផ្តើមប្រព្រឹត្តិចំពោះសមាជិកសម្ព័ន្ធផ្សេងៗទៀត ដូចជាពួកគេគឺជាអ្នកឈ្លានពានទៅវិញមិនដូចជាសម្ព័ន្ធមិត្តឡើយ។ ដោយថាហេតុ បុរីអាតែនបានគ្រប់ដណ្តប់លើបុរី-រដ្ឋនានាដើម្បីពង្រីកអំណាចរបស់ពួកឱ្យក្លាយជាចក្រភពមួយ។

វាយតម្លៃ៖ ពន្យល់ពីហេតុផលដែលនាំឱ្យអាតែនកាន់តែមានអំណាចខ្លាំង។

### 3. ការកែលម្អបុរីអាតែន

សំណួរគន្លឹះ៖ តើពេរីក្លេសកែលម្អអាតែនដោយរបៀបណា?

អាតែនត្រូវបានវាយឱ្យរាបដល់ដីនៅពេលដែលសង្គ្រាមជាពួកពែក្សត្រូវបានបញ្ចប់នៅក្នុងឆ្នាំ 479 មុនគ.ស។ កងទ័ពឈ្លានពានបានដុតបំផ្លាញផ្នែកនានានៃទីក្រុង និងកម្ទិចសំណង់នានាស្ទើទាំងស្រុង។ ពេរីក្លេសមើលឃើញថាវិនាសកម្មនេះ ថាជាឱកាសមួយសម្រាប់ការស្ថាបនាឡើងវិញ, កែលម្អ, និងលើកតម្កើនអាតែនឡើងវិញ។

ការស្ថាបនាអាតែនឡើងវិញ៖ បុរី-រដ្ឋនានារបស់ក្រិកបានបង់សួយសាអាករទៅឱ្យស្ថាប័នសម្ព័ន្ធដេលៀន។ មូលនីធិនេះត្រូវបានគេរំពឹងថានឹងប្រើប្រាស់ដើម្បីជួយស្ថាបនាអំណាចយោធានៅក្នុងសម្ព័ន្ធ។ ផ្ទុយទៅវិញពេរីក្លេសបានប្រើប្រាស់មូលនីធិនេះមួយចំនួនដើម្បីកែលម្អបុរីអាតែន។ លោកមិនបានស្នើសុំការយល់ព្រមពីសមាជិកទាំងឡាយនៅក្នុងសម្ព័ន្ធដើម្បីប្រើប្រាស់លុយទាំងនេះឡើយ ដែលជាហេតុនាំឱ្យបុរី-រដ្ឋផ្សេងៗជាសមាជិកមានការខឹងសម្បា។ ពេរីក្លេសបានចំណាយលុយទាំងនោះដើម្បីទិញទឹកមាស, ភ្លុក, ថ្មម៉ាបដើម្បីធ្វើជាបដិមា និងដើម្បីស្ថាបនាអាគារដ៏ស្រស់ស្អាតនានា។ ពេរីក្លេស ក៏បានប្រើប្រាស់ប្រាក់ដើម្បីជួលវិចិត្រករ, ស្ថាបត្យករ, និងជាងចម្លាក់ឱ្យធ្វើការនៅក្នុងគម្រោងទាំងឡាយរបស់លោក។

អាក្រូប៉ូលីស៖ តំបន់មួយដែលគេស្ថាបនាឡើងវិញគឺអាក្រូប៉ូលីស ឬ "ទីក្រុងខ្ពស់" នៅក្នុងបុរីអាតែន។ អាក្រូប៉ូលីសគឺជាតំបន់មួយដែលស្ថិតនៅក្នុងទីក្រុងរបស់ពួកក្រិកដែលមានប្រាសាទសំខាន់ៗ, បូជនីយស្ថាន, និងសំណង់នានា។ ពួកពែក្សបានវាយបំផ្លាញប្រាសាទ និងកម្ទិចរូបបដិមានានានៅក្នុងបុរីអាតែននៅអំឡុងពេលនៅសង្គ្រាម។ សំណង់អាគារថ្មីដែលត្រូវបានស្ថាបនាឡើងគឺប៉ាថេនុន។ វាត្រូវបានសាងសង់ឡើងដើម្បីធ្វើជាប្រាសាទសម្រាប់

អាទិទេពអាថេណា ដែលជាទេពធីតាសង្គ្រាម ដែលពួកអាតែនបានដាក់ឈ្មោះឱ្យ។ ប៉ាថេនុនត្រូវបានគេចាត់ទុកថាជាសំណង់ស្រស់ស្អាតបំផុតនៅអាក្រូប៉ូលីស។ វាគឺជាស្នាដៃឯកនៃរចនាបថស្ថាបត្យកម្ម ជាពិសេសទំហំដ៏សមស្រប, ភាពស៊ីគ្នា និងមានរបៀបរៀបរយ។

ស្វែងរកគោលគំនិត៖ ពន្យល់ពីវិធីដែលពេរីក្លេសធ្វើឱ្យអាតែនកាន់តែស្រស់ស្អាត។

## 4. សង្គ្រាមប៉េឡូប៉ូនេសៀន

សំណួរគន្លឹះ៖ តើមានអ្វីកើតឡើងខ្លះនៃអំឡុងសង្គ្រាមប៉េឡូប៉ូនេសៀន?

មានភាពខុសគ្នាយ៉ាងខ្លាំងបានលេចចេញរវាងបុរី-រដ្ឋអាតែន និងស្ពាត។ ឧទាហរណ៍ បុរីអាតែនមានប្រព័ន្ធរដ្ឋាភិបាលបែបប្រជាធិបតេយ្យ ខណៈពេលដែលបុរីស្ពាតមានវប្បធម៌មួយដែលលើកតម្កើនដល់កម្លាំងយោធា។ បុរី-រដ្ឋទាំងពីរចង់ក្លាយជាមហាអំណាចនៅក្នុងតំបន់ដូចគ្នា។ ការប្រកួតប្រជែងនេះបាននាំទៅដល់ការបះទង្គិចគ្នារវាងបុរី-រដ្ឋទាំងពីរ និងសម្ព័ន្ធមិត្តរបស់ពួកគេ។

ការផ្ទុះឡើងនៃសង្គ្រាម៖ មានកត្តាជាច្រើនដែលនាំទៅដល់ការផ្ទុះឡើងនៃសង្គ្រាម។ បុរី-រដ្ឋមួយចំនួនមានការភ័យខ្លាចចំពោះពួកអាតែន ដោយសារការក្ដោបយកអំណាច និងកិត្យានុភាពរបស់ពួកគេ។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពេរីក្លេស អាតែនបានរីកចម្រើនពីបុរី-រដ្ឋមួយក្លាយជាចក្រភពកងទ័ពជើងទឹកមួយ។ បុរី-រដ្ឋមួយចំនួនទៀតក៏មិនសប្បាយចិត្តចំពោះបុរីអាតែនដែលបានចំណាយលុយរបស់សម្ព័ន្ធដេលៀន ដើម្បីកែលម្អទីក្រុងរបស់ខ្លួនឯងឡើយ។ លុយត្រូវបានគេបម្រុងទុកដើម្បីការពារដល់បុរី-រដ្ឋទាំងអស់នៅក្នុងសម្ព័ន្ធ មិនមែនប្រើសម្រាប់ស្ថាបនាអាតែនឡើងវិញឡើយ។ ជម្លោះនេះបាននាំឱ្យបុរី-រដ្ឋមួយចំនួនព្យាយាមក្នុងការដោះខ្លួនចេញពីអំណាចរបស់អាតែន។ ប៉ុន្តែពេរីក្លេស បានដាក់ពិន័យដល់បុរី-រដ្ឋទាំងឡាយណាដែលប្រឆាំងទៅនឹងអំណាចត្រួតត្រារបស់អាតែន។ បុរីស្ពាតបានដឹកនាំសម្ព័ន្ធនៃបុរី-រដ្ឋមួយ ដើម្បីទទល់ទៅនឹងអំណាចរបស់ចក្រភពអាតែន។ សម្ព័ន្ធនេះត្រូវបានគេហៅថាសម្ព័ន្ធប៉េឡូប៉ូនេសៀន ដោយសារបុរី-រដ្ឋជាច្រើនដែលចូលក្នុងសម្ព័ន្ធនេះមានទីតាំងស្ថិតនៅតំបន់ប៉េឡូប៉ូនេស៊ូស។ ចុងក្រោយ នៅក្នុងឆ្នាំ 431 មុនគ.ស បុរីស្ពាតបានប្រកាសសង្គ្រាមជាមួយបុរីអាតែន។ ជម្លោះនេះត្រូវបានគេស្គាល់ថា សង្គ្រាមប៉េឡូប៉ូនេសៀន។

ការឆាបឆួលនៃសង្គ្រាម៖ ភាគីនីមួយៗនៅក្នុងសង្គ្រាមមានចំណុចយកប្រៀបរៀងៗខ្លួន។ ស្ពាតមានកងកម្លាំងយោធាផ្នែកជើងគោកខ្លាំងពូកែ។ ខណៈពេលដែលបុរីស្ពាតមានទីតាំងស្ថិតនៅឆ្ងាយពីសមុទ្រ បុរីនេះមិនអាចត្រូវបានវាយប្រហារតាមផ្លូវសមុទ្របានឡើយ។ បុរីអាតែនមានកងនាវាខ្លាំងពូកែ និងអាចវាយប្រហារសម្ព័ន្ធមិត្តរបស់ស្ពាតតាមផ្លូវសមុទ្រ។ ទីក្រុងរបស់អាតែនមានកំពង់ផែដ៏រឹងមាំមួយ ហើយលុយទាំងឡាយដែលបានមកពីរដ្ឋចំណុះរបស់ពួកគេ បានជួយដល់ការចំណាយសម្រាប់ធ្វើសង្គ្រាម។ ភាពខុសគ្នាទាំងនេះបាននាំដល់ការបង្កើតនូវយុទ្ធសាស្ត្រសង្គ្រាមរៀងៗខ្លួនសម្រាប់ភាគីនីមួយៗ។

យុទ្ធសាស្ត្ររបស់អាតែនគឺជៀសវាងការប្រយុទ្ធគ្នានៅលើដីគោក និងផ្តោតសំខាន់លើការប្រយុទ្ធតាមផ្លូវសមុទ្ទ។ តំបន់តូចមួយនៅជិតកូរីបានភ្ជាប់តំបន់ប៉េឡូប៉ូនេស៊ូសជាមួយនឹងតំបន់ក្រិកទាំងមូល។ ពួកអាតែនផ្តោតសំខាន់លើការវាយប្រហាររបស់ពួកគេនៅតំបន់នេះ ដោយសង្ឃឹមថាអាចរារាំងផ្លូវធ្វើដំណើររបស់ពួកស្ពាតទៅអាថែន។ យុទ្ធសាស្ត្ររបស់ពួកស្ពាតគឺធ្វើយ៉ាងណាបង្ខំឱ្យពួកអាតែនធ្វើសង្គ្រាមនៅលើដីគោក។ ពួកស្ពាតត្រួតត្រាតំបន់ជនបទនានានៅជុំវិញអាតែន និងព្យាយាមនៅក្នុងការកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀងអាហារដល់អាតែនតាមរយៈការកម្ទិចទិន្នផលដំណាំ។ ពេរីក្លេសបានបញ្ចុះបញ្ចូលពួកអាតែនឱ្យចាកចេញពីភូមិរបស់ពួកគេ ហើយទុកតំបន់ជនបទទាំងនោះឱ្យពួកស្ពាតវាយកម្ទិចចោលទៅចុះ។ ពេរីក្លេសបាននាំយកប្រជាជនទាំងឡាយដែលរស់នៅតំបន់ជុំវិញអាតែន ចូលមកក្នុងទីក្រុងដែលមានកំពែងព័ទ្ធជុំវិញយ៉ាងរឹងមាំដើម្បីការពារសុវត្ថភាពរបស់ពួកគេ។ អាតែនអាចផ្គត់ផ្គង់ស្បៀងអាហារតាមរយៈសមុទ្របាន។ ប៉ុន្តែ នៅក្នុងទីក្រុងរបស់អាតែនចាប់ផ្តើមមានមនុស្សច្រើនហួសកំណត់។

នៅក្នុងឆ្នាំ 430 មុនគ.ស នៅក្នុងឆ្នាំទី 2 នៃសង្គ្រាម ជំងឺអាសន្នរោគបានផ្ទុះឡើងនៅក្នុងបុរីអាតែន។ ជំងឺអាសន្នរោគគឺជាជំងឺមួយដែលរីករាយដាលយ៉ាងឆាប់រហ័ស ហើយជាទូទៅវាយអាចបង្កឱ្យមនុស្សស្លាប់។ អាតែនមានបាត់បង់ប្រជាជន និងកងទ័ពរបស់ខ្លួនប្រមាណ 1/3 ដោយសារតែជំងឺឆ្លងមួយនេះ។ ជនរងគ្រោះដែលគួរឱ្យកត់សំគាល់ជាងគេគឺពេរីក្លេស។ បន្ទាប់ពីការធ្វើសង្គ្រាមរយៈពេល 10 ឆ្នាំ ភាគីទាំងសងខាងមិនមានភាគីណាមួយមានប្រៀបអាចយកជ័យជំនះលើភាគីម្ខាងទៀតឡើយ។

នៅក្នុងឆ្នាំ 421 មុនគ.ស បុរីអាតែន និងបុរីស្ពាតបានចុះសន្ធិសញ្ញាមួយ ឬកិច្ចព្រមព្រៀងមួយដើម្បីបញ្ឈប់ការធ្វើសង្គ្រាមជាមួយគ្នា។ ប៉ុន្តែគ្មានភាគីមួយណាគោរពលក្ខខ័ណ្ឌនៅក្នុងកិច្ចព្រមព្រៀងបានយូរអង្វែងឡើយ ហើយសង្គ្រាមភ្លាមៗបានផ្ទុះឡើងសារជាថ្មីម្តងទៀត។ នៅក្នុងឆ្នាំ 415 មុនគ.ស អាតែនបានបើកការវាយប្រហារលើតំបន់ស៊ីស៊ីលីក្នុងគោលបំណងដើម្បីកាត់ផ្តាច់ការផ្គត់ផ្គង់ដល់ពួកស្ពាត។ នៅដើមដំបូង គម្រោងការនេះដំណើរការល្អ។ ប៉ុន្តែនៅក្នុងឆ្នាំ 413 មុនគ.ស ពួកស្ពាតបានវាយបកវិញ ដោយបានសម្លាប់ និងចាប់កងទ័ពទាំងឡាយរបស់ពួកអាតែននៅតំបន់ស៊ីស៊ីលី និងបានវាយកម្ទិចកងនាវារបស់អាតែនអស់មួយភាគធំ។ ពួកស្ពាតបានវាយប្រហារអាតែនម្តងទៀតនៅក្នុងឆ្នាំ 411 មុនគ.ស។ ពួកពែក្សបានចូលរួមនៅក្នុងសង្គ្រាមប្រឆាំងជាមួយពួកអាតែនដែរ ហើយបានជួយដល់ពួកស្ពាតដើម្បីលើកកម្ពស់កងកម្លាំងជើងទឹករបស់ពួកគេឱ្យកាន់តែប្រសើរ។ ពួកអាតែនទាប់ទល់ជាមួយសត្រូវបានមួយរយៈពេល ប៉ុន្តែនៅក្នុងឆ្នាំ 405 មុនគ.ស កងនាវារបស់ស្ពាតបានដណ្តើមកាន់កាប់កងនាវារបស់ពួកអាតែន។ អាតែនចុងក្រោយយល់ព្រមចុះចាញពួកស្ពាតនៅក្នុងឆ្នាំ 404 មុនគ.ស។

ហេតុបច្ច័យនៃសង្គ្រាម៖ សង្គ្រាមប៉េឡូប៉ូនេសៀនមានរយៈពេល 27 ឆ្នាំ។ ទីក្រុងនានា និងដំណាំត្រូវបានបំផ្លាញ ហើយប្រជាជនក្រិករាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិត។ បុរី-រដ្ឋទាំងឡាយរបស់ក្រិករងគ្រោះដោយសារការបាត់បង់សេដ្ឋកិច្ច និងឃោជា។ នៅភាគខាងជើងនៃបុរី-រដ្ឋនានារបស់ក្រិកនៅក្នុងប្រទេសម៉ាសេដូនៀស្តេចហ្វី

លីបទី 2 បានឡើងគ្រប់គ្រងអំណាចនៅក្នុងឆ្នាំ 359 មុនគ.ស។ ទ្រង់បានសម្លឹងមើលលើការពង្រីកទឹកដីមកកាន់ភាគខាងត្បូងនៅពេលដែលបុរី-រដ្ឋនានារបស់ក្រិកចុះអន់ថយ ដើម្បីស្ថាបនាចក្រភពមួយ។

បែងចែកព្រឹត្តិការណ៍៖ រាយបញ្ជីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងសង្គ្រាមប៉េឡូប៉ូសៀន និងពេលវេលាដែលព្រឹត្តិការណ៍ទាំងនោះកើតឡើង។

# មេរៀនទី 2 ៖ អាឡិចសាន់ឌឺដ៏អស្ចារ្យ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកបានសិក្សារួចមកហើយថា មេដឹកនាំដ៏ខ្លាំងក្លាមួយរូបជាទូទៅអាចបង្រួបបង្រួមក្រុមប្រជាជនដែលបែកបាក់គ្នា។ ខណៈពេលដែលបុរី-រដ្ឋទាំងឡាយរបស់ពួកក្រិកកំពុងតែជាប់រវល់វាយប្រយុទ្ធគ្នាទៅវិញទៅមក អំណាចថ្មីមួយចាប់ផ្តើមលេចឡើងនៅភាគខាងជើង។ ស្តេចគ្រប់គ្រងនៅទីនោះខ្លាំងពូកែណាស់។

## 1. ស្តេចនៃម៉ាសេដូនៀ

សំណួរគន្លឹះ៖ តើការអភិវឌ្ឍវិស័យយោធាម៉ាសេដូនៀរបស់ស្តេចហ្វីលីពបានជួយអ្វីខ្លះដល់ការឈ្លានពានរបស់ទ្រង់លើបុរី-រដ្ឋរបស់ក្រិច?

មហាអំណាចថ្មីមួយនៅភាគខាងជើងក្រិកគឺប្រទេសម៉ាសេដូនៀ។ ស្តេចដែលគ្រប់គ្រងនៅទីនោះគឺ ស្តេចហ្វីលីពទី 2 ដែលមានព្រះជន្ម 23 ព្រះវស្សា, ខ្លាំងពូកែ, និងមានភាពក្លាហាន។ ទ្រង់មានគម្រោងនៅក្នុងការស្ថាបនាចក្រភពមួយ ដែលរួមបញ្ចូលនូវទឹកដីរបស់ពួកក្រិក និងពែក្ស។

យោធាដែលមានទេពកោសល្យ៖ ជាក្មេងជំទង់ម្នាក់ ស្តេចហ្វីលីពធ្លាប់ជាឈ្លើយសឹកម្នាក់នៅក្នុងទីក្រុងថេប៊ែសរបស់ក្រិក។ នៅទីនោះទ្រង់បានអង្កេតមើលកងទ័ព និងយុទ្ធសាស្ត្រយោធារបស់ពួកថេប៊ែស។ ស្តេចហ្វីលីពបានដឹងថា កងទ័ពជំនាញ ឬកងទ័ពដែលធ្វើការពេញម៉ោង មានអត្ថប្រយោជន៍ជាងកងកម្លាំងស៊ីឈ្នួល។

ស្តេចហ្វីលីពបានរៀបចំកងទ័ពដែលទទួលការបណ្តុះបណ្តាលដ៏ល្អមួយ។ ទ្រង់បានបង្កើតក្បួនកងទ័ព និងយុទ្ធសាស្ត្រថ្មី និងធ្វើការសាល្បងក្នុងការប្រើប្រាស់កងទ័ពសេះ និងកងទ័ពថ្មើជើងរួមគ្នា។ ទ្រង់បានផ្តល់ឱ្យកងទ័ពរបស់ទ្រង់នូវអាវុធថ្មីៗ ដូចជាអាវុធសម្រាប់ក្រវាត់ជុំមូលជាដើម។ អាវុធសម្រាប់ក្រវាត់ជុំមូលគឺជាម៉ាស៊ីនមួយដែលគេប្រើសម្រាប់ចោលដុំថ្ម ឬព្រួញទៅលើកងទ័ពសត្រូវ និងជញ្ជាំងទីក្រុង។ កងទ័ពរបស់ស្តេចហ្វីលីពក៏ប្រើប្រាស់ប្រដាប់បុកទម្លាយដើម្បីបំបែកទ្វាច្រកចូល។

ស្តេចហ្វីលីពឈ្លានពានកាន់កាប់ក្រិក៖ បន្ទាប់ពីដណ្តើមកាន់កាប់តំបន់នៅជុំវិញម៉ាសេដូនៀរួច ស្តេចហ្វីលីពសម្លឹងទៅរកការឈ្លបពានបុរី-រដ្ឋនានារបស់ក្រិក។ បន្ទាប់ពីសង្គ្រាមប៉េឡូប៉ូនេសៀន បុរី-រដ្ឋនានារបស់ក្រិកបានចុះខ្សោយ និងបែកខ្ញែកគ្នា ដោយមិនអាចរួបរួមគ្នាដើម្បីតស៊ូប្រឆាំងជាមួយស្តេចហ្វីលីពបាន។ នៅក្នុងឆ្នាំ 338 មុនគ.ស ស្តេចហ្វីលីពបានសម្រេចការឈ្លានពានរបស់ទ្រង់លើពួកក្រិក និងបានក្លាយជាមេដឹកនាំនៅក្រិក។ ការគ្រប់គ្រងផ្តាច់ការរបស់ទ្រង់បានបញ្ចប់ការអនុវត្តប្រព័ន្ធប្រជាធិបតេយ្យរបស់ក្រិក។ ទ្រង់បានបញ្ចូលកងទ័ពរបស់ក្រិកទៅក្នុងកងយោធារបស់ទ្រង់ និងប្រុងប្រៀបដើម្បីធ្វើការវាយប្រហារពួកពែក្ស។

ប៉ុន្តែ នៅក្នុងឆ្នាំ 336 មុនគ.ស ស្តេចហ្វីលីពទី 2 ត្រូវបានគេលួចធ្វើឃាតនៅក្នុងពិធីអាពាហ៍ពិពាហ៍របស់បុត្រីទ្រង់។ រាជបុត្រារបស់ទ្រង់ ដែលព្រះជន្ម 20 ព្រះវស្សា ព្រះនាមអាឡិចសាន់ឌឺបានឡើងគ្រងរាជបល្ល័ង្គ។ បើ

ទោះបីជាទ្រង់មានព្រះជន្មក្មេងវ័យជាងស្តេចហ្វីលីពនៅពេលដែលទ្រង់ឡើងគ្រងរាជ្យដំបូងក៏ដោយ អាឡិចសាន់ឌឺបានបង្ហាញថាទ្រង់ប្រុងប្រៀបរួចជាស្រេចនៅក្នុងការត្រួតត្រាចក្រភពរបស់បិតាទ្រង់។

ធ្វើការពិចារណា៖ ពន្យល់ពីរការអភិវឌ្ឍវិស័យយោធាម៉ាសេដូនៀរបស់ស្តេចហ្វីលីពបានជួយដល់ការឈ្លានពានរបស់ទ្រង់លើបុរី-រដ្ឋរបស់ក្រិក។

## 2. អាឡិចសាន់ឌឺព្យាយាមនៅក្នុងការកាន់កាប់ពិភពលោក

សំណួរគន្លឹះ៖ តើអាឡិចសាន់ឌឺស្ថាបនាចក្រភពរបស់ទ្រង់ដោយរបៀបណា?

អាឡិចសាន់ឌឺ មានការរៀបចំបានយ៉ាងល្អសម្រាប់កិច្ចការងាររបស់ទ្រង់ដែលជាស្តេច។ ទ្រង់ធ្លាប់ត្រូវបានបង្រៀនដោយអ្នកប្រាជ្ញក្រិកដ៏ល្បីល្បាញនានា និងទទួលបានការបណ្តុះបណ្តាលនៅក្នុងជួរកងទ័ពម៉ាសេដូនៀ។ ទ្រង់បានបន្តគម្រោងរបស់បិតាទ្រង់ក្នុងការបង្កើតចក្រភពមួយ។

អាឡិចសាន់ឌឺយកជ័យជំនះលើពួកពែក្ស៖ នៅមុនពេលដែលអាឡិចសាន់ឌឺវាយប្រហារលើពួកពែក្ស បុរី-រដ្ឋមួយរបស់ក្រិកថេប៊ែសបានងើបឡើងបះបោរ។ អាឡិចសាន់ឌឺបានវាយកម្ទិចទីក្រុងថេប៊ែសចោល។ ភាពកាចសាហាវគ្មានមេត្តារបស់ទ្រង់បានធ្វើឱ្យបុរី-រដ្ឋនានារបស់ក្រិកមានការភ័យខ្លាចក្នុងការបះបោរ។ បន្ទាប់មក អាឡិចសាន់ឌឺបានចល័តកងទ័ពរបស់ទ្រងទៅតំបន់អាណាតូលៀ ជាទីកន្លែងដែលទ្រង់បានវាយប្រហារ និងយកជ័យជំនះលើកងកម្លាំងរបស់ពែក្ស។ ទ្រង់បានប្រើយុទ្ធសាស្ត្រវាយលុកដោយត្រង់ ដោយវាយសម្រុកទៅលើសត្រូវដែលមានទាហានរាប់ពាន់នាក់។ នៅដើមដំបូង អាឡិចសាន់ឌឺបានជួបជាមួយនឹងការប្រយុទ្ធតទល់ពីសំណាក់ពួកពែក្សផងដែរ ប៉ុន្តែដាយថាហេតុទ្រង់បានទទួលជ័យជំនះ។

អាឡិចសាន់ឌឺមិនបានធ្វើដំណើរត្រង់ទៅពែក្សឡើយ ទ្រង់បានធ្វើដំណើរទៅភាគខាងត្បូង និងចូលទៅកាន់ប្រទេសអេហ្ស៊ីប។ ពួកអេហ្ស៊ីបបានស្វាគមន៍អាឡិចសាន់ឌឺ ដោយសារតែពួកគេស្អប់ពួកពែក្ស។ ពួកអេហ្ស៊ីបថែមទាំងបានជ្រើសរើសអាឡិចសាន់ឌឺធ្វើជាផារ៉ូសទៀតផង។ បន្ទាប់មកអាឡិចសាន់ឌឺបានចល័តកងទ័ពរបស់ទ្រង់ពីអេហ្ស៊ីបឆ្លងកាត់មេសូប៉ូតាមីឆ្ពោះទៅរកពែក្ស។ ចុងក្រោយ ទ្រង់បានវាយកម្ទិច ពីសេប៉ូលីសដែលជារាជធានីរបស់ពួកពែក្ស។ ត្រឹមឆ្នាំ 331 មុនគ.ស អាឡិចសាន់ឌឺត្រួត្រាចក្រភពពែក្សទាំងស្រុង។

ការឈ្លានពានផ្សេងទៀតរបស់អាឡិចសាន់ឌឺ៖ នៅប៉ុន្មានឆ្នាំបន្ទាប់មក អាឡិចសាន់ឌឺបានរុញច្រានកងទ័ពរបស់ទ្រង់ឆ្ពោះទៅកាន់ភាគខាងកើត ដើម្បីឈ្លានពានតំបន់នានានៅអាស៊ីកណ្តាល។ នៅក្នុងឆ្នាំ 326 មុនគ.ស ពួកគេបានធ្វើដំណើរមកដល់តំបន់ជ្រលងទន្លេឥណ្ឌូស និងឥណ្ឌា។ អាឡិចសាន់ឌឺបានបង្ខំឱ្យកងទ័ពរបស់ទ្រង់បន្តធ្វើដំណើរឆ្ពោះទៅកាន់ភាគខាងកើត ប៉ុន្តែកងទ័ពរបស់ទ្រង់បានបដិសេធមិនបន្តដំណើរទៅមុខទៀតឡើយ។ ពួកគេបានប្រយុទ្ធអស់រយៈពេល 11 ឆ្នាំមកហើយ ហើយបានធ្វើដំណើរអស់ចម្ងាយរាប់ពាន់ម៉ាយពីផ្ទះ។ អាឡិចសាន់ឌឺត្រូវបានកងទ័ពទ្រង់បង្ខំឱ្យធ្វើដំណើរត្រឡប់ក្រោយវិញ។ នៅក្នុងឆ្នាំ 323 មុនគ.ស អាឡិចសាន់ឌឺ និងកងទ័ពរបស់ទ្រង់បានត្រឡប់មកកាន់បាប៊ីឡូនវិញ។ នៅពេលដែលពួកគេឈប់សម្រាក់នៅទីនោះ អាឡិចសាន់ឌឺ

បានធ្លាក់ខ្លួនឈឺជាមួយនឹងជម្ងឺគ្រុនក្តៅ ហើយទ្រង់ក៏បានសុគតនៅទីនោះទៅ។ នៅពេលនោះទ្រង់មានព្រះជន្ម 32 ព្រះវស្សា។ បើទោះបីជាទ្រង់មិនបានរស់នៅដល់ចាស់ក៏ដោយ ទ្រង់គឺជាអ្នកដែលរៀបចំបង្កើតបានជាចក្រភពដ៏ធំមួយ។ ដោយសារតែស្នាដៃដ៏អស្ចារ្យរបស់ទ្រង់ ទ្រង់ត្រូវបានគេចងចាំថា អាឡិចសាន់ឌឺដ៏អស្ចារ្យ។

អាឡិចសាន់ឌឺមិនមានពេលសម្រាប់បង្រួបបង្រួមចក្រភពរបស់ទ្រង់ឡើយ។ បន្ទាប់ពីទ្រង់សុគត មេដឹកនាំយោធានានារបស់ទ្រង់បានវាយប្រយុទ្ធគ្នាទៅវិញទៅមក ដើម្បីទទួលបានអំណាចគ្រប់គ្រងចក្រភព។ មិនមានឧត្តមសេនីយ៍របស់អាឡិចសាន់ឌឺមួយណាមានភាពខ្លាំងពូកែគ្រប់គ្រាន់ ដើម្បីត្រួតត្រាចក្រភពទាំងមូលឡើយ។ ជាយថាហេតុ ឧត្តមសេនីយ៍សំខាន់ៗ 3 រូបបានបែងចែកចក្រភព។

បែងចែកព្រឹត្តិការណ៍ៈ ពិពណ៌នាដោយសង្ខេបពីជំហាននានាដែលអាឡិចសាន់ឌឺបានប្រើដើម្បីស្ថាបនាចក្រភពរបស់ទ្រង់។

### 3. កេរ្តិ៍ដំណែលរបស់អាឡិចសាន់ឌឺ

សំណួរគន្លឹះៈ តើវប្បធម៌របស់ក្រិកលាយបញ្ចូលគ្នាជាមួយវប្បធម៌ដទៃទៀតដោយរបៀបណាដើម្បីបង្កើតបានជាវប្បធម៌ក្រិកចម្រុះ?

អាឡិចសាន់ឌឺ និងកងទ័ពរបស់ទ្រង់បាននាំយកវប្បធម៌ និងប្រពៃណីរបស់ពួកគេទៅកាន់គ្រប់ទីកន្លែងដែលពួកគេទៅដល់។ នៅពេលដែលអាឡិចសាន់ឌឺបានឈ្លានពានដែនដីពីមួយកន្លែងទៅមួយកន្លែង ទ្រង់បានបង្កើតអាណានិគមលើតំបន់នោះ។ ទ្រង់ក៏បានស្ថាបនារាជធានីនានាដែលផ្អែកទៅលើវប្បធម៌របស់ក្រិក។ ទ្រង់បានដាក់ឈ្មោះរាជធានីជាច្រើនតាមឈ្មោះរបស់ទ្រង់ ដែលរាជធានីទាំងនោះមានឈ្មោះថា អាឡិចសាន់ឌ្រៀ។ ប្រវត្តិវិទូឈ្មោះព្លូតាចដែលបានរស់នៅក្រិកប៉ុន្មានសតវត្សរ៍ក្រោយរាជ្យរបស់អាឡិចសាន់ឌឺ បានសរសេរថា អាឡិចសាន់ឌឺបានដាក់ឈ្មោះទីក្រុងចំនួន 70 ថាអាឡិចសាន់ឌ្រៀ។

វប្បធម៌ដែលលាយបញ្ចូលគ្នាៈ អាឡិចសាន់ឌឺបានដាក់ពួកក្រិកឱ្យគ្រប់គ្រងនៅដែនដីចក្រភពរបស់ទ្រង់។ ភាសាក្រិកបានក្លាយជាភាសាទូទៅនៅក្នុងដែនដីដែលទ្រង់គ្រប់គ្រង។ នៅក្នុងពេលជាមួយគ្នា អាឡិចសាន់ឌឺបានទទួលយកការស្លៀកពាក់ និងប្រពៃណីតាមបែបពែក្ស។ ទ្រង់បានបង្ខំឱ្យកងទ័ពរបស់ទ្រង់ធ្វើដូចទ្រង់។ ក្រុមអ្នកតាំងទីលំនៅជនជាតិក្រិកមួយចំនួនបានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីពែក្ស និងទទួលយករបៀបរបបរស់នៅតាមបែបពែក្ស។ នៅក្នុងប្រទេសអេហ្ស៊ីប មេដឹកនាំជនជាតិក្រិកបានទទួលយកវប្បធម៌របស់អេហ្ស៊ីប និងបានលាយបញ្ចូលវាជាមួយវប្បធម៌របស់ក្រិក។ នៅក្នុងប្រទេសឥណ្ឌា ការលាយបញ្ចូលគ្នានៃវប្បធម៌ដូចគ្នានេះក៏បានកើតឡើងផងដែរ។

ការលាយបញ្ចូលគ្នារវាងវប្បធម៌ និងប្រពៃណីរបស់ក្រិកជាមួយពែក្ស, អេហ្ស៊ីប, និងឥណ្ឌានេះត្រូវបានគេស្គាល់ថា វប្បធម៌ក្រិកចម្រុះ។ ពាក្យថាហេឡាសគឺជាភាសាក្រិកមានន័យថាប្រទេសក្រិក។ វប្បធម៌នេះនៅតែបន្តមានឥទ្ធិពលរាប់សតវត្សរ៍។

វប្បធម៌ចម្រុះបានជះឥទ្ធពលយ៉ាងសំខាន់ដល់ការសិក្សារៀនសូត្រ។ ការលាយបញ្ចូលគ្នានូវចំណេះដឹងរបស់ក្រិក, អេហ្ស៊ីប, អារ៉ាប់, និងឥណ្ឌាបាននាំទៅដល់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងឱសថសាស្ត្រ។

ទីក្រុងអាឡិចសាន់ដ្រៀ៖ ទីក្រុងល្បីល្បាញបំផុតនៃវប្បធម៌ក្រិកចម្រុះគឺ អាឡិចសាន់ដ្រៀ នៅប្រទេសអេហ្ស៊ីប ដែលអាឡិចសាន់ឌឺបានបង្កើតឡើងនៅក្នុងឆ្នាំ 332 មុនគ.ស។ ទីក្រុងនេះគឺជាមជ្ឈមណ្ឌលដ៏សំខាន់មួយសម្រាប់ការសិក្សាអស់រយៈពេល 400 ឆ្នាំ។ ប្រាសាទមូសេសនៅក្នុងទីក្រុងអាឡិចសាន់ដ្រៀដើរតួនាទីជាមជ្ឈមណ្ឌលស្រាវជ្រាវមួយសម្រាប់សិល្បៈ និងវិទ្យាសាស្ត្រ។ ប្រាសាទនេះត្រូវបានដាក់ឈ្មោះតាមមូសេស ដែលជាទេពធីតា 9 អង្គដែលគ្រប់គ្រងលើសិល្បៈ និងវិទ្យាសាស្ត្រផ្សេងៗគ្នា។ ប្រាសាទមូសេសមានភាពល្បីល្បាញដោយសារបណ្ណាល័យរបស់វា ដែលពេលខ្លះគេហៅថា បណ្ណាល័យអាឡិចសាន់ដ្រៀ។ នៅក្នុងបណ្ណាល័យនេះមានផ្ទុកនូវបណ្ដុំឯកសាររបស់ក្រិក, ពែក្ស, អេហ្ស៊ីប, ហេព្រូ, និងអត្ថបទផ្សេងៗទៀត។ អ្នកប្រាជ្ញមកពីតំបន់នានានៅជុំវិញតំបន់មេឌីទែរ៉ានេ និងអាស៊ីបានធ្វើដំណើរមកសិក្សានៅអាឡិចសាន់ដ្រៀ។ ផ្ទះបញ្ចាំងភ្លើងដ៏ធំមួយនៅកំពង់ផែអាឡិចសាន់ដ្រៀអាចមើលឃើញបានចម្ងាយ 35 ម៉ាយ។ វាត្រូវបានគេចាត់ទុកជាអច្ឆរិយៈវត្ថុមួយក្នុងចំណោមអច្ឆរិយៈវត្ថុបុរាណទាំង 7 ។

ស្វែករកគោលគំនិត៖ ពិពណ៌នាពីរបៀបដែលវប្បធម៌ក្រិកលាយបញ្ចូលគ្នាជាមួយវប្បធម៌ផ្សេងៗទៀតដែលបង្កើតបានជាវប្បធម៌ក្រិកចម្រុះ។

# មេរៀនទី 3 ៖ យុគមាសនៅក្នុងប្រទេសក្រិក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ បន្ទាប់ពីសង្គ្រាមពែក្សបានបញ្ចប់នៅក្នុងឆ្នាំ 479 មុនគ.ស អ្នកនិពន្ធ, សិល្បៈករ, និងស្ថាបត្យករជនជាតិក្រិកបានបង្កើតស្នាដៃឯកមួយចំនួនដែលមិនធ្លាប់មានពីមុនមក។ ស្នាដៃទាំងនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃវប្បធម៌លោកខាងលិច ដែលជាកេរ្ដិ៍ដំណែលរបស់ពួកអឺរ៉ុប និងសហរដ្ឋអាមេរិច។

## 1. សិល្បៈ និងស្ថាបត្យកម្ម

សំណួរគន្លឹះ៖ អ្វីទៅជាទម្រង់ទាំងពីរនៃល្ខោនរបស់ក្រិក ហើយទម្រង់ទាំងពីរនេះខុសគ្នាយ៉ាងដូចម្ដេច?

ពួកក្រិកបានបង្កើតល្ខោនធ្វើជាទម្រង់សិល្បៈមួយ។ ល្ខោនគឺជាស្នាដៃនិពន្ធមួយដែលរចនាឡើងសម្រាប់តួអង្គសម្ដែង។ ពួកក្រិកបានស្ថាបនារោងមហោស្រពដំបូងបំផុតនៅលោកខាងលិច។

ល្ខោន៖ ល្ខោនក្រិកគឺជាផ្នែកមួយនៃពិធីបុណ្យសាសនាទាំងឡាយនៅក្នុងទីក្រុង។ ប្រជាពលរដ្ឋមានទ្រព្យសម្បត្តិស្ដុកស្ដម្ភបានចំណាយលុយរបស់ពួកគេដើម្បីទំនុបបម្រុងដល់ផលិតកម្មល្ខោន។ អ្នកនិពន្ធដាក់ស្នើល្ខោនរបស់ពួកគេទៅកាន់មេដឹកនាំក្នុងទីក្រុង ក្រោយមកមេដឹកនាំក្នុងទីក្រុងធ្វើការជ្រើសរើសល្ខោនមួយចំនួនដែលល្អជាងគេសម្រាប់ការសម្ដែង។ បន្ទាប់មកល្ខោននីមួយៗត្រូវជ្រើសរើសក្រុមតួសម្ដែងសម្រាប់ផលិតកម្មរបស់ខ្លួន។ នៅពេលដែលល្ខោនសម្ដែង ការវាយតម្លៃត្រូវបានធ្វើឡើងដើម្បីផ្ដល់រង្វាន់ដល់អ្នកនិពន្ធដែលសរសេរល្ខោនបានល្អជាងគេ។

តួអង្គសម្ដែងល្ខោនសុទ្ធតែជាបុរសទាំងអស់ ដែលពួកគេក៏ដើរតួជាស្ត្រីផងដែរ។ តួអង្គពាក់សំលៀកបំពាក់និងរបាំងមុខមានពណ៌ស្រស់ឆើតឆាយដើម្បីពិពណ៌នាបុគ្គលិលក្ខណៈរបស់ពួកគេ។ ឆាកដែលរៀបចំឡើងក៏មានពណ៌ឆើតឆាយផងដែរ។ របាំមានសារៈសំខាន់ណាស់នៅក្នុងពិធីបុណ្យ និងការសម្ដែងល្ខោននៅក្រិក។ ជាទូទៅនៅក្នុងសម្ដែងល្ខោនតែងតែរួមបញ្ចូលឆាកមួយ ដែលក្រុមតួអង្គដ៏ច្រើនបានរាំ, ច្រៀង, និងសម្ដែងជាជួរ ដែលជាសកម្មភាពទូទៅនៅក្នុងការសម្ដែងល្ខោន។ ល្ខោនមានពីទម្រង់៖ សោកសៅ និងកំប្លែង។

សោកសៅ និងកំប្លែង៖ ទម្រង់ដំបូងគឺសោកសៅ គឺជាល្ខោនបែបសញ្ជិតសញ្ជឹងដែលបង្ហាញពីការធ្លាក់ខ្លួនរបស់បុគ្គលសំខាន់មួយ ដូចជាស្ដេចជាដើម។ គោលរឿងនៃល្ខោនសោកសៅ រួមមានសេចក្ដីស្រឡាញ់, សង្គ្រាម, សេចក្ដីក្រោធខឹង។

ល្ខោនការប្រឆាំង 7 លើកនៅថេបេសគឺជាឧទាហរណ៍មួយ។ នៅក្នុងការសម្ដែង ស្ដេចថេបេសបានការពាររាជធានីប្រឆាំងជាមួយការវាយប្រហារដែលដឹកនាំដោយព្រះរាមរបស់ទ្រង់។ បងប្អូនទាំងពីរនាក់គឺជាចៅរបស់ស្ដេចដំបូងបំផុតរបស់ថេបេសដែលបង្កឱ្យមានការដាក់បណ្ដាសារដល់ទីក្រុងនេះ ដោយសារតែការមិនគោរពដល់អាទិទេព។ នៅចុងបញ្ចប់នៃការសម្ដែង បងប្អូនទាំងពីរនាក់បានសម្លាប់គ្នាទៅវិញទៅមក ដែលនាំទៅដល់ការបញ្ចប់នៃបណ្ដាសារ។ ការប្រឆាំង 7 លើកនៅថេបេស សរសេរឡើងដោយអ៊ីឈីលូសអ្នកដែលរស់នៅចាប់ពីឆ្នាំ 525 ដល់ 456 មុនគ.ស។

ទម្រង់ល្ខោនទីពីរគឺកំប្លែងគឺជាការសម្តែងមួយដែលមើលទៅគួរឱ្យចង់សើច។ ក៏ដូចជារឿងកំប្លែងភាគច្រើននាពេលបច្ចុប្បន្ន រឿងកំប្លែងក្រិកសម័យបុរាណតែងតែចំអកលេងសើចទាក់ទងនិងនយោបាយ, មនុស្សសំខាន់ៗ, និងគំនិតអំពីពេលវេលា។ រឿងកំប្លែងជាទូទៅបញ្ចប់ជាមួយនឹងភាពសប្បាយរីករាយ។ អារីស្តូផានេសអ្នកដែលរស់នៅប្រហែលឆ្នាំ 450 ដល់ 388 មុនគ.ស គឺជាអ្នកនិពន្ធរឿងកំប្លែងដ៏ល្បីល្បាញមួយរូប។ ការសម្តែងមួយរបស់លោកគឺ សត្វស្លាប បានចំអកលេងសើចដល់ជនទាំងឡាយដែលខំប្រឹងយ៉ាងខ្លាំងដើម្បីទទួលបានអំណាច។ នៅក្នុងការសម្តែង ស្តេចមួយអង្គបានក្លាយជាសត្វស្លាប និងស្វែងរកទីក្រុងនៅលើមេឃ។ ទីក្រុងនោះត្រូវបានគេហៅថាដែនដីក្នុងក្តីសុបិន្ត។ វីរៈបុរសបានរារាំងមិនឱ្យអាទិទេពលូកដៃចូលក្នុងការគ្រប់គ្រងរបស់គាត់ ហើយបានប្រកាសខ្លួនលោកធ្វើជាស្តេចចក្រវាឡ។

ចម្លាក់៖ វិចិត្រករក្រិកមានគោលបំណងនៅក្នុងការបង្ហាញនូវគំនិតរបស់ពួកគេលើស្នាដៃចម្លាក់របស់ពួកគេ។ ក្នុងន័យម្យ៉ាងទៀត ពួកគេព្យាយាមនៅក្នុងការពិពណ៌នាអំពីវត្ថុនានា ដោយរួមទាំងមនុស្ស នៅក្នុងទម្រង់មួយដែលមានភាពល្អឥតខ្ចោះតាមតែអាចធ្វើទៅបាន។ វិចិត្រករព្យាយាមនៅក្នុងការបង្កើតគំនិតមួយអំពីភាពរៀបរាយ, ភាពស្រស់ស្អាត, និងភាពស៊ីសង្វាកគ្នានៅក្នុងគ្រប់ស្នាដៃរបស់ពួកគេ។

ដោយសារតែពួកក្រិកបានចំណាយពេលច្រើននៅខាងក្រៅផ្ទះ ស្នាដៃសិល្បៈភាគច្រើនគឺមានទីតាំងនៅកណ្តាលវាល។ សិល្បៈដែលធ្វើឡើងសម្រាប់ដាក់នៅកណ្តាលវាលជាទូទៅរចនាឡើងមានចំនួនច្រើន។ រូបបដិមាជនជាតិក្រិចជាច្រើនពិពណ៌នាអំពីអាទិទេព។ រូបបដិមាមួយចំនួនជាទូទៅត្រូវបានគេតំកល់នៅក្នុងប្រាសាទដែលស្ថាបនាឡើងដើម្បីឧទ្ទិសថ្វាយអាទិទេព។ បដិមាដែលល្បីល្បាញបំផុតមួយ ត្រូវបានគេបង្កើតឡើងដើម្បីឧទ្ទិសដល់អាទិទេពអាថេណា ដែលជាអាទិទេពការពារទីក្រុងអាតែន។ បដិមាករភីដៀសប្រើប្រាស់មាស និងភ្លុកដើម្បីធ្វើបដិមាអាថេណា។ បដិមានេះមានកម្ពស់ជាង 30 ហ្វីត។ បដិមានេះត្រូវបានគេដាក់តំកល់នៅក្នុងប្រាសាទមួយដែលគេហៅថាប៉ាថេនុន។

ស្ថាបត្យកម្ម៖ ស្ថាបត្យករក្រិកសម័យបុរាណបានរចនាប្រាសាទ, រោងមហោស្រប, ទីកន្លែងជួបប្រជុំ, និងគេហដ្ឋានរបស់ប្រជាពលរដ្ឋមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ពួកស្ថាបត្យករបានអនុវត្តតាមគោលការណ៍ស្រដៀងគ្នាទៅនឹងពួកជាងចម្លាក់។ ពួកគេធ្វើការដើម្បីបង្កើតសំណង់ដ៏ស្រស់ស្អាតនានាជាមួយនិងភាពសមសួន។ ស្ថាបត្យករក្រិកប្រើប្រាស់សមាសធាតុស្ថាបត្យកម្ម ឬផ្នែកផ្សេងៗជាច្រើនសម្រាប់សំណង់អាគារមួយ។ ធាតុដែលសំខាន់បំផុតនៃសំណង់អាគាររបស់ក្រិកគឺសសរ។ ជាទូទៅសសរមួយជុំនៃអាគារត្រូវបានគេហៅថា សសរស្តម្ភ ដែលគេដាក់ពីខាងក្រៅនៅជុំវិញអាគារសំណង់។ ផ្ទៃរាងត្រីកោណនៅចន្លោះរវាងចុងខាងលើសសរស្តម្ភ និងដំបូលគឺហៅថាហោជាង។ ភាគច្រើន រូបចម្លាក់ ឬរូបគំនូរត្រូវបានគេដាក់នៅលើហោជាងនៃអាគារ។ នៅក្នុងឆ្នាំ 447 មុនគ.ស ពេរីក្លេសបានចាត់តាំងស្ថាត្យករ ដើម្បីស្ថាបនាប្រាសាទប៉ាថេនុនដែលជាប្រាសាទមួយឧទ្ទិលដល់ទេពធីតាអាថេណា។ ពួកគេស្ថាបនាប្រាសាទប៉ាថេនុនជាមួយនឹងសសរស្តម្ភនៅជុំវិញជ្រុងទាំង 4 នៃប្រាសាទ ដែលជាទូទៅទម្រង់នៃស្ថាបត្យកម្មនេះត្រូវបានគេប្រើដើម្បីសាងសង់ប្រាសាទនៅក្រិក។ ភីដៀបានធ្វើការជាមួយស្ថាបត្យករ។ គាត់បាន

តែងលម្អហោជាងនៃប្រាសាទប៉ាថេនុនជាមួយនឹងចម្លាក់ដែលបង្ហាញពីជីវិតរស់នៅរបស់អាថេណា។ បដិមាទេពធីតាអាថេណាដែលគាត់បានឆ្លាក់ត្រូវបានគេដាក់តាំងនៅក្នុងប្រាសាទប៉ាថានុន។

ប្រៀបធៀប៖ បង្ហាញពីទម្រង់ល្ខោនក្រិកពីរ និងពិពណ៌នាពីភាពខុសប្លែកគ្នានៃទម្រង់ទាំងពីរនេះ។

## 2. ប្រជាធិបតេយ្យ, ប្រវត្តិវិទ្យា, និង ទស្សនវិទ្យា

សំណួរគន្លឹះ៖ តើវិធីសាស្ត្ររបស់ប្រវត្តិវិទូក្រិកធូស៊ីឌីដេសមានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះការសរសេរប្រវត្តិសាស្ត្រនាពេលបច្ចុប្បន្ន?

អ្នកនិពន្ធ និងទស្សនៈវិទូនៅក្នុងសម័យយុគមាសនៃក្រិកបានបង្កើតស្នាដៃមួយចំនួនដែលជាស្នាដៃដំបូង និងមានសារៈសំខាន់បំផុតនៃប្រវត្តិសាស្ត្រវិទ្យា និងទស្សនវិជ្ជា។ កេរ្តិ៍ដំណែលដ៏ល្អបំផុតរបស់ក្រិកដែលបានបន្សល់ទុកគឺគំនិតអំពីប្រជាធិបតេយ្យ ដែលប្រជាពលរដ្ឋនៃកន្លែងមួយគួរតែគ្រប់គ្រងរដ្ឋាភិបាលរបស់ពួកគេ។

ប្រជាធិបតេយ្យបានក្លាយជាការពិត៖ បន្ទាប់ពីបុរីអាតែនបានអភិវឌ្ឍប្រជាធិបតេយ្យ បុរីរដ្ឋផ្សេងៗទៀតរបស់ក្រិកក៏បានយកលំនាំរដ្ឋាភិបាលរបស់តាមទម្រង់របស់បុរីអាតែន។ បើទោះបីជាភាពជាប្រជាពលរដ្ឋ ជាទូទៅត្រូវបានកម្រិតត្រឹមតែបុរសដែលជាម្ចាស់កម្មសិទ្ធិដីធ្លីក៏ដោយ ក៏រដ្ឋាភិបាលទាំងនេះមានភាពបើកទូលាយ និងស្មើភាពជាងរដ្ឋាភិបាលផ្សេងៗដែលធ្លាប់មានកន្លងមក។ គំនិតរបស់ពួកក្រិកស្ដីអំពីរដ្ឋាភិបាលត្រូវបានយកលំនាំតាមដោយប្រទេសជាច្រើន ដោយក្នុងនោះមានទាំងសហរដ្ឋអាមេរិកផងដែរ។

ហេរ៉ូដូទឹស និងធូស៊ីឌីដេស៖ ពួកក្រិកស្ថិតនៅក្នុងចំណោមប្រទេសដែលមានអរិយធម៌ដំបូងៗដែលបានសរសេរប្រវត្តិសាស្ត្ររបស់ពួកគេ។ ពួកគេមិនត្រឹមតែប្រាប់អំពីតែរឿងរ៉ាវរបស់ពួកគេកាលពីអតីតកាលប៉ុណ្ណោះទេ។ ពួកគេពួកគេធ្វើការពិចារណាអំពីអតីតកាល និងព្យាយាមនៅក្នុងកំណត់អំពីការពិត និងសារៈសំខាន់នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានា។ លោកហេរ៉ូដូទឹសដែលបានរស់នៅចាប់ពីឆ្នាំ 484 ដល់ 425 មុនគ.ស ត្រូវបានគេហៅថា បិតាប្រវត្តិសាស្ត្រ។ គាត់មានចំណាប់អារម្មណ៍ចំពោះការសិក្សា និងកត់ត្រាអំពីរឿងរ៉ាវដែលទាក់ទងទងនឹងព្រឹត្តិការណ៍សំខាន់ៗ។ ក្នុងនាមលោកជាយុវជនមួយរូប លោកហេរ៉ូដូទឹសបានធ្វើដំណើរទៅគ្រប់ទីកន្លែង។ លោកបានសរសេរកំណត់ត្រាមួយស្ដីអំពីសង្គ្រាមពែក្ស ដែលគេហៅថាហ៊ីសស្តូរីមានន័យថាប្រវត្តិសាស្ត្រ។

ប្រវត្តិវិទូក្រិកមួយរូបទៀត លោកធូស៊ីឌីដេស រស់នៅប្រហែលឆ្នាំ 460 ដល់ 400 មុនគ.ស។ លោកបានសរសេរប្រវត្តិសាស្ត្រមួយស្ដីអំពីសង្គ្រាមប៉េឡូប៉ូនេស៊ី ខណៈពេលដែលសង្គ្រាមកំពុងនឹងបន្តកើតមាននៅឡើយ។ ដើម្បីបញ្ជាក់ឱ្យច្បាស់ថាកំណត់ត្រារបស់លោកត្រឹមត្រូវ លោកបានស្រាវជ្រាវឯកសារ និងព័ត៌មានពីសាក្សី។ វិធីសាស្ត្រនេះបានបង្កើតជាបទដ្ឋានមួយសម្រាប់ការសរសេរប្រវត្តិសាស្ត្រ ដែលគេបន្តប្រើរហូតមកដល់សព្វថ្ងៃ។

ការស្វែងរកសច្ចៈភាព៖ នៅដើមឆ្នាំ 600 មុនគ.ស ទស្សនវិទូក្រិកបានចាប់ផ្ដើមសាកល្បងពន្យល់ពីពិភពលោក ដោយប្រើនូវហេតុផលជាជាងទេវកថា។ អំឡុងនៃយុគមាស ការស្វែងរកការពន្យល់នេះ បានក្លាយជារឿងគួរឱ្យចាប់អារម្មណ៍ និងមានលក្ខណៈខ្លាំងក្លា។ នៅក្នុងការស្វែងរករបស់ពួកគេ ពួកក្រិកបានអភិវឌ្ឍ ទស្សនវិជ្ជា ឬ

ការសិក្សាអំពីមូលដ្ឋានគ្រឹះនៃសច្ចៈភាពអំពីចំណេះដឹង, តម្លៃ, និងពិភពលោក។ ទស្សនវិទូក្រិកធ្វើការស៊ើបអង្កេតទៅលើប្រធានបទជាច្រើន។ ពួកគេបានសួរសំណួរមួយចំនួន ដូចជា៖ តើមនុស្សម្នាក់ទទួលបានសុភមង្គលដោយរបៀបណា? តើទម្រង់រដ្ឋាភិបាលបែបណាដែលល្អបំផុត? អ្វីទៅជាចំណេះដឹង? សិស្សទស្សនវិទ្យានៅតែបន្តធ្វើការរិះគិតទៅលើប្រធានបទទាំងអស់នេះ។ ទស្សនវិទូក្រិកក៏បានសួរសំណួរមួយចំនួនដែលអ្នកវិទ្យាសាស្ត្រនានាធ្វើការសិក្សាស្រាវជ្រាវរហូតមកដល់សព្វថ្ងៃ ក្នុងនោះមានដូចជា៖ តើមានធាតុសំខាន់ៗអ្វីខ្លះដែលបង្កើតឱ្យមានបាតុភូតទាំងឡាយ? តើអ្វីទៅដែលធ្វើឱ្យមនុស្សម្នាក់រស់បាន?

សូក្រាត៖ ទស្សនវិទូក្រិកល្បីល្បាញបំផុតក្នុងចំណោមទស្សនវិទូទាំងឡាយរបស់ក្រិកគឺលោកសូក្រាត។ លោកបានលើកទឹកចិត្តឱ្យមនុស្សទាំងឡាយធ្វើការពិចារណាលើគំនិតរបស់ពួកគេ ដោយចោតសួរហើយសួរទៀត។ របៀបនៃការបង្រៀនដោយ សួរ-និង-ឆ្លើយ នេះត្រូវបានគេស្គាល់ថា វិធីសាស្ត្របែបសូក្រាត។ មនុស្សជាច្រើនចូលចិត្តការបង្រៀនរបស់សូក្រាត។ ប៉ុន្តែសត្រូវរបស់លោកបានចាប់លោកទៅកាត់ទោស ដោយចោទលោកពីបទបង្កឱ្យយុវជនងើបឡើងបះបោរ។ សូក្រាតបានប្រាប់ទៅចៅក្រមថា លោកចង់ជួយអាតែនតាមរយៈការដែលធ្វើឱ្យមនុស្សគិតអំពីតម្លៃ និងសកម្មភាពរបស់ពួកគេ។ ចៅក្រមមិនបានយល់ស្របទៅនឹងការបកស្រាយរបស់លោកឡើយ និងបានកាត់ទោសប្រហារជីវិតលោក។ លោកសូក្រាតស្លាប់ដោយការផឹកថ្នាំពុល ដែលគេហៅថាឈាមមានពិស។

លោកប្លាតូ និងអារីស្តូត៖ អ្នកដើរតាមសូក្រាតគឺលោកប្លាតូ។ លោករស់នៅប្រហែលឆ្នាំ 427 ដល់ 347 មុនគ.ស។ កំណត់ត្រាភាគច្រើនរបស់លោកប្លាតូ គឺកិច្ចសន្ទនា-ការជជែកគ្នារវាងលោកសូក្រាតជាមួយនិងមនុស្សផ្សេងៗ។ កិច្ចសន្ទនានេះបានផ្តល់ចម្លើយចំពោះសំណួរបែបទស្សនវិជ្ជាជាច្រើន។ លោកប្លាតូបានចាប់ផ្តើមសាលាសិក្សាជាន់ខ្ពស់ដ៏សំខាន់មួយ ដែលគេហៅថាបណ្ឌិតសភា។ សាលានេះបានបើកទ្វាអស់រយៈពេលប្រមាណ 900 ឆ្នាំ។ លោកអារីស្តូត គឺជាសិស្សជំនិតរបស់លោកប្លាតូ ដែលរស់នៅចាប់ពីឆ្នាំ 384 ដល់ 322 មុនគ.ស។ លោកបានបើកសាលាផ្ទាល់របស់លោកនៅអាតែន ដែលហៅថា បន្ទប់សម្តែងបាឋកថា។ កំណត់ត្រារបស់អារីស្តូត ដែលបានបង្ហាញនូវចម្លើយចំពោះសំណួរជាច្រើន គឺយោងទៅតាមការបង្អាត់បង្រៀនរបស់លោកនៅក្នុងថ្នាក់។ ក្នុងការបន្ថែមទៅលើស្នាដៃទស្សនវិជ្ជាដ៏ប្រសើររបស់លោក អារីស្តូតបានចំណាយពេល 3 ឆ្នាំបង្រៀនអាឡិចសាន់ឌឺ។

វាយតម្លៃ៖ ពន្យល់ថាតើវិធីសាស្ត្ររបស់ធូស៊ីឌីដេសបានជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះការសរសេររបស់អ្នកប្រវត្តិសាស្ត្រនាពេលបច្ចុប្បន្ន?

## 3. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

សំណួរគន្លឹះ៖ តើមុខវិជ្ជាអ្វីដែលអ្នកវិទ្យាសាស្ត្រ អ្នកគណិតសាស្ត្រហេឡេនបានសិក្សា?

ដូចដែលអ្នកបានអាននៅក្នុងមេរៀនទី 2 ការលាយបញ្ចូលគ្នារវាងវប្បធម៌របស់ក្រិក និងវប្បធម៌ផ្សេងៗទៀតបង្កើតបានជាវប្បធម៌ហេឡេន។ ពួកអ្នកប្រាជ្ញហេឡេនបានរក្សាការពារ និងពង្រីកនូវចំណេះវិទ្យាសាស្ត្រ និងគណិតសាស្ត្រដែលបានមកពីក្រិក, អេហ្ស៊ីប, និងឥណ្ឌា។ ត្រឹមទសវត្សរ៍ឆ្នាំ 200 មុនគ.ស ទីក្រុងអាឡិចសាន់ឌ្រៀ

នៅអេហ្ស៊ីបបានជំនួសដំណែងបុរីអាតែនដែលជាមជ្ឈមណ្ឌលវប្បធម៌ឈានមុខ។ អ្នកវិទ្យាសាស្ត្រភាគច្រើនដែលពិភាក្សានៅក្នុងផ្នែកនេះ រស់នៅក្នុងទីក្រុងអាឡិចសាន់ដ្រៀយ៉ាងហោចណាចក៏ពាក់កណ្តាលជីវិតរបស់ពួកគេដែរ។

តារាសាស្ត្រ៖ អ្នកវិទ្យាសាស្ត្រភាគច្រើននៅក្នុងទីក្រុងអាឡិចសាន់ដ្រៀបានសិក្សាពីតារាសាស្ត្រ ដែលជាវិទ្យាសាស្ត្រមួយធ្វើការស៊ើបអង្កេតអំពីភព និងផ្កាយ។ តារាវិទូ និងគណិតវិទូអឺរ៉ាតូស្តេនេស បានស្វែងរកឃើញវិធីមួយនៅក្នុងការប៉ាន់ប្រមាណអំពីប្រវែងរង្វង់មួយជុំផែនដី។ ការប៉ាន់ប្រមាណរបស់លោកត្រូវបានបង្ហាញថា មានលក្ខណៈប្រហាក់ប្រហែលទៅនឹងទំហំពិតប្រាកដរបស់ផែនដី។ តារាវិទូនៅទីក្រុងអាឡិចសាន់ដ្រៀមួយរូបទៀតឈ្មោះអារីស្តារឈូស បានព្យាយាមនៅក្នុងការបង្ហាញថាភពផែនដីធ្វើដំណើរវិលជុំវិញព្រះអាទិត្យ។ នៅក្នុងពេលជាមួយគ្នានោះ មានមនុស្សជាច្រើនជឿថា អ្វីៗគ្រប់យ៉ាងនៅក្នុងចក្រក្រវាបានធ្វើដំណើរវិលជុំវិញភពផែនដី។ លោកអារីស្តារឈូសបានព្យាយាមនៅក្នុងការប៉ាន់ប្រមាណអំពីទំហំរបស់ព្រះអាទិត្យ បើទោះបីជាលិទ្ធផលនៃការប៉ាន់ប្រមាណរបស់លោកបង្ហាញថាមានលក្ខណៈខុសឆ្ងាយពីទំហំពិតប្រាកដក៏ដោយ។

តារាវិទូលោកភ្តូឡេមី បានគាំទ្រគំនិតដែលថាភពផែនដីគឺជាចំណុចកណ្តាលនៃចក្រក្រវា។ លោកបានបង្កើតប្រព័ន្ធបែបគណិសាស្ត្រមួយដែលបរិយាយអំពីមុខងាររបស់ព្រះអាទិត្យ, ព្រះច័ន្ទ, និងភពផ្សេងៗទៀតដែលគេបានស្គាល់នៅពេលនោះ។ ប្រព័ន្ធរបស់លោកត្រូវបានតារាវិទូនានាយកមកប្រើអស់រយៈពេលប្រមាណ 1,400 ឆ្នាំ។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1500 ការរកឃើញកស្តុតាង និងចំណេះដឹងគណិសាស្ត្រថ្មីបានជួយឱ្យគេដឹងថាភពផែនដី និងភពផ្សេងៗទៀតធ្វើដំណើរវិលជុំវិញព្រះអាទិត្យ។

គណិតសាស្ត្រ និងរូបវិទ្យា៖ តារាវិទូត្រូវការដឹងពីភាពស្មុកស្មាញនៃគណិតសាស្ត្រដើម្បីធ្វើការងាររបស់ពួកគេ។ អ្នកវិទ្យាសាស្ត្រហេឡែន បានប្រើប្រាស់ចំណេះដឹងគណិសាស្ត្រដែលបានបង្កើតឡើងដោយពួកក្រិក និងគណិតវិទូហេឡែន។ គណិតវិទូក្រិក និងហេឡែនជាច្រើនមានជំនាញខាងធរណីមាត្រ ដែលជាការសិក្សាពីខ្សែបន្ទាត់, ត្រីកោណ, រង្វង់, ទម្រង់ផ្សេងៗទៀត។ គណិតវិទូអឺគ្លីដបានរៀបចំចងក្រងពីចំណេះដឹងធរណីមាត្រ និងចំណេះដឹងគណិតសាស្ត្រផ្សេងៗទៀតដែលគេរកឃើញពីមុនៗមក ទៅក្នុងសៀវភៅមួយឈុតដែលគេហៅថាជាតុ។ នៅក្នុងសៀវភៅទាំងនោះបានសរសេរនូវអំណះអំណាងបែបតក្កពន្យល់អំពីធរណីមាត្រ។ សៀវភៅជាតុរបស់អឺគ្លីដត្រូវបានគេយកមកប្រើធ្វើជាមូលដ្ឋានគ្រឹះនៃវគ្គសិក្សាធរណីមាត្ររហូតមកដល់ពេលបច្ចុប្បន្ន។ លោកអាឈីមេដេសបានពន្យល់អំពីច្បាប់នៃទម្ងន់។ ក្នុងនាមលោកជាអ្នកបង្កើតថ្មីមួយរូប លោកបានអភិវឌ្ឍកម្លាំងខ្សែរ៉ត។ លោកក៏ត្រូវបានគេជឿថាជាអ្នកបង្កើតឧបករណ៍មួយដើម្បីនាំយកទឹកបញ្ចូលក្នុងស្រែ។ គំនិតរបស់លោកអាឈីមេដេសត្រូវបានគេប្រើដើម្បីស្ថាបនាស្នប់ និងជាយថាហេតុបង្កើតបានជាម៉ាស៊ីនប្រើចំហាយទឹក។ គណិវិទូជាស្ត្រីដែលគួរឱ្យគត់សំគាល់ដំបូងគេគឺហីប៉ាទីដែលបង្រៀននៅទីក្រុងអាឡិចសាន់ដ្រៀ។ អ្នកស្រីហីប៉ាទីក៏ជាតារាវិទូផងដែរ។ អ្នកស្រីបានសរសេរអំពីកិច្ចការទាំងឡាយរបស់លោកភ្តូឡេមី និងលោកអឺគ្លីដ និងធរណីមាត្រផងដែរ។ អ្នកស្រីហីប៉ាទីក៏ជាអ្នកនាំមុខក្នុងការចលនាទស្សនមួយដោយផ្អែកលើកិច្ចការងាររបស់លោកប្លាតូ។

ស្វែងរកគោលគំនិត៖ ពិពណ៌នាមុខវិជ្ជាមួយចំនួនដែលអ្នកវិទ្យាសាស្ត្រ និងគណិតវិទូហេឡែនធ្វើការសិក្សា។

# ជំពូក 9 ៖ ចក្រភពរ៉ូមសម័យបុរាណ

## មេរៀនទី 1 ៖ សាធារណរដ្ឋរ៉ូម

ភ្ជាប់ទៅនឹងអ្វីដែលអ្នកបានដឹង៖ អ្នកប្រហែលជាធ្លាប់បានទស្សនាខ្សែភាពយន្តស្ដីអំពីរ៉ូមបុរាណ ជាមួយនឹង កីឡាដ្ឋាន និងអ្នកប្រយុទ្ធរបស់រ៉ូម។ ខ្សែភាពយន្តទាំងអស់នេះបានបង្ហាញពីភាពរីកចម្រើននៃចក្រភពរ៉ូម ប៉ុន្តែវាបានបង្ហាញយើងត្រឹមតែផ្នែកខ្លះនៃសាច់រឿងទាំងមូលប៉ុណ្ណោះ។ ការបង្កើតឡើងនៃអរិយធម៌មានចូលរួមចំណែកយ៉ាងច្រើនពីកត្តាទីតាំងភូមិសាស្ត្ររបស់ចក្រភពមួយនេះ។

### 1. ការចាប់ផ្ដើមឡើងដំបូងនៃចក្រភពរ៉ូម

សំណួរគន្លឹះ៖ តើអ្វីទៅជាប្រវត្តិសាស្ត្រដំបូងរបស់រ៉ូម?

ប្រវត្តិសាស្ត្ររ៉ូមសម័យបុរាណចាប់ផ្ដើមជាមួយនឹងការទម្លាក់ស្ដេចបរទេសនៅក្នុងឆ្នាំ 509 មុនគ.ស។ ប៉ុន្តែពួករ៉ូមហាក់ដូចជាចង់កំណត់យកការចាប់ផ្ដើមប្រវត្តិសាស្ត្ររបស់ពួកគេនៅឆ្នាំ 753 មុនគ.ស។ ដែលនៅក្នុងឆ្នាំនោះ មានវីរៈបុរសក្នុងរឿងព្រេងមួយរូប ដែលត្រូវបានគេហៅថា រ៉ូម៉ូលូសដែលត្រូវបានគេនិយាយថា ជាអ្នកបង្កើតរ៉ូម។ រឿងព្រេងនេះគឺជារឿងបែបប្រជាប្រិយមួយដែលបង្កើតឡើងតាំងពីសម័យបុរាណ ដែលគេមិនអាចបញ្ជាក់ថាជាការពិតបានទេ។ រឿងព្រេងស្ដីអំពីការបង្កើតរ៉ូមចាប់ផ្ដើមជាមួយនិងអ៊ីនាសដែលជាវីរៈបុរសមួយរូបនៅក្នុងសង្គ្រាមត្រូយ លោកបានរស់នៅក្នុងប្រទេសអ៊ីតាលីបន្ទាប់ពីរដ្ឋត្រូយត្រូវបានកម្ទិច។ អ្នកធ្លាប់បានរៀនពីសង្គ្រាមត្រូយនៅមេរៀនមុនរួចមកហើយ។

ការបង្កើតរ៉ូម៖ រឿងព្រេងបានបន្តជាមួយនឹងកូនភ្លោះពីរនាក់ឈ្មោះរ៉ូម៉ូលូស និងរ៉េម៉ូសដែលជាបុព្វការីជនរបស់អ៊ីនាសដែលជាអ្នកបង្កើតរ៉ូម។ ពួកគេត្រូវបានបំបោះបង់ចោលដោយម្ដាយរបស់ពួកគេ ប៉ុន្តែត្រូវបានជួយសង្គ្រោះដោយឆ្កែចចកមួយក្បាល។ នៅពេលដែលកូនភ្លោះទាំងពីរធំឡើង ពួកគេធ្វើការប្រយុទ្ធគ្នានៅលើដែនដីរ៉ូម។ រ៉ូម៉ូលូសបានសម្លាប់បងប្អូនភ្លោះរបស់លោក និងបានគូសបន្ទាត់ព្រុំប្រទល់របស់រ៉ូមនៅជុំវិញភ្នំប៉ាឡាទីន។

បន្ទាប់ពីរ៉ូម៉ូលូស មានស្ដេចរ៉ូមជាច្រើននាក់ទៀតដឹកនាំទីក្រុងនេះ។ ប៉ុន្តែ នៅក្នុងទសវត្សរ៍ឆ្នាំ 600 មុនគ.ស ពួកអ៊ីទ្រូស្កេនដែលធ្វើដំណើរមកពីភាគខាងជើងប្រទេសអ៊ីតាលីបានធ្វើការឈ្លានពានរ៉ូម។ ដើម្បីទទួលបានការគ្រប់គ្រងប្រទេសដោយខ្លួនឯង ពួករ៉ូមបានទម្លាក់ស្ដេចអ៊ីទ្រូស្កេននិងបានបង្កើតសាធារណរដ្ឋមួយនៅក្នុងឆ្នាំ 509 មុនគ.ស។ រដ្ឋសាធារណរដ្ឋគឺជារដ្ឋដែលរដ្ឋាភិបាលត្រូវបានប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសធ្វើជាតំណាងរបស់ខ្លួនក្នុងការដឹកនាំប្រទេស។

សង្ខេប៖ ពិពណ៌នាពីប្រវត្តិសាស្ត្រដំបូងរបស់រ៉ូម។

### 2. ទីតាំងភូមិសាស្ត្ររបស់រ៉ូម និងជីវភាពរស់នៅដំបូង

សំណួរគន្លឹះ៖ ហេតុអ្វីបានជាទីតាំងភូមិសាស្ត្ររបស់រ៉ូមគួរជាទីចាប់អារម្មណ៍?

បន្ទាប់ពីការទម្លាក់ស្ដេចអ៊ីទ្រូស្កេន រ៉ូមបានពង្រីកពីទីក្រុងក្លាយជាប្រទេសមួយ និងក្រោយមកជាយថាហេតុក្លាយជាចក្រភពមួយ។ ទីតាំងភូមិសាស្ត្រដ៏ល្អប្រសើររបស់ពួកគេបានជួយដល់ការពង្រឹងអំណាចនេះ។

ជ្រលងភ្នំទាបៗ និងទន្លេ៖ ក្រុមអ្នកតាំងទីលំនៅដំបូងនៅរ៉ូមគឺពួកឡាទីន។ ពួកគេបានធ្វើដំណើរមកពីតំបន់នានានៅជុំវិញរ៉ូម។ ពួកគេជ្រើសរើសតំបន់នេះដោយសារតែតំបន់នេះមានអាកាសធាតុល្អ, មានផ្ទៃដីដាំដុះល្អ, និងជាទីតាំងយុទ្ធសាស្ត្រ។ ពួកឡាទីន និងអ្នកតាំងទីលំនៅក្រោយៗទៀតបានស្ថាបនារ៉ូមនៅលើភ្នំស្រួច 7 ។ នៅពេលថ្ងៃក្រុមអ្នកតាំងទីលំនៅបានធ្វើស្រែរបស់ពួកគេនៅតំបន់វាលទំនាប ដែលសំបូរដោយជីជាតិដែលស្ថិតនៅតាមជើងភ្នំ។ នៅពេលយប់ ពួកគេត្រឡប់មកកាន់ទីលំនៅរបស់ពួកគេនៅលើកំពូលភ្នំ ដែលការធ្វើផ្ទះនៅលើភ្នំនេះអាចជួយការពារពួកគេពីការវាយប្រហារពីសត្រូវ។ រ៉ូមមានគុណសម្បត្តិផ្សេងៗទៀត។ វាមានទីតាំងស្ថិតនៅជិតផ្លូវពាណិជ្ជកម្មតាមសមុទ្រមេឌីទែរ៉ានេ។ វាក៏មានលាតសន្ធឹងនៅក្បែរទន្លេទីប័រ។ ទន្លេនេះមានសារៈសំខាន់ណាស់ដល់ការអភិវឌ្ឍនៅរ៉ូម ដោយសារតែវាបានផ្ដល់នូវប្រភពទឹកសម្រាប់ការធ្វើកសិកម្ម និងការប្រើប្រាស់ប្រចាំថ្ងៃ។

ឧបទ្វីបអ៊ីតាលី៖ ទីតាំងស្ថិតនៅលើឧបទ្វីបអ៊ីតាលីរបស់រ៉ូម ក៏បានដើរតួនាទីដ៏សំខាន់នៅក្នុងការអភិវឌ្ឍប្រទេសនេះដែរ។ ឧបទ្វីបអ៊ីតាលីលាតសន្ធឹងទៅភាគខាងត្បូងចាប់ពីអឺរ៉ុបទៅកាន់សមុទ្រមេឌីទែរ៉ានេ។ ទីតាំងស្ថិតនៅជិតមហាសមុទ្រមេឌីទែរ៉ានេរបស់រ៉ូម បានធ្វើឱ្យមានភាពងាយស្រួលសម្រាប់ការធ្វើដំណើររបស់នាវាពួករ៉ូមទៅកាន់ដែនដីផ្សេងៗទៀតនៅជុំវិញសមុទ្រ។ ទីតាំងនេះបានជួយដល់រ៉ូមក្នុងការឈ្លានពាន និងកាន់កាប់ដែនដីថ្មី។ វាក៏ជួយជ្រោមជ្រែងដល់ការអភិវឌ្ឍផ្លូវពាណិជ្ជកម្មផងដែរ។

ជួរភ្នំសំខាន់ៗពីរនៅអ៊ីតាលីបានជួយការពារពួករ៉ូម។ ជួរភ្នំអាពស្ថិតនៅព្រំដែនអ៊ីតាលីភាគខាងជើង និងជួរភ្នំអាពេននីនេសបង្កើតបានជាឆ្អឹងខ្នងរបស់អ៊ីតាលី ដែលមានប្រវែងជាង 800 ម៉ាយលាតសន្ធឹងកាត់ឧបទ្វីបអ៊ីតាលី។ អ៊ីតាលីក៏មានតំបន់វាលទំនាបដ៏ធំមួយដែលមានលក្ខណៈល្អប្រសើរសម្រាប់ការដាំដុះ។

ជីវិតរស់នៅដោយការដាំដុះ៖ ភាគច្រើននៃប្រជាជនរ៉ូមដំបូងដាំដុះនៅលើដីដែលមានទំហំតូចៗ។ ពួកគេដាំដុះដំណាំធញ្ញជាតិដូចជាស្រូវសាលី និងស្រូវប៉ាឡេជាដើម, ហើយពួកគេក៏ដាំដុះសណ្ដែក, បន្លែ, និងផ្លែឈើផងដែរ។ ក្រោយមកពួករ៉ូមមានរៀនដាំដុះដើមអូលីវ និងទំពាំងបាយជូរ។ ពួកគេចិញ្ចឹមជ្រូក, ពពែ, ចៀម, មាន់, ហើយពួកគេប្រើសត្វគោដើម្បីអូសនង្គ័លរបស់ពួកគេ។ នៅក្នុងប្រទេសរ៉ូមសម័យបុរាណ មានតែកសិករដែលមានទ្រព្យសម្បត្តិច្រើនប៉ុណ្ណោះដែលដាំដុះទំពាំងបាយជូរ ដោយសារពួកគេអាចមានលទ្ធភាពរងចាំការប្រមូលផលកសិផលលើកដំបូងរបស់ខ្លួនបានដល់ 2 ទៅ 3 ឆ្នាំ។ នៅដើមដំបូង ប្រជាកសិកររ៉ូមភាគច្រើនរស់នៅក្នុងផ្ទះសាមញ្ញ ដែលធ្វើឡើងពីដីឥដ្ឋ ឬឈើ។ នៅក្នុងផ្ទះរបស់ពួកគេមិនមានគ្រឿងសង្ហារឹមច្រើនទេ។ ប្រជាកសិកររ៉ូមរស់នៅជាលក្ខណៈគ្រួសារធំ ដែលមានជីដូនជីតា, ពូមីង, ក្មួយប្រុសក្មួយស្រី, និងជីដូនមួយ។ គុណភាពនៃបទវិន័យ, ភក្ដីភាព, និងការធ្វើការងារសកម្មដែលពួកប្រជាកសិករទាំងនេះបានអភិវឌ្ឍឡើងបានជួយនាំរ៉ូមទៅរកភាពជោគជ័យ។ វាគឺជាគុណភាពដែលបានធ្វើឱ្យកងទ័ពរ៉ូមទទួលបានជោគជ័យ។ នៅពេលដែលកងទ័ពទៅធ្វើសង្គ្រាម ពួកគេត្រូវតែ

គោរពបទបញ្ជា និងបំពេញការងាររបស់ពួកគេ។ អាកប្បកិរិយាបែបនេះបានជួយដល់រ៉ូមនៅក្នុងការដណ្តើមកាន់កាប់ដែនដីទាំងអស់នៅអ៊ីតាលី។

សង្ខេប៖ ពិពណ៌នាពីកត្តាដែលធ្វើឱ្យទីតាំងរបស់រ៉ូមក៏ជាទីចាប់អារម្មណ៍។

### 3. ការលេចឡើងនៃសាធារណរដ្ឋ

សំនួរគន្លឹះ៖ តើសាខាសំខាន់ទាំង 3 នៃសាធារណរដ្ឋរ៉ូមមានអ្វីខ្លះ ?

ដូចដែលរ៉ូមបានអភិវឌ្ឍទៅជាប្រទេសដែលមានអរិយធម៌ស្មុគស្មាញមួយ វណ្ណៈពីរបានលេចឡើង។ វិសមភាពនៃវណ្ណៈទាំងពីរនេះបាននាំទៅដល់ជម្លោះ។ ប៉ុន្តែជម្លោះនេះដោយថាហេតុបានជួយកំណត់អំពីភាពជាប្រជាពលរដ្ឋរ៉ូម និងសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលស្ថិតនៅក្រោមច្បាប់រ៉ូម។ អស់រយៈពេលប្រមាណ 500 ឆ្នាំ ពួករ៉ូមបានអនុវត្តប្រព័ន្ធនយោបាយមួយដែលបានដើរតួនាទីជាប្រព័ន្ធគំរូមួយសម្រាប់ប្រទេសប្រជាធិបតេយ្យជាច្រើននាពេលបច្ចុប្បន្ន។

ប៉ាទ្រីសៀន និងប្លេបៀន៖ នៅរ៉ូមសម័យបុរាណ វណ្ណៈជាន់ខ្ពស់ប៉ាទ្រីសៀនគឺជាវណ្ណៈរបស់ពួកម្ចាស់កម្មសិទ្ធិដីធ្លីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដែលមានតួនាទីជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាល។ ពួកប្លេបៀន គឺជាប្រជាជនសាមញ្ញ ដែលត្រូវបានគេអនុញ្ញាតឱ្យបោះឆ្នោត ប៉ុន្តែមិនមានតំណែងនៅក្នុងជួររដ្ឋាភិបាលរ៉ូមសម័យបុរាណឡើយ។ ការអាក់អន់ចិត្តចំពោះអំណាចរបស់ពួកប៉ាទ្រីសៀនបានបង្កឱ្យមានជម្លោះ។ ចុងក្រោយ ពួកប៉ាទ្រីសៀនបានអនុម័តធម្មនុញ្ញមួយដែលគេហៅថា តារាង 12 នៅរង្វង់ឆ្នាំ 450 មុនគ.ស។ តារាង 12 បានបង្កើតសិទ្ធិជាមូលដ្ឋានគ្រឹះ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋរ៉ូម។

រដ្ឋាភិបាលបែបសាធារណរដ្ឋ៖ មេដឹកនាំសាធារណរដ្ឋរ៉ូមបានបង្កើតរដ្ឋាភិបាលបែកជា 3 ផ្នែក។ រដ្ឋាភិបាលប្រភេទនេះមានស្ថាប័នអំណាចកំពូល 3 ៖ និតិបញ្ញត្តិ, តុលាការ, និងនិតិប្រតិបត្តិ។ ស្ថាប័ននិតិបញ្ញត្តិគឺជាអ្នកបង្កើតច្បាប់។ ស្ថាប័នតុលាការធ្វើការបកស្រាយច្បាប់នៅក្នុងការជុំនំជម្រះក្តី។ និងស្ថាប័ននិតិប្រតិបត្តិគឺជាអ្នកប្រតិបត្តិច្បាប់របស់ប្រទេស។

ស្ថាប័នកំពូលទាំង 3 ៖ ស្ថាប័ននិតិបញ្ញត្តិរបស់រដ្ឋាភិបាលរ៉ូមរួមមានព្រឹទ្ធសភា និងរដ្ឋសភា។ ព្រឹទ្ធសភាគឺជាស្ថាប័នដែលមានអំណាចកំពូល មានសមាជិក 300 នាក់ធ្វើការប្រឹក្សាយោបល់ដល់មេដឹកនាំរ៉ូម។ ភាគច្រើននៃសមាជិកព្រឹទ្ធសភាគឺពួកប៉ាទ្រីសៀន។ នៅក្នុងរដ្ឋសភាសមាជិកភាគច្រើនគឺពួកប្លេបៀន។ ពួកគេគឺជាតំណាងរាស្ត្រដែលជួយការពារសិទ្ធិរបស់ពួកប្លេបៀន។

ស្ថាប័នតុលាការរួមមានចៅក្រមចំនួន 8 រូបដែលបម្រើការក្នុងអាណត្តិមួយឆ្នាំ។ ពួកគេជាអ្នកកាត់ក្តីនៅក្នុងតុលាការ និងគ្រប់គ្រងតាមខេត្ត។ កុងស៊ុល 2 រូបដឹកនាំស្ថាប័ននិតិប្រតិបត្តិរបស់រ៉ូម។ ពួកគេដឹកនាំកងទ័ព និងដឹកនាំរដ្ឋាភិបាលក្នុងអាណត្តិមួយឆ្នាំ។ កុងស៊ុលម្នាក់មានអំណាចនៅក្នុងការវេតូ ឬបដិសេធទៅលើសំណើររបស់កុងស៊ុលម្នាក់ទៀត។

នៅក្នុងពេលដែលមានវិបត្តិ កុងស៊ុលទាំង 2 អាចជ្រើសរើសមេដឹកនាំផ្តាច់ការមួយរូប(មេដឹកនាំដែលមានអំណាចផ្តាច់មុខ) ដើម្បីដឹកនាំជំនួសកន្លែងរបស់ពួកគេក្នុងពេលកំណត់ណាមួយ។ នៅក្នុងឆ្នាំ 458 មុនគ.ស បុរសម្នាក់ឈ្មោះស៊ីនស៊ីនណាទឹស ត្រូវបានគេជ្រើសរើសឱ្យធ្វើជាមេដឹកនាំអំណាចផ្តាច់មុខដើម្បីការពាររ៉ូមពីការវាយប្រហារ។ យោងតាមរឿងព្រេង លោកបានយកជ័យជំនះលើសត្រូវ និងបានប្រគល់អំណាចឲ្យទៅកុងស៊ុលវិញនៅប៉ុន្មានថ្ងៃក្រោយមក។

ធ្វើចំណាត់ថ្នាក់៖ ពិពណ៌នាស្ថាប័នអំណាចកំពូលទាំង 3 នៃសាធារណរដ្ឋរ៉ូម។

## 4. ការពង្រីកសាធារណរដ្ឋ

សំណួរគន្លឹះ៖ អ្វីទៅជាលទ្ធផលនៃការពង្រីកអំណាចរបស់រ៉ូម?

អស់រយៈពេលជាច្រើនសតវត្សបន្ទាប់ពីការបង្កើតសាធារណរដ្ឋរ៉ូម ពួករ៉ូមបានពង្រីកទឹកដីរបស់ខ្លួន។ ត្រឹមទសវត្សរ៍ឆ្នាំ 300 ពួករ៉ូមបានគ្រប់ដណ្តប់លើអ៊ីតាលីភាគកណ្តាល។ ដោយថាហេតុ ពួកគេដណ្តើមកាន់កាប់អ៊ីទ្រូស្កេននៅភាគខាងជើង និងបុរី-រដ្ឋរបស់ពួកក្រិកនៅភាគអាគ្នេយ៍។ ត្រឹមឆ្នាំ 275 មុនគ.ស ឧបទ្វីបអ៊ីតាលីទាំងមូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួករ៉ូម។

ជាទូទៅ រ៉ូមមិនបានអនុវត្តការគ្រប់គ្រងឃោរឃៅលើប្រជាជនដែលរស់នៅលើដែនដីដែលពួកគេដណ្តើមកាន់កាប់ឡើយ។ សាធារណរដ្ឋរ៉ូមមានប្រគល់សញ្ជាតិរ៉ូមដល់ពួកគេភាគច្រើន និងអនុញ្ញាតឱ្យពួកគេដឹកនាំដោយខ្លួនឯង។ ក្នុងការតបស្នង ប្រជាពលរដ្ឋថ្មីត្រូវបង់ពន្ធ និងផ្តល់យោធាដល់ពួករ៉ូម។

សង្គ្រាមពូនិច៖ រ៉ូមត្រូវការកងទ័ពទាំងអស់នេះដើម្បីវាយប្រយុទ្ធនៅក្នុងសង្គ្រាមពូនិចដែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 264 មុនគ.ស។ សង្គ្រាមនេះកើតឡើង 3 លើកជាមួយនឹងពួកខាថេកដែលជាទីក្រុងពាណិជ្ជកម្មល្បីល្បាញមួយអាហ្វ្រិកខាងជើង។ ខាថេកគឺជាតំបន់មួយដែលស្ថិតនៅក្រោមអាណានិគមរបស់ពួកផូនីសៀ ដែលជាបុរី-រដ្ឋមួយក្រុមស្ថិតនៅសមុទ្រមេឌីទែរ៉ាណេ ដែលជំនាញនៅក្នុងការធ្វើពាណិជ្ជកម្មតាមសមុទ្រ។ ពាក្យថាពូនិចមកពីភាសាក្រិកថាផូនីសៀ។ ពួករ៉ូមឈ្នះរាល់ការប្រយុទ្ធទាំង 3 លើក ប៉ុន្តែស្ទើរតែចាប់នៅក្នុងការប្រយុទ្ធគ្នាលើកទី 2 ។ ហានីបាល់ដែលជាឧត្តមសេនីយ៍មួយរូបមកពីខាថេកបានឆ្លងកាត់តំបន់អាពជាមួយនឹងហ្វូងដំរី ហើយស្ទើរតែដណ្តើមកាន់កាប់រ៉ូមបាន។ ឧត្តមសេនីយ៍របស់រ៉ូមឈ្មោះស្គីពីអូ បានបង្កើតគម្រោងមួយដើម្បីវាយប្រហារលើពួកខាថេក។ គម្រោងវាយប្រហារនេះបានបង្ខំឱ្យហានីបាល់វិលត្រឡប់ទៅអាហ្វ្រិចវិញដើម្បីការពារទីក្រុងកំណើតរបស់ពួកគេ។ នៅក្នុងឆ្នាំ 202 មុនគ.ស នៅតំបន់ហ្សាម៉ានៅជិតខាថេក ពួករ៉ូមចុងបញ្ចប់បានវាយប្រយុទ្ធយកជ័យជំនះលើហានីបាល់។

នៅក្នុងឆ្នាំ 146 មុនគ.ស នៅក្នុងសង្គ្រាមពូនិចលើកទី 3 រ៉ូមបានឡោមព័ទ្ធខាថេក។ ចុងក្រោយរ៉ូមបានដណ្តើមកាន់កាប់ និងកម្ទិចទីក្រុងខាថេក។ ទីក្រុងខាថេកត្រូវបានដុតកម្ទិច ហើយប្រជាជននៅទីនោះ 5 ម៉ឺននាក់ត្រូវបានលក់ឱ្យធ្វើជាទាសករ។ ទឹកដីខាថេកត្រូវបានបញ្ចូលទៅជាខេត្តមួយរបស់រ៉ូម។ ជ័យជំនះរបស់រ៉ូមនៅក្នុងសង្គ្រាម

ពូនិច បានផ្តល់ឱ្យពួកគេនូវការគ្រប់ដណ្តប់ការគ្រប់គ្រងនៅតំបន់ភាគខាងលិចសមុទ្រមេឌីទែរ៉ាណេ។ ពួករ៉ូមនៅពេលនោះចាប់ផ្តើមធ្វើការឈ្លានពានតំបន់ភាគខាងកើតពាក់កណ្តាលទៀត។ ដោយថាហេតុចក្រភពរ៉ូមនៅតំបន់មេឌីទែរ៉ាណេបានលាតសន្ធឹងពីក្រិកនៅភាគខាងកើតដល់ឧបទ្វីបអ៊ីបេរៀននៅភាគខាងលិច។

ឥទ្ធិពលនៃការពង្រីកដែនដី៖ ក្រុមអ្នកឈ្លានពានរបស់រ៉ូមបាននាំត្រឡប់មកវិញនូវទ្រព្យសម្បត្តិ និងទាសករជាច្រើន។ ពួកគេបានទិញដីស្រែធំៗ និងដាំដុះលើដីស្រែនោះដោយប្រើទាសកររបស់ពួកគេ។ ប៉ុន្តែ ដោយសារតែប្រជាកសិករធ្វើស្រែតូចតាចមិនអាចប្រជែងជាមួយពួកគេបាន ពួកគេបានបាត់បង់ដីស្រែរបស់ពួកគេ។ ជាលទ្ធផល ចំនួនអ្នកអត់ការងារធ្វើ និងភាពក្រីក្របានកើនឡើង។ គម្លាតរបស់អ្នកមាន និងអ្នកក្របានកើនឡើងខ្ពស់។ ការនេះ បាននាំទៅដល់ការកើនឡើងនៃកំហឹង និងជម្លោះរបស់វណ្ណៈទាំងពីរនេះ។ ដូចដែលអ្នកនឹងអាននៅក្នុងមេរៀនបន្ទាប់ មូលហេតុនេះក្នុងចំណោមមូលហេតុផ្សេងៗទៀតដែលរួមចំណែកដល់ការផ្តួលរំលំសាធារណរដ្ឋរ៉ូម។

វិភាគអំពីឥទ្ធិពល៖ វិភាគអំពីលទ្ធផលនៃការពង្រីកដែនដីរបស់ពួករ៉ូម។

# មេរៀនទី 2 ៖ រ៉ូមក្លាយជាចក្រភពមួយ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងមេរៀនមុន អ្នកបានរៀនអំពីការពង្រីកទឹកដីនាំទៅដល់ការប្រែប្រួលសង្គមរបស់ពួករ៉ូម។ ការពង្រីកទឹកដីក៏នឹងផ្លាស់ប្តូរតុល្យភាពនៃអំណាចនៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋរ៉ូមផងដែរ។ ការផ្លាស់ប្តូរនេះបាននាំទៅដល់ការដួលរលំនៃសាធារណរដ្ឋ។

## 1. ជម្លោះនៅក្នុងប្រទេស

សំណួរគន្លឹះ៖ មូលហេតុអ្វីដែលនាំឱ្យកើតមានជម្លោះនៅរ៉ូម?

ដូចដែលទឹកដីរ៉ូមបានរីកធំ អ្នកមានទ្រព្យសម្បត្តិរ៉ូមជាច្រើនបោះបង់កាតព្វកិច្ចពលរដ្ឋរបស់ពួកគេ។ ពួកគេគិតតែពីធ្វើយ៉ាងមិចដើម្បីទទួលបានអំណាច និងទ្រព្យសម្បត្តិកាន់តែច្រើន។ ការនេះ បាននាំទៅដល់ការកើនឡើងនៃគម្លាតរវាងអ្នកមាននិងអ្នកក្រ។ ជាលទ្ធផល ការគំរាមកំហែងពីការបះបោរបានកើនឡើង ដូចដែលប្រជាជនសាមញ្ញមិនសប្បាយចិត្តកាន់តែខ្លាំងឡើងចំពោះអំណាច និងឯកសិទ្ធិរបស់ពួកអ្នកមាន។

ការធ្វើកំណែទម្រង់បរាជ័យ៖ ក្រុមអ្នកធ្វើកំណែទម្រង់បានព្យាយាមនៅក្នុងការធ្វើឱ្យបញ្ហាទាំងអស់នេះធូរស្រាល។ ពួកគេចង់ធ្វើការបំបែកដីធ្លីធំៗ ហើយបែងចែកទៅឱ្យអ្នកក្រ។ ប៉ុន្តែម្ចាស់កម្មសិទ្ធិដីធ្លីដែលមានទ្រព្យសម្បត្តិនៅក្នុងព្រឹទ្ធសភាមួយចំនួនយល់ថាការធ្វើដូច្នេះវាគឺជាការគំរាមកំហែងមួយ។ ពួកគេប្រឆាំងទៅនឹងការធ្វើកំណែទម្រង់ និងបានសម្លាប់ក្រុមអ្នកធ្វើកំណែទម្រង់។

សង្គ្រាមស៊ីវិល៖ នៅក្នុងពេលជាមួយគ្នានោះ ឧត្តមសេនីយ៍នានាដែលបានដណ្តើមកាន់កាប់ដែនដីផ្សេងៗចាប់ផ្តើមមានមហិច្ឆិតាចង់ទទួលបានអំណាចកាន់តែច្រើននៅរ៉ូម។ ពួកគេបានជួលប្រជាកសិករក្រីក្រឱ្យធ្វើជាទាហានស្ថិតនៅក្រោមបញ្ជារបស់ពួកគេ។ បន្តិចម្តងៗ កងទាហានទាំងអស់នេះបានផ្លាស់ប្តូរភក្តីភាពរបស់ពួកគេពីសាធារណរដ្ឋទៅឧត្តមសេនីយ៍របស់ពួកគេ។ ការចង់បានអំណាចរបស់ពួកឧត្តមសេនីយ៍បាននាំទៅដល់ជម្លោះ។ ជាយថាហេតុ សង្គ្រាមស៊ីវិលបានផ្ទុះឡើង។ សង្គ្រាមស៊ីវិលគឺជាជម្លោះប្រដាប់អាវុធរវាងលក្រុមផ្សេងៗនៅក្នុងប្រទេសតែមួយ។ នៅផ្នែកម្ខាងគឺជាក្រុមឧត្តមសេនីយ៍ដែលគាំទ្រដោយពួកប្លេបៀន។ ក្រុមម្ខាងទៀតគឺជាឧត្តមសេនីយ៍ដែលគាំទ្រពីក្រោយដោយពួកប៉ាទ្រីសៀន និងព្រឹទ្ធសមាជិក។ ឧត្តមសេនីយ៍មួយរូបឈ្មោះម៉ារូសធ្វើការវាយប្រយុទ្ធដើម្បីពួកប្លេបៀន ខណៈពេលដែលឧត្តមសេនីយ៍មួយរូបទៀតឈ្មោះស៊ូឡា វាយប្រយុទ្ធដើម្បីពួកប៉ាទ្រីសៀន។ ជម្លោះនេះបានអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ។ ចុងក្រោយ នៅក្នុងឆ្នាំ 82 នៃគ.ស ពួកប៉ាទ្រីសៀនបានទទួលជ័យជំនះ។ ស៊ូឡាបានក្តោបក្តាប់អំណាច និងបានក្លាយជាមេដឹកនាំផ្តាច់ការមួយរូប។

វិភាគអំពីមូលហេតុ៖ ពិពណ៌នាអំពីមូលហេតុដែលនាំឱ្យកើតមានសង្គ្រាមនៅរ៉ូម។

## 2. ជូលីស សេសា

សំណួរគន្លឹះ៖ តើស្នាដៃរបស់សេសាមានអ្វីខ្លះ?

បន្ទាប់ពីលោកស៊ូឡាស្លាប់ទៅ ឧត្តមសេនីយ៍ផ្សេងៗចាប់ផ្តើមកើនអំណាច។ ម្នាក់ក្នុងចំណោមពួកគេគឺជូលីស សេសាដែលជាឧត្តមសេនីយ៍, អ្នកនយោបាយ, និងជាជនផ្តាច់ការមួយរូប។ សេសាកើតនៅវង្វង់ឆ្នាំ 100 មុនគ.ស នៅក្នុងគ្រួសារអភិជនចំណាស់មួយ។ លោកគឺជាមនុស្សម្នាក់ដែលមានទេពកោសល្យ និងមានមហិច្ឆិតាដ៏ធំមួយ។ ប៉ុន្តែ ដើម្បីទទួលបានអំណាចពិតប្រាកដ លោកបានដឹងថាលោកត្រូវតែទទួលជ័យជំនះលើសមរភូមិ។

មេដឹកនាំយោធា៖ សេសាដំបូងឡើយបានសំឡឹងទៅរកការធ្វើសកម្មភាពយោធានៅ(បច្ចុប្បន្នស្ថិតនៅផ្នែកខ្លះនៃប្រទេសទួរគី) និងអេស្ប៉ាញ។ ប៉ុន្តែក្រោយមក លោកបានបង្ហាញខ្លួនលោកថាជាឧត្តមសេនីយ៍ដ៏អស្ចារ្យមួយរូបនៅហ្គោលដែលជាតំបន់មួយបច្ចុប្បន្នស្ថិតនៅប្រទេសបារាំង។ ពួកហ្គោលជាក្រុមអ្នកប្រយុទ្ធដ៏កាចសាហាវ។ ប៉ុន្តែដោយសារតែយុទ្ធនាការយោធាដ៏អស្ចារ្យមួយ សេសាបានយកជ័យជំនះលើពួកហ្គោល ហើយបានដណ្តើមកាន់កាប់តំបន់ទាំងមូល។ ការឈ្លានពានរបស់លោកបានផ្តល់ឱ្យរ៉ូមនូវទឹកដីថ្មី និងទ្រព្យសម្បត្តិដ៏ច្រើន។ ជ័យជំនះនេះក៏បានផ្តល់នូវកិត្តិនាម និងសំណាងដល់សេសាផងដែរ។ សេសា បានសរសេរអំពីការគ្រប់គ្រងអាណានិគមរបស់លោកនៅតំបន់ហ្គោល នៅក្នុងកំណត់ត្រាយោធាមួយដែលមានចំណងជើងថាវិចារណកថាអំពីសង្គ្រាមនៅហ្គោល។ ស្នាដៃនេះបានបង្កើតកិត្តិនាមរបស់លោកថាជាអ្នកនិពន្ធដែលសរសេរអក្សរឡាតាំងដ៏អស្ចារ្យមួយរូប។

ជនផ្តាច់ការអស់មួយជីវិត៖ ក្រៅពីជំនាញខាងយោធា សេសាក៏ជាអ្នកនយោបាយដ៏ពូកែមួយរូបផងដែរ។ លោកទទួលបានកិត្តិស័ព្ទ ក្នុងនាមលោកជាអ្នកធ្វើកំណែទម្រង់មួយរូបដែលគាំទ្រដល់ប្រជាជនសាមញ្ញ។ កិត្តិស័ព្ទនេះ បូករួមជាមួយកិត្តិនាមខាងយោធារបស់លោកផងនោះ បានធ្វើឱ្យលោកមានប្រជាប្រិយភាពក្នុងចំណោមពួកភ្លេបៀន។ ប៉ុន្តែ សេលាក៏មានសត្រូវផងដែរ។ ពួកអ្នកមានអំណាចរ៉ូមជាច្រើន ដោយរួមមានទាំងព្រឹទ្ធសមាជិកប៉ាទ្រីសៀនផង បានប្រឆាំងជាមួយសេសា។ អ្នកប្រឆាំងជាមួយលោកម្នាក់ឈ្មោះស៊ីសឺរ៉ូគឺជាទីប្រឹក្សារ៉ូមដ៏សំខាន់មួយរូប និងប្រហែលជាអ្នកវាគ្មិនដ៏ល្អបំផុតនៅក្នុងប្រវត្តិសាស្ត្ររ៉ូម។ ស៊ីសឺរ៉ូគឺជាអ្នកគាំទ្រសាធារណរដ្ឋដ៏ខ្លាំងក្លាមួយរូប។ លោកបានមិនជឿទុកចិត្តលើសេសា និងមេដឹកនាំណាដែលស្រលាញ់តែអំណាចឡើយ។ (អ្នកអាចសិក្សាបន្ថែមអំពីទំនាក់ទំនងរវាងស៊ីសឺរ៉ូ និងសេសាតាមរយៈការអានសំបុត្ររបស់លោកស៊ីសឺរ៉ូដែលជាប្រភពឯកសារដើមនៅខាងក្រោម)។ នៅពេលដែលសេលាត្រឡប់មកពីហ្គោលវិញ ព្រឹទ្ធសភាបានបញ្ជាឱ្យលោករំលាយកងទ័ព។ ផ្ទុយទៅវិញ លោកបានដឹកនាំកងទ័ពរបស់លោកចូលអ៊ីតាលី និងចាប់ផ្តើមវាយប្រយុទ្ធដើម្បីគ្រប់គ្រងរ៉ូម។ បន្ទាប់ពីនោះបានប៉ុន្មានឆ្នាំសេសាចាប់ផ្តើមមើលឃើញពីជ័យជំនះ។ នៅក្នុងឆ្នាំ 46 មុនគ.ស លោកត្រឡប់កាន់រ៉ូម ដែលជាទីកន្លែងដែលមានប្រជាជន និងកងទ័ពគាំទ្រលោក។ នៅក្នុងឆ្នាំជាមួយគ្នានោះ ព្រឹទ្ធសភាបានតែងតាំងលោកគឺជាមេដឹកនាំរ៉ូមតែម្នាក់គត់។ នៅក្នុងឆ្នាំ 44 មុនគ.ស សេសា ត្រូវបានគេតែងតាំងជាមេដឹកនាំផ្តាច់ការអស់មួយជីវិត ដែលផ្ទុយទៅនឹងច្បាប់ដែលជាធម្មតាមានរយៈពេលតែ 6 ខែប៉ុណ្ណោះ។

កំណែទម្រង់របស់សេសា៖ សេសាដឹកនាំរ៉ូមក្នុងនាមជាមេដឹកនាំអំណាចផ្តាច់មុខ ប៉ុន្តែចាប់ផ្តើមធ្វើកំណែទម្រង់មួយចំនួន។ លោកបានពង្រីកសមាជិកព្រឹទ្ធសភា ដោយបញ្ចូលអ្នកគាំទ្រលោកមកពីអ៊ីតាលី និងតំបន់ផ្សេងៗទៀត។ លោកក៏បានអនុម័តច្បាប់នានាប្រឆាំងជាមួយមួយបទឧក្រិដ្ឋ និងបានបង្កើតការងារសម្រាប់ប្រជាជនក្រី

ក្រ។ បើទោះបីជាមានការធ្វើកំណែទម្រង់បែបនេះក៏ដោយ មានប្រជាជនរ៉ូមមួយចំនួនភ័យខ្លាចថា សេសានឹងលើកខ្លួនលោកធ្វើជាស្តេច។ មិនត្រឹមតែលោកដឹកនាំរ៉ូមអស់មួយជីវិតទេ ប៉ុន្តែសមាជិកគ្រួសាររបស់លោកក៏នឹងដឹកនាំបន្តពីលោកផងដែរ។ ភាពស្អប់ខ្ពើមរបស់ពួករ៉ូមចំពោះស្តេចកើតមានឡើងតាំងពីការគ្រប់គ្រងរបស់ពួកអ៊ីទ្រូស្កែនមកម្លេះ។

ការធ្វើឃាត និងកេរ្តិ៍ដំណែល៖ ដោយមានការព្រួយបារម្ភអំពីការកើនឡើងនៃអំណាចរបស់សេសា បាននាំទៅដល់ការដួលរលំរបស់លោក។ ព្រឹទ្ធសភាដែលជាស្ថាប័នដឹកនាំរបស់រ៉ូម មានការមិនសប្បាយចិត្តចំពោះអំណាចរបស់លោក។ នៅថ្ងៃទី 15 ខែមីនា ឆ្នាំ 44 មុនគ.ស ព្រឹទ្ធសមាជិកមួយចំនួនចាប់ផ្តើមធ្វើសកម្មភាព។ ព្រឹទ្ធសភាបានបើកអង្គប្រជុំមួយនៅក្នុងថ្ងៃដ៏សំខាន់នោះ។ ព្រឹទ្ធសមាជិកចូលម្តងម្នាក់ៗ ហើយចុងក្រោយ សេសាបានចូលទៅក្នុងអង្គប្រជុំ។ លោកត្រូវបានឡោមព័ទ្ធ និងត្រូវបានធ្វើឃាតដោយក្រុមព្រឹទ្ធសមាជិក។ មេដឹកនាំផ្សេងៗទៀតដែលរួមគំនិតក្បត់ត្រូវបានសម្លាប់ ឬសម្លាប់ខ្លួន។ ប្រវត្តិវិទូមួយចំនួននៅតែមិនស្របគ្នាចំពោះការគ្រប់គ្រងរបស់សេសានៅរ៉ូមនៅពេលនោះ។ ប្រវត្តិវិទូមួយចំនួនបាននិយាយថាលោកគឺជាអ្នកធ្វើកំណែទម្រង់មួយរូប ដែលបានធ្វើការងារដើម្បីជួយដល់ប្រជាជនសាមញ្ញ។ អ្នកមួយចំនួនទៀតបាននិយាយថា លោកគឺជាជនផ្តាច់ការមួយរូបដែលស្រេកឃ្លានអំណាច។ នៅក្នុងករណីផ្សេងទៀត ការដឹកនាំរបស់សេសានិងការស្លាប់របស់លោកបាននាំមកនូវការបញ្ចប់នៃសាធារណរដ្ឋ។

សង្ខេប៖ ពិភាក្សាអំពីស្នាដៃរបស់សេសា។

## 3. អធិរាជដឹកនាំរ៉ូម

សំណួរគន្លឹះ៖ តើមានរឿងអ្វីកើតឡើងចំពោះរ៉ូមបន្ទាប់ពីការស្លាប់របស់សេសា?

បន្ទាប់ពីសេសាស្លាប់ មេដឹកនាំរ៉ូមមួយចំនួនបានប្រជែងគ្នាដើម្បីអំណាច។ ម្នាក់ក្នុងចំណោមមេដឹកនាំទាំងនេះគឺចៅក្មួយ និងកូនចិញ្ចឹមរបស់សេសាឈ្មោះអុកតាវៀន។ ការប្រជែងគ្នានេះបាននាំទៅដល់សង្គ្រាមស៊ីវិលម្តងទៀត ដែលបានអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ។ សង្គ្រាមបានបំផ្លាញសាធារណរដ្ឋរ៉ូម។ ដោយថាហេតុអុកតាវៀន បានទទួលជ័យជំនះលើសត្រូវនានារបស់លោក។ នៅក្នុងឆ្នាំ 27 មុនគ.ស លោកបានក្លាយជាមេដឹកនាំរ៉ូម។ ក្រោយមកលោកទទួលបានគោរម្យងារថាអូហ្គឹស្ទឹសដែលមានន័យថា "អ្នកខ្លាំងក្លាបំផុត" ឬមនុស្សដែលមានឋានៈនិងអំណាចខ្ពស់។

អូហ្គឹស្ទឹសស្ថាបនារ៉ូមឡើងវិញ៖ អូហ្គឹស្ទឹសគឺជាអធិរាជដំបូងបំផុតរបស់រ៉ូម ប៉ុន្តែលោកមិនប្រើគោរម្យនេះឡើយ។ លោកស្នើឱ្យគេហៅលោកថា "ប្រជាពលរដ្ឋទីមួយ"។ លោកបានស្តារឡើងវិញនូវទម្រង់មួយចំនួននៃរដ្ឋាភិបាលសាធារណរដ្ឋ។ ព្រឹទ្ធសមាជិក, ទីប្រឹក្សា, និងចៅក្រមជាថ្មីម្តងទៀតបានទទួលតំណែងរបស់ពួកគេ។ ប៉ុន្តែអូហ្គឹស្ទឹស មានអំណាចនៅពីលើពួកគេ។

អូហ្គីស្ទឹសដឹកនាំរ៉ូមមានភាពល្អប្រសើរ។ លោកដាក់ខេត្តនានាឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងពង្រឹងការការពារចក្រភព។ លោកក៏បានចាប់ផ្តើមបង្កើតឱ្យមានមន្ត្រីស៊ីវិល ដែលជាមន្ត្រីមួយក្រុមដែលជួលឱ្យធ្វើការដោយរដ្ឋាភិបាល។ មន្ត្រីស៊ីវិលរ៉ូមប្រមូលពន្ធ, គ្រប់គ្រងប្រព័ន្ធប្រៃសនីយ៍, និងគ្រប់គ្រងការផ្គត់ផ្គង់គ្រប់ធុញ្ញជាតិ។ អូហ្គីស្ទឹសបានស្ថាបនា និងកែលំអររ៉ូមផងដែរ។ លោកបានស្ថាបនាប្រាសាទ, រោងល្ខោន, និងបូជនីយស្ថានធំៗ។ លោកបានផ្លាស់ប្តូរសំណង់មួយចំនួនដែលធ្វើអំពីឥដ្ឋចាស់ៗ ដោយជំនួសដោយថ្មម៉ាប។ ស្ថិតនៅក្រោមការដឹកនាំរបស់អូហ្គីស្ទឹស រ៉ូមបានក្លាយជាទីក្រុងដ៏ស្រស់ឆើតឆាយមួយ។

សន្តិភាពរបស់រ៉ូម៖ រាជ្យរបស់អូហ្គីស្ទឹសចាប់ផ្តើមសម័យកាលសន្តិភាព និងស្ថេរភាពដ៏យូរអង្វែងមួយនៅក្នុងចក្រភពរ៉ូម ដែលគេហៅថាផិច រ៉ូម៉ាណា ឬ "សន្តិភាពរ៉ូម"។ ផិចរ៉ូម៉ាណា មានរយៈពេលប្រហែលជា 200 ឆ្នាំ។ នៅអំឡុងពេលនោះ ចក្រភពបានពង្រីកទំហំយ៉ាងធំ ដែលមានផ្ទៃក្រឡាប្រមាណ 2 លានម៉ាយការ៉េ។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អូហ្គីស្ទឹស កងទ័ពរបស់រ៉ូមបានក្លាយជាកងកម្លាំងដែលពូកែប្រយុទ្ធបំផុតនៅក្នុងពិភពលោក។ មានបុរសប្រមាណ 30 ម៉ឺននាក់បានបម្រើការងារនៅក្នុងជួរកងទ័ព។ ពួកគេការពារព្រំដែនរបស់ចក្រភព។ ពួកគេក៏ជាអ្នកស្ថាបនាផ្លូវ, ស្ពាន, និងផ្លូវរូងក្រោមដី ដែលបានជួយចងភ្ជាប់ដែនដីនានានៅក្នុងចក្រភព។ ជាងនេះទៅទៀតអូហ្គីស្ទឹស បានបង្កើតកងទ័ពជើងទឹកដ៏ខ្លាំងមួយរបស់រ៉ូម ដោយបានល្បាយនៅក្នុងសមុទ្រមេឌីទែរ៉ានេ។ ការធ្វើបែបនេះ បានអនុញ្ញាតឱ្យរ៉ូមបង្កើតអំណាច និងឥទ្ធិពលនៅពាសពេញតំបន់មេឌីទែរ៉ានេ។

រដ្ឋាភិបាលដ៏ខ្លាំងក្លាមួយ៖ ផិចរ៉ូម៉ាណាបានបន្តទៅមុខទៀតបន្ទាប់ពីការស្លាប់របស់អូហ្គីស្ទឹស នៅក្នុងឆ្នាំ 14 នៃគ.ស។ មានអធិរាជជាច្រើនដែលដឹកនាំបន្ទាប់ពីអូហ្គីស្ទឹស។ មានអ្នកមួយចំនួនគឺជាមេដឹកនាំល្អ ខណៈពេលដែលអ្នកមួយចំនួនទៀតដឹកនាំមិនបានល្អឡើយ។ ប៉ុន្តែ រដ្ឋាភិបាលបង្កើតឡើងដំបូងដោយអូហ្គីស្ទឹសមានប្រសិទ្ធិភាពខ្លាំង ដូច្នេះចក្រភពនៅតែមានភាពខ្លាំងក្លា។ ពួករ៉ូមបានបន្តគ្រប់គ្រងចក្រភព រហូតមកដល់ត្រឹមទសវត្សរ៍ឆ្នាំ 100 នៃគ.សពួកគេគ្រប់គ្រងចាប់ពីអេស្ប៉ាញ រហូតដល់មេឌីទែរ៉ានេ និងចាប់ពីអាហ្វ្រិកខាងជើងដល់អង់គ្លេស។ បូករួមខេត្តទាំងអស់នៅក្នុងចក្រភព មានមនុស្សនិយាយភាសា, វប្បធម៌, និងប្រពៃណីទំនៀមទម្លាប់ផ្សេងៗគ្នាជាច្រើន។

កសិកម្ម៖ កសិកម្ម និងពាណិជ្ជកម្មបានជួយដល់ភាពរុងរឿងនៃចក្រភព។ កសិកម្មគឺជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់បំផុតនៅក្នុងចក្រភព។ អ្វីៗគ្រប់យ៉ាងគឺពឹងលើវា។ ប្រជាជនភាគច្រើនមានមុខរបរជាអ្នកធ្វើស្រែចំការ។ ប្រជាជន រ៉ូមភាគច្រើនអាចរស់បានដោយសារតែផលិតផលដែលបានមកពីក្នុងតំបន់។ ពួកគេអាចទទួលបានចំណីអាហារផ្សេងៗទៀតតាមរយៈពាណិជ្ជកម្ម។ បើទោះបីការធ្វើស្រែចំការនៅតែជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចរ៉ូម ប៉ុន្តែឧស្សាហកម្មក៏កើនឡើងផងដែរ។ ការផលិតភាជន៍, ឧបករណ៍ធ្វើពីលោហៈ, និងកែវ បានកើនឡើង។ ក៏ដូចជាផលិតផលស្រាទំពាំងបាយជូរ និងប្រេងអូលីវ ក៏ដូចជាផលិតផលចំណីអាហារផ្សេងៗទៀតក៏បានកើនឡើងផងដែរ។

ពាណិជ្ជកម្ម៖ សេដ្ឋកិច្ចរបស់ចក្រភពរីកលូតលាស់តាមរយៈការប្រើប្រាស់ផ្លូវពាណិជ្ជកម្ម។ ពាណិជ្ជករធ្វើដំណើរតាមទូកតាមសមុទ្រមេឌីទែរ៉ានេទៅអេស្ប៉ាញ, អាហ្វ្រិក, និងអាស៊ីខាងលិច។ ពេលគេក៏ធ្វើដំណើរតាមផ្លូវគោកទៅកាន់ ហ្គោល និងផ្នែកផ្សេងៗទៀតនៃអឺរ៉ុប។ តាមរយៈការធ្វើពាណិជ្ជកម្ម រ៉ូមទទួលបាននូវវត្ថុមានតម្លៃ

នានាដែលមិនអាចរកបាននៅក្នុងចក្រភពរបស់ខ្លួន។ ពាណិជ្ជកររ៉ូមនាំត្រឡប់មកវិញនូវគ្រាប់ធុញ្ញជាតិ, ភ្លុក, សូត្រ, គ្រឿងទេស, មាស, និងប្រាក់, និងសូម្បីតែសត្វព្រៃនានា។ ភាគច្រើននៃការធ្វើពាណិជ្ជកម្មទាំងនេះពឹងផ្អែកលើគុណភាពនៃផ្លូវរបស់ចក្រភពរ៉ូម។ ពាណិជ្ជកម្មទាំងនេះក៏ពឹងផ្អែកលើសន្តិសុខដែលផ្តល់ឲ្យដោយកងយោធារ៉ូមផងដែរ។

រូបិយវត្ថុ៖ សេដ្ឋកិច្ចរបស់រ៉ូមក៏ត្រូវបានបង្រួបបង្រួមតាមរយៈការប្រើប្រាស់រូបិយវត្ថុ ឬលុយរួមមួយ។ នៅអំឡុងសម័យនៃការគ្រប់គ្រងរបស់អូហ្គីស្ទីស កាត់ធ្វើពីប្រាក់ ដែលគេហៅថាដេណារ៉ូសត្រូវបានគេប្រើនៅពាសពេញចក្រភព។ ការប្រើប្រាស់ទម្រង់លុយរួមបានធ្វើឱ្យការធ្វើពាណិជ្ជកម្មនៅតាមផ្នែកផ្សេងៗនៃចក្រភពកាន់តែមានភាពងាយស្រួល។ ពាណិជ្ជករអាចទិញ និងលក់ផលិតផលរបស់ពួកគេដោយមិនចាំបាច់ប្តូរលុយរបស់ពួកគេទៅជារូបិយវត្ថុផ្សេងឡើយ។ ការពង្រីកសេដ្ឋកិច្ចរបស់រ៉ូមមានអត្ថប្រយោជន៍យ៉ាងខ្លាំងដល់អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ជាលទ្ធផល ការបែងចែករវាងអ្នកមាន និងអ្នកក្រកាន់តែមានភាពខ្លាំងក្លាឡើង។ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីការបែងចែកនេះនៅក្នុងមេរៀនបន្ទាប់។

ស្វែងរកគំនិតសំខាន់៖ ពិពណ៌នាអំពីអ្វីដែលកើតមានឡើងនៅរ៉ូមបន្ទាប់ពីការស្លាប់របស់ជូលីស សេសា។

# មេរៀនទី 3 ៖ ជីវភាពរស់នៅប្រចាំថ្ងៃរបស់រ៉ូម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ចូរចងចាំថា នៅដើមដំបូងបំផុតនៃរ៉ូម គ្រួសារដែលមានសមាជិកច្រើនរស់នៅ និងធ្វើការនៅលើដីស្រែចំការតូចៗ។ សមាជិកគ្រួសារបានដឹងថាអ្វីទៅជាក្តីពឹងទុករបស់ពួកគេ។ អំឡុងសម័យចក្រភពរ៉ូម តួនាទីក្នុងគ្រួសារ និងសង្គមត្រូវបានរៀបចំដោយរចនាសម្ព័ន្ធច្បាស់លាស់។

## 1. គ្រួសារ និងសង្គម

សំណួរគន្លឹះ៖ តើគ្រួសារ និងសង្គមត្រូវបានគេរៀបចំឡើងយ៉ាងដូចម្តេច?

អ្នកគ្រប់គ្រងនៅក្នុងគ្រួសាររ៉ូមគឺឪពុក។ ឪពុកគឺជាអ្នកកាន់កាប់រាល់ទ្រព្យសម្បត្តិទាំងអស់ និងត្រួតត្រាលើសមាជិកទាំងឡាយនៅក្នុងគ្រួសារ។ ប៉ុន្តែ អំណាចរបស់ឪពុកត្រូវបានកម្រិតដោយមតិសាធារណ និងប្រពៃណី។ សង្គមរ៉ូមមិនអនុញ្ញាតឱ្យឪពុកដាក់ពិន័យសមាជិកគ្រួសារដោយគ្មានមូលហេតុច្បាស់លាស់ឡើយ។

ស្ត្រី៖ ស្ត្រីនៅក្នុងគ្រួសាររ៉ូមទទួលបានសិទ្ធិសេរីភាពមួយចំនួន។ ក៏ដូចជាស្ត្រីផ្សេងៗទៀតនៅជុំវិញពិភពលោក ស្ត្រីរ៉ូមត្រូវបានគេរំពឹងថានឹងជាអ្នកមើលការខុសត្រូវក្នុងគ្រួសារ និងមើលថែកូនចៅ។ ប៉ុន្តែ ពួកគេក៏អាចទទួលបានទ្រព្យសម្បត្តិ និងមើលការខុសត្រូវលើជំនួញគ្រួសារផងដែរ នៅពេលដែលប្តីរបស់គេចេញទៅឆ្ងាយ។ ប៉ុន្តែ ស្ត្រីរ៉ូមមានអំណាចតិចតួចនៅខាងក្រៅផ្ទះ ហើយពួកគេមិនមានសិទ្ធិបោះឆ្នោតឡើយ។

កុមារ៖ ឪពុកម្តាយភាគច្រើនផ្តល់ការអប់រំដល់កូនរបស់ពួកគេនៅផ្ទះ។ កូនប្រុសដែលស្ថិតនៅក្នុងគ្រួសារមានទ្រព្យសម្បត្តិស្តុកស្តម្ភ ជាទូទៅត្រូវបានគេបញ្ជូនឱ្យទៅរៀននៅសាលាឯកជន ខណៈពេលដែលកូនស្រីនៅផ្ទះរៀនពីជំនាញមេផ្ទះ។ ស្ត្រីជាទូទៅរៀបអាពាហ៍ពិពាហ៍នៅពេលដែលពួកគេមានអាយុ 14 ឆ្នាំ ខណៈពេលដែលបុរសរៀបការនៅពេលដែលពួកគេមានអាយុច្រើនជាងនេះ។

វណ្ណៈសង្គម៖ បន្តិចម្តងៗវណ្ណៈសង្គមរ៉ូមបានផ្លាស់ប្តូរ។ ការបែងចែកចាស់រវាងពួកប៉ាទ្រីសៀន និងពួកផ្លេបៀនបានវិវត្តទៅជាវណ្ណៈជាន់ខ្ពស់ និងជាន់ទាប។ ពួកប៉ាទ្រីសៀន និងពួកអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភផ្លេបៀនមួយចំនួនបានក្លាយជាអ្នកស្ថិតនៅក្នុងវណ្ណៈជាន់ខ្ពស់។ វណ្ណៈកណ្តាលថ្មីមួយក៏ត្រូវអភិវឌ្ឍឡើងផងដែរ។ ពាណិជ្ជករ និងមន្ត្រីមានទ្រព្យសម្បត្តិស្ថិតនៅក្នុងវណ្ណៈកណ្តាលនេះ។ ប្រជាកសិករស្ថិតនៅក្នុងវណ្ណៈជាន់ទាប។ ពួកទាសករស្ថិតនៅក្នុងវណ្ណៈទាបបំផុត និងមានចំនួនច្រើនជាងគេនៅក្នុងសង្គម។ មានប្រជាជនលើសពីមួយភាគបីនៃប្រជាជនសរុបគឺជាទាសករ។ មួយចំនួនគឺជាឈ្លើយសង្គ្រាម។ មួយចំនួនទៀតក្លាយជាទាសករដោយសារតែឪពុកម្តាយរបស់ពួកគេគឺជាទាសករ។ ទាសករមាននៅពាសពេញសង្គមរ៉ូម។ ទាសករមួយចំនួនធ្វើការនៅក្នុងវិស័យសាសនាដែលមានតួនាទីទាបបំផុត។ ប៉ុន្តែ ទាសករក៏ធ្វើការងារនានាដែលប្រើកម្លាំងពលកម្មផងដែរ។ ពួកគេធ្វើការជាអ្នកជីករ៉ែ, ធ្វើការនៅលើដីស្រែចំការធំៗ, និងធ្វើជាអ្នកបម្រើ។ ទាសករជាច្រើនទទួលរងគ្រោះដោយការប្រព្រឹត្តឃោឃៅមកលើពួកគេ។ ការបះបោររបស់ទាសករបានកើតឡើងជាញឹកញាប់ ប៉ុន្តមិនមានការបះបោរណាទទួលបាន

ជោគជ័យឡើយ។ ទាសកររាប់ពាន់នាក់បានស្លាប់នៅក្នុងការបះបោរទាំងនេះ មានការបះបោរមួយដែលល្បីល្បាញបំផុតដែលដឹកនាំដោយស្ប៉ាតាគូស។

គូសបង្ហាញពីសេចក្ដីសន្និដ្ឋាន៖ ពិពណ៌នាពីរបៀបដែលគ្រួសារ និងសង្គមត្រូវបានរៀបចំឡើង។

## 2. ជំនឿរបស់ពួករ៉ូម

សំណួរគន្លឹះ៖ តើអ្វីទៅជាជំនឿសាសនារបស់ពួករ៉ូម?

ជំនឿសាសនាបានចងភ្ជាប់សង្គមរ៉ូមជាមួយគ្នា។ នៅដើមដំបូងបំផុត ពួករ៉ូមគោរពបូជាព្រលឹងរាប់រយ។ ពួកគេជឿថាព្រលឹងទាំងអស់នេះ រស់នៅលើអ្វីៗទាំងអស់នៅជុំវិញខ្លួនពួកគេ ដោយរួមមានទន្លេ, ដើមឈើ, និងដីស្រែចំការផងដែរ។ គ្រួសាររបស់ពួករ៉ូមក៏ជឿថាអាទិទេពផ្ទះបានជួយការពារពួកគេ។ ពួកគេបានរៀបចំស្តូបនៅក្នុងផ្ទះរបស់ពួកគេដើម្បីបង្ហាញពីការគោរពដល់ព្រលឹងទាំងអស់នេះ។

ឥទ្ធិពលនៃសាសនា៖ ក្រោយមក ជំនឿរបស់ពួករ៉ូមបានទទួលរងឥទ្ធិពលពីវប្បធម៌ផ្សេងៗទៀត។ ជាពិសេសវប្បធម៌របស់ពួកអ៊ីទ្រូស្គែន និងក្រិកបានជះឥទ្ធិពលលើសាសនារបស់រ៉ូម។ ពួករ៉ូមបានទទួលយកគំនិតរបស់ពួកអ៊ីទ្រូស្គែនស្ដីអំពីអាទិទេពនៅក្នុងទម្រង់ជាមនុស្ស។ ពួកគេក៏អនុវត្តក្បួនពិធីរបស់ពួកអ៊ីទ្រូស្គែន ដែលរចនាឡើងដើម្បីទាយអំពីជោគវាសនា។ ពួករ៉ូមជឿថាក្បួនពិធីទាំងនេះអាចបង្ហាញពីសកម្មភាពជាក់លាក់មួយ ដូចជាសង្គ្រាមជាដើម ថាតើនឹងអាចទទួលលទ្ធផលល្អដែរឬទេ។ ពួករ៉ូមបានទទួលយកអាទិទេពជាច្រើនរបស់ក្រិកមកធ្វើជាអាទិទេពរបស់ពួកគេ។ ឧទាហរណ៍ អាទិទេពរ៉ូមជូពីទ័រដែលជាមេអាទិទេពទាំងឡាយ មានបុគ្គលិកលក្ខណៈជាច្រើនដូចគ្នាទៅនឹងអាទិទេពហ្សូសរបស់ក្រិក។ អាប៉ូឡូដែលជាអាទិទេពតន្ត្រី និងកវីនិពន្ធរបស់ក្រិក បានក្លាយជាអាទិទេពសំខាន់មួយរបស់ពួករ៉ូម ដែលមានឈ្មោះដូចគ្នាជាមួយក្រិក។

សាសនា និងជីវិតសាធារណៈ៖ ក៏ដូចជាពួកអេហ្ស៊ីបសម័យបុរាណដែរ នៅរ៉ូម សាសនា និងរដ្ឋាភិបាលមានទំនាក់ទំនងជាមួយគ្នា។ ពួកបព្វជិតគឺជាមន្ត្រីរបស់រដ្ឋាភិបាល ហើយអធិរាជគឺជាប្រមុខនៃព្រះវិហារ។ អាទិទេពរបស់រ៉ូមក៏ជានិមិត្តរូបនៃរដ្ឋផងដែរ។ ពួករ៉ូមត្រូវបានរំពឹងថានឹងផ្ដល់ការគោរពដល់អាទិទេពទាំងនេះនៅក្នុងពិធីបុណ្យសាធារណៈ។ បន្តិចម្ដងៗ សូម្បីតែអធិរាជខ្លួនទ្រង់ផ្ទាល់បានក្លាយជាអាទិទេពមួយរូប។ នៅដើមដំបូង ពួករ៉ូមគោរពបូជាដល់អធិរាជបន្ទាប់ពីទ្រង់សុគត់តែប៉ុណ្ណោះ។ ប៉ុន្តែ ចុងក្រោយ ពួកគេផ្តល់ការគោរពអធិរាជដែលនៅមានព្រះជន្មដូចជាអាទិទេព។ ភក្តីភាពចំពោះអធិរាជចាប់ផ្ដើមមានលក្ខណៈដូចគ្នាទៅនឹងភក្តីភាពចំពោះអាទិទេព។

ស្វែងរកគំនិតសំខាន់៖ ពិភាក្សាអំពីជំនឿសាសនារបស់ពួករ៉ូម។

## 3. ជីវិតរស់នៅក្នុងទីក្រុងរបស់ពួករ៉ូម

សំណួរគន្លឹះ៖ តើជីវិតរស់នៅក្នុងទីក្រុងរបស់ពួករ៉ូមមានលក្ខណៈយ៉ាងដូចម្ដេច?

នៅពេលចក្រភពរ៉ូមរីកចម្រើនដល់កំពូល ទីក្រុងរបស់រ៉ូមមានប្រជាជនរស់នៅជិតមួយលាននាក់។ ប្រជាជនពីគ្រប់ទិសទីទាំងអស់នៅក្នុងដែនដីចក្រភពបានធ្វើដំណើរមកកាន់រ៉ូម។ ភាពចម្រុះនៃប្រជាជននេះបានបង្កើតឱ្យមានការលាយបញ្ចូលគ្នានូវគំនិត និងវប្បធម៌ដ៏រស់រវើក។

ទីក្រុងដែលណែនណាន់តាន់តាប់៖ ចំនួនមនុស្សច្រើនក៏បង្កើតឱ្យមានបញ្ហានានាផងដែរ។ មជ្ឈមណ្ឌលរ៉ូមមានភាពណែនណាន់តាន់តាប់, កខ្វក់, និងសម្លេងថ្លង់។ ប្រជាជននៅក្នុងទីក្រុងភាគច្រើនគ្មានការងារធ្វើ និងក្រីក្រ។ ប្រជាជនទាំងអស់នោះរស់នៅក្នុងសំណង់ផ្ទះល្វែងទ្រុតទ្រោម។ ពួកគេរស់នៅក្នុងបន្ទប់តូចៗដោយមិនមានប្រព័ន្ធទឹក ឬបង្គន់ឡើយ។ ផ្ទះមុជទឹកសាធារណៈត្រូវបានគេបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងចំនួនមនុស្សដ៏ណែនណាន់តាន់តាប់នៅក្នុងទីក្រុង។ ប្រជាជនបោះចោលសម្រាមរបស់ពួកគេតាមបង្អួច ដែលនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្សដែលដើរនៅតាមដងផ្លូវ។ ភ្លើងឆេះក៏ជាគ្រោះថ្នាក់ដែលកើតឡើងជាប្រចាំផងដែរ។

អ្នកមាននិងអ្នកក្រ៖ ប្រជាជនរ៉ូមក្រីក្រក៏មានចំណីអាហារបន្តិចបន្តួចសម្រាប់បរិភោគផងដែរ។ ចំណីអាហារទូទៅរួមមាន នំបុ័ង, អូលីវ, និងផ្លែឈើ។ ប៉ុន្តែរដ្ឋាភិបាលបានផ្តល់នូវគ្រាប់ធុញ្ញជាតិដល់ប្រជាជនដោយមិនគិតថ្លៃដើម្បីធ្វើឱ្យពួកគេរីករាយ និងជៀសវាងការបង្កភាពចលាចល។

ផ្ទុយទៅវិញ ពួកអ្នកមានរ៉ូមរីករាយជាមួយនឹងជីវិតបែបប្រណិតភាព។ ពួកគេរស់នៅក្នុងផ្ទះដែលធំ និងមានផាសុខភាពនៅជាយក្រុង។ ពួកគេបានចំណាយពេលទៅរោងល្ខោន និងបង្កើតភាពរីករាយដោយខ្លួនគេផ្ទាល់។ ពួកគេក៏មានកម្មវិធីញុំាអាហារពេលល្ងាចដ៏សម្បូរបែបផងដែរ។ ចំណីអាហារទាំងនោះរួមមានល្មើ, អយស្ទ័រ, និងសាច់។ ពួកគេក៏ញុំាចំណីអាហារពិសេសមួយចំនួនដូចជា ត្រីពពុះទឹកប្រឡាក់អំបិល, សេកខ្វៃ, អណ្តាតសត្វកុកស្ទោរ។

ការឆ្លើយតបទៅនឹងបញ្ហាដែលកើតមានក្នុងទីក្រុង៖ ពួករ៉ូមបានស្វែងរកដំណោះស្រាយមួយចំនួនដើម្បីដោះស្រាយបញ្ហានានាដែលកើតមានក្នុងទីក្រុង។ ពួកគេបានស្ថាបនាប្រព័ន្ធសម្អួត និងប្រព័ន្ធលូដើម្បីលើកកម្ពស់អនាម័យ។ ពួកគេក៏បានស្ថាបនាផ្លូវនាំទឹកដែលជាប្រព័ន្ធប្រឡាយនាំយកទឹកស្អាតពីប្រភពទឹកនានាដូចជាអូរ, និងបឹងមកកាន់ទីក្រុង។ ទឹកហូរតាមរយៈប្រព័ន្ធប្រឡាយ និងបំពង់។ ភាគច្រើននៃប្រព័ន្ធទាំងនេះស្ថិតនៅក្រោមដី ប៉ុន្តែមានប្រព័ន្ធមួយចំនួនត្រូវបានគេធ្វើស្ពានឆ្លងកាត់ពីលើ។

កន្លែងមុជទឹកសាធារណៈគឺជាផ្នែកដ៏សំខាន់មួយទៀតនៃជីវិតរស់នៅក្នុងទីក្រុង។ ទីប្រជុំជនភាគច្រើន និងសូម្បីតែបន្ទាយរបស់រ៉ូមមានផ្ទះមុជទឹកសាធារណៈ។ ពួករ៉ូមមកពីគ្រប់វណ្ណៈទាំងអស់បានធ្វើដំណើរមកកន្លែងមុជទឹកដើម្បីមុជទឹក និងធ្វើសង្គមនីយកម្ម។ ភ្ជាប់ទៅនឹងផ្នែកខាងវិទ្យាសាស្ត្រនៅមេរៀនខាងមុខនឹងបង្ហាញស៊ីជម្រៅអំពីស្ថាបត្យកម្ម និងបច្ចេកវិទ្យានៃការស្ថាបនាផ្ទះមុខទឹករបស់ពួករ៉ូម។

ដើម្បីកាត់បន្ថយភាពតានតឹងពីបញ្ហានានាដែលកើតមាននៅក្នុងទីក្រុង រដ្ឋាភិបាលបានផ្តល់នូវការការកំសាន្តអារម្មណ៍នៅសង្វៀនសាធារណៈធំៗ។ នៅក្នុងចំណោមនោះ សង្វៀនសម្តែងសៀកម៉ាស៊ីមូសគឺជាពហុកីឡាដ្ឋានរាងពងក្រពើដ៏ធំមួយប្រើសម្រាប់ការប្រណាំងរទេះសេះ។ ដូចដែលអ្នកបានសិក្សានៅក្នុងមេរៀនបន្ទាប់ សង្វៀនដែលល្បីល្បាញមួយទៀតគឺកូឡូសស៊ាម។ កូឡូសស៊ាមត្រូវបានដាក់ឈ្មោះតាមបដិមាដ៏ធំមួយកូឡូសស៊ូសដែល

ជាអធិរាជរ៉ូមដែលគេដាក់តាំងនៅចំហៀងសង្វៀន។ នៅក្នុងសង្វៀន ពួករ៉ូមអាចទស្សនា អ្នកប្រយុទ្ធឬអ្នកជំនាញក្នុងការធ្វើសង្គ្រាម ដែលវាយប្រយុទ្ធគ្នាយកស្លាប់រស់។ នៅពីខាងលើមានរនាំងក្រណាត់បាំងដើម្បីការពារកំដៅថ្ងៃដល់សាធារណៈជន។ ហ្វូងមហាជនអាចនឹងឃើញពួកអ្នកប្រមាញ់សម្លាប់សត្វសាហាវៗ។ ប៉ុន្តែ ការប្រកួតប្រជែងដែលល្បីល្បាញបំផុតគឺការដាក់ឱ្យអ្នកប្រយុទ្ធពីរនាក់ប្រយុទ្ធទល់នឹងមួយ ឬអ្នកប្រយុទ្ធម្នាក់ប្រយុទ្ធទល់នឹងសត្វព្រៃមួយ។ ទស្សន៍យភាពដែលពួករ៉ូមបានទស្សនាបានលាយបញ្ចូលគ្នានូវសេចក្តីក្លាហាន និងហឹង្សា,កិត្តិយស និងអំពើឃោឃៅ។

ធ្វើទូទៅនីយកម្ម៖ ពិពណ៌នាអំពីជីវិតរស់នៅក្នុងទីក្រុងរបស់ពួករ៉ូម។

# មេរៀនទី 4 ៖ ការអភិវឌ្ឍឡើងនៃសាសនាគ្រឹស្ត

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ពិភពរ៉ូមមានលក្ខណៈចម្រុះ ដែលមានសាសនាជាច្រើន។ ជីវិតរស់នៅ និងការបង្រៀនរបស់គ្រូជនជាតិជ្វីបមួយរូបឈ្មោះយេស៊ូបានក្លាយជាមូលដ្ឋានគ្រឹះនៃសាសនាគ្រឹស្ត។

## 1. ឫសគល់នៃសាសនាគ្រឹស្តរបស់ពួកជ្វីប

សំណួរគន្លឹះ៖ តើពួកជ្វីបមានជំនឿយ៉ាងដូចម្តេចខ្លះចំពោះមេសស៊ៃ?

នៅក្នុងឆ្នាំ 63 មុនគ.ស ពួករ៉ូមបានឈ្លានពានព្រះរាជាណាចក្រយូដា ឬយូឌៀរបស់ពួកជ្វីប។ អំឡុងនៃការគ្រប់គ្រងរបស់ពួករ៉ូម ពួកជ្វីបជាញឹកញយត្រូវបានពួករ៉ូមធ្វើបាប។ ពួកជ្វីបជាច្រើនចង់បានឯករាជ្យពីការគ្រប់គ្រងរបស់បរទេស។ ពួកជ្វីបមួយចំនួនបានលួចសរសេរកិច្ចសន្យាមេសស៊ៃមួយ ហើយមានមនុស្សជាច្រើនបានជឿថា ព្រះជាម្ចាស់នឹងបញ្ជូនអ្នកដឹកនាំម្នាក់មកកាន់ភពផែនដី។ មានអ្នកមួយចំនួនទៀតជឿជាក់ថា មេដឹកនាំនេះគឺជាបុព្វការីជនរបស់ស្តេចដាវីឌ ដែលជាមេដឹកនាំអ៊ីស្រាអែលនៅអំឡុងឆ្នាំ 900 មុនគ.ស។ មានអ្នកផ្សេងទៀតជឿថា មេសស៊ៃនឹងរំដោះពួកគេឱ្យមានសេរីភាព។

សង្ខេប៖ ពិពណ៌នាអំពីជំនឿនានារបស់ពួកជ្វីបចំពោះមេសស៊ៃ។

## 2. ជីវិតរស់នៅរបស់ព្រះយេស៊ូ

សំណួរគន្លឹះ៖ តើសាវ័ករបស់ព្រះយូស៊ូជឿថាទ្រង់គឺជានណារ?

ក្នុងនាមជាជនជាតិជ្វីបមួយរូបកើតនៅក្នុងដែនដីចក្រភពរ៉ូម, យូឌៀព្រះយេស៊ូបានដើរតាមការអប់រំនានារបស់សាសនាយូដា។ ប៉ុន្តែ ទ្រង់ក៏បង្រៀនពីគំនិត និងការប្រតិបត្តិមួយចំនួនដែលខុសគ្នាពីអ្នកដ៏ទៃបង្រៀន។

ការចាប់កំណើត និងជីវិតរស់នៅដំបូង៖ យើងបានដឹងពីព្រះយេស៊ូតាមរយៈហ្គូស្ពែលដែលជាសៀវភៅរឿង 4 ក្បាល ស្តីអំពីជីវិតរស់នៅរបស់ព្រះយេស៊ូ ដែលបានសរសេរឡើងដោយម៉ាថ្យូ, ម៉ាក, លូគេ និងចន បន្ទាប់ពីការស្លាប់របស់ព្រះយេស៊ូ។ សៀវភៅហ្គូស្ពែល និងស្នាដៃផ្សេងៗទៀតរួមបញ្ចូលគ្នាបង្កើតបានជាសៀវភៅមរតកសាសនាថ្មី។

យោងតាមសៀវភៅហ្គូស្ពែល ព្រះយេស៊ូប្រសូត្រនៅបេថ្លេហេម និងធំធាត់នៅណាហ្សារេថ។ ក្រោយមកពួកអ្នកជឿសាសនាគ្រឹស្តបានអបអរថ្ងៃកំណើតរបស់ទ្រង់នៅថ្ងៃបុណ្យគ្រីស្មាស់។ នៅក្នុងសៀវភៅរឿងហ្គូស្ពែល ព្រះយូស៊ូ ត្រូវបានចិញ្ចឹមដោយម្តាយរបស់ទ្រង់ឈ្មោះម៉ារី និងឪពុកចូសេព។

អ្នកដើរតាមព្រះយេស៊ូ៖ ក្នុងនាមជាមនុស្សវ័យជំទង់មួយរូប ព្រះយេស៊ូបានក្លាយជាអ្នកដើរបង្រៀន។ នៅក្នុងសៀវភៅប៊ីបបាននិយាយថា ទ្រង់បានជួយព្យាបាលមនុស្សឈឺ និងពិការ និងបានធ្វើឱ្យទឹកក្លាយជាស្រានៅក្នុងពិធីអាពាហ៍ពិពាហ៍មួយនៅកាណា។ ព្រះយេស៊ូចាប់ផ្តើមប្រមូលអ្នកដើរតាមទ្រង់។ អ្នកដើរតាមទ្រង់ជិតស្និត

ត្រូវបានគេហៅថាសាវ័ក។ សាវ័កទាំង 12 របស់ព្រះយេស៊ូរួមមានពីទ័រ, អេនឌ្រូ, ជេមស៍, ចន, ហ្វីលីប, បាថូឡូមេវ, ថូម៉ាស់, ម៉ាថ្យូ, ជេមសន៍(កូនប្រុសរបស់អាលផាអឺស), ស៊ីម៉ុន, ថាដាអឺស, និងយូដាស អ៊ីសការ៉ូត ។

ការបង្រៀនរបស់ព្រះយេស៊ូ៖ ព្រះយេស៊ូប្រៀនប្រដៅអំពីយុត្តិធម៌, សេចក្ដីមេត្តាករុណា, និងការមកដល់នៃព្រះរាជាណាចក្ររបស់ព្រះជាម្ចាស់។ ទ្រង់តែងតែបង្ហាញសារទាំងនេះនៅក្នុងទម្រង់ជាឧបមាកថា ឬលក្ខណៈរឿងអមជាមួយការអប់រំសីលធម៌។ ឧបមាកថាដែលល្អឯក 3 របស់ព្រះយេស៊ូរួមមានសាម៉ារីតានល្អ, កូនប្រុសខ្ជះខ្ជាយ, និងសត្វចៀនដែលបាត់។ រឿងសាម៉ារូតានល្អបង្រៀនអំពីសារៈសំខាន់នៃការជួយអ្នកដទៃ, បើទោះបីជាពួកគេខុសប្លែកពីយើង និងមិនមានជាតិសាសន៍ ឬសាសនាដូចយើងក៏ដោយ។ រឿងកូនប្រុសខ្ជះខ្ជាយជាប់ទាក់ទងជាមួយនឹងការហៅរបស់ព្រះជាម្ចាស់ចំពោះការបាត់បង់ព្រលឹង និងសម្បជញ្ញៈ។ រឿងសត្វចៀនដែលបាត់ជាប់ទាក់ទងជាមួយនឹងការព្រួយបារម្ភរបស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងឡាយ ដោយមិនខ្វល់ថាពួកគេមាន ឬគ្មានសារៈសំខាន់។

ការបង្រៀនដ៏ល្បីល្បាញបំផុតរបស់ព្រះយេស៊ូធ្វើឡើងជាលក្ខណៈទេសនានៅលើភ្នំ។ ការទេសនាចាប់ផ្ដើមជាមួយនឹងការជូនពរ ឬការប្រសិទ្ធិពរ។ នៅក្នុងការទេសនានេះ ព្រះយេស៊ូបានលើកទឹកចិត្តមនុស្សទាំងឡាយមិនត្រឹមតែគោរពច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវផ្លាស់ប្ដូរចិត្តរបស់ពួកគេផងដែរ។ មនុស្សទាំងឡាយមិនត្រឹមតែទូន្មានមិនឱ្យសម្លាប់សត្រូវគេប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវស្រឡាញ់ និងអធិដ្ឋានសម្រាប់សត្រូវរបស់ពួកគេផងដែរ។ ព្រះយេស៊ូបានលើកទឹកចិត្តអ្នកដើរតាមទ្រង់ឱ្យរស់នៅជាលក្ខណៈសាមញ្ញ និងដាក់ខ្លួន(ដើម្បីដឹងលម្អិតអំពីការទេសនានេះ សូមមើលប្រភពឯកសារដើមនៅខាងក្រោម)។ ដោយសារតែការអប់រំរបស់ព្រះយេស៊ូ មានមនុស្សមួយចំនួនមានការក្រោធខឹងនៅពេលដែលឮការប្រៀនប្រដៅនេះ។ ឧទាហរណ៍ ព្រះយេស៊ូអត់ឱនទោសដល់មនុស្សដែលបានល្មើសទៅនឹងច្បាប់សាសនា ប៉ុន្តែមេដឹកនាំជ្វីបជាច្រើនគិតថា មានតែព្រះជាម្ចាស់តែមួយអង្គប៉ុណ្ណោះដែលមានសិទ្ធិនៅក្នុងការអត់ឱនទាំងនេះ។ ព្រះយេស៊ូក៏មានទំនាក់ទំនងជាមួយអ្នកសាងអំពើបាបផងដែរ អ្នកទាំងឡាយដែលមេដឹកនាំសាសនាចាត់ទុកថាជាមនុស្សក្រៅសង្គម។ ការភ្ញាក់ផ្អើលដ៏ធំធេងបំផុតនោះ គឺការអះអាងរបស់អ្នកដើរតាមព្រះយេស៊ូមួយចំនួន ដែលថាទ្រង់គឺជាមេសស៊ែ ដែលពួកគេបានរង់ចាំអស់រយៈពេលជាយូរមកហើយ។ កត្តាទាំងអស់នេះហើយដែលបានចូលរួមចំណែក នាំឱ្យមានមនុស្សមួយចំនួនធំមិនសប្បាយចិត្តជាមួយនិងព្រះយេស៊ូ។

សង្ខេប៖ ពិពណ៌នាពីការគិតរបស់សាវ័ករបស់ព្រះយេស៊ូថាទ្រង់គឺជានណារ?

### 3. ការសុគត់របស់ព្រះយេស៊ូ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាគ្រីស្តសាសនិកជឿថាអាចនឹងមានជាតិបន្ទាប់?

ការអះអាងដែលថាព្រះយេស៊ូគឺជាមេសស៊ែ ឬអ្នករំដោះ និងអ្នកដឹកនាំជនជាតិជ្វីប បានគំរាមកំហែងដល់ពួករ៉ូម ដោយសារវាបានចោទជាបញ្ហាដល់អំណាចនយោបាយ និងអំណាចគ្រប់គ្រងរបស់ពួកគេលើពួកជ្វីប។ ការអះអាងនេះក៏នាំឱ្យមានការភ្ញាក់ផ្អើលដល់មេដឹកនាំជ្វីបជាច្រើនផងដែរ។

ការចាប់ខ្លួន និងកាត់ទោស៖ យោងទៅតាមសៀវភៅរឿងហ្គូស្ពែលទាំង 3 អ្នកដើរតាមព្រះយេស៊ូបានគោរពទ្រង់ដូចជាស្តេច នៅពេលដែលទ្រង់ធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡឹម ដើម្បីចូលរួមអបអរសាទរថ្ងៃពិសិដ្ឋបុណ្យរំលងរបស់ជនជាតិជ្វីប។ នៅប្រាសាទដ៏ពិសិដ្ឋក្នុងទីក្រុង ព្រះយេស៊ូបានរិះគន់ជាសាធារណអំពីរបៀបនៃការគ្រប់គ្រងប្រាសាទ។ ព្រះយេស៊ូត្រូវបានចាប់ខ្លួន និងនាំត្រឡប់ទៅកាន់រ៉ូមដើម្បីដាក់ទោស។

រឿងរ៉ាវទាក់ទងនឹងការរស់ឡើងវិញ៖ មេដឹកនាំរ៉ូមប៉ុនទូស ពីឡាតេ បានបញ្ជាឱ្យគេប្រហារជីវិតព្រះយេស៊ូដោយចងនៅលើឈើឆ្កាងរហូតដល់ទ្រង់សុគត់។ បន្ទាប់ពីទ្រង់សុគត់ សាកសពរបស់ទ្រង់ត្រូវបានគេដាក់ចុះពីលើឈើឆ្កាង ហើយថ្មដ៏ធំមួយដុំត្រូវបានគេដាក់បាំងពីមុខផ្នូររបស់ទ្រង់។ យោងទៅតាមរឿងហ្គូស្ពែល 3 ថ្ងៃបន្ទាប់ពីការប្រហារជីវិតទ្រង់ អ្នកដើរតាមទ្រង់មួយចំនួនបានរាយការណ៍ថា ថ្មដែលដាក់បាំងនៅមុខផ្នូររបស់ទ្រង់បានរបើក ហើយនៅក្នុងផ្នូរមិនឃើញមានសាកសពរបស់ទ្រង់ឡើយ។ មានមនុស្សមួយចំនួនបាននិយាយថា ពួកគេបានឃើញព្រះយេស៊ូ ហើយបានដើរ និងនិយាយជាមួយទ្រង់ទៀតផង។

រឿងរ៉ាវនៃការរស់ឡើងវិញ ឬការត្រឡប់មកវិញរបស់ព្រះយេស៊ូទាំងនេះ បានបង្ហាញឱ្យអ្នកដើរតាមទ្រង់ជាច្រើនជឿថាទ្រង់គឺជាអាទិទេព។ ពួកគេជឿថា ព្រះយេស៊ូបានលះបង់ជីវិតរបស់ទ្រង់ដើម្បីជាប្រយោជន៍ដល់ព្រះរាជាណាចក្ររបស់ព្រះជាម្ចាស់។ តាមរយៈការសុគត់ និងការរស់ឡើងវិញរបស់ព្រះយេស៊ូ ព្រះជាម្ចាស់នឹងនាំជីវិតថ្មីមកកាន់ពិភពលោក។ ពិភពលោកនេះគឺជាពិភពដែលអំពើបាប និងសេចក្តីស្លាប់ត្រូវបរាជ័យ។ អ្នកដើរតាមព្រះយេស៊ូបាននិយាយថា អ្នកទាំងឡាយណាដែលជឿលើរឿងនេះ ពួកគេនឹងក្លាយជាផ្នែកមួយនៃព្រះជាម្ចាស់។

យោងទៅតាមគ្រីស្តសាសនិក ការចងព្រះយេស៊ូនៅលើឈើឆ្កាងត្រូវបានគេធ្វើឡើងនៅថ្ងៃសុក្រ ហើយការរស់ឡើងវិញរបស់ទ្រង់គឺនៅថ្ងៃអាទិត្រ។ ថ្ងៃបុណ្យរបស់ពួកគ្រីស្តសាសនិកថ្ងៃសុក្រដ៏ល្អ និងថ្ងៃអាទិត្យអ៊ីស្ទ័រ ដែលជាការរំលឹកអំពីព្រឹត្តិការណ៍ទាំងពីរនេះ ត្រូវបានគេប្រារព្ធឡើងចាប់តាំងពីពេលនោះមកដល់សព្វថ្ងៃ។

ទាញសេចក្តីសន្និដ្ឋាន៖ ពិភាក្សាអំពីមូលហេតុដែលនាំឱ្យពួកគ្រីស្តសាសនិកនានាជឿថាមានជាតិបន្ទាប់។

### 4. គ្រីស្តសាសនាដំបូង

សំណួរគន្លឹះ៖ តើពួកសាវ័ករបស់ព្រះយេស៊ូបានធ្វើអ្វីខ្លះបន្ទាប់ពីការសុគត់របស់ទ្រង់?

សាវ័កដំបូងរបស់ព្រះយេស៊ូគឺពួកជ្វីប។ បន្តិចម្តងៗ ពួកគេបានអភិវឌ្ឍជំនឿ និងការប្រតិបត្តិនានាដែលនាំទៅដល់ការបែកចេញពីសាសនាយូដាហើយជំនឿថ្មីនេះត្រូវបានគេស្គាល់ថាគ្រីស្តសាសនា។

ព្រះវិហារដំបូង៖ ពួកសាវ័កទ្រង់បានគិតថា ព្រះយេស៊ូគឺជាមនុស្សម្នាក់ដែលត្រូវទៅនឹងការព្យាករណ៍របស់ពួកជ្វីបអំពីមេសស៊ៃ។ ពួកសាវ័កទាំងនោះព្យាយាមនៅក្នុងការបញ្ចុះបញ្ចូលប្រជាជនជ្វីបផ្សេងៗទៀតឲ្យជឿថាព្រះយេស៊ូគឺជាមេសស៊ៃ។

ព្រះវិហារដំបូងបានផ្តោតសំខាន់ទៅលើការចែករំលែកទ្រព្យសម្បត្តិ ក៏ដូចជាការធ្វើអំពើមនុស្សធម៌, ការជួយអ្នកទោស, និងញ៉ាំអាហារជុំគ្នា។ ស្ត្រី និងទាសករត្រូវបានគេអនុញ្ញាតឱ្យចូលរួមផងដែរ ប្រហែលជាដោយសារតែ

ព្រះវិហារដែលបង្កើតឡើងថ្មីនេះបានបង្រៀនថា សមាជិកទាំងអស់គឺស្មើគ្នា។ ជំនឿនេះបាននាំឱ្យព្រះវិហារដំបូងនេះរីកចេញពីសាសនាផ្សេងនៅពេលនោះ។ សាវ័កទាំងឡាយមានសេចក្ដីសង្ឃឹមនៅក្នុងការសាយភាយសាររបស់ព្រះយេស៊ូ និងកែប្រែអ្នកផ្សេងៗទៀតឲ្យជឿតាមពួកគេ។

ការលេចឡើងនូវជម្លោះ៖ សមាជិកដំបូងៗរបស់ព្រះវិហារសាសនាគ្រឹស្តគឺជាពួកជ្វីប ដែលបានកែប្រែជំនឿរបស់ពួកគេទៅជាគ្រឹស្តសាសនា។ ការផ្លាស់ប្ដូរសាសនារបស់ជនបរទេស ឬប្រជាជនដែលមិនមែនជាជនជាតិជ្វីបទៅគ្រឹស្តសាសនា នាំឱ្យមានការពិភាក្សាដេញដោលមួយ។ អ្នកមួយចំនួនគិតថា ជនបរទេសគួរតែប្រតិបត្តិតាមគម្ពីរតូរ៉ោះ ខណៈពេលដែលមនុស្សមួយចំនួនទៀតគិតថាការប្រតិបត្តិនេះមិនមានលក្ខណៈចាំបាច់ឡើយ។

ដំបូងឡើយ មេដឹកនាំរ៉ូមមិនអើពើនឹងពួកគ្រឹស្តសាសនិកដំបូងនេះទេ។ ក៏ដូចជាគ្រឹស្តសាសនិកខ្លួនគេផ្ទាល់ពួករ៉ូមយល់ថា សាសនាគ្រឹស្តគ្រាន់តែជានិកាយមួយ ឬជាផ្នែកមួយនៃសាសនាយូដា។ ប៉ុន្តែ មេដឹកនាំជ្វីបនានាមិនយល់ស្របជាមួយនឹងការយល់ឃើញនេះឡើយ។

សង្ខេប៖ ពិពណ៌នាពីការប្រព្រឹត្តរបស់សាវ័កព្រះយេស៊ូ បន្ទាប់ពីទ្រង់សុគត់។

## 5. ប៉ូលសាយភាយគ្រឹស្តសាសនា

សំណួរគន្លឹះ៖ តើប៉ូលធ្វើដំណើរទៅទីណាខ្លះ? ហេតុអ្វី?

មនុស្សដែលបានក្លាយជាមេដឹកនាំព្រះវិហារសាសនាគ្រឹស្តដំបូងគឺសូល ដែលមានដើមកំណើតជាជនជាតិជ្វីប។ ក្នុងនាមជាយុវជនមួយរូប លោកបានសរសេរអំពីវិធីដែលលោកបានប្រឆាំងយ៉ាងខ្លាំងក្លាជាមួយនឹងព្រះវិហារសាសនាគ្រឹស្ត។ ក្រោយមកជំនឿរបស់លោកបានផ្លាស់ប្ដូរ។

ផ្លូវទៅកាន់ដាម៉ាកូស៖ ខណៈពេលធ្វើដំណើរទៅដាម៉ាកូស សូលបានជួបបទពិសោធន៍នៃការផ្លាស់ប្ដូរជំនឿសាសនាយ៉ាងឆាប់រហ័សមួយ។ យោងទៅតាមរឿងផ្ទាល់របស់លោក សូលមានអារម្មណ៍ថា ព្រះជាម្ចាស់បានបង្កើតព្រះយេស៊ូក្នុងនាមជាបុត្រារបស់ទ្រង់ ហើយចាត់តាំងសូលឱ្យផ្សព្វផ្សាយអំពីព្រះយេស៊ូក្នុងចំណោមជនបរទេសទាំងឡាយ។ សូលជឿថាព្រះយេស៊ូគឺជាមេសស៊ីរបស់ពួកជ្វីប។ មូលដ្ឋានគ្រឹះនៃវប្បធម៌ និងនយោបាយរបស់សូល បានជួយលោកនៅក្នុងការកែប្រែជំនឿរបស់មនុស្សទាំងឡាយ។ ក្នុងនាមជាអ្នកប្រកាន់សាសនាតឹងរឹងមួយរូប សូលស្គាល់ច្បាស់អំពីច្បាស់ជនជាតិជ្វីប។ លោកកើតនៅតាស៊ូស ដែលជាទីក្រុងមួយនៅអាស៊ីកណ្ដាលដែលទទួលឥទ្ធិពលវប្បធម៌ក្រិកយ៉ាងខ្លាំងក្លា។ សូលមានសញ្ជាតិរ៉ូម ដែលអាចអនុញ្ញាតឱ្យលោកធ្វើដំណើរដោយសេរីនៅពាសពេញចក្រភព។ នៅពេលដែលលោកធ្វើដំណើរ សូលបានប្រើឈ្មោះរ៉ូមរបស់លោកប៉ូល។ បន្ទាប់ពីធ្វើដំណើរអស់រយៈពេល 3 ឆ្នាំ យោងទៅតាមរូបចម្លាក់របស់សាសនាគ្រឹស្ត ប៉ូលបានក្លាយជាអ្នកធ្វើដំណើរក្នុងនាមជាបេសកទូតសាសនា ដែលជាមនុស្សម្នាក់ដែលគេបញ្ជូនទៅកន្លែងផ្សេងៗដើម្បីធ្វើការងាររឿងសាសនា។ អំឡុងពេលនៃការរស់នៅរបស់ប៉ូល ចក្រភពរ៉ូមបានជួបប្រទះនៃភិចរ៉ូម៉ាណា ឬ"សន្តិភាពនៅរ៉ូម"។ ដែលធ្វើឱ្យផ្លូវនានានៅក្នុងចក្រភពមានសុវត្ថិភាពសម្រាប់ការធ្វើដំណើរផ្សព្វផ្សាយសាសនារបស់ប៉ូល។

ការធ្វើដំណើរដែលនាំឲ្យមានផ្លាស់ប្តូរសាសនាគ្រឹស្ត៖ ទោះជាយ៉ាងណាក៏ដោយ ការធ្វើដំណើររបស់ប៉ូល មិនមានភាពងាយស្រួលឡើយ។ ការធ្វើដំណើរទៅផ្សព្វផ្សាយសាសនាចំនួន 4 លើក។ មួយលើកៗត្រូវចំណាយពេលអស់ជាច្រើនឆ្នាំ។ ប៉ូល និងបេសកទូតសាសនាផ្សេងៗទៀតបាននាំមកនូវការផ្លាស់ប្តូរនានា ដែលនាំឱ្យសាសនាគ្រឹស្តរីកសាយភាយនៅពាសពេញចក្រភពរ៉ូម។ អស់រយៈពេលជាច្រើនឆ្នាំ ប៉ូល និងមេដឹកនាំសាសនាគ្រឹស្តដំបូងៗមួយចំនួនទៀត បានតស៊ូពុះពារជាមួយនឹងរឿងមួយ ដែលថា តើពួកជនបរទេសត្រូវតែក្លាយជាជនជាតិជ្វីបសិនមុនពេលដែលពួកគេក្លាយជាគ្រឹស្តសាសនា ឬក៏យ៉ាងណា។ ប៉ូលបានទទូចថា ការផ្លាស់ប្តូរទៅសាសនាយូដាគឺមិនមានភាពចាំបាច់ឡើយ។ ជំនឿរបស់ប៉ូលនាំឱ្យមានការញែកចេញពីគ្នារវាងគ្រឹស្តសាសនា និងសាសានាយូដា។ វាក៏បានបង្កើតសាសនាថ្មីមួយដែលកាន់តែទាក់ទាញដល់ជនបរទេស។ ជាលទ្ធផល សាសនាគ្រឹស្តបានចាប់ផ្តើមរីកសាយភាយនៅពាសពេញចក្រភព។

សំបុត្រ៖ ប៉ូលចាប់ផ្តើមបង្កើតព្រះវិហារថ្មីជាច្រើន និងធ្វើទំនាក់ទំនងជាមួយព្រះវិហារទាំងនេះតាមរយៈការសរសេរសំបុត្រ។ សំបុត្ររបស់ប៉ូលបានពន្យល់អំពីជំនឿរបស់គ្រឹស្តសាសនា និងទទូចឱ្យធ្វើការកែប្រែរបៀបរស់នៅតាមច្បាប់របស់ព្រះជាម្ចាស់។ លោកប្រៀនប្រដៅថា សេចក្តីសង្គ្រោះគឺមានរាល់សម្រាប់អ្នកទាំងឡាយណាដែលជឿលើព្រះយេស៊ូ។ សំបុត្ររបស់ប៉ូលគឺស្ថិតនៅក្នុងចំណោមបណ្តុំសំបុត្រដែលបណ្តុំនៃសំបុត្រនេះបានក្លាយជាផ្នែកមួយនៃគម្ពីរតេកសាសនាថ្មី។ នៅក្នុងបណ្តុំសំបុត្រដ៏ល្បីល្បាញមួយ ប៉ូលបានសរសេរថា ការជឿលើព្រះយេស៊ូបានបំបាត់នូវរនាំងទាំងឡាយរវាងមនុស្សនិងមនុស្ស។

ការស្លាប់របស់ប៉ូល និងកេរ្តិ៍ដំណែល៖ ប៉ូលមានបំណងចង់ធ្វើដំណើរទៅកាន់រ៉ូមដើម្បីសាយភាយជំនឿគ្រឹស្តសាសនារបស់លោក។ លោកបានធ្វើដំណើរទៅដល់រ៉ូមមែន ប៉ុន្តែវាមិនដូចអ្វីដែលលោកសង្ឃឹមឡើយ។ នៅជិតចុងបញ្ចប់នៃជីវិតរបស់លោក ប៉ូលបានត្រឡប់មកកាន់យេរ៉ូសាឡឹមវិញ។ លោកត្រូវបានពួករ៉ូមចាប់ឃុំឃាំងនៅពេលដែលមានពាក្យចចាមអារ៉ាមថា លោកបាននាំយកជនបរទេសចូលទៅក្នុងប្រាសាទ។ បន្ទាប់ពីជាប់ក្នុងគុកអស់រយៈពេល 2 ឆ្នាំ ប៉ូលបានទាមទារឱ្យមានការជំនុំជម្រះនៅចំពោះមុខសេសារនៅរ៉ូម។ ប៉ូលបានធ្វើដំណើរជាលើកចុងក្រោយទៅកាន់រ៉ូមនៅចុងសរទរដូវឆ្នាំ 59 នៃគ.ស។ បន្ទាប់ពីធ្វើដំណើរមកដល់រ៉ូមនៅដើមឆ្នាំ 60 នៃគ.ស ប៉ូលត្រូវបានគេបន្តឃុំឃាំងនៅក្នុងផ្ទះអស់រយៈពេល 2 ឆ្នាំ។ លោកបានសរសេរសំបុត្រជាច្រើនអំពេលដែលលោកត្រូវបានគេចាប់ឃុំឃាំង។ បន្ទាប់មកលោកក៏បានបញ្ឈប់ការសរសេរតទាំងនោះ។ ប៉ូលប្រហែលជាស្លាប់នៅរ៉ូម។

ប៉ូលគឺជាសាវ័ក ឬអ្នកនាំសាររបស់ព្រះយេស៊ូដ៏មានឥទ្ធិពលដំបូងបំផុត ដោយសារតែការធ្វើដំណើរជាច្រើនលើក និងសំបុត្រជាច្រើនរបស់លោក។ លោកបានជួយដល់ការសាយភាយព្រះវិហារពីទឹកដីកំណើររបស់ព្រះយេស៊ូទៅកាន់តំបន់ផ្សេងៗទៀតនៅលើពិភពលោក។

សង្ខេប៖ ពិពណ៌នាអំពីការធ្វើដំណើររបស់ប៉ូល និងមូលហេតុនៃការធ្វើដំណើរទាំងនោះ។

# ជំពូក 10 ៖ ការធ្លាក់ចុះនៃចក្រភពរ៉ូម និងកើតដំណែល

## មេរៀនទី 1 ៖ រ៉ូម និងសាសនាគ្រឹស្ត

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកបានរៀនរួចមកហើយថា ជំនឿសាសនារបស់ពួករ៉ូមបានទទួលរងឥទ្ធិពលមកពីសាសនាដើម។ ដូចដែលសាសនាគ្រឹស្តបានរីកសាយភាយនៅពាសពេញពិភពលោកនៅមុនឆ្នាំ 100 នៃគ.ស ដូច្នេះ រ៉ូមបានព្យាយាមនៅក្នុងការគ្រប់គ្រងសាសនាថ្មីនេះ។

### 1. គោលនយោបាយរបស់រ៉ូមចំពោះសាសនាគ្រឹស្ត

សំណួរគន្លឹះ៖ តើរ៉ូមមានប្រតិកម្មយ៉ាងដូចម្តេចចំពោះគ្រឹស្តសាសនា?

ជាទូទៅ រ៉ូមមានការយោគយល់ចំពោះការប្រតិបត្តិសាសនារបស់ប្រជាជនក្នុងដែនដីដែលគេដណ្តើមកាន់កាប់។ ឧទាហរណ៍ ពួកគេមិនបានតម្រូវឱ្យពួកជ្វីបគោរពបូជាអធិរាជ និងអាទិទេពផ្សេងៗទៀតរបស់រ៉ូមឡើយ។ ប៉ុន្តែ រ៉ូមនឹងមិនអនុញ្ញាតឱ្យសាសនារបស់ប្រជាជនទាំងនោះបង្កើតឱ្យមានការបះបោរឡើយ។ សម្រាប់ហេតុផលនេះ នៅពេលដែលមានការបះបោរមួយរបស់ពួកជ្វីបកើតឡើងនៅយេរ៉ូសាឡឹម រ៉ូមបានកម្ទេចប្រាសាទរបស់ពួកជ្វីបនៅក្នុងឆ្នាំ 70 នៃគ.ស។

ការគំរាមកំហែងរបស់ពួកគ្រឹស្តសាសនិក៖ ការបដិសេធរបស់ពួកគ្រឹស្តសាសនិកនៅក្នុងការគោរពបូជាអាទិទេពនានារបស់រ៉ូម ត្រូវបានគេមើលឃើញថាជាទម្រង់នៃការបះបោរមួយ។ ជាងនេះទៅទៀត ការទាក់ទាញនៃគ្រឹស្តសាសនាចំពោះទាសករ និងស្ត្រីនាំឱ្យមានការព្រួយបារម្ភកាន់តែខ្លាំង។ ចុងក្រោយ ការនិយាយអំពីមេដឹកនាំម្នាក់ដែលនឹងបង្កើតព្រះរាជាណាចក្រថ្មីមួយ ហាក់ដូចជាបង្ហាញថាចក្រភពរ៉ូមនឹងត្រូវបញ្ចប់។ ដូចដែលជនបរទេស (អ្នកទាំងឡាយណាដែលមិនមែនជាជនជាតិជ្វីប)ជាច្រើន បានចូលរួមជាមួយចលនាគ្រឹស្តសាសនាតាមរយៈការកែប្រែជំនឿទៅជឿលើគ្រឹស្តសាសនា នាំឱ្យរ៉ូមយល់ថានេះគឺជាគំរាមកំហែងមួយ។

ការធ្វើទុក្ខបុកម្និញរបស់ពួករ៉ូម៖ ការភ័យខ្លាចរបស់រ៉ូមអំពីគ្រឹស្តសាសនា បានបង្កឱ្យមានការវាយប្រហារយ៉ាងខ្លាំងក្លាលើពួកគ្រឹស្តសាសនិក។ មេដឹកនាំរ៉ូមមួយចំនួនបានស្តីបន្ទោសដល់គ្រឹស្តសាសនិកថាជាអ្នកបង្កឱ្យមានបញ្ហានយោបាយ និងសេដ្ឋកិច្ច។ ក្នុងនោះ អធិរាជនេរ៉ូបានចោទប្រកាន់ពួកគ្រឹស្តសាសនិកដែលបង្កើតឱ្យមានការវាយប្រយុទ្ធមួយនៅក្នុងឆ្នាំ 64 នៃគ.ស ដែលអន្តរាយយ៉ាងខ្លាំងដល់រ៉ូម។ អំឡុងសតវត្សរ៍ទី 2 នៃគ.ស ការធ្វើទុក្ខបុកម្និញលើពួកគ្រឹស្តសាសនិកចាប់ផ្តើមមានភាពខ្លាំងក្លា។ មានមនុស្សជាច្រើនត្រូវបានគេចាប់ដាក់គុក ឬសម្លាប់ចោលដោយសារតែសាសនារបស់ពួកគេ។ ប៉ុន្តែ នៅតែមានមនុស្សជាច្រើនផ្លាស់ប្តូរសាសនារបស់ពួកគេទៅគ្រឹស្តសាសនា។

គ្រឹស្តសាសនិកផ្សេងៗទៀត ឬសូម្បីតែអ្នកមិនមែនគ្រឹស្តសាសនាមួយចំនួនចាត់ទុកអ្នកដែលត្រូវបានគេធ្វើទុក្ខបុកម្និញនេះថាជា ទុក្ករបុគ្គល។ ទុក្ករបុគ្គលគឺជាមនុស្សទាំងឡាយណាដែលស្ម័គ្រចិត្តនៅក្នុងការបូជាជីវិត

របស់ពួកគេសម្រាប់ប្រយោជន៍សាសនា ឬប្រយោជន៍អ្វីមួយ។ អំឡុងពេលនៃការធ្វើទុក្ខបុកម្និញរបស់ពួករ៉ូម ពួកទុក្ករបុគ្គលគ្រីស្តសាសនិកតែងតែត្រូវបានគេបញ្ចុះនៅកន្លែងបញ្ចុះសពលួចលាក់ដែលគេហៅថាកាតាខុម។ ពួកគ្រីស្តសាសនិកបានប្រមូលផ្តុំគ្នានៅ កាតាខុម ដើម្បីប្រារព្ធពិធីបុណ្យសពជូនដល់ទុក្ករបុគ្គល ក៏ដូចជាប្រារព្ធសួនពិធី និងពិធីបុណ្យនានា។

សាសនាជាសកលមួយ៖ បើទោះបីជាមានការធ្វើទុក្ខបុកម្និញចំពោះអ្នកដើរតាមក៏ដោយសាសនាគ្រីស្តបានក្លាយជាកម្លាំងដ៏ខ្លាំងក្លាមួយ។ នៅចុងទសវត្សឆ្នាំ 200 មានគ្រីស្តសាសនិករាប់លាននាក់រស់នៅក្នុងចក្រភពរ៉ូម និងតំបន់ផ្សេងៗទៀត។ គ្រីស្តសាសនាមានប្រជាប្រិយភាពដោយសារតែហេតុផលមួយចំនួន៖

1. សាសនារួមបញ្ចូលមនុស្សទាំងអស់៖ បុរស និងស្ត្រី, ទាសករ, អ្នកក្រ, និងអភិជន។
2. វាបានផ្តល់សេចក្តីសង្ឃឹមដល់អ្នកទន់ខ្សោយ។
3. ជំនឿខាងផ្លូវអារម្មណ៍កើតមានឡើងចំពោះអ្នកទាំងឡាយណាដែលមិនសប្បាយចិត្តជាមួយនឹងជីវិតរស់នៅបែបប្រណិតភាពរបស់ពួកអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភរ៉ូម។
4. សាសនាគ្រីស្តបានផ្តល់ឱ្យបុគ្គលម្នាក់នូវទំនាក់ទំនងជាមួយអាទិទេពដ៏គួរឱ្យស្រលាញ់មួយអង្គ។
5. ការអប់រំរបស់គ្រីស្តសាសនាបានសន្យាពីអនន្តភាពនៃជីវិតបន្ទាប់ពីការស្លាប់។

ដូចដែលសាសនាបានរីកចម្រើន សហគមន៍គ្រីស្តសាសនាបានផ្តល់ការគាំទ្រដល់សមាជិករបស់ពួកគេ។ ពួកគ្រីស្តសាសនិកបានបង្កើតមន្ទីរពេទ្យ, សាលារៀន, នឹងសេវាសង្គមផ្សេងៗទៀត។ ជាលទ្ធផល សទ្ធារបស់ពួកគេបានទាក់ទាញអ្នកដើរតាមកាន់តែច្រើនឡើង។ ក្រោយមក សមាជិករបស់ពួកគេបានរួមបញ្ចូលអ្នកមានអំណាចដ៏ខ្លាំងក្លាមួយរូប។

សង្ខេប៖ ពិភាក្សាអំពីប្រតិកម្មរបស់រ៉ូមចំពោះគ្រីស្តសាសនា។

## 2. ការផ្លាស់ប្តូរសាសនារបស់ខុនស្ទេនទីន

សំណួរគន្លឹះ៖ ហេតុអ្វីបានជាខុនស្ទេនទីនផ្លាស់ប្តូរមកកាន់គ្រីស្តសាសនា?

នៅក្នុងឆ្នាំ 306 ខុនស្ទេនទីនបានក្លាយជាអធិរាជរបស់រ៉ូម។ ដំបូងខុនស្ទេនទីនបានអនុញ្ញាតឱ្យមានការធ្វើទុក្ខបុកម្និញលើពួកគ្រីស្តសាសនិក។ ប៉ុន្តែ នៅក្នុងឆ្នាំ 312 ទ្រង់បានផ្លាស់គោលនយោបាយចំពោះគ្រីស្តសាសនា នៅពេលដែលទ្រង់កំពុងធ្វើសង្គ្រាមជាមួយនឹងគូរសត្រូវ 3 ដើម្បីបន្តគ្រប់គ្រងរ៉ូម។

សញ្ញាកាកបាទ៖ នៅក្នុងពេលកំពុងប្រយុទ្ធគ្នាខុនស្ទេនទីនបានបន់ស្រន់សុំជំនួយ។ ក្រោយមកទ្រង់អះអាងថាបានឃើញសញ្ញាកាកបាទរបស់គ្រីស្តសាសនាមួយនៅលើមេឃ ជាមួយនឹងពាក្យ "ជាមួយនឹងសញ្ញានេះអ្នកនឹងទទួលបានជ័យជំនះ"។ ទ្រង់បានបញ្ជាឱ្យកងទ័ពរបស់ទ្រង់ដាក់សញ្ញាកាកបាទនេះនៅលើខែល និងទង់សង្គ្រាមរបស់ពួកគេ។ ខុនស្ទេនទីន និងកងទ័ពរបស់ទ្រង់បានទទួលជ័យជំនះនៅក្នុងសមរភូមិ។ អធិរាជខុនស្ទេនទីនបានដឹងគុណចំពោះព្រះជាម្ចាស់របស់គ្រីស្តសាសនិកសម្រាប់ជ័យជំនះនេះ។

ការធ្វើឱ្យគ្រីស្តសាសនាស្របច្បាប់៖ ខុនស្ទែនទីន ភ្លាមៗបានបញ្ចប់ការធ្វើទុក្ខបុកម្និញចំពោះគ្រីស្តសាសនិក។ បន្ទាប់មក នៅក្នុងរាជក្រឹតមួយដែលគេស្គាល់ថាបទបញ្ញត្តិនៅមីឡាន ទ្រង់បានធ្វើឱ្យសាសនាគ្រីស្តក្លាយជាសាសនាស្របច្បាប់នៅក្នុងចក្រភពរ៉ូម។ ខុនស្ទែនទីនក៏បានស្ថាបនាព្រះវិហារ, ប្រើប្រាស់សញ្ញារបស់គ្រីស្តសាសនានៅលើកាក់, និងបានយកថ្ងៃអាទិត្យធ្វើជាថ្ងៃពិសិដ្ឋសម្រាប់ឈប់សម្រាក និងគោរពបូជា។ ប៉ុន្តែអធិរាជរ៉ូមដែលកាន់សាសនាគ្រីស្តដំបូងបានពន្យាពេលនៃការផ្លាស់ប្តូរសាសនាផ្លូវការរបស់ទ្រង់រហូតដល់ទ្រង់សោយទីវង្គត់។

គ្រីស្តសាសនាបានផ្លាស់ប្តូររ៉ូម៖ នៅក្នុងឆ្នាំ 380 អធិរាជថេអូដូស៊ូសបានធ្វើឱ្យសាសនាគ្រីស្តក្លាយជាសាសនាផ្លូវការរបស់រ៉ូម។ 11 ឆ្នាំក្រោយមកអធិរាជថេអូដូស៊ូសបានបិទនូវរាល់ប្រាសាទដែលមិនមែនគ្រីស្តសាសនាទាំងអស់។ ទ្រង់បាននិយាយថា "មនុស្សទាំងអស់ដែលយើងគ្រប់គ្រង ត្រូវតែប្រតិបត្តិសាសនាដែលសាវ័កពីទ័រ បានបញ្ជូនមកឱ្យរ៉ូម"។

វិភាគអំពីបុព្វហេតុ៖ ពន្យល់ពីមូលហេតុដែលនាំឱ្យខុនស្ទែនទីនផ្លាស់ប្តូរសាសនា។

### 3. ការចាប់ផ្តើមឡើងនៃព្រះវិហាររ៉ូម៉ាំងកាតូលិក

សំណួរគន្លឹះ៖ តើព្រះវិហារដំបូងមានជំនឿអ្វីខ្លះ?

គ្រីស្តសាសនានៅក្នុងទីក្រុងនានារបស់រ៉ូមមានរចនាសម្ព័ន្ធរួមគ្នាមួយ។ បុព្វជិក និងអ្នកមើលការខុសត្រូវព្រះវិហារត្រូវស្តាប់តាមព្រះសង្ឃរាជ ឬមេដឹកនាំព្រះវិហារ។ យោងទៅតាមប្រពៃណីរបស់រ៉ូម៉ាំងកាតូលិក ព្រះសង្ឃរាជរ៉ូមដំបូងគឺសាវ័កពីទ័រ។ ក្រោយមកទៀត ព្រះសង្ឃរាជនៅរ៉ូមបានក្លាយជាព្រះសង្ឃរាជដែលសំខាន់បំផុត ឬគេហៅថាសម្តេចប៉ាប។ នេះគឺជាសញ្ញាណនៃការចាប់ផ្តើមដំបូងនៃព្រះវិហាររ៉ូម៉ាំងកាតូលិក ព្រះវិហារសាសនាគ្រីស្តមួយដែលមានមូលដ្ឋាននៅរ៉ូម។ កាតូលិកមានន័យថា "សាកល"។

អ្នកនិពន្ធគ្រីស្តសាសនាដំបូងមួយចំនួន ដែលគេហៅថា លោកឪពុកក្នុងព្រះវិហារ បានអភិវឌ្ឍគោលជំនឿមួយ ឬ សេចក្តីថ្លែងការណ៍អំពីជំនឿ។ គោលជំនឿនេះបានរួមបញ្ចូលជំនឿមួយអំពីព្រះបីអង្គ ឬការលាយបញ្ចូលគ្នានៃអាទិទេព 3 រួមមានព្រះវរបិតា, រាជបុត្រ(ព្រះយេស៊ូ), និងព្រលឹងពិសិដ្ឋ នៅក្នុងព្រះជាម្ចាស់តែមួយ។ អូហ្គីសស្ទីដែលជាលោកឪពុកក្នុងព្រះវិហារមួយរូបមកពីអាហ្វ្រិកខាងជើងបានអប់រំថា មនុស្សត្រូវការការអនុគ្រោះពីព្រះជាម្ចាស់ដើម្បីសង្គ្រោះពួកគេ។ លោកបានបន្ថែមទៀតថា មនុស្សទាំងឡាយនឹងមិនអាចទទួលបានការសង្គ្រោះពីព្រះជាម្ចាស់បានឡើយ លុះត្រាតែពួកគេចូលរួមជាមួយព្រះវិហារ។ ព្រះវិហារក៏បានអភិវឌ្ឍក្បួនពិធីសាសនានានាដោយផ្តោតទៅលើព្រឹត្តិការណ៍នានាដែលបានកើតមានឡើងនៅក្នុងជីវិតរស់នៅរបស់ព្រះយេស៊ូ។ ពិធីលាងបាបគឺជាក្បួនពិធីមួយសម្រាប់ការលាងជម្រះដោយទឹកឱ្យបរិសុទ្ធ, ដែលជាសញ្ញាណនៃការចូលសាសនាគ្រីស្តរបស់ព្រះយេស៊ូ។ ក្បួនពិធីបានក្លាយជានិមិត្តរូបនៃការអនុញ្ញាតឱ្យអ្នកមានជំនឿទាំងឡាយចូលក្នុងសាសនា។ ដើម្បីថែរក្សាទម្រង់រស់នៅបែបគ្រីស្តសាសនា និងដើម្បីប្រារព្ធក្បួនពិធីទាំងនេះជាមួយគ្នា បុរស និងស្ត្រីដែលជាគ្រីស្តសាសនិកបានបង្កើតសហគមន៍មួយដែលគេហៅថាសហគមន៍បព្វជិក។ ក្រោយមកទៀត បុរសបានក្លាយជាអ្នក

ដែលមានតួនាទីខ្ពស់នៅក្នុងព្រះវិហារ ដោយបានក្លាយជាសង្ឃរាជ, បុព្វជិក, និងអ្នកមើលការខុសត្រូវព្រះវិហារ។ គ្រីស្តសាសនាបានផ្លាស់ប្តូរពីនិកាយតូចមួយទៅជាសាសនាដែលមានអំណាច និងទ្រព្យសម្បត្តិស្តុកស្តម្ភ។

ប៉ុន្តែ នៅខណៈពេលដែលគ្រីស្តសាសនាកំពុងរីកចម្រើន ចក្រភពរ៉ូមបែរជាចាប់ផ្តើមចុះអន់ថយទៅវិញ។ នៅមេរៀនក្រោយ អ្នកនឹងបានសិក្សាអំពីមូលហេតុនៃការធ្លាក់ចុះរបស់ចក្រភពរ៉ូម និងលទ្ធផលបន្ទាប់ពីការធ្លាក់ចុះនេះ។

វាយតម្លៃ៖ កំណត់អំពីជំនឿមួយចំនួនរបស់ព្រះវិហារគ្រីស្តសាសនាដំបូង។

# មេរៀនទី 2 ៖ ការធ្លាក់ចុះ និងការដួលរលំនៃចក្រភពរ៉ូម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ គិតថាបញ្ហាអ្វីដែលចក្រភពដ៏ធំនឹងប្រឈម រាប់ចាប់តាំងពីភាពខុសគ្នានៃសេដ្ឋកិច្ច រហូតដល់ការឈ្លានពានរបស់អ្នកខាងក្រៅ។ នៅក្នុងផ្នែកនេះ អ្នកនឹងបានសិក្សាអំពីការអភិវឌ្ឍឡើងនៃបញ្ហានានានៅក្នុងចក្រភពរ៉ូម ដែលមើលទៅហាក់ដូចជាគ្មានដំណោះស្រាយជាក់លាក់ណាមួយឡើយ។

## 1. ការចុះខ្សោយនៃចក្រភព

សំណួរគន្លឹះ៖ តើបញ្ហាអ្វីខ្លះដែលនាំឲ្យចក្រភពចុះខ្សោយ?

នៅចុងទសវត្សឆ្នាំ 100 ចក្រភពហាក់ដូចជានៅបន្តភាពខ្លាំងក្លាដដែល។ មិនទាន់មានបញ្ហាផ្ទៃក្នុងកើតមានឡើង ដែលនាំឱ្យមានការគំរាមកំហែងដល់ភាពរស់រានរបស់រ៉ូមឡើយ។

បញ្ហាសេដ្ឋកិច្ច៖ បញ្ហាមួយចំនួននៅរ៉ូមកើតឡើងដោយសារការចុះអន់ថយនៃសេដ្ឋកិច្ច។ អំឡុងទសវត្សរ៍ឆ្នាំ 100 ចក្រភពបានបញ្ឈប់ការពង្រីកដែនដីរបស់ខ្លួន។ ការបញ្ឈប់ការពង្រីកដែនដីថ្មី មានន័យថាជាការបញ្ចប់នូវការទទួលបានធនធានទ្រព្យសម្បត្តិថ្មី។ ជាលទ្ធផល រដ្ឋាភិបាលបានបង្កើនពន្ធ ដែលនាំឱ្យមានភាពលំបាកដល់ប្រជាពលរដ្ឋ។ ការចុះខ្សោយនៃវិស័យកសិកម្មក៏ជាកត្តាមួយដែលនាំឱ្យចក្រភពចុះអន់ថយផងដែរ។ ការប្រយុទ្ធគ្នាជាញឹកញាប់ និងការប្រើប្រាស់ច្រើនហួសហេតុ នាំឱ្យផ្ទៃដីកសិកម្មខូចខាត។ ជានេះទៅទៀត មិនមានការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាកសិកម្មឡើយ ដោយសារតែប្រជាកសិករភាគច្រើនពឹងផ្អែកតែទៅលើទាសករ ជាជាងពឹងផ្អែកជាឧបករណ៍ថ្មីៗដើម្បីធ្វើកសិកម្ម។ ជាលទ្ធផលនាំឲ្យមានកង្វះខាងស្បៀងអាហារ ដែលនាំឱ្យមានភាពចលាចលកើតឡើង។

បញ្ហាយោធា៖ ជាមួយនេះផងដែរ យោធារបស់រ៉ូមដែលជាយោធាដែលមានអំណាចខ្លាំងមួយ បានចាប់ផ្តើមបង្ហាញពីសញ្ញាណនៃការចុះអន់ថយ។ ចក្រភពទាំងមូលកើតមានសង្គ្រាមជាញឹកញាប់ជាមួយពួកចរកេជននៅភាគខាងជើង និងភាគឦសាន ក៏ដូចជាប្រជាជនដែលរស់នៅតាមព្រំដែនភាគខាងកើតរបស់ពួកគេផងដែរ។ រ៉ូមត្រូវការកម្លាំងយោធាច្រើនដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងទាំងនេះ ដូច្នេះពួកគេបានជួលទាហានស៊ីឈ្នួលបរទេស។ ទាហានស៊ីឈ្នួល គឺជាទាហានដែលគេអាចជួលបាន។ ទាហានស៊ីឈ្នួលជាញឹកញយតែងតែមិនមានភក្តីភាពចំពោះចក្រភពឡើយ។ ក្រោយមក កងទ័ពរបស់រ៉ូមជាទូទៅត្រូវបានគេមើលឃើញថាមិនសូវមានវិន័យ និងភក្តីភាពឡើយ។ ពួកគេមិនបានបង្ហាញពីភក្តីភាពរបស់ពួកគេចំពោះរ៉ូមឡើយ ប៉ុន្តែធ្វើឡើងចំពោះតែមេដឹកនាំយោធារបស់ពួកគេប៉ុណ្ណោះ។

បញ្ហានយោបាយ និងសង្គម៖ ទំហំដ៏ធំនៃដែនដីចក្រភពរ៉ូមនាំឱ្យមានភាពលំបាកនៅក្នុងការគ្រប់គ្រង។ មន្ត្រីរដ្ឋាភិបាលចាប់ផ្តើមជួបប្រទះបញ្ហា នៅក្នុងការទទួលបានព័ត៌មាននានាពីតំបន់ឆ្ងាយៗនៅក្នុងដែនដីចក្រភព។ កាលនេះ វាបានធ្វើឱ្យការលំបាកនៅក្នុងការស្វែងយល់ថាតើបញ្ហាបានអភិវឌ្ឍឡើងនៅទីកន្លែងណា។ ជាមួយនេះផងដែរ មន្ត្រីរដ្ឋាភិបាលមួយចំនួនជាមន្ត្រីដែលពុករលួយ សម្លឹងឃើញតែពីផលប្រយោជន៍ផ្ទាល់ខ្លួន។ បញ្ហានយោបាយ

ទាំងនេះមានបំផ្លាញនូវគំនិតអំពីភាពជាប្រជាពលរដ្ឋរបស់មនុស្សទាំងឡាយ។ ប្រជាជនរ៉ូមភាគជាច្រើនមិនយកចិត្តទុកដាក់កចំពោះការអនុវត្តករណីយកិច្ចសម្រាប់ចក្រភពទៀតឡើយ។ ទម្រង់ផ្សេងទៀតនៃសង្គមរបស់រ៉ូមក៏ជួបប្រទះបញ្ហាផងដែរ។ ការចំណាយសម្រាប់ថ្លៃសិក្សាបានកើនឡើង ដូច្នេះប្រជាជនរ៉ូមដែលក្រីក្រមានការលំបាកនៅក្នុងការទទួលបានការអប់រំ។ មនុស្សនៅក្នុងសង្គមទទួលបានព័ត៌មានតិចតួចអំពីបញ្ហាដែលកើតមាននៅក្នុងសង្គម។

សង្ខេប៖ ពិភាក្សាបញ្ហាដែលនាំឱ្យរ៉ូមចុះខ្សោយ។

## 2. រ៉ូមបានបែងចែកទៅជារ៉ូមខាងកើត និងរ៉ូមខាងលិច

សំណួរគន្លឹះ៖ ហេតុអ្វីបានជារ៉ូមបែកជាចក្រភពពីរ ?

ការផ្លាស់ប្តូរអធិរាជញឹកញាប់ ក៏នាំឱ្យរដ្ឋាភិបាលចុះខ្សោយផងដែរ។ ក្នុងរយៈពេល 49 ឆ្នាំ ចាប់ពីឆ្នាំ 235 ដល់ 284 រ៉ូមមានអធិរាជ 37 អង្គ។ ក្នុងចំណោមនេះ អធិរាជ 34 អង្គសុគត់ដោយសារសង្គ្រាមស៊ីវិល ឬដោយការលួចធ្វើឃាត។ ដោយសារតែការផ្លាស់ប្តូរអធិរាជញឹកញាប់ ប្រជាជនរ៉ូមមិនសូវយកចិត្តចំពោះច្បាប់នៃការឡើងស្នងរាជ្យឡើយ។

ការបែងចែកចក្រភព៖ នៅក្នុងឆ្នាំ 284 អធិរាជឌីអូក្លេតៀនបានឡើងគ្រប់គ្រងអំណាច។ ទ្រង់បានរៀបចំសណ្តាប់ធ្នាប់នៅក្នុងចក្រភពលោកវិញ តាមរយៈការដឹកនាំតាមរបៀបតឹងរឹង និងការយោគយល់តិចតួចចំពោះក្រុមអ្នកប្រឆាំង។ ឌីអូក្លេតៀនបានផ្លាស់ប្តូររបៀបនៃការធ្វើការងាររបស់យោធា ដោយដាក់កងទ័ពជាអចិន្ត្រៃយ៍នៅតាមព្រំដែនរបស់ចក្រភព។ ទ្រង់ក៏ធ្វើកំណែទម្រង់សេដ្ឋកិច្ចផងដែរ។ ដោយក្នុងនោះ ទ្រង់បានផ្តល់អាហារដល់អ្នកក្រីក្រ ទ្រង់រក្សាតម្លៃនំប៉ុងឱ្យនៅទាប។ ជាមួយគ្នានេះដែរ ឌីអូក្លេតៀនយល់ច្បាស់ថាទ្រង់មិនអាចគ្រប់គ្រងដោយមានប្រសិទ្ធភាពលើដែនដីចក្រភពដ៏ធំធេងបែបនេះឡើយ។ នៅក្នុងឆ្នាំ 285 ទ្រង់បានបែងចែកចក្រភពជាពីរផ្នែក គឺចក្រភពខាងកើត និងចក្រភពខាងលិច ដោយក្នុងនោះទ្រង់បានជ្រើសរើសយកចក្រភពខាងកើតសម្រាប់ការគ្រប់គ្រងរបស់ទ្រង់។ ទ្រង់ជ្រើសរើសតំបន់នេះដោយសារតែវាសំបូរទៅដោយទ្រព្យសម្បត្តិ និងសកម្មភាពពាណិជ្ជកម្ម បូករួមជាមួយនឹងទីក្រុងដ៏ស្រស់ឆើតឆាយ។ ឌីអូក្លេតៀនបានតែងតាំងម៉ាស៊ីមីលៀនដើម្បីឱ្យគ្រប់គ្រងនៅចក្រភពខាងលិច។ មេដឹកនាំទាំងពីររូបនេះដឹកនាំអស់រយៈពេល 20 ឆ្នាំ។

រាជធានីថ្មី៖ នៅក្នុងឆ្នាំ 306 សង្គ្រាមស៊ីវិលមួយផ្ទុះឡើងដើម្បីគ្រប់គ្រងចក្រភព។ មេបញ្ជាការយោធា 4 រូបបានវាយប្រយុទ្ធគ្នាដើម្បីគ្រប់គ្រងចក្រភពទាំងពីរនេះ។ មេបញ្ជាការម្នាក់នៅក្នុងចំណោមនេះគឺកុងស្តង់ទីន។ គាត់ទទួលបានអំណាចនៅក្នុងការគ្រប់គ្រងនៅអំឡុងសង្គ្រាមស៊ីវិល ហើយក្រោយមកបានក្លាយជាអធិរាជ។ នៅក្នុងមេរៀនមុន អ្នកបានដឹងរួចមកហើយថាកុងស្តង់ទីនបានប្រែក្លាយខ្លួនទ្រង់ជាគ្រីស្តសាសនិកផ្លូវការ។ សកម្មភាពសំខាន់ទី 2 របស់កុងស្តង់ទីន បានកើតមានឡើយនៅក្នុងឆ្នាំ 330 នៅពេលដែលទ្រង់បានផ្លាស់រាជធានីរបស់ចក្រភពពីរ៉ូមទៅកាន់ទីក្រុងបុរាណរបស់ក្រិកប៊ីហ្សង់ទីន។ កុងស្តង់ទីនបានប្តូរឈ្មោះទីក្រុងនោះថាកុងស្តង់ទីណុប។ ស្ថិតនៅលើផ្លូវខ្វែងគ្នាមួយរវាងខាងកើត និងខាងលិច ទីក្រុងត្រូវបានគេរៀបចំការការពារ និងការធ្វើពាណិជ្ជកម្ម

យ៉ាងល្អប្រសើរ។ រាជធានីនេះគឺជាសញ្ញាណមួយនៃការផ្លាស់អំពីណាចពីចក្រភពភាគខាងលិចទៅកាន់ចក្រភពភាគខាងកើត។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីមូលហេតុដែលនាំឱ្យរ៉ូមបែកចេញជាពីរផ្នែក។

### 3. ការដួលរលំនៃចក្រភពខាងលិច

សំណួរគន្លឹះ៖ តើកត្តាអ្វីដែលបណ្តាលឱ្យចក្រភពខាងលិចដួលរលំ?

បូកបន្ថែមជាមួយភាពលំបាកនៅខាងក្នុង ពួករ៉ូមក៏ប្រឈមជាមួយបញ្ហាសំខាន់មួយទៀតផងដែរ។ ក្រុមជនបរទេសចាប់ផ្តើមប្រមូលផ្តុំគ្នានៅជុំវិញព្រំដែនរ៉ូម។ ក្រោយមកពួកគេនឹងធ្វើការឈ្លានពាន ហើយចក្រភពនឹងចុះខ្សោយបន្តិចម្តងៗ ដែលនឹងនាំទៅដល់ការដួលរលំយ៉ាងឆាប់រហ័ស។

ការឈ្លានពាន និងការដណ្តើមកាន់កាប់៖ ក្រុមជនជាតិអាឡឺម៉ង់ជាច្រើនក្រុម ជាមួយនិងក្រុមជនជាតិដ៏ទៃទៀតរស់នៅឆ្ងាយពីព្រំដែនរបស់រ៉ូម។ ពួករ៉ូមមើលស្រាលទៅលើក្រុមទាំងអស់នេះ ប៉ុន្តែក៏មានការភ័យខ្លាំងខ្លះដែរ។ សម្រាប់ពួករ៉ូម ពួកគេគិតថាប្រជាជនអាឡឺម៉ង់គឺជាមនុស្សព្រៃភ្នំ។ សម្រាប់ពួករ៉ូមសម័យបុរាណ ពាក្យថាមនុស្សព្រៃភ្នំ មានន័យថា មនុស្សទាំងឡាយណាដែលជាមនុស្សបុរេ និងមិនមានអរិយធម៌។ ពួករ៉ូមបានប្រើប្រាស់ពាក្យនេះហៅសំដៅទៅលើអ្នកទាំងឡាយណាដែលរស់នៅក្រៅដែនដីចក្រភព។

អំឡុងនៃចុងទសវត្សរ៍ឆ្នាំ 300 ក្រុមជនជាតិអាឡឺម៉ង់ទាំងនេះចាប់ផ្តើមធ្វើដំណើរមកកាន់ទឹកដីរបស់រ៉ូម។ មូលហេតុដែលនាំឱ្យពួកគេឈ្លានពានទឹកដីរបស់រ៉ូមមានច្រើន។ ក្រុមមួយចំនួនធ្វើដំណើរមកកាន់ទឹកដីរ៉ូមដើម្បីស្វែងរកដីល្អ ឬស្វែករកទ្រព្យសម្បត្តិរបស់ពួករ៉ូម។ ក្រុមមួយចំនួនធំ បានរត់គេចពីក្រុមអ្នកឈ្លានពានដ៏សាហាវឃោឃៅមួយក្រុមដែលធ្វើដំណើរមកពីអាស៊ី ដែលគេស្គាល់ថាហ៊ុន។

ការដួលរលំរបស់រ៉ូម៖ នៅក្នុងឆ្នាំ 410 ក្រុមជនជាតិអាឡឺម៉ង់បានវាយប្រហារ និងឆក់ប្លន់ទីក្រុងរបស់រ៉ូម។ ឆក់ប្លន់មានន័យថា ការលួច ឬការយកអ្វីមួយដោយការបង្ខំ។ ការវាយប្រហារនេះ គឺជាការវាយប្រហារលើកដំបូងចាប់តាំងពីការវាយប្រហាររបស់ពួកចរកជនហ្គោល មកលើរ៉ូមនៅក្នុងឆ្នាំ 390 មុនគ.ស។ ក្រោយមក ពួកហ៊ុនក៏បានឈ្លានពានចក្រភពផងដែរ។ នៅក្នុងឆ្នាំ 476 ក្រុមកុលសម្ព័ន្ធជនជាតិអាឡឺម៉ង់បានដណ្តើមកាន់កាប់រ៉ូម។ កាលបរិច្ឆេទនេះគឺជាសញ្ញាណនៃការធ្លាក់ចុះនៃចក្រភពរ៉ូមខាងលិច។

លទ្ធផលបន្ទាប់ការធ្លាកចុះនៃចក្រភពរ៉ូម៖ នៅក្នុងឆ្នាំបន្ទាប់ អំណាចដ៏យូរអង្វែងរបស់រ៉ូមស្ថិតនៅភាគខាងលិចបានដួលរលំ។ នៅក្នុងឆ្នាំ 486 ខ្លូវីសមេដឹកនាំនៃក្រុមជនជាតិអាឡឺម៉ង់ ដែលត្រូវបានគេស្គាល់ថា ហ្វ្រេងបានដណ្តើមកាន់កាប់ដែនដីរ៉ូមដែលនៅសេសសល់នៅក្នុងខេត្តហ្គោល(បច្ចុប្បន្នប្រទេសបារាំង និងស្វីស) និងបានបង្កើតព្រះរាជាណាចក្រហ្វ្រេងគឺសមួយ។

បន្ទាប់ពីការដួលរលំនៃរ៉ូម ជីវិតរស់នៅនៅអឺរ៉ុបខាងលិចបានផ្លាស់ប្តូរជាច្រើន។ ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតបានខូចខាតដោយពុំមានការថែទាំ, ពាណិជ្ជកម្ម និងជំនួញបានធ្លាក់ចុះ។ ព្រះរាជាណាចក្រ

របស់អាឡឺម៉ង់នានាបានដណ្តើមកាន់កាប់អតីតដីរបស់ពួករ៉ូម ហើយព្រះវិហាររ៉ូម៉ាំងកាតូលិចបានបង្រួបបង្រួមគ្នា និងមានកម្លាំងដ៏ខ្លាំងក្លា។ បើទោះបីជា ចក្រភពភាគខាងលិចរដួលរលំក៏ដោយ ចក្រភពភាគខាងកើតនៅបន្តមានវត្តមាន។ ដូចដែលអ្នកនឹងបានអាននៅមេរៀនបន្ទាប់ អរិយធម៌របស់ចក្រភពភាគខាងកើតត្រូវបានគេស្គាល់ថា ចក្រភពប៊ីហ្សង់ទីន។

វិភាគអំពីឥទ្ធិពល៖ បង្ហាញពីមូលហេតុដែលនាំឱ្យចក្រភពខាងលិចដួលរលំ។

# មេរៀនទី 3៖ ចក្រភពប៊ីហ្សង់ទីន

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងមេរៀនមុន អ្នកបានសិក្សាមកហើយថា កង់ស្ទែនទីនបានផ្លាស់ប្តូររាជធានីរបស់ចក្រភពទៅកាន់ប៊ីហ្សង់ទីន ហើយបានផ្លាស់ប្តូរឈ្មោះរាជធានីទៅជាកង់ស្ទែនទីណុប។ វាបានក្លាយជារាជធានីរបស់ចក្រភពរ៉ូមខាងកើត។ ដោយសារតែយោងតាមឈ្មោះដើមនៃរាជធានីរបស់ចក្រភពរ៉ូមខាងកើត ប្រវត្តិវិទូនានាបានហៅចក្រភពរ៉ូមខាងកើតថាចក្រភពប៊ីហ្សង់ទីន។

## 1. ចក្រភពដែលបន្តមានវត្តមាន

សំណួរគន្លឹះ៖ អ្វីទៅជាស្នាដៃសំខាន់ៗរបស់ ចាស្ទីននៀន?

ចក្រភពប៊ីហ្សង់ទីននៅបន្តមានវត្តមានអស់រយៈពេលប្រហែល 1,000 ឆ្នាំទៀតបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូមខាងលិច។ អធិរាជរបស់ចក្រភពប៊ីហ្សង់ទីនគឺជាមេដឹកនាំដែលកាន់អំណាចផ្តាច់មុខ។ មានន័យថាទ្រង់ក្តោបអំណាចទាំងអស់។ ក៏ដូចជាអធិរាជនៅចក្រភពរ៉ូមខាងលិចដែរ អធិរាជចក្រភពប៊ីហ្សង់ទីនបានតស៊ូព្យាយាមនៅក្នុងទប់ទល់ជាមួយពួកជនជាតិអាឡឺម៉ង់ និងក្រុមអ្នកឈ្លានពានដ៏ទៃទៀតដែលឈ្លានពានទឹកដីរបស់ពួកគេ។ បើទោះបីជាមានការខំប្រឹងយ៉ាងនេះក៏ដោយ ក៏ទឹកដីរបស់ចក្រភពប៊ីហ្សង់ទីនមួយភាគធំត្រូវបាត់បង់។

ចាស្ទីននៀន៖ មេដឹកនាំដ៏ខ្លាំងក្លាមួយរូបឈ្មោះចាស្ទីននៀនអាចដណ្តើមមកវិញនូវដែនដីរ៉ូមមួយចំនួនដែលបានបាត់បង់ និងធ្វើការពង្រីកអំណាចរបស់ចក្រភពប៊ីហ្សង់ទីន។ ចាស្ទីននៀនគ្រប់គ្រងអំណាចចាប់ពីឆ្នាំ 527 ដល់ 565 ។ មហេសីរបស់ទ្រង់ ម្ចាស់ក្សត្រីថេអូដូរ៉ាក៏ជាមេដឹកនាំដែលដ៏ខ្លាំងក្លាមួយរូបផងដែរ។ កងទ័ពរបស់ចាស្ទីននៀនបានដណ្តើមកាន់កាប់បានមកវិញនូវទឹកដីដែលបានបាត់បង់ ដោយរួមមាន អ៊ីតាលី, អាហ្វ្រិកខាងជើង, និងតំបន់ឆ្នេរអេស្ប៉ាញខាងត្បូង។

ការស្ថាបនាកង់ស្ទែនទីណុបឡើងវិញ៖ ចាស្ទីននៀនបានចាប់ផ្តើមស្ថាបនាកង់ស្ទែនទីណុបឡើងវិញ បន្ទាប់ពីវាត្រូវបានរងការខូចខាតនៅអំឡុងនៃការបះបោរមួយ។ ទ្រង់បានស្ថាបនាកំពែងទីក្រុងឡើងវិញ និងការស្ថាបនាសាលារៀន, មន្ទីរពេទ្យ, អគារតុលាការ, និងព្រះវិហារ។ ព្រះវិហារដែលល្បីល្បាញបំផុតគឺ ហាជៀ សូហ្វៀ។ ឈ្មោះនេះមានន័យថា "បញ្ញាដ៏ពិសិដ្ឋ"។ ជាថ្មីម្តងទៀត កង់ស្ទែនទីណុបបានក្លាយជាទីក្រុងដ៏រុងរឿងមួយ។

ការថែរក្សាវប្បធម៌របស់រ៉ូម៖ ស្នាដៃរបស់ចាស្ទីននៀន ដែលគេស្គាល់ច្បាស់ជាងគេគឺ ក្រមច្បាប់ ដែលបានអភិវឌ្ឍឡើងនៅក្នុងរាជរបស់ទ្រង់។ ទ្រង់បានចាត់តាំងគណៈកម្មាធិការមួយដើម្បីបង្កើតក្រមច្បាប់មួយដោយផ្អែកសំខាន់លើច្បាប់របស់រ៉ូម។ ក្រុមអ្នកជំនាញទាំងនេះបានលុបចោលនូវច្បាប់ដែលហួសសម័យ និងសរសេរឡើងវិញនូវច្បាប់មួយចំនួនដើម្បីធ្វើឱ្យវាជាក់លាក់ជាងមុន។ ក្រមច្បាប់ថ្មីនេះត្រូវបានគេហៅថា ក្រមចាស្ទីននៀន។ វាបានរួមបញ្ចូលច្បាប់រៀបអាពាហ៍ពិពាហ៍, ទាសភាព, ទ្រព្យសម្បត្តិ, សិទ្ធិស្ត្រី, និងក្រមព្រហ្មទណ្ឌ។ បើទោះបីជាពួកគេនិយាយភាសាក្រិកក៏ដោយ ក៏ពួកប៊ីហ្សង់ទីនយល់ថាពួកគេក៏ជាផ្នែកមួយនៃទំនៀមទម្លាប់វប្បធម៌រ៉ូមផងដែរ។ សិស្សប៊ីហ្សង់ទីន សិក្សាពីភាសា ឡាទីន, ក្រិក, និងអក្សរសិល្ប៍ និងប្រវត្តិសាស្ត្ររ៉ូម។ ដោយហេតុនេះ ពួកចក្រភពរ៉ូម

ខាងលិចបានជួយថែរក្សាវប្បធម៌ក្រិក និងរ៉ូម។ នៅក្នុងអតីតដែនដីចក្រភពខាងលិច ពួកជនជាតិអាឡឺម៉ង់បានលាយបញ្ចូលគ្នានូវវប្បធម៌រ៉ូមជាមួយនឹងវប្បធម៌របស់ពួកគេ។ ប៉ុន្តែ នៅទីនោះមានការបាត់បង់ជាច្រើននូវចំណេះដឹងវិទ្យាសាស្ត្រ និងទស្សនៈវិជ្ជារបស់ក្រិក និងរ៉ូម។

សង្ខេប៖ លម្អិតអំពីស្នាដៃសំខាន់ៗមួយចំនួនរបស់ចាស្ទីនៀន។

## 2. ការបែងចែកគ្រីស្តសាសនាជាពីរផ្សេងគ្នា

សំណួរគន្លឹះ៖ ហេតុអ្វីបានជាព្រះវិហារគ្រីស្តសាសនាត្រូវបានបែងចែក?

ការបែងចែកចក្រភពជាពីរក៏ជះឥទ្ធិពលដល់គ្រីស្តសាសនាផងដែរ។ របៀបនៃការប្រតិបត្តិសាស្ត្រសាសនាផ្សេងគ្នាបានអភិវឌ្ឍឡើងនៅក្នុងព្រះវិហារគ្រីស្តសាសនានៅភាគខាងកើត និងភាគខាងលិច។ ការប្រតិបត្តិតាមវប្បធម៌រៀងៗខ្លួន និងការធ្វើទំនាក់ទំនងតិចតួចរវាងតំបន់ទាំងពីរនេះបណ្តាលឱ្យកើតមានភាពខុសគ្នា។

ព្រះវិហារបែកជាពីរ៖ ភាពខុសគ្នាដ៏សំខាន់មួយគឺទាក់ទងទៅនឹងអំណាចរបស់អធិរាជលើព្រះវិហារ។ នៅភាគខាងកើត អធិរាជមានអំណាចលើមេដឹកនាំព្រះវិហារ។ ចំណែកនៅភាគខាងលិច មិនមានអធិរាជទេ។ ដូច្នេះស្តេចសង្ឃ (ប៉ាប) ចាប់ផ្តើមមានទំនួលខុសត្រូវកាន់តែច្រើនឡើងដូចជាមេដឹកនាំមួយរូប នៅអតីតចក្រភពខាងលិច។

បញ្ហារវាងព្រះវិហារទាំងពីរនេះបានចាប់ផ្តើមកើនឡើង។ ស្តេចសង្ឃបានអះអាងអំពីអំណាចរបស់ខ្លួនលើព្រះវិហារទាំងនៅខាងកើត និងខាងលិច។ ប៉ុន្តែ អធិរាជនៅប៊ីហ្សង់ទីនចាត់ទុកខ្លួនទ្រង់ថា ជាអ្នកដែលមានអំណាចលើសគេលើសាសនា។ គណៈប្រតិភូរបស់ស្តេចសង្ឃបានព្យាយាមនៅក្នុងការដកមេដឹកនាំព្រះវិហារភាគខាងកើតចេញពីតំណែង។ ព្រះវិហារភាគខាងកើតឆ្លើយតបដោយការបដិសេធនៅក្នុងការទទួលស្គាល់អំណាចរបស់ស្តេចសង្ឃ។

ចុងក្រោយ នៅក្នុងឆ្នាំ 1054 ព្រះវិហារគ្រីស្តសាសនាបានបែងចែកជាពីរ។ ព្រះវិហារនៅភាគខាងលិចត្រូវបានគេស្គាល់ថា ព្រះវិហាររ៉ូម៉ាំងកាតិលិច។ សាខាគ្រីស្តសាសនាដែលបានអភិវឌ្ឍឡើងនៅចក្រភពរ៉ូមខាងកើតត្រូវបានគេស្គាល់ថាព្រះវិហារអូតូដុសខាងកើត។ អូតូដុសមានន័យថា "រក្សាជំនឿដើម"។ ក្រោយមក ការបែងចែកនេះបាននាំទៅរកការអភិវឌ្ឍឡើងនៃអរិយធម៌របស់អឺរ៉ុបពីរដាក់ពីគ្នា មួយផ្អែកទៅលើភាគខាងកើត និងមួយទៀតផ្អែកលើភាគខាងលិច។

សាសនា និងរដ្ឋាភិបាល៖ បន្ទាប់ពីការបែងចេញពីគ្នា ស្តេចសង្ឃបានអះអាងអំពីអំណាចរបស់ទ្រង់លើអធិរាជ និងស្តេចដែលកាន់គ្រីស្តសាសនា។ អំណាចនេះបានអនុញ្ញាតឱ្យព្រះវិហាររ៉ូម៉ាំងកាតូលិកមានឥទ្ធិពលលើរដ្ឋាភិបាលនៅក្នុងដែនដីដែលស្ថិតនៅចក្រភពរ៉ូមខាងលិច។ ភាពមិនយល់ស្របគ្នារវាងព្រះវិហារ និងស្តេច និងអធិរាជមួយចំនួននៅអឺរ៉ុបខាងលិចនាំឱ្យកើតមានជម្លោះដ៏ខ្លាំងក្លាមួយនាពេលក្រោយមកទៀត។

ដូចដែលបានសិក្សារួចមកហើយ អធិរាជនៃចក្រភពប៊ីហ្សង់ទីនគឺជាមេដឹកនាំគ្រប់គ្រងអំណាចផ្ដាច់មុខ។ ទ្រង់មានអំណាចលើព្រះវិហារ ក៏ដូចជារដ្ឋាភិបាល។ នេះមានន័យថា អធិរាជគ្រប់គ្រងលើព្រះសង្ឃរាជ ដែលជាមេដឹកនាំព្រះវិហារអូតូដុសភាគខាងកើត។ សរុបមក អធិរាជនៃចក្រភពប៊ីហ្សង់ទីនមានអំណាចច្រើនជាអធិរាជ ឬស្ដេចនានានៅចក្រភពរ៉ូមខាងលិច។

វិភាគអំពីឥទ្ធិពលៈ ពន្យល់ពីមូលហេតុដែលនាំឱ្យព្រះវិហារគ្រីស្តសាសនាបែងចែកជាពីរ។

## 3. ការដួលរលំនៃចក្រភពប៊ីហ្សង់ទីន

សំណួរគន្លឹះ៖ តើកត្តាអ្វីដែលបណ្ដាលឱ្យចក្រភពប៊ីហ្សង់ទីនដួលរលំ?

បន្ទាប់ពីអធិរាជចាស្ទីនៀនសុគត់នៅក្នុងឆ្នាំ 565 ចក្រភពប៊ីហ្សង់ទីនទទួលរងនូវបញ្ហាយ៉ាងច្រើន។ មានកុប្បកម្មនៅតាមដងផ្លូវ, ជម្លោះសាសនា, ការប្រយុទ្ធគ្នាដើម្បីរាជបល្ល័ង្ក, និងជំងឺឆ្លង។ ជាមួយគ្នានេះផងដែរ ចក្រភពក៏ប្រឈមជាមួយនឹងការឈ្លានពានពីសត្រូវបរទេសជាញឹកញាប់ផងដែរ។ ការវាយប្រហារកើតមានឡើងពីគ្រប់ទិសទី។ ពួកជនជាតិស្លាវិចតែងតែធ្វើការវាយប្រហារជាញឹកញាប់នៅតាមព្រំដែនភាគខាងជើង។ ក្រុមពែក្សដែលមានកម្លាំងខ្លាំងធ្វើការវាយប្រហារនៅភាគខាងកើត។ នៅក្នុងទសវត្សរ៍ឆ្នាំ 600 សាសនាមួយដែលគេហៅថា អ៊ីស្លាមបានលេចឡើងនៅតំបន់អារ៉ាប់។ កងទ័ពអារ៉ាប់បានរីកឡើង និងធ្វើការវាយប្រហារកុងស្ទង់ទីណុប និងទឹកដីក្បែរៗនោះ។ ក្រោយមក សង្គ្រាមស៊ីវិលក៏ដូចជាការវាយប្រហារពីពួកទួក និងស៊ែបនាំឱ្យចក្រភពចុះខ្សោយយ៉ាងខ្លាំង។

បន្តិចម្ដងៗ ចក្រភពប៊ីហ្សង់ទីនបានរួមតូចដោយសារតែការវាយប្រហែលទាំងនេះ។ ត្រឹមឆ្នាំ 1350 ទឹកដីចក្រភពដែលនៅសេសសល់មានតែទំហំតូចមួយនៅឧបទ្វីបអាណាតូលៀ និងដីមួយចម្រៀកនៅតាមបណ្ដោយសមុទ្រខ្មៅ និងអេជៀន។ ប៉ុន្តែ អគុណដល់កំពែង, កងនាវាចរណ៍, និងទីតាំងយុទ្ធសាស្ត្ររបស់ទីក្រុងនេះ កុងស្ទង់ទីណុបនៅបន្តរស់រានបានរយៈពេល 100 ឆ្នាំទៀត។ ចុងក្រោយ នៅក្នុងឆ្នាំ 1453 កងទ័ពរបស់ពួកទួកមួយក្រុមបានដណ្ដើមកាន់កាប់រាជធានីកុងស្ទង់ទីណុប ។ ការដណ្ដើមកាន់កាប់ទីក្រុងនេះ គឺជាសញ្ញាណនៃការបញ្ចប់ចក្រភពប៊ីហ្សង់ទីន ប្រហែលជាមួយពាន់ឆ្នាំបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូមខាងលិច។

ស្វែងរកគំនិតសំខាន់៖ ពិភាក្សាអំពីមូលហេតុដែលនាំឱ្យចក្រភពប៊ីហ្សង់ទីនដួលរលំ។

# មេរៀនទី 4 ៖ កេរ្តិ៍ដំណែលរបស់រ៉ូម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អ្នកបានសិក្សារួចមកហើយថា អរិយធម៌របស់ពួកក្រិកបានក្របដណ្តប់នៅតំបន់មេឌីទែរ៉ាណេមុនពួករ៉ូម។ ពួករ៉ូមបានឈ្លានពានពួកក្រិក ប៉ុន្តែបានទទួលរកឥទ្ធពលវប្បធម៌របស់ពួកក្រិកយ៉ាងខ្លាំង។

## 1. វប្បធម៌រ៉ូម

សំណួរគន្លឹះ៖ តើទម្រង់វប្បធម៌របស់រ៉ូមមួយណាដែលជះឥទ្ធិពលលើសង្គមដ៏ទៃ ?

វប្បធម៌របស់ពួករ៉ូមគឺផ្តោតសំខាន់ទៅលើតម្លៃនៃភាពរឹងមាំ, ភាពស្មោះត្រង់, និងភាពពិតប្រាកដនិយម។ ពួករ៉ូមបានទទួលយកគំនិតអំពីការសរសេរ និងសិល្បៈរបស់ក្រិកដែលមានភាពល្អឥតខ្ចោះ។ ជាមួយគ្នានោះសិល្បៈករ និងអ្នកនិពន្ធរ៉ូមក៏បានបង្កើតរចនាបទផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ ជាលទ្ធផល វាបានលេចចេញនូវវប្បធម៌មួយ ដែលជាការលាយបញ្ចូលគ្នារវាងគំនិតពិតប្រាកដនិយមរបស់រ៉ូម ជាមួយធាតុមួយចំនួននៃមនោគតិនិយមរបស់ក្រិក។

សិល្បៈ៖ ពួករ៉ូមមានការពេញនិយមនូវទម្រង់សិល្បៈដំបូងបំផុតមួយដែលគេហៅថា គំនូរផ្គុំរូបតូចៗ។ គំនូរផ្គុំរូបតូចៗគឺជារូបគំនូរដែលគេបង្កើតឡើយដោយផ្គុំដុំថ្ម, កញ្ចក់, ឬកញ្ចក់លាបពណ៌តូចៗនៅលើផ្ទៃលាតមួយ។ គំរូនៃគំនូរផ្គុំរូបតូចៗមួយចំនួនអាចត្រូវបានគេរកឃើញនៅតាមព្រះវិហារ និងសំណង់ផ្សេងៗទៀតនៅជុំវិញពិភពលោក។ ពួករ៉ូមរៀនអំពីចម្លាក់ពីពួកក្រិក ប៉ុន្តែមិនបានយកតាមប្រពៃណីរបស់ក្រិកដែលបង្ហាញតែពីទម្រង់នៃភាពល្អឥតខ្ចោះរបស់មនុស្សឡើយ។ ផ្ទុយទៅវិញ ពួករ៉ូមបានបង្កើតទម្រង់ចម្លាក់មួយដែលមានរូបរាងពិតប្រាកដនិយម ដែលមានលក្ខណៈក្រឡោត។ នៅក្នុងទម្រង់ចម្លាក់ក្រឡោត រូបចម្លាក់ត្រូវបានគេឆ្លាក់ឱ្យផុសចេញពីផ្ទៃបន្តិចបន្តួច។

អក្សរសិល្ប៍៖ ពួកក្រិកក៏ជះឥទ្ធិពលមកលើអក្សរសិល្ប៍រ៉ូមផងដែរ។ អ្នកនិពន្ធរ៉ូមបានប្រើប្រាស់ទម្រង់វីរកថារបស់ក្រិក ដែលជាកំណាព្យដ៏វែងមួយដែលរៀបរាប់អំពីដំណើរផ្សងព្រេងរបស់វីរបុរសម្នាក់។ រឿងអេនៀដ ដែលសរសេរឡើងដោយវីហ្គីល គឺជាវីរកថាដែលល្បីល្បាញមួយរបស់រ៉ូម។ វីហ្គីលបានយកលំនាំកំណាព្យរបស់លោកតាមវីរកថាពីររបស់ក្រិក គឺរឿងអូឌីសី និងអ៊ីលីយ៉ាដ។ រឿងបានបង្ហាញពីដំណើរផ្សងព្រេងរបស់វីរបុរសអេនៀដអ្នកបានរស់រានពីសង្គ្រាមត្រូយ និងបានធ្វើដំណើរតាមនាវាមកកាន់អ៊ីតាលី។ ដូចដែលអ្នកបានសិក្សាមកហើយស្នាដៃនិពន្ធ និងសន្ទរកថារបស់ស៊ីសេរ៉ូបានបង្ហាញនូវរូបភាពនៃជីវិតរស់នៅរបស់ពួករ៉ូម និងបានបន្ថែមចំណេះអំពីប្រវត្តិសាស្ត្ររ៉ូមដល់ពួកយើងផងដែរ។ ស៊ីសេរ៉ូ គឺជាគ្រូបង្រៀនជំនាញវាគ្មិនមួយរូប ដែលជាជំនាញសិល្បៈក្នុងការនិយាយជាសាធារណៈ។ សារៈសំខាន់នៃជំនាញវាគ្មិនគឺ ការបញ្ចុះបញ្ចូល ដែលជាចំណុចសំខាន់ណាស់សម្រាប់អ្នកនយោបាយរ៉ូម។

ពួករ៉ូមក៏សរសេរអំពីទស្សនវិជ្ជាផងដែរ។ អធិរាជម៉ាគូស អូរេលីស បានសរសេរអំពីការតាំងសម្មាធិ ដែលជាស្នាដៃមួយបង្ហាញពីគំនិតអត់ធ្មត់និយម។ អភិវឌ្ឍឡើងដោយទស្សនវិទូក្រិក អត់ធ្មត់និយមបានបង្ហាញពីសារៈសំខាន់នៃគុណធម៌, ករណីយកិច្ច, និងភាពអំណត់នៅក្នុងជីវិតរស់នៅ។

ភាសា៖ ឡាទីនគឺជាភាសារបស់រ៉ូមដែលទម្រង់វប្បធម៌របស់រ៉ូមមួយទៀតដែលបន្តនៅស្ថិតស្ថេរ។ បន្តិចម្តងៗភាសាឡាទីនបានវិវត្តទៅជាភាសាមួយក្រុមដែលគេហៅថា ភាសារ៉ូម៉ាំ(ពាក្យថារ៉ូម៉ាំប្រែក្លាយមកពីពាក្យរ៉ូម)។ បច្ចុប្បន្នភាសារ៉ូម៉ាំត្រូវបានគេនិយាយនៅក្នុងប្រទេសជាច្រើនដែលធ្លាប់មានទឹកដីស្ថិតនៅក្រោមការគ្រប់គ្រងរបស់រ៉ូម។

គូសបង្ហាញសេចក្តីសន្និដ្ឋាន៖ កំណត់អំពីទម្រង់នៃវប្បធម៌របស់រ៉ូមដែលបានជះឥទ្ធិពលលើសង្គមដទៃ។

## 2. ស្ថាបត្យកម្ម និងវិស្វកម្ម

សំណួរគន្លឹះ៖ តើស្នាដៃអ្វីខ្លះដែលពួករ៉ូមបានបង្កើតឡើងទាក់ទងទៅនឹងស្ថាបត្យកម្ម និងវិស្វកម្ម?

ស្ថាបត្យកម្មក្រិកបានជះឥទ្ធិពលលើអ្នកស្ថាបនាជនជាតិរ៉ូម។ អ្នកធ្លាប់បានសិក្សាមកហើយអំពីរចនាបថសំណង់របស់ក្រិក ជាមួយនិងការប្រើប្រាស់សសរស្តម្ភ, ហោជាង, និងទំហំសមាមាត្រ។ ពួករ៉ូមប្រើប្រាស់ធាតុទាំងអស់នេះ ប៉ុន្តែក៏បន្ថែមគំនិតផ្ទាល់របស់ពួកគេផងដែរ។ អ្នកទស្សនាមកពីតំបន់ទាំងឡាយនៅក្នុងចក្រភពបានស្ញប់ស្ញែងទៅនឹងស្ថាបត្យកម្មរបស់រ៉ូម។ ក្លោងទ្វារាងកោង, ដំបូលរាងមូល, និងបេតុង ត្រូវបានរួមបញ្ចូលគ្នាដើម្បីស្ថាបនាសំណង់ធំៗ ក្នុងនោះមានដូចជាកូឡូស៊ាមជាដើម។

រចនាបថថ្មីនៃស្ថាបត្យកម្ម៖ អ្នកស្ថាបនាជនជាតិរ៉ូមគឺជាវិស្វករដ៏ជំនាញ។ ពួកគេបានរកឃើញវិធីថ្មីនៅក្នុងការពង្រីករចនាសម្ព័ន្ធសំណង់។ គំនិតថ្មីទាំងនេះរួមមានក្លោងទ្វារាងកោង, ថៃវ, និងដំបូលរាងមូល។ ថៃវគឺជាក្លោងទ្វារាងកោង ផ្គុំគ្នាជាមួយពិដាន ឬដំបូល។ ការអភិវឌ្ឍរចនាសម្ព័ន្ធសំណង់របស់រ៉ូមបានអនុញ្ញាតឱ្យពួកគេអាចស្ថាបនាសំណង់ធំ និងខ្ពស់ៗ។ សំណង់សម័យទំនើបជាច្រើនបានប្រើប្រាស់របៀបរចនា និងរចនាសម្ព័ន្ធសំណង់របស់រ៉ូម។ ដំបូលរាងមូលនៃសំណង់អាគារកាពីតូរបស់សហរដ្ឋអាមេរិកគឺជាឧទាហរណ៍មួយដ៏សំខាន់។

សម្ភារៈសំណង់ថ្មី៖ ពួករ៉ូមបានអភិវឌ្ឍទម្រង់នៃបេតុងមួយដែលមានលក្ខណៈស្រាល និងរឹងមាំ។ ពួកគេបានចាក់ចូលនូវល្បាយបេតុងទៅក្នុងប្រហោងជញ្ជាំង ឬក៏ចាក់ពីលើផ្ទៃកោងដើម្បីបង្កើតថៃវដ៏រឹងមាំមួយ។ បេតុងគឺជាសម្ភារៈសំណង់ដែលគេប្រើប្រាស់ជាទូទៅនាពេលបច្ចុប្បន្ន។

ផ្លូវនាំទឹក៖ អ្នកធ្លាប់បានសិក្សារួចមកហើយថា ពួករ៉ូមបានស្ថាបនាផ្លូវនាំទឹកដើម្បីនាំទឹកមកកាន់ទីក្រុង។ ផ្លូវនាំទឹកធំចំនួន 11 ខ្សែបាននាំទឹកមកកាន់ទីក្រុងរ៉ូម។ ផ្លូវនាំទឹកដែលវែងជាងគេមានចម្ងាយរហូតដល់ 57 ម៉ាយ។ បច្ចុប្បន្នគេអាចមើលឃើញផ្លូវនាំទឹកមួយចំនួននៅក្នុងប្រទេសបារាំង និងអេស្ប៉ាញ, ដែលដែនដីទាំងនេះពីមុនគឺជាផ្នែកមួយនៃចក្រភពរ៉ូម។

ផ្លូវថ្នល់៖ ពួករ៉ូមមានភាពល្បីល្បាញបំផុតសម្រាប់ការស្ថាបនាផ្លូវដ៏មានគុណភាពរបស់ពួកគេ។ នៅក្នុងឆ្នាំ 312 មុនគ.ស ពួករ៉ូមបានស្ថាបនាផ្លូវជាច្រើនខ្សែលើកដំបូង។ វាត្រូវបានគេហៅថាវិថីអាបពៀន ហើយវាបានលាត

សន្ទឹងពីទីក្រុងរ៉ូមទៅកាន់ភាគអាគ្នេយ៍។ ក្រោយមក ប្រព័ន្ធផ្លូវថ្នល់មួយបានពង្រីកខ្វាតខ្វែងនៅពាសពេញចក្រភព។ រ៉ូមស្ថិតនៅចំណុចកណ្ដាលនៃប្រព័ន្ធផ្លូវថ្នល់។ ផ្លូវថ្នល់ជាច្រើនរបស់រ៉ូមត្រូវបានស្ថាបនាឡើង ដូច្នេះកងទ័ពអាចធ្វើដំណើរបានយ៉ាងឆាប់រហ័សទៅកាន់ទីកន្លែងនានាដែលពួកគេចង់ទៅនៅក្នុងចក្រភព។ ប្រព័ន្ធផ្លូវថ្នល់ក៏បានបង្កើនសកម្មភាពពាណិជ្ជកម្មផងដែរ ដោយសារពាណិជ្ជករ និងអ្នកជំនួញអាចធ្វើដឹកជញ្ជូនទំនិញរបស់ពួកគេបានកាន់តែងាយស្រួល។ បើទោះបីជាប្រព័ន្ធផ្លូវថ្នល់បានជួយដល់ការភ្ជាប់ទំនាក់ទំនងនៅក្នុងចក្រភពទាំងមូលក៏ដោយ ប៉ុន្តែវាក៏ធ្វើឱ្យមានភាពងាយស្រួលដល់កងទ័ពរបស់សត្រូវធ្វើដំណើរមកឈ្លានពានចក្រភពរ៉ូមផងដែរ។

ចំណាត់ថ្នាក់៖ ពិពណ៌នាអំពីស្នាដៃដែលពួករ៉ូមបានបង្កើតឡើងទាក់ទងទៅនឹងស្ថាបត្យកម្ម និងវិស្វកម្ម។

## 3. សាសនា និងច្បាប់

សំណួរគន្លឹះ៖ តើកេរ្តិ៍ដំណែលសាសនា និងច្បាប់អ្វីដែលរ៉ូមបានបន្សល់ទុក?

អរិយធម៌ដ៏អស្ចារ្យបានបន្សល់ទុកសញ្ញាណរបស់វាតាមរយៈគំនិត ក៏ដូចជាវត្ថុផ្សេងៗដែលយើងអាចប៉ះ និងអាចមើលឃើញ។ ក្នុងនោះចក្រភពរ៉ូមបានបន្សល់ទុកនូវស្នាដៃជាច្រើនរហូតមកដល់បច្ចុប្បន្នដែលទាក់ទង និងសាសនា និងច្បាប់។

ការរីកសាយភាយនៃគ្រីស្តសាសនា៖ ចក្រភពរ៉ូមបានដើរតួនាទីដ៏សំខាន់មួយនៅក្នុងធ្វើឱ្យគ្រីស្តសាសនារីកសាយភាយ។ បេសកទូតគ្រីស្តសាសនាបានកែប្រែមនុស្សជាច្រើននៅក្នុងចក្រភពឱ្យប្ដូរទៅជឿលើគ្រីស្តសាសនា។ ហើយបើទោះបីជាមេដឹកនាំរ៉ូមពីដំបូងប្រឆាំងជាមួយគ្រីស្តសាសនាក៏ដោយ ក្រោយមកពួកគេបានជាប់ចិត្តជាមួយនឹងការអប់រំរបស់សាសនានេះ និងបានធ្វើឱ្យវាក្លាយជាសាសនាផ្លូវការមួយ។ ក្នុងនាមជាចក្រភពដែលមានអំណាចជាងគេនៅក្នុងពិភពលោកនៅពេលនោះ រ៉ូមបានជួយអភិវឌ្ឍគ្រីស្តសាសនាឱ្យក្លាយជាសាសនាសំខាន់មួយ។ នៅពេលដែលចក្រភពរ៉ូមខាងលិចដួលរលំ គ្រីស្តសាសនាក៏នៅតែបន្តរុងរឿងនៅក្នុងដែនដីនេះដដែល។ ស្ដេច និងក្សត្រីជនជាតិអាឡឺម៉ង់បានក្លាយជាគ្រីស្តសាសនិក។ ជាមួយគ្នានោះ ចក្រភពប៊ីហ្សង់ទីនបានលើកកំពស់គ្រីស្តសាសនានៅភាគខាងកើត។ សកម្មភាពទាំងអស់នេះបានជំរុញឱ្យគ្រីស្តសាសនាក្លាយជាសាសនាមួយដែលមានអំណាចខ្លាំងនាពេលបច្ចុប្បន្ន។ សព្វថ្ងៃ ប្រហែល 1/3 នៃប្រជាជនទាំងអស់លើសាកលលោកគឺជាគ្រីស្តសាសនិក។

ច្បាប់ និងរដ្ឋាភិបាលរ៉ូម៖ ប្រហែលជាកេរ្តិ៍ដំណែលដែលស្ថិតស្ថេរបានយូរ និងរីកសាយភាយខ្លាំងក្លាបំផុតរបស់រ៉ូមគឺ ប្រព័ន្ធច្បាប់របស់ពួកគេ។ ចៅក្រម និងមេដឹកនាំនយោបាយរ៉ូមបានបង្កើតនូវច្បាប់នានាដែលឆ្លុះបញ្ចាំងពីគោលការណ៍អត់ធ្មត់ចំពោះករណីកិច្ច និងគុណធម៌។ ពួកគេបង្ហាញពីយុត្តិធម៌ និងគំនិតរួម។ ច្បាប់រ៉ូមបានលើកកំពស់គោលការណ៍មួយចំនួនដូចជា ភាពស្មើគ្នាចំពោះមុខច្បាប់ និងការសន្មត់ថាគ្មានទោសមុនពេលទទួលការជំនុំជម្រះទោស។ គោលការណ៍នៃច្បាប់របស់រ៉ូមបន្តស្ថិតស្ថេរ និងជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធច្បាប់នៅក្នុងប្រទេសជាច្រើននៅអឺរ៉ុប និងសហរដ្ឋអាមេរិក។

ចុងក្រោយគេ ពួករ៉ូមបានបង្កើតទម្រង់នៃរដ្ឋាភិបាលតំណាងមួយដែលប្រទេសជាច្រើនប្រើប្រាស់វានាពេលបច្ចុប្បន្ន។ រ៉ូមចាប់ផ្តើមដំបូងជាមួយទម្រង់សាធារណរដ្ឋមួយ ដែលប្រជាពលរដ្ឋទាំងអស់គឺជាអ្នកក្តោបក្តាប់អំណាច។ អំឡុងពេលនោះ ពួករ៉ូមបានបង្កើតសភាមួយចំនួន ក្នុងនោះរួមមាន ព្រឹទ្ធសភា ដើម្បីតាក់តែងច្បាប់ និងធ្វើជាអ្នកតំណាងឱ្យការយល់ឃើញរបស់ប្រជាពលរដ្ឋ។ បច្ចុប្បន្ន សភាបានលេចចេញនៅក្នុងប្រទេសជាច្រើននៅជុំវិញពិភពលោក។ នៅក្នុងសហរដ្ឋអាមេរិក ជាឧទាហរណ៍ សភាតំណាង និងព្រឹទ្ធសភាគឺជាស្ថាប័នតំណាងប្រជាពលរដ្ឋដ៏សំខាន់ពីរបស់ជាតិ។ ប្រជាពលរដ្ឋរបស់ប្រទេសធ្វើការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាង និងព្រឹទ្ធសភា។ សមាជិកនៅក្នុងសភានីមួយៗធ្វើការដើម្បីតាក់តែង និងអនុម័តច្បាប់ដែលប្រជាជនដែលពួកគេតំណាងឱ្យត្រូវការ។

សង្ខេប៖ ពិភាក្សាអំពីកេរ្តិ៍ដំណែលនានារបស់រ៉ូមដែលទាក់ទងទៅនឹងសាសនា និងច្បាប់។

# ជំពូក 11 ៖ ការលេចឡើងនៃសាសនាអ៊ីស្លាម

## មេរៀនទី 1 ៖ សាសនាអ៊ីស្លាម និងមហាម៉ាត់

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើអ្នកធ្លាប់ទស្សនាខ្សែភាពយន្តមួយដែលបានបង្ហាញពីរូបភាពនៅតំបន់វាលខ្សាច់ដែរឬទេ? រូបភាពដែលបានបង្ហាញនោះហាក់ដូចជាក្តៅខ្លាំង, ជាតំបន់ដែលពោរពេញទៅដោយដីខ្សាច់ និងមានទឹកប្រើប្រាស់តិចតួច។ តំបន់នោះគឺដូចគ្នាទៅនឹងតំបន់ឧបទ្វីបអារ៉ាប់ ដែលស្ថិតនៅអាស៊ីភាគនិរតី។ នៅទីនោះហើយដែលចក្រភពមូស្លីមបានលេចឡើង។

### 1. វប្បធម៌តំបន់វាលខ្សាច់

សំណួរគន្លឹះ៖ តើប្រជាជននៅតំបន់អារ៉ាប់រស់នៅសម្របខ្លួនយ៉ាងដូចម្តេចចំពោះសណ្ឋានដី និងអាកាសធាតុនៅទីនោះ។

វាលខ្សាច់នៅតំបន់ឧបទ្វីបអារ៉ាប់គ្របដណ្តប់នៅលើផ្ទៃដីរាប់ម៉ឺនម៉ាយការ៉េ។ តំបន់វាលខ្សាច់មួយនៅភាគខាងត្បូងគ្របដណ្តប់លើផ្ទៃដីជិត 25 ម៉ឺនម៉ាយការ៉េ ប្រហាក់ប្រហែលទៅនឹងទំហំនៃរដ្ឋតិចសាស់ទាំងមូល។ វាមានទំហំធំខ្លាំងណាស់ និងដាច់ស្រយោល ដែលពួកអារ៉ាប់ហៅថារូបអាល-ខាលីដែលមានន័យថា "តំបន់ដែលទទេស្អាត"។

រូបសណ្ឋាន និងអាកាសធាតុ៖ ឧបទ្វីបអារ៉ាប់គឺជាតំបន់មួយដែលស្ថិតនៅអាស៊ីភាគនិរតី ដែលស្ថិតនៅចន្លោះសមុទ្រក្រហម និងឈូងសមុទ្រពែក្ស។ វាមានប្រវែងប្រហែល 1,200 ម៉ាយ ត្រង់ចំណុចដែលវែងបំផុតពីភាគខាងជើងទៅភាគខាងត្បូង និងមានប្រវែង 1,300 ម៉ាយ ត្រង់ចំណុចដែលវែងបំផុតពីភាគខាងកើតទៅភាគខាងលិច។ តំបន់ស្ងួតហែងនេះមានទំហំប្រហែល ¼ នៃសហរដ្ឋអាមេរិក។ តំបន់នេះមានភ្លៀងធ្លាក់តិចតួច និងគ្របដណ្តប់មួយភាគធំដោយវាលខ្សាច់។ ដោយសារតែអាកាលធាតុ តំបន់នេះមានតែផ្ទៃដីតិចតួចប៉ុណ្ណោះដែលអាចធ្វើកសិកម្មបាន។ ដីសម្រាប់ធ្វើកសិកម្មមានទីតាំងស្ថិតនៅតំបន់ជួរភ្នំភាគខាងត្បូង និងភាគខាងជើងនៃឧបទ្វីប ដែលបច្ចុប្បន្នស្ថិតនៅប្រទេសស៊ីរី និងអ៊ីរ៉ាក់។

ចរកជន៖ ក្រុមអ្នកចិញ្ចឹមសត្វជនជាតិអារ៉ាប់ ដែលត្រូវបានគេហៅថាបេដូអ៊ីនបានសម្របការរស់នៅរបស់ពួកគេទៅនឹងទឹកដីស្ងួតហែងអស់រយៈពេលជាច្រើនសតវត្សរ៍។ ដោយសារនៅទីនោះមានផ្ទៃដីសម្រាប់ធ្វើកសិកម្មតិចតួច ពួកបេដូអ៊ីនរស់នៅជាលក្ខណៈពនេចរណ៍ ដែលបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយជាជាងរស់នៅតែមួយកន្លែងជាអចិន្ត្រៃ។ ពួកបេដូអ៊ីនធ្វើដំណើរនៅក្នុងតំបន់ជាក់លាក់មួយដើម្បីស្វែងរកទឹក និងស្មៅសម្រាប់សត្វចិញ្ចឹមរបស់ពួកគេ។ ផ្លូវដែលពួកគេជ្រើសរើសដើម្បីធ្វើដំណើរ ត្រូវផ្អែកលើកត្តាមួយចំនួន ដូចជាសណ្ឋានដី, ទំហំនៃទឹកភ្លៀង, និងបឹងអូអាស៊ីស។ បឹងអូអាស៊ីស គឺជាតំបន់មួយនៅលើវាលខ្សាច់ដែលមានព្រៃព័ទ្ធជុំវិញនិងមានទឹកបឹងនៅកណ្តាល។ ពួកបេដូអ៊ីនធ្វើទំនាក់ទំនងជាមួយក្រុមមនុស្សដែលរស់នៅជុំវិញបឹងអូអាស៊ីស ដោយរស់នៅ និងតាំងទីលំនៅដោយស្ងប់ស្ងៀម។ កាលពីអតីតកាល ទំនាក់ទំនងនេះតែងតែត្រូវបានគេមើលឃើញថា

ក្រុមមនុស្សអ្នកតាំងទីលំនៅបានដោះដូរចំណីអាហារដែលពួកគេបានដាំដុះជាមួយសត្វ ឬផលិតផលសត្វរបស់ពួកចរកជន។

ជីវិតក្នុងគ្រួសារ៖ ពួកបេដូអ៊ីនរស់នៅជាក្រុមដែលគេហៅថា កុលសម្ព័ន្ធ។ កុលសម្ព័ន្ធគឺជាក្រុមមនុស្សដែលមានបុព្វការីជនរួមគ្នាតែមួយ។ ក្រុមកុលសម្ព័ន្ធបេដូអ៊ីននីមួយៗមានស្ថាប័នគ្រប់គ្រងរបស់ពួកគេដោយផ្ទាល់។ ក្រុមកុលសម្ព័ន្ធនានាក៏បានផ្តល់នូវសន្តិសុខ និងគាំទ្រគ្នានៅពេលដែលពួកគេជួបស្ថានការណ៍លំបាកនៅលើវាលខ្សាច់។

ពួកបេដូអ៊ីន មានមោទនភាពចំពោះសមត្ថភាពរបស់ពួកគេនៅក្នុងសម្របខ្លួនក្នុងការរស់នៅលើតំបន់វាលខ្សាច់។ ពួកគេក៏មានមោទនភាពចំពោះជំនាញនៅក្នុងការវាយប្រយុទ្ធរបស់ពួកគេផងដែរ។ ពួកកុលសម្ព័ន្ធនីមួយៗត្រូវការពារខ្លួនគេជាមួយនឹងការវាយឆ្មក់របស់កុលសម្ព័ន្ធផ្សេងៗទៀត ដែលចង់ដណ្តើមទឹក, សត្វចិញ្ចឹម, ឬចំណីអាហារ។ ដោយសារតែសមត្ថភាពក្នុងការវាយប្រយុទ្ធរបស់ពួកគេ ពួកបេដូអ៊ីនបានក្លាយជាកងទ័ពស្នូលមួយដែលជួយដល់ការបង្កើតឡើងនៃចក្រភពមូស្លីម។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីរបៀបដែលប្រជាជនអារ៉ាប់សម្របខ្លួនរបស់ពួកគេទៅនឹងសណ្ឋានដី និងអាកាសធាតុ។

## 2. ចំណុចប្រសព្វគ្នានៃទ្វីប 3

សំណួរគន្លឹះ៖ ហេតុអ្វីបានជាផ្លូវពាណិជ្ជកម្មត្រូវបានអភិវឌ្ឍឡើងនៅឧបទ្វីបអារ៉ាប់?

ឧបទ្វីបអារ៉ាប់មានទីតាំងល្អសម្រាប់ការធ្វើពាណិជ្ជកម្ម។ តំបន់នេះគឺជាចំណុចប្រសព្វនៃទ្វីប 3 និងហ៊ុំព័ទ្ធជុំវិញទៅដោយសមុទ្រជាច្រើន។

ការរីកចម្រើននៃទីក្រុងពាណិជ្ជកម្ម៖ គិតត្រឹមទសវត្សរ៍ឆ្នាំ 600 មានជនជាតិអារ៉ាប់ជាច្រើនចាប់ផ្តើមធ្វើដំណើរមករស់នៅទីប្រជុំជន ឬតំបន់បឹងអូអាសេស។ ទីប្រជុំជនតូចៗមួយចំនួនបានរីកចម្រើនក្លាយជាទីក្រុង។ តំបន់តាំងទីលំនៅដ៏ធំនៅក្បែរតំបន់ឆ្នេរភាគខាងលិចអារ៉ាប់បានក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មក្នុងស្រុក, តំបន់, និងអន្តរជាតិ។ តំបន់ផ្សេងៗទៀត ដូចជាតំបន់បឹងអូអាសេស បានក្លាយជាទីសំចតនៅតាមបណ្តាយផ្លូវពាណិជ្ជកម្មជាច្រើនដែលឆ្លងកាត់ឧបទ្វីបនេះ។ ក្នុងចំណោមទីក្រុងបឹងអូអាសេសទាំងនោះមានដូចជាមេកា និងមេឌីណាជាដើម។ ផ្លូវសមុទ្រ និងផ្លូវគោកបានភ្ជាប់អារ៉ាប់ទៅកាន់មជ្ឈមណ្ឌលពាណិជ្ជកម្មសំខាន់ៗនានា។ ផលិតផលមកពីទ្វីបផ្សេងៗដូចជា អាស៊ី, អាហ្វ្រិក, និងអឺរ៉ុប ធ្វើដំណើរឆ្លងកាត់ផ្លូវនេះតាមរយៈក្បួនដឹកជញ្ជូនអូដ្ឋ។ ពួកពាណិជ្ជករបានធ្វើការដោះដូរសត្វ, ក្រណាត់, លោហៈ, និងគ្រឿងទេសដែលមានដូចជាម្រេច និងសាហ្វ្រ៊ុនជាដើម។

ពាណិជ្ជកម្មក៏មានសារៈសំខាន់នៅក្នុងការផ្លាស់ប្តូរវប្បធម៌គ្នាផងដែរ។ ពួកពាណិជ្ជករបាននាំយកមកជាមួយពួកគេនូវព័ត៌មានក៏ដូចជាផលិតផលនានា។ ឧទាហរណ៍ ពួកគេទទួលបាននូវចំណេះដឹងពីការប្រតិបត្តិសាសនាផ្សេងៗនៅក្នុងទីក្រុងដែលពួកគេបានទស្សនា។ សាសនាយូដា និងគ្រីស្តសាសនាបានរីកសាយភាយតាមរយៈការធ្វើដំណើររបស់ពាណិជ្ជករ។

ទីក្រុងដ៏ពិសិដ្ឋមេកកា៖ មេកកាគឺជាមជ្ឈមណ្ឌលសាសនា ក៏ដូចជាមជ្ឈមណ្ឌលសម្រាប់ការធ្វើពាណិជ្ជកម្មដ៏សំខាន់មួយ។ វាមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវពាណិជ្ជកម្មនៅអារ៉ាប់ខាងលិច។ ក្បួនដឹកជញ្ជូននានាបានឈប់សំចតនៅមេកកាអំឡុងពេលនៅខែពិសិដ្ឋមួយចំនួន។ ពួកគេបាននាំយកមនុស្សជាច្រើន ដែលធ្វើដំណើរមកដើម្បីគោរពបូជានៅព្រះវិហារសាសនាបុរាណមួយដែលគេហៅថា កាអាបាដែលមានទីតាំងស្ថិតនៅចំកណ្តាលនៃទីក្រុង។ ព្រះវិហារនេះគឺជាសំណង់ថ្មរាងបួនជ្រុង។ ជារៀងរាល់ឆ្នាំ មនុស្សធ្វើដំណើរមកពីគ្រប់ទីកន្លែងទាំងអស់នៅឧបទ្វីអារ៉ាប់ដើម្បីគោរពបូជានៅក្នុងទីក្រុងមេកកា។ ការធ្វើដំណើរទៅកាន់ទីកន្លែងដែលពិសិដ្ឋមួយត្រូវបានគេហៅថាធម្មយាត្រា។

សាសនាច្រើន៖ ពួកអារ៉ាប់មួយចំនួនបានភ្ជាប់ទំនាក់ទំនងកាអាបាជាមួយនឹងមេដឹកនាំសាសនាសម័យបុរាណអាប្រ៉ាហាម។ ពួកអារ៉ាប់ជាច្រើនយល់ថាពួកគេគឺជាបុព្វការីជនរបស់អាប្រ៉ាហាម។ ពួកគេជឿថា អាប្រ៉ាហាម និងកូនប្រុសរបស់គាត់ អ៊ីស្មាអែលបានស្ថាបនាប្រាសាទ កាអាបាសម្រាប់ព្រះជាម្ចាស់ (ជាភាសាអារ៉ាប់គេហៅថាអាឡា)។ ការជឿលើអាទិទេពតែមួយត្រូវបានគេហៅថាឯកទេពនិយម។ ពួកអារ៉ាប់មួយចំនួនទៀត ជាពិសេសអ្នកទាំងឡាយណាដែលរស់នៅតំបន់វាលខ្សាច់ មានជំនឿលើអាទិទេពជាច្រើន។ ជំនឿទៅលើអាទិទេពច្រើនត្រូវបានគេហៅថាពហុទេពនិយម។ ក្រោយមក ពួកអារ៉ាប់ដែលមានជំនឿបែបពហុទេពនិយមទាំងនេះក៏ចាប់ផ្តើមគោរពបូជានៅកាអាបាផងដែរ។

មានពួកជ្វីប និងគ្រីស្តសាសនិកជាច្រើនរស់នៅក្នុងដែនដីអារ៉ាប់។ ជាលទ្ធផល ជំនឿលើអាទិទេពតែមួយបានបន្តទៅដល់មនុស្សដែលរស់នៅឧបទ្វីបអារ៉ាប់។ ជាមួយគ្នានោះផងដែរ មានប្រជាជនអារ៉ាប់មួយចំនួនបានលាយបញ្ចូលគ្នានូវជំនឿ និងក្បួនពិធីរបស់ពួកជ្វីប និងគ្រីស្តសាសនិក ជាមួយនឹងជំនឿជាលក្ខណៈប្រពៃណីរបស់ពួកគេ។ នៅក្នុងបរិយាកាសនៃការលាយបញ្ចូលគ្នានេះហើយ ដែលមេដឹកនាំសាសនាដ៏មានឥទ្ធិពលបំផុតនៅលើពិភពលោក គឺព្យាការីមហាម៉ាត់បានចាប់កំណើតឡើងនៅក្នុងឆ្នាំ 570 នៃគ.ស។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីមូលហេតុដែលនាំឱ្យមានការអភិវឌ្ឍផ្លូវពាណិជ្ជកម្មជាច្រើននៅឧបទ្វីបអារ៉ាប់។

### 3. ជីវិតរស់នៅ និងការបង្រៀនរបស់មហាម៉ាត់

សំណួរគន្លឹះ៖ តើមហាម៉ាត់បានដើរតួនាទីអ្វីខ្លះនៅក្នុងការអភិវឌ្ឍសាសនាអ៊ីស្លាម?

មហាម៉ាត់កើតនៅក្នុងគ្រួសារដ៏មានអំណាចមួយនៅមេកកា ប៉ុន្តែលោកត្រូវបានបញ្ជូនឱ្យទៅរស់នៅមណ្ឌលថែទាំកុមារកំព្រានៅពេលដែលលោកស្ថិតនៅវ័យកុមារ។ នៅពេលដែលលោកមានអាយុ 25 ឆ្នាំ លោកបានរៀបអាពាហ៍ពិពាហ៍ជាមួយពាណិជ្ជករស្រីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភមួយរូប។ បន្តិចម្តងៗ មហាម៉ាត់បានប្រែក្លាយខ្លួនទៅជាពាណិជ្ជករមួយរូប។

មហាម៉ាត់ក្លាយជាព្យាការី៖ នៅពេលដែលលោកមានអាយុប្រហែល 40 ឆ្នាំ ជីវិតរស់នៅរបស់មហាម៉ាត់ បានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ ថ្ងៃមួយនៅពេលដែលកំពុងធ្វើការបន់ស្រន់ លោកបានគិតថា លោកបានលឺសំលេងមួយ

ដែលនិយាយទៅកាន់លោកថា "អ្នកគឺជាអ្នកនាំសាររបស់ព្រះជាម្ចាស់"។ មហាម៉ាត់ជឿថាព្រះជាម្ចាស់និយាយទៅកាន់លោកតាមរយៈទេពធីតាហ្គាប្រីល។ ពេលនោះលោកបានចាប់ផ្តើមធ្វើការប្រៀនប្រដៅដល់អ្នកដទៃថា មានតែព្រះជាម្ចាស់(អាឡា)តែមួយគត់ ហើយអាទិទេពផ្សេងៗទៀតត្រូវបានបដិសេធចោល។

នេះគឺជាគោលការសំខាន់មួយនៃសាសនាអ៊ីស្លាម ដែលជាសាសនាបែបឯកទេពនិយម ដោយផ្តោតសំខាន់លើការប្រតិបត្តិតាមបំណងរបស់ព្រះជាម្ចាស់។ នៅក្នុងភាសាអារ៉ាប់ អ៊ីស្លាម មានន័យថា "សន្តិភាពតាមរយៈការធ្វើតាមបំណងរបស់ព្រះជាម្ចាស់"។ អ្នកដែលដើរតាមសាសនាអ៊ីស្លាមត្រូវបានគេហៅមូស្លីម។ នៅដើមដំបូងមហាម៉ាត់ ទទួលបានជោគជ័យតិចតួចប៉ុណ្ណោះ។ ប្រឈមមុខទៅនឹងធ្វើទុក្ខបុកម្នេញរបស់ពួកមេកកាលើពួកមូស្លីម។ នៅក្នុងឆ្នាំ 622 មហាម៉ាត់ជាមួយនឹងអ្នកគាំទ្រលោកបានរត់គៀសខ្លួនទៅកាន់យ៉ាស់រីប ដែលមានចម្ងាយប្រមាណ 200 ម៉ាយភាគខាងជើងទីក្រុងមេកកា។ ការធ្វើអន្តោប្រវេសន៍នេះត្រូវបានគេហៅថាហ៊ីប្រា។ ក្រុមអ្នកដើរតាមមហាម៉ាត់បានប្តូរឈ្មោះទីក្រុងនេះថាមេឌីណា ដែលមានន័យថា "ទីក្រុងរបស់ព្យាការី"។ នៅក្នុងទីក្រុងមេឌីណាប្រជាជនប្រតិបត្តិតាមសាររបស់មហាម៉ាត់ដើម្បីជាការគោរពដល់បំណងរបស់អាឡា។

ភាពជាអ្នកដឹកនាំរបស់មហាម៉ាត់៖ ពួកមេកកានៅតែបន្តវាយប្រហារប្រឆាំងជាមួយមហាម៉ាត់ និងអ្នកតាមគាត់។ នៅក្នុងឆ្នាំ 630 មហាម៉ាត់ និងពួកមូស្លីមមួយម៉ឺននាក់បានធ្វើដំណើរត្រឡប់មកកាន់មេកកាវិញ។ ពួកគេបានវាយប្រយុទ្ធបង្ខំឱ្យពួកមេកកាចុះចាញ់។ ពេលនោះ មហាម៉ាត់ បានលើកលែងទោសដល់ពួកមេកកា និងបានធ្វើដំណើរទៅកាអាបា។ ពេលនោះហើយដែលលោកបានឧទ្ទិសថ្វាយព្រះវិហារនេះដល់អាឡា។ មហាម៉ាត់គឺជាមេដឹកនាំនយោបាយ និងយោធាមួយរូប ក៏ដូចជាមេដឹកនាំសាសនាផងដែរ។ លោកបានគ្រប់គ្រងមេឌីណា ហើយមានមនុស្សជាច្រើនបានគោរពលោក។ លោកបានចុះសន្ធិសញ្ញាជាមួយក្រុមកុលសម្ព័ន្ធនានានៅក្នុងឧបទ្វីប ដែលបានជួយដល់ការទទួលស្គាល់យកនិងការរីកសាយភាយនៃសាសនាអ៊ីស្លាម អំឡុងពេលនៃការរស់នៅរបស់លោក។ លោកបានប្រើប្រាស់នូវជំនាញយោធារបស់លោក ក្នុងការទប់ទល់ជាមួយនឹងការវាយប្រហារនានាមកលើមេឌីណា។ គិតត្រឹមពេលដែលលោកស្លាប់នៅក្នុងឆ្នាំ 632 មហាម៉ាត់បានបង្រួបបង្រួមតំបន់ជាច្រើននៅឧបទ្វីបអារ៉ាប់ឱ្យស្ថិតនៅក្រោមសាសនាអ៊ីស្លាម។

សង្ខេប៖ ពិពណ៌នាអំពីតួនាទីរបស់មហាម៉ាត់នៅក្នុងការអភិវឌ្ឍសាសនាអ៊ីស្លាម។

## 4. ជំនឿ, ការប្រតិបត្តិ, និងច្បាប់អ៊ីស្លាម

សំណួរគន្លឹះ៖ តើច្បាប់អ្វីដែលពួកមូស្លីមដើរតាមសម្រាប់ការប្រតិបត្តិសាសនា និងជីវិតរស់នៅប្រចាំថ្ងៃ?

ពួកមូស្លីមបានស្វែងរកឃើញនូវការណែនាំអំពីវិធីរស់នៅរបស់ពួកគេ នៅក្នុងប្រភពឯកសារដើមចំនួនពីរ។ ឯកសារទាំងពីរនេះគឺមានទំនាក់ទំនងជាមួយនឹងមហាម៉ាត់។

គម្ពីរកូរ៉ាន់ និងស៊ុនណា៖ ការអប់រំគោលរបស់សាសនាអ៊ីស្លាមគឺថា មានតែព្រះជាម្ចាស់តែមួយគត់គឺ អាឡា។ ពួកមូស្លីមជឿថាព្រះជាម្ចាស់បានបញ្ចេញសេចក្តីប្រកាសរបស់ទ្រង់តាមរយៈទេពធីតាហ្គាប្រីល អ្នកដែលបានបញ្ជូន

សេចក្តីប្រកាសនេះបន្តទៅមហាម៉ាត់។ នៅអំឡុងពេលនៃការរស់នៅរបស់មហាម៉ាត់ អ្នកដើរតាមគាត់បានស្តាប់ការអប់រំរបស់លោក។ ពួកគេក៏បានចងចាំ និងសរសេរឡើងវិញនូវសេចក្តីប្រកាសនានា ដែលបានបង្កើតជាគម្ពីសាសនាមួយដែលគេហៅថាកូរ៉ាន់។ បន្ទាប់ពីមហាម៉ាត់ស្លាប់ទៅ អ្នកដើរតាមគាត់បានប្រមូលគម្ពីកូរ៉ាន់បញ្ចូលទៅក្នុងសៀវភៅមួយក្បាលដែលសរសេរឡើងជាភាសាអារ៉ាប់។ វាគឺជាសៀវភៅពិសិដ្ឋរបស់ពួកមូស្លីម។

ពួកមូស្លីមជឿថា បេសកម្មរបស់មហាម៉ាត់ក្នុងនាមជាព្យាការីមួយរូបមិនមែនគឺដើម្បីតែប្រមូលផ្តុំនូវពាក្យប្រៀនប្រដៅរបស់អាឡាដើម្បីបង្កើតជាគម្ពីកូរ៉ាន់តែប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីបង្ហាញពីរបៀបនៃការអនុវត្តពាក្យប្រៀនប្រដៅទាំងនោះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃផងដែរ។ សម្រាប់ពួកគេ ស៊ុនណា ឬពាក្យ និងអំពើរបស់មហាម៉ាត់គឺជាមគ្គុទេសន៍សម្រាប់ការរស់នៅ។ ពួកអ្នកច្បាប់ ក្រោយមកបានរៀបចំពាក្យប្រៀនប្រដៅនៅក្នុងគម្ពីកូរ៉ាន់ និងស៊ុនណាទៅក្នុងប្រព័ន្ធច្បាប់មួយ។ ប្រព័ន្ធច្បាប់នេះត្រូវបានប្រើប្រាស់ដោយសហគមន៍មូស្លីមដើម្បីវិនិច្ឆ័យទៅលើបញ្ហាច្បាប់នានា ដូចជាការទទួលកេរ្តិ៍មរតក និងការដាក់ទោសទណ្ឌសម្រាប់ការប្រព្រឹត្តិបទឧក្រិដ្ឋ។

ជីវិតរស់នៅរបស់ពួកមូស្លីម៖ ពួកមូស្លីមព្យាយាមនៅក្នុងភ្ជាប់ការរស់នៅជាលក្ខណៈបុគ្គលរបស់ពួកគេជាមួយនឹងសាសនា។ ពួកគេធ្វើឱ្យសាសនារបស់ពួកគេរស់រានតាមរយៈការប្រតិបត្តិនៃសសរស្តម្ភទាំង 5 របស់អ៊ីស្លាមដែលបានបង្ហាញនៅខាងក្រោម។ សសរស្តម្ភទាំង 5 នេះគឺជាកាតព្វកិច្ចរបស់ពួកមូស្លីមទាំងឡាយដែលត្រូវតែអនុវត្តដើម្បីបង្ហាញពីការយល់ព្រមរបស់ពួកគេចំពោះគោលបំណងរបស់ព្រះជាម្ចាស់។

ទំនៀមទម្លាប់ និងច្បាប់ផ្សេងៗទៀតរបស់សាសនាអ៊ីស្លាមក៏បានជះឥទ្ធិពលលើជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកមូស្លីមផងដែរ។ ក្រុមអ្នកមានជំនឿបានតមនៅក្នុងការបរិភោគសាច់ជ្រូក និងផឹកគ្រឿងស្រវឹង។ ថ្ងៃសុក្រពេលរសៀលត្រូវបានគេកំណត់យកជាថ្ងៃសម្រាប់ការគោរពបូជា និងបន់ស្រន់របស់មនុស្សនៅក្នុងសហគមន៍ទាំងឡាយណាដែលអាចធ្វើដំណើរទៅប្រមូលផ្តុំនៅម៉ូស្គ ដែលជាសំណង់អាគារមួយប្រើសម្រាប់ការគោរពបូជារបស់ពួកម៉ូស្លីម។ គ្រប់ម៉ូស្គទាំងអស់សុទ្ធតែបែរមុខទៅរកទីក្រុងមេកកា ដូច្នេះពួកម៉ូស្លីមអាចធ្វើការបន់ស្រន់ឆ្ពោះទៅរកទិសនេះ។

ការជាប់ទាក់ទងទៅនឹងសាសនាយូដា និងគ្រឹស្តសាសនា៖ ពួកមូស្លីមបានភ្ជាប់ការចាប់ផ្តើមដំបូងនៃសាសនារបស់ពួកគេទៅនឹងអាប្រាហាម។ ពួកគេជឿថាលោកគឺជាព្យាការីរបស់ព្រះជាម្ចាស់ ដូចដែលពួកជ្វីប និងគ្រឹស្តសាសនិកជឿដែរ។ សម្រាប់ពួកមូស្លីម អាឡា គឺជាព្រះជាម្ចាស់តែមួយដែលគោរពបូជាដោយពួកគ្រឹស្តសាសនិក និងពួកជ្វីប។ ពួកមូស្លីមបានហៅពួកគ្រឹស្តសាសនិក និងជ្វីបថា "មនុស្សនៅក្នុងសៀវភៅ" ដោយសារតែសាសនារបស់ពួកគេមានគម្ពីពិសិដ្ឋ ជាមួយនឹងការបង្រៀនស្រដៀងគ្នាជាមួយនឹងគម្ពីកូរ៉ាន់។ អ្នកដើរតាមសាសនាទាំង 3 នេះសុទ្ធតែមានជំនឿលើឋានសួគ៌, ឋាននរក, និងថ្ងៃនៃការវិនិច្ឆ័យទោសចុងក្រោយ។

ប៉ុន្តែ ខុសពីគ្រឹស្តសាសនិក ពួកមូស្លីមយល់ឃើញថាព្រះយេស៊ូគឺជាព្យាការីមួយរូប មិនមែនជាបុត្រារបស់ព្រះជាម្ចាស់ឡើយ។ ពួកមូស្លីមជឿថាគម្ពីកូរ៉ាន់គឺជាបន្ទូលរបស់ព្រះជាម្ចាស់ដែលបានបង្ហាញប្រាប់ទៅកាន់មហាម៉ាត់។ ពួកជ្វីប និងគ្រឹស្តសាសនិកក៏ជឿថាបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញនៅក្នុងគម្ពីពិសិដ្ឋរបស់ពួកគេ។ ប៉ុន្តែ

មូស្លីមជឿថា គម្ពីគូរ៉ាន់គឺជាសៀវភៅនៃពាក្យបន្ទូលដំបូងរបស់ព្រះជាម្ចាស់។ ពួកក៏បានគិតថា មហាម៉ាត់គឺជាព្យាការីចុងក្រោយនៃព្រះជាម្ចាស់។

ច្បាប់របស់មូស្លីម បានតម្រូវឱ្យមេដឹកនាំមូស្លីមទាំងឡាយផ្តល់នូវការអត់ឱនផ្នែកសាសនាដល់អ្នកទាំងឡាយណាមិនមែនជាមូស្លីម ប៉ុន្តែពួកអ្នកមិនមែនមូស្លីមទាំងនោះត្រូវបានកម្រិតសិទ្ធិ និងត្រូវបង់ពន្ធបន្ថែម។ គោលនយោបាយនៃការអត់ឱនសម្រាប់អ្នកមិនមែនមូស្លីមនេះបានដើរតួនាទីដ៏សំខាន់មួយនៅក្នុងការពង្រីកចក្រភពមូស្លីមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកដែលបន្តវេនពីមហាម៉ាត់។

សង្ខេប៖ កំណត់អំពីច្បាប់ដែលពួកមូស្លីមបានដើរតាមសម្រាប់ការប្រតិបត្តិសាសនា និងជីវិតរស់នៅប្រចាំថ្ងៃ។

# មេរៀនទី 2 ៖ ការពង្រីកអំណាចរបស់ពួកម៉ូស្លីម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ការស្លាប់របស់មហាម៉ាត់នៅក្នុងឆ្នាំ 632 បាននាំមកនូវវិបត្តិមួយ។ តើសាសនាអ៊ីស្លាមបន្តមានជីវិតដោយរបៀបណា នៅពេលដែលគ្មានការដឹកនាំរបស់ព្យាការី?

## 1. មេដឹកនាំម៉ូស្លីមថ្មីលេចឡើង

សំណួរគន្លឹះ៖ ហេតុអ្វីបានជាអ្នកតំណាងឱ្យមហាម៉ាត់អត់ឱនឱ្យមនុស្សទាំងឡាយនៅក្នុងដែនដីដែលពួកគេដណ្ដើមកាន់កាប់?

អស់រយៈពេលជាង 20 ឆ្នាំ មហាម៉ាត់បានសាយភាយសាសនាអ៊ីស្លាមនៅពាសពេញឧបទ្វីបអារ៉ាប់។ លោកបានចាប់ផ្ដើមស្ថាបនាចក្រភពម៉ូស្លីមមួយ។ សារមួយដែលសំខាន់ដែលពួកចរកជនអារ៉ាប់ នានាទទួលយកគឺ សាសនាអ៊ីស្លាមនាំមកនូវសណ្ដាប់ធ្នាប់, យុត្តិធម៌, និងសេចក្ដីសង្ឃឹមអំពីឋានសួគ៌ទៅកាន់ជីវិតរបស់ពួកគេ។ ក្រោយមកនៅក្នុងខែមិថុនា ឆ្នាំ 623 មហាម៉ាត់បានស្លាប់។ ភ្លាមៗនោះពួកម៉ូស្លីមមិនមានមេដឹកនាំឡើយ។ ពួកគេមិនមានវិធីច្បាស់លាស់មួយណានៅក្នុងការជ្រើសរើសមេដឹកនាំថ្មីឡើយ។

ការស្លាប់របស់មហាម៉ាត់៖ យោងតាមទំនៀមទម្លាប់របស់ក្រុមម៉ូស្លីមនាពេលបច្ចុប្បន្ន មហាម៉ាត់មិនបានតែងតាំងអ្នកស្នងតំណែងបន្តពីលោក ឬបង្រៀនអ្នកដើរតាមលោកអំពីរបៀបនៃការជ្រើសរើសមេដឹកនាំថ្មីបន្ទាប់ពីលោកស្លាប់ឡើយ។ សេចក្ដីវង្វេង បានកើតមានឡើងនៅពាសពេញសហគមន៍ម៉ូស្លីម។ ឪពុកក្មេក និងជាមិត្តភ័ក្ដជិតស្និតរបស់មហាម៉ាត់ អាប៊ូបាកបានប្រកាសថាលោកនឹងរ៉ាប់រងបន្តពីមហាម៉ាត់។ លោកបាននិយាយថា "ប្រសិនជានៅក្នុងចំណោមអ្នកទាំងអស់គ្នា គោរពបូជាដល់មហាម៉ាត់ពេលនេះគាត់បានស្លាប់ហើយ។ ប៉ុន្តែ ប្រសិនបើអ្នកទាំងអស់គ្នាគោរពបូជាលើព្រះជាម្ចាស់ ទ្រង់នៅមានព្រះជន្មជារៀងរហូត"។ អាប៊ូបាកត្រូវបានគេគោរពសម្រាប់ការលះបង់របស់លោកចំពោះមហាម៉ាត់ ក៏ដូចជាសាសនាអ៊ីស្លាម។ ជាលទ្ធផល នៅក្នុងឆ្នាំ 632 មេដឹកនាំដែលមានឥទ្ធិពលនៅក្នុងសហគមន៍ម៉ូស្លីមបានជ្រើសរើស អាប៊ូបាកធ្វើជាអ្នកបន្តវេនពីមហាម៉ាត់។

អាប៊ូបាកបន្តតំណែងពីមហាម៉ាត់៖ នៅក្នុងឆ្នាំ 632 អាប៊ូបាកបានក្លាយជាអ្នកតំណាង ឬមានន័យថា "អ្នកបន្តវេន" ដំបូងរបស់មហាម៉ាត់។ លោកបានសន្យាជាមួយពួកម៉ូស្លីមថា លោកនឹងធ្វើតាមគំរូរបស់មហាម៉ាត់ឱ្យបានខ្ជាប់ខ្ជួន។

ភ្លាមៗពីការស្លាប់របស់ព្យាការីមហាម៉ាត់ ពួកក្រុមកុលសម្ព័ន្ធមួយចំនួននៅឧបទ្វីបអារ៉ាប់បានបោះបង់សាសនាអ៊ីស្លាមចោល។ ក្រុមកុលសម្ព័ន្ធមួយចំនួនទៀតបដិសេដនៅក្នុងការបង់ពន្ធ និងមានបុគ្គលមួយចំនួនតូចទៀតថែមទាំងបានប្រកាសខ្លួនឯងថាជាព្យាការីទៀតផង។ អំឡុងពេលការដឹកនាំរបស់លោក 2 ឆ្នាំ អាប៊ូបាកបានប្រើកម្លាំងយោធាដើម្បីបង្រួបបង្រួមសហគមន៍ម៉ូស្លីមឡើងវិញ។ បន្ទាប់ពីនាំយកតំបន់អារ៉ាប់កណ្ដាលដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម៉ូស្លីមមក លោកបានចាប់ផ្ដើមដណ្ដើមកាន់កាប់ដែនដីស្ថិតនៅភាគខាងជើង ដែលបច្ចុប្បន្នស្ថិតនៅប្រទេសអ៊ីរ៉ាក់ និងស៊ីរី។

អ្នកតំណាងអាប្រាហាម 4 នាក់ដំបូង៖ បន្ទាប់ពីអាប៊ូបាក អ្នកតំណាង 3 នាក់បន្ទាប់ទៀតត្រូវបានជ្រើសរើសដោយអ្នកមានជំនឿម៉ូស្លីមឋានៈខ្ពស់ ក្នុងនោះរួមមាន អ៊ូម៉ា, អ៊ូសម៉ាន, និងអាលី។ អ្នកទាំង 4 រូបនេះបានស្គាល់មហាម៉ាត់ និងគាំទ្របេសកកម្មរបស់លោកនៅក្នុងការសាយភាយសាសនាអ៊ីស្លាម។ តួនាទីរបស់ពួកគេគឺជាអ្នកតំណាង។ យោងតាមទំនៀមទម្លាប់ និងជំនឿរបស់ក្រុមមូស្លីមនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន អ្នកតំណាងទាំង 4 រូបនេះប្រើប្រាស់គម្ពីកូរ៉ាន់ និងសកម្មភាពរបស់មហាម៉ាត់ដើម្បីនាំផ្លូវពួកគេ។ ជាលទ្ធផល ក្រុមអ្នកកាន់សាសនាអ៊ីស្លាមទាំងអស់នេះបានហៅអ្នកតំណាង 4 រូបដំបូងនេះថា "មគ្គុទេសន៍តំណាងដ៏ត្រឹមត្រូវ"។ ពួកម៉ូស្លីមបានគ្រប់គ្រងតំបន់អារ៉ាប់ស្ទើរតែទាំងស្រុងនៅពេលដែលអាប៊ូបាកស្លាប់នៅក្នុងឆ្នាំ 634 ។

អ្នកតំណាងទី 2 អ៊ូម៉ាដឹកនាំបន្តពីអាប៊ូបាករហូតដល់ឆ្នាំ 644 ។ កងទ័ពដែលរហ័ស និងមានបទវិន័យខ្ពស់របស់លោកបានដណ្តើមកាន់កាប់ស៊ីរី និងអេហ្ស៊ីបក្រោម ដែលជាផ្នែកមួយនៃចក្រភពប៊ីហ្សង់ទីន។ កងទ័ពម៊ូស្លីមក៏ដណ្តើមទឹកទីពីចក្រភពពែក្សផងដែរ។ អ្នកតំណាងពីររូបបន្ទាប់បន្តពង្រីកដែនដីរបស់ម៉ូស្លីម និងសម្រេចនៅក្នុងការដណ្តើមកាន់កាប់ពែក្ស។ ត្រឹមឆ្នាំ 661 អ្នកបន្តវេនរបស់មហាម៉ាត់ បានពង្រីកទំហំដែនដីចក្រភពម៉ូស្លីមធំជាងមុនជិត 4 ដង ទាំងតាមរយៈការដណ្តើមកាន់កាប់ និងការចុះសន្ធិសញ្ញា។ ត្រឹមឆ្នាំ 750 ចក្រភពម៉ូស្លីមបានលាតសន្ធឹងប្រមាណ 5 ពាន់ម៉ាយ គឺចាប់ពីមហាសមុទ្រអាត្លង់ទិកទៅដល់ជ្រលងទន្លេឥណ្ឌូស ដែលមានចម្ងាយប្រហែលពីញ៉ូវយកទៅឡូអានជីឡេស 2 ដង។

ការដឹកនាំដ៏ជោគជ័យរបស់ពួកម៉ូស្លីម៖ ពួកម៉ូស្លីមបានមើលឃើញពីភាពជោគជ័យនៃកម្លាំងយោធាគឺជាសញ្ញាណមួយនៃការជួយរបស់ព្រះអាឡា។ ពួកគេត្រូវបានផ្តល់ថាមពលដោយជំនឿរបស់ពួកគេ ហើយពួកគេយល់ព្រមនៅក្នុងការប្រយុទ្ធដើម្បីសាយភាយសាសនាអ៊ីស្លាម។ នៅក្នុងបន្ថែមទៅលើជំនឿរបស់ពួកគេ មានមូលហេតុមួយចំនួនទៀតដែលនាំឱ្យកងទ័ពម៉ូស្លីមទទួលបានជោគជ័យ។ នៅក្នុងសមរភូមិ កងទ័ពម៉ូស្លីមមានវិន័យ ហើយមេដឹកនាំរបស់ពួកគេមានជំនាញខ្ពស់។ យុទ្ធសាស្ត្ររបស់ពួកគេ អាចអនុញ្ញាតឱ្យពួកគេយកជ័យជំនះលើកងកម្លាំងនានាដែរមិនសូវមានវិន័យ និងជំនាញ។ ការចុះខ្សោយនៃចក្រភពពីរនៅភាគខាងជើងអារ៉ាប់ក៏ជាកត្តាមួយនាំទៅដល់ជ័យជំនះរបស់ពួកម៉ូស្លីមផងដែរ។ ចក្រភពប៊ីហ្សង់ទីន និងចក្រភពពែក្សធ្វើការវាយប្រយុទ្ធគ្នាទៅវិញទៅមកអស់រយៈពេលជាយូរមកហើយ។ កងទ័ពរបស់ពួកគេបានថយកម្លាំង។ ចក្រភពប៊ីហ្សង់ទីន និងចក្រភពពែក្សបានធ្វើទុក្ខបុកម្និញចំពោះអ្នកទាំងឡាយណាដែលមិនគាំទ្រសាសនារបស់ពួកគេ។ ប្រជាជនដែលទទួលរងធ្វើទុក្ខបុកម្និញទាំងនេះជាទូទៅតែងតែស្វាគមន៍ក្រុមអ្នកឈ្លានពានម៉ូស្លីម ដោយពួកគេបានគិតថាពួកគេគឺជាអ្នកជួយរំដោះ។ ដោយសារតែគម្ពីកូរ៉ាន់មិនអនុញ្ញាតឱ្យពួកម៉ូស្លីមបង្ខំឱ្យនណារម្នាក់កែប្រែសាសនារបស់ពួកគេ ពួកម៉ូស្លីមអនុញ្ញាតឱ្យប្រជាជនដែលរស់នៅក្នុងដែនដីដែលពួកគេដណ្តើមកាន់កាប់ រក្សានូវជំនឿផ្ទាល់របស់ពួកគេប្រសិនណាបើពួកគេចង់។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកម៉ូស្លីម មានការលាយបញ្ចូលគ្នានូវវប្បធម៌យ៉ាងច្រើន។ ក្រោយមក ប្រជាជនដែលស្ថិតនៅក្នុងដែនដីដែលគ្រប់គ្រងដោយពួកម៉ូស្លីមបានផ្លាស់ប្តូរជំនឿរបស់ពួកគេទៅកាន់សាសនាអ៊ីស្លាម។ ពួកគេមានការចាប់អារម្មណ៍ទៅនឹងសាររបស់សាសនាអ៊ីស្លាមទាក់ទងនឹងសមភាព និងសេចក្តីសង្ឃឹមសម្រាប់ជួយសង្គ្រោះ។ ការផ្លាស់ទៅកាន់សាសនាអ៊ីស្លាមក៏នាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ចផងដែរ។ ពួកម៉ូ

ស្លីមមិនតម្រូវឱ្យបង់ពន្ធច្រើននោះទេ។ ពួកជ្វីប និងគ្រីស្តសាសនិក ដែលគេហៅថា "មនុស្សនៅក្នុងសៀវភៅ" ទទួលបានការយកចិត្តទុកដាក់យ៉ាងពិសេស។ ពួកគេត្រូវធ្វើជំរឿនម្តងក្នុងមួយឆ្នាំដើម្បីជាថ្នូរទៅនឹងការលើកលែងកាតព្វកិច្ចអនុវត្តយោធា។ ពួកជ្វីប និងគ្រីស្តសាសនិកក៏មានតួនាទីសំខាន់នៅក្នុងរដ្ឋមូស្លីមផងដែរ ដោយពួកគេមួយចំនួនធ្វើជាមន្ត្រី និងអ្នកប្រាជ្ញ។ ប៉ុន្តែ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យកែប្រែអ្នកដទៃឱ្យជឿសាសនារបស់ពួកគេឡើយ។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីមូលហេតុដែលនាំឱ្យអ្នកតំណាងមហាម៉ាតអត់ឱនចំពោះប្រជាជនដែលស្ថិតនៅក្នុងដែនដីដែលពួកគេដណ្តើមកាន់កាប់

## 2. ការបែកខ្ញែកនូវសាសនាអ៊ីស្លាម

សំណួរគន្លឹះ៖ តើបញ្ហានៃការជ្រើសរើសមេដឹកនាំ បានបែងចែកសហគមន៍មូស្លីមយ៉ាងដូចម្តេច?

ភាពជោគជ័យនៅក្នុងសមរភូមិបានអនុញ្ញាតឱ្យពួកម៉ូស្លីមពង្រីកចក្រភពរបស់ពួកគេ។ ប៉ុន្តែ ការប្រជែងអំណាចផ្ទៃក្នុងបង្កឲ្យមានភាពលំបាកសម្រាប់ពួកគេនៅក្នុងការរក្សាការគ្រប់គ្រងរួមមួយ។

អ៊ូម៉ាយយាដ្យកាន់កាប់អំណាច៖ នៅក្នុងឆ្នាំ 656 ក្រុមអ្នកបះបោរមួយក្រុមបានងើបឡើងប្រឆាំងទៅនឹងការដឹកនាំរបស់អ៊ូម៉ាន និងបានធ្វើឃាតលោក។ ការធ្វើឃាតគាត់នេះបានបង្កទៅជាសង្គ្រាមស៊ីវិលមួយ។ មានក្រុមជាច្រើនចាប់ផ្តើមប្រយុទ្ធគ្នាដើម្បីអំណាច។ ជីដូនមួយ និងជាកូនប្រសាររបស់មហាម៉ាត់ អាលី គឺជាអ្នកតំណាងមហាម៉ាត់បន្ទាប់ដែលត្រូវបានគេជ្រើសរើស។ ប៉ុន្តែ ការដឹកនាំរបស់លោកក៏ត្រូវបានប្រឆាំងផងដែរ។ នៅក្នុងឆ្នាំ 661 អាលី ត្រូវបានគេលួចធ្វើឃាត។ ប្រព័ន្ធនៃការជ្រើសរើសអ្នកតំណាងមហាម៉ាត់បានស្លាប់ទៅជាមួយលោក។

គ្រួសារមួយដែលគេស្គាល់ថា អ៊ូម៉ាយយាដ្យបានឡើងកាន់អំណាច និងបានបង្កើតសន្តិវង្សដែលស្នងរាជ្យបន្តពីឪពុកទៅកូនមួយ។ នេះមានន័យថា មេដឹកនាំត្រូវមកពីគ្រួសារតែមួយ និងទទួលមរតកនៅក្នុងការគ្រប់គ្រង។ អ៊ូម៉ាយយាដ្យ ក៏បានផ្លាស់ទីរាជធានីរបស់ម៉ូស្លីមពីមេឌីណាទៅដាម៉ាកូសដែលជាទីក្រុងទើបតែដណ្តើមបាន ដែលពីដំបូងឡើយជាផ្នែកមួយនៃចក្រភពប៊ីហ្សង់ទីន។ ទីក្រុងនេះមានទីតាំងប្រហែល 600 ម៉ាយភាគខាងជើងមេឌីណា ដើម្បីធ្វើឱ្យមានភាពងាយស្រួលសម្រាប់មេដឹកនាំម៉ូស្លីមនៅក្នុងការគ្រប់គ្រងដែនដីដែលពួកគេដណ្តើមកាន់កាប់។ ប៉ុន្តែ ពួកម៉ូស្លីមនៅអារ៉ាប់យល់ថា ដាម៉ាកូសមានចម្ងាយឆ្ងាយពេក។ សកម្មភាពនេះហើយដែលនាំឱ្យមានការបែងចែកពួកម៉ូស្លីម និងកើនឡើងនូវបញ្ហានៃការជ្រើសរើសមេដឹកនាំ។

សហគមន៍ម៉ូស្លីមបែកជាពីរ៖ ដោយសារតែពួកគេត្រូវការសន្តិភាពពួកម៉ូស្លីមជាច្រើនបានទទួលយកការដឹកនាំរបស់អ៊ូម៉ាយយាដ្យ។ ពួកអ្នកដែលទទួលយកទាំងអស់នោះត្រូវបានគេហៅថាស៊ុននី។ ពាក្យនេះមានន័យថាអ្នកដើរតាមគម្ពីស៊ុនណា ឬអ្នកដើរតាមគំរូរបស់មហាម៉ាត់។ ប៉ុន្តែ មានពួកម៉ូស្លីមមួយចំនួនតូចបានប្រឆាំងទៅនឹងការគ្រប់គ្រងរបស់អ៊ូម៉ាយយាដ្យ និងបានបដិសេធនៅក្នុងការទទួលស្គាល់លោកថាជាអ្នកតំណាងមហាម៉ាត់។ ពួកគេជឿថា អ្នកតំណាងមហាម៉ាត់ត្រូវតែជាអ្នកដែលមានទំនាក់ទំនងជាមួយព្យាការីមហាម៉ាត់។ ពួកក្រុមទាំង

អស់នេះត្រូវបានគេហៅថាស៊ីអាដែលមានន័យថា "ភាគី" ខាងអាលី។ សមាជិកនៃក្រុមនេះត្រូវបានគេស្គាល់ថាពួកស៊ីអ៊ីត។ ការបែងចែកនៅក្នុងសាសនាអ៊ីស្លាមនេះបានក្លាយជាអចិន្ត្រៃ ហើយការប្រឆាំងទៅនឹងអ៊ូម៉ាយយាដ្ស បន្តិចម្តងៗបានបណ្តាលឱ្យប្រព័ន្ធអ្នកតំណាងមហាម៉ាត់របស់ពួកគេដួលរលំ។

កំណត់បញ្ហា៖ ពន្យល់ពីបញ្ហានៃការជ្រើសរើសមេដឹកនាំដែលនាំឱ្យបែកខ្ញែកសហគមន៍ម៉ូស្លីម។

## 3. អ៊ូម៉ាយយាដ្ស

សំណួរគន្លឹះ៖ តើមូលហេតុអ្វីដែលនាំដល់ការធ្លាក់ចុះនៃអ៊ូម៉ាយយាដ្ស?

នៅពេលដែលអ៊ូម៉ាយយាដ្សបានក្លាយជាអ្នកគ្រប់គ្រង ពួកគេចាប់ផ្តើមធ្វើការឈ្លានពានដែនដីថ្មី។ នៅក្នុងរយៈពេលមិនដល់ 100 ឆ្នាំផង ចក្រភពរបស់ពួកគេបានគ្របដណ្តប់លើផ្នែកមួយចំនួននៃទ្វីប 3 ដែលមានអាស៊ី, អាហ្វ្រិក, និងអឺរ៉ុប។

ការពង្រីកឆ្ពោះទៅកាន់ភាគខាងកើត៖ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ៊ូម៉ាយយាដ្សចក្រភពម៉ូស្លីមត្រូវបានពង្រីក។ នៅពេលដែលពួកគេគ្រប់គ្រងអំណាចនៅក្នុងឆ្នាំ 661 ព្រំដែនភាគខាងកើតរបស់ចក្រភពបានពង្រីកទៅដល់ពែក្ស។ ពួកគេបានពង្រីកព្រំដែនរបស់ពួកគេឆ្ពោះទៅកាន់ភាគខាងកើតរហូតដល់តំបន់អាស៊ីកណ្តាល។ ដំបូងកងទ័ពរបស់អ៊ូម៉ាយយាដ្សអនុវត្តយុទ្ធសាស្ត្រ "វាយឆ្មក់ហើយរត់" ដោយវាយប្រហារលើទីក្រុងមួយចំនួនដូចជា ប៊ូខារ៉ា និងសាម៉ាកាណ្ឌ។ ទីក្រុងទាំងនេះគឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មក្នុងតំបន់។ ប៉ុន្តែ ក្រោយមកពួកគេបានប្រែពីការវាយឆ្មក់ទៅជាយុទ្ធនាការទ្រង់ទ្រាយធំដើម្បីដណ្តើមកាន់កាប់តែម្តង។ ត្រឹមដើមទសវត្សរ៍ឆ្នាំ 700 ពួកអ៊ូម៉ាយយាដ្សបានដណ្តើមកាន់កាប់ដែនដីភាគច្រើននៅអាស៊ីកណ្តាល។

ការពង្រីកឆ្ពោះទៅកាន់ភាគខាងលិច៖ ពួកអ៊ូម៉ាយយាដ្សក៏បានពង្រីកចក្រភពរបស់ពួកគេឆ្ពោះទៅកាន់ភាគខាងលិចផងដែរ។ ត្រឹមឆ្នាំ 710 ពួកគេត្រួតត្រាតំបន់អាហ្វ្រិកខាងជើងទាំងមូល ចាប់ពីទន្លេនីលរហូតដល់មហាសមុទ្រអាត្លង់ទិក។ មួយឆ្នាំក្រោយមក ពួកគេបានធ្វើដំណើរទៅកាន់ភាគខាងជើងឆ្លងកាត់សមុទ្រមេឌីទែរ៉ានេទៅកាន់ឧបទ្វីបអ៊ីប៉េរៀន។ ឧបទ្វីបអ៊ីប៉េរៀនស្ថិតនៅចុងភាគនិរតីនៃទ្វីបអឺរ៉ុបដែលបច្ចុប្បន្នស្ថិតនៅប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល។ ពីមូលដ្ឋានដ៏រឹងមាំនៅអេស្ប៉ាញ កងទ័ពមូលស្លីមបានបើការវាយឆ្មក់ឆ្ពោះទៅកាន់ទឹកដីអឺរ៉ុបកាន់តែជ្រៅ។ ប៉ុន្តែ កងទ័ពគ្រីស្តសាសនិកបានបញ្ឈប់ការរុលទៅមុខរបស់ពួកគេនៅក្នុងឆ្នាំ 732 នៅក្នុងសមរភូមិតួរ្ស។ ប៉ុន្មានឆ្នាំក្រោយមក កងទ័ពមូលស្លីមបានវិលត្រឡប់មកកាន់អេស្ប៉ាញវិញ។

ការរួមបញ្ចូលគ្នានូវប្រជាជនជាច្រើន៖ ត្រឹមទសវត្សរ៍ឆ្នាំ 800 ពួកអ៊ូម៉ាយយាដ្សបានត្រួតត្រាលើចក្រភពដ៏ធំមួយដែលគ្របដណ្តប់លើដែនដីជាច្រើន។ ដើម្បីគ្រប់គ្រងចក្រភពដ៏ធំធេងនេះ ពួកអ៊ូម៉ាយយាដ្សបាន យកលំនាំរដ្ឋាភិបាលរបស់ពួកគេតាមបែបការិយាធិបតេយ្យនៅលើដែនដីដែលពួកដណ្តើមបានពីចក្រភពប៊ីហ្សង់ទីន។ ការិយាធិបតេយ្យ គឺជាប្រព័ន្ធមួយដែលនាយកដ្ឋាន និងស្ថាប័នមួយទទួលបន្ទុកធ្វើការងារឱ្យរដ្ឋាភិបាល។ មេដឹកនាំរបស់អ៊ូម៉ាយយាដ្ស តាមរយៈប្រព័ន្ធការិយាធិបតេយ្យនេះ បានគ្រប់គ្រងចក្រភពទាំងមូលចេញពីរាជធានីរបស់ពួកគេ

នៅដាម៉ាសកូស។ ដើម្បីគ្រប់គ្រងខេត្តផ្សេងៗនៅក្នុងចក្រភព មេដឹកនាំរបស់អ៊ូម៉ាយយ៉ាដ្យបានតែងតាំងអភិបាលខេត្តម៉ូស្លីមដែលត្រូវបានគេហៅថាអ៊ីមីរ។ ថៅហ្វាយខេត្តទាំងនេះពឹងផ្អែកលើមេដឹកនាំកុលសម្ព័ន្ធក្នុងដំបូងដើម្បីជួយដល់ការគ្រប់គ្រងរបស់ពួកគេ។

ដំបូងឡើយ ភាសាបានរារាំងដល់ការបង្រួបបង្រួមនៅក្នុងចក្រភព។ ប្រជាជននៅក្នុងតំបន់ផ្សេងៗគ្នានៅក្នុងចក្រភពនិយាយភាសាផ្ទាល់ខ្លួនរបស់ពួកគេ។ អាបដ អាល-ម៉ាលីកដែលបានក្លាយជាមេដឹកនាំនៅក្នុងឆ្នាំ 685 បានដោះស្រាយបញ្ហានេះ។ ទ្រង់បានប្រកាសថា ភាសាអារ៉ាប់គឺជាភាសារបស់រដ្ឋាភិបាលនៅក្នុងដែលដីម៉ូស្លីមទាំងឡាយ។ មានភាសាប្រើក្នុងរដ្ឋាភិបាលរួមមួយបានជួយឱ្យប្រជាជននៅក្នុងចក្រភពទាំងមូលកាន់តែងាយស្រួលក្នុងការធ្វើទំនាក់ទំនងជាមួយតំបន់ដ៏ទៃទៀត។ បើទោះបីជាដូច្នេះក៏ដោយ ពួកម៉ូស្លីមភាគច្រើននៅតែនិយាយភាសារបស់ពួកគេនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ពួកម៉ូស្លីមនៅពាលពេញចក្រភពក៏បានចែករំលែកបទពិសោធន៍នៃការធ្វើធម្មយាត្រា ឬហាជទៅកាន់មេកកា។ នៅទីនោះពួកគេចែករំលែកវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ និងបាននាំមកនូវចំណេះដឹងអំពីវប្បធម៌អារ៉ាប់ និងការគ្រប់គ្រងរបស់អ៊ូម៉ាយយ៉ាដ្យត្រឡប់ទៅកាន់ដែនដីកំណើតរបស់ពួកគេ។ ដូច្នេះការធ្វើធម្មយាត្រា បាននាំមកនូវការលាយបញ្ចូលគ្នានូវវប្បធម៌ផ្សេងៗជាច្រើន។

ការទម្លាក់អ៊ូម៉ាយយ៉ាដ្យ៖ ពួកអ៊ូម៉ាយយ៉ាដ្យបានដណ្ដើមកាន់កាប់ដែនដីថ្មីៗជាច្រើន និងបាននាំយកសាសនាអ៊ីស្លាមទៅកាន់មនុស្សជាច្រើន។ ប៉ុន្តែ នៅត្រឹមពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 700 ពួកមូលស្លីមមួយចំនួនបានចោទប្រកាន់អ៊ូម៉ាយយ៉ាដ្យថា មានការចាប់អារម្មណ៍ខ្លាំងពេកទៅលើជីវិតរស់នៅបែបប្រណិតភាព និងក្ដោបកាន់អំណាច។ ក្រោយមក មានក្រុមផ្សេងៗបានចាប់ផ្ដើមប្រឆាំងជាមួយនឹងការគ្រប់គ្រងរបស់អ៊ូម៉ាយយ៉ាដ្យ។

ក្រុមមួយឈ្មោះ អាបបាស៊ីដបានទទួលការគាំទ្រពីពួកម៉ូស្លីមដែលប្រឆាំងជាមួយអ៊ូម៉ាយយ៉ាដ្យ។ ត្រឹមឆ្នាំ 750 ពួកអាបបាស៊ីដ និងអ្នកគាំទ្ររបស់ពួកគេបានដណ្ដើមអំណាចពីពួកអ៊ូម៉ាយយ៉ាដ្យ។ មេដឹកនាំអ៊ូម៉ាយយ៉ាដ្យមួយរូបព្រះនាម អាបដ អាល-រ៉ាម៉ានបានរត់គៀសខ្លួនទៅកាន់ប្រទេសអេស្ប៉ាញ។ នៅទីនោះ ទ្រង់បានបង្កើតសន្តតិវង្សអ៊ូម៉ាយយ៉ាដ្យ។ ចក្រភពមូលស្លីមពេលនោះបានបែងចែកទៅជាចក្រភពខាងកើត និងចក្រភពខាងលិច។ បើទោះបីជាមានការបែងចែកក៏ដោយ យុគសម័យមាសមួយរបស់មូលស្លីមក៏កំពុងចាប់ផ្ដើមឡើងផងដែរ។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីមូលហេតុដែលនាំឱ្យអ៊ូម៉ាយយ៉ាដ្យបាត់បង់អំណាច។

# មេរៀនទី 3 ៖ យុគសម័យមាសរបស់ពួកម៉ូស្លីម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ បន្ទាប់ពីអ៊ូម៉ាយយាដ្សដួលរលំ ចក្រភពម៉ូស្លីមបានបែងចែកជាចក្រភពខាងកើត និងចក្រភពខាងលិច។ នៅក្នុងចក្រភពខាងកើត វប្បធម៌របស់ម៉ូស្លីមបានរីកចម្រើននៅក្នុងចក្រភពអាបបាស៊ីដថ្មីមួយ។

បាដាដ៖ ពួកអាបបាស៊ីដក៏បានពង្រឹងអំណាចរបស់ពួកគេតាមរយៈការផ្លាស់ប្តូររាជធានីផងដែរ។ អ្នកគាំទ្រដ៏ស្មោះស្ម័គ្ររបស់ពួកគេរស់នៅភាគខាងកើតឆ្ងាយពីរាជធានីរបស់ពួកអ៊ូម៉ាយយាដ្សនៅដាម៉ាកូស។ ដើម្បីស្ថិតនៅជិតមូលដ្ឋានអំណាចរបស់ពួកគេ ពួកអាបបាស៊ីដបានជ្រើសរើសយក បាដាដធ្វើជារាជធានីរបស់ពួកគេនៅក្នុងឆ្នាំ 762 ។ មានទីតាំងស្ថិតនៅជិតទន្លេទីគ្រីសបាដាដសាតសន្ទឹងនៅលើផ្លូវពាណិជ្ជកម្មចាស់ពីភាគខាងកើតទៅភាគខាងលិច។ វាបានក្លាយជាតំបន់ទីផ្សារមមាញឹកមួយ និងជាមជ្ឈមណ្ឌលពាណិជ្ជដ៏ធំមួយនៅលើពិភពលោក។

ស្វែងរកគោលគំនិត៖ ពន្យល់ពីវិធីដែលពួកអាបបាស៊ីដពង្រឹងអំណាចរបស់ពួកគេ។

## 1. ការរីកចម្រើន និងការធ្លាក់ចុះរបស់អាបបាស៊ីដ

សំណួរគន្លឹះ៖ តើវប្បធម៌អ្វីខ្លះដែលពួកអាបបាស៊ីដបានអភិវឌ្ឍឡើង?

ភាពជឿនលឿននៃសេដ្ឋកិច្ចបានធ្វើឱ្យពួកអាបបាស៊ីដក្លាយជាអ្នកមាន។ ដើម្បីបង្ហាញពីទ្រព្យសម្បត្តិរបស់ពួកគេ អ្នកមួយចំនួនបានចាប់ផ្តើមគាំទ្រដល់សិល្បៈ និងការសិក្សារៀនសូត្រ។ ជាលទ្ធផល បន្ទាប់ពីឆ្នាំ 800 មក វប្បធម៌របស់មូលស្លីមបានក្លាយជាយុគសម័យមាសមួយ។ យុគសម័យមាស គឺជាសម័យមួយដែលសង្គមមួយប្រកបដោយភាពរុងរឿង និងការរីកចម្រើននៃវប្បធម៌។

សិល្បៈ និងអក្សរសិល្ប៍៖ ពួកម៉ូស្លីមមួយចំនួនគិតថា វាគឺជាកំហុសមួយនៅក្នុងការប្រើប្រាស់ មនុស្សនៅក្នុងទម្រង់សិល្បៈ។ ពួកគេជឿថា រូបមួយចំនួន អាចនឹងលើកទឹកចិត្តឱ្យមនុស្សគោរពបូជារូបទាំងនោះជាជាងគោរពបូជាព្រះជាម្ចាស់។ ជំនួសទៅវិញ ភាគច្រើននៃសិល្បៈម៉ូស្លីមផ្តោតសំខាន់ទៅលើរុក្ខជាតិ និងទម្រង់ធរណីមាត្រ។ សិល្បៈម៉ូស្លីមជាទូទៅក៏ប្រើប្រាស់តួអក្សរអារ៉ាប់ផងដែរ។ វិចិត្រករម៉ូស្លីមជាច្រើនបានក្លាយជាអ្នកសរសេរអក្សរផ្ចង់យ៉ាងស្ទាត់ជំនាញ។ ពួកអាបបាស៊ីដបានជួលអ្នកសរសេរអក្សរផ្ចង់ដើម្បីសរសេរលំអរលើអ្វីៗគ្រប់យ៉ាងរាប់ចាប់តាំងពីអាគារដល់អាវគ្រោះ។

ពួកម៉ូស្លីមភ្លាមៗនោះក៏បានអភិវឌ្ឍអក្សរសិល្ប៍របស់ពួកគេផ្ទាល់ផងដែរ។ រឿងមួយពាន់មួយរាត្រីភ្លាមៗបានក្លាយជាទីគួរចាប់អារម្មណ៍មួយ។ ការនិពន្ធក៏រីកចម្រើនផងដែរអំឡុងពេលនៃការគ្រប់គ្រងរបស់ពួកអាបបាស៊ីដ។ កំណាព្យ 4 ឃ្លា ដែលជាកំណាព្យមួយមាន 4 ជួរ ដែលជួរទីមួយ, ទីពីរ, និងទីបួនចួនគ្នា មានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ជនមូលស្លីមម្នាក់ដែលមានដើមកំណើតជាជនជាតិពេក្សឈ្មោះ អូម៉ារ ខាយយ៉ាមគឺជាអ្នកដែលមានជំនាញនៅក្នុងការសរសេរកំណាព្យ 4 ឃ្លា។

គណិតវិទ្យា និងតារាសាស្ត្រ៖ អ្នកប្រាជ្ញម៉ូស្លីមនៅក្នុងសម័យអាបបាស៊ីដបានខ្ចី និងបង្កើតឡើងនូវគោលគំនិតអំពីអរិយធម៌សម័យបុរាណ។ ឧទាហរណ៍ អាល ខ្វារីសមីបានខ្ចីប្រព័ន្ធលេខ និងលេខសូន្យពីអ្នកប្រាជ្ញឥណ្ឌា។ ការងាររបស់លោក បង្កើតបានជាប្រព័ន្ធលេខអារ៉ាប់ដែលនៅបន្តប្រើរហូតមកដល់សព្វថ្ងៃនៅក្នុងបណ្ដាលប្រទេសជាច្រើននៅលើពិភពលោក។ អាល-ខ្វារីសមីក៏បានសរសេរសៀវភៅដំបូងអំពីពិជគណិតផងដែរ។ ក្រៅតែពីការងារកវីនិពន្ធ អូម៉ារ ខាយយាមក៏ ជាគណិវិទូដ៏ល្បីល្បាញមួយរូបផងដែរ។ លោកបានសរសេរអំពីការសិក្សាជាន់ខ្ពស់របស់ក្រិកអំពីធរណីមាត្រ។ លោកក៏បានប្រើប្រាស់នូវចំណេះដឹងគណិតសាស្ត្រ និងតារាសាស្ត្ររបស់លោក ដើម្បីបង្កើតប្រតិទិនដ៏ត្រឹមត្រូវមួយ។ ស្នាដៃរបស់តារាវិទូជាទូទៅមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្ត។ ឧទាហរណ៍ តារាវិទូមួយរូបឈ្មោះ អាលប៊ីរូនីបានកំណត់ទិសដៅរបស់ទីក្រុងមេកកាពីគ្រប់ទិសទីទាំងអស់នៅលើភពផែនដី។ ការធ្វើដូច្នេះ អាចអនុញ្ញាតឱ្យពួកម៉ូស្លីមដែលរស់នៅគ្រប់ទីកន្លែងនៅក្នុងចក្រភព អាចបំពេញនូវកាតព្វកិច្ចនៅក្នុងការបន់ស្រន់ដោយបែរមុខឆ្ពោះទីរកទីក្រុងមាកកា។

ឱសថសាស្ត្រ៖ វេជ្ជបណ្ឌិតម៉ូស្លីម ក៏ដូចជាអ្នកប្រាជ្ញម៉ូស្លីមដែរ បានពង្រីកការស្រាវជ្រាវវិទ្យាសាស្ត្រដំបូងៗ។ អាល-រ៉ាហ្ស៊ី វេជ្ជបណ្ឌិតដើមកំណើតពែក្ស បានប្រើប្រាស់ការសិក្សាចាស់ដើម្បីជួយលោកនៅក្នុងកំណត់ និងពិពណ៌នាអំពីជំងឺនានា ដូចជាជំងឺអុតស្វាយ និងជំងឺកញ្ជ្រឹលជាដើម។ វេជ្ជបណ្ឌិតពែក្ស អ៊ីបន ស៊ីណាបានសរសេរគម្ពីនៃឱសថសាស្ត្រ ប្រហែលជា 1,000 ។ ស្នាដៃដ៏លម្អិតនេះបានបញ្ចូលនូវចំណេះដឹងទាំងឡាយដែលទាក់ទងផ្នែកវេជ្ជសាស្ត្រ។ សៀវភៅនេះនៅតែបន្តដើរតួនាទីជាសៀវភៅយោងផ្នែកវេជ្ជសាស្ត្រដ៏សំខាន់មួយអស់រយៈពេលជាង 600 ឆ្នាំ។ ពួកអាបបាស៊ីដបានបង្កើតមន្ទីរពេទ្យនៅពាសពេញចក្រភពរបស់ពួកគេ។ ដោយមិនដូចទៅនឹងមន្ទីរពេទ្យផ្សេងៗទៀតនៅលើពិភពលោក មជ្ឈមណ្ឌលវេជ្ជសាស្ត្រទាំងនេះទទួលព្យាបាលប្រជាជនក្រីក្រនានាដែលមិនមានលទ្ធភាពបង់ប្រាក់ផងដែរ។

ការធ្លាក់ចុះនៃអាបបាស៊ីដ៖ មេដឹកនាំអាបបាស៊ីដមួយចំនួនបានប្រងើយកន្តើយទៅនឹងទំនួលខុសត្រូវរបស់ពួកគេចំពោះរដ្ឋាភិបាល។ ជាមួយគ្នានោះផងដែរ ពួកគេធ្វើការងារតិចតួចដើម្បីការពារពួកពាណិជ្ជករពីការវាយប្រហាររបស់ពួកចោរប្លន់ ដែលនាំឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សកម្មភាពពាណិជ្ជកម្ម។ ដោយសារតែហេតុនេះ មេដឹកនាំអាបបាស៊ីដបានបង្កើនការយកពន្ធ។ ដោយនឹយហត់ទៅនឹងអាកប្បកិរិយាគិតតែប្រយោជន៍បុគ្គលរបស់ពួកគេ មានក្រុមមួយចំនួនបានចាប់ផ្ដើមងើបឡើងប្រឆាំងជាមួយការដឹកនាំរបស់អាបបាស៊ីដ។ ក្រុមមួយមានឈ្មោះថាហ្វាទីមីដបានបណ្ដេញពួកអាបបាស៊ីដចេញពីតំបន់អាហ្វ្រិកខាងជើង។ នៅពេលដែលមានការប្រឈមទៅនឹងការប្រឆាំងនៅខាងក្នុងដែនដីចក្រភពកាន់តែខ្លាំង អាបបាស៊ីដត្រូវប្រឈមទៅនឹងការវាយប្រហារពីខាងក្រៅកាន់តែខ្លាំងផងដែរ។ នៅក្នុងឆ្នាំ 1055 ពួកតួកសេលជូកដែលធ្វើដំណើរមកពីអាស៊ីកណ្ដាលបានដណ្ដើមកាន់កាប់ទីក្រុងបាដាដ។ មេដឹកនាំសេលជូកបានដណ្ដើមកាន់កាប់ចក្រភពទាំងមូល ប៉ុន្តែបានអនុញ្ញាតឱ្យមេដឹកនាំអាបបាស៊ីដបន្តធ្វើជាមេដឹកនាំសាសនាមួយរូប។ ក្រោយមក ពួកសេលជូកបានកែប្រែជំនឿរបស់ពួកគេទៅជឿសាសនាអ៊ីស្លាម។ ពួកគេក៏បានចាប់ផ្ដើមពង្រីកដែនដីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ។ នៅក្នុងឆ្នាំ 1071 ពួកគេដណ្ដើមកាន់កាប់ទីក្រុងយេរ៉ូសាឡឹម។ ត្រឹមទសវត្សរ៍ឆ្នាំ 1090 ពួកគេបានគំរាមកំហែងដល់រាជធានីកុងស្តង់ទីណុបរបស់

ចក្រភពប៊ីហ្សង់ទីន។ ក្នុងការឆ្លើយតប ប្រទេសដែលកាន់សាសនាគ្រឹស្តនៅអឺរ៉ុបបានបើកការវាយប្រហារជាច្រើនលើក ដែលគេហៅថាបូជនិយកិច្ច ដើម្បីធ្វើការបណ្តេញពួកសេលជូកត្រឡប់ទៅវិញ។ នៅក្នុងឆ្នាំ 1258 កុលសម្ព័ន្ធមួយនៅអាស៊ីកណ្តាល ដែលគេហៅថា ម៉ុងហ្គោល ធ្វើការឈ្លានពានបាដាដ។ ពួកគេបានវាយកម្ទេចទីក្រុង និងសម្លាប់មេដឹកនាំអាបបាស៊ីដ។ សន្តតិវង្សអាបបាស៊ីដត្រូវបានបញ្ចប់នៅពេលនោះ។

ធ្វើចំណាត់ថ្នាក់៖ កំណត់អំពីស្នាដៃវប្បធម៌របស់ពួកអាបបាស៊ីដ។

## 2. ពួកមូលស្លីមដឹកនាំអេស្ប៉ាញ

សំណួរគន្លឹះ៖ តើពួកអ៊ូម៉ាយយាដ្សបង្រួបបង្រួមឧបទ្វីបអ៊ីបេរៀនឱ្យស្ថិតនៅក្រោមការដឹកនាំរបស់ពួកមូលស្លីមដោយរបៀបណា?

នៅពេលដែលអាបដ អាល-រ៉ាម៉ានដែលជាមេដឹកនាំមួយរូបរបស់អ៊ូម៉ាយយាដ្សបានមកដល់អេស្ប៉ាញ លោកបានបង្កើតក្រុមមូលស្លីមជាច្រើនក្រុម ធ្វើការវាយប្រយុទ្ធដើម្បីត្រួតត្រាតំបន់នេះ។ ភ្លាមៗនោះទ្រង់បានធ្វើសកម្មភាពដើម្បីបង្រួបបង្រួមក្រុមទាំងអស់នោះ។ ប្រជាជនដែលនៅបន្តមានភក្តីភាពជាមួយអ៊ូម៉ាយយាដ្ស បានគាំទ្រដល់អាបដ អាល-រ៉ាម៉ាន។ ទ្រង់បានចុះសន្ធិសញ្ញាជាមួយក្រុមម៉ូស្លីមផ្សេងៗទៀត។ នៅពេលដែលទ្រង់គិតថាទ្រង់បានអំណាចរឹងមាំហើយ ទ្រង់ធ្វើការវាយប្រហារ និងយកជ័យជំនះលើមេដឹកនាំកុលសម្ព័ន្ធផ្សេងៗ។ នៅក្នុងឆ្នាំ 756 ទ្រង់បានប្រកាសខ្លួនទ្រង់ថាជាមេដឹកនាំនៃ អាលអានដាលូស ឬមូលស្លីមអេស្ប៉ាញ ហើយយកកូរដូបាធ្វើជារាជធានី។

ព័ត៌មានអំពីភាគជោគជ័យរបស់អាបដ អាល-រ៉ាម៉ាន បានរីកសាយភាយយ៉ាងឆាប់រហ័សទៅកាន់ភាគខាងកើតនៃដែនដីរបស់ពួកអាបបាស៊ីដ។ អ្នកមានភក្តីភាពចំពោះអ៊ូម៉ាយយាដ្សជាច្រើនបានធ្វើដំណើរទៅកាន់អេស្ប៉ាញ។ ការមកដល់នៃពួកគេបាននាំមកនូវការពង្រឹងរដ្ឋាភិបាល និងកងទ័ពរបស់អាបដ អាល-រ៉ាម៉ាន។ នៅពេលដែលទ្រង់សុគតនៅក្នុងឆ្នាំ 788 មានភាពខ្លាំងក្លា និងរួបរួមនៅអាលអានដាលូស។ អំឡុងទសវត្ស៍ឆ្នាំ 800 អំណាចរបស់អ៊ូម៉ាយយាដ្សបានធ្លាក់ចុះ។ នៅក្នុងឆ្នាំ 912 អាបដ អាល-រ៉ាម៉ានទី 3 បង្កើតការដឹកនាំដ៏ខ្លាំងក្លាជាថ្មីម្តងទៀត។ ទ្រង់បានប្រកាសខ្លួនទ្រង់ថាជាមេដឹកនាំដំបូងនៃកូរដូបានៅក្នុងឆ្នាំ 929 ។

សង្ខេប៖ ពន្យល់ពីវិធីដែលពួកអ៊ូម៉ាយយាដ្សបង្រួបបង្រួមឧបទ្វីបអ៊ីបេរៀន។

## 3. ការអភិវឌ្ឍរបស់អេស្ប៉ាញម៉ូស្លីម

សំណួរគន្លឹះ៖ ស្ថិតក្រោមការគ្រប់គ្រងរបស់អ៊ូម៉ាយយាដ្ស តើអ្វីទៅជាភាពល្អប្រសើរបំផុតរបស់កូរដូបា?

ភ្លាមៗនោះ មនុស្សទាំងឡាយនៅអឺរ៉ុប និងពួកម៉ូស្លីមនៅពេលពិភពលោកចាប់ផ្តើមស្គាល់អាបដ អាល-រ៉ាម៉ានទី 3 ។ ត្រឹមឆ្នាំ 1000 កូរដូបា បានក្លាយជាទីក្រុងបំផុតនៅអឺរ៉ុបខាងលិច។

ទីក្រុងកូរដូបា៖ ភាពត្រចះត្រចង់របស់កូរដូបាកើតមានឡើងដោយសារតែភាពរុងរឿងនៃសេដ្ឋកិច្ចរបស់វា។ ទីក្រុងនេះមានហាងទំនិញរាប់រយ ដែលផលិផលនានាក្នុងនោះមានដូចជាសូត្រជាដើម ដែលជាទំនិញដែលមានតម្រូវការខ្ពស់នៅក្នុងតំបន់អឺរ៉ុបទាំងមូល។ កូរដូបាក៏ជាមជ្ឈមណ្ឌលសំខាន់មួយសម្រាប់វប្បធម៌ និងការសិក្សាផងដែរ។ ពួកមេដឹកនាំកូរដូបា មានការខ្វាល់ខ្វាយទៅនឹងគូរសត្រូវដល់ខ្លាំងក្លារបស់ពួកគេ គឺពួកអាបបាស៊ីដ។ ពួកគេបានលើកទឹកចិត្តដល់អ្នកប្រាជ្ញទាំងឡាយឱ្យចាកចេញពីទីក្រុងបាដាដ ហើយធ្វើដំណើរមកកាន់អាលអានដាលូស។ ពួកអ្នកប្រាជ្ញដែលមកដល់ថ្មីទាំងនេះ បាននាំមកជាមួយពួកគេនូវចំណេះដឹងថ្មី និងវិធីសាស្រ្តផ្សេងៗក្នុងការសិក្សា។ ពួកគេក៏បានបន្ថែមកិត្តិនាមឱ្យកូរដូបា ទៅជាទីក្រុងមួយក្នុងចំណោមទីក្រុងល្អបំផុតលើលោក។

ការអភិវឌ្ឍនៃគំនិត៖ អ្នកប្រាជ្ញរបស់អាលអានដាលូសបានស្ថាបនា ឬពង្រីកកិច្ចការដែលទាក់ទងនិងគណិតសាស្រ្តដំបូងៗ។ ពួកគេបានជួលគណិតវិទូឱ្យបង្កើតប្រតិទិនជាក់លាក់មួយ។ ពួកគេបានឧបករណ៍ជាក់លាក់មួយចំនួនសម្រាប់ពិនិត្យមើលមេឃ និងស្ថាបនាសំណាកចក្រវាឡមួយ ដែលអាចធ្វើចលនាបាន ដោយយកលំនាំតាមចក្រវាឡពិតប្រាកដ។ អ្នកប្រាជ្ញមួយចំនួនមានការចាប់អារម្មណ៍ ទៅនឹងភពផែនដីច្រើនជាងមេឃ។ អាលអ៊ីទ្រីស៊ីប្រហែលជាអ្នកបានសិក្សាអំពីភូមិសាស្រ្តដ៏ល្បីល្បាញបំផុតមួយរូប។ នៅក្នុងឆ្នាំ 1154 លោកបានបញ្ចប់ការសរសេសព្វវចនាធិប្បាយភូមិសាស្រ្តមួយ។ វាបានរួមបញ្ចូលនូវផែនទីប្រមាណ 70 និងការពន្យល់អំពីទីតាំងភូមិសាស្រ្តរបស់តំបន់ជាច្រើននៅលើពិភពលោក។ លោកពឹងផ្អែកការងាររបស់លោកមួយភាគធំលើការធ្វើដំណើររបស់លោកនៅពេលដែលលោកនៅវ័យក្មេង។

យុគសម័យមាសមួយសម្រាប់ពួកជ្វីប៖ ពួកជ្វីបបានរស់នៅក្នុងប្រទេសអេស្ប៉ាញតាំងពីសម័យចក្រភពរ៉ូមមកម្ល៉េះ។ ពួកគេតែងតែប្រឈមទៅនឹងការធ្វើទុក្ខបុកម្នេញ។ ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ៊ូម៉ាយយាដ្ស ពួកគេត្រូវបានស្វាគមន៍ មិនត្រូវបានបដិសេដឡើយ។ ពួកជ្វីបមួយចំនួនទទួលបានតំណែងខ្ពស់នៅក្នុងជួររដ្ឋាភិបាល។ នៅក្នុងបរិយាកាសនៃការស្វាគមន៍នេះ ពួកជ្វីបដែលរស់នៅអេស្ប៉ាញបានរីកចម្រើន ហើយវប្បធម៌អេស្ប៉ាញ-ជ្វីបមួយបានអភិវឌ្ឍឡើង។ ពួកជ្វីបដែលប្រឈមទៅនឹងការធ្វើទុក្ខបុកម្នេញនៅក្នុងដែនដីរបស់ពួកគ្រិស្តសាសនាបានរត់ភៀសខ្លួនមកកាន់អាលអានដាលូសដើម្បីទទួលបានសេរីភាព។ ពួកគេបានចូលរួមចំណែកយ៉ាងសំខាន់មួយនៅក្នុងបង្កើតឲ្យមានយុគសម័យមាសនៅអាលអានដាលូស។

ក្នុងចំណោមអ្នកប្រាជ្ញជ្វីបជាច្រើននៅអាលអានដាលូស មៃម៉ូនីដេសបានឈរនៅលើគេ។ មៃម៉ូនីដេសបានសរសេរ និងបង្រៀននូវមុខវិជ្ជាជាច្រើនដោយក្នុងនោះរួមមាន សាសនា, វិទ្យាសាស្រ្ត, និងវេជ្ជសាស្រ្ត។ ស្នាដៃដ៏ល្បីល្បាញបំផុតរបស់លោកគឺ មគ្គុទេសសម្រាប់ភាពអល់អែក ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ 1190 ។ នៅក្នុងសៀវភៅនេះ លោកព្យាយាមនៅក្នុងការបង្ហាញថា ទស្សនវិជ្ជាអាចគាំទ្រដល់ជំនឿសាសនា។ ការសរសេររបស់លោកបានជះឥទ្ធិពលដល់ពួកទស្សនវិទូម៉ូស្លីម និងទស្សនវិទូគ្រីស្តសាសនិក។

ការធ្លាក់ចុះនៃអាលអានដាលូស៖ ចាប់តាំងពីពេលដែលលោកមៃម៉ូនីដេសបានស្លាប់នៅក្នុងឆ្នាំ 1204 មកអាលអានដាលូសបានចាប់ផ្តើមធ្លាក់ចុះ។ ក្រុមកុលសម្ព័ន្ធមូលស្លីមមួយចំនួនបានវាយប្រយុទ្ធគ្នាដើម្បីដណ្តើម

អំណាច ខណៈពេលដែលក្រុមមួយចំនួនទៀតបានបំបែកខ្លួនទៅបង្កើតព្រះរាជាណាចក្រតូចៗផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកគ្រីស្ទសាសនិកនៅភាគខាងជើងចាប់យកឱកាសពីការធ្លាក់ចុះនេះ និងចាប់ផ្តើមបើកការវាយប្រហារ។ ត្រឹមទសវត្សរ៍ឆ្នាំ 1240 ពួកគេបានវាយរុញច្រានទៅភាគខាងត្បូងរហូតដល់កូរដូបា និងសេវីលលេ។ រយៈពេល 250 ឆ្នាំទៅមុខទៀត កងទ័ពគ្រីស្ទសាសនិកបន្តិចម្តងៗបានដណ្តើមកាន់កាប់មកវិញនូវឧបទ្វីបអ៊ីបេរៀនទាំងមូល។

វាយតម្លៃ៖ ពន្យល់ពីមូលហេតុដែលនាំឱ្យទីក្រុងកូរដូបាបានការរីកចម្រើននៅពេលដែលវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកអ៊ីម៉ាយយ៉ាដ្ស។

# ជំពូក 12 ៖ អរិយធម៌អាហ្វ្រិក

## មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រ និងប្រជាជនអាហ្វ្រិក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ អាហ្វ្រិកគឺជាទ្វីបធំលំដាប់ទីពីរនៅលើពិភពលោក។ ទ្វីបមានទំហំគ្រប់គ្រាន់នៅក្នុងការរួមបញ្ចូលនូវទម្រង់ដីគ្រប់ប្រភេទ។ ទម្រង់ដីច្រើនប្រភេទនេះហើយដែលបានបង្កើតទម្រង់ប្រវត្តិសាស្ត្ររបស់ទ្វីបនេះ។

### 1. ភូមិសាស្ត្រចម្រុះនៃអាហ្វ្រិក

សំណួរគន្លឹះ៖ តើបរិស្ថានបែបណាខ្លះដែលប្រជាជននៅអាហ្វ្រិកត្រូវសម្របខ្លួន?

ដូចដែលតំបន់សាហារ៉ា (តំបន់វាលខ្សាច់ដ៏ធំមួយនៅអាហ្វ្រិកភាគខាងជើង) បានក្លាយជាតំបន់វាលខ្សាច់ និងស្ងួតហែងនៅអំឡុងឆ្នាំ 4000 មុនគ.ស ប្រជាជនបានផ្លាស់ទីទៅកាន់ភាគខាងត្បូង។ សាវ៉ាន់ណា ឬតំបន់ទំនាបវាលស្មៅដែលមានដើមឈើដុះមួយៗ និងតំបន់ព្រៃទឹកភ្លៀង គ្របដណ្តប់ភាគច្រើននៅអាហ្វ្រិកភាគខាងលិច, ភាគកណ្តាល, និងភាគខាងត្បូង។ អាហ្វ្រិកភាគខាងកើតជាតំបន់ខ្ពង់រាប និងជាប្រភពមានទន្លេនីល។

អាហ្វ្រិកភាគខាងលិច៖ មានតំបន់សារពើរុក្ខជាតិចំនួន 3 ផ្សេងៗគ្នានៅអាហ្វ្រិកភាគខាងលិច ក្នុងនោះរួមមាន តំបន់វាលខ្សាច់, តំបន់វាលស្មៅ, និងតំបន់ព្រៃឈើ។ តំបន់សារពើរុក្ខជាតិគឺជាតំបន់មួយមានរុក្ខជាតិច្រើនប្រភេទខុសៗគ្នា ដោយសារតែស្ថានភាពដី និងអាកាសធាតុ។ នៅផ្នែកខាងជើងនៃតំបន់អាហ្វ្រិកភាគខាងលិចគឺជាផ្នែកមួយនៃវាលខ្សាច់សាហារ៉ា។ ផ្នែកកណ្តាលនៃអាហ្វ្រិកភាគខាងលិចគឺជាតំបន់សាវ៉ាន់ណា។ សាវ៉ាន់ណាគ្របដណ្តប់ជាង 40 ភាគរយនៃផ្ទៃដីទ្វីបអាហ្វ្រិក។ តំបន់នេះភាគច្រើនជាតំបន់ទំនាប និងគ្របដណ្តប់ដោយស្មៅ និងមានរដូវក្តៅ និងរដូវភ្លៀងឆ្លាស់គ្នា។ ព្រៃទឹកភ្លៀងគ្របដណ្តប់នៅផ្នែកខាងត្បូងនៃអាហ្វ្រិកភាគខាងលិច។

អាហ្វ្រិកភាគខាងកើត៖ ទម្រង់ដីដែលមានលក្ខណៈរដិបរដុបជាងគេនៅអាហ្វ្រិកស្ថិតនៅភាគខាងកើត។ ទន្លេនីល ដែលជាទន្លេដែលវែងជាងគេនៅលើពិភពលោកហូរចេញពីតំបន់នេះ។ តំបន់នៃក៏គ្របដណ្តប់ដោយជួរភ្នំជាច្រើន ដោយក្នុងនោះរួមមាន ភ្នំគីលីម៉ានចារ៉ូ ដែលជាភ្នំខ្ពស់ជាងគេនៅអាហ្វ្រិក ដោយមានកម្ពស់ 19,341 ហ្វីត។ តំបន់កុយរមាសអាហ្វ្រិកស្ថិតនៅជាប់មហាសមុទ្ទឥណ្ឌា។

អាហ្វ្រិកភាគកណ្តាល និងភាគខាងត្បូង៖ អាហ្វ្រិកភាគកណ្តាល និងភាគខាងត្បូងគឺជាតំបន់ដ៏ធំមួយ។ ដោយសារតែវាមានទំហំធំ តំបន់នេះមានទម្រង់ភូមិសាស្ត្រច្រើនប្រភេទ។ ព្រៃទឹកភ្លៀងត្រូពិកដ៏ធំគ្របដណ្តប់ភាគច្រើនលើតំបន់អាហ្វ្រិកកណ្តាល។ ព្រៃឈើមួយចំនួនគឺជាជម្រករបស់ហ្វូងសត្វស្លាបរាប់ពាន់ប្រភេទ។ នៅតំបន់អាហ្វ្រិកខាងត្បូង សម្បូរទៅដោយតំបន់វាលស្មៅធំៗ។ សត្វដំរី, សត្វកវែង, គោ, សេះបង្កង់, និងសត្វជាច្រើនប្រភេទទៀតរស់នៅតាមតំបន់វាលស្មៅទាំងនេះ។ ភូមិសាស្ត្រនៃការរស់នៅរបស់មនុស្សក៏មានភាពចម្រុះផងដែរ។

តំបន់ទាំងនេះគឺជាទីលំនៅរបស់ក្រុមជនជាតិភាគតិចរាប់រយ។ ប៉ុន្តែ ក្រុមជនជាតិភាគតិចទាំងអស់នេះស្ថិតនៅក្នុងអម្បូររួមមួយ ដែលគេស្គាល់ថា ក្រុមអ្នកនិយាយភាសាបានទូ។

## 2. ការធ្វើអន្តោប្រវេសន៍របស់ពួកបានទូ

សំណួរគន្លឹះ៖ អ្វីទៅជាលទ្ធផលនៃការធ្វើអន្តោប្រវេសន៍របស់ពួកបានទូ?

ក្រុមអ្នកនិយាយភាសាបានទូ គឺជាក្រុមប្រជាជនដែលរស់នៅអាហ្វ្រិកភាគខាងលិចដែលនិយាយភាសាស្រដៀងគ្នាដោយស្ថិតនៅក្នុងអម្បូរភាសាមួយដែលបច្ចុប្បន្នគេហៅថាបានទូ។ នៅក្នុងអម្បូរភាសានេះមានភាសាតូចៗចំនួន 450 ។ ក្រុមមនុស្សដែលនិយាយភាសាបានទូមិនមែនមានតែមួយក្រុមឡើយ ពួកគេមានច្រើនក្រុម និងមានវប្បធម៌ស្រដៀងគ្នា។ ពួកគេគឺជាអ្នកធ្វើចំការ, អ្នកចិញ្ចឹមសត្វ, និងអ្នកស្មិតដែក។ ការរីកសាយភាយនៃក្រុមអ្នកនិយាយភាសាបានទូនៅពាសពេញទ្វីបអាហ្វ្រិក គឺជាការធ្វើអន្តោប្រវេសន៍ដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រ។

ការធ្វើអន្តោប្រវេសន៍ចាប់ផ្តើម៖ ចាប់ផ្តើមដំបូងនៅរង្វង់ឆ្នាំ 1000 មុនគ.ស ក្រុមកុលសម្ព័ន្ធបានទូជាច្រើនក្រុមបានចាប់ផ្តើមផ្លាស់ប្តូរទីលំនៅរបស់ពួកចេញពីតំបន់ក្បែរទន្លេបេនូអេ និងទន្លេនីហ្សែរនៅអាហ្វ្រិកភាគខាងលិច។ ពួកគេបានធ្វើអន្តោប្រវេសន៍ទៅកាន់ភាគខាងត្បូង និងខាងកើត។ ដូចដែលពួកគេបានផ្លាស់ទី ក្រុមអ្នលនិយាយភាសាបានទូបានកាប់រានដីថ្មីដើម្បីដាំដុះ និងចិញ្ចឹមសត្វ។ ចលនានេះ ដែលគេហៅថា ការធ្វើអន្តោប្រវេសន៍បានទូបានកើតមានឡើងជាបន្តបន្ទាប់អស់រយៈពេលរាប់ពាន់ឆ្នាំ។ ក្រុមអ្នកនិយាយភាសាបានទូមួយចំនួនជាយថាហេតុបានតាំងទីលំនៅនៅតំបន់ព្រៃទឹកភ្លៀងតាមបណ្តោយទន្លេកុងហ្គោ។ ពួកគេមួយចំនួនរស់នៅក្នុងភូមិតូចៗ និងដាំដុះតាមច្រាំងទន្លេ។ ក្រោយមក ក្រុមអ្នកភាសាបានទូបានផ្លាស់ទីទៅកាន់ភាគខាងត្បូងហួលពីតំបន់ព្រៃទៅដល់តំបន់វាលស្មៅនៅអាហ្វ្រិកភាគខាងត្បូង។ នៅទីនោះ ពួកគេចាប់ផ្តើមចិញ្ចឹមសត្វពាហនៈ និងដាំដុះគ្រាប់ធុញ្ញជាតិ។ ពួកគេនៅតែរក្សាសមត្ថភាពរបស់ពួកគេនៅក្នុងការស្មិតដែក ដែលធ្វើឱ្យពួកគេខុសគ្នាពីក្រុមដទៃ និងជួយដល់ពួកគេនៅក្នុងការដាំដុះ។

ឥទ្ធិពលនៃការធ្វើអន្តោប្រវេសន៍៖ ក្រុមអ្នកនិយាយភាសាបានទូបានសម្របខ្លួនពួកគេទៅនឹងទីកន្លែងរស់នៅថ្មី ដូចដែលពួកគេបានផ្លាស់ទីនៅពាសពេញទ្វីប។ ពួកគេបានផ្លាស់ទីទៅកាន់តំបន់នានា ដែលជាទីកន្លែងដែលក្រុមដទៃតាំងទីលំនៅរួចហើយ។ ក្រុមអ្នកនិយាយភាសាបានទូបានផ្លាស់ប្តូរគំនិត និងទំនៀមទម្លាប់ជាមួយក្រុមមនុស្សនៅក្នុងតំបន់ដែលពួកគេចូលទៅដល់ និងបានរៀបអាពាហ៍ពិពាហ៍ជាមួយពួកគេ។ ពួកគេបានចែករំលែកចំណេះដឹងអំពីការស្មិតដែក និងកសិកម្ម។ ដូចដែលក្រុមអ្នកនិយាយភាសាបានទូធ្វើអន្តោប្រវេសន៍ ភាសារបស់ពួកគេបានរីកសាយភាយ។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីលទ្ធផលនៃការធ្វើអន្តោប្រវេសន៍របស់ពួកបានទូ។

## 3. ជីវិតរស់នៅនៅអាហ្វ្រិក

សំណួរគន្លឹះ៖ ហេតុអ្វីបានជាការនិយាយតៗគ្នាមានសារៈសំខាន់នៅអាហ្វ្រិក?

ភាសា និងទំនៀមទម្លាប់ខុសៗគ្នាជាច្រើនត្រូវបានគេរកឃើញនៅអាហ្វ្រិក។ ប៉ុន្តែ មានវប្បធម៌អាហ្វ្រិកជាច្រើនមានលក្ខណៈប្រហាក់ប្រហែលគ្នា។ វប្បធម៌ទាំងអស់នេះមានឫសគល់មកពីអរិយធម៌បុរាណដែលបានអភិវឌ្ឍឡើងនៅអាហ្វ្រិក។

សារៈសំខាន់នៃគ្រួសារ៖ ទំនាក់ទំនងក្នុងគ្រួសារមានសារៈសំខាន់ណាស់នៅអាហ្វ្រិក។ ទំនាក់ទំនងក្នុងចំណោមប្រជាជនតាមរយៈលោហិត, អាពាហ៍ពិពាហ៍, ឬការចិញ្ចឹមបីបាច់ត្រូវបានគេហៅថា ញាតិសន្តាន។ ក្រុមញាតិសន្តានបានបង្កើតរដ្ឋាភិបាលនៅក្នុងសង្គមជាច្រើននៅអាហ្វ្រិក។ នៅក្នុងក្រុមនេះ ការធ្វើសេចក្ដីសម្រេចចិត្តជារឿយៗត្រូវបានធ្វើឡើងដោយសមាជិកនៃក្រុមប្រឹក្សាព្រឹទ្ធចារ្យមួយ។ សមាជិកនៃញាតិសន្តានទាំងនោះមានភក្ដីភាពចំពោះគ្នាទៅវិញទៅមក។ ក្រុមញាតិសន្តាននានាដែលមានបុព្វការីជនរួមគ្នាបានរួមគ្នាបង្កើតបានជាក្រុមធំមួយដែលគេហៅថា កុលសម្ព័ន្ធ។ កុលសម្ព័ន្ធដើរតាមបទបញ្ញារួមមួយ។ ឧទាហរណ៍ នៅក្នុងកុលសម្ព័ន្ធមួយចំនួន សមាជិកនៅក្នុងកុលសម្ព័ន្ធមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានឡើយ។

ការងារ និងវប្បធម៌៖ នៅក្នុងភូមិជាច្រើននៅអាហ្វ្រិក ជីវិតរស់នៅពឹងផ្អែកលើការធ្វើស្រែចំការ។ ស្ត្រីគឺជាអ្នករៀបចំម្ហូបអាហារ, មើលថែកូន, ផលិតភាជន៍, ធ្វើការនៅស្រែចំការ, និងដងទឹកមកភូមិ។ បុរសឃ្វាលហ្វូងសត្វពាហនៈ ដូចជាគោ និងអូដ, សម្អាតដីសម្រាប់ដាំដុះ, និងធ្វើផ្ទះ និងរបង។ កុមារជារឿយៗជាអ្នកប្រមូលអុស, ជួយដល់ឪពុករបស់ពួកគេថែរក្សាហ្វូងសត្វពាហនៈ និងជួយដល់ម្ដាយពួកគេនៅក្នុងការសំអាតផ្ទះ។

មនុស្សមួយចំនួនផ្ដោតសំខាន់ទៅលើប្រភេទការងារជាក់លាក់មួយចំនួន ដែលជាដំណើរមួយត្រូវបានគេស្គាល់ថា ឯកទេស។ ឧទាហរណ៍ សិប្បករមួយចំនួនត្បាញ់អម្បោះ។ អ្នកមួយចំនួនទៀតធ្វើការជាមួយលោហៈ។ ពួកគេផលិតសម្ភារៈកសិកម្មដែលមានភាពរឹងមាំ, ដែលបានជួយដល់កំណើនប្រជាជន និងភាពរុងរឿង។ ចុងក្រោយ មនុស្សមួយចំនួនបានដោះដូរទំនិញរបស់ពួកគេជាមួយក្រុមដទៃទៀត។

ការនិទានរឿង៖ តំបន់ភាគច្រើននៃអាហ្វ្រិកមិនមានភាសាសរសេរជាច្រើនសតវត្ស។ ជាលទ្ធផល ប្រជាជនអាហ្វ្រិកដំបូងមិនបានកត់ត្រាប្រវត្តិសាស្ត្រឡើយ។ ជំនួសមកវិញ ពួកគេបានផ្ទេរប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌របស់ពួកគេតាមរយៈរឿងព្រេងជាច្រើន។ នៅអាហ្វ្រិកភាគខាងលិច អ្នកនិយាយរឿងព្រេងត្រូវបានគេហៅថា ហ្គ្រោត។ ហ្គ្រោតនិទានរឿងថ្វាយស្ដេចក៏ដូចជាប្រជាជនសាមញ្ញនៅក្នុងភូមិ។ ហ្គ្រោតមានសារៈសំខាន់នៅក្នុងការផ្ទេរចំណេះដឹងប្រវត្តិសាស្ត្រអាហ្វ្រិក។ ហ្គ្រោនជាទូទៅជាផ្នែកមួយនៅក្នុងក្បួនពិធីសាសនា ដែលប្រជាជនបន់ស្រន់ដល់បុព្វការីជនរបស់ពួកគេដើម្បីសម្រេចបំណងប្រាថ្នា និងការពារពួកគេ។ នៅក្នុងជំនឿបែបប្រពៃណីនៅអាហ្វ្រិក ប្រជាជនជឿថាបុព្វការីជនរបស់ពួកគេដែលបានស្លាប់ហើយ អាចមើលឃើញពួកគេ និងអាចជួយដល់ពួកគេនៅក្នុងការធ្វើទំនាក់ទំនងជាមួយអាទិទេពបង្កើតចក្រវាឡ។ ពួកគេក៏ជឿលើជីវចលនិយមផងដែរ ដែលជាគំនិតមួយដែលថាព្រលឹងស្ថិតនៅក្នុងវត្ថុធម្មជាតិទាំងអស់ ក្នុងនោះមានដូចជាសត្វ, រុក្ខជាតិ, និងថ្មជាដើម។

សង្ខេប៖ ពន្យល់ពីសារៈសំខាន់នៃការនិទានរឿងព្រេងនៅអាហ្វ្រិក។

# មេរៀនទី 2 ៖ ចក្រភពនៃអាហ្វ្រិកភាគខាងលិច

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើកត្តាអ្វីដែលធ្វើឱ្យចក្រភពមួយរឹងមាំ? រ៉ូមមានកងទ័ពខ្លាំងពូកែ, ខណៈពេលដែលចក្រភពប៊ីហ្សង់ទីនមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីវិធីដែលចក្រភពនៅអាហ្វ្រិកខាងលិចហ្គាណា, ម៉ាលី, និងសុងហៃ ប្រើប្រាស់ការធ្វើពាណិជ្ជកម្មរបស់ពួកគេដើម្បីទទួលបានអំណាច។

## 1. ការលូតលាស់នៃចក្រភពហ្គាណា

សំណួរគន្លឹះ៖ ក្រៅពីទំនិញ តើមានអ្វីខ្លះទៀតដែលការធ្វើពាណិជ្ជនាំយកមកដល់ហ្គាណា?

មានមនុស្សជាច្រើនបានដាំដុះដំណាំនៅចន្លោះតំបន់សាហារ៉ា និងតំបន់ព្រៃឈើនៅអាហ្វ្រិកភាគខាងត្បូង។ មនុស្សទាំងអស់នេះហៅស្តេចរបស់ពួកគេថាហ្គាណា។ ដោយថាហេតុ ព្រះរាជាណាចក្រនៅទីនោះត្រូវបានគេហៅថាហ្គាណា។ ពួកគេបានដើរតួនាទីសំខាន់នៅក្នុងការធ្វើពាណិជ្ជកម្មមាស និងអំបិល។

ការធ្វើពាណិជ្ជកម្មនៅតំបន់សាហារ៉ា៖ តំបន់សារពើរុក្ខជាតិនីមួយៗនៅអាហ្វ្រិកភាគខាងលិចតែងមានប្រភេទធនធានជាក់លាក់របស់តំបន់នោះ។ តំបន់សាហារ៉ាសម្បូរទៅដោយអំបិល។ គ្រាប់ធុញ្ញជាតិ ដូចជាស្រូវមីយ៉េ ត្រូវបានគេដាំដុះយ៉ាងល្អប្រសើរនៅតំបន់សាវ៉ាន់ណា ហើយស្ថានភាពដីក៏អំណោយផលដល់ការចិញ្ចឹមសត្វពាហនៈផងដែរ។ តំបន់ព្រៃឈើភាគខាងត្បូងសម្បូរទៅដោយមាស។

ប្រជាជននៅតំបន់សាវ៉ាន់ណា និងតំបន់ព្រៃនៅអាហ្វ្រិកភាគខាងលិចមានមាសច្រើន ប៉ុន្តែមានអំបិលតិចតួច។ ប្រជាជននៅអាហ្វ្រិកភាគខាងជើងមានអំបិល ប៉ុន្តែពួកគេត្រូវការមាស។ ជាលទ្ធផល ផ្លូវពាណិជ្ជកម្មមាស និងអំបិលមួយឆ្លងកាត់តំបន់សាហារ៉ាត្រូវបានអភិវឌ្ឍឡើង។ ប្រជាជននៅតំបន់សាហារ៉ាជីករ៉ែអំបិល និងដោះដូរវាជាមួយរ៉ែមាសនៅតំបន់ព្រៃឈើអាហ្វ្រិកភាគខាងលិច។ ចំណីអាហារ និងទាសករក៏ត្រូវបានគេធ្វើពាណិជ្ជកម្មផងដែរ។ ដើម្បីធ្វើពាណិជ្ជកម្មរវាងតំបន់សាហារ៉ា, តំបន់សាវ៉ាន់ណា, និងតំបន់ព្រៃឈើ ប្រជាជនត្រូវតែដឹកជញ្ជូនទំនិញរបស់ពួកគេឆ្លងកាត់វាលខ្សាច់។ ពាណិជ្ជកម្មកាន់តែមានភាពងាយស្រួលនៅពេលដែលសត្វអូដត្រូវបានគេយកមកប្រើប្រាស់ ដោយចាប់ផ្តើមដំបូងនៅអំឡុងឆ្នាំ 300 នៃគ.ស។ សត្វអូដអាចធ្វើដំណើរបានចម្ងាយឆ្ងាយដោយវាត្រូវការចំណី និងទឹកតិចតួចប៉ុណ្ណោះ។

ការបង្កើតចក្រភព៖ ហ្គាណាភាគខាងជើងមានព្រំដែនជាប់ជាមួយតំបន់សាហារ៉ា។ ទំនិញបានដឹកជញ្ជូនឆ្លងកាត់តំបន់នេះ ហើយប្រជាជនហ្គាណាគឺជាអ្នកគ្រប់គ្រងការធ្វើពាណិជ្ជកម្មនៅទីនោះ។ ពួកគេបានរក្សារ៉ែមាសជាការសម្ងាត់ ដោយកម្រិតចំនួននៃការធ្វើពាណិជ្ជកម្ម និងមានដំឡើងតម្លៃវា។ ស្តេចរបស់ហ្គាណាទទួលបានទ្រព្យសម្បត្តិតាមរយៈការយកពន្ធការធ្វើពាណិជ្ជកម្ម ដែលបានអនុញ្ញាតឱ្យហ្គាណាពង្រីកខ្លួនយ៉ាងឆាប់រហ័សក្លាយជាចក្រភពមួយ។ ពួកគេបានដណ្តើមកាន់កាប់ដែនដីនៅជុំវិញ។ តំបន់ដែលពួកគេដណ្តើមកាន់កាប់ ត្រូវបានបង្ខំឱ្យផ្តល់សួយសារអាករ ឬបង់ប្រាក់ដល់ស្តេចហ្គាណា។

ការផ្លាស់ប្តូរសាសនា និងវប្បធម៌៖ ប្រជាជនភាគច្រើនដែលធ្វើពាណិជ្ជកម្មអំបិល និងទំនិញផ្សេងៗទៀតឆ្លងកាត់តំបន់សាហារ៉ាគឺមកពីក្រុមមួយដែលគេហៅថាប័រប័រ។ ពួកគេធ្វើដំណើរមកពីអាហ្វ្រិកភាគខាងជើងគោរពសាសនាអ៊ីស្លាម និងជាទូទៅនិយាយភាសាអារ៉ាប់។ ក្រុមពាណិជ្ជករប័រប័របាននាំភាសាសរសេរ (អារ៉ាប់) និងសាសនាអ៊ីស្លាមមកកាន់អាហ្វ្រិកភាគខាងលិច ដែលបានជះឥទ្ធពលដល់ចក្រភពនៅទីនោះ។ ស្តេចហ្គាណាមួយចំនួនបានផ្លាស់ប្តូរទៅជឿសាសនាអ៊ីស្លាម ប៉ុន្តែនៅតែប្រតិបត្តិផ្នែកមួយចំនួននៃសាសនាជាប្រពៃណីរបស់ពួកគេ។ ឧទាហរណ៍ នៅក្នុងសាសនាជាប្រពៃណីរបស់ហ្គាណា បុព្វការីជនរបស់ស្តេចមួយអង្គគឺជាអ្នកផ្តល់នូវសិទ្ធិដល់ទ្រង់នៅក្នុងការដឹកនាំ។ ប្រសិនបើស្តេចបដិសេធសាសនាជាប្រពៃណី ទ្រង់នឹងបាត់បង់សិទ្ធិនេះ។ ប៉ុន្តែ ឥទ្ធិពលនៃសាសនាអ៊ីស្លាមមិនអាចបញ្ឈប់ការធ្លាក់ចុះនៃហ្គាណាបានឡើយ។ ពួកម៉ូស្លីមមួយក្រុមដែលមានឈ្មោះថាអាលម៉ូរ៉ាវិឌ បានឡើងកាន់អំណាចនៅអំឡុងទសវត្សរ៍ឆ្នាំ 1000 ។ ពួកគេប្រកាសសង្គ្រាមជាមួយពួកហ្គាណា។ នៅក្នុងឆ្នាំ 1076 ពួកអាលម៉ូរ៉ាវិឌបានដណ្តើមកាន់កាប់រាជធានីរបស់ហ្គាណា គូបី សាលេ។

សង្ខេប៖ ពិពណ៌នាពីការនាំយកមកកាន់ហ្គាណាតាមរយៈពាណិជ្ជកម្ម ក្រៅពីទំនិញ។

## 2. ម៉ាលីស្ថាបនាឡើងលើគ្រឹះរបស់ហ្គាណា

សំណួរគន្លឹះ៖ អ្វីទៅជាកត្តាដែលនាំទៅដល់ការធ្លាក់ចុះនៃចក្រភពម៉ាលី ?

នៅឆ្នាំប្រមាណ 1240 ចក្រភពម៉ាលីត្រូវបានបង្កើតឡើងនៅតំបន់ភាគខាងត្បូងនៃអតីតទឹកដីចក្រភពហ្គាណា។ ចក្រភពនេះត្រូវបានបង្កើតឡើងដោយប្រជាជន ម៉ាលីនគេ។ ប្រជាជនម៉ាលីនគេត្រូវបានដឹកនាំដោយថៅហ្វាយដ៏ខ្លាំងពូកែមួយរូបឈ្មោះ សាន់ដៀតា។

សាន់ដៀតាឡើងគ្រប់គ្រងអំណាច៖ សាន់ដៀតាបានរៀបចំឱ្យមានកងទ័ពដ៏ខ្លាំងក្លាមួយ និងបានដណ្តើមកាន់កាប់អតីតរាជធានីរបស់ហ្គាណា។ ទ្រង់បានពង្រីកចក្រភពរបស់ទ្រង់ហួសពីព្រំដែនចាស់របស់ហ្គាណាទៅទៀត, បង្កើតឡើងវិញនូវការធ្វើពាណិជ្ជកម្មមាស និងអំបិល, និងបានពង្រីកផ្លូវពាណិជ្ជកម្ម។ សាន់ដៀតាបានអភិវឌ្ឍទីក្រុងទីមប៊ូកទូឱ្យក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងវប្បធម៌។ ទ្រង់ក៏បានគាំទ្រដល់ការអភិវឌ្ឍដំណាំគ្រាប់ធុញ្ញាតិ, ការដាំដុះកប្បាស, និងការត្បាញសសៃកប្បាស។ ទ្រង់បានលាយបញ្ចូលគ្នានូវជំនឿសាសនាអ៊ីស្លាមរបស់ទ្រង់ជាមួយនិងជំនឿសាសានបែបប្រពៃណីរបស់ទ្រង់ ដូចដែលស្តេចហ្គាណាភាគច្រើនបានធ្វើ។ សាន់ដៀតាគឺជាមួយដឹកនាំដែលមានប្រជាប្រិយមួយរូប។

ម៉ានសា មូសាពង្រីកចក្រភព៖ បន្ទាប់ពីសាន់ដៀតាសុគត មេដឹកនាំម៉ាលីក្រោយនៅតែបន្តពង្រីកដែនដីរបស់ចក្រភព។ នៅក្នុងឆ្នាំ 1312 ស្តេចល្បីល្បាញបំផុតរបស់ម៉ាលី ព្រះនាមម៉ានសា មូសាបានឡើងកាន់អំណាច។ ម៉ានសា មូសាគឺជាអ្នកគោរពបូជាលើសាសនាអ៊ីស្លាម ប៉ុន្តែទ្រង់អនុញ្ញាតឱ្យប្រជារាស្ត្ររបស់ទ្រង់ប្រតិបត្តិសាសនាផ្សេងៗបាន។ នៅក្នុងឆ្នាំ 1324 ម៉ានសា មូសាបានចាប់ផ្តើមធ្វើដំណើរស្វែងបុណ្យមួយទៅកាន់មេកកា។ នៅក្នុងដំណើរស្វែងបុណ្យរបស់ទ្រង់ ម៉ានសា មូសាបាននាំទៅជាមួយនូវទាសករចំនួន 12,000 នាក់, សត្វអូដចំនួន 80 ក្បាល, មាសចំនួន 300 ផោន។ ម៉ានសា មូសាជិះនៅលើខ្នងសេះ ជាមួយនឹងទាសករចំនួន 500 នាក់ស្លៀកពាក់

សូត្រដើរពីមុខទ្រង់។ ដំណើរស្វែងបុណ្យរបស់ម៉ានសា មូសាបានទាក់ទាញយ៉ាងខ្លាំងដល់មនុស្សម្នាដែលបានទស្សនាក្បួនដំណើររបស់ទ្រង់។ ពាណិជ្ជករនានាមានបំណងចង់ធ្វើដំណើរទៅកាន់ចក្រភពម៉ាលី ដែលជាហេតុនាំឱ្យពាណិជ្ជកម្មបានកើនឡើង។ ម៉ានសា មូសាបន្តពង្រីកព្រំដែនរបស់ចក្រភពរហូតដល់ទ្រង់សុគតនៅក្នុងរង្វង់ឆ្នាំ 1332 ។

ការធ្លាក់ចុះនៃម៉ាលី៖ បន្ទាប់ពីការសោយទីវង្គត់របស់ម៉ានសា មូសាបច្ចាជនរបស់ទ្រង់បានឈ្លោះប្រកែកគ្នានៅក្នុងគ្រប់គ្រងម៉ាលី។ ការវាយប្រយុទ្ធផ្ទៃក្នុងបានធ្វើឱ្យចក្រភពអន់ខ្សោយ។ តំបន់ដែលទើបតែដណ្តើមកាន់កាប់បានថ្មីៗបានចាប់ផ្តើមងើបបះបោរ។ ពួកសុងហៃ ជាប្រជាជននៅអាហ្វ្រិកភាគខាងលិចមួយក្រុម ដែលស្ថិតនៅភាគខាងកើតម៉ាលី បន្តិចម្តងៗបានបង្កើនអំណាចរបស់ខ្លួន។ ទីក្រុងសំខាន់របស់សុងហៃ ឈ្មោះកៅត្រូវបានដណ្តើមកាន់កាប់ដោយម៉ាលីនៅក្នុងឆ្នាំ 1325 ។ ប្រហែលជា 40 ឆ្នាំក្រោយមក ពួកសុងហៃបានរំដោះទីក្រុងនេះបានមកវិញ។ នៅភាគខាងជើង ក្រុមចរកជនប័រប័រដណ្តើមកាន់កាប់ដែនដីមួយភាគធំរបស់ម៉ាលី និងបានដណ្តើមកាន់កាប់ទីក្រុងទីមប៊ូកទូនៅក្នុងឆ្នាំ 1433 ។ នៅភាគខាងត្បូង ពួកចោរប្លន់បានច្បាប់ផ្តើមវាយឆ្មក់លើក្បួនពាណិជ្ជកម្ម និងប៉ុស្តិ៍យោធា។ ត្រឹមឆ្នាំ 1500 ក្រុមអ្នកបះបោរ និងក្រុងអ្នកឈ្លានពានបានកាត់បន្ថយដែនដីរបស់ម៉ាលីមកនៅត្រឹមដែនដីដើមដែលគ្រប់គ្រងដោយប្រជាជនម៉ាលីនកេ។ ម៉ាលីលែងក្លាយជាចក្រភពដ៏ខ្លាំងក្លាទៀតហើយ។

វិភាគអំពីមូលហេតុ៖ ពន្យល់ពីកត្តាដែលនាំឱ្យចក្រភពម៉ាលីធ្លាក់ចុះ។

## 3. ចក្រភពសុងហៃ

សំណួរគន្លឹះ៖ តើមេដឹកនាំខ្លាំងមួយរូបរបស់សុងហៃនាំយកមកនូវអត្ថប្រយោជន៍អ្វីខ្លះ ?

ដូចដែលអ្នកទើបតែបានអាន ទីក្រុងរបស់សុងហៃឈ្មោះថា កៅ បានប្រកាសឯករាជ្យពីម៉ាលីនៅរង្វង់ឆ្នាំ 1365 ។ ប៉ុន្មានទសវត្សរ៍ក្រោយមក ពួកសុងហៃបានព្យាយាមដោយមិនទទួលបានជោគជ័យនៅក្នុងការបង្កើតព្រះរាជាណាចក្រមួយ។

សុងហៃពង្រីក៖ ចាប់តាំងពីឆ្នាំ 1433 ពួកប័រប័របានត្រួតត្រាទីក្រុងទីមប៊ូកទូ។ នៅក្នុងឆ្នាំ 1468 មេដឹកនាំម៉ូស្លីមនៅក្នុងទីក្រុងនេះស្នើស្តេចសុងហៃព្រះនាម សាន់នី អាលី ឱ្យជួយបណ្តេញពួកប័រប័រចេញ។ ស្តេចសាន់នី អាលីបានដណ្តើមកាន់កាប់ទីក្រុងទីមប៊ូកទូ, បណ្តេញពួកប័រប័រចេញ, និងបានសម្លាប់មនុស្សដែលរស់នៅក្នុងទីក្រុងអស់ជាច្រើន។ ភ្លាមៗនោះសាន់នី អាលីបានបង្កើតកិត្តិសព្ទមួយក្នុងនាមជាមេដឹកនាំដ៏មានអំណាច និងឃោឃៅ។ ទ្រង់បានស្ថាបនាកងទ័ពជំនាញមួយជាមួយនឹងកងនាវាចម្បាំងមួយ។ ទ្រង់បានបន្តធ្វើការឈ្លានពានលើដែនដីដែលនៅក្បែរខាង។ ស្ថិតនៅក្រោមការដឹកនាំរបស់សាន់នី អាលីចក្រភពសុងហៃបានពង្រីកយ៉ាងធំ។ នៅពេលដែលទ្រង់សុគតនៅក្នុងឆ្នាំ 1492 រាជបុត្រារបស់ទ្រង់ត្រូវបានប្រកាសជាមេដឹកនាំ។ ប៉ុន្តែ មេដឹកនាំមួយរូបព្រះនាម អាសកៀ មហាម៉ាត់មានបំណងចង់ដណ្តើមរាជបល្លង្គ។ ទ្រង់ និងអ្នកដើរតាមទ្រង់មានអារម្មណ៍ថាស្តេចសាន់នី អាលី មិនបានប្រតិបត្តិសាសនាអ៊ីស្លាមឱ្យបានត្រឹមត្រូវឡើយ។ នៅក្នុងឆ្នាំ 1493 អាសកៀ មហាម៉ាត់បានយកជ័យជំនះលើរាជបុត្រារបស់សាន់នី និងបានក្លាយជាមេដឹកនាំរបស់ចក្រភពសុងហៃ។ អាសកៀ មហាម៉ាត់

បានគ្រប់គ្រងការដឹកវ៉ែអំបិលនៅភាគខាងជើង និងបានពង្រីកព្រំដែនរបស់ចក្រភពនៅទិសផ្សេងៗទៀត។ យ៉ាងឆាប់រហ័សចក្រភពសុងហៃបានគ្របដណ្តប់លើដែនដីដ៏ធំមួយ ដែលធំជាងដែនដីរបស់ចក្រភពម៉ាលីធ្លាប់មានទៅទៀត។

ស្ថាប័នរបស់អាសកៀ៖ ស្នាដៃដ៏ប្រសើរបំផុតរបស់អាសកៀ មហាម៉ាត់គឺការរៀបចំរដ្ឋាភិបាលនៅលើដែនដីចក្រភពដ៏ធំនេះ។ ទ្រង់បានចាប់ផ្តើមដំបូងដោយធ្វើការបែងចែកសុងហៃទៅជាខេត្ត។ បន្ទាប់មកទ្រង់ដាក់អាជ្ញាធរមួយរូបឱ្យទទួលខុសត្រូវតាមខេត្តនីមួយៗ។ អាសកៀ មហាម៉ាត់ក៏បានតែងតាំងមន្ត្រីធ្វើជានាយកហិរញ្ញវត្ថុ, នាយកកសិកម្ម, នាយកយោធា, និងនាយកកងទ័ពជើងទឹក។ ក្នុងការបន្ថែម ទ្រង់បានបង្កើតប្រព័ន្ធពន្ធដារមួយ។

ស្ថិតក្រោមការដឹកនាំរបស់អាសកៀ មហាម៉ាត់ សាសនាអ៊ីស្លាមបានរីកសាយភាយនៅពាលពេញចក្រភព។ ទ្រង់បានបញ្ជូនអ្នកប្រាជ្ញម៉ូស្លីមទៅកាន់តំបន់នានាដែលមានទំនាក់ទំនងតិចតួចជាមួយសាសនាអ៊ីស្លាម។ អ្នកប្រាជ្ញទាំងអស់បានផ្លាស់ប្តូរជំនឿមនុស្សជាច្រើននៅក្នុងទីក្រុងនានាឱ្យជឿលើអ៊ីស្លាម។ ប៉ុន្តែ នៅទីជនបទ សាសនាអ៊ីស្លាមនៅតែបន្តលាយបញ្ចូនគ្នាជាមួយការប្រតិបត្តិសាសនាបែបប្រពៃណី។ ឧទាហរណ៍ ប្រជាជននៅអាហ្វ្រិកភាគខាងលិចជឿលើវិញ្ញាណរបុិលរប៉ូច ដែលបានលេងល្បិចជាមួយមនុស្ស។ ជំនឿនេះគឺជាការលាយបញ្ចូនគ្នាជាមួយជំនឿនៅក្នុងសាសនាអ៊ីស្លាម ដែលជឿលើ ឌីជីន ឬទេពារក្ស ដែលដូចគ្នាទៅនឹងវិញ្ញាណដែលលេចឡើងចេញពីចង្កៀងអាឡាជាំនៅក្នុងរឿងមួយពាន់មួយយប់។

ការដួលរលំនៃសុងហៃ៖ រាជបុត្រារបស់អាសកៀ មហាម៉ាត់បានឡើងគ្រប់គ្រងរាជបល្លង្កបន្តពីទ្រង់។ មេដឹកនាំសុងហៃនានាបន្ទាប់ពីអាសកៀមានភាពទន់ខ្សោយ។ អំឡុងទសវត្សរ៍ឆ្នាំ 1580 កងកម្លាំងម៉ូរ៉ូកានបានប្រើប្រាស់កាំភ្លើងឈ្លានពាន និងដណ្តើមកាន់កាប់ទីក្រុងទីមប៊ូកទូ និងកៅ។ បើទោះបីជាពួកសុងហៃព្យាយាមនៅក្នុងការវាយបកវិញក៏ដោយ ចក្រភពបានដួលរលំភ្លាមៗបន្ទាប់ពីទីក្រុងទាំងនោះត្រូវបានឈ្លានពាន។

វាយតម្លៃ៖ ពន្យល់ពីអត្ថប្រយោជន៍ដែលមេនាំដ៏ខ្លាំងក្លាមួយរូបរបស់សុងហៃនាំយកមក។

# មេរៀនទី 3 ៖ អរិយធម៌ពាណិជ្ជរបស់អាហ្វ្រិក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងមេរៀនទី 1 អ្នកបានសិក្សារួចមកហើយអំពីក្រុមមនុស្សដែលនិយាយភាសាបានទូ ដែលបានរីកសាយភាយពាសពេញទ្វីបអាហ្វ្រិក។ ព្រះរាជាណាចក្រអាក់សាំបានអភិវឌ្ឍនៅអាហ្វ្រិកភាគខាងកើតនៅវង្វង់ឆ្នាំ 50 នៃគ.ស ប្រហែលជា 1,000 ឆ្នាំបន្ទាប់ពីការចាប់ផ្តើមធ្វើអន្តោប្រវេសន៍របស់ក្រុមអ្នកនិយាយភាសាបានទូ។

## 1. ការរះឡើងនៃអាក់សាំ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាការធ្វើពាណិជ្ជកម្មសារៈសំខាន់ចំពោះអាក់សាំ ?

ព្រះរាជាណាចក្រអាក់សាំរះឡើងនៅតំបន់កុយរមាសនៃទ្វីបអាហ្វ្រិក ដែលជាតំបន់មួយមានរូបសណ្ឋានដូចជាកុយរមាសស្ថិតនៅតាមបណ្តោយសមុទ្រក្រហម។ បច្ចុប្បន្នអាក់សាំមានទីតាំងស្ថិតនៅប្រទេសអេចូពី និងអេរីទ្រា។

ទីតាំងពាណិជ្ជកម្មដ៏ល្អឥតខ្ចោះ៖ ទីតាំងរបស់អាក់សាំអនុញ្ញាតឱ្យពួកគេអាចចូលទៅកាន់ពាណិជ្ជកម្មតាមសមុទ្រក្រហម, សមុទ្រមេឌីទែរ៉ាណេ, មហាសមុទ្រឥណ្ឌា, និងជ្រលងទន្លេនីល។ ពាណិជ្ជករអារ៉ាប់បានស្ថាបនាដែនដីអាណានិគម និងកំពង់ផែពាណិជ្ជកម្មនៅទីនោះ។ អាក់សាំបានក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយ ដែលទីនោះពាណិជ្ជកម្មបានចេញដំណើរទៅគ្រប់ទិស។ ពាណិជ្ជករបានធ្វើដំណើរមកពីអេហ្ស៊ីប, ផ្នែកផ្សេងៗនៃទ្វីបអាហ្វ្រិក, អារ៉ាប់, មេឌីទែរ៉ាណេភាគខាងកើត, ពែក្ស, និងឥណ្ឌា។ ពួកគេស្វែងរកទីតាំងមួយសម្រាប់ធ្វើការផ្លាស់ប្តូរទំនិញ។ អាឌូលីស ជាទីក្រុងមួយស្ថិតនៅសមុទ្រក្រហម គឺជាកំពង់ផែពាណិជ្ជកម្មចំបងរបស់ព្រះរាជាណាចក្រ។ នៅទីនោះ ពាណិជ្ជករធ្វើការផ្លាស់ប្តូរអំបិល, ភ្លុក, សំលៀកបំពាក់, ទង់ដែង, ដែក, មាស, កញ្ចក់, ប្រេងអូលីវ, និងស្រា។ ពាណិជ្ជករសត្វបានទិញសត្វនានាដូចជាសត្វកវែង និងដំរី។

ប្រជាជាតិពាណិជ្ជកម្មមួយ៖ នៅដើមដំបូង អាក់សាំមានទំហំតូច។ ក្រោយមក នៅទសវត្សរ៍ឆ្នាំ 300 នៃគ.ស ស្តេចអង់អាចមួយអង្គបានពង្រីកទឹកដី និងស្ថាបនាប្រជាជាតិដ៏មានអំណាចមួយ។ អេហ្សាណា គឺជាស្តេចដ៏ខ្លាំងមួយអង្គ ដែលបានឡើងកាន់អំណាចនៅក្នុងឆ្នាំ 325 នៃគ.ស។ ដំបូងទ្រង់ត្រួតត្រាអាណានិគមលើដែនដីពាណិជ្ជកម្មមួយដែលស្ថិតនៅឆ្នេរឧបទ្វីបអារ៉ាប់។ នៅអំឡុងពេលនោះ ចក្រភពរបស់អាក់សាំបានពង្រីកលើទឹកដីខាងក្នុង និងតាមបណ្តោយឆ្នេរសមុទ្រក្រហម។ ជាលទ្ធផល ព្រះរាជាណាចក្រអាក់សាំបានត្រួតត្រាលើបណ្តាញពាណិជ្ជកម្មដ៏ធំមួយ។

## 2. ស្ថាដែរបស់អាក់សាំ

វប្បធម៌ពិសេសមួយបានរះឡើងនៅអាក់សាំ ដែលជាការលាយបញ្ចូលគ្នារវាងឥទ្ធិពលមកពីតំបន់កុយរមាសនៃទ្វីបអាហ្វ្រិក និងអារ៉ាប់ភាគខាងត្បូង។ ក្នុងចំណោមស្នាដៃដ៏គួរឱ្យចាប់អារម្មណ៍របស់ព្រះរាជាណាចក្រគឺសសរស្តម្ភអាក់សាំ ដែលក្រុមអ្នកស្ថាបនាបានដាក់វានៅពាសពេញប្រទេស។ សសរស្តម្ភទាំងនេះឆ្លាក់ចេញមកពីបន្ទះថ្មមួយផ្ទាំង ដែលបន្ទះមួយចំនួនមានកម្ពស់ជាង 100 ហ្វីត ដោយគេស្ថាបនាវាឡើងដើម្បីអបអរដល់ជ័យជំនះ។

អាក់សាំមានភាសាសរសេរមួយដែលគេហៅថាហ្គេអេស។ ជនអន្តោប្រវេសន៍មកពីអារ៉ាប់បាននាំយកភាសានេះមកកាន់អាក់សាំ។ ហ្គេអេសបានក្លាយជាមូលដ្ឋានគ្រឹះរបស់ភាសាចំនួន 3 នៅក្នុងប្រទេសអេចូពី និងអេរីទ្រានាពេលបច្ចុប្បន្ន ក្នុងនោះរួមមាន អាំហារិច, ទីហ្គ្រីនយ៉ា, និងទីហ្គ្រេ។ ដើម្បីសម្របជាមួយសណ្ឋានដីរដិបរដុបនៅអាក់សាំ ប្រជាកសិករបានស្ថាបនាផ្ទៃដីជាថ្នាក់ៗ។ ដីថ្នាក់ៗអាចរក្សាសំណើមបានល្អប្រសើរជាងផ្ទៃដីនៅតាមជម្រាលភ្នំ។ ស្រែថ្នាក់បានបង្កើនផ្ទៃដីកសិកម្មរបស់អាក់សាំ។

ទាញសេចក្ដីសន្និដ្ឋាន៖ ពន្យល់ពីមួយហេតុដែលពាណិជ្ជកម្មានសារៈសំខាន់សម្រាប់អាក់សាំ។

### 3. អាហ្វ្រិកភាគខាងកើត និងអ៊ីស្លាម

សំណួរគន្លឹះ៖ តើពួកម៉ូស្លីមជះឥទ្ធិពលយ៉ាងដូចម្ដេចចំពោះការអភិវឌ្ឍនៅអាហ្វ្រិកភាគខាងកើត?

ត្រឹមឆ្នាំ 1100 ក្រុមអ្នកនិយាយភាសាបានទូជាច្រើនបានធ្វើអន្តោប្រវេសន៍ឆ្លងកាត់អាហ្វ្រិកភាគកណ្ដាលឆ្ពោះមកកាន់តំបន់ឆ្នេរភាគខាងកើត។ នៅអាហ្វ្រិកភាគខាងកើត ក្រុមអ្នកនិយាយភាសាបានទូបានស្ថាបនាភូមិកសិកម្ម និងប៉ុស្តិ៍ពាណិជ្ជកម្ម។

បុរី-រដ្ឋតាមតំបន់ឆ្នេរលេចឡើង៖ ពាណិជ្ជករអាហ្វ្រិកភាគខាងកើតបានផ្លាស់ប្ដូរទំនិញរបស់ពួកគេនៅពាសពេញមហាសមុទ្រឥណ្ឌាជាមួយពាណិជ្ជករផ្សេងដែលធ្វើដំណើរមកពីអារ៉ាប់, ពែក្ស, និងឥណ្ឌា។ ត្រឹមទសវត្សរ៍ឆ្នាំ 1200 បណ្ដាលទីក្រុងពាណិជ្ជកម្ម និងបុរី-រដ្ឋមួយបានលេចឡើងនៅតាមតំបន់ឆ្នេរ។ បុរី-រដ្ឋដែលសំខាន់បំផុតមួយគឺ គីលវ៉ា ដែលបង្កើតឡើងដោយក្រុមអ្នកតាំងទីលំនៅមកពីអារ៉ាប់ និងពែក្សនៅចុងទសវត្សរ៍ឆ្នាំ 900 ។ ពាណិជ្ជករអាហ្វ្រិកបានបញ្ជូនទំនិញរបស់ពួកគេទៅកាន់គីលវ៉ា ជាទីកន្លែងដែលពាណិជ្ជករមកពីតំបន់អាស៊ីទិញទំនិញទាំងនោះ។

ឥទ្ធិពលនៃសាសនាអ៊ីស្លាម៖ គីលវ៉ាគឺជាបុរី-រដ្ឋមួយក្នុងចំនួនបុរី-រដ្ឋមួយចំនួនរបស់ពួកអាហ្វ្រិកដែលមានទំនាក់ទំនងជាមួយពួកអារ៉ាប់។ ដូចដែលពាណិជ្ជកម្មនៅតាមមហាសមុទ្រឥណ្ឌាបានកើនឡើង ពាណិជ្ជករអារ៉ាប់បានតាំងទីលំនៅនៅតាមទីក្រុងកំពង់ផែមួយចំនួននៅអាហ្វ្រិកភាគខាងកើត។ ជាលទ្ធផល ប្រជាជនអាហ្វ្រិកដែលរស់នៅតាមតំបន់ឆ្នេរបានខ្ចីទម្រង់មួយចំនួននៃវប្បធម៌អារ៉ាប់។ លទ្ធផលមួយនៃទំនាក់ទំនងវប្បធម៌រវាងពួកអារ៉ាប់ និងអាហ្វ្រិកគឺភាសាថ្មីមួយ ដែលគេស្គាល់ថាស្វាហ៊ីលី។ ស្វាហ៊ីលីបានអភិវឌ្ឍទៅជាភាសាបានទូមួយ ដោយបានខ្ចីពាក្យជាច្រើនមកពីអារ៉ាប់។ ពួកអារ៉ាប់ការបានផ្សព្វផ្សាយជំនឿរបស់ពួកគេ គឺសាសនាអ៊ីស្លាមទៅដល់ពួកអាហ្វ្រិកភាគខាងកើត។ ពួកអាហ្វ្រិកដែលបានផ្លាស់ប្ដូរសាសនាទៅជាអ៊ីស្លាម ភាគច្រើនគឺជាពួកពាណិជ្ជករវណ្ណៈកណ្ដាល, ពាណិជ្ជករដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ, និងមន្ត្រីរដ្ឋាភិបាល។ ក្រុមមេដឹកនាំទាំងអស់នេះបានប្រើប្រាស់គំនិតអ៊ីស្លាមអំពីរដ្ឋាភិបាល និងច្បាប់។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីវិធីដែលពួកម៉ូស្លីមជះឥទ្ធិពលនៅអាហ្វ្រិកភាគខាងកើត។

## 4. សូណា និងមហាហ្ស៊ីមបាវេ

សំណួរគន្លឹះ៖ តើមហាហ្ស៊ីបាវេអាចគ្រប់គ្រងការធ្វើពាណិជ្ជកម្មមាសដោយរបៀបណា?

ដីខាងក្នុងឆ្ងាយពីទីក្រុងតាមឆ្នេរសមុទ្ទ ក្រុមអ្នកនិយាយភាសាបានទូផ្សេងទៀតបានបង្កើតចក្រភពដ៏មានអំណាចដោយផ្អែកលើធនធានដែលមានតម្លៃបំផុត និងផ្តល់ផលចំណេញនៅក្នុងតំបន់៖មាស។ អំឡុងទសវត្សរ៍ឆ្នាំ 800 ក្រុមអ្នកនិយាយភាសាបានទូមួយក្រុមដែលគេហៅថា សូណា បានតាំងទីលំនៅនៅតាមចជ្រលងទន្លេលីមប៉ូប៉ូ ដែលស្ថិតនៅអាហ្រ្វិកភាគខាងត្បូង។ ត្រឹមឆ្នាំ 1000 ពួកគេបានផ្លាស់ទីទៅកាន់តំបន់មួយដែលផ្ទៃដីកសិកម្មសម្បូរដោយជីជាតិ ស្ថិតនៅចន្លោះតំបន់ហ្សាំបេហ្ស៊ី និងទន្លេលីមប៉ូប៉ូ។ នៅទីនោះពួកសូណាបានបង្កើតចក្រភពដ៏ខ្លាំងក្លាមួយ។

ចក្រភពសូណា៖ ចក្រភពដែលពួកសូណាបង្កើតឡើងនៅតំបន់វាលស្មៅអាហ្រ្វិកភាគខាងត្បូងរួមមានហ្ស៊ីមបាវេ ឬទីលំនៅដែលហ៊ុំព័ទ្ធដោយជញ្ជាំងថ្មធំៗជាច្រើន។ បច្ចេកពាក្យហ្ស៊ីមបាវេមកពីពាក្យមួយរបស់ពួកសូណាថា ហ្ស៊ីបា ហ្សា ម៉ាបវេ ដែលមានន័យថា "ផ្ទះធ្វើពីថ្ម"។ សំណល់សំណង់ផ្ទះប្រហែល 150 ត្រូវបានគេរកឃើញនៅពាសពេញអាហ្រ្វិកភាពខាងត្បូងនាពេលបច្ចុប្បន្ន ដោយក្នុងនោះមានប្រទេសបូតស្វាណា, ម៉ូហ្សាំប៊ិក, និងហ្ស៊ីមបាវេ។

មហាហ្ស៊ីបាវេ៖ ទីលំនៅរបស់ពួកសូណាដែលធំជាងគេបំផុតត្រូវបានគេស្គាល់ថា មហាហ្ស៊ីមបាវេ។ វាគឺជាមជ្ឈមណ្ឌលរបស់សូណា។ ទីក្រុង និងតំបន់ដែលនៅព័ទ្ធជុំវិញគ្របដណ្តប់លើផ្ទៃដីជាង 100 អេក្រ៍ និងមានប្រជាជនចន្លោះពី 10,000 ទៅ 20,000 នាក់។ ទីតាំងភូមិសាស្រ្តបានដើរតួនាទីយ៉ាងសំខាន់នៅការធ្វើឱ្យមហាហ្ស៊ីមបាវេរីកចម្រើន។ តំបន់នេះហ៊ុំព័ទ្ធជុំវិញដោយវាលទំនាបដ៏ធំ ដែលពួកសូណាបានប្រើប្រាស់វាដើម្បីដាំដុះ និងចិញ្ចឹមសត្វ។ មហាហ្ស៊ីមបាវេក៏មានទីតាំងស្ថិតនៅជិតផ្លូវពាណិជ្ជកម្មសំខាន់ៗ។ មានផ្នែក 3 សំខាន់ៗនៅមហាហ្ស៊ីមបាវេ៖ តំបន់ជ្រលងភ្នំ, តំបន់ជម្រាលភ្នំ, និងតំបន់ហ៊ុំព័ទ្ធជុំវិញ។ តំបន់ហ៊ុំព័ទ្ធជុំវិញមានទំហំធំជាងគេ និងជាផ្នែកដែលមានសារៈសំខាន់ជាងគេ។ បុរាណវិទូគិតថា តំបន់ហ៊ុំព័ទ្ធជុំវិញត្រូវបានគេប្រើប្រាស់ធ្វើជាផ្ទះរបស់ស្តេច និងម្ចាស់ក្សត្រី។ មើលពីលើអាកាស តំបន់ហ៊ុំព័ទ្ធជុំវិញមានរូបរាងដូចជាខ្សែកយក្សមួយខ្សែ។ ជញ្ជាំងខាងក្រៅមានប្រវែងជុំវិញប្រមាណ 820 ហ្វិត និងមានកម្ពស់រហូតដល់ 36 ហ្វីត។ ជញ្ជាំងខាងក្នុងលាតសន្ធឹងតាមជញ្ជាំងខាងក្រៅ។ ជញ្ជាំងទាំងពីរនេះបង្កើតបានជាផ្លូវធ្វើដំណើរតូចចង្អៀតមួយធ្វើដំណើរទៅកាន់តួប៉មរាងដូចពោតមួយដែលមានកម្ពស់ 33 ហ្វីត។ គោលបំណងនៃការស្ថាបនាតួប៉មនេះស្ថិតនៅជារឿងអាថ៌កំបាំងមួយ។ នៅពេលមួយ នៅក្នុងតំបន់ហ៊ុំព័ទ្ធជុំវិញមានសំណង់ដ៏ប្រណិតៗស្ថាបនាឡើងដោយដាហ្គា ដែលជាឥដ្ឋធ្វើមកពីភក់ ឬដីឥដ្ឋ។ ក្រុមអ្នកស្ថាបនាសូណាបានកាត់ផ្ទាំងថ្មមកពីភ្នំថ្មក្រានីត ដែលស្ថិតនៅជុំវិញទីក្រុងសម្រាប់សាងសង់ជញ្ជាំងជុំវិញតំបន់ហ៊ុំព័ទ្ធជុំវិញ។ ពួកគេបានកាត់ផ្ទាំងថ្មដោយត្រង់ស្មើ ដោយមិនចាំបាច់ធ្វើអ្វីបន្ថែមទៀតឡើយក្រៅតែពីយកវាដាក់ឱ្យត្រូវតាមកន្លែង។ ជញ្ជាំងដែលហ៊ុំព័ទ្ធជុំវិញតំបន់ហ៊ុំព័ទ្ធជុំវិញជាច្រើនមានភាពរលោងដូចជញ្ជាំងធ្វើពីឥដ្ឋនាពេលបច្ចុប្បន្ន។ ជញ្ជាំងដែលប្រណិតបំផុតប្រហែលជាចុះកាលបរិច្ឆេទចន្លោះចាប់ពីទសវត្សរ៍ឆ្នាំ 1300 ដល់ 1400។

មាស, ពាណិជ្ជកម្ម, និងការធ្លាក់ចុះ៖ មហាហ្ស៊ីមបាវេបានក្លាយជាមជ្ឈមណ្ឌលទ្រព្យសម្បត្តិ និងអំណាចដ៏មានឥទ្ធិពលមួយដោយសារមានផ្លូវពាណិជ្ជកម្មជាច្រើនឆ្លងកាត់ទីក្រុងនេះ។ ផលិតផលសំខាន់ដែលបានធ្វើដំណើរតាមផ្លូវពាណិជ្ជកម្មទាំងនេះគឺមាស។ មាសគឺជាទំនិញសំខាន់មួយក្នុងការធ្វើពាណិជ្ជកម្មរវាងអាហ្វ្រិកជាមួយនិងឥណ្ឌា និងចិន។ មហាហ្ស៊ីមបាវេមិនមែនជាអ្នកផលិតមាសឡើយ។ ប៉ុន្តែវាស្ថិតនៅចន្លោះតំបន់ផលិតមាសដែលស្ថិតនៅភាគខាងលិច និងទីក្រុងពាណិជ្ជកម្មសំខាន់ៗដែលស្ថិតនៅតាមតំបន់ឆ្នេរភាគខាងកើត។ ជាលទ្ធផលមេដឹកនាំរបស់មហាហ្ស៊ីមបាវេ អាចយកពន្ធពីអ្នកទាំងឡាយណាដែលបានធ្វើដំណើតតាមផ្លូវពាណិជ្ជកម្មទាំងអស់នោះ។ ពួកគេក៏អាចទាមទារមាសពីមេដឹកនាំដែលមិនសូវមានអំណាចនៅក្នុងតំបន់។ ទីក្រុងនេះបានក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មមាសអន្តរជាតិ។ អ្នកប្រាជ្ញបានប៉ាន់ប្រមាណថា នៅចំណុចខ្ពស់បំផុត ក្រុមអ្នកធ្វើដំណើរអាចនាំយកនូវមាសច្រើនជាង 2,000 ផោនកាត់តាមមហាហ្ស៊ីមបាវេជារៀងរាល់ឆ្នាំ។ អំឡុងទសវត្សរ៍ឆ្នាំ 1400 មហាហ្ស៊ីមបាវេចាប់ផ្តើមធ្លាក់ចុះ។ ប្រវត្តិវិទូមួយចំនួននិយាយថាគ្រោះរាំងស្ងួត និងការប្រើប្រាស់វាលស្មៅហួសកម្រិតជាហេតុបណ្តាលឱ្យមានកង្វះខាតធនធាន។ អ្នកដ៏ទៃទៀតទទូចថា មនុស្សបានចាកចេញពីទីនោះដោយសារតែការផ្លាស់ប្តូរផ្លូវពាណិជ្ជកម្មថ្មី។ មិនថាហេតុផលមួយណាឡើយ មហាហ្ស៊ីមបាវេត្រូវបានគេបោះបង់ចោលនៅត្រឹមឆ្នាំ 1500 ។

សង្ខេប៖ ពន្យល់ពីរបៀបដែលមហាហ្ស៊ីមបាវេទទួលបានការគ្រប់គ្រងពាណិជ្ជកម្មមាស។

## 5. កុងហ្គោ និងព័រទុយហ្គាល់

សំណួរគន្លឹះ៖ តើទំនាក់ទំនងជាមួយពួកព័រទុយហ្គាល់មានឥទ្ធិពលយ៉ាងដូចម្តេចខ្លះដល់កុងហ្គោ?

ក្រុមអ្នកនិយាយភាសាបានទូជាច្រើនបានធ្វើអន្តោប្រវេសន៍ចេញពីអាហ្វ្រិកភាគខាងលិច-កណ្តាលទៅកាន់ពាសពេញតំបន់អាហ្វ្រិកភាគខាងត្បូង។ នៅក្នុងទសវត្សរ៍ឆ្នាំ 1300 ក្រុមអ្នកនិយាយភាសាបានទូមួយក្រុមដែលគេស្គាល់ថាកុងហ្គោ បានតាំងទីលំនៅតាមតំបន់ឆ្នេរភាគខាងលិច។

ការរីកលូតលាស់របស់កុងហ្គោ៖ ពួកកុងហ្គោតាំងទីលំនៅភាគខាងជើងទន្លេកុងហ្គោ ដែលហូរចម្ងាយជិត 3,000 ម៉ាយទៅកាន់មហាសមុទ្រអាត្លង់ទិក។ ពួកកុងហ្គោទទួលបានអត្ថប្រយោជន៍ពីតំបន់ដែលដីសម្បូរដោយជីជាតិ, រ៉ែដែក និងទង់ដែង, អំណោយផលដល់ការនេសាទ, និងភាពងាយស្រួលនៅក្នុងការធ្វើដំណើរតាមទន្លេកុងហ្គោ។ ត្រឹមទសវត្សរ៍ឆ្នាំ 1400 កុងហ្គោបានផ្លាស់ទីទៅកាន់ភាគខាងត្បូងទន្លេកុងហ្គោ និងបានដាក់ការគ្រប់គ្រងរបស់ពួកគេលើក្រុមអ្នកតាំងទីលំនៅនៅក្នុងតំបន់។ ដែនដីដែលពួកគេកាន់កាប់ថ្មីៗបានក្លាយជាព្រះរាជាណាចក្រដ៏ខ្លាំងក្លាមួយដែលគេស្គាល់ថាកុងហ្គោ។ មជ្ឈមណ្ឌលរបស់ព្រះរាជាណាចក្រកុងហ្គោគឺរាជធានីអ៊ឹមបានហ្សា ។ នៅទីនោះ មេដឹកនាំកុងហ្គោបានគ្រប់គ្រងនគររបស់ទ្រង់ដោយមានការរៀបចំខ្ពស់ និងទទួលបានផលចំណេញច្រើន។

កុងហ្គោ និងព័រទុយហ្គាល់៖ ដូចដែលព្រះរាជាណាចក្រកុងហ្គោកំពុងរីកចម្រើន បានផ្លាស់ប្តូរដ៏សំខាន់មួយបានកើតមានឡើងនៅពាសពេញពិភពលោក។ នៅក្នុងអឺរ៉ុប ទសវត្សរ៍ឆ្នាំ 1400 ជាសញ្ញាណនៃការចាប់ផ្តើមឡើងនៃយុគសម័យនៃការរុករក, ជាពេលមួយដែលក្រុមអ្នកធ្វើដំណើរអឺរ៉ុប ធ្វើដំណើរតាមនាវាឆ្លងកាត់មហាសមុទ្

នានាដើម្បីស្វែងរកដែនដីថ្មី។ ព័រទុយុហ្គាល់ ដែលជាប្រទេសតូចមួយស្ថិតនៅភាគខាងលិចនៃប្រទេសអេស្ប៉ាញ ជាប់មហាសមុទ្រអាត្លង់ទិក បាននាំមុខគេនៅក្នុងការរុករកនេះ។ នៅដើមទសវត្សរ៍ឆ្នាំ 1480 ក្រុមអ្នករុករកព័រទុយហ្គាល់ បានធ្វើដំណើរតាមនាវាតាមតំបន់ឆ្នេរអាហ្វ្រិកភាគខាងលិច និងបានជួបប្រទះព្រះរាជាណាចក្រកុងហ្គោ។ ទំនាក់ទំនងនេះនឹងនាំមកនូវការផ្លាស់ប្តូរជាច្រើន និងជាយថាហេតុបាននាំមកនូវផលលំបាកយ៉ាងខ្លាំងដល់កុងហ្គោ។

ពាណិជ្ជកម្ម និងទាសភាព៖ ទំនាក់ទំនងដំបូងរវាងព័រទុយហ្គាល់ និងកុងហ្គោមានភាពល្អប្រសើរ។ កុងហ្គោបានធ្វើពាណិជ្ជកម្មទង់ដែង, ដែក, និងភ្លុកទៅកាន់ព័រទុយហ្គាល់។ ត្រឡប់មកវិញ កុងហ្គោទទួលបានកាំភ្លើង, សេះ, និងទំនិញប្រើប្រាស់មួយចំនួន។ ឥទ្ធិពលរបស់ពួកព័រទុយហ្គាល់បានកើនឡើងនៅពេលដែល អ៊ិនហ្សីងហ្គាអ៊ឹមបេមបា បានក្លាយជាមេដឹកនាំកុងហ្គោនៅក្នុងឆ្នាំ 1506 ។ ស្តេចថ្មីនេះបានប្រើឈ្មោះជាភាសាអឺរ៉ុបថា អាហ្វុនសូទី 1 និងបានចម្លងនូវរបៀបរបបរបស់ព័រទុយហ្គាល់ជាច្រើន។ ទ្រង់បានរៀនអាន និងសរសេរភាសាព័រទុយហ្គាល់។ ទ្រង់បានយកសាសនារ៉ូម៉ាំងកាតូលិកធ្វើជាសាសនាផ្លូវការ។ ទ្រង់ក៏បានកែប្រែ ប្រព័ន្ធនយោបាយកុងហ្គោដើម្បីឆ្លុះបញ្ចាំងពីប្រពៃណីរបស់ពួកអឺរ៉ុប។ នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មដំបូងរបស់ពួកគេ កុងហ្គោបានចាប់ផ្តើមផ្គត់ផ្គង់ឱ្យពួកព័រទុយហ្គាលនូវទាសករអាហ្វ្រិក។ ពួកព័រទុយហ្គាល់ចង់បានពួកទាសករដើម្បីធ្វើការនៅលើដែនដីដែលពួកគេដណ្តើមកាន់កាប់បាន ក្នុងនោះមានដូចជាប្រទេសប្រេស៊ីល និងកោះសៅតូមេ ដែលស្ថិតនៅចុងឆ្នេរអាហ្វ្រិកភាគខាងលិច។ នៅក្នុងការផ្លាស់ប្តូរ មេដឹកនាំកុងហ្គោទទួលបានទំនិញនានារបស់អឺរ៉ុបដែលពួកគេចង់បាន។

ប៉ុន្តែ ដូចដែលតម្រូវការទាសករដើម្បីធ្វើការងាររបស់ពួកព័រទុយហ្គាល់បានកើនឡើង ពាណិជ្ជកម្មទាសករចាប់ផ្តើមធ្វើឱ្យប្រជាជនអាហ្វ្រិកភាគខាងត្បូងចុះថយ។ អាហ្វុនសូបានស្នើឱ្យស្តេចព័រទុយហ្គាល់បញ្ឈប់ការធ្វើពាណិជ្ជកម្មទាសករនេះ ប៉ុន្តែការស្នើសុំរបស់ទ្រង់មិនទទួលបានការឆ្លើយតបជាវិជ្ជមានឡើយ។ នៅត្រឹមពេលដែលស្តេចអាហ្វុនសូសុគតនៅក្នុងឆ្នាំ 1543 ពួកព័រទុយហ្គាល់បាននាំយកពួកអាហ្វ្រិករាប់ពាន់នាក់ក្នុងមួយឆ្នាំៗធ្វើជាទាសករ។ នៅក្នុងឆ្នាំ 1561 ព្រះរាជាណាចក្រកុងហ្គោបានកាត់ផ្តាច់ទំនាក់ទំនងជាមួយព័រទុយហ្គាល់។ ព្រះរាជាណាចក្រកុងហ្គោជួយប្រទះនូវអស្ថេរភាពបន្ទាប់ពីការសុគតរបស់អាហ្វុនសូ។ ដោយមិនអាចទទួលជ័យជំនះនៅក្នុងការធ្វើសង្គ្រាមជាមួយប្រទេសជិតខាងមួយរបស់ខ្លួន កុងហ្គោបានស្នើសុំជំនួយពីពួកព័រទុយហ្គាល់។ ព្រះរាជាណាចក្រវិលមករកស្ថេរភាពវិញយឺតៗនៅដើមទសវត្សរ៍ឆ្នាំ 1600 ។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីឥទ្ធិពលនៃការធ្វើទំនាក់ទំនងជាមួយពួកព័រទុយហ្គាល់មកលើកុងហ្គោ។

# ជំពូក 13 ៖ អរិយធម៌ទ្វីបអាមេរិក

## មេរៀនទី 1 ៖ ទីតាំងភូមិសាស្ត្រនៃទ្វីបអាមេរិក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើតំបន់មួយណាដែលអ្នកចូលចិត្តជាងគេ ភ្នំ, ប្រាំងសមុទ្រ, វាលខ្សាច់, ឬវាលទំនាប? អ្នកអាចស្វែងរកតំបន់ទាំងអស់នេះនៅអាមេរិកខាងជើង។ នៅក្នុងមេរៀននេះ អ្នកនឹងធ្វើការប្រៀបធៀបទីតាំងភូមិសាស្ត្រនៅអាមេរិកខាងជើងជាមួយនឹងទីតាំងភូមិសាស្ត្រនៅអាមេរិកខាងត្បូង។

### 1. រូបសណ្ឋានភូមិសាស្ត្រនៃទ្វីអាមេរិក

សំណួរគន្លឹះ៖ តើមានប្រព័ន្ធទន្លេសំខាន់ៗអ្វីខ្លះនៅអាមេរិកខាងជើង និងអាមេរិកខាងត្បូង?

សូមពិនិត្យមើលផែនទីអាមេរិកខាងជើង និងអាមេរិកខាងត្បូង។ អ្នកអាចកត់សំគាល់ថាទ្វីបទាំងពីរនេះជាប់គ្នា។ ស្ពានដីដ៏តូចមួយដែលគេហៅថាអ៊ីស្ទូសបានភ្ជាប់ទ្វីបទាំងពីរនេះ។ ប៉ុន្តែទីតាំងភូមិសាស្ត្រ និងអាកាសធាតុនៃទ្វីបទាំងពីរនេះមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង។

ទម្រង់ដី និងទន្លេ៖ ជួរភ្នំនានាបានលាតសន្ធឹងតាមតំបន់ភាគខាងលិចនៅទ្វីបទាំងពីរនេះ។ នៅអាមេរិកខាងជើងមានជួរភ្នំភាគខាងត្បូងមួយដែលគេហៅថាជួរភ្នំរ៉ូឃី ។ វាគឺជាផ្នែកមួយនៃជួរភ្នំមួយដែលលាតសន្ធឹងពីអាឡាស្កាហូតដល់ម៉ិចសិចកូភាគកណ្តាល។ នៅអាមេរិកខាងត្បូងមានជួរភ្នំមួយ ដែលគេហៅថាអានដេស ។ ជួរភ្នំអានដេសលាតសន្ធឹងប្រវែងប្រមាណ 5,500 ម៉ាយ និងមានកំពូលខ្ពស់ៗជាច្រើន។ ទឹកបានហូរចុះពីជួរភ្នំទាំងអស់នេះទៅកាន់ទន្លេធំៗ។ ប្រព័ន្ធទន្លេដែលធំជាងគេនៅអាមេរិកខាងជើងគឺទន្លេមីស៊ីស៊ីបពី។ ទន្លេអាម៉ាហ្សូន និងប៉ារ៉ាម៉ាគឺជាប្រព័ន្ធទន្លេដែលធំជាងគេនៅអាមេរិកខាងត្បូង។

អាកាសធាតុចម្រុះមួយ៖ ទីតាំងរបស់ទ្វីបទាំងពីរមានឥទ្ធិពលមកលើអាកាសធាតុ។ ទ្វីបអាមេរិកខាងជើងលាតសន្ធឹងភាគខាងជើងខ្សែអេក្វាទ័រ។ ភាគច្រើននៃទ្វីបអាមេរិកខាងត្បូងលាតសន្ធឹងនៅភាគខាងត្បូងនៃខ្សែអេក្វាទ័រ។ ជាលទ្ធផលរដូវរបស់ទ្វីបទាំងពីរនេះមានលក្ខណៈផ្ទុយគ្នា។ នៅពេលដែលទ្វីបអាមេរិកខាងជើងរដូវក្តៅ នៅទ្វីបអាមេរិកខាងត្បូងរដូវរងារ ហើយនៅពេលដែលទ្វីបអាមេរិកខាងជើងរដូវរងារ នៅទ្វីបអាមេរិកខាងត្បូងរដូវក្តៅ។ ទីតាំងរបស់ទ្វីបទាំងពីរនេះក៏មានឥទ្ធិពលអាកាសធាតុផងដែរ។ ភាគច្រើននៃទ្វីបអាមេរិកខាងជើងមានអាកាសធាតុក្តៅល្មម ឬស្ងួត ជាមួយនឹងរដូវ 4 ដាច់ដោយឡែកពីគ្នា។ មានមនុស្សតិចតួចរស់នៅកាណាដាភាគខាងជើង ជាទីកន្លែងដែលអាកាសធាតុមានភាពត្រជាក់ខ្លាំង។ ទ្វីបអាមេរិកខាងត្បូងក៏មានអាកាសធាតុចម្រុះផងដែរ។ ជាងនេះទៅទៀត ភាគច្រើននៃទ្វីបនេះទទួលបានបរិមាណទឹកភ្លៀងច្រើន។ ពាក់កណ្តាលនៃទ្វីបអាមេរិកខាងត្បូងមានអាកាសធាតុក្តៅល្មម និងមានភ្លៀងធ្លាក់។ តំបន់ដែលមានអាកាសធាតុក្តៅល្មម និងមានភ្លៀងធ្លាក់ទាំងនេះត្រូវបានគេហៅថា តំបន់ត្រូពិក។ តំបន់មួយចំនួននៅទ្វីបអាមេរិកខាងជើងក៏ជាតំបន់ត្រូពិកផងដែរ។ តំបន់ទាំងអស់នេះលាតសន្ធឹងមួយភាគធំនៅអាមេរិកកណ្តាល។ ប្រជាជនដែលបានស្ថាបនាអរិយធម៌បុរាណនៅអាមេរិកកណ្តាលបានរៀនសូត្រពីវិធីក្នុងការរស់នៅ និងអភិវឌ្ឍជាមួយអាកាសធាតុត្រូពិក។

ធ្វើចំណាត់ថ្នាក់៖ រាប់ឈ្មោះប្រព័ន្ធទន្លេសំខាន់ៗនៅទ្វីបអាមេរិកខាងជើង និងទ្វីបអាមេរិកខាងត្បូង។

## 2. ភូមិសាស្ត្រអង់ដេស

សំណួរគន្លឹះ៖ ហេតុអ្វីបានជាបរិស្ថាននៅអង់ដេសត្រូវបានគេចាត់ទុកថាមានលក្ខណៈកាចសាហាវ?

អរិយធម៌បុរាណបានអភិវឌ្ឍនៅលើទ្វីបទាំងពីរ។ អរិយធម៌មួយចំនួនរះឡើងនៅលើជួរភ្នំអង់ដេសនៅទ្វីបអាមេរិកខាងត្បូង។ អង់ដេសលាតសន្ធឹងចាប់ពីប្រទេសវេណេហ្សូអេឡា(ភាគខាងជើង)រហូតទៅដល់ប្រទេសឈីលី(ចុងភាគខាងត្បូងនៃទ្វីប)។ នៅតំបន់នេះមានខ្ពង់រាប និងភ្នំខ្ពស់ៗ។

កំពូលភ្នំ៖ កំពូលភ្នំនៅអង់ដេសមានកម្ពស់ខ្ពស់ជាគេនៅអាមេរិក។ កំពូលភ្នំជាច្រើនមានកម្ពស់លើសពី 20,000 ហ្វីត ឬក៏មានកម្ពស់ជិត 4 ម៉ាយ។ នៅលើកំពូលភ្នំគ្របដណ្តប់ដោយដីក្រួសស្ងួតៗតែប៉ុណ្ណោះ។ អង់ដេសមានទីតាំងស្ថិតនៅតាមបណ្តោយតំបន់មួយដែលមានចលនានៅក្រោមដី។ ចលនានេះបណ្តាលឱ្យមានការរញ្ជួយដី និងអាចនាំទៅដល់ការផ្ទុះឡើងនៃភ្នំភ្លើង។ អាកាសធាតុក៏មានលក្ខណៈធ្ងន់ធ្ងរ។ នៅតំបន់ដែលមានកម្ពស់ខ្ពស់គ្របដណ្តប់ដោយទឹកកក ហើយនៅតំបន់ជាច្រើនភ្លៀងធ្លាក់មិនត្រូវបានគេព្យាករណ៍ដឹងមុនបានឡើយ។

តំបន់ខ្ពង់រាប៖ នៅពីលើផ្ទៃលាតសន្ធឹងដ៏វែងរបស់អង់ដេស ជួរភ្នំបានបែកចេញជាពីរជួរ។ តំបន់ខ្ពស់រាបធំៗបានលាតសន្ធឹងនៅចន្លោះជួរភ្នំទាំងពីរនេះ។ តំបន់នេះពោរពេញទៅដោយកូនភ្នំតូចៗ, ជ្រលង, វាលទំនាប, និងវាលខ្សាច់។ មានទន្លេធំៗមួយចំនួនតូចបានហូរនៅក្នុងតំបន់នេះ។ ប៉ុន្តែនៅតំបន់វាលខ្សាច់ ភ្លៀងស្ទើរតែមិនដែលធ្លាក់។ ដូចដែលអ្នកអាចស្រមៃ ការដាំដុះបានជួបនូវបញ្ហាប្រឈមមួយនៅអង់ដេស។ ដើម្បីដាំដុះដំណាំរបស់ពួកគេ ប្រជាកសិករអង់ដេសបុរាណបានអភិវឌ្ឍប្រឡាយបង្ហូរទឹក។ ប្រឡាយនេះបាននាំយកទឹកមកស្រោចស្រប ដំឡូងបារាំង និងដំណាំផ្សេងៗទៀតដែលកសិករបានដាំ។

ប្រជាកសិករអង់ដេសក៏បានកាត់ជម្រាលភ្នំជាថ្នាក់ៗដើម្បីងាយស្រួលនៅក្នុងដាំដុះ។ ការកាត់ជម្រាលភ្នំបានធ្វើឱ្យភ្នំក្លាយជាថ្នាក់ៗដូចកាំជណ្តើរ។ បច្ចុប្បន្ន ក្រុមអ្នកចិញ្ចឹមសត្វបានប្រើប្រាស់តំបន់វាលស្មៅនៅតំបន់ខ្ពង់រាបទាំងនោះដើម្បីចិញ្ចឹមសត្វគោក្របី និងចៀម។ ពួកគេក៏ចិញ្ចឹមសត្វឡាម៉ា និងអាលប៉ាកា ដែលមានរូបរាងស្រដៀងសត្វអូដ។ សត្វទាំងនេះគឺជាសត្វដែលមានប្រភពដើមនៅទ្វីបអាមេរិកខាងត្បូង។ ពួកគេចិញ្ចឹមសត្វទាំងនោះភាគច្រើនដើម្បីយករោម និងសម្រាប់ដឹកជញ្ជូនទំនិញ។

វាយតម្លៃ៖ ពន្យល់ពីមូលហេតុដែលអង់ដេសត្រូវបានគេចាត់ទុកថាជាតំបន់មួយដែលមានបរិស្ថានកាចសាហាវ។

## 3. ភូមិសាស្ត្រតំបន់មេសូអាមេរិក

សំណួរគន្លឹះ៖ តើភូមិសាស្ត្រ និងអាកាសធាតុនៅតំបន់មេសូអាមេរិកមានលក្ខណៈផ្ទុយគ្នាពីតំបន់អង់ដេសយ៉ាងដូចម្តេច?

អរិយធម៌បុរាណបានរះឡើងនៅទ្វីបអាមេរិកខាងជើងនៅក្នុងភូមិភាគមួយដែលគេហៅថា មេសូអាមេរិក។ តំបន់មេសូអាមេរិករួមបញ្ចូលម៉ិចស៊ិចកូភាគកណ្តាល និងភាគខាងត្បូង និងប្រទេសមួយចំនួនអាមេរិកកណ្តាល ក្នុងនោះរួមមានហ្គាតេម៉ាឡា, អែលសាវ៉ាឌ័រ, បេលីហ្ស, និងផ្នែកខ្លះនៃប្រទេសហុនឌូរ៉ាស់ និងនីការ៉ាហ្គ័រ។ ផ្ទុះពីតំបន់ភ្នំអង់ដេស តំបន់មេសូអាមេរិកមានផ្ទៃដីទំនាបច្រើន និងមានអាកាសធាតុក្តៅល្មម។

ផ្ទៃដីនៅមេសូអាមេរិក៖ ភាគច្រើននៃផ្ទៃដីនៅមេសូអាមេរិកផ្នែកខាងជើងគឺជាតំបន់ខ្ពង់រាប។ ជួរភ្នំនានាបានលាតសន្ធឹងនៅជិតតំបន់ឆ្នេរសមុទ្រប៉ាស៊ីហ្វិក និងឈូងសមុទ្រម៉ិចស៊ិចកូ។ ប៉ុន្តែ ជួរភ្នំទាំងនេះមិនមានកម្ពស់ខ្ពស់ដូចជាជួរភ្នំនៅតំបន់អង់ដេសឡើយ។ មានខ្ពង់រាបខ្ពស់មួយបានលាទសន្ធឹងនៅចន្លោះជួរភ្នំពីរ។ វាគឺជារូបសណ្ឋានភូមិសាស្ត្រដែលធំជាងគេនៅក្នុងតំបន់នេះ។ ខ្ពង់រាបភាគកណ្តាល ដែលស្ថិតនៅតំបន់ទីក្រុងម៉ិចស៊ិចកូ ភាគច្រើនមានលក្ខណៈរាបស្មើ និងសម្បូរទៅដោយដីមានជីជាតិ។ តំបន់នេះគឺជាលំនៅឋានរបស់ "ល្អីនំប៉័ងម៉ិចស៊ិចកូ" ជាទីកន្លែងដែលគ្រាប់ធុញ្ញជាតិភាគច្រើននៅក្នុងប្រទេសត្រូវបានដាំដុះ។ តំបន់ទំនាបត្រូពិកគ្របដណ្តប់លើឆ្នេរឈូងសមុទ្ទម៉ិចស៊ិចកូ។ តំបន់ទាំងនេះគឺជាតំបន់ព្រៃស្រោងក្រាស់។ តំបន់ព្រៃស្រោងក្រាស់បែបនេះក៏ត្រូវបានគេរកឃើញនៅឧបទ្វីបយូកាតាន ដែលលាតសន្ធឹងនៅចន្លោះឈូងសមុទ្ទម៉ិចស៊ិចកូ និងសមុទ្ទការីបប៊ីន។

អាកាសធាតុ៖ មានតំបន់ភ្លៀងធ្លាក់ផ្សេងៗគ្នាជាច្រើននៅពាសពេញតំបន់។ នៅតំបន់ទំនាបអាចមានទឹកភ្លៀងជាង 80 អ៊ីងក្នុងមួយឆ្នាំ ដែលបានផ្តល់នូវបរិស្ថានល្អមួយសម្រាប់តាលព្រឹក្ស, ផ្លែប័រ, ដើមកាកាវ។ ប៉ុន្តែ នៅតំបន់ខ្ពង់រាប ខ្យល់មានភាពត្រជាក់ និងស្ងួត។ តំបន់ខ្ពស់រាបភាគកណ្តាលទទួលបានភ្លៀងធ្លាក់គ្រប់គ្រាន់ដើម្បីគាំទ្រដល់ការដាំដុះដំណាំជាច្រើនមុខ។ នៅតំបន់ភាគខាងជើងជាតំបន់ដែលមានភ្លៀងធ្លាក់តិចតួច។

ប្រជាកសិករមេសូអាមេរិកដំបូងត្រូវការអភិវឌ្ឍបច្ចេកទេសជាន់ខ្ពស់មួយ ដើម្បីដោះស្រាយជាមួយអាកាសធាតុនៅក្នុងតំបន់របស់ពួកគេ។ នៅតំបន់ខ្ពង់រាបដែលមានភាពស្ងួត ប្រជាកសិករបង្ហូរទឹកមកកាន់ចំការពោត, សណ្តែក, និងល្ពៅរបស់ពួកគេ។ នៅកន្លែងណាដែលមិនមានដីទំនាបធំ ពួកគេបានកាត់ជម្រាលភ្នំជាថ្នាក់ៗ។ នៅតំបន់ទំនាប ប្រជាកសិករបានអនុវត្តកសិកម្មព្រៃដុត។ ពួកគេសម្អាតព្រៃស្រោងតាមរយៈការកាប់ដើមរុក្ខជាតិនានា និងដុតវាចោល។ នៅពេលដែលដីចំការទាំងនោះផ្តល់ទិន្នផលតិច ប្រជាកសិករចាប់ផ្តើមដុតព្រៃនៅតំបន់ថ្មីមួយទៀត។

ប្រៀបធៀបភាពដូច និងខុសគ្នា៖ ប្រៀបធៀបភាពដូច និងខុសគ្នានៃភូមិសាស្ត្រ និងអាកាសធាតុនៅតំបន់មេសូអាមេរិក និងតំបន់អង់ដេស។

# មេរៀនទី 2 ៖ អាមេរិកកណ្ដាល និងអាមេរិកខាងជើង

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅអាមេរិកមានបរិស្ថានធម្មជាតិចម្រុះមួយ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីរបៀបដែលអរិយធម៌សំខាន់ៗចំនួន 4 រីកលូតលាស់នៅតាមតំបន់ផ្ទៃដីសម្បូរដីជាតិទាំងនេះ។

## 1. អូលមេច

សំណួរគន្លឹះ៖ ហេតុអ្វីបានជាអូលមេចត្រូវបានគេគិតថាជាមាតានៃវប្បធម៌មេសូអាមេរិក?

ប្រហែលជា 3,200 កន្លងមក មនុស្សមួយក្រុមដែលគេហៅថា អូលមេចបានតាំងទីលំនៅនៅតាមបណ្ដោយតំបន់ឆ្នេរឈូងសមុទ្ទ ដែលបច្ចុប្បន្នស្ថិតនៅម៉ិចស៊ិចកូភាគខាងត្បូង។ វប្បធម៌របស់ពួកគេគឺជាវប្បធម៌សំខាន់ដំបូងដែលត្រូវបានអភិវឌ្ឍនៅមេសូអាមេរិក។ អូលមេចក៏ដូចជាអរិយធម៌ដំបូងៗផ្សេងទៀតដែរ។ ពួកគេចាប់ផ្ដើមដំបូងដោយការដាំដុះនៅជិតទន្លេដែលជារឿយៗតែងតែជន់លិច និងបន្សល់ទុកនូវដីដែលសម្បូរដោយជីជាតិ។ ជាមួយនឹងការទទួលបានចំណីអាហារគ្រប់គ្រាន់ ពួកអូលមេចមួយចំនួនមានពេលទំនេរនៅក្នុងការធ្វើការងារផ្សេងៗទៀត។ អ្នកមួយចំនួនបានក្លាយជាអ្នកផលិតភាជន៍ ឬអ្នកតម្បាញ, ខណៈដែលអ្នកមួយចំនួនទៀតបានក្លាយជាបុព្វជិត ឬអ្នករដ្ឋបាល។

ត្រឹមឆ្នាំ 900 មុនគ.ស ពួកអូលមេចបានស្ថាបនាទីក្រុងធំៗ ដែលបច្ចុប្បន្នគេហៅថា សាន់ ឡូរេនហ្សូ និងឡា វេនតា។ ទីក្រុងទាំងនេះ គឺជាមជ្ឈមណ្ឌលសិល្បៈ និងពាណិជ្ជកម្មរបស់អូលមេច។ ពួកអូលមេចបានពូនពំនូកនិងបូជនីយស្ថានថ្មធំៗសម្រាប់ការរៀបចំពិធីជំនឿ។ នៅវង្វង់ឆ្នាំ 500 មុនគ.ស ពួកអូលមេចបានចាប់ផ្ដើមបោះបង់ទីក្រុងរបស់ពួកគេ។ មូលហេតុនៃការបោះបង់នេះនៅតែមានភាពមិនច្បាស់លាស់។ ត្រឹមឆ្នាំ 400 មុនគ.ស អរិយធម៌អូលមេចភាគច្រើនបានបាត់រូបរាង។ ប៉ុន្តែជំនឿរបស់ពួកអូលមេច និងរបៀបរបបនានានៅតែបន្តជះឥទ្ធិពលយ៉ាងខ្លាំងរាប់សិបឆ្នាំលើវប្បធម៌មេសូអាមេរិក។ ប្រវត្តិវិទូជាច្រើនចាត់ទុកថា អូលមេចគឺជាមាតាវប្បធម៌របស់មេសូអាមេរិក។ មាតាវប្បធម៌មួយគឺជាវិធីរស់នៅមួយដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់វប្បធម៌ក្រោយៗ។ សិល្បៈ, ស្ថាបត្យកម្ម, ជំនឿ, និងពាណិជ្ជកម្មរបស់អូលមេចបានជួយបង្កើតទ្រង់ទ្រាយវប្បធម៌ក្រោយៗ ក្នុងនោះមានដូចជាអាសតិច និងជាពិសេសម៉ាយ៉ា។

វាយតម្លៃ៖ ពន្យល់ពីមូលហេតុដែលនាំឱ្យគេចាត់ទុកថាអូលមេចគឺជាមាតាវប្បធម៌មួយ។

## 2. ម៉ាយ៉ា

សំណួរគន្លឹះ៖ តើប្រព័ន្ធវណ្ណៈរបស់ម៉ាយ៉ាមានរចនាសម្ព័ន្ធយ៉ាងដូចម្ដេច?

ម៉ាយ៉ារួមបញ្ចូលក្រុមប្រជាជនមេសូអាមេរិកដែលនិយាយភាសាផ្សេងៗគ្នា ដែលស្ថិតនៅក្នុងអម្បូរភាសាម៉ាយ៉ា។ សិល្បៈ និងបូជនីយស្ថានរបស់ពួកគេមានលក្ខណៈដូចគ្នាច្រើនជាមួយពួកអូលមេច។ សង្គមម៉ាយ៉ាបានអភិវឌ្ឍឡើងនៅវង្វង់ឆ្នាំ 1500 មុនគ.ស ភូមិកសិកម្មតូចរបស់ម៉ាយ៉ាចាប់ផ្ដើមលេចឡើង។ ពួកម៉ាយ៉ារស់នៅតំបន់ខ្ពង់រាបនិងទំនាបដែលបច្ចុប្បន្នស្ថិតនៅប្រទេសហ្គាតេម៉ាឡា និងបេលីហ្សេ, និងនៅឧបទ្វីបយូកាតាននៅម៉ិចស៊ិចកូ។ ក៏

ដូចជាពួកអូលមេចដែរ ភាពជោគជ័យនៃកសិកម្មនាំទៅដល់ការកើនឡើងនៃចំនួនប្រជាជន, ការអភិវឌ្ឍទីក្រុង, និងកម្មករជំនាញ។ ការបែងចែកការងារនៅក្នុងសង្គមម៉ាយ៉ានេះនាំទៅដល់ការអភិវឌ្ឍឡើងនៃប្រព័ន្ធវណ្ណៈមួយ។ មានវណ្ណៈសង្គមធំៗចំនួន 4 នៅក្នុងសង្គមម៉ាយ៉ា៖ វណ្ណៈអ្នកដឹកនាំ, អភិជន, ប្រជាកសិករ, និងទាសករ។ វណ្ណៈអ្នកដឹកនាំរួមមានស្តេច និងរាជវង្សរបស់ទ្រង់។ ស្តេចមួយអង្គដឹកនាំទីក្រុងមួយរបស់ម៉ាយ៉ា (នៅត្រង់ចំណុចកំពូលនៃអរិយធម៌ម៉ាយ៉ា មានទីក្រុងចំនួនជាង 40 បានលេចឡើង) ។ ស្តេចក៏ជាអ្នកបំពេញកិច្ចការជំនឿរបស់បព្វជិត។ ពួកអភិជនម៉ាយ៉ាគឺជាអ្នកទទួលបានការអប់រំ និងមានទ្រព្យសម្បត្តិ និងប្រហែលជាធ្វើការជាអ្នកប្រាជ្ញ, អ្នកប្រយុទ្ធ, និងពាណិជ្ជករ។ ពួកគេទទួលទានអាហារប្រសើរជាងប្រជាកសិករ។ ជាក់ស្តែង អាហារមួយចំនួន ដូចជាសូកូឡាត្រូវបានគេរៀបចំសម្រាប់តែពួកអភិជនតែប៉ុណ្ណោះ។

ប្រជាកសិករ អ្នកដែលគ្របដណ្តប់នៅក្នុងសង្គមម៉ាយ៉ា រស់នៅខុសគ្នាឆ្ងាយពីពួកអភិជន។ ពួកគេភាគច្រើនគឺជាកសិករ រស់នៅក្នុងភូមិតូចៗស្ថិតនៅជិតទីក្រុង។ ពួកគេដាំដុះគ្រាប់ធុញ្ញជាតិ ក្នុងនោះមានដូចជាពោត, សណ្តែក, ល្ពៅ, និងម្ទេស។ កសិករម៉ាយ៉ាប្រើប្រាស់នូវបច្ចេកទេសផ្សេងៗជាច្រើនដើម្បីដាំដុះដំណាំរបស់ពួកគេ។ ឧទាហរណ៍ នៅតំបន់ខ្ពង់រាប ពួកគេបង្កើនផ្ទៃដីដាំដុះរបស់ពួកគេតាមរយៈការកាត់ជម្រាលភ្នំជាថ្នាក់ៗ។ ទាសករភាគច្រើនជាឧក្រិដ្ឋជន, មនុស្សដែលគេចាប់ធ្វើជាឈ្លើយសឹក, និងមនុស្សកំព្រា។ ទាសករត្រូវបានកាន់កាប់ដោយវណ្ណៈផ្សេងៗទៀតនៅក្នុងសង្គមម៉ាយ៉ា។

ទីក្រុងរបស់ម៉ាយ៉ា៖ នៅអំឡុងសម័យបុរាណ រវាងឆ្នាំ 250 ដល់ 900 នៃគ.ស អរិយធម៌ម៉ាយ៉ាបានឡើងដល់កម្រិតកំពូល។ ទីក្រុងម៉ាយ៉ាជាច្រើន ក្នុងនោះមានដូចជា កូប៉ាន, ទីកាល, និងប៉ាលេនកេ បានបង្ហាញពីស្ថាបត្យកម្មដ៏សំខាន់។ ទីក្រុងនីមួយៗរួមមានទីលានកណ្តាលទីក្រុង, រាជវាំង, និងប្រាសាទពីរ៉ាមីត។ ទីក្រុងជាច្រើនក៏មានបូជនីយស្ថានធំៗស្ថាបនាថ្មដែលគេហៅថា ស្តេលេស។ នៅពីលើស្តេលេសទាំងនេះ ពួកម៉ាយ៉ាបានឆ្លាក់នូវអក្សរនិមិត្តសញ្ញាដែលបានបង្ហាញពីការបរិច្ឆេទ និងព្រឹត្តិការណ៍សំខាន់ៗ។

ភាពរីកចម្រើននៃការរៀនសូត្រ៖ ពួកម៉ាយ៉ាបានអភិវឌ្ឍប្រព័ន្ធសំណេរស្មុកស្មាញមួយដោយប្រើប្រាស់អក្សរនិមិត្តសញ្ញា។ ពួកគេសរសេរអក្សរនិមិត្តសញ្ញាលើក្រដាសដែលធ្វើមកពីសំបកឈើ។ ក្រដាសនេះត្រូវបានគេបត់បញ្ចូលគ្នាដើម្បីបង្កើតបានជាសៀវភៅមួយដែលគេហៅថា កូដិច។ បច្ចុប្បន្នសៀវភៅបែបនេះមាននៅសេះសល់តិចតួចប៉ុណ្ណោះ។ គណិតវិទ្យាម៉ាយ៉ាផ្អែកលើលេខ 20 ។ ផ្ទុយទៅវិញ ប្រព័ន្ធរបស់យើងផ្អែកលើលេខ 10 ។ ម៉ាយ៉ាគឺជាអ្នកដែលប្រើប្រាស់លេខសូន្យដំបូងគេក្នុងចំណោមក្រុមអ្នកប្រើប្រាស់លេខសូន្យ។ ដោយប្រើប្រាស់ប្រព័ន្ធគណិតសាស្ត្ររបស់ពួកគេ ម៉ាយ៉ាមានភាពរីកចម្រើនយ៉ាងខ្លាំងផ្នែកតារាសាស្ត្រ។ ឧទាហរណ៍ ពួកគេបានបង្កើតតារាងកន្លងគោចររបស់ភពនានាបានយ៉ាងត្រឹមត្រូវ។ ចំណេះដឹងរបស់ពួកគេបានអនុញ្ញាតឱ្យពួកបង្កើតបានប្រព័ន្ធប្រតិទិនដ៏ត្រឹមត្រូវមួយ។ ប្រព័ន្ធនេះបានជួយដល់ពួកម៉ាយ៉ាកំណត់ពេលនៃការដាំដុះ និងប្រមូលផល និងអនុញ្ញាតឱ្យពួកគេអាចកត់ត្រាបានច្បាស់លាស់។

ការធ្លាក់ចុះដ៏អាថ៌កំបាំង៖ នៅក្នុងទសវត្សរ៍ឆ្នាំ 800 ពួកម៉ាយ៉ាចាប់ផ្តើមបោះបង់ទីក្រុងនានារបស់ពួកគេនៅតំបន់ទំនាបភាគខាងត្បូង។ នៅក្នុងពេលជាមួយគ្នានោះ ចំនួនប្រជាជនរបស់ពួកគេបានថយចុះយ៉ាងច្រើន។ មូលហេតុនៃការធ្លាក់ចុះនេះស្ថិតនៅក្នុងភាពអាថ៌កំបាំង។ មូលហេតុអាចបណ្តាលមកពីគ្រោះអត់ឃ្លានដែលបណ្តាលមកពីការដាំដុះលើសកម្រិត ឬសង្គ្រាមរវាងទីក្រុងនានា។ ត្រឹមទសវត្សរ៍ឆ្នាំ 1400 ទីក្រុងនានានៅតំបន់ទំនាប និងតំបន់ខ្ពង់រាបភាគខាងជើងក៏ត្រូវបានបោះបង់ចោលផងដែរ។

ស្វែងរកគំនិតសំខាន់៖ រៀបរាប់ និងពិពណ៌នាអំពីផ្នែកផ្សេងៗនៃប្រព័ន្ធវណ្ណៈម៉ាយ៉ា។

### 3. ពួកអាសទិច

សំណួរគន្លឹះ៖ តើកត្តាអ្វីដែលនាំឲ្យចក្រភពអាសទិចដួលរលំ?

ពួកអាសទិចគឺជាក្រុមចរកជនបរបាញ់ និងប្រមូលផលក្នុងព្រៃ។ ពួកគេរស់នៅក្នុងតំបន់ដែលបច្ចុប្បន្នស្ថិតនៅវាលខ្សាច់ម៉ិចស៊ិចកូភាគពាយព្យ។ នៅចុងទសវត្សរ៍ឆ្នាំ 1200 ពួកគេចាប់ផ្តើមផ្លាស់ទីទៅភាគខាងត្បូង។ ដាយថាហេតុ ពួកគេបានធ្វើដំណើរមកដល់ជ្រលងម៉ិចស៊ិចកូ។

ការតាំងទីលំនៅនៃជ្រលងម៉ិចស៊ិចកូ៖ រឿងព្រេងអាសទិចបាននិយាយថា ពួកគេនឹងស្វែងរកលំនៅឋានថ្មីរបស់ពួកគេ ជាទីកន្លែងមួយដែលពួកគេឃើញសត្វឥន្ទ្រីទុំលើដើមដំបងយក្ស។ នៅក្នុងឆ្នាំ 1325 ពួកគេបានរកឃើញកន្លែងមួយ។ វាស្ថិតនៅលើកោះមួយនៅក្នុងបឹងដ៏ធំមួយ។ នៅទីនោះពួកគេបានស្ថាបនារាជធានីរបស់ពួកគេ តេណូចទីតឡាន។ ដែនដីដែលស្ថិតនៅជុំវិញតេណូចទីតឡានគឺជាតំបន់ភ្នំដែលមិនអំណោយផលដល់ការធ្វើកសិកម្មឡើយ។ ពួកអាសទិចបានសម្របខ្លួនតាមរយៈការស្ថាបនាឈើណាំប៉ះ ឬការធ្វើថ្នើរសួនដំណាំនៅលើបឹង។ ជាមួយនឹងការទទួលបានចំណីអាហារគ្រប់គ្រាន់ ចំនួនប្រជាជននៅតេណូទីតឡានបានកើនឡើង។ នៅកម្រិតខ្ពស់បំផុត រាជធានីនេះមានចំនួនប្រជាជនរហូតដល់ 250, 000 នាក់។

សាសនា និងវប្បធម៌របស់អាសទិច៖ ជីវិតរស់នៅរបស់ពួកអាសទិចគ្របដណ្តប់ដោយសាសនា។ សាសនានេះផ្តោតសំខាន់លើការគោរពបូជាលើអាទិទេពកសិកម្ម។ ពួកអាសទិចជឿជាក់លើអាទិទេពប្រហែល 1,000 ។ ពិធីបុណ្យដែលសំខាន់បំផុត គឺជាពិធីដែលគេរៀបចំឡើងដើម្បីបន់ស្រន់អាទិទេពឱ្យទទួលបានទិន្នផលច្រើន។ ពួកអាសទិចបានបង្កើតប្រតិទិនចំនួនពីរដាច់ពីគ្នាតាមរយៈការសិក្សាពីព្រះអាទិត្យ, ផ្កាយ, និងភពនានា។ ប្រតិទិនមួយគឺប្រតិទិនកសិកម្ម។ វាបានព្យាករណ៍ពីពេលវេលានៃការដាំដុះ និងការប្រមូលផល។ ប្រតិទិនមួយទៀតគឺជាប្រតិទិនសាសនាមួយដែលកំណត់ពេលវេលាសម្រាប់ការរៀបចំពិធីបុណ្យសាធារណប្រចាំឆ្នាំ។

មួយភាគធំ ប្រព័ន្ធសំណេររបស់អាសទិចមិនបានតំណាងឱ្យសំលេងនៃភាសានិយាយឡើយ។ ផ្ទុយទៅវិញពួកគេប្រើប្រាស់រូបភាព និងនិមិត្តសញ្ញា ដែលគេហៅថាអក្សរនិមិត្តសញ្ញា ដើម្បីតំណាងឱ្យពាក្យ និងគំនិត។ ពួកអាសទិចបង្កើតកំណត់ត្រាមួយនៅក្នុងទម្រង់អក្សរនិមិត្តសញ្ញា។ កំណត់ត្រានីមួយៗពោរពេញទៅដោយរូបភាព

ដែលរៀបរាប់លម្អិតអំពីជីវភាពរស់នៅប្រចាំថ្ងៃនៅក្នុងសង្គមអាសទិច។ ប្រវត្តិវិទូបានសិក្សាយ៉ាងច្រើនអំពីពួកអាសទិចពីកំណត់ត្រាទាំងអស់នេះ។

ការរះឡើង និងការដួលរលំនៃចក្រភព៖ ត្រឹមដើមទសវត្សរ៍ឆ្នាំ 1500 ចក្រភពអាសទិចបានលាតសន្ធឹងពីឈូងសមុទ្រម៉ិចស៊ិចកូរហូតដល់មហាសមុទ្រប៉ាស៊ីហ្វិក និងចាប់ពីច្រលងម៉ិចស៊ិចកូរហូតដល់តំបន់ដែលយើងស្គាល់បច្ចុប្បន្នថាហ្គាតេម៉ាឡា។ មានមនុស្សរហូតដល់ 12 លាននាក់រស់នៅក្នុងដែនដីដែលគ្រប់គ្រងដោយអាសទិច។ ពួកអាសទិចតម្រូវឱ្យប្រជាជនទាំងនេះបង់សួយឱ្យពួកគេនូវទំនិញនានា ក្នុងនោះមានដូចជាពោត, មាស, និងថ្លៃមថ្ម។ ចក្រភពឈានដល់កម្រិតកំពូលនៅក្នុងឆ្នាំ 1502 នៅពេលអធិរាជ ម៉ុនតេហ្ស៊ូម៉ា 2 ឡើងកាន់អំណាច។ ទ្រង់បានធ្វើឱ្យប្រជានុរាស្ត្រទ្រង់មានការមិនសប្បាយចិត្ត ដោយសារការទាមទារឱ្យពួកគេបង់សួយកាន់តែច្រើនឡើងៗ និងការបូជាជីវិតមនុស្សដើម្បីផ្គាប់ចិត្តអាទិទេពអាសទិច។ ប្រជានុរាស្ត្រមួយចំនួនបានចាប់ផ្តើមងើបឡើងបះបោរ ដែលធ្វើឱ្យអំណាចរបស់ចក្រភពចុះខ្សោយ។ នៅក្នុងឆ្នាំ 1519 ពួកអេស្ប៉ាញដែលដឹកនាំដោយ ហឺណានកូទេស បានធ្វើដំណើរមកដល់ចក្រភពអាសទិច។ ដោយសង្ឃឹមនៅក្នុងការបញ្ចៀសសង្គ្រាម ម៉ុងតេហ្ស៊ូម៉ាបានជួបជាមួយកូទេស។ ប៉ុន្តែពួកអេស្ប៉ាញបានចាប់ទ្រង់ឃុំខ្លួន ហើយក្រោយមកទ្រង់ត្រូវបានសម្លាប់នៅក្នុងសមរភូមិមួយ។ ភ្លាមៗនោះ ជំងឺដែលនាំយកមកដោយក្រុមអ្នកឈ្លានពានបានធ្វើឱ្យអាសទិចចុះខ្សោយ។ ដោយទទួលបានជំនួយពីក្រុមអ្នកបះបោររាប់ពាន់នាក់ ពួកអេស្ប៉ាញបានប្រើប្រាស់អាវុធទំនើបរបស់ពួកគេដើម្បីដណ្តើមកាន់កាប់រាជធានីតេណុចទីតឡាននៅក្នុងឆ្នាំ 1521 និងបានបញ្ចប់ចក្រភពអាសទិច។

វិភាគអំពីផលប៉ះពាល់៖ កត្តាអ្វីដែលនាំឱ្យចក្រភពអាសទិចធ្លាក់ចុះ។

## 4. ពួកអ៊ីនកា

សំណួរគន្លឹះ៖ តើពួកអ៊ីនកាស្ថាបនាចក្រភពមួយនៅអង់ដេសដោយរបៀបណា?

ពួកអ៊ីនកាបានរៀនពីរបៀបរស់នៅនៅលើដីថ្នាក់ៗនៅលើជួរភ្នំអង់ដេស ដែលបច្ចុប្បន្នស្ថិតនៅប្រទេសប៉េរូ។ រាជធានីរបស់ពួកគេគូស្កូស្ថិតនៅជ្រលងមួយនៅអង់ដេសដែលមានកម្ពស់ជាង 11,000 ហ្វីតពីលើនីវូទឹកសមុទ្រ។ ពីទីក្រុងគូស្កូ ពួកអ៊ីនកាបន្តិចម្តងៗបានស្ថាបនាចក្រភពដែលធំបំផុតនៅអាមេរិក។

ប៉ាឆាគូទីបង្កើតចក្រភពមួយ៖ ត្រឹមដើមទសវត្សរ៍ឆ្នាំ 1400 ពួកអ៊ីនកាបានពង្រីកការគ្រប់គ្រងរបស់ពួកគេទៅលើប្រជាជនដែលរស់នៅជុំវិញ។ នៅក្នុងឆ្នាំ 1438 មេដឹកនាំអ៊ីនកាទី 9 ព្រះនាមប៉ាឆាគូទីបានឡើងកាន់អំណាច។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ ពួកអ៊ីនកាបានដណ្តើមកាន់កាប់ដែនដីប៉េរូទាំងមូល និងដែនដីជុំវិញ។ ត្រឹមឆ្នាំ 1500 ចក្រភពអ៊ីនកាបានរីកធំទៅឆ្ងាយ ដោយពង្រីក 2,500 ម៉ាយតាមបណ្តោយឆ្នេរភាគខាងលិចនៃទ្វីបអាមេរិកខាងត្បូង។ មានប្រជាជនប្រមាណ 12 លាននាក់រស់នៅក្នុងចក្រភពនេះ។

ជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងចក្រភព៖ ទីតាំងភូមិសាស្ត្ររបស់អង់ដេសបានធ្វើឱ្យជីវិតរស់នៅរបស់ប្រជាជនក្នុងចក្រភពប្រឈមជាមួយបញ្ហាជាច្រើន។ ដីជម្រាលបានធ្វើឱ្យការដាំដុះមានភាពលំបាក។ ប្រជាកសិករបាន

កាត់ជម្រាលភ្នំជាថ្នាក់ៗដើម្បីប្រើប្រាស់វាដាំដុះដំណាំ។ ពួកគេដាំដុះដំណាំផ្សេងៗដូចជាដំឡូងបារាំង និងពោត និងចិញ្ចឹមសត្វពាហនៈមួយចំនួនដូចជា អាលប៉ាកា និងឡាម៉ា។ សត្វទាំងនេះផ្តល់នូវរោម និងសាច់។ ក៏ដូចជាការដាំដុះដែរ ការធ្វើទំនាក់ទំនងមានភាពលំបាក។ ពួកអ៊ីនកាបានថែរក្សាប្រព័ន្ធគមនាគមន៍របស់ពួកគេដោយតម្រូវឱ្យប្រជានជនម្នាក់ធ្វើការងារដាក់លាក់មួយចំនួនជាប្រចាំឆ្នាំ។ យ៉ាងហោចណាស់មានផ្លូវថ្នល់ប្រវែង 14,000 ម៉ាយនៅពាសពេញចក្រភព។ នៅលើផ្លូវថ្នល់ទាំងអស់នេះ ក្រុមអ្នករត់សំបុត្រដែលគេហៅថា ឆាស់គីស បាននាំយកសំបុត្រទៅកាន់តំបន់នានានៅពាសពេញចក្រភព។ កងទ័ព និងការធ្វើពាណិជ្ជកម្មក៏ធ្វើដំណើរតាមផ្លូវនេះផងដែរ។

ការដួលរលំរបស់ពួកអ៊ីនកាក្រោមពួកអេស្ប៉ាញ៖ ពួកប្រជាជននៅអង់ដេសផ្សេងៗទៀតមិនអាចយកជ័យជំនះលើពួកអ៊ីនកាបានឡើយ។ កងទ័ពចំនួន 200,000 នាក់របស់ពួកគេមានភាពខ្លាំង, ទទួលបានការហ្វឹកហ្វឺន, និងមានអាវុធល្អៗ។ ប៉ុន្តែ ចក្រភពអ៊ីនកាបានធ្លាក់ចុះខ្សោយដោយភាពចលាចល។ នៅក្នុងសង្គ្រាមស៊ីវិលមួយដែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1527 មេដឹកនាំមួយរូបព្រះនាម អាតាហ៊ូអាលប៉ា បានយកជ័យជំនះលើព្រះរាមរបស់ទ្រង់។ សង្គ្រាមបានបញ្ចប់នៅពេលដែលហ្វង់ស៊ីស្កូ ពីហ្សារ៉ូ បានមកដល់តំបន់ឆ្នេរសមុទ្រអាមេរិកខាងត្បូងនៅក្នុងឆ្នាំ 1532 ។ ក៏ដូចជាពួកអាសទិចដែរ ពួកអ៊ីនកាមិនអាចប្រជែងជាមួយពួកអេស្ប៉ាញ ដែលកងទ័ពរបស់ពួកគេជិះសេះ, ពាក់ពាសដែក, និងប្រើប្រាស់អាវុធធ្វើពីដែក។ ពួកអេស្ប៉ាញក៏បាននាំយកមកនូវជំងឺថ្មីៗដែលបណ្តាលឱ្យពួកអ៊ីនកាស្លាប់អស់ជាច្រើន។ ពីហ្សារ៉ូ បានជួបជាមួយអាតាហ៊ូអាលប៉ា និងបានចាប់ទ្រង់ដាក់គុក និងក្រោយមកប្រហារជីវិតទ្រង់។ បន្ទាប់ពីការសោយទិវង្គត់របស់អាតាហ៊ូអាលប៉ា ចក្រភពអ៊ីនកាបានធ្លាក់ចុះ។ ពួកអេស្ប៉ាញបានធ្វើដំណើរទៅកាន់គូស្កូ នៅខណៈពេលដែលក្រុមប្រជាជននៅទីនោះងើបឡើងប្រឆាំងជាមួយអ្នកគ្រប់គ្រងអ៊ីនការបស់ពួកគេ។ ត្រឹមឆ្នាំ 1535 ពួកអេស្ប៉ាញត្រួតត្រាលើដែនដីអ៊ីកាស្ទើរតែទាំងស្រុង។ បន្តិចម្តងៗ ប្រជាជនអ៊ីនកាពាប់លាននាក់បានស្លាប់ដោយសារជំងឺរបស់ពួកអឺរ៉ុប។ មេដឹកនាំអ៊ីនកាចុងក្រោយបានចុះចាញ់នៅក្នុងឆ្នាំ 1572 ហើយចាប់ពីពេលនោះមកចក្រភពអ៊ីនកាបានបាត់បង់រូបរាង។

គូសបង្ហាញសេចក្តីសនិដ្ឋាន៖ ពន្យល់ពីរបៀបដែលពួកអ៊ីនកាស្ថាបនា និងរក្សាចក្រភពរបស់ពួកគេ។

# មេរៀនទី 3៖ ប្រជាជននៅអាមេរិកខាងជើង

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ មុនការមកដល់អាមេរិករបស់ពួកអឺរ៉ុប សង្គមស្មុកស្មាញមួយបានលេចឡើងនៅម៉ិចស៊ិចកូ និងអាមេរិកកណ្តាល និងអាមេរិកខាងត្បូង។ រឿងដូចគ្នានេះដែរក៏បានលេចឡើងនៅអាមេរិកខាងជើង បើទោះបីជាសង្គមនៅអាមេរិកខាងជើងមានទំហំតូច និងមានទីក្រុងតិចតួច។

## 1. អរិយធម៌ដំបូង

សំណួរគន្លឹះ៖ តើបច្ចេកវិទ្យាអ្វីខ្លះដែលប្រជាជនភាគខាងនិរតីបានអភិវឌ្ឍ?

អាមេរិកខាងជើងគឺជាមជ្ឈមណ្ឌលអរិយធម៌សំខាន់ៗដំបូងចំនួន 2 ។ អរិយធម៌ទាំង 2 នេះបានជះឥទ្ធិពលដល់សង្គមជនជាតិដើមអាមេរិកនាពេលក្រោយមកទៀត។

ភាគនិរតី៖ នៅក្នុងឆ្នាំប្រហែល 300 មុនគ.ស វប្បធម៌ហូហូកាំ បានរះឡើងតាមបណ្តោយទន្លេហ្គីឡា និងទន្លេអំបិលដែលបច្ចុប្បន្នស្ថិតនៅអារីហ្សូណា។ ស្ថិតនៅក្នុងបរិស្ថានស្ងួត និងដីគ្មានជីជាតិនេះ ពួកហូហូកាំបានអភិវឌ្ឍប្រព័ន្ធបង្ហូរទឹកដើម្បីស្រោចស្រពលើដំណាំរបស់ពួកគេ។ ពួកគេបានស្ថាបនាតំបន់ដើម្បីបង្វែរទឹកទៅកាន់ប្រព័ន្ធប្រឡាយទឹកធំៗ។ ប្រឡាយមួយចំនួនលាតសន្ធឹងចម្ងាយជាង 15 ម៉ាយទៅកាន់ចំការដំណាំរបស់ពួកហូហូកាំ។ រវាងឆ្នាំ 1350 និង 1450 ពួកហូហូកាំបានបោះបង់ទីលំនៅរបស់ពួកគេ ប្រហែលជាដោយសារគ្រោះរាំងស្ងួត។ វប្បធម៌អាណាសាហ្ស៊ីរះឡើងនៅឆ្នាំប្រហែល 400 នៅក្នុងតំបន់មួយដែលអ៊ូតា, ខូឡូរ៉ាដូ, ញ៉ូវម៉ិចស៊ិចកូ, និងអារីហ្សូណាជួបប្រសព្វគ្នា។ ពួកអាណាសាហ្ស៊ីគឺជាអ្នកបរបាញ់-បេះផ្លែឈើ និងកសិករ។ ពួកគេក៏ជាអ្នកជំនាញខាងត្បាញ និងផលិតភាជន៍ផងដែរ។ នៅឆ្នាំប្រមាណ 750 ពួកគេចាប់ផ្តើមស្ថាបនា ពូអេប្លូស។ ភូមិទាំងអស់នេះគឺជាបណ្តុំនៃសំណង់ធ្វើអំពើថ្ម ឬឥដ្ឋផៅ ដែលមានលក្ខណៈដូចគ្នាទៅនឹងអាគារផ្ទះល្វែងច្រើនជាន់។ ជាទូទៅ ជាន់ថ្មីនីមួយៗត្រូវបានសាងសង់ឡើងលៀនចេញពីលើជាន់ក្រោមបន្តិច ដើម្បីបង្កើតជារានហាល។

ក្រុមអ្នកស្ថាបនាពំនូក៖ ក្រុមអ្នកស្ថាបនាពំនូកដីដែលភាគច្រើនមកពីអាមេរិកភាគខាងលិច និងភាគអាគ្នេយ៍បានស្ថាបនាសំណង់ធ្វើពីដីធំៗ ដើម្បីធ្វើជាពំនូកផ្នូរ និងប្រាសាទ។ វប្បធម៌ស្ថាបនាពំនូកដីរួមមាន អាដេណា និងមីស៊ីស៊ីបពី។ វប្បធម៌អាដេណាចាប់ផ្តើមនៅប្រហែលឆ្នាំ 1000 មុនគ.ស និងវប្បធម៌មីស៊ីស៊ីបពីបែកខ្ញែកនៅត្រឹមឆ្នាំ 1550 នៃគ.ស។ គុណភាព និងទំហំនៃពំនូកដីបានបង្ហាញថានៅទីនោះមានសង្គមមានការរៀបចំខ្ពស់មួយ។

សង្ខេប៖ ពន្យល់ពីបច្ចេកវិទ្យាសំខាន់ៗមួយចំនួននៅភាគនិរតី។

## 2. សង្គមជនជាតិដើមអាមេរិកលូតលាស់

សំណួរគន្លឹះ៖ តើចំណីអាហារពឹងផ្អែកយ៉ាងដូចម្តេចលើទីតាំងភូមិសាស្ត្រនៅអាមេរិកខាងជើង?

សង្គម និងសាសនាជនជាតិដើមអាមេរិកទាំងអស់គឺផ្តោតសំខាន់លើធម្មជាតិ។ សង្គមនីមួយៗប្រើប្រាស់នូវអ្វីៗដែលនៅជុំវិញខ្លួនពួកគេដើម្បីរស់រានៈ ដីធ្លីក្នុងតំបន់, អាកាសធាតុ, និងធនធានដែលអាចស្វែងរកបាន។ ប្រជាជននៅក្នុងតំបន់ផ្សេងៗគ្នាប្រើប្រាស់នូវវិធីផ្សេងៗគ្នា។

ភាគពាយព្យ៖ នៅតំបន់ប៉ាស៊ីហ្វិកភាគពាយព្យ សង្គមជនជាតិដើមអាមេរិកភាគច្រើនជាសង្គមបរបាញ់-ប្រមូលផលក្នុងព្រៃ ជាពិសេសនៅតំបន់ឆ្នេរសមុទ្រ។ ធនធានអាហារមានច្រើនក្រៃលែង ដូច្នេះការដាំដុះមិនសូវជាចាំបាច់ឡើយ។ ពួកហៃដារស់នៅតំបន់ដែលបច្ចុប្បន្នពួកអឺរ៉ុបហៅថា កោះម្ចាស់ក្សត្រីឆាឡូតេ និងកោះព្រះអង្គម្ចាស់នៃប្រទេសវែល ដែលស្ថិតនៅចុងឆ្នេរសមុទ្រកាណាដា។ ពួកហៃដារស់នៅក្នុងតំបន់នេះអស់រយៈពេលប្រហែល 10,000 ឆ្នាំ។ ភាពសម្បូរបែបនៃត្រី, សត្វព្រៃ, រុក្ខជាតិដែលអាចបរិភោគបាន អាចចិញ្ចឹមពួកហៃដាបានប្រមាណ 18,000 នាក់មុនការមកដល់នៃពួកអឺរ៉ុប។ ជាមួយនឹងភាពងាយស្រួលនៅក្នុងការស្វែងរកចំណីអាហារ ពួកហៃដាអាចបង្កើតជំនាញនៅក្នុងវិស័យផ្សេងទៀត។ ពួកគេក្លាយជាសិល្បៈករ និងសិប្បករដ៏ល្បីល្បាញ។ ឧទាហរណ៍ ពួកគេបានស្ថាបនានាវាដែលមានការតុបតែងយ៉ាងស្រស់ស្អាត និងរឹងមាំ។ នាវាមួយចំនួនមានប្រវែង 70 ហ្វីត និងអាចផ្ទុកមនុស្សបានចំនួន 30 នាក់ ឬផ្ទុកទំនិញបានរាប់តោន។ នាវារបស់ពួកគេអនុញ្ញាតឱ្យពួកគេអាចធ្វើពាណិជ្ជកម្មទ្រង់ទ្រាយធំជាមួយសង្គមមួយចំនួននៅលើគោក។ នាវាហៃដារបស់ពួកគេផ្ទាល់ក៏មានតម្លៃខ្ពស់ និងត្រូវបានគេធ្វើពាណិជ្ជកម្មផងដែរ។ ពួកហៃដាប្រតិបត្តិពិធីបុណ្យមួយដែលគេស្គាល់ថា ផ្តល់អំណោយ។ ពិធីផ្តល់អំណោយជាទូទៅត្រូវបានគេប្រព្រឹត្តិទៅនៅក្នុងឱកាសមួយចំនួនដូចជាអាពាហ៍ពិពាហ៍ ឬកំណើត។ អ្នករៀបចំពិធីផ្តល់នូវការជប់លៀងដ៏ធំមួយ និងផ្តល់ឲ្យនូវទ្រព្យសម្បត្តិមួយភាគធំរបស់ពួកគេឱ្យទៅអ្នកដទៃ។

ការប្រារព្ធពិធីផ្តល់អំណោយដ៏ធំបានបង្ហាញថា អ្នករៀបចំគឺជាអ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ វាក៏បានបង្កើនឋានៈរបស់ពួកគេតាមរយៈការធានាថាមនុស្សជាច្រើននឹងឃើញទ្រព្យសម្បត្តិ និងចិត្តសប្បុរសរបស់ពួកគេ។

វាលទំនាបធំ៖ តំបន់ទំនាបធំលាតសន្ធឹងទៅភាគខាងជើងចាប់ពីតំបន់បច្ចុប្បន្នព្រំដែនរដ្ឋតិចសាស-ម៉ិចស៊ិចកូរហូតដល់កាណាដាភាគខាងត្បូង។ ចាប់ពីភាគខាងកើតដល់ខាងលិច តំបន់នេះលាតសន្ធឹងចាប់ពីទន្លេមីស៊ីស៊ីបពីរហូតដល់ជួរភ្នំរ៉ូឃី។ ជនជាតិដើមអាមេរិករស់នៅក្នុងតំបន់នេះអស់រយៈពេលរាប់ពាន់ឆ្នាំមុនពេលមានទំនាក់ទំនងជាមួយពួកអឺរ៉ុប។ ពួកគេភាគច្រើនជាកសិករដោយរស់នៅក្នុងភូមិ។ អ្នកមួយចំនួនទៀតដើរតាម និងបរបាញ់គោព្រៃ ឬក្របីដោយថ្មើរជើង។ សត្វសេះត្រូវបាននាំយកមកអាមេរិកដោយពួកអឺរ៉ុប បានក្លាយជារឿងទូទៅនៅតំបន់វាលទំនាបធំត្រឹមឆ្នាំ 1750 ។ ការមកដល់នៃសត្វសេះបានបណ្តាលឱ្យមានការផ្លាស់ប្តូរដ៏ធំមួយលើវប្បធម៌វាលទំនាបធំ។ ជាមួយនឹងការបរបាញ់សត្វគោព្រៃកាន់តែមានភាពងាយស្រួលដោយការប្រើប្រាស់សត្វសេះ ក្រុមកុលសម្ព័ន្ធជាច្រើនបានប្រើប្រាស់ជីវិតរស់នៅតាមរយៈការបរបាញ់បែបចរកជន។ ក្រុមនានាដែលបានផ្លាស់ទីមកកាន់វាលទំនាបធំដើម្បីរត់គេចពីការពង្រីកដែនដីរបស់ពួកអឺរ៉ុប ក៏បានប្រើប្រាស់ជីវិតរស់នៅបែបនេះដែរ។ ជាមួយការពឹងផ្អែករបស់ក្រុមកុលសម្ព័ន្ធជាច្រើនលើសត្វក្របីដើម្បីធ្វើជាចំណីអាហារ ទំនាក់ទំនងរវាងក្រុមទាំងនោះបានកើន

ឡើង។ នៅក្នុងរដូវក្តៅ សត្វក្របីបានប្រមូលផ្តុំគ្នានៅតំបន់វាលស្មៅដ៏ធំមួយ ដូច្នេះក្រុមកុលសម្ព័ន្ធជាច្រើនបានមកជួបជុំគ្នានៅពេលនោះ។

ទំនាក់ទំនងនេះបណ្តាលឱ្យមានវប្បធម៌តំបន់ទំនាបរួមមួយលេចរូបរាងឡើង។ ពាណិជ្ជកម្ម ជាពិសេសការធ្វើពាណិជ្ជកម្មសត្វសេះបានកើនឡើង។ ក្រោយមក សញ្ញាណភាសារួមមួយនៅវាលទំនាបធំបានអភិវឌ្ឍឡើង ដើម្បីជួយដល់ការធ្វើពាណិជ្ជកម្ម និងការធ្វើទំនាក់ទំនងទូទៅ។ មិនមានសាសនារួមតែមួយនៅតំបន់វាលទំនាបឡើយ ប៉ុន្តែសាសនាមួយចំនួនត្រូវបានគេប្រតិបត្តិដូចគ្នា។ ក្រុមភាគច្រើនជឿថាវត្ថុធម្មជាតិទាំងអស់មានវិញ្ញាណដែលអាចជួយ និងអន្តរាយដល់មនុស្ស។ ការប្រតិបត្តិការស្វែងរកចក្ខុវិស័យក៏បានរីករាលដាលក្នុងតំបន់ផងដែរ។ ការស្វែងរកចក្ខុវិស័យមួយជាទូទៅរួមបញ្ចូលការនៅដាច់ពីគេតែម្នាក់ឯង, តមអាហារ, និងការបន់ស្រន់ជាច្រើនថ្ងៃ។ នៅអំឡុងពេលនោះ មនុស្សដែលស្វែងរកចក្ខុវិស័យសង្ឃឹមនៅក្នុងការធ្វើទំនាក់ទំនងជាមួយពិភពវិញ្ញាណនៅក្នុងវិធីដ៏មានន័យមួយ អាចតាមរយៈសុបិន្តមួយ។

សង្គមតំបន់វាលទំនាបជាច្រើនប្រតិបត្តិរបាំព្រះអាទិត្យ ដែលជាពិធីបុណ្យពិសិដ្ឋមួយដែលរៀបចំឡើងនៅដើមរដូវក្តៅ។ ជាទូទៅ ការរាំរបាំបើក និងបិទពិធីត្រូវប្រើពេលជាច្រើនថ្ងៃ ខណៈពេលដែលអ្នកដ៏ទៃគោះស្គរ, ច្រៀង, និងបន់ស្រន់។ ការរាំរបាំជោគជ័យមួយនាំមកនូវសេចក្តីសុខដល់ប្រជាជន និងធានាដល់ភាពរុងរឿងនៅឆ្នាំបន្ទាប់។ របាំព្រះអាទិត្យនៅតែបន្តប្រតិបត្តិដោយសង្គមវាលទំនាបធំជាច្រើននាពេលបច្ចុប្បន្ន។

ភាគឦសាន៖ ខេត្តមួយចំនួនរបស់កាណាដាបច្ចុប្បន្ន ក្នុងនោះរួមមាន ញ៉ូវប្រ៊ុនស្វិក, កោះព្រះអង្គម្ចាស់អេដវ៉ាដ, និងណូវ៉ា ស្កូតៀ ជាទីលំនៅរបស់ប្រជាជនម៉ិចម៉ាក។ ក៏ដូចជាពួកហៃដានៅភាគពាយព្យដែរ ពួកម៉ិចម៉ាកអាចធ្វើការបរបាញ់ និងប្រមូលផលក្នុងព្រៃដោយសារភូមិសាស្ត្រនៅជុំវិញពួកគេ។ ពួកគេប្រើប្រាស់នូវអ្វីដែលធម្មជាតិបានផ្តល់ឱ្យពួកគេទៅតាមរដូវកាល។ នៅក្នុងរដូវរំហើយ និងរដូវក្តៅ ពួកគេបានផ្លាស់ទីទៅកាន់តំបន់ឆ្នេរដើម្បីចាប់ ឬចាក់ត្រី, ប្រមូលសំបកខ្ចៅខ្យង, ចាប់សត្វស្លាប, និងបរបាញ់សត្វឆ្មាទឹក។ នៅក្នុងរដូវស្លឹកឈើជ្រុះ ពួកគេបានផ្លាស់ទីទៅកាន់ដីខាងក្នុងដើម្បីចាប់សត្វអន្ទង់នៅក្នុងទន្លេ និងបរបាញ់សត្វរមាំង, សត្វគោរ, សត្វខ្លាឃ្មុំ, និងសត្វព្រៃផ្សេងៗទៀត។

សហព័ន្ធអ៊ីរ៉ូខល់ គ្របដណ្តប់នៅលើតំបន់បច្ចុប្បន្នស្ថិតនៅរដ្ឋញ៉ូវយក, បង្កើតឡើងដោយក្រុមកាយូហ្គា, ម៉ូហាក់, អូណៃដា, អូណាន់ដាហ្គា, និងសេនាកា។ វាត្រូវបានបង្កើតឡើងនៅអំឡុងឆ្នាំ 1400 ។ ក្រុមប្រឹក្សាជាន់ខ្ពស់របស់សហព័ន្ធត្រូវបានបង្កើតឡើងដោយគណៈប្រតិភូមកពីក្រុមកុលសម្ព័ន្ធចំនួន 5 ។ ក្រុមប្រឹក្សាដោះស្រាយទំនាស់រវាងសមាជិកក្រុម និងចចារជាមួយក្រុមខាងក្រៅ។ សមាជិកក្រុមប្រឹក្សាទាំងអស់គឺជាបុរស។ ប៉ុន្តែបុរសទាំងអស់នេះត្រូវបានជ្រើសរើស និងអាចត្រូវបានដកចេញដោយស្ត្រីចំណាស់នៅក្នុងកុលសម្ព័ន្ធ។ ក្រុមនានានៅក្នុងសហព័ន្ធអ៊ីរ៉ូខល់ភាគច្រើនជាអ្នកធ្វើកសិកម្ម។ ប្រជាជននៅទីនោះហៅដំណាំគោលទាំង 3 (ពោត, សណ្តែក, និងល្ពៅ) របស់ពួកគេថា បងប្អូនស្រី 3 នាក់។ ជាទូទៅ ស្ត្រីគឺជាអ្នកថែទាំដំណាំ, ខណៈពេលដែលបុរសធ្វើការបរបាញ់ និងនេសាទ។ សត្វព្រៃ និងអុសនៅជុំវិញទីលំនៅរបស់ក្រុមអ៊ីរ៉ូខល់មួយនឹងត្រូវបានប្រើប្រាស់បានក្នុងរយៈពេល 15

ឆ្នាំម្តង ។ ក៏ដូចគ្នាដែរ រ៉ែនៅក្នុងដីក៏នឹងត្រូវប្រើប្រាស់ក្នុងរយៈពេល 15 ឆ្នាំម្តង។ ដូច្នេះបុរសត្រូវបានគេបញ្ជូនឱ្យធ្វើដំណើរទៅស្វែងរកកន្លែងថ្មី។ នៅពេលដែលពួកគេរកឃើញ ពួកគេកាប់សម្អាតព្រៃ ឬគុម្ពោត ហើយប្រជាជនស្ថាបនាភូមិឡើងវិញនៅកន្លែងថ្មីនេះ។

ភាគអាគ្នេយ៍៖ តំបន់ដីខាងក្នុងដែលស្ថិតនៅភាគអាគ្នេយ៍គឺជាលំនៅឋានរបស់សង្គមបែបកសិកម្មដ៏ជោគជ័យមួយចំនួន។ ពួកគេបានដាំដុះដំណាំដែលពួកគេត្រូវការ ប៉ុន្តែពួកគេក៏បរបាញ់សត្វព្រៃជាច្រើនប្រភេទ ជាពិសេសសត្វក្តាន់។ ដែនដីមួយរបស់ក្រុមទាំងនេះគឺ ឆេរ៉ូគីបានគ្របដណ្តប់លើរដ្ឋ 8 របស់សហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ន ដោយលាតសន្ធឹងពីអាឡាបាម៉ាដល់វើជីនៀ។ ឆេរ៉ូគីត្រូវបានបែងចែកទៅជា 7 កុលសម្ព័ន្ធ។ ប្រជាជនត្រូវតែរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សនៅក្រៅកុលសម្ព័ន្ធរបស់ពួកគេ។ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ បុរសត្រូវប្តូរទៅរស់នៅក្នុងកុលសម្ព័ន្ធរបស់ប្រពន្ធ។ កូនរបស់ប្តីប្រពន្ធត្រូវកំណត់ថាជាផ្នែកមួយនៃកុលសម្ព័ន្ធរបស់ម្តាយ។ អត្តសញ្ញាណគ្រួសារផ្អែកសំខាន់លើគ្រួសាររបស់ម្តាយ ជាជាងគ្រួសាររបស់ឪពុក ដែលគេស្គាល់ថា មរតកខាងម្តាយ។

នៅក្នុងមួយឆ្នាំៗ នៅឆេរ៉ូគីមានប្រារព្ធពិធីបុណ្យជាច្រើន។ ពិធីដែលសំខាន់បំផុតគឺ ពិធីបុណ្យពោតបៃតងដែលជាសញ្ញាណនៃការចាប់ផ្តើមប្រមូលផលពោត។ ពិធីនេះក៏ពេលវេលានៃការបោទសួរ និងទទួលការអត់ឱនទោសសម្រាប់ការប្រព្រឹត្តិកំហុសរបស់នរណាម្នាក់កាលពីឆ្នាំកន្លងមក។ ជាទូទៅពិធីបុណ្យនេះតែងតែអមជាមួយការលេងល្បែងមួយដែលគេហៅថា វាយកូនបាល់។ ពួកឆេរ៉ូគីហៅល្បែងនេះថា "ប្អូនតូចនៃសង្គ្រាម" ដែលពាក្យដែលគេប្រើនៅពេលលេងល្បែងនេះភាគច្រើនជាពាក្យបែបហឹង្សា។ វាយកូនបាល់ក៏ត្រូវបានលេងដោយសមាជិកមួយចំនួននៅក្នុងសហព័ន្ធអ៊ីរ៉ូខល់ផងដែរ។

វាយតម្លៃ៖ ពន្យល់ពីរបៀបដែលចំណីអាហារ និងទីតាំងភូមិសាស្ត្រមានទំនាក់ទំនងជាមួយគ្នានៅអាមេរិកខាងជើង។

# ជំពូក 14 ៖ សន្តតិវង្សនៅក្នុងប្រទេសចិន

## មេរៀនទី 1 ៖ ការបង្រួបបង្រួមប្រទេសចិន

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើពាក្យអ្វីខ្លះដែលអ្នកនឹងប្រើវាដើម្បីពិពណ៌នាអំពីប្រទេសចិន។ តើនៅក្នុងបញ្ជីពាក្យរបស់អ្នកមានពាក្យ ធំ និងមហាអំណាច ដែរឬទេ? នៅក្នុងមេរៀននេះ អ្នកនឹងដឹងថាប្រទេសចិនគឺជាប្រទេសដែលធំ និងមានអំណាចតាំងពី 1,500 មុនមកម្លេះ។

### 1. ការដួលរលំនៃសន្តតិវង្សហាន

សំណួរគន្លឹះ៖ តើមានអ្វីកើតឡើងបន្ទាប់ពីការដួលរលំនៃសន្តតិវង្សហាននៅក្នុងឆ្នាំ 220 នៃគ.ស?

នៅក្នុងជំពូក 6 អ្នកបានដឹងមកហើយថា អំឡុងសម័យសន្តតិវង្សហាន ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 202 មុនគ.ស ប្រទេសចិនបានជួបប្រទះនូវបទពិសោធន៍នៃសម័យការជឿនលឿន និងរុងរឿងមួយ។ ប៉ុន្តែ ក្រោយមកដោយសារតែការប្រកួតប្រជែងនយោបាយ, បញ្ហាសង្គម, និងគម្លាតរវាងអ្នកមាន និងអ្នកក្រកាន់តែខ្ពស់បានធ្វើឱ្យសន្តតិវង្សហានធ្លាក់ចុះ។ សន្តតិវង្សនេះដួលរលំនៅក្នុងឆ្នាំ 220 នៃគ.ស។

ជម្លោះ និងភាពចលាចល៖ ពេលវេលានៃភាពច្របូកច្របល់ដ៏ធំមួយបានកើតមានឡើង។ ព្រះរាជាណាចក្រមួយចំនួនបានវាយប្រយុទ្ធគ្នាទៅវិញទៅមក។ ក្រុមអ្នកឈ្លានពានដែលជាពួកចរកជនស្ថិតនៅភាគខាងជើង បានឆ្លងកាត់តំបន់ខ្ពង់រាបម៉ុងហ្គោលីមកកាន់ចិនភាគខាងជើង (ពួកចរកជនគឺជាក្រុមមនុស្សដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ)។ ទឹកជំនន់, គ្រោះរាំងស្ងួត, កង្វះខាតចំណីអាហារ, និងការខូចនៃគុណភាពដី។ បើទោះបីជាមានបញ្ហាទាំងអស់នេះក៏ដោយ ក៏វប្បធម៌របស់ចិននៅបន្តរីកចម្រើនផងដែរ។ នៅភាគខាងជើង ក្រុមអ្នកឈ្លានពានចរកជនបន្តិចម្តងៗបានចាប់អារម្មណ៍ និងទទួលយកវប្បធម៌របស់ចិន។ នៅភាគខាងត្បូង ការទទួលបានទិន្នផលដំណាំល្អ និងការកើនឡើងនៃពាណិជ្ជកម្មបានជួយឱ្យប្រជាជនរស់នៅសមរម្យ។ បើទោះបីជាយ៉ាងនេះក៏ដោយ ប្រជាជនចិនភាគច្រើនរស់នៅក្នុងជីវភាពលំបាក។

វិភាគអំពីឥទ្ធិពល៖ កំណត់អំពីឥទ្ធិពលនៃការដួលរលំនៃសន្តតិវង្សហាននៅក្នុងប្រទេសចិន។

### 2. ការផ្លាស់ប្តូរប្រព័ន្ធជំនឿ

សំណួរគន្លឹះ៖ តើមានការផ្លាស់ប្តូរអ្វីនៅក្នុងប្រព័ន្ធជំនឿរបស់ចិន?

ភាពចលាចលបន្ទាប់ពីការដួលរលំនៃសន្តតិវង្សហាន បាននាំទៅដល់ការផ្លាស់ប្តូរដ៏សំខាន់ៗមួយនៅក្នុងប្រព័ន្ធជំនឿរបស់ប្រទេសចិន។ ការផ្លាស់ប្តូរនេះបានជះឥទ្ធិពលលើវិធីរបស់នៅរបស់ប្រជាជន។

ខុងជឺនិយម៖អស់រយៈពេលជាច្រើនសតវត្សរ៍ ប្រជាជនចិនបានសម្លឹងរកលទ្ធិខុងជឺសម្រាប់ជាការលើកទឹកចិត្ត និងជាមគ្គុទេសក៍។ ខុងជឺនិយមគឺជាប្រព័ន្ធជំនឿមួយដែលផ្អែកលើគំនិតរបស់ខុងជឺ (551-479 មុនគ.ស) ។ លោកគឺជាអ្នកប្រាជ្ញមួយរូបដែលបានបង្រៀនអំពីគុណធម៌ និងសីលធម៌ ដែលជាគំនិតពិចារណាអ្វីខុសអ្វីត្រូវ។

នៅក្នុងការបង្រៀនរបស់លោក ខុងជឺសង្កត់ធ្ងន់ទៅលើគោលការណ៍ទាំងនេះ៖ (1) ប្រើប្រាស់ទំនាក់ទំនងត្រឹមត្រូវដើម្បីបង្កើតសណ្តាប់ធ្នាប់សង្គម។ (2) គោរពគ្រួសារ និងអ្នកជំនាន់មុន។ (3) ធ្វើការអប់រំបុគ្គល និងសង្គម។ (4) អនុវត្តឱ្យត្រឹមត្រូវតាមសីលធម៌ ។

ខុងជឺនិយមជះឥទ្ធិពលលើជីវិតរស់នៅរបស់ប្រជាជនចិន៖ ខុងជឺនិយមបានជះឥទ្ធិពលលើទម្រង់ជាច្រើននៃរដ្ឋាភិបាល និងសង្គមចិន។ ឧទាហរណ៍ ខុងជឺបង្រៀនថា ប្រជាជនអាចធ្វើឱ្យជីវិតរបស់ខ្លួនខ្ពស់បានតាមរយៈការអប់រំ។ ការអះអាងមួយដែលថាការអប់រំជួយដល់ការបង្កើតមន្ត្រីរដ្ឋាភិបាលដែលមានប្រសិទ្ធភាព។ គំនិតរបស់ខុងជឺក៏ជះឥទ្ធិពលដល់សង្គមផងដែរ។ លោកគិតថាសង្គមគួរតែត្រូវបានរៀបចំឡើងនៃជុំវិញទំនាក់ទំនងសំខាន់ៗទាំង 5 ។ ក្រុមប្រតិបត្តិមួយគឺជាអ្នកចាត់ចែងទំនាក់ទំនងទាំងនេះ។ ឧទាហរណ៍ ទំនាក់ទំនងមួយគឺរវាងមេដឹកនាំ និងប្រជានុរាស្ត្រ។ ខុងជឺបង្រៀនថា មេដឹកនាំគួរតែមានគុណធម៌ និងចិត្តល្អ។ ប្រជានុរាស្ត្រគួរតែមានភក្តីភាព និងគោរពច្បាប់។ ទំនាក់ទំនងផ្សេងៗទៀតជាប់ទាក់ទងជាមួយគ្រួសារ។ ខុងជឺជឿថាកូនៗត្រូវតែគោរពឪពុកម្តាយ និងអ្នកជំនាន់មុនរបស់ពួកគេ។ ប៉ុន្តែ នៅរង្វង់ឆ្នាំ 200 នៃគ.ស ខុងជឺនិយមបានចាប់ផ្តើមបាត់បង់ឥទ្ធិពលរបស់ខ្លួនដូចដែលសន្តតិវង្សហានបានបាត់បង់អំណាចរបស់ខ្លួន។

ការរីកសាយភាយនៃពុទ្ធសាសនា៖ ដូចដែលខុងជឺនិយមបានធ្លាក់ចុះ ប្រជាជនចិនជាច្រើនបានត្រឡប់ទៅរកពុទ្ធសាសនា។ ពុទ្ធសាសនាគឺជាសាសនាមួយដែលចាប់ផ្តើមដំបូងនៅក្នុងប្រទេសឥណ្ឌា ហើយសាសនានេះផ្តោតសំខាន់លើការអប់រំរបស់ព្រះអង្គម្ចាស់សិទ្ធត្ថគោតម។ ទ្រង់រស់នៅអំឡុងឆ្នាំ 566 ដល់ 486 មុនគ.ស ដែលត្រូវបានគេស្គាល់ថាព្រះពុទ្ធ ឬ "អ្នកត្រាស់ដឹង" ។ ពុទ្ធសាសនាអប់រំគោលការណ៍ដូចតទៅ៖ (1) ភាពឈឺចាប់គឺជាផ្នែកមួយនៃជីវិត។ (2) មូលហេតុដែលមនុស្សឈឺចាប់គឺដោយសារតែពួកគេមានចំណង់លើទ្រព្យសម្បត្តិលាភសក្ការៈ ហួលហេតុ និងមានគំនិតអត្មានិយម។ (3) តាមរយៈការរស់នៅដោយឧត្តមគតិ, សីលធម៌, និងការគិតពិចារណា មនុស្សបន្តិចម្តងៗអាចរៀនពីវិធីគេចចេញពីភាគឈឺចាប់។

អំឡុងសតវត្សរ៍ទី 1 នៃគ.ស បេសកទូតសាសនា និងពាណិជ្ជករបានចាប់ផ្តើមនាំយកការអប់រំរបស់ព្រះពុទ្ធមកកាន់ប្រទេសចិន។ ក្រោយមក សាសនានេះក៏បានរីកសាយភាយទៅកាន់ប្រទេសកូរ៉េ និងប្រទេសជប៉ុនផងដែរ។ ពុទ្ធសាសនាត្រូវបានគេប្រតិបត្តិយ៉ាងទូលំទូលាយបន្ទាប់ពីការដួលរលំនៃសន្តតិវង្សហាន។ ការអប់រំរបស់ព្រះពុទ្ធបានជួយដល់ប្រជាជននៅក្នុងការតស៊ូជាមួយភាពឈឺចាប់បន្ទាប់ពីការដួលរលំនៃសន្តតិវង្សហាន។

ការជះឥទ្ធិពលលើខុងជឺនិយម៖ ខុងជឺនិយមចាប់ផ្តើមរស់ឡើងវិញម្តងទៀតនៅអំឡុងទសវត្សរ៍ឆ្នាំ 600 ។ ប៉ុន្តែ បានផ្លាស់ប្តូរបន្តិចម្តងៗបានកើតមានឡើងលើទ្រឹស្តីរបស់ខុងជឺ។ ពុទ្ធសាសនា និងតាវនិយមគឺជាដើមហេតុដែលនាំឱ្យមានការផ្លាស់ប្តូរនេះ។ តាវនិយមគឺជាប្រព័ន្ធជំនឿមួយដែលស្វែងរកសុខដុមជាមួយធម្មជាតិ និងជាមួយអារម្មណ៍ខាងក្នុង។ តាវនិយមចាប់ផ្តើមឡើងនៅក្នុងប្រទេសចិននៅក្នុងទសវត្សរ៍ឆ្នាំ 500 មុនគ.ស។ នៅអំឡុងសន្តតិវង្សហាន ទ្រឹស្តីខុងជឺនិយមភាគច្រើនផ្តោតសំខាន់លើសីលធម៌សង្គម និងគោលការណ៍នយោបាយ។

ក្រោយមក អំឡុងសន្តតិវង្សសុង ក្រុមទស្សនៈវិទូខុងជឺបានសាយបញ្ចូលពុទ្ធសាសនា និងតាវនិយមទៅក្នុងខុងជឺនិយម។ ជាលទ្ធផល ខុងជឺនិយមបានពង្រីកទស្សនរបស់ខ្លួន។

ការផ្លាស់ប្តូរនៅក្នុងទ្រឹស្តីខុងជឺ៖ ខុងជឺនិយមថ្មីជាប់ទាក់ទងច្រើនជាមួយឥរិយាបថរបស់មនុស្ស និងទំនាក់ទំនងរបស់មនុស្សម្នាក់ជាមួយចក្រវាល។ វាសង្កត់ធ្ងន់ទៅលើគោលការណ៍៖ (1) សីលធម៌គឺជាគោលដៅខ្ពស់បំផុតដែលមនុស្សម្នាក់អាចទៅដល់។ (2) សិលធម៌នេះអាចសម្រេចទៅបានតាមរយៈការអប់រំ។ (3) ការអប់រំអាចកើតមានឡើងតាមរយៈសៀវភៅ, ការអង្កេត, ឬធ្វើទំនាក់ទំនងជាមួយអ្នកដែលមានឧត្តមគតិដ៏ទៃទៀត។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីរបៀបដែលប្រព័ន្ធជំនឿរបស់ចិនបានផ្លាសប្តូរ។

## 3. សន្តតិវង្សសួយ និងសន្តតិវង្សតាងបង្រួបបង្រួមប្រទេសចិន

សំណួរគន្លឹះ៖ តើសន្តតិវង្សសួយ និងសន្តតិវង្សតាងបង្រួបបង្រួម និងពង្រឹងប្រទេសចិនដោយរបៀបណា?

បន្ទាប់ពីការដួលរលំនៃសន្តតិវង្សហាន ប្រជាជនបានតស៊ូជាមួយភាពចលាចល និងជម្លោះជាង 350 ឆ្នាំ។ ចុងក្រោយ សន្តតិវង្សសួយបានបង្រួបបង្រួមប្រទេសចិនឡើងវិញនៅក្នុងឆ្នាំ 589 និងនាំមកនូវសណ្តាប់ធ្នាប់ឡើងវិញ។ បង្រួបបង្រួមមានន័យថានាំយកមនុស្សមួយក្រុមឱ្យរួបរួមគ្នាបន្ទាប់ពីវាត្រូវបានបែកខ្ញែក។ សន្តតិវង្សសួយដឹកនាំប្រទេសចិនរហូតដល់ឆ្នាំ 618 ។

សន្តតិវង្សសួយ៖ ព្រះអង្គម្ចាស់យ៉ាងជានគឺជាស្ថាបនិកសន្តតិវង្សសួយ។ ទ្រង់គឺជាឧត្តមសេនីយ៍មួយរូបរបស់ចូវ ដែលជាអ្នកគ្រប់គ្រងនៅចិនភាគខាងជើង។ នៅក្នុងឆ្នាំ 581 ទ្រង់បានឡើងកាន់អំណាចតាមរយៈការសម្លាប់រាជទាយាទរបស់ចូវ។ បន្ទាប់មកទ្រង់បានសម្លាប់ខ្សែរាជវង្សអស់ចំនួន 59 ព្រះអង្គ។ ត្រឹមឆ្នាំ 589 ទ្រង់បានដណ្តើមកាន់កាប់ភាគខាងជើង និងបានបង្រួបបង្រួមប្រទេសចិន។ ទ្រង់បានប្រកាសខ្លួនទ្រង់ជាអធិរាជដំបូងរបស់សន្តតិវង្សសួយ។ ដោយក្រោយមកគេស្គាល់ទ្រង់ថា អធិរាជវេនទី។

ព្រះអង្គម្ចាស់វេនទីបង្រួបបង្រួមប្រទេសចិន៖ អំឡុងពេលនៃការដឹកនាំរបស់ទ្រង់ ព្រះអង្គម្ចាស់វេនទីបានធ្វើឱ្យប្រជាជនមានអារម្មណ៍ថាមានការបង្រួបបង្រួមច្រើនជាងមុន។ ទ្រង់បានស្តារទំនៀមទម្លាប់នយោបាយចាស់ដែលបានរម្លឹកប្រជាជនអំពីភាពរុងរឿងរបស់ពួកគេកាលពីអតីតកាល។ ឧទាហរណ៍ នៅពេលដែលទ្រង់ឡើងគ្រងអំណាច ទ្រង់បានទទួលប្រពៃណីនៃការផ្តល់តង្វាយទ្វាក្រហមដល់រាជដំណាក់របស់ទ្រង់ និងគ្រងខ្សែក្រវ៉ាត់ពណ៌ក្រហម។ វេនទីក៏បានកាត់បន្ថយជម្លោះតាមរយៈការអនុញ្ញាឱ្យប្រជាជនអាចប្រតិបត្តិជំនឿផ្ទាល់ខ្លួនរបស់ពួកគេ។ បើទោះបីទ្រង់ជាពុទ្ធសាសនិកក៏ដោយ ទ្រង់បានលើកកម្ពស់ជំនឿ និការប្រតិបត្តិបែបតាវនិយម។

ដូចដែលអ្នកបានអាននៅដើមដំបូង ខុងជឺនិយមក៏ទទួលបានការរស់រានឡើងវិញនៅអំឡុងសម័យនេះផងដែរ។ ឧទាហរណ៍ បេក្ខជនសម្រាប់ការងាររដ្ឋាភិបាលជាថ្មីម្តងទៀតត្រូវតែទទួលការប្រឡង។ ការប្រឡងទាក់ទងជាមួយជំនឿរបស់ខុងជឺ ដែលរដ្ឋាភិបាលត្រូវតែស្ថាបនាជំនាញដល់ប្រជាជនរបស់ពួកគេ។ វេនទីក៏បានចាប់ផ្តើមគម្រោងការងារសាធារណផងដែរ។ ទ្រង់បានស្ថាបនាឡើងវិញនូវផ្នែកមួយចំនួននៃមហាកំពែង ដែលអ្នកនឹងបាន

រៀនលម្អិតនៅទំព័រខាងមុខ។ ទ្រង់ក៏ជាអ្នកចាប់ផ្ដើមមហាប្រឡាយផងដែរ។ មហាប្រឡាយនេះបានភ្ជាប់ទន្លេលឿងជាមួយទន្លេយង់សេ ដែលជាការភ្ជាប់ទំនាក់ទំនងរវាងចិនភាគខាងជើង និងចិនភាគខាងត្បូង។ ប្រជាកសិកររាប់ពាន់នាក់បានចំណាយរយៈពេល 5 ឆ្នាំដើម្បីជីកមហាប្រឡាយនេះ។ ជិតពាក់កណ្ដាលនៃពួកគេបានស្លាប់អំឡុងពេលនៅការជីកនេះ។ ព្រះអង្គម្ចាស់វេនទី និងអ្នកបន្តតំណែងពីទ្រង់គឺព្រះអង្គម្ចាស់យ៉ាងទី បានបង្កើនពន្ធដើម្បីចំណាយលើគម្រោងទាំងអស់នេះ។ នៅពេលនោះ ប្រជាជនចិនមានការមិនសប្បាយចិត្តចំពោះការតំឡើងពន្ធ និងចាប់ផ្ដើមងើបឡើងបះបោរ។ ជាលទ្ធផល សន្តតិវង្សនេះបានដួលរលំបន្ទាប់ពីគ្រប់គ្រងបានតែ 37 ឆ្នាំប៉ុណ្ណោះ។

សន្តតិវង្សតាង៖ ទោះបីជាសន្តតិវង្សស៊ួយមានអាយុកាលខ្លីក៏ដោយ សន្តតិវង្សនេះគឺជាមូលដ្ឋានគ្រឹះរបស់សន្តតិវង្សតាង។ សន្តតិវង្សតាងចាប់ផ្ដើមឡើងនៅក្នុងឆ្នាំ 618 និងដឹកនាំប្រទេសចិនអស់រយៈពេលជិត 300 ឆ្នាំ។ អំឡុងសម័យនេះ ប្រទេសចិនបានពង្រីកព្រំដែនរបស់ខ្លួនគ្រប់ផ្នែកទាំងអស់។ ជាងនេះទៅទៀត អធិរាជតាងបានពង្រីកបណ្ដាញផ្លូវថ្នល់ និងប្រឡាយដើម្បីបង្រួបបង្រួមប្រទេស។ ពាណិជ្ជកម្មបានរីកចម្រើននៅតាមផ្លូវសូត្រ ហើយប្រទេសចិនបានបង្កើតទំនាក់ទំនងរឹងមាំមួយជាមួយភាគខាងលិច។ ចក្រភពដ៏ធំមួយត្រូវការមន្ត្រីជាច្រើនដើម្បីគ្រប់គ្រង។ ដូច្នេះអធិរាជតាងបានប្រើប្រាស់យ៉ាងពេញលេញនូវទស្សនខុងជឺពីរបៀបដែលរដ្ឋាភិបាលគួរធ្វើការ។ ក៏ដូចជាសន្តតិវង្សស៊ួយ ពួកគេបានប្រើប្រាស់ការប្រឡងថ្នាក់ជាតិដើម្បីស្វែងរកបុគ្គលដែលមានសមត្ថភាពដើម្បីធ្វើការក្នុងជួររដ្ឋាភិបាល។ ប្រព័ន្ធរដ្ឋាភិបាលតាងគឺជាប្រព័ន្ធរដ្ឋាភិបាល ដែលមានភាពជឿនលឿន និងស្មុគស្មាញបំផុតមួយនៅលើពិភពលោកនៅពេលនោះ។

អធិរាជរបស់តាង៖ ព្រះអង្គម្ចាស់តៃជុងបានជួយបិតារបស់ទ្រង់ព្រះអង្គម្ចាស់កៅជូ ដើម្បីបង្កើតសន្តតិវង្សតាង។ ព្រះអង្គម្ចាស់តៃជុងដណ្ដើមរាជបល្ល័ង្កនៅក្នុងឆ្នាំ 626 បន្ទាប់ពីទ្រង់បានសម្លាប់បងប្អូនរបស់ទ្រង់ចំនួន 2 ព្រះអង្គ និងរាជបុត្រាទាំង 10 ព្រះអង្គរបស់បងប្អូនទ្រង់។ បើទោះបីជាព្រះអង្គម្ចាស់តៃជុងប្រើប្រាស់ហឹង្សាដើម្បីឡើងកាន់អំណាចក៏ដោយ ប្រជាជនចិនជាច្រើនបានចាត់ទុកទ្រង់ថាជាមេដឹកនាំដែលយុត្តិធម៌ និងត្រឹមត្រូវ។ ឧទាហរណ៍ ទ្រង់មិនបានយកពន្ធខ្ពស់លើប្រជាកសិករឡើយ។ ទ្រង់ក៏បានយកដីធ្លីមួយចំនួនពីអ្នកមានប្រគល់ឱ្យប្រជាកសិករផងដែរ។ នៅក្នុងឆ្នាំ 690 ម្ចាស់ក្សត្រីវ៉ូចាវ បានប្រកាសខ្លួនទ្រង់ជាអធិរាជ។ ទ្រង់គឺជាម្ចាស់ក្សត្រីតែមួយរូបគត់ដែលមានឋានៈគ្រងរាជបល្ល័ង្កនៅក្នុងប្រទេសចិន។ ម្ចាស់ក្សត្រីវ៉ូចាវបានបង្ហាញខ្លួនថាជាក្សត្រីមានសមត្ថភាពមួយអង្គ។ ទ្រង់បានកាត់បន្ថយពន្ធ, កាត់ផ្ដាច់អំពើពុករលួយក្នុងរដ្ឋាភិបាល, និងគាំទ្រយ៉ាងខ្លាំងដល់ពុទ្ធសាសនានៅក្នុងប្រទេសចិន។ ទ្រង់នៅតែមិនទាន់ចេញពីតំណែងឡើងរហូតដល់ឆ្នាំ 705 នៅពេលដែលទ្រង់មានព្រះជន្មជាង 80 ព្រះវស្សា។

វប្បធម៌តាង៖ អំឡុងសន្តតិវង្សតាង អក្សរសិល្ប៍ និងសិល្បៈចិនបានរីកចម្រើនដល់កម្រិតខ្ពស់មួយ។ អំឡុងសម័យតាងត្រូវបានគេស្គាល់ច្បាស់តាមរយៈកវីនិពន្ធដ៏ប៉ិនប្រសព្វ និងរស់រវើក។ បុរសទាំងឡាយដែលចាត់ទុកខ្លួនគេថាជាសុភាពបុរស តែងមានមោទនភាពចំពោះសមត្ថភាពរបស់គេក្នុងការសរសេរកំណាព្យ។ ប្រវត្តិវិទូប៉ាន់

ប្រមាណថាមានករីចំនួនជាង 2,000 រស់នៅអំឡុងសម័យតាង។ កំណាព្យរបស់ពួកគេជិត 50,000 នៅបន្សល់ទុករហូតមកដល់បច្ចុប្បន្ន។ ចម្លាក់សម័យតាងមានភាពសមសួន។ សិល្បៈករបានលាបពណ៌លើរូបចម្លាក់ដីឥដ្ឋជាមួយនឹងថ្នាំលាបពណ៌ក្រហម, បៃតង, និងស។ មុខរបស់សត្វនានាត្រូវបានគេឆ្លាក់យ៉ាងល្អប្រសើរដែលមានភាពងាយស្រួលក្នុងការសំគាត់ថាជាសត្វអ្វី។ សត្វដែលគេឆ្លាក់ជាទូទៅគឺសត្វអូដ និងសេះ។ ដោយសារតែភាពស្រស់ស្អាត ស្នាដៃទាំងអស់នេះគឺជាទំនិញពាណិជ្ជកម្មដែលមានតម្លៃ។ ជាងនេះទៅទៀត ប្រជាជនតែងតែដាក់រូបចម្លាក់នៅក្នុងផ្នូររបស់សាច់ញាតិរបស់ពួកគេ។ នៅក្នុងមេរៀនបន្ទាប់ អ្នកនឹងបានសិក្សាលម្អិតអំពីការអភិវឌ្ឍនៃចក្រភពរបស់ចិន។ ជាងនេះទៅទៀត អ្នកនឹងបានសិក្សាអំពីការភិវឌ្ឍកសិកម្ម, បច្ចេកវិទ្យា, និងពាណិជ្ជកម្មក្នុងប្រទេសចិន។

កំណាត់បញ្ហា និងដំណោះស្រាយ៖ រៀបរាប់ពីវិធីសាស្ត្រដែលសន្តតិវង្សសួយ និងសន្តតិវង្សតាងប្រើដើម្បីបង្រួបបង្រួម និងពង្រឹងប្រទេសចិន។

# មេរៀនទី 2 ៖ ការរីកចម្រើននៅក្នុងសម័យថាំង និងសុង

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលមេរៀនទី 1 បានពន្យល់ សន្តតិវង្សស្វួយបានបង្រួបបង្រួមប្រទេសចិន។ នៅក្នុងឆ្នាំ 618 សន្តតិវង្សតាងបានបន្តអំណាចពីសន្តតិវង្សស្វួយ។ មេដឹកនាំតាងប្រឈមជាមួយការងារថែរក្សាប្រទេសចិនឱ្យបន្តរួបរួមគ្នា។ ពួកគេក៏មានបំណងនៅក្នុងការពង្រីកអំណាចលើដែនដីដែលពួកគេដណ្តើមកាន់កាប់បាន។

## 1. ការស្តារនាឡើងវិញ/ការស្ថាបនារដ្ឋចក្រពត្តិ

សំណួរគន្លឹះ៖ តើរដ្ឋាភិបាលចិនត្រូវបានរៀបចំយ៉ាងដូចម្តេចអំឡុងនៃការគ្រប់គ្រងរបស់សន្តតិវង្សតាង និងសន្តតិវង្សសុង ?

ដឹកនាំប្រទេសធំមួយដូចជាប្រទេសចិនគឺជាកិច្ចការដ៏លំបាកមួយ។ ដើម្បីដឹកនាំប្រកបដោយប្រសិទ្ធភាពមេដឹកនាំតាងបានអភិវឌ្ឍរដ្ឋបែបចក្រពត្តិមួយ។ ចក្រពត្តិមានន័យដូចគ្នាទៅនឹងចក្រភពមួយ។ តាងបានប្រើប្រាស់នូវទស្សនមួយចំនួន ដែលពួកគេបានរៀនពីសន្តតិវង្សស្វួយដើម្បីបង្កើតស្ថាប័នរដ្ឋាភិបាលដែលមានរបៀប និងដំណើរការល្អមួយ។ ភាគច្រើន ស្ថាប័នរដ្ឋាភិបាល និងយោធារបស់តាងយកលំនាំតាមស្វួយ។ ជាងនេះទៅទៀតតាងបានប្រើប្រាស់ប្រព័ន្ធពន្ធរបស់ស្វួយ។ សូម្បីតែរាជធានីក៏ពួកគេយករាជធានីឆាងអានរបស់ស្វួយធ្វើជារាជធានីរបស់ពួកគេផងដែរ។ ឆាងអានមានសារៈសំខាន់ដោយសារតែវាមានទីតាំងស្ថិតនៅលើផ្លូវពាណិជ្ជសំខាន់ៗ។

រដ្ឋាភិបាលចិន៖ រដ្ឋាភិបាលរបស់តាងមានលក្ខណៈដូចជាពីរ៉ាមីត។ អធិរាជមួយអង្គដឹកនាំនៅពីលើ និងមានមនុស្សជាច្រើនបម្រើការងារជាច្រើនកម្រិតនៅពីក្រោមទ្រង់។ ប្រមុខទីប្រឹក្សារបស់អធិរាជធ្វើការជាមួយទ្រង់ដោយផ្ទាល់។ ពួកគេគឺជាមនុស្សដែលខ្ពស់លំដាប់ទី 2 នៃពីរ៉ាមីត។ នៅពីក្រោមទីប្រឹក្សាទាំងនេះគឺការិយាធិបតេយ្យ។ ការិយាធិបតេយ្យមួយគឺជារដ្ឋាភិបាលមួយដែលត្រូវបានគេបែងចែកទៅជានាយកដ្ឋាន។ នាយកដ្ឋាននីមួយៗនៅក្នុងប្រទេសចិនទទួលខុសត្រូវលើកិច្ចការជាក់លាក់មួយ, ក្នុងនោះមានដូចជាពន្ធដារ, កសិកម្ម, ឬកងទ័ព។ ប្រព័ន្ធនយោបាយនេះត្រូវបានប្រើប្រាស់នៅពាសពេញប្រទេសចិន។ រដ្ឋាភិបាលក្នុងតំបន់នៅក្នុងប្រទេសចិនទាំងមូលត្រូវតែសរសេររបាយការណ៍មកកាន់ការិយាធិបតេយ្យកណ្តាល។

ក្រមច្បាប់មួយ៖ មេដឹកនាំតាងបានបង្កើតក្រមច្បាប់ថ្មីមួយ។ ក្រមច្បាប់នេះបានរៀបរាប់អំពីច្បាប់ទាំងអស់នៅក្នុងប្រទេសចិន ដូច្នេះច្បាស់ដូចគ្នាតែមួយនឹងត្រូវប្រើប្រាស់នៅគ្រប់ទីកន្លែងទាំងអស់។ ក្រមថ្មីនេះបានបង្ហាញពីប្រសិទ្ធភាពខ្ពស់មួយ។ ប្រទេសចិនបានប្រើក្រមច្បាប់នេះចាប់ពីឆ្នាំប្រមាណ 624 រហូតដល់ចុងទសវត្សរ៍ឆ្នាំ 1200 ។

មន្ត្រី-អ្នកប្រាជ្ញ៖ តាងត្រូវការអប់រំមនុស្សដើម្បីធ្វើការនៅក្នុងការិយាធិបតេយ្យ។ សម្រាប់ការងារជាច្រើននៅក្នុងការិយាធិបតេយ្យ ប្រជាជនត្រូវតែធ្វើការប្រឡងមួយដែលរៀបចំដោយរដ្ឋាភិបាល។ សន្តតិវង្សហាន និងសន្តតិវង្សស្វួយក៏បានរៀបចំការប្រឡងសម្រាប់អ្នកស្វែងរកការងារ ប៉ុន្តែមេដឹកនាំតាងបានពង្រីកប្រព័ន្ធនេះឲ្យកាន់តែប្រសើរ។

ការប្រឡងថ្នាក់ជាតិបានសាកល្បងពីចំណេះដឹងទស្សនខុងជឺ, និងមុខវិជ្ជាផ្សេងៗទៀត។ ការប្រឡងនេះមានរយៈពេលវែង និងលំបាក។ មនុស្សភាគច្រើនបានធ្លាក់នៅក្នុងការប្រឡងនេះ។ មនុស្សម្នាក់ដែលប្រឡងជាប់ថ្នាក់ជាតិអាចក្លាយជាមន្ត្រី-អ្នកប្រាជ្ញមួយរូប ដែលជាមនុស្សចេះដឹងមួយរូបទទួលបានតំណែងមួយនៅក្នុងរដ្ឋាភិបាល។ ស្ទើរតែគ្រប់មន្ត្រី-អ្នកប្រាជ្ញទាំងអស់មកពីវណ្ណៈជាន់ខ្ពស់។ ក្រុមអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភភាគច្រើនបានសាច់ញាតិធ្វើការក្នុងជួររដ្ឋាភិបាល ហើយសាច់ញាតិទាំងនោះជារឿយៗបានជួយគ្នាទៅវិញទៅមកដើម្បីទទួលបានការងារ។ ជាទូទៅ មានតែគ្រួសារអ្នកមានប៉ុណ្ណោះដែលអ្នកបំពេញនូវតម្រូវការអប់រំដើម្បីប្រឡងជាប់។

សន្តតិវង្សសុង៖ បន្ទាប់ពីសន្តតិវង្សតាង សន្តតិវង្សសុងបានដឹកនាំប្រទេសចិនចាប់ពីឆ្នាំ 960 ដល់ឆ្នាំ 1279 ។ សន្តតិវង្សសុងបានពង្រីក និងធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធប្រឡង។ សន្តតិវង្សនេះបានបង្កើតសាលាច្រើនជាងមុន និងបានផ្លាស់ប្តូរមុខវិជ្ជាប្រឡងដោយផ្តោតសំខាន់ទៅលើមុខវិជ្ជាអនុវត្តច្រើនជាងមុន។ មនុស្សកាន់តែច្រើនបានចូលរួមការប្រឡង, ប្រឡងជាប់, និងទទួលបានការងាររដ្ឋាភិបាល។ បើទោះបីជាដូច្នេះក៏ដោយ មន្ត្រីរដ្ឋាភិបាលភាគច្រើននៅតែបន្តមកពីគ្រួសារអ្នកមានជាមួយនឹងឥទ្ធិពលនយោបាយ។

ស្វែងរកគំនិតសំខាន់៖ ពីពណ៌នាអំពីរបៀបដែលរដ្ឋាភិបាលចិនត្រូវបានរៀបចំឡើងនៅអំឡុងសន្តតិវង្សតាង និងសន្តតិវង្សសុង។

## 2. ភាពរុងរឿងពីការធ្វើពាណិជ្ជកម្ម និងការដាំដុះ

សំណួរគន្លឹះ៖ តើសេដ្ឋកិច្ចរបស់ប្រទេសចិនផ្លាស់ប្តូរយ៉ាងដូចម្តេចអំឡុងសម័យតាង និងសុង?

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សន្តតិវង្សតាង និងសន្តតិវង្សសុង សេដ្ឋកិច្ចរបស់ប្រទេសចិនបានកើនឡើង។ តាមពិត ប្រទេសចិនបានក្លាយជាប្រទេសដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភបំផុត និងមានការអភិវឌ្ឍបំផុតនៅលើពិភពលោក។ កត្តាសំខាន់មួយដែលបណ្តាលឱ្យមានការរីកចម្រើននេះគឺការលើកកម្ពស់ប្រព័ន្ធគមនាគមន៍។

ការផ្លាស់ប្តូរក្នុងការធ្វើដំណើរ និងពាណិជ្ជកម្ម៖ រដ្ឋាភិបាលតាង និងសុងបានស្ថាបនាផ្លូវថ្នល់ និងផ្លូវទឹកជាច្រើន។ ប្រព័ន្ធគមនាគមន៍នេះបានជួយផ្សារភ្ជាប់ចក្រភពចិនឱ្យនៅជាមួយគ្នា។ ប្រព័ន្ធគមនាគមន៍ល្អប្រសើរបានលើកកម្ពស់ពាណិជ្ជកម្ម។ ពាណិជ្ជករប្រើប្រាស់ផ្លូវថ្នល់ថ្មីៗដើម្បីដឹកជញ្ជូនគ្រាប់ធុញ្ញជាតិ, តែ, និងទំនិញផ្សេងៗទៀត។ នៅតាមផ្លូវថ្នល់មានផ្ទះសំណាក់ដែលក្រុមអ្នកធ្វើដំណើរអាចស្នាក់នៅបាន។ អ្នកនាំសារដោយយានជំនិះ និងដោយថ្មើរជើងបាននាំយកសំបុត្រតាមផ្លូវថ្នល់ ដែលបានលើកកម្ពស់ការធ្វើទំនាក់ទំនងយ៉ាងល្អប្រសើរ។

ផ្លូវទឹកក៏មានសារៈសំខាន់ផងដែរ។ រដ្ឋាភិបាលបានជួសជុលប្រឡាយចាស់ៗ និងស្ថាបនាប្រឡាយថ្មីដើម្បីភ្ជាប់ទន្លេសំខាន់ៗ។ លទ្ធផលនៃការលើកកម្ពស់ផ្លូវទឹកបានផ្តល់នូវវិធីដ៏មានប្រសិទ្ធភាពមួយនៅក្នុងការដឹកជញ្ជូនទំនិញ និងប្រជាជន។ ពាណិជ្ជកម្មត្រូវបានលើកកម្ពស់ដោយសារការអភិវឌ្ឍនៃបច្ចេកវិទ្យាមួយចំនួន ដោយក្នុងនោះរួមមាននាវាដឹកជញ្ជូនដ៏ធំមួយដែលដំណើរការដោយចែវ និងក្តោង។ នាវាមួយចំនួនធ្វើដំណើរនៅក្នុងសមុទ្រ

បានឆាប់រហ័ស និងសុវត្ថិភាព។ ការអភិវឌ្ឍនៃត្រីវស័យម៉ាញេទិច ក៏ដូចគ្នាដែរ បានលើកកម្ពស់ការធ្វើដំណើរនៅលើលំហសមុទ្ទ។

ការផ្លាស់ប្តូរនៅក្នុងវិស័យកសិកម្ម៖ នៅរង្វង់ឆ្នាំ 1000 នៃគ.ស ប្រជាកសិករចិនបានចាប់ផ្តើមដាំដុះស្រូវមួយប្រភេទថ្មីដែលមានប្រភពមកពីអាស៊ីអាគ្នេយ៍។ ស្រូវនេះទុំលឿនជាងប្រភេទស្រូវដែលធ្លាប់ដាំដុះកន្លងមក។ ជាមួយនឹងស្រូវថ្មីនេះ ប្រជាកសិករអាចដាំដុះដំណាំចំនួន 2 ឬសូម្បីតែ 3 មុខក្នុងមួយឆ្នាំ។ ការផ្គត់ផ្គង់ចំណីអាហារត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ដែលនាំឱ្យមានកំណើនប្រជាជនរហូតដល់ប្រមាណ 100 លាននាក់។ អំឡុងសម័យតាង និងសុង ប្រជាជនចិនបានប្រែក្លាយតំបន់នានានៅតាមជ្រឡងទន្លេយ៉ង់សេឱ្យក្លាយទៅជាតំបន់ដាំដុះស្រូវដែលមានទិន្នផលខ្ពស់។ ប្រជាកសិករប្រើប្រាស់ប្រដាប់បូម និងប្រឡាយដើម្បីបង្ហូរទឹកចេញពីវាលភក់។ ពួកគេបានកាត់ជម្រាលភ្នំជាថ្នាក់ៗ និងបានប្រើប្រាស់ប្រព័ន្ធធារាស្ត្រដើម្បីនាំយកទឹកទៅកាន់ទីនោះ។ តាមរយៈការផ្លាស់ប្តូរបរិស្ថាន ប្រជាកសិករចិនទទួលបានផ្ទៃដីសម្រាប់ធ្វើដាំដំណាំ។ ដីបន្ថែមនេះអនុញ្ញាតឱ្យពួកគេអាចដាំដុះស្រូវបានកាន់តែច្រើនបន្ថែមទៀត។ ការផ្លាស់ប្តូរនេះ និងអាកាសធាតុក្តៅល្មមអនុញ្ញាតឱ្យចិនភាគខាងត្បូងអាចដាំដុះស្រូវបានច្រើនជាងតម្រូវរបស់ប្រជាជននៅក្នុងតំបន់។ ប្រជាកសិករបានលក់ស្រូវលើសរបស់ពួកគេដល់ពាណិជ្ជករ ដោយពួកគេបានដឹកស្រូវទាំងនេះតាមប្រឡាយទៅកាន់មជ្ឈមណ្ឌលរបស់អាណាចក្រដែលស្ថិតនៅចិនភាគខាងជើង។ ទទួលបានចំណីអាហារលើសមានន័យថាមនុស្សតិចតួចប៉ុណ្ណោះដែលត្រូវការងារក្នុងវិស័យដាំដុះ។ ជាលទ្ធផល មនុស្សជាច្រើនអាចធ្វើការងារក្នុងវិស័យពាណិជ្ជកម្ម។

ការផ្លាស់ប្តូរក្នុងវិស័យពាណិជ្ជកម្ម៖ ត្រឹមសម័យសន្តតិវង្សសុង ពាណិជ្ជកម្មមានការរីកចម្រើននៅក្នុងប្រទេសចិន។ នាវា និងនាវាដឹកទំនិញនានាបានដឹកជញ្ជូនទំនិញតាមប្រឡាយ និងទន្លេ និងតាមតំបន់ឆ្នេរនៃប្រទេសចិន។ ពួកគេក៏បាននាំយកចំណីអាហារ និងផលិតផលផ្សេងៗទៀតរបស់ចិនទៅកាន់ដែនដីបរទេស មានដូចជាប្រទេសកូរ៉េ និងជប៉ុនជាដើម។ ការរីកចម្រើននៃពាណិជ្ជកម្មបាននាំទៅដល់ការពង្រីកយ៉ាងឆាប់រហ័សនៃការប្រើប្រាស់លុយនៅក្នុងទម្រង់ជាកាក់ដើម្បីបង់ថ្លៃទំនិញ។ ប៉ុន្តែ កាក់ក្នុងចំនួនច្រើនមានទម្ងន់ធ្ងន់ដែលមានភាពលំបាកនៅក្នុងនាំយកតាមខ្លួន។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលតាង និងសុងចាប់ផ្តើមបោះពុម្ពក្រដាស់ប្រាក់។ ពួកគេជារដ្ឋាភិបាលដំបូងនៅក្នុងប្រវត្តិសាស្ត្រដែលបានបោះពុម្ពក្រដាស់ប្រាក់។ ដូចដែលពាណិជ្ជកម្មបានកើនឡើង មនុស្សកាន់តែច្រើនបានក្លាយជាពាណិជ្ជករ។ វណ្ណៈពាណិជ្ជករចិនភាគច្រើនរស់នៅក្នុងទីក្រុង ឬទីប្រជុំជននានា ជាទីកន្លែងដែលពាណិជ្ជកម្មឯកជនភាគច្រើនត្រូវបានគេធ្វើ។ ទីក្រុងនានាបានរីកឡើង និងរុងរឿង។ ត្រឹមសម័យសុង ប្រទេសចិនមានទីក្រុងមួយចំនួនដែលមានប្រជាជនរស់នៅប្រមាន 1,000,000 នាក់។ ផ្ទុយទៅវិញ ទីក្រុងប៉ារីស ដែលជាទីក្រុងធំបំផុតមួយនៅអឺរ៉ុបមានប្រជាជនតែ 150,000 នាកក់ប៉ុណ្ណោះ។

វិភាគពីឥទ្ធិពល៖ ពន្យល់ពីរបៀបដែលសេដ្ឋកិច្ចផ្លាស់ប្តូរនៅអំឡុងសម័យសន្តតិវង្សតាង និងសន្តតិវង្សសុង។

### 3. ពេលវេលានៃភាពជោគជ័យដ៏អស្ចារ្យ

សំណួរគន្លឹះ៖ តើការអភិវឌ្ឍបច្ចេកវិទ្យាអ្វីខ្លះដែលត្រូវបានធ្វើឡើងនៅអំឡុងសន្តតិវង្សតាង និងសន្តតិវង្សសុង?

សន្តតិវង្សតាង និងសន្តតិវង្សសុងស្ថិតនៅក្នុងសម័យការឆ្នៃប្រឌិតបំផុងនៅក្នុងប្រវត្តិសាស្ត្រដ៏វែងឆ្ងាយរបស់ប្រទេសចិន។ ជាពិសេសកំណាព្យ និងសិល្បៈបានរីកដុះដាលនៅអំឡុងសម័យនេះ។

យុគមាសនៃកំណាព្យ និងសិល្បៈ៖ អ្នកនិពន្ធតាងចំនួន 3 រូបរួមមាន៖ លីពៃ, ទូហ្វូ, និងវ៉ាងវ៉េ ត្រូវបានគេចាត់ទុកថាជាកវីឆ្នើមបំផុតក្នុងចំណោមកវីរបស់ចិន។ លីពៃសរសេរអំពីភាពរីករាយនៃជីវិត។ ទូហ្វូលើកសរសើរពីសណ្តាប់ធ្នាប់ និងតម្លៃខុងជឺ។ និងវ៉ាងវ៉េសរសេរអំពីសម្រស់នៃធម្មជាតិ និងភាពមិនឋិតថេរនៃជីវិត។ សិល្បៈករតាងក៏ត្រូវបានគេស្គាល់តាមរយៈការផលិតនូវរូបចម្លាក់ធ្វើពីដីជិតដ៏ស្រស់ស្អាតផងដែរ។ អំឡុងសម័យសុង គំនូរទេសភាពបានក្លាយជាទម្រង់សិល្បៈដ៏សំខាន់មួយ។ វិចិត្រករសុងបានប្រើប្រាស់ទឹកខ្មៅតែមួយមុខ នៅក្នុងកម្រិតពណ៌ទាំងអស់ចាប់ពីពណ៌ប្រផេះស្លេករហូតដល់ពណ៌ខ្មៅដុតខ្លាំង។ ដូចដែលវិចិត្រករសុងមួយរូបបានកត់សំគាល់ថា "ខ្មៅមានដប់ពណ៌"។ បច្ចុប្បន្ន រូបចម្លាក់ធ្វើពីដីដុតរបស់តាង និងគំនូរទេសភាពរបស់សុងអាចត្រូវបានរកឃើញនៅក្នុងសារមន្ទីរនានានៅជុំវិញពិភពលោក។

ក្រដាស់ និងការបោះពុម្ព៖ អំឡុងសម័យហាន ចិនបានចាប់ផ្តើមបង្កើតក្រដាស់ចេញពីសសៃសំបកឈើ។ ក្រដាស់មានភាពងាយស្រួលនៅក្នុងការសរសេរជាបន្ទះឬស្សី ឬសូត្រដែលមានតម្លៃថ្លៃ។ ដូចដែលចក្រភពរបស់តាង និងសុងរីកចម្រើន និងសកម្មភាពពាណិជ្ជកម្មត្រូវបានពង្រីក រដ្ឋាភិបាលត្រូវការកត់ត្រាកាន់តែច្រើន។ ដូច្នេះចិនបានចាប់ផ្តើមបង្កើត និងប្រើប្រាស់ក្រដាស់នៅក្នុងបរិមាណច្រើន។ ចិនបានប្រើប្រាស់ពុម្ពបន្ទះឈើដើម្បីបោះពុម្ព។ ឧបករណ៍បោះពុម្ពត្រូវបានគេឆ្លាក់នៅលើបន្ទះឈើជាមួយនឹងទំហំសមល្មមសម្រាប់បោះពុម្ពលើក្រដាស់មួយទំព័រ។ ក្រោយមកឧបករណ៍បោះពុម្ពនៅអាស៊ីបូព៌ាត្រូវបានគេបង្កើតឡើងដោយអាចដោះដូរបាន។ តាមរយៈការប្រើប្រាស់ក្រដាស់ និងឧបរណ៍បោះពុម្ព ចិនអាចបោះពុម្ពសៀវភៅបានកាន់តែងាយ។ សៀវភៅពេញលេញចាស់បំផុតត្រូវបានបោះពុម្ពនៅក្នុងប្រទេសនៅក្នុងឆ្នាំ 868 ។ វាគឺជាបណ្តុំនៃពាក្យទូន្មានរបស់ព្រះពុទ្ធដែលគេហៅថា សូត្រពេជ្រ។

កាំភ្លើង និងត្រីវិស័យ៖ បច្ចេកវិទ្យាចិនមានឥទ្ធិពលជាសកល។ ការបង្កើតមួយដ៏សំខាន់បំផុតរបស់ចិនគឺរំសេវ។ ចិនបានប្រើប្រាស់វាជាដំបូងសម្រាប់ធ្វើកាំជ្រួច និងភ្លើងសញ្ញា និងក្រោយមកពួកគេបានប្រើប្រាស់វាធ្វើជាអាវុធ។ ឧទាហរណ៍ ពួកគេចងកញ្ចប់រំសេវទៅនឹងគ្រាប់ព្រួញ។ បន្ទាប់ពីពួកគេរុំគ្រាប់ព្រួញជាមួយគ្នា និងបានបាញ់វាទៅលើសត្រូវ។ ការប្រើប្រាស់រំសេវបានរីករាលដាលពាសពេញតំបន់អាស៊ី និងអឺរ៉ុប។ ក្រោយមក មនុស្សបានប្រើប្រាស់រំសេវដើម្បីអភិវឌ្ឍអាវុធថ្មីក្នុងនោះមានដូចជាកាំភ្លើងធំ និងកាំភ្លើងដៃ។ គ្រាប់កាំភ្លើងធំអាចទម្លុះជញ្ជាំងបន្ទាយ និងគ្រាប់កាំភ្លើងអាចបាញ់ទៅត្រង់តាមរយៈកាណុង។ សព្វាវុធទាំងនេះបានធ្វើឲ្យសង្គ្រាមកាន់តែសាហាវ។

ត្រីវិស័យម៉ាញេទិចបានធ្វើឱ្យការធ្វើដំណើរតាមសមុទ្រមានសុវត្ថិភាពជាងមុន។ ចិនរកឃើញថាសសៃម៉ាញេទិចមួយអណ្តែតនៅក្នុងចានទឹកមួយតែងតែចង្អុលទៅទិសខាងជើង និងខាងត្បូង។ នេះគឺជាការប្រើប្រាស់ត្រីវិស័យម៉ាញេទិចដំបូងនៅលើនាវា។ តាមរយៈការប្រើប្រាស់វា សំពៅរបស់ចិនអាចធ្វើដំណើរពាសពេញតំបន់

អាស៊ី។ នៅក្នុងទសវត្សរ៍ឆ្នាំ 1300 ពួកគេបានធ្វើដំណើតរហូតទៅដល់អាហ្វ្រិក។ ចំណេះដឹងអំពីត្រីវិស័យម៉ាញេទិច ជួយឱ្យយុគសម័យនៃការរុករកនៅអឺរ៉ុបកើតមានឡើងបាន។ អ្នកនឹងរៀនអំពីរឿងនេះនៅក្នុងជំពូក 18 ។

ព័រហ្សឺឡែន និងតែ៖ ចិនបានជះឥទ្ធិពលលើការរស់នៅប្រចាំថ្ងៃតាមរយៈការនាំចេញព័រហ្សឺឡែន និងតែទៅកាន់ពីភាពលោក។ ព័រហ្សឺឡែនគឺជាសេរ៉ាមិចពណ៌សដ៏រឹងមួយដែលជារឿយៗគេហៅថាចិន។ ប្រជាជនចូលចិត្តព័រហ្សឺឡែនដោយសារភាពស្រស់ស្អាតរបស់វា។ វាបានក្លាយជាទំនិញនាំចេញដ៏មានតម្លៃបំផុតមួយរបស់ប្រទេសចិន។ អស់រយៈពេលជាច្រើនសតវត្សរ៍ ចិនបានប្រើប្រាស់តែធ្វើជាឱសថមួយ។ អំឡុងសម័យតាង វាបានក្លាយជាភេសជ្ជៈពេញនិយមមួយ។ ក្រោយមក ពាណិជ្ជករបាននាំយកតែពីអាស៊ីបូព៌ាទៅកាន់អឺរ៉ុប។ តែបានក្លាយជាទំនិញសំខាន់មួយសម្រាប់ការធ្វើពាណិជ្ជកម្មនៅក្នុងទីផ្សារអន្តរជាតិ។ បើទោះបីជាប្រទេសចិនមានការអភិវឌ្ឍយ៉ាងល្អប្រសើរក៏ដោយ ប្រទេសនេះនៅតែប្រឈមជាមួយគ្រោះថ្នាក់ពីសំណាក់ពួកចរកជន។ នៅក្នុងទសវត្សរ៍ឆ្នាំ 1200 មេដឹកនាំនៃពួកចរកជនទាំងនេះឈ្មោះសង់ ស៊ីខាន់ បានក្លាយជាអ្នកឈ្លានពានដ៏ជោគជ័យបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។

សង្ខេប៖ កំណត់អំពីការអភិវឌ្ឍបច្ចេកវិទ្យាដែលត្រូវបានធ្វើឡើងនៅក្នុងសម័យតាង និងសុង។

# មេរៀនទី 3 ៖ ចក្រភពម៉ុងហ្គោល

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានអាននៅក្នុងមេរៀនទី 1 ពួកចរកជនមកពីភាគខាងជើង បានធ្វើការឈ្លានពានប្រទេសចិន នៅពេលដែលសន្តតិវង្សហានដួលរលំ។ នៅក្នុងទសវត្សរ៍ឆ្នាំ 1200 ក្រុងអ្នកក្រៅមួយក្រុមជាថ្មីម្តងទៀតធ្វើការឈ្លានពានមកលើប្រទេសចិន។ លើកនេះ អ្នកដែលឈ្លានពានគឺពួកម៉ុងហ្គោល។

## 1. ការឈ្លានពានរបស់ម៉ុងហ្គោល

សំណួរគន្លឹះ៖ តើចក្រភពម៉ុងហ្គោលមានទីតាំងស្ថិតនៅកន្លែងណា?

ពួកម៉ុងហ្គោល គឺជាក្រុងអ្នកប្រយុទ្ធចរកជនដ៏សាហាវមួយដែលរស់នៅតំបន់វាលទំនាបដ៏ធំមួយភាគពាយព្យនៃប្រទេសចិន។ នៅក្នុងទសវត្សរ៍ឆ្នាំ 1200 ពួកគេបានឈ្លានបាន និងដណ្តើមកាន់កាប់ប្រទេសចិន។

មេដឹកនាំដ៏អស្ចារ្យមួយរូប៖ ពួកម៉ុងហ្គោលរស់នៅជាលក្ខណៈក្រុមគ្រួសារឯករាជ្យមួយដែលគេហៅថាក្រុម។ ក្រុមទាំងនេះបានចូលរួមជាមួយគ្នាបង្កើតបានទៅជាកុលសម្ព័ន្ធមួយចំនួន។ កុលសម្ព័ន្ធទាំងនេះឯករាជ្យពីគ្នាទៅវិញទៅមក។ ប៉ុន្តែ នៅរង្វង់ឆ្នាំ 1206 មេដឹកនាំដ៏ខ្លាំងក្លាមួយរូបឈ្មោះ តេមូជីន បានបង្រួបបង្រួមកុលសម្ព័ន្ធម៉ុងហ្គោលទាំងអស់នេះ។ ម្តងមួយៗ ទ្រង់បានវាយប្រយុទ្ធ និងយកជ័យជំនះលើគូរសត្រូវដើម្បីធ្វើជាមេដឹកនាំទាំងអស់របស់ទ្រង់ ។ តាមរយៈការធ្វើដូច្នេះត្រូវបានក្លាយជា ខាន់ ឬអ្នកដឹកនាំនៃពួកម៉ុងហ្គោលទាំងអស់។ ទ្រង់បានប្រើឈ្មោះ សង់ស៊ី ខាន់ ដែលមានន័យថា "អ្នកដឹកនាំចក្រវាល"។ សង់ស៊ី ខាន់ បានរៀបចំក្រុមអ្នកប្រយុទ្ធម៉ុងហ្គោលទៅជាកងកម្លាំងប្រយុទ្ធដ៏ខ្លាំងក្លាមួយ និងចាប់ផ្តើមយុទ្ធនាការនៃការឈ្លានពានមួយ។ សង់ស៊ី ខាន់គឺជាអ្នកមានជំនាញខាងយុទ្ធសាស្ត្រដ៏ប៉ិនប្រសព្វមួយរូប ដោយទ្រង់បានប្រើប្រាស់ល្បិច និងយុទ្ធសាស្ត្របំភិតបំភ័យដោយអំពើភេរវកម្មដើម្បីធ្វើឱ្យសត្រូវច្របូកច្របល់។ ទ្រង់បានឈ្លានពានចិនភាគខាងជើង បន្ទាប់មកធ្វើដំណើរឆ្ពោះទៅភាគខាងលិចឆ្លងកាត់តំបន់អាស៊ីកណ្តាល។ នៅក្នុងប្រវត្តិសាស្ត្រ ក្រុមចរកជនជារឿយៗមានឃោជាមួយដែលមានប្រៀបជាងក្រុមប្រជាជនដែលតាំងទីលំនៅនៅមួយកន្លែង។ ក្រុមអ្នកតាំងទីលំនៅព្យាយាមនៅក្នុងការការពារទីក្រុង និងទីប្រជុំជនរបស់ពួកគេ។ ប៉ុន្តែ ពួកចរកជនបានផ្លាស់ទីយ៉ាងឆាប់រហ័ស ស្វែងរកចំណុចខ្សោយ វាយប្រហារ និងផ្លាស់ទីបន្តទៀត។ ការធ្វើដូច្នេះធ្វើឱ្យពួកគេទទួលបានជោគជ័យនៅក្នុងសង្គ្រាម។ ត្រឹមឆ្នាំ 1227 ពួកម៉ុងហ្គោលបានដណ្តើមកាន់កាប់តំបន់អាស៊ីកណ្តាលទាំងមូល។

ចក្រភពម៉ុងហ្គោល៖ នៅពេលដែលសង់ស៊ី ខាន់សុគតនៅក្នុងឆ្នាំ 1227 រាជបុត្រា និងចៅប្រុសរបស់ទ្រង់បានបន្តដឹកនាំការឈ្លានពាន។ ពីភាគខាងជើង និងខាងកើត ពួកគេបានដណ្តើមកាន់កាប់ប្រទេសចិនភាគខាងជើងទាំងស្រុង និងប្រទេសកូរ៉េទាំងមូល។ បន្ទាប់មក ពួកគេបានធ្វើដំណើរទៅភាគខាងលិចឆ្លងកាត់អាស៊ីទៅកាន់ប្រទេសរុស្ស៊ី និងអឺរ៉ុបខាងកើត។ ចុងក្រោយ ពួកគេបានធ្វើដំណើរមកភាគខាងត្បូង និងត្រួតត្រាលើពែក្ស។ មានតែការវាយប្រហារលើប្រទេសជប៉ុន និងផ្នែកខ្លះនៃអាស៊ីអាគ្នេយ៍ទេដែលមិនទទួលបានជោគជ័យ។ ត្រឹមឆ្នាំ 1279 ម៉ុយហ្គោលបានគ្រប់គ្រងលើដែនដីចក្រភពបង្រួបបង្រួមដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រ។ ដើម្បីគ្រប់គ្រងតំបន់ដ៏ធំ

នេះ ពួកម៉ុងហ្គោលបានបែងចែកវាទៅជា 4 ភូមិភាគ។ ភូមិភាគនីមួយៗត្រូវបានគេហៅថា ខាណាតេ ដែលត្រូវបានគ្រប់គ្រងដោយបច្ចាជនមួយរូបរបស់សង់ស៊ី ខាន់។

សង្ខេប៖ កំណត់អំពីតំបន់នានាដែលស្ថិតនៅក្នុងចក្រភពម៉ុងហ្គោល។

## 2. រដ្ឋាភិបាលម៉ុងហ្គោល

សំណួរគន្លឹះ៖ តើម៉ុងហ្គោលរក្សារបៀបត្រួតត្រារបស់ចិនយ៉ាងដូចម្ដេចខ្លះ?

ចៅប្រុសរបស់សង់ស៊ី ខាន់ ព្រះនាម គូប៊ីឡៃ ខាន់ ទទួលបានការគ្រប់គ្រងខាណាតេនរបស់អធិរាជខាន់។ ខាណាតេនេះគឺមានតម្លៃជាងគេក្នុងចំណោមខាណាតេទាំង 4 ដោយសារវារួមបញ្ចូលដែនដីចិន។ គូប៊ីឡៃ ខាន់គឺជាមេដឹកនាំដំបូងក្នុងចំណោមមេដឹកនាំម៉ុងហ្គោលដែលគ្រប់គ្រងប្រទេសចិនអស់រយៈពេល 300 ឆ្នាំ។ ជាងនេះទៅទៀត មិនធ្លាប់ដែលមានមហាអំណាចបរទេសណាធ្លាប់ត្រួតត្រាលើប្រទេសចិនឡើយរហូតមកទាល់នឹងការដណ្ដើមកាន់កាប់របស់ម៉ុងហ្គោល។ គូប៊ីឡៃ ខាន់ដឹកនាំរយៈពេល 15 ឆ្នាំមុនពេលដែលទ្រង់សុគតនៅក្នុងឆ្នាំ 1294។

ការរៀនសូត្រដើម្បីគ្រប់គ្រង៖ ពួកម៉ុងហ្គោលមិនមានបទពិសោធន៍ច្រើនជាមួយនឹងស្ថាប័នរដ្ឋាភិបាលផ្លូវការមួយឡើយ។ ផ្ទុយទៅវិញ ចិនមានប្រវត្តិដ៏យូរលង់មកហើយនៅក្នុងការរៀបចំរដ្ឋាភិបាល។ ដូច្នេះ គូប៊ីឡៃ ខាន់បានរក្សាទុកមួយភាគធំនូវទម្រង់នៃការគ្រប់គ្រងរបស់ចិន។ ដោយប្រើប្រាស់នូវបែបបទរដ្ឋាភិបាលដែលខ្លួនស្គាល់ច្បាស់ ធ្វើឱ្យការត្រួតត្រាប្រទេសចិនមានភាពងាយស្រួលសម្រាប់ពួកម៉ុងហ្គោល។ គូប៊ីឡៃ ខាន់បានផ្លាស់ប្ដូររាជធានីទៅកាន់ពៃជីង និងស្ថាបនានាវានៅក្នុងរចនាបថបែបប្រពៃណីចិន។ ទ្រង់បានប្រកាសខ្លួនទ្រង់ថាជាអធិរាជ ហើយនៅក្នុងឆ្នាំ 1279 ទ្រង់បានបង្កើតសន្តតិវង្សថ្មីមួយគឺសន្តតិវង្សយ័ន។

ការរក្សាការត្រួតត្រា៖ គូប៊ីឡៃ ខាន់បានរក្សាទុកនូវទ្រង់ទ្រាយដើមនៃទម្រង់រដ្ឋាភិបាលចិន។ ប៉ុន្តែ ទ្រង់ធ្វើឱ្យប្រាកដថា អ្នកនយោបាយចិននឹងមិនទទួលបានអំណាចច្រើនពេកឡើយ។ ទ្រង់រក្សាការត្រួតត្រាប្រទេសចិនឲ្យស្ថិតនៅក្រោមដៃរបស់ម៉ុងហ្គោល។ ទ្រង់បានបញ្ចប់ការប្រឡងថ្នាក់ជាតិដើម្បីជ្រើសរើសមន្ត្រីរាជការ។ ជំនួសមកវិញ ទ្រង់បានប្រគល់ការងារសំខាន់នៅក្នុងជួររដ្ឋាភិបាលដល់ជនជាតិម៉ុងហ្គោល ឬដល់ជនបរទេសដែលពួកគេជឿជាក់។ ពួកម៉ុងហ្គោលជឿថា ជនបរទេសទាំងនេះអាចគួរទុកចិត្តបានជាងជនជាតិចិន ដោយសារពួកបរទេសមិនមានភក្ដីភាពជាមួយប្រជាជនក្នុងតំបន់ឡើយ។ មន្ត្រីចិនត្រូវបានពួកម៉ុងហ្គោលប្រគល់តំណែងតិចតួចឱ្យប៉ុណ្ណោះ។ ភាគច្រើននៃការងារនេះស្ថិតនៅក្នុងកម្រិតតំបន់ និងមានអំណាចតិចតួច។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយ ទស្សនខុងជឺនៅតែមានឥទ្ធិពលខ្លាំងអំឡុងសម័យនៃការគ្រប់គ្រងរបស់ម៉ុងហ្គោល។ មន្ត្រីម៉ុងហ្គោលបានប្រើប្រាស់នូវយុទ្ធសាស្ត្រខុងជឺក្នុងការគ្រប់គ្រងរដ្ឋាភិបាល។ ជាងនេះទៅទៀត គូប៊ីឡៃ ខាន់បានចាត់តាំងអ្នកប្រាជ្ញខុងជឺឱ្យបង្រៀនកូនប្រុសរបស់ពួកអភិជនម៉ុងហ្គោល។

ពាណិជ្ជកម្មរបស់ម៉ុងហ្គោល៖ បើទោះបីជាទ្រង់មិនមែនជាជនជាតិចិនក៏ដោយ គូប៊ីឡៃ ខាន់គឺជាមេដឹកនាំមានសមត្ថភាពមួយរូប។ ទ្រង់បានធ្វើការងារដើម្បីស្ថាបនាប្រទេសចិនឡើងវិញបន្ទាប់ពីឆ្លងកាត់សង្គ្រាមអស់ជា

ច្រើនឆ្នាំ។ ទ្រង់បានស្តារឡើងវិញនូវមហាប្រឡាយ និងបានពង្រីកវាប្រវែង 135 ម៉ាយទៅភាគខាងជើងទៅកាន់ទីក្រុងពៃជីង។ ហើយទ្រង់បានស្ថាបនាផ្លូវហាយវេមួយដែលមានប្រវែងជាង 1,100 ម៉ាយ និងបានភ្ជាប់ពៃជីងទៅកាន់ហាងចូវ។ ផ្លូវគោក និងផ្លូវទឹកទាំងនេះបានធ្វើឱ្យការធ្វើដំណើររវាងភាគខាងជើង និងភាគខាងត្បូងកាន់តែមានភាពងាយស្រួល។ ពាណិជ្ជកម្មរវាងភូមិភាគទាំងពីរបានកើនឡើង។ ជាពិសេស ប្រជាកសិករនៅតំបន់ដីមានជីជាតិភាគខាងត្បូងបានលក់គ្រាប់ធុញ្ញជាតិកាន់តែច្រើនទៅកាន់ប្រជាជននៅភាគខាងជើង។ គូប៊ីឡៃ ខាន់ក៏បានធ្វើការផ្លាស់ប្តូរមួយចំនួនដែលបានជួយលើកកម្ពស់ពាណិជ្ជកម្ម និងទំនាក់ទំនងជាមួយផ្នែកផ្សេងៗទៀតនៅលើពិភពលោក។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីវិធីដែលម៉ុងហ្គោលរក្សារបៀបត្រួតត្រានៅក្នុងប្រទេសចិន។

## 3. ការបើកប្រទេសចិនទៅកាន់ពិភពលោក

សំណួរគន្លឹះ៖ តើម៉ុងហ្គោលលើកកម្ពស់ពាណិជ្ជកម្មដោយរបៀបណា?

អំឡុងពេលនៃការគ្រប់គ្រងរបស់គូប៊ីឡៃ ខាន់ ប្រទេសចិនបានបើកចំហរទ្វាសម្រាប់ពិភពលោក។ ពួកម៉ុងហ្គោលបានអភិវឌ្ឍពាណិជ្ជតាមផ្លូវសមុទ្ធដ៏រីកចម្រើនមួយ និងបានស្វាគមន៍ក្រុមអ្នកទស្សនាអន្តរជាតិ។

ផ្លូវពាណិជ្ជកម្ម៖ ម៉ុងហ្គោលបានលើកកម្ពស់ការធ្វើពាណិជ្ជកម្មតាមរយៈការការពារដល់ក្រុមអ្នកធ្វើដំណើរ។ កាលពីអតីតកាល ប្រទេសចិនពេលខ្លះបានបិទការធ្វើពាណិជ្ជកម្មតាមផ្លូវគោកដោយសារតែសង្គ្រាម និងចោរប្លន់។ ប៉ុន្តែឥឡូវនេះម៉ុងហ្គោលត្រួតត្រាតំបន់ទាំងអស់នៅអាស៊ីកណ្តាល។ ការត្រួតត្រារបស់ម៉ុងហ្គោលបានធ្វើឱ្យការធ្វើដំណើរតាមផ្លូវគោកមានសុវត្ថិភាព។ អំឡុងសម័យកាលនេះចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1200 រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1300 ពេលខ្លះត្រូវបានគេហៅថា សន្តិភាពម៉ុងហ្គោល។ ក្បួនដឹកជញ្ជូនបានធ្វើដំណើរឆ្លងកាត់ផ្លូវសូត្រ ដែលជាផ្លូវពាណិជ្ជកម្មបុរាណលាតសន្ធឹងពីប្រទេសចិនរហូតដល់សមុទ្រខ្មៅ។ ពួកពាណិជ្ជករបាននាំយកសូត្រ, ព័រហ្សឺឡែន, តែ, និងទំនិញផ្សេងៗទៀតទៅកាន់អាស៊ីខាងលិច និងអឺរ៉ុប។ ពួកពាណិជ្ជករបានយកត្រឡប់មកវិញនូវចំណីអាហារថ្មីៗ, រុក្ខជាតិ, និងរ៉ែផ្សេងៗ។ ម៉ុងហ្គោលក៏បានលើកកម្ពស់ការធ្វើពាណិជ្ជកម្មតាមផ្លូវសមុទ្ធជាមួយប្រទេសនានាដែលមានទីតាំងនៅមហាសមុទ្ទឥណ្ឌា និងសមុទ្ទចិនខាងត្បូង។ ពាណិជ្ជករនៅកំពង់ផែរបស់ចិនបានធ្វើពាណិជ្ជកម្មលើទំនិញនានាយ៉ាងរស់រវើកទាំងជាមួយភាគខាងកើត និងភាគខាងលិច។ ទស្សន និងការបង្កើតថ្មី ដូចជារំសេវបានធ្វើដំណើរអមជាមួយទំនិញផ្សេងៗទៀត។ ការបង្កើតថ្មីរបស់ចិនបានធ្វើដំណើរទៅដល់អឺរ៉ុប, ផ្នែកខ្លះនៃអាស៊ី, និងអាហ្រ្វិកអំឡុងសម័យកាលនេះ។

ទំនាក់ទំនងជាមួយបរទេស៖ ពាណិជ្ជកម្មបាននាំមកនូវកំណើននៃទំនាក់ទំនងជាមួយប្រជាជន និងវប្បធម៌បរទេស។ ប្រជាជនដែលមកពីអារ៉ាប់, ពែក្ស, និងឥណ្ឌាជាញឹកញយបានធ្វើដំណើរមកទស្សនាប្រទេសចិន។ អ្នកការទូតនានាដូចជាពួកអឺរ៉ុបជាដើមបានធ្វើដំណើរដ៏វែងឆ្ងាយមួយមកកាន់ប្រទេសចិន។ ក្រុមអ្នកមកទស្សនាទាំងអស់នេះបានជួយចែកចាយព័ត៌មានអំពីស្នាដៃនៃអរិយធម៌ចិន។ អ្នកតំណាងនិកាយសាសនាជាច្រើនក៏បានមកទស្សនាប្រទេសចិនផងដែរ។ គូប៊ីឡៃ ខាន់មានចំណាប់អារម្មណ៍ចំពោះពុទ្ធសាសនា ប៉ុន្តែទ្រង់ស្វាគមន៍មនុស្ស

មកពីគ្រប់ជំនឿទាំងអស់។ ទ្រង់បានអញ្ជើញគ្រីស្តសាសនិក, ម៊ូស្លីម, និងពុទ្ធសាសនិកមកកាន់រាជធានីរបស់ទ្រង់។ ទ្រង់ចង់ឱ្យពួកគេពន្យល់ពីទស្សនសាសនារបស់ពួកគេ។ អ្នកទស្សនាអឺរ៉ុបដែលល្បីល្បាញបំផុតនៅអំឡុងសម័យនេះគឺ ម៉ាកូ ប៉ូឡូ ដែលជាឈ្មួញវ័យក្មេងមួយរូបមកពីទីក្រុងវេនីសប្រទេសអ៊ីតាលី បានធ្វើដំណើរតាមផ្លូវសូត្រជាមួយឪពុក និងឪពុកមារបស់លោក។ លោកបានមកដល់ប្រទេសចិននៅវង្វង់ឆ្នាំ 1275 និងបានស្នាក់នៅទីនោះអស់រយៈពេល 17 ឆ្នាំ។ ប៉ូឡូបានក្លាយជាជំនួយការរបស់គូប៊ីឡៃ ខាន់ និងបានធ្វើដំណើរនៅពាសពេញប្រទេសចិនតាមរយៈបេសកកម្មរបស់រដ្ឋាភិបាល។ ក្រោយមកលោកបានបោះពុម្ពសៀវភៅមួយក្បាលអំពីដំណើរផ្សេងព្រេងរបស់លោក។ សៀវភៅរបស់ប៉ូឡូគឺជាជ័យជំនះដ៏អស្ចារ្យមួយ។ ប៉ុន្តែ ប្រជាជនអឺរ៉ុបជាច្រើនយល់ថាសាច់រឿងរបស់លោកអំពីប្រទេសចិនពិបាកនៅក្នុងការជឿណាស់។ បើទោះបីជាចក្រភពរបស់គូប៊ីឡៃ ខាន់មានភាពរឹងមាំក៏ដោយ ចក្រភពនេះមិនមានអាយុកាលវែងឡើយបន្ទាប់ពីការសោយទីវង្គត់របស់ទ្រង់។ ក្នុងរយៈពេលតិចជាងកន្លះសតវត្សរ៍ ចិនបានទម្លាក់ពួកម៉ុងហ្គោល និងបានស្ថាបនាចក្រភពចិនមួយឡើងវិញ។

សង្ខេប៖ ពិពណ៌នាអំពីវិធីដែលម៉ុងហ្គោលលើកកម្ពស់ការធ្វើពាណិជ្ជកម្ម។

# មេរៀនទី 4៖ ការត្រឡប់ទៅរកការគ្រប់គ្រងរបស់ចិនវិញ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ចិនមានមោទនភាពជាមួយនឹងប្រវត្តិសាស្ត្រនៃភាពជោគជ័យដ៏វែងឆ្ងាយរបស់ពួកគេ។ ពួកគេជាច្រើនមិនសប្បាយចិត្តជាមួយនឹងការគ្រប់គ្រងរបស់ពួកម៉ុងហ្គោលឡើយ។

## 1. ការទម្លាក់ពួកម៉ុងហ្គោល

សំណួរគន្លឹះ៖ តើសន្តតិវង្សមីុងផ្លាស់ប្តូរប្រទេសចិនដោយរបៀបណា?

បន្ទាប់ពីគូប៊ីឡៃ ខាន់សុគតនៅក្នុងឆ្នាំ 1294 អំណាចគ្រប់គ្រងរបស់ម៉ុងហ្គោលចាប់ផ្តើមធ្លាក់ចុះបន្តិចម្តងៗ។ នៅក្នុងឆ្នាំ 1368 កងទ័ពបះបោរមួយក្រុមបានទម្លាក់អំណាចរបស់អធិរាជម៉ុងហ្គោល។ កងទ័ពនេះដឹកនាំដោយជូយ័នចាង។

អធិរាជមីុងដំបូង៖ ជូយ័នចាងបានបង្កើតសន្តតិវង្សមីុងនៅក្នុងឆ្នាំ 1368 និងបានក្លាយជាអធិរាជដំបូងរបស់មីុងក្រោមព្រះនាមថាហុងវ៉ូ។ ទ្រង់បានលើកកម្ពស់ខុងជឺនិយម និងនាំមកវិញនូវការប្រឡងថ្នាក់ជាតិ។ ដើម្បីជួយដល់ការធ្វើពាណិជ្ជកម្ម ទ្រង់បានស្ថាបភាពផ្លូវ និងប្រឡាយឡើងវិញ។ ជាងនេះទៅទៀត ទ្រង់បានស្ថាបនាឡើងវិញ និងពង្រីកមហាកំពែង ដើម្បីលើកកម្ពស់ការការពារប្រទេសចិន។ ហុងវ៉ូក៏បានជួយប្រជាកសិករតាមរយៈការបន្ថយការយកពន្ធ និងផ្តល់ឱ្យពួកគេនូវដីធ្លីសម្រាប់ដាំដុះ។ ប៉ុន្តែ ហុងវ៉ូចាប់ផ្តើមបង្កើនអំណាចផ្ទាល់ខ្លួនរបស់ទ្រង់។ ទ្រង់បានដកចេញនូវតួនាទីនាយករដ្ឋមន្ត្រី និងបានត្រួតត្រាការិយាល័យរដ្ឋាភិបាលទាំងអស់។ ទ្រង់បានធ្វើសេចក្តីចិត្តទាំងអស់ដោយខ្លួនទ្រង់ផ្ទាល់ដោយមិនមានការប្រឹក្សាយោបល់ជាមួយទីប្រឹក្សារបស់ទ្រង់ឡើយ។ ទ្រង់បានបង្កើតអង្គការសម្ងាត់មួយដើម្បីធ្វើចារកកិច្ចលើប្រជាជន។ ជាងនេះទៅទៀត ទ្រង់បានចាប់ខ្លួនមួយរាប់មឺុននាក់សម្រាប់ទង្វើក្បត់ និងបានសម្លាប់ពួកគេចោល។

ការគ្រប់គ្រងរបស់យ៉ុងលឺ៖ ហុងវ៉ូសុគតនៅក្នុងឆ្នាំ 1398 ។ ទ្រង់បានជ្រើសរើសចៅប្រុសរបស់ទ្រង់ឱ្យបន្តតំណែងពីទ្រង់ ប៉ុន្តែមិនមែនមនុស្សគ្រប់រូបយល់ស្របជាមួយនឹងការជ្រើសរើសនេះឡើយ។ ការតស៊ូដើម្បីអំណាចបានចាប់ផ្តើម។ បន្ទាប់ពីការវាយប្រយុទ្ធគ្នាអស់រយៈពេលជិត 5 ឆ្នាំ យ៉ុងលឺដែលជារាជបុត្រមួយអង្គរបស់ហុងវ៉ូប្រកាសខ្លួនទ្រង់ជាអធិរាជ។

យ៉ុងលឺ ក៏ដូចជាបិតារបស់ទ្រង់ដែរ គឺជាមេដឹកនាំដ៏ខ្លាំងក្លា និងមានសមត្ថភាពមួយអង្គ។ ស្ថិតនៅក្រោមការដឹកនាំរបស់ទ្រង់ សន្តតិវង្សមីុងបានកើនអំណាស់ដល់កម្រិតកំពូល។ ស្នាដៃដ៏សំខាន់បំផុតមួយរបស់ទ្រង់គឺការពង្រីករាជធានីពៃជីង។ នៅក្នុងផ្នែកមួយនៃទីក្រុង កំពែងដែលមានកម្ពស់ 30 ហ្វូតព័ទ្ធជុំវិញតំបន់មួយដែលមានសំណង់ និងប្រាសាទជាង 800 ។ សំណង់នេះត្រូវបានគេស្គាល់ថា ទីក្រុងហាមឃាត់ ដោយសារតែប្រជាជនសាមញ្ញ និងជនបរទេសមិនត្រូវបានអនុញ្ញាតឱ្យចូលទៅទីនោះឡើយ។ ទីក្រុងហាមឃាត់ជានិមិត្តសញ្ញានៃអំណាច និងភាគខ្លាំងក្លារបស់ប្រទេសចិន។ យ៉ុងលឺចង់ឲ្យពិភពទាំងមូលស្គាល់ពីភាពអស្ចារ្យរបស់ទ្រង់។ បំណង

នេះបាននាំទៅរកស្នាដៃដ៏អស្ចារ្យមួយផ្សេងទៀត។ នៅដើមទសវត្សរ៍ឆ្នាំ 1400 យ៉ុងលឺបានបញ្ជូនបេសកកម្មតាមផ្លូវទឹកជាច្រើនលើកទៅកាន់តំបន់ផ្សេងៗ។

សង្ខេប៖ ពិពណ៌នាអំពីការផ្លាស់ប្តូរដែលត្រូវបានធ្វើឡើងអធិរាជម៉ីងរបស់ចិន។

## 2. ពាណិជ្ជកម្ម និងដំណើរក្រៅប្រទេស

សំណួរគន្លឹះ៖ តើម៉ីងផ្លាស់ប្តូរទំនាក់ទំនងការបរទេសរបស់ចិនដោយរបៀបណា?

យ៉ុងលឺចង់ទទួលបានសួយសារអាករពីប្រទេសនានា។ សួយសារអាករគឺជាការបង់មួយ ដែលធ្វើឡើងដោយមេដឹកនាំ ឬរដ្ឋាភិបាលមួយ ឱ្យទៅកាន់រដ្ឋាភិបាលមួយផ្សេងទៀតដើម្បីជានានៅក្នុងទទួលបានការការពារ។ ដើម្បីសម្រេចគោលដៅនេះ យ៉ុងលឺបានស្ថាបនាកងនាវាដ៏អស្ចារ្យមួយ។

ដំណើររបស់ចេង ហឺ៖ ស្តេចយ៉ុងលឺបានជ្រើសរើសចេង ហឺ ដើម្បីធ្វើជាឧត្តមនាវីកងនាវារបស់ចិន។ ចេង ហឺ គឺជាម៉ូស្លីមមួយរូបដែលធំដឹងក្តីនៅចិនភាគនិរតី។ ស្ថិតនៅក្រោមការបញ្ជារបស់យ៉ុងលឺ ចេង ហឺ បានដឹកនាំការធ្វើដំណើរតាមផ្លូវសមុទ្រជាច្រើនលើក។ បេសកកម្មនេះត្រូវបានធ្វើឡើងរវាងឆ្នាំ 1405 និង 1433 ។ អ្នកប្រាជ្ញបានប៉ាន់ប្រមាណថា ដំណើរនេះមានរយៈចម្ងាយសរុប 100,000 ម៉ាយ និងបានទស្សនាប្រទេសប្រមាណជា 30 នៅតំបន់អាស៊ីអាគ្នេយ៍, ឥណ្ឌា, អារ៉ាប់, និងអាហ្វ្រិក។ កងនាវារបស់ចេង ហឺទៅកាន់បរទេសធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំង ជារឿយៗកងនាវានេះ មាននាវារហូតដល់ 300 គ្រឿង និងមានមនុស្ស 28,000 នាក់។ បន្ថែមពីលើនាវិក និងក្រុមអ្នករុករក ក៏មានផងដែរនូវកងទ័ព, វេជ្ជបណ្ឌិត, ចុងភៅ, ស្មៀន, និងជាងជួសជុលនៅលើនាវាទាំងនេះ។ នាវាទាំងនេះបាននាំយកនូវចំណីអាហារបរិបូរណ៍សម្រាប់ការធ្វើដំណើរទាំងមូល។ ទឹកត្រូវបានគេដាក់បន្ថែមរៀងរាល់ 10 ថ្ងៃម្តង។ នាវាទាំងនោះបានដឹកជញ្ជូនជាមួយនូវវត្ថុនានាធ្វើពីមាស និងប្រាក់, សូត្រ, ចានព័រហ្ស៊ឺឡែន, និងទឹកអប់។ នៅពេលដែលលោកធ្វើដំណើរ ចេង ហឺ បានផ្តល់របស់របរទាំងអស់នេះទៅកាន់ប្រទេសដែលលោកបានទស្សនា ជាថ្នូរជាមួយនឹងការទទួលបានទំនិញផ្សេងៗមកវិញ។ លោកបានយកត្រឡប់មកវិញនូវគ្រឿងទេស, ត្បូង, ថ្នាំរុក្ខជាតិ, និងសត្វកម្រនានាដូចជាសេះបង្កង់, អូទ្រីស, និងសត្វកវែង។ នៅក្នុងការធ្វើដំណើរមួយ លោកត្រឡប់មកវិញជាមួយនឹងតំណាងរដ្ឋាភិបាលរបស់ប្រទេស 30 ផ្សេងៗគ្នា។ ពាណិជ្ជកម្មអន្តរជាតិ និងកេរ្តិ៍ឈ្មោះរបស់ចិន បានកើនឡើងដោយសារដំណើររបស់លោកទាំងនេះ។ ការធ្វើដំណើរនេះក៏បានផ្តល់នូវព័ត៌មានដល់រាជវាំងរបស់អធិរាជអំពីប្រទេខាងក្រៅទាំងនេះ។

ការផ្លាស់ប្តូរគោលនយោបាយមួយ៖ ត្រឹមទសវត្សរ៍ឆ្នាំ 1430 យ៉ុងលឺ និងចេង ហឺបានស្លាប់។ មេដឹកនាំចិនបានពិភាក្សាគ្នាថាតើគួរតែបន្តបញ្ជូនកងនាវាដ៏ធំនេះចេញទៅខាងក្រៅទៀតឬទេ។ ពួកខុងជឺមួយចំនួនបានប្រឆាំងជាមួយការធ្វើដំណើរនេះ ដោយសារពួកគេភ័យខ្លាចថា ការធ្វើពាណិជ្ជកម្មកាន់តែច្រើននឹងធ្វើឱ្យប្រទេសចិនពឹងលើពាណិជ្ជកម្មច្រើនពេក។ ពួកគេចង់ឱ្យប្រទេសចិនបន្តពឹងលើកសិកម្ម។ មេដឹកនាំផ្សេងទៀតចង់យកលុយប្រើសម្រាប់ការការពារជាតិជាជាងចំណាយលើការធ្វើដំណើររុករកនេះ។ ពួកគេគិតថាប្រទេសចិនត្រូវការការការពារដ៏ប្រសើរមួយប្រឆាំងជាមួយការវាយប្រហាររបស់ពួកចរកជនមកពីអាស៊ីកណ្តាល។ មេដឹកនាំជាច្រើនទទូចថា

ប្រទេសចិនគឺជាប្រទេសដែលមានទ្រព្យសម្បត្តិច្រើន និងសង្គមជឿនលឿនជាងគេនៅលើពិភពលោក។ ពួកគេជឿថា ប្រទេសចិនមិនត្រូវការស្តួយសារអាករពីដែនដីខាងក្រៅឡើយ។ ជាងនេះទៅទៀត ពួកគេជឿថា ប្រជាជននៅក្នុងតំបន់ផ្សេងទៀតមិនមានអ្វីដែលត្រូវបង្រៀនប្រទេសចិនឡើយ។ ត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1400 រដ្ឋាភិបាលម៉ីងបានបញ្ចប់ដំណើររុករកតាមផ្លូវទឹក។ បើទោះបីជាការធ្វើដំណើររុករកត្រូវបានបញ្ចប់ក៏ដោយ ប្រទេសចិនមិនបានស្ថិតនៅដាច់ពីផ្នែកផ្សេងៗនៅលើពិភពលោកឡើយ ពាណិជ្ជករចិនបានពង្រីកការធ្វើពាណិជ្ជកម្មជាមួយអាស៊ីអាគ្នេយ៍។ ជាងនេះទៅទៀត នាវារបស់អង់គ្លេស, ព័រទុយហ្គាល, និងហូឡង់បានធ្វើដំណើរមកកាន់ប្រទេសចិននៅត្រឹមដើមទសវត្សឆ្នាំ 1600 ។ ពួកចិនដោះដូរសូត្រ, តែ, និងព័រហ្សឺឡែនជាមួយនឹងទំនិញជាច្រើនរបស់ពួកអឺរ៉ុប ដោយក្នុងនោះរួមមានទាំងប្រាក់ផងដែរ។

ស្វែងរកគោលគំនិត៖ កំណត់អំពីការផ្លាស់ប្តូរដែលបានធ្វើឡើងដោយសន្តតិវង្សម៉ីងរបស់ចិន។

### 3. សន្តតិវង្សចុងក្រោយ

សំណួរគន្លឹះ៖ តើបញ្ហាអ្វីខ្លះដែលសន្តតិវង្សឈីងជួបប្រទះ?

សន្តតិវង្សម៉ីងចាប់ផ្តើមធ្លាក់ចុះបន្ទាប់ពីការកាន់អំណាចអស់រយៈពេលជិត 300 ឆ្នាំ។ មេដឹកនាំខ្សោយ, ការតំឡើងពន្ធ, និងការទទួលបានទិន្នផលតិចតួចនាំទៅដល់ការបះបោរមួយ។ ស្ថិតនៅចិនភាគឦសានគឺជាតំបន់មួយដែលគេហៅថាម៉ាន់ជូរី។ ប្រជាជនដែលរស់នៅទីនោះត្រូវបានគេស្គាល់ថា ម៉ាន់ជូ។ នៅក្នុងឆ្នាំ 1644 ពួកម៉ាន់ជូចាប់យកឱកាសនៃការធ្លាក់ចុះរបស់សន្តតិវង្សម៉ីង បានធ្វើការឈ្លានពានប្រទេសចិន។ ពួកគេបានបង្កើតសន្តតិវង្សឈីង។ ក៏ដូចជាមេដឹកនាំរបស់ម៉ីង ពួកម៉ាន់ជូបានអនុញ្ញាតឱ្យមានការធ្វើពាណិជ្ជកម្ម។ ជាទូទៅពួកគេបានកម្រិតការធ្វើទំនាក់ទំនងជាមួយបរទេស។ ប៉ុន្តែ ការប្រឹងប្រែងរបស់ពួកគេនៅក្នុងការកម្រិតឥទ្ធិពលបរទេសនៅក្នុងប្រទេសបានបរាជ័យ។ ជនបរទេស ភាគច្រើនមកពីអឺរ៉ុបមានបំណងចង់ធ្វើពាណិជ្ជកម្មជាមួយប្រទេសចិន។ នៅពីក្រោយដោយការគំរាមកំហែងដោយអំណាចយោធា ពួកជនបរទេសទាំងនេះបានបង្ខំឱ្យប្រទេសចិនធ្វើពាណិជ្ជកម្មជាមួយពួកគេ។ អំឡុងទសវត្សរ៍ឆ្នាំ 1800 ចក្រភពអង់គ្លេស, អាឡឺម៉ង់, រុស្ស៊ី និងជប៉ុនបានបង្កើតតំបន់ពិសេសរៀងៗខ្លួននៅក្នុងប្រទេសចិន។ នៅក្នុងតំបន់ទាំងអស់នេះ ពួកគេត្រួតត្រាលើសេដ្ឋកិច្ចរបស់ប្រទេសចិន។ ការកើនឡើងនៃឥទ្ធិពលរបស់បរទេសនៅក្នុងប្រទេសចិនបានធ្វើឲ្យអំណាចរបស់មេដឹកនាំឈីងធ្លាក់ចុះ។ វាក៏បានធ្វើឱ្យជនជាតិចិនជាច្រើនមានការខឹងសម្បាផងដែរ។ នៅក្នុងឆ្នាំ 1911 បដិវត្តមួយបានចាប់ផ្តើមឡើង ហើយភ្លាមៗនោះបានទម្លាក់អធិរាជឈីងចេញពីអំណាច។ រដ្ឋាភិបាលថ្មីគ្រប់គ្រងបែបសាធារណរដ្ឋ ដែលមេដឹកនាំត្រូវបានជ្រើសរើសដោយការបោះឆ្នោត។ ចាប់តាំងពីការធ្វើបដិវត្តមក ប្រទេសចិនមិនបានត្រឡប់ទៅរកការគ្រប់គ្រងដោយសន្តតិវង្សមួយឡើយ។

សង្ខេប៖ ពិពណ៌នាអំពីបញ្ហាដែលសន្តតិវង្សឈីងប្រឈម។

# ជំពូក 15 ៖ អរិយធម៌នៅអាស៊ី

## មេរៀនទី 1 ៖ អរិយធម៌ជប៉ុន

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើអ្នកគិតយ៉ាងណានៅពេលដែលអ្នកទទួលឥទ្ធិពលពីប្រទេសជិតខាងដែលធំ និងខ្លាំងជាងប្រទេសរបស់អ្នក។ ប្រទេសជប៉ុន ជាដែនកោះតូចមួយស្ថិតនៅក្បែរប្រទេសចិន ទទួលរងឥទ្ធិពលរបស់ចិនអស់ជាច្រើនសតវត្សរ៍។

### 1. ដែនដីព្រះអាទិត្យរះ

សំណួរគន្លឹះ៖ តើការអភិវឌ្ឍនៅក្នុងប្រទេសជប៉ុនជះឥទ្ធិពលពីប្រទេសជិតខាងចិន និងកូរ៉េដោយរបៀបណា?

ប្រទេសជប៉ុនមានទីតាំងចម្ងាយ 120 ម៉ាយខាងចុងឆ្នេរអាស៊ី។ នៅក្នុងវិធីមួយចំនួន ប្រទេសនេះគឺជាកន្លែងពិបាកនៅក្នុងការរស់នៅមួយ។ មានតែផ្ទៃដី 15 ភាគរយប៉ុណ្ណោះដែលមានលក្ខណៈរាបស្មើអាចដាំដុះបាន។ ដែនកោះនេះមានឥន្ទនៈធម្មជាតិដូចជាធ្យូងថ្ម និងប្រេងតិចតួចប៉ុណ្ណោះ។ ប៉ុន្តែប្រទេសជប៉ុនក៏មានសារៈប្រយោជន៍ផងដែរ។ ប្រទេសនេះមានអាកាសធាតុក្តៅល្មមជាមួយនិងភ្លៀងធ្លាក់គ្រប់គ្រាន់ ដូច្នេះនៅទីនោះការដាំដុះស្រូវមានលក្ខណៈល្អប្រសើរ។ ដោយសារតែជប៉ុនគឺជាកោះ មហាសមុទ្ទបានផ្តល់នូវភាពសម្បូរបែបនៃត្រីសម្រាប់ធ្វើជាអាហារ។ វាក៏បានផ្តល់នូវការការពារពីការឈ្លានពានផងដែរ។

ធម្មជាតិញ៉ាំងឱ្យលេចវប្បធម៌ជប៉ុនឡើង ៖ ភ្នំជាច្រើននៅក្នុងប្រទេសជប៉ុន និងភ្លៀងធ្លាក់ជាញឹកញាប់បណ្តាលឱ្យមានផ្ទៃដីបៃតងស្រងាត់។ វប្បធម៌ជប៉ុនជាទូទៅបង្ហាញពីសេចក្តីស្រលាញ់ចំពោះភាពស្រស់ស្អាតនៃធម្មជាតិនេះ។ ទម្រង់នៃការបង្ហាញមួយគឺសាសនាបែបប្រពៃណីដែលគេស្គាល់ថា ស៊ីនតូ។ ស៊ីនតូមានន័យថា "ផ្លូវរបស់ព្រះ"។ វាផ្តោតសំខាន់លើការគោរពធម្មជាតិ និងបុព្វការីជន។ យោងតាមស៊ីនតូ ថ្ម, ដើមឈើ, ទន្លេ, និងវត្ថុធម្មជាតិផ្សេងៗទៀតគឺជាលំនៅឋានរបស់វិញ្ញាណទេវតា។

ប្រទេសជិតខាងជប៉ុន៖ ប្រទេសដែលស្ថិតនៅជិតជប៉ុនបំផុតគឺប្រទេសចិន និងប្រទេសកូរ៉េ។ ប្រទេសទាំងពីរនេះបានជះឥទ្ធិពលមកលើប្រទេសជប៉ុន ប៉ុន្តែអរិយធម៌ដ៏មានអំណាចរបស់ចិនមានឥទ្ធិពលខ្លាំងជាងកូរ៉េ។ តាមពិតទៅ ប្រទេសចិនគឺជាអ្នកដាក់ឈ្មោះឱ្យប្រទេសជប៉ុន។ ចិនបានហៅសំដៅលើដែនកោះមួយដែលស្ថិតនៅភាគខាងកើតប្រទេសខ្លួនថា "ដែនដីព្រះអាទិត្យរះ" ដែលហៅជាភាសាជប៉ុនថា នីពពុន។ នីពពុនគឺជាឈ្មោះដែលជប៉ុនហៅឈ្មោះរបស់ប្រទេសពួកគេ។

អធិរាជជប៉ុន៖ អស់រយៈពេលជាច្រើនសតវត្សរ៍ សង្គមជប៉ុនមានទំនាក់ទំនងជុំវិញក្រុមកុលសម្ព័ន្ធដែលធំៗ និងមានអំណាច។ កុលសម្ព័ន្ធគឺជាក្រុមគ្រួសារនានាដែលមានទំនាក់ទំនងជាមួយគ្នាតាមរយៈបុព្វការីជនរួមគ្នា។ នៅក្នុងទសវត្សរ៍ឆ្នាំ 400 កុលសម្ព័ន្ធយ៉ាម៉ាតូដែលស្ថិតនៅជប៉ុនភាគកណ្តាលបានអភិវឌ្ឍខ្លួនក្លាយជាកុលសម្ព័ន្ធដែលមានអំណាចបំផុតមួយ។ អធិរាជដំបូងរបស់ជប៉ុនមកពីកុលសម្ព័ន្ធនេះ។ រឿងព្រេងប្រពៃណីបាននិយាយថា

សមាជិកនៃកុលសម្ព័ន្ធយ៉ាម៉ាតូគឺជាបុព្វការីជនរបស់អាទិទេពព្រះអាទិត្យ។ អធិរាជគឺជាមនុស្ស ប៉ុន្តែដោយសាររឿងព្រេងប្រពៃណីនេះ ប្រជាជនជប៉ុនក៏បានចាត់ទុកទ្រង់ថាជាទេវតាផងដែរ។ អធិរាជត្រូវបានគេចាត់ទុកថាជាអ្នកដែលដឹកនាំ។ ប៉ុន្តែ គ្រួសារអភិជនដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភគឺជាអ្នកកាន់អំណាចពិតប្រាកដ។ មេដឹកនាំមួយអង្គដែលមានអំណាចពិតប្រាកដគឺ ព្រះអង្គម្ចាស់សូតូគូ ទ្រង់មិនមែនជាអធិរាជឡើយប៉ុន្តែទ្រង់គឺជារាជានុសិទ្ធិមួយអង្គ។ រាជានុសិទ្ធិគឺជាអ្នកដែលដឹកនាំប្រទេសនៃពេលដែលមេដឹកនាំអវត្តមាន, មានជំងឺ, ឬមានវ័យក្មេងពេកក្នុងការដឹកនាំ។

រាជរបស់ព្រះអង្គម្ចាស់សូតូគូ៖ ព្រះអង្គម្ចាស់សូតូគូ ដែលបានដឹកនាំចាប់ពីឆ្នាំ 593 ដល់ 622 មានការចាប់អារម្មណ៍យ៉ាងខ្លាំងលើវប្បធម៌ចិន។ ទ្រង់បានបញ្ជូនអ្នកប្រាជ្ញជប៉ុននៅសិក្សានៅក្នុងប្រទេសចិន។ ទ្រង់ក៏បានស្វាគមន៍កម្មករជំនាញរបស់ចិនមកកាន់ប្រទេសជប៉ុនផងដែរ។ ព្រះអង្គម្ចាស់សូតូគូបានបើកស្ថានទូតមួយនៅក្នុងប្រទេសចិន។ ស្ថានទូតមួយគឺជាការិយាល័យនៃរដ្ឋាភិបាលរបស់ប្រទេសមួយនៅក្នុងប្រទេសមួយផ្សេងទៀត។ ជាងនេះទៅទៀត ទ្រង់បានបង្កើតគោលការណ៍ណែនាំសម្រាប់មេដឹកនាំជប៉ុន ដោយផ្អែកលើគោលការណ៍ខុងជឺ ក្នុងនោះមានដូចជាភក្តីភាព និងការគោរពជាដើម។ គោលការណ៍ណែនាំទាំងនេះបានក្លាយទៅជាអ្វីដែលគេស្គាល់ថា ធម្មនុញ្ញ 17 មាត្រា។ ទិដ្ឋភាពមួយនៃវប្បធម៌ចិនដែលទាក់ទាញចំណាប់អារម្មណ៍របស់សូតូគូគឺពុទ្ធសាសនា។ ជាមួយនឹងការលើកកម្ពស់របស់សូតូគូ ពុទ្ធសាសនាបានរីកសាយភាយយ៉ាងឆាប់រហ័សនៅក្នុងប្រទេសជប៉ុន។ ដូចដែលអ្នកបានដឹង ពុទ្ធសាសនាគឺផ្តោតសំខាន់លើការអប់រំរបស់ព្រះសិទ្ធត្ថគោតម ដែលប្រសូត្រនៅក្នុងប្រទេសឥណ្ឌា មិនមែនប្រទេសជប៉ុនឡើយ។ ហេតុដូច្នេះ ជនជាតិជប៉ុនជាច្រើនយល់ថាពុទ្ធសាសនាបានប្រជែងជាមួយស៊ីនតូ ដែលជាប្រព័ន្ធជំនឿបែបប្រពៃណីរបស់ជប៉ុន។ ពួកគេបានប្រឆាំងយ៉ាងខ្លាំងក្លាទៅនឹងការគាំទ្រពុទ្ធសាសនារបស់សូតូគូ។ ប៉ុន្តែ ជាយថាហេតុ ប្រជាជនជប៉ុនភាគច្រើនបានលាយបញ្ចូលគ្នានូវសាសនាទាំងពីរនេះ។ ពួកគេទទួលយកពុទ្ធសាសនា ប៉ុន្តែកែច្នៃវាឱ្យស៊ីជាមួយវប្បធម៌ប្រពៃណីរបស់ជប៉ុន។ នៅក្នុងពេលជាមួយគ្នានេះ ពួកគេនៅបន្តប្រតិបត្តិស៊ីនតូ។

សង្ខេប៖ ពន្យល់ពីមូលហេតុដែលការអភិវឌ្ឍនៅជប៉ុនទទួលរងឥទ្ធិពលពីប្រទេសជិតខាងចិន និងកូរ៉េ។

## 2. វប្បធម៌ជប៉ុន

សំណួរគន្លឹះ៖ តើអ្វីទៅជាចំណុចប្លែកនៃវប្បធម៌ជប៉ុន?

ប្រទេសជប៉ុនទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីវប្បធម៌របស់ចិន។ ប៉ុន្តែពួកជប៉ុនទទួលយកទស្សនបរទេសទាំងនេះ និងបានកែប្រែទស្សនទាំងនេះឱ្យត្រូវជាមួយនឹងតម្រូវការជាក់ស្តែងរបស់ពួកគេ។ ពុទ្ធសាសនាគឺជាឧទាហរណ៍ជាក់ស្តែងមួយសម្រាប់ការអនុវត្តនេះ។

ពុទ្ធសាសនានៅក្នុងប្រទេសជប៉ុន៖ ពុទ្ធសាសនាចាប់ផ្តើមនៅក្នុងប្រទេសឥណ្ឌាប្រមាណ 500 មុនគ.ស។ បន្ទាប់មកវាបានរីកសាយភាយមកកាន់ប្រទេសចិន និងប្រទេសកូរ៉េ និងបានមកដល់ប្រទេសជប៉ុននៅអំឡុងទសវត្សរ៍ឆ្នាំ 500 នៃគ.ស។ ពុទ្ធសាសនាបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាលើវប្បធម៌របស់ជប៉ុន។ ដំបូងឡើយសាសនា

នេះមានប្រជាប្រិយភាពសម្រាប់ពួកអភិជន និងក្រោយមកសម្រាប់ប្រជាជនសាមញ្ញ។ ពុទ្ធសាសនិកជឿថាសន្តិភាព និងសុភមង្គលអាចទទួលបានតាមរយៈការរស់នៅប្រកបដោយគុណធម៌ និងឧត្តមគតិរបស់មនុស្សទាំងឡាយ។ ទម្រង់ ឬនិកាយផ្សេងៗគ្នានៃពុទ្ធសាសនាបានអភិវឌ្ឍនៅក្នុងប្រទេសជប៉ុនអស់រយៈពេលជាច្រើនសតវត្សរ៍។ និកាយហ្សេន ដែលលើកឡើងថា អ្វីៗអស្ចារ្យ និងទេវភាពមាននៅក្នុងមនុស្សនីមួយៗ បានក្លាយជានិកាយដែលមានប្រជាប្រិយភាពបំផុត។ និកាយនេះសង្កត់ធ្ងន់លើការគ្រប់គ្រងខ្លួនឯង, ភាពសាមញ្ញ, និងសមាធិ។ អ្នកដើរតាមហ្សេនផ្តោតសំខាន់លើការសម្រេចបាននូវសន្តិភាពខាងក្នុង។ ពួកគេជឿថា ការឆ្លុះបញ្ចាំងពីខ្លួនឯងដោយស្ងៀមស្ងាត់គឺមានអត្ថប្រយោជន៍ជាងការរៀបចំក្បួនពិធី ឬសិក្សាសៀវភៅសាសនា។ នៅក្នុងពេលជាមួយគ្នានេះ ហ្សេនបានជម្រុញឱ្យមនុស្សធ្វើសកម្មភាពដោយក្លាហាន។ ការលាយបញ្ចូនគ្នានៃភាពសាមញ្ញ និងភាពជឿជាក់នេះបានធ្វើឱ្យហ្សេនមានប្រជាប្រិយភាពក្នុងចំណោមយោធា។

អក្សរសុល្ប៏ជប៉ុន៖ ឥទ្ធិពលរបស់ចិនក៏មានមកលើអក្សរសិល្ប៍ផងដែរ ប៉ុន្តែប្រទេសជប៉ុនបានអភិវឌ្ឍវប្បធម៌ប្រពៃណីរបស់ខ្លួនពួកគេផ្ទាល់។ កវីនិពន្ធដែលល្បីល្បាញបំផុតរបស់ជប៉ុនគឺ ម៉ូរ៉ាសាគី ស៊ីគីប៊ូ។ នាងរស់នៅក្នុងរាជវាំងរបស់អធិរាជនៅដើមទសវត្សរ៍ឆ្នាំ 1000 ។ ម៉ូរ៉ាសាគី បានសរសេរសៀវភៅ រឿងព្រេងហ្គេនជី ដែលជារឿងមួយនិយាយអំពីជីវិតរស់នៅរបស់ព្រះអង្គម្ចាស់មួយអង្គនៅក្នុងព្រះបរមរាជវាំង។ វាគឺជារឿងបែបពិតប្រាកដនិយមដែលវែងមួយ ផ្តោតសំខាន់លើតួអង្គតែមួយ។ ទម្រង់ទាំងនេះបានធ្វើឱ្យវាក្លាយជាប្រលោមលោកសំខាន់ដំបូងគេនៅលើពិភពលោក។ នៅក្នុងវិស័យល្ខោន ជប៉ុនបានអភិវឌ្ឍទម្រង់ពីរដាច់ដោយឡែកពីគ្នាគឺល្ខោនណូ និងកាប៊ូគី។ ការសម្តែងល្ខោនណូជាទូទៅជាការប្រាប់ឡើងវិញអំពីទេវកថា និងរឿងព្រេងនិទាន។ តួអង្គពាក់របាំងមុខឈើដែលលាបពណ៌ដើម្បីបង្ហាញពីអារម្មណ៍ផ្សេងៗ និងប្រើប្រាស់កាយវិការ, សំលៀកបំពាក់, និងតន្ត្រីដើម្បីនិយាយរឿង។ ការសំដែងទាំងនេះត្រូវបានគេធ្វើឡើងទាំងសម្រាប់អ្នកវណ្ណៈលើ និងប្រជាជនសាមញ្ញ។ កាប៊ូគីបានលាយបញ្ចូលគ្នានៃការច្រៀងចម្រៀងកំសត់ និងការរាំជាមួយនឹងសំលៀកបំពាក់ដ៏ឧឡារិក និងការផាត់មុខក្រាស់ៗ។ ល្ខោនប្រភេទនេះមានលក្ខណៈផ្លូវការជាងល្ខោនណូ។ ឈុតឆាករបស់វាភាគច្រើនជាប់ទាក់ទងជាមួយប្រជាជនសាមញ្ញ។ ទាំងល្ខោនណូ និងកាប៊ូគីនៅតែមានប្រជាប្រិយភាពរហូតមកដល់សព្វថ្ងៃ។

ទម្រង់កំណាព្យពិសេសមួយ៖ កំណាព្យដែលមានប្រជាប្រិយភាពបំផុតរបស់ជប៉ុនមានលក្ខណៈខ្លីយ៉ាងខ្លាំងបើប្រៀបធៀបជាមួយកំណាព្យរបស់ប្រទេសផ្សេងៗទៀត។ ទម្រង់កំណាព្យខ្លីមួយត្រូវបានគេហៅថា ហៃគូ។ វាមានតែ 17 ដោយក្នុងនោះមាន 3 ជួរ 5 ពាក្យ, 7 ពាក្យ, និង 5 ពាក្យ។ ម៉ាត្សូអូ បាសូ ដែលរស់នៅក្នុងទសវត្សរ៍ឆ្នាំ 1600 គឺជាកវីហៃគូដ៏ប្រសើរមួយរូប។ លោកបានសរសេរកំណាព្យនានាដែលមានលក្ខណៈស្ងប់ស្ងាត់, ការឆ្លុះបញ្ចាំងពីវិញ្ញាណបែបហ្សេន ដូចជាកំណាព្យអំពីស្រះមួយ៖ ស្រះចាស់ដ៏ស្ងប់ស្ងាត់មួយ..., នៅក្នុងស្រះសត្វកង្កែបមួយកំពុងលោត, ផ្លោត! ស្ងប់ស្ងាត់សារជាថ្មី។

សិល្បៈប្លែកៗរបស់ជប៉ុន៖ ទម្រង់ពីរដារឿយៗតែងបង្ហាញនៅក្នុងអក្សរសិល្ប៍ និងល្ខោនជប៉ុន ក្នុងនោះរួមមាន ភាពសាមញ្ញ និងសេចក្តីស្រលាញ់សម្រស់ធម្មជាតិ។ ទម្រង់ទាំងនេះក៏បានលេចឡើងនៅក្នុងទម្រង់សិល្បៈ

ផ្សេងទៀតរបស់ជប៉ុនផងដែរ។ ក៏ដូចជាចិន ជប៉ុនសរសេរនៅលើក្រដាស់ជាមួយជក់ និងទឹកខ្មៅ។ ពួកគេចាត់ទុកការសរសេរគឺជាវិធីមួយនៅក្នុងការបង្ហាញពីភាពស្រស់ស្អាត។ អក្សរផ្ចង់គឺជាសិល្បៈនៃការសរសេរដ៏ស្រស់ស្អាត។ តួអក្សរនីមួយៗត្រូវបានសរសេរទៅតាមលំដាប់លំដោយនៃសសៃជក់។ អ្នកសរសេរអក្សរផ្ចង់ សរសេរអក្សរមានទ្រង់ទ្រាយ និងទំហំខុសគ្នាៗដើម្បីបង្ហាញពីអត្ថន័យខុសៗគ្នា។ ការគូរគំនូរដោយប្រើជក់ និងទឹកខ្មៅលើរមូលក្រដាស់ និងសូត្របានចាប់ផ្តើមឡើងនៅក្នុងទសវត្សរ៍ឆ្នាំ 600 ។ ជាធម្មតាការរចនារបស់ជប៉ុនមានលក្ខណៈលម្អិតណាស់។ ពួកគេពណ៌នាអំពីទេសភាព, ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ, និងជីវិតរស់នៅប្រចាំថ្ងៃ។ ពេលខ្លះមានការសរសេរពណ៌នាខ្លីមួយនៅលើសិល្បៈនោះ។

សិល្បៈនៃការរៀបចំផ្កាគឺជាប្រពៃណីមួយទៀតដែលនាំយកមកប្រទេសជប៉ុនដោយពុទ្ធសាសនិក។ ប្រជាជនប្រើប្រាស់ការរៀបចំសាមញ្ញៗដែលបង្ហាញពីភាពស្រស់ស្អាតនៃផ្កា។ អ្នកថែសួនច្បារបែបទាសភាពក៏បានព្យាយាមនៅក្នុងការបង្កើតសួនច្បារដែលបង្ហាញពីសម្រស់នៃធម្មជាតិ។ សួនច្បារមួយចំនួនត្រូវបានរៀបចំជាមួយនឹងដុំថ្ម និងផ្លូវដើរ និងផ្កា ឬដើមឈើបន្តិចបន្តួច។ ការរៀបចំសួនច្បារ និងការរៀបចំផ្កានៅតែជាទម្រង់សិល្បៈសំខាន់នៅក្នុងប្រទេសជប៉ុននាពេលបច្ចុប្បន្ន។

គូសសេចក្តីបញ្ជាក់៖ កំណត់ពីអ្វីដែលមានលក្ខណៈប្លែកនៅក្នុងវប្បធម៌ជប៉ុន។

### 3. ការលេចឡើងនៃសង្គមយោធាមួយ

សំណួរគន្លឹះ៖ តើប្រទេសជប៉ុនក្លាយជាសង្គមយោធាមួយដោយរបៀបណា?

ប្រទេសជប៉ុននៅតែមានភាពខ្លាំង និងរួបរួមបន្ទាប់ពីព្រះអង្គម្ចាស់សូតូគូសុគតនៅក្នុងឆ្នាំ 622 ។ អធិរាជនៅតែជាប្រមុខរដ្ឋាភិបាលកណ្តាល ប៉ុន្តែទ្រង់គ្រាន់តែជាបដិទាននាមតែមួយអង្គប៉ុណ្ណោះ។ បដិទាននាមមានន័យថាជាមនុស្សម្នាក់ដែលមើលទៅហាក់ដូចជាមានអំណាចប៉ុន្តែតាមពិតមិនមានទេ។ ពួកអភិជនមានទ្រព្យសម្បត្តិស្តុកស្តម្ភគឺជាអ្នកមានអំណាចពិតប្រាកដនៅក្នុងប្រទេសជប៉ុន។ ប៉ុន្តែ អំឡុងទសវត្សឆ្នាំ 1100 អំណាចរបស់ពួកគេចាប់ផ្តើមធ្លាក់ចុះ។

សក្តិភូមិនិយមក្នុងប្រទេសជប៉ុន៖ ម្ចាស់កម្មសិទ្ធិដីធ្លីធំៗ ដែលគេស្គាល់ថា ដៃម្យូ ចាប់ផ្តើមមិនអើពើជាមួយរដ្ឋាភិបាលកណ្តាល។ ពួកគេបានធ្វើការកាន់តែឯករាជ្យក្នុងនាមមេដឹកនាំក្នុងតំបន់។ ពួកគេបានជួលក្រុមអ្នកប្រយុទ្ធដែលទទួលបានការបណ្តុះបណ្តាល ដែលគេហៅថា សាមូរៃ សម្រាប់ការការពារ និងវាយប្រហារលើដៃម្យូផ្សេងទៀត។ ដូចដែលអំណាចរបស់ដៃម្យូបានកើនឡើង ភាពគ្មានច្បាប់ទម្លាប់ក៏បានកើនឡើងដូចគ្នា។ ក្រុមម្ចាស់កម្មសិទ្ធិដីធ្លីតូចៗចង់ទទួលបានការការពារ។ ដើម្បីទទួលបានជំនួយពីស្តេចត្រាញ់ដែលមានអំណាចមួយរូប ពួកគេសន្យានៅក្នុងការបម្រើស្តេចត្រាញ់នោះ។ មនុស្សម្នាក់ដែលទទួលបានដី និងការការពារពីស្តេចត្រាញ់មួយរូបជាថ្នូរទៅនឹងការបម្រើដល់ស្តេចត្រាញ់នោះ ត្រូវបានគេហៅថា បរិវារ។ ប្រព័ន្ធស្តេចត្រាញ់-បរិវារនេះបានបង្កើនអំណាចដល់ដៃម្យូ។ វាក៏ជាសញ្ញាណនៃការចាប់ផ្តើមសក្តិភូមិនិយមនៅក្នុងប្រទេសជប៉ុន។ អ្នកនឹងបានអានកាន់តែច្រើនអំពីសក្តិភូមិនិយមនៅក្នុងជំពូក 16 ។

សូហ្គូន និងសាមូរ៉ៃ៖ អំឡុងចុងទសវត្សរ៍ឆ្នាំ 1100 មេដឹកនាំយោធាដែលគេហៅថា សូហ្គូន បានត្រួតត្រាប្រទេសជប៉ុន។ សូហ្គូនមានន័យថា "មេបញ្ជាការកងទ័ពជាន់ខ្ពស់"។ ពួកសូហ្គូនដឹកនាំមិនត្រឹមតែកងទ័ពទេ ពួកគេក៏គ្រប់គ្រងប្រទេសផងដែរ។ ពួកគេដឹកនាំក្នុងនាមអធិរាជ ប៉ុន្តែជាទូទៅអត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេគឺជារឿងចំបង។ សូហ្គូនដែលសំខាន់មួយរូបឈ្មោះ តូគូហ្គាវ៉ា អ៊ីអេយ៉ាស៊ូ ។ ប្រទេសជប៉ុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សូហ្គូន ឬយោធាអស់រយៈពេលជិត 700 ឆ្នាំ។ សូហ្គូនដឹកនាំកងទ័ពដ៏ខ្លាំងក្លាសាមូរ៉ៃ។ ជាអ្នកប្រយុទ្ធដ៏អង់អាច ពួកសាមូរ៉ៃអះអាងពីការបម្រើស្តេចត្រាញ់របស់ពួកគេរហូតដល់អស់ជីវិត។ ការស្លាប់ដោយកិត្តិយសមានសារៈសំខាន់សម្រាប់ពួកគេជាងការរស់នៅយូរអង្វែងទៅទៀត។ ពួកសាមូរ៉ៃរស់នៅជាមួយក្រុមដែលមិនមានកត់ត្រាមួយដែលមានឈ្មោះថា ប៊ូស៊ីដូ ដែលបានស្នើឱ្យមានកិត្តិយស, ភក្តីភាព, និងភាពក្លាហាន។ ពួកសាមូរ៉ៃក៏បានសន្យានៅក្នុងការបង្ហាញពីការគោរពដល់អាទិទេព និងចិត្តសប្បុរសសម្រាប់អ្នកក្រីក្រ។ ពុទ្ធសាសនាហ្សេនគឺជាទិដ្ឋភាពសំខាន់មួយសម្រាប់ជីវិតរស់នៅរបស់ពួកគេ។ តម្លៃ និងប្រពៃណីរបស់សាមូរ៉ៃបន្តលេចឡើងលើជនជាតិជប៉ុនជាច្រើនសូម្បីតែនាពេលបច្ចុប្បន្ន។

សូហ្គូនដ៏មានអំណាច 3 រូប៖ មេដឹកនាំយោធាដ៏ខ្លាំងក្លាបន្តបន្ទាប់គ្នា 3 រូបបានបញ្ចប់ការវាយប្រយុទ្ធគ្នាក្នុងចំណោមដៃម្យូ។ តាមរយៈការធ្វើដូច្នេះ ពួកគេបានជួយនៅក្នុងការបង្រួបបង្រួមប្រទេសជប៉ុន។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1500 អូដា ណូប៊ូណាហ្គា ដែលជាដៃម្យូដ៏មានអំណាចមួយរូបបានឡើងកាន់កាប់អំណាច។ កងទ័ពរបស់លោកគឺជាជនជាតិជប៉ុនដំបូងដែលបានប្រើប្រាស់កាំភ្លើងនៅក្នុងសមរភូមិ។ បើទោះបីជាពួកគេមានចំនួនតិចក៏ដោយ ជាទូទៅពួកគេតែងតែទទួលបានជ័យជំនះ។ តាមរយៈការធ្វើសង្គ្រាម និងការចរចារ ណូប៊ូណាហ្គាទទួលបានជ័យជំនះនៅក្នុងការគ្រប់គ្រងប្រទេសជប៉ុនជិតពាក់កណ្តាល។ ភ្លាមៗបន្ទាប់ការស្លាប់របស់ណូប៊ូណាហ្គានៅក្នុងឆ្នាំ 1582 ឧត្តមសេនីយ៍ដ៏ខ្លាំងរបស់លោកឈ្មោះ តូយ៉ូតូមី ហ៊ីដេយ៉ូស៊ី បានឡើងកាន់អំណាចបន្តពីលោក។ តាមរយៈការប្រើប្រាស់កម្លាំង និងសម្ព័ន្ធភាពនយោបាយ ហ៊ីដេយ៉ូស៊ីបានត្រួតត្រាប្រទេសជប៉ុនទាំងមូលនៅពេលដែលលោកស្លាប់នៅក្នុងឆ្នាំ 1598 ។ បន្ទាប់មកឧត្តមសេនីយ៍របស់លោកធ្វើសង្គ្រាមជាមួយគ្នាទៅវិញទៅមកដើម្បីដឹកនាំប្រទេសជប៉ុន។ អ្នកដែលទទួលបានជ័យជំនះ តូគូហ្គាវ៉ា អ៊ីអេយ៉ាស៊ូ ត្រូវបានគេតែងតាំងជាសូហ្គូននៅក្នុងឆ្នាំ 1603 ។ លោកបានបង្កើតសន្តតិវង្សមួយឈ្មោះថា សូហ្គូនតូគូហ្គាវ៉ា ដែលគ្រប់គ្រងអំណាចនៅក្នុងប្រទេសជប៉ុនរហូតដល់ឆ្នាំ 1867 ។ នៅពេលដែលអ៊ីអេយ៉ាស៊ូក្លាយជាសូហ្គូន ប្រទេសជប៉ុនបានបង្កើនទំនាក់ទំនងជាមួយពួកអឺរ៉ុប។ ប៉ុន្តែអ៊ីអេយ៉ាស៊ូ និងអ្នកបន្តតំណែងពីលោកមានការព្រួយបារម្ភណ៍អំពីឥទ្ធិពលរបស់បរទេសដែលនឹងនាំមកនូវការផ្លាស់ប្តូរនៅក្នុងប្រទេសជប៉ុន។ ដូច្នេះពួកគេបានបណ្តេញពួកពាណិជ្ជករ និងបេសកទូតសាសនាបរទេសចេញពីប្រទេសជប៉ុន។ ពួកគេបានហាមឃាត់គ្រីស្តសាសនា និងបានប្រហារជីវិតជនជាតិជប៉ុនដែលកាន់សាសនាគ្រីស្ត។ ពួកគេក៏បានហាមឃាត់មិនឱ្យប្រជាជនជប៉ុនចាកចេញពីប្រទេសជប៉ុន និងបានបញ្ចប់ពាណិជ្ជកម្មអន្តរជាតិស្ទើរតែទាំងស្រុង។ នៅពេលនោះ ប្រទេសជប៉ុនបានឈានទៅរកសម័យកាលនៅដាច់ពីគេមួយ ឬការផ្តាច់ខ្លួនចេញពីពិភពលោក ដែលបន្តរហូតដល់ទសវត្សរ៍ឆ្នាំ 1850 ។

វិភាគអំពីឥទ្ធិពល៖ ពិពណ៌នាអំពីរបៀបដែលប្រទេសជប៉ុនក្លាយជាសង្គមយោធាមួយ។

# មេរៀនទី 2៖ ប្រទេសកូរ៉េ និងអាស៊ីអាគ្នេយ៍

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានអាចនៅក្នុងជំពូកនេះ ការអភិវឌ្ឍរបស់ជប៉ុនទទួលរងឥទ្ធិពលយ៉ាងសំខាន់មួយមកពីប្រទេសចិន។ មិនមែនតែប្រទេសជប៉ុនមួយទេ ប្រទេសចិនក៏ជះឥទ្ធិពលដល់ប្រទេសជិតខាងរបស់ខ្លួនផងដែរ។ ព្រះរាជាណាចក្រតូចៗនៅក្នុងប្រទេសកូរ៉េ និងអាស៊ីអាគ្នេយ៍រះឡើងក្រោមស្រមោលរបស់ប្រទេសចិនដែលស្ថិតនៅភាគខាងជើង និងឥណ្ឌាស្ថិតនៅភាគខាងលិច។

## 1. កូរ៉េឯករាជ្យ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាប្រទេសកូរ៉េទទួលយកជាតុជាច្រើននៃវប្បធម៌របស់ប្រទេសចិន?

កូរ៉េគឺជាប្រទេសដែលមានអាយុកាលចំណាស់មួយនៅលើពិភពលោក។ យោងទៅតាមទេវកថា ប្រទេសនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 2300 មុនគ.ស។ ប្រទេសកូរ៉េបានអភិវឌ្ឍឯករាជ្យពីប្រទេសចិន ប៉ុន្តែប្រទេសនេះបានទទួលរងឥទ្ធិពលវប្បធម៌របស់ចិន។ នៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ កូរ៉េបានខ្ចីការប្រតិបត្តិ និងទស្សនរបស់ចិន។ ប៉ុន្តែ ក៏ដូចជាប្រទេសជប៉ុនដែរ ពួកគេទទួលយកនូវអ្វីដែលពួកគេខ្ចីមកប្រើឱ្យស៊ីគ្នាជាមួយនិងតម្រូវការជាក់ស្តែងរបស់ពួកគេ។

ទីតាំងភូមិសាស្ត្រប្រទេសកូរ៉េ៖ កូរ៉េគឺជាឧបទ្វីបមួយ។ វាបានលាតសន្ធឹងពីចិនភាគខាងជើងទៅភាគខាងត្បូង នៅអាស៊ីជីគោក។ មានតែទន្លេយ៉ាលូ និងទូមេនទេដែលបានញែកកូរ៉េចេញពីប្រទេសជិតខាងរបស់ខ្លួននៅភាគខាងជើង។ ដូច្នេះចលនារវាងប្រទេសទាំងពីរមានភាពងាយស្រួលនៅក្នុងប្រវត្តិសាស្ត្រ។ ប្រទេសកូរ៉េក៏ស្ថិតនៅជិតដែនកោះជប៉ុន។ វប្បធម៌ចិនពេលខ្លះរីកសាយភាយទៅកាន់ប្រទេសជប៉ុនតាមរយៈប្រទេសកូរ៉េ។

ការបង្កើតព្រះរាជាណាចក្រកូរ៉េ៖ ក្រុមអ្នកតាំងទីលំនៅដំបូងនៅក្នុងប្រទេសកូរ៉េ ប្រហែលជាពួកចរកជនមកពីភាគខាងជើង។ ពួកគេរស់នៅជាលក្ខណៈកុលសម្ព័ន្ធ។ នៅក្នុងឆ្នាំ 108 មុនគ.ស ចិនហានបានឈ្លានពានកូរ៉េភាគខាងជើង។ ពួកកូរ៉េបានតស៊ូប្រឆាំង និងទទួលជោគជ័យនៅក្នុងយកត្រឡប់មកវិញនូវដែនដីដែលបាត់បង់មួយភាគធំនៅត្រឹមឆ្នាំ 75 មុនគ.ស។ ក្នុងរយៈពេលជាង 700 ឆ្នាំ ព្រះរាជាណាចក្រសំខាន់ៗចំនួន 3 បានលេចឡើងនៅក្នុងប្រទេសកូរ៉េ។ ព្រះរាជាណាចក្រទាំង 3 នេះវាយប្រយុទ្ធគ្នាដើម្បីអំណាច ឬគ្រប់ដណ្តប់លើឧបទ្វីបកូរ៉េ។ ព្រះរាជាណាចក្រស៊ីឡាដែលស្ថិតនៅភាគអាគ្នេយ៍ បានដណ្តើមកាន់កាប់ព្រះរាជាណាចក្រពីរផ្សេងទៀតនៅអំឡុងទសវត្សឆ្នាំ 600 ។ ពួកគេបានវាយបញ្ចេញចេញនូវពួកចិនដែលនៅសះសល់ផងដែរ។

ព្រះរាជាណាចក្រស៊ីឡាបានបង្រួបបង្រួមប្រទេសកូរ៉េជាលើកដំបូង។ ប៉ុន្តែ ភ្លាមៗនោះពួកអភិជនស៊ីឡាបានវាប្រយុទ្ធគ្នាទៅវិញទៅមកដើម្បីដណ្តើមអំណាច។ ក៏ដូចគ្នាដែរ ប្រជាកសិករបានងើបឡើងបះបោរ។ ជម្លោះទាំងនេះបានបណ្តាលឱ្យស៊ីឡាដួលរលំនៅក្នុងឆ្នាំ 935 ។ ព្រះរាជាណាចក្រមួយដែលមានឈ្មោះថា កូយ៉ូ បានជំនួសស៊ីឡា។ ឈ្មោះរបស់ប្រទេសកូរ៉េវិវត្តមកពីឈ្មោះព្រះរាជាណាចក្រនេះ។

ឥទ្ធិពលរបស់ចិនលើប្រទេសកូរ៉េ៖ មេដឹកនាំកូយ៉ូបានយកគំរូរដ្ឋាភិបាលរបស់ពួកគេតាមលំនាំរបស់ចិន។ កូរ៉េក៏បានរៀនពីការដាំដុះដំណាំស្រូវ និងប្រហែលជាផលិតក្រដាស់ពីចិនផងដែរ។ ជាងនេះទៅទៀត ពួកគេបានទទួលយកនូវរចនាប័ទ្មសិល្បៈរបស់ចិន ដោយក្នុងនោះរួមមានទាំងវិធីសាស្ត្រនៅក្នុងការផលិតភាជន៍ផងដែរ។ តាមពិតទៅ ប្រទេសកូរ៉េមានភាពល្បីល្បាញសម្រាប់ការផលិតភាជន៍ពណ៌បៃតងស្រាល។ ពួកកូរ៉េក៏បានរៀនអំពីប្រព័ន្ធជំនឿ 2 របស់ចិន៖ ពុទ្ធសាសនា និងខុងជឺនិយម។ ពុទ្ធសាសនាត្រូវបានទទួលយកដំបូងដោយពួកអភិជន និងក្រោយមកដោយប្រជាជនសាមញ្ញ។ បន្ទាប់មកវាបានរីកសាយភាយនៅក្នុងប្រទេសកូរ៉េ និងប្រទេសជប៉ុន។

ការតស៊ូប្រឆាំងជាមួយការឈ្លានពានរបស់បរទេស៖ ប្រទេសកូរ៉េបន្តបង្រួបបង្រួម និងឯករាជ្យអស់ជាច្រើនសតវត្ស។ ប៉ុន្តែពួកគេត្រូវតស៊ូដើម្បីសេរីភាពពីការត្រួតត្រារបស់បរទេស។ នៅក្នុងឆ្នាំ 1231 ក្រុមអ្នកឈ្លានពានម៉ុងហ្គោលមកពីប្រទេសចិនបានធ្វើការឈ្លានពានលើប្រទេសកូរ៉េ។ ពួកគេទាមទារសួយសារអាករក្នុងទំហំដ៏ធំមួយ ដោយក្នុងនោះមានទាំងការផ្គត់ផ្គង់ និងយោធា។ ពួកគេក៏បាននាំយកកុមារ និងកម្មករជំនាញរាប់ពាន់ណាទៅធ្វើជាទាសករ។ ឥទ្ធិពលរបស់ម៉ុងហ្គោលលើប្រទេសកូរ៉េបានបន្តរហូតដល់ទសវត្សរ៍ឆ្នាំ 1360 នៅពេលដែលចក្រភពម៉ុងហ្គោលដួលរលំ។

នៅក្នុងឆ្នាំ 1392 គ្រួសារយីដែលមានអំណាចបានត្រួតត្រាប្រទេសកូរ៉េ។ ពួកគេបានបង្កើតសន្តតិវង្សថ្មីមួយគឺសន្តតិវង្សឆូស៊ុន ដែលបានដឹកនាំប្រទេសកូរ៉េអស់រយៈពេលជាង 500 ឆ្នាំ។ មេដឹកនាំឆូស៊ុនជ្រើសរើសរាជធានីថ្មីមួយដែលមានឈ្មោះថា សេអ៊ូល ស្ថិតនៅតាមដងទន្លេហាន ភាគកណ្តាលនៃប្រទេស។ ពួកគេក៏បានបោះជំហានទៅរកការពង្រឹងវិស័យការពាររបស់ពួកគេផងដែរ។ ពួកគេបានស្ថាបនាបន្ទាយនៅតាមព្រំដែនភាគខាងជើងជាមួយប្រទេសចិន ហើយពួកគេបានបណ្តាញពួកចោរសមុទ្ទជប៉ុនចេញពីកោះមួយចំនួននៅតាមតំបន់ឆ្នេរ។ សកម្មភាពទាំងនេះបាននាំមកនូវសម័យសន្តិភាពដ៏យូរអង្វែងមួយនៅក្នុងប្រទេសកូរ៉េ។ ប៉ុន្តែ នៅក្នុងឆ្នាំ 1592 កងកម្លាំងរបស់ជប៉ុនបានឈ្លានពានប្រទេសកូរ៉េ។ ពួកកូរ៉េជាមួយនឹងជំនួយពីសម្ព័ន្ធមិត្តចិន បានបញ្ឈប់ការរុលទៅមុខរបស់ជប៉ុននៅត្រង់ទន្លេយ៉ាលូ។ ប៉ុន្តែ ពួកគេត្រូវចំណាយពេល 6 ឆ្នាំទៀតដើម្បីបណ្តាញពួកឈ្លានពានចេញពីឧបទ្វីបកូរ៉េ។

វិភាគអំពីផលប៉ះពាល់៖ ពន្យល់ពីមូលហេតុដែលនាំឱ្យកូរ៉េទទួលយកជាតុជាច្រើននៃវប្បធម៌ចិន។

## 2. ចក្រភពខ្មែរ

សំណួរគន្លឹះ៖ តើចក្រភពខ្មែរសម្របជាមួយឥទ្ធិពលពីខាងក្រៅយ៉ាងដូចម្តេច?

មានឧបទ្វីបមួយទៀត គឺឧបទ្វីបឥណ្ឌូចិន លាតសន្ធឹងរហូតដល់ចិនភាគខាងត្បូង។ វាគឺជាទីតាំងរបស់ចក្រភពខ្មែរ ដែលជាព្រះរាជាណាចក្រដែលមានអំណាចខ្លាំងបំផុត និងវែងបំផុតនៅអាស៊ីអាគ្នេយ៍ដីគោក។ វាគឺមជ្ឈមណ្ឌលមួយដែលបច្ចុប្បន្នប្រទេសកម្ពុជា។ វប្បធម៌របស់ខ្មែរទទួលរងឥទ្ធិពលមកពីប្រទេសជិតខាងចិន។ ប៉ុន្តែប្រទេសជិតខាងភាគខាងលិចគឺប្រទេសឥណ្ឌា បានជះឥទ្ធិពលដ៏ខ្លាំងក្លាមួយ។ ខ្មែរបានយកទស្សនឥណ្ឌា

អំពីការដឹកនាំដោយទេវរាជមួយអង្គ, ប្រព័ន្ធសរសេរ, និងទម្រង់នៃពុទ្ធសាសនា និងហិណ្ឌូ។ ជាងនេះទៅទៀត យោងតាមរឿងព្រេង មេដឹកនាំខ្មែរគឺជាបច្ឆាជនរបស់សន្តតិវង្សមួយដែលរៀបចំអាពាហ៍ពិពាហ៍ដោយព្រះសិវៈ។

ប្រវត្តិសាស្ត្រដំបូង៖ នៅរង្វង់ឆ្នាំ 100 នៃគ.ស ប្រជាជនដែលបច្ចុប្បន្នស្ថិតនៅផ្នែកភាគខាងត្បូងនៃប្រទេសកម្ពុជាបានបង្កើតព្រះរាជាណាចក្រហ្វូណាន។ ប្រជាជនហ្វូណានគឺជាអ្នកធ្វើដំណើរតាមសមុទ្ទ ដោយពួកគេមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសចិន និងដែនដីផ្សេងៗទៀត។ ប៉ុន្តែ ពួកគេទទួលឥទ្ធិពលទំនៀបទម្លាប់ជាច្រើនរបស់ឥណ្ឌា ដោយក្នុងនោះរួមមានទាំងសាសនាហិណ្ឌូផងដែរ។ ត្រឹមទសវត្សរ៍ឆ្នាំ 500 ហ្វូណានចាប់ផ្តើមធ្លាក់ចុះ។ ប្រជាជនមកពីភាគខាងជើងដែលគេស្គាល់ថាខ្មែរ បានធ្វើដំណើរចូលមកកាន់តំបន់ភាគខាងត្បូង និងបានបង្កើតព្រះរាជាណាចក្រតូចៗជាច្រើន។ សេដ្ឋកិច្ចរបស់ព្រះរាជាចក្រទាំងនេះពឹងផ្អែកលើពាណិជ្ជកម្ម និងការដាំដុះ។ ប៉ុន្តែ ពួកគេរុងរឿងដោយសារតែពួកគេទទួលជោគជ័យនៅក្នុងការដាំដុះស្រូវ ដែលបានរៀនពីចិន។ ប្រជាកសិករបានស្ថាបនាយ៉ាងល្អប្រសើរនូវប្រព័ន្ធធារាសាស្ត្រ ដែលបានជួយពួកគេនៅក្នុងការដាំដុះដំណាំ។ ពួកគេក៏បានអភិវឌ្ឍគ្រាប់ពូជឱ្យកាន់តែប្រសើរ ដែលអាចអនុញ្ញាតឱ្យពួកគេអាចដាំដុះវាបាន 3 ដងក្នុងមួយឆ្នាំ។

សម័យអង្គរ៖ ត្រឹមទសវត្សរ៍ឆ្នាំ 800 ព្រះរាជាណាចក្រខ្មែរបានរួមបញ្ចូលគ្នាទៅជាចក្រភពដ៏ធំមួយ។ នៅពេលនោះ មេដឹកនាំខ្មែរចាប់ផ្តើមស្ថាបនារាជធានីថ្មីមួយនៅអង្គរ។ ប្រាសាទជាច្រើនត្រូវបានស្ថាបនានៅទីនោះ។ សំណង់ប្រាសាទដែលល្បីល្បាញបំផុតមួយត្រូវបានគេស្គាល់ថា អង្គរវត្ត ត្រូវបានស្ថាបនាឡើងនៅក្នុងទសវត្សរ៍ឆ្នាំ 1100 ។ ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក 5 សំណង់ប្រាសាទនេះត្រូវបានស្ថាបនាឡើងធ្វើជាភ្នំនិមិត្តរូបមួយដើម្បីឧទ្ទិសដល់អាទិទេពហិណ្ឌូមួយអង្គគឺព្រះវិស្ណុ។ ក្រុមអ្នកស្ថាបនាប្រាសាទបានឆ្លាក់នៅលើជញ្ជាំងប្រាសាទនូវរូបចម្លាក់ប្រគបដោយគុណភាពខ្ពស់បំផុត។ ចម្លាក់មួយចំនួនបង្ហាញពីសកម្មភាពរបស់ព្រះវិស្ណុ។ ចម្លាក់មួយចំនួនទៀតបង្ហាញពីរូបភាពនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ ចក្រភពខ្មែរបានឡើងដល់កម្រិតកំពូលនៅក្នុងទសវត្សរ៍ឆ្នាំ 1200 នៅពេលដែលពួកគេត្រួតត្រាលើតំបន់ឧបទ្វីបឥណ្ឌូចិនស្ទើរតែទាំងស្រុង។ ប៉ុន្តែ ចក្រភពនេះចាប់ផ្តើមធ្លាក់ចុះនៅក្នុងទសវត្សរ៍ឆ្នាំ 1300 ។ កម្មវិធីសាងសង់សំណង់ធំៗត្រូវបានបង្កើតឡើងដោយមេដឹកនាំខ្មែរបានធ្វើឱ្យធនធានរីងស្ងួត។ ក៏ដូចគ្នាដែរ ចក្រភពទទួលរងការវាយប្រហារពីសំណាក់ព្រះរាជាណាចក្រជិតខាង។ នៅក្នុងឆ្នាំ 1431 អង្គរបានធ្លាក់ក្រោមការត្រួតត្រារបស់សៀម ដែលមកពីតំបន់ថៃភាគខាងត្បូង។

សង្ខេប៖ បង្ហាញពីរបៀបដែលចក្រភពខ្មែរសម្របខ្លួនជាមួយនឹងឥទ្ធិពលមកពីខាងក្រៅ។

### 3. ព្រះរាជាណាចក្ររបស់វៀតណាម

សំណួរគន្លឹះ៖ តើចិនបានតួនាទីអ្វីខ្លះនៅក្នុងការអភិវឌ្ឍព្រះរាជាណាចក្ររបស់វៀតណាម ?

ជួរភ្នំបានញែកតំបន់ឧបទ្វីបអាស៊ីអាគ្នេយ៍ដីគោកជាមួយប្រទេសចិននៅភាគខាងជើង។ ដូច្នេះការធ្វើដំណើរទៅមកតំបន់ទាំងពីរនេះភាគច្រើនត្រូវធ្វើឡើងតាមសមុទ្ទ ឬតាមតំបន់ទំនាបឆ្នេរសមុទ្រ។ កងកម្លាំង, ពាណិជ្ជករ, និងបេសកទូតចិនបានធ្វើដំណើរតាមផ្លូវទាំងនេះ ដូចដែលពួកគេបាននាំយកវប្បធម៌របស់ចិនមកកាន់ប្រទេសវៀតណាម និងតំបន់ផ្សេងៗទៀត។

ព្រះរាជាណាចក្រវៀត៖ ពួកវៀតគឺជាប្រជាជនដែលរស់នៅភាគខាងត្បូងប្រទេសចិនដែលបច្ចុប្បន្នគឺជាប្រទេសវៀតណាម។ នៅក្នុងឆ្នាំ 111 មុនគ.ស ចិនបានដណ្តើមកាន់កាប់ព្រះរាជាណាចក្ររបស់ពួកគេ ដែលមានឈ្មោះថា អាណ្ណាម។ ដំបូង ការដឹកនាំរបស់ចិនមិនមានភាពកាចសាហាវឡើយ។ ភាគច្រើន មេដឹកនាំចិនចង់ប្រើប្រាស់កំពង់ផែនៅក្នុងតំបន់នេះដើម្បីធ្វើពាណិជ្ជកម្មក្នុងតំបន់។ នាវាពាណិជ្ជកម្មចិនត្រូវការទីកន្លែងដើម្បីឈប់សំចតនៅតាមផ្លូវទៅ និងមកពីប្រទេសចិន និងដែនកោះនៃអាស៊ីអាគ្នេយ៍។ ថ្វីបើដូច្នេះក៏ដោយ ភ្លាមៗនោះមេដឹកនាំចិនបានបង្ខំឱ្យពួកវៀតណាមទទួលយកវប្បធម៌របស់ពួកគេ។ ឧទាហរណ៍ ពួកគេតម្រូវឱ្យពួកវៀតណាមនិយាយភាសាចិន និងស្លៀកសំលៀកបំពាក់បែបចិន។ ពួកគេបានបង្ខំឱ្យពួកវៀតណាមអនុវត្តគោលការណ៍ខុងជឺនិយម និងតាវនិយមផងដែរ។ ប៉ុន្តែពួកវៀតណាមជាច្រើនបានប្រឆាំងជាមួយនឹងការបង្ខិតបង្ខំនេះ។

ការបណ្តេញពួកចិនចេញ៖ នៅក្នុងឆ្នាំ 40 នៃគ.ស ត្រុង ត្រាច ដែលជាស្ត្រីអភិជនមួយរូបដែលស្វាមីរបស់គាត់ត្រូវបានសម្លាប់ដោយចិន បានដឹកនាំការបះបោរមួយប្រឆាំងជាមួយការត្រួតត្រារបស់ចិន។ ប្អូនស្រីរបស់គាត់ឈ្មោះ ត្រុង នី ក៏បានចូលរួមជាមួយគាត់ផងដែរ។ កងកម្លាំងរបស់ពួកគេទទួលបានជោគជ័យនៅដើមដំបូង ប៉ុន្តែក្រោយមកត្រូវបានបង្ក្រាប។ ពួកវៀតណាមបានបះបោរជាច្រើនលើកនៅអំឡុងប៉ុន្មានសតវត្សរ៍បន្ទាប់។ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានោះពួកគេនៅតែបន្តទទួលយកធាតុនានានៃវប្បធម៌ចិន ដោយក្នុងនោះរួមមានទាំងពុទ្ធសាសនាផងដែរ។ នៅក្នុងទសវត្សរ៍ឆ្នាំ 900 សន្តតិវង្សតាងរបស់ចិនបានធ្លាក់ចុះ ដូច្នេះអាចទាមទារឯករាជ្យបានដោយជោគជ័យ។

ដាយវៀត៖ នៅក្នុងឆ្នាំ 939 វៀតណាមបានបង្កើតព្រះរាជាណាចក្រឯករាជ្យមួយឈ្មោះថាដាយវៀត។ មេដឹកនាំរបស់ព្រះរាជាណាចក្រនេះបានបង្កើតរដ្ឋាភិបាលកណ្តាលរឹងមាំមួយ និងជម្រុញឱ្យមានការដាំដុះ និងពាណិជ្ជកម្ម។ ប៉ុន្មានឆ្នាំក្រោយមក ព្រះរាជាណាចក្រនេះរុងរឿង។ ប៉ុន្តែ ប្រទេសចិននៅតែបន្តគំរាមកំហែងដល់ពួកគេ។ នៅក្នុងទសវត្សឆ្នាំ 1200 ពួកម៉ុងហ្គោលដែលបានដណ្តើមកាន់កាប់ប្រទេសចិន បានធ្វើការវាយប្រហារលើវៀតណាម។ ស្ថិតនៅក្រោមការដឹកនាំដ៏វៃឆ្លាតរបស់ឧត្តមសេនីយ៍ត្រានហុងថាវ ពួកវៀតណាមបានវាយបណ្តាញពួកឈ្លានពានឱ្យត្រឡប់ក្រោយចំនួន 3 លើក។ ប៉ុន្តែ ការវាយប្រយុទ្ធគ្នាបានបណ្តាលឱ្យព្រះរាជាណាចក្រនេះធ្លាក់ចុះយ៉ាងខ្លាំង។ នៅក្នុងឆ្នាំ 1407 កងកម្លាំងចិនរបស់សន្តតិវង្សម៉ីងបានឈ្លានពានព្រះរាជាណាក្រវៀតណាម។ ពួកគេយកជ័យជំនះលើវៀតណាម ប៉ុន្តែមិនអាចរក្សាការគ្រប់គ្រងអំណាចរបស់ពួកគេបានឡើយ។ បន្តិចម្តងៗ វៀតណាមបានវាយបណ្តាញពួកគេចេញនៅក្នុងឆ្នាំ 1428 និងត្រឡប់ទៅគ្រប់គ្រងប្រទេសដោយខ្លួនពួកឡើងវិញ។ ពេលនោះដាយវៀតបានពង្រឹងតួនាទីរបស់ពួកគេយតាមរយៈការដណ្តើមកាន់កាប់ចាម្ប៉ា ដែលជាព្រះរាជាណាចក្រមួយស្ថិតនៅភាគខាងត្បូងវៀតណាម។

វិភាគអំពីផលប៉ះពាល់៖ ពន្យល់ពីតួនាទីរបស់ប្រទេសចិននៅក្នុងការអភិវឌ្ឍព្រះរាជាណាចក្រនៅវៀតណាម។

# មេរៀនទី 3 ៖ ចក្រភពម៉ូហ្គាល់នៅឥណ្ឌា

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក 5 ប្រទេសឥណ្ឌាបានឆ្លងកាត់នូវយុគមាសមួយស្ថិតនៅក្រោមចក្រគុប្តៈ។ អំឡុងសម័យនេះ សាសនាហិណ្ឌូបានលេចឡើងជាសាសនាគ្របដណ្តប់ក្នុងប្រទេសឥណ្ឌាសារជាថ្មី។ ប៉ុន្តែ យុគមាសនេះមានអាយុកាលខ្លីណាស់។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 400 នៃគ.ស ពួកចរកជនមកពីអាស៊ីកណ្តាលបានឆ្លងកាត់តំបន់វាលទំនាប និងចូលមកកាន់ឥណ្ឌាភាគខាងជើង។ ពួកគេបានផ្តួលរំលំចក្រភពគុប្តៈនៅវង្វង់ឆ្នាំ 540 នៃគ.ស។

## 1. ប្រវត្តិសាស្ត្រដំបូងរបស់ម៉ូហ្គាល់

សំណួរគន្លឹះ៖ តើចក្រភពម៉ូហ្គាល់ស្ថាបនាឡើងដោយរបៀបណា?

បន្ទាប់ពីការដួលរលំនៃចក្រភពគុប្តៈ ប្រទេសឥណ្ឌាបានបែកខ្ញែកជាព្រះរាជាណាចក្រតូចជាច្រើន។ ព្រះរាជាណាចក្រទាំងអស់នេះបានវាយប្រយុទ្ធគ្នាទៅវិញទៅមក។ ពួកគេក៏ប្រឈមជាមួយនឹងបញ្ហាពីខាងក្រៅផងដែរ។ ទីមួយគឺការឈ្លានពានរបស់ពួកម៉ូស្លីមអារ៉ាប់។ ទីពីរគឺការមកដល់នៃពួកម៉ូស្លីមតួក និងបានត្រួតត្រាលើដែនដីភាគខាងលិចច្រលងទន្លេឥណ្ឌូស។ នៅវង្វង់ឆ្នាំ 1000 កងទ័ពដែលទទួលបានការបណ្តុះបណ្តាលយ៉ាងល្អរបស់តួកបានឆ្លងទន្លេឥណ្ឌូស។ នៅក្នុងយុទ្ធដ៏ឃោឃៅជាបន្តបន្ទាប់ ពួកគេដណ្តើមកាន់កាប់ឥណ្ឌាភាគខាងជើង។ ពួកតួកបានស្ថាបនាព្រះរាជាណាចក្រមួយដែលមានមូលដ្ឋាននៅទីក្រុងដេលីដែលមានឈ្មោះថាស៊ុលតង់ដេលី។ ពួកអ្នកដឹកនាំម៉ូស្លីមចាត់ទុកពួកប្រជារាស្ត្រហិណ្ឌូរបស់ពួកគេថាជាប្រជាជនដែលពួកគេដណ្តើមកាន់កាប់ និងបានអនុវត្តចំពោះពួកយ៉ាងព្រៃផ្សៃ។ ការគ្រប់គ្រងរបស់ស៊ុលតង់មានរយៈពេលប្រមាណ 300 ឆ្នាំរហូតដល់មានការឈ្លានពានមួយផ្សេងទៀតបានកើតឡើង។ នៅក្នុងឆ្នាំ 1398 ពួកម៉ុងហ្គោលមកពីអាស៊ីកណ្តាលបានឈ្លានពានមកលើឥណ្ឌា។ ដឹកនាំដោយអ្នកឈ្លានពានដ៏កាចសាហាវឈ្មោះ ទីមួរ ពួកគេម៉ុងហ្គោលបានដុតបំផ្លាញដេលី និងកម្ទេចស៊ុលតង់ចោល។ ជាថ្មីម្តងទៀត ឥណ្ឌាភាគខាងជើងបានបែកខ្ញែកទៅជាព្រះរាជាណាចក្រតូចៗ។

បាប៊ួរ៖ អស់រយៈពេលមួយសតវត្សរ៍ ព្រះរាជាណាចក្រតូចៗទាំងនេះបានធ្វើសង្គ្រាមជាមួយគ្នាទៅវិញទៅមក។ បន្ទាប់មកក្រុមដែលមានអំណាចថ្មីមួយបានឈ្លានពានចូលមកក្នុងប្រទេសឥណ្ឌា និងបានត្រួតត្រានៅទីនោះ។ ក្រុមមនុស្សទាំងនេះគឺជាពួកម៉ូហ្គាល់ដែលជាពួកក្រុមអ្នកឈ្លានពានម៉ូស្លីមមកពីអាស៊ីកណ្តាល។ មេដឹកនាំរបស់ពួកគេគឺ បាប៊ួរ ជាឧត្តសេនីយ៍វៃឆ្លាតមួយរូបដែលជាបច្ឆាជនរបស់ទាំងទីមួរ និងសង់ស៊ីខាន់ (អ្នកបានសិក្សាពីសង់ស៊ី ខាន់នៅក្នុងជំពូក 14)។ ចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1526 បាប៊ួរបានយកជ័យជំនះលើកងទ័ពរបស់ស៊ុលតង់ក្នុងតំបន់មួយចំនួននៅក្នុងសម័យភូមិនានា។ យោងតាមប្រភពឯកសារជាច្រើន ទ្រង់បានប្រើប្រាស់កងទ័ពតែ 12,000 នាក់ប៉ុណ្ណោះដើម្បីវាយប្រយុទ្ធនៅក្នុងសមរភូមិមួយប្រឆាំងជាមួយកងទ័ពស៊ុលតង់ដេលីដែលមានចំនួន 100,000 នាក់ និងដំរីរាប់រយក្បាល។ ដោយសារតែកងទ័ពរបស់បាប៊ួរមានវិន័យខ្ពស់ និងមានអាវុធ និងយុទ្ធភ័ណ្ឌល្អៗ ដូច្នេះកងទ័ពរបស់បាប៊ួរបានទទួលជ័យជំនះដ៏អស្ចារ្យមួយ។

ត្រឹមឆ្នាំ 1529 បាបួរបានដណ្តើមកាន់កាន់ដែនដីឥណ្ឌាភាគខាងជើងទាំងអស់ និងចាប់ផ្តើមបង្រួបបង្រួមព្រះរាជាណាចក្រតូចៗ។ ការបង្រួបបង្រួមនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃចក្រភពដ៏ធំមួយ។ ប៉ុន្តែ មួយឆ្នាំក្រោយមកទ្រង់បានសុគត។ រាជបុត្ររបស់ទ្រង់ព្រះនាម ហ៊ូម៉ាយុន ដែលជាអ្នកទទួលបានការអប់រំមួយរូបដែលគាំទ្រលើសិល្បៈ និងការរៀនសូត្រ បានឡើងគ្រប់គ្រងអំណាច។ ប៉ុន្តែទ្រង់ត្រូវបានគេចាត់ទុកថាជាមេដឹកនាំខ្សោយមួយអង្គ។ ទ្រង់ស្ទើតែបាត់បង់ការត្រួតត្រាចក្រភពដែលបិតារបស់ទ្រង់បានស្ថាបនា។ នៅក្នុងឆ្នាំ 1556 ហ៊ូម៉ាយុន បានសុគតដោយមិននឹងស្មាដល់មួយបន្ទាប់ពីទ្រង់ដួល។ ចៅរបស់បាបួរ ដែលទើបតែមានព្រះជន្ម 13 ព្រះវស្សាបានឡើងគ្រប់គ្រងអំណាច។

សង្ខេប៖ ពិពណ៌នាអំពីរបៀបដែលចក្រភពម៉ូហ្គាល់ត្រូវបានស្ថាបនាឡើង។

## 2. យុគមាសរបស់អាកបា

សំណួរគន្លឹះ៖ តើអាកបាបង្ហាញពីការអត់ឱន និងយល់ដឹងរបៀបណានៅក្នុងការដឹកនាំចក្រភពម៉ូហ្គាល់ ?

ចៅប្រុសរបស់បាបួរព្រះនាមអាកបា ដែលមានន័យថា "អ្នកដ៏អស្ចារ្យ"។ អំឡុងរាជរបស់ទ្រង់ ទ្រង់បានបង្ហាញពីភាពសាកសមរបស់ទ្រង់ចំពោះព្រះនាមនេះ។ នៅពេលដែលទ្រង់ទើបតែមានព្រះជន្ម 19 ព្រះវស្សា អាកបាបានត្រួតត្រាចក្រភពទាំងមូល។ ទ្រង់បានបង្ហាញពីទេពកោសល្យខាងយោធាតាមរយៈការស្ថាបនាចក្រភពរបស់ទ្រង់ និងឧត្តមគតិក្នុងការគ្រប់គ្រងវា។

មេដឹកនាំដ៏អស្ចារ្យមួយរូប៖ ក្នុងនាមជាឧត្តមសេនីយ៍មួយរូប អាកបាមិនមាននណាអាចប្រដែងបានឡើយ។ ទ្រង់បានបំពាក់កងទ័ពរបស់ទ្រង់ជាមួយកាំភ្លើងធំ។ ជាមួយនឹងអាវុធទាំងនេះ កងទ័ពរបស់ទ្រង់បានកម្ទេចជញ្ជាំងនៅជុំវិញទីក្រុងនានា។ យុទ្ធសាស្ត្រនេះធ្វើឱ្យកងទ័ពរបស់ទ្រង់ដណ្តើមកាន់កាប់ទីក្រុងនានាយ៉ាងងាយស្រួល។ អាកបាក៏បានតែងតាំងមេដឹកនាំយោធាក្នុងតំបន់ធ្វើជាមន្ត្រីនៅក្នុងជួរកងទ័ពរបស់ទ្រង់ផងដែរ។ ជាលទ្ធផល ទ្រង់បានត្រឡប់សត្រូវឱ្យក្លាយជាសម្ព័ន្ធមិត្ត។ បន្តិចម្តងៗទ្រង់បានពង្រីកចក្រភពម៉ូហ្គាល់ទៅកាន់តំបន់ខ្ពង់រាបដេកាន ដែលជាតំបន់ខ្ពង់រាបមួយនៅភាគកណ្តាលនៃឧបទ្វីបឥណ្ឌា។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាកបា ប្រជាជននៅក្នុងចក្រភពបានកើនឡើងរហូតដល់ប្រមាណ 100 លាននាក់ ដែលច្រើនជាងចំនួនមនុស្សរស់នៅអឺរ៉ុបទាំងមូលនៅពេលនោះ។

មេដឹកនាំប្រកបដោយឧត្តមគតិមួយរូប៖ ក្នុងនាមជាអធិរាជមួយអង្គ អាកបាបានបង្ហាញពីឧត្តមគតិ និងការអត់ឱនដ៏អស្ចារ្យ។ ទ្រង់គឺជាម៉ូស្លីម ប៉ុន្តែភាគច្រើននៃប្រជានុរាស្ត្ររបស់ទ្រង់មិនមែនជាម៉ូស្លីមឡើយ។ ទ្រង់ដឹងថាទ្រង់ត្រូវបានកិច្ចសហប្រតិបត្តិការរបស់ពួកគេដើម្បីដឹកនាំចក្រភពរបស់ទ្រង់ ដូច្នេះទ្រង់មិនបានបង្ខំឱ្យពួកគេទទួលយកជំនឿរបស់ទ្រង់ឡើយ។ ជាជាងទ្រង់បានអនុញ្ញាតឱ្យអ្នកដែលមិនមែនមូស្លីមអាចប្រតិបត្តិសាសនាផ្ទាល់របស់ពួកគេ។ ទ្រង់ក៏បានរៀបអភិសេកជាមួយស្ត្រីហិណ្ឌូ 2 រូប, ស្ត្រីគ្រីស្តសាសនិកមួយរូប, និងស្ត្រីម៉ូស្លីមមួយរូប(វាគឺជាទំនៀមទម្លាប់របស់បុរសម៉ូស្លីមដែលអាចយកប្រពន្ធបានច្រើនជាងមួយ)។ ជាងនេះទៅទៀត ទ្រង់បានបញ្ឈប់ការបង់ពន្ធរបស់ពួកហិណ្ឌូ នៅពេលដែលពួកគេធ្វើដំណើរស្វែងបុណ្យទៅកាន់ទីកន្លែងពិសិដ្ឋនៅក្នុង

ប្រទេសឥណ្ឌា។ អាកបាបានបង្កើតស្ថាប័នរដ្ឋាភិបាលដែលមានប្រសិទ្ធិភាពមួយ។ មនុស្សទាំងឡាយ ទាំងហិណ្ឌូ ឬម៉ូស្លីម, ម្ចាស់ស្រុក ឬបរទេស, អាចកាន់កាប់តំណែងសំខាន់ៗនៅក្នុងជួររដ្ឋាភិបាល។ ការអនុវត្តនេះគឺដើម្បីធានាថាមនុស្សមានទេពកោសល្យអាចកាន់កាប់តំណែងកំពូលបាន។ អាកបាក៏បានបង្កើតប្រព័ន្ធពន្ធថ្មីមួយផងដែរ។ ស្ថិតនៅក្រោមប្រព័ន្ធពន្ធថ្មីនេះ ប្រជាជនបង់ពន្ធដោយផ្អែកលើតម្លៃនៃដីធ្លីរបស់ពួកគេ។ ជាលទ្ធផល ម្ចាស់កម្មសិទ្ធិដីធ្លីមានទ្រព្យសម្បត្តិស្តុកស្តម្ភត្រូវបង់ពន្ធច្រើនជាងប្រជាកសិករក្រីក្រ។ កំណែទម្រង់ដីធ្លី៖ អាកបាក៏បានព្យាយាមនៅក្នុងការបែងចែកដីធ្លីឱ្យបានទូលំទូលាយផងដែរ។ ទ្រង់បានផ្តល់ឱ្យមន្ត្រីរដ្ឋាភិបាលនូវដីធ្លីសប្បុរស។ នៅពេលដែលមន្ត្រីរាជការម្នាក់ស្លាប់ ដីធ្លីនោះត្រូវប្រគល់ត្រឡប់ទៅឱ្យអាកបាគ្រប់គ្រងវិញ។ ប្រព័ន្ធនេះការពារមន្ត្រីរដ្ឋាភិបាលពីការកាន់កាប់ដីធ្លីធំៗ។ ប៉ុន្តែ ទ្រង់ក៏បានប្រគល់ឱ្យម្ចាស់កម្មសិទ្ធិដីធ្លីនូវបណ្ណកម្មសិទ្ធិដើម្បីលើកម្ពស់ទ្រព្យសម្បត្តិរបស់ពួកគេ។ ជំនួសមកវិញ មន្ត្រីបានចំណាយប្រាក់របស់ពួកគេទៅលើរបស់ប្រណិតៗដូចជាគ្រឿងអលង្កា, សំលៀកបំពាក់ប្រណិត, និងសេះអារ៉ាប់។

ការរីកឡើងនៃវប្បធម៌៖ ដូចដែលអាកបាពង្រីកចក្រភពរបស់ទ្រង់ ទ្រង់ស្វាគមន៍ឥទ្ធិពលវប្បធម៌មកពីតំបន់ផ្សេងៗទាំងឡាយ។ មនុស្សនៅក្នុងរាជវាំងនិយាយភាសាពែក្ស។ ប៉ុន្តែ ប្រជាជនសាមញ្ញនិយាយភាសាហិណ្ឌី ដែលជាការលាយបញ្ចូលគ្នាមួយនៃភាសាពែក្សជាមួយភាសាក្នុងតំបន់មួយ។ ចក្រភពម៉ូហ្គាល់បន្សល់ទុកនូវសមិទ្ធិផលដ៏អស្ចារ្យនានានៅក្នុងវិស័យអក្សរសិល្ប:, សិល្ប:, ស្ថាបត្យកម្ម, និងការអប់រំ។ នៅក្នុងផ្នែកអក្សរសិល្ប: កំណាព្យបានរីកលូតលាស់។ កំណាព្យមួយដែលមានចំណាងជើងថា បឹងពិសិដ្ឋដែលចេញមកពីស្នាដៃរបស់ព្រះរាម គឺជាការប្រាប់ឡើងវិញនៃទេវកថាឥណ្ឌារាមាយណៈ។ ឈុតឆាតសំខាន់របស់កំណាព្យនេះគឺរឿងរ៉ាវស្នេហារវាងព្រះរាម និងសិតា។ សិល្ប:រូបភាពក៏រីកលូតលាស់ផងដែរ។ វិចិត្រករបានបង្ហាញសៀវភៅរបស់ពួកជាមួយនឹងគំនូរតូចៗដែលមានពណ៌ជម្រុះដែលគេហៅថាគំនូរតូច។ គំនូរតូចដែលល្បីល្បាញបំផុតមួយរបស់ម៉ូហ្គាល់គឺ សៀវភៅអាកបា។ សៀវភៅនេះបានប្រាប់ពីរឿងដ៏គួរឱ្យរំភើបអំពីសកម្មភាពនៃការស្ថាបនាចក្រភពម៉ូហ្គាល់របស់អាកបា។ អាកបាមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើស្ថាបត្យកម្ម។ អំឡុងរាជរបស់ទ្រង់ ទ្រង់បានចាត់ចែងឱ្យមានការស្ថាបនាសំណង់នានាមិនត្រឹមតែធំប៉ុណ្ណោះទេប៉ុន្តែជាសំណង់ដែលធ្វើពីថ្មដ៏អស្ចារ្យ។ តាមពិតទៅ សេចក្តីស្រលាញ់របស់ទ្រង់ចំពោះស្ថាបត្យកម្មបាននាំទ្រង់ទៅស្ថាបនារាជធានីថ្មីមួយនៅ ហ្វាតេពួរ សិគ្រី។ ទីក្រុងនេះស្ថាបនាឡើងដោយថ្មកក់ក្រហម ជាឧទាហរណ៍នៃរចនាបថស្ថាបត្យកម្មដ៏អស្ចារ្យនេះ។ អាកបាស្ថាបនាទីក្រុងនេះដើម្បីថ្លែងអំណរគុណដល់មនុស្សពិសិដ្ឋម្នាក់ដែលបានទស្សទាយអំពីកំណើតរបស់រាជបុត្រដំបូងរបស់ទ្រង់។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីរបៀបដែលអាកបាបង្ហាញពីភាពអត់ឱន និងការយោគយល់នៅក្នុងការគ្រប់គ្រងចក្រភពម៉ូហ្គាល់។

### 3. អ្នកបន្តតំណែងពីអាកបា

សំណួរគន្លឹះ៖ តើរបស់គ្រប់គ្រងរបស់អ្នកបន្តដំណែងពីអាកបាមានលក្ខណៈខុសប្លែកគ្នាពីយុទ្ធសាស្រ្តរបស់អាកបាយ៉ាងដូចម្តេច?

អាកបាសុគតនៅក្នុងឆ្នាំ 1605 ។ អធិរាជចំនួន 3 អង្គដែលបន្តតំណែងពីទ្រង់បង្ហាញពីការចាប់អារម្មណ៍កាន់តែខ្លាំងលើការបង្កើនអំណាចនៅក្នុងការគ្រប់គ្រង។ ជាលទ្ធផល ពួកគេមិនសូវមានប្រសិទ្ធភាពដូចអាកបាឡើយ។

ចាហានជីរ និងណួរ ចាហាន៖ រាជបុត្ររបស់អាកបាមានព្រះនាមថា ចាហានជីរ ដែលមានន័យថា "អ្នកដណ្ដើមកាន់កាប់ពិភពលោក"។ នៅត្រង់ចំណុចមួយ ទ្រង់ធ្លាប់បានបះបោរប្រឆាំងជាមួយបិតារបស់ទ្រង់ និងមានបំណងចង់ធ្វើឃាតទ្រង់ទៀតផង។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយ អាកបាបានជ្រើសរើសទ្រង់ធ្វើជាអ្នកស្នងតំណែង។ ប៉ុន្តែចាហានជីរហាក់ដូចជាមេដឹកនាំខ្សោយមួយរូប។ មហេសីរបស់ទ្រង់ ដែលជាម្ចាស់ក្សត្រីពៃក្សមួយអង្គព្រះនាម ណួរ ចាហាន គឺជាអ្នកគ្រប់គ្រងអំណាចពិតប្រាកដ។ ព្រះនាងបានដាក់សមាជិកគ្រួសាររបស់ទ្រង់ជាច្រើនទៅក្នុងតួនាទីសំខាន់នៅក្នុងរដ្ឋាភិបាល។ ហើយនៅពេលដែលចាហានជីរកាន់តែចាស់ ព្រះនាងចាប់ផ្ដើមរៀបចំគម្រោងក្បត់អ្នកដែលនឹងត្រូវបន្តតំណែងពីទ្រង់។ ដំបូង ព្រះនាងចូលចិត្តព្រះរាជបុត្ររបស់ចាហានជីរព្រះនាម ឃូស្រៅ។ ប៉ុន្តែ ឃូស្រៅបានបះបោរប្រឆាំងជាមួយចាហានជីរ។ ជាលទ្ធផល ណួរ ចាហាន ត្រឡប់ទៅប្រឆាំងជាមួយទ្រង់ និងបានប្ដូរការចូលចិត្តរបស់ទ្រង់ទៅលើរាជបុត្រផ្សេងទៀត។ ការបះបោររបស់ឃូស្រៅជាសញ្ញាណនៃការចាប់ផ្ដើមឡើងនៃជម្លោះសាសនាដ៏ជូរជត់មួយ។ នៅពេលដែលកំពុងរត់គេចខ្លួន ឃូស្រៅបានត្រឡប់ទៅរកជំនួយពីពួកស៊ីខ។ ពួកគេជាក្រុមសាសនាមួយដែលលាយបញ្ចូលគ្នានូវពុទ្ធសាសនា, ហិណ្ឌូ, និងស៊ូហ្វីនិយម (ទម្រង់សាសនាអ៊ីស្លាមមួយ)។ មេដឹកនាំរបស់ពួកគេឈ្មោះ គូរូ អរជុន បានជួយការពារឃូស្រៅ។ ប៉ុន្តែ មេដឹកនាំម៉ូហ្គាល់បានចាប់ និងសម្លាប់គូរូ អរជុន។ បន្ទាប់ពីនោះមក ម៉ូហ្គាល់បានកំណត់គោលដៅពួកស៊ីខសម្រាប់ការធ្វើទុក្ខបុកម្នេញ។

សា ចាហាន៖ រាជបុត្ររបស់ចាហានជីរព្រះនាម សា ចាហាន បានឡើងកាន់អំណាចនៅក្នុងឆ្នាំ 1628 ។ ទ្រង់គឺជាអ្នកដែលទទួលបានសិក្សាខ្ពង់ខ្ពស់ និងស្រលាញ់រឿងដែលល្អៗ។ ប៉ុន្តែទ្រង់ឡើងគ្រងរាជតាមរយៈការសម្លាប់សត្រូវទាំងអស់របស់ទ្រង់។ លើសអ្វីៗទាំងអស់ សា ចាហាន ស្រលាញ់មហេសីរបស់ទ្រង់ព្រះនាម មូមតាស ម៉ាហាល។ ជារឿងគួរឱ្យសោកស្ដាយ ព្រះនាងសុគតនៅក្នុងព្រះជន្ម 39 ឆ្នាំ។ ដោយកើតទុក្ខ សា ចាហានសន្យានៅក្នុងការស្ថាបនាផ្នូរមួយឱ្យមាន "ភាពស្រស់ស្អាតដូចជាសម្រស់ព្រះនាង" ដើម្បីជាការចងចាំព្រះនាង។ បូជនីយស្ថានតាជ ម៉ាហាល ត្រូវបានគេចាត់ទុកថាជាសំណង់មួយដែលអស្ចារ្យ និងទទួលស្គាល់ច្រើនបំផុតនៅលើពិភពលោក។ វាបានបង្ហាញជាមួយថ្មម៉ាបពណ៌ស និងថ្មពាក់កណ្ដាលមានតម្លៃ។ សា ចាហានស្ថាបនាសំណង់អស្ចារ្យជាច្រើនទៀត។ ប៉ុន្តែ ដើម្បីប្រមូលលុយសម្រាប់ការស្ថាបនា ទ្រង់បានដំឡើងពន្ធខ្ពស់មួយដល់ប្រជានុរាស្ត្ររបស់ទ្រង់។ ប្រជាជនមិនអាចមានលទ្ធភាពនៅក្នុងការស្ថាបនាផ្លូវថ្នល់, ទិញសម្ភារៈកសិកម្ម, ឬជីកប្រឡាយនាំទឹកមកកាន់ដីស្រែរបស់ពួកគេ។ ជាលទ្ធផលបណ្ដាលឱ្យមានគ្រោះអត់ឃ្លាន និងការរីករាលដាលនៃកំហឹងប្រឆាំងជាមួយ សា ចាហាន។

អូរ៉ាំងហ្សេបៈ សា ចាហានបានធ្លាក់ខ្លួនប្រឈួននៅក្នុងឆ្នាំ 1657 ហើយរាជបុត្រទាំង 4 អង្គរបស់ទ្រង់ចាប់ផ្ដើមវាយប្រយុទ្ធគ្នាទៅវិញទៅមកដើម្បីដណ្ដើមរាជបល្ល័ង្ក។ រាជបុត្រទី 3 ព្រះនាមអូរ៉ាំងហ្សេបទទួលបានការគាំទ្រច្រើន ។ ទ្រង់បានសម្លាប់បងប្អូនប្រុសរបស់ទ្រង់ 2 អង្គដែលជាគូប្រជែង។ បន្ទាប់មកទ្រង់បានចាប់បិតារបស់ទ្រង់

ឃុំព្រះកាយ។ 7, 8 ឆ្នាំក្រោយមកសា ចាហាន បានសុគត។ អំឡុងរាជរបស់ទ្រង់ ចាប់ពី 1658 ដល់ 1707 អូរ៉ាងហ្សេបបានពង្រីកចក្រភពម៉ូហ្គាល់។ ទ្រង់បានបង្ខំឱ្យប្រជានុរាស្ត្រនៅក្នុងចក្រភពរបស់ទ្រង់អនុវត្តតាមច្បាប់អ៊ីស្លាម។ ទ្រង់បានហាមឃាត់ការផឹកគ្រឿងស្រវឹង, ការលេងល្បែង, និងអំពើអបាយមុខផ្សេងៗទៀត។ ទ្រង់ក៏បានដកពួកហិណ្ឌូចេញពីតំណែងមន្ត្រីជាន់ខ្ពស់ និងឱ្យពួកគេបង់ពន្ធថ្មីមួយ។ ការធ្វើដូច្នេះ ធ្វើឱ្យពួកគេមានការខឹងសម្បាយ៉ាងខ្លាំង។ ចក្រភពបានឈ្លានចូលទៅក្នុងសម័យកាលធ្លាក់ចុះដ៏វែងមួយ។

ប្រៀបធៀប៖ ប្រៀបធៀបរចនាបថរដ្ឋាភិបាលរបស់អ្នកស្នងតំណែងពីអាកបា ជាមួយនឹងយុទ្ធសាស្ត្ររបស់អាកបា។

## 4. ការធ្លាក់ចុះនៃចក្រភពម៉ូហ្គាល់

សំណួរគន្លឹះ៖ ហេតុអ្វីបានជាចក្រភពម៉ូហ្គាល់ធ្លាក់ចុះ?

មេដឹកនាំហិណ្ឌូបានងើបឡើងបះបោរប្រឆាំង។ អូរ៉ាងហ្សេបត្រូវធ្វើការសង្គ្រាមប្រយុទ្ធជាច្រើនលើកដើម្បីបង្ក្រាបការបះបោរទាំងនេះ។ ដើម្បីចំណាយលើយោធារបស់ទ្រង់ ទ្រង់បានបង្កើនការយកពន្ធកាន់តែខ្ពស់។ ការយកពន្ធខ្ពស់នាំទៅដល់ភាពចលាចល និងស្តង់ដានៃការរស់នៅបានធ្លាក់ចុះយ៉ាងខ្លាំង។ ប្រជាជនប្រមាណ 2 លាននាក់ស្លាប់ដោយសារអត់ឃ្លាន។ ប្រជានុរាស្ត្រភាគច្រើនរបស់អូរ៉ាងហ្សេបចាប់ផ្តើមបាត់បង់ភក្តីភាពចំពោះទ្រង់។ នៅពេលដែលទ្រង់សុគតនៅក្នុងឆ្នាំ 1707 ទ្រង់បានព្រះបន្ទូលថា "ខ្ញុំបានធ្វើអំពើបាបយ៉ាងធ្ងន់ធ្ងរ, ហើយខ្ញុំមិនបានដឹងថាការដាក់ទោសអ្វីដែលរងចាំខ្ញុំ"។ ជាលទ្ធផលមួយនៃការដឹកនាំខ្សោយបន្ទាប់ពីអាកបា រដ្ឋាភិបាលម៉ូហ្គាល់បានបាត់បង់ឥទ្ធិពលរបស់ប្រជាជន។ នៅក្នុងពេលជាមួយគ្នា ស្តេចត្រាញ់ក្នុងតំបន់ទទួលបានអំណាច។ បន្ទាប់ពីអូរ៉ាងហ្សេបសុគត រាជបុត្ររបស់ទ្រង់វាយប្រយុទ្ធគ្នាដើម្បីរាជបល្ល័ង្ក។ ជាង 12 ឆ្នាំបន្ទាប់ អធិរាជ 3 អង្គឡើងគ្រប់គ្រងអំណាច។ ចក្រភពម៉ូហ្គាល់មិនអាចធ្វើឱ្យយុគមាសរបស់ពួកគេរុងរឿងសារជាថ្មីឡើងវិញឡើយ។ ជាថ្មីម្តងទៀត ប្រទេសឥណ្ឌាបានបែកខ្ញែកទៅជារដ្ឋតូចៗជាច្រើន។ អំឡុងសម័យនៃការធ្លាក់ចុះរបស់ចក្រភពម៉ូហ្គាល់ពាណិជ្ជករបស្ចិមប្រទេសចាប់ផ្តើមបង្កើតកំពង់ផែពាណិជ្ជកម្មនៅឥណ្ឌា។ ពួកព័រទុយហ្គាល់បានមកដល់ដំបូងគេ បន្ទាប់មកពីហូឡង់, បារាំង, និងចក្រភពអង់គ្លេស។ ម៉ូហ្គាល់ថែមទាំងបានជួយពួកគេទៀតផង។ ឧទាហរណ៍ សា ចាហានបានអនុញ្ញាតឱ្យចក្រភពអង់គ្លេសស្ថាបនាកំពង់ផែពាណិជ្ជកម្មមួយនៅទីក្រុងម៉ាដ្រាស។ អំឡុងរាជរបស់អូរ៉ាងហ្សេប ចក្រភពអង់គ្លេសទទួលបានសិទ្ធត្រួតត្រាលើកំពង់ផែម៉ុមបៃ។ អ្នកនឹងបានអាននៅក្នុងជំពូក 20 នៅពេលដែលចក្រភពអង់គ្លេសគ្រប់គ្រងឥណ្ឌា។

# មេរៀនទី 4៖ ចក្រភពអូតូម៉ង់

ភ្ជាប់ពីអ្វីដែលអ្នកបានដឹង៖ នៅក្នុងជំពូក 10 អ្នកបានអានអំពីការដណ្តើមកាន់កាប់ទីក្រុងកុងស្តង់ទីណុប ដោយពួកតួកអូតូម៉ង់។ នៅក្នុងផ្នែកនេះអ្នកនឹងសិក្សាពីវិធីដែលអូតូម៉ង់អភិវឌ្ឍអំណាច។

## 1. ការលេចឡើងនៃអំណាច

សំណួរគន្លឹះ៖ តើអូតូម៉ង់រៀបចំរចនាសម្ព័ន្ធចក្រភពរបស់ពួកគេដោយរបៀបណា?

អាណាតូលីជាតំបន់មួយដែលស្ថិតនៅចន្លោះសមុទ្រមេឌីទែរ៉ានេ និងសមុទ្រខ្មៅ ត្រូវបានតាំងទីលំនៅភាគច្រើនដោយបច្ឆាជនរបស់ពួកចរកជនតួក។ ពួកគេមានភក្តីភាពចំពោះក្រុមរបស់ពួកគេនៅក្នុងតំបន់ និងមិនត្រូវបានគ្រប់គ្រងដោយមជ្ឈមណ្ឌលអំណាចមួយណាឡើយ។ ក្រុមមួយក្នុងចំណោមនេះ មេដឹកនាំមួយរូបឈ្មោះ អូស្មាន បានចាប់ផ្តើមបង្រួមបង្រួមពួកតួក និងស្ថាបនាចក្រភពថ្មីមួយ។

អូស្មាន់បង្កើតចក្រភពមួយ៖ អូស្មាន់បានបង្កើតចក្រភពអូតូម៉ង់នៅក្នុងទសវត្សឆ្នាំ 1300 ។ ឈ្មោះរបស់ចក្រភពយកមកពីទម្រង់ភាសាអារ៉ាប់នៃឈ្មោះអូស្មាន់៖ អូថម៉ាន់។ អ្នកបន្តតំណែងពីអូស្មាន់បានពង្រីកចក្រភពតាមរយៈការទិញទឹកដី និងតាមរយៈការបង្កើតសម្ព័ន្ធមិត្តជាមួយប្រទេសជិតខាង។ ប៉ុន្តែ ភាគច្រើននៃទឹកដីថ្មីរបស់ពួកគេទទួលបានតាមរយៈការដណ្តើមកាន់កាប់។ អំណាចយោធាអូតូម៉ង់គឺផ្អែកសំខាន់លើកាំភ្លើង។ ជាជាងប្រើប្រាស់ធ្នូ អូតូម៉ង់ប្រើប្រាស់កងកម្លាំងយោធាជាមួយនិងកាំភ្លើង។ ពួកគេជាក្រុមមួយក្នុងចំណោមក្រុមដំបូងៗដែលប្រើប្រាស់កាំភ្លើងធំធ្វើជាអាវុធសម្រាប់ឈ្លានពាន។

ការគ្រប់គ្រងចក្រភព៖ អូតូម៉ង់ភ្លាមៗបានបង្កើតប្រព័ន្ធមួយដើម្បីគ្រប់គ្រងចក្រភព។ ស៊ុលតង់គឺជាប្រមុខដឹកនាំរដ្ឋាភិបាលចក្រភពអូតូម៉ង់។ នៅពីក្រោមស៊ុលតង់គឺក្រុមប្រឹក្សាចក្រភពដែលគេហៅថា ឌីវ៉ាន់។ ឌីវ៉ាន់ប្រឹក្សាយោបល់ដោយស៊ុលតង់។ ព្រះចៅអធិរាជមួយអង្គដឹកនាំឌីវ៉ាន់ និងជាទីប្រឹក្សាសំខាន់របស់ស៊ុលតង់។ នៅពាសពេញចក្រភព មេដឹកនាំយោធា, មេសាសនា, និងម្ចាស់កម្មសិទ្ធិដីធ្លីធំៗជួយក្នុងការអនុវត្តន៍កិច្ចការក្នុងតំបន់។ រដ្ឋាភិបាលដែលមានច្រើនស្រទាប់នេះ បានអនុញ្ញាតឱ្យអូតូម៉ង់គ្រប់គ្រង និងដឹកនាំដែនដីរបស់ពួកគេប្រកបដោយប្រសិទ្ធិភាព។ ជាទូទៅ ពួកគេអនុវត្តជាមួយនឹងភាពអត់ឱនចំពោះដែនដីដែលពួកដណ្តើមកាន់កាប់។ ឧទាហរណ៍៖ អ្នកមិនមែនម៉ូស្លីមអាចប្រតិបត្តិសាសនាផ្ទាល់របស់ពួកគេ ប្រសិនបើពួកគេបង់ពន្ធដល់រដ្ឋាភិបាល។ អ្នកមិនមែនម៉ូស្លីមក៏អាចលើកលែងការបម្រើការងារនៅក្នុងវិស័យយោធាអូតូម៉ង់ប្រសិនបើពួកគេបង់ពន្ធ។

ស៊ូឡៃម៉ាន់ និងអ្នកបង្កើតច្បាប់៖ នៅក្នុងឆ្នាំ 1520 ស៊ុលតង់ថ្មីមួយអង្គថ្មីព្រះនាម ស៊ូឡៃម៉ាន់ទី I បានឡើងគ្រួតត្រាចក្រភព។ អំឡុងរាជរបស់ស៊ូឡៃម៉ាន់រយៈពេល 46 ឆ្នាំ ចក្រភពអូតូម៉ង់បង្កើតបានសិល្បៈ, ស្ថាបត្យកម្ម, និងអក្សរសិល្ប៍ដ៏ប្រសើរ។ ដោយសារតែភាពជោគជ័យនៃវប្បធម៌ទាំងនេះ ប្រជាជនជារឿយៗសំដៅទ្រង់ថា "ស៊ូឡៃម៉ាន់ដ៏អស្ចារ្យ"។ ប៉ុន្តែ ប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់ទ្រង់បានហៅទ្រង់ថា "អ្នកបង្កើតច្បាប់ស៊ូឡៃម៉ាន់" ពីព្រោះទ្រង់រៀបចំក្រមច្បាប់មួយដែលមានភាពល្បីល្បាញ។ ជាម៉ូស្លីម អូតូម៉ង់បានតម្រូវឱអនុវត្តតាមច្បាប់អ៊ីស្លាម។

ប៉ុន្តែ មានប្រធានបទជាច្រើនដែលមិនទាន់គ្របដណ្ដប់ដោយច្បាប់អ៊ីស្លាម។ ច្បាប់ឧក្រិដ្ឋ និងការយកពន្ធគឺជាប្រធានបទពីរក្នុងចំណោមនោះ។ ដូច្នេះស៊ូលតង់បានបង្កើតច្បាប់នានាដើម្បីដោះស្រាយស្ថានការណ៍មួយចំនួន។ ស៊ូឡៃម៉ាន់បានរៀបចំច្បាប់ទាំងនេះទៅជាក្រមច្បាប់មួយដែលអាចគ្រប់គ្រងដោយមានប្រសិទ្ធិភាពនៅលើចក្រភពដ៏ធំមួយ។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីរបស់ដែលអូតូម៉ង់រៀបចំរចនាសម្ព័ន្ធរបស់ចក្រភពរបស់ពួកគេ។

## 2. ការពង្រីកចក្រភព

សំណួរគន្លឹះ៖ តើតំបន់ណាខ្លះដែលអូតូម៉ង់បានពង្រីកទៅដល់?

ពួកអូតូម៉ង់ដណ្តើមកាន់កាប់មួយភាគធំនៃតំបន់អាស៊ីនិរតី និងអាហ្វ្រិកភាគខាងជើង ដែលក្នុងនោះរួមមានស៊ីរី, អារ៉ាប់, ពែក្ស, ប៉ាឡេស្ទីន, និងអេហ្ស៊ីប។ ជាមួយនឹងដែនដីដែលពួកដណ្តើមកាន់កាប់ទាំងនេះ អូតូម៉ង់បានត្រួតត្រាលើដែនដីដ៏ធំ និងមានអំណាចបំផុតមួយនៅលើពិភពលោក។ វារួមបញ្ចូលទាំងមេកកា និងមេឌីណាដែលត្រូវបានចាត់ទុកថាជាទីក្រុងពិសិដ្ឋរបស់អ៊ីស្លាម។ នៅក្នុងឆ្នាំ 1453 អូតូម៉ង់បានដណ្តើមកាន់កាប់រាជធានីកុងស្តង់ទីណុបរបស់ចក្រភពប៊ីហ្សង់ទីន។ ពួកគេបានប្តូរឈ្មោះទីក្រុងនេះទៅជាអ៊ីស្តង់ប៊ូល និងយកវាធ្វើជារាជធានីរបស់អូតូម៉ង់។ ការដណ្តើមកាន់កាប់នេះជាសញ្ញាណនៃការបញ្ចប់ចក្រភពប៊ីហ្សង់ទីន។ នៅក្នុងឆ្នាំ 1525 ស៊ូឡៃម៉ាន់បានវាយប្រហារលើចក្រភពរ៉ូម៉ាំងដ៏ពិសិដ្ឋ ដែលគ្រប់គ្រងដោយសន្តតិវង្សហាពស្ប៊ឺកដ៏មានអំណាច។ ពួកហាពស្ប៊ឺកគឺជាពួកអាឡឺមង់ និងជាសត្រូវដ៏ជូរជត់របស់បារាំង។ ជាលទ្ធផល នៅពេលដែលស៊ូឡៃម៉ាន់ធ្វើការវាយប្រហារលើទឹកដីរបស់ហាពស្ប៊ឺក បារាំងបានចងសម្ព័ន្ធភាពជាមួយជាមួយទ្រង់។ នៅក្នុងឆ្នាំ 1529 ស៊ូឡៃម៉ាន់បានវាយដណ្តើមកាន់កាប់រហូតដល់ទីក្រុងវីយែនប្រទេសអូទ្រីស ប៉ុន្តែស៊ូឡៃម៉ាន់មិនអាចផ្គត់ផ្គង់កងទ័ពរបស់ទ្រង់បានគ្រប់គ្រាន់ ដូច្នេះទ្រង់បានដកថយ។

សង្ខេប៖ រៀបរាប់តំបន់ដែលអូតូម៉ង់បានពង្រីកទៅដល់។

## 3. ជីវិតរស់នៅក្នុងចក្រភពអូតូម៉ង់

សំណួរគន្លឹះ៖ អ្វីទៅជាគោលនយោបាយរបស់អូតូម៉ង់ចំពោះប្រជាជនដែលពួកគេដណ្តើមកាន់កាប់?

មនុស្សខុសគ្នាជាច្រើន អាចរស់នៅប្រកបដោយសន្តិភាពក្រោមគោលនយោបាយរបស់ចក្រភពអូតូម៉ង់។ គោលនយោបាយទាំងនេះជួយដល់ភាពរុងរឿងនៃចក្រភព។

ឯកសិទ្ធិនៃប្រជាជនដែលត្រូវបានដណ្តើមកាន់កាប់៖ ដូចដែលអ្នកបានអាននៅខាងមុខ អូតូម៉ង់ផ្តល់នូវសេរីភាពនៅក្នុងការគោរពបូជាចំពោះគ្រីស្តសាសនិក និងពួកជ្វីបដែលរស់នៅក្នុងចក្រភពរបស់ពួកគេ។ ការអនុវត្តនេះយោងទៅតាមច្បាប់អ៊ីស្លាម។ គ្រីស្តសាសនិក និងពួកជ្វីបត្រូវបានអនុញ្ញាតឱ្យបង្កើតសហគមន៍ផ្ទាល់ខ្លួនរបស់ពួកគេ ដែលគេហៅថាមីលលេត។ ប្រជាជនដែលរស់នៅមីលលេតតម្រូវឱ្យបង្ហាញពីភក្តីភាពរបស់ពួកគេចំពោះអូតូម៉ង់ និងបង់ពន្ធដល់ពួកគេ។ ក្នុងការឆ្លើយតប ស៊ូតង់អនុញ្ញាតឱ្យពួកគេប្រតិបត្តិសាសនាផ្ទាល់របស់ពួកគេ, និយាយភាសាផ្ទាល់, និងដឹកនាំដោយខ្លួនពួកគេផ្ទាល់។

ទាសករ៖ ទាសករផ្ទាល់ខ្លួន 20,000 នាក់របស់ស៊ុលតង់បានបម្រើការនៅក្នុងរដ្ឋាភិបាលអូតូម៉ង់។ ទាសករទាំងអស់នេះជ្រើសរើសចេញមកពីដែនដីដែលអូតូម៉ង់ដណ្ដើមកាន់កាប់។ ពួកគេមួយចំនួនទទួលបានតួនាទីសំខាន់នៅក្នុងចក្រភពអូតូម៉ង់។ តាមពិត មនុស្សមួយចំនួនបានសូកមន្ត្រីអូតូម៉ង់ឱ្យយកកូនចៅរបស់ពួកគេធ្វើជាទាសករ។ បម្រើការឱ្យស៊ុលតង់គឺជាវិធីតែមួយគត់ដែលអ្នកមិនមែនម៉ូស្លីមអាចរះឡើងនៅក្នុងសង្គមអូតូម៉ង់។ ទាសករក៏បង្កើតផ្នែកមួយនៃកងទ័ពអូតូម៉ង់ដែលគេហៅថា ចានីសសារី។ កងទ័ពវរជន និងខ្លាំងជាងគេទាំងនេះជាយុវជនដែលមានកម្លាំងខ្លាំង ភាគច្រើនមកពីគ្រួសារគ្រីស្តសាសនិក។ ពួកអូតូម៉ង់បានអប់រំពួកគេ ប្រែក្លាយពួកគេទៅជាអ៊ីស្លាម និងបានបណ្ដុះបណ្ដាលជាមួយនឹងភក្ដីភាពចំពោះតែស៊ុលតង់តែមួយអង្គ។ កងទ័ពចានីសសារីស និងកងទ័ពអូតូម៉ង់ទាំងមូលគឺជាកងទ័ពដែលមានវិស័យ, រៀបចំច្បាស់លាស់, និងបំពាក់នូវអាវុធទំនើបចុងក្រោយ។ ដូចដែលអ្នកបានដឹងមកហើយ ការរួមបញ្ចូលគ្នានូវវិន័យ និងបច្ចេកវិទ្យាបានជួយឱ្យពួកអូតូម៉ង់ពង្រីកចក្រភពរបស់ពួកគេ។

ស្ត្រីនៅក្នុងចក្រភព៖ ស្ថានភាពរបស់ស្ត្រីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អូតូម៉ង់ពឹងផ្អែកលើវណ្ណៈសង្គមរបស់ពួកគេ និងទីកន្លែងដែលពួកគេរស់នៅ។ ច្បាប់អ៊ីស្លាមបានផ្ដល់ឱ្យស្ត្រីនូវសិទ្ធិនៅក្នុងការកាន់កាប់ និងទទួលទ្រព្យសម្បត្តិ និងស្នើសុំលែងលះបាន។ នៅទីជនបទ ស្ត្រីធ្វើការជាមួយបុរសលើការដាំដុះ និងចិញ្ចឹមសត្វ។ នៅក្នុងទីក្រុង ស្ត្រីជារឿយៗធ្វើការនៅផ្សារក្នុងនាមជាពាណិជ្ជករ និងធ្វើការនៅក្នុងរោងជាង ភាគច្រើនជាអ្នករវៃ និងអ្នកត្បាញ។ ស្ត្រីនៅក្នុងរាជវាំងរបស់ស៊ុលតង់ទទួលបានការអប់រំ ប៉ុន្តែជីវិតរស់នៅរបស់ពួកគេត្រូវបានកម្រិតឱ្យនៅតែក្នុងរាជវាំង។ ស្ត្រីក្នុងវាំងមួយចំនួនមានអំណាចខ្លាំង ជាពិសេសមាតារបស់ស៊ុលតង់។ ជាង 300 ឆ្នាំបន្ទាប់ ភ័ព្វសំណែងរបស់ចក្រភពអូតូម៉ង់ចាប់ផ្ដើមធ្លាក់ចុះបន្តិចម្ដងៗ។ នៅក្នុងពេលជាមួយគ្នានោះ អ្នកនឹងបានអាននៅក្នុងជំពូក 16 រាជានិយមដ៏មានអំណាចនៅអឺរ៉ុបចាប់ផ្ដើមរះឡើង។

ស្វែងរកគំនិតសំខាន់៖ ពិពណ៌នាអំពីគោលនយោបាយរបស់អូតូម៉ង់លើប្រជាជនដែលពួកគេដណ្ដើមកាន់កាប់។

# ជំពូក 16 ៖ សក្តិភូមិ និងចុងមជ្ឈិមសម័យនៅអឺរ៉ុប

## មេរៀនទី 1 ៖ សក្តិភូមិនិយមក្នុងមជ្ឈិមសម័យនៅអឺរ៉ុប

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅពេលដែលនិយាយអំពីមជ្ឈិមសម័យតើអ្នកគិតដល់អ្វីមុនគេ? អ្នកជិះសេះពាក់ពាលដែក? ប្រាសាទ? នៅក្នុងជំពូកនេះ អ្នកនឹងសិក្សាអំពីទម្រង់ផ្សេងៗនៅមជ្ឈិមសម័យ។ អ្នកក៏នឹងសិក្សាអំពីប្រព័ន្ធនយោបាយ, សេដ្ឋកិច្ច, និងសង្គមថ្មីមួយដែលគេស្គាល់ថាសក្តិភូមិនិយមដែលបានអភិវឌ្ឍអំឡុងសម័យនេះ។

### 1. ការលេចឡើងនៃមជ្ឈិមសម័យនៅអឺរ៉ុប

សំណួរគន្លឹះ៖ តើបានអ្វីប្រែប្រួលនៅអឺរ៉ុបបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូម?

ការដួលរលំនៃចក្រភពរ៉ូមនៅក្នុងឆ្នាំ 476 នាំទៅដល់ការលេចឡើងនៃសម័យមួយមានរយៈពេលប្រមាណ 1,000 ឆ្នាំដែលគេស្គាល់ថា យុគកណ្តាល។ សម័យកាលនេះក៏ត្រូវបានគេស្គាល់ថាមជ្ឈិមសម័យ ។ ទិដ្ឋភាពនៃនយោបាយ និងវប្បធម៌របស់អឺរ៉ុបបានផ្លាស់ប្តូរយ៉ាងខ្លាំងបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូម។ រ៉ូមមិនបានបន្តគ្រប់គ្រងតំបន់នានា តាមរយៈការបង្រួបបង្រួមក្រុមផ្សេងៗគ្នាជាច្រើនឱ្យស្ថិតនៅក្រោមរដ្ឋាភិបាលតែមួយទៀតឡើយ។ ផ្ទុយទៅវិញ ព្រះជាណាចក្រអាឡឺម៉ង់ជាច្រើនបានគ្របដណ្តប់លើដែនដីដែលធ្លាប់គ្រប់គ្រងដោយចក្រភពដ៏ខ្លាំងក្លាមួយ។

ពួករ៉ូម៉ាំងមានរដ្ឋាភិបាលដែលមានការអភិវឌ្ឍខ្ពស់មួយ។ ពួកគេក៏ផ្តោតសំខាន់ទៅលើការសិក្សាផងដែរ។ ប្រជាជនអាឡឺម៉ង់ ផ្ទុយទៅវិញរស់នៅក្នុងសហគមន៍តូចៗ។ ពួកគេរក្សាសណ្តាប់ធ្នាប់តាមរយៈច្បាប់ដែលមិនបានសរសេរ និងប្រពៃណី។ ជាលទ្ធផល ពួកគេមិនបានអភិវឌ្ឍរដ្ឋាភិបាលធំៗ ឬផលិតស្នាដៃសិក្សាឡើយ។ ក្រុមអ្នកទទួលបានការអប់រំវណ្ណៈកណ្តាលទាំងអស់បានបាត់រូបរាងនៅអំឡុងយុគកណ្តាល។ សាលារៀនភាគច្រើនបានបិទទ្វា ហើយមនុស្សតិចតួចប៉ុណ្ណោះដែលចេះអាន ឬសរសេរឡាតាំង។ ពួកអឺរ៉ុបភាគច្រើនបានភ្លេចអំពីស្នាដៃសិល្បៈ និងអប់រំរបស់ពួកក្រិក និងពួករ៉ូម៉ាំង។ ដូចដែលពាណិជ្ជកម្មនៅពាលពេញអឺរ៉ុបបានធ្លាក់ចុះ ទីក្រុងនានាជាច្រើនក៏ដូចគ្នាដែល។ អ្នករស់នៅក្នុងទីក្រុងជាច្រើនរស់នៅតាមរយៈការធ្វើដោះដូរទំនិញ។ កង្វះខាតពាណិជ្ជកម្មបណ្តាលឱ្យពួកគេភាគច្រើនផ្លាស់ទីទៅកាន់ជនបទ និងប្រកបការងារជាអ្នកដាំដុះ។

សង្ខេប៖ សង្ខេបពីការផ្លាស់ប្តូរសំខាន់នៅអឺរ៉ុបបន្ទាប់ពីការធ្លាក់ចុះនៃចក្រភពរ៉ូម។

### 2. សហគមន៍គ្រីស្តសាសនារីកចម្រើន និងរីកសាយភាយ

សំណួរគន្លឹះ៖ តើស្តេចរបស់ហ្វ្រង់ជួយដល់ការពង្រីកគ្រីស្តសាសនានៅពាសពេញអឺរ៉ុបដោយរបៀបណា?

ស្ថាប័នមួយដែលនៅរស់រានបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូមគឺព្រះវិហារគ្រឹស្តសាសនា។ មេដឹកនាំអាឡឺម៉ង់ជាច្រើន និងប្រជានុរាស្ត្របស់ពួកគេបានផ្លាស់ប្តូរទៅជឿសាសនាគ្រឹស្ត។ ភាគខាងជើងអាល់ ប្រជាជនអាឡឺម៉ង់មួយក្រុម ពួកហ្វ្រង់បានបង្កើតព្រះរាជាណាចក្រដ៏ខ្លាំងមួយ។ ពួកគេគឺជាអ្នកពង្រឹងគ្រឹស្តសាសនាយ៉ាងខ្លាំងក្លានៅអឺរ៉ុប។

ក្លូវីស និងហ្វ្រង់៖ នៅក្នុងឆ្នាំ 486 មេដឹកនាំហ្វ្រង់មួយរូបឈ្មោះក្លូវីសបានឈ្លានពានហ្គោលរ៉ូម៉ាំង (បច្ចុប្បន្នបារាំង)។ ទ្រង់បានយកជ័យជំនះលើកងទ័ពរ៉ូមដែលខ្លាំងចុងក្រោយនៅហ្គោល។ ក្លូវីសបន្ទាប់មកបន្តយកជ័យជំនះលើក្រុមអាឡឺម៉ង់ផ្សេងៗទៀត។ ត្រឹមឆ្នាំ 507 ព្រះរាជាណាចក្ររបស់ទ្រង់បានលាតសន្ធឹងពីលេចចាប់ពីទន្លេរីនរហូតដល់ជួរភ្នំពីរីណេស។ នៅពេលនោះក្លូវីសបានផ្លាស់ប្តូរទៅជឿលើគ្រឹស្តសាសនា។ ក្រោយមក ភាគច្រើននៃប្រជានុរាស្ត្ររបស់ទ្រង់ក៏បានក្លាយជាគ្រឹស្តសាសនិកផងដែរ។

ការគ្រប់គ្រងរបស់សាលឡឺម៉ាញ៖ នៅក្នុងឆ្នាំ 768 មេដឹកនាំថ្មីមួយរូបដែលប្រកបដោយមហិច្ឆិតាបានឡើងគ្រប់គ្រងអំណាចនៅព្រះរាជាណាចក្រហ្វ្រង់គីស។ សាល ដែលគេស្គាល់ថា សាលឡឺម៉ាញ បានស្ថាបនាចក្រភពអឺរ៉ុបមួយដែលមានលក្ខណៈប្រសើរជាងចក្រភពនានាដែលធ្លាប់ស្គាល់ចាប់តាំងពីសម័យរ៉ូមបុរាណ។ ទ្រង់ធ្វើដូច្នេះបានមួយភាគធំតាមរយៈជ័យជំនះយោធាដ៏យូរអង្វែងមួយអស់រយៈពេលជាច្រើនឆ្នាំ។ ត្រឹមឆ្នាំ 800 ភាគច្រើននៃអឺរ៉ុបខាងលិចបានក្លាយជាផ្នែកមួយនៃចក្រភពដ៏ដឹកនាំបានល្អរបស់ទ្រង់។ សាលឡឺម៉ាញបានបង្កើតច្បាប់ថ្មីៗដើម្បីជួយរក្សាសណ្តាប់ធ្នាប់។ ទ្រង់ក៏បានអនុញ្ញាតឱ្យប្រជាជនដែលទ្រង់ដណ្តើមកាន់កាប់បានមួយចំនួន រក្សានូវច្បាប់ប្រពៃណីរបស់ពួកគេ ដ៏រាបណាច្បាប់ទាំងនោះនៅតែអាចរក្សាសណ្តាបធ្នាប់, រៀបចំ និងសរសេរឡើងបានល្អ។ សាលឡឺម៉ាញក៏បានធ្វើកំណែទម្រង់ព្រះវិហារគ្រឹស្តសាសនាផងដែរ។ ទ្រង់បានលើកកម្ពស់ការអប់រំដល់បព្វជិត, រៀបចំអំណាចរបស់ព្រះវិហារ, និងបង្កើតសម្ព័ន្ធភាពជាមួយសម្តេចប៉ាប។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពន្យល់ពីរបៀបដែលស្តេចហ្វ្រង់គីសជួយដល់ការសាយភាយនៃគ្រឹស្តសាសនានៅអឺរ៉ុប។

### 3. សក្តិភូមិនិយម៖ សណ្តាប់ធ្នាប់សង្គមថ្មីមួយ

សំណួរគន្លឹះ៖ តើខ្ញុំកញ្ចះដើរតួនាទីអ្វីនៅក្នុងសក្តិភូមិនិយម?

បន្ទាប់ពីសាលឡឺម៉ាញសុគតនៅក្នុងឆ្នាំ 814 រាជបុត្ររបស់ទ្រង់ព្រះនាមល្វីបានក្លាយជាអធិរាជ។ នៅពេលដែលល្វីសុគត រាជបុត្រ 3 អង្គរបស់ទ្រង់បានវាយប្រយុទ្ធគ្នាទៅវិញទៅមកដើម្បីត្រួតត្រាព្រះរាជាណាចក្រ។ ពួកទ្រង់ទាំង 3 បានចុះហត្ថលេខាលើសន្ធិសញ្ញាមួយនៅក្នុងឆ្នាំ 843 ដែលបានបែងចែកចក្រភពទៅជា 3 ផ្នែក។ ការបែងចែកនេះបានធ្វើឱ្យព្រះរាជាណាចក្រហ្វ្រង់គីសចុះខ្សោយ។ ការធ្លាក់ចុះនៃការដឹកនាំរបស់ហ្វ្រង់គីសបាននាំទៅដល់ភាពចលាចលនៅពាសពេញអឺរ៉ុប។ ក្រុមអ្នកឈ្លានពានបានចាប់យកអត្ថប្រយោជន៍ពីភាពចលាចលនេះ។ ក្រុមចោរសមុទ្រស្តេនឌីណាវៀន ដែលគេហៅថាវីឃីង បានវាយប្រហារលើភូមិនានានៅតាមតំបន់ឆ្នេរសមុទ្រ។ ក្រុមមួយដែលគេស្គាល់ថាម៉ាក្យាបានវាយប្រហារលើទីប្រជុំជននានានៅពាសពេញអឺរ៉ុបកណ្តាល។ នៅត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 800 អឺរ៉ុបបានក្លាយជាទីកន្លែងមួយដែលពោរពេញទៅដោយជម្លោះ និងសង្គ្រាម។

ការលិចឡើងនៃសក្តិភូមិនិយមៈ អំឡុងសម័យនៃអំពើហឹង្សា មនុស្សចាប់ផ្តើមសម្លឹងទៅរកការការពារ។ ការនេះបាននាំទៅដល់ការបង្កើតឡើងនៃប្រព័ន្ធនយោបាយ និងសង្គមមួយដែលគេស្គាល់ថាសក្តិភូមិនិយម។ សក្តិភូមិនិយមគឺផ្តោតសំខាន់លើកិច្ចព្រមព្រៀងមួយរវាងក្រុមអភិជន 2 ក្រុមគឺស្តេចត្រាញ់ និងបរិវារ។ ស្តេចត្រាញ់មួយរូបគឺជាអភិជនដែលមានអំណាចមួយរូបអ្នកដែលកាន់កាប់ដីធ្លី។ ស្តេចត្រាញ់អនុញ្ញាតឱ្យអភិជនដែលទាបជាងខ្លួនដែលគេហៅថាបរិវារប្រើប្រាស់ផ្នែកខ្លះនៃដីធ្លីរបស់ខ្លួន។ ក្បាលដីទាំងអស់នេះត្រូវបានគេហៅថាអចលនទ្រព្យ។ ជាការតបស្នងចំពោះអចលនទ្រព្យនេះ បរិវារបានបម្រើស្តេចត្រាញ់នៅក្នុងរាជវាំង និងយោធា។ ជាមួយនឹងកងទ័ពរបស់ពួកបរិវារ ស្តេចត្រាញ់អាចការពារដីធ្លីរបស់ទ្រង់ពីការវាយប្រហារ។ បរិវារមួយចំនួនជាពួកអ្នកប្រយុទ្ធដែលគេស្គាល់ថាអ្នកជិះសេះចម្បាំង។

រចនាសម្ព័ន្ធសក្តិភូមិៈ សង្គមសក្តិភូមិជាសង្គមមួយដែលមានរចនាសម្ព័ន្ធខ្ពស់។ ស្តេចដឹកនាំនៅពីលើគេនៅក្នុងសង្គម។ បន្ទាប់មកពីម្ចាស់កម្មសិទ្ធិដីធ្លីមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងសមាជិកជាន់ខ្ពស់នៃព្រះវិហារគ្រីស្តសាសនា។ បម្រើការនៅពីក្រោមពួកគេគឺក្រុមអ្នកចម្បាំងជិះសេះ។ អ្នកដែលខាងក្រោមគេនៅក្នុងសង្គមគឺប្រជាកសិករ។ ប្រជាកសិករភាគច្រើនគឺជាខ្ញុំកញ្ជះ។ ខ្ញុំកញ្ជះរស់នៅ និងធ្វើការនៅលើដីដែលជាកម្មសិទ្ធិរបស់ស្តេចត្រាញ់មួយរូប ឬបរិវារមួយរូប។ ក៏ដូចជាបរិវារដែរ ខ្ញុំកញ្ជះស្វែងរកការការពារពីស្តេចត្រាញ់របស់ពួកគេ។ សក្តិភូមិនិយមបានបង្កើតរចនាសម្ព័ន្ធនយោបាយថ្មីមួយនៅអឺរ៉ុប។ ភូមិគ្រឹះធំៗ, អចលនាទ្រព្យនានាត្រូវបានគ្រប់គ្រងដោយពួកអភិជនមានអំណាច គឺជាផ្នែកដ៏សំខាន់មួយនៅក្នុងទិដ្ឋភាពនយោបាយថ្មីនេះ។

សង្ខេបៈ ពន្យល់ពីតួនាទីរបស់ខ្ញុំកញ្ជះនៅក្នុងសម័យសក្តិភូមិ។

## 4. ប្រព័ន្ធភូមិគ្រឹះ

សំណួរគន្លឹះៈ តើប្រព័ន្ធភូមិគ្រឹះបានដើរតួនាទីអ្វីនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់អឺរ៉ុបអំឡុងយុគកណ្តាល?

ដោយសារកង្វះខាតរដ្ឋាភិបាលកណ្តាលរឹងមាំមួយ អឺរ៉ុបហាក់ដូចជាបណ្តុំនៃព្រះរាជាណាចក្រមួយ ហើយដីធ្លីត្រូវបានកាន់កាប់ដោយពួកអភិជនជាន់ខ្ពស់។ ស្ថិតនៅក្នុងស្ថានភាពនេះ ការធ្វើទំនាក់ទំនងពាណិជ្ជកម្ម ឬជំនួញហាក់ដូចជាមានតិចតួច។ ជំនួសមកវិញ ដីធ្លីដែលកាន់កាប់ដោយពួកអភិជនបានក្លាយជាចំណុចស្នូលនៃសកម្មភាពសេដ្ឋកិច្ច។

តួនាទីរបស់ភូមិគ្រឹះៈ ផ្នែកដ៏សំខាន់នៃដីធ្លីរបស់ពួកអភិជនត្រូវបានគេហៅថាភូមិគ្រឹះ។ នៅចំណុចកណ្តាលនៃភូមិគ្រឹះគឺជាផ្ទះដែលស្តេចត្រាញ់ និងគ្រួសាររបស់ពួកគេរស់នៅ។ ជារឿយៗផ្ទះភូមិគ្រឹះគឺជាសំណង់ ឬប្រាសាទដ៏រឹងមាំមួយ។ ស្ថិតនៅជុំវិញផ្ទះភូមិគ្រឹះគឺជាអចលនទ្រព្យរបស់ស្តេចត្រាញ់។ ភាគច្រើននៃអចលនទ្រព្យគឺជាដីស្រែចំការ និងភូមិដែលប្រជាកសិកររស់នៅ។

ជីវិតរបស់នៅភូមិគ្រឹះ និងសេដ្ឋកិច្ចៈ ដូចដែលអ្នកបានអាន ប្រជាកសិករ(ភាគច្រើនគឺជាខ្ញុំកញ្ជះ)រស់នៅ និងធ្វើការនៅក្នុងភូមិគ្រឹះ។ ពួកគេបានដាំដុះនៅលើដីស្រែចំការ ដែលបានបង្កើតបានជាមូលដ្ឋានគ្រឹះសេដ្ឋកិច្ច

នៃប្រព័ន្ធភូមិគ្រឹះ។ ខ្ញុំកញ្ជះត្រូវបានគេនិយាយថា "ជាប់ជាមួយនឹងដី" ដែលមានន័យថាពួកគេត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃទ្រព្យសម្បត្តិ។ ពួកគេនៅតែបន្តរស់នៅលើដីធ្លីដដែលបើទោះបីជាមានស្តេចត្រាញ់ថ្មីកាន់កាប់ក៏ដោយ។ ជីវិតរស់នៅក្នុងរបបសក្តិភូមិនិយម និងភូមិគ្រឹះមានឥទ្ធិពលដ៏សំខាន់មួយលើសេដ្ឋកិច្ចរបស់អឺរ៉ុបនាមជ្ឈិមសម័យ។ ដីធ្លីនៅក្នុងភូមិគ្រឹះមួយបានផ្ទាល់ឱ្យអ្នករស់នៅក្នុងនោះអ្វីៗដែលពួកគេចង់បាន។ ជាលទ្ធផល សកម្មភាពជាច្រើន រាប់ចាប់តាំងពីការដាំដុះ, ការងារឈើ, រហូតដល់ដល់ការផលិតស្រា ត្រូវបានគេធ្វើឡើងនៅក្នុងភូមិគ្រឹះ។ ភូមិគ្រឹះបានក្លាយជាពិភពរស់នៅសម្រាប់ពួកគេផ្ទាល់ ហើយមានមនុស្សតិចតួចណាស់ដែលចាកចេញពីទីនោះ។

សង្ខេប៖ ពន្យល់ពីតួនាទីរបស់ប្រព័ន្ធភូមិគ្រឹះនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងយុគកណ្តាល។

## 5. យុគសម័យជីវ៉ាល់រី

សំណួរគន្លឹះ៖ អ្វីទៅជាជីវ៉ាល់រី?

ដូចដែលអ្នកបានរៀននៅខាងដើម ក្រុមអ្នកចម្បាំងជិះសេះភាគច្រើនជាបរិវារ ឬពួកអភិជនជាន់ទាប អ្នកដែលធ្វើសង្គ្រាមដើម្បីស្តេចត្រាញ់ជាថ្នូរទៅនឹងការទទួលបានដី។ អំឡុងយុគកណ្តាល ជម្លោះជារឿយៗបានកើតមានឡើងរវាងស្តេចត្រាញ់នានា។ ជាច្រើនលើក ពួកគេមានជម្លោះដោយសារការអះអាងពីភាពជាម្ចាស់លើដីធ្លី។ នៅក្នុងការប្រយុទ្ធគ្នា ស្តេចត្រាញ់ពឹងផ្អែកលើក្រុមអ្នកចម្បាំងជិះសេះ ដែលជាអ្នកមានជំនាញនៅក្នុងការជិះសេះ និងប្រយុទ្ធ។

ភាពជាអ្នកចម្បាំងជិះសេះ និងជីវ៉ាល់រី៖ អ្នកចម្បាំងជិះសេះមិនត្រឹមតែជាអ្នកប្រយុទ្ធដ៏ជំនាញប៉ុណ្ណោះទេ ពួកគេក៏ត្រូវបានរំពឹងនៅក្នុងការរស់នៅជាមួយក្រមនៃកិត្តិយសមួយដែលគេស្គាល់ថាជីវ៉ាល់រី។ ពួកគេត្រូវតែបង្ហាញពីជំនឿសាសនាដ៏រឹងមាំមួយ និងស្ម័គ្រចិត្តនៅក្នុងការការពារព្រះវិហារកាតូលិក។ ពួកគេក៏ត្រូវបានរំពឹងថានឹងការពារស្ត្រី និងអ្នកទន់ខ្សោយ។ ជាងនេះទៅទៀត អ្នកចម្បាំងជិះសេះត្រូវបានគេចាត់ទុកថាជាអ្នកប្រយុទ្ធប្រឆាំងជាមួយអំពើអយុត្តិធម៌ និងបង្ហាញពីសេចក្តីក្លាហាននៅរាល់សមរភូមិដែលពួកគេប្រយុទ្ធ។ សមរភូមិដែលអ្នកចម្បាំងជិះសេះ និងអ្នកប្រយុទ្ធផ្សេងៗទៀតប្រយុទ្ធរាប់ចាប់តាំងពីការការប្រយុទ្ធបង្ហូរឈាមនៅលើទីវាលរហូតដល់ការវាយប្រយុទ្ធគ្នាដ៏សាហាវនៅលើប្រាសាទ។ ដើម្បីដណ្តើមកាន់កាប់ប្រាសាទមួយ ស្តេចត្រាញ់ និងអ្នកចម្បាំងជិះសេះដែលកងកម្លាំងវាយប្រយុទ្ធជារឿយៗបានឡោមព័ទ្ធប្រាសាទ។ អំឡុងនៃការឡោមព័ទ្ធ កងទ័ពព្យាយាមនៅក្នុងការការពារការនាំយកស្បៀងអាហារ ឬការផ្គត់ផ្គង់នានាចូលទៅក្នុងប្រាសាទ។ គោលបំណងរបស់ពួកគេគឺដើម្បីធ្វើឱ្យមនុស្សនៅក្នុងប្រាសាទអត់អាហារ និងបង្ខំឱ្យពួកគេចុះចាញ់។

ក្រុមជីវ៉ាល់រី៖ ក្រុមអ្នកចម្បាំងជិះសេះមួយចំនួនបានពលីកម្រិតខ្ពស់មួយចំពោះព្រះវិហារគ្រឹស្តសាសនា។ ពួកគេបានក្លាយជាបរិវាររបស់ស្តេចប៉ាប និងបានបង្កើតស្ថាប័នយោធាសាសនានានាដែលគេស្គាល់ថាក្រុមជីវ៉ាល់រី។ ក្រុមដែលល្បីល្បាញជាងគេត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1119 ។ វាត្រូវបានគេហៅថា អ្នកចម្បាំងជិះសេះគ្រឹស្តសាសនាដ៏ក្រីក្រ និងប្រាសាទសូឡូមុន ឬអ្នកចម្បាំងជិះសេះតេមផ្ល័រ។ ពួកតេមផ្ល័របានស្បថពាក្យសម្បថ និងស្តាប់

ឱវាទរបស់ព្រះវិហារគ្រីស្តសាសន។ ពួកគេរស់នៅជាមួយគ្នា ដេកនៅក្នុងបន្ទប់រួមមួយ និងបរិភោគអាហារជាមួយជុំគ្នា។ ប៉ុន្តែ ភារកិច្ចសំខាន់របស់ពួកគេគឺវាយប្រយុទ្ធជាមួយសត្រូវរបស់ព្រះវិហារគ្រីស្តសាសនា។ ពួកតេមផ្ល័រ និងក្រុមជីវ៉ាល់រីផ្សេងៗទៀតត្រូវបានបង្កើតឡើងដើម្បីវាយប្រយុទ្ធជាមួយសត្រូវម៉ូស្លីមនៅក្នុង និងជុំវិញទីក្រុងជេរូសាឡឹម ជាទីកន្លែងមួយដែលគេស្គាល់ថាទឹកដីពិសិដ្ឋ។ ការវាយប្រយុទ្ធគ្នាទាំងនេះត្រូវបានគេហៅថាបូជនីយកិច្ច(អ្នកនឹងបានសិក្សាពីបូជនីយកម្មនៅក្នុងមេរៀនទី 2 )។

ស្វែងរកគំនិតសំខាន់៖ រៀបរាប់ និងពិពណ៌នាអំពីគំនិតសំខាន់នៃជីវ៉ាល់រី។

## 6. ការរីកលូតលាស់នៃទីប្រជុំជន

សំណួរគន្លឹះ៖ តើជីវិតរស់នៅទីប្រជុំជនមានលក្ខណៈដូចម្តេចអំឡុងយុគកណ្តាល?

នៅវង្វង់ឆ្នាំ 1000 នៃគ.ស ជីវិតរស់នៅបែបទីប្រជុំជនចាប់ផ្តើមត្រឡប់មកកាន់អឺរ៉ុបវិញ។ ស្តេចត្រាញ់មានអំណាចនានាបាននាំមកនូវសុវត្ថិភាព និងសន្តិសុខដល់តំបន់ជាច្រើន។ ពាណិជ្ជករចាប់ផ្តើមធ្វើដំណើរបានកាន់តែសេរីជាងមុន និងដោះដូរទំនិញរបស់ពួកគេ។ គ្រប់ទីកន្លែងដែលពួកពាណិជ្ជករតាំងទីលំនៅ ក្រុមអ្នកសាងសង់ និងក្រុមអ្នកជួញដូរផ្សេងៗទៀតបានប្រមូលផ្តុំជុំវិញពួកគេ។ ទីប្រជុំជនភាគច្រើននៅក្នុងយុគកណ្តាលជាទីកន្លែងដែលមានភាពកខ្វក់, ចង្អៀត, និងមមាញឹក។ នៅចំណុចកណ្តាលនៃទីប្រជុំជនគឺជាបរិវេណផ្សារ និងព្រះវិហារគ្រីស្តសាសនា។ ផ្លូវមានលក្ខណៈតូចចង្អៀត, កខ្វក់, និងជាធម្មតាមិនមានក្រាលគ្រួសឡើយ។ បន្ទាប់ពីមានភ្លៀងធ្លាក់ផ្លូវពោរពេញទៅដោយភក់ដែលជាទូទៅមានជម្រៅត្រឹមជង្គង់។ ផ្ទះភាគច្រើនធ្វើឡើងអំពីឈើ ដែលងាយស្រួលនៅក្នុងការបង្កអគ្គីភ័យ។ ជាលទ្ធផល ទីប្រជុំជនទាំងមូលជារឿយៗត្រូវបានអគ្គីភ័យបំផ្លាញ។ នៅរវាងឆ្នាំ 1200 ដល់ 1225 ទីក្រុងរ៉ូអង់របស់បារាំងត្រូវបានអគ្គីភ័យបំផ្លាញចំនួន 6 លើក។ នៅក្នុងទីប្រជុំជន ប្រជាជនដែលមានមុខរបរដូចគ្នាបានបង្កើតជាក្រុមនានាដែលគេហៅថាសមាគមន៍អាជីវកម្ម។ សមាគមន៍អាជីវកម្មជាច្រើនត្រូវបានបង្កើតឡើងដោយពួកអ្នកជំនួញ, ក្នុងនោះមានដូចជាជាងមាស, អ្នកធ្វើនំ, អ្នកតម្បាញ, អ្នកជ្រលក់សំពត់។ សមាគមន៍អាជីវកម្មបានបង្កើតច្បាប់ដើម្បីត្រួតពិនិត្យលើបរិមាណ និងគុណភាពនៃផលិតផលរបស់ពួកគេ។ សមាគមន៍អាជីវកម្មពិនិត្យមើលសមាជិករបស់ពួកគេ និងធ្វើសកម្មភាពផ្សេងៗដើម្បីធានាថាសមាជិកទាំងអស់មានការងារធ្វើ។ សារៈសំខាន់នៃសមាគមន៍អាជីវកម្ម ពួកគេមានឥទ្ធិពលប្រហាក់ប្រហែលទៅនឹងព្រះវិហារកាតូលិក ដូចដែលអ្នកនឹងបានសិក្សានៅក្នុងមេរៀនទី 2 ។

វង្វាយតម្លៃ៖ ពិពណ៌នាអំពីទីប្រជុំជននៅក្នុងយុគកណ្តាល។

# មេរៀនទី 2 ៖ ព្រះវិហារគ្រីស្តសាសនា និងបូជនីយកិច្ច

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងយុគកណ្តាល ពួកអឺរ៉ុបស្ទើរតែទាំងស្រុងគឺជាគ្រីស្តសាសនិក និងជាសមាជិកនៃព្រះវិហាររ៉ូម៉ាំងកាតូលិក។ នៅតំបន់អាស៊ីភាគនិរតី ប្រជាជនភាគច្រើនជាម៉ូស្លីម។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីមូលហេតុដែលគ្រីស្តសាសនិក និងម៉ូស្លីមមានជម្លោះជាមួយគ្នា។

## 1. អំណាចរបស់ព្រះវិហាររ៉ូម៉ាំងកាតូលិក

សំណួរគន្លឹះ៖ ហេតុអ្វីបានជាព្រះវិហាររ៉ូម៉ាំងកាតូលិកមានអំណាចខ្លាំងម្លេះ?

ចាប់តាំងពីទសវត្សរ៍ឆ្នាំ 1000 រហូតដល់ឆ្នាំ 1400 ទិដ្ឋភាពសក្តិភូមិនិយមមួយចំនួននៅតែត្រូវបានគេមើលឃើញនៅអឺរ៉ុប។ ជាឧទាហរណ៍ ពួកអភិជននៅតែគ្រប់គ្រងលើទីជនបទមួយភាគធំ។ ប៉ុន្តែ ទាំងព្រះវិហាររ៉ូម៉ាំងកាតូលិក និងរាជានិយមរបស់អឺរ៉ុបបានបង្កើនអំណាចរបស់ពួកគេ។ ព្រះវិហារ និងស្តេចក៏បានព្យាយាមនៅក្នុងការធ្វើមជ្ឈការនយោបាយ និងអំណាចសាសនា។

ស្ថាប័នព្រះវិហារគ្រីស្តសាសនា៖ ព្រះវិហាររ៉ូម៉ាំងកាតូលិកត្រូវការស្ថាប័នរឹងមាំមួយដើម្បីមប្រើដល់ឧបាសកឱ្យមានប្រសិទ្ធិភាព។ ឧបាសកគឺជាអ្នកទាំងឡាយណាដែលចំណុះឱ្យព្រះវិហារគ្រីស្តសាសនាមួយ ប៉ុន្តែមិនមែនជាសមាជិកនៃបព្វជិតឡើយ។ ព្រះវិហារមានអ្នកដឹកនាំជាច្រើនកម្រិតខុសៗគ្នានៅក្នុងចំណោមបព្វជិត ឬប្រជាជនដែលទទួលបានសិទ្ធិអំណាចដោយព្រះវិហារ។ សម្តេចប៉ាបគឺជាមេដឹកនាំខាងវិញ្ញាណ និងនយោបាយរបស់ព្រះវិហារគ្រីស្តសាសនា។ តួនាទីរបស់ទ្រង់ត្រូវបានគេហៅថា ប្រមុខនៃសាសនាកាតូលិក។ នៅពីក្រោមទ្រង់មានពួកបព្វជិតដែលមានឋានៈផ្សេងៗគ្នាជាច្រើនកម្រិត។

តួនាទីនយោបាយរបស់បព្វជិត៖ មនុស្សដែលកាន់តំណែងសំខាន់ៗនៅក្នុងព្រះវិហាគ្រីស្តសាសនាមានទំនាក់ទំនងសង្គម និងនយោបាយយ៉ាងរឹងមាំជាមួយក្រុមអភិជនអឺរ៉ុប។ ជាលទ្ធផល ពួកអភិជន និងមេដឹកនាំព្រះវិហារគ្រីស្តសាសនាមានកិច្ចការដូចគ្នាច្រើន និងជារឿយៗជួយគ្នាទៅវិញទៅមក។ ព្រះវិហារគ្រីស្តសាសនាក៏មានទ្រព្យសម្បត្តិស្តុកស្តម្ភផងដែរ ដែលបានធ្វើឱ្យវាក្លាយជាស្ថាប័នមួយដែលមានអំណាចកាន់តែខ្លាំង។ ទ្រព្យសម្បត្តិរបស់ប្រមុខនៃសាសនាកាតូលិកមានច្រើនជាងទ្រព្យសម្បត្តិរបស់ស្តេចនីមួយៗនៅអឺរ៉ុបទៅទៀត។ ក៏ដូចគ្នាដែរ អំណាចរបស់ស្តេចប៉ាបជារឿយៗមានច្រើនជាងស្តេច និងអធិរាជ។ អំណាចរបស់ស្តេចប៉ាបបានជម្រុញឱ្យស្តេចជាច្រើនសហការជាមួយព្រះវិហារគ្រីស្តសាសនា ប៉ុន្តែវាក៏បណ្តាលឱ្យមានជម្លោះផងដែរ។

រង្វាយតម្លៃ៖ ផ្តល់មូលហេតុដែលនាំឱ្យព្រះវិហារគ្រីស្តសាសនារឹងមាំ។

## 2. ព្រះវិហារគ្រីស្តសាសនា, នយោបាយ, និងសង្គម

សំណួរគន្លឹះ៖ អ្វីទៅជាទំនាក់ទំនងរបស់ព្រះវិហារគ្រីស្តសាសនាជាមួយសង្គមមជ្ឈិមសម័យ?

មេដឹកនាំព្រះវិហារគ្រឹស្តសាសនា និងស្តេចនៅអឺរ៉ុបបន្តិចម្តងៗបានកើតមានជម្លោះជាមួយគ្នា។ នៅក្នុងឆ្នាំ 1075 ជម្លោះមួយរវាងស្តេចប៉ាបក្រេហ្គូរទី 7 ជាមួយនឹងអធិរាជចក្រភពរ៉ូម៉ាំងដ៏ពិសិដ្ឋ ហេនរីទី 4 បានឈានដល់វិបត្តិមួយ។

ការបះទង្គិចគ្នារវាងមហាអំណាចពីរ៖ ចក្រភូមិរ៉ូម៉ាំងដ៏ពិសិដ្ឋគ្របដណ្តប់មួយភាគធំលើតំបន់អឺរ៉ុបកណ្តាល និងអ៊ីតាលីភាគខាងជើង។ ចក្រភពនេះចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 962 នៅពេលដែលស្តេចអាឡឺម៉ង់មួយអង្គព្រះនាម អូតតូ ត្រូវបានលើកឱ្យឡើងគ្រងរាជ្យដោយស្តេចប៉ាប។ ចក្រភពរ៉ូម៉ាំងដ៏ពិសិដ្ឋ បន្តស្ថិតនៅរហូតដល់ឆ្នាំ 1806 ។ អធិរាជក្រោយមួយអង្គព្រះនាមហេនរីទី 4 បានស្ថាបនាអំណាចនយោបាយតាមរយៈការតែងតាំងមន្ត្រីព្រះវិហារសាសនាគ្រឹស្ត។ ប៉ុន្តែ នៅក្នុងឆ្នាំ 1075 ស្តេចប៉ាបក្រេហ្គូរី បានប្រកួតប្រជែងជាមួយអំណាចរបស់ព្រះអង្គម្ចាស់ហេនរី។ ទ្រង់បានប្រកាសថា មានតែបព្វជិតតែប៉ុណ្ណោះដែលអាចតែងតាំងមន្ត្រីព្រះវិហារសាសនាគ្រឹស្ត។ ព្រះអង្គម្ចាស់ហេនរី និងសង្ឃរាជដែលគាំទ្រទ្រង់បានប្រកាសថាការសេចក្តីសម្រេចរបស់ស្តេចប៉ាបមិនអាចយកជាការបានឡើយ។ ស្តេចប៉ាបក្រេហ្គូរីបានឆ្លើយតបជាមួយនិងភាពរឹងទទឹងរបស់ហេនរីតាមរយៈការបណ្តេញព្រះអង្គម្ចាស់ហេនរីចេញពីព្រះវិហារសាសនាគ្រឹស្ត។ ព្រះអង្គបានប្រាប់ប្រជានុរាស្ត្ររបស់ព្រះអង្គម្ចាស់ហេនរីថា ពួកគេមិនចាំបាច់ស្តាប់បញ្ជាអធិរាជរបស់ពួកគេទៀតឡើយ។ ពួកអភិជន និងមន្ត្រីព្រះវិហារគ្រឹស្តសាសនាជាច្រើនពេលនោះបានត្រឡប់ទៅប្រឆាំងជាមួយហេនរី។ ដោយវៃឆ្លាតហេនរីបានជ្រើសរើសយកវិធីសូមទោសដល់ស្តេចប៉ាប។ ក្នុងនាមជាបព្វជិតក្រេហ្គូរីត្រូវតែអភ័យទោសដល់ព្រះអង្គម្ចាស់ហេនរី។ ព្រះអង្គម្ចាស់ហេនរីទទួលបានឋានៈរបស់ទ្រង់វិញ និងត្រួតត្រាលើប្រជានុរាស្ត្ររបស់ទ្រង់ ប៉ុន្តែទំនាស់រវាងស្តេចអឺរ៉ុបជាមួយនឹងស្តេចប៉ាបនៅតែបន្ត។

ព្រះវិហារគ្រឹស្តសាសនាដឹកនាំការអប់រំ៖ ព្រះវិហារគ្រឹស្តសាសនាបានដើរតួនាទីគ្របដណ្តប់លើវិស័យអប់រំ។ សាលារៀនត្រូវបានបង្កើតឡើងនៅក្នុងសាលព្រះវិហារគ្រឹស្តសាសនា។ សិស្សនៅក្នុងសាលារៀននេះជាទូទៅជាពួកអភិជនដែលជារឿយៗក្លាយជាមេដឹកនាំសាសនា ឬនយោបាយ។ សាលាក្នុងព្រះវិហារគ្រឹស្តសាសនាទាំងនេះក្រោយមកកាន់រីកលូតលាស់ក្លាយជាមហាវិទ្យាល័យដំបូងៗ។ អ្នកប្រាជ្ញបានសិក្សាពីទស្សនវិទ្យាបុរាណ ប៉ុន្តែមន្ត្រីព្រះវិហារគ្រឹស្តសាសនាមួយចំនួនមានការព្រួយបារម្ភថា គំនិតបុរាណមួយចំនួនបានប្រឆាំងជាមួយការអប់រំរបស់ព្រះវិហារគ្រឹស្តអំពីជំនឿ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1200 អ្នកប្រាជ្ញជនជាតិអ៊ីតាលីមួយរូបឈ្មោះថូម៉ាស់ អាគីណាស់បានអះអាងថា ទស្សនវិទ្យាបុរាណអាចលេចចេញដោយសុខដុមជាមួយជំនឿគ្រឹស្តសាសនា។ លោកបានលើកឡើងថា ជំនឿទាំងពីរ និងហេតុផលរបស់វាមកពីអាទិទេពដូចគ្នា។ អាគីណាស់ត្រូវបានគេចងចាំថាជាអ្នកប្រាជ្ញសាសនាដ៏ល្បីល្បាញមួយរូប។ ឋានៈសាសនាគឺជាស្ថាប័នអប់រំសំខាន់បំផុតរបស់ព្រះវិហារគ្រឹស្តសាសនា។ ឋានៈសាសនាមួយគឺជាមនុស្សមួយក្រុមដែលរស់នៅតាមរយៈច្បាប់មួយដែលកម្រិតជាក់លាក់អំពីឋានៈរបស់ពួកគេ។ វណ្ណៈបព្វជិតជាឋានៈសាសនាមួយដែលញែកពួកគេចេញពីសង្គមទាំងមូលដើម្បីផ្តោតសំខាន់ទៅលើការបន់ស្រន់ និងការរៀបចំពិធីសម្រាប់ព្រះជាម្ចាស់។ សម្រាប់បុរសដែលចូលរួមទៅក្នុងវណ្ណៈបព្វជិតត្រូវបានគេហៅថាព្រះសង្ឃ។ ពួកទ្រង់គង់នៅក្នុងព្រះវិហារ។ ស្ត្រីដែលចូលរួមទៅក្នុងវណ្ណៈបព្វជិតត្រូវបានគេហៅថាដូនជី ពួកគាត់រស់នៅក្នុងកុដ្ឋយាយជី។

វង្វាយតម្លៃ៖ ពិពណ៌នាអំពីរបៀបដែលព្រះវិហារគ្រីស្តសាសនាចូលរួមជាមួយសង្គមមជ្ឈិមសម័យ។

### 3. បូជនីយកិច្ចចាប់ផ្តើម

សំណួរគន្លឹះ៖ ហេតុអ្វីបានជាពួកគ្រីស្តសាសនិកចាប់ផ្តើមធ្វើសង្គ្រាមដើម្បីដណ្តើមកាន់កាប់ប៉ាឡេស្ទីន?

បូជនីយកិច្ចគឺជាដំណើរបេសកកម្មយោធាពីអឺរ៉ុបទៅកាន់ប៉ាឡេស្ទីន ដែលត្រូវបានគេស្គាល់ថាដែនដីពិសិដ្ឋ។ យេរ៉ូសាឡឹមមានទីតាំងនៅប៉ាឡេស្ទីន។ តំបន់នេះមានភាពស័ក្តិសិទ្ធិសម្រាប់គ្រីស្តសាសនិក, ម៉ូស្លីម, និងពួកជ្វីប។ បូជនីយកិច្ចមានឥទ្ធិពលរយៈពេលវែងមួយដល់នយោបាយ និងសង្គមអឺរ៉ុប។

មូលហេតុនៃបូជនីយកិច្ច៖ គ្រីស្តសាសនិកនៅអឺរ៉ុបចាប់ផ្តើមបូជនីយកិច្ចសម្រាប់ហេតុផលជាច្រើន។ ពួកសេលជូកតួកបានត្រួតត្រាតំបន់ប៉ាឡេស្ទីននៅក្នុងឆ្នាំ 1071 ។ ខុសពីមេដឹកនាំយេរ៉ូសាឡឹមមុនៗ សេលជូកបានធ្វើឱ្យដំណើរស្វែងបុណ្យរបស់ពួកគ្រីស្តសាសនិកទៅកាន់ទឹកដីពិសិដ្ឋស្ទើរតែមិនអាចទៅរួច។ ក៏ដូចគ្នាដែរ ព្រះអង្គម្ចាស់ និងពាណិជ្ជករអឺរ៉ុបនីមួយៗបានសំលឹងឃើញពីសង្គ្រាមនេះ។ ព្រះអង្គម្ចាស់ប្រើប្រាស់ភាពជោគជ័យនៅក្នុងសង្គ្រាមនេះធ្វើជាមធ្យោបាយមួយដើម្បីទទួលបានអំណាច។ ពាណិជ្ជករមានបំណងនៅក្នុងការផ្តល់ហិរញ្ញវត្ថុដល់បូជនីយកិច្ចនេះ ដោយសារពួកគេអាចចូលទៅកាន់ផ្លូវពាណិជ្ជកម្មសំខាន់ៗដែលភ្ជាប់ជាមួយតំបន់អាស៊ីនៅភាគខាងកើត។ ចុងក្រោយ កងកម្លាំងសេលជូកបានវាយប្រហារចក្រភពប៊ីហ្សង់ទីន បណ្តាលឱ្យអធិរាជប៊ីហ្សង់ទីនស្នើសុំជំនួយពីស្តេចប៉ាប។ ត្រឹមឆ្នាំ 1095 ស្តេចប៉ាបឃូបានទី 2 បានឆ្លើយតបជាមួយនឹងការស្នើសុំ ហើយត្រឹមឆ្នាំ 1096 បូជនីយកិច្ចដំបូងបានចាប់ផ្តើម។

បូជនីយកិច្ចដំបូង និងទី 2៖ នៅក្នុងឆ្នាំ 1096 កងទ័ពអឺរ៉ុបមួយចំនួនចាប់ផ្តើមចាកចេញពីទីក្រុងកង់ស្តង់ទីណុបរបស់ចក្រភពប៊ីហ្សង់ទីន។ ពីទីនោះពួកគេរៀបចំគម្រោងដើម្បីវាយប្រហារប៉ាឡេស្ទីន។ មានមនុស្សរាប់ម៉ឺននាក់បានស្លាប់នៅតាមផ្លូវ។ ប៉ុន្តែ កងកម្លាំងបូជនីយកិច្ចដ៏ធំមួយត្រូវបានរៀបចំដើម្បីធ្វើការវាយប្រហារលើប៉ាឡេស្ទីន។ កងកម្លាំងគ្រីស្តសានិកបានដណ្តើមកាន់កាប់ទីក្រុងនានានៅនីកាអ៊ា និងអានទូច ហើយនៅក្នុងឆ្នាំ 1099 ពួកគេបានដណ្តើមកាន់កាប់យេរ៉ូសាឡឹម។ ពួកគេបានបែងចែកដែនដីដែលឈ្លានពានបានទៅជារដ្ឋចំនួន 4 ៖ អេដេសសា, អានទូច, ទ្រីប៉ូលី, និងយេរ៉ូសាឡឹម។ បូជនីយកិច្ចលើកទី 2 (1147-1149) ចាប់ផ្តើមឡើងបន្ទាប់ពីពួកម៉ូស្លីមតួកបានដណ្តើមកាន់កាប់រដ្ឋបូជនីយកិច្ច អេដេសសានៅក្នុងឆ្នាំ 1144 ។ កងទ័ពអឺរ៉ុបត្រូវបានធ្វើឱ្យចុះខ្សោយដោយការធ្វើដំណើររយៈចម្ងាយឆ្ងាយទៅកាន់ទឹកដីពិសិដ្ឋ។ ជាលទ្ធផល កងកម្លាំងម៉ូស្លីមបានយកជ័យជំនះលើពួកបូជនីយកិច្ចនៅដាម៉ាសគូស។ ពួកគ្រីស្តសាសនិកនៅតែបន្តគ្រប់គ្រងរដ្ឋបូជនីយកិច្ចផ្សេងៗទៀត។ ពួកគេអាចបន្តស្ថិតនៅទីនោះទៀតបាន មួយផ្នែកដោយសារតែការបន្តមិនចុះសម្រុងគ្នាក្នុងចំណោមមេដឹកនាំម៉ូស្លីម។

ស្វែងរកគំនិតសំខាន់៖ រៀបរាប់ និងពិពណ៌នាពីមូលហេតុដែលនាំឱ្យបូជនីយកិច្ចចាប់ផ្តើមឡើង។

### 4. ម៉ូស្លីមទទួលជ័យជំនះ និងបរាជ័យ

សំណួរគន្លឹះ៖ តើពួកម៉ូស្លីមទទួលបានជោគជ័យយ៉ាងដូចម្តេចបន្ទាប់ពីបូជនីយកិច្ចលើកទី 1 ?

ភាពមិនចុះសម្រុងគ្នាក្នុងចំណោមពួកម៉ូស្លីមបានបញ្ចប់នៅចុងទសវត្សរ៍ឆ្នាំ 1100 ។ ការបង្រួបបង្រួមរបស់ពួកគេចាប់ផ្តើមកើតមានឡើងបន្ទាប់ពីការឡើងកាន់អំណាចរបស់សាឡា-អាល-ឌីន ដែលជាមេដឹកនាំនយោបាយ និងយោធាម៉ូស្លីមមួយរូប។

សាឡាឌីន និងបូជនីយកិច្ចលើកទី 3 ៖ សាឡា-អាល-ឌីនត្រូវបានពួកអឺរ៉ុបស្គាល់ថាសាឡាឌីន។ អស់រយៈពេលជាច្រើនឆ្នាំ សាឡាឌីនឡើងកាន់អំណាចយ៉ាងឆាប់រហ័សជាមួយដឹកនាំម៉ូស្លីមមួយរូប ដំបូងនៅអេហ្ស៊ីប និងបន្ទាប់មកនៅស៊ីរី។ ត្រូវបានគេស្គាល់ច្បាស់ថាជាបញ្ញាជនមួយរូប ជាមួយនិងការដឹកនាំដ៏មត់ចត់ ទ្រង់មិនត្រឹមតែរឹងមាំ និងហិង្សាប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏មានចិត្តសប្បុរស និងគិតគូរវែងឆ្ងាយផងដែរ។ នៅក្នុងឆ្នាំ 1187 សាឡាឌីនបានប្រមូលផ្តុំកងកម្លាំងដ៏ធំមួយដើម្បីវាយប្រហារលើរដ្ឋរបស់ពួកបូជនីយកិច្ច។ កងកម្លាំងរបស់សាឡាឌីនបានទទួលជ័យជំនះលើសមរភូមិជាច្រើន និងដណ្តើមកាន់កាប់ទីក្រុងយេរ៉ូសាឡឹមមកវិញ។ វាមិនបានចំណាយពេលវេលាច្រើនឡើយសម្រាប់ពួកអឺរ៉ុប សម្រាប់ព័ត៌មានស្តីអំពីជ័យជំនះរបស់សាឡាឌីន។ បន្ទាប់ពីការដួលរលំនៃទីក្រុងយេរ៉ូសាឡឹម ស្តេចប៉ាបបានស្នើឱ្យមានបូជនីយកិច្ចមួយផ្សេងទៀត។ មេដឹកនាំអឺរ៉ុបដែលមានអំណាចមួយចំនួនបានចូលរួមជាមួយននិងបូជនីយកិច្ចលើកទី 2 (1189-1192)។ ក្នុងចំណោមពួកគេរួមមានស្តេចអង់គ្លេសព្រះនាមរីឆាដនៃបេះដូងតោ។ រីឆាដបានក្លាយជាមេដឹកក្រុមបូជនីយកិច្ចដោយសារតែសមត្ថភាព និងជំនាញរបស់ទ្រង់នៅក្នុងសមរភូមិ។ ក្រុមអ្នកបូជនីយកិច្ចទទួលបានជោគជ័យនៅដើមដំបូង ប៉ុន្តែពួកគេមិនអាចសម្រេចគោលដៅសំខាន់របស់ពួកគេក្នុងការដណ្តើមទីក្រុងយេរ៉ូសាឡឹមមកវិញឡើយ។ នៅក្នុងឆ្នាំ 1192 សាឡាឌីន និងរីឆាដព្រមព្រៀងគ្នាក្នុងការផ្អាកសង្គ្រាម។ យេរ៉ូសាឡឹមនឹងនៅតែស្ថិតនៅក្រោមការត្រួតត្រារបស់ពួកម៉ូស្លីម។ ប៉ុន្តែក្នុងការឆ្លើយតប សាឡាឌីនយល់ព្រមក្នុងការអនុញ្ញាតឱ្យក្រុមអ្នកស្វែងបុណ្យគ្រិស្តសាសនិកអាចទស្សនទីកន្លែងពិសិដ្ឋៗនៅក្នុងទីក្រុងនេះបាន។

បូជនីយកិច្ចលើកទី 4 ៖ កិច្ចព្រមព្រៀងក្នុងការផ្អាកសង្គ្រាមនេះមិនមានរយៈពេលវែងឡើយ ហើយពួកអឺរ៉ុបបានចាប់ផ្តើមបូជនីយកិច្ចលើកទី 4 (1202-1204)។ ដើម្បីបង់ឱ្យពួកពាណិជ្ជករអ៊ីតាលីដែលបានដឹកជញ្ជូនពួកគេ ក្រុមអ្នកបូជនីយកិច្ចយល់ព្រមនៅក្នុងការវាយប្រហាររាជធានីហ្សារ៉ារបស់ប៊ីហ្សង់ទីន។ បន្ទាប់មកក្រុមអ្នកបូជនីយកិច្ចបានវាយបំផ្លាញទីក្រុងកុងស្តង់ទីណុប ដើម្បីដាក់សម្ព័ន្ធមិត្តនយោបាយមួយឱ្យគ្រប់គ្រងចក្រភពប៊ីហ្សង់ទីន។ ស្តេចប៉ាបបានខឹងសម្បាជាមួយពួកបូជនីយកិច្ចដែលបានវាយប្រហារទីក្រុងរបស់ពួកគ្រិស្តសាសនិក ប៉ុន្តែទ្រង់មិនអាចបញ្ឈប់ពួកគេបានឡើយ។ ការវាយប្រហារនេះបានធ្វើឱ្យចក្រភពប៊ីហ្សង់ទីនធ្លាក់ចុះខ្សោយយ៉ាងខ្លាំង។

ឥទ្ធិពលនៃបូជនីយកិច្ច៖ ទំនាក់ទំនងរបស់ពួកអឺរ៉ុបជាមួយវប្បធម៌របស់មេឌីទែរ៉ាណេភាគខាងកើតបានកើនឡើងអំឡុងពេលនៃការធ្វើបូជនីយកិច្ច។ ក្រុមអ្នកធ្វើបូជនីយកិច្ចបាននាំយកមកវិញនូវទំនិញរបស់អាស៊ី ដែលជាហេតុនាំឱ្យពាណិជ្ជកម្មកើនឡើង។ ទំនិញទាំងនោះរួមមាន៖ គ្រឿងទេស, រោមសត្វ, សំលៀកបំពាក់, ស្ករអំពៅ, អង្ករ, និងផ្លែឈើផ្សេងៗទៀត។ ការកើនឡើងនៃពាណិជ្ជកម្មឆ្លងកាត់តំបន់មេឌីទែរ៉ាណេបានជួយឱ្យទីប្រជុំជននៅអឺរ៉ុបរីកលូតលាស់ និងធ្វើឱ្យតួនាទីរបស់ពាណិជ្ជករនៅក្នុងទីក្រុងកាន់តែមានសារៈសំខាន់។ កេរ្តិ៍តំណែលមួយ

ទៀតនៃបូជនីយកិច្ចគឺការកើនឡើងនៃអរិភាពរបស់គ្រីស្តសាសនិកចំពោះពួកជ្វីប។ ពួកគ្រីស្តសាសនិកកាន់តែច្រើនទៅយល់ថាអ្នកមិនមែនជាគ្រីស្តសាសនិកគឺជាសត្រូវរបស់ពួកគេ។ ការសម្លាប់គ្នានៅតែបន្តនៅប៉ាឡេស្ទីន។ បន្ទាប់ពីការធ្វើបូជនីយកិច្ច ពួកជ្វីបត្រូវបាននិរទេសចេញពីអង់គ្លេសនៅក្នុងឆ្នាំ 1290 និងពីប្រទេសបារាំងនៅក្នុងឆ្នាំ 1306 និងម្តងទៀតនៅក្នុងឆ្នាំ 1394 ។ ពួកជ្វីបទាំងនេះភាគច្រើនបានផ្លាស់ទីទៅកាន់អឺរ៉ុបខាងភាគខាងកើត។ ប៉ុន្តែ ពួកម៉ូស្លីមបានអនុញ្ញាតឱ្យពួកជ្វីប និងគ្រីស្តសាសនិករស់នៅប្រកបដោយសន្តិភាពនៅករណីជាច្រើន។ ក្រុមអ្នកធ្វើបូជនីយកិច្ចជាច្រើនអ្នកដែលរស់នៅប៉ាឡេស្ទីនបានធ្វើការគោរពចំពោះពួកម៉ូស្លីម ប៉ុន្តែភាពមិនអត់ឱនរបស់ពួកគ្រីស្តសាសនិកចំពោះពួកជ្វីបនៅតែបន្ត។

រីខុនឃ្វីស្តា៖ មេដឹកនាំម៉ូស្លីមបានបណ្តេញពួកអ្នកធ្វើបូជនីយកិច្ចចេញពីប៉ាឡេស្ទីន។ ប៉ុន្តែនៅក្នុងប្រទេសអេស្ប៉ាញ អ្វីៗកើតឡើងផ្ទុយពីនេះ។ នៅទីនោះ ពួកកងទ័ពគ្រីស្តសាសនិកបានបណ្តេញមេដឹកនាំម៉ូស្លីមចេញ។ នៅក្នុងភាសាអេស្ប៉ាញ ព្រឹត្តិការណ៍នេះត្រូវបានគេហៅថា រីខុនឃ្វីស្តា។ ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក 11 ម៉ូស្លីមបានដណ្តើមកាន់កាប់ឧបទ្វីបអ៊ីបេរៀន ដែលបច្ចុប្បន្នរួមបញ្ចូលប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល នៅដើមទសវត្សរ៍ឆ្នាំ 700 ។ ប៉ុន្តែ ត្រឹមទសវត្សរ៍ឆ្នាំ 1000 ការបង្រួបបង្រួមរបស់ពួកម៉ូស្លីមនៅឧបទ្វីបនេះបានបែកបាក់។ ព្រះរាជាណាចក្រនានារបស់ពួកអេស្ប៉ាញ និងព័រទុយហ្គាលបានលេចឡើងដើម្បីប្រឆាំងជាមួយកងកម្លាំងម៉ូស្លីម។ នៅក្នុងទសវត្សរ៍ឆ្នាំ 1400 ស្តេចហ្វឺឌីណាន់ និងម្ចាស់ក្សត្រីអ៊ីសាប៊ែលឡាបានបង្រួបបង្រួមប្រទេសអេស្ប៉ាញតាមរយៈអំណាចយោធា និងសាសនា។ កងទ័ពរបស់ទ្រង់បានដណ្តើមកាន់កាប់ទីក្រុងនានា ហើយមន្ត្រីព្រះវិហារគ្រីស្តសាសនារបស់ទ្រង់ បានប្រើប្រាស់តុលាការដើម្បីដាក់ពិន័យដល់អ្នកទាំងឡាយណាដែលប្រឆាំងជាមួយនឹងការអប់រំរបស់ព្រះវិហារគ្រីស្តសាសនា។ តុលាការនេះ ដែលត្រូវបានប្រើប្រាស់នៅពាសពេញអឺរ៉ុបត្រូវបានគេហៅថា ការស៊ើបអង្កេតដោយហ្មត់ចត់។ ការស៊ើបអង្កេតដោយហ្មត់ចត់បានធ្វើទារុណកម្ម និងប្រហារជីវិតពួកជ្វីប និងម៉ូស្លីមអស់ជាច្រើននៅក្នុងប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល។ នៅក្នុងឆ្នាំ 1492 ស្តេចហ្វឺឌីណាង់ និងម្ចាស់ក្សត្រីអ៊ីសាប៊ែលឡាសម្រេចជោគជ័យរីខុនឃ្វីស្តា តាមរយៈការបង្ខំឱ្យមេដឹកនាំម៉ូស្លីមចុងក្រោយគេ និងអ្នកដើរតាមចេញពីប្រទេសអេស្ប៉ាញ។ ពួកជ្វីបជាច្រើនក៏ត្រូវបានបង្ខំឱ្យចាក់ចេញផងដែរ។

សង្ខេប៖ សង្ខេបអំពីភាពជោគជ័យនៃកងទ័ពម៉ូស្លីមបន្ទាប់ពីបូជនីយកិច្ចលើកទីមួយ។

# មេរៀនទី 3 ៖ ជំងឺប៉េស្ត និងសង្គ្រាមរាប់រយឆ្នាំ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ រហូតមកដល់ជំពូកនេះ អ្នកបានអានអំពីការចាប់ផ្ដើមដំបូង និងការងារដំបូងរបស់សក្តិភូមិនិយមនៅអឺរ៉ុប។ នៅក្នុងមេរៀនទី 3 អ្នកនឹងបានសិក្សាអំពីវិបត្តិមួយចំនួនដែលបានធ្វើឱ្យសក្តិភូមិនិយមធ្លាក់ចុះខ្សោយ។

## 1. ជំងឺប៉េស្ត

សំណួរគន្លឹះ៖ តើការរីករាលដាលនៃជំងឺគ្រុនប៉េស្តបានជះឥទ្ធិពលអ្វីខ្លះ ?

នៅមុនចុងបញ្ចប់នៃសតវត្សរ៍ ជំងឺប៉េស្តបានសម្លាប់មនុស្សអស់រាប់សិបលាននាក់នៅអឺរ៉ុប, អាហ្វ្រិកខាងជើង, និងអាស៊ីខាងលិច។ នៅអឺរ៉ុប មនុស្សប្រមាណ 1/3 នៃចំនួនប្រជាជនសរុបបានស្លាប់។

ការរីករាលដាលនៃជំងឺ៖ ជំងឺប៉េស្តដែលវាយប្រហារមកលើតំបន់អឺរ៉ាស៊ីភាគខាងលិចនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1300 ត្រូវបានគេហៅថាជំងឺគ្រុនប៉េស្ត។ ជនរងគ្រោះពីជំងឺនេះមានបទពិសោធន៍ជាមួយនឹងរងារញាក់, គ្រុនក្ដៅ, ប្រកាច់, និងក្អួតចង្អោរធ្ងន់ធ្ងរ។ ជនរងគ្រោះក៏មានលេចចេញនូវដុំពណ៌ខ្មៅនៅលើស្បែករបស់ពួកគេ និងហើមកូនកណ្ដុរ។ មនុស្សម្នាក់ដែលឆ្លងជំងឺគ្រុនប៉េស្តនេះជាទូទៅបានស្លាប់ក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ។ ជំងឺប៉េស្តនៅក្នុងទសវត្សរ៍ឆ្នាំ 1300 ក៏ត្រូវបានគេស្គាល់ថា ការស្លាប់ពណ៌ខ្មៅ។

ឥទ្ធិពលនៃជំងឺប៉េស្ត៖ ការបាត់បង់ជីវិតមនុស្សក្នុងចំនួនដ៏ច្រើនដែលបណ្ដាលមកពីជំងឺប៉េស្តបានជះឥទ្ធិពលសំខាន់មួយនៅអាស៊ី, អាហ្វ្រិកខាងជើង, និងអឺរ៉ុប។ ពួកគ្រីស្តសាសនិក និងម៉ូស្លីមប្រតិកម្មផ្សេងៗគ្នាចំពោះជំងឺប៉េស្ត។ គ្រីស្តសាសនិកជាទូទៅយល់ថាជំងឺប៉េស្តគឺជាការដាក់ពិន័យមួយសម្រាប់អំពើបាប។ ជាមួយគ្នានោះ ពួកម៉ូស្លីមយល់ថាជំងឺប៉េស្តគឺជាការសាកល្បងជំនឿរបស់ពួកគេចំពោះព្រះជាម្ចាស់។ ដោយមិនគិតពីជំនឿរបស់ពួកគេ ជំងឺប៉េស្តបានសម្លាប់មនុស្សប្រមាណពី 20 ទៅ 30 លាននាក់ត្រឹមឆ្នាំ 1400 ។ ក្នុងរយៈពេលដ៏ខ្លីមួយ សង្គ្រាមនានាត្រូវបានបញ្ឈប់ ហើយពាណិជ្ជកម្មបានធ្លាក់ចុះ។ ម្ចាស់កម្មសិទ្ធិដីធ្លីមួយចំនួនបានដួលរលំដោយសារតែកង្វះខាតកម្លាំងពលកម្ម។ ប៉ុន្តែ ហេតុការណ៍នេះត្រូវបានជួយដល់ការស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់មនុស្សមួយចំនួន។ ឧទាហរណ៍ ចំនួនកម្មករអឺរ៉ុបនៅពេលនោះមានកង្វះខាតយ៉ាងខ្លាំង ដូច្នេះអ្នកទាំងឡាយណាដែលអាចធ្វើការបានអាចទាមទារនូវប្រាក់កម្រៃខ្ពស់សម្រាប់ការធ្វើការងាររបស់ពួកគេ។ កង្វះខាតនៃកម្លាំងពលកម្ម និងអត្រាប្រាក់កម្រៃថ្លៃបានធ្វើឱ្យសក្តិភូមិនិយមធ្លាក់ចុះខ្សោយ ដោយសារតែកម្មករចាប់ផ្ដើមធ្វើអន្តោប្រវេសន៍ដើម្បីស្វែងរកការងារដែលមានប្រាក់កម្រៃខ្ពស់។ នៅអឺរ៉ុបអរិភាពចំពោះពួកជ្វីបដែលបានអភិវឌ្ឍឡើងអំឡុងពេលនៃការធ្វើបូជនីយកិច្ចបានបន្តអំឡុងពេលនៃការរីករាលដាលនៃជំងឺគ្រុនប៉េស្ត។ ពួកជ្វីបជារឿយៗត្រូវបានគេចោទថាជាអ្នកបង្ករឱ្យមានជំងឺប៉េស្តតាមរយៈការបំពុលទឹកនៅក្នុងអណ្ដូង។ ពួកគេត្រូវបានបណ្ដេញចេញពីទីប្រជុំជនជាច្រើនរបស់អាឡឺម៉ង់អំឡុងពេលនៃជំងឺប៉េស្ត។

សង្ខេប៖ ពិពណ៌នាអំពីឥទ្ធិពលនៃការរីករាលដាលនៃជំងឺគ្រុនប៉េស្ត។

## 2. សង្គ្រាមរាប់រយឆ្នាំ

សំណួរគន្លឹះ៖ តើហេតុអ្វីបានជាមានសង្គ្រាមប្រយុទ្ធគ្នារាប់រយឆ្នាំ?

នៅក្នុងទសវត្សរ៍ឆ្នាំ 1300 អង់គ្លេស និងបារាំងបានប្រឈមមិនត្រឹមតែជំងឺប៉េស្តប៉ុណ្ណោះទេ ប៉ុន្តែសង្គ្រាមជាញឹកញាប់ផងដែរ។ រវាងឆ្នាំ 1337 ដល់ឆ្នាំ 1453 អង់គ្លេស និងបារាំងបានវាយប្រយុទ្ធគ្នាទៅវិញទៅមកនៅក្នុងសង្គ្រាមរាប់រយឆ្នាំ។ វាគឺជាសង្គ្រាមដាច់ដោយឡែកពីគ្នាជាច្រើន មិនមែនជាសមរភូមិដែលបន្តប្រយុទ្ធគ្នាឡើយ។

សាវតារនៃសង្គ្រាម៖ ស្តេចវីលលៀម ព្រះអង្គម្ចាស់នៃណាមេនឌីជាអ្នកដែលចេញមកពីតំបន់ណាមេននៅប្រទេសបារាំង។ ទ្រង់បានប្រកាសថាទ្រង់គឺជាស្តេចស្របច្បាប់របស់អង់គ្លេស។ នៅក្នុងឆ្នាំ 1066 វីលលៀមបានដណ្តើមកាន់កាប់អង់គ្លេសនៅក្នុងអ្វីដែលគេហៅថាការឈ្លានពានណាមេន។ ទ្រង់ត្រូវបានគេស្គាល់ថាអ្នកដណ្តើមកាន់កាប់វិលលៀម និងបានបង្កើតចំណងទាក់ទងរវាងពួកអភិជនបារាំងជាមួយអភិជនអង់គ្លេស។ អស់រយៈច្រើនឆ្នាំកន្លងមក ជម្លោះបានកើនឡើងទៅលើបញ្ហាដែលថាអ្នកណាដែលមានសិទ្ធិនៅក្នុងការដឹកនាំតំបន់ទាំងនេះ។

ការប្រយុទ្ធគ្នារាប់ឆ្នាំ៖ ជម្លោះទាំងនោះបានផ្ទុះឡើងនៅដើមទសវត្សរ៍ឆ្នាំ 1300 ។ អង់គ្លេសបានអះអាងពីការកាន់កាប់ដែនដីដែលស្ថិតនៅបារាំងភាគនិរតី។ បារាំងបានគាំទ្រការប្រយុទ្ធរបស់ស្កុតលែនប្រឆាំងជាមួយអង់គ្លេស។ ក៏មានផងដែរនូវការជជែកគ្នាអំពីសិទ្ធិនៅក្នុងការធ្វើដំណើរតាមច្រកសមុទ្រអង់គ្លេស។ ការវាយប្រយុទ្ធគ្នាបានចាប់ផ្តើមនៅពេលដែលស្តេចបារាំងព្យាយាមនៅក្នុងយកដែនដី ដែលអះអាងកាន់កាប់ដោយអង់គ្លេសនៅបារាំងភាគខាងត្បូង។ ស្តេចអង់គ្លេសឆ្លើយតបជាមួយនឹងការអះអាងថា ទ្រង់គឺជាស្តេចស្របច្បាប់របស់បារាំង។ នៅក្នុងឆ្នាំ 1337 អង់គ្លេសបានវាយប្រហារលើបារាំង។ អង់គ្លេសបានទទួលជ័យជម្នះមួយចំនួននៅដើមដំបូង។ នៅក្នុងឆ្នាំ 1428 អង់គ្លេសបានវាយប្រហារលើអូឡេអង់ ដែលជាមូលដ្ឋានសំខាន់ចុងក្រោយរបស់បារាំង។ ស្ត្រីកសិករបារាំងមួយរូបដែលគេស្គាល់ថា ធ្នូចូន បានដឹកនាំពួកបារាំងយកជ័យជម្នះ។ ត្រឹមឆ្នាំ 1453 បារាំងបានបណ្តេញអង់គ្លេសចេញពីប្រទេសបារាំង និងបានបញ្ចប់សង្គ្រាម។

អាវុធថ្មីៗ៖ អាវុធថ្មីៗបានផ្លាស់ប្តូរការធ្វើសង្គ្រាមនៅអឺរ៉ុប និងជុំវិញពិភពលោក។ ធ្នូវែងដែលមានសមត្ថភាពនៅក្នុងការបាញ់ផ្លែព្រួញទម្លុះអាវគ្រោះរបស់អ្នកប្រយុទ្ធជិះសេះ។ ពួកអឺរ៉ុបក៏ចាប់យកប្រយោជន៍ពីអាវុធគ្រាប់រំសេវថ្មីផងដែរ។ បច្ចេកវិទ្យារំសេវមកពីប្រទេសចិន ប៉ុន្តែពួកអឺរ៉ុបបានអភិវឌ្ឍបច្ចេកវិទ្យានេះឱ្យក្លាយជាឧបករណ៍សំខាន់មួយនៅក្នុងសង្គ្រាម។ ឧទាហរណ៍ កាំភ្លើងធំអាចបំបែកជញ្ជាំងប្រាសាទ និងទម្លុះអាវគ្រោះរបស់អ្នកប្រយុទ្ធជិះសេះ។ អាវុធថ្មីទាំងនេះអាចយកជ័យជំនះដោយងាយស្រួលលើពួកអ្នកចម្បាំងជិះសេះ។ រយៈពេល 300 លក្ខណៈនៃសង្គ្រាមបានផ្លាស់ប្តូរយ៉ាងខ្លាំង។

សង្ខេប៖ ផ្តល់ហេតុផលដែលនាំឱ្យមានការវាយប្រយុទ្ធគ្នាអស់រាប់រយឆ្នាំ។

## 3. អឺរ៉ុបសម័យទំនើបដំបូងលេចឡើង

សំណួរគន្លឹះ៖ តើជីវិតផ្លាស់ប្តូរយ៉ាងដូចម្តេចបន្ទាប់ពីចុងបញ្ចប់នៃយុគកណ្តាល?

អស់រយៈពេលជាច្រើនសតវត្សរ៍ សង្គមអឺរ៉ុបជាច្រើនអនុវត្តរចនាសម្ព័ន្ធសក្តិភូមិដែលអ្នកបានសិក្សានៅក្នុងមេរៀនទី 1 ។ ប៉ុន្តែក្រោយមក សក្តិភូមិនិយមអឺរ៉ុបបានដួលរលំ និងជាសញ្ញាណនៃការបញ្ចប់នៃយុគកណ្តាល។

រចនាសម្ព័ន្ធសង្គម និងនយោបាយ៖ ពាណិជ្ជអឺរ៉ុបបានកើនឡើងនៅអំឡុងយុគកណ្តាល។ ចំនួន និងទំហំនៃទីប្រជុំជនក៏បានកើនឡើងផងដែរ ដូចដែលប្រជាជនបានផ្លាស់ទីពីទីជនបទមកកាន់ទីក្រុងដើម្បីសម្លឹងរកអនាគតថ្មី។ សកម្មភាពបានកើតមានឡើងបើទោះបីជាប្រជាជនអឺរ៉ុបទាំងមូលត្រូវចំណាយពេលរាប់ឆ្នាំដើម្បីស្តារឡើងវិញពីជំងឺប៉េស្ត, សង្គ្រាមរាប់រយឆ្នាំ, និងសង្គ្រាមផ្សេងៗទៀត។ ទីប្រជុំត្រូវការស្ថេរភាពដើម្បីធ្វើឱ្យជំនួញ និងពាណិជ្ជកម្មកាន់តែទុកចិត្តបាន។ ពួកពាណិជ្ជករមានទ្រព្យសម្បត្តិស្តុកស្តម្ភបានបង្កើនអំណាចរបស់ពួកគេនៅក្នុងតំបន់យ៉ាងឆាប់រហ័ស។ ពួកស្តេចអឺរ៉ុបក៏បានសម្លឹងទៅរកពាណិជ្ជករមានៗ, ជានាគារិក, និងអ្នកជំនួញ ដូចដែលពួកគេគឺជាប្រភពនៃលុយ តាមរយៈការយកពន្ធ និងកម្ចី។ ស្តេចដែលទទួលបានមូលនិធិគ្រប់គ្រាន់បានបង្កើតច្បាប់ និងសណ្តាប់ធ្នាប់, ផ្តល់នូវស្ថេរភាពនៅក្នុងទីក្រុង។ ជាលទ្ធផល ទីប្រជុំជនបានក្លាយជាមជ្ឈមណ្ឌលសម្រាប់ការគាំទ្រដល់ស្តេច ហើយជាការឆ្លើយតបស្តេចបានពង្រីកអំណាចដល់ពួកគេ។ ស្តេចទទួលបានអំណាចកាន់តែច្រើនបន្ទាប់ពីសង្គ្រាមរាប់រយឆ្នាំ។ ឧទាហរណ៍ ស្តេចបារាំងមិនចាំបាច់ព្រួយបារម្ភអំពីការអះអាងកាន់កាប់របស់អង់គ្លេសចំពោះរាជបល្ល័ង្ករបស់ទ្រង់ទៀតឡើយ។ ស្តេចល្វីទី 14 (1643-1715) របស់បារាំងបានក្លាយជានិមិត្តរូបរាជាធិបតេយ្យអំណាចផ្តាច់មុខ ជាប្រព័ន្ធនយោបាយមួយដែលស្តេច ឬក្សត្រីមានអំណាច និងការត្រួតត្រាទាំងស្រុងទៅលើទិដ្ឋភាពទាំងអស់នៃសង្គម។ ជាមួយនឹងជំនួយពីសំណាក់ទីប្រឹក្សាជំនាញ ស្តេចល្វីនឹងធ្វើឱ្យបារាំងក្លាយជាប្រទេសដែលមានអំណាចបំផុតនៅអឺរ៉ុប។

គំនិតថ្មីៗ៖ សម្រាប់ប្រវត្តិវិទូជាច្រើន ការបញ្ចប់នៃយុគកណ្តាលចាប់ផ្តើមជាមួយនឹងការអភិវឌ្ឍនៃប្រទេសជាតិធំៗដែលមានរដ្ឋាភិបាលកណ្តាលដ៏មានឥទ្ធិពលដែលដឹកនាំដោយស្តេច។ ដូចដែលយុគកណ្តាលឆ្ពោះទៅរកការបញ្ចប់ អ្នកប្រាជ្ញនៅតែបន្តសិក្សាអំពីអត្ថបទបុរាណ ដែលចាប់ផ្តើមជាមួយបុរសៗ ក្នុងនោះមានដូចជាលោកថូម៉ាស់ អាគីណាស់ ដែលអ្នកបានអាននៅក្នុងមេរៀនទី 2 រួចមកហើយ។ គំនិតថ្មីៗអំពីការសិក្សា, វិទ្យាសាស្ត្រ, និងសិល្បៈត្រូវបានអភិវឌ្ឍឡើងនៅក្នុងទីក្រុងនានានៅអ៊ីតាលី។ គំនិតថ្មីបានរីករាលដាលតាមបណ្តោយផ្លូវពាណិជ្ជកម្មនៅអឺរ៉ុប។ យុគសម័យថ្មីនេះត្រូវបានគេហៅថាបុនសម័យ (សម័យរីកចម្រើនឡើងវិញ) ហើយអ្នកនឹងបានអានរឿងនេះកាន់តែច្រើនទៀតនៅក្នុងជំពូក 17 ។

សង្ខេប៖ រៀបរាប់ពីការផ្លាស់ប្តូរនៅក្នុងជីវភាពរស់នៅនាចុងបញ្ចប់នៃយុគកណ្តាល។

# មេរៀនទី 4 ៖ ការចាប់ផ្តើមឡើងនៃរដ្ឋាភិបាលសម័យទំនើប

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ នៅក្នុងមេរៀនទី 3 អ្នកបានអានអំពីព្រឹត្តិការណ៍ដែលបានធ្វើឱ្យសក្តិភូមិនិយមចុះអន់ថយ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីការអនុវត្តច្បាប់ និងធម្មនុញ្ញរបស់អង់គ្លេសចាប់ពីទសវត្សរ៍ឆ្នាំ 1100 និង 1200 ដែលនៅតែមានសារៈសំខាន់រហូតមកដល់បច្ចុប្បន្ន។

## 1. រដ្ឋាភិបាលអង់គ្លេស

សំណួរគន្លឹះ៖ តើរដ្ឋាភិបាលអង់គ្លេសផ្លាស់ប្តូរដោយរបៀបណាអំឡុងសម័យនេះ?

នៅក្នុងយុគកណ្តាល អំណាចច្បាប់នៅក្នុងប្រទេសអង់គ្លេសចាប់ផ្តើមផ្លាស់ចេញបន្តិចម្តងៗព្រះស្តេច។ គំនិតដែលនាំទៅដល់ការផ្លាស់ចេញនេះ បានក្លាយជាមូលដ្ឋានគ្រឹះនៃការអនុវត្តច្បាប់សម័យទំនើបនានា។

ច្បាប់រួម៖ ព្រះអង្គម្ចាស់ហេនរីទី 2 (1154-1189) បាននាំមកនូវភាពរឹងមាំមួយសម្រាប់ប្រព័ន្ធច្បាប់របស់អង់គ្លេស តាមរយៈការបញ្ជូនរាជតុលាការទៅកាន់ផ្នែកទាំងឡាយនៃប្រទេស។ មុនពេលនោះ ច្បាប់គឺពឹងផ្អែកលើទំនៀបទម្លាប់ក្នុងតំបន់ និងការកំណត់របស់តុលាការមុនៗ។ នេះត្រូវបានគេហៅថាច្បាប់រួម។ វាមានន័យថាសេចក្តីសម្រេចនៅក្នុងផ្នែកណាមួយនៅក្នុងប្រទេសអង់គ្លេសអាចនឹងខុសគ្នាពីផ្នែកផ្សេងៗទៀត។ ប៉ុន្តែ ការធ្វើសេចក្តីសម្រេចចិត្តរបស់រាជតុលាការថ្មី មានគោលដៅនៅក្នុងការអនុវត្តទូទាំងអង់គ្លេសតែម្តង។ រាជនីតិហាក់ដូចជាបង្ហាញឱ្យឃើញកាន់តែច្បាស់ថាមនុស្សទាំងអស់នៅអង់គ្លេសនឹងទទួលបានការអនុវត្តស្មើៗគ្នា។

តុលាការឯករាជ្យ៖ រាជតុលាការបង្ហាញពីឯករាជ្យភាពពីនយោបាយក្នុងតំបន់។ ប៉ុន្តែ ពួកគេមិនទាន់ឯករាជ្យពីរាជរដ្ឋាភិបាល។ តុលាការមជ្ឈិមសម័យនៅអង់គ្លេសមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីតុលាការអង់គ្លេសនាពេលបច្ចុប្បន្ន។ ឧទាហរណ៍ តុលាការសហរដ្ឋអាមេរិកមានឯករាជ្យពីគ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាល។ នេះគេហៅថាតុលាការឯករាជ្យ ដែលអ្នកនឹងបានអានកាន់តែច្រើននៅជំពូកបន្ទាប់។

ម៉ាកណា ខាតា៖ នៅក្នុងឆ្នាំ 1199 រាជបុត្រាពៅរបស់ព្រះអង្គម្ចាស់ហេនរីទី 2 ព្រះនាមចនបានឡើងគ្រប់គ្រងអំណាច។ ព្រះអង្គម្ចាស់ចនបានវាយប្រយុទ្ធ និងបរាជ័យនៅក្នុងសង្គ្រាមជាច្រើន។ ការនេះបានធ្វើឱ្យហិរញ្ញវត្ថុអង់គ្លេសធ្លាក់ចុះខ្សោយ។ ពួកអភិជនជាច្រើនរបស់អង់គ្លេសបានប្រឆាំងជាមួយគោលនយោបាយរបស់ព្រះអង្គម្ចាស់ចន។ ពួកគេបានប្រាប់ព្រះអង្គម្ចាស់ចនថា ទ្រង់គួរតែទទួលស្គាល់សិទ្ធិរបស់ពួកគេ។ ពួកគេបានសរសេរសិទ្ធិទាំងនេះនៅក្នុងឯកសារមួយដែលគេហៅថា ម៉ាកណា ខាតា និងបានបង្ខំឱ្យព្រះអង្គម្ចាស់ចនឡាយព្រះហស្តលេខានៅក្នុងឆ្នាំ 1215 ។ ម៉ាកណា ខាតាធានាដល់ការការពារច្បាប់ និងការកាត់សេចក្តីដោយចៅក្រម។ វាក៏បានធានាថា ព្រះមហាក្សត្រមិនអាចប្រមូលលុយពីពួកអភិជនដោយមិនមានការយល់ព្រមពីពួកគេឡើយ។ ប្រជាជនអង់គ្លេសសាមញ្ញមិនទទួលបានអត្ថប្រយោជន៍ភ្លាមៗពីម៉ាកណា ខាតាឡើយ។ ប៉ុន្តែ ម៉ាកណា ខាតាបានបង្កើតជាគំរូមួយសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅក្នុងប្រទេសអង់គ្លេស និងពិភពលោកទាំងមូលនាពេលក្រោយមក។ នៅក្នុងជំពូក 19 អ្នកនឹងបានអានលម្អិតអំពីឥទ្ធិពលរបស់ម៉ាកណា ខាតាលើគំនិតប្រជាធិបតេយ្យ។

ស្វែងរកគំនិតសំខាន់៖ រៀបរាប់ពីវិធីសំខាន់ៗនៅក្នុងការផ្លាស់ប្តូររដ្ឋាភិបាលអង់គ្លេស។

## 2. ស្ថាប័នតំណាង

សំណួរគន្លឹះ៖ នៅក្នុងវិធីណាដែលសភាតំណាងរាស្ត្រអាចកម្រិតអំណាចរបស់ព្រះមហាក្សត្រ?

ប្រវត្តិវិទូមួយចំនួនយល់ឃើញថា ការអនុវត្តនយោបាយរបស់អង់គ្លេសនៅមជ្ឈិមសម័យគឺជាមូលដ្ឋានគ្រឹះនៃរដ្ឋាភិបាលតំណាងសម័យទំនើប។ ប៉ុន្តែការលេចឡើងនៃអំណាចរបស់សភាតំណាងរាស្ត្រមានលក្ខណៈយឺត និងទទួលបានជោគជ័យទាំងលំបាក។

អង្គដឹកនាំថ្មីមួយ៖ ជំហានសំខាន់មួយឆ្ពោះទៅរករដ្ឋាភិបាលតំណាងបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1264 ។ អភិជនអង់គ្លេសបានដកស្តេចហេនរីទី 2 ចេញពីអំណាចបន្ទាប់ពីទ្រង់បានល្មើសកិច្ចព្រមព្រៀងជាមួយពួកគេ។ ពួកគេបានដាក់ជំនួសទ្រង់ជាមួយនឹងអ្នកតំណាងមួយក្រុម ដែលក្រោយមកត្រូវបានគេហៅថាសភាតំណាងរាស្ត្រ។ សភាតំណាងរាស្ត្ររួមបញ្ចូលពួកអភិជន, មន្ត្រីព្រះវិហារគ្រីស្តសាសនាជាន់ខ្ពស់, និងតំណាងមកពីទីក្រុង និងទីប្រជុំជននានា។ រាជបុត្ររបស់ព្រះអង្គម្ចាស់ហេនរីព្រះនាមអេដវ៉ាដទី 1 បានឡើងគ្រងរាជ្យនៅក្នុងឆ្នាំ 1265 ប៉ុន្តែទ្រង់មិនមានបំណងក្នុងការកម្ចាត់សភាតំណាងរាស្ត្រទេ ដោយសារទ្រង់ត្រូវការការគាំទ្រនយោបាយពីពួកគេ។ នៅក្នុងឆ្នាំ 1295 សភាតំណាងរាស្ត្របានជួបប្រជុំគ្នា ដែលត្រូវបានគេយល់ឃើញជាទូទៅថាគឺជាសភាតំណាងរាស្ត្រពិតប្រាកដដំបូង។ វាត្រូវបានគេស្គាល់ថាសភាពតំណាងរាស្ត្រគំរូ។ តំណាងមកពីទីជនបទ, ស្រុក, និងទីក្រុងទាំងឡាយបានជួបប្រជុំគ្នា។ ព្រះអង្គម្ចាស់អេដវ៉ាដស្នើឱ្យកោះប្រជុំសភាតំណាងរាស្ត្រជាញឹកញាប់នៅអំឡុងរាជ្យរបស់ទ្រង់។ ប៉ុន្តែ នៅត្រឹមចុងរាជ្យរបស់ព្រះអង្គម្ចាស់អេដវ៉ាដនៅក្នុងឆ្នាំ 1307 អំណាចរបស់សភាតំណាងរាស្ត្រនៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយ។

អំណាចរបស់សភាតំណាងរាស្ត្រ៖ សភាតំណាងរាស្ត្របានបង្កើតក្រុមចំនួន 2 ដើម្បីដឹកនាំប្រទេស៖ សភារួម(សភាជាន់ទាប) និងសភាស្តេចត្រាញ់(សភាជាន់ខ្ពស់)។ សភាតំណាងរាស្ត្រជាយថាហេតុបានត្រួតត្រាលើការប្រមូលពន្ធ។ ជាលទ្ធផល ពួកគេអាចកម្រិតអំណាចរបស់ស្តេចអង់គ្លេស។ សភាតំណាងរាស្ត្របន្តិចម្តងៗក៏អាចស្នើ និងអនុម័តច្បាប់ផងដែរ។ ព្រះមហាក្សត្រមិនអាចប្រកាសច្បាប់ថ្មីដោយមិនមានការយល់ព្រមពីសភាតំណាងរាស្ត្របានឡើយ។ អំណាចរបស់សភាតំណាងរាស្ត្របានកើនឡើងយឺតៗ។ ការប្រែប្រួលដែលបានលើកឡើងខាងលើត្រូវចំណាយពេលរាប់សតវត្សរ៍ដើម្បីអភិវឌ្ឍ។ សង្គ្រាមនានាបានកើតមានឡើងដោយសារភាពមិនច្បាស់លាស់នៃអំណាចរបស់សភាតំណាងរាស្ត្រ។ ប៉ុន្តែ ការអនុវត្តច្បាប់ និងស្ថាប័ននៅអង់គ្លេសនាមជ្ឈិមសម័យនឹងក្លាយជាមគ្គុទេសមួយសម្រាប់អ្នកទស្សនវិទូនយោបាយនាពេលក្រោយមកទៀត។

សង្ខេប៖ សង្ខេបពីវិធីដែលសភាតំណាងរាស្ត្រកម្រិតអំណាចរបស់ស្តេច។

## 3. ការលេចឡើងនៃគំនិតប្រជាធិបតេយ្យសម័យទំនើប

សំណួរគន្លឹះ៖ តើគំនិតច្បាប់ និងនយោបាយសម័យទំនើបអ្វីខ្លះដែលមានឫសគល់នៅអង់គ្លេសនាមជ្ឈិមសម័យ?

តុលាការឯករាជ្យ, សិទ្ធិរបស់ប្រជាពលរដ្ឋ, និងទម្រង់ប្រជាធិបតេយ្យរបស់រដ្ឋាភិបាលដែលយើងស្គាល់នាពេលបច្ចុប្បន្នមិនបានលេចឡើងនៅអង់គ្លេសនាមជ្ឈិមសម័យឡើយ។ ក៏ដូចជាការអភិវឌ្ឍនៃសភាតំណាងរាស្ត្រ ការកើនឡើងនៃគំនិត និងស្ថាប័នទាំងនេះត្រូវចំណាយពេលរាប់សតវត្សរ៍។ ប៉ុន្តែ អំឡុងពេលនៃការអភិវឌ្ឍរបស់វា ការអនុវត្តច្បាប់ និងស្ថាប័ននៃអង់គ្លេសនាមជ្ឈិមសម័យជារឿយៗបានក្លាយជាមគ្គុទេសក៍មួយ។

តុលាការឯករាជ្យ៖ តុលាការឯករាជ្យបានអភិវឌ្ឍនៅពាសពេញពិភពលោក។ នៅក្នុងប្រទេសជាច្រើន តុលាការមានឯករាជ្យភាពពីសាខាផ្សេងៗទៀតរបស់រដ្ឋាភិបាល និងអាចធ្វើឱ្យប្រាកដថាមានតុល្យភាពអំណាចមួយ។ ឧទាហរណ៍ តុលាការអាចករារាំងរដ្ឋាភិបាលពីការអនុម័តច្បាប់ដែលរំលោភលើសិទ្ធិរបស់ប្រជាពលរដ្ឋ។ ច្បាប់សិទ្ធិមួយដែលប្រហែលជាចាប់ផ្តើមនៅអង់គ្លេសនាមជ្ឈិមសម័យគឺ ហាប៊ីស កូពូស។ សិទ្ធិនេះហាមឃាត់រដ្ឋាភិបាលក្នុងការឃុំខ្លួនមនុស្សដោយមិនបានជំនុំជម្រះទោស។ បច្ចុប្បន្ន ហាប៊ីស កូពូសតម្រូវឱ្យអាជ្ញាធរផ្តល់ភស្តុតាងផ្នែកច្បាប់សម្រាប់ការចាប់នណារម្នាក់ដាក់គុក។ សិទ្ធិដែលរៀបរាប់នៅក្នុងម៉ាកណា ខាតាបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ពួកអភិជនអង់គ្លេស។ ក្រោយមកអ្នកនយោបាយបានពង្រីកការប្រើប្រាស់វា។ ឧទាហរណ៍ ពួកអភិជនបាននិយាយថាស្តេចចនត្រូវតែប្រឹក្សាជាមួយពួកគេនៅពេលដែលទ្រង់ត្រូវការលុយ។ ប៉ុន្មានសតវត្សរ៍ក្រោយមក សភាតំណាងរាស្ត្រអង់គ្លេសអះអាងថា ស្តេចមិនអាចប្រមូលពន្ធដោយមិនមានការព្រមព្រៀងពីសភាតំណាងរាស្ត្រឡើយ។

រដ្ឋាភិបាលតំណាង៖ រដ្ឋាភិបាលមួយដែលបោះឆ្នោតជ្រើសរើសដោយប្រជាជនដើម្បីតំណាងឱ្យអត្ថប្រយោជន៍របស់ពួកគេគឺជារដ្ឋាភិបាលតំណាងមួយ។ រដ្ឋាភិបាលតំណាងដែលព្យាយាមនៅក្នុងការបញ្ចូលសមាជិកនៅក្នុងសង្គមទាំងអស់ទើបតែត្រូវបានអភិវឌ្ឍនាពេលថ្មីៗនេះប៉ុណ្ណោះ។ ប៉ុន្តែជាការពិតវាបានពង្រីកចេញមកពីប្រព័ន្ធសភាតំណាងរាស្ត្រ។ សភាតំណាងរាស្ត្រចាប់ផ្តើមដំណើរការ ដោយសារសមាជិកមួយចំនួននៅក្នុងសង្គមទាមទារក្នុងការបញ្ចេញមតិយោបល់អំពីវិធីដែលរដ្ឋាភិបាលគួរតែដំណើរការ។ នៅក្នុងរដ្ឋាភិបាលតំណាងសម័យទំនើប ក៏មានលក្ខណៈដូច្នេះដែរ។ មានតែបច្ចុប្បន្នទេដែលប្រជាពលរដ្ឋទាំងអស់ទាមទារនៅក្នុងបញ្ចេញយោបល់ មិនមែនត្រឹមតែអ្នកមានទ្រព្យ និងអ្នកមានអំណាចប៉ុណ្ណោះទេ។ វិធីសំខាន់ដែលប្រជាពលរដ្ឋបញ្ចេញយោបល់របស់ពួកគេទៅកាន់រដ្ឋាភិបាលរបស់ពួកគេគឺតាមរយៈការបោះឆ្នោត។ ការតស៊ូសម្រាប់ការបោះឆ្នោតជាសកល ឬសិទ្ធិនៅក្នុងការបោះឆ្នោត ត្រូវចំណាយពេលរាប់សិបឆ្នាំ។ បុរសអង់គ្លេសភាគច្រើនមិនអាចបោះឆ្នោតដើម្បីជ្រើសរើសសមាជិកសភាទេរហូតមកដល់ទសវត្សរ៍ឆ្នាំ 1800 ។ សម្រាប់ស្ត្រី សិទ្ធិនៅក្នុងការបោះឆ្នោតកាន់តែមានភាពលំបាកនៅក្នុងការទទួលបាន។ នៅក្នុងសហរដ្ឋអាមេរិក ស្ត្រីមិនអាចបោះឆ្នោតបានរហូតដល់ឆ្នាំ 1920 ហើយប្រជាជនអាមេរិកដើមកំណើតអាហ្វ្រិកជាច្រើនត្រូវបានរារាំងយ៉ាងមានប្រសិទ្ធិភាពពីការបោះឆ្នោតរហូតដល់ទសវត្សរ៍ឆ្នាំ 1960 ។

ស្វែងរកគំនិតសំខាន់៖ រៀបរាប់ និងពន្យល់ពីគំនិតច្បាប់ និងនយោបាយអង់គ្លេសនាមជ្ឈិមសម័យដែលបន្តរហូតមកដល់សម័យទំនើប។

# ជំពូក 17៖ បុនសម័យ និងការធ្វើកំណែទម្រង់

## មេរៀនទី 1៖ បុនសម័យនៅអ៊ីតាលី

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ខ្សែភាពយន្ត ឬតន្ត្រីដែលអ្នកចូលចិត្តគឺជាផ្នែកមួយនៃសិល្បៈ។ គំនូរ, ចម្លាក់, អក្សរសិល្ប៍, និងស្ថាបត្យកម្មក៏ជាសិល្បៈផងដែរ។ នៅក្នុងជំពូកនេះ អ្នកនឹងបានសិក្សាអំពីយុគសម័យនៃការរីកចម្រើនសិល្បៈដ៏សំខាន់បំផុតមួយនៅក្នុងប្រវត្តិសាស្ត្រអឺរ៉ុប។

### 1. ការប្រែប្រួលសង្គមអឺរ៉ុប

សំណួរគន្លឹះ៖ តើព្រឹត្តិការណ៍អ្វីខ្លះដែលបានជួយដល់ការបញ្ចប់សក្តិភូមិនិយម?

ស្ថិតនៅក្រោមសក្តិភូមិនិយម ព្រះរាជាណាចក្រតូចៗចំនួនរាប់រយបានលេចឡើងនៅអឺរ៉ុប។ ស្ថានភាពនេះចាប់ផ្តើមប្រែប្រួលជាមួយនឹងការអភិវឌ្ឍរបស់អង់គ្លេស និងបារាំងជាប្រទេសជាតិមួយនៅអំឡុងទសវត្សរ៍ឆ្នាំ 1100 និង 1200 ។ ជាលទ្ធផល ស្តេចត្រាញ់ និងម្ចាស់កម្មសិទ្ធិដីធ្លីនានាបានបាត់អំណាចរបស់ពួកគេយ៉ាងច្រើន។ របៀបរស់នៅបែបសក្តិភូមិក៏បានប្រែប្រួលយ៉ាងខ្លាំងនៅអំឡុងទសវត្សរ៍ឆ្នាំ 1300 ។ ជំងឺប៉េស្តដ៏មរណៈបានកាត់បន្ថយចំនួនរបស់ខ្ញុំកញ្ជះ។ ជាមួយនឹងខ្ញុំកញ្ជះតិចតួចធ្វើការនៅលើដីធ្លី ប្រព័ន្ធសក្តិភូមិបានចុះខ្សោយ។ សង្គ្រាមរាប់រយឆ្នាំជាសញ្ញាណនៃការបញ្ចប់នៃយុគសម័យជីវ៉ាលរី។ ការអភិវឌ្ឍនៃអាវុធដែលអាចទម្លុះអាវក្រោះធ្វើឱ្យក្រុមអ្នកប្រយុទ្ធជិះសេះចុះអន់ថយ។ ដូចដែលប្រព័ន្ធសក្តិភូមិចុះខ្សោយ ទីក្រុងនានានៅអឺរ៉ុបន្តរីកលូតលាស់។ ការរីកលូតលាស់នេះបណ្តាលមកពីការពង្រីកពាណិជ្ជកម្ម និងការអភិវឌ្ឍនៃវណ្ណៈពាណិជ្ជករដ៏រឹងមាំមួយ។ ការរះឡើងនៃចក្រភពម៉ុងហ្គោលធ្វើឱ្យផ្លូវពាណិជ្ជកម្មរវាងអឺរ៉ុប និងចិនកាន់តែមានសុវត្ថិភាព។ ការនេះបាននាំទៅដល់ការកើនឡើងនៃពាណិជ្ជកម្មតាមបណ្តោយផ្លូវពាណិជ្ជកម្មទាំងនេះនៅក្នុងទសវត្សរ៍ឆ្នាំ 1200 ។ អំឡុងឆ្នាំ 1300 ពាណិជ្ជករអ៊ីតាលីម៉ាកូប៉ូឡូបានបោះពុម្ពរឿងមួយនៃដំណើរដ៏វែងឆ្ងាយរបស់លោកកាត់តំបន់អាស៊ី។ រឿងរ៉ាវនៃការធ្វើដំណើររបស់លោក បានលើកទឹកចិត្តឱ្យពាណិជ្ជករអឺរ៉ុបបង្កើនការធ្វើពាណិជ្ជកម្មរបស់ពួកគេជាមួយអាស៊ី។ ការរីកលូតលាស់នៃពាណិជ្ជកម្មជាមួយអាស៊ីបានធ្វើឲ្យអឺរ៉ុបក្លាយជាមជ្ឈមណ្ឌលនៃទំនិញ និងគំនិតថ្មីៗ។

សង្ខេប៖ ពិពណ៌នាអំពីព្រឹត្តិការណ៍ដែលនាំមកនូវការបញ្ចប់នៃសក្តិភូមិនិយម។

### 2. វិធីក្នុងការគិតថ្មី

សំណួរគន្លឹះ៖ តើមនុស្សនិយមខុសគ្នាពីជំនឿនៅក្នុងយុគកណ្តាលយ៉ាងដូចម្តេច?

ព្រឹត្តិការណ៍នានាដែលបានកើតមានឡើងនៅចុងយុគកណ្តាល បានជះឥទ្ធិពលដ៏សំខាន់មួយលើពួកអឺរ៉ុប។ អ្នកទាំងឡាយណាដែលបានរស់រានពីព្រឹត្តិការណ៍ជំងឺប៉េស្ត និងសង្គ្រាមចង់បានជីវិតរស់នៅបែបសប្បាយរីករាយ។ នៅគ្រានោះ ការរីកលូតលាស់នៃពាណិជ្ជកម្មបាននាំមនុស្សកាន់តែច្រើនឱ្យស្គាល់ទំនិញ និងគំនិតថ្មីៗ។ ជាលទ្ធផល ឥរិយាបថថ្មីបានរីកសាយភាយនៅពាសពេញអឺរ៉ុប និងជួយដល់ការបង្កើតឡើងនូវវិធីក្នុងការគិតថ្មី។

ការរស់ឡើងវិញនូវការសិក្សាបែបបុរាណ៖ ការបញ្ចប់នៃយុគកណ្តាលបាននាំមកនូវថាមពលថ្មីសម្រាប់ការសិក្សានៅអឺរ៉ុប។ ដូចដែលអ្នកបានចងចាំ ការសិក្សាបានធ្លាក់ចុះនៃអំឡុងយុគកណ្តាល។ ការធ្លាក់ចុះនេះមួយភាគធំដោយសារសង្គ្រាម និងអស្ថេរភាពនយោបាយដែលបង្កឱ្យមានទំនាស់នៅក្នុងសង្គម។ ប៉ុន្តែត្រឹមទសវត្សរ៍ឆ្នាំ 1200 ប្រជាជនបានកើនឡើងនៃភាពស្រេកឃ្លានជាថ្មីម្តងទៀតក្នុងការទទួលបានចំណេះ និងការយល់ដឹង។ ដើម្បីទទួលបានចំណេះដឹងខ្ពង់ខ្ពស់ មនុស្សជាច្រើនបានត្រឡប់ទៅរកអតីតកាល។ ពួកគេបានធ្វើឱ្យរស់ឡើងវិញនៃទស្សនបុរាណរបស់ក្រិក និងរ៉ូម។ ពួកគេបានសិក្សាពីអត្ថបទជាច្រើនដែលទាក់ទងជាមួយអរិយធម៌ដំបូងៗទាំងនេះ ដោយសង្ឃឹមនៅក្នុងការសិក្សាពីទស្សនវិទូល្បីៗកាលពីអតីតកាល។

ការកើនឡើងនៃមនុស្សនិយម៖ ការសិក្សាអំពីអត្ថបទ និងគំនិតបុរាណនាំទៅដល់ចលនាមួយដែលគេស្គាល់ថា មនុស្សនិយម។ មនុស្សនិយមគឺជាវិធីគិតមួយដែលផ្តោតលើជីវិតមនុស្ស និងសក្តានុពលរបស់ពួកគេនៅក្នុងសម្រេចជោគជ័យ។ វាផ្តោតសំខាន់ទៅលើការសិក្សាលើមុខវិជ្ជាបុរាណនានាក្នុងនោះមានដូចជាប្រវត្តិសាស្ត្រ, វេយ្យករណ៍, អក្សរសិល្ប៍, និងទស្សនវិជ្ជា។ គោលដៅនៃមនុស្សនិយមគឺដើម្បីបង្កើតបទពិសោធន៍សម្រាប់បុគ្គលនីមួយៗ និងដើម្បីលើកទឹកចិត្តដល់មនុស្សទាំងឡាយឱ្យសម្រេចនូវអ្វីៗដែលពួកគេអាចធ្វើបាននៅក្នុងជីវិតរស់នៅ។ មេដឹកនាំដំបូងនៃចលនាមនុស្សនិយមគឺជាកវី និងអ្នកប្រាជ្ញជនជាតិអ៊ីតាលីមួយរូបឈ្មោះផេត្រាច។ លោកគឺជាទស្សនវិទូដំបូងម្នាក់ដែលលើកឡើងអំពីតម្លៃនៃការសិក្សាបុរាណ ឬការបង្រៀនពីក្រិក និងរ៉ូម។ លោកបានធ្វើការដើម្បីស្វែងរក និងស្តារឡើងវិញនូវកិច្ចការសំខាន់ៗជាច្រើនរបស់អ្នកនិពន្ធក្រិក និងរ៉ូម។ ជាការពិត អ្នកប្រាជ្ញនានាជឿថាពួកអ្នកនិពន្ធឡាតាំងសំខាន់មួយចំនួនដូចជាស៊ីសេរ៉ូ និងលីវីប្រហែលជាមិនត្រូវបានគេស្គាល់នាពេលបច្ចុប្បន្ននោះទេប្រសិនបើផេត្រាចមិនបានស្វែងរកស្នាដៃរបស់ពួកគេដែលកប់បាត់នៅក្នុងបណ្ណាល័យព្រះវិហារ។

ទស្សនមនុស្សនិយម៖ មនុស្សនិយមមានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃបុគ្គលនីមួយៗ។ វិធីនៅក្នុងការគិតនេះមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីគំនិតកាលពីយុគកណ្តាល ដែលបានលើកស្តេច និងស្ថាប័នមួយចំនួនដូចជាព្រះវិហារគ្រីស្តសាសនាឱ្យស្ថិតនៅលើអ្វីៗទាំងអស់។ មនុស្សនិយមក៏បានលើកកម្ពស់ឱ្យមានតុល្យភាពមួយរវាងបញ្ញាជាមួយជំនឿសាសនា។ ទស្សនវិទូមនុស្សនិយមបានបន្តសង្កត់ធ្ងន់អំពីសារៈសំខាន់នៃជីវិតរស់នៅបែបគ្រីស្តសាសនិក។ ប៉ុន្តែ ពួកគេបានជម្រុញឱ្យមនុស្សគិតអំពីខ្លួនពួកគេជាជាងសម្លឹងទៅរកព្រះវិហារគ្រីស្តសាសនាដើម្បីឆ្លើយចម្លើយគ្រប់យ៉ាង។ ពួកគេក៏បានបង្រៀនថា មនុស្សអាចរីករាយជាមួយនិងជីវិត និងនៅតែជាគ្រីស្តសាសនិកដ៏ល្អ។ ការអប់រំនេះមានលក្ខណៈខុសគ្នាពីជំនឿមុនៗដែលថាមនុស្សម្នាក់ត្រូវតែជៀសវាងជីវិតបែបកំសាន្តដើម្បីសុំសេចក្តីសង្គ្រោះពីព្រះជាម្ចាស់។

យុគសម័យថ្មីនៃការច្នៃប្រឌិត៖ មនុស្សនិយមបានជួយជម្រុញឱ្យមានកំណើតចំណង់ចំណូលចិត្តរបស់មនុស្សនៅក្នុងការពិសោធន៍, រុករក, និងបង្កើត។ បន្ទុះនៃគំនិតច្នៃប្រឌិត, ការរៀនសូត្រ, និងការរុករកចាប់ផ្តើមនៅឧបទ្វីបអ៊ីតាលី ហើយបន្តិចម្តងៗបានរីកសាយភាយនៅពាសពេញអឺរ៉ុប។ ចលនានេះជាសញ្ញាណនៃការបញ្ចប់យុគកណ្តាល និងជាការចាប់ផ្តើមឡើងនៃយុគសម័យថ្មីមួយ។

ប្រៀបធៀប៖ ពន្យល់ពីភាពខុសគ្នារវាងមនុស្សនិយមជាមួយជំនឿនៅយុគកណ្ដាល។

## 3. បុនសម័យចាប់ផ្ដើមនៅអ៊ីតាលី

សំណួរគន្លឹះ៖ តើកត្តាអ្វីដែលជួយឱ្យអ៊ីតាលីក្លាយជាកន្លែងកំណើតបុនសម័យ?

ដូចដែលអ្នកទើបតែបានអាន អឺរ៉ុបជួយបទពិសោធន៍នៃការកើនឡើងនៃទីក្រុង និងពាណិជ្ជកម្មអមជាមួយបានកើនឡើងនៃការផ្ដោតការយកចិត្តទុកដាក់លើការរៀនសូត្រ និងស្នាដៃរបស់មនុស្ស។ ការប្រែប្រួលទាំងនេះបាននាំទៅដល់ចលនាមួយដែលគេស្គាល់ថាបុនវុឌ្ឍ។ បច្ចេកពាក្យបុនវុឌ្ឍមានន័យថា "ការកើតឡើងវិញ"។ វាសំដៅទៅលើការកើតឡើងវិញនៃសិល្បៈ និងការសិក្សាបុរាណដែលបានកើតមានឡើងអំឡុងពេលនោះ។ ប៉ុន្តែអ្នកនិពន្ធនិងវិចិត្រករបុនសម័យក៏បានបង្កើតរចនាបថ និងវិធីនៃការគិតថ្មីផងដែរ។ បុនសម័យចាប់ផ្ដើមនៅរង្វង់ឆ្នាំ 1300 នៅក្នុងប្រទេសអ៊ីតាលី។ ត្រឹមឆ្នាំ 1600 វាបានរីកសាយភាយនៅពាសពេញអឺរ៉ុប។

ការកើនឡើងនៃទីក្រុងពាណិជ្ជកម្មឯករាជ្យ៖ បុនសម័យចាប់ផ្ដើមនៅអ៊ីតាលីក្នុងហេតុផលមួយចំនួន។ ក្នុងនោះហេតុផលមួយ អ៊ីតាលីធ្លាប់ជាមជ្ឈមណ្ឌលចក្រភពរ៉ូម។ ជាលទ្ធផល វិចិត្រករ និងអ្នកនិពន្ធនៅក្នុងប្រទេសអ៊ីតាលីមិនចាំបាច់ធ្វើដំណើរទៅឆ្ងាយដើម្បីបង្កើតឡើងវិញនូវរចនាបថកាលពីសម័យបុរាណឡើយ។ អត្ថប្រយោជន៍មួយទៀតសម្រាប់អ៊ីតាលីគឺទីក្រុងរបស់ពួកគេ។ ផ្លូវពាណិជ្ជកម្មជាច្រើនដែលបានអភិវឌ្ឍរវាងអឺរ៉ុប និងអាស៊ីនៅអំឡុងសម័យនោះបានធ្វើដំណើរកាត់តាមអ៊ីតាលីភាគខាងជើង។ ជាលទ្ធផលមជ្ឈមណ្ឌលទីប្រជុំជនធំៗមួយចំនួនបានអភិវឌ្ឍនៅក្នុងតំបន់។ ដោយក្នុងនោះរួមមានប្ល៉ូរែន, វេនីស, និងមីឡាន។ ទីក្រុងនានាបានក្លាយជាទីកន្លែងសំខាន់សម្រាប់ការផ្លាស់ប្ដូរទំនិញ និងគំនិតនានា។ ដូច្នេះទីក្រុងទាំងនោះគឺជាមជ្ឈមណ្ឌលគំនិតសម្រាប់ការបង្កើតរចនាបថថ្មី និងជាកន្លែងរីកសាយភាយគំនិតបុនវុឌ្ឍ។ វណ្ណៈពាណិជ្ជករមានទ្រព្យសម្បត្តិស្ដុកស្ដម្ភមួយត្រូវបានអភិវឌ្ឍឡើងនៅក្នុងទីក្រុងជាច្រើនរបស់អ៊ីតាលី។ សមាជិកជាច្រើននៃវណ្ណៈថ្មីនេះបានក្លាយជាមេដឹកនាំដ៏មានឥទ្ធិពលដែលបានគាំទ្រសិល្បៈយ៉ាងសកម្ម។ ការគាំទ្រនេះគឺជាមូលហេតុមួយដែលទីក្រុងនានារបស់អ៊ីតាលីបង្កើតបាននូវវិចិត្រករ និងអ្នកនិពន្ធជាច្រើន។

ប្ល៉ូរែនភ្លឺចែងចាំង៖ ទីក្រុងដែលមានសារៈសំខាន់ និងមានឥទ្ធិពលបំផុតនៅដើមសម័យបុនវុឌ្ឍគឺប្ល៉ូរែន។ ប្ល៉ូរែនបានទីតាំងស្ថិតនៅអ៊ីតាលីភាគខាងជើងតាមបណ្ដោយទន្លេអាណូ។ វាទទួលបានសារៈសំខាន់ក្នុងនាមជាមជ្ឈមណ្ឌលធនាគារ និងផលិតផលសំលៀកបំពាក់។ ការកើនឡើងនៃវិស័យធនាគារបាននាំប្ល៉ូរែនឆ្ពោះទៅរកការកើនឡើងនៃទ្រព្យសម្បត្តិ។ នៅត្រឹមដើមទសវត្សរ៍ឆ្នាំ 1300 ប្ល៉ូរែនបានប្រជាជនសរុបប្រមាណ 120,000 នាក់ ដែលបានធ្វើឱ្យទីក្រុងនេះក្លាយជាទីក្រុងដែលធំជាងគេនៅអឺរ៉ុប។ វិចិត្រករ និងអ្នកនិពន្ធជាច្រើនអ្នកដែលបានចូលរួមចំណែកដ៏គួរឱ្យចាប់អារម្មណ៍ក្នុងការបុនសម័យ បានរស់នៅ និងធ្វើការនៅប្ល៉ូរែន។ គ្រួសារអ្នកធនាគារដ៏មានឥទ្ធិពលមួយ មេឌីស៊ី បានដឹកនាំប្ល៉ូរែនអំឡុងបុនសម័យ។ គ្រួសារមេឌីស៊ី និងគ្រួសារមានទ្រព្យសម្បត្តិស្ដុកស្ដម្ភផ្សេងៗទៀតបានក្លាយជាអ្នកឧបត្ថម្ភដល់សិល្បៈ។ ក្នុងនាមជាអ្នកឧបត្ថម្ភ ពួកគេបានលើកទឹកចិត្តវិចិត្រករឱ្យបង្កើត

ស្នាដៃ និងគាំទ្រផ្នែកហិរញ្ញវត្ថុដល់ពួកគេ។ ការគាំទ្រមួយចំនួនបានជម្រុញឱ្យវិចិត្រករលះបង់ពេលវេលារបស់ពួកគេដើម្បីបង្កើតស្នាដៃរបស់ពួកគេ។

ស្វែងរកគំនិតសំខាន់៖ ពិពណ៌នាអំពីមូលហេតុដែលនាំឱ្យអ៊ីតាលីក្លាយជាទីកន្លែងកំណើតបុនសម័យ។

## 4. ការរីចម្រើនផ្នែកសិល្បៈ

សំណួរគន្លឹះ៖ តើសិល្បៈបុនសម័យខុសគ្នាយ៉ាងដូចម្ដេចពីសិល្បៈសម័យមុន?

វិចិត្រករបុនសម័យមានលក្ខណៈខុសគ្នាពីវិចិត្រករសម័យមុននៅក្នុងវិធីមួយចំនួន។ អំឡុងយុគកណ្ដាល សិល្បៈ និងអក្សរសិល្ប៍ជារឿយៗជាប់ទាក់ទងជាមួយបញ្ហាសាសនា។ វិចិត្រករបុនសម័យផ្ដោតសំខាន់លើការបង្ហាញពីមនុស្សតាមរបៀបជាក់ស្ដែង។ ជាងនេះទៅទៀត វិចិត្រករ និងជាងគំនូរបុនសម័យជួបបទពិសោធន៍ជាមួយនឹងរចនាបថ និងបច្ចេកទេសថ្មីៗដែលជាលទ្ធផលធ្វើឱ្យស្នាដៃមានលក្ខណៈប្លែក។ ស្នាដៃទាំងនេះជាច្រើននៅតែល្បីល្បាញរហូតមកដល់ពេលបច្ចុប្បន្នដោយសារតែភាពស្រស់ស្អាត និងពិប្រាកដរបស់វា។

បច្ចេកទេសថ្មី៖ វិចិត្រករបុនសម័យបន្តបង្ហាញពីប្រធានបទសាសនាជាច្រើន។ ប៉ុន្តែប្រធានបទទាំងនេះបានបង្ហាញនៅក្នុងទម្រង់ពិតប្រាកដមួយ។ នៅក្នុងសិល្បៈមជ្ឈិមសម័យភាគច្រើន គំនូរមើលទៅជាលក្ខណៈរាបស្មើនិងគ្មានជម្រៅ។ ដើម្បីបង្កើតអារម្មណ៍ពិប្រាកដ វិចិត្រករបុនសម័យបានប្រើប្រាស់បច្ចេកទេសមួយដែលគេស្គាល់ថានេត្រាទស្សន៍។ បច្ចេកទេសនេះបង្កើតបានជារូបរាងនៃជម្រៅ និងចម្ងាយនៅក្នុងស្នាដៃសិល្បៈនៅលើផ្ទៃរាបស្មើ។

វិចិត្រករនាំមុខ៖ វិចិត្រករចំនួន 3 រូបបានគ្របដណ្ដប់នៅក្នុងសម័យបុនវុឌ្ឍនៅអ៊ីតាលី។ ក្នុងនោះរួមមាន ឡេអូណាដូ ដា វីនស៊ី, មីឆេឡានហ្គេឡូ, និងរ៉ាផែល។ ឡេអូណាដូ ដា វីនស៊ីកើតនៅក្នុងឆ្នាំ 1452 នៅភូមិវីនស៊ីដែលស្ថិតនៅជិតទីក្រុងហ្វ្លរ៉ង់។ លោកទទួលបានការបណ្ដុះបណ្ដាលជាជាងគំនូរមួយរូប។ ប៉ុន្តែ លោកមានភាពប៉ុនប្រសព្វនៅក្នុងមុខវិជ្ជាមួយចំនួន ដោយក្នុងនោះរួមមានតារាសាស្ត្រ, ធរណីសាស្ត្រ, និងកាយវិទ្យា។ ក្នុងនាមជាជាងគំនូរមួយរូប លោកបានបង្កើតស្នាដៃជាច្រើន ក្នុងនោះរួមមាន ភាពអស្ចារ្យចុងក្រោយ និងម៉ូណា លីហ្សា។ មីឆេឡានហ្គេឡូ ឌី ប៊ូណារ៉ូទី ស៊ីម៉ូនី កើតនៅក្នុងភូមិអ៊ីតាលីមួយឈ្មោះកាប្រេសនៅក្នុងឆ្នាំ 1475។ លោកត្រូវបានបណ្ដុះបណ្ដាលជាចម្លងជាជាងចម្លាក់។ មីឆេឡានហ្គេឡូបានបង្កើតស្នាដៃដ៏អស្ចារ្យជាច្រើន ដោយក្នុងនោះរួមមានទាំងចម្លាក់ម៉ូសេផងដែរ។ ស្នាដៃសំខាន់បំផុតមួយរបស់លោកមិនមែនជាចម្លាក់ទេ ប៉ុន្តែជាផ្ទាំងគំនូរដ៏ធំមួយ។ វាត្រូវបានគូរនៅលើពិតាននៃព្រះវិហារស៊ីស្ទីននៅរ៉ូម។ រ៉ាផែលកើតនៅអ៊ូប៊ីណូប្រទេសអ៊ីតាលីនៅក្នុងឆ្នាំ 1483 ។ ក្នុងនាមជាយុវជនមួយរូប លោកបានផ្លាស់ទីលំនៅមកកាន់ហ្វ្លរ៉ង់ និងបានសិក្សាពីស្នាដៃសិល្បៈនានាដោយរួមមានទាំងស្នាដៃរបស់ដា វីនស៊ីផងដែរ។ ស្នាដៃដែលល្បីល្បាញបំផុតរបស់រ៉ាផែលគឺសាលាអាតែន។

វិចិត្រករដែលមានឥទ្ធិពលផ្សេងៗទៀត៖ អ្នកគូរគំនូរបុនសម័យផ្សេងៗទៀតបានជះឥទ្ធិពលដ៏សំខាន់។ ជាងគំនូរមួយរូបមកពីវេនីសឈ្មោះទូទានបានប្រើប្រាស់ពណ៌ឆើតៗ និងជក់ធំៗដើម្បីធ្វើឱ្យស្នាដៃរបស់លោកខុស

ពីស្នាដៃរបស់វិចិត្រករផ្សេងៗទៀត។ លោកបានបង្កើតស្នាដៃជាច្រើនក្នុងនោះរួមមានការបំពាក់មង្គុតជាមួយបន្លាជាដើម។ សេនដ្រូ បូតទីសេលលី គឺជាជាងគំនូរមួយរូបមកពីប្ល៉ូរែន។ ស្នាដៃរបស់លោកត្រូវបានគេស្គាល់តាមរយៈពណ៌ស្រាលៗ, បន្ទាត់រលក, និងកំណាព្យបង្ហាញពីអារម្មណ៍។ គំនូររបស់លោកជាទូទៅមិនមែនជាភាពពិតប្រាដកដូចជាវិចិត្រករបុនសម័យផ្សេងៗទៀតឡើយ។ កំណើតនៃព្រះនាងកាមទេព និងឡា ព្រីម៉ាវ៉េរ៉ា គឺជាស្នាដៃល្អបំផុតក្នុងចំណោមស្នាដៃនានារបស់លោក។

ស្ថាបត្យកម្ម និងវិស្វកម្ម៖ បុនសម័យក៏ជួបប្រទះជាមួយនិងការរកឃើញបច្ចេកទេសសំណង់ដ៏សំខាន់។ ស្ថាបត្យករដែលមានឥទ្ធិពលបំផុតមួយនៅក្នុងសម័យនេះគឺលោកហ្វីលីពប៉ូ ប្រ៊ូនេលឡេឈី។ លោកប្រហែលជាត្រូវបានគេស្គាល់ច្បាស់តាមរយៈការរចនា និងសាងសង់ដំបូលសម្រាប់ព្រះវិហារគ្រឹស្តសាសនា។ ដំបូលវិហារគ្រឹស្តសាសនាមួយដែលល្បីល្បាញបំផុតរបស់លោកគឺឌូម៉ូនៅប្ល៉ូរែន។ លោកក៏បានអភិវឌ្ឍបច្ចេកទេសសម្រាប់លើកសម្ភារៈសំណង់នានាទៅកាន់ការកំពង់សាងសង់ ឬអាគារផ្សេងៗ។

អ្នកនិពន្ធបុនសម័យ៖ ក៏ដូចជាជាងគំនូរ និងជាងចម្លាក់នៅពេលនោះដែរ អ្នកនិពន្ធចាប់ផ្ដើមផ្ដោតទៅលើការបង្ហាញពីជីវិតរស់នៅពិតប្រាកដរបស់បុគ្គលនីមួយៗ។ អ្នកនិពន្ធជនជាតិអ៊ីតាលីមួយរូបឈ្មោះដានតេ អាលីជីអេរី បានសរសេរស្នាដៃកំណាព្យ និងរឿងពិតជាច្រើន។ ស្នាដៃល្អបំផុតរបស់លោកគឺកំណាព្យដ៏វែងមួយដែលមានចំណងជើងថាកំប្លែងទេវតា។ វាបានប្រាប់ពីរឿងនៃការធ្វើដំណើរបែបស្រមើលស្រមៃមួយកាត់តាមឋាននរក, ឋានកណ្ដាលមួយដែលគេហៅថាកន្លែងព្រលឹងទទួលកំហុស, និងឋានសួគ៌។ មុនឆ្នាំ 1300 អ្នកប្រាជ្ញអឺរ៉ុបភាគច្រើនសរសេរជាភាសាឡាតាំង។ ប៉ុន្តែ ដានតេជារឿយៗសរសេរជាភាសាអ៊ីតាលី។ ទទួលរងឥទ្ធិពលដោយដានតេ អ្នកនិពន្ធបុនសម័យផ្សេងៗទៀតក៏បានចាប់ផ្ដើមសរសេរជាភាសាដើមរបស់ពួកគេ។ អ្នកនិពន្ធដែលមានឥទ្ធិពលមួយរូបផ្សេងទៀតគឺលោកនិចកូឡូ ម៉ាឆីវេលលី។ នៅក្នុងឆ្នាំ 1513 លោកបានបោះពុម្ពផ្សាយស្នាដៃដ៏ល្បីល្បាញបំផុតរបស់លោកដែលមានចំណងជើងថាព្រះអង្គម្ចាស់។ នៅក្នុងស្នាដៃនេះ ម៉ាឆីវេលលីបានផ្ដល់យោបល់ដល់ព្រះអង្គម្ចាស់មួយអង្គអំពីវិធីនៅក្នុងការទទួលបាន និងរក្សាអំណាចនយោបាយ។ លោកបានស្នើថាការកុហក និងហឹង្សាអាចត្រូវការដើម្បីសម្រេចស្ថេរភាពនៅក្នុងរដ្ឋាភិបាល។

វិភាគ៖ ពន្យល់ពីរបៀបដែលសិល្បៈបុនសម័យមានលក្ខណៈខុសគ្នាពីសិល្បៈសម័យមុន។

# មេរៀនទី 2៖ បុនសម័យរីកសាយភាយ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើអ្នកបានដឹងអ្វីខ្លះពី វីលលៀម សាគេស្ពៀរ? បើទោះបីជាលោករស់នៅកាលពី 400 ឆ្នាំមុនក៏ដោយ រោងមហាស្របនៅតែសម្តែងរឿងរបស់លោកជាទៀងទាត់។ រឿងមួយចំនួនដែលជា រ៉ូមេអូ និងជូលេតត្រូវបានគេប្រែក្លាយទៅជាខ្សែភាពយន្តដ៏ពេញនិយមដែលប្រហែលជាអ្នកធ្លាប់បានមើល។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាកាន់តែលម្អិតអំពីវីលលៀម សាគេស្ពៀរ និងវិចិត្រករគួរឱ្យកត់សំគាល់ផ្សេងទៀតដែលមកពីបុនសម័យភាគខាងជើង។

## 1. បុនវុឌ្ឍធ្វើដំណើរទៅភាគខាងជើង

សំណួរគន្លឹះ៖ តើកត្តាអ្វីដែលជួយឱ្យបុនវុឌ្ឍរីកសាយភាយទៅកាន់អឺរ៉ុបភាគខាងជើង។

អំឡុងចុងទសវត្សរ៍ឆ្នាំ 1400 គំនិតបុនវុឌ្ឍចាប់ផ្តើមរីកសាយភាយពីអ៊ីតាលីទៅភាគខាងជើង ទៅកាន់ប្រទេសបារាំង, អង់គ្លេស, និងផ្នែកផ្សេងៗទៀតនៅអឺរ៉ុប។ គំនិតរីកសាយភាយតាមរយៈទំនាក់ទំនងវប្បធម៌, ការកើនឡើងនៃទីប្រជុំជន, និងការគាំទ្រដោយមេដឹកនាំមានអំណាច។

ការរីកឡើងនៃទីក្រុង៖ នៅពេលដែលសង្គ្រាមរាប់រយឆ្នាំដ៏វិនាសកម្មរវាងអង់គ្លេស និងបារាំងបញ្ចប់នៅក្នុងឆ្នាំ 1453 ជីវិតមនុស្សជាច្រើនបានប្រែប្រួល។ ពាណិជ្ជកម្មបានពង្រីក និងទីក្រុងបានរីកឡើងយ៉ាងឆាប់រហ័ស។ គំនិតបុនវុឌ្ឍបានធ្វើដំណើរទៅកាន់ទីក្រុងទាំងនេះ និងជះឥទ្ធិពលដល់មនុស្សជាច្រើន។ ការរីកឡើងនៃទីក្រុងក៏បានជួយដល់ការបង្កើតឡើងនៃវណ្ណៈពាណិជ្ជករមានទ្រព្យសម្បត្តិស្តុកស្តម្ភមួយផងដែរ។ ក៏ដូចជាពាណិជ្ជករនៅក្នុងប្រទេសអ៊ីតាលីដែរ ក្រុមអ្នកជំនួញមានទ្រព្យសម្បត្តិស្តុកស្តម្ភទាំងនេះមានភាពស្រេកឃ្លានជាមួយនឹងការគាំទ្រវិចិត្រករ និងអ្នកនិពន្ធ។

តួនាទីរបស់ព្រះមហាក្សត្រ៖ រដ្ឋាភិបាលនៅអឺរ៉ុបខាងជើងក៏បានឈ្លានមួយជំហានឆ្ពោះទៅរកការគាំទ្រសិល្បៈផងដែរ។ អ៊ីតាលីមិនមែនជាប្រទេសបង្រួបបង្រួមមួយឡើយ ប៉ុន្តែជាបណ្តុំនៃទីក្រុងដែលមានអំណាច និងឯករាជ្យនានា។ ប៉ុន្តែ ប្រទេសអង់គ្លេស និងប្រទេសបារាំងគឺជាប្រទេសបង្រួបបង្រួមមួយដែលដឹកនាំដោយព្រះមហាក្សត្រមានអំណាច។ មេដឹកនាំទាំងនេះភាគច្រើនយល់ឃើញថាស្នាសាដៃសិល្បៈគឺជាប្រភពនៃមោទនភាពសម្រាប់ប្រទេសរបស់ពួកទ្រង់។ ជាលទ្ធផល ពួកទ្រង់បានផ្តល់នូវការគាំទ្រផ្នែកខាងហិរញ្ញវត្ថុដល់វិចិត្រករ និងអ្នកនិពន្ធជាច្រើន។

ទំនាក់ទំនងវប្បធម៌៖ វិចិត្រករអ៊ីតាលីអ្នកដែលនាំមុខគេនៅបុនសម័យ បន្តិចម្តងៗចាប់ផ្តើមមានទំនាក់ទំនងជាមួយជាងគំនូរ និងអ្នកនិពន្ធនានានៅពាសពេញតំបន់អឺរ៉ុប។ នៅត្រឹមចុងទសវត្សរ៍ឆ្នាំ 1400 សង្គ្រាមមួយបានផ្ទុះឡើងរវាងព្រះរាជាណាចក្រនានានៅអ៊ីតាលី។ ដូចដែលសង្គ្រាមនៅតែបន្ត វិចិត្រករអ៊ីតាលីជាច្រើនបានរត់គេចទៅរកទីកន្លែងដែលមានសុវត្ថិភាពនៅអឺរ៉ុបខាងជើង។ នៅទីនោះ ពួកគេបានចែករំលែករចនាបថ និងបច្ចេកទេសថ្មីៗរបស់ពួកគេជាមួយវិចិត្រករនៅក្នុងតំបន់។ ជាងនេះទៅទៀត វិចិត្រករមកពីអឺរ៉ុបភាគខាងជើងបានធ្វើដំណើរ

ទៅកាន់ប្រទេសអ៊ីតាលី និងបានសិក្សាអ្វីៗគ្រប់យ៉ាងដែលពួកគេអាចរៀនបានអំពីវិធីសាស្ត្រថ្មីៗ។ បន្ទាប់មកពួកគេបាននាំយកគំនិតបុនវុឌ្ឍត្រឡប់ទៅកាន់ទឹកដីកំណើតរបស់ពួកគេវិញ។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីកត្តាដែលជួយដល់ការរីកសាយភាយនៃបុនវុឌ្ឍទៅកាន់អឺរ៉ុបភាគខាងជើង។

## 2. វិចិត្រករ និងអ្នកនិពន្ធ

សំណួរគន្លឹះ៖ តើបុនសម័យនៃអឺរ៉ុបភាគខាងជើង និងនៅអ៊ីតាលីខុសគ្នាយ៉ាងដូចម្តេច?

បុនសម័យនៃអឺរ៉ុបភាគខាងជើងបានបង្កើតឱ្យចរន្តទីពីរនៃជាងគំនូរ, អ្នកនិពន្ធ, និងអ្នកប្រាជ្ញដ៏ប៉ុនប្រសព្វ។ ពួកគេបានអភិវឌ្ឍដ៏សំខាន់នៅក្នុងវិស័យសិល្បៈ និងការសិក្សា។ បុនសម័យនៃអឺរ៉ុបភាគខាងជើង និងបុនសម័យនៅអ៊ីតាលីខុសគ្នានៅក្នុងវិធីមួយចំនួន។ ភាពខុសគ្នាមួយគឺ អ្នកប្រាជ្ញអឺរ៉ុបភាគខាងជើងមិនបានសិក្សាពីបុរាណច្រើនដូចអ្នកប្រាជ្ញអ៊ីតាលីបានសិក្សាឡើយ។ ជាងនេះទៅទៀត វិចិត្រករភាគខាងជើងបង្កើតស្នាដៃដែលមានលក្ខណៈលម្អិតអំពីជីវិតរស់នៅប្រចាំថ្ងៃ។

វិចិត្រករអាឡឺម៉ង់ និងផ្លេមីស៖ តួអង្គមួយរូបដែលល្បីល្បាញសម្រាប់ស្នាដៃពិតប្រាកដនិយម និងលម្អិតរបស់លោកគឺវិចិត្រករអាឡឺម៉ង់ឈ្មោះអាលប្រេច ឌូរ័រ។ លោកត្រូវបានចាត់ទុកដោយមនុស្សជាច្រើនថាជាវិចិត្រករអាឡឺម៉ង់នាបុនសម័យដ៏អស្ចារ្យបំផុត។ គំនូរដ៏ល្អបំផុតមួយរបស់លោកគឺមនុស្សពិសិដ្ឋទាំង 4 ដែលបានបង្ហាញពីតួអង្គទាំង 4 នៅក្នុងគម្ពីរគ្រីស្តសាសនា។ ក្រៅពីគូរគំនូរ ឌូរ័រក៏បានបង្កើតចម្លាក់ឈើជាច្រើនផងដែរ។ ចម្លាក់ឈើមួយគឺជារូបចម្លាក់មួយដែលបង្កើតចេញមកពីឈើ។ ចាន វ៉ាន អាយ និងពីទ័រ ព្រូហ្គេល អេលឌ័រ គឺជាជាងគំនូរល្បីល្បាញ 2 រូបរបស់ផ្លេរីស។ បច្ចេកពាក្យផ្លេរីសគឺជាការពិពណ៌នាប្រជាជនដែលមកពីតំបន់មួយស្ថិតនៅអឺរ៉ុបភាគពាយព្យដែលគេហៅថាផ្លេនឌ័រ(បច្ចុប្បន្នប្រទេសប៊ែលហ្សិច)។ វ៉ាន អាយ ជារឿយៗធ្វើការឱ្យពួកអភិជនមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ គំនូររបស់លោកមានភាពលម្អិតខ្លាំង និងពណ៌ភ្លឺ។ គំនូរដែលល្បីល្បាញមួយចំនួនរបស់លោករួមមាន ការផ្សាយដំណឹង និងជីអូវ៉ាន់នី អាណូលហ្វីនី និងកូនក្រមុំរបស់លោក។ គំនូររបស់លោកពីទ័រ ព្រូហ្គេល អេលឌ័រជារឿយៗបង្ហាញពីរូបភាពប្រចាំថ្ងៃ ដូចជាការរាំរបស់ប្រជាកសិករ ឬកុមារកំពុងលេង។ ក៏ដូចជាវិចិត្រករផ្សេងៗទៀតដែរ អំឡុងពេលនៃបុនសម័យភាគខាងជើង ព្រូហ្គេលគូរគំនូរបែបលម្អិត។

សាគេស្ពៀរ៖ អ្នកនិពន្ធដ៏មានទេពកោសល្យនានាក៏បានជួយដល់បុនសម័យភាគខាងជើងផងដែរ។ ក្នុងចំណោមអ្នកនិពន្ធទាំងនេះមានអ្នកនិពន្ធមួយរូបដែលល្បីល្បាញបំផុតគឺលោកវីលលៀម សាគេស្ពៀរ។ លោកកើតនៅក្នុងឆ្នាំ 1564 នៅក្នុងទីក្រុងស្រ្តេតហ្វ័ដប្រទេសអង់គ្លេស។ នៅអំឡុងចុងទសវត្សរ៍ឆ្នាំ 1580 លោកបានផ្លាស់ទីមកកាន់ទីក្រុងឡុងដ៍ ជាទីកន្លែងដែលលោកប្រកបមុខរបរមួយនៅក្នុងរោងមហាស្រប។ ភ្លាមៗនោះសាគេស្ពៀរបានក្លាយជាអ្នកនិពន្ធរឿងល្ខោនដ៏មានប្រជាប្រិយភាពមួយរូបនៅក្នុងប្រទេសអង់គ្លេស។ អ្នកនិពន្ធល្ខោនគួរឱ្យគត់សំគាល់ផ្សេងៗទៀតនៅអំឡុងពេលនោះរួមមាន គ្រីស្តូហ្វ័រ ម៉ាឡូវ និងបេន ចនសុន។ សាគេស្ពៀរបានសរសេរល្ខោនបែបកំប្លែង, បែបសោកនាដកម្ម, និងបែបប្រវត្តិសាស្ត្រ។ ស្នាដៃដែលល្បីល្បាញបំផុតរបស់លោករួមមាន សុបិនក្នុងយប់មួយនាពាក់កណ្តាលរដូវក្តៅ, រ៉ូមេអូ និងជូលេត, និងភូមិតូច។ ស្នាដៃរបស់សាគេស្ពៀរបានបង្ហាញ

ពីការយល់ដឹងដ៏ខ្លាំងក្លាមួយនៃធម្មជាតិរបស់មនុស្ស។ ដោយសារតែហេតុនេះ ល្ខោនរបស់លោកនៅតែទាក់ទងជាមួយមនុស្សនាពេលបច្ចុប្បន្ន និងបន្តសម្តែងនៅពាសពេញពិភពលោក។

សាគេស្ពៀរសរសេរនៅអំឡុងពេលមួយនៅក្នុងប្រទេសអង់គ្លេសដែលគេស្គាល់ថា យុគសម័យអេលីហ្សាប៊ីថិន។ សម័យនេះត្រូវបានយកឈ្មោះតាមម្ចាស់ក្សត្រីអេលីហ្សាប៊ែតទី 1 ដែលបានដឹកនាំប្រទេសអង់គ្លេសចាប់ពីឆ្នាំ 1558 ដល់ 1603 ។ ស្តេចអេលីហ្សាប៊ែតបានលើកកម្ពស់គំនិតបុនវុឌ្ឍនៅក្នុងប្រទេសអង់គ្លេស។ ទ្រង់គឺជាអ្នកដែលទទួលបានការអប់រំខ្ពង់ខ្ពស់ និងនិយាយភាសាជាច្រើន។ ទ្រង់ក៏បានសរសេរកំណាព្យ និងតន្ត្រីផងដែរ។ ក្នុងនាមជាម្ចាស់ក្សត្រី ទ្រង់បានធ្វើការងារជាច្រើនដើម្បីគាំទ្រវិចិត្រករ និងអ្នកនិពន្ធអង់គ្លេស។

សឺវ៉ាន់តេស៖ អ្នកនិពន្ធជនជាតិអេស្ប៉ាញឈ្មោះមីហ្គូអេល ដេ សឺវ៉ាន់តេស ត្រូវបានគេស្គាល់យ៉ាងច្បាស់តាមរយៈស្នាដៃប្រលោមលោកឈ្មោះ ដុន គីហ្សូតេ។ ប្រលោមលោកនេះបានប្រាប់អំពីរឿងរ៉ាវរបស់ម្ចាស់កម្មសិទ្ធិដីធ្លីមួយរូបដែលបានស្រមើលស្រមៃថាលោកគឺជាអ្នកប្រយុទ្ធជិះសេះមួយរូប និងបានហៅខ្លួនលោកថា ដុន គីហ្សូតេ។ លោក និងអ្នកជួយលោកឈ្មោះសានឆូ ប៉ានហ្សា បានធ្វើដំណើរឆ្លងកាត់ប្រទេសអេស្ប៉ាញ និងមានរឿងគួរឱ្យអស់សំណើចជាច្រើននៅក្នុងដំណើរផ្សងព្រេងនេះ។

ប្រៀបធៀប៖ ពិពណ៌នាភាពខុសគ្នាមួយចំនួនរវាងបុនសម័យនៅភាគខាងជើង និងបុនសម័យនៅអ៊ីតាលី។

### 3. ភាពជឿនលឿននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

សំណួរគន្លឹះ៖ តើមានភាពជឿនលឿនអ្វីខ្លះទៀតនៅបុនសម័យក្រៅពីសិល្បៈ?

ទាំងបុនសម័យនៃអ៊ីតាលី និងបុនសម័យនៅភាគខាងជើងបង្កើតឱ្យមានភាពជឿនលឿនទៅឆ្ងាយលើសពីសិល្បៈ។ អ្នកប្រាជ្ញ និងទស្សនវិទូនៅក្នុងសម័យនេះបានបង្កើតរបកគំហើញនៅក្នុងវិស័យជាច្រើន ក្នុងនោះរួមមានគណិតវិទ្យា, វិទ្យាសាស្ត្រ, និងបច្ចេកវិទ្យា។

គណិត និងវិទ្យាសាស្ត្រ៖ អ្នកប្រាជ្ញបុនសម័យបានបន្សល់ទុកនូវស្នាដៃដ៏គួរឱ្យគត់សំគាល់របស់ពួកគេលើវិស័យគុវិជ្ជាមួយចំនួន។ ឧទាហរណ៍ គណិតវិទូបានអភិវឌ្ឍការសិក្សាអំពីពិជគណិតតាមរយៈការបង្កើតឱ្យមានការប្រើប្រាស់អក្សរនៅក្នុងសមីការ។ នៅខណៈពេលនោះ អ្នកវិទ្យាសាស្ត្របុនសម័យបានអភិវឌ្ឍទ្រឹស្តីថ្មីៗអំពីចក្រវាល។ អ្នកនឹងបានអានកាន់តែច្រើនអំពីភាពជឿនលឿននៃតារាសាស្ត្រនៅក្នុងជំពូក 18 ។ អ្នកប្រាជ្ញក៏បានអភិវឌ្ឍការផលិតផែនទីផងដែរ។ ដូចដែលពួកគេបានសិក្សាកាន់តែច្រើនពីពិភពលោកនៅជុំវិញពួកគេ ពួកអឺរ៉ុបបានបង្កើតផែនទីដែលមានលក្ខណៈកាន់តែត្រឹមត្រូវ។ អ្នកវិទ្យាសាស្ត្រក៏បានអភិវឌ្ឍការយល់ដឹងដ៏ប្រសើរមួយនៃខនិច និងរ៉ែដែលបង្កើតផ្ទៃផែនដី។ អ្នកប្រាជ្ញបុនសម័យបានអនុវត្តខ្លួនរបស់ពួកគេជាមួយនិងកាយវិទ្យា ការសិក្សាពីរាងកាយមនុស្ស។ អំឡុងយុគកណ្តាល ព្រះវិហាររ៉ូម៉ាំងកាតូលិកបានហាមឃាត់ការវះពិនិត្យរាងកាយរបស់មនុស្ស។ ប៉ុន្តែការរះឡើងនៃមនុស្សនិយមបាននាំឱ្យអ្នកវិទ្យាសាស្ត្រសិក្សាពីដំណើរការខាងក្នុងរបស់រាងកាយមនុស្ស។

ម៉ាស៊ីនបោះពុម្ព៖ ស្នាដៃបច្ចេកវិទ្យាសំខាន់បំផុតនៅបុនសម័យគឺការបង្កើតម៉ាស៊ីនបោះពុម្ព។ ការបង្កើតនេះបានស្ថាបនាពីលើបច្ចេកវិទ្យានៅដើមដំបូងមួយចំនួន ដោយក្នុងនោះមានឧបករណ៍បោះពុម្ពធ្វើពីដុំឈើរបស់ចិនផងដែរ។ នៅក្នុងឧបករណ៍បោះពុម្ពធ្វើពីដុំឈើ អ្នកបោះពុម្ពម្នាក់បានឆ្លាក់ឈើមួយដុំ ឬអក្សរមួយនៅលើដុំឈើ។ បន្ទាប់មកអ្នកបោះពុម្ពបានលាបទឹកថ្នាំនៅលើដុំឈើ និងប្រើវាដើម្បីបោះពុម្ពលើក្រដាស។ អំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1400 ជនជាតិអាឡឺម៉ង់មួយរូបឈ្មោះចូហាន ហ្គូតេនបឺក បានលាយបញ្ចូលគ្នានូវគំនិតអំពីឧបករណ៍បោះពុម្ពធ្វើពីដុំឈើជាមួយបច្ចេកវិទ្យាផ្សេងទៀតដើម្បីបង្កើតម៉ាស៊ីនបោះពុម្ព។ ម៉ាស៊ីនបោះពុម្ពគឺជាម៉ាស៊ីនមួយដែលសង្កត់ក្រដាស់ពីលើបន្ទះទឹកថ្នាំមួយដែលអាចចល័តបាន។ ហ្គូតេនបឺកបានបង្កើតពុម្ពអក្សររបស់លោកធ្វើពីលោហៈដែលអាចរក្សាទុកបានយូរជាងដុំឈើ។ ហ្គូតេនបឺកបានប្រើប្រាស់ម៉ាស៊ីនរបស់លោកដើម្បីបោះពុម្ពកំណែពេញលេញនៃគម្ពីរប៊ីបនៅក្នុងឆ្នាំ 1455 ។ លោកប្រហែលជាបានផលិតវាប្រហែលជា 180 ច្បាប់។ សៀវភៅនេះត្រូវបានគេស្គាល់ថាគម្ពីរប៊ីបហ្គូតេនបឺក។ ម៉ាស៊ីនបោះពុម្ពបានជះឥទ្ធិពលយ៉ាងធំធេងលើសង្គមអឺរ៉ុប។ សៀវភៅចាប់ផ្តើមមានតម្លៃថោក, ដូច្នេះមនុស្សកាន់តែច្រើនអាចទិញវាប្រើប្រាស់បានផ្ទាល់ខ្លួន។ មនុស្សកាន់តែច្រើនរៀនពីរបៀបសរសេរ ហើយគំនិតបានរីកសាយភាយកាន់តែឆាប់រហ័ស។ ជាងនេះទៅទៀត ម៉ាស៊ីនបោះពុម្ពបានលើកទឹកចិត្តអ្នកនិពន្ធកាន់តែច្រើនឱ្យសរសេរជាភាសាក្នុងស្រុក ឬភាសាដើមរបស់ពួកគេ។ មុនពេលការធ្វើដូច្នេះ អ្នកនិពន្ធភាពច្រើនសរសេរជាភាសាឡាតាំង, ភាសារបស់អ្នកទទួលបានការអប់រំខ្ពង់ខ្ពស់។ បច្ចុប្បន្ន អ្នកនិពន្ធចាប់ផ្តើមសរសេរសម្រាប់អ្នកអាននៅក្នុងភាសាប្រចាំថ្ងៃរបស់ពួកគេ។

បច្ចេកវិទ្យាផ្សេងៗទៀត៖ អំឡុងបុនសម័យ អ្នកប្រាជ្ញចាប់ផ្តើមស៊ើបអង្កេតពីពិភពលោកដោយផ្ទាល់។ ការសង្កត់ធ្ងន់ទៅលើការអង្កេត និងគំនិតដើមបាននាំមកនូវការអភិវឌ្ឍបច្ចេកវិទ្យាជាច្រើន។ ការពិសោធន៍ជាមួយនិងកញ្ចក់បាននាំទៅរកការអភិវឌ្ឍមីក្រូទស្សន៍ និងកែវយឺតនៅវង្វង់ឆ្នាំ 1600 ។ មីក្រូទស្សន៍បានអនុញ្ញាតឱ្យអ្នកវិទ្យាសាស្រ្តអាចមើលឃើញវត្ថុតូចៗជាងអ្វីៗដែលពួកគេធ្លាប់ឃើញកន្លងមក។ កែវយឺតបានបង្ហាញពីធម្មជាតិពិតប្រាកដនៃភពផែនដីជាលើកដំបូង។ វាក៏បានជួយដល់ការធ្វើនាវាចរណ៍ និងការធ្វើសង្គ្រាម។ ការអភិវឌ្ឍការផលិតនាឡិការួមមានវិធីសាស្រ្តថ្មីចំនួន 2 ក្នុងការធ្វើឱ្យនាឡិកាដើរ៖ រស័រ និងប៉ោល។ អ្នកផលិតនាឡិកាប្រើប្រាស់រស័រដើម្បីបង្កើតនាឡិកាអាចយកតាមខ្លួនបានជាលើកដំបូង។ នាឡិកាផ្សេងទៀតដែលដំណើរការដោយប៉ោលបានធ្វើឱ្យពេលវេលាកាន់តែត្រឹមត្រូវជាងពីមុន។ វ៉ែសេវ និងត្រីវិស័យជាលើកដំបូងត្រូវបានគេប្រាស់ប្រាស់ជាទូទៅនៅពាសពេញអឺរ៉ុបអំឡុងបុនសម័យ។ ក៏ដូចជាម៉ាស៊ីនបោះពុម្ព ប្រទេសចិនជាអ្នកដំបូងដែលបានអភិវឌ្ឍបច្ចេកវិទ្យាទាំងនេះ។

សង្ខេប៖ ពិពណ៌នាការអភិវឌ្ឍមួយចំនួននៅអំឡុងបុនសម័យក្រៅពីសិល្បៈ។

## 4. ជីវិតរស់នៅអំឡុងបុនសម័យ

សំណួរគន្លឹះ៖ ហេតុអ្វីបានជាបុនសម័យជះឥទ្ធពលភាគច្រើនលើវណ្ណៈជាន់ខ្ពស់?

បុនសម័យផ្តល់អត្ថប្រយោជន៍ជាចំបងលើវណ្ណៈជាន់ខ្ពស់។ ជាទូទៅ មានតែអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភមានពេលវេលានៅក្នុងការសិក្សាអត្ថបទបុរាណ និងពិសោធន៍គំនិតមនុស្សនិយម។ សមាជិក នៃវណ្ណៈកណ្តាល និងវណ្ណៈខាងក្រោមភាគច្រើនជាអ្នកដែលមិនទទួលបានការអប់រំខ្ពង់ខ្ពស់ឡើយ។ ជាលទ្ធផល ភាគច្រើននៃពួកគេមិនបានចូលរួមនៅក្នុងសមកម្មភាពនាបុនសម័យឡើយ។ ប៉ុន្តែ ក្រោយមកគំនិតបុនវុឌ្ឍបន្តិចម្តងៗបានរីកសាយភាយទៅកាន់ប្រជាជនកាន់តែច្រើនឡើង ដូចដែលមនុស្សកាន់តែច្រើនទទួលបានការអប់រំ។

វណ្ណៈជាន់ខ្ពស់៖ វណ្ណៈជាន់ខ្ពស់នៅបុនសម័យរួមមានពួកអភិជន និងពាណិជ្ជករមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ មនុស្សនៅក្នុងវណ្ណៈនេះបានធ្វើការងារដើម្បីក្លាយជាអ្នកទំនើប និងល្បីល្បាញ។ ពួកគេបានរៀនអំពីគុណតម្លៃរបស់សិល្បៈ និងអក្សរសិល្ប៍បុនសម័យ។ ពួកគេក៏បានស៊ើបអង្កេតលើវិស័យសិក្សាបុរាណជាច្រើន។ គោលបំណងរបស់ពួកគេគឺដើម្បីសម្រេចភាពជោគជ័យនៅក្នុងវិស័យជាច្រើន។ បច្ចុប្បន្ន យើងសំដៅលើមនុស្សម្នាក់ដែលធ្វើឱ្យប្រសើរឡើងនូវទិដ្ឋភាពជាច្រើននៅក្នុងជីវិតរស់នៅថាជា "មនុស្សបុនសម័យ"។ ស្ត្រីស្ថិតនៅក្នុងវណ្ណៈជាន់ខ្ពស់ក៏សម្លឹងទៅរកកេរ្តិ៍ឈ្មោះផងដែរ។ ពួកគេជាច្រើនទទួលបានការអប់រំ និងបានយល់ដឹងពីគុណតម្លៃនៃសិល្បៈ។ អ្នកមួយចំនួនបានក្លាយជាវិចិត្រករ និងអ្នកនិពន្ធពេញលេញ។ ឧទាហរណ៍ ករីជនជាតិអ៊ីតាលីវិតតូរៀកូឡូនណា លេចឡើងជាអ្នកនិពន្ធបុនសម័យគួរឱ្យគត់សំគាល់ និងគោរពមួយរូប។ អ្នកស្រីបានផ្លាស់ប្តូរពាក្យ និងកាព្យឃ្លោងជាច្រើនជាមួយមីធេឡានហ្គេឡូ។ ប៉ុន្តែ ស្ត្រីទទួលបានសិទ្ធិសង្គម និងនយោបាយតិចតួចប៉ុណ្ណោះអំឡុងបុនសម័យ។ ស្ត្រីអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភជាទូទៅនៅផ្ទះ។ ពួកគេចេញក្រៅនៅពេលដែលត្រូវទៅផ្សារ ឬទៅព្រះវិហារគ្រីស្តសាសនាប៉ុណ្ណោះ។ ភារៈកិច្ចសំខាន់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេគឺគ្រប់គ្រងការអប់រំកូនៗរបស់ពួកគេ និងចាត់ចែងអ្នកបម្រើ។

វណ្ណៈផ្សេងៗទៀត៖ អំឡុងបុនសម័យ មនុស្សភាគច្រើននៅអឺរ៉ុបមិនមានទ្រព្យសម្បត្តិច្រើនឡើយ។ ពួកគេភាគច្រើនជាប្រជាជនដែលស្ថិតនៅក្នុងវណ្ណៈកណ្តាលដែលប្រកបមុខរបរជាពាណិជ្ជករ ឬជាអ្នកជំនួញ។ មានមនុស្សជាច្រើនរស់នៅក្នុងភាពក្រីក្រ។ សមាជិកនៅក្នុងវណ្ណៈក្រោមជារឿយៗធ្វើការងារជាកម្មករ។ គំនិត និងការរកឃើញថ្មីៗនៅក្នុងបុនសម័យមិនបានទៅដល់អ្នកក្រីក្រឡើយ។

វិភាគ៖ ពន្យល់ពីមូលហេតុដែលបុនវុឌ្ឍជះឥទ្ធិពលយ៉ាងច្រើនលើវណ្ណៈជាន់ខ្ពស់។

# មេរៀនទី 3៖ ការចាប់ផ្តើមធ្វើកំណែទម្រង់

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើអ្នកធ្លាប់មិនយល់ស្របជាមួយនិងឥរិយាបថរបស់មិត្តភ័ក្តម្នាក់ និងសម្រេចចិត្តនៅក្នុងចំណាយពេលវេលាតិចតួចជាមួយនឹងមនុស្សម្នាក់នេះ? នៅអំឡុងទសវត្សរ៍ឆ្នាំ 1300 និង 1400 អ្នកដើរតាមជាច្រើនមិនយល់ស្របជាមួយសកម្មភាពរបស់ព្រះវិហាររ៉ូម៉ាំងកាតូលិក។ នៅក្នុងទសវត្សឆ្នាំ 1500 អ្នកមួយចំនួនបានចាកចេញពីព្រះវិហារគ្រីស្តសាសនា។

## 1. ការបែកខ្ញែកដ៏ធំ

សំណួរគន្លឹះ៖ តើការបែកខ្ញែកដ៏ធំបានធ្វើឱ្យព្រះវិហាររ៉ូម៉ាំងកាតូលិកចុះខ្សោយយ៉ាងដូចម្តេច?

ព្រះវិហាររ៉ូម៉ាំងកាតូលិកបានប្រកួតប្រជែងគ្នាដើម្បីអំណាចកណ្តាលចាប់ពីឆ្នាំ 1378 ដល់ 1417 ។ មូលហេតុចំបងនៃការបែកចេញពីគ្នានេះគឺសេចក្តីសម្រេចរបស់ស្តេចប៉ាប ក្លេម៉ង់ទី 5 ក្នុងការផ្លាស់ប្តូររដ្ឋាភិបាលកាតូលិកពីទីក្រុងរ៉ូមប្រទេសអ៊ីតាលីទៅកាន់ទីក្រុងអាវីកណុនប្រទេសបារាំង។

ស្តេចប៉ាបបារាំង៖ នៅក្នុទសវត្សរ៍ឆ្នាំ 1300 ការកើនឡើងនៃប្រទេសជាតិបានធ្វើឱ្យអំណាចរបស់ព្រះវិហារគ្រីស្តសាសនាចុះខ្សោយ។ ស្តេចមួយចំនួនបានកើនអំណាចគ្រប់គ្រាន់នៅក្នុងការបង្ខំឱ្យព្រះវិហារគ្រីស្តសាសនាគាំទ្រគោលនយោបាយរបស់ពួកគេ។ នៅក្នុងឆ្នាំ 1305 ស្តេចបារាំងបានប្រើប្រាស់អំណាចនយោបាយរបស់ទ្រង់ក្នុងការបោះឆ្នោតជ្រើសរើសក្លេម៉ង់ទី 5 ជាស្តេចប៉ាប។ 2 ឆ្នាំក្រោយមក ស្តេចប៉ាបបានផ្លាស់មជ្ឈមណ្ឌលព្រះវិហារគ្រីស្តសាសនាទៅកាន់អាវីកណុន។ បន្ទាប់ពីការផ្លាស់ទៅកាន់អាវីកណុន ភាគច្រើននៃស្តេចប៉ាបគឺជាជនជាតិបារាំង។ ពួកអឺរ៉ុបផ្សេងទៀត ក៏ដូចជាមន្ត្រីព្រះវិហារគ្រីស្តសាសនាជាច្រើន មានអារម្មណ៍ថាស្តេចបារាំងគឺជាអ្នកគ្រប់គ្រងស្តេចប៉ាប។ ការព្រួយបារម្ភនេះបង្កឱ្យមានការប្រឈមគ្នាមួយដើម្បីត្រួតត្រាព្រះវិហារគ្រីស្តសាសនា។ ព្រះវិហាររ៉ូម៉ាំងកាតូលិកបានអភិវឌ្ឍមជ្ឈមណ្ឌលអំណាចចំនួនពីរ៖ អាវីកណុន និងរ៉ូម។ នៅក្នុងឆ្នាំ 1378 ផ្នែកទាំងពីរនេះបានបែកចេញពីគ្នា និងបានបោះឆ្នោតជ្រើសរើសស្តេចប៉ាបរៀងៗខ្លួន។ ការបែកចេញពីគ្នានេះត្រូវបានគេហៅថា ការបែកខ្ញែកដ៏ធំ។ ស្តេចប៉ានទីមួយៗទាមទារឱ្យអ្នកដើរតាមត្រូវតែស្តាប់ឱវាទរបស់ទ្រង់ និងបណ្តេញចេញពីសាសនា ឬបណ្តេញចេញពីព្រះវិហាររ៉ូម៉ាំងកាតូលិកនូវអ្នកដើរតាមណាដែលប្រឆាំង។ សកម្មភាពទាំងនេះបណ្តាលឱ្យមានការភាន់ច្រលំ និងមន្ទិលពីសំណាក់គ្រីស្តសាសនិក និងបានធ្វើឱ្យព្រះវិហារគ្រីស្តសាសនាចុះខ្សោយ។

ការសម្រុះសម្រួលព្រះវិហារគ្រីស្តសាសនា៖ នៅក្នុងឆ្នាំ 1414 អធិរាជរ៉ូមពិសិដ្ឋបានស្នើឱ្យមានសន្និសិទមួយដើម្បីបញ្ចប់ការបែកខ្ញែក និងធ្វើកំណែទម្រង់ព្រះវិហារគ្រីស្តសាសាន។ ចងចាំថាចក្រភពរ៉ូមពិសិដ្ឋដឹកនាំអឺរ៉ុបកណ្តាលមួយភាគធំ និងមានទំនាក់ទំនងជិតស្និតជាមួយព្រះវិហាររ៉ូម៉ាំងកាតូលិក។ ជាលទ្ធផល អធិរាជរបស់រ៉ូមពិសិដ្ឋមានឥទ្ធិពលយ៉ាងខ្លាំង។ សន្និសិទធ្វើឡើងនៅក្នុងប្រទេសអាឡឺម៉ង់នៅចន្លោះឆ្នាំ 1414 ដល់ 1418 ។ មន្ត្រីព្រះវិហារគ្រីស្តសាសនាបានដេញស្តេចប៉ាបបារាំងចេញ និងជម្រុញឱ្យស្តេចប៉ាបរ៉ូមលាលែង។ នៅក្នុងឆ្នាំ 1417

ពួកគេបានបោះឆ្នោតជ្រើសរើសស្តេចប៉ាបម៉ាទីនទី 5 ។ មានមូលដ្ឋាននៅក្នុងទីក្រុងរ៉ូម ទ្រង់ចាប់ផ្តើមបង្រួបបង្រួមព្រះវិហារគ្រីស្តសាសនា។

វិភាគ៖ ពន្យល់ពីរបៀបដែលការបែកខ្ញែកដ៏ធំធ្វើឱ្យចុះខ្សោយដល់ព្រះវិហាររ៉ូម៉ាំងកាតូលិក។

## 2. ការរិះគន់លើព្រះវិហារគ្រីស្តសាសនា

សំណួរគន្លឹះ៖ តើក្រុមអ្នករិះគន់ព្រះវិហារគ្រីស្តសាសនាទាមទារឱ្យមានការធ្វើកំណែទម្រង់អ្វីខ្លះចាប់ពីទសវត្សរ៍ឆ្នាំ 1300 ដល់ 1500 ។

ការប្រឹងប្រែងរបស់ព្រះវិហារគ្រីស្តសាសនាដើម្បីដោះស្រាយបញ្ហារបស់ពួកគេ បានបង្កើនអំណាចរបស់ស្តេចប៉ាប។ បើទោះបីជាដូច្នេះក៏ដោយ ព្រះវិហារគ្រីស្តសាសនាបានបរាជ័យនៅក្នុងការប្រឹងប្រែងដើម្បីធ្វើកំណែទម្រង់។ មានភាពមិនទុកចិត្តគ្នារវាងព្រះវិហារគ្រីស្តសាសនា និងស្តេចប៉ាប ហើយអ្នកមានជំនឿមានភាពមិនច្បាស់លាស់ចំពោះអំណាចរបស់ព្រះវិហារសាសនាគ្រីស្ត។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1300 និង 1400 ការទាមទារឱ្យមានការធ្វើកំណែទម្រង់បានកើនឡើងយ៉ាងខ្លាំង។

ព្រះវិហារគ្រីស្តសាសនាពុករលួយ៖ អំឡុងយុគកណ្តាល ព្រះវិហារគ្រីស្តសាសនាបានក្លាយជាស្ថាប័នសេដ្ឋកិច្ចមួយ។ តាមរយៈការប៉ាន់ប្រមាណ ព្រះវិហារគ្រីស្តសាសនាកាន់កាប់ចាប់ពី 1/5 ទៅ 1/3 នៃដីធ្លីទាំងអស់នៅអឺរ៉ុប។ មេដឹកនាំព្រះវិហារគ្រីស្តសាសនាត្រូវការលុយក្នុងចំនួនដ៏ច្រើនមួយដើម្បីរក្សាការពារនូវស្ថាប័នរបស់ខ្លួន។ ក្រុមអ្នករិះគន់ និងអ្នកធ្វើកំណែទម្រង់បានការខឹងសម្បាទៅលើបញ្ហាមួយចំនួនដែលទាក់ទងជាមួយចំណូល និងចំណាយរបស់ព្រះវិហារគ្រីស្តសាសនា។ ពួកអឺរ៉ុបជាច្រើន ជាពិសេសអ្នកទាំងឡាយដែលរស់នៅខាងក្រៅប្រទេសអ៊ីតាលី មិនសប្បាយចិត្តជាមួយនិងការបង់ពន្ធទៅដល់ព្រះវិហារគ្រីស្តសាសនានៅរ៉ូមឡើយ។ ពួកគេក៏មានការអាក់អន់ចិត្តជាមួយនឹងព្រះវិហារគ្រីស្តសាសនាដែលមិនបានបង់ពន្ធលើដីធ្លីដ៏ច្រើនរបស់ពួកគេ។ ក្រុមអ្នកធ្វើកំណែទម្រង់ក៏បានប្រឆាំងចំពោះការលក់បណ្ណលើកលែងទោស។ បណ្ណលើកលែងទោសមួយគឺជាបណ្ណសម្រាប់ការលើកលែងការដាក់ទោសសម្រាប់ការប្រព្រឹត្តិអំពើបាប។ ប៉ុន្តែ ពេលខ្លះបណ្ណលើកលែងទោសត្រូវបានលក់ឱ្យអ្នកសុំខមាទោសចំពោះអំពើបាប ហើយប្រជាជនដែលទិញវាគិតថាពួកគេអាចជៀសវាងការដាក់ទោសនៅឋានបន្ទាប់។ ក្រុមអ្នកធ្វើកំណែទម្រង់មានការខឹងសម្បាចំពោះថ្នាក់ដឹកនាំរបស់ព្រះវិហារគ្រីស្តសាសនាដែលបានអនុញ្ញាតឱ្យប្រជាជនមានជំនឿថាពួកគេអាចទិញផ្លូវទៅកាន់ឋានសួគ៌។ ក្រុមអ្នករិះគន់ក៏មិនពេញចិត្តចំពោះវិធីដែលព្រះវិហារគ្រីស្តសាសនាចំណាយប្រាក់។ អំឡុងបុនសម័យ ស្តេចប៉ាបជាច្រើនបានចំណាយប្រាក់ជាច្រើនដើម្បីគាំទ្រសិល្បៈ និងការកំសាន្តផ្ទាល់ព្រះកាយរបស់ទ្រង់។ មន្ត្រីព្រះវិហារគ្រីស្តសាសនាផ្សេងទៀតបានយកគំរូតាមទ្រង់។ មនុស្សគ្រប់កម្រិតទាំងអស់នៅក្នុងសង្គម ដោយរួមមានទាំងពួកអភិជន, មនុស្សក្នុងទីក្រុង, និងអ្នកស្រែចំការបានស្នើឱ្យព្រះវិហារគ្រីស្តសាសនាបញ្ជាក់ជំនឿលើតម្លៃសម្ភារៈ។

ក្រុមអ្នកធ្វើកំណែទម្រង់ងើបឡើង៖ អំឡុងទសវត្សរ៍ឆ្នាំ 1300 និង 1400 អ្នកធ្វើកំណែទម្រង់សំខាន់ៗមួយចំនួនបានងើបឡើងប្រឆាំងជាមួយការអនុវត្តរបស់ព្រះវិហារគ្រីស្តសាសនា។ នៅក្នុងប្រទេសអង់គ្លេស

ទស្សនវិទូ និងជាបព្វជិតមួយអង្គព្រះនាម ចន វីគ្លីហ្វបានស្នើឱ្យព្រះវិហារគ្រីស្តសាសនាធ្វើកំណែទម្រង់។ ទ្រង់បានចោទសួរអំពីសិទ្ធិរបស់ស្តេចប៉ាបនៅក្នុងការហូតពន្ធ និងតែងតាំងមន្ត្រីព្រះវិហារគ្រីស្តសាសនាដោយមិនមានការយល់ព្រមពីស្តេច។ នៅដើមទសវត្សរ៍ឆ្នាំ 1500 បព្វជិត និងជាអ្នកប្រាជ្ញហូឡង់ព្រះនាមដេស៊ីដេរ៉ូស អ៊ីរ៉ាស្មូសបានរិះគន់មន្ត្រីព្រះវិហារគ្រីស្តសាសនាចំពោះការប្រងើយកន្តើយរបស់ពួកគេចំពោះតម្លៃគ្រីស្តសាសនា។ ប៉ុន្តែអ៊ីរ៉ាស្មូលក៏បានរិះគន់ក្រុមអ្នកធ្វើកំណែទម្រង់ សម្រាប់ការព្យាយាមនៅក្នុងការបំបែកបំបាក់ព្រះវិហារគ្រីស្តសាសនា។ ជាលទ្ធផល ទ្រង់មិនត្រូវបានជឿទុកចិត្តដោយភាគីទាំងសងខាង។ ស្នាដៃរបស់អ៊ីរ៉ាស្មូស និងអ្នកមនុស្សនិយមមុនសម័យផ្សេងៗទៀតបានជះឥទ្ធិពលយ៉ាងខ្លាំងលើម៉ាទីន លូធ័រ។ លូធ័របានចាប់ផ្តើមចលនានៅក្នុងឆ្នាំ 1500 ដែលគេស្គាល់ថាការធ្វើកំណែទម្រង់។

សង្ខេប៖ ពិពណ៌នាការទាមទាររបស់ក្រុមអ្នករិះគន់ឱ្យព្រះវិហារគ្រីស្តសាសនាធ្វើកំណែទម្រង់ចាប់ពីទសវត្សរ៍ឆ្នាំ 1300 ដល់ 1500 ។

### 3. លូធ័រប្រឈមជាមួយព្រះវិហារគ្រីស្តសាសនា

សំណួរគន្លឹះ៖ តើមានគំនិតសំខាន់អ្វីខ្លះចេញមកពីការកែប្រែសាសនា?

អ្នកធ្វើកំណែទម្រង់ដំបូងយល់ថាព្រះវិហារគ្រីស្តសាសនាជាមូលដ្ឋានគ្រឹះគឺជាស្ថាប័នល្អមួយ ដោយគ្រាន់តែតម្រូវធ្វើឱ្យប្រសើរជាងនេះតែប៉ុណ្ណោះ។ ប៉ុន្តែក្រុមអ្នកធ្វើកំណែទម្រង់ក្រោយយល់ឃើញថាព្រះវិហារគ្រីស្តសាសនាគឺជាស្ថាប័នមួយដែលពុករលួយ។ គឺជាគំនិតរបស់មនុស្សម្នាក់ ដែលជាអ្នកតំណាងឱ្យចលនាកំណែទម្រង់ថ្មីនេះ។ ឈ្មោះរបស់លោកគឺម៉ាទីន លូធ័រ។

ម៉ាទីន លីធ័រ៖ ម៉ាទីន លូធ័រកើតនៅក្នុងប្រទេសអាឡឺម៉ង់នៅក្នុងឆ្នាំ 1483 ។ លោកទទួលបានការអប់រំខ្ពង់ខ្ពស់ ហើយឪពុករបស់លោកចង់ឱ្យលោកសិក្សាផ្នែកច្បាប់។ ប៉ុន្តែ នៅក្នុងឆ្នាំ 1505 លូធ័រត្រូវបានជាប់នៅក្នុងខ្យល់ព្យុះមួយ ហើយស្ទើរតែត្រូវរន្ទះបាញ់។ ដោយមានការភ័យខ្លាចចំពោះជីវិតរបស់លោក លោកក៏បានសន្យាបួសជាព្រះសង្ឃមួយអង្គ។ លូធ័របានព្យាយាមនៅក្នុងរស់នៅក្នុងនាមជាអ្នកបង្រៀននៅក្នុងព្រះវិហារគ្រីស្តសាសនា។ ប៉ុន្តែលោកនៅតែមានអារម្មណ៍ថា លោកគឺជាប្រព្រឹត្តិអំពើបាបមួយរូប និងថាព្រះជាម្ចាស់នឹងមានកំហឹង និងដាក់ទោសលោក។ ភាពភ័យខ្លាចរបស់លូធ័របាននាំលោកឱ្យគិតអំពីអទិទេពថាជាអាទិទេពត្រាប្រណីមួយអង្គ។ លោកជឿថាមនុស្សអាចត្រូវបានសង្គ្រោះនៅពេលណាដែលពួកគេជឿលើព្រះគ្រីស្ត (ព្រះយេស៊ូ)។ ជាលទ្ធផល លោកចោទជាសំណួរអំពីគំនិតដែលថាសេចក្តីសង្គ្រោះអាចទទួលបានតាមរយៈការធ្វើអំពើល្អ។

ទ្រឹស្តីទាំង 95 របស់លូធ័រ៖ គំនិតរបស់លូធ័របាននាំទៅដល់ជម្លោះជាមួយព្រះវិហារកាតូលិក។ ជម្លោះចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1517 នៅវីថេនបឹកប្រទេសអាឡឺម៉ង់។ លូធ័របានដឹងថាមានមន្ត្រីព្រះវិហារគ្រីស្តសាសនាមួយរូបបានលក់បណ្ណលើកលែងទោសដើម្បីផ្តល់លុយដល់ព្រះវិហារគ្រីស្តសាសនាផេធ័រនៅទីក្រុងរ៉ូម។ លូធ័រមិនពេញចិត្តចំពោះរឿងនេះឡើយ ហើយបានសរសេរការប្រឆាំងទាំងឡាយរបស់លោកជាមួយព្រះវិហារគ្រីស្តសាសនានៅក្នុងទ្រឹស្តីទាំង 95 របស់លោក។ គំនិតទាំងអស់នេះក្នុងនោះមានដូចជាការលក់បណ្ណលើកលែងទោសជាដើម

គឺជាអ្វីដែលលូធ័រចង់ធ្វើការពិភាក្សានៅទីសាធារណៈ។ គំនិតរបស់លូធ័រមានដូចជា៖ (1) គម្ពីរប៊ីបគឺជាប្រភពនៃការពិតតែមួយគត់របស់សាសនា។ (2) មនុស្សទាំងឡាយមិនត្រូវការបព្វជិតដើម្បីបកស្រាយគម្ពីរប៊ីបឡើយ។ (3) យើងអាចទទួលបានសេចក្តីសង្គ្រោះតាមរយៈការជឿលើព្រះយេស៊ូតែមួយគត់។ ទ្រឹស្តីទាំង 95 របស់លូធ័របានប្រឆាំងដោយផ្ទាល់ជាមួយអំណាចរបស់ព្រះវិហារគ្រឹស្តសាសនា។ យោងតាមរឿងព្រេង លូធ័របានដំទ្រឹស្តីរបស់លោកភ្ជាប់ទៅនឹងទ្វារប្រាសាទព្រះវិហារគ្រឹស្តសាសនា ដែលត្រូវបានប្រើសម្រាប់ធ្វើជាផ្ទាំងព័ត៌មានទីក្រុង។ ប៉ុន្តែ អ្នកប្រាជ្ញនានាជឿថា លូធ័របានបញ្ជូនទ្រឹស្តីនេះទៅកាន់មន្ត្រីព្រះវិហារគ្រឹស្តសាសនាជាន់ខ្ពស់ជាមួយនឹងសំបុត្រមួយដែលរិះគន់អំពីការអនុវត្តការលក់បណ្ណលើកលែងទោស។ លូធ័រក៏បានចែករំលែកទ្រឹស្តីរបស់លោកជាមួយមិត្តភ័ក្តហើយភ្លាមៗសេចក្តីចម្លងនៃទ្រឹស្តីរបស់លោក និងកិច្ចការផ្សេងៗទៀតត្រូវបានគេអាន និងពិភាក្សាយ៉ាងទូលំទូលាយ។ ដូចដែលគំនិតរបស់លូធ័រកាន់តែពេញនិយម ស្តេចប៉ាបលេអូទី 10, អធិរាជរ៉ូមពិសិដ្ឋធាលទី 5, និងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតបានគំរាមនៅក្នុងការដាក់ទោសលូធ័រ ដ៏រាបណាលោកប្រមូលទ្រឹស្តីរបស់លោកត្រឡប់ទៅវិញ។ ប៉ុន្តែលូធ័រមិនបានធ្វើតាមឡើយ។ ជំនួសដោយការបន្តព្យាយាមនៅក្នុងការធ្វើកំណែទម្រង់ព្រះវិហារកាតូលិក លូធ័រនិងអ្នកដើរតាមលោកបានបង្កើតក្រុមសាសនាមួយផ្ទាល់របស់ពួកគេ។ ចលនានៃការប្រឆាំងជាមួយព្រះវិហារកាតូលិកត្រូវបានគេស្គាល់ថាការកែប្រែសាសនា។ នៅក្នុងឆ្នាំ 1529 ព្រះអង្គម្ចាស់អាឡឺម៉ង់មួយចំនួនដែលនៅបន្តមានភក្តីភាពជាមួយព្រះវិហារគ្រឹស្តសាសនា បានយល់ស្របនៅក្នុងការបង្រួបបង្រួមប្រឆាំងជាមួយគំនិតរបស់លូធ័រ។ ព្រះអង្គម្ចាស់ផ្សេងៗទៀតបានឡាយព្រះហស្តលេខាមួយជំទាល់ប្រឆាំងជាមួយកិច្ចព្រមព្រៀងនេះ។ ការជំទាល់នេះទទួលបានឈ្មោះមួយថាប្រូតេស្តង់។ បន្តិចម្តងៗប្រូតេស្តង់បានក្លាយជាឈ្មោះសម្រាប់គ្រឹស្តសាសនិកដែលបែកចេញពីព្រះវិហារកាតូលិកអំឡុង និងបន្ទាប់ពីទសវត្សរ៍ឆ្នាំ 1500 ។

វិភាគ៖ ពិពណ៌នាអំពីគំនិតសំខាន់នានាដែលចេញមកពីការកែសាសនា។

# មេរៀនទី 4៖ ការកែប្រែសាសនា និងប្រតិកម្ម

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ សហគមន៍របស់អ្នកប្រហែលជាមានព្រះវិហារគ្រីស្តសាសនាច្រើនប្រភេទ។ វាអាចរួមមានព្រះវិហារប៉ាទីស្ទ, កាតូលិក, ឬមេតូឌីស្ទ។ មុនម៉ាទីន លូធ័រ ភាគច្រើននៃព្រះវិហារគ្រីស្តសាសនា ជារ៉ូម៉ាំងកាតូលិក ឬអូតូដុសខាងកើត។ ការកែប្រែសាសនាបាននាំទៅដល់ការកើតឡើងនៃសាសនាគ្រីស្តជាច្រើនក្រុម។

## 1. ការកើនឡើងនៃកែប្រែសាសនា

សំណួរគន្លឹះ៖ តើចលនាប្រូតេស្តង់ណាដែលនាំមុខគេនៅក្នុងការអភិវឌ្ឍនៅអឺរ៉ុប?

គំនិតរបស់លូធ័របានរីកសាយភាយយ៉ាងឆាប់រហ័ស។ បព្វជិតដែលយល់ស្របជាមួយគំនិតរបស់លូធ័របានទេសនាសាររបស់លោក។ ចំណែកឯក្រុមអ្នកទៅព្រះវិហារជាទៀងទាត់បាននិយាយគំនិតថ្មីនេះនៅតាមផ្ទះ, នៅតាមផ្លូវ, និងនៅមហាវិទ្យាល័យ។ ការបោះពុម្ពក៏បានជួយដល់ការរីកសាយភាយនៃគំនិតរបស់លូធ័រផងដែរ។ ដំណើរការនៃការបោះពុម្ពចាប់ផ្តើមមានតម្លៃថោក ហើយហាងបោះពុម្ពមានចំនួនកាន់តែច្រើន។ ក៏ដូចគ្នាផងដែរ ប្រជាជនអឺរ៉ុបកាន់តែច្រើនអាចអានបាន, ហើយម៉ាស៊ីនបោះពុម្ពផលិតបានស្នាដៃជាច្រើន។ អស់រយៈពេលជាច្រើនសតវត្សរ៍ គម្ពីរប៊ីបត្រូវបានបោះពុម្ពតែជាភាសាឡាតាំងប៉ុណ្ណោះ។ ឥឡូវម៉ាស៊ីនបោះពុម្ពចាប់ផ្តើមផលិតគម្ពីរប៊ីបជាភាសាក្នុងតំបន់។ ជាលទ្ធផល ប្រជាជនអាចអាន និងបកស្រាយគម្ពីរប៊ីបដោយខ្លួនគេផ្ទាល់។ ការផ្លាស់ប្តូរនេះបានគំរាមកំហែងដល់អំណាចរបស់ព្រះវិហារកាតូលិក។

ការបះបោរ និងសង្គ្រាម៖ ប្រជាកសិករនៅពាសពេញអឺរ៉ុបបានសម្លឹងទៅរកសិទ្ធិសេរីភាពកាន់តែច្រើននៅអំឡុងទសវត្សរ៍ឆ្នាំ 1500 ។ ការទាមទាររបស់ពួកគេចំពោះថ្លៃប្រាក់ឈ្នួល និងស្ថានភាពរស់នៅប្រសើរជាងមុនដែលមិនជាប់ទាក់ទងជាមួយសាសនាឡើយ។ ប៉ុន្តែមានមនុស្សជាច្រើនជឿថាគំនិតរបស់លូធ័រអំពីសេរីភាពបុគ្គលត្រូវគ្នាជាមួយនឹងការបះបោររបស់ពួកគេ។ លូធ័របានថ្កោលទោសទាំងប្រជាកសិករសម្រាប់ការបះបោរហឹង្សារបស់ពួកគេ និងពួកអភិជនសម្រាប់ការមិនយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់ប្រជាកសិករ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1500 សមរភូមិសាសនាបានវាយប្រយុទ្ធពាសពេញអឺរ៉ុប។ ស្តេចឆាលទី 5 គឺជាអធិរាជរ៉ូម៉ាំពិសិដ្ឋ និងជាស្តេចរបស់ប្រទេសអូទ្រីស, អេស្ប៉ាញ, និងអាស្ប៉ាញនៅអាមេរិក។ នៅក្នុងប្រទេសអាឡឺម៉ង់ ព្រះអង្គម្ចាស់ដែលដើរតាមលូធ័រជាច្រើនបានធ្វើសង្គ្រាមប្រឆាំងជាមួយស្តេចឆាល។ ព្រះអង្គម្ចាស់ដែលគាំទ្រលូធ័រ និងព្រះអង្គម្ចាស់ដែលគាំទ្រកាតូលិកដាយថាហេតុមានជួបប្រជុំគ្នានៅក្នុងឆ្នាំ 1555 និងបានយល់ព្រមលើសន្ធិសញ្ញាសន្តិភាពមួយដែលគេស្គាល់ថាសន្តិភាពអូស្បឺហ្គ។ នៅចុងទសវត្សរ៍ឆ្នាំ 1500 នៅក្នុងប្រទេសបារាំង ពួកប្រូតេស្តង់ និងកាតូលិកបានវាយប្រយុទ្ធគ្នានៅក្នុងសង្គ្រាមសាសនាចំនួន 8 លើក។ នៅអំឡុងសម័យនេះ ខាធេរីន ដេ មេឌីស៊ីស បានធ្វើការដើម្បីដោះស្រាយជម្លោះនេះ។ ខាធេរីនមកពីគ្រួសារមេឌីស៊ីនៅអ៊ីតាលី ប៉ុន្តែទ្រង់បានក្លាយជាម្ចាស់ក្សត្រីនៃប្រទេសបារាំងនៅក្នុងឆ្នាំ 1547 ដែលជាមហេសីរបស់ស្តេចហេនរីទី 2 ។ បន្ទាប់ពីហេនរីសុគតនៅក្នុងឆ្នាំ 1559 រាជបុត្រ 3 អង្គរបស់ទ្រង់បានដឹកនាំបារាំងបន្តបន្ទាប់គ្នា។ ប៉ុន្តែខាធេរីនដើរតួរជាអ្នកកាន់អំណាចពិតប្រាកដនៅពីក្រោយពួកទ្រង់។

កាល់វីននិយម៖ លូធ័រជឿថាគម្ពីរប៊ីបគឺជាប្រភពនៃភាពជឿជាក់តែមួយគត់របស់សាសនា។ ប៉ុន្តែ មនុស្សអានគម្ពីរប៊ីបនៅក្នុងវិធីផ្សេងៗគ្នា ដែលនាំទៅដល់ការបកស្រាយខុសៗគ្នានៅក្នុងចំណោមសហគមន៍គ្រីស្តសាសនា។ ដូចដែលគំនិតរបស់លូធ័រសាយភាយ ភាពខុសគ្នានៃប្រូតេស្តង់និយមបានកើនឡើង។ ចន កាល់វីនគឺជាអ្នកធ្វើកំណែទម្រង់ជនជាតិបារាំងមួយរូប។ ការបកស្រាយរបស់លោកពីគម្ពីរប៊ីបនាំឱ្យលេចចេញនូវប្រូតេស្តង់និយមមួយបែបដែលគេហៅថាកាល់វីននិយម។ កាល់វីនទទួចថាគ្រីស្តសាសនិកមិនអាចធ្វើអ្វីដើម្បីទទួលបានការសង្គ្រោះឡើយ ព្រះជាម្ចាស់បានជ្រើសរើសមនុស្សសម្រាប់ការសង្គ្រោះរួចហើយតាំងពីមុនពេលដែលពួកគេកើតទៅទៀត។ គំនិតនេះត្រូវបានគេហៅថាបុព្វវាសនា។ យោងតាមបុព្វវាសនា ប្រសិនបើបុគ្គលមួយរូបត្រូវបានកាត់ទោសរួចហើយ ពួកគេមិនអាចធ្វើអ្វីបានទាំងអស់។ កាល់វីនខ្លួនលោកផ្ទាល់យល់ស្របថាជំនឿមួយមានរឿងច្រើនណាស់ដែលត្រូវគិត។ បើទោះជាយ៉ាងដូច្នេះក៏ដោយ លោកបានទាក់ទាញអ្នកដើរតាមជាច្រើន ហើយគំនិតរបស់លោកបានរីកសាយភាយនៅពាសពេញអឺរ៉ុប។

ព្រះវិហារគ្រីស្តសាសនានៅអង់គ្លេស៖ ការកែប្រែសាសនានៅក្នុងប្រទេសអង់គ្លេសចាប់ផ្តើមឡើងនៅពេលដែលស្តេចហេនរីទី 8 ចង់លែងលះជាមួយកាធេរីនអារ៉ាហ្គុន ប៉ុន្តែស្តេចប៉ាបមិនអនុញ្ញាត។ ជាលទ្ធផល ហេនរីបានបដិសេធនៅក្នុងការទទួលស្គាល់ព្រះវិហារកាតូលិក។ ហេនរីបានបង្កើតព្រះវិហារគ្រីស្តសាសនាអង់គ្លេស ឬព្រះវិហារអង់គ្លីកេន។ ព្រះវិហារនេះនៅរក្សាជំនឿស្ទើរតែទាំងស្រុងរបស់កាតូលិកប៉ុន្តែបដិសេធអំណាចរបស់ស្តេចប៉ាប។ ស្តេចរបស់អង់គ្លេសដើរតួនាទីជាប្រមុខនៃព្រះវិហារអង់គ្លីកេន។ អ្នកកំណែទម្រង់មួយចំនួនជឿថាព្រះវិហារអង់គ្លីកេនគួរតែបដិសេធកាតូលិកនិយមទាំងស្រុង។ ក្នុងចំណោមនោះ មានអ្នកកំណែទម្រង់មួយរូបឈ្មោះវិលៀម ទីនដេល។ មន្រ្តីអង់គ្លីកេនបានបណ្តេញទីនដេលមិនឱ្យធ្វើការនៅក្នុងប្រទេសអង់គ្លេស ដូច្នេះលោកបានធ្វើដំណើរទៅកាន់ប្រទេសអាឡឺម៉ង់។ មន្ត្រីកាតូលិកជាយថាហេតុបានចាប់ខ្លួនលោក និងប្រហារជីវិតលោកសម្រាប់ការប្រឆាំងជាមួយព្រះវិហារកាតូលិក។ សមរភូមិនៅអង់គ្លេសដើម្បីរក្សានូវជំនឿកាតូលិក ឬដើម្បីសម្លឹងទៅរកការធ្វើកំណែទម្រង់ប្រូតេស្តង់កាន់តែច្រើនបានបន្តអស់រយៈពេលជាច្រើនឆ្នាំ។

ស្វែងរកគំនិតសំខាន់៖ ពិពណ៌នាចលនាប្រូតេស្តង់នាំមុខគេដែលត្រូវបានអភិវឌ្ឍនៅពាសពេញអឺរ៉ុប។

## 2. ការប្រឈមជាមួយការកែប្រែសាសនា

សំណួរគន្លឹះ៖ តើព្រះវិហារកាតូលិកធ្វើដូម្តេចដើម្បីបញ្ឈប់ការរីកសាយភាយនៃប្រូតេស្តង់និយម ?

ព្រះវិហាររ៉ូម៉ាំងកាតូលិកចាប់ផ្តើមធ្វើកំណែទម្រង់ដើម្បីដោះស្រាយបញ្ហាមួយចំនួនដែលលូធ័រ និងអ្នកដទៃផ្សេងទៀតបានលើកឡើង។ ព្រះវិហារក៏បានធ្វើសកម្មភាពនានាដើម្បីបញ្ឈប់ការរីកសាយភាយនៃប្រូតេស្តង់និយម។ ការប្រឹងប្រែងនេះត្រូវបានគេស្គាល់ថា ការប្រឈមជាមួយការកែប្រែសាសនា ឬការកែប្រែសាសនាកាតូលិក។

ក្រុមប្រឹក្សាត្រេន៖ ព្រះវិហាររ៉ូម៉ាំងកាតូលិកបានសម្លឹងទៅរកការធ្វើកំណែទម្រង់ និងកំណត់ប្រព័ន្ធជំនឿកាតូលិក។ ក្រុមប្រឹក្សាត្រេនគឺជាការប្រមូលផ្តុំមួយនៃមន្ត្រីព្រះវិហារគ្រីស្តសាសនាជាន់ខ្ពស់។ ពួកគេជួយប្រជុំជាច្រើនលើករវាងឆ្នាំ 1545 និង 1563 ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីភាពខុសគ្នារវាងជំនឿកាតូលិក និងប្រូតេស្តង់

និយម។ ឧទាហរណ៍ ពួកប្រូតេស្តង់រកឃើញថាភាពជឿកជាក់នៃសាសនាមានតែនៅក្នុងគម្ពីរប៊ីបតែមួយគត់។ ប៉ុន្តែ ក្រុមប្រឹក្សានិយាយថាភាពជឿជាក់ក៏មាននៅក្នុងទំនៀមទម្លាប់របស់ព្រះវិហារគ្រីស្តសាសនាផងដែរ។

យេស៊ូអ៊ីត៖ ក្រុមប្រឹក្សាត្រេនគឺជាកម្លាំងតែមួយគត់ដែលបង្កើតឱ្យមានការប្រឈមជាមួយការកែប្រែសាសនា។ ព្រះវិហារគ្រីស្តសាសនាក៏បានទទួលស្គាល់ និងគាំទ្រដល់ស្ថាប័នសាសនាថ្មី។ ស្ថាប័នសាសនាថ្មីមួយដែលសំខាន់បំផុតគឺសង្គមព្រះយេស៊ូ ឬយេស៊ូអ៊ីត។ ជនជាតិអេស្ប៉ាញឈ្មោះ អ៊ីកណាទូសនៃឡូយ៉ូឡា បានបង្កើតយេស៊ូអ៊ីកនៅដើមទសវត្សរ៍ឆ្នាំ 1530 ។ អ៊ីកណាទូសកើតនៅក្នុងគ្រួសារអភិជនមួយ និងបានក្លាយជាទាហានមួយរូប។ លោកត្រូវបានបាញ់ត្រូវដោយគ្រាប់កាំភ្លើងធំ ដែលបានធ្វើឱ្យជើងលោកម្ខាងបានបាក់ និងរបួសផ្នែកផ្សេងៗទៀត។ នៅពេលដែលលោកជា លោកបានអានអំពីព្រះយេស៊ូ និងតួអង្គសំខាន់ៗផ្សេងទៀតនៅក្នុងសាសនាគ្រីស្ត និងបានសម្រេចចិត្តថាលោកគួរតែលះបង់ជីវិតរបស់លោកចំពោះព្រះជាម្ចាស់។ ក្រោយមកលោកបានបង្កើតយេស៊ូអ៊ីត។ នៅក្នុងវិធីមួយចំនួន យេស៊ូអ៊ីតមានលក្ខណៈដូចគ្នាទៅនឹងស្ថាប័នយោធាមួយជាងស្ថាប័នសាសនា។ អំណាចកណ្តាលដ៏រឹងមាំមួយបញ្ជាពីលើស្ថាប័ននេះ។ យេស៊ូអ៊ីតរៀនសូត្រពីការស្តាប់ឱវាទ និងវិន័យ។ ពួកគេសិក្សាពីការអប់រំរបស់ថូម៉ាស់ អាគីណាស់ អ្នកដែលអ្នកបានអាននៅក្នុងជំពូក 16 ។ ពួកគេក៏សិក្សាពីភាសានានា ដូច្នេះពួកគេអាចមានមធ្យោបាយដើម្បីសាយភាយកាតូលិកនិយមនៅទ្វីបអាហ្វ្រិក, អាស៊ី, និងអាមេរិក។ ការបណ្តុះបណ្តាលមួយចំនួនបានអនុញ្ញាតឱ្យយេស៊ូអ៊ីតក្លាយជាមេដឹកនាំដែលគាំទ្រការប្រឈមជាមួយការកែប្រែសាសនា។

ស្ថាប័នស៊ើបអង្កេត៖ ក្នុងការបន្ថែមទៅនឹងស្នើសុំរបស់ក្រុមប្រឹក្សាត្រេន និងការគាំទ្រស្ថាប័នសាសនាថ្មី ព្រះវិហារគ្រីស្តសាសនាក៏បានបង្កើតស្ថាប័នស៊ើបអង្កេត។ ស្ថាប័នស៊ើបអង្កេតគឺជាតុលាការមួយដែលបង្កើតឡើងដើម្បីស្វែងរក និងដាក់ទោសដល់មនុស្សទាំងឡាយណាដែលងាកចេញពីជំនឿកាតូលិក។ មន្ត្រីព្រះវិហារគ្រីស្តសាសនាបានប្រើប្រាស់ការគំរាមកំហែង ឬពេលខ្លះការធ្វើទារុណកម្មដើម្បីឲ្យប្រជាជនសារភាពអំពីអំពើបាបរបស់ពួកគេ ដោយក្នុងនោះរួមមានទាំងការជឿលើប្រូតេស្តង់។ ស្ថាប័នស៊ើបអង្កេតត្រូវបានប្រើប្រាស់នៅពាសពេញអឺរ៉ុប ប៉ុន្តែស្ថាប័នដែលល្បីល្បាញបំផុតគឺស្ថាប័នស៊ើបអង្កេតអេស្ប៉ាញ។ ស្តេចប៉ាបក៏បានបញ្ជាឲ្យមន្ត្រីព្រះវិហារគ្រីស្តសាសនាបង្កើតបញ្ជីសៀវភៅមួយដែលត្រូវបានចាត់ទុកថាគំរាមកំហែងដល់ជំនឿកាតូលិក។ ស្តេចប៉ាបបានប្រាប់ដល់ហាងលក់សៀវភៅនៅពាសពេញអឺរ៉ុបឱ្យប្រមូលសៀវភៅដែលត្រូវបានហាមឃាត់ទាំងនោះ និងដុតវាចោល។ នៅក្នុងបញ្ជីនោះរួមមានគម្ពីរប៊ីបដែលបកប្រែជាភាសាអាឡឺម៉ង់, អង់គ្លេស, និងភាសាក្នុងតំបន់ដ៏ទៃទៀត។ ព្រះវិហារកាតូលិកទទួលស្គាល់តែគម្ពីរប៊ីបដែលបកប្រែជាភាសាឡាតាំងតែមួយប៉ុណ្ណោះ ហើយមានតែបព្វជិតប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យអាន។ ត្រឹមចុងទសវត្សរ៍ឆ្នាំ 1500 ការប្រឈមជាមួយការកែប្រែសាសនាបានស្តារឡើងវិញនូវអំណាចរបស់ព្រះវិហាររ៉ូម៉ាំងកាតូលិក។

សង្ខេប៖ ពន្យល់ពីវិធីដែលព្រះវិហារកាតូលិកអនុវត្តដើម្បីបញ្ឈប់ការរីកសាយភាយនៃប្រតេស្តង់និយម។

### 3. បេសកទូតសាសនាសាយភាយសហគមន៍គ្រីស្តសាសនា

សំណួរគន្លឹះ៖ ហេតុអ្វីបានជាមានបេសកទូតកាតូលិកច្រើនជាងបេសកទូតប្រូតេស្តង់?

ក្រុមគ្រីស្តសាសនាជាច្រើនក្រុមបានបញ្ជូនសមាជិករបស់ពួកគេទៅកាន់ប្រទេសខាងក្រៅ ដើម្បីធ្វើកិច្ចការសាសនា។ ការប្រឹងប្រែងមួយចំនួនត្រូវបានគេហៅថាបេសកកម្ម។ មនុស្សម្នាក់ដែលចូលរួមនៅក្នុងបេសកកម្មនេះត្រូវបានគេហៅថាបេសកទូត។ ពេលខ្លះក្រុមសាសនារៀបចំបេសកកម្មនានាដើម្បីបញ្ចុះបញ្ចូលមនុស្សដែលមិនទាន់មានជំនឿដូចពួកគេឱ្យផ្លាស់ប្តូរ ឬទទួលយកជំនឿរបស់ពួកគេ។

បេសកទូតកាតូលិក៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1500 ព្រះវិហាររ៉ូម៉ាំងកាតូលិកបានដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់នានានៅក្នុងការប្រើប្រាស់បេសកទូតដើម្បីសាយភាយជំនឿរបស់ពួកគេនៅជុំវិញពិភពលោក។ បេសកកម្មទាំងនេះទទួលបានជោគជ័យយ៉ាងធំធេងនៅអាមេរិក។ ប៉ុន្តែបេសកកម្មកាតូលិកធ្វើមិនបានល្អឡើងនៅអាស៊ី។ ហ្វ្រង់ស៊ីសកេន, ដូមីនីកេន, និងយេស៊ូអ៊ីតគឺជាស្ថាប័ន 3 ក្នុងចំណោមស្ថាប័នរបស់កាតូលិកដែលបានអនុវត្តបេសកកម្មនេះ។ ហ្វ្រង់ស៊ីនៃអាស់ស៊ីស៊ីដែលជាជនជាតិអ៊ីតាលី បានបង្កើតស្ថាប័នសាសនាហ្វ្រង់ស៊ីសកេននៅដើមទសវត្សរ៍ឆ្នាំ 1200 ។ ហ្វ្រង់ស៊ីសកេនចាប់ផ្តើមដំបូងក្នុងនាមជាស្ថាប័នស្នូមមួយ។ ដូច្នេះពួកគេមិនមានទ្រព្យសម្បត្តិអ្វីឡើយ និងរស់នៅដោយការសុំទាន។ ដូចដែលពេលវេលាកន្លងទៅ និងស្ថាប័នរីកឡើង ហ្វ្រង់ស៊ីកេនបានក្លាយជាស្ថាប័នដែលមិនសូវតឹងតែងចំពោះការមានទ្រព្យសម្បត្តិឡើយ។ ដោយមិនសូវមានច្បាប់តឹងរឹងបានអនុញ្ញាតឱ្យពួកគេចាប់ផ្តើមរៀបចំដំណើរបេសកកម្មនានា។ ពួកដូមីនីកេនក៏ជាស្ថាប័នស្នូមផងដែរ។ បព្វជិតអេស្ប៉ាញមួយអង្គព្រះនាមដូមីនីចនៃអូស្មា បានបង្កើតស្ថាប័ននេះនៅក្នុងទសវត្សរ៍ឆ្នាំ 1200 ។ ការផ្តោតដំបូងរបស់លោកគឺការអប់រំ។ ប៉ុន្តែក៏ដូចជាហ្វ្រង់ស៊ីសកេនដែរ ស្ថាប័ននេះក៏បានអនុវត្តការបញ្ជូនបេសកទូតផ្សព្វផ្សាយសាសនាផងដែរ។ ដូមីនីកេនគឺជាក្រុមដំបូងក្នុងចំណោមក្រុមនានាដែលបានចូលរួមជាមួយពួកអេស្ប៉ាញ និងព័រទុយហ្គាលធ្វើដំណើរផ្សងព្រេងទៅកាន់អាមេរិក។ ស្ថាប័នយេស៊ូអ៊ីតចាប់ផ្តើមបញ្ជូនបេសកទូតទៅជុំវិញពិភពលោកភ្លាមៗបន្ទាប់ពីវាត្រូវបានបង្កើត។ ត្រឹមឆ្នាំ 1556 មានពួកយេស៊ូអ៊ីតប្រមាណ 1,000 នាក់ធ្វើការនៅអឺរ៉ុប, អាស៊ី, អាហ្វ្រិក, និងអាមេរិក។ ត្រឹមឆ្នាំ 1626 សមាជិករបស់ពួកគេបានកើនឡើងរហូតដល់ជាង 15,000 នាក់។

បេសកទូតប្រូតេស្តង់៖ រហូតមកដល់ទសវត្សរ៍ឆ្នាំ 1800 ប្រូតេស្តង់និយមបានរីកសាយភាយតែតាមរយៈពួកអឺរ៉ុបប្រូតេស្តង់ដែលតាំងទីលំនៅខាងក្រៅអឺរ៉ុបតែប៉ុណ្ណោះ។ នៅទីនោះ ពួកគេបានធ្វើការងារតិចតួចដើម្បីផ្លាស់ប្តូរជំនឿរបស់ប្រជាជននៅក្នុងតំបន់។ តែវាមានករណីពិសេសមួយចំនួន។ ឧទាហរណ៍ នៅដើមទសវត្សរ៍ឆ្នាំ 1600 ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់បានបញ្ជូនបេសកទូតសាសនាទៅកាន់តំបន់អាស៊ីអាគ្នេយ៍។ នៅអាមេរិកខាងជើង ពូរីតាន ចន អេលីអូត និង រ៉ូជឺ វីលៀម បានធ្វើការងារដើម្បីផ្លាស់ប្តូរជំនឿរបស់ជនជាតិដើមអាមេរិកឱ្យក្លាយជាសហគមន៍សាសនាគ្រីស្ត។ សង្គមមិត្តភាពរបស់អង់គ្លេស ឬក្វាកឃឺរ ក៏សម្លឹងទៅរកការផ្លាស់ប្តូរជំនឿរបស់ប្រជាជនខាងក្រៅ ជាពិសេសនៅអាមេរិកខាងជើង។

គូសបង្ហាញសេចក្តីសន្និដ្ឋាន៖ ពន្យល់ពីមូលហេតុដែលបេសកទូតកាតូលិកមានច្រើនជាងបេសកទូតប្រូតេស្តង់។

## 4. កេរ្តិ៍ដំណែលនៃការកែប្រែសាសនា

សំណួរគន្លឹះ៖ តើប្រូតេស្តង់និយមជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះការអនុវត្តន៍ប្រជាធិបតេយ្យ?

កេរ្តិ៍ដំណែលចំបងនៃការកែប្រែសាសនាគឺការបែងចែកសហគមន៍គ្រីស្តសាសនាអឺរ៉ុបខាងលិចទៅជា កាតូលិកនិយម និងប្រូតេស្តង់និយម។ អស់រយៈពេលជាច្រើនរយឆ្នាំ គ្រីស្តសាសនិកទាំងអស់នៅអឺរ៉ុបខាងលិចស្ថិតនៅខាងព្រះវិហារកាតូលិក។ ត្រឹមឆ្នាំ 1700 រឿងនេះមិនបន្តទៀតឡើយ។ អឺរ៉ុបត្រូវបានបែងចែកតាមរយៈសាសនា និងមិនដែលបានបង្រួបបង្រួមឱ្យស្ថិតនៅក្រោមព្រះវិហារតែមួយឡើងវិញឡើយ។

សង្គ្រាមសាសនាកាន់តែច្រើន៖ សង្គ្រាមសាសនានៅតែបន្តរវាងកាតូលិក និងប្រូតេស្តង់បន្ទាប់ពីសន្ធិសញ្ញាសន្តិភាពអូសប៊ឺហ្គ។ នៅក្នុងឆ្នាំ 1648 សន្ធិសញ្ញាសន្តិភាពវេសផាលីបានជួយនៅក្នុងការបញ្ចប់សង្គ្រាម។ វាបានទទួលស្គាល់ពីការបែងចែកអឺរ៉ុបខាងលិចទៅជាប្រទេសកាតូលិក និងប្រទេសប្រូតេស្តង់។ ជំនាញរបស់ស្ដេចបារាំង និងមន្ត្រីរដ្ឋាភិបាលបានជ័យឱ្យបារាំងជំនួសអេស្ប៉ាញក្នុងនាមជាមហាអំណាចកាតូលិកនៅអឺរ៉ុប។ ប្រទេសប្រូតេស្តង់មួយចំនួនដូចជាអង់គ្លេស, ហូឡង់, និងក្រោយមកព្រូសក៏កើនឡើងអំណាចផងដែរ។ ពួកគេក្រោយមកកើនមានទំនាល់ជាមួយកាតូលិកអេស្ប៉ាញ និងបារាំង។ ការផ្លាស់ប្តូរសាសនានៅអឺរ៉ុបជាយថាហេតុនាំទៅដល់ការផ្លាស់ប្តូរនយោបាយនៅអាមេរិក។

ប្រូតេស្តង់និយម និងប្រជាធិបតេយ្យ៖ ប្រវត្តិវិទូមួយចំនួនជឿថាការអនុវត្តរបស់ព្រះវិហារប្រូតេស្តង់អំពីការដឹកនាំដោយខ្លួនឯងបានជួយដល់ការអភិវឌ្ឍរដ្ឋាភិបាលប្រជាធិបតេយ្យ។ ឧទាហរណ៍ ចន កាល់វីនបានអនុញ្ញាតឱ្យអ្នកដើរតាមលោកចូលរួមនៅក្នុងការដឹកនាំព្រះវិហារ។ ពួកគេចូលរួមតាមរយៈស្ថាប័នមេដឹកនាំ និងរដ្ឋមន្ត្រីមួយដែលគេហៅថាស្ថាប័នបព្វជិត។ ការអនុវត្តនេះបានជះឥទ្ធិពលយ៉ាងខ្លាំងមួយដល់អ្នកសិទ្ធិនិយម និងអ្នកបព្វជិតនិយម ដែលទាំងពីរក្រុមតាំងទីលំនៅក្នុងដែនដីអាណានិគមរបស់អង់គ្លេស។ ពួកអ្នកសិទ្ធិនិយមជឿថាព្រះជាម្ចាស់បានចុះព្រមព្រៀងមួយជាមួយប្រជាជន ដោយសន្យាថាពួកគេនឹងត្រូវបានសង្គ្រោះ។ ជំនឿនេះនាំទៅដល់គំនិតមួយដែលថាគ្រីស្តសាសនិកអាចយល់ស្របនៅក្នុងចូលរួមជាមួយគ្នា និងដោយស្ម័គ្រចិត្តនៅក្នុងការបង្កើតព្រះវិហារមួយ។ គំនិតអំពីសមាជិកភាពរបស់ព្រះវិហារបែបប្រជាធិបតេយ្យនេះបានជះឥទ្ធិពលលើនយោបាយ។ មនុស្សទាំងអស់នេះជឿថាពួកគេអាចរួបរួមគ្នា និងដោយស្ម័គ្រចិត្តនៅក្នុងការបង្កើតរដ្ឋាភិបាលមួយ។ អ្នកប្រាជ្ញនានាក៏បានអះអាងថាកិច្ចព្រមព្រៀងបានជះឥទ្ធិពលលើការអភិវឌ្ឍសហព័ន្ធនិយម។ សហព័ន្ធនិយមគឺជាការចែករំលែកអំណាចរវាងស្ថាប័នមួយជាមួយផ្នែកផ្សេងៗដែលផ្សំវាឡើង។ ឧទាហរណ៍នៅក្នុងសហរដ្ឋអាមេរិក រដ្ឋាភិបាលសហព័ន្ធបានបែងចែកអំណាចជាមួយនឹងរដ្ឋនានា។ កិច្ចព្រមព្រៀងនៃព្រះវិហារកាល់វីនីសនិយមបានអនុញ្ញាតឱ្យសមាជិករបស់ព្រះវិហារចែករំលែកអំណាចជាមួយបព្វជិត។ ការអនុវត្តន៍ការបែងចែកអំណាចអាចជះឥទ្ធិពលលើគម្រោងនៃការរៀបចំរដ្ឋាភិបាល ដូចជាសហរដ្ឋអាមេរិកជាដើម។

វិភាគអំពីមូលហេតុ៖ ពន្យល់ពីមូលហេតុដែលប្រូតេស្តង់ជះឥទ្ធិពលលើការអនុវត្តន៍បែបប្រជាធិបតេយ្យ។

# ជំពូក 18 ៖ បដិវត្តវិទ្យាសាស្ត្រ និងយុគសម័យនៃការរុករក

## មេរៀនទី 1 ៖ បដិវត្តវិទ្យាសាស្ត្រ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ តើអ្នកធ្លាប់បានអានសៀវភៅមួយ ឬក៏មើលខ្សែភាពយន្តមួយដែលបានផ្លាស់ប្តូរការយល់ឃើញរបស់អ្នកទៅលើរបស់អ្វីមួយ? នៅក្នុងជំពូកនេះ អ្នកនឹងបានសិក្សាពីរបៀបដែលគំនិត និងការរុករកថ្មីៗជួយដល់ការផ្លាស់ប្តូរការយល់ឃើញប្រជាជននៅអឺរ៉ុបអំពីពិភពលោក។

### 1. ប្រវត្តិគំនិតវិទ្យាសាស្ត្រ

សំណួរគន្លឹះ៖ តើបុនសម័យជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះវិទ្យាសាស្ត្រ?

រវាងឆ្នាំ 600 មុនគ.សដល់ 200 នៃគ.ស អ្នកវិទ្យាសាស្ត្រក្រិកបានអភិវឌ្ឍគំនិតជាច្រើនអំពីរបៀបដែលពិភពលោកដំណើរការ។ ពួកគេជឿនៅក្នុងទ្រឹស្តីមួយដែលគេហៅថាសនិទាននិយម ដែលមនុស្សប្រើប្រាស់ហេតុផល ឬគំនិតបែបតក្កដើម្បីយល់ដឹងពីពិភពលោក។

ផែនដីជាចំណុចកណ្តាលនៃចក្រវាល៖ ទស្សនវិទូក្រិកអារីស្តូតដែលរស់នៅចាប់ពីឆ្នាំ 384 ដល់ 322 មុនគ.ស ត្រូវបានគេចាត់ទុកថាជាទស្សនវិទូដែលល្អបំផុត។ លោកបានសិក្សាពីតារា និងភពនៅក្នុងវិធីបែបសនិទាន។ ការសិក្សារបស់លោកបាននាំលោកទៅបង្កើត និងពង្រីកទ្រឹស្តីផែនដីជាចំណុចកណ្តាលនៃចក្រវាល។ ទ្រឹស្តីនេះ ដែលត្រូវបានគេប្រើប្រាស់ជាទូទៅនៅសម័យបុរាណ បានដាក់ផែនដីនៅចំណុចកណ្តាលនៃចក្រវាល។ នៅក្នុងទ្រឹស្តីរបស់អារីស្តូត ព្រះចន្ទ, ព្រះអាទិត្យ, និងភពផ្សេងៗទៀតបានវិលយ៉ាងទៀងទាត់លើគន្លងមួយជុំវិញផែនដី។ ប្រមាណជា 500 ឆ្នាំក្រោយមក ស្នាដៃរបស់តារាវិទូមួយរូបឈ្មោះផ្ទូលេមីបានយល់ស្របជាមួយ និងពង្រីកការយល់ឃើញរបស់អារីស្តូត។ ផ្ទូលេមីបានអះអាងថាព្រះចន្ទ និងភពផ្សេងៗទៀតវិលលើគន្លងមួយជុំវិញខ្លួនឯង។ ខណៈពេលដែលវិលលើគន្លងខ្លួនឯង ភពទាំងនោះក៏វិលលើគន្លងធំមួយជុំវិញផែនដី។ ការយល់ឃើញរបស់អារីស្តូត និងផ្ទូលេមីអំពីចក្រវាលត្រូវបានបង្ហាញភស្តុតាងថាខុស។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយ អ្នកវិទ្យាសាស្ត្រនានាបានទទួលយកគំនិតនេះអស់រយៈពេល 1,400 ឆ្នាំ។ មុនឆ្នាំ 1500 អ្នកប្រាជ្ញអឺរ៉ុបមួយចំនួនតូចបានប្រឆាំងជាមួយនឹងគំនិតវិទ្យាសាស្ត្រ និងការយល់ឃើញរបស់ទស្សនវិទូសម័យបុរាណ ដោយបានអង្កេតធម្មជាតិដោយយកចិត្តទុកដាក់ដោយខ្លួនពួកគេផ្ទាល់។

គណិតវិទ្យា និងវេជ្ជសាស្ត្រក្រិក៖ នៅក្នុងទសវត្សរ៍ឆ្នាំ 500 មុនគ.សអ្នកប្រាជ្ញក្រិកមួយរូបឈ្មោះភីថាហ្គ៉ាស់ព្យាយាមនៅក្នុងការពន្យល់ពីចក្រវាលនៅក្នុងបច្ចេកពាក្យគណិតសាស្ត្រ។ នៅក្នុងការយល់ឃើញរបស់លោក អ្វីៗបានរួមបញ្ចូលគ្នានៅក្នុងផ្លូវស្របគ្នាមួយដើម្បីបង្កើតចក្រវាលមួយ។ គំនិតអំពីការរួមបញ្ចូលគ្នានៃវត្ថុទាំងឡាយយ៉ាងត្រឹមត្រូវជាមួយគ្នាដើម្បីបង្កើតវត្ថុរួមមួយដែលគេស្គាល់ថាសុខដុម។ ស្នាដៃរបស់ភីថាហ្គ៉ាស់បានជះឥទ្ធិពលយ៉ាងខ្លាំងលើទស្សនវិជ្ជាក្រិចបុរាណ និងអឺរ៉ុប។ ប្រហែលជា 200 ឆ្នាំក្រោយមក អឺគ្លីដ បានបង្កើតទ្រឹស្តីរបស់ភីថាហ្គ៉ាស់។ លោកបានសិក្សាពីរូបសណ្ឋាននានាដូចជារង្វង់ និងត្រីកោណ។ កិច្ចការរបស់លោកបានបង្កើតមូលដ្ឋាន

គ្រឹះនៃការសិក្សាមួយដែលគេស្គាល់ថាធរណីមាត្រ។ បច្ចុប្បន្នវគ្គសិក្សាធរណីមាត្រនៅតែផ្តោតលើការសិក្សារបស់អឺគ្លីដ។

ពួកក្រិកក៏ជាអ្នកបង្កើតមូលដ្ឋានគ្រឹះនៃវេជ្ជសាស្ត្រទំនើបផងដែរ។ ហីបប៉ូក្រាតអ្នកដែលបានរស់នៅក្នុងទសវត្សរ៍ឆ្នាំ 400 មុនគ.ស ជឿថាវេជ្ជបណ្ឌិតអាចធ្វើរោគវិនិច្ឆ័យបានតាមរយៈការអង្កេតទៅលើករណីជាច្រើន។ ការអនុវត្តនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអនុវត្តវេជ្ជសាស្ត្រនាពេលក្រោយមកទៀត។ ហ្គាលេនអ្នកដែលបានរស់នៅទសវត្សរ៍ឆ្នាំ 100 បានផ្តោតសំខាន់លើកាយវិទ្យា, រចនាសម្ព័ន្ធរបស់វត្ថុមានជីវិត។ លោកទទួលបានចំណេះដឹងយ៉ាងច្រើនតាមរយៈការវះកាត់អង្កេតសរីរាង្គខាងក្នុង, រុក្ខជាតិ និងសត្វដើម្បីពិនិត្យមើលផ្នែកផ្សេងៗនៅក្នុងនោះ។

វិទ្យាសាស្ត្រនៅយុគកណ្តាល៖ អស់រយៈពេលជាច្រើនសតវត្សរ៍បន្ទាប់ពីការស្លាប់របស់ហ្គាលេន មានអ្នកវិទ្យាសាស្ត្រអឺរ៉ុបមួយចំនួនតូចបានធ្វើការសិក្សាពីវិទ្យាសាស្ត្រ។ ប៉ុន្តែ ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក 10 អ្នកប្រាជ្ញម៉ូស្លីមបានចាប់អារម្មណ៍ជាមួយចំណេះដឹងវិទ្យាសាស្ត្រសម័យបុរាណ។ រវាងពាក់កណ្តាលទសវត្សរ៍ឆ្នាំ 700 និងពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1200 អ្នកប្រាជ្ញម៉ូស្លីមបានខ្ចី និងអភិវឌ្ឍការសិក្សាពីក្រិកបុរាណ និងសង្គមបុរាណផ្សេងៗទៀត។ ក្រោយមក ការសិក្សា និងចំណេះដឹងរបស់ពួកគេបានរីកសាយភាយទៅកាន់អឺរ៉ុបខាងលិច។ អ្នកប្រាជ្ញម៉ូស្លីម, ជ្វីប, និងគ្រីស្តនៅអាលអានដាលូសបានជួយដល់ចលនានៃការស្រាវជ្រាវ។ ពួកគេជាច្រើនបានបកប្រែស្នាដៃវិទ្យាសាស្ត្រក្រិក និងអារ៉ាប់ទៅជាភាសាឡាតាំង។ អ្នកប្រាជ្ញគ្រីស្តសាសនាបានប្រមូលផ្តុំគ្នាទៅអេស្ប៉ាញដើម្បីសិក្សាពីស្នាដៃទាំងនេះ និងបាននាំយកវាមកកាន់អឺរ៉ុប។ អំឡុងសម័យនេះ អ្នកប្រាជ្ញជ្វីបដើរតួនាទីសំខាន់មួយ។ ក្នុងចំណោមអ្នកប្រាជ្ញជ្វីបទាំងនេះមានអ្នកប្រាជ្ញមួយរូបឈ្មោះជឺសូនីដេស អ្នកដែលបានរស់នៅក្នុងទសវត្សរ៍ឆ្នាំ 1300 ។ លោកបានបង្កើតឧបករណ៍មួយដើម្បីវាស់រយៈចម្ងាយរវាងវត្ថុនានានៅលើមេឃ។ ដោយប្រើប្រាស់វាលោកបានប៉ាន់ប្រមាណយ៉ាងត្រឹមត្រូវដែលថាផ្កាយនានាមានរយៈចម្ងាយដ៏ឆ្ងាយមួយពីផែនដី។ មុនពេលលោកប៉ាន់ប្រមាណ អ្នកប្រាជ្ញភាគច្រើនយល់ស្របជាមួយផ្នត់គំនិតដែលថាតារាមានចម្ងាយជិតផែនដីដោយឆ្ងាយជាងពីព្រះចន្ទមកផែនដីបន្តិចបន្តួច។ ដូចដែលចំណេះដឹងវិទ្យាសាស្ត្ររីកសាយភាយនៅពាសពេញអឺរ៉ុប ជម្លោះភ្លាមៗនោះបានកើតមានឡើងរវាងសហគមន៍គ្រីស្តសាសនា និងវិទ្យាសាស្ត្រ។ សហគមន៍គ្រីស្តសាសនាបង្ហាញពីការយល់ឃើញរបស់ពួកគេតាមរយៈជំនឿ ខណៈពេលដែលអ្នកវិទ្យាសាស្ត្រសង្កត់ធ្ងន់ទៅលើហេតុផល។ ដូចដែលអ្នកបានរៀននៅជំពូក 16 អ្នកប្រាជ្ញគ្រីស្តសាសនិក ថូម៉ាស់ អាគីណាស់ បានព្យាយាមនៅក្នុងបង្ហាញថា ការយល់ឃើញទាំងពីរនេះអាចលេចចេញមកក្នុងភាពសុខដុមបាន។ នៅពេលនោះ ការស្រាវជ្រាវរកឃើញបែបវិទ្យាសាស្ត្របាននាំទៅដល់ការគំរាមកំហែងសុខដុមរបស់សាសនា និងវិទ្យាសាស្ត្រ។

បុនសម័យនាំទៅដល់គំនិតថ្មីៗ៖ បន្ទាប់ពីចក្រភពប៊ីហ្សង់ទីនដួលរលំនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1400 អ្នកប្រាជ្ញប៊ីហ្សន់ទីនជាច្រើនបានរត់គេចទៅប្រទេសអ៊ីតាលី។ ពួកគេបាននាំយកទៅជាមួយពួកគេនូវចំណេះដឹងអក្សរសិល្ប៍របស់ក្រិក និងរ៉ូមបុរាណ។ អក្សរសិល្ប៍នេះបានបង្កើតជាមូលដ្ឋានគ្រឹះនៃមនុស្សនិយម ដែលជាវិធី

មួយនៅការគិតដែលផ្ដោតសំខាន់លើជីវិតមនុស្ស និងសក្ដានុពលរបស់វាដើម្បីទទួលបានជោគជ័យ។ នៅក្នុងពេលប្រហែលគ្នានេះ ការបង្កើតឡើងនូវឧបករណ៍បោះពុម្ពបានជួយដល់ការរីកសាយភាយនៃគំនិតមនុស្សនិយមនៅពាសពេញអឺរ៉ុប។ អ្នកប្រាជ្ញអឺរ៉ុបក៏ចាប់ផ្ដើមនៅក្នុងចោទជាសំណួរសម្រាប់ការសិក្សាពីបុរាណ។ មិនយូរប៉ុន្មានគំនិតថ្មីមួយអំពីការស៊ើបអង្កេតបានលេចឡើងនៅអឺរ៉ុប។ បដិវត្តនៅក្នុងវិស័យសិល្បៈអំឡុងបុនសម័យក៏បានជះឥទ្ធិពលលើវិទ្យាសាស្ត្រផងដែរ។ វិចិត្រករចង់បង្ហាញអំពីប្រធានបទរបស់ពួកគេនៅក្នុងវិធីពិតប្រាកដមួយ។ ដើម្បីធ្វើដូច្នេះ ពួកគេបានធ្វើការអង្កេតយ៉ាងយកចិត្តទុកដាក់លើមនុស្ស និងសត្វ។ អ្នកមួយចំនួនថែមទាំងបានធ្វើកោសល្យវិច័យលើសពមនុស្សទៀតផង។ ការសិក្សាដោយប្រុងប្រយ័ត្ននាំទៅដល់ចំណេះដឹងវិទ្យាសាស្ត្រកាន់តែត្រឹមត្រូវមួយអំពីកាយវិទ្យារបស់មនុស្ស។ អំឡុងបុនសម័យ ពួកអឺរ៉ុបបានស្វែងរកផ្លូវថ្មីមួយទៅកាន់អាស៊ី (អ្នកនឹងបានសិក្សាអំពីដំណើរនៃការរុករកនេះនៅក្នុងមេរៀនទី 2)។ ដំណើរទាំងនេះបានបង្កើនចំណេះដឹងអំពីទ្រង់ទ្រាយ, ទំហំ, និងអាកាសធាតុរបស់ផែនដី។ ចំណេះដឹងថ្មីនេះមួយចំនួនបានប្រឆាំងជាមួយគំនិតបុរាណ។

វិភាគអំពីឥទ្ធិពល៖ ពន្យល់ពីឥទ្ធិពលរបស់បុនសម័យលើវិទ្យាសាស្ត្រ។

## 2. **ភាពរីកចម្រើននៃវិទ្យាសាស្ត្រ**

សំណួរគន្លឹះ៖ តើគំនិត និងការបង្កើតថ្មីអ្វីខ្លះដែលអ្នកវិទ្យាសាស្ត្របានអភិវឌ្ឍឡើងអំឡុងទសវត្សរ៍ឆ្នាំ 1500 ដល់ 1700 ?

រងឥទ្ធិពលពីមនុស្សនិយម អ្នកប្រាជ្ញនៅក្នុងទសវត្សរ៍ឆ្នាំ 1500 បានចាប់ផ្ដើមមានចម្ងល់អំពីគំនិតវិទ្យាសាស្ត្របុរាណ និងជំនឿគ្រីស្តសាសនា។ ចម្ងល់អំពីទ្រឹស្ដីចាស់ត្រូវបានគេស្គាល់ថា បដិវត្តវិទ្យាសាស្ត្រ។ ការផ្លាស់ប្ដូរនៅក្នុងការគិតនេះបាននាំទៅដល់ការផ្ទុះឡើងនៃគំនិតថ្មីៗ។

ការបង្កើតថ្មីបែបវិទ្យាសាស្ត្រ៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1600 និង 1700 ការស៊ើបអង្កេតបែបវិទ្យាសាស្ត្រត្រូវបានធ្វើឱ្យកាន់តែងាយស្រួលជាងមុនតាមរយៈការបង្កើតឧបករណ៍ថ្មីៗ។ នៅក្នុងចំណោមនោះមានអតិសុខុមទស្សន៍, ប្រដាប់ស្ទង់កម្ដៅ, និងប្រដាប់ស្ទង់ធាតុអាកាស។ នៅក្នុងទសវត្សរ៍ឆ្នាំ 1670 អ្នកវិទ្យាសាស្ត្រហូឡង់មួយរូបឈ្មោះ អានតុន វ៉ាន់ ឡៀវិនហុកបានបង្កើតអតិសុខុមទស្សន៍មួយ។ បំពង់លម្ហិននេះបានផ្ទុកនូវកញ្ចក់កោងដែលពង្រីករបស់ផ្សេងៗបានចន្លោះពី 50 ទៅ 300 ដង។ ដោយប្រើអតិសុខុមទស្សន៍ វ៉ាន់ ឡៀវិនហុកបានអង្កេតបាក់តេរី ឬរបស់តូចៗដែលមានចលនានៅក្នុងវត្ថុរាវ។ លោកក៏បានអង្កេតពីការហូរនៃឈាមតាមរយៈសសៃឈាមតូចៗដែលគេហៅថាសសៃឈាម។ នៅដើមទសវត្សរ៍ឆ្នាំ 1600 អ្នកវិទ្យាសាស្ត្រអ៊ីតាលីឈ្មោះហ្គាលីឡេអូ ហ្គាលីឡេ (1564-1642) បានបង្កើតប្រដាប់ស្ទង់កម្ដៅ ជាឧបករណ៍មួយសម្រាប់វាស់សីតុណ្ហភាព។ ប្រដាប់ស្ទង់កម្ដៅរបស់ហ្គាលីឡេអូ គឺជាបំពង់កែវមួយដែលមានដុំរាងដូចខ្ទឹមបារាំងផ្ទុកទឹកនៅខាងក្នុង។ នៅពេលដែលក្ដៅដុំរាងដូចខ្ទឹមបារាំងនោះអណ្ដែតទៅខាងលើ និងពេលដែលត្រជាក់វាធ្លាក់ទៅខាងក្រោម។ ប្រមាណជា 100 ឆ្នាំក្រោយមក នៅក្នុងឆ្នាំ 1714 អ្នកវិទ្យាសាស្ត្រអាឡឺម៉ង់ឈ្មោះហ្គាប្រ៊ីល ដានីល ហ្វារ៉ែនហៃ បានបង្កើតប្រដាប់ស្ទង់កម្ដៅបារតជាលើដំបូង។ លោកក៏បានបង្កើតឱ្យមានប្រព័ន្ធវាស់សីតុណ្ហភាពផ្លូវការជាលើកដំបូងផងដែរ។ កម្រិតនៃការវាល់ហ្វារ៉ែនហៃ

បានបង្ហាញពីទឹកកកនៅសីតុណ្ហភាព 32° និងទឹកពុះនៅកម្រិត 212°។ នៅក្នុងឆ្នាំ 1643 មិត្តភ័ក្តិ និងជាអ្នកគាំទ្រម្នាក់របស់ហ្គាលីឡេអូឈ្មោះអេវ៉ាន់ជេលីស្តា តូរីសេលលី បានបង្កើតប្រដាប់ស្ទង់ធាតុអាកាស។ ឧបករណ៍នេះបានវាស់ពីសំពាធបរិយាកាសរបស់ផែនដី។ ក្រោយមក អ្នកវិទ្យាសាស្ត្របានប្រើប្រាស់ប្រដាប់ស្ទង់ធាតុអាកាសដើម្បីព្យាករណ៍ពីអាកាសធាតុ។

ចក្រវាលដែលមានព្រះអាទិត្យស្ថិតនៅកណ្តាល៖ នៅដើមទសវត្សរ៍ឆ្នាំ 1500 តារាវិទូប៉ូឡូញឈ្មោះនីកូឡៅ កូផ័រនីគូស បានប្រជែងជាមួយនឹងទ្រឹស្តីផែនដីជាចំណុចកណ្តាលនៃចក្រវាលរបស់ផ្តូលេមី។ កូផ័រនីគូសបានពន្យល់ថា តារា, ផែនដី, និងប្រហែលជាភពផ្សេងៗធ្វើចលនានៅជុំវិញព្រះអាទិត្យដែលនៅស្ងៀម។ ការយល់ឃើញរបស់កូផ័រនីគូសអំពីចក្រវាលត្រូវបានគេស្គាល់ថាទ្រឹស្តីព្រះអាទិត្យស្ថិតនៅកណ្តាលចក្រវាល។ វាគឺជាជំនឿមួយដែលថាព្រះអាទិត្យស្ថិតនៅចំកណ្តាលនៃចក្រវាល។ ជិត 100 ឆ្នាំក្រោយមកតារាវិទូអាឡឺម៉ង់ឈ្មោះចូហ៊ាននេស កែបលឺបានបង្កើតទ្រឹស្តីរបស់កូផ័រនីគូស និងបានធ្វើឱ្យវាកាន់តែត្រឹមត្រូវ។ កែបលឺបានប្រើប្រាស់ច្បាប់គណិតសាស្ត្រដើម្បីបង្ហាញថាភពនានាពិតជាបានធ្វើចលនានៅជុំវិញព្រះអាទិត្យ។ ច្បាប់មួយបង្ហាញថាភពនានាបានធ្វើចលនាលើកន្លងរាងពងក្រពើមិនមែនរាងមូលដូចដែលកូផ័រនីគូសយល់ឃើញឡើយ។

ហ្គាលីឡេអូប្រជែងជាមួយជំនឿ៖ ហ្គាលីឡេអូបានធ្វើឱ្យវិទ្យាសាស្ត្រមានភាពជឿលឿន ដែលប្រជែងជាមួយគំនិតបុរាណ។ បន្ទាប់ពីដឹងថាអ្នកបង្កើតកញ្ចក់ជនជាតិហូឡង់ម្នាក់បានបង្កើតឧបករណ៍មួយដែលអាចពង្រីក និងបង្រួមវត្ថុនានាបាន ហ្គាលីឡេអូបានបង្កើតកែវយឺតមួយផ្ទាល់របស់លោក។ ការអង្កេតដែលលោកបានធ្វើជាមួយនឹងកែវយឺតបានបង្ហាញយ៉ាងច្បាស់ពីភាពត្រឹមត្រូវនៃគំនិតរបស់កូផ័រនីគូស។ ប៉ុន្តែ នៅក្នុងការសន្និដ្ឋានរបស់លោកបាននាំលោកទៅរកជម្លោះជាមួយព្រះវិហារគ្រិស្តសាសនា។ ការយល់ឃើញរបស់កូផ័រនីគូសផ្ទុយជាមួយនឹងជំនឿរបស់មន្ត្រីព្រះវិហារគ្រិស្តសាសនាដែលបាននិយាយថា ចក្រវាលគឺមានផែនដីជាចំណុចកណ្តាល មិនមែនព្រះអាទិត្យជាចំណុចកណ្តាលឡើយ។ ជាលទ្ធផល មេដឹកនាំព្រះវិហារគ្រិស្តសាសនាបានប្រកាសបដិសេធចំពោះទ្រឹស្តីរបស់ហ្គាលីឡេអូ។ ពួកគេបានបង្ខំឱ្យលោកប្រកាសបដិសេធការរកឃើញរបស់លោកជាសាធារណៈ។ ប៉ុន្តែ ហ្គាលីឡេអូដឹងថាទ្រឹស្តីនេះគឺជារឿងដែលត្រឹមត្រូវ ហើយអ្នកវិទ្យាសាស្ត្រដទៃទៀតក៏យល់ឃើញដូច្នេះដែរ។

ច្បាប់សកលរបស់ញ៉ូវតុន៖ នៅចុងទសវត្សរ៍ឆ្នាំ 1600 អ្នកវិទ្យាសាស្ត្រអង់គ្លេសលោកអ៊ីសាក ញ៉ូវតុន បានរួមបញ្ចូលគ្នានូវគំនិតរបស់កូផ័រនីគូស, កែបឡឺ, និងហ្គាលីឡេអូទៅក្នុងទ្រឹស្តីតែមួយ។ ទ្រឹស្តីនេះបានលើកឡើងថា វត្ថុដែលមានរូបរាងទាំងអស់ទទួលរងឥទ្ធិពលដោយកម្លាំងដូចគ្នាមួយគឺទំនាញ។ កម្លាំងធម្មជាតិនេះហាក់ដូចជាទាញវត្ថុទាំងឡាយឱ្យខិតជិតគ្នា។ ទំនាញគឺជាកម្លាំងដែលរក្សាការវិលរបស់ភពនានាជុំវិញព្រះអាទិត្យ។ វាក៏បានរក្សាមនុស្សមិនឱ្យហោះឡើងផុតពីផ្ទៃផែនដីទៅកាន់លំហ។ ខណៈពេលដែលទំនាញមានអំពើលើវត្ថុទាំងអស់នៅក្នុងចក្រវាល ញ៉ូវតុនបានហៅទ្រឹស្តីរបស់លោកថាច្បាប់នៃទំនាញសកល។

ការរកឃើញក្នុងផ្នែកវេជ្ជសាស្ត្រ៖ អ្នកវិទ្យាសាស្ត្រមួយចំនួនសំលឹងទៅរកចំណេះដឹងអំពីចក្រវាល។ ចំណែកឯអ្នកវិទ្យាសាស្ត្រដ៏ទៃទៀតចង់ដឹងថាតើខ្លួនមនុស្សដំណើរការដោយរបៀបណា។ នៅក្នុងឆ្នាំ 1628 រូបវិទូអង់គ្លេសឈ្មោះ

វីលៀម ហាដវ៉េ បានបោះពុម្ពការពិពណ៌នាដ៏ត្រឹមត្រូវមួយអំពីវិធីដែលឈាមចរាចរនៅក្នុងខ្លួនមនុស្ស។ ការរកឃើញរបស់លោកបានផ្អែកលើការវះកាត់អង្កេតអាការៈខាងក្នុងខ្លួនមនុស្សដែលលោកបានអនុវត្ត។ ការអង្កេតរបស់លោកបានបង្ហាញថាបេះដូង មិនមែនថ្លើមដូចដែលលោកហ្គាលេនធ្លាប់ជឿនោះទេ ដែលជាអ្នកច្របាច់ឈាមទៅកាន់អាវៈយវៈនានា។

សង្ខេប៖ គំនិតពីការបង្កើត និងគំនិតថ្មីៗដែលអ្នកវិទ្យាសាស្ត្របានអភិវឌ្ឍរវាងឆ្នាំ 1500 ដល់ 1700 ។

## 3. វិធីសាស្ត្របែបវិទ្យាសាស្ត្រ

សំណួរគន្លឹះ៖ តើសនិទាននិយមបែបវិទ្យាសាស្ត្រជះឥទ្ធិពលយ៉ាងដូចម្តេចដល់នយោបាយ ?

នៅក្នុងទសវត្សរ៍ឆ្នាំ 1600 ទស្សនវិទូចំនួនពីររូបឈ្មោះរេនេ ដេសខារតេស និងហ្វ្រង់ស៊ីស បាខុន បានជះឥទ្ធិពលយ៉ាងខ្លាំងមួយអំពីវិធីដែលអ្នកវិទ្យាសាស្ត្រសិក្សាពីពិភពលោក។

ដេសខារតេស និងបាខុន៖ ជនជាតិបារាំងឈ្មោះរេនេ ដេសខារតេសជឿថាគំនិតទាំងអស់ត្រូវតែស្ថិតនៅក្នុងមន្ទិលរហូតដល់វាត្រូវបានបង្ហាញថាត្រឹមត្រូវតាមរយៈហេតុផល។ ដេសខារតេសផ្អែកវិធីសាស្ត្ររបស់លោកលើឃ្លាសាមញ្ញមួយ៖ "ខ្ញុំគិត, ដូច្នេះខ្ញុំដឹងថាខ្ញុំជានរណា"។ លោកអះអាងថាព្រះជាម្ចាស់បានបង្កើតភាពពិតប្រាដកចំនួនពីរ។ ទីមួយគឺភាពពិតប្រាកដនៃរូបរាងខាងក្រៅ។ មួយទៀតគឺភាពពិតប្រាកដនៅក្នុងចិត្តរបស់មនុស្ស។ ដេសខារតេសអះអាងថាមនុស្សអាចប្រើប្រាស់គំនិតរបស់ពួកគេដើម្បីយល់ដឹងពីពិភពរូបរាងខាងក្រៅ។ ជនជាតិអង់គ្លេសឈ្មោះហ្វ្រង់ស៊ីស បាខុនក៏ជឿជាក់នៅក្នុងការប្រើប្រាស់គំនិតបែបសនិទាន។ ប៉ុន្តែ បាខុនយល់ថាអ្នកវិទ្យាសាស្ត្រគួរតែប្រើប្រាស់ការពិសោធន៍ និងការអង្កេតជាជាងប្រើប្រាស់ហេតុផលសុទ្ធសាធដើម្បីយល់ដឹងពីពិភពលោក។ វិទ្យាសាស្ត្រសនិទានរបស់បាខុនបានបង្កើតឱ្យមានមូលដ្ឋានគ្រឹះមួយដែលបច្ចុប្បន្នត្រូវបានគេស្គាល់ថាវិធីសាស្ត្របែបវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្របែបវិទ្យាសាស្ត្រមានជំហានជាក់លាក់ដោយរួមមានទាំងការអង្កេត, សាកល្បង, វិភាគ, និងវាយតម្លៃ។

សនិទាននិយមបែបវិទ្យាសាស្ត្រ៖ គំនិតរបស់ដេសខារតេស និងបាខុនត្រូវបានគេស្គាល់ថាសនិទាននិយមបែបវិទ្យាសាស្ត្រ។ ត្រឹមទសវត្សរ៍ឆ្នាំ 1700 ឥទ្ធិពលនៃសនិទាននិយមបែបវិទ្យាសាស្ត្របានចាប់ផ្តើមកាត់បន្ថយអំណាចរបស់ព្រះវិហារគ្រីស្តសាសនា។ ហេតុអ្វីបានជារឿងនេះកើតមានឡើង ? សនិទាននិយមបែបវិទ្យាសាស្ត្របានលើកទឹកចិត្តមនុស្សឱ្យគិតដោយខ្លួនពួកគេផ្ទាល់ ជាជាងពឹងផ្អែកលើអំណាចរបស់ព្រះវិហារគ្រីស្តសាសនា។ អ្នកទស្សនននយោបាយមួយចំនួនបានអនុវត្តសនិទាននិយមបែបវិទ្យាសាស្ត្រនៅក្នុងរដ្ឋាភិបាល។ ឧទាហរណ៍ អ្នកទស្សនននយោបាយឈ្មោះចន ឡុកជឿជាក់ថាមនុស្សមានសមត្ថភាពធម្មជាតិនៅក្នុងទទួលខុសត្រូវលើកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេ។ លោកយល់ឃើញសមត្ថភាពនេះថាជាច្បាប់ធម្មជាតិ ឬសិទ្ធិ។ ជាជំនឿមួយដែលបានបណ្តុះគ្រាប់ពូជប្រជាធិបតេយ្យ ដែលបានលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងប្រទេសមួយចំនួនដូចជាសហរដ្ឋអាមេរិកជាដើម។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពន្យល់ពីរបៀបដែលសនិទាននិយមបែបវិទ្យាសាស្ត្រជះឥទ្ធិពលលើនយោបាយ?

# មេរៀនទី 2៖ យុគសម័យនៃការរុករក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ការបង្កើតថ្មី និងគំនិតអំពីការស៊ើបអង្កេតបានជួយនាំទៅដល់ការរកឃើញបែបវិទ្យាសាស្រ្តជាច្រើន។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីវិធីដែលការអភិវឌ្ឍវិទ្យាសាស្រ្ត និងភាពចង់បានទ្រព្យសម្បត្តិ នាំទៅដល់យុគសម័យនៃការរុករកមួយ។

## 1. ព័រទុយហ្គាល់នាំផ្លូវ

សំណួរគន្លឹះ៖ តើបច្ចេកវិទ្យាអ្វីដែលបានជួយដល់ការរុករករបស់ពួកព័រទុយហ្គាល់?

ចាប់តាំងពីយុគកណ្តាលមក ពួកអឺរ៉ុបប្រាថ្នាចង់បានទំនិញប្រណិតៗដូចជាសូត្រ និងគ្រឿងទេសពីអាស៊ី។ អំឡុងសម័យនោះ ពាណិជ្ជករអ៊ីតាលី និងម៉ូស្លីមបានត្រួតត្រាលើការធ្វើពាណិជ្ជកម្មតាមផ្លូវគោករវាងអឺរ៉ុប និងអាស៊ី។ ពាណិជ្ជករមកពីប្រទេសមួយចំនួនដូចជាប្រទេសព័រទុយហ្គាល់, អេស្ប៉ាញ, អង់គ្លេស, និងបារាំងចង់បានចំណែកនៃការធ្វើពាណិជ្ជកម្មនេះ។ ដើម្បីទទួលបាន ពាណិជ្ជករទាំងនេះត្រូវការស្វែងរកផ្លូវសមុទ្រមួយទៅកាន់អាស៊ី។

អ្នកធ្វើដំណើរតាមផ្លូវសមុទ្រហេនរី៖ ពួកពាណិជ្ជករព័រទុយហ្គាល់គឺជាជនជាតិអឺរ៉ុបដំបូងដែលបានបង្កើតពាណិជ្ជកម្មតាមផ្លូវសមុទ្រជាមួយអាស៊ី។ ពួកគេអាចធ្វើបានដូច្នេះដោយសារមួយភាគពួកគេទទួលបានការគាំទ្ររបស់រដ្ឋាភិបាល។ ព្រះអង្គម្ចាស់ហេនរី ដែលជារាជបុត្ររបស់ស្តេចព័រទុយហ្គាល់ គឺជាអ្នកគាំទ្រដ៏ខ្លាំងក្លាលើការរុករក។ លោកបានបង្កើតសាលាមួយនៅតំបន់ឆ្នេរប្រទេសព័រទុយហ្គាល់ភាគនិរតីសម្រាប់បណ្តុះបណ្តាលអ្នកបង្កើតផែនទី, អ្នកធ្វើដំណើរតាមផ្លូវសមុទ្រ, និងអ្នកផលិតទូក។ ទ្រង់ក៏បានឧបត្ថម្ភដល់ការធ្វើដំណើររុករកនានា។ អ្នកឧបត្ថម្ភគឺជាមនុស្សម្នាក់ដែលផ្តល់លុយសម្រាប់ការធ្វើអ្វីមួយដូចជាការធ្វើដំណើរផ្សងព្រេងជាដើម។ បើទោះបីជាទ្រង់បានធ្វើដំណើរតាមនាវាបានតិចតួចក៏ដោយ ក៏ហេនរីត្រូវបានគេស្គាល់ថា "អ្នកធ្វើដំណើរតាមផ្លូវសមុទ្រ"។

## 2. បច្ចេកវិទ្យា និងការរុករក

ភាពជឿនលឿននៃបច្ចេកវិទ្យាដែលបង្កើតឡើងនៅសាលារបស់ហេនរី បានជួយដល់ការរុករករបស់ព័រទុយហ្គាល់។ ក្រុមអ្នកសាងសង់នាវាបានផលិតយ៉ាងល្អឥតខ្ចោះនូវសំពៅខារ៉ាវ៉ែល ដែលជានាវាមួយរចនាឡើងសម្រាប់ការធ្វើដំណើរផ្លូវឆ្ងាយ។ ខារ៉ាវ៉ែលមានក្តោងរាងការ៉េប្រើនៅលើនាវារបស់ពួកអឺរ៉ុប និងក្តោងត្រីកោណប្រើនៅលើនាវារបស់ពួកអារ៉ាប់។ ក្តោងរាងការ៉េបានផ្តល់ឱ្យខារ៉ាវ៉ែលនូវថាមពល ហើយក្តោងរាងត្រីកោណអនុញ្ញាតឱ្យពួកគេអាចបត់បានលឿន។ ក្រោយមកអ្នកធ្វើដំណើរព័រទុយហ្គាល់ក៏បានខ្ចីឧបករណ៍ពីតំបន់ផ្សេងៗផងដែរ។ ពួកគេតាមដានទិសដៅរបស់ពួកគេជាមួយនឹងត្រីវិស័យ ដែលជាការបង្កើតមួយរបស់ចិន។ ពួកព័រទុយហ្គាល់ក៏បានប្រើប្រាស់ប្រដាប់ស្ទង់កម្ពស់តារា ដែលត្រូវបានបង្កើតឡើងដោយក្រិកបុរាណ និងអភិវឌ្ឍដោយពួកអារ៉ាប់។ ប្រដាប់ស្ទង់កម្ពស់តារាបានវាស់មុំរបស់ផ្កាយនៅក្នុងទម្រង់ផ្តេក។ ព័ត៌មាននេះជួយដល់អ្នកធ្វើដំណើរតាមនាវារករយៈទទឹងរបស់នាវាពួកគេ ឬចម្ងាយខាងជើង ឬខាងត្បូងនៃខ្សែអេក្វាទ័រ។

ការមកដល់ឥណ្ឌា៖ ត្រឹមពេលដែលនាវិកហេនរីសុគតនៅក្នុងឆ្នាំ 1460 ព័រទុយហ្គាល់បានបង្កើតកំពង់ផែសមុទ្រនៅតាមបណ្ដោយឆ្នេរសមុទ្រអាហ្វ្រិកភាគខាងលិច។ នៅទីនោះពួកគេបានអភិវឌ្ឍការធ្វើពាណិជ្ជកម្មមាស, ភ្លុក, និងទាសករដែលទទួលបានផលចំណេញច្រើនមួយ។ ប៉ុន្តែ ភ្លាមៗនោះពួកគេបង្កើតចក្ខុវិស័យរបស់ពួកទៅហួសពីអាហ្វ្រិក។ នៅក្នុងឆ្នាំ 1488 អ្នករុករកព័រទុយហ្គាល់ឈ្មោះបាតូឡូម័រ ដៀសបានធ្វើដំណើរវង់ជុំវិញអាហ្វ្រិកភាគខាងត្បូង។ វ៉ាស្កូ ដា ហ្គាម៉ា បានពង្រីកផ្លូវដំណើររបស់ដៀស ធ្វើដំណើរឆ្ពោះទៅទិសខាងកើតទៅកាន់ប្រទេសឥណ្ឌានៅក្នុងឆ្នាំ 1498 ។ ប៉ុន្មានឆ្នាំក្រោយមក ពួកព័រទុយហ្គាល់បានបង្កើតកំពង់ផែពាណិជ្ជកម្មមួយនៅប្រទេសឥណ្ឌា។ ពួកគេបន្តធ្វើដំណើរឆ្ពោះទៅភាគខាងកើត។ ក្រោយមក ពួកគេបានបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មមួយចំនួននៅកោះគ្រឿងទេស(បច្ចុប្បន្នប្រទេសឥណ្ឌូនេស៊ី)។ ការធ្វើពាណិជ្ជកម្មតាមផ្លូវគោកពីអាស៊ីទៅកាន់អឺរ៉ុបហាក់ដូចជាមានតម្លៃថ្លៃ ដោយសារទំនិញត្រូវលើកដាក់ និងលើចុះជាច្រើនលើក។ ប៉ុន្តែ ពាណិជ្ជកម្មតាមផ្លូវសមុទ្រមានលក្ខណៈថោកជាងច្រើន។ ទំនិញមិនចាំបាច់លើកចុះឡើងច្រើនលើកឡើយ។ ជាលទ្ធផល ពួកព័រទុយហ្គាល់ចំណាយតិចសម្រាប់គ្រឿងទេស។ នៅពេលនោះ ព័រទុយហ្គាល់កគ្រប់ដណ្ដប់លើពាណិជ្ជកម្មអឺរ៉ុបជាមួយអាស៊ី។

សង្ខេប៖ កំណត់អំពីបច្ចេកវិទ្យាដែលជួយដល់ការរុករករបស់ពួកព័រទុយហ្គាល់។

### 3. កូឡុំប៊ីសទៅដល់អាមេរិក

សំណួរគន្លឹះ៖ តើកំហុសអ្វីខ្លះដែលកូឡុំប៊ីសបានបង្កើតឡើងនៅក្នុងដំណើរផ្សងព្រេងរបស់លោក?

ខណៈពេលដែលពួកព័រទុយហ្គាល់ធ្វើដំណើរទៅភាគខាងកើតដើម្បីបង្កើតផ្លូវពាណិជ្ជកម្ម នាវិកជនជាតិអ៊ីតាលីឈ្មោះគ្រីស្តូហ្វ័រ កូឡុំប៊ីសសំលឹងទៅរកការធ្វើដំណើរទៅទិសខាងលិច។ លោកសង្ឃឹមនៅក្នុងការស្វែងរកផ្លូវពីទិសខាងលិចដើម្បីទៅដល់អាស៊ី។

ការធ្វើដំណើរលើកដំបូងរបស់កូឡុំប៊ីស៖ តាមរយៈការសិក្សាលើផែនដីដែលគេបានបង្កើតឡើង និងតាមរយៈរបាយការណ៍នានា កូឡុំប៊ីសដឹងថាផែនដីមានរាងមូល។ ផ្អែកលើចំណេះដឹងនេះ កូឡុំប៊ីសគិតថាលោកអាចទៅដល់អាស៊ីដោយប្រើពេលខ្លីប្រសិនបើលោកធ្វើដំណើរតាមទិសខាងលិច ជាជាងធ្វើដំណើរតាមទិសខាងកើតវង់តាមអាហ្វ្រិក។ ប៉ុន្តែ កូឡុំប៊ីសបានគណនាខុសអំពីចម្ងាយនៅជុំវិញផែនដី។ លោកបានប៉ាន់ប្រមាណចម្ងាយនេះបានតែ ¾ នៃចម្ងាយពិតប្រាកដរបស់វា។ សម្រាប់មនុស្សជាច្រើន គំនិតរបស់កូឡុំប៊ីសធ្វើដំណើរទៅភាគខាងលិចដើម្បីទៅដល់តំបន់ខាងកើតហាក់ដូចជាមានលក្ខណៈចម្លែកបន្តិច។ ព័រទុយហ្គាល់បានបដិសេធគំនិតនេះ ដោយបន្តការធ្វើដំណើររបស់ពួកគេតាមផ្លូវទិសខាងកើតទៅកាន់អាស៊ី។ សូម្បីតែពួកអេស្ប៉ាញដែលស្រែកឃ្លាននៅក្នុងការប្រកួតប្រជែងការធ្វើពាណិជ្ជកម្មក៏មានការសង្ស័យលើរឿងនេះផងដែរ។ ប៉ុន្តែ បន្ទាប់ពីនោះបាន 6 ឆ្នាំ កូឡុំប៊ីសបានបញ្ចុះបញ្ចូលស្ដេចអេស្ប៉ាញហ្វ័រឌីណង់ និងអ៊ីសាប៊ែលដើម្បីគាំទ្រគម្រោងរបស់លោក។ នៅដើមខែសីហា ឆ្នាំ 1492 កូឡុំប៊ីសបានចេញដំណើរពីប្រទេសអេស្ប៉ាញជាមួយនឹងសំពៅការ៉ាវែលចំនួន 3 គ្រឿង និងមនុស្សចំនួន 90 នាក់។ បន្ទាប់ពីការធ្វើដំណើរជិត 10 សប្តាហ៍នៅលើសមុទ្រក្រុមនាវិករបស់កូឡុំប៊ីសបានកើនឡើងនូវក្តីបារម្ភ។

ពួកគេមិនបានឃើញដីគោកអស់រយៈពេលមួយខែ និងចង់ត្រឡប់ទៅផ្ទះវិញ។ កូឡុំបឹសបានដាក់សម្ពាធពួកគេឱ្យបន្តដំណើរទៅមុខទៀត។ បន្ទាប់មក នៅថ្ងៃទី 12 ខែតុលា នាវិកម្នាក់បានស្រែកថា "ទីអឺរ៉ា, ទីអឺរ៉ា"(ដី, ដី)។

កំហុសរបស់កូឡុំបឹស៖ កូឡុំបឹសគិតថាដែនដីនេះគឺជាឥណ្ឌា។ លោកថែមទាំងបានហៅមនុស្សទាំងនោះដែលបានស្វាគមន៍លោក និងនាវិករបស់លោកថា អ៊ីនដូស(ឥណ្ឌា)។ ជាថ្មីម្តងទៀតលោកបានប្រព្រឹត្តកំហុស។ តាមពិតលោកបានចូលសំចតនៅលើកោះមួយនៅសមុទ្រការីបៀន។ កូឡុំបឹសបានរកឃើញកោះផ្សេងៗទៀត ប៉ុន្តែមិនបានជួបប្រទះទំនិញពាណិជ្ជកម្មអ្វីឡើយ។ បើទោះបីជាដូច្នេះក៏ដោយ លោកមានការរំភើបចិត្តចំពោះការរកឃើញអ្វីដែលលោកបានគិតថាជាផ្លូវមួយមកកាន់អាស៊ី។ លោកបានបង្កើតការតាំងទីលំនៅមួយនៅលើកោះហ៊ីស្ពានីអូឡា និងបន្ទាប់មកធ្វើដំណើរត្រឡប់មកកាន់ប្រទេសអេស្ប៉ាញ។ នៅក្នុងឆ្នាំ 1504 អ្នករុករកជនជាតិអ៊ីតាលី អាមេរីហ្គូ វេសពូស៊ី គឺជាមនុស្សដំបូងដែលបង្ហាញថាដែនដីថ្មីនេះមិនមែនជាអាស៊ីឡើយ ប៉ុន្តែជាទ្វីបថ្មីមួយ។

សន្ធិសញ្ញាតូដេស៊ីឡាស៖ ហ្វ័រឌីណង់ និងអ៊ីសាប៊ែលឡាចង់ធ្វើឱ្យច្បាស់ថាព័រទុយហ្គាល់ដែលជាគូរសត្រូវពាណិជ្ជកម្មរបស់ពួកគេនឹងមិនទទួលបានអត្ថប្រយោជន៍ពីការរកឃើញរបស់កូឡុំបឹស។ ពួកព័រទុយហ្គាល់មានការភ័យខ្លាចថាប្រសិនបើកូឡុំបឹសរកឃើញផ្លូវមួយទៅកាន់អាស៊ី អេស្ប៉ាញអាចនឹងកាន់កាប់ដែនដីដែលព័រទុយហ្គាល់បានកាន់កាប់រួចហើយ។ នៅក្នុងឆ្នាំ 1494 អេស្ប៉ាញ និងព័រទុយហ្គាល់បានចុះហត្ថលេខាលើសន្ធិសញ្ញាតូដេស៊ីឡាស។ សន្ធិសញ្ញានេះបានគូសបន្ទាត់មួយពីភាគខាងជើងទៅភាគខាងត្បូងនៃពិភពលោកដើម្បីបែងចែកតំបន់ភាគខាងលិច និងភាគខាងកើត។ អេស្ប៉ាញអាចកាន់កាប់ដែនដីទាំងឡាយដែលស្ថិតនៅភាគខាងលិចនៃបន្ទាត់។ ព័រទុយហ្គាល់អាចកាន់កាប់នូវរាល់ទឹកដីដែលស្ថិតនៅភាគខាងកើត។ ការនេះបានផ្តល់ឱ្យព័រទុយហ្គាល់នៃការត្រួតត្រាតំបន់មួយនៅអាមេរិកដែលបច្ចុប្បន្នជាប្រទេសប្រេស៊ីល។

ការធ្វើដំណើរបន្ថែមទៀត៖ ហ្វ័រឌីណង់ និងអ៊ីសាប៊ែលឡាមានការពេញចិត្តជាមួយនិងលទ្ធផលនៃការធ្វើដំណើរលើកទីមួយរបស់កូឡុំបឹស។ ពួកទ្រង់បានបញ្ជូនលោកឱ្យធ្វើដំណើរចំនួន 3 លើកទៀតទៅកាន់ភាគខាងលិចដើម្បីស្វែងរកឥណ្ឌាដីគោក។ បើទោះបីជាកូឡុំបឹសបានចូលសំចតនៅលើកោះជាច្រើនក៏ដោយ លោកមិនអាចរកឃើញអ្វីដែលអាចបង្ហាញថាវាគឺជាដែនដីទ្វីបអាស៊ី។ បន្តិចម្តងៗហ្វ័រឌីណង់ និងអ៊ីសាប៊ែលឡាបានបាត់បង់ចំណាប់អារម្មណ៍លើរូបលោក។ កូឡុំបឹសស្លាប់នៅក្នុងឆ្នាំ 1506 ក្នុងនាមជាមនុស្សជូរជត់ និងឯកោរម្នាក់។ ហេតុមកទល់នឹងការស្លាប់របស់លោក លោកនៅតែទទូចថាលោកបានធ្វើដំណើរមកដល់ប្រទេសឥណ្ឌា។ ប៉ុន្តែភ្លាមៗនោះមនុស្សចាប់ផ្តើមដឹងថា កូឡុំបឹសបានស្វែងរកឃើញដែនដីធំមួយដែលពីមុនមកមិនធ្លាប់មាននណារស្គាល់វាឡើយ។

ស្វែងរកគំនិតសំខាន់៖ ពន្យល់ពីកំហុសដែលកូឡុំបឹសបានធ្វើឡើងនៅក្នុងដំណើរផ្សងព្រេងរបស់លោក។

## 4. ការរុករកបន្ទាប់ពីកូឡុំបឹស

សំណួរគន្លឹះ៖ តើការរុករកនៅអាមេរិកបានផ្លាស់ប្តូរទស្សនអំពីពិភពលោករបស់ពួកអឺរ៉ុបយ៉ាងដូចម្តេច?

បន្ទាប់ពីដំណើរផ្សងព្រេងរបស់កូឡុំបឹស ប្រទេសមួយចំនួនបានឧបត្ថម្ភដល់ដំណើររុករកទៅកាន់អាមេរិក។ អ្នករុករកជាច្រើនដូចជាកូឡុំបឹសជាដើមមានបំណងក្នុងការស្វែងរកផ្លូវឆាប់រហ័សមួយទៅកាន់អាស៊ី។ អ្នកមួយចំនួនទៀតសំលឹងទៅរកទ្រព្យសម្បត្តិ។

ការធ្វើដំណើរជុំវិញភពផែនដី៖ នៅក្នុងឆ្នាំ 1519 អេស្ប៉ាញបានឧបត្ថម្ភការធ្វើដំណើរមួយដែលដឹកនាំដោយនាវិកជនជាតិព័រទុយហ្គាល់មួយរូបឈ្មោះហ្វ័រឌីណង់ ម៉ាហ្សេឡង់។ លោកបានចាប់ដំណើរពីប្រទេសអេស្ប៉ាញជាមួយនឹងនាវាចំនួន 5 គ្រឿងនិងមនុស្សប្រមាណ 240 នាក់។ គោលបំណងរបស់លោកគឺធ្វើដំណើរជុំវិញភពផែនដី។ រហូតមកដល់ពេលដែលលោកធ្វើដំណើរ មិនមាននណារម្នាក់ធ្វើបានសម្រេចកិច្ចការនេះបានឡើយ។ ម៉ាហ្សេឡង់បានធ្វើដំណើរជុំវិញចុងភាគខាងត្បូងនៃទ្វីបអាមេរិកខាងត្បូង និងចូលទៅកាន់ដែនទឹកដ៏ធំនៃមហាសមុទ្រប៉ាស៊ីហ្វិច។ នាវារបស់លោកធ្វើដំណើរអស់រយៈពេលជាច្រើនខែដោយមិនបានតម្រុញអំពីដីគោក, ដាយថាហេតុលោកបានមកដល់ដែនកោះហ្វីលីពីន។ នៅទីនោះម៉ាហ្សេឡង់ត្រូវបានសម្លាប់នៅក្នុងការធ្វើសង្គ្រាមជាមួយប្រជាជនក្នុងតំបន់។ នាវិករបស់លោកដែលស្ថិតនៅក្រោមការដឹកនាំរបស់ ចូន សេបាស្ទៀន ដេល កាណូ បានបន្តដំណើរទៅកាន់ដែនកោះគ្រឿងទេស និងបន្ទាប់មកត្រឡប់ទៅកាន់ប្រទេសអេស្ប៉ាញវិញ។ បន្ទាប់ពីដំណើរផ្សងព្រេងអស់រយៈពេលជិត 3 ឆ្នាំមានតែនាវាចំនួនមួយគ្រឿងជាមួយនឹងសមាជិកនាវិកចំនួន 18រូបប៉ុណ្ណោះដែលបានត្រឡប់មកកាន់អេស្ប៉ាញវិញ។ ប៉ុន្តែបេសកកម្មនេះបានទទួលជោគជ័យនៅក្នុងការធ្វើដំណើរជុំវិញពិភពលោក។ ជាងនេះទៅទៀត វាគឺជាភាពជោគជ័យមួយនៃសេដ្ឋកិច្ច ដោយសារនាវាបានផ្ទុកពេញទៅដោយគ្រឿងទេសអាស៊ី។

អ្នកដណ្តើមកាន់កាប់អេស្ប៉ាញ៖ នៅដើមទសវត្សរ៍ឆ្នាំ 1500 អ្នករុករកអេស្ប៉ាញជាច្រើនបានធ្វើដំណើរទៅកាន់អាមេរិកដើម្បីស្វែងរកមាស។ ដូចដែលអ្នកបានសិក្សាហើណាន កូតេសបានដណ្តើមកាន់កាប់ចក្រភពអាតិចដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ក្នុងរយៈពេល 20 ឆ្នាំអេស្ប៉ាញបានត្រួតត្រាលើដែនដីបច្ចុប្បន្នប្រទេសម៉ិកស៊ិកកូ និងអាមេរិកកណ្តាលទាំងមូល។ ពួកអេស្ប៉ាញបានចាប់មនុស្សភាគច្រើនដែលរស់នៅក្នុងតំបន់ទាំងនេះធ្វើជាទាសករ។ ភ្លាមៗបន្ទាប់ពីនោះ ជនជាតិអេស្ប៉ាញមួយរូបទៀតឈ្មោះប្រេនស៊ីស្កូ ភីហ្សារ៉ូ បានដឹកនាំការវាយប្រហារមួយលើពួកអ៊ីនកានៅអាមេរិកខាងត្បូង។ ពួកអេស្ប៉ាញបានសម្លាប់អធិរាជរបស់ចក្រភពអ៊ីនកា ភ្លាមៗនោះចក្រភពនេះបានដួលរលំ។ ត្រឹមឆ្នាំ 1535 ពួកអេស្ប៉ាញបានត្រួតត្រាមួយភាគធំនៃដែនដីរបស់ពួកអ៊ីនកា។ ពួកអ៊ីនកាជាច្រើនបានក្លាយជាទាសករនៅក្នុងអណ្តូងរ៉ែ និងកសិដ្ឋានរបស់ពួកអេស្ប៉ាញ។

ការរុករកបន្ទាប់ទៀត៖ ការចង់បានមាសក៏បានជម្រុញឱ្យក្រុមអ្នករុករកអេស្ប៉ាញបន្តដំណើរទៅភាគខាងជើង។ នៅក្នុងឆ្នាំ 1513 ចូន ប៉ូន ដេ ឡេអនបានចូលសំចតនៅលើតំបន់ឆ្នេរសមុទ្របច្ចុប្បន្នរដ្ឋផ្លរីដា និងកាន់កាប់ដែនដីនេះ។ ចាប់ពីឆ្នាំ 1539 ដល់ 1542 ហើណានដូ ដេ សូតូបានរកឃើញដែនដីដែលបច្ចុប្បន្នដែនដីអាមេរិកភាគខាងត្បូង។ នៅក្នុងឆ្នាំ 1540 ហ្វ្រង់ស៊ីស្កូ កូរ៉ូណាដូចាប់ផ្តើមស្វែងរកតំបន់មួយដែលបច្ចុប្បន្នស្ថិតនៅអាមេរិកភាគខាងលិច។ ពួកគេមិនបានរកឃើញមាសនៅក្នុងតំបន់ទាំងអស់នេះឡើយ។ ប្រទេសអង់គ្លេស និងបារាំងបានព្យាយាមជាច្រើនលើកដើម្បីស្វែងរកផ្លូវកាត់ទៅកាន់អាស៊ី។ ពួកគេបានឧបត្ថម្ភដល់ដំណើរបេសកកម្មនានាដើម្បី

ស្វែងរកច្រកផ្លូវទឹកភាគពាយព្យ ដែលជាផ្លូវទឹកក្នុងរឿងព្រេងមួយកាត់តាមអាមេរិកខាងជើងទៅកាន់អាស៊ី។ នៅចុងទសវត្សរ៍ឆ្នាំ 1490 នាវិកជនជាតិអ៊ីតាលីឈ្មោះចន កាបុតបានដឹកនាំដំណើរផ្សងព្រេងចំនួនពីរលើកសម្រាប់ប្រទេសអង់គ្លេស។ លោកបានកាន់កាប់តំបន់ឆ្នេរដែលបច្ចុប្បន្នប្រទេសកាណាដាភាគខាងកើត និងសហរដ្ឋអាមេរិក។ ប៉ុន្តែ លោកមិនបានរកឃើញច្រកផ្លូវទឹកឡើយ។ នៅក្នុងឆ្នាំ 1524 ជីអូវ៉ាន់នី ដា វឺរ៉ាហ្សាណូ ដែលជានាវិកជនជាតិអ៊ីតាលីមួយរូបទៀតបានស្វែងរកច្រកផ្លូវទឹកភាគពាយព្យសម្រាប់ប្រទេសបារាំង។ បើទោះបីជាលោកបរាជ័យនៅក្នុងការស្វែងរកផ្លូវទៅកាន់អាស៊ីក៏ដោយ លោកបានស្វែងរកឃើញនូវដែនដីមួយដែលបច្ចុប្បន្នជាកំពង់ផែញ៉ូវយ៉ក។

ការគូសផែនទី និងទស្សនអំពីពិភពលោកថ្មីមួយ៖ ការរកឃើញនីមួយៗរបស់ក្រុមអ្នករុករកបានជួយនៅក្នុងផ្លាស់ប្តូរវិធីដែលពួកអឺរ៉ុបសំលឹងមើលពិភពលោក។ មុនដំណើរផ្សងព្រេងរបស់កូឡុំបឹស ពួកអឺរ៉ុបមើលពិភពលោកដោយផ្តោតលើសមុទ្រមេឌីទែរ៉ាណេ និងដែនដីជុំវិញប៉ុណ្ណោះ។ បន្ទាប់ពីការរុករករបស់កូឡុំបឹស ទស្សនអំពីពិភពលោករបស់ពួកអឺរ៉ុប បានលាទសន្ទឹងពីអាមេរិកនៅភាគខាងលិចមកដល់ដែនកោះគ្រឿងទេសនៅភាគខាងកើត។ ក្រុមអ្នកគូសផែនទីបានដើរតួនាទីនាំមុខមួយនៅក្នុងការផ្លាស់ប្តូរទស្សនអំពីពិភពលោកនេះ។ ផែនទីនានានៅដើមទសវត្សរ៍ឆ្នាំ 1500 ចាប់ផ្តើមបង្ហាញទ្វីបថ្មីចំនួន 2 នៅភាគខាងលិច។ អ្នកគូសផែនទីបានដាក់ឈ្មោះទ្វីបទាំងពីរនេះថា "អាមេរិក" ដោយយកតាមឈ្មោះលោកអាមេរីហ្គូ វេសពូស៊ី។ វេសពូស៊ីគឺជាមនុស្សដំបូងដែលបានរុករក និងគូសផែនទីឆ្នេរសមុទ្រនានានៅក្នុងតំបន់ទាំងនេះ។ រឿងរ៉ាវនៃដំណើររុករករបស់លោកត្រូវបានបោះពុម្ពផ្សាយនៅក្រោមចំណងជើងថា ពិភពលោកថ្មី។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពន្យល់អំពីរបៀបដែលការរុករកនៅអាមេរិកបានផ្លាស់ប្តូរទស្សនអំពីពិភពលោករបស់ពួកអឺរ៉ុប។

# មេរៀនទី 3 ៖ អាណានិគមនិយម និងការផ្លាស់ប្តូរ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ស្វែងរកទ្រព្យសម្បត្តិ និងដែនដី ប្រទេសនានានៅអឺរ៉ុបចាប់ផ្តើមរុករកអាមេរិកនៅក្នុងទសវត្សរ៍ឆ្នាំ 1500 ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីឥទ្ធិពលនៃការរុករកនេះ។

## 1. ការផ្លាស់ប្តូរទំនិញ និងគំនិត

សំណួរគន្លឹះ៖ តើការរុករកជួយដល់ការរីកសាយភាយអ្វីខ្លះ ?

ការរុករករបស់ពួកអឺរ៉ុប នាំទៅដល់ការបង្កើតឡើងនៃបណ្តាញពាណិជ្ជកម្មថ្មីរវាងទ្វីបនានានៅលើពិភពលោក។ បណ្តាញពាណិជ្ជកម្មនេះបានបង្កើនការផ្លាស់ប្តូរគំនិត និងទំនិញនៅពាសពេញពិភពលោក។

ការផ្លាស់ប្តូរកូឡុំបៀ៖ ការផ្លាស់ប្តូរកូឡុំបៀគឺជាចលនានៃការផ្លាស់ប្តូររុក្ខជាតិ និងសត្វរវាងអឌ្ឍគោលខាងកើត និងខាងលិចដោយពាណិជ្ជករអឺរ៉ុប។ ការផ្លាស់ប្តូរចាប់ផ្តើមបន្ទាប់ពីដំណើរផ្សងព្រេងរបស់កូឡុំប៊ីសទៅកាន់អាមេរិក។ ពួកអឺរ៉ុបនាំយកស្រូវសាឡី, ខ្ទឹមបារាំង, ទំពាំងបាយជូរ, អំពៅ, និងក្រូចទៅកាន់អាមេរិក។ ពីអាមេរិកពួកគេនាំយកពោត, ដំឡូងបារាំង, ល្ពៅ, និងម្ទេស។ ពួកអឺរ៉ុបក៏បាននាំយកសត្វចិញ្ចឹមនានាដូចជាសេះ និងជំងឺឆ្លងនានាដូចជាអុតស្វាយ និងកញ្ជ្រិលទៅកាន់អាមេរិក។ ជនជាតិអាមេរិកដើមមិនមានអង់ទីករប្រឆាំងជាមួយជំងឺទាំងនេះឡើយ។ ជាលទ្ធផល ជំងឺបានសម្លាប់ជនជាតិដើមអាមេរិកប្រមាណ 20 លាននាក់។

ការផ្លាស់ប្តូរទម្រង់ពាណិជ្ជកម្ម៖ ការផ្លាស់ប្តូរកូឡុំបៀបណ្តាលឱ្យមានទម្រង់ពាណិជ្ជកម្មអន្តរជាតិថ្មីៗ។ ទម្រង់ទាំងនេះគឺផ្តោតសំខាន់លើផ្លូវពាណិជ្ជកម្មតាមមហាសមុទ្ទ ដែលត្រូវបានត្រួតត្រាស្ទើរតែគ្រប់ផ្នែកទាំងអស់ដោយពួកអឺរ៉ុប។ មួយភាគធំនៃពាណិជ្ជកម្មពិភពលោកត្រូវបានជុតបញ្ឆេះដោយរ៉ែប្រាក់នៅក្នុងដែនដីអាណានិគមអេស្ប៉ាញនៅម៉ិចស៊ិចកូ និងអាមេរិកខាងត្បូង។ ប្រាក់ត្រូវបាននាំយកពីអាមេរិកទៅកាន់អឺរ៉ុប និងបន្ទាប់មកទៅកាន់ប្រទេសចិន។ ក្នុងការផ្តោះប្តូរ, ទំនិញរបស់ចិននានាដូចជាសូត្រ និងព័រហ្សឺឡែនជាដើមត្រូវបាននាំយកមកកាន់អឺរ៉ុប។ ពាណិជ្ជករអឺរ៉ុបក៏បានប្រើប្រាស់ប្រាក់ដើម្បីទិញគ្រឿងទេសពីឥណ្ឌា និងឥណ្ឌាខាងកើត។ ពាណិជ្ជកម្មមួយបែបផ្សេងទៀតត្រូវបានអភិវឌ្ឍឡើងរវាងអាមេរិក, អឺរ៉ុប, និងអាហ្វ្រិក។ ស្ករអំពៅដែលត្រូវបានដាំដុះនៅឥណ្ឌាខាងលិចត្រូវបានគេដឹកជញ្ជូនទៅកាន់អឺរ៉ុប។ កម្លាំងពលកម្មដែលត្រូវការដើម្បីផលិតស្ករអំពៅត្រូវបានផ្តល់ដោយទាសករមកពីអាហ្វ្រិក។ ទំនិញរោងចក្រថោកៗត្រូវបានគេនាំយកពីអឺរ៉ុបទៅផ្តោះប្តូរជាមួយទាសករមកពីអាហ្វ្រិក។ ពាណិជ្ជកម្មត្រីកោណឆ្លងកាត់មហាសមុទ្ទអាត្លង់តិចនេះដំណើរការអស់រយៈពេលជាង 300 ឆ្នាំ។ នៅអំឡុងពេលនោះ ទាសករអាហ្វ្រិកប្រមាណ 10 លាននាក់ត្រូវបានគេដឹកជញ្ជូនទៅកាន់អាមេរិក។

ចលនាវប្បធម៌៖ ក៏ដូចជាទំនិញដែរ គំនិតត្រូវបានផ្លាស់ប្តូររវាងទ្វីបនានា។ ឧទាហរណ៍ សកម្មភាពដំបូងរបស់ក្រុងអ្នករុករកមកពីប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល់ជាប់ទាក់ទងជាមួយសាសនា។ ពួកគេព្យាយាមនៅក្នុងការផ្លាស់ប្តូរជំនឿរបស់ប្រជាជនដើមនៅលើដែនដីដែលពួកគេកាន់កាប់ទៅជារ៉ូម៉ាំងកាតូលិក។ ពួកគ្រីស្តបរិស័ទថ្មីៗទាំងនេះបានភ្ជាប់អត្តសញ្ញាណផ្ទាល់របស់ពួកគេជាមួយនឹងជំនឿរបស់ពួកគេ។ ពួកគេធ្វើដូច្នេះតាមរយៈការ

ច្របាច់បញ្ចូលគ្នារវាងជំនឿបែបប្រពៃណី និងជំនឿគ្រីស្តសាសនា។ ជាងនេះទៅទៀត ពួកអឺរ៉ុបជារឿយៗបាននាំចូលការប្រតិបត្តិវប្បធម៌មកពីដែនដីផ្សេងៗ។ ឧទាហរណ៍ ពួកអឺរ៉ុបជាច្រើនចូលចិត្តផឹកកាហ្វេមកពីអារ៉ាប់, លាយជាមួយស្ករសផលិតដោយទាសករអាហ្វ្រិកនៅអាមេរិក។

សង្ខេប៖ ពន្យល់ថាតើមានអ្វីខ្លះដែលការរុករកជួយធ្វើឱ្យរីកសាយភាយ។

## 2. ការប្រកួតប្រជែងសម្រាប់អាណានិគម

សំណួរគន្លឹះ៖ តើពួកអឺរ៉ុបប្រកួតប្រជែងគ្នាអ្វីខ្លះសម្រាប់ដែនដីអាណានិគម?

ដូចដែលពាណិជ្ជកម្មពិភពលោកបានកើនឡើង ប្រទេសនានានៅអឺរ៉ុបបានប្រកួតប្រជែងគ្នាសម្រាប់ដែនដីអាណានិគមខាងក្រៅ។ អាណានិគមផ្តល់នូវវត្ថុធាតុដើម និងទីផ្សារ។

ព័រទុយហ្គាល់ និងអេស្ប៉ាញ៖ ដំណើរផ្សងព្រេងទៅភាគខាងកើតរបស់ព័រទុយហ្គាល់បណ្តាលឱ្យលេចឡើងកំពង់ផែពាណិជ្ជកម្មនៅអាហ្វ្រិក, ឥណ្ឌា, និងអាស៊ីបូព៌ា។ នៅអាមេរិកខាងត្បូង សន្ធិសញ្ញាតូដេសីឡាសបានផ្តល់ឱ្យព័រទុយហ្គាល់នូវការត្រួតត្រាប្រទេសប្រេស៊ីល។ អេស្ប៉ាញកាន់កាប់ដែនកោះនានានៅប៉ាស៊ីហ្វិក ដូចជាប្រទេសហ្វីលីពីនជាដើម។ ប៉ុន្តែ អេស្ប៉ាញផ្តោតសំខាន់លើដែនដីអាណានិគមរបស់ពួកគេនៅអាមេរិក។ ការជីករ៉ែប្រាក់ និងមាសនៅប្រទេសប៉េរូ និងម៉ិចស៊ិចកូ ទទួលបានផលចំណេញយ៉ាងពិសេស។

ហូឡង់, បារាំង, និងអង់គ្លេស៖ ហូឡង់មានដែនដីអាណានិគមតូចមួយនៅអាមេរិកគឺស្ថិតនៅហូឡង់ថ្មី។ ប៉ុន្តែពួកគេគ្រប់គ្រងអាណានិគមមួយភាគធំនៃឥណ្ឌាខាងកើត។ បន្តិចម្តងៗ ហូឡង់ទទួលបានជ័យជំនះនៅក្នុងការត្រួតត្រាពាណិជ្ជកម្មរវាងឥណ្ឌាខាងកើតជាមួយអឺរ៉ុប។ ក៏ដូចគ្នាដែរ ប្រទេសបារាំងសង្ឃឹមនៅក្នុងការធ្វើពាណិជ្ជកម្មនៅឥណ្ឌាខាងកើត។ នៅទីបញ្ចប់ ពួកគេបានបង្កើតមូលដ្ឋានមួយនៅក្នុងប្រទេសឥណ្ឌា។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយ ការព្យាយាមនៅក្នុងការគ្រប់គ្រងអាណានិគមរបស់ពួកគេទទួលបានជោគជ័យខ្លាំងនៅអាមេរិកខាងជើង។

នៅដើមទសវត្សរ៍ឆ្នាំ 1600 ពួកគេបានបង្កើតគេប៊ិចនៅកាណាដា។ គេប៊ិចបានក្លាយជាមូលដ្ឋាននៃចក្រភពដ៏ធំមួយ។ វាបានលាតសន្ធឹងពីកាណាដាចុះតាមទន្លេមីស៊ីស៊ីពពីទៅដល់ការីបៀន។ ជម្រុញដោយប្រទេសអឺរ៉ុបនានា អង់គ្លេសបានបង្កើតដែនដីអាណានិគមនៅអាមេរិកខាងជើង។ នៅក្នុងឆ្នាំ 1587 អង់គ្លេសបានបង្កើតដែនដីអាណានិគមមួយនៅកោះរ៉ៅណូគេដែលបច្ចុប្បន្នជាការ៉ូលីណាខាងជើង។ នៅក្នុងឆ្នាំជាមួយគ្នានោះ នាវាមួយចាកចេញពីរ៉ៅណូគេដើម្បីទទួលយកគ្រឿងផ្គត់ផ្គង់សម្រាប់អាណានិគម។ នៅពេលដែលនាវាដឹកគ្រឿងផ្គត់ផ្គង់ត្រឡប់មកវិញនៅក្នុងឆ្នាំ 1590 ក្រុមនាវិកបានរកឃើញថាកោះរ៉ៅណូគេត្រូវបានគេបោះបង់ចោល។ មិនមានដាននៃក្រុមអ្នកដាក់អាណានិគមទាំងនេះត្រូវបានគេរកឃើញឡើយ។ នៅក្នុងឆ្នាំ 1607 អង់គ្លេសបានចាប់ផ្តើមទទួលបានជោគជ័យក្នុងការដាក់អាណានិគមនៅអាមេរិកជាលើកដំបូង។ វាត្រូវបានគេហៅថាជេមថោន, នៅវឺជីននៀ។ អ្នកដាក់អាណានិគមអង់គ្លេសដំបូងមានលោកភីលគ្រីមជាដើម។ ពួកគេបានតាំងទីលំនៅនៅម៉ាសាឈូ

សេតនៅក្នុងឆ្នាំ 1620 ដើម្បីគេចពីការធ្វើទុក្ខបុកម្នេញសាសនានៅអង់គ្លេស។ អង់គ្លេសក៏បានបង្កើតមូលដ្ឋាននៅការីបបៀន និងឥណ្ឌាផងដែរ។

អាម៉ាដាអេស្ប៉ាញ៖ វត្តមានរបស់អង់គ្លេសនៅអាមេរិកបាននាំមកនូវជម្លោះជាមួយអេស្ប៉ាញ។ វាយប្រហារដោយក្រុមនាវិកអង់គ្លេសលើនាវារបស់អេស្ប៉ាញបានធ្វើឱ្យស្តេចហ្វីលីបទី 2 មានការខឹងសម្បាយ៉ាងខ្លាំង។ ដូច្នេះនៅក្នុងឆ្នាំ 1588 ទ្រង់បានបញ្ជូនកងកម្លាំងមួយក្រុមដែលមាននាវាចំនួន 130 គ្រឿងដើម្បីប្រឆាំងជាមួយអង់គ្លេស។ កងទ័ពជើងទឹកអង់គ្លេស ដែលមានទំហំធំ និងអាវុធយុទ្ធភ័ណ្ឌល្អៗ បានវាយប្រហារ និងយកជ័យជំនះលើអាម៉ាដាអេស្ប៉ាញ។ ការបរាជ័យនេះបានធ្វើឱ្យអេស្ប៉ាញចុះខ្សោយ។ ប៉ុន្តែ ពួកគេនៅតែបន្តជាមហាអំណាចអឺរ៉ុបនាំមុខគេមួយ ដោយសារតែរ៉ែមាស និងប្រាក់របស់ពួកគេនៅអាមេរិក។

ចំណាត់ថ្នាក់៖ កំណត់ពីពួកអឺរ៉ុបនានាដែលប្រកួតប្រជែងគ្នាសម្រាប់ដែនដីអាណានិគមនៅអំឡុងពេលនោះ។

### 3. ការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់អឺរ៉ុប

សំណួរគន្លឹះ៖ តើការអភិវឌ្ឍសេដ្ឋកិច្ចអ្វីខ្លះដែលបានកើតមានឡើងនៅអឺរ៉ុបបន្ទាប់ពីយុគសម័យនៃការរុករក?

ការកើនឡើងនៃការធ្វើពាណិជ្ជកម្មក្រៅប្រទេស និងទ្រព្យសម្បត្តិថ្មីមកពីដែនដីអាណានិគមបានជះឥទ្ធិពលដ៏សំខាន់មួយលើសេដ្ឋកិច្ចនៅអឺរ៉ុប។ កត្តាទាំងនេះនាំទៅដល់ការចាប់ផ្តើមឡើងនៃជំនួញ និងការធ្វើពាណិជ្ជកម្មបែបថ្មី។

ផលចំណេញនិយម៖ អំឡុងពេលនោះ គោលនយោបាយសេដ្ឋកិច្ចថ្មីមួយដែលគេហៅថាផលចំណេញនិយមបានអភិវឌ្ឍឡើងនៅអឺរ៉ុប។ គោលនយោបាយផលចំណេញនិយមលើកឡើងថាអំណាចរបស់ប្រទេសជាតិមួយពឹងលើទ្រព្យសម្បត្តិរបស់ប្រទេសនោះ។ គោលនយោបាយនេះបានស្នើឱ្យរដ្ឋាភិបាលកំណត់ប្រព័ន្ធសេដ្ឋកិច្ចមួយរបស់ជាតិ។ ដែនដីអាណានិគមបានដើរតួនាទីសំខាន់នៅក្នុងគោលនយោបាយផលចំណេញនិយម។ នៅក្នុងករណីមួយចំនួន ពួកគេបានផ្តល់ឱ្យប្រទេសម្ចាស់អាណានិគមជាមួយនឹងធនធានមាស និងប្រាក់។ ជាងនេះទៅទៀត ដែនដីអាណានិគមផ្តល់នូវវត្ថុធាតុដើមដែលប្រទេសម្ចាស់អាណានិគមប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម។ ដែនដីអាណានិគមក៏ជាទីផ្សារមួយសម្រាប់ផលិតផលសម្រេចផងដែរ។

មូលធននិយម និងសេដ្ឋកិច្ចទីផ្សារមួយ៖ លទ្ធផលមួយនៃអាណានិគមនិយម និងពាណិជ្ជកម្មគឺការកើនឡើងនៃមូលធននិយម។ មូលធននិយមគឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលផ្អែកលើកម្មសិទ្ធិឯកជនលើធនធានសេដ្ឋកិច្ច និងប្រើប្រាស់ធនធានទាំងនោះដើម្បីទទួលបានផលចំណេញ។ ពាណិជ្ជករដែលវិនិយោគជោគជ័យនៅក្នុងអាណានិគមនិយម និងពាណិជ្ជកម្មទទួលបានប្រាក់ចំណេញយ៉ាងច្រើន។ ជារឿយៗ ពួកគេទទួលបានទ្រព្យសម្បត្តិថ្មីៗទាំងនេះតាមរយៈការវិនិយោគលើជំនួញបែបប្រថុយទាំងក្រៅ និងក្នុងប្រទេស។

ត្រឹមចុងទសវត្សរ៍ 1700 ប្រជាជនមួយចំនួនមានអារម្មណ៍ថារដ្ឋាភិបាលដើរតួនាទីខ្លាំងពេកនៅក្នុងវិស័យសេដ្ឋកិច្ច។ សេដ្ឋវិទូមួយចំនួនដូចជាអាដាំស្ម៊ីតទទូចឱ្យមានគំនិតអំពីសេដ្ឋកិច្ចទីផ្សារសេរីមួយ។ នៅក្នុងស្នាដៃដ៏មានឥទ្ធិពលរបស់លោកដែលមានចំណងជើងថា ទ្រព្យសម្បត្តិរបស់ជាតិ លោកស្ម៊ីតទទូចថា ដោយមិនមានការលូក

ដៃពីសំណាក់រដ្ឋាភិបាល ទីផ្សារនឹងជានាដល់ការរីកចម្រើននៃសេដ្ឋកិច្ច។ គំនិតរបស់ស្មីតបានផ្តល់នូវគំរូមួយសម្រាប់ប្រព័ន្ធសេដ្ឋកិច្ចសម័យទំនើបរបស់សហរដ្ឋអាមេរិក។

គូសបញ្ជាក់សេចក្តីសន្និដ្ឋាន៖ ពិពណ៌នាការអភិវឌ្ឍសេដ្ឋកិច្ចដែលបានកើតមានឡើងនៅអឺរ៉ុបបន្ទាប់ពីយុគសម័យនៃការរុករក។

# ជំពូក 19 ៖ ពិភពអាត្លង់ទិក 1492-1800

## មេរៀនទី 1 ៖ អេស្ប៉ាញស្ថាបនាចក្រភពអាមេរិកមួយ

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ការប្រកួតប្រជែងដើម្បីទ្រព្យសម្បត្តិនៅក្នុងទ្វីបអាស៊ីក្នុងចំណោមប្រទេសនានានៅអឺរ៉ុបមានភាពកាចសាហាវ។ ការប្រកួតប្រជែងនេះបានជម្រុញឱ្យមេបញ្ជាការសមុទ្រនៅចេណូសឈ្មោះគ្រីស្តូហ្វ័រ កូឡុំបឹស ធ្វើដំណើរផ្សងព្រេងមួយចេញពីអេស្ប៉ាញនៅក្នុងឆ្នាំ 1492 ។ ជំនួសដោយការធ្វើដំណើរទៅភាគខាងត្បូងវង់តាមទ្វីបអាហ្វ្រិចបន្ទាប់មកធ្វើដំណើរទៅទិសខាងកើត កូឡុំបឹសបានធ្វើដំណើរតាមទិសខាងលិចឆ្លងកាត់មហាសមុទ្រអាត្លង់ទិក ដើម្បីស្វែងរកផ្លូវពាណិជ្ជកម្មមួយផ្សេងទៀតទៅកាន់អាស៊ី និងកន្លែងដែលសម្បូរទៅដោយទំនិញ។ កុំឡុំបឹសមិនដែលទៅដល់ទ្វីបអាស៊ីឡើយ។ ផ្ទុយទៅវិញ លោកបានចូលទៅដល់កោះមួយនៅតំបន់ការីបៀន។ ព្រឹត្តិការណ៍បាននាំទៅដល់ការរួមបញ្ចូនគ្នានៃប្រជាជននៅអឺរ៉ុប, អាហ្វ្រិក, និងអាមេរិក។

### 1. ការធ្វើដំណើររបស់កូឡុំបឹស

នាវានីណា, ពីនតា, និងសាន់តា ម៉ារៀ បានធ្វើដំណើរចាកចេញពីកំពង់ផែមួយរបស់អេស្ប៉ាញនៅថ្ងៃទី 3 ខែសីហា ឆ្នាំ 1492 ។ ក្នុងរយៈពេលប៉ុន្មានខែក្រោយមក នាវារបស់កូឡុំបឹសបានធ្វើដំណើរទៅដល់តំបន់ឆ្នេរមួយដែលពួកអឺរ៉ុបហៅថាពិភពមួយដ៏គួរឱ្យភ្ញាក់ផ្អើល។

ការជួបប្រទះលើកដំបូង៖ នៅព្រលឹមថ្ងៃទី 12 ខែតុលា ឆ្នាំ 1492 ការរងចាំជាយូរបានមកដល់។ ក្រុមនាវិកនាវាពីនតាបានមើលឃើញឆ្នេរសមុទ្រមួយពីចម្ងាយ។ ពួកគេបានស្រែកថា "ទីអឺរ៉ា! ទីអឺរ៉ា!" ដែលមានន័យថា "ដី! ដី!"។ នៅពេលនោះកូឡុំបឹស និងនាវិករបស់លោកបានចូលសំចតនៅលើដីគោក។ ដោយគិតថាលោកទទួលបានជោគជ័យនៅក្នុងការធ្វើដំណើរទៅដល់ឥណ្ឌាខាងកើត កូឡុំបឹសបានហៅក្រុមមនុស្សដែលតាំងទីលំនៅនៅទីនោះថា ឡូស អ៊ីនដូស។ បច្ចេកពាក្យនេះបកប្រែថា "ឥណ្ឌា" ដែលជាពាក្យមួយត្រូវបានគេប្រើខុសដើម្បីហៅប្រជាជនដើមទាំងអស់នៅអាមេរិក។ នៅក្នុងដំណើរផ្សងព្រេងរបស់លោក កូឡុំបឹសបានរៀបរាប់អំពីជំនួបដំបូងរបស់លោកជាមួយប្រជាជនដើម។ កូឡុំបឹសបានគណនាខុសពីទីតាំងដែលលោកកំពុងស្ថិតនៅ។ លោកមិនបានទៅដល់ឥណ្ឌាខាងកើតទេ។ អ្នកប្រាជ្ញនានាជឿថាលោកបានចូលសំចតនៅលើកោះមួយនៅបាហាម៉ាស់ ដែលស្ថិតនៅសមុទ្រការ៉ាបឺន។ ជនជាតិដើមនៅទីនោះមិនមែនជាជនជាតិឥណ្ឌាទេ ប៉ុន្តែពួកគេជាក្រុមមួយដែលហៅខ្លួនគេថាតៃណូ។ ដោយមិនចាំបាច់និយាយ កូឡុំបឹសបានកាន់កាប់កោះនោះសម្រាប់អេស្ប៉ាញ។ លោកបានដាក់ឈ្មោះកោះនោះថាសាន់សាលវ៉ាឌ័រ ឬ "អ្នកជួយសង្គ្រោះដ៏ពិសិដ្ឋ"។ ក៏ដូចជាអ្នករុករកផ្សេងៗទៀតដែរ កូឡុំបឹសមានចំណាប់អារម្មណ៍ទៅលើមាស។ ដោយរកមិនឃើញមានមាសនៅលើកោះសាន់សាលវ៉ាឌ័រ លោកបានរុករកកោះផ្សេងៗទៀត ដោយអះអាងពីការកាន់កាប់របស់លោកពីកោះមួយទៅកោះមួយ។ លោកបានសរសេរថា "វាគឺជាក្តីប្រាថ្នារបស់ខ្ញុំដែលថាមិនមានកោះណាមួយដែលខ្ញុំមិនបានកាន់កាប់ឡើយ"។ នៅដើមឆ្នាំ 1493 កូឡុំបឹសបានត្រឡប់មកកាន់ប្រទេសអេស្ប៉ាញវិញ។ របាយការណ៍ដែលលោករម្លឹកពីដំណើរផ្សងព្រេងរបស់លោកបានធ្វើឱ្យ

ស្តេចអេស្ប៉ាញមានការសប្បាយចិត្តក្រៃលែង។ មេដឹកនាំអេស្ប៉ាញ អ្នកដែលបានឧបត្ថម្ភដល់ការធ្វើដំណើរលើកដំបូងរបស់លោក បានយល់ព្រមនៅក្នុងការផ្តល់ហិរញ្ញវត្ថុសម្រាប់ការធ្វើដំណើរចំនួន 3 លើកទៀត។ កូឡំបឹសបានធ្វើដំណើរលើកទី 2 របស់លោកទៅកាន់អាមេរិកនៅក្នុងខែកញ្ញា ឆ្នាំ 1493 ។ ដំណើរផ្សងព្រេងរបស់លោកមិនមែនជាដំណើរដើម្បីរុករកទៀតឡើយ ប៉ុន្តែជាដំណើរដើម្បីស្ថាបនាចក្រភពមួយ។ លោកបានដឹកនាំការធ្វើដំណើរមួយដែលមាននាវាចំនួន 17 គ្រឿងដោយនាំយកកងទាហាន, នាវិក, និងអាណានិគមជនចំនួនជាង 1,000 នាក់។ អេស្ប៉ាញមានបំណងនៅក្នុងការប្រែក្លាយកោះនានានៅសមុទ្រការ៉ាប៊ីនឱ្យក្លាយជាដែនដីអាណានិគម ឬដែនដីនានាដែលត្រួតត្រាដោយប្រទេសមួយផ្សេងទៀត។ ជាង 2 សតវត្សរ៍បន្ទាប់ ក្រុមអ្នករុករកអឺរ៉ុបផ្សេងៗទៀតបានចាប់ផ្តើមធ្វើដំណើរឆ្លងមហាសមុទ្រអាត្លង់ទិកដើម្បីស្វែងរកដែនដីថ្មីដើម្បីកាន់កាប់។

ក្រុមអ្នករុករកផ្សេងៗទៀតចាប់ផ្តើមចុះសមុទ្រ៖ នៅក្នុងឆ្នាំ 1500 អ្នករុករកព័ទុយហ្គាល់ឈ្មោះពេដ្រូ អាលវ៉ារេស កាប្រាល់បានធ្វើដំណើរមកដល់តំបន់ឆ្នេរសមុទ្រមួយបច្ចុប្បន្នប្រទេសប្រេស៊ីល និងបានអះអាងពីការកាន់កាប់ដែនដីនេះសម្រាប់ប្រទេសរបស់លោក។ មួយឆ្នាំក្រោយមក អាមេរិហ្គូ វេសពូស៊ី ដែលជាជនជាតិអ៊ីតាលីធ្វើការឱ្យព័ទុយហ្គាល់ក៏បានធ្វើដំណើរតាមបណ្តោយឆ្នេរសមុទ្រភាគខាងកើតអាមេរិកខាងត្បូង។ នៅពេលដែលលោកត្រឡប់មកកាន់អឺរ៉ុបវិញ លោកបានអះអាងថាដែនដីនេះមិនមែនជាផ្នែកមួយនៃអាស៊ីឡើយ ប៉ុន្តែវាគឺជាពិភពថ្មីមួយ។ នៅក្នុងឆ្នាំ 1507 អ្នកផលិតផែនទីជនជាតិអាឡឺម៉ង់មួយរូបបានដាក់ឈ្មោះទ្វីបថ្មីនេះថា "អាមេរិក" ជាការផ្តល់កិត្តិយសសម្រាប់អាមេរិហ្គូ វេសពូស៊ី។ នៅក្នុងឆ្នាំ 1519 អ្នករុករកជនជាតិព័ទុយហ្គាល់ឈ្មោះហ្វ័រឌីណាង់ម៉ាហ្សេឡង់បានដឹកនាំការរុករកដ៏អង់អាចមួយដែលមិនធ្លាប់មាន។ កាលពីប៉ុន្មានឆ្នាំមុន អ្នករុករកជនជាតិអេស្ប៉ាញឈ្មោះវ៉ាស្កូ នូនេស ដេ បាល់បាវបានធ្វើដំណើរកាត់តំបន់មួយដែលបច្ចុប្បន្នប្រទេសប៉ាណាម៉ា និងបានក្លាយជាជនជាតិអឺរ៉ុបដំបូងដែលបានធ្វើដំណើរទៅដល់មហាសមុទ្រប៉ាស៊ីហ្វិក។ ភ្លាមៗបន្ទាប់ពីនោះ ម៉ាហ្សេឡង់បានបញ្ចុះបញ្ចូលស្តេចអេស្ប៉ាញឱ្យឧបត្ថម្ភដំណើរផ្សងព្រេងរបស់លោកទៅកាន់មហាសមុទ្រដែលទើបរកឃើញថ្មី។

ជាមួយនឹងមនុស្សចំនួន 250 នាក់ និងនាវាចំនួន 5 គ្រឿង ម៉ាហ្សេឡង់បានធ្វើដំណើរជុំវិញតំបន់ចុងភាគខាងត្បូងនៃអាមេរិកខាងត្បូង និងបានធ្វើដំណើរទៅដល់ដែនទឹកមហាសមុទ្រប៉ាស៊ីហ្វិក។ នាវាបានធ្វើដំណើរជាច្រើនខែដោយមិនបានប្រទះដីគោក លើកលែងតែកោះតូចៗមួយចំនួន។ ស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ចាប់ផ្តើមអស់។ បន្ទាប់ពីការរកឃើញកោះហ្គាំ ម៉ាហ្សេឡង់ និងនាវិករបស់លោកបន្តិចម្តងៗបានធ្វើដំណើរទៅដល់ប្រទេសហ្វីលីពីន។ ជាអកុសល ម៉ាហ្សេឡង់បានចូលរួមនៅក្នុងសង្គ្រាមជាមួយមនុស្សនៅក្នុងតំបន់មួយ ហើយលោកត្រូវបានសម្លាប់នៅក្នុងសង្គ្រាមនោះ។ នាវិករបស់លោក ដែលត្រូវបានកាត់បន្ថយយ៉ាងច្រើនដោយសារជំងឺ និងគ្រោះអត់ឃ្លាន បានបន្តធ្វើដំណើរឆ្ពោះទៅភាគខាងលិចដើម្បីត្រឡប់ទៅអេស្ប៉ាញវិញ។ ក្នុងចំណោមនាវិករបស់ម៉ាហ្សេឡង់ចំនួន 250 នាក់ មានតែ 18 នាក់ និងនាវាមួយគ្រឿងប៉ុណ្ណោះដែលបានមកដល់អេស្ប៉ាញវិញនៅក្នុងឆ្នាំ 1522 ដែលមានរយៈពេលជិត 3 ឆ្នាំបន្ទាប់ពីការចាកចេញ។ ពួកគេគឺជាមនុស្សដំបូងដែលបានធ្វើដំណើរជុំវិញផែនដី។

## 2. អេស្ប៉ាញដណ្តើមកាន់កាប់ម៉ិកស៊ិកកូ

នៅក្នុងឆ្នាំ 1519 ដូចដែលម៉ាហ្សេឡង់បានចាប់ផ្តើមដំណើរផ្សងព្រេងជាប្រវត្តិសាស្ត្ររបស់លោក ជនជាតិអេស្ប៉ាញមួយរូបឈ្មោះហឺណាន់ដូ កូតេស បានចូលសំចតនៅតំបន់ឆ្នេរម៉ិកស៊ិកកូ។ បន្ទាប់ពីគ្រប់គ្រងអាណានិគមលើកោះមួយចំនួននៅសមុទ្ទការីប៊ីនមក អេស្ប៉ាញបានផ្តោតការយកចិត្តទុកដាក់របស់ពួកគេលើដែនដីគោកអាមេរិក។ កូតេសបានធ្វើដំណើរឡើងដីគោក ដើម្បីស្វែងរកការកាន់កាប់ដែនដីថ្មីសម្រាប់អេស្ប៉ាញ។ កូតេស និងអ្នករុករកជនជាតិអេស្ប៉ាញជាច្រើនទៀត ដែលបន្តតាមលោកត្រូវបានគេស្គាល់ថាក្រុមអ្នកដណ្តើមកាន់កាប់។ បោកបញ្ឆោតដោយពាក្យចចាមអារ៉ាមថាដែនដីនេះសម្បូរទៅដល់មាស និងប្រាក់ ក្រុមអ្នកដណ្តើមកាន់កាប់បានត្រួសត្រាយអាណានិគមនៅលើតំបន់មួយចំនួនដែលនឹងក្លាយជាប្រទេសម៉ិកស៊ិកកូ, អាមេរិកខាងត្បូង, និងសហរដ្ឋអាមេរិក។ ពួកអេស្ប៉ាញគឺជនជាតិអឺរ៉ុបដំបូងដែលបានតាំងទីលំនៅនៅអាមេរិក។ ជាលទ្ធផលនៃការដាក់អាណានិគមរបស់ពួកគេ អេស្ប៉ាញបានពង្រីកដែនដីអាណានិគមរបស់ពួកគេយ៉ាងធំ និងបានបន្សល់ទុកនូវសញ្ញាណវប្បធម៌នៅអាមេរិកខាងជើង និងអាមេរិកខាងត្បូងរហូតមកដល់បច្ចុប្បន្ន។

កូតេសដណ្តើមកាន់កាប់អាតិច៖ ភ្លាមៗបន្ទាប់ពីចូលសំចតនៅម៉ិកស៊ិកកូ កូតេសបានដឹងថាមានចក្រភពអាតិចដែលធំ និងមានទ្រព្យសម្បត្តិស្តុកស្តម្ភនៅដែនដីខាងក្នុង។ បន្ទាប់ពីធ្វើដំណើរអស់ជាច្រើនសប្តាហ៍កាប់តាមច្រកភ្នំដ៏លំបាក កូតេស និងកងកម្លាំងរបស់លោកដែលមានគ្នាប្រមាណ 600 នាក់ចុងក្រោយបានមកដល់តេណូចទីតឡានដែលរាជធានីសំខាន់របស់អាតិច។ អធិរាជអាតិចព្រះនាមមុនតេហ្ស៊ូម៉ាទី 2 ដំបូងឡើយត្រូវបានធ្វើឱ្យជឿថាកូតេសគឺជាក្រុមអ្នកប្រយុទ្ធពាក់អាវក្រោះធ្វើពីមាស។ ទ្រង់បានយល់ព្រមនៅក្នុងចែករំលែកឱ្យក្រុមអ្នករុករកអេស្ប៉ាញនូវមាសដែលចក្រភពមាន។ ពួកអ្នកដណ្តើមកាន់កាប់មិនបានស្តាប់ចិត្តចំពោះការចែករំលែងនេះឡើយ។ កូតេសអះអាងថាលោក និងយុទ្ធជនរបស់លោកមានជំងឺបេះដូងម្យ៉ាង ដែលមានតែមាសតែដែលអាចព្យាបាលជា។ នៅចុងរដូវរំហើយ ឆ្នាំ 1520 កងទ័ពមួយចំនួនរបស់កូតេសបានសម្លាប់ក្រុមអ្នកប្រយុទ្ធ និងស្តេចត្រាញ់ជាច្រើនរបស់អាតិចនៅខណៈពេលដែលពួកគេកំពុងប្រារព្ធពិធីសាសនាមួយ។ នៅក្នុងខែមិថុនា ឆ្នាំ 1520 អាតិចបានងើបឡើងបះបោរប្រឆាំងជាមួយក្រុមអ្នកឈ្លានពានអេស្ប៉ាញ និងបានបណ្តេញកងកម្លាំងរបស់កូតេសចេញពីទីនោះ។ ប៉ុន្តែ ពួកអេស្ប៉ាញបានវាយបកវិញ។ បើទោះបីជាកងទ័ពមានចំនួនតិចជាងពួកអាតិចក៏ដោយ កូតេស និងកងកម្លាំងរបស់លោកបានដណ្តើមកាន់កាប់អាតិចនៅក្នុងឆ្នាំ 1521 ។

មានកត្តាមួយចំនួនដែលបានដើរតួនាទីសំខាន់នៅក្នុងធ្វើឱ្យពួកអេស្ប៉ាញទទួលជ័យជំនះ។ ទីមួយគឺពួកអេស្ប៉ាញមានប្រៀបជាងដោយសារពួកគេមានអាវុធទំនើប។ គ្រាប់ព្រួញរបស់ពួកអាតិចមិនអាចប្រៀបជាមួយកាំភ្លើងច្រករំសេវ និងកាំភ្លើងធំរបស់ពួកអេស្ប៉ាញបានឡើយ។ ទីពីរ កូតេសអាចបញ្ចុះបញ្ចូលឱ្យក្រុមជនជាតិដើមមួយចំនួនជួយលោក។ ជាមួយនឹងការជួយបកប្រែរបស់ស្ត្រីជាជាតិដើមមួយរូបឈ្មោះម៉ាលីនឆេ កូតេសបានដឹងថាជនជាតិដើមមួយចំនួនមានការមិនសប្បាយចិត្តជាមួយពួកអាតិច។ ពួកគេមានការខឹងសម្បាចំពោះការអនុវត្តដ៏ឃោឃៅរបស់ពួកគេ ដោយក្នុងនោះមានទាំងការបូជាមនុស្សជាដើម។ តាមរយៈម៉ាលីនឆេ កូតេសត្រូវ

បានធ្វើឱ្យជឿថាជនជាតិដើមទាំងនេះនឹងនៅខាងលោកដើម្បីវាយប្រយុទ្ធ។ ចុងក្រោយ និងសំខាន់បំផុតនោះគឺពួកជនជាតិដើមមិនអាចធ្វើអ្វីបានជាដុំកំភួនដើម្បីបញ្ឈប់ក្រុមអ្នកប្រយុទ្ធដែលគ្មានរូបរាង ដែលបានធ្វើដំណើរមកជាមួយពួកអេស្ប៉ាញឡើយ ពួកគេគឺជំងឺ។ កញ្ជ្រិល, ស្រឡទែន, អុតស្វាយ, និងគ្រុនពោះវៀនគឺគ្រាន់តែជាជំងឺមួយចំនួនដែលពួកអឺរ៉ុបយកមកជាមួយពួកគេមកកាន់អាមេរិក។ ប្រជាជនដើមអាមេរិកមិនធ្លាប់កើតមានជម្ងឺទាំងអស់នេះឡើយ។ ដូច្នេះ ពួកគេមិនបានអភិវឌ្ឍប្រព័ន្ធភាពសាំមួយសម្រាប់ពួកគេឡើយ។ ជាលទ្ធផល ពួកគេបានស្លាប់អស់រាប់សែននាក់។ ត្រឹមពេលដែលកូតេសធ្វើការវាយប្រហារតេប ចំនួនប្រជាជនអាតិចបានថយចុះយ៉ាងច្រើនដោយសារជំងឺអុតស្វាយ និងកញ្ជ្រិល។ នៅពេលក្រោយមក ជំងឺរបស់ពួកអឺរ៉ុបបានបំផ្លិចបំផ្លាញប្រជាជនដើមនៅម៉ិកស៊ិកកូភាគកណ្តាល ដោយបង្កឱ្យមនុស្សរាប់លាននាក់ស្លាប់។

## 3. អេស្ប៉ាញដណ្តើមកាន់កាប់ប៉េរូ

នៅក្នុងឆ្នាំ 1532 អ្នកដណ្តើមកាន់កាប់ម្នាក់ផ្សេងទៀតឈ្មោះហ្វ្រង់ស៊ីស្កូ ពីហ្សារ៉ូ បានដឹកនាំកងកម្លាំងតូចមួយទៅកាន់អាមេរិកខាងត្បូង។ លោកបានដណ្តើមកាន់កាប់ចក្រភពអ៊ីនកា ដូចដែលអ្នកបានសិក្សានៅជំពូកមុន។

ពីហ្សារ៉ូបង្ក្រាបពួកអ៊ីនកា៖ ពីហ្សារ៉ូ និងកងទ័ពរបស់លោកប្រមាណ 200 នាក់បានជួបប្រជុំជាមួយមេដឹកនាំអ៊ីនកាព្រះនាមអាតាហ៊ូអាលប៉ា នៅក្បែរទីក្រុងកាចាម៉ាកា។ អាតាហ៊ូអាលប៉ា ដែលដឹកនាំកងកម្លាំងប្រមាណ 30,000 នាក់ បាននាំយកមនុស្សរាប់ពាន់នាក់ដែលភាគច្រើនប្រជាជនសាមញ្ញមកចូលរួមនៅក្នុងប្រជុំនេះ។ ពួកអេស្ប៉ាញបានរងចាំពួនស្ទាក់វាយឆ្មក់, វាយកម្ទេចកងកម្លាំងរបស់អ៊ីនកា, និងចាប់ពង្រត់អាតាហ៊ូអាលប៉ា។ អាតាហ៊ូអាលប៉ាស្នើនៅក្នុងការផ្តល់នូវមាសចំនួនមួយបន្ទប់ និងប្រាក់ចំនួនពីរបន្ទប់ជាថ្នូរទៅនឹងការដោះលែងទ្រង់។ ប៉ុន្តែ បន្ទាប់ពីទទួលបានថ្នូរហើយ ពួកអេស្ប៉ាញបានព្យួរកស្តេចរបស់អ៊ីនកា។ ដោយបាក់ទឹកចិត្តតាមរយៈការស្លាប់របស់មេដឹកនាំពួកគេ កងកម្លាំងអ៊ីនកាដែលនៅសេសសល់បានដកថយពីកាចាម៉ាកា។ ពេលនោះពីហ្សារ៉ូបានធ្វើដំណើរទៅកាន់រាជធានីរបស់អ៊ីនកា គូសកូ។ លោកបានដណ្តើមកាប់កាប់ដោយមិនមានការតស៊ូប្រឆាំងនៅក្នុងឆ្នាំ 1533 ។ ដូចដែលកូតេស និងពីហ្សារ៉ូដណ្តើមកាន់កាប់ដែនដីដែលជាអរិយធម៌អាមេរិក គ្នីគ្នារបស់ពួកគេក៏បានយកជ័យជំនះលើប្រជាជនដើម។ អ្នករុករកជនជាតិអេស្ប៉ាញក៏បានដណ្តើមកាន់កាប់ម៉ាយ៉ានៅយូកាតាន និងហ្គាតេម៉ាឡាផងដែរ។ ត្រឹមពាក់កណ្តាលសតវត្សរ៍ទី 16 អេស្ប៉ាញបានបង្កើតចក្រភពមួយនៅអាមេរិក។ វារួមបញ្ចូលអេស្ប៉ាញថ្មី(ម៉ិកស៊ិកកូ និងផ្នែកខ្លះនៃហ្គាតេម៉ាឡា), ក៏ដូចជាដែនដីផ្សេងៗទៀតនៅអាមេរិកកណ្តាល និងអាមេរិកខាងត្បូង និងសមុទ្ទការីប៊ីន។

ទម្រង់នៃការដណ្តើមកាន់កាប់របស់អេស្ប៉ាញ៖ នៅក្នុងការស្ថាបនាចក្រភពអាមេរិកថ្មីរបស់ពួកគេ ពួកអេស្ប៉ាញប្រើប្រាស់បច្ចេកទេសដែលបានប្រើប្រាស់អំឡុងពេលនៅការដណ្តើមកាន់កាប់អេស្ប៉ាញមកវិញ។ នៅពេលដែលពួកគេដណ្តើមកាន់កាប់អេស្ប៉ាញពីពួកម៉ូស្លីម ពួកអេស្ប៉ាញរស់នៅជាមួយពួកគេ និងបានបញ្ចូលវប្បធម៌អេស្ប៉ាញទៅលើពួកគេ។ ពួកអេស្ប៉ាញដែលតាំងទីលំនៅនៅអាមេរិក ត្រូវបានគេស្គាល់ថាឧបទ្វីបអេស្ប៉ាញដែលភាគច្រើនជាបុរស។ ជាលទ្ធផល ទំនាក់ទំនងរវាងក្រុមអ្នកតាំងទីលំនៅអេស្ប៉ាញ និងស្ត្រីជនជាតិដើមគឺជារឿងសាមញ្ញ។

ទំនាក់ទំនងទាំងនេះបានបង្កើតប្រជាជនមេស្ទីហ្សូ ឬការសាយបញ្ចូលគ្នានៃពួកអេស្ប៉ាញ និងជនជាតិដើមអាមេរិកដ៏ធំមួយ។ បើទោះបីជាក្រុងអ្នកដណ្តើមកាន់កាប់អេស្ប៉ាញរស់នៅលាយគ្នាជាមួយជនជាតិដើមក៏ដោយ ពួកគេក៏គាបសង្កត់ពួកគេផងដែរ។ នៅក្នុងព្យាយាមរបស់ពួកគេនៅដើម្បីកេងប្រវ័ញ្ចលើធនធានដ៏មានតម្លៃនៅលើទឹកដីនោះ ពួកអេស្ប៉ាញបានបង្ខំជនជាតិដើមអាមេរិកឱ្យធ្វើការនៅក្នុងប្រព័ន្ធមួយដែលគេស្គាល់ថាអេនកូមីអេនដា។ ស្ថិតនៅក្រោមប្រព័ន្ធនេះ ពួកជនជាតិដើមដាំដុះ, ចិញ្ចឹមសត្វ, ឬជីករ៉ែឱ្យស្តេចត្រាញ់អេស្ប៉ាញ។ ស្តេចត្រាញ់ទាំងអស់នេះបានទទួលសិទ្ធិនៅក្នុងប្រើប្រាស់កម្លាំងពលកម្មរបស់ជនជាតិដើមពីសំណាក់អាជ្ញាធរអេស្ប៉ាញ។ អ្នកដែលប្រើប្រាស់អេនកូមីអេនដាបានសន្យាចំពោះមេដឹកនាំអេស្ប៉ាញថាពួកគេនឹងអនុវត្តដោយយុត្តិធម៌ និងគោរពចំពោះកម្មករ។ ប៉ុន្តែ មានការរំលោភបំពានជាច្រើនទៅលើជនជាតិដើម និងកម្មករជាច្រើនស្លាប់ដោយសារការងារ ជាពិសេសការធ្វើការងារនៅក្នុងអណ្តូងរ៉ែដ៏គ្រោះថ្នាក់។

ពួកព័រទុយហ្គាល់នៅប្រេស៊ីល៖ តំបន់មួយស្ថិតនៅអាមេរិកខាងត្បូងដែលបន្តស្ថិតនៅក្រៅការត្រួតត្រារបស់ពួកអេស្ប៉ាញគឺប្រទេសប្រេស៊ីល។ នៅក្នុងឆ្នាំ 1500 កាប្រាល់បានអះអាងពីការកាន់កាប់ដែនដីនេះសម្រាប់ប្រទេសព័រទុយហ្គាល់។ អំឡុងទសវត្សរ៍ឆ្នាំ 1530 ពួកអាណានិគមបានចាប់ផ្តើមតាំងទីលំនៅនៅតំបន់ឆ្នេរសមុទ្ររបស់ប្រេស៊ីល។ ដោយសាររកឃើញមាស និងប្រាក់តិចតួច ពួកអ្នកតាំងទីលំនៅចាប់ផ្តើមដាំដុះដំណាំអំពៅនៅទីនោះ។ តាមរយៈការកាប់ឆ្ការដីព្រៃដ៏ធំ ពួកព័រទុយហ្គាល់បានស្ថាបនាចំការអំពៅធំៗ។ តម្រូវការស្ករនៅអឺរ៉ុបមានខ្ពស់ ហើយដែនដីអាណានិគមភ្លាមៗនោះបានបង្កើនទ្រព្យសម្បត្តិដល់ពួកព័រទុយហ្គាល់។ ក្រោយមក ពួកអាណានិគមបានពង្រីកការគ្រប់គ្រងរបស់ខ្លួនឆ្ពោះទៅប្រេស៊ីលភាគខាងលិច។ ពួកគេបង្កើនដែនដីសម្រាប់ដាំអំពៅកាន់តែច្រើន។

## 4. ការពង្រីកឥទ្ធិពលរបស់អេស្ប៉ាញ

អាណានិគមរបស់អេស្ប៉ាញនៅអាមេរិកបានជួយដល់ការបង្កើនទ្រព្យសម្បត្តិរបស់ពួកគេ ធ្វើឱ្យពួកគេក្លាយជាប្រទេសមហាអំណាចនៅក្នុងពិភពលោកអំឡុងសតវត្សរ៍ទី 16 ។ នាវាពេញទៅដោយទ្រព្យសម្បត្តិមកពីអាមេរិកបានធ្វើដំណើរមកកាន់កំពង់ផែអេស្ប៉ាញ។ ទ្រព្យសម្បត្តិថ្មីនេះបានជួយដល់ការលេចឡើងនៃយុគមាសមួយនៃសិល្បៈ និងវប្បធម៌អេស្ប៉ាញ។ ពេញមួយសតវត្សរ៍ទី 16 អេស្ប៉ាញក៏បានបង្កើនកម្លាំងយោធារបស់ពួកគេផងដែរ។ ដើម្បីការពារនាវាដឹកទ្រព្យសម្បត្តិរបស់ពួកគេ អេស្ប៉ាញបានស្ថាបនាកងទ័ពជើងទឹកដ៏មានអំណាចមួយ។ ពួកអេស្ប៉ាញក៏បានពង្រឹងកម្លាំងយោធាផ្សេងៗទៀតរបស់ពួកគេផងដែរ ដោយបានបង្កើតយោធាដែលមានជំនាញពេលលេញមួយ។ សម្រាប់រយៈពេលមួយសតវត្សរ៍កន្លះ កងទ័ពអេស្ប៉ាញកម្រនឹងចាញ់នៅក្នុងសមរភូមិណាស់។ នៅខណៈពេលនោះ អេស្ប៉ាញបានពង្រីកចក្រភពអាមេរិករបស់ពួកគេតាមរយៈការតាំងទីលំនៅនៅផ្នែកខ្លះនៃទឹកដីសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ន។

ក្រុមអ្នកដណ្តើមកាន់កាប់រុញច្រានទៅភាគខាងជើង៖ ក្តីសុបិន្តនៃការដណ្តើមកាន់កាប់ដែនដីថ្មីបានញ៉ាំងឱ្យពួកអេស្ប៉ាញគាំទ្របេសកកម្មមួយចំនួនឆ្ពោះទៅកាន់សហរដ្ឋអាមេរិកភាគនិរតី។ ពួកអេស្ប៉ាញតាមពិតទៅបានតាំងទីលំនៅនៅផ្នែកខ្លះនៃសហរដ្ឋអាមេរិកមុនពេលដែលពួកគេសុបិន្តនៅក្នុងស្ថាបនាចក្រភពមួយនៅលើអាមេរិក

ដីគោកទៅទៀត។ នៅក្នុងឆ្នាំ 1513 អ្នករុករកជនជាតិអេស្ប៉ាញឈ្មោះជោន ប៉ុន ដេ ឡេអន បានចូលសំចតនៅតំបន់ឆ្នេរសមុទ្រដែលបច្ចុប្បន្នជាផ្លរីដា និងបានអះអាងពីការកាន់កាប់ដែនដីនេះសម្រាប់ប្រទេសអេស្ប៉ាញ។ ត្រឹមឆ្នាំ 1540 បន្ទាប់ពីការស្លាបនាចក្រភពមួយដែលលាតសន្ធឹងពីម៉ិកស៊ិកកូដល់ប៉េរូ ពួកអេស្ប៉ាញជាថ្មីម្តងទៀតបានសម្លឹងទៅរកការបង្កើតចក្រភពលើដែនដីដែលបច្ចុប្បន្នជាសហរដ្ឋអាមេរិក។ នៅចម្លោះឆ្នាំ 1540-1541 ហ្វ្រង់ស៊ីលស្កូ វ៉ាស់កេស ដេ កូរ៉ូណាដូ បានដឹកនាំបេសកកម្មមួយទៅកាន់តំបន់មួយចំនួនដែលបច្ចុប្បន្នជាអារីហ្សូណា, ម៉ិកស៊ិកកូថ្មី, តិចហ្សាស់, អូក្លាហូម៉ា, និងកានសាស។ លោកបានស្វែងរកចក្រភពដែលមានទ្រព្យសម្បត្តិផ្សេងៗទៀតដើម្បីដណ្តើមកាន់កាប់។ កូរ៉ូណាដូបានស្វែងរកឃើញមាសតិចតួចនៅតំបន់វាលខ្សាច់នៅភាគនិរតី។ ជាលទ្ធផលស្តេចអេស្ប៉ាញបានតែងតាំងបព្វជិតជាច្រើនដើម្បីរុករក និងដាក់អាណានិគមលើដែនដីសហរដ្ឋអាមេរិកបន្តបន្ទាប់ទៀត។ បព្វជិតកាតូលិកបានអមដំណើរជាមួយក្រុមអ្នកឈ្លានពានចាប់តាំងពីការចាប់ផ្តើម ការដាក់អាណានិគមលើអាមេរិកដំបូងមកម្លេះ។ ក្រុមអ្នកដណ្តើមកាន់កាប់មកទីនោះដើម្បីស្វែងរកទ្រព្យសម្បត្តិ។ ពួកបព្វជិតដែលបានអមដំណើរជាមួយពួកគេមកទីនោះដើម្បីស្វែងរកការផ្លាស់ប្តូរសាសនា។ នៅក្នុងរដូវរំហើយឆ្នាំ 1609-1610 ពេដ្រូ ដេ ពេរ៉ាលតា អភិបាលតំបន់ភាគខាងជើងដែលអេស្ប៉ាញកាន់កាប់ ដែលគេហៅថាម៉ិកស៊ិកកូ បានដឹកនាំក្រុមអ្នកតាំងទីលំនៅទៅកាន់តំបន់ចំណុះមួយនៅរីអូក្រេនខាងលើ។ ពួកគេបានស្ថាបនារាជធានីមួយដែលមានឈ្មោះថា សេនតា ហ្វេ ឬ ជំនឿពិសិដ្ឋ។ នៅពីរទសវត្សរ៍បន្ទាប់ ហ្វូងបេសកទូតសាសនាគ្រីស្តបានរីកឡើងក្នុងចំណោមពួកពូអេប្លូ ដែលជាជនជាតិដើមតាំងទីលំនៅនៅក្នុងតំបន់នោះ។ តំបន់ទាំងនេះបានក្លាយជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសាសនាកាតូលិក។

## 5. ការប្រឆាំងជាមួយនឹងការគ្រប់គ្រងរបស់អេស្ប៉ាញ

បព្វជិតអេស្ប៉ាញធ្វើការដើម្បីពង្រីកសហគមន៍គ្រីស្តសាសនានៅអាមេរិក។ ពួកគេក៏បានរុញច្រានឱ្យមានការអនុវត្តកាន់តែប្រសើរសម្រាប់ជនជាតិដើមអាមេរិក។ បព្វជិតងើបឡើងប្រឆាំងជាមួយនឹងការអនុវត្តដ៏ឃោឃៅលើជនជាតិដើម។ ជាពិសេស ពួកគេបានរិះគន់ទៅទម្រង់ដ៏ឃោឃៅនៃការងារដែលលេចឡើងនៅក្រោមប្រព័ន្ធអេនកូមីអេនដា។ ព្រះសង្ឃសាសនាដូមីនីកេនព្រះនាមបាតូឡូមេ ដេ ឡាស់ កាសាស់បានសរសេរថា "គ្មានអ្វីដែលឃោឃៅជាងការសង្កត់សង្កិនរបស់ពួកអេស្ប៉ាញ បានបានប្រើប្រាស់ចំពោះពួកឥណ្ឌាដើម្បីធ្វើឱ្យពួកគេទទួលបានគុជខ្យង(ទ្រព្យសម្បត្តិ)"។

ការប្រឆាំងរបស់ទាសករអាហ្វ្រិក និងជនជាតិដើម៖ រដ្ឋាភិបាលអេស្ប៉ាញបានបោះបង់ប្រព័ន្ធអេនកូមីអេនដានៅក្នុងឆ្នាំ 1542 ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារលើដែនដីអាណានិគម ឡាស់ កាសាស បានស្នើឱ្យប្រើពួកអាហ្វ្រិក។ លោកបាននិយាយថា "ការងាររបស់ពួកអាហ្វ្រិកម្នាក់មានតម្លៃជាងពួកឥណ្ឌា 4 នាក់"។ បព្វជិតក្រោយមកបានផ្លាស់ប្តូរការយល់ឃើញរបស់លោក និងបានរិះគន់លើរបបទាសភាពអាហ្វ្រិក។ ប៉ុន្តែ អ្នកដ៏ទៃទៀតបានលើកកម្ពស់វា។ ការប្រឆាំងទៅនឹងវិធីសាស្ត្ររបស់អេស្ប៉ាញក្នុងការដាក់អាណានិគមមិនមែនកើតមានឡើងតែពីពួកបព្វជិតអេស្ប៉ាញប៉ុណ្ណោះទេ បានកើតមានឡើងពីពួកជនជាតិដើមខ្លួនគេផ្ទាល់ផងដែរ។ ការប្រឆាំងជាមួយ

នឹងការព្យាយាមក្នុងការគ្រប់សង្កត់របស់អេស្ប៉ាញ ចាប់ផ្តើមភ្លាមៗបន្ទាប់ពីពួកអេស្ប៉ាញមកដល់តំបន់ការ៉ាបៀន។ នៅក្នុងខែវិច្ឆិកា ឆ្នាំ 1493 កូឡុំបឹសបានបង្ក្រាបការបះបោរប្រឆាំងជាមួយការព្យាយាមរបស់លោកក្នុងការកាន់កាប់ដែនដីបច្ចុប្បន្នកោះក្រូស។ មុនពេលដែលពួកគេចុះចាញ់ ក្រុមអ្នកតាំងទីលំនៅជនជាតិដើមការពារខ្លួនពួកគេដោយការបាញ់ព្រួញមានពិស។ រហូតមកដល់ចុងសតវត្សរ៍ទី 17 ជនជាតិដើមនៅម៉ិកស៊ិកកូថ្មីបានវាយប្រយុទ្ធប្រឆាំងជាមួយការដឹកនាំរបស់ពួកអេស្ប៉ាញ។ បើទោះបីជាពួកគេមិនមានហានិភ័យដល់ជីវិតរបស់ពួកគេនៅក្នុងអណ្តូងរ៉ែប្រាក់ក៏ដោយ ពួកជនជាតិដើមនៅតែមានអារម្មណ៍ថាមានសម្ពាតពីសំណាក់ការបង្ខិតបង្ខំរបស់ពួកអេស្ប៉ាញ។ នៅក្នុងការផ្លាស់ប្តូរជំនឿរបស់ពួកគេ បព្វជិតអេស្ប៉ាញ និងយោធាបានដុតបំផ្លាញវត្ថុពិសិដ្ឋ និងហាមឃាត់ការប្រារព្ធក្បួនពិធីរបស់ជនជាតិដើម។ ពួកអេស្ប៉ាញក៏បានបង្ខំឱ្យជនជាតិដើមធ្វើការឱ្យពួកគេ និងពេលខ្លះរំលោភបំពានលើរាងកាយរបស់ពួកគេ។ នៅក្នុងឆ្នាំ 1680 មេដឹកនាំពូអេប្លូមួយរូបបានដឹកនាំអង្គការចាត់តាំងមួយបះបោរប្រឆាំងជាមួយពួកអេស្ប៉ាញ។ ការបះបោរនេះមានការចូលរួមពីសំណាក់ក្រុមអ្នកប្រយុទ្ធជាង 8,000 នាក់ដែលមកពីភូមិនានានៅពាសពេញម៉ិកស៊ិកកូថ្មី។ ក្រុមអ្នកប្រយុទ្ធជនជាតិដើមបានបណ្តេញពួកអេស្ប៉ាញត្រឡប់ទៅកាន់អេស្ប៉ាញថ្មី។ សម្រាប់រយៈពេល 12 ឆ្នាំបន្ទាប់ រហូតដល់ពេលដែលពួកអេស្ប៉ាញគ្រប់គ្រងតំបន់នោះឡើងវិញ តំបន់សហរដ្ឋអាមេរិកភាគនិរតីបានធ្លាក់ទៅក្រោមការគ្រប់គ្រងឡើងវិញរបស់ជនជាតិដើមដែលតាំងទីលំនៅនៅទីនោះ។ ប៉ុន្តែ នៅត្រឹមពេលនោះមេដឹកនាំអេស្ប៉ាញមានការព្រួយបារម្ភយ៉ាងខ្លាំង។ ប្រទេសផ្សេងៗទៀតនៅអឺរ៉ុបបានចាប់ផ្តើមបង្កើតដែនដីអាណានិគមរបស់ពួកគេផ្ទាល់នៅអាមេរិក។

# មេរៀនទី 2 ៖ប្រទេសនៅអឺរ៉ុបតាំងទីលំនៅអាមេរិកខាងជើង

រម្លឹកពីអ្វីដែលអ្នកបានដឹង៖ ការព្យាយាមគ្រប់គ្រងអាណានិគមដ៏ជោគជ័យរបស់អេស្ប៉ាញនៅអាមេរិកមិនបានស្ងប់ស្ងាត់ឡើយ។ ប្រទេសផ្សេងៗទៀតនៅអឺរ៉ុប ដូចជាអង់គ្លេស, បារាំង, និងហូឡង់ភ្លាមៗនោះបានចាប់អារម្មណ៍ជាមួយនឹងការទទួលបានដែនដីអាណានិគមផ្ទាល់របស់ពួកគេ។ សន្ធិសញ្ញាតូដេស៊ីលឡាស់ដែលបានចុះហត្ថលេខានៅក្នុងឆ្នាំ 1494 បានបែងចែកដែនដីដែលរុករកឃើញថ្មីរវាងអេស្ប៉ាញ និងព័រទុយហ្គាល់។ ប៉ុន្តែប្រទេសនៅអឺរ៉ុបផ្សេងទៀតបានបដិសេធសន្ធិសញ្ញានេះ។ ពួកគេមានបំណងនៅក្នុងការស្ថាបនាចក្រភពផ្ទាល់របស់ពួកគេនៅអាមេរិក។ ហេតុនេះបណ្តាលឱ្យមានការតស៊ូមួយសម្រាប់ដែនដីអាមេរិកខាងជើង។

## 1. ការប្រកួតប្រជែងគ្នាដើម្បីកាន់កាប់អាមេរិកខាងជើង

ដំណើរផ្សងព្រេងរបស់ម៉ាហ្សេឡង់បានបង្ហាញថា នាវាអាចធ្វើដំណើរទៅដល់អាស៊ីតាមរយៈមហាសមុទ្រប៉ាស៊ីហ្វិក។ អេស្ប៉ាញបានអះអាងពីការកាន់កាប់ផ្លូវទឹកនៅជុំវិញតំបន់ចុងភាគខាងត្បូងនៃអាមេរិកខាងត្បូង។ ប្រទេសអឺរ៉ុបផ្សេងៗទៀតសង្ឃឹមនៅក្នុងការស្វែងរកផ្លូវដែលមានភាពងាយស្រួល និងត្រង់ទៅកាន់មហាសមុទ្រប៉ាស៊ីហ្វិក។ ប្រសិនបើពួកគេរកឃើញ ផ្លូវពាណិជ្ជកម្មភាគពាយព្យមួយកាត់តាមអាមេរិកខាងជើងទៅកាន់អាស៊ី និងទទួលបានផលចំណេញខ្ពស់។ ដោយរកមិនឃើញមានផ្លូវ បារាំង, អង់គ្លេស, និងហូឡង់ផ្ទុយទៅវិញបានបង្កើតដែនដីអាណានិគមនៅអាមេរិកខាងជើង។

ក្រុមអ្នករុករកបង្កើតបារាំងថ្មី៖ អ្នករុករកជនជាតិបារាំងដំបូងបានធ្វើដំណើរទៅភាគខាងលិចជាមួយក្តីសង្ឃឹមថាពួកគេនៅទៅដល់ឥណ្ឌាខាងកើត។ អ្នករុករកម្នាក់ឈ្មោះជីអូវ៉ាន់នី ដា វីរ៉ាហ្សាណូ ដែលជាជនជាតិអ៊ីតាលីបម្រើការឱ្យបារាំង។ នៅក្នុងឆ្នាំ 1524 លោកបានធ្វើដំណើរទៅកាន់អាមេរិកខាងជើងដើម្បីស្វែងរកផ្លូវសមុទ្រមួយទៅកាន់មហាសមុទ្រប៉ាស៊ីហ្វិក។ ខណៈពេលដែលលោកមិនបានរកឃើញផ្លូវ វីរ៉ាហ្សាណូបានស្វែងរកឃើញដែនដីមួយដែលបច្ចុប្បន្នជាកំពង់ផែញ៉ូវយក។ 10 ឆ្នាំក្រោយមក ជនជាតិបារាំងឈ្មោះហ្សាកកេស កាទីយ៉ែបានធ្វើដំណើរដល់ឈូងសមុទ្រមួយនៅតំបន់ឆ្នេរកាណាដាភាគខាងកើតដែលនាំទៅដល់ទន្លេដ៏ធំមួយ។ កាទីយ៉ែបានដាក់ឈ្មោះកន្លែងនោះថាឡាវ៉ែន។ លោកបានធ្វើដំណើរចូលតាមទន្លេនោះរហូតទៅដល់កោះដ៏ធំមួយដែលគ្របដណ្តប់ដោយភ្នំមួយ។ លោកបានដាក់ឈ្មោះកោះនោះថាមោនរៀល(ភ្នំភូមិន្ទ)ដែលក្រោយមកត្រូវបានគេស្គាល់ថាម៉ុងត្រេអាល។ នៅក្នុងឆ្នាំ 1608 អ្នករុករកជនជាតិបារាំងមួយរូបទៀតឈ្មោះសាមូអែល ដេ ឆាមផ្លេនបានធ្វើដំណើរចេញពីឡាវ៉ែនជាមួយអាណានិគមជន 32 នាក់។ ពួកគេបានរកឃើញកេប៊ិច ដែលបានក្លាយជាមួយមូលដ្ឋាននៃចក្រភពអាណាគមបារាំងនៅអាមេរិកខាងជើង ដែលគេស្គាល់ថាបារាំងថ្មី។ បន្ទាប់មកបារាំងបានជ្រាបចូលទៅកាន់ទ្វីបអាមេរិកខាងជើង។ នៅក្នុងឆ្នាំ 1673 បព្វជិតសាសនាយេស៊ូជនជាតិបារាំងឈ្មោះហ្សាកកេស ម៉ាកេតេ និងពាណិជ្ជករល្វីស ចូលីអេត បានរុករកឃើញបឹងធំ និងទន្លេមីស៊ីស៊ីបពីលើ។ ជិត 10 ឆ្នាំបន្ទាប់លោកសៀយដេ ឡា សាលឡេបានរុករកឃើញទន្លេមីស៊ីស៊ីបពីក្រោម។ លោកបានអះអាងពីការកាន់កាប់ទន្លេទាំងមូលសម្រាប់បារាំង។ លោកបានដាក់ឈ្មោះវាថាល្វីសៀណា ដើម្បីជាកិត្តិយសដល់ស្តេចបារាំងល្វីទី 14 ។ ត្រឹមដើមទសវត្សរ៍ឆ្នាំ

1700 បារាំងថ្មីគ្របដណ្តប់មួយភាគធំលើទឹកដីបច្ចុប្បន្នសហរដ្ឋអាមេរិកពាក់កណ្តាលទៅខាងលិច និងកាណាដាភាគខាងកើត។

ចក្រភពពាណិជ្ជកម្មមួយ៖ ចក្រភពបារាំងនៅអាមេរិកខាងជើងមានទំហំធំមហិមា ប៉ុន្តែមានប្រជាជនតិចតួច។ ត្រឹមឆ្នាំ 1760 ប្រជាជនអឺរ៉ុបនៅបារាំងថ្មីបានកើនឡើងត្រឹមតែប្រមាណ 65,000 នាក់ប៉ុណ្ណោះ។ អាណានិគមជនបារាំងមួយចំនួនធំមិនមានបំណងនៅក្នុងការស្ថាបនាទីប្រជុំជន ឬពង្រីកចំនួនគ្រួសារឡើយ។ ក្រុមអ្នកតាំងទីលំនៅទាំងនេះរួមមានទាំងបព្វជិតកាតូលិកដែលសំលឹងរកការផ្លាស់ប្តូរសាសនារបស់ជនជាតិដើមអាមេរិក។ ពួកគេក៏រួមមានបុរសវ័យក្មេង និងនៅលីវ ដែលបានចូលរួមនៅក្នុងអ្វីដែលបានក្លាយជាសកម្មភាពសេដ្ឋកិច្ចចំបងរបស់បារាំងថ្មីគឺពាណិជ្ជកម្មរោមសត្វ។ ខុសពីពួកអង់គ្លេស ពួកបារាំងមានចំណាប់អារម្មណ៍តិចតួចនៅក្នុងការកាន់កាប់ទឹកដីជាងការបង្កើតលុយនៅលើដែនដីនោះ។

## 2. អង់គ្លេសមកដល់អាមេរិកខាងជើង

ការរុករករបស់អេស្ប៉ាញ និងបារាំងបានជម្រុញទឹកចិត្តអង់គ្លេស។ នៅក្នុងឆ្នាំ 1606 ក្រុមហ៊ុនវិនិយោគមួយនៅទីក្រុងឡុងដ៍បានទទួលពីស្តេចជេមនូវកិច្ចសន្យាមួយ ដើម្បីផ្តល់មូនិធិដល់ការដាក់អាណានិគមមួយនៅអាមេរិកខាងជើង។ នៅចុងឆ្នាំ1606 នាវាចំនួន 3 គ្រឿងរបស់ក្រុមហ៊ុន និងក្រុមអ្នកតាំងទីលំនៅជាង 100 នាក់បានចាកចេញពីកំពង់ផែអង់គ្លេស។ ប្រហែលជា 4 ខែក្រោយមក នៅក្នុងឆ្នាំ 1607 ពួកគេបានធ្វើដំណើរទៅដល់តំបន់ឆ្នេរសមុទ្រវឺជីនៀ។ ពួកអាណានិគមជនបានអះអាងពីការកាន់កាប់របស់ពួកគេនៅទីនោះ។ ពួកគេបានដាក់ឈ្មោះទីកន្លែងដែលពួកគេតាំងទីលំនៅថាជេមថោន ដើម្បីជាកិត្តិយសដល់ស្តេចរបស់ពួកគេ។

ការតាំងទីលំនៅនៅជេមថោន៖ ការចាប់ផ្តើមដំបូងនៃការដាក់អាណានិគមប្រកបដោយភយន្តរាយ។ ក្រុមអ្នកតាំងទីលំនៅមានចំណាប់អារម្មណ៍ខ្លាំងទៅលើកការស្វែងរកមាសជាជាងការដាំដុះដំណាំ។ អំឡុងពេលប៉ុន្មានឆ្នាំដំបូង 7 ក្នុងចំណោមមនុស្ស 10 នាក់បានស្លាប់ដោយគ្រោះអង់ឃ្លាន, ជំងឺ, ឬសង្គ្រាមជាមួយជនជាតិដើមអាមេរិក។ បើទោះបីជាពួកគេសុបិនអាក្រក់នៅពេលចាប់ផ្តើមដំបូង ពួកអាណានិគមជនជាយថាហេតុទទួលបាននូវទីតាំងឈរជើងមួយនៅដែនដីថ្មីរបស់ពួកគេ។ ជេនថោនបានក្លាយជាទីកន្លែងតាំងទីលំនៅអចិន្ត្រៃដំបូងរបស់អង់គ្លេសនៅអាមេរិកខាងជើង។ មូលដ្ឋានរបស់ពួកអាណានិគមត្រូវបានពង្រឹងយ៉ាងល្អប្រសើរបន្ទាប់ពីកសិករនៅទីនោះរកឃើញដំណាំថ្នាំជក់។ ដោយសារតម្រូវថ្នាំជក់ខ្ពស់នៅអង់គ្លេសបានប្រែក្លាយវាជាដំណាំដែលទទួលបានផលចំណេញច្រើន។

ក្រុមអ្នកប្រកាន់គោលការណ៍សាសនាតឹងរឹងបង្កើត "អង់គ្លេសថ្មី"៖ នៅក្នុងឆ្នាំ 1620 មនុស្សមួយក្រុមដែលគេស្គាល់ថាអ្នកធម្មយាត្រាបានបង្កើតដែនដីអាណានិគមទីពីររបស់អង់គ្លេសឰ្លីម៉ៅនៅម៉ាសាឈូសេត។ ដោយសារតែការធ្វើទុកបុកម្និញលើជំនឿសាសនារបស់ពួកគេនៅអង់គ្លេស ពួកអាណានិគមជនទាំងនេះបានសម្លឹងរកសេរីភាពខាងសាសនា។ 10 ឆ្នាំក្រោយមក មនុស្សមួយក្រុមដែលគេស្គាល់ថាក្រុមអ្នកប្រកាន់គោលការណ៍សាសនាតឹងរឹងក៏បានសម្លឹងរកសេរីភាពពីព្រះវិហារគ្រីស្តសាសនាអង់លីកេនរបស់អង់គ្លេស។ ពួកគេបានបង្កើតដែនដីអាណានិគមដ៏ធំមួយនៅជិតឈូងសមុទ្រម៉ាសាឈូសេត។ ក្រុមអ្នកប្រកាន់គោលការណ៍សាសនាតឹងរឹងចង់បង្កើតសហគមន៍

គំរូមួយដែលនឹងបង្ហាញពីឧទាហរណ៍មួយសម្រាប់គ្រីស្តសាសនិកឱ្យអនុវត្តតាម។ បើទោះបីជាពួកអាណានិគមប្រឈមទៅនឹងការលំបាកនៅគ្រាដំបូងក៏ដោយ បន្តិចម្តងៗពួកគេអាចឈរជើងបាន។ នេះដោយសារពួកគេមានគ្រួសារដែលមានសមាជិកច្រើននៅក្នុងដែនដីអាណានិគម មិនដូចជាប្រជាជននៅជេមថោនដែលភាគច្រើនជាបុរសនៅលីវ។

ពួកហូឡង់បង្កើតហូឡង់ថ្មី៖ អ្នកដែលបន្តពីអង់គ្លេស និងបារាំងក្នុងការចូលទៅកាន់អាមេរិកខាងជើងគឺហូឡង់។ នៅក្នុងឆ្នាំ 1609 ហេនរី ហូដសាន់ ដែលជាជនជាតិអង់គ្លេសបម្រើឱ្យហូឡង់បានធ្វើដំណើរទៅភាគខាងលិច។ លោកស្វែងរកផ្លូវសមុទ្រមួយនៅភាគពាយព្យដើម្បីធ្វើដំណើរទៅកាន់អាស៊ី។ ហូដសាន់មិនបានរកឃើញផ្លូវមួយណាឡើយ។ ប៉ុន្តែលោកបានរកឃើញផ្លូវទឹកចំនួន 3 ដែលក្រោយមកត្រូវបានគេដាក់ឈ្មោះតាមលោកថា ទន្លេហូដសាន់, ឈូងសមុទ្រហូដសាន់, និងច្រកសមុទ្រហូដសាន់។ ពួកហូឡង់បានអះអាងពីការកាន់កាប់តំបន់នៅតាមបណ្តោយផ្លូវទឹកទាំងអស់នេះ។ ពួកគេបានបង្កើតពាណិជ្ជកម្មស្បែកសត្វជាមួយនឹងពួកឥណ្ឌាអ៊ីរ៉ូគ័រ។ ពួកគេបានស្ថាបនាកំពង់ផែពាណិជ្ជកម្មនៅតាមបណ្តោយទន្លេហូដសាន់នៅហ្វ័រ អូរេង(បច្ចុប្បន្នអាល់បានី) និងនៅលើកោះម៉ាន់ហាតតាន់។ ពាណិជ្ជករហូឡង់បង្កើតក្រុមហ៊ុនហូឡង់ឥណ្ឌាខាងលិច។ នៅក្នុងឆ្នាំ 1621 រដ្ឋាភិបាលហូឡង់បានផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុននូវការគ្រប់គ្រងអាណានិគមតំបន់ទាំងនេះ និងពង្រីកការធ្វើពាណិជ្ជកម្មស្បែកសត្វ។ ការកាន់កាប់នៅអាមេរិកខាងជើងរបស់ហូឡង់ត្រូវបានគេស្គាល់ថាហូឡង់ថ្មី។ បើទោះបីជាក្រុមហ៊ុនហូឡង់ទទួលបានប្រាក់ចំណេញពីការធ្វើពាណិជ្ជកម្មស្បែកសត្វរបស់ពួកគេក៏ដោយ វាមានភាពយឺតនៅក្នុងការទាក់ទាញអាណានិគមជនហូឡង់។ ដើម្បីលើកទឹកចិត្តដល់ក្រុមអ្នកតាំងទីលំនៅ អាណានិគមបានបើកទ្វារដល់មនុស្សមកពីគ្រប់ទិសទី។ បន្តិចម្តងៗពួកហូឡង់កាន់តែច្រើន, ក៏ដូចជាពួកអាឡឺម៉ង់, បារាំង, ស្កេនឌីណាវៀន, និងពួកអឺរ៉ុបផ្សេងទៀតបានតាំងទីលំនៅនៅក្នុងតំបន់នោះ។

ការដាក់អាណានិគមនៅការីប៊ីន៖ អំឡុងទសវត្សឆ្នាំ 1600 ប្រទេសអឺរ៉ុបនានាក៏បានដាក់អាណានិគមនៅការីប៊ីនផងដែរ។ បារាំងដណ្តើមកាន់កាប់ដែនដីបច្ចុប្បន្នប្រទេសហៃទី, ហ្គូដេលូព, និងម៉ាទីនិក។ ពួកអង់គ្លេសតាំងទីលំនៅនៅបាបាដូស និងចាមៃកា។ នៅក្នុងឆ្នាំ 1634 ពួកហូឡង់ដណ្តើមកាន់កាប់ដែនដីបច្ចុប្បន្នហូឡង់អានទីលេស និងអារូបាពីពួកអេស្ប៉ាញ។ នៅលើកោះទាំងអស់នេះ ពួកអឺរ៉ុបបានស្ថាបនាចំការដំណាំកប្បាស និងអំពៅធំៗ។ ផលិតផលទាំងនេះ បើទោះបីជាទទួលបានផលចំណេញ វាតម្រូវឱ្យមានកម្លាំងកម្មករក្នុងចំនួនច្រើន និងទៀងទាត់មួយ។ ទាសករអាហ្វ្រិកជាយថាហេតុបានផ្តល់ផ្តល់កម្លាំងពលកម្មនេះ។

### 3. ការតស៊ូសម្រាប់អាមេរិកខាងជើង

ដូចដែលពួកគេពង្រីកការតាំងទីលំនៅរបស់ពួកគេនៅអាមេរិកខាងជើង ប្រទេសបារាំង, អង់គ្លេស, និងហូឡង់បានវាយប្រយុទ្ធគ្នាទៅវិញទៅមកសម្រាប់ឧត្តមភាពអាណានិគម។

អង់គ្លេសបណ្តេញហូឡង់ចេញ៖ សម្រាប់អង់គ្លេស ហូឡង់ថ្មីបានបែងចែកដែនដីអាណានិគមភាគខាងជើង និងភាគខាងត្បូងរបស់ពួកគេ។ នៅក្នុងឆ្នាំ 1664 ស្តេចអង់គ្លេសព្រះនាមឆាលទី 2 បានផ្តល់ការអនុញ្ញាតដល់

អនុជរបស់ទ្រង់ព្រះនាមព្រះអង្គម្ចាស់យ៉កធ្វើការបណ្ដេញពួកហូឡង់ចេញ។ នៅពេលដែលនាវារបស់ព្រះអង់ម្ចាស់ធ្វើដំណើរមកដល់ហូឡង់ថ្មី ពួកហូឡង់បានចុះចាញ់ដោយមិនបានការប្រយុទ្ធគ្នាឡើយ។ ព្រះអង្គម្ចាស់យ៉កបានអះអាងពីការកាន់កាប់អាណានិគមរបស់អង់គ្លេសលើដែនដីនេះ និងបានប្ដូរឈ្មោះវាថាញូវយ៉ក។ ជាមួយនឹងការចាកចេញរបស់ពួកហូឡង់ អង់គ្លេសបានគ្រប់គ្រងអាណានិគមលើតំបន់ឆ្នេរសមុទ្រអាត្លង់ទិចនៅអាមេរិកខាងជើង។ ត្រឹមឆ្នាំ 1750 ក្រុមអ្នកតាំងទីលំនៅអង់គ្លេសប្រមាណ 1.2 លាននាក់រស់នៅតំបន់អាណានិគមទាំង 13 ចាប់ពីមេនរហូតដល់ចចៀ។

អង់គ្លេសប្រយុទ្ធជាមួយបារាំង៖ អង់គ្លេសចាប់ផ្ដើមស្រែកឃ្លានទឹកដីបន្ថែមទៀតសម្រាប់ប្រជាជនក្នុងដែនដីអាណានិគមរបស់ពួកគេ។ ដូច្នេះពួកគេបានរុញច្រានឆ្ពោះទៅភាគខាងលិចនៃទ្វីប។ ការធ្វើដូច្នេះ ពួកគេជួបប្រទះជាមួយដែនដីរបស់បារាំងនៅអាមេរិកខាងជើង។ ដូចដែលដែនដីអាណានិគមរបស់ពួកគេពង្រីក បារាំង និងអង់គ្លេសចាប់ផ្ដើមជ្រៀតជ្រែកគ្នាទៅវិញទៅមក។ វាហាក់ដូចជាថាជម្លោះដ៏ធំមួយនឹងមកដល់ឆាប់ៗ។ នៅក្នុងឆ្នាំ 1754 ជម្លោះមួយទាក់ទងជាមួយការអះអាងលើការកាន់កាប់ដែនដីនៅជ្រលងអូហៃយ៉ូបាននាំទៅដល់សង្គ្រាមមួយរវាងចក្រភពអង់គ្លេស និងបារាំងនៅភាគខាងជើងដែលបានក្លាយជាសង្គ្រាមដ៏ធំមួយដែលគេស្គាល់ថាសង្គ្រាម 7 ឆ្នាំ។ ចក្រភពអង់គ្លេស និងបារាំងអមជាមួយសម្ព័ន្ធមិត្តអឺរ៉ុបរបស់ពួកគេក៏បានវាយប្រយុទ្ធគ្នាសម្រាប់ឧត្តមភាពនៅអឺរ៉ុប, ឥណ្ឌាខាងលិច, និងឥណ្ឌា។ នៅអាមេរិខាងជើង អាណានិគមជនអង់គ្លេសជាមួយនឹងចំនួយរបស់យោធាអង់គ្លេសបានយកជ័យជំនះលើបារាំងនៅក្នុងឆ្នាំ 1763 ។ បារាំងបានយល់ព្រមប្រគល់ដែនដីដែលពួកគេកាន់កាប់នៅអាមេរិកខាងជើង។ ជាលទ្ធផលនៃសង្គ្រាម អង់គ្លេសជណ្ដើមកាន់កាប់ពាក់កណ្ដាលភាគខាងកើតនៃអាមេរិកខាងជើង។

## 4. ជនជាតិដើមអាមេរិកឆ្លើយតប

ក៏ដូចជានៅម៉ិកស៊ិកកូ និងអាមេរិកខាងត្បូង ការមកដល់នៃពួកអឺរ៉ុបនៅដែនដីបច្ចុប្បន្នសហរដ្ឋអាមេរិកបានជះឥទ្ធពលយ៉ាងខ្លាំងមួយដល់ជនជាតិដើមអាមេរិក។ ការដាក់អាណានិគមរបស់អឺរ៉ុបភាគច្រើនបាននាំមកនូវវិនាសកម្មសម្រាប់ក្រុមជនជាតិដើមដែលតាំងទីលំនៅលើដែនដីអាណានិគមទាំងនោះ។

ទំនាក់ទំនងដ៏តានតឹងមួយ៖ ក្រុមអ្នកតាំងទីលំនៅបារាំង និងហូឡង់បានអភិវឌ្ឍទំនាក់ទំនងបែបសហប្រតិបត្តិការជាមួយជនជាតិដើមអាមេរិក។ ការធ្វើដូច្នេះមួយភាគធំដោយសារពួកគេចង់ទទួលបានអត្ថប្រយោជន៍ទៅវិញទៅមកពីការធ្វើពាណិជ្ជកម្មរោមសត្វ។ ជនជាតិដើមអាមេរិកដាក់អន្ទាក់សត្វជាច្រើន និងបន្ទាប់មកដោះដូរស្បែកសត្វទាំងនោះជាមួយនឹងសម្ភារៈមួយចំនួនរបស់បារាំង ក្នុងនោះមានដូចជាកាំភ្លើង, មួក, កញ្ចក់, និងអង្កាំ។ ពួកហូឡង់ក៏បានសហប្រតិបត្តិការជាមួយជនជាតិដើមអាមេរិក នៅក្នុងការព្យាយាមមួយដើម្បីបង្កើតសហគ្រាសពាណិជ្ជកម្មស្បែកសត្វមួយ។ ក្រុមទាំងនេះមិនបានរស់នៅជាមួយគ្នាដោយសុខដុមពេញលេញឡើយ។ ក្រុមអ្នកតាំងទីលំនៅហូឡង់ បានវាយប្រយុទ្ធគ្នាជាមួយជនជាតិដើមអាមេរិកជាច្រើនក្រុមលើបញ្ហានៃការអះអាងពីការ

កាន់កាប់ដែនដី និងសិទ្ធិនៃការធ្វើពាណិជ្ជកម្ម។ ប៉ុន្តែ សម្រាប់ផ្នែកជាច្រើនអាណានិគមជនបារាំង និងហូឡង់រស់នៅជាមួយគ្នាដោយសន្តិភាពជាមួយម្ចាស់ដែនដីជនជាតិដើមអាមេរិក។

យើងមិនអាចនិយាយរឿងដូចគ្នាចំពោះអង់គ្លេសឡើយ។ ទំនាក់ទំនងដំបូងរវាងក្រុមអ្នកតាំងទីលំនៅអង់គ្លេសជាមួយជនជាតិដើមអាមេរិកមានលក្ខណៈសហការគ្នា។ ប៉ុន្តែ ទំនាក់ទំនងនេះភ្លាមៗកាន់តែអាក្រក់ទៅលើបញ្ហាដីធ្លី និងសាសនា។ ខុសពីប្រទេសបារាំង និងហូឡង់ អង់គ្លេសសម្លឹងទៅរកការតាំងទីលំនៅក្នុងដែនដីអាណានិគមនៅអាមេរិកខាងជើង។ ការនេះមានន័យថារុញច្រានជនជាតិដើមចេញពីដីរបស់ពួកគេ។ ពួកអាណានិគមជនអង់គ្លេសបានដណ្តើមកាន់កាប់ដែនដីកាន់តែច្រើនដើម្បីប្រជាជនរបស់ពួកគេ និងដើម្បីដាំដុះដំណាំថ្នាំជក់។ ភាពខុសគ្នានៃសាសនាក៏បង្កើនជម្លោះផងដែរ។ ក្រុមអ្នកតាំងទីលំនៅអង់គ្លេសចាត់ទុកជនជាតិដើមអាមេរិកជាអ្នកមិនមានជំនឿសាសនា។ ក្រោយមក ពួកអ្នកប្រកាន់គោលការណ៍សាសនាតឹងរឹងជាច្រើនបានមើលឃើញថាជនជាតិដើមអាមេរិកគឺជាភ្នាក់ងារនៃវិញ្ញាណបិសាច និងជាការគំរាមមួយដល់សង្គមជឿលើសាសនារបស់ពួកគេ។ ជនជាតិដើមអាមេរិកបានអភិវឌ្ឍនូវការយល់ឃើញស្រដៀងគ្នាពីភាពឃោរឃៅនៃក្រុមអ្នកឈ្លានពានអឺរ៉ុប។

ការប្រយុទ្ធគ្នារវាងក្រុមអ្នកតាំងទីលំនៅ និងជនជាតិដើមអាមេរិក៖ អរិភាពរវាងក្រុមអ្នកតាំងទីលំនៅអង់គ្លេសជាមួយជនជាតិដើមអាមេរិកបាននាំទៅដល់ការផ្ទុះឡើងនៃសង្គ្រាម។ នៅដើមឆ្នាំ 1622 ក្រុមកុលសម្ព័ន្ធប៉ូហាតានបានវាយប្រហារលើភូមិអាណានិគមនៅជុំវិញទីក្រុងជេនថោន និងបានសម្លាប់ក្រុមអ្នកតាំងទីលំនៅប្រមាណ 350 នាក់។ អំឡុងពេលប៉ុន្មានឆ្នាំក្រោយមក ពួកអាណានិគមជនបានវាយបក និងសម្លាប់រង្គាលលើកពួកប៉ូហាតានអស់រាប់រយនាក់។ ជម្លោះដ៏បង្ហូរឈាមមួយរវាងពួកអាណានិគមជន និងជនជាតិដើមអាមេរិកត្រូវបានគេស្គាល់ថាសង្គ្រាមស្តេចហ្វីលីប។ វាបានចាប់ផ្តើមនៅក្នុងឆ្នាំ 1675 នៅពេលដែលមេដឹកនាំជនជាតិដើមអាមេរិកឈ្មោះមេតាខុម (ក៏ត្រូវបានគេស្គាល់ថាស្តេចហ្វីលីប) បានដឹកនាំការវាយប្រហារមួយទៅលើភូមិអាណានិគមនានានៅពាសពេញម៉ាសាឈូសេត។ ប៉ុន្មានខែក្រោយមក ភាគីទាំងសងខាងបានសម្លាប់រង្គាលលើជនរងគ្រោះរាប់រយនាក់។ បន្ទាប់ពីវាយប្រយុទ្ធគ្នាអស់រយៈពេលមួយឆ្នាំ ពួកអាណានិគមជនបានយកជ័យជំនះលើពួកជនជាតិដើម។ នៅអំឡុងសតវត្សរ៍ទី 17 ការប៉ះទង្គិចគ្នាជាច្រើនបានផ្ទុះឡើងនៅពាសពេញអាមេរិកខាងជើង។

ជនជាតិដើមធ្លាក់ទៅក្នុងជម្ងឺឆ្លង៖ អ្វីដែលគ្រោះថ្នាក់ជាងអាវុធរបស់ពួកអឺរ៉ុបគឺជំងឺរបស់ពួកគេ។ ក៏ដូចជាពួកអេស្ប៉ាញនៅអាមេរិកកណ្តាល និងអាមេរិកខាងត្បូង ពួកអឺរ៉ុបដែលតាំងទីលំនៅនៅអាមេរិកខាងជើងបាននាំមកជាមួយពួកគេនូវជំងឺជាច្រើនប្រភេទ។ ជំងឺទាំងនេះបានបង្កគ្រោះមហន្តរាយដល់ជនជាតិដើមនៅអាមេរិកខាងជើង។ ឧទាហរណ៍ នៅក្នុងឆ្នាំ 1616 ជំងឺឆ្លងអុតស្វាយបានបំផ្លិចបំផ្លាញជីវិតរបស់ពួកជនជាតិដើមអាមេរិកនៅតាមបណ្តោយឆ្នេរសមុទ្រអង់គ្លេសថ្មី។ ប្រជាជននៅក្នុងកុលសម្ព័ន្ធមួយនៅម៉ាសាឈូសេតបានធ្លាក់ចុះពី 24,000 នាក់មកនៅត្រឹម 750 នាក់ត្រឹមឆ្នាំ 1631 ។ ចាប់តាំងពីការ៉ូលីណាភាគខាងត្បូងដល់មីសូរី កុលសម្ព័ន្ធស្ទើរតែទាំងស្រុងបានឆ្លងជំងឺអុតស្វាយ, កញ្ជ្រិល, និងជម្ងឺផ្សេងៗទៀត។ ឥទ្ធិពលដ៏សំខាន់មួយនៃការបាត់បង់នេះគឺកង្វះខាតធ្ងន់ធ្ងរនៃកម្លាំងពលកម្មនៅក្នុងដែនដីអាណានិគម។ ដើម្បីឆ្លើយតបជាមួយការកើនឡើងនៃតម្រូវការកម្លាំង

ពលកម្ម, ពួកអាណានិគមជនអឺរ៉ុបភ្លាមៗនោះបានត្រឡប់ការចាប់អារម្មណ៍របស់ពួកគេទៅលើក្រុមមួយទៀតគឺពួកអាហ្វ្រិកដែលត្រូវបានគេចាប់យកមកធ្វើជាទាសកររាប់លាននាក់។

# មេរៀនទី 3 ៖ពាណិជ្ជកម្មទាសករនៅអាត្លង់ទិក

ភ្ជាប់ទៅនិងអ្វីដែលអ្នកបានដឹង៖ ការដាំដុះដំណាំអំពៅ និងថ្នាក់ជក់តម្រូវឱ្យមានការផ្គត់ផ្គង់កម្លាំងកម្មករច្រើនដើម្បីធ្វើឱ្យដំណាំទាំងនោះទទួលបានផលចំណេញសម្រាប់ម្ចាស់របស់ពួកវា។ ម្ចាស់ចំការដាំណាំជនជាតិអឺរ៉ុបមានបំណងនៅក្នុងការប្រើប្រាស់ជនជាតិដើមអាមេរិកធ្វើជាធនធានពលកម្មក្នុងតម្លៃថោកមួយ។ ប៉ុន្តែជនជាតិដើមអាមេរិករាប់លាននាក់បានស្លាប់ដោយសារជំងឺ, សង្គ្រាម, និងការអនុវត្តដ៏ឃោឃៅចំពោះពួកគេ។ ដូច្នេះពួកអឺរ៉ុបនៅក្នុងប្រទេសប្រេស៊ីល, ការីប៊ីន, និងដែនដីអាណានិគមភាគខាងត្បូងនៃអាមេរិកខាងជើងភ្លាមៗនោះបានត្រឡប់ការចាប់អារម្មណ៍របស់ពួកគេលើកម្មករអាហ្វ្រិក។ តម្រូវការសម្រាប់កម្លាំងពលកម្មថោកនេះនាំទៅដល់ការលេចឡើងនៃពាណិជ្ជកម្មទាសករដ៏ព្រៃផ្សៃ។

## 1. មូលហេតុនៃទាសភាពអាហ្វ្រិក

ចាប់ផ្ដើមដំបូងនៅវង្វង់ឆ្នាំ 1500 ពួកអាណានិគមជនអឺរ៉ុបនៅអាមេរិកដែលត្រូវបានកម្លាំងពលកម្មថោកចាប់ផ្ដើមប្រើប្រាស់ទាសករអាហ្វ្រិកនៅក្នុងចំការដំណាំរបស់ពួកគេ។

ទាសភាពនៃអាហ្វ្រិក៖ ទាសភាពបានលេចឡើងនៅអាហ្វ្រិកអស់រយៈពេលជាច្រើនសតវត្សរ៍។ នៅក្នុងតំបន់ភាគច្រើន វាលេចឡើងក្នុងកម្រិតស្ថាប័នតូចមួយប៉ុណ្ណោះ។ ប៉ុន្តែ ការសាយភាយនៃសាសនាអ៊ីស្លាមមកកាន់អាហ្វ្រិកអំឡុងសតវត្សរ៍ទី 7 បានបង្កើនឱ្យមានទាសភាព និងពាណិជ្ជកម្មទាសករ។ មេដឹកនាំម៉ូស្លីមនៅអាហ្វ្រិកយុត្តិកម្មទាសភាពជាមួយនឹងជំនឿសាសនាដែលថាអ្នកទោសសង្គ្រាមមិនមែនម៉ូស្លីមអាចត្រូវបាននាំយក និងលក់ធ្វើជាទាសករ។ ជាលទ្ធផល រវាងឆ្នាំ 650 ដល់ 1600 ពួកម៉ូស្លីមបានដឹកជញ្ជូនពួកអាហ្វ្រិកប្រមាណ 17 លាននាក់ទៅកាន់ដែនដីនានារបស់ពួកម៉ូស្លីមនៅអាហ្វ្រិកខាងជើង និងអាស៊ីនិរតី។ នៅក្នុងសង្គមអាហ្វ្រិក និងម៉ូស្លីមភាគច្រើនទាសករមានសិទ្ធិផ្នែកច្បាប់មួយចំនួន និងមានឱកាសមួយសម្រាប់ការចូលរួមជាមួយសង្គម។ នៅក្នុងពិភពម៉ូស្លីមទាសករមួយចំនួនតូចថែមទាំងបានកាន់កាប់តួនាទីដែលមានឥទ្ធិពល និងមានអំណាចថែមទៀតផង។ អ្នកមួយចំនួនបម្រើការជាឧត្តមសេនីយ៍នៅក្នុងជួរកងទ័ព។ នៅក្នុងសង្គមអាហ្វ្រិក ទាសករអាចដោះខ្លួនចេញពីទាសភាពនៅក្នុងវិធីជាច្រើន ដោយក្នុងនោះរួមមានទាំងការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្រួសារដែលពួកគេបម្រើផងដែរ។

តម្រូវការពួកអាហ្វ្រិក៖ ពួកអឺរ៉ុបដំបូងដែលរកឃើញអាហ្វ្រិកគេគឺពួកព័រទុយហ្គាល់នៅអំឡុងទសវត្សរ៍ឆ្នាំ 1400 ។ ចាប់ផ្ដើមដំបូង ពាណិជ្ជករព័រទុយហ្គាល់មានចំណាប់អារម្មណ៍តែទៅលើការធ្វើពាណិជ្ជកម្មមាសជាជាងការចាប់ពួកអាហ្វ្រិក។ មានការផ្លាស់ប្ដូរជាមួយការដាក់អាណានិគមនៅអាមេរិក ដូចដែលជនជាតិដើមនៅទីនោះថយចុះរាប់លាននាក់។ ពួកអឺរ៉ុបបានមើលឃើញពីអត្ថប្រយោជន៍នៅក្នុងការប្រើប្រាស់ពួកអាហ្វ្រិកនៅអាមេរិក។ ដំបូង ពួកអាហ្វ្រិកជាច្រើនធ្លាប់ឆ្លងជម្ងឺរបស់ពួកអឺរ៉ុប និងបានស្ថាបនាប្រព័ន្ធការពារមួយចំនួន។ ទីពីរ ពួកអាហ្វ្រិកជាច្រើនមានបទពិសោធន៍នៅក្នុងការដាំដុះ និងអាចបង្រៀនពីការងារដាំដុះ។ ទីបី ពួកអាហ្វ្រិកប្រហែលជាមិនរត់គេចបានឡើយព្រោះពួកគេមិនស្គាល់ទីតាំងនៅលើដែនដីថ្មី។ ទីបួនពណ៌ស្បែករបស់ពួកគេមានភាពងាយស្រួលនៅក្នុងការកំណត់ចំណាំប្រសិនបើពួកគេរត់គេច និងព្យាយាមនៅក្នុងការរស់នៅបន្លំខ្លួនជាមួយអ្នកដ៏ទៃ។ ក្រោយ

មក ការទិញ និងលក់ពួកអាហ្វ្រិកដើម្បីធ្វើជាកម្មករនៅអាមេរិក ដែលត្រូវបានគេស្គាល់ថាពាណិជ្ជកម្មទាសករនៅអាត្លង់ទិក បានក្លាយជាសហគ្រាសដ៏ធំមួយ។ រវាងឆ្នាំ 1500 និង 1600 មានប្រជាជនអាហ្វ្រិកជិត 300,000 នាក់ត្រូវបានគេដឹកជញ្ជូនទៅកាន់អាមេរិក។ អំឡុងពេលមួយសតវត្សរ៍ក្រោយមក ចំនួនបានកើនឡើងទៅដល់ 1.3 លាននាក់។ នៅត្រឹមពេលដែលពាណិជ្ជកម្មទាសករនៅអាត្លង់ទិកត្រូវបានបញ្ចប់នៅរង្វង់ឆ្នាំ 1870 ពួកអឺរ៉ុបបាននាំចូលប្រជនជានអាហ្វ្រិកប្រមាណ 9.5 លាននាក់ទៅកាន់អាមេរិក។

អេស្ប៉ាញ និងព័រទុយហ្គាល់នាំមុខ៖ ពួកអេស្ប៉ាញបាននាំមុខគេនៅក្នុងការនាំយកពួកអាហ្វ្រិកទៅកាន់ដែនដីអាមេរិក។ អេស្ប៉ាញបានផ្លាស់ប្តូរពីការីប៊ូន និងចាប់ផ្តើមគ្រប់គ្រងអាណានិគមលើអាមេរិកដីគោក។ ជាលទ្ធផលពួកអេស្ប៉ាញបាននាំចូលពួកអាហ្វ្រិករាប់ពាន់នាក់មកធ្វើជាទាសករ។ ត្រឹមឆ្នាំ 1650 កម្មករអាហ្វ្រិកជិត 300,000 ធ្វើការនៅពាសពេញដែនដីអេស្ប៉ាញអាមេរិក នៅក្នុងចំការដំណាំ និងអណ្តូងរ៉ែមាស និងប្រាក់។ ប៉ុន្តែ នៅពេលនោះពួកព័រទុយហ្គាល់បាននាំមុខពួកអេស្ប៉ាញនៅក្នុងការនាំចូលពួកអាហ្វ្រិកទៅកាន់អាមេរិក។ អំឡុងទសវត្សរ៍ឆ្នាំ 1600 ប្រេស៊ីលបានគ្រប់ដណ្តប់លើទីផ្សារស្ករនៅអឺរ៉ុប។ ដូចដែលឧស្សាហ៍កម្មស្ករបស់ដែនដីអាណានិគមកើនឡើង ពួកអាណានិគមជនអឺរ៉ុបក៏ត្រូវការកម្លាំងពលកម្មថោកៗផងដែរ។ អំឡុងសតវត្សរ៍ទី 17 ជាង 40% នៃប្រជាជនអាហ្វ្រិកដែលត្រូវបាននាំយកមកកាន់អាមេរិក ស្ថិតនៅក្នុងប្រទេសប្រេស៊ីល។

## 2. ទាសភាពរីកសាយភាយពាសពេញអាមេរិក

ដូចដែលប្រទេសអឺរ៉ុបផ្សេងៗទៀតបង្កើតដែនដីអាណានិគមនៅអាមេរិក តម្រូវការកម្លាំងពលកម្មថោកៗរបស់ពួកគេបានកើនឡើង។ ដូច្នេះ ពួកគេក៏បានចាប់ផ្តើមនាំចូលពួកអាហ្វ្រិកក្នុងចំនួនដ៏ច្រើនមួយ។

អង់គ្លេសគ្រប់ដណ្តប់លើពាណិជ្ជកម្មទាសករ៖ ដូចដែលវត្តមានរបស់អង់គ្លេសនៅក្នុងអាមេរិកកើនឡើងពួកគេបានក្លាយជាអ្នកគ្រប់ដណ្តប់ពាណិជ្ជកម្មទាសករនៅអាត្លង់ទិក។ ចាប់ពីឆ្នាំ 1690 រហូតដល់ពេលដែលអង់គ្លេសបោះបង់ចោលការធ្វើពាណិជ្ជកម្មទាសករនៅក្នុងឆ្នាំ 1807 ពួកគេបាននាំមុខគេនៅក្នុងនាំយកពួកអាហ្វ្រិកមកធ្វើជាទាសករ។ នៅត្រឹមពេលដែលពាណិជ្ជកម្មទាសករអាហ្វ្រិកបានបញ្ចប់ ពួកអង់គ្លេសបានដឹកជញ្ជូនប្រជាជនអាហ្វ្រិកជិត 1.7 លាននាក់មកកាន់ដែនដីអាណានិគមរបស់ពួកគេនៅឥណ្ឌាខាងលិច។ ទាសករអាហ្វ្រិកក៏ត្រូវបាននាំយកមកកាន់ដែនដីដែលបច្ចុប្បន្នជាសហរដ្ឋអាមេរិកផងដែរ។ ជាសរុប មានប្រជាជនអាហ្វ្រិកជិត 400,000 នាក់ត្រូវបាននាំយកមកកាន់ដែនដីអាណានិគមអាមេរិកខាងជើងរបស់អង់គ្លេស។ ជាមួយគ្នាផងដែរ ចំនួនទាសករនៅអាមេរិកខាងជើង បានកើនឡើងយ៉ាងឆាប់រហ័ស។ ត្រឹមឆ្នាំ 1830 មានទាសករប្រមាណ 2 លាននាក់បានតាំងទីលំនៅនៅសហរដ្ឋអាមេរិក។

អាហ្វ្រិកសហការ និងបះបោរ៖ មេដឹកនាំ និងពាណិជ្ជករអាហ្វ្រិកជាច្រើនបានដើរតួនាទីដោយសុទ្ធចិត្តនៅក្នុងការធ្វើពាណិជ្ជកម្មទាសករនៅអាត្លង់ទិក។ ពាណិជ្ជករអឺរ៉ុបភាគច្រើន ជាជាងធ្វើដំណើរទៅកាន់ដែនដីខាងក្នុងពួកគេរង់ចាំនៅកំពង់ផែតាមបណ្តោយឆ្នេរសមុទ្រអាហ្វ្រិក។ ពាណិជ្ជករអាហ្វ្រិកជាមួយនឹងការជួយពីសំណាក់មេដឹកនាំក្នុងតំបន់ បានចាប់ពួកអាហ្វ្រិកធ្វើជាទាសករ។ ពេលនោះពួកគេដឹកជញ្ជូនពួកគេមកឱ្យពួកអឺរ៉ុបដើម្បីដោះ

ដូរជាមួយមាស, កាំភ្លើង, និងទំនិញផ្សេងៗទៀត។ ដូចដែលពាណិជ្ជកម្មទាសករកើនឡើង មេដឹកនាំអាហ្វ្រិកមួយចំនួនបង្ហាញពីការប្រឆាំងរបស់ពួកគេចំពោះការអនុវត្តបែបនេះ។ ដោយមិនចាំបាច់និយាយ ពាណិជ្ជកម្មទាសករនៅតែបន្តកើនឡើងយ៉ាងខ្លាំង។ ដោយទាក់ទងជាមួយនឹងផលចំណេញរបស់វា មេដឹកនាំអាហ្វ្រិកជាច្រើននៅតែបន្តចូលរួមនៅក្នុងការធ្វើពាណិជ្ជកម្មនេះ។ ពាណិជ្ជករអាហ្វ្រិកបានអភិវឌ្ឍផ្លូវពាណិជ្ជកម្មថ្មីៗដើម្បីវាងមេដឹកនាំណាដែលបដិសេធនៅក្នុងការសហការ។

### 3. ដំណើរផ្សងព្រេងដោយការបង្ខំ

បន្ទាប់ពីត្រូវបានចាប់ខ្លួន បុរស និងស្ត្រីជនជាតិអាហ្វ្រិកត្រូវបានគេដឹកជញ្ជូនតាមនាវាទៅកាន់អាមេរិក ដែលជាផ្នែកមួយនៃបណ្តាញពាណិជ្ជកម្មដែលទទួលបានផលចំណេញមួយ។ នៅតាមផ្លូវ មានជនជាតិអាហ្វ្រិករាប់លាននាក់បានស្លាប់។

ពាណិជ្ជកម្មត្រីកោណ៖ ការដឹកជញ្ជូនពួកអាហ្វ្រិកទៅកាន់អាមេរិកគឺជាផ្នែកមួយនៃបណ្តាញពាណិជ្ជកម្មឆ្លងមហាសមុទ្រអាត្លង់ទិកមួយដែលគេស្គាល់ថាពាណិជ្ជកម្មត្រីកោណ។ នៅលើផ្លូវពាណិជ្ជកម្មមួយ ពួកអឺរ៉ុបបានដឹកជញ្ជូនទំនិញរោងចក្រនានាទៅកាន់តំបន់ឆ្នេរសមុទ្រអាហ្វ្រិកភាគខាងលិច។ នៅទីនោះ ពាណិជ្ជករបានផ្តោះប្តូរទំនិញទាំងអស់នេះជាមួយពួកអាហ្វ្រិកដែលគេចាប់បាន។ ពេលនោះពួកអាហ្វ្រិកទាំងនោះត្រូវបានគេដឹកជញ្ជូនឆ្លងកាត់មហាសមុទ្រអាត្លង់ទិក និងលក់នៅឥណ្ឌាខាងលិច។ ពួកពាណិជ្ជករនាំយកស្ករ, កាហ្វេ, និងថ្នាំជក់ពីឥណ្ឌាខាងលិច និងធ្វើដំណើរទៅកាន់អឺរ៉ុបជាមួយនិងផលិតផលទាំងនេះ។ នៅលើផ្លូវពាណិជ្ជកម្មត្រីកោណមួយទៀត ពាណិជ្ជករបាននាំយកស្រា និងទំនិញផ្សេងៗទៀតពីដែនដីអាណានិគមអង់គ្លេសថ្មីទៅកាន់អាហ្វ្រិក។ នៅទីនោះពួកគេបានផ្តោះប្តូរទំនិញរបស់ពួកគេជាមួយទាសករអាហ្វ្រិក។ ពាណិជ្ជករបានដឹកជញ្ជូនពួកអាហ្វ្រិកទៅកាន់ឥណ្ឌាខាងលិច និងដោះដូរពួកគេជាមួយស្ករ និងទឹករង្វ។ បន្ទាប់មកពួកគេលក់ទំនិញទាំងនេះទៅដល់អ្នកផលិតស្រានៅអង់គ្លេសថ្មី។ មានផ្លូវពាណិជ្ជកម្មឆ្លងមហាសមុទ្រអាត្លង់ទិកផ្សេងៗជាច្រើនទៀតបានលេចឡើង។ ពាណិជ្ជកម្ម "ត្រីកោណ" រួបបញ្ចូលបណ្តាញផ្លូវពាណិជ្ជកម្មមួយដែលខ្វាត់ខ្វែងដែនដីអាណានិគមភាគខាងជើង និងភាគខាងត្បូង, ឥណ្ឌាខាងលិច, អង់គ្លេស, អឺរ៉ុប, និងអាហ្វ្រិក។ បណ្តាញពាណិជ្ជកម្មនេះបាននាំយកមកនូវទំនិញពាណិជ្ជកម្មដ៏សម្បូរបែប។

ដំណើរពាក់កណ្តាលផ្លូវ៖ ការធ្វើដំណើរដែលនាំយកពួកអាហ្វ្រិកដែលគេចាប់យកទៅឥណ្ឌាខាងលិច និងក្រោយមកអាមេរិកខាងជើង និងអាមេរិកខាងត្បូងត្រូវបានគេស្គាល់ថាដំណើរពាក់កណ្តាលផ្លូវ។ វាត្រូវបានគេចាត់ទុកថាជាដំណើរពាក់កណ្តាលផ្លូវនៃពាណិជ្ជកម្មត្រីកោណឆ្លងកាត់មហាសមុទ្រអាត្លង់ទិក។ លក្ខណៈនៃការធ្វើដំណើរផ្សងព្រេងនេះមានភាពសាហាវឃោឃៅ។ នៅកំពង់ផងនៅអាហ្វ្រិក ពាណិជ្ជករអឺរ៉ុបបានដាក់ពួកអាហ្វ្រិកចូលទៅក្នុងបន្ទប់ងងឹតនៅលើនាវាធំៗ។ នៅលើនាវា ពួកអាហ្វ្រិកស៊ូទ្រាំទៅនិងការវាត់ និងវាយដំពីសំណាក់ពួកពាណិជ្ជករ ក៏ដូចជាជម្ងឺដែលបានរីករាលដាលពេញនាវា។ មានពួកអាហ្វ្រិកជាច្រើនបានស្លាប់ដោយសារជំងឺ និងការរំលោភបំពាន់លើរាងកាយពួកគេនៅលើនាវាដឹកពួកទាសករ។ ពួកគេជាច្រើនទៀតបានធ្វើអត្តឃាតដោយ

លោតចូលទៅក្នុងទឹក។ អ្នកប្រាជ្ញបានប៉ាន់ប្រមាណថាប្រហែលជា 20% នៃពួកអាហ្វ្រិកដែលត្រូវបានគេដឹកជញ្ជូនតាមនាវាដឹកទាសករនីមួយៗបានស្លាប់នៅអំឡុងពេលនៃការធ្វើដំណើរដ៏ព្រៃផ្សៃនេះ។

### 4. ទាសភាពនៅអាមេរិក

ពួកអាហ្វ្រិកដែលរស់រានពីការធ្វើដំណើរឆ្លងកាត់មហាសមុទ្ទ ប្រឈមទៅនឹងជីវិតដ៏លំបាកនៅអាមេរិក។ ឆ្លើយតបជាមួយនិងការបង្ខំឱ្យធ្វើការនៅលើដែនដីចម្លែកមួយ ពួគទាសករអាហ្វ្រិកបានដោះស្រាយបញ្ហានេះដោយវិធីផ្សេងៗ។

ជីវិតរស់នៅដ៏វេទនា៖ នៅពេលដែលពួកគេមកដល់អាមេរិក ពួកអាហ្វ្រិកដែលត្រូវបានគេចាប់ជាទូទៅត្រូវបានគេដាក់ដេញថ្លៃដើម្បីរកម្ចាស់ណាដែលហ៊ានឱ្យតម្លៃខ្ពស់ជាងគេ។ បន្ទាប់ពីត្រូវបានលក់ហើយ ទាសករត្រូវធ្វើការនៅក្នុងអណ្តូងរ៉ែ ឬស្រែចំការ ឬអ្នកបម្រើក្នុងផ្ទះ។ ទាសកររស់នៅយ៉ាងលំបាក។ ពួកគេជាច្រើនរស់នៅជាមួយនឹងចំណីអាហារតិចតួច និងនៅក្នុងខ្ទមតូច និងអាប់អួរមួយ។ ពួកគេធ្វើការពេញមួយថ្ងៃ និងទទួលរងការវាយដំ។ នៅក្នុងដែនដីអាមេរិកភាគច្រើន ទាសភាពមានលក្ខណៈពេញមួយជីវិត និងតពូជផងដែរ។

ការតស៊ូប្រឆាំង និងការបះបោរ៖ ដើម្បីទាប់ទល់ជាមួយនឹងភាពឃោឃៅនៃទាសភាព ពួកអាហ្វ្រិកបានអភិវឌ្ឍវិធីរស់នៅមួយដោយផ្អែកលើមរតកវប្បធម៌របស់ពួកគេ។ ពួកគេបានរក្សាទុកនូវរបស់មួយចំនួនដូចជាឧបករណ៍តន្ត្រីបុរាណក៏ដូចជារឿងរ៉ាវនានារបស់បុព្វការីជនរបស់ពួកគេ។ ទាសករក៏បានស្វែងរកវិធីនៅក្នុងការប្រឆាំងផងដែរ។ ពួកគេបានធ្វើឱ្យផលិតកម្មមានការថយចុះតាមរយៈការបំបែកឧបករណ៍ប្រើប្រាស់, ដកឬសដំណាំ, និងធ្វើការយឺតៗ។ មានទាសកររាប់ពាន់នាំបានរត់គេចខ្លួន។ ទាសករមួយចំនួនបានរុញច្រានការប្រឆាំងរបស់ទៅដល់ការបះបោរ។ នៅដើមដំបូង ត្រឹមឆ្នាំ 1522 មានទាសករប្រមាណ 20 នាក់នៅហ៊ីស្ប៉ានីអូឡាបានវាយប្រហារ និងសម្លាប់អាណានិគមជនអេស្ប៉ាញអស់ជាច្រើននាក់។ ការបះបោរធំៗបានលេចឡើងនៃពាសពេញតំបន់ដែលពួកអេស្ប៉ាញតាំងទីលំនៅនៅអំឡុងសតវត្សរ៍ទី 16 ។ ការងើបឡើងបះបោរយូរៗម្តងក៏កើតមានឡើងនៅប្រេស៊ីល, ឥណ្ឌាខាងលិច, និងអាមេរិកខាងជើងផងដែរ។ នៅក្នុងឆ្នាំ 1739 ទាសករមួយក្រុមនៅអារ៉ូលីណាខាងត្បូងបានដឹកនាំការបះបោរមួយដែលគេស្គាល់ថាការបះបោរស្តូណូ។ ការងើបឡើងបះបោរបន្តរហូតដល់ទសវត្សរ៍ឆ្នាំ 1800 ។

### 5. ហេតុបច្ច័យនៃពាណិជ្ជកម្មទាសករ

ពាណិជ្ជកម្មទាសករអាត្លង់ទិកជះឥទ្ធិពលដ៏ធំធេងមួយទាំងលើទ្វីបអាហ្វ្រិក និងអាមេរិក។ នៅអាហ្វ្រិកវប្បធម៌ជាច្រើនបានបាត់បង់អ្នកជំនាន់ក្រោយ ដោយសារយុវជន និងអ្នកមានសមត្ថភាពត្រូវបានពាណិជ្ជករ និងម្ចាស់ចំការដំណាំនាំយកទៅកាន់អាមេរិក។ ជាងនេះទៅទៀត គ្រួសារអាហ្វ្រិករាប់មិនអស់ត្រូវបានបែកបាក់គ្នា។ ពួកគេមួយភាគធំមិនដែលបានជួបជុំគ្នាវិញឡើយ។ ពាណិជ្ជកម្មទាសករបានធ្វើឱ្យមហន្តរាយដល់សង្គមអាហ្វ្រិកនៅក្នុងវិធីមួយផ្សេងទៀត៖ តាមរយៈការនាំយកអាវុធទៅកាន់ទ្វីបនេះ។ ខណៈពេលដែលពួកគេមិនមានឆន្ទៈនៅក្នុងការធ្វើឱ្យរីកលូតលាស់នៃអាណានិគម ទាសករអាហ្វ្រិកបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងវប្បធម៌នៅ

អាមេរិក។ ការរួមចំណែកដ៏សំខាន់បំផុតរបស់ពួកគេគឺកម្លាំងការងាររបស់ពួកគេ។ ប្រសិនបើមិនមានការ៉ាប់រងការងាររបស់ពួកគេ ដែនដីអាណានិគមមួយចំនួនដូចជាហៃទី និងបាបាដូសនឹងមិនអាចរស់បានឡើយ។ បន្ថែមទៅលើកម្លាំងរបស់ពួកគេ ទាសករអាហ្វ្រិកបាននាំយកមកជាមួយពួកគេនូវជំនាញនានា, ជាពិសេសជំនាញនៅក្នុងវិស័យកសិកម្ម។ ពួកគេក៏បាននាំយកវប្បធម៌របស់ពួកគេមកផងដែរ។ សិល្បៈ, តន្ត្រី, សាសនា, និងចំណីអាហាររបស់ពួកគេបានបន្តមានឥទ្ធិពលលើសង្គមអាមេរិក។ លំហូរជនជាតិអាហ្វ្រិកជាច្រើនមកកាន់អាមេរិកក៏បានបន្សល់ទុកនូវចំនួនប្រជាជនអាហ្វ្រិកដ៏ច្រើនផងដែរ។ ចាប់ពីសហរដ្ឋអាមេរិករហូតដល់ប្រេស៊ីល ប្រទេសជាច្រើននៅហេមីស្ពែភាគខាងលិចនាពេលបច្ចុប្បន្នមានប្រជាជនអាហ្វ្រិក-អាមេរិកច្រើនគួរសម។ ប្រទេសអាមេរិកឡាទីនជាច្រើនមានប្រជាជនលាយជាតិសាសន៍ច្រើនល្មម។ ដូចដែលមេរៀនបន្ទាប់នឹងពន្យល់ មិនមែនមានតែពួកអាហ្វ្រិកប៉ុណ្ណោះទេ ដែលត្រូវបានគេដឹកជញ្ជូនឆ្លងកាត់មហាសមុទ្រអាត្លង់ទិចនៅអំឡុងសម័យអាណានិគមនៅអាមេរិក។ ក្រុមអ្នកតាំងទីលំនៅនៅអាមេរិកបាននាំយកវត្ថុខុសគ្នាជាច្រើនមកពីអឺរ៉ុប, អាស៊ី, និងអាហ្វ្រិកមកកាន់អាមេរិកខាងជើង និងអាមេរិកខាងត្បូង។ ពួកគេក៏បាននាំយកវត្ថុនានានៅអាមេរិកទៅកាន់ពិភពលោកទាំងមូល។

# មេរៀនទី 3 ៖ ការផ្លោះប្តូរកូឡុំប៊ី និងពាណិជ្ជកម្មសកល

រម្លឹកពីអ្វីដែលអ្នកបានដឹង៖ អាណានិគមនៅអាមេរិកបានផ្លាស់ប្តូរពិភពលោកយ៉ាងខ្លាំង។ វាបានជម្រុញឱ្យមានមនុស្សរាប់លាននាក់ធ្វើអន្តោប្រវេសន៍ដោយស្ម័គ្រចិត្ត និងដោយបង្ខំ។ វាបាននាំទៅដល់ការបង្កើតឡើងនៃសង្គមថ្មី និងមានអំណាចនានា។ ឥទ្ធិពលផ្សេងទៀតនៃការតាំងទីលំនៅរបស់ពួកអឺរ៉ុបនៅអាមេរិកគឺមិនសូវមានការគត់សំគាល់ប៉ុន្តែមានសារៈសំខាន់ដូចគ្នា។ ការដាក់អាណានិគមបណ្តាលឱ្យមានការផ្លាស់ប្តូរនូវរបស់ថ្មីៗដែលបានជះឥទ្ធិពលយ៉ាងខ្លាំងលើជីវិតរស់នៅរបស់ប្រជាជននៅពាសពេញពិភពលោក។ ទ្រព្យសម្បត្តិថ្មីមកពីអាមេរិកបណ្តាលឱ្យមានការអនុវត្តជំនួញ និងពាណិជ្ជកម្មថ្មីនៅអឺរ៉ុប។

## 1. ការផ្លោះប្តូរកូឡុំប៊ី

ការផ្លាស់ប្តូរជាសកលនៃចំណីអាហារ, ដំណាំ, និងសត្វអំឡុងពេលនៃការដាក់អាណានិគមនៅអាហ្វ្រិកត្រូវបានគេស្គាល់ថាការផ្តោះប្តូរកូឡុំប៊ី។ នាវាមកពីអាមេរិកបាននាំយកត្រឡប់មកវិញនូវរបស់របរជាច្រើនដែលពួកអឺរ៉ុប, អាស៊ី, អាហ្វ្រិកមិនធ្លាប់ដែលឃើញពីមុនមក។ ក្នុងនោះរួមមានទាំងដំណាំមួយចំនួនដូចជាដំឡូងបារាំង, ល្ពៅ, ម្នាស់, ថ្នាំជក់, និងកាការ (សម្រាប់ធ្វើសូកូឡា)។ ហើយក៏មានផងដែរនូវសត្វមួយចំនួនដូចជាទួគី, ដែលបានក្លាយជាធនធានចំណីអាហារមួយនៅហេមីស្វែភាគខាងកើត។ ប្រហែលជារបស់ដែលសំខាន់បំផុតដែលបានធ្វើដំណើរពីអាមេរិកទៅកាន់ពិភពលោកទាំងមូលគឺពោត និងដំឡូងបារាំង។ ដំណាំទាំងពីរនេះមានតម្លៃនៅក្នុងការដាំដុះ និងអាហារូបត្ថម្ភ។ ជាពិសេសដំឡូងបារាំងបានផ្តល់នូវវិតាមីន និងសារជាតិរ៉ែសំខាន់ៗជាច្រើន។ ក្រោយមកដំណាំទាំងពីរប្រភេទនេះបានក្លាយជាអាហារសំខាន់មួយនៅពាសពេញពិភពលោក។ ចំណីអាហារទាំងអស់នេះបានជួយឱ្យមនុស្សអាចរស់នៅបានយូរ។ ដូច្នេះវាបានដើរតួនាទីដ៏សំខាន់មួយនៅក្នុងការនបង្កើនចំនួនប្រជាជននៅលើពិភពលោក។ ការដាំដុះដំណាំដំឡូងបារាំងពណ៌សដំបូងត្រូវបានធ្វើឡើងនៅអៀកឡង់ និងដំឡូងបារាំងផ្អែមដំបូងនៅក្នុងប្រទេសចិន ប្រហែលជាបានផ្លាស់ប្តូរជីវិតរស់នៅច្រើនជាងការអនុវត្តរបស់ស្តេច 100 អង្គទៅទៀត។ ប៉ុន្តែ ការធ្វើចរាចរណ៍ឆ្លងកាត់មហាសមុទ្រអាត្លង់ទិកមិនមែនកើតមានឡើងតែទិសដៅមួយឡើយ។ ពួកអឺរ៉ុបបាននាំយកសត្វរស់ជាច្រើនប្រភេទទៅកាន់អាមេរិក។ ក្នុងនោះរួមមានសត្វសេះ, ពពែ, ចៀម, និងជ្រូក។ ចំណីអាហារមកពីអាហ្វ្រិក(ដោយរួមមានមួយចំនួនមានប្រភពដើមនៅអាស៊ី) បានធ្វើដំណើរទៅភាគខាងលិចតាមនាវារបស់ពួកអឺរ៉ុប។ ក្នុងនោះរួមមានចេក, សណ្តែកភ្នែកខ្មៅ, និងដំឡូងផ្វា។ គ្រាប់ធុញ្ញជាតិដែលបាននាំយកទៅកាន់អាមេរិករួមមានស្រូវសាលី, ស្រូវអង្ករ, ស្រូវប៉ាឡេ, និងស្រូវអូត។ ទិដ្ឋភាពមួយចំនួននៃការផ្តោះប្តូរកូឡុំប៊ីបានជះឥទ្ធិពលយ៉ាងសំខាន់មួយលើជនជាតិដើមអាមេរិក។ ជំងឺក៏ជាផ្នែកមួយដែលសំខាន់នៃការផ្តោះប្តូរកូឡុំប៊ីដូចជាទំនិញ និងចំណីអាហារផងដែរ។ ជំងឺដែលពួកអឺរ៉ុបបាននាំយកមកជាមួយពួកគេ ដោយក្នុងនោះរួមមានទាំងអុតស្វាយ និងកញ្ជ្រិល បណ្តាលឱ្យជនជាតិដើមអាមេរិករាប់លាននាក់បានស្លាប់។ ជំងឺផ្សេងៗទៀតដែលពួកអឺរ៉ុបបាននាំយកមកជាមួយពួកគេរួមមានផ្តាសាយ, គ្រុនពោល, គ្រុនចាញ់, និងខាន់ស្លាក់។

## 2. ពាណិជ្ជកម្មសកល

ការបង្កើតឡើងនៃចក្រភពអាណានិគមនៅអាមេរិក បានជះឥទ្ធិពលក្នុងវិធីផ្សេងៗលើប្រទេសនានានៅអឺរ៉ុប។ ទ្រព្យសម្បត្តិថ្មីមកពីអាមេរិកបានមកព្រមគ្នាជាមួយការកើនឡើងយ៉ាងខ្លាំងនៃពាណិជ្ជកម្មក្រៅប្រទេស។ កត្តាទាំងពីរនេះជម្រុញឱ្យមានរលកនៃការអនុវត្តជំនួញ និងពាណិជ្ជកម្មថ្មីៗនៅអឺរ៉ុបអំឡុងសតវត្សរ៍ទី 16 និង 17 ។ ការអនុវត្តនេះដែលភាគច្រើនដើរតួនាទីជាឫសគល់មួយនៃពាណិជ្ជកម្មហិរញ្ញវត្ថុនាពេលសព្វថ្ងៃ បានផ្លាស់ប្ដូរបរិយាកាសសេដ្ឋកិច្ចនៅអឺរ៉ុប។

ការរីកឡើងនៃមូលធននិយម៖ ទិដ្ឋភាពមួយនៃបដិវត្តសេដ្ឋកិច្ចអឺរ៉ុបគឺការកើនឡើងនៃមូលធននិយម។ មូលធននិយមគឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលផ្អែកសំខាន់លើកម្មសិទ្ធិឯកជន និងធនធានវិនិយោគ ក្នុងនោះមានដូចជាលុយជាដើម សម្រាប់ផលចំណេញ។ រដ្ឋាភិបាលមិនមែនជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិមហាសាលទៀតឡើយ។ ដោយសារការដាក់អាណានិគម និងពាណិជ្ជកម្មក្រៅប្រទេស ពាណិជ្ជករជាច្រើនទទួលបានទ្រព្យសម្បត្តិមហាសាល។ ពាណិជ្ជករទាំងនេះបន្តវិនិយោគលុយរបស់ពួលគេនៅក្នុងពាណិជ្ជកម្ម និងការរុករកដែនដីខាងក្រៅ។ ផលចំណេញដែលបានមកពីការវិនិយោគទាំងនេះអនុញ្ញាតឱ្យពាណិជ្ជករ និងអ្នកជំនួញបន្តវិនិយោគលុយកាន់តែច្រើននៅក្នុងសហគ្រាសផ្សេងៗទៀត។ ជាលទ្ធផល ជំនួញបានរីកឡើង និងលូតលាស់នៅពាសពេញអឺរ៉ុប។ ការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចនៅអឺរ៉ុប បាននាំទៅរកការកើនឡើងនៃការផ្គត់ផ្គង់លុយដល់ប្រទេសជាច្រើន។ ការកើនឡើងនេះនាំមកនូវអតិផរណា ឬការកើនឡើងយ៉ាងឆាប់រហ័សនៃតម្លៃទំនិញ។ អតិផរណាកើតមានឡើងនៅពេលដែលមនុស្សមានលុយច្រើនដើម្បីចំណាយ ដូច្នេះវាធ្វើឱ្យមានតម្រូវការទំនិញ និងសេវាកម្មកាន់តែច្រើន។ ដោយសារតែការផ្គត់ផ្គង់ទំនិញមានតិចជាងតម្រូវការរបស់ពួកគេ ទំនិញបានក្លាយជារបស់ដែលពិសិដ្ឋ និងមានតម្លៃ។ បន្ទាប់មកថ្លៃទំនិញទាំងនោះនឹងកើនឡើង។ នៅពេលនោះនៅអឺរ៉ុប តម្លៃរបស់ទំនិញជាច្រើនបានកើនឡើង។ ឧទាហរណ៍ ប្រទេសអេស្ប៉ាញបានប្រឈមជាមួយនឹងអតិផរណាដ៏ខ្លាំងក្លាមួយនៅអំឡុងទសវត្សរ៍ឆ្នាំ 1600 ដូចដែលការដឹកជញ្ជូននូវមាស និងប្រាក់មកពីអាមេរិកបានបង្កើនការផ្គត់ផ្គត់លុយជាតិយ៉ាងច្រើន។

ក្រុមហ៊ុនចូលហ៊ុនគ្នា៖ ការធ្វើជំនួញមួយបែបទៀតដែលបានអភិវឌ្ឍឡើងនៅអំឡុងពេលនោះត្រូវបានគេស្គាល់ថាក្រុមហ៊ុនចូលហ៊ុនគ្នា។ ក្រុមហ៊ុនចូលហ៊ុនគ្នាដំណើរការមួយភាគធំដូចជាសាជីវកម្មនាពេលបច្ចុប្បន្នដោយអ្នកវិនិយោគទិញភាគហ៊ុនពីក្រុមហ៊ុនមួយ។ វាបានរួមបញ្ចូលនូវទ្រព្យសម្បត្តិរបស់មនុស្សជាច្រើនសម្រាប់គោលដៅរួមមួយ។ នៅអឺរ៉ុបអំឡុងទសវត្សរ៍ឆ្នាំ 1500 និង 1600 គោលបំណងរួមនេះគឺការដាក់អាណានិគមនៅអាមេរិក។ វាត្រូវការលុយក្នុងទំហំដ៏ធំមួយដើម្បីបង្កើតដែនដីអាណានិគមក្រៅប្រទេស។ ជាងនេះទៅទៀត ខណៈពេលដែលផលចំណេញនឹងទទួលបានច្រើន វាក៏មានហានិភ័យខ្ពស់ផងដែរ។ ឧទាហរណ៍ នាវាជាច្រើនមិនបានសម្រេចជោគជ័យនៅក្នុងការធ្វើដំណើរឆ្លងកាត់មហាសមុទ្រដែលមានចម្ងាយឆ្ងាយ និងមានគ្រោះថ្នាក់នេះឡើយ។ ដោយសារតែក្រុមហ៊ុនចូលហ៊ុនគ្នាចូលរួមដោយអ្នកវិនិយោគច្រើន សមាជិតនីមួយៗបង់ប្រាក់មួយផ្នែកតូចនៃតម្លៃសរុបនៃការចំណាយលើការដាក់អាណានិគម។ ប្រសិនបើអាណានិគមបរាជ័យ អ្នកវិនិយោគបាត់បង់ភាគ

ហ៊ុនរបស់ពួកគេមួយភាគតូចប៉ុណ្ណោះ។ ប្រសិនបើអាណានិគមលូតលាស់ អ្នកវិនិយោគចែករំលែងផលចំពេញគ្នា។ មានក្រុមហ៊ុនចូលហ៊ុនគ្នាមួយដែលទទួលខុសត្រូវលើការបង្កើតជេមថោន ដែលជាដែនដីអាណានិគមអង់គ្លេសដំបូងបំផុតនៅអាមេរិកខាងជើង។

### 3. ការកើនឡើងនៃការស្វែងរកប្រាក់ចំណេញនិយម

អំឡុងសម័យនោះ ប្រទេសនានានៅអឺរ៉ុបបានបង្កើតគោលនយោបាយសេដ្ឋកិច្ចថ្មីមួយដែលគេស្គាល់ថាការស្វែងរកប្រាក់ចំណេញនិយម។ នៅក្នុងទ្រឹស្តីការស្វែងរកប្រាក់ចំណេញនិយមបានលើកឡើងថាអំណាចរបស់ប្រទេសមួយពឹងផ្អែកយ៉ាងសំខាន់ទៅលើទ្រព្យសម្បត្តិរបស់ប្រទេសនោះ។ ជាងនេះទៅទៀត ទ្រព្យសម្បត្តិបានអនុញ្ញាតឱ្យប្រទេសជាតិនោះស្ថាបនាកងទ័ពជើងទឹករឹងមាំមួយ និងទិញទំនិញសំខាន់ៗ។ ជាលទ្ធផល គោលបំណងរបស់ប្រទេសទាំងឡាយផ្តោតសំខាន់លើកការស្វែងរកទ្រព្យសម្បត្តិឱ្យកាន់តែច្រើនតាមតែអាចធ្វើទៅបាន។

តុល្យភាពនៃពាណិជ្ជកម្ម៖ យោងតាមទ្រឹស្តីការស្វែងរកប្រាក់ចំណេញនិយម ប្រទេសជាតិមួយអាចបង្កើនទ្រព្យសម្បត្តិ និងអំណាចរបស់ពួកគេនៅក្នុងវិធី 2 ។ ទីមួយពួកគេអាចរក្សាទុកនូវមាស និងប្រាក់ឱ្យបានកាន់តែច្រើនតាមតែអាចធ្វើទៅបាន។ ទីពីរ ពួកគេអាចបង្កើតតុល្យភាពពាណិជ្ជកម្មអំណោយផលមួយ ដែលលក់ចេញទំនិញច្រើនជាងការទិញចូល។ គោលដៅចុងក្រោយរបស់ប្រទេសជាតិមួយដែលស្ថិតនៅក្រោមទ្រឹស្តីការស្វែងរកប្រាក់ចំណេញនិយមគឺចង់ក្លាយជាអ្នកដែលអាចរស់នៅដោយខ្លួនឯង មិនមែនពឹងផ្អែកលើទំនិញរបស់ប្រទេសដ៏ទៃឡើយ។ អ្នកនិពន្ធអង់គ្លេសមួយរូបបានសរសេរអំពីគំនិតសេដ្ឋកិច្ចបែបស្វែងរកប្រាក់ចំណេញនិយមថា៖ ការស្វែងរកប្រាក់ចំណេញនិយមត្រូវបានអនុវត្តពីមួយទៅមួយជាមួយនិងអាណានិគមនិយម សម្រាប់ដែនដីអាណានិគមបានដើរតួនាទីសំខាន់មួយនៅក្នុងការអនុវត្តសេដ្ឋកិច្ចបែបថ្មីនេះ។ ក្រៅពីការផ្តល់ប្រាក់ និងមាស ដែនដីអាណានិគមក៏បានផ្តល់នូវវត្ថុធាតុដើមដែលគេមិនអាចស្វែងរកបាននៅក្នុងប្រទេសម្ចាស់អាណានិគម ក្នុងនោះមានដូចជាឈើ ឬរោមសត្វជាដើម។ នៅក្នុងបន្ថែមទៅលើតួនាទីជាអ្នកផ្គត់ផ្គង់ ដែនដីអាណានិគមក៏ជាទីផ្សារមួយផងដែរ។ ប្រទេសម្ចាស់អាណានិគមអាចលក់ទំនិញរបស់ពួកគេនៅក្នុងដែនដីអាណានិគម។

បដិវត្តសេដ្ឋកិច្ចផ្លាស់ប្តូរសង្គមនៅអឺរ៉ុប៖ ការផ្លាស់ប្តូរសេដ្ឋកិច្ចដែលបានកើតមានឡើងពាសពេញអឺរ៉ុបអំឡុងសម័យនៃការដាក់អាណានិគមនៅអាមេរិកក៏បាននាំទៅដល់ការផ្លាស់ប្តូរសង្គមអឺរ៉ុបផងដែរ។ បដិវត្តសេដ្ឋកិច្ចរុញច្រានឱ្យមានការរីកឡើងនៃទីប្រជុំជន និងការកើនឡើងនៃវណ្ណៈពាណិជ្ជករមួយដែលជាអ្នកត្រួតត្រាលើទ្រព្យសម្បត្តិមហាសាល។ ប៉ុន្តែការផ្លាស់ប្តូរសង្គមនៅអឺរ៉ុបបានកើតមានឡើងយ៉ាងខ្លាំង។ ខណៈពេលដែលទីប្រជុំជន និងទីក្រុងនានាបានកើនទំហំ ប្រជាជននៅអឺរ៉ុបភាគច្រើនបន្តរបស់នៅតំបន់ជនបទ។ ហើយបើទោះបីជាពាណិជ្ជករ និងអ្នកជំនួញរីករាយជាមួយអភិជនភាពរបស់ពួកគេនៅក្នុងសង្គមក៏ដោយ ក៏ភាគច្រើននៃប្រជាជនអឺរ៉ុបបន្តរស់នៅក្នុងភាពក្រីក្រ។ ដោយគ្មានអ្វីសំខាន់ជាងនេះ បដិវត្តសេដ្ឋកិច្ចបានបង្កើនទ្រព្យសម្បត្តិរបស់ប្រទេសជាតិនានានៅអឺរ៉ុប។ ជាងនេះទៅទៀត ការស្វែងរកប្រាក់ចំណេញនិយមចូលរួមចំណែកនៅក្នុងការបង្កើតអត្តសញ្ញាណជាតិ

មួយ។ ដូចគ្នា ដូចដែលពិពណ៌នានៅក្នុងជំពូក 20 ការអនុវត្តសេដ្ឋកិច្ចថ្មីបាននាំមកនូវជោគជ័យដល់ការពង្រីកអំណាចរបស់ស្តេចអឺរ៉ុប ដែលបានក្លាយជាមេដឹកនាំដែលមានអំណាច។

# ជំពូក 20៖ រាជាធិបតេយ្យផ្តាច់ការនៅអឺរ៉ុប 1500-1800

## មេរៀនទី 1៖ ចក្រភពអេស្ប៉ាញ និងលទ្ធិផ្តាច់ការនៅអឺរ៉ុប

ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក 18 ចាប់ពីឆ្នាំ 1520 ដល់ 1566 ព្រះអង្គម្ចាស់ស៊ូឡៃម៉ាន់ទី 1 បានកាន់អំណាចជាស៊ុលតង់នៅចក្រភពអូតូម៉ង់។ ព្រះមហាក្សត្រនៅអឺរ៉ុបមួយអង្គក្នុងពេលជាមួយគ្នានេះព្រះនាមឆាលទី 5 មានអំណាចប្រហាក់ប្រហែលជាមួយព្រះអង្គម្ចាស់ស៊ូឡៃម៉ាន់។ ក្នុងនាមជាព្រះមហាក្សត្រហាបប៊ឺក ព្រះអង្គម្ចាស់ឆាសគ្រប់គ្រងប្រទេសអេស្ប៉ាញ, ដែនដីអាណានិគមរបស់អេស្ប៉ាញនៅអាមេរិក, ផ្នែកខ្លះនៃប្រទេសអ៊ីតាលី, និងដែនដីនៅអូទ្រីស និងហូឡង់។ ក្នុងនាមជាអធិរាជរ៉ូម៉ាំងពិសិដ្ឋ ទ្រង់ដឹកនាំដែនដីអាឡឺម៉ង់មួយភាគធំ។ វាគឺជាលើកដំបូងចាប់តាំងពីឆាលឡឺម៉ាញមកដែលមេដឹកនាំអឺរ៉ុបមួយអង្គត្រួតត្រាលើដែនដីដ៏ធំមែននេះ។

### 1. ចក្រភពអេស្ប៉ាញដ៏មានអំណាចមួយ

ក្នុងនាមជាអ្នកជឿស៊ប់កាតូលិក ព្រះអង្គម្ចាស់ឆាលមិនត្រឹមតែវាយប្រយុទ្ធជាមួយពួកម៉ូស្លីមប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានប្រឆាំងជាមួយពួកលូធេរ៉ាន់ផងដែរ។ នៅក្នុងឆ្នាំ 1555 ទ្រង់បានយល់ព្រមដោយគ្មានឆន្ទៈចំពោះសន្ធិសញ្ញាសន្តិភាពអ៉ាវស្បឺក ដែលបានអនុញ្ញាតឱ្យព្រះអង្គម្ចាស់អាឡឺម៉ង់ជ្រើសរើសសាសនាសម្រាប់ដែនដីរបស់ទ្រង់។ នៅឆ្នាំបន្ទាប់ ព្រះអង្គម្ចាស់ឆាលទី 5 បានបែងចែកចក្រភពដ៏ធំរបស់ទ្រង់ និងបានចូលនិវត្តន៍បួសជាព្រះសង្ឃមួយអង្គ។ ទ្រង់បានប្រគល់ឱ្យអនុជរបស់ទ្រង់ព្រះនាមហ្វេឌីណង់គ្រប់គ្រងប្រទេសអូទ្រីស និងចក្រភពរ៉ូម៉ាំងពិសិដ្ឋ។ រាជបុត្រារបស់ទ្រង់ព្រះនាមហ្វីលីបទី 2 គ្រប់គ្រងប្រទេសអេស្ប៉ាញ, ហូឡង់, និងដែនដីអាណានិគមនៅអាមេរិក។

ចក្រភពរបស់ព្រះអង្គម្ចាស់ហ្វីលីប៖ ព្រះអង្គម្ចាស់ហ្វីលីបមានភាពខ្មាស់អៀន, រម្យទម, និងដូចគ្នាជាមួយបិតារបស់ទ្រង់គោរពជឿយ៉ាងខ្លាំងលើសាសនា។ ទ្រង់ក៏ជាអ្នកដែលធ្វើការយ៉ាងស្វិតស្វាញផងដែរ។ ប៉ុន្តែព្រះអង្គម្ចាស់ហ្វីលីបមិនអនុញ្ញាតឱ្យនរណាម្នាក់ជួយទ្រង់ឡើយ។ ដោយមានការសង្ស័យច្រើន ទ្រង់មិនជឿជាក់លើនរណាម្នាក់ឡើយ។ ដូចដែលប្រវត្តិវិទូប្រចាំរាជវាំងផ្ទាល់របស់ទ្រង់សរសេរថា "ទ្រង់ញញឹម ហើយដាវរបស់ទ្រង់នៅជិតទ្រង់យ៉ាងខ្លាំង"។ ប្រហែលជាលើសពីនេះទៀត ព្រះអង្គម្ចាស់ហ្វីលីបមានភាពកាចសាហាវដើម្បីជាប្រយោជន៍ដល់ចក្រភពរបស់ទ្រង់។ នៅក្នុងឆ្នាំ 1580 ព្រះមហាក្សត្រព័រទុយហ្គាល់សុគត់ដោយគ្មានអ្នកស្នងមរតក។ ដោយសារតែព្រះអង្គម្ចាស់ហ្វីលីបគឺជាក្មួយរបស់ព្រះមហាក្សត្រព័រទុយហ្គាល់ ទ្រង់បានកាន់កាប់ព្រះរាជាណាចក្រព័រទុយហ្គាល់។ ដោយរាប់បញ្ចូលទាំងមូលដ្ឋានរបស់ព័រទុយហ្គាល់នៅអាហ្វ្រិក, ឥណ្ឌា, និងឥណ្ឌាខាងកើត ឥឡូវនេះទ្រង់មានចក្រភពមួយដែលព័ទ្ធជុំវិញពិភពលោក។ ចក្រភពរបស់ព្រះអង្គម្ចាស់ហ្វីលីបបានផ្តល់ឱ្យទ្រង់នូវទ្រព្យសម្បត្តិដ៏មហាសាល។ ត្រឹមឆ្នាំ 1600 ការជីករ៉ែនៅអាមេរិកបានផ្តល់ឱ្យអេស្ប៉ាញនូវមាសប្រមាណ 339,000 ផោន។ រវាងឆ្នាំ 1550 ដល់ 1650 ប្រាក់ប្រមាណ 16,000 តោនត្រូវបានទម្លាក់ចុះពីនាវារបស់អេស្ប៉ាញ។ ព្រះ

មហាក្សត្ររបស់អេស្ប៉ាញទាមទារចែករម្លែកចម្លោះពី 1/4 ឬ 1/5 នូវរាល់ទ្រព្យសម្បត្តិលើនាវាទាំងឡាយ។ ជាមួយនិងទ្រព្យសម្បត្តិនេះ អេស្ប៉ាញអាចគាំទ្រដល់កងទ័ពដ៏ធំមួយដែលមាន 50,000 នាក់។

អ្នកការពារកាតូលិកនិយម៖ នៅពេលដែលព្រះអង្គម្ចាស់ហ្វីលីបឡើងគ្រងរាជបល្ល័ង្ក អឺរ៉ុបកំពុងប្រឈមជាមួយនឹងសង្គ្រាមសាសនាដែលបណ្តាលមកពីការកែប្រែសាសនា។ ប៉ុន្តែ ជម្លោះសាសនាមិនមែនជារឿងថ្មីឡើងនៅក្នុងប្រទេសអេស្ប៉ាញ។ រីខុនគីស្តា ដែលជាយុទ្ធនាការមួយក្នុងការបណ្តេញពួកម៉ូស្លីមចេញពីប្រទេសអេស្ប៉ាញទើបតែត្រូវបានគេអនុវត្តកាលពី 64 ឆ្នាំមុនប៉ុណ្ណោះ។ ជាងនេះទៅទៀត ជីទួតរបស់ព្រះអង្គម្ចាស់ហ្វីលីបព្រះនាមអ៊ីសាវ៉ែលឡា និងហ្វ៊ែឌីណង់បានប្រើប្រាស់ស្ថាប័នស៊ើបអង្កេតមួយដើម្បីស៊ើបអង្កេតជនដែលប្រព្រឹត្តិខុសក្នុងសាសនា ឬអ្នកដែលមិនជឿលើសាសនាគ្រីស្ត។ ព្រះអង្គម្ចាស់ហ្វីលីបជឿថាវាគឺជាកាតព្វកិច្ចរបស់ទ្រង់នៅក្នុងការការពារកាតូលិកនិយមប្រឆាំងជាមួយពួកម៉ូស្លីមនៃចក្រភពអូតូម៉ង់ និងពួកប្រូតេស្តង់នៅអឺរ៉ុប។ នៅក្នុងឆ្នាំ 1571 ស្តេចប៉ាបបានស្នើព្រះអង្គម្ចាស់កាតូលិកទាំងអស់ ឱ្យងើបឡើងប្រឆាំងជាមួយចក្រភពអូតូម៉ង់ដែលកំពុងតែកើនអំណាច។ ព្រះអង្គម្ចាស់ហ្វីលីបបានឆ្លើយតបក្នុងនាមជាអ្នកបូជនីយកិច្ចដ៏ស្មោះស្ម័គ្រមួយរូប។ នាវារបស់អេស្ប៉ាញ និងរបស់ពួកវេនីសជាង 200 គ្រឿងបានយកជោគជ័យលើកងនាវាដ៏ធំមួយរបស់ចក្រភពអូតូម៉ង់នៅក្នុងសមរភូមិមួយនៅឡេប៉ាន់តូ។ នៅក្នុងឆ្នាំ 1588 ព្រះអង្គម្ចាស់ហ្វីលីបបានបើកការវាយប្រហារលើអាម៉ាដាអេស្ប៉ាញក្នុងគោលបំណងដើម្បីដាក់ទណ្ឌកម្មដល់ពួកប្រូតេស្តង់អង់គ្លេស និងម្ចាស់ក្សត្រីរបស់ពួកគេអេលីហ្សាប៉ែតទី 1 ។ ម្ចាស់ក្សត្រីអេលីហ្សាប៉ែតទី 1 បានគាំទ្រដល់អ្នកគោរពជឿប្រូតេស្តង់ដែលបានងើបឡើងបះបោរប្រឆាំងជាមួយព្រះអង្គម្ចាស់ហ្វីលីប។ ប៉ុន្តែ កងនាវារបស់ទ្រង់បានបរាជ័យ។ បើទោះបីជាការបរាជ័យនេះបានធ្វើឱ្យអេស្ប៉ាញចុះខ្សោយក៏ដោយ ក៏ទ្រព្យសម្បត្តិរបស់ពួកគេបានផ្តល់ឱ្យពួកគេនូវភាពរឹងមាំក្នុងរយៈពេលដ៏វែងមួយ។ វិមានថ្មក្រានីតពណ៌ប្រផេះរបស់ព្រះអង្គម្ចាស់ហ្វីលីបឈ្មោះថាអេស្គូរៀលមានជញ្ជាំងខ្ពស់ និងក្លោងទ្វារធំដែលបានបង្ហាញពីអំណាចរបស់ទ្រង់។ អេស្គូរៀលក៏បានឆ្លុះបញ្ចាំងពីជំនឿរបស់ព្រះអង្គម្ចាស់ហ្វីលីបផងដែរ។ នៅខាងក្នុងជញ្ជាំងរបស់វិមានព្រះវិហារមួយក៏ដូចជារាជវាំងមួយផងដែរ។

## 2. យុគមាសនៃសិល្បៈ និងអក្សរសិល្ប៍អេស្ប៉ាញ

ទ្រព្យសម្បត្តិមហាសាលរបស់អេស្ប៉ាញមិនត្រឹមតែប្រើដើម្បីគាំទ្រកងទ័ពជើងទឹក និងស្ថាបនារាជវាំងប៉ុណ្ណោះទេ។ វាក៏បានអនុញ្ញាតឱ្យព្រះមហាក្សត្រ និងពួកអភិជនក្លាយជាអ្នកឧបត្ថម្ភដល់សិល្បៈករ។ អំឡុងសតវត្សរ៍ទី 16 និង 17 អេស្ប៉ាញជួបប្រទះនូវយុគមាសមួយនៅក្នុងវិស័យសិល្បៈ។ ស្នាដៃរបស់ជាងគំនូរដ៏ល្បីល្បាញចំនួនពីរូបបានបង្ហាញទាំងជំនឿ និងមោទនភាពរបស់អេស្ប៉ាញអំឡុងសម័យនោះ។

អេល គ្រេកូ និងវេឡាស់កេស៖ កើតនៅក្រេតេ អេល គ្រេកូ បានចំណាយពេលយុវវ័យរបស់លោកមួយភាគធំនៅក្នុងប្រទេសអេស្ប៉ាញ។ ឈ្មោះពិតរបស់លោកគឺដូមេនីកូស ថេអូតូកូប៉ូឡូស ប៉ុន្តែពួកអេស្ប៉ាញហៅលោកថា អេល គ្រេកូ ដែលមានន័យថា "ក្រិក"។ សិល្បៈរបស់អេល គ្រេកូជារឿយៗធ្វើឱ្យមនុស្សនៅសម័យនោះមានការងឿងឆ្ងល់។ លោកបានជ្រើសរើសពណ៌ភ្លឺ, ពេលខ្លះពណ៌ចម្រុះ , បង្ខូចទ្រង់ទ្រាយមនុស្ស, និងបង្ហាញនិមិត្តសញ្ញា

អារម្មណ៍នៅក្នុងគំនូររបស់លោក។ បើទោះបីជាខុសប្រក្រតី បច្ចេកទេសរបស់អេល គ្រេកូបានបង្ហាញពីជំនឿកាតូលិកដ៏ជ្រាលជ្រៅរបស់អេស្ប៉ាញ។ លោកបានគូពួកបរិសុទ្ធ និងទុក្ករបុគ្គលជាតួអង្គធំៗ និងមានជើងវែងដែលមានខ្យល់អាកាសអស្ចារ្យមួយ។ គំនូររបស់ឌីអេហ្គូ វេឡាស់កេស ផ្ទុយទៅវិញ បានឆ្លុះបញ្ចាំងពីមោទនភាពនៃស្តេចអេស្ប៉ាញ។ វេឡាស់កេសអ្នកដែលបានគូរគំនូរ 50 ឆ្នាំបន្ទាប់ពីអេល គ្រេកូ គឺជាជាងគំនូរប្រចាំរាជវាំងរបស់ព្រះអង្គម្ចាស់ហ្វីលីបទី 4 របស់អេស្ប៉ាញ។ លោកត្រូវបានគេស្គាល់ច្បាស់តាមរយៈគំនូររបស់លោកអំពីគ្រួសាររាជវង្ស និងរូបភាពនៃជីវិតរស់នៅក្នុងរាជវាំង។ ក៏ដូចជាអេល គ្រេកូដែរ លោកត្រូវបានគេកត់សំគាល់តាមរយៈការប្រើប្រាស់ពណ៌ដ៏សម្បូរបែប។

ដុន គីហ្សូតេ៖ ការបោះពុម្ពផ្សាយប្រលោមលោកដែលមានចំណងជើងថា ដុន គីហ្សូតេ ដេ ឡា ម៉ានចា នៅក្នុងឆ្នាំ 1605 ជារឿយៗត្រូវបានគេហៅថាការចាប់កំណើតនៃប្រលោមលោកសម័យទំនើបនៅអឺរ៉ុប។ នៅក្នុងសៀវភៅនេះ មីគូអេល ដេ សឺវ៉ាន់តេស បានសរសេរអំពីអភិជនអេស្ប៉ាងដ៏កម្សត់មួយរូបដែលចាប់ផ្តើមមានបញ្ហាខួរក្បាលបន្ទាប់ពីអានសៀវភៅច្រើនពេកអំពីវីរបុរសអ្នកប្រយុទ្ធជិះសេះ។ ដោយសង្ឃឹមនៅក្នុងការកែប្រែកំហុសគ្រប់បែបយ៉ាង ដុន គីហ្សូតេ បានជិះសេះដ៏ខ្សោយមួយជាមួយនឹងអាវក្រោះដែលច្រេះចាប់មួយ។ នៅត្រង់ចំណុចមួយ លោកបានយល់ច្រលំថាម៉ាស៊ីនកិនដើរដោយខ្យល់ថាជារបស់យក្ស។ អ្នករិះគន់មួយចំនួនជឿថាសឺវ៉ាន់តេសចង់ចំអកឱ្យឆីវ៉ាលរី ដែលជាក្រុមអ្នកប្រយុទ្ធជិះសេះនៅយុគកណ្តាល។ អ្នកផ្សេងទៀតប្រកាន់ថាសៀវភៅនេះនិយាយអំពីមនុស្សឧត្តមគតិមួយរូបដែលចង់បានអតីតកាលដ៏រ៉ូមែនទិច ដោយសារលោកមានការខកចិត្តចំពោះពិភពសម្ភារៈនិយមរបស់លោក។

### 3. ចក្រភពអេស្ប៉ាញចុះខ្សោយ

យ៉ាងជាក់ច្បាស់ យុគសម័យដែលសឺវ៉ាន់តេសសរសេរប្រលោមលោកគឺជាយុគសម័យសម្ភារៈនិយមមួយ។ មាស និងប្រាក់មកពីអាមេរិកបានធ្វើឱ្យអេស្ប៉ាញក្លាយជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភជាបណ្តោះអាសន្ន។ ប៉ុន្តែទ្រព្យសម្បត្តិមួយចំនួនបានបង្កឱ្យមានបញ្ហាសេដ្ឋកិច្ចរយៈពេលវែង។

អតិផរណា និងពន្ធ៖ បញ្ហាមួយនៅក្នុងចំណោមបញ្ហាទាំងនេះគឺអតិផរណាដ៏ធ្ងន់ធ្ងរ ដែលជាការធ្លាក់ចុះនៃតម្លៃលុយ អមជាមួយនឹងការកើនឡើងនៃតម្លៃទំនិញ និងសេវាកម្ម។ អតិផរណានៅក្នុងប្រទេសអេស្ប៉ាញបណ្តាលមកពីមូលហេតុសំខាន់ៗចំនួន 2 ។ ទីមួយ ប្រជាជនអេស្ប៉ាញបានកើនឡើង។ ដូចដែលមនុស្សកាន់តែច្រើនមានតម្រូវការលើចំណីអាហារ និងទំនិញផ្សេងៗទៀត ពាណិជ្ជករអាចតម្លើងថ្លៃទំនិញបាន។ ទីពីរ ប្រាក់បានហូរចូលទៅក្នុងទីផ្សារយ៉ាងច្រើន ដែលនាំឱ្យតម្លៃរបស់វាធ្លាក់ចុះ។ មនុស្សត្រូវការប្រាក់កាន់តែច្រើនទៅៗដើម្បីទិញទំនិញ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់អេស្ប៉ាញក៏បណ្តាលមកពីមូលហេតុផ្សេងៗដែរ។ នៅពេលដែលអេស្ប៉ាញនិរទ្ទេសពួកជ្វីប និងម៉ូស្លីមចេញពីអេស្ប៉ាញនៅវង្វង់ឆ្នាំ 1500 ពួកគេបានបាត់បង់សិប្បករ និងអ្នកជំនួញដ៏មានតម្លៃជាច្រើន។ ជាងនេះទៅទៀត ពួកអភិជនអេស្ប៉ាញមិនបានបង់ពន្ធឡើយ។ បន្ទុកនៃការបង់ពន្ធបានធ្លាក់ទៅលើក្រុម

មនុស្សវណ្ណៈក្រោម។ បន្ទុកនេះបានរារាំងពួកគេក្នុងការប្រមូលទ្រព្យសម្បត្តិឱ្យបានគ្រប់គ្រាន់ដើម្បីបើកជំនួញផ្ទាល់ខ្លួន។ ជាលទ្ធផល អេស្ប៉ាញមិនដែលបានអភិវឌ្ឍវណ្ណៈកណ្តាលមួយទៀតឡើយ។

ធ្វើឱ្យសត្រូវអេស្ប៉ាញក្លាយជាអ្នកមាន៖ សមាគមន៍ពាណិជ្ជកម្មបានលេចឡើងនៅក្នុងយុគកណ្តាលនៅតែគ្របដណ្តប់លើជំនួញនៅអេស្ប៉ាញ។ សមាគមន៍ពាណិជ្ជកម្មមួយចំនួនប្រើប្រាស់វិធីសាស្ត្របែបបុរាណ។ ការធ្វើដូចនេះនាំឱ្យសំលៀកបំពាក់ និងទំនិញរោងចក្ររបស់អេស្ប៉ាញមានតម្លៃថ្លៃជាងកន្លែងផ្សេងទៀត។ ជាលទ្ធផល ប្រជាជនអេស្ប៉ាញទិញយ៉ាងច្រើននូវអ្វីដែលពួកគេត្រូវការពីប្រទេសបារាំង, អង់គ្លេស, និងហូឡង់។ ទ្រព្យសម្បត្តិមហាសាលរបស់អេស្ប៉ាញបានហូរចូលហោប៉ៅរបស់ពួកបរទេស ដែលភាគច្រើនជាសត្រូវរបស់អេស្ប៉ាញ។ ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់ការធ្វើសង្គ្រាមរបស់ពួកគេ ស្តេចអេស្ប៉ាញបានខ្ចីលុយពីធនាគារនៅប្រទេសអាឡឺម៉ង់ និងអ៊ីតាលី។ នៅពេលដែលនាវាដឹកប្រាក់មកដល់ លុយត្រូវបានបញ្ជូនទៅក្រៅប្រទេសដើម្បីសងបំណុល។ សេដ្ឋកិច្ចបានធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់ស្តេចហ្វីលីបត្រូវប្រកាសរដ្ឋក្ស័យធនរហូតដល់ 3 លើក។

ការបះបោររបស់ហូឡង់៖ នៅក្នុងប្រទេសហូឡង់ ព្រះអង្គម្ចាស់ហ្វីលីបត្រូវរក្សានូវកងទ័ពមួយដើម្បីរក្សាការត្រួតត្រាប្រជានុរាស្ត្ររបស់ទ្រង់។ ពួកហូឡង់មានភាពដូចគ្នាតិចតួចជាមួយមេដឹកនាំអេស្ប៉ាញរបស់ពួកគេ។ ខណៈពេលដែលអេស្ប៉ាញកាន់សាសនាកាតូលិក ហូឡង់ភាគច្រើនជាក្រុមជំនុំកាលវីន។ ក៏ដូចគ្នា អេស្ប៉ាញមានសេដ្ឋកិច្ចធ្លាក់ចុះ ខណៈពេលដែលហូឡង់មានវណ្ណៈកណ្តាលរុងរឿងមួយ។ ព្រះអង្គម្ចាស់ហ្វីលីបបានតម្លើងពន្ធនៅហូឡង់ និងបោះជំហានទៅរកកាន់បង្ក្រាបប្រូតេស្តង់និយម។ នៅក្នុងការឆ្លើយតប នៅក្នុងឆ្នាំ 1566 ពួកប្រូតេស្តង់ដែលមានកំហឹងបានឡោមព័ទ្ធវាយប្រហារទៅលើព្រះវិហារកាតូលិក។ ព្រះអង្គម្ចាស់ហ្វីលីបបានបញ្ជូនកងទ័ពមួយក្រុមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គម្ចាស់អេស្ប៉ាញអាលវ៉ាដើម្បីដាក់ទោសដល់ក្រុមបះបោរ។ ក្នុងរយៈពេលតែមួយថ្ងៃនៅក្នុងឆ្នាំ 1568 ព្រះអង្គម្ចាស់មានប្រហារជីវិតពួកប្រូតេស្តង់ចំនួន 1,500 នាក់ និងជនសង្ស័យដែលជាពួកឧទ្ទាមផ្សេងៗទៀត។ ពួកហូឡង់បន្តវាយប្រយុទ្ធជាមួយពួកអេស្ប៉ាញអស់រយៈពេល 11 ឆ្នាំទៀត។ ចុងក្រោយ នៅក្នុងឆ្នាំ 1579 ខេត្តចំនួន 7 ដែលស្ថិតនៅហូឡង់ភាគខាងលិច ដែលភាគច្រើនជាពួកប្រូតេស្តង់បានបង្រួបបង្រួមគ្នា និងប្រកាសឯករាជ្យពីប្រទេសអេស្ប៉ាញ។ ពួកគេបានក្លាយជាខេត្តបង្រួបបង្រួមរបស់ហូឡង់។ ខេត្ត 10 ភាគខាងត្បូង(បច្ចុប្បន្នប្រទេសប៊ែលហ្សិកគឺជាពួកកាតូលិក និងបន្តស្ថិតនៅក្រោមការត្រួតត្រារបស់អេស្ប៉ាញ។

## 4. ហូឡង់ឯករាជ្យរុងរឿង

ខេត្តបង្រួបបង្រួមរបស់ហូឡង់មានភាពខុសគ្នាពីរដ្ឋផ្សេងៗទៀតនៅអឺរ៉ុប។ ភាពខុសគ្នាមួយ ប្រជាជននៅទីនោះប្រតិបត្តិសាសនាត្រាប្រណី។ ជាងនេះទៅទៀត ខេត្តបង្រួបបង្រួមមិនមែនជាព្រះរាជាណាចក្រមួយឡើយ ប៉ុន្តែជាសាធារណរដ្ឋ។ ខេត្តនីមួយៗមានអភិបាលមួយដែលចេញមកពីការបោះឆ្នោត ដែលអំណាចរបស់ពួកគេពឹងផ្អែកលើការគាំទ្រពីសំណាក់ពាណិជ្ជករ និងម្ចាស់កម្មសិទ្ធិដីធ្លី។

សិល្បៈហូឡង់៖ អំឡុងទសវត្សរ៍ឆ្នាំ 1600 ហូឡង់បានក្លាយទៅជាអ្វីដែលផ្លូរែនធ្លាប់មានអំឡុងទសវត្សរ៍ឆ្នាំ 1400 ។ ពួកគេមិនមែនមានត្រឹមតែធនាគាដែលល្អបំផុតតែប៉ុណ្ណោះទេ ប៉ុន្តែក៏មានសិល្បៈករល្បីៗជាច្រើនផងដែរ។ ក៏ដូចជានៅផ្លូរែន ពាណិជ្ជករមានទ្រព្យសម្បត្តិស្តុកស្តម្ភបានឧបត្ថម្ភដល់សិល្បៈករជាច្រើន។ រេមប្រាន វ៉ាន់ រីច គឺជាសិល្បៈករល្បីល្បាញបំផុតរបស់ហូឡង់នៅក្នុងសម័យនោះ។ រេមប្រានបានគូរគំនូរពាណិជ្ជករវណ្ណៈកណ្តាលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ លោកក៏បានបង្កើត រូបភាពជាក្រុមផងដែរ។ នៅក្នុងស្នាដៃនាឡិការាត្រី លោកបានគូរអ្នកយាមទីក្រុងមួយក្រុម។ រេនប្រានបានប្រើប្រាស់ពន្លឺភ្លឺខ្លាំង និងស្រមើលដើម្បីទាក់ទាញចំណាប់អារម្មណ៍ទៅលើគំនូររបស់លោក។ វិចិត្រករមួយរូបទៀតដែលផ្តោតសំខាន់លើពន្លឺ និងភាពងងឹតគឺលោកជេន វ៉រម៉ែ។ ក៏ដូចជាវិចិត្រករហូឡង់ផ្សេងៗទៀត លោកបានជ្រើសរើសអ្វីដែលនៅក្នុងផ្ទះសម្រាប់គំនូររបស់លោក។

## 5. លិទ្ធិផ្តាច់ការនៅអឺរ៉ុប

បើទោះបីជាព្រះអង្គម្ចាស់ហ្វីលីបទី 2 បានបាត់បង់ការត្រួតត្រារបស់ទ្រង់លើប្រទេសហូឡង់ក៏ដោយ ទ្រង់គឺជាមេដឹកនាំដ៏មានអំណាចខ្លាំងមួយ។ ទ្រង់ព្យាយាមនៅក្នុងការត្រួតត្រាគ្រប់ទិដ្ឋភាពទាំងអស់នៃកិច្ចការក្នុងចក្រភពរបស់ទ្រង់។ អំឡុងពេលប៉ុន្មានសតវត្សរ៍បន្ទាប់ ព្រះមហាក្សត្រនៅអឺរ៉ុបជាច្រើនក៏នឹងអះអាងពីអំណាចនៅក្នុងការត្រួតត្រាដោយមិនមានដែនកំណត់។

ទ្រឹស្តីនៃលិទ្ធិផ្តាច់ការ៖ មេដឹកនាំទាំងអស់នេះចង់ក្លាយជារាជាផ្តាច់ការ ជាប្រព័ន្ធមួយដែលស្តេច ឬម្ចាស់ក្សត្រីដែលត្រួតត្រាលើអំណាចទាំងអស់នៅក្នុងដែនដីរបស់ពួកទ្រង់។ គោលបំណងរបស់ពួកគេគឺត្រួតត្រាលើទិដ្ឋភាពទាំងអស់នៅក្នុងសង្គ្រាម។ រាជាផ្តាច់ការជាការផ្តល់សិទ្ធិពីឋានសួគ៌ ជាគំនិតមួយដែលថាព្រះជាម្ចាស់បានបង្កើតរាជានិយម ដូច្នេះស្តេចដើរតួនាទីជាអ្នកតំណាងឱ្យព្រះជាម្ចាស់នៅលើផែនដី។ រាជាផ្តាច់ការមួយអង្គឆ្លើយតបតែជាមួយព្រះជាម្ចាស់ប៉ុណ្ណោះ មិនឆ្លើយតបចំពោះប្រជានុរាស្ត្ររបស់ទ្រង់ឡើយ។

ការកើនឡើងនៃអំណាចរបស់ព្រះមហាក្សត្រនៅអឺរ៉ុប៖ ដូចដែលអឺរ៉ុបចេញផុតពីយុគកណ្តាល ព្រះមហាក្សត្របានកើនអំណាចយ៉ាងខ្លាំង។ ការធ្លាក់ចុះនៃសក្តិភូមិនិយម, ការរីកឡើងនៃទីក្រុង, និងការកើនឡើងនៃប្រទេសបែបព្រះរាជាណាចក្របានជួយដល់ការធ្វើមជ្ឈការអំណាច។ ជាងនេះទៅទៀត ពួកវណ្ណៈកណ្តាលដែលកំពុងតែរីកចម្រើនជាទូទៅគាំទ្រព្រះមហាក្សត្រ ដោយសារតែពួកគេ ទ្រង់សន្យានៅក្នុងការធ្វើឱ្យមានសន្តិភាព និងបរិកាសគាំទ្រដល់ជំនួញ។ ព្រះមហាក្សត្រ ប្រើប្រាស់ទ្រព្យសម្បត្តិដែលបានមកពីដែនដីអាណានិគមដើម្បីចំណាយលើមហិច្ឆិតារបស់ទ្រង់។ អំណាចរបស់ព្រះវិហារគ្រឹស្តសាសនាក៏បានធ្លាក់ចុះនៅអំឡុងចុងយុគកណ្តាល និងការកែប្រែសាសនា។ ហេតុនេះបានបើកផ្លូវឱ្យស្តេចទទួលបានការត្រួតត្រាកាន់តែច្រើន។

វិបត្តិនាំទៅដល់លិទ្ធិផ្តាច់ការ៖ សតវត្សរ៍ទី 17 គឺជាសម័យកាលចលាចលខ្លាំងមួយនៅអឺរ៉ុប។ ជម្លោះសាសនា និងទឹកដីរវាងរដ្ឋ និងរដ្ឋបាននាំទៅដល់ការធ្វើសង្គ្រាមជាបន្តបន្ទាប់។ សង្គ្រាមនេះបណ្តាលឱ្យរដ្ឋាភិបាលស្ថាបនាយោធាដ៏ធំមួយ និងយកពន្ធកាន់តែច្រើនពីប្រជាជនដែលកំពុងតែរងគ្រោះរួចទៅហើយ។ ការនោះបានជម្រុញឱ្យមានការរីករាលដាលនៃភាពចលាចល។ ពេលខ្លះប្រជាកសិករបានងើបឡើងបះបោរ។ ឆ្លើយតបទៅនិង

វិបត្តិទាំងនេះ ព្រះមហាក្សត្រព្យាយាមនៅក្នុងការរក្សាសណ្តាប់ធ្នាប់តាមរយៈការបង្កើនអំណាចរបស់ខ្លួនទ្រង់ផ្ទាល់។ ក្នុងនាមជាមេដឹកនាំផ្តាច់ការ ទ្រង់ដាក់កម្រិតអ្វីៗគ្រប់យ៉ាងរាប់ចាប់ពីការគោរពបូជាសាសនារហូតដល់ការប្រមូលផ្តុំគ្នា។ ទ្រង់បានបង្កើតការិយាល័យរដ្ឋាភិបាលថ្មីដើម្បីត្រួតត្រាលើសេដ្ឋកិច្ចរបស់ប្រទេសទ្រង់។ គោលបំណងរបស់ទ្រង់គឺដើម្បីធ្វើឱ្យខ្លួនទ្រង់មានសេរីភាពពីការកម្រិតអំណាចដោយពួកអភិជន និងស្ថាប័នតំណាងនានាដូចជាសភាជាដើម។

# មេរៀនទី 2៖ រាជរបស់ព្រះអង្គម្ចាស់ល្វីទី 14

នៅក្នុងឆ្នាំ 1559 ព្រះអង្គម្ចាស់ហេនរីទី 2 របស់បារាំងបានសុគត់ ដែលបានបន្សល់នូវរាជបុត្រ 4 អង្គ។ ក្នុងចំណោមនោះមានរាជបុត្រ 3 អង្គបានដឹកនាំបន្តបន្ទាប់គ្នា ប៉ុន្តែពួកទ្រង់ទាំងអស់សុទ្ធតែមិនមានសមត្ថភាព។ អំណាចពិតប្រាកដនៅពីក្រោយរាជបល្ល័ង្កអំឡុងសម័យនោះគឺមាតារបស់ពួកទ្រង់ព្រះនាមកាថេរីន ដេ មេឌីស៊ីស។ ម្ចាស់ក្សត្រីកាថេរីនព្យាយាមនៅក្នុងការរក្សាអំណាចរបស់រាជា ប៉ុន្តែការកើនឡើងនៃជម្លោះរវាងពួកកាតូលិក និងហ៊ូហ្គេណូត(ប្រូតេស្តង់នៅបារាំង)បានធ្វើឱ្យរង្គោះរង្គើប្រទេស។ រវាងឆ្នាំ 1562 និង 1598 ពួកហ៊ូហ្គេណូត និងកាតូលិកបានវាយប្រយុទ្ធគ្នានៅក្នុងសង្គ្រាមសាសនាចំនួន 8 លើក។ ភាពចលាចលបានរីករាលដាលពេញប្រទេសបារាំង។

## 1. សង្គ្រាមសាសនា និងការប្រជែងអំណាច

នៅក្នុងឆ្នាំ 1572 ការសម្លាប់រង្គាលនៅប៉ារីសនៅថ្ងៃបាថូឡូមេវ បានបញ្ឆេះឱ្យការសម្លាប់រង្គាលទូទាំងប្រទេសលើពួកហ៊ូហ្គេណូតក្នុងរយៈពេល 6 សប្តាហ៍។ ការសម្លាប់រង្គាលបានកើតមានឡើងនៅពេលដែលពួកអភិជនហ៊ូហ្គេណូតជាច្រើនកំពុងស្ថិតនៅក្នុងទីក្រុងបារីស។ ពួកគេកំពុងតែចូលរួមពិធីរៀបអភិសេករបស់បុត្រីម្ចាស់ក្សត្រីកាថេរីនជាមួយព្រះអង្គម្ចាស់ហ៊ូហ្គេណូតមួយអង្គ។ ភាគច្រើននៃពួកអភិជនទាំងនេះបានស្លាប់ ប៉ុន្តែហេនរីនៅរស់។

ហេរីនៃណាវ៉ារេះ ជាបច្ចាជនរបស់ព្រះអង្គម្ចាស់ល្វីទី 9 ដែលមានប្រជាប្រិយភាពនៅអំឡុងមជ្ឈិមសម័យ ហេនរីមានភាពរឹងមាំ, អត្តពលិក, និងសង្ហា។ នៅក្នុងឆ្នាំ 1589 នៅពេលដែលម្ចាស់ក្សត្រីកាថេរីន និងរាជបុត្រចុងក្រោយរបស់ទ្រង់សុគតព្រះអង្គម្ចាស់ហេរីបានឡើងគ្រងរាជ្យ។ ទ្រង់បានក្លាយជាហេនរីទី 4 ជាព្រះមហាក្សត្រសន្តតិវង្សបួប៊ុនដំបូងនៅក្នុងប្រទេសបារាំង។ ក្នុងនាមជាព្រះមហាក្សត្រ ទ្រង់បានបង្ហាញខ្លួនទ្រង់ថាជាមនុស្សម៉ឺងម៉ាត់, មិនភ័យខ្លួនក្នុងសមរភូមិ, និងជាអ្នកនយោបាយដ៏វៃឆ្លាតមួយរូប។ ពួកកាតូលិកជាច្រើន ដោយរួមមានទាំងប្រជាជននៅក្នុងទីក្រុងប៉ារីសផងបានប្រឆាំងជាមួយហេនរី។ សម្រាប់ជាប្រយោជន៍ដល់ប្រទេសដែលញាំញីដោយសង្គ្រាម ហេនរីបានលះបង់ប្រតេស្តង់និយមរបស់ទ្រង់ និងបានក្លាយជាអ្នកកាតូលិក។ ក្នុងការពន្យល់ពីការផ្លាស់ប្តូរសាសនារបស់ទ្រង់ ព្រះអង្គម្ចាស់ហេនរីប្រកាសថា "ទីក្រុងប៉ារីសមានតម្លៃល្អណាស់"។ នៅក្នុងឆ្នាំ 1598 ព្រះអង្គម្ចាស់ហេនរីបានបោះជំហានទៅរកការព្យាបាលរបួសរបស់បារាំង។ ទ្រង់បានប្រកាសថា ពួកហ៊ូហ្គេណូតអាចរស់នៅដោយសន្តិភាពនៅក្នុងប្រទេសបារាំង និងអាចបង្កើតផ្ទះសម្រាប់គោរពបូជាផ្ទាល់របស់ពួកគេនៅតាមទីក្រុងមួយចំនួន។ ការប្រកាសពីការគ្រាប្រណីដល់សាសនានេះត្រូវបានគេហៅថា បញ្ញត្តិរបស់ណានតេស។ ជួយដោយទីប្រឹក្សាមួយរូបដែលបានអនុវត្តគោលនយោបាយហិរញ្ញវត្ថុដ៏ឆ្លាតវៃ ព្រះអង្គម្ចាស់ហេនរីបានបូជារាជរបស់ទ្រង់ក្នុងការស្តាបនាប្រទេសបារាំង និងភាពរុងរឿងឡើងវិញ។ ទ្រង់បានស្តារឡើងវិញនូវរាជាធិបតេយ្យបារាំងឱ្យស្ថិតនៅក្នុងតួនាទីរឹងមាំមួយ។ បន្ទាប់ពីការធ្វើសង្គ្រាមអស់មួយជំនាន់ ប្រជាជនបារាំងភាគច្រើនស្វាគមន៍សន្តិភាព។ ប៉ុន្តែ ប្រជាជនមួយចំនួនមិនសប្បាយចិត្តជាមួយហេនរីសម្រាប់ការសម្រុះសម្រួលសាសនារបស់ទ្រង់។ នៅក្នុងឆ្នាំ 1610 អ្នកងុបងល់នឹងសាសនាមួយរូបបានលោតចូលទេះសេះ និងបានចាក់សម្លាប់ហេនរី។

ព្រះអង្គម្ចាស់ល្វីទី 13 និងខាឌីណាល រីឆេលីយ៉េះ បន្ទាប់ពីការសុគតរបស់ព្រះអង្គម្ចាស់ល្វីទី 4 រាជបុត្ររបស់ទ្រង់ព្រះនាមល្វីទី 13 បានឡើងគ្រងរាជ្យ។ ព្រះអង្គម្ចាស់ល្វីទី 13 គឺជាស្តេចដែលអន់ខ្សោយមួយអង្គ ប៉ុន្តែនៅក្នុងឆ្នាំ 1624 ទ្រង់បានតែងតាំងរដ្ឋមន្ត្រីខ្លាំងក្លាមួយរូបអ្នកដែលបានបំពេញបន្ថែមនូវរាល់ចំណុចខ្សោយរបស់ទ្រង់។ នៅក្នុងការអនុវត្ត ខាឌីណាល រីឆេលីយ៉េបានក្លាយជាមេដឹកនាំរបស់បារាំង។ អស់រយៈពេលជាច្រើនឆ្នាំ លោកគឺជាមេដឹកនាំធ្វើការងារសកម្មមួយរូបសម្រាប់ព្រះវិហារកាតូលិកនៅក្នុងប្រទេសបារាំង។ បើទោះបីជាលោកព្យាយាមនៅក្នុងការដឹកនាំដោយផ្អែកលើគោលការសិលធម៌ក៏ដោយ ក៏លោកជាអ្នកដែលមានមហិច្ឆិតា និងរីករាយជាមួយការគ្រប់គ្រងអំណាចផងដែរ។ ក្នុងនាមជារដ្ឋមន្ត្រីមួយរូបរបស់ព្រះអង្គម្ចាស់ល្វីទី 13 ទ្រង់អាចបំពេញនូវមហិច្ឆិតារបស់លោកនៅក្នុងសង្វៀននយោបាយ។ រីឆេលីយ៉េបានប្រើប្រាស់ចំហាន 2 ដើម្បីបង្កើនអំណាចរបស់រាជាធិបតេយ្យបួប៊ុន។ ដំបូង លោកធ្វើចលនាប្រឆាំងជាមួយពួកហ៊ូហ្គេណូត។ លោកជឿថាពួកប្រូតេស្តង់និយមជារឿយៗបានដើរតួនាទីជាជម្រុញឱ្យមាននយោបាយមិនទុកចិត្តប្រឆាំងជាមួយស្តេចកាតូលិក។ បើទោះបីជារីឆេលីយ៉េមិនបានយកចេញនូវសិទ្ធិនៅក្នុងការគោរពបូជារបស់ពួកហ៊ូហ្គេណូរក៏ដោយ លោកបានហាមឃាត់ទីក្រុងនានារបស់ពួកប្រូតេស្តង់មិនឱ្យមានកំពែង។ លោកមិនចង់ឱ្យពួកគេអាចបះបោរប្រឆាំងជាមួយស្តេច ហើយបន្ទាប់មកដកថយនៅពីក្រោយការការពារដ៏រឹងមាំ។ ទីពីរ លោកសម្លឹងទៅរកការធ្វើឱ្យអំណាចរបស់ពួកអភិជនចុះខ្សោយ។ រីឆេលីយ៉េបានបញ្ជាឱ្យពួកអភិជនរុះរើប្រាសាទដែលមានកំពែងរឹងមាំរបស់ខ្លួន។ លោកបានបង្កើនអំណាចរបស់ភ្នាក់ងាររដ្ឋាភិបាល ដែលមកពីវណ្ណៈកណ្តាល។ ព្រះមហាក្សត្រពឹងផ្អែកលើភ្នាក់ងារទាំងនេះ ដូច្នេះទ្រង់អាចកាត់បន្ថយការប្រើប្រាស់មន្ត្រីអភិជន។ រីឆេលីយ៉េក៏ចង់ធ្វើឱ្យបារាំងក្លាយជាប្រទេសមួយដែលខ្លាំងបំផុតនៅអឺរ៉ុប។ លោកជឿថាឧបសគ្គសំខាន់បំផុតសម្រាប់រឿងនេះ គឺមេដឹកនាំហាពស្បឺក ដែលគ្រប់គ្រងទឹកដីនៅជុំវិញប្រទេសបារាំង។ ពួកហាពស្បឺកដឹកនាំអេស្ប៉ាញ, អូទ្រីស, ហូឡង់, និងផ្នែកខ្លះនៃចក្រភពរ៉ូម៉ាំងពិសិដ្ឋ។ ដើម្បីកម្រិតអំណាចរបស់ពួកហាពស្បឺក រីឆេលីយ៉េបាននាំបារាំងចូលទៅក្នុងសង្គ្រាម 13 ឆ្នាំ។

## 2. អ្នកនិពន្ធត្រឡប់ឆ្ពោះទៅរកសង្ស័យនិយម

ដូចដែលប្រទេសបារាំងទទួលបានមកវិញនូវអំណាចនយោបាយ ចលនាបញ្ញវន្តបារាំងថ្មីមួយត្រូវបានអភិវឌ្ឍ។ ទស្សនវិទូបារាំងបានមើលឃើញពីសង្គ្រាមសាសនាដោយភាពភ័យរន្ធត់។ អ្វីដែលពួកគេបានឃើញបានប្រែត្រឡប់ពួកគេឆ្ពោះទៅរកសង្ស័យនិយម ជាគំនិតមួយដែលថាគ្មានអ្វីដែលគេដឹងច្បាស់បានឡើយ។ ទស្សនវិទូទាំងនោះបង្ហាញពីឥរិយាបថសង្ស័យចំពោះព្រះវិហារគ្រីស្តសាសនា ដែលបានអះអាងថាមានតែគោលលិទ្ធិមួយប៉ុណ្ណោះដែលត្រឹមត្រូវ។ អ្នកសង្ស័យនិយមយល់ឃើញថាការសង្ស័យទៅលើគំនិតចាស់គឺជាជំហានដំបូងឆ្ពោះទៅរកការស្វែងរកការពិត។

ម៉ុងតែនេ និងដេសកាតេស៖ មីសែល ដេ ម៉ុងតែនេរស់នៅអំឡុងសម័យកាលអាក្រក់បំផុតនៃសង្គ្រាមសាសនានៅក្នុងប្រទេសបារាំង។ បន្ទាប់ការស្លាប់របស់មិត្តភ័ក្តជិតស្និតមួយរូប ម៉ុងតែនេគិតយ៉ាងខ្លាំងអំពីអត្ថន័យនៃជីវិត។ ដើម្បីប្រាប់អំពីគំនិតរបស់លោក ម៉ុងតែនេបានអភិវឌ្ឍទម្រង់អក្សរសិល្ប៍ថ្មីមួយគឺ តែងសេចក្តី។ តែងសេចក្តីមួយគឺ

ជាស្នាដៃសង្ខេបមួយដែលបង្ហាញពីការគិត និងយោបល់របស់មនុស្សម្នាក់។ នៅក្នុងតែងសេចក្តីមួយ ម៉ុងតែនេបានបង្ហាញថានៅពេលដែលជំនឿថ្មីមួយលេចឡើង វាបានជំនួសជំនឿចាស់ដែលមនុស្សធ្លាប់គិតថាវាត្រឹមត្រូវ។ លោកបន្តទៀតថា នៅក្នុងវិធីដូចគ្នានេះជំនឿថ្មីក៏នឹងប្រហែលជាជំនួសគំនិតខុសៗគ្នាមួយចំនួនអំពីអនាគត់។ សម្រាប់ហេតុផលនេះ ម៉ុងតែនេជឿថាមនុស្សមិនអាចមានចំណេះដឹងដាច់ខាតអំពីអ្វីដែលត្រឹមត្រូវនោះឡើយ។ អ្នកនិពន្ធបារាំងមួយរូបទៀតឈ្មោះរេនេ ដេសកាតេស គឺជាទស្សនវិទូដ៏វៃឆ្លាតមួយរូប។ នៅក្នុងស្នាដៃរបស់លោកដែលមានចំណងជើងថាសមាធិលើទស្សនវិជ្ជាដំបូង ដេសកាតេសបានពិនិត្យមើលអំពីអំណោះអំណាងបែបមន្ទិលថា មនុស្សម្នាក់មិនអាចដឹងប្រាកដពីអ្វីៗបានឡើង។ នៅក្នុងការធ្វើដូច្នេះ លោកបានបង្កើតទស្សនវិជ្ជាមួយដែលជះឥទ្ធិពលលើទស្សនវិទូសម័យទំនើបដែលជួយដល់ការអភិវឌ្ឍវិធីសាស្ត្របែបវិទ្យាសាស្ត្រ។ ដោយហេតុនេះលោកបានក្លាយជាតួអង្គសំខាន់មួយនៅក្នុងយុគពន្លឺ ដែលអ្នកនឹងបានអាននៅក្នុងជំពូក 21 ។

### 3. ព្រះអង្គម្ចាស់ល្វីទី 14 ឡើងកាន់អំណាច

ការប្រឹងប្រែងរបស់ព្រះអង្គម្ចាស់ហេនរីទី 4 និងរីឆេលីយឺដើម្បីពង្រឹងរាជាធិបតេយ្យបារាំងបានត្រួសត្រាយផ្លូវសម្រាប់មេដឹកនាំដែលខ្លាំងបំផុតនៅក្នុងប្រវត្តិសាស្ត្របារាំង-ល្វីទី 14 ។ នៅក្នុងការយល់ឃើញរបស់ព្រះអង្គម្ចាស់ល្វីទី 14 ទ្រង់ជាមួយនឹងរដ្ឋគឺតែមួយ និងដូចគ្នា។ កំណត់ហេតុរបស់ទ្រង់បានលើកឡើងថា "ខ្ញុំគឺជារដ្ឋ"។ បើទោះបីជាព្រះអង្គម្ចាស់ល្វីទី 14 បានក្លាយជាស្តេចខ្លាំងបំផុតនៅអំឡុងរាជ្យរបស់ទ្រង់ក៏ដោយ ទ្រង់មានព្រះជន្មទើបតែ 4 ព្រះវស្សាប៉ុណ្ណោះនៅពេលដែលទ្រង់ឡើងគ្រងរាជ្យ។

ព្រះអង្គម្ចាស់ល្វី,ព្រះមហាក្សត្រវ័យក្មេងៈ នៅពេលដែលព្រះអង្គម្ចាស់ល្វីក្លាយជាព្រះមហាក្សត្រនៅក្នុងឆ្នាំ 1643 បន្ទាប់ពីបិតារបស់ទ្រង់ព្រះអង្គម្ចាស់ល្វីទី 13 សុគតអ្នកដឹកនាំពិតប្រាកដរបស់បារាំងគឺអ្នកស្នងតំណែងរបស់រីឆេលីយឺឈ្មោះកាឌីណាល់ ម៉ាហ្សារីន។ ជោគជ័យដ៏ប្រសើរបំផុតរបស់ម៉ាហ្សរីនកើតមានឡើងនៅក្នុងឆ្នាំ 1648 ជាមួយនឹងការបញ្ចប់នៃសង្គ្រាម 13 ឆ្នាំ។ ប្រជាជនជាច្រើននៅក្នុងប្រទេសបារាំង ជាពិសេសពួកអភិជន មិនចូលចិត្តម៉ាហ្សរីនឡើយដោយសារលោកបានបង្កើនពន្ធ និងពង្រឹងរដ្ឋាភិបាលកណ្តាល ចាប់ពីឆ្នាំ 1648 ដល់ 1653 កុប្បកម្មហឹង្សាប្រឆាំងម៉ាហ្សារីនបានបំបែកបារាំងជាផ្នែកៗ។ នៅពេលនោះ ពួកអភិជនដែលដឹកនាំកុប្បកម្មបានគំរាមកំហែងដល់ជីវិតរបស់ស្តេចវ័យក្មេង។ សូម្បីតែបន្ទាប់ពីអំពើហឹង្សាបានបញ្ចប់ក៏ដោយ ព្រះអង្គម្ចាស់ល្វីមិនដែលបំភ្លេចពីភាពភ័យខ្លាច ឬកំហឹងរបស់ទ្រង់ចំពោះពួកអភិជនឡើយ។ ទ្រង់បានកំណត់ថាទ្រង់នឹងបង្កើនអំណាចរបស់ទ្រង់ឱ្យរឹងមាំដូច្នេះពួកគេមិនអាចគំរាមកំហែងទ្រង់សារជាថ្មីទៀតបានឡើយ។ នៅចុងបញ្ចប់ ការបះបោររបស់ពួកអភិជនបានបរាជ័យដោយសារហេតុផល 3 យ៉ាង។ មេដឹកនាំចលនាបះបោរមិនទុកចិត្តគ្នាទៅវិញទៅមកខ្លាំងជាងពួកគេមិនទុកចិត្តម៉ាហ្សារីនទៅទៀត។ ជាងនេះទៅទៀត រដ្ឋាភិបាលបានប្រើប្រាស់ការបង្ក្រាបដោយហឹង្សា។ ចុងក្រោយ ប្រជាកសិករ និងប្រជាជននៅក្នុងទីក្រុងមានណឿយណាយកាន់តែខ្លាំងឡើងអំពីអសណ្តាប់ធ្នាប់ និងការវាយប្រយុទ្ធគ្នា។ អស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ ប្រជាជនបារាំងទទួលយកច្បាប់សង្កត់សង្កិនរបស់ស្តេចផ្តាច់ការ។ ពួកគេជឿថាការធ្វើការបះបោរនឹងធ្វើឱ្យស្ថានការណ៍កាន់តែអាក្រក់។

ព្រះអង្គម្ចាស់ល្វីធ្វើឲ្យអំណាចរបស់ពួកអភិជនចុះខ្សោយ៖ នៅពេលដែលកាឌីណាល់ ម៉ាហ្សារីនស្លាប់នៅក្នុងឆ្នាំ 1661 ព្រះអង្គម្ចាស់ល្វីដែលមានព្រះជន្ម 22 ព្រះវស្សាបានឡើងត្រួតត្រារដ្ឋាភិបាលដោយខ្លួនទ្រង់ផ្ទាល់។ ទ្រង់បានធ្វើឱ្យចុះខ្សោយនូវអំណាចរបស់ពួកអភិជនតាមរយៈការដកពួកគេចេញពីក្រុមប្រឹក្សារបស់ទ្រង់។ ផ្ទុយទៅវិញ ទ្រង់បានបង្កើនអំណាចភ្នាក់ងាររដ្ឋាភិបាលដែលគេហៅថាអយុត្តកៈ ដែលជាអ្នកប្រមូលពន្ធ និងគ្រប់គ្រងវិស័យយុត្តិធម៌។ ដើម្បីរក្សាអំណាចឱ្យស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលកណ្តាល ទ្រង់ធ្វើឱ្យប្រាកដថាមន្ត្រីក្នុងតំបន់បានធ្វើទំនាក់ទំនងជាប្រចាំជាមួយទ្រង់។

សេដ្ឋកិច្ចរីកលូតលាស់៖ ព្រះអង្គម្ចាស់ល្វីបានពលីខ្លួនទ្រង់ចំពោះការជួយទទួលបានភាពរុងរឿងផ្នែកសេដ្ឋកិច្ច, នយោបាយ, និងវប្បធម៌។ គ្មាននរណាជួយលោកដើម្បីសម្រេចគោលដៅនេះច្រើនជាងរដ្ឋមន្ត្រីហិរញ្ញវត្ថុរបស់ទ្រង់ឈ្មោះ ហ្សង់ បាបទីសតេ កូលបឺត។ កូលបឺតជឿលើទ្រឹស្តីការគិតពីផលចំណេញនិយម។ ដើម្បីការពារការហូរទ្រព្យសម្បត្តិចេញពីប្រទេស កូលបឺតបានព្យាយាមនៅក្នុងការធ្វើឱ្យប្រទេសបារាំងអាចពឹងលើខ្លួនឯង។ លោកចង់ឱ្យប្រទេសបារាំងអាចផលិតនូវអ្វីៗដែលពួកគេត្រូវការជាជាងពឹងផ្អែកលើការនាំចូល។ ដើម្បីពង្រីកការផលិត កូលបឺតបានផ្តល់មូលនិធិ និងពន្ធលើផលចំណេញរបស់រដ្ឋាភិបាលឱ្យទៅក្រុមហ៊ុនបារាំង។ ដើម្បីការពារដល់ឧស្សាហកម្មបារាំង លោកបានដាក់អត្រាពន្ធខ្ពស់មួយលើទំនិញដែលនាំចូលមកពីប្រទេសផ្សេងៗ។ កូលបឺតក៏បានទទួលស្គាល់អំពីសារៈសំខាន់នៃការដាក់អាណានិគម ដែលបានផ្តល់នូវវត្ថុធាតុដើម និងទីផ្សារមួយសម្រាប់ទំនិញរោងចក្រ។ រដ្ឋាភិបាលបារាំងបានលើកទឹកចិត្តដល់ប្រជាជន ឱ្យធ្វើអន្តោប្រវេសន៍ទៅកាន់ដែនដីអាណានិគមបារាំងនៅកាណាដា។ នៅទីនោះពាណិជ្ជកម្មរោមសត្វបានរួមចំណែកលើពាណិជ្ជកម្ម និងទ្រព្យសម្បត្តិរបស់បារាំង។ បន្ទាប់ពីកូលបឺតស្លាប់ ព្រះអង្គម្ចាស់ល្វីបានប្រកាសគោលនយោបាយមួយដែលបានបន្ថយល្បឿនសេដ្ឋកិច្ចរបស់បារាំង។ នៅក្នុងឆ្នាំ 1685 ទ្រង់បានលុបចោលនូវបញ្ញត្តិនៃណានតេស ដែលការពារសេរីភាពសាសនារបស់ពួកហ៊ូហ្គេណូត។ នៅក្នុងការឆ្លើយតប ពួកវិចិត្រករ និងអ្នកជំនួញហ៊ូហ្គេណូតរាប់ពាន់នាក់បានរត់ចេញពីប្រទេសបារាំង។ គោលនយោបាយរបស់ស្តេចល្វីបានធ្វើឱ្យបារាំងបាត់បង់កម្មករជំនាញជាច្រើន។

### 4. រចនាបថដ៏អស្ចារ្យរបស់ព្រះមហាក្សត្រព្រះអាទិត្យ

ជាមួយនឹងហិរញ្ញវត្ថុផ្ទាល់ព្រះកាយរបស់ទ្រង់ ព្រះអង្គម្ចាស់ល្វីបានចំណាយទ្រព្យសម្បត្តិរបស់ទ្រង់ទៅលើរបស់ប្រណិតៗ។ ឧទាហរណ៍ រាល់ការសោយម្តងៗត្រូវបានគេរៀបចំជាពិធីជប់លៀង។ អ្នកអង្កេតមួយរូបបានអះអាងថា ក្នុងអាហារមួយពេលព្រះមហាក្សត្រតែមួយអង្គឯងសោយស៊ុបចំនួន 4 ចាន, សត្វស្លាបមួយទាំងមូល, សត្វលលកក្នុងទឹកប្រលក់ខ្ទឹមស, ហែមពីរបន្ទះ, សាលាដមួយចាន, នំមួយចាន, ផ្លែឈើ, និងពងមាន់ស្ងោរ។ ចុងភៅ, អ្នកលើកម្ហូប, និងអ្នកបម្រើផ្សេងទៀតជិត 500 នាក់បានធ្វើការដើម្បីផ្តល់នូវរស់ជាតិដែលទ្រង់ពេញចិត្ត។

ព្រះអង្គម្ចាស់ត្រួតត្រាលើពួកអភិជន៖ នៅរៀងរាល់ព្រឹក ប្រធានអ្នកបម្រើបានដាស់ព្រះអង្គម្ចាស់ល្វីនៅម៉ោង 8:30 ។ នៅខាងក្រៅនៃវាំងននគ្រែបុស្បុករបស់ស្តេចល្វីមានពួកអភិជនដែលមានអភ័យឯកសិទ្ធិខ្ពស់បំផុតយ៉ាងហោចណាស់ 100 នាក់ឈរនៅចាំទ្រង់។ ពួកគេចាំដើម្បីជួយស្លៀកពាក់ឱ្យទ្រង់។ មានតែមនុស្ស 4 នាក់

ប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យកាន់ស្បែកជើងប្រគល់ឱ្យទ្រង់ ឬកាន់ដៃអាវឱ្យទ្រង់។ នៅខណៈពេលនោះ នៅខាងក្រៅបន្ទប់គេង, ពួកអភិជនមួយចំនួនរងចាំទ្រង់នៅក្នុងសាលរាជវាំង និងសង្ឃឹមថាស្តេចល្វីនឹងចាប់អារម្មណ៍ទៅលើពួកគេ។ ការងក់ក្បាល, ការសម្លឹងដោយយល់ស្របមួយ, ពាក្យករុណាមួយ, សញ្ញានៃចំណាប់អារម្មណ៍របស់ព្រះមហាក្សត្រទាំងនេះទាំងនេះត្រូវបានគេកំណត់ថាអភិជនមួយរូបជោគជ័យ ឬបរាជ័យ។ វត្តមានរបស់ពួកអភិជននៅក្នុងរាជវាំងបានបង្កើនអំណាចរបស់រាជានៅក្នុងវិធីពីរយ៉ាង។ វាធ្វើឱ្យពួកអភិជនពឹងផ្អែកទាំងស្រុងទៅលើស្តេចល្វី។ វាក៏បាននាំយកពួកគេមកពីផ្ទះ ដូច្នេះវាបានផ្តល់អំណាចកាន់តែច្រើនដល់ពួកអាយុត្តកៈ។ ព្រះអង្គម្ចាស់ល្វីតម្រូវឱ្យពួកអភិជនរាប់រយនាក់ រស់នៅជាមួយទ្រង់នៅក្នុងរាជវាំងរុងរឿងមួយដែលទ្រង់បានស្ថាបនានៅវែរសៃ ដែលមានចម្ងាយ 11 ម៉ាយភាគនិរតីនៃទីក្រុងប៉ារីស។ អ្វីៗគ្រប់យ៉ាងនៅរាជវាំងវែរសៃមានលក្ខណៈធំមហិមា។ នៅខាងមុខមានទីធ្លារាជវាំងដ៏ធំមួយដែលគ្របដណ្តប់ដោយរូបសំណាក់ព្រះអង្គម្ចាស់ល្វីទី 14 ។ រាជវាំងផ្ទាល់លាតសន្ធឹងប្រវែង 500 យ៉ាដ។ ដោយសារតែទំហំធំ វែរសៃដូចជាទីក្រុងតូចមួយ។ ការតុបតែង និងគ្រឿងសង្ហារឹមដ៏សម្បូរបែបរបស់វាបានបង្ហាញយ៉ាងច្បាស់ពីទ្រព្យសម្បត្តិ និងអំណាចរបស់ព្រះអង្គម្ចាស់ល្វីដល់មនុស្សទាំងឡាយដែលបានមកដល់រាជវាំង។

ការឧបត្ថម្ភដល់សិល្បៈ៖ វែរសៃគឺជាមជ្ឈមណ្ឌលនៃសិល្បៈមួយអំឡុងរាជ្យរបស់ព្រះអង្គម្ចាស់ល្វី។ ព្រះអង្គម្ចាស់ល្វីបានធ្វើឱ្យល្ខោនអូប៉េរ៉ា និងរបាំបាឡេកាន់តែមានប្រជាប្រិយភាព។ ទ្រង់ថែមទាំងបានរាំរបាំបាឡេដែលមានឈ្មោះថាព្រះមហាក្សត្រព្រះអាទិត្យ។ អ្នកនិពន្ធដែលទ្រង់ពេញចិត្តមួយរូបឈ្មោះមូលីអេរ អ្នកដែលបានសរសេររឿងកំប្លែងបំផុតមួយចំនួននៅក្នុងអក្សរសិល្ប៍បារាំង។ រឿងកំប្លែងរបស់មូលីអេររួមមាន តាទូហ្វេ ដែលបានចំអកដល់ការលាក់ពុតសាសនា។ ចាប់តាំងពីព្រះអង្គម្ចាស់អូហ្គឹស្តឹសនៃចក្រភពរ៉ូមមក មិនធ្លាប់មានព្រះមហាក្សត្រនៅអឺរ៉ុបណាគាំទ្រដល់សិល្បៈខ្លាំងដូចជាព្រះអង្គម្ចាស់ល្វីឡើយ។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គម្ចាស់ល្វី គោលដៅសំខាន់នៃសិល្បៈមិនមែនលើកតម្កើនព្រះជាម្ចាស់ ដូចកាលពីយុគកណ្តាលទៀតឡើយ។ ហើយគោលបំណងរបស់វាក៏មិនមែនលើកតម្កើនសក្តានុពលរបស់មនុស្ស ដូចដែលធ្លាប់មាននៅបុនសម័យផងដែរ។ ឥឡូវនេះគោលបំណងនៃសិល្បៈគឺលើកតម្កើងព្រះមហាក្សត្រ និងលើកកម្ពស់តម្លៃដែលគាំទ្រដល់ការគ្រប់គ្រងផ្តាច់ការរបស់ព្រះអង្គម្ចាស់ល្វី។

## 5. ព្រះអង្គម្ចាស់ល្វីវាយប្រយុទ្ធនៅក្នុងសង្គ្រាមដ៏មហន្តរាយ

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គម្ចាស់ល្វី ប្រទេសបារាំងគឺជាប្រទេសដែលខ្លាំងបំផុតនៅអឺរ៉ុប។ នៅក្នុងឆ្នាំ 1660 ប្រទេសបារាំងមានប្រជាជនប្រហែល 20 លាននាក់។ ចំនួននេះច្រើនជាងប្រជាជនអង់គ្លេស 4 ដង និង 10 ដងច្រើនជាងចំនួនប្រជាជនសាធារណរដ្ឋហូឡង់។ កងទ័ពរបស់បារាំងមានទំហំ, ការហ្វឹកហ្វឺន , និងអាវុធនាំមុខរដ្ឋដ៏ទៃទៀត។

ការព្យាយាមនៅក្នុងការពង្រីកព្រំដែនរបស់បារាំង៖ នៅក្នុងឆ្នាំ 1667, 6 ឆ្នាំបន្ទាប់ពីការស្លាប់របស់ម៉ាហ្សារីនព្រះអង្គម្ចាស់ល្វីបានឈ្លានពានហូឡង់របស់អេស្ប៉ាញ នៅក្នុងការព្យាយាមមួយដើម្បីពង្រីកព្រំដែនរបស់បារាំង។

តាមរយៈយុទ្ធនាការនេះ ទ្រង់ទទួលបានទីក្រុងចំនួន 12 ។ ជម្រុញទឹកចិត្តដោយភាពជោគជ័យរបស់ទ្រង់ ទ្រង់បានដឹកនាំកងទ័ពដោយផ្ទាល់ទៅកាន់ហូឡង់នៅក្នុងឆ្នាំ 1672 ។ ពួកហូឡង់បានជួយសង្គ្រោះប្រទេសរបស់ពួកគេតាមរយៈការបើកទំនប់ និងធ្វើឱ្យជន់លិចនៅទីជនបទ។ យុទ្ធសាស្ត្រនេះដូចគ្នាទៅនិងយុទ្ធសាស្ត្រដែលពួកគេធ្លាប់បានប្រើនៅក្នុងការបះបោររបស់ពួកគេប្រឆាំងជាមួយអេស្ប៉ាញកាលពីមួយសតវត្សរ៍មុន។ សង្គ្រាមបានបញ្ចប់នៅក្នុងឆ្នាំ 1678 ជាមួយនិងសន្ធិសញ្ញានីចមេហ្គេន។ បារាំងទទួលបានទីក្រុងមួយចំនួន និងតំបន់មួយដែលហៅថាបារាំង-កុំតេ។ ព្រះអង្គម្ចាស់ល្វីសម្រេចចិត្តនៅក្នុងការធ្វើសង្គ្រាមបន្ថែមទៀត ប៉ុន្តែលាភសំណាងរបស់ទ្រង់បានបាត់បង់។ ត្រឹមចុងទសវត្សរ៍ឆ្នាំ 1680 សម្ព័ន្ធមិត្តអឺរ៉ុបមួយត្រូវបានបង្កើតឡើងដើម្បីបញ្ឈប់បារាំង។ តាមរយៈការរួមបញ្ចូលគ្នា ប្រទេសខ្សោយៗទាំងនេះអាចប្រកួតជាមួយប្រទេសបារាំងដែលខ្លាំងបាន។ យុទ្ធសាស្ត្រការពារនេះមានគោលបំណងនៅក្នុងការធ្វើឱ្យមានតុល្យភាពអំណាចមួយ ដែលមិនមានប្រទេស ឬក្រុមមួយណាអាចគ្របដណ្តប់លើប្រទេសដ៏ទៃបានឡើយ។ នៅក្នុងឆ្នាំ 1689 ព្រះអង្គម្ចាស់វីលលៀមអូរេងរបស់ហូឡង់បានក្លាយជាព្រះមហាក្សត្ររបស់អង់គ្លេស។ ទ្រង់បានចូលរួមសម្ព័ន្ធអូស្បឺក ដែលរួមមានអធិរាជហាបប៊ឺករបស់អូទ្រីស, ព្រះមហាក្សត្ររបស់ស៊ុយអ៊ែត និងអេស្ប៉ាញ, និងមេដឹកនាំរដ្ឋតូចៗផ្សេងទៀតនៅអឺរ៉ុប។ ដោយបូកបញ្ចូលគ្នាប្រទេសទាំងនេះមានភាពខ្លាំងស្មើនិងប្រទេសបារាំង។ បារាំងនៅពេលនោះបានធ្លាក់ចុះខ្សោយដោយសារការប្រមូលផលមិនបានល្អជាច្រើនឆ្នាំ។ បញ្ហានេះបូកបន្ថែមជាមួយការធ្វើសង្គ្រាមជាញឹកញាប់ បាននាំឱ្យប្រជាជនបារាំងរកទុក្ខយ៉ាងខ្លាំង។ ក៏ដូចគ្នាដែល ប្រជាជនបារាំងរងគ្រោះពីការពន្ធថ្មីដែលព្រះអង្គម្ចាស់ល្វីបានដាក់ចេញដើម្បីគាំទ្រដល់ការធ្វើសង្គ្រាមរបស់ទ្រង់។

សង្គ្រាមនៃការស្នងរាជសម្បត្តិរបស់អេស្ប៉ាញ៖ នឿយហត់ជាមួយនឹងភាពលំបាក, ប្រជាជនបារាំងចង់បានសន្តិភាព។ ប៉ុន្តែអ្វីដែលពួកគេទទួលបានគឺសង្គ្រាមមួយផ្សេងទៀត។ នៅក្នុងឆ្នាំ 1700 ព្រះមហាក្សត្រដែលមិនបានបុត្ររបស់អេស្ប៉ាញព្រះនាមឆាលទី 2 បានសុគតបន្ទាប់ពីបានសន្យានៅក្នុងប្រគល់រាជបល្ល័ង្កដល់ចៅប្រុសអាយុ 16 ព្រះវស្សារបស់ព្រះអង្គម្ចាស់ល្វីទី 14 ព្រះនាមហ្វីលីបអានចូ។ មហាអំណាចទាំងពីរនៅអឺរ៉ុបនេះគឺជាសត្រូវជាមួយគ្នាអស់រយៈពេលជាយូរមកហើយ ឥឡូវមហាអំណាចទាំងពីរនេះដឹកនាំដោយរាជវង្សបារាំងបួបុន។ ប្រទេសដ៏ទៃមានអារម្មណ៍ថាមានការគំរាមកំហែងតាមរយៈការបង្កើនអំណាចរបស់សន្តតិវង្សបួបុននេះ។ នៅក្នុងឆ្នាំ 1701 ប្រទេសអង់គ្លេស, អូទ្រីស, សាធារណរដ្ឋហូឡង់, ព័រទុយហ្គាល់, និងរដ្ឋមួយចំនួននៅអាឡឺម៉ង់ និងអ៊ីតាលីបានចូលរួមជាមួយគ្នាដើម្បីការពារការរួមបញ្ចូលគ្នានៃរាជបល្ល័ង្កបារាំង និងអេស្ប៉ាញ។ ការតស៊ូដ៏យូរអង្វែងមួយដែលនឹងកើតឡើងបន្ទាប់ត្រូវបានគេស្គាល់ថាសង្គ្រាមនៃការស្នងរាជសម្បត្តិរបស់អេស្ប៉ាញ។ សង្គ្រាមដ៏បង្ហិនបង្ហោចនេះបានបន្តរហូតដល់ឆ្នាំ 1714 ។ សន្ធិសញ្ញាអ៊ូត្រេចត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំនោះ។ ស្ថិតនៅក្រោមលក្ខខ័ណ្ឌនៃសន្ធិសញ្ញានេះ ចៅប្រុសរបស់ព្រះអង្គម្ចាស់ល្វីត្រូវបានអនុញ្ញាតឱ្យបន្តធ្វើជាស្តេចនៅអេស្ប៉ាញដ៏រាបណារាជបល្ល័ង្កអេស្ប៉ាញ និងបារាំងមិនត្រូវបានរួមបញ្ចូលគ្នា។ អ្នកដែលទទួលបានជោគជ័យធំបំផុតនៅក្នុងសង្គ្រាមនេះគឺចក្រភពអង់គ្លេស។ ពីប្រទេសអេស្ប៉ាញ អង់គ្លេសយកហ្គីប្រាលតា ដែលជាបន្ទាយមួយដែលត្រួតត្រាច្រកចេញចូលសមុទ្រមេឌីទែរ៉ាណេ។ អេស្ប៉ាញក៏បានផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនអង់គ្លេសមួយឈ្មោះអាសៀនតូនៅក្នុងការបញ្ជូន

ទាសករអាហ្វ្រិកទៅកាន់ដែនដីអាណានិគមអេស្ប៉ាញនៅអាមេរិក។ ការនេះបានបង្កើនការចូលរួមរបស់អង់គ្លេសនៅក្នុងពាណិជ្ជកម្មទាសករអាហ្វ្រិក។ ជាងនេះទៅទៀត បារាំងបានប្រគល់ឱ្យអង់គ្លេសនូវដែនដីអាណានិគមភាគខាងជើងណូវ៉ា ស្កូតៀ និងញ៉ូវហ្វោនលេន និងបោះបង់ចោរដែនដីដែលខ្លួនអះអាងក្នុងការកាន់កាប់នៅតំបន់ឈូងសមុទ្ទហ៊ូដស៊ុន។ ប្រទេសអូទ្រីសហាបស្បឹកយកប្រទេសហូឡង់អេស្ប៉ាញ និងដែនដីផ្សេងៗទៀតរបស់អេស្ប៉ាញនៅអ៊ីតាលី។ ព្រូស និងសាវ៉ូយត្រូវបានទទួលស្គាល់ថាជាព្រះរាជាណាចក្រ។

ការសុគតរបស់ព្រះអង្គម្ចាស់ល្វី និងកេរ្តិ៍ដំណែល៖ ប៉ុន្មានឆ្នាំចុងក្រោយនៃរាជ្យរបស់ព្រះអង្គម្ចាស់ល្វីគឺមានការឈឺចាប់ជាងភាពរុងរឿង។ ដោយដឹងថាសង្គ្រាមរបស់ទ្រង់បានបំផ្លិចបំផ្លាញប្រទេសបារាំង ទ្រង់បានការសោកស្តាយចំពោះភាពឈឺចាប់ដែលទ្រង់បាននាំយកមកឱ្យប្រជាជនបារាំង។ ទ្រង់សុគតនៅលើគ្រែក្នុងឆ្នាំ 1715 ។ ព័ត៌មានអំពីការសុគតរបស់ទ្រង់បានជម្រុញឱ្យមានការរីករាយនៅពាសពេញប្រទេស។ ប្រជាជនបារាំងមានការធ្អែតធ្អន់ជាមួយនិងព្រមហាក្សត្រព្រះអាទិត្យ (ល្វីសទី 14)។ ព្រះអង្គម្ចាស់ល្វីបានបន្សល់ទុកនូវកេរ្តិ៍ដំណែលចម្រុះសម្រាប់ប្រទេសរបស់ទ្រង់។ នៅខាងផ្នែកវិជ្ជមាន បារាំងក្លាយជាប្រទេសមហាអំណាចមួយនៅអឺរ៉ុប។ បារាំងស្ថិតនៅកម្រិតលើប្រទេសដ៏ទៃទៀតផ្នែកខាងសិល្បៈ, អក្សរសិល្ប៍, និងភាពជារដ្ឋអំឡុងរាជរបស់ស្តេចល្វី។ ជាងនេះទៅទៀត បារាំងត្រូវបានចាត់ទុកថាជាប្រទេសដែលមានវិស័យយោធាឈានមុខគេនៅអឺរ៉ុប។ វិស័យយោធាបានអនុញ្ញាតឱ្យបារាំងអភិវឌ្ឍចក្រភពដែនដីអាណានិគមដ៏រឹងមាំមួយ ដែលបានផ្តល់នូវធនធាន និងទំនិញសម្រាប់ការធ្វើពាណិជ្ជកម្ម។ នៅខាងផ្នែកអវិជ្ជមាន ការធ្វើសង្គ្រាមជាញឹកញាប់ និងការស្ថាបនារាជវាំងវែរសៃបាននាំបារាំងធ្លាក់ទៅក្នុងបំណុល។ ក៏ដូចគ្នាដែរ ការមិនសប្បាយចិត្តចំពោះការយកពន្ធខ្ពស់លើប្រជាជនក្រីក្រ និងការរំលោភអំណាចរបស់ស្តេចល្វីនឹងបង្កបញ្ហាដល់អ្នកស្នងមរតកពីទ្រង់ និងជាយថាហេតុនាំទៅដល់ការធ្វើបដិវត្ត។ ការដឹកនាំបែបផ្តាច់ការមិនបានស្លាប់ទៅជាមួយព្រះអង្គម្ចាស់ល្វីទី 14 ឡើយ។ សត្រូវរបស់ទ្រង់នៅព្រូស និងអូទ្រីសបានទទួលបទពិសោធន៍ជាមួយនឹងទ្រង់ដឹកនាំបែបរាជាធិបតេយ្យផ្តាច់ការរបស់ពួកគេ ដូចដែលអ្នកនឹងបានអាននៅក្នុងមេរៀនទី 3 ។

# មេរៀនទី 3 ៖ ព្រះមហាក្សត្រនៅអឺរ៉ុបកណ្តាលប៉ះទង្គិចគ្នា

មេដឹកនាំអាឡឺម៉ង់នានាហាក់ដូចជាអាចដោះស្រាយបញ្ហានៃភាពខុសគ្នានៃសាសនារបស់ពួកគេ តាមរយៈសន្ធិសញ្ញាសន្តិភាពអូស្ប៊ឺក (1555) បានរយៈពេលខ្លីមួយ។ ពួកគេបានយល់ស្របថាជំនឿរបស់ព្រះអង្គម្ចាស់នីមួយៗនឹងកំណត់ពីសាសនារបស់ប្រជានុរាស្ត្ររបស់ទ្រង់។ ព្រះវិហារសាសនាគ្រឹស្តនៅក្នុងប្រទេសអាឡឺម៉ង់អាចជាលូថេរ៉ាន់ ឬកាតូលិក ប៉ុន្តែមិនមែនកាលវីននិយមឡើយ។ សន្ធិសញ្ញាសន្តិភាពនេះមានរយៈពេលខ្លី ភាមៗនោះត្រូវបានជំនួសដោយសង្គ្រាមវែងអន្លាយមួយ។ បន្ទាប់ពីសន្ធិសញ្ញាសន្តិភាពអូស្ប៊ឺក ព្រះអង្គម្ចាស់នានានៅអាឡឺម៉ង់ដែលកាន់សាសនាលូថេរ៉ាន់ និងកាតូលិកសំលឹងមើលគ្នាដោយភាពមិនទុកចិត្ត។

## 1. សង្គ្រាម 30 ឆ្នាំ

ទាំងព្រះអង្គម្ចាស់កាន់សាសនាលូថេរ៉ាន់ និងកាតូលិកព្យាយាមនៅក្នុងការទទួលបានអ្នកដើរតាម។ ជាងនេះទៅទៀត ភាគីទាំងពីរមានអារម្មណ៍ថាពួកគេត្រូវបានគំរាមកំហែងដោយពួកកាលវីននិយម ដែលបានរីកសាយភាយនៅក្នុងប្រទេសអាឡឺម៉ង់ និងទទួលបានអ្នកដើរតាមជាច្រើន។ ជម្លោះបានផ្ទុះឡើងនៅពេលដែលពួកលូថេរ៉ាន់បានចូលរួមជាមួយសហភាពប្រូតេស្តង់នៅក្នុងឆ្នាំ 1608 ។ នៅឆ្នាំបន្ទាប់ ព្រះអង្គម្ចាស់កាតូលិកនានាបានបង្កើតសម្ព័ន្ធកាតូលិកមួយ។ ឥឡូវនេះវាត្រូវការតែកម្ទេចភ្លើងប៉ុណ្ណោះដើម្បីបញ្ឆេះសង្គ្រាម។

បូហេមេនប្រូតេស្តង់បះបោរ៖ កម្ទេចភ្លើងបានកើតមានឡើងនៅក្នុងឆ្នាំ 1618 ។ អនាគតអធិរាជចក្រភពរ៉ូម៉ាំងពិសិដ្ឋព្រះនាមហ្វឺឌីណង់ទី 2 គឺជាមេគ្រួសារហាបស្ប៊ឺក។ ក្នុងនោះទ្រង់បានដឹកនាំព្រះរាជាណាចក្របូហេមេនរបស់ឆេក។ ប្រូតេស្តង់នៅបូហេមេនមិនបានជឿទុកចិត្តលើព្រះអង្គម្ចាស់ហ្វឺឌីណង់ឡើយ ដោយសារទ្រង់ជាជនបរទេស និងជាអ្នកកាតូលិក។ នៅពេលដែលទ្រង់បិទព្រះវិហារប្រូតេស្តង់មួយចំនួន ពួកប្រូតេស្តង់បានបះបោរ។ ព្រះអង្គម្ចាស់ហ្វឺឌីណង់បានបញ្ជូនកងទ័ពមួយក្រុមទៅកាន់នបូហេមេនដើម្បីបង្ក្រាបការបះបោរ។ ព្រអង្គម្ចាស់អាឡឺម៉ង់មួយចំនួនដែលកាន់សាសនាប្រូតេស្តង់ បានចាប់យកឱកាសនៅក្នុងការប្រជែងជាមួយអធិរាជកាតូលិករបស់ពួកគេ។ ដូច្នេះ សង្គ្រាម 30 ឆ្នាំបានចាប់ផ្តើមឡើង ដែលជាជម្លោះមួយលើបញ្ហាសាសនា និងទឹកដី និងដើម្បីអំណាចក្នុងចំណោមគ្រួសារអ្នកដឹកនាំនៅអឺរ៉ុប។ សង្គ្រាមត្រូវបានគេចែកជាពីរដំណាក់កាលសំខាន់ៗ៖ ដំណាក់កាលដែលហាបស្ប៊ឺកទទួលជ័យជំនះ និងដំណាក់កាលដែលហាបស្ប៊ឺកបរាជ័យ។

ជ័យជំនះរបស់ហាបស្ប៊ឺក៖ សង្គ្រាម 30 ឆ្នាំចាប់ផ្តើមពីឆ្នាំ 1618 រហូតដល់ឆ្នាំ 1648 ។ អំឡុងពេល 12 ឆ្នាំដំបូង កងទ័ពរបស់ហាបស្ប៊ឺកមកពីប្រទេសអូទ្រីស និងអេស្ប៉ាញបានបង្ក្រាមកងទ័ពនានាដែលជួលដោយព្រះអង្គម្ចាស់នានារបស់ប្រូតេស្តង់។ ពួកគេទទួលជោគជ័យនៅក្នុងការបង្ក្រាមការបះបោរនៅឆេក។ ពួកគេក៏យកជ័យជំនះលើពួកប្រតេស្តង់អាឡឺម៉ង់ដែលគាំទ្រឆេក។ ព្រះអង្គម្ចាស់ហ្វឺឌីណង់បានផ្តល់ការអនុញ្ញាតឱ្យកងទ័ពរបស់ទ្រង់ចំនួន 125,000 នាក់លួចប្លន់ភូមិនានានៅអាឡឺម៉ង់។ កងទ័ពដ៏ធំនេះបានកម្ទេចនូវអ្វីៗទាំងអស់នៅតាមផ្លូវដែលពួកគេធ្វើដំណើរ។

ការបរាជ័យរបស់ហាបស្បឺក៖ មេដឹកនាំប្រូតេស្តង់ហ្គូស្តាវូស អាដូលភូសរបស់ស៊ុយអ៊ែត និងកងទ័ពប្រកបដោយវិន័យរបស់ទ្រង់ចំនួន 23,000 នាក់បានផ្លាស់ប្តូរទំនោរនៃសង្គ្រាមនៅក្នុងឆ្នាំ 1630 ។ ពួកគេបានបណ្តេញកងទ័ពហាបស្បឺកចេញពីអាឡឺម៉ង់ភាគខាងជើង។ ប៉ុន្តែស្តាវូស អាដូលភូសត្រូវបានសម្លាប់នៅក្នុងសមរភូមិមួយនៅក្នុងឆ្នាំ 1632 ។ កាឌីណាល់ រីឆេលីយឺ និងកាឌីណាល់ម៉ាហ្សារីនរបស់បារាំងបានគ្របដណ្តប់រយៈពេលសង្គ្រាមដែលនៅសេសសល់។ បើទោះបីជាកាតូលិក៏ដោយ កាឌីណាស់ទាំងពីររូបនេះមានការភ័យខ្លួនចំពោះពួកហាបស្បឺកច្រើនជាងពួកប្រូតេស្តង់។ ពួកគេមិនចង់ឱ្យមេដឹកនាំអឺរ៉ុបផ្សេងទៀតមានអំណាចខ្លាំងដូចស្តេចបារាំងឡើយ។ ដូច្នេះ នៅក្នុងឆ្នាំ 1635 រីឆេលីយឺបានបញ្ជូនកងទ័ពបារាំងទៅចូលរួមជាមួយពួកប្រូតេស្តង់អាឡឺម៉ង់ និងស៊ុយអ៊ែតនៅក្នុងការតស៊ូរបស់ពួកគេប្រឆាំងជាមួយកងទ័ពហាបស្បឺក។

សន្ធិសញ្ញាសន្តិភាពវេសផាលៀ៖ សង្គ្រាមបានបង្កការខូចខាតយ៉ាងខ្លាំងដល់អាឡឺម៉ង់។ ប្រជាជនរបស់ពួកគេបានធ្លាក់ចុះពី 20 លាននាក់មកនៅត្រឹមប្រហែល 16 លាននាក់។ ទាំងពាណិជ្ជកម្ម និងកសិកម្មត្រូវបានអង្អាក់ ហើយសេដ្ឋកិច្ចរបស់អាឡឺម៉ង់បានរាបដល់ដី។ អាឡឺម៉ង់ត្រូវចំណាយពេលដ៏វែង និងពិបាកមួយដើម្បីស្តារគ្រោះមហន្តរាយនេះ។ នេះហើយជាមូលហេតុសំខាន់មួយដែលពួកគេមិនអាចក្លាយជារដ្ឋបង្រួបបង្រួមមួយរហូតដល់ទសវត្សរ៍ឆ្នាំ 1800 ។ សន្ធិសញ្ញាសន្តិភាពវេសផាលៀ (1648) បានបញ្ចប់សង្គ្រាម។ សន្ធិសញ្ញានេះមានហេតុបច្ច័យសំខាន់ៗដូចជា៖(1) ធ្វើឱ្យរដ្ឋហាបស្បឺកនានារបស់អេស្ប៉ាញ និងអូទ្រីសចុះខ្សោយ។ (2) ពង្រឹងអំណាចបារាំងតាមរយៈការផ្តល់ទឹកដីអាឡឺម៉ង់ដល់ពួកគេ។ (3) ធ្វើឱ្យព្រះអង្គម្ចាស់អាឡឺម៉ង់នានាទទួលបានឯករាជ្យពីអធិរាជរ៉ូម៉ាំងពិសិដ្ឋ។ (4) បញ្ចប់សង្គ្រាមសាសនានៅអឺរ៉ុប។ (5) បង្កើតវិធីសាស្ត្រចរចាសន្តិភាពថ្មីមួយតាមរយៈការជួយគ្នាពីគ្រប់ភាគីទាំងអស់ដើម្បីស្វែងរកដំណោះស្រាយចំពោះមួយនៃសង្គ្រាម និងធ្វើសេចក្តីសម្រេចនៅក្នុងបរិបទសន្តិភាព។ វិធីសាស្ត្រនេះនៅតែត្រូវបានគេប្រើប្រាស់រហូតមកដល់សព្វថ្ងៃ។

ការចាប់ផ្តើមឡើងនៃរដ្ឋទំនើប៖ សន្ធិសញ្ញាបានបោះបង់ចោលនូវគំនិតអំពីចក្រភពកាតូលិកដែលនឹងត្រួតត្រាមួយភាគធំលើអឺរ៉ុប។ វាបានទទួលស្គាល់អឺរ៉ុបថាជាក្រុមមួយដែលមានភាពស្មើគ្នា, ជារដ្ឋឯករាជ្យ។ នេះគឺជាការចាប់ផ្តើមដំបូងនៃប្រព័ន្ធរដ្ឋទំនើប និងជាលទ្ធផលសំខាន់បំផុតនៃសង្គ្រាម 30 ឆ្នាំ។

## 2. ទម្រង់រដ្ឋនៅអឺរ៉ុបកណ្តាល

រដ្ឋខ្លាំងៗនៅអឺរ៉ុបកណ្តាលត្រូវបានបង្កើតឡើងយឺតជាងនៅអឺរ៉ុបខាងលិច។ មហាអំណាចនៅក្នុងតំបន់នេះរួមមានព្រះរាជាណាចក្រប៉ូឡូញ, ចក្រភពរ៉ូម៉ាំងពិសិដ្ឋ, និងចក្រភពអូតូម៉ង់។ មិនមានរដ្ឋមួយណាខ្លាំងណាស់ពេកទេនៅត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1600 ។

ភាពខុសគ្នានៃសេដ្ឋកិច្ចជាមួយពួកខាងលិច៖ មូលហេតុមួយសម្រាប់ការអភិវឌ្ឍយឺតនេះគឺថាសេដ្ឋកិច្ចនៅអឺរ៉ុបកណ្តាលបានអភិវឌ្ឍខុសពីនៅអឺរ៉ុបខាងលិច។ នៅចុងយុគកណ្តាល ពួកខ្ញុំកញ្ជះនៅអឺរ៉ុបខាងលិចបន្តិចម្តងៗទទួលបានសេរីភាព និងផ្លាស់ទីទៅកាន់ទីក្រុង។ នៅទីនោះ ពួកគេបានចូលរួមជាមួយពួកវណ្ណៈកណ្តាលនៅក្នុងទីក្រុងអ្នកដែលទទួលបានអំណាចសេដ្ឋកិច្ចដោយសារតែការធ្វើបដិវត្តពាណិជ្ជកម្ម និងការអភិវឌ្ឍនៃមូលធននិយម។

ផ្ទុយទៅវិញ ពួកអភិជនដែលជាម្ចាស់កម្មសិទ្ធិដីធ្លីនៅអឺរ៉ុបកណ្ដាលបានបង្កើតច្បាស់កម្រិតសមត្ថភាពរបស់ពួកខ្ញុំកញ្ជះក្នុងការទទួលបានសិទ្ធិសេរីភាព និងផ្លាស់ប្តូរទៅកាន់ទីក្រុង។ ពួកអភិជនទាំងអស់នេះចង់រក្សាពួកខ្ញុំកញ្ជះនៅលើដីរបស់ពួកគេ ជាទីកន្លែងដែលពួកគេអាចដាំដុះបាននូវទិន្នផលច្រើន។ ពេលនោះពួកអភិជនអាចលក់ទិន្នផលលើសទៅកាន់ទីក្រុងនានានៅអឺរ៉ុបខាងលិចដោយទទួលបានប្រាក់ចំណេញច្រើន។

ចក្រភពចុះអន់ខ្សោយមួយចំនួន៖ អភិជនដែលជាម្ចាស់កម្មសិទ្ធិដីធ្លីនៅអឺរ៉ុបកណ្ដាលមិនត្រូវតែកាន់កាប់ខ្ញុំកញ្ជះប៉ុណ្ណោះទេ ប៉ុន្តែក៏បានរារាំងមិនឱ្យមានការកើនឡើងនៃស្តេចខ្លាំងផងដែរ។ ឧទាហរណ៍ ពួកអភិជនប៉ូឡូញគឺជាអ្នកបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រប៉ូឡូញ និងកម្រិតអំណាចរបស់ទ្រង់។ ពួកគេផ្តល់ឱ្យព្រះមហាក្សត្រនូវចំណូលតិចតួច, មិនមានច្បាប់រាជវាំង, និងមិនមានកងទ័ពរឹងមាំ។ ជាលទ្ធផល មិនមានមេដឹកនាំរឹងមាំមួយដែលអាចបង្កើតរដ្ឋបង្រួបបង្រួមមួយបានឡើយ។ ចក្រភពចំនួន 2 នៅអឺរ៉ុបកណ្ដាលក៏ខ្សោយផងដែរ។ បើទោះបីជាស៊ុលតង់ម៉ាន់ដ៏រុងរឿងបានដណ្ដើមកាន់កាប់ប្រទេសហុងគ្រី និងគំរាមកំហែងដល់វីយែនណានៅក្នុងឆ្នាំ 1529 ក៏ដោយ ក៏ចក្រភពអូតូម៉ង់មិនអាចដណ្ដើមកាន់កាប់អឺរ៉ុបទៅមុខទៀតបានឡើយ។ ចាប់ពីពេលនោះមក ចក្រភពអូតូម៉ង់បានធ្លាក់ចុះអំណាចរបស់ខ្លួន។ ជាងនេះទៅទៀត ចក្រភពរ៉ូម៉ាំងពិសិដ្ឋបានចុះខ្សោយយ៉ាងខ្លាំងដោយសារសង្គ្រាម 30 ឆ្នាំ។ ដោយមិនអាចបន្តបញ្ជាលើរដ្ឋអាឡឺម៉ង់នានា ចក្រភពរ៉ូម៉ាំងពិសិដ្ឋមិនមានអំណាចពិតប្រាកដឡើយ។ ចក្រភព និងព្រះរាជាណាចក្រដែលចាស់ៗ និងចុះខ្សោយទាំងនេះបានបន្សល់ទុកនូវអំណាចតិចតួចនៅអឺរ៉ុបកណ្ដាល។ នៅចុងទសវត្សរ៍ឆ្នាំ 1600 គ្រួសារនិយាយភាសាអាឡឺម៉ង់ពីរបានសម្រេចចិត្តនៅក្នុងការបំពេញនូវអំណាចដែលមានតិចតួចតាមរយៈការឡើងកាន់អំណាចផ្ដាច់មុខដោយខ្លួនឯងផ្ទាល់។

អូទ្រីសកើនអំណាច៖ គ្រួសារមួយនៅក្នុងចំណោមគ្រួសារទាំងពីរនេះគឺហាបស្បឺកអូទ្រីស។ ហាបស្បឺកអូទ្រីសបានអនុវត្តនូវជំហានមួយចំនួនដើម្បីក្លាយជារាជាធិបតេយ្យផ្តាច់ការ។ ដំបូង អំឡុងសង្គ្រាម 30 ឆ្នាំពួកគេបានដណ្ដើមកាន់កាប់បូហេមៀសារជាថ្មី។ ហាបស្បឺកបានបោសសម្អាតពួកប្រូតេស្តង់នៅទីនោះ និងបានបង្កើតពួកអភិជនឆេកថ្មីមួយក្រុមដែលមានភក្ដីភាពចំពោះពួកគេ។ ទីពីរ បន្ទាប់ពីសង្គ្រាមមេដឹកនាំហាបស្បឺកបានធ្វើមជ្ឈការរដ្ឋាភិបាល និងបង្កើតយោធារឹងមាំមួយ។ ទីបី ត្រឹមឆ្នាំ 1699 ពួកហាបស្បឺកបានដណ្ដើមកាន់កាប់ហុងគ្រីឡើងវិញពីចក្រភពអូតូម៉ង់។ នៅក្នុងឆ្នាំ 1711 ស្តេចឆាលទី 6 បានក្លាយជាមេដឹកនាំហាបស្បឺក។ ចក្រភពរបស់ស្តេចឆាលគឺជាចក្រភពមួយដែលពិបាកនៅក្នុងការគ្រប់គ្រង។ នៅក្នុងព្រំប្រទល់របស់ចក្រភពមានប្រជាជនរស់នៅជម្រុះគ្នា ដោយក្នុងនោះរួមមានពួកឆេក, ហុងគ្រី, អ៊ីតាលី, ក្រូអាត, និងអាឡឺម៉ង់។ មានតែរឿងតែមួយគត់ដែលអាចរក្សាចក្រភពឱ្យនៅរួបរួមគ្នានោះគឺមេដឹកនាំហាបស្បឺកត្រូវបំពាក់មកុដដល់អូទ្រីស, ហុងគ្រី, និងបូហេមៀ។

ព្រះនាងម៉ារីយ៉ា ថេរីសាស្នងមរតករាជបល្ល័ង្កអូទ្រីស៖ តើហាបស្បឺកធ្វើយ៉ាងដូចម្តេចដើម្បីធានាថាពួកអាចបន្តដឹកនាំដែនដីទាំងនេះបន្តទៀត? ព្រះអង្គម្ចាស់ឆាលទី 6 បានចំណាយពេលពេញមួយរាជរបស់ទ្រង់ដើម្បីឆ្លើយតបជាមួយនឹងបញ្ហានេះ។ ជាមួយនិងការគំរាមកំហែងមិនចេះចប់ចេះហើយ ទ្រង់បានបញ្ចុះបញ្ចូលមេដឹកនាំនៅអឺរ៉ុបផ្សេងៗទៀតឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលប្រកាសថាពួកគេនឹងទទួលស្គាល់បុត្រីរបស់ស្តេច

ឆាលជាអ្នកស្នងមរតកពីរាល់ដែនដីទាំងអស់របស់ហាបស្ប៊ឺក។ អ្នកស្នងមរតកនេះគឺជាស្ត្រីវ័យក្មេងមួយរូបឈ្មោះ ម៉ារីយ៉ា ថេរីសា។ ជាទ្រឹស្តី កិច្ចព្រមព្រៀងនេះធានាដល់សន្តិភាពមួយសម្រាប់រាជ្យរបស់ថេរីសា។ ផ្ទុយទៅវិញ ព្រះនាងប្រឈមនូវសង្គ្រាមជាច្រើនឆ្នាំ។ សត្រូវសំខាន់របស់ទ្រង់គឺព្រូស ដែលជារដ្ឋមួយស្ថិតនៅភាគខាងជើងអូទ្រីស។

## 3. ព្រូសប្រជែងជាមួយអូទ្រីស

ក៏ដូចជាអូទ្រីស, អំណាចរបស់ព្រូសរីកឡើងនៅចុងទសវត្សរ៍ឆ្នាំ 1600 ។ ក៏ដូចជាហាបស្ប៊ឺកអូទ្រីស គ្រួសារដឹកនាំរបស់ព្រូសគឺហូហេនហ្សូលឡឺន ក៏ជាគ្រួសារដែលមានមហិច្ឆតា។ មហិច្ឆតានេះបានគំរាមកំហែងដល់តុល្យភាពអំណាចដែលទន់ខ្សោយរបស់អឺរ៉ុបកណ្តាល។

ការរីកឡើងនៃព្រូស៖ ហូហេនហ្សូលឡឺនបានស្ថាបនារដ្ឋរបស់ពួកគេចាប់ផ្តើមពីការគ្រប់គ្រងដែនដីតូចៗ ចាប់ផ្តើមដំបូងជាមួយនិងរដ្ឋអាឡឺម៉ង់ប្រេនដេនបឺក និងព្រូស។ នៅក្នុងឆ្នាំ 1640 ពួកហូហេនហ្សូលឡឺនមួយរូបដែលមានអាយុ 20 ឆ្នាំឈ្មោះហ្វេដឺរីក វីលៀម ទទួលបានតំណែងជាអ្នកជាប់ឆ្នោតប្រេនដេនបឺក។ បន្ទាប់ពីពីមើលឃើញពីវិនាសកម្មនៃសង្គ្រាម 30 ឆ្នាំ ហ្វេដឺរីក វីលៀមក្រោមមកត្រូវបានគេស្គាល់ថាអ្នកជាប់ឆ្នោតដ៏អស្ចារ្យបានសម្រេចចិត្តថាការមានកងទ័ពរឹងមាំមួយគឺជាវិធីតែមួយគត់ដែលធានាដល់សុវត្ថិភាព។ ដើម្បីការពារដែនដីរបស់ពួកគេ អ្នកជាប់ឆ្នោតដ៏អស្ចារ្យ និងបច្ឆាជនរបស់ទ្រង់បានធ្វើដំណើរឆ្ពោះទៅរករាជាធិបតេយ្យផ្តាច់ការ។ ពួកគេបានបង្កើតយោធារឹងមាំ និងល្អបំផុតមួយនៅអឺរ៉ុប។ ពួកគេបានស្ថាបនាកងកម្លាំងមួយដែលយោធាចំនួន 80,000 នាក់។ ដើម្បីចំណាយលើកងទ័ព ពួកគេបានបង្កើតការយកពន្ធអចិន្ត្រៃ។ ចាប់ផ្តើមដំបូងជាមួយរាជបុត្ររបស់អ្នកជាប់ឆ្នោតដ៏អស្ចារ្យ ពួកគេបានហៅខ្លួនពួកគេថាស្តេច។ ពួកគេក៏បានធ្វើឱ្យចុះខ្សោយនូវសភាតំណាងនៃទឹកដីរបស់ពួកគេ។ ពួកអភិជនដែលជាម្ចាស់កម្មសិទ្ធិដីធ្លីព្រូសគឺពួកជុនខ័រ បានប្រឆាំងជាមួយនិងការកើនឡើងនៃអំណាចរបស់ស្តេច។ ប៉ុន្តែ នៅដើមទសវត្សរ៍ឆ្នាំ 1700 ស្តេចហ្វេដឺរីច វីលៀមទី 1 បាននាំមកនូវការសហការជាមួយពួកគេ។ ទ្រង់បានផ្តល់ឱ្យពួកជុនខ័រនូវសិទ្ធិពិសេសដើម្បីក្លាយជាមន្ត្រីនៅក្នុងជួរយោធារបស់ទ្រង់។ ជាលទ្ធផលព្រូសបានក្លាយជាសង្គមយោធាខ្ពស់មួយដែលមានការគ្រប់គ្រងយ៉ាងតឹងរឹង។

ព្រះអង្គម្ចាស់ហ្វេដឺរីចដ៏អស្ចារ្យ៖ ព្រះអង្គម្ចាស់ហ្វេដឺរីច វីលៀមមានការព្រួយបារម្ភថារាជបុត្ររបស់ទ្រង់ព្រះនាមហ្វេដឺរីចមិនមានសមត្ថភាពយោធាគ្រប់គ្រាន់នៅក្នុងគ្រប់គ្រងប្រទេស។ ព្រះអង្គម្ចាស់ស្រលាញ់តន្ត្រី, ទស្សនវិជ្ជា, និងកំណាព្យ, នៅក្នុងឆ្នាំ 1730 នៅពេលដែលទ្រង់ និងមិត្តភ័ក្តមួយរូបរបស់ទ្រង់ព្យាយាមនៅក្នុងការរត់គេចពួកទ្រង់ត្រូវបានចាប់ខ្លួន។ ដើម្បីដាក់ទោសដល់ហ្វេដឺរីច ព្រះមហាក្សត្របានបញ្ជាឱ្យទ្រង់កាត់ក្បាលមិត្តភ័ក្តរបស់ទ្រង់ដោយផ្ទាល់។ បើទោះបីជាមានការចង់ចាំដ៏ជូរជត់ព្រះអង្គម្ចាស់ហ្វេដឺរីកទី 2 ដែលគេស្គាល់ថាព្រះអង្គម្ចាស់ហ្វេដឺរីចដ៏អស្ចារ្យបានអនុវត្តគោលនយោបាយយោធាតាមបិតារបស់ទ្រង់ នៅពេលដែលទ្រង់ឡើងកាន់អំណាច។ ប៉ុន្តែ ទ្រង់ក៏បានបន្ធូបន្ថយច្បាប់មួយចំនួនរបស់បិតាទ្រង់។ ជាមួយនឹងកិច្ចការក្នុងស្រុក ទ្រង់បានលើកទឹកចិត្តដល់ការអត់ឱនខាងសាសនា និងការធ្វើកំណែទម្រង់ច្បាប់។ យោងតាមទ្រឹស្តីរបស់ទ្រង់អំពីរដ្ឋាភិបាល ព្រះអង្គម្ចាស់ហ្វេឌឺរីកជឿថាមេដឹកនាំមួយរូបគួរតែដូចជាឪពុកមួយរូបរបស់ប្រជាជន។

សង្គ្រាមនៃអ្នកស្នងមរតកអូទ្រីស៖ នៅក្នុងឆ្នាំ 1740 ព្រះនាងម៉ារីយ៉ា ថេរីសា បានស្នងតំណែងបន្តបិតារបស់ទ្រង់ 5 ខែបន្ទាប់ពីហ្វ្រេដឺរីកបានក្លាយជាស្តេចព្រុស។ ព្រះអង្គម្ចាស់ហ្វ្រេដឺរីកចង់បានដែនដីស៊ីលេសៀរបស់អូទ្រីសដែលមានព្រំប្រទល់ជាប់ព្រុស។ ស៊ីលេសៀផលិតរ៉ែដែក, សសៃអម្បោះ, និងផលិតផលចំណីអាហារ។ ហ្វ្រេដឺរីកមើលងាយពីសមត្ថភាពរបស់ព្រះនាងម៉ារីយ៉ា ថេរីសា។ ទ្រង់បានសន្មត់ថា ដោយសារតែព្រះនាងម៉ារីយ៉ា ថេរីសាជាស្ត្រី ដូច្នេះព្រះនាងនឹងមិនមានអំណាចគ្រប់គ្រាន់នៅក្នុងការការពារដែនដីរបស់ព្រះនាងឡើយ។ នៅក្នុងឆ្នាំ 1740 ទ្រង់បានបញ្ជូនកងទ័ពរបស់ទ្រង់ទៅកាន់កាប់ស៊ីលេសៀ ដែលនាំទៅដល់ការកើតឡើងនៃសង្គ្រាមជាមួយអ្នកស្នងមរតកអូទ្រីស។ បើទោះបីជា ព្រះនាងម៉ារីយ៉ា ថេរីសាទើបតែសម្រាលបុត្រថ្មីៗក៏ដោយ ទ្រង់បានធ្វើដំណើរទៅកាន់ហុងគ្រី។ នៅទីនោះទ្រង់បានឱបបុត្ររបស់ទ្រង់នៅក្នុងដៃ ដូចដែលទ្រង់បានស្នើសុំជំនួយពីពួកអភិជនហុងគ្រី។ បើទោះបីជាពួកអភិជនមានការមិនសប្បាយចិត្តជាមួយមេដឹកនាំហាបស្បឺករបស់ពួកគេក៏ដោយ ពួកគេបានយល់ព្រមនៅក្នុងផ្តល់ឱ្យព្រះនាងម៉ារីយ៉ា ថេរីសានូវកងទ័ពមួយក្រុម។ ចក្រភពអង់គ្លេសក៏បានចូលរួមជាមួយអូទ្រីសនៅក្នុងការវាយប្រយុទ្ធជាមួយបារាំងដែលជាសត្រូវដ៏យូរអង្វែងរបស់ពួកគេ ដែលពេលនោះជាសម្ព័ន្ធមិត្តរបស់ព្រុស។ បើទោះបីជាព្រះនាងម៉ារីយ៉ា ថេរីសាអាចបញ្ឈប់ការឈ្លានពានរបស់ព្រុសបានក៏ដោយ ក៏ទ្រង់បានបាត់បង់ស៊ីលេសៀតាមរយៈសន្ធិសញ្ញាអៃហ្ស-ឡា-ឆាប៉េលឡេនៅក្នុងឆ្នាំ 1748 ។ ជាមួយនិងការទទួលបានទឹកដីស៊ីលេសៀ ព្រុសបានក្លាយជាមហាអំណាចមួយនៅអឺរ៉ុប។

សង្គ្រាម 7 ឆ្នាំ៖ ព្រះនាងម៉ារីយ៉ា ថេរីសាបានសម្រេចចិត្តថាស្តេចបារាំងមិនមែនជាសត្រូវសំខាន់របស់អូទ្រីសទៀតឡើយ។ ដូច្នេះទ្រង់បានបង្កើតសម្ព័ន្ធភាពជាមួយពួកគេ។ ជាលទ្ធផលគឺការធ្វើបដិវត្តទំនាក់ទំនងការទូត។ នៅពេលដែលព្រះអង្គម្ចាស់ហ្វ្រេដឺរីកឮអំពីសកម្មភាពរបស់ទ្រង់ ទ្រង់បានចុះហត្ថលេខាមួយជាមួយចក្រភពអង់គ្លេសដែលជាអតីតសម្ព័ន្ធមិត្តរបស់អូទ្រីស។ ឥឡូវនេះអូទ្រីស, បារាំង, រុស្ស៊ី, និងប្រទេសផ្សេងៗទៀតបានចងសម្ព័ន្ធមិត្តជាមួយគ្នាប្រឆាំងជាមួយចក្រភពអង់គ្លេស និងព្រុស។ មិនត្រឹមតែអូទ្រីស និងព្រុសប៉ុណ្ណោះដែលបានផ្លាស់ប្តូរសម្ព័ន្ធមិត្ត ប៉ុន្តែជាលើកដំបូងដែលប្រទេសរុស្ស៊ីដើរតួនាទីនៅក្នុងកិច្ចការអឺរ៉ុប។ នៅក្នុងឆ្នាំ 1756 ព្រះអង្គម្ចាស់ហ្វ្រេដឺរីកបានវាយប្រហារសាហ្សូនី ដែលជាសម្ព័ន្ធមិត្តរបស់អូទ្រីស។ ភ្លាមៗនោះមហាអំណាចអឺរ៉ុបទាំងអស់បានចូលរួមនៅក្នុងសង្គ្រាម។ ការវាយប្រយុទ្ធគ្នានៅអឺរ៉ុប, ឥណ្ឌា, និងអាមេរិកខាងជើង, សង្គ្រាមនេះបន្តរហូតដល់ឆ្នាំ 1763 ។ វាត្រូវបានគេហៅថាសង្គ្រាម 7 ឆ្នាំ។ សង្គ្រាមនេះមិនបានផ្លាស់ប្តូរស្ថានភាពដែនដីនៅអឺរ៉ុបឡើយ។ វាមានរឿងមួយផ្សេងទៀតនៅទឹកដីខាងក្រៅ។ ទាំងបារាំង និងចក្រភពអង់គ្លេសគឺជាម្ចាស់ដែនដីអាណានិគមនៅអាមេរិកខាងជើង និងឥណ្ឌាខាងលិច។ ប្រទេសទាំងពីរបានប្រកួតប្រជែងសេដ្ឋកិច្ចគ្នានៅក្នុងប្រទេសឥណ្ឌា។ ចក្រភពអង់គ្លេសលេចឡើងជាអ្នកទទួលបានជោគជ័យនៅក្នុងសង្គ្រាម 7 ឆ្នាំ។ បារាំងបានបាត់បង់ដែនដីអាណានិគមរបស់ពួកគេនៅអាមេរិកខាងជើង, ហើយអង់គ្លេសទទួលបានការគ្រប់ដណ្តប់សេដ្ឋកិច្ចតែម្នាក់ឯងនៅក្នុងប្រទេសឥណ្ឌា។ ហេតុនេះបានបង្កើតជាជំហានបន្ទាប់របស់អង់គ្លេស ក្នុងការពង្រីកអំណាចរបស់ខ្លួននៅឥណ្ឌានៅទសវត្សរ៍ឆ្នាំ 1800 ដូចដែលអ្នកនឹងបានអាននៅក្នុងជំពូក 26 ។

# មេរៀនទី 4៖ មេដឹកនាំផ្តាច់ការនៅរុស្ស៊ី

ព្រះអង្គម្ចាស់អ៊ីវ៉ាន់ទី 3 នៃម៉ូស្គូ ដែលបានដឹកនាំប្រទេសរុស្ស៊ីចាប់ពីឆ្នាំ 1462 ដល់ឆ្នាំ 1505 បានបង្កើតស្នាដៃមួយចំនួន។ ទីមួយ ទ្រង់បានដណ្តើមកាន់កាប់ដែនដីជាច្រើននៅជុំវិញម៉ូស្គូ។ ទីពីរ ទ្រង់រំដោះប្រទេសរុស្ស៊ីពីពួកម៉ុងហ្គោល។ ទីបី ទ្រង់ចាប់ផ្តើមធ្វើមជ្ឈការរដ្ឋាភិបាលរុស្ស៊ី។ ព្រះអង្គម្ចាស់អ៊ីវ៉ាន់ទី 3 ត្រូវបានស្នងតំណែងបន្តដោយរាជបុត្ររបស់ទ្រង់ព្រះនាមវ៉ាស៊ីលីដែលបានដឹកនាំរុស្ស៊ីអស់រយៈពេល 28 ឆ្នាំ។ ព្រះអង្គម្ចាស់វ៉ាស៊ីលីបន្តធ្វើកិច្ចការរបស់បិតាទ្រង់ក្នុងការបន្ថែមទឹកដីទីក្នុងរដ្ឋកំពុងរីកចម្រើនរុស្ស៊ី។ ទ្រង់ក៏បានបង្កើនអំណាចរបស់រដ្ឋាភិបាលកណ្តាលផងដែរ។ និន្នាការនេះនៅតែបន្តធ្វើក្រោយការគ្រប់គ្រងរបស់រាជបុត្រទ្រង់ព្រះនាមអ៊ីវ៉ាន់ទី 4 ដែលនឹងក្លាយជាមេដឹកនាំផ្តាច់ការមួយអង្គ។

## 1. ស្តេចហ្សាដំបូង

ព្រះអង្គម្ចាស់អ៊ីវ៉ាន់ទី 4 ដែលគេហៅថា ព្រះអង្គម្ចាស់អ៊ីវ៉ាន់ដ៏អស្ចារ្យ ឡើងគ្រប់គ្រងអំណាចនៅក្នុងឆ្នាំ 1533 នោះពេលដែលទ្រង់ទើបតែមានព្រះជន្ម 3 ព្រះវស្សា។ ជីវិតវ័យក្មេងរបស់ទ្រង់ត្រូវបានឆាឆៅដោយការប្រជែងអំណាចគ្នាក្នុងចំណោមពួកអភិជនដែលជាម្ចាស់កម្មសិទ្ធិដីធ្លីរុស្ស៊ី ដែលគេស្គាល់ថាបូយ៉ា។ ពួកបូយ៉ាបានវាយប្រយុទ្ធគ្នាដើម្បីគ្រប់គ្រងស្តេចវ័យក្មេងអ៊ីវ៉ាន់។ នៅពេលដែលទ្រង់មានព្រះជន្ម 16 ព្រះវស្សា ព្រះអង្គម្ចាស់អ៊ីវ៉ាន់បានដណ្តើមអំណាច និងលើកខ្លួនទ្រង់ឱ្យឡើងគ្រងរាជជាស្តេចហ្សា។ គោរមងារមានន័យថា "កៃសា" ហើយអ៊ីវ៉ាន់គឺជាមេដឹកនាំរុស្ស៊ីដំបូងគេដែលប្រើប្រាស់គោលរម្យងារនេះជាផ្លូវការ។ ទ្រង់ក៏បានរៀបអភិសេកជាមួយព្រះនាងអាណាស្តាសៀដ៏ស្រស់ស្អាត ដែលជាខ្សែស្រឡាយគ្រួសារបូយ៉ាចាស់មួយគឺ រ៉ូម៉ាណូវ។ ចាប់ពីឆ្នាំ 1547 ដល់ 1560 ជាទូទៅត្រូវបានគេហៅថា សម័យល្អរបស់ព្រះអង្គម្ចាស់អ៊ីវ៉ាន់។ ទ្រង់ទទួលបានជោគជ័យដ៏អស្ចារ្យ, បន្ថែមទឹកដីដល់រុស្ស៊ី, បង្កើតក្រមច្បាប់នានាដល់រុស្ស៊ី, និងដឹកនាំត្រឹមត្រូវ។

ដឹកនាំដោយភេរវកម្ម៖ សម័យអាក្រក់របស់ព្រះអង្គម្ចាស់អ៊ីវ៉ាន់ចាប់ផ្តើមនៅក្នុងឆ្នាំ 1560 បន្ទាប់ពីព្រះនាងអាណាស្តាសៀសុគត។ ដោយចោតប្រកាន់ពួកបូយ៉ាថាបានបំពុលមហេសីរបស់ទ្រង់ ព្រះអង្គម្ចាស់អ៊ីវ៉ាន់បានងាកទៅប្រឆាំងជាមួយពួកគេ។ ទ្រង់បានរៀបចំកងកម្លាំងប៉ូលីសផ្ទាល់មួយរបស់ទ្រង់ ដែលពួកគេមានភារកិច្ចចំបងក្នុងការស្វែងរក និងសម្លាប់អ្នកទាំងឡាយណាដែលអ៊ីវ៉ាន់ចាត់ទុកថាជាជនក្បត់។ សមាជិកនៃក្រុមប៉ូលីសនេះស្លៀកពាក់ខ្មៅ និងជិះលើខ្នងសេះ។ ដោយប្រើប្រាស់ប៉ូលីសសម្ងាត់ទាំងនេះ ព្រះអង្គម្ចាស់អ៊ីវ៉ាន់បានសម្លាប់ពួកបូយ៉ា, គ្រួសាររបស់ពួកគេ, និងប្រជាកសិករដែលធ្វើការនៅលើដីរបស់ពួកបូយ៉ាអស់ជាច្រើន។ មានមនុស្សរាប់ពាន់នាក់បានស្លាប់។ ព្រះអង្គម្ចាស់អ៊ីវ៉ាន់បានដណ្តើមកាន់កាន់អចលនទ្រព្យរបស់ពួកបូយ៉ា និងបានផ្តល់វាទៅឱ្យពួកវណ្ណៈអភិជនថ្មីមួយ អ្នកដែលបន្តមានភក្តីភាពចំពោះទ្រង់។ ជាយថាហេតុ ព្រះអង្គម្ចាស់អ៊ីវ៉ាន់ប្រព្រឹត្តិនូវសកម្មភាពមួយដែលជាសោកនាដកម្មសម្រាប់បុគ្គលម្នាក់ៗផង និងជាគ្រោះថ្នាក់មួយសម្រាប់ជាតិផង។ នៅក្នុងឆ្នាំ 1581 អំឡុងពេលនៃជម្លោះហឹង្សាមួយ ទ្រង់បានសម្លាប់រាជបុត្រច្បង និងជាអ្នកស្នងមរតករបស់ទ្រង់។ នៅ

ពេលដែលព្រះអង្គម្ចាស់អ៊ីវ៉ាន់សុគតនៅ 3 ឆ្នាំបន្ទាប់ មានតែរាជបុត្រទី 2 ទន់ខ្សោយរបស់ទ្រង់គង់នៅដើម្បីដឹកនាំប្រទេស។

ការរះឡើងនៃរ៉ូម៉ាណូវ៖ រាជបុត្ររបស់ព្រះអង្គម្ចាស់អ៊ីវ៉ាន់គឺជាមេដឹកនាំដែលអសមត្ថភាពទាំងកម្លាំងកាយ និងគំនិត។ បន្ទាប់ពីទ្រង់សុគតដោយគ្មានអ្នកស្នងមរតក ប្រទេសរុស្ស៊ីជួបប្រទះនូវសម័យកាលចលាចលមួយ ដែលគេស្គាល់ថាពេលវេលានៃភាពវឹកវរ។ ពួកបូយ៉ាបានប្រយុទ្ធគ្នាដើម្បីអំណាច ហើយអ្នកស្នងមរតកពីស្តេចហ្សាសុគតក្រោមស្ថានភាពចម្លែកៗ។ អ្នកសំខាន់ៗមួយចំនួនព្យាយាមនៅក្នុងការអះអាងអំពីការគ្រប់គ្រងរាជបល្ល័ង្ក។ ចុងក្រោយ នៅក្នុងឆ្នាំ 1613 តំណាងមកពីទីក្រុងជាច្រើនរបស់រុស្ស៊ីបានជួបប្រជុំដើម្បីជ្រើសរើសស្តេចហ្សាថ្មី។ ពួកគេបានជ្រើសរើសព្រះអង្គម្ចាស់មីសែល រ៉ូម៉ាណូវ ដែលជាចៅក្មួយរបស់មហេសីរបស់ព្រះអង្គម្ចាស់អ៊ីវ៉ាន់ដ៏អស្ចារ្យព្រះនាងអាណាស្តាសៀ។ ដូច្នេះវាជាការចាប់ផ្តើមនៃសន្តតិវង្សរ៉ូម៉ាណូវ ដែលដឹកនាំប្រទេសរុស្ស៊ីអស់រយៈពេល 300 ឆ្នាំ (1613-1917)។

## 2. ព្រះអង្គម្ចាស់ពីទ័រដ៏អស្ចារ្យឡើងកាន់អំណាច

ក្រោយមកព្រះអង្គម្ចាស់ រ៉ូម៉ាណូវបានស្តារសណ្តាប់ឡើងវិញនៅក្នុងប្រទេសរុស្ស៊ី។ ពួកគេបានពង្រឹងរដ្ឋាភិបាលតាមរយៈការអនុម័តក្រមច្បាប់មួយ និងបង្រ្កាបការបះបោរ។ ហេតុនេះបានត្រួសត្រាយផ្លូវសម្រាប់ការគ្រប់គ្រងបែបផ្តាច់ការរបស់ស្តេចហ្សាពីទ័រទី 1 ។ ដំបូង ព្រះអង្គម្ចាស់ពីទ័រចែករំលែករាជបល្ល័ង្កជាមួយប្អូនរបស់ទ្រង់។ ប៉ុន្តែនៅក្នុងឆ្នាំ 1696 ព្រះអង្គម្ចាស់ពីទ័របានក្លាយជាមេដឹកនាំតែម្នាក់ឯងនៅក្នុងប្រទេសរុស្ស៊ី។ ទ្រង់ត្រូវបានគេស្គាល់នៅក្នុងប្រវត្តិសាស្ត្រថាព្រះអង្គម្ចាស់ពីទ័រដ៏អស្ចារ្យ ដោយសារទ្រង់គឺជាអ្នកធ្វើកំណែទម្រង់ដែលអស្ចារ្យបំផុតមួយរូបរបស់ប្រទេសរុស្ស៊ី។ ទ្រង់ក៏បានបន្តបង្កើនអំណាចរបស់ស្តេចហ្សាផងដែរ។

រុស្ស៊ីបង្កើតទំនាក់ទំនងជាមួយអឺរ៉ុប៖ នៅពេលដែលព្រះអង្គម្ចាស់ពីទ័រទី 1 ឡើងកាន់អំណាច ប្រទេសរុស្ស៊ីនៅតែជាដែនដីមួយដែលពោរពេញទៅដោយបូយ៉ា និងខ្ញុំកញ្ជះ។ ខ្ញុំកញ្ជះនៅក្នុងប្រទេសរុស្ស៊ីបន្តមានរហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 ដែលមានរយៈពេលយូរជាងប្រទេសនានានៅអឺរ៉ុបខាងលិច។ ម្ចាស់កម្មសិទ្ធិដីធ្លីរុស្ស៊ីចង់ឱ្យខ្ញុំកញ្ជះរស់នៅលើដីរបស់ពួកគេ និងផលិតនូវទិន្នផលដ៏ធំមួយ។ ពួកម្ចាស់កម្មសិទ្ធិដីធ្លីចាត់ទុកពួកខ្ញុំកញ្ជះដូចជាទ្រព្យសម្បត្តិរបស់ពួកគេ។ នៅពេលដែលម្ចាស់កម្មសិទ្ធិដីធ្លីលក់ដីរបស់គេណាមួយផ្នែក ពួកគេលក់ទាំងខ្ញុំកញ្ជះនៅលើដីនោះផងដែរ។ ម្ចាស់កម្មសិទ្ធិដីធ្លីអាចផ្តល់ខ្ញុំកញ្ជះទៅអ្នកដ៏ទៃធ្វើជាអំណោយ ឬដើម្បីបង់ថ្លៃបំណុល។ វាក៏ជារឿងខុសច្បាប់ផងដែរចំពោះខ្ញុំកញ្ជះណាដែលរត់ចោលម្ចាស់របស់ពួកគេ។ ភាគច្រើននៃពួកបូយ៉ាដឹងតិចតួចអំពីអឺរ៉ុបខាងលិច។ នៅយុគកណ្តាល រុស្ស៊ីបានសម្លឹងទៅរកកុងស្តង់ទីណូបសម្រាប់ការគ្រប់គ្រង មិនមែនរ៉ូមឡើយ។ បន្ទាប់មកការគ្រប់គ្រងរបស់ម៉ុងហ្គោលបានកាត់ផ្តាច់ប្រទេសរុស្ស៊ីពីបុនសម័យ និងយុគសម័យនៃការរុករក។ រនាំងភូមិសាស្ត្រក៏បានផ្តាច់រុស្ស៊ីចេញពីអឺរ៉ុបផងដែរ។ កំពង់ផែសមុទ្រតែមួយគត់របស់រុស្ស៊ីដែលមានឈ្មោះថាអាធានហ្គេលស្ថិតនៅរុស្ស៊ីភាគខាងជើងគ្របដណ្តប់ដោយទឹកកកស្ទើរពេញមួយឆ្នាំ។ ពួកអ្នកធ្វើដំណើរមួយចំនួនតូចដែលបានមកដល់ម៉ូស្គូភាគច្រើនជាពួកហូឡង់ និងអាឡឺម៉ង់ ហើយពួកគេត្រូវស្នាក់នៅផ្នែកដាច់

ដោយឡែកមួយនៃទីក្រុង។ ភាពខុសគ្នានៃសាសនាបានពង្រីកគម្លាតរវាងអឺរ៉ុបខាងលិចជាមួយរុស្ស៊ី។ រុស្ស៊ីប្រតិបត្តិគ្រីស្តសាសនានិកាយអូតូដុកខាងកើត។ ប៉ុន្តែ ពួកអឺរ៉ុបខាងលិចភាគច្រើនប្រតិបត្តិនិកាយកាតូលិក ឬប្រូតេស្តង់ ហើយពួករុស្ស៊ីយល់ឃើញថាវាជានិកាយខុសឆ្គង និងជៀសវាងនិកាយទាំងនេះ។

ព្រះអង្គម្ចាស់ពីទ័រទេស្សនកិច្ចភាគខាងលិច៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1680 តំបន់ដែលប្រជាជនអាទ្បឺម៉ង់រស់នៅនៅម៉ូស្គូស៊ាំងទៅនឹងការមើលឃើញយុវជនពីទ័រដើរកាត់ផ្ទះអ្នកជិតខាងរបស់ពួកគេ ជាមួយនិងជើងដ៏វែងរបស់ទ្រង់(ព្រះអង្គម្ចាស់ពីទ័រមានកម្ពស់ជាង 6.5 ហ្វីត)។ ទ្រង់ចាប់អារម្មណ៍ជាមួយនិងរបស់របរ និងម៉ាស៊ីនទំនើបៗដែលដាក់លក់នៅក្នុងហាងរបស់ជនបរទេស។ លើសពីនេះទៅទៀត ទ្រង់មានចំណាប់អារម្មណ៍ចំពោះនាវា និងសមុទ្ទ។ ស្តេចហ្សាវ័យក្មេងជឿថាអនាគត់របស់ប្រទេសរុស្ស៊ីពឹងផ្អែកលើការមានកំពង់ផែទឹកក្តៅស្នមមួយ។ នៅពេលនោះរ៉ូស្ស៊ីអាចប្រជែងជាមួយរដ្ឋទំនើបជាងខ្លួននៅអឺរ៉ុបខាងលិចបាន។ ព្រះអង្គម្ចាស់ពីទ័រមានព្រះជន្ម 24 ព្រះវស្សានៅពេលដែលទ្រង់ក្លាយជាអ្នកដឹកនាំតែមួយអង្គឯងនៅក្នុងប្រទេសរុស្ស៊ី។ មួយឆ្នាំក្រោយមក នៅក្នុងឆ្នាំ 1697 ទ្រង់បានចាប់ផ្តើមធ្វើដំណើរទេស្សនកិច្ចដ៏វែងមួយទៅកាន់អឺរ៉ុបខាងលិច។ គោលបំណងមួយរបស់ព្រះអង្គម្ចាស់ពីទ័រគឺសិក្សាពីប្រពៃណី និងបច្ចេកទេសផលិតរបស់អឺរ៉ុប។ ពីមុនមកមិនធ្លាប់មានស្តេចហ្សាអង្គណាធ្វើដំណើរមកកាន់អឺរ៉ុបខាងលិចឡើយ។

### 3. ព្រះអង្គម្ចាស់ពីទ័រដឹកនាំបែបផ្តាច់ការ

ជម្រុញទឹកចិត្តដោយការធ្វើដំណើររបស់ទ្រង់ទៅកាន់ភាគខាងលិច ព្រះអង្គម្ចាស់ពីទ័រយល់ឃើញថាប្រទេសរុស្ស៊ីនឹងប្រជែងជាមួយពួកអឺរ៉ុបទាំងផ្នែកយោធា និងពាណិជ្ជកម្ម។ គោលបំណងបស្ចិមនីយកម្មរបស់ពីទ័រ ដែលប្រើប្រាស់អឺរ៉ុបខាងលិចធ្វើជាគំរូនៅការផ្លាស់ប្តូរ មិនមែនជាការធ្វើឱ្យប្រទេសរុស្ស៊ីបាត់បង់អ្វីៗរបស់ខ្លួនឯងឡើយ។ ព្រះអង្គម្ចាស់ពីទ័រយល់ថាវាគឺជាវិធីមួយដែលធ្វើឱ្យរុស្ស៊ីកាន់តែរឹងមាំ។

កំណែរទម្រង់របស់ព្រះអង្គម្ចាស់ពីទ័រ៖ បើទោះបីជាព្រះអង្គម្ចាស់ពីទ័រជឿថាប្រទេសរុស្ស៊ីត្រូវបានផ្លាស់ប្តូរក៏ដោយ ទ្រង់ដឹងច្បាស់ថាប្រជាជនភាគច្រើនរបស់ទ្រង់នឹងមិនយល់ព្រមឡើយ។ ដូចដែលទ្រង់និយាយទៅកាន់មន្ត្រីមួយរូបថា "សម្រាប់អ្នក, អ្នកយល់ថារបស់មួយវាល្អ និងចំបាច់ដោយខ្លួនឯង ប៉ុន្តែប្រជាជនរបស់យើងនឹងយល់ពីវាដ៏រាបណាយើងបង្ខំឱ្យពួកគេយល់"។ ដើម្បីបង្ខំឱ្យមានការផ្លាស់ប្តូរ ព្រះអង្គម្ចាស់ពីទ័របានបង្កើនអំណាចរបស់ទ្រង់ទៅជាមេដឹកនាំផ្តាច់ការមួយអង្គ។ ព្រះអង្គម្ចាស់ពីទ័របានដាក់ព្រះវិហារអូតូដុកនៅរុស្ស៊ីឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។ ទ្រង់បានលុបបំបាត់ការិយាល័យព្រឹទ្ធចារ្យដែលជាប្រមុខនៃព្រះវិហារ។ ទ្រង់បានបង្កើតក្រុមមួយដែលគេហៅថា ស៊ីណូដពិសិដ្ឋដើម្បីគ្រឡប់ព្រះវិហារឱ្យដើរតាមទិសដៅរបស់ទ្រង់។ ក៏ដូចជាព្រះអង្គម្ចាស់អ៊ីវ៉ាន់ដ៏អស្ចារ្យ ព្រះអង្គម្ចាស់ពីទ័របានកាត់បន្ថយអំណាចរបស់ពួកម្ចាស់កម្មសិទ្ធិដីធ្លីធំៗ។ ទ្រង់បានជ្រើសរើសមនុស្សមកពីគ្រួសារវណ្ណៈទាប។ បន្ទាប់មកទ្រង់បានផ្តល់ឱ្យពួកគេនូវតួនាទីជាអង្គាធរ និងផ្តល់រង្វាន់ដល់ពួកគេនូវដីធ្លីធំៗ។ ដើម្បីធ្វើទំនើបកម្មដល់យោធារបស់ទ្រង់ ព្រះអង្គម្ចាស់ពីទ័របានជួលមន្ត្រីអឺរ៉ុបមកហ្វឹកហ្វឺនកងកម្លាំងរបស់ទ្រង់ជាមួយនឹងយុទ្ធសាស្ត្រ និងអាវុធបែបអឺរ៉ុប។ យោធាគឺជាការងារពេញមួយជីវិត។ នៅត្រឹមពេលដែលព្រះ

អង្គម្ចាស់ពីទ័រសុគត កងទ័ពរបស់រុស្ស៊ីមានចំនួន 200,000 នាក់។ ដើម្បីចំណាយលើកងទ័ពដែលមានចំនួនដ៏ច្រើននេះ ពីទ័រកម្រិតការយកពន្ធធ្ងន់ធ្ងរមួយ។

បស្ចិមនីយកម្មរុស្ស៊ីៈ ជាផ្នែកមួយនៃការព្យាយាមរបស់ទ្រង់ដើម្បីធ្វើបស្ចិមនីយកម្មរុស្ស៊ី ព្រះអង្គម្ចាស់ពីទ័រអនុវត្តដូចជាៈ (1) នាំមកនូវការដាំដុះដំឡូងបារាំង ដែលក្រោយមកបានក្លាយជាអាហារចំបងរបស់រុស្ស៊ី។ (2) ចាប់ផ្ដើមកាសែតដំបូងរបស់រុស្ស៊ី និងធ្វើការកែសម្រួលការបោះពុម្ពផ្សាយលើកទីមួយដោយខ្លួនផ្ទាល់។ (3) លើកកម្ពស់តួនាទីរបស់ស្ត្រីតាមរយៈការអនុញ្ញាឱ្យពួកគេចូលរួមនៅក្នុងការជួបជុំសាធារណៈ។ (4) បញ្ជាឱ្យពួកអភិជនបោះបង់នូវសំលៀកបំពាក់បែបប្រពៃណីរបស់ពួកគេចោល និងប្រើជំនួសដោយសំលៀកបំពាក់បែបអឺរ៉ុប។ (5) លើកកម្ពស់ការអប់រំតាមរយៈការបើកសាលារុករកមួយ និងបង្កើតសាលាសិល្បៈ និងវិទ្យាសាស្ត្រ។ ព្រះអង្គម្ចាស់ពីទ័រជឿថាការអប់រំគឺជាគន្លឹះមួយសម្រាប់ភាពជឿនលឿនរបស់រុស្ស៊ី។ កាលពីអតីតកាល ប្រជាជនត្រូវបានហាមឃាត់មិនឱ្យសិក្សាពីវិទ្យាសាស្ត្រនៅដែនដីបរទេសឡើយ។ ប៉ុន្តែឥឡូវប្រជាជនមិនត្រឹមតែគេអនុញ្ញាតឱ្យចាចេញពីប្រទេសនោះទេ ថែមទាំងបានបង្ខំពួកគេឱ្យចាកចេញទៀតផង។

ការបង្កើតទីក្រុងពីទ័រស្បឺកៈ ដើម្បីលើកកម្ពស់ការអប់រំ និងការរីកលូតលាស់ ព្រះអង្គម្ចាស់ពីទ័រចង់បានកំពង់ផែសមុទ្រមួយដែលបង្កលក្ខណៈងាយស្រួលនៅក្នុងការធ្វើដំណើរទៅកាន់ភាគខាងលិច។ ដូច្នេះ ពីទ័របានវាយប្រយុទ្ធជាមួយពួកស៊ុយអ៊ែតដើម្បីទទួលបានដែនដីមួយផ្នែកនៅឆ្នេរសមុទ្របាល់ទិក។ បន្ទាប់ពីធ្វើសង្គ្រាមអស់រយៈពេល 21 ឆ្នាំ ចុងក្រោយរុស្ស៊ីទទួលបាន "ទ្វារទៅកាន់អឺរ៉ុប" ដែលពីទ័រចង់បានជាទីបំផុត។ តាមពិតទៅ ពីទ័រកាន់កាប់ប្រកទ្វារនេះប៉ុន្មានឆ្នាំមុនការចុះចាញ់ជាផ្លូវការរបស់ស៊ុយអ៊ែតទៅទៀត។ នៅក្នុងឆ្នាំ 1703 ទ្រង់បានចាប់ផ្ដើមស្ថាបនាទីក្រុងថ្មីមួយនៅលើទឹកដីដែលដណ្ដើមកាន់កាប់ដោយកងទ័ពរុស្ស៊ីពីពួកស៊ុយអ៊ែត។ បើទោះបីជា តំបន់វាល់ភក់មិនមែនជាទីតាំងល្អក៏ដោយ វាហាក់ដូចជាល្អសម្រាប់ព្រះអង្គម្ចាស់ពីទ័រ។ នាវាអាចធ្វើដំណើរចុះតាមទន្លេនេវ៉ាទៅកាន់សមុទ្របាល់ទិក និងបន្តដំណើរទៅអឺរ៉ុបខាងលិច។ ព្រះអង្គម្ចាស់ពីទ័របានហៅទីក្រុងនេះថា ពីទ័រស្បឺក ដែលជាឈ្មោះយកតាមបុព្វបុរសរបស់ទ្រង់។ ដើម្បីស្ថាបនាទីក្រុងមួយនៅលើវាលភក់ដាច់ស្រយាល់មួយមិនមែនជារឿងងាយស្រួលឡើយ។ នៅរៀងរាល់រដូវក្ដៅ កងកម្លាំងយោធារាប់ពាន់នាក់ដែលជាខ្ញុំកញ្ជះបានធ្វើដំណើរចាកចេញពីផ្ទះនិងធ្វើការនៅពីទ័រស្បឺក។ ក្នុងការប៉ាន់ប្រមាណមានមនុស្សចន្លោះពី 25,000 ទៅ 100,000 នាក់បានស្លាប់ដោយសារស្ថានភាពការងារអាក្រក់ និងការរីករាលដាលនៃជម្ងឺ។ នៅពេលដែលការស្ថាបនាពីទ័រស្បឺកត្រូវបានបញ្ចប់ ព្រះអង្គម្ចាស់ពីទ័របានបញ្ជាឱ្យពួកអភិជនរុស្ស៊ីជាច្រើននាក់ចាកចេញពីទីលំនៅសុខស្រួលនៅម៉ូស្គូទៅតាំងទីលំនៅនៅរដ្ឋធានីថ្មីរបស់ទ្រង់។ ក្រោយមក ពីទ័រស្បឺកបានក្លាយជាកំពង់ផែដ៏មមាញឹកមួយ។ កាន់តែប្រសើរឬអាក្រក់ជាងនេះ ព្រះអង្គម្ចាស់ពីទ័រដ៏អស្ចារ្យបានព្យាយាមនៅក្នុងការធ្វើបស្ចិមនីយកម្ម និងកំណែទម្រង់វប្បធម៌ និងរដ្ឋាភិបាលរុស្ស៊ី។ ក្នុងកម្រិតគួរឱ្យភ្ញាក់ផ្អើលមួយ គឺទ្រង់ទទួលបានជោគជ័យនៅក្នុងការធ្វើបស្ចិមនីយកម្មនេះ។ ត្រឹមពេលដែលទ្រង់សុគតនៅក្នុងឆ្នាំ 1725 រុស្ស៊ីគឺជាមហាអំណាចមួយដែលអាចគន់គូរជាមួយអឺរ៉ុបបាន។ នៅខណៈពេលនោះ មហាអំណាចអឺរ៉ុបមួយផ្សេងទៀតគឺប្រទេសអង់គ្លេសបានអភិវឌ្ឍទម្រង់រដ្ឋាភិបាលថ្មីមួយដែលបានកម្រិតអំណាចរាជាផ្ដាច់ការ ដូចដែលអ្នកនឹងបានឃើញនៅក្នុងមេរៀនទី 5 ។

# មេរៀនទី 5៖ សភាតំណាងរាស្ត្រអំណាចព្រះមហាក្សត្រនៅអង់គ្លេស

អំឡុងរាជរបស់ម្ចាស់ក្សត្រីអេលីហ្សាប៊ែតទី 1 របស់អង់គ្លេសទ្រង់តែងមានជម្លោះជាញឹកញាប់ជាមួយសភាតំណាងរាស្ត្រ។ បញ្ហាភាគច្រើនជាប់ទាក់ទងជាមួយលុយ, ដោយសារតេនាគារមិនមានថវិការគ្រប់គ្រាន់ដើម្បីបំពេញការចំណាយរបស់ម្ចាស់ក្សត្រី។ នៅត្រឹមពេលដែលម្ចាស់ក្សត្រីអេលីហ្សាប៊ែតសុគតនៅក្នុងឆ្នាំ 1603 ទ្រង់បានបន្សល់ទុកនូវបំណុលដ៏ធំមួយសម្រាប់អ្នកស្នងមរតកពីទ្រង់ដើម្បីដោះស្រាយ។ អំណាចហិរញ្ញវត្ថុរបស់សភាតំណាងរាស្ត្រគឺជាឧបសគ្គមួយសម្រាប់មេដឹកនាំអង់គ្លេសដែលចង់បានអំណាចផ្ដាច់មុខ។ លទ្ធផលនៃការតស៊ូរវាងសភាតំណាងរាស្ត្រជាមួយនឹងស្ដេចបានបង្កផលបះពាល់យ៉ាងធ្ងន់ធ្ងរដល់អង់គ្លេស។

## 1. ព្រះមហាក្សត្របង្កហេតុជាមួយសភាតំណាងរាស្ត្រ

ម្ចាស់ក្សត្រីអេលីហ្សាប៊ែតមិនមានរាជបុត្រាឡើយ ហើយសាច់ញាតិជិតស្និតបំផុតរបស់ទ្រង់គឺបងប្អូនជីដូនមួយរបស់ទ្រង់ព្រះនាមជេមស៍ ស្ទួត។ ដោយក្លាយជាស្ដេចស្កុតឡែនរួចហើយ ព្រះអង្គម្ចាស់ជេមស៍ ស្ទួតបានក្លាយជាស្ដេចជេមទី 1 របស់អង់គ្លេសនៅក្នុងឆ្នាំ 1603 ។ បើទោះបីជាអង់គ្លេស និងស្កុតឡែនមិនបានបង្រួបបង្រួមគ្នារហូតដល់ឆ្នាំ 1707 ក៏ដោយ ប៉ុន្តែពេលនោះប្រទេសទាំងពីរនេះមានមេដឹកនាំរួម។

បញ្ហារបស់ព្រះអង្គម្ចាស់ស្ដេចជេមស៍៖ ព្រះអង្គម្ចាស់ជេមស៍ទទួលមរតកបញ្ហាដែលមិនទាន់ដោះស្រាយនៅក្នុងរាជ្យរបស់ម្ចាស់ក្សត្រីអេលីហ្សាប៊ែត។ ការតស៊ូដ៏លំបាកបំផុតរបស់ទ្រង់ជាមួយសភាតំណាងរាស្ត្រគឺបញ្ហាលុយ។ ក្នុងការបន្ថែម ជេមស៍ប្រឆាំងជាមួយពួកពូរីតានដែលជាសមាជិកសភាតំណាងរាស្ត្រ។ ពួកពូរីតានសង្ឃឹមថាទ្រង់នឹងធ្វើកំណែទម្រង់ដើម្បីបន្សុទ្ធព្រះវិហារអង់គ្លេសឱ្យប្រតិបត្តិកាតូលិក។ ប៉ុន្តែ លើកលែងតែការយល់ព្រមនៅក្នុងបកប្រែគម្ពីរប៊ីបថ្មីមួយ ទ្រង់បានបដិសេធនៅក្នុងការធ្វើកំណែទម្រង់តាមពួកពូរីតាន។

ព្រះអង្គម្ចាស់ឆាលទី 1 វាយប្រយុទ្ធជាមួយសភាតំណាងរាស្ត្រ៖ នៅក្នុងឆ្នាំ 1625 ព្រះអង្គម្ចាស់ជេមស៍ទី 1 បានសុគត។ រាជបុត្ររបស់ទ្រង់ព្រះអង្គម្ចាស់ឆាលទី 1 បានឡើងគ្រងរាជ្យបន្ត។ ព្រះអង្គម្ចាស់ឆាលតែងតែត្រូវការលុយ មូលហេតុដោយសារទ្រង់ធ្វើសង្គ្រាមជាមួយអេស្ប៉ាញ និងបារាំង។ ជាច្រើនលើកនៅពេលដែលសភាតំណាងរាស្ត្របដិសេធក្នុងការផ្ដល់ថវិកាដល់ទ្រង់ ទ្រង់បានរំលាយសភាតំណាងរាស្ត្រចោល។ ត្រឹមឆ្នាំ 1628 ព្រះអង្គម្ចាស់ឆាលត្រូវបានបង្ខំឱ្យកោះហៅសភាតំណាងរាស្ត្រសារជាថ្មី។ នៅពេលនោះពួកគេបដិសេធនៅក្នុងការផ្ដល់ថវិកាដល់ទ្រង់ ដ៏រាបណាទ្រង់ឡាយព្រះហស្តលេខាលើឯកសារមួយដែលត្រូវបានគេស្គាល់ថាញត្តិនៃសិទ្ធិ។ នៅក្នុងញត្តិនេះ ស្ដេចយល់ព្រម 4 ចំណុច៖ (1) ទ្រង់នឹងមិនចាប់ប្រជានុរាស្ត្រដាក់គុកដោយគ្មានមូលហេតុឡើយ។ (2) ទ្រង់នឹងមិនយកពន្ធដោយគ្មានការយល់ព្រមពីសភាតំណាងរាស្ត្រឡើយ។ (3) ទ្រង់នឹងមិនដាក់ទាហានឱ្យស្ថិតនៅជាលក្ខណៈឯកជនឡើយ។ (4) ទ្រង់នឹងមិនដាក់ច្បាប់អាជ្ញាសឹកក្នុងពេលគ្មានសង្គ្រាមឡើយ។ បន្ទាប់ពីយល់ព្រមជាមួយញត្តិ ស្ដេចឆាលមិនបានយកចិត្តទុកចំពោះវា។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយ ញត្តិនេះមានសារៈសំខាន់ណាស់។ ចំណុចទាំង 4 នៅក្នុងញត្តិនេះបង្ហាញថាច្បាប់ខ្ពស់ជាងស្ដេចទៅទៀត។ គំនិតនេះផ្ទុយគ្នាជាមួយទ្រឹស្ដីរាជាធិបតេយ្យផ្ដាច់ការ។ នៅក្នុងឆ្នាំ 1629 ព្រះអង្គម្ចាស់ឆាលបានរំលាយសភាតំណាងរាស្ត្រ និង

បដិសេធនៅក្នុងការកោះប្រជុំសារជាថ្មី។ ដើម្បីទទួលបានថវិកា ទ្រង់បានដាក់ចេញនូវថ្លៃសេវា និងការផាកពិន័យគ្រប់ប្រភេទលើប្រជាជនអង់គ្លេស។ ប្រជាប្រិយភាពរបស់ទ្រង់បានធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ។

## 2. សង្គ្រាមស៊ីវិលនៅអង់គ្លេស

ព្រះអង្គម្ចាស់ឆាលបានប្រឆាំងជាមួយពួកពូរីតាន តាមរយៈឧបត្ថម្ភដល់ការប្រោរព្ធក្បួនពិធីនៅក្នុងព្រះវិហារអង់គ្លីកាន។ ជាងនេះទៅទៀត នៅក្នុងឆ្នាំ 1637 ព្រះអង្គម្ចាស់ឆាលព្យាយាមនៅក្នុងបង្ខំឱ្យពួកប្រេសប៊ីធើរៀន ស្កុតទទួលយកសៀវភៅបន់ស្រន់មួយរបស់អង់គ្លីកាន។ ទ្រង់ចង់ឱ្យព្រះរាជាណាចក្រទាំងពីររបស់ទ្រង់ដើរតាមសាសនាតែមួយ។ ពួកស្កុតបានបះបោរប្រឆាំង ប្រមូលផ្តុំទាហាដ៏ធំមួយ និងគំរាមកំហែងនៅក្នុងការឈ្លានពានអង់គ្លេស។ ដើម្បីប្រឈមជាមួយគ្រោះថ្នាក់នេះ ព្រះអង្គម្ចាស់ឆាលត្រូវការលុយ លុយដែលទ្រង់អាចទទួលបានតាមរយៈការកោះហៅសភាតំណាងរាស្ត្រប្រជុំ។ ហេតុនេះបានផ្តល់ឱកាលមួយឱ្យសភាតំណាងរាស្ត្រប្រឆាំងទ្រង់។

សង្គ្រាមផ្តួលរំលំព្រះមហាក្សត្រ៖ អំឡុងសរទរដូវឆ្នាំ 1641 សភាតំណាងរាស្ត្រអនុម័តច្បាប់មួយចំនួនដើម្បីកម្រិតអំណាចរបស់រាជវង្ស។ ដោយកំហឹង ព្រះអង្គម្ចាស់ឆាលព្យាយាមនៅក្នុងការចាប់ខ្លួនមេដឹកនាំសភាតំណាងរាស្ត្រនៅក្នុងខែមករា ឆ្នាំ 1642 ប៉ុន្តែលោកបានរត់គេចខ្លួន។ ដោយកំហឹងដូចគ្នា ហ្វូងមហាជននៅក្រុងឡុងដ៍បានប្រមូលផ្តុំខាងក្រៅរាជវាំង។ ព្រះអង្គម្ចាស់ឆាលរត់គេចពីទីក្រុងឡុងដ៍ និងប្រមូលទ័ពមួយក្រុមនៅអង់គ្លេសភាគខាងជើង ជាទីកន្លែងដែលប្រជាជនមានភក្តីភាពចំពោះទ្រង់។ ចាប់ពីឆ្នាំ 1642 ដល់ឆ្នាំ 1649 អ្នកគាំទ្រ និងអ្នកប្រឆាំងព្រះអង្គម្ចាស់ឆាលបានវាយប្រយុទ្ធគ្នានៅក្នុងសង្គ្រាមស៊ីវិលនៅអង់គ្លេស។ អ្នកទាំងឡាយណាដែលនៅបន្តមានភក្តីភាពចំពោះស្តេចឆាលត្រូវបានគេហៅថាអ្នករាជានិយម ឬកាវ៉ាលីយើ។ នៅមួយផ្នែកទៀតពួកពូរីតានគាំទ្រសភាតំណាងរាស្ត្រ។ ដោយសារតែពួកពូរីតានទាំងនេះកាត់សក់ពួកគេខ្លីលើត្រចៀក ពួកកាវ៉ាលីយើហៅពួកគេថាពួកគេថាពួកក្បាលមូល។ នៅពេលប្រយុទ្ធគ្នាដំបូងភាគីទាំងសងខាងមិនមានភាគីណាមានប្រៀបលើភាគីណាឡើយ។ ប៉ុន្តែ ត្រឹមឆ្នាំ 1644 ពួកពូរីតានបានផ្តល់ជំនួយដល់ឧត្តមសេនីយ៍មួយរូបឈ្មោះអូលីវើ ក្រូមវ៉ែលដែលអាចយកឈ្នះលើសង្គ្រាម។ នៅក្នុងឆ្នាំ 1645 កងទ័ពគំរូថ្មីរបស់ក្រូមវ៉ែលបានចាប់ផ្តើមយកជ័យជំនះលើពួកកាវ៉ាលីយើ ហើយជ័យជំនះបានត្រឡប់ឆ្ពោះទៅរកពួកពូរីតាន។ នៅក្នុងឆ្នាំ 1647 ពួកគេបានចាប់ព្រះមហាក្សត្រឃុំខ្លួន។ នៅក្នុងឆ្នាំ 1649 ក្រូមវ៉ែល និងពួកពូរីតានបាននាំយកព្រះអង្គម្ចាស់ឆាលទៅកាត់ទោសសម្រាប់អំពើក្បត់ជាតិប្រឆាំងសភាតំណាងរាស្ត្រ។ ពួកគេបានរកឃើញថាទ្រង់មានទោស និងកាត់ទោសប្រហារជីវិតទ្រង់។ ការប្រហារជីវិតព្រះអង្គម្ចាស់ឆាលគឺជាការធ្វើបដិវត្តមួយ។ ព្រះមហាក្សត្រជាញឹកញាយត្រូវបានទម្លាក់ពីតំណែង, សម្លាប់នៅក្នុងសមរភូមិ, ឬសម្លាប់ដោយអាថ៌កំបាំង។ ប៉ុន្តែ មិនធ្លាប់មានពីមុនមកទេដែលព្រះមហាក្សត្រត្រូវបានគេកាត់ទោស និងប្រហារជីវិតចំពោះសាធារណជនបែបនេះ។

ការដឹកនាំរបស់ក្រូមវ៉ែល៖ ឥឡូវនេះក្រូមវ៉ែលគឺជាអ្នកស្នងតំណែង។ នៅក្នុងឆ្នាំ 1649 លោកបានបោះបង់រាជាធិបតេយ្យ និងសភាពជាន់ខ្ពស់។ លោកបានបង្កើតទម្រង់រដ្ឋាភិបាលបែបសាធារណរដ្ឋមួយដែលមានឈ្មោះថាខំមិនវ៉ែល។ នៅក្នុងឆ្នាំ 1653 ក្រូមវ៉ែលបានបញ្ជូនសមាជិកសភាតំណាងរាស្ត្រដែលនៅសេសសល់ទៅផ្ទះវិញ។

ជំនួយការរបស់ក្រូមវែលឈ្មោះចន ឡាំបឺត បានពង្រាងធម្មនុញ្ញមួយ ដែលជាធម្មនុញ្ញសម័យទំនើបដំបូងរបស់ទាំងឡាយនៅប្រទេសអឺរ៉ុប។ ប៉ុន្តែ ក្រូមវែលជាយថាហេតុបានហែកឯកសារនោះចោល និងបានក្លាយជាមេដឹកនាំយោធាផ្តាច់ការ។ ក្រូមវែលស្ទើរតែភ្លាមៗបង្ក្រាបការបះបោរមួយនៅអៀកឡង់។ ប្រទេសអង់គ្លេសបានដាក់អាណានិគមលើអៀកឡង់នៅក្នុងទសវត្សរ៍ឆ្នាំ 1100 ស្ថិតនៅក្រោមព្រះអង្គម្ចាស់ហេនរីទី 2 ។ ព្រះអង្គម្ចាស់ហេនរីទី 3 និងរាជបុត្ររបស់ទ្រង់បាននាំយកប្រទេសនេះឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់អង់គ្លេសនៅអំឡុងទសវត្សរ៍ឆ្នាំ 1500 ។ នៅក្នុងឆ្នាំ 1649 ក្រូមវែលបានធ្វើដំណើរទៅដល់ឆ្នេរសមុទ្រអៀកឡង់ជាមួយនឹងកងទ័ពមួយក្រុម និងបង្ក្រាបការបះបោរ។ ទ្រង់បានដណ្តើមកាន់កាប់ដី និងផ្ទះរបស់ពួកអៀកឡង់ និងបានផ្តល់វាឱ្យទៅទាហានអង់គ្លេស។ ការវាយប្រយុទ្ធ, ជំងឺប៉េស្ត, និងគ្រោះអត់ឃ្លានបានសម្លាប់មនុស្សរាប់ម៉ឺននាក់។

សីលធម៌ពូរីតាន៖ នៅក្នុងប្រទេសអង់គ្លេសក្រូមវែល និងពួកពូរីតានសម្លឹងទៅរកការធ្វើកំណែទម្រង់សង្គម។ ពួកគេបានបង្កើតច្បាប់នានាដើម្បីលើកកម្ពស់សីលធម៌ពូរីតាម និងលុបបំបាត់ចោលសកម្មភាពទាំងឡាយណាដែលពួកគេរកឃើញថាជាអំពើបាប ក្នុងនោះមានដូចជាពោងកុន, ព្រឹត្តិការណ៍កីឡា, និងការរាំជាដើម។ បើទោះបីជាលោកគឺជាពូរីតានដ៏តឹងរឹងមួយរូបក៏ដោយ ក្រូមវែលចូលចិត្តការអត់ឱនខាងសាសនាសម្រាប់គ្រីស្តបរិស័ទទាំងអស់លើកលែងតែកាតូលិក។ លោកថែមទាំងបានអនុញ្ញាតឱ្យពួកជ្វីបត្រឡប់មកកាន់ប្រទេសអង់គ្លេសវិញថែមទៀតផង បន្ទាប់ពីពួកគេត្រូវបាននិរទេសចេញពីអង់គ្លេសនៅក្នុងឆ្នាំ 1290 ។

### 3. ការស្តារឡើងវិញ និងបដិវត្ត

អូលីវើ ក្រូមវែលដឹកនាំអង់គ្លេសរហូតដល់លោកស្លាប់នៅក្នុងឆ្នាំ 1658 ។ ភ្លាមៗបន្ទាប់ពីនោះ រដ្ឋាភិបាលដែលលោកបានបង្កើតបានដួលរលំ ហើយសភាតំណាងរាស្ត្រថ្មីមួយត្រូវបានបោះឆ្នោតជ្រើសរើស។ ប្រជាជនអង់គ្លេសមានការមិនសប្បាយចិត្តជាមួយនឹងការដឹកនាំបែបយោធាឡើយ។ នៅក្នុងឆ្នាំ 1659 សភាតំណាងរាស្ត្របានបោះឆ្នោតដើម្បីស្នើរាជបុត្រច្បងរបស់ព្រះអង្គម្ចាស់ឆាលទី 1 ឱ្យដឹកនាំអង់គ្លេស។

រាជ្យរបស់ព្រះអង្គម្ចាស់ឆាលទី 2 ៖ នៅពេលដែលព្រះអង្គម្ចាស់ឆាលចូលមកកាន់ទីក្រុងឡុងដ៍នៅក្នុងឆ្នាំ 1660 ហ្វូងមហាជនមានភាពសប្បាយរីករាយ ហើយជួងបានបន្លឺឡើង។ នៅក្នុងការអបអរសាទរដ៏គួរឱ្យគត់សំគាល់នេះ រាជ្យរបស់ព្រះអង្គម្ចាស់ឆាលទី 2 បានចាប់ផ្តើមឡើង។ ដោយសារទ្រង់ស្តារឡើងវិញនូវរាជានិយម សម័យកាលនៃការគ្រប់គ្រងរបស់ទ្រង់ត្រូវបានគេហៅថាការស្តារឡើងវិញ។ អំឡុងរាជ្យរបស់ព្រះអង្គម្ចាស់ឆាលទី 2 សភាតំណាងរាស្ត្របានអនុម័តច្បាប់ជានាដល់សេរីភាពដ៏សំខាន់មួយហាបឺស កូពូស។ ហាបឺស កូពូសជាភាសាឡាតាំងដែលមានន័យថា "មានខ្លួន"។ ច្បាប់ឆ្នាំ 1679 នេះបានឱ្យអ្នកទោសទាំងអស់នូវសិទ្ធិនៅក្នុងការទទួលបានឯកសារបេទបញ្ជាមួយ ដែលអ្នកទោសត្រូវចាប់ខ្លួនយកមកជំនុំជម្រះដើម្បីកំណត់អំពីទោសដែលប្រឆាំងជាមួយគេ។ ចៅក្រមនឹងសម្រេចថាតើអ្នកទោសគួរតែត្រូវកាត់ទោស ឬដោះលែង។ ដោយសារតែច្បាប់ហាបឺស កូពូសព្រះមហាក្សត្រមិនអាចចាប់នណារម្នាក់ដាក់គុក ដោយគ្រាន់តែពួកគេមានគំនិតប្រឆាំងជាមួយមេដឹកនាំឡើយ។ ក៏ដូចគ្នា អ្នកទោលមិនត្រូវបានឃុំខ្លួនដោយគ្មានការជំនុំជម្រះក្តីឡើយ។ ជាងនេះទៅទៀត សភាតំណាងរាស្ត្រ

បានពិភាក្សាថាតើនណារនឹងត្រូវស្នងមរតករបស់ព្រះអង្គម្ចាស់ឆាល។ ដោយសារតែព្រះអង្គម្ចាស់ឆាលមិនមានរាជបុត្រស្របច្បាប់ អ្នកស្នងមរតករបស់ទ្រង់គឺអនុជរបស់ទ្រង់ព្រះអង្គម្ចាស់ជេមស៍ ដែលជាអ្នកកាតូលិក។ ក្រុមមួយដែលគេហៅថាវីហ្គបានប្រឆាំងជាមួយព្រះអង្គម្ចាស់ជេមស៍ និងក្រុមមួយឈ្មោះតូរីសគាំទ្រព្រះអង្គម្ចាស់ជេមស៍។ ក្រុមទាំងពីរនេះគឺជាបុព្វការីជននៃគណបក្សនយោបាយដំបូងរបស់អង់គ្លេស។

ព្រះអង្គម្ចាស់ជេមស៍ទី 2 និងបដិវត្តន៍ដ៏រុងរឿង៖ នៅក្នុងឆ្នាំ 1685 ព្រះអង្គម្ចាស់ឆាលទី 2 បានសុគត ហើយព្រះអង្គម្ចាស់ជេមស៍ទី 2 បានឡើងធ្វើជាស្តេច។ ព្រះអង្គម្ចាស់ជេមស៍ភ្លាមៗនោះបានប្រឆាំងជាមួយប្រជានុរាស្ត្ររបស់ទ្រង់តាមរយៈការបង្ហាញពីកាតូលិកនិយមរបស់ទ្រង់។ ដោយប្រឆាំងជាមួយច្បាប់អង់គ្លេស ទ្រង់បានតែងតាំងពួកកាតូលិកជាច្រើននៅក្នុងតំណែងមន្ត្រីជាន់ខ្ពស់។ នៅពេលដែលសភាតំណាងរាស្ត្រធ្វើការតវ៉ា ព្រះអង្គម្ចាស់ជេមសន៍បានរំលាយសភាតំណាងរាស្ត្រចោល។ នៅក្នុងឆ្នាំ 1688 មហេសីទី 2 របស់ព្រះអង្គម្ចាស់ជេមស៍បានផ្តល់កំណើរដល់រាជបុត្រាមួយអង្គ។ ពួកប្រូតេស្តង់អង់គ្លេសមានការភ័យខ្លាចចំពោះខ្សែស្រឡាយស្តេចដែលនឹងត្រូវឡើងគ្រងរាជ្យជាកាតូលិក។ ព្រះអង្គម្ចាស់ជេមន៍មានបងស្រីមួយអង្គព្រះនាមម៉ារីជាអ្នកប្រូតេស្តង់។ ព្រះនាងក៏ជាមហេសីរបស់ព្រះអង្គម្ចាស់វីលៀមអូរែង ដែលជាស្តេចរបស់ហូឡង់។ សមាជិកសភាតំណាងរាស្ត្រមួយចំនួនបានអញ្ជើញព្រះអង្គម្ចាស់វីលៀម និងព្រះនាងម៉ារីដើម្បីទម្លាក់ព្រះអង្គម្ចាស់ជេមស៍ចេញពីដំណែងដើម្បីជាប្រយោជន៍ដល់ប្រូតេស្តង់និយម។ នៅពេលដែលព្រះអង្គម្ចាស់វីលៀមដឹកនាំកងទ័ពរបស់ទ្រង់មកកាន់ទីក្រុងឡុងដ៍នៅក្នុងឆ្នាំ 1688 ព្រះអង្គម្ចាស់ជេមស៍បានរត់គេចទៅប្រទេសបារាំង។ ការទម្លាក់ព្រះអង្គម្ចាស់ជេមស៍ទី 2 ចេញពីតំណែងដោយមិនមានការបង្ហូរឈាមគ្នានេះត្រូវបានគេហៅថាបដិវត្តដ៏រុងរឿង។

## 4. ការកម្រិតអំណាចរបស់ព្រះរាជា

នៅក្នុងពិធីឡើងគ្រងរាជ្យរបស់ទ្រង់ ព្រះអង្គម្ចាស់វីលៀម និងព្រះនាងម៉ារីសច្ចានៅក្នុងការទទួលស្គាល់សភាតំណាងរាស្ត្រដូចជាឪពុកម្តាយរបស់ពួកទ្រង់។ ប្រទេសអង់គ្លេសមិនបានក្លាយជាប្រទេសរាជាធិបតេយ្យផ្តាច់ការទៀតឡើង ប៉ុន្តែជាប្រទេសបែបរាជាធិបតេយ្យអាស្រ័យធម្មនុញ្ញ ដែលច្បាប់នានាបានកម្រិតអំណាចរបស់មេដឹកនាំ។

បញ្ជីនៃច្បាប់៖ ដើម្បីធ្វើឱ្យច្បាស់ដល់ការកម្រិតអំណាចរបស់រាជវង្ស សភាតំណាងរាស្ត្របានធ្វើសេចក្តីព្រាងបញ្ជីនៃច្បាប់មួយនៅក្នុងឆ្នាំ 1689 ។ ឯកសារនេះរៀបរាប់នូវរឿងជាច្រើនដែលមេដឹកនាំមិនអាចធ្វើបាន៖ (1) មិនត្រូវព្យួរច្បាប់របស់សភាតំណាងរាស្ត្រឡើយ។ (2) មិនត្រូវយកពន្ធដោយមិនមានការយល់ព្រមដាក់លាក់ពីសភាតំណាងរាស្ត្រឡើយ។ (3) មិនត្រូវជ្រៀតជ្រែកដល់សេរីភាពបញ្ចេញមតិនៅក្នុងសភាតំណាងរាស្ត្រឡើយ។ (4) មិនមានការដាក់ពិន័យចំពោះប្រជាជនណាដែលដាក់ញត្តិទូថ្វាយព្រះមហាក្សត្រពីទុក្ខព្រួយរបស់ពួកគេឡើយ។ ព្រះអង្គម្ចាស់វីលៀម និងព្រះនាងម៉ារីយល់ព្រមចំពោះបញ្ជីនៃច្បាប់នេះ និងច្បាប់ដ៏ទៃទៀតដែលកម្រិតអំណាចរបស់រាជវង្សទ្រង់។

ប្រព័ន្ធគណៈរដ្ឋមន្ត្រីត្រូវបានអភិវឌ្ឍឡើង៖ បន្ទាប់ពីឆ្នាំ 1688 គ្មានព្រះមហាក្សត្រអង់គ្លេសអង្គណាអាចដឹកនាំដោយមិនមានការយល់ព្រមពីសភាតំណាងរាស្ត្រឡើង។ នៅក្នុងពេលជាមួយគ្នានោះ សភាតំណាងរាស្ត្រមិនអាចដឹកនាំដោយមិនមានការយល់ស្របពីព្រះមហាក្សត្របានឡើយ។ ប្រសិនបើតួអង្គទាំងពីរនេះមិនយល់ស្រប រដ្ឋាភិបាលឈានទៅរកការជាប់គាំ។ អំឡុងទសវត្សរ៍ឆ្នាំ 1700 បញ្ហាដ៏មានសក្តានុពលនេះត្រូវបានលុបបំបាត់តាមរយៈការអភិវឌ្ឍឡើងនៃរដ្ឋមន្ត្រីរដ្ឋាភិបាលមួយក្រុមដែលគេហៅថាគណៈរដ្ឋមន្ត្រី។ រដ្ឋមន្ត្រីទាំងអស់នេះធ្វើការក្នុងនាមជាមេដឹកនាំ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ពួកគេតំណាងឱ្យគណបក្សដែលទទួលបានសំលេងច្រើននៅក្នុងសភាតំណាងរាស្ត្រ។ ដូច្នេះ ពួកគេបានក្លាយជាបណ្តាញទំនាក់ទំនងរវាងព្រះមហាក្សត្រ និងគណបក្សដែលមានសំលេងច្រើននៅក្នុងសភាតំណាងរាស្ត្រ។ ក្រោយមកគណៈរដ្ឋមន្ត្រីបានក្លាយជាមណ្ឌលអំណាច និងជាអ្នកធ្វើគោលនយោបាយ។ ស្ថិតនៅក្រោមប្រព័ន្ធគណៈរដ្ឋមន្ត្រី មេដឹកនាំគណបក្សសំលេងភាគច្រើននៅក្នុងសភាតំណាងរាស្ត្រជាអ្នកដឹកនាំគណៈរដ្ឋមន្ត្រីដែលត្រូវបានគេហៅថានាយករដ្ឋមន្ត្រី។ ប្រព័ន្ធរដ្ឋាភិបាលអង់គ្លេសនេះបានបន្តរហូតមកដល់សព្វថ្ងៃ។

# ជំពូក 21៖ សករាជពន្លឺ និងបដិវត្ត 1550-1789

## មេរៀនទី 1៖ បដិវត្តវិទ្យាសាស្ត្រ

ដូចដែលអ្នកបានដឹង នៅរវាងឆ្នាំ 1300 ដល់ 1600 គឺជាពេលវេលាដែលមានការផ្លាស់ប្តូរខ្លាំងបំផុតនៅអឺរ៉ុប។ បុនសម័យ ការកើតឡើងវិញការសិក្សា និងសិល្បៈ បានបំផុសស្មារតីចង់ឃើញឡើងវិញនូវវិស័យជាច្រើន។ អ្នកប្រាជ្ញចាប់ផ្តើមចោទសួរអំពីទស្សនដែលធ្លាប់ត្រូវបានទទួលយកអស់រយៈពេលរាប់រយឆ្នាំ។ នៅខណៈពេលនោះ ចលនាសាសនាមួយដែលគេស្គាល់ថាការកែប្រែសាសនា យ៉ាងឆាប់រហ័សបានទាក់ទាញអ្នកដើរតាមដើម្បីប្រជែងទៅនឹងវិធីនៃការគិតអំពីព្រះជាម្ចាស់ និងសេចក្តីសង្គ្រោះ។ ខណៈពេលដែលការកែប្រែសាសនាបានកើតឡើង បដិវត្តគំនិតមួយផ្សេងទៀតនៅអឺរ៉ុបបានចាប់ផ្តើមឡើង ជាបដិវត្តមួយដែលនឹងផ្លាស់ប្តូរជាអចិន្ត្រៃពីរបៀបដែលមនុស្សយល់ឃើញពីពិភពលោក។

### 1. ឫសគល់នៃវិទ្យាសាស្ត្រសម័យទំនើប

មុនឆ្នាំ 1500 អ្នកប្រាជ្ញនានាបានសម្រេចថាអ្វីពិត ឬមិនពិតដោយយោងទៅលើអ្នកនិពន្ធក្រិក ឬរ៉ូមបុរាណ ឬគម្ពីរប៊ីប។ អ្នកប្រាជ្ញអឺរ៉ុបមួយចំនួនតូចបានប្រឆាំងជាមួយគំនិតវិទ្យាសាស្ត្ររបស់ទស្សនវិទូបុរាណ ឬព្រះវិហារគ្រីស្តសាសនាតាមរយៈការអង្កេតធម្មជាតិដោយខ្លួនពួកផ្ទាល់។

ការយល់ឃើញនៅមជ្ឈិមសម័យ៖ អំឡុងយុគកណ្តាល អ្នកប្រាជ្ញភាគច្រើនជឿថាភពផែនដីគឺជារបស់មួយដែលគ្មានចលនាមានទីតាំងស្ថិតនៅចំណុចកណ្តាលនៃចក្រវាល។ យោងទៅតាមជំនឿនេះ, ព្រះចន្ទ, ព្រះអាទិត្យ, និងភពផ្សេងៗទៀតវិលយ៉ាងត្រឹមត្រូវតាមកន្លងមួយជុំវិញភពផែនដី។ មនុស្សទូទៅហាក់ដូចជាគាំទ្រគំនិតនេះ។ ចុងក្រោយគេ ព្រះអាទិត្យហាក់ដូចជាធ្វើចលនាជុំវិញផែនដី ដូចដែលវារះឡើងនៅពេលព្រឹក និងលិចនៅពេលពេលល្ងាច។ គំនិតដែលថាផែនដីនៅកណ្តាលចក្រវាលនេះត្រូវបានគេហៅថាទ្រឹស្តីផែនដីជាចំណុចស្នូល។ គំនិតនេះលេចចេញមកពីអារីស្តូត ដែលជាទស្សនវិទូជនជាតិក្រិកនៅក្នុងសតវត្សរ៍ទី 4 មុនគ.ស។ តារាវិទូជនជាតិក្រិកឈ្មោះផ្តូឡេមីបានពន្យល់ទ្រឹស្តីនេះនៅក្នុងសតវត្សរ៍ទី 2 នៃគ.ស។ ជាងនេះទៅទៀត សហគមន៍គ្រីស្តសាសនាបានបង្រៀនថាព្រះជាម្ចាស់បានកំណត់ឱ្យភពផែនដីស្ថិតនៅកណ្តាលចក្រវាល។ ដូច្នេះភពផែនដីជាទីកន្លែងពិសេសមួយដែលរឿងដ៏អស្ចារ្យនៃជីវិតត្រូវបានលាតត្រដាង។

វិធីនៅក្នុងការគិតថ្មីមួយ៖ នៅដើមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1500 អ្នកប្រាជ្ញមួយចំនួនតូចបានបោះពុម្ពស្នាដៃដែលប្រឆាំងជាមួយគំនិតរបស់ទស្សនវិទូបុរាណ និងព្រះវិហារគ្រីស្តសាសនា។ ដូចដែលអ្នកប្រាជ្ញទាំងនេះជំនួសការសន្មត់ចាស់ជាមួយនិងទ្រឹស្តីថ្មីៗ ពួកគេបាននាំទៅដល់ការផ្លាស់ប្តូរការគិតនៅអឺរ៉ុប ដែលប្រវត្តិវិទូហៅថាបដិវត្តវិទ្យាសាស្ត្រ។ បដិវត្តវិទ្យាសាស្ត្រគឺជាវិធីគិតថ្មីមួយអំពីពិភពធម្មជាតិ។ វិធីគិតនេះគឺផ្អែកលើការអង្កេតដោយយកចិត្តទុកដាក់ និងមានឆន្ទៈមួយនៅក្នុងការចោទសួរអំពីជំនឿដែលគេបានទទួលយក។ ការរួមបញ្ចូលគ្នានៃការរកឃើញថ្មីៗ និងព្រឹត្តិការណ៍នានាបាននាំទៅដល់ការធ្វើបដិវត្តវិទ្យាសាស្ត្រ និងជួយសាយភាយឥទ្ធិពលរបស់វា។

អំឡុងបុនសម័យ អ្នករុករកអឺរ៉ុបបានធ្វើដំណើរទៅកាន់អាហ្វ្រិក, អាស៊ី, និងអាមេរិក។ ដែនដីមួយចំនួនត្រូវបានតាំងទីលំនៅដោយមនុស្ស និងសត្វដែលគេមិនធ្លាប់ស្គាល់ពីមុនមកទេនៅអឺរ៉ុប។ ការរកឃើញថ្មីៗនេះបានបើកឱ្យពួកអឺរ៉ុបយល់ឃើញថា ប្រហែលជាមានការពិតថ្មីត្រូវនឹងត្រូវរកឃើញ។ ការបង្កើតឡើងនៃឧបករណ៍បោះពុម្ពអំឡុងសម័យនោះបានជួយដល់ការរីកសាយភាយនៃការប្រដែងគំនិតកាន់តែទូលំទូលាយទាំងចាស់ និងថ្មី ក្នុងចំណោមទស្សនវិទូអឺរ៉ុប។ យុគសម័យនៃការរុករករបស់ពួកអឺរ៉ុបក៏បានជុតបញ្ឆេះការស្រាវជ្រាវវិទ្យាសាស្ត្រយ៉ាងទូលំទូលាយផងដែរ ជាពិសេសនៅក្នុងវិស័យតារាសាស្ត្រ និងគណិតវិទ្យា។ អ្នកធ្វើដំណើរតាមសមុទ្រត្រូវការឧបករណ៍ និងការវាល់វែងភូមិសាស្ត្រកាន់តែប្រសើរជាងមុន ដើម្បីកំណត់អំពីទីតាំងរបស់ពួកគេនៅក្នុងលំហសមុទ្រជាដើម។ ដូចដែលអ្នកវិទ្យាសាស្ត្រចាប់ផ្តើមសម្លឹងកាន់តែជិតចំពោះពិភពនៅជុំវិញពួកគេ ពួកគេបានធ្វើការអង្កេតដែលមិនស៊ីគ្នាជាមួយជំនឿបុរាណ។ ពួកគេរកឃើញថាពួកគេបានមកដល់ដែនកំណត់នៃចំណេះដឹងពិភពលោកសម័យបុរាណ។ ប៉ុន្តែ ពួកគេនៅតែត្រូវការដឹងបន្ថែមទៀត។

## 2. បដិវត្តគំរូនៃចក្រវាលមួយ

ការប្រជែងដំបូងដើម្បីទទួលយកគំនិតបែបវិទ្យាសាស្ត្រស្ថិតនៅក្នុងវិស័យតារាសាស្ត្រ។ វាបានចាប់ផ្តើមនៅពេលដែលអ្នកប្រាជ្ញមួយក្រុមតូចចាប់ផ្តើមចោទសួរអំពីទ្រឹស្តីផែនដីស្ថិតនៅកណ្តាលចក្រវាល។

ទ្រឹស្តីព្រះអាទិត្យស្ថិតនៅកណ្តាលចក្រវាល៖ បើទោះបីជាគាំទ្រដោយអាជ្ញាធរ និងមនុស្សទូទៅក៏ដោយ ទ្រឹស្តីផែនដីស្ថិតនៅកណ្តាលចក្រវាលមិនត្រូវបានពន្យល់ឱ្យបានត្រឹមត្រូវពីចលនារបស់ព្រះអាទិត្យ, ព្រះចន្ទ, និងភពនានា។ បញ្ហានេះបាននាំទៅដល់ការរំខានដល់បព្វជិត និងតារាវិទូជនជាតិប៉ូឡូញឈ្មោះនីកូឡៅ កូប៉ែរនីគូស។ នៅដើមទសវត្សរ៍ឆ្នាំ 1500 កូប៉ែរនីគូសបានចាប់ផ្តើមចាប់អារម្មណ៍លើគំនិតក្រិកបុរាណដែលថាព្រះអាទិត្យស្ថិតនៅកណ្តាលនៃចក្រវាល។ បន្ទាប់ពីការសិក្សាចលនានៃភពនានាអស់រយៈពេលជាង 25 ឆ្នាំ កូប៉ែរនីគូសទទួលបានហេតុផលយ៉ាងច្បាស់ថា តារា, ភពផែនដី, និងភពផ្សេងៗទៀតវិលជុំវិញព្រះអាទិត្យ។ ទ្រឹស្តីព្រះអាទិត្យស្ថិតនៅកណ្តាលចក្រវាល ឬព្រះអាទិត្យកណ្តាលរបស់កូប៉ែរនីគូសមិនទាន់បានពន្យល់ពេញលេញថាហេតុអ្វីបានជាភពនានាវិលជុំវិញកន្លងរបស់ពួកវា។ លោកក៏បានដឹងដែលថាអ្នកប្រាជ្ញ និងបព្វជិតភាគច្រើននឹងបដិសេធចំពោះទ្រឹស្តីរបស់លោកដោយសារតែវាផ្ទុយទៅនឹងការយល់ឃើញរបស់សាសនា។ ដោយមានការភ័យខ្លាចចំពោះការចំអក ឬការធ្វើទុក្ខបុកម្និញ កូប៉ែរនីគូសមិនបានបោះពុម្ពការរកឃើញរបស់លោកឡើយរហូតមកដល់ឆ្នាំ 1543 ដែលជាឆ្នាំចុងក្រោយនៃជីវិតរបស់លោក។ លោកទទួលបានច្បាប់ចម្លងនៃសៀវភៅរបស់លោកមួយក្បាលនៅលើគ្រែដែលលោកស្លាប់ដែលមានចំណងជើងថា ស្តីអំពីបដិវត្តនៃតួអង្គឋានសួគ៌។ ខណៈពេលកំពុងធ្វើបដិវត្ត សៀវភៅរបស់កូប៉ែរនីគូសទទួលបានការចាប់អារម្មណ៍តិចតួចនៅដើមដំបូង។ បន្ទាប់ពីនោះមួយសតវត្សរ៍កន្លះ អ្នកវិទ្យាសាស្ត្រនានាបានស្ថាបនាមូលដ្ឋាគ្រឹះដែលលោកបានបង្កើតឡើង។ តារាវិទូជនជាតិដាណឺម៉ាកឈ្មោះទីឆូ ប្រាហេ បានកត់ត្រាដោយយកចិត្តទុកដាក់អំពីចលនានៃភពនានាអស់រយៈពេលជាច្រើនឆ្នាំ។ ប្រាហេបានបង្កើតទិន្នន័យត្រឹមត្រូវជាច្រើនដោយផ្អែកលើការអង្កេតរបស់លោក។ ប៉ុន្តែ វាបានបន្សល់ទុកឱ្យអ្នកដើរតាមលោកនៅក្នុងការស្វែងរកការ

ពន្យល់បែបគណិតវិទ្យា។ បន្ទាប់ពីប្រាហេស្លាប់នៅក្នុងឆ្នាំ 1601 ជំនួយការរបស់លោក ដែលជាគណិតវិទូដ៏វៃឆ្លាតមួយរូបឈ្មោះចូហាននេស កេផ្លែរបានបន្តកិច្ចការរបស់លោក។ បន្ទាប់ពីសិក្សាទិន្នន័យរបស់ប្រាហេ កេផ្លែរសន្និដ្ឋានថាច្បាប់គណិតវិទ្យាជាក់លាក់មួយចំនួនបានដឹកនាំការធ្វើចលនារបស់ភពនានា។ ច្បាប់ទាំងនេះបង្ហាញថាភពនានាវិលជុំវិញព្រះអាទិត្យនៅក្នុងកន្លងរាងពងក្រពើមិនមែនមូលដូចដែលគេធ្លាប់គិតដូចមុនឡើយ។ ច្បាប់របស់កេផ្លែរបានបង្ហាញថាគំនិតគោលរបស់កូផឺរនីគូសគឺត្រឹមត្រូវ។ ពួកគេបានបង្ហាញជាលក្ខណៈគណិតសាស្ត្រថាភពនានាវិលជុំវិញព្រះអាទិត្យ។

ការរកឃើញរបស់ហ្គាលីឡេអូ៖ អ្នកវិទ្យាសាស្ត្រអ៊ីតាលីមួយរូបឈ្មោះហ្គាលីឡេអូ ហ្គាលីឡេ បានស្ថាបនាទ្រឹស្តីថ្មីអំពីតារាសាស្ត្រ។ ជាយុវជនមួយរូប ហ្គាលីឡេអូបានរៀនសូត្រពីអ្នកផលិតកែវហូឡង់មួយរូបដែលបានស្ថាបនាឧបករណ៍មួយដែលអាចពង្រីកវត្ថុដែលនៅឆ្ងាយបាន។ ហ្គាលីឡេអូបានស្ថាបនាកែវយឺតផ្ទាល់របស់លោក និងប្រើប្រាស់វាដើម្បីសិក្សាពីមេឃនៅក្នុងឆ្នាំ 1609 ។ បន្ទាប់មកនៅក្នុងឆ្នាំ 1610 លោកបានបោះពុម្ពសៀវភៅតូចមួយដែលមានឈ្មោះថាអ្នកនាំសារអំពីផ្កាយ ដែលបានពិពណ៌នាអំពីការអង្កេតតារាសាស្ត្ររបស់លោក។ ហ្គាលីឡេអូប្រកាសថាហ្វូងផ្កាយពន្ធគ្រោះមានព្រះចន្ទចំនួន 4 ហើយព្រះអាទិត្យមានផ្នែកខ្លះងងឹត។ លោកក៏បានកត់ចំណាំថាព្រះចន្ទមានផ្ទៃរដិបរដុបមិនរាបស្មើឡើយ។ ការអះអាងនេះខុសពីទ្រឹស្តីរបស់អារីស្តូតដែលថាព្រះចន្ទ និងផ្កាយនានាត្រូវបានបង្កើតឡើងសារធាតុសុទ្ធល្អឥតខ្ចោះ។ ការអង្កេតរបស់ហ្គាលីឡេអូ ក៏ដូចជាច្បាប់ចលនារបស់លោក ក៏បានគាំទ្រយ៉ាងពិតប្រាកដលើទ្រឹស្តីរបស់កូផឺរនីគូសផងដែរ។

ជម្លោះជាមួយព្រះវិហារគ្រឹស្តសាសនា៖ ការរកឃើញរបស់ហ្គាលីឡេអូបានធ្វើឱ្យតក់ស្លុតទាំងមេដឹកនាំកាតូលិក និងប្រូតេស្តង់ ដោយសារការរកឃើញនេះប្រឆាំងជាមួយការអប់រំ និងអំណាចរបស់ព្រះវិហាគ្រឹស្តសាសនា។ ប្រសិនបើមនុស្សទូទៅជឿថាព្រះវិហារគ្រឹស្តសាសនាអាចខុសចំពោះចំណុចនេះ ពួកគេក៏នឹងចោទសួរអំពីការអប់រំនានារបស់ព្រះវិហារគ្រឹស្តសាសនាផងដែរ។ នៅក្នុងឆ្នាំ 1616 ព្រះវិហារគ្រឹស្តសាសនាបានព្រមានដល់ហ្គាលីឡេអូមិនត្រូវការពារគំនិតរបស់កូផឺរនីគូសឡើយ។ បើទោះបីជាហ្គាលីឡេអូបន្តស្ថិតក្នុងភាពស្ងៀមស្ងាត់មិននិយាយជាសាធារណក៏ដោយ ក៏លោកនៅតែបន្តសិក្សា។ បន្ទាប់មកនៅក្នុងឆ្នាំ 1632 លោកបានបោះពុម្ពសៀវភៅមួយដែលមានចំណងជើងថា សន្ទនាដែលទាក់ទងជាមួយនិងប្រព័ន្ធពិភពលោកសំខាន់ 2 ។ សៀវភៅនេះបង្ហាញទាំងគំនិតរបស់កូផឺរនីគូស និងផ្ទូឡេមី ប៉ុន្តែវាបានបង្ហាញយ៉ាងច្បាស់ថាហ្គាលីឡេអូគាំទ្រទ្រឹស្តីរបស់កូផឺរនីគូស។ ស្តេចប៉ាបដោយកំហឹងបានកោះហៅហ្គាលីឡេអូទៅកាន់ទីក្រុងរ៉ូមដើម្បីជំនុំជម្រះទោសនៅមុខចៅក្រមស៊ើបអង្កេត។ ហ្គាលីឡេអូឈរនៅមុខចៅក្រមនៅក្នុងឆ្នាំ 1633 ។ ស្ថិតនៅក្រោមការគំរាមកំហែងក្នុងការធ្វើទារុណកម្ម លោកលុតជង្គង់នៅចំពោះមុខកាឌីណាល់ និងអានសេចក្តីសារភាពទទួលកំហុសមួយខ្លាំងៗ។ នៅក្នុងសេចក្តីសារភាពនោះ លោកយល់ស្របថាគំនិតរបស់កូផឺរនីគូសគឺខុស។ ហ្គាលីឡេអូមិនមែនជាមនុស្សមានសេរីភាពទៀតឡើយ។ លោករស់នៅក្រោមការឃុំខ្លួននៅក្នុងផ្ទះរហូតដល់លោកស្លាប់នៅក្នុងឆ្នាំ 1642 នៅផ្ទះវិឡារបស់លោកនៅជិតផ្លូរែន។ ប៉ុន្តែ សៀវភៅ និងគំនិតរបស់លោកនៅតែរីកសាយភាយពាសពេញអឺរ៉ុប( នៅក្នុងឆ្នាំ 1992 ព្រះវិហារកាតូលិកជាផ្លូវការទទួលស្គាល់ថាគំនិតរបស់ហ្គាលីឡេអូពិតជាត្រឹមត្រូវ )។

### 3. វិធីសាស្ត្របែបវិទ្យាសាស្ត្រ

បដិវត្តនៅក្នុងគំនិតវិទ្យាសាស្ត្រដែលកូផ័រនូគូស, កេផ្លែរ, និងហ្គាលីឡេអូបានចាប់ផ្តើម ដោយថាហេតុបានអភិវឌ្ឍទៅជាវិធីសាស្ត្រថ្មីមួយសម្រាប់វិទ្យាសាស្ត្រដែលគេហៅថា វិធីសាស្ត្របែបវិទ្យាសាស្ត្រ។ វិធីសាស្ត្របែបវិទ្យាសាស្ត្រគឺជាដំណើរការតក្កមួយសម្រាប់ប្រមូល និងពិសោធន៍គំនិត។ វាចាប់ផ្តើមជាមួយបញ្ហា ឬសំណួរមួយដែលលេចចេញមកពីការអង្កេត។ អ្នកវិទ្យាសាស្ត្រក្រោមមកបង្កើតសម្មតិកម្មមួយ ឬការសន្មត់ដែលមិនទាន់បញ្ជាក់ការពិត។ សម្មតិកម្មក្រោយមកត្រូវបានសាកល្បងនៅក្នុងការពិសោធន៍មួយ ឬលើទិន្នន័យមូលដ្ឋានគ្រឹះមួយ។ នៅដំហានចុងក្រោយ អ្នកវិទ្យាសាស្ត្រវិភាគ និងបកស្រាយទិន្នន័យរបស់ពួកគេដើម្បីឈានទៅដល់ការសន្និដ្ឋានថ្មីមួយ។ ការសន្និដ្ឋាននេះអាចទទួលយក ឬបដិសេធសម្មតិកម្ម។

បាខុន និងដេសកាត៖ វិធីសាស្ត្របែបវិទ្យាសាស្ត្រមិនមែនអភិវឌ្ឍតែមួយយប់ឡើយ។ ស្នាដៃរបស់ទស្សនវិទូសំខាន់ពីររូបនៅក្នុងទសវត្សរ៍ឆ្នាំ 1600 គឺលោកហ្វង់ស៊ីស បាខុន និងលោករេនេ ដេសកាត បានទទួលជោគជ័យក្នុងការអភិវឌ្ឍវិធីសាស្ត្រថ្មី។ លោកហ្វង់ស៊ីល បាខុនជារដ្ឋបុរស និងជាអ្នកនិពន្ធអង់គ្លេសមួយរូប មានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើវិទ្យាសាស្ត្រ។ លោកជឿថាតាមរយៈការយល់ដឹងពីពិភពលោក អ្នកវិទ្យាសាស្ត្រនឹងបង្កើតឱ្យមានចំណេះដឹងក្នុងការអនុវត្តដែលនឹងលើកកម្ពស់ការរស់នៅរបស់មនុស្ស។ នៅក្នុងសំណេររបស់លោក បាខុនបានវាយប្រហារលើអ្នកប្រាជ្ញយុគកណ្តាលសម្រាប់ការពឹងផ្អែកខ្លាំងពេកលើសេចក្តីសន្និដ្ឋានរបស់អារីស្តូត និងទស្សនវិទូបុរាណផ្សេងៗទៀត។ ជាជាងសំអាងហេតុផលដែលបានមកពីទ្រឹស្តីដែលមិនច្បាស់លាស់ លោកបានទទូចឱ្យអ្នកវិទ្យាសាស្ត្រធ្វើការពិសោធន៍ ហើយបន្ទាប់មកទាញសេចក្តីសន្និដ្ឋាន។ វិធីសាស្ត្រនេះត្រូវបានគេហៅថាពិសោធន៍និយម ឬវិធីសាស្ត្របែបពិសោធន៍។ នៅក្នុងប្រទេសបារាំងលោករេនេ ដេសកាតក៏បានចាប់អារម្មណ៍ជាមួយវិទ្យាសាស្ត្រផងដែរ។ លោកបានអភិវឌ្ឍធរណីមាត្រវិភាគ ដែលបានភ្ជាប់ពីជគណិត ជាមួយធរណីមាត្រ។ វិធីនេះបានផ្តល់នូវឧបករណ៍សំខាន់ថ្មីមួយសម្រាប់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ ក៏ដូចជាលោកបាខុនដែរ លោកដេសកាតជឿថាអ្នកវិទ្យាសាស្ត្រត្រូវតែបដិសេធការសន្មត់ និងការអប់រំចាស់ៗ។ ប៉ុន្តែ ក្នុងនាមជាគណិតវិទូមួយរូប វិធីសាស្ត្ររបស់លោកក្នុងការទទួលបានចំណេះដឹងមានលក្ខណៈខុសគ្នាពីលោកបាខុន។ ជាជាងប្រើការពិសោធន៍ ដេសកាតពឹងផ្អែកលើគណិតវិទ្យា និងតក្ក។ លោកជឿថាអ្វីៗទាំងអស់គួរតែស្ថិតនៅក្នុងភាពសង្ស័យរហូតដល់វាត្រូវបានបានបញ្ជាក់ដោយមូលហេតុ។ មានតែរបស់មួយប៉ុណ្ណោះដែលលោកបានដឹងច្បាស់គឺ វត្តមានរបស់លោក លោកបានសរសេរថា "ដោយសារខ្ញុំគិត, ដូច្នេះខ្ញុំដឹងថាខ្ញុំជានណារ"។ ចាប់ផ្តើមពីចំណុចដំបូងនេះ លោកបានដើរតាមបទដ្ឋាននៃការវែកញែកហេតុផលដ៏តឹងរឹងមួយដើម្បីឈានដល់ការយល់ដឹងពីការពិតមួយ។ វិធីសាស្ត្របែបវិទ្យាសាស្ត្រសម័យទំនើបគឺពឹងផ្អែកលើគំនិតរបស់បាខុន និងដេសកាត។ អ្នកវិទ្យាសាស្ត្របានបង្ហាញថាការអង្កេត និងការពិសោធន៍រួមជាមួយច្បាប់ទូទៅដែលអាចបង្ហាញបែបគណិតវិទ្យា អាចនាំមនុស្សទៅរកការយល់ដឹងកាន់តែច្បាស់អំពីពិភពធម្មជាតិ។

## 4. ញ៉ូវតុនពន្យល់ពីច្បាប់ទំនាញផែនដី

ត្រឹមពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1600 ស្នាដៃរបស់កូផ៌រនីគូស, កេផ្លែរ, និងហ្គាលីឡេអូបានធ្វើឱ្យបះពាល់ដល់ការយល់ឃើញចាស់អំពីតារាសាស្ត្រ និងរូបសាស្ត្រ។ ក្រោយមក អ្នកវិជ្ជាសាស្ត្រអង់គ្លេសដ៏ល្បីល្បាញមួយរូបឈ្មោះអ៊ីសាក ញ៉ូវតុនបានជួយនៅក្នុងនាំយកទ្រឹស្ដីផ្សេងៗគ្នារបស់ពួកគេមកដាក់នៅក្រោមទ្រឹស្ដីនៃចលនាតែមួយ។ ញ៉ូវតុងបានសិក្សាពីគណិតវិទ្យា និងរូបវិទ្យានៅសាកលវិទ្យាល័យខេមប្រ៊ិច។ នៅពេលដែលលោកមានអាយុ 26 ឆ្នាំ ញ៉ូវតុនបានជឿច្បាស់ថារាល់វត្ថុមានរូបទាំងអស់ទទួលរងឥទ្ធិពលដោយស្មើគ្នាដោយកម្លាំងដូចគ្នា។ ការរកឃើញដ៏អស្ចារ្យរបស់ញ៉ូវតុនគឺថា កម្លាំងដូចគ្នាបានគ្រប់គ្រងចលនារបស់ភពនានា និងរាល់សកម្មភាពនៅលើផែនដី និងនៅក្នុងលំហរ។ គំនិតសំខាន់ដែលភ្ជាប់ចលនានៅលើមេឃជាមួយចលនានៅលើផែនដីគឺជាច្បាប់នៃទំនាញសកល។ យោងតាមច្បាប់នេះ វត្ថុទាំងអស់នៅក្នុងចក្រវាលបានទាញគ្នាទៅវិញទៅមក។ កម្រិតនៃការទំនាញនោះគឺអាស្រ័យទៅលើម៉ាស់ និងចម្ងាយរវាងវត្ថុទាំងនោះ។ នៅក្នុងឆ្នាំ 1687 ញ៉ូវតុនបានបោះពុម្ពផ្សាយគំនិតរបស់លោកនៅក្នុងស្នាដៃមួយដែលមានឈ្មោះថា គោលការគណិតសាស្ត្រនៃទស្សនធម្មជាតិ។ វាគឺជាសៀវភៅវិទ្យាសាស្ត្រដ៏សំខាន់បំផុតមួយក្នុងចំណោមសៀវភៅវិទ្យាសាស្ត្រនានា។ ចក្រវាលដែលលោកពិពណ៌នាគឺដូចជានាឡិកាយក្សមួយ។ ផ្នែកទាំងអស់នៃចក្រវាលរបស់យើង ធ្វើការជាមួយគ្នាយ៉ាងឥតខ្ចោះនៅក្នុងវិធីមួយ ដែលអាចត្រូវបានបង្ហាញតាមរយៈគណិតសាស្ត្រ។ ញ៉ូវតុនជឿថាព្រះជាម្ចាស់ដែលជាអ្នកបង្កើតចក្រវាលដ៏មានរបៀបរៀបរយនេះ គឺជាអ្នកបង្កើតនាឡិកាដែលបានគំនត់ឱ្យអ្វីៗទាំងអស់ត្រូវមានចលនា។

## 5. ការរីកសាយភាយនៃបដិវត្តវិទ្យាសាស្ត្រ

ដូចដែលតារាវិទូរកឃើញអាថ៌កំបាំងនៃចក្រវាល អ្នកវិទ្យាសាស្ត្រផ្សេងទៀតចាប់ផ្ដើមសិក្សាអាថ៌កំបាំងនៃធម្មជាតិនៅលើផែនដី។ ការអង្កេតដោយការយកចិត្តទុកដាក់ និងការប្រើប្រាស់វិធីសាស្ត្របែបវិទ្យាសាស្ត្របន្តិចម្តងៗបានក្លាយជារឿងសំខាន់សម្រាប់វិស័យផ្សេងៗជាច្រើន។

សម្ភារៈបែបវិទ្យាសាស្ត្រ៖ អ្នកវិទ្យាសាស្ត្របានអភិវឌ្ឍឧបករណ៍ និងសម្ភារៈថ្មីៗដើម្បីធ្វើឱ្យការអង្កេតមានភាពច្បាស់លាស់ ដែលវិធីសាស្ត្របែបវិទ្យាសាស្ត្រត្រូវការ។ អតិសុខុមទស្សន៍ដំបូងត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1590 ដោយអ្នកផលិតវ៉ែនតាជនជាតិហូឡង់មួយរូបឈ្មោះ ហ្សាធារាយស៍ ជេនស៍សេន។ នៅក្នុងទសវត្សរ៍ឆ្នាំ 1670 ពាណិជ្ជករសម្លៀកបំពាក់ និងជាអ្នកវិទ្យាសាស្ត្រមិនមែនវិជ្ជាជីវៈម្នាក់ឈ្មោះអេនតុន វ៉ាន់ លីវ៉ិនហុកបានប្រើប្រាស់អតិសុខុមទស្សន៍មួយដើម្បីអង្កេតមើលបាតេរីដែលហែលនៅក្នុងសំណាកយកចេញមកពីធ្មេញ។ លោកក៏បានពិសោធន៍កោសិកាឈាមក្រហមជាលើកដំបូងផងដែរ។ នៅក្នុងឆ្នាំ 1643 សិស្សម្នាក់របស់ហ្គាលីឡេអូឈ្មោះអេវ៉ាន់ជេលីស្តា តូរីសេលលីបានអភិវឌ្ឍប្រដាប់ស្ទង់ធាតុអាកាសបារត ដែលជាឧបករណ៍មួយសម្រាប់វាល់សម្ពាតបរិយាកាស និងព្យាករណ៍អាកាសធាតុ។ នៅក្នុងឆ្នាំ 1714 រូបវិទូជនជាតិអាឡឺម៉ង់ឈ្មោះហ្គាប្រ៊ីល ហ្វារេនហៃត៍បានបង្កើតប្រដាប់ស្ទង់កំដៅដំបូងគេដែលប្រើប្រាស់បារតនៅក្នុងបំពង់កែវ។ ប្រដាប់ស្ទង់កំដៅរបស់ហ្វារេនហៃត៍បានបង្ហាញថាទឹកកកនៅកម្រិត 32 ហ្វារេនហៃ។ តារាវិទូជនជាតិស៊ុយអែតមួយរូបឈ្មោះអង់ឌឺស សេលសឺស

បានបង្កើតកម្រិតមួយផ្សេងទៀតសម្រាប់ប្រដាប់ស្ទង់កំដៅបារតនៅក្នុងឆ្នាំ 1742 ។ កម្រិតរបស់សេលសឺសបាន បង្ហាញថាទឹកកកនៅកម្រិត 0 អង្សាសេ។

វេជ្ជសាស្ត្រ និងរាងកាយមនុស្ស៖ អំឡុងយុគកណ្ដាល វេជ្ជបណ្ឌិតជនជាតិអឺរ៉ុបបានទទួលយកការសរសេររបស់គ្រូពេទ្យក្រិកបុរាណមួយរូបឈ្មោះហ្គាលេនថាពិតជាត្រឹមត្រូវ។ ប៉ុន្តែ ហ្គាលេនមិនដែលវះកាត់វិភាគរាងកាយរបស់មនុស្សឱ្យបានល្អិតល្អន់ឡើយ។ ផ្ទុយទៅវិញ លោកបានសិក្សាកាយវិទ្យារបស់ជ្រូក និងសត្វផ្សេងៗទៀត។ ហ្គាលេនសន្មត់ថាកាយវិទ្យារបស់មនុស្សដូចគ្នាជាមួយកាយវិទ្យារបស់សត្វទាំងនោះ។ គ្រូពេទ្យជនជាតិហូឡង់មួយរូបឈ្មោះអង់ឌ្រាស វេសាលូសបានបង្ហាញថាការសន្មត់របស់ហ្គាលេនគឺខុស។ វេសាលូសបានវះកាត់ត្រួតពិនិត្យសាកសពមនុស្ស និងបានបោះពុម្ពផ្សាយការអង្កេតរបស់លោក។ សៀវភៅរបស់លោកដែលមានចំណងជើងថា អំពីរចនាសម្ព័ន្ធនៃរាងកាយមនុស្ស (1543) បានបង្ហាញលម្អិតអំពីរូបភាពគ្រឿងក្នុង, ឆ្អឹង, និងសសៃប្រសាទរបស់មនុស្ស។ នៅចុងទសវត្សរ៍ឆ្នាំ 1700 គ្រូពេទ្យជនជាតិអង់គ្លេសមួយរូបឈ្មោះអេដវឺដ ជេនន័របានបង្កើតវ៉ាក់សាំងមួយដើម្បីការពារជំងឺអុតស្វាយ។ ការចាត់បញ្ចូលមេរោគដោយប្រើប្រាស់មេរោគអុតស្វាយរស់ត្រូវបានអនុវត្តនៅអាស៊ីអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ ខណៈពេលដែលវាផ្តល់អត្ថប្រយោជន៍ បច្ចេកទេសនេះក៏មានគ្រោះថ្នាក់ផងដែរ។ ចេនន័ររកឃើញថាការចាប់បញ្ចូលមេរោគជាមួយនឹងមេរោគដែលយកមកពីជំងឺនៅលើសត្វពាហនៈមួយដែលគេហៅថា អុតស្វាយគោ បានផ្តល់នូវការការពារជាអចិន្ត្រៃសម្រាប់ជំងឺអុតស្វាយលើមនុស្ស។ ដោយសារជំងឺអុតស្វាយគោគឺជាជំងឺដែលស្រាល ហានីភ័យនៃការចាក់បញ្ចូលមេរោគប្រភេទនេះគឺមានកម្រិតតិចតួចណាស់។ ចេនន័របានប្រើប្រាស់មេរោគអុតស្វាយគោដើម្បីផលិតជាវ៉ាក់សាំងដំបូងបំផុតនៅលើពិភពលោក។

ការរកឃើញនៅក្នុងវិស័យគីមី៖ លោករ៉ូបឺត បិយឡេ ជាអ្នកត្រួសត្រាយផ្លូវនៅក្នុងការប្រើប្រាស់វិធីសាស្ត្របែបវិទ្យាសាស្ត្រនៅក្នុងវិស័យគីមី។ លោកត្រូវបានគេចាត់ទុកថាជាស្ថាបនិកនៃគីមីសម័យទំនើប។ នៅក្នុងសៀវភៅមួយដែលមានចំណងជើងថា គីមីវិទូដែលគួរឱ្យសង្ស័យ (1661) លោកបិយឡេបានប្រឆាំងជាមួយគំនិតរបស់អារីស្តូតដែលថាពិភពរូបវន្តរួមបញ្ចូលនៃជាតុចំនួន 4 គឺដី, ខ្យល់, ភ្លើង, និងទឹក។ ផ្ទុយទៅវិញ បិយឡេបានលើកឡើងថារូបធាតុត្រូវបានបង្កើតឡើងដោយភាគល្អិតតូចៗដែលភ្ជាប់គ្នាតាមរបៀបផ្សេងៗគ្នា។ ការរួមចំណែកដ៏ល្បីល្បាញបំផុតរបស់បិយឡេចំពោះគីមីវិទ្យាគឺច្បាប់បិយឡេ។ ច្បាប់នេះបានពន្យល់ពីរបៀបដែលមាឌ, សីតុណ្ហភាព, និងសម្ពាតនៃឧស្ម័នជះឥទ្ធិពលលើគ្នាទៅវិញទៅមក។ គោលគំនិតអំពីហេតុផល និងលំដាប់លំដោយ ដែលជំរុញឱ្យមានការទម្លាយជាច្រើននៅក្នុងវិទ្យាសាស្ត្រ ភ្លាមៗនោះបានផ្លាស់ទៅក្នុងវិស័យផ្សេងៗទៀតនៃជីវិត។ ទស្សនវិទូ និងអ្នកប្រាជ្ញនៅពាសពេញអឺរ៉ុបចាប់ផ្តើមគិតឡើងវិញនូវជំនឿដ៏យូរអង្វែងអំពីស្ថានភាពមនុស្ស ជាពិសេសសិទ្ធិ និងសេរីភាពនៃប្រជាជនសាមញ្ញ។ ទស្សនវិទូទាំងអស់នេះបានជួយជម្រុញឱ្យមានចលនាមួយដែលប្រឆាំងជាមួយទំនាក់ទំនងសម័យចាស់រវាងរដ្ឋាភិបាលមួយ និងប្រជាជន និងជាយថាហេតុបានផ្លាស់ប្តូរជារៀងរហូតនូវទិដ្ឋភាពនយោបាយនៅក្នុងសង្គមជាច្រើន។

# មេរៀនទី 2៖ សករាជពន្លឺនៅអឺរ៉ុប

នៅក្នុងដំណើរការនៃបដិវត្តវិទ្យាសាស្ត្រ នៅវិធីថ្មីនៅក្នុងការគិតកំពុងរីកចម្រើន អ្នកប្រាជ្ញ និងទស្សនវិទូចាប់ផ្តើមវាយតម្លៃឡើងវិញអំពីគោលគំនិតចាស់ៗអំពីទិដ្ឋភាពផ្សេងៗនៃសង្គម។ ពួកគេបានស្វែងរកការយល់ដឹងថ្មីអំពីមូលដ្ឋាននៃជំនឿទាក់ទងជាមួយរដ្ឋាភិបាល, សាសនា, សេដ្ឋកិច្ច, និងការអប់រំ។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេបានជំរុញឱ្យមានសករាជពន្លឺ ដែលជាចលនាបញ្ញាថ្មីមួយដែលសង្កត់ធ្ងន់លើហេតុផល, និងការគិត, និងអំណាចរបស់បុគ្គលក្នុងការដោះស្រាយបញ្ហា។ ត្រូវបានគេស្គាល់ផងដែរថាជាយុគសម័យនៃហេតុផល ចលនានេះបានឈានដល់កំពូលរបស់ខ្លួននៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1700 ហើយបាននាំមកនូវការផ្លាស់ប្តូរដ៏អស្ចារ្យដល់ទិដ្ឋភាពជាច្រើននៃអរិយធម៌លោកខាងលិច។

## 1. ទស្សនពីរអំពីរដ្ឋាភិបាល

សករាជពន្លឺចាប់ផ្តើមពីគំនិតសំខាន់ៗមួយចំនួន ដែលបានបង្កើតឡើងដោយទស្សនវិទូនយោបាយអង់គ្លេសចំនួន 2 រូបនៃទសវត្សរ៍ឆ្នាំ 1600 គឺលោកថូម៉ាស់ ហូបបឺស និងលោកចន ឡុក។ អ្នកទាំងពីរនាក់មានបទពិសោធន៍ចំពោះភាពចលាចលផ្នែកនយោបាយនៅក្នុងប្រទេសអង់គ្លេសនៅដើមសតវត្សរ៍នោះ។ ប៉ុន្តែ ពួកគេទាំង 2 សន្និដ្ឋានខុសគ្នាអំពីធម្មជាតិរបស់រដ្ឋាភិបាល និងមនុស្ស។

កិច្ចសន្យាសង្គមរបស់ហូបបឺស៖ លោកថូម៉ាស់ ហូបបឺសបានបង្ហាញពីទស្សនៈរបស់គាត់នៅក្នុងស្នាដៃមួយដែលមានឈ្មោះថា លេវៀថេន (1651) ។ ភាពភ័យរន្ធត់នៃសង្គ្រាមស៊ីវិលនៅអង់គ្លេសបានបញ្ចុះបញ្ចូលគាត់ថាមនុស្សទាំងអស់ជាធម្មជាតិគឺជាមនុស្សអាត្មានិយម និងអាក្រក់។ លោកហូបបឺសបាននិយាយថា បើគ្មានរដ្ឋាភិបាលដើម្បីរក្សាសណ្តាប់ធ្នាប់ទេ នឹងមាន "សង្គ្រាម . . . របស់មនុស្សទាំងឡាយប្រឆាំងនឹងមនុស្សទាំងឡាយ" ហើយជីវិតនឹងទៅជា "មានតែម្នាក់ឯង, ក្រីក្រ, អាក្រក់, ឃោរឃៅ, និងខ្លី"។ ហូបបឺសបានទទូចថា ដើម្បីគេចចេញពីជីវិតដ៏ក្រៀមក្រំបែបនេះ មនុស្សត្រូវប្រគល់សិទ្ធិរបស់ពួកគេទៅឱ្យអ្នកគ្រប់គ្រងដ៏រឹងមាំមួយរូប។ នៅក្នុងការផ្លោះប្តូរ ពួកគេទទួលបានច្បាប់ និងសណ្តាប់ធ្នាប់។ ហូបបឺសបានហៅកិច្ចព្រមព្រៀងតាមរយៈការដែលមនុស្សបង្កើតរដ្ឋាភិបាលមួយនេះថា កិច្ចសន្យាសង្គម។ ហូបបឺសបាននិយាយថា ដោយសារតែមនុស្សធ្វើសកម្មភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ អ្នកគ្រប់គ្រងត្រូវការអំណាចទាំងស្រុងដើម្បីរក្សាពលរដ្ឋឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ រដ្ឋាភិបាលដ៏ល្អបំផុតមួយគឺជារដ្ឋាភិបាលដែលមានអំណាចដ៏អស្ចារ្យនៃឡេវៀថេន (បិសាចសមុទ្រ)។ តាមទស្សនៈរបស់ហូបបឺស រដ្ឋាភិបាលបែបនេះជារដ្ឋាភិបាលបែបរាជាធិបតេយ្យផ្តាច់ការ ដែលអាចដាក់បទបញ្ជា និងទាមទារឱ្យមានការគោរពប្រតិបត្តិ។

សិទ្ធិធម្មជាតិរបស់ឡុក៖ ទស្សនវិទូចន ឡុក បានប្រកាន់ទស្សនៈផ្សេងគ្នាមួយ មានលក្ខណៈវិជ្ជមានជាងហូបបឺស អំពីធម្មជាតិរបស់មនុស្ស។ គាត់ជឿថាមនុស្សអាចរៀនពីបទពិសោធន៍ និងកែលម្អខ្លួនឯង។ ក្នុងនាមជាមនុស្សដែលមានហេតុផល ពួកគេមានសមត្ថភាពពីធម្មជាតិក្នុងការគ្រប់គ្រងកិច្ចការផ្ទាល់របស់ខ្លួន និងថែរក្សាសុខុមាលភាពសង្គម។ លោកឡុកបានរិះគន់របបរាជានិយមផ្តាច់ការ និងពេញចិត្តចំពោះគំនិតនៃការគ្រប់គ្រង

ដោយខ្លួនឯង។ យោងតាមលោកឡុកមនុស្សទាំងអស់កើតមកមានសេរីភាព និងស្មើភាពគ្នាជាមួយនឹងសិទ្ធិធម្មជាតិ 3 យ៉ាងគឺ ជីវិត, សេរីភាព, និងទ្រព្យសម្បត្តិ។ លោកឡុកបាននិយាយថា គោលបំណងរបស់រដ្ឋាភិបាលគឺដើម្បីការពារសិទ្ធិទាំងនេះ។ ប្រសិនបើរដ្ឋាភិបាលបរាជ័យក្នុងការការពារសិទ្ធិទាំងនេះ ប្រជាពលរដ្ឋមានសិទ្ធិទម្លាក់រដ្ឋាភិបាលនោះចោល។ ទ្រឹស្តីរបស់ឡុកមានឥទ្ធិពលយ៉ាងជ្រាលជ្រៅមួយលើគំនិតនយោបាយសម័យទំនើប។ ជំនឿរបស់គាត់ដែលថាអំណាចរបស់រដ្ឋាភិបាលកើតចេញពីការយល់ព្រមពីប្រជាជន គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យសម័យទំនើប។ គំនិតអំពីរដ្ឋាភិបាលដែលកើតចេញតាមរយៈការយល់ព្រមពីប្រជាជន និងសិទ្ធិក្នុងការបះបោរប្រឆាំងនឹងអ្នកគ្រប់គ្រងអយុត្តិធម៌បានជួយជំរុញការតស៊ូដើម្បីសេរីភាពនៅអឺរ៉ុប និងអាមេរិក។

## 2. ទស្សនវិទូតស៊ូមតិអំពីហេតុផល

សករាជពន្លឺបានឈានដល់កម្ពស់របស់ខ្លួននៅប្រទេសបារាំងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1700 ។ ទីក្រុងប៉ារីសបានក្លាយជាកន្លែងប្រជុំសម្រាប់មនុស្សដែលចង់ពិភាក្សាអំពីនយោបាយ និងគំនិត។ អ្នករិះគន់សង្គមនៅសម័យនោះនៅប្រទេសបារាំងត្រូវបានគេស្គាល់ថាជាទស្សនវិទូ។ ទស្សនវិទូជឿថា មនុស្សអាចប្រើប្រាស់ហេតុផលសម្រាប់ទិដ្ឋភាពទាំងអស់នៃជីវិត ដូចអ៊ីសាក ញ៉ូវតុនបានប្រើហេតុផលវិទ្យាសាស្ត្រ។ គោលគំនិតចំនួន 5 បានបង្កើតជាស្នូលនៃជំនឿរបស់ពួកគេ៖ (1) ហេតុផល៖ ទស្សនវិទូសករាជពន្លឺជឿថា ការពិតអាចរកឃើញតាមរយៈហេតុផល ឬការគិតបែបកត្ត។ (2) ធម្មជាតិ៖ ទស្សនវិទូជឿថាអ្វីដែលជាធម្មជាតិក៏ល្អ និងសមហេតុផលផងដែរ។ (3) សុភមង្គល៖ ទស្សនវិទូបានបដិសេធគោលគំនិតមជ្ឈិមសម័យ ដែលថាមនុស្សគួរតែមានសេចក្តីរីករាយនៅឋានបរលោក និងបានជំរុញមនុស្សឱ្យស្វែងរកសុខុមាលភាពនៅលើផែនដី។ (4) វឌ្ឍនភាព៖ ទស្សនវិទូបានសង្កត់ធ្ងន់ថា សង្គមនិងមនុស្សជាតិអាចប្រសើរឡើង។ (5) សេរីភាព៖ ទស្សនវិទូបានអំពាវនាវឱ្យមានសេរីភាពដែលប្រជាជនអង់គ្លេសបានឈ្នះតាមរយៈការធ្វើបដិវត្តរុងរឿង និងច្បាប់ផ្តល់សិទ្ធិដល់ពួកគេ។

វ៉ុលទែរប្រឈមជាមួយភាពមិនអត់ឱន៖ ប្រហែលជាទស្សនវិទូដែលអស្ចារ្យ និងមានឥទ្ធិពលបំផុតគឺហ្វង់ស័រម៉ារី អារុត។ ដោយប្រើប៊ិចឈ្មោះវ៉ុលទែរ លោកបានបោះពុម្ពសៀវភៅជាង 70 ក្បាលអំពីអត្ថបទនយោបាយ, ទស្សនវិជ្ជា, និងល្ខោន។ ជារឿយៗ វ៉ុលទែរបាននិពន្ធតិះដៀលប្រឆាំងនឹងគូប្រជែងរបស់គាត់។ ជាញឹកញាប់លោកបាននិពន្ធតិះដៀលលើពួកបព្វជិត, អភិជន, និងរដ្ឋាភិបាល។ អណ្តាតមុតស្រួចរបស់គាត់បានធ្វើឱ្យគាត់ជាសត្រូវរបស់តុលាការបារាំង ហើយលោកធ្លាប់ត្រូវបានគេបញ្ជូនទៅដាក់គុកចំនួន 2 លើក។ បន្ទាប់ពីការជាប់គុកលើកទី 2 របស់លោក វ៉ុលទែរត្រូវបានគេនិរទេសទៅប្រទេសអង់គ្លេសអស់រយៈពេលជាង 2 ឆ្នាំ។ ទោះបីជាគាត់បានបង្កើតសត្រូវជាមួយអ្នកដែលមានឥទ្ធិពលក៏ដោយ វ៉ុលទែរមិនដែលឈប់តស៊ូដើម្បីការអត់ឱន, ហេតុផល, សេរីភាពនៃជំនឿសាសនា, និងសេរីភាពក្នុងការបញ្ចេញមតិ។ លោកបានប្រើប៊ិចឃ្វីលរបស់លោកធ្វើជាអាវុធប្រល័យមួយនៅក្នុងការធ្វើសង្គ្រាមគំនិតប្រឆាំងជាមួយនឹងសត្រូវដ៏អាក្រក់បំផុតរបស់មនុស្សជាតិ៖ ការមិនអត់ឱន, ការប្រកាន់ពូជសាសន៍, និងអបិយជំនឿ។ លោកបានសរសេរសង្ខេបអំពីការការពារសេរីភាពដ៏រឹងមាំរបស់លោក

នៅក្នុងសម្រង់ពាក្យដ៏ល្បីបំផុតមួយរបស់គាត់៖ "ខ្ញុំមិនយល់ស្របនឹងពាក្យដែលអ្នកនិយាយទេ ប៉ុន្តែខ្ញុំនឹងការពាររហូតដល់ស្លាប់នូវសិទ្ធិរបស់អ្នកក្នុងការនិយាយវា"។

ម៉ុងតេស្គីយឺ និងការបំបែកអំណាច៖ អ្នកនិពន្ធជនជាតិបារាំងដ៏មានឥទ្ធិពលមួយរូបទៀតឈ្មោះ បារុន ដឺ ម៉ុងតេស្គីយឺ បានពលីខ្លួនឯងក្នុងការសិក្សាអំពីសេរីភាពនយោបាយ។ លោកម៉ុងតេស្គីយឺជឿថា ចក្រភពអង់គ្លេសគឺជាប្រទេសដែលគ្រប់គ្រងល្អបំផុត និងមានតុល្យភាពនយោបាយល្អបំផុតនៅសម័យដែលគាត់រស់នៅ។ ព្រះមហាក្សត្រអង់គ្លេស និងរដ្ឋមន្ត្រីរបស់ទ្រង់កាន់អំណាចប្រតិបត្តិ។ ពួកគេបានអនុវត្តច្បាប់របស់រដ្ឋ។ សមាជិកសភាកាន់អំណាចនីតិបញ្ញត្តិ។ ពួកគេបានបង្កើតច្បាប់។ ចៅក្រមនៃតុលាការអង់គ្លេសកាន់អំណាចតុលាការ។ ពួកគេបានបកស្រាយច្បាប់ ដើម្បីមើលថាតើច្បាប់មួយណាដែលត្រូវយកមកអនុវត្តចំពោះករណីជាក់លាក់មួយ។ ម៉ុងតេស្គីយឺ បានហៅការបែងចែកអំណាចនេះក្នុងចំណោមសាខាផ្សេងៗគ្នានេះថា ការបំបែកអំណាច។ ម៉ុងតេស្គីយឺ បានគិតសាមញ្ញពេកអំពីប្រព័ន្ធនយោបាយរបស់អង់គ្លេស ។ តាមពិត វាមិនបានបំបែកអំណាចតាមវិធីនេះទ្បើយ។ ទោះជាយ៉ាងណាក៏ដោយ គំនិតរបស់គាត់បានក្លាយជាផ្នែកមួយនៃសៀវភៅដ៏ល្បីល្បាញបំផុតរបស់គាត់គឺដែលមានចំណងជើងថា ស្តីអំពីវិញ្ញាណនៃច្បាប់ (1748)។ នៅក្នុងសៀវភៅរបស់លោក ម៉ុងតេស្គីយឺបានស្នើថា ការបំបែកអំណាចនឹងរារាំងបុគ្គល ឬក្រុមណាមួយពីការទទួលបានការគ្រប់គ្រងទាំងស្រុងលើរដ្ឋាភិបាល។ គាត់បានសរសេរថា "អំណាចគួរតែជាការត្រួតពិនិត្យដោយអំណាច"។ គំនិតនេះក្រោយមកត្រូវបានគេហៅថាការត្រួតពិនិត្យ និងតុល្យភាព។ សៀវភៅរបស់ម៉ុងតេស្គីយឺត្រូវបានកោតសរសើរដោយមេដឹកនាំនយោបាយនៅក្នុងអាណានិគមអង់គ្លេសនៅអាមេរិកខាងជើង។ គំនិតរបស់គាត់ស្តីអំពីការបំបែកអំណាច និងការត្រួតពិនិត្យ និងតុល្យភាពបានក្លាយជាមូលដ្ឋានសម្រាប់រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក។

រ៉ូសស្សូ៖យុទ្ធនាការសេរីភាព៖ ទស្សនវិទូដ៏អស្ចារ្យទីបីគឺ ហ្សង់ ហ្សាក រ៉ូសស្សូ មានការប្តេជ្ញាចិត្តយ៉ាងខ្លាំងចំពោះសេរីភាពបុគ្គល។ ជាកូនប្រុសរបស់អ្នកផលិតនាឡិកាជនជាតស្វីសដ៏ក្រីក្រមួយ រ៉ូសស្សូទទួលបានការទទួលស្គាល់ថាជាអ្នកសរសេរអត្ថបទមួយរូប។ ជាមនុស្សចម្លែក, អស្ចារ្យ, និងចម្រូងចម្រាស រ៉ូសស្សូមិនយល់ស្របយ៉ាងខ្លាំងជាមួយទស្សនវិទូសករាជពន្លឺ ផ្សេងទៀតលើបញ្ហាជាច្រើន។ ទស្សនវិទូភាគច្រើនជឿថាហេតុផល, វិទ្យាសាស្ត្រ, និងសិល្បៈនឹងធ្វើអោយជីវិតមនុស្សទាំងអស់មានភាពប្រសើរឡើង។ ទោះជាយ៉ាងណាក៏ដោយ រ៉ូសស្សូបានទទូចថាអរិយធម៌បានធ្វើឱ្យខូចដល់ភាពល្អនៃធម្មជាតិរបស់មនុស្ស។ គាត់បានសរសេរថា "មនុស្សកើតមកមានសេរីភាព ហើយគ្រប់ទីកន្លែងដែលគាត់ជាប់ច្រវាក់"។ រ៉ូសស្សូជឿថារដ្ឋាភិបាលដែលល្អ គឺជារដ្ឋាភិបាលមួយដែលត្រូវបានបង្កើតឡើងដោយប្រជាជន និងដឹកនាំដោយ "ឆន្ទៈទូទៅ" នៃសង្គម ដែលជាលទ្ធិប្រជាធិបតេយ្យផ្ទាល់។ ក្រោមរដ្ឋាភិបាលបែបនេះ មនុស្សយល់ព្រមលះបង់សិទ្ធិសេរីភាពខ្លះដើម្បីប្រយោជន៍រួម។ នៅឆ្នាំ 1762 គាត់បានពន្យល់អំពីទស្សនវិជ្ជានយោបាយរបស់គាត់នៅក្នុងសៀវភៅមួយដែលមានឈ្មោះថា កិច្ចសន្យាសង្គម។ ទស្សនៈរបស់រ៉ូសស្សូអំពីកិច្ចសន្យាសង្គមខុសគ្នាយ៉ាងខ្លាំងពីហូបបឹស។ សម្រាប់ ហូបបឹសកិច្ចសន្យាសង្គមគឺជាកិច្ចព្រមព្រៀងរវាងសង្គមមួយ និងរដ្ឋាភិបាលរបស់ខ្លួន។ សម្រាប់ រ៉ូសស្សូវាគឺជាកិច្ចព្រមព្រៀងក្នុងចំណោមបុគ្គលដែលមានសេរីភាពក្នុងការបង្កើតសង្គម និងរដ្ឋាភិបាល។ ក៏ដូចឡុកដែរ រ៉ូស្សូបានទទូចថាភាពស្របច្បាប់របស់រដ្ឋាភិបាល

មួយបានមកពីការយល់ព្រមរបស់អ្នកដែលត្រូវបានគេគ្រប់គ្រង។ ទោះយ៉ាងណាក៏ដោយ រ៉ូសសូជឿជាក់លើលទ្ធិប្រជាធិបតេយ្យមានភាពទូលំទូលាយជាងអ្វីដែលឡុកបានលើកឡើង។ លោកបានទទូចថា មនុស្សទាំងអស់មានភាពស្មើគ្នា ហើយឋានៈអភិជនគួរត្រូវបានលុបចោល។ គំនិតរបស់រ៉ូសសូ បានបំផុសគំនិតមេដឹកនាំបដិវត្តបារាំងជាច្រើន ដែលបានផ្តួលរំលំរបបរាជានិយមក្នុងឆ្នាំ 1789 ។

បេកការៀលើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ៖ ទស្សនវិទូជនជាតិអ៊ីតាលីមួយរូបឈ្មោះ សេសា បូនេសាណា បេកការៀបានប្រែក្លាយគំនិតរបស់លោកទៅជាប្រព័ន្ធយុត្តិធម៌។ លោកជឿថា ច្បាប់បង្កើតចេញមកដើម្បីរក្សាសណ្តាប់ធ្នាប់សង្គម មិនមែនដើម្បីសងសឹកចំពោះឧក្រិដ្ឋកម្មឡើយ។ បេកការៀបានរិះគន់ជាប្រចាំចំពោះការបំពានលើយុត្តិធម៌។ ក្នុងនោះរួមមានការធ្វើទារុណកម្មសាក្សី, និងជនសង្ស័យ, ដំណើរការមិនទៀងទាត់ក្នុងសវនាការ, និងការផ្តន្ទាទោសដែលបំពាន ឬឃោរឃៅ។ លោកបានលើកឡើងថា ជនត្រូវចោទពីបទឧក្រិដ្ឋគួរតែទទួលបានការកាត់ទោសយ៉ាងឆាប់រហ័ស ហើយទារុណកម្មមិនគួរប្រើប្រាស់ឡើយ។ ជាងនេះទៅទៀត លោកថាកម្រិតនៃការដាក់ទោសត្រូវផ្អែកលើភាពធ្ងន់ធ្ងរនៃបទល្មើស។ លោកក៏មានជំនឿថា ការដាក់ទោសប្រហារជីវិតគួរត្រូវបានលុបបំបាត់។ បេកការៀផ្តោតសំខាន់លើគំនិតរបស់គាត់ស្តីអំពីគោលការណ៍យុត្តិធម៌ ដែលថារដ្ឋាភិបាលគួរតែស្វែងរកអ្វីដែលល្អបំផុតសម្រាប់មនុស្សច្រើនបំផុត។ គំនិតរបស់លោកមានឥទ្ធិពលលើអ្នកកែទម្រង់ច្បាប់ព្រហ្មទណ្ឌនៅអឺរ៉ុប និងអាមេរិកខាងជើង។

### 3. ស្ត្រី និងសករាជពន្លឺ

ទស្សនវិទូនានាបានប្រឆាំងទៅនឹងការសន្មត់ជាច្រើនអំពីរដ្ឋាភិបាល និងសង្គម។ ប៉ុន្តែជារឿយៗពួកគេប្រកាន់យកទស្សនៈបែបប្រពៃណីចំពោះស្ត្រី។ ឧទាហរណ៍ លោករ៉ូសសូបានបង្កើតគំនិតរីកចម្រើនជាច្រើនអំពីការអប់រំ។ ទោះជាយ៉ាងណាក៏ដោយ គាត់ជឿថាការអប់រំរបស់ក្មេងស្រី គួរតែបង្រៀនពួកគេជាចម្បងពីរបៀបធ្វើជាប្រពន្ធ និងម្តាយដែលមានប្រយោជន៍។ អ្នករិះគន់សង្គមបុរសផ្សេងទៀតបានស្តីបន្ទោសស្ត្រីដែលបានអានប្រលោមលោក ព្រោះពួកគេគិតថាវាលើកទឹកចិត្តឱ្យមានភាពទំនេរ និងអំពើទុច្ចរិត។ ទោះយ៉ាងណាក៏ដោយ អ្នកនិពន្ធប្រុសមួយចំនួនបានទាមទារឱ្យមានការអប់រំបន្ថែមសម្រាប់ស្ត្រី និងសមភាពរបស់ស្ត្រីក្នុងការរៀនអាពាហ៍ពិពាហ៍។ អ្នកនិពន្ធស្ត្រីមួយចំនួនក៏បានព្យាយាមកែលម្អស្ថានភាពរបស់ស្ត្រីផងដែរ។ នៅឆ្នាំ 1694 អ្នកនិពន្ធជនជាតិអង់គ្លេសម៉ារី អាស្តេល បានបោះពុម្ពផ្សាយសៀវភៅមួយដែលមានចំណងជើងថា សំណើរដ៏ធ្ងន់ធ្ងរសម្រាប់ស្ត្រី។ សៀវភៅរបស់នាងបានលើកឡើងអំពីកង្វះឱកាសអប់រំសម្រាប់ស្ត្រី។ នៅក្នុងការសរសេរក្រោយមក នាងបានប្រើអំណះអំណាងសករាជពន្លឺអំពីរដ្ឋាភិបាលដើម្បីរិះគន់ទំនាក់ទំនងមិនស្មើគ្នារវាងបុរស និងស្ត្រីក្នុងអាពាហ៍ពិពាហ៍។ នាងបានសរសេរថា "ប្រសិនបើអធិបតេយ្យភាពមិនមានភាពចាំបាច់នៅក្នុងរដ្ឋមួយ តើវាកើតឡើងក្នុងគ្រួសារយ៉ាងដូចម្តេច?...បើមនុស្សប្រុសទាំងអស់កើតមកមានសេរីភាព តើស្ត្រីទាំងអស់កើតមកជាទាសករយ៉ាងណា? នៅអំឡុងឆ្នាំ 1700 ស្ត្រីផ្សេងទៀតបានជ្រើសរើសប្រធានបទទាំងនេះ។ ក្នុងចំណោមអ្នកបញ្ចុះបញ្ចូលល្អបំផុតគឺម៉ារី វ៉ូលស្តូនក្រាហ្វត៍ ដែលបានបោះពុម្ពអត្ថបទមួយមានឈ្មោះថា ការបញ្ជាក់អំពីសិទ្ធិស្ត្រីនៅឆ្នាំ 1792 ។ នៅក្នុងអត្ថបទនោះ នាងមិន

យល់ស្របនឹងលោករ៉ូសសូដែលថា ការអប់រំរបស់ស្ត្រីគួរតែមានកម្រិតទាបជាងបុរស។ ផ្ទុយទៅវិញ នាងបានទទូចថា ស្ត្រីក៏ដូចជាបុរសដែរ ត្រូវការការអប់រំដើម្បីក្លាយជាមនុស្សមានគុណធម៌ និងមានប្រយោជន៍។ វ៉ូលស្តូនក្រាហ្វត៍ក៏បានជំរុញឱ្យស្ត្រីចូលរួមក្នុងវិស័យវេជ្ជសាស្ត្រ និងនយោបាយដែលគ្រប់គ្រងដោយបុរស។ ស្ត្រីបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសករាជពន្លឺតាមរយៈវិធីផ្សេងៗ។ នៅទីក្រុងប៉ារីស និងទីក្រុងនានានៅអឺរ៉ុប ស្ត្រីអ្នកមានបានជួយផ្សព្វផ្សាយគំនិតសករាជពន្លឺតាមរយៈការជួបជុំសង្គមដែលហៅថា សាឡុន ដែលអ្នកនឹងអានអំពីនៅពេលក្រោយនៅក្នុងជំពូកនេះ។ ស្ត្រីម្នាក់មានសំណាងទទួលបានការអប់រំនៅក្នុងវិទ្យាសាស្ត្រគឺ អេមីលី ឌូ ឆាតេលេត ។ ឌូ ឆាតេលេតគឺជាស្ត្រីអភិជនមួយរូបដែលត្រូវបានបណ្តុះបណ្តាលឱ្យក្លាយជាគណិតវិទូ និងរូបវិទូ។ ដោយការបកប្រែការងាររបស់ញ៉ូវតុន ពីឡាតាំងទៅជាភាសាបារាំងនាងបានជួយជំរុញចំណាប់អារម្មណ៍លើវិទ្យាសាស្ត្រនៅក្នុងប្រទេសបារាំង។

## 4. កេរ្តិ៍ដំណែលនៃសករាជពន្លឺ

ក្នុងរយៈពេលពីរបីទសវត្សរ៍មកនេះ អ្នកនិពន្ធសករាជពន្លឺបានជំទាស់ទៅនឹងគំនិតដែលបានរក្សាទុកជាយូរមកហើយអំពីសង្គម។ ពួកគេបានពិនិត្យមើលគោលការណ៍មួយចំនួនដូចជាសិទ្ធិទេវភាពរបស់ព្រះមហាក្សត្រ, ទំនាក់ទំនងនៃព្រះវិហារគ្រីស្តសាសនា និងរដ្ឋ, និងអត្ថិភាពនៃវណ្ណៈសង្គមដែលមិនស្មើគ្នា។ ពួកគេបានប្រកាន់យកជំនឿទាំងនេះ ដោយផ្អែកលើពន្លឺនៃហេតុផល ហើយបានរកឃើញថាពួកគេត្រូវការធ្វើកំណែទម្រង់។ ទស្សនវិទូភាគច្រើនរស់នៅក្នុងពិភពនៃគំនិត។ ពួកគេបានបង្កើត និងធ្វើឱ្យស្គាល់ទ្រឹស្តីថ្មី។ ទោះបីជាពួកគេលើកទឹកចិត្តដល់ការធ្វើកំណែទម្រង់ក៏ដោយ ក៏ពួកគេមិនមែនជាអ្នកបដិវត្តសកម្មដែរ។ ទោះជាយ៉ាងណាក៏ដោយ ទ្រឹស្តីរបស់ពួកគេនៅទីបំផុតបានបំផុសគំនិតឱ្យមានបដិវត្តនៅអាមេរិក និងបារាំង និងចលនាបដិវត្តផ្សេងទៀតនៅក្នុងទសវត្សរ៍ឆ្នាំ 1800 ។ សករាជពន្លឺបានបង្កើតឥទ្ធិពលរយៈពេលវែងបីផ្សេងទៀត ដែលជួយសម្រួចអារ្យធម៌លោកខាងលិច។

ជំនឿលើវឌ្ឍនភាព៖ ឥទ្ធិពលដំបូងគឺជំនឿលើវឌ្ឍនភាព។ អ្នកត្រួសត្រាយផ្លូវមួយចំនួនដូចជា ហ្គាលីឡេអូ និងញ៉ូវតុន បានរកឃើញកូនសោរសម្រាប់ដោះស្រាយអាថ៌កំបាំងនៃធម្មជាតិក្នុងទសវត្សរ៍ឆ្នាំ 1500 និង 1600 ។ ជាមួយនឹងការបើកទ្វារនេះ ការរីកចម្រើននៃចំណេះដឹងផ្នែកវិទ្យាសាស្ត្រហាក់ដូចជាបង្កើនល្បឿនក្នុងទសវត្សរ៍ឆ្នាំ 1700 ។ អ្នកវិទ្យាសាស្ត្របានបង្កើតរបកគំហើញថ្មីសំខាន់ៗនៅក្នុងវិស័យគីមីវិទ្យា, រូបវិទ្យា, ជីវវិទ្យា, និងមេកានិច។ ជោគជ័យនៃបដិវត្តវិទ្យាសាស្ត្របានផ្តល់ឱ្យមនុស្សនូវទំនុកចិត្តថា ហេតុផលរបស់មនុស្សអាចដោះស្រាយបញ្ហាសង្គមបាន។ ទស្សនវិទូ និងអ្នកកែទម្រង់បានទទូចឱ្យបញ្ចប់ការអនុវត្តរបបទាសភាព និងទទូចឱ្យមានសមភាពសង្គមកាន់តែប្រសើរ ក៏ដូចជាទម្រង់រដ្ឋាភិបាលប្រជាធិបតេយ្យកាន់តែច្រើន។

ទស្សនវិស័យផ្នែកសាសនាកាន់តែច្រើន៖ លទ្ធផលទី 2 គឺការកើនឡើងនៃទស្សនវិស័យផ្នែកសាសនា ឬមិនទាក់ទងសាសនាកាន់តែច្រើន។ អំឡុងពេលនៃសករាជពន្លឺ មនុស្សចាប់ផ្តើមសួរដោយបើកចំហអំពីជំនឿសាសនារបស់ពួកគេ និងការបង្រៀនរបស់ព្រះវិហារគ្រឹះសាសនា។ នៅមុនបដិវត្តវិទ្យាសាស្ត្រ មនុស្សបានទទួលយកអាថ៌កំបាំងនៃសកលលោកថាជាកិច្ចការរបស់ព្រះ។ ម្តងមួយៗ អ្នកវិទ្យាសាស្ត្របានរកឃើញថា អាថ៌កំបាំង

ទាំងនេះអាចពន្យល់បានតាមគណិតវិទ្យា។ ញ៉ូវតុនខ្លួនលោកផ្ទាល់ជាអ្នកកាន់សាសនាជ្រៅជ្រះមួយរូប ហើយគាត់បានសម្លឹងទៅរកការបង្ហាញពីភាពរុងរឿងរបស់ព្រះតាមរយៈការងាររបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ ការរកឃើញរបស់គាត់ជារឿយៗបានធ្វើឱ្យមនុស្សផ្លាស់ប្តូររបៀបដែលពួកគេគិតអំពីព្រះ។ ទន្ទឹមនឹងនេះ លោកវ៉ុលទែរ និងអ្នករិះគន់ផ្សេងទៀតបានវាយប្រហារលើជំនឿ និងការអនុវត្តមួយចំនួននៃស្ថាប័នគ្រីស្តសាសនា។ ពួកគេចង់លុបបំបាត់ជំនឿសាសនាបែបអបិយជំនឿ និងការភ័យខ្លាច និងលើកកម្ពស់ការអត់ឱនចំពោះគ្រប់សាសនាទាំងឡាយ។

សារៈសំខាន់នៃជំនឿបុគ្គល៖ ជំនឿនៅក្នុងវិទ្យាសាស្ត្រ និងភាពជឿនលឿនបានបង្កើតលទ្ធផលទី 3 គឺការកើនឡើងនៃបុគ្គលនិយម។ នៅពេលដែលមនុស្សចាប់ផ្តើមងាកចេញពីការណែនាំរបស់ព្រះវិហារ និងរាជវង្ស ពួកគេបានសម្លឹងមើលលើខ្លួនឯងជំនួសវិញ។ ទស្សនវិជ្ជាបានលើកទឹកចិត្តមនុស្សឱ្យប្រើសមត្ថភាពរបស់ខ្លួនក្នុងការវែកញែកដើម្បីវិនិច្ឆ័យថាអ្វីត្រូវឬខុស។ ពួកគេក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃបុគ្គលនៅក្នុងសង្គមផងដែរ។ ពួកគេបានអះអាងថា រដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយបុគ្គលទាំងឡាយ ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ពួកគេ។ ទស្សនវិទូជនជាតិអង់គ្លេស អាដាម ស្មីត បានពង្រីកការសង្កត់ធ្ងន់លើបុគ្គលម្នាក់ៗចំពោះការគិតអំពីសេដ្ឋកិច្ច។ លោកជឿថា បុគ្គលដែលធ្វើសកម្មភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ បានបង្កើតឱ្យមានភាពជឿនលឿនដល់ផ្នែកសេដ្ឋកិច្ច។ ទ្រឹស្តីរបស់ស្មីតត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងជំពូក 24 ។ នៅអំឡុងពេលនៃសករាជពន្លឺ ហេតុផលជាចំកណ្តាលនៃឆាក។ គំនិតដ៏អស្ចារ្យបំផុតនៅអឺរ៉ុបបានកើតចេញតាមរយៈការតាមដានការងារគ្នាទៅវិញទៅមកជាមួយនឹងចំណាប់អារម្មណ៍ និងបានជួបគ្នាជាញឹកញាប់ដើម្បីពិភាក្សាអំពីគំនិតរបស់ពួកគេ។ ព្រះមហាក្សត្រ និងក្សត្រីមួយចំនួននៅអឺរ៉ុបក៏មានចំណាប់អារម្មណ៍ខ្លាំងណាស់ដែរ។ ដូចដែលអ្នកនឹងរៀននៅក្នុងមេរៀនទី 3 ពួកទ្រង់បានសំលឹងទៅរកការអនុវត្តគំនិតមួយចំនួនរបស់ទស្សនវិទូដើម្បីបង្កើតវឌ្ឍនភាពនៅក្នុងប្រទេសរបស់ពួកទ្រង់។

# មេរៀនទី 3៖ សករាជពន្លឺរីកសាយភាយ

ទស្សនៈរបស់ទស្សនវិទូអំពីសង្គម តែងតែធ្វើឱ្យពួកគេជួបប្រទះជាមួយបញ្ហា។ នៅប្រទេសបារាំង វាជារឿងខុសច្បាប់ក្នុងការរិះគន់ព្រះវិហារកាតូលិក ឬរដ្ឋាភិបាល។ ទស្សនវិទូជាច្រើនបានជាប់គុក ឬត្រូវបាននិរទេស។ ឧទាហរណ៍ វ៉ុលតែរបានឆ្លងកាត់ទាំងការផ្តន្ទាទោស និងការនិរទេស។ ទោះជាយ៉ាងណាក៏ដោយ សករាជពន្លឺបានរីករាលដាលពាសពេញទ្វីបអឺរ៉ុប ដោយសារមានជំនួយពីសៀវភៅ, ទស្សនាវដ្តី, និងពាក្យសម្តី។ យូរៗទៅសករាជពន្លឺបានជះឥទ្ធិពលគ្រប់បែបយ៉ាង រាប់ចាប់ពីពិភពសិល្បៈ រហូតដល់រាជវាំងនៅពាសពេញទ្វីបអឺរ៉ុប។

## 1. ពិភពនៃទស្សនមួយ

នៅក្នុងទសវត្សរ៍ឆ្នាំ 1700 ប៉ារីសគឺជារាជធានីនៃវប្បធម៌ និងបញ្ញារបស់អឺរ៉ុប។ យុវជនមកពីជុំវិញទ្វីបអឺរ៉ុប និងមកពីអាមេរិកផងដែរ បានធ្វើដំណើរមកសិក្សា ទស្សនវិជ្ជា និងរីករាយជាមួយវប្បធម៌នៃទីក្រុងដ៏អ៊ូអរនេះ។ គំនិតភ្លឺស្វាងបំផុតនៅអំឡុងពេលនោះបានប្រមូលផ្តុំគ្នានៅទីនោះ។ គំនិតរបស់ពួកគេបានបំភ្លឺសករាជពន្លឺ។ ការចាប់អារម្មណ៍ចំពោះសករាជពន្លឺ បានកើតឡើងខ្លាំងបំផុតក្នុងចំណោមស្ត្រីអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភជាច្រើននៃទីក្រុងប៉ារីស។ នៅទីនោះ នៅក្នុងបន្ទប់គំនូរដ៏ធំរបស់ពួកគេ ក្រុមអ្នកទទួលភ្ញៀវទាំងនេះ បានប្រារព្ធពិធីជួបជុំសង្គមជាទៀងទាត់ដែលហៅថា សាឡន។ នៅក្នុងព្រឹត្តិការណ៍ទាំងនេះ ទស្សនវិទូ, អ្នកនិពន្ធ, សិល្បករ, អ្នកវិទ្យាសាស្ត្រ និងបញ្ញវន្តដ៏អស្ចារ្យផ្សេងទៀតបានជួបប្រជុំគ្នាដើម្បីពិភាក្សាអំពីគំនិត។

សព្វវចនាធិប្បាយរបស់ឌីឌ័រ៉ូត៖ អ្នកដែលមានឥទ្ធិពលបំផុតក្នុងចំណោមអ្នកទទួលភ្ញៀវក្នុងកម្មវិធីសាឡននៅក្នុងសម័យរបស់វ៉ុលតែរគឺម៉ារី-តេរេស។ អ្នកស្រីបានជួយផ្តល់ហិរញ្ញប្បទានដល់គម្រោងរបស់ទស្សនវិទូឈានមុខគេដែលមានឈ្មោះថាដេនីស ឌីឌ័រ៉ូត។ ឌីឌ័រ៉ូតបានបង្កើតសៀវភៅដ៏ធំមួយ ដែលអ្នកប្រាជ្ញឈានមុខគេជាច្រើននៅ អឺរ៉ុបបានបានចូលរួមចំណែកជាអត្ថបទ និងតែងសេចក្តី។ គាត់បានហៅវាថា សព្វវចនាធិប្បាយ ហើយលោកបានចាប់ផ្តើមបោះពុម្ពភាគដំបូងនៅឆ្នាំ 1751។ ភ្លាមៗនោះ ទស្សនៈនៃសករាជពន្លឺដែលបានបង្ហាញនៅក្នុងអត្ថបទទាំងនោះ បានធ្វើឱ្យរដ្ឋាភិបាលបារាំង និងព្រះវិហារកាតូលិកមានការខឹងសម្បា។ ក្រុមអ្នកត្រួតពិនិត្យការបោះពុម្ព បានហាមឃាត់ការងារនេះ។ ពួកគេបាននិយាយថា វាបានធ្វើឱ្យខូចដល់សិទ្ធិអំណាចរបស់រាជវង្សលើកទឹកចិត្តដល់ស្មារតីនៃការបះបោរ និងបានជំរុញឱ្យមាន "អំពើពុករលួយខាងសីលធម៌, ការមិនគោរពសាសនា និងការមិនមានជំនឿ"។ ទោះជាយ៉ាងណាក៏ដោយឌីឌ័រ៉ូតនៅតែបន្តបោះពុម្ពសព្វវចនាធិប្បាយរបស់គាត់។ សាឡន និងសព្វវចនាធិប្បាយ បានជួយដល់ការផ្សព្វផ្សាយសករាជពន្លឺដល់មនុស្សដែលមានការអប់រំនៅទូទាំងទ្វីបអឺរ៉ុប។ គំនិតសករាជពន្លឺក៏បានផ្សព្វផ្សាយជាយថាហេតុតាមរយៈកាសែត, ខិត្តបណ្ណ, និងសូម្បីតែចម្រៀងនយោបាយ។ គំនិតសករាជពន្លឺអំពីរដ្ឋាភិបាល និងសមភាពបានទាក់ទាញចំណាប់អារម្មណ៍ក្នុងចំណោមអ្នកបញ្ញវន្តវណ្ណៈកណ្តាលដែលកំពុងរីកចម្រើន ដែលអាចមានលទ្ធភាពទិញសៀវភៅជាច្រើន និងគាំទ្រការងាររបស់សិល្បករ។

## 2. រចនាបថសិល្បៈថ្មី

ទស្សនសករាជពន្លឺនៃសណ្តាប់ធ្នាប់ និងហេតុផលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសិល្បៈដែលរួមមាន៖ តន្ត្រី, អក្សរសិល្ប៍, គំនូរ, និងស្ថាបត្យកម្ម។

រចនាបទបុរាណសម័យថ្មីលេចចេញ៖ សិល្បៈអឺរ៉ុបនៃទសវត្សរ៍ឆ្នាំ 1600 និងដើមទសវត្សរ៍ឆ្នាំ 1700 គ្របដណ្តប់ដោយរចនាបទដែលគេហៅថាបារ៉ាកេ ដែលត្រូវបានកំណត់ដោយការរចនាតុបតែងដ៏អស្ចារ្យមួយ។ រចនាបទបារ៉ាកេ អាចត្រូវបានគេមើលឃើញនៅក្នុងវិមានដ៏អស្ចារ្យនានាដូចជាវ៉ែកសៃ និងនៅក្នុងគំនូរផ្សេងៗទៀតជាច្រើន។ នៅក្រោមឥទ្ធិពលនៃសករាជពន្លឺ រចនាបទបានចាប់ផ្តើមផ្លាស់ប្តូរ។ វិចិត្រករ និងស្ថាបត្យករបានធ្វើការក្នុងរចនាបទមួយដែលសាមញ្ញ និងឆើតឆាយ ដែលបានខ្ចីគំនិត និងប្រធានបទពីក្រិក និងរ៉ូមបុរាណ។ រចនាបទសិល្បៈនៃចុងទសវត្សរ៍ឆ្នាំ 1700 ត្រូវបានគេហៅថា "បុរាណសម័យថ្មី" ។

ការផ្លាស់ប្តូរនៅក្នុងតន្ត្រី និងអក្សរសិល្ប៍៖ រចនាបទតន្ត្រីក៏បានផ្លាស់ប្តូរផងដែរ ដើម្បីឆ្លុះបញ្ចាំងពីគំនិតសករាជពន្លឺ។ ឆាកតន្ត្រីនៅអឺរ៉ុបត្រូវបានគ្រប់គ្រងដោយអ្នកនិពន្ធដូចជា ចូហាន សេបាស្ទៀន បាច់ នៃប្រទេសអាល្លឺម៉ង់ និងចច ហ្វ្រីឌ្រិច ហានដេល នៃប្រទេសអង់គ្លេស។ វិចិត្រករទាំង 2 រូបនេះបាននិពន្ធបទភ្លេងដ៏គួរឱ្យកត់សម្គាល់។ នៅអំឡុងពេលនៃសករាជពន្លឺ រចនាបទតន្ត្រីថ្មីមួយដែលស្រាល និងឆើតឆាយជាងមុន ដែលគេស្គាល់ថាការលេចឡើងបែបបុរាណ។ អ្នកនិពន្ធចំនួន 3 នាក់នៅទីក្រុងវីយែននៃប្រទេសអូទ្រីស ជាប់ចំណាត់ថ្នាក់ក្នុងចំណោមបុគ្គលដ៏អស្ចារ្យបំផុតនៃសម័យបុរាណនៃតន្ត្រី។ ក្នុងចំណោមពួកគេរួមមាន ហ្វ្រង់ហ៍ ចូសេផ ហេដន៍, វ៉ូលហ្វហ្គេង អាម៉ាដឺស ម៉ូហ្សាត, និងលូដវីក វ៉ាន់ ប៊ីថូវេន។ វិចិត្រករទាំងនេះបាននិពន្ធបទភ្លេងដ៏គួរឱ្យកត់សម្គាល់។ អ្នកនិពន្ធនៅសតវត្សរ៍ទី 18 ក៏បានបង្កើតរចនាបទ និងទម្រង់អក្សរសិល្ប៍ថ្មីៗផងដែរ។ អ្នកនិពន្ធអឺរ៉ុបមួយចំនួនបានចាប់ផ្តើមសរសេរប្រលោមលោក ដែលជាស្នាដៃវែងនៃពាក្យសំដីបែបប្រឌិត។ ស្នាដៃរបស់ពួកគេត្រូវបានរៀបចំ យ៉ាងប្រុងប្រយ័ត្ន, ប្រើប្រាស់ភាពស្រពិចស្រពិល, និងស្វែងយល់ពីគំនិត និងអារម្មណ៍របស់តួអង្គ។ សៀវភៅទាំងនេះមានប្រជាប្រិយភាពជាមួយអ្នកអានវណ្ណៈកណ្តាលជាច្រើន អ្នកដែលចូលចិត្តរឿងកម្សាន្តដែលសរសេរជាភាសាប្រចាំថ្ងៃ។ អ្នកនិពន្ធ រួមទាំងស្ត្រីជាច្រើនផង តាក់តែងរឿងប្រលោមលោកដ៏ពេញនិយមយ៉ាងច្រើននៅក្នុងទសវត្សរ៍ឆ្នាំ 1700 ។ សៀវភៅប៉ាមេឡារបស់សាម៉ូអែល រីឆាដសុន ជារឿយៗត្រូវបានគេចាត់ទុកថាជាប្រលោមលោកភាសាអង់គ្លេសពិតប្រាកដដំបូង។ វាបានប្រាប់ពីរឿងរបស់នារីបម្រើវ័យក្មេងមួយរូបដែលបដិសេធពីភាពជឿនលឿនរបស់ម្ចាស់នាង។ ស្នាដៃភាសាអង់គ្លេសមួយទៀតគឺ ថម ចនស៍ ដែលសរសេរឡើងដោយហេនរី ហ្វីលដឹង បានប្រាប់ពីរឿងក្មេងកំព្រាម្នាក់ដែលធ្វើដំណើរជុំវិញប្រទេសអង់គ្លេសដើម្បីស្វែងរកស្ត្រីដែលគាត់ស្រលាញ់។

## 3. សករាជពន្លឺ និងរាជាធិបតេយ្យ

ចាប់ពីសាឡុន, ស្ទូឌីយ៉ូសិល្បករ, និងសាលប្រគុំតន្ត្រីនៅអឺរ៉ុប ស្មារតីសករាជពន្លឺក៏បានសាយភាយពាសពេញរាជវាំងរបស់អឺរ៉ុបផងដែរ។ ទស្សនវិទូជាច្រើន រួមមានទាំងលោកវ៉ុលតែរផងដែរ ជឿថាទម្រង់រដ្ឋាភិបាលល្អបំផុតគឺរាជាធិបតេយ្យដែលអ្នកគ្រប់គ្រងគោរពសិទ្ធិរបស់ប្រជាជន។ ទស្សនវិទូបានព្យាយាមបញ្ចុះបញ្ចូលស្តេចឱ្យ

គ្រប់គ្រងដោយយុត្តិធម៌។ ព្រះមហាក្សត្រមួយចំនួនបានទទួលយកគំនិតថ្មី ហើយបានធ្វើកំណែទម្រង់ដែលឆ្លុះបញ្ចាំងពីស្មារតីសករាជពន្លឺ។ ពួកគេត្រូវបានគេស្គាល់ថាអ្នកកាន់អំណាចផ្តាច់ការសករាជពន្លឺ។ អ្នកកាន់អំណាចផ្តាច់ការសករាជពន្លឺបានគាំទ្រគំនិតរបស់ទស្សនវិទូ។ ប៉ុន្តែពួកគេក៏មិនមានចេតនាលះបង់អំណាចណាមួយរបស់ទ្រង់ផងដែរ។ ការផ្លាស់ប្តូរដែលពួកទ្រង់បានធ្វើ ត្រូវបានជំរុញដោយបំណងប្រាថ្នាចំនួន 2 ៖ ពួកគេចង់ធ្វើឱ្យប្រទេសរបស់ពួកគេកាន់តែរឹងមាំ និងការគ្រប់គ្រងរបស់ពួកគេកាន់តែមានប្រសិទ្ធភាព។ អ្នកកាន់អំណាចផ្តាច់ការសករាជពន្លឺដែលល្បីល្បាញបំផុតរបស់អឺរ៉ុបរួមមានហ្វ្រេឌ្រិចទី 2 នៃព្រូស, អធិរាជយ៉ូម៉ាំងពិសិដ្ឋ ចូសែបទី 2 នៃអូទ្រីស, និងខាធើរីនដ៏អស្ចារ្យនៃប្រទេសរុស្ស៊ី។ ហ្វ្រេឌ្រិចដ៏អស្ចារ្យទី 2 ដែលជាព្រះមហាក្សត្រនៃព្រូសពីឆ្នាំ 1740 ដល់ 1786 បានប្តេជ្ញាខ្លួនទ្រង់នៅក្នុងការកែទម្រង់ព្រូស។ គាត់បានផ្តល់សេរីភាពសាសនាកាន់តែច្រើន, កាត់បន្ថយការចាប់ពិរុទ្ធ, និងកែលម្អការអប់រំ។ លោកក៏បានកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងលុបបំបាត់ការប្រើទារុណកម្ម។ ទោះយ៉ាងណាក៏ដោយ ការផ្លាស់ប្តូររបស់ហ្វ្រេឌ្រិច ដំណើរការនៅពេលក្រោយមកទៀតតែប៉ុណ្ណោះ។ ឧទាហរណ៍ ទ្រង់ជឿថាខ្ញុំកញ្ជះគឺមិនល្អ ប៉ុន្តែទ្រង់មិនបានធ្វើអ្វីដើម្បីបញ្ចប់វាឡើយ ដ៏រាបណាទ្រង់ត្រូវការការគាំទ្រពីម្ចាស់ដីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ជាលទ្ធផល ទ្រង់មិនដែលព្យាយាមផ្លាស់ប្តូររបៀបរបបសង្គមដែលមានស្រាប់នោះឡើយ។ ប្រហែលជាការរួមចំណែកដ៏សំខាន់បំផុតរបស់ហ្វ្រេឌ្រិចគឺអាកប្បកិរិយារបស់គាត់ចំពោះការធ្វើជាស្តេច។ គាត់បានហៅខ្លួនគាត់ថា "អ្នកបំរើដំបូងរបស់រដ្ឋ" ។ តាំងពីដើមរជ្ជកាល ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា គោលដៅរបស់ទ្រង់គឺដើម្បីបម្រើ និងពង្រឹងប្រទេសរបស់គាត់។ អាកប្បកិរិយានេះគឺច្បាស់ណាស់ថាជាអាកប្បកិរិយាមួយដែលទាក់ទាញទស្សនវិទូ។

ចូសែបទី 2៖ អ្នកកែទម្រង់រាជានិយមជ្រុលមួយរូបគឺចូសែបទី 2 នៃប្រទេសអូទ្រីស។ រាជបុត្រ និងជាអ្នកស្នងតំណែងបន្តពីព្រះនាមម៉ារីយ៉ា ថេរីសា ព្រះនាមចូសែបទី 2 បានគ្រប់គ្រងប្រទេសអូទ្រីសពីឆ្នាំ 1780 ដល់ឆ្នាំ 1790 ។ ទ្រង់នាំមកនូវការធ្វើកំណែទម្រង់ច្បាប់ និងសេរីភាពសារព័ត៌មាន។ គាត់ក៏បានគាំទ្រសេរីភាពនៃការគោរពប្រតិបត្តិសាសនា សូម្បីតែសម្រាប់ប្រូតេស្តង់, អូតូដុក, និងយូដានិយម។ នៅក្នុងកំណែទម្រង់ដ៏ខ្លាំងក្លាបំផុតរបស់ទ្រង់ យ៉ូសែបបានលុបចោលខ្ញុំកញ្ជះ ហើយបានបញ្ជាឱ្យបង់ជាសាច់ប្រាក់ដល់កសិករសម្រាប់ការងាររបស់ពួកគេ។ មិនមាអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលថាពេលនោះពួកអភិជនបានប្រឆាំងយ៉ាងម៉ឺងម៉ាត់ចំពោះការផ្លាស់ប្តូរនេះ។ ក៏ដូចជាការធ្វើកំណែទម្រង់ជាច្រើនទៀយ ការធ្វើកំណែទម្រង់របស់យ៉ូសែប ត្រូវបានលុបបំបាត់ចោលបន្ទាប់ពីទ្រង់សុគត។

ខាធីរីនដ៏អស្ចារ្យ៖ មេដឹកនាំដែលទស្សនវិទូដែលគួរឱ្យកោតសរសើរបំផុតគឺខាធីរីនទី 2, ត្រូវបានគេស្គាល់ថាជាខាធីរីនដ៏អស្ចារ្យ។ ព្រះនាងបានគ្រប់គ្រងប្រទេសរុស្ស៊ីចាប់ពីឆ្នាំ 1762 ដល់ឆ្នាំ 1796 ។ ទ្រង់ជាអធិរាជដែលមានការអប់រំខ្ពង់ខ្ពស់បានអានស្នាដៃទស្សនវិទូ ហើយព្រះនាងបានផ្លាស់ប្តូរសំបុត្រជាច្រើនជាមួយវ៉ុលទែរ។ ព្រះនាងបានគ្រប់គ្រងដោយអំណាចផ្តាច់ការ ប៉ុន្តែទ្រង់ក៏បានសំលឹងទៅរកការកែទម្រង់ប្រទេសរុស្ស៊ីផងដែរ។ នៅក្នុងឆ្នាំ 1767 ម្ចាស់ក្សត្រីខាធីរីនបានបង្កើតគណៈកម្មាការមួយដើម្បីពិនិត្យច្បាប់របស់រុស្ស៊ី។ ព្រះនាងបានបង្ហាញវាជាមួយនឹងសំណើដ៏អស្ចារ្យមួយសម្រាប់កំណែទម្រង់ដោយផ្អែកលើគំនិតរបស់ម៉ុងតេស្គីយឺ និងបេកការៀ។ ក្នុង

ចំណោមការផ្លាស់ប្តូរផ្សេងទៀត ទ្រង់បានផ្តល់អនុសាសន៍ឱ្យមានការអត់ឱនខាងសាសនា និងការលុបបំបាត់ការធ្វើទារុណកម្ម និងការផ្តន្ទាទោសប្រហារជីវិត។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាការរបស់របស់ព្រះនាងមិនបានសម្រេចគោលដៅដ៏ខ្ពង់ខ្ពស់ទាំងនេះទេ។ នៅទីបំផុត ម្ចាស់ក្សត្រីខាធើរីនបានដាក់ឱ្យដំណើរការការធ្វើកំណែទម្រង់មួយ ប៉ុន្តែការធ្វើកំណែទម្រង់របស់ព្រះនាងមានកម្រិតតិចតួចប៉ុណ្ណោះដើម្បីកែលម្អជីវិតរបស់កសិកររុស្ស៊ី។ ទស្សនៈរបស់ព្រះនាងអំពីសករាជពន្លឺបានផ្លាស់ប្តូរបន្ទាប់ពីការបះបោរដ៏ធំនៃពួកខ្ញុំកញ្ជះនៅក្នុងឆ្នាំ 1773។ ជាមួយនឹងភាពឃោរឃៅ កងទ័ពរបស់ខាធើរីនបានបង្ក្រាបការបះបោរនេះ។ កាលពីដំបូងម្ចាស់ក្សត្រីខាធើរីនមានបំណងនៅក្នុងការបញ្ចប់ខ្ញុំកញ្ជះ។ ទោះយ៉ាងណាក៏ដោយ ការបះបោរនេះបានញ៉ាំងឱ្យព្រះនាងយល់ថា ព្រះនាងត្រូវការការគាំទ្រពីពួកអភិជនដើម្បីរក្សាបល្ល័ង្ករបស់ព្រះនាង។ ដូច្នេះហើយ ទើបព្រះនាងប្រគល់អំណាចផ្តាច់មុខដល់ពួកអភិជនក្នុងការគ្រប់គ្រងលើពួកខ្ញុំកញ្ជះ។ ជាលទ្ធផល ខ្ញុំកញ្ជះរុស្ស៊ីបានបាត់បង់ជានចុងក្រោយនៃសេរីភាពរបស់ខ្លួន។

ខាធើរីនពង្រីកប្រទេសរុស្ស៊ី៖ ពីទ័រដ៏អស្ចារ្យដែលបានគ្រប់គ្រងប្រទេសរុស្ស៊ីនៅដើមទសវត្សរ៍ឆ្នាំ 1700 បានប្រយុទ្ធអស់រយៈពេលជាច្រើនឆ្នាំដើម្បីយកជ័យជំនះលើកំពង់ផែមួយនៅសមុទ្របាល់ទិក។ ក៏ដូចគ្នានេះដែរ ខាធើរីនបានសំលឹងរកផ្លូវចូលទៅក្នុងសមុទ្រខ្មៅ។ នៅក្នុងការធ្វើសង្គ្រាមចំនួន 2 លើកជាមួយពួកតួកអូតូម៉ង់ កងទ័ពរបស់ទ្រង់បានចុងក្រោយបានយកជ័យជំនះលើការគ្រប់គ្រងលើតំបន់ឆ្នេរភាគខាងជើងនៃសមុទ្រខ្មៅ។ ប្រទេសរុស្ស៊ីក៏ទទួលបានសិទ្ធិនៅក្នុងការបញ្ជូននាវាធ្វើដំណើរកាត់តាមច្រកសមុទ្រអូតូម៉ង់ ដែលជាច្រកចេញពីសមុទ្រខ្មៅទៅកាន់សមុទ្រមេឌីទែរ៉ាណេ។ ខាធើរីនក៏បានពង្រីកអាណាចក្ររបស់ទ្រង់ទៅភាគខាងលិចទៅកាន់ប្រទេសប៉ូឡូញ។ នៅប្រទេសប៉ូឡូញពេលនោះអំណាចស្តេចមានសភាពទន់ខ្សោយ ហើយពួកអភិជនដែលមានឯករាជ្យបានកាន់អំណាចច្រើនបំផុត។ មហាអំណាចជិតខាងទាំង 3 រួមមានរុស្ស៊ី, ព្រូស, និងអូទ្រីសបានព្យាយាមអះអាងពីឥទ្ធិពលរបស់ខ្លួនលើប្រទេសប៉ូឡូញ។ នៅក្នុងឆ្នាំ 1772 ប្រទេសជិតខាងដែលស្រេកឃ្លានទឹកដីទាំងនេះ បានយក ផ្នែកនីមួយៗនៃដែនដីរបស់ប៉ូឡូញ នៅក្នុងអ្វីដែលហៅថា ការបែងចែកប្រទេសប៉ូឡូញដំបូង។ នៅក្នុងការបែងចែកបន្ថែមទៀតនៅឆ្នាំ 1793 និង 1795 ពួកគេបានដណ្តើមយកទឹកដីដែលនៅសល់របស់ប៉ូឡូញ។ ជាមួយនឹងការបែងចែកទាំងនេះ ប៉ូឡូញបានបាត់ខ្លួនជាប្រទេសឯករាជ្យអស់រយៈពេលជាងមួយសតវត្សរ៍។ នៅចុងបញ្ចប់នៃរជ្ជកាលដ៏អស្ចារ្យរបស់ទ្រង់ ម្ចាស់ក្សត្រីខាធើរីនបានពង្រីកចក្រភពរុស្ស៊ីយ៉ាងធំ។ ទន្ទឹមនឹងនេះដែរ នៅខណៈពេលប្រទេសរុស្ស៊ីក្លាយជាមហាអំណាចអន្តរជាតិ មហាអំណាចមួយទៀតគឺចក្រភពអង់គ្លេសបានប្រឈមមុខនឹងបញ្ហាពីសំណាក់ដែនដីអាណានិគមរបស់ខ្លួននៅអាមេរិកខាងជើង។ បំផុសគំនិតដោយទស្សនសករាជពន្លឺ មេដឹកនាំអាណានិគមបានសម្រេចចិត្តធ្វើរឿងមួយដែលមិននឹកស្មានដល់៖ បំបែកចេញពីការគ្រប់គ្រងរបស់ពួកគេ ហើយបង្កើតសាធារណរដ្ឋឯករាជ្យមួយ។

# មេរៀនទី 4៖ បដិវត្តនៅអាមេរិក

ទស្សនវិទូដូចជាលោកវ៉ុលទែរ បានចាត់ទុករដ្ឋាភិបាលរបស់ប្រទេសអង់គ្លេសថាជារដ្ឋាភិបាលដែលមានការរីកចម្រើនបំផុតនៅអឺរ៉ុប។ បដិវត្តរុងរឿងនៃឆ្នាំ 1688 បានផ្តល់ឱ្យប្រទេសអង់គ្លេសនូវរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញមួយ។ នៅក្នុងខ្លឹមសារនៃធម្មនុញ្ញ បានចែងនូវច្បាប់ផ្សេងៗ ដើម្បីកំណត់អំណាចរបស់ព្រះមហាក្សត្រអង់គ្លេស។ ប៉ុន្តែ ទោះបីជាមានការយល់ឃើញរបស់ទស្សនវិទូបែបនេះក៏ដោយ ដែនដីអាណានិគមរបស់អង់គ្លេសជាច្រើននៅអាមេរិកខាងជើងបានចោទប្រកាន់ប្រទេសអង់គ្លេសពីការគ្រប់គ្រងបែបទុច្ចរិត។ ជំរុញដោយទស្សនសករាជពន្លឺ ពួកគេបានព្យាយាមក្នុងការផ្តួលរំលំប្រទេសមួយដែលនៅពេលនោះជាមហាអំណាចពិភពលោក ហើយបង្កើតប្រជាជាតិផ្ទាល់ខ្លួនមួយ។

## 1. អង់គ្លេស និងដែនដីអាណានិគមអាមេរិករបស់ពួកគេ

អំឡុងទស្សវត្សរ៍ឆ្នាំ 1600 និងទស្សវត្សរ៍ឆ្នាំ 1700 ពួកអាណានិគមអង់គ្លេសបានតាំងទីលំនៅដ៏ច្រើន និងមានការរីកចម្រើននៅតាមបណ្តោយឆ្នេរភាគខាងកើតនៃអាមេរិកខាងជើង។ នៅពេលដែលព្រះអង្គម្ចាស់ចចទី 3 បានក្លាយជាព្រះមហាក្សត្រនៃចក្រភពអង់គ្លេសនៅឆ្នាំ 1760 ដែនដីអាណានិគមនៅអាមេរិកខាងជើងរបស់ទ្រង់បានរីកចម្រើនដោយលោតផ្លោះ។ ចំនួនប្រជាជនសរុបទាំងអស់បានកើនឡើងពីប្រហែល 250,000 ក្នុងឆ្នាំ 1700 ដល់ 2,150,000 ក្នុងឆ្នាំ 1770 ដែលជាការកើនឡើងជិត 9 ដង។ ខាងផ្នែកសេដ្ឋកិច្ច ដែនដីអាណានិគមបានរីកចម្រើនលើការធ្វើពាណិជ្ជកម្មជាមួយពួកអឺរ៉ុប។ ទន្ទឹមនឹងការកើនឡើងនៃចំនួនប្រជាជន និងវិបុលភាព គំនិតអំពីអត្តសញ្ញាណថ្មីមួយបានកើនឡើងនៅក្នុងគំនិតរបស់ពួកអាណានិគម។ ត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1700 ពួកអាណានិគមបានរស់នៅក្នុងសហរដ្ឋអាមេរិកអស់ជិត 150 ឆ្នាំមកហើយ។ ដែនដីអាណានិគមនីមួយៗក្នុងចំណោមដែនដីអាណានិគមទាំង 13 មានរដ្ឋាភិបាលផ្ទាល់ខ្លួន និងប្រជាជនទទួលបានឯករាជ្យកម្រិតខ្ពស់មួយ។ ពួកអាណានិគមយល់ឃើញថាខ្លួនពួកគេជាជនជាតិអង់គ្លេសតិចជាង ការដែលពួកគេយល់ឃើញថាពួកគេជាពួកវើជីនៀ ឬផេនស៊ីលវ៉ានៀទៅទៀត។ ទោះយ៉ាងណាក៏ដោយ ពួកគេនៅតែជាប្រជាជនរបស់ចក្រភពអង់គ្លេស ហើយត្រូវបានគេរំពឹងថានឹងគោរពតាមច្បាប់របស់ចក្រភពអង់គ្លេស។ នៅឆ្នាំ 1651 សភាតំណាងរាស្ត្រអង់គ្លេសបានអនុម័តច្បាប់ពាណិជ្ជកម្មមួយហៅថាច្បាប់នាវាចរណ៍។ ច្បាប់ពាណិជ្ជកម្មនេះ និងច្បាប់ក្រោយៗមកទៀតបានរារាំងពួកអាណានិគមមិនឱ្យលក់ផលិតផលមានតម្លៃបំផុតរបស់ពួកគេទៅកាន់ប្រទេសណាមួយ លើកលែងតែចក្រភពអង់គ្លេស។ លើសពីនេះ ពួកអាណានិគមត្រូវបង់ពន្ធខ្ពស់លើការនាំចូលទំនិញពីប្រទេសបារាំង និងហូឡង់។ យ៉ាងណាក៏ដោយ គោលនយោបាយរបស់ចក្រភពអង់គ្លេសផ្តល់ប្រយោជន៍ដល់ទាំងដែនដីអាណានិគម និងមាតុប្រទេស។ អង់គ្លេសបានទិញវត្ថុធាតុដើមពីអាមេរិកក្នុងតម្លៃទាប ហើយលក់ផលិតផលសម្រេចឱ្យទៅឱ្យពួកអាណានិគម។ ហើយទោះបីជាមានការរឹតបន្តឹងពាណិជ្ជកម្មរបស់អង់គ្លេសក៏ដោយ ក៏ពួកឈ្មួញនៅដែនដីអាណានិគមមានការរីកចម្រើនផងដែរ។ យ៉ាងណាក៏ដោយ ស្មារតីនៃការភាពសុខដុមបែបនេះ នឹងផ្លាស់ប្តូរភ្លាមៗ។

## 2. អាមេរិកទទួលបានឯករាជ្យ

នៅឆ្នាំ 1754 សង្គ្រាមបានផ្ទុះឡើងនៅអាមេរិកខាងជើងរវាងចក្រភពអង់គ្លេស និងប្រទេសបារាំង។ ដូចដែលអ្នកចងចាំ, ប្រទេសបារាំងក៏បានដាក់អាណានិគមលើផ្នែកខ្លះនៅអាមេរិកខាងជើងនៅអំឡុងទសវត្សរ៍ឆ្នាំ 1600 និង ទសវត្សរ៍ឆ្នាំ 1700 ផងដែរ។ ជម្លោះនេះត្រូវបានគេស្គាល់ថាជាសង្គ្រាមបារាំង និងឥណ្ឌា។ (ឈ្មោះនេះកើតចេញដោយសារ បារាំងបានបញ្ចូលកុលសម្ព័ន្ធជនជាតិអាមេរិកជាច្រើនក្រុមដើម្បីចូលរួមប្រយុទ្ធនៅខាងពួកគេ) ការប្រយុទ្ធគ្នាបានបន្តរហូតដល់ឆ្នាំ 1763 នៅពេលដែលចក្រភពអង់គ្លេស និងអាណានិគមរបស់ពួកគេបានទទួលជ័យជម្នះ ហើយបានដណ្ដើមយកដែនដីអាណានិគមរបស់បារាំងស្ទើរតែទាំងអស់នៅអាមេរិកខាងជើង។ យ៉ាងណាមិញ ការទទួលជ័យជម្នះនេះ បានត្រឹមតែនាំឱ្យមានភាពតានតឹងកាន់តែខ្លាំងរវាងចក្រភពអង់គ្លេស និងដែនដីអាណានិគមរបស់ខ្លួន។ ដើម្បីប្រយុទ្ធនៅក្នុងសង្គ្រាម ចក្រភពអង់គ្លេសបានជំពាក់បំណុលដ៏ច្រើន។ ដោយសារតែពួកអាណានិគមនៅអាមេរិកទទួលបានផលប្រយោជន៍ពីជ័យជំនះរបស់ចក្រភពអង់គ្លេស ចក្រភពអង់គ្លេសរំពឹងទុកពួកអាណានិគមនឹងជួយបង់ថ្លៃចំណាយនៅក្នុងសង្គ្រាមនេះ។ នៅឆ្នាំ 1765 សភាបានអនុម័តច្បាប់បោះត្រា។ យោងតាមច្បាប់នេះ ពួកអាណានិគមត្រូវបង់ពន្ធ ដើម្បីបោះត្រាផ្លូវការលើបណ្ណាំមរតក, ប្លង់អចលនទ្រព្យ, កាសែត, និងឯកសារបោះពុម្ពផ្សេងទៀត។ ពួកអាណានិគមអាមេរិកបានខឹងសម្បារយ៉ាងខ្លាំងចំពោះច្បាប់នេះ។ ពីមុនមកពួកគេមិនដែលបង់ប្រាក់ពន្ធដោយផ្ទាល់ទៅរដ្ឋាភិបាលអង់គ្លេសឡើយ។ ពួកមេធាវីអាណានិគមបានអះអាងថាពន្ធប្រថាប់ត្រាបានរំលោភលើសិទ្ធិធម្មជាតិរបស់ពួកអាណានិគម ហើយពួកគេបានចោទប្រកាន់រដ្ឋាភិបាលពី "ការយកពន្ធដោយគ្មានហេតុផល" ។ នៅចក្រភពអង់គ្លេស ប្រជាពលរដ្ឋបានយល់ស្របលើការយកពន្ធនេះ តាមរយៈតំណាងរបស់ពួកគេនៅក្នុងសភាតំណាងរាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ពួកអាណានិគមមិនមានតំណាងនៅក្នុងសភាទេ។ ដូច្នេះហើយបានជាពួកគេប្រកែកថាមិនអាចយកពន្ធបានទេ។

ការកើនឡើងនៃអរិភាពនាំឱ្យមានសង្គ្រាម៖ ក្នុងរយៈពេលមួយទសវត្សរ៍ក្រោយមក អរិភាពរវាងភាគីទាំងពីរបានកើនឡើង។ នៅដែនដីអាណានិគមខ្លះ មេដឹកនាំបានគាំទ្រឱ្យមានឯករាជ្យភាពពីចក្រភពអង់គ្លេស។ នៅឆ្នាំ 1773 ដើម្បីតវ៉ាទៅនឹងការយកពន្ធនាំចូលលើតែ ពួកអាណានិគមមួយក្រុមបានបោះចោលតែដ៏ច្រើនសន្ធឹកសន្ធាប់របស់អង់គ្លេសចូលទៅក្នុងទឹកនៅកំពង់ផែបូស្តុន។ ព្រះអង្គម្ចាស់ចចទី 3, មានការខឹងសម្បារទៅនឹងអ្វីគេហៅថា "ពិធីជប់លៀងតែបូស្តុន" និងបានបញ្ជាឱ្យកងទ័ពជើងទឹកអង់គ្លេសបិទកំពង់ផែបូស្តុន។ យុទ្ធសាស្ត្រឃោរឃៅរបស់អង់គ្លេសបែបនេះ បានធ្វើឱ្យមនុស្សជាច្រើននៅដែនដីអាណានិគមក្លាយជាសត្រូវរបស់អង់គ្លេស។ នៅខែកញ្ញាឆ្នាំ 1774 អ្នកតំណាងមកពីគ្រប់ដែនដីអាណានិគម លើកលែងតែហ្សកហ្ស៊ី បានប្រមូលផ្តុំគ្នានៅទីក្រុងហ្វីឡាដេលហ្វៀដើម្បីរៀបចំសមាជទ្វីបលើកទីមួយ។ ក្រុមនេះប្រឆាំងនឹងការអនុវត្តនៅបូស្តុន។ នៅពេលដែលព្រះមហាក្សត្រអង់គ្លេស យកចិត្តទុកដាក់តិចតួចចំពោះកង្វល់របស់ពួកគេ ពួកអាណានិគមបានសម្រេចចិត្តក្នុងរៀបចំសមាជទ្វីបលើកទីពីរ ដើម្បីពិភាក្សាអំពីវិធានការបន្ទាប់របស់ពួកគេ។ នៅថ្ងៃទី 19 ខែមេសា ឆ្នាំ 1775 ទាហានចក្រភពអង់គ្លេស និងកងជីវពលអាមេរិកបានបាញ់ប្រហារទៅភូមិបៃតង ក្នុងទីក្រុង លេស៊ីងតុន នៃរដ្ឋម៉ាសាឆូសេតស៍ ។ ការប្រយុទ្ធគ្នានេះ បានរីករាលដាលដល់តំបន់ខុនខដ ដែលស្ថិតនៅក្បែរនោះ។ សមាជទ្វីបលើក

ទីពីរ បានបោះឆ្នោតឱ្យមានការកេណ្ឌកងទ័ព និងរៀបចំការប្រយុទ្ធក្រោមបញ្ជាការរបស់លោកចច វ៉ាស៊ីនតុន ។ បដិវត្តអាមេរិចបានចាប់ផ្តើមឡើង។

ឥទ្ធិពលនៃសករាជពន្លឺ៖ ពួកមេដឹកនាំអាណានិគមបានប្រើទស្សនសករាជពន្លឺដើម្បីបង្ហាញពីឯករាជ្យភាពរបស់ពួកគេ។ ពួកអាណានិគមបានស្នើសុំឱ្យមានសិទ្ធិនយោបាយដូចជាប្រជាជននៅអង់គ្លេសដែរ ប៉ុន្តែព្រះមហាក្សត្របានបដិសេធយ៉ាងដាច់ខាត។ ដូច្នេះ ពួកអាណានិគមមានសិទ្ធិនៅក្នុងការបះបោរប្រឆាំងនឹងពួកផ្តាច់ការ ដែលបានបំពានលើកិច្ចសន្យាសង្គម។ នៅខែកក្កដា ឆ្នាំ 1776 សមាជទ្វីបលើកទីពីរបានចេញសេចក្តីប្រកាសឯករាជ្យ។ សេចក្តីប្រកាសនេះសរសេរឡើងដោយមេដឹកនាំនយោបាយមួយរូបឈ្មោះថូម៉ាស់ ជេហ្វើសុន ដោយផ្អែកលើគំនិតរបស់លោកចន ឡុក និងទស្សនសករាជពន្លឺ។ សេចក្តីថ្លែងការណ៍បានឆ្លុះបញ្ចាំងពីទស្សនទាំងនេះ នៅក្នុងអំណះអំណាងដ៏ឧឡារិកសម្រាប់សិទ្ធិធម្មជាតិ។ សេចក្តីផ្តើមនៃសេចក្តីប្រកាសចែងថា "យើងចង់ឱ្យការពិតទាំងនេះត្រូវបានបង្ហាញឱ្យឃើញដោយខ្លួនឯង មនុស្សទាំងឡាយត្រូវបានបង្កើតឡើងដោយស្មើភាពគ្នា ដែលពួកគេត្រូវបានផ្តល់ឱ្យដោយអ្នកបង្កើតពួកគេនូវសិទ្ធិដែលមិនអាចកាត់ផ្តាច់បាន ដែលនៅក្នុងចំណោមនោះរួមមាន ជីវិត, សេរីភាព, និងការស្វែងរកសុភមង្គល។ ដោយសារ លោកចន ឡុកបានអះអាងថាមនុស្សមានសិទ្ធិបះបោរប្រឆាំងនឹងអ្នកគ្រប់គ្រងអយុត្តិធម៌ សេចក្តីប្រកាសឯករាជ្យបានរួមបញ្ចូលនូវបញ្ជីដ៏វែងនៃការបំពានរបស់ព្រះអង្គម្ចាស់ចចទី 3 ។ ឯកសារនេះបានបញ្ចប់ដោយការប្រកាសបំបែកដែនដីអាណានិគមពីចក្រភពអង់គ្លេស។ សេចក្តីថ្លែងការណ៍បាននិយាយថា ដែនដីអាណានិគម "បានដកភក្តីភាពទាំងអស់ចេញពីមកុដរបស់អង់គ្លេស" ។

### 3. ជោគជ័យសម្រាប់ពួកអាណានិគម

ចក្រភពអង់គ្លេសមិនមានបំណងចង់ឱ្យដែនដីអាណានិគមរបស់ពួកគេ ចាកចេញដោយគ្មានការប្រយុទ្ធនោះទេ។ មិនយូរប៉ុន្មានបន្ទាប់ពីផ្សព្វផ្សាយសេចក្តីប្រកាសឯករាជ្យ ភាគីទាំង 2 បានធ្វើសង្គ្រាមជាមួយគ្នា។ នៅជំហានដំបូង, ពួកអាណានិគមអាមេរិកហាក់ដូចជាឆ្ពោះទៅរកភាពបរាជ័យ។ កងទ័ពដែលទទួលបានការហ្វឹកហ្វឺនមិនល្អរបស់ក្រុងវ៉ាស៊ីនតោនបានប្រឈមមុខនឹងកងកម្លាំងដែលបានហ្វឹកហ្វឺនយ៉ាងល្អរបស់អង់គ្លេស ដែលជាប្រទេសដែលមានឥទ្ធិពលបំផុតនៅលើពិភពលោក។ ទោះជាយ៉ាងណាក៏ដោយនៅទីបញ្ចប់ ពួកអាមេរិកបានបានឈ្នះសង្គ្រាមដើម្បីឯករាជ្យរបស់ពួកគេ។ មានហេតុផលជាច្រើនដែលពន្យល់ពីភាពជោគជ័យរបស់ពួកអាណានិគម។ ទីមួយ ការលើកទឹកចិត្តរបស់ប្រជាជនអាមេរិកសម្រាប់ការប្រយុទ្ធគឺមានច្រើនជាងពួកអង់គ្លេសទៅទៀត ព្រោះកងទ័ពរបស់គេកំពុងការពារមាតុភូមិ។ ទីពីរ ដោយសារមានទំនុកចិត្តខ្លាំងពេកឧត្តមសេនីយ៍អង់គ្លេសបានបង្កកំហុសជាច្រើន។ ទីបី ពេលវេលា គឺស្ថិតនៅលើដៃរបស់ពួកអាមេរិក។ ចក្រភពអង់គ្លេសអាចឈ្នះការប្រយុទ្ធពីសមរភូមិមួយទៅសមរភូមិ ប៉ុន្តែពួកគេនៅតែចាញ់សង្គ្រាម។ ការប្រយុទ្ធនៅក្នុងសង្គ្រាមនៅក្រៅប្រទេសដែលមានចម្ងាយ 3,000 ម៉ាយពីទីក្រុងឡុងដ៍មានការចំណាយខ្ពស់ណាស់។ ប៉ុន្មានឆ្នាំក្រោយមក ពលរដ្ឋអង់គ្លេសដែលបានចំណាយលើការបង់ពន្ធបានអំពាវនាវឱ្យមានសន្តិភាព។ ទីបំផុត ពួកអាមេរិកមិនបានប្រយុទ្ធតែម្នាក់ឯងទេ។ ព្រះអង្គម្ចាស់ល្វីទី 16 នៃប្រទេសបារាំងបានយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះចំពោះគំនិតបដិវត្តរបស់អាមេរិក។

ប៉ុន្តែ ទ្រង់ចង់ធ្វើឱ្យគូប្រជែងរបស់បារាំងគឺចក្រភពអង់គ្លេសចុះខ្សោយ។ ការចូលទៅក្នុងសង្គ្រាមរបស់បារាំងនៅឆ្នាំ 1778 គឺជាការធ្វើឡើងជាចាំបាច់។ នៅឆ្នាំ 1781 កងកម្លាំងចម្រុះរបស់អាមេរិកប្រហែល 9,500 នាក់ និងបារាំងចំនួន 7,800 នាក់បានឡោមព័ទ្ធមេបញ្ជាការកងទ័ពអង់គ្លេសឈ្មោះលដ ខនវ៉ាល់លីស និងជិតទីក្រុងយ៉កថោន រដ្ឋវីជីនៀ។ ដោយមិនអាចគេចខ្លួនបានចុងក្រោយ ខនវ៉ាល់លីស បានចុះចាញ់។ ជនជាតិអាមេរិកបានធ្វើឱ្យពិភពលោកភ្ញាក់ផ្អើល និងបានឈ្នះឯករាជ្យរបស់ពួកគេ។

### 4. អាមេរិកបង្កើតសាធារណរដ្ឋមួយ

ភ្លាមៗបន្ទាប់ពីការប្រកាសឯករាជ្យរបស់ពួកគេ រដ្ឋទាំង 13 បានទទួលស្គាល់អំពីតម្រូវការសម្រាប់រដ្ឋាភិបាលជាតិមួយ។ នៅពេលដែលជ័យជម្នះមានភាពពិតប្រាកដ រដ្ឋទាំង 13 បានផ្តល់សច្ចាប័នលើរដ្ឋធម្មនុញ្ញនៅឆ្នាំ 1781 ។ គម្រោងនៃការបង្កើតរដ្ឋាភិបាលនេះត្រូវបានគេស្គាល់ថា មាត្រានៃសហព័ន្ធ។ មាត្រានេះបានបង្កើតសហរដ្ឋអាមេរិកដែលជាប្រទេសបែបសាធារណរដ្ឋ ដែលមានរដ្ឋាភិបាលមួយគ្រប់គ្រងដោយពលរដ្ឋ តាមរយៈបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។

រដ្ឋាភិបាលជាតិដែលទន់ខ្សោយ៖ ដើម្បីការពារសិទ្ធិអំណាចរបស់ពួកគេ រដ្ឋទាំង 13 បានបង្កើតសហភាពធូរលុងមួយ ដែលរដ្ឋនៅក្នុងសហព័ន្ធនីមួយៗនៅបន្តគ្រប់គ្រងអំណាចភាគច្រើន។ ដូច្នេះ មាត្រានៃសហព័ន្ធមានចេតនាបង្កើតរដ្ឋាភិបាលជាតិទន់ខ្សោយមួយ។ គ្មានស្ថាប័ននីតិប្រតិបត្តិ ឬតុលាការទេ។ ផ្ទុយទៅវិញ មាត្រាបានបង្កើតស្ថាប័នរដ្ឋាភិបាលតែមួយគត់គឺសភា។ រដ្ឋនីមួយៗ ដោយមិនគិតពីទំហំ មានសំលេងឆ្នោតតែមួយដូចគ្នានៅក្នុងសភា។ សភាអាចប្រកាសសង្គ្រាម, ចុះសន្ធិសញ្ញា និងបោះពុម្ពប្រាក់។ ទោះយ៉ាងណាក៏ដោយ ស្ថាប័ននេះគ្មានអំណាចដើម្បីប្រមូលពន្ធ ឬគ្រប់គ្រងពាណិជ្ជកម្មឡើយ។ ការអនុម័តច្បាប់ថ្មីគឺមានភាពពិបាក ព្រោះច្បាប់ត្រូវការការអនុម័តពីរដ្ឋចំនួន 9 ក្នុងចំណោមរដ្ឋទាំង 13 ។ ការកម្រិតលើរដ្ឋាភិបាលជាតិទាំងនេះ មិនយូរប៉ុន្មានបានបង្កើតបញ្ហាជាច្រើន។ ទោះបីជារដ្ឋាភិបាលជាតិថ្មីត្រូវការលុយដើម្បីដំណើរការក៏ដោយ ពួកគេបានត្រឹមស្នើតែសុំការរួមចំណែកពីរដ្ឋនានាតែប៉ុណ្ណោះ។ អតីតយុទ្ធជនសង្គ្រាមបដិវត្តបានត្អូញត្អែរថាសភានៅតែជំពាក់ប្រាក់សំណងសម្រាប់សេវាកម្មរបស់ពួកគេ។ ទន្ទឹមនឹងនេះ រដ្ឋមួយចំនួនបានបោះពុម្ពលុយផ្ទាល់ខ្លួន។ រដ្ឋខ្លះថែមទាំងយកពន្ធលើទំនិញពីរដ្ឋជិតខាងទៀតផង។

រដ្ឋធម្មនុញ្ញថ្មីមួយ៖ មេដឹកនាំដែនដីអាណានិគមនៅទីបំផុតបានទទួលស្គាល់តម្រូវការរដ្ឋាភិបាលជាតិដ៏រឹងមាំមួយ។ នៅខែកុម្ភៈឆ្នាំ 1787 សភាបានអនុម័តអនុសញ្ញាធម្មនុញ្ញមួយដើម្បីកែសម្រួលមាត្រានៃសហព័ន្ធ។ អនុសញ្ញាធម្មនុញ្ញបានបើកសម័យប្រជុំលើកដំបូងនៅថ្ងៃទី 25 ខែឧសភា ឆ្នាំ 1787 ។ ប្រតិភូចំនួន 55 នាក់គឺជារដ្ឋបុរសដែលមានបទពិសោធន៍ និងធ្លាប់ស្គាល់ពីទ្រឹស្តីនយោបាយរបស់ចន ឡុក, ម៉ុងតេស្គីយ៉ឺ, និងរ៉ូសស្សូ។ ទោះបីជាគណៈប្រតិភូបានយល់ស្របគ្នាទៅគំនិតជាមូលដ្ឋានអំពីរដ្ឋាភិបាលក៏ដោយ ពេលខ្លះពួកគេមិនយល់ស្របលើរបៀបនៃការដាក់វាឱ្យអនុវត្ត។ អស់រយៈពេលជិត 4 ខែដែលប្រតិភូបានពិភាក្សាលើសំណួរសំខាន់ៗ។ តើអ្នកណាគួរត្រូវជ្រើសរើសធ្វើជាតំណាងនៅក្នុងសភា? តើរដ្ឋនីមួយៗគួរមានតំណាងប៉ុន្មាននាក់? ការពិភាក្សារបស់គណៈ

ប្រតិភូមិនត្រឹមតែបង្កើតឱ្យមានការសម្របសម្រួលប៉ុណ្ណោះទេ ប៉ុន្តែក៏មានវិធីសាស្ត្រថ្មីក្នុងការគ្រប់គ្រងផងដែរ។ ដោយប្រើគំនិតនយោបាយនៃសករាជពន្លឺ គណៈប្រតិភូបានបង្កើតប្រព័ន្ធរដ្ឋាភិបាលថ្មីមួយ។

ប្រព័ន្ធសហព័ន្ធ៖ ក៏ដូចជាម៉ុងតេស្គីយឺ ប្រតិភូមិនទុកចិត្តរដ្ឋាភិបាលកណ្តាល ដែលគ្រប់គ្រងដោយមនុស្សតែម្នាក់ ឬក្រុមមួយឡើយ។ ដូច្នេះហើយ ពួកគេបានបង្កើតសាខាបីដាច់ដោយឡែកពីគ្នា គឺនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ ការរៀបចំនេះបានផ្តល់នូវប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាព ដែលភ្ជាប់មកជាមួយសាខានីមួយៗ ដើម្បីពិនិត្យមើលសកម្មភាពរបស់សាខាពីរផ្សេងទៀត។ ជាឧទាហរណ៍ ប្រធានាធិបតីបានទទួលអំណាចក្នុងការវេតូច្បាប់ទាំងឡាយដែលអនុម័តដោយសភា។ ប៉ុន្តែ សភាក៏អាចបដិសេធការវេតូរបស់ប្រធានាធិបតីដោយមានការយល់ព្រមពីសមាជិកពីរភាគបីនៃតំណាងរាស្ត្រក្នុងសភា។ បើទោះបីជារដ្ឋធម្មនុញ្ញបានបង្កើតរដ្ឋាភិបាលកណ្តាលដ៏រឹងមាំក៏ដោយ ក៏វាមិនបានលុបបំបាត់រដ្ឋាភិបាលមូលដ្ឋានឡើយ។ ផ្ទុយទៅវិញ រដ្ឋធម្មនុញ្ញបានបង្កើតប្រព័ន្ធសហព័ន្ធ ដែលអំណាចត្រូវបានបែងចែករវាងរដ្ឋាភិបាលជាតិ និងរដ្ឋ។

ច្បាប់ស្តីអំពីសិទ្ធិ៖ ប្រតិភូបានចុះហត្ថលេខាលើរដ្ឋធម្មនុញ្ញថ្មីនៅថ្ងៃទី 17 ខែកញ្ញា ឆ្នាំ 1787។ ទោះជាយ៉ាងណាក៏ដោយដើម្បីក្លាយជាច្បាប់ រដ្ឋធម្មនុញ្ញតម្រូវឱ្យមានការអនុម័តដោយអនុសញ្ញានៅក្នុងរដ្ឋយ៉ាងហោចណាស់ 9 ក្នុងចំណោមរដ្ឋទាំង 13 ។ អនុសញ្ញាទាំងនេះត្រូវបានសម្គាល់ដោយការជជែកដេញដោលយ៉ាងមុតស្រួច។ អ្នកគាំទ្ររដ្ឋធម្មនុញ្ញត្រូវបានគេហៅថាអ្នកសហព័ន្ធនិយម។ នៅក្នុងស្នាដៃដ៏ល្បីល្បាញរបស់ពួកគេគឺ កាសែតសហព័ន្ធ ពួកគេបានទាមទារឱ្យរដ្ឋាភិបាលថ្មីត្រូវតែផ្តល់នូវតុល្យភាពកាន់តែប្រសើរឡើងរវាងអំណាចជាតិ និងរដ្ឋ។ គូបដិបក្ខរបស់ពួកគេ គឺពួកប្រឆាំងសហព័ន្ធនិយម ខ្លាចថារដ្ឋធម្មនុញ្ញបានផ្តល់អំណាចដល់រដ្ឋាភិបាលកណ្តាលច្រើនពេក។ ពួកគេក៏ចង់បានច្បាប់ស្តីអំពីសិទ្ធិនានាដើម្បីការពារសិទ្ធិរបស់ពលរដ្ឋម្នាក់ៗ។ ដើម្បីទទួលបានការគាំទ្រ សហព័ន្ធបានសន្យាថានឹងបន្ថែមច្បាប់ស្តីអំពីសិទ្ធិទៅក្នុងរដ្ឋធម្មនុញ្ញ។ ការសន្យានេះបានបើកផ្លូវសម្រាប់ការអនុម័ត។ សភាបានបន្ថែមជាផ្លូវការទៅក្នុងរដ្ឋធម្មនុញ្ញនូវវិសោធនកម្មទីដប់ដែលគេស្គាល់ថាជាច្បាប់ស្តីអំពីសិទ្ធិ។ វិសោធនកម្មទាំងនេះបានការពារសិទ្ធិជាមូលដ្ឋានដូចជា សេរីភាពក្នុងការបញ្ចេញមតិ, សារព័ត៌មាន, ការជួបប្រជុំ, និងសាសនា។ ភាគច្រើននៃសិទ្ធិទាំងនេះ ត្រូវបានតស៊ូមតិដោយវ៉ុលទែរ, រ៉ូសសូ, និងឡុក។ រដ្ឋធម្មនុញ្ញ និងច្បាប់នៃសិទ្ធិបានបង្ហាញពីរបត់នៃគំនិតរបស់ប្រជាជនអំពីរដ្ឋាភិបាល។ ឯកសារទាំងពីរនេះបានដាក់ទស្សនសករាជពន្លឺទៅក្នុងការអនុវត្ត។ ពួកគេបានសម្តែងនូវទស្សនសុទិដ្ឋិនិយមថា ហេតុផល និងការកែទម្រង់អាចទទួលបានជ័យជំនះ ហើយវឌ្ឍនភាពនឹងជៀសមិនរួច។ សុទិដ្ឋិនិយមបែបនេះបានសាយភាយពេញតំបន់អាត្លង់ទិក។ ទោះជាយ៉ាងណា រាជាធិបតេយ្យ និងវណ្ណៈឯកសិទ្ធិមិនបោះបង់អំណាច និងមុខតំណែងពួកគេដោយងាយនោះទេ។ ដូចដែលជំពូកទី 22 នឹងពន្យល់ពីការតស៊ូដើម្បីសម្រេចបាននូវគោលការណ៍នៃសករាជពន្លឺ ដែលឈានដល់បដិវត្តហិង្សាមួយនៅប្រទេសបារាំង។

# ជំពូក 22 ៖ បដិវត្តនៅបារាំង និងណាប៉ូឡេអុង 1789-1815

## មេរៀនទី 1 ៖ ការចាប់ផ្តើមឡើងនៃបដិវត្តនៅបារាំង

នៅក្នុងទសវត្សរ៍ឆ្នាំ 1700 ប្រទេសបារាំងត្រូវបានគេចាត់ទុកថាជាប្រទេសជឿនលឿនបំផុតមួយនៅទ្វីបអឺរ៉ុប។ ប្រទេសនេះមានប្រជាជនច្រើន និងមានពាណិជ្ជកម្មអន្តរជាតិរីកចម្រើន។ វាជាមជ្ឈមណ្ឌលនៃសកករាជពន្លឺ ហើយវប្បធម៌របស់បារាំងត្រូវបានគេសរសើរជាទូទៅ ហើយពិភពលោកទាំងមូលបានយកតម្រាប់តាម។ ប៉ុន្តែ រូបរាងនៃភាពជោគជ័យគ្រាន់តែជាការបញ្ឆោតប៉ុណ្ណោះ។ មានភាពចលាចលយ៉ាងខ្លាំងនៅក្នុងប្រទេសបារាំង ដែលបណ្តាលមកពីការប្រមូលផលមិនល្អ, តម្លៃទំនិញខ្ពស់, ពន្ធខ្ពស់, និងការចោទសួរជាច្រើនដែលលេចឡើងដោយទស្សនសកករាជពន្លឺរបស់ឡុក, រ៉ូសសូ, និងវ៉ុលទែរ។

### 1. សណ្តាប់ធ្នាប់ចាស់

នៅទសវត្សរ៍ឆ្នាំ 1770 ប្រព័ន្ធសង្គម និងនយោបាយនៃប្រទេសបារាំង - របបចាស់ - នៅតែបន្តអនុវត្ត។ នៅក្រោមប្រព័ន្ធនេះ ប្រជាជនបារាំងត្រូវបានបែងចែកជាវណ្ណៈសង្គម ឬម្ចាស់កម្មសិទ្ធិដីធ្លី 3 ធំៗ។

ឯកសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិដីធ្លី៖ វណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លី 2 ដំបូង ទទួលបានឯកសិទ្ធិនានា រួមមានទាំងការធ្វើការនៅក្នុងការិយាល័យខ្ពស់ និងការលើកលែងពីការបង់ពន្ធ ដែលវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 មិនទទួលបានឡើយ។ ពួកបព្វជិតព្រះវិហាររ៉ូម៉ាំងកាតូលិកស្ថិតនៅក្នុងវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 1 ដោយកាន់កាប់ 10 ភាគរយនៃផ្ទៃដីសរុបនៅក្នុងប្រទេសបារាំង។ ពួកគេបានផ្តល់សេវាអប់រំ និងសេវាជំនួយដល់ជនក្រីក្រ និងបានផ្តល់នូវប្រាក់ចំណូលរបស់ខ្លួនប្រហែល 2 ភាគរយដល់រដ្ឋាភិបាល។ វណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 2 គ្របដណ្តប់ដោយពួកអភិជន។ ទោះបីជាពួកគេមានចំនួនត្រឹមតែ 2 ភាគរយនៃចំនួនប្រជាជនក៏ដោយ ប៉ុន្តែពួកអភិជនបានកាន់កាប់ដីប្រមាណ 20 ភាគរយ ហើយស្ទើរតែមិនបានបង់ពន្ធទល់តែសោះ។ ភាគច្រើននៃពួកបព្វជិត និងពួកអភិជនបានមើលងាយទស្សនសកករាជពន្លឺថាជាទស្សនជ្រុលនិយមដែលគំរាមកំហែងដល់ឋានៈ និងអំណាចរបស់ពួកគេជាបុគ្គលមានឯកសិទ្ធិ។

វណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 ៖ ប្រហែល 97 ភាគរយនៃប្រជាជនស្ថិតនៅក្នុងវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 ។ ក្រុម 3 ដែលស្ថិតនៅក្នុងវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 នេះមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងលក្ខខណ្ឌសេដ្ឋកិច្ចរបស់ពួកគេ។ ក្រុមទី 1 ពួកប៊ូស្វាហ្ស៊ី ឬវណ្ណៈកណ្តាល ភាគច្រើនគឺជាធនាគារិក, ម្ចាស់រោងចក្រ, ពាណិជ្ជករ, អ្នកជំនាញ, និងសិប្បករជំនាញ។ ជាទូទៅ ពួកគេទទួលបានការអប់រំយ៉ាងល្អ ហើយមានជំនឿយ៉ាងមុតមាំលើទស្សនសកករាជពន្លឺអំពីសេរីភាព និងសមភាព។ ថ្វីត្បិតតែពួកប៊ូស្វាហ្ស៊ីខ្លះជាអ្នកមានដូចជាពួកអភិជនក៏ដោយ ក៏ពួកគេបានបង់ពន្ធខ្ពស់ ហើយក៏ដូចជាអ្នកផ្សេងទៀតនៅក្នុងវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 ដែរ គឺមិនមានឯកសិទ្ធិ។ មនុស្សជាច្រើនមានអារម្មណ៍ថា ទ្រព្យសម្បត្តិរបស់ពួកគេជាអ្នកផ្តល់សិទ្ធិឱ្យពួកគេក្នុងការទទួលបានកម្រិតកាន់តែខ្ពស់នៃឋានៈសង្គម និងអំណាចនយោបាយ។ កម្មករនៃទីក្រុងនានារបស់ប្រទេសបារាំងបានស្ថិតនៅក្នុងក្រុមទី 2 និង

ជាអ្នកក្រីក្របំផុតនៅក្នុងនៃវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 ។ កម្មករនៅទីក្រុងទាំងនេះរួមមាន ឈ្មួញតូចតាច, កូនជាង, កម្មករ, និងអ្នកបម្រើតាមផ្ទះ។ ទទួលបានប្រាក់ខែតិច ហើយជាញឹកញាប់មិនមានការងារធ្វើ ដែលបណ្តាលឱ្យពួកគេតែងតែហូបចុកមិនគ្រប់គ្រាន់។ ប្រសិនបើតម្លៃនំប៉័ងកើនឡើង ហ្វូងកម្មករទាំងនេះអាចវាយប្រហាររទេះដឹកគ្រាប់ធញ្ញជាតិ និងហាងនំប៉័ង ដើម្បីលួចរបស់ដែលពួកគេត្រូវការ។ កសិករគឺជាក្រុមធំជាងគេនៅក្នុងវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 ដែលមានចំនួនច្រើនជាង 80% នៃចំនួនប្រជាជនបារាំងសរុប 26 លាននាក់។ កសិករបានបង់ប្រាក់បំណុលប្រហែលពាក់កណ្ដាលនៃប្រាក់ចំណូលរបស់ពួកគេដល់ពួកអភិជន 1/10 ដល់សាសនាចក្រ និងបង់ពន្ធដល់ភ្នាក់ងាររបស់ព្រះមហាក្សត្រ។ ពួកគេថែមទាំងបានបង់ពន្ធបន្ថែមលើទំនិញមួយចំនួនដូចជាអំបិលជាដើម។ កសិករ និងអ្នកក្រីក្រក្នុងទីក្រុងមានការមិនសប្បាយចិត្តចំពោះពួកបព្វជិត និងពួកអភិជនចំពោះឯកសិទ្ធិ និងយកចិត្តទុកដាក់ជាពិសេសលើពួកគេ។ វណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីទី 3 ដែលជាប់ពន្ធខ្ពស់ និងមានការមិនសប្បាយចិត្តនោះ មានបំណងចង់ផ្លាស់ប្តូរ។

## 2. កម្លាំងនៃការផ្លាស់ប្តូរ

បន្ថែមពីលើការអាក់អន់ចិត្តកាន់តែខ្លាំងឡើងក្នុងចំណោមពួកវណ្ណៈជាន់ទាប កត្តាផ្សេងទៀតបានរួមចំណែកដល់គំនិតបដិវត្តនៅប្រទេសបារាំង។ គំនិតថ្មីៗអំពីរដ្ឋាភិបាល, បញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរ, និងភាពជាអ្នកដឹកនាំទន់ខ្សោយ និងមិនច្បាស់លាស់ សុទ្ធតែបានជួយបង្កើតឱ្យមានបំណងប្រាថ្នាមួយសម្រាប់ការផ្លាស់ប្តូរ។

ទស្សនសករាជពន្លឺ៖ ទស្សនៈថ្មីៗអំពីអំណាច និងសិទ្ធិអំណាចរបស់រដ្ឋាភិបាល បានរីករាលដាលក្នុងចំណោមវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ។ សមាជិកនៃវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ត្រូវបានបំផុសគំនិតដោយភាពជោគជ័យនៃការធ្វើបដិវត្តនៅអាមេរិច។ ពួកគេបានចាប់ផ្តើមចោទសួរអំពីគោលគំនិតជាយូរមកហើយអំពីរចនាសម្ព័ន្ធសង្គម។ ដោយដកស្រង់ពីលោករ៉ូសសូ និងវ៉ុលទែរ ពួកគេបានចាប់ផ្តើមទាមទារឱ្យមានសមភាព, សេរីភាព, និងលទ្ធិប្រជាធិបតេយ្យ។

បញ្ហាសេដ្ឋកិច្ច៖ នៅទស្សវត្សរ៍ឆ្នាំ 1780 សេដ្ឋកិច្ចដែលធ្លាប់រីកចម្រើនរបស់ប្រទេសបារាំងបានធ្លាក់ចុះ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចនេះបានបង្កការភ្ញាក់ផ្អើលជាខ្លាំង ជាពិសេសក្នុងចំណោមអាជីវករ, ម្ចាស់រោងចក្រ, និងធនាគារិកនៃវណ្ណៈកម្មសិទ្ធិដីធ្លីទី 3។ មើលពីខាងក្រៅ សេដ្ឋកិច្ចហាក់ដូចជាមានសន្ទុះ ព្រោះទាំងផលិតកម្ម និងពាណិជ្ជកម្មបានរីកចម្រើនយ៉ាងឆាប់រហ័ស។ ប៉ុន្តែ បន្ទុកពន្ធដ៏ធ្ងន់បានធ្វើឱ្យពួកគេស្ទើរតែមិនអាចធ្វើអាជីវកម្មបានផលចំណេញនៅក្នុងប្រទេសបារាំង។ លើសពីនេះ ការចំណាយក្នុងការរស់នៅបានកើនឡើងយ៉ាងខ្លាំង។ ជាងនេះទៅទៀត អាកាសធាតុអាក្រក់ក្នុងទសវត្សរ៍ឆ្នាំ 1780 បានបណ្តាលឱ្យការដាំដុះបរាជ័យ នាំទៅដល់ការខ្វះខាតគ្រាប់ធញ្ញជាតិយ៉ាងធ្ងន់ធ្ងរ។ តម្លៃនំប៉័ងបានកើនឡើងទ្វេដងនៅឆ្នាំ 1789 ហើយមនុស្សជាច្រើនប្រឈមនឹងការអត់ឃ្លាន។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1779 និងឆ្នាំ 1780 រដ្ឋាភិបាលបារាំងបានធ្លាក់ចូលទៅក្នុងបំណុលយ៉ាងច្រើន។ ផ្នែកមួយនៃបញ្ហានេះគឺការចំណាយដ៏ច្រើនលើសលប់របស់ព្រះអង្គម្ចាស់ល្វីទី 16 និងម្ចាស់ក្សត្រីរបស់ទ្រង់ព្រះនាមម៉ារី អង់តូនេតេ ។ ព្រះអង្គម្ចាស់ល្វី ក៏បានទទួលមរតកបំណុលយ៉ាងច្រើនពីស្តេចមុនៗផងដែរ។ ទ្រង់បានខ្ចីប្រាក់យ៉ាងច្រើនដើម្បីជួយពួកបដិវត្តអាមេរិក ក្នុងសង្គ្រាមរបស់ពួកគេប្រឆាំងជាមួយនឹងចក្រភពអង់គ្លេសដែលជាគូ

ប្រដែងដ៏សំខាន់របស់បារាំង។ ហេតុនេះវាបានបង្កើនបំណុលរបស់រដ្ឋាភិបាលជិតពីរដង។ នៅឆ្នាំ 1786 នៅពេលដែលធនាគារិកបដិសេធមិនឱ្យរដ្ឋាភិបាលខ្ចីលុយ ទៀតទេព្រះអងម្ចាស់ល្វីបានប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរ។

អ្នកដឹកនាំខ្សោយ៖ ភាពជាអ្នកដឹកនាំខ្លាំងអាចដោះស្រាយបញ្ហាទាំងនេះ និងបញ្ហាផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គម្ចាស់ល្វីទី 16 មានភាពមិនច្បាស់លាស់នៅក្នុងការបញ្ចប់បញ្ហាទាំងនេះ។ ទ្រង់បានយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះចំពោះទីប្រឹក្សារដ្ឋាភិបាលរបស់ទ្រង់ ហើយមានការយកចិត្តទុកដាក់តិចតួចចំពោះព័ត៌មានលម្អិតអំពីការគ្រប់គ្រង។ ម្ចាស់ក្សត្រីបានត្រឹមតែបន្ថែមបញ្ហារបស់ព្រះអង្គម្ចាស់ល្វីតែប៉ុណ្ណោះ។ ជារឿយៗព្រះនាងបានជ្រៀតជ្រែកក្នុងកិច្ចការរបស់រដ្ឋាភិបាល ហើយជាញឹកញាប់បានផ្តល់ដំបូន្មានមិនល្អដល់ព្រះអង្គម្ចាស់ល្វី។ លើសពីនេះទៅទៀត ដោយសារព្រះនាងម៉ារី អង់តូនេតេ ជាសមាជិកនៃគ្រួសាររាជវង្សនៃប្រទេសអូទ្រីស ដែលជាសត្រូវដ៏យូរលង់របស់ប្រទេសបារាំង ទ្រង់មិនមានប្រជាប្រិយភាពតាំងពីពេលដែលទ្រង់បានឈានជើងចូលក្នុងប្រទេសបារាំង។ អាកប្បកិរិយារបស់ព្រះនាងកាន់តែធ្វើឱ្យស្ថានភាពកាន់តែអាក្រក់ទៅៗ។ ក្នុងនាមជាម្ចាស់ក្សត្រី ព្រះនាងបានចំណាយប្រាក់យ៉ាងច្រើនទៅលើសម្លៀកបំពាក់, គ្រឿងអលង្ការ, ល្បែងស៊ីសង, និងអំណោយផ្សេងៗ ដែលព្រះនាងត្រូវបានគេស្គាល់ថាជា "អ្នកស្រីចំណាយលើសចំណូល"។ ជាជាងកាត់បន្ថយការចំណាយព្រះអង្គម្ចាស់ល្វី មិនបានដោះស្រាយគ្រោះអាសន្ននេះឡើយរហូតដល់ទ្រង់អស់ប្រាក់ពីខ្លួន។ ដំណោះស្រាយរបស់ទ្រង់គឺយកពន្ធលើពួកអភិជន។ ទោះជាយ៉ាងណាក៏ដោយ វណ្ណៈកម្មសិទ្ធិដីធ្លីទី 2 បានបង្ខំឱ្យទ្រង់កោះប្រជុំវណ្ណៈកម្មសិទ្ធិដីធ្លីទូទៅមួយ ដែលជាការជួបប្រជុំគ្នានៃអ្នកតំណាងមកពីវណ្ណៈកម្មសិទ្ធិដីធ្លីទាំង 3 ដើម្បីអនុម័តពន្ធថ្មីមួយ។ កិច្ចប្រជុំនេះជាលើកដំបូងក្នុងរយៈពេល 175 ឆ្នាំត្រូវបានប្រារព្ធឡើងនៅថ្ងៃទី 5 ខែឧសភាឆ្នាំ 1789 នៅវ៉ែកសៃ។

### 3. ដើមដំបូងនៃបដិវត្ត

ពួកបព្វជិត និងពួកអភិជនបានគ្របដណ្តប់លើវណ្ណៈកម្មសិទ្ធិដីធ្លីទូទៅនៅអំឡុងមជ្ឈិមសម័យ ហើយពួកគេរំពឹងថានឹងធ្វើដូច្នេះទៀតនៅក្នុងកិច្ចប្រជុំឆ្នាំ 1789 ។ នៅក្រោមច្បាប់មជ្ឈិមសម័យរបស់សភា ប្រតិភូនៃវណ្ណៈកម្មសិទ្ធិដីធ្លីនីមួយៗបានជួបប្រជុំគ្នាក្នុងសាលដាច់ដោយឡែកមួយដើម្បីបោះឆ្នោត ហើយវណ្ណៈកម្មសិទ្ធិដីធ្លីនីមួយៗមានសំលេងបោះឆ្នោតមួយ។ វណ្ណៈកម្មសិទ្ធិដីធ្លីដែលមានឯកសិទ្ធិទី 1 និងទី 2 តែងតែបោះឆ្នោតចាញ់វណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ជានិច្ចដោយសារពួកគេមានសំលេងច្រើនជាង។

រដ្ឋសភា៖ គណៈប្រតិភូវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ដែលភាគច្រើនជាសមាជិកនៃវណ្ណៈប៊ូស្វាហ្ស៊ី ដែលទស្សនរបស់ពួកគេត្រូវបានសម្រួចដោយសករាជពន្លឺ មានបំណងចង់ធ្វើការផ្លាស់ប្តូរក្នុងរដ្ឋាភិបាល។ ពួកគេបានទទូចឱ្យវណ្ណៈកម្មសិទ្ធិដីធ្លីទាំង 3 ជួបជុំគ្នា ហើយប្រតិភូនីមួយៗមានសំឡេងឆ្នោតមួយ។ ការធ្វើដូច្នេះវានឹងផ្តល់អត្ថប្រយោជន៍ដល់វណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ដែលមានចំនួនប្រតិភូច្រើនស្មើវណ្ណៈកម្មសិទ្ធិដីធ្លី 2 ផ្សេងទៀតរួមបញ្ចូលគ្នា។ ដោយឈរនៅខាងពួកអភិជន ព្រះមហាក្សត្របានបញ្ជាឱ្យវណ្ណៈកម្មសិទ្ធិដីធ្លីទូទៅធ្វើតាមច្បាប់មជ្ឈិមសម័យ។ ទោះយ៉ាងណាក៏ដោយ គណៈប្រតិភូនៃវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 តាំងចិត្តកាន់តែខ្លាំងនៅក្នុងការទាមទារអំណាច។ អ្នក

នាំពាក្យនាំមុខនៅក្នុងការបង្ហាញអំពីទស្សនរបស់ពួកគេ គឺជាអ្នកបួសដែលមានចិត្តអាណិតអាសូរចំពោះបុព្វហេតុរបស់ពួកគេឈ្មោះអេម៉ានូអ៊ែល-ចូសេផ ស៊ីយ៉េស។ នៅក្នុងសុន្ទរកថាដ៏គួរឱ្យភ្ញាក់ផ្អើល លោកស៊ីយ៉េសបានស្នើឱ្យប្រតិភូវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ដាក់ឈ្មោះខ្លួនពួកគេថារដ្ឋសភា ហើយអនុម័តច្បាប់ និងកំណែទម្រង់ក្នុងនាមប្រជាជនបារាំង។ បន្ទាប់ពីការជជែកដេញដោលដ៏ភ្ញាក់ផ្អើលអស់មួយយប់ ប្រតិភូនៃវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 បានយល់ស្របចំពោះគំនិតរបស់ ស៊ីយ៉េស ដោយសំលេងភាគច្រើនលើសលប់។ នៅថ្ងៃទី 17 ខែមិថុនា ឆ្នាំ 1789 ពួកគេបានបោះឆ្នោតបង្កើតរដ្ឋសភា និងបានប្រកាសការបញ្ចប់របបរាជានិយមផ្តាច់មុខ និងការចាប់ផ្តើមនៃរដ្ឋាភិបាលតំណាង។ ការបោះឆ្នោតនេះជាការធ្វើបដិវត្តនដោយចេតនាលើកដំបូង។ បីថ្ងៃក្រោយមក ប្រតិភូវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 បានរកឃើញថាខ្លួនត្រូវបានគេចាក់សោរមិនឱ្យចេញពីបន្ទប់ប្រជុំរបស់ពួកគេ។ ពួកគេបានទម្លាយទ្វារចេញតាមទីលានវាយកូនបាល់មួយ ដោយសន្យាបន្តធ្វើរហូតដល់ពួកគេអាចបង្កើតរដ្ឋធម្មនុញ្ញថ្មីបាន។ ការសន្យានេះត្រូវបានគេស្គាល់ថាជា ពាក្យសម្បថទីលានវាយកូនបាល់។ បន្តិចក្រោយមក ពួកអភិជន និងសមាជិកនៃបព្វជិតដែលពេញចិត្តនឹងកំណែទម្រង់បានចូលរួមជាមួយវណ្ណៈកម្មសិទ្ធិដីធ្លីទី 3 ។ ជាការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ទាំងនេះ ព្រះអង្គម្ចាស់ល្វី បានប្រមូលផ្តុំទាហានស៊ីឈ្នួលផ្ទាំស្វីសរបស់ទ្រង់នៅជុំវិញរាជវាំងវ៉ែកសៃ ។

ការទ្បោមព័ទ្ធពន្ធនាគារបាស្ទីលឡេះ នៅប៉ារីស ពាក្យចចាមអារ៉ាមបានផ្ទុះឡើង។ មនុស្សមួយចំនួនបានលើកឡើងថា ព្រះអង្គម្ចាស់ល្វីមានចេតនាប្រើកម្លាំងយោធាដើម្បីរំលាយរដ្ឋសភា។ អ្នកខ្លះទៀតចោទថាទាហានបរទេសមកក្រុងប៉ារីសដើម្បីសម្លាប់ពលរដ្ឋបារាំង។ ប្រជាជនបានចាប់ផ្តើមប្រមូលផ្តុំអាវុធដើម្បីការពារទីក្រុងប្រឆាំងនឹងការវាយប្រហារ។ នៅថ្ងៃទី 14 ខែកក្កដា ហ្វូងមនុស្សដែលកំពុងស្វែងរកកាំភ្លើង និងអាវុធបានសម្រុកចូលពន្ធនាគារបាស្ទីលឡេដែលជាពន្ធនាគារនៅក្នុងទីក្រុងប៉ារីស។ ហ្វូងមនុស្សបានទ្បោមព័ទ្ធឆ្មាំគុក និងបានដណ្តើមបានការគ្រប់គ្រងអគារ។ ក្រុមអ្នកវាយប្រហារដែលមានការខឹងសម្បារបានវាយប្រហារមេបញ្ជាការពន្ធនាគារ និងឆ្មាំគុកជាច្រើននាក់រហូតដល់ស្លាប់ ហើយបន្ទាប់មកបានដើរដង្ហែរជុំវិញផ្លូវដោយយកក្បាលរបស់ពួកគេដោតនៅលើលំពែង។ ការដួលរលំនៃពន្ធនាគារបាស្ទីលឡេ បានក្លាយជានិមិត្តរូបដ៏អស្ចារ្យមួយនៃបដិវត្តសម្រាប់ប្រជាជនបារាំង។ ចាប់តាំងពីពេលនោះមក នៅថ្ងៃទី 14 ខែកក្កដា ទិវាបាស្ទីលឡេ គឺជាថ្ងៃបុណ្យជាតិរបស់បារាំងដែលស្រដៀងនឹងថ្ងៃទី 4 ខែកក្កដានៅក្នុងសហរដ្ឋអាមេរិក។

## 4. ភាពភ័យខ្លាចដ៏អស្ចារ្យមួយបោកបក់មកលើប្រទេសបារាំង

មិនយូរប៉ុន្មាន ការបះបោរបានរីករាលដាលពីទីក្រុងប៉ារីសចូលទៅដល់ទីជនបទ។ ពីភូមិមួយទៅភូមិមួយមានពាក្យចចាមអារ៉ាមថា ពួកអភិជនជួលអ្នកក្រៅច្បាប់ដើម្បីប្រព្រឹត្តិអំពើភេរវកម្មមកលើកសិករ។ រលកនៃការភ័យស្លន់ស្លោ ដែលត្រូវបានគេហៅថា ការភ័យខ្លាចដ៏អស្ចារ្យ បានកើតមានឡើងនៅជុំវិញប្រទេសបារាំង។ មិនយូរប៉ុន្មាន កសិករក៏ក្លាយជាជនក្រៅច្បាប់ដោយខ្លួនគេផ្ទាល់។ ប្រដាប់ដោយចបផាយដី និងឧបករណ៍កសិកម្មផ្សេងទៀត ពួកគេបានវាយលុកចូលផ្ទះរបស់ពួកអភិជន ហើយបានបំផ្លាញឯកសារច្បាប់ចាស់ ដែលបង្ខំឱ្យពួកគេបង់ពន្ធ។ ក្នុងករណីខ្លះ កសិករបានដុតបំផ្លាញភូមិគ្រឹះរបស់ពួកអភិជនតែម្តង។ នៅខែតុលា ឆ្នាំ 1789 ក្រុមស្ត្រីនៅប៉ារីស

រាប់ពាន់នាក់បានធ្វើកុបកម្មជុំវិញការឡើងថ្លៃនៃនំប៉័ង។ ដោយក្រវីកាំបិត, ពូថៅ, និងអាវុធដ៏ទៃទៀត ក្រុមស្ត្រីទាំងនោះបានដើរដង្ហែរឆ្ពោះទៅរាជវាំងវ៉ែកសៃ។ ជាដំបូង ពួកគេទាមទារឱ្យរដ្ឋសភាចាត់វិធានក្នុងការផ្តល់នំប៉័ង។ បន្ទាប់មក ពួកគេបានបង្វែរកំហឹងទៅលើព្រះមហាក្សត្រ និងម្ចាស់ក្សត្រី។ ពួកគេបានសម្រុកចូលទៅក្នុងវាំងដោយសម្លាប់ឆ្មាំមួយចំនួន។ ក្រុមស្ត្រីបានទាមទារឱ្យព្រះអង្គម្ចាស់ល្វី និងម្ចាស់ក្សត្រីម៉ារី អង់តូនេតេ ត្រឡប់ទៅប៉ារីសវិញ។ នៅពេលនោះ ព្រះអង្គម្ចាស់ល្វីសបានយល់ព្រម។ ប៉ុន្មានម៉ោងក្រោយមក ព្រះមហាក្សត្រ, គ្រួសាររាជវង្ស, និងអ្នកបម្រើបានចាកចេញពីរាជវាំងវ៉ែកសៃ ដោយមិនបានឃើញវិមានដ៏អស្ចារ្យនេះម្តងទៀតឡើយ។ ការចាកចេញរបស់ពួកគេបានបង្ហាញពីការផ្លាស់ប្តូរអំណាច និងកំណែទម្រង់ដ៏ខ្លាំងក្លាមួយនៅក្នុងប្រទេសបារាំង។

# មេរៀនទី 2៖ បដិវត្តនាំមកនូវការធ្វើកំណែទម្រង់ និងភេរវកម្ម

កសិករមិនមែនជាសមាជិកនៃសង្គមបារាំងតែមួយទេដើម្បីមានអារម្មណ៍ភ័យខ្លាចដ៏អស្ចារ្យ។ ពួកអភិជន និងមន្ត្រីនៃព្រះវិហារគ្រីស្តសាសនាក៏មានការភ័យខ្លាចដូចគ្នាដែរ។ នៅទូទាំងប្រទេសបារាំង ក្រុមកសិករខឹងសម្បារបានវាយប្រហារទៅលើសមាជិកនៃវណ្ណៈជាន់ខ្ពស់ ដោយវាយប្រហារ និងបំផ្លាញផ្ទះសំបែងជាច្រើនរបស់ពួកអភិជន។ នៅរដូវក្តៅឆ្នាំ 1789 ពីរបីខែមុនការហែលក្បួនរបស់ក្រុមស្ត្រីទៅកាន់ទីក្រុងវែកសៃ ពួកអភិជន និងសមាជិកបព្វជិតមួយចំនួននៅក្នុងរដ្ឋសភាបានឆ្លើយតបទៅនឹងការបះបោរនៅក្នុងកិច្ចប្រជុំយប់ជ្រៅដ៏រំជួលចិត្តមួយ។

## 1. សភាធ្វើកំណែទម្រង់ប្រទេសបារាំង

ពេញមួយយប់ថ្ងៃទី 4 ខែសីហា ឆ្នាំ 1789 ពួកអភិជនបានធ្វើសុន្ទរកថាដ៏ធំ ដោយប្រកាសពីសេចក្តីស្រឡាញ់របស់ពួកគេចំពោះសេរីភាព និងសមភាព។ ដោយភាពភ័យខ្លាចជាជាងដោយឧត្តមគតិ ពួកគេបានចូលរួមជាមួយសមាជិកដទៃទៀតនៃរដ្ឋសភាក្នុងការលុបបំបាត់អភ័យឯកសិទ្ធិសក្តិភូមិរបស់វណ្ណៈកម្មសិទ្ធិដីធ្លីទី 1 និងទី 2 ធ្វើដូច្នេះទើបធ្វើឲ្យមនុស្សសាមញ្ញស្មើភាពគ្នាជាមួយនឹងពួកអភិជន និងបព្វជិត។ នៅពេលព្រឹកឡើយ របបចាស់បានដួលរលំ។

សិទ្ធិរបស់មនុស្ស៖ 3 សប្តាហ៍ក្រោយមក រដ្ឋសភាបានអនុម័តសេចក្តីថ្លែងការណ៍អំពីទស្សនបដិវត្ត, សេចក្តីប្រកាសសិទ្ធិ មនុស្ស និងសិទ្ធិរបស់ប្រជាពលរដ្ឋ។ សិទ្ធិទាំងនេះរួមមាន "សេរីភាព, ទ្រព្យសម្បត្តិ, សន្តិសុខ, និងការតស៊ូប្រឆាំងនឹងការគៀបសង្កត់"។ ឯកសារនេះក៏បានធានាចំពោះពលរដ្ឋនូវភាពស្មើគ្នានៃយុត្តិធម៌, សេរីភាពក្នុងការបញ្ចេញមតិ, និងសេរីភាពខាងសាសនា។ ដោយគោរពតាមគោលការណ៍ទាំងនេះ មេដឹកនាំបដិវត្តបានប្រកាន់យកពាក្យ "សេរីភាព, សមភាព, ភាតរភាព" ធ្វើជាពាក្យស្លោករបស់ពួកគេ។ យ៉ាងណាក៏ដោយ ចំណុចទាំងអស់នេះមិនបានអនុវត្តចំពោះមនុស្សគ្រប់គ្នាទេ។ នៅពេលដែលអ្នកនិពន្ធឈ្មោះអូលីម ដឺ ហ្គូស បោះពុម្ពផ្សាយសេចក្តីប្រកាសអំពីសិទ្ធិស្ត្រី គំនិតរបស់នាងត្រូវបានគេច្រានចោល។ ក្រោយមកនៅឆ្នាំ 1793 នាងត្រូវបានប្រកាសថាជាសត្រូវរបស់បដិវត្ត ហើយត្រូវបានគេសម្លាប់។

ព្រះវិហារគ្រីស្តសាសនាដែលគ្រប់គ្រងដោយរដ្ឋ៖ កំណែទម្រង់ដំបូងរបស់រដ្ឋសភាភាគច្រើនផ្តោតលើព្រះវិហារគ្រីស្តសាសនា។ សភាបានរឹបអូសយកដីធ្លីរបស់ព្រះវិហារគ្រីស្តសាសនា ហើយបានប្រកាសថា មន្ត្រី និងសង្ឃព្រះវិហារគ្រីស្តសាសនា ត្រូវបានជ្រើសរើស និងផ្តល់ប្រាក់ឈ្នួលក្នុងនាមជាមន្ត្រីរាជការ។ ដូច្នេះ ព្រះវិហារកាតូលិកបានបាត់បង់ទាំងដីធ្លី និងឯករាជ្យនយោបាយរបស់ខ្លួន។ សកម្មភាពរបស់សភាទាំងនេះភាគច្រើនទាក់ទងជាមួយហេតុផលសេដ្ឋកិច្ច។ ប្រាក់ចំណូលពីការលក់ដីព្រះវិហារសាសនាគ្រីស្តបានជួយដល់ការសងបំណុលដ៏ច្រើនរបស់ប្រទេសបារាំង។ សកម្មភាពរបស់សភាបានធ្វើឱ្យកសិករបារាំងរាប់លាននាក់មានការភ្ញាក់ផ្អើល ដែលភាគច្រើនជាអ្នកកាន់សាសនាកាតូលិក។ ការព្យាយាមដើម្បីធ្វើឲ្យព្រះវិហារគ្រីស្តសាសនាក្លាយជាផ្នែកមួយនៃរដ្ឋ បានធ្វើឱ្យពួកប្រជាជនអាក់អន់ចិត្តបើទោះបីជាវាស្របតាមទស្សនសករាជពន្លឺក៏ដោយ។ ពួកគេជឿថាសម្តេចប៉ាបគួរ

តែគ្រប់គ្រងលើព្រះវិហារគ្រឹស្តសាសនាដោយឯករាជ្យពីរដ្ឋ។ ចាប់ពីពេលនោះមក កសិករជាច្រើនបានជំទាស់ទៅនឹងកំណែទម្រង់របស់សភា។

ព្រះអង្គម្ចាស់ល្វីព្យាយាមគេចចេញ៖ នៅពេលដែលរដ្ឋសភារៀបចំឡើងវិញនូវទំនាក់ទំនងរវាងព្រះវិហារគ្រឹស្តសាសនា និងរដ្ឋ ព្រះអង្គម្ចាស់ល្វីទី 16 បានពិចារណាអំពីជោគវាសនារបស់គាត់ក្នុងនាមជាព្រះមហាក្សត្រ។ ទីប្រឹក្សាមួយចំនួនរបស់ទ្រង់បានព្រមានទ្រង់ថា ទ្រង់ និងរាជវង្សរបស់ទ្រង់ស្ថិតនៅក្នុងគ្រោះថ្នាក់។ អ្នកគាំទ្ររបបរាជានិយមជាច្រើនគិតថា ប្រទេសបារាំងគ្មានសុវត្ថិភាព ហើយបានចាកចេញពីប្រទេស។ បន្ទាប់មកនៅខែមិថុនា ឆ្នាំ 1791 ព្រះរាជា និងក្រុមគ្រួសារបានព្យាយាមរត់គេចពីប្រទេសបារាំងទៅកាន់ប្រទេសអូទ្រីស-ហុងគ្រី។ ទោះជាយ៉ាងណា នៅពេលដែលពួកទ្រង់ធ្វើដំណើរទៅជិតដល់ព្រំដែន ពួកទ្រង់ត្រូវបានចាប់ខ្លួនយកត្រឡប់មកកាន់ក្រុងប៉ារីសវិញក្រោមការឃាមកាមដ៏តឹងរឹង។ ការប៉ុនប៉ងរត់គេចខ្លួនរបស់ព្រះអង្គម្ចាស់ល្វី បានបង្កើនឥទ្ធិពលដល់សត្រូវជ្រុលនិយមរបស់ទ្រង់នៅក្នុងរដ្ឋាភិបាល និងបានកម្រិតជោគវាសនារបស់ទ្រង់។

## 2. ការអភិវឌ្ឍនៃការបែងចែក

អស់រយៈពេលពីរឆ្នាំ រដ្ឋសភាបានជជែកគ្នាជុំវិញរដ្ឋធម្មនុញ្ញថ្មីសម្រាប់ប្រទេសបារាំង។ នៅឆ្នាំ 1791 គណៈប្រតិភូបានធ្វើការផ្លាស់ប្តូរយ៉ាងសំខាន់នៅក្នុងរដ្ឋាភិបាល និងសង្គមរបស់ប្រទេសបារាំង។

របបរាជានិយមមានកម្រិត៖ នៅខែកញ្ញា ឆ្នាំ 1791 រដ្ឋសភាបានធ្វើសម្រេចរដ្ឋធម្មនុញ្ញថ្មី ដែលព្រះអង្គម្ចាស់ល្វីបានអនុម័តដោយស្ទាក់ស្ទើរ។ រដ្ឋធម្មនុញ្ញនេះបានបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ វាបានដកអំណាចជាច្រើនរបស់ព្រះមហាក្សត្រ។ វាក៏បានបង្កើតស្ថាប័ននីតិប្បញ្ញត្តិថ្មីមួយ ពោលគឺសភានីតិបញ្ញត្តិ។ ស្ថាប័ននេះមានអំណាចបង្កើតច្បាប់ និងអនុម័ត ឬបដិសេធការប្រកាសសង្គ្រាម។ ទោះជាយ៉ាងណា ព្រះមហាក្សត្រនៅតែកាន់អំណាចនិតិប្រតិបត្តិដើម្បីអនុវត្តច្បាប់។

បក្សពួកបំបែកបំបាក់បារាំង៖ ទោះបីជាមានរដ្ឋាភិបាលថ្មីក៏ដោយ ក៏បញ្ហាចាស់ៗ ដូចជាកង្វះស្បៀងអាហារ និងបំណុលរបស់រដ្ឋាភិបាលនៅតែមាន។ សំណួរអំពីរបៀបដោះស្រាយបញ្ហាទាំងនេះបានធ្វើឱ្យសភានីតិបញ្ញត្តិបែងចែកជា 3 ក្រុម ដែលក្រុមនីមួយៗអង្គុយនៅផ្នែកផ្សេងគ្នានៃសាលប្រជុំ។ ពួកជ្រុលនិយមដែលអង្គុយនៅផ្នែកខាងឆ្វេងនៃសាលប្រជុំ បានប្រឆាំងទៅនឹងគំនិតរបបរាជានិយម និងចង់បានការផ្លាស់ប្តូរយ៉ាងទូលំទូលាយនៅក្នុងវិធីដែលរដ្ឋាភិបាលកំពុងដំណើរការ។ អ្នកសម្របសម្រួលអង្គុយនៅកណ្តាលសាល ហើយចង់បានការផ្លាស់ប្តូរមួយចំនួននៅក្នុងរដ្ឋាភិបាល ប៉ុន្តែមិនច្រើនដូចជាពួកជ្រុលនិយមឡើយ។ អ្នកអភិរក្សនិយមអង្គុយនៅខាងស្តាំសាល។ ពួកគេបានប្រកាន់ខ្ជាប់នូវគំនិតរបបរាជានិយមមានកម្រិត និងចង់បានការផ្លាស់ប្តូរតិចតួចនៅក្នុងរដ្ឋាភិបាល។ លើសពីនេះ បក្សពួកនៅក្រៅសភានិតិបញ្ញត្តិក៏ចង់មានឥទ្ធិពលលើការដឹកនាំរបស់រដ្ឋាភិបាលផងដែរ។ អេមីក្រេស, ពួកអភិជន, និងអ្នកផ្សេងទៀតដែលបានភៀសខ្លួនចេញពីប្រទេសបារាំង សង្ឃឹមថានឹងលុបចោលបដិវត្ត និងស្តាររបបចាស់ឡើងវិញ។ ផ្ទុយទៅវិញ កម្មករនៅប៉ារីស និងម្ចាស់ហាងតូចៗមួយចំនួនចង់ឱ្យបដិវត្តនាំមកនូវការផ្លាស់ប្តូរកាន់តែខ្លាំងឡើងចំពោះប្រទេសបារាំង។ ពួកគេត្រូវបានគេហៅថា សេនស៍-គូឡូត ឬ "អ្នកដែលគ្មានខោត្រឹម

ជង្គង់"។ ខុសពីវណ្ណៈលើដែលស្លៀកខោត្រឹមជង្គង់ដ៏ប្រណិតនោះ ពួកសេនស៍-គូឡូតស្លៀកខោធម្មតា។ ទោះបីជាពួកគេមិនមានតួនាទីនៅក្នុងសភាក៏ដោយ ក៏ពួកគេធាប់រកឃើញវិធីដើម្បីបញ្ចេញអំណាចនៅតាមដងផ្លូវនៃទីក្រុងប៉ារីស។

### 3. សង្គ្រាម និងការសម្លាប់

ព្រះមហាក្សត្រ និងពួកអភិជនក្នុងបណ្តាលប្រទេសអឺរ៉ុបជាច្រើនបានឃ្លាំមើលការផ្លាស់ប្តូរដែលកើតឡើងនៅក្នុងប្រទេសបារាំជាមួយនឹងក្តីបារម្ភ។ ពួកគេភ័យខ្លាចថា ការបះបោរស្រដៀងគ្នានេះអាចនឹងផ្ទុះឡើងនៅក្នុងប្រទេសរបស់ពួកគេផងដែរ។ តាមពិតទៅ ពួកអ្នកជ្រុលនិយមខ្លះមានបំណងចង់ផ្សព្វផ្សាយគំនិតបដិវត្តរបស់ពួកគេនៅទូទាំងទ្វីបអឺរ៉ុប។ ជាលទ្ធផលប្រទេសមួយចំនួនបានចាត់វិធានការ។ ឧទាហរណ៍ ប្រទេសអូទ្រីស និងព្រូសបានជំរុញឱ្យពួកបារាំង ស្តារឡើងវិញនូវមុខតំណែងរបស់ព្រះអង្គម្ចាស់ល្វីជាព្រះមហាក្សត្រផ្តាច់ការឡើងវិញ។ សភានីតិបញ្ញត្តិបានឆ្លើយតបដោយការប្រកាសសង្គ្រាមនៅខែមេសា ឆ្នាំ 1792។

ប្រទេសបារាំងធ្លាក់ក្នុងសង្គ្រាម៖ សង្គ្រាមបានចាប់ផ្តើមបង្កបញ្ហាយ៉ាងធ្ងន់ធ្ងរសម្រាប់ជនជាតិបារាំង។ នៅរដូវក្តៅឆ្នាំ 1792 កងកម្លាំងព្រូសបានធ្វើដំណើរឆ្ពោះមកកាន់ទីក្រុងប៉ារីស។ មេបញ្ជាការព្រូសបានគំរាមបំផ្លាញទីក្រុងប៉ារីស ប្រសិនបើពួកបដិវត្តធ្វើបាបសមាជិកណាមួយនៃគ្រួសាររាជវង្ស។ ការនេះបានធ្វើឱ្យប្រជាជនប៉ារីសមានការខឹងសម្បារ។ នៅថ្ងៃទី 10 ខែសីហា បុរស និងស្ត្រីប្រហែល 20.000 នាក់បានលុកលុយទូលីរី ដែលជារាជវាំងសម្រាប់គ្រួសាររាជវង្សគង់នៅ។ ហ្វូងមនុស្សបានសម្លាប់រង្គាលលើឆ្មាំរាជវង្ស និងចាប់ឃុំព្រះកាយព្រះអង្គម្ចាស់ល្វី, ម្ចាស់ក្សត្រីម៉ារី អង់តូនេតេ, និងបុត្ររបស់ពួកទ្រង់។ ភ្លាមៗនោះ កងទ័ពបារាំងដែលការពារទីក្រុងប៉ារីស ត្រូវបានបញ្ជូនមកជួយពង្រឹងកងទ័ពបារាំងដែលកំពុងស្ថិតនៅក្នុងរាជវាំង។ មានពាក្យចចាមអារ៉ាមបានចាប់ផ្តើមរីករាលដាលថា ក្រុមអ្នកគាំទ្រព្រះមហាក្សត្រដែលជាប់ឃុំនៅក្នុងពន្ធនាគារនៅទីក្រុងប៉ារីសគ្រោងនឹងបំបែកគុក និងដណ្តើមកាន់កាប់ទីក្រុង។ ពលរដ្ឋដែលខឹង និងភ័យខ្លាចបានឆ្លើយតបដោយយកច្បាប់មកដាក់ក្នុងដៃរបស់ខ្លួន។ អស់រយៈពេលជាច្រើនថ្ងៃនៅដើមខែកញ្ញា ពួកគេបានធ្មក់ចូលពន្ធនាគារ និងសម្លាប់អ្នកទោសជាង 1,000 នាក់។ ពួកអភិជន, បព្វជិត, និងអ្នកអាណិតអាសូររាជានិយមជាច្រើននាក់បានក្លាយជាជនរងគ្រោះនៅក្នុងការសម្លាប់រង្គាលដោយហ្វូងមនុស្សដែលមានកំហឹងនៅខែកញ្ញានេះ។ នៅក្រោមសម្ពាធពីសំណាក់ពួកជ្រុលនិយមនៅតាមដងផ្លូវ និងក្នុងចំណោមសមាជិករបស់ពួកគេ សភានីតិបញ្ញត្តិបានដកចេញនូវរដ្ឋធម្មនុញ្ញឆ្នាំ 1791។ ពួកគេបានបានប្រកាសថា ព្រះមហាក្សត្រត្រូវបានទម្លាក់, សភាត្រូវបានរំលាយ, និងបានអំពាវនាវឱ្យមានការបោះឆ្នោតស្ថាប័ននីតិបញ្ញត្តិថ្មី។ ស្ថាប័នគ្រប់គ្រងថ្មីនេះ សន្និបាទជាតិ បានចូលកាន់តំណែងនៅថ្ងៃទី 21 ខែកញ្ញា។ យ៉ាងឆាប់រហ័សស្ថាប័ននេះបានលុបចោលនូវរបបរាជានិយម ហើយបានប្រកាសប្រទេសបារាំងជាប្រទេសសាធារណៈរដ្ឋ។ ប្រជាពលរដ្ឋដែលជាបុរសពេញវ័យត្រូវបានផ្តល់សិទ្ធិក្នុងការបោះឆ្នោត និងកាន់តំណែង។ ទោះបីជាពួកគេទទួលបានដើរតួនាទីសំខាន់នៅក្នុងការធ្វើបដិវត្តក៏ដោយ ក៏ស្ត្រីមិនត្រូវបានគេផ្តល់សិទ្ធិនៅក្នុងការបោះឆ្នោតឡើយ។

ចាកូប៊ីនគ្រប់គ្រងអំណាច៖ ភាគច្រើននៃមនុស្សពាក់ព័ន្ធនៅក្នុងការផ្លាស់ប្តូររដ្ឋាភិបាលក្នុងខែកញ្ញា 1792 គឺជាសមាជិកនៃអង្គការនយោបាយជ្រុលនិយមមួយដែលមានឈ្មោះថា ក្លឹបចាកូប៊ីន។ សមាជិកម្នាក់ក្នុងចំណោមសមាជិកក្លឹបចាកូប៊ីនដែលលេចធ្លោជាងគេគឺ លោកជីន-ប៉ូល ម៉ារ៉ាត។ នៅអំឡុងពេលបដិវត្ត គាត់គឺជាអ្នកកែសម្រួលកាសែតមួយដែលមានឈ្មោះថា មិត្តរបស់ប្រជាជន។ នៅក្នុងវិចារណកថាដ៏ក្តៅគគុករបស់លោក ម៉ារ៉ាត បានអំពាវនាវឱ្យសម្លាប់នូវរាល់អ្នកទាំងឡាយណាដែលបន្តគាំទ្រស្តេច។ លោក ចច ដាន់តុន ដែលជាមេធាវីមួយរូបស្ថិតក្នុងចំណោមវាគ្មិនដែលមានទេពកោសល្យ និងជាទីស្រលាញ់បំផុតរបស់ក្លឹប។ គាត់ក៏ត្រូវបានគេស្គាល់ផងដែរតាមរយៈការលះបង់របស់គាត់ដើម្បីសិទ្ធិរបស់ប្រជាជនក្រីក្រនៅទីក្រុងប៉ារីស។ សន្និបាទជាតិបានកាត់បន្ថយតួនាទីរបស់ព្រះអង្គម្ចាស់ល្វីទី 16 ពីព្រះមហាក្សត្រទៅជាពលរដ្ឋសាមញ្ញ និងជាអ្នកទោស។ ឥឡូវនេះ ស្ថិតនៅក្រោមការណែនាំរបស់ពួកចាកូប៊ីនជ្រុលនិយម ពួកគេចង់ឱ្យមានការកាត់ទោលព្រះអង្គម្ចាស់ល្វីពីបទក្បត់ជាតិ។ សន្និបាទបានរកឃើញថាទ្រង់មានទោស ហើយដោយការបោះឆ្នោតយ៉ាងប្រកៀកប្រកិតគ្នាបំផុត បានសម្រេចកាត់ទោសប្រហារជីវិតទ្រង់។ នៅថ្ងៃទី 21 ខែមករា ឆ្នាំ 1793 អតីតព្រះមហាក្សត្របានដើរដោយសេចក្តីថ្លៃថ្នូរ និងស្ងប់ស្ងាត់ឡើងជណ្តើរទៅកាន់កន្លែងដែលទ្រង់ត្រូវកាត់ក្បាលដោយម៉ាស៊ីនមួយដែលគេហៅថា ម៉ាស៊ីនកាត់ក្បាល ។

សង្គ្រាមនៅតែបន្ត៖ សន្និបាទជាតិក៏ត្រូវប្រឈមជាមួយនឹងសង្គ្រាមដែលនៅតែបន្តកើតមានជាមួយអូទ្រីស និងព្រូស។ នៅពេលសន្និបាទចូលកាន់តំណែង កងទ័ពបារាំងបានទទួលជ័យជម្នះដ៏គួរឱ្យភ្ញាក់ផ្អើលប្រឆាំងនឹងពួកអូទ្រីស និងព្រូសនៅក្នុងសមរភូមិវ៉ាល់មី។ ទោះយ៉ាងណាក៏ដោយ នៅដើមឆ្នាំ 1793 ចក្រភពអង់គ្លេស, ហូឡង់, និងអេស្ប៉ាញបានចូលរួមជាមួយពួកព្រូស និងអូទ្រីសប្រឆាំងជាមួយនឹងបារាំង។ ដោយតតាំងជាមួយសត្រូវច្រើនក្នុងពេលតែមួយ បារាំងបានទទួលរងបរាជ័យជាបន្តបន្ទាប់។ ដើម្បីពង្រឹងកងទ័ពរបស់បារាំង មេដឹកនាំចាកូប៊ីននៅក្នុងសន្និបាទបានបោះជំហានយ៉ាងខ្លាំងក្លាមួយ។ តាមរយៈការជំរុញរបស់ពួកគេ នៅខែកុម្ភៈ ឆ្នាំ 1793 សន្និបាទបានបញ្ជាឱ្យកេណ្ឌពលរដ្ឋបារាំងចំនួន 300.000 នាក់ដែលមានអាយុចន្លោះពី 18 ទៅ 40 ឆ្នាំ។ នៅត្រឹមឆ្នាំ 1794 កងទ័ពបានកើនឡើងដល់ 800.000 នាក់ ក្នុងនោះរួមបញ្ចូលទាំង ស្ត្រីផង។

## 4. ភេរវកម្មនិងប្រតិកម្មបារាំង

កងទ័ពបរទេសមិនមែនជាសត្រូវតែមួយគត់របស់សាធារណរដ្ឋបារាំងនោះទេ។ ចាកូប៊ីនមានសត្រូវរាប់ពាន់នាក់នៅក្នុងប្រទេសបារាំង។ ពួកគេទាំងនេះរួមមានប្រជាកសិករដែលមានក្តីរន្ធត់ដោយការប្រហារជីវិតរបស់ព្រះមហាក្សត្រ, ពួកបព្វជិតដែលមិនព្រមទទួលយកការគ្រប់គ្រងរបស់រដ្ឋាភិបាល, និងមេដឹកនាំគូប្រជែងដែលកំពុងញុះញង់ឱ្យមានការបះបោរនៅតាមខេត្ត។ របៀបនៅក្នុងទប់ស្កាត់ និងគ្រប់គ្រងសត្រូវទាំងនេះបានក្លាយជាបញ្ហាចម្បង។

រ៉ូបស្ព្យែរទទួលបានការគ្រប់គ្រង៖ នៅដើមខែដំបូងនៃឆ្នាំ 1793 មេដឹកនាំចាកូប៊ីនមួយរូបឈ្មោះម៉ាស៊ីមីលែន រ៉ូបស្ព្យែរចាប់ផ្តើមទទួលបានអំណាចបន្តិចម្តងៗ។ រ៉ូបស្ព្យែរ និងអ្នកគាំទ្ររបស់គាត់បានកំណត់ក្នុងការកសាង "សាធារណរដ្ឋនៃគុណធម៌" ដោយលុបបំបាត់នូវរាល់ដាននៃអតីតកាលរបស់ប្រទេសបារាំង។ ក្រុមអ្នកជឿយ៉ាង

ម៉ឺងម៉ាត់ បានផ្លាស់ប្តូរប្រតិទិន ដោយកំណត់ 30 ថ្ងៃសម្រាប់ខែទាំង 12 ហើយប្តូរឈ្មោះខែនីមួយ។ ប្រតិទិននេះគ្មានថ្ងៃអាទិត្យទេ ព្រោះពួកជ្រុលនិយមបានចាត់ទុកថាវាជាថ្ងៃរបស់សាសនាចាស់ និងមានគ្រោះថ្នាក់។ ពួកគេថែមទាំងបានបិទព្រះវិហារទាំងអស់ក្នុងទីក្រុងប៉ារីស ហើយទីក្រុងនានា និងទីប្រជុំជនទូទាំងប្រទេសបារាំងក៏ធ្វើដូចគ្នាដែរ។ នៅខែកក្កដាឆ្នាំ 1793 រ៉ូបស្ព្យែរ បានក្លាយជាមេដឹកនាំនៃគណៈកម្មាធិការសុវត្ថិភាពសាធារណៈ។ សម្រាប់ឆ្នាំបន្ទាប់ រ៉ូបស្ព្យែរ បានគ្រប់គ្រងប្រទេសបារាំងស្ទើរតែជាជនផ្តាច់ការ ហើយរយៈពេលនៃការគ្រប់គ្រងរបស់គាត់ត្រូវបានគេស្គាល់ថាជារាជនៃភេរវកម្ម។ ភារកិច្ចចម្បងរបស់គណៈកម្មាធិការសុវត្ថិភាពសាធារណៈគឺដើម្បីការពារបដិវត្តពីសត្រូវរបស់ខ្លួន។ ក្រោមការដឹកនាំរបស់រ៉ូបស្ព្យែរ គណៈកម្មាធិការនេះតែងតែកាត់ទោស "សត្រូវ" ទាំងនេះនៅពេលព្រឹក ហើយត្រូវបានកាត់ក្បាលនៅពេលរសៀល។ លោករ៉ូបស្ព្យែរបានបង្ហាញពីភាពត្រឹមត្រូវចំពោះការប្រើប្រាស់អំពើភេរវកម្មរបស់គាត់ ដោយលោកលើកឡើងថា វាបានអនុញ្ញាតឱ្យពលរដ្ឋបារាំងរក្សាភាពស្មោះត្រង់ចំពោះទស្សនៃបដិវត្ត។ "ខ្មាំងសត្រូវនៃបដិវត្ត" ដែលបង្កបញ្ហាដល់រ៉ូបស្ព្យែរបំផុតគឺជាពួកជ្រុលនិយមដែលប្រឆាំងនឹងការដឹកនាំរបស់លោក។ នៅឆ្នាំ 1793 និង 1794 មនុស្សជាច្រើនដែលធ្លាប់បានចូលរួមដឹកនាំបដិវត្តបានទទួលការកាត់ទោសប្រហារជីវិត។ ឧក្រិដ្ឋកម្មតែមួយគត់របស់ពួកគេនោះគឺដោយសារតែពួកគេមិនសូវជ្រុលនិយមខ្លាំងដូចរ៉ូបស្ព្យែរ។ នៅដើមឆ្នាំ 1794 សូម្បីតែលោកចច ដាន់តុន ក៏ទទួលរងគ្រោះថ្នាក់ផងដែរ។ មិត្តភ័ក្តិរបស់ ដាន់តុន នៅក្នុងសន្និបាតជាតិមានការភ័យខ្លាចក្នុងការការពារគាត់ និងបានចូលរួមក្នុងការថ្កោលទោសលោក។ នៅលើរន្ទា គាត់បានប្រាប់ពេជ្ឈឃាតថា «កុំភ្លេចបង្ហាញក្បាលខ្ញុំដល់ប្រជាជន ។ វាពិតជាមានតម្លៃណាស់ក្នុងការឃើញ»។ ភេរវកម្ម មិនត្រឹមតែធក់យកជីវិតរបស់អ្នកល្បីល្បាញដូចជាដាន់តុន និងម្ចាស់ក្សត្រីម៉ារី អង់តូនេតេ ដែលជាម្ចាស់ក្សត្រីមេម៉ាយប៉ុណ្ណោះទេ។ មនុស្សមិនស្គាល់មុខរាប់ពាន់នាក់ក៏ត្រូវបានបញ្ជូនទៅកាត់ក្បាលផងដែរ ដែលជារឿយៗត្រូវបានចោទប្រកាន់ដោយមិនសមហេតុសមផល។ ឧទាហរណ៍ យុវជនអាយុ 18 ឆ្នាំម្នាក់ត្រូវបានកាត់ទោសប្រហារជីវិតចំពោះការកាប់ដើមឈើដែលបានដាំជានិមិត្តរូបនៃសេរីភាព។ មនុស្សប្រមាណ 40,000 នាក់ត្រូវបានប្រហារជីវិតនៅអំឡុងពេលនៃភេរវកម្មនេះ។ ប្រហែល 85 ភាគរយគឺជាកសិករ ឬសមាជិកនៃគ្រួសារក្រីក្រក្នុងទីក្រុង ឬវណ្ណៈកណ្តាល អ្នកដែលបានទទួលបានអត្ថប្រយោជន៍ពីការធ្វើបដិវត្ត។

## 5. ការបញ្ចប់នៃអំពើភេរវកម្ម

នៅខែកក្កដា ឆ្នាំ 1794 ដោយភ័យខ្លាចសុវត្ថិភាពផ្ទាល់ខ្លួន សមាជិកមួយចំនួននៃសន្និបាទជាតិបានត្រឡប់ទៅប្រឆាំងជាមួយរ៉ូបស្ព្យែរ។ ពួកគេទាមទារឱ្យចាប់ខ្លួន និងប្រហារជីវិតលោក។ រដ្ឋកាលនៃភេរវកម្ម ដែលជាដំណាក់កាលជ្រុលនិយមនៃបដិវត្តបារាំង បានបញ្ចប់នៅថ្ងៃទី 28 ខែកក្កដា ឆ្នាំ 1794 នៅពេលដែលលោករ៉ូបស្ព្យែរត្រូវបានគេនាំយកទៅកាត់ក្បាល។ ទស្សនរបស់មហាជនបារាំងបានផ្លាស់ប្តូរយ៉ាងខ្លាំងបន្ទាប់ពីការស្លាប់របស់រ៉ូបស្ព្យែរ។ មនុស្សគ្រប់វណ្ណៈ មានការនឿយហត់នឹងភេរវកម្ម។ ពួកគេក៏ធុញទ្រាន់នឹងឡើងយ៉ាងខ្ពស់នៃតម្លៃនំប៉័ង, អំបិល, និងរបស់របរផ្សេងៗទៀតសម្រាប់ការរស់នៅ។ នៅឆ្នាំ 1795 មេដឹកនាំកណ្តាលនិយមនៅក្នុងសន្និបាទជាតិបានព្រាងផែនការថ្មីរបស់រដ្ឋាភិបាល ដែលជាកាតព្រាងលើកទី 3 ចាប់តាំងពីឆ្នាំ 1789 មក ។ ផែនការនេះបានប្រគល់អំណាចទៅឱ្យពួកវណ្ណៈកណ្តាលជាន់ខ្ពស់ និងបានអំពាវនាវឱ្យមានសភានីតិបញ្ញត្តិចំនួន 2 ថ្នាក់ និងស្ថាប័ននិតិ

ប្រតិបត្តិដែលដឹកនាំដោយមនុស្ស 5 រូប ។ សមាជិកទាំង 5 នាក់នេះជាកណ្តាលនិយម មិនមែនជាអ្នកបដិវត្តនិយមទេ។ ពួកគេខ្លះពុករលួយ ហើយធ្វើឱ្យខ្លួនពួកគេក្លាយជាអ្នកមានតាមរយៈការប្រើប្រាស់លុយជាតិ។ ទោះជាយ៉ាងនេះក្តី ពួកគេបានធ្វើឱ្យប្រទេសដែលកំពុងមានបញ្ហា មានសណ្តាប់ធ្នាប់បានមួយរយៈ។ ពួកគេក៏បានរកឃើញឧត្តមសេនីយ៍សមស្របមួយរូបដើម្បីបញ្ជាកងទ័ពរបស់បារាំងដែរ គឺណាប៉ូឡេអុង បូណាផាត។

## 6. ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងដណ្ដើមអំណាច

ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុង បូណាផាត កើតនៅឆ្នាំ 1769 នៅលើកោះកូស៊ីកានៅមេឌីទែរ៉ាណេ។ នៅពេលដែលទ្រង់មានព្រះជន្ម 9 ឆ្នាំឪពុកម្តាយរបស់ទ្រង់បានបញ្ជូនទ្រង់ទៅកាន់សាលាយោធា។ នៅឆ្នាំ 1785 នៅពេលដែលមានព្រះជន្ម 16 ព្រះវស្សាទ្រង់បានបញ្ចប់ការសិក្សាហើយបានក្លាយជាអនុសេនីយ៍ឯកនៅក្នុងកងកាំភ្លើងធំ។ នៅពេលដែលបដិវត្តផ្ទុះឡើង ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានចូលរួមជាមួយកងទ័ពនៃរដ្ឋាភិបាលថ្មី។

វីរៈបុរសក្នុងមួយប៉ប្រិចភ្នែក៖ នៅខែតុលា ឆ្នាំ 1795 ជោគវាសនាបានផ្តល់ឱ្យមន្ត្រីវ័យក្មេងនូវឱកាសសម្រាប់ភាពរុងរឿង។ នៅពេលដែលពួកឧទ្ទាមរាជានិយមបានដើរដង្ហែឆ្ពោះទៅរកសន្និបាតជាតិ មន្ត្រីរដ្ឋាភិបាលម្នាក់បានប្រាប់ណាប៉ូឡេអ៊ុងឱ្យការពារប្រតិភូ។ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុង និងខ្មាន់កាំភ្លើងរបស់ទ្រង់បានស្វាគមន៍ពួករាជានិយមរាប់ពាន់នាក់ដោយគ្រាប់កាំភ្លើងធំ។ ក្នុងរយៈពេលប៉ុន្មាននាទី ពួកអ្នកវាយប្រហារបានរត់គេចខ្លួនដោយភ័យស្លន់ស្លោ និងចលាចល។ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុង បូណាផាត បានក្លាយជាវីរបុរសក្នុងមួយប៉ប្រិចភ្នែក ហើយត្រូវបានសាទរពេញទីក្រុងប៉ារីសថាជាអ្នកសង្គ្រោះសាធារណរដ្ឋបារាំង។ នៅឆ្នាំ 1796 ស្ថានប័ននីតិប្រតិបត្តិបានតែងតាំងព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងឱ្យដឹកនាំកងទ័ពបារាំង ប្រឆាំងនឹងកងកម្លាំងនៃប្រទេសអូទ្រីស និងព្រះរាជាណាចក្រសាឌីនៀ។ ឆ្លងកាត់ភ្នំអាល់ ឧត្តមសេនីយវ័យក្មេងបានវាយលុកចូលប្រទេសអ៊ីតាលី ហើយបានទទួលជ័យជម្នះគួរឱ្យកត់សម្គាល់ជាបន្តបន្ទាប់។ បន្ទាប់មក នៅក្នុងការប៉ុនប៉ងដើម្បីការពារផលប្រយោជន៍ពាណិជ្ជកម្មរបស់បារាំង និងដើម្បីបង្អាក់ពាណិជ្ជកម្មរបស់អង់គ្លេសជាមួយឥណ្ឌា ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានដឹកនាំបេសកកម្មមួយទៅកាន់ប្រទេសអេហ្ស៊ីប។ ប៉ុន្តែទ្រង់មិនបានទទួលជោគជ័យដូចដែលទ្រង់ធ្លាប់បានទទួលនៅអឺរ៉ុបឡើយ។ កងទ័ពរបស់ទ្រង់ត្រូវបានឡោមព័ទ្ធជាប់នៅអេហ្ស៊ីប ហើយឧត្តមនាវីឯកអង់គ្លេសហូរ៉ាទីអូ នេលសុនបានយកជ័យជំនះលើកងទ័ពជើងទឹករបស់ទ្រង់។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានគ្រប់គ្រងរឿងរ៉ាវស្តីអំពីការបរាជ័យរបស់ទ្រង់ចេញពីកាសែត ហើយដោយហេតុនេះ ទ្រង់នៅតែជាវីរបុរសដ៏អស្ចារ្យសម្រាប់ប្រជាជនបារាំង។

# មេរៀនទី 3 ៖ ណាប៉ូឡេអុងបង្កើតចក្រភពមួយ

ណាប៉ូឡេអុង បូណាផាត ជាមនុស្សម្នាក់ដែលមានកម្ពស់ទាបណាស់ ដោយមានកម្ពស់ត្រឹមតែ 5 ហ្វីត 3 អ៊ិញ តែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់បានបង្ហាញស្រមោលយ៉ាងយូរមួយលើប្រវត្តិសាស្ត្រសម័យទំនើប។ ទ្រង់ត្រូវបានគេទទួលស្គាល់ថាជាកំពូលអ្នកមានទេពកោសល្យខាងយោធាដ៏អស្ចារ្យបំផុតនៅលើពិភពលោក ដូចគ្នាទៅនឹងអាឡិចសាន់ឌឺដ៏អស្ចារ្យនៃម៉ាសេដូនៀ, ហាននីបាល់នៃកាថេក, និងជូលៀ សេសានៃរ៉ូម។ ក្នុងរយៈពេលត្រឹមតែ 4 ឆ្នាំប៉ុណ្ណោះ ចាប់ពីឆ្នាំ 1795 ដល់ឆ្នាំ 1799 ណាប៉ូឡេអុងបានងើបចេញពីដំណែងមិនច្បាស់លាស់ដែលជាមន្ត្រីមួយរូបក្នុងជួរកងទ័ពបារាំង ក្លាយជាអ្នកគ្រប់គ្រងប្រទេសបារាំង។

រដ្ឋប្រហារ៖ នៅត្រឹមឆ្នាំ 1799 ស្ថាប័ននីតិប្រតិបត្តិបានបាត់បង់ការគ្រប់គ្រងរបស់ខ្លួនលើស្ថានភាពនយោបាយ និងបាត់បង់ទំនុកចិត្តពីសំណាក់ប្រជាជនបារាំង។ នៅពេលព្រះអង្គម្ចាស់ណាប៉ូឡេអុងត្រលប់មកពីអេហ្ស៊ីប មិត្តរបស់ទ្រង់បានជំរុញឱ្យទ្រង់ដណ្តើមអំណាចនយោបាយ។ ព្រះអង្គម្ចាស់ណាប៉ូឡេអុងបានចាត់វិធានការដំបូងនៅខែក្នុងវិច្ឆិកា ឆ្នាំ 1799 ។ កងទ័ពក្រោមបញ្ជាការរបស់ទ្រង់បានឡោមព័ទ្ធសភាជាតិ ហើយបានបណ្តេញសមាជិកសភាមួយភាគធំចេញ។ សមាជិកសភាដែលនៅសេសសល់ពេលនោះបានបោះឆ្នោតរំលាយស្ថាប័ននីតិប្រតិបត្តិ។ ជំនួសមកវិញ ពួកគេបានបង្កើតក្រុមប្រឹក្សាចំនួន 3 រូប ដែលក្នុងនោះមួយរូបជាព្រះអង្គម្ចាស់ណាប៉ូឡេអុង។ ព្រះអង្គម្ចាស់ណាប៉ូឡេអុងភ្លាមៗនោះបានទទួលតំណែងជាទីប្រឹក្សាទី 1 និងបានកាន់អំណាចផ្តាច់មុខ។ ការដណ្តើមអំណាចភ្លាមៗដូចជាការដណ្តើមអំណាចរបស់ព្រះអង្គម្ចាស់ណាប៉ូឡេអុងត្រូវបានគេស្គាល់ថា រដ្ឋប្រហារ ដែលយកចេញពីភាសាបារាំងថា យូដេតា ឬ "ការផាត់រដ្ឋចេញ"។ នៅអំឡុងពេលនៃធ្វើរដ្ឋប្រហាររបស់ព្រះអង្គម្ចាស់ណាប៉ូឡេអុង ប្រទេសបារាំងនៅតែបន្តមានសង្គ្រាម។ នៅឆ្នាំ 1799 ប្រទេសអង់គ្លេស, អូទ្រីស, និងរុស្ស៊ីបានចូលរួមកម្លាំងក្នុងគោលដៅតែមួយ គឺដើម្បីបណ្តេញព្រះអង្គម្ចាស់ណាប៉ូឡេអុងចេញពីអំណាច។ ជាថ្មីម្តងទៀត ព្រះអង្គម្ចាស់ណាប៉ូឡេអុងបានធ្វើដំណើរចេញពីប៉ារីសមកបញ្ជាកងទ័ពរបស់ទ្រង់ដោយផ្ទាល់។ នៅទីបំផុត ដោយសារតែសង្គ្រាម និងការទូត ប្រទេសទាំង 3 បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពមួយជាមួយប្រទេសបារាំង។ នៅឆ្នាំ 1802 អឺរ៉ុបមានសន្តិភាពជាលើកដំបូងក្នុងរយៈពេលដប់ឆ្នាំ។ ព្រះអង្គម្ចាស់ណាប៉ូឡេអុងមានសេរីភាពក្នុងការផ្តោតថាមពលរបស់ទ្រង់លើការស្តារសណ្តាប់ធ្នាប់នៅក្នុងប្រទេសបារាំងឡើងវិញ។

## 1. ព្រះអង្គម្ចាស់ណាប៉ូឡេអុងគ្រប់គ្រងប្រទេសបារាំង

ដំបូងឡើយ ព្រះអង្គម្ចាស់ណាប៉ូឡេអុងធ្វើពុតថាខ្លួនទ្រង់ថាជាមេដឹកនាំដែលត្រូវបានជ្រើសរើសត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសេរីមួយ។ នៅឆ្នាំ 1800 ប្រជាសិទ្ធិ ឬការបោះឆ្នោតរបស់ប្រជាជនត្រូវបានប្រារព្ធឡើងដើម្បីអនុម័តរដ្ឋធម្មនុញ្ញថ្មី។ ដោយអស់សង្ឃឹមចំពោះការដឹកនាំកន្លងមក ប្រជាជនបានបោះឆ្នោតគាំទ្រយ៉ាងលើសលប់លើរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញនេះបានផ្តល់អំណាចពិតប្រាកដទាំងអស់ដល់ព្រះអង្គម្ចាស់ណាប៉ូឡេអុងជាទីប្រឹក្សាទី 1 ។

ការស្តារសណ្តាប់ធ្នាប់នៅក្នុងប្រទេស៖ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុង មិនបានព្យាយាមក្នុងការត្រឡប់ប្រទេសទៅរកសម័យព្រះអង្គម្ចាស់ល្វីទី 16 នោះទេ។ ផ្ទុយទៅវិញ ទ្រង់បានរក្សាការផ្លាស់ប្តូរជាច្រើនដែលបានកើតឡើងអំឡុងពេលបដិវត្ត។ ជាទូទៅ ទ្រង់បានគាំទ្រច្បាប់ដែលនឹងពង្រឹងរដ្ឋាភិបាលកណ្តាល និងសម្រេចនូវគោលដៅមួយចំនួននៃបដិវត្ត។ ភារកិច្ចដំបូងរបស់ទ្រង់គឺធ្វើឱ្យសេដ្ឋកិច្ចដំណើរការលើមូលដ្ឋានរឹងមាំមួយ។ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុង បានបង្កើតវិធីសាស្ត្រប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព និងបង្កើតប្រព័ន្ធធនាគារជាតិ។ បន្ថែមពីលើការធានាដល់រដ្ឋាភិបាលនូវការផ្គត់ផ្គង់ប្រាក់ពន្ធប្រកបដោយស្ថេរភាព សកម្មភាពទាំងនេះបានលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ និងការគ្រប់គ្រងសេដ្ឋកិច្ចកាន់តែប្រសើរឡើង។ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងក៏បានចាត់វិធានការនានាដើម្បីបញ្ចប់អំពើពុករលួយ និងអសមត្ថភាពក្នុងជួររដ្ឋាភិបាលផងដែរ។ ទ្រង់បានបណ្តេញមន្ត្រីពុករលួយ ហើយដើម្បីផ្តល់ឱ្យរដ្ឋាភិបាលនូវមន្ត្រីដែលបានទទួលបានការបណ្តុះបណ្តាល ទ្រង់បានបង្កើតសាលាលីសេ ឬសាលាសាធារណៈដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ លីសេទាំងនេះត្រូវបានបើកសម្រាប់សិស្សប្រុសមកពីគ្រប់មជ្ឈដ្ឋាន។ និស្សិតបញ្ចប់ការសិក្សាត្រូវបានតែងតាំងជាមន្ត្រីសាធារណៈដោយផ្អែកលើគុណសម្បត្តិជាជាងទំនាក់ទំនងគ្រួសារ។ ផ្នែកមួយដែលណែនាំដោយបដិវត្តឱ្យមានការផ្លាស់ប្តូរនោះគឺសាសនា ប៉ុន្តែព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងមិនបានអើពើឡើយ។ ទាំងបព្វជិត និងកសិករភាគច្រើនចង់ស្តារតំណែងព្រះវិហារគ្រឹស្តសាសនានៅប្រទេសបារាំងឡើងវិញ។ ឆ្លើយតបទៅនឹងការចង់បានរបស់ពួកគេ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានចុះហត្ថលេខាលើអនុសញ្ញា ឬកិច្ចព្រមព្រៀងមួយជាមួយសម្តេចប៉ាបពូសទី 7 ។ កិច្ចព្រមព្រៀងនេះបានបង្កើតទំនាក់ទំនងថ្មីមួយរវាងព្រះវិហារ និងរដ្ឋ។ រដ្ឋាភិបាលបានទទួលស្គាល់ឥទ្ធិពលរបស់ព្រះវិហារគ្រឹស្តសាសនា ប៉ុន្តែបានបដិសេធការគ្រប់គ្រងព្រះវិហារគ្រឹស្តសាសនាលើកិច្ចការជាតិ។ អនុសញ្ញានេះបាននាំឱ្យព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងទទួលបានការគាំទ្រពីព្រះវិហារគ្រឹស្តសាសនា ក៏ដូចជាប្រជាជនបារាំងទូទៅ។ ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានគិតថាការងារដ៏អស្ចារ្យបំផុតរបស់ទ្រង់គឺប្រព័ន្ធច្បាប់ដ៏ទូលំទូលាយរបស់ទ្រង់ ដែលត្រូវបានគេស្គាល់ថាជាក្រមណាប៉ូឡេអ៊ុង។ ក្រមនេះបានផ្តល់ឱ្យប្រទេសបារាំងនូវសំណុំច្បាប់ដូចគ្នាមួយ និងលុបបំបាត់ភាពអយុត្តិធម៌ជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ វាពិតជាបានកម្រិតសេរីភាព និងបានលើកកម្ពស់សណ្តាប់ធ្នាប់ និងសិទ្ធិអំណាចសិទ្ធិបុគ្គល។ ឧទាហរណ៍ សេរីភាពនៃការបញ្ចេញមតិ និងសារព័ត៌មាន ដែលត្រូវបានបង្កើតឡើងនៅអំឡុងពេលនៃការធ្វើបដិវត្ត ត្រូវបានដាក់កម្រិតក្រោមក្រម។ ក្រមនេះក៏បានស្តារឡើងវិញនូវរបបទាសភាពក្នុងដែនដីអាណានិគមបារាំងនៅតំបន់ការ៉ាប៊ីនផងដែរ។

ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងឡើងគ្រងរាជ្យជាអធិរាជ៖ នៅឆ្នាំ 1804 ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានសម្រេចចិត្តតែងតាំងខ្លួនទ្រង់ជាអធិរាជ ហើយក្រុមអ្នកបោះឆ្នោតបារាំងបានគាំទ្រទ្រង់។ នៅថ្ងៃទី 2 ខែធ្នូ ឆ្នាំ 1804 ដោយស្លៀកពាក់អាវផាយពណ៌ស្វាយដ៏ប្រណិត ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងបានដើរតាមច្រកផ្លូវដ៏វែងនៃវិហារណោតត្រេដាំក្នុងទីក្រុងប៉ារីស។ សម្តេចប៉ាបបានរង់ចាំទ្រង់ជាមួយនឹងមកុដដ៏ភ្លឺចែងចាំង។ ដូចដែលមនុស្សរាប់ពាន់នាក់កំពុងទស្សនា ព្រះចៅអធិរាជថ្មីបានយកមកុដពីសម្តេចប៉ាប ហើយដាក់វានៅលើព្រះកេសរបស់ទ្រង់ដោយផ្ទាល់។ ជាមួយ

នឹងកាយវិការនេះ ព្រះអង្គម្ចាស់ណាប៉ូឡេអុងបានបង្ហាញថាគាត់មានកម្លាំងខ្លាំងជាងព្រះវិហារគ្រីស្តសាសនា ដែលជាប្រពៃណីបំពាក់មកុដដល់មេដឹកនាំបារាំង។

## 2. អធិរាជណាប៉ូឡេអុងបង្កើតចក្រភព

អធិរាជណាប៉ូឡេអុងមិនសូវពេញចិត្តក្នុងការធ្វើជាមេដឹកធម្មតារបស់បារាំងឡើយ។ ទ្រង់ចង់គ្រប់គ្រងតំបន់អឺរ៉ុបទាំងមូល និងដើម្បីអះអាងពីអំណាចរបស់បារាំងនៅអាមេរិកឡើងវិញ។ ទ្រង់បាននឹកស្រមៃពីអាណាចក្រខាងលិចរបស់ទ្រង់ ដោយក្នុងនោះរួមមានរដ្ឋល្វីស៊ាណា, ផ្លូរីដា, បារាំងហ្គាណា, និងបារាំងឥណ្ឌាខាងលិច។ ទ្រង់ដឹងថាគន្លឹះសំខាន់នៃតំបន់នេះគឺដែនដីអាណានិគមផលិតស្ករសេន ដូមីនហ្គេ (បច្ចុប្បន្នស្ថិតនៅហៃទី) នៅលើកោះហ៊ីស្ប៉ានីអូឡា។

ការបាត់បង់ដែនដីអាណានិគមអាមេរិក៖ នៅឆ្នាំ 1789 នៅពេលដែលគំនិតបដិវត្តបានទៅដល់ក្រុមអ្នកដាំដុះនៅសេន ដូមីនហ្គេ ពួកគេបានទាមទារឱ្យរដ្ឋសភាផ្តល់ឱ្យពួកគេនូវឯកសិទ្ធិដូចគ្នានឹងប្រជាជនបារាំង។ នៅទីបំផុត ជនជាតិអាហ្វ្រិកដែលជាទាសករនៅក្នុងដែនដីអាណានិគមបានទាមទារសិទ្ធិរបស់ពួកគេផងដែរ ឬក៏ហៅម្យ៉ាងទៀតថាសេរីភាពរបស់ពួកគេ។ សង្គ្រាមស៊ីវិលបានផ្ទុះឡើង ហើយពួកទាសករអាហ្វ្រិកក្រោមការដឹកនាំរបស់ទូសេនត៍ ឡូវ៉ែទូរ បានដណ្តើមកាន់កាប់ដែនដីអាណានិគម។ នៅឆ្នាំ 1801 អធិរាជណាប៉ូឡេអុងបានសម្រេចចិត្តយកដែនដីអាណានិគមនេះមកវិញ ហើយស្តារឧស្សាហកម្មផលិតស្ករឡើងវិញ។ ទោះជាយ៉ាងណា កងកម្លាំងរបស់បារាំងត្រូវបានហិនហោចដោយសារជំងឺ។ ហើយក្រុមឧទ្ទាមបានបង្ហាញពីការប្រយុទ្ធដ៏អង់អាចរបស់ពួកគេ។ បន្ទាប់ពីការបរាជ័យនៃបេសកកម្មទៅកាន់សេន ដូមីនហ្គេ អធិរាជណាប៉ូឡេអុងបានសម្រេចចិត្តកាត់បន្ថយការខាតបង់របស់ទ្រង់នៅអាមេរិក។ គាត់បានស្នើលក់ទឹកដីរដ្ឋល្វីស៊ាណាទាំងអស់ឱ្យទៅសហរដ្ឋអាមេរិក ហើយនៅឆ្នាំ 1803 រដ្ឋបាលរបស់ប្រធានាធិបតីចេហ្វហ្វឺសុនបានយល់ព្រមទិញដីនេះក្នុងតម្លៃ 15 លានដុល្លារ។ អធិរាជណាប៉ូឡេអុងបានមើលឃើញអត្ថប្រយោជន៍ពីរយ៉ាងចំពោះការលក់នេះ។ ទីមួយ ទ្រង់នឹងទទួលបានប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការនៅអឺរ៉ុប។ ទីពីរទ្រង់នឹងដាក់ទណ្ឌកម្មដល់ពួកអង់គ្លេស។ ទ្រង់សង្កេតឃើញថា "ការលក់នេះនឹងធានាជារៀងរហូតនូវអំណាចរបស់សហរដ្ឋអាមេរិក ហើយខ្ញុំបានផ្តល់ឱ្យគូប្រជែង អង់គ្លេស យ៉ាងឆាប់ ឬក្រោយមក នូវការបន្ទាបលើមោទនភាពហួសហេតុរបស់ពួកគេ" ។

ការដណ្តើមកាន់កាប់ទ្វីបអឺរ៉ុប៖ ដោយបានបោះបង់ចោលនូវមហិច្ឆិតារបស់ទ្រង់លើដែនដីថ្មីនៅអាមេរិក អធិរាជណាប៉ូឡេអុងបានបង្វែរចំណាប់អារម្មណ៍របស់ទ្រង់ទៅលើតំបន់អឺរ៉ុប។ ទ្រង់បានបញ្ចូលប្រទេសអូទ្រីស, ហូឡង់, និងផ្នែកខ្លះនៃអ៊ីតាលី ទៅក្នុងចក្រភពប្រទេសបារាំង និងបានបង្កើតរដ្ឋាភិបាលអាយ៉ងមួយនៅប្រទេសស្វីស។ ឥឡូវនេះ ទ្រង់សម្លឹងទៅរកការពង្រីកឥទ្ធិពលរបស់ទ្រង់បន្ថែមទៀត។ ដោយមានការព្រួយបារម្ភពីមហិច្ឆតារបស់ទ្រង់ អង់គ្លេសបានបញ្ចុះបញ្ចូលរុស្ស៊ី, អូទ្រីស, និងស៊ុយអែត ឱ្យចូលរួមជាមួយពួកគេប្រឆាំងនឹងបារាំង។ អធិរាជណាប៉ូឡេអុងបានប្រឈមជាមួយបញ្ហានេះដាមួយនឹងភាពក្លាហានរបស់ទ្រង់។ ក្នុងការប្រយុទ្ធដ៏ខ្លាំងក្លាជាបន្តបន្ទាប់ ទ្រង់បានវាយកម្ទេចក្រុមប្រឆាំង។ មេបញ្ជាការនៃកងទ័ពសត្រូវ មិនអាចទស្សន៍ទាយពីចលនាបន្ទាប់របស់

ទ្រង់បានឡើយ ហើយជារឿយៗពួកគេមានការខាតបង់យ៉ាងធ្ងន់ធ្ងរ។ ក្រោយមក ជោគជ័យក្នុងសមរភូមិប្រយុទ្ធរបស់អធិរាជណាប៉ូឡេអុង បានបង្ខំឱ្យមេដឹកនាំនៃប្រទេសអូទ្រីស, ព្រូស, និងរុស្ស៊ីចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពមួយជាមួយបារាំង។ ជោគជ័យទាំងនេះក៏បានអនុញ្ញាតឱ្យទ្រង់អាចស្ថាបនាចក្រភពអឺរ៉ុបដ៏ធំបំផុតចាប់តាំងពីសម័យរ៉ូមមក។ សត្រូវដ៏សំខាន់តែមួយគត់របស់បារាំង ដែលមិនបានបរាជ័យគឺជាមហាអំណាចកងទ័ពជើងទឹកអង់គ្លេស។

សមរភូមិត្រាហ្វាលហ្គារ៉៖ ក្នុងការព្យាយាមរបស់ទ្រង់ក្នុងការបង្កើតចក្រភពអឺរ៉ុប អធិរាជណាប៉ូឡេអុងបានបរាជ័យសមរភូមិដ៏សំខាន់តែមួយគត់គឺ សមរភូមិត្រាហ្វាហ្គារ៉ ។ ទោះជាយ៉ាងណាក៏ដោយ ការបរាជ័យរបស់កងទ័ពជើងទឹកនេះគឺសំខាន់ជាងជ័យជម្នះទាំងអស់របស់ទ្រង់នៅលើគោក។ ការប្រយុទ្ធគ្នាបានកើតឡើងនៅឆ្នាំ 1805 នៅឆ្នេរសមុទ្រភាគនិរតីនៃប្រទេសអេស្ប៉ាញ។ មេទ័ពអង់គ្លេសមួយរូបឈ្មោះហូរ៉ាទីអូ នេលសុន ជាអ្នកដែលពូកែខាងធ្វើសង្គ្រាមនៅសមុទ្រ ដូចជាអធិរាជណាប៉ូឡេអុងពូកែធ្វើសង្គ្រាមនៅលើគោក។ នៅក្នុងការប្រយុទ្ធដ៏អង់អាចលោកបានបំបែកកងនាវារបស់បារាំងដែលមានទំហំធំជាង ដោយបានចាប់យកនាវាជាច្រើន។ ការបំផ្លិចបំផ្លាញនៃកងនាវាបារាំងផ្តល់នូវលទ្ធផលសំខាន់ៗចំនួនពីរ។ ទីមួយ វាធានានូវឧត្តមភាពនៃកងទ័ពជើងទឹកអង់គ្លេសសម្រាប់រយៈពេល 100 ឆ្នាំខាងមុខ។ ទីពីរ វាបានបង្ខំអធិរាជណាប៉ូឡេអុងឱ្យបោះបង់ផែនការរបស់ទ្រង់ក្នុងការឈ្លានពានចក្រភពអង់គ្លេស។ ទ្រង់ត្រូវស្វែងរកមធ្យោបាយមួយផ្សេងទៀតដើម្បីគ្រប់គ្រងសត្រូវដ៏មានឥទ្ធិពលរបស់ទ្រង់នៅត្រើយម្ខាងទៀតនៃច្រកសមុទ្រអង់គ្លេស។ នៅទីបំផុត កិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លារបស់អធិរាជណាប៉ូឡេអុងដើម្បីកម្ទេចចក្រភពអង់គ្លេស នឹងនាំទៅដល់ការកម្ទេចខ្លួនឯង។

ចក្រភពបារាំង៖ នៅអំឡុងដើមដំបូងនៃទសវត្សរ៍ឆ្នាំ 1800 ជ័យជំនះរបស់អធិរាជណាប៉ូឡេអុងបានផ្តល់ឱ្យទ្រង់នូវភាពជាម្ចាស់លើដែនដីអឺរ៉ុបមួយភាគធំ។ នៅឆ្នាំ 1812 មានតែតំបន់តែមួយចំនួនតូចនៃទ្វីបអឺរ៉ុបដែលរួចផុតពីការគ្រប់គ្រងរបស់អធិរាជណាប៉ូឡេអុង ក្នុងនោះរួមមានចក្រភពអង់គ្លេស, ព័រទុយហ្គាល់, ស៊ុយអែត, និងចក្រភពអូតូម៉ង់។ ក្រៅពីទឹកដីនៃចក្រភពបារាំង អធិរាជណាប៉ូឡេអុងក៏បានត្រួតត្រាប្រទេសឯករាជ្យផ្សេងៗទៀតជាច្រើនផងដែរ។ ក្នុងនោះរួមមានប្រទេសអេស្ប៉ាញ, ព្រះរាជាណាចក្រវ៉ារស, និងព្រះរាជាណាចក្រមួយចំនួនរបស់ពួកអាល្លឺម៉ង់នៅអឺរ៉ុបកណ្តាល។ មេដឹកនាំនៃប្រទេសទាំងនេះគឺជាអាយ៉ងរបស់អធិរាជណាប៉ូឡេអុង ដោយពួកគេមួយចំនួនជាសមាជិកនៃរាជវង្សរបស់ទ្រង់។ ជាងនេះទៅទៀត ប្រទេសមហាអំណាចមួយចំនួនដូចជារុស្ស៊ី, ព្រូស, និងអូទ្រីស បានភ្ជាប់ជាមួយចក្រភពរបស់អធិរាជណាប៉ូឡេអុងយ៉ាងងាយស្រួលតាមរយៈការចងសម្ព័ន្ធភាព។ ទោះបីជាមិនស្ថិតក្រោមការគ្រប់គ្រងរបស់អធិរាជណាប៉ូឡេអុងទាំងស្រុងក៏ដោយ ក៏ពួកគេមានភាពងាយស្រួលក្នុងការបញ្ជា ដោយសារតែការពួកគេត្រូវបានគំរាមកំហែងក្នុងការប្រើប្រាស់កម្លាំងយោធា។ ចក្រភពបារាំងមានទំហំធំ ប៉ុន្តែមិនស្ថិតស្ថេរឡើយ។ អធិរាជណាប៉ូឡេអុងអាចរក្សាចក្រភពនេះបានត្រឹមរយៈពេលតែប្រាំឆ្នាំប៉ុណ្ណោះគឺពីឆ្នាំ 1807 ដល់ឆ្នាំ 1812។ បន្ទាប់មកវាបានដួលរលំភ្លាមៗ។ ការដួលរលំភ្លាមៗរបស់វាត្រូវមួយផ្នែកបង្កឡើងដោយសកម្មភាពរបស់អធិរាជណាប៉ូឡេអុងផ្ទាល់។

# មេរៀនទី 4៖ ចក្រភពរបស់អធិរាជណាប៉ូឡេអុងដួលរលំ

អធិរាជណាប៉ូឡេអុងមានការព្រួយបារម្ភអំពីអ្វីដែលនឹងកើតឡើងចំពោះចក្រភពដ៏ធំរបស់ទ្រង់ បន្ទាប់ពីការសោយទីវង្គតរបស់ទ្រង់។ ទ្រង់ខ្លាចថាវាអាចនឹងធ្លាក់ចុះ លុះត្រាតែទ្រង់មានអ្នកស្នងតំណែងបន្តពីទ្រង់មួយរូបមិនមានជម្លោះ។ មហេសីរបស់ទ្រង់ព្រះនាមចូសេភីនបានបរាជ័យក្នុងការបង្កើតរាជបុត្រឱ្យទ្រង់។ ដូច្នេះទ្រង់បានលែងលះព្រះនាង ហើយបានបង្កើតសម្ព័ន្ធភាពជាមួយគ្រួសាររាជវង្សអូទ្រីស ដោយរៀបអភិសេកជាមួយព្រះនាងម៉ារី លូវីស ដែលជាចៅស្រីរបស់ម្ចាស់ក្សត្រម៉ារី អង់តូនេតេ។ នៅឆ្នាំ 1811 ម្ចាស់ក្សត្រីម៉ារី លូវីស បានប្រសូត្ររាជបុត្រាមួយអង្គគឺណាប៉ូឡេអុងទី 2 ដែលអធិរាជណាប៉ូឡេអុងដាក់ព្រះនាមឱ្យទ្រង់ថា ស្ដេចនៃទីក្រុងរ៉ូម។

## 1. កំហុសដ៏ធំរបស់អធិរាជណាប៉ូឡេអុង

បុគ្គលិកលក្ខណៈផ្ទាល់របស់អធិរាជណាប៉ូឡេអុង បានបង្ហាញឱ្យឃើញពីគ្រោះថ្នាក់ដ៏ធំបំផុតចំពោះអនាគតនៃចក្រភពរបស់ទ្រង់។ បំណងប្រាថ្នាក្នុងការគ្រប់គ្រងអំណាចរបស់ទ្រង់បានរុញច្រានទ្រង់ឱ្យឡើងដល់កម្រិតខ្ពស់មួយ ហើយការស្រឡាញ់អំណាចរបស់ទ្រង់ ដូចគ្នាបាននាំទ្រង់ទៅរកសេចក្ដីវិនាស។ នៅក្នុងការខិតខំប្រឹងប្រែងរបស់ទ្រង់ដើម្បីពង្រីកចក្រភពបារាំង និងកម្ទេចចក្រភពអង់គ្លេស អធិរាជណាប៉ូឡេអុងបានប្រព្រឹត្តិកំហុស 3 យ៉ាង។

ប្រព័ន្ធដីទ្វីប៖ នៅក្នុងខែវិច្ឆិកា ឆ្នាំ 1806 អធិរាជណាប៉ូឡេអុងបានបង្កើតការបិទខ្ទប់មួយ ដោយបានបង្ខំឱ្យបិទកំពង់ផែទាំងឡាយដើម្បីទប់ស្កាត់រាល់ការធ្វើពាណិជ្ជកម្ម និងការទំនាក់ទំនងរវាងចក្រភពអង់គ្លេស និងប្រទេសអឺរ៉ុបផ្សេងៗទៀត។ អធិរាជណាប៉ូឡេអុងបានហៅគោលនយោបាយនេះថា ប្រព័ន្ធដីទ្វីប ព្រោះវាត្រូវបានគេចាត់ទុកថាធ្វើឱ្យទ្វីបអឺរ៉ុបកាន់តែពឹងផ្អែកលើខ្លួនឯង។ អធិរាជណាប៉ូឡេអុងក៏មានបំណងចង់បំផ្លាញសេដ្ឋកិច្ចពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ចក្រភពអង់គ្លេសផងដែរ។ ទោះជាយ៉ាងនេះក្ដី ការបិទខ្ទប់របស់អធិរាជណាប៉ូឡេអុង មិនមានភាពតឹងរឹងគ្រប់គ្រាន់នោះទេ។ ដោយមានជំនួយពីចក្រភពអង់គ្លេស ពួកអ្នករត់ពន្ធអាចនាំទំនិញពីអង់គ្លេសចូលទៅអឺរ៉ុប។ ជួនកាល សម្ព័ន្ធមិត្តរបស់អធិរាជណាប៉ូឡេអុង ក៏មិនយកចិត្តទុកដាក់ចំពោះការបិទខ្ទប់នេះដែរ។ សូម្បីតែសមាជិកនៃរាជវង្សរបស់អធិរាជណាប៉ូឡេអុងបានជំទាស់នឹងគោលនយោបាយនេះ ក្នុងនោះរួមមានទាំងព្រះរាមរបស់ទ្រង់ព្រះនាមល្វី ដែលទ្រង់បានឡើងសោយរាជ្យនៅប្រទេសហូឡង់។ ខណៈពេលដែលការបិទខ្ទប់ធ្វើឱ្យពាណិជ្ជកម្មអង់គ្លេសចុះខ្សោយ តែវាមិនខ្ទេចឡើយ។ បន្ថែមពីលើនេះ អង់គ្លេសបានឆ្លើយតបដោយការបិទខ្ទប់ខ្លួនពួកគេដោយខ្លួនឯង។ ហើយដោយសារអង់គ្លេសមានទ័ពជើងទឹកខ្លាំងជាង ពួកគេមានសមត្ថភាពល្អជាងបារាំងក្នុងការធ្វើឱ្យការបិទខ្ទប់ដំណើរការ។ ដើម្បីអនុវត្តការបិទខ្ទប់ កងទ័ពជើងទឹករបស់អង់គ្លេសបានបញ្ឈប់កប៉ាល់អព្យាក្រឹតដែលដឹកទំនិញទៅកាន់ដីទ្វីប ហើយបង្ខំពួកគេឱ្យពួកគេបើកបរទៅកាន់កំពង់ផែអង់គ្លេសដើម្បីត្រួតពិនិត្យ និងបង់ពន្ធ។ កប៉ាល់អាមេរិកស្ថិតក្នុងចំណោមកប៉ាល់ដែលត្រូវបានបញ្ឈប់ដោយកងទ័ពជើងទឹកអង់គ្លេស។ ដោយកំហឹង សភាសហរដ្ឋអាមេរិកបានប្រកាសសង្គ្រាមជាមួយចក្រភពអង់គ្លេសនៅឆ្នាំ 1812។ ទោះបីជាសង្គ្រាមឆ្នាំ 1812 មានរយៈពេល 2 ឆ្នាំក៏ដោយ វាគ្រាន់តែជាការរអាក់រអួលបន្តិចបន្តួចចំពោះចក្រភពអង់គ្លេសក្នុងការតស៊ូជាមួយអធិរាជណាប៉ូឡេអុង។

សង្គ្រាមឧបទ្វីបៈ នៅឆ្នាំ 1808 អធិរាជណាប៉ូឡេអុងបានធ្វើកំហុសសំខាន់ទី 2 ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យព័រទុយហ្គាល់ទទួលយកប្រព័ន្ធដីទ្វីប ទ្រង់បានបញ្ជូនកងកម្លាំងឈ្លានពានឆ្លងកាត់ប្រទេសអេស្ប៉ាញ។ ប្រជាជនអេស្ប៉ាញពេលនោះបានតវ៉ាចំពោះសកម្មភាពនេះ។ ជាការឆ្លើយតប អធិរាជណាប៉ូឡេអុងបានដកស្តេចអេស្ប៉ាញចេញចេញពីតំណែង ហើយបានដាក់អនុជរបស់ទ្រង់ព្រះនាមយ៉ូសែបឱ្យឡើងគ្រងរាជ្យ។ ការធ្វើដូច្នេះបានបណ្តាលឱ្យប្រជាជនអេស្ប៉ាញកាន់តែខឹងសម្បា និងបានបង្កឱ្យគំនិតជាតិនិយមរបស់ពួកគេឆេះឡើង។ ពួកអេស្ប៉ាញដែលកាន់សាសនាកាតូលិកក៏មានការព្រួយបារម្ភថា អធិរាជណាប៉ូឡេអុងនឹងវាយប្រហារមកលើព្រះវិហារគ្រីស្តសាសនា។ ពួកគេបានឃើញពីបទពិសោធន៍ដែលបដិវត្តបារាំងបានធ្វើឱ្យព្រះវិហារកាតូលិកចុះខ្សោយនៅក្នុងប្រទេសបារាំង ហើយពួកគេបារម្ភថារឿងដដែលនឹងកើតឡើងចំពោះព្រះវិហារគ្រីស្តសាសនានៅក្នុងប្រទេសអេស្ប៉ាញ។ អស់រយៈពេល 6 ឆ្នាំ ក្រុមយុទ្ធជនកសិករអេស្ប៉ាញ ដែលគេស្គាល់ថាជាទ័ពព្រៃ បានវាយប្រហារលើកងទ័ពបារាំងក្នុងប្រទេសអេស្ប៉ាញ។ ទ័ពព្រៃមិនមែនជាកងទ័ពដែលអធិរាជណាប៉ូឡេអុងអាចយកឈ្នះក្នុងសមរភូមិបើកចំហបាននោះទេ។ ផ្ទុយទៅវិញ ពួកគេបានធ្វើការជាក្រុមតូចៗដែលវាយឆ្មក់កងទ័ពបារាំង ហើយបន្ទាប់មកបានរត់គេចទៅលាក់ខ្លួន។ អង់គ្លេសបានបន្ថែមបញ្ហាដល់បារាំង តាមរយៈការបញ្ជូនទ័ពទៅជួយអេស្ប៉ាញ។ ណាប៉ូឡេអុងបានបាត់បង់កងទ័ពប្រហែល 300,000 នាក់ក្នុងអំឡុងពេលនៃសង្គ្រាមឧបទ្វីបនេះ វាត្រូវបានគេហៅដូច្នេះ ដោយសារតែប្រទេសអេស្ប៉ាញស្ថិតនៅលើឧបទ្វីបអ៊ីប័ររៀន។ ការខាតបង់ទាំងនេះបានធ្វើឱ្យចក្រភពបារាំងចុះខ្សោយ។ នៅក្នុងប្រទេសអេស្ប៉ាញ និងកន្លែងផ្សេងទៀត ជាតិនិយម ឬភក្តីភាពចំពោះប្រទេសរបស់ខ្លួនបានក្លាយទៅជាអាវុធដ៏មានឥទ្ធិពលប្រឆាំងនឹងអធិរាជណាប៉ូឡេអុង។ ប្រជាជនដែលបានស្វាគមន៍បារាំងពីដំបូងក្នុងនាមជាអ្នករំដោះរបស់ពួកគេ ឥឡូវមានអារម្មណ៍ថាពួកគេគឺជាអ្នកឈ្លានពាន។ ក៏ដូចជាទ័ពព្រៃអេស្ប៉ាញ ជនជាតិអាឡឺម៉ង់, អ៊ីតាលី, និងតំបន់ដែលបារាំងដណ្តើមកាន់កាប់ផ្សេងទៀតបានងាកមកប្រឆាំងជាមួយនឹងបារាំង។

ការលុកលុយរុស្ស៊ី៖ កំហុសដ៏មហន្តរាយបំផុតរបស់អធិរាជណាប៉ូឡេអុងបានកើតឡើងនៅឆ្នាំ 1812 ។ ទោះបីជាព្រះអង្គម្ចាស់អាឡិចសាន់ឌឺទី 1 បានក្លាយជាសម្ព័ន្ធមិត្តរបស់អធិរាជណាប៉ូឡេអុងក៏ដោយ ក៏ព្រះមហាក្សត្ររុស្ស៊ីអង្គនេះបានបដិសេធក្នុងការឈប់លក់គ្រាប់ធញ្ញជាតិទៅឱ្យចក្រភពអង់គ្លេស។ លើសពីនេះ មេដឹកនាំបារាំង និងរុស្ស៊ីបានសង្ស័យគ្នាទៅវិញទៅមកថា ក្នុងការប្រកួតប្រជែងគ្នាដើម្បីដណ្តើមប្រទេសប៉ូឡូញ។ ដោយសារតែការបែកបាក់នៅក្នុងសម្ព័ន្ធភាពរបស់ពួកទ្រង់ អធិរាជណាប៉ូឡេអុងបានសម្រេចចិត្តក្នុងការឈ្លានពានប្រទេសរុស្ស៊ី។ នៅខែមិថុនា ឆ្នាំ 1812 អធិរាជណាប៉ូឡេអុង និងកងទ័ពដ៏ច្រើនរបស់ទ្រង់ ដែលមានទាហានជាង 420,000 នាក់បានធ្វើដំណើរឆ្ពោះទៅកាន់ប្រទេសរុស្ស៊ី។ នៅពេលដែលអធិរាជណាប៉ូឡេអុងបានរុលទៅមុខ ព្រះអង្គម្ចាស់អាឡិចសាន់ឌឺបានដកទ័ពរបស់ទ្រង់មកវិញ ដោយបដិសេធក្នុងការចូលទៅក្នុងសមរភូមិដែលមិនស្មើភាពគ្នា។ ក្នុងការដកថយនេះ ជនជាតិរុស្ស៊ីបានអនុវត្តគោលនយោបាយដុតកម្ទេចផែនដី។ គោលនយោបាយនេះពាក់ព័ន្ធនឹងការដុតចំការ និងសម្លាប់សត្វពាហនៈ ដើម្បីកុំឱ្យខ្មាំងសត្រូវអាចយកធ្វើជាចំណីបរិភោគ។ នៅថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1812 ទីបំផុតកងទ័ពទាំង 2 បានប៉ះទង្គិចគ្នានៅក្នុងសមរភូមិបូរ៉ូឌីណូ។ បន្ទាប់ពីការប្រយុទ្ធគ្នាមិនច្បាស់លាស់ជាច្រើនម៉ោង ពួករុស្ស៊ីបានថយក្រោយ ដោយអនុញ្ញាតឱ្យអធិរាជណាប៉ូឡេអុងធ្វើដំណើរចូលទីក្រុង

មូស្គូ។ 7 ថ្ងៃក្រោយមក នៅពេលដែលអធិរាជណាប៉ូឡេអុងចូលដល់ទីក្រុងមូស្គូ ទីក្រុងនេះត្រូវបានដុតបំផ្លាញ។ ជាជាងប្រគល់ "ទីក្រុងបរិសុទ្ធ" របស់រុស្ស៊ីទៅឱ្យទៅពួកបារាំង ព្រះអង្គម្ចាស់អាឡិចសាន់ឌឺបានដុតបំផ្លាញវាចោល។ អធិរាជណាប៉ូឡេអុងបានស្នាក់នៅក្នុងទីក្រុងដែលរងការខូចខាតរហូតដល់ពាក់កណ្តាលខែតុលា ទើបទ្រង់សម្រេចចិត្តត្រឡប់មកបារាំងវិញ។ នៅពេលដែលព្រិល និងសីតុណ្ហភាពចាប់ផ្តើមធ្លាក់ចុះនៅដើមខែវិច្ឆិកា ក្រុមអ្នកវាយឆ្មក់រុស្ស៊ីបានវាយប្រហារដោយឥតមេត្តាលើកងទ័ពរបស់អធិរាជណាប៉ូឡេអុងដែលកំពុងដកថយ។ ទាហានជាច្រើនត្រូវបានស្លាប់ក្នុងការប៉ះទង្គិចទាំងនេះ ឬស្លាប់ដោយសាររបួស។ ប៉ុន្តែពួកគេមួយភាគធំមានស្លាប់ដោយសារភាពនឿយហត់, ស្រេកឃ្លាន, និងត្រជាក់។ ទីបំផុត នៅពាក់កណ្តាលខែធ្នូ ក្រុមអ្នករស់រានមានជីវិតចុងក្រោយបានរត់ចេញពីប្រទេសរុស្ស៊ី។ ការដកថយពីទីក្រុងមូស្គូបានបំផ្លិចបំផ្លាញកងទ័ពដ៏ធំនៅសល់តែប្រមាណ 10,000 នាក់ប៉ុណ្ណោះ ។

## 2. ការដួលរលំរបស់អធិរាជណាប៉ូឡេអុង

ខ្មាំងសត្រូវរបស់ណាប៉ូឡេអុង យ៉ាងឆាប់រហ័សបានទាញយកប្រយោជន៍ពីភាពទន់ខ្សោយរបស់ទ្រង់។ ចក្រភពអង់គ្លេស, រុស្ស៊ី, ព្រូស, និងស៊ុយអែត បានចូលរួមកម្លាំងគ្នាប្រឆាំងជាមួយទ្រង់។ ប្រទេសអូទ្រីសក៏បានប្រកាសសង្គ្រាមជាមួយអធិរាជណាប៉ូឡេអុងផងដែរ បើទោះបីជាទ្រង់បានរៀបអភិសេកជាមួយម្ចាស់ក្សត្រីម៉ារីល្វីក៏ដោយ។ មហាអំណាចសំខាន់ៗទាំងអស់របស់អឺរ៉ុបឥឡូវនេះកំពុងធ្វើសង្គ្រាមជាមួយបារាំង។

អធិរាជណាប៉ូឡេអុងរងបរាជ័យ៖ ក្នុងរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ អធិរាជណាប៉ូឡេអុងអាចបង្កើនកងទ័ពដ៏ធំបានមួយទៀត។ ទោះយ៉ាងណាក៏ដោយ កងទ័ពរបស់ទ្រង់ភាគច្រើនមិនទទួលបានការហ្វឹកហាត់ និងត្រៀមខ្លួនសម្រាប់ការប្រយុទ្ធឡើយ។ ទ្រង់បានប្រឈមមុខនឹងកងទ័ពសម្ព័ន្ធមិត្តនៃមហាអំណាចអឺរ៉ុបនៅខាងក្រៅទីក្រុងលីពស៊ីរបស់អាល្លឺម៉ង់ ក្នុងខែតុលា ឆ្នាំ 1813។ កងកម្លាំងសម្ព័ន្ធមិត្ត យ៉ាងងាយស្រួលបានកម្ចាត់កងទ័ពដែលគ្មានបទពិសោធន៍របស់ទ្រង់ ហើយការតស៊ូរបស់បារាំងបានដួលរលំយ៉ាងឆាប់រហ័ស។ នៅខែមករា ឆ្នាំ 1814 កងទ័ពសម្ព័ន្ធមិត្តបានរុលទៅមុខឆ្ពោះទៅកាន់ទីក្រុងប៉ារីស។ 2 ខែក្រោយមក ព្រះមហាក្សត្រហ្វ្រេឌឺរិច វីលៀមទី 3 របស់ព្រូស និងហ្សាអាឡិចសាន់ឌឺ របស់រុស្ស៊ីបានដឹកនាំកងទ័ពរបស់ពួកទ្រង់នៅក្នុងក្បួនដង្ហែជ័យជំនះឆ្លងកាត់រដ្ឋធានីបារាំង។ អធិរាជណាប៉ូឡេអុងនៅតែបន្តចង់ប្រយុទ្ធ ប៉ុន្តែមេទ័ពរបស់ទ្រង់បានបដិសេធ។ នៅខែមេសា ឆ្នាំ 1814 ទ្រង់បានទទួលយកលក្ខខណ្ឌនៃការចុះចាញ់ហើយបានលះបង់រាជបល្ល័ង្ករបស់គាត់។ ពួកអ្នកឈ្នះបានផ្តល់ឱ្យណាប៉ូឡេអុងនូវប្រាក់សោធន៍និវត្តន៍តូចមួយ ហើយបាននិរទេស ឬបណ្តេញទ្រង់ទៅកាន់អេលបាដែលជាកោះតូចមួយនៅឆ្នេរសមុទ្រអ៊ីតាលី។ សម្ព័ន្ធមិត្តរំពឹងថានឹងមិនមានបញ្ហាអ្វីទៀតទេបន្ទាប់ពីណាប៉ូឡេអុង ប៉ុន្តែពួកគេគិតខុស។

មួយរយថ្ងៃ៖ ព្រះរាមរបស់ព្រះអង្គម្ចាស់ល្វីទី 16 បានឡើងគ្រងរាជជាល្វីទី 18 (រាជបុត្ររបស់ព្រះមហាក្សត្រដែលត្រូវបានប្រហារជីវិតល្វីទី 17 បានសុគតក្នុងគុកនៅឆ្នាំ 1795 )។ ទោះជាយ៉ាងណាក៏ដោយ ព្រះមហាក្សត្រថ្មីយ៉ាងឆាប់រហ័សបានក្លាយទៅជាក្សត្រដែលមិនមានប្រជាប្រិយភាពក្នុងចំណោមរាស្ត្ររបស់ទ្រង់ ជាពិសេស

ពួកកសិករ។ ពួកគេសង្ស័យថាទ្រង់ចង់លុបចោលការធ្វើកែទម្រង់ដីធ្លីរបស់បដិវត្ត។ ដំណឹងអំពីបញ្ហារបស់ព្រះអង្គម្ចាស់ល្វីទី 18 បានជម្រុញទឹកចិត្តអធិរាជណាប៉ូឡេអ៊ុងក្នុងការព្យាយាមដណ្ដើមអំណាចមកវិញ។ ទ្រង់បានរត់គេចពីកោះអេលបា ហើយនៅថ្ងៃទី 1 ខែមីនា ឆ្នាំ 1815 ទ្រង់បានធ្វើដំណើរមកដល់ប្រទេសបារាំង។ ហ្វូងមនុស្សរីករាយស្វាគមន៍ទ្រង់ ពេលដែលទ្រង់ធ្វើដំណើរទៅទីក្រុងប៉ារីស។ ហើយអ្នកស្ម័គ្រចិត្តរាប់ពាន់នាក់បានចូលធ្វើជាកងទ័ពរបស់ទ្រង់។ ប៉ុន្មានថ្ងៃក្រោយមក អធិរាជណាប៉ូឡេអ៊ុងបានក្លាយជាអធិរាជបារាំងម្ដងទៀត។ ជាការឆ្លើយតបសម្ព័ន្ធមិត្តអឺរ៉ុបបានប្រមូលផ្ដុំកងទ័ពរបស់ខ្លួនយ៉ាងឆាប់រហ័ស។ កងទ័ពអង់គ្លេសដែលដឹកនាំដោយអ្នកអង្គម្ចាស់នៃទីក្រុងវ៉ែលលីងតុន បានប្រុងប្រៀបសម្រាប់ការប្រយុទ្ធនៅជិតភូមិវ៉ាត់ធីលូក្នុងប្រទេសប៊ែលហ្សិក។ នៅថ្ងៃទី 18 ខែមិថុនា ឆ្នាំ 1815 អធិរាជណាប៉ូឡេអ៊ុងបានធ្វើការវាយប្រហារ។ កងទ័ពអង់គ្លេសបានការពារទឹកដីរបស់ខ្លួនពេញមួយថ្ងៃ។ ពេលរសៀល កងទ័ពព្រូសបានមកដល់។ កងកម្លាំងរួមគ្នារវាងអង់គ្លេស និងព្រូស បានវាយប្រហារលើបារាំង។ 2 ថ្ងៃក្រោយមក កងទ័ពដែលនឿយហត់របស់អធិរាជណាប៉ូឡេអ៊ុងបានដកថយ ហើយកងកម្លាំងអង់គ្លេស និងព្រូសបានដេញពួកគេចេញពីសមរភូមិ។ ការបរាជ័យនេះបានបញ្ចប់ការតស៊ូចុងក្រោយរបស់អធិរាជណាប៉ូឡេអ៊ុងសម្រាប់អំណាច ដែលហៅថា មួយរយថ្ងៃ។ ដោយមិនមានឱកាសដូចលើកមុនទៀត អង់គ្លេសបានបញ្ជូនអធិរាជណាប៉ូឡេអ៊ុងទៅកាន់ហេឡេណាជាកោះដាច់ស្រយាលនៅអាត្លង់ទិកខាងត្បូង។ នៅទីនោះ ទ្រង់បានរស់នៅដោយនិរទេសឯកោអស់រយៈពេល 6 ឆ្នាំ ដោយបានកត់ត្រានូវអនុស្សាវរីយ៍ជាច្រើនរបស់ទ្រង់នៅទីនោះ។ ទ្រង់បានសុគតនៅឆ្នាំ 1821 ដោយសារជំងឺក្រពះ ប្រហែលជាមហារីក។ ដោយគ្មានការសង្ស័យ អធិរាជណាប៉ូឡេអ៊ុងគឺជាអ្នកដែលពូកែខាងយោធា និងជាអ្នកគ្រប់គ្រងដ៏អស្ចារ្យម្នាក់។ ទោះជាយ៉ាងណាក៏ដោយ ជ័យជំនះទាំងអស់របស់គាត់ និងសមិទ្ធិផលផ្សេងទៀតត្រូវតែវាស់វែងទល់នឹងជីវិតរាប់លាននាក់ដែលបានបាត់បង់នៅក្នុងការធ្វើសង្គ្រាមរបស់ទ្រង់។ អ្នកនិពន្ធជនជាតិបារាំងមួយរូបឈ្មោះអាឡេស៊ីស ដេ តូកេវីល បានសង្ខេបពីអត្តចរិតរបស់អធិរាជណាប៉ូឡេអ៊ុងដោយនិយាយថា "ទ្រង់មានភាពអស្ចារ្យដូចជាមនុស្សម្នាក់ដែលគ្មានគុណធម៌"។ ការបរាជ័យរបស់អធិរាជណាប៉ូឡេអ៊ុងបានបើកទ្វារសម្រាប់បណ្ដាប្រទេសអឺរ៉ុបដែលទទួលបានសេរីភាពក្នុងការបង្កើតសណ្ដាប់ធ្នាប់ថ្មីមួយ។

# មេរៀនទី 5៖ សន្និបាតនៃទីក្រុងវីយែន

ប្រមុខរដ្ឋាភិបាលអឺរ៉ុបកំពុងសម្លឹងទៅរកការបង្កើតសន្តិភាព និងស្ថិរភាពយូរអង្វែងមួយនៅទ្វីបអឺរ៉ុប បន្ទាប់ពីបរាជ័យរបស់អធិរាជណាប៉ូឡេអ៊ុង។ ពួកគេមានគោលដៅក្នុងការបង្កើតសណ្តាប់ធ្នាប់ថ្មីមួយនៅអឺរ៉ុប ដែលជាសន្តិសុខ និងស្ថិរភាពរួមសម្រាប់ទ្វីបទាំងមូល។ កិច្ចប្រជុំជាបន្តបន្ទាប់នៅទីក្រុងវីយែន ដែលគេស្គាល់ថាសន្និបាទនៃទីក្រុងវីយែន បានស្នើឱ្យមានការរៀបចំគោលនយោបាយនានាដើម្បីសម្រេចបាននូវគោលដៅនេះ។ដើមឡើយ សន្និបាទនៃទីក្រុងវីយែន ត្រូវបានកំណត់ពេលរយៈពេលចំនួន 4 សប្តាហ៍។ ផ្ទុយទៅវិញ វាបានបន្តអស់រយៈពេល 8 ខែ។

## 1. ផែនការរបស់មេតថ័រនិចសម្រាប់អឺរ៉ុប

ការសម្រេចចិត្តភាគច្រើនដែលត្រូវបានធ្វើឡើងនៅទីក្រុងវីយែននារដូវរងាឆ្នាំ 1814-1815 ត្រូវបានធ្វើឡើងដោយសម្ងាត់ក្នុងចំណោមអ្នកតំណាងនៃ "មហាអំណាច" ទាំង 5 ដែលក្នុងនោះរួមមាន រុស្ស៊ី, ព្រូស, អូទ្រីស, ចក្រភពអង់គ្លេស និងបារាំង។ នៅពេលនោះ អ្នកដែលមានឥទ្ធិពលបំផុតក្នុងចំណោមអ្នកតំណាងទាំងនេះ គឺរដ្ឋមន្ត្រីការបរទេសនៃប្រទេសអូទ្រីស ព្រះអង្គម្ចាស់ខ្លេមេនស៍ វុន មេតថ័រនិច ។ ព្រះអង្គម្ចាស់មេតថ័រនិច មិនទុកចិត្តលើទស្សនប្រជាធិបតេយ្យនៃបដិវត្តបារាំងឡើយ។ ក៏ដូចជាពួកអភិជនអឺរ៉ុបដទៃទៀតដែរ ទ្រង់មានអារម្មណ៍ថា អាកប្បកិរិយារបស់អធិរាជណាប៉ូឡេអ៊ុងគឺជាលទ្ធផល នៃការពិសោធន៍លទ្ធិប្រជាធិបតេយ្យ។ ព្រះអង្គម្ចាស់មេតថ័រនិច ចង់រក្សាអ្វីៗដូចដើម ហើយបានកត់សម្គាល់ថា "ការចាប់អារម្មណ៍ដំបូង និងធំបំផុតសម្រាប់ប្រជាជនគ្រប់ជាតិសាសន៍នោះគឺស្ថេរភាពនៃច្បាប់ដែលមិនត្រូវបានផ្លាស់ប្តូរ"។ ព្រះអង្គម្ចាស់មេតថ័រនិច រកបានគោលដៅចំនួន 3 នៅសន្និបាតទីក្រុងវីយែន។ ទី 1 ទ្រង់ចង់ការពារការឈ្លានពានរបស់បារាំងនាពេលអនាគតដោយឡោមព័ទ្ធបារាំងជាមួយប្រទេសខ្លាំងៗ។ ទី 2 ទ្រង់ចង់ស្តារតុល្យភាពអំណាចឡើងវិញ ដើម្បីកុំឱ្យប្រទេសណាមួយអាចគំរាមកំហែងប្រទេសមួយផ្សេងទៀត។ ទី 3 ត្រង់ចង់ស្តារនូវរាជបល្ល័ង្ករបស់គ្រួសាររាជវង្សអឺរ៉ុបឡើងវិញ ដែលពួកគេបានកាន់កាប់មុនការឈ្លានពានរបស់អធិរាជណាប៉ូឡេអ៊ុង។

ការហ៊ុមព័ទ្ធប្រទេសបារាំង៖ សន្និបាតបានចាត់វិធានការដូចខាងក្រោមដើម្បីធ្វើឱ្យប្រទេសទន់ខ្សោយទាំងឡាយដែលស្ថិតនៅជុំវិញប្រទេសបារាំងកាន់តែរឹងមាំ៖ (1) អតីតអូទ្រីសហូឡង់ និងសាធារណរដ្ឋហូឡង់បានរួបរួមគ្នាបង្កើតជាព្រះរាជាណាចក្រហូឡង់។ (2) ក្រុមរដ្ឋទាំង 39 របស់អាល្លឺម៉ង់ត្រូវបានរួមបញ្ចូលគ្នាបែបធូរលុងដូចដែលសហភាពអាឡឺម៉ង់ដែលទើបបង្កើតថ្មី គ្របដណ្តប់ដោយអូទ្រីស។ (3) ប្រទេសស្វីសត្រូវបានទទួលស្គាល់ថាជាប្រទេសឯករាជ្យ។ (4) ព្រះរាជាណាចក្រសារឌីនៀក្នុងប្រទេសអ៊ីតាលីត្រូវបានពង្រឹងកម្លាំងតាមរយៈការបូកបន្ថែមជេណូអា។ ការផ្លាស់ប្តូរទាំងនេះបានធ្វើឱ្យបណ្តាប្រទេសនៅអឺរ៉ុបអាចទប់ស្កាត់បារាំង និងរាំងប្រទេសនេះមិនឱ្យមានអំណាចលើប្រទេសទន់ខ្សោយ។

តុល្យភាពនៃអំណាច៖ ទោះបីជាមេដឹកនាំអឺរ៉ុបចង់ធ្វើឱ្យប្រទេសបារាំងចុះខ្សោយក៏ដោយ ក៏ពួកគេមិនចង់ទុកឱ្យប្រទេសនេះគ្មានអំណាចដែរ។ បើគេដាក់ទណ្ឌកម្មបារាំងធ្ងន់ធ្ងរពេក គេប្រហែលជាលើកទឹកចិត្តបារាំងឱ្យសងសឹក។ បើពួកគេបំបែកបារាំង នោះប្រទេសមួយទៀតអាចនឹងខ្លាំងដែលនឹងគំរាមពួកគេទាំងអស់។ ដូច្នេះ

មហាអំណាចដែលទទួលបានជ័យជម្នះមិនបានទាមទារយកតម្លៃធ្ងន់ធ្ងរពេកទេពីប្រទេសដែលចាញ់នោះទេ។ ជាលទ្ធផល បារាំងនៅតែជាមហាអំណាចអឺរ៉ុបដ៏សំខាន់មួយ ប៉ុន្តែអំណាចថយចុះជាងមុន។ ម្យ៉ាងទៀត គ្មានប្រទេសណាមួយនៅអឺរ៉ុបអាចយកឈ្នះប្រទេសផ្សេងបានដោយងាយនោះទេ។

ភាពស្របច្បាប់៖ មហាអំណាចបានបញ្ជាក់ពីគោលការណ៍នៃភាពស្របច្បាប់ ដោយយល់ស្របគ្នាថា អ្នកគ្រប់គ្រងទាំងឡាយដែលអធិរាជណាប៉ូឡេអុងបានបណ្តេញចេញពីបល្ល័ង្ករបស់ពួកគេ ត្រូវស្តារអំណាចរបស់ពួកគេឡើងវិញឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។ គ្រួសាររាជវង្សដែលកំពុងកាន់អំណាចនៅប្រទេសបារាំង, អេស្ប៉ាញ, និងរដ្ឋមួយចំនួនក្នុងប្រទេសអ៊ីតាលី និងអឺរ៉ុបកណ្តាលបានទទួលរាជ្យសម្បត្តិរបស់ពួកគេឡើងវិញ។ អ្នកចូលរួមនៅក្នុងសន្និបាតនៃទីក្រុងវីយែនបានជឿថា ការវិលត្រឡប់របស់អតីតព្រះមហាក្សត្រនឹងធ្វើឱ្យទំនាក់ទំនងនយោបាយមានស្ថេរភាពក្នុងចំណោមប្រជាជាតិនានា។ សន្និបាតនៃទីក្រុងវីយែន គឺជាជ័យជំនះផ្នែកនយោបាយតាមវិធីជាច្រើន។ ជាលើកដំបូងដែលប្រជាជាតិនៃទ្វីបអឺរ៉ុបទាំងមូលបានសហការគ្នាដើម្បីគ្រប់គ្រងកិច្ចការនយោបាយ។ ដំណោះស្រាយដែលពួកគេបានព្រមព្រៀងគ្នាគឺសមល្មម ដែលគ្មានប្រទេសណាមួយត្រូវបានទុកឱ្យមានការខឹងសម្បារ។ ដូច្នេះ សន្និបាតមិនបានសាបព្រោះគ្រាប់ពូជនៃសង្គ្រាមទៅថ្ងៃអនាគតទេ។ ក្នុងន័យនេះ វាទទួលបានជោគជ័យជាងការប្រជុំសន្តិភាពជាច្រើនទៀតនៅក្នុងប្រវត្តិសាស្ត្រ។ តាមរយៈការយល់ព្រមក្នុងការស្វែងរកជំនួយពីគ្នាទៅវិញទៅមកក្នុងករណីមានការគំរាមកំហែងដល់សន្តិភាព ប្រជាជាតិអឺរ៉ុបបានធានាជាបណ្តោះអាសន្នថានឹងមានតុល្យភាពនៃអំណាចនៅលើទ្វីបនេះ។ បន្ទាប់មក សន្និបាតក្រុងវីយែនបានបង្កើតសម័យកាលសន្តិភាពមួយនៅអឺរ៉ុប។ វាជាសន្តិភាពយូរអង្វែង។ មុនពេលដែលចក្រភពអង់គ្លេស និងបារាំងបានប្រយុទ្ធគ្នាជាមួយរុស្ស៊ីនៅក្នុងសង្គ្រាមគ្រីមេ គ្មានមហាអំណាចណាមួយក្នុងចំនោមមហាអំណាចទាំងប្រាំបានធ្វើសង្គ្រាមលើគ្នាទៅវិញទៅមកអស់រយៈពេលជិត 40 ឆ្នាំ។

## 2. ការផ្លាស់ប្តូរនយោបាយបន្ទាប់ពីសន្និបាតទីក្រុងវីយែន

សន្និបាតនៃទីក្រុងវីយែនគឺជាជ័យជំនះមួយសម្រាប់ពួកអ្នកអភិរក្សនិយម។ ពីប្រទេសមួយទៅប្រទេសមួយ ព្រះមហាក្សត្រ និងព្រះអង្គម្ចាស់បានបន្តកាន់អំណាចឡើងវិញ ស្របតាមគោលដៅរបស់ព្រះអង្គម្ចាស់មេតថ៍រនិច។ ទោះជាយ៉ាងណាក៏ដោយ មានភាពខុសគ្នាសំខាន់ៗពីប្រទេសមួយទៅប្រទេសមួយទៀត។ អង់គ្លេស និងបារាំងឥឡូវនេះមានរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ។ និយាយជាទូទៅ រដ្ឋាភិបាលនៅអឺរ៉ុបខាងកើត និងកណ្តាលគឺមានលក្ខណៈអភិរក្សជាង។ អ្នកគ្រប់គ្រងនៅរុស្ស៊ី, ព្រូស, និងអូទ្រីស គឺជាព្រះរាជាផ្តាច់ការ។

អភិរក្សនិយមនៅអឺរ៉ុប៖ មេដឹកនាំទាំងឡាយនៅទ្វីបអឺរ៉ុបមានការភ័យខ្លាចយ៉ាងខ្លាំងចំពោះកេរ្តិ៍ដំណែលនៃបដិវត្តបារាំង។ ពួកគេព្រួយបារម្ភថាទស្សនអំពីសេរីភាព, សមភាព, និងភាតរភាពអាចជំរុញឱ្យមានបដិវត្តនៅកន្លែងផ្សេងៗទៀត។ នៅចុងឆ្នាំ 1815 អធិរាជអាឡិចសាន់ឌឺទី 1 នៃប្រទេសរុស្ស៊ី, អធិរាជហ្វ្រង់ស៊ីសទី 1 នៃប្រទេសអូទ្រីស, និងព្រះមហាក្សត្រហ្វ្រេឌ្រិចវីលៀមទី 3 នៃព្រូសបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយហៅថាសម្ព័ន្ធពិសិដ្ឋ។ នៅក្នុងកិច្ចព្រមព្រៀងនោះ ពួកគេបានសន្យាថានឹងផ្អែតទំនាក់ទំនងរបស់ពួកគេជាមួយនឹង

ប្រទេសដទៃទៀតដោយឈរលើគោលការណ៍គ្រីស្តសាសនា ដើម្បីប្រយុទ្ធប្រឆាំងនឹងកម្លាំងបដិវត្ត។ ចុងក្រោយ សម្ព័ន្ធភាពមួយចំនួនដែលបង្កើតឡើងដោយព្រះអង្គម្ចាស់មេតចំរ៉ែនិច ដែលត្រូវបានហៅថាការប្រគុំតន្ត្រីនៃទ្វីបអឺរ៉ុប បានធានាថាប្រទេសនានានឹងជួយគ្នាទៅវិញទៅមកប្រសិនបើមានបដិវត្តណាមួយកើតឡើង។ នៅទូទាំងទ្វីបអឺរ៉ុប ពួកអភិរក្សនិយមបានគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ចំពោះរដ្ឋាភិបាល ប៉ុន្តែពួកគេមិនអាចលុបបំបាត់គំនិតដែលបានកើតឡើងនៅអំឡុងបដិវត្តបារាំងនោះទេ។ នយោបាយរបស់ប្រទេសបារាំងក្រោយឆ្នាំ 1815 ត្រូវបានបែងចែកយ៉ាងខ្លាំង។ ពួកអ្នកអភិរក្សនិយមបានសប្បាយរីករាយជាមួយនឹងរាជាធិបតេយ្យរបស់ព្រះអង្គម្ចាស់ល្វីទី 18 ហើយបានប្តេជ្ញាចិត្តក្នុងការធ្វើឱ្យវាស្ថិតស្ថេរ។ ទោះជាយ៉ាងណាក៏ដោយ ពួកសេរីនិយមចង់ឱ្យព្រះមហាក្សត្រចែករំលែកអំណាចបន្ថែមទៀតទៅឱ្យស្ថាប័ននីតិប្បញ្ញត្តិ។ ហើយមនុស្សជាច្រើននៅក្នុងវណ្ណៈទាបនៅតែបន្តប្តេជ្ញាចិត្តចំពោះទស្សននៃសេរីភាព, សមភាព, និងភាតរភាព។ ស្រដៀងគ្នានេះដែរ នៅក្នុងប្រទេសផ្សេងទៀត មានការផ្ទុះឡើងនូវភាពខុសគ្នានៃទស្សន និងបក្សពួកនិយម ដែលនឹងរួមចំណែកដោយផ្ទាល់ដល់ការលេចឡើងនៃបដិវត្តឆ្នាំ 1830 និង 1848 ។ ទោះបីជាមានការខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីលុបបំបាត់ចោលនូវបដិវត្តបារាំងក៏ដោយ ក៏មេដឹកនាំនៅសន្និបាតនៃទីក្រុងវីយែនមិនអាចបង្វិលម៉ោងត្រឡប់ថយក្រោយវិញបានឡើយ។ បដិវត្តបានផ្តល់ឱ្យពួកអឺរ៉ុបនូវការពិសោធន៍លើកដំបូងរបស់ខ្លួន នូវក្នុងប្រព័ន្ធរដ្ឋាភិបាលបែបប្រជាធិបតេយ្យ។ ទោះបីជាការពិសោធន៍នោះបានបរាជ័យក៏ដោយ វាបានកំណត់ទស្សននយោបាយថ្មីឱ្យមានចលនា។ ចលាចលនយោបាយសំខាន់ៗនៅដើមទសវត្សរ៍ឆ្នាំ 1800 មានឫសគល់មកពីបដិវត្តបារាំង។

បដិវត្តនៅអាមេរិកឡាទីន៖ សកម្មភាពរបស់សន្និបាតក្រុងវីយែនមានផលវិបាកលើសពីព្រឹត្តិការណ៍នៅអឺរ៉ុប។ នៅពេលដែលអធិរាជណាប៉ូឡេអ៊ុងទម្លាក់ស្តេចអេស្ប៉ាញចេញពីអំណាចនៅអំឡុងសង្គ្រាមឧបទ្វីប ពួកសេរីនិយមក្រេអូលេស(ពួកអាណានិគមអេស្ប៉ាញកើតនៅអាមេរិក) បានដណ្តើមកាន់កាប់ដែនដីអាណានិគមជាច្រើននៅអាមេរិក។ នៅពេលដែលសន្និបាតនៃទីក្រុងវីយែនបានស្តារឡើងវិញនូវរាជ្យបល្ល័ង្ករបស់ស្តេចអេស្ប៉ាញ ពួករាជានិយមឧបទ្វីប (ពួកអាណានិគមនិយមកើតនៅអេស្ប៉ាញ) បានព្យាយាមគ្រប់គ្រងឡើងវិញនូវរដ្ឋាភិបាលអាណានិគមទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ពួកក្រេអូលេស បានព្យាយាមរក្សា និងពង្រីកអំណាចរបស់ពួកគេ។ ជាការឆ្លើយតប ព្រះមហាក្សត្រអេស្ប៉ាញបានចាត់វិធានការក្នុងការរឹតបន្តឹងការគ្រប់គ្រងរបស់ទ្រង់លើដែនដីអាណានិគមនៅអាមេរិក។ សកម្មភាពនេះបានធ្វើឱ្យប្រជាជនម៉ិកស៊ិកកូមានការខឹងសម្បា និងបានងើបបះបោរ និងផ្តួលរំលំការគ្រប់គ្រងរបស់អេស្ប៉ាញបានដោយជោគជ័យ។ ដែនដីអាណានិគមអេស្ប៉ាញផ្សេងទៀតនៅអាមេរិកឡាទីនក៏បានទាមទារឯករាជ្យផងដែរ។ ក្នុងពេលជាមួយគ្នានោះ ប្រទេសប្រេស៊ីលបានប្រកាសឯករាជ្យពីប្រទេសព័រទុយហ្គាល់ (សូមមើលជំពូកទី 23)។

កេរ្តិ៍ដំណែលរយៈពេលវែង៖ សន្និបាទនៃទីក្រុងវីយែនបានបន្សល់ទុកនូវកេរ្តិ៍ដំណែលដែលនឹងមានឥទ្ធិពលលើនយោបាយពិភពលោកសម្រាប់រយៈពេល 100 ឆ្នាំខាងមុខ។ កិច្ចខិតខំប្រឹងប្រែងទូទាំងទ្វីបអឺរ៉ុបដើម្បីបង្កើត និងរក្សាតុល្យភាពនៃអំណាចបានបន្ថយទំហំ និងអំណាចរបស់ប្រទេសបារាំង។ ក្នុងពេលជាមួយគ្នានោះ អំណាចរបស់ចក្រភពអង់គ្លេស និងព្រូសបានកើនឡើង។ គំនិតជាតិនិយមបានចាប់ផ្តើមរីករាលដាលនៅក្នុងប្រទេសអ៊ីតាលី,

អាល្លឺម៉ង់, ក្រិក, និងទៅកាន់តំបន់ផ្សេងទៀតដែលសន្និបាតបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេស។ នៅទីបំផុតទៅ គំនិតជាតិនិយមនឹងផ្ទុះឡើងជាបដិវត្ត ហើយប្រជាជាតិថ្មីនឹងត្រូវបានបង្កើតឡើង។ ដែនដីអាណានិគមអឺរ៉ុបក៏បានឆ្លើយតបទៅនឹងការផ្លាស់ប្តូរអំណាចផងដែរ។ ដែនដីអាណានិគមរបស់អេស្ប៉ាញបានឆ្លៀតចាប់យកប្រយោជន៍ពីព្រឹត្តិការណ៍នានានៅអឺរ៉ុប ដើម្បីប្រកាសឯករាជ្យរបស់ខ្លួន និងផ្តាច់ខ្លួនចេញពីអេស្ប៉ាញ។ ទន្ទឹមនឹងនេះ គំនិតអំពីមូលដ្ឋានគ្រឹះនៃអំណាច និងសិទ្ធិគ្រប់គ្រងបានផ្លាស់ប្តូរជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីបដិវត្តបារាំង។ កាន់តែច្រើនឡើងៗ ប្រជាជនបានមើលឃើញថាលទ្ធិប្រជាធិបតេយ្យជាមធ្យោបាយដ៏ល្អបំផុតក្នុងការធានានូវសមភាព និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា។ បដិវត្តបារាំងនៅពេលនោះបានផ្លាស់ប្តូរអាកប្បកិរិយា និងការសន្មតក្នុងសង្គម ដែលបានគ្របដណ្តប់នៅអឺរ៉ុបអស់ជាច្រើនសតវត្សរ៍មកហើយ។ យុគសម័យថ្មីមួយបានចាប់ផ្តើម។

# ជំពូក 23 ៖ បដិវត្តជាតិនិយមបោកបក់នៅភាគខាងលិច 1789-1900

## មេរៀនទី 1 ៖ ប្រជាជនអាមេរិកឡាទីនទទួលបានឯករាជ្យ

ភាពជោគជ័យនៃបដិវត្តនៅអាមេរិច, បដិវត្តនៅបារាំង, និងសករាជពន្លឺបានផ្លាស់ប្តូរទស្សនអំពីថាតើនណារ ដែលគួរគ្រប់គ្រងរដ្ឋាភិបាល។ ទស្សនអំពីសេរីភាព, សមភាព, និងការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យបានរកឃើញផ្លូវរបស់ពួកគេឆ្លងកាត់សមុទ្រទៅកាន់ដែនដីអាណានិគមនានារបស់ពួកអឺរ៉ុប។ នៅអាមេរិកឡាទីន ប្រជាជនភាគច្រើនមិនសប្បាយចិត្តចំពោះការត្រួតត្រារបស់មហាអំណាចអាណានិគមអឺរ៉ុបឡើយ។ ពេលវេលាហាក់ដូចជាសមស្របសម្រាប់ប្រជាជនដែលរស់នៅទីនោះ ដើម្បីបោសសម្អាតមេដឹកនាំអាណានិគមចាស់ និងទទួលបានការគ្រប់គ្រងលើទឹកដី។

### 1. សង្គមអាណានិគមបែងចែក

នៅក្នុងសង្គមអាណានិគមអាមេរិកឡាទីន វណ្ណៈគឺជាអ្នកកំណត់ទីតាំងរបស់មនុស្សនៅក្នុងសង្គម និងការងារ។ នៅកម្រិតកំពូលនៃសង្គមអាណានិគមអេស្ប៉ាញនៅអាមេរិកគឺពួកឧបទ្វីប ដែលជាក្រុមមនុស្សកើតនៅប្រទេសអេស្ប៉ាញដែលស្ថិតនៅលើឧបទ្វីអ៊ីបេរៀន ។ វណ្ណៈនេះមានចំនួនប្រជាជនតិចតួច។ មានតែពួកឧបទ្វីបតែប៉ុណ្ណោះដែលអាចកាន់តំណែងខ្ពស់នៅក្នុងរដ្ឋាភិបាលអាណានិគមអេស្ប៉ាញនៅអាមេរិក។ ពួកក្រេអូលេសដែលជាពួកជនជាតិអេស្បាញកើតនៅអាមេរិកឡាទីនមានវណ្ណៈទាបជាងពួកឧបទ្វីប។ ពួកក្រេអូលេសមិនអាចកាន់តំណែងនយោបាយកម្រិតខ្ពស់បានឡើយ ប៉ុន្តែពួកគេអាចឡើងតំណែងជាមន្ត្រីក្នុងជួរកងទ័ពអាណានិគមអេស្ប៉ាញបាន។ ក្រុមទាំង 2 នេះបានរួមគ្នាគ្រប់គ្រងទឹកដី, ទ្រព្យសម្បត្តិ, និងអំណាចនៅក្នុងដែនដីអាណានិគមអេស្ប៉ាញ។ នៅពីក្រោមពួកឧបទ្វីប និងពួកក្រេអូលេស គឺពួកមេស្ទីហ្សូសដែលជាក្រុមមនុស្សដែលមានបច្ឆាជនលាយគ្នារវាងអឺរ៉ុប និងឥណ្ឌា ។ បន្ទាប់មកទៀតគឺពួកម៉ូឡាតតូស ជាក្រុមមនុស្សដែលមានបច្ឆាជនលាយគ្នារវាងអឺរ៉ុប និងអាហ្វ្រិក និងពួកទាសកជនជាតិអាហ្វ្រិក។ ពួកឥណ្ឌាស្ថិតនៅខាងក្រោមគេនៃឋានៈសង្គម។

### 2. បដិវត្តនៅអាមេរិក

នៅត្រឹមចុងទស្សវត្សរ៍ឆ្នាំ 1700 ប្រជាជននៅដែនដីអាណានិគមនៅអាមេរិកឡាទីនដែលបានដឹងរួចមកហើយនូវទស្សនសករាជពន្លឺ ត្រូវបានផ្តល់ថាមពលតាមរយៈព័ត៌មានអំពីការធ្វើបដិវត្តនៅអាមេរិច និងបារាំង។ ជោគជ័យនៃបដិវត្តអាមេរិច បានលើកទឹកចិត្តពួកគេក្នុងការតស៊ូព្យាយាមដើម្បីទទួលបានសេរីភាពពីមេដឹកនាំអឺរ៉ុបរបស់ពួកគេ។

បដិវត្តនៅប្រទេសហៃទី៖ ដែនដីអាណានិគមបារាំងដែលគេហៅថាសេន ដូមីនហ្គូ គឺជាដែនដីនៅអាមេរិកឡាទីនដំបូងគេដែលបានរំដោះខ្លួនចេញពីការគ្រប់គ្រងរបស់ពួកអឺរ៉ុប។ ដែនដីអាណានិគមដែលបច្ចុប្បន្នគេស្គាល់ថាជាប្រទេសហៃទីបានគ្របដណ្តប់ 1/3 ភាគខាងលិចនៃកោះហ៊ីស្ប៉ានីអូឡាក្នុងសមុទ្រការ៉ាប៊ីន។ ពួកអាហ្វ្រិកដែលជាទាសករជិត 500,000 នាក់បានធ្វើការនៅលើចំការរបស់ពួកបារាំង ហើយពួកគេមានចំនួនច្រើនជាង

ចៅហ្វាយនាយរបស់ពួកគេយ៉ាងខ្លាំង។ ចៅហ្វាយនាយជនជាតិស្បែកសបានប្រើវិធីសាស្ត្រឃោរឃៅដើម្បីបំភ័យពួកគេ និងធ្វើឱ្យពួកគេគ្មានអំណាច។ ខណៈពេលដែលបដិវត្តបារាំងកំពុងកើតឡើង ប្រជាជនដែលត្រូវបានជិះជាន់នៅក្នុងដែនដីអាណានិគមបារាំងនៅប្រទេសហៃទីបានក្រោកឡើងប្រឆាំងនឹងចៅហ្វាយនាយបារាំងរបស់ពួកគេ។ នៅខែសីហាឆ្នាំ 1791 ពួកទាសករអាហ្វ្រិកប្រមាណ 100,000 នាក់បានងើបឡើងបះបោរ។ មិនយូរប៉ុន្មានមានមេដឹកនាំមួយរូបឈ្មោះទូសេន ឡូវែទូរ បានលេចចេញមក។ ជាអតីតទាសករទូសេនមិនសូវស្គាល់ច្បាស់រឿងយោធា និងការទូតឡើយ។ ទោះបីជាយ៉ាងនេះក្តី លោកបានវិវត្តខ្លួនក្លាយជាឧត្តមសេនីយ៍ដ៏ជំនាញ និងជាអ្នកជំនាញការទូតមួយរូប។ នៅឆ្នាំ 1801 ទូសេន បានកាន់កាប់កោះទាំងមូលហើយបានផ្តល់សេរីភាពដល់ជនជាតិអាហ្វ្រិកទាំងអស់ដែលធ្វើទាសករ។ នៅខែមករាឆ្នាំ 1802 កងទ័ពបារាំងចំនួន 30,000 នាក់បានធ្វើដំណើរមកដល់សេន ដូមីនហ្គូ ដើម្បីដកទូសេនចេញពីអំណាច។ នៅខែឧសភា ទូសេនបានយល់ព្រមបញ្ឈប់ការធ្វើបដិវត្តប្រសិនបើបារាំងយល់ព្រមនៅក្នុងការបញ្ចប់របបទាសភាព។ ទោះបីជាមានការព្រមព្រៀងក៏ដោយ ក៏មិនយូរប៉ុន្មានបារាំងបានចោទប្រកាន់លោកពីបទរៀបចំការបះបោរមួយផ្សេងទៀត។ ពួកគេបានចាប់គាត់ ហើយបញ្ជូនលោកទៅឃុំខ្លួននៅភ្នំអាល់នៅបារាំង ជាកន្លែងដែលលោកបានស្លាប់នៅខែមេសា ឆ្នាំ 1803។

ឯករាជ្យរបស់ប្រទេសហៃទី៖ អនុសេនីយ៍ឯកមួយរូបរបស់ទូសេន គឺលោកហ្សង់-ហ្សាក់ ដេសសាលីន បានធ្វើការតស៊ូដើម្បីសេរីភាព។ នៅថ្ងៃទី 1 ខែមករា ឆ្នាំ 1804 ឧត្តមសេនីយ៍ដេសសាលីនបានប្រកាសដែនដីអាណានិគមជាប្រទេសឯករាជ្យ។ វាជាដែនដីអាណានិគមជនជាតិស្បែកខ្មៅដំបូងគេដែលបានរំដោះខ្លួនចេញពីការគ្រប់គ្រងរបស់ពួកអឺរ៉ុប។ ដេសសាលីនបានហៅឈ្មោះប្រទេសនេះថាហៃទី ដែលជាភាសារបស់ជនជាតិដើមអារ៉ាវ៉ាក់ ដែលមានន័យថា "ដីភ្នំ" ។

### 3. ពួកក្រេអូលេសនាំមុខក្នុងការទាមទារឯករាជ្យ

ទោះបីជាពួកគេមិនអាចកាន់តំណែងជាមន្ត្រីសាធារណៈជាន់ខ្ពស់បានក៏ដោយ ក៏ពួកក្រេអូលេសទទួលរងការជិះជាន់តិចបំផុតក្នុងចំណោមអ្នកដែលកើតនៅអាមេរិកឡាទីន។ ពួកគេក៏ជាអ្នកទទួលបានការអប់រំខ្ពង់ខ្ពស់ផងដែរ។ តាមពិតទៅ ពួកក្រេអូលេសវ័យក្មេងជាច្រើនបានធ្វើដំណើរទៅអឺរ៉ុបដើម្បីបន្តការសិក្សារបស់ពួកគេ។ នៅអឺរ៉ុប ពួកគេបានអាន និងទទួលយកទស្សនសករាជពន្លឺ។ នៅពេលពួកគេត្រឡប់ទៅអាមេរិកឡាទីនវិញ ពួកគេបាននាំយកគំនិតនៃបដិវត្តមកជាមួយពួកគេ។ ការឈ្លានពានរបស់អធិរាជណាប៉ូឡេអុងលើប្រទេសអេស្ប៉ាញក្នុងឆ្នាំ 1808 បានបង្កឱ្យមានការបះបោរនៅក្នុងដែនដីអាណានិគមអេស្ប៉ាញ។ បន្ទាប់ពីដកព្រះមហាក្សត្រអេស្ប៉ាញហ្វឺដីណង់ទី 7 ចេញពីអំណាច អធិរាជណាប៉ូឡេអុងបានតែងតាំងអនុជរបស់ទ្រង់ព្រះនាមយ៉ូសែបធ្វើជាព្រះមហាក្សត្ររបស់អេស្ប៉ាញ។ ពួកក្រេអូលេសភាគច្រើនប្រហែលជាអ្នកដែលគាំទ្រព្រះមហាក្សត្រអេស្ប៉ាញ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមានអារម្មណ៍ថាពួកគេមិនមានភក្តីភាពចំពោះព្រះមហាក្សត្រដែលតែងតាំងដោយបារាំងឡើយ។ ពួកក្រេអូលេសបានរំលឹកពីគំនិតរបស់ចន ឡុកអំពីការយល់ព្រមក្នុងការគ្រប់គ្រង បានទទូចថានៅពេលដែលស្តេចពិតប្រាកដត្រូវបានដកចេញ អំណាចបានផ្លាស់ប្តូរទៅប្រជាជន។ នៅឆ្នាំ 1810 ការបះបោរបានផ្ទុះឡើងនៅក្នុង

តំបន់ជាច្រើននៅអាមេរិកឡាទីន។ ការជំរុញឆ្ពោះទៅរកឯករាជ្យភាពបានចាប់ផ្តើមឡើង។ សង្គ្រាមដើម្បីឯករាជ្យនៅអាមេរិកខាងត្បូងស្ថិតនៅក្រោមស្នាដៃរបស់ឧត្តមសេនីយ៍ក្រេអូលេស 2 រូប។ ម្នាក់ឈ្មោះស៊ីម៉ន់ បូលីវ៉ា ដែលជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភវេណេហ្ស៊ូអេឡា។ អ្នករំដោះដ៏អស្ចារ្យម្នាក់ទៀតគឺលោកចូសេ ដឺ សាន់ម៉ាទីជាជនជាតិអាហ្សង់ទីន។

វិថីរបស់បូលីវ៉ាទៅកាន់ជ័យជំនះ៖ ស៊ីម៉ន់ បូលីវ៉ា មានដើមកំណើតនៅវេណេហ្ស៊ូអេឡាបានប្រកាសឯករាជ្យរបស់ខ្លួនពីប្រទេសអេស្ប៉ាញក្នុងឆ្នាំ 1811។ ប៉ុន្តែការតស៊ូដើម្បីឯករាជ្យទើបតែបានចាប់ផ្តើមប៉ុណ្ណោះ។ កងទ័ពបដិវត្តស្ម័គ្រចិត្តរបស់ បូលីវ៉ាបានទទួលរងបរាជ័យជាច្រើនលើក។ លោកបូលីវ៉ាត្រូវបាននិរទេសខ្លួនចំនួន 2 លើក។ ចំណុចរបត់មួយបានកើតឡើងនៅក្នុងខែសីហា ឆ្នាំ 1819 ។ លោកបូលីវ៉ា បានដឹកនាំទាហានចំនួនជាង 2,000 នាក់ដើរដង្ហែដ៏ក្លាហានឆ្លងកាត់តំបន់អង់ដ្រេសចូលទៅក្នុងតំបន់ដែលបច្ចុប្បន្នជាប្រទេសកូឡុំប៊ី។ ដោយចាប់ផ្តើមចេញពីទិសដៅនេះ លោកបានយកជ័យជំនះលើកងទ័ពអេស្ប៉ាញនៅទីក្រុងបូហ្គោតាដោយភ្ញាក់ផ្អើល។ នៅឆ្នាំ 1821 លោកបូលីវ៉ាបានទទួលជ័យជំនះក្នុងការទាមទារឯករាជ្យឱ្យវេណេហ្ស៊ូអេឡា។ បន្ទាប់មក គាត់បានធ្វើដំណើរទៅទិសខាងត្បូងចូលទៅក្នុងទឹកដីប្រទេសអេក្វាឌ័រ។ នៅប្រទេសអេក្វាឌ័រ លោកបូលីវ៉ាបានជួបចូសេ ដឺ សាន់ម៉ាទីន។ ដោយរួបរួមគ្នាពួកគេទាំង 2 នឹងសម្រេចពីអនាគតនៃចលនាបដិវត្តនៅអាមេរិកឡាទីន។

សាន់ម៉ាទីនដឹកនាំកងកម្លាំងរំដោះភាគខាងត្បូង៖ ប្រទេសអាហ្សង់ទីនរបស់លោកសាន់ម៉ាទីនបានប្រកាសឯករាជ្យរបស់ខ្លួននៅឆ្នាំ 1816។ ទោះជាយ៉ាងណាក៏ដោយ កងកម្លាំងអេស្ប៉ាញស្ថិតនៅជិតប្រទេសឈីលី និងប៉េរូនៅតែបង្កការគំរាមកំហែងដល់ពួកគេ។ នៅឆ្នាំ 1817 លោកសាន់ម៉ាទីនបានដឹកនាំកងទ័ពយ៉ាងលំបាកឆ្លងកាត់តំបន់អង់ដ្រេសទៅកាន់ប្រទេសឈីលី។ លោកត្រូវបានចូលរួមនៅទីនោះដោយកងកម្លាំងដែលដឹកនាំដោយលោកប៊ឺណាដូ អូហ៊ីហ្គីន ដែលជាកូនប្រុសរបស់អតីតមេដឹកនាំប៉េរូ។ ដោយមានជំនួយពីអូហ៊ីហ្គីនទីបំផុត សាន់ម៉ាទីនបានរំដោះប្រទេសឈីលី។ នៅឆ្នាំ 1821 លោកសាន់ម៉ាទីនបានរៀបចំគម្រោងបណ្តេញកងកម្លាំងអេស្ប៉ាញដែលនៅសេសសល់ ចេញពីទីក្រុងលីម៉ាប្រទេសប៉េរូ។ ប៉ុន្តែដើម្បីធ្វើដូច្នេះបាន គាត់ត្រូវការកម្លាំងធំជាងនេះ។ លោកសាន់ម៉ាទីន និងលោកបូលីវ៉ាបានពិភាក្សាអំពីបញ្ហានេះនៅពេលដែលពួកគេបានជួបគ្នានៅហ្គួយ៉ាឈីលប្រទេសអេក្វាឌ័រនៅក្នុងឆ្នាំ 1822 ។ គ្មាននរណាម្នាក់ដឹងថាតើពួកគេទាំង 2 នាក់ព្រមព្រៀងគ្នារបៀបណាឡើយ។ ប៉ុន្តែលោកសាន់ម៉ាទីនបានប្រគល់កងទ័ពរបស់លោកឲ្យលោកបូលីវ៉ា។ ជាមួយនឹងការបង្រួបបង្រួមកម្លាំងបដិវត្តកងទ័ពរបស់លោកបូលីវ៉ាបានបន្តកម្ចាត់ពួកអេស្ប៉ាញនៅសមរភូមិអាយ៉ាឈូឆូ (ប្រទេសប៉េរូ) នៅថ្ងៃទី 9 ខែធ្នូ ឆ្នាំ 1824 ។ នៅក្នុងសមរភូមិដ៏សំខាន់ចុងក្រោយនៃសង្គ្រាមដើម្បីឯករាជ្យនេះ ពួកអាណានិគមអេស្ប៉ាញនៅអាមេរិកឡាទីនបានទទួលសេរីភាពរបស់ពួកគេ។ អនាគតប្រទេសវេណេហ្ស៊ុយអេឡា, កូឡុំប៊ី, ប៉ាណាម៉ា, និងអេក្វាឌ័រ ត្រូវបានបង្រួបបង្រួមជាប្រទេសមួយហៅថាមហាកូឡុំប៊ី។

## 4. ម៉ិកស៊ិកកូបញ្ចប់ការគ្រប់គ្រងរបស់អេស្ប៉ាញ

នៅក្នុងប្រទេសនានានៅអាមេរិកឡាទីនភាគច្រើនពួកក្រេអូលេសគឺជាអ្នកដឹកនាំចលនាបដិវត្ត។ ប៉ុន្តែនៅប្រទេសម៉ិកស៊ិកកូ ក្រុមជនជាតិភាគតិច និងជាតិសាសន៍ផ្សេងៗទៀតបានលាយបញ្ចូលគ្នាដោយសេរី។ នៅទីនោះ ពួកឥណ្ឌា និងពួកមេស្ទីហ្សូបានឈានមុខគេ។

សម្រែកដើម្បីសេរីភាព៖ នៅឆ្នាំ 1810 ប៉ាដ្រេ មីគេល ហ៊ីដាល់ហ្គូ ដែលជាបូជាចារ្យនៅក្នុងភូមិតូចមួយនៅដូឡូរេស បានបោះជំហានដំបូងគេឆ្ពោះទៅរកឯករាជ្យ។ ហ៊ីដាល់ហ្គូគឺជាបុរសក្រីក្រម្នាក់ ប៉ុន្តែទទួលបានការអប់រំល្អ។ គាត់ជឿជាក់យ៉ាងមុតមាំលើទស្សនសករាជពន្លឺ។ នៅថ្ងៃទី 16 ខែកញ្ញា ឆ្នាំ 1810 លោកបានបន្លឺកណ្តឹងព្រះវិហារភូមិរបស់លោក។ នៅពេលដែលពួកប្រជាកសិករប្រមូលផ្តុំគ្នានៅក្នុងព្រះវិហារ លោកបានអំពាវនាវឱ្យមានការបះបោរមួយប្រឆាំងជាមួយពួកអេស្ប៉ាញ។ សព្វថ្ងៃនេះ ការអំពាវនាវនេះត្រូវបានគេស្គាល់ថាគ្រីតូ ដឺ ដូឡូរេស (សម្រែករបស់ដូឡូរេស)។ នៅថ្ងៃបន្ទាប់ ពួកអ្នកដើរតាមជនជាតិឥណ្ឌា និងមេស្ទីហ្សូរបស់ហ៊ីដាល់ហ្គូបានចាប់ផ្តើមធ្វើដំណើរឆ្ពោះទៅទីក្រុងម៉ិកស៊ិក។ កងទ័ពដែលមិនចេះចាវនេះមិនយូរប៉ុន្មានបានកើនឡើងដល់ចំនួន 80,000 នាក់។ ការបះបោររបស់ពួកវណ្ណៈទាបបានបង្កការភ្ញាក់ផ្អើលដល់កងទ័ពរបស់អេស្ប៉ាញ និងពួកក្រេអូឡេដែលមានការភ័យខ្លាចចំពោះការបាត់បង់ទ្រព្យសម្បត្តិ, ការគ្រប់គ្រងដែនដី, និងអាយុជីវិតរបស់ពួកគេ។ កងទ័ពអេស្ប៉ាញបានសម្លាប់លោកហ៊ីដាល់ហ្គូក្នុងឆ្នាំ 1811។ បន្ទាប់មកពួកអ្នកបះបោរបានប្រមូលផ្តុំគ្នាជុំវិញមេដឹកនាំដ៏រឹងមាំម្នាក់ទៀតគឺលោកប៉ាដ្រេ ចូសេ ម៉ារៀ ម៉ូរេឡូស។ លោកម៉ូរេឡូសបានដឹកនាំការធ្វើបដិវត្តរយៈពេល 4 ឆ្នាំ។ ទោះយ៉ាងណាក៏ដោយនៅឆ្នាំ 1815 មន្ត្រីក្រេអូឡេមួយរូបឈ្មោះអាហ្គូស្ទីន ដឺ អ៊ីទូប៊ីដេ បានសម្លាប់លោក។

ឯករាជ្យរបស់ម៉ិកស៊ិកកូ៖ ព្រឹត្តិការណ៍នៅម៉ិកស៊ិកកូបានឈានដល់ចំណុចសំខាន់មួយទៀតនៅឆ្នាំ 1820 នៅពេលដែលបដិវត្តនៅអេស្ប៉ាញបានផ្តល់អំណាចដល់ក្រុមសេរីនិយមមួយ។ ពួកក្រេអូឡេរបស់ម៉ិកស៊ិកកូមានការភ័យខ្លាចចំពោះការបាត់បង់សិទ្ធិរបស់ពួកគេនៅក្នុងដែនដីអាណានិគម ដែលគ្រប់គ្រងដោយអេស្ប៉ាញ។ ដូច្នេះ ពួកគេបានចូលរួមគាំទ្រឯករាជ្យភាពរបស់ម៉ិកស៊ិកកូពីប្រទេសអេស្ប៉ាញ។ ជារឿងដែលគួរឱ្យអស់សំណើចលោកអាហ្គូស្ទីន ដឺ អ៊ីទូប៊ីដេ ដែលជាអ្នកកម្ចាត់មេដឹកនាំបះបោរប៉ាដ្រេ ម៉ូរេឡូស បានប្រកាសឯករាជ្យនៅឆ្នាំ 1821 ។ មុនពេលបដិវត្តម៉ិកស៊ិកកូផ្ទុះឡើង តំបន់អាមេរិកកណ្តាលគឺជាផ្នែកមួយនៃចក្រភពអេស្ប៉ាញថ្មី។ វាត្រូវបានគ្រប់គ្រងដោយពួកអេស្ប៉ាញក្រោមស្លាករដ្ឋាភិបាលអាណានិគមនៅម៉ិកស៊ិកកូ។ នៅឆ្នាំ 1821 ប្រទេសនានានៅអាមេរិកកណ្តាលជាច្រើនបានប្រកាសឯករាជ្យរបស់ពួកគេពីប្រទេសអេស្ប៉ាញ និងពីម៉ិកស៊ិកកូផងដែរ។ ទោះជាយ៉ាងណាក៏ដោយលោកអ៊ីទូប៊ីដេ (ដែលបានប្រកាសខ្លួនឯងជាអធិរាជ) បានបដិសេធមិនទទួលស្គាល់ការប្រកាសឯករាជ្យរបស់តំបន់ផ្សេងៗ។ ទីបំផុត លោកអ៊ីទូប៊ីដេត្រូវបានគេទម្លាក់ពីអំណាចនៅឆ្នាំ 1823។ ពួកអាមេរិកកណ្តាលបានប្រកាសឯករាជ្យរបស់ពួកគេទាំងស្រុងពីម៉ិកស៊ិកកូ។ ពួកគេបានប្រើឈ្មោះខេត្តបង្រួបបង្រួមនៃអាមេរិកកណ្តាល។ អនាគតប្រទេសនីការ៉ាហ្គ័រ, ហ្គាតេម៉ាឡា, ហុងឌូរ៉ាស់, អែលសាល់វ៉ាឌ័រ, និងកូស្តារីកា នឹងត្រូវបានអភិវឌ្ឍនៅក្នុងតំបន់នេះ។

### 5. រាជវង្សអ្នករំដោះប្រទេសប្រេស៊ីល

ការស្វែងរកឯករាជ្យរបស់ប្រទេសប្រេស៊ីល គឺមានតែមួយគត់នៅក្នុងប្រវត្តិសាស្ត្រអាមេរិកឡាទីននេះ ព្រោះវាបានកើតឡើងដោយគ្មានភាពចលាចល និងដោយគ្មានអំពើហិង្សា ឬការបង្ហូរឈាមឡើយ។ តាមពិតទៅសមាជិកនៃគ្រួសាររាជវង្សព័រទុយហ្គាល់ ពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរំដោះប្រេស៊ីលចេញពីព័រទុយហ្គាល់។ នៅឆ្នាំ 1807 កងទ័ពរបស់អធិរាជណាប៉ូឡេអ៊ុងបានលុកលុយទាំងប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល់។ គោលបំណងរបស់អធិរាជណាប៉ូឡេអ៊ុង គឺបិទកំពង់ផែនៃប្រទេសទាំង 2 នេះពីការដឹកជញ្ជូនទំនិញរបស់អង់គ្លេស។ នៅពេលដែលកងទ័ពបារាំងចូលទៅជិតទីក្រុងលីសបូន ដែលរាជធានីរបស់ព័រទុយហ្គាល់ ព្រះអង្គម្ចាស់ចន (ក្រោយមកចនទី 6 ) និងព្រះរាជវង្សានុវង្សបានឡើងជិះកប៉ាល់ដើម្បីគេចពីការចាប់ខ្លួន។ ពួកគេបានយកគ្រួសាររាជវង្ស និងរតនាវត្ថុនានារបស់ពួកគេទៅកាន់ដែនដីអាណានិគមធំជាងគេរបស់ព័រទុយហ្គាល់ គឺប្រទេសប្រេស៊ីល។ រីអូ ដឺ ជេណេរ៉ូ បានក្លាយជារាជធានីនៃចក្រភពព័រទុយហ្គាល់។ អស់រយៈពេល 14 ឆ្នាំជនជាតិព័រទុយហ្គាល់បានគ្រប់គ្រងចក្រភពរបស់ពួកគេពីប្រេស៊ីល។ បន្ទាប់ពីការបរាជ័យរបស់អធិរាជណាប៉ូឡេអ៊ុងនៅឆ្នាំ 1815 ហើយ 6 ឆ្នាំក្រោយមកព្រះអង្គម្ចាស់ចន និងរដ្ឋាភិបាលព័រទុយហ្គាល់បានវិលត្រលប់ទៅកាន់ប្រទេសព័រទុយហ្គាល់វិញ ។ ព្រះអង្គម្ចាស់ដុម ប៉េដ្រូ ដែលជារាជបុត្ររបស់ព្រះអង្គម្ចាស់ចនបន្តគង់នៅក្នុងប្រទេសប្រេស៊ីល។ ព្រះអង្គម្ចាស់ចនមានគម្រោងក្នុងការធ្វើឱ្យប្រេស៊ីលក្លាយជាដែនដីអាណានិគមសារជាថ្មី។ ប៉ុន្តែ ប្រជាជនប្រេស៊ីលជាច្រើនមិនអាចទទួលយកការវិលត្រឡប់ទៅកាន់ឋានៈអាណានិគមឡើងវិញបានឡើយ។ នៅឆ្នាំ 1822 ពួកក្រេអូឡេសបានទាមទារឯករាជ្យរបស់ប្រទេសប្រេស៊ីលពីពួកព័រទុយហ្គាល់។ ប្រជាជនប្រេស៊ីលចំនួន 8,000 នាក់បានចុះហត្ថលេខាលើញត្តិមួយសុំឱ្យព្រះអង្គម្ចាស់ដុម ប៉េដ្រូ ធ្វើជាអ្នកគ្រប់គ្រងប្រទេសប្រេស៊ីល។ ពេលនោះទ្រង់បានយល់ព្រម។ នៅថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1822 ទ្រង់បានប្រកាសឯករាជ្យរបស់ប្រទេសប្រេស៊ីលជាផ្លូវការ។ ប្រេស៊ីលបានទទួលឯករាជ្យរបស់ខ្លួននៅក្នុងបដិវត្តមួយដោយគ្មានការបង្ហូរឈាម។ ទន្ទឹមនឹងនេះ គំនិតអំពីបដិវត្តបារាំង និងផលវិបាកនៃសង្គ្រាមណាប៉ូឡេអ៊ុង បានបង្កភាពចលាចលនៅអឺរ៉ុប ដូចដែលអ្នកនឹងរៀននៅក្នុងមេរៀនទី 2 ។

# មេរៀនទី 2៖ អឺរ៉ុបប្រឈមជាមួយការធ្វើបដិវត្ត

នៅពេលដែលបដិវត្តបានអង្រួនដែនដីអាណានិគមនៅអាមេរិកឡាទីន នៅអឺរ៉ុបក៏កំពុងតែមានការផ្លាស់ប្តូរយ៉ាងខ្លាំងផងដែរ។ ក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់មេតថ័រនិចនៃប្រទេសអូទ្រីស សន្និបាទនៃទីក្រុងវីយែនបានព្យាយាមស្តារឡើងវិញនូវរបបរាជានិយម និងការបែងចែកទឹកដីដែលមាននៅមុនបដិវត្តបារាំង។ (សូមមើលជំពូកទី 22 )។ នៅកម្រិតអន្តរជាតិ ការប៉ុនប៉ងដើម្បីបង្វែរប្រវត្តិសាស្ត្រនេះបានទទួលជោគជ័យ។ មួយសតវត្សរ៍ក្រោយមក បណ្តាប្រទេសនៅនានាអឺរ៉ុបកម្រងាកមកធ្វើសង្គ្រាមដើម្បីដោះស្រាយការខ្វែងគំនិតគ្នារបស់ខ្លួនណាស់។ ទោះជាយ៉ាងណាក៏ដោយ នៅកម្រិតប្រទេសវិញ ការខិតខំប្រឹងប្រែងនេះបានបរាជ័យ។ បដិវត្តបានផ្ទុះឡើងនៅទូទាំងទ្វីបអឺរ៉ុបនៅចន្លោះឆ្នាំ 1815 និង 1848 ។

## 1. ការប៉ះទង្គិចផ្នែកទស្សនវិជ្ជា

នៅពាក់កណ្តាលទីមួយនៃទសវត្សរ៍ឆ្នាំ 1800 សាលាគំនិតនយោបាយចំនួន 3 បានតស៊ូដើម្បីភាពខ្ពង់ខ្ពស់នៅក្នុងសង្គមអឺរ៉ុប។ ម្នាក់ៗជឿថា ទម្រង់រដ្ឋាភិបាលរបស់ខ្លួននឹងបម្រើប្រជាជនបានល្អបំផុត។ សាលាគំនិតនីមួយៗគ្នាបានទាក់ទាញក្រុមអ្នកដើរតាមផ្សេងគ្នា។ ទស្សនវិជ្ជា, គោលដៅ, និងអ្នកដើរតាមទាំងនោះរួមមាន៖ (1) អភិរក្សនិយម៖ ភាគច្រើនជាម្ចាស់កម្មសិទ្ធិដីធ្លីមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងអភិជន។ ពួកគេបានតស៊ូសម្រាប់ការការពាររាជាធិបតេយ្យបែបប្រពៃណីរបស់អឺរ៉ុប។ (2) សេរីនិយម៖ ភាគច្រើនជាអ្នកដឹកនាំជំនួញថ្នាក់កណ្តាល និងពាណិជ្ជករ។ ពួកគេចង់ផ្តល់អំណាចបន្ថែមដល់សភាជាប់ឆ្នោត ប៉ុន្តែមានតែអ្នកចេះដឹង និងម្ចាស់ដីប៉ុណ្ណោះដែលអាចបោះឆ្នោតបាន។ (3) ជ្រុលនិយម៖ អនុញ្ញាតឱ្យមានការផ្លាស់ប្តូរដ៏ធំមួយ ដើម្បីពង្រីកលទ្ធិប្រជាធិបតេយ្យដល់មនុស្សទាំងអស់។ ពួកគេជឿថារដ្ឋាភិបាលគួរតែអនុវត្តទស្សនៃបដិវត្តបារាំង ដែលក្នុងនោះរួមមានសេរីភាព, សមភាព, និងភាតរភាព។

## 2. ជាតិនិយមរីកចម្រើន

នៅពេលដែលពួកអភិរក្សនិយម, សេរីនិយម, និងជ្រុលនិយមពិភាក្សាអំពីបញ្ហារដ្ឋាភិបាល ចលនាថ្មីមួយហៅថាជាតិនិយមបានលេចឡើង។ ជាតិនិយម គឺជាជំនឿដែលថា ភក្តីភាពរបស់ប្រជាជន មិនគួរមានតែចំពោះស្តេច ឬចក្រភពនោះឡើយ ប៉ុន្តែគួរតែមានចំពោះប្រជាជាតិមួយដែលប្រជាជនមានវប្បធម៌ និងប្រវត្តិសាស្ត្ររួមគ្នា។ ចលនាជាតិនិយមនឹងធ្វើឱ្យរលុបបន្ទាត់ដែលបែងចែកទ្រឹស្តីនយោបាយទាំង 3 ។ នៅពេលដែលប្រទេសមួយមានរដ្ឋាភិបាលឯករាជ្យរបស់ខ្លួន វាបានក្លាយជាប្រទេសជាតិ។ រដ្ឋមួយការពារទឹកដី និងរបៀបរស់នៅរបស់ជាតិ ហើយពួកគេតំណាងឱ្យជាតិទៅកាន់ពិភពលោក។ នៅទ្វីបអឺរ៉ុបក្នុងឆ្នាំ 1815 មានតែប្រទេសបារាំង,អង់គ្លេស, និងអេស្ប៉ាញប៉ុណ្ណោះដែលអាចត្រូវបានគេហៅថាជារដ្ឋ។ ប៉ុន្តែមិនយូរប៉ុន្មាននោះនឹងមានការផ្លាស់ប្តូរ ខណៈចលនាជាតិនិយមទទួលបានជោគជ័យ។ ភាគច្រើននៃប្រជាជនដែលជឿលើជាតិនិយម គឺជាអ្នកសេរីនិយម ឬជ្រុលនិយម។ ក្នុងករណីភាគច្រើន វណ្ណៈកណ្តាលសេរីនិយម រួមមានគ្រូបង្រៀន, មេធាវី, និងអ្នកជំនួញ បានដឹកនាំការតស៊ូដើម្បីរដ្ឋាភិបាលបែបធម្មនុញ្ញ និងការបង្កើតរដ្ឋប្រជាជាតិមួយ។ ឧទាហរណ៍ នៅប្រទេសអាឡឺម៉ង់ ពួកសេរីនិយម

ចង់ប្រមូលផ្តុំរដ្ឋអាឡឺម៉ង់ផ្សេងៗគ្នាជាច្រើនទៅជារដ្ឋប្រជាជាតិតែមួយ។ ពួកសេរីនិយមផ្សេងទៀតនៅក្នុងចក្រភពធំៗ ដូចជាជនជាតិហុងគ្រីក្នុងចក្រភពអូទ្រីស ចង់បំបែកខ្លួនចេញ ហើយបង្កើតការគ្រប់គ្រងដោយខ្លួនឯង។

### 3. អ្នកជាតិនិយមប្រកួតប្រជែងអំណាចជាមួយពួកអភិរក្សនិយម

មនុស្សដំបូងគេដែលឈ្នះលើការគ្រប់គ្រងដោយខ្លួនឯងនៅអំឡុងពេលនោះគឺជនជាតិក្រិក។ អស់ជាច្រើនសតវត្សរ៍មកហើយ ប្រទេសក្រិកបានក្លាយជាផ្នែកមួយនៃចក្រភពអូតូម៉ង់។ អូតូម៉ង់បានគ្រប់គ្រងដែនដីមួយភាគធំនៃតំបន់បាល់កង់។ តំបន់នោះរាប់បញ្ចូលប្រទេសនាពេលបច្ចុប្បន្ន ក្រិក, អាល់បានី, ប៊ុលហ្គារី, រ៉ូម៉ានី, ទួគី, និងអតីតប្រទេសយូហ្គោស្លាវី។ យ៉ាងណាមិញ ជនជាតិក្រិកបានរក្សាទុកនូវការចងចាំអំពីប្រវត្តិសាស្ត្រ និងវប្បធម៌បុរាណរបស់ពួកគេ។ ដោយជំរុញដោយស្មារតីជាតិនិយម ពួកគេបានទាមទារឯករាជ្យ និងបះបោរប្រឆាំងនឹងប្រទេសអូតូម៉ង់ទួកនៅឆ្នាំ 1821។

ពួកក្រិកទទួលបានឯករាជ្យ៖ ពួករដ្ឋាភិបាលអឺរ៉ុបខ្លាំងៗបានប្រឆាំងទៅនឹងបដិវត្ត។ ទោះជាយ៉ាងណាក៏ដោយ បុព្វហេតុនៃឯករាជ្យភាពរបស់ក្រិកបង្កឱ្យមានការចាប់អារម្មណ៍ពីសំណាក់មនុស្សនានាជុំវិញពិភពលោក។ ឧទាហរណ៍ ពួករុស្ស៊ីមានអារម្មណ៍ថាមានទំនាក់ទំនងជាមួយពួកក្រិកកាន់គ្រីស្តសាសនាអូតូដុកដែលត្រូវបានគ្រប់គ្រងដោយម៉ូស្លីមអូតូម៉ង់។ ជនជាតិអឺរ៉ុប និងអាមេរិកដែលទទួលបានការអប់រំ ស្រឡាញ់ និងគោរពវប្បធម៌របស់ក្រិកបុរាណ។ នៅទីបំផុត នៅពេលដែលការគាំទ្រដ៏ពេញនិយមសម្រាប់ប្រទេសក្រិកកើនឡើង ប្រទេសដ៏មានឥទ្ធិពលនៃទ្វីបអឺរ៉ុបបានជ្រើសរើសយកភាគីក្រិក។ នៅឆ្នាំ 1827 កងនាវារួមគ្នារវាងអង់គ្លេស, បារាំង, និងរុស្ស៊ីបានបំផ្លាញកងនាវារបស់អូតូម៉ង់នៅសមរភូមិណាវ៉ារីណូ។ នៅឆ្នាំ 1830 ចក្រភពអង់គ្លេស, បារាំង, និងរុស្ស៊ីបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ធានានូវឯករាជ្យរបស់ព្រះរាជាណាចក្រក្រិក។

ការបង្រ្កាមការបះបោរនៅទសវត្សរ៍ឆ្នាំ 1830 ៖ នៅទសវត្សរ៍ឆ្នាំ 1830 សណ្តាប់ធ្នាប់ចាស់ ដែលត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ននៅឯសន្និបាតនៃទីក្រុងវីយែនត្រូវបានបំបែក។ ការខ្វះខ្នែងក្នុងការធ្វើបដិវត្តបានសាយភាយពាសពេញទ្វីបអឺរ៉ុប។ ពួកសេរីនិយម និងជាតិនិយមនៅទូទាំងទ្វីបអឺរ៉ុបបានបះបោរដោយបើកចំហប្រឆាំងនឹងរដ្ឋាភិបាលអភិរក្សនិយម។ កុប្បកម្មជាតិនិយមបានផ្ទុះឡើងប្រឆាំងនឹងការគ្រប់គ្រងរបស់ហូឡង់នៅក្នុងទីក្រុងព្រុចសែលនៃប្រទេសប៊ែលហ្ស៊ិក។ នៅខែតុលាឆ្នាំ 1830 ប្រទេសប៊ែលហ្ស៊ិកបានប្រកាសឯករាជ្យពីការគ្រប់គ្រងរបស់ហូឡង់។ នៅក្នុងប្រទេសអ៊ីតាលី ក្រុមអ្នកជាតិនិយមបានធ្វើការដើម្បីបង្រួបបង្រួមបញ្ចូលគ្នារដ្ឋផ្សេងៗគ្នាជាច្រើននៅឧបទ្វីបអ៊ីតាលី។ រដ្ឋមួយចំនួនឯករាជ្យ និងរដ្ឋមួយចំនួនទៀតត្រូវបានគ្រប់គ្រងដោយអូទ្រីស ឬដោយសម្តេចប៉ាប។ នៅទីបំផុតព្រះអង្គម្ចាស់មេតច័រនិចបានបញ្ជូនកងទ័ពអូទ្រីសដើម្បីស្តារសណ្តាប់ធ្នាប់នៅក្នុងប្រទេសអ៊ីតាលី។ ពួកប៉ូឡូញដែលរស់នៅក្រោមការគ្រប់គ្រងរបស់រុស្ស៊ីបានធ្វើការបះបោរនៅវ៉ាសនៅចុងឆ្នាំ 1830។ កងទ័ពរុស្ស៊ីបានចំណាយពេលជិតពេញមួយឆ្នាំដើម្បីបង្រ្កាបការបះបោររបស់ពួកប៉ូឡូញ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1830 សណ្តាប់ធ្នាប់ចាស់ហាក់ដូចជាត្រូវបានស្តារឡើងឡើងវិញដោយខ្លួនឯង។ ប៉ុន្តែស្ថេរភាពសណ្តាប់ធ្នាប់ចាស់មិនមានរយៈពេលយូរឡើយ។

បដិវត្តឆ្នាំ 1848 បរាជ័យក្នុងការបង្រួបបង្រួម៖ នៅឆ្នាំ 1848 ការបះបោរជនជាតិភាគតិចបានផ្ទុះឡើងនៅទូទាំងទ្វីបអឺរ៉ុប។ បន្ទាប់ពីហ្វូងមនុស្សដែលពិបាកគ្រប់គ្រងនៅទីក្រុងវីយែនបានប៉ះទង្គិចជាមួយប៉ូលីស ព្រះអង្គម្ចាស់មេតថ៍នេិចបានលាលែងពីតំណែង ហើយការបះបោរជាច្រើនបានផ្ទុះឡើងពាសពេញចក្រភពអូទ្រីស។ នៅទីក្រុងប៊ូដាប៉េស មេដឹកនាំជាតិនិយមលោកល្វីស កូសស៊ូស បានអំពាវនាវឱ្យមានសភា និងរដ្ឋាភិបាលផ្ទាល់ខ្លួនសម្រាប់ប្រទេសហុងគ្រី។ ក្នុងពេលជាមួយគ្នានោះ នៅទីក្រុងប្រាគ ក្រុមសេរីនិយមឆេកទាមទារឯករាជ្យសម្រាប់ប្រទេសបូហេមែន។ នយោបាយអឺរ៉ុបបានបន្តផ្លាស់ប្តូរ។ ការទទួលបានជាច្រើនរបស់ពួកសេរីនិយមត្រូវបានបាត់បង់ទៅឱ្យពួកអភិរក្សនិយមក្នុងរយៈពេលមួយឆ្នាំ។ ពីប្រទេសមួយបន្តទៅប្រទេសមួយទៀត ពួកបដិវត្តបរាជ័យក្នុងការបង្រួបបង្រួមខ្លួនពួកគេ ឬប្រជាជាតិរបស់ពួកគេ។ ពួកអភិរក្សនិយមបានទទួលសរសៃឈាម និងអំណាចរបស់ពួកគេ។ នៅឆ្នាំ 1849 អឺរ៉ុបបានត្រលប់ទៅគំនិតអភិរក្សនិយមដែលបានគ្រប់គ្រងរដ្ឋាភិបាលមុនឆ្នាំ 1848 ។

## 4. ក្រុមជ្រុលនិយមផ្លាស់ប្តូរប្រទេសបារាំង

ក្រុមជ្រុលនិយមបានចូលរួមក្នុងការបះបោរជាច្រើននៃឆ្នាំ 1848 ។ យ៉ាងណាមិញ មានតែនៅប្រទេសបារាំងប៉ុណ្ណោះដែលគោលដៅចម្បងនៃបដិវត្តរបស់ពួកជ្រុលនិយម គឺទាមទារឱ្យមានរដ្ឋាភិបាលបែបប្រជាធិបតេយ្យ។ នៅឆ្នាំ 1830 ព្រះអង្គម្ចាស់ឆាលទី 10 របស់ប្រទេសបារាំងបានព្យាយាមក្នុងការវិលត្រឡប់ទៅកាន់របបរាជានិយមផ្តាច់ការ។ ការប៉ុនប៉ងនេះបានបង្កឱ្យមានកុបកម្ម និងបានបង្ខំឱ្យព្រះអង្គម្ចាស់ឆាលភៀសព្រះកាយទៅកាន់ចក្រភពអង់គ្លេស។ ទ្រង់ត្រូវបានជំនួសតំណែងដោយព្រះអង្គម្ចាស់ល្វី-ហ្វីលីព ដែលបានគាំទ្រការធ្វើកំណែទម្រង់សេរីនិយមនៅក្នុងប្រទេសបារាំងជាយូរមកហើយ។

សាធារណរដ្ឋទី 3៖ ទោះយ៉ាងណាក៏ដោយ នៅឆ្នាំ 1848 បន្ទាប់ពីការសោយរាជ្យដែលមានរយៈពេលជិត 18 ឆ្នាំ បានធ្លាក់ចុះនូវប្រជាប្រិយភាព។ ជាថ្មីម្តងទៀត ហ្វូងមនុស្សនៅក្នុងទីក្រុងប៉ារីសបានផ្តួលរំលំរបបរាជាធិបតេយ្យ ហើយបានបង្កើតរបបសាធារណរដ្ឋមួយ។ រដ្ឋាភិបាលសាធារណរដ្ឋថ្មីនេះបានចាប់ផ្តើមដួលរលំស្ទើរតែភ្លាមៗបន្ទាប់ពីបានបង្កើត។ ពួកជ្រុសនិយមបានបែកបាក់ទៅជាបក្សពួក។ ភាគីម្ខាងចង់បានតែការធ្វើកំណែទម្រង់នយោបាយតែប៉ុណ្ណោះ។ ភាគីម្ខាងទៀតក៏ចង់បានការធ្វើកំណែទម្រង់សង្គម និងសេដ្ឋកិច្ចផងដែរ។ ភាពខុសគ្នានេះបានបង្កឱ្យមានការប្រយុទ្ធបង្ហូរឈាមគ្នានៅតាមដងផ្លូវប៉ារីស។ អំពើហិង្សាបានធ្វើឱ្យពលរដ្ឋបារាំងចេញឆ្ងាយពីក្រុមជ្រុលនិយម។ ជាលទ្ធផល រដ្ឋធម្មនុញ្ញកម្រិតមធ្យមមួយត្រូវបានបង្កើតឡើងនៅពេលក្រោយក្នុងឆ្នាំ 1848 ។ វាបានស្នើឱ្យមានសភា និងប្រធានាធិបតីដ៏រឹងមាំមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជន។ ប្រទេសបារាំងទទួលបានមេដឹកនាំដ៏រឹងមាំមួយនៅខែធ្នូ ឆ្នាំ 1848 គឺព្រះអង្គម្ចាស់ល្វី-ណាប៉ូឡេអ៊ុងដែលត្រូវជាក្មួយប្រុសរបស់ព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុង បូណាផាត ដែលបានទទួលជ័យជំនះនៅក្នុងការបោះឆ្នោតប្រធានាធិបតី។ 4 ឆ្នាំក្រោយមក ព្រះអង្គម្ចាស់ល្វី-ណាប៉ូឡេអ៊ុងបានទទួលគោរម្យងារថា អធិរាជណាប៉ូឡេអ៊ុងទី 3 ។ ភាគច្រើននៃពួកអ្នកបោះឆ្នោតបារាំងបានទទួលយកលទ្ធផលនេះដោយគ្មានការជំទាស់ឡើយ។ ពួកបារាំងធុញទ្រាន់ទៅនឹងអស្ថិរភាព។ ពួកគេបានស្វាគមន៍អ្នកគ្រប់គ្រងដ៏រឹងមាំមួយរូបដែលនឹងនាំមកនូវសន្តិភាពដល់ប្រទេសបារាំង។ ក្នុង

នាមជាអធិរាជរបស់ប្រទេសបារាំង ព្រះអង្គម្ចាស់លូី-ណាប៉ូឡេអុងប្រកបដោយមហិច្ឆតាបានសាងសង់ផ្លូវដែក, លើកទឹកចិត្តដល់ឧស្សាហូបនីយកម្ម, និងលើកកម្ពស់កម្មវិធីកិច្ចការសាធារណៈ ។ បន្តិចម្តងៗ ដោយសារគោលនយោបាយរបស់ព្រះអង្គម្ចាស់លូី-ណាប៉ូឡេអុងភាពអត់ការងារធ្វើបានថយចុះនៅក្នុងប្រទេសបារាំង ហើយប្រទេសនេះបានជួបប្រទះនូវភាពរុងរឿងពិតប្រាកដមួយ។

## 5. កំណែទម្រង់នៅប្រទេសរុស្ស៊ី

មិនដូចប្រទេសបារាំងឡើយ ប្រទេសរុស្ស៊ីក្នុងទសវត្សរ៍ឆ្នាំ 1800 មិនទាន់ឈានជើងចូលទៅក្នុងពិភពឧស្សាហូបនីយកម្មទំនើបនៅឡើយ។ នៅក្រោមប្រព័ន្ធសក្តិភូមិរបស់រុស្ស៊ី ពួកខ្ញុំកញ្ជះត្រូវបានចងភ្ជាប់ជាមួយពួកអភិជនដែលមានដីធ្លីសម្រាប់ពួកគេធ្វើការ។ ពួកអភិជនបានរីករាយនឹងអំណាចស្ទើរតែគ្មានដែនកំណត់លើពួកខ្ញុំកញ្ជះទាំងនេះ។ នៅទសវត្សរ៍ឆ្នាំ 1820 ពួករុស្ស៊ីជាច្រើនជឿថា ប្រព័ន្ធខ្ញុំកញ្ជះត្រូវតែបញ្ចប់។ នៅក្នុងក្រសែភ្នែករបស់ពួកគេ ប្រព័ន្ធនេះគឺខុសឆ្គងខាងសីលធម៌។ វាក៏បានរារាំងដល់ការរីកចំរើនផ្នែកសេដ្ឋកិច្ចរបស់ចក្រភពផងដែរ។ ទោះជាយ៉ាងនេះក្តី ព្រះមហាក្សត្រមានភាពស្ទាក់ស្ទើរក្នុងការផ្តល់សេរីភាពដល់ពួកខ្ញុំកញ្ជះ។ ការផ្តល់សេរីភាពដល់ពួកគេនឹងធ្វើឱ្យពួកម្ចាស់ដីធ្លីមានការខឹងសម្បា ដែលព្រះមហាក្សត្រត្រូវការការគាំទ្ររបស់ពួកគេដើម្បីរក្សាអំណាច។

ការបរាជ័យនាំមកនូវការផ្លាស់ប្តូរ៖ ដោយថាហេតុ កង្វះការអភិវឌ្ឍនៅក្នុងប្រទេសរុស្ស៊ីបានក្លាយជារឿងដែលប្រជាជនរុស្ស៊ី និងពិភពលោកទាំងមូលមើលឃើញជាក់ស្តែង។ នៅឆ្នាំ 1853 អធិរាជនីកូឡាទី 1 បានគំរាមក្នុងដណ្តើមកាន់កាប់ផ្នែកនានានៃចក្រភពអូតូម៉ង់នៅក្នុងសង្គ្រាមគ្រីមៀ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធឧស្សាហកម្ម និងដឹកជញ្ជូនរបស់រុស្ស៊ីបានបរាជ័យក្នុងការផ្តល់ការផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់កងទ័ពរបស់ប្រទេសនេះ។ ជាលទ្ធផលនៅឆ្នាំ 1856 ប្រទេសរុស្ស៊ីបានចាញ់សង្គ្រាមប្រឆាំងនឹងកងកម្លាំងចម្រុះនៃប្រទេសបារាំង, ចក្រភពអង់គ្លេស, សាឌីនៀ, និងចក្រភពអូតូម៉ង់។ បន្ទាប់ពីសង្គ្រាមរាជបិត្រារបស់អធិរាជនីកូឡាទី 1 គឺព្រះអង្គម្ចាស់អាឡិចសាន់ឌឺទី 2 បានសម្រេចព្រះទ័យនៅក្នុងការផ្លាស់ប្តូរប្រទេសរុស្ស៊ីឆ្ពោះទៅរកការធ្វើទំនើបកម្ម និងការផ្លាស់ប្តូរសង្គម។ ព្រះអង្គម្ចាស់អាឡិចសាន់ឌឺ និងទីប្រឹក្សារបស់ទ្រង់ជឿថា ការធ្វើកំណែទម្រង់របស់ទ្រង់ នឹងអនុញ្ញាតឱ្យរុស្ស៊ីអាចប្រកួតប្រជែងជាមួយអឺរ៉ុបខាងលិចធ្វើជាមហាអំណាចពិភពលោកបាន។

កំណែទម្រង់ និងប្រតិកម្ម៖ ការកែទម្រង់ដំបូង និងខ្លាំងបំផុតរបស់អាឡិចសាន់ឌឺ គឺការចេញក្រឹត្យមួយដើម្បីដោះលែងពួកខ្ញុំកញ្ជះនៅឆ្នាំ 1861។ ទោះបីជាយ៉ាងណាក៏ដោយ ការលុបបំបាត់ប្រព័ន្ធខ្ញុំកញ្ជះបានដំណើរការតែពាក់កណ្តាលប៉ុណ្ណោះ។ សហគមន៍កសិករ ជាជាងកសិករម្នាក់ៗ ទទួលបានដីស្រែប្រហែលពាក់កណ្តាលនៃផ្ទៃដីដាំដុះនៅក្នុងប្រទេស។ ពួកអភិជននៅរក្សាការគ្រប់គ្រងពាក់កណ្តាល។ រដ្ឋាភិបាលបានបង់លុយឱ្យពួកអភិជនសម្រាប់ការដកហូតដីធ្លីរបស់ពួកគេ។ ម្យ៉ាងវិញទៀត សហគមន៍កសិករនីមួយៗមានពេល 49 ឆ្នាំដើម្បីបង់លុយឱ្យរដ្ឋាភិបាលសម្រាប់ដីធ្លីដែលពួកគេទទួលបានពីរដ្ឋាភិបាល។ ដូច្នេះ ខណៈពួកខ្ញុំកញ្ជះមានសេរីភាពតាមផ្លូវច្បាប់ បំណុលនៅតែចងជាប់ពួកគេជាមួយនឹងដីធ្លី។ កំណែទម្រង់នយោបាយ និងសង្គមបានបញ្ឈប់ជិត

ពាក់កណ្តាល នៅពេលភេរវករបានលួចធ្វើគតព្រះអង្គម្ចាស់អាឡិចសាន់ឌឺទី 2 ក្នុងឆ្នាំ 1881។ អ្នកស្នងតំណែងរបស់គាត់គឺ ព្រះអង្គម្ចាស់អាឡិចសាន់ឌឺទី 3 បានរឹតបន្តឹងការគ្រប់គ្រងលើប្រទេស។ ទោះយ៉ាងណាក៏ដោយ ព្រះអង្គម្ចាស់អាឡិចសាន់ឌឺទី និងរដ្ឋមន្ត្រីរបស់ទ្រង់បានលើកទឹកចិត្តដល់ការអភិវឌ្ឍឧស្សាហកម្មដើម្បីពង្រីកអំណាចរបស់រុស្ស៊ី។ កម្លាំងដ៏សំខាន់នៅពីក្រោយការជំរុញរបស់រុស្ស៊ីឆ្ពោះទៅរកការពង្រីកឧស្សាហកម្មគឺជាតិនិយម។ ជាតិនិយមក៏បានញុះញង់ដល់ជនជាតិដទៃទៀតដែរ។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1800 ក្រុមជនជាតិទាំងនេះបានរួបរួមគ្នាជាជាតិមួយ និងកសាងឧស្សាហកម្មដើម្បីរស់រានក្នុងចំណោមប្រទេសផ្សេងៗទៀត។

# មេរៀនទី 3៖ ជាតិនិយម

ជាតិនិយមគឺជាគំនិតដ៏មានឥទ្ធិពលបំផុតនៃទសវត្សរ៍ឆ្នាំ 1800។ ឥទ្ធិពលរបស់វាបានលាតសន្ធឹងពាសពេញទ្វីបអឺរ៉ុប និងអាមេរិក។ វាធ្វើឱ្យលេចចេញប្រទេសនានាតាមរយៈការបង្កើតថ្មី ឬបំបែកប្រទេសចេញពីប្រទេសចាស់។ នៅទ្វីបអឺរ៉ុប វាក៏ធ្វើឱ្យខូចខាតដល់តុល្យភាពនៃអំណាច ដែលត្រូវបានបង្កើតឡើងនៅសន្និបាទទីក្រុងវីយែនក្នុងឆ្នាំ 1815 ដែលបង្កឱ្យមានផលប៉ះពាល់ដល់ជីវិតមនុស្សរាប់លាននាក់។ ចក្រភពនានានៅអឺរ៉ុបត្រូវបានបង្កើតឡើងដោយមនុស្សជាច្រើនក្រុម។ ជាតិនិយមបានបណ្ដុះបំណងប្រាថ្នារបស់ក្រុមមនុស្សទាំងនោះឱ្យស្វែងរកសេរីភាពពីការគ្រប់គ្រងរបស់ចក្រភព និងគ្រប់គ្រងដែនដីរបស់ពួកគេដោយខ្លួនឯង។

## 1. ជាតិនិយម៖ កម្លាំងដើម្បីឯកភាពជាតិ ឬការបំបែកបំបាក់

នៅអំឡុងទសវត្សរ៍ឆ្នាំ 1800 ជាតិនិយមបានជំរុញឱ្យមានកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងប្រទេសជាតិ។ អ្នកជាតិនិយមមិនភក្ដីភាពតែចំពោះព្រះមហាក្សត្រទេ ប៉ុន្តែពួកគេមានភក្ដីភាពចំពោះប្រជាជនរបស់ពួកគេ អ្នកដែលមានចំណងប្រាថ្នារួម។ អ្នកជាតិនិយមជឿថាប្រជាជនដែលមាន "ជាតិសាសន៍តែមួយ" ឬពូជពង្សតែមួយគួរតែរួបរួមគ្នានៅក្រោមរដ្ឋាភិបាលតែមួយ។ ប៉ុន្តែ អ្នកដែលចង់ស្តារសណ្តាប់ធ្នាប់ចាស់តាំងពីមុនបដិវត្តបារាំង មើលឃើញថាជាតិនិយមជាកម្លាំងបង្រួបបង្រួមជាតិមួយ។ បន្តិចម្តងៗ មេដឹកនាំផ្តាច់ការបានចាប់ផ្តើមមើលឃើញថាជាតិនិយមក៏អាចជាកម្លាំងបង្រួបបង្រួមមហាជនបានផងដែរ។ មិនយូរប៉ុន្មាន ពួកគេបានចាប់ផ្តើមប្រើគំនិតជាតិនិយមសម្រាប់គោលបំណងផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកគេបានបង្កើតប្រទេសជាតិនៅក្នុងតំបន់ដែលពួកគេនៅតែបន្តគ្រប់គ្រងយ៉ាងរឹងមាំ។ នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន ក្រុមនានានៅតែបន្តប្រើគំនិតជាតិនិយម ដើម្បីបង្រួបបង្រួម, បំបែក, ឬកសាងប្រទេសជាតិ។

## 2. ជាតិនិយមរំលំចក្រភពចាស់ៗ

ចក្រភពយ៉ែចំណាស់ចំនួន 3 រួមមាន ចក្រភពអូទ្រីសរបស់ពួកហាពស្ប៊ឺក, ចក្រភពរុស្ស៊ីរបស់ពួករ៉ូម៉ាណូវ, និងចក្រភពអូតូម៉ង់របស់ពួកទួគី មានក្រុមជនជាតិភាគតិចរស់នៅលាយឡំគ្នាយ៉ាងច្រើន។ ការគ្រប់គ្រងលើទឹកដី និងក្រុមជនជាតិភាគតិចបានផ្លាស់ប្តូរទៅវិញទៅមករវាងចក្រភពទាំង 3 នេះ អាស្រ័យលើជ័យជំនះ ឬបរាជ័យក្នុងការធ្វើសង្គ្រាម និងលើការរៀបអភិសេករវាងខ្សែរាជវង្ស។ នៅពេលដែលគំនិតជាតិនិយមបានលេចឡើងក្នុងសតវត្សរ៍ទី 19 ភាពចលាចលនៃជនជាតិភាគតិចបានគំរាមកំហែងចក្រភព ហើយទីបំផុតបានផ្តួលរំលំចក្រភពទាំងនេះ។

ការបែកបាក់នៃចក្រភពអូទ្រីស៖ ចក្រភពអូទ្រីសប្រមូលផ្តុំដោយជនជាតិស្លាវ, ហុងគ្រី, អាល្លឺម៉ង់, ឆេក, ស្លូវ៉ាគី, ក្រូអាត, ប៉ូឡូញ, ស៊ែប, និងអ៊ីតាលី។ នៅឆ្នាំ 1866 ពួកព្រូសបានយកជ័យជំនះលើប្រទេសអូទ្រីសក្នុងសង្គ្រាមអូទ្រីស-ព្រូស។ ជាមួយនឹងជ័យជម្នះរបស់ខ្លួន ពួកព្រូសទទួលបានការគ្រប់គ្រងលើ សហព័ន្ធអាឡឺម៉ង់ខាងជើង ដែលទើបតែត្រូវបានបង្កើតថ្មី ដែលជាការរួមបញ្ចូលគ្នារវាង ព្រូស និងអង្គភាពនយោបាយអាល្លឺម៉ង់តូចៗចំនួន 21 ។ បន្ទាប់មក ដោយមានការគាបសង្កត់ដោយពួកហុងគ្រី ព្រះចៅអធិរាជហ្វ្រង់ស៊ីស ចូសេបនៃប្រទេសអូទ្រីស បាន

បំបែកអាណាចក្ររបស់ទ្រង់ជា 2 ដោយបានបង្កើតរដ្ឋឯករាជ្យអូទ្រីស និងហុងគ្រី ដោយព្រះអង្គជាអ្នកគ្រប់គ្រងរដ្ឋឯករាជ្យទាំង 2 នេះ។ ចក្រភពនេះត្រូវបានគេហៅថាអូទ្រីស-ហុងគ្រី។ ជម្លោះជាតិនិយមបានបន្តធ្វើឱ្យចក្រភពនេះចុះខ្សោយអស់រយៈពេលជាង 40 ឆ្នាំមកហើយ។ ទីបំផុតបន្ទាប់ពីសង្គ្រាមលោកលើកទី 1 អូទ្រីស-ហុងគ្រីបានបំបែកទៅជារដ្ឋដាច់ដោយឡែកពីគ្នាមួយចំនួន។

ចក្រភពរុស្ស៊ីដួលរលំ៖ ជាតិនិយមក៏បានជួយបំបែកចក្រភពដែលមានអាយុកាល 370 ឆ្នាំនៅក្នុងប្រទេសរុស្ស៊ីផងដែរ។ បន្ថែមពីលើជនជាតិរុស្ស៊ីផ្ទាល់ ព្រះចៅអធិរាជបានគ្រប់គ្រងលើពួកអ៊ុយក្រែនចំនួនជាង 22 លាននាក់, ពួកប៉ូឡូញចំនួន 8 លាននាក់, និងមួយភាគតូចនៃជនជាតិលីទុយអានី, ឡាតវី, អេស្តូនី, ហ្វាំងឡង់, ជ្វីប, រ៉ូម៉ានី, ហ្សកហ្ស៊ី, អាមេនី, ទួគី, និងក្រុមផ្សេងៗទៀត។ ក្រុមនីមួយៗមានវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ។ រាជវង្សរ៉ូម៉ាណូវដែលកំពុងកាន់អំណាចនៅក្នុងប្រទេសរុស្ស៊ី បានប្ដេជ្ញាក្នុងការរក្សាការគ្រប់គ្រងយ៉ាងតឹងរឹងលើជនជាតិចម្រុះនេះ។ ពួកគេបានបង្កើតគោលនយោបាយរ៉ុស្ស៊ីនីយកម្ម ដោយបានបង្ខំឱ្យក្រុមជនជាតិភាគតិចទាំងអស់នៅក្នុងចក្រភពអនុវត្តនៃវប្បធម៌របស់រុស្ស៊ី។ តាមពិតទៅ គោលនយោបាយនេះបានជួយពង្រឹងគំនិតជាតិនិយមរបស់ជនជាតិភាគតិច និងបានជួយក្នុងការបំបែកបំបាក់រុស្ស៊ី។ ទីបំផុតទៅចក្រភពហ្សានិយមមួយទន់ខ្សោយមួយនេះ មិនអាចទប់ទល់នឹងព្រឹត្តិការណ៍តក់ស្លុតចំនួន 2 ដងគឺសង្គ្រាមលោកលើកទី 1 និងបដិវត្តកុម្មុយនិស្តបានឡើយ។ ហ្សាររ៉ូម៉ាណូវចុងក្រោយបានលះបង់អំណាចរបស់ទ្រង់នៅឆ្នាំ 1917 ។

ចក្រភពអូតូម៉ង់ចុះខ្សោយ៖ ពួកទួគដែលដឹកនាំចក្រភពអូតូម៉ង់បានគ្រប់គ្រងលើពួកក្រិក, ស្លាវ, អារ៉ាប់, ប៊ុលហ្គារី, និងអាមេនៀ។ នៅឆ្នាំ 1856 ក្រោមសម្ពាធពីចក្រភពអង់គ្លេស និងបារាំង ចក្រភពអូតូម៉ង់បានផ្ដល់សញ្ជាតិស្មើៗគ្នាដល់ប្រជាជនទាំងអស់នៅក្រោមការគ្រប់គ្រងរបស់ពួកគេ។ វិធានការនោះបានធ្វើឱ្យពួកអភិរក្សនិយមទួគីមានការខឹងសម្បា អ្នកដែលមិនចង់ឱ្យមានការផ្លាស់ប្ដូរស្ថានការណ៍ និងបានបង្កឱ្យមានជម្លោះក្នុងចក្រភព។ ឧទាហរណ៍ ក្នុងការឆ្លើយតបនឹងពួកជាតិនិយមនៅអាមេនី ពួកអូតូម៉ង់បានសម្លាប់រង្គាល និងនិរទេសជនជាតិអាមេនីចាប់ពីឆ្នាំ 1894 ដល់ឆ្នាំ 1896 និងម្ដងទៀតនៅឆ្នាំ 1915។ ក៏ដូចជាអូទ្រីស-ហុងគ្រីដែរ ចក្រភពអូតូម៉ង់បានបែកបាក់ភ្លាមៗបន្ទាប់ពីសង្គ្រាមលោកលើកទី 1 ។

### 3. លោកកាវួរបង្រួបបង្រួមអ៊ីតាលី

ខណៈពេលជាតិនិយមបំផ្លាញចក្រភពនានា វាក៏បានកសាងជាតិផងដែរដែរ។ ប្រទេសអ៊ីតាលីគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលកើតចេញមកពីដែនដីនៃចក្រភពដួលរលំមួយ។ រវាងឆ្នាំ 1815 និង 1848 ជនជាតិអ៊ីតាលីតិចទៅតិចដែលមានចិត្តចង់រស់នៅក្រោមការគ្រប់គ្រងរបស់បរទេស។

លោកកាវួរដឹកនាំការបង្រួបបង្រួមអ៊ីតាលី៖ ពួកអ្នកជាតិនិយមអ៊ីតាលីបានសំលឹងរកការដឹកនាំរបស់ព្រះរាជាណាចក្រពីដម៉ុន-សាឌីនៀ ដែលជារដ្ឋធំបំផុត និងមានឥទ្ធិពលបំផុតក្នុងចំណោមរដ្ឋនានានៅអ៊ីតាលី។ ព្រះរាជាណាចក្រនេះបានអនុម័តរដ្ឋធម្មនុញ្ញបែបសេរីនិយមមួយនៅក្នុងឆ្នាំ 1848។ ដូច្នេះចំពោះពួសេរីនិយមអ៊ីតាលីវណ្ណៈកណ្ដាល ការបង្រួបបង្រួមនៅក្រោមព្រះរាជាណាចក្រពីដម៉ុន-សាឌីនៀហាក់ដូចជាផែនការដ៏ល្អមួយ។ នៅ

ឆ្នាំ 1852 ព្រះមហាក្សត្រសាឌីនៀ វិចទ័រ អេម៉ានូអែលទី 2 បានតែងតាំងលោក ខោនត៍ កាមីលឡូ ឌី កាវួរ ជានាយករដ្ឋមន្ត្រីរបស់ទ្រង់។ លោកកាវួរគឺជារដ្ឋបុរសដែលមានល្បិចកលម្នាក់ ដែលបានធ្វើការដោយមិននឿយហត់ដើម្បីពង្រីកអំណាចរបស់ព្រះរាជាណាចក្រពីដម៉ុន-សាឌីនៀ។ ដោយប្រើជំនាញការទូតដ៏ប៉ិនប្រសប់ និងការជ្រើសរើសសម្ព័ន្ធមិត្តបានយ៉ាងល្អ លោកមានបំណងក្នុងការបង្កើតការគ្រប់គ្រងរបស់សាឌីនៀលើតំបន់នានាដែលស្ថិតនៅអ៊ីតាលីភាគខាងជើង។ លោកកាវួរបានដឹងថា អ្នកដែលរាំងផ្លូវក្នុងការបញ្ចូលតំបន់អ៊ីតាលីភាគខាងជើងគឺប្រទេសអូទ្រីស។ នៅក្នុងឆ្នាំ 1858 អធិរាជបារាំងណាប៉ូឡេអុងទី 3 បានយល់ព្រមជួយបណ្តេញប្រទេសអូទ្រីសចេញពីអ៊ីតាលីភាគខាងជើង។ បន្ទាប់មក លោកកាវួរបានបង្កសង្គ្រាមជាមួយជនជាតិអូទ្រីស។ កងទ័ពបារាំង-សាឌីនៀដែលរួមបញ្ចូលគ្នាបានទទួលជ័យជម្នះយ៉ាងរហ័សចំនួន 2 លើក។ ពួកសាឌីនៀទទួលបានជោគជ័យក្នុងការដណ្តើមយកអ៊ីតាលីភាគខាងជើង លើកលែងតែតំបន់វេនេចៀ។

ហ្គារីបាល់ឌីនាំមកនូវការរួបរួម៖ ខណៈដែលលោកាវួរកំពុងបង្រួបបង្រួមអ៊ីតាលីភាគខាងជើង លោកចាប់ផ្តើមជួយក្រុមអ្នកបះបោរជាតិនិយមដោយសម្ងាត់នៅអ៊ីតាលីភាគខាងត្បូង។ នៅខែឧសភា ឆ្នាំ 1860 កងទ័ពតូចមួយក្រុមរបស់អ្នកជាតិនិយមអ៊ីតាលីដែលដឹកនាំដោយទាហានក្លាហាន និងមានចក្ខុវិស័យមួយរូបឈ្មោះហ្គូសេពប៉េ ហ្គារីបាល់ឌី បានដណ្តើមកាន់កាប់តំបន់ស៊ីស៊ីលី។ នៅក្នុងសមរភូមិ លោកហ្គារីបាល់ឌី ក៏ដូចជាអ្នកដើរតាមលោកតែងតែពាក់អាវពណ៌ក្រហម។ ជាលទ្ធផល ពួកគេត្រូវបានគេស្គាល់ថាជាក្រុមអាវក្រហម។ ពីស៊ីស៊ីលី លោកហ្គារីបាល់ឌី និងកងកម្លាំងរបស់លោកបានឆ្លងទៅអ៊ីតាលីដីគោក និងបានធ្វើដំណើរឆ្ពោះទៅភាគខាងជើង។ នៅទីបំផុត លោកហ្គារីបាល់ឌីបានយល់ព្រមបង្រួបបង្រួមតំបន់ភាគខាងត្បូងដែលលោកដណ្តើមកាន់កាប់បានជាមួយព្រះរាជាណាចក្រពីដម៉ុន-សាឌីនៀ។ លោកកាវួរបានរៀបចំឱ្យព្រះអង្គម្ចាស់វិចទ័រ អេម៉ានូអែលទី 2 ជួបជាមួយលោកហ្គារីបាល់ឌីនៅតំបន់ណាពលេស ។ "ពួកក្រហម" បានយល់ព្រមចុះចេញពីតំណែង និងអនុញ្ញាតឱ្យស្តេចសាឌីនៀគ្រប់គ្រង។ នៅឆ្នាំ 1866 ខេត្តវេនេតៀរបស់អូទ្រីស ដែលរួមបញ្ចូលទាំងទីក្រុង វេនីសផងនោះបានក្លាយជាផ្នែកមួយនៃប្រទេសអ៊ីតាលី។ នៅឆ្នាំ 1870 កងកម្លាំងអ៊ីតាលីបានដណ្តើមកាន់កាប់ដែនដីចុងក្រោយមួយដែលគេស្គាល់ថាជារដ្ឋប៉ាប៉ាល់។ ជាមួយនឹងជ័យជម្នះនេះ ទីក្រុងរ៉ូមបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ៊ីតាលី។ មិនយូរប៉ុន្មាន ទីក្រុងរ៉ូមបានក្លាយជារាជធានីនៃព្រះរាជាណាចក្រអ៊ីតាលី។ ទោះជាយ៉ាងណាក៏ដោយ សម្តេចប៉ាបនឹងបន្តគ្រប់គ្រងផ្នែកមួយនៃទីក្រុងរ៉ូម ដែលគេស្គាល់ថាជាទីក្រុងវ៉ាទីកង់។

### 4. ប៊ីស្មាក់បង្រួបបង្រួមប្រទេសអាល្លឺម៉ង់

ក៏ដូចជាប្រទេសអ៊ីតាលី អាឡឺម៉ង់ក៏សម្រេចបានឯកភាពជាតិនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 ដែរ។ ចាប់ផ្តើមនៅឆ្នាំ 1815 រដ្ឋនានារបស់អាឡឺម៉ង់ចំនួន 39 បានរួមបញ្ចូលគ្នាបង្កើតបានជាក្រុមធូរលុងមួយហៅថាសហព័ន្ធអាល្លឺម៉ង់។ ចក្រភពអូទ្រីសបានគ្រប់គ្រងសហព័ន្ធនេះ។ ទោះជាយ៉ាងណាក៏ដោយ ពួកព្រូសបានត្រៀមខ្លួនជាស្រេចដើម្បីបង្រួបបង្រួមរដ្ឋអាល្លឺម៉ង់ទាំងអស់នេះ។

ព្រូសដឹកនាំការបង្រួបបង្រួមអាល្លឺម៉ង់៖ ព្រូសទទួលបានអត្ថប្រយោជន៍ជាច្រើនដែលនឹងជួយពួកគេក្នុងការបង្កើតរដ្ឋអាល្លឺម៉ង់ដ៏រឹងមាំមួយ។ ដំបូងឡើយ មិនដូចចក្រភពអូទ្រីស-ហុងគ្រីទេ ព្រូសមានប្រជាជនអាល្លឺម៉ង់រស់នៅជាចម្បង។ ជាលទ្ធផល ជាតិនិយមបានជួយបង្រួបបង្រួមព្រូស។ ផ្ទុយទៅវិញ ក្រុមជនជាតិនានាក្នុងប្រទេសអូទ្រីស-ហុងគ្រី បានបំបែកចក្រភពជាផ្នែក។ ជាងនេះទៅទៀត កងទ័ពរបស់ព្រូសមានកម្លាំងខ្លាំងបំផុតនៅអឺរ៉ុបកណ្ដាល។ នៅឆ្នាំ 1848 ក្រុមអ្នកបះបោរនៅប៊ែរឡាំងបានបង្ខំឱ្យមានការកែប្រែរដ្ឋធម្មនុញ្ញមួយឲ្យមានលក្ខណៈសេរីនិយមសម្រាប់រាជាណាចក្រ ដោយត្រួសត្រាយផ្លូវសម្រាប់ការបង្រួបបង្រួម។

ការគ្រប់គ្រងរបស់ប៊ីស្មាក់៖ នៅឆ្នាំ 1861 ព្រះអង្គម្ចាស់វីលហេមទី 1 បានឡើងគ្រងរាជ្យបន្តពីព្រះអង្គម្ចាស់ហ្វេឌីរិច វីលលៀម ។ សភាសេរីនិយមបានបដិសេធក្នុងការផ្តល់លុយឱ្យទ្រង់សម្រាប់ការកំណែទម្រង់ ដែលនឹងបង្កើនកម្លាំងរបស់កងទ័ពទ្វេដង។ ព្រះអង្គម្ចាស់វីលហេម បានយល់ឃើញថាការបដិសេធរបស់សភាជាបញ្ហាប្រឈមដ៏សំខាន់ចំពោះសិទ្ធិអំណាចរបស់ទ្រង់។ ទស្សនរបស់ទ្រង់ត្រូវបានគាំទ្រដោយពួកអភិជនដែលជាសាខាមួយនៃក្រុមអភិរក្សនិយមជ្រុលស្ថិតក្នុងវណ្ណៈម្ចាស់កម្មសិទ្ធិដីធ្លីរបស់ព្រូស។ នៅឆ្នាំ 1862 ព្រះអង្គម្ចាស់វីលហេមបានជ្រើសរើសអភិជនអភិរក្សនិយមមួយរូបដែលមានឈ្មោះថាអូតតូ វុន ប៊ីស្មាក់ ធ្វើជានាយករដ្ឋមន្ត្រីរបស់ទ្រង់។ ប៊ីស្មាក់គឺជាមេដឹកនាំនៃអ្វីដែលត្រូវបានគេស្គាល់ថាជារៀលប៉ូលីទីក។ ពាក្យអាល្លឺម៉ង់នេះមានន័យថា "នយោបាយការពិត" ។ ពាក្យនេះត្រូវបានប្រើដើម្បីពណ៌នាអំពីអំណាចនយោបាយរឹងមាំមួយគឺគ្មានកន្លែងសម្រាប់គំនិតនិយមឡើយ។ ជាមួយនឹងរៀលប៉ូលីទីកដែលជារចនាបថរបស់លោក ប៊ីស្មាក់នឹងក្លាយជាតួសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រអាល្លឺម៉ង់។ ដោយមានការយល់ព្រមពីព្រះមហាក្សត្រ ប៊ីស្មាក់បានប្រកាសថាលោកនឹងគ្រប់គ្រងដោយមិនចាំបាច់មានការយល់ព្រមពីសភា និងដោយមិនចាំបាច់មានច្បាប់ថវិកាជាតិឡើយ។ សកម្មភាពទាំងនោះគឺជាការបំពានផ្ទាល់ទៅនឹងរដ្ឋធម្មនុញ្ញ។ នៅក្នុងសុន្ទរកថាដំបូងរបស់លោកក្នុងនាមជានាយករដ្ឋមន្ត្រី លោកបានប្រាប់សមាជិកសភាព្រូសថា "វាមិនមែនដោះស្រាយតាមរយៈការនិយាយឡើយ ហើយការសម្រេចដោយមតិភាគច្រើនដើម្បីដោះស្រាយបញ្ហាសំខាន់ៗគឺជាកំហុសដ៏ធំនៅក្នុងឆ្នាំ 1848 និង 1849 ប៉ុន្តែគេគួរតែដោះស្រាយដោយការបង្ហូរឈាម និងអាវុធ"។

ការពង្រីកព្រូស៖ នៅឆ្នាំ 1864 ប៊ីស្មាក់បានបោះជំហានដំបូងឆ្ពោះទៅរកការបង្កើតចក្រភពមួយ។ ព្រូសនិងអូទ្រីសបានបង្កើតសម្ព័ន្ធភាពមួយ ហើយបានធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសដាណឺម៉ាក ដើម្បីដណ្តើមយកខេត្តជាប់ព្រំដែនចំនួន 2 គឺស្លេសស្វីង និងហូលស្ទៀន។ ជ័យជំនះដ៏រហ័សនេះបានបង្កើនមោទនភាពជាតិក្នុងចំណោមប្រជាជនព្រូស។ វាក៏ទទួលបានការគោរពពីជនជាតិអាឡឺម៉ង់ផ្សេងទៀត និងផ្តល់ការគាំទ្រដល់ព្រូសធ្វើជាប្រមុខនៃប្រទេសអាល្លឺម៉ង់បង្រួបបង្រួមមួយ។ បន្ទាប់ពីជ័យជំនះ ព្រូសបានគ្រប់គ្រងស្លេសស្វីង ខណៈពេលដែលអូទ្រីសគ្រប់គ្រងហូលស្ទៀន។

សង្គ្រាម 7 សប្តាហ៍៖ ប៊ីស្មាក់មានចេតនាបញ្ឆេះជម្លោះជាមួយប្រទេសអូទ្រីសលើបញ្ហាតំបន់ស្លេសស្វីង និងហូលស្ទៀន។ ភាពតានតឹងបានជំរុញឱ្យប្រទេសអូទ្រីសប្រកាសសង្គ្រាមជាមួយព្រូសក្នុងឆ្នាំ 1866 ។ ជម្លោះនេះ

ត្រូវបានគេស្គាល់ថាជាសង្គ្រាម 7 សប្ដាហ៍។ ពួកព្រូសកងទ័ពដែលទទួលបានប្រើការហ្វឹកហ្វឺន និងអាវុធទំនើបៗ ដើម្បីដណ្ដើមបានជ័យជម្នះក្នុងសង្គ្រាមដ៏បង្ហូរឈាមនេះ។ ពួកគេបានធ្វើឱ្យប្រទេសអូទ្រីសអាម៉ាស់មុខ។ ពួកអូទ្រីសបានបាត់បង់តំបន់វេនេទៀ ដែលត្រូវបានផ្ដល់ទៅឱ្យអ៊ីតាលី។ ពួកគេត្រូវយល់ព្រមចំពោះការភ្ជាប់ទឹកដីអាល្លឺម៉ង់បន្ថែមទៀតទៅក្នុងព្រះរាជាណាចក្រព្រូស។ ជាមួយនឹងជ័យជម្នះរបស់ខ្លួននៅក្នុងសង្គ្រាម 7 សប្ដាហ៍ ព្រូសបានគ្រប់គ្រងប្រទេសអាល្លឺម៉ង់ភាគខាងជើង ។ ជាលើកដំបូងដែលផ្នែកខាងកើត និងខាងលិចនៃរាជាណាចក្រព្រូសត្រូវបានរួមបញ្ចូលគ្នា។ នៅឆ្នាំ 1867 រដ្ឋដែលនៅសេសសល់នៃភាគខាងជើងបានចូលរួមជាមួយសហភាពអាឡឺម៉ង់ខាងជើងដែលព្រូសជាអ្នកគ្រប់គ្រងទាំងស្រុង។

សង្គ្រាមបារាំង-ព្រូស៖ នៅឆ្នាំ 1867 រដ្ឋអាល្លឺម៉ង់ភាគខាងត្បូងមួយចំនួននៅតែឯករាជ្យពីការគ្រប់គ្រងរបស់ពួកព្រូស។ ភាគច្រើននៃជនជាតិអាឡឺម៉ង់ភាគខាងត្បូងគឺជាអ្នកកាន់សាសនាកាតូលិក។ មនុស្សជាច្រើនក្នុងតំបន់បានទប់ទល់នឹងការត្រួតត្រាដោយប្រូតេស្តង់របស់ព្រូស។ ទោះជាយ៉ាងណាក៏ដោយ ប៊ីស្មាក់យល់ថាលោកអាចទទួលបានការគាំទ្រពីប្រជាជនភាគខាងត្បូង ប្រសិនបើពួកគេប្រឈមទៅនឹងការគំរាមកំហែងពីខាងក្រៅ។ លោកបានលើកហេតុផលថា សង្គ្រាមជាមួយបារាំងនឹងទទួលបានការគាំទ្រពីពួកភាគខាងត្បូង។ ប៊ីស្មាក់គឺជាអ្នកជំនាញខាងផលិត "ឧប្បត្តិហេតុ" ដើម្បីសម្រេចគោលដៅរបស់លោក។ ឧទាហរណ៍ គាត់បានបង្កើតការចាប់អារម្មណ៍ដោយថា ឯកអគ្គរដ្ឋទូតបារាំងបានដេរប្រមាថព្រះមហាក្សត្រព្រូស ។ ពួកបារាំងបានប្រតិកម្មចំពោះការបោកបញ្ឆោតរបស់ ប៊ីស្មាក់ដោយប្រកាសសង្គ្រាមជាមួយពួកព្រូសនៅថ្ងៃទី 19 ខែកក្កដា ឆ្នាំ 1870។ ភ្លាមៗនោះកងទ័ពព្រូសបានវាយលុកបារាំងភាគខាងជើង។ នៅខែកញ្ញា ឆ្នាំ 1870 កងទ័ពព្រូសបានឡោមព័ទ្ធកងកម្លាំងបារាំងនៅសេដាន់។ ក្នុងចំណោមឈ្លើយសឹកបារាំងចំនួន 83,000 នាក់ក្នុងនោះមានព្រះអង្គម្ចាស់ណាប៉ូឡេអ៊ុងទី 3 ផងដែរ។ ប្រជាជនប៉ារីសបានទប់ទល់នឹងការឡោមព័ទ្ធរបស់អាល្លឺម៉ង់ រហូតដល់ភាពអត់ឃ្លានបានបង្ខំឱ្យពួកគេចុះចាញ់។ សង្គ្រាមបារាំង-ព្រូសគឺជាដំណាក់កាលចុងក្រោយក្នុងការបង្រួបបង្រួមអាល្លឺម៉ង់។ ឥឡូវនេះ គំនិតជាតិនិយមក៏រីករាលដាលទៅលើប្រជាជនអាល្លឺម៉ង់ភាគខាងត្បូងផងដែរ។ ទីបំផុតពួកគេបានទទួលយកការដឹកនាំរបស់ព្រូស។ នៅថ្ងៃទី 18 ខែមករា ឆ្នាំ 1871 នៅឯរាជវាំងវ៉ែកសៃរបស់បារាំងដែលពួកព្រូសដណ្ដើមកាន់កាប់បាន ព្រះមហាក្សត្រវីលហេមទី 1 របស់ព្រូសត្រូវបានលើកឱ្យឡើងគ្រង់រាជ្យជាខៃស័រ ឬអធិរាជ។ ជនជាតិអាល្លឺម៉ង់បានហៅចក្រភពរបស់ពួកគេថា រិចទី 2 ( ចក្រភពរ៉ូមដ៏បរិសុទ្ធ គឺជារិចទី 1)។ ប៊ីស្មាក់បានសម្រេចការគ្រប់គ្រងរបស់ប្រូសលើប្រទេសអាល្លឺម៉ង់ និងអឺរ៉ុបតាមរយៈ "ការបង្ហូរឈាម និងអាវុធ"។

## 5. ការផ្លាស់ប្ដូរអំណាច

សន្និបាតក្រុងវីយែនឆ្នាំ 1815 បានបង្កើតមហាអំណាចចំនួនប្រាំនៅអឺរ៉ុបក្នុងនោះរួមមាន ចក្រភពអង់គ្លេស, បារាំង, អូទ្រីស, ព្រូស ,និងរុស្ស៊ី។ នៅឆ្នាំ 1815 មហាអំណាចទាំងអស់មានកម្លាំងស្មើរតែស្មើគ្នាទាំងអស់។ សង្គ្រាមនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1800 បានពង្រឹងយ៉ាងខ្លាំងនូវមហាអំណាចមួយ ដូចដែលព្រូសបានចូលរួមជាមួយរដ្ឋអាល្លឺម៉ង់ផ្សេងទៀតដើម្បីបង្កើតប្រទេសអាល្លឺម៉ង់។ នៅឆ្នាំ 1871 ច្បាស់ណាស់ថាអង់គ្លេស និងអាឡឺម៉ង់

គឺជាអ្នកដែលមានខ្លាំងអំណាចបំផុត ទាំងផ្នែកយោធា និងសេដ្ឋកិច្ច។ អូទ្រីស និងរុស្ស៊ីបានដើរថយក្រោយឆ្ងាយ។ បារាំងបានតស៊ូស្ថិតនៅកណ្តាល។ តុល្យភាពអំណាចនៅអឺរ៉ុបបានបែកបាក់។ ការផ្លាស់ប្តូរនេះក៏ត្រូវបានគេមើលឃើញតាមរយៈសិល្បៈនៃសម័យកាលនោះផងដែរ។ ជាការពិត ក្នុងអំឡុងសតវត្សរ៍នោះ សិល្បករ, អ្នកតែងបទភ្លេង, និងអ្នកនិពន្ធបានចង្អុលបង្ហាញផ្លូវដែលពួកគេជឿថាសង្គមអឺរ៉ុបគួរតែដើរតាម។

# មេរៀនទី 4៖ បដិវត្តសិល្បៈ

នៅអំឡុងពាក់កណ្តាលទីមួយនៃទសវត្សរ៍ឆ្នាំ 1800 វិចិត្រករបានផ្តោតលើគំនិតនៃសេរីភាព, សិទ្ធិរបស់បុគ្គល, និងទស្សនៈប្រកបដោយទស្សននិយមមួយអំពីប្រវត្តិសាស្ត្រ។ បន្ទាប់ពីបដិវត្តដ៏អស្ចារ្យនៅឆ្នាំ 1848 ការចាប់អារម្មណ៍នយោបាយបានផ្លាស់ប្តូរឆ្ពោះទៅរកមេដឹកនាំដែលអនុវត្តនយោបាយពិតប្រាកដ។ ដូចគ្នានេះដែរ បញ្ញវន្ត និងវិចិត្រករបានសម្តែងនូវទស្សនៈ "ប្រាកដនិយម" អំពីពិភពលោក។ ក្នុងទិដ្ឋភាពដូចគ្នានេះ ពួកអ្នកមានបានស្វែងរកផលប្រយោជន៍សម្រាប់ខ្លួនពួកគេផ្ទាល់ ខណៈពេលដែលមនុស្សសាមញ្ញជួបការលំបាក និងវេទនា។ រូបថតដែលទើបនឹងនាមបង្កើតថ្មី បានក្លាយជាវិធីមួយក្នុងការបង្ហាញលម្អិតអំពីការតស៊ូនេះ និងជាឧបករណ៍សម្រាប់ការស៊ើបអង្កេតបែបវិទ្យាសាស្ត្រ។

## 1. ចលនារ៉ូមែនទិច

នៅចុងសតវត្សរ៍ទី 18 ទស្សនសកលជពន្លឺអំពីហេតុផលជាបណ្តើរៗ បានបើកផ្លូវសម្រាប់ចលនាដ៏សំខាន់មួយទៀតនៅក្នុងសិល្បៈ និងគំនិតគឺ រ៉ូមែនទិចនិយម។ ចលនានេះបានឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្លាទាំងនៅក្នុងធម្មជាតិ និងនៅក្នុងគំនិត និងឆ្លុះបញ្ចាំងពីអារម្មណ៍របស់មនុស្សម្នាក់ៗ។ នៅក្នុងវិធីជាច្រើន អ្នករ៉ូមែនទិចនិយម និងអ្នកនិពន្ធបានប្រតិកម្មប្រឆាំងនឹងទស្សនសកលជពន្លឺ។ ពួកគេបានប្រែក្លាយពីហេតុផលទៅជាអារម្មណ៍ និងពីសង្គមទៅជាធម្មជាតិ។ អ្នករ៉ូមែនទិចនិយមបានប្រានចោលនូវពិភពឋានានុក្រមយ៉ាងតឹងរឹងនៃវណ្ណៈកណ្តាល។ ជាតិនិយមក៏បានបញ្ឆេះការស្រមើស្រមៃបែបរ៉ូមែនទិចផងដែរ។ ឧទាហរណ៍ លោកចច ហ្គដុន និងលោកលដ ប៊ីយ៉ុន ដែលជាកវីរ៉ូមែនទិចឈានមុខគេនៅសម័យនោះ បានប្រយុទ្ធដើម្បីសេរីភាពរបស់ប្រទេសក្រិក។

ទស្សនបែបរ៉ូមែនទិចនិយម៖ ចិត្តរំភើប ជួនកាលជាចិត្តរំភើបបែបរវើរវាយ គឺជាធាតុសំខាន់នៃរ៉ូមែនទិចនិយម។ ទោះយ៉ាងណាក៏ដោយ រ៉ូមែនទិចនិយមមានលក្ខណៈទៅហួលឆ្ងាយពីអារម្មណ៍។ រ៉ូមែនទិចនិយមបានបង្ហាញពីគំនិត និងអាកប្បកិរិយាយ៉ាងទូលំទូលាយ។ ជាទូទៅ អ្នករ៉ូមែនទិចនិយម និងអ្នកសិល្បៈចែករំលែកជំនឿទាំងនេះ៖ (1) សង្កត់ធ្ងន់លើអារម្មណ៍ខាងក្នុង, ចិត្តរំភើប, និងការស្រមើលស្រមៃ។ (2) ផ្តោតលើអាថ៌កំបាំង, ជំនឿអរូបី, និងរឿងចម្លែក, អាក្រក់ ឬរន្ធត់។ (3) ចូលចិត្តភាពស្រស់ស្អាតនៃធម្មជាតិដែលមិនអាចកាត់ថ្លៃបាន។ (5) បង្កើតគំនិតអំពីអតីតកាលជាពេលវេលាដ៏សាមញ្ញ និងថ្លៃថ្នូរ។ (6) លើកតម្កើងវីរបុរស និងសកម្មភាពវីរជន។ (7) ស្រឡាញ់ប្រពៃណីប្រជាប្រិយ, តន្ត្រី, និងរឿង។ (8) ឲ្យតម្លៃមនុស្សសាមញ្ញ និងបុគ្គល។ (9) លើកកម្ពស់ឱ្យមានការផ្លាស់ប្តូរខ្លាំងក្លា និងលទ្ធិប្រជាធិបតេយ្យ។

រ៉ូមែនទិចនិយមនៅក្នុងអក្សរសិល្ប៍៖ កំណាព្យ, តន្ត្រី, និងគំនូរគឺជាសិល្បៈដែលមានឥទ្ធិពលបំផុតព្រោះពួកវាអាចចាប់យកចិត្តរំភើបនៃរ៉ូមែនទិចនិយម។ សម្រាប់រ៉ូមែនទិច កំណាព្យគឺជាទម្រង់នៃការបង្ហាញអារម្មណ៍ខ្ពស់បំផុត។ កវីរ៉ូមែនទិចនិយមជនជាតិអង់គ្លេសឈ្មោះវីលៀម វើដសួរ និងសាម៉ូអែល ថៃឡឺ កូលីរីដ ទាំងពីររូបបានលើកសរសើរធម្មជាតិថាជាប្រភពនៃសេចក្តីពិត និងភាពស្រស់ស្អាត។ កវីរ៉ូមែនទិចនិយមអង់គ្លេសក្រោយៗមកដូចជាលដ ប៊ីរុន, ផឺស៊ី ប៊ីស៊ី សេលឡី, និងចន គីត បានសរសេរកំណាព្យលើកសរសើរដល់វីរបុរសដឹកនាំការបះ

បោរ, ស្នេហាងប់ងល់, និងអាថ៌កំបាំង និងភាពស្រស់ស្អាតនៃធម្មជាតិ។ ក៏ដូចជាអ្នករ៉ូមែនទិចនិយមជាច្រើនទៀត កវីជនជាតិអង់គ្លេសទាំងនេះបានរស់នៅដោយទទួលរងព្យុះភ្លៀង និងស្លាប់ទាំងវ័យក្មេង។ ឧទាហរណ៍ លោកប៊ីរុនបានស្លាប់នៅអាយុ 36 ឆ្នាំ ខណៈពេលដែលលោកសេលឡីបានស្លាប់នៅអាយុ 29 ឆ្នាំ។ ប្រទេសអាល្លឺម៉ង់បានបង្កើតអ្នកនិពន្ធរ៉ូមែនទិចនិយមដំបូង និងអស្ចារ្យបំផុត។ នៅឆ្នាំ 1774 លោកចូហាន វ៉ូលហ្វកាង វ៉ុន ហ្គោដឺ បានបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថាទុក្ខព្រួយរបស់បុរសវ័យក្មេង។ ប្រលោមលោករបស់ហ្គោដឺបាននិយាយពីបុរសវ័យក្មេងដ៏រហ័សរហួនម្នាក់ អ្នកដែលសេចក្ដីស្រឡាញ់ដោយអស់សង្ឃឹមចំពោះស្ត្រីរៀបការរួចមួយរូបមានគុណធម៌ ដែលបានជំរុញឱ្យគាត់ធ្វើអត្តឃាត។ ក៏ដូចគ្នាផងដែរ នៅប្រទេសអាឡឺម៉ង់បងប្អូនប្រុសចាកូប និងវីលហេម គ្រីម បានប្រមូលរឿងនិទានអាល្លឺម៉ង់ ហើយបានបង្កើតវចនានុក្រម និងវេយ្យាករណ៍នៃភាសាអាល្លឺម៉ង់។ ទាំងរឿងនិទាន និងវចនានុក្រមបានលើកសរសើរដល់វិញ្ញាណអាឡឺម៉ង់។ លោកវិចទ័រ ហ៊ូហ្គូ បាននាំមុខគេខាងរ៉ូមែនទិចនិយមនៅបារាំង។ ស្នាដៃរបស់លោកក៏ឆ្លុះបញ្ចាំងពីរ៉ូមែនទិចដ៏គួរឱ្យចាប់អារម្មណ៍ជាមួយនឹងប្រវត្តិសាស្ត្រ និងបុគ្គលផងដែរ។ ប្រលោមលោករបស់គាត់ដែលមានចំណងជើងថាសេចក្ដីវេទនា និងមនុស្សគមខ្នងនៅណតត្រេ ដាម បង្ហាញពីការតស៊ូរបស់បុគ្គលម្នាក់ៗប្រឆាំងនឹងសង្គមអភិជន។

ប្រលោមលោកបែបអាថ៌កំបាំង៖ រឿងរ៉ាវអាថ៌កំបាំងបែបភ័យរន្ធត់បានក្លាយជារឿងពេញនិយមយ៉ាងខ្លាំង។ ប្រលោមលោកទាំងនេះជារឿយៗបានកើតឡើងនៅក្នុងប្រាសាទអាថ៌កំបាំងនៅមជ្ឈិមសម័យ។ រឿងទាំងនេះពោរពេញទៅដោយការភ័យខ្លាច, ហិង្សា, ជួនកាលព្រឹត្តិការណ៍បែបអរូបី។ ម៉ារី សេលឡី ដែលជាភរិយារបស់កវីផឺស៊ី ប៊ីស៊ី សេលឡី បានសរសេរប្រលោមលោកបែបអាថ៌កំបាំងភ័យរន្ធត់ដំបូងបំផុត និងជោគជ័យបំផុតដែលមានចំណងជើងថាហ្វង់កេនស្ទែន។ ប្រលោមលោកបានប្រាប់ពីដំណើររឿងនៃសត្វចម្លែកដែលបង្កើតឡើងពីផ្នែកមួយចំនួននៃរាងកាយរបស់មនុស្សដែលស្លាប់។

អ្នកតែងនិពន្ធបានសង្កត់ធ្ងន់លើចិត្តរំភើប៖ ចិត្តរំភើបបានគ្របដណ្ដប់លើតន្ត្រីដែលផលិតដោយអ្នកនិពន្ធរ៉ូមែនទិចនិយម។ អ្នកនិពន្ធទាំងនេះបានងាកចេញយ៉ាងឆ្ងាយពីការតែងនិពន្ធផ្លូវការនៃសករាជពន្លឺ។ ផ្ទុយទៅវិញពួកគេបានលើកសរសើរវីរភាព និងមោទនភាពជាតិជាមួយនឹងអំណាចថ្មីនៃការបង្ហាញអារម្មណ៍។ ដោយសារតន្ត្រីបានក្លាយជាផ្នែកមួយនៃជីវិតរបស់ពួកវណ្ណៈកណ្ដាល, តន្ត្រីករ និងអ្នកតែងបានក្លាយជាវីរបុរសដ៏ពេញនិយម។ ឧទាហរណ៍ អ្នកនិពន្ធ និងអ្នកលេងព្យ៉ាណូលោកហ្វង់ លីសទទួលបានប្រាក់ចំណូល និងប្រជាប្រិយភាពដែលអាចប្រៀបធៀបជាមួយនឹងតារារ៉ុកនាពេលបច្ចុប្បន្ននេះ។ អ្នកនិពន្ធម្នាក់ដែលឈានមុខគេក្នុងសម័យរ៉ូមែនទិកគឺលោក លូដវីក វ៉ាន់ បេថូហ្វិន។ ស្នាដៃរបស់គាត់គឺការអភិវឌ្ឍពីតន្ត្រីបុរាណសករាជពន្លឺ ទៅជាការតែងនិពន្ធបែបរ៉ូមែនទិច។ ស្នាដៃរបស់លោកដែលមានចំណងជើងថា ស៊ីមហ្វូនីទី 9 បានលើកតម្កើន, លើកសរសើរសេរីភាព, សេចក្ដីថ្លៃថ្នូរ, និងជ័យជំនះនៃស្មារតីរបស់មនុស្ស។ អ្នកនិពន្ធរ៉ូមែនទិចនិយមក្រោយៗមកទៀត ក៏បានទាក់ទាញចិត្តអ្នកស្ដាប់ផងដែរ។ ការតែងនិពន្ធរបស់រ៉ូបឺត ស្ហូមែន បានបញ្ចេះឱ្យមានសេចក្ដីសប្បាយក្អាកក្អាយ ។ ក៏ដូចជាអ្នកនិពន្ធរ៉ូមែនទិចនិយមជាច្រើនទៀត លោកហ្វេឡិច មេនដេលសុន បានផ្ដោតសំខាន់លើអក្សរសិល្ប៍នានា ដែលក្នុងនោះមានដូចជាស្នាដៃអក្សរសិល្ប៍របស់សាកេស្ពៀ សុបិន្តនារាត្រីនារដូវក្ដៅមួយ ដើម្បីបំផុសគំនិតសម្រាប់តន្ត្រី

របស់លោក។ អ្នកនិពន្ធជនជាតិប៉ូឡូញ និងជាអ្នកលេងព្យ៉ាណូប្រគុំតន្ត្រីឈ្មោះហ្វ្រេឌីរិច ឆូពីន បានប្រើចង្វាក់រាំប៉ូឡូញនៅក្នុងតន្ត្រីរបស់គាត់។ លោកហ្គីសប៉េ វើឌី និងលោករីឆាដ វ៉េងន័រ បាននាំល្ខោនអូប៉េរ៉ាអឺរ៉ុបទៅកាន់ចំណុចខ្ពស់បំផុតមួយ។

## 2. ការផ្លាស់ប្តូរទៅរកភាពប្រាកដនិយមក្នុងសិល្បៈ

នៅពាក់កណ្តាលសតវត្សរ៍ទី 19 ឧស្សាហូបនីយកម្មយ៉ាងឆាប់រហ័សបានប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃនៅអឺរ៉ុបយ៉ាងខ្លាំង។ វណ្ណៈកម្មករឧស្សាហ៍កម្មដែលកំពុងកើនឡើង រស់នៅយ៉ាងក្រៀមក្រំនៅក្នុងទីក្រុងដែលមានភាពកខ្វក់ និងមានមនុស្សច្រើន។ ឧស្សាហូបនីយកម្មបានចាប់ផ្តើមធ្វើឱ្យសុបិននៃរ៉ូមែនទិចនិយមហាក់ដូចជាគ្មានន័យ។ នៅក្នុងអក្សរសិល្ប៍ និងសិល្បៈទស្សនីយ ភាពប្រាកដនិយមបានព្យាយាមបង្ហាញពីជីវិតដែលធ្លាប់កើតមាន មិនមែនបង្ហាញពីអ្វីដែលវាគួរតែកើតមាននោះទេ។ គំនូរបែបប្រាកដនិយមបានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃនយោបាយរបស់វណ្ណៈកម្មករក្នុងទសវត្សរ៍ឆ្នាំ 1850 ។ អមជាមួយនឹងគំនូរ ប្រលោមលោកបានបង្ហាញឲ្យឃើញពីភាពសមស្របមួយសម្រាប់ពិពណ៌នាអំពីទុក្ខលំបាករបស់កម្មករ។

អ្នកថតរូបចាប់យកការពិត៖ ក៏ដូចជាវិចិត្រករ និងអ្នកនិពន្ធប្រាកដនិយមដែលបានរៀបរាប់អំពីជីវិតរបស់មនុស្សជាក់ស្តែង អ្នកថតរូបអាចថតបានភ្លាមៗជាមួយនឹងភាពជាក់ស្តែងដែលមានលក្ខណៈបែបវិទ្យាសាស្ត្រ។ រូបថតជាក់ស្តែងដំបូងត្រូវបានគេហៅថា ដាគ័រអេរ៉ូថៃប ។ រូបថតទាំងនេះត្រូវបានគេដាក់ឈ្មោះតាមអ្នកបង្កើតជនជាតិបារាំងលោកល្វីស ដាគ័រអេរ៉ូ។ រូបភាពបែបដាគ័រអេរ៉ូថៃបរបស់លោកពិតជាគួរឱ្យភ្ញាក់ផ្អើល និងមានភាពល្បីល្បាញទូទាំងពិភពលោក។ អ្នកបង្កើតជនជាតិអង់គ្លេសវីលៀម តាលបូត បានបង្កើតក្រដាសដែលងាយផ្តិតរូបភាពមួយ ដែលគាត់ប្រើដើម្បីបង្កើតរូបថតដែលផ្តិតចេញមកពីហ្វីល។ អត្ថប្រយោជន៍នៃក្រដាសនេះគឺថាគេអាចផ្តិចរូបថតដដែលជាច្រើនលើកចេញមកពីហ្វីលតែមួយ។ ដំណើរការ នេះក៏អនុញ្ញាតឱ្យរូបថតត្រូវបានយកទៅបោះពុម្ពនៅក្នុងសៀវភៅ និងកាសែតផងដែរ។ ការចែកចាយក្នុងទ្រង់ទ្រាយធំ បានទាក់ទាញចំណាប់អារម្មណ៍របស់ទស្សនិកជនយ៉ាងច្រើនអំពីភាពប្រាកដនិយមនៃការថតរូប។ ជាមួយនឹងលក្ខណៈវិទ្យាសាស្ត្រ, មេកានិច, និងការផលិតក្នុងទ្រង់ទ្រាយធំរបស់វា ការថតរូបគឺជាសិល្បៈនៃយុគសម័យឧស្សាហកម្មថ្មី។

អ្នកនិពន្ធសិក្សាពីសង្គម៖ ភាពប្រាកដនិយមក្នុងអក្សរសិល្ប៍បានរីកដុះដាលនៅប្រទេសបារាំងជាមួយនឹងអ្នកនិពន្ធមួយចំនួនដូចជាលោកហូណូរ៉េ ដឺ បាលហ្សេច និងលោកអេមីឡេ ហ្សូឡា។ បាលហ្សេចបានសរសេររឿងប្រលោមលោកដ៏ធំមួយមួយមានចំនួនជិតជិត 100 ភាពដែលមានចំណងជើងថា រឿងកំប្លែងរបស់មនុស្ស។ រឿងទាំងនោះបានពិពណ៌នាយ៉ាងលម្អិតអំពីការតស៊ូដ៏ឃោរឃៅដើម្បីទ្រព្យសម្បត្តិ និងអំណាចក្នុងចំណោមមនុស្សគ្រប់វណ្ណៈទាំងអស់នៅក្នុងសង្គមបារាំង។ ប្រលោមលោករបស់លោកហ្សូឡាបានលាតត្រដាងពីទុក្ខវេទនារបស់កម្មករជនជាតិបារាំងនៅក្នុងហាងតូចៗ, រោងចក្រ, និងអណ្តូងរ៉ែធ្យូងថ្ម។ ការបង្ហាញរបស់លោកបានធ្វើឱ្យអ្នកអានភ្ញាក់ផ្អើល និងជំរុញឲ្យមានការធ្វើកំណែទម្រង់ច្បាប់ការងារ និងលក្ខខណ្ឌការងារនៅក្នុងប្រទេសបារាំង។ អ្នកនិពន្ធរឿងប្រលោមលោកពិតប្រាកដនិយមជនជាតិអង់គ្លេសដ៏ល្បីល្បាញ ឈ្មោះឆាល ឌិចខេន បានបង្កើតតួអង្គ

និងឈុតឆាកដែលមិនអាចបំភ្លេចបាននៃកម្មករក្រីក្រនៅទីក្រុងឡុងដ៍។ ឈុតឆាកជាច្រើនមានលក្ខណៈកំប្លែង ប៉ុន្តែខ្លះទៀតបង្ហាញពីភាពអស់សង្ឃឹមនៃអ្នកក្រីក្រក្នុងទីក្រុងឡុងដ៍។ នៅក្នុងសៀវភៅដែលមានចំណងជើងថា ដូរីតតូច របស់លោកឌិចខេនបានពិពណ៌នាអំពីជីវិតរបស់មនុស្សក្នុងវណ្ណៈកម្មករថា ជាភាពឯកោដ៏កម្រដែលបានកំណត់នៅក្នុងសង្កាត់ដ៏អាប់អួរមួយ។

### 3. អ្នកអារម្មណ៍និយមប្រតិកម្មប្រឆាំងនឹងពិតប្រាកដនិយម

ចាប់ផ្តើមដំបូងនៅទសវត្សរ៍ឆ្នាំ 1860 វិចិត្រករមួយក្រុមនៅទីក្រុងប៉ារីសមានប្រតិកម្មប្រឆាំងនឹងរចនាបទពិតប្រាកដនិយម។ ជាជាងបង្ហាញពីជីវិត "ដូចជាការពិត" ពួកគេបានព្យាយាមបង្ហាញពីចំណាប់អារម្មណ៍របស់ពួកគេចំពោះប្រធានបទ ឬព្រឹត្តិការណ៍នៅក្នុងណាមួយ។ ដោយហេតុនេះហើយទើបរចនាបថសិល្បៈរបស់ពួកគេត្រូវបានគេហៅថាអារម្មណ៍និយម។ ធ្វើឱ្យចាប់អារម្មណ៍តាមរយៈពន្លឺ វិចិត្រករអារម្មណ៍និយមបានប្រើពណ៌ភ្លឺចែងចាំង ដើម្បីឱ្យរូបភាពរបស់ពួកគេទទួលបានភាពទាក់ទាញ។

ជីវិតក្នុងទេសកាលៈ មិនដូចអ្នកប្រាកដនិយមឡើយ អ្នកអារម្មណ៍និយមបានបង្ហាញពីទស្សនៈវិជ្ជមានបន្ថែមទៀតអំពីសង្គមទីក្រុងថ្មីនៅអឺរ៉ុបខាងលិច។ ជំនួសឱ្យកម្មករដែលត្រូវគេរំលោភបំពាន ពួកគេបានបង្ហាញស្មៀនហាង និងកម្មករកំពង់ផែកំពុងរីករាយនៅក្នុងសាលរាំ និងហាងកាហ្វេ។ ពួកគេបានគូរអ្នកសំដែងនៅក្នុងរោងកុន និងសៀក។ ហើយពួកគេបានលើកតម្កើងភាពរីករាយនៅក្នុងជីវិតរស់នៅរបស់ពួកវណ្ណៈកណ្តាលដែលកំពុងកើនឡើង។ លោកខ្លូដ ម៉ូណេត, លោកអេដហ្គា ដឺហ្គាស, និងលោកព្យែរ-អូហ្គឹស រ៉េនអឺ ជាអ្នកដឹកនាំនៅក្នុងចលនានេះ ដែលទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំង។ អ្នកនិពន្ធក៏បង្កើតចំណាប់អារម្មណ៍លើអារម្មណ៍ និងបរិយាកាសផងដែរ។ ដោយប្រើឧបករណ៍ចម្រុះ, ទម្រង់សម្លេង, និងរចនាសម្ព័ន្ធតន្ត្រីផ្សេងៗគ្នា ពួកគេអាចបង្កើតរូបភាពផ្លូវចិត្តនានាដូចជាពន្លឺភ្លើង, អារម្មណ៍នៃកក់ក្តៅមួយនារដូវក្តៅ, ឬការមើលឃើញសមុទ្រ។ អ្នកនិពន្ធជនជាតិបារាំងលោកម៉ូរីស រ៉ាវែល និងក្លូដ ដេប៊ូសស៊ី គឺជាសមាជិកដ៏គួរឱ្យកត់សម្គាល់បំផុតនៃចលនាតន្ត្រីអារម្មណ៍និយម។ ការផ្លាស់ប្តូរនៅក្នុងចលនានយោបាយ, សង្គម, សិល្បៈ, និងបញ្ញានៅអំឡុងសតវត្សរ៍ទី 19 ជាសញ្ញាបង្ហាញពីការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងជីវិតប្រចាំថ្ងៃ។ មូលហេតុដ៏សំខាន់បំផុតមួយនៃការផ្លាស់ប្តូរនេះគឺឧស្សាហូបនីយកម្ម ដែលអ្នកនឹងរៀនអំពីជំពូកទី 24 ។

# ជំពូក 24 ៖ បដិវត្តឧស្សាហកម្ម 1700-1900

## មេរៀនទី 1 ៖ ការចាប់ផ្តើមឡើងនៃបដិវត្តឧស្សាហកម្ម

នៅក្នុងសហរដ្ឋអាមេរិក, បារាំង, និងអាមេរិកឡាទីន, បដិវត្តនយោបាយបាននាំមកនូវការបង្កើតទម្រង់រដ្ឋាភិបាលថ្មីៗ។ បដិវត្តផ្សេងៗគ្នាមួយចំនួនទៀត បាននាំទៅដល់ការផ្លាស់ប្តូររបៀបដែលមនុស្សធ្វើការ។ បដិវត្តឧស្សាហកម្ម សំដៅទៅលើការកើនឡើងយ៉ាងច្រើននៃផលិតផលដែលផលិតឡើងដោយគ្រឿងម៉ាស៊ីន ដែលចាប់ផ្តើមឡើងដំបូងនៅក្នុងប្រទេសអង់គ្លេសនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1700 ។ មុនបដិវត្តឧស្សាហកម្ម មនុស្សត្បាញក្រណាត់ដោយដៃ។ បន្ទាប់មក ម៉ាស៊ីនបានចាប់ផ្តើមធ្វើការងារនេះ និងការងារដ៏ទៃទៀត។ ភ្លាមៗនោះបដិវត្តឧស្សាហកម្មបានរីកសាយភាយពីអង់គ្លេសទៅកាន់ទ្វីបអឺរ៉ុប និងអាមេរិកខាងជើង។

### 1. បដិវត្តឧស្សាហកម្មចាប់ផ្តើមដំបូងនៅចក្រភពអង់គ្លេស

នៅក្នុងឆ្នាំ 1700 ដីស្រែចំការតូចៗបានគ្របដណ្តប់នៅពាលពេញចក្រភពអង់គ្លេស។ ប៉ុន្តែក្រោយមកម្ចាស់កម្មសិទ្ធិដីធ្លីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភនានា បានចាប់ផ្តើមប្រមូលទិញដីស្រែចំការទាំងឡាយដែលប្រជាកសិករធ្លាប់ធ្វើកសិកម្ម។ ពួកម្ចាស់កម្មសិទ្ធិដីធ្លីធំៗបានអភិវឌ្ឍគួរឲ្យចាប់អារម្មណ៍នូវវិធីដាំដុះថ្មីៗរបស់ពួកគេ។ ការបង្កើតថ្មីនេះគឺស្ថិតនៅក្នុងចំណោមការធ្វើបដិវត្តកសិកម្ម។

បដិវត្តកសិកម្មបានត្រួសត្រាយផ្លូវ៖ បន្ទាប់ពីទិញយកដីរបស់ពួកប្រជាកសិករ ពួកម្ចាស់កម្មសិទ្ធិដីធ្លីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ បានហ៊ុំព័ទ្ធដីរបស់ពួកគេជាមួយនឹងរបង ឬបង្គោលឈើ។ ការបង្កើននូវទំហំដីរបស់ពួកគេបានអនុញ្ញាតឱ្យពួកគេអាចដាំដុះលើផ្ទៃដីដ៏ធំមួយ។ នៅក្នុងផ្ទៃដីដាំដុះដ៏ធំនេះ ដែលគេហៅថា ការហ៊ុំព័ទ្ធដីធ្លី, ម្ចាស់កម្មសិទ្ធិដីធ្លីបានសាកល្បងដាំដុះគ្រប់ពូជដែលទទួលបានទិន្នផលច្រើន និងវិធីសាស្ត្រប្រមូលផលផ្សេងៗដើម្បីបង្កើនទិន្នផលគ្រាប់ធុញ្ញជាតិរបស់ពួកគេ។ ចលនានៃការហ៊ុំព័ទ្ធដីធ្លីនេះបានផ្តល់នូវលទ្ធផលពីរសំខាន់ៗ។ ទីមួយ ម្ចាស់កម្មសិទ្ធិដីធ្លីបានសាកល្បងវិធីសាស្ត្រធ្វើកសិកម្មថ្មី។ ទីពីរ ម្ចាស់កម្មសិទ្ធិដីធ្លីធំៗបានជម្រុញឱ្យប្រជាកសិករតូចតាចក្លាយជាអ្នកជួលដីដើម្បីធ្វើស្រែ ឬបោះបង់ការធ្វើស្រែរបស់ពួកគេ ហើយធ្វើដំណើរទៅកាន់ទីក្រុង។

លោក ជេស្រូ ទូស គឺជាប្រជាកសិករបែបវិទ្យាសាស្ត្រម្នាក់នៅក្នុងចំណោមនោះ។ លោកបានមើលឃើញថាវិធីនៅក្នុងការបណ្តុះគ្រាប់ពូជដោយការបាចវាទៅលើដីគឺជាការខ្ជះខ្ជាយ។ គ្រាប់ពូជជាច្រើនមិនបានដុះឡើយ។ លោកបានដោះស្រាយបញ្ហានេះជាមួយនឹងការបង្កើតគំនិតថ្មីមួយដែលហៅថា ការសាបព្រោះគ្រាប់ពូជ នៅក្នុងឆ្នាំប្រហែល 1701។ វាអនុញ្ញាតឱ្យប្រជាកសិករអាចបណ្តុះពូជរបស់ពួកគេត្រង់ជួរ និងមានគម្លាតពីគ្នាបានល្អ និងមានជម្រៅជាក់លាក់។ គ្រាប់ពូជជាច្រើនបានដុះឡើង ដែលនាំឱ្យកើនឡើងនូវទិន្នផលគ្រាប់ធុញ្ញជាតិ។

ការផ្លាស់ប្តូរមុខដាំណាំ៖ ដំណើរការនៃការផ្លាស់ប្តូរការដាំដុះមុខដំណាំត្រូវបានគេចាត់ទុកថាជាការអភិវឌ្ឍដ៏ប្រសើរមួយដោយប្រជាកសិករដែលមានលក្ខណៈបែបវិទ្យាសាស្ត្រ។ ដំណើរការនេះបានអភិវឌ្ឍពីលើវិធីសាស្ត្រនៃការផ្លាស់ប្តូរការដាំដុះដំណាំបែបចាស់ៗ ដែលក្នុងនោះមានដូចជាប្រព័ន្ធដាំណាំ 3 ប្រភេទនៅសម័យកណ្តាល។

ឧទាហរណ៍ ឆ្នាំទីមួយ ប្រជាកសិករម្នាក់ដាំស្រូវសាលីនៅលើដីរបស់ពួកគេ ដែលបានស្រូបយកសារជាតុចិញ្ចឹមអស់ជាច្រើនពីក្នុងដី។ ឆ្នាំបន្ទាប់មកទៀតប្រជាកសិករនោះដាំដុះដំណាំមើមម្តង ដែលមានដូចជាស្ពៃមើមជាដើម ដើម្បីបង្កើតសារជាតុចិញ្ចឹមឡើងវិញ។ ហើយនៅឆ្នាំបន្ទាប់ទៀតពួកគេត្រឡប់ទៅដាំដុះស្រូវបាឡេ និងបន្ទាប់មកដំណាំមើម។

អ្នកបង្កាត់ពូជសត្វចិញ្ចឹមក៏បានអភិវឌ្ឍវិធីសាស្រ្តរបស់ពួកគេផងដែរ។ ឧទាហរណ៍ នៅក្នុងទសវត្សរ៍ឆ្នាំ 1700 លោក រ៉ូប៊ឺត ប៊ែកវ៉ែល បានបង្កើនផលិតផលសាច់ចៀមរបស់លោក តាមរយៈការអនុញ្ញាតឱ្យតែសត្វចៀមល្អៗប៉ុណ្ណោះអាចបង្កាត់ពូជបាន។ ប្រជាកសិករដទៃទៀតបានអនុវត្តតាមវិធីសាស្ត្ររបស់លោក ប៊ែកវ៉ែល ។ រវាងឆ្នាំ 1700 ដល់ឆ្នាំ 1786 ទំហំមធ្យមនៃសត្វចៀមមួយក្បាលបានកើនឡើងពី 18 ទៅដល់ 50 ផោន។ ដូចដែលការផ្គត់ផ្គង់ចំណីអាហារបានកើនឡើង និងស្ថានភាពរស់នៅបានល្អប្រសើរ ប្រជាជនអង់គ្លេសបានរីកឡើង។ ការកើនឡើងនៃចំនួនប្រជាជនបានពង្រីកនូវតម្រូវការចំណីអាហារ និងទំនិញ ដូចជាសំលៀកបំពាក់ជាដើម។ ដូចដែលប្រជាកសិករបានបាត់បង់នូវដីស្រែរបស់ពួកគេទៅឱ្យពួកម្ចាស់កម្មសិទ្ធិដីធ្លីធំៗ ពួកគេជាច្រើនបានក្លាយជាកម្មកររោងចក្រ។

ហេតុអ្វីបានជាបដិវត្តឧស្សាហកម្មចាប់ផ្តើមឡើងនៅអង់គ្លេស៖ បន្ថែមពីលើចំនួនប្រជាជនដ៏ច្រើនដែលធ្វើជាកម្មករ ប្រទេសជីកោះមួយនេះមានធនធានធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់។ ឧស្សាហូបនីយកម្ម ដែលជាដំណើរការមួយនៃការអភិវឌ្ឍម៉ាស៊ីនដើម្បីផលិតទំនិញ, តម្រូវឲ្យមានធនធានមួយចំនួន។ ធនធានធម្មជាតិទាំងនោះរួមមាន៖

1. កម្លាំងទឹក និងធ្យូងថ្មដើម្បីដុតនៅក្នុងម៉ាស៊ីនថ្មី។
2. រ៉ែដែកដើម្បីស្ថាបនាម៉ាស៊ីន, ឧបករណ៍ប្រើប្រាស់, និងសំណង់អាគារនានា។
3. ទន្លេសម្រាប់ការដឹកជញ្ជូនក្នុងស្រុក។
4. កំពង់ផែសមុទ្រដែលជាទីកន្លែងសម្រាប់នាវាប្រើម៉ាស៊ីនចេញដំណើរ។

ក្នុងការបន្ថែមទៅនឹងធនធានធម្មជាតិរបស់ពួកគេ, ចក្រភពអង់គ្លេសមានសេដ្ឋកិច្ចដ៏ធំមួយដើម្បីគាំទ្រដល់ឧស្សាហូបនីយកម្ម។ អ្នកជំនួញបានវិនិយោគនៅក្នុងរោងចក្រដែលបង្កើតថ្មី។ ប្រព័ន្ធធនាគារដែលមានការអភិវឌ្ឍកម្រិតខ្ពស់របស់ចក្រភពអង់គ្លេសនៅពេលនោះ ក៏បានចូលរួមចំណែកនៅក្នុងការបង្កើតឱ្យមានឧស្សាហូបនីយកម្មនៅក្នុងប្រទេសផងដែរ។ ប្រជាជនត្រូវបានលើកទឹកចិត្ត តាមរយៈការផ្តល់ប្រាក់កម្ចីដើម្បីវិនិយោគទៅលើម៉ាស៊ីនដែលទើបបង្កើតថ្មី និងពង្រីកប្រតិបត្តិការរបស់ពួកគេ។ ការកើនឡើងនូវពាណិជ្ជកម្មក្រៅប្រទេស, ភាពរុងរឿងនៃសេដ្ឋកិច្ច, និងបរិយាកាសនៃការរីកចម្រើនមួយ បាននាំទៅដល់ការកើនឡើងនូវតម្រូវការចំពោះមុខទំនិញ។

ស្ថេរភាពនយោបាយរបស់អង់គ្លេស បានផ្តល់ឱ្យប្រទេសនេះនូវអត្ថប្រយោជន៍ដ៏ធំមួយប្រសើរជាងប្រទេសជិតខាងរបស់គេ។ តាមរយៈការដែលចក្រភពអង់គ្លេសចូលរួមនៅក្នុងការធ្វើសង្គ្រាមជាច្រើនសារនៅអំឡុងទសវត្សរ៍ឆ្នាំ 1700 គ្មានសង្គ្រាមមួយណាកើតឡើងនៅលើដីចក្រភពអង់គ្លេសឡើយ។ ភាពជោគជ័យនៃវិស័យយោធាបាន

ផ្តល់ឱ្យពួកអង់គ្លេសនូវតំរិបថវិជ្ជមានមួយ។ សភាតំណាងរាស្ត្រក៏បានអនុម័តច្បាប់នានាដើម្បីជួយជម្រុញ និងការពារសកម្មភាពជំនួញ។ ប្រទេសផ្សេងៗមួយចំនួនទៀតក៏មានអត្ថប្រយោជន៍ទាំងអស់នេះដែរ។ ប៉ុន្តែចក្រភពអង់គ្លេសមាននូវរាល់គ្រប់កត្តាសម្រាប់ផលិកម្ម ដែលក្នុងនោះមានកត្តាធនធានដែលគេត្រូវការដើម្បីផលិតនូវទំនិញ និងកត្តាសេវាកម្មដែលបដិវត្តឧស្សាហកម្មតម្រូវឱ្យមាន។ កត្តាទាំងអស់នោះរួមមាន ដី, ពលកម្ម, និងដើមទុន(ឬទ្រព្យសម្បត្តិ)។

## 2. ការបង្កើតថ្មីនាំទៅដល់ឧស្សាហូបនីយកម្ម

ការផ្ទុះឡើងនូវគំនិតច្នៃប្រឌិត និងការបង្កើតថ្មីបាននាំឲ្យមានបដិវត្តឧស្សាហកម្ម។ ឧស្សាហកម្មតម្បាញក្រណាត់រោមចៀម, ក្រណាត់ទ្បែន, និងក្រណាត់កប្បាសរបស់ចក្រភពអង់គ្លេសបានគ្របដណ្តប់នៅលើពិភពលោក។ ឧស្សាហកម្មនេះគឺជាការផ្លាស់ប្តូរជាលើកដំបូង។ ពាណិជ្ជករលក់សំលៀកបំពាក់បានបង្កើនចំណូលរបស់ពួកគេដោយការបង្កើនសង្វាក់ផលិតកម្មរបស់អ្នករវៃ និងអ្នកតម្បាញដើម្បីផលិតសំលៀកបំពាក់។

ការផ្លាស់ប្តូរនៅក្នុងឧស្សាហកម្មវាយនភ័ណ្ឌ៖ អ្នកនឹងត្រូវសិក្សានៅចំណុចបន្ទាប់ស្តីអំពីបច្ចេកវិទ្យាតម្បាញមេរៀនខាងមុខ ត្រឹមឆ្នាំ 1800 ការបង្កើតថ្មីៗជាច្រើនបាននាំឱ្យមានការធ្វើទំនើបកម្មនៅក្នុងឧស្សាហកម្មកប្បាស។ ការបង្កើតថ្មីមួយនាំទៅដល់ការបង្កើតថ្មីមួយផ្សេងទៀត។ នៅក្នុងឆ្នាំ 1733 យន្តការីមួយរូបឈ្មោះ ចន ខេ បានបង្កើតឧបករណ៍ត្រល់មួយដែលអាចរត់ទៅរត់មកបានដោយប្រើកង់របស់វា។ ឧបករណ៍ត្រល់នេះ ធ្វើឡើងពីបន្ទះឈើមានរូបរាងដូចជាទូក ដែលគេភ្ជាប់សរសៃអំបោះជាមួយវា អ្នកតម្បាញអាចបង្កើនសង្វាក់ផលិតកម្មរបស់ពួកគេបានគុណនឹងពីរ។ ដោយសារតែអ្នករវៃមិនអាចរវៃទាន់ក្រុមអ្នកត្បាញដ៏លឿននេះ មានការផ្តល់រង្វាន់ជាសាច់ប្រាក់ដើម្បីទាក់ទាញការប្រគួតប្រជែងក្នុងការផលិតម៉ាស៊ីនរវៃដែលល្អប្រសើរមួយ។ នៅរង្វង់ឆ្នាំ 1764 កម្មករតម្បាញមួយរូបឈ្មោះថា ជេម ហាគ្រេវ បានបង្កើតកង់បង្វិលមួយ ដោយលោកបានដាក់ឈ្មោះវាតាមឈ្មោះកូនស្រីរបស់លោក។ កង់បង្វិលជេននីរបស់លោកបានអនុញ្ញាតឱ្យអ្នករវៃអាចរវៃសសៃអំបោះចំនួន 8 ក្នុងពេលតែមួយ។

ដំបូងឡើយ កម្មការតម្បាញប្រើប្រាស់ត្រល់ និងកង់បង្វិលជេននីដោយប្រើប្រាស់ដៃ។ បន្ទាប់មកលោក រីឆាត អាកវ៉េ បានបង្កើតម៉ាស៊ីនបង្វិលដោយប្រើទឹកនៅក្នុងឆ្នាំ 1769។ ម៉ាស៊ីនេះប្រើប្រាស់ចំហាយទឹកដើម្បីរុញកង់បង្វិល។ នៅក្នុងឆ្នាំ 1779 លោក សាម៉ូអ៊ែល ក្រូមតុន បានផ្គុំបញ្ចូលគ្នានូវកង់បង្វិលជេននីជាមួយនឹងម៉ាស៊ីនបង្វិលដោយប្រើទឹក ដើម្បីបង្កើតបានជារទេះរវៃមួយ។ រទេះរវៃបានធ្វើឱ្យសរសៃអំបោះការតែរឹងមាំ, ស្អាត, និងត្រឹមត្រូវជាងម៉ាស៊ីនបង្វិលដំបូង។ ដើរដោយចំហាយទឹក កីតម្បាញរបស់លោក អេដមុន ខារ៉ៃ បានបង្កើនល្បឿនក្នុងការត្បាញបន្ទាប់ពីការបង្កើតវាឡើងនៅក្នុងឆ្នាំ 1787។

ម៉ាស៊ីនបង្វិលដោយប្រើចំហាយទឹក, រទេះរវៃ, និងកីតម្បាញជាម៉ាស៊ីនដែលមានទំហំធំ និងមានតម្លៃថ្លៃ។ ម៉ាស៊ីនទាំងនេះបាននាំយកការងាររវៃ និងត្បាញចេញមកខាងក្រៅផ្ទះ។ ពាណិជ្ជករវាយនភ័ណ្ឌមានទ្រព្យសម្បត្តិច្រើនបានរៀបចំម៉ាស៊ីនទាំងនេះនៅក្នុងអាគារធំៗ ដែលគេហៅថា រោងចក្រ។ រោងចក្រត្រូវការកម្លាំងចំហាយទឹក, ដូច្នេះរោងចក្រដំបូងត្រូវបានគេស្ថាបនាឡើងនៅជិតទន្លេ និងស្ទឹង។

### 3. ការរីកចម្រើននៃគមនាគមន៍

ភាពជឿនលឿននៅក្នុងឧស្សាហកម្មវាយនភ័ណ្ឌ បានជម្រុញឱ្យឧស្សាហកម្មផ្សេងៗទៀតមានការរីកចម្រើន។ ការអភិវឌ្ឍដំបូងៗមួយចំនួនដូចជា ម៉ាស៊ីនប្រើចំហាយទឹក, លេចចេញមកពីការស្វែងរកនូវធនធានដែលមានចំនួនច្រើន និងមានតម្លៃថោក។ នៅដើមឆ្នាំ 1705 អ្នកជីកជម្រុងថ្មបានប្រើប្រាស់ម៉ាស៊ីនប៉ូមដែលប្រើកម្លាំងចំហាយទឹកដើម្បីយកទឹកចេញពីអណ្តូងរ៉ែជ្រៅៗ។ ប៉ុន្តែប្រភេទនៃម៉ាស៊ីប្រើចំហាយទឹកដំបូងនេះត្រូវការឥន្ធនៈក្នុងបរិមាណដ៏ច្រើន ដែលធ្វើមានការចំណាយច្រើនក្នុងការប្រើប្រាស់វា។

សំឡីកប្បាសរបស់អង់គ្លេស ត្រូវបានគេយកមកពីតំបន់ដាំដុះដំណាំកប្បាសនៅអាមេរិកខាងត្បូង នៅអំឡុងទសវត្សរ៍ឆ្នាំ 1790 ។ ការយកចេញនូវគ្រាប់ពីកប្បាសគឺជាការងារដ៏លំបាកមួយ។ នៅក្នុងឆ្នាំ 1793 អ្នកបង្កើតថ្មីជនជាតិអាមេរិកមួយរូបឈ្មោះ អេលី វីតនី បានបង្កើតម៉ាស៊ីនមួយដើម្បីបង្កើនល្បឿនការងារនេះ។ ម៉ាស៊ីនយកគ្រាប់កប្បាសចេញរបស់លោកបានបង្កើនល្បឿនយកគ្រាប់កប្បាសចេញបានទ្វេដង។ ផលិផលសំឡីកប្បាសរបស់អាមេរិកបានកើនឡើងពី 1.5 លានផោននៅក្នុងឆ្នាំ 1970 រហូតដល់ 85 លានផោននៅក្នុងឆ្នាំ 1810 ។

ម៉ាស៊ីនចំហាយទឹករបស់លោក វ៉ាត៖ អ្នកផលិតឧបករណ៍គណិតវិទ្យាមួយរូបនៅសាកលវិទ្យាល័យក្លាសកូវ ប្រទេសស្កុតលែន បានគិតអំពីបញ្ហានេះអស់រយៈពេលពីរឆ្នាំ។ នៅក្នុងឆ្នាំ 1765 លោក វ៉ាត បានស្វែងរកឃើញនូវវិធីមួយដើម្បីបង្កើតម៉ាស៊ីនចំហាយទឹកដើរលឿន និងមានប្រសិទ្ធភាពខ្ពស់ ខណៈពេលដែលប្រើប្រាស់ឥន្ធនៈតិចតួចប៉ុណ្ណោះ។ នៅក្នុងឆ្នាំ 1774 លោក វ៉ាត បានចូលរួមជាមួយនឹងអ្នកជំនួញមួយរូបឈ្មោះថា ម៉ាស៊ូ បូតុន ។ លោក បូតុន គឺជាសហគ្រិនមួយរូប ដែលជាអ្នករៀបចំ, គ្រប់គ្រង, និងពិនិត្យមើលលើហានិភ័យនៃជំនួញមួយ។ លោកបានផ្តល់ប្រាក់ខែដល់លោក វ៉ាត និងបានលើកទឹកចិត្តឱ្យគាត់ស្ថាបនាម៉ាស៊ីនចំហាយទឹកដ៏ប្រសើរមួយ។

ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹក៖ ចំហាយទឹកក៏អាចរុញច្រានទូកឱ្យទៅមុខបានផងដែរ។ អ្នកបង្កើតថ្មីជនជាតិអាមេរិកម្នាក់ឈ្មោះ រ៉ូបឺត ហ្វ៊ុតុន បានកម្មង់ម៉ាស៊ីនចំហាយទឹករបស់លោក បូតុន និងលោក វ៉ាត ។ លោកបានស្ថាបនានាវាប្រើចំហាយទឹកមួយដែលគេហៅថា ក្លឺមុន ដែលវាបានធ្វើដំណើរដោយជោគជ័យជាលើកដំបូងនៅក្នុងឆ្នាំ 1807 ។ នាវា ក្លឺមុន ក្រោយមកបានដឹកជញ្ជូនអ្នកធ្វើដំណើរទៅមកនៅតាមដងទន្លេ ហុតសុន នៅញូវយ៉ក។

នៅក្នុងប្រទេសអង់គ្លេស ការដឹកជញ្ជូនតាមផ្លូវទឹកត្រូវបានអភិវឌ្ឍឡើងជាមួយនឹងការបង្កើតប្រព័ន្ធព្រែកជីកមួយ ឬគេហៅថា ប្រព័ន្ធផ្លូវទឹកដែលបង្កើតឡើងដោយមនុស្ស។ ត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 តាមរយៈព្រែកជីកប្រវែងប្រមាណ 4,250 ម៉ាយ វាបានជួយកាត់បន្ថយការចំណាយលើការដឹកជញ្ជូនទាំងវត្ថុធាតុដើម និងផលិតផលសម្រេច។

ប្រព័ន្ធដឹកជញ្ជូនផ្លូវគោក៖ ផ្លូវថ្នល់នៅចក្រភពអង់គ្លេសត្រូវបានអភិវឌ្ឍដូចជាផ្លូវទឹកដែរ អរគុណដល់ការប្រឹងប្រែងរបស់លោក ចន ម៉ាកអាដាំ ដែលជាវិស្វ័ករជនជាតិស្កុតលែន។ ចាប់ផ្តើមធ្វើការងារនៅដើមទសវត្សរ៍ឆ្នាំ 1800 លោក បានចាក់លើខ្នងផ្លូវនូវដុំថ្មធំទ្រាបពីលើដីសម្រាប់សម្ងួតទឹក។ នៅពីលើថ្មធំៗនេះ លោកបានចាក់

ទ្រនាប់ថ្មតូចៗឱ្យស្មើ។ បើទោះបីជាស្ថិតនៅក្នុងរដូវភ្លៀងក៏ដោយរទេះកង់បួនអាចធ្វើដំណើរពីលើផ្លូវចាក់ថ្មថ្មីនេះដោយមិនជាប់ផុងឡើយ។

អ្នកវិនិយោគឯកជននានាបានបង្កើតក្រុមហ៊ុនដើម្បីស្ថាបនាផ្លូវថ្នល់ ហើយបន្ទាប់មកបានដំណើរការវាដើម្បីស្វែងរកប្រាក់ចំណេញ។ ប្រជាជនបានហៅផ្លូវថ្មីនេះថា ផ្លូវយកលុយ ដោយសារតែអ្នកធ្វើដំណើរទាំងឡាយត្រូវតែឈប់នៅបញ្ចបង់ប្រាក់ដើម្បីបង់ប្រាក់ថ្លៃឆ្លងកាត់ នៅពេលដែលយើងចង់ធ្វើដំណើរទៅមុខទៀត។

## 4. យុគសម័យផ្លូវដែកបានចាប់ផ្តើមឡើង

ម៉ាស៊ីនចំហាយទឹកបានបានបង្កើនអំណាចដល់រោងចក្រនានានៅអង់គ្លេស នៅចុងទសវត្សរ៍ឆ្នាំ 1700។ ម៉ាស៊ីនចំហាយទឹកមួយដែលមានកង់រត់លើផ្លូវដែក (ក្បាលអយស្ម័យយាន) បានជំរុញឲ្យឧស្សាហកម្មនៅអង់គ្លេសកាន់តែមានសន្ទុះខ្លាំងបន្ទាប់ពីឆ្នាំ 1820។

ក្បាលអយស្ម័យយានប្រើចំហាយទឹក៖ នៅក្នុងឆ្នាំ 1804 វិស្វករជនជាតិអង់គ្លេសមួយរូបឈ្មោះ រីឆាត ត្រេវីស៊ីក មានឈ្នះការភ្នាល់មួយដែលមានទឹកប្រាក់រាប់ពាន់ដុល្លា។ លោកឈ្នះការភ្នាល់នេះតាមរយៈការដឹកជញ្ជូនដែកចំនួន 10 តោនក្នុងរយៈចំងាយផ្លូវជិត 10 ម៉ាយ នៅលើក្បាលអយស្ម័យយានប្រើចំហាយទឹកមួយ។ វិស្វករអង់គ្លេសដ៏ទៃទៀត ភ្លាមៗនោះបានអភិវឌ្ឍក្បាលអយស្ម័យយានរបស់លោក ត្រេវីស៊ីក ។ វិស្វករផ្លូវដែកដំបូងម្នាក់នៅក្នុងចំណោមនោះគឺលោក ចច ស្តេហ្វិនសុន ។ លោកទទួលបានកិត្តិនាមដ៏ល្បីល្បាញមួយតាមរយៈការស្ថាបនាម៉ាស៊ីនចំនួនជាង 20 សម្រាប់ដំណើរការដឹករុករករ៉ែនៅភាគខាងជើងអង់គ្លេស។ នៅក្នុងឆ្នាំ 1821 លោក ស្តេហ្វិនសុន បានចាប់ផ្តើមធ្វើការលើគម្រោងផ្លូវដែកដំបូងបំផុតលើលោក។ វាមានប្រវែង 27 ម៉ាយ ដោយចេញដំណើរពីតំបន់ធ្យូងថ្មយ៉កស៊ី ទៅកាន់កំពង់ផែស្តុកតុន នៅសមុទ្ទខាងជើង។ នៅក្នុងឆ្នាំ 1825 ផ្លូវដែកត្រូវបានគេដាក់ឱ្យដំណើរការ។ វាត្រូវបានប្រើប្រាស់ក្បាលអយស្ម័យយាន 4 ដែលលោក ស្តេហ្វិនសុន បានរចនា និងស្ថាបនាឡើង។

ផ្លូវដែក លីវើភូល-មែនឆេស្ទ័រ៖ ព័ត៌មានអំពីភាពជោគជ័យនេះបានរីករាលដាលយ៉ាងឆាប់រហ័សនៅពាសពេញចក្រភពអង់គ្លេស។ សហគ្រិននានានៅអង់គ្លេសភាគខាងជើងចង់បានផ្លូវដែកមួយខ្សែដើម្បីភ្ជាប់តំបន់កំពង់ផែលីវើភូល ជាមួយទីក្រុងមែនឆេស្ទ័រ។ ក្រោយមកផ្លូវដែកនេះត្រូវបានគេស្ថាបនាឡើង។ នៅក្នុងឆ្នាំ 1829 ការវិន័ច្ឆ័យត្រូវបានធ្វើឡើងដើម្បីជ្រើសរើសក្បាលអយស្ម័យយានដែលល្អបំផុតសម្រាប់ប្រើប្រាស់នូវលើផ្លូវដែកថ្មីនេះ។ មានក្បាលម៉ាស៊ីនអយស្ម័យយានចំនួន 5 បានចូលរួមនៅក្នុងការប្រកួតប្រជែងនេះ។ គ្មានក្បាលអយស្ម័យយានមួយណាអាចប្រជែងជាមួយ រកកែត ដែលរចនាឡើងដោយលោក ស្តេហ្វិនសុន និងកូនរបស់លោកបានឡើយ។

ផ្សែងបានហ៊ុយចេញពីបំពង់ផ្សែងដ៏វែងរបស់ "រកកែត" ហើយវាមានបឺស្តុងចំនួន 2 នៅពីខាងមុខ ដោយកង់ខាងមុខគឺជាអ្នកអូសទូររថភ្លើងទាំងមូល។ ក្បាលអយស្ម័យយានអាចដឹកជញ្ជូនទំនិញបានទម្ងន់ រហូតដល់ 13 តោន នៅក្នុងល្បឿនថ្មីមួយ គឺជាង 24 ម៉ាយក្នុងមួយម៉ោង។ ផ្លូវដែក លីវើភូល-មែនឆេស្ទ័រ បានបើកដំណើរការជាផ្លូវការនៅក្នុងឆ្នាំ 1830។ វាគឺជាជោគជ័យដ៏ធំធេងមួយ។

ផ្លូវដែកធ្វើឱ្យប្រែប្រួលជីវិតរស់នៅនៅអង់គ្លេស៖ ការបង្កើត និងធ្វើឱ្យប្រសើរឡើងនូវក្បាលអយស្ម័យយាន បានជះឥទ្ធិពលសំខាន់ៗយ៉ាងតិចចំនួន 4 ។ ទី 1 ផ្លូវដែកបានរុញច្រានឱ្យឧស្សាហកម្មរីកលូតលាស់ តាមរយៈការផ្តល់ឱ្យម្ចាស់សហគ្រាសនូវការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចក្នុងតម្លៃថោកមួយ។ ទី 2 បន្ទុះនៃផ្លូវដែក បានបង្កើតការងារថ្មីរាប់ម៉ឺនសម្រាប់កម្មករផ្លូវដែក និងកម្មករជីករ៉ែ។ ពួកកម្មករជីករ៉ែទាំងនេះបានផ្តល់នូវដែកសម្រាប់ធ្វើផ្លូវ និងធ្យូងថ្មសម្រាប់ម៉ាស៊ីនប្រើចំហាយទឹក។ ទី 3 ផ្លូវដែកបានលើកកម្ពស់កសិកម្ម និងឧស្សាហកម្មនេសាទរបស់អង់គ្លេស ដែលប្រជាកសិករអាចដឹកជញ្ជូន ទំនិញរបស់ពួកគេទៅកាន់ទីក្រុងឆ្ងាយៗ។

ចុងក្រោយ តាមរយៈការផ្តល់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរ ផ្លូវដែកបានជម្រុញឱ្យមនុស្សនៅទីជនបទធ្វើដំណើរទៅកាន់ទីក្រុងឆ្ងាយៗដើម្បីស្វែងរកការងារធ្វើ។ ជាមួយនោះផងដែរ ផ្លូវដែកក៏បានទាក់ទាញអ្នករស់នៅក្នុងទីក្រុងឱ្យទៅកំសាន្តនៅទីជនបទផងដែរ។ ក៏ដូចជាផ្លូវដែកដែលរត់ខ្វាត់ខ្វែងពេញផ្ទៃប្រទេសដែរ បដិវត្តឧស្សាហកម្មបាននាំមកនូវការផ្លាស់ប្តូរជីវិតរស់នៅរបស់ប្រជាជនយ៉ាងខ្លាំង។

# មេរៀនទី 2 ៖ ឧស្សាហូបនីយកម្ម

បដិវត្តនៃឧស្សាហកម្ម បានជះឥទ្ធិពលលើគ្រប់ផ្នែកទាំងអស់នៃជីវិតរស់នៅនៅក្នុងចក្រភពអង់គ្លេស ប៉ុន្តែឥទ្ធិពលនៅមានទាំងវិជ្ជមាន និងអវិជ្ជមាន។ ដោយថាហេតុ ឧស្សាហូបនីយកម្មបាននាំទៅដល់ជីវិតរស់នៅប្រកបដោយគុណភាពកាន់តែប្រសើរមួយសម្រាប់ប្រជាជនភាគច្រើន។ ប៉ុន្តែការផ្លាស់ប្តូរទៅរកការផលិតដោយប្រើគ្រឿងម៉ាស៊ីនបានបង្កើតឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្ស។ ឧស្សាហូបនីយកម្មយ៉ាងឆាប់រហ័សបាននាំទៅដល់ការកើនឡើងនៃការងារដ៏ច្រើន ប៉ុន្តែវាក៏បណ្តាលឱ្យមានលក្ខខ័ណ្ឌការងារមិនល្អនានា, ការបំពុលខ្យល់ និងទឹក, និងបញ្ហាពលកម្មកុមារ។ វាក៏បាននាំទៅដល់ជម្លោះវណ្ណៈ ជាពិសេសរវាងវណ្ណៈពលជីព និងវណ្ណៈកណ្តាល។

## 1. ឧស្សាហូបនីយកម្មផ្លាស់ប្តូរជីវិតរស់នៅ

ឧស្សាហូបនីយកម្មបានបង្កើនល្បឿនយ៉ាងឆាប់រហ័សនៅចក្រភពអង់គ្លេស។ ត្រឹមទសវត្សរ៍ឆ្នាំ 1800 ប្រជាជនអាចទទួលបានប្រាក់ម៉ោងនៅក្នុងរោងចក្រខ្ពស់ជាងការធ្វើស្រែចំការ។ ជាមួយនឹងប្រាក់ទាំងនេះ មនុស្សកាន់តែច្រើនអាចបង្កើនកម្តៅនៅក្នុងផ្ទះរបស់ពួកគេជាមួយនឹងការដុះធ្យូងថ្ម ដែលគេយកមកពីប្រទេសវ៉េល និងអាចញ៉ាំអាហារពេលល្ងាចជាមួយនឹងសាច់គោមកពីប្រទេសស្កុតលែន។ ពួកគេស្លៀកសំលៀកបំពាក់ល្អៗដែលត្បាញចេញមកពីម៉ាស៊ីនតម្បាញនៅក្នុងទីក្រុងឧស្សាហកម្មនានារបស់អង់គ្លេស។ ទីក្រុងពោរពេញទៅដោយអ្នកស្វែងរកការងារធ្វើ។

ទីក្រុងឧស្សាហកម្មបានរីកឡើង៖ អស់រយៈពេលជាច្រើនសតវត្សរ៍ ពួកអឺរ៉ុបភាគច្រើនរស់នៅតំបន់ជនបទ។ បន្ទាប់ពីឆ្នាំ 1800 មកប្រជាជនទាំងនោះចាប់ផ្តើមផ្លាស់ទៅរស់នៅក្នុងទីក្រុង។ ការផ្លាស់ប្តូរនេះបណ្តាលមកពីការរីកចម្រើននៃបណ្តុំរោងចក្រ ជាទីកន្លែងដែលរោងចក្រផលិតទំនិញប្រមូលផ្តុំគ្នានៅក្នុងមជ្ឈមណ្ឌលតែមួយ។ រវាងឆ្នាំ 1800 ដល់ឆ្នាំ 1850 ចំនួនទីក្រុងនៅអឺរ៉ុបបានកើនឡើងពី 22 ទៅដល់ 47 ដែលមានប្រជាជនរស់នៅច្រើនជាង 10 ម៉ឺននាក់។ ភាគច្រើននៃតំបន់ប្រជុំជននៅអឺរ៉ុបបានកើនឡើងនៃចំនួនប្រជាជនយ៉ាងតិចចំនួន 2 ដង តំបន់ខ្លះកើនឡើងរហូតដល់ 4 ដង។ សម័យកាលនេះគឺជាសម័យកាលនគរូបនីយកម្មមួយ ដែលជាការកើនឡើងនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ទីរបស់ប្រជាជនចូលក្នុងទីក្រុង។

រោងចក្រត្រូវប្រមូលផ្តុំទៅជាក្រុម ដោយសារសហគ្រិននានាបានស្ថាបនារោងចក្រទាំងនោះនៅជិតប្រភពថាមពល ដែលមានដូចជាទឹក និងធ្យូងថ្មជាដើម។ មជ្ឈមណ្ឌលឧស្សាហកម្មថ្មីធំៗបានរីកឡើងនៅចន្លោះតំបន់សម្បូរធ្យូងថ្មភាគខាងត្បូងប្រទេសវែល និងជ្រលងទន្លេគ្លីដ នៅប្រទេសស្កុតលែន។ ប៉ុន្តែ មជ្ឈមណ្ឌលឧស្សាហកម្មដែលធំបំផុតមួយត្រូវបានបង្កើតឡើងនៅអង់គ្លេស ។

រាជធានីរបស់ចក្រភពអង់គ្លេស ទីក្រុងឡុងដ៍ គឺជាទីក្រុងដែលសំខាន់បំផុត។ គិតត្រឹមឆ្នាំ 1800 ទីក្រុងនេះមានប្រជាជនប្រមាណជា 1 លាននាក់។ អំឡុងទសវត្សរ៍ឆ្នាំ 1800 ចំនួនប្រជាជននៅក្នុងទីក្រុងនេះបានរីកធំឡើង

ដែលបានផ្តល់នូវកម្លាំងពលកម្ម និងទីផ្សារសម្រាប់ឧស្សាហកម្មថ្មី។ ទីក្រុងឡុងដ៍ បានក្លាយជាទីក្រុងដែលធំជាងគេនៅអឺរ៉ុប ដែលមានចំនួនប្រជាជនប្រហែល 2 ដងនៃចំនួនប្រជាជននៅក្នុងទីក្រុងប៉ារីស។ មានទីក្រុងថ្មីៗបានប្រជែងជាមួយនឹងភាពនាំមុខផ្នែកខាងឧស្សាកម្មរបស់ទីក្រុងឡុងដ៍។ ទីក្រុងប៊ីមីងហេម និងទីក្រុងសីហ្វៀល បានក្លាយជាមជ្ឈមណ្ឌលស្មិតដែក។ ទីក្រុងលីដ និងទីក្រុងមេនឆេស្ទ័រ បានកគ្រប់ដណ្តប់លើផលិតផលវាយនភ័ណ្ឌ។ តាមបណ្តោយកំពង់ផែនៅលីវើភូល និងមេនឆេស្ទ័រ បានក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្មកប្បាសនៅចក្រភពអង់គ្លេស។ អំឡុងទសវត្សរ៍ឆ្នាំ 1800 ប្រជាជននៅក្នុងទីក្រុងមេនឆេស្ទ័រ បានបានកើនឡើងយ៉ាងឆាប់រហ័ស ពីរង្វង់ 45,000 នាក់នៅក្នុងឆ្នាំ 1760 ទៅ 30ម៉ឺននាក់ត្រឹមឆ្នាំ 1850។

ស្ថានភាពនៃការរស់នៅ៖ ដោយសារតែទីក្រុងនានានៅអង់គ្លេសបានរីកឡើងយ៉ាងឆាប់រហ័ស ទីក្រុងទាំងនោះមិនមានផែនការអភិវឌ្ឍ, ក្រឹតក្រមអនាម័យ, និងក្រឹតក្រមសំណង់ត្រឹមត្រូវឡើយ។ ជាងនេះទៅទៀត នៅក្នុងទីក្រុងទាំងនោះ មានកង្វះខាតទីកន្លែងស្នាក់នៅសមរម្យ, ការអប់រំ, និងការការពាររបស់ប៉ូលីសចំពោះប្រជាជននានាដែលបានផ្លាស់ប្តូរទៅលំនៅរបស់ពួកគេពីទីជនបទដើម្បីស្វែងរកការងារធ្វើនៅក្នុងទីក្រុង។ ផ្លូវភាគច្រើនដែលមិនទាន់ក្រាលថ្ម តែងមានទឹកដក់ និងគំនរសម្រាមនៅលើនោះ។ កម្មកររស់នៅទីកន្លែងងងឹត និងកង្វក់ ដែលគ្រួសារទាំងមូលរស់នៅប្រមូលផ្តុំគ្នានៅក្នុងបន្ទប់តែមួយ។ ជំងឺឆ្លងមានរីករាលដាល។ ជំងឺអាសន្នរោគបានឆ្លងរីករាលដាលនៅគ្រប់ទីកន្លែងក្នុងទីក្រុងឧស្សាហកម្មរបស់ចក្រភពអង់គ្លេស។ នៅក្នុងឆ្នាំ 1842 ការសិក្សាមួយរបស់រដ្ឋាភិបាលចក្រភពអង់គ្លេស បានបង្ហាញពីជាមធ្យមពួកកម្មករនៅក្នុងទីក្រុងធំមួយ រស់បាន 17 ឆ្នាំ ប្រៀបធៀបជាមួយនឹងតំបន់ជនបទក្បែរនោះគឺ រស់បាន 38 ឆ្នាំ។ ប៉ុន្តែមិនមែនមនុស្សរស់នៅទីប្រជុំជនទាំងអស់សុទ្ធតែរស់នៅលំបាកឡើយ។ ពាណិជ្ជករ និងម្ចាស់រោងចក្រជាទូទៅរស់នៅក្នុងផ្ទះប្រណិតៗនៅជាយក្រុង។

ស្ថានភាពការងារ៖ ដើម្បីបង្កើនផលិតផល ម្ចាស់រោងចក្រចង់រក្សាម៉ាស៊ីននៅក្នុងរោងចក្ររបស់ពួកគេឱ្យបន្តដំណើរការឱ្យបានកាន់តែច្រើនម៉ោងតាមតែអាចធ្វើទៅបាន។ ជាលទ្ធផល ជាមធ្យមកម្មករម្នាក់ចំណាយពេល 14 ម៉ោងក្នុងមួយថ្ងៃ និង 6 ថ្ងៃក្នុងមួយសប្តាហ៍នៅកន្លែងការងាររបស់ពួកគេ។ ការងារក្នុងរោងចក្រមិនបានផ្លាស់ប្តូរតាមរដូវកាលដូចការធ្វើស្រែចំការឡើយ។ ផ្ទុយទៅវិញ ការធ្វើការងារនៅក្នុងរោងចក្រនៅតែបន្តធ្វើពីមួយសប្តាហ៍ទៅមួយសប្តាហ៍, ពីមួយឆ្នាំទៅមួយឆ្នាំ។

ឧស្សាហកម្មក៏នាំមកនូវគ្រោះថ្នាក់ថ្មីមួយសម្រាប់កម្មករផងដែរ។ រោងចក្រមិនសូវមានពន្លឺថ្ងៃ ឬអនាម័យឡើយ។ ម៉ាស៊ីនមួយចំនួនបានបង្ករបួសដល់កម្មករ។ ផ្ទាំងដាំទឹកអាចនឹងផ្ទុះ ឬខ្សែពានអាចនឹងគាប់ដៃ។ មិនមានកម្មវិធីរបស់រដ្ឋាភិបាលដើម្បីផ្តល់ការឧបត្ថម្ភក្នុងករណីកម្មករមានគ្រោះថ្នាក់ឡើយ។ អ្នកដែលប្រឈមទៅនឹងស្ថានការណ៍ដែលមានគ្រោះថ្នាក់បំផុតនោះគឺកម្មករជីកធ្យូងថ្ម។ ឧបទ្ទវហេតុតែងកើតឡើងជាញឹកញយ, រស់នៅក្នុងស្ថានភាពងងឹត, ការស្រូបកម្ទេចធ្យូងថ្មជាប្រចាំ បានធ្វើឱ្យអាយុជាមធ្យមរបស់កម្មករជីកធ្យូងថ្មខ្លីជាងកម្មករនៅក្នុងរោងចក្រ 10 ឆ្នាំ។ ស្ត្រី និងកុមារជាច្រើន ត្រូវបានគេជួលឱ្យធ្វើការនៅក្នុងឧស្សាហកម្មជីករ៉ែដោយសារតែពួកគេជាប្រភពកម្លាំងការងារដែលមានតម្លៃថោក។

### 2. ជម្លោះវណ្ណៈបានកើនឡើង

បើទោះបីជាភាពក្រីក្របានគគ្របដណ្ដប់លើវណ្ណៈកម្មករនៅក្នុងចក្រភពអង់គ្លេស បដិវត្តឧស្សាកម្មបានបង្កើនទ្រព្យសម្បត្តិរបស់ប្រទេសជាតិយ៉ាងច្រើន។ លុយថ្មីទាំងអស់នេះគឺជារបស់ម្ចាស់រោងចក្រ, អ្នកដឹកជញ្ជូនទំនិញ, និងពាណិជ្ជករ។ ក្រុមមនុស្សទាំងនេះគឺជាផ្នែកមួយនៃពួកវណ្ណៈកណ្ដាលថ្មី, ពួកវណ្ណៈកណ្ដាលទាំងនេះរួមមានពួកកម្មករជំនាញ, អ្នកជំនាញវិជ្ជាជីវៈ, អ្នកជំនួញ, និងប្រជាកសិករដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ។

វណ្ណៈកណ្ដាល៖ វណ្ណៈកណ្ដាលថ្មីបានផ្លាស់ប្ដូររចនាសម្ព័ន្ធសង្គមនៅក្នុងចក្រភពអង់គ្លេស។ កាលពីអតីតកាល ម្ចាស់កម្មសិទ្ធិដីធ្លី និងពួកអភិជនបានកាន់កាប់ដំណែងកំពូលៗនៅក្នុងសង្គមអង់គ្លេស។ ជាមួយនឹងទ្រព្យសម្បត្តិដ៏ច្រើន ពួកគេទទួលបានអំណាចសង្គម និងនយោបាយ។ ប៉ុន្តែក្រោយមក ម្ចាស់រោងចក្រ, ពាណិជ្ជករ, និងធនាគារិកបានកើនទ្រព្យសម្បត្តិច្រើនជាងពួកម្ចាស់កម្មសិទ្ធិដីធ្លី និងពួកអភិជន។ ភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងសង្គមបានបែងចែកវណ្ណៈទាំង 2 នេះ។ ម្ចាស់កម្មសិទ្ធិដីធ្លីមើលងាយអ្នកទាំងឡាយដែលបានបង្កើនទ្រព្យសម្បត្តិរបស់ពួកគេតាមរយៈពិភពជំនួញដ៏ថោកទាប។ រហូតដល់ចុងទសវត្សរ៍ឆ្នាំ 1800 ពួកសហគ្រិនមានទ្រព្យសម្បត្តិមួយចំនួនត្រូវបានគេចាត់ទុកថាមានឋានៈសង្គមស្មើពួកអភិជននៅជនបទ។

បន្តិចម្ដងៗ វណ្ណៈកណ្ដាលដ៏ធំមួយ ដោយមិនមែនជាអ្នកមាន និងមិនមែនអ្នកក្រ បានលេចឡើង។ វណ្ណៈកណ្ដាលកម្រិតលើ រួមមាន មន្ត្រីរដ្ឋាភិបាល, វេជ្ជបណ្ឌិត, មេធាវី, និងអ្នកគ្រប់គ្រងរោងចក្រ, អណ្ដូងរ៉ែ , និងហាងទំនិញ។ អ្នកវណ្ណៈកណ្ដាលកម្រិតទាប រួមមាន អ្នកមើលខុសត្រូវក្នុងរោងចក្រ, និងកម្មករជំនាញមួយចំនួនដូចជាអ្នកផលិតសម្ភារៈប្រើប្រាស់, អ្នកផ្គុំគ្រឿងម៉ាស៊ីន, និងអ្នកបោះពុម្ព។ ក្រុមមនុស្សទាំងនេះរីករាយជាមួយនឹងជីវិតរស់នៅដ៏សុខស្រួលមួយ។

វណ្ណៈកម្មករ៖ អំឡុងឆ្នាំ 1800 ដល់ឆ្នាំ 1850 កម្មករ ឬវណ្ណៈកម្មករ មានការអភិវឌ្ឍជីវភាពរស់នៅ និងស្ថានភាពការងារតិចតួច។ ពួកគេបានគិតថាការងាររបស់ពួកគេនឹងបាត់បង់ ដូចដែលម៉ាស៊ីននឹងជំនួសតំណែងរបស់ពួកគេ។ ដោយមិនបានគិតឱ្យបានវែងឆ្ងាយ មានកម្មករមួយចំនួនបានវាយបំបែកម៉ាស៊ីន ដែលពួកគេគិតថានឹងបណ្ដាលឱ្យពួកគេគ្មានការងារធ្វើ។ ក្រុមកម្មករមួយក្រុមមានឈ្មោះថា លូឌីត។ ឈ្មោះនេះត្រូវបានដាក់តាមលោកនេដ លូឌ ។ លោកលូឌ ប្រហែលជាកម្មករអង់គ្លេសនៅក្នុងរឿងព្រេងមួយ ត្រូវបានគេនិយាយថាបានបំផ្លាញម៉ាស៊ីនតម្បាញនៅវង្វង់ឆ្នាំ 1770 ។ ពួកលូឌីត បានធ្វើការវាយប្រហារលើរោងចក្រនានានៅអង់គ្លេសភាគខាងជើង ដោយចាប់ផ្ដើមដំបូងនៅក្នុងឆ្នាំ 1811 ដោយធ្វើការវាយបំផ្លាញម៉ាស៊ីនដែលប្រើកម្លាំងកម្មករតិច។ នៅខាងក្រៅរោងចក្រ ហ្វូងកម្មករបានធ្វើកុប្បកម្ម ដោយសារតែបញ្ហាទាក់ទងនឹងស្ថានភាពនៃការរស់នៅ និងការងារ។

### 3. ឥទ្ធពលវិជ្ជមាននៃបដិវត្តឧស្សាហកម្ម

បើទោះបីជាមានបញ្ហានានាកើតមានឡើងបន្ទាប់ពីឧស្សាហូបនីយកម្មក៏ដោយ បដិវត្តឧស្សាហកម្មមានឥទ្ធិពលវិជ្ជមានជាច្រើន។ វាបានបង្កើតការងារសម្រាប់កម្មករ។ វាបានបង្កើនទ្រព្យសម្បត្តិដល់ប្រទេសជាតិ។ វាបានជម្រុញឱ្យមានភាគជឿនលឿននៃបច្ចេកវិទ្យា និងការបង្កើតថ្មី។ វាបានបង្កើនការផលិតនូវផលិតផលយ៉ាងល្អប្រសើរ និង

បង្កើនបទដ្ឋាននៃការរស់នៅ។ ប្រហែលជាចំណុចដែលសំខាន់ជាងគេនោះគឺ វាបានផ្តល់នូវសេចក្តីសង្ឃឹមសម្រាប់ការអភិវឌ្ឍជីវភាពរស់នៅរបស់មនុស្ស។

បដិវត្តឧស្សាហកម្មបានបង្កើតឲ្យមានអត្ថប្រយោជន៍មួយចំនួនទៀតផងដែរ។ ក្នុងនោះរួមមាន ចំណីអាហារដែលប្រកបដោយសុខភាព, ទីកន្លែងរស់នៅសមរម្យ និងមានតម្លៃថោក, ផលិតផលសំលៀកបំពាក់យ៉ាងច្រើន។ ដោយសារតែបដិវត្តឧស្សាហកម្ម វាបានបង្កើនតម្រូវការវិស្វករ ក៏ដូចជាស្មៀន និងកម្មករជំនាញ វាបានពង្រីកឱកាសនៃការសិក្សា។

វណ្ណៈកណ្តាល និងវណ្ណៈខ្ពស់ទទួលបានភាពរុងរឿងយ៉ាងឆាប់រហ័សពួកបដិវត្តឧស្សាហកម្ម។ សម្រាប់កម្មករ វាត្រូវការពេលវេលាយូរមួយ ប៉ុន្តែជីវភាពរស់នៅរបស់ពួកគេបានអភិវឌ្ឍបន្តិចម្តងៗនៅអំឡុងទសវត្សរ៍ឆ្នាំ 1800 ។ កម្មករបន្តិចម្តងៗទទួលបានប្រាក់ម៉ោងខ្ពស់, ធ្វើការតិចម៉ោងជាងមុន, និងស្ថានភាពការងារល្អប្រសើរ បន្ទាប់ពីពួកគេបានចូលរួមជាមួយគ្នានៅក្នុងការបង្កើតជាសហជីព។

ឥទ្ធិពលរយៈពេលវែង៖ ឥទ្ធិពលរយៈពេលវែងនៃបដិវត្តឧស្សាហកម្មនៅតែបន្តមានរហូតមកដល់បច្ចុប្បន្ន។ មនុស្សភាគច្រើននាពេលបច្ចុប្បន្ននៅក្នុងប្រទេសឧស្សាហកម្ម អាចទទួលបានផលិតផលប្រើប្រាស់នានា ដែលកាលពី 50 ទៅ 60 ឆ្នាំមុនផលិតផលទាំងនេះត្រូវបានគេចាត់ទុកថាជារបស់ប្រណិត។ ជាមួយគ្នានេះផងដែរ ស្ថានភាពរស់នៅ និងស្ថានភាពការងាររបស់ពួកគេមានការអភិវឌ្ឍច្រើនជាងកម្មករនៅក្នុងសតវត្សរ៍ទី 19 ។ បន្ថែមពីលើនេះ ប្រាក់ចំណូលដែលបានមកពីឧស្សាហូបនីយកម្មបានបង្កើតបានជាពន្ធលើប្រាក់ចំណេញ។ លុយពន្ធទាំងនេះបានអនុញ្ញាឱ្យរដ្ឋាភិបាលតំបន់, រដ្ឋ, និងសហព័ន្ធអាចវិនិយោគលើការភិវឌ្ឍទីក្រុង និងបង្កើនបទដ្ឋាននៃការរស់នៅសម្រាប់មនុស្សទាំងឡាយនៅក្នុងទីក្រុង។

ភាពជោគជ័យនៃសេដ្ឋកិច្ចដែលបណ្តាលមកពីបដិវត្តឧស្សាហកម្ម និងបញ្ហាដែលកើតមានឡើងដោយសារវា ត្រូវបានបង្ហាញនៅក្នុងទីក្រុងឧស្សាហកម្មថ្មីៗរបស់ចក្រភពអង់គ្លេស ដែលក្នុងនោះមានដូចជាទីក្រុងមេនធេស្ទ័រជាដើម។

# មេរៀនទី 3៖ ឧស្សាហូបនីយកម្មរីកសាយភាយ

## 1. ការអភិវឌ្ឍឧស្សាហកម្មនៅសហរដ្ឋអាមេរិក

សហរដ្ឋអាមេរិកមានធនធានដូចគ្នាទៅនឹងចក្រភពអង់គ្លេស ដែលអនុញ្ញាតិឱ្យពួកគេអាចធ្វើយន្តកម្មឧស្សាហកម្មរបស់គេ។ អាមេរិកមានទន្លេដែលមានទឹកហូរលឿន, តំបន់ដែលសម្បូរត្បូងថ្ម និងដែក, និងការផ្គត់ផ្គង់កម្លាំងពលកម្មដែលបានមកពីប្រជាកសិករ និងជនអន្តោប្រវេសន៍។ នៅអំឡុងពេលនៃការធ្វើសង្គ្រាមឆ្នាំ 1812 ចក្រភពអង់គ្លេសបានរាំងខ្ទប់សហរដ្ឋអាមេរិក ដើម្បីទាប់ស្កាត់ពួកគេនៅក្នុងចូលរួមក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ។ ការរាំងខ្ទប់នេះបានជម្រុញឱ្យប្រទេសក្មេងខ្ចីមួយនេះប្រើប្រាស់នូវធនធានផ្ទាល់ខ្លួនរបស់ពួកគេដើម្បីអភិវឌ្ឍឧស្សាហកម្មដោយឯករាជ្យមួយ។ ឧស្សាកម្មនេះនឹងផលិតនូវផលិតផលទំនិញណាដែលសហរដ្ឋអាមេរិកមិនអាចនាំចូលបាន។

ឧស្សាហូបនីយកម្មនៅក្នុងសហរដ្ឋអាមេរិក៖ ក៏ដូចជានៅក្នុងចក្រភពអង់គ្លេសដែរ ឧស្សាហូបនីយកម្មនៅក្នុងសហរដ្ឋអាមេរិកចាប់ផ្តើមជាមួយនឹងឧស្សាហកម្មវាយនភ័ណ្ឌ។ ដោយមានបំណងចង់រក្សាភាពសម្ងាត់នៃឧស្សាហូបនីយកម្មសម្រាប់ប្រើប្រាស់ខ្លួនគេផ្ទាល់ ចក្រភពអង់គ្លេសបានហាមឃាត់វិស្វករ, ជាងម៉ាស៊ីន, និងអ្នកផលិតសម្ភារៈផ្សេង មិនឱ្យចាកចេញពីប្រទេសឡើយ។ ប៉ុន្តែ នៅក្នុងឆ្នាំ 1789 កម្មករទឹកដោះគោវ័យក្មេងជនជាតិអង់គ្លេសមួយរូបឈ្មោះថា សាម៉ូអ៊ែល ស្លាទ័រ បានធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិក។ នៅទីនោះ លោកស្លាទ័រ បានបង្កើតម៉ាស៊ីនបង្វិលមួយដោយរចនាឡើងតាមរយៈការចងចាំ និងការអនុវត្តរបស់លោក។ មួយឆ្នាំក្រោយមកលោក ម៉ូសេ ប្រោន បានបើករោងចក្រដំបូងនៅសហរដ្ឋអាមេរិក ក្នុងតំបន់ផាទូកេត, កោះ រ៉ូដេ ដែលជាទីកន្លែងដែលលោក ស្លាទ័រ ផលិតម៉ាស៊ីនបង្វិល។ ប៉ុន្តែ រោងចក្រផាទូកេត ផលិតតែផ្នែកមួយនៃផលិតផលសំលៀកបំពាក់ប៉ុណ្ណោះ គឺសសៃអម្បោះ។ នៅក្នុងឆ្នាំ 1813 ហ្វេនស៊ីស កាបូត ឡូវែល នៅរដ្ឋ បូស្តុន និងអ្នកវិនិយោជ 4 រូបផ្សេងទៀតបានធ្វើបដិវត្តនីយកម្មលើឧស្សាហកម្មវាយនភ័ណ្ឌនៅអាមេរិក។ ពួកគេធ្វើយន្តកម្មនូវរាល់សង្វាក់ផលិតកម្មសំលៀកបំពាក់។ រោងចក្រតម្បាញរបស់ពួកគេនៅវ៉ល់សាំ រដ្ឋម៉ាសាឆូសេត បានផ្តល់ប្រាក់ចំណេញឱ្យពួកគេគ្រប់គ្រាន់នៅក្នុងការបង្កើតតំបន់រោងចក្រថ្មីមួយដែលធំជាងមុន ដោយលោកដាក់ឈ្មោះរោងចក្រនោះថា ឡូវែល ។ ត្រឹមចុងទសវត្សរ៍ឆ្នាំ 1820 តំបន់រោងចក្រឡូវែល នៅរដ្ឋម៉ាសាឆូសេត ក្លាយជាមជ្ឈមណ្ឌលរោងចក្រដ៏ធំមួយ និងជាគំរូមួយសម្រាប់តំបន់ផ្សេងៗទៀត។

ស្ត្រីវ័យក្មេងនៅលីវរាប់ពាន់នាក់ បានចាក់ចេញពីតំបន់ជនបទដែលពួកគេរស់នៅទៅធ្វើជាកម្មកររោងចក្រនៅក្នុងទីក្រុង។ នៅទីនោះ ពួកគេអាចទទួលបានប្រាក់ម៉ោងខ្ពស់ និងមានសេរីភាពច្រើន។ ប៉ុន្តែ ដើម្បីធ្វើឱ្យប្រាកដអំពីភាពសមរម្យនៃអាកប្បកិរិយា ពួកគេត្រូវបានឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ពីថៅកែរបស់ពួកគេទាំងខាងក្នុង និងខាងក្រៅរោងចក្រ។ កម្មករស្ត្រីទាំងនេះត្រូវធ្វើការងារច្រើនជាង 12 ម៉ោងក្នុងមួយថ្ងៃ និង 6 ថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីទទួលបានប្រាក់ម៉ោងសមរម្យ។

ការពង្រីកឧស្សាហកម្មនៅសហរដ្ឋអាមេរិកនៅពេលក្រោយមកទៀត៖ នៅភូមិភាគឦសានជួបប្រទះនូវការរីកចម្រើនផ្នែកខាងឧស្សាកម្មយ៉ាងខ្លាំងនៅដើមទសវត្សរ៍ឆ្នាំ 1800 ។ ដោយមិនចាំបាច់និយាយ សហរដ្ឋអាមេរិកនៅតែជាប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម រហូតដល់សង្គ្រាមស៊ីវិលចប់នៅក្នុងឆ្នាំ 1856 ។ អំឡុងនៃចុងទសវត្សរ៍ឆ្នាំ 1800 ប្រទេសនេះបានជួបប្រទះនូវបន្ទុះបច្ចេកវិទ្យាមួយ។ ក៏ដូចជានៅក្នុងចក្រភពអង់គ្លេសដែរ មានកត្តាជាច្រើនដែលនាំឱ្យកើតមានបន្ទុះបច្ចេកវិទ្យានេះ។ កត្តាទាំងនោះរួមមាន ធនធានធម្មជាតិដែលមានតម្លៃនានាដូចជា ប្រេងឥន្ធនៈ, ធ្យូងថ្ម, និងដែក, ការបង្កើតថ្មីជាច្រើន ដែលក្នុងនោះមានដូចជាអំពូលអេឡិចត្រូនិចនិងទូរស័ព្ទ, និងការរីកឡើងនៃប្រជាជននៅក្នុងទីក្រុងដែលបានបង្កើនតម្រូវការទំនិញរោងចក្រថ្មីៗ។

ក៏ដូចជានៅក្នុងចក្រភពអង់គ្លេសដែរ ផ្លូវដែកបានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងឧស្សាហូបនីយកម្មនៅសហរដ្ឋអាមេរិក។ ទីក្រុងនានាដូចជា ឈីកាហ្គូ និង មីនៀប៉ូលីស ជាដើមបានរីកឡើងយ៉ាងឆាប់រហ័សអំឡុងទសវត្សរ៍ឆ្នាំ 1800 ។ មូលហេតុដោយសារតែទីក្រុងទាំងនេះមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវដែកសំខាន់ៗ។ ឧស្សាហកម្មចិញ្ចឹមសត្វនៅឈីកាហ្គូ និងឧស្សាហកម្មគ្រាប់ធុញ្ញជាតិនៅ មីនៀប៉ូលីស បានរីកចម្រើនតាមរយៈការលក់ផលិតផលទាំងនោះទៅកាន់តំបន់នានានៅសហរដ្ឋអាមេរិកទាំងមូល។ ជាក់ស្តែង ផ្លូវដែកឯកជនត្រូវបានគេយល់ថាជាជំនួញដែលផ្តល់ប្រាក់ចំណូលខ្ពស់មួយ។ ត្រឹមចុងទសវត្សរ៍ឆ្នាំ 1800 ក្រុមហ៊ុនដែលមានអំណាច និងធំៗមួយចំនួនបានត្រួតត្រាជាង 2/3 លើប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែកនានា។ ផ្លូវដែកបាននាំឱ្យកើតមានការជំនួញរួមបញ្ចូលគ្នា។ ក្រុមហ៊ុនតូចៗបានរួមបញ្ចូនគ្នាដើម្បីបង្កើតបានជាសហគ្រាសមួយធំមួយ។

ការរីកឡើងនៃសាជីវកម្ម៖ ការស្ថាបនាជំនួញធំៗដូចជា ជំនួញផ្លូវដែកតម្រូវឱ្យមានដើមទុនច្រើន។ ដើម្បីប្រមូលដើមទុន ក្រុមសហគ្រិនបានលក់ភាគហ៊ុន ឬសិទ្ធិក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិមួយផ្នែក។ មនុស្សទាំងឡាយដែលបានទិញភាគហ៊ុនបានក្លាយជាម្ចាស់កម្មសិទ្ធិមួយផ្នែកនៃជំនួញទាំងនេះ ដែលគេហៅថា សាជីវកម្ម។ សាជីវកម្មមួយគឺជាជំនួញមួយដែលកាន់កាប់ដោយម្ចាស់ភាគហ៊ុននានា ដែលនឹងចែករំលែកប្រាក់ចំណេញគ្នា ប៉ុន្តែពួកគេមិនទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះបំណុលនានាឡើយ។ សាជីវកម្មអាចប្រមូលបាននូវដើមទុនក្នុងទំហំដ៏ធំមួយដែលពួកគេត្រូវការ ដើម្បីវិនិយោគទៅលើបរិក្ខារឧស្សាហកម្ម។ នៅចុងទសវត្សរ៍ឆ្នាំ 1800 សាជីវកម្មធំៗដូចជា សាជីវកម្មបទដ្ឋានប្រេង(បង្កើតឡើងដោយលោក ចន ឌី.រ៉ូកេហ្វល័រ) និងក្រុមហ៊ុនសាជីវកម្មដែក ខាណេហ្គី (បង្កើតឡើងដោយលោកអេនឌ្រូ ខាណេហ្គី) ត្រូវបានបង្កើតឡើង។ ពួកគេសម្លឹងទៅរកការគ្រប់គ្រងគ្រប់ទម្រង់ទាំងអស់នៃឧស្សាហកម្មដោយខ្លួនគេផ្ទាល់ដើម្បីទទួលបានប្រាក់ចំនេញច្រើន។ ជំនួញធំ ឬសាជីវកម្មយក្សដែលត្រួតត្រាលើឧស្សាហកម្មទាំងមូលក៏បង្កើនប្រាក់ចំណូលបានច្រើន តាមរយៈការកាត់បន្ថយថ្លៃផលិតទំនិញ។ នៅក្នុងសហរដ្ឋអាមេរិក ក៏ដូចជាទីកន្លែងផ្សេងៗ កម្មករទទួលបានប្រាក់ម៉ោងទាបពីការធ្វើការងារជាច្រើនម៉ោងរបស់ពួកគេ ខណៈពេលដែលម្ចាស់ភាគហ៊ុនទទួលបានប្រាក់ចំណេញច្រើន ចំណែកឯមេដឹកនាំសាជីវកម្មបានក្លាយជាអ្នកមាន។

## 2. ឧស្សាហូបនីយកម្មនៅទ្វីបអឺរ៉ុប

ពួកអ្នកជំនួញអឺរ៉ុបនានាចង់បង្កើតឱ្យមាន "អព្ភូតហេតុនៅអង់គ្លេស" ដែលជាលទ្ធផលចេញមកពីការបង្កើតវិធីសាស្ត្រក្នុងការផលិតទំនិញថ្មីដ៏មានប្រយោជន៍មួយរបស់ចក្រភពអង់គ្លេស។ ប៉ុន្តែ បញ្ហាបានកើតមានឡើងដោយសារតែការធ្វើបដិវត្តនៅបារាំង និងសង្គ្រាមណាប៉ូឡេអុងរវាងឆ្នាំ 1789 និង 1815 ដែលបានរាំងស្ទះការធ្វើពាណិជ្ជកម្ម, រំខានដល់ការធ្វើទំនាក់ទំនង, និងបណ្តាលឱ្យមានអតិផរណានៅក្នុងតំបន់មួយចំនួននៃទ្វីអឺរ៉ុប។ ប្រទេសនៅអឺរ៉ុបនានាបានមើលឃើញពីគម្លាតយ៉ាងធំរវាងពួកគេជាមួយនឹងចក្រភពអង់គ្លេស។ ដូច្នេះ ឧស្សាហូបនីយកម្មបន្តិចម្តងៗបានរីករាលដាលដល់ទ្វីបអឺរ៉ុប។

ការចាប់ផ្តើមដំបូងនៅបែលហ្សិក៖ ប្រទេសបែលហ្សិកបាននាំមុខគេនៅអឺរ៉ុប នៅក្នុងការទទួលយកបច្ចេកវិទ្យាថ្មីរបស់ចក្រភពអង់គ្លេស។ ប្រទេសនេះសំបូរទៅដោយរ៉ែដែក និងធ្យូងថ្ម ក៏ដូចជាផ្លូវទឹកល្អៗសម្រាប់ការដឹកជញ្ជូន។ ក៏ដូចជានៅក្នុងសហរដ្ឋអាមេរិកដែរ កម្មករជំនាញជនជាតិអង់គ្លេសបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងឧស្សាហូបនីយកម្មនៅប្រទេសបែលហ្សិក។

លោក សាម៉ូអែល ស្លាទ័រ បានលួចនាំយកវិធីផលិតម៉ាស៊ីនបង្វិលទៅកាន់សហរដ្ឋអាមេរិក។ ក៏ដូចរូបឡើងដែរ ជាងឈើនៅតំបន់ លេនកាស័រ មួយរូបឈ្មោះ វីលលៀម កូកេរីល បានធ្វើដំណើរដោយខុសច្បាប់ទៅកាន់ប្រទេសបែលហ្សិកនៅក្នុងឆ្នាំ 1799 ។ លោកបាននាំយកគម្រោងសម្ងាត់នានាសម្រាប់ការបង្កើតម៉ាស៊ីបង្វិល។ កូនរបស់លោកឈ្មោះ ចន បន្តិចម្តងៗបានបង្កើតសហគ្រាសឧស្សាហកម្មមួយចំនួននៅបែលហ្សិកភាគខាងកើត។ សហគ្រាសនេះផលិតនូវម៉ាស៊ីនបរិក្ខារគ្រប់ប្រភេទ ដោយរួមមាន ម៉ាស៊ីនប្រើចំហាយទឹក, និងក្បាលអយស្ម័យយានរត់លើផ្លូវដែក។ មានកម្មករអង់គ្លេសជាច្រើនបានធ្វើដំណើរមកធ្វើការជាមួយលោក កូកេរីល ដោយបាននាំយកនូវបច្ចេកវិទ្យាថ្មីរបស់អង់គ្លេសមកជាមួយពួកគេ។ ពួកគេមួយចំនួន ក្រោយមកបានបង្កើតក្រុមហ៊ុនរបស់ពួកគេដោយផ្ទាល់នៅអឺរ៉ុប។

ឧស្សាហូបនីកម្មនៅអាឡឺម៉ង់៖ ប្រទេសអាឡឺម៉ង់មានការបែងចែកនយោបាយនៅដើមទសវត្សរ៍ឆ្នាំ 1800 ។ សេដ្ឋកិច្ចឯកកោរ និងធនធានរាយពាយបានបង្កភាពលំបាកដល់ការធ្វើឧស្សាហូបនីយកម្មនៅក្នុងប្រទេសនេះ។ ប៉ុន្តែ ឧស្សាហូបនីយកម្មមួយបានលេចឡើងនៅតំបន់សំបូរធ្យូងថ្ម ស្ថិតនៅតំបន់ជ្រលង រូ ភាគខាងលិចអាឡឺម៉ង់កណ្តាល។ នៅរង្វង់ដើមឆ្នាំ 1835 ប្រទេសអាឡឺម៉ង់ចាប់ផ្តើមចម្លងតាមគំរូរបស់ចក្រភពអង់គ្លេស។ ប្រទេសអាឡឺម៉ង់បាននាំចូលបរិក្ខារ និងវិស្វករពីចក្រភពអង់គ្លេស។ ម្ចាស់រោងចក្រកម្មន្តសាលក៏បានបញ្ជូលកូនៗរបស់ពួកគេទៅកាន់ប្រទេសអង់គ្លេសដើម្បីរៀនសូត្រពីរបៀបគ្រប់គ្រងរោងចក្រឧស្សាហកម្ម។

កាន់តែសំខាន់ជាងនេះទៅទៀត អាឡឺម៉ង់ស្ថាបនាផ្លូវដែកដែលបានភ្ជាប់ទីក្រុងឧស្សាហកម្មធំៗក្នុងនោះមានដូចជា ប្រេងហ្វឺត ជាមួយនឹងតំបន់សំបូរធ្យូងថ្ម និងដែកនៅចជ្រលងរូ ។ នៅក្នុងឆ្នាំ 1858 សេដ្ឋវិទូជនជាតិអាឡឺម៉ង់មួយរូបបានសរសេរថា "ហាងលក់ក្បាលអយស្ម័យយាន និងម៉ាស៊ីន, អណ្តូងរ៉ែធ្យូងថ្ម និងរោងចក្រស្មិតដែក, កន្លែងរវៃ និងមូលសសៃអម្បោះ ហាក់ដូចជាផុសឡើងចេញពីដី, ផ្សែងបានហុយចេញពីបំពង់ផ្សែងដូចជាផ្សិត"។

ភាពរឹងមាំនៃសេដ្ឋកិច្ចរបស់អឺរ៉ុបបានបង្កើនសមត្ថភាពរបស់ពួកគេនៅក្នុងការអភិវឌ្ឍអំណាចយោធាមួយ។ ត្រឹមចុងទសវត្សរ៍ឆ្នាំ 1800 ចក្រភពអាឡឺម៉ង់បង្រួបបង្រួមមួយមានក្លាយទៅជាយក្សឧស្សាហកម្ម និងយោធាមួយ។

ការពង្រីកទៅតំបន់ផ្សេងៗទៀតនៅអឺរ៉ុប៖ នៅក្នុងទ្វីបអឺរ៉ុបទាំងមូល ក៏ដូចជានៅក្នុងប្រទេសអាឡឺម៉ង់ដែរ ឧស្សាហូបនីយកម្មអំឡុងដើមទសវត្សរ៍ឆ្នាំ 1800 បានដំណើរការនៅតាមតំបន់ ជាជាងប្រទេសទាំងមូល។ សូម្បីតែក្នុងប្រទេសមួយចំនួនដែលគ្រប់ដណ្តប់ដោយកសិកម្មក៏ដោយ បណ្តុំនៃឧស្សាហូបនីយកម្មបានរីកឡើង។ ឧទាហរណ៍ តំបន់បូហេមៀ បានអភិវឌ្ឍឧស្សាហកម្មតម្បាញមួយ។ តំបន់កាតាឡូនៀ នៅប្រទេសអេស្ប៉ាញបានផលិតកប្បាសបានច្រើនជាងប៉ែលហ្សិកទៅទៀត។ តំបន់អ៊ីតាលីភាគខាងជើង បានធ្វើយន្តកម្មការផលិតផលវាយនភ័ណ្ឌរបស់ពួកគេ ជាពិសេសតម្បាញសូត្រ។ ពួកកម្មករធ្វើការនៅក្នុងរោងចក្រនៅតំបន់នានានៅជុំវិញទីក្រុងមូស្គូ និងសង់ពីទែរប៊ើក។

នៅក្នុងប្រទេសបារាំង ការរីកចម្រើននៃឧស្សាហកម្មបានកើតមានឡើងបន្ទាប់ពីឆ្នាំ 1830។ ឧស្សាហូបនីយកម្មនៅបារាំងមានភាពយឺត និងងាយស្រួលគ្រប់គ្រងជាងតំបន់ផ្សេងៗទៀត ដោយសារតែសេដ្ឋកិច្ចដែលមកពីវិស័យកសិកម្មនៅមានកម្លាំងខ្លាំង។ ជាលទ្ធផល បារាំងបានជៀសផុតពីបញ្ហាសង្គម និងសេដ្ឋកិច្ចដែលបង្កឡើងដោយឧស្សាហូបនីយកម្ម។ ភាពជឿនលឿននៃទីផ្សារផលិតផលរបស់បារាំងបានកើតមានឡើងនៅក្នុងឆ្នាំ 1850 នៅពេលដែលរដ្ឋាភិបាលបានចាប់ផ្តើមស្ថាបនាផ្លូវដែក។ មានហេតុផលជាច្រើន ដែលប្រទេសនៅអឺរ៉ុបជាច្រើនមិនបានធ្វើឧស្សាហូបនីយកម្ម។ នៅក្នុងប្រទេសមួយចំនួន រចនាសម្ព័ន្ធសង្គមបានពន្យាពេលនៅក្នុងការទទួលយកវិធីសាស្ត្រផលិតថ្មី។ បញ្ហានៃទីតាំងភូមិសាស្ត្រក៏ជាកត្តារាំងនេះផងដែរ។ នៅក្នុងប្រទេសអូទ្រីស-ហុងគ្រី និងប្រទេសអេស្ប៉ាញ វិស័យដឹកជញ្ជូនបានចោទជាបញ្ហាយ៉ាងខ្លាំង។ ជួរភ្នំនៅប្រទេសអូទ្រីស-ហុងគ្រីមានរារាំងដល់ការស្ថាបនាផ្លូវដែក។ នៅប្រទេសអេស្ប៉ាញមានកង្វះខាងទាំងផ្លូវថ្នល់ និងផ្លូវទឹកល្អៗ។

## 3. ឥទ្ធិពលនៃឧស្សាហូបនីយកម្ម

បដិវត្តឧស្សាហកម្មបានផ្លាស់ប្តូរតុល្យភាពអំណាចនៅលើពិភពលោក។ វាបានបង្កើនការប្រគួតប្រជែងរវាងប្រទេសឧស្សាហកម្មជាមួយនឹងប្រទេសដែលក្រីក្រមានការអភិវឌ្ឍតិចតួច។

ការរីកឡើងនៃវិសមភាពសកល៖ ឧស្សាហូបនីយកម្មបានពង្រីកកម្លាតទ្រព្យសម្បត្តិរវាងប្រទេសឧស្សាហកម្មជាមួយនឹងប្រទេសមិនមែនឧស្សាហកម្ម ប៉ុន្តែវាក៏បានពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរបស់ពួកគេផងដែរ។ ដើម្បីរក្សាដំណើរការរោងចក្រ និងកម្លាំងពលកម្ម ប្រទេសឧស្សាហកម្មត្រូវការការផ្គត់ផ្គង់វត្ថុធាតុដើមជាច្រើនពីប្រទេសដែលមានការអភិវឌ្ឍតិចតួច។ ត្រឡប់មកវិញ ប្រទេសឧស្សាហកម្មទាំងនោះបានសម្លឹងឃើញប្រទេសក្រីក្រទាំងនោះគឺជាទីផ្សារសម្រាប់ផលិផលទំនិញរបស់ពួកគេ។

ចក្រភពអង់គ្លេសបាននាំមុខគេនៅក្នុងស្វែងរកដែនដីខាងក្រៅដើម្បីដាក់អាណានិគម ដើម្បីទទួលបានធនធាន និងទីផ្សារ។ បន្ទាប់មកប្រទេសនៅអឺរ៉ុបនានា, សហរដ្ឋអាមេរិក, រុស្ស៊ី, ជប៉ុនបានបន្តតាមពីក្រោយចក្រភពអង់គ្លេស ក្នុងជណ្តើមកាន់កាប់ដែនដីអាណានិគមដើម្បីទទួលបានធនធានសម្រាប់សេដ្ឋកិច្ចរបស់ពួកគេ។ ចក្រពត្តិ

និយម ជាគោលនយោបាយដែលពង្រីកអំណាចគ្រប់គ្រងរបស់ប្រទេសមួយទៅលើតំបន់ជាច្រើន, ដែលនាំឱ្យប្រទេសនោះទទួលបានអំណាច និងទ្រព្យសម្បត្តិកាន់តែច្រើនឡើងបន្ថែមពីលើអ្វីដែលពួកគេមានស្រាប់ហើយ។ ចក្រពត្តិនិយម បានបង្កើតវដ្តនៃឧស្សាហូបនីយកម្មដែលទាក់ទងទៅនឹងតម្រូវការនៃធនធានសម្រាប់ផ្គត់ផ្គង់រោងចក្រនៅអឺរ៉ុប និងការអភិវឌ្ឍទីផ្សារថ្មីនៅជុំវិញពិភពលោក។

ការផ្លាស់ប្តូរសង្គម៖ នៅរវាងឆ្នាំ 1700 ដល់ឆ្នាំ 1900 បដិវត្តកសិកម្ម, ផលិតកម្ម, គមនាគមន៍, និងទំនាក់ទំនងបានផ្លាស់ប្តូរការរស់នៅរបស់ប្រជាជននៅអឺរ៉ុបខាងលិច និងសហរដ្ឋអាមេរិក។ ឧស្សាហូបនីយកម្មបានផ្តល់ឱ្យអឺរ៉ុបនូវអំណាចសេដ្ឋកិច្ចដ៏ខ្លាំងក្លាមួយ។ ផ្ទុយទៅវិញ សេដ្ឋកិច្ចរបស់អាស៊ី និងអាហ្វ្រិកនៅតែបន្តពឹងផ្អែកលើកសិកម្ម និងរោងសិប្បកម្មតូចៗ។ ឧស្សាហូបនីយកម្មបានផ្លាស់ប្តូរទម្រង់ទាំងឡាយនៃសង្គម ចាប់តាំងពីជីវភាពរស់នៅប្រចាំថ្ងៃរហូតដល់ជីវិតសង្ឃឹមរស់។ បើទោះបីជានៅដើមដំបូងមានការលំបាកសម្រាប់កម្មករនៅក្នុងទីក្រុងក៏ដោយ ក៏ប្រជាជន, សុខភាព, និងទ្រព្យសម្បត្តិ បន្តិចម្តងៗបានកើនឡើងយ៉ាងខ្លាំងនៅក្នុងបណ្តាលប្រទេសឧស្សាហកម្ម។ ការអភិវឌ្ឍឡើងនៃវណ្ណៈកណ្តាលបង្កើតបានជាឱកាសដ៏ប្រសើរមួយសម្រាប់ការអប់រំ និងការចូលរួមបែបប្រជាធិបតេយ្យ។ គ្រឡប់មក ការចូលរួមបែបប្រជាធិបតេយ្យកាន់តែច្រើន បង្កើតឲ្យមានចលនាដ៏មានអំណាចមួយសម្រាប់ការធ្វើកំណែរទម្រង់សង្គម។

# មេរៀនទី 4 ៖ការធ្វើកំណែទម្រង់ឧស្សាហកម្មនៅលើពិភពលោក

## 1. ទស្សនៈស្តីអំពីឧស្សាហូបនីយកម្ម

ពាក្យគន្លឹះថា លៃហ្សេ ហ្វែ សំដៅទៅលើគោលនយោបាយសេដ្ឋកិច្ចមួយ ដែលអនុញ្ញាតឱ្យម្ចាស់រោងចក្រ និងអ្នកជំនួញអាចបង្កើតស្ថានភាពការងារបានដោយខ្លួនឯងដោយមិនមានការជ្រៀតជ្រែក។ គោលនយោបាយនេះផ្តោតសំខាន់ទៅលើទីផ្សារសេរីមួយ ដែលមិនមានការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល។ ពាក្យនេះមកពីភាសាបារាំង ដែលមានន័យថា "អនុញ្ញាតឱ្យធ្វើ" និងនៅក្នុងន័យពេញ "អនុញ្ញាឱ្យមនុស្សធ្វើអ្វីដែលពួកគេចង់ធ្វើ"។

សេដ្ឋកិច្ចបែប លៃហ្សេ ហ្វែ៖ សេដ្ឋកិច្ចបែប លៃហ្សេ ហ្វែ បង្កើតចេញមកពីទស្សនៈវិទូសេដ្ឋកិច្ចបារាំងនៅក្នុងអំឡុងសម័យសករាជពន្លឺ។ ពួកគេរិះគន់ទៅលើគំនិតដែលថា ប្រទេសជាតិមួយអាចបង្កើនទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈការយកពន្ធច្រើនលើទំនិញនាំចូល។ ផ្ទុយទៅវិញពួកគេទទូចថា ការកំណត់របស់រដ្ឋាភិបាលនេះគ្រាន់តែជាការជ្រៀតជ្រែកដើម្បីបង្កើនទ្រព្យសម្បត្តិប៉ុណ្ណោះរបស់ពួកគេប៉ុណ្ណោះ។ ទស្សនៈវិទូទាំងនេះជឿថា ប្រសិនបើរដ្ឋាភិបាលអនុញ្ញាតឱ្យមានពាណិជ្ជកម្មសេរី ដែលជាលំហូរនៃពាណិជ្ជកម្មនៅក្នុងទីផ្សារពិភពលោក ដោយមិនមានការកំណត់ពីរដ្ឋាភិបាល នោះសេដ្ឋកិច្ចនឹងរុងរឿង។

លោក អាដាំស្មីត៖ លោកអាដាំស្មីតជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យក្លាសកូវនៃប្រទេសស្កុតលែន លោកបានសរសេរគាំទ្រគំនិតស្តីអំពីសេដ្ឋកិច្ចសេរី ឬទីផ្សារសេរី នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា ទ្រព្យសម្បត្តជាតិ ដែលបានបោះពុម្ពនៅក្នុងឆ្នាំ 1776 ។ យោងតាមលោកស្មីត សេរីភាពនៃសេដ្ឋកិច្ចធានាដល់ដំណើរការសេដ្ឋកិច្ច។ ដូច្នេះ រដ្ឋាភិបាលមិនគួរចូលជ្រៀតជ្រែកឡើយ។ អំណះអំណាងរបស់លោកស្មីតមាននៅក្នុងអ្វីដែលលោកហៅវាថា ច្បាប់ធម្មជាតិ៣នៃសេដ្ឋកិច្ច៖

1. ច្បាប់នៃចំណូចចិត្តផ្ទាល់ខ្លួន-មនុស្សធ្វើការងារដើម្បីភាគល្អប្រសើររបស់ខ្លួនគេ។
2. ច្បាប់នៃការប្រគួតប្រជែង-ការប្រគួតប្រជែងបានជម្រុញឱ្យមនុស្សផលិតនូវផលិតផលកាន់តែប្រសើរ។
3. ច្បាប់នៃការផ្គត់ផ្គង់ និងតម្រូវការ-ទំនិញសំបូរបែប នឹងនាំឱ្យតម្លៃធ្លាក់ចុះដល់កម្រិតមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារសេដ្ឋកិច្ចមួយ។

អ្នកសេដ្ឋកិច្ចបែបមូលធននិយម៖ គំនិតសំខាន់របស់លោកស្មីតត្រូវបានគាំទ្រដោយសេដ្ឋវិទូជនជាតិអង់គ្លេសពីរូបគឺលោក ថូម៉ាស់ ម៉ាលស៊ូស និងលោក ដេវីដ រីខាដូ ។ ក៏ដូចជាគោលគំនិតរបស់លោកស្មីតដែល ពួកគេជឿថា ច្បាប់ធម្មជាតិជាអ្នកគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ច។ គំនិតសំខាន់របស់ពួកគេគឺជាមូលដ្ឋានគ្រឹះនៃ លៃហ្សេ ហ្វែ មូលធននិយម។ មូលធននិយមគឺជាប្រព័ន្ធសេដ្ឋកិច្ចមួយ ដែលកត្តានៃផលិតកម្មត្រូវបានគ្រប់គ្រងជាលក្ខណៈឯកជន ហើយលុយត្រូវបានវិនិយោគនៅក្នុងគម្រោងជំនួញដើម្បីបង្កើតប្រាក់ចំណេញ។ គំនិតនេះក៏បានជួយនាំមកនូវបដិវត្តឧស្សាហកម្មផងដែរ។

នៅក្នុងតែងសេចក្តីមួយស្តីអំពីគោលការណ៍នៃប្រជាជន ដែលសរសេរឡើងនៅក្នុងឆ្នាំ 1789 លោក ថូម៉ាស់ ម៉ាលស៊ូស បានអះអាងថាចំនួនប្រជាជននឹងកើនឡើងយ៉ាងច្រើនជាងការផ្គត់ផ្គង់ចំណីអាហារ។ ដោយគ្មានសង្គ្រាម និងជំងឺឆ្លងដែលនាំឱ្យមនុស្សស្លាប់ទេ មនុស្សភាគច្រើននឹងប្រឈមទៅនឹងភាគក្រីក្រ និងជួបការលំបាក។ ការប៉ាន់ស្មានរបស់លោក ម៉ាលស៊ូស ហាក់ដូចជាបានកើតឡើងពិតប្រាកដនៅក្នុងទសវត្សរ៍ឆ្នាំ 1840 ។ លោក ដេវីដ រីខាដូ ម្ចាស់ភាគហ៊ុនដ៏មានស្តុកស្តម្ភមួយរូបបានប្រើប្រាស់ទ្រឹស្តីរបស់លោក ម៉ាលស៊ូស និងបានឈានទៅមុខមួយជំហានទៀត នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា គោលការណ៍នៃនយោបាយសេដ្ឋកិច្ច និងពន្ធដារ(1817)។ ក៏ដូចជាលោក ម៉ាលស៊ូស ដែរ លោក រីខាដូ ជឿថា ពួកវណ្ណៈក្រោមគេតែងតែក្រីក្រជានិច្ច។ នៅក្នុងប្រព័ន្ធទីផ្សារមួយ ប្រសិនបើមានកម្មករច្រើន និងធនធានច្រើនពេក ពេលនោះកម្លាំងពលកម្ម និងធនធាននឹងមានតម្លៃថោក។ ប្រសិនបើមានកម្មករ និងធនធានតិចតួច នៅពេលនោះវានឹងមានតម្លៃថ្លៃ។ លោក រីខាដូ ជឿថាប្រាក់ម៉ោងនឹងធ្លាក់ចុះនៅពេលដែលចំនួនប្រជាជនកើនឡើង។ ទស្សនៈវិទូ លៃហ្សេ ហ្វ៊ែ នានាដូចជាលោកស្មីត, លោក ម៉ាលស៊ូស, និងលោក រីខាដូ បានប្រឆាំងទៅនឹងការព្យាយាមរបស់រដ្ឋាភិបាលក្នុងការជួយកម្មករក្រីក្រ។ ពួកគេគិតថា ការបង្កើតច្បាប់ប្រាក់ម៉ោងអប្បបរមា និងស្ថានភាពការងារល្អប្រសើរនឹងបះពាល់ដល់ប្រព័ន្ធទីផ្សារសេរីនាំឱ្យទទួលបានប្រាក់ចំណូលទាប, និងធ្វើឱ្យចុះអន់ថយដល់ការបង្កើតទ្រព្យសម្បត្តិនៅក្នុងសង្គម។

## 2. ការរីកឡើងនៃសង្គមនិយម

ផ្ទុយទៅនឹងទស្សនៈ លៃហ្សេ ហ្វ៊ែ ដែលបានណែនាំឱ្យរដ្ឋាភិបាលមិនត្រូវជ្រៀតជ្រែកនៅក្នុងការងារជំនួញ អ្នកបង្កើតទ្រឹស្តីផ្សេងទៀតបានជឿថា រដ្ឋាភិបាលគួរតែចូលអន្តរាគមន៍។ ក្រុមទស្សនៈវិទូទាំងនេះជឿថា អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬរដ្ឋាភិបាលគួរតែធ្វើសកម្មភាពនានាដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់មនុស្សកាន់តែប្រសើរ។

ផលប្រយោជន៍និយម៖ ទស្សនៈវិទូជនជាតិអង់គ្លេសមួយរូបឈ្មោះ ជេរ៉េមី បេនថាម បានកែប្រែគោលគំនិតរបស់លោក អាដាំ ស្មីត ។ នៅចុងទសវត្សរ៍ឆ្នាំ 1700 លោក បេនថាម បានបង្កើតទ្រឹស្តីទស្សនៈវិជ្ជាមួយស្តីអំពីផលប្រយោជន៍និយម។ លោក បេនថាម បានសរសេរស្នាដៃដ៏មានឥទ្ធផលមួយរបស់លោកនៅចុងទសវត្សរ៍ឆ្នាំ 1700 ។ យោងតាមទ្រឹស្តីរបស់លោក បេនថាម មនុស្សទាំងឡាយគួរតែត្រូវបានគេវិនិច្ឆ័យថាតើគំនិត, ការចាត់ចែង, និងសកម្មភាពរបស់ពួកគេ មានប្រយោជន៍ ឬមានតម្លៃដែរឬទេ។ លោកបានទទូចថា រដ្ឋាភិបាលគួរតែព្យាយាមនៅក្នុងការលើកកម្ពស់ឱ្យបានល្អប្រសើរបំផុតដល់មនុស្សនានា។ គោលនយោបាយរបស់រដ្ឋាភិបាលមានអត្ថប្រយោជន៍នៅពេលណាដែលវាបានលើកកម្ពស់ដល់គោលបំណងនេះ។ លោក បេនថាម ជឿថាជាទូទៅបុគ្គលនីមួយៗ គឺតែស្វែងរកបានដោយសេរីនូវអត្ថប្រយោជន៍របស់ពួកគេដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាល។ លោក ចន ស្តូតមីល ដែលជាទស្សនៈវិទូ និងសេដ្ឋវិទូ បានដឹកនាំចលនាដើម្បីអត្ថប្រយោជន៍នៅក្នុងទសវត្សរ៍ឆ្នាំ 1800 ។ លោក មីល ចាប់ផ្តើមចោទសួរអំពីការមិនជ្រៀតជ្រែកចំពោះមូលធននិយម។ លោកជឿថា វាគឺជាកំហុសមួយដែលថា កម្មករគួរតែទុកឱ្យរស់នៅក្នុងភាពក្រីក្រ ដែលពេលខ្លះស្ថិតនៅក្នុងភាពអត់ឃ្លាន។ លោក មីល ប្រាថ្នាចង់ជួយកម្មករសាមញ្ញទាំងនោះជាមួយនឹងគោលនយោបាយ ថានឹងនាំទៅដល់ការបែងចែកប្រាក់ចំណេញឱ្យស្មើភាពគ្នា។ លោក

ក៏ចាប់អារម្មណ៍ជាមួយនឹងប្រព័ន្ធកសិកម្មបែបសហករណ៍មួយ និងសិទ្ធិរបស់ស្ត្រី ដោយរួមបញ្ចូលទាំងសិទ្ធិនៅក្នុងការបោះឆ្នោតផង។ លោកបានស្នើឱ្យរដ្ឋាភិបាលលុបបំបាត់គម្លាតកាន់តែខ្ពស់នៃទ្រព្យសម្បត្តិ។ ពួកអត្ថប្រយោជន៍និយមក៏បានរុញច្រានឱ្យមានការធ្វើកំណែទម្រង់នៅក្នុងប្រព័ន្ធច្បាប់ និងពន្ធនាគារ និងការអប់រំ។

សុខក្សេមក្សាន្តនិយម៖ អ្នកធ្វើកំណែទម្រង់មួយចំនួនបានប្រើប្រាស់នូវយុទ្ធសាស្ត្រកាន់តែមានប្រសិទ្ធិភាពមួយ។ តក់ស្លុតដោយភាពវេទនា និងភាពក្រីក្ររបស់ពួកវណ្ណៈកម្មករ ម្ចាស់កម្មសិទ្ធិរោងចក្រជនជាតិអង់គ្លេសមួយរូបឈ្មោះ រ៉ូប៊ីត អូវេន បានបង្កើនស្ថានភាពការងារឱ្យបានល្អប្រសើរសម្រាប់និយោជិករបស់លោក។ នៅជិតរោងចក្រផលិតសសៃអម្បោះកម្បាសរបស់លោកនៅ ញូ ឡាណាក ប្រទេសស្កុតលែន លោក អូវេន បានស្ថាបនាផ្ទះជាច្រើន ដែលលោកបានជួលក្នុងតម្លៃថោកដល់កម្មករ។ លោកបានហាមឃាត់មិនឱ្យកុមារដែលមានអាយុ 10 ឆ្នាំធ្វើការនៅក្នុងរោងចក្រសសៃអម្បោះរបស់លោកឡើយ ហើយលោកបានផ្តល់ឱ្យពួកគេនូវការសិក្សាដោយមិនគិតថ្លៃ។ បន្ទាប់មក នៅក្នុងឆ្នាំ 1824 លោកបានធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិក។ លោកបានបង្កើតសហគមន៍រួមមួយដែលមានឈ្មោះថា សុខដុមថ្មី នៅអ៊ីនដៀណា នៅក្នុងឆ្នាំ 1825 ។ លោកបានប្រើក្លាយសហគមន៍នេះឱ្យក្លាយជាសហគមន៍ក្សេមក្សាន្ត ឬកន្លែងរស់នៅដែលមានភាពល្អឥតខ្ចោះមួយ។ សហគមន៍សុខដុមថ្មីមានវត្តមានបានតែ 3 ឆ្នាំប៉ុណ្ណោះ ប៉ុន្តែវាបានជម្រុញឱ្យមានការបង្កើតសហគមន៍ដទៃទៀត។

សង្គមនិយម៖ អ្នកកំណែទម្រង់និយមជនជាតិបារាំងមួយចំនួនដូចជាលោក ហ្វ្រាល ហ្វូរីយេ, លោក សេន-ស៊ីម៉ុន, និងអ្នកមួយចំនួនទៀតបានសម្លឹងទៅរកលុបបំបាត់នូវឥទ្ធិពលអាក្រក់ដែលកើតចេញមកពីឧស្សាហូបនីយកម្មតាមរយៈប្រព័ន្ធសេដ្ឋកិច្ចថ្មីមួយដែលហៅថាសង្គមនិយម។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសង្គមនិយម កត្តានៃផលិតកម្មកាន់កាប់ដោយសាធារណៈជន ហើយរាល់ប្រតិបត្តិការទាំងឡាយត្រូវបម្រើឱ្យសុខុមាលភាពរបស់ប្រជាជនទាំងអស់។

សង្គមនិយមបានបង្កើតគំនិតសុទិដ្ឋិនិយមមួយអំពីធម្មជាតិនៃមនុស្ស, ជំនឿលើភាពជឿនលឿន, និងខ្វល់ខ្វាយអំពីយុត្តិធម៌សង្គម។ អ្នកសង្គមនិយមបានទទូចថា រដ្ឋាភិបាលគួរតែរៀបចំគម្រោងសេដ្ឋកិច្ចមួយជាជាងពឹងផ្អែកលើទីផ្សេងសេរីបែបមូលធននិយម។ ពួកគេទទូចថា នៅពេលដែលរដ្ឋាភិបាលត្រួតត្រាលើរោងចក្រ, អណ្តូងរ៉ែ, ផ្លូវដែក, និងឧស្សាហកម្មសំខាន់ៗនានា នោះភាពក្រីក្រនឹងត្រូវបញ្ចប់ ហើយសមភាពនឹងត្រូវលើកកម្ពស់ផងដែរ។ ពួកគេជឿថា ការកាន់កាប់ជាសាធារណៈ នឹងជួយដល់កម្មករនានា ដែលនឹងទទួលបានការប្រោសប្រណីពីសំណាក់និយោជក់របស់ពួកគេ។ អ្នកសង្គមនិយមមួយចំនួនដូចជាលោកល្វី ប្លង់ បានតស៊ូមតិឱ្យមានការផ្លាស់ប្តូរតាមរយៈការលើកកម្ពស់សិទ្ធិនៅក្នុងការបោះឆ្នោត។

### 3. ម៉ាក្សនិយម៖សង្គមនិយមជ្រុល

ស្នាដៃនិពន្ធនានារបស់អ្នកការសែតជនជាតិអាឡឺម៉ង់ម្នាក់ឈ្មោះ កាលម៉ាក្ស បានបង្ហាញពិភពលោកនូវប្រភេទនៃសង្គមនិយមជ្រុលមួយដែលហៅថាម៉ាក្សនិយម។ លោកម៉ាក្ស និងលោក ហ្វ្រេឌ្រិច អេនហ្គែល ដែលជាជនជាតិអាឡឺម៉ង់ ដែលមានឪពុកជាម្ចាស់កម្មសិទ្ធិរោងចក្រសសៃអម្បោះមួយនៅទីក្រុងមេនចេស្ទ័រ បានពង្រាងគំនិតរបស់ពួកគេនៅក្នុងចុល្លលិខិតមួយដែលមានកម្រាស់ 23 ទំព័រ មានចំណងជើងថា សេចក្តីប្រកាសកុំម្មុយនីស្ត។

នៅក្នុងបណ្ណ សេចក្តីប្រកាសកុំម្មុយនីស្ត របស់ពួកគេ លោកម៉ាក្ស និងលោកអេនហ្គេល បានទទូចថា សង្គមមនុស្សតែងតែត្រូវបានបែងចែកទៅជាវណ្ណៈនានាដែលប្រយុទ្ធប្រឆាំងជាមួយគ្នា។ វណ្ណៈទាំងនោះមាន វណ្ណៈកណ្តាល "អ្នកមាន" ឬនិយោជក ដែលគេហៅថា វណ្ណៈគហិបតី និងវណ្ណៈ "អ្នកក្រ" ឬកម្មករ ដែលគេហៅថា វណ្ណៈពលជីព។ ខណៈពេលដែលពួកអ្នកមានទ្រព្យសម្បត្តិត្រួតត្រាលើប្រាក់ចំណូលបានមកពីផលិតផល អ្នកក្រីក្រអនុវត្តការងារយ៉ាងពិបាក និងស្ថិតនៅក្នុងស្ថានភាពដ៏គ្រោះថ្នាក់។ ដែលស្ថានការណ៍នេះនាំទៅដល់ជម្លោះ។

សេចក្តីប្រកាសកុំម្មុយនីស្ត(1848) របស់កាលម៉ាក្ស និងហ្វ្រេឌ្រិច អេនហ្គេលៈ យោងតាមលោកម៉ាក្ស និងលោកអេនហ្គេល បដិវត្តឧស្សាហកម្មបានបង្កើនទ្រព្យសម្បត្តិដល់អ្នកមាន និងធ្វើឱ្យអ្នកក្រកាន់តែក្រីក្រ។ អ្នកនិពន្ធទាំងពីរបានព្យាករណ៍ថា កម្មករនឹងយកជ័យជំនះលើថៅកែ៖ "ពួកពលជីពមិនមានអ្វីដែលត្រូវបាត់បង់ទេ ប៉ុន្តែពួកគេមានបណ្តាញ។ ពួកគេមានពិភពលោកមួយដើម្បីយកជ័យជំនះ។ កម្មករនៅគ្រប់ប្រទេសទាំងអស់នឹងធ្វើការបង្រួបបង្រួមគ្នា។

អនាគតកាលយោងតាមម៉ាក្ស៖ ម៉ាក្សជឿថា ប្រព័ន្ធមូលធននិយម ដែលបង្កើតបដិវត្តឧស្សាហកម្មបន្តិចម្តងៗ នឹងកម្ទេចខ្លួនឯងដោយមូលហេតុមួយចំនួន។ រោងចក្រនឹងធ្វើឱ្យសិប្បកម្មតូចៗបិទទ្វា ដោយបន្សល់ទុកនូវម្ចាស់រោងចក្រមួយចំនួនតូចគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់។ ពួកពលជីពជាច្រើននឹងធ្វើការបះបោរ ដណ្តើមកាន់កាប់រោងចក្រពីពួកមូលធននិយម ហើយពួកកម្មករទាំងនោះនឹងផលិតនូវអ្វីដែលសង្គមត្រូវការ។ ការចែករំលែកប្រាក់ចំណេញដល់កម្មករ នឹងនាំមកនូវសមភាពនៃសេដ្ឋកិច្ចសម្រាប់មនុស្សទាំងអស់គ្នា។ កម្មករនឹងត្រួតត្រារដ្ឋាភិបាលនៅក្នុងទម្រង់ "អំណាចផ្តាច់ការរបស់ពលជីព"។ បន្ទាប់ពីការរស់នៅ និងរៀនសូត្រជាសហករណ៍ រដ្ឋ ឬរដ្ឋាភិបាលនឹងបាត់បង់សារៈសំខាន់ ហើយវណ្ណៈសង្គមមួយនឹងអភិវឌ្ឍឡើង។ ម៉ាក្សបានហៅជំហានចុងក្រោយនេះថា កុំម្មុយនីស្តបរិសុទ្ធ។ ម៉ាក្សបានពិពណ៌នា កុំម្មុយនីស្តថាជាទម្រង់នៃសង្គមនិយមពេញលេញមួយ ដែលធនធានផលិតកម្ម-ដីធ្លីទាំងអស់, អណ្តូងរ៉ែ, រោងចក្រ, ផ្លូវដែក, និងជំនួញ និងត្រូវកាន់កាប់ដោយប្រជាជន។ ទ្រព្យសម្បត្តិឯកជននឹងត្រូវលុបបំបាត់ទាំងស្រុង។ រាល់ទំនិញ និងសេវាកម្មទាំងអស់នឹងត្រូវចែករំលែកស្មើៗគ្នា។ បោះពុម្ពនៅក្នុងឆ្នាំ 1848 សេចក្តីប្រកាសកុំម្មុយនីស្ត បានបង្កើតលទ្ធផលរយៈពេលខ្លីមួយចំនួន។ តាមរយៈការរីកសាយភាយនៃការបះបោរដែលកើតមានឡើងនៅអឺរ៉ុបនៅអំឡុងឆ្នាំ 1848 ដល់ 1849 មេដឹកនាំអឺរ៉ុបនានាបន្តិចម្តងៗបានបង្ក្រាបការបះបោរនេះ។ មួយសតវត្សរ៍ក្រោយមកទើបសេចក្តីប្រកាសរបស់ម៉ាក្សបង្កើតបានជាលទ្ធផលដ៏ធំមួយ។ នៅក្នុងទសវត្សរ៍ឆ្នាំ 1900 ម៉ាក្សនិយមបានបង្កើតឱ្យមានបដិវត្តនានា ក្នុងនោះមានដូចជា បដិវត្តរបស់លេនីននៅប្រទេសរុស្ស៊ី, បដិវត្តរបស់ម៉ៅសេងទុងនៅប្រទេសចិន, និងបដិវត្តរបស់ហ្វីដែលកាស្ត្រូនៅប្រទេសកុយបាជាដើម។ មេដឹកនាំទាំងអស់នេះបានកែប្រែជំនឿរបស់ម៉ាក្សឱ្យត្រូវទៅនឹងស្ថានការណ៍ និងតម្រូវការរបស់ពួកគេ។ នៅក្នុងសេចក្តីប្រកាសកុំម្មុយនីស្ត លោកម៉ាក្ស និងអេនហ្គេល បានបង្ហាញពីជំនឿរបស់ពួកគេថា មានតែកម្លាំងសេដ្ឋកិច្ចតែមួយគត់គឺជាអ្នកគ្របដណ្តប់លើសង្គម។ ប៉ុន្តែ ពេលវេលាធ្លាប់បានបង្ហាញថា សាសនា, ជាតិនិយម, ភក្តីភាពរបស់ជាតិពន្ធុ, និងចំណូលចិត្តនៃការធ្វើកំណែទម្រង់បែបប្រជាធិបតេយ្យមួយអាចនឹងជះឥទ្ធិពលយ៉ាងខ្លាំងលើសង្គមដូចជាកម្លាំងសេដ្ឋកិច្ចដែរ។ ជាងនេះទៅទៀត គម្លាតរវាងអ្នកមាន និងអ្នកក្រនៅក្នុងប្រទេសឧស្សាហកម្មទាំង

ឡាយមិនបានកើនឡើងដូចអ្វីដែលម៉ាក្ស និងបានព្យាករណ៍ឡើយ ភាគច្រើនដោយសារតែមានការធ្វើកំណែរទម្រង់មួយចំនួនរបស់រដ្ឋាភិបាល។

### 4. សហជីពការងារ និងច្បាប់កំណែទម្រង់

កម្មកររោងចក្រប្រឈមទៅនឹងការធ្វើការងារច្រើនម៉ោង ស្ថានភាពកាងារដែលកង្វក់ និងមានគ្រោះថ្នាក់ និងការប្រឈមទៅនឹងការបញ្ឈប់ពីការងារ។ ត្រឹមទសវត្សរ៍ឆ្នាំ 1800 ពួកកម្មករបានក្លាយទៅជាជនសកម្មនៅក្នុងនយោបាយ។ ដើម្បីរុញច្រានឱ្យមានការធ្វើកំណែទម្រង់ កម្មករបានរួបរួមគ្នានៅក្នុងសមាគមន៍ការងារស្ម័គ្រចិត្តដែលគេហៅថា សហជីព។

ការបង្កើតសហជីព៖ សហជីពមួយគឺតំណាងឱ្យកម្មករទាំងឡាយនៅក្នុងវិស័យពាណិជ្ជកម្មជាក់លាក់ណាមួយ។ សហជីពចូលរួមនៅក្នុងការទាមទារ និងធ្វើការចរចារជាសមូហភាព រវាងកម្មករ និងនិយោជករបស់ពួកគេ។ ពួកគេទាមទារឱ្យមានស្ថានភាពការងារល្អប្រសើរ និងការដំឡើងប្រាក់ម៉ោង។ ប្រសិនបើម្ចាស់រោងចក្របដិសេធទៅនឹងការទាមទារទាំងនោះ សមាជិករបស់សហជីពនិងធ្វើកូដកម្ម ឬបដិសេធនៅក្នុងការធ្វើការងារ។ កម្មករជំនាញបាននាំមុខគេនៅក្នុងការបង្កើតជាសហជីព ដោយសារជំនាញពិសេសរបស់ពួកគេបានផ្តល់ឱ្យពួកគេនូវអំណាចបន្ថែមក្នុងការទាមទារ។ អ្នកគ្រប់គ្រងរោងចក្រ មានភាពលំបាកនៅក្នុងការផ្លាស់ប្តូរកម្មករជំនាញដែលមានដូចជា ជាងឈើ, អ្នកបោះពុម្ភ, និងអ្នករវៃ។ ដូច្នេះ សហជីពដំបូងបំផុតបានជួយដល់វណ្ណៈកណ្តាលកម្រិតទាបច្រើនជាងជួយវណ្ណៈកម្មករក្រីក្រ។ ចលនាសហជីពវិវត្តទៅមុខយឺតៗ រីកចម្រើនតិចតួចនៅទាំងចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ អស់រយៈពេលច្រើនឆ្នាំ រដ្ឋាភិបាលអង់គ្លេសបានបដិសេធសិទ្ធិកម្មករនៅក្នុងការបង្កើតសហជីព។ រដ្ឋាភិបាលចាត់ទុកសហជីពថាជាការគំរាមកំហែងមួយដល់សណ្តាប់ធ្នាប់ និងស្ថេរភាពសង្គម។ ជាងនេះទៅទៀត ច្បាប់នៃការរួមបញ្ជូលគ្នានៅក្នុងឆ្នាំ 1799 និងឆ្នាំ 1800 បានប្រកាសថាការបង្កើតសហជីព និងការធ្វើកូដកម្មគឺជារឿងខុសច្បាប់។ ដោយមិនភ័យខ្លាចចំពោះការចាប់ដាក់គុក ឬបាត់បង់ការងារ កម្មកររោងចក្រនៅតែបន្តចូលរួមជាមួយសហជីព។ ចុងក្រោយសភាតំណាងរាស្ត្របានសម្រេចលុបច្បាប់នៃការរួបបញ្ជូលគ្នាចោលនៅក្នុងឆ្នាំ 1824 ។ បន្ទាប់ពីឆ្នាំ 1825 រដ្ឋាភិបាលអង់គ្លេសបានអនុគ្រោះទាំងមិនសប្បាយចិត្តដល់សហជីព។

សហជីពទាំងឡាយនៅអង់គ្លេសមានគោលបំណងរួមមួយនៅក្នុងការបង្កើនប្រាក់ម៉ោង និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពការងារដល់សមាជិកទាំងឡាយរបស់ពួកគេ។ ត្រឹមឆ្នាំ 1875 សហជីពពាណិជ្ជកម្មនៅអង់គ្លេសបានទទួលបានសិទ្ធិនៅក្នុងការធ្វើកូដកម្ម និងបាតុកម្មដោយសន្តិភាព។ ពួកគេក៏បានបង្កើនសមាជិករហូតទៅដល់ជិតមួយលាននាក់។

នៅក្នុងសហរដ្ឋអាមេរិក កម្មករជំនាញបានរួបរួមគ្នាទៅជាសហជីពចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ 1800 មកម្ល៉េះ។ នៅក្នុងឆ្នាំ 1886 សហជីពមួយចំនួនបានរួមបញ្ជូលគ្នាដើម្បីបង្កើតទៅជាអង្គការមួយដែលក្រោយមកបានក្លាយជាសហព័ន្ធការងារអាមេរិក។ ជោគជ័យនៃការធ្វើកូដកម្មមួយចំនួនបានធ្វើឲ្យសមាជិករបស់សហព័ន្ធការងារអាមេរិកទទួលបានការតំឡើងប្រាក់ម៉ោងច្រើនជាងមុន និងកាត់បន្ថយចំនួនម៉ោងធ្វើការ។

ច្បាប់កំណែទម្រង់៖ បន្តិចម្តងៗ អ្នកធ្វើកំណែទម្រង់ និងសហជីពបានបង្ខំឱ្យមេដឹកនាំនយោបាយពិនិត្យមើលលើឥទ្ធិពលអាក្រក់នានាដែលបណ្តាលមកពីឧស្សាហូបនីយកម្ម។ ទាំងនៅចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ច្បាប់ថ្មីៗមួយចំនួនបានធ្វើកំណែទម្រង់បញ្ហាមួយចំនួនដែលរងឥទ្ធិពលមកពីឧស្សាហូបនីយកម្ម។ ឧទាហរណ៍ នៅក្នុងទសវត្សរ៍ឆ្នាំ 1820 និង 1830 សភាតំណាងរាស្ត្របានចាប់ផ្តើមស៊ើបអង្កេតលើពលកម្មកុមារ និងស្ថានភាពការងារនៅក្នុងរោងចក្រ និងអណ្តូងរ៉ែ។ ជាលទ្ធផល បន្ទាប់ពីការរកឃើញរបស់ពួកគេ សភាតំណាងរាស្ត្របានអនុម័តច្បាប់រោងចក្រនៅក្នុងឆ្នាំ 1833 ។ ច្បាប់ថ្មីនេះបានចាត់ទុកការជួលកុមារដែលមានអាយុក្រោម 9 ឆ្នាំឱ្យធ្វើការងារគឺជារឿងខុសច្បាប់។ កុមារដែលមានអាយុចាប់ពី 9 ឆ្នាំ ដល់ 12 ឆ្នាំមិនអាចធ្វើការលើសពី 8 ម៉ោងក្នុងមួយថ្ងៃបានទេ។ មនុស្សពេញវ័យដែលមានអាយុចាប់ពី 13 ឆ្នាំ ដល់ 17 ឆ្នាំមិនអាចធ្វើការលើសពី 12 ម៉ោងក្នុងមួយថ្ងៃបានទេ។ នៅក្នុងឆ្នាំ 1842ច្បាប់អណ្តូងរ៉ែ ការពារមិនឱ្យស្ត្រី និងកុមារធ្វើការងារនៅក្រោមដីឡើយ។ នៅក្នុងឆ្នាំ 1847 សភាតំណាងរាស្ត្របានអនុម័តច្បាប់មួយដែលជួយដល់ស្ត្រីក៏ដូចជាកូនរបស់ពួកគេ។ ច្បាប់ 10 ម៉ោង ដែលអនុម័តនៅក្នុងឆ្នាំ 1847 បានកម្រិតចំនួនម៉ោងធ្វើការងាររបស់ស្ត្រី និងកុមារនៅក្នុងរោងចក្រ មកនៅត្រឹម 10 ម៉ោងក្នុងមួយថ្ងៃ។ អ្នកធ្វើកំណែទម្រង់នៅក្នុងសហរដ្ឋអាមេរិកក៏បានអនុម័តច្បាប់នានាដើម្បីការងារដល់កម្មករកុមារ។ នៅក្នុងឆ្នាំ 1904 ក្រុមអ្នកធ្វើកំណែទម្រង់ជឿនលឿនមួយបានរៀបចំគណៈកម្មាធិការជាតិការងារកុមារដើម្បីបញ្ចប់ពលកម្មកុមារ។ ទទូចថា ពលកម្មកុមារនាំឱ្យកម្មករទាំងឡាយទទួលបានប្រាក់ម៉ោងទាប សហជីពបានចូលរួមនៅក្នុងការធ្វើកំណែទម្រង់នេះ។ ដោយរួមគ្នា ពួកគេបានដាក់សម្ពាធដល់អ្នកនយោបាយថ្នាក់ជាតិ និងថ្នាក់រដ្ឋឱ្យហាមឃាត់ពលកម្មកុមារ និងកម្រិតម៉ោងការងារអប្បបរមា។ នៅក្នុងឆ្នាំ 1919 ថៅក្រមកំពូលរបស់សហរដ្ឋអាមេរិកបានប្រឆាំងទៅនឹងច្បាប់ពលកម្មកុមាររបស់សហព័ន្ធ ដោយបានអះអាងថាវាបានជ្រៀតជ្រែកទៅក្នុងសិទ្ធិរបស់រដ្ឋនានាក្នុងការគ្រប់គ្រងការងារ។ ប៉ុន្តែ រដ្ឋមួយចំនួនបានអនុញ្ញាតឱ្យមានការកម្រិតម៉ោងធ្វើការងាររបស់ស្ត្រី និងក្រោយមកសម្រាប់បុរស។

## 5. ចលនាកំណែទម្រង់រីកសាយភាយ

ចាប់តាំងពីដើមដំបូងមក ចលនាកំណែទម្រង់បានរីកឡើងដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលអវិជ្ជមាននៃឧស្សាហូបនីយកម្ម។ កំណែទម្រង់ទាំងនេះរួមមាន ការធ្វើឱ្យប្រសើរឡើងនៅកន្លែងធ្វើការងារ និងពង្រីកសិទ្ធិនៅក្នុងការបោះឆ្នោតដល់វណ្ណៈកម្មករបុរស។ ជាមួយគ្នានោះមានកម្លាំងរុញច្រានមួយបានកើតឡើងអមជាមួយនឹងការធ្វើកំណែទម្រង់ គឺបដិវត្តនៅបារាំង ដែលវាក៏បានជួយដល់ការបញ្ចប់នូវរបបទាសភាព និងលើកកម្ពស់សិទ្ធិស្ត្រី និងកុមារ។

ការបោះបង់របបទាសភាព៖ លោក វិលលៀម វីលប័រហ្វស ដែលជាមន្ត្រីជាន់ខ្ពស់មួយរូបនៅក្នុងសាសនា និងជាសមាជិកមួយរូបនៅក្នុងសភាតំណាងតរាស្ត្របានដឹកនាំការទាមទារឱ្យមានការបោះបង់ និងការបញ្ចប់នូវពាណិជ្ជកម្មទាសករ និងរបបទាសភាពនៅក្នុងចក្រភពអង់គ្លេស។ សភាតំណាងរាស្ត្របានអនុម័យច្បាប់មួយដើម្បីបញ្ចប់ការធ្វើពាណិជ្ជកម្មទាសករនៅក្នុងដែនដីឥណ្ឌាខាងលិចរបស់ចក្រភពអង់គ្លេសនៅក្នុងឆ្នាំ 1807 ។

បន្ទាប់ពីលោកចូលនិវត្តន៍ពីសភាតំណាងរាស្ត្រនៅក្នុងឆ្នាំ 1825 លោក វីលប័រហ្វស បានបន្តការប្រយុទ្ធប្រឆាំងរបស់លោកដើម្បីផ្តល់សេរីភាពដល់ទាសករ។ ចុងក្រោយចក្រភពអង់គ្លេសបានបោះបង់របបទាសភាពនៅក្នុងដែនដីចក្រភពរបស់ពួកគេនៅក្នុងឆ្នាំ 1833 ។ សកម្មជនប្រឆាំងរបបទាសភាពអង់គ្លេសបានបំណងផ្សេងៗគ្នានៅក្នុងការទាមទារឱ្យមានការបោះបង់របបទាសភាពនេះ។ អ្នកមួយចំនួន ដែលជាលោក វីលប័រហ្វស ជាដើម មានបំណងប្រឆាំងជាមួយរបបទាសភាព។ អ្នកមួយចំនួនទៀតយល់ឃើញថាពលកម្មរបស់ទាសករគឺជាការគំរាមកំហែងដល់សេដ្ឋកិច្ច។ ម្យ៉ាងទៀត វណ្ណៈឧស្សាហករថ្មីមួយបានអភិវឌ្ឍឡើង ដែលពួកគេគាំទ្រដល់ពលកម្មតម្លៃថោកជាងពលកម្មទាសករ។ ពួកគេភ្លាមៗនោះទទួលបានអំណាចនៅក្នុងសភាតំណាងរាស្ត្រ។ នៅក្នុងសហរដ្ឋអាមេរិកចលនាទាមទារឲ្យមានការអនុវត្តនូវកិច្ចសន្យាបញ្ចប់របបទាសភាព ដែលមាននៅក្នុងសេចក្តីប្រកាសឯករាជ្យ បានរីកឡើងនៅដើមទសវត្សរ៍ឆ្នាំ 1800 ។ ការចាប់ប្រជាជនអាហ្វ្រិកធ្វើជាទាសករបានបញ្ចប់នៅក្នុងសហរដ្ឋអាមេរិកនៅពេលដែលពួកសហព័ន្ធបានទទួលជ័យជំនះលើសង្គ្រាមស៊ីវិលនៅក្នុងឆ្នាំ 1865 ។ ពេលនោះ របបទាសភាពនៅទ្វីអាមេរិកមាននៅសល់តែតំបន់ផ័រតូ រីកូ, គុយបា, និងប្រេស៊ីលតែប៉ុណ្ណោះ។ នៅក្នុងប្រទេសផ័រតូ រីកូ របបទាសភាពបានបញ្ចប់នៅក្នុងឆ្នាំ 1873 , ពួកអេស្ប៉ាញចុងក្រោយបានបោះបង់ចោលរបបទាសភាពនៅដែនដីអាណានិគមគុយបារបស់ពួកគេនៅក្នុងឆ្នាំ 1886 ។ រហូតមកដល់ឆ្នាំ 1888 ប្រជាជនដែលភាគច្រើនជាទាសករនៅប្រេស៊ីលទទួលបានសេរីភាព។

ការប្រយុទ្ធដើម្បីសិទ្ធិស្ត្រី៖ បដិវត្តឧស្សាហកម្ម បានផ្តល់នូវផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានដល់ស្ត្រី។ នៅក្នុងផលប៉ះពាល់វិជ្ជមាន ការធ្វើការងារនៅក្នុងរោងចក្រទទួលបានប្រាក់ម៉ោងខ្ពស់ជាងការធ្វើការងារនៅផ្ទះ។ ឧទាហរណ៍ ស្ត្រីអ្នកវៃនៅក្នុងទីក្រុងមេនឆេស្ទ័ ទទួលបានប្រាក់ច្រើនជាងស្ត្រីដែលធ្វើការនៅក្នុងផ្ទះដើម្បីវៃសសៃអម្បោះកម្បាស។ ផ្ទុយទៅវិញ កម្មកររោងចក្រដែលជាស្ត្រី ជាទូទៅទទួលបានប្រាក់តែ 1/3 នៃចំនួនប្រាក់ដែលកម្មករបុរសទទួលបានប៉ុណ្ណោះ។

ស្ត្រីបានដឹកនាំចលនាកំណែទម្រង់ដើម្បីដោះស្រាយបញ្ហានេះ និងបញ្ហាផ្សេងៗទៀតនៅក្នុងសង្គម។ ឧទាហរណ៍ អំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 ស្ត្រីបានបង្កើតសហជីពពាណិជ្ជកម្ម ដែលអ្នកធ្វើការក្នុងវិស័យនេះភាគច្រើនគឺជាស្ត្រី។ នៅក្នុងចក្រភពអង់គ្លេស ស្ត្រីមួយចំនួនបានបម្រើការងារជាអ្នកត្រួតពិនិត្យសុវត្ថិភាពនៅក្នុងរោងចក្រដែលជាទីកន្លែងដែលស្ត្រីធ្វើការ។ នៅក្នុងសហរដ្ឋអាមេរិក ស្ត្រីដែលសិក្សានៅមហាវិទ្យាល័យ ដូចជា ជេន អាដាំបានបើកដំណើរការផ្ទះដួល។ មជ្ឈមណ្ឌលសហគមន៍ទាំងនេះបម្រើដល់ប្រជាជនក្រីក្រ។ ទាំងនៅសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ស្ត្រីដែលបានចូលរួមនៅក្នុងការទាមទារឱ្យមានការបោះបង់ចោលនូវរបបទាសភាព បានចាប់ផ្តើមចោទជាសំណួរថា ហេតុអ្វីបានជាសិទ្ធិរបស់ពួកគេត្រូវបានបដិសេធដោយផ្អែកទៅលើភេទទៅវិញ។ ចលនាដើម្បីសិទ្ធិស្ត្រីចាប់ផ្តើមឡើងនៅសហរដ្ឋអាមេរិកនៅដើមឆ្នាំ 1848 ។ ស្ត្រីដែលជាសកម្មជននៅជុំវិញពិភពលោកបានរួបរួមគ្នាបង្កើតជា ក្រុមប្រឹក្សាអន្តរជាតិសម្រាប់ស្ត្រី នៅក្នុងឆ្នាំ 1888 ។ មានគណៈប្រតិភូ និងអ្នកអង្កេតការមកពីប្រទេសចំនួន 27 បានចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សានេះនៅក្នុងឆ្នាំ 1899 ។

កំណែទម្រង់បានរីកសាយភាយទៅដល់ផ្នែកផ្សេងៗទៀតនៃជីវភាពរស់នៅ៖ នៅក្នុងសហរដ្ឋអាមេរិក និងអឺរ៉ុបខាងលិច អ្នកធ្វើកំណែទម្រង់បានព្យាយាមនៅក្នុងការកែប្រែបញ្ហានានាដែលកើតមាននៅក្នុងប្រទេសឧស្សាហកម្មថ្មី។ កំណែទម្រង់លើការអប់រំសាធារណៈ និងពន្ធនាគារស្ថិតនៅក្នុងបញ្ជីដំបូងនៃការធ្វើកំណែទម្រង់របស់ពួកអ្នកធ្វើកំណែទម្រង់ទាំងនោះ។ អ្នកធ្វើកំណែទម្រង់ដ៏ល្បីល្បាញបំផុតរបស់សហរដ្ឋអាមេរិកគឺលោក ហូរេស ម៉ាន នៃរដ្ឋម៉ាសាឆូសេត ដែលមានបំណងចង់ឱ្យមានការអប់រំសាធារណៈដែលមិនបង់ថ្លៃសម្រាប់កុមារទាំងឡាយ។ លោក ម៉ាន ដែលបានចំណាយវ័យកុមាររបស់លោកធ្វើការនៅក្នុងរោងចក្រ ដាស់តឿនថា "ប្រសិនបើយើងមិនបានរៀបចំកុមារឱ្យក្លាយជាប្រជាពលរដ្ឋល្អទេ... ប្រសិនបើយើងមិនបានពង្រីកគំនិតរបស់ពួកគេជាមួយនឹងចំណេះដឹងនាំទេ, ពេលនោះសាធារណៈរដ្ឋរបស់ពួកយើងនិងធ្លាក់ទៅរកវិនាសកម្ម"។

ត្រឹមទសវត្សរ៍ឆ្នាំ 1850 រដ្ឋជាច្រើនបានចាប់ផ្ដើមប្រព័ន្ធសាលារដ្ឋ។ នៅអឺរ៉ុបខាងលិច ការសិក្សានៅសាលារដ្ឋដោយមិនបង់ថ្លៃចាប់ផ្ដើមឡើងនៅចុងទសវត្សរ៍ឆ្នាំ 1800 ។ នៅក្នុងឆ្នាំ 1831 អ្នកនិពន្ធជនជាតិបារាំងមួយរូបឈ្មោះអាឡេស៊ីស ដេ តូកេវីល បានប្រៀបធៀបស្ថានភាពឃោឃៅនៅក្នុងពន្ធនាគារនៅអាមេរិកទៅនឹង "សេរីភាពដ៏ទូលំទូលាយ" នៅក្នុងសង្គមអាមេរិក។ អ្នកដែលសំលឹងទៅរកការធ្វើកំណែទម្រង់ពន្ធនាគារ បានបញ្ជាក់ពីគោលបំណងនៃការផ្ដល់ឲ្យអ្នកទោសនូវអត្ថប្រយោជន៍នានានៅពេលដែលពួកគេជាប់ក្នុងពន្ធនាគារ ថាវានឹងមានប្រយោជន៍ចំពោះជីវិតរបស់ពួកគេនៅពេលដែលពួកគេត្រូវបានដោះលែង។ អំឡុងទសវត្សរ៍ឆ្នាំ 1800 ប្រជាធិបតេយ្យបានរីកឡើងនៅក្នុងប្រទេសឧស្សាហកម្ម ក៏ដូចជាដែនដីអាណានិគមរបស់ពួកគេផងដែរ។ ប្រជាធិបតេយ្យនៅក្នុងប្រទេសឧស្សាហកម្មប្រឈមទៅនឹងទៅនឹងបញ្ហានានាទាំងនៅក្នុង និងក្រៅប្រទេស។ អ្នកនឹងបានសិក្សាអំពីបញ្ហាទាំងនេះនៅក្នុងជំពូកក្រោយ។

# ជំពូក 25 ៖ យុគសម័យនៃប្រជាធិបតេយ្យ និងភាពជឿនលឿន 1815-1914

## មេរៀនទី 1 ៖ កំណែទម្រង់ប្រជាធិបតេយ្យ និងសកម្មនិយម

### 1. ការធ្វើកំណែទម្រង់នៅអង់គ្លេស

នៅក្នុងជំពូកមុនបានពន្យល់ពីដំណើរការ ដែលចក្រភពអង់គ្លេសបានក្លាយជាប្រទេសប្រកាន់របបនយោបាយបែបរាជាធិបតេយ្យអាស្រ័យធម្មនុញ្ញមួយនៅចុងទសវត្សរ៍ឆ្នាំ 1600 ។ ស្ថិតនៅក្រោមប្រព័ន្ធរដ្ឋាភិបាលបែបនេះ ព្រះមហាក្សត្រដើរតួនាទីជាប្រមុខរដ្ឋ ប៉ុន្តែសភាតំណាងគឺជាអ្នកកាន់កាប់អំណាចពិតប្រាកដ។ សភាតំណាងរាស្ត្រនៅអង់គ្លេសរួមមាន សភាជាន់ខ្ពស់ និងសភាជាន់ទាប។ ជាប្រពៃណី សមាជិកនៃសភាជាន់ខ្ពស់ទទួលបានតំណែងតាមរយៈការបន្តវេន និងការតែងតាំង។ ប៉ុន្តែ ការធ្វើបែបនេះត្រូវបានផ្លាស់ប្តូរនៅក្នុងឆ្នាំ 1699 នៅពេលដែលស្ថាប័ននិតិបញ្ញត្តិបានអនុម័តច្បាប់មួយលុបបំបាត់សិទ្ធិនៃការស្នងមរតកកៅអីនៅសភាជាន់ខ្ពស់។ សមាជិកនៅក្នុងសភាជាន់ទាបត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជនអង់គ្លេស។

នៅដើមទសវត្សរ៍ឆ្នាំ 1800 វិធីសាស្ត្រនៃការជ្រើសរើសរដ្ឋាភិបាលរបស់អង់គ្លេសមិនមានលក្ខណៈបែបប្រជាធិបតេយ្យពិតប្រាកដឡើយ។ មានតែប្រជាជនអង់គ្លេសប្រហែលជា 5 ភាគរយប៉ុណ្ណោះដែលមានសិទ្ធិនៅក្នុងបោះឆ្នោតជ្រើសរើសសមាជិកសភាជាន់ទាប។ ការបោះឆ្នោតត្រូវបានគេកម្រិតឱ្យតែបុរសដែលមានសិទ្ធិកាន់កាប់ដីធ្លីធំៗប៉ុណ្ណោះ។ ស្ត្រីមិនអាចបោះឆ្នោតបានទេ។ ជាលទ្ធផល ពួកវណ្ណៈលើបានគ្រប់ដណ្តប់លើរដ្ឋាភិបាល។

ច្បាប់កំណែទម្រង់ឆ្នាំ 1832៖ ក្រុមដំបូងដែលបានទាមទារឱ្យមានសំលេងកាន់តែប្រសើរនៅក្នុងនយោបាយគឺពួកវណ្ណៈកណ្តាលដែលមានទ្រព្យសម្បត្តិច្រើន ដែលក្នុងនោះមានដូចជា ម្ចាស់រោងចក្រ, ធនាគារិក, និងពាណិជ្ជករ។ ចាប់ផ្តើមនៅក្នុងឆ្នាំ 1830 ការធ្វើបាតុកម្មបានកើតឡើងនៅពាសពេញប្រទេសអង់គ្លេស ដើម្បីទាមទារឱ្យសភាតំណាងរាស្ត្របង្កើតច្បាប់មួយដែលនឹងពង្រីកសិទ្ធិបោះឆ្នោត។ បដិវត្តនៅក្នុងឆ្នាំ 1830 នៅប្រទេសបារាំង បានធ្វើឱ្យមេដឹកនាំសភាតំណាងរាស្ត្រអង់គ្លេសមានការភ័យខ្លាច។ ពួកគេខ្លាចថា ការធ្វើបដិវត្តដ៏ហិង្សានេះនឹងរីករាលដាលដល់ចក្រភពអង់គ្លេស។ ដូច្នេះ សភាតំណាងរាស្ត្របាននុម័តច្បាប់កំណែទម្រង់មួយនៅក្នុងឆ្នាំ 1832។ ច្បាប់នេះបានលុបចោលនូវការតម្រូវឱ្យមានទ្រព្យសម្បត្តិច្រើនដើម្បីមានសិទ្ធិបោះឆ្នោត ដូច្នេះច្បាប់នេះអនុញ្ញាតឱ្យមនុស្សសាមញ្ញនៅក្នុងវណ្ណៈកណ្តាលអាចមានសិទ្ធិបោះឆ្នោតបាន។ ច្បាប់កំណែទម្រង់ក៏បានធ្វើទំនើបកម្មមណ្ឌលសម្រាប់បោះឆ្នោតសភាតំណាងរាស្ត្រ និងបានបង្កើនចំនួនតំណាងរាស្ត្រនៅក្នុងទីក្រុងឧស្សាហកម្មថ្មី។

ចលនាអ្នកធម្មនុញ្ញ៖ បើទោះបីជាច្បាប់កំណែទម្រង់បានបង្កើនចំនួនអ្នកបោះឆ្នោតនៅអង់គ្លេសក៏ដោយ មានតែបុរសមួយចំនួនតូចប៉ុណ្ណោះដែលមានសិទ្ធិនៅក្នុងការបោះឆ្នោត។ មានចលនាប្រជាជនមួយបានរីកឡើងនៅក្នុងចំណោមកម្មករ និងក្រុមផ្សេងៗទៀតដែលមិនមានសិទ្ធិក្នុងការបោះឆ្នោត ដើម្បីរុញច្រានឱ្យមានការផ្តល់សិទ្ធិបោះឆ្នោតកាន់តែច្រើនទៀត។ វាត្រូវបានគេហៅថា ចលនាអ្នកធម្មនុញ្ញ ដោយសារតែក្រុមទាំងនេះដំបូងឡើយ

បានបង្ហាញការទាមទាររបស់ពួកគេទៅកាន់សភាតំណាងរាស្ត្រនៅក្នុងញត្តិមួយដែលគេហៅថា ធម្មនុញ្ញរបស់ប្រជាជនឆ្នាំ 1838។

ធម្មនុញ្ញរបស់ប្រជាជន បានស្នើរឱ្យមានការផ្តល់សិទ្ធិដល់មនុស្សទាំងឡាយដើម្បីបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រ។ វាគេក៏បានស្នើរឱ្យមានការធ្វើកំណែទម្រង់សភាតំណាងរាស្ត្រអង់គ្លេសនៅក្នុងវិធីមួយចំនួន។ នៅចក្រភពអង់គ្លេសនាពេលនោះ បុរសដែលមានសិទ្ធិបោះឆ្នោតបានធ្វើការបោះឆ្នោតដោយបើកចំហរ។ នៅពេលដែលការបោះឆ្នោតរបស់ពួកគេមិនមានភាពសម្ងាត់ ពួកគេអាចនឹងរងសម្ពាធនៅក្នុងបោះឆ្នោតដោយសារកត្តាមួយចំនួន។ សមាជិកនៃសភាតំណាងរាស្ត្រត្រូវតែជាម្ចាស់កម្មសិទ្ធិដីធ្លី និងមិនទទួលបានប្រាក់ខែឡើយ ដូច្នេះសភាតំណាងរាស្ត្រត្រូវតែជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ។

ពួកអ្នកធម្មនុញ្ញចង់ធ្វើឱ្យសភាតំណាងរាស្ត្រគឺជាអ្នកតំណាងឱ្យប្រជាជនវណ្ណៈទាប។ ដើម្បីធ្វើដូច្នេះ ពួកគេចង់ឱ្យមានការបោះឆ្នោតជាលក្ខណៈសម្ងាត់, ធ្វើឡើងជាប្រចាំឆ្នាំ, បញ្ឈប់ការដែលតម្រូវឱ្យមានទ្រព្យសម្បត្តិស្តុកស្តម្ភដើម្បីចូលបម្រើការងារនៅក្នុងសភាតំណាងរាស្ត្រ, និងត្រូវផ្តល់ប្រាក់ខែដល់សមាជិកសភាតំណាងរាស្ត្រ។ សភាតំណាងរាស្ត្របានបដិសេធចំពោះការទាមទាររបស់ក្រុងអ្នកធម្មនុញ្ញទាំងនេះ។ ប៉ុន្តែ ការធ្វើបាតុកម្មទាមទាររបស់ពួកគេបានធ្វើឱ្យមនុស្សជាច្រើនគិតថា ការទាមទាររបស់កម្មករគឺជារឿងត្រឹមត្រូវ។ អស់រយៈពេលជាច្រើនឆ្នាំកម្មករបន្តរុញច្រើនឱ្យមានការធ្វើកំណែទម្រង់នយោបាយ ហើយសភាតំណាងរាស្ត្រក៏បានឆ្លើយតប។ សភាតំណាងរាស្ត្របានផ្តល់សិទ្ធិបោះឆ្នោតដល់វណ្ណៈកម្មករនៅក្នុងឆ្នាំ 1867 និងកម្មករប្រុសនៅជនបទនៅក្នុងឆ្នាំ 1884 ។ បន្ទាប់ពីឆ្នាំ 1884 បុរសពេញវ័យភាគច្រើននៅចក្រភពអង់គ្លេសមានសិទ្ធិនៅក្នុងការបោះឆ្នោត។ នៅដើមទសវត្សរ៍ឆ្នាំ 1900 រាល់ការទាមទាររបស់ពួកធម្មនុញ្ញ លើកលែងតែការបោះឆ្នោតប្រចាំឆ្នាំមួយចេញ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់។

យុគសម័យវិចតូរីយ៉ា៖ តួអង្គសំខាន់ជាងគេដែលគ្របដណ្តប់លើការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រនេះគឺ ម្ចាស់ក្សត្រីវិចតូរីយ៉ា។ ម្ចាស់ក្សត្រីវិចតូរីយ៉ា បានឡើងគ្រងរាជ្យនៅក្នុងឆ្នាំ 1837 នៅពេលដែលទ្រង់មានព្រះជន្ម 18 ព្រះវស្សា។ ទ្រង់បានគ្រងរាជធ្វើជាក្សត្រីអស់រយៈពេលជិត 64 ឆ្នាំ។ នៅអំឡុងនៃរជ្ជកាលរបស់ម្ចាស់ក្សត្រីវិចតូរីយ៉ា ចក្រភពអង់គ្លេសបានឡើងដល់កម្រិតកម្ពស់នូវទ្រព្យសម្បត្តិ និងអំណាចរបស់ខ្លួន។ ម្ចាស់ក្សត្រីវិចតូរីយ៉ាមានប្រជាប្រិយភាពសម្រាប់ប្រជានុរាស្ត្ររបស់ទ្រង់ ហើយទ្រង់បានអនុវត្តតួនាទីរបស់ទ្រង់ប្រកបទៅដោយសមត្ថភាព។ ប៉ុន្តែ ទ្រង់ត្រូវបានបង្ខំឱ្យទទួលយកនូវការដឹកនាំដែលមានអំណាចតិចតួចក្នុងតួនាទីជាព្រះមហាក្សត្រ។ មហាក្សត្រអង់គ្លេសមុនៗដែលគ្រងរាជ្យមុនម្ចាស់ក្សត្រីវិចតូរីយ៉ា នៅចន្លោះទសវត្សរ៍ឆ្នាំ 1700 និង 1800 បានឥទ្ធិពលយ៉ាងខ្លាំងលើសភាតំណាងរាស្ត្រ។ ការរីកសាយភាយនៃប្រជាធិបេយ្យនៅក្នុងទសវត្សរ៍ឆ្នាំ 1800 បានផ្លាស់ប្តូរអំណាចនយោបាយស្ទើរតែទាំងស្រុងពីព្រះមហាក្សត្រទៅសភាតំណាងរាស្ត្រ និងជាពិសេសទៅលើសភាជាន់ទាប។ ដូច្នេះ រដ្ឋាភិបាលត្រូវបានគ្រងគ្រងដោយនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី។

## 2. ស្ត្រីទទួលបានសិទ្ធិក្នុងការបោះឆ្នោត

គិតត្រឹមឆ្នាំ 1890 ប្រទេសឧស្សាហកម្មជាច្រើនបានផ្ដល់សិទ្ធិឱ្យបុរសទាំងអស់មានសិទ្ធិក្នុងការបោះឆ្នោត។ ប៉ុន្តែ គ្មានប្រទេសមួយណាអនុញ្ញាតឱ្យស្ត្រីបោះឆ្នោតឡើយ។ ដូចដែលបុរសទទួលបានសិទ្ធិនៅក្នុងការបោះឆ្នោតកាន់តែច្រើន ស្ត្រីកាន់តែច្រើនបានទទួលសិទ្ធិបោះឆ្នោតដូចបុរសដែរ។

ការរៀបចំ និងការតស៊ូប្រឆាំង៖ អំឡុងទសវត្សរ៍ឆ្នាំ 1800 ទាំងស្ត្រីនៅចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកបានធ្វើការជាមួយគ្នាដើម្បីទទួលបានសិទ្ធិនៅក្នុងការបោះឆ្នោត។ ស្ត្រីនៅចក្រភពអង់គ្លេសបានរៀបចំក្រុមកំណែទម្រង់ និងបាតុកម្មប្រឆាំងជាមួយនឹងច្បាប់ និងប្រពៃណីដែលមិនស្មើភាពគ្នា។ ដូច្នេះ ដូចដែលស្ត្រីកាន់តែមានសំលេងច្រើន ការប្រឆាំងទៅនឹងការទាមទារសិទ្ធិរបស់ពួកគេកាន់តែកើនឡើង។ មនុស្សជាច្រើន ទាំងបុរស និងស្ត្រីបានគិតថា ការដែលស្ត្រីមានសិទ្ធិបោះឆ្នោតវាហាក់ដូចជាខុសទៅនឹងទំនៀមទម្លាប់ខ្លាំងពេក។ អ្នកមួយចំនួនអះអាងថា ស្ត្រីខ្វះនូវសមត្ថភាពនៅក្នុងការចូលរួមធ្វើនយោបាយ។

ការទាមទារដោយហិង្សា៖ បន្ទាប់ពីការព្យាយាមដោយសន្តិវិធីអស់រយៈពេលរាប់ទសវត្សរ៍ដើម្បីទទួលបានសិទ្ធិនៅក្នុងបោះឆ្នោតមក ស្ត្រីមួយចំនួនបានឈានទៅរកការទាមទារកាន់តែខ្លាំងក្លាមួយ។ នៅក្នុងចក្រភពអង់គ្លេស អេមមេលីន ផានខូស បានបង្កើតស្ថាប័នសង្គមស្ត្រី និងសហភាពនយោបាយ នៅក្នុងឆ្នាំ 1903 ។ ស្ថាប័នសង្គមស្ត្រី និងសហភាពនយោបាយ បានក្លាយជាស្ថាប័នសកម្មបំផុតមួយដើម្បីទាមទារសិទ្ធិស្ត្រី។ គោលដៅរបស់ស្ថាប័ននេះគឺដើម្បីទាញការចាប់អារម្មណ៍មួយក្នុងការទាមទារសិទ្ធិសម្រាប់ការបោះឆ្នោតរបស់ស្ត្រី។ នៅពេលសួរថាហេតុអ្វីបានជាក្រុមនេះជ្រើសរើសការទាមទារដោយហិង្សាដើម្បីទទួលបានសិទ្ធិសម្រាប់ស្ត្រី ផានខូសបាននិយាយថា៖

ខ្ញុំចង់និយាយនៅទីនេះ និងឥឡូវថា មានតែវិធីបែបហិង្សា, មានតែវិធីធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ, មានតែវិធីធ្វើឱ្យមានហានិភ័យ ដើម្បីធ្វើឱ្យជីវិតរបស់អ្នកដ៏ទៃរស់ស្រួលទេ គឺជាអ្វីដែលអ្នកត្រូវព្យាយាមប្រើប្រាស់នូវមធ្យោបាយគ្រប់យ៉ាងដើម្បីធ្វើវា។

## 3. បារាំង និងប្រជាធិបតេយ្យ

ខណៈពេលដែលចក្រភពអង់គ្លេសធ្វើដំណើរឆ្ពោះទៅរកប្រជាធិបតេយ្យកាន់តែប្រសើរមួយ នៅចុងទសវត្សរ៍ឆ្នាំ 1800 ចុងក្រោយប្រជាធិបតេយ្យបានបោះមូលដ្ឋាននៅក្នុងប្រទេសបារាំង។

សាធារណរដ្ឋទី 3៖ ជាលទ្ធផលនៃសង្គ្រាមបារាំង-ព្រូស បាននាំឱ្យបារាំងជួបនូវវិបត្តិជាច្រើន។ រវាងឆ្នាំ 1871 ដល់ឆ្នាំ 1914 ជាមធ្យមក្នុងមួយឆ្នាំ បារាំងបានផ្លាស់ប្ដូររដ្ឋាភិបាលរបស់ខ្លួនម្ដង។ គណបក្សនយោបាយជាង 10 បានប្រកួតប្រជែងគ្នាដើម្បីអំណាច។ រហូតមកដល់ឆ្នាំ 1875 ទើបសភាជាតិបានយល់ស្របគ្នានៅក្នុងការបង្កើតរដ្ឋាភិបាលថ្មីមួយ។ បន្តិចម្ដងៗ សមាជិកសភាបានបោះឆ្នោតបង្កើតរដ្ឋាភិបាលបែបសាធារណរដ្ឋមួយ។ សាធារណរដ្ឋទី៣ មានអាយុកាលជាង 60 ឆ្នាំ។ ប៉ុន្តែ បារាំងនៅតែមានការបែកបាក់គ្នា។

បញ្ហាលោកដ្រេហ្វូស៖ អំឡុងទសវត្សរ៍ឆ្នាំ 1880 និង 1890 សាធារណរដ្ឋទី 3 ត្រូវបានរងការគំរាមកំហែងពីសំណាក់អ្នករាជានិយម, អភិជន, បព្វជិត, និងមេដឹកនាំយោធា។ ក្រុមទាំងនេះចង់ឱ្យស្ដេច ឬយោធាមួយរូបដឹកនាំប្រទេស។ បដិវាទនេះត្រូវបានគេស្គាល់ថា បញ្ហាលោកដ្រេហ្វូស ដែលបានក្លាយជាសមរភូមិមួយសម្រាប់ក្រុមទាំង 2 នេះ។ ការរីករាលដាលនៃ ចលនាប្រឆាំងជនជាតិជ្វីប ឬការប្រកាន់ពូជសាសន៍ប្រឆាំងជនជាតិជ្វីប ក៏មានដើរតួនាទីសំខាន់នៅក្នុងវិបត្តិនេះដែរ។

នៅក្នុងឆ្នាំ 1894 អនុសេនីយ៍ឯក អាលហ្វ្រេដ ដ្រេហ្វូស ដែលជាមន្ត្រីជនជាតិជ្វីបម្នាក់នៅក្នុងចំណោមជនជាតិជ្វីបដែលធ្វើការងារនៅក្នុងជួរកងទ័ពបារាំង ត្រូវបានចោទប្រកាន់ថាបានលក់ព័ត៌មានសំងាត់របស់យោធាឱ្យទៅប្រទេសអាឡឺម៉ង់។ ចៅក្រមម្នាក់បានរកឃើញថាលោកមានទោស ដោយផ្អែកលើភស្តុតាងក្លែងក្លាយ និងបានកាត់ទោសលោកឱ្យជាប់គុកអស់មួយជីវិត។ ប៉ុន្មានឆ្នាំក្រោយមក មានភស្តុតាងថ្មីមួយដែលបង្ហាញថាលោក ដ្រេហ្វូស ត្រូវបានទម្លាក់កំហុសដាក់ដោយមន្ត្រីយោធាផ្សេងទៀត។ សាធារណមតិត្រូវបានបែកចែកយ៉ាងខ្លាំងទៅលើរឿងអាស្រូវនេះ។ មេដឹកនាំយោធា, អ្នកជាតិនិយម, មេដឹកនាំបព្វជិត, ក្រុមប្រឆាំងជនជាតិជ្វីបបានបដិសេធមិនឱ្យមានការសើរើករណីនេះឡើងវិញឡើយ។ ពួកគេមានការភ័យខ្លាចថា ការធ្វើសកម្មភាពភ្លាមៗណាមួយនឹងអាចបង្កឱ្យប៉ះពាល់ដល់កិត្តិយសរបស់កងទ័ព។ អ្នកការពារលោកដ្រេហ្វូស បានទទូចថា យុត្តិធម៌មានសារៈសំខាន់ជាងនេះ។ នៅក្នុងឆ្នាំ 1898 អ្នកនិពន្ធ ម្នាក់ឈ្មោះ អេមីឡេ ហ្សូឡា បានបោះពុម្ពលិខិតបើកចំហរមួយដែលមានចំណងជើងថា ខ្ញុំត្រូវបានគេចោទប្រកាន់ នៅក្នុងការសែតដែលមានប្រជាប្រិយមួយរបស់បារាំង។ នៅក្នុងលិខិតនោះ លោកហ្សូឡាបានបរិហារកងទ័ពដែលទាក់ទងទៅនឹងរឿងអាស្រូវមួយនេះ។ លោកហ្សូឡាត្រូវបានគេកាត់ទោសឱ្យជាប់គុកមួយឆ្នាំដោយសារតែការបង្ហាញពីទស្សនរបស់លោកនេះ ប៉ុន្តែលិខិតរបស់លោកបានផ្ដល់ផលវិជ្ជមានដល់ករណីរបស់លោកដ្រេហ្វូស។ ដាយថាហេតុ រដ្ឋាភិបាលបារាំងបានប្រកាសពីភាពគ្មានទោសរបស់លោកដ្រេហ្វូស។

ការរីកឡើងនៃចលនាបង្កើតរដ្ឋជ្វីបឡើងវិញ៖ ករណីរបស់លោកដ្រេហ្វូសបានបង្ហាញពីចលនាប្រឆាំងជនជាតិជ្វីបដ៏ខ្លាំងក្លាមួយនៅក្នុងប្រទេសបារាំង និងផ្នែកផ្សេងៗទៀតនៅអឺរ៉ុបខាងលិច។ ប៉ុន្តែ ការធ្វើទុក្ខបុកម្និញលើជនជាតិជ្វីប ហាក់ដូចជាមានលក្ខណៈកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតនៅអឺរ៉ុបភាគខាងកើត។ មន្ត្រីរុស្ស៊ីត្រូវបានអនុញ្ញាតឱ្យបង្កើតចលនាលុបបំបាត់ជនជាតិជ្វីប, រៀបចំយុទ្ធនាការហិង្សាប្រឆាំងជាមួយជនជាតិជ្វីប។ ចាប់ពីចុងទសវត្សរ៍ឆ្នាំ 1880 ពួកជ្វីបរាប់ពាន់នាក់បានរត់គេចចេញពីអឺរ៉ុបខាងកើត។ ពួកគេភាគច្រើនធ្វើដំណើរទៅសហរដ្ឋអាមេរិក។ សម្រាប់ជនជាតិជ្វីបភាគច្រើន យល់ថាប្រវត្តិនៃការនិរទ្ទេសក្នុងរយៈដ៏យូរ និងការធ្វើទុក្ខបុកម្និញបានជម្រុញឱ្យពួកគេធ្វើការដើម្បីត្រឡប់ទៅកាន់ស្រុកកំណើតរបស់ពួកគេវិញនៅប៉ាឡេស្ទីន។ នៅក្នុងទសវត្សរ៍ឆ្នាំ 1890 ចលនាមួយដែលត្រូវបានគេស្គាល់ថា ចលនាបង្កើតរដ្ឋជ្វីបឡើងវិញ ត្រូវបានអភិវឌ្ឍឡើងដើម្បីអនុវត្តគោលបំណងនេះ។ មេដឹកនាំចលនានេះគឺលោក ថេអូដូរហឺរ ដែលជាអ្នកនិពន្ធមួយរូបនៅទីក្រុងវីយ៉ាណា។ ប៉ុន្តែ វាត្រូវការចំណាយពេលវេលាជាច្រើន មុនពេលដែលរដ្ឋអ៊ីស្រាអែលត្រូវបានបង្កើតឡើង។

# មេរៀនទី 2៖ ការទាមទារឯករាជ្យរបស់ប្រទេសដែលស្ថិតនៅក្រោមអាណានិគមរបស់អង់គ្លេស

## 1. ការទាមទារឯករាជ្យរបស់កាណាដា

កាណាដាដើមឡើយគឺជាទីលំនៅនៃប្រជាជនដើមអាមេរិកជាច្រើន។ ប្រទេសអឺរ៉ុបដំបូងដែលបានដាក់អាណានិគមលើប្រទេសកាណាដាមុនគេគឺប្រទេសបារាំង។ ក្នុងចំណោមពួកម្ចាស់អាណានិគមបារាំងដំបូងបំផុតនៅអំឡុងទសវត្សរ៍ឆ្នាំ 1600 ដល់ 1700 រួមមានមួយភាគធំគឺជាអ្នកបរបាញ់សត្វយករោម និងបេសកទូតសាសនា។ ពួកគេរស់នៅលាយឡំគ្នាជាមួយនឹងពួកជនជាតិដើមអាមេរិក។ បារាំងមួយចំនួនបានរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិដើមអាមេរិក។

ចក្រភពអង់គ្លេសកាន់កាប់ប្រទេសនេះនៅក្នុងឆ្នាំ 1763 បន្ទាប់ពីពួកគេយកជ័យជំនះលើពួកបារាំងនៅក្នុងសង្គ្រាមបារាំង-ឥណ្ឌា។ ជនជាតិបារាំងនៅតែបន្តរស់នៅភាគច្រើននៅតំបន់ទំនាបជ្រលងឡូរេន ។ ម្ចាស់អាណានិគមនិយាយអង់គ្លេសជាច្រើនបានមកដល់ប្រទេសកាណាដា បន្ទាប់ពីប្រទេសនេះធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស។ មានអ្នកមួយចំនួនមកពីចក្រភពអង់គ្លេស និងអ្នកមួយចំនួនទៀតគឺជាពួកអាមេរិកដែលបន្តភក្តីភាពចំពោះចក្រភពអង់គ្លេសបន្ទាប់ពីការធ្វើបដិវត្តនៅអាមេរិក។ ពួកគេតាំងទីលំនៅដាក់ដោយឡែកពីពួកបារាំងនៅតាមតំបន់ឆ្នេរសមុទ្រអាតាឡង់ទិក និងតំបន់បឹងធំៗ។

ជនជាតិបារាំង និងអង់គ្លេសនៅកាណាដា៖ ភាពខុសគ្នានៃសាសនា និងវប្បធម៌រវាងពួកបារាំងដែលភាគច្រើនកាន់សាសនារ៉ូម៉ាំងកាតូលិក និងពួកអង់គ្លេសដែលភាគច្រើនកាន់សាសនាប្រូតេសស្តង់បានបណ្តាលឱ្យមានជម្លោះកើតឡើងនៅក្នុងប្រទេសកាណាដា។ ក្រុមទាំងពីរបានរុញច្រានចក្រភពអង់គ្លេសឱ្យមានសំឡេងកាន់តែច្រើននៅក្នុងជួររដ្ឋាភិបាលរបស់ពួកគេផ្ទាល់នៅកាណាដា។ នៅក្នុងឆ្នាំ 1791 សភាតំណាងរាស្ត្រចក្រភពអង់គ្លេសបានព្យាយាមនៅក្នុងការដោះស្រាយបញ្ហាទាំងពីរនេះតាមរយៈការបង្កើតខេត្តពីរថ្មីនៅកាណាដា។ កាណាដាលើ (បច្ចុប្បន្នអងតារីអូ) មានអ្នកនិយាយភាសាអង់គ្លេសភាគច្រើន។ កាណាដាក្រោម (បច្ចុប្បន្នកេប៊ិក) មានអ្នកនិយាយភាសាបារាំងភាគច្រើន។ ខេត្តនីមួយៗមានសភាតំណាងរាស្ត្ររបស់ពួកគេផ្ទាល់។

របាយការណ៍របស់ឌូហាំ៖ ការបែងចែកកាណាដាលើ និងកាណាដាក្រោមបានបង្កឱ្យមានចម្លោះមួយរយៈពេលខ្លី។ នៅក្នុងតំបន់អាណានិគមទាំងពីរនេះ រាជរដ្ឋាភិបាល និងក្រុមអ្នកមានទ្រព្យសម្បត្តិជនជាតិអង់គ្លេសបានក្តោបក្តាប់អំណាចស្ទើតែទាំងស្រុង។ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ 1800 វណ្ណៈកណ្តាលនៅក្នុងតំបន់អាណានិគមទាំងពីរចាប់ផ្តើមទាមទារឱ្យមានការធ្វើកំណែទម្រង់នយោបាយ និងសេដ្ឋកិច្ច។ នៅកាណាដាក្រោម ការទាមទារនេះក៏បានផ្ទុះឡើង ដោយសារតែការមិនសប្បាយចិត្តរបស់ជនជាតិបារាំងចំពោះការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស។ នៅចុងទសវត្សរ៍ឆ្នាំ 1830 ការបះបោរបានផ្ទុះឡើងនៅក្នុងតំបន់ទាំងពីរ ទាំងកាណាដាលើ និងកាណាដាក្រោម។ សភាតំណាងរាស្ត្ររបស់អង់គ្លេសបានបញ្ជូនអ្នកកំណែទម្រង់និយមម្នាក់ឈ្មោះ ឡដ ឌូហាំ ដើម្បីធ្វើការស៊ើបអង្កេត។

នៅក្នុងឆ្នាំ 1839 លោកឌូហាំ បានផ្ញើរបាយការណ៍មួយទៅកាន់សភាតំណាងរាស្ត្រ ដែលក្នុងនោះទទូចឱ្យមានការធ្វើកំណែទម្រង់ពីរសំខាន់ៗ។ ទីមួយ កាណាដាលើ និងកាណាដាក្រោមគួរតែត្រូវបង្រួបបង្រួមបញ្ចូលគ្នាជាកាណាដាតែមួយ ហើយគួរតែជម្រុញឱ្យជនជាតិអង់គ្លេសធ្វើអន្តោប្រវេសន៍ទៅកាន់ទីនោះ។ នៅក្នុងវិធីនេះ បន្តិចម្តងៗជនជាតិបារាំងនៅកាណាដាទាំងនោះនឹងត្រូវគ្របដណ្តប់ដោយវប្បធម៌អង់គ្លេស។ ទី 2 ម្ចាស់អាណានិគមនៅកាណាដាគួរតែត្រូវបានអនុញ្ញាតឱ្យពួកគេអាចដឹកនាំដោយខ្លួនគេផ្ទាល់ចំពោះបញ្ហានានានៅក្នុងស្រុក។

អាណាចក្រកាណាដា៖ ត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 ប្រជាជនកាណាដាជឿថា កាណាដាត្រូវការរដ្ឋាភិបាលកណ្តាលមួយ។ រដ្ឋាភិបាលកណ្តាលមួយអាចជួយការពារអត្ថប្រយោជន៍ប្រជាជនកាណាដាប្រឆាំងជាមួយសហរដ្ឋអាមេរិក ដែលពេលនោះបានពង្រីកទឹកដីពីមហាសមុទ្រអាត្លង់តិកដល់មហាសមុទ្រប៉ាស៊ីហ្វិក។ នៅក្នុងឆ្នាំ 1867 ណូវ៉ា ស្កូទៀ និងញូវ ប្រូនស្វីក បានចូលរួមជាមួយកាណាដាបង្កើតបានជាអាណាចក្រកាណាដា។ ក្នុងនាមជាអាណាចក្រមួយ កាណាដាដឹកនាំប្រទេសដោយផ្ទាល់លើកិច្ចការខាងក្នុងប្រទេស ប៉ុន្តែបន្តស្ថិតជាផ្នែកមួយនៃចក្រភពអង់គ្លេស។

ការពង្រីកឆ្ពោះទៅភាគខាងលិចរបស់កាណាដា៖ នាយករដ្ឋមន្ត្រីទីមួយរបស់កាណាដា លោកចន ម៉ាកដូណាលបានពង្រីកកាណាដាឆ្ពោះទៅភាគខាងលិចតាមរយៈការទិញដី និងបញ្ចុះបញ្ចូលតំបន់ក្បែរៗនោះឱ្យរួបរួមគ្នាជាសហភាពមួយ។ កាណាដាបានលាតសន្ធឹងទៅដល់សមុទ្រប៉ាស៊ីហ្វិកត្រឹមឆ្នាំ 1871 ។ លោក បានចាប់ផ្តើមស្ថាបនាផ្លូវរថភ្លើងកាត់ទ្វីបមួយ ដោយបានបញ្ចប់ជាស្ថាពរនៅក្នុងឆ្នាំ 1885 ។

## 2. ប្រទេសអូស្ត្រាលី និងញូវហ្ស៊ីឡែន

ឧត្តមនាវីជនជាតិអង់គ្លេស ជេម យូក បានអះអាងថាញូវហ្ស៊ីឡែន (1769) និងផ្នែកខ្លះនៃអូស្ត្រាលី (1770) ជារបស់ចក្រភពអង់គ្លេស ។ ដែនដីទាំងពីរនេះមានមនុស្សតាំងទីលំនៅរួចមកហើយ។ នៅក្នុងប្រទេសញូវហ្ស៊ីឡែន លោកយូក ត្រូវបានស្វាគមន៍ដោយក្រុមមនុស្សម៉ាវរីដែលជាក្រុមចម្រុះជាតិសាសន៍មួយ ដែលបានមកតាំងទីលំនៅ នៅញូវហ្ស៊ីឡែននៅវង្វង់ឆ្នាំ 800 នៃគ.ស។ វប្បធម៌របស់ពួក គឺពឹងផ្អែកលើការធ្វើកសិកម្ម, បរបាញ់, និងនេសាទ។ នៅពេលដែលលោក យូក មកដល់អូស្ត្រាលី លោកគិតថាដែនដីនេះមិនមានអ្នកតាំងទីលំនៅឡើយ។ តាមពិត ប្រទេសអូស្ត្រាលីនៅពេលនោះរស់នៅរាយពាយដោយក្រុមអាបូរីជីន (អ្នកស្រុកដើម) ដូចដែលក្រោយមកពួកអឺរ៉ុបបានហៅពួកគេថា ប្រជាជនដើម។ ក្រុមអាបូរីជីន គឺជាក្រុមដែលថែរក្សានូវវប្បធម៌បានយូរជាងគេនៅលើពិភពលោក។ ក្រុមចរកជនទាំងនេះគឺជាអ្នកនេសាទ, បរបាញ់, និងបេះផ្លែឈើ។

ដែនដីអាណានិគមសម្រាប់អ្នកទោសអង់គ្លេស៖ ចក្រភពអង់គ្លេសចាប់ផ្តើមដាក់អាណានិគមលើអូស្ត្រាលីនៅក្នុងឆ្នាំ 1788 ជាមួយនឹងការបញ្ជូនអ្នកប្រព្រឹត្តបទឧក្រិដ្ឋទៅកាន់ទីនោះ។ នៅក្នុងគុកនៅប្រទេសអង់គ្លេសមានភាពណែនចង្អៀតទៅដោយអ្នកទោស។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលរបស់អង់គ្លេសបានបង្កើតដែនដីអាណានិគមសម្រាប់អ្នកទោសមួយនៅក្នុងប្រទេសអូស្ត្រាលី។ ដែនដីអាណានិគមសម្រាប់អ្នកទោសមួយគឺជាទីកន្លែងមួយដែលអ្នកប្រព្រឹត្តបទឧក្រិដ្ឋត្រូវបានគេបញ្ជូនមកអនុវត្តទោសរបស់ពួកគេ។ ប្រទេសអឺរ៉ុបជាច្រើន

ប្រើប្រាស់ដែនដីអាណានិគមសម្រាប់អ្នកទោស នៅក្នុងវិធីមួយដើម្បីការពារភាពណែនចង្អៀតទៅដោយអ្នកទោសនៅក្នុងគុក។ បន្ទាប់ពីពួកគេត្រូវបានដោះលែង អ្នកទោសដែលមានសេរីភាពទាំងនេះអាចទិញដី និងតាំងទីលំនៅនៅទីនោះ។

អ្នកតាំងទីលំនៅដែលជាមនុស្សមានសេរីភាពបានមកដល់៖ អ្នកតាំងទីលំនៅជនជាតិអង់គ្លេសដែលមានសេរីភាពជាយថាហេតុបានចូលរួមជាមួយអ្នកប្រព្រឹត្តបទឧក្រិដ្ឋមករស់នៅទាំងអូស្ត្រាលី និងញូវហ្ស៊ីឡែន។ នៅដើមទសវត្សរ៍ឆ្នាំ 1800 អ្នកតាំងទីលំនៅនៅក្នុងប្រទេសអូស្ត្រាលីបានធ្វើការពិសោធន៍លើការចិញ្ចឹមសត្វចៀម រហូតដល់ពួកគេរកឃើញសត្វចៀមមួយប្រភេទដែលមានរោមមានគុណភាពខ្ពស់ និងធំធាត់នៅក្នុងប្រទេសដែលមានអាកាសធាតុក្តៅល្មម និងស្ងួត។ បើទោះសត្វចៀមមិនមែនជាសត្វដើមនៅក្នុងប្រទេសអូស្ត្រាលីក៏ដោយ ការចិញ្ចឹម និងការនាំចេញរោមចៀមបានក្លាយជាជំនួញដ៏ធំមួយនៅក្នុងប្រទេសនេះ។ ដើម្បីជម្រុញឱ្យមានការធ្វើអន្តោប្រវេសន៍ រដ្ឋាភិបាលបានផ្តល់ឱ្យអ្នកតាំងទីលំនៅនូវការលក់ដីថោក។ ប្រជាជនបានកើនឡើងយ៉ាងឆាប់រហ័សនៅដើមទសវត្សរ៍ឆ្នាំ 1800 និងកើនឡើងលឿនដូចកាំជ្រួចបន្ទាប់ការជីករកឃើញរ៉ែមាសនៅក្នុងឆ្នាំ 1851។ ការរស់នៅរាយពាយរបស់អ្នកតាំងទីលំនៅនៅក្នុងប្រទេសអូស្ត្រាលីនៅតំបន់ឆ្នេរភាគខាងកើត បានបង្កឱ្យមានការបែងចែកពួកម្ចាស់អាណានិគម។ នៅខណៈពេលនោះ ក្រុមអ្នកត្រួសត្រាយមួយចំនួនបានធ្វើដំណើរទៅកាន់ភាគខាងលិចដោយឆ្លងកាត់តំបន់ស្ងួតហែងដ៏ធំមួយ និងបានបង្កើតមូលដ្ឋានមួយនៅអូស្ត្រាលីភាគខាងលិច។

ការតាំងទីលំនៅនៅប្រទេសញូវហ្ស៊ីឡែន៖ ការតាំងលំនៅរបស់ពួកអឺរ៉ុបនៅក្នុងប្រទេសញូវហ្ស៊ីឡែនបានកើនឡើងយឺត។ មូលហេតុដោយសារតែចក្រភពអង់គ្លេស មិនបានប្រកាសពីភាពជាម្ចាស់លើប្រទេសញូវហ្ស៊ីឡែនដូចដែលខ្លួនបានធ្វើចំពោះអូស្ត្រាលីឡើយ។ ប៉ុន្តែពួកគេទទួលស្គាល់អ្នកដែលមានសិទ្ធិលើដែនដីនេះគឺពួកម៉ាវរី។ នៅក្នុងឆ្នាំ 1814 ក្រុមបេសកទូតផ្សព្វផ្សាយសាសនាចាប់ផ្តើមធ្វើដំណើរមកពីប្រទេសញូវហ្ស៊ីឡែន ដើម្បីធ្វើការកែប្រែជំនឿរបស់ពួកម៉ាវរីឱ្យជឿលើគ្រីស្តសាសនា។ ការមកដល់នៃជនបរទេសកាន់តែច្រើនបានបង្កឱ្យមានជម្លោះរវាងពួកម៉ាវរី និងអ្នកតាំងទីលំនៅអឺរ៉ុបលើបញ្ហាដីធ្លី។ ឆ្លើយតបទៅនឹងការស្នើសុំរបស់ក្រុមអ្នកតាំងទីលំនៅ ចក្រភពអង់គ្លេសបានសម្រេចនៅក្នុងការភ្ជាប់ប្រទេសញូវហ្ស៊ីឡែនជាឧបសម្ព័ន្ធនៅក្នុងឆ្នាំ 1839 និងបានតែងតាំងទេសាភិបាលម្នាក់ឱ្យទៅចចារជាមួយពួកម៉ាវរី។ នៅក្នុងសន្ធិសញ្ញាមួយដែលចុះហត្ថលេខានៅក្នុងឆ្នាំ 1840 ពួកម៉ាវរីទទួលយកការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស ជាថ្នូរទៅនឹងការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ។

រដ្ឋាភិបាលស្វ័យភាព៖ ក៏ដូចកាណាដាដែរ ពួកម្ចាស់អាណានិគមនៅក្នុងប្រទេសអូស្ត្រាលី និងញូវហ្ស៊ីឡែនចង់ដឹកនាំដោយខ្លួនគេផ្ទាល់ ប៉ុន្តែស្ថិតនៅក្រោមចក្រភពអង់គ្លេស។ អំឡុងទសវត្សរ៍ឆ្នាំ 1850 ពួកម្ចាស់អាណានិគមនៅក្នុងប្រទេសទាំងពីរ ទាំងអូស្ត្រាលី និងញូវហ្ស៊ីឡែនបានក្លាយជាប្រទេសដែលមានស្វ័យភាព និងបានបង្កើតទម្រង់រដ្ឋាភិបាលបែបសភានិយម។ នៅក្នុងឆ្នាំ 1901 ដែនដីអាណានិគមនានានៅអូស្ត្រាលីត្រូវបានដាក់ឱ្យស្ថិតនៅក្រោមច្បាប់ធម្មនុញ្ញសហព័ន្ធរួមមួយគឺ ធម្មនុញ្ញខុមមិនវែលអូស្ត្រាលី។ នៅដើមទសវត្សរ៍ឆ្នាំ 1900 ទាំងអូស្ត្រាលី និងញូវហ្ស៊ីឡែនបានក្លាយជាអាណាចក្រ។ ប្រជាជននៅប្រទេសអូស្ត្រាលី និងញូវហ្ស៊ីឡែនបង្កើតឱ្យ

មានការធ្វើកំណែទម្រង់នយោបាយមួយចំនួន។ ឧទាហរណ៍ សន្លឹកឆ្នោតសម្ងាត់ ពេលខ្លះគេហៅថាសន្លឹកឆ្នោតអូស្រ្តាលី ត្រូវបានប្រើប្រាស់ជាលើកដំបូងនៅក្នុងប្រទេសអូស្រ្តាលីនៅក្នុងទសវត្សរ៍ឆ្នាំ 1850 ។ នៅក្នុងឆ្នាំ 1893 ប្រទេសញូវហ្ស៊ីឡែនបានក្លាយជាប្រទេសទីមួយនៅក្នុងពិភពលោកដែលបានផ្តល់សិទ្ធិបោះឆ្នោតពេញលេញដល់ស្ត្រី។ ប៉ុន្តែ មានតែស្ត្រីស្បែកសប៉ុណ្ណោះដែលទទួលបានសិទ្ធិនេះ។

តួនាទីរបស់ប្រជាជនដើម៖ ប្រជាជនដើម និងអ្នកតាំងទីលំនៅមិនមែនជនជាតិអឺរ៉ុបផ្សេងទៀតត្រូវបានគេផាត់ចេញពីប្រជាធិបតេយ្យ និងភាពរុងរឿង។ ជំងឺដែលបាននាំយកមកដោយពួកអឺរ៉ុបបានសម្រាប់ពួកអាបូរីជីន និងពួកម៉ាវរី។ ដូចដែលការតាំងទីលំនៅនៅក្នុងប្រទេសអូស្ត្រាលីបានកើនឡើង ពួកម្ចាស់អាណានិគមបានផ្លាស់ទីកន្លែង ឬសម្រាប់ពួកអាបូរីជីនអស់ជាច្រើន។

នៅក្នុងប្រទេសញូវហ្ស៊ីឡែន ជម្លោះរវាងពួកអ្នកតាំងទីលំនៅជាមួយពួកម៉ាវរីបានបន្តកើនឡើងបន្ទាប់ពីវាបានក្លាយជាដែនដីអាណានិគមរបស់អង់គ្លេស។ រវាងឆ្នាំ 1845 ដល់ឆ្នាំ 1872 រដ្ឋាភិបាលអាណានិគមបានប្រយុទ្ធគ្នាជាច្រើនលើជាមួយពួកម៉ាវរី។ ការថយចុះដោយសារជំងឺ និងការសម្លាប់ដោយអាវុធរបស់ពួកអង់គ្លេស ពួកម៉ាវរីចុងក្រោយបានបណ្តេញឱ្យទៅរស់នៅតំបន់ដាច់ស្រយាលមួយ។

### 3. ពួកអៀកឡង់ទទួលជ័យជំនះក្នុងការគ្រប់គ្រងប្រទេស

ការពង្រីករបស់អង់គ្លេសទៅក្នុងប្រទេសអៀកឡង់បានចាប់ផ្តើមឡើងនៅអំឡុងទសវត្សរ៍ឆ្នាំ 1100 នៃគ.ស នៅពេលដែលសម្តេចប៉ាបបានផ្តល់សិទ្ធិត្រួតត្រាអៀកឡង់ទៅឱ្យស្តេចអង់គ្លេស។ កងទ័ពសេះរបស់អង់គ្លេសបានឈ្លានពានអៀកឡង់ ហើយពួកគេមួយចំនួនបានតាំងទីលំនៅនៅទីនោះ ដើម្បីបង្កើតជាវណ្ណៈអភិជនថ្មីមួយ។ ពួកជនជាតិអៀកឡង់ដែលមានពូជពង្ស, វប្បធម៌, និងភាសាផ្ទាល់ខ្លួនរបស់ពួកគេបានទទួលរងនូវភាពល្វីងជូរជត់ដោយសារវត្តមានរបស់ពួកអង់គ្លេស។ ច្បាប់ដែលបង្កើតឡើងដោយពួកអង់គ្លេសនៅក្នុងទសវត្សរ៍ឆ្នាំ 1500 និង 1600 បានកម្រិតសិទ្ធិពួករ៉ូម៉ាំងកាតូលិក និងលម្អៀងទៅរកប្រូទេស្តង់ និងភាសាអង់គ្លេស។ អស់រយៈពេលជាច្រើនឆ្នាំ រដ្ឋាភិបាលចក្រភពអង់គ្លេសប្តេជ្ញានៅក្នុងការរក្សាការគ្រប់គ្រងរបស់ពួកគេលើអៀកឡង់។ អង់គ្លេសបានបញ្ចូលអៀកឡង់ជាដែនដីចក្រភពផ្លូវការនៅក្នុងឆ្នាំ 1801។ បើទោះបីវាជាបញ្ហាមួយសម្រាប់អ្នកជាតិនិយមអៀកឡង់ ការបញ្ចូលនេះបានផ្តល់ឱ្យអៀកឡង់នូវអ្នកតំណាងនៅក្នុងសភាតំណាងរាស្រ្តអង់គ្លេស។ មេដឹកនាំអៀកឡង់លោក ដាញែល អូខន់ណែលបានបញ្ចុះបញ្ចូលឱ្យសភាតំណាងរាស្រ្តអនុម័ត ច្បាប់សេរីភាពសាសនារ៉ូម៉ាំងកាតូលិក នៅក្នុងឆ្នាំ 1829 ។ ច្បាប់នេះបានស្តារឡើងវិញនូវសិទ្ធិជាច្រើនដល់សាសនារ៉ូម៉ាំងកាតូលិក។

មហាគ្រោះអត់ឃ្លាន៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1840 អៀកឡង់ជួបប្រទះនូវគ្រោះអត់ឃានដ៏អាក្រក់បំផុតនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប។ អស់រយៈពេលជាច្រើនឆ្នាំ ប្រជាកសិករអៀកឡង់បានពឹងផ្អែកលើដំឡូងបារាំងដែលជាធនធានដ៏សំខាន់មួយរបស់ពួកសម្រាប់ធ្វើជាចំណីអាហារ។ ចាប់ពីឆ្នាំ 1845 ដល់ឆ្នាំ 1848 មេរោគផ្សិតម្យ៉ាងបានកម្ទេចដំណាំដំឡូងបារាំងរបស់អៀកឡង់ស្ទើរតែទាំងស្រុង។ ក្នុងចំណោមប្រជាជនសរុប 8 លាននាក់

មានប្រជាជនប្រហែលមួយលាននាក់បានស្លាប់ដោយសារគ្រោះអត់ឃ្លាន និងជំងឺឆ្លង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំប៉ុណ្ណោះ។

អំឡុងពេលនៃគ្រោះអត់ឃ្លាន មានប្រជាជនប្រមាណមួយលាននាក់កន្លះបានរត់ចេញពីអៀកឡង់។ ភាគច្រើននៃពួកគេធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិក មួយចំនួនទៀតទៅកាន់អង់គ្លេស, កាណាដា, និងអូស្ត្រាលី។ ចំណែកនៅក្នុងប្រទេសអៀកឡង់ រដ្ឋាភិបាលអង់គ្លេសបានបង្ខំឱ្យពួកប្រជាកសិករអៀកឡង់បង់ប្រាក់ថ្លៃជួលដីតាមការទាមទាររបស់ម្ចាស់កម្មសិទ្ធិដីជនជាតិអង់គ្លេស។ ពួកជនជាតិអៀកឡង់ជាច្រើនបានបាត់បង់ដីធ្លីរបស់ពួកគេ និងធ្លាក់ខ្លួនទៅជាអ្នកជំពាក់បំណុលគេ ខណៈពេលដែលម្ចាស់កម្មសិទ្ធិដីធ្លីទទួលបានអត្ថប្រយោជន៍ពីការឡើងថ្លៃនៃតម្លៃចំណីអាហារ។

ការទាមទារដើម្បីគ្រប់គ្រងប្រទេស៖ អំឡុងនៃពាក់កណ្តាលទី 2 នៃឆ្នាំ 1800 ការប្រឆាំងទៅនឹងការគ្រប់គ្រងរបស់អង់គ្លេសលើប្រទេសអៀកឡង់មានទម្រង់ពីរ។ ពួកអៀកឡង់មួយចំនួនចង់បានឯករាជ្យសម្រាប់អៀកឡង់។ ពួកអៀកឡង់មួយភាគធំទៀតចង់បានការគ្រប់គ្រងប្រទេសដោយខ្លួនឯង ដែលម្ចាស់ប្រទេសអាចគ្រប់គ្រងបានតែលើកិច្ចការផ្ទៃក្នុងតែប៉ុណ្ណោះ។ ពួកអង់គ្លេសភាពច្រើនមានការភ័យខ្លាចថាពួកអៀកឡង់នឹងបន្តឆ្ពោះទៅរកការទាមទារឯករាជ្យ ដូច្នេះពួកគេបានបដិសេធចំពោះសំណើរទាំងនេះ។ មានហេតុផលមួយដែលអង់គ្លេសបដិសេធក្នុងការផ្តល់ការគ្រប់គ្រងប្រទេសដោយខ្លួនឯងដល់អៀកឡង់ គឺទាក់ទងទៅនឹងការព្រួយបារម្ភអំពីអ្នកកាន់សាសនាប្រូទេស្តង់នៅអៀកឡង់។ ពួកគេខ្លាចថាពួកអ្នកកាន់សាសនាប្រូទេស្តង់ទាំងនោះនឹងក្លាយជាជនភាគតិចមួយនៅក្នុងប្រទេសអៀកឡង់ ដែលកគ្របដណ្តប់ទៅដោយពួករ៉ូម៉ាំងកាតូលិក។ ពួកប្រូទេស្តង់ភាគច្រើនរស់នៅអៀកឡងភាគខាងជើង ដែលគេស្គាល់ថា អូលស្ទ័រ ។ ចុងក្រោយ នៅក្នុងឆ្នាំ 1914 សភាតំណាងរាស្ត្របានពិភាក្សាច្បាប់នៃការគ្រប់គ្រងប្រទេសដោយខ្លួនឯងសម្រាប់អៀកឡង់ភាគខាងត្បូង។ មួយខែមុនពេលច្បាប់នេះត្រូវបានអនុម័ត សង្គ្រាមលោកលើកទីមួយបានផ្ទុះឡើងនៅទ្វីបអឺរ៉ុប។ ការគ្រប់គ្រងប្រទេសដោយខ្លួនឯងរបស់អៀកឡង់ត្រូវបានពន្យាពេល។

ការបះបោរ និងការបែងចែក៖ ដោយមិនសប្បាយចិត្តចំពោះការពន្យាពេលក្នុងការទទួលបានឯករាជ្យ ក្រុមអ្នកជាតិនិយមអៀកឡង់មួយក្រុមបានធ្វើការបះបោរនៅឌូប្លីន អំឡុងថ្ងៃបុណ្យអីស្ទ័រ នៅក្នុងឆ្នាំ 1916 ។ កងទ័ពអង់គ្លេសបានបង្ក្រាបការងើបបះបោរថ្ងៃបុណ្យអីស្ទ័រ និងបានប្រហារជីវិតមេដឹកនាំចលនានេះ។ ប៉ុន្តែ ភាពរងគ្រោះរបស់ពួកគេបានដាស់ប្រជាជនអៀកឡង់យ៉ាងច្រើនឱ្យគាំទ្រចលនាជាតិនិយម។ បន្ទាប់ពីសង្គ្រាមលោកលើកទី 1 ចប់ អ្នកជាតិនិយមអៀកឡង់បានទទួលជ័យជំនះនៅក្នុងការបោះឆ្នោតនៅក្នុងសភាតំណាងរាស្ត្រអង់គ្លេស។ ដើម្បីប្រឆាំងជាមួយនឹងការពន្យាការគ្រប់គ្រងប្រទេសដោយខ្លួនឯង សមាជិកអ្នកជាតិនិយមបានសម្រេចចិត្តនៅក្នុងការមិនចូលប្រជុំនៅក្នុងសភាតំណាងរាស្ត្រ។ ជំនួសទៅវិញ ពួកគេបានបង្កើតរដ្ឋាភិបាលអៀកឡង់លួចលាក់មួយ និងបានប្រកាសឯករាជ្យជាឯកតោភាគី។ កងទ័ពសាធារណរដ្ឋអៀកឡង់ ជាកងទ័ពមិនផ្លូវការមួយបង្កើតឡើងដើម្បីទាមទារឯករាជ្យដល់អៀកឡង់ បានធ្វើការវាយប្រហារជាច្រើនលើកប្រឆាំងជាមួយនឹងមន្ត្រីអង់គ្លេសនៅក្នុង

ប្រទេសអៀកឡង់។ ការវាយប្រហារនេះបានបញ្ឆេះឱ្យមានសង្គ្រាមរវាងអ្នកជាតិនិយមជាមួយនឹងរដ្ឋាភិបាលអង់គ្លេស។ នៅក្នុងឆ្នាំ 1921 អង់គ្លេសបានបែងចែកអៀកឡង់ជា 2 ហើយអៀកឡង់ខាងត្បូងទទួលបានការគ្រប់គ្រងប្រទេសដោយខ្លួនឯង។ អូស្ទ័រ ឬអៀកឡង់ខាងជើងនៅបន្តជាផ្នែកមួយនៃចក្រភពអង់គ្លេស។ អៀកឡង់ខាងត្បូងបានក្លាយជាអាណាចក្រមួយដែលមានឈ្មោះថា រដ្ឋឯករាជ្យអៀកឡង់។ ប៉ុន្តែ អ្នកជាតិនិយមអៀកឡង់ជាច្រើន នៅតែបន្តទាមទារឯករាជ្យពេញលេញពីចក្រភពអង់គ្លេស។ នៅក្នុងឆ្នាំ 1949 រដ្ឋឯករាជ្យអៀកឡង់ បានប្រកាសជាឯកតោភាគីនូវឯករាជ្យរបស់សាធារណរដ្ឋអៀកឡង់។

# មេរៀនទី 3 ៖ សង្គ្រាមដើម្បីពង្រីកដែនដីនៅសហរដ្ឋអាមេរិក

## 1. អាមេរិកពង្រីកទៅភាគខាងលិច

នៅក្នុងឆ្នាំ 1803 ប្រធានាធិបតី ថូម៉ាស់ ដេហ្វឺសុន បានទិញទឹកដី លូីសៀណា ពីបារាំង។ ការទិញដែនដី លូីសៀណា បានបង្កើនទំហំផ្ទៃដីសាធារណរដ្ឋថ្មីគុណនិង 2 និងបានពង្រីកព្រំប្រទល់របស់ពួកគេដល់តំបន់ជួរភ្នំរ៉ូឃី។ នៅក្នុងឆ្នាំ 1819 ប្រទេសអេស្ប៉ាញបានប្រគល់ដែនដីផ្លរីដាឱ្យទៅសហរដ្ឋអាមេរិក។ នៅក្នុងឆ្នាំ 1846 សន្ធិសញ្ញាមួយជាមួយចក្រភពអង់គ្លេសបានផ្តល់ឱ្យសហរដ្ឋអាមេរិកទឹកដី អូរេហ្គុនមួយផ្នែក។ សហរដ្ឋអាមេរិកនៅពេលនោះលាតសន្ធឹងចាប់ពីមហាសមុទ្រអាត្លង់ទិកដល់មហាសមុទ្រប៉ាស៊ីហ្វិក។

ជោគវាសនាជាក់ស្តែង៖ ប្រជាជនអាមេរិកជាច្រើនជឿលើជោគវាសនាជាក់ស្តែង ជាគំនិតមួយដែលថាសហរដ្ឋអាមេរិកមានសិទ្ធិ និងកាតព្វកិច្ចនៅក្នុងការដឹកនាំអាមេរិកខាងជើងចាប់ពីមហាសមុទ្រអាត្លង់ទិកដល់មហាសមុទ្រប៉ាស៊ីហ្វិក។ មេដឹកនាំរដ្ឋាភិបាលបានប្រើប្រាស់ជោគវាសនាជាក់ស្តែងដើម្បីធ្វើជាហេតុផលបណ្តេញពួកជនជាតិដើមអាមេរិកចេញពីដែនដីកុលសម្ព័ន្ធរបស់ពួកគេ។

ច្បាប់ដកពួកឥណ្ឌាចេញ នៅក្នុងឆ្នាំ 1830 បានធ្វើឱ្យសកម្មភាពមួយចំនួនក្លាយជាគោលនយោបាយផ្លូវការ។ ច្បាប់នេះអនុញ្ញាតឱ្យរដ្ឋាភិបាលសហព័ន្ធបង្ខំឱ្យជនជាតិដើមអាមេរិកដែលរស់នៅភាគខាងកើត ឱ្យផ្លាស់ទីទៅកាន់ភាគខាងលិច។ ក្រុមកុលសម្ព័ន្ធឆេរ៉ូគី នៅក្នុងរដ្ឋចចៀ បានប្រឆាំងជាមួយនឹងច្បាប់នេះ និងបានប្តឹងទៅកាន់តុលាការកំពូល។ ប៉ុន្តែ ចៅក្រមបានប្រកាសថា ការប្តឹងទាស់នេះយកជាការមិនបាន។ ពួកឆេរ៉ូគី ត្រូវតែផ្លាស់ទីកន្លែង។ ពួកគេភាគច្រើនធ្វើដំណើរក្នុងចម្ងាយផ្លូវ 800 ម៉ាយទៅកាន់រដ្ឋអូខ្លាហូម៉ា ដោយភាគច្រើនធ្វើដំណើរដោយថ្មើរជើង នៅក្នុងដំណើរមួយដែលក្រោយមកគេហៅថា ផ្លូវលំទឹកភ្នែក ។ ប្រហែលជា ¼ នៃពួកកុលសម្ព័ន្ធឆេរ៉ូគី បានស្លាប់នៅអំឡុងពេលធ្វើដំណើរនេះ។

នៅពេលដែលពួកឆេរ៉ូគី បានធ្វើដំណើរដល់គោលដៅរបស់ពួកគេ ពួកគេដេកនៅលើដីដែលក្រាលដោយអ្វីៗដែលពួកគេយកមកតាម។ នៅពេលដែលពួកអ្នកតាំងទីលំនៅផ្លាស់ទីទៅកាន់ភាគខាងលិចអំឡុងសតវត្សរ៍ទី 19 រដ្ឋាភិបាលបានបន្តរុញច្រើនជនជាតិដើមអាមេរិកឱ្យចាកចេញពីដីរបស់ពួកគេបន្តទៀត។

រដ្ឋតិចសាសចូលរួមជាមួយសហរដ្ឋអាមេរិក៖ នៅពេលដែលប្រទេសម៉ិកស៊ិកកូទទួលបានឯករាជ្យពីប្រទេសអេស្ប៉ាញនៅក្នុងឆ្នាំ 1821 ទឹកដីរបស់ពួកគេបានរួមបញ្ចូលទាំងដែនដីភាគខាងលិចរដ្ឋលូីសៀណា ដែលបានទិញពីបារាំង។ ជាមួយនឹងការអនុញ្ញាតរបស់ម៉ិកស៊ិកកូអ្នកតាំងទីលំនៅជនជាតិអាមេរិកបានផ្លាស់ទីទៅកាន់ទឹកដីម៉ិកស៊ិកកូនៅតិចសាស។ ប៉ុន្តែ ពួកអ្នកតាំងទីលំនៅមានការមិនសប្បាយចិត្តជាមួយនឹងការគ្រប់គ្រងរបស់ម៉ិកស៊ិកកូឡើយ។ នៅក្នុងឆ្នាំ 1836 ពួកតិចសាសធ្វើការបះបោរប្រឆាំងទៅនឹងការគ្រប់គ្រងរបស់ម៉ិកស៊ិកកូ ហើយចុងក្រោយពួកគេទទួលបានឯករាជ្យ។ បន្ទាប់មក នៅក្នុងឆ្នាំ 1845 សហរដ្ឋអាមេរិកបានបញ្ចូលរដ្ឋតិចសាសជា

ឧបសម្ព័ន្ធ។ នៅពេលនោះម៉ិកស៊ិកកូនៅតែចាត់ទុកតិចសាសថាជាដែនដីរបស់ពួកគេ គេយល់ថាការភ្ជាប់នេះគឺជាការប្រកាសសង្គ្រាមមួយ។

សង្គ្រាមជាមួយម៉ិកស៊ិកកូ៖ នៅរវាងខែឧសភា ឆ្នាំ 1846 និងខែកុម្ភៈ ឆ្នាំ 1848 សង្គ្រាមបានផ្ទុះឡើងរវាងប្រទេសទាំងពីរ។ ចុងក្រោយ ម៉ិកស៊ិកកូចុះចាញ់។ ជាការសងទៅនឹងការខាតបង់នៅក្នុងសង្គ្រាមអាមេរិក-ម៉ិកស៊ិកកូ ម៉ិកស៊ិកកូបានកាត់ទឹកដីរបស់ពួកគេឱ្យទៅសហរដ្ឋអាមេរិក។ ដែនដីដែលម៉ិកស៊ិកកូកាត់ទៅឲ្យអាមេរិកនោះរួមមានរដ្ឋកាលីហ្វ័រនៀ និងតំបន់ដ៏ធំមួយនៅភាគនិរតី។ នៅក្នុងឆ្នាំ 1853 រដ្ឋហ្គាដស្តេនត្រូវបានទិញពីម៉ិកស៊ិកកូ ដែលបាននាំឱ្យទឹកដីទីបរបស់សហរដ្ឋអាមេរិកបានរីកធំប៉ុនទំហំសព្វថ្ងៃ។

## 2. សង្គ្រាមស៊ីវិលសាគស្បេងពីប្រជាធិបតេយ្យ

ការពង្រីកទឹកដីរបស់អាមេរិកឆ្ពោះទៅភាគខាងលិចបានចោទជាសំណួរមួយដែលថា តើច្បាប់ និងប្រពៃណីអ្វីដែលត្រូវប្រើប្រាស់នៅភាគខាងលិច។ ចាប់តាំងពីរដ្ឋនេះចាប់ផ្តើមដំបូង ផ្នែកខាងជើង និងខាងត្បូងនៃសហរដ្ឋអាមេរិកមានវិធីរស់នៅផ្សេងៗគ្នា។ ផ្នែកនីមួយៗចង់ពង្រីករបៀបរស់នៅរបស់ពួកគេទៅកាន់ទឹកដី និងរដ្ឋថ្មីៗនៅភាគខាងលិច។

ភាគខាងជើង និងខាងត្បូង៖ តំបន់ភាគខាងជើងមានសេដ្ឋកិច្ចចម្រុះមួយ ដែលមានទាំងកសិកម្ម និងឧស្សាហកម្ម។ ទាំងរោងចក្រ និងស្រែចំការ ពួកភាគខាងជើងពឹងផ្អែកលើកម្មករមានសេរីភាព។ ផ្ទុយទៅវិញ សេដ្ឋកិច្ចនៅភាគខាងត្បូង គឺពឹងផ្អែកលើការដាំដំណាំគ្រប់ធុញ្ញជាតិមួយចំនួនតូចប៉ុន្តែ សល់ពីនោះភាគច្រើនគឺជាដំណាំកប្បាស។ ក្រុមអ្នកដាំដំណាំនៅភាគខាងត្បូងពឹងផ្អែកលើកម្លាំងពលកម្មរបស់ទាសករ។

ភាពខុសគ្នានៃសេដ្ឋកិច្ចរបស់តំបន់ទាំង 2 នេះ បាននាំទៅដល់ជម្លោះមួយទាក់ទងនឹងរបបទាសភាព។ ប្រជាជនភាគខាងជើងជាច្រើនចាត់ទុកថារបបទាសភាពគឺជារឿងដែលខុសទៅនឹងសិលធម៌។ ពួកគេចង់លុបបំបាត់របបទាសភាពនៅក្នុងរដ្ឋថ្មីៗភាគខាងលិច។ ប្រជាជនភាគខាងជើងដែលភាគច្រើនជាពួកស្បែកស ជឿថាទាសករមានភាពចាំបាច់សម្រាប់សេដ្ឋកិច្ចរបស់ពួកគេ។ ពួកគេចង់បានច្បាប់មួយដើម្បីការពាររបបទាសភាពនៅភាគខាងលិច ដូច្នេះពួកគេអាចបន្តដាំដុះដំណាំកប្បាសនៅលើផ្ទៃដីដែលមានដីជាតិទាំងនោះបាន។ ការខ្វែងគំនិតគ្នាលើបញ្ហារបបទាសភាពនេះបាន បង្កើតឱ្យមានជជែកគ្នាអំពីសិទ្ធិរបស់រដ្ឋនីមួយៗទល់ជាមួយនឹងរដ្ឋាភិបាលសហព័ន្ធ។ អ្នកនយោបាយភាគខាងត្បូងទទូចថា រដ្ឋនានាមានសិទ្ធិសេរីភាពនៅក្នុងការចូលសហព័ន្ធ ដូច្នេះពួកគេមានសិទ្ធិសេរីភាពនៅក្នុងការចាកចេញ។ ពួកភាគខាងជើងភាគច្រើនគិតថា រដ្ឋធម្មនុញ្ញ បានបង្កើតសហព័ន្ធមួយឡើងសម្រាប់រដ្ឋទាំងអស់។

សង្គ្រាមស៊ីវិលផ្ទុះឡើង៖ ជម្លោះរវាងពួកភាគខាងជើង និងភាគខាងត្បូងបានឈានដល់កម្រិតខ្ពស់បំផុតនៅក្នុងឆ្នាំ 1860 នៅពេលដែលលោក អាប្រាហាំ លីនឃុន ត្រូវបានបោះឆ្នោះជាប់ជាប្រធានាធិបតី។ ពួកភាគខាងត្បូងប្រឆាំងយ៉ាងខ្លាំងជាមួយនឹងលោក លីនឃុន ដែលបានសន្យានៅក្នុងការបញ្ឈប់ការរីករាលដាលនៃរបប

ទាសភាព។ ម្តងមួយៗ រដ្ឋនានានៅភាគខាងត្បូងចាប់ផ្តើមបែក ឬដកខ្លួនចេញពីសហព័ន្ធ។ រដ្ឋទាំងនោះបានរួមបញ្ចូលគ្នាក្លាយជា រដ្ឋសម្ព័ន្ធអាមេរិក។

នៅថ្ងៃទី 12 ខែមេសា ឆ្នាំ 1861 កងកម្លាំងសម្ព័ន្ធបានវាយប្រហារលើបន្ទាយសាំទ័រ ដែលជាបន្ទាយមួយរបស់រដ្ឋសហព័ន្ធនៅឆាលេស្តុន រដ្ឋការ៉ូលីណាខាងត្បូង។ លោកលីនឃុន បានបញ្ជាឱ្យកងទ័ពនាំយករដ្ឋបះបោរមកដាក់ក្រោមការគ្រប់គ្រងរបស់សហព័ន្ធវិញ។ សង្គ្រាមស៊ីវិលនៅសហរដ្ឋអាមេរិកបានចាប់ផ្តើមឡើង។ មានការប្រយុទ្ធគ្នាអស់រយៈពេល 4 ឆ្នាំ ដែលភាគច្រើនធ្វើឡើងនៅភាគខាងត្បូង។ បើទោះបីជាពួកខាងត្បូងមានមេដឹកនាំយោធាខ្លាំងក្លាក៏ដោយ តែពួកភាគខាងជើងមានប្រជាជនច្រើនជាង, ផ្លូវដឹកជញ្ជូនល្អជាង, មានធនធានច្រើនជាង, និងមានរោងចក្រច្រើនជាង។ អត្ថប្រយោជន៍ទាំងនេះធ្វើឱ្យពួកភាគខាងជើងមានប្រៀបយ៉ាងខ្លាំង ហើយនៅក្នុងខែមេសា ឆ្នាំ 1865 ពួកភាគខាងត្បូងបានចុះចាញ់។

ការបោះបង់ចោលនូវរបបទាសភាព៖ លោកលីនឃុនបានប្រកាសថា សង្គ្រាមដែលកើតមានឡើងគឺដើម្បីការពារសហព័ន្ធ និងមិនមែនដើម្បីបញ្ចប់របបទាសភាពលោក។ ដោយថាហេតុ លោកបានសម្រេចថា ការបញ្ចប់របបទាសភាពនឹងជួយការពារដល់សហព័ន្ធ។ នៅដើមឆ្នាំ 1863 លោកបានចេញ សេចក្តីប្រកាសស្តីពីការផ្តល់សិទ្ធិសេរីភាព ដោយបានប្រកាសថា រាល់ទាសករទាំងឡាយនៅក្នុងរដ្ឋសម្ព័ន្ធត្រូវមានសេរីភាពឡើងវិញ។ ដំបូងឡើយ ការធ្វើសេចក្តីប្រកាសនេះមិនបានផ្តល់សិទ្ធិសេរីភាពដល់ទាសករណាម្នាក់ឡើយ ដោយសារតែរដ្ឋសម្ព័ន្ធនានាមិនបានទទួលយកច្បាប់នេះឡើយ។ ប៉ុន្តែ នៅពេលដែលកងទ័ពសហព័ន្ធបានធ្វើដំណើរទៅដល់ភាពខាងត្បូង ពួកគេបានផ្តល់សេរីភាពដល់ទាសករក្នុងតំបន់ដែលពួកគេដណ្តើមកាន់កាប់បាន។ សេចក្តីប្រកាសស្តីពីការផ្តល់សិទ្ធិសេរីភាព ក៏បានបង្ហាញប្រទេសនៅអឺរ៉ុបនានាថា សង្គ្រាមធ្វើឡើងដើម្បីប្រឆាំងជាមួយរបបទាសភាព។ ជាលទ្ធផល ប្រទេសទាំងនេះមិនបានបញ្ជូនលុយ និងការផ្គត់ផ្គង់នានាដែលពួកភាគខាងត្បូងសង្ឃឹមថាពួកគេនឹងទទួលបាន។ បន្ទាប់ពីសង្គ្រាម សភាសហរដ្ឋអាមេរិកបានអនុម័ត ច្បាប់វិសោធនកម្មទី 13 នៅក្នុងធម្មនុញ្ញ ដែលបានលុបបំបាត់របបទាសភាពនៅក្នុងសហរដ្ឋអាមេរិក។ ច្បាប់វិសោធនកម្មទី 14 និងច្បាប់វិសោធនកម្មទី 15 បានពង្រីកសិទ្ធិសេរីភាពដល់ប្រជាពលរដ្ឋអាមេរិកទាំងអស់ និងធានាដល់សិទ្ធិនៅក្នុងបោះឆ្នោតរបស់អតីតទាសករ។

ការស្តាបនាឡើងវិញ៖ ចាប់ពីឆ្នាំ 1865-1877 កងទ័ពរបស់សហព័ន្ធបានកាន់កាប់តំបន់ភាគខាងត្បូង និងបានដាក់តំបន់នោះជាតំបន់អាណាព្យាបាល។ សម័យកាលនេះត្រូវបានគេហៅថា ការស្តាបនាឡើងវិញ។ បន្ទាប់ពីពួកកងទ័ពសហព័ន្ធចកចេញពីតំបន់ភាគខាងត្បូង ពួកស្បែកសនៅភាគខាងត្បូងបានអនុម័តច្បាប់នានាដែលកម្រិតសិទ្ធិសេរីភាពរបស់ប្រជាជនអាមេរិកមានដើមកំណើតអាហ្វ្រិក ហើយធ្វើឱ្យពួកគេមានភាពលំបាកនៅក្នុងការបោះឆ្នោត។ ច្បាប់មួយចំនួនក៏បានលើកទឹកចិត្តឱ្យមានការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នារវាងពួកស្បែកខ្មៅ និងស្បែកសនៅភាគខាងត្បូង។ ប្រជាជនអាមេរិកមានដើមកំណើតអាហ្វ្រិក ក៏បន្តទទួលបានការរើសអើងនៅភាគខាងជើងផងដែរ។

### 3. សេដ្ឋកិច្ចក្រោយសង្គ្រាម

តម្រូវការនៃផលិផលដ៏ច្រើន និងការចែកចាយទំនិញអំឡុងពេលនៃសង្គ្រាមស៊ីវិលបានបង្កើនល្បឿនឧស្សាហូបនីយកម្ម។ បន្ទាប់ពីសង្គ្រាម សហរដ្ឋអាមេរិកបានជួបប្រទះនូវការពង្រីកឧស្សាហាកម្មយ៉ាងខ្លាំងនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ត្រឹមឆ្នាំ 1914 ប្រទេសនេះបានក្លាយជាប្រទេសនាំមុខគេខាងឧស្សាហាកម្ម។

ការធ្វើអន្តោប្រវេសន៍៖ ឧស្សាហូបនីយកម្មមិនអាចនឹងកើតមានយ៉ាងឆាប់រហ័សបានទេ ប្រសិនបើគ្មានការធ្វើអន្តោប្រវេសន៍។ អំឡុងទសវត្សរ៍ឆ្នាំ 1870 ពួកអ្នកធ្វើអន្តោប្រវេសន៍បានមកដល់សហរដ្ឋអាមេរិក គឺជាមធ្យមប្រមាណ 2,000 នាក់ក្នុងមួយថ្ងៃ។ ត្រឹមឆ្នាំ 1914 មានមនុស្សប្រមាណ 20 លាននាក់មានផ្លាស់ទីលំនៅទៅកាន់សហរដ្ឋអាមេរិក ដែលក្នុងនោះមកពីអឺរ៉ុប និងអាស៊ី។ ពួកគេភាគច្រើនតាំងទីលំនៅនៅក្នុងទីក្រុងនានានៅភាគឦសាន និងខាងលិចកណ្ដាល។ អ្នកមួយចំនួនទៀតតាំងទីលំនៅនៅតំបន់ល្ហល្ហេវភាគខាងលិច។

ផ្លូវរថភ្លើង៖ ដូចដែលអ្នកតាំងទីលំនៅបានផ្លាស់ទៅកាន់ភាគខាងលិច ដូច្នេះប្រព័ន្ធរថភ្លើងក៏ត្រូវបានតភ្ជាប់ទៅកាន់ទីនោះផងដែរ។ នៅក្នុងឆ្នាំ 1862 សភាបានអនុម័តថវិកានៅក្នុងស្ថាបនាផ្លូវរថភ្លើងឆ្លងទ្វីបមួយ។ អស់រយៈពេល 7 ឆ្នាំ អ្នកធ្វើអន្តោប្រវេសន៍ និងកម្មករផ្សេងទៀតជីករូងភ្នំ, ស្ថាបនាស្ពាន, និងដំឡើងផ្លូវដែក។ នៅពេលដែលផ្លូវដែកត្រូវបានស្ថាបនារួចរាល់នៅក្នុងឆ្នាំ 1869 ផ្លូវដែកនោះបានភ្ជាប់រដ្ឋកាលីហ្វ័រញ៉ា ជាមួយនឹងអាមេរិកភាគខាងកើត។

ត្រឹមឆ្នាំ 1900 ផ្លូវដែកប្រហែល 20 ម៉ឺនម៉ាយបានរត់ឆ្លងកាត់សហរដ្ឋអាមេរិក។ ប្រព័ន្ធផ្លូវដែកនេះបានភ្ជាប់ស្រុកស្រែចំការជាមួយទីក្រុង និងលើកកម្ពស់ពាណិជ្ជកម្ម និងឧស្សាហាកម្ម។ ផ្លូវដែលត្រូវបានប្រើដើម្បីដឹកជញ្ជូនដែកក្នុងបរិមាណដ៏ច្រើន។ ដូចគ្នាផងដែរ រថភ្លើងបានដឹកជញ្ជូនធនធានមួយចំនួនដូចជា ធ្យូងថ្ម និងដែកទៅកាន់រោងចក្រ និងដឹកជញ្ជូនផលិតផលសម្រេចទៅកាន់ទីផ្សារ។ រថភ្លើងក៏បាននាំយកពោត, ស្រូវសាលី, និងសត្វពាហនៈពីតំបន់វាលទំនាបទៅកាន់តំបន់កែច្នៃបន្តនៅសេនល្វី, ឆីកាហ្គោ, និង មីននីប៉ូលីស ។ ការអភិវឌ្ឍនេះបានជួយឱ្យសហរដ្ឋអាមេរិកក្លាយជាមេដឹកនាំនៅលើពិភពលោក។

# មេរៀនទី 4 ៖ ភាពជឿនលឿននៅសតវត្សរ៍ទី 19

## 1. ការបង្កើតថ្មីធ្វើឱ្យជីវិតកាន់តែខាយស្រួល

នៅដើមទសវត្សរ៍ឆ្នាំ 1800 ធ្យូងថ្ម និងចំហាយទឹកធ្វើឱ្យម៉ាស៊ីនឧស្សាកម្មដំណើរការ។ ត្រឹមចុងទស្សវត្សរ៍ឆ្នាំ 1800 ថាមពលថ្មីៗត្រូវបានគេយកមកប្រើប្រាស់។ នៅក្នុងនោះមាន ប្រេងឥន្ធនៈ(ផលិតមកពីប្រេងកាត) ដែលបានបង្កើតចំហេះនៅក្នុងតួម៉ាស៊ីន។ ម៉ាស៊ីនប្រភេទនេះនឹងធ្វើឱ្យយានយន្តដំណើរការបាន។ ថាមពលមួយផ្សេងទៀតគឺ អគ្គិសនី។ នៅក្នុងទសវត្សរ៍ឆ្នាំ 1870 ម៉ាស៊ីនផលិតអគ្គិសនីត្រូវបានអភិវឌ្ឍឡើង ដែលបានបង្កើតចរន្តមួយដែលអាចធ្វើឱ្យម៉ាស៊ីនដំណើរការបាន។

ការបង្កើតថ្មីរបស់លោក អេឌីសុន៖ អំឡុងពេលនៃការធ្វើការងារ លោក ថូម៉ាស អេឌីសុន បានបង្កើតវត្ថុថ្មីៗបានជាងមួយពាន់ ដោយក្នុងនោះរួមមាន អំពូលភ្លើង និងឧបករណ៍បំពងសំលេង។ នៅពេលដែលលោកធ្វើការដំបូង លោក អេឌីសុន បានបង្កើតមន្ទីរស្រាវជ្រាវមួយនៅ ឧទ្យានមេនឡូ រដ្ឋញូវជើស៊ី ។ ភាគច្រើននៃស្នាដៃសំខាន់ៗរបស់លោក ត្រូវបានបង្កើតនៅទីនោះ ជាមួយនឹងជំនួយពីពួកអ្នកស្រាវជ្រាវនានាដែលលោកបានជួលមកធ្វើការដែលក្នុងនោះមានដូចជាលោក ឡេវីស អេជ. ឡាទីម័រ ជាដើមដែលជាអ្នកបង្កើតថ្មីជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក។ ជាការពិតណាស់ គំនិតអំពីការបង្កើតមន្ទីរស្រាវជ្រាវគឺជាការបង្កើតថ្មីដ៏សំខាន់បំផុតរបស់លោក អេឌីសុន ។

បដិវត្តនៅក្នុងការធ្វើទំនាក់ទំនងរបស់លោកប៊ែល និងម៉ាកូនី៖ អ្នកបង្កើតថ្មីផ្សេងទៀតបានប្រើប្រាស់បណ្តាញអគ្គិសនីដើម្បីបញ្ជូនសំលេងបានឆ្ងាយ។ លោកអាឡិចសាន់ដឺ ហ្គ្រាហាំ ប៊ែល គឺជាគ្រូបង្រៀនសិស្សគរថ្លង់មួយរូបដែលបានបង្កើតទូរស័ព្ទនៅអំឡុងពេលទំនេររបស់លោក។ លោកបានដាក់តាំងបង្ហាញឧបករណ៍របស់លោកនៅក្នុងកម្មវិធីពិព័រណ៍នៅហ្វីឡាដែលហ្វៀនៅក្នុងឆ្នាំ 1876 ។ អ្នកបង្កើតថ្មីជនជាតិអ៊ីតាលីលោកហ្គូលីអ៊ែលម៉ូ ម៉ាកូនីបានប្រើប្រាស់ទ្រឹស្តីដែលលោកស្រាវជ្រាវរកឃើញអំពីរលកម៉ាញ៉េទិក ដើម្បីបង្កើតវិទ្យុជាលើកដំបូងនៅក្នុង 1895 ។ ឧបករណ៍នេះមានសារៈសំខាន់ណាស់ ដោយសារវាអាចបញ្ជូនសារ (ប្រើប្រាស់កូដសំលេង) តាមរយៈរលកខ្យល់ ដោយមិនចាំបាច់ប្រើខ្សែ។ វិទ្យុដំបូងបំផុតបានក្លាយជាឧបករណ៍ទូទៅមួយសម្រាប់នាវានៅសមុទ្ទ។

លោកហ្វ័តបញ្ឆេះឧស្សាហកម្មយានយន្ត៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1880 អ្នកបង្កើតថ្មីជនជាតិអាឡឺម៉ង់បានប្រើប្រាស់ម៉ាស៊ីនប្រើប្រេងឥន្ធនៈដើម្បីធ្វើឱ្យយានជំនិះទៅមុខ-យានយន្ត។ បច្ចេកវិទ្យាយានយន្តត្រូវបានអភិវឌ្ឍយ៉ាងឆាប់ ប៉ុន្តែចាប់តាំងពីដើមដំបូងរថយន្តត្រូវបានផលិតដោយដៃ វាមានតម្លៃថ្លៃ។ យន្តការីជនជាតិអាមេរិកម្នាក់ឈ្មោះ ហេនរី ហ្វ័ត បានសម្រេចនៅក្នុងការផលិតរថយន្តដែលមានលក្ខណៈថោកល្មមសម្រាប់មនុស្សនានា។ លោក ហ្វ័ត ប្រើប្រាស់ទម្រង់រួមមួយ និងអាចផ្លាស់ប្តូរតាមផ្នែកបាន។ លោកក៏ផលិតវាជាលក្ខណៈខ្សែសង្វាក់មួយដែលនៅក្នុងខ្សែសង្វាក់នេះកម្មករដំឡើងផ្នែកមួយលើរថយន្តដែលមិនទាន់បញ្ចប់ បន្ទាប់មកពួកគេបញ្ជូនរថយន្តនោះបន្តទៅផ្នែកផ្សេងទៀត។ កម្មករនៅក្នុងខ្សែសង្វាក់អាចតម្លើងរថយន្តប្រភេទ ធី ហ្វ័ត មួយទាំងមូលបាននៅក្នុងរយៈតិចជាង 2 ម៉ោង។ នៅពេលដែលលោក បានបង្ហាញពីរថយន្តដែលរាបស្មើ, ពណ៌ខ្មៅ, និងអាចទុកចិត្តបានរបស់លោកនៅក្នុងឆ្នាំ 1908 រថយន្តនេះមានតម្លៃ 850 ដុល្លា។ ដូចដែលថ្លៃផលិតរបស់លោកមានតម្លៃទាប

ដូច្នេះលោកបានបញ្ចុះតម្លៃរថយន្តរបស់លោក។ ដោយហេតុ វាបានចុះមកនៅត្រឹមក្រោម 300 ដុល្លា។ រោងចក្រផ្សេងៗទៀតបានយកគំនិតរបស់លោក ហ្វ័ត ទៅប្រើ។ ត្រឹមឆ្នាំ 1916 រថយន្តប្រមាណ 3.5 លានគ្រឿងបានធ្វើដំណើរតាមដងវិថីនានានៅពាសពេញអាមេរិក។

ការហោះហើររបស់បងប្អូនរ៉ាយ ៖ យន្តការីទោចក្រយានយន្តពីររូបដែលមកពី ដេតុន រដ្ឋ អូហៃយ៉ូ ឈ្មោះថា វិលប៊ូ និង អូវីឡេ រ៉ាយ បានបង្កើតយន្តហោះមួយ។ នៅថ្ងៃទី 17 ខែធ្នូ ឆ្នាំ 1907 ពួកគេបានហោះហើរយន្តហោះប្រើម៉ាស៊ីនមួយនៅ គីតទី ហក រដ្ឋការ៉ូលីណា ។ ការហោះហើរនេះមានរយៈពេលយូរបំផុត 59 វិនាទី ប៉ុន្តែវាបានចាប់ផ្តើមឧស្សាហកម្មយន្តហោះ។

## 2. គំនិតថ្មីអំពីឱសថ

ដូចដែលអ្នកបានរៀននៅក្នុងជំពូកមុន នៅសតវត្សរ៍មុនមានការបង្កើតវិធីសាស្ត្រស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ ឥឡូវវិធីសាស្ត្របែបវិទ្យាសាស្ត្រនេះ បាននាំមកនូវការយល់ដឹងកាន់តែច្បាស់អំពីធម្មជាតិ ក៏ដូចជាការអនុវត្ត។

ទ្រឹស្តីអំពីមេរោគនៃជំងឺ៖ ការរកឃើញដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រនៃឱសថគឺទ្រឹស្តីមេរោគនៃជំងឺ។ វាត្រូវបានអភិវឌ្ឍដោយជនជាតិបារាំងលោក ល្វីស ប៉ាស្ទ័រ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 ។ ខណៈពេលកំពុងពិសោធន៍ដំណើរការវិវត្តនៃអាកុល លោកប៉ាស្ទ័រ បានរកឃើញថាការវិវត្តនេះបណ្តាលមកពីពពួកសរីរៈអតិសុខុមដែលលោកហៅថាបាតេរី។ លោកក៏បានសិក្សាដឹងថា កម្តៅអាចសម្លាប់បាតេរីបាន។ ការនោះបាននាំលោកទៅរកការអភិវឌ្ឍដំណើរការនៃការកម្តៅសម្លាប់មេរោគ ដើម្បីសម្លាប់មេរោគនៅក្នុងសារធាតុរាវនានាដូចជាទឹកដោះគោជាដើម។ ភ្លាមៗនោះ លោក ប៉ាស្ទ័រ និងអ្នកដទៃទៀតចាប់ផ្តើមដឹងច្បាស់ថាបាតេរីក៏បង្កឱ្យមានជំងឺផងដែរ។ វេជ្ជបណ្ឌិតផ្នែកវះកាត់ជនជាតិអង់គ្លេសមួយរូបឈ្មោះចូសេប លីស្ទ័រ បានអានកិច្ចការរបស់លោកប៉ាស្ទ័រ ។ លោកបានគិតថា មេរោគជាមូលហេតុដែលនាំឱ្យអ្នកជំងឺដែលលោកវះកាត់ប្រហែលជាពាក់កណ្តាលស្លាប់ដោយសារឆ្លងរោគ។ នៅក្នុងឆ្នាំ 1865 លោកបានស្នើថា ឧបករណ៍សម្រាប់ធ្វើការវះកាត់របស់លោកត្រូវតែសម្អាតឱ្យបានស្អាតល្អ។ លោកបានទទូចថា របួសត្រូវតែលាងជាមួយថ្នាំសម្លាប់មេរោគ ឬសារធាតុរាវសម្រាប់សម្រាប់មេរោគ។ ជាលទ្ធផល 85 ភាគរយនៃអ្នកជំងឺរបស់លោក លីស្ទ័រ រស់រានមានជីវិតបន្ទាប់ពីការវះកាត់។ មន្ទីរពេទ្យផ្សេងៗទៀតបានអនុវត្តតាមវិធីសាស្ត្ររបស់លោកលីស្ទ័រ ។ មន្ត្រីសាធារណៈ ក៏ដូចគ្នាចាប់ផ្តើមយល់ដឹងថា ការសម្អាតអាចជួយការពារការរីករាលដាលនៃជំងឺ។ នៅក្នុងទីក្រុងគេបានស្ថាបនាប្រព័ន្ធបំពង់ទឹក និងប្រព័ន្ធលូបង្ហូរទឹកល្អយ និងអនុវត្តវិធានការមួយចំនួនទៀតដើម្បីលើកកម្ពស់សុខភាពសាធារណៈ។ ខណៈពេលនោះដែរ អ្នកស្រាវជ្រាវផ្នែកខាងវេជ្ជសាស្ត្របានអភិវឌ្ឍវ៉ាក់សាំង ឬថ្នាំព្យាបាលជំងឺកាចសាហាវមួយចំនួនដូចជា គ្រុនក្តៅ, គ្រុនពោះវៀន, ខាន់ស្លាក់, និងគ្រុនឈាម។ ការរកឃើញនេះបានជួយដល់មនុស្សឱ្យរស់នៅបានយូរ និងមានសុខភាពល្អជាងមុន។

## 3. គំនិតថ្មីអំពីវិទ្យាសាស្ត្រ

គ្មានគំនិតបែបវិទ្យាសាស្ត្រសម័យទំនើបណា បង្កឱ្យមានឡើងការខ្វែងគំនិតគ្នាដូចគំនិតបែបវិទ្យាសាស្ត្ររបស់ធម្មជាតិវិទូជនជាតិអង់គ្លេសលោក ឆាល ដារវីន ឡើយ។ មូលហេតុដែលនាំឱ្យមានការខ្វែងគំនិតគ្នានេះដោយសារ

ចម្លើយរបស់លោក ដារីន ប្រឈមជាមួយសំណួរអ្នកជីវៈវិទូថា៖ តើយើងអាចពន្យល់ពីការកកើតឡើងនៃរុក្ខជាតិ និងសត្វជាច្រើនប្រភេទនៅលើផែនដីដោយរបៀបណា? ចម្លើយដែលគេទទួលយកជាទូទៅនៅក្នុងទសវត្សរ៍ឆ្នាំ 1800 គឺថា វាជាការបង្កើតដ៏ពិសេសមួយ រុក្ខជាតិ និងសត្វគ្រប់ប្រភេទទាំងអស់ ត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់នៅពេលដែលភពផែនដីកើតឡើងផ្តើមដំបូង ហើយបន្តនៅដដែលរហូតមកដល់សព្វថ្ងៃ។

ទ្រឹស្តីនៃការវិវត្តនៃរបស់លោកដារីន៖ លោកដារីន បានប្រឆាំងជាមួយគំនិតស្តីអំពីការបង្កើតពិសេស។ ផ្អែកទៅលើការស្រាវជ្រាវរបស់លោក ក្នុងនាមជាធម្មជាតិវិទូមួយរូបនៅក្នុងការធ្វើដំណើរតាមសមុទ្របីហ្គល លោកបានអភិវឌ្ឍទ្រឹស្តីមួយដែលថារាល់ជីវិតទាំងអស់ រួមទាំងមនុស្សផង បានវិវត្តចេញមកពីជីវិតដំបូងមួយ ដែលកើតមានឡើងរាប់លានឆ្នាំមកហើយ។ នៅក្នុងឆ្នាំ 1859 លោកដារីន បានបោះពុម្ពផ្សាយទស្សនៈរបស់លោកនៅក្នុងសៀវភៅមួយដែលមានចំណងជើងថា ដើមកំណើតនៃអម្បូរនានាតាមរយៈការសម្របខ្លួនជាមួយធម្មជាតិ។ យោងតាមគំនិតអំពី ការសម្របខ្លួនទៅនឹងធម្មជាតិ ប្រជាជនអាចនឹងកើនឡើងលឿនជាងការផ្គត់ផ្គង់ចំណីអាហារ ដូច្នេះពួកគេត្រូវត្រូវដណ្តើមចំណីអាហារគ្នា។ សមាជិកនៅក្នុងក្រុមមួយដែលនៅរស់រានមានជីវិតបាន គឺជាអ្នកដែលចេះសម្របខ្លួនយ៉ាងប្រសើរទៅនឹងបរិស្ថានដែលពួកគេរស់នៅ។ សមាជិកក្រុមដែលនៅរស់រានទាំងនេះបានបង្កើតកូនចៅដែលនឹងចេះសម្របខ្លួនដូចពួកគេដែរ។ បន្តិចម្តងៗ អស់រយៈពេលជាច្រើនជំនាន់ ក្រុមនេះនឹងធ្វើការផ្លាស់ប្តូរ។ នៅក្នុងវិធីនេះ ក្រុមថ្មីមួយទៀតនឹងវិវត្តឡើងខុសពីក្រុមចាស់។ គំនិតរបស់លោក ដារីន ស្តីអំពីការផ្លាស់ប្តូរតាមរយៈការសម្របខ្លួនទៅនឹងធម្មជាតិត្រូវបានគេហៅថា ទ្រឹស្តីនៃការវិវត្ត។

លោកមេនដេល និងហ្សែន៖ បើទោះបីជាលោក ដារីន បាននិយាយថា របស់ដែលមានជីវិតទាំងឡាយបានផ្លាស់ប្តូរពីមួយជំនាន់ទៅមួយជំនាន់ក៏ដោយ លោកមិនបានដឹងថាតើពួកគេផ្លាស់ប្តូរយ៉ាងដូចម្តេចឡើយ? នៅក្នុងទសវត្សរ៍ឆ្នាំ 1850 និង 1860 ព្រះសង្ឃអូទ្រីសមួយអង្គព្រះនាម មេនដេល បានរកឃើញថា មានទម្រង់មួយដែលនាំឱ្យរូបរាងជាក់លាក់មួយនឹងកាត់តាម។ បើទោះបីជាការរកឃើញរបស់លោកមិនត្រូវបានគេស្គាល់ទូលំទូលាយរហូតដល់ឆ្នាំ 1900 ក៏ដោយ ការរកឃើញរបស់លោ មេនដេល គឺជាចំណុចចាប់ផ្តើមឡើងនៃវិទ្យាសាស្ត្រហ្សែន។

ការរីកចម្រើននៃគីមីសាស្ត្រ និងរូបសាស្ត្រ៖ នៅក្នុងឆ្នាំ 1803 គីមីវិទូជនជាតិអង់គ្លេសឈ្មោះចន ដាលតុន បានបង្កើតទ្រឹស្តីមួយដែលថា រាល់រូបធាតុទាំងអស់គឺកើតឡើងដោយជាតុតូចល្អិតមួយដែលហៅថាអាតូម។ លោក បានបង្ហាញថា សារធាតុមានផ្ទុកនូវអាតូមតែមួយប្រភេទប៉ុណ្ណោះ ដែលមានទម្ងន់ជាក់លាក់មួយ។ ផ្ទុយទៅវិញ សមាសធាតុមានផ្ទុកនូវអាតូមច្រើនប្រភេទ។ នៅក្នុងឆ្នាំ 1869 លោកដេមីទ្រី មេនដេឡេយេវ ដែលជាគីមីវិទូជនជាតិរុស្ស៊ី បានរៀបចំតារាងមួយ ដែលសារធាតុដែលគេស្គាល់ទាំងអស់ត្រូវបានរៀបទៅតាមលំដាប់លំដោយនៃទម្ងន់ ពីស្រាលបំផុតទៅធ្ងន់បំផុត។ ប្រអប់ចំហរនៅខាងឆ្វេងនៃតារាង គឺសម្រាប់ដាក់ឈ្មោះសារធាតុថ្មីដែលលោកព្យាករណ៍នឹងត្រូវស្រាវជ្រាវរកឃើញ។ ក្រោយមក ការព្យាករណ៍របស់ពិតជាត្រឹមត្រូវមែន។ តារាងរបស់មេនដេឡេយេវ ដែលគេហៅថា តារាងខួប ត្រូវបានគេបន្តប្រើរហូតមកដល់សព្វថ្ងៃ។ ប្តីប្រពន្ធមួយគូដែលធ្វើការនៅក្នុងទីក្រុងប៉ារីស គឺម៉ារីយេ និងពីយែរ គូរីយេ បានរកឃើញសារធាតុពីរទៀត ដែលពួកគេបានដាក់ឈ្មោះថា

រ៉ាដ្យូម និងប៉ូឡូញ៉ូម ។ សារធាតុនេះត្រូវបានរកឃើញនៅក្នុងខនិជមួយប្រភេទដែលគេហៅថា លាយបញ្ចូលគ្នា ដែលវាបានបញ្ចេញថាមពលដ៏មានអនុភាពមួយប្រភេទ។ នៅក្នុងឆ្នាំ 1898 ម៉ារីយេ និងគូរីយេបានហៅឈ្មោះថាមពលនេះថា វិទ្យុសកម្ម។ នៅក្នុងឆ្នាំ 1903 លោកគូរីយេ ទទួលបានពានរង្វាន់ណូបែលផ្នែករូបសាស្ត្រសម្រាប់ការរកឃើញថាមពលវិទ្យុសកម្មរបស់លោក។ នៅក្នុងឆ្នាំ 1911 បានឈ្នះពានរង្វាន់ណូបែលផ្នែកគីមីសាស្ត្រ សម្រាប់ការរកឃើញនៃសារធាតុ រ៉ាដ្យូម និងប៉ូឡូញ៉ូម ។

រូបវិទូនៅវង្វង់ឆ្នាំ 1900 បានបន្តដោះស្រាយភាពអាថ៌កំបាំងនៃអាតូម។ អ្នកវិទ្យាសាស្ត្រដំបូងជឿថា អាតូមគឺជាធាតុតូចល្អិតជាគេបំផុត។ រូបវិទូជនជាតិអង់គ្លេសមួយរូបឈ្មោះ អ៊ីនេស រូថឺហ្វ៍ត បានស្នើថា អាតូមមិនមែនជាធាតុតូចល្អិតជាគេបំផុតនោះទេ។ លោកបាននិយាយថា អាតូមនីមួយៗ មានមូលីគុលមួយ ឬច្រើននៅព័ទ្ធជុំវិញវា ដែលគេហៅថា អេឡិចត្រុង។ ភ្លាមៗ រូបវិទូមួយចំនួនទៀតដូចជាលោក ម៉ាស ផ្លេន,លោក នីល បូ, និង អាលបឺត អេនស្តៀន បានធ្វើការសិក្សាពីរចនាសម្ព័ន្ធនៃថាមពលអាតូម។

### 4. វិទ្យាសាស្ត្រសង្គមស្រាវជ្រាវពីឥរិយាបថ

ទ្រឹស្តីវិទ្យាសាស្ត្រនៅទសវត្សរ៍ឆ្នាំ 1800 បានញុំាងឱ្យអ្នកប្រាជ្ញនានាធ្វើការសិក្សាពីសង្គម និងឥរិយាបថមនុស្សនៅក្នុងវិធីបែបវិទ្យាសាស្ត្រ។ ចំណាប់អារម្មណ៍លើផ្នែកនេះបានកើនឡើងយ៉ាងខ្លាំងអំឡុងក្នុងសតវត្សរ៍ទី 19 ដូចដែលការធ្វើដំណើររុករកជុំវិញពិភពលោក នាំឱ្យរកឃើញថ្មីជាច្រើនអំពីអរិយធម៌បុរាណ និងវប្បធម៌ពិភពលោក។ ការនេះនាំទៅដល់ការអភិវឌ្ឍនូវវិទ្យាសាស្ត្រសង្គមសម័យទំនើប ដែលក្នុងនោះរួមមាន បុរាណវិទ្យា, នរវិទ្យា, និងសង្គមវិទ្យា។

វិទ្យាសាស្ត្រសង្គមថ្មីដែលមានសារៈសំខាន់គឺ ចិត្តវិទ្យា គឺជាការសិក្សាអំពីចិត្ត និងឥរិយាបថមនុស្ស។ សរិរៈ-ចិត្តវិទូរុស្ស៊ីឈ្មោះ អ៊ីវ៉ាន់ ប៉ាវឡូវ បានជឿថា សកម្មភាពមនុស្សជាទូទៅតែងតែប្រតិកម្មដោយមិនដឹងខ្លួនចំពោះបាតុភូត និងអាចផ្លាស់ប្តូរបានតាមរយៈការបណ្តុះបណ្តាល។ អ្នកត្រួសត្រាយចិត្តវិទ្យាម្នាក់ទៀត គឺវេជ្ជបណ្ឌិតជនជាតិអូទ្រីសឈ្មោះ ស៊ីកម៉ុន ផ្រយ ក៏ជឿថា ចិត្តដែលយើងមិនដឹងបានដឹកនាំការគិត និងសកម្មភាពរបស់យើង។ នៅក្នុងការយល់ឃើញរបស់លោក ផ្រយ ចិត្តដែលយើងមិនដឹងគឺជាអ្នកជម្រុញឱ្យមានការចង់ចាំ, ចំណង់, និងឥរិយាបថ។ លោកបានរកឃើញប្រភេទនៃវិធីព្យាបាលផ្លូវចិត្តម្យ៉ាងដែលហៅថា ចិត្តវិភាគ ដើម្បីដោះស្រាយបញ្ហាចិត្តសាស្ត្រដែលបង្កើតឡើងដោយកម្លាំងជម្រុញទាំងនេះ។ ទ្រឹស្តីរបស់លោកផ្រយ មានឥទ្ធិពលយ៉ាងខ្លាំង។ ប៉ុន្តែគំនិតរបស់លោកដែលថា ចិត្តមិនអាចគ្រប់គ្រងការដឹងបានទេ បានធ្វើឱ្យមនុស្សជាច្រើនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ទ្រឹស្តីរបស់លោក ផ្រយ និងលោក ប៉ាវឡូវ បានប្រឆាំងជាមួយមូលដ្ឋានគ្រឹះនៃគំនិត ដែលទាក់ទងទៅនឹងការដឹង-វិចារណញ្ញាណគឺធំជាងគេ។ គំនិតថ្មីអំពីចិត្តវិទ្យាបានចាប់ផ្តើមធ្វើឱ្យវង្គុះវង្គើដល់ជំនឿ នៅសតវត្សរ៍ទី 19 ដែលថា មនុស្សអាចធ្វើឱ្យខ្លួនគេ និងសង្គមល្អឥតខ្ចោះបានតាមរយៈវិចារណញ្ញាណ។

## 5. ការរីកឡើងនៃទម្រង់វប្បធម៌

នៅសម័យដំបូង, សិល្បៈ, តន្ត្រី, និងល្ខោនត្រូវបានកំសាន្តសប្បាយដោយអ្នកមានទ្រព្យសម្បត្តិ។ ក្រុមអ្នកមានទាំងនេះ មានលុយ, មានពេលលំហែរកាយ, និងទទួលបានការសិក្សាដើម្បីដឹងអំពីតម្លៃនៃវប្បធម៌។ រហូតមកដល់ឆ្នាំ 1900 ទើបមនុស្សអាចបង្ហាញទម្រង់វប្បធម៌ ដែលរួមមានសិល្បៈ, សំណេរ, តន្ត្រី និងទម្រង់ផ្សេងៗទៀតនៃការកំសាន្តទៅកាន់ហ្វូងមហាជន។

ទម្រង់វប្បធម៌បង្កើតឱ្យមានការផ្លាស់ប្តូរ៖ មានឥទ្ធិពលជាច្រើនដែលបង្កឡើយដោយការរីកឡើងនៃទម្រង់វប្បធម៌។ ឥទ្ធិពលរបស់វាបានផ្លាស់ប្តូរជីវិតរស់នៅនៅក្នុងទ្វីបអឺរ៉ុប និងអាមេរិកខាងជើង។ កំណត់សំគាល់នៅក្នុងតារាងនៅទំព័របន្ទាប់ អំពីរបៀបដែលមនុស្សស្ថិតក្នុងវណ្ណៈកម្មរស់នៅ ត្រូវបានផ្លាស់ប្តូរដោយទម្រង់វប្បធម៌។ តម្រូវការនៃសកម្មភាពសម្រាប់កំសាន្តនានា ជាហេតុជម្រុញឱ្យមាន ការស្វែងរកនូវអ្វីដែលថ្មីៗមួយចំនួនសម្រាប់ឱ្យមនុស្សកំសាន្តសប្បាយ។ មនុស្សបានចូលរួមទស្សនាការប្រគុំតន្ត្រី, មើលភាពយន្ត, និងទស្សនាព្រឹត្តិការណ៍កីឡានានា។

សាលតន្ត្រី, ការសម្តែងចល័ត, និងរោងភាពយន្ត៖ សកម្មភាពកំសាន្តអារម្មណ៍ពេញនិយមមួយគឺការ ធ្វើដំណើរទៅសាលតន្ត្រី។ នៅពេលរសៀល សាលតន្ត្រីមួយនឹងរៀបចំនូវការសម្តែងខុសៗគ្នាជាច្រើន។ អាចនឹងមានការសម្តែងរបស់អ្នកចម្រៀង, អ្នករាំ, អ្នកកម្លែង, អ្នកលេងសៀកផ្ចិនភ្នែក, និងសៀករហ័សកម្ម។ នៅក្នុងសហរដ្ឋអាមេរិក តន្ត្រីជាច្រើនប្រភេទត្រូវបានគេសម្តែង ដែលគេហៅថា ការសម្តែងចល័ត។ ការសម្តែង ចល័តបានធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ ដែលការសម្តែងធ្វើឡើងនៅរោងមហោស្រប។ អំឡុងទសវត្សរ៍ឆ្នាំ 1880 អ្នកបង្កើតថ្មីមួយចំនួនធ្វើការដើម្បីផលិតរូបភាពភាពយន្ត។ ការរចនាដ៏ជោគជ័យមួយគឺមកពីប្រទេសបារាំង។ ផ្សេងទៀតគឺមកពីមន្ទីរពិសោធន៍របស់ ថូម៉ាស់ អេឌីសុន ។ ភាពយន្តរូបភាពដំបូងបំផុតមានរូបភាពពណ៌សខ្មៅ និងមានរយៈពេលតិចជាងមួយនាទី។ ត្រឹមដើមទសវត្សរ៍ឆ្នាំ 1900 អ្នកផលិតខ្សែភាពយន្តបានផលិតខ្សែភាពយន្តដោយប្រើហ្វីលជាលើកដំបូង។ ភាពយន្តយ៉ាងឆាប់រហ័សបានក្លាយជាជំនួញដ៏ធំមួយ។ ត្រឹមឆ្នាំ 1910 ប្រជាជនអាមេរិក 5 លាននាក់ចូលទស្សនារោងភាពយន្តប្រមាណ 1 ម៉ឺនជារៀងរាល់ថ្ងៃ។ ឧស្សាហកម្មភាពយន្តនៅអឺរ៉ុបក៏មានការរីកចម្រើនដូចគ្នាដែរ។

កីឡាបានផ្តល់ការកំសាន្តដល់មនុស្សរាប់លាននាក់៖ ជាមួយនឹងពេលវេលាទំនេររបស់ពួកគេ មនុស្សកាន់តែច្រើនចាប់ផ្តើមកំសាន្តសប្បាយជាមួយកីឡា និងសកម្មភាពក្រៅផ្ទះនានា។ ការទស្សនាកីឡាបានក្លាយជាការកំសាន្តអារម្មណ៍មួយ។ នៅក្នុងសហរដ្ឋអាមេរិក កីឡាបាល់ឱប និងបាល់បោះមានប្រជាប្រិយភាពយ៉ាងខ្លាំង។ នៅអឺរ៉ុប ក្លឹបបាល់ទាត់អាជីពដំបូងត្រូវបានបង្កើតឡើង និងបានទាក់ទាញមនុស្សជាច្រើន។ កីឡាដែលគួរឱ្យចាប់អារម្មណ៍របស់ពួកអង់គ្លេស ដែលមានដូចជា កីឡាគ្រីចកេត បានរីករាលដាលទៅកាន់ដែនដីអាណានិគមរបស់ចក្រភពអង់គ្លេសនៅអូស្ត្រាលី, ឥណ្ឌា, និងអាហ្វ្រិកខាងត្បូង។ ជាលទ្ធផលនៃការកើនឡើងនូវចំណាប់អារម្មណ៍នៃកីឡា ល្បែងកីឡាអូឡាំពិកអន្តរជាតិបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1896 ។ ល្បែងនេះយកលំនាំតាមប្រពៃណី

របស់ក្រិកបុរាណដោយធ្វើការប្រកួតប្រជែងអត្តពលកម្មជារៀងរាល់ 4 ឆ្នាំម្តង។ ជាការគោរព កីឡាអូឡាំពិកសម័យទំនើបដំបូងធ្វើឡើងនៅទីក្រុងអាតែន ប្រទេសក្រិក ដែលជាម្ចាស់ដើមនៃកីឡានេះ។

# ជំពូក 26 ៖ យុគសម័យចក្រពត្តិនិយម 1850-1914

## មេរៀនទី 1 ៖ ដំណើរទៅកាន់ទ្វីបអាហ្វ្រិក

### 1. អាហ្វ្រិកមុនការគ្រប់ដណ្តប់របស់ពួកអឺរ៉ុប

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1800 មុនការគ្រប់ដណ្តប់របស់ពួកអឺរ៉ុបលើតំបន់អាហ្វ្រិក ប្រជាជនដែលរស់នៅក្នុងទ្វីបនេះ ត្រូវបានបែងចែកជាក្រុមជនជាតិភាគតិចរាប់រយ និងមានភាសាផ្សេងៗគ្នា ។ ពួកគេភាគច្រើនបន្តអនុវត្តជំនឿបែបប្រពៃណី ខណៈពេលមានប្រជាជនអាហ្វ្រិកមួយចំនួនបានកែប្រែទៅជឿសាសនាអ៊ិស្លាម ឬសាសនាគ្រឹស្ត។ ក្រុមទាំងនេះនិយាយភាសាផ្សេងៗគ្នាជាង 1,000។ ផ្នែកខាងនយោបាយ ក្រុមទាំងនេះមានរាប់ចាប់ពីចក្រភពធំៗដែលបានបង្រួបបង្រួមក្រុមជនជាតិភាគតិចជាច្រើន រហូតដល់ក្រុមកុលសម្ព័ន្ធឯករាជ្យតូចមួយ។

ពួកអឺរ៉ុបបានបង្កើតទំនាក់ទំនងជាមួយនឹងពួកអាហ្វ្រិកនៅតំបន់សាហារ៉ា នៅដើមដំបូងបំផុតនៅក្នុងទសវត្សរ៍ឆ្នាំ 1450 ។ ប៉ុន្តែ កងទ័ពដ៏មានឥទ្ធិពលរបស់អាហ្វ្រិកអាចទប់ទល់ជាមួយនឹងការឈ្លានពានរបស់ពួកអឺរ៉ុបបានរយៈពេល 400 ឆ្នាំ។ តាមពិតទៅ នៅត្រឹមឆ្នាំ 1880 ពួកអឺរ៉ុបគ្រប់គ្រងដែនដីអាហ្វ្រិកបានតែ 10 ភាគរយប៉ុណ្ណោះ ដែលភាគច្រើនដែនដីតំបន់ឆ្នេរ។ ម្យ៉ាងទៀត ពួកអឺរ៉ុបមិនអាចធ្វើដំណើររយៈចម្ងាយឆ្ងាយទៅកាន់ដែនដីខាងក្នុងដ៏ធំនេះបានទេ។ ពួកអឺរ៉ុបមិនអាចធ្វើនាវាចរណ៍នៅលើទន្លេនៅអាហ្វ្រិកបានទេ ដោយសារទន្លេទាំងនោះមានចំណោតច្រើន, មានល្បាក់, និងផ្លាស់ប្តូរខ្សែទឹកហូរ។ ការបង្កើតឡើងនៃនាវាប្រចំហាយទឹកនៅដើមទសវត្សរ៍ឆ្នាំ 1800 បានអនុញ្ញាតឱ្យពួកអឺរ៉ុបអាចធ្វើដំណើរទៅកាន់ដែនដីខាងក្នុងរបស់អាហ្វ្រិក។ ជំងឺក៏បានរារាំងដល់ការរុករករបស់ពួកអឺរ៉ុបផងដែរ។ ចុងក្រោយ ពួកអាហ្វ្រិកបានត្រួតត្រាបណ្តាញពាណិជ្ជកម្ម និងបានផ្គត់ផ្គង់ផលិតផលដោយខ្លួនគេផ្ទាល់។ បណ្តាញទាំងអស់នេះគឺជាអ្នកមានជំនាញ។ ឧទាហរណ៍ ពួកឆូករវេ បានបូជាខ្លួនពួកគេដើម្បីប្រមូលភ្លុក និងក្រមួន នៅតំបន់ខ្ពង់រាប អង់ហ្គោឡាន ។

ប្រទេសនានាប្រជែងគ្នាដើម្បីបង្កើតចក្រភពនៅក្រៅស្រុក៖ ពួកអឺរ៉ុបដែលបានធ្វើដំណើរចូលទៅក្នុងដែនដីភាគខាងក្នុងរបស់អាហ្វ្រិកគឺជាអ្នកស្រាវជ្រាវ, បេសកទូតសាសនា, ឬពួកអ្នកធ្វើការផ្នែកមនុស្សធម៌ដែលប្រឆាំងជាមួយនឹងពាណិជ្ជកម្មទាសកររបស់ពួកអឺរ៉ុប និងអាមេរិក។ ពួកអឺរ៉ុប និងអាមេរិកសិក្សាពីអាហ្វ្រិកតាមរយៈសៀវភៅធ្វើដំណើរ និងកាសែត។ ស្ថាប័នបោះពុម្ពផ្សាយទាំងនេះបានប្រកួតប្រជែងគ្នាក្នុងការទាក់ទាញអ្នកអានដោយពួកគេបានជួលអ្នករាយការណ៍ដើម្បីរុករកជុំវិញផែនដី ដើម្បីធ្វើការសសេរអំពីរឿងរ៉ាវអំពីដំណើរផ្សងព្រេង, អាថ៌កំបាំង, និងរំជួលចិត្ត។

កុងហ្គោបញ្ឆេះឱ្យមានការចាប់អារម្មណ៍៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1860 លោកដេវីឌ លីវីងស្តូន ដែលជាបេសកទូតមួយរូបមកពីប្រទេសស្កុតលែន បានធ្វើដំណើរជាមួយពួកអាហ្វ្រិកមួយក្រុមធ្វើដំណើរចូលជ្រៅទៅកាន់អាហ្វ្រិកកណ្តាលដើម្បីផ្សព្វផ្សាយសាសនាគ្រឹស្ត។ ប៉ុន្មានឆ្នាំក្រោយមក ដោយមិនលឺដំណឹងពីលោក និងគ្នីគ្នារបស់លោក មនុស្សជាច្រើនខ្លាចថាលោកនឹងស្លាប់។ ការសែតអាមេរិកមួយបានជួលអ្នករាយការណ៍ម្នាក់ឈ្មោះហេនរី ស្ទេនលី

ដើម្បីទៅស្វែងរកលោកលីវីងស្តូន ។ នៅក្នុងឆ្នាំ 1871 លោកបានរកឃើញបណ្ឌិតលីវីងស្តូន នៅមាត់បឹងតានហ្គានយីកា ។ ពាក្យស្វាគមន៍ដ៏ល្បីល្បាញរបស់លោកគឺ "លោកបណ្ឌិតលីវីងស្តូនខ្ញុំកំពុងសុបិន្ត?" បានចុះផ្សាយនៅទំព័រមុខនៅជុំវិញពិភពលោក។ លោកស្ទែនលី បានធ្វើដំណើររុករកអាហ្វ្រិកដោយខ្លួនលោកផ្ទាល់ ហើយលោកបានធ្វើដំណើរទៅដល់ទន្លេកុងហ្គោ។ ការរុករកឃើញរបស់លោក បានបញ្ឆេះឱ្យមានការចាប់អារម្មណ៍ពីសំណាក់ស្តេច លេអូប៉ូដ 2 របស់បែលហ្ស៊ិច ដែលទ្រង់បានផ្តល់កម្រៃ និងអំណាចដល់លោក ស្ទែនលី ដើម្បីជួយដល់ទ្រង់ក្នុងការកាន់កាប់កុងហ្គោ។ រវាងឆ្នាំ 1879 ដល់ឆ្នាំ 1882 លោកស្ទែនលី បានចុះសន្ធិសញ្ញាមួយចំនួនជាមួយមេដឹកនាំនៅតំបន់ជ្រលងទន្លេកុងហ្គោ។ សន្ធិសញ្ញាបានប្រគល់ឱ្យស្តេច លេអូប៉ូដ 2 របស់បែលហ្ស៊ិចនូវសិទ្ធិត្រួតត្រាលើដែនដីទាំងនេះ។ ស្តេច លេអូប៉ូដ 2 បានអះអាងថា បំណងសំខាន់បំផុតរបស់ទ្រង់នៅក្នុងការបង្កើតដែនដីអាណានិគមគឺដើម្បីលុបបំបាត់ចោលពាណិជ្ជកម្មទាសករ និងផ្សព្វផ្សាយសាសនាគ្រឹស្ត។ ប៉ុន្តែ ក្រុមហ៊ុននានារបស់ទ្រង់ បានកេងប្រវ័ញ្ចយ៉ាងឃោឃៅលើពួកអាហ្វ្រិក តាមរយៈការបង្ខំឱ្យពួកគេប្រមូលជ័រពីដើមកៅស៊ូ។ យ៉ាងហោចណាស់មានជនជាតិកុងហ្គោយ៉ាងតិច 10 លាននាក់ណាក់ស្លាប់ដោយសារតែការរំលោភបំពាននៅអំឡុងសម័យនៃការគ្រប់គ្រងរបស់ស្តេច លេអូប៉ូដ 2 ។ ជាលទ្ធផលនៃភាពឃោឃៅរបស់ទ្រង់ ក្រុមអ្នកធ្វើការដើម្បីមនុស្សធម៌នៅជុំវិញពិភពលោកបានទាមទារឱ្យមានការផ្លាស់ប្តូរ។ នៅក្នុងឆ្នាំ 1908 រដ្ឋាភិបាលបែលហ្ស៊ិកបានដកហូតការគ្រប់គ្រងដែនដីអាណានិគមពីស្តេច លេអូប៉ូដ 2 ។ កុងហ្គោ ដែលគេដឹងថាក្រោយមកក្លាយជាដែនដីអាណានិគមរបស់បែលហ្ស៊ិក មានទំហំ 80 ដងធំជាងប្រទេសបែលហ្ស៊ិក។ ការចាប់យកដែនដីកុងហ្គោរបស់រដ្ឋាភិបាលបែលហ្ស៊ិកបានប្រកាសអាសន្នដល់ប្រទេសបារាំង។ នៅដើមដំបូង នៅក្នុងឆ្នាំ 1882 បារាំងបានចុះសន្ធិសញ្ញាមួយដែលបានផ្តល់ឱ្យបារាំងនូវការត្រួតត្រាលើដែនដីច្រាំងភាគខាងជើងនៃទន្លេកុងហ្គោ។ ភ្លាមៗនោះ ចក្រភពអង់គ្លេស, អាឡឺម៉ង់, អ៊ីតាលី, ព័រទុយហ្គាល, និងអេស្ប៉ាញ ក៏បានកាន់កាប់ផ្នែកនានានៅទ្វីបអាហ្វ្រិកផងដែរ។

## 2. កម្លាំងដែលជម្រុញឱ្យមានចក្រពត្តិនិយម

បំណងដែលចង់ពង្រីកអាណានិគមននៅក្នុងទ្វីបអាហ្វ្រិកក៏បានរីកទៅដល់តំបន់ផ្សេងៗទៀតដែរ។ សេដ្ឋកិច្ច, នយោបាយ, និង សង្គមគឺជាកម្លាំងជម្រុញឱ្យមានកំណើននៃការពង្រីកការគ្រប់គ្រងអាណានិគមលើដែនដីទាំងឡាយនៃជុំវិញពិភពលោក។ ជាពិសេស បដិវត្តឧស្សាហកម្មបានផ្តល់ឱ្យពួកអឺរ៉ុបនូវហេតុផលមួយនៅក្នុងការពង្រីកដែនដីអាណានិគមរបស់ពួកគេ។ ដូចដែលប្រទេសនៅអឺរ៉ុបមួយចំនួនជាប្រទេសឧស្សាហកម្ម ពួកគេស្វែងរកទីផ្សារថ្មី និងវត្ថុធាតុដើមនានាដើម្បីអភិវឌ្ឍសេដ្ឋកិច្ចរបស់ពួកគេ។

ជំនឿដែលថាពួកអឺរ៉ុបគឺជាមនុស្សដែលប្រសើរជាងគេ៖ ហេតុផលនៃការពង្រីកដែនដីអាណានិគម ក៏ចេញមកពីគំនិតមោទនភាពជាតិដ៏ខ្លាំងក្លាមួយ។ ពួកអឺរ៉ុបយកឃើញថា ចក្រភពមួយអាចបង្ហាញពីភាគល្អប្រសើរនៃជាតិមួយ។ ដូចដែលការប្រកួតប្រជែងគ្នាក្នុងការដណ្តើមដែនដីអាណានិគមកើនឡើងខ្លាំង ប្រទេសនីមួយៗមានបំណងចង់ដាក់ទង់ជាតិរបស់ពួកគេនៅលើដែនដីនានានៅជុំវិញលោកឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។

ពួកអឺរ៉ុបជាច្រើនជឿថា ពួកគេជាមនុស្សដែលប្រសើរជាងអ្នកដទៃ។ ពួកគេជឿថា ជាតិសាសន៍មួយគឺល្អប្រសើរជាងជាតិសាសន៍ដែលគេហៅថា ប្រកាន់ពូជសាសន៍។ ឥរិយាបថនេះគឺជាឆ្លុះបញ្ចាំងពី ទ្រឹស្តីការវិវត្តនៃសង្គម ដែលជាទ្រឹស្តីសង្គមដ៏សំខាន់មួយនៅពេលនោះ។ នៅក្នុងទ្រឹស្តីនេះ គំនិតរបស់លោកឆាល ដាវីន អំពីការវិវត្តនិងការសម្របខ្លួនជាមួយធម្មជាតិត្រូវបានគេយកមកអនុវត្តចំពោះសង្គមមនុស្ស។ អ្នកដែលអាចសម្របខ្លួនល្អបំផុតក្នុងការរស់នៅ មានទ្រព្យសម្បត្តិច្រើន និងទទួលជោគជ័យ ត្រូវបានគេចាត់ទុកថាជាអ្នកដែលប្រសើរជាងអ្នកដទៃ។ យោងតាមទ្រឹស្តីនេះ អ្នកទាំងឡាយណាមិនមែនជាជនជាតិអឺរ៉ុបត្រូវបានគេចាត់ទុកថាជាជនដែលមានការអភិវឌ្ឍវប្បធម៌ និងរូបរាងតិចតួច ដោយសារពួកគេមិនបានបង្កើតភាពជឿនលឿននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដូចពួកអឺរ៉ុប។ ពួកអឺរ៉ុបជឿថាពួកគេមានសិទ្ធិ និងកាតព្វកិច្ចនៅក្នុងការនាំយកភាពជឿនលឿនដែលពួកគេបានបង្កើតទៅកាន់ប្រទេសដទៃ។ លោក សេស៊ីល រ៉ូដេស អ្នកជំនួញជោគជ័យមួយរូប និងជាអ្នកគាំទ្រដ៏សំខាន់មួយចំពោះការពង្រីកដែនដីអាណានិគមរបស់អង់គ្លេស។

ច្បាស់ណាស់ថាបេសកទូតផ្សព្វផ្សាយសាសនាផងដែរ ដែលជាអ្នកដែលជម្រុញឱ្យមានការពង្រីកដែនដីអាណានិគមផងដែរ ដែលពួកគេបានធ្វើការដើម្បីផ្លាស់ប្តូរជំនឿរបស់ប្រជាជនអាស៊ី, អាហ្វ្រិក, និងដែនកោះនៅប៉ាស៊ីហ្វិកឱ្យជឿលើសាសនាគ្រឹស្ត។ បេសកទូតផ្សព្វផ្សាយសាសនាជាច្រើនជឿថា ការដឹកនាំរបស់ពួកអឺរ៉ុប គឺជាវិធីល្អបំផុតនៅក្នុងការបញ្ចប់អំពើឃោរឃៅនានា ដូចជាពាណិជ្ជកម្មទាសករជាដើម។ ពួកគេក៏ចង់ "ស៊ីវីល័យ" ឬ "បស្ចិមនីយម្ម" ដល់ប្រជាជនទាំងអស់នៅលើដែនដីខាងក្រៅ។

កត្តាដែលជម្រុញឱ្យមានចក្រពត្តិនិយមនៅទ្វីអាហ្វ្រិក៖ មានកត្តាជាច្រើនដែលរួមចំណែកនៅក្នុងជម្រុញឱ្យពួកអឺរ៉ុបដណ្តើមកាន់កាប់ទឹកដីនៅអាហ្វ្រិក។ កត្តាដែលសំខាន់ជាងគេនោះគឺ ភាពរីកចម្រើននៃបច្ចេកវិទ្យារបស់ពួកអឺរ៉ុប។ កាំភ្លើងម៉ាហ្ស៊ីម ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1884 គឺជាកាំភ្លើងម៉ាស៊ីនស្វ័យប្រវត្តិដំបូងបំផុតនៅលើកពិភពលោក។ ប្រទេសនៅអឺរ៉ុបនានា ចាប់ផ្តើមប្រើប្រាស់កាំភ្លើងម៉ាហ្ស៊ីម នៅខណៈពេលដែលពួកអាហ្វ្រិកពឹងផ្អែកតែទៅលើអាវុធហួសសម័យប៉ុណ្ណោះដើម្បីធ្វើការតស៊ូប្រឆាំង ។ ប្រទេសអឺរ៉ុបក៏ទទួលបានធនធានពីដែនដីដែលពួកគេគ្រប់គ្រងផងដែរ។ ការបង្កើតម៉ាស៊ីនប្រើចំហាយទឹក បានអនុញ្ញាតឱ្យពួកអឺរ៉ុបមានភាពងាយស្រួលនៅក្នុងការធ្វើដំណើរតាមទន្លេ ដើម្បីស្ថាបនាមូលដ្ឋានគ្រប់គ្រងនានានៅក្នុងទ្វីបអាហ្វ្រិក។ ផ្លូវរថភ្លើង, ខ្សែពួរ, និងនាវាប្រើចំហាយទឹក ធ្វើឲ្យកាន់តែមានភាពងាយស្រួលនៅក្នុងការទំនាក់ទំនងនៅក្នុងដែនដីអាណានិគមមួយរវាងម្ចាស់អាណានិគមនៅក្នុងដែនដីអាណានិគម និងប្រទេសដើមរបស់ពួកគេ។

បើទោះបីជាពួកគេមានកងទ័ពខ្លាំងក្លា និងមានម៉ាស៊ីនប្រើចំហាយទឹកដើម្បីដឹកជញ្ជូនពួកគេក៏ដោយ ក៏មានកត្តាផ្សេងទៀតដែលនាំឱ្យពួកគេនៅជាប់គាំងត្រឹមតំបន់ឆ្នេរ។ ពួកគេងាយនឹងឆ្លងជំងឺគ្រុនចាញ់, ដែលជាជំងឺមួយចម្លងដោយសត្វមូសនៅផ្ទៃដីខាងក្នុងទ្វីបអាហ្វ្រិក។ ការរកឃើញថ្នាំ គីនីន នៅក្នុងឆ្នាំ 1829 ជាយថាហេតុមានជួយការពារពួកអឺរ៉ុបពីការឆ្លងជំងឺនេះ។

កត្តាផ្សេងៗទៀតនៅក្នុងទ្វីបអាហ្វ្រិក ក៏ធ្វើឱ្យមានភាពងាយស្រួលសម្រាប់ពួកអឺរ៉ុបដាក់អាណានិគមលើទ្វីបនេះ។ ភាពចម្រុះនៃភាសា និងវប្បធម៌របស់ពួកអឺរ៉ុបក៏បានរាំងដល់ការបង្រួបបង្រួមរបស់ពួកគេ។ សង្គ្រាមដែលបានកើតឡើងរវាងក្រុមកុលសម្ព័ន្ធដើម្បីដណ្តើមកាន់កាប់ដី, ផ្លូវទឹក, និងសិទ្ធិនៅក្នុងការធ្វើពាណិជ្ជកម្ម ក៏បានរាំងដល់ការបង្រួបបង្រួមរបស់ពួកគេផងដែរ។ ពួកអឺរ៉ុបបានសិក្សាស្វែងយល់ពីរឿងនេះ និងបានប្រើប្រាស់ក្រុមកុលសម្ព័ន្ធមួយដើម្បីប្រឆាំងជាមួយក្រុមមួយទៀត។

## 3. ការបែងចែកអាហ្វ្រិក

ការដណ្តើមកាន់កាប់ដែនដីអាហ្វ្រិកបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1880 ។ នៅពេលនោះ ប្រទេសបារាំងបានចាប់ផ្តើមពង្រីកដែនដីអាណានិគមរបស់ខ្លួន ពីតំបន់ឆ្នេរអាហ្វ្រិកភាគខាងលិចទៅកាន់ស៊ូដង់ភាគខាងលិច។ ការរុករកឃើញរ៉ែពេជ្រនៅក្នុងឆ្នាំ 1867 និងរ៉ែមាសនៅក្នុងឆ្នាំ 1886 នៅអាហ្វ្រិកខាងត្បូង បានបង្កើនការចាប់អារម្មណ៍របស់ពួកគេអឺរ៉ុបក្នុងការដាក់អាណានិគមលើទ្វីបអាហ្វ្រិក។ មិនមានពួកអឺរ៉ុបណាដែលចង់បោះបង់ចោលការប្រជែងយកដែនដីអាណានិគមមួយនេះឡើយ។

សន្និសីទទីក្រុងប៉ែរឡាំងដើម្បីបែងចែកអាហ្វ្រិក៖ មានការប្រកួតប្រជែងគ្នាកាន់តែខ្លាំងក្លាឡើយ ដូច្នេះ ពួកអឺរ៉ុបទាំងឡាយមានការព្រួយបារម្ភថាអាចនឹងកើតមានសង្គ្រាមក្នុងចំណោមពួកគេ។ ដើម្បីការងារពីការផ្ទុះជម្លោះ ប្រទេសនៅអឺរ៉ុបចំនួន 14 បានជួបប្រជុំគ្នានៅក្នុងសន្និសីទទីក្រុងប៉ែរឡាំង នៅក្នុងឆ្នាំ 1884-85 ដើម្បីបែងចែកការគ្រប់គ្រងលើទ្វីបអាហ្វ្រិក។ ពួកគេយល់ស្របគ្នាថា ប្រទេសនៅអឺរ៉ុបទាំងឡាយអាចមានសិទ្ធិកាន់កាប់ដែនដីនៅក្នុងទ្វីបអាហ្វ្រិក តាមរយៈការជូនដំណឹងដល់ប្រទេសផ្សេងៗទៀតអំពីការកាន់កាប់របស់ពួកគេ និងត្រូវបង្ហាញថាពួកគេអាចគ្រប់គ្រងតំបន់នោះបាន។ ពួកអឺរ៉ុបបានបែងចែកទ្វីបអាហ្វ្រិកជាមួយនឹងការគិតគូរតិចតួចអំពីថាតើគួរបែងចែកក្រុមជនជាតិភាគតិច ឬក្រុមនិយាយភាសាផ្សេងៗគ្នាទាំងអស់នេះដោយរបៀបណា។ មិនមានមេដឹកនាំនៅអាហ្វ្រិករូបណាត្រូវបានគេអញ្ជើញឱ្យចូលរួមនៅក្នុងជំនួបនេះឡើយ សន្និសីទនេះបានបញ្ចប់ដោយគវាសនារបស់អាហ្វ្រិក។ ត្រឹមឆ្នាំ 1914 មានតែចំនួន 2 ប៉ុណ្ណោះគឺ ប្រទេសលីបេរីយ៉ា និង ប្រទេសអេត្យូពី ដែលមិនធ្លាក់ក្រោមការគ្រប់គ្រងរបស់ពួកអឺរ៉ុប។

តម្រូវការវត្ថុធាតុដើមបង្កើតឱ្យមានការដាក់អាណានិគម៖ នៅពេលដែលពួកអឺរ៉ុបចាប់ផ្តើមដាក់អាណានិគម ពួកគេជឿច្រើនជឿថា ពួកអាហ្វ្រិកនឹងទិញទំនិញរបស់ពួកអឺរ៉ុបក្នុងបរិមាណដ៏ច្រើន។ ពួកគេបានគិតខុស មានប្រជាជនអាហ្វ្រិកតិចតួចប៉ុណ្ណោះដែលបានទិញទំនិញពួកអឺរ៉ុប។ ប៉ុន្តែ អ្នកជំនួញជនជាតិអឺរ៉ុបនៅតែត្រូវការវត្ថុធាតុដើមពីអាហ្វ្រិក។ ធនធានដែលសំខាន់បំផុតនៅអាហ្វ្រិកគឺធនធានរ៉ែក្រោមដី។ ប៊ែលហ្ស៊ិច-កុងហ្គោ មានផ្ទុកនូវធនធានរ៉ែទង់ដែង និងសំណប៉ាហាំង ដែលជាទ្រព្យមហាសាលមិនអាចគណនាបាន។ បើទោះបីជាដូច្នេះក៏ដោយ ក៏ភាពសម្បូរបែបនៃរ៉ែទង់ដែង និងសំណប៉ាហាំងហាក់ដូចជាមានទំហំតូច បើប្រៀបធៀបជាមួយនឹងរ៉ែមាស និងរ៉ែពេជ្រនៅអាហ្វ្រិកខាងត្បូង។ ពួកពាណិជ្ជករ ជាយថាហេតុ បានអភិវឌ្ឍការដាំដុះដំណាំមួយចំនួនដូចជា សណ្តែកដី, ដូងប្រេង, ដើមកាកាវ, និងដើមកៅស៊ូ។

## 4. ជីក្រុមប៉ះទង្គិចគ្នាដើម្បីដណ្ដើមដែនដីអាហ្វ្រិចខាងត្បូង

អាហ្វ្រិកខាងត្បូងបានបង្ហាញពីឥទ្ធិពលដែលពួកអឺរ៉ុបបានជះមកលើប្រជាជនអាហ្វ្រិក។ ប្រវត្តិសាស្ត្រដែលសំខាន់ជាងគេរបស់អាហ្វ្រិកខាងត្បូងគឺ ប្រវត្តិនៃការបះទង្គិចគ្នាមួយរវាងពួកអាហ្វ្រិក, ហូឡង់, និងចក្រភពអង់គ្លេសដើម្បីដណ្ដើមដែនដី និងធនធាន។ បើទោះបីជាដែនដីអាហ្វ្រិកហាក់ដូចជាដែនដីទទេមួយសម្រាប់ពួកអឺរ៉ុបក៏ដោយ មានក្រុមកុលសម្ព័ន្ធតូចៗជាច្រើនបានប្រកួតប្រជែងគ្នាដើម្បីដណ្ដើមកាន់កាប់ដែនដីដ៏ធំនេះ។ ការដណ្ដើមការគ្រប់គ្រងរបស់អ្នកស្រុកដើមលើដីទាំងនេះ ជាពិសេសនៅភាគខាងកើត បានបង្កឱ្យមានជម្លោះអស់រយៈពេលប្រហែល 100 ឆ្នាំមកហើយ។

ពួកហ្ស៊ូលូ ប្រយុទ្ធជាមួយចក្រភពអង់គ្លេស៖ ចាប់ពីចុងសតវត្សរ៍ទី 18 រហូតដល់ចុងសតវត្សរ៍ទី 19 សង្គ្រាមរវាងអ្នកស្រុកដើមបានកើតឡើងនៅអាហ្វ្រិកខាងត្បូង។ នៅរង្វង់ឆ្នាំ 1816 មេដឹកនាំហ្ស៊ូលូ មួយរូបឈ្មោះសាកា បានប្រើប្រាស់នូវកងទ័ពមានវិន័យខ្ពស់ និងស្ថាប័នយោធាដ៏ល្អមួយដើម្បីបង្កើតរដ្ឋដ៏ធំមួយ។ ប៉ុន្តែ អ្នកបន្តដំណែងពីសាកា មិនអាចរក្សាការពារព្រះរាជាណាចក្រនេះពីការវាយប្រហារពីសំណាក់កងទ័ពដ៏ខ្លាំងក្លារបស់ចក្រភពអង់គ្លេសបានឡើយ។ នៅក្នុងឆ្នាំ 1879 បន្ទាប់ពីស្ដេចរបស់ ហ្ស៊ូលូ ព្រះនាម សេតស្វាយ៉ូ បដិសេធនៅក្នុងការរំលាយកងទ័ពរបស់ទ្រង់ និងទទួលយកការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស អង់គ្លេសបានឈ្លានពានព្រះរាជាណាចក្រហ្ស៊ូលូ។ បើទោះបីជាពួកហ្ស៊ូលូប្រើប្រាស់លំពែង និងខែលដើម្បីប្រឆាំងជាមួយនឹងកាំភ្លើងរបស់អង់គ្លេសក៏ដោយ ពួកគេស្ទើរតែយកជ័យជំនះលើកងទ័ពដ៏ខ្លាំងពូកែរបស់ពួកអង់គ្លេស។ ប៉ុន្តែ នៅក្នុងខែកក្កដា ឆ្នាំ 1879 ពួកហ្ស៊ូលូបានចាញ់សង្គ្រាមនៅ អ៊ូលូនឌី និងព្រះរាជាណាចក្ររបស់ពួកគេ។ ព្រះរាជាណាចក្រហ្ស៊ូលូធ្លាក់ក្រោមការគ្រប់គ្រងរបស់ចក្រភពអង់គ្លេសនៅក្នុងឆ្នាំ 1887 ។

ពួកហូឡង់ និងពួកអង់គ្លេសតាំងទីលំនៅនៅខេព ៖ ជនជាតិអឺរ៉ុបដំបូងដែលបានតាំងទីលំនៅនៅអាហ្វ្រិកខាងត្បូងគឺពួកហូឡង់។ ពួកហូឡង់បានធ្វើដំណើរមកដល់ ជ្រោយនៃក្ដីសង្ឃឹមដ៏ល្អ នៅក្នុងឆ្នាំ 1652 ដើម្បីបង្កើតស្ថានីយមួយសម្រាប់ការធ្វើនាវាចរណ៍របស់ពួកគេរវាង ហូឡង់ឥណ្ឌាខាងកើត និងហូឡង់។ ក្រុមអ្នកតាំងទីលំនៅជនជាតិហូឡង់ដែលគេស្គាល់ថា បួរ (ភាសាហូឡង់មានន័យថាប្រជាកសិករ) បន្តិចម្ដងៗបានកាន់កាប់ដែនដីរបស់ពួកអាហ្វ្រិក និងបានបង្កើតផ្ទៃដីដាំដុះដ៏ធំមួយ។

នៅពេលដែលចក្រភពអង់គ្លេសដាក់អាណានិគមលើតំបន់ ខេព ជាអចិន្ត្រៃយនៅដើមសតវត្សរ៍ទី 19 ពួកគេ និងពួកហូឡង់បានបះទង្គិចគ្នា ដោយសារតែគោលនយោបាយរបស់អង់គ្លេសស្ដីអំពីដីធ្លី និងទាសករ។ នៅទសវត្សរ៍ឆ្នាំ 1830 ដើម្បីគេចចេញពីពួកអង់គ្លេស ពួកហូឡង់រាប់ពាន់នាក់បានធ្វើដំណើរទៅភាគខាងជើង។ ចលនានៅការផ្លាស់ទីនេះត្រូវបានគេស្គាល់ថា ការធ្វើដំណើរដ៏អស្ចារ្យ ។ ពួកហូឡង់ភ្លាមៗនោះបានវាយប្រយុទ្ធគ្នាជាមួយពួកហ្ស៊ូលូ និងក្រុមកុលសម្ព័ន្ធអាហ្វ្រិកផ្សេងៗទៀត ដែលដីរបស់ពួកគេត្រូវបានដណ្ដើមដោយពួកហូឡង់។

សង្គ្រាមហូឡង់៖ ពេជ្រ និងមាសត្រូវបានរកឃើញនៅអាហ្វ្រិកភាគខាងត្បូងនៅក្នុងទសវត្សរ៍ឆ្នាំ 1860 និង 1880។ ភ្លាមៗនោះ ក្រុមអ្នកធ្វើដំណើរផ្សងព្រេងពីគ្រប់ទិសទីតាំងអស់នៅលើពិភពលោកបានធ្វើដំណើរយ៉ាង

ប្រញាប់ប្រញាល់មកកាន់តំបន់នេះ ដើម្បីបង្កើតលាបសំណាងរបស់ពួកគេ។ ពួកហូឡង់ព្យាយាមនៅក្នុងការទាប់ស្កាត់ក្រុមអ្នកពីខាងក្រៅទាំងនេះ មិនឱ្យទទួលបានសិទ្ធិនយោបាយនៅទីនោះឡើយ។ ការប៉ុនប៉ង់បះបោរមួយបានកើតមានឡើងប្រឆាំងជាមួយពួកហូឡង់ ប៉ុន្តែត្រូវបរាជ័យ។ ពួកហូឡង់បានបន្ទោសបញ្ហានេះលើពួកអង់គ្លេស ហើយនៅក្នុងឆ្នាំ 1899 ពួកហូឡង់បានប្រើប្រាស់កងទ័ពប្រឆាំងជាមួយពួកគេ។ មានកត្តាមួយចំនួនដែលគេយល់ថាសង្គ្រាមហូឡង់ (ក៏ត្រូវបានគេស្គាល់ថាសង្គ្រាមអាហ្វ្រិកខាងត្បូង) រវាងចក្រភពអង់គ្លេស និងពួកហូឡង់គឺជាសង្គ្រាម "ពេញលេញ" សម័យទំនើប។ ពួកហូឡង់បានបើការវាយឆ្មក់របស់ក្រុមកម្មង់ដូ និងប្រើប្រាស់យុទ្ធសាស្ត្រទ័ពព្រៃនៅក្នុងការប្រយុទ្ធជាមួយពួកអង់គ្លេស។ ពួកអង់គ្លេសឆ្លើយតបតាមរយៈការដុតបំផ្លាញចំការដាំណាំរបស់ពួកហូឡង់ និងចាប់ស្ត្រី និងកុមារហូឡង់ដាក់នៅក្នុងជំរុំលត់ដំនានា។

ពួកជនជាតិស្បែកខ្មៅអាហ្វ្រិកខាងត្បូងក៏ចូលរួមនៅក្នុងសង្គ្រាមនេះផងដែរ។ អ្នកមួយចំនួនចូលរួមប្រយុទ្ធ, អ្នកមួយចំនួនធ្វើជាចារកិច្ច, អ្នកមួយចំនួនធ្វើជាអ្នកយាម, អ្នកមួយចំនួនធ្វើជាអ្នកបើកបរ, និងអ្នកមួយចំនួនទៀតធ្វើជាកម្មករ។ ពួកជនជាតិស្បែកខ្មៅអាហ្វ្រិកខាងត្បូងជាច្រើនត្រូវបានពួកអង់គ្លេសចាប់ខ្លួន និងដាក់នៅក្នុងជំរុំលត់ដំ ដែលនៅទីនោះមានមនុស្សប្រហែល 14.000 នាក់បានស្លាប់។

ចុងក្រោយអង់គ្លេសបានឈ្នះសង្គ្រាម។ នៅក្នុងឆ្នាំ 1910 សាធារណៈរដ្ឋហូឡង់បានចូលទៅក្នុងសហភាពអាហ្វ្រិកខាងត្បូង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស។ ការបង្កើតដែនដីអាណានិគមគឺជាសញ្ញាណនៃការផ្លាស់ប្តូរជីវិតរស់នៅរបស់ប្រជាជនអាហ្វ្រិក។ ពួកអឺរ៉ុបបានព្យាយាមនៅក្នុងផ្លាស់ប្តូរនយោបាយ, សេដ្ឋកិច្ច, និងសង្គមរស់នៅរបស់ប្រជាជននៅក្នុងប្រទេសដែលពួកគេបានដណ្តើមកាន់កាប់។ អ្នកនឹងបានសិក្សាអំពីការផ្លាស់ប្តូរនេះនៅក្នុងមេរៀនទី 2 ។

# មេរៀនទី 2 ៖ ចក្រពត្តិនិយម

## 1. យុគសម័យថ្មីនៃចក្រពត្តិនិយម

ចក្រពត្តិនិយមនៅក្នុងសតវត្សរ៍ទី 18 និងទី 19 ត្រូវបានធ្វើឡើងខុសប្លែកពីការរុករកនៅសតវត្សទី 15 និងទី 16 ។ នៅដើមដំបូង មហាអំណាចចក្រពត្តិនិយមនានាជាទូទៅមិនបានធ្វើដំណើរទៅឈ្លានពានតំបន់ឆ្ងាយៗនៅអាស៊ី និងអាហ្វ្រិកឡើយ។ ហើយពួកគេក៏មិនបានជះឥទ្ធិពលអ្វីធំដុំលើការរស់នៅរបស់ប្រជាជនឡើយ។ អំឡុងនៃយុគសម័យថ្មីនៃចក្រពត្តិនិយម ពួកអឺរ៉ុបត្រូវការឥទ្ធិពលកាន់តែច្រើនលើសេដ្ឋកិច្ច, នយោបាយ, និងសង្គមរស់នៅរបស់ប្រជាជន។ ពួកគេមានបំណងក្នុងការរៀបចំសេដ្ឋកិច្ចនៅលើដែនដីដែលពួកគេត្រួតត្រាដើម្បីផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចដល់ពួកគេ។ ពួកគេក៏ចង់ឱ្យប្រជាជនទទួលយកនូវវប្បធម៌របស់ពួកអឺរ៉ុប។

ទម្រង់នៃការគ្រប់គ្រង៖ ប្រទេសអឺរ៉ុបនីមួយៗមានគោលនយោបាយ និងគោលបំណងជាក់លាក់មួយសម្រាប់ការបង្កើតដែនដីអាណានិគម។ ដើម្បីបង្កើតការគ្រប់គ្រងលើតំបន់មួយ ពួកអឺរ៉ុបប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា។ បន្តិចម្តងៗ ទម្រង់នៃការគ្រប់គ្រងអាណានិគមបានលេចឡើង៖ អាណានិគម, អាណាព្យាបាល, ស្ថិតក្នុងរង្វង់នៃឥទ្ធិពល, និងចក្រពត្តិនិយមលើសេដ្ឋកិច្ច។ នៅក្នុងការអនុវត្ត ការត្រួតត្រាលើតំបន់មួយអាចនឹងប្រើប្រាស់ទម្រង់មួយចំនួននៅក្នុងទម្រង់ខាងលើ។

វិធីសាស្ត្រនៅក្នុងការគ្រប់គ្រង៖ មេដឹកនាំអឺរ៉ុបក៏បានអភិវឌ្ឍវិធីសាស្ត្រនានានៅក្នុងការគ្រប់គ្រងដែនដីអាណានិគមរបស់ពួកគេ។ វិធីសាស្ត្រសំខាន់ចំនួន 2 បានលេចឡើង។ ចក្រភពអង់គ្លេស និងប្រទេសផ្សេងៗទៀតដែលមានដូចជាសហរដ្ឋអាមេរិកដែលគ្រប់គ្រងដែនដីរបស់គេនៅដែនកោះប៉ាស៊ីហ្វិក ជ្រើសរើសយកការគ្រប់គ្រងដោយប្រយោល។ បារាំង និងប្រទេសអឺរ៉ុបភាគច្រើនជ្រើសរើសយកការគ្រប់គ្រងដោយផ្ទាល់។ ក្រោយមក នៅពេលដែលប្រទេសស្ថិតក្រោមអាណានិគមទាំងនោះទទួលបានឯករាជ្យ វិធីសាស្ត្រនៅក្នុងគ្រប់គ្រងដែលពួកគេបានប្រើប្រាស់ បានជះឥទ្ធិពលលើការជ្រើសរើសប្រភេទរដ្ឋាភិបាលរបស់ប្រទេសទាំងនោះ។

ការត្រួតត្រាដោយប្រយោល៖ ការត្រួតត្រាដោយប្រយោលពឹងផ្អែកលើមេដឹកនាំនយោបាយដែលមានស្រាប់។ នៅក្នុងតំបន់មួយចំនួន ចក្រភពអង់គ្លេសបានស្នើរឱ្យមេដឹកនាំនៅក្នុងតំបន់មួយរូបទទួលយកអំណាចរបស់អង់គ្លេសនៅក្នុងការដឹកនាំតំបន់នោះ។ មន្ត្រីនៅក្នុងតំបន់ទាំងនេះកាន់កាប់លើការគ្រប់គ្រងប្រចាំថ្ងៃនៅក្នុងដែនដីអាណានិគម។ ជាងនេះទៅទៀត ប្រទេសអាណានិគមនីមួយៗមានក្រុមប្រឹក្សានិតិបញ្ញត្តិមួយដែលរួមបញ្ចូលសមាសភាព មន្ត្រីអាណានិគម ក៏ដូចជាពាណិជ្ជករក្នុងតំបន់ និងអ្នកជំនាញនានាដែលជ្រើសរើសដោយអាជ្ញាធរអាណានិគម។ គោលបំណងគឺដើម្បីឱ្យក្រុមប្រឹក្សាធ្វើការបណ្តុះបណ្តាលមេដឹកនាំនៅក្នុងតំបន់ពីរបៀបដឹកនាំរដ្ឋាភិបាលតាមបែបអង់គ្លេស ហើយមេដឹកនាំនៅក្នុងតំបន់ទាំងនេះនឹងដឹកនាំប្រជាជនរបស់ពួកគេដោយខ្លួនឯង។ ការធ្វើរបៀបនេះបានកើតមានឡើងដើមដំបូង ក្នុងដែនដីអាណានិគមរបស់អង់គ្លេសនៅអូស្ត្រាលី និងកាណាដា។ នៅទសវត្សរ៍ឆ្នាំ 1890 សហរដ្ឋអាមេរិកចាប់ផ្តើមធ្វើអាណានិគម។ ពួកគេបានជ្រើសរើសវិធីសាស្ត្រការគ្រប់គ្រងដោយប្រយោលលើប្រទេសហ្វីលីពីន។

ការត្រួតត្រាដោយផ្ទាល់៖ បារាំង និងប្រទេសអឺរ៉ុបជាច្រើនទៀតបានជ្រើសរើសយកការគ្រប់គ្រងដោយផ្ទាល់លើដែនដីអាណានិគមរបស់ពួកគេ។ ពួកគេយល់ឃើញថា ពួកអាហ្វ្រិកមិនមានសមត្ថភាពអាចគ្រប់គ្រងកិច្ចការប្រទេសជាតិដ៏ស្មុកស្មាញបានទេ។ ដោយផ្អែកលើការគិតបែបនេះ ពួកអឺរ៉ុបបានអភិវឌ្ឍគោលនយោបាយមួយដែលគេហៅថា ភាពជាឪពុក ។ ដោយប្រើគោលនយោបាយនេះ ពួកអឺរ៉ុបបានគ្រប់គ្រងប្រជាជនក្នុងនាមជាអាណាព្យាបាល ដោយផ្តល់ឱ្យនូវអ្វីដែលពួកគេត្រូវការ ប៉ុន្តែមិនបានផ្តល់សិទ្ធិសេរីភាពដល់ពួកគេឡើយ។ ដើម្បីគាំទ្រដល់គោលនយោបាយនេះ ពួកអឺរ៉ុបបានអនុវត្តនូវរបៀបធ្វើការបែបការិយាធិបតេយ្យរបស់ពួកគេ និងមិនបានបណ្តុះបណ្តាលប្រជាជនក្នុងតំបន់ពីរបៀបដឹកនាំបែបអឺរ៉ុបឡើង។

បារាំងក៏គាំទ្រគោលនយោបាលធ្វើត្រាប់តាមផងដែរ។ គោលនយោបាយនេះផ្អែកសំខាន់ទៅលើគំនិតនៅពេលនោះ ដែលថា ប្រជាជននៅក្នុងតំបន់នឹងទទួលយកនូវវប្បធម៌បារាំង ហើយពួកគេនឹងដូចបារាំង។ ដើម្បីជួយដល់ការផ្លាស់ប្តូរនេះ សាលានៅក្នុងតំបន់ទាំងអស់, តុលាការ, និងការធ្វើជំនួញត្រូវធ្វើឱ្យមានទម្រង់ដូចបារាំង។ នៅក្នុងការអនុវត្ត បារាំងបានបោះបង់គំនិតអំពី ទាំងស្រុង ប៉ុន្តែមានកន្លែងខ្លះពួកគេបានបង្កើតគោលនយោបាយមួយស្តីអំពី "សមាគម" ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការគ្រប់គ្រងដោយប្រយោល។ ពួកគេទទួលស្គាល់ស្ថាប័ន និងវប្បធម៌របស់អាហ្វ្រិក ប៉ុន្តែចាត់ទុកពួកគេថាជាអ្នកដែលមានវប្បធម៌ទាបជាងបារាំង។

ការគ្រប់គ្រងដែនដីអាណានិគម៖ នៅក្នុងសម័យថ្មីនៃចក្រពត្តិនិយម វាមានភាពចាំបាច់មិនត្រឹមតែការដណ្តើមកាន់កាប់ដែនដីប៉ុណ្ណោះទេ ប៉ុន្តែក៏មានភាពចាំបាច់នៅក្នុងការគ្រប់គ្រងប្រជាជនដែលរស់នៅទីនោះផងដែរ។ ប៉ុន្តែ ការគ្រប់គ្រងប្រទេសនីហ្សេរីយ៉ាមិនមានភាពងាយស្រួលឡើយ។ ប្រទេសមួយនេះគឺជាប្រទេសដែលមានវប្បធម៌ចម្រុះបំផុតនៅក្នុងទ្វីបអាហ្វ្រិក។ មានក្រុមជនជាតិភាគតិចប្រហែល 250 ក្រុមរស់នៅក្នុងប្រទេសនេះ។ ក្រុមដែលធំជាងគេ 3 រួមមាន ក្រុមហាយូសា-ហ្វ៊ូឡានី ស្ថិតនៅភាគខាងជើង, ក្រុមយ៉ូរូបា ស្ថិតនៅភាគនិរតី, និងក្រុមអ៊ីកបូ ស្ថិតនៅភាគអាគ្នេយ៍។ ក្រុមទាំងនេះមានលក្ខណៈខុសគ្នាពីក្រុមផ្សេងៗទៀតដោយផ្អែកទៅលើកត្តាជាច្រើន ដោយរួមមានភាសា, វប្បធម៌, និងសាសនាជាដើម។ ពួកជនជាតិហាយូសា-ហ្វ៊ូឡានី គឺជាអ្នកកាន់សាសនាអ៊ីស្លាម និងមានរដ្ឋាភិបាលកណ្តាលរឹងមាំមួយ។ ពួកជនជាតិអ៊ីកបូ និងយ៉ូរូបាបានអនុវត្តជំនឿសាសនាបែបប្រពៃណី និងពឹងផ្អែកលើមេដឹកនាំក្នុងតំបន់ដើម្បីគ្រប់គ្រងពួកគេ។

ចក្រភពអង់គ្លេសមិនមានកងទ័ពច្រើនគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងលើតំបន់ដ៏ស្មុកស្មាញមួយនេះឡើយ។ ជាលទ្ធផល អង់គ្លេសបានត្រឡប់ទៅរកការគ្រប់គ្រងដោយប្រយោលលើដែនដីនេះ។ ការដឹកនាំដោយប្រយោលតាមរយៈមេដឹកនាំក្នុងតំបន់បានដំណើរការល្អជាមួយក្រុមជនជាតិហាយូសា-ហ្វ៊ូឡានី ។ ប៉ុន្តែ វិធីសាស្ត្រនៅក្នុងការគ្រប់គ្រងនេះមិនបានដំណើរការល្អទេជាមួយនឹងក្រុមជនជាតិអ៊ីកបូ និងយ៉ូរីបា។ មេដឹកនាំនៅក្នុងតំបន់របស់ពួកគេមិនសប្បាយចិត្តទៅនឹងការកម្រិតអំណាចរបស់ពួកគេដោយពួកអង់គ្លេស។

## 2. ការតស៊ូប្រឆាំងរបស់ពួកអាហ្វ្រិក

ក៏ដូចជានៅក្នុងប្រទេសនីហ្សេរីយ៉ាដែរ ប្រជាជនទាំងអស់នៅពាលពេញអាហ្វ្រិកបានងើបឡើងប្រឆាំងជាមួយការប៉ុនប៉ង់របស់ពួកអឺរ៉ុបក្នុងការដាក់អាណានិគមលើដែនដីរបស់ពួកគេ។ ប៉ុន្តែ ការប្រយុទ្ធគ្នារវាងពួកអាហ្វ្រិក និងមហាអំណាចអឺរ៉ុបមិនមានភាពស្មើគ្នាឡើយ ដោយសារតែពួកអឺរ៉ុបមានកងទ័ពដ៏ខ្លាំងក្លា។ ពួកអាហ្វ្រិកបានតស៊ូប្រឆាំងជាមួយពួកអឺរ៉ុបដោយប្រើប្រាស់កម្លាំងទាំងឡាយដែលពួកគេមាន ហើយតែងតែធ្វើឱ្យពួកអឺរ៉ុបមានការភ្ញាក់ផ្អើលជាមួយនឹងសមត្ថភាពយោធារបស់ពួកគេ។ ជាមួយនឹងករណីពិសេសមួយនៅប្រទេសអេត្យូពី រាល់ការប៉ុនប៉ង់របស់ពួកអឺរ៉ុបត្រូវបានបរាជ័យ។

ចលនាដែលមិនទទួលបានជោគជ័យ៖ ការតស៊ូប្រឆាំងដែលមិនទទួលបានជោគជ័យរួមមានទាំងការតស៊ូបែបយោធាយ៉ាងសកម្ម និងការតស៊ូតាមរយៈចលនាសាសនា។ អាលហ្សេរី ធ្វើការតស៊ូប្រឆាំងជាមួយការគ្រប់គ្រងរបស់បារាំងអស់រយៈពេលជិត 50 ឆ្នាំ គឺជាឧទាហរណ៍មួយនៃការតស៊ូយ៉ាងសកម្ម។ ចលនាតស៊ូដែលដឹកនាំដោយលោកសាម៉ូរី ទូរេ នៅអាហ្វ្រិកខាងលិចប្រឆាំងជាមួយបារាំងគឺជាឧទាហរណ៍មួយផ្សេងទៀត។ បន្ទាប់ពីធ្វើទំនើបកម្មកងទ័ពរបស់លោក លោក ទូរេ បានវាយប្រយុទ្ធជាមួយបារាំងអស់រយៈពេល 16 ឆ្នាំ។ ពួកអាហ្វ្រិកនៅក្នុងដែនដីអាឡឺម៉ង់អាហ្វ្រិកខាងកើត បានធ្វើការតស៊ូតាមរយៈជំនឿមន្តអាគមន៍។ ពួកអ្នកស្រុកជនជាតិអាហ្វ្រិកប្រឆាំងទៅនឹងបង្ខំរបស់ពួកអាឡឺម៉ង់ឱ្យពួកគេដាំដុះដំណាំកប្បាស, ដំណាំគ្រាប់ធុញ្ញជាតិសម្លាប់នាំចេញ ជាជាងដាំដុះដាំណាំចំណីអាហាររបស់ពួកគេ។ នៅក្នុងឆ្នាំ 1905 ពួកគេមានជំនឿថា ទឹកពិសិដ្ឋិមួយ(ម៉ាជី-ម៉ាជី) ដែលស្រោចនៅលើខ្លួនរបស់ពួកគេនឹងប្រែក្លាយគ្រាប់កាំភ្លើងរបស់ពួកអាឡឺម៉ង់ទៅជាទឹក។ ការបះបោរដែលគេស្គាល់ថា ការបះបោរម៉ាជីម៉ាជី ។ មានក្រុមជនជាតិភាគតិចប្រមាណជាង 20 ក្រុមមានរួបរួមគ្នាវាយប្រយុទ្ធដើម្បីសេរីភាពរបស់ពួកគេ។ ក្រុមអ្នកប្រយុទ្ធទាំងនោះជឿថា សង្គ្រាមរបស់ពួកគេត្រូវបានរៀបចំឡើងដោយព្រះជាម្ចាស់ ហើយបុព្វការីជនរបស់ពួកគេនឹងរស់ឡើងវិញ និងជួយដល់ការតស៊ូប្រឆាំងរបស់ពួកគេ។ ប៉ុន្តែ នៅពេលដែលក្រុមអ្នកតស៊ូប្រយុទ្ធដែលបំពាក់ដោយលំពែង និងការពារដោយទឹកវេទមន្តធ្វើការវាយប្រហារលើពួកអាឡឺម៉ង់ដែលបំពាក់ដោយកាំភ្លើងយន្ត ពួកគេត្រូវបានបាញ់សម្លាប់អស់រាប់ពាន់នាក់។ ជាផ្លូវការ អាឡឺម៉ង់បានសម្លាប់អ្នកបះបោរអស់ 75,000 នាក់។ ប៉ុន្តែ ចំនួនមនុស្សច្រើនជាង 2 ដងបានជួបប្រទះទៅនឹងគ្រោះអត់ឃ្លានបន្ទាប់ពីព្រឹត្តិការណ៍។ ពួកអាឡឺម៉ង់រង្គោះរង្គើដោយសារតែការបះបោរ និងលទ្ធផលនៃការបះបោរនេះ។ ជាលទ្ធផល ពួកគេបានធ្វើកំណែរទម្រង់មួយចំនួននៅក្នុងការគ្រប់គ្រង ដើម្បីធ្វើការគ្រប់គ្រងអាណានិគមរបស់ពួកគេអាចទទួលយកបានពីសំណាក់ប្រជាជនអាហ្វ្រិក។

អេត្យូពី-ការតស៊ូដែលទទួលបានជោគជ័យ៖ ប្រទេសអេត្យូពីគឺជាប្រទេសនៅអាហ្វ្រិកតែមួយគត់ដែលទទួលបានជោគជ័យនៅក្នុងតស៊ូប្រឆាំងជាមួយពួកអឺរ៉ុប។ ជ័យជំនះរបស់ពួកគេគឺដោយសារមេដឹកនាំម្នាក់ឈ្មោះមេនេលីក 2 ។ ទ្រង់បានក្លាយជាអធិរាជរបស់អេត្យូពីនៅក្នុងឆ្នាំ 1889 ។ ទ្រង់ទទួលបានជោគជ័យនៅក្នុងការប្រើប្រាស់ពួកអ៊ីតាលី, បារាំង, និងអង់គ្លេសឱ្យប្រយុទ្ធគ្នាទៅវិញទៅមក ដែលពួកគេទាំងអស់មានបំណងចង់នាំយក

ប្រទេសអេត្យូពី បញ្ចូលទៅក្នុងរង្វង់ដែលជីអាណានិគមរបស់ពួកគេ។ នៅពេលនោះ ទ្រង់បានស្ថាបនាឃ្លាំងស្តុកអាវុធសម័យទំនើបដ៏ធំមួយ ដែលពួកគេបានទិញពីបារាំង និងរុស្ស៊ី។ នៅក្នុងឆ្នាំ 1889 ភ្លាមៗបន្ទាប់ពីអធិរាជ មេនេលីក 2 បានឡាយព្រះហស្ថលេខាលើសន្ធិសញ្ញាមួយជាមួយប្រទេសអ៊ីតាលី ទ្រង់បានរកឃើញថាមានចំណុចខុសគ្នារវាងសន្ធិសញ្ញាដែលសរសេរជាភាសាអេត្យូពី និងភាសាអ៊ីតាលី។ អធិរាជ មេនេលីក 2 ជឿថា ទ្រង់បានផ្តល់នូវទឹកដីមួយផ្នែកតូចរបស់អេត្យូពីឱ្យទៅអ៊ីតាលី។ ប៉ុន្តែ ពួកអ៊ីតាលីបានអះអាងពីការកាន់កាប់ដែនដីទាំងអស់របស់អេត្យូពីក្នុងនាមជាអាណាព្យាបាលមួយ។ នៅខណៈពេលនោះ កងកម្លាំងរបស់អ៊ីតាលីបានធ្វើដំណើរមកដល់អេត្យូពីភាគខាងជើង។ អធិរាជ មេនេលីក 2 បានប្រកាសសង្គ្រាម។ នៅក្នុង 1896 នៅក្នុងសមរភូមិដែលខ្លាំងក្លាបំផុតនៅក្នុងប្រវត្តិសាស្ត្រអាហ្វ្រិក គឺសមរភូមិនៅ អាដូវ៉ា កងកម្លាំងរបស់អេត្យូពីបានទទួលជោគជ័យលើកងទ័ពអ៊ីតាលី និងរក្សាប្រទេសឱ្យស្ថិតនៅឯករាជ្យ។ បន្ទាប់ពីសមរភូមិនេះ អធិរាជ មេនេលីក 2 បន្តស្តុបទុកនូវកាំភ្លើង និងអាវុធទំនើបៗផ្សេងទៀត ក្នុងករណីមានមហាអំណាចបរទេសមួយណាឈ្លានពានប្រទេសអេត្យូពី។

### 3. កេរ្តិ៍ដំណែលនៃការគ្រប់គ្រងអាណានិគម

ការគ្រប់គ្រងអាណានិគមរបស់ពួកអឺរ៉ុបបានផ្លាស់ប្តូរជីវិតរស់នៅរបស់ពួកអាហ្វ្រិក។ នៅក្នុងករណីមួយចំនួន ពួកអឺរ៉ុបបាននាំមកនូវផលចំណេញ ប៉ុន្តែក្នុងករណីជាច្រើន ឥទ្ធិពលនៅការគ្រប់គ្រងអាណានិគមរបស់ពួកអឺរ៉ុបមានផលអវិជ្ជមាន។

ឥទ្ធិពលអវិជ្ជមាន៖ នៅផ្នែកខាងអវិជ្ជមាន ពួកអាហ្វ្រិកបាត់បង់ការគ្រប់គ្រងដែនដី និងឯករាជ្យរបស់ពួកគេ។ មានប្រជាជនជាច្រើនស្លាប់ដោយសារជំងឺថ្មីៗ ដែលមានដូចជាជំងឺអាសន្នរោគជាដើម។ ពួកគេក៏បាត់បង់ជីវិតអស់រាប់ពាន់នាក់ផងដែរ ដោយសារតែការតស៊ូប្រឆាំងជាមួយពួកអឺរ៉ុប។ គ្រោះអត់ឃ្លានកើតឡើងដោយសារតែការផ្លាស់ប្តូរពីការដាំដុះដំណាំស្បៀងអាហារ ជំនួសដោយការដាំដុះដំណាំគ្រាប់ធុញ្ញជាតិ។ ពួកអាហ្វ្រិកក៏រងទុក្ខដោយសារតែការផ្លាស់ប្តូរវប្បធម៌ប្រពៃណីរបស់ពួកគេផងដែរ។ អាជ្ញាធរសំខាន់ៗត្រូវបានគេដកចេញ។ ផ្ទះ និងទ្រព្យសម្បត្តិ ត្រូវបានផ្ទេរពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ដោយមិនបានគិតពីសារៈសំខាន់នៃរបស់ទាំងនោះចំពោះប្រជាជនឡើយ។ បុរសត្រូវបានបង្ខំឱ្យចាកចេញពីភូមិរបស់ពួកទៅស្វែងរកការងារធ្វើ ដើម្បីផ្គត់ផ្គង់ខ្លួនគេ និងក្រុមគ្រួសារ។ ការមិនឱ្យតម្លៃចំពោះការរស់នៅបែបប្រពៃណីរបស់អាហ្វ្រិក និងការឱ្យតម្លៃទៅលើការរស់នៅបែបទំនើបរបស់ពួកអឺរ៉ុបបាននាំឱ្យប៉ះពាល់ដល់ស្ថេរភាពសង្គម ហើយបង្កឱ្យមានបញ្ហាដល់អត្តសញ្ញាណរបស់ពួកអាហ្វ្រិក។ កេរ្តិ៍ដំណែលនយោបាយដែលមានគ្រោះថ្នាក់បំផុតដែលបន្សល់ទុកដោយពួកអាណានិគមនោះគឺការបែងចែកទ្វីបអាហ្វ្រិក។ មេដឹកនាំដែលជាគូប្រជែងគ្នារយៈពេលវែង ពេលខ្លះក៏បានបង្រួបបង្រួមគ្នា ប៉ុន្តែនៅពេលដែលពួកអឺរ៉ុបមកដល់ ក្រុមមេដឹកនាំទាំងនោះបានបែកចេញពីគ្នាទៅតាមការបែងចែកដែនដីអាណានិគមរបស់ពួកអឺរ៉ុប។ ព្រំប្រទល់ដែលបង្កើតឡើងដោយពួកអឺរ៉ុបបានបង្រួបបង្រួម ឬបែងចែកក្រុមទាំងនោះ ដែលបង្កជាបញ្ហាញាំញីនៅក្នុងដែនដីអាណានិគមអំឡុងពេលនៃការកាន់កាប់របស់ពួកអឺរ៉ុប។ ព្រំដែនទាំងនេះនៅតែបន្តបង្កើតបញ្ហាដល់ប្រទេសជាតិនានា បន្ទាប់ពីទទួលបានឯករាជ្យពីពួកអឺរ៉ុប។

ឥទ្ធិពលវិជ្ជមាន៖ នៅខាងផ្នែកវិជ្ជមាន អាណានិគមនិយមបានកាត់បន្ថយការធ្វើសង្គ្រាមនៅក្នុងតំបន់។ ក្រុមអ្នកធ្វើការងារមនុស្សធម៌បានព្យាយាមនៅក្នុងបង្កើនអនាម័យ និងផ្តល់ការថែទាំជំងឺ និងសាលាដល់ប្រទេសអាណានិគមមួយចំនួន។ ជាលទ្ធផល ជីវិតសង្ឃឹមរស់បានកើនឡើង ហើយអត្រាអ្នកចេះអក្សរក៏កើនឡើងផងដែរ។ ក៏មានផលវិជ្ជមានសម្រាប់ការពង្រីកវិស័យសេដ្ឋកិច្ចផងដែរ។ ផលិតផលរបស់អាហ្វ្រិកចាប់ផ្តើមមានតម្លៃនៅលើទីផ្សារអន្តរជាតិ។ ដើម្បីជួយដល់ការរីកលូតលាស់នូវសេដ្ឋកិច្ច, ផ្លូវរថភ្លើង, ទំនប់, និងបណ្តាញទូរស័ព្ទ និងទូរសារត្រូវបានស្ថាបនាឡើងនៅក្នុងដែនដីអាណានិគមអាហ្វ្រិក។ ប៉ុន្តែភាគច្រើន អត្ថប្រយោជន៍ទាំងនេះធ្លាក់ទៅលើតែពួកអ្នកជំនួញអឺរ៉ុបប៉ុណ្ណោះ មិនមែនប្រជាជនអាហ្វ្រិកឡើយ។

របៀបនៃការគ្រប់គ្រងរបស់ពួកមហាអំណាចចក្រពត្តិនិយមមានលក្ខណៈស្រដៀងគ្នាមិនថាដែនដីអាណានិគមរបស់ពួកគេស្ថិតនៅទីកន្លែងណាទេ។ ទាក់ទងជាមួយនឹងប្រពៃណី និងប្រជាជនក្នុងតំបន់នៅតែបន្តបង្កើតបញ្ហានៅក្នុងដែនដីអាណានិគមរបស់ពួកអឺរ៉ុប។ ការតស៊ូប្រឆាំងទៅនឹងពួកចក្រពត្តិអឺរ៉ុបនៅតែបន្ត ដែលអ្នកនឹងបានឃើញនៅក្នុងមេរៀនទី 3 ។

# មេរៀនទី 3៖ ពួកអឺរ៉ុបដណ្តើមកាន់កាប់ដែនដីរបស់ពួកម៉ូស្លីម

## 1. ចក្រភពអូតូម៉ង់បាត់បង់អំណាច

ចក្រភពអូតូម៉ង់ដែលបានចុះអន់ខ្សោយទៅហើយនោះ មានភាពលំបាកនៅក្នុងការសម្របខ្លួនរបស់ពួកគេចូលទៅពិភពលោកសម័យទំនើប។ ប៉ុន្តែ ចក្រភពអូតូម៉ង់បានព្យាយាមនៅក្នុងការផ្លាស់ប្តូរខ្លួនគេមុនពេលដែលគេធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ពួមមហាអំណាចចក្រពត្តិនិយមអឺរ៉ុប។

បរាជ័យនៃការធ្វើកំណែទម្រង់៖ នៅពេលដែលស្តេចស៊ូតង់ ស៊ូឡៃម៉ាន់ទី 1 ដែលជាស្តេចខ្លាំងពូកែចុងក្រោយរបស់ចក្រភពអូតូម៉ង់សុគតនៅក្នុងឆ្នាំ 1566 អ្នកបន្តតំណែងពីទ្រង់ភាគច្រើនគឺជាស្តេចដែលអន់ខ្សោយ។ រដ្ឋាភិបាលនៅក្នុងរាជវាំងបានបែងចែកជាបក្សពួកច្រើនក្រុម និងពុករលួយ។ ការធ្លាក់ចុះនៃអំណាចនាំមកនូវបញ្ហាជាច្រើន។ អំពើពុករលួយ និងការលួចបណ្តាលឱ្យបាត់បង់ហិរញ្ញវត្ថុជាច្រើន។ លុយកាក់បានបាត់បង់តម្លៃដែលនាំឱ្យមានអតិផរណា។ នៅពេលមុន ចក្រភពអូតូម៉ង់បានចាប់យកបច្ចេកវិទ្យាសម័យទំនើប ប៉ុន្តែក្រោយមកពីគេស្ថិតនៅពីក្រោយពួកអឺរ៉ុបកាន់តែឆ្ងាយទៅៗ។

នៅពេលដែលស្តេចសេលីម 3 ឡើងកាន់អំណាចនៅក្នុងឆ្នាំ 1789 ទ្រង់បានព្យាយាមនៅក្នុងការធ្វើទំនើបកម្មវិស័យយោធា។ ប៉ុន្តែ ក្រុមអង្គភាពចានីសសារី ចាស់បានប្រឆាំងទៅនឹងការព្យាយាមរបស់ទ្រង់។ ស្តេចសេលីមទី 3 ត្រូវបានទម្លាក់ពីអំណាច ហើយចលនាធ្វើកំណែរទម្រង់ត្រូវបានគេផ្អាកជាបណ្តោះអាសន្ន។ នៅខណៈពេលនោះគំនិតជាតិនិយមបានចាប់ផ្តើមផុះឡើងនៅក្នុងចំណោមប្រជាជនទាំងឡាយនៅក្នុងចក្រភពអូតូម៉ង់។ នៅក្នុងឆ្នាំ 1830 ពួកក្រិកទទួលបានឯករាជ្យរបស់ពួកគេ ហើយពួកស៊ែបប៊ីទទួលបានសិទ្ធិនៅក្នុងការគ្រប់គ្រងដោយខ្លួនឯង។ ពួកមហាអំណាចអឺរ៉ុបមើលឃើញយ៉ាងច្បាស់ពីការចុះខ្សោយនៃចក្រភពអូតូម៉ង់ ដែលវាជាឱកាលមួយនៅក្នុងពង្រីកដែលដីអាណានិគមរបស់ពួកគេ។ ពួកគេចាប់ផ្តើមស្វែងរកវិធីនានាដើម្បីដណ្តើមយកដីពីពួកអូតូម៉ង់។

## 2. ការគ្រសោបយកដែនដីរបស់ពួកអឺរ៉ុប

ភូមិសាស្ត្រនយោបាយ៖ ការចាប់អារម្មណ៍ ឬការដណ្តើមយកដែនដីសម្រាប់ធ្វើជាតំបន់យុទ្ធសាស្ត្រ ឬបង្កើនផលិផល បានតើតួនាទីដ៏សំខាន់មួយនាំឱ្យចក្រភពអូតូម៉ង់ដួលរលំ។ មហាអំណាចពិភពលោកបានចាប់អារម្មណ៍លើតំបន់នេះ ដោយសារវាជាតំបន់យុទ្ធសាស្ត្រមួយ។ ចក្រភពអូតូម៉ង់ត្រួតត្រាតំបន់ពាណិជ្ជកម្មតាមសមុទ្រមេឌីទែរ៉ាណេ និងអាត្លង់ទិក។ ពាណិជ្ជករនៅតាមបណ្តាលប្រទេសដែលមិនជាប់សមុទ្ទ ដែលស្ថិតនៅឆ្ងាយពីសមុទ្ទខ្មៅ ត្រូវតែធ្វើដំណើរតាមដែនដីរបស់ចក្រភពអូតូម៉ង់។ ឧទាហរណ៍ ប្រទេសរុស្ស៊ីចង់បានផ្លូវមួយសម្រាប់នាំចេញគ្រប់ធុញ្ញជាតិរបស់ពួកគេឆ្លង់កាត់តាមសមុទ្ទខ្មៅ និងបន្តទៅសមុទ្រមេឌីរ៉ាណេ។ គោលបំណងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងលើកទំនាក់ទំនងរបស់រុស្ស៊ីជាមួយនឹងចក្រភពអូតូម៉ង់។ រុស្ស៊ីបានព្យាយាមនៅក្នុងការយកជ័យជំនះលើពួកអូតូម៉ង់ ដោយបង្កើតសម្ព័ន្ធមិត្តជាមួយសត្រូវរបស់ចក្រភពអូតូម៉ង់ ហើយចុងក្រោយបានធ្វើសង្គ្រាម

ប្រឆាំងជាមួយពួកអូតូម៉ង់។ ការរកឃើញប្រេងកាតនៅពែក្សរង្វង់ឆ្នាំ 1900 និងឧបទ្ទិបអារ៉ាប់បន្ទាប់ពីសង្គ្រាមលោកលើកទីមួយបានធ្វើឱ្យមហាអំណាចទាំងឡាយចាប់អារម្មណ៍កាន់តែខ្លាំងលើតំបន់នេះ។

រុស្ស៊ី និងសង្គ្រាមគ្រីមេ៖ ក្រុមជនជាតិរុស្ស៊ីគ្រប់ជំនាន់បានធ្វើសង្គ្រាមជាមួយពួកអូតូម៉ង់ដើម្បីដណ្ដើមកាន់កាប់ដែនដីនៅសមុទ្រខ្មៅ។ គោលបំណងគឺដើម្បីបង្កើតកំពង់ផែមួយរបស់រុស្ស៊ីនៅតំបន់ដែលមានអាកាសធាតុក្តៅស្នម។ នៅក្នុងឆ្នាំ 1853 សង្គ្រាមបានផ្ទុះឡើងរវាងរុស្ស៊ី ជាមួយនឹងចក្រភពអូតូម៉ង់។ សង្គ្រាមត្រូវបានគេហៅថាសង្គ្រាមគ្រីមេ បន្ទប់ពីសង្គ្រាមបានផ្ទុះឡើងស្ទើរគ្រប់តំបន់ទាំងអស់នៅឧបទ្វីបមួយនៅសមុទ្រខ្មៅ។ ចក្រភពអង់គ្លេស និងបារាំងចង់ការពារការត្រួតត្រារបស់រុស្ស៊ីលើដែនដីរបស់ចក្រភពអូតូម៉ង់បន្ថែមទៀត។ ដូច្នេះ ពួកគេបានចូលរួមនៅក្នុងសង្គ្រាមដោយស្ថិតនៅខាងភាគីចក្រភពអូតូម៉ង់។ កងទ័ពដែលជាការរួមបញ្ចូលគ្នារវាងចក្រភពអូតូម៉ង់, អង់គ្លេស, និងបារាំងបានយកជ័យជំនះលើរុស្ស៊ី។ សង្គ្រាមគ្រីមេ គឺជាសង្គ្រាមលើកដំបូងដែលស្ត្រី ដែលដឹកនាំដោយ ហ្វ្លរេន ណៃទីងហ្គាល បានបង្កើតតួនាទីរបស់ពួកក្នុងនាមជាកងទ័ពពេទ្យ។ វាក៏ជាសង្គ្រាមដំបូងដែលត្រូវបានរាយការណ៍ដោយអ្នកសារព័ត៌មាននៅលើក្រេបមុខការសែតផងដែរ។ សង្គ្រាមគ្រីមេបានបង្ហាញពីភាពអន់ខ្សោយនៃកងទ័ពរបស់ចក្រភពអូតូម៉ង់។ បើទោះបីជាមានការជួយពីសំណាក់អង់គ្លេស និងបារាំងក៏ដោយ ចក្រភពអូតូម៉ង់នៅតែបន្តបាត់បង់ដី។ រុស្ស៊ីចាប់ផ្តើមផ្តល់ជំនួយដល់ពួកស្លាវ នៅតំបន់បាល់កង់ ដែលបានងើបឡើងបះបោរប្រឆាំងជាមួយអូតូម៉ង់។ ចក្រភពអូតូម៉ង់បានបាត់បង់ការគ្រប់គ្រងរបស់ខ្លួនលើប្រទេសរ៉ូមានី, ម៉ុងតេនេក្រូ, ស៊ីព្រួស, បូស្នៀ, ហឺហ្សេហ្គោវិណា, និងតំបន់មួយដែលក្រោយមកក្លាយជាប្រទេសប៊ុលការី។ អូតូម៉ង់ក៏បាត់បង់ដែនដីរបស់ពួកគេនៅអាហ្វ្រិកផងដែរ។ ត្រឹមការចាប់ផ្តើមនៃសង្គ្រាមលោកលើកទី 1 ដែនដីរបស់ចក្រភពអូតូម៉ង់បានរួមតូច និងធ្លាក់ចុះយ៉ាងខ្លាំង។

ល្បែងដ៏អស្ចារ្យ៖ ស្ទើរតែពេញមួយសតវត្សរ៍ទី 19 ចក្រភពអង់គ្លេស និងរុស្ស៊ីបានចូលរួមនៅក្នុងជម្លោះភូមិសាស្ត្រមួយផ្សេងទៀតលើដែនដីរបស់ពួកម៉ូស្លីមនៅអាស៊ីកណ្តាល។ ដោយគេស្គាល់ថា "ល្បែងដ៏អស្ចារ្យ" សង្គ្រាមនេះបានផ្ទុះឡើងនៅប្រទេសឥណ្ឌា ដែលជាដែនដីអាណានិគមដ៏សំខាន់បំផុតរបស់ចក្រភពអង់គ្លេស។ រុស្ស៊ីបានសម្លឹងឃើញពីការពង្រីកដែនដីចក្រភពរបស់ពួកគេ និងអាចចូលទៅកាន់តំបន់សប្បុរសប្បាយនៅឥណ្ឌា។ អង់គ្លេសបានការពារដែនដីអាណានិគម និងព្យាយាមនៅក្នុងការពង្រីកដែនដីចក្រភពរបស់ពួកគេហួសឆ្ងាយពីព្រំដែនឥណ្ឌាទៅមុខ។ ប្រទេសអាហ្គានីស្ថាន ដែលស្ថិតនៅចន្លោះចក្រភពអង់គ្លេស និងចក្រភពរុស្ស៊ី បានក្លាយជាចំណុចកណ្តាលនៃជម្លោះរបស់ពួកគេ។

នៅក្នុងទសវត្សរ៍ឆ្នាំ 1800 ប្រទេសអាហ្គានីស្ថានគឺជាព្រះរាជាណាចក្រម៉ូស្លីមឯករាជ្យមួយ។ ភាពរាំងស្ងួត, ផ្ទៃដីសម្បូរទៅដោយភ្នំរបស់ប្រទេសនេះ បានជម្រុញឱ្យប្រជាជនមិនសូវចាប់អារម្មណ៍ចំពោះការឈ្លានពានរបស់ពួកមហាអំណាចចក្រព័ត្តិនិយមឡើយ។ បន្ទាប់ពីការវាយប្រយុទ្ធគ្នាអស់ជាច្រើនទសវត្សរ៍មក ចុងក្រោយចក្រភពអង់គ្លេសបានដកខ្លួនចេញពីប្រទេសអាហ្គានីស្ថាននៅក្នុងឆ្នាំ 1881។ នៅក្នុងឆ្នាំ 1921 ជាផ្លូវការចក្រភពអង់គ្លេសបានយល់ព្រមថា ដែនដីចក្រភពរបស់ពួកគេនឹងមិនពង្រីកឱ្យឆ្ងាយលើសពីតំបន់ច្រកព្រំដែនឃីប័រឡើយ ដែល

បច្ចុប្បន្នស្ថិតនៅព្រំដែនភាគខាងកើតអាហ្គានីស្ថាន។ នៅខណៈពេលនោះ សហភាពសូវៀតដែលទើបតែបង្កើតថ្មី បានចុះហត្ថលេខាលើកតិការសញ្ញាមិនឈ្លានពានមួយជាមួយអាហ្គានីស្ថាន។ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់រហូតដល់ឆ្នាំ 1979 នៅពេលដែលសហភាពសូវៀតធ្វើការឈ្លានពានអាហ្គានីស្ថាន។

### 3. ការចាប់ផ្តើមការធ្វើកំណែទម្រង់នៅអេហ្ស៊ីប

ដោយមើលឃើញពីក្លារធ្លាក់ចុះបន្តិចម្តងៗនៅចក្រភពអូតូម៉ង់ មេដឹកនាំម៉ូស្លីមមួយចំនួនបានសម្រេចថាប្រទេសរបស់ពួកគេគួរតែសម្របខ្លួនឱ្យស៊ីគ្នាជាមួយនឹងពិភពលោកសម័យទំនើប ឬទទួលយកភាពទំនើបនេះតែម្តង។ អេហ្ស៊ីបចាប់ផ្តើមធ្វើកំណែទម្រង់នយោបាយ និងសង្គមរបស់ពួកគេនៅលើផ្នែកខ្លះដើម្បីរារាំងដល់ការកគ្រប់ដណ្តាប់របស់ពួកអឺរ៉ុបមកលើដែនដីរបស់ពួកគេ។

កំណែទម្រង់យោធា និងសេដ្ឋកិច្ច៖ ទំនើបកម្មកើតមានឡើងនៅក្នុងប្រទេសអេហ្ស៊ីប ដោយសារតែពួកបារាំងមានការចាប់អារម្មណ៍លើរឿងអំឡុងពេលនៃការកាន់កាប់របស់ពួកគេ។ ទីតាំងយុទ្ធសាស្ត្ររបស់អេហ្ស៊ីបដែលស្ថិតនៅសមុទ្រក្រហមនេះ ត្រូវបានមើលឃើញពីអត្ថប្រយោជន៍ដោយពួកបារាំង និងអង់គ្លេស។ បន្ទាប់ពីស្តេចណាប៉ូឡេអុងបរាជ័យនៅក្នុងការដណ្តើមកាន់កាប់អេហ្ស៊ីប មេដឹកនាំថ្មីមួយបានលេចឡើងគឺ មហាម៉ាត់អាលី។ ចក្រភពអូតូម៉ង់បានបញ្ជូនលោកក្នុងនាមជាកងកម្លាំងបន្ថែមមួយរូបឱ្យមកដឹកនាំអេហ្ស៊ីប ប៉ុន្តែភ្លាមៗនោះ លោកបានផ្តាច់ខ្លួនចេញពីការគ្រប់គ្រងរបស់ចក្រភពអូតូម៉ង់។ នៅដើមឆ្នាំ 1831 លោកបានបើកការវាយប្រយុទ្ធមួយចំនួនដោយលោកជ័យជំនះលើការគ្រប់គ្រងប្រទេសស៊ីរី និងអារ៉ាប់ប៊ី។ តាមរយៈការធ្វើការរួមគ្នាដើម្បីទប់ទល់នឹងការឈ្លានពានរបស់ពួកមហាអំណាចអឺរ៉ុប មហាម៉ាត់អាលី និងអ្នកបន្តវេនពីលោកត្រូវបានទទួលស្គាល់ថាជាមេដឹកនាំតពូជនៅអេហ្ស៊ីប។ មហាម៉ាត់អាលីបានចាប់ផ្តើមធ្វើកំណែទម្រង់មួយចំនួននៅក្នុងវិស័យយោធា និងសេដ្ឋកិច្ច។ ដោយគ្មានជំនួយពីពួកបរទេស មហាម៉ាត់អាលីខ្លួនលោកផ្ទាល់បានធ្វើការផ្លាស់ប្តូរកសិកម្មកម្មអេហ្ស៊ីបទៅរកការដាំដុះដំណាំបែបកសិកម្មឧស្សាកម្មវិញ គឺកប្បាស។ ការផ្លាស់ប្តូរនេះបាននាំអេហ្ស៊ីបទៅកាន់ទីផ្សារអន្តរជាតិ ប៉ុន្តែវានាំឱ្យប៉ះពាល់ដល់ប្រជាកសិករ។ ពួកគេបានបាត់បង់ដីស្រែចំការដែលពួកគេធ្វើជាលក្ខណៈបែបប្រពៃណី និងត្រូវបានបង្ខំឱ្យដាំដុះដំណាំកសិកម្មឧស្សាហកម្មជំនួសដំណាំស្បៀងអាហាររបស់ពួកគេ។

ព្រែកជីកស៊ុយអេ៖ ការប្រឹងប្រែងរបស់មហាម៉ាត់អាលីនៅក្នុងការធ្វើទំនើបកម្មអេហ្ស៊ីត្រូវបានបន្តដោយចៅរបស់លោកដែលមានឈ្មោះថា អ៊ីស្មាអ៊ីល។ អ៊ីស្មាអ៊ីល បានគាំទ្រដល់ការស្ថាបនាព្រែកជីកស៊ុយអេ។ ព្រែកនេះគឺជាផ្លូវទឹកមួយដែលគេបានជីកកាត់ផ្តាច់ដីនៅស៊ុយអេ។ វាបានភ្ជាប់សមុទ្រក្រហមជាមួយនឹងសមុទ្រមេឌីទែរ៉ាណេ។ វាត្រូវបានស្ថាបនាឡើយដោយប្រើប្រាស់លុយដែលបានមកពីក្រុមហ៊ុនឯកជនបារាំង ដោយប្រើប្រាស់កម្មករអេហ្ស៊ីប។ ព្រែកជីកស៊ុយអេបើកដំណើរការនៅក្នុងឆ្នាំ 1869 ជាមួយនឹងការសម្ពោធជាលក្ខណៈអន្តរជាតិដ៏ធំមួយ។ ប៉ុន្តែ ការព្យាយាមធ្វើទំនើបកម្មរបស់ អ៊ីស្មាអ៊ីល មានដូចជាកម្រោងប្រព័ន្ធធារាសាស្ត្រ និងបណ្តាញទំនាក់ទំនង គឺមានការចំណាយខ្ពស់។ អេហ្ស៊ីបនៅពេលនោះបានជំពាក់លុយធនាគារអឺរ៉ុបជាច្រើន ដោយគ្រាន់តែការប្រាក់តែ

មួយមុខមានចំនួន 450 លានទៅហើយ។ អង់គ្លេសបានទាមទារការគ្រប់គ្រងលើផ្នែកហិរញ្ញវត្ថុរបស់ព្រែកជីកនេះ ហើយនៅក្នុងឆ្នាំ 1882 អង់គ្លេសបានកាន់កាប់ប្រទេសអេហ្ស៊ីប។

## 4. ពែក្សរេចសម្ពាធឱ្យមានការផ្លាស់ប្តូរ

ក្រៅពីតំបន់អាស៊ីនិតី ប្រទេសរុស្ស៊ី និងអង់គ្លេសបានប្រកួតប្រជែងគ្នានៅក្នុងការកេងប្រវ័ញ្ចលើពាណិជ្ជកម្មរបស់ពែក្ស និងនាំយកប្រទេសនេះដាក់ឱ្យស្ថិតនៅក្រោមរង្វង់ឥទ្ធិពលរបស់ពួកគេ ។ រុស្ស៊ីបានចាប់អារម្មណ៍ខ្លាំងបំផុតលើការទទួលបានការកាន់កាប់តំបន់ឈូងសមុទ្រពែក្ស និងមហាសមុទ្រឥណ្ឌា។ តំបន់ទាំងពីររបស់ពែក្សនេះបានធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់រុស្ស៊ី បន្ទាប់ពីពួកគេចាញ់សង្គ្រាមរុស្ស៊ីនៅក្នុងឆ្នាំ 1813 និងឆ្នាំ 1828 ។

អង់គ្លេសមានចំណាប់អារម្មណ៍នៅក្នុងការប្រើប្រាស់អាហ្គានីស្ថាន ធ្វើជាតំបន់ទ្រនាប់មួយរវាងដែនដីឥណ្ឌា និងរុស្ស៊ី។ នៅក្នុងឆ្នាំ 1857 ពួកពែក្សបានបដិសេធទៅនឹងការទាមទាររបស់របស់អង់គ្លេស ប៉ុន្តែពួកគេត្រូវបានបង្ខំឱ្យបោះបង់ចោលនូវរាល់ការគ្រប់គ្រងទាំងអស់នៅអាហ្គានីស្ថាន។ ចំណាប់អារម្មណ៍របស់អង់គ្លេសលើតំបន់ពែក្សបានកើនឡើងយ៉ាងខ្លាំង បន្ទាប់ពីការរកឃើញប្រេងកាតនៅតំបន់នេះនៅក្នុងឆ្នាំ 1908 ។ ពួកពែក្សខ្វះខាតដើមទុនដើម្បីអភិវឌ្ឍធនធានរបស់ពួកគេ។ ដើម្បីទទួលបានលុយ និងដើម្បីធ្វើឱ្យសេដ្ឋកិច្ចរុងរឿង មេដឹកនាំពែក្សចាប់ផ្តើមផ្តល់សម្បទានដល់អ្នកជំនួញជនជាតិអឺរ៉ុប។ ការធ្វើសម្បទាននេះបានអនុញ្ញាតឲ្យអ្នកជំនួញអាចទិញសិទ្ធិនៅក្នុងការធ្វើប្រតិបត្តិការនៅក្នុងតំបន់មួយចំនួន ឬអភិវឌ្ឍលើផលិតផលជាក់លាក់ណាមួយ។ ឧទាហរណ៍សាជីវកម្មអង់គ្លេសមួយ ឈ្មោះថា ក្រុមហ៊ុនប្រេងកាតអង់គ្លេស-ពែក្ស ចាប់ផ្តើមអភិវឌ្ឍតំបន់សម្បូរប្រេងកាតរបស់ពែក្សនៅដើមទសវត្សរ៍ឆ្នាំ 1900។

សមរភូមិថ្នាំជក់៖ ជម្លោះបានកើតឡើងរវាងមេដឹកនាំពួករលួយនានាជាមួយប្រជាជន ដែលមេដឹកនាំទាំងនោះមានបំណងចង់លក់សម្បទានឱ្យពួកអឺរ៉ុប។ ប្រជាជនដែលជាទូទៅនៅពីក្រោយដោយមេដឹកនាំសាសនា ដែលមានការព្រួយបារម្ភអំពីការផ្លាស់ប្តូរ ឬមិនសប្បាយចិត្តជាមួយនឹងឥទ្ធិពលរបស់ពួកលោកខាងលិចនៅក្នុងប្រទេសរបស់ពួកគេ។ នៅក្នុងឆ្នាំ 1890 មេដឹកនាំពែក្សមួយរូបឈ្មោះ ណាស៊ែរ អាលឌីន បានលក់សម្បទានមួយដល់ក្រុមហ៊ុនអង់គ្លេសដើម្បីនាំចេញថ្នាំជក់របស់ពែក្ស។ សកម្មភាពនេះបានធ្វើឱ្យលោកចាម៉ាល អាលឌីន អាលអាហ្គានីដែលជាមេដឹកនាំមួយរូបដែលគាំទ្រការធ្វើទំនើបកម្មនៅពែក្ស មានការមិនសប្បាយចិត្ត។ លោកបានជួយបង្កើតឱ្យមានការធ្វើពាហិការរបស់ប្រជាជនពែក្សចំពោះបារី។

ការធ្វើពាហិការចំពោះបារីបានដំណើរការ។ កុប្បកម្មបានផ្ទុះឡើង ហើយមេដឹកនាំត្រូវបានបង្ខំឱ្យលុបចោលការធ្វើសម្បទាននេះ។ ដូចដែលភាពចលាចលនៅតែបន្តនៅពែក្ស ដូច្នេះ រដ្ឋាភិបាលមិនអាចគ្រប់គ្រងស្ថានការណ៍បានឡើយ។ នៅក្នុងឆ្នាំ 1906 កងកម្លាំងធ្វើបដិវត្តមួយក្រុមបានបង្ខំឱ្យមេដឹកនាំបង្កើតធម្មនុញ្ញមួយ។ នៅក្នុងឆ្នាំ 1907 រុស្ស៊ី និងអង់គ្លេសបានដណ្តើមកាន់កាប់ប្រទេសពែក្ស និងបានបែងចែកតំបន់នេះទៅក្នុងដែននៃឥទ្ធិពលរបស់ពួកគេ។ ពួកគេធ្វើការត្រួតត្រាលើសេដ្ឋកិច្ចរបស់ពែក្ស។ នៅក្នុងដែនដីរបស់ពួកម៉ូស្លីម ពួកចក្រពត្តិអឺរ៉ុបជាច្រើនបានគ្រប់គ្រង ដោយប្រើប្រាស់ចក្រពត្តិនិយលើសេដ្ឋកិច្ច និងបង្កើតដែនឥទ្ធិពលរបស់ពួកគេ។ បើទោះបីជា

រដ្ឋាភិបាលមួយចំនួនបានព្យាយាមនៅក្នុងការធ្វើទំនើបកម្មប្រទេសជាតិរបស់ពួកគេក៏ដោយ នៅក្នុងករណីខ្លះពួកគេធ្វើបានតិចតួច និងយឺតយ៉ាវ។ នៅក្នុងតំបន់ផ្សេងៗទៀតនៅលើពិភពលោក ពួកចក្រពត្តិនិយមបានផ្តល់នូវការធ្វើទំនើបកម្ម។ ឧទាហរណ៍ ប្រទេសឥណ្ឌាបានក្លាយជាតំបន់អាណានិគមដែលទទួលបានការផ្លាស់ប្តូរយ៉ាងច្រើនដោយសារការគ្រប់គ្រងរបស់ពួកចក្រពត្តិអង់គ្លេស។ អ្នកនឹងបានសិក្សាពីឥណ្ឌានៅក្នុងមេរៀនទី 4 ។

# មេរៀនទី 4 ៖ ចក្រពត្តិនិយមអង់គ្លេសនៅឥណ្ឌា

## 1. អង់គ្លេសពង្រីកការគ្រប់គ្រងលើប្រទេសឥណ្ឌា

តំបន់ដែលត្រួតត្រាដោយក្រុមហ៊ុនឥណ្ឌាខាងកើតបានកើនឡើងបន្តិចម្តងៗ។ ដោយថាហេតុ ពួកគេបានត្រួតត្រាដោយផ្ទាល់ និងដោយប្រយោលលើតំបន់មួយដែលរួមបញ្ចូលប្រទេសបង់ក្លាដែស, ភាគច្រើននៃឥណ្ឌាខាងត្បូង, និងដែនដីស្ទើរទាំងអស់នៅតាមបណ្តោយទន្លេគង្គានៅភាគខាងជើង។

ក្រុមហ៊ុនឥណ្ឌាខាងកើតគ្រប់ដណ្តប់៖ ជាផ្លូវការ រដ្ឋាភិបាលអង់គ្លេសជានៅពីក្រោយការប្រឹងប្រែងរបស់ក្រុមហ៊ុនឥណ្ឌាខាងកើតទាំងនៅទីក្រុងឡុងដ៍ និងនៅឥណ្ឌា។ រហូតដល់ដើមសតវត្សរ៍ទី 19 ក្រុមហ៊ុននេះបានគ្រប់គ្រងឥណ្ឌាជាមួយនឹងការជ្រៀតជ្រែកតិចតួចពីរដ្ឋាភិបាលអង់គ្លេស។ ក្រុមហ៊ុននេះថែមទាំងមានកងទ័ពផ្ទាល់ខ្លួន ដែលដឹកនាំដោយមន្ត្រីអង់គ្លេស និងបម្រើការងារដោយកងទ័ពឥណ្ឌា។ មេដឹកនាំនៅ ម៉ុមបៃ លោកម៉ោនស្តាត អេលភីនស្តូន បានឆ្លុះបញ្ចាំងកងទ័ពឥណ្ឌាថាជា "ជាម៉ាស៊ីនដែលប៉ុនប្រសព្វ និងមានគ្រោះថ្នាក់មួយ ប្រសិនបើរៀបចំមិនបានស្រួលវាគេអាចនឹងត្រឡប់មកប្រឆាំងជាមួយយើងវិញ"។

"ត្បូងនៅលើមកុដ"របស់អង់គ្លេស៖ ដំបូងអង់គ្លេសវាយតម្លៃឥណ្ឌាថាពួកគេមានសក្តានុពលច្រើនជាងអ្វីដែលពួកគេមានពិតប្រាកដ។ បដិវត្តឧស្សាហកម្មបានប្រែក្លាយអង់គ្លេសឱ្យក្លាយជាកន្លែងផលិតនូវផលិតផលសម្រាប់ពិភពលោក ហើយឥណ្ឌាគឺជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើមដ៏សំខាន់មួយសម្រាប់ការផលិតនេះ។ ប្រជាជន 300 លាននាក់របស់ឥណ្ឌាក៏ជាសក្តានុពលដ៏ធំមួយផងដែរសម្រាប់ទីផ្សារផលិតផលរបស់អង់គ្លេស។ ក្រោយមកវាមិនមែនជារឿងដែលគួរឱ្យភ្ញាក់ផ្អើលនោះទេដែលអង់គ្លេសចាត់ទុកឥណ្ឌាគឺជា "ត្បូងនៅលើមកុដ" ដ៏ភ្លឺចិញ្ចែងចញ្ចាច ដែលជាដែនដីអាណានិគមដ៏មានតម្លៃបំផុតសម្រាប់អង់គ្លេស។ អង់គ្លេសបានដាក់កំហិតមួយចំនួនដើម្បីការពារសេដ្ឋកិច្ចឥណ្ឌាពីការប្រតិបត្តិដោយពួកគេខ្លួនឯង។ គោលនយោបាយរបស់អង់គ្លេស បានស្នើរឱ្យពួកឥណ្ឌាផលិតនូវវត្ថុធាតុដើមសម្រាប់រោងចក្រសហគ្រាសអង់គ្លេស និងទិញទំនិញរបស់អង់គ្លេស។ ក្នុងការបន្ថែមការប្រកួតប្រជែងរបស់ឥណ្ឌាជាមួយនឹងទំនិញរបស់អង់គ្លេសត្រូវបានហាមឃាត់។ ឧទាហរណ៍ ឧស្សាហកម្មត្បាញក្រណាត់ដោយដៃរបស់ឥណ្ឌាស្ទើរលែងដំណើរការ ដោយសារតែការនាំចូលក្រណាត់របស់អង់គ្លេស។ សម្លៀកបំពាក់ថោកៗរបស់អង់គ្លេសបានហូរចូលទីផ្សារឥណ្ឌា ដែលធ្វើឱ្យផលិតផលក្នុងស្រុកថយចុះ។

ការដឹកជញ្ជូនទំនិញពាណិជ្ជកម្ម៖ ឥណ្ឌាបានចាប់ផ្តើមមានតម្លៃសម្រាប់អង់គ្លេសកាន់តែខ្លាំងបន្ទាប់ពីពួកគេបានបង្កើតបណ្តាញផ្លូវរថភ្លើងនៅទីនោះ។ ផ្លូវរថភ្លើងត្រូវបានប្រើសម្រាប់ការដឹកជញ្ជូនវត្ថុធាតុដើមពីដែនដីខាងក្នុងមានកាន់កំពង់ផែសមុទ្ទ និងការដឹកជញ្ជូនទំនិញរោងចក្រត្រឡប់មកវិញ។ ភាគច្រើននៃវត្ថុធាតុដើមគឺជាផលិតផលកសិកម្មដែលបានមកពីការដាំដុះ។ ដំណាំដែលគេដាំពេលនោះរួមមានតែ, ម្សៅពណ៌, កាហ្វេ, កប្បាស, និងដើមក្រចៅ។ ដំណាំដែលសំខាន់មួយទៀតគឺអាភៀន។ ពួកអង់គ្លេសបានដឹកជញ្ជូនអាភៀនតាមនាវាទៅកាន់ប្រទេសចិនដើម្បីផ្តោះប្តូរជាមួយតែ ដែលពួកគេត្រូវយកទៅលើនៅអង់គ្លេស។ ការធ្វើពាណិជ្ជកម្មលើផលិតផលកសិកម្មទាំងនេះគឺមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយព្រឹត្តិការណ៍អន្តរជាតិ។ ឧទាហរណ៍ សង្គ្រាមគ្រីមេនៅក្នុង

ទសវត្សរ៍ឆ្នាំ 1850 បានកាត់ផ្ដាច់ការផ្គត់ផ្គង់ដើមក្រចៅរបស់ប្រទេសរុស្ស៊ីទៅកាន់រោងម៉ាស៊ីនក្រចៅរបស់ស្កុតឡែន។ ការនេះបានបង្កើនការនាំចេញដើមក្រចៅផៅពីតំបន់បេងហ្គាល ដែលជាខេត្តមួយរបស់ឥណ្ឌា។ ក៏ដូចគ្នាដែរ ផលិតផលកប្បាសនៅឥណ្ឌា បានកើនឡើងនៅពេលដែលសង្គ្រាមស៊ីវិលនៅសហរដ្ឋអាមេរិកបានកាត់ផ្ដាច់ការផ្គត់ផ្គង់កប្បាយទៅកាន់រោងម៉ាស៊ីនតម្បាញរបស់អង់គ្លេស។

ឥទ្ធិពលនៃអាណានិគមនិយម៖ ឥណ្ឌាទទួលបានទាំងផលប្រយោជន៍ និងរងគ្រោះដោយសារតែការដាក់អាណានិគមរបស់អង់គ្លេស។ នៅក្នុងផ្នែកអវិជ្ជមាន អង់គ្លេសបានក្ដោបក្ដាប់អំណាចនយោបាយ និងសេដ្ឋកិច្ចស្ទើរតែទាំងស្រុង។ ពួកអង់គ្លេសបានដាក់កំហិតលើឧស្សាហកម្មរបស់ឥណ្ឌា ដែលមានដូចជាឧស្សាហកម្មតម្បាញកប្បាសជាដើម។ ការពឹងផ្អែកលើដំណាំកសិឧស្សាហកម្ម បណ្ដាលឱ្យបាត់បង់ស្វ័យភាពរបស់អ្នកស្រុកជាច្រើន។ ការផ្លាស់ប្ដូរទៅដាំដំណាំបែបកសិឧស្សាហកម្មបានកាត់បន្ថយផលិត ផលចំណីអាហារ ដែលបណ្ដាលឱ្យមានគ្រោះអត់ឃ្លាននៅចុងសតវត្សរ៍ទី 19 ។ អង់គ្លេសជាផ្លូវការបានអនុវត្តគោលនយោបាយបើកទូលាយចំពោះសាសនា និងប្រពៃណីសង្គមរបស់ឥណ្ឌា។ បើទោះបីជាដូច្នេះក៏ដោយ ការកើនឡើងនៃវត្តមានរបស់បេសកទូតសាសនា និងឥរិយាបថប្រកាន់ពូជសាសនរបស់មន្ត្រីអង់គ្លេស បានគំរាមកំហែងដល់ជីវិតរស់នៅបែបប្រពៃណីរបស់ប្រជាជនឥណ្ឌា។

នៅខាងផ្នែកវិជ្ជមាន ការធ្វើឱ្យប្រទេសឥណ្ឌាក្លាយជាប្រទេសមានបណ្ដាញផ្លូវរថភ្លើងធំជាងគេលំដាប់ទី 3 គឺជាស្នាដៃដ៏សំខាន់មួយរបស់អង់គ្លេស។ នៅពេលដែលវាធ្វើរួចរាល់ ផ្លូវរថភ្លើងបានអនុញ្ញាតឱ្យឥណ្ឌាអាចអភិវឌ្ឍសេដ្ឋកិច្ចទំនើបមួយ និងបាននាំមកនូវការបង្រួបបង្រួមតំបន់ទាំងឡាយនៅឥណ្ឌា។ ជា មួយនឹងផ្លូវរថភ្លើង, បណ្ដាញផ្លូវថ្នល់សម័យទំនើប, បណ្ដាញទូរស័ព្ទ និងទូរសារ, ទំនប់, ស្ពាន, និងប្រព័ន្ធធារាសាស្ត្របានអនុញ្ញាតឱ្យឥណ្ឌាអាចធ្វើទំនើបកម្ម។ អនាម័យ និងសុខភាពសាធារណត្រូវបានបង្កើន។ សាលារៀន និងមហាវិទ្យាល័យត្រូវបានបង្កើតឡើង ហើយអត្រាអ្នកចេះអក្សរបានកើនឡើង។ ជាមួយនេះផងដែរ កងទ័ពរបស់ពួកអង់គ្លេសបានបោសសម្អាតក្រុមចោរប្លន់នៅឥណ្ឌាភាគកណ្ដាល និងបានបញ្ចប់សង្គមក្នុងតំបន់រវាងមេដឹកនាំនានា។

## 2. កងទ័ពរបស់ឥណ្ឌាធ្វើការបះបោរ

ត្រឹមឆ្នាំ 1850 អង់គ្លេសគ្រប់គ្រងដែនដីឧបទ្វីបឥណ្ឌាស្ទើរតែទាំងស្រុង។ ប៉ុន្តែ មានការមិនសប្បាយចិត្តកើនមានឡើងចំពោះប្រជាជនឥណ្ឌា។ ប្រជាជនឥណ្ឌាជាច្រើនជឿថា ក្នុងការបន្ថែមទៅនឹងការគ្រប់គ្រងទឹកដីរបស់ពួកគេ ពួកអង់គ្លេសព្យាយាមនៅក្នុងការកែប្រែពួកឱ្យជឿលើសាសនាគ្រីស្ត។ ប្រជាជនឥណ្ឌាក៏មានការមិនសប្បាយចិត្តចំពោះការប្រកាន់ពូជសាសន៍ ដែលពួកអង់គ្លេសបានសំដែងដាក់ពួកគេ។

ការបះបោររបស់ឥណ្ឌា៖ ដូចដែលបញ្ហាសេដ្ឋកិច្ចបានកើនឡើងសម្រាប់ប្រជាជនឥណ្ឌា នាំឱ្យពួកគេមានអារម្មណ៍មិនសប្បាយចិត្ត និងមានគំនិតជាតិនិយម។ នៅក្នុងឆ្នាំ 1857 ពាក្យខ្សឹបខ្សៀវបានសាយភាយក្នុងចំណោមកងទ័ពឥណ្ឌាដែលថា គ្រាប់របស់កាំភ្លើងថ្មីម៉ាក អេនហ្វៀល របស់ពួកគេ ត្រូវបានលាបខ្លាញ់គោ និងខ្លាញ់ជ្រូក។ ដើម្បីប្រើប្រាស់គ្រាប់កាំភ្លើងទាំងនេះ កងទ័ពត្រូវតែខាំចុងរបស់វា។ តាមរយៈព័ត៌មាននេះ ទាំងពួក

ហិណ្ឌូ ដែលចាត់ទុកសត្វគោថាជាសត្វពិសិដ្ឋ និងពួកម៉ូស្លីមដែលមិនបរិភោគសាច់ជ្រូក មានការខឹងសប្បាយយ៉ាងខ្លាំង។ មេបញ្ជាការយោធភូមិភាគមួយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលកងទ័ពឥណ្ឌា 85 នាក់ក្នុងចំណោម 90 នាក់បដិសេធនៅក្នុងការប្រើប្រាស់គ្រាប់កាំភ្លើង។ អង់គ្លេសដោះស្រាយបញ្ហានេះដោយអំពើឃោឃៅ។ កងទ័ពដែលមិនស្ដាប់បញ្ជាត្រូវបានចាប់ដាក់គុក។ មួយថ្ងៃក្រោយមក គឺនៅថ្ងៃទី 10 ខែឧសភា ឆ្នាំ 1857 ពួកកងទ័ពឥណ្ឌាបានបះបោរ។ ពួកគេបានធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងដេលី គឺជាទីកន្លែងដែលពួកបានចូលរួមជាមួយកងទ័ពឥណ្ឌាផ្សេងទៀតដែលមានមូលដ្ឋាននៅទីនោះ។ ពួកគេដណ្ដើមកាន់កាប់ទីក្រុងដេលី។ ចេញពីដេលី ការបះបោរបានរីកសាយភាយទៅកាន់ឥណ្ឌាភាគខាងជើង និងឥណ្ឌាភាគកណ្ដាល។ ប្រវត្តិវិទូមួយចំនួនបានហៅការងើបឡើងនេះថា ការបះបោររបស់កងទ័ពឥណ្ឌា។ ការបះបោរបានរីករាលដាលនៅឥណ្ឌាភាគខាងជើង។ ការវាយប្រយុទ្ធគ្នាដ៏សាហាវមួយបានកើតឡើង។ ទាំងអង់គ្លេស និងកងទ័ពឥណ្ឌា ព្យាយាមនៅក្នុងការសម្លាប់គ្នាទៅវិញទៅមក។ ក្រុមហ៊ុនឥណ្ឌាខាងកើតចំណាយពេលជាងមួយឆ្នាំដើម្បីទទួលបានការគ្រប់គ្រងឥណ្ឌាឡើងវិញ។ រដ្ឋាភិបាលអង់គ្លេសបានបញ្ជូនកងទ័ពទៅជួយពួកគេ។ ពួកឥណ្ឌាមិនអាចបង្រួបបង្រួមគ្នាប្រឆាំងជាមួយអង់គ្លេសបានឡើយ ដោយសារតែភាពកំសោយនៃការដឹកនាំ និងការបែកចេញពីគ្នានូវអ្នកកាន់សាសនាហិណ្ឌូ និងអ្នកកាន់សាសនាអ៊ីស្លាម។ ពួកហិណ្ឌូមិនចង់ឱ្យចក្រភពម៉ូហ្គាលរបស់អ៊ីស្លាមស្ដារឡើងវិញឡើយ។ ជាងនេះទៅទៀត ពួកហិណ្ឌូសុខចិត្តឱ្យពួកអង់គ្លេសគ្រប់គ្រងជាជាងឱ្យពួកម៉ូស្លីមគ្រប់គ្រង។ ភាគច្រើននៃព្រះអង្គម្ចាស់ និងមហារាជា ដែលចងសម្ព័ន្ធមិត្តជាមួយក្រុមហ៊ុនឥណ្ឌាខាងកើតមិនបានចូលរួមនៅក្នុងការបះបោរនេះឡើយ។ ពួកស៊ីខ ដែលជាក្រុមសាសនាមួយដែលជាសត្រូវរបស់ម៉ូហ្គាល ក៏នៅតែបន្តមានភក្ដីភាពជាមួយអង់គ្លេស។ តាមពិតទៅពុកចង្កា និងឈ្នួតរបស់ពួកស៊ីខបានក្លាយជាអត្តសញ្ញាណមួយនៃកងទ័ពរបស់អង់គ្លេសនៅក្នុងប្រទេសឥណ្ឌា។

ការផ្លាស់ប្ដូរៈ ការបះបោររបស់កងទ័ពឥណ្ឌានាំឱ្យមានការផ្លាស់ប្ដូរដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រឥណ្ឌា។ ជាលទ្ធផលនៃការបះបោរ នៅក្នុងឆ្នាំ 1858 រដ្ឋាភិបាលអង់គ្លេសបានគ្រប់គ្រងដោយផ្ទាល់លើប្រទេសឥណ្ឌា។ ពាក្យថារាជ សំដៅលើការគ្រប់គ្រងរបស់អង់គ្លេស បន្ទាប់ពីឥណ្ឌាធ្លាក់ក្រោមការគ្រប់គ្រងរបស់អង់គ្លេសអំឡុងរាជ្យរបស់ម្ចាស់ក្សត្រីវិចតូរីយ៉ា ។ គណៈរដ្ឋមន្ត្រីមួយនៅក្នុងទីក្រុងឡុងដ៍ជាអ្នកចាត់ចែងគោលនយោបាយ ហើយឧត្តសេនីយ៍អង់គ្លេសដែលគ្រប់គ្រងនៅឥណ្ឌាត្រូវស្ដាប់បទបញ្ជារបស់រដ្ឋាភិបាលអង់គ្លេស។ បន្ទាប់ពីឆ្នាំ 1877 ឧត្តមសេនីយ៍អង់គ្លេសដែលគ្រប់គ្រងនៅឥណ្ឌានេះទទួលតួនាទីជាស្ដេចត្រាញ់។

ចំពោះព្រះអង្គម្ចាស់នានាដែលបន្តមានភក្ដីភាពចំពោះអង់គ្លេស ពួកអង់គ្លេសសន្យានៅក្នុងការគោរពលើរាល់សន្ធិសញ្ញាដែលក្រុមហ៊ុនឥណ្ឌាខាងកើតបានចុះជាមួយពួកគេ។ ពួកគេក៏បានសន្យាផងដែរថា រដ្ឋនានារបស់ឥណ្ឌាដែលនៅទំនេរ នឹងនៅតែបន្តមានឯករាជ្យភាពដដែល។ ប៉ុន្តែ ជាលក្ខណៈមិនផ្លូវការ អង់គ្លេសទទួលបានការគ្រប់គ្រងលើរដ្ឋនានានៅឥណ្ឌាកាន់តែច្រើនឡើងៗ។ ការបះបោររបស់កងទ័ពឥណ្ឌាបានបញ្ជេះឥរិយាបថប្រកាន់ពូជសាសន៍របស់អង់គ្លេស។

### 3. ជាតិនិយមលេចឡើងនៅឥណ្ឌា

នៅដើមសតវត្សរ៍ទី 19 ពួកឥណ្ឌាមួយចំនួនចាប់ផ្ដើមធ្វើការទាមទារឱ្យមានការធ្វើទំនើបកម្ម និងបង្កើនតួនាទីរបស់ពួកគេនៅក្នុងការដឹកនាំប្រទេសដោយខ្លួនឯង។ ទស្សនៈវិទូសម័យទំនើបមួយរូបឈ្មោះរ៉ាម ម៉ូហ៊ុន រ៉ូយ ដែលទទួលបានការបណ្តុះបណ្តាលខ្ពង់ខ្ពស់នៅក្នុងប្រទេសឥណ្ឌា ចាប់ផ្ដើមយុទ្ធនាការមួយដើម្បីផ្លាស់ប្តូរប្រទេសឥណ្ឌាឱ្យចេញឆ្ងាយពីគំនិង និងការប្រតិបត្តិបែបប្រពៃណី។ លោក រ៉ាម ម៉ូហ៊ុន រ៉ូយ យល់ឃើញថាការរៀបចំចាត់ចែងអាពាហ៍ពិពាហ៍របស់កូនចៅ និងការបែងចែកវណ្ណៈតឹងរឹងដែលជាផ្នែកមួយនៅក្នុងសង្គមរស់នៅរបស់ប្រទេសឥណ្ឌាត្រូវការការផ្លាស់ប្តូរ។ លោកជឿជាក់ថា ប្រសិនបើការប្រតិបត្តិនេះមិនបានផ្លាស់ប្តូរទេ ឥណ្ឌានឹងនៅតែបន្តគ្រប់គ្រងដោយជនបរទេស។ ការសរសេររបស់លោក រ៉ូយ បានជម្រុញធ្វើឱ្យអ្នកកំណែទម្រង់ឥណ្ឌាផ្សេងទៀតស្នើឱ្យមានការប្រតិបត្តិតាមបែបបច្ចិមប្រទេស។ លោក រ៉ូយ បានបង្កើតឱ្យមានចលនាកំណែទម្រង់សង្គមមួយ ដែលនឹងផ្លាស់ប្តូរប្រទេសឥណ្ឌា។ ក្រៅពីការធ្វើទំនើបកម្ម និងបស្ចិមនីយកម្ម គំនិតជាតិនិយមក៏ចាប់ផ្ដើមផុសឡើងនៅក្នុងប្រទេសឥណ្ឌាផងដែរ។ ប្រជាជនឥណ្ឌាមិនសប្បាយចិត្តជាមួយនិងប្រព័ន្ធមួយ ដែលធ្វើឱ្យពួកគេក្លាយជាប្រជាពលរដ្ឋស្ថិតនៅក្នុងវណ្ណៈកម្រិតទី 2 នៅក្នុងប្រទេសរបស់ពួកគេផ្ទាល់។ ពួកគត្រូវបានហាមឃាត់មិនឱ្យមានតួនាទីកម្រិកកំពូលនៅក្នុងជួរមន្ត្រីស៊ីវិលក្នុងប្រទេសឥណ្ឌាឡើយ។ ក្រុមអ្នកដែលទទួលបានការងារក្នុងឋានៈកម្រិតកណ្ដាល តែងតែទទួលបានប្រាក់ខែតិចជាងពួកអឺរ៉ុប។ ឧទាហរណ៍ វិស្វករជនជាតិអង់គ្លេសមួយរូបដែលធ្វើការនៅក្នុងក្រុមហ៊ុនផ្លូវរថភ្លើងឥណ្ឌាខាងកើត ទទួលបានប្រាក់ខែ 20 ដងច្រើនជាងប្រាក់ខែរបស់វិស្វករឥណ្ឌា។

ក្រុមអ្នកជាតិនិយមត្រូវបានបង្កើតឡើង៖ ការកើនឡើងនៃគំនិតជាតិនិយមនេះ នាំទៅដល់ការបង្កើតឡើងនៃក្រុមអ្នកជាតិនិយម 2 ក្រុម ក្នុងនោះមាន ក្រុមសមាជជាតិឥណ្ឌាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1885 និងក្រុមសម្ព័ន្ធម៊ូស្លីម ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1906 ។ នៅដើមដំបូង ក្រុមមួយចំនួនបានផ្តោតសំខាន់លើការដោះស្រាយបញ្ហានានាដែលប្រជាជនឥណ្ឌាជួបប្រទះ។ ប៉ុន្តែ ត្រឹមដើមសតវត្សរ៍ទី 19 ពួកគេបានស្នើឱ្យមានការគ្រប់គ្រងប្រទេសដោយខ្លួនឯង។ គំនិតជាតិនិយមត្រូវបានបញ្ឆេះឱ្យកាន់តែខ្លាំងឡើងនៅក្នុងឆ្នាំ 1905 តាមរយៈការបែងចែកតំបន់បេងហ្គាល។ ខេត្តនេះមានទំហំធំពេលដែលពិបាកនៅក្នុងការគ្រប់គ្រងផ្នែករដ្ឋបាល ដូច្នេះ អង់គ្លេសបានបែងចែកតំបន់នេះជា 2 ផ្នែក ដោយម្ខាងជាផ្នែករបស់ពួកហិណ្ឌូ និងម្ខាងទៀតជាផ្នែករបស់ពួកម៉ូស្លីម។ ការញែកក្រុមសាសនាទាំងពីរចេញពីគ្នា នាំឱ្យមានភាពលំបាកសម្រាប់ពួកគេក្នុងការបង្រួបបង្រួមគ្នាដើមទាមទារឯករាជ្យ។ នៅក្នុងឆ្នាំ 1911 អង់គ្លេសបានបញ្ចូលតំបន់ទាំង 2 នេះវិញ ប៉ុន្តែបានធ្វើការបែងចែកខេត្តនេះនៅក្នុងវិធីផ្សេងវិញ។

ជម្លោះដើម្បីគ្រប់គ្រងឧបទ្វីបឥណ្ឌាបានអភិវឌ្ឍឡើងរវាងឥណ្ឌា និងអង់គ្លេសនៅប៉ុន្មានឆ្នាំបន្ទាប់។ នៅកន្លែងផ្សេងទៀតនៅតំបន់អាស៊ីអាគ្នេយ៍ ការប្រយុទ្ធគ្នាដើម្បីគ្រប់គ្រងដែនដីដូចគ្នានេះបានកើតឡើងរវាងក្រុមប្រជាជនក្នុងតំបន់ជាមួយនឹងមហាអំណាចអឺរ៉ុប។ អ្នកនឹងបានរៀនពីព្រឹត្តិការណ៍នេះនៅក្នុងមេរៀនទី 5 ។

# មេរៀនទី 5៖ ចក្រពត្តិនិយមនៅតំបន់អាស៊ីអាគ្នេយ៍

## 1. មហាអំណាចអឺរ៉ុបឈ្លានពានតំបន់ជាយប៉ាស៊ីហ្វិក

នៅដើមសតវត្សរ៍ទី 18 ក្រុមហ៊ុនហូឡង់ឥណ្ឌាខាងកើតបានបង្កើតការត្រួតត្រាស្ទើរតែទាំងស្រុងលើតំបន់ប្រជុំកោះនៃឥណ្ឌូនេស៊ីដែលមានប្រវែងប្រមាណ 3,000 ម៉ាយ។ អង់គ្លេសបានស្ថាបនាកំពង់ផែពាណិជ្ជកម្មសំខាន់មួយនៅសិង្ហបុរី។ បារាំងដណ្ដើមកាន់កាប់ឥណ្ឌូចិនដែលស្ថិតនៅអាស៊ីអាគ្នេយ៍ដីគោក។ អាឡឺម៉ង់បានកាន់កាប់ដែនកោះម៉ាសាល និងផ្នែកខ្លះនៃញូវហ្គីណេ និងដែនកោះសូឡូម៉ុន ។ ផ្ទៃដីនៅតំបន់អាស៊ីអាគ្នេយ៍មានលក្ខណៈល្អប្រសើរសម្រាប់ការដាំដុះដំណាំ។ ដំណាំគេផ្ដោតសំខាន់ជាគេគឺ ដំណាំស្ករអំពៅ, កាហ្វេ, កាកាវ, កៅស៊ូ, ដូង, ចេក, និងម្នាស់។ ដូចដែលផលិតផលទាំងនេះចាប់ផ្ដើមមានសារៈសំខាន់សម្រាប់ទីផ្សារពាណិជ្ជកម្មអន្តរជាតិ ពួកអឺរ៉ុបចាប់ផ្ដើមប្រកួតប្រជែងគ្នាដើម្បីកាន់កាប់ដីទាំងនេះ។

ហូឡង់ពង្រីកការត្រួតត្រា៖ ក្រុមហ៊ុនហូឡង់ឥណ្ឌាខាងកើត ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1602 ដោយចាប់ផ្ដើមស្វែងរកការគ្រប់គ្រងដែនដីនានានៅតំបន់អាស៊ីអាគ្នេយ៍។ ពួកគេបានដណ្ដើមកាន់កាប់ម៉ាឡាកាពីពួកព័រទុយហ្គាល់ និងធ្វើវាយប្រយុទ្ធជាមួយអង់គ្លេស និងពួកជនជាតិជ្វា ដើម្បីត្រួតត្រាកោះជ្វា។ ការរកឃើញប្រេងកាត និងទង់ដែងនៅលើកោះនេះ និងមានគោលបំណងក្នុងការដាំដុះដំណាំកៅស៊ូផងនោះ ជម្រុញឱ្យពួកហូឡង់ធ្វើការពង្រីកការគ្រប់គ្រងរបស់ពួកគេបន្តិចម្ដងៗទៅលើកោះស៊ូម៉ាត្រា, ផ្នែកខ្លះនៃកោះ ប៊ូនេអូ, សេឡេបេស, ម៉ូលូកាស, និងបាលី។ ចុងក្រោយហូឡង់បានគ្រប់គ្រងប្រជុំកោះឥណ្ឌូនេស៊ីទាំងមូល ដែលក្រោមមកគេហៅឈ្មោះថាហូឡង់ឥណ្ឌាខាងកើត។

ការគ្រប់គ្រងការដាំដុះ និងពាណិជ្ជកម្មបាននាំឱ្យមានវត្តមានរបស់ប្រជាជនហូឡង់នៅលើដែនកោះនេះ។ ផ្ទុយទៅនិងពួកអង់គ្លេស ដែលរស់នៅជាបណ្ដោះអាសន្ននៅក្នុងប្រទេសឥណ្ឌា ប៉ុន្តែនៅពេលដែលពួកគេចូលនិវត្តន៍ពួកគេត្រឡប់ទៅកាន់ប្រទេសអង់គ្លេសវិញ តែពួកហូឡង់យល់ថាឥណ្ឌូនេស៊ីគឺជាផ្ទះរបស់ពួកគេ។ ពួកគេធ្វើដំណើរមកកាន់ប្រទេសឥណ្ឌូនេស៊ី និងបានបង្កើតវណ្ណៈសង្គមតឹងរឹងមួយនៅទីនោះ។ ពួកហូឡង់ស្ថិតនៅក្នុងវណ្ណៈកំពូល, អ្នកមានទ្រព្យសម្បត្តិ និងអ្នកចេះដឹងឥណ្ឌូនេស៊ីស្ថិតនៅក្នុងវណ្ណៈបន្ទាប់, និងកម្មការដាំដំណាំស្ថិតនៅក្នុងវណ្ណៈក្រោមគេ។ ពួកហូឡង់ក៏បានបង្ខំឱ្យប្រជាកសិករប្រើប្រាស់ 1/5 នៃដីរបស់ពួកគេដើម្បីដាំដុះដំណាំកសិឧស្សាហកម្មសម្រាប់នាំចេញផងដែរ។

អង់គ្លេសដណ្ដើមកាន់កាប់ឧបទ្វីបម៉ាឡាយ៉ា៖ ដើម្បីប្រកួតប្រជែងជាមួយហូឡង់ អង់គ្លេសបានសំលឹងទៅរកការបង្កើតមូលដ្ឋានពាណិជ្ជកម្មមួយ ដែលនឹងដើរតួនាទីជាកន្លែងមួយសម្រាប់ចំណតនាវាដែលធ្វើដំណើរពីឥណ្ឌាទៅចិន។ ពួកគេបានបង្កើត និងតាំងទីលំនៅនៅកំពង់ផែដ៏ធំមួយនៅសិង្ហបុរី ដែលជាកោះមួយដាច់ចេញបន្តិចបន្តួចប៉ុណ្ណោះពីឧបទ្វីបម៉ាឡេ។ ការបើកឱ្យប្រើប្រាស់ព្រែកជីកស៊ុយអេ និងការកើនឡើងនូវតម្រូវការទង់ដែង និងកៅស៊ូ បានធ្វើឱ្យសិង្ហបុរីក្លាយជាកំពង់ផែដែលមមាញឹកជាងគេបំផុតលើពិភពលោក។ អង់គ្លេសក៏កាន់កាប់អាណានិគមនៅម៉ាឡេស៊ី និងភូមា(បច្ចុប្បន្នមីយ៉ាន់ម៉ា)ផងដែរ។ ម៉ាឡេស៊ីសម្បូរទៅដោយរ៉ែទង់ដែង

និងបានក្លាយជាប្រទេសដែលនាំចេញកៅស៊ូឈានមុខគេលើពិភពលោក។ ដោយសារតម្រូវការកម្មករដើម្បីជីករ៉ែទង់ដែង និងជៀជ័រកៅស៊ូ អង់គ្លេសបានលើកទឹកចិត្តឱ្យជនជាតិចិនធ្វើអន្តោប្រវេសន៍មកកាន់ម៉ាឡេស៊ី។ ជនជាតិចិនបានគ្របដណ្តប់នៅក្នុងតំបន់។ ជាលទ្ធផលនៃការធ្វើអន្តោប្រវេសន៍ ជនជាតិម៉ាឡេយ៉ាងឆាប់រហ័សបានក្លាយជាជនជាតិភាគតិចនៅក្នុងប្រទេសរបស់ពួកគេ។ ជម្លោះរវាងអ្នកតាំងទីលំនៅជនជាតិចិន និងជនជាតិដើមម៉ាឡេនៅតែមិនអាចដោះស្រាយបានរហូតមកដល់សព្វថ្ងៃ។

បារាំងគ្រប់គ្រងឥណ្ឌូចិន៖ បារាំងមានសកម្មភាពខ្លាំងក្លានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចាប់តាំងពីសតវត្សរ៍ទី 17 មកម្លេះ។ ពួកគេថែមទាំងបានជួយសន្តតិវង្សង្វៀនឱ្យឡើងកាន់អំណាចនៅក្នុងប្រទេសវៀតណាមទៀតផង។ នៅក្នុងទសវត្សរ៍ឆ្នាំ 1840 អំឡុងពេលនៃការគ្រប់គ្រងរបស់អធិរាជដែលមានគោលនយោបាយប្រឆាំងជាមួយគ្រីស្តសាសនា បេសកទូតបារាំង 7 រូបត្រូវបានសម្លាប់។ មេដឹកនាំព្រះវិហារគ្រីស្តសាសនា និងអ្នកមូលធននិយមដែលចង់បានចំណែកទីផ្សារជំមួយនៅក្រៅប្រទេស បានទាមទារឱ្យមានការអន្តរាគមន៍ផ្នែកយោធា។ អធិរាជណាប៉ូឡេអ៊ុងទី 3 បានបញ្ជាឱ្យកងទ័ពបារាំងធ្វើការឈ្លានពានវៀតណាមភាគខាងត្បូង។ ក្រោយមកបារាំងបានបញ្ចូលឡាវ, កម្ពុជា, និងវៀតណាមភាគខាងជើងទៅក្នុងដែនដីអាណានិគមរបស់ពួកគេ។ ការរួមបញ្ចូនគ្នានៃរដ្ឋទាំងអស់នោះជាយថាហេតុត្រូវបានគេហៅថា បារាំងឥណ្ឌូចិន។ ដោយប្រើប្រាស់ការគ្រប់គ្រងដោយផ្ទាល់ ជនជាតិបារាំងខ្លួនគេផ្ទាល់បានកាន់កាប់តំណែងសំខាន់ៗទាំងអស់នៅក្នុងជួររដ្ឋាភិបាលបែបការិយាធិបតេយ្យ។ ពួកគេមិនបានលើកទឹកចិត្តឱ្យមានការអភិវឌ្ឍឧស្សាកម្មនៅក្នុងតំបន់ឡើយ។ ផ្ទៃដី 4/5 ត្រូវបានគេប្រើប្រាស់សម្រាប់ដាំដុះដំណាំស្រូវ។ ប៉ុន្តែ ការប្រើប្រាស់ស្រូវអង្កររបស់ប្រជាកសិករបានថយចុះ ដោយសារតែស្រូវភាគច្រើនត្រូវបាននាំចេញ។ ដោយមិនសប្បាយចិត្តចំពោះការកាត់បន្ថយនេះ បានជម្រុញឱ្យប្រជាជនវៀតណាមធ្វើការបះបោរប្រឆាំងជាមួយបារាំង។

ផលប៉ះពាល់នៃអាណានិគម៖ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ការដាក់អាណានិគមបាននាំមកនូវលទ្ធផលជម្រុះ។ សេដ្ឋកិច្ចកើនឡើងដោយសារទិន្នផល ឬផលិតកសិឧស្សាហកម្ម ដែលអាចលក់បាននៅលើទីផ្សារអន្តរជាតិ។ ផ្លូវថ្នល់, កំពង់ផែ, ប្រព័ន្ធផ្លូវរថភ្លើងបានបង្កើនទំនាក់ទំនង និងការដឹកជញ្ជូន ប៉ុន្តែភាគច្រើនផ្តល់អត្ថប្រយោជន៍ដល់ពួកអ្នកជំនួញអឺរ៉ុបប៉ុណ្ណោះ។ ប៉ុន្តែ ប្រព័ន្ធអប់រំ, សុខភាព, និងអនាម័យត្រូវបានធ្វើឱ្យប្រសើរឡើង។ ខុសពីតំបន់អាណានិគមផ្សេងៗទៀត ប្រជាជនរាប់លាននាក់នៅក្នុងតំបន់អាស៊ី និងពិភពលោកបានធ្វើអន្តោប្រវេសន៍មកកាន់តំបន់អាស៊ីអាគ្នេយ៍ ដើម្បីធ្វើការក្នុងវិស័យកសិឧស្សាហកម្ម និងកម្មករជីករ៉ែ។ តំបន់នេះបានក្លាយជាតំបន់ដែលលាយបញ្ចូលគ្នានូវពួកហិណ្ឌូ, ពួកម៉ូស្លីម, ពួកគ្រីស្ត, និងពួកពុទ្ធសាសនិក។ លទ្ធផលនៃការផ្លាស់ប្តូរសាសនា ជាទូទៅនាំទៅរកការប្រកាន់ពូជសាសន៍ និងជម្លោះសាសនាដែលមានបន្តរហូតដល់សព្វថ្ងៃ។

## 2. សៀមបន្តរក្សាឯករាជ្យ

នៅខណៈពេលដែលប្រទេសជិតខាងទាំងអស់ បានធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ពួកចក្រពត្តិនិយម។ សៀម(បច្ចុប្បន្នថៃឡង់ដ៍) បន្តរក្សាឯករាជ្យរបស់គេពេញមួយសម័យការអាណានិគម។ សៀមស្ថិតនៅចម្លោះប្រទេសភូមាដែលគ្រប់គ្រងដោយអង់គ្លេស និងបារាំងឥណ្ឌូចិន។ បារាំង និងអង់គ្លេសមានគោលបំណងរៀងៗខ្លួន

ក្នុងការពារការគ្រប់គ្រងអាណានិគមរបស់ភាគីណាមួយលើប្រទេសសៀម។ ដោយដឹងរឿងនេះ ស្តេចសៀមបានកែប្រែសៀមឱ្យក្លាយជាតំបន់អព្យាក្រឹតមួយរវាងមហាអំណាចទាំង 2 នេះ។

សៀមធ្វើទំនើបកម្មខ្លួនគេផ្ទាល់ដោយស្ថិតនៅក្រោមការដឹកនាំរបស់ស្តេចមង្គុត និងរាជបុត្ររបស់ទ្រង់ ស្តេចជូឡាឡុងកន។ នៅក្នុងរាជប្រកាសមួយ ស្តេចជូឡាឡុងកនបានបង្ហាញពីការយល់ដឹងរបស់ទ្រង់ចំពោះសារៈសំខាន់នៃការធ្វើទំនើបកម្ម។ ដើម្បីសម្រេចឱ្យបាននូវការផ្លាស់ប្តូរនេះ សៀមចាប់ផ្តើមស្ថាបនាសាលារៀន, ធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់, និងរៀបចំរដ្ឋាភិបាលឡើងវិញ។ រដ្ឋាភិបាលបានស្ថាបនាប្រព័ន្ធផ្លូវរថភ្លើង និងទូរសារដោយខ្លួនគេផ្ទាល់ និងបញ្ចប់របបទាសភាព។ ដោយសារតែការផ្លាស់ប្តូរធ្វើឡើងដោយរដ្ឋាភិបាលរបស់ពួកគេផ្ទាល់ ប្រជាជនសៀមបានជៀសផុតពីភាពចលាចលនៅក្នុងសង្គម, ការប្រកាន់ពូជសាសន៍, និងការកេងប្រវ័ញ្ចសេដ្ឋកិច្ច ដែលតែងតែកើតមានឡើងនៅក្នុងបណ្តាលប្រទេសដែលគ្រប់គ្រងដោយជនបរទេស។

### 3. ចក្រពត្តិនិយមអាមេរិកនៅដែនកោះប៉ាស៊ីហ្វិក

ដោយសារតែអាមេរិកធ្លាប់បានវាយប្រយុទ្ធដើម្បីទាមទារឯករាជ្យពីអង់គ្លេស ដូច្នេះពួកគេភាគច្រើនមិនពេញចិត្តទៅនឹងគំនិតនៃការដាក់អាណានិគមលើប្រទេសដ៏ទៃឡើយ។ ប៉ុន្តែ ជនជាតិអាមេរិក 2 ក្រុម បានបង្ហាញពីការគាំទ្ររបស់ពួកគេចំពោះគោលនយោបាយចក្រពត្តិនិយម។ ក្រុមមួយដែលមានមហិច្ឆិតាចង់ស្ថាបនាចក្រភពអាមេរិក គិតថាសហរដ្ឋអាមេរិកគួរតែសម្រេចឱ្យបាននូវគោលដៅធ្វើជាមហាអំណាចពិភពលោក តាមរយៈការធ្វើអាណានិគមដូចពួកអឺរ៉ុបដែរ។ ក្រុមមួយទៀត ចាប់អារម្មណ៍ជាមួយនឹងផលប្រយោជន៍សេដ្ឋកិច្ច ចង់ឱ្យមានការបើកទីផ្សារ និងពាណិជ្ជកម្មថ្មី។

ហ្វីលីពីនផ្លាស់ប្តូរអ្នកគ្រប់គ្រង៖ សហរដ្ឋអាមេរិកទទួលបានដែនកោះហ្វីលីពីន, ផ័រតូ រីកូ, និងហ្គាំ បន្ទាប់ពីសង្គ្រាមអេស្ប៉ាញ-អាមេរិកនៅក្នុងឆ្នាំ 1898 ។ ការទទួលបានហ្វីលីពីននាំឱ្យមានការពិភាក្សាគ្នាមួយនៅសហរដ្ឋអាមេរិកអំពីគោលនយោបាយចក្រពត្តិនិយម។ ការបង្ហាញរបស់ប្រធានាធិបតី ម៉ាកគីនលី បានទាក់ទាញមនុស្សជាច្រើនមកឈរនៅខាងគាត់។ លោកបានប្រាប់ទៅកាន់ក្រុមមេបព្វជិតសាសនាមួយក្រុមអំពីគោលបំណងរបស់លោក គឺដើម្បី "អប់រំប្រជាជនហ្វីលីពីន, និងផ្សព្វផ្សាយសាសនាគ្រីស្តនៅទៅនោះ"។ អ្នកជាតិនិយមហ្វីលីពីនមានការមិនសប្បាយចិត្តនៅក្នុងដាក់អាណានិគមរបស់ពួកអេស្ប៉ាញម្តងរួចមកហើយ ឥឡូវដល់វេនអាមេរិកម្តង។ លោក អេមីលីអូ អាហ្គីណាលដូ មេដឹកនាំចលនាជាតិនិយមហ្វីលីពីន បានអះអាងថា សហរដ្ឋអាមេរិកបានសន្យាថានឹងផ្តល់ឯករាជ្យដល់ហ្វីលីពីនភ្លាមៗបន្ទាប់ពីសង្គ្រាមអេស្ប៉ាញ-អាមេរិកបញ្ចប់។ អ្នកជាតិនិយមបានប្រកាសឯករាជ្យ និងបានបង្កើតសាធារណរដ្ឋហ្វីលីពីន។ សហរដ្ឋអាមេរិកបានបើកការប្រយុទ្ធមួយជាមួយនិងពួកអ្នកជាតិនិយមហ្វីលីពីននៅក្នុងឆ្នាំ 1899 និងបានយកជ័យជំនះលើពួកគេនៅក្នុងឆ្នាំ 1902 ។ សហរដ្ឋអាមេរិកសន្យាចំពោះប្រជាជនហ្វីលីពីនថា ពួកគេនឹងរៀបចំឱ្យហ្វីលីពីនគ្រប់គ្រងប្រទេសដោយខ្លួនឯង។ ដើម្បីសម្រេចគោលដៅនេះ សហរដ្ឋអាមេរិកបានស្ថាបនាផ្លូវថ្នល់, ផ្លូវរថភ្លើង, និងមន្ទីរពេទ្យ, និងបានបង្កើតប្រព័ន្ធសិក្សាមួយ។ ប៉ុន្តែ ក៏ដូចជាតំបន់ផ្សេងៗទៀតនៅអាស៊ីអាគ្នេយ៍ ពួកអ្នកជំនួញបានលើកទឹកចិត្តឱ្យមានការដាំដុះដំណាំកសិឧស្សាហកម្ម ដែលមានដូចជា

ដំណាំស្ករអំពៅជាដើមនៅលើផ្ទៃដីដាំដុះដំណាំស្បៀងអាហារ។ កាលនេះនាំទៅដល់កង្វះខាតស្បៀងអាហារសម្រាប់ប្រជាជនហ្វីលីពីន។

ហាវៃក្លាយជាសាធារណរដ្ឋ៖ ចំណាប់អារម្មណ៍របស់សហរដ្ឋអាមេរិកលើហាវៃបានចាប់ផ្ដើមឡើងនៅវង្វង់ទសវត្សរ៍ឆ្នាំ 1790 នៅពេលដែលហាវៃគឺជាកំពង់ផែមួយតាមផ្លូវធ្វើដំណើរទៅកាន់ប្រទេសចិន និងឥណ្ឌាខាងកើត។ នៅដើមទសវត្សរ៍ឆ្នាំ 1820 ពាណិជ្ជកម្មស្ករសបានផ្លាស់ប្ដូរសេដ្ឋកិច្ចរបស់ហាវៃ។ អាមេរិកបានស្ថាបនាចំការដំណាំស្ករអំពៅ និងទទួលបានទិន្នផលល្អប្រសើរ។ ត្រឹមពាក់កណ្ដាលសតវត្សរ៍ទី 19 ចំការដំណាំស្ករអំពៅរបស់អាមេរិកស្មើរនឹង 75% នៃទ្រព្យសម្បត្តិរបស់ហាវៃ។ នៅក្នុងពេលជាមួយគ្នានោះ ជនជាតិអាមេរិកដែលជាម្ចាស់ចំការដំណាំស្ករអំពៅ ក៏ទទួលបានអំណាចនយោបាយដ៏សំខាន់មួយនៅហាវៃ។ បន្ទាប់មកនៅក្នុងឆ្នាំ 1890 ច្បាប់ពន្ធនាំចូលម៉ាកគីនលី ត្រូវបានអនុម័តដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកដែលបង្កើតឱ្យមានវិបត្តិនៅដែនកោះហាវៃ។ ច្បាប់នេះបានលុបចោលនូវរាល់ពន្ធនាំចូលស្ករសទាំងឡាយ ដែលនាំចូលសហរដ្ឋអាមេរិក។ ដូច្នេះ ស្ករសដែលនាំមកពីហាវៃលែងមានតម្លៃថោកជាងផលិតផលស្ករសផ្សេងៗទៀតឡើយ។ ការផ្លាស់ប្ដូរនេះបានកាត់បន្ថយប្រាក់ចំណេញរបស់អ្នកផលិតស្ករស។ អ្នកជំនួញរបស់សហរដ្ឋអាមេរិកមួយចំនួនបានជម្រុញឱ្យមានការភ្ជាប់ហាវៃ ឬបញ្ចូលហាវៃទៅជាដែនដីរបស់សហរដ្ឋអាមេរិក។ ធ្វើឱ្យហាវៃក្លាយជាផ្នែកមួយនៃសហរដ្ឋអាមេរិក មានន័យថាស្ករសរបស់ហាវៃ អាចចំណេញច្រើនដោយសារអ្នកផលិតស្ករសជនជាតិអាមេរិកទទួលបានលុយបន្ថែមចំនួន 2 សេនក្នុងមួយផោនពីរដ្ឋាភិបាលសហរដ្ឋអាមេរិក។ នៅក្នុងពេលជាមួយគ្នានោះ មេដឹកនាំហាវៃថ្មី ម្ចាស់ក្សត្រី លីលីអ៊ូកាឡានី បានឡើងគ្រងរាជ្យ។ នៅក្នុងឆ្នាំ 1893 ទ្រង់បានស្នើរឱ្យមានធម្មនុញ្ញថ្មីមួយដែលនឹងបង្កើនអំណាចដល់ទ្រង់។ វាក៏នឹងស្តារឡើងវិញនូវអំណាចនយោបាយរបស់ហាវៃដែលស្ថិតនៅក្នុងដៃរបស់ម្ចាស់ចំការដំណាំ។ ដើម្បីការពារកុំឱ្យរឿងនេះក៏មានឡើង អ្នកជំនួញអាមេរិកមួយក្រុមបានដឹកនាំការបះបោរមួយដើម្បីទម្លាក់ស្ដេចហាវៃចេញពីអំណាច។ នៅក្នុងឆ្នាំ 1893 ម្ចាស់ក្សត្រី លីលីអ៊ូកាឡានី ត្រូវបានគេដកចេញពីអំណាច។ នៅក្នុងឆ្នាំ 1984 ម្ចាស់ចំការ និងអ្នកនយោបាយមានទ្រព្យសម្បត្តិស្ដុកស្ដម្ភម្នាក់ឈ្មោះ សេនហ្វ៊ដ ប៊ី. ដូល ត្រូវបានគេតែងតាំងជាប្រធានាធិបតីនៃសាធារណរដ្ឋហាវៃ។ ប្រធានាធិបតីនៃសាធារណរដ្ឋថ្មីបានស្នើរសហរដ្ឋអាមេរិកភ្ជាប់ដែនដីរបស់ពួកគេទៅក្នុងសហរដ្ឋ។ ដំបូងឡើយប្រធានាធិបតី ក្លេវលែន បានបដិសេធ។ ប៉ុន្តែ នៅក្នុងឆ្នាំ 1898 សាធារណរដ្ឋហាវៃត្រូវបានភ្ជាប់ជាមួយសហរដ្ឋអាមេរិក។ យុគសម័យនៃចក្រពត្តិនិយមគឺជាពេលវេលាមួយដែលមហាអំណាចអឺរ៉ុបមានអំណាចខ្លាំងក្លា និងគ្រប់ដណ្ដប់លើប្រទេសដទៃ។ នៅចុងសតវត្សរ៍ទី 19 ដែនដីនានានៅលើពិភពលោកត្រូវបានកាន់កាប់ដោយមហាអំណាច។ មហាអំណាចអឺរ៉ុបបានប្រឈមមុខដាក់គ្នាទៅវិញទៅមកក្នុងការដណ្ដើមដែនដីអាណានិគម។ សមរភូមិរបស់ពួកគេបានចាប់ផ្ដើមឡើងកាន់តែខ្លាំងនៅសតវត្សរ៍ទី 20 ។

# ជំពូក 27 ៖ ការផ្លាស់ប្តូរជាសកល 1800-1914

## មេរៀនទី 1 ៖ ចិនតស៊ូប្រឆាំងជាមួយឥទ្ធិពលពីខាងក្រៅ

### 1. ចិន និងពួកបច្ចិមប្រទេស

ប្រទេសចិនអាចបដិសេធនៅក្នុងការទទួលយក នូវរាល់ឥទ្ធិពលទាំងឡាយរបស់ពួកលោកខាងលិច ដោយសារតែពួកគេអាចពឹងផ្អែកលើខ្លួនឯងបាន។ មូលដ្ឋានគ្រឹះដ៏សំខាន់មួយដែលអាចឱ្យពួកគេអាចពឹងផ្អែកលើខ្លួនឯងបានគឺ សេដ្ឋកិច្ចផ្នែកខាងកសិកម្មដ៏ប្រសើរមួយរបស់ពួកគេ។ នៅអំឡុងសតវត្សរ៍ទី 11 ចិនទទួលបានផលិតផលស្រូវយ៉ាងច្រើនពីតំបន់អាស៊ីអាគ្នេយ៍។ នៅអំឡុងសម័យរាជវង្សឈីង ទិន្នផលស្រូវបានកើនឡើងនៅពាសពេញតំបន់ភាគខាងត្បូងនៃប្រទេស។ នៅក្នុងពេលជាមួយគ្នានោះ នៅក្នុងសតវត្សរ៍ទី 17 និងទី 18 ពាណិជ្ជករអេស្ប៉ាញ និងព័រទុយហ្គាល់ បាននាំយកដំណាំពោត, ដំឡូងជ្វា, និងសណ្តែកដីពីទ្វីបអាមេរិកមកកាន់ប្រទេសចិន។ ដំណាំទាំងអស់នេះបានជួយឱ្យចិនបង្កើនទិន្នផល និងផ្គត់ផ្គង់ចំណីកាន់តែមានប្រសិទ្ធភាពដល់ប្រជាជនដ៏ច្រើនរបស់ពួកគេ។

ចិនក៏មានឧស្សាហកម្មរ៉ែ និងរោងចក្រកម្មន្តសាលជាច្រើនផងដែរ។ ភាពសម្បូរបែបនៃរ៉ែអំបិល, ទង់ដែង, ប្រាក់, និងដែក បានបង្កើតឲ្យមានរ៉ែក្នុងបរិមាណដ៏ច្រើនមួយ។ រ៉ែបានផ្តល់ការងារដល់ប្រជាជនរាប់ម៉ឺននាក់។ ពួកជនជាតិចិត្តក៏បានផលិតសូត្រដ៏ស្រស់ស្អាត, កប្បាសដែលមានគុណភាពខ្ពស់, និងគ្រឿងសេរ៉ាមិចដ៏ប្រណិត។

ទំនាក់ទំនងរវាងតែ និងអាភៀន៖ ដោយសារតែពួកគេអាចពឹងផ្អែកលើខ្លួនឯងបាន ពួកជនជាតិចិនមានចំណាប់អារម្មណ៍តិចតួចនៅក្នុងធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយពួកបស្ចិមប្រទេស។ អស់រយៈពេលជាច្រើនទសវត្សរ៍ មានតែកន្លែងមួយគត់ដែលពួកគេអនុញ្ញាតឱ្យមានការធ្វើជំនួញគឺតំបន់កំពង់ផែភាគខាងត្បូងហ្គ័ងចូវ។ ហើយតុល្យភាពនៃជញ្ជីងពាណិជ្ជកម្មនៅហ្គ័ងចូវ ច្បាស់ណាស់គឺបានទៅខាងប្រទេសចិន។ នេះមានន័យថាប្រទេសចិនអាចទទួលបានប្រាក់ចំណេញច្រើនពីការនាំចេញ ច្រើនជាងការចំណាយលើការនាំចូល។ ពាណិជ្ជករជនជាតិអឺរ៉ុបបានព្យាយាមនៅក្នុងការស្វែងរកផលិតផលមួយដែលចិននឹងទិញក្នុងបរិមាណច្រើន។ ដោយថាហេតុពួកគេបានរកឃើញទំនិញមួយគឺ អាភៀន។ អាភៀនគឺជាសារធាតុម្យ៉ាងធ្វើឱ្យអ្នកប្រើប្រាស់ញៀនវាបង្កើតឡើងពីដើមអាភៀន។ វេជ្ជបណ្ឌិតចិនធ្លាប់បានប្រើប្រាស់វាដើម្បីកាត់បន្ថយការឈឺចាប់អស់រយៈពេលរាប់រយឆ្នាំមកហើយ។ ប៉ុន្តែនៅចុងសតវត្សរ៍ទី 18 ពាណិជ្ជករអង់គ្លេសបានរត់ពន្ធអាភៀនចូលក្នុងប្រទេសចិន ដោយមិនមែនសម្រាប់ប្រើប្រាស់ក្នុងវិស័យវេជ្ជសាស្ត្រឡើយ។ វាត្រូវការចំណាយពេលជាច្រើនទសវត្សរ៍ដើម្បីទាក់ទាញឱ្យប្រជាជនចិនប្រើប្រាស់អាភៀន ប៉ុន្តែត្រឹមឆ្នាំ 1835 មានប្រជាជនចិនរហូតដល់ទៅ 12 លាននាក់ធ្លាក់ខ្លួនជាអ្នកញៀនថ្នាំ។

សង្គ្រាមបានផ្ទុះឡើង៖ ការកើនឡើងនៃការផ្គត់ផ្គង់អាភៀនបណ្តាលឱ្យមានបញ្ហាជាច្រើនកើតឡើងនៅក្នុងប្រទេសចិន។ អធិរាជរបស់ឈីង មានការខឹងសម្បាចំពោះស្ថានការណ៍នេះ។ នៅក្នុងឆ្នាំ 1839 ទីប្រឹក្សាជាន់ខ្ពស់មួយរូបបានសរសេរលិខិតអង្វរករមួយទៅកាន់ម្ចាស់ក្សត្រីអង់គ្លេស វិចតូរីយ៉ា អំពីបញ្ហានេះ។ ការអង្វរកររបស់

ចិននេះមិនមានការឆ្លើយតបឡើយ ហើយអង់គ្លេសបានបដិសេធនៅក្នុងការបញ្ឈប់ការធ្វើពាណិជ្ជកម្មអាភៀន។ លទ្ធផលចុងក្រោយគឺ នៅក្នុងឆ្នាំ 1839 មានការបះទង្គិចគ្នារវាងអង់គ្លេស និងចិន ដែលគេស្គាល់ថា សង្គ្រាមអាភៀន ។ សមរភូមិប្រយុទ្ធភាគច្រើនធ្វើឡើងនៅសមុទ្ទ។ នាវាហ្វួលសម័យរបស់ចិន មិនអាចប្រជែងគ្នាជាមួយនាវាចម្បាំងប្រើម៉ាស៊ីនចំហាយទឹករបស់អង់គ្លេសបានទេ។ ជាលទ្ធផល ពួកជនជាតិចិនចាញ់សង្គ្រាមនេះយ៉ាងអាម៉ាស់បំផុត។ នៅក្នុងឆ្នាំ 1842 ពួកគេបានចុះសន្ធិសញ្ញាសន្តិភាពមួយ គឺសន្ធិសញ្ញាណានជីង។ សន្ធិសញ្ញានេះបានផ្តល់ឱ្យអង់គ្លេសនូវកោះហុងកុង។ បន្ទាប់ពីចុះហត្ថលេខាលើសន្ធិសញ្ញាមួយផ្សេងទៀតនៅក្នុងឆ្នាំ 1844, សហរដ្ឋអាមេរិក និងជនបរទេសផ្សេងៗទៀតក៏ទទួលបានសិទ្ធិក្នុងការគ្រប់គ្រងដែនដីខាងក្រៅ។ ស្ថិតនៅក្រោមសិទ្ធិទាំងនេះ ជនបរទេសមិនស្ថិតនៅក្រោមច្បាប់របស់ចិននៅតំបន់ហ្គ័ងចូវ និងតំបន់កំពង់ផែ 4 ផ្សេងទៀត។ ប្រជាជនចិនជាច្រើនមានការមិនសប្បាយចិត្តជាខ្លាំងជាមួយជនបរទេស និងការកើនឡើងនៃពាណិជ្ជកម្មអាភៀនដែលពួកគេបានធ្វើ។

## 2. ការកើនឡើងនៃបញ្ហាផ្ទៃក្នុង

ជនបរទេសមិនមែនជាបញ្ហាដែលចំបងជាងគេនៅក្នុងប្រទេសចិនទេនាពាក់កណ្តាលសតវត្សរ៍ទី 19 ។ ប៉ុន្តែ ប្រជាជនចិនខ្លួនឯងទេដែលជាអ្នកបង្កឱ្យមានបញ្ហាដ៏ខ្លាំងក្លាមួយ។ ចំនួនប្រជាជនចិនបានកើនឡើងរហូតដល់ 430 លាននាក់នៅក្នុងឆ្នាំ 1850 មានការកើនឡើង 30% នៅក្នុងរយៈពេលតែ 60 ឆ្នាំប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ ផលិតផលចំណីអាហារបានកើនឡើងតិចតួចបំផុត។ ជាលទ្ធផល ភាពអត់ឃ្លានបានរីករាលដាលពេញប្រទេសចិន។ ប្រជាជនជាច្រើនបានបាក់ទឹកចិត្ត ហើយចំនួនអ្នកញៀនថ្នាំបានកើនឡើងយ៉ាងឆាប់រហ័ស។ ស្ថិតនៅក្នុងស្ថានការណ៍ដែលពោរពេញទៅដោយបញ្ហា ប្រជាជនចិនបានចាប់ផ្តើមងើបឡើងបះបោរប្រឆាំងជាមួយរាជវង្សឈីង។

ការបះបោរថៃភីង៖ នៅអំឡុងចុងទសវត្សរ៍ឆ្នាំ 1830 ហុងស៊ីឈ័ន ដែលជាបុរសវ័យក្មេងម្នាក់មកពីខេត្តហ្គ័ងទុងដែលស្ថិតនៅភាគខាងត្បូងប្រទេសចិន ចាប់ផ្តើមប្រមូលអ្នកដើរតាមដើម្បីជួយលោកនៅក្នុងការស្ថាបនា "ព្រះរាជាណាចក្រសន្តិភាពដ៏អស្ចារ្យ"។ នៅក្នុងព្រះរាជាណាចក្រនេះ រាល់ប្រជាជនចិនទាំងអស់នឹងបញ្ចូលទ្រព្យសម្បត្តិរបស់ពួកគេជាមួយគ្នា ហើយគ្មានណារម្នាក់អាចរស់នៅជាមួយនឹងទ្រព្យសម្បត្តិឯកជនបានឡើយ។ ចលនារបស់ព្រះអង្គម្ចាស់ហុង ត្រូវបានគេហៅថា ការបះបោរថៃភីង ដែលជាភាសាចិនមានន័យថា "សន្តិភាពដ៏អស្ចារ្យ"។ ត្រឹមទសវត្សរ៍ឆ្នាំ 1850 ព្រះអង្គម្ចាស់ហុង បានបានរៀបចំកងទ័ពប្រជាកសិករដ៏ច្រើនមួយដែលក្នុងនោះមានអ្នកចូលរួមប្រមាណជាមួយលាននាក់។ បន្តិចម្តងៗ កងទ័ពថៃភីងបានត្រួតត្រាលើតំបន់ដ៏ធំស្ថិតនៅចិនភាគអាគ្នេយ៍។ បន្ទាប់មក នៅក្នុងឆ្នាំ 1853 ព្រះអង្គម្ចាស់ហុង បានដណ្តើមកាន់កាប់ទីក្រុងណានជីង និងប្រកាសយកទីក្រុងនេះធ្វើជារាជធានីរបស់ព្រះរាជាណាចក្រទ្រង់។ ព្រះអង្គម្ចាស់ហុង ភ្លាមៗលាលែងពីតំណែង និងរស់នៅក្នុងជីវភាពសាមញ្ញ ដោយបានបន្សល់ទុកឱ្យសមាជិកគ្រួសារ និងមន្ត្រីជាន់ខ្ពស់ដែលលោកទុកចិត្តទទួលខុសត្រូវលើកិច្ចការរបស់រដ្ឋាភិបាលក្នុងព្រះរាជាណាចក្ររបស់ទ្រង់។ ប៉ុន្តែ មេដឹកនាំរបស់រដ្ឋាភិបាលថៃភីងបានធ្វើការវាយប្រយុទ្ធគ្នា

ទៅវិញទៅមក។ ជាមួយគ្នានោះផងដែរ កងទ័ពរបស់អធិរាជឈីង, កងទ័ពបារាំង, និងអង់គ្លេសទាំងអស់គ្នាបានបើកការវាយប្រហារប្រឆាំងជាមួយពួកថៃភីង។ ឆ្នាំ 1864 ការលាយបញ្ចូលគ្នានៃកងទ័ពក្នុងប្រទេសជាមួយកងទ័ពបរទេសបានផ្តួលរំលំរដ្ឋាភិបាលថៃភីង។ ប៉ុន្តែចិនបានបាត់បង់ប្រជាជនអស់ជាច្រើននៅក្នុងសង្គ្រាមនេះ។ យ៉ាងហោចណាស់មានប្រជាជនចិនប្រហែលជា 20 លាននាក់បានស្លាប់នៅអំឡុងនៃចលនាបះបោរនេះ។

### 3. ការកើនឡើងនៃឥទ្ធិពលបរទេស

ការបះបោរថៃភីង និងការបះបោរតូចៗជាច្រើនផ្សេងទៀតបង្កឱ្យមានសម្ពាធពីខាងក្នុងប្រទេសយ៉ាងខ្លាំងមួយលើរដ្ឋាភិបាលចិន។ ហើយ បើទោះបីជាមានសន្ធិសញ្ញាណានជីងក៏ដោយ សម្ពាធពីមហាអំណាចខាងក្រៅប្រទេសក៏បានកើនឡើងផងដែរ។ នៅក្នុងរាជវាំងឈីង មានការពិភាក្សាគ្នាដ៏ខ្លាំងក្លាមួយដើម្បីស្វែងរកដំណោះស្រាយដ៏សមស្របមួយចំពោះបញ្ហាទាំងអស់នេះ។ មេដឹកនាំរដ្ឋាភិបាលមួយចំនួនបានស្នើឱ្យមានការធ្វើកំណែទម្រង់តាមលំនាំពួកបច្ចិមប្រទេស។ ប៉ុន្តែ អ្នកមួយចំនួនទៀត ចង់ឱ្យមានការធ្វើកំណែទម្រង់តាមបែបប្រពៃណី និងទទួលយកការធ្វើកំណែទម្រង់នោះទាំងទើសទាល់បំផុត។

ការតស៊ូដើម្បីការផ្លាស់ប្តូរ៖ នៅអំឡុងចុងសតវត្សរ៍ទី 19 មានមនុស្សម្នាក់ដែលមានអំណាចខ្លាំងបំផុតនៅក្នុងរាជវាំងអធិរាជឈីង។ ម្ចាស់ក្សត្រីយានីសឺស៊ីបានក្តោបក្តាប់អំណាចនៅក្នុងប្រទេសចិនចាប់ពីឆ្នាំ 1862 រហូតដល់ឆ្នាំ 1908។ បើទោះបីជាទ្រង់គឺជាអ្នកឱ្យតម្លៃលើប្រពៃណីក៏ដោយ ម្ចាស់ក្សត្រីយានី បានគាំទ្រឱ្យមានការធ្វើកំណែទម្រង់មួយចំនួន។ ឧទាហរណ៍ នៅក្នុងទសវត្សរ៍ឆ្នាំ 1860 ទ្រង់បានគាំទ្រដល់ចលនាពង្រឹងខ្លួនឯង។ កម្មវិធីនេះមានគោលបំណងនៅក្នុងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធអប់រំ, កិច្ចការការបរទេស, និងវិស័យយោធានៅក្នុងប្រទេសចិន។ ស្ថិតនៅក្រោមកម្មវិធីនេះ ចិនបានបង្កើតរោងចក្រជាច្រើនដើម្បីផលិតនាវាចម្បាំងប្រើចំហាយទឹក, កាំភ្លើង, និងអាវុធយុទ្ធភ័ណ្ឌផ្សេងៗទៀត។ ប៉ុន្តែ ចលនាពង្រឹងខ្លួនឯងនេះទទួលបានទាំងលទ្ធផលល្អផង និងអាក្រក់ផង។

ប្រទេសផ្សេងទៀតចូលមកក្នុងប្រទេសចិន៖ ប្រទេសផ្សេងៗទៀតបានដឹងយ៉ាងច្បាស់អំពីបញ្ហាដែលកើតមាននៅក្នុងប្រទេសចិន។ នៅចុងសតវត្សរ៍ទី 19 ពួកបរទេសជាច្រើនបានចាប់យកឱកាសពីស្ថាបការណ៍ដែលកើតមាននៅក្នុងប្រទេសចិននេះ និងធ្វើការវាយប្រហារពួកគេ។ ការចរចារសន្ធិសញ្ញាបន្ទាប់ពីការវាយប្រហារនីមួយៗ បានផ្តល់ឱ្យពួកបរទេសទាំងនោះនូវការពង្រីកការត្រួតត្រាលើសេដ្ឋកិច្ចរបស់ចិន។ មហាអំណាចអឺរ៉ុបជាច្រើន រួមជាមួយជប៉ុនផងទទួលបាននូវមូលដ្ឋានគ្រឹះយ៉ាងរឹងមាំមួយនៅក្នុងប្រទេសចិន។ មូលដ្ឋាន ឬដែននៃឥទ្ធិពលនេះគឺជាតំបន់មួយដែលពួកបរទេសទាំងនោះត្រួតត្រាពាណិជ្ជកម្ម និងការវិនិយោគ។

សហរដ្ឋអាមេរិកគឺជាដៃគូរពាណិជ្ជកម្មដ៏យូរលង់មួយរបស់ចិន។ ពួកជនជាតិអាមេរិកមានការព្រួយបារម្ភថា ប្រទេសផ្សេងៗនឹងធ្វើការបែងចែកប្រទេសចិនទៅជាតំបន់អាណានិគមរបស់ពួកគេ និងបណ្តេញពាណិជ្ជករជនជាតិអាមេរិកចេញពីទីនោះ។ ដើម្បីការពារកុំឱ្យរឿងនេះកើតមានឡើង នៅក្នុងឆ្នាំ 1899 សហរដ្ឋអាមេរិកបានប្រកាសគោលនយោបាយបើកចំហរទ្វា។ គោលនយោបាយនេះបានស្នើថា ទ្វារបស់ចិនត្រូវបើកសម្រាប់ពាណិជ្ជករគ្រប់ប្រទេសទាំងអស់។ អង់គ្លេស និងប្រទេសអឺរ៉ុបផ្សេងៗទៀតបានយល់ព្រមចំពោះការស្នើរនេះ។ គោល

នយោបាយនេះបានការពារទាំងសិទ្ធិនៅក្នុងការធ្វើពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសចិន និងឯករាជ្យរបស់ចិនពីការគ្រប់គ្រងអាណានិគម។ ប៉ុន្តែ ប្រទេសនេះនៅតែផ្តល់សម្បទានដល់មហាអំណាចបរទេស។

## 4. ការកញ្ជៀលឡើងនៃគំនិតជាតិនិយមរបស់ប្រជាជនចិន

ដោយអាម៉ាស់មុខចំពោះការបាត់បង់អំណាចរបស់ពួកគេ ប្រជាជនចិនជាច្រើនបានរុញច្រានឱ្យមានការធ្វើកំណែទម្រង់ដ៏ខ្លាំងក្លាមួយ។ នៅក្នុងចំណោមអ្នកដែលទាមទារឱ្យមានការធ្វើកំណែទម្រង់នេះគឺ អធិរាជវ័យក្មេងមួយអង្គរបស់ប្រទេសចិន ព្រះនាមហ្គ័ងស៊ូ។ នៅក្នុងខែមិថុនា ឆ្នាំ 1898 ព្រះអង្គម្ចាស់ហ្គ័យស៊ូ មានបង្កើតនូវវិធានការមួយចំនួនដើម្បីធ្វើទំនើបកម្មប្រទេសចិន។ វិធានការទាំងនេះបានស្នើឱ្យមានការរៀបចំឡើងវិញនូវប្រព័ន្ធអប់រំ, ពង្រឹងសេដ្ឋកិច្ច, ធ្វើទំនើបកម្មវិស័យយោធា, និងរៀបចំរដ្ឋាភិបាលក្នុងប្រទេសចិនឡើងវិញ។ មន្ត្រីឈីងភាគច្រើនបានយល់ឃើញការបង្កើតថ្មីនេះគឺជាការគំរាមកំហែងដល់អំណាចរបស់ពួកគេ។ ពួកគេបានប្រតិកម្មជាមួយនឹងការប្រកាសអាសន្នមួយ ដោយបានស្នើឱ្យម្ចាស់ក្សត្រីយានីធ្វើការគ្រប់គ្រងក្នុងរាជវាំងអធិរាជ។ នៅពេលដែលទ្រង់ត្រឡប់មកកាន់អំណាចវិញ ទ្រង់បានឆ្លើយតបយ៉ាងលឿនចំពោះការស្នើសុំរបស់មន្ត្រីឈីង។ ទ្រង់បានចាប់ស្តេចហ្គ័ងស៊ូឃុំខ្លួន និងធ្វើការត្រួតត្រារដ្ឋាភិបាលជំនួសស្តេចហ្គ័ងស៊ូ។ បន្ទាប់មកទ្រង់បានលុបចោលនូវរាល់ការធ្វើកំណែទម្រង់ទាំងឡាយរបស់ស្តេចហ្គង់ស៊ូ។ ការប្រឹងប្រែងរបស់ស្តេចហ្គ័ងស៊ូមិនបាននាំឱ្យមានការផ្លាស់ប្តូរអ្វីទាំងអស់។ ការមិនសប្បាយរបស់ប្រជាជនចិនជាមួយនឹងស្ថានការណ៍ដែលកើតមានឡើងនៅក្នុងប្រទេសចិនបានបន្តកើនឡើងកាន់តែខ្លាំង។

ការបះបោរអ្នកប្រដាល់៖ ការរីករាលដាលនូវភាពមិនសប្បាយចិត្តនេះចុងក្រោយបានបង្កទៅជាអំពើហិង្សា។ ប្រជាកសិករក្រីក្រ និងកម្មករមានការមិនសប្បាយចិត្តចំពោះការទទួលបានឯកសិទ្ធិពិសេសរបស់ជនបរទេសនៅក្នុងប្រទេសចិន។ ពួកគេក៏មានការមិនសប្បាយចិត្តចំពោះពួកគ្រីស្តសាសនិកចិន អ្នកដែលជឿតាមជំនឿរបស់បរទេស។ ដើម្បីបង្ហាញពីភាពទោមនស្សរបស់ពួកគេ ពួកគេបានបង្កើតអង្គការលួចលាក់មួយដែលគេហៅថា ក្រុមកណ្តាប់ដៃត្រឹមត្រូវ និងសាកសម។ ពួកគេក្រោយមកត្រូវបានគេស្គាល់ថា ក្រុមអ្នកប្រដាល់។ ពួកគេធ្វើយុទ្ធនាការប្រឆាំងជាមួយនឹងការដឹកនាំរបស់ម្ចាស់ក្សត្រីយានី និងឯកសិទ្ធិរបស់ជនបរទេស ដែលត្រូវបានគេហៅថា ការបះបោររបស់អ្នកប្រដាល់។

នៅក្នុងរដូវរំហើយឆ្នាំ 1900 ពួកអ្នកប្រដាល់បានផ្ទុះឡើងនៅក្នុងទីក្រុងប៉េកាំង។ ដោយបានស្រែកថា "សម្លាប់ពួកបិសាចបរទេស" ពួកអ្នកប្រដាល់បានឡោមព័ទ្ធតំបន់ដែលមានពួកអឺរ៉ុបនៅក្នុងទីក្រុងប៉េកាំង។ ពួកគេរក្សាការឡោមព័ទ្ធនេះអស់ជាច្រើនខែ។ ម្ចាស់ក្សត្រីយានីបានបង្ហាញពីការគាំទ្រដល់ក្រុមអ្នកប្រដាល់ ប៉ុន្តែមិនបានផ្តល់ជំនួយផ្នែកយោធាដល់ចលនានេះឡើយ។ នៅក្នុងខែសីហា កងកម្លាំងចម្រុះជាតិសាសន៍មួយដែលមានចំនួន 19,000 នាក់បានធ្វើដំណើរមកកាន់ទីក្រុងប៉េកាំង ហើយភ្លាមៗនោះបានទទួលជ័យជំនះលើពួកអ្នកប្រដាល់។ បើទោះបីជាការបះបោររបស់អ្នកប្រដាល់បរាជ័យក៏ដោយ ក៏គំនិតជាតិនិយមដ៏ខ្លាំងក្លាមួយបានលេចឡើងនៅក្នុងប្រទេសចិន។ ប្រជាជនចិនបានដឹងច្បាស់ថា ប្រទេសរបស់ពួកគេត្រូវតែប្រឆាំងជាមួយការជ្រៀតជ្រែកកាន់តែ

ច្រើនឡើងរបស់ពួកបរទេស។ កាន់តែសំខាន់ជាងនេះទៅទៀត ពួកគេយល់ថារដ្ឋាភិបាលគួរតែក្លាយជារដ្ឋាភិបាលដែលតំណាងឱ្យតម្រូវការរបស់ពួកគេ។

ការចាប់ផ្តើមការធ្វើកំណែទម្រង់៖ នៅត្រង់ចំណុចនេះ សូម្បីតែរាជវាំងឈីងក៏បានដឹងច្បាស់ដែលថាប្រទេសចិនត្រូវតែធ្វើការផ្លាស់ប្តូរស៊ីជម្រៅមួយដើម្បីរស់រានបាន។ នៅក្នុងឆ្នាំ 1905 ម្ចាស់ក្សត្រីយានីបានបញ្ជូនមន្ត្រីចិនមួយក្រុម ធ្វើដំណើរទស្សនកិច្ចសិក្សាអំពីប្រតិបត្តិការនៃរដ្ឋាភិបាលនានានៅលើពិភពលោក។ ពួកក្រុមមន្ត្រីទាំងនោះបានធ្វើដំណើរទៅកាន់ប្រទេសជប៉ុន, សហរដ្ឋអាមេរិក, អង់គ្លេស, បារាំង, អាឡឺម៉ង់, រុស្ស៊ី, និងអ៊ីតាលី។ នៅពេលដែលពួកគេត្រឡប់មកវិញនៅក្នុងឆ្នាំ 1906 ពួកមន្ត្រីបានផ្តល់យោបល់ចំពោះការរៀបចំរចនាសម្ព័ន្ធរដ្ឋាភិបាលចិនថ្មី។ ពួកគេបានស្នើឱ្យមានការរៀបចំប្រព័ន្ធរដ្ឋាភិបាលបែបរាជាធិបតេយ្យអាស្រ័យធម្មនុញ្ញតាមប្រទេសជប៉ុន។ ម្ចាស់ក្សត្រីយានីទទួលយកការផ្តល់យោបល់នេះ និងចាប់ផ្តើមធ្វើកំណែទម្រង់នានា។ បើទោះបីជាទ្រង់បានបង្កើតឱ្យមានសភាជាតិមួយ អស់រយៈពេលមួយឆ្នាំទៅហើយក៏ដោយ ក៏ការផ្លាស់ប្តូរមានភាពយឺតយ៉ាវ។ នៅក្នុងឆ្នាំ 1908 រាជវាំងបានប្រកាសថា ពួកគេនឹងបង្កើតឱ្យមានរដ្ឋាភិបាលអាស្រ័យធម្មនុញ្ញតពេញលេញមួយត្រឹមឆ្នាំ 1917 ។ ប៉ុន្តែ ភាពចលាចលនៅក្នុងប្រទេសចិនមិនបានបញ្ចប់ជាមួយនឹងជំហានទៅមុខនេះឡើយ។ ប្រទេសចិនជួបប្រទះនូវភាពចលាចលក្នុងរយៈពេល 4 ទសវត្សរ៍ទៅមុខទៀត ដូចដែលពួកគេ បន្តប្រឈមជាមួយនឹងការគំរាមកំហែងទាំងខាងក្នុង និងខាងក្រៅ។ ប្រទេសជប៉ុនដែលជាប្រទេសជិតខាងចិនក៏ប្រឈមជាមួយនឹងសម្ពាធរបស់ពួកបច្ចិមប្រទេសផងដែរនៅអំឡុងពេលនោះ។ ប៉ុន្តែ ជប៉ុនបានឆ្លើយតបទៅនឹងឥទ្ធិពលរបស់ពួកបស្ចិមប្រទេសនៅក្នុងវិធីផ្សេងគ្នាពីប្រទេសចិន។

# មេរៀនទី 2 ៖ ទំនើបកម្មក្នុងប្រទេសជប៉ុន

## 1. ជប៉ុនបញ្ចប់ភាពឯកកោរបស់ខ្លួន

ជប៉ុនស្ទើរតែមិនមានទំនាក់ទំនងអ្វីសោះជាមួយនឹងបណ្តាលប្រទេសឧស្សាហកម្ម នៅអំឡុងពេលនៃការអនុវត្តគោលនយោបាយឯកកោនិយម។ ប៉ុន្តែ ពួកគេបានបន្តធ្វើពាណិជ្ជកម្មជាមួយប្រទេសចិន និងជាមួយពាណិជ្ជករហូឡង់នៅឥណ្ឌូនេស៊ី។ ពួកគេក៏មានទំនាក់ទំនងការទូតជាមួយកូរ៉េផងដែរ។ ប៉ុន្តែ ការធ្វើពាណិជ្ជកម្មចាប់ផ្តើមមានសារៈសំខាន់កាន់តែខ្លាំង ទាំងខាងក្នុង និងខាងក្រៅជប៉ុន។

ការទាមទារឱ្យមានពាណិជ្ជកម្មអន្តជាតិ៖ នៅដើមសតវត្សរ៍ទី 19 ពួកបស្ចិមប្រទេសបានព្យាយាមនៅក្នុងការបញ្ចុះបញ្ចូលឱ្យពួកជប៉ុនបើកកំពង់ផែរបស់ពួកគេដើម្បីធ្វើពាណិជ្ជកម្ម។ ពួកមន្ត្រីអង់គ្លេស, បារាំង, រុស្ស៊ី, និងអាមេរិកបានចូរលំចតជាញឹកញ៉ាប់នៅតំបន់ឆ្នេររបស់ជប៉ុន។ ប៉ុន្តែ ក៏ដូចជាប្រទេសចិនដែរ ជប៉ុនបដិសេធម្តងហើយម្តងទៀតនៅក្នុងការទទួលពួកគេ។ បន្ទាប់មក នៅក្នុងឆ្នាំ 1853 មេបញ្ជាការអាមេរិកឈ្មោះម៉ាស៊ូ ផ័រី បាននាំយកនាវា 4 គ្រឿងចូលទៅកាន់កំពង់ផែទីក្រុងតូក្យូ។ នាវាធ្វើពីឈើពណ៌ខ្មៅដ៏ធំទាំងនេះ ត្រូវបានបំពាក់ដោយម៉ាស៊ីប្រើចំហាយទឹកបានធ្វើឱ្យពួកជប៉ុនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ កាំភ្លើងធំនៅលើនាវានោះក៏បានធ្វើឱ្យពួកគេតក់ស្លុតផងដែរ។ តូគូហ្គាវ៉ា សូហ្គុន ដឹងច្បាស់ថាទ្រង់មិនមានជម្រើសឡើយ មានតែទទួលលោកផ័រី និងសំបុត្ររបស់ប្រធានាធិបតីមីលឡាដ ហ្វីលម័រ ដែលលោកផ័រីបាននាំយកមក។

នៅក្នុងសំបុត្ររបស់ប្រធានាធិបតីហ្វីលម័រ យ៉ាងគួរសមលោកបានស្នើឱ្យសូហ្គុន អនុញ្ញាតឱ្យមានការធ្វើពាណិជ្ជកម្មដោយសេរីរវាងសហរដ្ឋអាមេរិក និងជប៉ុន។ ប៉ុន្តែ លោកផ័រីបាននាំយកសំបុត្រនេះមកជាមួយនឹងការគំរាមកំហែងមួយ។ នៅឆ្នាំក្រោយលោកនឹងត្រឡប់មកវិញជាមួយនឹងកងនាវាដ៏ធំមួយដើម្បីទទួលការឆ្លើយតបរបស់ជប៉ុន។ ការឆ្លើយតបនោះត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ 1854 តាមរយៈសន្ធិសញ្ញាកាណាហ្គាវ៉ា។ ស្ថិតនៅក្រោមសន្ធិសញ្ញានេះ ជប៉ុនបានបើកកំពង់ផែពីរដែលអនុញ្ញាឱ្យនាវារបស់សហរដ្ឋអាមេរិកអាចចូរសំចតបាន។ បន្ទាប់ពីសហរដ្ឋអាមេរិកបានរុញច្រានឱ្យប្រទេសជប៉ុនបើកជំហរទ្វាររបស់ខ្លួន មានមហាអំណាចបច្ចិមប្រទេសផ្សេងទៀតបានអនុវត្តតាមសហរដ្ឋអាមេរិកដែរ។ ត្រឹមឆ្នាំ 1860 ប្រទេសជប៉ុនក៏ដូចជាចិនដែរ បានផ្តល់ការអនុញ្ញាតឱ្យពួកបរទេសធ្វើពាណិជ្ជកម្មនៅតាមកំពង់ផែមួយចំនួនដែលបានចុះសន្ធិសញ្ញា។ ពួកគេក៏បានពង្រីកសិទ្ធិគ្រប់គ្រងដែនដីដល់បរទេសជាច្រើនផងដែរ។

កំណែទម្រង់ម៉ីជិ និងការធ្វើទំនើបកម្ម៖ ប្រជាជនជប៉ុន មានការខឹងសម្បាចំពោះ សូហ្គុន ដែលបានផ្តល់ឱ្យពួកបរទេសនូវអ្វីដែលពួកគេទាមទារ។ ពួកគេបានត្រឡប់ទៅរកអធិរាជវ័យក្មេងរបស់ជប៉ុន ព្រះនាម ម៉ូស៊ូហ៊ីតុ អ្នកដែលគេយល់ថាជានិមិត្តរូបនៃមោតនភាពជាតិ និងគំនិតជាតិនិយម។ នៅក្នុងឆ្នាំ 1867 តូគូហ្គាវ៉ា សូហ្គុន បានចុះចេញពីតំណែង និងបានបញ្ចប់ការគ្រប់គ្រងបែបយោធាផ្តាច់ការនៅក្នុងប្រទេសជប៉ុន ដែលមានតាំងពីសតវត្សរ៍ទី 12 មក។ អធិរាជម៉ូស៊ូហ៊ីតុ បានត្រួតត្រារដ្ឋាភិបាល។ ទ្រង់បានជ្រើសរើសឈ្មោះម៉ីជិ សម្រាប់រជ្ជកាល

របស់ទ្រង់ ដែលមានន័យថា "ការដឹកនាំដែលពោរពេញទៅដោយពន្លឺ"។ រាជ្យរបស់មុ៊ូស៊ូហ៊ីតុ ដែលមានរយៈពេល 45 ឆ្នាំ ត្រូវបានគេស្គាល់ថា សម័យមុ៊ីជិ ។

អធិរាជមុ៊ីជិ បានដឹងច្បាស់ថា មធ្យោបាយដែលល្អបំផុតដើម្បីទប់ទល់ជាមួយនឹងឥទ្ធិពលរបស់ពួកបស្ចិមប្រទេសគឺការធ្វើទំនើបកម្ម។ ទ្រង់បានបញ្ជូលមន្ត្រីការទូតទៅកាន់អឺរ៉ុប និងអាមេរិកខាងជើងដើម្បីរៀនសូត្រពីគំរូរបស់ពួកបស្ចិមប្រទេស។ ពួកជប៉ុនពេលនោះបានជ្រើសរើស អរិយធម៌បស្ចិមប្រទេស ដែលពួកគេជឿជាក់ថាល្អបំផុតយកមកអនុវត្តនៅក្នុងប្រទេសរបស់ពួកគេ។ ឧទាហរណ៍ ពួកគេមានការស្ងើចសរសើរចំពោះប្រព័ន្ធរដ្ឋាភិបាលដែលមានអំណាចកណ្តាលរឹងមាំរបស់អាឡឺម៉ង់។ ពួកគេបានយកប្រព័ន្ធរដ្ឋាភិបាលនេះដាក់បញ្ចូលទៅក្នុងធម្មនុញ្ញដើម្បីធ្វើជាគំរូសម្រាប់ពួកគេ។ ពួកជប៉ុនការបានស្ងើចសរសើរគោលវិន័យរបស់កងទ័ពអាឡឺម៉ង់ និងជំនាញរបស់កងទ័ពជើងទឹកអង់គ្លេស។ ពួកគេព្យាយាមនៅក្នុងការធ្វើគ្រាប់តាមមហាអំណាចអឺរ៉ុបទាំងនេះ នៅក្នុងការធ្វើទំនើបកម្មវិស័យយោធារបស់ពួកគេ។ ប្រទេសជប៉ុនបានអនុវត្តប្រព័ន្ធនៃការអប់រំសាធារណរបស់អាមេរិក ហើយតម្រូវឱ្យកុមារជប៉ុនទាំងអស់ត្រូវចូលរៀន។ គ្រូរបស់ពួកគេជាទូទៅគឺជាអ្នកជំនាញការបរទេស។ សិស្សក៏អាចធ្វើដំណើរទៅក្រៅប្រទេសដើម្បីសិក្សាផងដែរ។ អធិរាជក៏គាំទ្រយ៉ាងពេញទំហឹងនៅក្នុងការអនុវត្ត ឧស្សាហូវនីយកម្មតាមបែបអឺរ៉ុបផងដែរ។ ត្រឹមដើមសតវត្សរ៍ទី 20 សេដ្ឋកិច្ចរបស់ជប៉ុនបានក្លាយជាសេដ្ឋកិច្ចបែបទំនើបដូចជាប្រទេសផ្សេងៗទៀតនៅលើពិភពលោក។ ប្រទេសនេះបានស្ថាបនាផ្លូវរថភ្លើងដំបូងរបស់ខ្លួននៅក្នុងឆ្នាំ 1872 ។ ផ្លូវរថភ្លើងនោះបានភ្ជាប់ទីក្រុងតូក្យូ ដែលជារាជធានីរបស់ជប៉ុនទៅកាន់កំពង់ផែយូកូហាម៉ាដែលមានរយៈចំងាយ 20 ម៉ាយភាគខាងត្បូងតូក្យូ។ ត្រឹមឆ្នាំ 1914 ប្រទេសជប៉ុនមានផ្លូវរថភ្លើងប្រមាណ 7,000 ម៉ាយ។ ផលិតផលធ្យូងថ្មបានកើនឡើងជាងកន្លះលានតោននៅក្នុងឆ្នាំ 1875 ទៅដល់ជាង 21 លានតោននៅក្នុងឆ្នាំ 1913 ។ នៅក្នុងពេលជាមួយគ្នានោះ ក្រុមហ៊ុនធំៗដែលគាំទ្រដោយរដ្ឋ បានស្ថាបនារោងចក្ររាប់ពាន់។ ឧស្សាហកម្មបែបប្រពៃណីរបស់ជប៉ុន ដែលមានដូចជា រោងចក្រផលិតតែ និងសូត្រ ត្រូវបានពង្រីកឡើងឱ្យក្លាយជាផលិតផលសំខាន់មួយរបស់ជប៉ុនដើម្បីធ្វើពាណិជ្ជកម្មទៅខាងក្រៅ។ ការអភិវឌ្ឍឧស្សាហកម្មទំនើប ដូចជាឧស្សាហកម្មផលិតនាវា បានធ្វើឱ្យជប៉ុនអាចប្រកួតប្រជែងជាមួយពួកបច្ចិមប្រទេសបាន។

## 2. ចក្រពត្តិជប៉ុន

យុទ្ធនាការធ្វើទំនើបកម្មរបស់ជប៉ុនបានផ្តល់ផលជាទីគាប់ចិត្ត។ ត្រឹមឆ្នាំ 1890 ប្រទេសនេះមាននាវាចម្បាំងជាច្រើនគ្រឿង និងមានកងទ័ពដែលទទួលបានការរឹករឹង និងបំពាក់អាវុធទំនើបៗប្រមាណ 50 មុឺននាក់។ ប្រទេសនេះបានក្លាយជាប្រទេសដែលមានអំណាចយោធាខ្លាំងជាងគេនៅក្នុងទ្វីបអាស៊ី។ ជប៉ុនទទួលបាននូវភាពរឹងមាំផ្នែកយោធា, នយោបាយ, និងសេដ្ឋកិច្ច។ ពេលនេះពួកគេសំលឹងទៅរកការដកចេញនូវសិទ្ធិគ្រប់គ្រងដែនដីរបស់ពួកបរទេសក្នុងប្រទេសជប៉ុន។ រដ្ឋមន្ត្រីការបទេសជប៉ុនជានាអះអាងចំពោះជនបរទេសថា ពួកគេអាចជឿទុកចិត្តលើការអនុវត្តដោយស្មើភាពនៅក្នុងប្រទេសជប៉ុន។ លោកបានពន្យល់ថា នេះដោយសារតែធម្មនុញ្ញ និងក្រមច្បាប់របស់ជប៉ុនមានលក្ខណៈស្រដៀងគ្នាទៅនឹងធម្មនុញ្ញរបស់បណ្តាលប្រទេសនៅអឺរ៉ុប។ ហេតុផលរបស់

លោកបានធ្វើឱ្យពួកអឺរ៉ុបទទួលយកបាន ហើយនៅក្នុងឆ្នាំ 1894 មហាអំណាចបរទេសទាំងឡាយបានយល់ព្រមបោះបង់ចោលនូវសិទ្ធិគ្រប់គ្រងដែនដីរបស់ខ្លួននៅក្នុងប្រទេសជប៉ុន។ ជប៉ុនមានអារម្មណ៍ថាខ្លួនមានភាពរឹងមាំ និងស្មើភាពជាមួយពួកបស្ចិមប្រទេស។ ដូចដែលជប៉ុនយល់ថាអំណាចរបស់ខ្លួនកើនឡើង ប្រទេសមួយនេះចាប់ផ្តើមមានគំនិតចក្រពត្តិនិយមកាន់តែខ្លាំង។ ក៏ដូចជានៅអឺរ៉ុបដែរ មោទនភាពជាតិបានដើរតួនាទីដ៏សំខាន់នៅគំនិតចក្រពត្តិនិយមរបស់ជប៉ុន។ ពួកជប៉ុនមានបំណងនៅក្នុងការបង្ហាញពិភពលោកថាពួកគេគឺជាប្រទេសដ៏ខ្លាំងមួយ។

ជប៉ុនវាយប្រហារប្រទេសចិន៖ ពួកជប៉ុនជាដំបូងបានសម្លឹងទៅរកប្រទេសជិតខាងរបស់គេ គឺប្រទេសកូរ៉េ។ នៅក្នុងឆ្នាំ 1876 ជប៉ុនបានបង្ខំឱ្យប្រទេសកូរ៉េបើកកំពង់ផែចំនួន 3 សម្រាប់ការធ្វើពាណិជ្ជកម្មរបស់ជប៉ុន។ ប៉ុន្តែប្រទេសចិនក៏ចាត់ទុកប្រទេសកូរ៉េថាជាដៃគូពាណិជ្ជកម្ម និងជាមូលដ្ឋានយោធាដ៏សំខាន់មួយផងដែរ។ ដោយទទួលស្គាល់ការចាប់អារម្មណ៍ដូចគ្នាទៅលើប្រទេសកូរ៉េ ជប៉ុន និងចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ។ នៅក្នុងឆ្នាំ 1885 ប្រទេសទាំងពីរបានអះអាងថាពួកគេនឹងមិនបញ្ជូនកងទ័ពរបស់ពួកគេទៅកាន់ប្រទេសកូរ៉េឡើយ។ ប៉ុន្តែ នៅក្នុងខែមិថុនា ឆ្នាំ 1894 ចិនបានក្បត់កិច្ចព្រមព្រៀងនេះ។ ការបះបោរបានផ្ទុះឡើងប្រឆាំងជាមួយស្តេចកូរ៉េ។ ទ្រង់បានស្នើប្រទេសចិនឱ្យបញ្ចូលកងទ័ពដើម្បីជួយដល់ទ្រង់ក្នុងការបង្ក្រាបការបះបោរនេះ។ កងទ័ពចិនបានធ្វើដំណើរមកកាន់ប្រទេសកូរ៉េ។ ជប៉ុនបានប្រឆាំង និងបានបញ្ចូលកងទ័ពរបស់ពួកគេទៅកាន់ប្រទេសកូរ៉េដើម្បីប្រយុទ្ធជាមួយកងទ័ពចិន។ សង្គ្រាមចិន-ជប៉ុន មានរយៈតែប៉ុន្មានខែប៉ុណ្ណោះ។ នៅពេលនោះ ជប៉ុនបានបណ្តេញចិនចេញពីប្រទេសកូរ៉េ, បំផ្លាញកងទ័ពជើងទឹកចិន, នៅកាន់កាប់មូលដ្ឋានមួយនៅតំបន់ម៉ាន់ជូរី។ នៅក្នុងឆ្នាំ 1895 ប្រទេសចិន និងប្រទេសជប៉ុនបានចុះសន្ធិសញ្ញាសន្តិភាពមួយ។ សន្ធិសញ្ញានេះបានផ្តល់ឱ្យជប៉ុននូវដែនដីអាណានិគមដំបូង គឺកោះតៃវ៉ាន់ និងដែនកោះប៉េស្កាដូរ៉េ ។

សង្គ្រាមរូស្ស៊ី-ជប៉ុន៖ ជ័យជំនះរបស់ជប៉ុនលើប្រទេសចិនបានផ្លាស់ប្តូរតុល្យភាពនៃអំណាចលើពិភពលោក។ រុស្ស៊ី និងជប៉ុនលេចឡើងជាមហាអំណាចសំខាន់ពីរនៅអាស៊ីបូព៌ា និងក៏ជាសត្រូវជាមួយគ្នាផងដែរ។ ប្រទេសទាំងពីរនេះភ្លាមៗនោះបានធ្វើសង្គ្រាមជាមួយគ្នាដើម្បីដណ្តើមតំបន់ម៉ាន់ជូរី។ នៅក្នុងឆ្នាំ 1903 ជប៉ុននឹងទទួលស្គាល់សិទ្ធិរបស់រុស្ស៊ីនៅតំបន់ម៉ាន់ជូរីប្រសិនបើរូស្ស៊ីយល់ព្រមនៅក្នុងការដកខ្លួនចេញពីប្រទេសកូរ៉េ។ ប៉ុន្តែប្រទេស រុស្ស៊ីបានបដិសេធ។ នៅក្នុងខែកុម្ភៈ ឆ្នាំ 1904 ជប៉ុនបានបើកការវាយប្រហារដ៏ភ្ញាក់ផ្អើលមួយលើនាវារបស់រុស្ស៊ីដែលបានចូលសំចតនៅឆ្នេរសមុទ្រម៉ាន់ជូរី។ ជាលទ្ធផលនៅក្នុងសង្គ្រាមរុស្ស៊ី-ជប៉ុន ប្រទេសជប៉ុនបានបណ្តេញកងទ័ពរុស្ស៊ីចេញពីប្រទេសកូរ៉េ និងចាប់បានកងនាវាមួយភាគធំរបស់រុស្ស៊ីនៅសមុទ្រប៉ាស៊ីហ្វិក។ ពួកគេក៏បានកម្ទិចកងនាវារបស់រុស្ស៊ីនៅសមុទ្របាល់ទិក ដែលបានធ្វើដំណើរជុំវិញទ្វីបអាហ្វ្រិកដើម្បីចូលរួមនៅក្នុងសង្គ្រាម។ នៅក្នុងឆ្នាំ 1905 ប្រទេសជប៉ុន និងប្រទេសរុស្ស៊ីចាប់ផ្តើមចរចារសន្តិភាព។ ប្រធានាធិបតីសហរដ្ឋអាមេរិក លោកថេអូដររ៉ូស្វែលត៍ បានជួយពង្រាងសន្ធិសញ្ញាមួយ ដែលប្រទេសទាំងពីរនេះបានចុះហត្ថលេខានៅលើនាវាមួយនៅឆ្នេរ ផូតស្មូស បច្ចុប្បន្នរដ្ឋញ៉ូវហែមសឺ។ កិច្ចព្រមព្រៀងនេះ (សន្ធិសញ្ញាផូតស្មូស) បានផ្តល់ឱ្យជប៉ុននូវដែនដីដែលពួកគេដណ្តើមកាន់កាប់បាន។ សន្ធិសញ្ញានេះក៏បានបង្ខំឱ្យរុស្ស៊ីដកកងទ័ពរបស់ខ្លួនចេញពីតំបន់ម៉ាន់ជូរី និងស្ថិតនៅឱ្យឆ្ងាយពីប្រទេសកូរ៉េ។

ពួកជប៉ុនកាន់កាប់ប្រទេសកូរ៉េ៖ បន្ទាប់ពីយកជ័យជំនះលើប្រទេសរុស្ស៊ី ជប៉ុនបានធ្វើការវាយប្រហារលើប្រទេសកូរ៉េជាមួយនឹងការសេងសឹក។ នៅក្នុងឆ្នាំ 1905 ពួកគេបានដាក់អាណាព្យាបាលលើប្រទេសកូរ៉េ។ ជប៉ុនបានបញ្ចូល "ទីប្រឹក្សា" ដែលក្រសោបយកអំណាចកាន់តែច្រើនឡើងៗពីរដ្ឋាភិបាលកូរ៉េ។ ស្តេចកូរ៉េមិនអាចស្វែងរកការគាំទ្របរបស់ទ្រង់ពីសំណាក់អន្តរជាតិបានឡើយ។ នៅក្នុងឆ្នាំ 1907 ទ្រង់បានបោះបង់ការត្រួតត្រាប្រទេស។ នៅក្នុងរយៈពេល 2 ឆ្នាំ កងទ័ពអធិរាជកូរ៉េបានបែកខ្ញែកគ្នា។ នៅក្នុងឆ្នាំ 1910 ជាផ្លូវការជប៉ុនបានភ្ជាប់ដែនដីកូរ៉េទៅក្នុងចក្រភពរបស់ខ្លួន ឬដាក់ប្រទេសកូរ៉េឱ្យស្ថិតក្រោមការត្រួតត្រារបស់ខ្លួន។ ពួកជប៉ុនគឺជាអ្នកដែលគ្រប់គ្រងបែបឃោរឃៅ។ ពួកគេបានបិទកាសែតកូរ៉េ និងកាន់កាប់សាលារៀនកូរ៉េ។ នៅក្នុងសាលារៀនពួកគេបានដកចេញនូវការសិក្សាភាសា និងប្រវត្តិសាស្ត្រកូរ៉េ ដោយដាក់ជំនួសមកវិញនូវមុខវិជ្ជារបស់ជប៉ុន។ ពួកគេយករឹបអូសយកដីធ្លីរបស់ប្រជាកសិករកូរ៉េ និងផ្តល់ដីទាំងនោះឱ្យទៅអ្នកតាំងទីលំនៅជនជាតិជប៉ុន។ ពួកគេបានលើកទឹកចិត្តឱ្យអ្នកជំនួញជប៉ុនបង្កើតរោងចក្រឧស្សាហកម្មនៅក្នុងប្រទេសកូរ៉េ ប៉ុន្តែបានហាមឃាត់ជនជាតិកូរ៉េមិនឱ្យធ្វើជំនួញ។ ការមិនសប្បាយចិត្តចំពោះការបង្ក្រាបរបស់ជប៉ុនបានកើនឡើង ដែលជម្រុញឱ្យមានចលនាជាតិនិយមរបស់ប្រជាជនកូរ៉េដ៏ខ្លាំងក្លាមួយ។ ពិភពលោកទាំងមូលបានមើលឃើញយ៉ាងច្បាស់ពីលទ្ធផលដ៏ឃោឃៅនៃចក្រពត្តិនិយមរបស់ជប៉ុន។ យ៉ាងណាក៏ដោយ សហរដ្ឋអាមេរិក និងប្រទេសអឺរ៉ុបនានាភាគច្រើនមិនបានអើពើទៅនឹងអ្វីដែលបានកើតមានឡើងនៅក្នុងប្រទេសកូរ៉េឡើយ។ ពួកគេជាប់រវល់ជាមួយនឹងគោលដៅចក្រពត្តិនិយមរបស់ពួកគេផ្ទាល់ ដូចដែលអ្នកនឹងបានសិក្សានៅក្នុងមេរៀនទី 3 ។

# មេរៀនទី 3 ៖ សេដ្ឋកិច្ចបែបចក្រពត្តិនិយមរបស់សហរដ្ឋអាមេរិក

## 1. អាមេរិកឡាទីនបន្ទាប់ពីទទួលបានឯករាជ្យ

ឯករាជ្យផ្នែកនយោបាយ មានន័យតិចតួចសម្រាប់ប្រជាជនភាគច្រើននៅក្នុងបណ្តាលប្រទេសថ្មីៗនៅអាមេរិកឡាទីន។ ភាពច្រើននៃប្រជាជននៅក្នុងបណ្តាលប្រទេសទាំងនោះនៅតែជាកម្មករក្រីក្រដែលរស់នៅក្នុងភាពក្រីក្រតកូនតចៅ។

កេរ្តិ៍ដំណែលរបស់អាណានិគម៖ ទាំងមុន និងក្រោយទទួលបានឯករាជ្យ ភាគច្រើននៃប្រជាជនអាមេរិកឡាទីនធ្វើការឱ្យម្ចាស់ដីធំៗ។ និយោជកបានផ្តល់ឱ្យកម្មកររបស់ពួកគេនូវប័ណ្ណសាច់ប្រាក់ ដែលពួកកម្មករទាំងនោះអាចប្រើប័ណ្ណសាច់ប្រាក់ទាំងនេះ បានតែនៅក្នុងហាងទំនិញរបស់និយោជកប៉ុណ្ណោះ។ ដូចដែលតម្លៃពលកម្មថោក ហើយតម្លៃទំនិញកើនឡើង កម្មករជាច្រើនបានក្លាយជាកូនបំណុល។ បំណុលរបស់ពួកគេបានកើនឡើង និងបន្តពីមួយជំនាន់ទៅមួយជំនាន់។ នៅក្នុងប្រព័ន្ធនេះគេស្គាល់ថា កម្មករ "សេរី" ដែលមានលក្ខណៈប្រសើរជាងទាសករបន្តិច។

ផ្ទុយទៅវិញ ម្ចាស់កម្មសិទ្ធិដីធ្លី កាន់តែមានទ្រព្យសម្បត្តិច្រើនឡើងបន្ទាប់ពីទទួលបានឯករាជ្យ។ រដ្ឋាភិបាលថ្មីៗជាច្រើននៅអាមេរិកឡាទីន បានដណ្តើមយកដីដែលកាន់កាប់ដោយជនជាតិដើម និងកាន់កាប់ដោយព្រះវិហារសាសនារ៉ូម៉ាំងកាតូលិក។ បន្ទាប់មកពួកគេបានដាក់លក់ដីទាំងនោះ។ ម្ចាស់កម្មសិទ្ធិដីធ្លីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ គឺជាប្រជាជនតែមួយគត់ដែលអាចមានលទ្ធភាពទិញដីទាំងនោះបាន ដូច្នេះពួកគេបានទិញដីទាំងនោះទុក។ ប៉ុន្តែ ដូចដែលកាសែតអាហ្សង់ទីនមួយបានរាយការណ៍ថា "ដីធ្លីដ៏ច្រើនរបស់ពួកគេ មិនមានតុល្យភាពជាមួយនឹងសមត្ថភាពនៃការប្រើប្រាស់របស់ពួកគេឡើយ"។ ភាពមិនស្មើគ្នានៅក្នុងការបែងចែកដីធ្លី និងអសមត្ថភាពនៅក្នុងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធិភាពរបស់ម្ចាស់កម្មសិទ្ធិដីធ្លី បានរារាំងដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅអាមេរិកឡាទីន។

អស្ថេរភាពនយោបាយ៖ អស្ថេរភាពនយោបាយគឺជាបញ្ហាទូទៅមួយនៅអាមេរិកឡាទីននៅក្នុងសតវត្សរ៍ទី 19 ។ មេដឹកនាំកងទ័ពនៅអាមេរិកឡាទីនជាច្រើនបានទទួលកត្តិនាម និងអំណាចអំឡុងពេលនៃការតស៊ូទាមទារឯករាជ្យដ៏យូរអង្វែងមួយ។ ពួកគេជាទូទៅបានបន្តការងារអំណាចរបស់ពួកគេ។ ពួកគេត្រួតត្រាប្រទេសជាតិថ្មីរបស់ពួកគេតាមបែបយោធាផ្តាច់ការ ឬ ប្រមុខទ័ព។ ពួកគេអាចក្តោបក្តាប់អំណាចបានដោយសារតែពួកយោធានៅក្រោយពួកគេ។ ត្រឹមពាក់កណ្តាលសតវត្សរ៍ទី 19 ស្ទើរតែគ្រប់ប្រទេសទាំងអស់នៅអាមេរិកឡាទីនត្រូវបានគ្រប់គ្រងដោយមេដឹកនាំយោធាផ្តាច់ការ។ ក្នុងនោះមានដូចជា មេដឹកនាំយោធាផ្តាច់ការចូន វីសេនតេ ហ្គោមេសជាដើម។ លោកគឺជាមនុស្សដែលគ្មានមេត្តា ដែលបានដឹកនាំប្រទេសវេណេហ្ស៊ូអេឡាអស់រយៈពេលជិត 30 ឆ្នាំបន្ទាប់ពីលោកដណ្តើមអំណាចបាននៅក្នុងឆ្នាំ 1908 ។ លោកបានលើកឡើងដោយអំណួតថា "វេណេហ្ស៊ូអេឡាទាំងមូលគឺជាវាលចិញ្ចឹមគោក្របីរបស់ខ្ញុំ"។ ប៉ុន្តែ មានករណីលើកលែងមួយចំនួនសម្រាប់មេដឹកនាំយោធាផ្តាច់ការទាំងនោះ។ ប្រធានាធិបតីដែលមានគំនិតនៅក្នុងការធ្វើកំណែទម្រង់មួយចំនួន ដូចជាលោកដីមីនហ្គោ សាមានតូ

ដែលជាប្រធានាធិបតីអាហ្សង់ទីន បានតាំងចិត្តខ្ពស់នៅក្នុងការធ្វើឱ្យវិស័យអប់រំប្រសើរឡើង។ អំឡុងពេលដែលលោកសាមានតូ ធ្វើជាប្រធានាធិបតី រវាងឆ្នាំ 1868 ដល់ 1874 ចំនួនសិស្សនៅក្នុងប្រទេសអាហ្សង់ទីនបានកើនឡើងគុណនិងពីរ។ ប៉ុន្តែមេដឹកនាំធ្វើកំណែទម្រង់មួយចំនួន កាន់ដំណែងបានរយៈពេលខ្លីប៉ុណ្ណោះ។ ជាញឹកញ៉យមេដឹកនាំយោធាផ្តាច់ការមួយរូបទទួលបានការគាំទ្រពីពួកយោធា និងដណ្តើមការគ្រប់គ្រងរដ្ឋាភិបាល។ ពួកមេដឹកនាំយោធាផ្តាច់ការទាំងនោះប្រឈមជាមួយនឹងការប្រឆាំងតិចតួចណាស់។ ម្ចាស់កម្មសិទ្ធិដីធ្លីមានទ្រព្យសម្បត្តិស្តុកស្តម្ភជាទូទៅគាំទ្រពួកគេ ដោយសារតែមេដឹកនាំយោធាទាំងនោះ ប្រឆាំងជាមួយនឹងការផ្តល់សិទ្ធិអំណាចទៅដល់មនុស្សដែលមានវណ្ណៈទាប។ ជាងនេះទៅទៀត ពួកអាមេរិកឡាទីនទទួលបានបទពិសោធន៍តិចតួចជាមួយនឹងប្រជាធិបតេយ្យនៅពេលដែលពួកគេស្ថិតនៅក្រោមការគ្រប់គ្រងអាណានិគមរបស់ពួកអឺរ៉ុប។ ដូច្នេះ ការដឹកនាំបែបផ្តាច់ការរបស់ពួកយោធាហាក់ដូចជាមិនមានអ្វីប្លែកសម្រាប់ពួកគេឡើយ។ ប៉ុន្តែ សូម្បីតែនៅពេលដែលមេដឹកនាំយោធាផ្តាច់ការមិនឡើងកាន់អំណាចក៏ដោយ ក៏ប្រជាជនអាមេរិកឡាទីនបានសំលេងតិចតួចនៅក្នុងរដ្ឋាភិបាល។ សិទ្ធិនៅក្នុងការបោះឆ្នោត និងអំណាចនយោបាយត្រូវបានកម្រិតសម្រាប់តែពួកវណ្ណៈលើ និងវណ្ណៈកណ្តាលមួយចំនួនតូចប៉ុណ្ណោះ ដែលជាអ្នកមានទ្រព្យសម្បត្តិ និងអាចអានអក្សរបាន។

## 2. ការកើនឡើងនៃសេដ្ឋកិច្ចស្ថិតក្រោមឥទ្ធិពលបរទេស

នៅពេលដែលការគ្រប់គ្រងអាណានិគមចាប់ផ្តើមដំបូងនៅអាមេរិកឡាទីននៅដើមសតវត្សរ៍ទី 19 ប្រទេសដែលកើតឡើងថ្មីៗ មិនត្រូវបានគេបន្តកម្រិតការធ្វើពាណិជ្ជជាមួយនឹងមហាអំណាចអាណានិគមនានាឡើយ។ អង់គ្លេស និងក្រោយមកសហរដ្ឋអាមេរិកបានក្លាយជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់អាមេរិកឡាទីន។

ផលិតផលចាស់ និងទីផ្សារថ្មី៖ សេដ្ឋកិច្ចរបស់អាមេរិកឡាទីនបន្តពឹងផ្អែកលើការនាំចេញ មិនថាប្រទេសណាដែលពួកគេធ្វើពាណិជ្ជកម្មជាមួយឡើយ។ ក៏ដូចជាអំឡុងសម័យអាណានិគមដែរ ប្រទេសនីមួយៗចាប់អារម្មណ៍លើតែផលិតផលមួយ ឬពីរមុខប៉ុណ្ណោះ។ ប៉ុន្តែ ជាមួយនឹងភាពរីកចម្រើននៃបច្ចេកវិទ្យា ការនាំចេញរបស់អាមេរិកឡាទីនបានកើនឡើង។ ឧទាហរណ៍ ការអភិវឌ្ឍឡើងនៃនាវាប្រើចំហាយទឹក និងការស្ថាបនាផ្លូវរថភ្លើងនៅក្នុងសតវត្សរ៍ទី 19 បានបង្កើនសកម្មភាពពាណិជ្ជកម្មរបស់អាមេរិកឡាទីនយ៉ាងខ្លាំង។ នៅចុងសតវត្សរ៍ទី 19 ការបង្កើតឡើងនៃទូទឹកកកបានជួយបង្កើនការនាំចេញរបស់អាមេរិកឡាទីន។ ការលក់សាច់គោ, ផ្លែឈើ, បន្លែ, និងទំនិញឆាប់ស្អុយផ្សេងៗទៀតបានកើនឡើង។

ប៉ុន្តែ ពួកបរទេសទទួលបានផលចំណេញពីការកើនឡើងនៃពាណិជ្ជកម្មច្រើនជាងពួកអាមេរិកឡាទីន។ នៅក្នុងការផ្លាស់ប្តូរជាមួយនឹងការនាំចេញរបស់ពួកគេ ពួកអាមេរិកឡាទីនបាននាំចូលផលិតផលរោងចក្ររបស់អឺរ៉ុប និងអាមេរិកខាងជើង។ ជាលទ្ធផល ពួកគេមានហេតុផលតិចតួចនៅក្នុងការអភិវឌ្ឍឧស្សាហកម្មរោងចក្រផលិតផ្ទាល់ខ្លួនរបស់ពួកគេ។ ហើយនៅពេលណាដែលអាមេរិកឡាទីននៅបន្តជាប្រទេសមិនមែនឧស្សាហកម្ម ពួកគេមិនអាចមានតួនាទីសំខាន់អ្វីនៅលើឆាកសេដ្ឋកិច្ចពិភពលោកឡើយ។

ការវិនិយោគពីខាងក្រៅ និងការជៀតជ្រែក៖ ជាមួយគ្នានោះដែរ ប្រទេសនៅអាមេរិកឡាទីនបានប្រើប្រាស់តិចតួចនូវចំណូលពីការនាំចេញរបស់ពួកគេដើម្បីស្ថាបនាផ្លូវថ្នល់, សាលារៀន, ឬមន្ទីរពេទ្យ។ ពួកគេមិនបានស្វែករកការអនុវត្តកម្មវិធីនានាដើម្បីជួយដល់ពួកគេឱ្យក្លាយជាប្រទេសពឹងផ្អែកខ្លួនឯងឡើយ។ ផ្ទុយទៅវិញពួកគេតែងតែខ្ចីលុយដែលមានអត្រាការប្រាក់ខ្ពស់យកមកអភិវឌ្ឍរោងចក្រសម្រាប់ឧស្សាហកម្មនាំចេញរបស់ពួកគេ។ ប្រទេសមួយចំនួន ដូចជាអង់គ្លេស, បារាំង, សហរដ្ឋអាមេរិក, និងអាឡឺម៉ង់គឺជាអ្នកផ្តល់ប្រាក់កម្ចីដល់ពួកគេ។ ប៉ុន្តែ ប្រទេសនានានៅអាមេរិកឡាទីន ជាទូទៅមិនអាចសងត្រឡប់នូវប្រាក់ដែលពួកគេបានខ្ចីទៅកាន់ម្ចាស់បំណុលបានឡើយ។ ក្នុងការឆ្លើយតប ម្ចាស់បំណុលបរទេសទាំងនោះ ពេលខ្លះបានគំរាមកំហែងនៅក្នុងប្រមូលប្រាក់បំណុលរបស់ពួកគេមកវិញតាមមធ្យោបាយហិង្សា។ ពេលខ្លះ ពួកម្ចាស់បំណុលទាំងនោះបានគំរាមកំហែងនៅក្នុងការត្រួតត្រារោងចក្រដែលបានយកលុយពួកគេមកសាងសង់។ នៅក្នុងវិធីនេះ ក្រុមហ៊ុនបរទេសនានាទទួលបានសិទ្ធិនៅក្នុងការត្រួតត្រារោងចក្រឧស្សាហកម្មជាច្រើននៅអាមេរិកឡាទីន។ នេះគឺជាការចាប់ផ្តើមឡើងនៃយុគសម័យនៃអាណានិគមសេដ្ឋកិច្ចមួយនៅអាមេរិកឡាទីន។

### 3. ចក្រភពអាមេរិកឡាទីនមួយ

នៅមុនពេលដែលសហរដ្ឋអាមេរិក មានចំណាប់អារម្មណ៍លើសេដ្ឋកិច្ចនៅក្នុងបណ្តាលប្រទេសនានានៅអាមេរិកឡាទីន ពួកគេបានដឹងច្បាស់ថា ពួកគេមានទំនាក់ទំនងយ៉ាងរឹងមាំមួយជាមួយអ្នកជិតខាងភាគខាងត្បូងរបស់ពួកគេ។ មេដឹកនាំនានានៅសហរដ្ឋអាមេរិកមានការយល់ដឹងយ៉ាងច្បាស់ថា សន្តិសុខនៃប្រទេសរបស់ពួកគេពឹងផ្អែកលើសន្តិសុខនៅអាមេរិកឡាទីន។

សេចក្តីប្រកាសម៉ូនរ៉េ៖ ប្រទេសអាណានិគមអាមេរិកឡាទីនភាគច្រើនទទួលបានឯករាជ្យរបស់ពួកគេត្រឹមដើមសតវត្សរ៍ទី 19 ។ ប៉ុន្តែឯករាជ្យរបស់ពួកគេមិនទាន់មានមានសុវត្ថិភាពឡើយ។ ពួកអាមេរិកឡាទីនជាច្រើនមានការព្រួយបារម្ភថា ប្រទេសអឺរ៉ុបនានានឹងព្យាយាមនៅក្នុងការដណ្តើមកាន់កាប់ពួកគេសារជាថ្មី។ សហរដ្ឋអាមេរិកដែលជាប្រទេសវ័យក្មេងមួយនៅពេលនោះ ក៏មានការភ័យខ្លាចដូចគ្នា។ ដូច្នេះ នៅក្នុងឆ្នាំ 1823 ប្រធានាធិបតីជេម ម៉ូនរ៉េ បានចេញសេចក្តីប្រកាសមួយ ដែលក្រោយមកក្លាយជា សេចក្តីប្រកាសម៉ូនរ៉េ។ នៅក្នុងសេចក្តីប្រកាសនេះបានថ្លែងថា "ប្រទេសនៅទ្វីបអាមេរិកទាំងអស់...ចាប់ពីពេលនោះតទៅ មិនត្រូវបានចាត់ទុកថាជាប្រទេសសម្រាប់ការដាក់អាណានិគមរបស់មហាអំណាចអឺរ៉ុបឡើយ"។ រហូតដល់ឆ្នាំ 1989 សហរដ្ឋអាមេរិកបានធ្វើការតិចតួចដើម្បីធ្វើឱ្យសេចក្តីប្រកាសម៉ូនរ៉េដំណើរការ។ ប្រទេសគុយបាបានផ្តល់នូវការសាកល្បងពិតប្រាកដមួយ។

គុយបាប្រកាសឯករាជ្យ៖ គុយបាដែលស្ថិតនៅដែនកោះការីប៊ីន គឺជាដែនដីអាណានិគមចុងក្រោយគេបង្អស់របស់អេស្ប៉ាញនៅទ្វីបអាមេរិក។ នៅក្នុងឆ្នាំ 1868 ប្រទេសគុយបាបានប្រកាសឯករាជ្យរបស់ពួកគេ និងបានធ្វើការវាយប្រយុទ្ធអស់រយៈពេល 10 ឆ្នាំជាមួយពួកអេស្ប៉ាញ។ នៅក្នុងឆ្នាំ 1878 ជាមួយនឹងភាពខ្ចិចខ្ចី ពួកគុយបាបានបោះបង់ចោលការប្រយុទ្ធ។ ប៉ុន្តែ ពួកគុយបាមួយចំនួននៅតែបន្តស្វែងយកឯករាជ្យពីប្រទេសអេស្ប៉ាញ។ នៅក្នុងឆ្នាំ 1895 អ្នកនិពន្ធមួយរូបឈ្មោះចូសេ ម៉ាទី អ្នកដែលត្រូវបាននិរទេសពីគុយបាទៅកាន់ប្រទេសអេស្ប៉ាញ

បានត្រឡប់មកកាន់គុយបាវិញ ដើម្បីការដឹកនាំការប្រយុទ្ធជាលើកទី 2 ដើម្បីឯករាជ្យរបស់គុយបា។ លោក ម៉ាទី ត្រូវបានសម្លាប់នៅពេលដែលសង្គ្រាមចាប់ផ្ដើមដំបូង ប៉ុន្តែពួកគុយបាបានបន្តការប្រយុទ្ធនេះ។ ត្រឹមពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1890 សហរដ្ឋអាមេរិកបានអភិវឌ្ឍមូលដ្ឋានជំនួញដ៏ធំមួយនៅប្រទេសគុយបា។ ដូច្នេះ មូលដ្ឋានសេដ្ឋកិច្ចដ៏សំខាន់របស់ពួកគេត្រូវជួបបញ្ហាដោយសារតែសង្គ្រាមនៅក្នុងប្រទេសនេះ។ ជាងនេះទៅទៀត ពួកអេស្ប៉ាញបានបង្ខំឱ្យជនស៊ីវិលគុយបាជាច្រើនទៅរស់នៅក្នុងជុំរុំលត់ដំ។ ប្រជាជនអាមេរិកបានប្រឆាំងទៅនឹងអំពើឃោឃៅរបស់អេស្ប៉ាញនេះ។ នៅក្នុងឆ្នាំ 1898 សហរដ្ឋអាមេរិកបានចូលរួមជាមួយគុយបានៅក្នុងសង្គ្រាមដើម្បីទាមទារឯករាជ្យ។ ជម្លោះនេះ មានរយៈពេលប្រហែល 4 ខែ។ កងទ័ពសហរដ្ឋអាមេរិកបានបើកការវាយប្រយុទ្ធរបស់ពួកគេលើអេស្ប៉ាញជាលើកដំបូងមិនមែននៅប្រទេសគុយបាឡើយ ប៉ុន្តែបានធ្វើការវាយប្រហារនៅដែនកោះហ្វីលីពីនដែលជាដែនដីអាណានិគមមួយរបស់អេស្ប៉ាញដែលមានចម្ងាយរាប់ពាន់ម៉ាយពីគុយបា។ ដោយមិនបានត្រៀមទុកជាមុនសម្រាប់សង្គ្រាមមួយដែលមានសមរភូមិពីរ កងទ័ពរបស់អេស្ប៉ាញបានដួលរលំយ៉ាងឆាប់រហ័ស។ នៅក្នុងឆ្នាំ 1901 ប្រទេសគុយបាបានក្លាយជាប្រទេសឯករាជ្យ ប៉ុន្តែមានតែនាមប៉ុណ្ណោះ។ ប៉ុន្តែ សហរដ្ឋអាមេរិកបានលើកបណ្ដុបរដ្ឋាភិបាលឃោជាមួយ និងបន្តត្រួតត្រាលើកិច្ចការរបស់ប្រទេសគុយបា។ ការនេះបានបណ្ដាលឱ្យមានការមិនសប្បាយជាខ្លាំងក្នុងចំណោមប្រជាជនគុយបា អ្នកដែលធ្លាប់គិតថាគោលបំណងនៅក្នុងការអន្តរាគមន៍របស់សហរដ្ឋអាមេរិកគឺដើម្បីជួយគុយបាឱ្យក្លាយជាប្រទេសឯករាជ្យពិតប្រាកដ។ ការកើនឡើងនូវភាពបាក់បែករវាងសហរដ្ឋអាមេរិក និងគុយបានៅពេលនោះ បានធ្វើឱ្យប្រទេសជិតខាងដែលមានចម្ងាយតែប៉ុន្មានម៉ាយពីគ្នាទាំងពីរនេះ នៅបន្តដាច់ចេញពីគ្នាអស់រយៈពេលជាងមួយសតវត្សរ៍ក្រោយមក។ បន្ទាប់ពីទទួលជ័យជំនះនៅក្នុងសង្គ្រាមអេស្ប៉ាញ-អាមេរិក អេស្ប៉ាញបានប្រគល់ដែនដីអាណានិគមចុងក្រោយរបស់ពួកគេឱ្យទៅសហរដ្ឋអាមេរិក។ ព័រតូ រីកូ, ហ្គាំ, និងហ្វីលីពីនបានកាយជាដែនដីរបស់សហរដ្ឋអាមេរិក។ ដោយកាយជាមហាអំណាចចក្រពត្តិនិយមគ្របដណ្ដប់នៅអាមេរិកឡាទីន ជំហានបន្ទាប់ដែលសហរដ្ឋាអាមេរិកសម្លឹងគឺប្រទេសប៉ាណាម៉ា។

ការតភ្ជាប់មហាសមុទ្រ៖ ពួកអាមេរិកឡាទីនចាប់ផ្ដើមទទួលស្គាល់សហរដ្ឋអាមេរិកថាជា មហាអំណាចនយោបាយ និងសេដ្ឋកិច្ចនៅភាគខាងជើង។ សហរដ្ឋអាមេរិកក៏ជាមហាអំណាចក្នុងបរិបទភូមិសាស្ត្រផងដែរ។ ត្រឹមទសវត្សរ៍ឆ្នាំ 1870 ផ្លូវរថភ្លើងឆ្លងទ្វីបបានភ្ជាប់តំបន់ឆ្នេរភាគខាងកើតទៅកាន់តំបន់ឆ្នេរភាគខាងលិច។ ប៉ុន្តែការធ្វើដំណើរតាមផ្លូវគោកនៅតែត្រូវចំណាយពេលច្រើន និងមានភាពលំបាក។ ហើយនៅក្នុងការធ្វើដំណើរតាមផ្លូវទឹកពីតំបន់ឆ្នេរភាគខាងកើតទៅឆ្នេរភាគខាងលិចមានរយៈចំងាយប្រមាណ 13,000 ម៉ាយ ដោយត្រូវធ្វើដំណើរព័ទ្ធជុំវិញទ្វីបអាមេរិកខាងត្បូង។ ប៉ុន្តែ ប្រសិនបើព្រែកមួយត្រូវបានជីកឡើងនៅត្រង់ចំណុចតូចមួយនៅអាមេរិកកណ្ដាល ការធ្វើដំណើរពីឆ្នេរខាងកើតទៅខាងលិចនឹងត្រូវកាត់បន្ថយចម្ងាយពាក់កណ្ដាល។ សហរដ្ឋអាមេរិកបានគិតអំពីគម្រោងមួយចំនួនចាប់តាំងពីដើមសតវត្សរ៍ទី 19 មកម្ល៉េះ។ នៅទសវត្សរ៍ឆ្នាំ 1880 ក្រុមហ៊ុនបារាំងមួយបានព្យាយាមនៅក្នុងការស្ថាបនាព្រែកមួយឆ្លងកាត់ប្រទេសប៉ាណាម៉ាប៉ុន្តែបរាជ័យ។ បើទោះបីជាគម្រោងនេះបរាជ័យក៏ដោយក៏ពួកអាមេរិកនៅតែរំជើបរំជួលចំពោះព្រែកនេះផងដែរ។ ហើយគ្មាននណារំជើបរំជួលជាងប្រធានាធិបតីថេអូដរ រូស្វែលត៍ឡើយ ដោយលោកបានដឹកនាំសហរដ្ឋអាមេរិកចាប់ពីឆ្នាំ 1901 ដល់ឆ្នាំ 1909។ នៅក្នុងឆ្នាំ 1903

ប៉ាណាម៉ាគឺជាខេត្តមួយរបស់ប្រទេសកូឡុំប៊ី។ លោកប្រធានាធិបតីរ៉ូស្វែលត៍បានផ្តល់ឱ្យប្រទេសនេះនូវទឹកប្រាក់ 10 លានដុល្លា បូករួមជាមួយនឹងការបង់ប្រាក់ប្រចាំឆ្នាំសម្រាប់ការទទួលបានសិទ្ធិស្ថាបនាព្រែកមួយ។ នៅពេលដែលរដ្ឋាភិបាលកូឡុំប៊ីទាមទារប្រាក់បន្ថែម សហរដ្ឋអាមេរិកបានឆ្លើយតបជាមួយនិងលើកទឹកចិត្តឱ្យមានការធ្វើបដិវត្តនៅប៉ាណាម៉ា។ ប្រជាជនប៉ាណាម៉ាបានព្យាយាមនៅក្នុងការបំបែកខ្លួនចេញពីប្រទេសកូឡុំប៊ីអស់រយៈពេលជិតមួយសតវត្សរ៍មកហើយ។ នៅក្នុងឆ្នាំ 1903 ជាមួយនិងជំនួយរបស់កងទ័ពជើងទឹករបស់សហរដ្ឋអាមេរិក ពួកគេទទួលបានជ័យជំនះនៅក្នុងការទាមទារឯករាជ្យ។ នៅក្នុងការថ្លែងអំណារគុណ ប៉ាណាម៉ាបានប្រគល់ឱ្យសហរដ្ឋអាមេរិកនូវតំបន់មួយដែលមានទំហំ 10 ម៉ាយ ដើម្បីស្ថាបនាព្រែកមួយ។ អស់រយៈពេលជាច្រើនទសវត្សរ៍ វិស្វករអាមេរិកបានតស៊ូប្រយុទ្ធជាមួយនឹងទឹកជំនន់ និងកម្តៅដើម្បីស្ថាបនាផ្លូវទឹកដ៏ធំមួយ។ ប៉ុន្តែ បញ្ហាដែលចំបងជាងគេនោះគឺសត្វល្អិតដែលផ្ទុកនូវជំងឺដែលបានគ្របដណ្តប់នៅពាសពេញតំបន់នោះ។ សហរដ្ឋអាមេរិកបានបើកយុទ្ធនាការមួយដើម្បីកំចាត់សត្វមូសដែលនាំមកនូវជំងឺគ្រុនឈាម និងគ្រុនចាញ់ និងសត្វកណ្តុរដែលបង្កឱ្យមានជម្ងឺអាសន្នរោគ។ ការព្យាយាមនៅក្នុងការគ្រប់គ្រងជំងឺនេះដោយថាហេតុទទួលបានជោគជ័យ។ បើទោះបីជាដូច្នេះក៏ដោយ កម្មកររាប់ពាន់នាក់បានស្លាប់អំឡុងពេលនៃការស្ថាបនាព្រែកនេះ។ ព្រែកប៉ាណាម៉ា ចុងក្រោយត្រូវបានបើកនៅក្នុងឆ្នាំ 1914 ។ នាវានៅជុំវិញពិភពលោកភ្លាមៗនោះបានចាប់ផ្តើមធ្វើដំណើរតាមព្រែកនេះ។ អាមេរិកឡាទីនបានក្លាយជាចំណុចប្រសព្វមួយនៃពាណិជ្ជកម្មពិភពលោក។ ហើយសហរដ្ឋអាមេរិកគឺជាអ្នកយកលុយពីការប្រើប្រាស់ព្រែកជីកមួយនេះ។

សេចក្តីប្រកាសបន្ថែមរ៉ូស្វែលត៍៖ ការស្ថាបនាព្រៃជីកប៉ាណាម៉ាគឺជាវិធីតែមួយគត់ដែលសហរដ្ឋអាមេរិកអាចពង្រីកឥទ្ធិពលរបស់ពួកគេនៅក្នុងតំបន់អាមេរិកឡាទីននៅដើមសតវត្សរ៍ទី 20 ។ វត្តមានរបស់ពួកគេនៅគុយបា និងការវិនិយោគដ៏ធំរបស់ពួកគេនៅក្នុងប្រទេសជាច្រើននៅអាមេរិកកណ្តាល និងអាមេរិកខាងត្បូងបានពង្រឹងមូលដ្ឋានរបស់ពួកគេនៅអាមេរិកឡាទីន។ ដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចទាំងនេះ នៅក្នុងឆ្នាំ 1904 ប្រធានាធិបតីបានចេញសេចក្តីប្រកាសមួយបន្ថែមក្នុងសេចក្តីប្រកាសម៉ូនរ៉េ។ សេចក្តីប្រកាសបន្ថែមរ៉ូស្វែលត៍បានផ្តល់ឱ្យសហរដ្ឋអាមេរិកនូវសិទ្ធិ កាយជាកម្លាំងប៉ូលីសអន្តជាតិមួយនៅក្នុងដែនអឌ្ឍគោលរបស់បស្ចិមប្រទេស។ សហរដ្ឋអាមេរិកបានប្រើប្រាស់សេចក្តីប្រកាសរ៉ូស្វែលត៍ បន្ថែមជាច្រើនដងនៅក្នុងឆ្នាំបន្តបន្ទាប់ដើម្បីធ្វើជាខ្នងបង្អែកនៅក្នុងអន្តរាគមន៍របស់សហរដ្ឋអាមេរិកនៅអាមេរិកឡាទីន។ កងទ័ពសហរដ្ឋអាមេរិកបានកាប់កាប់ប្រទេសមួយចំនួនអស់រយៈពេលជាច្រើនទសវត្សរ៍។ ពួកអាមេរិកឡាទីនជាច្រើនបានប្រឆាំងជាមួយនឹងការអន្តរាគមន៍នេះ ប៉ុន្តែ ពួកគេមិនមានអំណាចគ្រាប់គ្រាន់នៅក្នុងបញ្ឈប់ប្រទេសជិតខាងនៅភាគខាងជើងដ៏ធំមួយរបស់ពួកគេបានឡើយ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកតែងតែធ្វើមិនដឹងធ្វើមិនលឺចំពោះការប្រឆាំងរបស់ពួកគេ។ ប៉ុន្តែ ពួកគេមិនអាចមិនខ្វល់ខ្វាយចំពោះការធ្វើបដិវត្តដ៏ខ្លាំងក្លាមួយនៅប្រទេសម៉ិកស៊ិកកូ ដែលជាប្រទេសមួយនៅក្បែរព្រំដែនរបស់ពួកគេបានឡើយ។ អ្នកនឹងបានរៀនពីការធ្វើបដិវត្តនេះនៅក្នុងមេរៀនទី 4 ។

# មេរៀនទី 4៖ ភាពចលាចល និងការផ្លាស់ប្តូរនៅម៉ិកស៊ិកកូ

## 1. សាន់តា អានណា និងសង្គ្រាមម៉ិកស៊ិកកូ

អំឡុងសតវត្សរ៍ទី 19 មិនមានជនណាម្នាក់ដែលអាចកគ្របដណ្តប់លើនយោបាយម៉ិកស៊ិកកូច្រើនជាង លោកអេនតូនីអូ ឡូម៉េស ដេ សាន់តា អានណាឡើយ។ លោកសាន់តា អានណាបានដើរតួនាទីសំខាន់មួយនៅក្នុងការវាយប្រយុទ្ធរបស់ម៉ិកស៊ិកកូដើម្បីទាមទារឯករាជ្យពីអេស្ប៉ាញនៅក្នុងឆ្នាំ 1821។ នៅក្នុងឆ្នាំ 1829 លោកបានវាយប្រយុទ្ធជាមួយអេស្ប៉ាញម្តងទៀត ដូចដែលមហាអំណាចអឺរ៉ុបមួយនេះព្យាយាមនៅក្នុងការដណ្តើមកាន់កាប់ម៉ិកស៊ិកកូឡើងវិញ។ បន្ទាប់មកនៅក្នុងឆ្នាំ 1833 លោកសាន់តា អានណាបានក្លាយជាប្រធានាធិបតីរបស់ម៉ិកស៊ិកកូ។

មេដឹកនាំយោធាផ្តាច់ការរបស់អាមេរិកឡាទីនដែលខ្លាំងក្លាបំផុតគឺ លោកសាន់តា អានណាគឺជាអ្នកនយោបាយដ៏វៃឆ្លាតមួយរូប។ លោកនឹងគាំទ្រគោលនយោបាយមួយក្នុងរយៈពេលមួយឆ្នាំ ហើយលោកនឹងប្រឆាំងវានៅឆ្នាំបន្ទាប់ប្រសិនបើលោកគិតថាវានឹងធ្វើឱ្យបះពាល់ដល់អំណាចរបស់លោក។ គោលនយោបាយរបស់លោកហាក់ដូចជាដំណើរការបានល្អ។ រវាងឆ្នាំ 1833 ដល់ឆ្នាំ 1855 លោកសាន់តា អានណាបានក្លាយជាប្រធានាធិបតីម៉ិកស៊ិកកូ 4 ដង។ ប៉ុន្តែ លោកបានបោះបង់តួនាទីជាប្រធានាធិបតីចំនួន 2 លើក ដើម្បីទៅបម្រើការងារបន្ទន់ដោយដឹកនាំកងទ័ពម៉ិកស៊ិកកូនៅក្នុងសង្គ្រាមមួយដើម្បីដណ្តើមយកមកវិញនូវទឹកដីតិចសាស។

ការបះបោរនៅតិចសាស៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1820 ម៉ិចកស៊ិកកូបានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋអាមេរិកធ្វើការផ្លាស់ទីមកកាន់ដែនដីរបស់ម៉ិកស៊ិកកូនៅតិចសាស ដើម្បីធ្វើឱ្យមានមនុស្សរស់នៅច្រើននៅតំបន់នោះ។ ពួកអាណានិគមនិយាយភាសាអង់គ្លេសរាប់ពាន់នាក់បានឆ្លើយតបទៅនឹងការហៅនេះ។ ជាថ្នូរទៅនឹងការទទួលបានដីដែលមានតម្លៃថោក ពួកគេយល់ព្រមគោរពតាមច្បាប់របស់ម៉ិកស៊ិកកូ។ ដូចដែលក្រុមអ្នកនិយាយភាសាអង់គ្លេសបានកើនឡើង ជម្លោះបានអភិវឌ្ឍឡើងរវាងពួកអាណានិគមជាមួយនិងម៉ិកស៊ិកកូលើបញ្ហាមួយចំនួនដោយរួមមានបញ្ហារបបទាសភាព និងសាសនាជាដើម។ ជាលទ្ធផល ពួកអាណានិគមនៅតិចសាសជាច្រើនចង់បានការគ្រប់គ្រងដោយខ្លួនគេផ្ទាល់។ ប៉ុន្តែនៅពេលដែលប្រទេសម៉ិកស៊ិកកូបដិសេធនៅក្នុងការផ្តល់ឱ្យនូវអ្វីដែលពួកគេទាមទារ មេដឹកនាំពួកប្រជាជននិយាយភាសាអង់គ្លេសមួយរូបឈ្មោះស្ទេហ្វេន អូស្ទីន បានលើកទឹកចិត្តឱ្យមានការបះបោរមួយប្រឆាំងម៉ិកស៊ិកកូនៅក្នុងឆ្នាំ 1835 ។ លោកសាន់តា អានណាបានដឹកនាំកងទ័ពម៉ិកស៊ិកកូឆ្ពោះទៅកាន់ភាគខាងជើងដើម្បីបង្ក្រាបការបះបោរនេះ។ លោកបានទទួលជ័យជំនះលើសមរភូមិដំបូងៗមួយចំនួនរួមមានសមរភូមិដ៏ជូរចត់មួយនៅអាឡាម៉ូ ដែលជាបេសកម្មមួយនៅសាន់ អេនតូនីអូ។ ប៉ុន្តែ ភ័ពសំណាងរបស់លោកបានផ្លាស់ប្តូរនៅក្នុងសមរភូមិសាន់ ចាស៊ីនតូ។ កងទ័ពរបស់បានចាញ់ ហើយលោកត្រូវបានចាប់ខ្លួន។ មេដឹកនាំតិចសាសលោកសាំ ហ៊ូស្តុន បានដោះលែងលោកសាន់តា អានណាបន្ទាប់ពីលោកសន្យាថានឹងគោរពឯករាជ្យភាពរបស់តិចសាស។ នៅពេលដែលលោកសាន់តា អានណាត្រឡប់ទៅកាន់ម៉ិកស៊ិកកូនៅក្នុងឆ្នាំ 1836 ភ្លាមៗនោះលោកត្រូវបានគេដកចេញពីអំណាច។

សង្គ្រាម និងការធ្លាក់ខ្លួនរបស់សាន់តា អានណា៖ ក្រោយមក លោកសាន់តា អានណាទទួលបានអំណាចឡើងវិញ និងធ្វើការវាយប្រយុទ្ធជាមួយសហរដ្ឋអាមេរិកម្តងទៀត។ នៅក្នុងឆ្នាំ 1845 សហរដ្ឋអាមេរិកបានភ្ជាប់តិចសាសជាឧបសម្ព័ន្ធ។ ពួកម៉ិកស៊ិកកូមានកំហឹងយ៉ាងខ្លាំង និងបានចាត់ទុកថាវាគឺជាសកម្មភាពឈ្លានពានមួយ។ នៅក្នុងជម្លោះមួយដែលទាក់ទងនឹងបញ្ហាព្រំដែន សហរដ្ឋអាមេរិកបានឈ្លានពានម៉ិកស៊ិកកូ។ កងទ័ពរបស់លោកសាន់តា អានណាបានវាយប្រយុទ្ធប្រកបដោយសេចក្តីក្លាហាន ប៉ុន្តែកងទ័ពសហរដ្ឋអាមេរិកបានយកជ័យជំនះលើពួកគេបន្ទាប់ពីធ្វើសង្គ្រាមអស់រយៈពេល 2 ឆ្នាំមក។ នៅក្នុងឆ្នាំ 1848 ប្រទេសទាំងពីរនេះបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយដែលមានឈ្មោះថា សន្ធិសញ្ញាហ្គូដាលូប៉េ ហ៊ីដាលហ្គោ។ សហរដ្ឋអាមេរិកទទួលបាន 1/3 នៃដែនដីម៉ិកស៊ិកកូភាគខាងជើង ដោយក្នុងនោះរួមបញ្ចូលទាំងរដ្ឋកាលីហ្វូនៀ និងរដ្ឋមួយចំនួននៅអាមេរិកភាគនិរតី។ លោកសាន់តា អានណាត្រូវបាននិរទេសចេញពីប្រទេស។ ប៉ុន្តែ លោកបានត្រឡប់មកគ្រប់គ្រងអំណាចជាលើកចុងក្រោយវិញនៅក្នុងឆ្នាំ 1853 ។ បន្ទាប់ពីលោកធ្លាក់ខ្លួននៅក្នុងឆ្នាំ 1855 លោកបន្តរស់នៅនិរទេសអស់រយៈពេលជិត 20 ឆ្នាំ។ បន្ទាប់ពីលោកត្រឡប់មកកាន់ប្រទេសម៉ិកស៊ិកកូនៅក្នុងឆ្នាំ 1874 នៅពេលនោះលោកក្រីក្រ, ពិការភ្នែក, គ្មានអំណាច, និងមិនត្រូវបានគេចាប់អារម្មណ៍ឡើយ។

## 2. លោកជូរេស និងការធ្វើកំណែទម្រង់

អំឡុងពាក់កណ្តាលសតវត្សរ៍ទី 19 ដូចដែលអំណាចរបស់លោកសាន់តា អានណាបានរះឡើង និងធ្លាក់ចុះ អ្នកធ្វើកំណែទម្រង់សេរីនិយមមួយរូបឈ្មោះបេនីតូ ជូរេសបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាមួយលើនយោបាយម៉ិកស៊ិកកូ។ លោកជូរេសមានលក្ខណៈខុសគ្នាទាំងស្រុងពីលោកសាន់តា អានណា ទាំងសាវតា និងគោលដៅ។ លោកសាន់តា អានណាមកពីគ្រួសារក្រេអូឡេ មានទ្រព្យសម្បត្តិស្តុកស្តម្ភមួយ។ ចំណែកឯលោកជូរេស គឺជាជនជាតិហ្សាប៉ូតិច-ឥណ្ឌាដ៏ក្រីក្រម្នាក់ ដែលបានក្លាយជាកុមារកំព្រានៅពេលដែលលោកមានអាយុ 3 ឆ្នាំ។ ខណៈពេលដែលលោកសាន់តា អានណាគិតពីអំណាចផ្ទាល់ខ្លួនរបស់លោកជាសំខាន់ លោកជូរេសគិតជាចំបងទៅលើការបម្រើប្រទេសជាតិ។

លោកជូរេសឡើងគ្រប់គ្រងអំណាច៖ សាវតារបស់បុព្វការីជន និងពូជសាសន៍គឺជាធាតុដ៏សំខាន់មួយដើម្បីទទួលបានអំណាចនយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេសម៉ិកស៊ិកកូនាសតវត្សរ៍ទី 19 ។ ដោយហេតុផលនេះ ការឡើងកាន់អំណាចរបស់លោកបេនីតូ ជូរេស គឺច្បាស់ណាស់ថាដោយសារសមត្ថភាពនៃការដឹកនាំរបស់លោកផ្ទាល់។ លោកជូរេសគឺជាកសិករដាំដុះនៅលើដីស្រែតូចមួយនៅក្នុងរដ្ឋអូអាហ្សាកានៅម៉ិកស៊ិកកូ។ នៅពេលដែលលោកមានអាយុ 12 ឆ្នាំ លោកបានផ្លាស់ទីរស់នៅក្នុងទីក្រុងអូអាហ្សាកា។ លោកបានចូលសាលានៅពេលដែលលោកមានអាយុ 15 ឆ្នាំ ហើយនៅក្នុងឆ្នាំ 1829 លោកបានចូលរៀនសកលវិទ្យាល័យរបស់រដ្ឋដែលទើបតែបើកថ្មី។ លោកទទួលបានសញ្ញាបត្រផ្នែកច្បាប់នៅក្នុងឆ្នាំ 1831 ។ បន្ទាប់មកលោកត្រឡប់ទៅកាន់ទីក្រុងអូអាហ្សាកាវិញ ដែលជាទីកន្លែងលោកបានបើកការិយាល័យច្បាប់មួយ។ ភាគច្រើននៃអតិថិជនរបស់លោកគឺជាប្រជាជនក្រីក្រអ្នកដែលមិនអាចមានលទ្ធភាពនៅក្នុងការស្វែងរកជំនួយផ្នែកច្បាប់។ លោកជូរេសទទួលបានកិត្តិនាមមួយ

សម្រាប់ភាពស្មោះត្រង់, សុចរិតភាព, ការប្រឹងប្រែធ្វើការ, និងការវិនិច្ឆ័យដ៏ត្រឹមត្រូវ។ លោកត្រូវបានបោះឆ្នោតឱ្យធ្វើការនៅក្នុងស្ថាប័ននិតិបញ្ញត្តិក្នុងទីក្រុង ហើយបន្ទាប់មកចាប់ផ្តើមទទួលបានអំណាចយ៉ាងឆាប់រហ័ស។ ចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ 1847 លោកបានធ្វើការងារជាអភិបាលរដ្ឋអូអាហ្សាកា ។

លោកជូរេសធ្វើការងារដើម្បីធ្វើកំណែទម្រង់៖ នៅចន្លោះចុងទសវត្សរ៍ឆ្នាំ 1840 ដល់ដើមទសវត្សរ៍ឆ្នាំ 1850 លោកជូរេសបានចាប់ផ្តើមចលនាកំណែទម្រង់សេរីនិយមមួយ។ លោកបានហៅចលនានេះថា ការធ្វើកំណែទម្រង់។ គោលដៅសំខាន់នៃចលនានេះគឺ ការបែងចែកដីធ្លី, ការញែកចេញរវាងព្រះវិហារកាតូលិកជាមួយនិងរដ្ឋ, និងបង្កើនឱកាសសិក្សាសម្រាប់ប្រជាជនក្រីក្រ។ ប៉ុន្តែ នៅក្នុងឆ្នាំ 1853 លោក បាននិរទេសលោកជូរេសនិងមេដឹកនាំចលនាការធ្វើកំណែទម្រង់ផ្សេងៗទៀតចេញក្រៅប្រទេស។ ពីរឆ្នាំក្រោយមក ការបះបោរប្រឆាំងលោកសាន់តា អានណា មួយបានផ្តួលរំលំរដ្ឋាភិបាលរបស់លោក។ លោកជូរេសនិងមេដឹកនាំសេរីនិយមផ្សេងៗទៀតបានត្រឡប់មកកាន់ប្រទេសម៉ិកស៊ិកកូវិញដើម្បីដោះស្រាយបញ្ហាដែលញាំញីនៅក្នុងប្រទេស។ ក៏ដូចជានៅក្នុងប្រទេសអាមេរិកឡាទីនផ្សេងទៀតដែរ ម្ចាស់កម្មសិទ្ធិដីធ្លីមានទ្រព្យសម្បត្តិស្តុកស្តម្ភបន្តធ្វើឱ្យប្រជាជនម៉ិកស៊ិកកូផ្សេងៗទៀតឱ្យរស់នៅជាមួយនឹងបំណុល និងភាពក្រីក្របន្តកូនចៅ។ មេដឹកនាំសេរីនិយមលោកប៉ុនស៊ីអាណូ អារៀហ្គាបានពិព៌ណនាស្ថានការណ៍ទាំងនេះថា អាចបណ្តាលកើតមានបញ្ហាដ៏ធំមួយសម្រាប់ប្រជាជនក្រីក្រ និងរដ្ឋាភិបាល។

ដោយមិនមានការភ្ញាក់ផ្អើល គំនិតរបស់លោក និងគំនិតរបស់អ្នកសេរីនិយមផ្សេងទៀតនៅក្នុងរដ្ឋាភិបាលបានគំរាមកំហែងដល់ពួកអ្នកអភិរក្សនិយមវណ្ណៈលើ។ ពួកអភិរក្សនិយមជាច្រើនបានឆ្លើយតបតាមរយៈការបះបោរមួយប្រឆាំងជាមួយរដ្ឋាភិបាលសេរីនិយមនៅក្នុងឆ្នាំ 1858 ។ ពួកគេទទួលបានជោគជ័យនៅក្នុងប្រយុទ្ធដំបូង និងបានដណ្តើមកាន់កាប់ទីក្រុងម៉ិកស៊ិកកូ។ ពួកអ្នកសេរីនិយមបានរក្សាការវាយប្រយុទ្ធពីមូលដ្ឋានរបស់ពួកគេនៅក្នុងទីក្រុងវេរ៉ាគ្រូស។ ជាយថាហេតុ ពួកសេរីនិយមចាប់ផ្តើមមានប្រៀបជាង ហើយបន្ទាប់ពីសង្គ្រាមស៊ីវិលដ៏ជូរជត់រយៈពេល 3 ឆ្នាំមក ពួកគេបានយកជ័យជំនះលើក្រុមបះបោរ។ នៅក្នុងឆ្នាំ 1861 បន្ទាប់ពីជាប់ឆ្នោត លោក ជូរេសបានក្លាយជាប្រធានាធិបតីនៃប្រទេសម៉ិកស៊ិកកូ។

បារាំងឈ្លានពានប្រទេសម៉ិកស៊ិកកូ៖ ការបញ្ចប់នៃសង្គ្រាមស៊ីវិលមិនបានធ្វើឱ្យបញ្ហានៅក្នុងប្រទេសម៉ិកស៊ិកកូបញ្ចប់ឡើយ។ ពួកអ្នកអភិរក្សដែលនិរទេសខ្លួនមួយចំនួនបានរៀបចំគម្រោងក្បត់ជាមួយពួកអឺរ៉ុបដើម្បីដណ្តើមម៉ិកស៊ិកកូសារជាថ្មី។ នៅក្នុងឆ្នាំ 1862 មេដឹកនាំបារាំងស្តេចណាប៉ូឡេអុងទី 3 ឆ្លើយតបតាមរយៈការបញ្ជូនកងទ័ពជើងទឹកដ៏ធំមួយទៅកាន់ប្រទេសម៉ិកស៊ិកកូ។ នៅក្នុងរយៈពេល 18 ខែ បារាំងបានដណ្តើមកាន់កាប់ប្រទេសនេះ។ ស្តេចណាប៉ូឡេអុងទី 3 បានតែងតាំងលោកអូសគ្រៀន អាចឌូកេ ម៉ាស៊ីមីលៀន ជាអធិរាជដើម្បីដឹកនាំប្រទេសម៉ិកស៊ិកកូ។ លោកជូរេស និងប្រជាជនម៉ិកស៊ិកកូផ្សេងៗទៀតបានវាយប្រយុទ្ធជាមួយការដឹកនាំរបស់បារាំង។ បន្ទាប់ពីស្ថិតនៅក្រោមការឡោមព័ទ្ធ បារាំងបានគិតថា ការធ្វើសង្គ្រាមជាមួយពួកម៉ិកស៊ិកកូត្រូវចំណាយច្រើន។ នៅក្នុងឆ្នាំ 1867 ស្តេចណាប៉ូឡេអុងទី 3 បានបញ្ជាឱ្យកងទ័ពជើងទឹកបារាំងដកចេញពីប្រទេសម៉ិកស៊ិកកូ។ អធិរាជម៉ាស៊ីមីលៀន ត្រូវបានចាប់ខ្លួន និងប្រហារជីវិត។ លោកជូរេសបានជាប់ឆ្នោតធ្វើជា

ប្រធានាធិបតីសារជាថ្មីម្តងទៀតនៅក្នុងឆ្នាំ 1867 ។ លោកបានត្រឡប់ទៅធ្វើកំណែទម្រង់ដែលលោកបានស្នើឡើងកាលពីជាង 10 ឆ្នាំមុន។ លោកចាប់ផ្តើមស្ថាបនាប្រទេសឡើងវិញ ដែលត្រូវបានខ្ទេចខ្ទីដោយសារសង្គ្រាម។ លោកបានលើកកម្ពស់ពាណិជ្ជកម្មជាមួយបរទេស តាមរយៈការស្ថាបនាផ្លូវថ្នល់ថ្មី, ផ្លូវរថភ្លើង, និងបង្កើតសេវាកម្មទូរសារ។ លោកបានបង្កើតប្រព័ន្ធអប់រំជាតិមួយដែលដាច់ដោយឡែកពីប្រព័ន្ធរបស់ព្រះវិហារកាតូលិក។ នៅក្នុងឆ្នាំ 1871 លោកជូរេសបានទទួលមរណៈភាពដោយសារជំងឺគាំបេះដូង។ ប៉ុន្តែ បន្ទាប់ពីប្រទេសម៉ិកស៊ិកកូឆ្លងកាត់នូវសង្គ្រាមស៊ីវិល និងភាពចលាចលអស់រយៈពេលកន្លះសតវត្សរ៍មក លោកជូរេសបានបន្សល់ទុកនូវកេរ្តិ៍ដំណែលមួយដែលទាក់ទងជាមួយសន្តិភាព, ភាពជឿនលឿន, និងកំណែទម្រង់សម្រាប់ប្រទេសរបស់លោក។

### 3. លោកប៉ូហ្វីរីអូ ដៃហ្ស "សណ្តាប់ធ្នាប់ និងភាពជឿនលឿន"

យុគសម័យនៃការធ្វើកំណែទម្រង់របស់លោកជូរេសមិនមានរយៈពេលយូរឡើយ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1870 មេដឹកនាំយោធាផ្តាច់ការថ្មីឈ្មោះប៉ូហ្វីរីអូ ដៃហ្សបានឡើងកាន់អំណាច។ ក៏ដូចជាលោកជូរេសដែល លោកដៃហ្សគឺជាជនជាតិឥណ្ឌាមកពីរដ្ឋអូអាហ្សាកា។ លោកទទួលបានអំណាចតាមរយៈកងទ័ព ហើយលោកបានក្លាយជាឧត្តមសេនីយល្បីល្បាញមួយរូបនៅអំឡុងសង្គ្រាមស៊ីវិល និងបានវាយប្រយុទ្ធជាមួយបារាំង។ លោកដៃហ្ស រំពឹងថានឹងទទួលបានតំណែងមួយនៅក្នុងជួររដ្ឋាភិបាលសម្រាប់ការដើរតួនាទីដ៏សំខាន់របស់លោកក្នុងការយកជ័យជំនះលើបារាំង។ ប៉ុន្តែ លោកជូរេសបានបដិសេធទៅនឹងសំណើររបស់លោក។ បន្ទាប់ពីនោះមកលោកដៃហ្សបានប្រឆាំងជាមួយលោកជូរេស។ នៅក្នុងឆ្នាំ 1867 លោកដៃហ្សទទួលបានអំណាចត្រួតត្រាប្រទេសម៉ិកស៊ិកកូតាមរយៈការទម្លាក់ប្រធានាធិបតីចេញពីអំណាច។ លោកទទួលបានការគាំទ្រពីយោធា, ដែលត្រូវបានកាត់បន្ថយអំណាចនៅអំឡុងពេលនៃការគ្រប់គ្រងរបស់លោកជូរេស។ ពួកជនជាតិឥណ្ឌា និងម្ចាស់កម្មសិទ្ធិដីធ្លីតូចៗក៏គាំទ្រលោកផងដែរ ដោយសារតែពួកគេគិតថាលោកដៃហ្សនឹងធ្វើកំណែទម្រង់ដីធ្លីកាន់តែខ្លាំងក្លាជាងនេះ។ អំឡុងពេលនៃការគ្រប់គ្រងរបស់ ការបោះឆ្នោតគ្មានន័យអ្វីឡើយ។ លោកដៃហ្សបានប្រគល់ដី, អំណាច, ឬនយោបាយដល់អ្នកទាំងឡាយណាដែលគាំទ្រលោក។ លោកបានទុក្ខបុកម្នេញលើជនទាំងឡាយណាដែលមិនគាំទ្រលោកតាមរយៈការបញ្ជាឱ្យគេវាយដំ ឬចាប់ដាក់គុក។ ដោយប្រើប្រាស់នូវវិធីសាស្រ្តបែបហិង្សា លោកដៃហ្សអាចបន្តអំណាចបានរហូតដល់ឆ្នាំ 1911 ។ អស់រយៈពេលជាច្រើនឆ្នាំ លោកដៃហ្សបានប្រើប្រាស់នូវពាក្យស្លោកនយោបាយមួយដែលស្នើឱ្យប្រជាជនរួបរួមគ្នាដែលត្រូវបានបង្កើតឡើងនៅក្នុងយុគសម័យជូរេស។ លោកជូរេសបានស្នើឱ្យមាន "សេរីភាព, សណ្តាប់ធ្នាប់, និងភាពជឿនលឿន"។ ប៉ុន្តែ លោក ចង់បានតែ "សណ្តាប់ធ្នាប់ និងភាពជឿនលឿន"។ ការប្រើប្រាស់អំណាចផ្តាច់ការរបស់លោកដៃហ្សគឺដើម្បីធានាដល់សណ្តាប់ធ្នាប់នៅក្នុងប្រទេសម៉ិកស៊ិកកូ។ ប៉ុន្តែ ស្ថិតក្រោមការដឹកនាំរបស់លោកដៃហ្សប្រទេសនេះក៏មានភាពជឿនលឿនផងដែរ។ ផ្លូវរថភ្លើងត្រូវបានពង្រីក, ធនាគារត្រូវបានស្ថាបនា, រូបិយវត្ថុមានស្ថេរភាព, ហើយការវិនិយោគបរទេសមានការកើនឡើង។ ប្រទេសម៉ិកស៊ិកកូមើលទៅហាក់ដូចជាប្រទេសដែលមានស្ថេរភាព និងជឿនលឿនមួយ។ ប៉ុន្តែ រូបរាងសំបកក្រៅគ្រាន់តែជាការបោកបញ្ឆោតប៉ុណ្ណោះ។ ពួកអ្នកមានកាន់កាប់ដីកាន់តែច្រើនទៅច្រើនទៅ ដែលពួកគេមិនបានប្រើ

ប្រាស់ដីធ្លីទាំងនោះឱ្យបានល្អឡើយ។ ជាលទ្ធផល តម្លៃចំណីអាហារបានកើនឡើងយ៉ាងខ្លាំង។ ប្រជាជនម៉ិកស៊ិកកូភាគច្រើននៅតែជាកសិករ និងកម្មករក្រីក្រ ហើយពួកគេកាន់ក្រទៅៗ។

## 4. ការធ្វើបដិវត្ត និងសង្គ្រាមស៊ីវិល

នៅដើមសតវត្សរ៍ទី 20 ប្រជាជនម៉ិកស៊ិកកូមកពីស្រទាប់គ្រប់វណ្ណៈទាំងអស់ចាប់ផ្តើមធ្វើការតវ៉ាប្រឆាំងជាមួយនឹងការដឹកនាំដ៏ឃោឃៅរបស់លោកដៃហ្ស។ ក្រុមអ្នកគំនិតសេរីនិយមស្រេកឃ្លានសេរីភាពរបស់ពួកគេ។ អ្នកស្រែចំការស្រេកឃ្លានដីធ្លីរបស់ពួកគេ។ កម្មករស្រេកឃ្លានប្រាក់ម៉ោងសមរម្យ និងស្ថានភាពការងារល្អប្រសើរ។ សូម្បីតែសម្ព័ន្ធមិត្តនយោបាយមួយចំនួនរបស់លោកដៃហ្សក៏បានស្នើឱ្យមានការធ្វើកំណែទម្រង់ផងដែរ។ គណបក្សនយោបាយជាច្រើនដែលប្រឆាំងជាមួយលោកដៃហ្សបានចាប់ផ្តើមបង្កើតឡើង។ ក្នុងចំណោមគណបក្សនយោបាយទាំងនោះ មានគណបក្សនយោបាយមួយដែលដឹកនាំដោយលោកហ្វង់ស៊ីស្កូ ម៉ាដេរ៉ូ មានអំណាចខ្លាំងជាងគេ។

លោកម៉ាដេរ៉ូចាប់ផ្តើមការធ្វើបដិវត្ត៖ កើតនៅក្នុងគ្រួសារដែលមានជាងគេលំដាប់ទី 10 នៅក្នុងប្រទេសម៉ិកស៊ិកកូ លោកហ្វង់ស៊ីស្កូ ម៉ាដេរ៉ូបានសិក្សានៅសហរដ្ឋអាមេរិក និងប្រទេសបារាំង។ លោកជឿជាក់លើលទ្ធិប្រជាធិបតេយ្យ និងចង់ពង្រឹងលទ្ធិនេះនៅក្នុងប្រទេសម៉ិកស៊ិកកូ។ លោកម៉ាដេរ៉ូបានប្រកាសធ្វើជាបក្ខភាពប្រធានាធិបតីម៉ិកស៊ិកកូនៅដើមឆ្នាំ 1910 ។ ភ្លាមៗនោះ លោកដៃហ្សបានចាប់ខ្លួនលោក។ ពីសហរដ្ឋអាមេរិកដែលជាទីកន្លែងដែលលោកត្រូវបាននិរទេស លោកម៉ាដេរ៉ូបានស្នើឱ្យមានការធ្វើបដិវត្តប្រដាប់អាវុធមួយប្រឆាំងជាមួយលោកដៃហ្ស។ ការធ្វើបដិវត្តរបស់ប្រជាជនម៉ិកស៊ិកកូចាប់ផ្តើមឡើងដោយយឺតៗ។ មេដឹកនាំលេចចេញឡើងពីតំបន់ផ្សេងៗនៅក្នុងប្រទេសម៉ិកស៊ិកកូ និងប្រមូលផ្តុំកងទ័ពផ្ទាល់ខ្លួនរបស់ពួកគេ។ នៅភាគខាងជើង លោកហ្វ៉ង់ស៊ីស្កូ ប៉ាន់ឆូ វីឡា មានប្រជាប្រិយភាពយ៉ាងខ្លាំង។ លោកមានគោលនយោបាយដូច រ៉ូប៊ីនហ៊ូត គឺយកលុយពីអ្នកមានជួយដល់អ្នកក្រ។ ស្ថិតនៅម៉ិចស៊ិចកូភាគខាងត្បូង មានមេដឹកនាំខ្លាំងក្លា និងមានប្រជាប្រិយភាពមួយរូបផ្សេងទៀតគឺលោកអេមីលៀណូ ហ្សាប៉ាតាបានបង្កើតកងទ័ពបដិវត្តដ៏ខ្លាំងក្លាមួយ។ ក៏ដូចជាលោកវីឡាដែរ លោកហ្សាប៉ាតាចេញមកពីគ្រួសារក្រីក្រមួយ។ លោកចង់ឃើញដីធ្លីត្រូវបានប្រគល់ត្រឡប់ទៅឱ្យប្រជាកសិករ និងអ្នកស្រែចំការវិញ។ លោកចង់ធ្វើមានការធ្វើកំណែទម្រង់ច្បាប់ដើម្បីការពារសិទ្ធិរបស់ពួកគេ។ "ដីធ្លី និងសេរីភាព" គឺជាពាក្យដែលលោកប្រកាសក្នុងសមរភូមិ។ លោកវីឡា, លោកហ្សាប៉ាតា, និងកងទ័ពបដិវត្តផ្សេងៗទៀតបានទទួលជ័យជំនះដ៏សំខាន់មួយលើកងទ័ពរបស់លោកដៃហ្ស។ ត្រឹមរដូវរំហើយឆ្នាំ 1911 លោកដៃហ្សបានយល់ព្រមនៅក្នុងការចុះចេញពីតំណែង។ លោកបានស្នើឱ្យមានការបោះឆ្នោតថ្មីមួយ។

មេដឹកនាំម៉ិកស៊ិកកូប្រយុទ្ធគ្នាដើម្បីអំណាច៖ លោកម៉ាដេរ៉ូ បានបោះឆ្នោតជាប់ជាប្រធានាធិបតីនៅក្នុងខែវិច្ឆិកា ឆ្នាំ 1911 ។ ប៉ុន្តែ អ្នកមួយចំនួនយល់ថាគោលនយោបាយរបស់លោកហាក់ដូចជាសេរីពេក និងអ្នកមួយចំនួនទៀតយល់ថាមិនទាន់មានការធ្វើបដិវត្តគ្រប់គ្រាន់នៅឡើយ។ អ្នកមួយចំនួនដែលធ្លាប់គាំទ្រលោកម៉ាដេរ៉ូដោយរួមមានទាំងលោកវីឡា និងលោកហ្សាប៉ាតា បានដឹកនាំកងទ័ពប្រឆាំងជាមួយលោក។ នៅក្នុងឆ្នាំ 1913 ដោយដឹងច្បាស់ថាលោកនឹងមិនអាចកាន់កាប់អំណាចបានទៀតលោកម៉ាដេរ៉ូបានលាលែងពីតំណែង។ មេដឹកនាំ

យោធាមួយរូប លោកឧត្តមសេនីយ៍វិចតូរីអាណូ ហ៊ូអឺតាពេលនោះឡើងធ្វើជាប្រធានាធិបតី។ ភ្លាមៗបន្ទាប់ពីនោះមក លោកម៉ាដេរ៉ូត្រូវបានគេលួចធ្វើឃាត ប្រហែលជាការបញ្ជារបស់លោកហ៊ូអឺតា។ លោកហ៊ូអឺតាមិនសូវមានប្រជាប្រិយភាពក្នុងចំណោមប្រជាជនម៉ិកស៊ិកកូឡើយ ក្នុងនោះរួមមានទាំងលោកវីឡា និងលោកហ្សាប៉ាតាផងដែរ។ មេដឹកនាំបដិវត្តទាំងអស់ចង់ចងសម្ព័ន្ធមិត្តជាមួយនិងលោកវេនូស្តៀណូ ការ៉ាន់ហ្សាដែលជាអ្នកនយោបាយមួយរូបដែលចង់ទម្លាក់លោកហ៊ូអឺតា។ កងទ័ពរបស់មេដឹកនាំទាំង 3 មានប្រៀប និងបានដណ្តើមកាន់កាប់តំបន់ជនបទពីកងកម្លាំងរបស់លោកហ៊ូអឺតា និងបានធ្វើដំណើរឆ្ពោះមកកាន់រដ្ឋធានីទីក្រុងម៉ិកស៊ិកកូ។ ពួកគេចំណាយពេលត្រឹមតែ 15 ខែ ប៉ុណ្ណោះដើម្បីទម្លាក់លោកហ៊ូអឺតាបន្ទាប់ពីលោកឡើងកាន់អំណាច។ លោកការ៉ាន់ហ្សា បានគ្រប់គ្រងរដ្ឋាភិបាល ហើយបន្ទាប់មកបានបង្វែរកងទ័ពរបស់លោកប្រយុទ្ធជាមួយអតីតសម្ព័ន្ធមិត្តបដិវត្តរបស់លោកវិញ។ ទាំងលោកវីឡា និងហ្សាប៉ាតាបន្តវាយប្រយុទ្ធ។ ប៉ុន្តែ នៅក្នុងឆ្នាំ 1919 លោកការ៉ាន់ហ្សាបានបញ្ឆោតលោកហ្សាប៉ាតាឱ្យចូលក្នុងអន្ទាក់មួយ និងបានសម្លាប់លោក។ ជាមួយនិងការស្លាប់របស់លោកហ្សាប៉ាតាសង្គ្រាមស៊ីវិលក៏បានដល់ទីបញ្ចប់។ មានប្រជាជនម៉ិកស៊ិកកូជាងមួយលាននាក់បានបាត់បង់ជីវិតអំឡុងសង្គ្រាមស៊ីវិលនេះ។

ធម្មនុញ្ញថ្មីរបស់ម៉ិកស៊ីកកូ៖ លោកការ៉ាន់ហ្សាបានចាប់ផ្តើមធ្វើការពិនិត្យធម្មនុញ្ញម៉ិកស៊ិកកូឡើងវិញ។ ធម្មនុញ្ញនេះត្រូវបានអនុម័តនៅក្នុងឆ្នាំ 1917 ។ វាគឺជាឯកសារធ្វើកំណែទម្រង់មួយ ហើយធម្មនុញ្ញនេះនៅបន្តប្រើប្រាស់រៀងរហូតមក ។ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ ធម្មនុញ្ញនេះបានលើកកម្ពស់វិស័យអប់រំ, ធ្វើកំណែទម្រង់ដីធ្លី, និងផ្តល់សិទ្ធិដល់កម្មករ។ ប៉ុន្តែ លោកមិនបានគាំទ្រដល់ពង្រាងចុងក្រោយនៃធម្មនុញ្ញនេះឡើយ ហើយនៅក្នុងឆ្នាំ 1920 លោកត្រូវបានទម្លាក់ចេញពីតំណែងដោយឧត្តមសេនីយ៍មួយរូបរបស់លោកឈ្មោះអាល់វ៉ារ៉ូ អូប្រេហ្គូន។

បើទោះបីជាលោកអូប្រេហ្គូនដណ្តើមអំណាចដោយហិង្សាក៏ដោយ ក៏លោកមិនបានបន្តដឹកនាំបែបផ្តាច់ការតទៅទៀតឡើយ។ ផ្ទុយទៅវិញ លោកគាំទ្រការធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ ជាពិសេសស្នើឱ្យមានការធ្វើកំណែទម្រង់ដីធ្លី។ លោកក៏បានលើកកម្ពស់ការអប់រំសាធារណៈផងដែរ។ សាលារដ្ឋរបស់ម៉ិចស៊ិចកូបានបង្រៀនភាសារួមមួយគឺភាសា អេស្ប៉ាញ និងសង្កត់ធ្ងន់ទៅលើគំនិតជាតិនិយម។ នៅក្នុងវិធីនេះ គោលនយោបាយរបស់លោកបានជួយបង្រួបបង្រួមសាសនា និងប្រជាជននៅក្នុងប្រទេស។ យ៉ាងណាក៏ដោយលោកអូប្រេហ្គូនត្រូវបានគេលួចធ្វើឃាតនៅក្នុងឆ្នាំ 1928 ។ មួយឆ្នាំក្រោយមក គណបក្សនយោបាយថ្មីមួយឡើងគ្រប់គ្រងអំណាច គឺគណបក្សបដិវត្តស្ថាប័ន។ បើទោះបីជាគណបក្សនេះមិនយោគយល់ដល់អ្នកប្រឆាំងក៏ដោយ ក៏គណបក្សនេះបានបង្កើតឱ្យមានសម័យកាលសន្តិភាព និងស្ថេរភាពនយោបាយនៅក្នុងប្រទេសម៉ិកស៊ិកកូផងដែរ។ ប៉ុន្តែ ខណៈពេលដែលប្រទេសម៉ិកស៊ិកកូកំពុងតស៊ូដើម្បីសន្តិភាព ពិភពលោកកំពុងស្ថិតនៅមាត់ច្រកនៃសង្គ្រាម។

# ជំពូក 28 ៖ សង្គ្រាមលោក 1914-1918

## មេរៀនទី 1 ៖ ដំណើរឆ្ពោះទៅរកសង្គ្រាម

### 1. ការលេចឡើងនៃជម្លោះនៅអឺរ៉ុប

ខណៈពេលដែលសន្តិភាព និងសុខដុមបានលេចឡើងនៅពាលពេញអឺរ៉ុបនៅដើមទសវត្សរ៍ឆ្នាំ 1900 ក៏ដោយ ក៏មានភាពស្រពិចស្រពិល និងអួរអាប់បានលេចឡើងដំណាលគ្នាផងដែរ។ នៅពីក្រោយរូបភាពនៃសន្តិភាព និងមិត្តភាព អឺរ៉ុបជួបប្រទះទៅនិងការអភិវឌ្ឍបន្តិចម្តងៗ ដែលចុងក្រោយបានរុញច្រានទ្វីបនេះទៅរកសង្គ្រាម។

ការលេចឡើងនៃគំនិតជាតិនិយម៖ មួយក្នុងចំណោមការអភិវឌ្ឍមួយដែលបានលេចឡើងនៅអឺរ៉ុបនោះគឺការកើនឡើងនៃគំនិតជាតិនិយម ឬការពលីដ៏ខ្លាំងក្លាមួយរបស់នណារម្នាក់ចំពោះប្រទេសជាតិរបស់គេ។ គំនិតជាតិនិយមអាចដើរតួនាទីជាកម្លាំងជម្រុញឱ្យមានការបង្រួបបង្រួមនៅក្នុងប្រទេសមួយ។ ប៉ុន្តែ វាក៏បណ្តាលឱ្យមានការប្រគួតប្រជែងគ្នាដ៏ខ្លាំងក្លាមួយក្នុងចំណោមប្រទេសនានាផងដែរ ដែលប្រទេសជាតិមួយមានបំណងចង់គ្រប់សង្កត់លើប្រទេសមួយផ្សេងទៀត។ ត្រឹមដើមសតវត្សរ៍ទី 20 ការប្រគួតប្រជែងគ្នាដ៏សាហាវមួយមានអភិវឌ្ឍឡើងក្នុងចំណោមមហាអំណាចនានានៅអឺរ៉ុប។ ប្រទេសទាំងនោះរួមមាន ប្រទេសអាឡឺម៉ង់, អូទ្រីស-ហុងគ្រី, ចក្រភពអង់គ្លេស, រុស្ស៊ី, អ៊ីតាលី, និងបារាំង។

ការកើនឡើងនៃការប្រគួតប្រជែងក្នុងចំណោមពួកអឺរ៉ុបនេះ កើតឡើងដោយសារមូលហេតុជាច្រើន។ ការប្រគួតប្រជែងដើម្បីវត្ថុធាតុដើម និងទីផ្សារគឺជាមូលហេតុមួយ ។ ចំណែកឯជម្លោះដែនដីគឺជាបញ្ហាមួយទៀត។ ឧទាហរណ៍ បារាំងមិនដែលបំភ្លេចការបាត់បង់ទឹកដីអាល់សាល-ឡូរ៉ែនទៅប្រទេសអាឡឺម៉ង់ នៅក្នុងសង្គ្រាមបារាំង-ព្រូសឆ្នាំ 1870 ។ ប្រទេសអូទ្រីស-ហុងគ្រី និងប្រទេសរុស្ស៊ីបានប្រជែងគ្នានៅក្នុងការគ្រប់គ្រងតំបន់បាល់កង់ ដែលជាតំបន់មួយស្ថិតនៅភាគអាគ្នេយ៍អឺរ៉ុប។ នៅក្នុងតំបន់បាល់កង់គំនិតជាតិនិយមខ្លាំងក្លារបស់ពួកស៊ែប, ប៊ុលហ្គារី, រូម៉ានី, និងក្រុមជនជាតិផ្សេងៗទៀតបាននាំទៅដល់ការទាមទារឯករាជ្យ។

ចក្រពត្តិនិយម និងយោធានិយម៖ កម្លាំងមួយទៀតដែលជួយជម្រុញឱ្យកើតមានសង្គ្រាមនៅអឺរ៉ុបគឺចក្រពត្តិនិយម។ នៅក្នុងជំពូក 26 បានពន្យល់ពីការប្រកួតប្រជែងរបស់ពួកអឺរ៉ុបយ៉ាងខ្លាំងក្លាក្នុងការដណ្តើមដែនដីអាណានិគមនៅទ្វីបអាហ្វ្រិក និងអាស៊ី។ ការដណ្តើមដែនដីអាណានិគមពេលខ្លះបានរុញច្រានឱ្យប្រទេសអឺរ៉ុបនានាធ្វើសង្គ្រាមជាមួយគ្នា។ ដូចដែលប្រទេសនានាអឺរ៉ុបបន្តប្រកួតប្រជែងគ្នាដើម្បីពង្រីកដែនដីចក្រភពរបស់ពួកគេ គំនិតនៃការប្រជែង និងការមិនទុកចិត្តគ្នាក្នុងចំណោមពួកគេកាន់តែមានខ្លាំងឡើង។

មានការអភិវឌ្ឍគួរឱ្យព្រួយបារម្ភមួយផ្សេងទៀតនៅដើមសតវត្សទី 20 គឺការប្រកួតប្រជែងផ្នែកយោធាដ៏មានគ្រោះថ្នាក់មួយរបស់ពួកអឺរ៉ុប។ ប្រទេសនានានៅអឺរ៉ុប ជឿថាដើម្បីមានអំណាចពិប្រាកដ ពួកគេត្រូវមានវិស័យយោធាដ៏ខ្លាំងក្លាមួយ។ ត្រឹមឆ្នាំ 1914 មហាអំណាចទាំងអស់នៅអឺរ៉ុប លើកលែងតែចក្រភពអង់គ្លេសចាប់ផ្តើមមានយោធាក្នុងចំនួនដ៏ច្រើនមួយ។ ជាមួយគ្នានេះផងដែរ អ្នកជំនាញការយោធា បានបង្ហាញពីសារៈសំខាន់នៃការ

ប្រមូលកម្លាំងបានឆាប់រហ័ស ឬការរៀបចំ និងចល័តកងទ័ពក្នុងករណីមានសង្គ្រាមកើតឡើង។ ឧត្តមសេនីយ៍នៅក្នុងប្រទេសនីមួយៗបានអភិវឌ្ឍគម្រោងការលម្អិតមួយសម្រាប់ធ្វើការប្រមូលផ្តុំកងទ័ព។

គោលនយោបាយនៅក្នុងការពង្រីកអំណាចយោធា និងដាក់ឱ្យកងទ័ពប្រុងប្រៀបដើម្បីធ្វើសង្គ្រាមត្រូវបានគេស្គាល់ថា យោធានិយម។ ការមានកងទ័ពដែលមានចំនួនច្រើន និងខ្លាំងក្លាមួយ ធ្វើឱ្យប្រជាពលរដ្ឋមានអារម្មណ៍ថាជាការស្នេហាមាតុភូមិ។ ប៉ុន្តែ វាក៏ធ្វើឱ្យមនុស្សមួយចំនួនមានការភ័យខ្លាចផងដែរ។

## 2. សម្ព័ន្ធមិត្តដ៏ស្មុគស្មាញ

ការកើនឡើងនៃការប្រកួតប្រជែងគ្នា និងការមិនទុកចិត្តគ្នាទៅវិញទៅមកបាននាំទៅដល់ការបង្កើតឡើងនៃសម្ព័ន្ធមិត្តយោធាក្នុងចំណោមមហាអំណាចនានានៅដើមទសវត្សរ៍ឆ្នាំ 1870 ។ ប្រព័ន្ធសម្ព័ន្ធមិត្តនេះត្រូវបានបង្កើតឡើងដើម្បីរក្សាសន្តិភាពនៃអឺរ៉ុប។ ប៉ុន្តែ ផ្ទុយទៅវិញវាបានជួយរុញច្រានទ្វីបឱ្យកើតមានសង្គ្រាមទៅវិញ។

ប៊ីស្មាក់ត្រួសត្រាយឱ្យមានកតិកាសញ្ញាដំបូង៖ រវាងឆ្នាំ 1864 ដល់ឆ្នាំ 1871 អធិការបតីឈាម-និង-ដែករបស់ព្រូស ឈ្មោះអូតតូ វុន ប៊ីស្មាក់បានប្រើប្រាស់សង្គ្រាមដើម្បីបង្រួបបង្រួមប្រទេសអាឡឺម៉ង់បានយ៉ាងងាយ។ ប៉ុន្តែនៅក្នុងឆ្នាំ 1871 ប៊ីស្មាក់បានប្រកាសថា អាឡឺម៉ង់នឹងជា "មហាអំណាចពេញលេញ" មួយ។ ហើយពេលនោះលោកនឹងប្រើប្រាស់អំណាចរបស់លោកដើម្បីរក្សាសន្តិភាពនៅអឺរ៉ុប។

លោកប៊ីស្មាក់បានមើលឃើញប្រទេសបារាំងថាជាការគំរាមកំហែងដល់សន្តិភាព។ លោកជឿថាបារាំងនៅតែចង់សងសឹកអាឡឺម៉ង់សម្រាប់ការបរាជ័យរបស់ពួកគេនៅក្នុងសង្គ្រាមបារាំង-ព្រូស។ ដូច្នេះ គោលបំណងទី 1 របស់លោកប៊ីស្មាក់គឺធ្វើឱ្យប្រទេសបារាំងឯកោរ។ លោកប៊ីស្មាក់បានថ្លែងថា "នៅពេលដែលពួកគេគ្មានសម្ព័ន្ធមិត្តប្រទេសបារាំងនឹងមិនមានគ្រោះថ្នាក់សម្រាប់យើងឡើង"។ នៅក្នុងឆ្នាំ 1879 លោកប៊ីស្មាក់បានបង្កើតសម្ព័ន្ធមិត្តទ្វេភាគីរវាងប្រទេសអាឡឺម៉ង់ និងប្រទេសអូទ្រីស-ហុងគ្រី។ បីឆ្នាំក្រោយមក ប្រទេសអ៊ីតាលីបានចូលរួមជាមួយប្រទេសទាំងពីរនេះដែរ ដោយបង្កើតបានជាសម្ព័ន្ធមិត្តត្រីភាគី។ នៅក្នុងឆ្នាំ 1881 លោកប៊ីស្មាក់បានចុះសន្ធិសញ្ញាមួយជាមួយប្រទេសរុស្ស៊ី ដែលពេលនោះអាឡឺម៉ង់គិតថាប្រទេសរុស្ស៊ីអាចក្លាយជាសម្ព័ន្ធមិត្តរបស់បារាំង។

ការផ្លាស់ប្តូរសម្ព័ន្ធមិត្តបានគំរាមកំហែងដល់សន្តិភាព៖ នៅក្នុងឆ្នាំ 1890 គោលនយោបាយកាលបរទេសរបស់ប្រទេសអាឡឺម៉ង់បានផ្លាស់ប្តូរគួរឱ្យគត់សំគាល់។ នៅក្នុងឆ្នាំនោះ លោកខៃស័រ វីលហេមទី 2 ដែលបានក្លាយជាមេដឹកនាំអាឡឺម៉ង់នៅក្នុងឆ្នាំ 1888 បានបង្ខំឱ្យលោកប៊ីស្មាក់លាលែងពីតំណែង។ លោកខៃស័រ វីលហេមទី 2 ដែលជាមនុស្សមានអំនួត និងមានៈ មិនចង់ចែករំលែងអំណាចជាមួយនណាឡើយ។ ក្រៅតែពីចង់ក្តោបយកអំណាចផ្ទាល់ខ្លួន មេដឹកនាំថ្មីរូបនេះចង់បង្ហាញឱ្យពិភពលោកឃើញថា ប្រទេសអាឡឺម៉ង់ខ្លាំងពូកែប៉ុណ្ណា។ លោកមានភាពក្រអឺតក្រទមដោយលោកកងទ័ពរបស់លោក។ លោកវីលហេមបានប្រកាសភ្លាមៗបន្ទាប់ពីលោកឡើងកាន់អំណាចថា "ខ្ញុំ និងកងទ័ពគឺកើតឡើងជាមួយគ្នា"។

លោកវីលហេមបានបញ្ចប់សន្ធិសញ្ញាជាមួយប្រទេសរុស្ស៊ីនៅក្នុងឆ្នាំ 1890 ។ រុស្ស៊ីឆ្លើយតបតាមរយៈការបង្កើតសម្ព័ន្ធមិត្តយោធាមួយជាមួយប្រទេសបារាំងនៅក្នុងឆ្នាំ 1892 និង 1894 ។ សម្ព័ន្ធមិត្តនេះហើយដែលលោកប៊ីស្មាក់ធ្លាប់មានការភ័យខ្លាច។ ក្នុងចំណោមប្រទេសបារាំង និងប្រទេសរុស្ស៊ី ទោះបីអាឡឺម៉ង់ធ្វើសង្គ្រាមជាមួយប្រទេសមួយក៏ដោយ គឺស្មើនឹងអាឡឺម៉ង់ធ្វើសង្គ្រាមជាមួយប្រទេសទាំងពីរនេះ។ ប្រទេសអាឡឺម៉ង់នឹងធ្វើសង្គ្រាមលើសមរភូមិពីរក្នុងពេលតែមួយ ឬធ្វើសង្គ្រាមទាំងនៅព្រំដែនភាគខាងកើតផង និងភាគខាងលិចផង។

បន្ទាប់មក លោកប៊ីស្មាក់ចាប់ផ្ដើមបង្កើតគម្រោងស្ថាបនានាវាដ៏ធំមួយដើម្បីធ្វើឱ្យកងទ័ពជើងទឹកអាឡឺម៉ង់មានកម្លាំងស្មើទៅនឹងកងទ័ពជើងទឹកដ៏ខ្លាំងក្លារបស់ចក្រភពអង់គ្លេស។ ដោយការគំរាមកំហែង ចក្រភពអង់គ្លេសបានបង្កើតកិច្ចព្រមព្រៀងមួយជាមួយបារាំង។ នៅក្នុងឆ្នាំ 1907 អង់គ្លេសបានបង្កើតកិច្ចព្រមព្រៀងទាំងជាមួយប្រទេសបារាំង និងប្រទេសរុស្ស៊ី។ កិច្ចព្រមព្រៀងនេះត្រូវបានគេហៅថា កិច្ចព្រមព្រៀងត្រីភាគី ។ កិច្ចព្រមព្រៀងនេះមិនបានរារាំងអង់គ្លេសនៅក្នុងការវាយប្រយុទ្ធជាមួយបារាំង និងរុស្ស៊ីឡើយ។ ប៉ុន្តែ កិច្ចព្រមព្រៀងនេះបានធានាស្ទើរតែ 100% ថា អង់គ្លេសនឹងមិនវាយប្រហារប្រឆាំងជាមួយនឹងពួកគេឡើយ។

ត្រឹមឆ្នាំ 1907 មានគូរសត្រូវពីរក្រុមបានលេចឡើងនៅអឺរ៉ុប។ ភាគីម្ខាងគឺសម្ព័ន្ធត្រីភាគីដែលមានប្រទេសអាឡឺម៉ង់, ប្រទេសអូទ្រីស-ហុងគ្រី, និងប្រទេសអ៊ីតាលី។ ចំណែកភាគីម្ខាងទៀតគឺ កិច្ចព្រមព្រៀងត្រីភាគី ដែលមានចក្រភពអង់គ្លេស, ប្រទេសបារាំង, និងប្រទេសរុស្ស៊ី។ ជម្លោះណាមួយរវាងគូរសត្រូវមហាអំណាចទាំងពីរក្រុមអាចនាំឱ្យប្រទេសទាំងឡាយនៅអឺរ៉ុបធ្លាក់ក្នុងសង្គ្រាម។

## 3. វិបត្តិនៅតំបន់បាល់កង់

គ្មានកន្លែងណាដែលអាចនឹងកើតមានជម្លោះច្រើនជាងនៅឧបទ្វីបបាល់កង់ឡើង។ ឧបទ្វីបដែលសម្បូរទៅដោយភ្នំនៅអឺរ៉ុបភាគអាគ្នេយ៍នេះ គឺជាទីលំនៅរបស់ក្រុមជនជាតិផ្សេងៗគ្នាជាច្រើនក្រុម។ ជាមួយនិងប្រវត្តិយូរអង្វែងនៃការបះបោររបស់អ្នកជាតិនិយម និងការបះទង្គិចគ្នារវាងក្រុមជនជាតិនានា តំបន់បាល់កងត្រូវបានគេស្គាល់ថាជា "កំប៉ុងម្សៅ" របស់អឺរ៉ុប។

តំបន់មួយដែលគ្មានភាពកក់ក្ដៅ៖ ត្រឹមដើមទសវត្សរ៍ឆ្នាំ 1900 ចក្រភពអូតូម៉ង់ ដែលរួមបញ្ចូលទាំងតំបន់បាល់កង់ផងនោះ បានធ្លាក់ចុះយ៉ាងឆាប់រហ័ស។ នៅខណៈពេលដែលក្រុមមួយចំនួននៅតំបន់បាល់កង់ ធ្វើការប្រយុទ្ធតស៊ូដើម្បីទាមទារឯករាជ្យពីចក្រភពអូតូម៉ង់របស់ពួកទួក មានក្រុមមួយចំនួនទៀតបានទទួលជោគជ័យនៅក្នុងការបំបែកខ្លួនចេញពីការគ្រប់គ្រងរបស់ពួកទួក។ ក្រុមមនុស្សទាំងនោះបានបង្កើតប្រទេសថ្មី ដោយរួមមានបុលហ្គារី, ក្រិក, ម៉ុងតេនេក្រូ, រ៉ូម៉ានី, និងស៊ែប៊ី។

ជាតិនិយមគឺជាកម្លាំងដ៏មានឥទ្ធិពលមួយនៅក្នុងប្រទេសទាំងនេះ។ ក្រុមនីមួយៗមានបំណងចង់ពង្រីកដែនដីរបស់ពួកគេ។ ឧទាហរណ៍ ប្រទេសស៊ែប៊ីដែលមានជនជាតិស្លាវរស់នៅយ៉ាងច្រើនពួកគេប្រាថ្នាចង់កាន់កាប់ដែនដីរបស់ក្រុមស្លាវទាំងអស់នៅឧបទ្វីបបាល់កង់។ ប្រទេសរុស្ស៊ី ដែលជាប្រទេសមួយដែលសម្បូរទៅដោយជនជាតិស្លាវដែរនោះ បានគាំទ្រគំនិតជាតិនិយមរបស់ពួកស៊ែប៊ីនេះ។ ប៉ុន្តែ ប្រទេសជិតខាងដ៏ខ្លាំងក្លាមួយរបស់ស៊ែប៊ី

គឺប្រទេសអូទ្រីស-ហុងគ្រី ប្រឆាំងទៅនឹងការប៉ុនប៉ង់នេះ។ ពួកអូទ្រីសមានការព្រួយបារម្ភថា ការព្យាយាមនៅក្នុងការបង្កើតរដ្ឋរបស់ពួកស្លាវមួយ និងនាំឱ្យមានការបះបោរក្នុងចំណោមពួកជនជាតិស្លាវដែលរស់នៅក្នុងទឹកដីអូទ្រី-ហុងគ្រី។

នៅក្នុងឆ្នាំ 1908 ប្រទេសអូទ្រីបានភ្ជាប់តំបន់ បូស្នៀ និងហឺហ្សេហ្គូវីណាទៅក្នុងដែនដីរបស់ខ្លួន។ តំបន់ទាំងពីរនេះស្ថិតនៅនៅឧបទ្វីបបាល់កង់ដែលមានប្រជាជនស្លាវរស់នៅច្រើន។ មេដឹកនាំស៊ែប៊ី ដែលមានបំណងចង់គ្រប់គ្រងតំបន់ទាំងពីរនេះដែរ មានកំហឹងជាខ្លាំង។ មួយឆ្នាំក្លាយមក ជម្លោះរវាងស៊ែប៊ី និងអូទ្រីសបានកើតឡើងយ៉ាងខ្លាំងក្លា។ ស៊ែប៊ីនៅតែបន្តអះអាងថាខ្លួននឹងដណ្តើមយកតំបន់បូស្នៀ និងហឺហ្សេហ្គូវីណាពីអូទ្រីស។ នៅក្នុងការឆ្លើយតប អូទ្រី-ហុងគ្រីបានអះអាងថានឹងវាយកម្ទេចរាល់ការប៉ុនប៉ង់ណាមួយរបស់ស៊ែប៊ីក្នុងការដណ្តើមកាន់កាប់តំបន់នានានៅបាល់កង់ ដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន។

ស្នូកាំភ្លើងបន្លឺឡើងពាសពេញអឺរ៉ុប៖ ស្ថិតនៅក្នុងបរិយាកាសនៃការមិនចូលចិត្ត និងការមិនទុកចិត្តគ្នាទៅវិញទៅមកនេះ រាជទាយាតអូទ្រីស-ហុងគ្រីព្រះនាមអាចឌុកេ ហ្វ្រង់ ហ្វ័រឌីណង់ និងមហេសីព្រះនាមសូហ្វីបានឡើងគ្រងរាជ្យ។ នៅថ្ងៃ 28 ខែមិថុនា ឆ្នាំ 1914 ក្សត្រទាំងពីរព្រះអង្គបានធ្វើដំណើរទស្សនៈកិច្ចផ្លូវរដ្ឋទៅកាន់សារ៉ាចេវ៉ូ ដែលជារាជធានីរបស់ប៊ូស្នៀ។ វាគឺជាដំណើរទស្សនៈចុងក្រោយរបស់ទ្រង់ទាំងពីរ។ ក្សត្រទាំងពីព្រះអង្គត្រូវបានខ្មាន់កាំភ្លើងបាញ់ នៅអំឡុងពេលដែលទ្រង់ទាំងពីរបានធ្វើដំណើរតាមរយៈរថយន្តបើកដំបូលមួយតាមផ្លូវនៅសារ៉ាចេវ៉ូ។ ខ្មាន់កាំភ្លើងនោះឈ្មោះហ្គាវ្រីឡូ ប្រ៊ីនសីប មានអាយុ 19 ឆ្នាំ ដែលជាជនជាតិស៊ែប៊ី និងជាសមាជិកក្រុមដៃខ្មៅ។ ក្រុមដៃខ្មៅ គឺជាក្រុមសង្គមងងឹតមួយដែលធ្វើសកម្មភាពដើម្បីកម្ចាត់ពួកអូទ្រីសចេញពីប៊ូស្នៀ។

ដោយសារតែអ្នកធ្វើឃាតគឺជាជនជាតិស៊ែប៊ី ពួកអូទ្រីសបានសម្រេចចិត្តនៅក្នុងការប្រើប្រាស់ការឃាតកម្មនេះធ្វើជាហេតុផលសម្រាប់ដាក់ទណ្ឌកម្មស៊ែប៊ី។ នៅថ្ងៃទី 23 ខែកក្កដា អូទ្រីសបានដាក់ឱសានវាទមួយដល់ស៊ែប៊ីដោយភ្ជាប់ជាមួយនឹងការទាមទារមួយចំនួន។ ស៊ែប៊ីបានដឹងច្បាស់ថា ការបដិសេធទៅនឹងឱសានវាទនេះ នឹងនាំទៅដល់ការផ្ទុះឡើងនៃសង្គ្រាមជាមួយមហាអំណាចអូទ្រីស។ ដូច្នេះ ស៊ែប៊ី បានយល់ព្រមស្ទើតែរាល់ការទាមទាររបស់អូទ្រីស។ ពួកគេបានរៀបចំឱ្យមានការចរចាផ្សះផ្សានានា តាមរយៈសន្និសិទអន្តរជាតិមួយផងដែរ។

ប៉ុន្តែ អូទ្រីស មិនមានចំណាប់អារម្មណ៍នៅក្នុងការចរចាឡើយ។ មេដឹកនាំប្រទេសនេះ ហាក់ដូចជាសម្រេចចិត្តនៅក្នុងការធ្វើសង្គ្រាមរួចទៅហើយ។ នៅថ្ងៃទី 28 ខែកក្កដា អូទ្រីសបានបដិសេធការផ្តល់ឱ្យរបស់ស៊ែប៊ី និងបានប្រកាសសង្គ្រាម។ នៅក្នុងថ្ងៃជាមួយគ្នានោះ ប្រទេសរុស្ស៊ី ដែលជាសម្ព័ន្ធមិត្តរបស់ស៊ែប៊ី ជាមួយនឹងប្រជាជនស្លាវដ៏ច្រើនរបស់ពួកគេបានធ្វើសកម្មភាព។ មេដឹកនាំរុស្ស៊ីបានបញ្ជាឱ្យមានការចល័តកងទ័ពទៅកាន់តំបន់ព្រំដែនអូទ្រីស។

មេដឹកនាំទាំងឡាយនៅអឺរ៉ុបភ្លាមៗនោះចាប់ផ្តើមប្រុងប្រៀបខ្លួន។ ស្ថេរភាពដ៏ផុយស្រួយនៅអឺរ៉ុបមើលទៅហាក់ដូចជាធ្លាក់ចូលទៅក្នុងជម្លោះប្រដាប់អាវុធ។ រដ្ឋមន្ត្រីការបរទេសអង់គ្លេស, រដ្ឋាភិបាលអ៊ីតាលី, និងសូម្បីតែ

លោកខៃស័រ វីលហេមខ្លួនលោកផ្ទាល់បានស្នើឱ្យប្រទេសអូទ្រីស និងរុស្ស៊ីធ្វើការចរចារគ្នា។ ប៉ុន្តែវាយឺតពេលទៅហើយ។ ម៉ាស៊ីនសង្គ្រាមត្រូវបានបញ្ឆេះរួចទៅហើយ។

# មេរៀនទី 2 ៖ អឺរ៉ុបលិចលង់ដោយសង្គ្រាម

## 1. សង្គ្រាមលោកចាប់ផ្តើម

ក្នុងការឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់ប្រទេសអូទ្រីស ប្រទេសរុស្ស៊ីដែលជាសម្ព័ន្ធមិត្តរបស់ប្រទេសស៊ែប៊ី បានចល័តកងទ័ពរបស់ពួកគេឆ្ពោះទៅកាន់ព្រំដែនរុស្ស៊ី-អូទ្រីស។ ដោយគិតថាប្រទេសអាល្លឺម៉ង់នឹងចូលរួមជាមួយប្រទេសអូទ្រីស ប្រទេសរុស្ស៊ីក៏បានចល័តកងទ័ពទៅពង្រាយតាមព្រំដែនអាល្លឺម៉ង់ផងដែរ។ សម្រាប់ប្រទេសអាល្លឺម៉ង់ ការចល័តកងទ័ពរបស់ប្រទេសរុស្ស៊ីគឺស្មើនឹងការប្រកាសសង្គ្រាមមួយ។ នៅថ្ងៃទី 1 ខែសីហា រដ្ឋាភិបាលអាល្លឺម៉ង់បានប្រកាសសង្គ្រាមជាមួយប្រទេសរុស្ស៊ី។

ប្រទេសរុស្ស៊ីបានសម្លឹងទៅរកការជួយពីសម្ព័ន្ធមិត្តរបស់ពួកគេ គឺប្រទេសបារាំង។ ប៉ុន្តែ ប្រទេសអាល្លឺម៉ង់មិនបានរងចាំរហូតទល់តែមានប្រតិកម្មពីប្រទេសបារាំងឡើយ។ ពីរថ្ងៃបន្ទាប់ពីប្រកាសសង្គ្រាមជាមួយប្រទេសរុស្ស៊ី ប្រទេសអាល្លឺម៉ង់ក៏ប្រកាសសង្គ្រាមជាមួយប្រទេសបារាំងផងដែរ។ ភ្លាមៗបន្ទាប់ពីការប្រកាសរបស់អាល្លឺម៉ង់ ចក្រភពអង់គ្លេសក៏បានប្រកាសសង្គ្រាមជាមួយប្រទេសអាល្លឺម៉ង់ផងដែរ។ ពេលនោះ ប្រទេសភាគច្រើនចាប់ផ្តើមត្រៀមខ្លួនចូលទៅក្នុងសមរភូមិ។

ភាគីដែលចូលរួមក្នុងសង្គ្រាម៖ ត្រឹមពាក់កណ្តាលខែសីហា ឆ្នាំ 1914 ព្រំដែនសង្គ្រាមត្រូវបានគូសឡើងយ៉ាងច្បាស់។ ភាគីម្ខាងរួមមាន ប្រទេសអាល្លឺម៉ង់ និងអូទ្រីស-ហុងគ្រី។ ភាគីនេះត្រូវបានគេស្គាល់ថាមហាអំណាចកណ្តាល ដោយសារតែទីតាំងរបស់ភាគីនេះមានទីតាំងស្ថិតនៅកណ្តាលទ្វីបអឺរ៉ុប។ ប្រទេសប៊ុលហ្គារី និងចក្រភពអូតូម៉ង់ ក្រោយមកបានចូលរួមជាមួយមហាអំណាចកណ្តាលដោយសង្ឃឹមថាពួកគេនឹងអាចទទួលបានមកវិញនូវទឹកដីដែលបាត់បង់។

ភាគីម្ខាងទៀតរួមមានចក្រភពអង់គ្លេស, បារាំង, និងរុស្ស៊ី។ ប្រទេសទាំង 3 នេះត្រូវបានគេស្គាល់ថា មហាអំណាចសម្ព័ន្ធ ឬក្រុមសម្ព័ន្ធមិត្ត។ ប៉ុន្មានសប្តាហ៍ក្រោយមក ប្រទេសជប៉ុនបានចូលរួមជាមួយក្រុមសម្ព័ន្ធមិត្ត។ ក្រោយមកអ៊ីតាលីក៏បានចូលរួមជាមួយពួកគេ។ ប្រទេសអ៊ីតាលីគឺជាសមាជិកមួយនៅក្នុងសម្ព័ន្ធមិត្តត្រីភាគីជាមួយប្រទេសអាល្លឺម៉ង់ និងអូទ្រីស-ហុងគ្រី។ ប៉ុន្តែ ប្រទេសអ៊ីតាលីបានចូលរួមជាមួយភាគីម្ខាងទៀត បន្ទាប់ពីបានចោទប្រកាន់អតីតសម្ព័ន្ធមិត្តរបស់ពួកគេថាបានប្រកាសសង្គ្រាមដោយមិនត្រឹមត្រូវ។

នៅចុងរដូវក្តៅ ឆ្នាំ 1914 កងទ័ពរាប់លាននាក់បានធ្វើដំណើរទាំងសប្បាយចិត្តចូលទៅក្នុងសមរភូមិ ដោយពួកគេគិតថាសង្គ្រាមនឹងរយៈពេលខ្លីប៉ុណ្ណោះ។ មានមនុស្សតិចតួចប៉ុណ្ណោះដែលមើលឃើញពីគ្រោះអាក្រក់នៅពេលខាងមុខ។ អ្នកដែលមើលឃើញច្បាស់ជាងគេគឺរដ្ឋមន្ត្រីការបរទេសអង់គ្លេស លោកអេដវ៉ាត គ្រី ។ ដោយថ្លែងចេញពីទីក្រុងឡុងដ៍ទាំងយប់ លោកគ្រីបាននិយាយទាំងស្រពាប់ស្រពោនទៅកាន់មិត្តម្នាក់ថា "ពន្លឺបានចាកចេញពីអឺរ៉ុបទាំងមូល។ យើងនឹងមិនបានឃើញវាទៀតឡើងនៅក្នុងជាតិនេះ"។

## 2. សង្គ្រាមដ៏បង្ហូរឈាមមួយចាប់ផ្ដើមនៅទ្រឹង

គេមិនចាំបាច់ចំណាយពេលច្រើនឡើយ ក្នុងការមើលឃើញពីភាពត្រឹមត្រូវនៃការទស្សន៍ទាយរបស់លោក អេដវ៉ាត គ្រី ឡើយ។ ដូចដែលរដូវក្ដៅឆ្នាំ 1914 បានបញ្ចប់ សង្គ្រាមបានចាប់ផ្ដើមប្រែក្លាយទៅរកសង្គ្រាមរយៈពេលយូរ និងចាប់ផ្ដើមនៅទ្រឹងមួយកន្លែងតាមបណ្ដាយសមរភូមិនៅបារាំង។ តំបន់ជាប់គាំនេះស្ថិតនៅភាគខាងជើងប្រទេសបារាំង ដែលត្រូវបានគេស្គាល់ថា សមរភូមិខាងលិច។

ការបះទង្គិចគ្នាបានចាប់ផ្ដើម៖ ប្រឈមទៅនឹងសង្គ្រាមមួយដែលមានសមរភូមិពីរ អាឡឺម៉ង់បានអភិវឌ្ឍយុទ្ធសាស្ត្រសង្គ្រាមមួយដែលគេស្គាល់ថាផែនការស្លីហ្វេន ដែលដាក់ឈ្មោះតាមអ្នករចនាយុទ្ធសាស្ត្រនេះគឺឧត្ដមសេនីយ៍អាលហ្វ្រេដ ក្រាហ្វ វ៉ុន ស្លីហ្វេន ។ គម្រោងបានស្នើឱ្យមានការវាយប្រហារ និងយកជ័យជំនះលើប្រទេសបារាំងនៅភាគខាងលិច ហើយបន្ទាប់មកប្រញាប់ប្រញាល់ធ្វើដំណើរទៅខាងកើតដើម្បីប្រយុទ្ធជាមួយប្រទេសរុស្ស៊ី។ ប្រទេសអាឡឺម៉ង់គិតថាពួកគេអាចអនុវត្តគម្រោងការនេះបានដោយសារ ប្រព័ន្ធផ្លូវរថភ្លើងប្រទេសរុស្ស៊ីមិនមានភាពជឿនលឿនដូចប្រទេសអឺរ៉ុបផ្សេងៗឡើយ ដូច្នេះពួកគេត្រូវចំណាយពេលច្រើនក្នុងការដឹកជញ្ជូលសម្ភារៈទៅផ្គត់ផ្គង់ក្នុងសមរភូមិ។ ដូច្នេះ ល្បឿនគឺជាចំណុចសំខាន់នៅក្នុងផែនការស្លីហ្វេន។ មេដឹកនាំអាឡឺម៉ង់បានដឹងថាពួកគេត្រូវការជ័យជំនះយ៉ាងឆាប់រហ័សមួយលើប្រទេសបារាំង។

នៅដើមដំបូង វាហាក់ដូចជាប្រទេសអាឡឺម៉ង់អាចធ្វើបានតាមផែនការ។ ត្រឹមដើមខែកញ្ញា កងកម្លាំងរបស់អាឡឺម៉ង់បានវាយសម្រុកចូលក្នុងប្រទេសបារាំង និងបានធ្វើដំណើរទៅដល់ជាយក្រុងប៉ារីស។ ជ័យជំនះដ៏ធំរបស់អាឡឺម៉ង់នេះហាក់ដូចជាមានរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ។ ប៉ុន្តែ នៅថ្ងៃទី 5 ខែកញ្ញា ពួកសម្ព័ន្ធមិត្តបានប្រមូលផ្ដុំគ្នា និងធ្វើការវាយប្រហារលើអាឡឺម៉ង់នៅភាគឦសាននៃទីក្រុងប៉ារីស ដែលស្ថិតនៅតាមជ្រលងទន្លេម៉ានេ។ កងទ័ពមានទាំងប៉ុន្មានត្រូវបានបញ្ជូលទៅកាន់សមរភូមិនេះ។ នៅពេលដែលត្រូវការជំនួយបន្ថែម មានរថយន្តក្រុងជាង 600 បានដឹកកងទ័ពពីក្នុងទីក្រុងប៉ារីសទៅកាន់សមរភូមិ។

បន្ទាប់ពីការវាយប្រយុទ្ធគ្នាអស់រយៈពេល 4 ថ្ងៃ ឧត្ដមសេនីយ៍អាឡឺម៉ង់បានបញ្ជាឱ្យកងទ័ពដកថយ។ បើទោះបីវាគឺជាការបះទង្គិចគ្នាលើកដំបូងតែម្ដងគត់នៅសមភូមិខាងលិចក៏ដោយ ក៏សមរភូមិដំបូងនៅម៉ានេ ប្រហែលជាព្រឹត្តិការណ៍ដែលសំខាន់ជាងគេនៅក្នុងសង្គ្រាមនេះ។ ការបរាជ័យនៃកងទ័ពអាឡឺម៉ង់បានធ្វើឱ្យផែនការស្លីហ្វេនត្រូវរលាយ។ ការយកជ័យជំនះនៅភាគខាងលិចឱ្យបានឆាប់រហ័សមើលទៅហាក់ដូចជាមិនអាចទៅរួចឡើយ។ នៅភាគខាងកើត កងទ័ពរបស់រុស្ស៊ីបានចាប់ផ្ដើមធ្វើការឈ្លានពានប្រទេសអាឡឺម៉ង់។ ប្រទេសអាឡឺម៉ង់ត្រូវវាយប្រយុទ្ធក្នុងសមរភូមិពីរក្នុងពេលតែមួយ។ ដោយយល់ច្បាស់ពីរឿងនេះ មេបញ្ជាការជាន់ខ្ពស់របស់អាឡឺម៉ង់បានបញ្ជូនកងទ័ពរាប់ពាន់នាក់ពីប្រទេសបារាំង ដើម្បីទៅជួយដល់កងទ័ពនៅភាគខាងកើត។ នៅខណៈពេលនោះ សង្គ្រាមនៅសមរភូមិខាងលិចបានស្ថិតនៅជាប់ទ្រឹងមួយកន្លែង។

សង្គ្រាមនៅក្នុងលេណដ្ឋាន៖ ត្រឹមដើមឆ្នាំ 1915 កងទ័ពទាំងសងខាងនៅសមរភូមិខាងលិចបានជីកលេណដ្ឋានរាប់ម៉ាយដើម្បីការពារខ្លួនពីការវាយប្រហាររបស់សត្រូវ។ ការជីកនេះបានបង្កើតឱ្យមានអ្វីមួយដែលគេ

ហៅថា សង្គ្រាមលេណដ្ឋាន។ នៅក្នុងសង្គ្រាមប្រភេទនេះ កងទ័ពវាយប្រយុទ្ធគ្នាទៅវិញទៅមកពីក្នុងលេណដ្ឋាន។ ហើយកងទ័ពត្រូវបាត់បង់ជីវិតជាច្រើនដើម្បីជាថ្នូរទៅនឹងដណ្តើមកាន់កាប់ទឹកដីបន្តិចបន្តួច។

ជីវិតរស់នៅក្នុងលេណដ្ឋានគឺពិតជាមានភាពវេទនាខ្លាំងណាស់។ "កងទ័ពដេកនៅលើភក់, មុជទឹកភក់, ញ៉ាំនៅលើភក់, និងយល់សុបិនឃើញភក់" នេះគឺជាការសរសេររបស់កងទ័ពមួយរូប។ លេណដ្ឋានពោពេញទៅដោយសត្វកណ្តុរ។ មិនមានចំណីអាហារស្រស់ៗឡើយ។ ស្ទើតែមិនមានពេលកេងឡើយ។

ជន្លោះរវាងលេណដ្ឋានគូបដិបក្សទាំងពីរត្រូវបានគេដាក់ឈ្មោះថា "ដីគ្មានមនុស្ស"។ នៅពេលដែលមេបញ្ជាការបញ្ជាឱ្យមានការវាយប្រយុទ្ធ កងទ័ពចេញពីក្នុងលេណដ្ឋាន ឡើងទៅលើដីវាល។ នៅលើដីវាបនេះ ពួកគេតែងតែពើបប្រទះទៅនឹងគ្រាប់កាំភ្លើងស្វ័យប្រវត្តិជុំទិស។ ប៉ុន្តែ ការស្ថិតនៅក្នុងលេណដ្ឋានក៏មិនបានធានាដល់សុវត្ថិភាពរបស់កងទ័ពឡើយ។ គ្រាប់កាំភ្លើងធំក៏ត្រូវបានបាញ់ផ្លោងចូលក្នុងលេណដ្ឋានផងដែរ។ ទាហានបារាំងមួយរូបបានសរសេរថា "គ្រាប់កាំភ្លើងធំគ្រាប់ប្រភេទទាំងអស់បានផ្លោងចូលលេណដ្ឋានរបស់យើង" ។ "លេណដ្ឋានបានបាត់រូបរាង ដីបានចាក់លុប...មិនមានខ្យល់សម្រាប់ដកដង្ហើមឡើយ។ កងទ័ពរបស់យើងមួយចំនួនខ្លះងងឹតភ្នែក, ខ្លះរងរបួស, ខ្លះវាលូន, ខ្លះស្រែកឈឺ បានដេកដួលមកលើយើងជាបន្តបន្ទាប់ និងអ្នកមួយចំនួនទៀតបានស្លាប់ដោយសាចឈាមមកលើយើង។ វាគឺជាការរស់នៅក្នុងឋាននរក"។

សមរភូមិខាងលិចបានក្លាយជា "តំបន់មរណៈ" មួយ។ វាបានលាទសន្ធឹងចម្ងាយជិត 500 ម៉ាយចាប់ពីសមុទ្រខាងជើងមកដល់ព្រំដែនប្រទេសស្វីស។ មន្ត្រីអង់គ្លេសមួយរូបបានពិពណ៌នានៅក្នុងសំបុត្រមួយថា៖ ឧស្ម័ន, រថក្រោះ, កាំភ្លើងធំ មិនបានធ្វើឱ្យសង្គ្រាមបញ្ចប់យ៉ាងឆាប់រហ័សដូចដែលពួកគេរំពឹងនោះឡើយ។ បច្ចេកវិទ្យាថ្មីទាំងអស់នេះមិនអាចសម្លាប់មនុស្សក្នុងចំនួនច្រើនបានដោយមានប្រសិទ្ធភាពឡើយ។

ការកាប់សម្លាប់បានឈានដល់កម្រិតកំពូលមួយនៅក្នុងឆ្នាំ 1916 ។ នៅក្នុងខែកុម្ភៈ អាឡឺម៉ង់បានបើការវាយប្រហារទ្រង់ទ្រាយធំមួយប្រឆាំងជាមួយបារាំងនៅជិតវ៉ឺដុន។ ភាគីទាំងសងខាងបានបាត់បង់កងទ័ពរបស់ខ្លួនជាង 30 ម៉ឺននាក់។ នៅក្នុងខែកក្កដា កងទ័ពអង់គ្លេសបានព្យាយាមនៅក្នុងធ្វើឱ្យស្ថានការណ៍នៅក្នុងប្រទេសបារាំងបានធូស្រាល។ កងទ័ពអង់គ្លេសបានវាយប្រហារពួកអាឡឺម៉ង់នៅភាគពាយ័ព្យវ៉ឺដុននៅតាមជ្រលងទន្លេ សមមេ។ នៅក្នុងថ្ងៃដំបូងនៃការប្រយុទ្ធគ្នា កងទ័ពអង់គ្លេសជាង 2 ម៉ឺននាក់ត្រូវបានសម្លាប់។ នៅពេលដែលសមរភូមិនៅសមមេបានបញ្ចប់នៅក្នុងខែវិច្ឆិកា កងទ័ពរបស់ភាគីទាំងសងខាងបានស្លាប់ និងរបួសជាងកន្លះលាននាក់រៀងៗខ្លួន។

តើភាគីទាំងសងខាងទទួលបានអ្វីនៅពេលនោះ? នៅជិតវ៉ឺដុនកងទ័ពអាឡឺម៉ង់បានរុលទៅមុខបានចម្ងាយប្រហែល 4 ម៉ាយ។ នៅជ្រលងសមមេអង់គ្លេសបានរុលទៅមុខបានចម្ងាយប្រមាណ 5 ម៉ាយ។

### 3. ការប្រយុទ្ធគ្នានៅសមរភូមិខាងកើត

បើទោះបីជាសង្គ្រាមនៅសមរភូមិខាងលិចបានទាញយកជីវិតមនុស្សអស់រាប់ពាន់នាក់ក៏ដោយ ក៏ភាគីទាំងសងខាងបានបញ្ជូនកងទ័ពរាប់លាននាក់បន្ថែមទៀត ទៅវាយប្រយុទ្ធគ្នានៅសមរភូមិខាងកើត។ តំបន់នេះគឺ

ជាសមរភូមិដែលលាទសន្ធឹងតាមបណ្ដោយព្រំដែនអាឡឺម៉ង់ និងរុស្ស៊ី។ នៅក្នុងសមរភូមិនេះ កងទ័ពរុស្ស៊ី និងស៊ែប៊ី បានវាយប្រយុទ្ធជាមួយកងទ័ពអាឡឺម៉ង់ និងអូទ្រីស-ហុងគ្រី។ សមរភូមិនៅភាគខាងកើតគឺជាសង្គ្រាមដែលមានការរំកិលលឿនជាងសង្គ្រាមនៅភាគខាងលិច។ ប៉ុន្តែ ការកាប់សម្លាប់ និងការជាប់ទ្រឹងមានលក្ខណៈដូចគ្នាជាមួយភាគខាងលិច។

ការប្រយុទ្ធគ្នាដំបូង៖ នៅដើមដំបូងនៃសង្គ្រាម កងកម្លាំងរបស់រុស្ស៊ីបានបើកការវាយប្រយុទ្ធទៅលើទាំងអូទ្រីស និងអាឡឺម៉ង់។ នៅចុងខែសីហា អាឡឺម៉ង់បានវាយបកវិញនៅតំបន់មួយជិតទីប្រជុំជនតាននេនបឺក។ អំឡុងនៃការប្រយុទ្ធគ្នារយៈពេល 4 ថ្ងៃ អាឡឺម៉ង់បានវាយកម្ទេចកងទ័ពលុកលុយរុស្ស៊ី និងបានបណ្ដេញពួកគេឱ្យចេញពីទឹកដីរបស់អាឡឺម៉ង់។ មានកងទ័ពរុស្ស៊ីចំនួនប្រមាណ 3 ម៉ឺននាក់ត្រូវបានសម្លាប់។

រុស្ស៊ីអាចវាយប្រយុទ្ធប្រឆាំងជាមួយអូទ្រីសបានល្អជាង។ កងទ័ពរុស្ស៊ីបានយកជ័យជំនះលើកងទ័ពអូទ្រីសចំនួនពីរលើនៅក្នុងខែកញ្ញា ឆ្នាំ 1914 ដោយបានធ្វើដំណើរចូលជ្រៅទៅក្នុងប្រទេសនេះ។ រហូតដល់ខែធ្នូ ទើបកងទ័ពអូទ្រីសអាចវាយបកវិញបាន។ អូទ្រីសបានយកជ័យជំនះលើរុស្ស៊ី និងជាយថាហេតុបានរុញច្រើនពួកគេឱ្យចាកចេញពីអូទ្រីស-ហុងគ្រី។

ការតស៊ូរបស់រុស្ស៊ី៖ ត្រឹមឆ្នាំ 1916 ការតស៊ូប្រយុទ្ធរបស់រុស្ស៊ីនៅក្នុងសង្គ្រាមនេះស្ទើរតែដួលរលំ។ ខុសពីប្រទេសនានានៅអឺរ៉ុបខាងលិច ប្រទេសរុស្ស៊ីមិនទាន់ក្លាយជាប្រទេសឧស្សាហកម្មនៅឡើយ។ ជាលទ្ធផល កងទ័ពរុស្ស៊ីនៅតែបន្តខ្វះស្បៀង, កាំភ្លើង, អាវុធយុទ្ធភ័ណ្ឌ, សំលៀកបំពាក់, ស្បែកជើង, និងភួយ។ ជាងនេះទៅទៀត ពួកសម្ព័ន្ធមិត្តអាចដឹកជំនួយមកកាន់ប្រទេសរុស្ស៊ីបានតិចតួចបំផុត ដោយសារពេលនោះអាឡឺម៉ង់បានត្រួតត្រាលើកសមុទ្របាល់ទិក រួមជាមួយយុទ្ធនាការឥតឈប់ឈរនៃកងនាវាមុជទឹករបស់អាឡឺម៉ង់នៅសមុទ្រខាងជើង និងតំបន់ផ្សេងៗទៀត។ នៅភាគខាងត្បូង អូតូម៉ង់បន្តត្រួតត្រាច្រកដែលភ្ជាប់សមុទ្រមេឌីទែរ៉ាណេទៅកាន់សមុទ្រខ្មៅ។

កងទ័ពរុស្ស៊ីមានតែគុណសម្បត្តិមួយគត់គឺ បរិមាណ។ នៅក្នុងសង្គ្រាម កងទ័ពរុស្ស៊ីបានទទួលបរាជ័យនៅក្នុងសមរភូមិជាច្រើន។ ប៉ុន្តែកងទ័ពរុស្ស៊ីនៅតែបន្តស្ដាបនាឡើងវិញនូវសមត្ថភាពរបស់ពួកគេ។ ក្នុងរយៈពេលជាង 3 ឆ្នាំ កងទ័ពរុស្ស៊ីអាចទប់ទល់ជាមួយកងទ័ពអាឡឺម៉ង់រាប់សែននាក់នៅភាគខាងកើត។ ជាលទ្ធផល អាឡឺម៉ង់មិនអាចបញ្ជូនកងទ័ពរបស់ពួកគេទាំងអស់ទៅប្រយុទ្ធនៅភាគខាងលិចបានឡើយ។ ប៉ុន្តែ អាឡឺម៉ង់ និងសម្ព័ន្ធមិត្តរបស់គេមិនត្រឹមតែជាប់ទាក់ទងជាមួយសមរភូមិខាងកើត និងខាងលិចឡើយ។ ដូចដែលសង្គ្រាមបានផ្ទុះឡើង ការប្រយុទ្ធគ្នាបានរីករាលដាលទៅដល់អាហ្វ្រិក ក៏ដូចជាអាស៊ីនិរតី និងអាស៊ីអាគ្នេយ៍ផងដែរ។ នៅប៉ុន្មានឆ្នាំក្រោយពេលសង្គ្រាមចាប់ផ្ដើម ជម្លោះដ៏ធំនៅក្នុងតំបន់អឺរ៉ុបនេះបានក្លាយជាសង្គ្រាមលោកមួយ។

# មេរៀនទី 3 ៖ ជម្លោះជាសកលមួយ

## 1. សង្គ្រាមជះឥទ្ធិពលដល់ពិភពលោក

ដូចដែលសង្គ្រាមបន្តផ្ទុះឡើង ក្រុមអ្នកប្រយុទ្ធសំខាន់ៗបានស្វែងរកវិធីមួយដើម្បីបញ្ចប់ភាពនៅជាប់ទ្រឹងនៃសង្គ្រាម។ ប៉ុន្តែ មិនមានក្រុមសម្ព័ន្ធមិត្ត ឬការប្រយុទ្ធមួយណាដែលអាចបញ្ចប់សង្គ្រាមយឺតៗ និងគ្មានទីបញ្ចប់នេះបានទេ។

យុទ្ធនាការហ្គាលលីប៉ូលី៖ យុទ្ធសាស្ត្រដ៏ជោគជ័យមួយរបស់ក្រុមសម្ព័ន្ធគឺការវាយប្រហារតំបន់មួយនៅក្នុងចក្រភពអូតូម៉ង់ ដែលគេស្គាល់ថាដាដានែលលេស។ តំបន់ច្រកសមុទ្រដ៏តូចនេះគឺជាផ្លូវទឹកធ្វើដំណើរទៅកាន់រាជធានីរបស់អូតូម៉ង់ គឺកុងស្តង់ទីណុប។ តាមរយៈការកាន់កាប់ដាដានែលលេសពួកសម្ព័ន្ធមិត្តជឿថា ពួកគេអាចដណ្តើមកាន់កាប់កុងស្តង់ទីណុបបាន និងយកជ័យជំនះលើពួកទួគី និងអាចបង្កើតផ្លូវដឹកជញ្ជូនសម្ភារៈផ្គត់ផ្គង់មួយទៅកាន់រុស្ស៊ីបាន។

ការព្យាយាមនៅក្នុងការដណ្តើមកាន់កាប់ច្រកដាដានែលលេសបានចាប់ផ្តើមឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ 1915 ។ វាត្រូវបានគេស្គាល់ថា យុទ្ធនាការហ្គាលលីប៉ូលី។ កងទ័ពអង់គ្លេស, អូស្ត្រាលី, ញូវហ្ស៊ីលែន, និងបារាំងបានបើកការវាយប្រហារផ្ទួនៗគ្នាទៅលើឧបទ្វីបហ្គាលលីប៉ូលីពីភាគខាងលិចនៃច្រកសមុទ្រ។ កងទ័ពរបស់ទួគី ដែលមួយចំនួនដឹកនាំដោយមន្ត្រីរបស់អាឡឺម៉ង់បានការពារតំបន់យ៉ាងខ្លាំងក្លា។ ត្រឹមខែឧសភា ឧបទ្វីបហ្គាលលីប៉ូលីបានប្រែក្លាយទៅជាតំបន់បង្ហូរឈាមគ្នាមួយទៀតដែលនៅជាប់ទ្រឹង។ ភាគីទាំងសងខាងបានជីកលេណដ្ឋាន ដើម្បីបន្តធ្វើសង្គ្រាមរហូតដល់ចុងឆ្នាំ។ នៅក្នុងខែធ្នូ ក្រុមសម្ព័ន្ធមិត្តបានបោះបង់ចោលយុទ្ធនាការនេះ និងបានចាប់ផ្តើមជម្លៀសចេញពីតំបន់នោះ។ ពួកគេបានរងរបួស និងបាត់បង់ជីវិតប្រហែល 25 ម៉ឺននាក់។

សមរភូមិនៅអាហ្វ្រិក និងអាស៊ី៖ នៅក្នុងផ្នែកមួយចំនួននៅក្នុងទ្វីបអាហ្វ្រិក និងអាស៊ី ដែនដីអាណានិគមរបស់អាឡឺម៉ង់ត្រូវបានវាយប្រហារ។ ជប៉ុនបានដណ្តើមកាន់កាប់យ៉ាងឆាប់រហ័សនូវតំបន់គ្រប់គ្រងរបស់អាឡឺម៉ង់នៅក្នុងប្រទេសចិន។ ពួកគេក៏ដណ្តើមកាន់កាប់ដែនកោះអាណានិគមនានារបស់អាឡឺម៉ង់នៅប៉ាស៊ីហ្វិកផងដែរ។ កងទ័ពអង់គ្លេស និងបារាំងបានវាយប្រហារលើដែនដីអាណានិគមទាំង 4 របស់អាឡឺម៉ង់នៅទ្វីបអាហ្វ្រិក។ ពួកគេដណ្តើមកាន់កាប់បាន 3 ។

នៅកន្លែងផ្សេងទៀតនៅក្នុងទ្វីបអាស៊ី និងអាហ្វ្រិក អង់គ្លេស និងបារាំងបានកេណ្ឌប្រជាជននៅក្នុងដែនដីអាណានិគមរបស់ពួកគេដើម្បីចូលរួមប្រយុទ្ធ។ មានកងទ័ពប្រយុទ្ធ ក៏ដូចជាកម្មករមកពីប្រទេសឥណ្ឌា, អាហ្វ្រិកខាងត្បូង, សេនីហ្គាល, អេហ្ស៊ីប, អាហ្ស៊ែរី, និងឥណ្ឌូចិន។ ពួកគេជាច្រើនបានចូលរួមប្រយុទ្ធនឹងបានស្លាប់នៅក្នុងសមរភូមិ។ អ្នកមួយចំនួនទៀតបានបម្រើការជាអ្នកផ្គត់ផ្គង់សម្ភារៈនៅសមរភូមិមុខ។ វាច្បាស់ណាស់ថា ប្រជាជននៅក្នុងដែនដីអាណានិគមមួយចំនួន ដែលចូលរួមប្រយុទ្ធមិនចង់បានអ្វីពីម្ចាស់អាណានិគមអឺរ៉ុបរបស់ពួកគេឡើយ។ អ្នកស្ម័គ្រចិត្តចូលរួមប្រយុទ្ធមួយចំនួនសង្ឃឹមថា ការចូលរួមរបស់ពួកគេនឹងនាំទៅដល់ឯករាជ្យភាពរបស់

ពួកគេ។ នេះគឺជាការយល់ឃើញរបស់មេដឹកនាំនយោបាយឥណ្ឌាប៉ូហានដាស ហ្គាដជី អ្នកដែលបានគាំទ្រការចូលរួមរបស់ឥណ្ឌានៅក្នុងសង្គ្រាម។ លោកបានសរសេរថា "ប្រសិនបើយើងអាចលើកកម្ពស់ឋានៈរបស់យើងបានតាមរយៈការជួយ និងសហការជាមួយអង់គ្លេស វាគឺជាកាតព្វកិច្ចរបស់ពួកយើងនៅក្នុងការគាំទ្រដល់ការជួយនេះតាមរយៈការឈរខាងពួកគេគ្រប់ពេលដែលពួកគេត្រូវការយើង"។

សហរដ្ឋអាមេរិកចូលរួមក្នុងការប្រយុទ្ធ៖ នៅក្នុងឆ្នាំ 1917 ការសង្គ្រាមបានផ្តោតសំខាន់ទៅលើការប្រយុទ្ធគ្នានៅក្នុងសមុទ្រ។ នៅក្នុងឆ្នាំនោះ អាឡឺម៉ង់ចាប់ផ្តើមធ្វើសង្គ្រាមដោយប្រើប្រាស់នាវាមុជទឹកដែលបានល្បាតនៅក្នុងមហាសមុទ្រអាត្លង់ទិកចាប់តាំងពីសង្គ្រាមទើបតែចាប់ផ្តើមមកម្លេះ។ នៅក្នុងខែមករា ឆ្នាំ 1917 អាឡឺម៉ង់បានប្រកាសថា នាវាមុជទឹករបស់ពួកគេនឹងបាញ់ពន្លិចនាវាទាំងឡាយដែលធ្វើដំណើរនៅជុំវិញដែនទឹកអង់គ្លេស ដោយមិនចាំបាច់ជូនដំណឹងជាមុនឡើយ។ គោលនយោបាយនេះត្រូវបានគេហៅថា សង្គ្រាមនាវាមុជទឹកដែលគ្មានដែនកំណត់។

អាឡឺម៉ង់បានព្យាយាមនៅក្នុងការអនុវត្តគោលនយោបាយនេះទាំងពីមុននេះមកម្លេះ។ នៅថ្ងៃទី 7 ខែឧសភា ឆ្នាំ 1915 នាវាមុជទឹកមួយរបស់អាឡឺម៉ង់ ឬគេហៅថា នាវារាងអក្សរយូ បានបាញ់ពន្លិចនាវាដឹកអ្នកដំណើររបស់អង់គ្លេសមួយគ្រឿងឈ្មោះថាលូស៊ីតានៀ។ ការវាយប្រហារនេះបានបណ្តាលឱ្យមនុស្ស 1190 នាក់បានស្លាប់ដោយក្នុងនោះរួមមានប្រជាពលរដ្ឋអាមេរិក 128 នាក់ផងដែរ។ អាឡឺម៉ង់បានអះអាងថា នាវានោះបានដឹកគ្រឿងអាវុធយុទ្ធភ័ណ្ឌ ប៉ុន្តែរឿងនេះមិនត្រឹមត្រូវឡើយ។ ហេតុនេះបានធ្វើឱ្យអាមេរិកមានកំហឹងយ៉ាងខ្លាំង។ ប្រធានាធិបតីវូទ្រូ វីលសុនបានបង្ហាញការតវ៉ាយ៉ាងខ្លាំងក្លាមួយទៅកាន់អាឡឺម៉ង់។ បន្ទាប់ពីមានការវាយប្រហារដូចគ្នានេះចំនួនពីរដងទៀត ចុងក្រោយអាឡឺម៉ង់បានយល់ព្រមនៅក្នុងការបញ្ឈប់ការវាយប្រហារនាវាអព្យាក្រឹត្យ និងនាវាដឹកអ្នកដំណើរ។

ប៉ុន្តែ ដោយព្រួយបារម្ភទៅនឹងការមានប្រៀបរបស់ក្រុមសម្ព័ន្ធមិត្ត អាឡឺម៉ង់បានត្រឡប់ទៅប្រើប្រាស់គោលនយោបាយ សង្គ្រាមនាវាមុជទឹកដែលគ្មានដែនកំណត់ នៅក្នុងឆ្នាំ 1917 ។ ពួកគេដឹងថាវានឹងនាំទៅដល់សង្គ្រាមជាមួយសហរដ្ឋអាមេរិក។ ពួកគេគិតទាំងប្រថុយថា ការរាំងខ្ទប់ផ្លូវទឹករបស់ពួកគេនឹងធ្វើឱ្យអង់គ្លេសខ្វះស្បៀងរហូតដល់ចុះចាញ់ មុនពេលដែលសហរដ្ឋអាមេរិកអាចចល័តទ័ពមកដល់។ ដោយធ្វើមិនដឹងមិនលឺពីការប្រមានរបស់ប្រធានាធិបតីវីលសុននាវាមុជទឹកអាឡឺម៉ង់បានបាញ់ពន្លិចនាវារបស់អាមេរិកចំនួន 3 គ្រឿង។

នៅក្នុងខែកុម្ភៈ ឆ្នាំ 1917 សកម្មភាពមួយផ្សេងទៀតរបស់អាឡឺម៉ង់បានរុញច្រានឱ្យសហរដ្ឋអាមេរិកខិតទៅរកសង្គ្រាម។ មន្ត្រីអាមេរិកចាប់បានទូរសារមួយដែលសរសេរដោយ អគ្គលេខាក្រសួងការបរទេសអាឡឺម៉ង់ អាត ធូរ ហ្ស៊ីមម័រម៉ាន់ ដោយបានថ្លែងថា អាឡឺម៉ង់នឹងជួយប្រទេសម៉ិកស៊ិកកូ "ដណ្តើមកាន់កាប់វិញ" នូវដែនដីដែលពួកគេបានបាត់បង់ទៅសហរដ្ឋអាមេរិក ប្រសិនម៉ិកស៊ិកកូចង់សម្ព័ន្ធមិត្តជាមួយប្រទេសអាឡឺម៉ង់។

កំណត់ត្រារបស់លោកហ្ស៊ីមម័រម៉ាន់បានបង្ហាញពីការបោះភ្លើងទៅលើចំបើង។ ប្រជាជនអាមេរិកមួយចំនួនធំបានគាំទ្រក្រុមសម្ព័ន្ធមិត្តរួចទៅហើយ។ ជាពិសេស អាមេរិកយល់ថាខ្លួនមានទំនាក់ទំនងមួយជាមួយអង់គ្លេស។

ប្រទេសទាំងពីរនេះមានបុព្វការីជន និងភាសា ក៏ដូចជាស្ថាប័នប្រជាធិបតេយ្យ និងប្រព័ន្ធច្បាស់ដូចគ្នា។ ជាងនេះទៅទៀត ទំនាក់ទំនងសេដ្ឋកិច្ចរបស់អាមេរិកជាមួយក្រុមសម្ព័ន្ធមិត្ត មានភាពខ្លាំងក្លាជាងទំនាក់ទំនងជាមួយក្រុមមហាអំណាចកណ្តាល។ នៅថ្ងៃទី 2 ខែមេសា ឆ្នាំ 1917 ប្រធានាធិបតីវីលសុនបានស្នើសភាឱ្យប្រកាសសង្គ្រាមជាមួយអាឡឺម៉ង់។ សហរដ្ឋអាមេរិកចូលរួមនៅក្នុងសង្គ្រាមក្នុងនាមភាគីខាងក្រុមសម្ព័ន្ធមិត្ត។

## 2. ការចូលរួមសង្គ្រាមរបស់សហរដ្ឋអាមេរិកបានជះឥទ្ធិពលលើសមរភូមិមុខនៅអឺរ៉ុប

នៅត្រឹមពេលដែលសហរដ្ឋអាមេរិកចូលរួមជាមួយក្រុមសម្ព័ន្ធមិត្ត ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានទៅមុខទៀតអស់រយៈពេល 3 ឆ្នាំ។ នៅក្នុងរយៈពេល 3 ឆ្នាំនេះ អឺរ៉ុបបានបាត់បង់ជីវិតកងទ័ពនៅក្នុងសមរភូមិច្រើនជាងការបាត់បង់នៅក្នុងសង្គ្រាមរយៈពេល 3 ទសវត្សរ៍មុនទៅទៀត។ សង្គ្រាមបានទាញយកជីវិតមនុស្សអស់រាប់លាននាក់ និងបានផ្លាស់ប្តូរជីវភាពរស់នៅរបស់មនុស្សរាប់មិនអស់។ ជម្លោះនេះត្រូវបានគេស្គាល់ថា សង្គ្រាមលោក បានជះឥទ្ធិពលដល់មនុស្សរាល់គ្នា។ វាមិនត្រឹមតែប៉ះពាល់ដល់តែកងទ័ពនៅក្នុងលេណដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់ជនស៊ីវិលផងដែរ។

រដ្ឋាភិបាលធ្វើសង្គ្រាមផ្តាច់ព្រ័ត្រ៖ សង្គ្រាមលោកលើកទីមួយភ្លាមៗបានក្លាយជាសង្គ្រាមផ្តាច់ព្រ័ត្រ។ នេះមានន័យថាប្រទេសទាំងអស់បានលះបង់នូវរាល់ធនធានទាំងអស់ដែលពួកគេមានដើម្បីធ្វើសង្គ្រាម។ នៅក្នុងចក្រភពអង់គ្លេស, អាឡឺម៉ង់, អូទ្រីស, រុស្ស៊ី, និងបារាំង កងកម្លាំងទាំងអស់របស់រដ្ឋាភិបាលបានធ្វើការពលីគ្រប់បែបយ៉ាងដើម្បីយកជ័យជំនះលើសង្គ្រាម។ នៅក្នុងប្រទេសនីមួយៗ រដ្ឋាភិបាលសម័យសង្គ្រាមបានត្រួតត្រាលើសេដ្ឋកិច្ច។ រដ្ឋាបាលបានប្រាប់ទៅរោងចក្រនានាថាគួរផលិតអ្វី និងក្នុងចំនួនប៉ុន្មាន។ រោងចក្រជាច្រើនត្រូវបានកែប្រែឱ្យក្លាយជារោងចក្រផលិតអាវុធយុទ្ធភ័ណ្ឌ។ ជនស៊ីវិលមានកាយសម្បទាគ្រប់គ្រាន់ស្ទើរតែទាំងអស់ ត្រូវបានគេបញ្ចូលឱ្យទៅធ្វើការ។ អាត្រាអ្នកអត់ការងារធ្វើនៅក្នុងបណ្តាលប្រទេសអឺរ៉ុបទាំងអស់មិនមានទៀតឡើយ។

ការផ្គត់ផ្គង់ទំនិញជាច្រើនប្រភេទជួបប្រទះការខ្វះខាត ដូច្នេះរដ្ឋាភិបាលបានកំណត់ចំនួននៅក្នុងការទិញទំនិញ។ ស្ថិតនៅក្រោមប្រព័ន្ធនេះ ប្រជាជនអាចទិញនូវទំនិញមួយចំនួនបានតិចតួចប៉ុណ្ណោះ ដោយសារទំនិញទាំងនោះក៏ត្រូវការយកទៅផ្គត់ផ្គង់នៅក្នុងសមរភូមិផងដែរ។ ជាយថាហេតុ ការកំណត់ចំនួននៅក្នុងការទិញទំនិញបានគ្របដណ្តប់លើទំនិងស្ទើគ្រប់ប្រភេទ ចាប់តាំងពីប៊ឺរហូតដល់ស្រោមជើង។

រដ្ឋាភិបាលក៏បានបង្ក្រាបទៅលើសកម្មភាពដែលប្រឆាំងការធ្វើសង្គ្រាមផងដែរ ពេលខ្លះឈានទៅដល់ការប្រើកម្លាំងបាយទៀតផង។ ជាងនេះទៅទៀត ពួកគេបានរាំងខ្ទប់ព័ត៌មាននានាអំពីសង្គ្រាមផងដែរ។ មេដឹកនាំមួយចំនួនបានការព្រួយបារម្ភថា ការរាយការណ៍ពិតអំពីសង្គ្រាមអាចនឹងនាំឱ្យប្រជាជនងើបឡើងប្រឆាំងជាមួយពួកគេ។ រដ្ឋាភិបាលក៏បានប្រើប្រាស់ការឃោសនាពីព័ត៌មានតែមួយចំហៀង ដែលគេបានរចនាឡើងដើម្បីទាក់ទាញ និងដើម្បីរក្សាការទឹកចិត្ត និងការគាំទ្ររបស់ប្រជាជនចំពោះសង្គ្រាម។

ស្ត្រី និងសង្គ្រាម៖ នៅក្នុងសង្គ្រាមផ្តាច់ព្រ័ត្រ រដ្ឋាភិបាលចាប់ផ្តើមត្រូវការជំនួយពីស្ត្រីដែលមិនដែលធ្លាប់មានពីមុនមកទេ។ ស្ត្រីរាប់ពាន់នាក់បានចូលធ្វើការជំនួសបុរសនៅក្នុងរោងចក្រ, ការិយាល័យ, និងហាងទំនិញ។

ស្ត្រីបានផលិតថង្រោះ និងអាវុធយុទ្ធភ័ណ្ឌនានា, ភ្ជួរស្រែ, ធ្វើចំការ, ធ្វើផ្លូវ, និងបម្រើការនៅក្នុងមន្ទីរពេទ្យ។ ពួកគេក៏បានជួយនៅក្នុងការផ្គត់ផ្គង់ចំណីអាហារ, សំលៀកបំពាក់, និងអាវុធដល់កងទ័ពផងដែរ។ បើទោះបីជាស្ត្រីភាគច្រើនបានឈប់ធ្វើការងារទាំងនេះបន្ទាប់ពីសង្គ្រាមបញ្ចប់ក៏ដោយ វាបានផ្លាស់ប្តូរការយល់ឃើញរបស់មនុស្សទូទៅអំពីសមត្ថភាពដែលស្ត្រីអាចធ្វើបាន។ ស្ត្រីក៏ត្រូវបានគេមើលឃើញពីវីរៈភាពនៅក្នុងសង្គ្រាមផងដែរ តាមរយៈការធ្វើនៅក្នុង ឬជិតសមរភូមិមុខក្នុងនាមជាគិលានុបដ្ឋាក។

### 3. ក្រុមសម្ព័ន្ធមិត្តឈ្នះសង្គ្រាម

ជាមួយនឹងការចូលរួមនៅក្នុសង្គ្រាមរបស់សហរដ្ឋអាមេរិក តុល្យភាពហាក់ដូចជាផ្អៀងទៅខាងក្រុមសម្ព័ន្ធមិត្ត។ ប៉ុន្តែ មុនពេលរឿងនេះកើតឡើង ព្រឹត្តិការណ៍នានានៅក្នុងប្រទេសរុស្ស៊ីបានបណ្តាលឱ្យអាឡឺម៉ង់យកជ័យជំនះនៅសមរភូមិខាងកើត ដែលបណ្តាលឱ្យមានសេចក្តីសង្ឃឹមមួយក្នុងការយកជ័យជំនះលើសង្គ្រាម។

រុស្ស៊ីដកខ្លួនចេញពីសង្គ្រាម៖ នៅក្នុងខែមីនា ឆ្នាំ 1917 ភាពចលាចលកើតមានឡើងនៅក្នុងប្រទេសរុស្ស៊ីដោយសារតែតំបន់ជាច្រើនខ្វះខាតស្បៀងអាហារ និងឥទ្ធនៈដែលបណ្តាលមកពីសង្គ្រាម ដែលបានបង្ខំឱ្យស្តេចហ្សានីកូឡាស់ចុះចេញពីអំណាច។ រដ្ឋាភិបាលបណ្តោះអាសន្នមួយត្រូវបានបង្កើតឡើងដើម្បីជំនួសតំណែងរបស់លោក។ ប៉ុន្តែ ត្រឹមឆ្នាំ 1917 កងទ័ពរុស្ស៊ីជិត 5.5 លាននាក់បានរងរបួស, ស្លាប់, និងត្រូវបានចាប់ធ្វើជាឈ្លើយសឹក។ ជាលទ្ធផល កងទ័ពរុស្ស៊ីដែលអស់កម្លាំងនឹងសង្គ្រាមបានបដិសេធនៅក្នុងការប្រយុទ្ធជាបន្តទៀត។

8 ខែបន្ទាប់ពីការបង្កើតរដ្ឋាភិបាលថ្មី បដិវត្តមួយបានផ្ទុះឡើងនៅរុស្ស៊ី (សូមមើលជំពូក 29)។ នៅក្នុងខែវិច្ឆិកា ឆ្នាំ 1917 មេដឹកនាំបក្សកុំម្មុយនីស្ត វ្លាឌីមៀ អ៊ីលយីច លេនីនបានក្តោបអំណាច។ លេនីនបានទទូចឱ្យប្រទេសរុស្ស៊ីបញ្ឈប់ការចូលរួមនៅក្នុងសង្គ្រាមបន្តទៅទៀត។ កិច្ចការដំបូងបំផុតមួយរបស់លោកគឺចុះសន្ធិសញ្ញាមួយជាមួយអាឡឺម៉ង់។ នៅក្នុងខែមីនា ឆ្នាំ 1918 អាឡឺម៉ង់ និងរុស្ស៊ីបានចុះហត្ថលេខាលើសន្ធិសញ្ញាប្រេស្ត-លីតូវ ដែលបានបញ្ចប់សង្គ្រាមរវាងប្រទេសទាំងពីរ។

ក្រុមហាអំណាចកណ្តាលដួលរលំ៖ ការដកខ្លួនចេញពីសង្គ្រាមរបស់រុស្ស៊ីយ៉ាងហោចណាស់បានអនុញ្ញាតឱ្យអាឡឺម៉ង់បញ្ជូនកងទ័ពរបស់ខ្លួនស្ទើទាំងស្រុងទៅកាន់សមរភូមិខាងលិច។ នៅក្នុងខែមីនា ឆ្នាំ 1918 អាឡឺម៉ង់បានបើកយុទ្ធនាការចុងក្រោយមួយ ដោយធ្វើការវាយប្រហារទ្រង់ទ្រាយធំមួយលើក្រុមសម្ព័ន្ធមិត្តនៅប្រទេសបារាំង។ ដូចដែលនៅសប្តាហ៍ដំបូងនៃការវាយប្រយុទ្ធ កងទ័ពអាឡឺម៉ង់បានវាយកម្ទិតនូវរាល់អ្វីៗដែលរាំងផ្លូវពួកគេ។ ត្រឹមចុងខែឧសភា ឆ្នាំ 1918 អាឡឺម៉ង់បានធ្វើដំណើរដល់ទន្លេម៉ានេ។ បារីសមានចម្ងាយមិនដល់ 40 ម៉ាយពីទន្លេនេះឡើយ។ ជ័យជំនះមើលទៅកាន់តែជិតមកដល់ហើយ។

ប៉ុន្តែ នៅពេលនោះ កងទ័ពរបស់អាឡឺម៉ង់បានខ្សោយកម្លាំង។ ការព្យាយាមនៅក្នុងការដណ្តើមកាន់កាប់តំបន់ បានចំណាយកងទ័ពក៏ដូចជាស្បៀងអស់ជាច្រើន។ ដោយឃើញពីភាគចុះខ្សោយនេះ ក្រុមសម្ព័ន្ធមិត្តជាមួយនឹងជំនួយកងទ័ពរបស់សហរដ្ឋអាមេរិកជិត 14 ម៉ឺននាក់បានបើកការវាយប្រហារមួយ។ នៅក្នុងខែកក្កដា ឆ្នាំ 1918 ក្រុមសម្ព័ន្ធមិត្ត និងអាឡឺម៉ង់បានបះទង្គិចគ្នាជាលើកទីពីរនៅក្នុងសមរភូមិម៉ានេ។ ការវាយប្រហាររបស់

សម្ព័ន្ធមិត្តនាំមុខដោយរថក្រោះចំនួន 350 គ្រឿងដែលបើកទៅមុខឃីតៗវាយសម្រុកចូលក្នុងខ្សែត្រៀមរបស់អាឡឺម៉ង់។ ជាមួយនឹងការមកដល់នៃកងទ័ពអាមេរិក 2 លាននាក់បន្ថែម កងទ័ពសម្ព័ន្ធមិត្តចាប់ផ្ដើមមានប្រៀបលើពួកអាឡឺម៉ង់។

ភ្លាមៗនោះ ពួកមហាអំណាចកណ្ដាលចាប់ផ្ដើមបែកខ្ញែកគ្នា។ ដំបូងប្រទេសប៊ុលហ្គារី និងបន្ទាប់មកអូតូម៉ង់របស់ពួកទួក បានចុះចាញ់។ នៅក្នុងខែតុលា បដិវត្តបានរីករាលដាលពាលពេញប្រទេសអូទ្រីស-ហុងគ្រី។ នៅក្នុងប្រទេសអាឡឺម៉ង់ កងទ័ពចាប់ផ្ដើមបះបោរ ហើយសារណជនចាប់ផ្ដើមងើមឡើងប្រឆាំងជាមួយខៃស័រ ។

នៅថ្ងៃ 9 ខែវិច្ឆិកា ឆ្នាំ 1918 ខៃស័រ វីលហេមទី 2 បានចុះចេញពីតំណែង។ ប្រទេសអាឡឺម៉ង់ប្រកាសប្រទេសជាសាធារណរដ្ឋ។ តំណាងរដ្ឋាភិបាលថ្មីរបស់អាឡឺម៉ង់ម្នាក់បានជួបជាមួយមេបញ្ជាការបារាំងឧត្ដមសេនីយ៍ ហ្វូចនៅក្នុងទូររថភ្លើងមួយនៅជិតទីក្រុងប៉ារីស។ ភាគីទាំងពីរបានចុះហត្ថលេខាលើបទឈប់បាញ់មួយ។ នៅថ្ងៃទី 11 ខែវិច្ឆិកា សង្គ្រាមលោកលើកទី 1 បានបញ្ចប់។

### 4. កេរ្តិ៍ដំណែលនៃសង្គ្រាម

សង្គ្រាមលោកលើកទី 1 គឺជាសង្គ្រាមបែបថ្មីមួយ។ វាបានរួបបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ វាបានបង្ហាញឱ្យឃើញពីសង្គ្រាមដែលមានទំហំធំ និងជាលក្ខណៈអន្តរជាតិមួយ។ វាក៏បានបន្សល់ទុកនូវមនុស្សស្លាប់ និងវិនាសកម្មនានាដែលមិនធ្លាប់មានពីមុនមក។

ភាគីទាំងសងខាងនៅក្នុងសង្គ្រាមលោកលើកទី 1 បានចំណាយទៅលើអាយុជីវិតមនុស្សអស់យ៉ាងច្រើន។ កងទ័ពប្រមាណ 8.5 លាននាក់បានស្លាប់ដោយសារសង្គ្រាម។ មានកងទ័ពប្រមាណ 21 លាននាក់ទៀតរងរបួស។ ជាងនេះទៅទៀត សង្គ្រាមបានបណ្ដាលឱ្យជនស៊ីវិលស្លាប់រាប់មិនអស់ ដោយសារគ្រោះអត់ឃ្លាន, ជំងឺ, និងការសម្លាប់។ បូករួមបញ្ចូលគ្នា ចំនួននេះគឺជាសោកនាដកម្មដ៏ធំមួយ ដែលស្មើនឹងការធ្វើឱ្យសាបសូន្យមនុស្សមួយជំនាន់នៅអឺរ៉ុប។

សង្គ្រាមក៏បំផ្លិចបំផ្លាញសេដ្ឋកិច្ចនៅអឺរ៉ុបផងដែរ។ ជម្លោះដ៏ធំនេះបានធ្វើឱ្យរីងស្ងួតនូវទ្រព្យសម្បត្តិបណ្ដាលប្រទេសនានានៅអឺរ៉ុប។ មានរបាយការណ៍មួយបានបង្ហាញពីចំនួនសរុបនៃការចំណាយនៅក្នុងសង្គ្រាមគឺមានចំនួន 338 ពាន់លានដុល្លា ដែលជាចំនួនដ៏ច្រើនមួយនៅពេលនោះ។ សង្គ្រាមក៏បានបំផ្លិចបំផ្លាញដីស្រែចំការ, ក៏ដូចជាផ្ទះសំបែង, ភូមិដ្ឋាន, និងទីក្រុងនានា។

ភាពរងគ្រោះដ៏ធំធេងដែលបណ្ដាលមកពីសង្គ្រាមលោកលើកទី 1 បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសង្គមរស់នៅរបស់ពួកបស្ចិមប្រទេសផងដែរ។ ភាពខកចិត្តបានដក់ជាប់នៅក្នុងអារម្មណ៍របស់អ្នករស់រានមានជីវិត។ អសន្តិសុខ និងភាពអស់សង្ឃឹមដែលមនុស្សជាច្រើនបានជួបប្រទះ បានឆ្លុះបញ្ចាំងតាមរយៈសិល្បៈ និងស្នាដៃអក្សរសិល្ប៍នៅពេលនោះ។

កេរ្តិ៍ដំណែលដ៏សំខាន់មួយទៀតនៃសង្គ្រាមគឺជាប់ទាក់ទងជាមួយកិច្ចព្រមព្រៀងសន្តិភាព។ ដូចដែលអ្នកនឹងបានអាននៅក្នុងមេរៀនបន្ទាប់ សន្ធិសញ្ញានានាដែលធ្វើឡើងដើម្បីបញ្ចប់សង្គ្រាមលោកលើកទី 1 បានដំណើរ

បន្តិចម្តងៗ បន្ទាប់ពីមានការជជែកគ្នា និងសម្រុះសម្រួលគ្នាមក។ ខណៈពេលដែលពួកគេសម្លឹងទៅរកការនាំមកវិញនូវសន្តិសុខ និងសន្តិភាពសម្រាប់ពិភពលោក ពួកគេក៏ជម្រុញឲ្យមានភាពខឹងសម្បា និងភាពអាក់អន់ចិត្តផងដែរ។

# មេរៀនទី 4៖ សន្តិភាពដ៏ផុយស្រួយមួយ

## 1. ក្រុមសម្ព័ន្ធមិត្តជួយប្រជុំ និងជជែកគ្នា

បើទោះបីជាមានតំណាងមកពីប្រទេសជាច្រើនក៏ដោយ សេចក្តីសម្រេចចិត្តសំខាន់ៗនៅក្នុងអង្គប្រជុំនេះត្រូវសម្រេចដោយមនុស្សមួយក្រុមដែលគេស្គាល់ថា បងធំទាំង 4 ដោយក្នុងនោះរួមមាន លោកវូទ្រូ វីលសុនរបស់សហរដ្ឋអាមេរិក, លោកចច ក្លេម៉ង់សូរបស់ប្រទេសបារាំង, លោកដេវីដ លយ ចចរបស់ចក្រភពអង់គ្លេស, លោកវីតតូរីអូ អូលេនដូរបស់ប្រទេសអ៊ីតាលី។ រុស្ស៊ីដែលជាប្រទេសកំពុងញ៉ាំញីដោយសង្គ្រាមស៊ីវិល មិនមានអ្នកតំណាងចូលរួមឡើយ។ ប្រទេសអាឡឺម៉ង់ និងសម្ព័ន្ធមិត្តរបស់គេក៏មិនបានចូលរួមដែរ។

ផែនការសន្តិភាពរបស់លោកវីលសុន៖ នៅខែមករា ឆ្នាំ 1918 នៅខណៈពេលដែលសង្គ្រាមនៅកំពុងតែបន្តផ្ទុះឡើង លោកប្រធានាធិបតីអាមេរិកវីលសុនបានបង្ហាញពីសំណើរសន្តិភាពមួយចំនួន។ ត្រូវបានគេស្គាល់ថា 14 ចំណុច សំណើរនេះបានពង្រាងផែនការមួយសម្រាប់នាំមកនូវសន្តិភាពពិតប្រាកដ និងយូរអង្វែងមួយ។

ចំណុច 4 ដំបូងរួមមាន ការបញ្ចប់នូវសន្ធិសញ្ញាសម្ងាត់នានា, សេរីភាពនៅក្នុងលំហរសមុទ្ទ, ពាណិជ្ជកម្មសេរី, និងការកាត់បន្ថយកងទ័ព និងកងនាវីជាតិ។ គោលបំណងទី 5 គឺធ្វើការកែប្រែដែនដីអាណានិគមរបស់ខ្លួនឱ្យមានភាពយុត្តិធម៌សម្រាប់ប្រជាជនក្នុងដែនដីអាណានិគមទាំងនោះ។ ចំណុចទី 6 ដល់ចំណុចទី 13 គឺផ្តោតសំខាន់លើការស្នើឱ្យមានការកែប្រែព្រំដែន និងការបង្កើតប្រទេសជាតិថ្មី។ គោលបំណងសំខាន់នៅក្នុងចំណុចទាំងនេះគឺ ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង។ នេះមានន័យថា ត្រូវអនុញ្ញាតឱ្យប្រជាជនសម្រេចដោយខ្លួនគេថាពួកគេប្រាថ្នាចង់រស់នៅក្រោមរដ្ឋាភិបាលប្រភេទណា។

ចុងក្រោយ ចំណុចទី 14 បានស្នើឱ្យមានការបង្កើតឡើងនូវ "សមាគមប្រជាជាតិទូទៅ" មួយ ដែលនឹងជួយការពារ "រដ្ឋធំ និងរដ្ឋតូចស្មើៗគ្នា"។ ចំណុចនេះបានបង្ហាញពីបំណងប្រាថ្នារបស់លោកវីលសុនដែលចង់ឱ្យមានស្ថាប័នមួយ ដែលអាចស្វែងរកដំណោះស្រាយប្រកបដោយសន្តិភាពចំពោះបញ្ហានានាដែលកើតលើពិភពលោក។

សន្ធិសញ្ញាទីក្រុងវែរសៃ៖ ដូចដែលសន្និសិទសន្តិភាពទីក្រុងប៉ារីសបានបើកឡើង អង់គ្លេស និងបារាំងបានបង្ហាញពីសញ្ញាយល់ព្រមតិចតួចចំពោះគោលបំណងសន្តិភាពរបស់លោកវីលសុន។ ប្រទេសទាំងពីរបានការព្រួយបារម្ភអំពីសន្តិសុខជាតិ។ ពួកគេក៏មានបំណងចង់ដាក់ពិន័យប្រទេសអាឡឺម៉ង់សម្រាប់ការបង្កសង្គ្រាមលោកលើកទី 1 ។

គោលបំណងខុសគ្នារវាងបារាំង, អង់គ្លេស, និងសហរដ្ឋអាមេរិកបាននាំទៅដល់ការជជែងគ្នាយ៉ាងតានតឹងក្នុងចំណោមមេដឹកនាំប្រទេសនីមួយៗ។ ចុងក្រោយពួកគេបានឈានទៅដល់កិច្ចព្រមព្រៀងគ្នាមួយ។ សន្ធិសញ្ញាទីក្រុងវែរសៃរវាងប្រទេសអាឡឺម៉ង់ និងក្រុមសម្ព័ន្ធមិត្តត្រូវបានចុះហត្ថលេខានៅថ្ងៃទី 28 ខែមិថុនា ឆ្នាំ1919 គឺមានរយៈពេល 5 ឆ្នាំគត់បន្ទាប់ពីការលបធ្វើឃាតស្តេចហ្វង់ ហ្វ័រឌីណង់នៅសារ៉ាយេវ្វ ។ ដោយអនុលោមតាមចំណុចទី

14 របស់ប្រធានាធិបតីវីលសុនសន្ធិសញ្ញាបានបង្កើតសម្ព័ន្ធប្រជាជនមួយ។ សម្ព័ន្ធនេះគឺជាសមាគមន៍អន្តរជាតិមួយដែលមានគោលដៅថែរក្សាសន្តិភាពក្នុងចំណោមប្រជាជាតិទាំងអស់។

សន្ធិសញ្ញានេះក៏បានដាក់ពិន័យប្រទេសអាឡឺម៉ង់ផងដែរ។ ប្រទេសដែលចាញ់សង្គ្រាមបានបាត់បង់ដែនដីមួយចំនួនធំ និងត្រូវកម្រិតយ៉ាងតឹងរឹងលើប្រតិបត្តិយោធារបស់ពួកគេ។ មាត្រាទី 231 គឺជាមាត្រាដែលមានភាពធ្ងន់ធ្ងរជាងគេនៅក្នុងសន្ធិសញ្ញានេះ។ វាក៏ត្រូវបានគេស្គាល់ថា អនុប្រយោជ "ពិរុទ្ធភាពសង្គ្រាម"។ មាត្រានេះបានដាក់ការទទួលខុសត្រូវទាំងស្រុងនៃសង្គ្រាមលើកងទ័ពរបស់អាឡឺម៉ង់។ ជាលទ្ធផល ប្រទេសអាឡឺម៉ង់ត្រូវបង់ថ្លៃខូចខាតដល់សម្ព័ន្ធមិត្ត។

ទឹកដីរបស់អាឡឺម៉ង់ទាំងអស់នៅទ្វីបអាហ្វ្រិក និងតំបន់ប៉ាស៊ីហ្វិកត្រូវបានប្រកាសថាជាដែនដីដែលត្រូវគ្រប់គ្រងដោយសម្ព័ន្ធប្រជាជាតិ។ ស្ថិតនៅក្រោមកិច្ចព្រមព្រៀងសន្តិភាព ប្រទេសសម្ព័ន្ធមិត្តនឹងត្រួតត្រាដែនដីទាំងនោះរហូតដល់ដែនដីទាំងនោះត្រូវបានវិនិច្ឆ័យថាអាចទទួលបានឯករាជ្យ។

## 2. សន្ធិសញ្ញាមួយដែលបន្តឱ្យមានបញ្ហា

សន្ធិសញ្ញាទីក្រុងវែរសៃគឺគ្រាន់តែជាសន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាចំនួន 5 ដែលបានចរចារដោយសម្ព័ន្ធមិត្ត។ នៅចុងបញ្ចប់ កិច្ចព្រមព្រៀងទាំងអស់នេះបានបង្កើតឱ្យមានអារម្មណ៍ល្វីងជូរជត់ និងក្បត់គ្នាក្នុងចំណោមក្រុមអ្នកឈ្នះ និងអ្នកចាញ់សង្គ្រាម។

ការបង្កើតឡើងនូវប្រទេសជាតិថ្មីៗ៖ នៅក្នុងឆ្នាំ 1919 និង 1920 មហាអំណាចលោកខាងលិចបានចុះហត្ថលេខាសន្តិភាពផ្សេងៗគ្នាទៅវិញទៅមកជាមួយប្រទេសដែលចាញ់សង្គ្រាម ដែលក្នុងនោះរួមមានប្រទេសអូទ្រីស-ហុងគ្រី, ប្រទេសប៊ុលហ្គារី, និងចក្រភពអូតូម៉ង់។ សន្ធិសញ្ញាទាំងអស់នេះ បានបណ្តាលឱ្យក្រុមប្រទេសអំណាចកណ្តាលបានបង់ដែនដីមួយភាគធំផងដែរ។ ប្រទេសជាតិថ្មីៗជាច្រើនត្រូវបានបង្កើតឡើងចេញពីចក្រភពអូទ្រីស-ហុងគ្រី។ ប្រទេសអូទ្រីស, ហុងគ្រី, ឆេកូស្លូវ៉ាគី, និងយូហ្គូស្លាវី ត្រូវបានគេទទួលស្គាល់ថាជាប្រទេសដែលមានឯករាជ្យ។

ចក្រភពអូតូម៉ង់របស់ពួកទួក ត្រូវបានបង្ខំឱ្យបះបង់ចោលនូវទឹកដីក្នុងចក្រភពរបស់ពួកគេស្ទើតែទាំងស្រុង។ ពួកគេអាចរក្សាបានតែទឹកដីមួយគត់ដែលបច្ចុប្បន្នគឺជាប្រទេសទួគី។ ពួកសម្ព័ន្ធមិត្តបានកាត់ជៀកយកទឹកដីដែលចក្រភពអូតូម៉ង់បានបាត់បង់នៅតំបន់អាស៊ីនិរតី ដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ជាជាងផ្តល់ឯករាជ្យឱ្យប្រទេសទាំងនោះ។ រដ្ឋប៉ាឡេស្ទីន, ប្រទេសអ៊ីរ៉ាក់, និងត្រេនស៍ចូដានបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស, ប្រទេសស៊ីរី និងឡេបាណន់ ធ្លាក់ក្រោមការគ្រប់គ្រងរបស់ប្រទេសបារាំង។

ប្រទេសរុស្ស៊ីដែលបានដកខ្លួនចេញពីសង្គ្រាមមុនគេ ក៏រងគ្រោះដោយការបាត់បង់ទឹកដីផងដែរ។ ប្រទេសរ៉ូម៉ានី និងប្រទេសប៉ូឡូញទាំងពីរនេះទទួលបានទឹកដីពីប្រទេសរុស្ស៊ី។ ប្រទេសហ្វាំងឡង់, ប្រទេសអេស្តូនី, ប្រទេសឡាវីយ៉ា, និងប្រទេសលីទុយអានី ដែលជាអតីតផ្នែកមួយនៃប្រទេសរុស្ស៊ី បានក្លាយជាប្រទេសឯករាជ្យ។

"សន្តិភាពមួយដែលស្ថាបនាឡើងនៅលើខ្សាច់ផុង"៖ នៅចុងបញ្ចប់ សន្ធិសញ្ញាទីក្រុងវែរសៃបានធ្វើការតិចតួចដើម្បីស្ថាបនាសន្តិភាពយូរអង្វែងមួយ។ សម្រាប់ហេតុផលមួយ គឺសហរដ្ឋអាមេរិកដែលចាត់ទុកថាជាប្រទេសដែលមានឥទ្ធិពលជាងគេនៅលើពិភពលោកបន្ទាប់ពីសង្គ្រាម ទីបញ្ចប់ទៅបានបដិសេធសន្ធិសញ្ញានេះ។ ប្រជាជនអាមេរិកជាច្រើនបានប្រឆាំងទៅនឹងការកិច្ចព្រមព្រៀងនេះ ជាពិសេសប្រឆាំងទៅនឹងការបង្កើតសម្ព័ន្ធប្រជាជាតិរបស់ប្រធានាធិបតីវីលសុន។ ប្រជាជនអាមេរិកជឿថា ដើម្បីទទួលបានសន្តិភាពសម្រាប់របស់សហរដ្ឋអាមេរិក គឺត្រូវនៅឱ្យឆ្ងាយពីពួកអឺរ៉ុប។ សហរដ្ឋអាមេរិកបានបង្កើតសន្ធិសញ្ញាដាច់ដោយឡែកមួយផ្សេងទៀតជាមួយប្រទេសអាឡឺម៉ង់ និងសម្ព័ន្ធមិត្តរបស់គេនៅក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក។

ជាងនេះទៅទៀត សន្ធិសញ្ញាជាមួយប្រទេសអាឡឺម៉ង់ ជាពិសេសនៅត្រង់ចំណុចពិរុទ្ធភាពសង្គ្រាម ដែលជាកេរ្តិ៍ដំណែលដ៏ល្វីងជូរចត់ និងគួរឱ្យស្អប់ខ្ពើមនៅក្នុងចិត្តរបស់ប្រជាជនអាឡឺម៉ង់។ ប្រទេសមួយចំនួនទៀតក៏មានអារម្មណ៍ថាកិច្ចព្រមព្រៀងនេះបានបោកប្រាស់ និងក្បត់ពួកគេផងដែរ។ នៅក្នុងទ្វីបអាហ្វ្រិក និងអាស៊ី ប្រជាជនដែលត្រូវបានគេប្រគល់ទឹកដីឱ្យទៅក្រុមប្រទេសសម្ព័ន្ធមិត្តគ្រប់គ្រង មានការខឹងសម្បាទៅនឹងពួកសម្ព័ន្ធមិត្តដែលបានប្រងើយកន្តើយចំពោះការចង់បានឯករាជ្យរបស់ពួកគេឡើយ។ សម្រាប់ពួកគេ មហាអំណាចអឺរ៉ុបហាក់ដូចជាគ្រាន់តែនិយាយ អំពីគោលការណ៍នៃការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងរបស់ប្រទេសជាតិតែប៉ុណ្ណោះ។ អាណានិគមនិយមអឺរ៉ុប ដែលបានលាក់បាំងនៅក្រោមស្លាកប្រព័ន្ធប្រគល់ទឹកដីឱ្យគ្រប់គ្រងបណ្តោះអាសន្ន ដែលបន្តនៅអាស៊ី និងអាហ្វ្រិកដដែល។

មហាអំណាចមួយចំនួនក្នុងក្រុមសម្ព័ន្ធមិត្ត ក៏មានការមិនសប្បាយចិត្តចំពោះលទ្ធផលដែលខ្លួនទទួលបានផងដែរ។ ទាំងប្រទេសជប៉ុន និងប្រទេសអ៊ីតាលី ដែលបានចូលរួមនៅក្នុងសង្គ្រាមដើម្បីដណ្តើមទឹកដីដែលនោះ ទទួលបាននូវដែនដីតិចតួចជាងអ្វីដែលពួកគេចង់បាន។ ដោយសារមានការគាំទ្រតិចតួចពីសហរដ្ឋអាមេរិក និងក្រោយមកមហាអំណាចផ្សេងៗទៀតនៅលើពិភពលោកក៏ឈប់គាំទ្រ អង្គការសម្ព័ន្ធប្រជាជាតិ មិនមានតួនាទីអ្វីនៅក្នុងការចាត់វិធានការដើម្បីដោះស្រាយទៅលើបញ្ហាទាំងនេះ និងបណ្តឹងផ្សេងៗទៀតឡើយ។ កិច្ចព្រមព្រៀងនៅទីក្រុងវែរសៃបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការគូសបញ្ជាក់មួយរបស់អ្នកអង្កេតថាជា "សន្តិភាពមួយដែលស្ថាបនាឡើងនៅលើខ្សាច់ផុង"។ ជាក់ស្តែងណាស់ ខ្សាច់ផុតនេះបន្តិចម្តងៗបានពន្លិចសន្តិភាពនេះ។ នៅក្នុងរយៈពេលជាងពីរទសវត្សរ៍តិចតួច កេរ្តិ៍ដំណែលដ៏ល្វីងជូរចត់នៃសន្ធិសញ្ញាទាំងនេះបានជួយរុញច្រានឱ្យពិភពលោកធ្លាក់ទៅក្នុងសង្គ្រាមដ៏មហាមហន្តរាយមួយផ្សេងទៀត។

# ជំពូក 29 ៖ ការធ្វើបដិវត្ត និងគំនិតជាតិនិយម 1900-1939

## មេរៀនទី 1 ៖ បដិវត្តនៅក្នុងប្រទេសរុស្ស៊ី

### 1. ស្តេចហ្សាររុស្ស៊ីប្រឆាំងជាមួយការផ្លាស់ប្តូរ

នៅក្នុងឆ្នាំ 1881 ស្តេចអាឡិចសាន់ឌឺទី 3 បានស្នងតំណែងពីបិតារបស់ទ្រង់គឺព្រះអង្គម្ចាស់ អាឡិចសាន់ឌឺទី 2 និងបានបញ្ឈប់ការធ្វើកំណែទម្រង់ទាំងឡាយនៅក្នុងប្រទេសរុស្ស៊ី។ ក៏ដូចជាព្រះអយ្យកោរបស់ទ្រង់ព្រះអង្គម្ចាស់ នីកូឡាស់ទី 1 ដែរ ព្រះអង្គម្ចាស់អាឡិចសាន់ឌឺទី 3 ប្រកាន់ខ្ជាប់នូវគោលការអត្តាធិបតេយ្យ(ផ្តាច់ការ) ដែលជាទម្រង់រដ្ឋាភិបាលមួយ ដែលអំណាចទាំងអស់ស្ថិតនៅទ្រង់តែម្នាក់ឯង។ មនុស្សទាំងឡាយណាដែលប្រឆាំងទៅនឹងអំណាចផ្តាច់មុខរបស់ព្រះមហាក្សត្រ ឬហ្សា (ជាភាសារុស្ស៊ី) ក៏ដូចជាជនទាំងឡាយណាដែលគោរពបូជាសាសនាផ្សេងក្រៅពីគ្រីស្តសាសនានិកាយអូតូដុករបស់រុស្ស៊ី ឬនិយាយភាសាផ្សេងក្រៅពីភាសារុស្ស៊ី ត្រូវបានគេចាត់ទុកថាជាជនដែលអាចបង្កឱ្យមានគ្រោះថ្នាក់។

ស្តេចរុស្ស៊ីបន្តការដឹកនាំបែបផ្តាច់ការ៖ ដើម្បីលប់បំបាត់ការធ្វើបដិវត្ត ស្តេចអាឡិចសាន់ឌឺទី 3 បានប្រើប្រាស់វិធានការដ៏ឃោឃៅមួយ។ ទ្រង់បានតាក់តែងក្រមត្រួតពិនិត្យដ៏តឹងរឹងមួយលើការបោះពុម្ពផ្សាយ និងឯកសារនានាដោយរួមទាំងលិខិតឯកជនផងដែរ។ ប៉ូលីសសំងាត់របស់ទ្រង់បានឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ទាំងនៅវិទ្យាល័យ និងមហាវិទ្យាល័យ។ គ្រូបង្រៀនត្រូវតែបញ្ជូនរបាយការណ៍លម្អិតអំពីសិស្សនីមួយៗ។ អ្នកទោសនយោបាយត្រូវបានគេបញ្ជូនទៅកាន់តំបន់ស៊ីប៉េរី ដែលជាតំបន់ដាច់ស្រយាលមួយនៅរុស្ស៊ីភាគខាងកើត។

ដើម្បីបង្កើតហ្សាមានទម្រង់រួមមួយនៃវប្បធម៌របស់រុស្ស៊ី ស្តេចអាឡិចសាន់ឌឺទី 3 បានធ្វើទុកបុកម្និញលើក្រុមជនជាតិផ្សេងៗទៀតដែលរស់នៅក្នុងប្រទេសរុស្ស៊ី។ ទ្រង់បានកំណត់ភាសារុស្ស៊ីជាភាសាផ្លូវការនៅក្នុងចក្រភព ហើយហាមឃាត់ក្នុងការប្រើប្រាស់ភាសារបស់ជនជាតិភាគតិចផ្សេងៗនៅក្នុងសាលារៀន ដែលក្នុងនោះមានដូចជាភាសាប៉ូឡូញជាដើម។ ស្តេចអាឡិចសាន់ឌឺទី 3 បានចាត់ទុកពួកជ្វីបគឺជាគោលដៅនៅក្នុងការធ្វើទុកបុកម្និញ។ មានកម្មវិធីមួយចំនួន ដែលត្រូវបានរៀបចំឡើងដើម្បីបង្កអំពើហិង្សាលើជនជាតិជ្វីប ត្រូវបានគេបង្កើតឡើងនៅពាលពេញប្រទេសរុស្ស៊ី។ ប៉ូលីស និងកងទ័ពធ្វើការគាំទ្រ និងឈរមើលប្រជាពលរដ្ឋរុស្ស៊ីលួចប្លន់ និងកម្ទេចផ្ទះ, ហាងទំនិញ, និងព្រះវិហាររបស់ពួកជ្វីប។ នៅពេលដែលព្រះអង្គម្ចាស់នីកូឡាស់ទី 2 បានឡើងធ្វើជាស្តេចនៅក្នុងឆ្នាំ 1894 ទ្រង់នៅតែបន្តប្រពៃណីនៃការគ្រប់គ្រងប្រទេសរុស្ស៊ីបែបផ្តាច់ការដដែល។ ជាអកុសល ការគ្រប់គ្រងបែបនេះធ្វើហ្សាទ្រង់មិនបានយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរស្ថានការណ៍មួយចំនួននៅក្នុងរាជ្យរបស់ទ្រង់ឡើយ។

### 2. បដិវត្តឧស្សាហកម្មនៅក្នុងប្រទេសរុស្ស៊ី

ឧស្សាហូបនីយកម្មដ៏ឆាប់រហ័សបានផ្លាស់ប្តូរមុខមាត់នៃសេដ្ឋកិច្ចរបស់រុស្ស៊ី។ ចំនួនរោងចក្របានកើនឡើងជាងពីរដងនៅរវាងឆ្នាំ 1863 ដល់ឆ្នាំ 1900 ។ ប៉ុន្តែ ប្រទេសរុស្ស៊ីនៅតែដើរនៅពីក្រោយប្រទេសឧស្សាហកម្មនានានៅអឺរ៉ុបខាងលិច។ នៅក្នុងទសវត្សរ៍ឆ្នាំ 1890 រដ្ឋមន្ត្រីដ៏មានសមត្ថភាពជាងគេរបស់ស្តេចនីកូឡាស់ទី 2 បាន

បង្កើតកម្មវិធីមួយដើម្បីធ្វើឲ្យប្រទេសរុស្ស៊ីដើរទៅមុខ។ ក្នុងការស្វែងរកហិរញ្ញវត្ថុដើម្បីស្ថាបនាឧស្សាហកម្មនៅក្នុងប្រទេសរុស្ស៊ី រដ្ឋាភិបាលបានសម្លឹងរកវិនិយោគិនបរទេស និងបង្កើនពន្ធ។ វិធានការទាំងអស់នេះបានលើកកម្ពស់ឲ្យមានកំណើនឧស្សាហកម្មធន់ធ្ងន់ ជាពិសេសឧស្សាហកម្មដែកថែប។ ត្រឹមវង្វង់ឆ្នាំ 1900 ប្រទេសរុស្ស៊ីបានក្លាយជាប្រទេសដែលផលិតដែកថែបចំណាត់ថ្នាក់ទី 4 នៅលើពិភពលោក។ មានតែសហរដ្ឋអាមេរិក, អាឡឺម៉ង់, និងចក្រភពអង់គ្លេសប៉ុណ្ណោះដែលផលិតដែកថែបបានច្រើនជាងរុស្ស៊ី។

ជាមួយនឹងជំនួយរបស់វិនិយោគិនអង់គ្លេស និងបារាំង ការស្ថាបនាផ្លូវរថភ្លើងដែលវែងជាគេនៅលើពិភពលោក គឺផ្លូវរថភ្លើងត្រេន-ស៊ីប៉េរីត្រូវបានចាប់ផ្តើមឡើង។ ដោយចាប់ផ្តើមស្ថាបនាដំបូងនៅក្នុងឆ្នាំ 1891 ផ្លូវរថភ្លើងបន្តធ្វើរហូតដល់ឆ្នាំ 1916 ទើបបញ្ចប់។ វាបានភ្ជាប់តំបន់អឺរ៉ុប-រុស្ស៊ីភាគខាងលិចទៅកាន់កំពង់ផែរុស្ស៊ីនៅមហាសមុទ្រប៉ាស៊ីហ្វិកដែលស្ថិតនៅភាគខាងកើត។

ចលនាបដិវត្តចាប់ផ្តើមកើនឡើង៖ ឧស្សាហូបនីយកម្មដ៏ឆាប់រហ័សបានជម្រុញឲ្យមានភាពទោមនស្សក្នុងចំណោមប្រជាជនរុស្ស៊ី។ ការកើនឡើងនៃរោងចក្របាននាំមកនូវបញ្ហាថ្មីៗជាច្រើន ដែលមានដូចជាស្ថានការការងារដ៏ហត់នើយ, ប្រាក់ម៉ោងដ៏តិចតួច, និងពលកម្មកុមារជាដើម។ រដ្ឋាភិបាលបានរារាំងដល់ការបង្កើតសហជីពពាណិជ្ជកម្ម។ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ កម្មករដែលមិនសប្បាយចិត្តចំពោះបទដ្ឋាននៃការរស់នៅដ៏ទាបរបស់ពួកគេ និងកង្វះខាតអំណាចនយោបាយ បានរៀបចំឱ្យមានការតវ៉ា។

ដោយសារតែកត្តាទាំងអស់នេះ ចលនាបដិវត្តមួយចំនួនបានចាប់ផ្តើមរីកឡើង និងប្រកួតប្រជែងគ្នាដើម្បីអំណាច។ ក្រុមមួយដែលដើរតាមទស្សនរបស់លោក កាលមាក្សបានទទួលជោគជ័យនៅក្នុងការបង្កើតចលនាមួយនៅក្នុងប្រទេសរុស្ស៊ី។ ក្រុមអ្នកធ្វើបដិវត្តបែបមាក្សជឿថា វណ្ណៈកម្មករនៅក្នុងរោងចក្រឧស្សាហកម្មនិងទម្លាក់ស្តេច។ ពេលនោះកម្មករទាំងនេះនឹងបង្កើត "អំណាចផ្តាច់មុខរបស់វណ្ណៈអធន់មួយ"។ នេះមានន័យថា វណ្ណៈអធន់(កម្មករ) នឹងដឹកនាំប្រទេស។

នៅក្នុងឆ្នាំ 1903 ពួកមាក្សនិយមជនជាតិរុស្ស៊ីបានបែកចេញជាពីរក្រុម ដោយសារបញ្ហាដែលទាក់ទងជាមួយយុទ្ធសាស្ត្រនៅក្នុងការធ្វើបដិវត្ត។ ក្រុមនិយមកណ្តាលមេនសេវិក ចង់ឱ្យប្រជាជនរុស្ស៊ីទូទៅចូលរួមនៅក្នុងការធ្វើបដិវត្ត។ ចំនែកឯក្រុមជ្រុលនិយមបូលសេវិកចង់ឱ្យមានតែក្រុមបដិវត្តមួយក្រុមតូចប៉ុណ្ណោះដែលសុខចិត្តពលីអ្វីៗគ្រប់យ៉ាងដើម្បីធ្វើបដិវត្ត។

មេដឹកនាំសំខាន់ជាងគេនៅក្នុងក្រុមបូសេវិកគឺលោកវ្លាឌីមៀ អ៊ីលយីច អ៊ូលយ៉ាណូវ។ ក្រោយមកលោកបានប្រើឈ្មោះ លេនីន។ លោកមានបុគ្គលិកលក្ខណៈគួរឱ្យស្រលាញ់ និងជាអ្នកដឹកនាំដ៏ល្អមួយរូប។ លោកក៏ជាមនុស្សម្នាក់គ្មានមេត្តាផងដែរ។ លក្ខណៈទាំងនេះបានជួយឱ្យលោកបន្តិចម្តងៗទទួលបានអំណាចនៅក្នុងក្រុមបូលសេវិក។ នៅដើមទសវត្សរ៍ឆ្នាំ 1900 លោកលេនីនបានរត់គេចទៅកាន់អឺរ៉ុបខាងលិចដើម្បីចៀសវាងការចាប់ខ្លួនលោកពីសំណាក់រដ្ឋាភិបាល។ នៅទីនោះលោកបានរក្សាទំនាក់ទំនងជាមួយក្រុមបូលសេវិកផ្សេងទៀតនៅក្នុងប្រទេសរុស្ស៊ី ។ លេនីននៅពេលនោះបានរង់ចាំរហូតដល់លោកអាចធ្វើដំណើរមកកាន់ប្រទេសរុស្ស៊ីដោយសុវត្ថិភាព។

### 3. វិបត្តិនៅក្នុង និងក្រៅប្រទេស

ពួកអ្នកធ្វើបដិវត្ត មិនចាំបាច់ចំណាយពេលយូរនៅក្នុងការធ្វើឱ្យសម្រេចគោលដៅរបស់ពួកគេឡើយ។ រវាងឆ្នាំ 1904 ដល់ឆ្នាំ 1917 ប្រទេសរុស្ស៊ីបានប្រឈមជានឹងបញ្ហាជាច្រើន។ ព្រឹត្តិការណ៍ទាំងនេះបានបង្ហាញពីភាពខ្សោយរបស់ស្តេច និងបានត្រួសត្រាយផ្លូវសម្រាប់ការធ្វើបដិវត្ត។

សង្គ្រាមរុស្ស៊ី-ជប៉ុន៖ នៅចុងទសវត្សរ៍ឆ្នាំ 1800 ប្រទេសរុស្ស៊ី និងជប៉ុនបានប្រកួតប្រជែងគ្នាដើម្បីត្រួតត្រាប្រទេសកូរ៉េ និងតំបន់ម៉ាន់ជូរី។ ប្រទេសទាំងពីរនេះបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួនស្តីអំពីបញ្ហាទឹកដី ប៉ុន្តែប្រទេសរុស្ស៊ីបានល្មើសកិច្ចព្រមព្រៀងទាំងនោះ។ ប្រទេសជប៉ុនបានធ្វើការសងសឹកតាមរយៈការវាយប្រហារពួករុស្ស៊ីនៅកំពង់ផែអាថ័រតំបន់ម៉ាន់ជូរី នៅក្នុងខែកុម្ភៈ ឆ្នាំ 1904 ។ ព័ត៌មានអំពីការបរាជ័យផ្ទួនៗរបស់រុស្ស៊ី បានបង្កឱ្យមានភាពចលាចលនៅក្នុងប្រទេសរុស្ស៊ី និងនាំទៅដល់ការបះបោរមួយនៅក្នុងពេលកំពុងមានសង្គ្រាមជាមួយជប៉ុន។

ថ្ងៃអាទិត្យដ៏បង្ហូរឈាម-បដិវត្តឆ្នាំ 1905 ៖ នៅថ្ងៃទី 22 ខែមករា ឆ្នាំ 1905 កម្មករ និងគ្រួសាររបស់ពួកគេប្រមាណ 2 សែននាក់បានធ្វើដំណើរមកដល់រាជវាំងរដូវរងាររបស់ស្តេចនៅពីទ័រស្បឺក។ ពួកគេបាននាំយកជាមួយនូវញត្តិមួយដែលស្នើឱ្យមានស្ថានការណ៍ការងារល្អប្រសើរ, សេរីភាគបុគ្គលឱ្យកាន់តែទូលំទូលាយ, និងស្ថាប័ននីតិបញ្ញត្តិជាតិមួយដែលចេញពីការបោះឆ្នោត។ ឧត្តមសេនីយ៍របស់ស្តេចនីកូឡាស់ទី 2 បានបញ្ជាឱ្យកងទ័ពធ្វើការបាញ់ប្រហារទៅលើហ្វូងមហាជន។ មានមនុស្សជាង 1,000 នាក់បានរងរបួស និងប៉ុន្មានរយនាក់ទៀតបានស្លាប់។ ប្រជាជនរុស្ស៊ីភ្លាមៗនោះបានដាក់ឈ្មោះព្រឹត្តិការណ៍នេះថា "ថ្ងៃអាទិត្យដ៏បង្ហូរឈាម" ។

ថ្ងៃអាទិត្យដ៏បង្ហូរឈាមបានជម្រុញឱ្យមានរលកនៃការបះបោរ និងហិង្សារីករាលដាលនៅពាសពេញប្រទេស។ នៅក្នុងខែតុលា ឆ្នាំ 1905 ស្តេចនីកូឡាស់បានសន្យាដោយទើសទាល់នៅក្នុងការផ្តល់សិទ្ធិសេរីដល់ប្រជាជនច្រើនជាងមុន។ ទ្រង់បានអនុញ្ញាតឱ្យមានការបង្កើតឡើងនូវ សភាឌូម៉ា ដែលជាសភាតំណាងរាស្ត្រដំបូងរបស់ប្រទេសរុស្ស៊ី។ សភាឌូម៉ាជួបប្រជុំគ្នាជាលើកដំបូងនៅក្នុងខែឧសភា ឆ្នាំ 1906 ។ មេដឹកនាំសភាឌូម៉ាគឺមនុស្សនិយមកណ្តាល ដែលចង់ឱ្យប្រទេសរុស្ស៊ីក្លាយជាប្រទេសមួយដែលប្រកាន់របបរាជាធិបតេយ្យអាស្រ័យធម្មនុញ្ញស្រដៀងគ្នាទៅនិងចក្រភពអង់គ្លេស។ ប៉ុន្តែ ដោយសារតែស្តេចមានភាពស្ទាក់ស្ទើរនៅក្នុងការបែងចែកអំណាចរបស់ទ្រង់ ស្តេចនីកូឡាស់ទី 2 បានរំលាយសភាឌូម៉ាបន្ទាប់ពីវាបង្កើតឡើងបាន 10 សប្តាហ៍។

សង្គ្រាមលោកលើកទី 1-ការផ្ទុះឡើងជាលើកចុងក្រោយ៖ នៅក្នុងឆ្នាំ 1914 ស្តេចនីកូឡាស់ទី 2 បានធ្វើសេចក្តីសម្រេចចិត្តដ៏សំខាន់មួយក្នុងការនាំប្រទេសរុស្ស៊ីចូលទៅក្នុងសង្គ្រាមលោកលើកទី 1 ។ ប្រទេសរុស្ស៊ីមិនបានត្រៀមទុកជាមួយនូវការប្រើប្រាស់កងទ័ព និងការចំណាយនានាក្នុងការធ្វើសង្គ្រាមឡើយ។ មេបញ្ជាការកងទ័ពដ៏ខ្សោយ និងកងទ័ពដែលបំពាក់អាវុធយុទ្ធភ័ណ្ឌហួសសម័យរបស់ពួកគេមិនអាចប្រៀបធៀបជាមួយនឹងកងទ័ពរបស់អាឡឺម៉ង់បានឡើយ។ កាំភ្លើងយន្តរបស់អាឡឺម៉ង់បានបាញ់សម្លាប់កងទ័ពរុស្ស៊ីដែលរត់សម្រុកចូលស្លាប់រាប់មិនអស់។ រុស្ស៊ីចាញ់ម្តងហើយម្តងទៀត។ មុនពេលសង្គ្រាមបញ្ចប់មួយឆ្នាំ កងទ័ពរុស្ស៊ីជាង 4 លាននាក់ត្រូវ

បានសម្លាប់, រងរបួស, ឬចាប់ធ្វើជាឈ្លើយសឹក។ ក៏ដូចជាសង្គ្រាមរុស្ស៊ី-ជប៉ុនដែល ការចូលរបស់រុស្ស៊ីនៅក្នុងសង្គ្រាមលោកលើកទី 1 បានបង្ហាញពីភាពខ្សោយរបស់ស្ដេច និងការដឹកនាំយោធា។

នៅក្នុងឆ្នាំ 1915 ស្តេចនីកូឡាស់ទី 2 បានផ្លាស់ប្តូរមូលដ្ឋានរបស់ទ្រង់ទៅកាន់សមរភូមិមុខ។ នៅទីនោះទ្រង់សង្ឃឹមថានឹងអាចជួយលើកទឹកចិត្តកងទ័ពរបស់ទ្រង់ឱ្យខំប្រឹងដើម្បីទទួលជោគជ័យ។ មហេសីរបស់ទ្រង់ព្រះម្ចាស់ក្សត្រីហ្សារីណា អាឡេហ្សាន់ដ្រាបានដឹកនាំរដ្ឋាភិបាលខណៈពេលអវត្តមានរបស់ទ្រង់។ ទ្រង់មិនបានយកចិត្តទុកដាក់ចំពោះប្រមុខទីប្រឹក្សារបស់ព្រះមហាក្សត្រឡើយ។ ផ្ទុយទៅវិញ ទ្រង់យល់ថាស្ថិតនៅក្រោមឥទ្ធិពលរបស់គ្រូវេទមន្តឈ្មោះរ៉ាសពូទីន។ លោកបានអះអាងខ្លួនឯងថាជា "មនុស្សពិសិដ្ឋ" លោកមានអំណាចវេទមន្តក្នុងការព្យាបាលជំងឺ។

ស្តេចនីកូឡាស់ និងរាជបុត្ររបស់ស្តេចអាឡិចសាន់ឌឺ ព្រះនាមអាឡេស៊ីស កើតមានជំងឺមេរោគក្នុងឈាមដែលជាជំងឺមួយគំរាមកំហែងដល់អាយុជីវិត។ លោករ៉ាសពូទីនហាក់ដូចជាបានធ្វើឱ្យធូរស្រាយនូវជំងឺរបស់ស្តេច។ ដើម្បីជាការតបស្នងរបស់ទ្រង់ ស្តេចអាឡិចសាន់ឌឺបានអនុញ្ញាតឱ្យរ៉ាសពូទីនធ្វើសេចក្តីសម្រេចចិត្តលើកិច្ចការនយោបាយសំខាន់ៗ។ លោកបានប្រឆាំងទៅនឹងវិធានការកំណែទម្រង់នានា និងបានផ្តល់តំណែងសំខាន់ៗដល់មិត្តភ័ក្តរបស់លោក។ នៅក្នុងឆ្នាំ 1916 ក្រុមអភិជនមួយក្រុមបានសម្លាប់រ៉ាសពូទីន។ ពួកគេមានការព្រួយបារម្ភអំពីការកើនឡើងនៃតួនាទីរបស់រ៉ាសពូទីននៅក្នុងកិច្ចការងាររដ្ឋាភិបាល។

ខណៈពេលនោះ នៅឯសមរភូមិមុខវិញ កងទ័ពរុស្ស៊ីបានបះបោរ, រត់ចោលជួរ, ឬបដិសេធនៅក្នុងការស្តាប់បញ្ជា។ នៅឯក្នុងប្រទេសវិញ ស្បៀងអាហារ និងឥទ្ធនៈសម្រាប់ប្រើប្រាស់បានរីងស្ងួត។ តម្លៃទំនិញបានឡើងថ្លៃយ៉ាងខ្លាំង។ មនុស្សមកពីវណ្ណៈទាំងអស់បានតវ៉ាឱ្យមានការផ្លាស់ប្តូរ និងបញ្ចប់ការធ្វើសង្គ្រាម។ ទាំងនីកូឡាស់ និង អាឡិចសាន់ឌឺមិនមានសមត្ថភាពនៅក្នុងការដោះស្រាយបញ្ហាទាំងនេះបានឡើយ។

## 4. បដិវត្តខែមីនា

នៅក្នុងខែមីនា ឆ្នាំ 1917 កម្មការនីរោងចក្រតម្បាញនៅក្នុងទីក្រុងភេត្រូក្រាដបានដឹកនាំការធ្វើកូដកម្មមួយ។ 5 ថ្ងៃបន្ទាប់មក ការបះបោរបានផ្ទុះឡើងដោយសារបញ្ហាកង្វះខាតនំប័ុង្គ និងឥទ្ធនៈ។ មានកម្មករជិត 2 សែននាក់បានដើរក្បួនតាមផ្លូវនឹងបានស្រែកថា "ផ្តួលរំលំរបបផ្តាច់ការ" និង "បញ្ចប់សង្គ្រាម" ។ នៅដើមដំបូងកងទ័ពបានស្តាប់បញ្ជានៅក្នុងការបាញ់បង្រ្កាបលើក្រុមកុប្បករ ប៉ុន្តែក្រោយមកពួកគេត្រឡប់ទៅគាំទ្រក្រុមកុប្បករវិញ។

ស្តេចចុះចេញពីអំណាច៖ ការតវ៉ានៅក្នុងតំបន់បានផ្ទុះទៅជាការបះបោរជាទូទៅមួយដែលគេហៅថា បដិវត្តខែមីនា។ ការបះបោរនេះបានបង្ខំឱ្យស្តេចនីកូឡាស់ទី 2 ដាក់រាជ្យរបស់ទ្រង់។ មួយឆ្នាំក្រោយមកក្រុមអ្នកបដិវត្តមានប្រហារជីវិតស្តេចនីកូឡាស់ និងគ្រួសាររបស់ទ្រង់។ គ្រួសាររាជវង្សរ៉ូម៉ាណូវដែលគ្រប់គ្រងប្រទេសរុស្ស៊ីអស់រយៈពេល 3 សតវត្សរ៍ចុងគ្នាបានដួលរលំ។ បដិវត្តខែមីនា ទទួលបានជោគជ័យនៅក្នុងការទម្លាក់មហាក្សត្រ។ ប៉ុន្តែបដិវត្តនេះបានបរាជ័យនៅក្នុងការបង្កើតរដ្ឋាភិបាលរឹងមាំមួយដើម្បីជំនួសកន្លែងរបស់របបមុន។

មេដឹកនាំសភាឌូម៉ាបានបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ។ លោកអាឡិចសាន់ឌ័រ ក័រេនស្គីបានដឹកនាំរដ្ឋាភិបាលនេះ។ ការសម្រេចចិត្តរបស់លោកនៅក្នុងការបន្តប្រយុទ្ធនៅក្នុងសង្គ្រាមលោកលើកទី 1 បានបណ្ដាលឱ្យលោកបាត់បង់ការគាំទ្រទាំងផ្នែកកងទ័ព និងស៊ីវិល។ ដូចដែលសង្គ្រាមបន្តក្ដៅគគុក ស្ថានការណ៍នៅក្នុងប្រទេសរុស្ស៊ីកាន់តែអាក្រក់ទៅៗ។ ប្រជាកសិករដែលមានការខឹងសម្បា បានទាមទារដីស្រែចំការរបស់ពួកគេ។ កម្មករនៅក្នុងទីក្រុងកាន់តែជ្រុលនិយមទៅៗ។ អ្នកបដិវត្តសង្គមនិយមដែលប្រកួតប្រជែងដើម្បីអំណាចបានបង្កើតសូវៀត។ សូវៀត គឺជាក្រុមប្រឹក្សាក្នុងតំបន់ដែលរួមបញ្ចូលកម្មករ, អ្នកស្រែចំការ, និងកងទ័ព។ នៅក្នុងទីក្រុងជាច្រើន សូវៀតមានឥទ្ធិពលខ្លាំងជាងរដ្ឋាភិបាលបណ្ដុះអាសន្នទៅទៀត។

លេនីនត្រឡប់មកកាន់ប្រទេសរុស្ស៊ីវិញ៖ ពួកអាឡឺម៉ង់ជឿជាក់ថា លេនីន និងអ្នកគាំទ្រចលនាបូលសេវិករបស់លោក និងជម្រុញឱ្យមានភាពចលាចលនៅក្នុងប្រទេសរុស្ស៊ី និងធ្វើឱ្យអន្តរាយដល់ការប្រឹងប្រែងរបស់រុស្ស៊ីក្នុងការធ្វើសង្គ្រាមសង្គ្រាមប្រឆាំងប្រទេសអាឡឺម៉ង់។ ពួកគេបានរៀបចំឱ្យមានការត្រឡប់របស់លេនីនទៅកាន់ប្រទេសរុស្ស៊ីបន្ទាប់ពីការនិរទេសអស់រយៈពេលជាច្រើនឆ្នាំ។ ដោយធ្វើដំណើរតាមទូរថភ្លើងបិទជិតមួយ លេនីនបានមកដល់ទីក្រុងពេត្រូក្រាដនៅក្នុងខែមេសា ឆ្នាំ 1917 ។

## 5. បដិវត្តបូលសេវិក

លេនីន និងពួកបូលសេវិកភ្លាមៗនោះទទួលបានការគ្រប់គ្រងសូវៀតនៅពេត្រូក្រាដក៏ដូចជាសូវៀតនៅក្នុងទីក្រុងសំខាន់ៗផ្សេងទៀតនៅរុស្ស៊ី។ ត្រឹមរដូវស្លឹកឈើជ្រុះ ឆ្នាំ 1917 ប្រជាជននៅក្នុងទីក្រុងនានាបានប្រមូលផ្ដុំគ្នាដើម្បីស្នើ "រាល់អំណាចទាំងអស់ត្រូវប្រគល់ឱ្យសូវៀត"។ ពាក្យស្លោករបស់លេនីន "សន្តិភាព, ទឹកដី, និងនំប៉ុង" ទទួលបានការគាំទ្រយ៉ាងទូលំទូលាយ។ លេនីនបានសម្រេចចិត្តនៅក្នុងការធ្វើសកម្មភាព។

រដ្ឋាភិបាលបណ្ដោះអាសន្នដួលរលំ៖ នៅក្នុងខែវិច្ឆិកា ឆ្នាំ 1917 ដោយមិនមានការប្រកាសជាមុន កងកម្លាំងកម្មកររោងចក្របានឡោមព័ទ្ធរាជវាំងរដូវត្រជាក់នៅពេត្រូក្រាដ។ ដោយហៅខ្លួនឯងថាក្រហមបូលសេវិកពួកគេបានកាន់កាប់ការិយាល័យរដ្ឋាភិបាល និងចាប់ខ្លួនមេដឹកនាំរដ្ឋាភិបាលបណ្ដោះអាសន្ន។ លោកក័រេនស្គី និងសហការីរបស់លោកបានបាត់ខ្លួនយ៉ាងឆាប់រហ័សដូចពួកក្រុមរាជានិយម ដែលលោកបានទម្លាក់។

បូលសេវិកឡើងគ្រប់គ្រងអំណាច៖ ប៉ុន្មានថ្ងៃបន្ទាប់ពី ឡើងគ្រប់គ្រងអំណាច លេនីនបានបញ្ជាឱ្យមានការបែងចែកដីស្រែចំការទាំងអស់ឱ្យទៅអ្នកស្រែចំការ។ លេនីន និងបូលសេវិកបានប្រគល់ការគ្រប់គ្រងរោងចក្រដល់កម្មករ។ រដ្ឋាភិបាលបូលសេវិកក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយប្រទេសអាឡឺម៉ង់ដើម្បីបញ្ឈប់រាល់ការប្រយុទ្ធគ្នា និងចាប់ផ្ដើមការចរចារសន្តិភាព។

នៅក្នុងខែមីនា ឆ្នាំ 1918 ប្រទេសរុស្ស៊ី និងប្រទេសអាឡឺម៉ង់បានចុះហត្ថលេខាលើសន្ធិសញ្ញាប្រេស្ត-លីតូវ ។ ប្រទេសរុស្ស៊ីបានចុះចាញ់ និងបានប្រគល់ទឹកដីមួយផ្នែកធំរបស់ពួកគេឱ្យទៅប្រទេសអាឡឺម៉ង់ និងសម្ព័ន្ធមិត្តរបស់អាឡឺម៉ង់។ ចំណុចដែលគួរឱ្យអាម៉ាស់នៅក្នុងសន្ធិសញ្ញានេះបានបង្កឱ្យមានកំហឹងក្នុងចំណោមប្រជាជនរុស្ស៊ី

ជាច្រើន។ ពួកគេប្រឆាំងជាមួយពួកបូលសេវិកនិងគោលនយោបាយរបស់ពួកគេ និងប្រឆាំងទៅនឹងការធ្វើឃាតគ្រួសារាជវង្ស។

សង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅក្នុងប្រទេសរុស្ស៊ី៖ ពួកបូលសេវិកឥឡូវនេះប្រឈមជានឹងបញ្ហាថ្មីមួយគឺការលេចចេញនូវសត្រូវផ្ទៃក្នុងរបស់ពួកគេ។ គូរសត្រូវរបស់ពួកគេបានបង្កើតកងទ័ពស។ កងទ័ពសត្រូវបានបង្កើតឡើងពីក្រុមផ្សេងៗគ្នាជាច្រើន។ ក្រុមទាំងនេះមួយចំនួនគឺជាអ្នកដែលគាំទ្រឱ្យស្តេចត្រឡប់មកគ្រាប់គ្រងអំណាចវិញ ចំណែកក្រុមមួយចំនួនចង់មានរដ្ឋាភិបាលបែបប្រជាធិបតេយ្យ ហើយក៏មានក្រុមសង្គមនិយមមួយចំនួនដែលគាំទ្រលទ្ធិសង្គមនិយមបែបលេនីនផងដែរ។ ដើម្បីអាចយកជ័យជំនះលើពួកបូលសេវិកទល់តែពួកគេរួបរួមគ្នាតែមួយ។ ក្រុមទាំងនេះស្ទើតែមិនសហការជាមួយគ្នាសោះ។ នៅពេលខ្លះក្រុមកងទ័ពស 3 ក្រុមបានវាយប្រយុទ្ធគ្នាជាមួយកងទ័ពក្រហមរបស់ពួកបូលសេវិក។

មេដឹកនាំបដិវត្តលោកលេនីន គឺជាអ្នកមានជំនាញនៅក្នុងការដឹកនាំកងទ័ពក្រហមរបស់ពួកបូលសេវិក។ ចាប់ពីឆ្នាំ 1918 ដល់ឆ្នាំ 1920 សង្គ្រាមស៊ីវិលបានញ៉ាំញីនៅក្នុងប្រទេសរុស្ស៊ី។ ប្រទេសលោកខាងលិចមួយចំនួនដោយរួមមានទាំងសហរដ្ឋអាមេរិកផងនោះបានបញ្ជូនជំនួយយោធា និងកងទ័ពទៅកាន់ប្រទេសរុស្ស៊ីដើម្បីជួយដល់កងទ័ពស។ ប៉ុន្តែ ពួកគេហាក់ដូចជាជួយតិចតួចណាស់។

សង្គ្រាមស៊ីវិលនៅក្នុងប្រទេសរុស្ស៊ី បានបណ្តាលឱ្យមនុស្សស្លាប់ច្រើនជាងការធ្វើបដិវត្តនៅពេលមុនទៅទៀត។ មានប្រជាជនរូស្ស៊ីប្រហែល 14 លាននាក់បានស្លាប់ក្នុងរយៈពេលនៃការប្រយុទ្ធគ្នា 3 ឆ្នាំ និងគ្រោះអត់ឃ្លានបន្ទាប់ពីការប្រយុទ្ធគ្នានេះ។ វិនាសកម្ម និងការបាត់បង់ជីវិតដោយសារការប្រយុទ្ធគ្នា, គ្រោះអត់ឃ្លាន, និងជំងឺឆ្លង នាំឱ្យប្រទេសរុស្ស៊ីធ្លាក់ក្នុងភាពចលាចល។ នៅចុងក្រោយ កងទ័ពក្រហមបានវាយកម្ទិចរាល់គូរសត្រូវទាំងអស់។ ជ័យជំនះនេះ បានបង្ហាញថាពួកបូលសេវិកមានសមត្ថភាពទាំងដណ្តើមអំណាច និងការពារអំណាច។

ប្រៀបធៀបការធ្វើបដិវត្តនៅជុំវិញពិភពលោក៖ សម្រាប់ឥទ្ធិពលរយៈពេលខ្លី និងរយៈពេលវែង បដិវត្តនៅប្រទេសរុស្ស៊ីមានលក្ខណៈដូចគ្នាទៅនិងបដិវត្តនៅប្រទេសបារាំងជាងបដិវត្តនៅសហរដ្ឋអាមេរិក។ បដិវត្តនៅសហរដ្ឋអាមេរិក បានពង្រីកគំនិតនយោបាយរបស់អង់គ្លេសឱ្យទៅជារដ្ឋាភិបាលធម្មនុញ្ញមួយដែលស្ថាបនាឡើងផ្អែកលើរចនាសម្ព័ន្ធជាច្រើនដែលមានស្រាប់។ ផ្ទុយទៅវិញ ទាំងបដិវត្តន៍នៅបារាំង និងបដិវត្តនៅរុស្ស៊ីបានព្យាយាមនៅក្នុងការបំផ្លាញនូវរាល់រចនាសម្ព័ន្ធសង្គម និងនយោបាយដែលមានស្រាប់។ អ្នកធ្វើបដិវត្តនៅបារាំង និងរុស្ស៊ីប្រើប្រាស់អំពើហិង្សា និងភេរវកម្មដើម្បីគ្រប់គ្រងប្រជាជន។ បារាំងបានក្លាយជាប្រទេសរាជាធិបតេយ្យអាស្រ័យធម្មនុញ្ញបានមួយគ្រា ប៉ុន្តែបដិវត្តនៅរុស្ស៊ីបានបង្កើតសង្គមមួយដែលគ្រប់គ្រងដោយរដ្ឋអស់រយៈពេលជាច្រើនទសវត្សរ៍។

## 6. លេនីនរៀបចំសណ្តាប់ធ្នាប់ឡើងវិញ

សង្គ្រាម និងបដិវត្តបានបំផ្លិចបំផ្លាញសេដ្ឋកិច្ចរបស់ប្រទេសរុស្ស៊ី។ ពាណិជ្ជកម្មនៅទ្រឹងមួយកន្លែង។ ផលិតផលឧស្សាហកម្មបានធ្លាក់ចុះ ហើយកម្មករជំនាញជាច្រើនបានរត់ទៅកាន់ប្រទេសផ្សេង។ លេនីនបានប្រែត្រឡប់សេដ្ឋកិច្ចឱ្យរស់ឡើងវិញ និងបានរៀបចំរចនាសម្ព័ន្ធរដ្ឋាភិបាលឡើងវិញ។

គោលនយោបាយសេដ្ឋកិច្ចថ្មី៖ នៅក្នុងខែមីនា ឆ្នាំ 1921 លេនីនបានទុកផែនការណ៍រដ្ឋគ្រប់គ្រងសេដ្ឋកិច្ចរបស់លោកនៅម្ខាងជាបណ្តោះអាសន្នសិន។ ផ្ទុយទៅវិញ លោកបានស្តាបនាឡើងវិញនូវមូលធននិយមកម្រិតទាបមួយដែលហៅថា គោលនយោបាយសេដ្ឋកិច្ចថ្មី។ ការធ្វើកំណែទម្រង់ក្រោមគោលនយោបាយសេដ្ឋកិច្ចថ្មីបានអនុញ្ញាតឱ្យប្រជាកសិករលក់ទិន្នផលដំណាំលើសរបស់ពួកគេ ជំនួសដោយការប្រគល់វាទៅឱ្យរដ្ឋាភិបាល។ រដ្ឋាភិបាលនៅបន្តគ្រប់គ្រងឧស្សាហកម្មសំខាន់ៗ, ធនាគារ, និងវិស័យគមនាគមន៍, ប៉ុន្តែបានអនុញ្ញាតឱ្យរោងចក្រ, ការធ្វើជំនួញ, និងកសិដ្ឋានតូចៗមួយចំនួនដំណើរការដោយម្ចាស់កម្មសិទ្ធិឯកជន។ រដ្ឋាភិបាលក៏បានលើកទឹកចិត្តឱ្យមានវិនិយោគបរទេសផងដែរ។

ដោយសារតែគោលនយោបាយថ្មី និងសន្តិភាពដែលកើតមានឡើងបន្ទាប់ពីសង្គ្រាមស៊ីវិល ប្រទេសរុស្ស៊ីចាប់ផ្តើមស្តារឡើងវិញបន្តិចម្តងៗ។ ត្រឹមឆ្នាំ 1928 ស្រែចំការ និងរោងចក្ររបស់រុស្ស៊ី ផលិតបាននូវផលិតផលជាច្រើនដូចដែលធ្លាប់មានមុនសង្គ្រាមលោកលើកទី 1 ។

កំណែទម្រង់នយោបាយ៖ មេដឹកនាំបូលសេវិកបានយល់ឃើញថាគំនិតជាតិនិយមគឺជាការគំរាមកំហែងមួយដល់ការបង្រួបបង្រួម និងភក្តីភាពចំពោះគណបក្ស។ ដើម្បីត្រួតពិនិត្យលើគំនិតជាតិនិយម លេនីនបានរៀបចំបែងចែកប្រទេសរុស្ស៊ីឱ្យទៅជាតំបន់មួយចំនួនដែលមានរដ្ឋាភិបាលផ្ទាល់ខ្លួន ប៉ុន្តែស្ថិតនៅក្រោមរដ្ឋាភិបាលកណ្តាល។ នៅក្នុងឆ្នាំ 1922 ប្រទេសនេះត្រូវបានដាក់ឈ្មោះថា សាធារណរដ្ឋសង្គមនិយមសហភាពសូវៀត, នៅក្នុងការផ្តល់កិត្តិយសដល់ក្រុមប្រឹក្សាដែលបានជួយបង្កើតបដិវត្តបូលសេវិក។

ពួកបូលសេវិកបានប្តូរឈ្មោះគណបក្សរបស់ពួកគេថាគណបក្សកុំម្មុយនីស្ត។ ឈ្មោះនេះត្រូវបានយកចេញមកពីសំណេររបស់កាល់មាក្ស។ លោកបានប្រើពាក្យ កុំម្មុយនីស្ត ដើម្បីពិពណ៌នាវណ្ណៈសង្គមដែលនឹងលេចចេញបន្ទាប់ពីកម្មករដណ្តើមកាន់កាប់អំណាច។ នៅក្នុងឆ្នាំ 1924 ពួកកុំម្មុយនីស្តបានបង្កើតរដ្ឋធម្មនុញ្ញមួយដែលផ្អែកលើគោលការណ៍សង្គមនិយម និងប្រជាធិបតេយ្យ។ នៅក្នុងការអនុវត្ត គណបក្សកុំម្មុយនីស្តកាន់កាប់អំណាចទាំងអស់។ លេនីនបានបង្កើតរបបដឹកនាំផ្តាច់ការមួយដែលស្ថិតក្រោមគណបក្សកុំម្មុយនីស្ត មិនមែន "របបដឹកនាំផ្តាច់ការស្ថិតក្រោមវណ្ណៈអធន់" ដូចដែលកាល់មាក្សបានលើកឡើងទេ។

### 7. ស្តាលីនក្លាយជាជនផ្តាច់ការ

លេនីនកើតជំងឺដាច់សសៃឈាមក្នុងខួរក្បាលនៅក្នុងឆ្នាំ 1922 ។ លោកនៅរស់ ប៉ុន្តែឧប្បត្តិហេតុនេះបានបង្កើតឱ្យមានចលនាប្រកួតប្រជែងមួយដើម្បីដឹកនាំគណបក្សកុំម្មុយនីស្ត។ នៅក្នុងនោះមនុស្សដែលល្បីល្បាញបំផុត 2 រូបគឺ លោកឡេអន ត្រូតស្គី និងលោកចូសេព ស្តាលីន ។ ស្តាលីនជាមនុស្សនឹងធឹង, រឹងមាំ, និងប្រុងប្រយ័ត្ន។ អំឡុងពេលដែលលោកចូលក្នុងចលនាបូលសេវិកដំបូងលោកបានប្តូរឈ្មោះថា ស្តាលីន ដែលជាភាសារុស្ស៊ីមានន័យថា "បុរសដែកថែប"។ ឈ្មោះនេះគឺស៊ីគ្នាជាមួយលោកណាស់។

ស្តាលីនបានចាប់ផ្តើមឡើងធ្វើជាមេដឹកនាំរដ្ឋាភិបាលរវាងឆ្នាំ 1922 ដល់ឆ្នាំ 1927 ។ នៅក្នុងឆ្នាំ 1922 ក្នុងនាមជាអគ្គលេខាទូទៅនៃគណបក្សកុំម្មុយនីស្ត លោកធ្វើការងារក្នុងគោលបំណងដើម្បីលើកអ្នកគាំទ្ររបស់លោក

ឱ្យកាន់តំណែងសំខាន់ៗនៅក្នុងគណបក្សកុំម្មុយនីស្ត។ លេនីនជឿថាស្តាលីនគឺមនុស្សម្នាក់ដែលមានគ្រោះថ្នាក់។ មុនពេលដែលលោកស្លាប់នៅក្នុងឆ្នាំ 1924 លេនីនបានសរសេរថា "យុទ្ធជនស្តាលីន...បានប្រមូលផ្តុំអំណាចជាច្រើនដាក់នៅក្នុងដៃរបស់គេ ហើយខ្ញុំមិនច្បាស់ទេថាគាត់ដឹងពីវិធីនៅក្នុងការប្រើប្រាស់អំណាចទាំងនោះដោយប្រុងប្រយ័ត្នដែរឬទេ"។ ត្រឹមឆ្នាំ 1929 ស្តាលីនគ្រប់គ្រងគណបក្សកុំម្មុយនីស្តទាំងស្រុង។ លោកត្រូតស្គីត្រូវបានបង្ខំឱ្យនិរទេសនៅក្នុងឆ្នាំ 1929 ដែលជាហេតុនាំឱ្យលែងមាននណារគំរាមកំហែងបន្តទៀត។ ស្តាលីនពេលនោះបានប្រើប្រាស់អំណាចផ្តាច់មុខរបស់លោកជាជនផ្តាច់ការមួយរូប។

# មេរៀនទី 2៖ លទ្ធិផ្តាច់ការ

## 1. រដ្ឋាភិបាលមួយដែលគ្រប់គ្រងអំណាចទាំងស្រុង

ពាក្យថា លទ្ធិផ្តាច់ការ ត្រូវបានពិពណ៌នាថាជាប្រព័ន្ធរដ្ឋាភិបាលមួយដែលរដ្ឋគ្រប់គ្រង និងធ្វើវិជ្ជការអំណាចលើរាល់ទម្រង់សាធារណៈ និងឯកជនទាំងអស់។ មេដឹកនាំផ្តាច់ការដើរតួនាទីជាអ្នកផ្តល់គំនិតអំពីសន្តិសុខ និងបង្ហាញទិសដៅមួយសម្រាប់អនាគត់។ នៅក្នុងសតវត្សរ៍ទី 20 ដោយសារតែការរីករាលដាលនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងការទំនាក់ទំនង វាបានជះឥទ្ធិពលលើរាល់ទម្រង់រស់នៅរបស់ប្រជាជន។

មេដឹកនាំដែលសកម្មមួយរូប ដែលអាចធ្វើឱ្យអ្នកដទៃគាំទ្រគោលនយោបាយ និងពេញចិត្តចំពោះសកម្មភាពរបស់ខ្លួន ភាគច្រើនគឺជាអ្នកដឹកនាំរដ្ឋាភិបាលបែបផ្តាច់ការ។ ជាទូទៅមេដឹកនាំនោះបានប្រើប្រាស់ប៉ូលីសសម្ងាត់ដើម្បីបង្ក្រាបក្រុមអ្នកប្រឆាំង និងធ្វើឱ្យប្រជាជនមានការភ័យខ្លាចចំពោះពួកគេ។ គ្មាននណារម្នាក់រួចផុតពីការសង្ស័យ ឬចោទប្រកាន់ថាពួកគេថាជាសត្រូវរបស់រដ្ឋឡើយ។

លទ្ធិផ្តាច់ការប្រឈមជាមួយនឹងប្រជាធិបតេយ្យរបស់លោកខាងលិចដែលឱ្យតម្លៃខ្ពស់បំផុតទៅលើ ហេតុផល, សេរីភាព, សេចក្តីថ្លៃថ្នូររបស់មនុស្ស, និងតម្លៃរបស់បុគ្គលនីមួយៗ។ ដូចដែលតារាងនៅទំព័របន្ទាប់បានបង្ហាញរាល់រដ្ឋផ្តាច់ការទាំងអស់មានលក្ខណៈដូចគ្នា។

ដើម្បីគ្របដណ្តប់លើប្រទេសជាតិទាំងមូល មេដឹកនាំផ្តាច់ការបានបង្កើតវិធីសាស្ត្រនៅក្នុងការគ្រប់គ្រង និងការបញ្ចុះបញ្ចូល។ វិធីសាស្ត្រទាំងនេះរួមមាន ការប្រើប្រាស់ភេរវកម្ម, ការបំពាក់បំប៉នមនោគមវិជ្ជា, ការឃោសនា, ការវិតត្បិត, និងការធ្វើទុក្ខបុកម្និញលើសាសនា ឬជនជាតិភាគតិច។

ប៉ូលីសភេរវកម្ម៖ មេដឹកនាំរបបផ្តាច់ការប្រើប្រាស់ភេរវកម្ម និងហិង្សាដើម្បីបង្ខំឱ្យគេស្តាប់តាមបង្គាប់ និងដើម្បីបង្ក្រាបក្រុមអ្នកប្រឆាំង។ ជាទូទៅ ប៉ូលីសត្រូវបានគេរំពឹងថានឹងឆ្លើយតបចំពោះសកម្មភាពឧក្រិដ្ឋកម្មនានា និងការពារប្រជាជន។ នៅក្នុងរដ្ឋប្រកាន់លទ្ធិផ្តាច់ការ ប៉ូលីសដើរតួនាទីជាអ្នកបម្រើឱ្យគោលនយោបាយរបស់រដ្ឋាភិបាលកណ្តាល។ ពួកគេដើរតួនាទីជាអ្នកស៊ើបការណ៍ប្រជាជន ឬគំរាមកំហែងពួកគេ។ ពេលខ្លះពួកគេប្រើប្រាស់កម្លាំងទាំងកម្រោល ឬពេលខ្លះដើម្បីសម្រេចគោលដៅពួកគេអាចឈានដល់ការសម្លាប់ប្រជាជនទៀតផង។

ការបំពាក់បំប៉នមនោគមវិជ្ជា៖ រដ្ឋប្រកាន់របបផ្តាច់ការជឿជាក់លើការបំពាក់បំប៉នមនោគមវិជ្ជាតាមរយៈការបង្រៀនអំពីគោលនយោបាយរបស់រដ្ឋាភិបាលទៅដល់ប្រជាជន។ ការត្រួតត្រាវិស័យអប់រំគឺជារឿងសំខាន់បំផុតដើម្បីធ្វើការផ្សព្វផ្សាយអំពីកិត្តិសព្ទ និងគោលនយោបាយរបស់មេដឹកនាំ និងដើម្បីធ្វើប្រជាជនទាំងអស់ជឿថា ពួកគេត្រូវតែមានភក្តីភាព និងគាំទ្រមេដឹកនាំរបស់ពួកគេដោយឥតលក្ខខ័ណ្ឌ។ ការបំពាក់បំប៉នមនោគមវិជ្ជាចាប់ផ្តើមជាមួយនឹងកុមារតូចៗតាមរយៈការបញ្ចុះបញ្ចូលរបស់ក្រុមយុវជន និងការអប់រំនៅសាលារៀន។

ការឃោសនា និងការវិតត្បិត៖ រដ្ឋប្រកាន់របបផ្តាច់ការបានឃោលនានូវព័ត៌មានដែលលំអៀង ឬមិនគ្រប់ជ្រុងជ្រោយដើម្បីធ្វើឱ្យប្រជាជនទទួលយកគោលនយោបាយ ឬសកម្មភាពមួយចំនួនរបស់រដ្ឋាភិបាល។ ការត្រួតត្រា

លើប្រព័ន្ធផ្សព្វផ្សាយទាំងអស់បានអនុញ្ញាតឱ្យរដ្ឋាភិបាលអាចឃោលនានូវព័ត៌មានទាំងអស់នេះបាន។ មិនមានការបោះពុម្ពផ្សាយ, ខ្សែភាពយន្ត, សិល្បៈ, ឬតន្ត្រីណាត្រូវបានអនុញ្ញាតឱ្យចេញផ្សាយដោយមិនមានការយល់ព្រមពីរដ្ឋឡើយ។ ប្រជាជនត្រូវហ៊ុំព័ទ្ធទៅដោយព័ត៌មានមិនពិត ដែលមើលទៅហាក់ដូចជាពិតអញ្ចឹង។ ការបញ្ចេញយោបល់អំពីភាពមិនត្រឹមត្រូវនៃព័ត៌មាន ត្រូវបានគេចាត់ទុកថាជាសកម្មភាពក្បត់ជាតិ និងត្រូវទទួលពិន័យធ្ងន់ធ្ងរ។ បុគ្គលទាំងឡាយណាដែលមិនយល់ស្របត្រូវបានគេដកចេញពីការងារ ឬពួកគេអាចត្រូវបានគេចាប់ដាក់គុក ឬសម្លាប់ចោល។

ការធ្វើទុក្ខបុកម្និញលើសាសនា និងជនជាតិភាគតិច៖ មេដឹកនាំរបបផ្តាច់ការតែងតែបង្កើតពាក្យ "សត្រូវរបស់រដ្ឋ" ដើម្បីចោទប្រកាន់ទៅលើជនទាំងឡាយណាដែលធ្វើខុសពីគោលនយោបាយរបស់រដ្ឋាភិបាល។ ជាទូទៅសត្រូវទាំងនេះភាគច្រើនគឺជាសមាជិកក្រុមសាសនា ឬក្រុមជនជាតិភាគតិច។ ក្រុមទាំងនេះមានភាពងាយស្រួលនៅក្នុងការកំណត់អត្តសញ្ញាណ និងជាជនរងគ្រោះនៃអំពើភេរវកម្ម និងអំពើហិង្សា។ ពួកគេត្រូវបានបង្ខំឱ្យរស់នៅក្នុងតំបន់ដាក់លាក់ណាមួយ ឬស្ថិតនៅក្រោមច្បាប់មួយចំនួនដែលប្រើសម្រាប់តែពួកគេប៉ុណ្ណោះ។

## 2. ស្តាលីនស្ថាបនារដ្ឋប្រកាន់របបផ្តាច់ការមួយ

ស្តាលីនបានគោលបំណងចង់បង្កើតរដ្ឋកុំម្មុនីស្តល្អឥតខ្ចោះមួយនៅក្នុងប្រទេសរុស្ស៊ី។ ដើម្បីសម្រេចគោលបំណងរបស់លោក ស្តាលីនបានរៀបចំផែនការមួយដើម្បីប្រែក្លាយសហភាពសូវៀតឱ្យក្លាយជារដ្ឋប្រកាន់របបផ្តាច់ការមួយ។ លោកចាប់ផ្តើមស្ថាបនារដ្ឋផ្តាច់ការរបស់លោក ដោយធ្វើការកម្ចាត់សត្រូវរបស់លោក ទាំងសត្រូវពិត និងសត្រូវដែលលោកសង្ស័យ។

ប៉ូលីសរដ្ឋ៖ ស្តាលីនបានបង្កើតប៉ូលីសរដ្ឋមួយដើម្បីរក្សាអំណាចរបស់លោក។ ប៉ូលីសសំងាត់របស់ស្តាលីនបានប្រើប្រាស់រថក្រោះ និងរថពាសដែកដើម្បីបញ្ឈប់កុប្បកម្មនានា។ ពួកគេតាមដានខ្សែទូរស័ព្ទ, អានសំបុត្រ, និងដាក់អ្នកស៊ើបការគ្រប់ទីកន្លែង។ សូម្បីតែកុមារក៏ត្រូវរាយការណ៍ដល់អាជ្ញាធរអំពីចំណុចមិនស្មោះត្រង់របស់ឪពុកម្តាយរបស់ពួកគេ ដែលពួកគេបានស្តាប់ឮ។ គ្រួសារទាំងអស់មានការភ័យខ្លាចថាមានអ្នកមកគោះទ្វារនៅព្រឹកព្រលឹម ដែលជាទូទៅនៅពេលដែលមានគោះទ្វាបែបនេះ នោះនឹងមានសមាជិកគ្រួសារណាម្នាក់ត្រូវបានគេចាប់ខ្លួនជាមិនខាន។ ប៉ូលីសសម្ងាត់ចាប់ខ្លួន និងសម្លាប់ជនទាំងឡាយណាដែលគេហៅថាជាក្បត់អស់រាប់លាននាក់។ នៅក្នុងឆ្នាំ 1934 ស្តាលីនបានត្រឡប់ទៅកម្ចាត់ជនក្បត់នៅក្នុងគណបក្សកុំម្មុយនីស្តម្តង។ នៅក្នុងឆ្នាំ 1937 លោកបានបើកយុទ្ធនាការធ្វើវិសុទ្ធកម្មដ៏ធំមួយ ដែលជាយុទ្ធនាការភេរវកម្មមួយសំដៅទៅដល់ការដកចេញនូវជនទាំងឡាយណាដែលគំរាមកំហែងដល់អំណាចរបស់លោក។ ពួកបូលសេវិកចាស់រាប់ពាន់អ្នក ដែលបានជួយបង្កើតឱ្យមានបដិវត្តឆ្នាំ 1917 ត្រូវបានចាប់យកទៅកាត់ទោស។ ពួកគេត្រូវបានសម្លាប់ ឬបញ្ជូនទៅកាន់ជុំរុំការងារសម្រាប់ការប្រព្រឹត្តិបទឧក្រិដ្ឋប្រឆាំងរដ្ឋសូវៀត។ នៅពេលដែលការធ្វើវិសុទ្ធកម្មដ៏ធំត្រូវបានបញ្ចប់នៅក្នុងឆ្នាំ 1938 ស្តាលីនទទួលបានសិទ្ធិនៅក្នុងការគ្រប់គ្រងរដ្ឋាភិបាលសូវៀត និងគណបក្សកុំម្មុយនីស្តទាំងមូល។

ប្រវត្តិវិទូប៉ាន់ប្រមាណថា អំឡុងពេលនៃការធ្វើវិសុទ្ធកម្មនេះ ស្តាលីនបានសម្លាប់មនុស្សចន្លោះពី 8 លាន ទៅ 13 លាននាក់។

ការឃោសនា និងការរិតត្បិតនៅរុស្ស៊ី៖ រដ្ឋាភិបាលរបស់ស្តាលីនបានត្រួតត្រាលើកាសែត, ភាពយន្ត, វិទ្យុ, និងប្រភពព័ត៌មានទាំងអស់។ អ្នកនិពន្ធ, អ្នកតែងភ្លេង, និងវិចិត្រករសូវៀតជាច្រើនក៏ជាជនរងគ្រោះនៃការរិតត្បិតនេះផងដែរ។ ស្តាលីននឹងមិនអនុញ្ញាតឱ្យមានស្នាដៃច្នៃប្រឌិតណាមួយដែលមិនបានអនុលោមតាមគោលការណ៍របស់រដ្ឋឡើយ។ ការសែត និងវិទ្យុសូវៀតផ្សព្វផ្សាយលើកសរសើរពីស្នាដៃរបស់កុំម្មុយនីស្ត, ស្តាលីន, និងកម្មវិធីសេដ្ឋកិច្ចរបស់លោក។

ស្ថិតនៅក្រោមការដឹកនាំរបស់ស្តាលីន សិល្បៈក៏ត្រូវបានគេប្រើដើម្បីឃោសនាផងដែរ។ នៅក្នុងឆ្នាំ 1930 នៅក្នុងវិចារណកថាមួយនៅក្នុងកាសែតគណបក្សកុំម្មុយនីស្តឈ្មោះថាប្រាវដា បានពន្យល់ពីគោលបំណងនៃសិល្បៈថា "អក្សរសិល្ប៍, រោងភាពយន្ត, និងសិល្បៈត្រូវស្ថិតនៅក្រោមដៃរបស់វណ្ណៈអធន់ ដែលគេត្រូវប្រើវាដើម្បីបង្ហាញពីគំរូជាវិជ្ជមាននៃអ្នកផ្តួចផ្តើមគំនិង និងវីរៈបុរសការងារ"។

ការអប់រំ និងការបំពាក់បំប៉នមនោគមវិជ្ជា៖ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តាលីន រដ្ឋាភិបាលគ្រប់គ្រងវិស័យអប់រំទាំងមូលចាប់ពីសាលាមត្តេយ្យសិក្សាដល់មហាវិទ្យាល័យ។ កុមាររៀនពីគុណូបការរបស់គណបក្សកុំម្មុយនីស្ត។ សាស្ត្រាចារ្យ និងនិស្សិតនៅមហាវិទ្យាល័យអ្នកដែលមិនយល់ស្របចំពោះការបកស្រាយប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្ររបស់គណបក្សកុំម្មុយនីស្ត ប្រឈមទៅនឹងការបាត់បង់ការងារ ឬប្រឈមទៅនឹងការចាប់ដាក់គុក។ មេដឹកនាំគណបក្សនៅក្នុងសហភាពសូវៀតបានបង្រៀនកម្មករ និងអ្នកស្រែចំការអំពីមនោគមរបស់កុំម្មុយនីស្ត។ ពួកគេក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការបូជា និងប្រឹងប្រែងចំពោះការងារដើម្បីស្ថាបនារដ្ឋកុំម្មុយនីស្ត។ ក្រុមយុវជនដែលគាំទ្រដោយរដ្ឋបានបណ្តុះបណ្តាលសមាជិកបក្សថ្មី។

ការធ្វើទុក្ខបុកម្នេញលើសាសនា៖ ពួកកុំម្មុយនីស្តមានគោលបំណងនៅក្នុងការផ្លាស់ប្តូរពីការអប់រំសាសនាទៅជាការអប់រំមនោគមកុំម្មុយនីស្តវិញ។ ស្ថិតនៅក្រោមការដឹកនាំរបស់ស្តាលីន រដ្ឋាភិបាល និងសម្ព័ន្ធយោធាដែលគ្មានជំនឿ ដែលជាក្រុមផ្លូវការមួយគាំទ្រគំនិតដែលថាមិនមានអាទិទេព បានធ្វើការឃោសនាវាយប្រហារលើសាសនា។ "សារមន្ទីរអអាទិទេពនិយម" បានដាក់តាំងរូបភាពនានា ដើម្បីបង្ហាញថាជំនឿសាសនាគឺជារឿងអបិយជំនឿ។ ប៉ុន្តែមានប្រជាជននៅក្នុងសហភាពសូវៀតជាច្រើននៅតែប្រកាន់ភ្ជាប់នូវជំនឿរបស់ពួកគេ។

ព្រះវិហារអូតូដុកនៅរុស្ស៊ីគឺជាគោលដៅចំបងនៅការធ្វើទុក្ខបុកម្នេញ។ ក្រុមសាសនាផ្សេងៗទៀតក៏ទទួលរងគ្រោះខ្លាំងណាស់ដែរ។ ប៉ូលីសបានកម្ទិចសំណង់ព្រះវិហារ និងទីសក្ការៈដ៏ល្អធេតធាយ ហើយមេដឹកនាំសាសនាជាច្រើនត្រូវបានសម្លាប់ និងបញ្ជូនទៅកាន់ជុំរុំការងារ។

ដើម្បីការទទួលបានជោគជ័យនៅក្នុងការធ្វើឲ្យរដ្ឋកុំម្មុយនីស្តមានភាពល្អឥតខ្ចោះ ប្រជាពលរដ្ឋសូវៀតត្រូវលះបង់ក្នុងទំហំដ៏ធំមួយ។ ការគ្រប់គ្រងសង្គមទាំងមូលរបស់ស្តាលីនបានលុបបំបាត់នូវសិទ្ធិរបស់ប្រជាពលរដ្ឋ និងសេរីភាព ក្នុងគោលបំណងដើម្បីបង្កើនអំណាចដល់រដ្ឋ។

## 3. ស្តាលីនដណ្តើមការគ្រប់គ្រងសេដ្ឋកិច្ច

ដូចដែលស្តាលីនទទួលបានអំណាចគ្រប់គ្រងសង្គមទាំងមូល លោកបានបង្កើតគម្រោងមួយនៅក្នុងការរុះរើសេដ្ឋកិច្ច។ លោកបានប្រកាសថា "យើងស្ថិតនៅពីក្រោយប្រទេសជឿនលឿន 50 ទៅ 100 ឆ្នាំ"។ ជាការល្អប្រើយើងត្រូវតែធ្វើឱ្យគម្លាតនេះនៅត្រឹម 10 ឆ្នាំ។ នៅក្នុងឆ្នាំ 1928 គម្រោងរបស់ស្តាលីនដែលបានស្នើឱ្យមានសេដ្ឋកិច្ចបង្គាប់បញ្ជា ដែលជាប្រព័ន្ធមួយដែលរដ្ឋាភិបាលធ្វើសេចក្តីសម្រេចចិត្តលើសេដ្ឋកិច្ច។ ស្ថិតនៅក្រោមប្រព័ន្ធនេះមេដឹកនាំនយោបាយបានកំណត់អំពីតម្រូវការសេដ្ឋកិច្ចរបស់ប្រទេស និងកំណត់ថាត្រូវធ្វើយ៉ាងដូចម្តេចដើម្បីបំពេញតម្រូវការនោះ។

បដិវត្តឧស្សាហកម្មមួយ៖ ស្តាលីនបានពង្រាងជាដំបូងនូវ ផែនការ 5 ឆ្នាំ សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចសហភាពសូវៀត។ ផែនការ 5 ឆ្នាំ បានដាក់ចេញនូវការកំណត់ ឬគោលបំណងធំៗមួយចំនួនដែលមិនអាចធ្វើបាន ដែលមានដូចជា ការបង្កើនផលិតផលដែកថែប, ធ្យូងថ្ម, ប្រេង, និងអេឡិចត្រូនិច។ ដើម្បីសម្រេចគោលដៅទាំងនេះរដ្ឋាភិបាលបានកម្រិតការផលិតទំនិញសម្រាប់ការប្រើប្រាស់នានា។ ជាលទ្ធផល ប្រជាជនប្រឈមទៅនឹងកង្វះខាតទីលំនៅ, ចំណីអាហារ, សំលៀកបំពាក់, និងទំនិញចំបាច់ផ្សេងៗទៀត។

វិធីសាស្ត្រតឹងរឹងរបស់ស្តាលីនបានបង្កើតឱ្យមានលទ្ធផលសេដ្ឋកិច្ចដ៏គួរឲ្យចាប់អារម្មណ៍។ បើទោះបីជាគោលដៅភាគច្រើននៃផែនការ 5 ឆ្នាំលើកទី 1 បានបរាជ័យក៏ដោយ ក៏ពួកសូវៀតទទួលបានអត្ថប្រយោជន៍ច្រើនគួរសម។ ផែនការទី 2 ត្រូវបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1933 ដែលសម្មត់ថាទទួលបានជោគជ័យពាក់កណ្តាល។ ចាប់ពីឆ្នាំ 1928 ដល់ឆ្នាំ 1937 ផលិតផលឧស្សាហកម្មដែកថែបបានកើនឡើងជាង 25%។

បដិវិត្តកសិកម្មមួយ៖ នៅក្នុងឆ្នាំ 1928 រដ្ឋាភិបាលបានចាប់ផ្តើមរឹបអូសយកដីកសិកម្មពីម្ចាស់កម្មសិទ្ធិឯកជនប្រមាណ 25 លាននាក់នៅក្នុងសហភាពសូវៀត។ ពួកគេបានបញ្ចូលដីស្រែចំការទាំងនោះជាមួយគ្នាឱ្យក្លាយជាដីដ៏ធំមួយ រដ្ឋាភិបាលកាន់កាប់ដីស្រែចំការទាំងនោះ ដែលគេហៅថា សហកណ៍បង្កបង្កើនផល។ គ្រួសាររាប់រយធ្វើការនៅលើស្រែចំការទាំងនេះ ដែលគេហៅថាសហករណ៍រួបរួម, ដោយបង្កបង្កើនផលសម្រាប់រដ្ឋ។ រដ្ឋាភិបាលរំពឹងថា ការធ្វើទំនើបកម្មម៉ាស៊ីនដែលប្រើប្រាស់នៅក្នុងសហករណ៍បង្កបង្កើនផលនឹងលើកម្ពស់ផលិតផលចំណីអាហារ និងកាត់បន្ថយចំនួនកម្មករ។ ការប្រឆាំងកើតមានឡើងខ្លាំងក្លាក្នុងចំណោមពួកគូឡាក់ដែលជាប្រជាកសិករមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ រដ្ឋាភិបាលសូវៀតបានសម្រេចនៅក្នុងការកំចាត់ពួកគេចោល។

ប្រជាកសិករបានវាយប្រយុទ្ធយ៉ាងខ្លាំងក្លាជាមួយនឹងការព្យាយាមរបស់រដ្ឋាភិបាល ក្នុងការយកដីធ្លីរបស់ពួកគេ។ មានប្រជាជនជាច្រើនបានសម្លាប់សត្វចិញ្ចឹម និងកម្ទេចផលដំណាំរបស់ពួកគេដើម្បីធ្វើការប្រឆាំង។ ប៉ូលីសសម្ងាត់សូវៀតបានប្រមូលផ្តុំប្រជាកសិករឱ្យទៅជាសហករណ៍បង្កបង្កើនផល តាមរយៈការបង្ខិតបង្ខំដោយប្រើចុងកាំភ្លើង។ មានប្រជាកសិករចន្លោះពី 5 លាន ទៅ 10 លាននាក់បានស្លាប់ដោយសារលទ្ធិផលនៃបដិវត្តកសិកម្មរបស់ស្តាលីន។ ត្រឹមឆ្នាំ 1938 មានប្រជាកសិករជាង 90 ភាគរយរស់នៅក្នុងសហករណ៍បង្កបង្កើនផល។ ដូចដែលអ្នកឃើញនៅក្នុងតារាងខាងក្រោម ផលិតផលកសិកម្មស្ថិតនៅក្នុងទិសដៅនៃការកើនឡើង។ នៅក្នុងឆ្នាំនោះ

ប្រទេសសូវៀតផលិតផលស្រូវសាលីបានកើនឡើងពីរដងធៀបទៅនឹងផលិតផលក្នុងឆ្នាំ 1928 មុនពេលបង្កើតសហករណ៍បង្កបង្កើនផល។

នៅក្នុងតំបន់ដែលការធ្វើស្រែចំការមានភាពលំបាក រដ្ឋាភិបាលបានបង្កើតជាកសិដ្ឋានរបស់រដ្ឋ។ កសិដ្ឋានរដ្ឋទាំងអស់នេះដំណើរការដូចជារោងចក្រដែរ។ កម្មករទទួលបានប្រាក់ម៉ោងជំនួសដោយការចែករំលែកផលចំណេញ។ កសិដ្ឋានរដ្ឋទាំងនេះមានទំហំធំជាងសហករណ៍ ហើយភាគច្រើនដាំដុះដំណាំស្រូវសាលី។

## 4. ជីវភាពរស់នៅប្រចាំថ្ងៃក្រោមស្តាលីន

ការគ្រប់គ្រងបែបផ្តាច់ការរបស់ស្តាលីននាំឱ្យប្រែប្រួលសង្គមសូវៀត។ តួនាទីរបស់ស្ត្រីបានកើនឡើងយ៉ាងច្រើន។ ប្រជាជនទទួលបានការបណ្តុះបណ្តាលប្រសើរជាងមុន និងស្ទាត់ជំនាញលើបច្ចេកវិទ្យាថ្មីៗ។ ការផ្លាស់ប្តូរដ៏ខ្លាំងក្លានូវជីវភាពរស់នៅរបស់ប្រជាជន នាំមកនូវផលប៉ះពាល់ដ៏ខ្លាំងក្លាមួយ។ ប្រជាពលរដ្ឋសូវៀតយល់ឃើញថាសេរីភាពរបស់ពួកគេត្រូវបានកម្រិត, ការផ្គត់ផ្គង់ទំនិញប្រើប្រាស់មានកង្វះខាត, និងការប្រឆាំងត្រូវបានហាមឃាត់។

ផែនការសេដ្ឋកិច្ចរបស់ស្តាលីនបានជម្រុញឱ្យមានតម្រូវការកម្មករជំនាញក្នុងចំនួនដ៏ច្រើនមួយ។ សកលវិទ្យាល័យ និងការបណ្តុះបណ្តាលបច្ចេកទេសបានក្លាយជាកន្លឹះសំខាន់មួយសម្រាប់ធ្វើឱ្យជីវិតរស់នៅល្អប្រសើរ។ ដូចដែលយុវជនម្នាក់បានពន្យល់ថា "ប្រសិនបើមនុស្សម្នាក់មិនចង់ក្លាយជាកសិករនៅក្នុងសហករណ៍ ឬគ្រាន់តែជាស្ត្រីបោះសម្អាតម្នាក់នោះទេ មានតែវិធីតែមួយគត់ គឺអ្នកត្រូវទទួលការអប់រំ"។

ស្ត្រីទទួលបានសិទ្ធិ៖ បដិវត្តបូលសេវិកឆ្នាំ 1917 បានប្រកាសថាបុរស និងស្ត្រីគឺស្មើគ្នា។ ច្បាប់នានាត្រូវបានគេអនុម័តដើម្បីផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រីទាំងឡាយ។ បន្ទាប់ពីស្តាលីនក្លាយជាមេដឹកនាំផ្តាច់ការ ស្ត្រីបានជួយដល់សេដ្ឋកិច្ចដែលគ្រប់គ្រងដោយរដ្ឋឱ្យរុងរឿង។ ស្ថិតនៅក្រោមផែនការ 5 ឆ្នាំ ពួកគេមិនមានជម្រើសឡើយគឺត្រូវចូលរួមនៅក្នុងការធ្វើការងារ។ រដ្ឋបានផ្តល់ការមើលថែទាំកូនរបស់កម្មករស្ត្រីទាំងឡាយ។ ស្ត្រីវ័យក្មេងមួយចំនួនធ្វើការដូចគ្នាទៅនឹងបុរស។ ស្ត្រីរាប់លាននាក់ធ្វើការនៅក្នុងរោងចក្រ និងការងារស្ថាបនានានា។ ប៉ុន្តែ ប៉ុន្តែនៅតែកាន់កាប់ការងារសំខាន់ៗដដែល។

ដោយទទួលបានឱកាសថ្មីនៅក្នុងការសិក្សា ស្ត្រីបានប្រុងប្រៀបនៅក្នុងការធ្វើការងារនៅក្នុងវិស័យវិស្វកម្ម និងវិទ្យាសាស្ត្រ។ ជាពិសេសជំនាញឱសថសាស្ត្របានទាក់ទាញស្ត្រីជាច្រើន។ ត្រឹមឆ្នាំ 1950 វេជ្ជបណ្ឌិតនៅសូវៀត 75 ភាគរយគឺជាស្ត្រី ។

ស្ត្រីសូវៀតត្រូវធ្វើការយ៉ាងច្រើនសម្រាប់ការកើនឡើងនៃតួនាទីរបស់ពួកគេនៅក្នុងសង្គម។ ក្រៅពីធ្វើការងារពេញម៉ោង ពួកគេត្រូវទទួលខុសត្រូវនៅក្នុងការធ្វើកិច្ចការផ្ទះ និងមើលថែកូន។ សម្រាប់របបផ្តាច់ការ ការបង្កើតកូនត្រូវបានគេចាត់ទុកថាជាកិច្ចការស្នេហាជាតិមាតុភូមិមួយ។ ស្ត្រីសូវៀតត្រូវបានគេរំពឹងថានឹងផ្តល់ឱ្យរដ្ឋនូវអ្នកជំនាន់ក្រោយដែលជាប្រជាពលរដ្ឋមានភក្តីភាព និងស្តាប់ឱវាទ។

## 5. ការសម្រេចការគ្រប់គ្រងទាំងមូល

ត្រឹមពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1930 ស្តាលីនបានប្រើអំណាចដើម្បីផ្លាស់ប្តូរសហភាពសូវៀតទៅជារបបផ្ដាច់ការមួយ និងក្លាយជាមហាអំណាចឧស្សាហកម្ម និងនយោបាយមួយ។ លោកបានឡើងធ្វើជាមេដឹកនាំ និងរក្សាអំណាចរបស់លោកនៅក្នុងគណបក្សកុំម្មុយនីស្តដោយមិនមាននណារម្នាក់អាចប្រឆាំងជាមួយលោកបានឡើយ។ ស្តាលីននឹងមិនអនុញ្ញាតឱ្យមានការបញ្ចេញគំនិតយោបល់របស់បុគ្គលឡើយ។ លោកយល់ថាការបញ្ចេញគំនិតនេះគឺជាការគំរាមកំហែងមួយដល់ការធ្វើតាមរួមគ្នា និងការស្តាប់ឱវាទរបស់ប្រជាជនដែលជាតម្រូវការចំបាច់នៅក្នុងរដ្ឋផ្ដាច់ការមួយ។ ក្នុងអំឡុងនៃដឹកនាំរបស់លោក លោកបានគ្រប់គ្រងសង្គមទាំងមូល និងដឹកនាំដោយអំពើភេរវកម្ម ជាជាងដឹកនាំបែបរដ្ឋាភិបាលអាស្រ័យធម្មនុញ្ញ។

ក៏ដូចជាប្រទេសរុស្ស៊ីដែរ ប្រទេសចិនបានធ្លាក់ក្រោមឥទ្ធិពលនៃទ្រឹស្តីរបស់កាល់មាក្ស និងជំនឿលើកុំម្មុយនីស្ត។ មេដឹកនាំដ៏សកម្ម ម៉ៅសេងទុង បានត្រួសត្រាយផ្លូវនៅក្នុងការផ្លាស់ប្តូរប្រទេសចិនឱ្យក្លាយជារដ្ឋកុំម្មុយនីស្តផ្ដាច់ការមួយ ដែលអ្នកនឹងបានអាននៅក្នុងមេរៀនទី 3 ។

# មេរៀនទី 3 ៖ ចក្រភពចិនដួលរលំ

## 1. ពួកអ្នកជាតិនិយមទម្លាក់រាជវង្សឈីង

ក្នុងចំណោមក្រុមដែលរុញច្រានឱ្យមានការធ្វើទំនើបកម្ម និងជាទូបនីយកម្មគឺក្រុមគូមីនតាង ឬគណបក្សអ្នកជាតិនិយម។ មេដឹកនាំដ៏ខ្លាំងក្លាដំបូងរបស់គណបក្សនេះឈ្មោះថា ស៊ុនយ៉ាតសេន។ នៅក្នុងឆ្នាំ 1911 សម្ព័ន្ធបដិវត្ត ដែលនាំមុខដោយគណបក្សអ្នកជាតិនិយម ទទួលបានជោគជ័យនៅក្នុងទម្លាក់អធិរាជចុងក្រោយរបស់រាជវង្សឈីងចេញពីតំណែង។ រាជវង្សឈីងបានគ្រប់គ្រងប្រទេសចិនចាប់តាំងពីឆ្នាំ 1644 មក។

អស្ថេភាពចាប់ផ្តើមឡើងនៅក្នុងសាធារណរដ្ឋថ្មី៖ នៅក្នុងឆ្នាំ 1912 ស៊ុនយ៉ាតសេនបានក្លាយជាប្រធានាធិបតីនៃសាធារណរដ្ឋចិនថ្មី។ លោកស៊ុនមានគោលបំណងនៅក្នុងការបង្កើតរដ្ឋាភិបាលសម័យទំនើបមួយដែលផ្អែកលើ "គោលការណ៍ 3 របស់ប្រជាជន" ដែលក្នុងនោះរួមមាន ទីមួយគំនិតជាតិនិយម (បញ្ចប់ការត្រួតត្រារបស់បរទេស), ទីពីរសិទ្ធិរបស់ប្រជាជន (ប្រជាធិបតេយ្យ), និងទីបីជីវភាពរស់នៅរបស់ប្រជាជន (សន្តិសុខសេដ្ឋកិច្ចសម្រាប់ប្រជាជនចិនទាំងអស់)។ ស៊ុនយ៉ាតសេនចាត់ទុកថាគំនិតជាតិនិយមគឺជាអាយុជីវិត។ លោកបាននិយាយថា "ប្រជាជនចិន...ដែលមិនមានព្រលឹងជាតិ។ ដូច្នេះ បើទោះបីជាយើងមានប្រជាជន 400 លាននាក់ ដែលរស់នៅប្រមូលផ្តុំគ្នានៅក្នុងប្រទេសចិនក៏ដោយ តាមពិតមនុស្សទាំងអស់នោះគ្រាន់តែជាពំនូកខ្សាច់មួយប៉ុណ្ណោះ"។ បើទោះបីជាលោកជាមេដឹកនាំបដិវត្តមួយរូប ដែលមានឥទ្ធិពលរយៈពេលវែងមួយក៏ដោយ ក៏លោកខ្វះនូវអំណាច និងការគាំទ្រពីយោធាដើម្បីធានាដល់ការបង្រួបបង្រួមជាតិ។

ស៊ុនយ៉ាតសេនបានប្រគល់តំណែងជាប្រធានាធិបតីឱ្យទៅឧត្តមសេនីយ៍ដ៏មានអំណាចមួយរូបឈ្មោះ យ័នសឺខាយ ភ្លាមៗនោះលោកបានបោះបង់ចោលនូវគំនិតនៃការធ្វើបដិវត្តតាមបែបប្រជាធិបតេយ្យ។ សកម្មភាពរបស់លោកបានបង្កឱ្យមានការបះបោរនៅក្នុងតំបន់។ បន្ទាប់ពីឧត្តមសេនីយ៍យ័នសឺខាយបានស្លាប់នៅក្នុងឆ្នាំ 1916 សង្គ្រាមស៊ីវិលបានផ្ទុះឡើង។ អំណាចពិតប្រាកដបានធ្លាក់ទៅក្នុងដៃស្តេចត្រាញ់នៅតាមខេត្តនីមួយៗ ឬមេដឹកនាំយោធាដែលមានអំណាច។ ពួកគេចង់គ្រប់គ្រងដែនដីកាន់តែធំតាមតែកងទ័ពរបស់ពួកគេអាចឈ្លានពានបាន។

សង្គ្រាមលោកលើកទី 1 បង្កឱ្យមានបញ្ហាកាន់តែច្រើន៖ នៅក្នុងឆ្នាំ 1917 រដ្ឋាភិបាលនៅទីក្រុងប៉េកាំងសង្ឃឹមថាពីសម្ព័ន្ធមិត្តនឹងទទួលជ័យជំនះ ដោយបានប្រកាសសង្គ្រាមជាមួយប្រទេសអាឡឺម៉ង់។ មេដឹកនាំមួយចំនួនជឿជាក់ដោយយល់ច្រលំថា ការចូលរួមរបស់ចិននិងធ្វើឱ្យពួកសម្ព័ន្ធមិត្តអរគុណ និងប្រគល់ត្រឡប់មកឱ្យពួកគេវិញនូវការគ្រប់គ្រងដែនដីចិនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសអាឡឺម៉ង់ពីមុនមក។ ប៉ុន្តែស្ថិតនៅក្រោមសន្ធិសញ្ញាទីក្រុងវ៉ែរសៃមេដឹកនាំប្រទេសសម្ព័ន្ធមិត្ត បានផ្តល់ឱ្យជប៉ុនគ្រប់គ្រងដែនដីទាំងអស់នោះ។

នៅពេលដែលព័ត៌មានអំពីសន្ធិសញ្ញាទីក្រុងវ៉ែរសៃបានមកដល់ប្រទេសចិន ការបះបោរបានផ្ទុះឡើងពាសពេញប្រទេសចិន។ នៅថ្ងៃទី 4 ខែឧសភា ឆ្នាំ 1919 និស្សិតដែលមានការខឹងសម្បាប្រមាណ 3,000 នាក់បានប្រមូលផ្តុំគ្នានៅកណ្តាលទីក្រុងប៉េកាំង។ ការធ្វើបាតុកម្មបានរីករាលដាលទៅដល់ទីក្រុងផ្សេងៗទៀត និងបានផ្ទុះ

ទៅជាចលនាជាតិមួយ។ វាត្រូវបានគេហៅថា ចលនា 4 ឧសភា។ កម្មករ, អ្នកលក់ដូរ, និងអ្នកធ្វើការងារជំនាញបានចូលរួមនៅក្នុងចលនានេះ។ បើទោះបីជាផ្លូវការ វាមិនមែនជាការធ្វើបដិវត្តមួយ ក៏ការធ្វើបាតុកម្មទាំងនេះបានបង្ហាញពីការតាំងចិត្តរបស់ប្រជាជនចិននៅក្នុងធ្វើឱ្យប្រទេសចិនក្លាយជាប្រទេសមួយដែលរឹងមាំ និងទំនើប។ លោកស៊ុនយ៉ាតសេន និងសមាជិកគណបក្សអ្នកជាតិនិយមក៏មានគោលបំណងដូចចលនានេះផងដែរ។ ប៉ុន្តែពួកគេមិនអាចពង្រឹងអំណាចកណ្ដាលរបស់ពួកគេដោយខ្លួនឯងបានឡើយ។ យុវជនចិនជាច្រើនបានត្រឡប់មកប្រឆាំងជាមួយជំនឿរបស់ស៊ុនយ៉ាតសេនលើប្រជាធិបតេយ្យរបស់ពួកលោកខាងលិច ដោយពួកគេចាប់អារម្មណ៍ទៅលើប្រភេទកុំម្មុយនីស្តសូវៀតរបស់លេនីន។

## 2. គណបក្សកុំម្មុយនីស្តនៅក្នុងប្រទេសចិន

នៅក្នុងឆ្នាំ 1921 មនុស្សមួយក្រុមបានជួបប្រជុំគ្នានៅទីក្រុងសៀងហៃ ដើម្បីបង្កើតគណបក្សកុំម្មុយនីស្តចិន។ ម៉ៅសេងទុងដែលជាជំនួយការបណ្ណារក្សនៅសាកលវិទ្យាល័យប៉េកាំង ស្ថិតនៅក្នុងចំណោមស្ថាបនិក។ ក្រោយមកលោកបានក្លាយជាមេដឹកនាំបដិវត្តដ៏ល្បីល្បាញបំផុតរបស់ចិន។

ម៉ៅសេងទុងបានចាប់ផ្ដើមអភិវឌ្ឍប្រភេទកុំម្មុនីស្តមួយផ្ទាល់របស់លោក។ លេនីនបានផ្ដោតបដិវត្តមាកហ្សីសរបស់លោក លើស្ថាប័នរបស់លោកនៅតាមទីក្រុងនានានៅក្នុងប្រទេសរុស្ស៊ី។ ម៉ៅសេងទុងបានប្រើប្រាស់វិធីផ្សេងពីនេះ។ លោកជឿថាលោកអាចនាំយកបដិវត្តទៅកាន់តំបន់ទីជនបទ ជាទីកន្លែងដែលប្រជាកសិករអាចជាជនបដិវត្តដ៏ពិតប្រាកដ។

លេនីនជួយសង្គ្រោះប្រទេសចិន៖ ខណៈពេលដែលគណបក្សកុំម្មុយនីស្តត្រូវបានបង្កើតឡើង ស៊ុនយ៉ាតសេន និងគណបក្សអ្នកជាតិនិយមបានបង្កើតរដ្ឋាភិបាលមួយនៅប្រទេសចិនភាគខាងត្បូង។ ក៏ដូចជាពួកកុំម្មុយនីស្តដែរ ស៊ុនយ៉ាតសេនបានស្រងាកចិត្តជាមួយនឹងប្រជាធិបតេយ្យរបស់លោកខាងកលិចដែលបដិសេធនៅក្នុងការគាំទ្ររដ្ឋាភិបាលរបស់លោក។ ស៊ុនយ៉ាតសេនបានសម្រេចចិត្តនៅក្នុងការចងសម្ព័ន្ធមិត្ត រវាងគណបក្សជាតិនិយមរបស់លោកជាមួយគណបក្សកុំម្មុយនីស្តដែលទើបបង្កើតថ្មី។ លោកសង្ឃឹមថាអាចបង្រួបបង្រួមក្រុមអ្នកធ្វើបដិវត្តទាំងអស់ដើម្បីធ្វើសកម្មភាពរួមគ្នាមួយ។

លេនីនបានចាប់យកឱកាសដើម្បីជួយរដ្ឋាភិបាលជាតិនិយមរបស់ចិន។ នៅក្នុងឆ្នាំ 1923 លោកបានបញ្ជូនទីប្រឹក្សា និងសម្ភារៈយោធាមកឱ្យពួកអ្នកជាតិនិយមជាការតបស្នងទៅនឹងការអនុញ្ញាតឱ្យអ្នកកុំម្មុយនីស្តចិនចូលរួមគ្នាជាមួយគណបក្សជាតិនិយម។

ប្រជាកសិករគម្រង់ជួរចូលរួមជាមួយពួកកុំម្មុយនីស្ត៖ បន្ទាប់ពីលោកស៊ុនយ៉ាតសេនស្លាប់នៅក្នុងឆ្នាំ 1925 ជៀងជីស៊ី ដែលគេស្គាល់ជាទូទៅថា ចាងកាយចៀក បានដឹកនាំគណបក្សជាតិនិយម។ ចាងកាយចៀកគឺជាកូនរបស់ពាណិជ្ជករវណ្ណៈកណ្ដាលម្នាក់។ អ្នកដើរតាមចាងកាយចៀកភាគច្រើនគឺជាម្ចាស់ធនាគារ និងអ្នកជំនាញ។ ក៏ដូចជាចាងកាយចៀកដែរ ពួកគេមានការភ័យខ្លាចចំពោះគោលបំណងរបស់កុំម្មុយនីស្តដែលចង់បង្កើតសេដ្ឋកិច្ចបែបសង្គមនិយមមួយដែលយកលំនាំតាមសហភាពសូវៀត។

ចាងកាយចៀកបានសន្យាក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងផ្តល់សិទ្ធិនយោបាយដល់ប្រជាជនចិនទាំងអស់។ ប៉ុន្តែរដ្ឋាភិបាលរបស់លោកបន្តិចម្តងៗ បានក្លាយជារដ្ឋាភិបាលដែលមានប្រជាធិបតេយ្យតិចតួចទៅៗ និងកាន់តែពុករលួយ។ ប្រជាកសិករភាគច្រើនជឿថា ចាងកាយចៀក ធ្វើការតិចតួចដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។ ជាលទ្ធផល ប្រជាកសិករជាច្រើនបានផ្លាស់ប្តូរការគាំទ្ររបស់ពួកគេទៅកាន់គណបក្សកុំម្មុយនីស្តវិញ។ ដើម្បីបញ្ចុះបញ្ចូលឱ្យប្រជាកសិករគាំទ្រ ម៉ៅសេងទុងបានបែងចែកដីដែលពួកកុំម្មុយនីស្តកាន់កាប់ឱ្យទៅប្រជាកសិករនៅក្នុងតំបន់។

អ្នកជាតិនិយម និងពួកកុំម្មុយនីស្តបះទង្គិចគ្នា៖ នៅដើមដំបូង ចាងកាយចៀក បានទុកគំនិតខុសគ្នារបស់លោកជាមួយពួកកុំម្មុយនីស្តនៅម្ខាងសិន។ ដោយសហការគ្នា កម្លាំងជាតិនិយមរបស់ចាងកាយចៀក និងកុំម្មុយនីស្តបានទទួលជោគជ័យនៅក្នុងការវាយប្រយុទ្ធជាមួយស្តេចត្រាញ់នានា។ ភ្លាមៗបន្ទាប់ពីនោះមក លោកប្រែត្រឡប់ជាប្រឆាំងជាមួយនឹងពួកកុំម្មុយនីស្តវិញ។

នៅខែមេសា ឆ្នាំ 1927 កងទ័ពជាតិនិយម និងហ្វូងមនុស្សប្រដាប់ដោយអាវុធបានធ្វើដំណើរទៅកាន់ទីក្រុងសៀងហៃ។ ពួកគេបានសម្លាប់មេដឹកនាំកុំម្មុយនីស្ត និងសមាជិកសហភាពពាណិជ្ជកម្មអស់ជាច្រើននៅតាមដងផ្លូវក្នុងទីក្រុង។ មានការសម្លាប់ដូចគ្នានេះ ក៏បានកើតមានឡើងនៅក្នុងទីក្រុងផ្សេងៗទៀតដែរ។ ពួកជាតិនិយមស្ទើរតែបោសសម្អាតពួកកុំម្មុយនីស្តចិនទាំងស្រុង។

នៅក្នុងឆ្នាំ 1928 ចាងកាយចៀកបានក្លាយជាប្រធានាធិបតីនៃសាធារណរដ្ឋជាតិនិយមចិន។ ទាំងចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកជាផ្លូវការបានទទួលស្គាល់រដ្ឋាភិបាលថ្មីនេះ។ ដោយសារតែការកាប់សម្លាប់ពួកកុំម្មុយនីស្តនៅសៀងហៃ ពួកកុំម្មុយនីស្តមិនបានទទួលស្គាល់រដ្ឋាភិបាលថ្មីនេះឡើយ។ ការក្បាត់ពួកកុំម្មុយនីស្តរបស់ចាងកាយចៀកក៏បានជះឥទ្ធិពលរយៈពេលវែងផងដែរ។ កំហឹងដ៏ឈឺចាប់របស់ពួកកុំម្មុយនីស្តចំពោះការសម្លាប់រង្គាលនេះ បាននាំទៅដល់សង្គ្រាមស៊ីវិលមួយដែលផ្ទុះឡើងរហូតដល់ឆ្នាំ 1949 ។

### 3. សង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅក្នុងប្រទេសចិន

ត្រឹមឆ្នាំ 1930 ពួកអ្នកជាតិនិយម និងពួកកុំម្មុយនីស្តបានវាយប្រយុទ្ធគ្នាដ៏បង្ហូរឈាមនៅក្នុងសង្គ្រាមស៊ីវិលមួយ។ ម៉ៅសេងទុង និងមេដឹកនាំកុំម្មុយនីស្តផ្សេងៗទៀតបានបង្កើតមូលដ្ឋានដោយខ្លួនឯងមួយនៅតំបន់ភ្នំមួយស្ថិតនៅប្រទេសចិនខាងត្បូងភាគកណ្តាល ។ ម៉ៅសេងទុងបានសំដៅយុទ្ធសាស្ត្ររបស់លោកនៅក្នុងការនាំយកបដិវត្តទៅកាន់ទីជនបទថាជា "ការហែលទឹកនៅក្នុងសមុទ្រអ្នកស្រែចំការ"។ លោកបានជ្រើសរើសប្រជាកសិករដើម្បីចូលរួមនៅក្នុងកងទ័ពក្រហមរបស់លោក។ ពេលនោះលោកបានបណ្តុះបណ្តាលឱ្យពួកគេចេះធ្វើសង្គ្រាមបែបទ័ពព្រៃ។ ពួកអ្នកជាតិនិយមបានវាយប្រហារពួកកុំម្មុយនីស្តជាច្រើនលើកច្រើនសារ ប៉ុន្តែបរាជ័យនៅក្នុងការកម្ចាត់ពួកគេ។

ដំណើរព្យុះហយាត្រាដ៏ឆ្ងាយ៖ នៅក្នុងឆ្នាំ 1933 ចាងកាយចៀកបានប្រមូលផ្តុំកងទ័ពមួយក្រុមដែលមានចំនួនយ៉ាងហោចណាស់ 70 ម៉ឺននាក់។ កងទ័ពរបស់ចាងកាយចៀកនៅពេលនោះបានឡោមព័ទ្ធមូលដ្ឋានរបស់

ពួកកុំម្មុយនីស្តនៅតំបន់ភ្នំ។ ដោយសារកងទ័ពរបស់ចាងកាយចៀកមានចំនួនច្រើនជាង មេដឹកនាំកុំម្មុយនីស្តបានដឹងច្បាស់ថា ពួកគេនឹងប្រឈមទៅនឹងការបរាជ័យ។ ក្នុងការដោះស្រាយទៅនឹងស្ថានការណ៍នេះ កងកម្លាំងកុំម្មុយនីស្ត 10 ម៉ឺននាក់បានភៀសខ្លួន។ ពួកគេចាប់ផ្តើមធ្វើដំណើរផ្សងព្រេងក្នុងរយៈចម្ងាយផ្លូវ 6,000 ម៉ាយ ដែលគេហៅថាដំណើរព្យុះហយាត្រាដ៏ឆ្ងាយ។ រវាងឆ្នាំ 1934 ដល់ឆ្នាំ 1935 ពួកកុំម្មុយនីស្តបានដើរមុនកងទ័ពរបស់ចាងកាយចៀកតែមួយជំហានប៉ុណ្ណោះ។ មានមនុស្សរាប់ពាន់នាក់បានស្លាប់ដោយសារភាពអត់ឃ្លាន, រងារ, កម្តៅ, និងរបួស។

ចុងក្រោយ បន្ទាប់ពីការធ្វើដំណើរជាងមួយឆ្នាំមក ម៉ៅសេងទុងជាមួយនឹងអ្នករស់រានកុំម្មុយនីស្ត 7 ទៅ 8 ពាន់នាក់បានរស់នៅក្នុងរូងភ្នំមួយនៅប្រទេសចិនភាគពាយព្យ។ នៅទីនោះពួកគេទទួលបានអ្នកដើរតាមថ្មីៗជាច្រើន។ នៅខណៈពេលដែលសង្គ្រាមស៊ីវិលរវាងពួកជាតិនិយម និងកុំម្មុយនីស្តកំពុងផ្ទុះឡើង ជប៉ុនបានឈ្លានពានប្រទេសចិន។

ការផ្អាកសង្គ្រាមស៊ីវិលបណ្តោះអាសន្នៈ នៅក្នុងឆ្នាំ 1931 ដូចដែលប្រជាជនចិនកំពុងប្រយុទ្ធគ្នាជាមួយចិនគ្នាឯង ប្រទេសជប៉ុនបានមើលឃើញពីការដណ្តើមអំណាចគ្នានេះជាមួយនឹងការចាប់អារម្មណ៍មួយ។ កងទ័ពរបស់ជប៉ុនបានចាប់យកឱកាសពីស្ថានការណ៍ចុះខ្សោយរបស់ប្រទេសចិននេះ។ ពួកគេបានឈ្លានពានតំបន់ម៉ាន់ជូរី ដែលជាខេត្តឧស្សាហកម្មមួយស្ថិតនៅប្រទេសចិនភាគឦសាន។

នៅក្នុងឆ្នាំ 1937 ជប៉ុនបានបើកការវាយប្រហារឈ្លានពានប្រទេសចិនទាំងមូល។ ការទម្លាក់គ្រាប់បែកដ៏ខ្លាំងក្លានៅតាមភូមិ និងទីក្រុងនានាបានសម្រាប់ប្រជាជនចិនរាប់ពាន់នាក់។ វិនាសកម្មនៃស្រែចំការបង្កឱ្យមានមនុស្សជាច្រើនស្លាប់ដោយគ្រោះអត់ឃ្លាន។ ត្រឹមឆ្នាំ 1938 ជប៉ុនបានគ្រប់គ្រងប្រទេសចិនមួយភាគធំ។

ការគំរាមកំហែងរបស់ជប៉ុន បានជម្រុញឱ្យមានកិច្ចព្រមព្រៀងដែលមិនងាយទៅរួចមួយរវាងកងកម្លាំងចាងកាយចៀក និងម៉ៅសេងទុង។ សង្គ្រាមស៊ីវិលបន្តិចម្តងៗត្រូវបានបញ្ឈប់ ដូចដែលពួកជាតិនិយម និងកុំម្មុយនីស្តបានបង្រួបបង្រួមគ្នាជាបណ្តោះអាសន្នដើម្បីប្រយុទ្ធគ្នាជាមួយពួកជប៉ុន។ សភាជាតិបានយល់ស្រមនៅក្នុងការលើកកម្ពស់ការធ្វើកំណែទម្រង់ "គោលការណ៍ទាំង 3 របស់ប្រជាជា" ជាតិនិយម, ប្រជាធិបតេយ្យ, និងជីវភាពរស់នៅរបស់ប្រជាជន ដែលពង្រាងដោយស៊ុនយ៉ាតសេន។ ដូចដែលអ្នកនឹងរៀននៅក្នុងមេរៀនទី 4 គោលការណ៍ស្រដៀងគ្នានេះក៏បានដើរតួនាទីជាកម្លាំងជម្រុញមួយនៅក្នុងប្រទេសឥណ្ឌា និងអាស៊ីនិរតី។

# មេរៀនទី 4៖ ជាតិនិយមនៅក្នុងប្រទេសឥណ្ឌា និងអាស៊ីអាគ្នេយ៍

## 1. ការកើនឡើងនៃគំនិតជាតិនិយមនៅក្នុងប្រទេសឥណ្ឌា

មានក្រុមពីរដែលត្រូវបានបង្កើតឡើងដើម្បីកម្ចាត់ការគ្រប់គ្រងរបស់បរទេសលើប្រទេសឥណ្ឌា ទី 1 គឺក្រុមសមាជជាតិឥណ្ឌាហិណ្ឌូ ឬគណបក្សសមាជ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1885 និងក្រុមទី 2 សម្ព័ន្ធម៉ូស្លីម ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1906 ។ បើទោះបីជាមានការបែងចែកយ៉ាងខ្លាំងរវាងពួកហិណ្ឌូ និងម៉ូស្លីមក៏ដោយ ក៏ពួកគេមានចំណុចរួមមួយចំនួនផងដែរ។ ពួកគេទទួលបានមរតកនៃការគ្រប់គ្រងរបស់អង់គ្លេស និងយល់ដឹងពីគោលគំនិតអំពីប្រជាធិបតេយ្យដូចគ្នា។ ក្រុមទាំងពីរនេះធ្វើការក្នុងគោលបំណងរួមគ្នាគឺដើម្បីទទួលបានឯករាជ្យពីប្រទេសអង់គ្លេស។

សង្គ្រាមលោកលើកទី 1 បង្កើនសកម្មភាពជាតិនិយម៖ រហូតមកដល់សង្គ្រាមលោកលើកទី 1 ប្រជាជនឥណ្ឌាភាគច្រើនមានចំណាប់អារម្មណ៍តិចតួចចំពោះគំនិតជាតិនិយម។ ស្ថានការណ៍បានប្រែប្រួល ដូចដែលប្រជាជនឥណ្ឌាជាងមួយលាននាក់ត្រូវបានបញ្ចូលធ្វើជាកងទ័ពអង់គ្លេស។ ក្នុងការតបស្នងចំពោះការងាររបស់ពួកគេ រដ្ឋាភិបាលអង់គ្លេសសន្យានៅក្នុងការធ្វើកំណែទម្រង់នានាដែលនឹងនាំឱ្យឥណ្ឌាមានរដ្ឋាភិបាលផ្ទាល់ខ្លួនមួយ។

នៅក្នុងឆ្នាំ 1918 កងទ័ពរបស់ឥណ្ឌាបានត្រឡប់ពីសង្គ្រាមមកកាន់ប្រទេសឥណ្ឌាវិញ។ ពួកគេរំពឹងថាអង់គ្លេសនឹងបំពេញការសន្យារបស់ពួកគេ។ ផ្ទុយទៅវិញ ជាថ្មីម្តងទៀតពួកគេត្រូវបានចាត់ទុកប្រជាជនវណ្ណៈទី 2 ដដែល។ អ្នកជាតិនិយមជ្រុលមួយចំនួនបានចាប់ផ្តើមសកម្មភាពហិង្សា ដើម្បីបង្ហាញពីការមិនពេញចិត្តរបស់ពួកគេចំពោះការគ្រប់គ្រងរបស់អង់គ្លេស។ ដើម្បីទប់ស្កាត់ចំពោះការប្រឆាំង នៅក្នុងឆ្នាំ 1919 អង់គ្លេសបានអនុម័តច្បាប់រ៉ូវឡេត។ ច្បាប់នេះបានអនុញ្ញាតឱ្យរដ្ឋាភិបាលអាចចាប់អ្នកធ្វើបាតុកម្មដាក់គុកបានរយៈពេលរហូតដល់ 2 ឆ្នាំ ដោយមិនចាំបាច់ជំនុំជម្រះក្តី។ សម្រាប់ប្រជាជនឥណ្ឌាដែលទទួលបានការអប់រំពីបស្ចិមប្រទេស ការបដិសេធនៅក្នុងជំនុំជម្រះក្តីដោយចៅក្រម គឺជាការរំលោភទៅលើសិទ្ធិបុគ្គលរបស់ពួកគេ។

ការសម្លាប់រង្គាលនៅអំរីតសារ៖ ដើម្បីប្រឆាំងជាមួយនឹងច្បាស់រ៉ូវឡេតនៅរដូវស្លឹកឈើលាស់ឆ្នាំ 1919 ពួកហិណ្ឌូ និងម៉ូស្លីមប្រមាណ 1 ម៉ឺននាក់បានប្រមូលផ្តុំគ្នានៅអំរីតសារដែលជាទីក្រុងធំមួយនៅតំបន់ប៉ុនចាប។ នៅក្នុងកម្មវិធីបុណ្យដ៏ធំមួយនៅក្នុងទីធ្លាមួយជ្រុងបិទជិតមួយ ពួកគេប៉ុនប៉ង់នៅក្នុងការតមអាហារ និងធ្វើការបន់ស្រន់ និងស្តាប់ការថ្លែងសារនយោបាយ។ ការធ្វើបាតុកម្មនេះ ត្រូវបានគេយល់ថាជាការផ្ទុះឡើងនៃគំនិតជាតិនិយមដែលជាការប្រកាសអាសន្នមួយសម្រាប់អង់គ្លេស។ ពួកគេមានការព្រួយបារម្ភជាពិសេសទៅលើសម្ព័ន្ធភាពរបស់ពួកហិណ្ឌូ និងម៉ូស្លីម។

មនុស្សភាគច្រើនដែលប្រមូលផ្តុំគ្នា បានដឹងថារដ្ឋាភិបាលអង់គ្លេសបានហាមឃាត់ការជួបប្រជុំគ្នាជាសាធារណៈ។ ដូច្នេះ មេបញ្ជាការយោធានៅអំរីតសារជឿថាពួកគេមានបំណងចង់ប្រឆាំងជាមួយនឹងការហាមឃាត់ដោយបើកចំហរ។ លោកបានបញ្ជាឱ្យកងទ័ពរបស់លោកបាញ់ប្រហារទៅលើហ្វូងមហាជនដោយមិនមានការជូន

ដំណឹងជាមុន។ ការបាញ់ប្រហារនៅក្នុងទីធ្លាបិទជិតបានបន្តអស់រយៈពេល 10 នាទី។ របាយការណ៍ផ្លូវការបានបង្ហាញថាមានប្រជាជនឥណ្ឌាជិត 400 នាក់បានស្លាប់ និង 1,200 ទៀតរងរបួស។ អ្នកមួយចំនួនទៀតបានវាយតម្លៃថាចំនួនអ្នកស្លាប់ និងរបួសអាចមានច្រើនជាងនេះ។

ព័ត៌មានអំពីការកាប់សម្លាប់ ដែលគេហៅថា ការសម្លាប់រង្គាលនៅ បានបណ្តាលឲ្យផ្ទុះឡើងការខឹងសម្បានៅពាញពេញប្រទេសឥណ្ឌា។ ភ្លាមៗនោះ ប្រជាជនឥណ្ឌារាប់លាននាក់បានផ្លាស់ប្តូរពីភក្តីភាពចំពោះអង់គ្លេសទៅជាជាតិនិយមវិញ។ ប្រជាជនឥណ្ឌាទាំងអស់នេះទាមទារឯករាជ្យ។

## 2. យុទ្ធសាស្ត្របែបអហិង្សារបស់គន្ធី

ការសម្លាប់រង្គាលនៅអំរីតសារបានបង្កើតវិបត្តិការមួយសម្រាប់លោកមហាត្មៈ គន្ធីលេចឡើងជាមេដឹកនាំចលនាជាតិនិយមមួយ។ យុទ្ធសាស្ត្ររបស់គន្ធីសម្រាប់ប្រយុទ្ធជាមួយនឹងភាពអយុត្តិធម៌ ដែលបានវិវត្តចេញមកពីគោលការសាសនាដ៏ខ្លាំងក្លារបស់លោក ទៅជាសកម្មភាពនយោបាយ។ ការអប់រំរបស់លោក បានលាយបញ្ចូលគ្នានូវគោលគំនិតរបស់សាសនាសំខាន់ៗនៅលើពិភពលោក ដោយរួមមាន សាសនាហិណ្ឌូ, សាសនាជេន, សាសនាព្រះពុទ្ធ, សាសនាអ៊ីស្លាម, និងសាសនាគ្រឹស្ត។ គន្ធីបានទាក់ទាញអ្នកដើរតាមលោកបានរាប់លាននាក់។ ភ្លាមៗនោះអ្នកដើរតាមលោកបានហៅលោកថាមហាត្មៈ មានន័យថា "វិញ្ញាណដ៏ប្រសើរ" ។

ការមិនសហការ៖ នៅពេលដែលអង់គ្លេសមិនបានដាក់ទណ្ឌកម្មទៅលើមន្ត្រីទាំងឡាយដែលទទួលខុសត្រូវក្នុងការសម្លាប់រង្គាលនៅអំរីតសារលោកគន្ធី បានទទូចឱ្យសភាជាតិឥណ្ឌាអនុវត្តគោលនយោបាយមួយគឺ ការមិនសហការជាមួយរដ្ឋាភិបាលអង់គ្លេស។ នៅក្នុងឆ្នាំ 1920 គណបក្សសមាជ បានអនុម័តច្បាប់ ការមិនស្តាប់បង្គាប់របស់ជនស៊ីវិល ដោយមិនធ្វើការពិភាក្សា និងបដិសេធជាសាធារណនៅក្នុងការគោរពច្បាស់ដែលមិនត្រឹមត្រូវ និងប្រើប្រាស់វិធីបែបអហិង្សាដើម្បីទទួលបានឯករាជ្យ។ លោកគន្ធីពេលនោះបានបើកយុទ្ធនាការផ្សព្វផ្សាយច្បាប់ការមិនស្តាប់បង្គាប់របស់ជនស៊ីវិល ដើម្បីធ្វើឱ្យអំណាច និងសេដ្ឋកិច្ចរបស់រដ្ឋាភិបាលអង់គ្លេសនៅប្រទេសឥណ្ឌាចុះខ្សោយ។

ការធ្វើពហិការ៖ គន្ធីបានស្នើឱ្យប្រជាជនឥណ្ឌាបដិសេធនៅក្នុងការទិញទំនិញរបស់អង់គ្លេស, ចូលរៀនក្នុងសាលារបស់អង់គ្លេស, បង់ពន្ធឱ្យអង់គ្លេស, ឬចូលរួមនៅក្នុងការបោះឆ្នោត។ គន្ធីទទួលបានជោគជ័យនៅក្នុងការធ្វើពហិការសម្លៀកបំពាក់អង់គ្លេស ដែលជាប្រភពទ្រព្យសម្បត្តិដ៏សំខាន់មួយរបស់អង់គ្លេស។ លោកបានទទូចឱ្យប្រជាជនឥណ្ឌាទាំងអស់ ត្បាញសម្លៀកបំពាក់ផ្ទាល់ខ្លួន។ គន្ធីខ្លួនលោកផ្ទាល់បានចំណាយពេលមួយថ្ងៃ 2 ម៉ោងនៅក្នុងការបង្វិលខ្សែអំបោះដោយប្រើប្រាស់ឧបករណ៍បង្វិលដៅធម្មតាមួយ។ លោកស្លៀកពាក់តែសំលៀកបំពាក់ដែលត្បាញនៅផ្ទះដោយខ្លួនឯងប៉ុណ្ណោះ ហើយលោកបានលើកទឹកចិត្តឱ្យប្រជាជនឥណ្ឌាយកគំរូតាមលោក។ ជាលទ្ធផលនៃការធ្វើពហិការនេះ ការលក់សម្លៀកបំពាក់របស់អង់គ្លេសនៅក្នុងប្រទេសឥណ្ឌាមានការធ្លាក់ចុះយ៉ាងខ្លាំង។

ការបះបោរ និងបាតុកម្ម៖ អាវុធ ការមិនស្តាប់បង្គាប់របស់ជនស៊ីវិល របស់គន្ធីនាំឱ្យសេដ្ឋកិច្ចរបស់អង់គ្លេសជួយប្រទះបញ្ហា។ ពួកគេបានតស៊ូដើម្បីរក្សាការដំណើរការនៃរថភ្លើង, ការដំណើរការនៃរោងចក្រ, និងការផ្ទុះការ

បះបោររបស់ហ្វូងអ្នកទោស។ ពេញមួយឆ្នាំ 1920 អង់គ្លេសបានចាប់ខ្លួនប្រជាជនឥណ្ឌារាប់ពាន់នាក់ អ្នកដែលបានចូលរួមនៅក្នុងការបះបោរ និងបាតុកម្ម។ ប៉ុន្តែ បើទោះជាមានការស្នើសុំរបស់គន្ធីកុំឱ្យប្រើប្រាស់អំពើហិង្សា ការបះបោរជាទូទៅបានប្រែក្លាយជាកុប្បកម្ម។

ព្យុះហយាត្រាអំបិល៖ នៅក្នុងឆ្នាំ 1930 គន្ធីបានរៀបចំបាតុកម្មមួយដើម្បីប្រឆាំងជាមួយនឹងច្បាប់អំបិល។ យោងទៅតាមច្បាប់អង់គ្លេសទាំងនេះ ប្រជាជនឥណ្ឌាអាចទិញអំបិលបានតែពីរដ្ឋាភិបាលតែប៉ុណ្ណោះ។ ពួកគេក៏ត្រូវបង់ពន្ធលើការលក់អំបិលផងដែរ។ ដើម្បីបង្ហាញការប្រឆាំងគន្ធី និងអ្នកដើរតាមគាត់បានធ្វើដំណើរប្រហែល 240 ម៉ាយទៅកាន់តំបន់ឆ្នេរសមុទ្រ។ នៅទីនោះ ពួកគេចាប់ផ្តើមផលិតអំបិលដោយខ្លួនឯង តាមរយៈការដួសទឹកសមុទ្រ និងទុកឱ្យវាយបង្ហួត។ ការបះបោរបែបសន្តិភាពនេះត្រូវបានគេហៅថា ព្យុះហយាត្រាអំបិល។

ភ្លាមៗបន្ទាប់ពីនោះ អ្នកធ្វើបាតុកម្មមួយចំនួនបានរៀបចំគម្រោងមួយនៅក្នុងធ្វើដំណើរទៅកាន់តំបន់មួយដែលរដ្ឋាភិបាលអង់គ្លេសផលិតអំបិល។ ពួកគេមានបំណងចង់កម្ទេចកន្លែងផលិតអំបិលនេះ។ មន្ត្រីប៉ូលីសជាមួយដំបងដែកធ្វើការវាយប្រហារទៅលើបាតុករ។ អ្នកយកព័ត៌មានអាមេរិកម្នាក់បានឃើញហេតុការនេះផ្ទាល់នឹងភ្នែក។ លោកបានពិពណ៌នាអំពី "ការវាយដោយដំបងទៅលើក្បាលដែលគ្មានអ្វីការពារ" ហើយប្រជាជន "រមិចរមួលជាមួយនឹងការឈឺចាប់ជាមួយនឹងការបែកក្បាល ឬបាក់ស្មា"។ ប៉ុន្តែប្រជាជននៅតែបន្តធ្វើដំណើរទៅមុខដោយសន្តិភាព បដិសេធនៅក្នុងការប្រឆាំងតបតជាមួយក្រុមអ្នកដែលវាយប្រហារពួកគេ។ ការសែតនៅពាសពេញពិភពលោកបានចុះផ្សាយអត្ថបទរបស់អ្នកកាសែតអាមេរិក ដែលជាហេតុនាំឱ្យមនុស្សនៅពាលពេញពិភពលោកគាំទ្រចលនាទាមទារឯករាជ្យរបស់គន្ធី។

មានបាតុកម្មជាច្រើនទៀតបានផ្ទុះឡើងនៅពាលពេញប្រទេសឥណ្ឌា ដើម្បីប្រឆាំងជាមួយពន្ធអំបិល។ ជាយថាហេតុ មានមនុស្ស 6 ម៉ឺននាក់ ដោយរួមទាំងគន្ធី ត្រូវបានចាប់ខ្លួន។

### 3. អង់គ្លេសប្រគល់សិទ្ធិគ្រប់គ្រងដោយខ្លួនឯងដែលមានកម្រិត

គន្ធី និងអ្នកតាមលោកបន្តិចម្តងៗទទួលបានផលពីយុទ្ធនាការ ការមិនស្តាប់បង្គាប់របស់ជនស៊ីវិល របស់ពួកគេ និងទទួលបានអំណាចនយោបាយកាន់តែប្រសើរជាងមុនសម្រាប់ប្រជាជនឥណ្ឌា។ នៅក្នុងឆ្នាំ 1935 សភាតំណាងរាស្ត្រអង់គ្លេសបានអនុម័ត ច្បាស់រដ្ឋាភិបាលអង់គ្លេស។ ច្បាប់នេះបានផ្តល់ឱ្យឥណ្ឌានូវរដ្ឋាភិបាលផ្ទាល់ខ្លួន និងការបោះឆ្នោតបែបប្រជាធិបតេយ្យមានកម្រិតមួយ ប៉ុន្តែមិនបានផ្តល់ឱ្យឥណ្ឌានូវឯករាជ្យទាំងស្រុងឡើយ។

ប៉ុន្តែ ច្បាប់រដ្ឋាភិបាលឥណ្ឌានេះក៏បានបញ្ឆេះឱ្យមានជម្លោះរវាងពួកម៉ូស្លីម និងពួកហិណ្ឌូផងដែរ។ ក្រុមទាំងពីរនេះមានគោលគំនិតផ្សេងគ្នាអំពីអំពីអនាគត់ប្រទេសឥណ្ឌាបន្ទាប់ពីក្លាយជាប្រទេសឯករាជ្យ។ ពួកឥណ្ឌាម៉ូស្លីម ដែលមានចំនួនតិចជាងពួកហិណ្ឌូ មានការព្រួយបារម្ភថា ពួកហិណ្ឌូនឹងធ្វើការត្រួតត្រាប្រទេសឥណ្ឌា ប្រសិនបើប្រទេសនេះទទួលបានឯករាជ្យ។ នៅក្នុងជំពូក 33 អ្នកនឹងបានអានអំពីលទ្ធផលនៃការស្នើសុំឯករាជ្យរបស់ឥណ្ឌា។

## 4. ជាតិនិយមនៅអាស៊ីនិរតី

ការដួលរលំនៃចក្រភពអូតូម៉ង់ និងការកើនឡើងនៃចំណាប់អារម្មណ៍របស់ពួកលោកខាងលិចទៅលើនយោបាយ និងសេដ្ឋកិច្ចនៅអាស៊ីនិរតី បានជម្រុងឱ្យមានការរីកឡើងនៃគំនិតជាតិនិយមនៅក្នុងតំបន់។ ក៏ដូចជាប្រជាជនឥណ្ឌាដែរ ដែលបានវាយប្រយុទ្ធដើម្បីទទួលបានឯករាជ្យបន្ទាប់ពីសង្គ្រាមលោកលើកទីមួយ ប្រជាជននៅអាស៊ីនិរតីក៏បានចាប់ផ្តើមចលនាទាមទារឯករាជ្យដើម្បីរំដោះខ្លួនគេចេញពីមេដឹកនាំចក្រភព។

ទួគីក្លាយជាសាធារណរដ្ឋ៖ នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទី 1 ចក្រភពអូតូម៉ង់ត្រូវបានបង្ខំឱ្យបោះបង់ដែនដីទាំងអស់របស់ពួកគេ លើកលែងតែទួគី។ ដែនដីទួគីរួមបញ្ចូលដែនដីកំណើតរបស់ពួកទួគីនៅអាណាតូលី និងដីមួយចម្រៀកតូចនៅជុំវិញទីក្រុងអ៊ីស្តង់ប៊ុល។

នៅក្នុងឆ្នាំ 1919 កងទ័ពក្រិចបានឈ្លានពានទួគី និងបានគំរាមកំហែងនៅក្នុងការដណ្តើមកាន់កាប់ប្រទេសនេះ។ ស្តេចស៊ូតង់ទួគីនៅពេលនោះមានអំណាចខ្សោយមិនអាចទប់ស្កាត់ពួកក្រិកបានឡើយ។ ដូច្នេះ នៅក្នុងឆ្នាំ 1922 មេបញ្ជាការដ៏ខ្លាំងពូកែមួយរូបឈ្មោះម៉ូសតាហ្វា គេម៉ាល់បានទទួលជោគជ័យនៅក្នុងការដឹកនាំអ្នកជាតិនិយមទួគីប្រយុទ្ធទប់ទល់ជាមួយក្រិក និងពួកអង់គ្លេសដែលជាខ្នងបង្អែករបស់ពួកគេ។ បន្ទាប់ពីទទួលបានសន្តិភាព អ្នកជាតិនិយមបានទម្លាក់ស្តេចស៊ូតង់ចុងក្រោយ។

នៅក្នុងឆ្នាំ 1923 លោកគេម៉ាល់បានក្រោយជាប្រធានាធិបតីនៃសាធារណរដ្ឋទួគីថ្មី ដែលជាសាធារណរដ្ឋដំបូងបំផុតនៅអាស៊ីនិរតី។ ដើម្បីសម្រេចគោលបំណងរបស់លោកនៅក្នុងការប្រែក្លាយប្រទេសទួគីឱ្យក្លាយជាប្រទេសទំនើបមួយ លោកបានអនុវត្តការធ្វើកំណែទម្រង់មួយចំនួន ដែលរួមមាន៖

1. ញែកចេញពីគ្នារវាងច្បាប់សាសនាអ៊ីស្លាម និងច្បាប់របស់ប្រទេស។
2. លុបបំបាត់ចោលនូវតុលាការសាសនា និងបង្កើតប្រព័ន្ធច្បាប់ថ្មីមួយដោយផ្អែកលើច្បាប់របស់ពួកអឺរ៉ុប។
3. ផ្តល់សិទ្ធិបោះឆ្នោតឱ្យស្ត្រី និងអាចកាន់តំណែងជាមន្ត្រីសាធារណបាន។
4. បង្កើតកម្មវិធីនានាដែលឧបត្ថម្ភដោយរដ្ឋាភិបាលដើម្បីធ្វើឧស្សាហូបនីយកម្ម និងលើកកម្ពស់សេដ្ឋកិច្ចទួគី។

លោកគេម៉ាល់ស្លាប់នៅក្នុងឆ្នាំ 1938 ។ ដោយសារការដឹកនាំរបស់លោក ទួគីទទួលបានគំនិតថ្មីមួយអំពីអត្តសញ្ញាណជាតិរបស់ពួកគេ។ ឥទ្ធិពលរបស់លោកមានលក្ខណៈខ្លាំងក្លា ដូច្នេះប្រជាជនទួគីបានផ្តល់ឈ្មោះឱ្យលោកថាអាតាទួកដែលមានន័យថា "បិតានៃជនជាតិទួក"។

ពែក្សក្លាយជាអ៊ីរ៉ង់៖ មុនសង្គ្រាមលោកលើកទី 1 ទាំងចក្រភពអង់គ្លេស និងរុស្ស៊ីបានបង្កើតរង្វង់ឥទ្ធិពលរបស់ពួកគេនៅក្នុងប្រទេសពែក្សបុរាណ។ បន្ទាប់ពីសង្គ្រាមលោកលើកទី 1 នៅពេលដែលប្រទេសរុស្ស៊ីកំពុងរង្គោះរង្គើដោយសារបដិវត្តបូលសេវិក ចក្រភពអង់គ្លេសបានព្យាយាមនៅក្នុងការដណ្តើមកាន់កាប់ពែក្សទាំងមូល។ ហេតុនេះបានបង្កឱ្យមានការបះបោរមួយរបស់ក្រុមអ្នកជាតិនិយមក្នុងប្រទេសពែក្ស។ នៅក្នុងឆ្នាំ 1921 មន្ត្រីកងទ័ពពែក្សមួយរូបបានក្តោបយកអំណាច។ នៅក្នុងឆ្នាំ 1925 លោកបានទម្លាក់ស្តេចសាលចេញពីអំណាច។

មេដឹកនាំពែក្សថ្មី ឈ្មោះរ៉េហ្សា សា ប៉ាឡាវី ក៏ដូចជាលោកគេម៉ាល់នៅក្នុងប្រទេសទួគីដែរបានកែប្រែប្រទេសរបស់លោកឱ្យក្លាយជាប្រទេសទំនើប។ លោកបានបង្កើតសាលារដ្ឋ, ស្ថាបនាផ្លូវថ្នល់ និងផ្លូវរថភ្លើង, លើកកម្ពស់កំណើនឧស្សាហកម្ម, និងពង្រីកសិទ្ធិរបស់ស្ត្រី។ ខុសពីលោកគេម៉ាល់លោក រ៉េហ្សា សា ប៉ាឡាវី រក្សាអំណាចទាំងអស់នៅក្នុងដៃរបស់លោក។ នៅក្នុងឆ្នាំ 1935 លោកបានផ្លាស់ប្តូរឈ្មោះប្រទេសពីភាសាក្រិកថាពែក្សទៅជាឈ្មោះបែបប្រពៃណីថា អ៊ីរ៉ង់។

សាអូឌីតអារ៉ាប៊ីរក្សាប្រពៃណីអ៊ីស្លាម៖ ខណៈពេលដែលប្រទេសទួគីបានកែប្រែនូវប្រពៃណីអ៊ីស្លាមជាច្រើនប្រទេសថ្មីមួយផ្សេងទៀតបានអនុវត្តនៃច្បាប់អ៊ីស្លាមដ៏តឹងតឹង។ នៅក្នុងឆ្នាំ 1902 លោកអាប អាល់-អាហ្សីស អ៊ីបិន សៅដ៍ ដែលសមាជិកមួយរូបនៃគ្រួសារអារ៉ាប់ដែលមានអំណាចមួយ ចាប់ផ្តើមយុទ្ធនាការដោគជ័យមួយដើម្បីបង្រួបបង្រួមអារ៉ាប់។ នៅក្នុងឆ្នាំ 1932 លោកបានប្តូរឈ្មោះព្រះរាជាណាចក្រថ្មីរបស់លោកថា សាអូឌីតអារ៉ាប៊ីដែលដាក់ឈ្មោះតាមគ្រួសាររបស់លោក។

អ៊ីបិន សៅដ៍ បានលើកកម្ពស់ប្រពៃណីអារ៉ាប់ និងអ៊ីស្លាម។ ភក្តីភាពចំពោះរដ្ឋាភិបាលសាអូឌីតគឺផ្អែកទៅលើទំនៀមទម្លាប់, សាសនា, និងទំនាក់ទំនងគ្រួសារ។ ក៏ដូចជាលោកគេម៉ាល់ និងលោករ៉េហ្សា សា ដែរ អ៊ីបិន សៅដ៍ បាននាំមកនូវបច្ចេកវិទ្យាសម័យទំនើបមកកាន់ប្រទេសរបស់ទ្រង់ ដូចជាទូរស័ព្ទ និងវិទ្យុ។ ប៉ុន្តែ ទំនើបកម្មនៅក្នុងប្រទេសសាអូឌីតអារ៉ាប៊ីត្រូវបានកម្រិតឱ្យស្របទៅនឹងការអនុញ្ញាតរបស់សាសនា។ មិនមានការប្រឹងប្រែងនៅក្នុងការអនុវត្តលិទ្ធិប្រជាធិបតេយ្យឡើយឡើយ។

ប្រេងកាតបង្កើនការអភិវឌ្ឍ៖ ខណៈពេលដែលគំនិតជាតិនិយមបានដើរតួនាទីជាកម្លាំងសំខាន់មួយនៅក្នុងតំបន់អាស៊ីនិរតី សេដ្ឋកិច្ចនៅក្នុងតំបន់ក៏ឆ្ពោះទៅរកទិសដៅថ្មីមួយផងដែរ។ ការកើនឡើងនូវតម្រូវការផលិតផលប្រេងឥន្ទនៈនៅក្នុងបណ្តាលប្រទេសឧស្សាហកម្ម បាននាំឱ្យមានការរុករកប្រេងថ្មីៗនៅក្នុងតំបន់អាស៊ីនិរតី។ អំឡុងទសវត្សរ៍ឆ្នាំ 1920 និង 1930 ក្រុមហ៊ុននៅអឺរ៉ុប និងក្រុមហ៊ុននៅអាមេរិកបានរុករកឃើញអណ្តូងប្រេងជាច្រើននៅប្រទេសអ៊ីរ៉ង់, អ៊ីរ៉ាក់, សាអូឌីតអារ៉ាប៊ី, និងគុយវេទ។ អ្នកជំនួញបរទេសបានវិនិយោគក្នុងទំហំទឹកប្រាក់ដ៏ច្រើនដើម្បីអភិវឌ្ឍអណ្តូងប្រេងទាំងអស់នេះ។ ឧទាហរណ៍ ក្រុមហ៊ុនប្រេងអង់គ្លេស-ពែក្ស ដែលជាក្រុមហ៊ុនរបស់ប្រទេសអង់គ្លេសចាប់ផ្តើមអភិវឌ្ឍអណ្តូងប្រេងនៅក្នុងប្រទេសអ៊ីរ៉ង់។ ក្រោយមកអ្នកភូមិសាស្ត្របានសិក្សារកឃើញថា នៅតំបន់ជុំវិញឈូងសមុទ្រពែក្សផ្គត់ផ្គង់នូវប្រេងកាត 2/3 នៃប្រេងសម្រាប់ពិភពលោក។ ធនធានដ៏សំខាន់នេះបាននាំទៅដល់ការផ្លាស់ប្តូរសេដ្ឋកិច្ច និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស និងខ្លាំងក្លា។

ដោយសារតែប្រេងកាតបានផ្តល់នូវផលចំនេញយ៉ាងច្រើន ប្រទេសលោកខាងលិចបានព្យាយាមនៅក្នុងការកាន់កាប់តំបន់នេះ។ ជាមួយគ្នានោះ ប្រទេសលោកខាងលិចទាំងនេះក៏ប្រឈមជាមួយនឹងបញ្ហាជាច្រើនផងដែរ ដោយសារតែមេដឹកនាំស្រេកឃ្លានអំណាចបានដណ្តើមការគ្រប់គ្រងនៅក្នុងប្រទេសអ៊ីតាលី និងអាឡឺម៉ង់។

# ជំពូក 30 ៖ ទសវត្សរ៍នៃវិបត្តិ 1919-1939

## មេរៀនទី 1 ៖ ការប្រែប្រួលក្រោយសង្គ្រាម

### 1. បដិវត្តថ្មីក្នុងវិស័យវិទ្យាសាស្ត្រ

គំនិតរបស់អាល់ប៊ែរ អាញ់ស្តាញ់ និងស៊ីកម៉ុនដ៍ ផ្រយដ៍ មានឥទ្ធិពលយ៉ាងខ្លាំងនៅសតវត្សរ៍ទី 20។ ទស្សនវិទូទាំង 2 រូបនេះគឺជាមាគ៌ាមួយសម្រាប់ការធ្វើបដិវត្តវិទ្យាសាស្ត្រមួយដែលមានសារៈសំខាន់ដូច ដែលលោកកូផ័រនីគូស និងលោកហ្គាលីឡេអូបានបង្កើតឡើងមួយសតវត្សរ៍មុនដែរ។

ឥទ្ធិពលនៃទ្រឹស្តីភាពអាចប្រែប្រួលរបស់អាល់ប៊ែរ អាញ់ស្តាញ់៖ រូបវិទូអាល់ប៊ែរ អាញ់ស្តាញ់ដែលមានដើមកំណើតជាជនជាតិអាឡឺម៉ង់ បានបង្កើតឱ្យមានគំនិតថ្មីៗអំពីលំហរអាកាស, ពេលវេលា, ថាមពល, និងបាតុភូត។ អ្នកវិទ្យាសាស្ត្ររូបនេះបានរកឃើញថា ពន្លឺធ្វើដំណើរក្នុងល្បឿនដូចគ្នាទាំងអស់នៅលើភពផែនដី មិនថាស្ថិតក្នុងទិសដៅណាឡើយ។ នៅក្នុងឆ្នាំ 1905 លោកបានបង្កើតទ្រឹស្តីមួយដែលថា ខណៈពេលដែលល្បឿននៃពន្លឺមិនប្រែប្រួល ល្បឿននៃវត្ថុផ្សេងៗដូចជាលំហរអាកាស និងពេលវេលាជាដើម ដែលយើងមើលឃើញថាវាមិនប្រែប្រួលដែរនោះ គឺអាចប្រែប្រួល។ ល្បឿននៃលំហរអាកាស និងពេលវេលា អាចផ្លាស់ប្តូរនៅពេលដែលយើងវាល់វាភ្ជាប់ជាមួយនឹងវត្ថុមួយដែលផ្លាស់ទីនៅជិតល្បឿននៃពន្លឺ ដែលមានល្បឿនប្រហែល 186,000 ម៉ាយក្នុងមួយវិនាទី។ ដូចគ្នានេះដែលការប្រែប្រួលនៃចលនាគឺជាគន្លឹះសំខាន់នៃគំនិតរបស់លោកអែនស្វែនវាត្រូវបានគេហៅថា ទ្រឹស្តីនៃការប្រែប្រួល។ គំនិតរបស់លោកអាញ់ស្តាញ់មិនត្រឹមតែជាប់ទាក់ទងជាមួយតែវិទ្យាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាជាប់ទាក់ទងជាមួយនឹងការយល់ឃើញរបស់មនុស្សចំពោះភពផែនដី។ ឥឡូវនេះទ្រឹស្តី ភាពមិនជាក់លាក់ និងភាពអាចប្រែប្រួលបានជំនួសទ្រឹស្តីអ៊ីសាក ដែលជាជំនឿរបស់លោកញ៉ូវតុនស្តីអំពីចលនានៃភពផែនដីដោយលោកផ្អែកទៅលើច្បាស់មិនប្រែប្រួលនៃចលនា និងទំនាញ។

ឥទ្ធពលនៃចិត្តវិទ្យារបស់ផ្រយដ៏៖ គំនិតរបស់រូបវិទូជនជាតិអូទ្រីសស៊ីកម៉ុនដ៍ ផ្រយដ៍គឺជាបដិវត្តគំនិតមួយដូចអាញ់ស្តាញ់ដែរ។ ផ្រយដ៍បានព្យាបាលអ្នកជំងឺដែលមានបញ្ហាផ្លូវចិត្ត។ យោងតាមបទពិសោធន៍របស់លោក លោកបានបង្កើតទ្រឹស្តីមួយអំពីចិត្តមនុស្ស។ លោកជឿថា ឥរិយាបថជាច្រើនរបស់មនុស្សគឺកើតឡើងដោយយើងមិនបានដឹង(អវិចារណញ្ញាណ) ឬនៅពីក្រោយហេតុផល។ លោកបានហៅផ្នែកដែលយើងមិនដឹងនោះថា អវិចារណញ្ញាណ (ការមិនដឹងខ្លួន)។ នៅក្នុងអវិចារណញ្ញាណ មានកម្លាំងជម្រុញមួយចំនួនបានលេចឡើង ជាពិសេសកម្លាំងជម្រុញការស្វែងរកសេចក្តីសប្បាយ ដែលវិចារណញ្ញាណ (ការដឹងខ្លួន) របស់យើងមិនបានដឹង។ គំនិតរបស់ផ្រយដ៍បានធ្វើឱ្យជំនឿលើហេតុផល ចុះខ្សោយ។ បើទោះបីជាដូច្នេះក៏ដោយ មកដល់ទសវត្សរ៍ឆ្នាំ 1920 ទើបទ្រឹស្តីរបស់ផ្រយដ៍បានរីកសាយភាពឥទ្ធិពល។

**2. អក្សរសិល្ប៍នៅទសវត្សរ៍ឆ្នាំ 1920**

អំពើព្រៃផ្សៃនៅក្នុងសង្គ្រាមលោកលើកទី 1 បានបណ្ដាលឱ្យទស្សនវិទូ និងអ្នកនិពន្ធមានភាពស្ទាក់ស្ទើរនៅក្នុងទទួលយកគំនិតអំពីហេតុផល និងភាពជឿនលឿន។ ធ្វើឱ្យស្រងាកចិត្តដោយសារសង្គ្រាម មនុស្សជាច្រើនក៏មានការភ័យខ្លាចអំពីអនាគតកាល និងបង្ហាញពីភាពសង្ស័យអំពីជំនឿលើសាសនាបែបប្រពៃណី។ អ្នកនិពន្ធ និងទស្សនវិទូមួយចំនួនបានបង្ហាញពីភាពតានតឹងអារម្មណ៍របស់ពួកគេ តាមរយៈការចែកចាយអំពីទស្សនវិស័យចំពោះបច្ចុប្បន្នកាល និងអនាគតកាល។

នៅក្នុងឆ្នាំ 1922 លោកអេលីអូត កវីជនជាតិអាមេរិកដែលរស់នៅក្នុងប្រទេសអង់គ្លេស បានសរសេរថា សង្គមរបស់អឺរ៉ុបបានបាត់បង់តម្លៃខាងវិញ្ញាណ។ លោកបានបរិយាយអំពីពិភពលោកក្រោយសម័យសង្គ្រាមថា ជា "ដីវាលគ្មានជីជាតិ" ដែលរីងស្ងួតសេចក្ដីសង្ឃឹម និងជំនឿ។ នៅក្នុងឆ្នាំ 1921 កវីជនជាតិអៀកឡង់ម្នាក់ឈ្មោះ វីលៀម ប៊ូតល័រ យីតស៍ បានបង្កើតគំនិតអំពីពេលវេលាដ៏ខ្មៅងងឹកនៅពេលខាងមុខនៅក្នុងកំណាព្យមួយដែលមានចំណងជើងថា "លើកទី 2 មកដល់"៖ "អ្វីៗនឹងដួលរលំ, មិនអាចគ្រប់គ្រងស្ថានការណ៍បាន, ភាពអនាធិបតេយ្យនឹងផ្ទុះឡើងនៅពាសពេញពិភពលោក"។

អ្នកនិពន្ធឆ្លុះបញ្ចាំងពីកង្វល់សង្គម៖ សេចក្ដីរន្ធត់នៃសង្គ្រាមបានដិតដាមយ៉ាងជ្រៅនៅក្នុងចិត្តរបស់អ្នកនិពន្ធជាច្រើន។ អ្នកនិពន្ធជនជាតិឆេកលោកហ្វ្រង់ កាហ្វកា បានសរសេរប្រលោមលោកបែបព្រឺព្រួចមួយចំនួនដូចជា ការកាត់ទោស (1925) និងប៉ម (1926)។ សៀវភៅរបស់លោកបង្ហាញពីមនុស្សស្ថិតនៅក្នុងស្ថានការណ៍តក់ស្លុតដែលពួកគេមិនបានដឹង និងរត់គេចចេញបាន។ សៀវភៅទាំងនេះបានធ្វើឱ្យអ្នកអានបានដឹង និងយល់ស្របអំពីភាពលំបាកក្រោយសង្គ្រាម។ ប្រលោមលោកជាច្រើនបានទទួលរងឥទ្ធិពលពីទ្រឹស្ដីរបស់លោកផ្រយដ៍ ស្ដីអំពីអវិចារណញ្ញាណ។ អ្នកនិពន្ធជនជាតិអៀកឡង់លោកជេម ចយស៍ទទួលបានការចាប់អារម្មណ៍ពីសារណជនតាមរយៈប្រលោមលោកបែបអវិចារណញ្ញាណរបស់លោកដែលមានចំណងជើងថា អ៊ូលីស (1922)។ សៀវភៅនេះផ្ដោតសំខាន់លើជីវិតរស់នៅរយៈពេលមួយថ្ងៃរបស់មនុស្ស 3 នាក់នៅឌុប្លីនប្រទេសអៀកឡង់។ លោកចយស៍មិនសូវប្រើរចនាសម្ព័ន្ធប្រយោគ និងវាក្យស័ព្ទធម្មតាឡើយ ដោយលោកព្យាយាមនៅក្នុងការឆ្លុះបញ្ចាំងពីដំណើរការនៃចិត្តរបស់មនុស្ស។

ទស្សនវិទូប្រតិកម្មទៅនិងទ្រឹស្ដីភាពអាចប្រែប្រួល៖ នៅក្នុងការស្វែងរករបស់ពួកគេ ចំពោះអត្ថន័យនៅក្នុងពិភពមិនទៀងទាត់មួយ ទស្សនវិទូមួយចំនួនបានប្រែវាឱ្យក្លាយក្លាយជាទស្សនវិទ្យាមួយដែលគេស្គាល់ថាអត្ថិភាពនិយម។ មេដឹកនាំមួយរូបដែលសំខាន់ជាងគេនៅក្នុងចលនានេះគឺទស្សនវិទូជនជាតិបារាំងជីន ប៉ូល សាត្រេ។ អត្ថិភាពនិយមជឿថា មនុស្សទាំងឡាយមិនមានអត្ថន័យនៃជីវិតដូចគ្នាឡើយ។ មនុស្សម្នាក់ៗបង្កើតអត្ថន័យនៃជីវិតរបស់ពួកគេផ្ទាល់តាមរយៈជម្រើសដែលពួកគេរើស និងសកម្មភាពដែលពួកគេធ្វើ។

ពួកអ្នកអត្ថិភាពនិយមបានទទួលរងឥទ្ធិពលពីទស្សនវិទូជនជាតិអាឡឺម៉ង់លោកហ្វ្រីឌ្រិច និតស្សេ។ នៅក្នុងទសវត្សរ៍ឆ្នាំ 1880 លោកនិតស្សេបានសរសេរថា គំនិតនានារបស់ពួកលោកខាងលិចដូចជាហេតុផល, ប្រជាធិបតេយ្យ,

និងភាពជឿនលឿនបានបញ្ឈប់គំនិតឆ្នៃប្រឌិត និងសកម្មភាពរបស់មនុស្ស។ លោកនិតស្សេបានទទូចឱ្យត្រឡប់ទៅប្រើគំនិតរបស់វីរបុរសសម័យបុរាណអំពីមោទនភាព, សេចក្ដីជឿជាក់, និងកម្លាំង។ គំនិតរបស់លោកទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅសតវត្សរ៍ទី 20 និងជះឥទ្ធិពលដ៏សំខាន់មួយលើនយោបាយក្នុងប្រទេសអ៊ីតាលី និងអាឡឺម៉ង់នៅក្នុងទសវត្សរ៍ឆ្នាំ 1920 និង 1930។

### 3. បដិវត្តសិល្បៈ

បើទោះបីជាមានទម្រង់នៃការគូរគំនូរ និងទម្រង់នៃតន្ត្រីថ្មីៗជាច្រើនបានចាប់ផ្ដើមឡើងនៅមុនសង្គ្រាមក៏ដោយ ក៏មានទម្រង់នៃគំនូរ និងតន្ត្រីជាច្រើនបានវិវត្តផងដែរបន្ទាប់ពីសង្គ្រាម។

វិចិត្រករតស៊ូប្រឆាំងនឹងប្រពៃណី៖ វិចិត្រករបានតស៊ូប្រឆាំងជាមួយរចនាបទគំនូរបែបពិតប្រាកដនិយមនៅសម័យមុន។ ពួកគេចង់បានបង្ហាញពីចិត្តរំភើប និងការស្រមើលស្រមៃជាជាងការបង្ហាញភាពពិប្រាកដលើវត្ថុអ្វីមួយ។ វិចិត្រករវិញ្ញាត្តិនិយម (ការសម្ដែងមនោសញ្ចេតនា) នានា ដូចជាលោកប៉ូល ក្លេ និងលោកវ៉ាស៊ីលី កាន់ឌីស្គីបានប្រើប្រាស់ទម្រង់គំនូរបែបពណ៌ដុតៗ និងក្រវេងក្រវាម។ បំផុសគំនិតដោយសិល្បៈអាហ្វ្រិកបុរាណ លោកចចប្រាក ដែលជាជនជាតិបារាំង និងលោកប៉ាប្លូ ពីកាសូ ដែលជាជនជាតិអេស្ប៉ាញបានបង្កើតគំនូរបែប ធឡ័ង្គនិយមនៅក្នុងឆ្នាំ 1907 ។ គំនូរបែប ធឡ័ង្គនិយម បានផ្លាស់ប្ដូរទម្រង់បែបធម្មជាតិទៅជាទម្រង់ធរណីមាត្រ។ វត្ថុនានាត្រូវបានបំបែងទៅជាផ្នែកផ្សេងៗគ្នាជាមួយនិងរូបសណ្ឋានជ្រុងៗ និងគែមស្មើត្រឹម។ ជាទូទៅអត្ថន័យជាច្រើនបានបង្ហាញនៅលើរូបភាពតែមួយ។

លើសពីការពិតនិយម៖ ចលនាសិល្បៈមួយដែលដែលសំលឹងទៅរកការភ្ជាប់ពិភពសុបិន្តជាមួយនឹងជីវិតរស់នៅពិប្រាកដ ត្រូវបានបំផុសគំនិតដោយទ្រឹស្ដីរបស់ផ្រយដ៍ ។ ពាក្យថា លើសពីការពិត មានន័យថា "នៅពីក្រោយ ឬលើសពីការពិត"។ ពួកអ្នកលើសពីការពិតនិយម ព្យាយាមនៅក្នុងការបង្កើតចិត្តអវិចារណញ្ញាណរបស់ពួកគេ។ គំនូររបស់ពួកគេភាគច្រើនមានលក្ខណៈចំឡែក ដូចជានៅក្នុងសុបិន្ត និងពិពណ៌នាវត្ថុនានានៅក្នុងគំនិតបែបមិនពិតប្រាដក។

អ្នកនិពន្ធបទភ្លេងសាកល្បងទម្រង់ថ្មី៖ ទាំងនៅក្នុងតន្ត្រីបែបបុរាណ និងបែបប្រជាប្រិយ អ្នកនិពន្ធបទភ្លេងបានផ្លាស់ប្ដូរចេញពីបទភ្លេងបែបប្រពៃណី។ នៅក្នុងស្នាដៃឯកនៃតន្ត្រីរបាំប៉ាឡេមួយ ដែលមានចំណងជើងថា ក្បួននៃការបង្វិល អ្នកនិពន្ធបទភ្លេងជនជាតិរុស្ស៊ី លោកអ៊ីហ្គោ ស្ត្រាវីនស្គី បានប្រើប្រាស់ចង្វាក់មិនទៀងទាត់ និងសំលេងមិនស៊ីគ្នា ឬសំលេងដែលពិបាកស្ដាប់។ អ្នកនិពន្ធបទភ្លេងជនជាតិអូទ្រីសលោកអាណូលដ៍ ស្គូអេនបឺកមិនប្រើប្រាស់នូវតន្ត្រីដែលមានសំលេងស៊ីគ្នា និងកម្រិតស្មើគ្នាឡើយ។ រចនាបទតន្ត្រីប្រជាប្រិយថ្មីមួយដែលគេហៅថាហ្សាស បានលេចឡើងនៅសហរដ្ឋអាមេរិក។ វាត្រូវបានអភិវឌ្ឍឡើងដោយតន្ត្រីករនានា ភាគច្រើនជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក នៅក្នុងរដ្ឋញូវអូលែនស៍, មេមភីស, និងឈីកាហ្គោ។ វាបានញ៉ែកសហរដ្ឋអាមេរិក និងអឺរ៉ុប។ តន្ត្រីហ្សាស់ ញាក់តិចៗដ៏សប្បាយរីករាយ ហាក់ដូចជាចាប់យកយុគសម័យថ្មីនៃសេរីភាព។

### 4. សង្គមប្រជែងជាមួយអនុសញ្ញា

សង្គ្រាមលោកលើកទី 1 បានរំខានដល់ទម្រង់សង្គមបែបប្រពៃណី។ គំនិត និងរបៀបរស់នៅថ្មីៗ បាននាំឱ្យកើតមានសេរីភាពបុគ្គលថ្មីមួយនៅអំឡុងទសវត្សរ៍ឆ្នាំ 1920 ។ មនុស្សក្មេងៗមានឆន្ទៈនៅក្នុងការផ្តាច់ខ្លួនចេញពីអតីតកាល និងពិសោធន៍ជាមួយតម្លៃសម័យទំនើប។

តួនាទីស្ត្រីផ្លាស់ប្តូរ៖ គំនិតអំពីឯករាជ្យភាពនៃពេលវេលាបានបង្ហាញយ៉ាងច្បាស់នៅក្នុងការផ្លាស់ប្តូររបស់ស្ត្រីដែលបានធ្វើឡើងនៅក្នុងជីវិតរស់នៅរបស់ពួកគេ។ សង្គ្រាមបានអនុញ្ញាតឱ្យស្ត្រីទទួលបានតួនាទីថ្មីមួយ។ កិច្ចការងាររបស់ពួកគេនៅក្នុងសង្គ្រាម គឺជាកន្លឹះសំខាន់មួយនៅក្នុងការជួយពួកគេទទួលជោគជ័យក្នុងការទទួលបានសិទ្ធិនៅក្នុងការបោះឆ្នោត។ បន្ទាប់ពីសង្គ្រាម សិទ្ធិបោះឆ្នោតរបស់ស្ត្រីបានក្លាយជាច្បាប់នៅក្នុងប្រទេសជាច្រើនដោយក្នុងនោះរួមមានសហរដ្ឋអាមេរិក, ចក្រភពអង់គ្លេស, អាឡឺម៉ង់, ស៊ុយអែត, និងអូទ្រីស។

ស្ត្រីបានបោះបង់ចោលរបៀបស្លៀកពាក់ និងម៉ូតសក់បែបតឹងរឹង។ ពួកគេស្លៀកសំលៀកបំពាក់ខ្លីៗ, រលង់ៗ និងកាត់សក់ខ្លី។ ពួកគេតុបតែងមុខ, បើករថយន្ត, និងផឹកស្រា និងជក់បារីនៅទីសាធារណៈ។ បើទោះបីជាស្ត្រីភាគច្រើននៅតែបន្តរបៀបនៃការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារបែបប្រពៃណី ក៏មានមនុស្សមួយចំនួនបានទាមទារឱ្យមានសេរីភាពកាន់តែច្រើននៅក្នុងជីវិតរបស់នៅរបស់ពួកគេ។ ម៉ាហ្គារ៉េត សានច័រ និងអេមម៉ា ហ្គោលមែន ប្រឈមទៅនឹងការចាប់ខ្លួនដោយសារនិយាយគាំទ្រដល់ការត្រួតពិនិត្យកំណើត។ នៅពេលដែលស្ត្រីស្វែងរកអាជីពថ្មី ចំនួនស្ត្រីដែលធ្វើការនៅក្នុងផ្នែកវេជ្ជសាស្ត្រ, ការអប់រំ, សារព័ត៌មាន, និងវិជ្ជាជីវៈផ្សេងទៀតបានកើនឡើង។

### 5. បច្ចេកវិទ្យាជឿនលឿនធ្វើអោយជីវិតប្រសើរឡើង

នៅអំឡុងសង្គ្រាមលោកលើកទី 1 អ្នកវិទ្យាសាស្ត្របានបង្កើតថ្នាំថ្មី និងការព្យាបាលវេជ្ជសាស្ត្រដែលជួយដល់មនុស្សរាប់លាននាក់ក្រោយសម័យក្រោយសង្គ្រាម។ ភាពជឿនលឿនខាងបច្ចេកវិទ្យានៅអំឡុងសង្គ្រាម ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីកែលម្អការដឹកជញ្ជូន និងការធ្វើទំនាក់ទំនងបន្ទាប់ពីសង្គ្រាម។

យានយន្តផ្លាស់ប្តូរសង្គម៖ យានយន្តទទួលបានអត្ថប្រយោជន៍ពីការច្នៃប្រឌិត និងការកែលម្អជាច្រើនក្នុងសម័យសង្គ្រាម ដូចជាម៉ាស៊ីនបញ្ឆេះប្រើអគ្គិសនី, សំបកកង់សប់ខ្យល់, និងម៉ាស៊ីនដែលមានថាមពលខ្លាំងជាង។ រថយន្តឥឡូវមានភាពរលោង និងក្លីចែងចាំង បំពាក់ដោយភ្លើងមុខ និងកាងស្រោបដោយក្រូម។ នៅចក្រភពអង់គ្លេសមុនសង្គ្រាម រថយន្តត្រូវបានកាន់កាប់ភាគច្រើនដោយអ្នកមាន។ រោងចក្រនៅអង់គ្លេសបានផលិតរថយន្តចំនួន 34,000 គ្រឿងក្នុងឆ្នាំ 1913 ។ បន្ទាប់ពីសង្គ្រាម តម្លៃបានធ្លាក់ចុះ ហើយវណ្ណៈកណ្តាលអាចមានលទ្ធភាពទិញរថយន្តបាន។ នៅឆ្នាំ 1937 ជនជាតិអង់គ្លេសបានផលិតរថយន្តចំនួន 511,000 គ្រឿងក្នុងមួយឆ្នាំ។ ការកើនឡើងនៃការប្រើប្រាស់យានយន្តជាលក្ខណៈគ្រួសារនាំឱ្យមានការផ្លាស់ប្តូររបៀបរស់នៅ។ មនុស្សកាន់តែច្រើនបានធ្វើដំណើរទៅកម្សាន្ត។ នៅអឺរ៉ុប និងសហរដ្ឋអាមេរិក អាជីវកម្មថ្មីៗត្រូវបានបើកដើម្បីបម្រើភ្ញៀវទេសចរណ៍។ រថយន្តក៏ជះឥទ្ធិពលដល់ទីកន្លែងដែលមនុស្សរស់នៅ និងធ្វើការផងដែរ។ ប្រជាជនបានផ្លាស់ទៅរស់នៅជាយក្រុង ហើយធ្វើដំណើរទៅធ្វើការនៅក្នុងទីក្រុង។

យន្តហោះផ្លាស់ប្តូរការធ្វើដំណើរ៖ ការធ្វើដំណើរតាមផ្លូវអាកាសអន្តរជាតិបានក្លាយជាគោលដៅសំខាន់ បន្ទាប់ពីសង្គ្រាម។ នៅឆ្នាំ 1919 អ្នកបើកយន្តហោះជនជាតិអង់គ្លេស 2 នាក់បានធ្វើការហោះហើរដោយជោគជ័យជាលើកដំបូងឆ្លងកាត់មហាសមុទ្រអាត្លង់ទិកដោយធ្វើដំណើរពីញូវហ្វោនលែនទៅអៀរឡង់។ នៅឆ្នាំ 1927 អ្នកបើកយន្តហោះជនជាតិអាមេរិកម្នាក់ឈ្មោះឆាល លីនដ៍ប៊ឺក បានទាក់ទាញចំណាប់អារម្មណ៍ពិភពលោកជាមួយនឹងការហោះហើរឥតឈប់រយៈពេល 33 ម៉ោងពីទីក្រុងញូវយ៉កទៅកាន់ទីក្រុងប៉ារីស។ ក្រុមហ៊ុនអាកាសចរណ៍ដឹកអ្នកដំណើរធំៗរបស់ពិភពលោកភាគច្រើនត្រូវបានបង្កើតឡើងក្នុងអំឡុងឆ្នាំ 1920 ។ ដំបូងឡើយ មានតែអ្នកមានទេដែលអាចមានលទ្ធភាពធ្វើដំណើរតាមផ្លូវអាកាស។ ទោះយ៉ាងណាក៏ដោយ មនុស្សគ្រប់គ្នារីករាយជាមួយនឹងការទាញយកអត្ថប្រយោជន៍ពីសំណាក់អ្នកត្រួសត្រាយផ្លូវអាកាស ដោយក្នុងរួមទាំងទាំងអាមេលៀ អ៊ាហាតផងដែរ។ នៅក្នុងឆ្នាំ 1932 អ្នកស្រីបានក្លាយជាស្ត្រីជនជាតិអាមេរិកដំបូងគេដែលហោះហើរឥតឈប់ឆ្លងកាត់មហាសមុទ្រអាត្លង់ទិក។

វិទ្យុ និងភាពយន្តគ្រប់គ្រងការកម្សាន្តដ៏ពេញនិយម៖ លោកហ្គូគលីលម៉ូ ម៉ាកូនី បានធ្វើការពិសោធន៍ដោយជោគជ័យដំបូងរបស់គាត់ជាមួយវិទ្យុនៅឆ្នាំ 1895 ។ ទោះជាយ៉ាងណាក៏ដោយ ការជំរុញពិតប្រាកដសម្រាប់ការអភិវឌ្ឍវិទ្យុបានកើតឡើងអំឡុងសង្គ្រាមលោកលើកទី 1 ។ នៅឆ្នាំ 1920 ស្ថានីយ៍វិទ្យុពាណិជ្ជកម្មដំបូងបង្អស់របស់ពិភពលោកនៅទីក្រុងពីតស្បឺករដ្ឋផេនស៊ីលវ៉ានៀបានចាប់ផ្តើមចាក់ផ្សាយ។ . ស្ទើរតែពេញមួយយប់, វិទ្យុម៉ានៀបានចាក់ផ្សាយពាសពេញសហរដ្ឋអាមេរិក។ ទីក្រុងធំៗនីមួយៗមានស្ថានីយ៍ផ្សាយព័ត៌មាន, កន្លែងលេងកំសាន្ត, និងសូម្បីតែព្រឹត្តិការណ៍កីឡាផ្ទាល់។ មិនយូរប៉ុន្មាន គ្រួសារភាគច្រើនមានវិទ្យុសម្រាប់ស្តាប់។ រូបភាពមានចលនាក៏ជាឧស្សាហកម្មដ៏សំខាន់មួយក្នុងទសវត្សរ៍ឆ្នាំ 1920 ។ ប្រទេសជាច្រើនចាប់ពីគុយបាដល់ប្រទេសជប៉ុនបានផលិតខ្សែភាពយន្ត។ នៅអឺរ៉ុប ភាពយន្តគឺជាទម្រង់សិល្បៈដ៏សំខាន់មួយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសង្កាត់ហូលីវូដនៃទីក្រុងឡូស អេនជឺឡេស ជាកន្លែងដែល 90% នៃខ្សែភាពយន្តទាំងអស់ត្រូវបានបង្កើតឡើង ដែលខ្សែភាពយន្តទាំងនោះគឺជាខ្សែភាពយន្តសម្រាប់ការកម្សាន្ត។ ស្តេចនៃខ្សែភាពយន្តគ្មានសំលេងរបស់ហូលីវូដគឺលោកឆាលី ឆាពលីន ដែលមានដើមកំណើតនៅអង់គ្លេស ជាអ្នកដែលមានទេពកោសល្យក្នុងការកំប្លែង។ នៅចុងទសវត្សរ៍ឆ្នាំ 1920 ការបន្ថែមនៃសំឡេងបានផ្លាស់ប្តូរខ្សែភាពយន្ត។ ភាពជឿនលឿននៃការដឹកជញ្ជូន និងទំនាក់ទំនង ដែលកើតឡើងក្រោយសង្គ្រាមបាននាំពិភពលោកឱ្យកាន់តែមានភាពជិតស្និទ្ធ។ ភាពរុងរឿងជាសកលបានមកអាស្រ័យលើសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រទេសធំៗទាំងអស់ ជាពិសេសសហរដ្ឋអាមេរិក។

# មេរៀនទី 2 ៖ វិបត្តិសេដ្ឋកិច្ចជាសកល

## 1. អឺរ៉ុបក្រោយសង្គ្រាម

បើនិយាយអំពីឈឺចាប់របស់មនុស្ស និងការខូចខាតនៃសេដ្ឋកិច្ច ផលប៉ះពាល់នៃសង្គ្រាមលោកលើកទី 1 គឺមានទំហំធំធេងណាស់។ សង្គ្រាមលោកលើកទី 1 បានធ្វើឱ្យប្រទេសធំៗទាំងឡាយនៅអឺរ៉ុបស្ទើរតែក្ស័យធន។ លើសពីនេះ ការត្រួតត្រារបស់អឺរ៉ុបលើកិច្ចការពិភពលោកបានធ្លាក់ចុះក្រោយសង្គ្រាម។

ប្រជាធិបតេយ្យថ្មីដែលមិនស្ថិតស្ថេរ៖ បន្ទាប់ពីសង្គ្រាមបានបញ្ចប់គេបានមើលឃើញពីការកើនឡើងភ្លាមៗនៃលទ្ធិប្រជាធិបតេយ្យថ្មី។ ពីឆ្នាំ 1914 ដល់ឆ្នាំ 1918 មេដឹកនាំផ្ដាច់ការចុងក្រោយរបស់អឺរ៉ុបត្រូវបានផ្ដួលរំលំ។ រដ្ឋាភិបាលថ្មីដំបូងបង្អស់ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសរុស្ស៊ីក្នុងឆ្នាំ 1917 ។ វាត្រូវបានគេហៅ រដ្ឋាភិបាលបណ្ដោះអាសន្ន ត្រូវបានគេរំពឹងថានឹងបង្កើតច្បាប់រដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យ។ ទោះយ៉ាងណាក៏ដោយក្នុងរយៈពេលប៉ុន្មានខែ រដ្ឋាភិបាលនេះបានធ្លាក់ទៅក្នុងរបបផ្ដាច់ការបែបកុំម្មុយនីស្ត។ ទោះជាយ៉ាងនេះក្ដី វាជាលើកដំបូងដែលប្រទេសអឺរ៉ុបមួយភាគធំមានរដ្ឋាភិបាលបែបប្រជាធិបតេយ្យ។ ប្រជាពលរដ្ឋភាគច្រើននៅប្រទេសប្រជាធិបតេយ្យថ្មីៗមានបទពិសោធន៍តិចតួចជាមួយរដ្ឋាភិបាលតំណាង។ អស់ជាច្រើនជំនាន់ ព្រះមហាក្សត្រ និងអធិរាជបានគ្រប់គ្រងប្រទេសអាល្លឺម៉ង់ និងប្រទេសថ្មីដែលបែកចេញពីចក្រភពអូទ្រីស-ហុងគ្រី។ សូម្បីតែនៅប្រទេសបារាំង និងអ៊ីតាលី ដែលមានសភាតាំងពីមុនសង្គ្រាមលោកលើកទី 1 មកម្លេះ គណបក្សនយោបាយដែលមានចំនួនច្រើន បានធ្វើឱ្យប្រសិទ្ធភាពរបស់រដ្ឋាភិបាលជួបការលំបាក។ ប្រទេសខ្លះមានក្រុមនយោបាយរាប់សិបឬច្រើនជាងនេះ។ នៅក្នុងប្រទេសទាំងនេះ វាស្ទើរតែមិនអាចទៅរួចទេដែលភាគីម្ខាងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ នៅពេលដែលគ្មានគណបក្សតែមួយឈ្នះសំឡេងភាគច្រើន រដ្ឋាភិបាលចម្រុះឬសម្ព័ន្ធភាពបណ្ដោះអាសន្នដែលមានការចូលរួមពីគណបក្សច្រើន ចាំបាច់ត្រូវបង្កើតឡើងដើម្បីបង្កើតសភាសំលេងភាគច្រើនមួយ។ ដោយសារជាញឹកញាប់ភាគីនីមួយៗមិនសូវស្របគ្នាលើគោលនយោបាយ ដូច្នេះក្រុមចម្រុះកម្រមានរយៈពេលយូរណាស់។ ការផ្លាស់ប្ដូររដ្ឋាភិបាលជាញឹកញាប់បានធ្វើឱ្យប្រទេសប្រជាធិបតេយ្យមានការលំបាកក្នុងការអភិវឌ្ឍភាពជាអ្នកដឹកនាំដ៏រឹងមាំ និងឆ្ពោះទៅរកគោលដៅរយៈពេលវែង។ ភាពទន់ខ្សោយរបស់រដ្ឋាភិបាលចម្រុះបានក្លាយជាបញ្ហាចម្បងនៅក្នុងគ្រាមានវិបត្តិ។ អ្នកបោះឆ្នោតនៅក្នុងប្រទេសមួយចំនួនមានឆន្ទៈក្នុងការលះបង់រដ្ឋាភិបាលបែបប្រជាធិបតេយ្យជាថ្នូរទៅនឹងការដឹកនាំដ៏រឹងមាំបែបផ្ដាច់ការ។

## 2. សាធារណរដ្ឋវីម៉ា

រដ្ឋាភិបាលបែបប្រជាធិបតេយ្យថ្មីរបស់អាល្លឺម៉ង់ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1919 ។ ត្រូវបានគេស្គាល់ថាជាសាធារណរដ្ឋវីម៉ា ឈ្មោះនេះត្រូវបានគេដាក់តាមទីក្រុងដែលសភាជាតិបានជួបប្រជុំគ្នា។ សាធារណរដ្ឋវីម៉ាមានចំណុចខ្សោយយ៉ាងច្រើនតាំងពីដំបូង។ ទីមួយ អាឡឺម៉ង់ខ្វះបទពិសោធន៍ប្រជាធិបតេយ្យ។ លើសពីនេះ អាឡឺម៉ង់ក្រោយសង្គ្រាម មានគណបក្សនយោបាយធំៗ និងគណបក្សតូចៗជាច្រើន។ កាន់តែអាក្រក់ជាងនេះទៅទៀតជនជាតិអាល្លឺម៉ង់រាប់លាននាក់បានស្ដីបន្ទោសរដ្ឋាភិបាលវីម៉ា ដែលតាមពិតទៅមិនមែនជាអ្នកដឹកនាំក្នុងសម័យ

សង្គ្រាម ចំពោះភាពបរាជ័យរបស់ប្រទេសអាឡឺម៉ង់ និងភាពអាម៉ាស់ក្រោយសង្គ្រាមដែលបណ្ដាលមកពីសន្ធិសញ្ញាទីក្រុងវែរសៃ។

អតិផរណាបណ្ដាលឱ្យវិបត្តិនៅប្រទេសអាឡឺម៉ង់៖ អាឡឺម៉ង់ក៏ប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ចដ៏ធំសម្បើមមួយផងដែល វាបានចាប់ផ្ដើមឡើងនៅអំឡុងពេលនៃសង្គ្រាម។ ខុសពីប្រទេសអង់គ្លេស និងបារាំងទេ អាឡឺម៉ង់មិនបានបង្កើនពន្ធក្នុងសម័យសង្គ្រាមទេ។ ដើម្បីបង់ថ្លៃចំណាយក្នុងសង្គ្រាម អាល្លឺម៉ង់បានបោះពុម្ពលុយយ៉ាងច្រើន។ បន្ទាប់ពីការបរាជ័យរបស់អាល្លឺម៉ង់ ក្រដាសលុយនេះបានបាត់បង់តម្លៃរបស់វាជាលំដាប់។ ដោយមានបន្ទុកលើការទូទាត់សំណងយ៉ាងច្រើនដល់ក្រុមសម្ព័ន្ធមិត្ត និងបញ្ហាសេដ្ឋកិច្ចផ្សេងៗទៀត អាល្លឺម៉ង់បានបោះពុម្ពក្រដាស់ប្រាក់បន្ថែមទៀត។ ជាលទ្ធផល តម្លៃនៃរូបិយបណ្ណម៉ាករបស់អាល្លឺម៉ង់បានធ្លាក់ចុះយ៉ាងខ្លាំង។ អតិផរណាធ្ងន់ធ្ងរបានកើតមានឡើង។ ជនជាតិអាឡឺម៉ង់ត្រូវការលុយកាន់តែច្រើនដើម្បីទិញសូម្បីតែទំនិញជាមូលដ្ឋានបំផុត។ ឧទាហរណ៍ នៅទីក្រុងប៊ែរឡាំង នំប៉័ងមួយដុំមានតម្លៃតិចមួយម៉ាកនៅឆ្នាំ 1918 និងជាង 160 ម៉ាកនៅឆ្នាំ 1922, និងប្រហែល 200 ពាន់លានម៉ាកនៅចុងឆ្នាំ 1923 ។ មនុស្សបានយករទេះរុញដែលពោរពេញដោយលុយដើម្បីទិញអាហារ។ ជាលទ្ធផល ជនជាតិអាល្លឺម៉ង់ជាច្រើនបានចោទសួរពីតម្លៃនៃរដ្ឋាភិបាលប្រជាធិបតេយ្យថ្មីរបស់ពួកគេ។

### 3. ការប៉ុនប៉ងធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព

ប្រទេសអាឡឺម៉ង់បានងើបឡើងវិញពីអតិផរណាឆ្នាំ 1923 អរគុណច្រើនចំពោះការងាររបស់គណៈកម្មាធិការអន្តរជាតិ។ គណៈកម្មាធិការនេះដឹកនាំដោយលោកឆាល ដាវេស ដែលជាធនាគារិកជនជាតិអាមេរិក។ ផែនការដាវេសបានផ្ដល់ប្រាក់កម្ចី 200 លានដុល្លារពីធនាគារអាមេរិក ដើម្បីធ្វើមានស្ថិរភាពរូបិយប័ណ្ណអាល្លឺម៉ង់ និងពង្រឹងសេដ្ឋកិច្ចរបស់ខ្លួន។ ផែនការនេះក៏បានកំណត់កាលវិភាគជាក់ស្តែងបន្ថែមទៀតសម្រាប់ការទូទាត់សំណងរបស់ប្រទេសអាល្លឺម៉ង់ផងដែរ។ ចូលជាធរមាននៅឆ្នាំ 1924 ផែនការដាវេសបានជួយកាត់បន្ថយអតិផរណា។ នៅពេលដែលសេដ្ឋកិច្ចអាល្លឺម៉ង់ចាប់ផ្ដើមងើបឡើងវិញ វាបានទាក់ទាញការផ្ដល់ប្រាក់កម្ចី និងការវិនិយោគកាន់តែច្រើនពីសហរដ្ឋអាមេរិក។ នៅឆ្នាំ 1929 រោងចក្រអាឡឺម៉ង់ចាប់ផ្ដើមផលិតបានច្រើនដូចដែលពួកគេធ្លាប់បានធ្វើមុនសម័យសង្គ្រាម។

កិច្ចខិតខំប្រឹងប្រែងដើម្បីសន្តិភាពយូរអង្វែង៖ នៅពេលដែលវិបុលភាពបានត្រលប់មកវិញ រដ្ឋមន្ត្រីការបរទេសអាល្លឺម៉ង់លោកហ្គូស្ទេវ ស្ទ្រេសឺមែន និងរដ្ឋមន្ត្រីការបរទេសបារាំងលោកអារីស្ទីដ ប្រាយអេនដ៍ បានព្យាយាមកែលម្អទំនាក់ទំនងរវាងប្រទេសទាំង 2 ។ នៅឆ្នាំ 1925 រដ្ឋមន្ត្រីទាំង 2 បានជួបគ្នានៅក្នុងទីក្រុងឡូខាណូ ប្រទេសស្វីសរួមជាមួយមន្ត្រីមកពីប្រទេសប៊ែលហ្សិក អ៊ីតាលី និងអង់គ្លេស។ ពួកគេបានចុះហត្ថលេខាលើសន្ធិសញ្ញាមួយដោយសន្យាថាបារាំង និងអាល្លឺម៉ង់នឹងមិនធ្វើសង្គ្រាមដើម្បីប្រឆាំងគ្នាឡើយ។ អាល្លឺម៉ង់ក៏បានយល់ព្រមគោរពព្រំដែនដែលមានស្រាប់របស់ប្រទេសបារាំង និងប៊ែលហ្ស៊ិកផងដែរ។ បន្ទាប់មកវាត្រូវបានគេបញ្ចូលទៅក្នុងសម្ព័ន្ធប្រជាជាតិ។ នៅឆ្នាំ 1928 ក្ដីសង្ឃឹមដែលបង្កើតឡើងដោយ "ស្មារតីនៃឡូខាណូ" បាននាំទៅដល់កតិកាសញ្ញាសន្តិភាពកេឡូក-ប្រាយអេនដ៍។ លោកហ្វេង កេឡូក ដែលជារដ្ឋលេខាធិការរបស់សហរដ្ឋអាមេរិកបានរៀបចំកិច្ចព្រមព្រៀងនេះ

ជាមួយលោកប្រាយអេនដ៍របស់បារាំង។ ស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក រួមទាំងសហភាពសូវៀតផង នោះ បានចុះហត្ថលេខាលើកតិកាសញ្ញាសន្តិភាពនេះ។ ពួកប្រទេសទាំងនោះបានសន្យាថានឹងលះបង់ការយកសង្គ្រាម មកធ្វើជាឧបករណ៍នៃគោលនយោបាយជាតិ។ ជាអកុសល សន្ធិសញ្ញានេះមិនមានមធ្យោបាយដើម្បីអនុវត្ត បទប្បញ្ញត្តិរបស់ខ្លួនឡើយ។ សម្ព័ន្ធនៃប្រជាជាតិដែលជាជម្រើសក្នុងការអនុវត្តជាក់ស្តែងពុំមានកងកម្លាំងប្រដាប់អាវុធ ទេ។ ការបដិសេធរបស់សហរដ្ឋអាមេរិកក្នុងការចូលរួមក្នុងសម្ព័ន្ធនេះក៏បានធ្វើឱ្យវាចុះខ្សោយផងដែរ។ យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងសន្តិភាពហាក់ដូចជាការចាប់ផ្តើមដ៏ល្អមួយ។

## 4. ការដួលរលំផ្នែកហិរញ្ញវត្ថុ

នៅចុងទសវត្សរ៍ឆ្នាំ 1920 វិបុលភាពសេដ្ឋកិច្ចរបស់អាមេរិកបានរួមចំណែកយ៉ាងខ្លាំងនៅក្នុងការទ្រទ្រង់សេដ្ឋកិច្ចពិភពលោក។ ប្រសិនបើសេដ្ឋកិច្ចអាមេរិកចុះខ្សោយ ប្រព័ន្ធសេដ្ឋកិច្ចពិភពលោកទាំងមូលអាចនឹងដួលរលំ។ នៅឆ្នាំ 1929 រឿងនេះបានកើតឡើង។

កំហុសនៃសេដ្ឋកិច្ចអាមេរិក៖ ទោះបីជាមានភាពរីកចម្រើនក៏ដោយ ភាពទន់ខ្សោយជាច្រើននៅក្នុងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកបានបង្កឱ្យមានបញ្ហាធ្ងន់ធ្ងរ។ ភាពទន់ខ្សោយទាំងនោះរួមមាន ភាពមិនស្មើគ្នានៃការបែងចែកទ្រព្យសម្បត្តិ, ការផលិតហួសនៅក្នុងវិស័យអាជីវកម្ម និងកសិកម្ម, និងការចំណាយតិចតួចរបស់ជនជាតិអាមេរិក។ នៅឆ្នាំ 1929 រោងចក្រអាមេរិកបានផលិតស្ទើរតែពាក់កណ្តាលនៃទំនិញឧស្សាហកម្មរបស់ពិភពលោក។ ការកើនឡើងនៃផលិតភាពនេះនាំទៅរកការកើនឡើងនៃប្រាក់ចំណេញដ៏ធំសម្បើម។ ទោះជាយ៉ាងណាក៏ដោយ ទ្រព្យសម្បត្តិថ្មីនេះមិនត្រូវបានចែកចាយស្មើៗគ្នាទេ។ អ្នកមានបំផុត 5% នៃចំនួនប្រជាជនសរុបទទួលបាន 33% នៃប្រាក់ចំណូលទាំងនេះក្នុងឆ្នាំ 1929 ។ ប៉ុន្តែ 60 ភាគរយនៃគ្រួសារអាមេរិកទាំងអស់រកបានប្រាក់ចំណូលតិចជាង 2,000 ដុល្លារក្នុងមួយឆ្នាំ ដូច្នេះហើយ គ្រួសារភាគច្រើនមានជីវភាពក្រីក្រយ៉ាងខ្លាំងដែលបណ្តាលឱ្យពួកគេមិនអាចទិញទំនិញដែលត្រូវបានផលិត។ ដោយមិនអាចលក់ទំនិញទាំងអស់របស់ពួកគេបាន ម្ចាស់ហាងនៅទីបំផុតបានកាត់បន្ថយការបញ្ជាទិញរបស់ពួកគេពីរោងចក្រ។ រោងចក្រកាត់បន្ថយការផលិត និងបញ្ឈប់កម្មករ។ ការធ្លាក់ចុះនៃវដ្តសេដ្ឋកិច្ចបានចាប់ផ្តើម។ ដោយសារកម្មករកាន់តែច្រើនបាត់បង់ការងារ គ្រួសារដែលទិញទំនិញមានកាន់តែតិច។ ម្យ៉ាងវិញទៀត រោងចក្របានកាត់បន្ថយផលិតកម្ម និងបញ្ឈប់កម្មករបន្ថែមទៀត។ នៅអំឡុងឆ្នាំ 1920 ការផលិតហួសប្រមាណបានប៉ះពាល់ដល់កសិករអាមេរិកផងដែរ។ វិធីសាស្ត្រកសិកម្មបែបវិទ្យាសាស្ត្រ និងគ្រឿងយន្តកសិកម្មថ្មីបានបង្កើនទិន្នផលដំណាំយ៉ាងខ្លាំង។ កសិករអាមេរិកបានផលិតអាហារកាន់តែច្រើន។ ទន្ទឹមនឹងនេះ ពួកគេបានប្រឈមមុខនឹងការប្រកួតប្រជែងថ្មីពីកសិករនៅប្រទេសអូស្ត្រាលី, អាមេរិកឡាទីន, និងអឺរ៉ុប។ ជាលទ្ធផល ភាពលើសនៃផលិតផលកសិកម្មទូទាំងពិភពលោកបានធ្វើឱ្យតម្លៃ និងប្រាក់ចំណេញធ្លាក់ចុះ។ មិនអាចទទួលបានប្រាក់ចំណេញពីការលក់ផលិតផលដំណាំរបស់ពួកគេបាន កសិករជាច្រើនមិនអាចសងប្រាក់កម្ចីដល់ធនាគារដែលជាប្រាក់អាចឱ្យពួកគេបន្តធ្វើអាជីវកម្មបានទេ។ បំណុលដែលមិនទាន់បានបង់របស់ពួកគេបានធ្វើឱ្យធនាគារទន់ខ្សោយ ហើយបង្ខំឱ្យធនាគារមួយចំនួនបិទទ្វា។ សញ្ញាគ្រោះថ្នាក់នៃផលិតកម្មហួសហេតុដោយ

រោងចក្រ និងកសិដ្ឋានគួរតែដាស់តឿនប្រជាជនឱ្យប្រយ័ត្នក្នុងការលេងល្បែងនៅក្នុងផ្សារភាគហ៊ុន។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានអ្នកណាស្ដាប់ចាប់អារម្មណ៍ចំពោះការដាស់តឿននេះឡើយ។

ការដួលរលំនៃផ្សារហ៊ុន៖ នៅក្នុងឆ្នាំ 1929 វ៉លស្ទ្រីតនៅទីក្រុងញូវយ៉កគឺជារដ្ឋធានីហិរញ្ញវត្ថុរបស់ពិភពលោក។ ធនាគារ និងក្រុមហ៊ុនវិនិយោគតម្រង់ជួរនៅតាមផ្លូវនានានៅទីនោះ។ នៅផ្សារហ៊ុនវ៉លស្ទ្រីត នៅញូវយ៉កភាពសុទិដ្ឋិនិយមអំពីសេដ្ឋកិច្ចអាមេរិកដែលកំពុងរីកចម្រើនបានបង្ហាញពីការកើនឡើងនៃតម្លៃភាគហ៊ុន។ ដើម្បីឈានទៅរកការរីកចំរើន អ្នកដែលមានចំណូលមធ្យមភាគជាច្រើនបានចាប់ផ្ដើមទិញភាគហ៊ុនដោយបង់រំលោះ។ មានន័យថាដំបូងពួកគេបានបង់ប្រាក់មួយភាគតូចនៃតម្លៃភាគហ៊ុនសរុប នៅសល់ប៉ុន្មានទៀតពួកគេត្រូវជាការទូទាត់ជាលក្ខណៈរំលោះ ហើយពួកគេបានខ្ចីប្រាក់ដែលនៅសល់ពីឈ្មួញកណ្ដាល។ ប្រព័ន្ធនេះដំណើរការបានល្អដរាបណាតម្លៃភាគហ៊ុនកើនឡើង។ ទោះជាយ៉ាងណាប្រសិនបើតម្លៃភាគហ៊ុនធ្លាក់ចុះ អ្នកវិនិយោគគ្មានប្រាក់ដើម្បីសងប្រាក់កម្ចីនោះទេ។ នៅខែកញ្ញាឆ្នាំ 1929 អ្នកវិនិយោគមួយចំនួនបានចាប់ផ្ដើមគិតថាតម្លៃភាគហ៊ុនឡើងខ្ពស់ខុសពីធម្មតា។ ពួកគេបានចាប់ផ្ដើមលក់ភាគហ៊ុនរបស់ពួកគេ ដោយជឿថាតម្លៃនឹងធ្លាក់ចុះឆាប់ៗនេះ។ គិតត្រឹមថ្ងៃព្រហស្បតិ៍ ទី 24 ខែតុលា ការធ្លាក់ចុះបន្តិចម្ដងៗនៃតម្លៃភាគហ៊ុនបាននាំទៅដល់ការធ្លាក់ចុះដ៏ធំមួយ។ ភាពភ័យស្លន់ស្លោមួយបានកើតឡើង។ គ្រប់គ្នាចង់លក់ភាគហ៊ុន ហើយគ្មាននរណាម្នាក់ចង់ទិញទេ។ តម្លៃបានធ្លាក់ចុះដល់កម្រិតទាបបំផុតមួយនៅថ្ងៃអង្គារ ទី 29 ខែតុលា។ ភាគហ៊ុនចំនួន 16 លានត្រូវបានលក់។ បន្ទាប់មកទីផ្សារបានដួលរលំ។

## 5. មហាវិបត្តិសេដ្ឋកិច្ច

មនុស្សមិនអាចបង់លុយដែលពួកគេជំពាក់លើការទិញភាគហ៊ុនបង់រំលោះ។ ភាគហ៊ុនដែលពួកគេបានទិញក្នុងតម្លៃខ្ពស់ឥឡូវនេះគ្មានតម្លៃទេ។ ក្នុងរយៈពេលប៉ុន្មានខែនៃការដួលរលំ អត្រាអ្នកអត់ការងារធ្វើបានចាប់ផ្ដើមកើនឡើង ដោយសារផលិតកម្មឧស្សាហកម្ម, តម្លៃ, និងប្រាក់ឈ្នួលបានធ្លាក់ចុះ។ ការធ្លាក់ចុះអាជីវកម្មក្នុងរយៈពេលដ៏យូរមួយ ដែលត្រូវបានគេហៅថា មហាវិបត្តិសេដ្ឋកិច្ច បានកើតឡើងតាមក្រោយ។ ការធ្លាក់ទីផ្សារភាគហ៊ុនតែមួយ មិនបណ្ដាលឱ្យមានមហាវិបត្តិសេដ្ឋកិច្ចនោះទេ ប៉ុន្តែការដួលរលំនៃសេដ្ឋកិច្ចយ៉ាងឆាប់រហ័សបានបណ្ដាយឱ្យវិបត្តិសេដ្ឋកិច្ចកាន់តែមានលក្ខណៈធ្ងន់ធ្ងរ។ នៅឆ្នាំ 1932 ផលិតកម្មរោងចក្រត្រូវបានកាត់បន្ថយពាក់កណ្ដាល។ អាជីវកម្មរាប់ពាន់បានដួលរលំ ហើយធនាគារបានបិទទ្វា។ មនុស្សប្រហែល 9 លាននាក់បានបាត់បង់ប្រាក់នៅក្នុងគណនីសន្សំរបស់ពួកគេនៅខណៈពេលដែលធនាគារមិនមានប្រាក់សម្រាប់ទូទាត់ឱ្យពួកគេ។ កសិករជាច្រើនបានបាត់បង់ដីរបស់ពួកគេ នៅពេលដែលពួកគេមិនអាចបង់រំលោះបាន។ នៅឆ្នាំ 1933 មួយភាគបួននៃកម្មករអាមេរិកទាំងអស់គ្មានការងារធ្វើទេ។

វិបត្តិសេដ្ឋកិច្ចជាសកល៖ ការដួលរលំនៃសេដ្ឋកិច្ចរបស់អាមេរិកបានបញ្ជូននូវរលករន្ធត់ជុំវិញពិភពលោក។ ធនាគារិកអាមេរិកដែលមានការព្រួយបារម្ភទាមទារឱ្យសងប្រាក់កម្ចីនៅបរទេសរបស់ពួកគេ ហើយអ្នកវិនិយោគអាមេរិកបានដកប្រាក់របស់ពួកគេពីអឺរ៉ុប។ ទីផ្សារអាមេរិកសម្រាប់ទំនិញអឺរ៉ុបបានធ្លាក់ចុះយ៉ាងខ្លាំង នៅពេលដែល

សភាអាមេរិកបានកំណត់ពន្ធខ្ពស់លើទំនិញនាំចូល ដូច្នេះប្រាក់ដុល្លារអាមេរិកនឹងបន្តស្ថិតនៅសហរដ្ឋអាមេរិក និងចំណាយសម្រាប់ទំនិញអាមេរិក។ គោលការណ៍នេះបានបរាជ័យ។ ស្ថានភាពកាន់តែអាក្រក់សម្រាប់សហរដ្ឋអាមេរិក។ ប្រទេសជាច្រើនដែលពឹងផ្អែកលើការនាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិកក៏ទទួលរងគ្រោះផងដែរ។ ជាងនេះទៅទៀត នៅពេលដែលសហរដ្ឋអាមេរិកដំឡើងពន្ធ វាបានបង្កឱ្យមានប្រតិកម្មជាសង្វាក់មួយ។ ប្រទេសផ្សេងទៀតបានកំណត់ពន្ធខ្ពស់របស់ខ្លួនផងដែរ។ ពាណិជ្ជកម្មពិភពលោកបានធ្លាក់ចុះ 65% ។ ការធ្លាក់ចុះនេះបានរួមចំណែកបន្ថែមទៀតដល់ការធ្លាក់ចុះសេដ្ឋកិច្ច។ អត្រាអ្នកគ្មានការងារធ្វើបានកើនឡើង។

ឥទ្ធិពលជុំវិញពិភពលោក៖ ដោយសារតែបំណុលសង្គ្រាម, និងការពឹងផ្អែកលើប្រាក់កម្ចី, និងការវិនិយោគរបស់អាមេរិក ប្រទេសអាល្លឺម៉ង់ និងអូទ្រីសបានរងផលប៉ះពាល់យ៉ាងខ្លាំងជាពិសេស។ នៅឆ្នាំ 1931 ធនាគារធំជាងគេរបស់អូទ្រីសបានដួលរលំ។ នៅអាស៊ី ទាំងកសិករ និងកម្មករនៅក្នុងទីក្រុងបានរងទុក្ខ ដោយសារតម្លៃនៃការនាំចេញបានធ្លាក់ចុះពាក់កណ្តាលរវាងឆ្នាំ 1929 និង 1931។ ឧបទ្ទវហេតុនេះក៏ជះឥទ្ធិពលយ៉ាងខ្លាំងនៅអាមេរិកឡាទីនផងដែរ។ នៅពេលដែលតម្រូវការរបស់អឺរ៉ុប និងសហរដ្ឋអាមេរិកសម្រាប់ផលិតផលអាមេរិកឡាទីនដូចជាស្ករ, សាច់គោ, និងទង់ដែងបានធ្លាក់ចុះ តម្លៃក៏បានធ្លាក់ចុះ។

## 6. ពិភពលោកប្រឈមមុខនិងវិបត្តិ

វិបត្តិសេដ្ឋកិច្ចបានបណ្តាលឱ្យមានបញ្ហាប្រឈមដល់លទ្ធិប្រជាធិបតេយ្យ ដោយសារប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយរបស់វាបង្កឱ្យមានបញ្ហាដ៏ធ្ងន់ធ្ងរ។ ប្រទេសនីមួយៗជួបវិបត្តិតាមរបៀបរបស់ខ្លួន។

ចក្រភពអង់គ្លេសចាត់វិធានការកែលម្អសេដ្ឋកិច្ចរបស់ខ្លួន៖ វិបត្តិសេដ្ឋកិច្ចបានវាយប្រហារលើចក្រភពអង់គ្លេសយ៉ាងធ្ងន់ធ្ងរ។ ដើម្បីឆ្លើយតបនឹងភាពអាសន្ននេះ ក្រុមអ្នកបោះឆ្នោតអង់គ្លេសបានបោះឆ្នោតជ្រើសរើសសម្ព័ន្ធពហុបក្សដែលគេស្គាល់ថារដ្ឋាភិបាលជាតិ។ រដ្ឋាភិបាលនេះបានអនុម័តពន្ធការពារខ្ពស់, បង្កើនពន្ធ, និងគ្រប់គ្រងរូបិយប័ណ្ណ។ ពួកគេក៏បានទម្លាក់អត្រាការប្រាក់ផងដែរ ដើម្បីជំរុញឱ្យមានកំណើនឧស្សាហកម្ម។ វិធានការទាំងនេះបាននាំមកនូវការងើបឡើងវិញយឺតៗ ប៉ុន្តែមានស្ថេរភាព។ នៅឆ្នាំ 1937 ភាពអត់ការងារធ្វើត្រូវបានកាត់បន្ថយពាក់កណ្តាល ហើយកម្រិតផលិតកម្មបានកើនឡើងលើសពីឆ្នាំ 1929 ។ អង់គ្លេសបានគេចផុតពីភាពជ្រុលនិយមខាងនយោបាយ និងរក្សាលទ្ធិប្រជាធិបតេយ្យ។

បារាំងឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ច៖ ខុសពីប្រទេសអង់គ្លេស បារាំងមានសេដ្ឋកិច្ចពឹងផ្អែកលើខ្លួនឯងច្រើន។ នៅឆ្នាំ 1930 ប្រទេសបារាំងនៅតែជាប្រទេសដែលខ្លាំងខាងកសិកម្ម ហើយមិនសូវពឹងផ្អែកលើពាណិជ្ជកម្មបរទេសឡើយ។ យ៉ាងណាក៏ដោយ នៅឆ្នាំ 1935 កម្មករបារាំងមួយលាននាក់អត់ការងារធ្វើ។ វិបត្តិសេដ្ឋកិច្ចបានរួមចំណែកដល់អស្ថេរភាពនយោបាយក្នុងប្រទេសបារាំង។ នៅឆ្នាំ 1933 មានរដ្ឋាភិបាលចម្រុះចំនួន 5 ត្រូវបានបង្កើតឡើង និងដួលរលំទៅវិញ។ មេដឹកនាំនយោបាយជាច្រើនមានការភ័យខ្លាចចំពោះការកើនឡើងនៃកម្លាំងប្រឆាំងលទ្ធិប្រជាធិបតេយ្យទាំងនៅក្នុងប្រទេសបារាំង និងនៅតំបន់ផ្សេងទៀតនៃទ្វីបអឺរ៉ុប។ ដូច្នេះនៅឆ្នាំ 1936 ពួកកណ្តាលនិយម, សង្គមនិយម, និងកុម្មុយនិស្ត បានបង្កើតរដ្ឋាភិបាលចម្រុះ។ រដ្ឋាភិបាលនេះត្រូវបានគេហៅឈ្មោះថា រណសិរ្ស

ប្រជាប្រិយ បានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ដើម្បីជួយដល់កម្មករ។ ជាអកុសល ការកើនឡើងនៃតម្លៃយ៉ាងឆាប់រហ័ស បានទូទាត់ជាមួយកំណើនប្រាក់ឈ្នួល។ ភាពអត់ការងារធ្វើនៅតែមានកម្រិតខ្ពស់។ ប៉ុន្តែបារាំងក៏បានការពាររដ្ឋាភិបាលបែបប្រជាធិបតេយ្យផងដែរ។

រដ្ឋាភិបាលសង្គមនិយមស្វែងរកដំណោះស្រាយ៖ រដ្ឋាភិបាលសង្គមនិយមនៅក្នុងបណ្តាប្រទេសស្កែនឌីណាវនៃប្រទេសដាណឺម៉ាក, ស៊ុយអែត, និងន័រវេសក៏បានជួបបញ្ហាប្រឈមនៃវិបត្តិសេដ្ឋកិច្ចយ៉ាងពេញទំហឹងផងដែរ។ ពួកគេបានបង្កើតកម្មវិធីស្តារឡើងវិញរបស់ពួកគេ បន្ថែមពីលើកម្មវិធីបែបប្រពៃណីដែលមានឈ្មោះថាសកម្មភាពសហគមន៍រួបរួម ដែលមានស្រាប់។ នៅក្នុងប្រទេសស៊ុយអែត គម្រោងការងារសាធារណៈដ៏ធំដែលឧបត្ថម្ភដោយរដ្ឋាភិបាល បានរក្សាមនុស្សឲ្យមានការងារធ្វើ និងផលិតកម្ម។ ប្រទេសស្កែនឌីណាវទាំងអស់បានដំឡើងប្រាក់សោធនសម្រាប់មនុស្សចាស់ និងបង្កើនការធានារ៉ាប់រងលើភាពអត់ការងារធ្វើ, ប្រាក់ឧបត្ថម្ភសម្រាប់លំនៅដ្ឋាន, និងអត្ថប្រយោជន៍សុខុមាលភាពផ្សេងទៀត។ ដើម្បីចំណាយលើអត្ថប្រយោជន៍ទាំងនេះ រដ្ឋាភិបាលបានយកពន្ធលើប្រជាពលរដ្ឋទាំងអស់។ លទ្ធិប្រជាធិបតេយ្យនៅរក្សាដដែល។

ការងើបឡើងវិញនៅសហរដ្ឋអាមេរិក៖ នៅឆ្នាំ 1932 នៅក្នុងការបោះឆ្នោតប្រធានាធិបតីលើកដំបូងបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចបានចាប់ផ្តើម ក្រុមអ្នកបោះឆ្នោតអាមេរិកបានជ្រើសរើសលោកហ្វ្រែងគ្លីន ដេឡាណូ រូសេវេលថ៍។ អាកប្បកិរិយាប្រកបដោយទំនុកចិត្តរបស់លោក បានទាក់ទាញប្រជាជនអាមេរិករាប់លាននាក់ដែលសុញគំនិតដោយវិបត្តិសេដ្ឋកិច្ច។ នៅថ្ងៃទី 4 ខែមីនា ឆ្នាំ 1933 ប្រធានាធិបតីថ្មីបានព្យាយាមស្តារជំនឿចិត្តរបស់ជនជាតិអាមេរិកលើប្រទេសរបស់ពួកគេ។ លោករូសេវេលថ៍បានចាប់ផ្តើមកម្មវិធីកំណែទម្រង់រដ្ឋាភិបាលភ្លាមៗ ដែលគាត់បានហៅថាដំណោះស្រាយថ្មី។ គម្រោងការងារសាធារណៈធំៗបានជួយផ្តល់ការងារដល់អ្នកអត់ការងារធ្វើ។ ភ្នាក់ងាររដ្ឋាភិបាលថ្មីបានផ្តល់ជំនួយហិរញ្ញវត្ថុដល់អាជីវកម្ម និងកសិដ្ឋាន។ ថវិកាសាធារណៈមួយចំនួនធំត្រូវបានចំណាយលើកម្មវិធីសុខុមាលភាព និងជំនួយសង្គ្រោះ។ លោករូសេវេលថ៍ និងទីប្រឹក្សារបស់លោកជឿថាការចំណាយរបស់រដ្ឋាភិបាលនឹងបង្កើតការងារ និងធ្វើឱ្យសេដ្ឋកិច្ចចាប់ផ្តើមងើបឡើងវិញ។ បទប្បញ្ញត្តិត្រូវបានដាក់ដើម្បីធ្វើកំណែទម្រង់ទីផ្សារភាគហ៊ុន និងប្រព័ន្ធធនាគារ។ ជាយថាហេតុកម្មវិធីដំណោះស្រាយថ្មីបានធ្វើកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចអាមេរិក។ ការដឹកនាំរបស់លោករូសេវេលថ៍ បានរក្សាជំនឿប្រជាជនអាមេរិកលើប្រព័ន្ធនយោបាយបែបប្រជាធិបតេយ្យរបស់ខ្លួន។ វាក៏បានធ្វើឱ្យលោកក្លាយជាមេដឹកនាំនៃលទ្ធិប្រជាធិបតេយ្យមួយរូបនៅក្នុងពិភពលោក ដែលកំពុងត្រូវបានគំរាមកំហែងដោយពួកផ្តាច់ការឃោរឃៅ ដូចដែលអ្នកនឹងអាននៅក្នុងមេរៀនទី 3 ។

# មេរៀនទី 3៖ ហ្វាស៊ីសនិយមលេចឡើងនៃអឺរ៉ុប

## 1. ហ្វាស៊ីសនិយមលេចឡើងនៅអ៊ីតាលី

ហ្វាស៊ីសនិយម គឺជាចលនានយោបាយបែបសកម្មប្រយុទ្ធថ្មីមួយ ដែលសង្កត់ធ្ងន់លើភាពស្មោះត្រង់ចំពោះរដ្ឋ និងការគោរពប្រតិបត្តិចំពោះមេដឹកនាំរបស់ខ្លួន។ ខុសពីលទ្ធិកុំម្មុយនីស្ត ហ្វាស៊ីសនិយមមិនមានទ្រឹស្តី ឬកម្មវិធីកំណត់ជាក់លាស់ទេ។ ទោះជាយ៉ាងណាក៏ដោយ ពួកហ្វាស៊ីសភាគច្រើនបានចែករំលែកគំនិតមួយចំនួន។ ពួកគេបានអធិប្បាយបែបជ្រុលនិយមអំពីជាតិនិយម ឬភាពស្មោះត្រង់ចំពោះប្រទេសរបស់ខ្លួន។ ពួកហ្វាស៊ីសបានជឿថា ប្រជាជាតិនានាត្រូវតែតស៊ូ—រដ្ឋដែលមានសន្តិភាពនឹងត្រូវវិនាសដោយការដណ្តើមយកបាន។ ពួកគេបានសន្យាក្នុងការស្មោះត្រង់ចំពោះមេដឹកនាំផ្តាច់ការ ដែលបានដឹកនាំ និងនាំមកមនូវសណ្តាប់ធ្នាប់ដល់រដ្ឋ។ នៅក្នុងប្រទេសនីមួយៗ ពួកហ្វាស៊ីសបានស្លៀកឯកសណ្ឋានពណ៌ជាក់លាក់, ប្រើប្រាស់របៀបគោរពពិសេស, និងប្រមូលផ្តុំហ្វូងមហាជន។ នៅក្នុងវិធីខ្លះ ហ្វាស៊ីសនិយមគឺស្រដៀងនឹងលទ្ធិកុំម្មុយនីស្ត។ ប្រព័ន្ធទាំងពីរនេះត្រូវបានគ្រប់គ្រងដោយជនផ្តាច់ការដែលអនុញ្ញាតឱ្យមានតែគណបក្សនយោបាយរបស់ខ្លួន (ការគ្រប់គ្រងដោយបក្សតែមួយ)។ ប្រព័ន្ធទាំង 2 បានបដិសេធសិទ្ធិបុគ្គល។ នៅក្នុងប្រព័ន្ធនយោបាយទាំង 2 នេះរដ្ឋមានអំណាចកំពូល។ ប្រព័ន្ធទាំង 2 នេះមិនបានអនុវត្តទម្រង់លទ្ធិប្រជាធិបតេយ្យណាមួយឡើយ។ ទោះយ៉ាងណា ដោយខុសពីកុំម្មុយនីស្ត ពួកហ្វាស៊ីសមិនបានស្វែងរកសង្គមដែលគ្មានវណ្ណៈទេ។ ផ្ទុយទៅវិញ ពួកគេជឿថា ថ្នាក់នីមួយៗមានកន្លែង និងមុខងាររបស់វា។ ក្នុងករណីភាគច្រើន គណបក្សហ្វាស៊ីសត្រូវបានបង្កើតឡើងដោយពួកអភិជន និងពួកឧស្សាហ៍កម្ម, អតីតយុទ្ធជនសង្គ្រាម, និងវណ្ណៈកណ្តាលកម្រិតទាប។ ម្យ៉ាងទៀត ពួកហ្វាស៊ីសនិយមជាអ្នកជាតិនិយម ហើយកុំម្មុយនីស្តជាអ្នកអន្តរជាតិនិយម ដោយមានបំណងនៅក្នុងការបង្រួបបង្រួមកម្មករទូទាំងពិភពលោក។

មូស្សូលីនីគ្រប់គ្រងអំណាច៖ ការកើនឡើងនៃហ្វាស៊ីសនិយមនៅក្នុងប្រទេសអ៊ីតាលីត្រូវបានជំរុញដោយការខកចិត្តដ៏ជូរចត់ចំពោះការបរាជ័យក្នុងការទទួលបានទឹកដីដ៏ធំនៅក្នុងសន្និសីទសន្តិភាពទីក្រុងប៉ារីសឆ្នាំ 1919 ។ ការកើនឡើងអតិផរណា និងភាពអត់ការងារធ្វើក៏បានរួមចំណែកដល់ភាពចលាចលក្នុងសង្គមដែលកំពុងរីករាលដាលផងដែរ។ ចំពោះការកើនឡើងនៃចំនួនប្រជាជនអ៊ីតាលី រដ្ឋាភិបាលប្រជាធិបតេយ្យរបស់ពួកគេហាក់ដូចជាអស់សង្ឃឹមក្នុងការដោះស្រាយបញ្ហារបស់ប្រទេស។ ពួកគេចង់បានអ្នកដឹកនាំដែលអាចចាត់វិធានការដោះស្រាយបញ្ហាបាន។ និពន្ធនាយកកាសែត និងអ្នកនយោបាយម្នាក់ឈ្មោះបេនីតូ មូស្សូលីនី បានសន្យាយ៉ាងក្លាហានថានឹងជួយសង្គ្រោះប្រទេសអ៊ីតាលីដោយការធ្វើឱ្យសេដ្ឋកិច្ចរបស់ខ្លួនរស់ឡើងវិញ និងកសាងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឡើងវិញ។ លោកបានប្តេជ្ញាផ្តល់ឱ្យប្រទេសអ៊ីតាលីនូវភាពជាអ្នកដឹកនាំដ៏រឹងមាំមួយរូប។ មូស្សូលីនីបានបង្កើតគណបក្សហ្វាស៊ីសនៅឆ្នាំ 1919 ។ នៅពេលដែលស្ថានភាពសេដ្ឋកិច្ចកាន់តែអាក្រក់ ប្រជាប្រិយភាពរបស់លោកបានកើនឡើងយ៉ាងឆាប់រហ័ស។ ទីបំផុត មូស្សូលីនីបានរិះគន់រដ្ឋាភិបាលអ៊ីតាលីជាសាធារណៈ។ ក្រុមនានារបស់ពួកហ្វាស៊ីសដែលពាក់អាវខ្មៅបានវាយប្រហារលើពួកកុំម្មុយនីស្ត និងពួកសង្គមនិយមនៅតាមដងផ្លូវ។ ដោយសារតែមូស្សូលីនីបានប្រើប្រាស់ការបំភ័យអំពីការបះបោររបស់កម្មករ លោកចាប់ផ្តើមទទួលបានការគាំទ្រពីវណ្ណៈកណ្តាល,

ពួកអភិជន, និងមេដឹកនាំឧស្សាហកម្ម។ នៅខែតុលាឆ្នាំ 1922 ពួកហ្វាស៊ីសប្រហែល 30.000 នាក់បានដើរនៅក្នុងទីក្រុងរ៉ូម។ ពួកគេបានទាមទារឱ្យព្រះមហាក្សត្រវិចទ័រ អេម៉ានូអែលទី 3 ដាក់មូស្ស៊ូលីនីឱ្យគ្រប់គ្រងរដ្ឋាភិបាល។ ព្រះមហាក្សត្របានសម្រេចចិត្តថា មូស្ស៊ូលីនីគឺជាក្តីសង្ឃឹមដ៏ល្អបំផុតសម្រាប់រស់រានមានជីវិតរបស់រាជវង្សទ្រង់។ បន្ទាប់ពីការរីករាលដាលនៃអំពើហិង្សា និងការបះបោរ លោកមូស្ស៊ូលីនីបានឡើងកាន់អំណាច "ស្របច្បាប់" ។

ភាពជាអ្នកដឹកនាំរបស់អ៊ីលឌូស៖ ឥឡូវនេះមូស្ស៊ូលីនីគឺជាអ៊ីលឌូស ឬអ្នកដឹកនាំ។ គាត់បានលុបចោលលទ្ធិប្រជាធិបតេយ្យ និងហាមប្រាមគណបក្សនយោបាយទាំងអស់ លើកលែងតែពួកហ្វាស៊ីស។ ប៉ូលីសសម្ងាត់បានចាប់អ្នកប្រឆាំងជាមួយលោក។ ការហាមឃាត់របស់រដ្ឋាភិបាលបានបង្ខំឱ្យស្ថានីយ៍វិទ្យុ និងការបោះពុម្ពនានា ផ្សព្វផ្សាយ ឬបោះពុម្ពតែលទ្ធិហ្វាស៊ីសប៉ុណ្ណោះ។ លោកមូស្ស៊ូលីនីបានប្រកាសថាកូដកម្មជាអំពើខុសច្បាប់។ គាត់បានស្វែងរកការគ្រប់គ្រងសេដ្ឋកិច្ចដោយចងសម្ព័ន្ធមិត្តហ្វាស៊ីសជាមួយអ្នកឧស្សាហកម្ម និងម្ចាស់ដីធំៗ។ ទោះជាយ៉ាងណាក៏ដោយ លោកមូស្ស៊ូលីនីមិនដែលបានគ្រប់គ្រងប្រទេសអ៊ីតាលីបានទាំងស្រុងដូចដែលលោកចូសេព ស្តាលីនបានអនុវត្តនៅសហភាពសូវៀត ឬអាឌុល ហ៊ីត្លែ បានអនុវត្តនៅប្រទេសអាល្លឺម៉ង់នោះទេ។

## 2. ហ៊ីត្លែរឡើងកាន់អំណាចនៅប្រទេសអាល្លឺម៉ង់

នៅពេលដែលមូស្ស៊ូលីនីក្លាយមេដឹកនាំផ្តាច់ការនៅក្នុងប្រទេសអ៊ីតាលីនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1920 អាដុល ហ៊ីត្លែរ គឺជាមេដឹកនាំនយោបាយមួយរូបដែលគេមិនសូវស្គាល់ ហើយឆាកជីវិតដំបូងរបស់លោកត្រូវបានកត់សម្គាល់ជាមួយនឹងភាពខកចិត្ត។ នៅពេលដែលសង្គ្រាមលោកលើកទី 1 បានផ្ទុះឡើង ហ៊ីត្លែរបានសម្លឹងឃើញពីការចាប់ផ្តើមថ្មីមួយ។ គាត់បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពអាឡឺម៉ង់ ហើយបានទទួលពានរង្វាន់ដែកខ្វែង ចំនួន 2 ដង ដែលជាមេដាយសម្រាប់ភាពក្លាហាន។

ការលេចឡើងនៃពួកណាស៊ី៖ នៅចុងបញ្ចប់នៃសង្គ្រាម ហ៊ីត្លែរបានតាំងទីលំនៅនៅទីក្រុងមុយនិច។ នៅឆ្នាំ 1919 គាត់បានចូលរួមជាមួយក្រុមនយោបាយស្តាំនិយមតូចមួយ។ ក្រុមនេះមានជំនឿដូចជារូបលោកដែរ ដែលថាអាល្លឺម៉ង់ត្រូវតែលុបចោលសន្ធិសញ្ញាវ៉ែរសៃ និងប្រយុទ្ធប្រឆាំងនឹងលទ្ធិកុំម្មុយនីស្ត។ ក្រុមនេះក្រោយមកបានដាក់ឈ្មោះខ្លួនឯងថា គណបក្សសង្គមនិយមជាតិកម្មករអាល្លឺម៉ង់ដែលហៅដោយខ្លីថាណាស៊ី។ គោលនយោបាយរបស់គណបក្សនេះ គឺការបង្កើតសាខាហ្វាស៊ីសនិយមនៅអាល្លឺម៉ង់ដែលត្រូវបានគេស្គាល់ថាជាណាស៊ីស។ គណបក្សនេះបានយករូបឈើឆ្កាងធ្វើជានិមិត្តសញ្ញារបស់ពួកគេ។ ពួកណាស៊ីសក៏បានបង្កើតកងជីវពលឯកជនមួយដែលមានឈ្មោះថាទាហានខ្យល់ព្យុះ ឬទាហានអាវត្នោត។ ក្នុងរយៈពេលដ៏ខ្លី ដោយសារភាពជោគជ័យរបស់ហ៊ីត្លែរក្នុងនាមជាអ្នករៀបចំ និងជាវាគ្មិននាំឱ្យលោកត្រូវបានជ្រើសរើសជា ឌឺ ហ្វ៊ូអឺ ឬជាមេដឹកនាំនៃគណបក្សណាស៊ី។ ដោយសារតែមានការបំផុសគំនិតដោយការដើរក្បួនរបស់មូស្ស៊ូលីនីនៅក្នុងទីក្រុងរ៉ូម ហ៊ីត្លែរ និងពួកណាស៊ីមានគម្រោងនៅក្នុងការដណ្តើមអំណាចនៅទីក្រុងមុយនិចក្នុងឆ្នាំ 1923 ។ ការប៉ុនប៉ងនេះបានបរាជ័យ ហើយហ៊ីត្លែរត្រូវបានចាប់ខ្លួន។ គាត់ត្រូវបានកាត់ទោសពីបទក្បត់ជាតិ ប៉ុន្តែត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារត្រឹមតែ 5 ឆ្នាំប៉ុណ្ណោះ។ លោកបានជាប់ឃុំតិចជាង 9 ខែ។ ពេលជាប់ឃុំ ហ៊ីត្លែរបានសរសេរសៀវភៅមួយក្បាលដែលមាន

ចំណាងជើងថា ការតស៊ូរបស់ខ្ញុំ។ សៀវភៅនេះបង្ហាញពីជំនឿ និងគោលដៅរបស់លោកសម្រាប់ប្រទេសអាល្លឺម៉ង់។ ហ៊ីត្លែរបានអះអាងថា ជនជាតិអាល្លឺម៉ង់ដែលលោកហៅដោយមិនត្រឹមត្រូវថាជាពួក "អារ្យ៉ន" ដែលជា "ពូជមេ"។ គាត់បានប្រកាសថា "ពូជសាសន៍" មិនមែនអារ្យ៉ន ដូចជាសាសន៍យូដា, ស្លាវ, និងហ្គីបស៊ីគឺជាពូជសាសន៍ជាន់ទាប។ លោកបានហៅសន្ធិសញ្ញាវ៉ែរសៃថាជាការប្រមាថមួយ ហើយបានប្តេជ្ញាថានឹងដណ្តើមយកទឹកដីអាល្លឺម៉ង់មកវិញ។ ហ៊ីត្លែរក៏បានប្រកាសថា អាល្លឺម៉ង់មានភាពចង្អៀតណែន ហើយត្រូវការកន្លែងរស់នៅបន្ថែមទៀត។ លោកបានសន្យាថានឹងទទួលបានកន្លែងទាំងនោះដោយការដណ្តើមកាន់កាប់អឺរ៉ុបខាងកើត និងរុស្ស៊ី។ បន្ទាប់ពីចាកចេញពីគុកនៅឆ្នាំ 1924 ហ៊ីត្លែរបានបង្កើតគណបក្សណាស៊ីឡើងវិញ។ ជនជាតិអាឡឺម៉ង់ភាគច្រើនមិនបានអើពើនឹងរូបលោក និងសារដ៏ខឹងសម្បាររបស់លោកឡើយ រហូតដល់មហាវិបត្តិសេដ្ឋកិច្ចបានបញ្ចប់កា រងើបឡើងវិញមួយរយៈពេលខ្លីនៃប្រទេសអាឡឺម៉ង់ក្រោយសង្គ្រាម។ នៅពេលដែលការផ្តល់ប្រាក់កម្ចីរបស់អាមេរិកត្រូវបានបញ្ឈប់ សេដ្ឋកិច្ចអាល្លឺម៉ង់បានដួលរលំ។ ចលាចលនៅក្នុងសង្គមបានផ្ទុះឡើង។ ដោយសារតែភាពភ័យខ្លាច និងច្របូកច្របល់ ជនជាតិអាឡឺម៉ង់ឥឡូវនេះបានងាកទៅរកហ៊ីត្លែរ ដោយសង្ឃឹមសម្រាប់សន្តិសុខ និងការដឹកនាំដ៏រឹងមាំ។

### 3. ហ៊ីត្លែរក្លាយជាអធិការបតី

ណាស៊ីបានក្លាយទៅជាគណបក្សនយោបាយដ៏ធំបំផុតនៅឆ្នាំ 1932 ។ មេដឹកនាំអភិរក្សមួយចំនួនបានយល់ច្រឡំថាពួកគេអាចគ្រប់គ្រងហ៊ីត្លែរបាន ហើយប្រើគាត់សម្រាប់គោលបំណងរបស់ពួកគេ។ នៅខែមករា ឆ្នាំ 1933 ពួកគេបានស្នើឱ្យប្រធានាធិបតីប៉ូល វ៉ុន ហ៊ីនដេនបឺក ឱ្យតែងតាំងហ៊ីត្លែរជាអធិការបតី ។ ដូច្នេះ ហ៊ីត្លែរ បានឡើងកាន់អំណាចដោយស្របច្បាប់។ នៅពេលឡើងកាន់តំណែង ហ៊ីត្លែរបានអំពាវនាវឱ្យមានការបោះឆ្នោតថ្មី ដោយសង្ឃឹមថានឹងឈ្នះសំឡេងភាគច្រើនក្នុងសភា។ ប្រាំមួយថ្ងៃមុនការបោះឆ្នោត ភ្លើងបានបំផ្លាញអគាររ៉ៃស្ទេក ដែលជាកន្លែងប្រជុំសភា។ ពួកណាស៊ីបានបន្ទោសលើពួកកុំម្មុយនីស្ត។ ដោយការញុះញង់ឱ្យមានការភ័យខ្លាចចំពោះពួកកុំម្មុយនីស្ត, ណាស៊ីស និងសម្ព័ន្ធមិត្តរបស់ពួកគេបានឈ្នះឆ្នោតដោយសំលេងភាគច្រើនតិចតួច។ ហ៊ីត្លែរបានប្រើអំណាចថ្មីរបស់គាត់ដើម្បីបង្វែរប្រទេសអាល្លឺម៉ង់ទៅជារដ្ឋផ្តាច់ការ។ លោកបានហាមប្រាមគណបក្សនយោបាយផ្សេងទៀតទាំងអស់ ហើយបានចាប់ខ្លួនក្រុមអ្នកប្រឆាំង។ ទន្ទឹមនឹងនេះ កងវរសេនាតូចឯកសណ្ឋានពណ៌ខ្មៅ ហៅថាអេសអេស (ក្រុមការពារ) ត្រូវបានបង្កើតឡើង។ ពួកគេស្មោះត្រង់ចំពោះតែហ៊ីត្លែរ។ នៅឆ្នាំ 1934 ពួកអេសអេសបានចាប់ខ្លួន និងសម្លាប់សត្រូវរបស់ហ៊ីត្លែររាប់រយនាក់។ សកម្មភាពដ៏ឃោរឃៅនេះ និងអំពើភេរវកម្មដែលបានអនុវត្តដោយហ្គេស្តាប៉ូ ដែលជាប៉ូលីសសម្ងាត់របស់ណាស៊ី បានធ្វើឱ្យជនជាតិអាល្លឺម៉ង់ភាគច្រើនមានការភ្ញាក់ផ្អើល និងស្តាប់បង្គាប់ពួកណាស៊ីទាំងស្រុង។ យ៉ាងឆាប់រហ័ស ពួកណាស៊ីបានគ្រប់គ្រងលើសេដ្ឋកិច្ច។ ច្បាប់ថ្មីបានហាមប្រាមកូដកម្ម, រំលាយសហជីពឯករាជ្យ, និងផ្តល់សិទ្ធិអំណាចដល់រដ្ឋាភិបាលលើអាជីវកម្ម និងការងារ។ ហ៊ីត្លែរបានដាក់ជនជាតិអាល្លឺម៉ង់រាប់លាននាក់ឱ្យធ្វើការ។ ពួកគេបានសាងសង់រោងចក្រ,សាងសង់ផ្លូវហាយវេ, ផលិតអាវុធ, និងបម្រើក្នុងជួរកងទ័ព។ ជាលទ្ធផល ចំនួនអ្នកអត់ការងារធ្វើបានធ្លាក់ចុះពីប្រហែល 6 លាននាក់មក 1.5 លាននាក់ក្នុងឆ្នាំ 1936 ។

ហ៊ីត្លែរ ធ្វើសង្គ្រាមលើជនជាតិយូដា៖ ការស្អប់ជនជាតិយូដា ឬប្រឆាំងនឹងពួកយូដា គឺជាផ្នែកសំខាន់នៃមនោគមវិជ្ជារបស់ណាស៊ី។ ទោះបីជាជនជាតិជ្វីបមានតិចជាង 1 ភាគរយនៃចំនួនប្រជាជនសរុបនៅក្នុងប្រទេសអាឡឺម៉ង់ក៏ដោយ ក៏ពួកណាស៊ីបានប្រើពួកគេធ្វើជាអ្នកទទួលរងកំហុសសម្រាប់បញ្ហាទាំងឡាយរបស់ប្រទេសអាល្លឺម៉ង់ចាប់តាំងពីសង្គ្រាមមក។ ការធ្វើបែបនេះបានបណ្តាលឱ្យមានរលកនៃការប្រឆាំងពួកយូដានៅទូទាំងប្រទេសអាល្លឺម៉ង់។ ចាប់ផ្តើមនៅឆ្នាំ 1933 ពួកណាស៊ីបានអនុម័តច្បាប់ដែលដកហូតសិទ្ធិភាគច្រើនរបស់ជនជាតិយូដា។ អំពើហិង្សាលើជនជាតិយូដាបានកើនឡើង។ នៅយប់ថ្ងៃទី 9 ខែវិច្ឆិកា ឆ្នាំ 1938 ក្រុមណាស៊ីបានវាយប្រហារជនជាតិយូដានៅតាមផ្ទះ និងតាមដងផ្លូវ ហើយបានបំផ្លាញអគាររាប់ពាន់ដែលគ្រប់គ្រងដោយពួកជនជាតិយូដា។ ការផ្ទុះឡើងនេះត្រូវបានគេហៅថា រាត្រីនៃកញ្ចក់បែក ជាសញ្ញានៃការចាប់ផ្តើមដ៏ពិតប្រាកដនៃដំណើរការលុបបំបាត់ជនជាតិយូដាចេញពីអាល្លឺម៉ង់។ អ្នកនឹងស្វែងយល់បន្ថែមអំពីរឿងនេះនៅក្នុងជំពូកទី 32។

## 4. ប្រទេសផ្សេងៗទៀតធ្លាក់ទៅក្នុងរបបផ្តាច់ការ

ខណៈពេលដែលពួកហ្វាស៊ីសបានឡើងកាន់អំណាចនៅក្នុងប្រទេសអ៊ីតាលី និងអាល្លឺម៉ង់ ប្រទេសជាតិដែលបានបង្កើតឡើងនៅអឺរ៉ុបខាងកើតបន្ទាប់ពីសង្គ្រាមលោកលើកទី 1 ក៏កំពុងតែធ្លាក់ក្រោមការគ្រប់គ្រងរបស់មេដឹកនាំផ្តាច់ការផងដែរ។ នៅប្រទេសហុងគ្រី នៅក្នុងឆ្នាំ 1919 បន្ទាប់ពីរបបកុំម្មុយនីស្តគ្រប់គ្រងអំណាចបានមួយរយៈពេលខ្លី កងកម្លាំងយោធា និងម្ចាស់ដីដែលមានទ្រព្យសម្បត្តិបានចូលរួមដើម្បីធ្វើឱ្យឧត្តមនាវីឯកមីកឡូស ហូស៊ីក្លាយជាមេដឹកនាំផ្តាច់ការដំបូងនៅអឺរ៉ុបក្រោយសង្គ្រាម។ នៅប្រទេសប៉ូឡូញឧត្តមសេនីយ៍ ចូហ្សេហ្វ ពីលស៊ូដស្គីបានដណ្តើមអំណាចនៅឆ្នាំ 1926 ។ នៅយូហ្គោស្លាវី, អាល់បានី, ប៊ុលហ្គារី, និងរូម៉ានី ព្រះមហាក្សត្របានងាកទៅរកការគ្រប់គ្រងបែបបុរសខ្លាំង។ ពួកគេបានព្យួររដ្ឋធម្មនុញ្ញ និងបំបិទមាត់សត្រូវ។ នៅឆ្នាំ 1935 ប្រទេសដែលស្ថិតនៅអឺរ៉ុបខាងកើតដែលបន្តប្រកាន់លទ្ធិប្រជាធិបតេយ្យតែមួយគត់គឺប្រទេសឆេកូស្លូវ៉ាគី។ មានតែប្រទេសនៅអឺរ៉ុបដែលមានទំនៀមទម្លាប់ប្រជាធិបតេយ្យខ្លាំង ដូចជាប្រទេសអង់គ្លេស, បារាំង, និងប្រទេសស្កែនឌីណាវ ប៉ុណ្ណោះដែលលទ្ធិប្រជាធិបតេយ្យនៅបន្តរស់រានមានជីវិត។ ដោយមិនមានបទពិសោធន៍លទ្ធិប្រជាធិបតេយ្យ និងបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរ ជនជាតិអឺរ៉ុបជាច្រើនបានមើលឃើញថា របបផ្តាច់ការជាមធ្យោបាយតែមួយគត់ក្នុងការទប់ស្កាត់

អស្ថិរភាព។ នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1930 ប្រទេសដែលមានឥទ្ធិពលនៅពិភពលោកត្រូវបានបំបែកជាជុំរុំប្រឆាំងគ្នាចំនួន 2 គឺ ប្រជាធិបតេយ្យ និងផ្ដាច់ការ។ ហើយដើម្បីទទួលបានការបញ្ចប់បញ្ហានេះ របបផ្ដាច់ការហ្វាស៊ីសបានបង្ហាញឆន្ទៈនៅក្នុងការប្រើប្រាស់ការឈ្លានពានយោធា។ ទោះបីជារបបផ្ដាច់ការទាំងអស់នេះបានរឹតបន្តឹងសិទ្ធិស៊ីវិលក៏ដោយ ក៏គ្មាននរណាម្នាក់អះអាងថាការគ្រប់គ្រងរបស់ពួកកុំម្មុយនីស្តរុស្ស៊ី ឬពួកណាស៊ីមានភាពឃោរឃៅឡើយ។

# មេរៀនទី 4៖ ក្រុមអ្នកឈ្លានពានធ្វើការឈ្លានពានលើប្រទេសជាតិនានា

## 1. ជប៉ុនសម្លឹងទៅរកការបង្កើតចក្រភពមួយ

នៅអំឡុងទសវត្សរ៍ឆ្នាំ 1920 លទ្ធិប្រជាធិបតេយ្យនៅក្នុងរដ្ឋាភិបាលជប៉ុនកាន់តែមានលក្ខណៈល្អប្រសើរ។ នៅឆ្នាំ 1922 ប្រទេសជប៉ុនបានចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិមួយដែលយល់ព្រមគោរពព្រំដែនរបស់ប្រទេសចិន។ នៅឆ្នាំ 1928 ពួកគេបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ឈប់សង្គ្រាម កតិកាសញ្ញាកេលឡុក-ប្រាយអេដ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធសភារបស់ជប៉ុននៅមានចំណុចខ្សោយមួយចំនួន។ រដ្ឋធម្មនុញ្ញរបស់ពួកគេបានកំណត់យ៉ាងតឹងរឹងលើអំណាចរបស់នាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី។ អ្វីដែលសំខាន់បំផុត មេដឹកនាំស៊ីវិលមានអំណាចគ្រប់គ្រងតិចតួចលើកងកម្លាំងប្រដាប់អាវុធ។ មេដឹកនាំយោធារាយការណ៍តែចំពោះព្រះចៅអធិរាជតែប៉ុណ្ណោះ។

ពួកយោធាកាន់កាប់ជប៉ុន៖ ដរាបណាជប៉ុននៅតែរីកចម្រើន រដ្ឋាភិបាលស៊ីវិលនៅតែរក្សាអំណាច។ ប៉ុន្តែនៅពេលដែលមហាវិបត្តិសេដ្ឋកិច្ចបានផ្ទុះឡើងនៅឆ្នាំ 1929 ជនជាតិជប៉ុនជាច្រើនបានស្តីបន្ទោសដល់រដ្ឋាភិបាល។ មេដឹកនាំយោធាទទួលបានការគាំទ្រ ហើយមិនយូរប៉ុន្មានបានឈ្នះការគ្រប់គ្រងប្រទេស។ មិនដូចពួកហ្វាស៊ីសនៅអឺរ៉ុបទេ ពួកយោធានិយមមិនបានព្យាយាមបង្កើតប្រព័ន្ធរដ្ឋាភិបាលថ្មីទេ។ ពួកគេចង់ស្តារការគ្រប់គ្រងបែបប្រពៃណីរបស់រដ្ឋាភិបាលសម្រាប់ពួកយោធា។ ជំនួសឱ្យមេដឹកនាំដែលមានអំណាចខ្លាំងដូចជាមូស្សូលីនី ឬហ៊ីត្លែរ ពួកសកម្មប្រយុទ្ធបានលើកអធិរាជធ្វើជានិមិត្តរូបនៃអំណាចរបស់រដ្ឋ។ ការរក្សាអធិរាជហ៊ីរ៉ូហ៊ីតូជាប្រមុខរដ្ឋបានទទួលការគាំទ្រយ៉ាងខ្លាំងពីពួកមេដឹកនាំកងទ័ព អ្នកដែលបានគ្រប់គ្រងប្រទេសជប៉ុនក្នុងនាមទ្រង់។ ក៏ដូចជាហ៊ីត្លែរ និងមូស្សូលីនី ពួកយោធានិយមរបស់ជប៉ុន គឺជាអ្នកជាតិនិយមជ្រុល។ ពួកគេចង់ដោះស្រាយបញ្ហាសេដ្ឋកិច្ចរបស់ប្រទេសតាមរយៈការពង្រីកអំណាចលើបរទេស។ ពួកគេបានរៀបចំផែនការក្នុងការបង្កើតចក្រភពប៉ាស៊ីហ្វិកមួយដែលរួមបញ្ចូលក្នុងការដណ្តើមកាន់កាប់ប្រទេសចិនផងដែរ។ ចក្រភពនឹងផ្តល់ឱ្យប្រទេសជប៉ុននូវវត្ថុធាតុដើម និងទីផ្សារសម្រាប់ទំនិញរបស់ខ្លួន។ វាក៏នឹងផ្តល់ឱ្យប្រទេសជប៉ុននូវដែមដីមួយសម្រាប់បង្កើនចំនួនប្រជាជនរបស់ខ្លួន។

ជប៉ុនឈ្លានពានតំបន់ម៉ាន់ជូរី៖ អាជីវករជប៉ុនបានវិនិយោគយ៉ាងច្រើននៅក្នុងតំបន់ម៉ាន់ជូរីដែលស្ថិតនៅចិនភាគឦសាន។ វាជាតំបន់ដែលសម្បូរទៅដោយរ៉ែដែក និងធ្យូងថ្ម។ នៅឆ្នាំ 1931 កងទ័ពជប៉ុនបានដណ្តើមកាន់កាប់ទីក្រុងម៉ាន់ជូរី ទោះបីជាមានការជំទាស់ពីសភាជប៉ុនក៏ដោយ។ បន្ទាប់មក កងទ័ពបានបង្កើតរដ្ឋាភិបាលអាយ៉ងមួយនៅទីនោះ។ វិស្វករ និងអ្នកបច្ចេកទេសជប៉ុន បានចាប់ផ្តើមចូលមកកាន់តំបន់នោះក្នុងចំនួនដ៏ច្រើនដើម្បីសាងសង់អណ្តូងរ៉ែ និងរោងចក្រ។ ការវាយប្រហាររបស់ជប៉ុនលើតំបន់ម៉ាន់ជូរី គឺជាការប្រជែងដោយផ្ទាល់ជាលើកដំបូងចំពោះអង្គការសម្ព័ន្ធប្រជាជាតិ។ នៅដើមទសវត្សរ៍ឆ្នាំ 1930 សមាជិករបស់សម្ព័ន្ធប្រជាជាតិបានរួមបញ្ចូលប្រទេសដែលប្រកាន់លទ្ធិប្រជាធិបតេយ្យសំខាន់ៗទាំងអស់ លើកលែងតែសហរដ្ឋអាមេរិក។ សម្ព័ន្ធប្រជាជាតិក៏បានរួមបញ្ចូលប្រទេសទាំង 3 ដែលបានគំរាមកំហែងយ៉ាងខ្លាំងចំពោះសន្តិភាពពិភពលោកផងដែរ ដែលក្នុងនោះរួមមានប្រទេសអាល្លឺម៉ង់, ជប៉ុន, និងអ៊ីតាលី។ នៅពេលដែលជប៉ុនដណ្តើមកាន់កាប់តំបន់ម៉ាន់ជូរី សមាជិក

សម្ព័ន្ធប្រជាជាតិជាច្រើនបានធ្វើការតវ៉ាយ៉ាងខ្លាំងក្លា។ ប្រទេសជប៉ុនមិនបានអើពើទៅនឹងការតវ៉ានេះឡើយ ហើយបានដកខ្លួនចេញពីសម្ព័ន្ធប្រជាជាតិនៅឆ្នាំ 1933 ។

ជប៉ុនចូលឈ្លានពានប្រទេសចិន៖ 4 ឆ្នាំក្រោយមក ឧប្បត្តិហេតុតាមព្រំដែនមួយបានជះឥទ្ធិពលដល់សង្គ្រាមពេញលេញមួយរវាងជប៉ុន និងចិន។ កងកម្លាំងជប៉ុនបានវាយលុកចូលទៅកាន់ប្រទេសចិនភាគខាងជើង។ ទោះបីជាមានចំនួនទាហាន 1 លាននាក់ក៏ដោយ ក៏កងទ័ពរបស់ចិនដែលដឹកនាំដោយចាងកាយចៀក មិនអាចទប់ទល់ជាមួយកងទ័ពជប៉ុនដែលបំពាក់អាវុធ និងហ្វឹកហាត់បានល្អជាងពួកគេឡើយ។ ទីក្រុងប៉េកាំង និងទីក្រុងភាគខាងជើងផ្សេងទៀត ក្នុងនោះរួមមានទាំងរដ្ឋធានីណានជីងផង បានធ្លាក់ក្រោមការគ្រប់គ្រងរបស់ជប៉ុននៅឆ្នាំ 1937។ កងទ័ពជប៉ុនបានសម្លាប់ទាហាន និងជនស៊ីវិលដែលពួកចាប់ខ្លួននៅណានជីងអស់រាប់ម៉ឺននាក់។ ចាងកាយចៀកបានដកថយទៅភាគខាងលិច និងបានបង្កើតរដ្ឋធានីថ្មីមួយនៅឆុងឈី។ ទន្ទឹមនឹងនេះ ពួកទ័ពព្រៃចិនដែលដឹកនាំដោយមេដឹកនាំកុម្មុយនិស្តចិន ម៉ៅសេទុង បានបន្តប្រយុទ្ធជាមួយពួកជប៉ុននៅក្នុងតំបន់ដែលពួកគេបានដណ្តើម។

## 2. ក្រុមអ្នកឈ្លានពានអឺរ៉ុបកំពុងធ្វើដំណើរ

ភាពបរាជ័យរបស់សម្ព័ន្ធប្រជាជាតិនៅក្នុងការបញ្ឈប់ពួកជប៉ុន បានលើកទឹកចិត្តដល់ពួកហ្វាស៊ីសនៅអឺរ៉ុបឱ្យរៀបចំផែនការឈ្លានពានរបស់ពួកគេ។ មេដឹកនាំអ៊ីតាលីលោកមូស្សូលីនីសុបិនចង់កសាងដែនដីអាណានិគមនៅទ្វីបអាហ្វ្រិកដូចប្រទេសអង់គ្លេស និងបារាំងដែរ។

មូស្សូលីនីបានវាយប្រហារលើអេត្យូពី៖ អេត្យូពី គឺជាប្រទេសឯករាជ្យមួយនៅទ្វីបអាហ្វ្រិក។ ជនជាតិអេត្យូពីបានទប់ទល់ដោយជោគជ័យទៅនឹងការប៉ុនប៉ងដណ្តើមកាន់កាប់របស់អ៊ីតាលីនៅអំឡុងទសវត្សរ៍ឆ្នាំ 1890 ។ ដើម្បីសងសឹកចំពោះការបរាជ័យនោះ មូស៊ីលីនីបានបញ្ជាឱ្យមានការលុកលុយក្នុងទ្រង់ទ្រាយធំមួយលើប្រទេសអេត្យូពីនៅក្នុងខែតុលា ឆ្នាំ 1935 ។ លំពែង និងដាវរបស់ជនជាតិអេត្យូពីមិនអាចប្រៀបផ្ទឹមជាមួយយន្តហោះ, រថក្រោះ, កាំភ្លើង, និងឧស្ម័នពុលរបស់អ៊ីតាលីបានឡើយ។ អធិរាជអេត្យូពីព្រះអង្គម្ចាស់ ហៃ សេឡាស៊ីបានអំពាវនាវជាបន្ទាន់ទៅកាន់សម្ព័ន្ធប្រជាជាតិសម្រាប់ជំនួយ។ ទោះបីជាសម្ព័ន្ធប្រជាជាតិបានថ្កោលទោសចំពោះការវាយប្រហារនេះក៏ដោយ ក៏សមាជិករបស់ខ្លួនមិនបានធ្វើអ្វីទាំងអស់។ ចក្រភពអង់គ្លេសបានបន្តអនុញ្ញាតឱ្យកងទ័ព និងការផ្គត់ផ្គង់នានារបស់អ៊ីតាលីឆ្លងកាត់ព្រែកជីកស៊ុយអេដែលគ្រប់គ្រងដោយពួកគេ ធ្វើដំណើរទៅកាន់ប្រទេសអេត្យូពី។ តាមរយៈការប្រគល់ទៅឱ្យមូស្សូលីនីនូវនៅទ្វីបអាហ្វ្រិក អង់គ្លេស និងបារាំងសង្ឃឹមថានឹងរក្សាសន្តិភាពនៅអឺរ៉ុប។

ហ៊ីត្លែរបដិសេធសន្ធិសញ្ញាទីក្រុងវែរសៃ៖ ហ៊ីត្លែរបានសន្យាជាយូរមកហើយថានឹងលុបចោលសន្ធិសញ្ញាទីក្រុងវែរសៃ។ ក្នុងចំណោមបទប្បញ្ញត្តិរបស់ខ្លួន សន្ធិសញ្ញាបានកំណត់ទំហំនៃកងទ័ពរបស់ប្រទេសអាល្លឺម៉ង់។ នៅខែមីនា ឆ្នាំ 1935 ហ៊្វូអឺបានប្រកាសថាអាល្លឺម៉ង់នឹងមិនគោរពតាមការរឹតបន្តឹងទាំងនេះទៀតទេ។ សម្ព័ន្ធប្រជាជាតិបានត្រឹមតែប្រកាសថ្កោលទោសតែប៉ុណ្ណោះ។ ការបរាជ័យរបស់សម្ព័ន្ធក្នុងការបញ្ឈប់អាឡឺម៉ង់ពីការរៀបចំកងទ័ពឡើងវិញ បានជម្រុញឱ្យហ៊ីត្លែរអនុវត្តសកម្មភាពដែលមានហានិភ័យកាន់តែខ្លាំង។ សន្ធិសញ្ញាបានហាមប្រាមទាហានអាល្លឺម៉ង់មិនឱ្យចូលទៅក្នុងតំបន់ដែលមានចម្ងាយ 30 ម៉ាយនៅតំបន់សងខាងនៃទន្លេរីន។ តំបន់នេះត្រូវបានគេស្គាល់ថា

រីនលែនដែលបានបង្កើតជាតំបន់ទ្រនាប់រវាងអាល្លឺម៉ង់ និងបារាំង។ វាក៏ជាតំបន់ឧស្សាហកម្មដ៏សំខាន់មួយផងដែរ។ នៅថ្ងៃទី 7 ខែមីនាឆ្នាំ 1936 កងទ័ពអាឡឺម៉ង់បានចល័តទៅកាន់តំបន់រីនលែន។ ដោយស្រឡាំងកាំង បារាំងមិនបានប្រថុយប្រថានក្នុងការធ្វើសង្គ្រាមឡើយ។ ដើម្បីរក្សាសន្តិភាព អង់គ្លេសបានជំរុញឱ្យមានការបន្ធូរបន្ថយតាមរយៈការអនុញ្ញាតឱ្យអ្នកឈ្លានពានអាចចូលទៅកាន់តំបន់នេះបាន។ ក្រោយមក ហ៊ីត្លែរបានទទួលស្គាល់ថាគាត់នឹងធ្វើការឆ្លើយតបប្រសិនបើបារាំង និងអង់គ្លេសបានជំទាស់នឹងគាត់។ ការកាន់កាប់របស់អាល្លឺម៉ង់ឡើងវិញនៃតំបន់រីនលែនបានបង្ហាញពីរបត់មួយនៅក្នុងដំណើរឆ្ពោះទៅរកសង្គ្រាម។ ទី 1 វាបានពង្រឹងអំណាច និងកិត្យានុភាពរបស់ហ៊ីត្លែរនៅក្នុងប្រទេសអាល្លឺម៉ង់។ ទី 2 តុល្យភាពនៃអំណាចបាននាំមកនូវការផ្លាស់ប្តូរបំណងរបស់ពួកអាល្លឺម៉ង់។ ឥឡូវនេះបារាំង និងបែលហ្សិកបានប្រឈមទៅនឹងការវាយប្រហារពីសំណាក់ទាហានរបស់អាល្លឺម៉ង់។ ទីបំផុត ដោយសារការឆ្លើយតបដ៏ទន់ខ្សោយរបស់បារាំង និងអង់គ្លេសបានលើកទឹកចិត្តហ៊ីត្លែរឱ្យពន្លឿនការពង្រីកឥទ្ធិពលរបស់លោក។ ដោយសារភាពរឹងមាំរបស់ហ៊ីត្លែរបានជម្រុញមូស្សូលីនីថា លោកគួរតែស្វែងរកសម្ព័ន្ធភាពជាមួយអាល្លឺម៉ង់។ នៅខែតុលា ឆ្នាំ 1936 មេដឹកនាំផ្តាច់ការទាំង 2 បានឈានដល់កិច្ចព្រមព្រៀងមួយដែលត្រូវបានគេស្គាល់ថា អេស៊ីសរ៉ូម-ប៊ែរឡាំង។ មួយខែក្រោយមក អាឡឺម៉ង់ក៏បានចុះកិច្ចព្រមព្រៀងមួយជាមួយប្រទេសជប៉ុន។ អាល្លឺម៉ង់, អ៊ីតាលី, និងជប៉ុន ត្រូវបានគេហៅថាជាមហាអំណាចអេស៊ីស។

សង្គ្រាមស៊ីវិលផ្ទុះឡើងនៅអេស្ប៉ាញ៖ ហ៊ីត្លែរ និងមូស្សូលីនី ជាថ្មីម្តងទៀតបានសាកល្បងនូវឆន្ទៈលទ្ធិប្រជាធិបតេយ្យនៅទ្វីបអឺរ៉ុប នៅក្នុងសង្គ្រាមស៊ីវិលអេស្ប៉ាញ។ អេស្ប៉ាញធ្លាប់ប្រកាន់របបរាជាធិបតេយ្យរហូតដល់ឆ្នាំ 1931 នៅពេលដែលសាធារណរដ្ឋមួយត្រូវបានប្រកាសឡើង។ រដ្ឋាភិបាលដែលគ្រប់គ្រងដោយពួកសេរីនិយម និងសង្គមនិយម បានកាន់តំណែងចំពេលមានវិបត្តិជាច្រើន។ នៅខែកក្កដា ឆ្នាំ 1936 មេដឹកនាំកងទ័ពនានាដែលគាំទ្ររដ្ឋាភិបាលបែបហ្វាស៊ីសបានចូលរួមជាមួយឧត្តមសេនីយ៍ហ្វ្រង់ស៊ីស្កូ ហ្វ្រង់កូក្នុងការបះបោរ។ ដូច្នេះហើយវាបានបង្កឱ្យមានសង្គ្រាមស៊ីវិលដែលអូសបន្លាយអស់រយៈពេលបីឆ្នាំនៅក្នុងប្រទេសអេស្ប៉ាញ។ ហ៊ីត្លែរ និងមូសូលីនីបានបញ្ជូនកងទ័ព, រថក្រោះ, និងយន្តហោះ ដើម្បីជួយដល់កងកម្លាំងរបស់ហ្វ្រង់កូ ដែលត្រូវបានគេហៅថា ពួកជាតិនិយម។ កងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋ ក្នុងនាមជាអ្នកគាំទ្ររដ្ឋាភិបាលជាប់ឆ្នោតរបស់អេស្ប៉ាញបានទទួលជំនួយតិចតួចប៉ុណ្ណោះពីបរទេស។ ពួកប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យលោកខាងលិចនៅរក្សាភាពអព្យាក្រឹតរបស់ពួកគេ។ មានតែសហភាពសូវៀតតែមួយប៉ុណ្ណោះដែលបានបញ្ជូនសម្ភារៈ និងទីប្រឹក្សាទៅកាន់ប្រទេសអេស្ប៉ាញ។ កងពលតូចអន្តរជាតិមួយក្រុមដែលជាទាហានស្ម័គ្រចិត្តបានប្រយុទ្ធនៅខាងសាធារណរដ្ឋ។ នៅដើមឆ្នាំ 1939 ការតស៊ូរបស់សាធារណរដ្ឋបានដួលរលំ។ ហ្វ្រង់កូបានក្លាយជាមេដឹកនាំផ្តាច់ការហ្វាស៊ីសនៅក្នុងប្រទេសអេស្ប៉ាញ។

### 3. ប្រទេសប្រជាធិបតេយ្យព្យាយាមរក្សាសន្តិភាព

ជាជាងប្រកាន់ជំហរប្រឆាំងនឹងការឈ្លានពានរបស់ពួកហ្វាស៊ីសក្នុងទសវត្សឆ្នាំ 1930 ចក្រភពអង់គ្លេស និងបារាំងបានធ្វើសម្បទានម្តងហើយម្តងទៀតដោយសង្ឃឹមថានឹងរក្សាសន្តិភាព។ ប្រទេសទាំង 2 កំពុងដោះស្រាយ

បញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរដែលបណ្ដាលមកពីមហាវិបត្តិសេដ្ឋកិច្ច។ លើសពីនេះទៀត ភាពភ័យរន្ធត់នៃសង្គ្រាមលោកលើកទី 1 បានជម្រុញឱ្យមានបំណងប្រាថ្នាដ៏ខ្លាំងក្លាមួយដើម្បីចៀសវាងសង្គ្រាម។

សហរដ្ឋអាមេរិកអនុវត្តតាមគោលការណ៍ឯកោមួយ៖ ជនជាតិអាមេរិកជាច្រើនបានគាំទ្រគោលនយោបាយឯកោនិយម ដោយពួកគេជឿថាទំនាក់ទំនងនយោបាយជាមួយប្រទេសផ្សេងៗទៀតគួរតែត្រូវបានជៀសវាង។ ពួកឯកោនិយមបានអះអាងថា ការចូលទៅក្នុងសង្គ្រាមលោកលើកទី 1 គឺជាកំហុសដ៏ធំធេងមួយ។ ចាប់ផ្ដើមនៅឆ្នាំ 1935 សភាបានអនុម័តច្បាប់អព្យាក្រឹតចំនួន 3 ។ ច្បាប់ទាំងនេះបានហាមប្រាមការផ្ដល់ប្រាក់កម្ចី និងការលក់អាវុធឱ្យបណ្ដាលប្រទេសនានាដែលចូលរួមនៅក្នុងការធ្វើសង្គ្រាម។

ការលេចឡើងនៃចក្រភពអាឡឺម៉ង់៖ នៅថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 1937 ហ៊ីត្លែរបានប្រកាសទៅកាន់ទីប្រឹក្សារបស់លោកអំពីផែនការរបស់លោកក្នុងការបញ្ចូលប្រទេសអូទ្រីស, និងឆេកូស្លូវ៉ាគី ចូលទៅក្នុងចក្រភពអាល្លឺម៉ង់។ សន្ធិសញ្ញាទីក្រុងវែរសៃបានហាមឃាត់ការរួបបញ្ចូលគ្នារវាងអូទ្រីស និងអាល្លឺម៉ង់។ ទោះយ៉ាងណាក៏ដោយ ជនជាតិអូទ្រីសជាច្រើនបានគាំទ្រការរួបរួមជាមួយអាល្លឺម៉ង់។ នៅខែមីនា ឆ្នាំ 1938 ហ៊ីត្លែរបានបញ្ជូនកងទ័ពរបស់លោកចូលទៅក្នុងប្រទេសអូទ្រីសហើយបានបញ្ចូលប្រទេសនេះជាឧបសម្ព័ន្ធ។ បារាំង និងអង់គ្លេសមិនអើពើចំពោះការសន្យារបស់ពួកគេក្នុងការការពារឯករាជ្យរបស់អូទ្រីសឡើយ។ បន្ទាប់មក ហ៊ីត្លែរ ងាកទៅរកឆេកូស្លូវ៉ាគី។ មានប្រជាជនដែលនិយាយភាសាអាឡឺម៉ង់ប្រហែល 3 លាននាក់រស់នៅក្នុងតំបន់ព្រំដែនភាគខាងលិចនៃប្រទេសឆេកូស្លូវ៉ាគីហៅថាស៊ូដថេនលែន។ តំបន់ដែលមានកំពែងរឹងមាំនេះបានក្លាយជាតំបន់ការពារដ៏សំខាន់របស់ឆេកប្រឆាំងទៅនឹងការឈ្លានពានរបស់អាល្លឺម៉ង់។ ដែនដីឧបសម្ព័ន្ធអូទ្រីស បានជម្រុញឱ្យមានគំនិតគាំទ្រណាស៊ីក្នុងចំណោមជនជាតិអាល្លឺម៉ង់នៅស៊ូដថេនលែន។ នៅខែកញ្ញា ឆ្នាំ 1938 ហ៊ីត្លែរបានទាមទារឱ្យប្រទេសឆេកូស្លូវ៉ាគីប្រគល់តំបន់ស៊ូថេនលែនឱ្យអាល្លឺម៉ង់។ ប្រទេសឆេកូស្លូវ៉ាគីបានបដិសេធ ហើយបានស្នើសុំជំនួយពីបារាំង។

អង់គ្លេស និងបារាំងជាថ្មីម្ដងទៀតជ្រើសរើសការរក្សាភាពស្ងប់ស្ងាត់៖ ប្រទេសបារាំង និងអង់គ្លេសបានត្រៀមខ្លួនសម្រាប់ធ្វើសង្គ្រាម នៅពេលលោកមូស្សូលីនីស្នើឲ្យមានកិច្ចប្រជុំរវាងអាល្លឺម៉ង់, បារាំង, អង់គ្លេស, និងអ៊ីតាលីក្នុងទីក្រុងមូនិចប្រទេសអាល្លឺម៉ង់។ សន្និសីទទីក្រុងមូនិចត្រូវបានធ្វើឡើងនៅថ្ងៃទី 29 ខែកញ្ញា ឆ្នាំ 1938។ ពួកឆេកមិនត្រូវបានគេអញ្ជើញឱ្យចូលរួមឡើយ។ នាយករដ្ឋមន្ត្រីអង់គ្លេសលោកនេវីល ចាំប័រឡេន ជឿជាក់ថា លោកអាចរក្សាសន្តិភាពបានតាមរយៈការអនុវត្តតាមការទាមទាររបស់ហ៊ីត្លែរ។ អង់គ្លេស និងបារាំងបានព្រមព្រៀងគ្នាថា ហ៊ីត្លែរអាចដណ្ដើមកាន់កាប់ទឹកដីស៊ូដថេនលែនបាន។ ជាថ្នូរ ហ៊ីត្លែរបានសន្យាការគោរពចំពោះព្រំដែនថ្មីរបស់ឆេកូស្លូវ៉ាគី។ នៅពេល ចាំប័រឡេនត្រឡប់មកទីក្រុងឡុងដ៏វិញ លោកបានប្រាប់ហ្វូងមហាជនដែលកំពុងអបអរសាទរលោកថា "ខ្ញុំជឿថាវាជាសន្តិភាពសម្រាប់ពួកយើង" ។ លោកវីនស្តុន ឆឺឈីល ដែលពេលនោះជាសមាជិកសភាអង់គ្លេស បានប្រឆាំងសេចក្ដីសម្រេចនេះយ៉ាងខ្លាំងក្លា។ គាត់បានប្រឆាំងនឹងគោលនយោបាយបន្ធូរបន្ថយ ហើយបានព្រមានអំពីផលវិបាករបស់វា។ 5 ខែជាងបន្ទាប់ពីកិច្ចប្រជុំនៅទីក្រុងមូនិច ហ៊ីត្លែរបានយកឈ្លានពានដណ្ដើមយកប្រទេសឆេកូស្លូវ៉ាគី។ មិនយូរប៉ុន្មាន មូស្សូលីនីបានដណ្ដើមកាន់កាប់ប្រទេសអាល់បានី។ បន្ទាប់មក ហ៊ីត្លែរបានទាមទារឱ្យ

ប្រទេសប៉ូឡូញប្រគល់កំពង់ផែដានហ្សីងត្រឡប់ទៅឱ្យអាល្លឺម៉ង់វិញ។ ប្រទេសប៉ូឡូញបានបដិសេធ ហើយងាកទៅរកអង់គ្លេស និងបារាំងដើម្បីសុំជំនួយ។ ប៉ុន្តែភាពស្ងប់ស្ងៀមបានធ្វើឱ្យហ៊ីត្លែរជឿថាប្រទេសទាំង 2 នឹងមិនហ៊ានប្រថុយក្នុងការធ្វើសង្គ្រាមឡើយ។

ណាស៊ី និងសូវៀតចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនឈ្លានពាន៖ ចក្រភពអង់គ្លេស និងបារាំងបានស្នើសុំឱ្យសហភាពសូវៀតចូលរួមជាមួយពួកគេក្នុងការបញ្ឈប់ការឈ្លានពានរបស់ហ៊ីត្លែរ។ នៅពេលដែលស្តាលីនកំពុងពិភាក្សាជាមួយអង់គ្លេស និងបារាំង លោកក៏កំពុងចរចាជាមួយហ៊ីត្លែរផងដែរ។ មេដឹកនាំផ្តាច់ការទាំង 2 បានឈានដល់កិច្ចព្រមព្រៀងមួយ។ ដោយធ្លាប់ជាសត្រូវដ៏ជូរចត់ ហ្វាស៊ីសអាល្លឺម៉ង់ និងកុំម្មុយនីស្តរុស្ស៊ីឥឡូវនេះបានសន្យាជាសាធារណៈថានឹងមិនវាយប្រហារគ្នាទៅវិញទៅមកឡើយ។ នៅថ្ងៃទី 23 ខែសីហា ឆ្នាំ 1939 មេដឹកនាំរបស់ប្រទេសទាំង 2 បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនឈ្លានពានមួយ។ នៅពេលដែល មហាអំណាចអេស៊ីសបានផ្លាស់ប្តូរដោយគ្មានការត្រួតពិនិត្យ នៅចុងបញ្ចប់នៃទសវត្សរ៍នេះសង្គ្រាមបានលេចឡើងដោយជៀសមិនរួច។

# ជំពូក 31៖ សង្គ្រាមលោកលើកទី 2 1939-1945

## មេរៀនទី 1៖ ហ៊ីត្លែបញ្ឆេះសង្គ្រាម

### 1. អាឡឺម៉ង់បញ្ឆេះសង្គ្រាមថ្មីមួយនៅអឺរ៉ុប

នៅត្រង់ចំណុចនេះ ដូចដែលអ្នកបានដឹងនៅក្នុងជំពូក 30 មេដឹកនាំផ្តាច់ការរបស់សូវៀត ចូសេផ ស្តាលីន បានចុះហត្ថលេខាលើកតិការសញ្ញាមិនឈ្លានពានគ្នាទៅវិញទៅមករយៈពេល 10 ឆ្នាំជាមួយហ៊ីត្លែរ។ បន្ទាប់ពីត្រូវបានគេដកចេញពីសន្និសីទទីក្រុងមូនិច ស្តាលីនមិនមានចំណង់នៅក្នុងការចូលរួមជាមួយលោកខាងលិចឡើយ។ ក៏ដូចគ្នាដែរ ហ៊ីត្លែរបានសន្យានៅក្នុងការមិនឈ្លានពានទឹកដី។ នៅក្នុងតកិការសញ្ញាសម្ងាត់មួយ អាឡឺម៉ង់ និងសហភាពសូវៀត បានយល់ព្រមនៅក្នុងការបែងចែកប្រទេសប៉ូឡូញជាពីរចំនែកសម្រាប់ពួកគេ។ ពួកគេក៏យល់ព្រមផងដែរថា សហភាពសូវៀតអាចកាន់កាប់ប្រទេសហ្វាំងឡង់ និងប្រទេសនៅតំបន់បាល់ទិច ដែលក្នុងនោះមានប្រទេសលីទុយអានី, ឡាតវីយ៉ា, និងអេស្តូនៀ។

ការវាយប្រហារដូចផ្លេតបន្ទោររបស់អាឡឺម៉ង់៖ បន្ទាប់ពីចុះហត្ថលេខាលើកតិការសញ្ញានេះ ហ៊ីត្លែរបានយ៉ាងឆាប់រហ័សបានដើរទៅមុខមួយជំហានដោយរៀបចំគម្រោងឈ្លានពានប្រទេសប៉ូឡូញ។ ការវាយប្រហារដ៏គួរឱ្យភ្ញាក់ផ្អើលរបស់លោកបានកើតឡើងនៅថ្ងៃទី1 ខែកញ្ញា ឆ្នាំ 1939 ។ រថក្រោះ និងរថយន្តដឹកកងទ័ពអាឡឺម៉ង់បានធ្វើដំណើរឆ្លងចូលព្រំដែនប្រទេសប៉ូឡូញ។ នៅក្នុងពេលជាមួយគ្នានោះ យន្តហោះចម្បាំង និងកាំភ្លើងធំរបស់អាឡឺម៉ង់បានចាប់ផ្តើមវាយប្រហារដ៏ខ្លាំងក្លាលើទីក្រុងវ៉សេររបស់ប៉ូឡូញ។

ប្រទេសបារាំង និងចក្រភពអង់គ្លេសបានប្រកាសសង្គ្រាមជាមួយប្រទេសអាឡឺម៉ង់នៅថ្ងៃទី 2 ខែកញ្ញា។ ប៉ុន្តែ ប្រទេសប៉ូឡូញបានបាត់បង់ទឹកដីមួយភាគធំមុនពេលដែលប្រទេសបារាំង និងចក្រភពអង់គ្លេសធ្វើការឆ្លើយតបយោធាចំពោះការវាយប្រហាររបស់អាឡឺម៉ង់។ បន្ទាប់ពីទទួលបានជ័យជំនះ ហ៊ីត្លែរបានភ្ជាប់ទឹកដីប៉ូឡូញពាក់កណ្តាលភាពខាងលិចទៅក្នុងដែនដីរបស់ខ្លួន។ តំបន់នេះមានប្រជាជនអាឡឺម៉ង់រស់នៅយ៉ាងច្រើន។

ការឈ្លានពានរបស់អាឡឺម៉ង់លើប្រទេសប៉ូឡូញ គឺជាការសាកល្បងលើដំបូងនៃយុទ្ធសាស្ត្រយោធាថ្មីរបស់អាឡឺម៉ង់ ដែលមានឈ្មោះថាប្លីហ្សរេហ្គ ឬ "សង្គ្រាមផ្លេតបន្ទោរ"។ យុទ្ធសាស្ត្រនេះរួមមាន ការចល័តកងយន្តហោះ និងកងរថក្រោះយ៉ាងឆាប់រហ័សទៅមុខ និងបន្តពីក្រោយដោយកងទ័ពថ្មើរជើង ដោយធ្វើការវាយប្រហារដោយមិនប្រាប់ជាមុន និងយ៉ាងឆាប់រហ័សលើពួកគេ។ នៅក្នុងករណីប្រទេសប៉ូឡូញ យុទ្ធសាស្ត្រនេះទទួលបានជោគជ័យ។

សូវៀតធ្វើចលនា៖ នៅថ្ងៃទី 17 ខែកញ្ញា ស្តាលីនបានបញ្ជូនកងទ័ពសូវៀតទៅដណ្តើមកាន់កាប់ប្រទេសប៉ូឡូញពាក់កណ្តាលភាពខាងកើត។ បន្ទាប់មក ស្តាលីនបានបន្តដណ្តើមកាន់កាប់ប្រទេសភាគខាងជើងប៉ូឡូញ។ ប្រទេសលីទុយអានី, ឡាតវីយ៉ា, និងអេស្តូនីបានចុះចាញ់ដោយមិនចាំបាច់ប្រយុទ្ធ ប៉ុន្តែប្រទេសហ្វាំងឡង់បានតស៊ូប្រយុទ្ធ។ នៅក្នុងខែវិច្ឆិកា ស្តាលីនបានបញ្ជូនកងទ័ពសូវៀតជិត 1 លាននាក់ទៅកាន់ប្រទេសហ្វាំងឡង់។ សូវៀត

រំពឹងថានឹងទទួលបានជ័យជំនះយ៉ាងឆាប់រហ័សមួយ ដូច្នេះពួកគេមិនបានរៀបចំដើម្បីត្រៀមធ្វើសង្គ្រាមរដូវរងារឡើយ។ នេះគឺជាកំហុសដ៏ធំមួយ។

ពួកហ្វាំងឡង់គឺមានចំនួនប្រជាជន និងអាវុធតិចតួច ប៉ុន្តែពួកគេតស៊ូការពារប្រទេសរបស់ពួកគេយ៉ាងខ្លាំងក្លា។ នៅសីតុណ្ហភាពដ៏ត្រជាក់នៅក្នុងរដូវរងារ កងទ័ពជិះស្គីលើទឹកកកយ៉ាងលឿងធ្វើការវាយប្រហារលើទីតាំងរបស់កងទ័ពសូវៀត។ ផ្ទុយទៅវិញ សូវៀតបានធ្វើការតស៊ូប្រឆាំងវិញតាមរយៈការជិករណ្តៅទឹកកក។ សូវៀតរងគ្រោះយ៉ាងខ្លាំងពីការវាយប្រហារនេះ ប៉ុន្តែចុងក្រោយពួកគេនៅតែទទួលជ័យជំនះដោយសារតែចំនួនកងទ័ពរបស់ពួកគេមានច្រើនជាង។ ត្រឹមខែមីនា ឆ្នាំ 1940 ស្តាលីនបានបង្ខំឱ្យហ្វាំងឡង់យល់ព្រមចុះចាញ់។

សង្គ្រាមស្ងាប់ស្ងាត់៖ បន្ទាប់ពីប្រកាសសង្គ្រាមជាមួយអាឡឺម៉ង់ ប្រទេសបារាំង និងចក្រភពអង់គ្លេសបានប្រមូលផ្តុំកងទ័ពរបស់ពួកគេ។ ពួកគេបានបោះមូលដ្ឋានកងទ័ពរបស់ពួកគេនៅតាមបណ្តោយខ្សែត្រៀមស្ថិតនៅម៉ាជីនូត ដែលជាមូលដ្ឋានសឹកមួយនៅតាមបណ្តោយព្រំដែនបារាំងជាមួយអាឡឺម៉ង់។ នៅទីនោះពួកគេបានរងចាំការវាយប្រហាររបស់អាឡឺម៉ង់ ប៉ុន្តែអាឡឺម៉ង់មិនបានធ្វើការវាយប្រហារឡើយ។ ដោយមិនមានការវាយប្រហារ កងទ័ពសម្ព័ន្ធមិត្តដែលរងចាំដោយអន្ទះសារ ដោយចាប់ផ្តើមរំកិលបន្តិចម្តងៗឆ្ពោះទៅរកសត្រូវរបស់ពួកគេនៅភាគខាងកើត។ កងទ័ពអាឡឺម៉ង់ដែលអន្ទះសារដែលនោះ ចាប់ផ្តើមដកថយចេញពីខ្សែត្រៀមរបស់ពួកគេនៅសេចហ្វ្រិដ។ ជាការលេងសើច អាឡឺម៉ង់បានហៅវាថា សីតក្រេច ឬ "សង្គ្រាមអង្គុយ"។ កាសែតមួយចំនួនបានហៅសង្គ្រាមនេះថា "សង្គ្រាមស្ងាប់ស្ងាត់"។

ភ្លាមៗនោះ នៅថ្ងៃទី 9 ខែមេសា ឆ្នាំ 1940 ភាពអត់ធ្មត់ត្រូវបានបញ្ចប់។ ហ៊ីត្លែរបានបើកការវាយប្រហារដ៏ភ្ញាក់ផ្អើលមួយឈ្លានពានប្រទេសដាណឺម៉ាក និងណូវែស។ បន្ទាប់ពីការវាយប្រហាររយៈពេល 4 ម៉ោង ប្រទេសដាណឺម៉ាកបានបរាជ័យ។ 2 ខែក្រោយមក ប្រទេសណូវែសក៏បានចុះចាញ់ផងដែរ។ បន្ទាប់មកអាឡឺម៉ង់បានចាប់ផ្តើមស្ថាបនាមូលដ្ឋានកងទ័ពរបស់ខ្លួននៅតាមបណ្តោយឆ្នេរសមុទ្រណូវែស និងដាណឺម៉ាក ដែលពួកគេអាចបើកការវាយប្រហារលើចក្រភពអង់គ្លេសបាន។

## 2. បារាំងដួលរលំ

នៅក្នុងខែឧសភា ឆ្នាំ 1940 ហ៊ីត្លែរ ចាប់ផ្តើមធ្វើដំណើរបត់បែនដ៏ស្មុកស្មាញមួយកាត់តាមប្រទេសហូឡង់, បែលហ្ស៊ិច, និងលុចហ្សំបួរ។ នេះគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រមួយនៅក្នុងការវាយប្រហារប្រទេសបារាំង។ ដើម្បីធ្វើឱ្យសម្ព័ន្ធមិត្តកាន់តែចាប់អារម្មណ៍ជាមួយនឹងប្រទេសទាំងនោះ ពេលនោះហ៊ីត្លែរបានបញ្ជូនកងរថក្រោះ និងកងទ័ពកាន់តែច្រើនបន្ថែមទៀតទៅពង្រាយនៅតំបន់អាដេននេស។ តំបន់នេះគឺជាតំបន់ដែលសំបូរទៅដោយព្រៃឈើនៅភាគខាងជើងប្រទេសបារាំង, ប្រទេសលុចហ្សំបួរ, និងប្រទេសបែលហ្ស៊ិច។ ដោយធ្វើដំណើរកាត់តាមព្រៃឈើ កងទ័ពអាឡឺម៉ង់បាន "គាបទាំងសងខាង" លើខ្សែត្រៀមម៉ាជីនូត។ នៅទីនោះ ពួកគេចាប់ផ្តើមធ្វើដំណើរចូលមកកាន់ប្រទេសបារាំង និងបានមកដល់ឆ្នេរភាគខាងជើងបារាំងនៅក្នុងរយៈពេល 10 ថ្ងៃ។

ការជួយសង្គ្រោះនៅដុនគឺគ៖ បន្ទាប់ពីធ្វើដំណើរមកដល់ឆ្នេរសមុទ្របារាំង កងទ័ពរបស់អាឡឺម៉ង់បានធ្វើដំណើរត្រឡប់ទៅភាគខាងជើងវិញ និងបានចូលរួមជាមួយកងទ័ពអាឡឺម៉ង់នៅបែលហ្សិច។ ត្រឹមចុងខែឧសភា ឆ្នាំ 1940 អាឡឺម៉ង់បានឡោមព័ទ្ធកងទ័ពសម្ព័ន្ធមិត្តនៅជុំវិញទីក្រុងលីលីរបស់បារាំងភាគខាងជើង។ ដោយសារចំនួនកងទ័ព និងអាវុធតិចជាង និងដោយសារការវាយប្រហារពីលើអាកាស កងទ័ពសម្ព័ន្ធមិត្តបានដកថយទៅកាន់ឆ្នេរដុនគឺគដែលជាទីក្រុងកំពង់ផែមួយរបស់បារាំងនៅជិតព្រំដែនប្រទេសបែលហ្សិច។ ពួកគេត្រូវបានឡោមព័ទ្ធដោយទល់ខ្នងទៅនឹងសមុទ្រ។

នៅក្នុងសង្គ្រាមជាលក្ខណៈប្រវត្តិសាស្ត្រមួយ ចក្រភពអង់គ្លេសបានបញ្ជូនកងទ័ពដើម្បីជួយសង្គ្រោះ។ ពួកគេបានបញ្ជូននាវាចម្បាំងប្រមាណ 850 គ្រឿងកាត់តាមសមុទ្រអង់គ្លេសទៅកាន់ទីក្រុងដុនគឺគ។ នាវាជើងទឹកភូមិន្ទ, នាវាស៊ីវិល, នាវាសង្គ្រោះ, ម៉ូតូទឹក, នាវាប្រើចំហាយទឹក, និងវានេសាទបានចូលរួមនៅក្នុងការជួយសង្គ្រោះ។ ចាប់ពីថ្ងៃទី 26 ខែឧសភា ដល់ថ្ងៃទី 4 ខែមិថុនា កងនាវាជួយសង្គ្រោះទាំងនេះទទួលរងការវាយប្រហារយ៉ាងខ្លាំងក្លាពីយន្តហោះទម្លាក់គ្រាប់បែករបស់អាឡឺម៉ង់ ដោយធ្វើដំណើរទៅមកៗរវាងអង់គ្លេស និងដុនគឺគ។ នាវាទាំងអស់នោះបាននាំយកកងទ័ពដែលត្រូវឡោមព័ទ្ធប្រមាណ 338,000 នាក់មកកាន់កន្លែងមានសុវត្ថិភាព។

បារាំងដួលរលំ៖ បន្ទាប់ពីបរាជ័យរបស់កងទ័ពសម្ព័ន្ធមិត្តនៅដុនគឺគ ការតស៊ូនៅក្នុងប្រទេសបារាំងចាប់ផ្តើមចុះខ្សោយ។ ត្រឹមថ្ងៃទី 14 ខែមិថុនា កងទ័ពអាឡឺម៉ង់បានដណ្តើមកាន់កាប់ទីក្រុងប៉ារីស។ ដោយដឹងថាមិនអាចទប់ទល់បាន មេដឹកនាំបារាំងបានចុះចាញ់នៅថ្ងៃទី 22 ខែមិថុនា ឆ្នាំ 1940 ។ អាឡឺម៉ង់បានត្រួតត្រាប្រទេសបារាំងភាគខាងជើង។ ពួកគេទុកភាគខាងត្បូងឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលអាយ៉ងដែលដឹកនាំដោយឧត្តមសេនីយ៍ហ្វីលីបពេ ប៉េតង់ ដែលជាវីរបុរសបារាំងនៅក្នុងសង្គ្រាមលោកលើកទី 1 ។ មូលដ្ឋានរបស់រដ្ឋាភិបាលនេះស្ថិតនៅក្នុងទីក្រុងវីឆី។

បន្ទាប់ពីបារាំងដួលរលំ លោកហ្សាល ដឺហ្គោល ដែលជាឧត្តមសេនីយ៍បារាំងមួយរូប បានបង្កើតរដ្ឋាភិបាលនិរទេសមួយនៅទីក្រុងឡុងដ៍។ លោកបានតាំងចិត្តនៅក្នុងការប្រើប្រាស់នូវរាល់ថាមពលទាំងអស់របស់លោកដើម្បីដណ្តើមកាន់កាប់បារាំងវិញ។ នៅក្នុងផ្សព្វផ្សាយតាមវិទ្យុមួយចេញពីប្រទេសអង់គ្លេស លោកដឺហ្គោលបានស្នើឱ្យប្រជាជនបារាំងចូលរួមជាមួយលោកដើម្បីតស៊ូប្រឆាំងជាមួយអាឡឺម៉ង់។ លោកបានរៀបចំឱ្យមានកងយោធារំដោះបារាំងដែលវាយប្រយុទ្ធជាមួយពួកណាហ្ស៊ីរហូតដល់រំដោះបារាំងបាននៅឆ្នាំ 1944។

### 3. សមរភូមិនៅអង់គ្លេស

ជាមួយនឹងការដួលរលំនៃប្រទេសបារាំង ចក្រភពអង់គ្លេសឈរតែម្នាក់ឯងប្រឆាំងជាមួយពួកណាហ្ស៊ី។ លោកវីនស្តុន ឆឺឈីល ដែលជានាយករដ្ឋមន្ត្រីថ្មីរបស់អង់គ្លេស បានប្រកាសរួមមកហើយថាប្រទេសរបស់លោកនឹងមិនចុះចាញ់ឡើយ។ នៅក្នុងសន្ទរកថាដើម្បីជំរុញទឹកចិត្តមួយ លោកបានប្រកាសថា "យើងត្រូវតែវាយប្រយុទ្ធនៅលើសមុទ្រ, យើងត្រូវតែប្រយុទ្ធនៅលើដី, យើងត្រូវតែប្រយុទ្ធនៅលើដីស្រែចំការ និងនៅតាមផ្លូវ... យើងនឹងមិនចុះចាញ់ជាដាច់ខាត"។

បន្ទាប់ពីកាន់កាប់ប្រទេសបារាំង ហ៊ីត្លែរបានផ្ដោតការយកចិត្តទុកដាក់ក្នុងការឈ្លានពានចក្រភពអង់គ្លេស។ គម្រោងរបស់លោកគឺដំបូងត្រូវកម្ចាត់កងទ័ពភូមិន្ទអាកាស ហើយបន្ទាប់មកបញ្ជូនកងទ័ព 25 ម៉ឺននាក់ទៅកាន់ឆ្នេរសមុទ្រអង់គ្លេស។ នៅក្នុងរដូវក្ដៅ ឆ្នាំ 1940 កងទ័ពជើងអាកាសអាឡឺម៉ង់លូហ្វវ៉ាហ្វេ ចាប់ផ្ដើមទម្លាក់គ្រាប់បែកលើចក្រភពអង់គ្លេស។ ដំបូង អាឡឺម៉ង់ផ្ដោតសំខាន់ទៅលើអាកាសយានដ្ឋាន និងរោងចក្រផលិតយន្តហោះរបស់អង់គ្លេស។ បន្ទាប់មក នៅថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1940 ពួកគេចាប់ផ្ដើមផ្ដោតទៅលើទីក្រុង ជាពិសេសទីក្រុងឡុងដ៍ ដើម្បីធ្វើឱ្យអង់គ្លេសបាក់ទឹកចិត្ត។ បើទោះបីជាទទួលរងការបំផ្លិចបំផ្លាញ និងបាត់បង់ជីវិតក៏ដោយ អង់គ្លេសមិនចុះចាញ់ឡើយ។

កងទ័ពភូមិន្ទអាកាស បើទោះបីជាមានចំនួនតិចតួចក៏ដោយ បានចាប់ផ្ដើមវាយបកវិញយ៉ាងខ្លាំងក្លា។ ឧបករណ៍បច្ចេកវិទ្យាសំខាន់ 2 ដែលបានផ្ដល់អត្ថប្រយោជន៍ដល់កងទ័ពភូមិន្ទអាកាស ។ ទីមួយគឺប្រព័ន្ធតាមដានអេឡិចត្រូនិចមួយដែលគេស្គាល់ថា រ៉ាដា។ អភិវឌ្ឍឡើងនៅចុងទសវត្សរ៍ឆ្នាំ 1930 រ៉ាដា អាចប្រាប់ពីចំនួន, ល្បឿន, និងទិសដៅរបស់យន្តហោះដែលហោះមក។ ឧបករណ៍ទីពីរគឺ ម៉ាស៊ីនបង្កើតកូដអាឡឺម៉ង់ ដែលមានឈ្មោះថា អេនិកម៉ា។ ម៉ាស៊ីនអេនិកម៉ាមួយត្រូវបានគេលួចមកកាន់ចក្រភពអង់គ្លេសនៅចុងទសវត្សរ៍ឆ្នាំ 1930 ។ អេនិកម៉າអាចអនុញ្ញាតឱ្យអង់គ្លេសបំបែកកូដសារសម្ងាត់របស់អាឡឺម៉ង់។ ជាមួយនឹងព័ត៌មានលម្អិតដែលទទួលបានពីឧបករណ៍ទាំងពីរនេះ កងទ័ពភូមិន្ទអាកាស អាចវាយប្រហារយ៉ាងឆាប់រហ័សទៅលើសត្រូវ។

ដើម្បីជៀសវាងការវាយប្រហាររបស់កងទ័ពភូមិន្ទអាកាស អាឡឺម៉ង់បានបោះបង់ចោលការវាយឆ្មក់ពេលថ្ងៃនៅក្នុងខែតុលា ឆ្នាំ 1940 ដោយធ្វើការទម្លាក់គ្រាប់បែកនៅពេលយប់វិញ។ នៅពេលថ្ងៃលិច សម្លេងស៊ីរ៉ែនបានបន្លឺឡើង ប្រជាជនជននៅក្នុងទីក្រុងឡុងដ៍បានរត់ទៅក្នុងផ្លូវរថភ្លើងក្រោមដី ដែលជាកន្លែងសម្រាប់គេចពីការវាយឆ្មក់តាមផ្លូវអាកាស។ អ្នកមួយចំនួនទៀតគេចពីការវាយឆ្មក់តាមរយៈការពួននៅក្នុងរូងក្រោមដីតូចៗនៅក្នុងផ្ទះរបស់ពួកគេ។ សមរភូមិនៅអង់គ្លេសនេះបានបន្តរហូតដល់ថ្ងៃទី 10 ខែឧសភា ឆ្នាំ 1941 ។ ដោយទទួលការស៊ូពីអង់គ្លេស ហ៊ីត្លែរបានសម្រេចចិត្តនៅក្នុងបញ្ឈប់ការវាយប្រហារនេះ។ ជំនួសមកវិញ លោកបង្វែរការយកចិត្តទុកដាក់របស់លោកទៅលើតំបន់សមុទ្រមេឌីទែរ៉ាណេ និងអឺរ៉ុបខាងកើត។ សមរភូមិនៅអង់គ្លេសបានបង្រៀនមេរៀនដ៏សំខាន់មួយដល់សម្ព័ន្ធមិត្ត។ ការវាយប្រហាររបស់ហ៊ីត្លែរអាចរាំងខ្ទប់បាន។

## 4. សមរភូមិសមុទ្រមេឌីទែរ៉ាណេ និងអឺរ៉ុបខាងកើត

ការតស៊ូយ៉ាងស្វិតស្វាញរបស់អង់គ្លេសនៅក្នុងសមរភូមិនៅអង់គ្លេស បណ្ដាលឱ្យហ៊ីត្លែរផ្លាស់ប្ដូរយុទ្ធសាស្ត្ររបស់ខ្លួននៅអឺរ៉ុប។ ហ៊ីត្លែរសម្រេចចិត្តនៅក្នុងការប្រយុទ្ធជាមួយអង់គ្លេសនៅពេលក្រោយ។ ពេលនោះលោកបានត្រឡប់ការយកចិត្តទុកដាក់របស់លោកមកលើតំបន់សមុទ្រមេឌីទែរ៉ាណេ និងតំបន់បាល់កង់ និងតំបន់ដែលសំខាន់បំផុតគឺសហភាពសូវៀត។

កងកម្លាំងអេស៊ីសវាយប្រហារលើអាហ្វ្រិកខាងជើង៖ គោលដៅដំបូងរបស់អាឡឺម៉ង់នៅក្នុងតំបន់សមុទ្រមេឌីទែរ៉ាណេគឺអាហ្វ្រិកខាងជើង ជាពិសេសដោយសារតែដៃគូរបស់ហ៊ីត្លែរ គឺលោកមូស្សូលីនី។ បើទោះបីជាអ៊ីតាលី

ជាសម្ព័ន្ធមិត្តជាមួយអាឡឺម៉ង់ក៏ដោយ ក៏អ៊ីតាលីបបន្តស្ថិតនៅអព្យាក្រឹតនៅដើមដំបូងនៃសង្គ្រាម។ ប៉ុន្តែ ជាមួយនឹងការដណ្តើមកាន់កាប់របស់ហ៊ីត្លែរលើប្រទេសបារាំង លោកមូស្សូលីនីបានដឹងថាលោកត្រូវតែធ្វើសកម្មភាព។ បន្ទាប់ពីប្រកាសសង្គ្រាមជាមួយប្រទេសបារាំង និងចក្រភពអង់គ្លេស លោកមូស្សូលីនីបានធ្វើដំណើរឆ្ពោះទៅរកប្រទេសបារាំង។

លោកមូស្សូលីនីបានអនុវត្តជំហានបន្ទាប់របស់លោកឆ្ពោះទៅកាន់អាហ្វ្រិកខាងជើងនៅក្នុងខែកញ្ញា ឆ្នាំ 1940 ។ ខណៈពេលដែលសមរភូមិនៅអង់គ្លេសបានផ្ទុះឡើង លោកបានបញ្ជាឱ្យកងទ័ពរបស់លោកវាយប្រហារប្រទេសអេហ្ស៊ីបដែលស្ថិតក្រោមការត្រួតត្រារបស់អង់គ្លេស។ ព្រែកជីកស៊ុយអេរបស់អេហ្ស៊ីបគឺជាកូនសោរមួយដើម្បីធ្វើដំណើរទៅដល់តំបន់អណ្តូងរ៉ែនៅមជ្ឈិមបូព៌ា។ ក្នុងរយៈពេលមួយសប្តាហ៍ កងទ័ពអ៊ីតាលីបានលុកលុយចូលប្រទេសអេហ្ស៊ីប 60 ម៉ាយ ដោយរុញច្រានឱ្យអង់គ្លេសដកថយ។ បន្ទាប់មកភាគីទាំងសងខាងជីកលានដ្ឋាន និងរងចាំប្រយុទ្ធគ្នា។

អង់គ្លេសវាយបក៖ ចុងក្រោយ នៅក្នុងខែធ្នូ អង់គ្លេសបានវាយបកវិញ។ លទ្ធផលនោះគឺ អ៊ីតាលីទទួលរងវិនាសកម្ម។ នៅក្នុងខែកុម្ភៈ ឆ្នាំ 1941 អង់គ្លេសបានរំដោះតំបន់អាហ្វ្រិកខាងជើងប្រមាណ 500 ម៉ាយ និងចាប់ខ្លួនឈ្លើយសឹកអ៊ីតាលី 130,000 នាក់។ ហ៊ីត្លែរត្រូវតែលូកដៃដើម្បីជួយសង្គ្រោះភាគីអេស៊ីសរបស់លោក។ ដើម្បីបន្ថែមកម្លាំងដល់អ៊ីតាលី ហ៊ីត្លែរបានបញ្ជូនកងរថក្រោះអាឡឺម៉ង់មួយកងពល ដែលស្ថិតនៅក្រោមបញ្ជាការរបស់ឧត្តមសេនីយ៍អេរីន រ៉ូមមេល។ នៅចុងខែមីនា ឆ្នាំ 1941 កងរថក្រោះរបស់លោក ចាប់ផ្តើមធ្វើការវាយប្រហារ។ ប្រឈមទៅនឹងការវាយប្រហារដោយមិនបានត្រៀមខ្លួនជាមុន កងទ័ពរបស់អង់គ្លេសបានដកថយទៅកាន់តូប្រ៊ូកប្រទេសលីប៊ី។

បន្ទាប់ពីការវាយប្រយុទ្ធគ្នាដ៏ខ្លាំងក្លានៅតូប្រ៊ូក អង់គ្លេសចាប់ផ្តើមវាយបណ្តេញរ៉ូមមេលឱ្យថយក្រោយ។ ត្រឹមពាក់កណ្តាលខែមករា ឆ្នាំ 1942 លោករ៉ូមមេលបានដកថយទៅដល់ទីតាំងដើមរបស់លោកវិញ។ ត្រឹមខែមិថុនា ឆ្នាំ 1942 សមរភូមិចាប់ផ្តើមសារជាថ្មីម្តងទៀត។ លោករ៉ូមមេលបានរៀបចំកងទ័ពលោកវិញ និងធ្វើការវាយប្រហាររុញច្រានអង់គ្លេសឱ្យថយក្រោយឆ្លងការតំបន់វាលខ្សាច់ និងដណ្តើមកាន់កាប់តូប្រ៊ូកដែលវាជាបរាជ័យដ៏ធ្ងន់ធ្ងរមួយរបស់ក្រុមសម្ព័ន្ធមិត្ត។ ជ័យជំនះរបស់លោករ៉ូមមេលនៅអាហ្វ្រិកខាងជើងផ្តល់ឱ្យលោកនូវឈ្មោះក្រៅមួយថា "ចចកលើវាលខ្សាច់"។

សង្គ្រាមនៅតំបន់បាល់កង់៖ ខណៈពេលដែលលោករ៉ូមមេលកំពុងធ្វើយុទ្ធនាការនៅអាហ្វ្រិកខាងជើង ឧត្តមសេនីយ៍អាឡឺម៉ង់ផ្សេងទៀតធ្វើការយ៉ាងសកម្មនៅតំបន់បាល់កង់។ ហ៊ីត្លែរ បានចាប់ផ្តើមរៀបចំគម្រោងវាយប្រហារសម្ព័ន្ធមិត្តរបស់លោកគឺ សហភាពសូវៀត តាំងពីរដូវក្តៅ ឆ្នាំ 1940 មកម្លេះ។ ប្រទេសនៅតំបន់បាល់កង់ដែលស្ថិតនៅអឺរ៉ុបភាគអាគ្នេយ៍គឺជាគន្លឹះសំខាន់នៃគម្រោងឈ្លានពានរបស់ហ៊ីត្លែរ។ ហ៊ីត្លែរចង់ស្ថាបនាមូលដ្ឋាននៅអឺរ៉ុបភាគអាគ្នេយ៍សម្រាប់ការវាយប្រហារសហភាពសូវៀត។ លោកក៏ចង់ធ្វើឱ្យច្បាស់ថាអង់គ្លេសនឹងមិនចូលអន្តរាគមន៍ឡើយ។

ដើម្បីប្រុងប្រៀបសម្រាប់ការឈ្លានពានរបស់លោក ហ៊ីត្លែរបានពង្រីកឥទ្ធិពលរបស់លោកនៅតំបន់បាល់កង់។ ត្រឹមដើមឆ្នាំ 1941 តាមរយៈការគំរាមកំហែងក្នុងការប្រើប្រាស់កម្លាំង លោកបានបញ្ចុះបញ្ចូលឱ្យប្រទេសប៊ុលហ្គារី, រ៉ូម៉ានី, និងប្រទេសហុងគ្រីចូលរួមជាមួយកម្លាំងអេស៊ីស។ ប្រទេសយេហ្គូស្លាវី និងប្រទេសក្រិកដែលមានរដ្ឋាភិបាលគាំទ្រអង់គ្លេសបានតស៊ូប្រឆាំង។ នៅដើមខែមេសា ឆ្នាំ 1941 ហ៊ីត្លែរបានឈ្លានពានប្រទេសទាំងពីរនេះ។ ប្រទេសយេហ្គូស្លាវីបានដួលរលំក្នុងរយៈពេល 11 ថ្ងៃ។ ប្រទេសក្រិកចុះចេញនៅថ្ងៃទី 17 មេសា។ នៅអាតែន ពួកណាហ្ស៊ីបានប្រារព្ធពិធីជ័យជំនះរបស់ពួកគេដោយរាំច្រៀងនៅអាក្រូប៉ូលីស។

ហ៊ីត្លែរឈ្លានពានសហភាពសូវៀត៖ ជាមួយនឹងការត្រួតត្រាពេញលេញលើតំបន់បាល់កង់ ហ៊ីត្លែរអាចឈានទៅរកប្រតិបត្តិការបាបារ៉ូស្សាដែលជាគម្រោងរបស់លោកធ្វើការឈ្លានពានសហភាពសូវៀត។ នៅព្រឹកព្រលឹមថ្ងៃទី 22 ខែមិថុនា ឆ្នាំ 1941 សំលេងរថក្រោះ និងយន្តហោះអាឡឺម៉ង់បានប្រកាសពីការចាប់ផ្តើមឈ្លានពាន។ សហភាពសូវៀតមិនបានប្រុងប្រៀបក្នុងការប្រយុទ្ធឡើយ។ បើទោះបីជាប្រទេសនេះមានចំនួនកងទ័ពច្រើនជាងគេនៅលើពិភពលោកក៏ដោយ ការបំពាក់អាវុធ និងការហ្វឹកហ្វឺនកងទ័ពរបស់ពួកគេមានភាពអន់ខ្សោយ។

ការឈ្លានពានបន្តពីមួយសប្តាហ៍ទៅមួយសប្តាហ៍រហូតដល់អាឡឺម៉ង់អាចរុញច្រាន 500 ម៉ាយចូលទៅក្នុងដែនដីសហភាពសូវៀត។ ដូចដែលកងទ័ពសូវៀតបានដកថយ ពួកគេដុត និងវាយកម្ទិចអ្វីៗគ្រប់យ៉ាងដែលស្ថិតនៅតាមផ្លូវដែលសត្រូវពួកគេធ្វើដំណើរ។ រុស្ស៊ីធ្លាប់បានប្រើប្រាស់យុទ្ធសាស្រ្តដុតកម្ទិចដែនដីនេះប្រឆាំងជាមួយណាប៉ូឡេអុង។

នៅថ្ងៃទី 8 ខែកញ្ញា កងទ័ពរបស់អាឡឺម៉ង់បានឡោមព័ទ្ធទីក្រុងលេនីនក្រាដ។ ត្រឹមដើមខែវិច្ឆិកា ទីក្រុងនេះត្រូវបានកាត់ផ្តាច់ចេញពីតំបន់ផ្សេងៗទៀតរបស់សហភាពសូវៀត។ ដើម្បីបង្ខំឱ្យពួកគេចុះចាញ់ ហ៊ីត្លែរបានប្រុងប្រៀបនៅក្នុងការបង្អត់អាហារប្រជាជនជាង 2.5 លាននាក់ក្នុងទីក្រុងនេះ។ អាឡឺម៉ង់បានទម្លាក់គ្រាប់បែកកម្ទេចឃ្លាំដាក់ទំនិញ ដែលជាកន្លែងដែលស្បៀងអាហារត្រូវបានគេស្តុបទុក។ ដោយសារតែអត់ឃ្លាន ប្រជាជនចាប់ផ្តើមបរិភោគសត្វគោក្របី និងសេះ ក៏ដូចជាសត្វឆ្មា និងឆ្កែ ហើយចុងក្រោយគឺសត្វកង្កែប និងកណ្តុរ។ មនុស្សជិតមួយលាននាក់បានស្លាប់នៅក្នុងទីក្រុងលេនីនក្រាដអំឡុងរដូវរងារឆ្នាំ 1941-1942 ។ ប៉ុន្តែទីក្រុងនេះបដិសេធនៅក្នុងចុះចាញ់។

ដោយមិនយកចិត្តទុកដាក់ជាមួយនឹងដំណើរការនៅទីក្រុងលេនីនក្រាដហ៊ីត្លែរសម្លឹងទៅរកម៉ូស្គូ ដែលជារដ្ឋធានី និងបេះដូងនៃសហភាពសូវៀត។ ការវាយប្រហាររបស់ណាហ្ស៊ីលើទីក្រុងម៉ូស្គូចាប់ផ្តើមឡើងនៅថ្ងៃទី 2 ខែតុលា ឆ្នាំ 1941 ។ ត្រឹមខែធ្នូ កងទ័ពអាឡឺម៉ង់បានរុលទៅដល់ជាយក្រុងម៉ូស្គូ។ ឧត្តមសេនីយ៍សូវៀតហាចជី ហ្ស៊ូកូវធ្វើការប្រយុទ្ធតបវិញ។ ដូចដែលសីតុណ្ហភាពចុះត្រជាក់ ពួកអាឡឺម៉ង់ដែលស្ថិតនៅក្នុងឯកសណ្ឋានរដូវក្តៅ បានដកថយ។ ដោយបំភ្លេចនូវបរាជ័យក្នុងរដូវរងាររបស់ណាប៉ូឡេអុងកាលពី 130 ឆ្នាំមុន ហ៊ីត្លែរបានបញ្ជាទៅឧត្តមសេនីយ៍របស់លោកយ៉ាងម៉ឺងម៉ាត់ថា "មិនត្រូវដកថយឡើយ"។ កងទ័ពអាឡឺម៉ង់ជិកលានដ្ឋានប្រហែល125 ម៉ាយ

ភាគខាងលិចម៉ូស្គូ។ ពួកគេប្រយុទ្ធគ្នាជាមួយពួកសូវៀតរហូតដល់ខែមីនា ឆ្នាំ 1943 ។ ការលុកលុយរបស់ហ៊ីត្លែរចូលសហភាពសូវៀតមិនទទួលបានអ្វីឡើយ ប៉ុន្តែបានបណ្ដាលឱ្យកងទ័ពអាឡឺម៉ង់ 50 ម៉ឺននាក់ស្លាប់។

## 5. សហរដ្ឋអាមេរិកផ្ដល់ជំនួយដល់សម្ព័ន្ធមិត្ត

ប្រជាជនអាមេរិកភាគច្រើនយល់ថាសហរដ្ឋអាមេរិកមិនគួរលូកដៃចូលក្នុងសង្គ្រាមឡើយ។ រវាងឆ្នាំ 1935 ដល់ឆ្នាំ 1937 សភាបានអនុម័តច្បាប់អព្យាក្រឹតមួយចំនួន។ ច្បាប់ដែលមិនអនុញ្ញាតឱ្យលក់អាវុធ ឬផ្ដល់ប្រាក់កម្ចីដល់ប្រទេសដែលកំពុងមានសង្គ្រាមឡើយ។ ប៉ុន្តែ ប្រធានាធិបតីរ៉ូសឺវែលដឹងច្បាស់ថាប្រសិនបើសម្ព័ន្ធមិត្តចាញ់ សហរដ្ឋអាមេរិកនឹងធ្លាក់ទៅក្នុងសង្គ្រាម។ នៅក្នុងខែកញ្ញា ឆ្នាំ 1939 លោកបានស្នើសភាអនុញ្ញាតឱ្យសម្ព័ន្ធមិត្តអាចទិញអាវុធពីអាមេរិកបាន។ សម្ព័ន្ធមិត្តនឹងបង់ជាលុយសុទ្ធ និងដឹកយកទំនិញដោយប្រើប្រាស់នាវារបស់ពួកគេផ្ទាល់។

ស្ថិតនៅក្រោមច្បាប់ខ្ចី-ជួល ដែលអនុម័តក្នុងខែមីនា ឆ្នាំ 1941 ប្រធានាធិបតីអាចផ្ដល់ប្រាក់កម្ចី ឬជួលអាវុធ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដល់ប្រទេសទាំងឡាយដែលជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក។ ត្រឹមរដូវក្ដៅ ឆ្នាំ 1941 កងទ័ពជើងទឹកអាមេរិកបានអមដំណើរកងនាវាអង់គ្លេសដែលដឹកអាវុធអាមេរិក។ ក្នុងការឆ្លើយតបហ៊ីត្លែរបានបញ្ជាឱ្យនាវាមុជទឹករបស់អាឡឺម៉ង់បាញ់ពន្លិចនូវរាល់នាវាដឹកទំនិញដែលពួកគេជួបប្រទះ។

បើទោះបីជាសហរដ្ឋអាមេរិកមិនទាន់ចូលរួមនៅក្នុងសង្គ្រាមក៏ដោយ ក៏ប្រធានាធិបតីរ៉ូសឺវែល និងលោកឆឺឈីលបានជួយគ្នាដោយសម្ងាត់ និងបានធ្វើសេចក្ដីប្រកាសរួមគ្នាមួយដែលហៅថា ធម្មនុញ្ញអាត្លង់ទិក។ ធម្មនុញ្ញនេះបានលើកកម្ពស់ឱ្យមានពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរ និងសិទ្ធិសេរីភាពរបស់ប្រជាជននៅក្នុងការជ្រើសរើសរដ្ឋាភិបាលផ្ទាល់ខ្លួនរបស់ពួកគេ។ ធម្មនុញ្ញនេះក្រោយមកបានដើរតួនាទីជាផែនការសន្តិភាពរបស់ក្រុមសម្ព័ន្ធមិត្តបន្ទាប់ពីសង្គ្រាមលោកលើកទី 2 បានបញ្ចប់។

នៅថ្ងៃទី 4 ខែកញ្ញា នាវាមុជទឹកអាឡឺម៉ង់មួយគ្រឿងបានបាញ់កម្ទេចនាវាពិឃាតរបស់សហរដ្ឋអាមេរិកនៅក្នុងមហាសមុទ្រអាត្លង់ទិក។ នៅក្នុងការឆ្លើយតប លោកប្រធានាធិបតីរ៉ូសឺវែលបានបញ្ជាឱ្យឧត្ដមនាវីបាញ់កម្ទេចនាវាមុជទឹករបស់អាឡឺម៉ង់ណាដែលខ្លួនជួបប្រទះ។ សហរដ្ឋអាមេរិកចាប់ផ្ដើមចូលរួមនៅក្នុងសង្គ្រាមផ្លូវទឹកដោយមិនប្រកាស ជាមួយហ៊ីត្លែរ។ ប៉ុន្តែ ជាការភ្ញាក់ផ្អើលសម្រាប់មនុស្សគ្រប់គ្នា ការវាយប្រហារដែលរុញឱ្យអាមេរិកចូលរួមនៅក្នុងសង្គ្រាមនោះមិនមែនកើតចេញមកពីអាឡឺម៉ង់ឡើយ។ វាកើតចេញមកពីប្រទេសជប៉ុន។

# មេរៀនទី 2៖ យុទ្ធនាការរបស់ប្រទេសជប៉ុននៅតំបន់ប៉ាស៊ីហ្វិក

## 1. ការវាយប្រហារដ៏គួរឱ្យភ្ញាក់ផ្អើរលើកំពង់ផែភើល ហារ៍ប៊ឺរ

ត្រឹមខែតុលា ឆ្នាំ 1940 អាមេរិកបានបំបែកកូដដែលជប៉ុនប្រើដើម្បីបញ្ជូនសារសំងាត់។ ដូច្នេះ ពួកគេបានយល់ដឹងយ៉ាងច្បាស់ពីគម្រោងរបស់ជប៉ុនលើតំបន់អាស៊ីអាគ្នេយ៍។ ប្រសិនបើជប៉ុនឈ្លានពានទឹកដីអាណានិគមអឺរ៉ុបនៅទីនោះ វាក៏ជាការគំរាមកំហែងដែនកោះហ្វីលីពីន និងហ្គាំដែលស្ថិតនៅក្រោមការត្រួតត្រារបស់សហរដ្ឋអាមេរិក។ ដើម្បីបញ្ឈប់ការរុលទៅមុខរបស់ជប៉ុន រដ្ឋាភិបាលសហរដ្ឋអាមេរិកបានបញ្ជូនជំនួយដើម្បីពង្រឹងក្រុមតស៊ូប្រឆាំងនៅចិន។ ហើយនៅពេលដែលជប៉ុនធ្វើការឈ្លានពានបារាំងឥណ្ឌូចិន(វៀតណាម, កម្ពុជា, និងឡាវ) នៅក្នុងឆ្នាំ 1941 ប្រធានាធិបតីរ៉ូសឺវែលបានកាត់ផ្តាច់ការផ្គត់ផ្គង់ប្រេងកាតដល់ប្រទេសជប៉ុន។

បើទោះបីជាខ្វះខាតប្រេងកាតក៏ដោយ ជប៉ុននៅតែបន្តការឈ្លានពានរបស់ពួកគេ។ ពួកគេសង្ឃឹមនៅក្នុងការដណ្តើមកាន់កាប់ដែនដីអាណានិគមរបស់ពួកអឺរ៉ុប និងសហរដ្ឋអាមេរិកតាមរយៈការវាយប្រហារដោយមិនជូនដំណឹងជាមុន។ ដូច្នេះពួកគេបានរៀបចំគម្រោងមួយដើម្បីវាយប្រហារជាទ្រង់ទ្រាយធំមួយលើដែនដីអាណានិគមអង់គ្លេស និងហូឡង់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងដែនដីអាណានិគមអាមេរិកនៅតំបន់ប៉ាស៊ីហ្វិក នៅក្នុងពេលតែមួយ។ ឧត្តមនាវីអ៊ីសូរ៉ូគូ យ៉ាម៉ាម៉ូតូ អ្នករៀបចំយុទ្ធសាស្ត្រផ្លូវទឹកដ៏ខ្លាំងបំផុតរបស់ជប៉ុន ក៏បានស្នើឱ្យមានការវាយប្រហារមួយលើមូលដ្ឋានយោធាអាមេរិកនៅហាវ៉ៃ។ លោកបាននិយាយថា វាគឺជា "ឆ្អឹងមួយដែលនៅជាប់បំពង់ករបស់ជប៉ុន" ហើយត្រូវតែកម្ទេចវាចោល។

ថ្ងៃដ៏ទុរយសះ នៅព្រឹកព្រលឹមថ្ងៃទី 7 ខែធ្នូ ឆ្នាំ 1941 ពលទាហានជើងទឹកអាមេរិកនៅកំពង់ផែភើល ហារ៍ប៊ឺរ បានភ្ញាក់ឡើងដោយសារតែឮសំលេងផ្ទុះ។ ការវាយប្រហាររបស់ជប៉ុនកំពុងកើតមានឡើង! មេដឹកនាំយោធាសហរដ្ឋអាមេរិកបានដឹកតាមរយៈកូដមួយដែលជាសាររបស់ពួកជប៉ុន ដោយដឹងថាការវាយប្រហារមួយនឹងកើតមានឡើង។ ប៉ុន្តែពួកគេមិនបានដឹងថានៅពេលណា ឬទីកន្លែងណាដែលនឹងរងការវាយប្រហារនេះឡើយ។ នៅក្នុងរយៈពេល 2 ម៉ោង ជប៉ុនបានវាយប្រហារនាវា 19 គ្រឿង ដោយក្នុងនោះរួមមាននាវាចម្បាំងចំនួន 8 គ្រឿងផងដែលចតនៅកំពង់ផែភើល ហារ៍ប៊ឺរ៍។ កងទ័ពអាមេរិកជាង 2,300 នាក់ត្រូវបានសម្លាប់ និងត្រូវរបួស1,100 នាក់។ ព័ត៌មានស្តីពីការវាយប្រហារបានធ្វើឱ្យប្រជាជនអាមេរិកស្រឡាំងកាំង។ មួយថ្ងៃបន្ទាប់មក ប្រធានាធិបតីរ៉ូសឺវែលបានថ្លែងនៅមុខសភា។ ថ្ងៃទី 7 ខែធ្នូ ឆ្នាំ 1941 លោកបានប្រកាសថា "ថ្ងៃមួយដែលយើងរស់នៅជាមួយនឹងភាពទុរយស"។ សភាភ្លាមៗនោះបានយល់ព្រមតាមសំណើររបស់លោកក្នុងការប្រកាសសង្គ្រាមជាមួយប្រទេសជប៉ុន និងសម្ព័ន្ធមិត្ត។

ដំណាលគ្នាជាមួយនឹងការវាយប្រហារកំពង់ផែភើល ហារ៍ប៊ឺរ៍ជប៉ុនបានបើកការវាយធ្មក់ទម្លាក់គ្រាប់បែកលើដែនដីអាណានិគមអង់គ្លេសនៅហុងកុង និងដែនកោះហ្គាំ និងវ៉ាកេដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាមេរិក។ ពួកគេក៏បានបោះមូលដ្ឋានកងទ័ពនៅក្នុងប្រទេសថៃផងដែរ។ ការប៉ុនប៉ងរបស់ជប៉ុននៅក្នុងការបង្កើតចក្រភពមួយនៅតំបន់ប៉ាស៊ីហ្វិកកំពុងដំណើរការ។

## 2. ជប៉ុនទទួលជ័យជំនះ

ដោយមានការការពារតិចតួច ដែនកោះហ្គាំ និងវ៉ាកេយ៉ាងឆាប់រហ័សបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ជប៉ុន។ បន្ទាប់មកជប៉ុនបានបង្វែរការយកចិត្តទុកដាក់របស់ពួកគេទៅកាន់ដែនកោះហ្វីលីពីន។ នៅក្នុងខែមករា ឆ្នាំ 1942 ពួកគេបានធ្វើដំណើរឆ្ពោះទៅកាន់រដ្ឋធានីរបស់ហ្វីលីពីន ម៉ានីឡា។ កងទ័ពអាមេរិក និងហ្វីលីពីនបានបោះមូលដ្ឋាននៅបាតាន ដើម្បីទប់ទល់ការវាយប្រហាររបស់ជប៉ុននៅឧបទ្វីប ដែលស្ថិតនៅជាយភាគពាយព្យឈូងសមុទ្រម៉ានីឡា។ ក្នុងពេលជាមួយគ្នានោះ រដ្ឋាភិបាលហ្វីលីពីនបានផ្លាស់ប្តូរទៅកាន់កោះកូរ៉េជីដូរ ដែលស្ថិតនៅភាគខាងត្បូងបាតាន។ បន្ទាប់ពីការវាយប្រយុទ្ធគ្នារយៈពេលប្រមាណជា 3 ខែ ជប៉ុនបានដណ្តើមកាន់កាប់ឧបទ្វីបាតាននៅក្នុងខែមេសា។ កូរ៉េជីដូរក៏បានដួលរលំនៅខែបន្ទាប់។

ជប៉ុនក៏បានបន្តធ្វើការវាយប្រហារប្រឆាំងជាមួយអង់គ្លេសនៅអាស៊ី។ បន្ទាប់ពីដណ្តើមកាន់កាប់ហុងកុង ពួកគេធ្វើការឈ្លានពានម៉ាឡាយ៉ាតាមផ្លូវសមុទ្ទ និងដីគោកតាមប្រទេសថៃ។ ត្រឹមខែកុម្ភៈ ឆ្នាំ 1942 ជប៉ុនបានធ្វើដំណើរមកដល់សិង្ហបុរី ដែលជាទីតាំងយុទ្ធសាស្ត្រស្ថិតនៅចុងភាគខាងត្បូងឧបទ្វីបម៉ាឡេ។ បន្ទាប់ពីការវាយប្រយុទ្ធគ្នាដ៏ខ្លាំងក្លាមក ពួកអាណានិគមបានចុះចាញ់។ ក្នុងរយៈពេលមួយខែ ជប៉ុនបានដណ្តើមកាន់កាប់តំបន់សម្បូរធនធាន ហូឡង់ឥណ្ឌាខាងកើត (បច្ចុប្បន្នឥណ្ឌូនេស៊ី) ដោយក្នុងនោះរួមមានដែនកោះ ចាវ៉ា, ស៊ូម៉ាត្រា, ប៉ូនេអូ, និងសេឡេបេស។ ជប៉ុនក៏បានធ្វើដំណើរឆ្ពោះទៅភាគខាងលិច ដើម្បីដណ្តើមកាន់កាប់ប្រទេសភូមាផងដែរ។ នៅទីនោះ ពួកគេមានគម្រោងនៅក្នុងការវាយប្រហារមួយប្រឆាំងជាមួយឥណ្ឌា ដែលជាដែនដីអាណានិគមធំជាងគេរបស់ចក្រភពអង់គ្លេស។ ត្រឹមពេលដែលភូមាដួលរលំ ជប៉ុនបានត្រួតត្រាដែនដីនៅអាស៊ីក្នុងទំហំជាង 1 លានម៉ាយការ៉េ។ មានប្រជាជនប្រមាណ 150 លាននាក់រស់នៅក្នុងតំបន់ដ៏ធំនេះ។ មុនការឈ្លានពាននេះ ជប៉ុនបានព្យាយាមនៅក្នុងការគាំទ្រប្រជាជនអាស៊ី ជាមួយនឹងគំនិតប្រឆាំងជាមួយអាណានិគម "អាស៊ីខាងកើតសម្រាប់ប្រជាជនអាស៊ី"។ ប៉ុន្តែ បន្ទាប់ពីទទួលជ័យជំនះ ភ្លាមៗនោះជប៉ុនបង្ហាញយ៉ាងច្បាស់ថាពួកគេមកនេះគឺក្នុងនាមជាអ្នកឈ្លានពាន។ ពួកគេជាទូទៅតែងតែប្រព្រឹត្តិដាក់ប្រជាជននៅក្នុងដែនដីអាណានិគមថ្មីរបស់ពួកគេយ៉ាងសាហាវឃោឃៅ។

ប៉ុន្តែ ជប៉ុនបានប្រព្រឹត្តិយ៉ាងសាហាវឃោឃៅដាក់ពួកឈ្លើយសឹកសម្ព័ន្ធមិត្ត។ ជប៉ុនចាត់ទុកថាវាគឺជារឿងអាប់ឱនកិត្តិយសបំផុតសម្រាប់ការចុះចាញ់ ហើយពួកគេមើលងាយមើលថោកដល់ឈ្លើយសឹកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ។ នៅក្នុងការធ្វើដំណើរដ៏មរណៈទៅបាតានដែលជាការធ្វើដំណើរដោយបង្ខំមួយក្នុងចម្ងាយផ្លូវប្រមាណ 50 ម៉ាយពីឧបទ្វីប ជប៉ុនបានប្រព្រឹត្តិយ៉ាងឃោឃៅបំផុតលើឈ្លើយសឹករបស់ពួកគេ។ មានឈ្លើយសឹកប្រមាណ 7 ម៉ឺននាក់បានចូលរួមនៅក្នុងការធ្វើដំណើរដ៏មរណៈទៅបាតាន ក្នុងនោះមានតែឈ្លើយសឹកតែ 54,000 ប៉ុណ្ណោះដែលនៅរស់។

## 3. សម្ព័ន្ធមិត្តវាយបក

បន្ទាប់ពីទទួលបានជ័យជំនះជាបន្តបន្ទាប់គ្នា ជប៉ុនមើលទៅហាក់ដូចជាពិបាកនៅក្នុងការយកជ័យជំនះលើ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមសម្ព័ន្ធមិត្ត ជាពិសេសសហរដ្ឋអាមេរិក និងអូស្ត្រាលី បានអន្ទះសារនៅក្នុង

ការវាយបកនៅក្នុងតំបន់ប៉ាស៊ីហ្វិក។ ជាពិសេសសហរដ្ឋអាមេរិកចង់សងសឹកសម្រាប់ការវាយប្រហារកំពង់ផែភើល ហាប៊ឺរ។ នៅក្នុងខែមេសា ឆ្នាំ 1942 យន្តហោះទម្លាក់គ្រាប់បែក បេ-52 ដែលស្ថិតនៅក្រោមបញ្ជាការរបស់វរសេនីយ៍ឯក ជេម អេដ. ដូលីតថល បានធ្វើការទម្លាក់គ្រាប់បែកលើទីក្រុងតូក្យូ និងទីក្រុងរបស់ជប៉ុនមួយចំនួនទៀត។ ការទម្លាក់គ្រាប់បែកនេះធ្វើឱ្យបះពាល់តិចតួចប៉ុណ្ណោះ។ ប៉ុន្តែ ការវាយឆ្មក់នេះ ជាចំណុចចិត្តសាស្ត្រដ៏សំខាន់មួយសម្រាប់ទាំងអាមេរិក និងជប៉ុន៖ ប្រទេសជប៉ុនជាប្រទេសដែលមិនងាយនិងវាយប្រហារ។

សម្ព័ន្ធមិត្តត្រឡប់ស្ថានការណ៍៖ ការវាយឆ្មក់របស់អាមេរិកលើប្រទេសជប៉ុនបានលើកកម្ពស់ទឹកចិត្តរបស់ប្រជាជនអាមេរិក និងធ្វើឱ្យមានការបាត់បង់ទំនុកចិត្តរបស់ប្រជាជនមួយចំនួននៅជប៉ុន។ ដូចដែលប្រជាជនជប៉ុនម្នាក់លើកឡើងថា "ពួកយើងចាប់ផ្តើមមានមន្ទិលដែលថាពួកយើងមិនចេះបរាជ័យ"។ ជាងនេះទៅទៀតប្រជាជនជប៉ុនមួយចំនួនមានការព្រួយបារម្ភថា ការការពារ និងត្រួតត្រាចក្រភពដ៏ធំមួយអាចនឹងបណ្តាលឱ្យធនធានរបស់ពួកគេរួមថយ។

បន្តិចម្តងៗ សម្ព័ន្ធមិត្តចាប់ផ្តើមបង្វែរទិសដៅសង្គ្រាម។ នៅដើមខែឧសភា ឆ្នាំ 1942 កងនាវាអាមេរិកមួយក្រុម ជាមួយនឹងការគាំទ្រពីអូស្ត្រាលីបានស្ទាត់ចាប់នាវាចម្បាំងជប៉ុនដែលធ្វើដំណើរឆ្ពោះទៅកំពង់ផែម៉ូរេសប៊ី នៅញូវហ្គីណេ។ ទីក្រុងនេះគឺជាមូលដ្ឋានទ័ពអាកាសសំខាន់មួយរបស់សម្ព័ន្ធមិត្ត។ ការត្រួតត្រាមូលដ្ឋានទ័ពអាកាសនេះ នឹងធ្វើឱ្យជប៉ុនមានភាពងាយស្រួលនៅក្នុងការវាយប្រហារអូស្ត្រាលី។

នៅក្នុងសមរភូមិដែលកើតក្រោយមកទៀត គឺសមរភូមិសមុទ្រកូរ៉ាល់ភាគីទាំងសងខាងបានប្រើប្រាស់យុទ្ធសាស្ត្របែបថ្មីមួយក្នុងធ្វើសង្គ្រាមជើងទឹក។ នាវារបស់ភាគីម្ខាងមិនធ្វើការបាញ់ប្រហារមួយគ្រាប់ណាទៅលើនាវារបស់ភាគីម្ខាងទៀតឡើយ។ ដោយសារតែជាទូទៅពួកគេមិនបានមើលឃើញគ្នាឡើយ។ ផ្ទុយទៅវិញ ពួកគេប្រើប្រាស់យន្តហោះដែលហោះចេញពីនាវាផ្ទុកយន្តហោះ ដើម្បីធ្វើការវាយប្រហារលើនាវាទាំងនោះ។ ពួកសម្ព័ន្ធមិត្តទទួលរងគ្រោះដោយបាត់បង់នាវា និងកងទ័ពច្រើនជាងពួកជប៉ុន។ ប៉ុន្តែ សមរភូមិសមុទ្រកូរ៉ាល់អាចចាត់ទុកថាជាជ័យជំនះមួយរបស់ក្រុមសម្ព័ន្ធមិត្ត ដោយសារតែពួកគេអាចបញ្ឈប់ការរុលទៅមុខរបស់ជប៉ុនឆ្ពោះទៅភាគខាងត្បូង។

សមរភូមិនៅមីដវេ៖ គោលដៅបន្ទាប់របស់ជប៉ុនគឺកោះមីដវេដែលមានចម្ងាយប្រមាណ 1,500 ម៉ាយភាគខាងលិចហាវៃ ដែលជាមូលដ្ឋានកងទ័ពអាកាសដ៏សំខាន់មួយរបស់អាមេរិក។ អរគុណដល់អ្នកបំបែកកូដរបស់ក្រុមសម្ព័ន្ធមិត្ត ឧត្តមនាវីឆេស្ទ័រ នីមីត្ស មេបញ្ជាការអាមេរិកទទួលបន្ទុកកងនាវានៅតំបន់ប៉ាស៊ីហ្វិក ដែលបានដឹងថា កងកម្លាំងដ៏ច្រើនរបស់ជប៉ុនកំពុងតែធ្វើដំណើរឆ្ពោះមកកាន់មីដវេ។ ឧត្តមនាវីយ៉ាម៉ាម៉ូតូខ្លួនលោកផ្ទាល់គឺជាមេបញ្ជាការកងនាវារបស់ជប៉ុន។ លោកសង្ឃឹមថាការវាយប្រហារលើកោះមីដវេនឹងអាចកាត់ផ្តាច់កងទ័ពជើងទឹកអាមេរិកនៅតំបន់ប៉ាស៊ីហ្វិកទាំងមូលចេញពីការការពារកំពង់ផែភើល ហាប៊ឺរ។

នៅថ្ងៃទី 4 ខែមិថុនា ជាមួយនឹងការលាក់ខ្លួនរបស់កងកម្លាំងអាមេរិក ឧត្តមនាវីនីមីត្សបានអនុញ្ញាតឱ្យពួកជប៉ុនចាប់ផ្តើមចូលឈ្លានពានលើកោះមីដវេ។ នៅពេលដែលយន្តហោះរបស់ជប៉ុនមួយគ្រឿងដំបូងបានហោះឡើងទៅលើអាកាស យន្តហោះរបស់អាមេរិកបានហោះចុះមកវាយប្រហារកងនាវារបស់ជប៉ុន។ យន្តហោះជា

ច្រើនរបស់ជប៉ុនកំពុងស្ថិតនៅលើនាវាផ្ទុកយន្តហោះនៅឡើយ។ យុទ្ធសាស្ត្រនេះទទួលបានជោគជ័យ។ អ្នកបើកបរយន្តហោះអាមេរិកបានកម្ទេចយន្តហោះជប៉ុន 332 គ្រឿង, នាវាផ្ទុកយន្តហោះទាំង 4 គ្រឿង, និងនាវាគាំទ្រមួយ។ លោក បានបញ្ជាឱ្យកងនាវាពិឃាតរបស់លោកដកថយ។ ត្រឹមថ្ងៃទី 7 ខែមិថុនា ឆ្នាំ 1942 សមរភូមិនេះបានបញ្ចប់។ សមរភូមិមីដវេ បានត្រឡប់ស្ថានការណ៍នៃសង្គ្រាមនៅតំបន់ប៉ាស៊ីហ្វិក។

### 4. ការវាយលុករបស់សម្ព័ន្ធមិត្ត

ជាមួយនឹងទឹកចិត្តក្លៀវក្លាបន្ទាប់ពីទទួលជ័យជំនះនៅ ពួកសម្ព័ន្ធមិត្តចាប់ផ្តើមធ្វើការវាយបកវិញ។ សង្គ្រាមនៅក្នុងតំបន់ប៉ាស៊ីហ្វិកមានរយៈចម្ងាយដ៏ឆ្ងាយ។ កងទ័ពជប៉ុនបានបោះមូលដ្ឋាននៅលើកោះរាប់រយនៅពាលពេញផ្ទៃមហាសមុទ្រ។ ឧត្តមសេនីដូក្លាស់ ម៉ាកអាធឺរ មេបញ្ជាការកងទ័ពជើងគោករបស់ក្រុមសម្ព័ន្ធមិត្តនៅតំបន់ប៉ាស៊ីហ្វិកបានអភិវឌ្ឍផែនការមួយដើម្បីដោះស្រាយបញ្ហានេះ។

លោកម៉ាកអាធឺរ ជឿថា ការវាយប្រហារលើកោះម្តងមួយៗអាចនឹងត្រូវចំណាយពេល និងកម្លាំងច្រើន។ ផ្ទុយទៅវិញ លោកចង់ធ្វើដំណើរជៀសឱ្យឆ្ងាយពីកោះដែលជាមូលដ្ឋានយោធារបស់ជប៉ុន។ បន្ទាប់មកដណ្តើមកាន់កាប់កោះនានាដែលមិនមានការការពាររឹងមាំ ប៉ុន្តែមានទីតាំងស្ថិតនៅជិតប្រទេសជប៉ុន។

គោលដៅដំបូងរបស់លោកម៉ាកអាធឺរ ចាប់ផ្តើមលេចចេញជារូបរាងភ្លាមៗ។ មេដឹកនាំយោធាអាមេរិកបានដឹងថាជប៉ុនកំពុងតែស្ថាបនាមូលដ្ឋានកងទ័ពអាកាសដ៏ធំមួយនៅលើកោះហ្គាដាលកាណាល់ ដែលស្ថិតនៅដែនកោះសូឡូម៉ន់។ ពួកសម្ព័ន្ធមិត្តត្រូវតែវាយប្រហារយ៉ាងឆាប់រហ័សមុនពេលដែលមូលដ្ឋាននេះធ្វើរួចរាល់ ហើយក្លាយជាមូលដ្ឋានយោធារបស់ជប៉ុន។ នៅថ្ងៃទី 7 ខែសីហា ឆ្នាំ 1942 កងទ័ពជើងទឹកអាមេរិករាប់ពាន់នាក់ជាមួយនឹងការគាំទ្រពីអូស្ត្រាលី បានចុះសំចតនៅលើកោះហ្គាដាលកាណាល់ និងកោះទូឡាជីដែលស្ថិតនៅក្បែរនោះ។

កងទ័ពជើងទឹកអាមេរិកមានបញ្ហាតិចតួចប៉ុណ្ណោះ នៅក្នុងការដណ្តើមកាន់កាប់អាកាសយាដ្ឋាននៅហ្គាដាលកាណាល់។ ប៉ុន្តែសមរភូមិដើម្បីត្រួតត្រាកោះនេះបានត្រឡប់ទៅជាការប្រយុទ្ធគ្នាដ៏សាហាវ ដូចដែលភាគីទាំងសងខាងបានបញ្ជូនកងទ័ពជំនួយមកកាន់កោះនេះ។ នៅក្នុងខែកុម្ភៈ ឆ្នាំ 1943 បន្ទាប់ពីការវាយប្រយុទ្ធគ្នាទាំងនៅលើគោក និងលើសមុទ្រអស់រយៈពេល 3 ខែមក សមរភូមិហ្គាដាលកាណាល់ចុងក្រោយបានបញ្ចប់។ បន្ទាប់ពីបាត់បង់កងទ័ព 24,000 នាក់ក្នុងចំណោមកងទ័ពសរុប 36,000 នាក់មក ជប៉ុនបានបោះបង់ចោលកោះដែលពួកគេបានហៅវាថា "កោះមរណៈ"។

សម្រាប់អ្នកឆ្លើយឆ្លងព័ត៌មាន រ៉ាលហ្វ ម៉ាទីន និងកងទ័ពអាមេរិកដែលបានប្រយុទ្ធគ្នានៅទីនោះបាននិយាយថា កោះហ្គាដាលកាណាល់ពេលនោះមើលទៅដូចជា "ឋានរក"។

ដូចដែលជប៉ុនកំពុងធ្វើការដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងថ្មីមួយនៅអាស៊ីអាគ្នេយ៍ និងតំបន់ប៉ាស៊ីហ្វិក ពួកណាហ្ស៊ីបានធ្វើដំណើរឆ្ពោះទៅមុខជាមួយផែនការប្រព័ន្ធគ្រប់គ្រងថ្មីមួយរបស់ហ៊ីត្លែរនៅអឺរ៉ុប។ ផែនការនេះរួម

មាន ការដោះស្រាយជាមួយអ្នកទាំងឡាយណាដែលហ៊ីត្លែរចាត់ទុកថាមិនស៊ីគ្នាជាមួយនឹងពួកណាហ្ស៊ី។ អ្នកនិង បានសិក្សាអំពីបញ្ហានេះនៅក្នុងមេរៀនទី 3 ។

# មេរៀនទី 3 ៖ ហូឡូខូស (ការសម្លាប់ដោយប្រើភ្លើង)

## 1. ហូឡូខូសចាប់ផ្ដើមឡើង

ដើម្បីទទួលបានការគាំទ្រគំនិតរើសអើងពូជសាសន៍របស់ខ្លួន លោកហ៊ីត្លែរបានដឹងថាត្រូវតែជម្រុញឱ្យមានការស្អប់ពួកជនជាតិជ្វីប ដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រវត្តិសាស្ត្ររបស់ពួកអឺរ៉ុប។ អស់ជាច្រើនជំនាន់មកហើយ ប្រជាជនអាឡឺម៉ង់ជាច្រើន ជាមួយនឹងប្រជាជនអឺរ៉ុបផ្សេងទៀត បានចាត់ទុកពួកជ្វីបថាជាមូលហេតុដែលនាំឱ្យពួកគេធ្លាក់ចុះ។ ប្រជាជនអាឡឺម៉ង់មួយចំនួនបានបន្ទោសទៅលើពួកជ្វីប សម្រាប់ការបរាជ័យរបស់អាឡឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទី 1 និងការជួបប្រទះបញ្ហាសេដ្ឋកិច្ចបន្ទាប់ពីសង្គ្រាម។

នៅពេលនោះ ពួកណាហ្ស៊ីបានបង្កើតគោលនយោបាយរបស់រដ្ឋាភិបាលមួយ សំដៅទៅលើពួកជ្វីប។ ច្បាប់ទីក្រុងនូរេមប៊ឺកដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ 1935 ដកហូតសិទ្ធិភាពជាប្រជាពលរដ្ឋអាឡឺម៉ង់របស់ពួកជ្វីប និងហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិជ្វីបជាមួយនឹងអ្នកមិនមែនជនជាតិជ្វីប។ ច្បាប់មួយចំនួនដែលអនុម័តនៅពេលក្រោយមកទៀត ក៏បានកម្រិតប្រភេទនៃការងារដែលពួកជ្វីបអាចធ្វើផងដែរ។

"យប់ដែលកញ្ចក់បែក"៖ ភាពអាក្រក់បំផុតមិនទាន់មកដល់ឡើយ។ នៅដើមខែវិច្ឆិកា ឆ្នាំ 1939 យុវជនជនជាតិជ្វីបឈ្មោះហឺស្កេល គ្រីនស្ប៉ាន ដែលមានអាយុ 17 ឆ្នាំដែលធ្វើដំណើរមកពីប្រទេសអាឡឺម៉ង់ដើម្បីសួរសុខទុក្ខពូនៅទីក្រុងប៉ារីស។ នៅពេលដែល បានទៅដល់ទីនោះ លោកទទួលបានសំបុត្រមួយ។ នៅក្នុងសំបុត្រនោះបាននិយាយថា បន្ទាប់ពីរស់នៅក្នុងប្រទេសអាឡឺម៉ង់អស់រយៈពេល 27 ឆ្នាំ ឪពុករបស់គាត់ត្រូវបានគេនិរទេសទៅកាន់ប្រទេសប៉ូឡូញ។ នៅថ្ងៃទី 7 ខែវិច្ឆិកា ដោយសង្ឃឹមនៅក្នុងការសងសឹកការនិរទេសរបស់ឪពុកលោកគ្រីនស្ប៉ានបានបាញ់ប្រហារទៅលើអ្នកការទូតអាឡឺម៉ង់ម្នាក់ដែលរស់នៅក្នុងទីក្រុងប៉ារីស។

នៅពេលដែលមេដឹកនាំណាហ្ស៊ីឮពីដំណឹងនេះ ពួកគេបានបើកការវាយប្រហារដ៏ហិង្សាមួយលើសហគមន៍ជនជាតិជ្វីប។ នៅថ្ងៃទី ៩ ខែវិច្ឆិកា ណាហ្ស៊ីបានប្រមូលកងទ័ពដើម្បីវាយប្រហារលើផ្ទះ, ហាងទំនិញ, និងព្រះវិហាររបស់ជនជាតិជ្វីបនៅពាសពេញប្រទេសអាឡឺម៉ង់ ហើយបានសម្លាប់ជនជាតិជ្វីបជិត 100 នាក់។ ជនជាតិអាមេរិកម្នាក់ឈ្មោះលីបហ្សិកបានសរសេរថា "បង្អួចហាងទំនិញរបស់ពួកជ្វីបរាប់រយត្រូវបានគេវាយកម្ទេចជាប្រព័ន្ធ... នៅតាមផ្លូវធំៗនៅក្នុងទីក្រុងពោរពេញទៅដោយអំបែងចានកែវដែលគេវាយបំបែក"។ នេះហើយជាមូលហេតុដែលយប់ថ្ងៃទី 9 ខែវិច្ឆិកា ត្រូវបានគេហៅថាគ្រីស្តល់នាច ឬ "យប់ដែលកញ្ចក់បែក"។ គ្រីស្តល់នាចបានបង្ហាញពីជំហានដ៏សំខាន់មួយនៃគោលនយោបាយធ្វើទុក្ខបុកម្នេញរបស់ពួកណាហ្ស៊ីលើជនជាតិជ្វីប។ អនាគតនៃជនជាតិជ្វីបនៅក្នុងប្រទេសអាឡឺម៉ង់មើលទៅពិតជាអាក្រក់។

ជំនន់ជនភៀសខ្លួន៖ បន្ទាប់ពីគ្រីស្តល់នាច ប្រជាជនជ្វីបមួយចំនួនបានដឹងច្បាស់ថា អំពើហិង្សាប្រឆាំងជាមួយពួកគេនឹងកើនឡើងកាន់តែខ្លាំង។ ត្រឹមចុងឆ្នាំ 1939 ជនជាតិជ្វីបនៅអាឡឺម៉ង់មួយចំនួនបានរត់គេចខ្លួន

ទៅកាន់ប្រទេសផ្សេងៗ។ ប៉ុន្តែមានជនជាតិជ្វីបជាច្រើនបន្តស្ថិតនៅក្នុងប្រទេសអាឡឺម៉ង់។ ក្រោយមក ហ៊ីត្លែរបានឈ្លានពានដណ្តើមកាន់កាប់ដែនដីដែលមានជនជាតិជ្វីបជាងមួយលាននាក់រស់នៅ។

ដំបូង ហ៊ីត្លែរគិតថាការបណ្តេញពួកគេទៅកាន់ប្រទេសផ្សេងគឺជាដំណោះស្រាយមួយសម្រាប់អ្វីដែលលោកហៅថា "បញ្ហាជនជាតិជ្វីប"។ ប៉ុន្តែ ការស្វែងរកប្រទេសផ្សេងដែលយល់ព្រមទទួលយកជនជាតិជ្វីបអាឡឺម៉ង់ទាំងនេះគឺជាបញ្ហា។ បន្ទាប់ពីទទួលយកជនភៀសខ្លួនជ្វីបរាប់ម៉ឺននាក់មក ប្រទេសមួយចំនួនដូចជាបារាំង, អង់គ្លេស, និងសហរដ្ឋអាមេរិកភ្លាមៗនោះបានបិទទ្វាររបស់ពួកគេសម្រាប់ជនភៀសខ្លួនបន្ថែមទៀត។ រដ្ឋមន្ត្រីការបរទេសអាឡឺម៉ង់បានអង្កេតឃើញថា "យើងទាំងអស់គ្នាចង់លុបបំបាត់ជនជាតិជ្វីបដែលរស់នៅក្នុងប្រទេសយើង"។ បញ្ហាលំបាកនោះគឺថាគ្មានប្រទេសណាមួយមានបំណងចង់ទទួលពួកគេឡើយ"។

ការដាក់ជនជាតិជ្វីបឱ្យឯកកោរ៖ នៅពេលដែលហ៊ីត្លែររកឃើញថា លោកមិនអាចលុបបំបាត់ជនជាតិជ្វីបតាមរយៈការបណ្តេញទៅកាន់ប្រទេសផ្សេងបានទេ លោកបានអនុវត្តគម្រោងការមួយទៀត។ លោកបានបញ្ជាឱ្យជនជាតិជ្វីបនៅក្នុងប្រទេសទាំងអស់ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់លោកធ្វើដំណើរទៅកាន់ទីក្រុងនានាដែលគេរៀបចំទុកជាមុន។ នៅក្នុងទីក្រុងទាំងនោះ ពួកណាហ្ស៊ីបានកេណ្ឌពួកជ្វីបឱ្យទៅរស់នៅក្នុងតំបន់ដាច់ស្រយាលដែលមានលក្ខណៈតូចចង្អៀត និងគួរឱ្យសង្វេគ។ បន្ទាប់មកពួកណាហ្ស៊ីបានរាំងខ្ទប់តំបន់ដាច់ស្រយាលទាំងនោះជាមួយនឹងបន្លាលួស និងជញ្ជាំងថ្ម។ ពួកគេសង្ឃឹមថាពួកជ្វីបដែលរស់នៅក្នុងនោះនឹងអត់ឃ្លានស្លាប់ ឬស្លាប់ដោយសារជម្ងឺ។

បើទោះបីជាស្ថិតនៅក្នុងស្ថានការណ៍យ៉ាប់យឺនយ៉ាងនេះក៏ដោយ ក៏ពួកជ្វីបនៅតែបន្តតស៊ូ។ មានជនជាតិជ្វីបមួយចំនួន ជាពិសេសពួកជនជាតិជ្វីបនៅក្នុងទីក្រុងវ៉ាសវប្រទេសប៉ូឡូញ បានបង្កើតជាស្ថាប័នមួយចំនួនដើម្បីប្រឆាំងជាមួយនឹងការដាក់ខ្លួននៅតំបន់ដាច់ស្រយាល។ ពួកគេក៏តស៊ូនៅក្នុងការថែរក្សាប្រពៃណីរបស់ពួកគេផងដែរ។ រោងល្ខោននៅតំបន់ដាច់ស្រយាលបានបង្កើតល្បែងកំសាន្ត និងការប្រគំតន្ត្រី។ គ្រូបង្រៀន បង្រៀនមេរៀននៅក្នុងសាលាលួចលាក់។ អ្នកប្រាជ្ញសរសេរកំណត់ត្រា ដូច្នេះថ្ងៃណាមួយមនុស្សនឹងដឹងពីការពិត។

## 2. "**ដំណោះស្រាយចុងក្រោយ**"

ភ្លាមៗនោះ ហ៊ីត្លែរ អន្ទះសារនៅក្នុងការរងចាំពួកជនជាតិជ្វីបស្លាប់ដោយសារការអត់ឃ្លាន ឬជំងឺ។ លោកសម្រេចនៅក្នុងការចាត់វិធានការដោយផ្ទាល់តែម្តង។ ផែនការរបស់លោកត្រូវបានគេហៅថា "ដំណោះស្រាយចុងក្រោយ"។ តាមពិតទៅ វាគឺកម្មវិធី ប្រល័យពូជសាសន៍មួយ ដែលជាការសម្លាប់ក្រុមមនុស្សទាំងមូលជាលក្ខណៈប្រព័ន្ធ។

ហ៊ីត្លែរជឿថា ផែនការនៃការឈ្លានពានរបស់លោកគឺដើម្បីធ្វើឱ្យអម្បូរអារ្យ៉ែនបរិសុទ្ធ។ ដើម្បីការពារដល់ភាពបរិសុទ្ធនៃអម្បូរអារ្យ៉ែន ពួកណាហ្ស៊ីត្រូវតែដកចេញនូវអម្បូរ, ជនជាតិ, ឬក្រុងផ្សេងៗទៀតដែលពួកគេយល់ឃើញថាជាអម្បូរអន់ថយ។ ពួកគេរួមបញ្ចូល ពួករ៉ូម៉ា (ពួកចរកជនមួយក្រុមដែលធ្វើដំណើរមកពីឥណ្ឌា), ពួកប៉ូឡូញ,

ពួករុស្ស៊ី, មនុស្សស្រឡាញ់ភេទដូចគ្នា, មនុស្សវិកលចរិត, មនុស្សពិការ, និងមនុស្សដែលមានជំងឺមើលមិនជា។ ប៉ុន្តែពួកណាហ្ស៊ីផ្តោតជាពិសេសទៅលើពួកជនជាតិជ្វីប។

ការសម្លាប់ចាប់ផ្តើម៖ ដូចដែលកងទ័ពណាហ្ស៊ីធ្វើដំណើរឆ្លងកាត់តំបន់អឺរ៉ុបខាងកើត និងសហភាពសូវៀត ការសម្លាប់ក៏ចាប់ផ្តើមឡើង។ កងទាហានដែលមកពី អេសអេស (កងកម្លាំងសន្តិសុខថ្នាក់លើរបស់ហ៊ីត្លែរ ធ្វើដំណើរពីទីក្រុងមួយទៅកាន់ទីក្រុងមួយដើម្បីតាមប្រម៉ាញ់ជនជាតិជ្វីប។ ក្រុមអេសអេសនិងក្រុមអ្នកសហការជាមួយពួកគេ ប្រមូលផ្តុំបុរស, ស្ត្រី, កុមារ, និងសូម្បីតែទារក និងបាននាំយកពួកគេទៅឃុំទុកនៅកន្លែងដាច់ដោយឡែក។ បន្ទាប់មកពីគេបានបាញ់សម្លាប់អ្នកទោសរបស់ពួកគេនៅក្នុងរណ្តៅ ដែលវាបានក្លាយជាផ្នូររបស់អ្នកទោសទាំងនោះ។

ជនជាតិជ្វីបដែលស្ថិតនៅក្នុងសហគមន៍ដែលក្រុមកងសម្លាប់មិនបានទៅដល់ត្រូវបានគេប្រមូលផ្តុំហើយបញ្ជូនទៅកាន់ជំរុំប្រមូលផ្តុំ ឬធ្វើជាកម្មករនៅក្នុងគុក។ ជំរុំទាំងនេះមានទីតាំងភាគច្រើននៅក្នុងប្រទេសអាឡឺម៉ង់ និងប៉ូឡូញ។ ហ៊ីត្លែរសង្ឃឹមថា ស្ថានការណ៍ដ៏អាក្រក់នៅក្នុងជំរុំនឹងបង្កើនល្បឿននៅក្នុងការលុបបំបាត់ជនជាតិជ្វីប។

អ្នកទោសត្រូវធ្វើការ 7 ថ្ងៃក្នុងមួយសប្តាហ៍ និងធ្វើជាទាសករសម្រាប់ពួកអេសអេស ឬសម្រាប់ជំនួញរបស់ពួកអាឡឺម៉ង់។ ឆ្មាំគុកបានវាយធ្វើបាប ឬសម្លាប់អ្នកទោសរបស់ពួកគេដោយសារតែពួកគេមិនធ្វើការឱ្យបានឆាប់រហ័ស។ ជាមួយនឹងអាហារ ទឹកស៊ុបតិចតួច, នំប៉័ងមួយចំនិត, និងសំបកដំឡូងបារាំង, អ្នកទោសភាគច្រើនបានបាត់បង់ទម្ងន់ 50 ផោនក្នុងរយៈពេលប៉ុន្មានខែដំបូង។ ភាពអត់ឃ្លានកើតមានយ៉ាងខ្លាំង អ្នករស់រានម្នាក់បានរម្លឹកថា "ប្រសិនបើទឹកស៊ុបបន្តិចបន្តួចកំពប់ អ្នកទោលនឹង... យកស្លាបព្រារបស់ពួកគេដួលទឹកស៊ុបនៅលើដី និងបឺតទឹកស៊ុបនោះចូលក្នុងមាត់របស់ពួកគេ"។

ដំណាក់កាលចុងក្រោយ៖ សង្គ្រាមរបស់ហ៊ីត្លែរជាមួយជនជាតិជ្វីបបានឆ្ពោះទៅរក "ដំណោះស្រាយចុងក្រោយ" នៅក្នុងឆ្នាំ 1942 ពួកណាហ្ស៊ីបានស្ថាបនាជំរុំសម្រាប់សម្លាប់ពួកជ្វីបដោយបំពាក់នូវបន្ទប់ឧស្ម័នដ៏ធំ ដែលអាចសម្លាប់មនុស្សបានរហូតដល់ 6,000 នាក់ក្នុងមួយថ្ងៃ។

នៅពេលដែលអ្នកទោសមកដល់អូឈ្វីសដែលជាជំរុំសម្លាប់ធំជាងគេបំផុត ពួកគេធ្វើដំណើរយឺតនៅចំពោះមុខក្រុមគណៈកម្មការវេជ្ជបណ្ឌិតអេសអេស។ ជាមួយនិងការបក់ដៃ វេជ្ជបណ្ឌិតទាំងនេះបានញែកអ្នកមានកម្លាំងខ្លាំង(ភាគច្រើនជាបុរស) ចេញពីអ្នកខ្សោយ(ភាគច្រើនជាស្ត្រី, កុមារ, មនុស្សចាស់, និងអ្នកជំងឺ)។ អ្នកទាំងឡាយណាដែលត្រូវបានគេកំណត់ថាខ្សោយនឹងត្រូវស្លាប់នៅក្នុងថ្ងៃនោះ។ ពួកគេត្រូវបានប្រាប់ឱ្យដោះសម្លៀកបំពាក់ដើម្បីមុជទឹក បន្ទាប់មកត្រូវបានគេនាំចូលទៅក្នុងបន្ទប់មួយដែលមានក្បាលផ្កាឈូកសម្រាប់មុជទឹកក្លែងក្លាយ។ បន្ទាប់ពីទ្វាបន្ទប់ត្រូវបានបិទឧស្ម័នស៊ីអានីដេ ឬកាបូនឌីអ៊ុកស៊ីត បានហ៊ុយចេញមកពីក្បាលផ្កាឈូកសម្រាប់មុជទឹក ឬប្រហោងនៅលើពិដាន។ មនុស្សទាំងអស់នៅក្នុងបន្ទប់បានស្លាប់ក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ បន្ទាប់មក ពួកណាហ្ស៊ីបានដំឡើងឈាបនដ្ឋាន ឬឡ សម្រាប់ដុយសាកសព។

អ្នករស់រានៈ ប្រជាជនជ្វីបនៅអឺរ៉ុបប្រមាណ 6 លាននាក់បានស្លាប់នៅក្នុងជុំរុំសម្លាប់ទាំងនេះ និងដោយសារការសម្លាប់រង្គាលរបស់ពួកណាហ្ស៊ី។ មានជនជាតិជ្វីបមិនដល់ 4 លាននាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត។ អ្នកមួយចំនួនគេចផុតពីការចាប់បញ្ជូនទៅជុំរុំមរណៈ ដោយសារតែការជួយពីសំណាក់ប្រជាជនមិនមែនជនជាតិជ្វីប។ អ្នកជួយសង្គ្រោះទាំងអស់នេះ បានប្រថុយទៅនឹងហានិភ័យដល់អាយុជីវិតផ្ទាល់ខ្លួនរបស់ពួកគេ លាក់បំពួនជនជាតិជ្វីបនៅក្នុងផ្ទះរបស់ពួកគេ ឬជួយពួកគេរត់គេចទៅកាន់ប្រទេសអព្យាក្រឹត្យនានា។ អ្នកទាំងឡាយដែលបានរស់រានពីជុំរុំចងចាំបទពិសោធន៍នេះអស់មួយជីវិតរបស់ពួកគេ។

# មេរៀនទី 4៖ ជ័យជំនះរបស់ក្រុមសម្ព័ន្ធមិត្ត

## 1. ការត្រឡប់ស្ថានការណ៍លើសមរភូមិពីរ

លោកធីឈីលចង់ឱ្យចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកធ្វើការវាយលុកដំបូងនៅអាហ្វ្រិកខាងជើង និងអឺរ៉ុបខាងត្បូង។ យុទ្ធសាស្ត្រនេះធ្វើឱ្យស្តាលីនមានការខឹងសម្បា។ លោកចង់ឱ្យក្រុមសម្ព័ន្ធមិត្តបើកសមរភូមិទី 2 នៅក្នុងប្រទេសបារាំង។ ដូច្នេះ សហភាពសូវៀត អាចងើបឡើងដោយខ្លួនឯងប្រឆាំងជាមួយអាឡឺម៉ង់។ ទាំងអង់គ្លេស និងសហរដ្ឋអាមេរិកអាចជួយសហភាពសូវៀតតាមរយៈការផ្គត់ផ្គង់ជំនួយ។ ទោះជាយ៉ាងណាក៏ដោយ នៅចុងឆ្នាំ 1942 ក្រុមសម្ព័ន្ធមិត្តចាប់ផ្តើមត្រឡប់ស្ថានការណ៍សង្គ្រាមទាំងនៅតំបន់មេឌីទែរ៉ាណេ និងនៅសមរភូមិខាងកើត។

យុទ្ធនាការនៅអាហ្វ្រិកខាងជើង៖ ដូចដែលអ្នកបានអាននៅក្នុងមេរៀនទី 1 ឧត្តមសេនីយ៍អេវីន រ៉ូមមែល ដណ្តើមកាន់កាប់កំពង់ផែសំខាន់មួយនៅទីក្រុងតូប្រ៊ូកប្រទេសលីប៊ីនៅក្នុងខែមិថុនា ឆ្នាំ 1942 ។ ជាមួយនឹងការដួលរលំទីក្រុងឡុងដ៍បានបញ្ជូនឧត្តមសេនីយ៍បឺណាដ ម៉ុងហ្គូមេរី (កងទ័ពរបស់លោកហៅលោកថាម៉ុងទី) ដើម្បីគ្រប់គ្រងកងទ័ពរបស់អង់គ្លេសនៅអាហ្វ្រិកខាងជើង។ ប៉ុន្តែ នៅពេលដែលលោកម៉ុងហ្គូមេរីបានមកដល់ ពួកអាឡឺម៉ង់បានធ្វើដំណើរមកដល់ភូមិមួយរបស់អេស៊ីសដែលមានឈ្មោះថាអិល អាឡាមែន ដែលស្ថិតនៅភាគខាងលិចទីក្រុងអាឡិចសាន់ឌ្រៀ។ ពួកគេបានជីកលានដ្ឋានយ៉ាងល្អប្រសើរ ដែលកងទ័ពរបស់អង់គ្លេសមិនអាចចូលទៅក្បែរពួកគេបានឡើយ។ លោកម៉ុងហ្គូមេរីបានសម្រេចថា មានតែវិធីមួយគត់ដែលអាចបណ្តេញពួកគេចេញបាន គឺធ្វើការវាយលុកដោយផ្ទាល់ក្នុងទ្រង់ទ្រាយធំមួយ។ សមរភូមិអិល អាឡាមែនចាប់ផ្តើមឡើងនៅយប់ថ្ងៃទី 23 ខែតុលា។ ស្នូរកាំភ្លើងប្រមាណជា 1,000 របស់ទាហានអង់គ្លេសធ្វើឱ្យកងទ័ពអេស៊ីសមានការភ្ញាក់ផ្អើល យ៉ាងខ្លាំង។ ពួកគេវាយប្រយុទ្ធតបវិញយ៉ាងខ្លាំងក្លា និងការពារមូលដ្ឋានរបស់ពួកគេបានរយៈពេលប៉ុន្មានថ្ងៃ។ ប៉ុន្តែ ត្រឹមថ្ងៃទី 4 ខែវិច្ឆិកា កងទ័ពរបស់រ៉ូមមែលត្រូវបានវាយបំបាក់។ លោក ជាមួយនិងកងទ័ពរបស់លោកបានត្រឡប់ក្រោយ។

ដូចដែលរ៉ូមមែលបានដកថយទៅភាគខាងលិច ក្រុមសម្ព័ន្ធមិត្តបានបើកប្រតិបត្តិការតូច។ នៅថ្ងៃទី 8 ខែវិច្ឆិកា កងកម្លាំងសម្ព័ន្ធមិត្តមួយក្រុងដែលមានគ្នាជាង 10 ម៉ឺននាក់ ដែលភាគច្រើនជាទាហានអាមេរិកបានធ្វើដំណើរទៅដល់ប្រទេសម៉ូរ៉ូកូ និងអាល់ហ្សេរី។ ឧត្តមសេនីយអាមេរិកលោកឌ្វៃត៍ អេសិនហូវ័រ ជាអ្នកដឹកនាំកងទ័ពទាំងអស់នេះ។ ស្ថិតនៅចន្លោះនៃការឡោមព័ទ្ធរវាងកងទ័ពរបស់ឧត្តមសេនីយ៍ម៉ុងហ្គូមេរី និងឧត្តមសេនីយ៍ អេសិនហូវ័រ ចុងក្រោយកងទ័ពអាហ្វ្រិកា កូប របស់ឧត្តមសេនីយ៍រ៉ូមមែលត្រូវបានវាយបំបែកនៅក្នុងខែឧសភា ឆ្នាំ 1943 ។

សមរភូមិឆ្ពោះទៅរកស្តាលីនហ្គាដ៖ ដូចដែលឧត្តមសេនីយ៍រ៉ូមមែលទទួលរងបរាជ័យនៅអាហ្វ្រិកខាងជើង កងទ័ពអាឡឺម៉ង់ក៏ជួបប្រទះជានឹងការប្រយុទ្ធនៅក្នុងសហភាពសូវៀតផងដែរ។ ការរុលទៅមុខរបស់អាឡឺម៉ង់ត្រូវបានបញ្ឈប់នៅទីក្រុងលេនីនក្រាដ និងក្រុងម៉ូស្គូនៅចុងឆ្នាំ 1941 ។ ហើយរដូវរងារដ៏ជូរចត់បានធ្វើឱ្យស្ថានការណ៍កាន់តែអាក្រក់។ ប៉ុន្តែ នៅពេលដែលរដូវក្តៅឆ្នាំ 1942 បានមកដល់ហ៊ីត្លែរបានបញ្ជូនកងទ័ពទី 6 របស់លោក ដែលស្ថិតនៅក្រោមបញ្ជាការរបស់ឧត្តមសេនីហ្វ្រីឌ្រិច ប៉ូលូស ឱ្យដណ្តើមកាន់កាប់តំបន់អណ្តូងប្រេងនៅតំបន់ជួរភ្នំកៅកាស៊ូស (បច្ចុប្បន្នវ៉ុលហ្គូក្រាដ) ដែលជាមជ្ឈមណ្ឌលឧស្សាហកម្មសំខាន់មួយនៅទន្លេវ៉ុលហ្គា។

សមរភូមិស្តាលីនក្រាដចាប់ផ្តើមឡើងនៅថ្ងៃទី 23 ខែសីហា ឆ្នាំ 1942 ។ លូហ្វត៍វ៉ាហ្វហ្វេ បានការវាយឆ្មក់ដោយធ្វើការទម្លាក់គ្រាប់បែកនៅពេលយប់ដែលនាំឱ្យទីក្រុងមួយភាគធំឆេះ និងក្លាយជាកម្ទេចកម្ទី។ ស្ថានការណ៍មើលទៅគួរឱ្យអស់សង្ឃឹមយ៉ាងខ្លាំង។ បើទោះបីជាយ៉ាងណាក៏ដោយ ស្តាលីនបានប្រាប់មេបញ្ជាការរបស់លោករួចមកហើយថាត្រូវការពារទីក្រុងដែលដាក់ឈ្មោះតាមលោកនេះរហូតដល់ស្លាប់។

ត្រឹមដើមខែវិច្ឆិកា ឆ្នាំ 1942 អាឡឺម៉ង់បានគ្រប់គ្រងទីក្រុងដែលរាបដល់ដីនេះ 90%។ បន្ទាប់មករដូវរងារនៅក្នុងប្រទេសរុស្ស៊ីបានមកដល់។ នៅថ្ងៃទី 19 ខែវិច្ឆិកា កងទ័ពសូវៀតនៅខាងក្រៅទីក្រុងបានបើកការវាយប្រយុទ្ធតទល់ជាមួយពួកអាឡឺម៉ង់។ ដោយបោះមូលដ្ឋាននៅជុំវិញទីក្រុងស្តាលីនក្រាដ ពួកគេឡោមព័ទ្ធទាហានអាឡឺម៉ង់នៅក្នុងទីក្រុង និងកាត់ផ្តាច់ការផ្គត់ផ្គង់។ ឧត្តមសេនីយប៉ូលូស បានអង្វរហ៊ីត្លែរឱ្យបញ្ជាឱ្យកងទ័ពដកថយ។ ប៉ុន្តែហ៊ីត្លែរបដិសេធ ដោយនិយាយថា ទីក្រុងនេះ "ត្រូវតែដណ្តើមកាន់កាប់ឱ្យបានទោះក្នុងតម្លៃណាក៏ដោយ"។

នៅថ្ងៃទី 2 ខែកុម្ភៈ ឆ្នាំ 1943 កងទ័ពដែលត្រជាក់ និងអត់ឃ្លានស្ទើរស្លាប់ ៩ម៉ឺននាក់របស់អាឡឺម៉ង់ចុះចាញ់កងទ័ពសូវៀត។ កងទ័ពនៅរស់រានដ៏គួរឲ្យអាណិតទាំងអស់នេះ គឺនៅសេសសល់ពីកងទ័ពដែលមានចំនួនសរុប 33 ម៉ឺននាក់។ ការការពារទីក្រុងស្តាលីនក្រាដបានបណ្តាលឲ្យសូវៀតបាត់បង់កងទ័ពជាងមួយលាននាក់។ ទីក្រុងនេះ 99% ត្រូវបានបំផ្លាញ។ ប៉ុន្តែ អាឡឺម៉ង់កំពុងក្លាយជាអ្នកការពារខ្លួនវិញម្តង ដូចដែលកងទ័ពសូវៀតកំពុងតែវាយរុញច្រានពួកគេយ៉ាងឆាប់រហ័សឆ្ពោះទៅភាគខាងលិច។

ការឈ្លានពានប្រទេសអ៊ីតាលី៖ ដូចដែលសមរភូមិនៅផ្ទុះឡើងស្តាលីនក្រាដ ស្តាលីននៅតែបន្តទទូចឱ្យចក្រភពអង់គ្លេស និងអាមេរិកធ្វើការរំដោះប្រទេសបារាំង។ ប៉ុន្តែ ប្រធានាធិបតីរ៉ូសេវេលថ៍ និងលោកធីឈីលសម្រេចចិត្តនៅក្នុងការវាយប្រហារប្រទេសអ៊ីតាលីជាមុនសិន។ នៅថ្ងៃទី 10 ខែកក្កដា ឆ្នាំ 1943 កងទ័ពសម្ព័ន្ធមិត្តបានធ្វើដំណើរទៅដល់ស៊ីស៊ីលីមួយខែក្រោយមក ពួកគេបានដណ្តើមកាន់កាប់តំបន់នេះពីកងទ័ពអ៊ីតាលី និងអាឡឺម៉ង់។

ការដណ្តើមកាន់កាប់តំបន់ស៊ីស៊ីលីរបស់ក្រុមសម្ព័ន្ធមិត្ត បានជម្រុញឱ្យលោកមូស្សូលីនីចុះចេញពីតំណែង។ នៅថ្ងៃទី 25 ខែកក្កដា ស្តេចវិចទ័រ អេម៉ានូអែលទី 3 បានចាប់ខ្លួនមេដឹកនាំផ្តាច់ការមូស្សូលីនី។ នៅថ្ងៃទី 3 ខែកញ្ញា ប្រទេសអ៊ីតាលីបានចុះចាញ់។ ប៉ុន្តែ អាឡឺម៉ង់បានវាយដណ្តើមកាន់កាប់អ៊ីតាលីភាគខាងជើង និងដាក់មូស្សូលីនីឱ្យគ្រប់គ្រងអំណាចឡើងវិញ។ ចុងក្រោយ អាឡឺម៉ង់បានដកថយឆ្ពោះទៅភាគខាងជើង ហើយកងទ័ពរបស់សម្ព័ន្ធមិត្តដែលទទួលជ័យជំនះបានចូលទៅកាន់កាប់ទីក្រុងរ៉ូមនៅថ្ងៃទី 4 ខែមិថុនា ឆ្នាំ 1944 ។ ប៉ុន្តែ ការវាយប្រយុទ្ធនៅក្នុងប្រទេសអ៊ីតាលី នៅតែបន្តរហូតដល់អាឡឺម៉ង់ដួលរលំនៅក្នុងខែឧសភា ឆ្នាំ 1945 ។ នៅថ្ងៃទី 27 ខែមេសា ឆ្នាំ 1945 ពួកឧទ្ទាមអ៊ីតាលីបានពួនស្ទាក់វាយប្រហារលើក្បួនរថយន្តរបស់អាឡឺម៉ង់នៅជិតទីក្រុងមីឡាន ដែលស្ថិតនៅអ៊ីតាលីភាគខាងជើង។ នៅក្នុងរថយន្តមួយគ្រឿងដែលពួកគេវាយឆ្មក់នោះពួកគេបានរកឃើញមូស្សូលីនី ដែលតែងខ្លួនធ្វើជាទាហានអាឡឺម៉ង់។ មួយថ្ងៃបន្ទាប់មក ពួកគេបានបាញ់សម្លាប់លោក និងចងសាកសពរបស់លោកនៅជាយក្រុងមីឡានដើម្បីឱ្យមនុស្សគ្រប់គ្នាបានឃើញ។

## 2. ការប្រឈមក្នុងប្រទេសរបស់ពួកសម្ព័ន្ធមិត្ត

គ្រប់ពេលដែលកងទ័ពសម្ព័ន្ធមិត្តវាយប្រយុទ្ធ ប្រជាជននៅក្នុងប្រទេសបានគាំទ្រពួកគេយ៉ាងពេញទំហឹង។ នៅក្នុងទីក្រុងរបស់ប្រទេសមានសង្គ្រាមមួយចំនួនដូចជាសហភាពសូវៀត និងចក្រភពអង់គ្លេស ប្រជាជនស៊ីវិលត្រូវតែស៊ូជាមួយនិងភាពលំបាកគ្រប់បែបយ៉ាង។ មានមនុស្សជាច្រើនត្រូវបាត់បង់ជីវិត។ លើកលែងតែអ្នកមួយចំនួន ដែលទឹកដីរបស់ពួកគេមិនបានទទួលរងឈ្លានពាន ឬការទម្លាក់គ្រាប់បែក ដែលក្នុងនោះមានដូចជាកោះហាវៃរបស់សហរដ្ឋអាមេរិកជាដើម។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនអាមេរិកនៅក្នុងប្រទេសបានចូលរួមចំណែកយ៉ាងធំធេងដល់ការប្រឹងប្រែងរបស់ក្រុមសម្ព័ន្ធមិត្ត។ ប្រជាជនអាមេរិកផលិតអាវុធ និងឧបករណ៍នានាដែលជួយដល់ការធ្វើសង្គ្រាម។

ការប្រមូលផ្តុំដើម្បីធ្វើសង្គ្រាម៖ ដើម្បីយកជ័យជំនះលើពួកអេស៊ីស ត្រូវឱ្យមានការប្រមូលផ្តុំមួយដើម្បីធ្វើសង្គ្រាមសរុប។ នៅក្នុងសហរដ្ឋអាមេរិក រោងចក្រនានាបានប្រែក្លាយសង្វាក់ផលិតកម្មមុនសង្គ្រាមឱ្យក្លាយជាសង្វាក់ផលិតកម្មសង្គ្រាម ហើយផលិតនូវអ្វីៗគ្រប់យ៉ាងរាប់ចាប់ពីកាំភ្លើងយន្តរហូតដល់ស្បែកជើង។ រោងចក្រផលិតយានយន្តបានផលិតរថក្រោះ។ ក្រុមហ៊ុនអង្គលីលេខបានផលិតសំបកគ្រាប់កាំភ្លើង។ ត្រឹមឆ្នាំ 1944 កម្មករនៅសហរដ្ឋអាមេរិកចន្លោះពី 17 ទៅ 18 លាននាក់ ដែលភាគច្រើនជាស្ត្រី បានធ្វើការនៅក្នុងរោងចក្រឧស្សាហកម្មសង្គ្រាម។

ដោយសារតែរោងចក្រភាគច្រើនត្រឡប់ទៅផលិតនូវផលិតផលសង្គ្រាម ភាពខ្វះខាតនៃទំនិញប្រើប្រាស់ចាំថ្ងៃបានកើតមាននៅក្នុងសហរដ្ឋអាមេរិក។ រាប់ចាប់តាំងពីត្រីសាច់ និងស្ករស រហូតដល់សំបកកង់រថយន្ត និងប្រេងឥន្ធនៈ, រាប់ចាប់ពីស្រោមជើងនីឡុង រហូតដល់ម្សៅសាប៊ូ, រដ្ឋាភិបាលអាមេរិកបានកម្រិតចំនួនដែលអាចទិញបានចំពោះទំនិញខ្វះខាងទាំងអស់នេះ។ ការកំណត់ល្បឿនបើកបរក្នុងល្បឿន 35 ម៉ាយក្នុងមួយម៉ោងក៏អាចជួយសន្សំសំចៃប្រេងឥន្ធនៈ និងសំបកកង់កៅស៊ូផងដែរ។ នៅក្នុងបណ្តាលប្រទេសនៅអឺរ៉ុបដែលរងឥទ្ធិពលដោយផ្ទាល់ពីសង្គ្រាម ការកំណត់ចំនួនទំនិញដែលអាចទិញបានមានលក្ខណៈកាន់តែតឹងរឹង។

ដើម្បីជម្រុញឱ្យប្រជាជនរបស់ពួកគេកាន់តែតស៊ូប្រឹងប្រែង រដ្ឋាភិបាលសម្ព័ន្ធមិត្តបានប្រើប្រាស់នូវយុទ្ធនាការឃោសនាដ៏មានប្រសិទ្ធភាពខ្ពស់មួយ។ នៅក្នុងសហភាពសូវៀត យុវជនម្នាក់នៅក្នុងទីក្រុងម៉ូស្គូបានប្រមូលបំណែកលោហៈដែលគេប្រើប្រាស់រួចផលិតបានសំបកគ្រាប់កាំភ្លើង 14,000 គ្រាប់។ គ្រួសារជេនជាតិរុស្ស៊ីមួយបានប្រើប្រាស់ប្រាក់សន្សំរបស់ពួកគេដើម្បីទិញរថក្រោះមួយសម្រាប់កងទ័ពក្រហម។ នៅក្នុងសហរដ្ឋអាមេរិក យុវជនបានសន្សំលុយរបស់ពួកគេ និងបានទិញតែមសង្គ្រាមរបស់រដ្ឋាភិបាល និងបានចូលប្រាក់ដើម្បីជួយដល់សង្គ្រាម។

សង្គ្រាមបានកម្រិតសិទ្ធិសេរីភាពស៊ីវិល៖ ការឃោសនារបស់រដ្ឋាភិបាលក៏មានឥទ្ធិពលអវិជ្ជមានផងដែរ។ បន្ទាប់ពីការវាយប្រហារកំពង់ផែភើល ហាប៊ើរ៍ រលកនៃការប្រកាន់ពូជសាសន៍បានរីកសាយភានៅពាសពេញសហរដ្ឋអាមេរិកប្រឆាំងជាមួយប្រជាជនអាមេរិកដើមកំណើតជប៉ុន។ ភាគច្រើនអ្នកដែលរស់នៅហាវៃ និងតំបន់ឆ្នេរភាគខាងលិច។ ការទម្លាក់គ្រាប់បែកនៅកំពង់ផែភើល ហាប៊ើរ៍ បានធ្វើឱ្យប្រជាជនអាមេរិកមានការភ័យខ្លាច។ ការភ័យខ្លាចនេះ ដែលត្រូវបានជម្រុញដោយការឃោសនារបស់រដ្ឋាភិបាល បានប្រែក្លាយជាអំពើហិង្សាប្រឆាំងជាមួយ

ប្រជាជនអាមេរិកដើមកំណើតជប៉ុន។ ពួកគេភ្លាមៗនោះត្រូវបានគេយល់ឃើញថាជា "សត្រូវ"។ នៅថ្ងៃទី 19 ខែកុម្ភៈ ឆ្នាំ 1942 ប្រធានាធិបតីរ៉ូសេវេសច៍បានអនុម័តបទបញ្ញាពិសេសមួយ ស្នើឱ្យចាប់ប្រជាជនអាមេរិកដើមកំណើតជប៉ុនឃុំទុក ដោយសារតែពួកគេត្រូវបានចាត់ទុកថាជាអ្នកគំរាមកំហែងដល់សហរដ្ឋអាមេរិក។

នៅក្នុងខែមីនា យោធាចាប់ផ្ដើមប្រមូលផ្ដុំ "ជនបរទេស" និងបានដឹកពួកគេតាមនាវាទៅតាំងទីលំនៅថ្មីនៅក្នុងជំរុំ។ ពួកគេយល់ឃើញថា ការផ្លាស់ប្ដូរពួកគេទៅកាន់ទីតាំងថ្មីអាចនឹងការពារ "សត្រូវបរទេស" ទាំងអស់នេះពីការជួយការឈ្លានពានរបស់ជប៉ុន។ ប៉ុន្តែ 2/3 នៃអ្នកដែលគេចាប់ឃុំទាំងអស់នោះគឺជាជនជាតិអាស៊ីដែលមានដើមកំណើតនៅសហរដ្ឋអាមេរិក ប៉ុន្តែមានឪពុកម្ដាយជាជនជាតិជប៉ុន។ ពួកគេជាច្រើនបានស្ម័គ្រចិត្តបម្រើការនៅក្នុងវិស័យយោធា និងធ្វើការប្រយុទ្ធយ៉ាងអង់អាចដើម្បីសហរដ្ឋអាមេរិក បើទោះបីជាគ្រួសាររបស់ពួកគេត្រូវបានគេឃុំនៅក្នុងជំរុំក៏ដោយ។

## 3. ជ័យជំនះនៅអឺរ៉ុប

ខណៈពេលដែលក្រុមសម្ព័ន្ធមិត្តកំពុងតែជាប់រវល់នៅក្នុងការដោះស្រាយបញ្ហានានា ដែលកើតមានក្នុងប្រទេស ពួកគេក៏បានប្រុងប្រៀបដើម្បីដណ្ដើមជ័យជំនះនៅអឺរ៉ុបផងដែរ។ នៅក្នុងឆ្នាំ 1943 ពួកសម្ព័ន្ធមិត្តបានចាប់ផ្ដើមស្ថាបនាកងកម្លាំងឈ្លានពានសម្ងាត់មួយនៅចក្រភពអង់គ្លេស។ ផែនការរបស់ពួកគេគឺបើកការវាយប្រហារមួយលើពួកអាឡឺម៉ង់នៅបារាំងដោយឆ្លងកាត់តាមសមុទ្រអង់គ្លេស។

ការឈ្លានពានថ្ងៃ-ឌី៖ ត្រឹមខែឧសភា ឆ្នាំ 1944 កងកម្លាំងឈ្លានពានបានប្រុងប្រៀបរួចរាល់។ យន្តហោះ, នាវា, រថក្រោះរាប់ពាន់គ្រឿង រួមជាមួយទាហានជាង 3 លាននាក់បានប្រុងប្រៀបរង់ចាំការវាយប្រហារ។ ឧត្តសេនីយ៍ដ្វៃត៍ អេសិនហូវ៉ែមេបញ្ជាការកងកម្លាំងដ៏ច្រើននេះ បានរៀបចំផែនការវាយប្រហារលើឆ្នេរណ្ឌរមេនឌី ដែលស្ថិតនៅបារាំងភាគពាយព្យ។ ពួកអាឡឺម៉ង់បានដឹងថាការវាយប្រហារមួយនឹងមកដល់។ ប៉ុន្តែពួកគេមិនបានដឹងថាការវាយប្រហារនោះនឹងធ្វើនៅកន្លែងណាឡើយ។ ដើម្បីធ្វើឱ្យហ៊ីត្លែរទាយ ក្រុមសម្ព័ន្ធមិត្តបានបង្កើតក្រុមកងទ័ពក្លែងក្លាយដ៏ធំមួយ ដែលមានមូលដ្ឋានយោធា និងសម្ភារៈដូចក្រុមទាហានមែនទែនដែរ។ ការរៀបចំកងទ័ពក្លែងក្លាយនេះ ធ្វើឱ្យគេជឿថាពួកសម្ព័ន្ធមិត្តកំពុងរៀបចំការវាយប្រហារតំបន់កំពង់ផែកាឡៃសរបស់បារាំង។

ឈ្មោះនេះត្រូវបានគេកូដថា ប្រតិបត្តិការអធិរាជ ដែលជាការឈ្លានពាននៅតំបន់ណ្ឌរមេនឌី គឺជាការវាយប្រយុទ្ធលើគោក និងលើសមុទ្រដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រ។ ការឈ្លានពាននេះបានចាប់ផ្ដើមនៅថ្ងៃទី 6 ខែមិថុនា ឆ្នាំ 1944 ដែលត្រូវបានគេស្គាល់ថា ថ្ងៃ-ឌី។ ព្រឹកព្រលឹងថ្ងៃនេះ កងទ័ពអង់គ្លេស, អាមេរិក, បារាំង, និងកាណាដាបានវាយប្រយុទ្ធនៅតាមបណ្ដោយឆ្នេរណ្ឌរមេនឌីដែលមានប្រវែង 60 ម៉ាយ( សូមមើលផែនទីនៅក្នុងទំព័រនេះ )។ ពួកអាឡឺម៉ង់បានដឹកលានដ្ឋានជាមួយនិងកាំភ្លើងយន្ត, កាំភ្លើងបាញ់គ្រាប់រ៉ុកែត, និងកាំភ្លើងធំ។ ពួកគេស្ថិតនៅពីក្រោយជញ្ជាំងស៊ីម៉ង់ដែលមានកម្រាស់ពាហ្វីត។ ដោយមិនមានការភ្ញាក់ផ្អើរ ពួកសម្ព័ន្ធមិត្តរងគ្រោះយ៉ាងធំធេង។ ក្នុងចំណោមទាហានអាមេរិកតែមួយ មានទាហាន 2,700 នាក់បានស្លាប់នៅថ្ងៃដែលប្រយុទ្ធគ្នាតាមឆ្នេរនេះ។

បើទោះបីជាមានការបាត់បង់ជាច្រើនក៏ដោយ ក្រុមសម្ព័ន្ធមិត្តបានដណ្តើមកាន់កាប់តំបន់ឆ្នេរនេះ។ នៅក្នុងរយៈពេលមួយខែនៃការវាយលុក ថ្ងៃ-ឌី មានកងទ័ពបន្ថែមជាងមួយលាននាក់បានមកដល់។ បន្ទាប់មកនៅថ្ងៃទី 25 ខែកក្កដា ក្រុមសម្ព័ន្ធមិត្តបានវាយបើកផ្លូវមូលដ្ឋានការពារមួយរបស់អាឡឺម៉ង់នៅជិតសេនត៍-ឡូ ហើយកងទ័ពទី 3 របស់សហរដ្ឋអាមេរិកដែលដឹកនាំដោយឧត្តមសេនីយចច ប៉ាតតុន បានវាយបំបែកមូលដ្ឋាននេះ។ មួយខែក្រោយមក ក្រុមសម្ព័ន្ធមិត្តបានធ្វើដំណើរប្រែកបដោយជោគជ័យទៅកាន់ប៉ារីស។ ត្រឹមខែកញ្ញា ពួកគេបានរំដោះប្រទេសបារាំង, ប៊ែលហ្សិច, និងលុចហ្សំបួរ។ បន្ទាប់មកពួកគេបានរៀបចំទិសដៅរបស់ពួកគេទៅកាន់អាឡឺម៉ង់។

សមរភូមិប៊ូលហ្គេ៖ ដូចដែលកងកម្លាំងសម្ព័ន្ធមិត្តធ្វើដំណើរឆ្ពោះទៅកាន់ប្រទេសអាឡឺម៉ង់ពីភាគខាងលិច កងទ័ពសូវៀតក៏បានធ្វើដំណើររុលឆ្ពោះទៅកាន់អាឡឺម៉ង់ពីភាគខាងកើត។ ហ៊ីត្លែរ ឥឡូវនេះប្រឈមនៅនិងសង្គ្រាមមួយសមរភូមិ 2 ។ នៅក្នុងប្រថុយទៅនិងសង្គ្រាមនេះ លោកបានសម្រេចចិត្តនៅក្នុងការប្រយុទ្ធតទល់ជាមួយនិងក្រុមសម្ព័ន្ធមិត្តនៅភាគខាងលិច។ ហ៊ីត្លែរគិតថាដើម្បីជ័យជំនះ អាឡឺម៉ង់ត្រូវវាយបំបែកកងកម្លាំងអាមេរិក និងអង់គ្លេសឱ្យដាច់ចេញពីគ្នា និងត្រូវវាយកាត់ផ្តាច់ផ្លូវផ្គត់ផ្គង់របស់ក្រុមសម្ព័ន្ធមិត្ត។ ហ៊ីត្លែរបានពន្យល់ពីមូលហេតុនៃផែនការរបស់លោកថា "សមរភូមិនេះគឺជាការសម្រេចថាលោករស់ ឬស្លាប់... រាល់ការប្រឆាំងទាំងអស់នឹងត្រូវវាយកម្ទេចដោយរលកនៃភេរវកម្ម"។

នៅថ្ងៃទី 16 ខែធ្នូ កងរថក្រោះអាឡឺម៉ង់បានវាយបំបែកក្រុមការពារអន់ខ្សោយរបស់អាមេរិកតាមបណ្តោយខ្សែត្រៀមមួយដែលមានប្រវែង 75 ម៉ាយនៅអាដេននេស ។ យុទ្ធនាការនៃការវាយរុលចូលទៅក្នុងខ្សែត្រៀមរបស់សម្ព័ន្ធមិត្តត្រូវបានគេហៅឈ្មោះថា សមរភូមិប៊ូលហ្គេ។ បើទោះបីជា មានចន្លោះប្រហោងក៏ដោយ ក៏បន្តិចម្តងៗក្រុមសម្ព័ន្ធមិត្តបានវាយរុញច្រានទាហានអាឡឺម៉ង់ឱ្យត្រឡប់ថយក្រោយវិញ។ ពួកអាឡឺម៉ង់មានជម្រើសតិចតួច ប៉ុន្តែពួកគេសម្រេចចិត្តនៅក្នុងការដកថយ ដូចដែលពួកគេមិនមានកងទ័ពជំនួយ។

អាឡឺម៉ង់ចុះចាញ់ដោយឥតលក្ខខ័ណ្ឌ៖ បន្ទាប់ពីសមរភូមិប៊ូហ្គេមកសង្គ្រាមនៅអឺរ៉ុបយ៉ាងចាប់ហ័សឆ្ពោះទៅរកទីបញ្ចប់មួយ។ នៅចុងខែមីនា ឆ្នាំ 1945 ក្រុមសម្ព័ន្ធមិត្តបានធ្វើដំណើរឆ្លងកាត់ទន្លេរីនឆ្ពោះទៅកាន់ប្រទេសអាឡឺម៉ង់។ ត្រឹមពាក់កណ្តាលខែមេសា ស្នូកាំភ្លើងត្រូវបានគេលឺនៅក្បែរៗទីក្រុងប៊ែឡាំង។ កងទ័ពសម្ព័ន្ធមិត្តប្រមាណ 3 លាននាក់បានមកដល់ទីក្រុងប៊ែឡាំងពីទិសនិរតី។ កងទ័ពសូវៀតប្រមាណ 6 លាននាក់ទៀតបានមកដល់ទីក្រុងប៊ែឡាំងពីទិលខាងកើត។ ត្រឹមថ្ងៃទី 25 ខែមេសា ឆ្នាំ 1945 សូវៀតបានឡោមព័ទ្ធទីក្រុងប៊ែឡាំង និងបានវាយប្រហារទីក្រុងនេះជាមួយនឹងកាំភ្លើងធំ។

ខណៈពេលដែលសូវៀតបាញ់ផ្លោងគ្រាប់កាំភ្លើងធំចូលទីក្រុងប៊ែឡាំង ហ៊ីត្លែរបានរៀបចំបញ្ចប់ជីវិតរបស់លោកនៅទីបញ្ជាការសម្ងាត់មួយដែលស្ថិតនៅពីក្រោមគំនរបែកបាក់នៃទីក្រុង។ នៅថ្ងៃទី 29 ខែមេសា លោកបានរៀបការជាមួយគូដណ្តឹងរយៈពេលយូររបស់លោកឈ្មោះអេវ៉ា ប្រូន។ នៅថ្ងៃបន្ទាប់ ហ៊ីត្លែរ និងអេវ៉ា ប្រូនបានធ្វើអត្តឃាត។ សាកសពរបស់អ្នកទាំងពីរត្រូវបានគេយកចេញមកក្រៅ និងបានបូជា។

នៅថ្ងៃទី 7 ខែឧសភា ឆ្នាំ 1945 ឧត្តមសេនីយ៍អេសិនហូវ័រ បានទទួលយកការចុះចាញ់ដោយឥតល័ក្ខខ័ណ្ឌរបស់កងទ័ពអាឡឺម៉ង់។ ប៉ុន្តែ ប្រធានាធិបតីរូសេវេលថ៍មិនបានរស់នៅរហូតដល់បានឃើញជ័យជំនះនេះឡើយ។ លោកបានស្លាប់ភ្លាមៗនៅថ្ងៃទី 12 ខែមេសា នៅខណៈពេលដែលកងទ័ពសម្ព័ន្ធមិត្តធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងប៊ែឡាំង។ អ្នកបន្តតំណែងពីប្រធានាធិបតីរូសេវេលថ៍ គឺលោកហារី ទ្រូម៉ាន់បានទទួលព័ត៌មានពីការចុះចាញ់របស់ពួកណាហ្ស៊ី។ នៅថ្ងៃទី 9 ខែឧសភា ការចុះចាញ់នេះត្រូវបានចុះហត្ថលេខាជាផ្លូវការនៅក្នុងទីក្រុងប៊ែឡាំង។ សហរដ្ឋអាមេរិក និងក្រុមសម្ព័ន្ធមិត្តផ្សេងទៀតបានប្រារព្ធពិធីអបអរសាទរ ថ្ងៃអ៊ី-វី (ថ្ងៃជ័យជំនះនៅអឺរ៉ុប)។ បន្ទាប់ពីការវាយប្រយុទ្ធគ្នាអស់រយៈពេលជិត 6 ឆ្នាំ សង្គ្រាមនៅអឺរ៉ុបបានបិទបញ្ចប់។

### 4. ជ័យជំនះនៅតំបន់ប៉ាស៊ីហ្វិក

បើទោះបីជាសង្គ្រាមនៅអឺរ៉ុបបានបញ្ចប់ក៏ដោយ ពួកសម្ព័ន្ធមិត្តនៅបន្តវាយប្រយុទ្ធជាមួយពួកជប៉ុននៅតំបន់ប៉ាស៊ីហ្វិក។ ប៉ុន្តែ ជាមួយនឹងជ័យជំនះរបស់សម្ព័ន្ធមិត្តនៅហ្គូដាល់កាណាល់ការរុលទៅមុខរបស់ជប៉ុននៅតំបន់ប៉ាស៊ីហ្វិកបានបញ្ឈប់។ សម្រាប់ការធ្វើសង្គ្រាមទាំងមូល ជប៉ុនបានដកថយ ជាពេលដែលក្រុមសម្ព័ន្ធមិត្តធ្វើការវាយប្រហារតបវិញ។

ជប៉ុនដកថយ៖ ត្រឹមរដូវស្លឹកឈើជ្រុះ ឆ្នាំ 1944 ក្រុមសម្ព័ន្ធមិត្តបានធ្វើដំណើរទៅកាន់ប្រទេសជប៉ុន។ នៅក្នុងខែតុលា កងទ័ពសម្ព័ន្ធមិត្តបានធ្វើដំណើរទៅដល់កោះឡីតេនៅប្រទេសហ្វីលីពីន។ ឧត្តមសេនីយ៍ឌូគឡាស់ម៉ាក់អាតសឺ ដែលត្រូវបានគេបញ្ជាឱ្យចាក់ចេញពីកោះនេះមុនពេលដែលអាមេរិកចុះចេញនៅក្នុងខែឧសភា ឆ្នាំ 1942 បានចុះជាន់លើកោះ ជាមួយនឹងកងទ័ពរបស់លោក។ នៅពេលដែលធ្វើដំណើរដល់ឆ្នេរ លោកបានប្រកាសថា "ប្រជាជនហ្វីលីពីន ខ្ញុំបានត្រឡប់មកវិញហើយ"។

តាមពិតទៅ ការដណ្ដើមកាន់កាប់កោះនេះមិនមានភាពងាយស្រួលឡើយ។ ជប៉ុនបានរៀបចំផែនការដ៏មុតស្រួចមួយដើម្បីទាប់ស្កាត់ការមកដល់របស់សម្ព័ន្ធមិត្ត។ ពួកគេនឹងកម្ទេចកងនាវារបស់អាមេរិក ដើម្បីការពារកុំឱ្យពួកគេផ្គត់ផ្គង់សម្ភារៈដល់កងទ័ពនៅលើដីគោក។ ប៉ុន្តែ គម្រោងនេះ តម្រូវឱ្យកងនាវាស្ទើរទាំងស្រុងរបស់ជប៉ុនប្រឈមជាមួយហានិភ័យ។ ពួកគេសម្រេចជ្រើសរើសយកល្បែងនេះនៅថ្ងៃទី 23 ខែតុលា នៅក្នុងសមរភូមិឈូងសមុទ្រឡីតេ។ ក្នុងរយៈពេល 4 ថ្ងៃ កងនាវាជើងទឹករបស់ជប៉ុនបានជួបប្រទះទៅនឹងគ្រោះមហន្តរាយ ដោយត្រូវបានក្រុមសម្ព័ន្ធមិត្តវាយកម្ទាត់ខ្ទេចខ្ទីមិនអាចធ្វើសង្គ្រាមទៀតបាន។ ឥឡូវនេះ មានតែកងទ័ពជប៉ុន និងក្រុមកាមីកាហ្សេ ដ៏គួរឱ្យភ័យខ្លាចប៉ុណ្ណោះដែលឈរប្រយុទ្ធគ្នាជាមួយសម្ព័ន្ធមិត្ត។ ក្រុមកាមីកាហ្សេ គឺជាក្រុមអ្នកបើកយន្តហោះធ្វើអត្តឃាតរបស់ជប៉ុន។ ពួកគេអាចនឹងពន្លិចនាវារបស់ក្រុមសម្ព័ន្ធមិត្តដោយបើកយន្តហោះទម្លាក់គ្រាប់បែករបស់ពួកគេបំបុកលើនាវានោះ។

នៅក្នុងខែមីនា ឆ្នាំ 1945 បន្ទាប់ពីការប្រយុទ្ធគ្នាដ៏ស្វិតស្វាញ និងបាត់បង់ជីវិតកងទ័ពដ៏ច្រើនអស់រយៈពេលមួយខែមក កងទ័ពជើងទឹកអាមេរិកដណ្ដើមកាប់កាប់កោះអ៊ីវ៉ូ ជីម៉ាដែលជាកោះមួយមានចម្ងាយ 760 ម៉ាយពីទីក្រុងតូក្យូ។ នៅថ្ងៃទី 1 ខែមេសា កងទ័ពអាមេរិកបានធ្វើដំណើរទៅកាន់កោះអូគីណាវ៉ាដែលមានចម្ងាយតែ

350 ម៉ាយភាគខាងត្បូងជប៉ុនប៉ុណ្ណោះ។ ជប៉ុនបានបានសម្រេចក្នុងការវាយប្រយុទ្ធទាំងអស់សង្ឃឹម។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី 21 ខែមិថុនា សមរភូមិដ៏បង្ហូរឈាមមួយត្រូវបានបញ្ចប់។ ជប៉ុនបាត់បង់កងទ័ពរបស់ខ្លួនប្រមាណ 10 ម៉ឺននាក់ ចំណែកឯអាមេរិកបាត់បង់ជីវិតកងទ័ព 12,000 នាក់។

ជប៉ុនចុះចាញ់៖ បន្ទាប់ពីដណ្តើមកាន់កាប់កោះអូគីណាវ៉ាជំហានបន្ទាប់របស់ក្រុមសម្ព័ន្ធមិត្តគឺធ្វើដំណើរទៅកាន់ទឹកដីជប៉ុន។ ទីប្រឹក្សារបស់ប្រធានាធិបតីទ្រូម៉ាន់បានជូនដំណឹងលោកថាការឈ្លានពានចូលទឹកដីរបស់ជប៉ុនអាចនឹងបណ្តាលឱ្យកងទ័ពក្រុមសម្ព័ន្ធមិត្តបាត់បង់ជីវិតកន្លះលាននាក់។ លោកទ្រូម៉ាន់ត្រូវធ្វើសេចក្តីសម្រេចចិត្តមួយថាគួរតែប្រើមហាអាវុធធំមួយដែលគេឱ្យឈ្មោះថា គ្រាប់បែកអាតូមិច ឬគ្រាប់បែក-អេ ឬក៏អត់។ ទីប្រឹក្សាភាគច្រើនរបស់លោកយល់ឃើញថា ការប្រើប្រាស់គ្រាប់បែកនេះនឹងនាំឱ្យសង្គ្រាមបញ្ចប់យ៉ាងឆាប់រហ័ស។ គ្រាប់បែកនេះត្រូវបានអភិវឌ្ឍឡើងដោយគម្រោងម៉ាហាតតានដែលសម្ងាត់បំផុត ដែលដឹកនាំដោយឧត្តមសេនីយ៍ លេសលី គ្រូវ និងប្រធានក្រុមអ្នកវិទ្យាសាស្ត្ររ៉ូបឺត អូផេនហៃម័រ។ លោកទ្រូម៉ាន់ទើបតែបានដឹងពីការបង្កើតគ្រាប់បែកនេះ នៅពេលដែលលោកឡើងធ្វើជាប្រធានាធិបតីប៉ុណ្ណោះ។

គ្រាប់បែកអាតូមិចលើកដំបូងត្រូវបានគេសាកល្បងនៅតំបន់វាលខ្សាច់មួយនៅក្នុងរដ្ឋម៉ិកស៊ិកកូថ្មី នៅថ្ងៃទី 16 ខែកក្កដា ឆ្នាំ 1945 ។ ប្រធានាធិបតីទ្រូម៉ាន់បានគំរាមទៅលើប្រទេសជប៉ុន។ លោកបានប្រាប់ជប៉ុនថាប្រសិនបើពួកគេមិនចុះចាញ់នោះទេ ពួកគេនឹងទទួលរង "គ្រាប់ភ្លៀងដែលបង្កវិនាសកម្មពីលើអាកាស" ។ ជប៉ុនមិនបានឆ្លើយតបឡើយ។ ដូច្នេះ នៅថ្ងៃទី 6 ខែសីហា ឆ្នាំ 1945 សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកអាតូមិចមួយគ្រាប់លើទីក្រុងហេរ៉ូស៊ីម៉ា ដែលជាទីក្រុងមួយរបស់ជប៉ុនមានប្រជាជនរស់នៅជិត 35 ម៉ឺននាក់។ មានមនុស្សរវាង 7 ម៉ឺនទៅ 8 ម៉ឺននាក់បានស្លាប់ដោយសារការវាយប្រហារនេះ។ 3 ថ្ងៃក្រោយមក គឺនៅថ្ងៃទី 9 ខែសីហា គ្រាប់បែកទី 2 ត្រូវបានទម្លាក់លើទីក្រុងណាកាសាគី ដែលជាទីក្រុងមួយមានប្រជាជនរស់នៅ 27 ម៉ឺននាក់។ មានប្រជាជនជាង 7 ម៉ឺននាក់បានស្លាប់ភ្លាមៗបន្ទាប់ពីការទម្លាក់គ្រាប់បែកនេះ។ សារធាតុវិទ្យុសកម្មដែលសាយភាយចេញពីគ្រាប់បែកទាំងពីរនេះបានសម្លាប់មនុស្សយ៉ាងច្រើន។

ជប៉ុនចុងក្រោយយល់ព្រមចុះចាញ់ឧត្តមសេនីយ៍ឌូគឡាស់ ម៉ាក់អាតសឺនៅថ្ងៃទី 2 ខែកញ្ញា។ ពីធីនេះធ្វើឡើងនៅលើនាវាចម្បាំងរបស់សហរដ្ឋអាមេរិកឈ្មោះថា មីសួរី នៅក្នុងឈូងសមុទ្រតូក្យូ។ ជាមួយនិងការចុះចាញ់របស់ជប៉ុន សង្គ្រាមត្រូវបានបញ្ចប់។ បន្ទាប់មក ប្រទេសនានាត្រូវប្រឈមទៅនឹងករណីកិច្ចនៅក្នុងការស្តាបនាប្រទេសឡើងវិញដែលខ្ទេចខ្ទីដោយសារសង្គ្រាម។

# មេរៀនទី 5៖ អឺរ៉ុប និងជប៉ុនស្ថិតក្នុងវិនាសកម្ម

## 1. ការបំផ្លិចបំផ្លាញនៅអឺរ៉ុប

នៅពេលដែលសង្គ្រាមលោកលើកទី 2 បានបញ្ចប់ អឺរ៉ុបបានរាបដល់ដី។ មានប្រជាជនអឺរ៉ុបជិត 40 លាននាក់បានស្លាប់ 2/3 នៃចំនួននេះគឺជាជនស៊ីវិល។ ការទម្លាក់គ្រាប់បែក និងការបាញ់ផ្លោងដ៏ខ្លាំងក្លាបានប្រែក្លាយទីក្រុងរាប់រយឱ្យក្លាយជាផេះផង់។ សង្គ្រាមលើគោកបានធ្វើឱ្យទីជនបទជាច្រើនខ្ទេចខ្ទី។ ការផ្លាស់ទីរបស់មនុស្សជាច្រើនមកពីប្រទេសផ្សេងបណ្តាលឱ្យខ្វះទីជម្រក។

លទ្ធផលនៃវិនាសកម្ម៖ ទីក្រុងសំខាន់ៗមួយចំនួនតូចនៅអឺរ៉ុប ដូចជាប៉ារីស, រ៉ូម, និងព្រុសសែល មិនសូវទទួលរងគ្រោះធ្ងន់ធ្ងរដោយសង្គ្រាមទេ។ ប៉ុន្តែ ទីក្រុងមួយភាគធំទៀតទទួលរងការបំផ្លិចបំផ្លាញដ៏ធ្ងន់ធ្ងរបំផុត។ សមរភូមិអង់គ្លេស បានបណ្តាលឱ្យទីក្រុងឡុងដ៏ខូចខាតយ៉ាងខ្លាំង។ ទីក្រុងវ៉ាសវដែលជារដ្ឋធានីរបស់ប៉ូឡូញ ត្រូវបានបំផ្លិចបំផ្លាញស្ទើទាំងស្រុង។ នៅក្នុងឆ្នាំ 1939 ទីក្រុងវ៉ាសវមានប្រជាជនរស់នៅជិត 1.3 លាននាក់។ នៅពេលដែលកងទ័ពសូវៀតចូលក្នុងទីក្រុងនេះនៅក្នុងខែមករា ឆ្នាំ 1945 មានតែប្រជាជន 153,000 នាក់ប៉ុណ្ណោះដែលនៅសេះសល់។ ការទម្លាក់គ្រាប់បែករាប់ពាន់តោនរបស់ក្រុមសម្ព័ន្ធមិត្ត បានបំផ្លិចបំផ្លាញមជ្ឈមណ្ឌលសំខាន់ៗនៅទីក្រុងប៊ែកឡាំង 95%។ មន្ត្រីរបស់អាមេរិកដែលមានមូលដ្ឋាននៅរដ្ឋធានីរបស់អាឡឺម៉ង់បានរាយការណ៍ថា "អ្វីៗដែលយើងមើលឃើញគឺសុទ្ធតែហិនហោច។ វាប្រៀបបានទៅនឹងទីក្រុងខ្មោច"។

បន្ទាប់ពីបញ្ចប់ការទម្លាក់គ្រាប់បែក ប្រជាជនស៊ីវិលបន្តរស់នៅកន្លែងដែលគេធ្លាប់រស់នៅ និងព្យាយាមនៅក្នុងការរស់នៅជាមួយនឹងអ្វីដែលពួកគេមាន។ អ្នកមួយចំនួនរស់នៅជាមួយផ្ទះ ឬសំណង់បាក់បែក។ អ្នកមួយចំនួនទៀតប្រមូលផ្តុំគ្នារស់នៅក្នុងបន្ទប់ក្រោមដី ឬរូងក្រោមដី។ ពួកគេមិនមានទឹក, អគ្គិសនី, និងមានចំណីអាហារតិចតួចបំផុត។

មនុស្សជាច្រើនមិនបានរស់នៅកន្លែងដែលពួកគេធ្លាប់រស់នៅឡើយ។ ផ្ទុយទៅវិញពួកគេរស់នៅតាមដងផ្លូវ។ អ្នកផ្លាស់ទីទាំងអស់នេះ រួមមានអ្នករស់រានពីជំរុំប្រមូលផ្តុំ, ឈ្លើយសឹក, ជនភៀសខ្លួនដែលយល់ថាខ្លួនធ្វើដំណើរខុសប្រទេស នៅពេលដែលសន្ធិសញ្ញានានាក្រោយសង្គ្រាមបានផ្លាស់ប្តូរព្រំដែនរបស់ប្រទេសរបស់ពួកគេ។ ពួកគេចង់ធ្វើដំណើរឆ្លងកាត់អឺរ៉ុប ដោយសង្ឃឹមថាពួកគេអាចស្វែងរកឃើញក្រុមគ្រួសាររបស់ពួកគេ ឬស្វែងរកកន្លែងមានសុវត្ថិភាពមួយដើម្បីរស់នៅ។

ភាពទុគ៌តនៅតែបន្តបន្ទាប់ពីសង្គ្រាម៖ ភាពទុគ៌តនៅអឺរ៉ុបនៅតែបន្តកើតមានឡើងអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីសង្គ្រាម។ ការវាយប្រយុទ្ធគ្នាបានបំផ្លិចបំផ្លាញទីជនបទនៃអឺរ៉ុប ហើយកសិកម្មតាមត្រូវបានរាំងស្ទះស្ទើរទាំងស្រុង។ មនុស្សប្រុសពេញកម្លាំងជាច្រើនបានចូលបម្រើការងារក្នុងវិស័យោធា ចំណែកឯស្ត្រីធ្វើការនៅក្នុងរោងចក្រផលិតផលិតផលសង្គ្រាម។ មានមនុស្សតិចតួចប៉ុណ្ណោះដែលបន្តនៅធ្វើស្រែចំការ។ ជាមួយការខូចខាតប្រព័ន្ធដឹកជញ្ជូន ទិន្នផលកសិកម្មដែលគេប្រមូលផលបានជាទូទៅមិនបានដឹកមកដល់ទីក្រុងឡើយ។ មានមនុស្ស

ជាច្រើនពាន់នាក់បានស្លាប់ដោយសារគ្រោះអត់ឃ្លាន និងជំងឺ ដែលបានរីករាលដាល់នៅពាលពេញទីក្រុងនានាដែលទទួលរងគ្រោះដោយការទម្លាក់គ្រាប់បែក។ រដូវរងារលើកដំបូងក្រោយសង្គ្រាមបាននាំមកនាំទុក្ខលំបាកកាន់តែខ្លាំងសម្រាប់ប្រជាជនដែលធ្វើដំណើរដោយគ្មានស្បែកជើង និងអាវរោមសត្វ។

## 2. រដ្ឋាភិបាល និងនយោបាយក្រោយសង្គ្រាម

ប្រជាជននៅអឺរ៉ុបដែលរស់នៅអស់សង្ឃឹម តែងតែបន្ទោសមេដឹកនាំរបស់ពួកគេដែលនាំឱ្យកើតមានសង្គ្រាម និងផលប៉ះពាល់នៃសង្គ្រាម។ នៅពេលដែលអាឡឺម៉ង់ចាញ់សង្គ្រាម រដ្ឋាភិបាលមុនសង្គ្រាមមួយចំនួន ដូចជាបែលហ្ស៊ិច, ហូឡង់, ដាណឺម៉ាក, និងន័រវេស បានត្រឡប់មកកាន់អំណាចវិញភ្លាមៗ។ ប៉ុន្តែ នៅក្នុងបណ្ដាលប្រទេសមួយចំនួនដូចជាអាឡឺម៉ង់, អ៊ីតាលី, និងបារាំង ការត្រឡប់មកវិញរបស់រដ្ឋាភិបាលចាស់មិនត្រូវបានគេចង់បានឡើយ។ រដ្ឋាភិបាលណាហ្ស៊ីរបស់ហ៊ីត្លែបាននាំប្រទេសអាឡឺម៉ង់ឱ្យរាបដល់ដី។ មូស្សូលីនីបានដឹកនាំឱ្យអ៊ីតាលីចាញ់។ រដ្ឋាភិបាលវីឆីបានសហការជាមួយពួកណាហ្ស៊ី។ ភាគច្រើននៃរដ្ឋាភិបាលចាស់បានស្អុយកេរ្តិ៍ឈ្មោះ។ ជាមួយគ្នានេះផងដែរ អ្នកប្រយុទ្ធតស៊ូជាច្រើនគឺជាពួកកុំម្មុយនីស្ត។

បន្ទាប់ពីសង្គ្រាម គណបក្សកុំម្មុយនីស្តបានសន្យានៅក្នុងការផ្លាស់ប្ដូរ ហើយមានមនុស្សរាប់លាននាក់បានប្រុងប្រៀបនៅក្នុងការស្ដាប់។ ទាំងនៅបារាំង និងអ៊ីតាលី សមាជិកគណបក្សកុំម្មុយនីស្តកើនឡើងដូចគាំជ្រួច។ ពួកកុំម្មុយនីស្តទទួលបានសំលេងយ៉ាងច្រើននៅក្នុងការបោះឆ្នោតលើកដំបូងបន្ទាប់ពីសង្គ្រាម។ ដោយអន្ទះសារនៅក្នុងការបង្កើនល្បឿនដើម្បីគ្រប់គ្រងនយោបាយ ពួកកុំម្មុយនីស្តបានបង្កឱ្យមានការបះបោរដ៏ហិង្សាមួយចំនួន។ ប្រជាជនបារាំង និងអ៊ីតាលីដែលមានការព្រួយបារម្ភបានឆ្លើយតបតាមរយៈការបោះឆ្នោតឱ្យគណបក្សដែលប្រឆាំងកុំម្មុយនីស្ត។ សមាជិកគណបក្សកុំម្មុយនីស្ត និងឥទ្ធិពលរបស់ពួកគេបានចាប់ផ្ដើមធ្លាក់ចុះ។ ហើយពួកគេកាន់តែធ្លាក់ចុះថែមទៀតនៅខណៈពេលដែលសេដ្ឋកិច្ចរបស់បារាំង និងអ៊ីតាលីចាប់ផ្ដើមងើបឡើងវិញ។

ការកាត់ទោសនៅនូរេមបឺក៖ ខណៈពេលដែលប្រទេសជាច្រើនកំពុងតស៊ូជាមួយនឹងការស្ដារឡើងវិញនូវនយោបាយ និងសេដ្ឋកិច្ច ពួកគេក៏បានបើកការកាត់ទោសដើម្បីដោះស្រាយជាមួយនឹងបញ្ហានៃឧក្រិដ្ឋកម្មសង្គ្រាម។ អំឡុងឆ្នាំ 1945 និងឆ្នាំ 1946 តុលាការយោធាអន្តរជាតិមួយដែលមានតំណាងមកពី 23 ប្រទេសបាននាំយកពួកឧក្រិដ្ឋជនសង្គ្រាមណាហ្ស៊ីមកកាត់ទោសនៅនូរេមបឺកប្រទេសអាឡឺម៉ង់។ នៅក្នុងការកាត់ទោសដំបូងនៅនូរេមបឺកមេដឹកនាំណាហ្ស៊ីចំនួន 22 នាក់ត្រូវបានកាត់ទោសពីបទបង្កឱ្យមានសង្គ្រាមឈ្លានពាន។ ពួកគេក៏ត្រូវបានចោទថាបានប្រព្រឹត្ត "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលបានសម្លាប់មនុស្សអស់ 11 លាននាក់។

លោកអាឌុលហ្វ ហ៊ីត្លែរ និងប្រមុខអេសអេសលោកហេនរីច ហ៊ីមល័រ និងរដ្ឋមន្ត្រីក្រសួងឃោសនា ចូលេផ ហ្គូអេបបេល បានសម្លាប់ខ្លួនមុនពេលដែលការកាត់ទោសចាប់ផ្ដើម។ ប៉ុន្តែលោកហ័រម៉ាន់ ហ្គូរីង មេបញ្ជាការ លូតហ្វាំហ្វហ្វេ, លោករូឌុលហ្វ ហេស អតីតលេខារបស់ហ៊ីត្លែ, និងមេដឹកនាំណាហ្ស៊ីជាន់ខ្ពស់មួយចំនួនទៀតត្រូវបានគេចាប់យកទៅកាត់ទោស។

លោកហេស ត្រូវបានគេរកឃើញថាមានទោស និងត្រូវបានកាត់ទោសឱ្យជាប់គុកអស់មួយជីវិត។ លោក ហ្វូរីង ត្រូវបានកាត់ទោសប្រហារជីវិត ប៉ុន្តែលោកបានបោកបញ្ឆោតពេជ្ឈឃាត ដោយធ្វើអត្តឃាតខ្លួនឯង។ មេដឹកនាំណាហ្ស៊ី 10 នាក់ផ្សេងទៀតត្រូវបានចងព្យួរកនៅថ្ងៃទី 16 ខែតុលា ឆ្នាំ 1946 ។ លោកហានស៍ ហ្វេង ដែលជា "ពេជ្ឈឃាតដៃឆៅ" គឺជាមន្ត្រីជាន់ខ្ពស់របស់ណាហ្ស៊ីតែមួយរូបគត់ដែលបានបង្ហាញពីវិប្បដិសារីរបស់ខ្លួន ដោយលោកបាននិយាយថា "បើទោះបីជាមួយពាន់ឆ្នាំទៅមុខទៀតក៏ដោយ ក៏មិនអាចលុបលាងកំហុសរបស់អាឡឺម៉ង់បានឡើយ"។ សាកសពរបស់អ្នកដែលត្រូវគេប្រហារជីវិតទាំងនោះត្រូវបានគេដុតនៅក្នុងជំរុំប្រមូលផ្តុំដាកហៅ។ ពួកគេត្រូវបានរំលាយសពនៅក្នុងនៅក្នុងឡតែមួយដែលធ្លាប់បានដុតជនរងគ្រោះជាច្រើននាក់។

## 3. ប្រទេសជប៉ុនក្រោយសង្គ្រាម

ការបរាជ័យដ៏ឈឺចាប់របស់ជប៉ុននៅក្នុងសង្គ្រាមលោកលើកទី 2 បានបន្សល់ប្រទេសនេះនូវវិនាសកម្ម។ ជីវិតមនុស្ស 2 លាននាក់បានបាត់បង់។ ទីក្រុងធំៗរបស់ប្រទេសនេះ ដោយរួមទាំងរាជធានីតូក្យូផង មួយភាគធំត្រូវបានបំផ្លាញដោយការទម្លាក់គ្រាប់បែក។ គ្រាប់បែកអាតូមិកបានប្រែក្លាយទីក្រុងហេរ៉ូស៊ីម៉ា និងណាកាសាគីឱ្យក្លាយទៅជាផេះផង់។ ពួកសម្ព័ន្ធមិត្តក៏បានរឹបអូសយកដែលដីអាណិគមរបស់ជប៉ុនផងដែរ។

ការកាន់កាប់ប្រទេសជប៉ុន៖ ឧត្តមសេនីយ៍ឌូគឡាស់ ម៉ាក់អាតថ័រអ្នកដែលទទួលយកការចុះចាញ់របស់ជប៉ុន ទទួលខុសត្រូវលើការកាន់កាប់របស់សហរដ្ឋអាមេរិកលើប្រទេសជប៉ុន។ លោកម៉ាក់អាតថ័របានប្ដេជ្ញានៅក្នុងការឱ្យមានយុត្តិធម៌ និងមិនបណ្ដុះគ្រាប់ពូជសង្គ្រាមទៅថ្ងៃអនាគតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាថា សន្តិភាពនឹងបន្តស្ថិតស្ថេរ លោកបានចាប់ផ្ដើមដំណើរនៃការធ្វើវិយោធកម្ម (រំលាយ) កងទ័ពជប៉ុន។ លោកទទួលបានជោគជ័យនៅក្នុងការរំលាយនេះយ៉ាងឆាប់រហ័ស ដោយបន្សល់ទុកឱ្យជប៉ុននូវកងកម្លាំងប៉ូលីសតិចតួចប៉ុណ្ណោះ។ លោកម៉ាក់អាតថ័រក៏បានចាប់ផ្ដើមនាំយកឧក្រិដ្ឋជនសង្គ្រាមយកទៅកាត់ទោសផងដែរ។ ក្នុងចំណោមចុងចោទ 25 នាក់ ក្នុងនោះអតីតនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ 6 នាក់ទៀតត្រូវបានគេកាត់ទោសប្រហារជីវិតដោយក្បួរក។

លោកម៉ាក់អាតថ័រពេលនោះ បានត្រឡប់ការយកចិត្តទុកដាក់របស់លោកទៅលើការធ្វើប្រជាធិបតេយ្យូបនីយកម្ម ដែលជាដំណើរការនៃការបង្កើតរដ្ឋាភិបាលមួយតាមរយៈការបោះឆ្នោត។ នៅក្នុងខែកុម្ភៈ ឆ្នាំ 1946 លោក និងទីប្រឹក្សានយោបាយអាមេរិករបស់លោក បានព្រាងធម្មនុញ្ញថ្មីមួយ។ វាបានផ្លាស់ប្ដូរប្រព័ន្ធនយោបាយប្រទេសជប៉ុនទៅជារាជាធិបតេយ្យអាស្រ័យធម្មនុញ្ញដូចចក្រភពអង់គ្លេសដែរ។ ប្រជាជនជប៉ុនបានទទួលយកធម្មនុញ្ញថ្មីនេះ។ ធម្មនុញ្ញថ្មីនេះចូលជាធរមាននៅថ្ងៃទី 3 ខែឧសភា ឆ្នាំ 1947 ។

លោកម៉ាក់អាតថ័រមិនត្រូវបានគេប្រាប់ឱ្យស្ដារសេដ្ឋកិច្ចជប៉ុនឡើងវិញឡើយ។ ប៉ុន្តែ លោកបានណែនាំឱ្យពង្រីកកម្មសិទ្ធិដីធ្លីឯកជន និងបង្កើនការចូលរួមរបស់កម្មករ និងកសិករនៅក្នុងប្រជាធិបតេយ្យថ្មី។ ដើម្បីធ្វើដូចនេះ លោកម៉ាក់អាតថ័របានដាក់ចេញនូវផែនការមួយដែលតម្រូវឱ្យម្ចាស់កម្មសិទ្ធិដីធំៗដែលមិនបានប្រើប្រាស់ លក់ដីទាំងនោះឱ្យរដ្ឋាភិបាល។ បន្ទាប់មករដ្ឋាភិបាលបានលក់ដីទាំងនោះឱ្យទៅប្រជាកសិករក្នុងតម្លៃថោក។ ការធ្វើកំណែ

ទម្រង់ផ្សេងទៀត ដែលធ្វើឡើងដោយលោកម៉ាក់អាតថ័របានផ្តល់ឱ្យកម្មករនូវសិទ្ធិក្នុងការបង្កើតសហជីពការងារឯករាជ្យ។

## 4. ការកាន់កាប់បាននាំមកនូវការប្រែប្រួលដ៏ខ្លាំងក្លា

ធម្មនុញ្ញថ្មីគឺជាសមទ្ធផលដ៏សំខាន់បំផុតនៃការកាន់កាប់របស់សហរដ្ឋអាមេរិក។ វាបាននាំមកនូវការកែប្រែសង្គមជប៉ុនយ៉ាងខ្លាំងក្លាមួយ។ ប្រពៃណីដ៏យូរលង់មួយរបស់ជប៉ុន បានយល់ឃើញថាអធិរាជគឺជាអាទិទេព។ ទ្រង់ក៏ជាមេដឹកនាំអំណាចផ្តាច់មុខមួយអង្គ ដែលពាក្យសំដីរបស់ទ្រង់គឺជាច្បាប់។ ឥឡូវនេះ អធិរាជត្រូវប្រកាសថាទ្រង់មិនមែនជាអាទិទេពទៀតទេ។ ការប្រកាសរបស់ទ្រង់បានធ្វើឱ្យប្រជាជនជប៉ុនមានការរន្ធត់ដូចដែលជប៉ុនចាញ់សង្គ្រាមដូច្នេះដែរ។ អំណាចរបស់ទ្រង់ក៏ត្រូវបានកាត់បន្ថយយ៉ាងច្រើនផងដែរ។ ក៏ដូចជាមេដឹកនាំនៅចក្រភពអង់គ្លេស អធិរាជក្លាយជានិមិត្តរូបនៃប្រទេសជប៉ុន។

ធម្មនុញ្ញថ្មីបានធានាថា អំណាចនយោបាយពិតប្រាកដនៅក្នុងប្រទេសជប៉ុនគឺស្ថិតនៅក្នុងដៃប្រជាជន។ ប្រជាជនបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងសភាទាំង 2 ថ្នាក់ ដែលគេហៅថាដាយអេត។ ប្រជាពលរដ្ឋទាំងអស់ដែលមានអាយុលើសពី 20 ឆ្នាំ ដោយរួមទាំងស្ត្រីផង មានសិទ្ធិនៅក្នុងការបោះឆ្នោត។ រដ្ឋាភិបាលត្រូវដឹកនាំដោយនាយរដ្ឋមន្ត្រីមួយរូបដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយសំលេងភាគច្រើននៅក្នុងសភា។ មាត្រាមួយនៅក្នុងធម្មនុញ្ញបានលើកម្ពស់ និងការពារមូលដ្ឋានគ្រឹះនៃសិទ្ធិសេរីភាព។ មាត្រាបន្ថែមមួយទៀតនៅក្នុងធម្មនុញ្ញគឺមាត្រា 7 បានលើកឡើងថា ប្រទេសជប៉ុនមិនអាចធ្វើសង្គ្រាមបានទៀតឡើយ។ ពួកគេអាចប្រយុទ្ធដើម្បីតែការពារខ្លួនពីការវាយប្រហារប៉ុណ្ណោះ។

នៅក្នុងខែកញ្ញា ឆ្នាំ 1951 សហរដ្ឋអាមេរិក និងប្រទេស 47 ផ្សេងទៀតបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពផ្លូវការមួយជាមួយប្រទេសជប៉ុន។ សន្ធិសញ្ញានេះបានបញ្ចប់សង្គ្រាមជាផ្លូវការ។ 6 ខែក្រោយមក ការកាន់កាប់របស់សហរដ្ឋអាមេរិកលើប្រទេសជប៉ុនត្រូវបានបញ្ចប់។ ប៉ុន្តែ ដោយសារគ្មានកងទ័ព ជប៉ុនបានយល់ព្រមឱ្យបន្តវត្តមានកងទ័ពសហរដ្ឋអាមេរិកដើម្បីការពារទឹកដីរបស់ពួកគេ។ សហរដ្ឋអាមេរិក និងជប៉ុន ដែលពីមុនជាសត្រូវដ៏ជូរជត់ជាមួយគ្នា ពេលនេះបានក្លាយជាសម្ព័ន្ធមិត្តនឹងគ្នា។

នៅលើពិភពលោកបន្ទាប់ពីសង្គ្រាម សត្រូវមិនត្រឹមតែក្លាយជាសម្ព័ន្ធមិត្តជាមួយគ្នាប៉ុណ្ណោះទេ ប៉ុន្តែ ពេលខ្លះសម្ព័ន្ធមិត្តបានក្លាយជាសត្រូវជាមួយគ្នា។ សង្គ្រាមលោកលើកទី 2 បានផ្លាស់ប្តូរទិដ្ឋភាពនយោបាយនៅអឺរ៉ុប។ សហភាពសូវៀត និងសហរដ្ឋអាមេរិកបានលេចចេញពីសង្គ្រាមក្នុងនាមជាមហាអំណាចពិភពលោកសំខាន់ 2 ។ ពួកគេក៏បានបញ្ចប់សង្គ្រាមក្នុងនាមជាសម្ព័ន្ធមិត្ត។ ប៉ុន្តែ ភ្លាមៗនោះវាច្បាស់ណាស់ថា គោលដៅក្រោយសង្គ្រាមរបស់ពួកគេទាំងពីរមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង។ ភាពខុសគ្នានេះបង្កឱ្យមានជម្លោះដែលនឹងបះពាល់ដល់ពិភពលោកអស់ជាច្រើនទសវត្សរ៍។

# ជំពូក 32៖ ការស្ថាបនាពិភពលោកវិញក្រោយសង្គ្រាម 1945-បច្ចុប្បន្ន

## មេរៀនទី 1៖ សង្គ្រាមត្រជាក់៖ ការប្រឈមដាក់គ្នារវាងមហាអំណាច

### 1. សម្ព័ន្ធមិត្តក្លាយជាសត្រូវ

សម្បីតែនៅមុនពេលដែលសង្គ្រាមលោកលើកទី 2 បញ្ចប់ក៏ដោយ ក្រុមសម្ព័ន្ធមិត្តសហរដ្ឋអាមេរិក ជាមួយសហភាពសូវៀតចាប់ផ្ដើមមានបញ្ហាជាមួយគ្នា។ សហរដ្ឋអាមេរិកមានការមិនសប្បាយចិត្តជាមួយលោក ចូសេព ស្តាលីន មេដឹកនាំសូវៀត ដែលបានចុះកតិកាសញ្ញាមិនឈ្លានពានមួយជាមួយប្រទេសអាឡឺម៉ង់នៅក្នុងឆ្នាំ 1939 ។ ក្រោយមក លោកស្តាលីនបានស្តីបន្ទោសដល់ក្រុមសម្ព័ន្ធចំពោះការឈ្លានពានតំបន់ដែលអាឡឺម៉ង់កាន់កាប់នៅអឺរ៉ុបនៅមុនឆ្នាំ 1944 ។ ជម្រុញដោយបញ្ហាទាំងអស់នេះ និងភាពមិនចុះសម្រុងគ្នាផ្សេងៗទៀត ក្រុមសម្ព័ន្ធមិត្តទាំងពីរនេះចាប់ផ្ដើមមានគោលដៅប្រឆាំងគ្នា។

សន្និសិទទីក្រុងយ៉ាលតា-ផែនការក្រោយសង្គ្រាមមួយ៖ សង្គ្រាមមិនទាន់ត្រូវបានបញ្ចប់ឡើយនៅត្រឹមខែកុម្ភៈ ឆ្នាំ 1945 ។ ប៉ុន្តែ មេដឹកនាំរបស់សហរដ្ឋអាមេរិក, ចក្រភពអង់គ្លេស, និងសហភាពសូវៀតបានជួបប្រជុំគ្នារមណីដ្ឋានយ៉ាលតាដែលស្ថិតនៅសមុទ្រខ្មៅសូវៀត។ នៅទីនោះ មេដឹកនាំទាំងអស់នេះបានយល់ស្របនៅក្នុងការបែងចែកប្រទេសអាឡឺម៉ង់ទៅជាតំបន់ៗនៃការគ្រប់គ្រងរបស់កងកម្លាំងសម្ព័ន្ធមិត្ត។ ប្រទេសអាឡឺម៉ង់ក៏តម្រូវឱ្យបង់ថ្លៃសំណងដោយសហភាពសូវៀតសម្រាប់ការបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិ។ ស្តាលីនបានយល់ស្របនៅក្នុងការចូលរួមសង្គ្រាមប្រឆាំងជាមួយប្រទេសជប៉ុន។ លោកក៏បានសន្យាថា អឺរ៉ុបខាងកើតនឹងមានការបោះឆ្នោតដោយសេរី។ អ្នកដែលមានការសង្ស័យច្រើនលោកវីនស្តុន ឆឺឈីល បានទស្សទាយថា ស្តាលីននឹងរក្សាការអះអាងរបស់លោកនៅពេលណាដែលពួកអឺរ៉ុបខាងកើតអនុសោមតាម "គោលនយោបាយមិត្តភាពមួយចំពោះរុស្ស៊ី"។

ការបង្កើតអង្គការសហប្រជាជាតិ៖ នៅក្នុងខែមិថុនា ឆ្នាំ 1945 សហរដ្ឋអាមេរិក និងសហភាពសូវៀតជាបណ្ដោះអាសន្នបានទុកភាពខ្វែងគំនិតគ្នាមួយឡែក។ ពួកគេជាមួយប្រទេស 48 ផ្សេងទៀតបានចូលរួមនៅក្នុងការបង្កើតអង្គការសហប្រជាជាតិ។ អង្គការអន្តរជាតិនេះមានគោលដៅនៅក្នុងការការពារប្រទេសដែលជាសមាជិកពីការឈ្លានពាននានា។ មូលដ្ឋានរបស់អង្គការត្រូវស្ថិតនៅទីក្រុងញូវយ៉ក។

ធម្មនុញ្ញសម្រាប់អង្គការថែរក្សាសន្តិភាពថ្មីមួយនេះ បង្កើតបានស្ថាប័នធំមួយដែលគេហៅថា មហាសន្និបាទ។ នៅទៅនោះ សមាជិករបស់អង្គការសហប្រជាជាតិនីមួយៗអាចធ្វើសេចក្ដីសម្រេចចិត្តតាមរយៈការបោះឆ្នោតចំពោះដំណោះស្រាយបញ្ហានានា។ ស្ថាប័នមួយដែលមានសមាជិក 11 ប្រទេស ដែលគេហៅថា ក្រុមប្រឹក្សាសន្តិសុខមានអំណាចពិតប្រាកដនៅក្នុងការស៊ើបអង្កេត និងដោះស្រាយបញ្ហានានា។ ស្ថាប័ននេះមានសមាជិកអចិន្ត្រៃចំនួន 5 ដែលក្នុងនោះរួមមាន ចក្រភពអង់គ្លេស, ចិន, បារាំង, សហរដ្ឋអាមេរិក, និងសហភាពសូវៀត។ សមាជិកអចិន្ត្រៃនីមួយៗអាចបោះឆ្នោតបដិសេធ (វេតូ) ចំពោះអន្តរាគមន៍របស់ក្រុមប្រឹក្សាសន្តិសុខ។ ការផ្តល់សិទ្ធិនៅក្នុង

បដិសេធនេះមានគោលដៅនៅក្នុងការការពារសមាជិកនៅក្នុងក្រុមប្រឹក្សាធ្វើការបោះឆ្នោតគាំទ្រជាលក្ខណៈប្លុក ដើម្បីប្រឆាំងជាមួយសមាជិកផ្សេងទៀត។

ភាគខុសគ្នានៃគោលដៅរបស់សហរដ្ឋអាមេរិក និងសហភាពសូវៀត៖ បើទោះបីជាមានការព្រមព្រៀងគ្នានៅក្នុងសន្និសិទទីក្រុងយ៉ាលតា និងវត្តមានរបស់ពួកគេនៅក្នុងក្រុមប្រឹក្សាសន្តិសុខក៏ដោយ ក៏សហរដ្ឋអាមេរិក និងសហភាពសូវៀតបានងាកចេញពីគ្នាយ៉ាងខ្លាំងបន្ទាប់ពីសង្គ្រាម។ សង្គ្រាមបានជះឥទ្ធិពលដល់ប្រទេសទាំងពីរនេះនៅក្នុងវិធីផ្សេងគ្នា។ សហរដ្ឋអាមេរិក ដែលជាប្រទេសដែលមានជាងគេ និងជាប្រទេសដែលមានអំណាចជាគេនៅលើពិភពលោក រងគ្រោះដោយកងទ័ព 400,000 ស្លាប់។ ប៉ុន្តែ ទីក្រុង និងរោងចក្រនានារបស់ពួកគេនៅដំណើរការដដែល។ សហភាពសូវៀតមានអ្នកស្លាប់យ៉ាងហោចណាស់ 50 ដងច្រើនជាងសហរដ្ឋអាមេរិក។ ម្នាក់ក្នុងចំណោមប្រជាជនសូវៀតបួននាក់បានរងរបួស ឬសម្លាប់។ ជាមួយគ្នានេះដែរ ទីក្រុងជាច្រើនរបស់សូវៀតត្រូវបានកម្ទេច។ ស្ថានភាពខុសគ្នាទាំងនេះ ក៏ដូចជាភាពខុសគ្នាផ្នែកខាងនយោបាយ និងសេដ្ឋកិច្ច បានជះឥទ្ធិពលដែលគោលដៅរបស់ប្រទេសទាំងពីរបន្ទាប់ពីសង្គ្រាម។

## 2. ទាំខននដែករបស់អឺរ៉ុបខាងកើត

គោលដៅសំខាន់បំផុតមួយរបស់សហភាពសូវៀត គឺការបង្កើតខែលមួយដើម្បីការពារពួកគេពីការឈ្លានពានពីពួកលោកខាងលិច។ ប្រវត្តិសាស្ត្ររាប់សតវត្សរ៍បានបង្រៀនសូវៀតឱ្យមានការភ័យខ្លាចពីការឈ្លានពាន។ ដោយសារតែមានកង្វះខាតព្រំដែនធម្មជាតិនៅភាគខាងលិច រុស្ស៊ីបានក្លាយជាជនរងគ្រោះដោយសារប្រជិតខាងរបស់ខ្លួន។ នៅក្នុងសតវត្សរ៍ទី 17 ពួកប៉ូឡូញបានដណ្តើមកាន់កាប់ទីក្រុងឡាំង។ អំឡុងពេលប៉ុន្មានសតវត្សរ៍ក្រោយមក ពួកស៊ុយអែតបានធ្វើការវាយប្រហារលើពួកគេ។ ណាប៉ូឡេអុង ឈ្លានពានទីក្រុងម៉ូស្គូនៅក្នុងឆ្នាំ 1812។ ប្រទេសអាឡឺម៉ង់បានឈ្លានពានប្រទេសរុស្ស៊ីនៅអំឡុងសង្គ្រាមលោកលើកទី 1 និងទី 2។

សហភាពសូវៀតស្ថាបនាតំបន់ទ្រនាប់មួយ៖ ដូចដែលសង្គ្រាមលោកលើកទី 2 ជិតនឹងបញ្ចប់នាពេលឆាប់ៗ កងទ័ពរបស់សហភាពសូវៀតបានរុញច្រានពួកណាស៊ីសចេញពីអឺរ៉ុបខាងកើត។ នៅពេលដែលសង្គ្រាមបានបញ្ចប់ កងទ័ពទាំងអស់នេះបានគ្រប់គ្រងលើប្រទេសមួយចំនួនដែលស្ថិតនៅតាមបណ្តោយព្រំដែនភាពខាងលិចរបស់សហភាពសូវៀត។ ស្តាលីនចាត់ទុកប្រទេសទាំងអស់នេះគឺជាតំបន់ទ្រនាប់ ឬក៏ជាជញ្ជាំងចំបាច់មួយសម្រាប់ការពារសូវៀត។ លោកបានបំភ្លេចចោលនូវកិច្ចព្រមព្រៀងទីក្រុងយ៉ាលតា និងបានលើកបង្កើត និងការពាររដ្ឋាភិបាលកុំម្មុយនីស្តនៅក្នុងប្រទេសអាលបានី, ប៊ុលហ្គារី, ហុងហ្គារី, ឆេកូស្លូវ៉ាគី, រ៉ូម៉ានី, ប៉ូឡូញ, និងយេហ្គូស្លាវី។

សមភាគីរបស់សហភាពសូវៀតនៅយ៉ាលតា ប្រធានាធិបតីហ្វ្រែងគ្លីន ដេឡាណូ រូសេវេលថ៍ បានស្លាប់នៅថ្ងៃទី 12 ខែមេសា ឆ្នាំ 1945។ សម្រាប់អ្នកដែលបន្តដំណែងពីលោក រូសេវេលថ៍ គឺលោក ហារី អេស. ទ្រូម៉ាន់ ការបដិសេធរបស់ស្តាលីននៅក្នុងការអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសេរីនៅអឺរ៉ុបខាងកើត គឺជាការរំលោភបំពានយ៉ាងពិប្រាកដទៅលើសិទ្ធិរបស់ប្រទេសជាតិទាំងអស់នោះ។ ប្រធានាធិបតីទ្រូម៉ាន់, ស្តាលីន, និងឆឺឈីលបានជួបប្រជុំគ្នានៅទីក្រុងផតដាំ ប្រទេសអាឡឺម៉ង់នៅក្នុងខែកក្កដា ឆ្នាំ 1945។ នៅទីនោះ លោកទ្រូម៉ាន់បានជម្រុញឱ្យ

ស្តាលីនអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសេរីនៅអឺរ៉ុបខាងកើត។ ពេលនោះមេដឹកនាំសូវៀតបានបដិសេធ។ នៅក្នុងការថ្លែងសន្ទរកថាមួយនៅដើមឆ្នាំ 1946 ស្តាលីនបានប្រកាសថា កុំម្មុយនីស្ត និងមូលធននិយមមិនអាចលេចចេញនៅក្នុងពិភពតែមួយទេ។

វាំងននដែកមួយបែងចែកខាងកើត និងខាងលិច៖ អឺរ៉ុបត្រូវបានបែងចែកទៅជាអឺរ៉ុបខាងកើត និងខាងលិច។ ប្រទេសអាឡឺម៉ង់ត្រូវបានបែងចែកទៅជាពីរផ្នែក។ សហភាពសូវៀតត្រួតត្រាមួយផ្នែកភាគខាងកើត ដោយក្នុងនោះរួមមានទាំងរដ្ឋធានីប៊ែកឡាំពាក់កណ្តាលផងដែរ។ ស្ថិតនៅក្រោមរដ្ឋាភិបាលកុំម្មុយនីស្តមួយ អាឡឺម៉ង់ខាងកើតត្រូវបានដាក់ឈ្មោះថា សាធារណរដ្ឋប្រជាធិបតេយ្យអាឡឺម៉ង់។ តំបន់ភាគខាងលិចបានក្លាយជាសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់នៅក្នុងឆ្នាំ 1949 ។ លោកវីនស្តុន ឆឺឈីល បានពិពណ៌នាការបែងចែកអឺរ៉ុបនេះថា៖ "វាំងននដែក" តំណាងឱ្យការបែងចែកអឺរ៉ុបទៅជាអឺរ៉ុបខាងលិចដែលភាគច្រើនប្រកាន់របបប្រជាធិបតេយ្យ និងអឺរ៉ុបខាងកើតដែលប្រកាន់របបកុំម្មុយនីស្ត។

### 3. សហរដ្ឋអាមេរិកព្យាយាមនៅក្នុងការហ៊ុំព័ទ្ធសហភាពសូវៀត

ទំនាក់ទំនងអាមេរិក-សូវៀតកាន់តែបន្តធ្លាក់ចុះនៅក្នុងឆ្នាំ 1946 និង 1947 ។ ដោយមានការព្រួយបារម្ភកាន់តែកើនឡើងខ្លាំង សហរដ្ឋអាមេរិកបានព្យាយាមនៅក្នុងការទប់ស្កាត់ការកើនឡើងនៃការគំរាមកំហែងរបស់សូវៀតចំពោះអឺរ៉ុបខាងកើត។ ប្រធានាធិបតីទ្រូម៉ាន់បានបង្កើតគោលនយោបាយការបរទេសមួយដែលមានឈ្មោះថា ការហ៊ុំព័ទ្ធ ។ វាគឺជាគោលនយោបាយមួយមានគោលដៅនៅក្នុងការរាំងខ្ទប់ឥទ្ធពលរបស់សូវៀត និងបញ្ឈប់ការពង្រីកលិទ្ធិកុំម្មុយនីស្ត។ គោលនយោបាយហ៊ុំព័ទ្ធនេះរួមមាន ការបង្កើតសម្ព័ន្ធមិត្ត និងជួយដល់ប្រទេសទន់ខ្សោយនៅក្នុងការប្រឆាំងវត្តមានរបស់សូវៀត។

គោលការណ៍ទ្រូម៉ាន់៖ នៅក្នុងការថ្លែងសន្ទរកថាមួយដើម្បីស្នើឱ្យសភាផ្តល់ជំនួយអន្តរជាតិដល់ប្រទេសទួគី និងក្រិក ប្រធានាធិបតីទ្រូម៉ាន់បានបង្ហាញពីភាពផ្ទុយគ្នារវាងប្រជាធិបតេយ្យ និងកុំម្មុយនីស្ត។ ការគាំទ្ររបស់ទ្រូម៉ាន់ចំពោះប្រទេសដែលបដិសេធលិទ្ធិកុំម្មុយនីស្តត្រូវបានគេហៅថា គោលការណ៍ទ្រូម៉ាន់។ វាបណ្តាលឱ្យមានភាពចម្រូងចម្រាស់យ៉ាងខ្លាំង។ ក្រុមអ្នកប្រឆាំងមួយចំនួនបានប្រឆាំងចំពោះកិច្ចអន្តរាគមន៍របស់អាមេរិកនៅក្នុងកិច្ចការរបស់ប្រទេសដ៏ទៃ។ អ្នកមួយចំនួនទៀតទទូចថា សហរដ្ឋអាមេរិកមិនអាចមានលទ្ធភាពនៅក្នុងការប្រឆាំងជាសកលមួយជាមួយនឹងកុំម្មុយនីស្តឡើយ។ ប៉ុន្តែ សភាយ៉ាងឆាប់រហ័សបានយល់ព្រមនៅក្នុងការផ្តល់ប្រាក់ជំនួយច្រើនជាង 400 លានដុល្លាដល់ប្រទេសទួគី និងក្រិក។

ផែនការម៉ាសាល៖ ប្រទេសភាគច្រើននៅអឺរ៉ុបខាងលិចបានក្លាយជាផះផង់បន្ទាប់ពីសង្គ្រាម។ ហើយពួកគេក៏ជួបភាពចលាចលផ្នែកខាងសេដ្ឋកិច្ចផងដែរ ជាពិសេសកង្វះខាតការងារ និងចំណីអាហារ។ នៅក្នុងឆ្នាំ 1947 រដ្ឋលេខាសហរដ្ឋអាមេរិកលោក ចច ម៉ាសាល បានស្នើឱ្យសហរដ្ឋអាមេរិកផ្តល់ជំនួយដល់ប្រទេសអឺរ៉ុបនានាដែលមានតម្រូវការ។ កម្មវិធីជំនួយនេះ ត្រូវបានគេហៅថា ផែនការម៉ាសាល នឹងផ្តល់នូវចំណីអាហារ, គ្រឿងម៉ាស៊ីន, និងសម្ភារៈផ្សេងៗទៀតដើម្បីស្តាបនាអឺរ៉ុបខាងលិចឡើងវិញ។ ដូចដែលសភាកំពុងពិភាក្សាអំពីកម្មវិធីជំនួយដែល

មានទំហំទឹកប្រាក់ 12.5 ពាន់លានដុល្លានេះនៅក្នុងឆ្នាំ 1948 ពួកកុំម្មុយនីស្តបានដណ្តើមកាន់កាប់អំណាចនៅក្នុងប្រទេសឆេកូស្លូវ៉ាគី។ ភ្លាមៗនោះសភាបានបោះឆ្នោតគាំទ្រកម្មវិធីជំនួយនេះ។ ផែនការនេះទទួលជោគជ័យយ៉ាងអស្ចារ្យ។ សូម្បីតែប្រទេសកុំម្មុយនីស្តយេហ្គូស្លាវីក៏ទទួលបានជំនួយនេះផងដែរបន្ទាប់ពីពួកគេបានបំបែកខ្លួនចេញពីឥទ្ធិពលរបស់សូវៀត។

ការដឹកជញ្ជូនតាមផ្លូវអាកាសទៅកាន់ទីក្រុងប៊ែកឡាំង៖ ខណៈពេលប្រទេសអឺរ៉ុបនានាកំពង់ស្តាបនាឡើងវិញ សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តរបស់ខ្លួនបានបះទង្គិចគ្នាជាមួយសហភាពសូវៀតលើបញ្ហាប្រទេសអាឡឺម៉ង់។ សូវៀតចង់រក្សាអតីតសត្រូវរបស់ពួកគេឱ្យនៅខ្សោយ និងបែកខ្ញែក។ ប៉ុន្តែ នៅក្នុងឆ្នាំ 1948 ប្រទេសបារាំង, អង់គ្លេស, និងសហរដ្ឋអាមេរិកបានសម្រេចនៅក្នុងការដកកងទ័ពរបស់ពួកគេចេញពីអាឡឺម៉ង់ និងបានអនុញ្ញាតឱ្យតំបន់ដែលពួកគេកាន់កាប់បង្កើតជាប្រទេសជាតិមួយ។ សហភាពសូវៀតបានឆ្លើយតបដោយហ៊ុំព័ទ្ធទីក្រុងប៊ែកឡាំខាងលិចធ្វើជាចំណាត់ខ្លាំង។

បើទោះបីជាទីក្រុងប៊ែកឡាំងស្ថិតនៅក្នុងតំបន់ដែលសូវៀតកាន់កាប់នៅអាឡឺម៉ង់ក៏ដោយ ទីក្រុងនេះក៏ដូចជាប្រទេសអាឡឺម៉ង់ដែរ ត្រូវបានបែងចែកជា 4 តំបន់។ សហភាពសូវៀតបានកាត់ផ្តាច់ផ្លូវហាយវេ, ទឹក, និងផ្លូវរថភ្លើងចូលទៅកាន់តំបន់ភាគខាងលិចទីក្រុងប៊ែកឡាំង។ ទីក្រុងប៊ែកឡាំងភាគខាងលិចពេលនោះប្រឈមជាមួយនឹងគ្រោះអត់ឃ្លាន។ ស្តាលីនបានភ្នាល់ថា ពួកសម្ព័ន្ធមិត្តនឹងបោះបង់ទីក្រុងប៊ែកឡាំងខាងលិច ឬបោះបង់គំនិតរបស់ពួកគេនៅក្នុងការបង្រួបបង្រួបប្រទេសអាឡឺម៉ង់។ ប៉ុន្តែ សហរដ្ឋអាមេរិក និងអង់គ្លេសបានដឹកជញ្ជូនស្បៀងអាហារ និងសម្ភារៈផ្គត់ផ្គង់នានាតាមយន្តហោះទៅកាន់ទីក្រុងប៊ែកឡាំងខាងលិចអស់រយៈពេលជិត 11 ខែ។ នៅក្នុងខែឧសភា ឆ្នាំ 1949 សហភាពសូវៀតបានយល់ព្រមចុះចាញ់ និងបានដកចេញនូវការហ៊ុំព័ទ្ធ។

## 4. សង្គ្រាមត្រជាក់បែងចែកពិភពលោក

ជម្លោះទាំងអស់នេះគឺជាសញ្ញាណនៃការចាប់ផ្តើមឡើងនៃសង្គ្រាមត្រជាក់រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត។ សង្គ្រាមត្រជាក់មួយគឺជាការប្រឈមមុខដាក់គ្នាមួយចំពោះភាគខុសគ្នាផ្នែកខាងនយោបាយ តាមរយៈមធ្យោបាយយោធា និងសង្គ្រាមរយៈពេលខ្លី។ ចាប់ផ្តើមឡើងនៅក្នុងឆ្នាំ 1949 មហាអំណាចទាំងពីរបានប្រើប្រាស់ចារកិច្ច, ការឃោសនា, ការទូត, និងប្រតិបត្តិការសម្ងាត់នានានៅក្នុងការប្រឈមមុខដាក់គ្នាទៅវិញទៅមក។ ភាគច្រើនប្រទេសទាំងឡាយនៅក្នុងពិភពលោកបានចូលជាសម្ព័ន្ធមិត្តរបស់ភាគីនីមួយៗ។ តាមពិតទៅ រហូតដល់ពេលដែលសហភាពសូវៀតបែកបាក់នៅក្នុងឆ្នាំ 1991 សង្គ្រាមត្រជាក់មិនត្រឹមតែទាក់ទងតែជាមួយគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក និងសហភាពសូវៀតប៉ុណ្ណោះទេ ប៉ុន្តែវាបានជះឥទ្ធិពលដល់ក្រុមសម្ព័ន្ធមិត្តទាំងសងខាងផងដែរ។

មហាអំណាចបង្កើតសម្ព័ន្ធមិត្តប្រឆាំងគ្នា៖ ការហ៊ុំព័ទ្ធទីក្រុងប៊ែកឡាំងបានបង្កើនភាពភ័យខ្លាចដល់អឺរ៉ុបខាងលិចចំពោះការឈ្លានពានរបស់សូវៀត។ ជាលទ្ធផល នៅក្នុងឆ្នាំ 1949 ប្រទេសនៅអឺរ៉ុបខាងលិចចំនួន 10 បានចូលរួមជាមួយសហរដ្ឋអាមេរិក និងប្រទេសកាណាដា បង្កើតសម្ព័ន្ធមិត្តយោធាមួយ។ សម្ព័ន្ធមិត្តយោធានេះត្រូវ

បានគេហៅថា អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង(ណាតូ)។ ការវាយប្រហារណាមួយមកលើប្រទេសជាសមាជិករបស់ណាតូ នឹងជួបជាមួយការឆ្លើយតបយោធារបស់ប្រទេសជាសមាជិកទាំងអស់។

សហភាពសូវៀតបានយល់ឃើញថាណាតូគឺជាការគំរាមកំហែងមួយ និងបានបង្កើតសម្ព័ន្ធមិត្តមួយផ្ទាល់ខ្លួននៅក្នុងឆ្នាំ 1955 ។ សម្ព័ន្ធមិត្តយោធានេះត្រូវបានគេហៅថា កតិកាសញ្ញាវ៉ាសូវី ដោយក្នុងនោះរួមមានសហភាពសូវៀត, អាឡឺម៉ង់ខាងកើត, ឆេកូស្លូវ៉ាគី, ប៉ូឡូញ, ហុងគ្រី, រ៉ូម៉ានី, បុលហ្គារី, និងអាល់បានី។ នៅក្នុងឆ្នាំ 1961 អាឡឺម៉ង់ខាងកើតបានស្ថាបនាជញ្ជាំងមួយដើម្បីបែងចែកទីក្រុងប៊ែកឡាំងខាងកើត និងខាងលិច។ ជញ្ជាំងទីក្រុងប៊ែកឡាំងគឺជានិមិត្តសញ្ញាមួយដែលបង្ហាញពីការបែងចែកពិភពលោកទៅជាគូរប្រជែងគ្នា។ ប៉ុន្តែ មិនមែនគ្រប់ប្រទេសទាំងអស់សុទ្ធតែចូលរួមជាមួយសម្ព័ន្ធមិត្តថ្មីនេះឡើយ។ ប្រទេសមួយចំនួន ដូចជាប្រទេសឥណ្ឌាជាដើម សម្រេចនៅក្នុងការជ្រើសរើសយកការមិនចូលរួមជាមួយសម្ព័ន្ធមិត្តមួយណាឡើយ។ ហើយប្រទេសចិនដែលជាប្រទេសកុំម្មុយនីស្តដែលធំបំផុតចាប់ផ្តើមបាត់បង់ទំនុកចិត្តចំពោះសហភាពសូវៀត។ ប្រទេសនេះនៅតែរក្សាការមិនចូលបក្សសម្ព័ន្ធ។

ការគំរាមកំហែងនៃសង្គ្រាមនុយក្លេអ៊ែរ៖ ដូចដែលក្រុមសម្ព័ន្ធមិត្តទាំងនេះត្រូវបានបង្កើតឡើង សង្គ្រាមត្រជាក់បានកើនឡើងនូវការគំរាមកំហែងចំពោះការកម្ទេចពិភពលោក។ សហរដ្ឋអាមេរិកមានគ្រាប់បែកអាតូមិចរួចទៅហើយ។ នៅក្នុងឆ្នាំ 1949 សហភាពសូវៀតបានបំផ្ទុះសាកល្បងនូវគ្រាប់បែកអាតូមិចផ្ទាល់របស់ពួកគេ។ ប្រធានាធិបតីទ្រូម៉ាន់បានកំណត់នៅក្នុងការអភិវឌ្ឍ សព្វាវុធកាន់តែប្រល័យជាមុនមួយមុនពេលដែលសូវៀតធ្វើវាបានមុន។ លោកបានអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍអាវុធនុយក្លេអ៊ែរនៅក្នុងឆ្នាំ 1950 ។

គ្រាប់បែកអ៊ីដ្រូសែនអាចនឹងមានកម្លាំងខ្លាំងជាងគ្រាប់បែកអាតូមិចរាប់ពាន់ដង។ កម្លាំងរបស់វាបានមកពីការលាយបញ្ចូលគ្នានៃអាតូមនានា ជាជាងការបំបែកអាតូមដូចនៅក្នុងគ្រាប់បែកអាតូមិក។ នៅក្នុងឆ្នាំ 1952 សហរដ្ឋអាមេរិកបានសាកល្បងគ្រាប់បែកអ៊ីដ្រូសែនជាលើកដំបូង។ សហភាពសូវៀតបានសាកល្បងគ្រាប់បែករបស់ពួកគេនៅក្នុងឆ្នាំ 1953 ។

ដ្វៃត៍ អេសិនហូវ័រ បានក្លាយជាប្រធាធិបតីអាមេរិកនៅក្នុងឆ្នាំ 1953 ។ លោកបានតែងតាំងអ្នកប្រឆាំងកុំម្មុយនីស្តយ៉ាងម៉ឺងម៉ាត់ ចន ហ្វសធឺ ឌូលិស ជារដ្ឋលេខារបស់លោក។ លោក ឌូលិស បានគំរាមថា ប្រសិនបើសហភាពសូវៀត ឬប្រទេសដែលគាំទ្រគេវាយប្រហារលើអត្ថប្រយោជន៍របស់សហរដ្ឋអាមេរិក "សហរដ្ឋអាមេរិកនឹងសងសឹកភ្លាមៗ តាមមធ្យោបាយ និងកន្លែងដែលយើងជ្រើសរើស"។ គំនិតនេះបាននាំទៅដល់គែមនៃសង្គ្រាម ដែលគេស្គាល់ថា គោលនយោបាយប្រកបដោយគ្រោះថ្នាក់ដើម្បីធានាសុវត្ថិភាព។ គោលនយោបាយនេះតម្រូវឱ្យមានអាវុធនុយក្លេអ៊ែ និងយន្តហោះដឹកវាយកទៅទម្លាក់ដែលអាចទុកចិត្តបាន។ ដូច្នេះ សហរដ្ឋអាមេរិកបានពង្រឹងកងទ័ពអាកាសរបស់ពួកគេ និងចាប់ផ្តើមសាងសង់ឃ្លាំងសម្រាប់ដាក់សព្វាវុធនុយក្លេអ៊ែរ។ សហភាពសូវៀតឆ្លើយតបជាមួយការស្ថាបនាវិស័យយោធារបស់ពួកគេ ដែលជាការប្រណាំងប្រជែងវិស័យយោធាមួយដែលមានរយៈពេល 4 ទសវត្សរ៍។

សង្គ្រាមត្រជាក់នៅលើមេឃ៖ សង្គ្រាមត្រជាក់ក៏បានជះឥទ្ធិពលលើកម្មវិធីវិទ្យាសាស្ត្រ និងការអប់រំរបស់ប្រទេសទាំងពីរផងដែរ។ នៅក្នុងខែសីហា ឆ្នាំ 1957 សហភាពសូវៀតបានប្រកាសពីការអភិវឌ្ឍន៍គ្រាប់រ៉ុក្កែតមួយដែលអាចធ្វើដំណើរបានរយៈចម្ងាយឆ្ងាយ ដែលជាគ្រាប់មីសីលឆ្លងទ្វីប។ នៅថ្ងៃទី 4 ខែតុលា សហភាពសូវៀតបានប្រើប្រាស់គ្រាប់មីលីសឆ្លងទ្វីបដើម្បីបញ្ជូន ស្ពូតនីក ដែលជាផ្កាយរណបគ្មានមនុស្សបែកដំបូង ទៅក្រៅដែនទំនាញផែនដី។ អាមេរិកយល់ថាពួកគេហាក់ដូចជានៅពីក្រោយសហភាពសូវៀតផ្នែកខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយរដ្ឋាភិបាលបានទម្លាក់លុយចូលទៅក្នុងការអប់រំវិទ្យាសាស្ត្រ។ នៅក្នុងឆ្នាំ 1958 សហរដ្ឋអាមេរិកបានបាញ់បង្ហោះផ្កាយរណបរបស់គេ។

នៅក្នុងឆ្នាំ 1960 ជាថ្មីម្តងទៀតមេឃបានក្លាយជាសង្វៀនសម្រាប់ការប្រកួតប្រជែងរបស់មហាអំណាចទាំងពីរ។ កាលពី 5 ឆ្នាំមុន អេសិនហូវ័រ បានស្នើថា សហរដ្ឋអាមេរិក និងសហភាពសូវៀតអាចនឹងហោះហើយលើដែនដីគ្នាទៅវិញទៅមកដើម្បីត្រួតពិនិត្យមើលការវាយប្រហារនុយក្លេអ៊ែរ ដោយមិនបានត្រៀមទុកជាមុនណាមួយ។ សហភាពសូវៀតបានបដិសេធ។ នៅក្នុងការឆ្លើយតប ទីភ្នាក់ងារស៊ើបការណ៍កណ្តាលរបស់សហរដ្ឋអាមេរិកបានចាប់ផ្តើមហោះហើយក្នុងរយៈកម្ពស់ខ្ពស់មួយលើទឹកដីសហភាពសូវៀតដើម្បីស៊ើបការណ៍ ដោយប្រើប្រាស់យន្តហោះ យូ-2 ។ នៅក្នុងខែឧសភា ឆ្នាំ 1960 សហភាពសូវៀតបានបាញ់ទម្លាក់យន្តហោះ យូ-2 មួយគ្រឿង ហើយអ្នកបើកយន្តហោះ ប្រាង់ស៊ីស ហ្គារី ផារ៉ វ ត្រូវបានចាប់ខ្លួន។ ឧប្បត្តិហេតុយន្តហោះ យូ-2 នេះបានបង្កើនជម្លោះនៅក្នុងសង្គ្រាមត្រជាក់។

ខណៈពេលដែលពួកកុំម្មុយនីស្តនៅសូវៀតកំពុងប្រឆាំងជាមួយសហរដ្ឋអាមេរិក ពួកកុំម្មុយនីស្តនៅក្នុងប្រទេសចិនបានវាយប្រយុទ្ធនៅក្នុងសង្គ្រាមស៊ីវិលមួយដើម្បីគ្រប់គ្រងប្រទេស។

# មេរៀនទី 2 ៖ កុំម្មុយនីស្តឡើងកាន់អំណាចនៅក្នុងប្រទេសចិន

## 1. ពួកកុំម្មុយនីស្តទល់ជាមួយពួកជាតិនិយម

ដូចដែលអ្នកបានអាចនៅក្នុងជំពូក 30 សង្គ្រាមស៊ីវិលដ៏ជូរចត់មួយបានកើតមានឡើងរវាងក្រុមអ្នកជាតិនិយមជាមួយនិងពួកកុំម្មុយនីស្តនៅពេលដែលជប៉ុនឈ្លានពានប្រទេសចិននៅក្នុងឆ្នាំ 1937 ។ នៅអំឡុងសង្គ្រាមលោកលើកទី 2 គូរទំនាស់នយោបាយបានបង្រួបបង្រួមគ្នាជាបណ្តោះអាសន្នដើម្បីប្រយុទ្ធជាមួយជប៉ុន។ ប៉ុន្តែពួកគេបន្តប្រជែងគ្នាដើម្បីកាន់អំណាចនៅក្នុងប្រទេសចិន។

សង្គ្រាមលោកលើកទី 2 នៅក្នុងប្រទេសចិន៖ ស្ថិតនៅក្រោមការដឹកនាំរបស់ម៉ៅ សេងទុង ពួកកុំម្មុយនីស្តមានមូលដ្ឋាននៅប្រទេសចិនភាគពាយព្យ។ នៅទីនោះ ពួកគេបានកេណ្ឌប្រជាកសិករដើម្បីធ្វើសង្គ្រាមទ័ពព្រៃ (សង្គ្រាមឈ្លប) ជាមួយពួកជប៉ុននៅភាគឦសាន។ ដោយសារការប្រឹងប្រែរបស់ពួកគេនៅក្នុងការលើកកម្ពស់អក្ខរកម្ម និងបង្កើនទិន្នផលចំណីអាហារ ពួកកុំម្មុយនីស្តទទួលបានភក្តីភាពពីសំណាក់ប្រជាកសិករ។ ត្រឹមឆ្នាំ 1945 ពួកគេត្រួត្រាចិនភាគជើងស្ទើរតែទាំងស្រុង។

នៅខណៈពេលនោះ កងកម្លាំងរបស់ពួកជាតិនិយមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជាង កាយចៀកគ្របដណ្តប់នៅចិនភាគនិរតី។ ដោយសារមានការពារការឈ្លានពានរបស់ជប៉ុនដោយជួរភ្នំដ៏រឹងមាំ លោកជាងបានប្រមូលកម្លាំងទ័ពបានចំនួន 2.5 លាននាក់។ ចាប់ពីឆ្នាំ 1942 ដល់ 1945 សហរដ្ឋអាមេរិក បានបញ្ជូនជំនួយដល់ពួកជាតិនិយមប្រមាណ 1.5 ពាន់លានដុល្លា ដើម្បីវាយប្រយុទ្ធជាមួយជប៉ុន។ ប៉ុន្តែ ជំនួសឱ្យការជួយដល់វិស័យយោធា ការផ្គត់ផ្គង់សម្ភារៈ និងលុយទាំងអស់នេះជាញឹកញាប់ធ្លាក់ទៅក្នុងដៃរបស់មន្ត្រីពុករលួយមួយចំនួន។ កងទ័ពរបស់ជាងធ្វើការប្រយុទ្ធតិចតួចនៅក្នុងសមរភូមិជាមួយជប៉ុន។ ជំនួសមកវិញ កងទ័ពពួកជាតិនិយមរក្សាទុកកម្លាំងរបស់ពួកគេសម្រាប់ត្រៀមប្រយុទ្ធជាមួយកងទ័ពក្រហមរបស់ម៉ៅ។ បន្ទាប់ពីប្រទេសជប៉ុនចុះចាញ់សង្គ្រាម ពួកជាតិយម និងពួកកុំម្មុយនីស្តបានបន្តការប្រយុទ្ធគ្នា។

សង្គ្រាមស៊ីវិញបន្តឡើងវិញ៖ សង្គ្រាមស៊ីវិញចាប់ផ្តើមសារជាថ្មីឡើងវិញនេះមានរយៈពេលចាប់ពីឆ្នាំ 1946 រហូតដល់ឆ្នាំ 1949 ។ ដំបូង ពួកជាតិនិយមមានប្រៀបជាង។ កងទ័ពរបស់ពួកគេមានចំនួនច្រើនជាងកងទ័ពរបស់ពួកកុំម្មុយនីស្តរហូតដល់ទៅ 3 ដង។ ហើយសហរដ្ឋអាមេរិកនៅតែបន្តគាំទ្រពួកគេ ដោយបានផ្តល់ជំនួយជិត 2 ពាន់លានដុល្លា។ ប៉ុន្តែ កងកម្លាំងរបស់ពួកជាតិនិយមបានធ្វើការតិចតួចដើម្បីទទួលបានការគាំទ្រពីសាធារណជន។ ជាមួយការដួលរលំនៃសេដ្ឋកិច្ចរបស់ប្រទេសចិន កងកម្លាំងរបស់ពួកជាតិនិយមរាប់ពាន់នាក់បានចុះចូលជាមួយពួកកុំម្មុយនីស្ត។ នៅនិទាឃរដូវ ឆ្នាំ 1949 ទីក្រុងធំៗរបស់ប្រទេសចិនបានធ្លាក់ក្នុងដៃរបស់កងទ័ពក្រហមដែលទទួលបានការហ្វឹកហ្វឺនយ៉ាងល្អ។ កងទ័ពរបស់ម៉ៅក៏មានការរីករាយជាមួយនិងការសន្យារបស់ម៉ៅនៅក្នុងការប្រគល់ដីត្រឡប់ទៅឱ្យប្រជាកសិករវិញ។ កងទ័ពដែលនៅសេះសល់របស់ជាង បានរត់គៀសខ្លួនទៅភាគខាងត្បូង។ នៅក្នុងខែតុលា ឆ្នាំ 1949 ម៉ៅ សេងទុង ទទួលបានជ័យជំនះនៅក្នុងការគ្រប់គ្រងប្រទេសចិន។ លោកបានប្រកាស

របបថ្មីរបស់លោកថា សាធារណរដ្ឋប្រជាមានិតចិន។ លោកជាង និងមេដឹកនាំជាតិនិយមផ្សេងៗទៀតបានរត់ភៀសខ្លួនទៅកាន់កោះតៃវ៉ាន់ ដែលពេលនោះពួកលោកខាងលិចហៅថា ហ្វ័រម៉ូសា ។

ជ័យជំនះរបស់ម៉ៅ សេងទុង បានដុតបញ្ឆេះគំនិតប្រឆាំងកុំម្មុយនីស្តនៅក្នុងសហរដ្ឋអាមេរិក។ គំនិតប្រឆាំងកុំម្មុយនីស្តបានកើនឡើងកាន់តែខ្លាំង បន្ទាប់ពីប្រទេសចិនជាមួយសហភាពសូវៀតបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយនៅក្នុងឆ្នាំ 1950 ។ ប្រជាជនជាច្រើននៅក្នុងសហរដ្ឋអាមេរិកបានយល់ឃើញពីការដណ្តើមអំណាចរបស់ពួកកុំម្មុយនីស្តនៅក្នុងប្រទេសចិន ថាជាជំហានមួយផ្សេងទៀតរបស់ពួកកុំម្មុយនីស្តនៅក្នុងការត្រួតត្រាពិភពលោក។

## 2. ប្រទេសចិនទាំងពីរដះឥទ្ធិពលដល់សង្គ្រាមត្រជាក់

ប្រទេសចិនបានបែកចេញជាពីរ។ មួយគឺកោះតៃវ៉ាន់ ឬចិនជាតិនិយម ដែលមានផ្ទៃក្រឡាប្រមាណ 13,000 ម៉ាយការ៉េ។ មួយទៀតគឺពួកដីគោក ឬសាធារណរដ្ឋប្រជាមានិតចិន ដែលមានផ្ទៃក្រឡាប្រមាណ 3.5 លានម៉ាតការ៉េ។ ការលេចចេញនូវប្រទេសចិនពីរនេះ និងការខ្វែងគំនិតគ្នាជាលក្ខណៈអន្តរជាតិនៅក្នុងការគាំទ្រពួកគេ បានបង្កឱ្យសង្គ្រាមត្រជាតិកាន់តែកើនកម្តៅ។

ប្រតិកម្មពីមហាអំណាច៖ បន្ទាប់ពីជាង កាយចៀករត់ភៀសខ្លួនទៅតៃវ៉ាន់ សហរដ្ឋអាមេរិកបានជួយលោកនៅក្នុងការបង្កើតរដ្ឋាភិបាលជាតិនិយមមួយនៅលើកោះតូចមួយនេះ។ រដ្ឋាភិបាលនេះត្រូវបានហៅឈ្មោះថា សាធារណរដ្ឋចិន។ សហភាពសូវៀតបានផ្តល់ជំនួយហិរញ្ញវត្ថុ, យោធា, និងបច្ចេកទេសដល់ចិនកុំម្មុយនីស្ត។ ជាមួយគ្នានោះ ចិនកុំម្មុយនីស្ត និងសហភាពសូវៀតបានព្រមព្រៀងនៅក្នុងការការពារគ្នាទៅវិញទៅមកពីការវាយប្រហារមកលើពួកគេ។ សហរដ្ឋអាមេរិកបានព្យាយាមនៅក្នុងការទប់ការពង្រីកឥទ្ធិពលរបស់សហភាពសូវៀតនៅអាស៊ី។ ឧទាហរណ៍ នៅពេលកងទ័ពសហភាពសូវៀតកាន់កាប់ប្រទេសភាគខាងជើងពាក់កណ្តាលបន្ទាប់ពីសង្គ្រាមលោកលើកទី 2 និងបានបង្កើតរដ្ឋាភិបាលកុំម្មុយនីស្តមួយ សហរដ្ឋអាមេរិកបានគាំទ្រដល់ពួកកូរ៉េភាគខាងត្បូង។

ការពង្រីកប្រទេសចិនក្រោមរបបកុំម្មុយនីស្ត៖ នៅប៉ុន្មានឆ្នាំដំបូងៗនៃការគ្រប់គ្រងរបស់ម៉ៅ កងទ័ពចិនបានពង្រីកចូលទៅក្នុងតំបន់ទីបេ, ឥណ្ឌា, និងភាគខាងត្បូង, ម៉ុងហ្គោលី។ នៅភាគខាងជើង, ម៉ុងហ្គោលី ដែលមានព្រំដែនជាប់ជាមួយសហភាពសូវៀត បន្តស្ថិតនៅក្នុងដែនវង្វង់របស់សហភាពសូវៀត។

នៅក្នុងការវាយប្រហារដ៏ឃោឃៅមួយនៅក្នុងឆ្នាំ 1950 និង 1951 ប្រទេសចិនបានដណ្តើមកាន់កាប់ទីបេ។ ប្រទេសចិនបានសន្យានៅក្នុងការផ្តល់ស្វ័យភាពដល់ប្រជាជនទីបេ ដែលពួកគេភាគច្រើនដើរតាមមេដឹកនាំសាសនាដាឡៃ ឡាម៉ា។ នៅពេលដែលការត្រួតត្រារបស់ចិនលើទីបេកាន់តែតឹងរឹងនៅចុងទសវត្សរ៍ឆ្នាំ 1950 ដាឡៃ ឡាម៉ាបានរត់ភៀសខ្លួនទៅកាន់ប្រទេសឥណ្ឌា។ ប្រទេសឥណ្ឌាបានទទួលយកជនភៀសខ្លួនទីបេជាច្រើនបន្ទាប់ពីពួកគេបរាជ័យនៅក្នុងការបះបោរនៅទីបេនៅក្នុងឆ្នាំ 1959 ។ ជាលទ្ធផល ទំនាស់រវាងប្រទេសឥណ្ឌា និងចិនបានកើនឡើង។ នៅក្នុងឆ្នាំ 1962 ប្រទេសទាំងពីរនេះបានប៉ះទង្គិចគ្នាមួយរយៈពេលខ្លីនៅតាមព្រំដែន។ បើទោះបីជាការប្រយុទ្ធគ្នាបានបញ្ឈប់ ប៉ុន្តែទំនាស់នៅតែបន្ត។

### 3. ពួកកុំម្មុយនីស្តផ្លាស់ប្តូរប្រទេសចិន

អស់រយៈពេលជាច្រើនទសវត្សរ៍ ប្រទេសចិនស្ថិតនៅក្នុងភាពចលាចល, កើតមានឡើងនូវសង្គ្រាមស៊ីវិល ឬវាយប្រយុទ្ធគ្នាជាមួយពួកជប៉ុន។ ដូច្នេះ នៅពេលដែលពួកកុំម្មុយនីស្តដណ្តើមកាន់កាប់អំណាច ពួកគេបានដំណើរការយ៉ាងឆាប់រហ័សនូវការពង្រឹងការគ្រប់គ្រងរបស់ពួកគេ លើប្រជាជននៅក្នុងប្រទេសចិនពេលនោះដែលមានចំនួន 500 លាននាក់។ ពួកគេក៏មានគោលបំណងនៅក្នុងការស្តារប្រទេសចិនឱ្យក្លាយជាមហាអំណាចមួយផងដែរ។

ពួកកុំម្មុយនីស្តអះអាងអំពី "អាណត្តិនៃឋានសួគ៌"ថ្មីមួយ៖ បន្ទាប់ពីត្រួតត្រាប្រទេសចិន ពួកកុំម្មុយនីស្តចាប់ផ្តើមពង្រឹងអំណាចគ្រប់គ្រងរបស់ពួកគេ។ សភាពជិករបស់គណបក្ស 4.5 លាននាក់ស្មើនឹងមួយភាគរយនៃប្រជាជនសរុប។ ប៉ុន្តែពួកគេគឺជាក្រុមដែលមានវិន័យខ្ពស់មួយ។ ក៏ដូចជាសហភាពសូវៀតដែរ ចិនកុំម្មុយនីស្តបង្កើតស្ថាប័នស្របគ្នាចំនួនពីរ គឺគណបក្សកុំម្មុយនីស្ត និងរដ្ឋាភិបាលជាតិ។ ម៉ៅគ្រប់គ្រងលើស្ថាប័នទាំងពីរនេះរហូតដល់ឆ្នាំ 1959 ។

លំនាំសង្គមនិយមម៉ាក្សរបស់ម៉ៅ៖ ម៉ៅមានគោលបំណងនៅក្នុងការកែប្រែសេដ្ឋកិច្ចរបស់ចិនដោយផ្អែកលើសង្គមនិយមម៉ាក្ស។ ប្រជាជនប្រមាណ 80 % រស់នៅទីជនបទ ប៉ុន្តែពួកគេភាគច្រើនមិនមានដីកម្មសិទ្ធិឡើយ។ ផ្ទុយទៅវិញ 10 % នៃប្រជាជននៅជនបទកាន់កាប់ 70 % នៃដីកសិកម្ម។ ស្ថិតនៅក្រោមច្បាប់កំណែទម្រង់កសិកម្មឆ្នាំ 1950 ម៉ៅដណ្តើមពីម្ចាស់កម្មសិទ្ធិដីធ្លីនូវដីទាំងអស់របស់ពួកគេយកមកកាន់កាប់។ ការដណ្តើមរបស់លោកបានសម្លាប់ម្ចាស់កម្មសិទ្ធិដីធ្លីប្រមាណជាងមួយលាននាក់ ដោយសារតែពួកគេបានប្រឆាំង។ បន្ទាប់មកលោកបានបែងចែកដីធ្លីទាំងអស់នោះទៅឱ្យប្រជាកសិករ។ ក្រោយមក ក្នុងការអនុវត្តគោលការសង្គមនិយមរបស់ម៉ៅ រដ្ឋាភិបាលបានបង្ខំឱ្យប្រជាជនចូលរួមធ្វើស្រែចំការជាសមូហភាព។ ក្រុមនីមួយៗមានការចូលរួមពី ចន្លោះពី 200 ទៅ 300 គ្រួសារ។

ការផ្លាស់ប្តូររបស់ម៉ៅក៏បានកែប្រែឧស្សាហកម្ម និងជំនួញ។ បន្តិចម្តងៗ ក្រុមហ៊ុនឯកជនត្រូវបានប្រែក្លាយជារបស់ជាតិ ឬដល់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ នៅក្នុងឆ្នាំ 1953 ម៉ៅបានអនុវត្តផែនការ 5 ឆ្នាំដែលកំណត់នៅក្នុងការបង្កើនផលិតកម្មនៅក្នុងវិស័យឧស្សាហកម្ម។ ត្រឹមឆ្នាំ 1957 ផលិតផលធ្យូងថ្ម, ស៊ីម៉ង់ដ៍, ដែក, និងគ្រឿងអេឡិចត្រូនិចបានកើនឡើងយ៉ាងឆាប់រហ័ស។

"មហាលោតផ្លោះ"៖ ដើម្បីពង្រីកភាពជោគជ័យនៃផែនការ 5 ឆ្នាំលើកទីមួយ ម៉ៅបានប្រកាសពីផែនការ "មហាលោតផ្លោះ" នៅដើមឆ្នាំ 1958 ។ ផែនការនេះបានស្នើឱ្យមានការធ្វើស្រែចំការជាសមូហភាព ឬសហករណ៍ឱ្យកាន់តែធំជាងមុន។ នៅត្រឹមចុងឆ្នាំ 1958 សហករណ៍ប្រមាណ 26,000 ត្រូវបានបង្កើតឡើង។ ជាមធ្យមសហករណ៍មួយមានទំហំផ្ទៃដីប្រមាណ 15,000 អេក្រ៏ និងមានប្រជាជនលើសពី 25,000 នាក់។ នៅក្នុងការត្រួតត្រាដ៏តឹងរឹងទៅលើជីវិតរស់នៅនៅក្នុងសហករណ៍ ប្រជាជនធ្វើការនៅលើដីស្រែចំការរួមគ្នា។ ពួកគេបរិភោគអាហារនៅក្នុងបន្ទប់បរិភោគអាហាររួម, ដេកនៅក្នុងអន្តេវាសិកដ្ឋានសហករណ៍ និងកុមារត្រូវចិញ្ចឹមនៅក្នុងកុមារដ្ឋាន

សហករណ៍។ ពួកគេគ្មានទ្រព្យសម្បត្តិផ្ទាល់ខ្លួនឡើយ។ ប្រជាកសិករមិនមានកម្លាំងចិត្តនៅក្នុងការធ្វើការងារសកម្មឡើយ នៅពេលដែលផលចំណេញពីការធ្វើការងាររបស់ពួកគេបានទៅលើតែរដ្ឋប៉ុណ្ណោះ។

ផែនការ "មហាលោតផ្លោះ" គឺជាការបោះជំហានថយក្រោយមួយយ៉ាងឆ្ងាយ។ ដោយមិនមានផែនការច្បាស់លាស់ និងគ្មានប្រសិទ្ធភាព សេដ្ឋកិច្ចគ្រួសារ និងឧស្សាហកម្មមិនបានកើនឡើងឡើយ។ កម្មវិធីនេះបានបញ្ចប់នៅក្នុងឆ្នាំ 1961 បន្ទាប់ការធ្លាក់ចុះនៃទិន្នផលស្បៀងអាហារ នាំទៅដល់គ្រោះទុរ្ភិក្ស ដែលបណ្តាលឱ្យមនុស្សប្រមាណ 20 លានបានស្លាប់។

គោលនយោយថ្មី និងការឆ្លើយតបរបស់ម៉ៅ៖ ប្រទេសចិនបានប្រឈមជាមួយបញ្ហាផ្ទៃក្នុងក៏ដូចជាបញ្ហាខាងក្រៅផងដែរនៅអំឡុងទសវត្សរ៍ឆ្នាំ 1950 ។ គំនិតអំពីកិច្ចសហប្រតិបត្តិការរវាងសហភាពសូវៀត និងចិនចាប់ផ្តើមរសាត់បាត់។ ប្រទេសនីមួយៗសំលឹងទៅរកការដឹកនាំចលនាកុំម្មុយនីស្តពិភពលោក។ ដ៏ដែលប្រទេសទាំងពីរនេះមានព្រំដែនជាប់ជាមួយគ្នាវែងជាងគេនៅលើពិភពលោក ពួកគេក៏ប្រឈមជាមួយនឹងបញ្ហាជម្លោះព្រំដែនផងដែរ។

បន្ទាប់បរាជ័យនៃផែនការមហាលោតផ្លោះ និងបែកខ្ញែកពីសហភាពសូវៀតមក ម៉ៅបានកាត់បន្ថយតួនាទីរបស់លោកនៅក្នុងរដ្ឋាភិបាល។ មេដឹកនាំមួយចំនួនបានងាកចេញពីគំនិតសង្គមនិយមតឹងរឹងរបស់ម៉ៅ។ ឧទាហរណ៍ គ្រួសារកេសិករអាចរស់នៅផ្ទះរបស់ពួកគេផ្ទាល់ និងអាចលក់ទិន្នផលកសិកម្មរបស់ពួកគេដែលធ្វើនៅលើដីឯកជនតូចមួយ។ កម្មកររោងចក្រអាចប្រគួតប្រជែងដើម្បីទទួលបានការដំឡើងប្រាក់ខែ និងតំណែង។

ម៉ៅគិតថា គោលនយោបាយសេដ្ឋកិច្ចថ្មីរបស់ចិនបានធ្វើឱ្យអន់ថយនូវគោលដៅសមភាពសង្គមរបស់កុំម្មុយនីស្ត។ លោកបានប្តេជ្ញាចិត្តនៅក្នុងការធ្វើបដិវត្តឡើងវិញ។ នៅក្នុងឆ្នាំ 1966 លោកបានទទូចឱ្យយុវជននៅក្នុងប្រទេសចិនរៀនសូត្រពីបដិវត្តតាមរយៈការធ្វើបដិវត្ត។ សិស្សវិទ្យាល័យ និងនិស្សិតមហាវិទ្យាល័យរាប់លាននាក់បានឆ្លើយតបចំពោះការទទូចរបស់លោក។ ពួកគេបានចាកចេញពីថ្នាក់រៀនរបស់ពួកគេ និងបានបង្កើតជាកងយោធាដែលគេហៅថា ឆ្មាំក្រហម។

បដិវត្តវប្បធម៌៖ ពួកឆ្មាំក្រហមបានដឹកនាំការបះបោរដ៏ធំមួយដែលគេស្គាល់ថា បដិវត្តវប្បធម៌។ គោលដៅនៃបដិវត្តនេះគឺដើម្បីបង្កើតសង្គមប្រជាកសិករ និងកម្មករមួយដែលមានភាពស្មើគ្នា។ វីរៈបុរសថ្មីគឺប្រជាកសិករដែលធ្វើការជាមួយដៃរបស់ពួកគេ។ គំនិតគិតពិចារណា-សកម្មភាពទាក់ទងនឹងជំនេះដឹង និងសិល្បៈ ត្រូវបានចាត់ទុកថាគ្មានប្រយោជន៍ និងគ្រោះថ្នាក់។ ដើម្បីលុបបំបាត់ចោលការគំរាមកំហែងនេះ ឆ្មាំក្រហមបានបិទមហាវិទ្យាល័យ និងសាលានានា។ ពួកគេសម្លឹងទៅរកអ្នកទាំងឡាយណាដែលប្រឆាំងជាមួយរបបនេះ។ បញ្ញវន្តត្រូវបន្សុទ្ធខ្លួនរបស់ពួកគេតាមរយៈការធ្វើការងារនឿយហេតុនៅភូមិដាច់ស្រយាល។ មានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ ឬចាប់ដាក់គុក។

ភាពចលាចលបានគំរាមកំហែងដល់ទិន្នផលកសិកម្ម និងការបិទទ្វានៃរោងចក្រ។ សង្រ្គាមស៊ីវិលមើលទៅអាចកើតមានឡើង។ ត្រឹមឆ្នាំ 1968 សូម្បីតែម៉ៅក៏ទទួលស្គាល់ថាបដិវត្តវប្បធម៌ត្រូវតែបញ្ឈប់។ កងទ័ពត្រូវបានបញ្ជាឱ្យបង្រ្កាបពួកឆ្មាំក្រហម។ ជូ អេងឡាយ ស្ថាបនិកគណបក្សកុំម្មុយនីស្តចិន និងជានាយករដ្ឋមន្ត្រីចិនចាប់

តាំងពីឆ្នាំ 1949 មក បានចាប់ផ្តើមរៀបចំសណ្តាប់ធ្នាប់ឡើងវិញ។ ខណៈពេលដែលប្រទេសចិនកំពុងតស៊ូដើម្បីធ្វើឱ្យមានស្ថេរភាព សង្គ្រាមត្រជាក់នៅតែបន្ត។ ការប្រយុទ្ធគ្នាពេញលេញចំនួនពីរបានលេចឡើងគឺនៅក្នុងប្រទេសកូរ៉េ និងវៀតណាម។

# មេរៀនទី 3 ៖ សង្គ្រាមនៅក្នុងប្រទេសកូរ៉េ និងវៀតណាម

## 1. សង្គ្រាមនៅក្នុងប្រទេសកូរ៉េ

នៅត្រឹមឆ្នាំ 1949 ទាំងសហរដ្ឋអាមេរិក និងសហភាពសូវៀតបានដកកងទ័ពរបស់ពួកគេមួយភាគធំចេញពីប្រទេសកូរ៉េ។ សហភាពសូវៀតប៉ាន់ស្មានថាសហរដ្ឋអាមេរិកនឹងមិនជួយការពារកូរ៉េខាងត្បូងឡើយ។ ដូច្នេះ ពួកគេបានផ្តល់ឱ្យប្រទេសកូរ៉េខាងជើងនូវរថក្រោះ, យន្តហោះចម្បាំង, និងលុយដើម្បីប៉ុនប៉ងនៅក្នុងការដណ្តើមកាន់កាប់ឧបទ្វីបកូរ៉េទាំងមូល។

ការជាប់គាំនៅខ្សែស្របទី 38 ៖ នៅថ្ងៃទី 25 ខែមិថុនា ឆ្នាំ 1950 ប្រទេសកូរ៉េខាងជើងបានធ្វើដំណើរឆ្លងកាត់ខ្សែស្របទី 38 ដើម្បីធ្វើការវាយប្រហារដ៏ភ្ញាក់ផ្អើលមួយលើប្រទេសកូរ៉េខាងត្បូង។ នៅក្នុងរយៈតែប៉ុន្មានថ្ងៃប៉ុណ្ណោះ កងទ័ពកូរ៉េខាងជើងបានរុលជ្រៅចូលទៅក្នុងទឹកដីកូរ៉េខាងត្បូង។ ប្រធានាធិបតីទ្រូម៉ាន់ជឿជាក់ថាការឈ្លានពានរបស់កូរ៉េខាងជើងនឹងអនុវត្តឡើងវិញនូវអ្វីដែលហ៊ីត្លែរ, មូស្សូលីនី, និងពួកជប៉ុនបានធ្វើនៅអំឡុងទសវត្សរ៍ឆ្នាំ 1930។ គោលនយោបាយហ៊ុំព័ទ្ធរបស់ទ្រូម៉ាន់កំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើតេស្ត។ ជាដំណោះស្រាយទ្រូម៉ាន់សម្រេចនៅក្នុងការជួយប្រទេសកូរ៉េខាងត្បូងដើម្បីប្រឆាំងជាមួយកុំម្មុយនីស្ត។

ប្រទេសកូរ៉េខាងត្បូងក៏បានស្នើសុំឱ្យមានកិច្ចអន្តរាគមន៍ពីសំណាក់អង្គការសហប្រជាជាតិ។ នៅពេលមានការបោះឆ្នោតសម្រេចចិត្តនៅក្នុងក្រុមប្រឹក្សាសន្តសុខ សហភាពសូវៀតនៅពេលបានអវត្តមាន។ ពួកគេបានបដិសេធនៅក្នុងការចូលរួមជាមួយក្រុមប្រឹក្សាសន្តិសុខ ដើម្បីប្រឆាំងជាមួយនឹងការអនុញ្ញាតឱ្យពួកជាតិនិយមចិន (តៃវ៉ាន់) ជាជាងការអនុញ្ញាតឱ្យចិនកុំម្មុយនីស្តមានអាសន្នៈនៅអង្គការសហប្រជាជាតិ។ ជាលទ្ធផល សហភាពសូវៀត មិនអាចបោះឆ្នោតវេតូប្រឆាំងជាមួយផែនការរបស់អង្គការសហប្រជាជនក្នុងការបញ្ជូនកងកម្លាំងអន្តរជាតិទៅកាន់ប្រទេសកូរ៉េ ដើម្បីបញ្ឈប់ការឈ្លានពាន។ មានប្រទេសសរុបចំនួន 15 ដោយក្នុងនោះមានសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស បានចូលរួមក្រោមបញ្ជាការរបស់ឧត្តមសេនីយ៍ឌូគឡាស់ ម៉ាក់អាតដប័រ ។

ខណៈពេលនោះ ប្រទេសកូរ៉េខាងជើងបានបន្តរុលឆ្ពោះទៅមុខ។ ត្រឹមខែកញ្ញា ឆ្នាំ 1950 ពួកគេបានត្រួតត្រាឧបទ្វីកូរ៉េទាំងមូលលើកលែងតែតំបន់តូចមួយនៅជុំវិញតំបន់ពូសាន ដែលស្ថិតនៅចុងភាគខាងត្បូង។ ប៉ុន្តែ នៅក្នុងខែនោះផងដែរ លោកម៉ាក់អាតច័រ បានធ្វើការវាយប្រហារដ៏ភ្ញាក់ផ្អើលមួយ។ កងទ័ពបានធ្វើដំណើរឆ្ពោះទៅភាគខាងជើង ដោយចេញដំណើរពីពូសានដើម្បីទៅជួបជាមួយកងកម្លាំងមួយក្រុមទៀតដែលបានចូលសំចតនៅអ៊ីនឆុន។ ដោយជាប់នៅក្នុង "សកម្មភាពគាបសងខាង" នេះ កងទ័ពកូរ៉េខាងជើងប្រហែលពាក់កណ្តាលបានចុះចាញ់ចំណែកកងទ័ពដែលនៅសេះសល់បានដកថយ។

ការវាយប្រយុទ្ធនៅតែបន្ត៖ កងទ័ពរបស់អង្គការសហប្រជាជាតិបានដេញតាមកងទ័ពកូរ៉េខាងជើងដែលបានដកថយឆ្លងខ្សែស្របទី 38 ចូលទៅកាន់កូរ៉េខាងជើង។ កងទ័ពអង្គការសហប្រជាជាតិបានរុញច្រានពួកគេស្ទើរតែដល់ទន្លេយ៉ាលូ ដែលស្ថិតជាប់ព្រំដែនជាមួយប្រទេសចិន។ កងកម្លាំងរបស់អង្គការសហប្រជាជាតិភាគច្រើនគឺជា

កងទ័ពមកពីសហរដ្ឋអាមេរិក។ ពួកចិនកុំម្មុនីស្តយល់ថាមានការគំរាមកំហែងពីកងទ័ពទាំងនេះ និងនាវាមួយគ្រឿងរបស់អាមេរិកបានចូលចតនៅតំបន់ឆ្នេរពួកគេ។ នៅក្នុងខែតុលា ឆ្នាំ 1950 ពួកគេបានបញ្ជូនកងទ័ពចំនួន 300,000 នាក់ទៅកាន់ប្រទេសកូរ៉េខាងជើង។

កងទ័ពរបស់ចិនមានចំនួនច្រើនជាងចំនួនកងទ័ពរបស់អង្គការសហប្រជាជាតិឆ្ងាយ។ ត្រឹមខែមករា ឆ្នាំ 1951 ពួកគេបានវាយរុញច្រានកងទ័ពអង្គការសហប្រជាជាតិ និងកូរ៉េខាងត្បូងចេញពីប្រទេសកូរ៉េខាងជើង។ កងទ័ពចិនពេលនោះបានធ្វើដំណើរចូលក្នុងប្រទេសកូរ៉េខាងត្បូង និងបានដណ្តើមកាន់កាប់ទីក្រុងសេអ៊ូល។ លោកម៉ាក់អាតថ័រ បានប្រកាសថា "យើងប្រឈមជាមួយសង្គ្រាមថ្មីស្រឡាងមួយ"។ លោកបានស្នើឱ្យមានការវាយប្រហារអាវុធនុយក្លេអ៊ែមួយប្រឆាំងជាមួយប្រទេសចិន។ ទ្រូម៉ាន់យល់ឃើញថាការស្នើសុំរបស់ម៉ាក់អាតថ័រ ជាគំនិតឆៅឆាវមួយ។ លោកបាននិយាយថា "យើងទាំងអស់គ្នាព្យាយាមនៅក្នុងការពារកុំឱ្យមានសង្គ្រាមលោកមួយ, យើងមិនត្រូវចាប់ផ្តើមវាឡើយ"។ ម៉ាក់អាតថ័របានព្យាយាមប្រឆាំងជាមួយប្រធានាធិបតីដោយបានបញ្ជូនករណីរបស់លោកទៅកាន់សភា និងសាព័ត៌មាន។ នៅក្នុងការឆ្លើយតប ប្រធានាធិបតីទ្រូម៉ាន់បានដកលោកចេញពីតំណែង។

ជាងពីរឆ្នាំក្រោយមក កងទ័ពរបស់អង្គការសហប្រជាជាតិបានវាយប្រយុទ្ធបណ្តេញកងទ័ពចិន និងកូរ៉េខាងជើងឱ្យត្រឡប់ថយក្រោយ។ ត្រឹមឆ្នាំ 1952 កងទ័ពរបស់អង្គការសហប្រជាជាតិទទួលបានមកវិញនូវការត្រួតត្រាប្រទេសកូរ៉េខាងត្បូង។ ចុងក្រោយ នៅក្នុងខែកក្កដា ឆ្នាំ 1953 កងទ័ពរបស់អង្គការសហប្រជាជាតិ និងកូរ៉េខាងជើងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឈប់បាញ់មួយ។ ព្រំដែនរវាងប្រទេសកូរ៉េទាំងពីរត្រូវបានកំណត់យកជិតខ្សែស្របទី 38 ស្ទើតែដូចគ្នាទៅនឹងព្រំដែនដែលធ្លាប់មានមុនសង្គ្រាម។ នៅក្នុងពេលជាមួយគ្នានោះ កងទ័ព និងជនស៊ីវិលប្រមាណ 4 លាននាក់បានស្លាប់។

លទ្ធផលនៃសង្គ្រាម៖ បន្ទាប់ពីសង្គ្រាម កូរ៉េនៅតែបន្តបែងចែកជាពីរ។ តំបន់គ្មានកងទ័ពមួយ ដែលនៅតែមានរហូតដល់បច្ចុប្បន្ន បានបែងចែកប្រទេសទាំងពីរនេះ។ នៅក្នុងប្រទេសកូរ៉េខាងជើង ជនផ្តាច់ការកុំម្មុយនីស្តគីម អ៊ីលស៊ុង បានបង្កើតសហករណ៍ធ្វើស្រែចំការ, អភិវឌ្ឍឧស្សាហកម្មធុនធ្ងន់, និងស្ថាបនាយោធា។ នៅពេលដែលលោកគីមស្លាប់នៅក្នុងឆ្នាំ 1994 កូនប្រុសរបស់លោកគីម ជុងអ៊ីល បានឡើងកាន់អំណាចបន្ត។ ស្ថិតនៅក្រោមការដឹកនាំរបស់លោក កុំម្មុយនីស្តកូរ៉េខាងជើងបានអភិវឌ្ឍអាវុធនុយក្លេអ៊ែជាច្រើន ប៉ុន្តែពួកគេក៏ប្រឈមជាមួយបញ្ហាសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរផងដែរ។ ផ្ទុយទៅវិញ ប្រទេសកូរ៉េខាងត្បូងមានភាពរុងរឿង ដោយសារមួយផ្នែកបានមកពីជំនួយរបស់សហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត។ នៅក្នុងទសវត្សរ៍ឆ្នាំ 1960 ប្រទេសកូរ៉េខាងត្បូងបានយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍឧស្សាហកម្មរបស់ពួកគេ និងពង្រីកពាណិជ្ជកម្មអន្តរជាតិ។ របបផ្តាច់ការជាបន្តបន្ទាប់បានគ្រប់គ្រងប្រទេសដែលកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ប៉ុន្តែ ជាមួយនឹងការបង្កើតធម្មនុញ្ញប្រជាធិបតេយ្យមួយនៅក្នុងឆ្នាំ 1987 ប្រទេសកូរ៉េខាងត្បូងបានបង្កើតនូវការបោះឆ្នោតដោយសេរី។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1980 និង 1990 ប្រទេសកូរ៉េខាងត្បូងបានក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតមួយនៅលើពិភពលោក។

ដោយសារនយោបាយខុសគ្នា ប្រទេសកូរ៉េទាំងពីរនៅតែបន្តបែងចែកដាច់ពីគ្នា បើទោះបីជាមានការពិភាក្សាគ្នាជាច្រើនលើកច្រើនសារអំពីការបង្រួបបង្រួមប្រទេសកូរ៉េឡើងវិញក៏ដោយ។ មហិច្ឆតាអាវុធនុយក្លេអ៊ែរបស់កូរ៉េខាងជើងគឺជាឧបសគ្គដ៏ចំបងមួយក្នុងការបង្រួបបង្រួមនេះ។ សហរដ្ឋអាមេរិកនៅតែបន្តរក្សាទុកកងទ័ពរបស់ខ្លួននៅក្នុងប្រទេសកូរ៉េខាងត្បូង។

## 2. សង្គ្រាមផ្ទុះឡើងនៅវៀតណាម

ក៏ដូចជាការចូលរួមរបស់ពួកគេនៅក្នុងសង្គ្រាមកូរ៉េ ការចូលរួមរបស់សហរដ្ឋអាមេរិកនៅក្នុងសង្គ្រាមវៀតណាមផ្ដើមចេញពីគោលនយោបាយហ៊ុំព័ទ្ធនៃសង្គ្រាមត្រជាក់។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 ការបញ្ឈប់ការរីករាលដាលនៃលទ្ធិកុំម្មុយនីស្តគឺជាគោលដៅចំបងនៃគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក។

ផ្លូវឆ្ពោះទៅរកសង្គ្រាម៖ នៅដើមទសវត្សរ៍ឆ្នាំ 1900 ប្រទេសបារាំងបានត្រួតត្រាស្ទើរតែទាំងស្រុងនៃតំបន់សម្បូរធនធាននៅអាស៊ីអាគ្នេយ៍។ បារាំងឥណ្ឌូចិន រួបបញ្ចូលបច្ចុប្បន្នប្រទេសវៀតណាម, ឡាវ, និងកម្ពុជា។ ប៉ុន្តែចលនាជាតិនិយមដើម្បីឯករាជ្យបានចាប់ផ្ដើមអភិវឌ្ឍឡើយ។ អ្នកជាតិនិយមវៀតណាមវ័យក្មេងមួយឈ្មោះ ហូជីមិញ បានស្នើឱ្យពួកកុំម្មុយនីស្តជួយលោកនៅក្នុងការតស៊ូដើម្បីឯករាជ្យ។ អំឡុងទសវត្សរ៍ឆ្នាំ 1930 គណបក្សកុំម្មុយនីស្តឥណ្ឌូចិនរបស់ហូជីមិញ បានដឹកនាំការបះបោរ និងវាយប្រហារលើបារាំង។

បារាំងបានឆ្លើយតបតាមរយៈការចាប់ក្រុមអ្នកបះបោរដាក់គុក។ ពួកគេក៏បានកាត់ទោសប្រហារជីវិតហូជីមិញផងដែរ។ លោកបាននិរទេសខ្លួនចេញក្រៅប្រទេស ប៉ុន្តែលោកបានត្រឡប់មកកាន់ប្រទេសវៀតណាមវិញនៅក្នុងឆ្នាំ 1941 មួយឆ្នាំបន្ទាប់ពីជប៉ុនដើម្បីកាន់កាប់ប្រទេសរបស់លោកនៅអំឡុងសង្គ្រាមលោកលើកទី 2 ។ ហូជីមិញ និងអ្នកជាតិនិយមផ្សេងទៀតបានបង្កើតសម្ព័ន្ធវៀតមិញ (ឯករាជ្យ)។ ជប៉ុនត្រូវបានបង្ខំឱ្យចេញពីវៀតណាមបន្ទាប់ពីពួកគេចុះចាញ់សង្គ្រាមនៅក្នុងឆ្នាំ 1945 ។ ហូជីមិញជឿជាក់ថាឯករាជ្យរបស់វៀតណាមនឹងទទួលបានបន្ទាប់ពីការចាកចេញនេះ ប៉ុន្តែប្រទេសបារាំងបានព្យាយាមនៅក្នុងដាក់អាណានិគមលោកវិញ។

ការវាយប្រយុទ្ធចាប់ផ្ដើម៖ អ្នកជាតិនិយម និងពួកកុំម្មុយនីស្តវៀតណាមបានចូលរួមជាមួយគ្នាដើម្បីវាយប្រយុទ្ធជាមួយកងទ័ពបារាំង។ បារាំងកាន់កាប់ទីក្រុងសំខាន់ៗភាគច្រើន ប៉ុន្តែពួកវៀតមិញទទួលបានការគាំទ្រនៅតាមទីជនបទ។ ពួកវៀតមិញបានប្រើយុទ្ធសាស្ត្រវាយហើយរត់ដើម្បីបង្ខំឱ្យបារាំងចេញពីទីក្រុង។ នៅក្នុងប្រទេសបារាំងប្រជាជនចាប់ផ្ដើមពិភាក្សាគ្នាអំពីការតស៊ូដាក់អាណានិគមឡើងវិញរបស់ពួកគេ ដែលបណ្ដាលឱ្យខាតបង់អាយុជីវិត និងថវិកា។ នៅក្នុងឆ្នាំ 1954 បារាំងបានបរាជ័យដ៏ធ្ងន់ធ្ងរមួយនៅក្នុងសមរភូមិ ឌៀនបៀនភូ។ ពួកគេបានចុះចេញហូជីមិញ។

សហរដ្ឋអាមេរិកបានគាំទ្របារាំងនៅវៀតណាម។ ជាមួយនឹងលការបរាជ័យរបស់បារាំង សហរដ្ឋអាមេរិកយល់ឃើញថាវាគឺជាកើនឡើងនូវការគំរាមកំហែងមួយសម្រាប់ទ្វីបអាស៊ីទាំងមូល។ ប្រធានាធិបតីអេសិនហូវ័របានពិពណ៌នាការគំរាមកំហែងនេះនៅក្នុងបច្ចេកពាក្យ ទ្រឹស្ដីដូមីណូ។ លោកបាននិយាយថា ប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ប្រៀបដូចជាដូមីណូដំរៀបគ្នាមួយជួរ។ ការធ្លាក់ប្រទេសមួយណាទៅក្នុងដៃកុំម្មុយនីស្ត នឹងនាំ

ទៅដល់ការដួលរលំនៃប្រទេសជិតខាងរបស់គេ។ ទ្រឹស្តីនេះបានក្លាយជាយុត្តិកម្មដ៏សំខាន់មួយសម្រាប់គោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកអំឡុងសម័យសង្គ្រាមត្រជាក់។

វៀតណាម-ប្រទេសដែលបែងចែកជា 2 ៖ បន្ទាប់ពីបារាំងបរាជ័យ សន្និសិទសន្តិភាពអន្តរជាតិមួយត្រូវបានធ្វើឡើងនៅទីក្រុងហ្សឺណែវដើម្បីពិភាក្សាអនាគតរបស់តំបន់ឥណ្ឌូចិន។ ដោយផ្អែកលើកិច្ចប្រជុំនេះ ប្រទេសវៀតណាមត្រូវបានចែកជាពីរត្រង់ខ្សែរយៈទទឹងទី 17 ។ ពាក់កណ្ដាលភាគខាងជើងកងកម្លាំងកុំម្មុយនីស្ដរបស់ហូជីមិញជាអ្នកគ្រប់គ្រង។ ពាក់កណ្ដាលនៅភាគខាងត្បូង សហរដ្ឋអាមេរិក និងបារាំងបានបង្កើតរដ្ឋាភិបាលប្រឆាំងកុំម្មុយនីស្ដមួយដែលស្ថិតនៅក្រោមការដឹកនាំរបស់ង៉ូ ឌិញដៀម។

លោកដៀមដឹកនាំវៀតណាមខាងត្បូងក្នុងនាំជាជនផ្ដាច់ការមួយរូប។ ការប្រឆាំងជាមួយរដ្ឋាភិបាលរបស់លោកបានកើនឡើង។ ចលនាទ័ពព្រៃកុំម្មុយនីស្ដ ដែលគេហៅថា វៀតកុង ចាប់ផ្ដើមបង្កើនឥទ្ធិពលនៅវៀតណាមខាងត្បូង។ ខណៈពេលពួកវៀតកុងមួយចំនួនគឺជាកងកម្លាំងដែលមានការបណ្ដុះបណ្ដាលមកពីវៀតណាមខាងជើងមួយភាគធំទៀតគឺជាប្រជាជនវៀតណាមដែលស្អប់ដៀម។ បន្តិចម្ដងៗ ពួកវៀតកុងទទួលជ័យជំនះនៅក្នុងត្រួតត្រាតំបន់ជាច្រើននៅទីជនបទ។ នៅក្នុងឆ្នាំ 1963 ក្រុមឧត្ដមសេនីយវៀតណាមខាងត្បូងមួយក្រុងបានធ្វើឃាតដៀម។ ប៉ុន្តែ មេដឹកនាំថ្មីនៅតែមិនមានប្រជាប្រិយភាពដូចជាមេដឹកនាំមុនដដែល។ វាហាក់ដូចជាថា ការដណ្ដើមកាន់កាប់វៀតណាមខាងត្បូងដោយពួកវៀតកុងដែលគាំទ្រដោយវៀតណាមខាងជើងនឹងជៀសមិនរួចឡើយ។

### 3. សហរដ្ឋអាមេរិកចូលរួម

ប្រឈមជាមួយភាពអាចទៅរួចនៃជ័យជំនះរបស់ពួកកុំម្មុយនីស្ដ សហរដ្ឋអាមេរិកបានសម្រេចចិត្តនៅក្នុងការបង្កើតការចូលរួមរបស់ពួកគេនៅវៀតណាមខាងត្បូង។ កងទ័ពអាមេរិកមួយចំនួនបានបម្រើការជាទីប្រឹក្សារបស់វៀតណាមខាងត្បូងចាប់តាំងពីចុងទសវត្សឆ្នាំ 1950 មក។ ប៉ុន្តែចំនួននៃកងទ័ពរបស់អាមេរិកបានកើនឡើងយ៉ាងច្រើន ដូចដែលយន្តហោះ និងសម្ភារៈយោធាផ្សេងៗជាច្រើនត្រូវបានបញ្ជូនទៅកាន់វៀតណាមខាងត្បូង។

កងទ័ពអាមេរិកចូលរួមនៅក្នុងការប្រយុទ្ធ៖ នៅក្នុងខែសីហា ឆ្នាំ 1964 ប្រធានាធិបតីអាមេរិក លីនដុន ចនសុន បានប្រាប់ទៅសភាថា នាវាល្បាតរបស់វៀតណាមខាងជើងបានវាយប្រហារនាវាពិឃាតពីគ្រឿងរបស់សហរដ្ឋអាមេរិកនៅជ្រោយតុងកឹង។ ជាលទ្ធផល សភាបានអនុញ្ញាតឱ្យប្រធានាធិបតីបញ្ជូនកងទ័ពអាមេរិកទៅប្រយុទ្ធនៅវៀតណាម។ ត្រឹមចុងឆ្នាំ 1965 កងកម្លាំងអាមេរិកជាង 185,000 នាក់ត្រូវបានបញ្ជូលមកកាន់ប្រទេសវៀតណាម។ យន្តហោះរបស់សហរដ្ឋអាមេរិកក៏បានចាប់ផ្ដើមទម្លាក់គ្រាប់បែកលើវៀតណាមខាងជើង។ ត្រឹមឆ្នាំ 1968 កងកម្លាំងអាមេរិកជាងពាក់កណ្ដាលកំពុងប្រយុទ្ធនៅក្នុងប្រទេសវៀតណាម។

សហរដ្ឋអាមេរិកមានកងទ័ពដែលល្អ និងបំពាក់គ្រឿងយុទ្ធភ័ណ្ឌល្អជាងគេនៅលើពិភពលោក។ ប៉ុន្តែពួកគេជួបប្រទះបញ្ហាសំខាន់ៗចំនួនពីរ។ ទីមួយកងទ័ពរបស់សហរដ្ឋអាមេរិកវាយប្រយុទ្ធនៅក្នុងសង្គ្រាមទ័ពព្រៃនៅក្នុងតំបន់ព្រៃដែលពួកគេមិនស្គាល់ភូមិសាស្ត្រច្បាស់។ ទីពីរ រដ្ឋាភិបាលវៀតណាមខាងត្បូងដែលពួកគេកំពុងការពារគឺជារដ្ឋាភិបាលដែលមិនមានប្រជាប្រិយភាព។ នៅក្នុងពេលជាមួយគ្នានោះ ការគាំទ្រដល់ពួកវៀតកុងបានកើនឡើង

ជាមួយនឹងការជួយ និងផ្គត់ផ្គង់សម្ភារៈពីសំណាក់ហូជីមិញ, សហភាពសូវៀត, និងប្រទេសចិន។ ដោយមិនអាចទទួលជ័យជំនះនៅក្នុងការប្រយុទ្ធគ្នានៅលើដី សហរដ្ឋអាមេរិកបានត្រឡប់ទៅប្រើប្រាស់ផ្លូវអាកាស។ កងទ័ពអាកាសអាមេរិកបានទម្លាប់គ្រាប់បែកលើដីស្រែចំការ និងព្រៃឈើរាប់លានអេក្រ៊ី ក្នុងគោលបំណងវាយប្រហារមូលដ្ឋានរបស់សត្រូវ។ ការទម្លាក់គ្រាប់បែកនេះ បាននាំទៅដល់ការកើនឡើងនៃការប្រឆាំងរបស់ប្រជាកសិករចំពោះរដ្ឋាភិបាលវៀតណាមខាងត្បូង។

សហរដ្ឋអាមេរិកដកខ្លួន៖ អំឡុងចុងទសវត្សរ៍ឆ្នាំ1960 សង្គ្រាមបានកើនឡើងនូវអប្រជាប្រិយភាពនៅសហរដ្ឋអាមេរិក។ យុវជនដែលមិនពេញចិត្តចំពោះសង្គ្រាមចាប់ផ្តើមធ្វើការប្រឆាំងតវ៉ាចំពោះការបាត់បង់អាយុជីវិតយ៉ាងច្រើននៅក្នុងការប្រយុទ្ធគ្នា។ ស្ថិតនៅក្រោមសម្ពាធរបស់សាធារណជន ប្រធានាធិបតីរីឆាដ និកសុន ចាប់ផ្តើមដកកងទ័ពសហរដ្ឋអាមេរិកចេញពីវៀតណាមនៅក្នុងឆ្នាំ 1969 ។

និកសុនមានផែនការមួយដែលលោកហៅថា វៀតណាមនីយកម្ម។ ផែនការនេះអនុញ្ញាតឱ្យកងទ័ពអាមេរិកដកចេញពីវៀតណាមបន្តិចម្តងៗ ខណៈពេលដែលបង្កើនតួនាទីនៅក្នុងការប្រយុទ្ធដល់កងទ័ពវៀតណាមខាងត្បូង។ ខណៈពេលកំពុងអនុវត្តផែនការវៀតណាមនីយកម្ម និងដើម្បីការពារដល់រដ្ឋាភិបាលវៀតណាមខាងត្បូង និកសុនបានអនុញ្ញាតឱ្យមានយុទ្ធនាការទម្លាក់គ្រាប់បែកទ្រង់ទ្រាយធំមួយប្រឆាំងជាមួយមូលដ្ឋាន និងផ្លូវផ្គត់ផ្គង់សម្ភារៈរបស់វៀតណាមខាងជើង។ លោកបានអនុញ្ញាតឱ្យមានការទម្លាក់គ្រាប់បែកលើប្រទេសជិតខាងវៀតណាមគឺប្រទេសឡាវ និងកម្ពុជាដើម្បីកម្ទេចកន្លែងលាក់ខ្លួនរបស់ពួកវៀតកុង។

ដើម្បីឆ្លើយតបជាមួយសម្ពាធនយោបាយ និងបាតុកម្មនៅក្នុងប្រទេស និកសុននៅតែបន្តដកកងទ័ពអាមេរិកចេញពីវៀតណាមបន្តិចម្តងៗ។ កងទ័ពអាមេរិកត្រូវបានដកចេញពីវៀតណាមទាំងស្រុងនៅក្នុងឆ្នាំ 1973 ។ 2 ឆ្នាំបន្ទាប់មក វៀតណាមខាងជើងបានយកជ័យជំនះលើវៀតណាខាងត្បូង។ សង្គ្រាមបានបញ្ចប់ ប៉ុន្តែមានជនជាតិវៀតណាម 1.5 លាននាក់ និងអាមេរិក 58,000 បានបាត់បង់អាយុជីវិត។

### 4. អាស៊ីអាគ្នេយ៍ក្រោយសង្គ្រាម

ការបញ្ចប់នៃសង្គ្រាមមិនបាននាំមកនូវការបញ្ចប់ការបង្ហូរឈាម និងភាពចលាចលភ្លាមៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ឡើយ។ ប្រទេសកម្ពុជាស្ថិតនៅក្រោមការឡោមព័ទ្ធរបស់ក្រុងបះបោរកុំម្មុយនីស្ត។ អំឡុងពេលនៃសង្គ្រាមប្រទេសនេះបានរងគ្រោះពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ដោយសារប្រទេសនេះត្រូវបានប្រើប្រាស់ជាលាក់ខ្លួនរបស់ពួកវៀតណាមខាងជើង និងវៀតកុង។

ប្រទេសកម្ពុជាស្ថិតនៅក្នុងភាពចលាចល៖ នៅក្នុងឆ្នាំ 1975 ពួកបះបោរកុំម្មុយនីស្តដែលគេស្គាល់ថា ខ្មែរក្រហមបានបង្កើតរដ្ឋាភិបាលកុំម្មុយនីស្តឃោឃៅមួយដែលស្ថិតនៅក្រោមការដឹកនាំរបស់ប៉ុលពត។ នៅក្នុងការព្យាយាមដ៏សាហាវព្រៃផ្សៃមួយដើម្បីប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមកុំម្មុយនីស្តមួយ អ្នកដើរតាមប៉ុលពតបានកាប់សម្លាប់មនុស្សប្រមាណ 2 លាននាក់។ ចំនួននេះស្មើរតែស្មើ ¼ នៃប្រជាជនកម្ពុជាសរុបនៅពេលនោះ។ ក្រោយមកវៀតណាមបានឈ្លានពានកម្ពុជានៅក្នុងឆ្នាំ 1978 ។ ពួកគេបានទម្លាក់ខ្មែរក្រហម និងបានបង្កើតរដ្ឋាភិបាលថ្មី

មួយដែលមិនកាច់សាហាវដូចពួកខ្មែរក្រហម។ ប៉ុន្តែការប្រយុទ្ធគ្នានៅតែបន្តទៅមុខទៀត។ កងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ 1989 ។ នៅក្នុងឆ្នាំ 1993 ស្ថិតនៅក្រោមការរៀបចំរបស់ក្រុមអ្នករក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ប្រទេសកម្ពុជាបានបង្កើតធម្មនុញ្ញបែបប្រជាធិបតេយ្យមួយ និងរៀបចំឱ្យមានការបោះឆ្នោតដោយសេរី។

ប្រទេសវៀតណាមបន្ទាប់ពីសង្គ្រាម៖ បន្ទាប់ពីឆ្នាំ 1975 ពួកវៀតណាមខាងជើងដែលទទួលបានជ័យជំនះបានដាក់ចេញនូវការត្រួតត្រាយ៉ាងតឹងរឹងមួយលើវៀតណាមខាងត្បូង។ មន្ត្រីបានបញ្ជូនប្រជាជនរាប់ពាន់នាក់ទៅកាន់ "ជុំរុំរៀនសូត្រឡើងវិញ" ដើម្បីបណ្ដុះបណ្ដាលទ្រឹស្ដីកុំម្មុយនីស្ដ។ ពួកគេបានធ្វើជាតូបនីយកម្មលើវិស័យឧស្សាហកម្ម និងគ្រប់គ្រងទៅលើការធ្វើជំនួញយ៉ាងតឹងរឹង។ ពួកគេក៏បានផ្លាស់ប្ដូរឈ្មោះទីក្រុងសៃហ្គន ដែលជាអតីតរដ្ឋធានីរបស់ប្រទេសវៀតណាមខាងត្បូងថា ទីក្រុងហូជីមិញ។ ការធ្វើទុក្ខបុកម្និញរបស់ពួកកុំម្មុយនីស្ដបណ្ដាលឱ្យមានប្រជាជនប្រមាណ 1.5 លាននាក់រត់ចេញពីប្រទេសវៀតណាម។ ភាគច្រើនរត់គេចខ្លួនតាមរយៈទូកដែលណែនចង្អៀតប្រកបដោយគ្រោះថ្នាក់។ មាន "ប្រជាជនទូក" ចំនួនជាង 200,000 នាក់បានស្លាប់នៅក្នុងសមុទ្រ។ អ្នកដែលរស់រានមានជីវិតភាគច្រើនបានចំនួនពេលរាប់ខែរស់នៅក្នុងជុំរុំជនភៀសខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ បន្តិចម្ដងៗមានប្រជាជនវៀតណាមប្រមាណ 70,000 បានតាំងទីលំនៅថ្មីក្នុងសហរដ្ឋអាមេរិក និងកាណាដា។ បើទោះបីជាពួកកុំម្មុនីស្ដនៅតែបន្តគ្រប់គ្រងប្រទេសវៀតណាម ប្រទេសនេះឥឡូវបានបើកទ្វាស្វាគមន៍ការវិនិយោគអន្តរជាតិ។ សហរដ្ឋអាមេរិកបានបង្កើតទំនាក់ទំនងឡើងវិញជាមួយវៀតណាមនៅក្នុងឆ្នាំ 1995 ។

ខណៈពេលដែលមហាអំណាចកំពុងតស៊ូដើម្បីឃ្មុប្រៀបលើគ្នាអំឡុងសង្គ្រាមកូរ៉េ និងសង្គ្រាមវៀតណាម ពួកគេក៏សម្លឹងទៅរកការពង្រីកឥទ្ធិពលលើតំបន់ផ្សេងៗទៀតនៅលើពិភពលោក។

# មេរៀនទី 4៖ សង្គ្រាមត្រជាក់បែងចែកពិភពលោក

## 1. ការវាយប្រយុទ្ធសម្រាប់លោកទីបី

ប្រទេសលោកទីបីទាំងឡាយមានទីតាំងស្ថិតនៅអាមេរិកឡាទីន, អាស៊ី, និងអាហ្វ្រិក។ ប្រទេសទាំងនោះភាគច្រើនមានសេដ្ឋកិច្ចក្រីក្រ និងអស្ថេរភាពនយោបាយ។ បញ្ហានេះមួយភាគធំបណ្តាលមកពីការដាក់អាណានិគមក្នុងរយៈពេលដ៏វែងមួយ។ ប្រទេសទាំងអស់នេះក៏រងគ្រោះដោយជម្លោះជាតិសាសន៍ និងកង្វះខាងបច្ចេកវិទ្យា និងការអប់រំ។ ប្រទេសនីមួយៗត្រូវការប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចសមស្របមួយដើម្បីស្ថាបនាសង្គមរបស់ពួកគេ។ លទ្ធិកុម្មុនីស្តបែបសូវៀត និងប្រជាធិបតេយ្យទីផ្សារសេរីបែបអាមេរិកគឺជាជម្រើសសំខាន់បំផុត។

យុទ្ធសាស្ត្រសង្គ្រាមត្រជាក់៖ សហរដ្ឋអាមេរិក, សហភាពសូវៀត, និងប្រទេសចិន នៅក្នុងករណីមួយចំនួនបានប្រើប្រាស់បច្ចេកទេសជាច្រើនដើម្បីពង្រីកឥទ្ធិពលលើបណ្តាលប្រទេសលោកទីបី។ ពួកគេស្ថិតនៅពីក្រោយសង្គ្រាមបដិវត្ត, រំដោះ, និងការប្រឆាំងបដិវត្ត។ ទីភ្នាក់ងារស៊ើបការសហរដ្ឋអាមេរិក ស៊ីអាយអេ និងទីភ្នាក់ងារស៊ើបការសហភាពសូវៀតកាហ្សេបេ បានចូលរួមនៅក្នុងសកម្មភាពសម្ងាត់ជាច្រើន រាប់ចាប់ពីការធ្វើចារកិច្ចដើម្បីប៉ុនប៉ងធ្វើឃាត។ សហរដ្ឋអាមេរិកក៏ផ្តល់ជំនួយយោធា, ស្ថាបនាសាលារៀន, បង្កើតកម្មវិធីនានាដើម្បីប្រឆាំងជាមួយភាពក្រីក្រ, និងបានបញ្ជូនកម្មករស្ម័គ្រចិត្តទៅកាន់ប្រទេសកំពុងអភិវឌ្ឍជាច្រើន។ សហភាពសូវៀតបានផ្តល់ជំនួយផ្នែកយោធា និងបច្ចេកទេស ជាពិសេសទៅកាន់ប្រទេសឥណ្ឌា និងអេហ្ស៊ីប។

សមាគមន៍ប្រជាជាតិមិនចូលបក្សសម្ព័ន្ធ៖ ប្រទេសកំពុងអភិវឌ្ឍផ្សេងៗទៀតក៏មានតម្រូវការជំនួយផងដែរ។ ប្រទេសទាំងអស់នេះបានក្លាយជាតួអង្គសំខាន់នៅក្នុងការប្រកួតប្រជែងនៅក្នុងសង្គ្រាមត្រជាក់ រវាងសហរដ្ឋអាមេរិក, សហភាពសូវៀត និងក្រោយមកប្រទេសចិន។ ប៉ុន្តែមិនមែនប្រទេសលោកទីបីទាំងអស់ប្រាថ្នាចង់ក្លាយជាតួអង្គមួយនៅក្នុងសង្គ្រាមត្រជាក់ឡើយ។ ដូចដែលបានបង្ហាញពីខាងដើម ប្រទេសឥណ្ឌាបានប្រកាសនៅការបន្តស្ថិតនៅអព្យាក្រឹត្យ។ ប្រទេសឥណ្ឌូនេស៊ី ដែលជាប្រទេសដីកោះមួយនៅអាស៊ីអាគ្នេយ៍ ក៏បានតស៊ូនៅក្នុងការរក្សាការមិនចូលរួមរបស់ខ្លួន។ នៅក្នុងឆ្នាំ 1955 ប្រទេសនេះបានស្វាគមន៍មេដឹកនាំជាច្រើនមកពីអាស៊ី និងអាហ្វ្រិកចូលរួមនៅក្នុងសន្និសិទទីក្រុងបានដុង។ ពួកគេទាំងអស់គ្នាបានជួបប្រជុំដើម្បីបង្កើតនូវអ្វីដែលគេហៅថា "កម្លាំងទីបី" នៃក្រុមប្រទេសឯករាជ្យ ឬក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធ។ ប្រទេសខ្លះដូចជាប្រទេសឥណ្ឌា និងឥណ្ឌូនេស៊ី អាចរក្សាអព្យាក្រឹត្យភាពរបស់ខ្លួនបាន។ ប៉ុន្តែ ប្រទេសមួយចំនួនទៀតបានចូលរួមជាមួយភាគីមហាអំណាច ឬប្រកួតប្រជែងគ្នាទៅវិញទៅមក។

## 2. ការប្រឈមមុខដាក់គ្នានៃអាមេរិកឡាទីន

បន្ទាប់ពីសង្គ្រាមលោកលើកទី 2 ឧស្សាហូបនីយកម្មយ៉ាងឆាប់រហ័ស, កំណើនប្រជាជន, និងកម្លាតយ៉ាងឆ្ងាយរវាងអ្នកមាន និងអ្នកក្រ បានបណ្តាលឱ្យប្រទេសនានានៅអាមេរិកឡាទីនសម្លឹងរកជំនួយពីមហាអំណាចទាំងពីរ។ ក្នុងពេលជាមួយគ្នានោះ ប្រទេសទាំងនេះភាគច្រើនបានផ្លាស់ប្តូរពីការគ្រប់គ្រងបែបប្រជាធិបតេយ្យ

ដែលមានអាយុកាលខ្លីមួយទៅរកការគ្រប់គ្រងបែបយោធាឃោរឃៅ។ ដូចដែលបានពិពណ៌នានៅក្នុងជំពូកទី 28 សហរដ្ឋអាមេរិកបានចូលរួមជាមួយអាមេរិកឡាទីនតាំងពីមុខសង្គ្រាមលោកលើកទី 2 មកម្លេះ។ អ្នកជំនួយអាមេរិកបានគាំទ្រមេដឹកនាំទាំងឡាយណាដែលការពារអត្ថប្រយោជន៍អាមេរិក ប៉ុន្តែមេដឹកនាំទាំងអស់នោះភាគច្រើនគឺជាអ្នកដែលជិះជាន់ប្រជាជនរបស់ខ្លួនឯង។ បន្ទាប់ពីសង្គ្រាម គំនិតកុំម្មុយនីស្ត និងជាតិនិយមបានជម្រុញឱ្យមានចលនាបដិវត្តនានា។ ចលនាទាំងនេះទទួលបានគាំទ្រយ៉ាងខ្លាំងក្លាពីសហភាពសូវៀត។ ក្នុងការឆ្លើយតប សហរដ្ឋអាមេរិកបានផ្តល់ជំនួយផ្នែកយោធា និងសេដ្ឋកិច្ចដល់មេដឹកនាំផ្តាច់ការទាំងឡាយណាដែលប្រឆាំងកុំម្មុយនីស្ត។

ហ្វីឌែល កាស្ត្រូ និងបដិវត្តនៅគុយបា៖ នៅក្នុងទសវត្សរ៍ឆ្នាំ 1950 ប្រទេសគុយបាត្រូវបានគ្រប់គ្រងដោយមេដឹកនាំផ្តាច់ការអប្រជាប្រិយភាពមួយរូបគឺ ហ្វូលជេនស៊ីអូ បាទីស្តា អ្នកដែលគាំទ្រសហរដ្ឋអាមេរិក។ ការមិនសប្បាយចិត្តរបស់ប្រជាជនគុយបាបាននាំទៅដល់ការធ្វើបដិវត្តប្រជាជនមួយ ដែលបានទម្លាក់បាទីស្តាពីអំណាចនៅក្នុងខែមករា ឆ្នាំ 1959 ។ អ្នកច្បាប់វ័យក្មេងមួយរូបឈ្មោះ ហ្វីឌែល កាស្ត្រូ គឺជាអ្នកដឹកនាំការធ្វើបដិវត្តនេះ។ ដំបូងឡើយ មានមនុស្សជាច្រើនកើតសសើរកាស្ត្រូចំពោះការធ្វើកំណែទម្រង់សង្គមគុយបា និងលើកកម្ពស់សេដ្ឋកិច្ច។ ប៉ុន្តែកាស្ត្រូគឺជាមេដឹកនាំផ្តាច់ការឃោរឃៅមួយរូប។ លោកបានពន្យាពេលបោះឆ្នោត, ដាក់គុក ឬប្រហារជីវិតក្រុមអ្នកប្រឆាំងលោក, និងត្រួតពិនិត្យយ៉ាងតឹងរឹងលើសារព័ត៌មាន។ នៅពេលដែលកាស្ត្រូធ្វើជាតិបនីយកម្មលើសេដ្ឋកិច្ចគុយបា លោកបានកាន់កាប់រោងចក្រកិនអំពៅ និងជម្រាញ់ស្ករបស់សហរដ្ឋអាមេរិក។ នៅក្នុងការឆ្លើយតប អេសិនហូវ័របានបញ្ជាឱ្យបញ្ឈប់ការធ្វើពាណិជ្ជកម្មជាមួយប្រទេសគុយបា។ ពេលនោះកាស្ត្រូបានត្រឡប់ទៅរកជំនួយផ្នែកសេដ្ឋកិច្ច និងយោធាពីសហភាពសូវៀត។

នៅក្នុងឆ្នាំ 1960 ស៊ីអាយអេចាប់ផ្តើមបណ្តុះបណ្តាលក្នុងអ្នកប្រឆាំងលោកកាស្ត្រូដែលបាននិរទេសខ្លួនចេញក្រៅប្រទេស។ នៅក្នុងខែមេសា ឆ្នាំ 1961 ពួកគេបានឈ្លានពានប្រទេសគុយបា ដោយបានចូលសំចតនៅជ្រោយជ្រូក។ ប៉ុន្តែសហរដ្ឋអាមេរិកមិនបានជួយវាយប្រហារតាមផ្លូវអាកាសជួយក្រុមអ្នកប្រឆាំងទាំងអស់នោះឡើយ។ កងកម្លាំងរបស់លោកកាស្ត្រូទទួលជ័យជំនះលើក្រុមអ្នកឈ្លានពានបានយ៉ាងងាយស្រួល ដែលបានធ្វើឱ្យអាមេរិកអាម៉ាស់មុខ។

ការប្រឈមមុខក្នុងការប្រើប្រាស់អាវុធនុយក្លេអ៊ែ-វិបត្តិមីស៊ីលនៅគុយបា៖ បរាជ័យនៅក្នុងឈ្លានពាននៅជ្រោយជ្រូកបានឱ្យមេដឹកនាំសូវៀតលោកនីគីតា គ្រូសឆេវ ជឿថាសហរដ្ឋអាមេរិកនឹងមិនប្រឆាំងជាមួយការពង្រីកឥទ្ធិពលរបស់សហភាពសូវៀតនៅអាមេរិកឡាទីនឡើយ។ ដូច្នេះ នៅក្នុងខែកក្កដា ឆ្នាំ 1962 លោកគ្រូសឆេវ ជាសម្ងាត់បានចាប់ផ្តើមស្ថាបនាមូលដ្ឋានមីស៊ីលចំនួន 42 នៅក្នុងប្រទេសគុយបា។ នៅក្នុងខែតុលា យន្តហោះស៊ើបការមួយរបស់អាមេរិកបានរកឃើញទីតាំងទាំងអស់នោះ។ ប្រធានាធិបតី ចន អេហ្វ ខេនណឺឌី បានប្រកាសថា មីស៊ីលដែលមានចម្ងាយជិតដែនដីសហរដ្ឋអាមេរិកពេក គឺជាការគំរាមកំហែងមួយ។ លោកបានទាមទារឱ្យមានដក់ចេញនូវមីស៊ីលទាំងអស់នោះ និងបានប្រកាសឱ្យមានការបិទខ្ទប់ផ្លូវទឹកនានាចូលទៅកាន់ប្រទេសគុយបាដើម្បីការពារការដំឡើងមីស៊ីលកាន់តែច្រើនពីសំណាក់សហភាពសូវៀតលើទឹកដីគុយបា។ នៅក្នុងការសម្ភាសន៍មួយនៅថ្ងៃទី 27

ខែតុលា ឆ្នាំ 1962 លោកកាស្រ្តូបានតវ៉ា និងថាប្រទេសរបស់លោកត្រូវបានគេយកធ្វើជាកូនអុកនៅក្នុងសង្គ្រាមត្រជាក់៖ ប្រទេសគុយបាមិនបានដើរតួជាអ្នកស្ថិតនៅចំកណ្តាលក្នុងជម្លោះរវាងលោកខាងលិច និងលោកខាងកើតឡើយ។ អ្វីដែលយើងចាប់អារម្មណ៍នោះគឺអធិបតេយ្យពេញលេញរបស់ជាតិ។ ប្រទេសគុយបាមិនមានបំណងណាមួយចូលរួមនៅក្នុងសង្គ្រាមត្រជាក់ឡើយ។

ប៉ុន្តែតាមពិតទៅលោកកាស្រ្តូ និងគុយបាបានចូលរួមយ៉ាងខ្លាំងក្លានៅក្នុងសង្គ្រាមត្រជាក់។ ការទាមទាររបស់លោកខេនណឺឌីដើម្បីឱ្យមានការដកចេញនូវមីស៊ីលរបស់សហភាពសូវៀតបានរុញច្រានឱ្យសហរដ្ឋអាមេរិក និងសហភាពសូវៀតស្ថិតនៅស្ថានភាពនៃការបះទង្គិចគ្នាមួយ។ ប្រជាជននៅលើពិភពលោកមានការភ័យខ្លាចចំពោះសង្គ្រាមនុយក្លេអ៊ែ។ ជាសំណាងល្អ លោកគ្រូសឆេវបានយល់ព្រមនៅក្នុងការដកចេញនូវមីស៊ីល ជាថ្នូរទៅនឹងការសន្យារបស់អាមេរិកក្នុងការមិនឈ្លានពានប្រទេសគុយបា។ ដំណោះស្រាយវិបត្តិមីស៊ីលនៅគុយបាបានបន្សល់ឱ្យលោកកាស្រ្តូនូវបានពឹងផ្អែកទាំងស្រុងលើជំនួយរបស់សូវៀត។ ក្នុងការផ្លាស់ប្តូរទៅនឹងជំនួយនេះ លោកកាស្រ្តូបានគាំទ្រការធ្វើបដិវត្តកុំម្មុយនីស្តនៅអាមេរិកឡាទីន និងអាហ្រ្វិក។ ប៉ុន្តែ ជំនួយរបស់សូវៀតដល់ប្រទេសគុយបាបានបញ្ចប់ភ្លាមៗបន្ទាប់ពីការដួលរលំនៃសហភាពសូវៀតនៅក្នុងឆ្នាំ 1991 ។ ហេតុការណ៍នេះបានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ប្រទេសគុយបា។ បន្តិចម្តងៗ លោកកាស្រ្តូបានកាត់បន្ថយការត្រួតត្រារបស់រដ្ឋលើសេដ្ឋកិច្ច និងសម្លឹងទៅរកការធ្វើទំនាក់ទំនងឱ្យកាន់តែប្រសើរជាមួយប្រទេសដទៃទៀត។

សង្គ្រាមស៊ីវិលនៅក្នុងប្រទេសនីការ៉ាហ្គ័រ៖ ក៏ដូចជាសហរដ្ឋអាមេរិកដែលបានគាំទ្រលោកបាទីស្តានៅក្នុងប្រទេសគុយបា ពួកគេក៏បានផ្តល់ជំនួយដល់មេដឹកនាំផ្តាច់ការនីការ៉ាហ្គ័រ លោកអាណាស្តាស៊ីអូ សូម៉ូហ្សា និងគ្រួសាររបស់លោកចាប់ផ្តាំពីឆ្នាំ 1933 មក។ នៅក្នុងឆ្នាំ 1979 ពួកកុំម្មុយនីស្តសេនឌីនីស្តាបានបះបោរដណ្តើមអំណាចពីកូនប្រុសរបស់សូម៉ូហ្សា។ ទាំងសហរដ្ឋអាមេរិក និងសហភាពសូវៀតបានបង្ហាញពីគោលបំណងនៅក្នុងការបញ្ជូនជំនួយដល់ពួកសេនឌីនីស្តា និងមេដឹកនាំរបស់ពួកគេ ដាញែល អូតេហ្គា។ ប៉ុន្តែ ពួកសេនឌីនីស្តា បានផ្តល់ជំនួយដល់ក្រុមបះបោរម៉ាក្សនិយមផ្សេងទៀតដល់ប្រទេសជិតខាង អែលសាលវ៉ាឌ័រ។ ដើម្បីជួយដល់រដ្ឋាភិបាលអែលសាលវ៉ាឌ័រ ប្រយុទ្ធជាមួយពួកបះបោរទាំងនោះ សហរដ្ឋអាមេរិកបានគាំទ្រកងកម្លាំងប្រឆាំងកុំម្មុយនីស្តនីការ៉ាហ្គ័រដែលមានឈ្មោះថា ក្រុមប្រឆាំង ឬក្រុមប្រឆាំងបដិវត្ត។

សង្គ្រាមស៊ីវិលនៅនីការ៉ាហ្គ័របានអូសបន្លាយអស់រយៈពេលជាងមួយទសវត្សរ៍ និងបណ្តាលចុះខ្សោយយ៉ាងខ្លាំងក្លាដល់សេដ្ឋកិច្ចប្រទេសប្រទេសនេះ។ នៅក្នុងឆ្នាំ 1990 ប្រធានាធិបតី អូតេហ្គា បានយល់ព្រមនៅក្នុងការរៀបចំឱ្យមានការបោះឆ្នោតដោយសេរី ដែលជាការបោះឆ្នោតលើកដំបូងនៅក្នុងប្រវត្តិសាស្រ្តប្រទេសនីការ៉ាហ្គ័រ។ លោកវីអូឡេតា ចាម៉ូរ៉ូ ដែលជាបេក្ខជនកំណែទម្រង់មួយរូបបានទទួលជ័យជំនះលើលោកអូតេហ្គា។ ពួកសេនឌីនីស្តាក៏បរាជ័យនៅក្នុងការបោះឆ្នោតឆ្នាំ 1996 និង 2001 ។

### 3. ការប្រឈមមុខដាក់គ្នានៅមជ្ឈឹមបូព៌ា

ការប្រឈមមុខដាក់គ្នានៃសង្គ្រាមត្រជាក់នៅតែបន្តកើតមានឡើងនៅពាសពេញពិភពលោក។ តំបន់ដែលសម្បូរប្រេងកាតនៅមជ្ឈិមបូព៌ាញគឺជាតំបន់ដែលមានការទាក់ទាញមហាអំណាចទាំងពីរផងដែរ។

តម្លៃសាសនា និងអាណាចក្រប៉ះទង្គិចគ្នានៅអ៊ីរ៉ង់៖ នៅពាសពេញតំបន់មជ្ឈិមបូព៌ា ទ្រព្យសម្បត្តិដែលបានមកពីឧស្សាហកម្មប្រេងកាត បានជម្រុញឱ្យមានការប៉ះទង្គិចគ្នារវាងតម្លៃអ៊ីស្លាមប្រពៃណីជាមួយនិងសម្ភារៈនិយមបែបលោកខាងលិច។ មិនមានប្រទេសណាដែលមានបញ្ហាវប្បធម៌ខ្លាំងក្លាដូចប្រទេសអ៊ីរ៉ង់ (ពៃក្សមុនឆ្នាំ 1935) ឡើយ។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 មេដឹកនាំអ៊ីរ៉ង់ លោកសាម៉ូហាមេដ រ៉េហ្សា ប៉ាឡាវី បានចាប់យកប្រព័ន្ធរដ្ឋាភិបាលបែបលោកខាងលិច និងក្រុមហ៊ុនប្រេងកាតល្បីៗរបស់ពួកលោកខាងលិច។ ក្រុងអ្នកជាតិនិយមអ៊ីរ៉ង់មានការមិនសប្បាយចិត្តចំពោះការចងសម្ព័ន្ធភាពជាមួយបរទេសនេះ និងបានបង្រួបបង្រួមគ្នាស្ថិតនៅក្រោយការដឹកនាំរបស់នាយករដ្ឋមន្ត្រីមហាមេដ ម៉ូសាដេក។ ពួកគេបានធ្វើជាតូបនីយកម្មលើក្រុមហ៊ុនប្រេងកាតមួយដែលកាន់កាប់ដោយអង់គ្លេសនៅក្នុងឆ្នាំ 1953 និងបានជម្រុញឱ្យស្តេចរត់គៀសខ្លួន។ ដោយមានការភ័យខ្លាចថាប្រទេសអ៊ីរ៉ង់នឹងងាកទៅរកការគាំទ្រពីសំណាក់សហភាពសូវៀត សហរដ្ឋអាមេរិកបានជួយនៅក្នុងការស្តារអំណាចស្តេចអ៊ីរ៉ង់ឡើងវិញ។

សហរដ្ឋអាមេរិកគាំទ្រការគ្រប់គ្រងបែបអាណាចក្រ៖ ជាមួយនឹងការគាំទ្ររបស់សហរដ្ឋអាមេរិក ស្តេចអ៊ីរ៉ង់បានធ្វើបស្ចិមនីយកម្មលើប្រទេសរបស់ទ្រង់។ ត្រឹមចុងទសវត្សរ៍ឆ្នាំ 1950 រាជធានីរបស់ប្រទេសអ៊ីរ៉ង់ តេអេរ៉ង់ពោរពេញទៅដោយអាគារខ្ពស់ៗ, ធនាគារបរទេស, និងរោងចក្រសម័យទំនើប។ ប៉ុន្តែ ប្រជាជនអ៊ីរ៉ង់រាប់លាននាក់នៅតែបន្តរស់នៅក្នុងភាពក្រីក្រតោកយ៉ាក។ ស្តេចអ៊ីរ៉ង់ព្យាយាមនៅក្នុងការធ្វើឱ្យទន់ខ្សោយនូវឥទ្ធិពលនយោបាយពីសំណាក់មេដឹកនាំម៉ូស្លីមអភិរក្សនិយម ដែលគេស្គាល់ថា អាយ៉ាតូឡះ អ្នកដែលប្រឆាំងជាមួយឥទ្ធិពលបស្ចិមលោក។ មេដឹកនាំសាសនាប្រឆាំងនេះឈ្មោះ អាយ៉ាតូឡះ រូហូឡា ខូម៉ីនី រស់នៅនិរទេសខ្លួនខាងក្រៅប្រទេស។ ជម្រុញដើយសារសំឡេងរបស់លោក ប្រជាជនអ៊ីរ៉ង់បានងើបឡើងធ្វើកុប្បកម្មតាមទីក្រុងសំខាន់ៗទាំងឡាយនៅចុងឆ្នាំ 1978 ។ ដោយប្រឈមជាមួយការប្រឆាំងគ្រប់ទីកន្លែង ស្តេចអ៊ីរ៉ង់បានរត់ចេញពីប្រទេសនៅក្នុងឆ្នាំ 1979 ។ អ្នកទទួលបានជ័យជំនះ លោកខូម៉ីនី បានត្រឡប់មកបង្កើតរដ្ឋអ៊ីស្លាមមួយ និងបានបង្កើតយោជាអ៊ីរ៉ង់ចេញមកពីអ៊ីស្លាម។

ការប្រឆាំងរបស់លោកខូម៉ីនីចំពោះគោលនយោបាយរបស់សហរដ្ឋអាមេរិក៖ ការប្រកាន់ខ្ជាប់ខ្លួនចំពោះសាសនាអ៊ីស្លាម ស្ថិតនៅក្នុងគោលនយោបាយក្នុងស្រុងរបស់លោកខូម៉ីនី។ ប៉ុន្តែម លោកមានការមិនសប្បាយចិត្តចំពោះសហរដ្ឋអាមេរិក ដោយសារសហរដ្ឋអាមេរិកបានគាំទ្រស្តេចអ៊ីរ៉ង់ ហើយវាគឺជាចំណុចស្នូលនៃគោលនយោបាយការបរទេសរបស់លោក។ នៅក្នុងឆ្នាំ 1979 ជាមួយនឹងការប្រសិទ្ធិពរពីអាយ៉ាតូឡះ ក្រុមអ្នកបដិវត្តអ៊ីស្លាមវ័យក្មេងបានដណ្តើមកាន់កាប់ស្ថានទូតសហរដ្ឋអាមេរិកនៅក្នុងទីក្រុងតេអេរ៉ង់។ ពួកគេចាប់ជនជាតិអាមេរិកជាង 60 នាក់ធ្វើជាចំណាត់ខ្មាំង និងបានទាមទារឱ្យសហរដ្ឋអាមេរិកបង្ខំឱ្យស្តេចអ៊ីរ៉ង់ត្រឡប់មកប្រឈមជាមួយនឹងការកាត់ក្តី។

ភាគច្រើននៃចំណាត់ខ្មាំងបន្តស្ថិតនៅក្នុងគុកអស់រយៈពេល 444 ថ្ងៃមុនពេលដែលត្រូវបានដោះលែងនៅក្នុងឆ្នាំ 1981 ។

លោកខូមីនី បានលើកទឹកចិត្តដល់ពួកម៉ូស្លីមជ្រុលនិយមគ្រប់ទីកន្លែង ឱ្យទម្លាក់រដ្ឋាភិបាលអាណាចក្ររបស់ពួកគេ។ ដោយមានបំណងនៅក្នុងការបង្រួបបង្រួមពួកម៉ូស្លីម គោលនយោបាយនេះបានបង្កើនទំនាស់រវាងប្រទេសអ៊ីរ៉ង់ជាមួយប្រទេសជិតខាងរបស់ខ្លួន និងបង្កទំនាស់ដែនដីជាមួយគូសត្រូវរបស់ពួកគេគឺប្រទេសអ៊ីរ៉ាក់។ មេដឹកនាំយោធាមួយរូបឈ្មោះ សាដាម ហូសេន គឺជាអ្នកដឹកនាំប្រទេសអ៊ីរ៉ាក់ក្នុងនាមជារដ្ឋអាណាចក្រមួយ។

សង្គ្រាមបានផ្ទុះឡើងរវាងប្រទេសអ៊ីរ៉ង់ និងអ៊ីរ៉ាក់នៅក្នុងឆ្នាំ 1980 ។ សហរដ្ឋអាមេរិកបានផ្តល់ជំនួយជាសម្ងាត់ដល់ភាគីទាំងសងខាង ដោយសារពួកគេមិនចង់ឱ្យមានការប្រែប្រួលតុល្យភាពនៃអំណាចនៅក្នុងតំបន់នេះឡើយ។ ផ្ទុយទៅវិញ សហភាពសូវៀតគឺជាអ្នកគាំទ្រប្រទេសអ៊ីរ៉ាក់តាំងពីដើមរៀងមក។ មានប្រជាជនអ៊ីរ៉ង់ និងអ៊ីរ៉ាក់រាប់លាននាក់បានស្លាប់នៅក្នុងសង្គ្រាម មុនពេលដែលអង្គការសហប្រជាជាតិធ្វើការចរចារឱ្យមានកិច្ចឈប់បាញ់មួយនៅក្នុងឆ្នាំ 1988 ។

មហាអំណាចប្រឈមមុខដាក់គ្នានៅក្នុងប្រទេសអាហ្គានីស្ថាន៖ អស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីសង្គ្រាមលោកលើកទី 2 ប្រទេសអាហ្គានីស្ថានអាចរក្សាឯករាជ្យភាពរបស់ពួកគេពីសហភាពសូវៀត និងសហរដ្ឋអាមេរិក។ ប៉ុន្តែ នៅក្នុងទសវត្សរ៍ឆ្នាំ 1950 ឥទ្ធិពលរបស់សហភាពសូវៀតនៅក្នុងប្រទេសបានកើនឡើង។ នៅចុងទសវត្សរ៍ឆ្នាំ 1970 ការបះបោរមួយរបស់ពួកម៉ូស្លីមបានគំរាមកំហែងទៅរកការផ្តួលរំលំអំណាចរបស់របបកុំម្មុយនីស្តនៅក្នុងប្រទេសអាហ្គានីស្ថាន។ ការបះបោរនាំទៅដល់ការឈ្លានពានរបស់សហភាពសូវៀតនៅក្នុងឆ្នាំ 1979 ។

សហភាពសូវៀតសង្ឃឹមថាខ្លួនអាចជួយគាំទ្រពួកកុំម្មុយនីស្តអាហ្គានីស្ថាន និងដកចេញពីប្រទេសនេះបានឆាប់រហ័ស។ ប៉ុន្តែ ក៏ដូចជាសហរដ្ឋអាមេរិកនៅក្នុងប្រទេសវៀតណាមដែល សហភាពសូវៀតបានជាប់គាំនៅក្នុងប្រទេសអាហ្គានីស្ថាន។ ហើយដូចជាពួកវៀតកុងនៅក្នុងប្រទេសវៀតណាម កងកម្លាំងបះបោរមានចំនួនច្រើនជាកងយោធារបស់សហភាពសូវៀត។ ដោយទទួលបានការផ្គត់ផ្គង់សម្ភារៈពីអាមេរិក ក្រុងបះបោរអាហ្គានីស្ថានដែលគេហៅថា ម៉ូចាហ៊ីឌីន ឬអ្នកប្រយុទ្ធដ៏ពិសិដ្ឋ បានបន្តប្រយុទ្ធជាមួយយោធាសហភាពសូវៀត។

សហរដ្ឋអាមេរិកបានផ្តល់អាវុធដល់ពួកបះបោរដោយសារពួកគេចាត់ទុកថាការឈ្លានពានរបស់សូវៀតគឺជាការគំរាមកំហែងមួយដល់តំបន់មជ្ឈិមបូព៌ាដែលជាតំបន់ផ្គត់ផ្គង់ប្រេងកាត។ លោកប្រធានាធិបតី ជីមី ខាតធ័រ បានប្រមានសូវៀតចំពោះការព្យាយាមណាមួយនៅក្នុងការត្រួតត្រាឈូងសមុទ្រពៃក្ស។ ដើម្បីប្រឆាំងជាមួយនឹងការឈ្លានពានលោកបានបញ្ឈប់ការដឹកជញ្ជូនគ្រាប់ធុញ្ញជាតិរបស់អាមេរិកទៅកាន់សហភាពសូវៀត និងបានបញ្ជាឱ្យមានការធ្វើពហិការរបស់សហរដ្ឋអាមេរិកចំពោះកីឡាអូឡាំពិកនៅម៉ូស្គូឆ្នាំ 1980 ។ នៅក្នុងទសវត្សរ៍ឆ្នាំ 1980 ប្រធានាធិបតីថ្មីរបស់សូវៀត លោកមីខាអ៊ីល ហ្គូបាឆេវ បានទទួលស្គាល់ថាសង្គ្រាមបានបណ្តាលឱ្យមានគ្រោះអត់ឃ្លាន។ លោកបានដកកងទ័ពទាំងអស់របស់សូវៀតចេញពីប្រទេសអាហ្គានីស្ថានត្រឹមឆ្នាំ 1989 ។ នៅពេលនោះ ភាពចលាចលនៅក្នុងស្រុក និងបញ្ហាសេដ្ឋកិច្ចបានធ្វើឱ្យសហភាពសូវៀតបែកខ្ញែកគ្នាដោយខ្លួនឯង។

# មេរៀនទី 5៖ សង្គ្រាមត្រជាក់រលាយ

## 1. គោលនយោបាយសូវៀតនៅអឺរ៉ុបខាងកើត និងប្រទេសចិន

មានមេដឹកនាំសូវៀតដែលចេះថ្លឹងថ្លែងច្បាស់លាស់ បានឡើងកាន់អំណាចបន្ទាប់ពីមរណៈភាពរបស់ស្តាលីន។ ពួកគេបានអនុញ្ញាតឱ្យប្រទេសដែរណបពួកគេគ្រប់ទីកន្លែងទទួលបានឯករាជ្យកាន់តែច្រើន ដ៏រាបណាពួកគេនៅតែបន្តចងសម្ព័ន្ធមិត្តជាមួយសហភាពសូវៀត។ ប៉ុន្តែ នៅអំឡុងទសវត្សរ៍ឆ្នាំ 1950 និង 1960 ការកើនឡើងនៃចលានាប្រឆាំងនៅអឺរ៉ុបខាងកើត បានគំរាមកំហែងការគ្រប់ដណ្តាប់អំណាចរបស់សូវៀតនៅក្នុងតំបន់។ ការកើនឡើងនៃជម្លោះជាមួយប្រទេសចិនក៏បានកាត់បន្ថយការយកចិត្តទុកដាក់ និងកម្លាំងរបស់សូវៀត។

ការលុបបំបាត់ស្តាលីន និងការផ្ទុះនៃការតវ៉ា៖ បន្ទាប់ពីលោកស្តាលីនស្លាប់នៅក្នុងឆ្នាំ 1953 លោកនីគីតា គ្រូសឆេវ បានក្លាយជាមេដឹកនាំលេចធ្លោរបស់សូវៀត។ នៅក្នុងឆ្នាំ 1956 លោកគ្រូសឆេវបានបរិហារលោកស្តាលីនចំពោះការចាប់ដាក់គុក និងសម្លាប់ប្រជាពលរដ្ឋសូវៀត។ សន្ទរកថារបស់លោកជាសញ្ញាណនៃការចាប់ផ្តើមគោលនយោបាយមួយដែលគេហៅថា ការលុបបំបាត់ស្តាលីន ឬលាងសម្អាតការចាងចាំពីលោកស្តាលីននៅក្នុងប្រទេស។ កម្មករបានវាយកម្ទេចរូបសំណាក់នានារបស់អតីតជនផ្តាច់ការ។ លោកគ្រូសឆេវបានស្នើឱ្យមាន "ការប្រកួតប្រជែងដោយសន្តិភាព" ជាមួយរដ្ឋមូលធននិយម។

ប៉ុន្តែ ទស្សនវិស័យថ្មីរបស់សូវៀតនេះមិនបានផ្លាស់ប្តូរជីវភាពរស់នៅរបស់បណ្តាលប្រទេសរណបខ្លួនឡើយ។ ការមិនសប្បាយចិត្តរបស់ពួកគេដក់ពេលវេលាដែលត្រូវងើបឡើងតវ៉ា។ ឧទាហរណ៍ នៅក្នុងខែតុលា ឆ្នាំ 1956 កងទ័ពហុងគ្រីបានចូលរួមជាមួយក្រុមអ្នកតវ៉ា ដើម្បីទម្លាក់រដ្ឋាភិបាលហុងគ្រីដែលស្ថិតក្រោមការគ្រប់គ្រងរបស់សូវៀត។ ដោយធ្វើដំណើរឆ្ពោះទៅកាន់រដ្ឋធានីប៊ូដាប៉េស ក្រុមកុប្បករបានក្រវីទង់ជាតិហុងគ្រី ជាមួយនឹងការកាត់ទម្លាក់និមិត្តសញ្ញាកុំម្មុយនីស្ត ញញួរ និងកណ្តៀវ។ អ្នកតវ៉ាម្នាក់បានប្រកាសថា "ចាប់ពីកុមាររហូតដល់មនុស្សចាស់មិនមាននណារម្នាក់ចង់បានកុំម្មុយនីស្តឡើយ"។

មេដឹកនាំកុំម្មុយនីស្តហុងគ្រីដែលមានប្រជាប្រិយភាព និងជាអ្នកសេរីនិយមឈ្មោះ អ៊ីមរេ ណាហ្គី បានបង្កើតរដ្ឋាភិបាលថ្មីមួយ។ ណាហ្គីបានសន្យារៀបចំឲ្យមានការបោះឆ្នោតដោយសេរី និងបានទាមទារឱ្យកងទ័ពសូវៀតចាកចេញពីប្រទេសហុងគ្រី។ នៅក្នុងការឆ្លើយតប កងរថក្រោះ និងកងទ័ពថ្មើជើងបានធ្វើដំណើរចូលទីក្រុងប៊ូដាប៉េសនៅក្នុងខែវិច្ឆិកា។ ក្រុមអ្នកប្រយុទ្ធដើម្បីសេរីហុងគ្រីរាប់ពាន់នាក់បានងើបឡើងកាន់អាវុធ និងដបសាំង ប៉ុន្តែពួកគេត្រូវបានបង្ក្រាប។ រដ្ឋាភិបាលគាំទ្រសូវៀតមួយត្រូវបានបង្កើតឡើង ហើយណាហ្គីត្រូវបានប្រហារជីវិត។

ការបះបោរនៅឆេកូស្លូវ៉ាគី៖ បើទោះបីជាបានបង្ហាញពីការប្រើកម្លាំងទ័ពនៅក្នុងប្រទេសហុងគ្រីក៏ដោយក៏លោកគ្រូសឆេវ បានបាត់បង់កិត្តិនាមរបស់លោកនៅក្នុងប្រទេស ដែលបណ្តាលមកពីវិបត្តិមីស៊ីលនៅគុយបានៅក្នុងឆ្នាំ 1962 ។ នៅក្នុងឆ្នាំ 1964 មេដឹកនាំនានានៅក្នុងបក្សបានបោះឆ្នោតដកលោកចេញពីអំណាច។ អ្នកដែលជំនួសតំណែងរបស់លោកលីអូនីដ ប្រេសនេវ ភ្លាមៗបានបង្កើតឱ្យមានគោលនយោបាយគាបសង្កត់នៅក្នុងស្រុក។

បក្សកុំម្មុយនីស្តបានបង្កើតច្បាប់នានាដែលកម្រិតសិទ្ធិជាមូលដ្ឋានមួយចំនួន ដូចជាសិទ្ធិសេរីភាពនៅក្នុងការបញ្ចេញមតិយោបល់ និងសេរីភាពជំនឿ។ រដ្ឋាភិបាលបានត្រួតត្រាយ៉ាងតឹងរឹងលើរាល់ការបោះពុម្ពផ្សាយទាំងឡាយ។ លោកប្រេសនេវ បានបង្ក្រាបលើអ្នកទាំងឡាយណាដែលមានបំណងចង់ប្រឆាំងជាមួយគោលនយោបាយរបស់លោក។ ឧទាហរណ៍ នគរបាលសម្ងាត់បានចាប់ខ្លួនក្រុមអ្នកប្រឆាំងជាច្រើន ដោយក្នុងនោះមានលោកអាលេកសេនសូលហ្សេនីតស៊ីន ដែលជាជ័យលាភីពានរង្វាន់ណូបែលផ្នែកអក្សរសាស្ត្រឆ្នាំ 1970 ។ បន្ទាប់មកពួកគេបាននិរទេសលោកចេញពីសហភាពសូវៀត។ លោកប្រេសនេវបង្ហាញយ៉ាងច្បាស់ថា លោកនឹងមិនអត់ឱនដល់ក្រុមអ្នកប្រឆាំងនៅអឺរ៉ុបខាងកើតដូចគ្នា។ គោលនយោបាយរបស់លោកត្រូវបានសាកល្បងនៅដើមឆ្នាំ 1968 ។ នៅពេលនោះ មេដឹកនាំកុំម្មុយនីស្តឆេក ឈ្មោះអាឡិចសាន់ឌ័រ ឌូបឆេក បានបន្ធូរបន្ថយការគ្រប់គ្រងបែបតឹងរឹងដោយជំនួសមកវិញនូវការគ្រប់គ្រងបែបសង្គមនិយមដែលមានលក្ខណៈធូរលុងមួយ។ អំឡុងសម័យនៃការធ្វើកំណែទម្រង់នេះ នៅពេលដែលរដ្ឋធានីរបស់ប្រទេសឆេកូស្លូវ៉ាគីរីកដុះដាលនូវគំនិតថ្មីៗ ត្រូវបានគេហៅថា និទាឃរដូវទីក្រុងប្រាក។ ប៉ុន្តែ វាមិនបានស្ថិតស្ថេរដល់រដូវក្តៅឡើយ។ នៅថ្ងៃទី 20 ខែកក្កដា កងកម្លាំងមកពីប្រទេសជាសមាជិកកតិកាសញ្ញាវ៉ាសាវីបានឈ្លានពានប្រទេសឆេកូស្លូវ៉ាគី។ លោកប្រេសនេវបានគាំទ្រការឈ្លានពាននេះដោយអះអាងថា សហភាពសូវៀតមានសិទ្ធិនៅក្នុងការការពារប្រទេសរណបពួកគេពីការបដិសេធលិទ្ធិកុំម្មុយនីស្តជាគោលនយោបាយមួយដែលគេហៅថា យុទ្ធសាស្ត្រប្រេសនេវ។

សូវៀត និងចិនបែកបាក់៖ ខណៈពេលប្រទេសរណបជាច្រើនបានបះបោរប្រឆាំងជាមួយការគ្រប់គ្រងរបស់កុំម្មុយនីស្ត ប្រទេសចិនបានប្តេជ្ញាចិត្តចំពោះកុំម្មុយនីស្ត។ នៅចំពោះមុខ ដើម្បីពង្រឹកចំណងទាក់ទងរវាងមហាអំណាចកុំម្មុយនីស្ត ម៉ៅ និងស្តាលីនបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព 30 ឆ្នាំមួយនៅក្នុងឆ្នាំ 1950 ។ ប៉ុន្តែ ស្មារតីនៃកិច្ចសហប្រតិបត្តិការរបស់ពួកគេបានបាត់បង់មុនពេលដែលសន្ធិសញ្ញានេះបានធ្វើទៅទៀត។

សូវៀតគិតថាចិននឹងអនុវត្តតាមការដឹកនាំរបស់សូវៀតនៅក្នុងកិច្ចការពិភពលោក។ ប៉ុន្តែ ដូចដែលប្រទេសចិនកាន់តែមានទំនុកចិត្តលើខ្លួនឯង ការមិនសប្បាយចិត្តរបស់ពួកគេចាប់ផ្តើមមានចំពោះទីក្រុងម៉ូស្គូ។ ពួកគេចាប់ផ្តើមពង្រីកសាខាកុំម្មុយនីស្តរបស់ពួកគេផ្ទាល់ទៅកាន់ទ្វីបអាហ្វ្រិក និងផ្នែកផ្សេងៗទៀតនៃទ្វីបអាស៊ី។ នៅក្នុងឆ្នាំ 1959 លោកគ្រូសឆេវបានដាក់ទណ្ឌកម្មចិន ដោយបដិសេធនៅក្នុងការចែករំលែកបច្ចេកវិទ្យាសម្ងាត់នុយក្លេអ៊ែ។ នៅឆ្នាំបន្ទាប់ សហភាពសូវៀតបានបញ្ចប់ជំនួយបច្ចេកទេសសេដ្ឋកិច្ចដល់ប្រទេសចិន។ ការបែកបាក់រវាងសូវៀត និងចិនកាន់តែកើនឡើងខ្លាំងដែលនាំទៅដល់ការវាយប្រយុទ្ធគ្នានៅតាមព្រំដែនរវាងប្រទេសទាំងពីរ។ បន្ទាប់ពីឧប្បត្តិហេតុផ្ទួនៗ ប្រទេសជិតខាងទាំងពីរបានព្រមព្រៀងសន្តិភាពដ៏ផុយស្រួយមួយជាមួយគ្នា។

## 2. ពីគោលនយោបាយប្រឈមមុខដាក់គ្នាឆ្ពោះទៅរកការបញ្ចប់ជម្លោះ

នៅក្នុងទសវត្សរ៍ឆ្នាំ 1970 សហរដ្ឋអាមេរិក និងសហភាពសូវៀតបានងាកចេញពីគោលនយោបាយប្រឈមមុខដាក់គ្នាដែលពួកគេបានអនុវត្តបន្ទាប់ពីចប់សង្គ្រាមលោកលើកទី 2 ។ មហាអំណាចទាំងពីរបានបន្ធូរបន្ថយជម្លោះបន្តិចម្តងៗ។

គោលនយោបាយប្រឈមមុខដាក់គ្នាត្រូវបានលុបបំបាត់៖ គោលនយោបាយប្រឈមមុខដាក់គ្នាត្រូវបានអនុវត្តជាបន្តបន្ទាប់អំឡុងសម័យកាលរបស់ប្រធានាធិបតីអេសិនហូវ័រ, កេនណឺឌី, និងចនស៊ុន ដែលនាំទៅដល់វិបត្តិកាន់តែធ្ងន់ធ្ងរពីមេដឹកនាំមួយទៅមេដឹកនាំមួយ។ តាមរយៈការផ្ទុះឡើងនៃវិបត្តិទូទាំងពិភពលោក ពួកគេមានភាពភ័យខ្លាចដូចៗគ្នា គឺសង្គ្រាមនុយក្លេអ៊ែដែលនឹងអាចកើតមានឡើង។

នៅក្នុងឆ្នាំ 1960 ឧប្បត្តិហេតុយូ-2 បានរារាំងដល់ជំនួបរបស់សហរដ្ឋអាមេរិក និងសហភាពសូវៀតដើម្បីពិភាក្សាអំពីការស្តាបនាយោធារបស់ភាគីទាំងសងខាង។ បន្ទាប់មក អំឡុងសម័យកាលនៃការគ្រប់គ្រងរបស់ប្រជាធិបតីចន អេហ្វ. កេនណឺឌី នៅដើមទសវត្សរ៍ឆ្នាំ 1960 វិបត្តិមីស៊ីលនៅគុយបាបានធ្វើឱ្យការប្រើប្រាស់នុយក្លេអ៊ែរបស់មហាអំណាចអាចនឹងកើតមានពិតប្រាកដ។ វិបត្តិនេះបានបញ្ចប់នៅពេលដែលនាវារបស់សូវៀតបានបើកត្រឡប់ថយក្រោយវិញដើម្បីជៀសវៀងការប្រឈមមុខដាក់គ្នានៅសមុទ្ទ។ រដ្ឋលេខាសហរដ្ឋអាមេរិកលោកឌីន រូស បាននិយាយថា "ភ្នែករបស់យើងម្នាក់ៗបានបើកធំៗ ហើយខ្ញុំបានគិតថាអ្នកដ៏ទៃផ្សេងគ្រាន់តែព្រិកតែប៉ុណ្ណោះ"។ ប៉ុន្តែរដ្ឋលេខាការពារជាតិរបស់កេនណឺឌី លោកម៉ាកណាម៉ារ៉ា បានបង្ហាញថាពិភពលោកបានឈ្លានជិតដល់គ្រោះមហន្តរាយប៉ុណ្ណោះ នៅចំពោះមុខនៃការវាយប្រហារតាមផ្លូវអាកាសមួយនៅគុយបា និងនៅចំពោះមុខភាពអាចទៅរួចនៅការវាយប្រហារលើដី ហើយខ្ញុំអាចនឹងនិយាយបានថា វាពិតជាច្បាស់ណាស់ថា ដោយមិនចាំបាច់ទទួលការអនុញ្ញាតពីទីក្រុងម៉ូស្គូ មេបញ្ជាការរបស់គុយបា ឬមន្ត្រីរបស់សូវៀតដែលទទួលបន្ទុកមីស៊ីលនឹងបាញ់មីស៊ីលរយៈចម្ងាយឆ្ងាយដែលភ្ជាប់ក្បាលនុយក្លេអ៊ែមួយ ឬច្រើនគ្រាប់មកលើទីក្រុងមួយ ឬច្រើនរបស់អាមេរិកដែលស្ថិតនៅតំបន់ឆ្នេរភាគខាងកើត។

ជម្លោះនៅតែបន្តកើនមានខ្លាំង។ បន្ទាប់ពីការលួចធ្វើឃាតលោកកេនណឺឌីនៅក្នុងឆ្នាំ 1963 លោក លីនដុន ចនស៊ុន បានបន្តដំណែងជាប្រធានាធិបតី។ ដោយប្តេជ្ញានៅក្នុងការបញ្ឈប់ការរីករាលដាលនៃលទ្ធិកុំម្មុយនីស្តប្រធានាធិបតី ចនស៊ុនបានបង្កើនការចូលរួមរបស់សហរដ្ឋអាមេរិកនៅក្នុងសង្គ្រាមវៀតណាម។

សហរដ្ឋអាមេរិកត្រឡប់ទៅរកការបញ្ចប់ជម្លោះ៖ ការធ្វើបាតុកម្មបានរីករាលដាលនៅពាសពេញសហរដ្ឋអាមេរិកអំឡុងសង្គ្រាមវៀតណាម។ ហើយភាពចលាចលមិនត្រូវបានបញ្ចប់ឡើយបន្ទាប់ពីការដកខ្លួនចេញរបស់សហរដ្ឋអាមេរិកចេញពីសង្គ្រាមវៀតណាម។ ដូចដែលពួកគេព្យាយាមនៅក្នុងព្យាបាលរបួសផ្ទៃក្នុង សហរដ្ឋអាមេរិកបានបញ្ចប់គោលនយោបាយប្រឈមមុខផ្ទាល់ជាមួយសហភាពសូវៀត។ ការបញ្ចប់ជម្លោះ គឺជាគោលនយោបាយមួយដែលការកាត់បន្ថយជម្លោះនៅក្នុងសង្គ្រាមត្រជាក់ឱ្យស្ថិតនៅតិចតួច ដែលជំនួយគោលនយោបាយប្រឈមមុខដាក់គ្នា ស្ថិតនៅក្រោយរដ្ឋកាលរបស់លោក រីឆាដ អ៊ឹម. និចសុន ។

ការធ្វើដំណើររបស់ប្រធានាធិបតីនិចស៊ុនឆ្ពោះទៅរកការបញ្ចប់ជម្លោះលេចចេញមកពីទស្សនវិជ្ជាមួយដែលគេស្គាល់ថា រៀលប៉ូលីតិក ។ បច្ចេកពាក្យនេះមកពីភាសាអាឡឺម៉ង់ ដែលមានន័យថា "នយោបាយពិតប្រាកដ"។ នៅក្នុងការអនុវត្ត គោលនយោបាយពិតប្រាកដ មានន័យថា ត្រូវដោះស្រាយជាមួយប្រទេសដ៏ទៃដោយប្រើការអនុវត្ត

ជាក់ស្តែង និងមានភាពបត់បែន។ ខណៈពេលដែលសហរដ្ឋអាមេរិកនៅតែបន្តព្យាយាមនៅក្នុងការទប់ទល់ការរីកសាយភាយនៃលទ្ធិកុំម្មុយនីស្ត មហាអំណាចទាំងពីរបានព្រមព្រៀងគ្នានៅក្នុងការអនុវត្តន៍គោលនយោបាយបញ្ចប់ជម្លោះដើម្បីកាត់បន្ថយជម្លោះជាមួយគ្នា។

និចសុនធ្វើទស្សនៈកិច្ចទៅកាន់មហាអំណាចកុំម្មុយនីស្ត៖ គោលនយោបាយថ្មីរបស់និចសុនបានបង្ហាញពីការប្រែត្រឡប់ជាលក្ខណៈបុគ្គល ក៏ដូចជាការផ្លាស់ប្តូរនយោបាយមួយសម្រាប់ប្រទេសជាតិ។ ការរះឡើងនៃនយោបាយរបស់លោកនៅក្នុងទសវត្សរ៍ឆ្នាំ 1950 មួយផ្នែកធំដោយសារការប្រឆាំងកុំម្មុយនីស្តដ៏ខ្លាំងក្លារបស់លោក។ 20 ឆ្នាំក្រោយមក លោកបានក្លាយជាប្រធានាធិបតីអាមេរិកដំបូងដែលបានធ្វើដំណើរទស្សនៈទៅកាន់ប្រទេសកុំម្មុយនីស្តចិន។ ដំណើរទស្សនៈកិច្ចបានបង្ហាញថា មហាអំណាចពិភពលោកមាន 3 មិនមែនមានតែ 2 ឡើយ។ និចសុនបានពន្យល់ថា "យើងចង់ឱ្យប្រទេសចិននៅជាមួយយើងអង្គុយ និងចចារជាមួយរុស្ស៊ី"។

3 ខែបន្ទាប់ពីទស្សនៈកិច្ចនៅទីក្រុងប៉េកាំងនៅក្នុងខែកុម្ភៈ ឆ្នាំ 1972 ប្រធានាធិបតីនិចសុនបានធ្វើដំណើរទស្សនៈកិច្ចទៅកាន់សហភាពសូវៀត។ បន្ទាប់ពីជំនួបមួយចំនួនដែលគេហៅថា កិច្ចសន្ទនាកម្រិតយុទ្ធសាស្ត្រយោធាមក លោកនិចសុន និងលោកប្រេសនេវបានចុះហត្ថលេខាលើសន្ធិសញ្ញាកិច្ចសន្ទនាកម្រិតយុទ្ធសាស្ត្រយោធា 1 ។ កិច្ចព្រមព្រៀងរយៈពេល 5 ឆ្នាំនេះ កម្រិតនូវចំនួនគ្រាប់មីស៊ីលឆ្លងទ្វីប និងនាវាមុជទឹកបាញ់គ្រាប់មីស៊ីលដែលប្រទេសនីមួយៗត្រូវមាន។ នៅក្នុងឆ្នាំ 1975 មានប្រទេសចំនួន 33 បានចូលរួមជាមួយសហរដ្ឋអាមេរិក និងសហភាព សូវៀតចុះហត្ថលេខាលើការប្តេជ្ញាចំពោះគោលនយោបាយបញ្ចប់ជម្លោះ និងកិច្ចសហប្រតិបត្តិការ, កិច្ចព្រមព្រៀង ហេលស៊ីនគី។

### 3. ការដួលរលំនៃគោលនយោបាយបញ្ចប់ជម្លោះ

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានាធិបតីនិចសុន និងហ្គេរ៉ាល ហ្វដ សហរដ្ឋអាមេរិកបានបង្កើនទំនាក់ទំនងជាមួយប្រទេសចិន និងសហភាពសូវៀត។ ប៉ុន្តែ នៅចុងទសវត្សរ៍ឆ្នាំ 1970 ប្រធានាធិបតី ជីមមី ខារច័រ មានការព្រួយបារម្ភចំពោះការបង្ក្រាបដ៏ឃោឃៅលើក្រុមអ្នកតវ៉ានៅក្នុងសហភាពសូវៀត។ ការនេះបានគំរាមកំហែងដល់ការរក្សាកិច្ចព្រមព្រៀង កិច្ចសន្ទនាកម្រិតយុទ្ធសាស្ត្រយោធាជុំទី 2 ។ នៅក្នុងឆ្នាំ 1979 លោកខារច័រ និងលោកប្រេសនេវ ចុងក្រោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង កិច្ចសន្ទនាកម្រិតយុទ្ធសាស្ត្រយោធា 2 ។ ប៉ុន្តែ នៅពេលដែលសហភាពសូវៀតឈ្លានពានប្រទេសអាហ្គានីស្ថាន សភាអាមេរិកបានបដិសេធនៅក្នុងការផ្តល់សច្ចាប័នដល់កិច្ចសន្ទនាកម្រិតយុទ្ធសាស្ត្រយោធា 2 ។ ការព្រួយបារម្ភបានកើនឡើងកាន់តែខ្លាំង ដូចដែលប្រទេសកាន់តែច្រើនដូចជាប្រទេសចិន និងឥណ្ឌាជាដើម បានចាប់ផ្តើមស្ថាបនាអាវុធនុយក្លេអ៊ែ។

លោករីហ្គេនចាប់យកជំហប្រឆាំងកុំម្មុយនីស្ត៖ ប្រធានាធិបតីអាមេរិកដែលប្រឆាំងកុំម្មុយនីស្តដ៏ខ្លាំងក្លាមួយរូបលោក រ៉ូណាល់ រីហ្គេន បានឡើងកាន់អំណាចនៅក្នុងឆ្នាំ 1981 ។ លោកបានបន្តចេញឆ្ងាយពីគោលនយោបាយបញ្ចប់ជម្លោះ។ លោកបានបង្កើនការចំណាយលើវិស័យការពារជាតិ ដោយដាក់សម្ពាធ ទាំងសេដ្ឋកិច្ច និងយោធាលើសហភាសូវៀត។ នៅក្នុងឆ្នាំ 1983 លោករីហ្គេនបានប្រកាសពី គំនិតផ្តួចផ្តើមយុទ្ធសាស្ត្រការពារ ដែលជាកម្ម

វិធីមួយដើម្បីការពារប្រឆាំងជាមួយមីស៊ីលសត្រូវ។ វាមិនត្រូវបានគេដាក់ឱ្យប្រើប្រាស់ឡើយ ប៉ុន្តែវានៅតែជានិមិត្តសញ្ញាមួយនៃគំនិតប្រឆាំងជាមួយកុំម្មុយនីស្តរបស់អាមេរិក។

ជម្លោះបានកើនឡើង ដូចដែលសកម្មភាពរបស់សហរដ្ឋអាមេរិកមួយចំនួនដូចជាការបំពាក់អាវុធដល់ក្រុមប្រឆាំងនៅនីការ៉ាហ្គ័រ បានរុញច្រានសហរដ្ឋអាមេរិក និងសហភាពសូវៀតឃ្លាតឆ្ងាយពីគោលនយោបាយបញ្ចប់ជម្លោះ។ ប៉ុន្តែ ការផ្លាស់ប្តូរមេដឹកនាំនៅក្នុងសហភាពសូវៀតនៅក្នុងឆ្នាំ 1985 បាននាំទៅដល់ការបង្កើតគោលនយោបាយថ្មីមួយចំពោះសហរដ្ឋអាមេរិក និងនាំមកនូវការរលាយជាចុងក្រោយនៃសង្គ្រាមត្រជាក់។ នៅខណៈពេលនោះ ដូចដែលអ្នកនឹងបានអាននៅជំពូកបន្ទាប់ ប្រទេសកំពុងអភិវឌ្ឍបានបន្តតស៊ូដើម្បីឯករាជ្យ។

# ជំពូក 33៖ ដែនដីអាណានិគមក្លាយជាប្រទេសថ្មី

## មេរៀនទី 1៖ ឧបទ្វីបឥណ្ឌាទទួលបានសេរីភាព

### 1. ចលនាឆ្ពោះទៅរកឯករាជ្យ

អង់គ្លេសបានគ្រប់គ្រងប្រទេសឥណ្ឌាអស់រយៈពេលជិត 2 សតវត្សរ៍មកហើយ។ ការតស៊ូរបស់ឥណ្ឌាក្នុងការទាមទារឯករាជ្យពីចក្រភពអង់គ្លេសមានតាំងពីដើមដំបូងមកម្លេះ ប៉ុន្តែការតស៊ូនេះកាន់តែមានភាពខ្លាំងក្លាក្នុងឆ្នាំ 1939 នៅពេលដែលចក្រភពអង់គ្លេសបានបញ្ជូនកងកម្លាំងប្រដាប់អាវុធរបស់ឥណ្ឌាចូលប្រយុទ្ធនៅក្នុងសង្គ្រាមលោកលើកទី 2 ដោយមិនពិគ្រោះជាមួយតំណាងរាស្ត្ររបស់ដែនដីអាណានិគមជាមុនសិន។ ទង្វើនេះបានធ្វើឱ្យក្រុមអ្នកជាតិនិយមឥណ្ឌាមានភាពស្រឡាំងកាំង និងអាម៉ាស់មុខ។ មេដឹកនាំឥណ្ឌាមហាត្មៈ គន្ធីបានចាប់ផ្តើមយុទ្ធនាការអហិង្សាមួយដោយការមិនសហការជាមួយអង់គ្លេស។ មន្ត្រីរដ្ឋាភិបាលបានចាប់ឃុំក្រុមអ្នកជាតិនិយមជាច្រើននាក់សម្រាប់សកម្មភាពនេះ។ នៅឆ្នាំ 1942 អង់គ្លេសបានព្យាយាមដើម្បីទទួលបានការគាំទ្រពីពួកអ្នកជាតិនិយមដោយសន្យាក្នុងការផ្លាស់ប្តូររដ្ឋាភិបាលបន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់។ ប៉ុន្តែការផ្តល់ជូនទាំងនេះមិនបានរួមបញ្ចូលការផ្តល់ឯករាជ្យដល់ឥណ្ឌាឡើយ។ នៅពេលដែលពួកគេបានបង្កើនការតស៊ូប្រឆាំងនឹងអង់គ្លេសប្រជាជនឥណ្ឌាខ្លួនឯងផ្ទាល់តស៊ូប្រឆាំងគ្នាទៅវិញទៅមកផងដែរ។ ប្រទេសឥណ្ឌាគឺជាលំនៅឋានរបស់ក្រុមអ្នកកាន់សាសនាសំខាន់ចំនួន 2 ជាយូរមកហើយ។ នៅទសវត្សរ៍ឆ្នាំ 1940 ប្រទេសឥណ្ឌាមានអ្នកកាន់សាសនាហិណ្ឌូចំនួនប្រហែល 350 លាននាក់ និងប្រហែលចំនួន 100 លាននាក់ជាម៉ូស្លីម។ សមាជជាតិឥណ្ឌា ឬគណបក្សសមាជ គឺជាគណបក្សនយោបាយជាតិរបស់ប្រទេសឥណ្ឌា។ សមាជិកភាគច្រើននៃគណបក្សសមាជគឺជាអ្នកកាន់សាសនាហិណ្ឌូ ប៉ុន្តែជួនកាលគណបក្សនេះមានសមាជិកជាពួកម៉ូស្លីមជាច្រើន។ អ្នកដែលប្រកួតប្រជែងជាមួយគណបក្សសមាជគឺ សម្ព័ន្ធម៉ូស្លីមដែលជាអង្គការមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1906 ក្នុងប្រទេសឥណ្ឌាដើម្បីការពារផលប្រយោជន៍ជនម៉ូស្លីម។ សមាជិកនៃសម្ព័ន្ធនេះយល់ថា គណបក្សសមាជភាគច្រើនសម្លឹងទៅរកផលប្រយោជន៍សម្រាប់ពួកហិណ្ឌូជាចម្បង។ មេដឹកនាំនៃសម្ព័ន្ធម៉ូស្លីម លោកមហាម៉ាត់ អាលី ជីនណាបានអំពាវនាវឱ្យជនម៉ូស្លីមទាំងអស់លាលែងពីគណបក្សសមាជ។ សម្ព័ន្ធម៉ូស្លីមបាននិយាយថា ខ្លួននឹងមិនទទួលយកឯករាជ្យរបស់ឥណ្ឌាឡើយ ប្រសិនបើប្រទេសនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណបក្សសមាជដែលគ្របដណ្តប់ដោយពួកហិណ្ឌូ។ ជីនណាបាននិយាយថា "រឿងតែមួយគត់ដែលម៉ូស្លីមមានដូចគ្នាជាមួយហិណ្ឌូគឺភាពជាទាសភាពរបស់ពួកគេចំពោះអង់គ្លេស" ។

### 2. សេរីភាពនាំមកនូវភាពចលាចល

នៅពេលដែលសង្គ្រាមលោកលើកទី 2 បានបញ្ចប់ ចក្រភពអង់គ្លេសបានជួបប្រទះនឹងបំណុលសង្គ្រាមដ៏ធំសម្បើម។ ជាលទ្ធផល មេដឹកនាំអង់គ្លេសចាប់ផ្តើមគិតឡើងវិញអំពីការចំណាយលើការថែរក្សា និងគ្រប់គ្រងដែនដីអាណានិគមឆ្ងាយៗ។ ដោយសារតែឥណ្ឌាកំពុងតែបន្តតស៊ូដើម្បីឯករាជ្យរបស់ពួកគេ ដូច្នេះពេលវេលានេះសម

ស្របសម្រាប់អង់គ្លេសក្នុងការប្រគល់អំណាច។ ទោះយ៉ាងណាក៏ដោយ បញ្ហាសំខាន់មួយបានកើតឡើង៖ តើអ្នកណាគួរទទួលបានអំណាចពួកហិណ្ឌូ ឬម៉ូស្លីម?

ការបែកបាក់ និងការបង្ហូរឈាម៖ ពួកម៉ូស្លីមបានប្រឆាំងនឹងការប៉ុនប៉ងដើម្បីបញ្ចូលពួកគេនៅក្នុងរដ្ឋាភិបាលឥណ្ឌាដែលគ្រប់គ្រងដោយពួកហិណ្ឌូ។ កុបកម្មរបស់ក្រុមទាំង 2 បានផ្ទុះឡើងនៅក្នុងទីក្រុងមួយចំនួនរបស់ឥណ្ឌា។ នៅខែសីហា ឆ្នាំ 1946 ការប៉ះទង្គិចគ្នារយៈពេល 4 ថ្ងៃនៅកាល់គូតាបានធ្វើឱ្យមនុស្សជាង 5.000 នាក់បានស្លាប់ និងជាង 15.000 នាក់ទៀតរងរបួស។ មិនយូរប៉ុន្មាន មន្ត្រីអង់គ្លេសបានជឿជាក់ថា ការបែងចែក ដែលជាគំនិតដំបូងដែលស្នើឡើងដោយអ្នកកាន់សាសនាឥស្លាមរបស់ប្រទេសឥណ្ឌា នឹងក្លាយជាមធ្យោបាយតែមួយគត់ដើម្បីធានាបាននូវសុវត្ថិភាព និងសន្តិសុខក្នុងតំបន់។ ការបែងចែកគឺជាពាក្យដែលសំដៅទៅលើការបែងចែកប្រទេសឥណ្ឌាទៅជាប្រទេសសម្រាប់ពួកហិណ្ឌូ និងសម្រាប់ពួកម៉ូស្លីមដាច់ដោយឡែកពីគ្នា។ តំបន់ភាគពាយ័ព្យ និងភាគខាងកើតនៃប្រទេសឥណ្ឌា ដែលជាកន្លែងដែលមានជនម៉ូស្លីមភាគច្រើនរស់នៅ នឹងក្លាយជាប្រជាជាតិថ្មី ប៉ាគីស្ថាន (ប៉ាគីស្ថានមានរដ្ឋពីរដាច់ដោយឡែកពីគ្នានៅឆ្នាំ 1947៖ ប៉ាគីស្ថានខាងលិច និងប៉ាគីស្ថានខាងកើត)។ សភាអង់គ្លេសបានអនុម័តច្បាប់មួយនៅថ្ងៃទី 16 ខែកក្កដា ឆ្នាំ 1947 ដែលបានផ្តល់ឱ្យប្រទេសចំនួន 2 គឺប្រទេសឥណ្ឌា និងប៉ាគីស្ថាន ទទួលបានឯករាជ្យក្នុងរយៈពេលមួយខែបន្ទាប់។ . ក្នុងរយៈពេលដ៏ខ្លីនោះ ព្រះអង្គម្ចាស់នៅក្នុងតំបន់ជាង 500 អង្គត្រូវសម្រេចថាតើប្រទេសណាដែលពួកទ្រង់នឹងចូលរួម។ ការគ្រប់គ្រងតុលាការ, យោធា, ផ្លូវដែក, និងប៉ូលីស, មន្ត្រីស៊ីវិលទាំងមូលត្រូវបែងចែក។ ជាការលំបាកបំផុត ក្នុងចំណោមពលរដ្ឋឥណ្ឌារាប់លាននាក់ ដែលរួមមានពួកហិណ្ឌូ, ពួកម៉ូស្លីម, និងក្រុមសាសនាសំខាន់មួយទៀតគឺពួកស៊ីក ត្រូវសម្រេចចិត្តថាតើពួកគេត្រូវទៅទីណា។ នៅអំឡុងរដូវក្តៅឆ្នាំ 1947 មនុស្សចំនួន 10 លាននាក់កំពុងផ្លាស់ប្តូរទីលំនៅក្នុងឧបទ្វីបឥណ្ឌា។ នៅពេលដែលមនុស្សកំពុងច្របូកច្របល់ក្នុងផ្លាស់ប្តូរទីលំនៅ អំពើហិង្សាក្នុងចំណោមក្រុមសាសនាផ្សេងៗបានផ្ទុះឡើង។ ប្រជាជនម៉ូស្លីមបានសម្លាប់ពួកស៊ីខដែលកំពុងផ្លាស់ទៅកាន់ប្រទេសឥណ្ឌា។ ពួកហិណ្ឌូ និងពួកស៊ីកបានសម្លាប់ជនម៉ូស្លីមដែលបានធ្វើដំណើរចូលទៅក្នុងប្រទេសប៉ាគីស្ថាន។ សរុបមកមានមនុស្សប្រហែល 1 លាននាក់បានស្លាប់។ លោកហ្សាហ៊ីដា អាំចាដ អាលីបានដកស្រង់ចេញពីសៀវភៅសេរីភាព, របួស, ការបន្តទៀត លោកមហាត្មៈ គន្ធី បានលើកឡើងថា "មានអ្វីដែលត្រូវអបអរសាទរ? ខ្ញុំមិនឃើញអ្វីក្រៅពីទន្លេឈាម"។ លោកមហាត្មៈ គន្ធីផ្ទាល់បានធ្វើដំណើរទៅរដ្ឋធានីដេលីនៃប្រទេសឥណ្ឌា ដើម្បីអង្វរករយុត្តិធម៌ដល់ជនភៀសខ្លួនម៉ូស្លីម។ អំឡុងពេលនៅទីនោះ គាត់ផ្ទាល់បានក្លាយជាជនរងគ្រោះនៃអំពើហិង្សាក្នុងប្រទេស។ ជនជ្រុលនិយមហិណ្ឌូម្នាក់ដែលគិតថា លោកមហាត្មៈ គន្ធី ការពារជនម៉ូស្លីមខ្លាំងពេក បានបាញ់សម្លាប់លោកនៅថ្ងៃទី 30 ខែមករា ឆ្នាំ 1948 ។

សមរភូមិកាស្មៀរ៖ ប្រសិនបើការបែងចែកប្រទេសមិនបណ្តាលឱ្យមានការបង្ហូរឈាមរវាងពួកម៉ូស្លីម និងពួកហិណ្ឌូគ្រប់គ្រាន់ទេ ក្រុមទាំង 2 បានវាយប្រយុទ្ធគ្នានៅតំបន់តូចមួយនៅកាស្មៀរ។ កាស្មៀរស្ថិតនៅភាគខាងជើងនៃប្រទេសឥណ្ឌា ជាប់និងប៉ាគីស្ថាន។ ទោះបីជាអ្នកគ្រប់គ្រងរបស់ខ្លួនជាហិណ្ឌូក៏ដោយ កាស្មៀរមានប្រជាជនម៉ូស្លីមរស់នៅភាគច្រើន។ ភ្លាមៗបន្ទាប់ពីទទួលបានឯករាជ្យ ឥណ្ឌា និងប៉ាគីស្ថានបានចាប់ផ្តើមប្រយុទ្ធគ្នាទៅវិញ

ទៅមកដើម្បីគ្រប់គ្រងតំបន់នេះ។ ការប្រយុទ្ធគ្នាបានបន្តរហូតដល់អង្គការសហប្រជាជាតិរៀបចំបទឈប់បាញ់នៅឆ្នាំ 1949 ។ បទឈប់បាញ់នេះបានបន្សល់ទុក 1/3 នៃតំបន់កាស្មៀរនៅក្រោមការគ្រប់គ្រងរបស់ប្រទេសប៉ាគីស្ថាន ហើយនៅសល់ 2/3 ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសឥណ្ឌា។ ប្រទេសទាំងពីរបន្តប្រយុទ្ធគ្នាជុំវិញតំបន់នេះរហូតមកដល់សព្វថ្ងៃ។

### 3. ប្រទេសឥណ្ឌាសម័យទំនើប

ជាមួយនឹងការទទួលបានឯករាជ្យរបស់ខ្លួននៅថ្ងៃទី 15 ខែសីហា ឆ្នាំ 1947 ឥណ្ឌាបានក្លាយជាប្រទេសប្រជាធិបតេយ្យដ៏ធំបំផុតរបស់ពិភពលោក។ នៅពេលដែលពេលវេលានៃការរង់ចាំដ៏យូរនៃសេរីភាពរបស់ប្រទេសឥណ្ឌាបានខិតជិតមកដល់ លោកចាវ៉ាហាឡាល នេរុ ដែលជានាយករដ្ឋមន្ត្រីដំបូងរបស់ប្រទេសនៅពេលទទួលបានឯករាជ្យបានថ្លែងទៅកាន់មេដឹកនាំនយោបាយរបស់ប្រទេសនេះថា៖ 17 ឆ្នាំដំបូងនៃឯករាជ្យភាព។ គាត់ធ្លាប់ជាអ្នកដើរតាមលោកមហាត្មៈ គន្ធីដែលលះបង់ច្រើនបំផុត។ បានទទួលការសិក្សានៅចក្រភពអង់គ្លេស នេរុ ទទួលបានប្រជាប្រិយភាពក្នុងចំណោមក្រុមទាំងអស់នៅក្នុងប្រទេសឥណ្ឌា។ លោកបានសង្កត់ធ្ងន់ទៅលើលទ្ធិប្រជាធិបតេយ្យ, ឯកភាព, និងទំនើបកម្មសេដ្ឋកិច្ច។ នេរុបានប្រើការដឹកនាំរបស់លោកដើម្បីជំរុញប្រទេសឥណ្ឌាធ្វើដំណើរទៅមុខ។ លោកបានដឹកនាំប្រទេសឯករាជ្យថ្មីផ្សេងទៀតនៅលើពិភពលោក ក្នុងការបង្កើតសម្ព័ន្ធភាពក្នុងចំណោមបណ្ដាប្រទេសដែលមានអព្យាក្រឹតភាពក្នុងជម្លោះសង្គ្រាមត្រជាក់រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត។ នៅក្នុងប្រទេស នេរុបានអំពាវនាវឱ្យមានការរៀបចំរដ្ឋឡើងវិញតាមភាសា។ លោកក៏បានជំរុញឱ្យមានឧស្សាហូបនីយកម្ម និងឧបត្ថម្ភដល់កំណែទម្រង់សង្គមផងដែរ។ គាត់បានព្យាយាមលើកកម្ពស់ឋានៈរបស់ពួកវណ្ណៈទាប ឬអ្នកដែលនៅផ្នែកខាងក្រោមនៃសង្គម និងជួយស្ត្រីឱ្យទទួលបានសិទ្ធិដែលបានសន្យាដោយរដ្ឋធម្មនុញ្ញ។

ពេលវេលារឹករវះ លោកនេរុបានស្លាប់នៅក្នុងឆ្នាំ 1964 ។ ការស្លាប់របស់គាត់បានបន្សល់ទុកនូវគណបក្សសមាជដោយមិនមានមេដឹកនាំដែលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រមូលផ្ដុំគណបក្សនយោបាយជាច្រើនដែលបានលេចឡើងបន្ទាប់ពីឯករាជ្យរបស់ប្រទេសឥណ្ឌា។ បន្ទាប់មកនៅឆ្នាំ 1966 កូនស្រីរបស់នេរុឈ្មោះអ៊ីនឌីរ៉ា គន្ធីត្រូវបានជ្រើសរើសជានាយករដ្ឋមន្ត្រី។ បន្ទាប់ពីបានបណ្ដេញចេញពីតំណែងមួយរយៈពេលខ្លី ប៉ុន្តែអ្នកស្រីបានជាប់ឆ្នោតឡើងវិញនៅឆ្នាំ 1980 ។ ទោះបីជាអ្នកស្រីបានគ្រប់គ្រងប្រកបដោយសមត្ថភាពក៏ដោយ ក៏គន្ធីបានប្រឈមមុខជាមួយនឹងបញ្ហាជាច្រើន ដោយក្នុងនោះរួមមានទាំងការគំរាមកំហែងកាន់តែខ្លាំងឡើងពីពួកជ្រុលនិយមស៊ីខដែលខ្លួនពួកគេចង់បានរដ្ឋឯករាជ្យមួយ។ ប្រាសាទមាសនៅអាំរីត គឺជាមជ្ឈមណ្ឌលសាសនាសម្រាប់ពួកស៊ីខ។ នៅទីនោះ ពួកអ្នកជាតិនិយមស៊ីខ បានប្រជុំយនៅក្នុងការវាយប្រហារលើនិមិត្តសញ្ញារបស់អាជ្ញាធរឥណ្ឌា។ នៅខែមិថុនា ឆ្នាំ 1984 កងទ័ពឥណ្ឌាបានវាយលុកចូលប្រាសាទមាស។ ពួកគេបានសម្លាប់ពួកស៊ីខប្រហែល 500 នាក់ និងបំផ្លាញទ្រព្យសម្បត្តិពិសិដ្ឋនៅទីនោះ។ នៅក្នុងការសងសឹក អង្គរក្សស៊ីខដែលត្រូវបានតែងតាំងឱ្យការពារអ៊ីនឌីរ៉ា គន្ធី បានបាញ់សម្លាប់អ្នកស្រី។ អំពើហិង្សានេះបានបង្កឱ្យមានការផ្ទុះឡើងនូវការកាប់សម្លាប់មួយផ្សេងៗទៀត ដែលបណ្ដាលឱ្យពួកស៊ីខរាប់ពាន់នាក់ស្លាប់។ បន្ទាប់ពីឃាតកម្មលើអ្នកស្រីអ៊ីនឌីរ៉ា គន្ធី កូនប្រុសរបស់អ្នក

ស្រីឈ្មោះ ប៉ាជីរ គន្ទីបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី។ ប៉ុន្តែ គណបក្សរបស់លោកបានបាត់បង់អំណាចនៅក្នុងឆ្នាំ 1989 ដោយសារតែការចោទប្រកាន់ពីរឹករាលដាលនៃអំពើពុករលួយ។ នៅឆ្នាំ 1991 ខណៈពេលកំពុងធ្វើយុទ្ធនាការដើម្បីប្រជែងសម្រាប់តំណែងនាយករដ្ឋមន្ត្រីនៅជិតទីក្រុងម៉ាដ្រាស លោករ៉ាជីវត្រូវបានសម្លាប់ដោយការបោកគ្រាប់បែកមួយ។ សមាជិកនៃក្រុមដែលប្រឆាំងនឹងគោលនយោបាយរបស់គាត់បានអះអាងទទួលខុសត្រូវលើរឿងនេះ។

ការប្រកួតប្រជែងនៅសតវត្សរ៍ទី 21 ៖ ចាប់តាំងពីឈ្នះការបោះឆ្នោតជានាយករដ្ឋមន្ត្រីក្នុងឆ្នាំ 1998 លោកអាតាល បីហារី វាចប៉ាយី មេដឹកនាំគណបក្សជាតិនិយមហិណ្ឌូបានគ្រប់គ្រងប្រទេសយ៉ាងរស់រវើក ប៉ុន្តែជារឿយៗមិនមានស្ថិរភាពឡើយ។ លោកបានប្រឈមនឹងបញ្ហាជាច្រើនដែលកើតមានឡើង ដោយសារការកើនឡើងនៃចំនួនប្រជាជនដែលរំពឹងថានឹងរុញឥណ្ឌាឱ្យវ៉ាប្រទេសចិន ក្នុងនាមជាប្រទេសដែលមានប្រជាជនច្រើនជាងគេបំផុតរបស់ពិភពលោកនៅត្រឹមឆ្នាំ 2035។ លើសពីនេះ ប្រទេសនេះត្រូវបានប្រេះឆាដោយវិសមភាពសង្គម និងត្រូវបានគំរាមកំហែងជាបន្តបន្ទាប់ដោយជម្លោះសាសនា។ អ្វីដែលជាបញ្ហាធ្ងន់ធ្ងរទៀតនោះ គឺទំនាក់ទំនងតានតឹងរវាងប្រទេសឥណ្ឌាជាមួយនិងប្រទេសប៉ាគីស្ថានដែលជាអ្នកជិតខាងខ្លួន បូករួមទាំងប្រទេសទាំង 2 នេះបានក្លាយជាមហាអំណាចនុយក្លេអ៊ែរផងដែរ។ នៅឆ្នាំ 1974 ឥណ្ឌាបង្កើតគ្រាប់បែកនុយក្លេអ៊ែរដោយស្ងៀមស្ងាត់។ ក្នុងរយៈពេល 24 ឆ្នាំបន្ទាប់ ប្រទេសនេះបានធ្វើការយ៉ាងស្ងៀមស្ងាត់លើការកសាងសមត្ថភាពនុយក្លេអ៊ែររបស់ខ្លួន។ ក្នុងឆ្នាំ 1998 មន្ត្រីឥណ្ឌាបានធ្វើការសាកល្បងគ្រាប់បែកនុយក្លេអ៊ែរនៅក្រោមដីចំនួន 5 លើក។ ទន្ទឹមនឹងនេះ ប៉ាគីស្ថានក៏កំពុងតែបង្កើតកម្មវិធីនុយក្លេអ៊ែរផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ ភ្លាមៗបន្ទាប់ពីឥណ្ឌាបានធ្វើការសាកល្បងគ្រាប់បែកនុយក្លេអ៊ែររបស់ខ្លួន ប៉ាគីស្ថានបានបង្ហាញថាខ្លួនក៏មានអាវុធនុយក្លេអ៊ែរផងដែរ។ វត្តមានអាវុធនៅក្នុងដៃរបស់ប្រទេសដែលខ្មាំងសត្រូវជាមួយគ្នា និងជាប្រទេសជិតខាងដ៏ជូរចត់ទាំង 2 នេះ បានបង្កជា ការព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់អន្តរជាតិ ជាពិសេសការកើនឡើងនៃការវាយប្រយុទ្ធគ្នានៅតំបន់កាស្មៀរ។

## 4. ប៉ាគីស្ថានតស៊ូដើម្បីសេរីភាព

ប្រវត្តិសាស្ត្ររបស់ប៉ាគីស្ថាន ចាប់តាំងពីទទួលបានឯករាជ្យមកមានភាពចលាចលមិនចាញ់ប្រទេសឥណ្ឌាឡើយ។ តាមពិតទៅ នៅដើមដំបូងប៉ាគីស្ថានបានចាប់ផ្តើមជារដ្ឋ 2 ដាច់ដោយឡែកពីគ្នាគឺប៉ាគីស្ថានខាងកើត និងប៉ាគីស្ថានខាងលិច។ ប៉ាគីស្ថានខាងកើតស្ថិតនៅខាងកើតឥណ្ឌា ប៉ាគីស្ថានខាងលិចនៅភាគពាយ័ព្យ។ តំបន់ទាំង 2 នេះត្រូវបានបំបែកចេញពីគ្នាដោយទឹកដីឥណ្ឌាជាង 1,000 ម៉ាយ។ ជាលក្ខណៈវប្បធម៌, ភាសា, ប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, សេដ្ឋកិច្ច, និងដើមកំណើតជាតិសាសន៍ តំបន់ទាំង 2 នេះមានភាពខុសគ្នាខ្លាំង។ មានតែសាសនាឥស្លាមមួយគត់ដែលបានបង្រួបបង្រួមពួកគេ។

សង្គ្រាមស៊ីវិល៖ តាំងពីដើមមក តំបន់ទាំង 2 របស់ប៉ាគីស្ថាននេះបានជួបប្រទះទៅនឹងទំនាក់ទំនងដ៏តានតឹង។ ខណៈពេលដែលប៉ាគីស្ថានខាងកើតមានប្រជាជនច្រើន ជារឿយៗវាមិនត្រូវបានអើពើដោយប៉ាគីស្ថានខាងលិចដែលជាមូលដ្ឋានរបស់រដ្ឋាភិបាលកណ្តាល។ នៅឆ្នាំ 1970 ព្យុះស៊ីក្លូន និងរលកយក្សបានវាយប្រហារប៉ាគីស្ថាន

ខាងកើត ហើយបានសម្លាប់ប្រជាជនប្រមាណ 266,000 នាក់។ ខណៈពេលដែលជំនួយអន្តរជាតិត្រូវបានបញ្ជូនទៅកាន់ប្រទេសប៉ាគីស្ថាន រដ្ឋាភិបាលនៅប៉ាគីស្ថានខាងលិចមិនបានផ្ទេរជំនួយនោះភ្លាមៗទៅកាន់ប៉ាគីស្ថានខាងកើតនោះឡើយ។ បាតុកម្មបានផ្ទុះឡើងនៅប៉ាគីស្ថានខាងកើត ហើយក្រុមអ្នកតវ៉ាបានអំពាវនាវឱ្យបញ្ចប់ទំនាក់ទំនងទាំងអស់ជាមួយប៉ាគីស្ថានខាងលិច។ នៅថ្ងៃទី 26 ខែមីនា ឆ្នាំ 1971 ប៉ាគីស្ថានខាងកើតបានប្រកាសខ្លួនឯងថាជាប្រទេសឯករាជ្យមួយហៅថាបង់ក្លាដេស។ សង្គ្រាមស៊ីវិលបានកើតឡើងរវាងបង់ក្លាដេស និងប៉ាគីស្ថាន។ នៅទីបំផុត កងកម្លាំងឥណ្ឌាបានឈានជើងចូល និងស្ថិតនៅជាភាគីខាងបង់ក្លាដេស។ កងកម្លាំងប៉ាគីស្ថានបានចុះចាញ់។ មនុស្សជាង 1 លាននាក់បានស្លាប់នៅក្នុងសង្គ្រាមនេះ។ ប៉ាគីស្ថានបានបាត់បង់ដែនដីប្រហែល 1/7 និងបាត់បង់ចំនួនប្រជាជនប្រហែលពាក់កណ្ដាលទៅបង់ក្លាដេស។

ទម្រង់នៃអស្ថិរភាព៖ លោកម៉ូហាម៉ាត់ អាលី ជីនណា ដែលជាអគ្គទេសាភិបាលទីមួយនៃប្រទេសប៉ាគីស្ថានបានស្លាប់ភ្លាមៗបន្ទាប់ពីទទួលបានឯករាជ្យ។ ការស្លាប់របស់លោកបានធ្វើឱ្យប្រទេសជាតិមិនមានការដឹកនាំរឹងមាំ ហើយប៉ាគីស្ថានបានឆ្លងកាត់រដ្ឋប្រហារយោធាជាបន្តបន្ទាប់ ដែលចាប់ផ្ដើមដំបូងក្នុងឆ្នាំ 1958 ។ លោកអាលី ប៊ូតូ បានកាន់កាប់ប្រទេសបន្ទាប់ពីសង្គ្រាមស៊ីវិល។ រដ្ឋប្រហារយោធាក្នុងឆ្នាំ 1977 ដឹកនាំដោយឧត្ដមសេនីយ៍ហ្សៀ បានដកលោកប៊ូតូចេញពីអំណាច ដែលក្រោយមកត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិអំឡុងពេលលោកកាន់តំណែង។ បន្ទាប់ពីការស្លាប់របស់លោកហ្សៀកូនស្រីរបស់លោកប៊ូតូ ឈ្មោះបេណាហ្ស៊ី ប៊ូតូ បានជាប់ឆ្នោតជានាយករដ្ឋមន្ត្រីចំនួន 2 លើក។ បន្ទាប់ពីញ៉ាំញីដោយបញ្ហាជាច្រើនខែមក លោកស្រីត្រូវបានដកចេញពីតំណែងនៅឆ្នាំ 1996 ។ លោកណាវ៉ាស់ សារីហ្វ បានក្លាយជានាយករដ្ឋមន្ត្រីបន្ទាប់ពីការបោះឆ្នោតឆ្នាំ 1997 ។ នៅឆ្នាំ 1999 មេដឹកនាំកងទ័ពដែលដឹកនាំដោយឧត្ដមសេនីយ៍គីវេហ្ស ម៉ូសារ៉ាហ្វ បានបណ្ដេញលោកសារីហ្វចេញពីអំណាចតាមរយៈការធ្វើរដ្ឋប្រហារមួយផ្សេងទៀត ហើយបានដាក់ការគ្រប់គ្រងបែបយោធានៅក្នុងប្រទេសប៉ាគីស្ថាន។ បន្ទាប់ពីការវាយប្រហារថ្ងៃទី 11 ខែកញ្ញា លើសហរដ្ឋអាមេរិកមក លោកម៉ូសារ៉ាហ្វបានក្លាយជាសម្ព័ន្ធមិត្តដ៏សំខាន់របស់អាមេរិក។ ទោះយ៉ាងណាក៏ដោយនៅឆ្នាំ 2007 គាត់ប្រឈមមុខនឹងការប្រឆាំងនយោបាយកាន់តែខ្លាំងឡើងនៅក្នុងប្រទេស។

## 5. ការតស៊ូរបស់បង់ក្លាដេស និងស្រីលង្កា

ទន្ទឹមនឹងបញ្ហារបស់នៅប៉ាគីស្ថាន ប្រទេសដែលទើបបង្កើតថ្មីបង់ក្លាដេស និងស្រីលង្កាបានតស៊ូជាមួយនឹងបញ្ហាសំខាន់ៗរបស់ពួកគេបន្ទាប់ពីទទួលបានឯករាជ្យ។

បង់ក្លាដេសប្រឈមមុខនឹងបញ្ហាជាច្រើន៖ សង្គ្រាមជាមួយប៉ាគីស្ថានបានបំផ្លាញសេដ្ឋកិច្ចរបស់ប្រទេសបង់ក្លាដេស និងធ្វើឱ្យប្រេះស្រាំប្រព័ន្ធទំនាក់ទំនងរបស់ខ្លួន។ ការកសាងប្រទេសដែលបែកបាក់ឡើងវិញ ហាក់ដូចជាកិច្ចការដ៏លើសលប់មួយ។ លោកស៊ីក ម៉ូជីប៊ូ រ៉ាមែន បានក្លាយជានាយករដ្ឋមន្ត្រីទីដំបូងរបស់ប្រទេសបង់ក្លាដេស។ លោកមានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើការពង្រឹងអំណាចរបស់លោក ជាជាងការកសាងជាតិឡើងវិញ។ មិនយូរប៉ុន្មានលោកបានកាន់កាប់អំណាចទាំងស្រុង ហើយបានប្រកាសបង់ក្លាដេសជារដ្ឋឯកបក្ស។ នៅខែសីហា ឆ្នាំ

1975 មេដឹកនាំយោធាបានធ្វើឃាតរូបលោក។ ប៉ុន្មានឆ្នាំមកនេះ ប្រទេសបង់ក្លាដេសបានព្យាយាមជាមួយនឹងការលំបាកយ៉ាងខ្លាំង ក្នុងការបង្កើតឱ្យមានទម្រង់រដ្ឋាភិបាលមួយដែលមានលក្ខណៈប្រជាធិបតេយ្យបន្ថែមទៀត។ ការចោទប្រកាន់ពីការក្លែងបន្លំការបោះឆ្នោត និងអំពើពុករលួយរបស់រដ្ឋាភិបាលគឺជារឿងទូទៅនៅអំឡុងពេលនោះ។ ទោះយ៉ាងណាក៏ដោយ ប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលកាន់តែមានស្ថិរភាព។ ការបោះឆ្នោតចុងក្រោយបំផុតត្រូវបានធ្វើឡើងនៅខែតុលា ឆ្នាំ 2001 ហើយលោកបេហ្គាំ ខាឡេដា ហៀ្យ បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីរបស់ប្រទេស។ ប្រទេសបង់ក្លាដេសក៏ត្រូវប្រឈមមុខនឹងគ្រោះមហន្តរាយធម្មជាតិដ៏ធ្ងន់ធ្ងរផងដែរ។ បង់ក្លាដេសជាប្រទេសសណ្ឋានដីទាប ដែលត្រូវទទួលរងព្យុះស៊ីក្លូន និងរលកទឹកជោរ ឬនាចជាច្រើន។ ខ្យល់ព្យុះដ៏ធំតែងតែនាំមកនូវភាពជន់លិចបំផ្លាញដំណាំ និងផ្ទះសម្បែង និងឆក់យកជីវិតមនុស្ស។ ព្យុះស៊ីក្លូនក្នុងឆ្នាំ 1991 បានសម្លាប់មនុស្សប្រហែល 139,000 នាក់។ គ្រោះមហន្តរាយបែបនេះ រួមជាមួយនឹងចំនួនប្រជាជនដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស បានធ្វើឱ្យមានបញ្ហាប្រឈមជាច្រើនដល់សេដ្ឋកិច្ចរបស់ប្រទេស។ បង់ក្លាដេសជាប្រទេសក្រីក្របំផុតមួយក្នុងពិភពលោក។ ប្រាក់ចំណូលសម្រាប់មនុស្សម្នាក់មានប្រហែល 360 ដុល្លារក្នុងមួយឆ្នាំ។

ជម្លោះញ៉ាំញីក្នុងប្រទេសស្រីលង្កា៖ ប្រទេសដែលទើបទទួលបានសេរីភាព និងប្រឈមជាមួយបញ្ហាយ៉ាងធ្ងន់ធ្ងរមួយទៀតនៅឧបទ្វីបឥណ្ឌាគឺប្រទេសស្រីលង្កា ជាប្រទេសកោះតូចមួយដែលមានរាងដូចដំណក់ទឹក មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសឥណ្ឌា។ កាលពីមុនវាត្រូវបានគេស្គាល់ថា សីឡង់ ប្រទេសនេះទទួលបានឯករាជ្យពីចក្រភពអង់គ្លេសនៅខែកុម្ភៈ ឆ្នាំ 1948 ។ មានក្រុមជនជាតិសំខាន់ចំនួន 2 បានគ្រប់គ្រងប្រទេស។ 3/4 នៃចំនួនប្រជាជនគឺពួកស៊ីនហាលេសដែលជាអ្នកកាន់ពុទ្ធសាសនា។ 1/5 ជាជនជាតិតាមិល ជាប្រជាជនហិណ្ឌូដែលរស់ភាគនៅភាគខាងត្បូងនៃប្រទេសឥណ្ឌា និងស្រីលង្កាភាគខាងជើង។ ប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសស្រីលង្កាក៏គ្របដណ្តប់ជាមួយភាពចលាចលផងដែរ។ ក្រុមសកម្មប្រយុទ្ធជនជាតិតាមិលបានតស៊ូប្រដាប់អាវុធជាយូរមកហើយដើម្បីបង្កើតប្រទេសតាមីលដាច់ដោយឡែកមួយ។ ចាប់តាំងពីឆ្នាំ 1981 មនុស្សរាប់ពាន់នាក់បានបាត់បង់ជីវិត។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចប់អំពើហិង្សា លោករ៉ាជីវ គន្ធី និងប្រធានាធិបតីស្រីលង្កាបានព្យាយាមហូតដល់កិច្ចព្រមព្រៀងមួយនៅឆ្នាំ 1987 ។ កិច្ចព្រមព្រៀងនេះបានស្នើឱ្យកងទ័ពឥណ្ឌាចូល ក្នុងប្រទេសស្រីលង្កា និងជួយក្នុងការដកហូតអាវុធរបស់ពួកឧទ្ទាមតាមិល។ កិច្ចខិតខំប្រឹងប្រែងនេះមិនបានជោគជ័យឡើយ ហើយកងទ័ពឥណ្ឌាបានចាកចេញពីប្រទេសនេះនៅឆ្នាំ 1990។ សង្គ្រាមស៊ីវិលរវាងជនជាតិតាមិល និងជនជាតិស្រីលង្កានៅតែបន្តរហូតមកដល់បច្ចុប្បន្ន។ នៅសម័យក្រោយឯករាជ្យ ប្រទេសទាំងឡាយនៅឧបទ្វីបឥណ្ឌាជួបប្រទះភាពលំបាកដូចគ្នាជាមួយអតីតប្រទេសអាណានិគមផ្សេងៗទៀត។ ដូចដែលអ្នកនឹងបានអាននៅក្នុងមេរៀនបន្ទាប់ ទឹកដីមួយចំនួនដែលធ្លាប់ត្រូវបានកាន់កាប់ដោយពួកអាណានិគមនៅតំបន់អាស៊ីអាគ្នេយ៍បានប្រឈមនឹងបញ្ហាជាច្រើននៅពេលដែលពួកគេក្លាយជាប្រទេសឯករាជ្យ។

# មេរៀនទី 2 ៖ ប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យ

## 1. ហ្វីលីពីនទទួលបានឯករាជ្យ

ហ្វីលីពីនបានក្លាយជាប្រទេសអាណានិគមដំបូងគេនៅលើពិភពលោក ដែលទទួលបានឯករាជ្យបន្ទាប់ពីសង្គ្រាមលោកលើកទី 2 ។ សហរដ្ឋអាមេរិកបានផ្តល់ឯករាជ្យដល់ប្រទេសហ្វីលីពីននៅឆ្នាំ 1946 ចំថ្ងៃខួបនៃការប្រកាសឯករាជ្យរបស់ខ្លួនថ្ងៃទី 4 ខែកក្កដា។

សហរដ្ឋអាមេរិក និងហ្វីលីពីន៖ គោលដៅភ្លាមៗរបស់ប្រជាជនហ្វីលីពីន គឺការកសាងសេដ្ឋកិច្ច និងការស្តាររដ្ឋធានីម៉ានីលឡើងវិញ។ ទីក្រុងនេះត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរនៅក្នុងសង្គ្រាមលោកលើកទី 2 ។ សហរដ្ឋអាមេរិកបានសន្យាផ្តល់សំណងក្នុងការធ្វើសង្គ្រាមដល់ប្រទេសហ្វីលីពីនចំនួន 620 លានដុល្លារ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានអំពាវនាវឱ្យប្រជាជនហ្វីលីពីនយល់ព្រមលើច្បាប់ប៊ែល ជាថ្នូរទៅនឹងការទទួលបានប្រាក់សំណងនេះ។ ច្បាប់នេះនឹងបង្កើតពាណិជ្ជកម្មសេរីរវាងសហរដ្ឋអាមេរិក និងហ្វីលីពីនសម្រាប់រយៈពេល 8 ឆ្នាំ និងបន្តដោយការដំឡើងពន្ធជាបណ្តើរៗ។ ប្រជាជនហ្វីលីពីនព្រួយបារម្ភថាអាជីវករអាមេរិកនឹងកេងប្រវ័ញ្ចធនធាន និងបរិស្ថានរបស់ប្រទេសហ្វីលីពីន។ ទោះបីជាមានការព្រួយបារម្ភបែបនេះក៏ដោយ ប្រជាជនហ្វីលីពីនបានអនុម័តច្បាប់ប៊ែល និងបានទទួលប្រាក់សំណងរបស់ពួកគេ។ សហរដ្ឋអាមេរិកក៏ចង់រក្សាវត្តមានយោធារបស់ខ្លួននៅក្នុងប្រទេសហ្វីលីពីនផងដែរ។ ជាមួយនឹងការចាប់ផ្តើមនៃសង្គ្រាមត្រជាក់ (សូមមើលជំពូកទី 32) សហរដ្ឋអាមេរិកចាំបាច់ត្រូវការពារផលប្រយោជន៍របស់ខ្លួននៅតំបន់អាស៊ី។ ទាំងចិន និងសហភាពសូវៀត គឺជាគូប្រជែងរបស់សហរដ្ឋអាមេរិកនៅពេលនោះ។ ប្រទេសទាំង 2 នេះគឺជាមហាអំណាចតំបន់ប៉ាស៊ីហ្វិកដែលមានមូលដ្ឋានស្ថិតនៅជិតសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក និងស្ថិតនៅជិតធនធានដ៏សំខាន់សម្រាប់ផលប្រយោជន៍របស់សហរដ្ឋអាមេរិក។ ដូច្នេះ សហរដ្ឋអាមេរិកទាមទារក្នុងការជួលមូលដ្ឋានទ័ព និងទ័ពជើងទឹករបស់ខ្លួនរយៈពេល 99 ឆ្នាំនៅក្នុងប្រទេសហ្វីលីពីន។ មូលដ្ឋានទ័ពអាកាសក្លាក និងមូលដ្ឋានកងទ័ពជើងទឹកឈូងសមុទ្រស៊ូប៊ិច ដែលស្ថិតនៅជិតទីក្រុងម៉ានីឡា មានសារៈសំខាន់ចំពោះសហរដ្ឋអាមេរិកយ៉ាងខ្លាំងនៅដំណាក់កាលនៃសង្គ្រាមកូរ៉េ និងវៀតណាម។ មូលដ្ឋានយោធាទាំង 2 នេះក៏បានក្លាយជាប្រភពនៃជម្លោះដ៏ធំបំផុតតែមួយគត់រវាងសហរដ្ឋអាមេរិក និងហ្វីលីពីន។ ប្រជាជនហ្វីលីពីនជាច្រើនបានចាត់ទុកមូលដ្ឋាននេះជាភស្តុតាងនៃចក្រពត្តិនិយមអាមេរិក។ កិច្ចព្រមព្រៀងក្រោយមកបានកាត់បន្ថយលក្ខខណ្ឌនៃការជួល ហើយសហរដ្ឋអាមេរិកបានបោះបង់ចោលមូលដ្ឋានទាំង 2 នៅក្នុងឆ្នាំ 1992។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 រដ្ឋាភិបាលហ្វីលីពីននៅតែពឹងផ្អែកស្ទើរតែទាំងស្រុងលើសហរដ្ឋអាមេរិកទាំងផ្នែកសេដ្ឋកិច្ច និងនយោបាយ។ រដ្ឋាភិបាលហ្វីលីពីនបានស្វែងរកមធ្យោបាយកាត់បន្ថយភាពពឹងអាស្រ័យនេះ។ ពួកគេបានស្វាគមន៍ការវិនិយោគរបស់ជប៉ុន។ ពួកគេក៏បានពង្រីកទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសអាស៊ីអាគ្នេយ៍ជិតខាង និងជាមួយក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធផងដែរ។

ពីម៉ាកូសដល់រ៉ាម៉ូស៖ លោកហ្វឺឌីណង់ ម៉ាកូសបានជាប់ឆ្នោតជាប្រធានាធិបតីហ្វីលីពីនក្នុងឆ្នាំ 1965។ ប្រទេសនេះបានរងទុក្ខនៅក្រោមការគ្រប់គ្រងរបស់លោកចាប់ពីឆ្នាំ 1966 ដល់ឆ្នាំ 1986។ លោកម៉ាកូសគ្រប់គ្រងប្រទេស

បែបផ្តាច់ការ និងបានលួចលុយរាប់លានដុល្លារពីរតនាគារសាធារណៈ។ ទោះបីជារដ្ឋធម្មនុញ្ញបានកំណត់ឱ្យលោកម៉ាកូសកាន់តំណែងរយៈពេល 8 ឆ្នាំក៏ដោយ ក៏លោកបានអនុវត្តលើសពីការកម្រិតនេះ តាមរយៈការដាក់ច្បាប់អាជ្ញាសឹកចាប់ពីឆ្នាំ 1972 ដល់ឆ្នាំ 1981។ 2 ឆ្នាំក្រោយមក គូប្រជែងដ៏សំខាន់របស់លោកគឺលោក បេនីណូ អាគីណូ ត្រូវបានគេលួចធ្វើឃាត នៅពេលដែលលោកត្រឡប់ពីសហរដ្ឋអាមេរិកមកកាន់ហ្វីលីពីនវិញដើម្បីចូលរួមការបោះឆ្នោតនាពេលខាងមុខ។ នៅក្នុងការបោះឆ្នោតឆ្នាំ 1986 ភរិយារបស់លោកអាគីណូ គឺអ្នកស្រីកូរ៉ាហ្សូន អាគីណូ បានប្រកួតប្រជែងជាមួយលោកម៉ាកូស។ អ្នកស្រីអាគីណូ បានឈ្នះឆ្នោតភ្លុកទឹកភ្លុកដី ប៉ុន្តែលោកម៉ាកូស បានបដិសេធមិនទទួលស្គាល់ជ័យជម្នះរបស់អ្នកស្រី។ នៅពេលដែលលោកបានប្រកាសខ្លួនឯងថាជាអ្នកឈ្នះជាផ្លូវការ ការតវ៉ាជាសាធារណៈបានកើតមានឡើង។ លោកត្រូវបានបង្ខំឱ្យនិរទេសខ្លួនទៅកាន់រដ្ឋហាវ៉ៃ ដែលក្រោយមកលោកបានស្លាប់នៅទីនោះ។ នៅឆ្នាំ 1995 ហ្វីលីពីនបានទទួលជោគជ័យក្នុងការយកមកវិញនូវទឹកប្រាក់ចំនួន 475 លានដុល្លារដែលលោកម៉ាកូសបានលួចពីប្រទេសហ្វីលីពីនដាក់ក្នុងធនាគារស្វីស។ នៅពេលដែលលោកស្រីអាគីណូស្បថចូលកាន់តំណែង លោកស្រីបានសន្យាថានឹងដឹកនាំរដ្ឋាភិបាលក្នុងទម្រង់បើកចំហ និងមានលក្ខណៈប្រជាធិបតេយ្យជាងមុន។

ក្នុងអំឡុងពេលកាន់តំណែងជាប្រធានាធិបតីរបស់អ្នកស្រីអាគីណូ រដ្ឋាភិបាលហ្វីលីពីនបានផ្តល់សច្ចាប័នលើរដ្ឋធម្មនុញ្ញថ្មីមួយ។ រដ្ឋាភិបាលហ្វីលីពីនក៏បានចរចាដោយជោគជ័យជាមួយសហរដ្ឋអាមេរិក ដើម្បីបញ្ចប់ការជួលមូលដ្ឋានយោធារបស់សហរដ្ឋអាមេរិក។ នៅឆ្នាំ 1992 លោកហ្វីដែល វី. រ៉ាម៉ូស បានកាន់តំណែង ប្រធានាធិបតីបន្តពីអ្នកស្រីអាគីណូ។ លោករ៉ាម៉ូស ត្រូវបានកំណត់អាណត្តិដោយរដ្ឋធម្មនុញ្ញត្រឹមរយៈពេល 6 ឆ្នាំប៉ុណ្ណោះ។ ការកំណត់រយៈពេលតែមួយអាណត្តិរយៈពេល 6 ឆ្នាំគឺមានបំណងការពារការរំលោភបំពានអំណាចដែលធ្លាប់បានកើតឡើងនៅអំឡុងពេលនៃការគ្រប់គ្រងរយៈពេល 20 ឆ្នាំរបស់លោកម៉ាកូស។

រដ្ឋាភិបាលប្រយុទ្ធជាមួយក្រុមឧទ្ទាមៈ ចាប់តាំងពីទទួលបានឯករាជ្យមក ប្រទេសហ្វីលីពីនត្រូវប្រយុទ្ធប្រឆាំងជាមួយក្រុមផ្តាច់ខ្លួន។ អស់ជាច្រើនសតវត្សរ៍មកហើយ តំបន់ភាគខាងត្បូងនៃប្រទេសនេះ គឺជាបន្ទាយដ៏រឹងមាំរបស់ជនម៉ូស្លីមដែលត្រូវបានគេស្គាល់ថាជាម៉ូរ៉ូ។ នៅដើមទសវត្សរ៍ឆ្នាំ 1970 ក្រុមម៉ូរ៉ូសបានបង្កើតរណសិរ្សរំដោះជាតិម៉ូរ៉ូ។ ពួកគេបានចាប់ផ្តើមការតស៊ូប្រដាប់អាវុធដើម្បីឯករាជ្យភាពពីការគ្រប់គ្រងរបស់ហ្វីលីពីន។ ក្នុងឆ្នាំ 1996 រដ្ឋាភិបាល និងក្រុមឧទ្ទាមបានចុះកិច្ចព្រមព្រៀងឈប់បាញ់មួយ ហើយម៉ូរ៉ូត្រូវបានទទួលស្គាល់ថាជាតំបន់ស្វយ័តនៅភាគខាងត្បូងប្រទេសហ្វីលីពីន។ យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនេះមិនបានបំពេញចិត្តក្រុមរណសិរ្សរំដោះជាតិម៉ូរ៉ូដែលគេហៅថា អាប៊ូ សាយយ៉ាហ្វទេ។ ក្រុមឧទ្ទាមទាំងនេះបានបន្តប្រយុទ្ធជាមួយរដ្ឋាភិបាល ដោយជារឿយៗពួកគេបានប្រើយុទ្ធសាស្ត្រភេរវកម្មដើម្បីសម្រេចគោលដៅរបស់ពួកគេ។ នៅឆ្នាំ 2000 ពួកគេបានចាប់ពង្រត់មនុស្ស 21 នាក់រួមទាំងអ្នកទេសចរបរទេសផងដែរ។ បើទោះបីជាក្រុមមនុស្សទាំងនោះទីបំផុតត្រូវបានដោះលែងវិញក៏ដោយ ការចាប់ពង្រត់ និងការបំផ្ទុះគ្រាប់បែកជាបន្តបន្ទាប់ដោយក្រុមអាប៊ូ សាយយ៉ាហ្វបានសម្លាប់ និងបង្ករបួសស្នាមដល់មនុស្សរាប់រយនាក់។ ប្រធានាធិបតីហ្វីលីពីនបច្ចុប្បន្នស្រី ក្លូរៀ ម៉ាកាប៉ាហ្គាល់ អារ៉ូយ៉ូ បានចាប់ផ្តើម

ការឆ្លើយតបដោយកម្លាំងយោធាចំពោះក្រុមនេះ។ សហរដ្ឋអាមេរិកបានផ្តល់ជំនួយយោធាដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលហ្វីលីពីន។

## 2. ដែនដីអាណានិគមអង់គ្លេសទទួលបានឯករាជ្យ

ពេលវេលារបស់ចក្រភពអង់គ្លេស ក្នុងការផ្តល់ឯករាជ្យដល់ដែនដីអាណានិគមនៅអាស៊ីអាគ្នេយ៍របស់ខ្លួនគឺអាស្រ័យលើកាលៈទេសៈក្នុងដែនដីនោះ។ ភូមាបានដាក់សម្ពាធក្នុងការទាមទារឯករាជ្យពីអង់គ្លេសអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ ប្រទេសនេះបានក្លាយជាប្រទេសឯករាជ្យបែបសាធារណៈនៅឆ្នាំ 1948។ នៅឆ្នាំ 1989 ភូមាត្រូវបានដាក់ឈ្មោះជាផ្លូវការថា មីយ៉ាន់ម៉ា ដែលជាឈ្មោះជាភាសាភូមា។

ភូមាជួបប្រទះភាពចលាចលៈ បន្ទាប់ពីទទួលបានសេរីភាព ភូមាបានទទួលរងនូវភាពចលាចលផ្នែកនយោបាយជាបន្តបន្ទាប់។ ប្រជាជនរបស់ភូមាបានប្រឈមជាមួយនឹងការតស៊ូរវាងរដ្ឋាភិបាលយោធាដែលគាបសង្កត់ និងកងកម្លាំងគាំទ្រលទ្ធិប្រជាធិបតេយ្យ។ ជម្លោះក្នុងចំណោមក្រុមកុម្មុយនីស្ត និងក្រុមជនជាតិភាគតិចក៏បានប៉ះពាល់ដល់ប្រទេសជាតិផងដែរ។ នៅឆ្នាំ 1962 នាយឧត្តមសេនីយ៍នេ វីនបានបង្កើតរដ្ឋាភិបាលយោធាមួយដោយមានគោលដៅធ្វើឱ្យភូមាក្លាយជារដ្ឋសង្គមនិយម។ ទោះបីជាលោកនេ វីនបានចុះចេញពីដំណែងនៅឆ្នាំ 1988 ក៏ដោយ ក៏យោធានៅតែបន្តគ្រប់គ្រងប្រទេសដដែល។ នៅឆ្នាំ 1988 លោកស្រីអ៊ុងសាន ស៊ូជីបានត្រឡប់មកកាន់ប្រទេសភូមាវិញ បន្ទាប់ពីរស់នៅក្រៅប្រទេសអស់ជាច្រើនឆ្នាំ។ លោកស្រីគឺជាកូនស្រីរបស់លោកអ៊ុងសានដែលជាមេដឹកនាំកងទ័ពជាតិនិយមភូមា ដែលត្រូវបានគេលួចសម្លាប់កាលពីប៉ុន្មានឆ្នាំមុនដោយគូប្រជែងនយោបាយ។ លោកស្រី អ៊ុងសាន ស៊ូជីបានក្លាយជាសកម្មជននៅក្នុងសម្ព័ន្ធជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលទើបបង្កើតថ្មី។ ដោយសារតែសកម្មភាពគាំទ្រលទ្ធិប្រជាធិបតេយ្យ លោកស្រីត្រូវបានរដ្ឋាភិបាលដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនក្នុងផ្ទះរយៈពេល 6 ឆ្នាំ។ នៅក្នុងការបោះឆ្នោតឆ្នាំ 1990 ដែលជាការបោះឆ្នោតពហុបក្សលើកដំបូងរបស់ប្រទេសក្នុងរយៈពេល 30 ឆ្នាំ គណបក្សសម្ព័ន្ធជាតិដើម្បីលទ្ធិប្រជាធិបតេយ្យបានឈ្នះ 80% នៃអាសនៈសភាសរុប។ រដ្ឋាភិបាលយោធាបានបដិសេធមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ហើយពួកគេបានបន្តឃុំខ្លួនលោកស្រីអ៊ុងសាន ស៊ូជីនៅក្នុងផ្ទះជាបន្ត។ ទីបំផុតអ្នកស្រីត្រូវបានដោះលែងនៅឆ្នាំ 1995 ហើយត្រូវបានឃុំខ្លួនក្នុងផ្ទះឡើងវិញក្នុងឆ្នាំ 2000។ អ្នកស្រីត្រូវបានដោះលែងនៅឆ្នាំ 2002 និងត្រូវបានគេឃុំឃាំងម្តងទៀតក្នុងឆ្នាំ 2003 ។ នៅខែមិថុនា ឆ្នាំ 2007 ការឃុំខ្លួនក្នុងផ្ទះរបស់លោកស្រីអ៊ុងសាន ស៊ូជីត្រូវបានពន្យារពេលមួយឆ្នាំទៀត។

ម៉ាឡេស៊ី និងសិង្ហបុរីៈ នៅអំឡុងសង្គ្រាមលោកលើកទី 2 ជប៉ុនបានដណ្តើមកាន់កាប់ឧបទ្វីបម៉ាឡេ ដែលពីមុនគ្រប់គ្រងដោយអង់គ្លេស។ អង់គ្លេសបានត្រលប់ទៅឧបទ្វីបនេះវិញបន្ទាប់ពីការបរាជ័យរបស់ជប៉ុនក្នុងឆ្នាំ 1945 ។ ពួកគេបានបរាជ័យក្នុងការរៀបចំជនជាតិម៉ាឡាយ៉ាផ្សេងៗគ្នាឱ្យទៅជារដ្ឋតែមួយ។ ពួកគេក៏បានតស៊ូដើម្បីបង្ក្រាបការបះបោររបស់ពួកកុម្មុយនីស្តផងដែរ។ ពួកក្រុមជនជាតិភាគតិចបានទប់ទល់ទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់អង់គ្លេសក្នុងការបង្រួបបង្រួមដែនដីអាណានិគមរបស់ពួកគេនៅលើឧបទ្វីប ជាមួយនិងតំបន់កោះបូនេអ៊ូភាគខាងជើង។ ជនជាតិម៉ាឡេគឺជាក្រុមភាគច្រើនជាងគេនៅលើឧបទ្វីប ខណៈជនជាតិចិនជាក្រុមធំជាងគេនៅកោះសិង្ហបុរី

ដែលស្ថិតនៅភាគខាងត្បូង។ នៅឆ្នាំ 1957 សហព័ន្ធម៉ាឡាយ៉ាត្រូវបានបង្កើតឡើង ដែលជាការរួមបញ្ចូលគ្នានៃប្រទេសសិង្ហបុរី, ម៉ាឡាយ៉ា, សារ៉ាវ៉ាក់, និងសាបា។ តំបន់ទាំងពីរ — នៅឧបទ្វីបម៉ាឡេ និងតំបន់នៅបូនេអ៊ូភាគខាងជើង ត្រូវបានបំបែកចេញពីគ្នាដោយមហាសមុទ្រចម្ងាយ 400 ម៉ាយ។ នៅឆ្នាំ 1965 សិង្ហបុរីបានបំបែកខ្លួនចេញពីសហព័ន្ធ និងបានក្លាយជារដ្ឋឯករាជ្យ។ សហព័ន្ធដែលមានម៉ាឡាយ៉ា, សារ៉ាវ៉ាក, និងសាបា ត្រូវបានបានប្ដូរឈ្មោះទៅជាម៉ាឡេស៊ី។ ការចងសម្ព័ន្ធក្នុងចំណោមក្រុមជនជាតិភាគតិចជាច្រើន បានរក្សានូវវឌ្ឍនភាពសេដ្ឋកិច្ចប្រកបដោយស្ថិរភាពនៅក្នុងប្រទេសម៉ាឡេស៊ី។ ប្រទេសសិង្ហបុរីដែលមានកំពង់ផែដ៏មមាញឹកបំផុតមួយនៅក្នុងពិភពលោកបានក្លាយជាប្រទេសដែលមានការរីកចម្រើនខ្លាំង។ លោកលី ក្វានយូ បានគ្រប់គ្រងប្រទេសសិង្ហបុរីក្នុងនាមជានាយករដ្ឋមន្ត្រីចាប់ពីឆ្នាំ 1959 ដល់ឆ្នាំ 1990។ ក្រោមការដឹកនាំរបស់លោក សិង្ហបុរីបានលេចចេញជាមជ្ឈមណ្ឌលធនាគារ ក៏ដូចជាមជ្ឈមណ្ឌលពាណិជ្ជកម្មផងដែរ។ ប្រទេសនេះមានស្តង់ដារនៃការរស់នៅខ្ពស់ជាងប្រទេសជិតខាងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅឆ្នាំ 1997 វេទិកាសេដ្ឋកិច្ចពិភពលោកទីក្រុងហ្សឺណែវបានចុះបញ្ជីប្រទេសដែលមានសេដ្ឋកិច្ចខ្លាំងបំផុតរបស់ពិភពលោក។ សិង្ហបុរីឈរនៅលំដាប់កំពូល និងបន្តពីក្រោយដោយហុងកុង, សហរដ្ឋអាមេរិក, កាណាដា, នូវែលសេឡង់, ស្វីស, និងចក្រភពអង់គ្លេស។

### 3. ឥណ្ឌូនេស៊ីទទួលបានឯករាជ្យពីហូឡង់

ក៏ដូចបណ្ដាលប្រទេសអ៊ឺរ៉ុបផ្សេងៗទៀតដែរ ពួកហូឡង់ដែលគ្រប់គ្រងលើប្រទេសឥណ្ឌូណេស៊ីបានមើលឃើញពីការដួលរលំនៃការគ្រប់គ្រងអាណានិគមរបស់ពួកគេ ជាមួយនឹងការចាប់ផ្តើមឡើងនៃសង្គ្រាមលោកលើកទី 2 ។ ជប៉ុនបានដណ្តើមកាន់កាប់តំបន់នេះ និងបានបំផ្លាញសណ្តាប់ធ្នាប់នៃការគ្រប់គ្រងរបស់ហូឡង់។ នៅពេលដែលសង្គ្រាមបានបញ្ចប់ ហើយជនជាតិជប៉ុនដែលចាញ់សង្គ្រាមត្រូវបានបង្ខំឱ្យចាកចេញ ប្រជាជនឥណ្ឌូនេស៊ីបានធ្វើដំណើរឆ្ពោះទៅរកការបង្កើតប្រទេសឯករាជ្យមួយ។

ស៊ូកាណូដឹកនាំចលនាទាមទារឯករាជ្យ៖ អ្នកដែលនាំមុខគេនៅក្នុងការតស៊ូដើម្បីទាមទារឯករាជ្យសម្រាប់ប្រទេសឥណ្ឌូនេស៊ីគឺលោកស៊ូកាណូ ដែលមានតែនាមខ្លួន។ នៅខែសីហា ឆ្នាំ 1945 ពីរថ្ងៃបន្ទាប់ពីជប៉ុនចុះចាញ់ ស៊ូកាណូបានប្រកាសឯករាជ្យរបស់ប្រទេសឥណ្ឌូនេស៊ី ហើយប្រកាសខ្លួនឯងជាប្រធានាធិបតី។ ពួកទ័ពព្រៃបានគាំទ្រលោក។ ពួកហូឡង់ ដែលគាំទ្រដំបូងដោយអង់គ្លេស និងសហរដ្ឋអាមេរិក បានព្យាយាមដណ្តើមគ្រប់គ្រងប្រទេសឥណ្ឌូនេស៊ីឡើងវិញ។ ប៉ុន្តែបន្ទាប់ពីបាត់បង់ការគាំទ្រពីអង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិក ហូឡង់បានយល់ព្រមផ្តល់ឯករាជ្យដល់ប្រទេសឥណ្ឌូនេស៊ីនៅឆ្នាំ 1949 ។ ឥណ្ឌូនេស៊ីថ្មីបានក្លាយជាប្រទេសដែលមានប្រជាជនច្រើនជាងគេលំដាប់ទី 4 លើពិភពលោក។ ប្រទេសនេះមានកោះជាង 13,600 មានក្រុមជនជាតិភាគតិចចំនួន 300 ផ្សេងគ្នា និងមានភាសាចំនួន 250 និងសាសនាសំខាន់ៗនៅពិភពលោក។ ប្រទេសនេះមានប្រជាជនអ៊ីស្លាមច្រើនជាងគេលើពិភពលោក។ លោកស៊ូកាណូដែលបានទទួលងារជាផ្លូវការជា "ប្រធានាធិបតីពេញមួយជីវិត" បានព្យាយាមដឹកនាំប្រជាជាតិចម្រុះនេះនៅក្នុងប្រព័ន្ធនយោបាយប្រជាធិបតេយ្យអាស្រ័យសភា។

អស្ថិរភាព និងភាពចលាចលៈ កិច្ចខិតខំប្រឹងប្រែងរបស់លោកស៊ូកាណូក្នុងការកសាងប្រទេសបែបប្រជាធិបតេយ្យប្រកបដោយស្ថិរភាពមិនទទួលបានជោគជ័យឡើយ។ លោកមិនអាចគ្រប់គ្រងសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ីបានទេ ហើយប្រទេសនេះបានធ្លាក់ចុះយ៉ាងឆាប់រហ័ស។ ធនាគារបរទេសបានបដិសេធក្នុងការផ្តល់ ប្រាក់កម្ចីទៅឱ្យប្រទេសឥណ្ឌូនេស៊ី ហើយអតិផរណាម្តងម្កាលកើនឡើងដល់មួយពាន់ភាគរយ។ នៅឆ្នាំ 1965 មន្ត្រីយោធាវ័យក្មេងមួយក្រុមបានប៉ុនប៉ងធ្វើរដ្ឋប្រហារ។ ឧត្តមសេនីយ៍ម្នាក់ឈ្មោះស៊ូហារតូបានបង្ក្រាបការបះបោរនេះ។ បន្ទាប់មកលោកបានដណ្តើមអំណាចដោយខ្លួនឯង ហើយបានចាប់ផ្តើមការបង្ហូរឈាមនៅក្នុងប្រទេស ដែលបណ្តាលឱ្យប្រជាជនឥណ្ឌូនេស៊ីប្រមាណពី 500,000 ទៅ 1 លាននាក់ត្រូវបានសម្លាប់។ លោកស៊ូហារតូ ដែលត្រូវបានតែងតាំងជាប្រធានាធិបតីជាផ្លូវការនៅឆ្នាំ 1967 បានប្រែក្លាយប្រទេសឥណ្ឌូនេស៊ីទៅជារដ្ឋយោធាមួយ ហើយបានប្រកាសច្បាប់អាជ្ញាសឹកជាញឹកញាប់។ អ្នកសង្កេតការណ៍ខាងក្រៅ បានរិះគន់លោកយ៉ាងខ្លាំងចំពោះការបញ្ចូលទីម័រខាងកើតនៅក្នុងឆ្នាំ 1976 ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ឥណ្ឌូនេស៊ី និងចំពោះការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ។ រដ្ឋាភិបាលរបស់ស៊ូហារតូក៏បានបង្ហាញពីការអត់ឱនតិចតួចចំពោះសេរីភាពខាងសាសនា។ នៅអំឡុងពេលនោះ ការស៊ីសំណូក និងអំពើពុករលួយបានក្លាយជារឿងធម្មតា។ ក្រោមការដឹកនាំរបស់លោកស៊ូហាតូសេដ្ឋកិច្ចបានប្រសើរឡើងវិញមួយរយៈ ប៉ុន្តែចាប់ពីឆ្នាំ 1997 ដល់ឆ្នាំ 1998 ប្រទេសនេះបានទទួលរងនូវវិបត្តិហិរញ្ញវត្ថុដ៏អាក្រក់បំផុតមួយនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ភាពចលាចលបានកើតឡើងកាន់តែខ្លាំងដោយសារតែការគាបសង្កត់របស់រដ្ឋាភិបាល និងវិបត្តិសេដ្ឋកិច្ចដ៏អាក្រក់ បានជំរុញឲ្យលោកស៊ូហារតូ ចុះចេញពីដំណែងនៅឆ្នាំ 1998 ។ ខណៈពេលដែលភាពចលាចលនៅតែបន្តកើតមានឡើងពាសពេញប្រទេស វាបានផ្លាស់ប្តូរបន្តិចម្តងៗឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ។ កូនស្រីរបស់លោកស៊ូកាណូ ឈ្មោះមេហ្គាវ៉ាទី ស៊ូកាណូពូទ្រី ត្រូវបានបោះឆ្នោតជ្រើសរើសធ្វើជាប្រធានាធិបតីក្នុងឆ្នាំ 2001 ។ នៅពេលចូលកាន់តំណែង ប្រធានាធិបតីថ្មីបានសាទរចំពោះគុណធម៌នៃលទ្ធិប្រជាធិបតេយ្យ និងបានជំរុញឱ្យប្រជាជនឥណ្ឌូនេស៊ីធ្វើអ្វីដែលពួកគេអាចធ្វើបានដើម្បីរក្សាទម្រង់រដ្ឋាភិបាលបែបនេះ។ ស៊ូកាណូពូទ្រីបានប្រឈមទៅនឹងបញ្ហាដ៏ច្រើន។ ក្នុងនោះរួមទាំងភាពផុយស្រួយនៃសេដ្ឋកិច្ច, ជម្លោះជនជាតិភាគតិច, បញ្ហាសន្តិសុខ, និងអំពើពុករលួយរបស់រដ្ឋាភិបាល។

ទីម័រខាងកើតទទួលបានឯករាជ្យៈ ខណៈដែលដែលប្រទេសឥណ្ឌូនេស៊ីកំពុងធ្វើការដើម្បីជម្នះឧបសគ្គជាច្រើនរបស់ខ្លួន ពួកគេបានបាត់បង់ការគ្រប់គ្រងរបស់ពួកគេលើទីម័រខាងកើត។ កងកម្លាំងឥណ្ឌូណេស៊ីបានគ្រប់គ្រងទឹកដីនេះដោយប្រើកម្លាំងដ៏ឃោរឃៅ ចាប់តាំងពីសម័យលោកស៊ូហារតូដណ្តើមកាន់កាប់វាក្នុងទសវត្សរ៍ឆ្នាំ 1970 ។ ទោះជាយ៉ាងនេះក្តី ពួកទីម័រខាងកើត មិនដែលបញ្ឈប់ការទាមទារសេរីភាពរបស់ពួកគេឡើយ។ លោកចូសេ រ៉ាម៉ូស ហូរតា ដែលជាអ្នកធ្វើយុទ្ធនាការដើម្បីទាមទារឯករាជ្យឱ្យទីម័រខាងកើត បានឈ្នះពានរង្វាន់ណូបែលសន្តិភាពនៅក្នុងឆ្នាំ 1996 (រួមជាមួយព្រះសង្ឃរ៉ូម៉ាំងកាតូលិករបស់ទីម័រខាងកើត) សម្រាប់ការខិតខំប្រឹងប្រែងរបស់លោកដើម្បីទទួលបានឯករាជ្យសម្រាប់តំបន់ដោយគ្មានអំពើហិង្សា។ នៅក្នុងការធ្វើប្រជាមតិនៅខែសីហាឆ្នាំ 1999 ដែលបានឧបត្ថម្ភដោយអង្គការសហប្រជាជាតិ ប្រជាជនទីម័រខាងកើតបានបោះឆ្នោតជ្រើសរើសយកឯករាជ្យ។ ការបោះឆ្នោតបានធ្វើឱ្យកងកម្លាំងគាំទ្រឥណ្ឌូនេស៊ីខឹងសម្បារ។ ពួកគេមិនអើពើនឹងលទ្ធផល

ប្រជាមតិនេះឡើយ ហើយបានបន្តការបង្ក្រាប។ ពួកគេបានសម្លាប់មនុស្សរាប់រយនាក់ និងបង្ខំឱ្យមនុស្សរាប់ពាន់នាក់ឱ្យចូលទៅក្នុងជុំរុំជនភៀសខ្លួននៅទីម័រខាងលិចដែលជាផ្នែកមួយនៃប្រទេសឥណ្ឌូនេស៊ី។ នៅទីបំផុតកងកម្លាំងអន្តរាគមន៍របស់អង្គការសហប្រជាជាតិបាននាំមកនូវសន្តិភាពដល់តំបន់នោះ។ នៅឆ្នាំ 2002 ទីម័រខាងកើតបានប្រារព្ធពិធីឯករាជ្យជាតិរបស់ខ្លួន។ នៅខែឧសភា ឆ្នាំ 2007 លោកចូសេ រ៉ាម៉ូស ហូរតា បានឈ្នះតំណែងជាប្រធានាធិបតី។ សព្វថ្ងៃនេះ លោកហូរតាបានជួបប្រទះនឹងបញ្ហាប្រឈមក្នុងការអភិវឌ្ឍធនធានសម្រាប់ប្រទេសវ័យក្មេងរបស់លោក។ ក៏ដូចជានៅឧបទ្វីបឥណ្ឌាដែរ អំពើហិង្សា និងការតស៊ូគឺជាផ្នែកមួយនៃការផ្លាស់ប្ដូរនៅអាស៊ីអាគ្នេយ៍ពីការគ្រប់គ្រងអាណានិគមទៅជាប្រទេសសេរី។ ដូចគ្នានេះដែរ នៅទ្វីបអាហ្វ្រិកដែលជាកន្លែង អតីតដែនដីអាណានិគមជាច្រើនបានផ្ដួលរំលំការគ្រប់គ្រងរបស់ពួកអឺរ៉ុប និងបានបង្កើតប្រទេសឯករាជ្យបន្ទាប់ពីសង្គ្រាមលោកលើកទី 2 ។

# មេរៀនទី 3៖ ប្រជាជាតិថ្មីនៅអាហ្វ្រិក

## 1. ការទទួលបានឯករាជ្យ

តាមពិតទៅ ការតស៊ូរបស់អាហ្វ្រិកដើម្បីទទួលបានឯករាជ្យបានចាប់ផ្តើមឡើងតាំងពីមុនសង្គ្រាមលោកលើកទី 2 ទៅទៀត។ ជនជាតិអាហ្វ្រិកដែលនិយាយភាសាបារាំង និងឥណ្ឌាខាងលិចបានចាប់ផ្តើមបង្ហាញពីការយល់ដឹង និងមោទនភាពរបស់ពួកគេកាន់តែខ្លាំងឡើងចំពោះប្រពៃណីអាហ្វ្រិក។ ពួកគេបានបង្កើតចលនាណេគ្រីទូដដែលជាចលនាមួយដើម្បីលើកកម្ពស់វប្បធម៌, បេតិកភណ្ឌ, និងតម្លៃរបស់អាហ្វ្រិក។ នៅពេលដែលសង្គ្រាមលោកលើកទី 2 បានផ្ទុះឡើង ទាហានអាហ្វ្រិកបានចូលរួមជាមួយពួកអឺរ៉ុបដើម្បីប្រយុទ្ធ "ការពារសេរីភាព" ។ បទពិសោធន៍នេះបានធ្វើឱ្យពួកគេចាប់ផ្តើមបដិសេធការត្រួតត្រារបស់ពួកអាណានិគម នៅពេលពួកគេត្រឡប់មកស្រុកវិញ។ សង្គ្រាមក៏បានផ្លាស់ប្តូរការគិតរបស់ប្រជាជនអឺរ៉ុបផងដែរ។ មនុស្សជាច្រើនចាប់ផ្តើមចោទសួរពីការចំណាយ និងសិលធម៌ចំពោះការរក្សាដែនដីអាណានិគមនៅក្រៅប្រទេស។ កត្តាទាំងនេះ និងកត្តាផ្សេងទៀតបានជួយឱ្យដែនដីអាណានិគមអាហ្វ្រិកទាំងអស់ទទួលបានសេរីភាពរបស់ពួកគេនៅអំឡុងទសវត្សរ៍ឆ្នាំ 1950 និង 1960 ។ ទោះជាយ៉ាងនេះក្តី មធ្យោបាយដែលប្រទេសនានានៅអាហ្វ្រិកទទួលបានឯករាជ្យ មានភាពខុសៗគ្នានៅទូទាំងទ្វីប។ នៅក្នុងជំពូកទី 25 អ្នកបានដឹងមកហើយថា ប្រជាជននៅអឺរ៉ុបប្រើទម្រង់នៃការគ្រប់គ្រងចំនួន 2 នៅក្នុងដែនដីអាណានិគមអាហ្វ្រិក គឺដោយផ្ទាល់ និងដោយប្រយោល។ នៅក្រោមការគ្រប់គ្រងដោយប្រយោល មន្ត្រីមូលដ្ឋានបានធ្វើការគ្រប់គ្រងប្រទេសដោយខ្លួនឯងមួយភាគធំ ហើយពួកអាណានិគមធ្វើការគ្រប់គ្រងដោយផ្ទាល់មានកម្រិតតិចតួច។ ជាលទ្ធផល ដែនដីអាណានិគមទាំងនេះជាទូទៅមានភាពងាយស្រួលនៅក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកឯករាជ្យ។ សម្រាប់ដែនដីអាណានិគមដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ ពួកបរទេសបានគ្រប់គ្រងគ្រប់ជាន់ថ្នាក់ និងគ្មានការគ្រប់គ្រងមន្ត្រីមូលដ្ឋានខ្លួនឯងឡើយ ឯករាជ្យភាពមានភាពលំបាកក្នុងការទទួលបានជាងដែនដីដែលគ្រប់គ្រងអាណានិគមដោយប្រយោល។ ដែនដីអាណានិគមខ្លះត្រូវធ្វើសង្គ្រាមដើម្បីទទួលបានឯករាជ្យផងដែរ ដោយសារក្រុមអ្នកតាំងលំនៅអឺរ៉ុបបដិសេធមិនព្រមប្រគល់អំណាចឱ្យក្រុមជាតិនិយមអាហ្វ្រិក។ ទោះបីជាពួកគេទទួលបានសេរីភាពបែបណាក៏ដោយ ក៏ប្រទេសអាហ្វ្រិកថ្មីភាគច្រើនពិបាកក្នុងការស្វែងរកឃើញផ្លូវទៅកាន់ប្រទេសរឹងមាំ និងស្ថិរភាពណាស់។ ពួកគេត្រូវដោះស្រាយគ្រប់បែបយ៉ាង ចាប់ពីការបង្កើតរដ្ឋាភិបាលថ្មីរហូតដល់ការអភិវឌ្ឍសេដ្ឋកិច្ចបន្ទាប់ពីទទួលបានឯករាជ្យ។ ប្រទេសថ្មីៗជាច្រើនក៏ត្រូវបានញាំញីដោយជម្លោះរវាងក្រុមជនជាតិភាគតិចផងដែរ។ ក្នុងការដាក់អាណានិគមលើទ្វីបអាហ្វ្រិក ពួកអឺរ៉ុបបានបង្កើតព្រំដែនសិប្បនិម្មិត្ត ដែលជាប់ទាក់ទងតិចតួចជាមួយតំបន់ដែលក្រុមជនជាតិភាគតិចរស់នៅ។ ខណៈពេលដែលព្រំដែនប្រទេសជាតិបានបំបែកមនុស្សដែលមានវប្បធម៌ស្រដៀងគ្នា ពួកគេក៏បានដាក់បញ្ចូលសត្រូវប្រពៃណីឱ្យចូលគ្នា ដែលពួកគេបានចាប់ផ្តើមប្រយុទ្ធគ្នាភ្លាមៗបន្ទាប់ពីពួកអឺរ៉ុបបានចាកចេញ។ សម្រាប់ប្រទេសជាច្រើននៅទ្វីបអាហ្វ្រិក សកម្មភាពទាំងអស់នេះនាំទៅរកអស្ថិរភាព, អំពើហិង្សា, និងការតស៊ូដើម្បីដោះស្រាយជាមួយនឹងការទទួលបានឯករាជ្យថ្មីរបស់ពួកគេ។

## 2. ប្រទេសហ្គាណានាំមុខ

ដែនដីអាណានិគមអង់គ្លេសនៃហ្គូលខូសត៍ បានក្លាយជាដែនដីអាណានិគមអាហ្វ្រិកដំបូងគេនៅភាគខាងត្បូងនៃសាហារ៉ាដែលទទួលបានឯករាជ្យ។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 ជនជាតិអង់គ្លេសនៅតំបន់ហ្គូលខូសត៍បានចាប់ផ្តើមរៀបចំចាកចេញ។ ឧទាហរណ៍ ពួកគេបានអនុញ្ញាតឱ្យជនជាតិអាហ្វ្រិកបន្ថែមទៀតត្រូវបានតែងតាំងនៅក្រុមប្រឹក្សានីតិបញ្ញត្តិ។ ទោះយ៉ាងណាក៏ដោយ ជនជាតិអាហ្វ្រិកចង់បានសេរីភាពពេញលេញ។ មេដឹកនាំនៃចលនាអហិង្សាដ៏ធំរបស់ពួកគេគឺលោកក្វាមេ គ្រូម៉ា។ នៅដើមឆ្នាំ 1947 លោកបានធ្វើការដើម្បីរំដោះហ្គូលខូសត៍ពីចក្រភពអង់គ្លេស។ គ្រូម៉ាបានរៀបចំកូដកម្ម និងធ្វើពហិការ ហើយជារឿយៗលោកត្រូវបានចាប់ដាក់គុកដោយរដ្ឋាភិបាលអង់គ្លេស។ ទីបំផុតការខិតខំប្រឹងប្រែងរបស់លោកបានទទួលជោគជ័យ។ នៅពេលទទួលបានឯករាជ្យនៅឆ្នាំ 1957 ហ្គូលខូសត៍ត្រូវបានប្តូរឈ្មោះទៅជាហ្គាណា។ ឈ្មោះនេះត្រូវបានគេប្រើដើម្បីជាការផ្តល់កិត្តិយសដល់នគរអាហ្វ្រិកខាងលិចដ៏ល្បីល្បាញមួយកាលពីអតីតកាល។ គ្រូម៉ាបានក្លាយជានាយករដ្ឋមន្ត្រីដំបូងរបស់ប្រទេសហ្គាណា ហើយក្រោយមកជាប្រធានាធិបតីពេញមួយជីវិត។ គ្រូម៉ាបានរុញច្រានឱ្យមានការស្ថាបនាផ្លូវថ្មី, សាលារៀនថ្មី, និងការពង្រីកមណ្ឌលសុខភាព។ គម្រោងដែលមានតម្លៃថ្លៃទាំងអស់នេះភ្លាមៗបានបណ្តាលឱ្យប្រទេសជាប់គាំង។ កម្មវិធីរបស់លោកសម្រាប់ឧស្សាហូបនីយកម្ម, សុខភាព, សុខុមាលភាព, និងការពង្រីកមណ្ឌលអប់រំបានបង្ហាញពីចេតនាល្អ។ ទោះជាយ៉ាងណាក៏ដោយ ការចំណាយលើកម្មវិធីទាំងនេះបានបណ្តាលឲ្យខូចសេដ្ឋកិច្ច និងបង្កើនការប្រឆាំងលើរូបលោក។ លើសពីនេះ គ្រូម៉ាជារឿយៗត្រូវបានរិះគន់ចំពោះការចំណាយពេលច្រើនពេកលើកិច្ចខិតខំប្រឹងប្រែងក្នុងការបង្រួមបង្រួមអាហ្វ្រិក និងការមិនយកចិត្តទុកដាក់ចំពោះបញ្ហាសេដ្ឋកិច្ចនៅក្នុងប្រទេស។ លោកសុបិនអំពីការបង្កើត "សហរដ្ឋអាហ្វ្រិក" ។ នៅឆ្នាំ 1966 ខណៈពេលដែល គ្រូម៉ាស្ថិតនៅក្នុងប្រទេសចិន កងទ័ព និងប៉ូលីសនៅក្នុងប្រទេសហ្គាណាបានដណ្តើមអំណាច។ ចាប់តាំងពីពេលនោះមក ប្រទេសបានផ្លាស់ប្តូរការគ្រប់គ្រងទៅវិញទៅមករវាងមេដឹកនាំស៊ីវិល និងយោធា ហើយបានតស៊ូដើម្បីស្ថិរភាពសេដ្ឋកិច្ច។ នៅឆ្នាំ 2000 ហ្គាណាបានរៀបចំការបោះឆ្នោតបើកចំហជាលើកដំបូងរបស់ខ្លួន។

## 3. ការតស៊ូដើម្បីសេរីភាព

ផ្ទុយពីប្រទេសហ្គាណា ប្រទេសមួយចំនួនដូចជាកេនយ៉ា និងអាល់ហ្សេរី ត្រូវកាន់អាវុធដើម្បីប្រឆាំងជាមួយពួកអ្នកគ្រប់គ្រងអឺរ៉ុបរបស់ពួកគេ ដើម្បីដណ្តើមសេរីភាពរបស់ពួកគេ។

កេនយ៉ាទាមទារឯករាជ្យ៖ អង់គ្លេសបានគ្រប់គ្រងប្រទេសកេនយ៉ា ហើយក្រុមអ្នកតាំងទីលំនៅអង់គ្លេសជាច្រើនបានប្រឆាំងនឹងឯករាជ្យភាពរបស់កេនយ៉ា ជាពិសេសអ្នកដែលបានកាន់កាប់ដីស្រែចំការនៅតំបន់ខ្ពង់រាបភាគខាងជើងនៃប្រទេស។ ពួកគេត្រូវបានបង្ខំឱ្យទទួលស្គាល់រដ្ឋាភិបាលស្វ័យរបស់អាហ្វ្រិក ដែលបណ្តាលមកពីការអភិវឌ្ឍចំនួនពីរ។ ទីមួយគឺការដឹកនាំដ៏រឹងមាំរបស់អ្នកជាតិនិយមកេនយ៉ាលោកចូម៉ូ កេនយ៉ាតា។ ទីពីរគឺការកើនឡើងនៃក្រុមមួយដែលគេស្គាល់ថាក្រុមម៉ាវម៉ាវ។ ក្រុមនេះគឺជាក្រុមសង្គមសម្ងាត់មួយដែលបង្កើតឡើងដោយប្រជាកសិករកេនយ៉ា ដែលភាគច្រើនត្រូវបានបង្ខំឲ្យចេញពីតំបន់ខ្ពង់រាបដោយពួកអង់គ្លេស។ ដោយប្រើយុទ្ធសាស្ត្រ

សង្គ្រាមទ័ពព្រៃ ក្រុមម៉ាវម៉ាវបានតស៊ូក្នុងការបណ្តេញពួកកសិករស្បែកសឱ្យចាកចេញពីតំបន់ខ្ពង់រាប។ លោកកេនយ៉ាតា អះអាងថាលោកមិនមានទំនាក់ទំនងជាមួយក្រុមម៉ាវម៉ាវឡើយ។ ទោះជាយ៉ាងណា លោកបដិសេធក្នុងការថ្កោលទោសក្រុមនេះ។ ជាលទ្ធផល អង់គ្លេសបានចាប់លោកដាក់គុកជិតមួយទសវត្សរ៍។ ត្រឹមពេលដែលអង់គ្លេសផ្តល់ឯករាជ្យដល់ប្រទេសកេនយ៉ានៅក្នុងឆ្នាំ 1963 ពួកអាហ្វ្រិកជាង 10,000 និងអ្នកតាំងលំនៅចំនួន 100 ត្រូវបានសម្លាប់។ លោកកេនយ៉ាតាបានក្លាយជាប្រធានាធិបតីនៃប្រជាជាតិថ្មី។ គាត់បានខិតខំប្រឹងប្រែងដើម្បីបង្រួបបង្រួមក្រុមជនជាតិ និងភាសាផ្សេងៗរបស់ប្រទេស។ លោកកេនយ៉ាតាបានស្លាប់នៅឆ្នាំ 1978 ។ អ្នកស្នងតំណែងបន្តពីលោកគឺលោកដានៀល អារ៉ាប់ មួយ ដែលមិនសូវជោគជ័យក្នុងការគ្រប់គ្រងប្រទេសឡើយ។ លោកមួយប្រឈមនឹងការប្រឆាំងកាន់តែខ្លាំងឡើងចំពោះការគ្រប់គ្រងដោយបក្សតែមួយរបស់លោក។ អ្វីដែលកាន់តែបន្ថែមទៅលើបញ្ហារបស់ប្រទេសជាតិ គឺអំពើពុករលួយនៅក្នុងជួររដ្ឋាភិបាលរបស់លោក និងជម្លោះជនជាតិភាគតិចដែលបានសម្លាប់មនុស្សរាប់រយនាក់ និងរាប់ពាន់នាក់គ្មានផ្ទះសម្បែង។ លោកមួយបានលាលែងពីតំណែងក្នុងឆ្នាំ 2002 ហើយគណបក្សថ្មីមួយទទួលបានអំណាចតាមរយៈការបោះឆ្នោតដោយសេរី។

អាល់ហ្សេរីតស៊ូដើម្បីឯករាជ្យ៖ ដែនដីអាណានិគមនៅក្រៅប្រទេសដ៏សំខាន់មួយរបស់ប្រទេសបារាំងគឺអាល់ហ្សេរី ដែលមានពួកម្ចាស់អាណានិគមជនជាតិបារាំងចំនួនមួយលាននាក់ និងពួកអារ៉ាប់ និងប៊ឺបឺម៉ូស្លីមចំនួន 9 លាននាក់។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 បានបញ្ចប់ ពួកម្ចាស់អាណានិគមបារាំងបានបដិសេធក្នុងការចែករំលែកអំណាចនយោបាយជាមួយជនជាតិដើមអាល់ហ្សេរី។ នៅឆ្នាំ 1954 រណសិរ្សរំដោះជាតិអាល់ហ្សេរីបានប្រកាសពីចេតនារបស់ខ្លួនក្នុងការប្រយុទ្ធដើម្បីឯករាជ្យ។ បារាំងបានបញ្ជូនកងទ័ពប្រហែលកន្លះលានចូលទៅក្នុងប្រទេសអាល់ហ្សេរី ដើម្បីប្រយុទ្ធប្រឆាំងជាមួយរណសិរ្សរំដោះជាតិអាល់ហ្សេរី។ ភាគីទាំង 2 បានប្រព្រឹត្តអំពើឃោរឃៅទៅវិញទៅមក។ រណសិរ្សរំដោះជាតិអាល់ហ្សេរីបានយកឈ្នះការប្រយុទ្ធនេះ ហើយអាល់ហ្សេរីទទួលបានឯករាជ្យនៅខែកក្កដា ឆ្នាំ 1962 ។ មេដឹកនាំរណសិរ្សរំដោះជាតិអាល់ហ្សេរី គឺលោកអាល់មេដ បេន បេឡា បានក្លាយជាប្រធានាធិបតីដំបូងរបស់អាល់ហ្សេរីដែលទើបនឹងទទួលបានឯករាជ្យ។ លោកបានព្យាយាមធ្វើឱ្យអាល់ហ្សេរីក្លាយជារដ្ឋសង្គមនិយម ប៉ុន្តែត្រូវបានផ្តួលរំលំនៅឆ្នាំ 1965 ដោយមេបញ្ជាការកងទ័ពរបស់លោក។ ចាប់ពីឆ្នាំ 1965 ដល់ឆ្នាំ 1988 ពួកអាល់ហ្សេរីបានបរាជ័យក្នុងការធ្វើទំនើបកម្ម និងឧស្សាហូបនីយកម្មរបស់ប្រទេស។ ភាពអត់ការងារធ្វើ និងការមិនពេញចិត្តចំពោះរដ្ឋាភិបាល បានរួមចំណែកក្នុងការជម្រុញឱ្យមានកំណើនអ្នកសាសនានិយមដែលចង់ធ្វើឱ្យប្រទេសអាល់ហ្សេរីក្លាយជារដ្ឋអ៊ីស្លាម។ គណបក្សអ៊ីស្លាមដែលធំជាងគេ រណសិរ្សសង្គ្រោះអ៊ីស្លាមបានឈ្នះការបោះឆ្នោតក្នុងតំបន់ និងសភាក្នុងឆ្នាំ 1990 និង 1991។ ទោះជាយ៉ាងណាក៏ដោយរដ្ឋាភិបាល និងកងទ័ពដែលកំពុងកាន់អំណាចបានបដិសេធមិនទទួលយកលទ្ធផលបោះឆ្នោតនោះទេ។ ជាលទ្ធផល សង្គ្រាមស៊ីវិលបានផ្ទុះឡើងរវាងក្រុមសកម្មប្រយុទ្ធអ៊ីស្លាម និងរដ្ឋាភិបាល។ សង្គ្រាមនៅតែបន្តកើតមាន រហូតមកដល់សព្វថ្ងៃនេះ។

## 4. សង្គ្រាមស៊ីវិលនៅកុងហ្គោ និងអង់ហ្គោឡា

សង្គ្រាមស៊ីវិលក៏បានញាំញីនៅក្នុងប្រទេសថ្មីកុងហ្គោ និងអង់ហ្គោឡាផងដែរ។ បញ្ហារបស់កុងហ្គោជាប់ទាក់ទងជាមួយរបបផ្តាច់ការពុករលួយ និងអរិភាពក្នុងចំណោមក្រុមជនជាតិភាគតិច។ ទន្ទឹមនឹងនេះ ការលំបាករបស់អង់ហ្គោឡាកើតចេញពីការខ្វែងគំនិតគ្នាយ៉ាងខ្លាំងផ្នែកខាងនយោបាយ។

សេរីភាព និងភាពចលាចលនៅកុងហ្គោ៖ ក្នុងចំណោមដែនដីអាណានិគមអឺរ៉ុបទាំងអស់នៅក្នុងទ្វីបអាហ្វ្រិក កុងហ្គោគឺជាដែនដីដែលទទួលរងការកេងប្រវ័ញ្ចបំផុតមួយពីសំណាក់ពួកប៊ែលហ្ស៊ិក។ បែលហ្ស៊ិកបានប្លន់យកធនធានកៅស៊ូ និងទង់ដែងដ៏សម្បូរបែបរបស់ដែនដីអាណានិគមនេះ។ លើសពីនេះ មន្ត្រីប៊ែលហ្ស៊ិកបានគ្រប់គ្រងដោយឃោរឃៅ និងមិនបានផ្តល់សេវាសង្គមដល់ប្រជាជនឡើយ។ ពួកគេក៏មិនមានចេតនាក្នុងការរៀបចំឱ្យប្រជាជនប្រុងប្រៀបក្នុងការទទួលបានឯករាជ្យឡើយ។ មិនមានអ្វីគួរឱ្យភ្ញាក់ផ្អើល ការផ្តល់ឯករាជ្យរបស់ប៊ែលហ្ស៊ិកដល់កុងហ្គោក្នុងឆ្នាំ 1960 (ត្រូវបានគេស្គាល់ថាហ្សៃរ៉េចាប់ពីឆ្នាំ 1971 ដល់ឆ្នាំ 1997 ) បានបណ្តាលឱ្យមានការចលាចល។ បន្ទាប់ពីសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ មេទ័ពម្នាក់គឺវរសេនីយ៍ឯកចូសេផ ម៉ូប៊ូទូដែលក្រោយមកគេស្គាល់ថា ម៉ូប៊ូទូ សេសេ សេកូបានដណ្តើមអំណាចនៅឆ្នាំ 1965 ។ អស់រយៈពេល 32 ឆ្នាំ ម៉ូប៊ូទូបានគ្រប់គ្រងប្រទេសដែលលោកបានប្តូរឈ្មោះថាហ្សៃរ៉េ។ លោកបានរក្សាការគ្រប់គ្រងរបស់លោកដោយការរួមបញ្ចូលគ្នានៃការប្រើប្រាស់កម្លាំង, ការគ្រប់គ្រងដោយបក្សតែមួយ, និងការផ្តល់អំណោយដល់អ្នកគាំទ្រ។ លោកម៉ូប៊ូទូបានទទួលជោគជ័យក្នុងការទប់ទល់ការបះបោរប្រដាប់អាវុធជាច្រើនលើក។ ទីបំផុតលោកត្រូវបានផ្តួលរំលំនៅឆ្នាំ 1997 ដោយមេដឹកនាំឧទ្ទាមឈ្មោះឡូរ៉ែនត៍ កាប៊ីឡា បន្ទាប់ពីវាយប្រយុទ្ធគ្នានៅក្នុងសង្គ្រាមស៊ីវិលអស់ជាច្រើនខែ។ មិនយូរប៉ុន្មាន ប្រទេសនេះត្រូវបានប្តូរឈ្មោះទៅជាសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ នៅពេលក្លាយជាប្រធានាធិបតី លោកកាប៊ីឡាបានសន្យាថានឹងមានការផ្លាស់ប្តូរទៅកាន់លទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតដោយសេរីនៅខែមេសា ឆ្នាំ 1999 ។ ការបោះឆ្នោតបែបនេះមិនដែលកើតមានឡើយ។ នៅឆ្នាំ 2000 ប្រជាជាតិបានប្រឈមជាមួយនឹងសង្គ្រាមស៊ីវិលមួយផ្សេងទៀត ខណៈដែលក្រុមឧទ្ទាមបីក្រុមដាច់ដោយឡែកពីគ្នាបានស្វែងរកការផ្តួលរំលំការគ្រប់គ្រងរបស់លោកកាប៊ីឡា។ នៅខែមករា ឆ្នាំ 2001 អង្គរក្សម្នាក់បានលួចធ្វើឃាតកាប៊ីឡា។ កូនប្រុសរបស់លោកឈ្មោះចូសេផ កាប៊ីឡាបានឡើងកាន់អំណាច ហើយបានចាប់ផ្តើមដំណើរស្វែងរកសន្តិភាព។ នៅឆ្នាំ 2002 រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពជាមួយក្រុមឧទ្ទាម និងប្រទេសជិតខាង។ នៅឆ្នាំ 2006 លោកកាប៊ីឡាត្រូវបានជ្រើសរើសជាប្រធានាធិបតីក្រោមរដ្ឋធម្មនុញ្ញថ្មី។

សង្គ្រាមហែកហួរនៅអង់ហ្គោឡា៖ ប្រទេសអង់ហ្គោឡាស្ថិតនៅភាគនិរតីនៃប្រទេសកុងហ្គោ គឺជាប្រទេសមួយដែលមិនត្រឹមតែត្រូវប្រយុទ្ធដើម្បីទទួលបានសេរីភាពរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែត្រូវការរួបរួមគ្នាបន្ទាប់ពីទទួលបានឯករាជ្យ។ ពួកព័រទុយហ្គាល់បានគ្រប់គ្រងប្រទេសអង់ហ្គោឡាជាយូរមកហើយ ហើយគ្មានបំណងចង់បញ្ឈប់ការគ្រប់គ្រងរបស់ពួកគេឡើយ។ នៅពេលដែលចលនាទាមទារឯករាជ្យមួយបានផ្ទុះឡើងនៅក្នុងដែនដីអាណានិគមអង់ហ្គោឡា ព័រទុយហ្គាល់បានបញ្ជូនទាហានចំនួន 50,000 នាក់ទៅកាន់ទីនោះ។ ការចំណាយលើជម្លោះនេះ

មានចំនួនជិតពាក់កណ្ដាលនៃថវិកាជាតិរបស់ប្រទេសព័រទុយហ្គាល់។ ការចំណាយដ៏ធ្ងន់នៅក្នុងការប្រយុទ្ធ ក៏ដូចជាការកើនឡើងនៃអ្នកប្រឆាំងការសង្គ្រាមក្នុងចំណោមប្រជាជនព័រទុយហ្គាល់ បានជំរុញឱ្យពួកព័រទុយហ្គាល់ដកខ្លួនចេញពីប្រទេសអង់ហ្គោឡាក្នុងឆ្នាំ 1975 ។ ភ្លាមៗនោះ ចលនាប្រជាប្រិយដើម្បីរំដោះអង់ហ្គោឡាដែលមាននិន្នាការកុំម្មុយនីស្ត បានប្រកាសថាខ្លួនជារដ្ឋាភិបាលស្របច្បាប់របស់ប្រទេសថ្មីនេះ។ ហេតុនេះបានបង្កឱ្យមានសង្គ្រាមស៊ីវិលអូសបន្លាយ ដូចដែលក្រុមឧទ្ទាមផ្សេងៗបានវាយប្រយុទ្ធជាមួយរដ្ឋាភិបាល និងប្រយុទ្ធគ្នាទៅវិញទៅមកដើម្បីអំណាច។ ក្រុមនីមួយៗបានទទួលជំនួយពីប្រភពខាងក្រៅ។ ចលនាប្រជាប្រិយដើម្បីរំដោះអង់ហ្គោឡាត្រូវបានជួយដោយទាហានគុយបាប្រហែល 50,000 នាក់ និងដោយសហភាពសូវៀត។ អ្នកដែលប្រឆាំងដ៏ធំចំពោះចលនាប្រជាប្រិយដើម្បីរំដោះអង់ហ្គោឡាគឺ សហភាពជាតិសម្រាប់ឯករាជ្យភាពបរិបូរណ៍របស់អង់ហ្គោឡា ដែលអាហ្វ្រិកខាងត្បូង និងសហរដ្ឋអាមេរិកគាំទ្រ។ អស់ជាច្រើនទស្សវត្សរ៍ ភាគីទាំងពីរបានព្រមព្រៀងគ្នា ហើយបន្ទាប់មកបានបោះបង់ចោលកិច្ចព្រមព្រៀងឈប់បាញ់ផ្សេងៗ។ ក្នុងឆ្នាំ 2002 ភាគីជម្លោះបានព្រមព្រៀងគ្នានៅក្នុងកិច្ចព្រមព្រៀងសន្តិភាព ហើយសង្គ្រាមស៊ីវិលដ៏យូរមកហើយត្រូវបានបញ្ចប់។ នៅពេលដែលដែនដីអាណានិគមនៅទ្វីបអាហ្វ្រិកបានធ្វើការដើម្បីក្លាយជាប្រទេសដែលមានស្ថិរភាព ប្រជាជាតិថ្មីរបស់អ៊ីស្រាអែលបានកំពុងលេចឡើងនៅតំបន់មជ្ឈិមបូព៌ា។ ការរីកចម្រើនរបស់ពួកគេ ដូចដែលអ្នកនឹងបានអាននៅក្នុងមេរៀនបន្ទាប់ បានធ្វើឱ្យប្រជាជនជាច្រើននៅក្នុងពិភពអារ៉ាប់មានការខកចិត្ត ហើយបានជំរុញឱ្យមានជម្លោះដែលអូសបន្លាយដ៏យូរបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប។

# មេរៀនទី 4៖ ជម្លោះនៅមជ្ឈិមបូព៌ា

## 1. អ៊ីស្រាអែលក្លាយជារដ្ឋមួយ

ទឹកដីដែលគេហៅថាប៉ាឡេស្ទីន ឥឡូវនេះរួមមានអ៊ីស្រាអែល, វេសប៊ែង, និងហ្គាសាស្ទ្រីប។ សម្រាប់ពួកយូដា ពួកគេបានអះអាងថាដែនដីនេះគឺជាកម្មសិទ្ធិរបស់ពួកគេតាំងពី 3,000 ឆ្នាំមុនមកម្លេះ នៅពេលដែលស្តេចយូដានានាបានគ្រប់គ្រងតំបន់នេះនៅយេរ៉ូសាឡឹម។ សម្រាប់ជនជាតិប៉ាឡេស្ទីន (ទាំងម៊ូស្លីម និងគ្រីស្តសាសនិក) ទឹកដីនេះជាកម្មសិទ្ធិរបស់ពួកគេតាំងពីពួកយូដាត្រូវបានបណ្តេញចេញនៅប្រហែលឆ្នាំ 135 នៃគ.ស។ សម្រាប់ពួកអារ៉ាប់ ទឹកដីនេះជាកម្មសិទ្ធិរបស់ពួកគេតាំងពីពេលដែលពួកគេដណ្តើមកាន់កាប់តំបន់នេះនៅសតវត្សរ៍ទី 7 ។

បន្ទាប់ពីត្រូវបានបង្ខំឱ្យចាកចេញពីប៉ាឡេស្ទីននៅអំឡុងសតវត្សរ៍ទី 2 ប្រជាជនជ្វីហ្វមិនអាចបង្កើតរដ្ឋផ្ទាល់ខ្លួនរបស់ពួកគេបានឡើយ និងបានរស់នៅក្នុងប្រទេសផ្សេងៗនៅទូទាំងពិភពលោក។ ការបែកខ្ញាត់ខ្ចាយជាសកលនៃពួកយូដានេះត្រូវបានគេស្គាល់ថាជាការបែកខ្ញែក។ នៅចុងសតវត្សរ៍ទី 19 និងដើមសតវត្សទី 20 ពួកយូដាមួយក្រុម បានចាប់ផ្តើមវិលត្រឡប់ទៅតំបន់ ដែលបុព្វបុរសរបស់ពួកគេបានភៀសខ្លួនចេញតាំងពីយូរណាស់មកហើយ។ ពួកគេត្រូវបានគេស្គាល់ថាជាពួកហ្ស៊ីអននិយម ដែលជាក្រុមមនុស្សចង់ឱ្យមានរដ្ឋជ្វីហ្វមួយនៅទឹកដីប៉ាឡេស្ទីន។ នៅពេលនេះ ប៉ាឡេស្ទីននៅតែជាផ្នែកមួយនៃចក្រភពអូតូម៉ង់ ដែលគ្រប់គ្រងដោយជនជាតិទួគីអ៊ីស្លាម។ បន្ទាប់ពីការបរាជ័យរបស់ពួកអូតូម៉ង់ក្នុងសង្គ្រាមលោកលើកទី 1 សម្ព័ន្ធប្រជាជាតិបានស្នើសុំឱ្យចក្រភពអង់គ្លេសត្រួតត្រាលើដែនដីប៉ាឡេស្ទីនរហូតដល់ពួកគេត្រៀមខ្លួនរួចរាល់ដើម្បីទទួលបានឯករាជ្យ។ នៅពេលនោះ ពួកយូដាកាន់តែមានវត្តមានច្រើនឡើងៗនៅក្នុងដែនដីប៉ាឡេស្ទីន និងកំពុងរុញច្រានឱ្យមានរដ្ឋរបស់ពួកគេនៅក្នុងទឹកដីនេះ។ ជនជាតិអារ៉ាប់ដែលរស់នៅក្នុងតំបន់នេះបានប្រឆាំងយ៉ាងខ្លាំងចំពោះទង្វើបែបនេះ។ នៅក្នុងសំបុត្រមួយដែលសរសេរឡើងនៅក្នុងឆ្នាំ 1917 ផ្ញើរទៅកាន់មេដឹកនាំហ្ស៊ីអននិយម រដ្ឋមន្ត្រីការបរទេសអង់គ្លេសលោក អាថ៌រ បាល់ហ្វ័រ បានបង្ហាញពីគំនិតក្នុងការបង្កើតរដ្ឋជ្វីហ្វមួយនៅប៉ាឡេស្ទីន ខណៈពេលដែលការពារ "សិទ្ធិរបស់សហគមន៍ដែលមិនមែនជាជនជាតិជ្វីហ្វ"។ ទោះបីជាយ៉ាងណាក៏ដោយ បើទោះបីជាមានសេចក្តីប្រកាសរបស់លោកបាល់ហ្វ័រ ក៏ដោយក៏កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតរដ្ឋជ្វីហ្វបានបរាជ័យ ហើយអរិភាពរវាងពួកអារ៉ាប់ប៉ាឡេស្ទីន និងពួកយូដាបានបន្តកើនឡើង។

នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទី 2 អង្គការសហប្រជាជាតិបានចាត់វិធានការ។ នៅឆ្នាំ 1947 មហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតបែងចែកប៉ាឡេស្ទីនទៅជារដ្ឋប៉ាឡេស្ទីនអារ៉ាប់ និងរដ្ឋជ្វីហ្វ។ ក្រុងយេរ៉ូសាឡឹមត្រូវក្លាយជាទីក្រុងអន្តរជាតិដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីទាំងសងខាង។ លក្ខខណ្ឌនៃការបែងចែកនេះបានផ្តល់ឱ្យពួកយូដានូវដែនដីចំនួន 55 ភាគរយនៃតំបន់នេះ ទោះបីជាពួកគេមានចំនួនត្រឹមតែ 34% នៃចំនួនប្រជាជនសរុបក៏ដោយ។ ដោយសារស្ថានការណ៍នៃសង្គ្រាម និងការសម្លាប់រង្គាល សហរដ្ឋអាមេរិក និងប្រទេសអឺរ៉ុបជាច្រើនមានការអាណិតអាសូរយ៉ាងខ្លាំងចំពោះពួកយូដា។ ប្រទេសឥស្លាមទាំងអស់បានបោះឆ្នោតប្រឆាំងនឹងការបែងចែកនេះ ហើយប៉ាឡេស្ទីនបានច្រានចោលទាំងស្រុង។ ពួកគេបានអះអាងថា អង្គការសហ

ប្រជាជាតិមិនមានសិទ្ធិក្នុងបែងចែកទឹកដី ដោយមិនគិតពីបំណងប្រាថ្នារបស់ប្រជាជនភាគច្រើននៅទីនោះទេ។ នៅទីបំផុត កាលបរិច្ឆេទត្រូវបានកំណត់សម្រាប់ការបង្កើតរដ្ឋអ៊ីស្រាអែល ថ្ងៃទី 14 ខែឧសភា ឆ្នាំ 1948។ នៅថ្ងៃនោះ លោកដេវីដ បេន ហ្គូរីអន ដែលជាមេដឹកនាំយូដាតស៊ូប្រឆាំងនៅប៉ាឡេស្ទីនជាច្រើនឆ្នាំមកហើយ បានប្រកាសបង្កើតរដ្ឋអ៊ីស្រាអែលឯករាជ្យមួយ។

## 2. អ៊ីស្រាអែល និងរដ្ឋអារ៉ាប់កើតមានជម្លោះ

រដ្ឋអ៊ីស្រាអែលថ្មីទទួលបានការស្វាគមន៍យ៉ាងអរិភាពពីប្រទេសជិតខាង។ មួយថ្ងៃបន្ទាប់ពីពួកគេបានប្រកាសខ្លួនជារដ្ឋឯករាជ្យ រដ្ឋអ៊ីស្លាមចំនួន 6 ដែលក្នុងនោះរួមមានអេហ្ស៊ីប, អ៊ីរ៉ាក់, ហ្ស៊កដានី, លីបង់, អារ៉ាប៊ីសាអូឌីត, និងស៊ីរី បានលុកលុយអ៊ីស្រាអែល។ សង្គ្រាមអារ៉ាប់-អ៊ីស្រាអែលលើកទី 1 នេះបានបញ្ចប់ក្នុងរយៈពេលប៉ុន្មានខែ ដោយអ៊ីស្រាអែលជាអ្នកទទួលជ័យជម្នះ។ សង្គ្រាមទ្រង់ទ្រាយធំបានផ្ទុះឡើងជាថ្មីទៀតនៅឆ្នាំ 1956, 1967, និង 1973។ ដោយសារតែភាពតានតឹងរវាងអារ៉ាប់-អ៊ីស្រាអែល ពួកយូដារាប់សែននាក់ដែលរស់នៅក្នុងទឹកដីអារ៉ាប់បានផ្លាស់ទៅរស់នៅក្នុងប្រទេសអ៊ីស្រាអែល។ ដោយសារតែការប្រយុទ្ធគ្នានេះ រដ្ឋដែលអង្គការសហប្រជាជាតិបានកំណត់សម្រាប់ពួកអារ៉ាប់ មិនបានលេចចេញជារូបរាងឡើយ។ អ៊ីស្រាអែលបានដណ្តើមយកដែនដីពាក់កណ្តាលក្នុងការប្រយុទ្ធគ្នាឆ្នាំ 1948-1949 ។ ខណៈពេលដែលការប្រយុទ្ធគ្នាបានផ្ទុះឡើង យ៉ាងហោចណាស់មានប្រជាជនប៉ាឡេស្ទីនចំនួន 600,000 នាក់បានភៀសខ្លួនចេញពីតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ៊ីស្រាអែល។ ពួកគេបានតាំងទីលំនៅក្នុងជំរុំជនភៀសខ្លួនដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិ ដែលស្ថិតនៅតាមព្រំដែនប្រទេសនានាព័ទ្ធជុំវិញអតីតដែនដីកំណើតរបស់ពួកគេ។ ទន្ទឹមនឹងនោះ ប្រទេសអារ៉ាប់ផ្សេងទៀត បានដណ្តើមយកទឹកដីប៉ាឡេស្ទីនផ្សេងទៀត។ អេហ្ស៊ីបបានគ្រប់គ្រងតំបន់ហ្គាហ្សាស្ទ្រីប ខណៈពេលដែលហ្ស៊កដានីបានបញ្ចូលតំបន់វេសប៊ែងនៅទន្លេហ្ស៊កដាន។

វិបត្តិស៊ុយអេឆ្នាំ 1956៖ សង្គ្រាមអារ៉ាប់-អ៊ីស្រាអែលលើកទី 2 បានផ្ទុះឡើងនៅឆ្នាំ 1956។ នៅក្នុងឆ្នាំនោះ អេហ្ស៊ីបបានដណ្តើមគ្រប់គ្រងព្រែកជីកស៊ុយអេ ដែលលាតសន្ធឹងតាមបណ្តោយព្រំដែនភាគខាងកើតនៃប្រទេសអេហ្ស៊ីបរវាងឈូងសមុទ្រស៊ុយអេ និងសមុទ្រមេឌីទែរ៉ាណេ។ ប្រធានាធិបតីអេហ្ស៊ីបលោកហ្គាម៉ាល់ អាប់ឌែល ណាស៊ែរ បានបញ្ជូនកងទ័ពទៅដណ្តើមកាន់កាប់ព្រែកជីកស៊ុយអេ ដែលពេលនោះគ្រប់គ្រងដោយអង់គ្លេស។ សកម្មភាពយោធានេះ មួយផ្នែកធំត្រូវបានជំរុញធំដោយការខឹងសម្បាររបស់ណាស៊ែរ ចំពោះការបាត់បង់ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក និងអង់គ្លេសសម្រាប់ការសាងសង់ទំនប់អាស្វានរបស់ប្រទេសអេហ្ស៊ីប។ ដោយមានការខឹងសម្បារ អង់គ្លេសបានចុះកិច្ចព្រមព្រៀងមួយជាមួយបារាំង និងអ៊ីស្រាអែល ដើម្បីដណ្តើមយកព្រែកជីកនេះមកវិញ។ ដោយមានការគាំទ្រតាមផ្លូវអាកាសដែលផ្តល់ដោយសម្ព័ន្ធមិត្តអឺរ៉ុបរបស់ពួកគេ កងទ័ពអ៊ីស្រាអែលបានធ្វើដំណើរឆ្ពោះទៅកាន់ព្រែកជីកស៊ុយអេ ហើយបានកម្ចាត់ពួកអេហ្ស៊ីបយ៉ាងឆាប់រហ័ស។ ទោះជាយ៉ាងណាក៏ដោយ សម្ពាធពីសហគមន៍ពិភពលោក រួមទាំងសហរដ្ឋអាមេរិក និងសហភាពសូវៀត បានបង្ខំឱ្យអ៊ីស្រាអែល និងអឺរ៉ុបដកខ្លួន

ចេញពីអេហ្ស៊ីប។ ការដកចេញរបស់អ៊ីស្រាអែលបានបន្សល់ទុកព្រែកជីកឱ្យអេហ្ស៊ីជាអ្នកគ្រប់គ្រង ដូច្នេះវិបត្តិស៊ុយអេបានបញ្ចប់ ។

សង្គ្រាមអារ៉ាប់-អ៊ីស្រាអែលបន្ត៖ ភាពតានតឹងរវាងអ៊ីស្រាអែល និងរដ្ឋអារ៉ាប់បានចាប់ផ្ដើមកើតមានឡើងម្ដងទៀត នៅប៉ុន្មានឆ្នាំក្រោយការដោះស្រាយវិបត្តិស៊ុយអេ។ នៅដើមឆ្នាំ 1967 លោកណាស៊ែរ និងសម្ព័ន្ធមិត្តអារ៉ាប់របស់គាត់ដែលបំពាក់ដោយរថក្រោះ និងយន្តហោះសូវៀត យល់ថាពួកគេបានត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈមមុខជាមួយនឹងអ៊ីស្រាអែល។ លោកណាស៊ែរបានប្រកាសថា "យើងខ្នះខ្នែងក្នុងការប្រយុទ្ធដើម្បីបង្ខំសត្រូវឱ្យភ្ញាក់ពីសុបិនរបស់ពួកគេ ហើយជួបតទល់ដោយផ្ទាល់ជាមួយអារ៉ាប់"។ លោកបានបិទឈូងសមុទ្រអាហ្កាបា ដែលជាច្រកចេញរបស់អ៊ីស្រាអែលទៅកាន់សមុទ្រក្រហម។ ភ្លាមៗនោះអ៊ីស្រាអែលបានចាប់ផ្ដើមការវាយប្រហារលើអាកាសយានដ្ឋាននានារបស់ពួកអារ៉ាប់ ក្នុងនោះរួមមានអាកាសយានដ្ឋានរបស់ប្រទេសអេហ្ស៊ីប, អ៊ីរ៉ង់, ហ្ស៊កដានី, និងស៊ីរី។ ដោយធានាសុវត្ថិភាពពីការវាយប្រហារតាមផ្លូវអាកាស កងកម្លាំងជើងគោកអ៊ីស្រាអែលបានវាយប្រហារដូចផ្លេកបន្ទោរលើសមរភូមិចំនួន 3 ។ អ៊ីស្រាអែលបានយកឈ្នះរដ្ឋអារ៉ាប់ទាំងនោះនៅក្នុងសង្គ្រាមដែលគេស្គាល់ថាសង្គ្រាម 6 ថ្ងៃ ព្រោះសង្គ្រាមនេះបានបញ្ចប់ក្នុងរយៈពេល 6 ថ្ងៃ។ អ៊ីស្រាអែលបានបាត់បង់ទាហាន 800 នាក់ក្នុងការប្រយុទ្ធ ខណៈដែលការខាតបង់របស់ពួកអារ៉ាប់មានលើសពី 15.000 នាក់។ ជាលទ្ធផលនៃសង្គ្រាម 6 ថ្ងៃ អ៊ីស្រាអែលបានគ្រប់គ្រងទីក្រុងចាស់យេរូសាឡឹម, ឧបទ្វីបស៊ីណៃ, ខ្ពង់រាបហ្គោឡាន, និងវេសប៊ែង។ ពួកអ៊ីស្រាអែលយល់ឃើញថាដែនដីកាន់កាប់ថ្មីនៅតាមបណ្ដោយព្រំដែនភាគខាងត្បូង, ខាងកើត, និងខាងលិចរបស់ពួកគេ គឺជាតំបន់ការពារដ៏សំខាន់ប្រឆាំងនឹងការវាយប្រហាររបស់អារ៉ាប់បន្ថែមទៀត។ ជនជាតិអារ៉ាប់ដែលរស់នៅក្រុងយេរូសាឡឹមត្រូវបានផ្ដល់ជម្រើសសញ្ជាតិអ៊ីស្រាអែល ឬហ្សកដានី។ ភាគច្រើនជ្រើសរើសយកសញ្ជាតិហ្សកដានី។ ប្រជាជនដែលរស់នៅក្នុងតំបន់ផ្សេងទៀតមិនត្រូវបានផ្ដល់សញ្ជាតិអ៊ីស្រាអែលទេ ហើយពួកគេគ្រាន់តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកជ្វីហ្វ។ ជម្លោះអារ៉ាប់-អ៊ីស្រាអែលលើកទី 4 បានផ្ទុះឡើងក្នុងខែតុលា ឆ្នាំ 1973 ។ អ្នកស្នងតំណែងបន្តពីលោកណាស៊ែរគឺប្រធានាធិបតីអាន់វ៉ា សាដាត បានគ្រោងនឹងវាយប្រហាររួមគ្នារបស់ពួកអារ៉ាប់នៅថ្ងៃបុណ្យយុមគីពួរ ដែលជាថ្ងៃបុណ្យឈប់សម្រាកដ៏ពិសិដ្ឋបំផុតរបស់ជនជាតិជ្វីហ្វ។ លើកនេះជនជាតិអ៊ីស្រាអែលទទួលរកការវាយប្រហារដោយភ្ញាក់ផ្អើល។ កងកម្លាំងអារ៉ាប់បានធ្វើឱ្យពួកអ៊ីស្រាអែលស្លាប់ និងរបួសយ៉ាងច្រើន និងបានដណ្ដើមយកមកវិញនូវទឹកដីមួយចំនួនដែលបានបាត់បង់ក្នុងឆ្នាំ 1967។ ពួកអ៊ីស្រាអែល ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រីរបស់ពួកគេគឺលោកហ្គោលដា មៀ បានបើកការវាយលុក និងដណ្ដើមយកមកវិញនូវទឹកដីភាគច្រើនដែលបានបាត់បង់។ ភាគីទាំង 2 បានយល់ព្រមលើបទឈប់បាញ់មួយបន្ទាប់ពីការប្រយុទ្ធគ្នាជាច្រើនសប្ដាហ៍ ហើយសង្គ្រាមយុមគីពួរបានបញ្ចប់។

អង្គការរំដោះប៉ាឡេស្ទីន៖ នៅពេលដែលអ៊ីស្រាអែល និងប្រទេសជិតខាងអារ៉ាប់បានប្រយុទ្ធគ្នា ប្រជាជនប៉ាឡេស្ទីនអារ៉ាប់បានតស៊ូដើម្បីការទទួលស្គាល់។ ខណៈពេលដែលអង្គការសហប្រជាជាតិបានផ្ដល់ទឹកដីកំណើតដល់ជនជាតិប៉ាឡេស្ទីន ជនជាតិអ៊ីស្រាអែលបានរឹបអូសយកទឹកដីនោះអស់ជាច្រើន រួមទាំងតំបន់វេសប៊ែង និងហ្គាហ្សាស្ទ្រីបនៅអំឡុងពេលសង្គ្រាមនានា។ អ៊ីស្រាអែលបានអះអាងថា ទង្វើបែបនេះមានសារៈសំខាន់ចំពោះ

សន្តិសុខជាតិរបស់ខ្លួន។ នៅឆ្នាំ 1964 មន្ត្រីប៉ាឡេស្ទីនបានបង្កើតអង្គការរំដោះប៉ាឡេស្ទីន ដើម្បីជំរុញឱ្យមានការបង្កើតរដ្ឋប៉ាឡេស្ទីនអារ៉ាប់ដែលនឹងរួមបញ្ចូលទឹកដីដែលអះអាងដោយអ៊ីស្រាអែល។ ដើមឡើយអង្គការរំដោះប៉ាឡេស្ទីនគឺជាអង្គការឆ័ត្រដែលបង្កើតឡើងដោយក្រុមផ្សេងៗគ្នា ក្នុងនោះរួមមានកម្មករ, គ្រូបង្រៀន, មេធាវី, និងយុទ្ធជនទ័ពព្រៃ។ មិនយូរប៉ុន្មាន ក្រុមទ័ពព្រៃបានចូលមកគ្រប់គ្រងអង្គការ ហើយបានទទូចថា មធ្យោបាយតែមួយគត់ដើម្បីសម្រេចបាននូវគោលដៅរបស់ពួកគេគឺតាមរយៈការតស៊ូប្រដាប់អាវុធ។ នៅឆ្នាំ 1969 លោកយ៉ាស៊ីអារ៉ាហ្វាត បានក្លាយជាប្រធានអង្គការរំដោះប៉ាឡេស្ទីន ។ ពេញមួយទសវត្សរ៍ឆ្នាំ 1960 និង 1970 ក្រុមនេះបានធ្វើការវាយប្រហារភេរវករជាច្រើនប្រឆាំងនឹងអ៊ីស្រាអែល។ ប្រទេសជិតខាងអារ៉ាប់មួយចំនួនរបស់អ៊ីស្រាអែលបានគាំទ្រគោលដៅរបស់អង្គការរំដោះប៉ាឡេស្ទីន ដោយអនុញ្ញាតឱ្យក្រុមទ័ពព្រៃអង្គការរំដោះប៉ាឡេស្ទីនធ្វើប្រតិបត្តិការពីក្នុងទឹកដីរបស់ពួកគេ។

កិច្ចខិតខំប្រឹងប្រែងដើម្បីសន្តិភាព៖ នៅក្នុងខែវិច្ឆិកា ឆ្នាំ 1977 ត្រឹមតែបួនឆ្នាំបន្ទាប់ពីសង្គ្រាមយុមគីពួរ លោកអាន់វ៉ា សាដាត បានធ្វើឱ្យពិភពលោកភ្ញាក់ផ្អើលដោយការពង្រីកទំនាក់ទំនងជាមួយអ៊ីស្រាអែល។ គ្មានប្រទេសអារ៉ាប់មួយណាដែលធ្លាប់ទទួលស្គាល់សិទ្ធិប្រទេសអ៊ីស្រាអែលឡើយ។ ក្នុងកាយវិការដ៏គួរឱ្យភ្ញាក់ផ្អើល លោកសាដាតបានធ្វើដំណើរទៅកាន់វិមានសភាក្នេសសេតអ៊ីស្រាអែល ហើយបានអញ្ជើញអតីតសត្រូវរបស់លោកឱ្យចូលរួមក្នុងការស្វែងរកសន្តិភាព។ លោកសាដាតបានសង្កត់ធ្ងន់ថា ជាថ្នូរនឹងសន្តិភាព អ៊ីស្រាអែលត្រូវតែទទួលស្គាល់សិទ្ធិរបស់ប៉ាឡេស្ទីន។ លើសពីនេះ ពួកគេត្រូវដកខ្លួនចេញពីទឹកដីដែលរឹបអូសបានក្នុងឆ្នាំ 1967 ពីប្រទេសអេហ្ស៊ីប, ហ្ស៊កដានី, និងស៊ីរី។ ប្រធានាធិបតីអាមេរិកលោកជីមី ខាតធ័រ បានទទួលស្គាល់ថាលោកសាដាតបានបង្កើតឱកាសជាប្រវត្តិសាស្ត្រសម្រាប់សន្តិភាព។ នៅឆ្នាំ 1978 លោកខាតធ័របានអញ្ជើញលោកសាដាត និងនាយករដ្ឋមន្ត្រីអ៊ីស្រាអែលមេណាឆេម មេហ្គីនទៅកាន់ខេមដាវីដដែលជាកន្លែងសម្រាកលំហែរបស់ប្រធានាធិបតីនៅជនបទម៉ារីលែន។ ដោយនៅឆ្ងាយពីសារព័ត៌មាន និងឆ្ងាយពីសម្ពាធនយោបាយក្នុងស្រុកលោក សាដាត និងមេហ្គីនបានធ្វើការដើម្បីឈានដល់កិច្ចព្រមព្រៀងមួយ។ បន្ទាប់ពីការចរចារយៈពេល 13 ថ្ងៃ លោក ខាតធ័របានប្រកាសដោយជោគជ័យថា អេហ្ស៊ីបបានទទួលស្គាល់អ៊ីស្រាអែលជារដ្ឋស្របច្បាប់។ ជាថ្នូរនឹងគ្នា អ៊ីស្រាអែលបានយល់ព្រមប្រគល់ឧបទ្វីបស៊ីណៃទៅអេហ្ស៊ីបវិញ។ ចុះហត្ថលេខានៅឆ្នាំ 1979 កិច្ចព្រមព្រៀងខេមដាវីដបានបញ្ចប់រយៈពេល 30 ឆ្នាំនៃអរិភាពរវាងអេហ្ស៊ីប និងអ៊ីស្រាអែល ហើយបានក្លាយជាកិច្ចព្រមព្រៀងដំបូងដែលបានចុះហត្ថលេខារវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់។ ខណៈពេលដែលមេដឹកនាំពិភពលោកសរសើរ លោកសាដាត គំនិតផ្តួចផ្តើមសន្តិភាពរបស់គាត់បានធ្វើឱ្យប្រទេសអារ៉ាប់ជាច្រើនមានការខឹងសម្បារ។ នៅឆ្នាំ 1981 ក្រុមជ្រុលនិយមម៉ូស្លីមបានធ្វើឃាតលោក។ ទោះយ៉ាងណាក៏ដោយ មេដឹកនាំថ្មីរបស់ប្រទេសអេហ្ស៊ីបលោក ហូសនី ម៉ូបារ៉ាក់បានបន្តធ្វើការដើម្បីរក្សាសន្តិភាពជាមួយអ៊ីស្រាអែល។

ភាពតានតឹងរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីនកើនឡើង៖ ក្រុមអារ៉ាប់មួយដែលបានបន្តប៉ះទង្គិចជាមួយអ៊ីស្រាអែលគឺពួកប៉ាឡេស្ទីន ដែលមួយចំនួនធំរស់នៅក្នុងតំបន់វេសប៊ែង និងហ្គាហ្សាស្ទ្រីបដែលជាទឹកដីគ្រប់គ្រងដោយអ៊ីស្រាអែល។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1970 និង 1980 ក្រុមយោធាដែលជាសាខានៃអង្គការរំដោះប៉ាឡេស្ទីន

បានធ្វើយុទ្ធនាការប្រឆាំងនឹងអ៊ីស្រាអែល។ អ៊ីស្រាអែលបានឆ្លើយតបយ៉ាងខ្លាំង ដោយទម្លាក់គ្រាប់បែកលើមូលដ្ឋានដែលសង្ស័យថាជាក្រុមឧទ្ទាមក្នុងក្រុងនានារបស់ប៉ាឡេស្ទីន។ នៅឆ្នាំ 1982 កងទ័ពអ៊ីស្រាអែលបានលុកលុយប្រទេសលីបង់ក្នុងការប៉ុនប៉ងបំផ្លាញទីតាំងរឹងមាំរបស់ប៉ាឡេស្ទីន។ អ៊ីស្រាអែលបានចូលរួមក្នុងសង្គ្រាមស៊ីវិលនៅលីបង់ ហើយក្រោយមកត្រូវបានបង្ខំឱ្យដកខ្លួនចេញ។ នៅឆ្នាំ 1987 ប៉ាឡេស្ទីនបានចាប់ផ្តើមបង្ហាញពីការខកចិត្តរបស់ពួកគេ តាមរយៈការរីករាលដាលនៃយុទ្ធនាការមិនស្តាប់បង្គាប់របស់ជនស៊ីវិលដែលហៅថា អ៊ីទីហ្វាដា ឬ "ការបះបោរ" ។ អ៊ីទីហ្វាដាបានយកទម្រង់នៃការធ្វើពហិការ, បាតុកម្ម, ការវាយប្រហារលើទាហានអ៊ីស្រាអែល និងការគប់ដុំថ្មរបស់យុវជន។ អ៊ីទីហ្វាដាបានបន្តរហូតដល់ទសវត្សរ៍ឆ្នាំ 1990 ជាមួយនឹងការរីកចម្រើនតិចតួចចំពោះការស្វែងរកដំណោះស្រាយ។ ទោះបីជាយ៉ាងណាក៏ដោយ ការមិនស្តាប់បង្គាប់បានជះឥទ្ធិពលដល់មតិរបស់ពិភពលោកដែលជាហេតុនាំឱ្យមានសម្ពាធលើអ៊ីស្រាអែល ដើម្បីស្វែងរកការចរចាជាមួយប៉ាឡេស្ទីន។ ទីបំផុត នៅខែតុលា ឆ្នាំ 1991 ប្រតិភូអ៊ីស្រាអែល និងប៉ាឡេស្ទីនបានជួបចរចាសន្តិភាពជាបន្តបន្ទាប់។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងអូស្លូ៖ ការចរចារវាងភាគីទាំង 2 មានការវិវឌ្ឍតិចតួច ដោយសារតែមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំងចំពោះកំណត់ឋានៈនៃទឹកដីប៉ាឡេស្ទីន។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ 1993 កិច្ចចរចាសម្ងាត់ដែលបានធ្វើឡើងនៅទីក្រុងអូស្លូប្រទេសន័រវេស បានបង្កើតកិច្ចព្រមព្រៀងដ៏គួរឱ្យភ្ញាក់ផ្អើលមួយ៖ ឯកសារមួយហៅថា សេចក្តីប្រកាសនៃគោលការណ៍ ដែលត្រូវបានគេស្គាល់ថាជាកិច្ចព្រមព្រៀងសន្តិភាពអូស្លូ។ អ៊ីស្រាអែលក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រីយីតហ្សាក់ រ៉ាប៊ីន បានយល់ព្រមផ្តល់សិទ្ធិឱ្យប៉ាឡេស្ទីនគ្រប់គ្រងដោយខ្លួនឯងនៅតំបន់ហ្គាហ្សាស្ទ្រីប និងវេសប៊ែង ដោយចាប់ផ្តើមពីទីក្រុងជេរីឆូ។ លោករ៉ាប៊ីន និងលោកអារ៉ាហ្វាត បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 1993 ។ ភាពលំបាកក្នុងការធ្វើឱ្យកិច្ចព្រមព្រៀងនេះដំណើរការ ត្រូវបានបង្ហាញដោយការធ្វើឃាតលោករ៉ាប៊ីនក្នុងឆ្នាំ 1995 ។ លោកត្រូវបានសម្លាប់ដោយពួកជ្រុលនិយមជ្វីហ្វស្តាំនិយមដែលប្រឆាំងនឹងការសម្បទានដល់ប៉ាឡេស្ទីន។ លោកបេនចាមីន នេតានយ៉ាហ៊ូ ដែលបានស្នងតំណែងបន្តលោករ៉ាប៊ីនធ្វើជានាយករដ្ឋមន្ត្រី បានប្រឆាំងកិច្ចព្រមព្រៀងទីក្រុងអូស្លូ។ ទោះយ៉ាងណាក៏ដោយ លោកនេតានយ៉ាហ៊ូបានខិតខំប្រឹងប្រែងដើម្បីរក្សាកិច្ចព្រមព្រៀងនេះ។ នៅខែមករា ឆ្នាំ 1997 លោកនេតានយ៉ាហ៊ូបានជួបជាមួយលោអារ៉ាហ្វាត ដើម្បីរៀបចំផែនការសម្រាប់ការដកអ៊ីស្រាអែលមួយផ្នែកចេញពីតំបន់វេសប៊ែង។

## 3. ការបាត់បង់សន្តិភាព

នៅឆ្នាំ 1999 ភាពយឺតយ៉ាវ និងភាពពិបាករវាងអ៊ីស្រាអែល និងប៉ាឡេស្ទីនក្នុងការចរចាសន្តិភាព ហាក់ដូចជាទទួលបានការជំរុញ។ លោកអេហ៊ូដ បារ៉ាក់បានឈ្នះការបោះឆ្នោតជានាយករដ្ឋមន្ត្រីអ៊ីស្រាអែល។ អ្នកសង្កេតការណ៍ជាច្រើនបានចាត់ទុកលោកថាជាអ្នកគាំទ្រផែនការសន្តិភាពខ្លាំងជាងលោកនេតានយ៉ាហ៊ូ។ សហគមន៍អន្តរជាតិដែលដឹកនាំដោយសហរដ្ឋអាមេរិកបានប្តេជ្ញាចិត្តទាញយកអត្ថប្រយោជន៍ពីការអភិវឌ្ឍនេះ។ នៅខែកក្កដា ឆ្នាំ 2000 ប្រធានាធិបតីសហរដ្ឋអាមេរិកលោកប៊ីល គ្លីនតុនបានរៀបចំកិច្ចប្រជុំកំពូលរយៈពេល 15 ថ្ងៃនៅឯខេមដាវីដ រវាងលោកអេហ៊ូដ បារ៉ាក់ និងលោកយ៉ាស៊ី អារ៉ាហ្វាត។ ទោះជាយ៉ាងណា មេដឹកនាំទាំង 2 មិនអាចឈានដល់ការ

សម្រុះសម្រួលបានឡើយ ហើយផែនការសន្តិភាពបានជាប់គាំងម្តងទៀត។ 2 ខែក្រោយមក មេដឹកនាំនយោបាយអ៊ីស្រាអែលលោកអារៀល សារុនបានធ្វើដំណើរទៅទស្សនាប្រាសាទភ្នំយេរ៉ូសាឡឹមដែលជាកន្លែងពិសិដ្ឋសម្រាប់ទាំងពួកយូដា និងម៉ូស្លីម។ នៅថ្ងៃបន្ទាប់ វិទ្យុសម្លេងប៉ាឡេស្ទីន ដែលជាស្ថានីយ៍វិទ្យុផ្លូវការរបស់អាជ្ញាធរប៉ាឡេស្ទីនបានអំពាវនាវឱ្យប្រជាជនប៉ាឡេស្ទីនតវ៉ាចំពោះដំណើរទស្សនកិច្ចនេះ។ កុប្បកម្មបានផ្ទុះឡើងនៅក្នុងទីក្រុងយេរ៉ូសាឡឹម និងតំបន់វេសប៊ែង ហើយអ៊ីនទីហ្វាដាទី 2 ដែលពេលខ្លះហៅថាអាល់-អាកសា អ៊ីនទីហ្វាដាបានចាប់ផ្តើម។

ជម្លោះកាន់តែខ្លាំងឡើង អ៊ីនទីហ្វាដាទី 2 បានចាប់ផ្តើមដូចជាលើកទី 1 ដែរ ជាមួយនឹងការធ្វើបាតុកម្ម, ការវាយប្រហារលើទាហានអ៊ីស្រាអែល, និងការគប់ដុំថ្មដោយក្មេងជំទង់។ ប៉ុន្តែលើកនេះ ក្រុមសកម្មប្រយុទ្ធប៉ាឡេស្ទីនបានចាប់ផ្តើមប្រើអាវុធថ្មី គឺក្រុមអ្នកបំផ្ទុះគ្រាប់បែកអត្តឃាត។ ការវាយប្រហាររបស់ពួកគេលើទីកន្លែងតាំងទីលំនៅរបស់ជនជាតិជ្វីហ្វនៅក្នុងទឹកដីដែលពួកគេដណ្តើមកាន់កាប់ និងលើទីតាំងជនស៊ីវិលទូទាំងប្រទេសអ៊ីស្រាអែល ដែលបានបង្កើនកម្រិតនៃការបង្ហូរឈាមយ៉ាងខ្លាំង។ នៅពេលដែល អ៊ីនទីហ្វាដាទី 2 បានបន្តរហូតដល់ឆ្នាំ 2007 ប្រជាជនអ៊ីស្រាអែល និងប៉ាឡេស្ទីនរាប់ពាន់នាក់បានស្លាប់នៅក្នុងជម្លោះនេះ។ កងទ័ពអ៊ីស្រាអែលបានចូលទៅក្នុងជុំវិញជនភៀសខ្លួនប៉ាឡេស្ទីន និងបានបង្ក្រាបពួកភេរវករ។ កងទ័ពបានបំផ្លាញអគារដែលពួកគេសង្ស័យថាពួកជ្រុលនិយមកំពុងលាក់ខ្លួន និងឈូសឆាយទីប្រជុំជន និងជំរំប៉ាឡេស្ទីនទាំងមូល។ កងទ័ពអ៊ីស្រាអែលបានទម្លាក់គ្រាប់បែកលើទីស្នាក់ការរបស់លោកអារ៉ាហ្វាត ដោយលោកបានជាប់នៅក្នុងបរិវេណទីស្នាក់ការនោះអស់ជាច្រើនថ្ងៃ។ ទំនាក់ទំនងអារ៉ាប់-អ៊ីស្រាអែលមិនបានធ្វើប្រសើរឡើងជាមួយនាយករដ្ឋមន្ត្រីបន្ទាប់របស់អ៊ីស្រាអែលលោកអារៀល សារុន។ លោកសារុនដែលជាអតីតមេដឹកនាំយោធា បានបដិសេធមិនចរចាជាមួយប៉ាឡេស្ទីនរហូតដល់ការវាយប្រហារលើអ៊ីស្រាអែលត្រូវបានបញ្ឈប់។ នៅទីបំផុត ក្រោមសម្ពាធយ៉ាងខ្លាំងពីសហគមន៍អន្តរជាតិ លោកអារ៉ាហ្វាតបានយល់ព្រមទទួលយកតួនាទីមិនសូវសំខាន់ក្នុងកិច្ចចរចាសន្តិភាព។ នៅដើមឆ្នាំ 2003 អាជ្ញាធរប៉ាឡេស្ទីនបានតែងតាំងនាយករដ្ឋមន្ត្រីដំបូងគេរបស់ខ្លួនគឺលោកម៉ាម៉ូដ អាបាល់ដែលជាមន្ត្រីរបស់អង្គការរំដោះប៉ាឡេស្ទីន ។ មិនយូរប៉ុន្មានប្រធានាធិបតីសហរដ្ឋអាមេរិកលោកចច ដាប់បែលយូ. ប៊ូសបាននាំលោកសារុន និងអាបាល់ ជួបគ្នាដើម្បីចាប់ផ្តើមធ្វើការលើផែនការសន្តិភាពថ្មីមួយដែលគេស្គាល់ថាជា "ផែនទីបង្ហាញផ្លូវ"។ ប៉ុន្តែអំពើហិង្សាបានកើនឡើងម្តងទៀតក្នុងឆ្នាំ 2003 ហើយការចរចាបានជាប់គាំង។

ការផ្លាស់ប្តូរអំណាច និងសម្ព័ន្ធភាព៖ នៅរដូវក្តៅឆ្នាំ 2005 អ៊ីស្រាអែលបានជម្លៀសដោយឯកតោភាគីនូវអ្នកតាំងលំនៅ និងយោធាទាំងអស់របស់ខ្លួនចេញពីតំបន់ហ្គាហ្សាស្ទ្រីប។ បន្ទាប់មកនៅក្នុងឆ្នាំ 2006 ក្រុមហាម៉ាស់ដែលជាក្រុមភេរវករសកម្ម ដែលមានចេតនាជំនួសអ៊ីស្រាអែលដោយរដ្ឋអ៊ីស្លាមបានឈ្នះការគ្រប់គ្រងភាគច្រើននៅក្នុងការបោះឆ្នោតរបស់អាជ្ញាធរប៉ាឡេស្ទីន។ អ៊ីស្រាអែលបដិសេធមិនទទួលស្គាល់រដ្ឋាភិបាលថ្មីរបស់ក្រុមហាម៉ាស។ ផ្ទុយទៅវិញ នៅខែសីហា ឆ្នាំ 2007 នាយករដ្ឋមន្ត្រីថ្មីរបស់អ៊ីស្រាអែលលោកអេហ៊ូដ អូលមឺត បានចាប់ផ្តើមកិច្ចពិភាក្សាផ្លូវការជាបន្តបន្ទាប់ជាមួយលោកម៉ាម៉ូត អាបាល់។ ទាំងលោកអូលមឺត និងលោកអាបាស់ យល់ស្របនៅក្នុងការដោះស្រាយឱ្យមានរដ្ឋចំនួន 2 នៅដែនដីជម្លោះប៉ាឡេស្ទីន ហើយមេដឹកនាំទាំង 2 មានចំណាប់អារម្មណ៍

ក្នុងការបង្កើតកិច្ចព្រមព្រៀងដែលមិនពាក់ព័ន្ធនឹងក្រុមហាម៉ាស។ បន្ទាប់ពីអំពើហិង្សាជាច្រើនឆ្នាំ ក្តីសង្ឃឹមដែលថាភាពសុខដុមរមនានៅថ្ងៃណាមួយនឹងមកដល់តំបន់នេះនៅតែមាន។

# មេរៀនទី 5៖ ការតស៊ូនៅអាស៊ីកណ្ដាល

## 1. សេរីភាពនាំមកនូវការប្រឈមថ្មី

នៅឆ្នាំ 1991 សហភាពសូវៀតបានដួលរលំ ហើយសាធារណរដ្ឋដែលខ្លួនបានសញ្ជ័យយក បានលេចចេញជាប្រទេសឯករាជ្យចំនួន 15 ។ ក្នុងចំណោមពួកគេមានព្រំដែនស្ថិតនៅភាគខាងត្បូងនៃចក្រភពសូវៀត។ ពួកអ្នកភូមិសាស្ត្រតែងតែកំណត់ប្រទេសថ្មីទាំងនេះទៅជាតំបន់ភូមិសាស្ត្រចំនួន 2 ។ ប្រទេសអាមេនី, អាស៊ែបៃហ្សង់, និងហ្សកហ្ស៊ី បង្កើតជាសាធារណរដ្ឋកៅកាស៊ូស។ ប្រទេសទាំង 3 នេះស្ថិតនៅលើភ្នំកៅកាស៊ូល ដែលស្ថិតនៅចម្លោះសមុទ្រខ្មៅ និងសមុទ្រកាសព្យែន។ ខាងកើតនៃសមុទ្រកាសព្យែន និងលាតសន្ធឹងដល់ភ្នំធានសាន និងប៉ាមីរ គ្របដណ្ដប់ដោយប្រទេសចំនួន 5 ដែលគេស្គាល់ថាជាសាធារណរដ្ឋអាស៊ីកណ្ដាល។ ក្នុងចំណោមនោះរួមមានប្រទេសអ៊ូសបេគីស្ថាន, តួមិននីស្ថាន, តាជីគីស្ថាន, កាហ្សាក់ស្ថាន, និងកៀហ្ស៊ីស៊ីស្ថាន។

ការតស៊ូផ្នែកសេដ្ឋកិច្ច៖ ចាប់តាំងពីទទួលបានឯករាជ្យ ប្រជាជាតិទាំងនេះបានតស៊ូផ្នែកសេដ្ឋកិច្ច ហើយសព្វថ្ងៃជាប្រទេសក្រីក្របំផុតមួយក្នុងប្រទេសក្រីក្រនៅលើពិភពលោក។ បញ្ហាភាគច្រើនកើតចេញពីការពឹងផ្អែកទាំងស្រុងរបស់ពួកគេទៅលើសហភាពសូវៀតសម្រាប់ជំនួយផ្នែកសេដ្ឋកិច្ច។ ជាលទ្ធផល ពួកគេមានការលំបាកក្នុងការឈរដោយខ្លួនឯង។ របៀបនៃការអនុវត្តសេដ្ឋកិច្ចក្នុងសម័យសូវៀតបានបង្កើតបញ្ហាបន្ថែម។ ជាឧទាហរណ៍ សហភាពសូវៀតបានប្រែក្លាយតំបន់ដីស្រែចំការដែលមាននៅក្នុងសាធារណរដ្ឋអាស៊ីកណ្ដាល ដើម្បីដាំដំណាំកប្បាសដែលជា "មាសស" ។ ការពឹងផ្អែកលើដំណាំតែមួយមុខ បានប៉ះពាល់ដល់ការអភិវឌ្ឍតុល្យភាពសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងនេះ។ ប្រទេសអាស៊ែបៃហ្សង់ ដែលស្ថិតនៅក្នុងចំណោមតំបន់ប្រេងកាតនៅសមុទ្រកាសព្យែន មានឱកាសល្អបំផុតក្នុងការកសាងសេដ្ឋកិច្ចឱ្យរឹងមាំ ដោយផ្អែកលើប្រាក់ចំណូលដែលបានមកពីប្រេង និងផលិតផលប្រេង។ ទន្ទឹមនឹងនេះ ប្រទេសកាហ្សាក់ស្ថាន និងតួមិននីស្ថានកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីទាញយកទុនបម្រុងដ៏ធំនៃប្រេង និងឧស្ម័នធម្មជាតិរបស់ពួកគេ។

វិវាទរវាងក្រុមជនជាតិភាគតិច និងសាសនាផ្សេងៗ៖ ការប្រយុទ្ធគ្នាបានបង្កជាឧបសគ្គមួយផ្សេងទៀតសម្រាប់ស្ថិរភាពនៅក្នុងប្រទេសជាច្រើននៅអាស៊ីកណ្ដាលដែលទើបនឹងទទួលបានឯករាជ្យថ្មីៗ។ តំបន់នេះជាទីជម្រករបស់ប្រជាជនផ្សេងគ្នាមួយចំនួន ហើយតំបន់ខ្លះធ្លាប់មានប្រវត្តិអរិភាពចំពោះគ្នាជាយូរមកហើយ។ ជាមួយនឹងការគ្រប់គ្រងដោយកណ្ដាប់ដៃដែករបស់ខ្លួន សូវៀតបានរក្សាការបិទបាំងលើអរិភាពទាំងនេះ និងបានការពារមិនឱ្យមានការប៉ះទង្គិចគ្នាណាមួយកើតមានឡើង។ ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីការបែកបាក់នៃសហភាពសូវៀត ការប្រណាំងប្រជែងរវាងជនជាតិភាគតិកបានផ្ទុះឡើង។ ការប្រណាំងប្រជែងខ្លះបានក្លាយទៅជាសង្គ្រាមក្នុងតំបន់។ ដូចជាករណីនៅប្រទេសអាស៊ែបៃហ្សង់ជាដើម។ ប្រទេសម៉ូស្លីមមួយនេះ គ្របដណ្ដប់មួយភាគធំលើតំបន់ណាហ្គូណូ-ការ៉ាបាខ ដែលជាតំបន់តូចមួយតាំងទីលំនៅដោយពួកគ្រីស្ទសាសនិកអាមេនី។ បន្ទាប់ពីការដួលរលំនៃសហភាពសូវៀត ប្រជាជននៃតំបន់នេះបានប្រកាសឯករាជ្យរបស់ពួកគេ។ អាស៊ែបៃហ្សង់គ្មានចេតនាបោះបង់ចោលទឹកដីនេះទេ ហើយការប្រយុទ្ធគ្នាបានផ្ទុះឡើងយ៉ាងឆាប់រហ័ស។ អាមេនីដែលនៅជិតខាងបានប្រញាប់ប្រញាល់

ទៅជួយប្រជាជនអាមេនីនៅទីនោះ។ សង្គ្រាមបានផ្ទុះឡើងចាប់ពីឆ្នាំ 1991 ដល់ឆ្នាំ 1994 នៅពេលដែលភាគីទាំង 2 បានព្រមព្រៀងលើបទឈប់បាញ់មួយ។ រហូតមកដល់ឆ្នាំ 2007 ស្ថានភាពរបស់ តំបន់ណាហ្គូណូ-ការ៉ាបាខនៅតែមិនទាន់ត្រូវបានដោះស្រាយ។

## 2. អាហ្វហ្គានីស្ថាន និងពិភពលោក

ស្ថិតនៅភាគខាងត្បូងនៃសាធារណរដ្ឋអាស៊ីកណ្តាល គឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលលេចធ្លោជាងគេក្នុងតំបន់។ អាហ្វហ្គានីស្ថានជាប្រទេសតូចមួយដែលគ្របដណ្តប់ដោយភ្នំ និងវាលខ្សាច់។ វាជាប្រទេសមួយក្នុងចំនោមប្រទេសដែលមានការអភិវឌ្ឍតិចបំផុតនៅលើពិភពលោក ដោយសារប្រជាជនភាគច្រើនជាកសិករឬអ្នកចិញ្ចឹមសត្វ។ យ៉ាងណាក៏ដោយ ក្នុងរយៈពេលជាច្រើនទសវត្សកន្លងមកនេះ ប្រទេសដែលមានប្រជាជនកាន់សាសនាឥស្លាមភាគច្រើននេះ បានទាក់ទាញការចាប់អារម្មណ៍របស់ពិភពលោកជាមួយនឹងសង្គ្រាមដ៏ល្បីល្បាញចំនួន 2 លើក ដែលលើកទី 1 ប្រឆាំងជាមួយនឹងសហភាពសូវៀត និងមួយទៀតប្រឆាំងនឹងសហរដ្ឋអាមេរិក។

ការតស៊ូដើម្បីសេរីភាព៖ អាហ្វហ្គានីស្ថានមានប្រវត្តិតស៊ូដ៏យូរអង្វែងមួយ។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1800 ទាំងរុស្ស៊ី និងអង់គ្លេសបានប្រកួតប្រជែងគ្នាដើម្បីដណ្តើមការគ្រប់គ្រងរបស់ពួកគេលើទឹកដីអាហ្វហ្គានីស្ថាន។ រុស្ស៊ីមានបំណងចង់ចូលទៅមហាសមុទ្ទឥណ្ឌាកាត់តាមអាហ្វហ្គានីស្ថាន ខណៈអង់គ្លេសចង់គ្រប់គ្រងទឹកដីនេះដើម្បីការពារព្រំដែនភាគខាងជើងរបស់ចក្រភពឥណ្ឌា។ ចក្រភពអង់គ្លេសបានធ្វើសង្គ្រាមចំនួន 3 ដាច់ដោយឡែកពីគ្នាជាមួយពួកអាហ្វហ្គានីស្ថាន មុនពេលពួកចាកចេញនៅក្នុងឆ្នាំ 1919 ។ នៅឆ្នាំនោះ អាហ្វហ្គានីស្ថានបានប្រកាសខ្លួនជាប្រទេសឯករាជ្យ និងបានបង្កើតរបបរាជានិយម។ រដ្ឋាភិបាលបានអនុវត្តកំណែទម្រង់ផ្សេងៗ និងព្យាយាមធ្វើទំនើបកម្មប្រទេស។ ក្នុងឆ្នាំ 1964 ប្រទេសនេះបានបង្កើតរដ្ឋធម្មនុញ្ញមួយដែលព្យាយាមបង្កើតទម្រង់រដ្ឋាភិបាលបែបប្រជាធិបតេយ្យបន្ថែមទៀត។ ទោះយ៉ាងណាក៏ដោយ មន្ត្រីមួយចំនួនមិនបានយល់ស្របលើកម្មវិធីកំណែទម្រង់ទេ ហើយមនុស្សភាគច្រើនបង្ហាញចំណាប់អារម្មណ៍តិចតួចចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីផ្លាស់ប្តូររដ្ឋាភិបាល។ ជាលទ្ធផល ការអភិវឌ្ឍប្រព័ន្ធប្រជាធិបតេយ្យបានបរាជ័យ។

ការរុញច្រានសូវៀតត្រឡប់មកវិញ៖ ទោះជាយ៉ាងណាក៏ដោយ អាហ្វហ្គានីស្ថានបានរីកចម្រើនគ្រប់គ្រាន់ដើម្បីបង្កើតទំនាក់ទំនងល្អជាមួយបណ្តាប្រទេសជាច្រើននៅអឺរ៉ុបខាងលិច និងដើម្បីប្រកាន់ជំហរដោយខ្លួនឯងនៅលើឆាកអន្តរជាតិ។ នៅពេលដែលជម្លោះសង្គ្រាមត្រជាក់រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀតផ្ទុះឡើង អាហ្វហ្គានីស្ថានបានជ្រើសរើសយកការរក្សាអព្យាក្រឹតភាព។ ទោះជាយ៉ាងណាក៏ដោយ នៅអំឡុងពេលនោះ អាហ្វហ្គានីស្ថានបានទទួលជំនួយពីប្រទេសមហាអំណាចដែលប្រឆាំងទាំង 2 នេះ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារមានទីតាំងស្ថិតនៅជិតសហភាពសូវៀត អាហ្វហ្គានីស្ថានមិនអាចទប់ទល់នឹងកម្លាំងកុំម្មុយនីស្តបានជារៀងរហូតបានទេ។ នៅឆ្នាំ 1973 មេដឹកនាំយោធាបានផ្តួលរំលំរដ្ឋាភិបាល។ 5 ឆ្នាំក្រោយមកនៅឆ្នាំ 1978 ក្រុមគូប្រជែងដែលមានទំនាក់ទំនងខ្លាំងជាមួយសហភាពសូវៀតបានដណ្តើមកាន់កាប់ប្រទេស។ ប្រជាជនភាគច្រើនបានប្រឆាំងនឹងក្រុមនេះ និងទំនាក់ទំនងយ៉ាងខ្លាំងរបស់ពួកគេជាមួយនឹងលទ្ធិកុំម្មុយនីស្ត។ ប្រជាជនអាហ្វហ្គានីស្ថាន

ជាច្រើនមានអារម្មណ៍ថា គោលនយោបាយកុំម្មុយនីស្តមានទំនាស់ជាមួយនឹងការអប់រំរបស់សាសនាឥស្លាម។ ក្រុមកម្លាំងប្រឆាំងបានរួបរួមគ្នា បង្កើតក្រុមមួយដែលគេស្គាល់ថាមូចាហ៊ីឌីន ឬអ្នកចម្បាំងពិសិដ្ឋ។ ពួកឧទ្ទាមទាំងនេះបានកាន់អាវុធ ហើយបានប្រយុទ្ធយ៉ាងខ្លាំងក្លាប្រឆាំងនឹងរដ្ឋាភិបាលដែលគាំទ្រដោយសូវៀត។ ការបះបោរនេះភ្លាមៗបានជំរុញឱ្យសហភាពសូវៀតឈានជើងចូល។ នៅឆ្នាំ 1979 និង 1980 កងទ័ពសូវៀតបាន ចូលទៅក្នុងប្រទេសអាហ្វហ្គានីស្ថានដើម្បីដណ្ដើមកាន់កាប់ប្រទេសនេះ និងបានបញ្ចូលប្រទេសទៅក្នុងចក្រភពកុំម្មុយនីស្តរបស់ពួកគេ។ ជាមួយនឹងកម្លាំងយោធាដ៏ខ្លាំងក្លា និងសព្វាវុធទំនើបៗរបស់សូវៀត សង្គ្រាមមានដំណើរការយ៉ាងឆាប់រហ័ស និងមានប្រៀបខាងសូវៀត។ ប៉ុន្តែក្រុមឧទ្ទាមអាហ្វហ្គានីស្ថានបានប្រើប្រាស់ភូមិសាស្ត្រ និងយុទ្ធសាស្ត្រទ័ពព្រៃនៅក្នុងការធ្វើសង្គ្រាម។ លើសពីនេះទៀត សហរដ្ឋអាមេរិកបានផ្ដល់ជំនួយផ្នែកហិរញ្ញវត្ថុ និងយោធាដល់ពួកគេផងដែរ។ បន្ទាប់ពីការប្រយុទ្ធគ្នាដ៏បង្ហូរឈាម និងគ្មានផ្លែផ្កាអស់រយៈពេលជិត 10 ឆ្នាំ សហភាពសូវៀតបានដកកងទ័ពរបស់ខ្លួនចេញពីអាហ្វហ្គានីស្ថាន។ អាហ្វហ្គានីស្ថានបានប្រយុទ្ធជាមួយមហាអំណាចកុំម្មុយនីស្តពិភពលោក ហើយពួកគេទទួលបានជ័យជំនះ។

ការលេចឡើង និងការដួលរលំនៃពួកតាលីបង់៖ ជាមួយនឹងការចាកចេញរបស់សូវៀត ក្រុមឧទ្ទាមអាហ្វហ្គានីស្ថានផ្សេងៗបានចាប់ផ្ដើមប្រយុទ្ធគ្នាដើម្បីគ្រប់គ្រងប្រទេស។ ក្រុមអ៊ីស្លាមអភិរក្សនិយមដែលគេស្គាល់ថាតាលីបង់គឺជាក្រុមដែលទទួលបានជ័យជំនះ។ នៅឆ្នាំ 1998 ពួកគេបានគ្រប់គ្រង 90 ភាគរយនៃប្រទេស។ ក្រុមឧទ្ទាមមួយទៀតគឺសម្ព័ន្ធខាងជើង ដែលកាន់កាប់ទំបន់ភាគភាគពាយ័ព្យនៃប្រទេស។ ដំបូងឡើយ ក្រុមអ្នកសង្កេតការណ៍បានចាត់ទុកក្រុមតាលីបង់ថាជាកម្លាំងវិជ្ជមាន ព្រោះវានាំមកនូវសណ្ដាប់ធ្នាប់ដល់ប្រទេសដែលហែកហួរដោយសង្គ្រាម, លុបបំបាត់អំពើពុករលួយ, និងជម្រុញឱ្យមានកំណើនអាជីវកម្ម។ ទោះជាយ៉ាងណាក៏ដោយ ក្រុមនេះបានអនុវត្តយ៉ាងតឹងរឹងតាមច្បាប់អ៊ីស្លាម និងបានអនុវត្តច្បាប់នេះស្ទើរតែគ្រប់ផ្នែកទាំងអស់នៃសង្គមអាហ្វហ្គានីស្ថាន។ មេដឹកនាំតាលីបង់បានដាក់កំហិតលើជីវិតរស់នៅរបស់ស្ត្រី ដោយហាមមិនឱ្យពួកគេទៅសាលា ឬធ្វើការ។ ពួកគេបានហាមឃាត់ការកំសាន្តគ្រប់បែបយ៉ាងចាប់ពីទូរទស្សន៍ និងភាពយន្តរហូតដល់តន្ត្រីទំនើប។ ការដាក់ទណ្ឌកម្មចំពោះការបំពានច្បាប់រួមមានការវាយដំធ្ងន់ធ្ងរ, ការកាត់អវៈយវៈ, និងសូម្បីតែការប្រហារជីវិត។ អ្វីដែលកាន់តែបង្កបញ្ហាដល់សហគមន៍អន្តរជាតិនោះគឺ តួនាទីរបស់ពួកតាលីបង់ចំពោះបញ្ហាភេរវកកម្មដែលកំពុងកើនឡើងនៅលើពិភពលោក ដែលអ្នកនឹងអានបន្ថែមអំពីរឿងនេះនៅក្នុងជំពូក 35 ។ មេដឹកនាំលោកខាងលិចបានចោទប្រកាន់ពួកតាលីបង់ថាអនុញ្ញាតឱ្យក្រុមភេរវករហ្វឹកហាត់នៅប្រទេសអាហ្វហ្គានីស្ថាន។ ពួកតាលីបង់ក៏បានផ្ដល់ជម្រកដល់មេដឹកនាំភេរវករនានា ក្នុងនោះរួមទាំងលោកអូសាម៉ា ប៊ីនឡាឌិន ដែលមេដឹកនាំអង្គការអាល់-កៃដា ដែលត្រូវបានគេយល់ថាជាអ្នកទទួលខុសត្រូវចំពោះការវាយប្រហារជាច្រើនលើពួកលោកខាងលិច ដោយរួមទាំងការវាយប្រហារលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកនៅទីក្រុងញូវយ៉ក, មន្ទីរបញ្ចកោណក្នុងទីក្រុងវ៉ាស៊ីនតុន ឌី.ស៊ី. នៅថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 2001។ បន្ទាប់ពីការវាយប្រហារថ្ងៃទី 11 ខែកញ្ញា រដ្ឋាភិបាលសហរដ្ឋអាមេរិកបានទាមទារឱ្យពួកតាលីបង់ប្រគល់ខ្លួនលោកប៊ីនឡាឌិនឱ្យខ្លួន។ បន្ទាប់ពីមេដឹកនាំតាលីបង់បដិសេធ សហរដ្ឋអាមេរិកបានចាត់វិធានការដោយកម្លាំងយោធា។ នៅខែតុលា ឆ្នាំ 2001 កងកម្លាំងអាមេរិកបានចាប់ផ្ដើមទម្លាក់គ្រាប់បែកលើប្រព័ន្ធ

ការពារដែនអាកាស, ទីលានយន្តហោះ, និងទីបញ្ជាការរបស់តាលីបង់ ក៏ដូចជាជុំរុំហ្វឹកហាត់របស់ក្រុមអាល់កៃដា។ នៅលើដី សហរដ្ឋអាមេរិកបានផ្តល់ជំនួយដល់កងកម្លាំងប្រឆាំងពួកតាលីបង់ ដូចជាសម្ព័ន្ធភាគខាងជើងជាដើម។ នៅខែធ្នូ សហរដ្ឋអាមេរិកបានបណ្តេញពួកតាលីបង់ចេញពីអំណាច។

បញ្ហាប្រឈមនៅពេលខាងមុខ៖ ខណៈក្រុមតាលីបង់បានប្រមូលផ្តុំគ្នាឡើងវិញនៅតំបន់ដាច់ស្រយាលនៅប្រទេសអាហ្វហ្គានីស្ថាន និងប៉ាគីស្ថាន មន្ត្រីអាហ្វហ្គានីស្ថានបានជ្រើសរើសរដ្ឋាភិបាលថ្មីក្រោមការដឹកនាំរបស់លោកហាមីដ កាហ្សៃ។ ក្រោយមកនៅឆ្នាំ 2004 លោកបានជាប់ឆ្នោតជាប្រធានាធិបតីសម្រាប់អាណត្តិ 5 ឆ្នាំម្តងទៀត។ រដ្ឋាភិបាលរបស់លោកប្រឈមមុខនឹងការកសាងប្រទេសមួយដែលបានរងគ្រោះដោយសង្គ្រាមជាងពីរទសវត្សរ៍មកហើយ។ ទោះយ៉ាងណាក៏ដោយ ក្នុងឆ្នាំ 2006 ពួកតាលីបង់បានលេចឡើងជាថ្មី ហើយកងទ័ពណាតូបានធ្វើប្រតិបត្តិការយោធានៅភាគខាងត្បូង។ ការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាជាមួយពួកតាលីបង់បានបន្តរហូតដល់ឆ្នាំ 2007 ។ ការប្រឈមនៅប្រទេសអាហ្វហ្គានីស្ថាន មិនមែនជារឿងប្លែក ឬថ្មីនោះទេ។ ដូចដែលអ្នកនឹងអាននៅក្នុងជំពូកបន្ទាប់ ក្នុងរយៈពេលជាង 50 ឆ្នាំកន្លងមកនេះ ប្រទេសជុំវិញពិភពលោកបានព្យាយាមលុបបំបាត់ទម្រង់នៃការគ្រប់គ្រងចាស់ដែលភាគច្រើននៅក្នុងទម្រង់បែបគាបសង្កត់ ហើយអនុវត្តទម្រង់រដ្ឋាភិបាលបែបប្រជាធិបតេយ្យបន្ថែមទៀត។

# ជំពូក 34 ៖ ការតស៊ូដើម្បីប្រជាធិបតេយ្យ

## មេរៀនទី 1 ៖ ប្រជាធិបតេយ្យ

### 1. គោលដៅប្រជាធិបតេយ្យ

តារាងខាងក្រោមបានបង្ហាញពីការអនុវត្តនៃចំនួន 4 នៅក្នុងលទ្ធិប្រជាធិបតេយ្យ រួមជាមួយនឹងលក្ខខណ្ឌដែលជួយឱ្យការអនុវត្តលទ្ធិប្រជាធិបតេយ្យទាំងនេះទទួលបានជោគជ័យ។ ប្រជាជាតិជាច្រើនបានធ្វើតាមការអនុវត្តទាំងនេះក្នុងកម្រិតខ្ពស់មួយ។ ទោះយ៉ាងណាក៏ដោយ ការស្ថាបនាលទ្ធិប្រជាធិបតេយ្យ គឺជាដំណើរការមួយដែលចំណាយពេលរាប់ឆ្នាំ។ សូម្បីតែនៅសហរដ្ឋអាមេរិក ការស្ថាបនាលទ្ធិប្រជាធិបតេយ្យក៏ត្រូវការពេលវេលាផងដែរ។ ទោះបីជាគោលការណ៍សមភាពជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញក៏ដោយ ក៏ជនជាតិអាមេរិកជាច្រើនបានតស៊ូដើម្បីសិទ្ធិស្មើគ្នា។ ជាឧទាហរណ៍ ស្ត្រីមិនបានទទួលសិទ្ធិបោះឆ្នោតទេរហូតដល់ឆ្នាំ 1920។ លទ្ធិប្រជាធិបតេយ្យតែងតែជា "ការងារដែលកំពុងដំណើរការ" ។ ស្ថាប័នប្រជាធិបតេយ្យអាចនឹងមិនធានាឱ្យមានស្ថិរភាព និងរដ្ឋាភិបាលស៊ីវិលប្រសិនបើលក្ខខណ្ឌផ្សេងទៀតមិនមានវត្តមាន។ ការចូលរួមរបស់ពលរដ្ឋប្រទេសមួយក្នុងរដ្ឋាភិបាលគឺមានសារៈសំខាន់ចំពោះលទ្ធិប្រជាធិបតេយ្យ។ ការអប់រំ និងអក្ខរកម្មគឺសមត្ថភាពអាន និងសរសេរ បានផ្តល់ឱ្យពលរដ្ឋនូវឧបករណ៍ដែលពួកគេត្រូវការដើម្បីធ្វើការសម្រេចចិត្តនយោបាយ។ ម្យ៉ាងទៀត សេដ្ឋកិច្ចដែលមានស្ថិរភាពជាមួយនឹងវណ្ណៈកណ្តាលរឹងមាំ និងឱកាសសម្រាប់ការរីកចម្រើនក៏ជួយដល់លទ្ធិប្រជាធិបតេយ្យផងដែរ។ វាបានធ្វើឱ្យពលរដ្ឋមានចំណែកចំពោះអនាគតប្រទេសជាតិខ្លួន។ មានលក្ខខណ្ឌផ្សេងៗទៀតដែលជួយជំរុញលទ្ធិប្រជាធិបតេយ្យ។ ទីមួយ គឺជំនឿយ៉ាងម៉ឺងម៉ាត់លើសិទ្ធិរបស់បុគ្គល, លើកកម្ពស់ការប្រព្រឹត្តិដោយយុត្តិធម៌, និងស្មើភាពរបស់ប្រជាពលរដ្ឋ។ ទីពីរ ការគ្រប់គ្រងដោយច្បាប់ បានជួយការពារមេដឹកនាំពីការបំពានអំណាចដោយមិនខ្លាចការដាក់ទណ្ឌកម្ម។ ទីបី ស្មារតីនៃអត្តសញ្ញាណជាតិ ជួយលើកទឹកចិត្តប្រជាពលរដ្ឋឱ្យធ្វើការរួមគ្នាដើម្បីប្រយោជន៍ជាតិ។ ការតស៊ូដើម្បីបង្កើតលទ្ធិប្រជាធិបតេយ្យបានបន្តរហូតដល់សតវត្សរ៍ទី 21 ខណៈដែលប្រទេសជាច្រើនបានបោះបង់ចោលការគ្រប់គ្រងបែបផ្តាច់ការ ជំនួសមកវិញនូវស្ថាប័នប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សារបស់អង្គការសហប្រជាជាតិដែលបានចេញផ្សាយក្នុងខែកក្កដា ឆ្នាំ 2002 បានព្រមានថាការរីករាលដាលនៃលទ្ធិប្រជាធិបតេយ្យនៅជុំវិញពិភពលោកអាចនឹងត្រូវបានរារាំង ប្រសិនបើការបោះឆ្នោតដោយសេរីនៅក្នុងប្រទេសក្រីក្រមិនត្រូវបានអនុវត្តអនុលោមតាមកំណើនសេដ្ឋកិច្ច។ របាយការណ៍ប្រចាំឆ្នាំរបស់កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិបានព្រមានជាពិសេសអំពីតំបន់អាមេរិកឡាទីន។

### 2. ករណីសិក្សាប្រទេសប្រេស៊ីល៖ របបផ្តាច់ការ និងលទ្ធិប្រជាធិបតេយ្យ

ប្រទេសនៅអាមេរិកឡាទីនជាច្រើនបានទទួលឯករាជ្យពីប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយហ្គាល់នៅដើមទសវត្សរ៍ឆ្នាំ 1800 ។ ទោះយ៉ាងណាក៏ដោយ រយៈពេល 3 សតវត្សរ៍នៃការគ្រប់គ្រងអាណានិគម ពួកគេបានបន្សល់ទុកនូវបញ្ហាជាច្រើន។ បញ្ហាទាំងនោះរួមមាន យោធាដ៏មានឥទ្ធិពល, សេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងពេកលើ

ដំណាំតែមួយមុខ, និងគម្លាតដ៏ធំរវាងអ្នកមាននិងអ្នកក្រ។ បញ្ហាទាំងនេះបានបន្តមកដល់សម័យទំនើប។ បន្ទាប់ពីទទួលបានឯករាជ្យពីព័រទុយហ្គាល់នៅឆ្នាំ 1822 ប្រទេសប្រេស៊ីលបានក្លាយជារដ្ឋរាជាធិបតេយ្យ។ ប្រព័ន្ធនយោបាយនេះបានបន្តរហូតដល់ឆ្នាំ 1889 នៅពេលដែលប្រជាជនប្រេស៊ីលបានបង្កើតរដ្ឋាភិបាលសាធារណរដ្ឋមួយ ដែលក្រុមអភិជនជាអ្នកគ្រប់គ្រង។ បន្ទាប់មកនៅទសវត្សរ៍ឆ្នាំ 1930 លោកហ្គេទូលីអូ វ៉ាហ្គាស់ បានក្លាយជាមេដឹកនាំផ្តាច់ការ។ លោកវ៉ាហ្គាស់បានបង្ក្រាបក្រុមអ្នកប្រឆាំងនយោបាយ។ ទោះយ៉ាងណាក៏ដោយ ក្នុងពេលជាមួយគ្នានេះគាត់បានលើកកម្ពស់កំណើនសេដ្ឋកិច្ច និងបានជួយប្រែក្លាយប្រេស៊ីលទៅជាប្រទេសឧស្សាហកម្មទំនើប។

កម្មវិធីប្រកបដោយមហិច្ឆតារបស់គូប៊ីតសេក៖ បន្ទាប់ពីលោកវ៉ាហ្គាស់ មានប្រធានាធិបតីជាប់ឆ្នោតចំនួន 3 រូបទៀតបានព្យាយាមដឹកនាំប្រទេសប្រេស៊ីលឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ។ លោកជូសសេលីណូ គូប៊ីតសេក ដែលគ្រប់គ្រងប្រទេសចាប់ពីឆ្នាំ 1956 ដល់ឆ្នាំ 1961 បានបន្តអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រេស៊ីល។ លោកគូប៊ីតសេកបានលើកទឹកចិត្តដល់ការវិនិយោគបរទេស ដើម្បីជួយចំណាយសម្រាប់គម្រោងអភិវឌ្ឍ។ លោកបានសាងសង់រដ្ឋធានីថ្មីប្រេស៊ីលៀននៅខាងក្នុងរបស់ប្រទេស។ ក្តីសុបិន្តរបស់លោកគូប៊ីតសេកបានបង្ហាញថាមានតម្លៃធំធេងណាស់។ បំណុលបរទេសរបស់ប្រទេសនេះបានកើនឡើង ហើយអតិផរណាក៏បានកើនឡើងផងដែរ។ អ្នកស្នងតំណែងរបស់លោកគូប៊ីតសេក បានស្នើឱ្យមានការធ្វើកំណែទម្រង់ដើម្បីបន្ធូរបន្ថយបញ្ហាសេដ្ឋកិច្ច និងសង្គម។ ពួកអ្នកអភិរក្សនិយមបានប្រឆាំងយ៉ាងខ្លាំងចំពោះរឿងនេះ។ ជាពិសេសពួកគេបានប្រឆាំងជាមួយផែនការ កំណែទម្រង់ដីធ្លី - ការបំបែកអចលនៈទ្រព្យធំៗ និងការចែកចាយដីនោះដល់កសិករ។ នៅឆ្នាំ 1964 ដោយមានការគាំទ្រពីអ្នកមានស្តុកស្តម្ភប្រេស៊ីល កងទ័ពបានដណ្តើមអំណាចនៅក្នុងរដ្ឋប្រហារយោធាមួយ។

មេដឹកនាំយោធាផ្តាច់ការ៖ រយៈពេល 2 ទសវត្សរ៍ មេដឹកនាំយោធាផ្តាច់ការ បានគ្រប់គ្រងប្រទេសប្រេស៊ីល។ ដោយសង្កត់ធ្ងន់លើកំណើនសេដ្ឋកិច្ច ឧត្តមសេនីយ៍យោធាបានជំរុញការវិនិយោគបរទេស។ ពួកគេបានចាប់ផ្តើមគម្រោងអភិវឌ្ឍន៍ដ៏ធំនៅក្នុងព្រៃអាម៉ាហ្សូន។ សេដ្ឋកិច្ចពេលនោះបានរីកចម្រើន។ ការរីកចម្រើននេះក៏បានជះឥទ្ធិពលអាក្រក់ផងដែរ។ រដ្ឋាភិបាលបានបង្កកប្រាក់ឈ្នួល និងកាត់បន្ថយកម្មវិធីសង្គម។ ការធ្វើដូច្នេះ បានបណ្តាលឱ្យមានការថយចុះនៃកម្រិតជីវភាពរស់នៅ ដែលត្រូវបានវិនិច្ឆ័យដោយបរិមាណទំនិញដែលមនុស្សមាន។ នៅពេលដែលប្រជាជនប្រេស៊ីលធ្វើការតវ៉ា រដ្ឋាភិបាលបានធ្វើការបង្ក្រាប។ សម្លាប់អ្នករិះគន់រដ្ឋាភិបាលពេលខ្លះ ពួកគេត្រូវបានចាប់ដាក់គុក និងធ្វើទារុណកម្មផងដែរ។ យ៉ាងណាក៏ដោយ ការប្រឆាំងនឹងការគ្រប់គ្រងដោយយោធានៅតែបន្តកើនឡើង។

ផ្លូវទៅកាន់លទ្ធិប្រជាធិបតេយ្យ៖ នៅដើមទសវត្សរ៍ឆ្នាំ 1980 វិបត្តិសេដ្ឋកិច្ច ឬការធ្លាក់ចុះនៃសេដ្ឋកិច្ចបានគ្របដណ្តប់លើប្រទេសប្រេស៊ីល។ នៅពេលនោះ ឧត្តមសេនីយ៍យោធាបានសម្រេចចិត្តក្នុងការបើកលំហរនយោបាយឡើងវិញ។ ពួកគេបានអនុញ្ញាតឱ្យមានការបោះឆ្នោតជ្រើសរើសមន្ត្រីថ្នាក់មូលដ្ឋាន, ថ្នាក់រដ្ឋ, និងថ្នាក់ជាតិ។ នៅឆ្នាំ 1985 ប្រធានាធិបតីស៊ីវិលថ្មីលោកជចូសេ សានី បានចូលកាន់តំណែង។ លោកសានីបានទទួលមរតកវិបត្តិបំណុលបរទេស និងអតិផរណា។ លោកមិនអាចដោះស្រាយបញ្ហាទាំងនេះបានឡើយ ហើយលោកបានបាត់បង់

ការគាំទ្រ។ ប្រធានាធិបតីជាប់ឆ្នោតបន្ទាប់កាន់តែអាក្រក់។ លោកបានលាលែងពីតំណែងដោយសារបទចោទពីអំពើពុករលួយ។ នៅឆ្នាំ 1994 និងម្តងទៀតក្នុងឆ្នាំ 1998 ប្រជាជនប្រេស៊ីលបានបោះឆ្នោតជ្រើសរើសលោកហ្វឺណាន់ដូ ហេនរីគេ ខារដូសូ ដែលបានទទួលជោគជ័យមួយចំនួនក្នុងការដោះស្រាយបញ្ហាសេដ្ឋកិច្ច និងបញ្ហានយោបាយរបស់ប្រទេស។ ទោះបីជាត្រូវបានបណ្តុះបណ្តាលជាអ្នកប្រាជ្ញម៉ាក្សនិយមក៏ដោយ ក៏លោកខារដូសូបានក្លាយជាអ្នកតស៊ូមតិដ៏រឹងមាំសម្រាប់ទីផ្សារសេរី។ កង្វល់ចម្បងមួយរបស់លោកគឺការរីកឡើងនៃគម្លាតប្រាក់ចំណូលនៅក្នុងប្រទេសប្រេស៊ីល។ លោកបានចាប់ផ្តើមកម្មវិធីលើកកម្ពស់កំណែទម្រង់សេដ្ឋកិច្ចមួយ។

ការបោះឆ្នោតប្រធានាធិបតីឆ្នាំ 2002៖ នៅក្នុងការបោះឆ្នោតប្រធានាធិបតីខែតុលា ឆ្នាំ 2002 អ្នកស្នងតំណែងបន្តពីលោកខារដូសូ ដែលត្រូវបានជ្រើសរើសដើម្បីដឹកនាំក្រុមចម្រុះកណ្តាលរបស់លោកគឺលោកចូសេ សឺរ៉ា។ លោកសឺរ៉ាបានប្រឈមមុខជាមួយនឹងបេក្ខជន 2 រូបផ្សេងទៀតដែលបានស្នើឱ្យបញ្ឈប់គោលនយោបាយគាំទ្រអាជីវកម្មរបស់លោកខារដូសូ។ បេក្ខជនទាំងនោះរួមមានទាំងលោកល្វីស អ៊ីណាស៊ីអូ លូឡា ដា ស៊ីលវ៉ា ដែលជាបេក្ខជននៃគណបក្សពលករឆ្វេងនិយម។ ក្នុងឆ្នាំ 2002 វិបត្តិសេដ្ឋកិច្ចបានវាយប្រហារលើប្រទេសជាច្រើននៅអាមេរិកខាងត្បូង រួមទាំងប្រទេសប្រេស៊ីលផងដែរ។ ដោយសារតែកំណើនសេដ្ឋកិច្ចជាប់គាំង, ការកើនឡើងភាពអត់ការងារធ្វើ, និងភាពក្រីក្រ បណ្តាលឱ្យមានប្រតិកម្មប្រឆាំងនឹងគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី។ ហេតុនេះបានធ្វើឱ្យការបោះឆ្នោតឆ្នាំ 2002 មានការប្រកួតប្រជែងយ៉ាងប្រកៀកប្រកិត។ លោកដា ស៊ីលវ៉ា ដែលជាបេក្ខភាពឆ្វេងនិយមបានឈ្នះការបោះឆ្នោតដ៏ក្តៅគគុកនេះ ដោយបានយកជ័យជំនះលើបេក្ខភាពមកពីបក្សកាន់អំណាចគឺលោកសឺរ៉ា។ លោកដា ស៊ីលវ៉ាបានបង្ហាញឱ្យឃើញថាលោកប្រធានាធិបតីដែលនិយមកណ្តាល ខុសពីអ្វីដែលអ្នកគាំទ្រ និងគូប្រជែងរបស់គាត់បានរំពឹងទុក។ ទោះបីជាប្រទេសប្រេស៊ីលប្រឈមមុខនឹងបញ្ហាជាច្រើនក៏ដោយ ក៏ពួកគេនៅតែបន្តដើរនៅលើផ្លូវប្រជាធិបតេយ្យ។

### 3. ករណីសិក្សាប្រទេសម៉ិកស៊ិកកូ៖ ការគ្រប់គ្រងដោយបក្សតែមួយ

ខុសពីប្រទេសប្រេស៊ីល ម៉ិកស៊ិកកូបានរីករាយជាមួយនឹងស្ថិរភាពនយោបាយនៅក្នុងសតវត្សរ៍ទី 20 ។ បន្ទាប់ពីបដិវត្តម៉ិកស៊ិកកូ រដ្ឋាភិបាលបានអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយនៅក្នុងឆ្នាំ 1917 ។ រដ្ឋធម្មនុញ្ញថ្មីនេះបានគូសបញ្ជាក់អំពីលទ្ធិប្រជាធិបតេយ្យ និងបានសន្យានៅក្នុងការធ្វើកំណែទម្រង់។

ការចាប់ផ្តើមនៃការគ្រប់គ្រងដោយបក្សតែមួយ៖ ចាប់ពីឆ្នាំ 1920 ដល់ឆ្នាំ 1934 ម៉ិកស៊ិកកូបានជ្រើសរើសឧត្តមសេនីយ៍យោធាមួយចំនួនធ្វើជាប្រធានាធិបតី។ ទោះយ៉ាងណាក៏ដោយ ឧត្តមសេនីយ៍យោធាទាំងនេះមិនបានគ្រប់គ្រងជាយោធាផ្តាច់ការឡើយ។ ពួកគេបានបង្កើតគណបក្សកាន់អំណាចមួយគឺគណបក្សបដិវត្តជាតិ ដែលគ្រប់គ្រងប្រទេសម៉ិកស៊ិកកូក្រោមឈ្មោះផ្សេងៗនៅអំឡុងសតវត្សរ៍ទី 20 ។ ចាប់ពីឆ្នាំ 1934 ដល់ឆ្នាំ 1940 ប្រធានាធិបតីឡាហ្សារ៉ូ ខារដេណាស់ បានព្យាយាមកែលម្អជីវភាពរស់នៅរបស់កសិករ និងកម្មករ។ លោកបានអនុវត្តការធ្វើកំណែទម្រង់ដីធ្លី និងលើកកម្ពស់សិទ្ធិការងារ។ លោកបានធ្វើជាតូបនីយកម្មលើវិស័យឧស្សាហកម្មប្រេងម៉ិកស៊ិកកូ ដោយបណ្តេញក្រុមហ៊ុនប្រេងបរទេសចេញ និងបង្កើតឧស្សាហកម្មប្រេងដែលគ្រប់គ្រងដោយរដ្ឋ។

ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីលោកខារដេណាស់ ប្រធានាធិបតីអភិរក្សនិយមជាបន្តបន្ទាប់បានងាកចេញពីការធ្វើកំណែទម្រង់នេះ។

គណបក្សប្តូរឈ្មោះទៅជាគណបក្សបដិវត្តស្ថាប័ន៖ នៅឆ្នាំ 1946 គណបក្សនយោបាយសំខាន់មួយបានប្តូរឈ្មោះទៅជាគណបក្សបដិវត្តស្ថាប័ន។ នៅកន្លះសតវត្សរ៍ក្រោយមក គណបក្សបដិវត្តស្ថាប័នបានក្លាយជាកម្លាំងដ៏សំខាន់សម្រាប់ស្ថិរភាពនយោបាយនៅក្នុងប្រទេសម៉ិកស៊ិកកូ។ ទោះបីជាមានស្ថិរភាពក៏ដោយ រដ្ឋាភិបាលមិនមែនជារដ្ឋាភិបាលដែលមានលក្ខណៈប្រជាធិបតេយ្យពេញលេញឡើយ។ គណបក្សបដិវត្តស្ថាប័នបានគ្រប់គ្រងសភា និងឈ្នះរាល់ការបោះឆ្នោតប្រធានាធិបតីទាំងអស់។ រដ្ឋាភិបាលបានអនុញ្ញាតឱ្យគណបក្សប្រឆាំងចូលរួមប្រកួតប្រជែង ប៉ុន្តែការក្លែងបន្លំ និងអំពើពុករលួយបានធ្វើឱ្យមានបញ្ហាដល់ការបោះឆ្នោត។ ទោះបីជាសេដ្ឋកិច្ចម៉ិកស៊ិកកូរីកចម្រើនយ៉ាងឆាប់រហ័សក៏ដោយ ក៏ម៉ិកស៊ិកកូនៅតែបន្តរងទុក្ខដោយបញ្ហាសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ។ ដោយខ្វះដី និងការងារ ប្រជាជនម៉ិកស៊ិកកូរាប់លាននាក់បានតស៊ូយ៉ាងលំបាកដើម្បីរស់រានមានជីវិត។ លើសពីនេះ បំណុលបរទេសដ៏ច្រើនបានបង្ខំឱ្យរដ្ឋាភិបាលចំណាយប្រាក់យ៉ាងច្រើនដើម្បីបង់ការប្រាក់។ មានរឿងចំនួន 2 ដែលបានលើកឡើងពីការលំបាកដែលកំពុងកើនឡើងនៅម៉ិកស៊ិកកូ។ នៅចុងទសវត្សរ៍ឆ្នាំ 1960 និស្សិត និងកម្មករបានចាប់ផ្តើមអំពាវនាវឱ្យមានការធ្វើកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយ។ នៅថ្ងៃទី 2 ខែតុលា ឆ្នាំ 1968 ក្រុមអ្នកតវ៉ាបានប្រមូលផ្តុំគ្នានៅផ្សារបុរាណអាស់ទិចនៅទីក្រុងម៉ិកស៊ិកកូ។ ទាហានដែលលាក់ខ្លួនក្នុងប្រាសាទបានបើកការបាញ់ប្រហារលើបាតុករ។ ការសម្លាប់រង្គាលនេះបានឆក់យកជីវិតមនុស្សរាប់រយនាក់។ រឿងសំខាន់ទីពីរបានកើតឡើងនៅដើមទសវត្សរ៍ឆ្នាំ 1980 ។ នៅពេលនោះ ទុនបម្រុងប្រេង និងឧស្ម័នធម្មជាតិថ្មីៗជាច្រើនត្រូវបានរកឃើញនៅក្នុងប្រទេសម៉ិកស៊ិកកូ។ សេដ្ឋកិច្ចពឹងផ្អែកទាំងស្រុងលើការនាំចេញប្រេង និងឧស្ម័ន។ នៅឆ្នាំ 1981 តម្លៃប្រេងពិភពលោកបានធ្លាក់ចុះ ដោយបានកាត់បន្ថយប្រាក់ចំណូលប្រេង និងឧស្ម័នរបស់ម៉ិកស៊ិកកូពាក់កណ្តាល។ សេដ្ឋកិច្ចរបស់ម៉ិកស៊ិកកូបានធ្លាក់ចុះ។

វិបត្តិសេដ្ឋកិច្ច និងនយោបាយ៖ នៅអំឡុងទសវត្សរ៍ឆ្នាំ 1980 និង 1990 ប្រទេសម៉ិកស៊ិកកូបានមើលឃើញពីការប្រឈមទៅនឹងវិបត្តិផ្សេងៗជាច្រើន។ នៅឆ្នាំ 1988 គណបក្សប្រឆាំងបានប្រកួតប្រជែងជាមួយគណបក្សបដិវត្តស្ថាប័ននៅក្នុងការបោះឆ្នោតជាតិ។ បេក្ខជនមកពីគណបក្សបដិវត្តស្ថាប័នលោកខារឡូស សាលីណាស់បានឈ្នះតំណែងជាប្រធានាធិបតី។ ទោះយ៉ាងនេះក្តី គណបក្សប្រឆាំងបានទទួលអាសនៈក្នុងសភា ហើយចាប់ផ្តើមបង្ខំឱ្យបើកលំហរនយោបាយបន្តិចម្តងៗ។ នៅអំឡុងពេលធ្វើជាប្រធានាធិបតី លោកសាលីណាស់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើងបានដកចេញនូវរបាំងពាណិជ្ជកម្មរវាងប្រទេសម៉ិកស៊ិកកូជាមួយនឹងសហរដ្ឋអាមេរិក និងកាណាដា។ នៅដើមឆ្នាំ 1994 ពួកឧទ្ទាមកសិករនៅរដ្ឋឆៃប៉ាស់ដែលស្ថិតនៅម៉ិកស៊ិកកូភាគខាងត្បូង បានចាប់ផ្តើមការបះបោរដ៏ធំមួយ។ បន្តិចក្រោយមក ខ្មាន់កាំភ្លើងម្នាក់បានលួចធ្វើឃាតលោកល្វីស ដូណាល់ដូ កូឡូស៊ីអូ ដែលជាបេក្ខជនប្រធានាធិបតីរបស់គណបក្សបដិវត្តស្ថាប័នសម្រាប់ការបោះឆ្នោតនាពេលខាងមុខ។

គណបក្សបដិវត្តស្ថាប័នបាត់បង់ការគ្រប់គ្រង៖ បន្ទាប់ពីព្រឹត្តិការណ៍ទាំងនេះ ប្រជាជនម៉ិកស៊ិកកូមានការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីអនាគតនៃស្ថិរភាពប្រជាធិបតេយ្យ។ យ៉ាងណាក៏ដោយ ការបោះឆ្នោតឆ្នាំ 1994 បានដំណើរការទៅមុខជាប្រក្រតី។ បេក្ខជនថ្មីរបស់គណបក្សបដិវត្តស្ថាប័នលោកអេនេស្តូ ហ្សេឌីលឡូ បានឈ្នះការបោះឆ្នោត។ គណបក្សប្រឆាំងបានបន្តប្រកួតប្រជែងជាមួយគណបក្សបដិវត្តស្ថាប័ន។ នៅឆ្នាំ 1997 គណបក្សប្រឆាំងចំនួន 2 បានឈ្នះអាសនៈសភាមួយចំនួនធំ ដោយបញ្ឈប់ការគ្រប់គ្រងរបស់គណបក្សបដិវត្តស្ថាប័ននៅក្នុងសភា។ បន្ទាប់មកនៅឆ្នាំ 2000 អ្នកបោះឆ្នោតម៉ិកស៊ិកកូបានបញ្ចប់ការគ្រប់គ្រងរបស់គណបក្សបដិវត្តស្ថាប័នដែលបានគ្រប់គ្រងអំណាចនៅកស៊ិកកូអស់រយៈពេល 71 ឆ្នាំ ដោយបានជ្រើសរើសបេក្ខជនកណ្តាលស្តាំនិយមលោកវីសេនទេ ហ្វុក ធ្វើជាប្រធានាធិបតី។

គោលនយោបាយ និងកម្មវិធីថ្មី៖ របៀបវារៈរបស់លោកហ្វុកប្រកបដោយមហិច្ឆតា។ លោកបានតស៊ូមតិក្នុងការធ្វើកំណែទម្រង់ប៉ូលីស, ការលុបបំបាត់អំពើពុករលួយផ្នែកនយោបាយ, បញ្ចប់ការបះបោរនៅឆៃប៉ាស់ និងបើកសេដ្ឋកិច្ចរបស់ម៉ិកស៊ិកកូទៅក្នុងទីផ្សារសេរី។ លោកហ្វុកក៏បានទទូចថា សហរដ្ឋអាមេរិកគួរតែផ្តល់ឱ្យពលករអន្តោប្រវេសន៍ម៉ិកស៊ិកកូខុសច្បាប់រាប់លាននាក់ធ្វើនូវភាពស្របច្បាប់។ លោកហ្វុកសង្ឃឹមថាកិច្ចព្រមព្រៀងដែលបានចរចារវាងសហរដ្ឋអាមេរិក និងម៉ិកស៊ិកនឹងផ្តល់ការលើកលែងទោសដល់កម្មករម៉ិកស៊ិកកូដែលគ្មានឯកសារទាំងនេះនៅសហរដ្ឋអាមេរិក។ បន្ទាប់ពីលោកហ្វេលីពេ កាល់ដេរុនដែលជាអ្នកអភិរក្សនិយមបានជាប់ឆ្នោតជាប្រធានាធិបតីក្នុងឆ្នាំ 2006 គាត់បានបន្តគោលនយោបាយភាគច្រើនរបស់លោកហ្វុក។ ទោះជាយ៉ាងណាក៏ដោយ ភាពតានតឹងរវាងរដ្ឋាភិបាលម៉ិកស៊ិកកូ និងសហរដ្ឋអាមេរិកបានបន្តកើនឡើងជុំវិញផែនការរបស់ទីក្រុងវ៉ាស៊ីនតោនក្នុងការសាងសង់របងនៅតាមព្រំដែននៃប្រទេសទាំង 2 ។

## 4. ករណីសិក្សាប្រទេសអាហ្សង់ទីន៖ វិបត្តិនយោបាយ និងសេដ្ឋកិច្ច

ម៉ិកស៊ិកកូ និងប្រេស៊ីលមិនមែនជាប្រទេសតែមួយនៅអាមេរិកឡាទីនទេ ដែលលទ្ធិប្រជាធិបតេយ្យមានការរីកចម្រើន។ នៅចុងទសវត្សឆ្នាំ 1990 ភាគច្រើននៃប្រទេសនៅអាមេរិកឡាទីនស្ថិតនៅក្រោមការគ្រប់គ្រងបែបប្រជាធិបតេយ្យ។

លោកប៉េរ៉ុនដឹកនាំអាហ្សង់ទីន៖ អាហ្សង់ទីនបានតស៊ូដើម្បីស្ថាបនាលទ្ធិប្រជាធិបតេយ្យ។ ប្រទេសនេះជាអ្នកនាំចេញគ្រាប់ធញ្ញជាតិ និងសាច់គោដ៏ធំ។ ពួកគេក៏ជាប្រទេសឧស្សាហកម្ម ដែលមានវណ្ណៈកម្មករដ៏ធំ។ នៅឆ្នាំ 1946 កម្មករអាហ្សង់ទីនបានគាំទ្រមន្ត្រីកងទ័ពម្នាក់ឈ្មោះលោកចូន ប៉េរ៉ុន ដែលបានឈ្នះតំណែងជាប្រធានាធិបតីហើយបន្ទាប់មកលោកបានបង្កើតរបបផ្តាច់ការនៅអាហ្សង់ទីន។ លោកប៉េរ៉ុនមិនបានគ្រប់គ្រងតែម្នាក់ឯងឡើយ។ លោកបានទទួលការគាំទ្រយ៉ាងខ្លាំងពីភរិយារបស់លោកឈ្មោះអេវ៉ា ដែលត្រូវបានជនជាតិអាហ្សង់ទីនរាប់លាននាក់ស្គាល់ថាអេវីតា។ ដោយរួមគ្នាជាមួយលោកប៉េរ៉ុន អ្នកទាំងពីរបានបង្កើតរដ្ឋសុខុមាលភាពមួយ។ រដ្ឋបានផ្តល់នូវកម្មវិធីសង្គមសម្រាប់ប្រជាជនជាច្រើន ប៉ុន្តែសេរីភាពនៅមានកម្រិត។ បន្ទាប់ពីការស្លាប់របស់អេវ៉ាក្នុងឆ្នាំ 1952 ប្រជាប្រិយភាពរបស់លោកប៉េរ៉ុនបានធ្លាក់ចុះ ហើយសត្រូវរបស់លោក ក្នុងនោះរួមមានពួកយោធា និងព្រះវិហារ

កាតូលិក បានងើបឡើងប្រឆាំងនឹងរូបលោក។ នៅឆ្នាំ 1955 ពួកយោធាបានបណ្តេញលោកប៉េរ៉ុនចេញពីអំណាច និងបាននិរទេសលោកចេញក្រៅប្រទេស។

ការបង្ក្រាបនៅអាហ្សង់ទីន៖ អស់រយៈពេលជាច្រើនឆ្នាំ យោធាបានគ្រប់គ្រងនយោបាយនៅអាហ្សង់ទី។ លោកប៉េរ៉ុនបានត្រលប់មកកាន់អំណាចម្តងទៀតក្នុងឆ្នាំ 1973 ប៉ុន្តែលោកគ្រប់គ្រងអំណាចបានត្រឹមតែមួយឆ្នាំប៉ុណ្ណោះមុនពេលទទួលមរណភាពក្នុងពេលកំពុងកាន់តំណែង។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1970 អាហ្សង់ទីនស្ថិតនៅក្នុងភាពវឹកវរ។ នៅឆ្នាំ 1976 ឧត្តមសេនីយ៍យោធាបានដណ្តើមអំណាចម្តងទៀត។ ពួកគេបានបង្កើតរបបផ្តាច់ការដ៏ឃោរឃៅ និងតាមប្រមាញ់ក្រុមអ្នកប្រឆាំងនយោបាយ។ អស់រយៈពេលជាច្រើនឆ្នាំមកនេះ ការធ្វើទារុណកម្ម និងឃាតកម្មបានកើតមានឡើងជាប្រចាំថ្ងៃ។ នៅដើមទសវត្សរ៍ឆ្នាំ 1980 ប្រជាជនអាហ្សង់ទីនជាច្រើនពាន់នាក់បានបាត់ខ្លួនយ៉ាងស្ងប់ស្ងាត់ ដែលពួកគេត្រូវបានចាប់ពង្រត់ដោយរដ្ឋាភិបាលផ្ទាល់របស់ពួកគេ។

លទ្ធិប្រជាធិបតេយ្យ និងសេដ្ឋកិច្ច៖ នៅឆ្នាំ 1982 រដ្ឋាភិបាលយោធាបានធ្វើសង្គ្រាមជាមួយអង់គ្លេសលើកោះហ្វល់លែនដែលស្ថិតនៅជិតនោះ ហើយបានទទួលរងបរាជ័យ។ ដោយក្តីអាម៉ាស់មុខ ពួកមេទ័ពបានយល់ព្រមចុះចេញពីតំណែង។ នៅឆ្នាំ 1983 អាហ្សង់ទីនបានបោះឆ្នោតជ្រើសរើសលោកប្រធានាធិបតីអ៉ាអ៊ូល អាល់ហ្វុនស៊ីននៅក្នុងការបោះឆ្នោតដោយសេរីលើកដំបូងរបស់ប្រទេសក្នុងរយៈពេល 37 ឆ្នាំ។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1980 លោកអាល់ហ្វុនស៊ីនបានធ្វើការដើម្បីកសាងលទ្ធិប្រជាធិបតេយ្យ និងសេដ្ឋកិច្ចឡើងវិញ។ លោកខារឡូស ម៉េនេមបានទទួលតំណែងជាប្រធានាធិបតីក្នុងឆ្នាំ 1989 និងបានបន្តដំណើរការនេះ។ គាត់បានព្យាយាមរក្សាស្ថិរភាពរូបិយប័ណ្ណ និងធ្វើឯកជនភាវូបនីយកម្មលើវិស័យឧស្សាហកម្ម។ ទោះយ៉ាងណា នៅចុងទសវត្សរ៍ឆ្នាំ 1990 បញ្ហាសេដ្ឋកិច្ចកាន់តែកើនឡើង ខណៈប្រទេសចំណាយលើសពីសមត្ថភាពរបស់ខ្លួន។

វិបត្តិដែលកំពុងកើនឡើង៖ នៅក្នុងខែធ្នូ ឆ្នាំ 2001 មូលនិធិរូបិយវត្ថុអន្តរជាតិបានបដិសេធមិនផ្តល់ជំនួយហិរញ្ញវត្ថុដល់ប្រទេសអាហ្សង់ទីន។ បន្ទាប់មក ប្រធានាធិបតីហ្វឺណាន់ដូ ដេ ឡា រ៉ូល បានលាលែងពីតំណែង នៅចំពោះមុខការតវ៉ាជុំវិញបញ្ហាសេដ្ឋកិច្ច។ លោកត្រូវបានស្នងតំណែងបន្តដោយលោកអេឌូដូ ឌូហាល់ដេដែលបានព្យាយាមដោះស្រាយវិបត្តិសេដ្ឋកិច្ច និងសង្គម។ ក្នុងឆ្នាំ 2002 អាហ្សង់ទីនមានអត្រាអ្នកគ្មានការងារធ្វើប្រហែល 24% ។ ប្រទេសនេះបានជំពាក់បំណុលគេចំនួន 132 ពាន់លានដុល្លារ ដែលជាបំណុលធំបំផុតក្នុងប្រវត្តិសាស្ត្រ និងបានទម្លាក់តម្លៃរូបិយប័ណ្ណរបស់ខ្លួន។ បន្ទាប់ពីលោកនេសតូ គីចនីបានក្លាយជាប្រធានាធិបតីក្នុងឆ្នាំ 2003 ប្រទេសនេះបានចរចាឡើងវិញនូវបំណុលរបស់ខ្លួនជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ។ នៅក្នុងឆ្នាំ 2006 អាហ្សង់ទីនបានសងបំណុលរបស់ពួកគេដោយជោគជ័យ។

# មេរៀនទី 2៖ បញ្ហាប្រឈមនៃលទ្ធិប្រជាធិបតេយ្យនៅអាហ្វ្រិក

## 1. ពួកអាណានិគមកម្រិតលទ្ធិប្រជាធិបតេយ្យ

ឥទ្ធិពលនៃអាណានិគមនិយម បានកំពុងបណ្តាលឱ្យធ្លាក់ចុះដល់កិច្ចខិតខំប្រឹងប្រែងដើម្បីកសាងស្ថិរភាពសេដ្ឋកិច្ច និងរដ្ឋប្រជាធិបតេយ្យ។ រឿងនេះអាចត្រូវបានគេមើលឃើញនៅទូទាំងទ្វីបអាហ្វ្រិក។

គោលនយោបាយរបស់ពួកអឺរ៉ុបបង្កឱ្យមានបញ្ហា៖ នៅពេលដែលពួកអឺរ៉ុបបានបង្កើតព្រំដែនអាណានិគម ពួកគេមិនអើពើទៅនឹងការបែងចែកជាតិសាសន៍ ឬវប្បធម៌ដែលមានស្រាប់ឡើយ។ ព្រំដែនថ្មីបានបែងចែកមនុស្សដែលមានសាវតារដូចគ្នា ឬបានរួមបញ្ចូលគ្នានូវក្រុមមនុស្សខុសៗគ្នា ដែលជាញឹកញយជាគូប្រជែងនឹងគ្នា។ ដោយសារតែបែបនេះហើយ ទើបគំនិតអត្តសញ្ញាណជាតិមានភាពលំបាកនៅក្នុងការអភិវឌ្ឍ។ ក្រោយទទួលបានឯករាជ្យព្រំដែនអាណានិគមចាស់បានក្លាយជាព្រំដែននៃរដ្ឋដែលទើបតែទទួលបានឯករាជ្យ។ ជាលទ្ធផល ជម្លោះជនជាតិ និងវប្បធម៌នៅតែបន្តកើតមាន។ បញ្ហាផ្សេងទៀតមានជាប់ទាក់ទងជាមួយសេដ្ឋកិច្ច។ មហាអំណាចអឺរ៉ុបបានសម្លឹងឃើញដែនដីអាណានិគមជាប្រភពនៃទ្រព្យសម្បត្តិសម្រាប់ប្រទេសកំណើត។ មហាអំណាចអាណានិគមបានលើកទឹកចិត្តឱ្យមានការនាំចេញដំណាំតែមួយ ឬពីរមុខ ដូចជាកាហ្វេ ឬកៅស៊ូ ជាជាងការផលិតនូវផលិតផលច្រើនប្រភេទ ដើម្បីបំពេញតម្រូវការក្នុងស្រុក។ ជនជាតិអឺរ៉ុបបានបង្កើតចម្ការ និងអណ្តូងរ៉ែ ប៉ុន្តែពួកគេបានបង្កើតរោងចក្រតិចតួច។ ទំនិញរោងចក្រត្រូវបាននាំចូលមកពីបណ្តាប្រទេសនៅអឺរ៉ុប។ គោលនយោបាយទាំងនេះបានធ្វើឱ្យប្រទេសអាហ្វ្រិកថ្មីមានសេដ្ឋកិច្ចមិនមានតុល្យភាព និងមានវណ្ណៈកណ្តាលតូចមួយ។ បញ្ហាសេដ្ឋកិច្ចបែបនេះបានបន្ថយឱកាសរបស់ពួកគេក្នុងការបង្កើតឱ្យមានស្ថិរភាពប្រជាធិបតេយ្យ។ ការគ្រប់គ្រងរបស់អឺរ៉ុបក៏បានរំខានដល់ជីវភាពគ្រួសារ និងសហគមន៍អាហ្វ្រិកផងដែរ។ ក្នុងករណីខ្លះ មហាអំណាចអាណានិគមបានផ្លាស់ទីជនជាតិអាហ្វ្រិកឱ្យចេញឆ្ងាយពីគ្រួសារ និងភូមិរបស់ពួកគេទៅធ្វើការក្នុងអណ្តូងរ៉ែ ឬនៅលើដីចម្ការ។ លើសពីនេះ ប្រទេសឯករាជ្យថ្មីភាគច្រើននៅតែខ្វះខាតកម្លាំងការងារដែលមានជំនាញ និងចេះអក្សរ និងអាចទទួលយកភារកិច្ចកសាងប្រទេសជាតិថ្មី។

លទ្ធិប្រជាធិបតេយ្យដែលមានអាយុកាលខ្លី៖ នៅពេលដែលអង់គ្លេស និងបារាំងបោះបង់ចោលដែនដីអាណានិគម ពួកគេបានបន្សល់ទុកនូវរដ្ឋាភិបាលប្រជាធិបតេយ្យដែលផុយស្រួយមួយនៅនឹងកន្លែង។ មិនយូរប៉ុន្មានបញ្ហានានាបានគំរាមកំហែងដល់រដ្ឋាភិបាលទាំងនោះ។ ក្រុមជនជាតិភាគតិចដែលជាគូប្រជែងតែងតែប្រយុទ្ធគ្នាដើម្បីអំណាច។ កម្លាំងយោធាខ្លាំងបានក្លាយជាឧបករណ៍សម្រាប់មេដឹកនាំដែលមានមហិច្ឆតា។ ក្នុងករណីជាច្រើនរបបផ្តាច់ការយោធាបានជំនួសលទ្ធិប្រជាធិបតេយ្យ។

## 2. សង្គ្រាមស៊ីវិលនៅនីហ្សេរីយ៉ា

នីហ្សេរីយ៉ា ដែលជាអតីតដែនដីអាណានិគមរបស់អង់គ្លេស បានទទួលឯករាជ្យរបស់ខ្លួនដោយសន្តិវិធីនៅក្នុងឆ្នាំ 1960 ។ នីហ្សេរីយ៉ាគឺជាប្រទេសដែលមានប្រជាជនច្រើនជាងគេនៅទ្វីបអាហ្វ្រិក និងជាប្រទេសមួយក្នុង

ចំណោមប្រទេសអ្នកមានបំផុតរបស់ទ្វីបនេះ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសនេះត្រូវបានបែងចែកដោយជាតិសាសន៍នានា។ មិនយូរប៉ុន្មានការបែបចែកនេះបានបង្កើតបញ្ហានានា ដែលនាំឱ្យមានសង្គ្រាម។

ដែនដីដែលមានប្រជាជនជាច្រើន៖ ក្រុមជនជាតិភាគតិចធំៗចំនួន 3 ក្រុមបានរស់នៅក្នុងព្រំដែនប្រទេសនីហ្សេរីយ៉ា។ នៅភាគខាងជើងមានជនជាតិហៅសា-ហ៊្វូឡានីដែលភាគច្រើនជាមូស្លីម។ នៅភាគខាងត្បូងមានជនជាតិយូរ៉ូបា និងអ៊ីកប៉ូ ដែលភាគច្រើនជាគ្រឹស្តសាសនិក, មូស្លីម ឬអ្នកជីវចលនិយមដែលជឿថាវិញ្ញាណមានវត្តមាននៅក្នុងសត្វ, រុក្ខជាតិ, និងវត្ថុធម្មជាតិ។ ជនជាតិយូរ៉ូបាដែលជាអ្នកធ្វើស្រែចម្ការមានប្រពៃណីបែបរាជានិយមរស់នៅភាគខាងលិច។ ជនជាតិអ៊ីកប៉ូដែលជាអ្នកធ្វើស្រែចំការដែលមានទំនៀមទម្លាប់បែបប្រជាធិបតេយ្យរស់នៅភាគខាងកើត។ បន្ទាប់ពីឯករាជ្យ ប្រទេសនីហ្សេរីយ៉ាបានអនុម័តប្រព័ន្ធនយោបាយសហព័ន្ធ។ នៅក្នុងប្រព័ន្ធនយោបាយសហព័ន្ធ អំណាចត្រូវបានចែករំលែករវាងរដ្ឋាភិបាលរដ្ឋ និងអាជ្ញាធរកណ្តាល។ ជនជាតិនីហ្សេរីយ៉ាបានបង្កើតរដ្ឋចំនួន 3 ដែលរដ្ឋមួយសម្រាប់តំបន់ និងក្រុមជនជាតិភាគតិចនីមួយៗអមជាមួយនឹងគណបក្សមួយនយោបាយសម្រាប់តំបន់នីមួយៗ។

សង្គ្រាមជាមួយបៃប្រា៖ ទោះបីជាក្រុមនីមួយៗបានគ្រប់គ្រងរដ្ឋរៀងៗខ្លួនក៏ដោយ ក៏នៅក្នុងរដ្ឋនីមួយៗ មានជនជាតិភាគតិចជាច្រើនក្រុមផងដែរ។ នៅតំបន់ភាគខាងលិច ជនជាតិភាគតិចដែលមិនមែនជាជនជាតិយ៉ូរ៉ូបាបានចាប់ផ្តើមមិនសប្បាយចិត្តនឹងការគ្រប់គ្រងរបស់ពួកយ៉ូរ៉ូបា។ នៅឆ្នាំ 1963 ពួកគេបានព្យាយាមបំបែកខ្លួន និងបង្កើតតំបន់ផ្ទាល់ខ្លួនរបស់ពួកគេ។ ការនេះបានបណ្តាលឱ្យមានការប្រយុទ្ធគ្នា។ នៅខែមករា ឆ្នាំ 1966 មន្ត្រីកងទ័ពមួយក្រុមដែលភាគច្រើនជាពួកអ៊ីកប៉ូបានដណ្តើមអំណាចនៅក្នុងរដ្ឋធានីឡាហ្គោស។ មន្ត្រីទាំងនេះបានលុបចោលរដ្ឋាភិបាលក្នុងតំបន់ និងប្រកាសច្បាប់អាជ្ញាសឹក ឬការគ្រប់គ្រងបែបយោធាជាបណ្តោះអាសន្ន។ ជនជាតិហៅសា-ហ្វ៊ូឡានីដែលមិនជឿទុកចិត្តលើពួកអ៊ីកប៉ូ បានបើកការវាយប្រហារពីភាគខាងជើង។ ពួកគេបានធ្វើទុក្ខបុកម្នេញ និងសម្លាប់ពួកអ៊ីកប៉ូអស់ជាច្រើននាក់។ អ្នករស់រានមានជីវិតបានភៀសខ្លួនទៅភាគខាងកើត។ នៅឆ្នាំ 1967 តំបន់ភាគបូព៌ាបានបំបែកចេញពីប្រទេសនីហ្សេរីយ៉ាដោយប្រកាសខ្លួនឯងថាជាប្រជាជាតិថ្មី បៃប្រា ។ ក្រោយមករដ្ឋាភិបាលនីហ្សេរីយ៉ាបានធ្វើសង្គ្រាមដើម្បីបង្រួបបង្រួមប្រទេសឡើងវិញ។ ពួកអ៊ីកប៉ូមានចំនួនកងទ័ព និងអាវុធតិចជាង។ ជាលទ្ធផលនៅឆ្នាំ 1970 ពួកបៃប្រាបានចុះចាញ់។ ប្រទេសនីហ្សេរីយ៉ាត្រូវបានបង្រួបបង្រួមឡើងវិញ ប៉ុន្តែ ពួកអ៊ីកប៉ូប្រហែលជាជាងមួយលាននាក់បានស្លាប់ ដែលភាគច្រើនបណ្តាលមកពីភាពអត់ឃ្លាន។

### 3. ការកសាងជាតិប្រទេសនីហ្សេរីយ៉ាឡើងវិញ

បន្ទាប់ពីសង្គ្រាម ជនជាតិនីហ្សេរីយ៉ាបានវិលត្រលប់ទៅកសាងប្រទេសឡើងវិញ។ មន្ត្រីម្នាក់បានកត់សម្គាល់ថា៖ "នៅពេលសង្គ្រាមបានបញ្ចប់ វាដូចជាអាជ្ញាកណ្តាលផ្លុំកញ្ចែបញ្ចប់ការប្រកួតបាល់ទាត់។ ប្រជាជនគ្រាន់តែទម្លាក់កាំភ្លើង ហើយត្រឡប់ទៅរកស៊ីចិញ្ចឹមជីវិតវិញ"។ រដ្ឋាភិបាលនីហ្សេរីយ៉ាមិនបានដាក់ទណ្ឌកម្មលើជនជាតិអ៊ីកប៉ូទេ។ គេបានប្រើប្រាស់លុយសហព័ន្ធដើម្បីស្តាបនាតំបន់អ៊ីកប៉ូឡើងវិញ។

រដ្ឋាភិបាលសហព័ន្ធបានស្តារឡើងវិញ៖ យោធាបានគ្រប់គ្រងប្រទេសនីហ្សេរីយ៉ាមួយភាគធំនៃទសវត្សរ៍ឆ្នាំ 1970 ។ នៅអំឡុងពេលនោះ មេដឹកនាំនីហ្សេរីយ៉ាបានព្យាយាមបង្កើតប្រព័ន្ធសហព័ន្ធដែលមានស្ថិរភាពជាងមុន ជាមួយនឹងរដ្ឋាភិបាលកណ្តាលដ៏រឹងមាំ និងអង្គភាពក្នុងតំបន់មួយចំនួន។ រដ្ឋាភិបាលក៏បានព្យាយាមកសាងសេដ្ឋកិច្ចឱ្យទំនើបជាងមុន ដោយផ្អែកលើចំណូលដែលបានមកពីប្រេង។ នៅឆ្នាំ 1979 យោធាបានប្រគល់អំណាចត្រឡប់ទៅឲ្យអ្នកគ្រប់គ្រងស៊ីវិលវិញ។ ប្រជាជននីហ្សេរីយ៉ាមានការសប្បាយចិត្តចំពោះការវិលត្រឡប់ទៅរកលទ្ធិប្រជាធិបតេយ្យវិញ។ យ៉ាងណាក៏ដោយ ប្រជាពលរដ្ឋមួយចំនួននៅតែមានការព្រួយបារម្ភអំពីការបែកបាក់ជាតិសាសន៍ក្នុងប្រទេស។ លទ្ធិប្រជាធិបតេយ្យនីហ្សេរីយ៉ាមានរយៈពេលខ្លី។ នៅឆ្នាំ 1983 យោធាបានផ្តួលរំលំរដ្ឋាភិបាលស៊ីវិលដោយចោទប្រកាន់ពីបទពុករលួយ។ របបយោធាថ្មីមួយដែលគ្រប់ដណ្តប់ដោយពួកហៅសា-ហ្វ៊ូឡានី បានគ្រប់គ្រងអំណាច។

ការវិលត្រឡប់ទៅកាន់ការគ្រប់គ្រងរបស់ជនស៊ីវិល៖ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យោធាបានគ្រប់គ្រងប្រទេសនីហ្សេរីយ៉ា ខណៈពេលដែលពួកគេសន្យាថានឹងប្រគល់ការគ្រប់គ្រងឱ្យជនស៊ីវិលវិញ។ ពួកកងទ័ពបានរៀបចំការបោះឆ្នោតនៅឆ្នាំ 1993 ជាលទ្ធផលមេដឹកនាំដ៏មានប្រជាប្រិយលោកម៉ូស៊ូដ អាប៊ីអ៊ូឡាទទួលបានជ័យជម្នះ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមន្ត្រីបានប្រកាសថាលទ្ធផលមិនអាចយកជាការបាន ហើយមេដឹកនាំផ្តាច់ការមួយរូបគឺលោកសានី អាបាឆាបានគ្រប់គ្រងអំណាច។ ឧត្តមសេនីយយោអាអាបាឆាបានហាមឃាត់សកម្មភាពនយោបាយ និងឃុំខ្លួនក្រុមអ្នកប្រឆាំងរដ្ឋាភិបាល។ នៅពេលដែលលោកអាបាឆាបានស្លាប់ក្នុងឆ្នាំ 1998 ឧត្តមសេនីយយោធាអាប់ឌុលសាឡាមី អាប៊ូបាកាបានដណ្តើមអំណាច ហើយបានសន្យាថានឹងបញ្ចប់ការគ្រប់គ្រងបែបយោធា។ លោកបានរក្សាពាក្យសន្យារបស់គាត់។ នៅឆ្នាំ 1999 ជនជាតិនីហ្សេរីយ៉ាបានបោះឆ្នោតជ្រើសរើសប្រធានាធិបតីស៊ីវិលជាលើកដំបូងរបស់ពួកគេក្នុងរយៈពេលជិត 20 ឆ្នាំ ដោយបានបោះឆ្នោតជ្រើសរើសលោកអ៊ូលូសេហ្គុន អ៊ូបាសានចូ។ នៅឆ្នាំ 2003 លោកអ៊ូបាសានចូត្រូវបានជ្រើសរើសម្តងទៀត។

ប្រធានាធិបតីស៊ីវិល៖ លោកអ៊ូបាសានចូគឺជាជនជាតិយ៉ូរូបាមកពីភាគនិរតីនៃប្រទេសនីហ្សេរីយ៉ា។ ក្នុងនាមជាអ្នករិះគន់របបយោធានីហ្សេរីយ៉ា លោកបានជាប់គុកចំនួន 3 ឆ្នាំ (1995-1998) ក្រោមការដឹកនាំរបស់លោកសានី អាបាឆា ។ ក្នុងនាមជាអតីតឧត្តមសេនីយ៍យោធាលោកអ៊ូបាសានចូទទួលបានការគាំទ្រពីយោធា។ លោកអ៊ូបាសានចូប្រឹងប្រែងយ៉ាងខ្លាំងដើម្បីធ្វើឱ្យប្រទេសនីហ្សេរីយ៉ារឹងមាំ និងរួបរួម។ លោកបានធ្វើឱ្យមានវឌ្ឍនភាពខ្លះក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ លោកក៏ព្យាយាមទាក់ទាញចំណាប់អារម្មណ៍របស់ពិភពលោកចំពោះតម្រូវការសម្រាប់ការបន្ធូរបន្ថយបំណុលសម្រាប់ប្រទេសនីហ្សេរីយ៉ា។ លោកអ៊ូបាសានចូបានមើលឃើញថា ការបន្ធូរបន្ថយបំណុលជាកត្តាចាំបាច់សម្រាប់ការសង្គ្រោះនៃភាពអត់ឃ្លាន និងអនាគតនៃលទ្ធិប្រជាធិបតេយ្យនៅអាហ្វ្រិក។ ប្រធានាធិបតីអ៊ូម៉ារូ យ៉ាអាឌូបានឡើងកាន់អំណាចនៅក្នុងការបោះឆ្នោតឆ្នាំ 2007 ដ៏ចម្រូងចម្រាស។ ក៏ដូចជាអ្នកណែនាំរបស់លោកគឺលោកអ៊ូបាសានចូ ប្រធានាធិបតីយ៉ាអាឌូបានប្រឈមមុខជាមួយនឹងបញ្ហាជាច្រើន។ ក្នុងនោះរួមមានសង្គ្រាម, អំពើហិង្សា, អំពើពុករលួយ, ភាពក្រីក្រ, ការបំពុលបរិស្ថាន, និងភាពអត់ឃ្លាន។ លើសពីនេះក្រុមសកម្មប្រយុទ្ធកំពុងគំរាមកំហែងដល់ការនាំចេញប្រេងរបស់ប្រទេសនីហ្សេរីយ៉ា និងកំណើនសេដ្ឋកិច្ច។

## 4. អាហ្វ្រិកខាងត្បូងក្រោមរបបប្រកាន់ពូជសាសន៍

នៅអាហ្វ្រិកខាងត្បូង ជម្លោះពូជសាសន៍គឺជាលទ្ធផលបណ្ដាលមកពីការគ្រប់គ្រងអាណានិគម។ តាំងពីដើមដំបូងដែលក្រោមការគ្រប់គ្រងរបស់ហូឡង់ និងអង់គ្លេស អាហ្វ្រិកខាងត្បូងត្រូវបានបែងចែកពូជសាសន៍។ ជនជាតិភាគតិចស្បែកសមួយក្រុមតូចបានគ្រប់គ្រងជនជាតិស្បែកខ្មៅដែលជាប្រជាជនភាគច្រើន។ នៅឆ្នាំ 1910 អាហ្វ្រិកខាងត្បូងបានទទួលស្វ័យភាពក្នុងការគ្រប់គ្រងដោយខ្លួនឯងដោយស្ថិតនៅក្រោមចក្រភពអង់គ្លេស។ នៅឆ្នាំ 1931 ពួកគេបានក្លាយជាសមាជិកឯករាជ្យនៃខំមិនវែលអង់គ្លេស។ ទោះបីជាប្រទេសអាហ្វ្រិកខាងត្បូងមានរដ្ឋាភិបាលអាស្រ័យរដ្ឋធម្មនុញ្ញក៏ដោយ រដ្ឋធម្មនុញ្ញបានផ្ដល់អំណាចដល់ជនជាតិស្បែកស និងបានបដិសេធសិទ្ធិរបស់ជនជាតិស្បែកខ្មៅដែលជាប្រជាជនភាគច្រើន។

ការប្រកាន់ពូជសាសន៍បែងចែកសង្គម៖ នៅឆ្នាំ 1948 គណបក្សជាតិបានឡើងកាន់អំណាចនៅអាហ្វ្រិកខាងត្បូង។ គណបក្សនេះបានលើកកម្ពស់ជនជាតិអាហ្វ្រីកាន័រ ឬជនជាតិហូឡង់នៅអាហ្វ្រិកខាងត្បូង។ គណបក្សនេះក៏បានបង្កើតគោលនយោបាយប្រកាន់ពូជសាសន៍ ដែលបែងចែកជាតិសាសន៍ឱ្យដាច់ដោយឡែកពីគ្នា។ រដ្ឋាភិបាលរបស់ជនជាតិស្បែកសបានហាមឃាត់ទំនាក់ទំនងសង្គមរវាងជនជាតិស្បែកស និងជនជាតិស្បែកខ្មៅ។ ពួកគេបានបង្កើតសាលារៀន, មន្ទីរពេទ្យ, និងសង្កាត់ដាច់ដោយឡែករវាងពួកស្បែកស និងស្បែកខ្មៅ។ នៅឆ្នាំ 1959 រដ្ឋាភិបាលជនជាតិស្បែកសបានបង្កើតតំបន់រក្សាទុក ដែលគេហៅថា មាតុភូមិ សម្រាប់ក្រុមស្បែកខ្មៅដែលជាប្រជាជនភាគច្រើននៅក្នុងប្រទេស។ ជនជាតិស្បែកខ្មៅត្រូវបានហាមឃាត់មិនឱ្យរស់នៅក្នុងតំបន់ពួកស្បែកស លើកលែងតែពួកគេជាអ្នកបម្រើ ឬកម្មកររបស់ជនជាតិស្បែកស។ គោលនយោបាយមាតុភូមិមិនមានតុល្យភាពឡើយ។ ទោះបីជាជនជាតិស្បែកខ្មៅមានចំនួនប្រហែល 75% នៃចំនួនប្រជាជនសរុបក៏ដោយ ក៏រដ្ឋាភិបាលបានកំណត់ទុកដីត្រឹមតែ 13% ប៉ុណ្ណោះសម្រាប់ពួកគេ។ ពួកស្បែកសបានរក្សាទុកដីល្អៗសម្រាប់ពួកគេ។

ការប្រឆាំងរបស់ជនជាតិស្បែកខ្មៅ៖ ជនជាតិស្បែកខ្មៅអាហ្វ្រិកខាងត្បូងបានប្រឆាំងនឹងការគ្រប់គ្រង ដោយជនជាតិភាគតិចស្បែកស។ នៅឆ្នាំ 1912 ពួកគេបានបង្កើតសមាជជាតិអាហ្វ្រិកដើម្បីធ្វើការប្រយុទ្ធដើម្បីសិទ្ធិរបស់ពួកគេ។ សមាជជាតិអាហ្វ្រិកបានរៀបចំការធ្វើកូដកម្ម និងធ្វើពហិការ ដើម្បីប្រឆាំងគោលនយោបាយប្រកាន់ពូជសាសន៍។ រដ្ឋាភិបាលបានហាមប្រាម សមាជជាតិអាហ្វ្រិក និងបានចាប់សមាជិកជាច្រើនដាក់គុក។ ម្នាក់នៅក្នុងចំណោមនោះគឺជាមេដឹកនាំសមាជជាតិអាហ្វ្រិកគឺលោកនេលសុន មេនដេឡា។ បញ្ហានៅតែបន្ត។ នៅឆ្នាំ 1976 កុប្បកម្មលើគោលនយោបាយសាលារៀន បានផ្ទុះឡើងនៅក្នុងតំបន់ទីប្រជុំជនរបស់ពួកខ្មៅ សូវេតូ ដែលបណ្ដាលឱ្យសិស្សប្រហែល 600 នាក់បានស្លាប់។ នៅឆ្នាំ 1977 ប៉ូលីសបានវាយមេដឹកនាំបាតុករដ៏មានប្រជាប្រិយលោក ស្ទេហ្វេន ប៊ីកូរហូតដល់ស្លាប់នៅខណៈពេលដែលលោកកំពុងជាប់ឃុំឃាំង។ នៅពេលដែលការតវ៉ាកើនឡើង រដ្ឋាភិបាលបានប្រកាសដាក់រដ្ឋក្នុងភាពអាសន្នទូទាំងប្រទេសនៅឆ្នាំ 1986។

## 5. ការតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ

នៅចុងទសវត្សរ៍ឆ្នាំ 1980 អាហ្វ្រិកខាងត្បូងស្ថិតនៅក្រោមសម្ពាធយ៉ាងខ្លាំងក្នុងការផ្លាស់ប្ដូរ។ អស់ជាច្រើនឆ្នាំមកនេះ ព្រះសង្ឃជនជាតិអាហ្វ្រិកខាងត្បូងស្បែកខ្មៅព្រះនាមដេសម៉ុន ទូទូ បានដឹកនាំយុទ្ធនាការសេដ្ឋកិច្ចប្រឆាំងនឹងការរើសអើងជាតិសាសន៍។ លោកបានស្នើឱ្យបរទេសទាំងឡាយឈប់ធ្វើជំនួញជាមួយអាហ្វ្រិកខាងត្បូង។ ជាការឆ្លើយតប ប្រទេសជាច្រើនបានដាក់កំហិតពាណិជ្ជកម្មជាមួយអាហ្វ្រិកខាងត្បូង។ ពួកគេក៏បានដាក់ប្រទេសអាហ្វ្រិកខាងត្បូងឱ្យនៅឯកោតាមវិធីផ្សេងទៀតផងដែរ ឧទាហរណ៍ ដោយហាមអាហ្វ្រិកខាងត្បូងពីការចូលរួមប្រកួតកីឡាអូឡាំពិក។ នៅក្នុងឆ្នាំ 1984 លោកទូទូបានឈ្នះរង្វាន់ណូបែលសន្តិភាពសម្រាប់វិធីសាស្ត្រអហិង្សារបស់លោក។

ជំហានដំបូង៖ នៅឆ្នាំ 1989 ជនជាតិស្បែកសអាហ្វ្រិកខាងត្បូងបានជ្រើសរើសលោកក្លឹកជាប្រធានាធិបតីថ្មី។ គោលដៅរបស់គាត់គឺធ្វើកំណែទម្រង់អាហ្វ្រិកខាងត្បូង និងបញ្ចប់ភាពឯកោរបស់ខ្លួន។ ក្នុងខែកុម្ភៈ ឆ្នាំ 1990 លោកបានទទួលស្គាល់សមាជជាតិអាហ្វ្រិក ហើយក៏បានដោះលែងលោកនេលសុន មេនដេឡាពីពន្ធនាគារផងដែរ។ សកម្មភាពដ៏សំខាន់ទាំងនេះ គឺជាសញ្ញាណនៃការចាប់ផ្ដើមឡើងនៃយុគសម័យថ្មីនៅអាហ្វ្រិកខាងត្បូង។ ក្នុងរយៈពេល 18 ខែបន្ទាប់ សភាអាហ្វ្រិកខាងត្បូងបានលុបចោលច្បាប់ប្រកាន់ពូជសាសន៍ ដែលបានបែងចែកទីកន្លែងសាធារណៈ និងរឹតបន្តឹងកម្មសិទ្ធិដីធ្លីសម្រាប់ពួកស្បែកខ្មៅ។ មេដឹកនាំពិភពលោកបានស្វាគមន៍ការផ្លាស់ប្ដូរទាំងនេះ ហើយបានចាប់ផ្ដើមបន្ធូរបន្ថយការរឹតបន្តឹងសេដ្ឋកិច្ចលើអាហ្វ្រិកខាងត្បូង។ ទោះបីជាបញ្ហាផ្នែកច្បាប់មួយចំនួនត្រូវបានដោះស្រាយក៏ដោយ ប៉ុន្តែបញ្ហាផ្សេងៗទៀតនៅតែបន្តមានរហូតដល់រដ្ឋធម្មនុញ្ញថ្មីចូលជាធរមាន។ ដំបូង ប្រទេសត្រូវបង្កើតរដ្ឋាភិបាលចម្រុះ។ បន្ទាប់ពីការចរចាជាយូរមក លោកប្រធានាធិបតីក្លឹកបានយល់ព្រមរៀបចំការបោះឆ្នោតជាសកលជាលើកដំបូងរបស់អាហ្វ្រិកខាងត្បូងក្នុងខែមេសា ឆ្នាំ 1994 ដែលមានប្រជាជនគ្រប់ជាតិសាសន៍ទាំងអស់អាចបោះឆ្នោតបាន។

ពួកភាគច្រើនដឹកនាំប្រទេស៖ ក្នុងចំណោមបេក្ខជនប្រធានាធិបតីរួមមានលោកក្លឹក និងលោកបនេលសុន មេនដេឡា។ នៅអំឡុងយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សសេរីភាពអ៊ីកាថាដែលជាគណបក្សប្រជែងនឹងគណបក្សសមាជជាតិអាហ្វ្រិក បានគំរាមក្នុងការបង្អាក់ដំណើរការបោះឆ្នោតនេះ។ យ៉ាងណាក៏ដោយ ការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូន។ ប្រជាជនអាហ្វ្រិកខាងត្បូងគ្រប់ជាតិសាសន៍ទាំងអស់បានឈររង់ចាំជាជួរដ៏វែងដោយសន្តិវិធីដើម្បីរង់ចាំការបោះឆ្នោត។ ដោយមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលគណបក្សសមាជជាតិអាហ្វ្រិក ទទួលបានសំឡេង 63% នៃការបោះឆ្នោត។ ពួកគេបានឈ្នះអាសនៈចំនួន 252 ក្នុងចំណោមអាសនៈចំនួន 400 ក្នុងរដ្ឋសភា។ លោកមេនដេឡា ត្រូវបានជ្រើសរើសជាប្រធានាធិបតី។ លោកមេនដេឡាបានចុះចេញពីដំណែងនៅឆ្នាំ 1999 ប៉ុន្តែរដ្ឋាភិបាលប្រជាធិបតេយ្យរបស់ប្រទេសនេះនៅតែបន្ត។

រដ្ឋធម្មនុញ្ញថ្មីនៅឆ្នាំ 1996 ៖ បន្ទាប់ពីការជជែកពិភាក្សាគ្នាយ៉ាងច្រើន សមាជិកសភាអាហ្វ្រិកខាងត្បូងបានអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយដែលមានលក្ខណៈប្រជាធិបតេយ្យជាងមុន។ ធម្មនុញ្ញថ្មីនេះធានាដល់សិទ្ធិស្មើគ្នាសម្រាប់

ប្រជាពលរដ្ឋទាំងអស់។ រដ្ឋធម្មនុញ្ញរួមបញ្ចូលច្បាប់អំពីសិទ្ធិដែលយកគំរូតាមច្បាប់អំពីសិទ្ធិរបស់សហរដ្ឋអាមេរិក។ ការផ្លាស់ប្តូរនយោបាយដែលអាហ្វ្រិកខាងត្បូងបានសម្រេច បានផ្តល់ឱ្យប្រជាជនដទៃទៀតនៅជុំវិញពិភពលោកនូវក្តីសង្ឃឹមដ៏អស្ចារ្យសម្រាប់អនាគតនៃលទ្ធិប្រជាធិបតេយ្យ។

ប្រទេសអាហ្វ្រិកខាងត្បូងនាពេលបច្ចុប្បន្ន៖ ក្នុងឆ្នាំ 1999 មន្ត្រីរបស់គណបក្សសមាជជាតិអាហ្វ្រិកលោកថាបូ អ៊ឹមបេគី បានទទួលជ័យជំនះនៅក្នុងការបោះឆ្នោតប្រធានាធិបតី ដែលជាការផ្លាស់ប្តូរអំណាចដោយសន្តិវិធី។ នៅពេលដែលលោកអ៊ឹមបេគីចូលកាន់តំណែង លោកបានប្រឈមទៅនឹងបញ្ហាធ្ងន់ធ្ងរមួយចំនួន។ បញ្ហាទាំងនោះរាប់បញ្ចូលទាំងអត្រាឧក្រិដ្ឋកម្មខ្ពស់ ដោយអត្រានៃការចាប់រំលោភ និងឃាតកម្មនៅអាហ្វ្រិកខាងត្បូងស្ថិតក្នុងចំណោមអត្រាដែលខ្ពស់បំផុតក្នុងពិភពលោក។ ភាពអត់ការងារធ្វើមានប្រហែល 40% ក្នុងចំណោមពួកស្បែកខ្មៅនៅអាហ្វ្រិកខាងត្បូង ហើយប្រហែល 60% រស់នៅក្រោមកម្រិតនៃភាពក្រីក្រ។ លើសពីនេះ ការធ្លាក់ចុះនៃសេដ្ឋកិច្ចបានបង្អាក់ការវិនិយោគបរទេស។ លោកអ៊ឹមបេគីបានលើកកម្ពស់គោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី ដើម្បីជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់អាហ្វ្រិកខាងត្បូង និងលើកទឹកចិត្តអ្នកវិនិយោគបរទេស។ ក្នុងឆ្នាំ 2002 អាហ្វ្រិកខាងត្បូងបានចូលរួមក្នុងការចរចា ដើម្បីបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសមួយចំនួនជុំវិញពិភពលោក ក្នុងនោះរួមទាំងសហភាពអឺរ៉ុប ក៏ដូចជាប្រទេសជប៉ុន, កាណាដា, និងសហរដ្ឋអាមេរិក។ ទាំងនេះគឺជាការប៉ុនប៉ងមួយក្នុងការបើកសេដ្ឋកិច្ចអាហ្វ្រិកខាងត្បូង ឱ្យមានការប្រកួតប្រជែង និងការវិនិយោគពីបរទេស និងការលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការងារ។ បញ្ហាដ៏ធំបំផុតមួយដែលអាហ្វ្រិកខាងត្បូងកំពុងប្រឈមមុខគឺជំងឺអេដស៍។ ការប៉ាន់ប្រមាណមួយចំនួនបានសន្និដ្ឋានថា ជនជាតិអាហ្វ្រិកខាងត្បូង 6 លាននាក់ទំនងជាស្លាប់ដោយសារជំងឺអេដស៍នៅឆ្នាំ 2010 ។ លោកអ៊ឹមបេគីបានជំទាស់ទៅនឹងការអះអាងដែលថាជំងឺអេដស៍គឺបណ្តាលមកពីមេរោគអេដអាយវី។ គំនិតរបស់លោកបាននាំឱ្យឱ្យអាហ្វ្រិកខាងត្បូងប្រឆាំងជាមួយនឹងការយល់ស្របខាងវិទ្យាសាស្ត្រនៅទូទាំងពិភពលោក។ កាសែតញូវយ៉កថាមបាននិយាយថា លោកអ៊ឹមបេគីស្ថិតនៅក្នុងគ្រោះថ្នាក់ ដោយលោកអាចធ្វើឱ្យខូចខាតដល់ "ការងារល្អទាំងអស់របស់លោកជាមួយនឹងជំហររបស់លោកលើជំងឺអេដស៍" ។ នៅក្នុងមេរៀនទី 3 អ្នកនឹងបានអានពីរបៀបដែលលទ្ធិប្រជាធិបតេយ្យបានផ្លាស់ប្តូរផ្នែកមួយផ្សេងទៀតនៃពិភពលោកជាពិសេសសហភាពសូវៀត-កុំម្មុយនីស្ត។

# មេរៀនទី 3៖ ការដួលរលំនៃសហភាពសូវៀត

## 1. ហ្គោបាឆេវធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ

នាយករដ្ឋមន្ត្រីសូវៀតឡេអូនីដ ប្រេស្នេវ និងការិយាល័យនយោបាយដែលជាគណៈកម្មាធិការកាន់អំណាចនៃបក្សកុំម្មុយនីស្ត បានបង្ក្រាបលើក្រុមប្រឆាំងនយោបាយទាំងឡាយ។ ក្រុមអ្នកត្រួតពិនិត្យ សម្រេចថាតើអ្នកនិពន្ធអាចបោះពុម្ពផ្សាយអ្វីខ្លះ។ បក្សកុំម្មុយនីស្តក៏រឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិ និងជំនឿសាសនាផងដែរ។ បន្ទាប់ពីការស្លាប់របស់លោកប្រេស្នេវក្នុងឆ្នាំ 1982 ភាពជាអ្នកដឹកនាំដ៏ចំណាស់របស់សហភាពសូវៀតបានព្យាយាមក្នុងការបន្តកាន់អំណាច។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្នងតំណែងបន្តបន្ទាប់ទាំង 2 នាក់របស់លោកប្រេស្នេវម្នាក់ៗបានស្លាប់បន្ទាប់ពីបានកាន់តំណែងបានប្រហែលមួយឆ្នាំប៉ុណ្ណោះ។ តើអ្នកណានឹងបន្តតំណែងពីពួកគេ?

អ្នកដឹកនាំវ័យក្មេង៖ ដើម្បីឆ្លើយសំណួរនោះ ការិយាល័យនយោបាយបានពិភាក្សាគ្នាក្នុងចំណោមមនុស្សចំនួន 2 រូប។ ម្នាក់ក្នុងចំណោមនោះគឺលោកមីខាអ៊ីល ហ្គោបាឆេវ។ អ្នកគាំទ្ររបស់លោកហ្គោបាឆេវបានសរសើរចំពោះយុវភាព, ថាមពល, និងជំនាញនយោបាយរបស់លោក។ ជាមួយនឹងការគាំទ្ររបស់ពួកគេ លោកហ្គោបាឆេវបានក្លាយជាអគ្គលេខាធិការថ្មីរបស់គណបក្ស។ ក្នុងការជ្រើសរើសគាត់ សមាជិកការិយាល័យនយោបាយមិនបានដឹងថាពួកគេកំពុងជម្រុញបដិវត្តន៍ស៊ើមួយផ្សេងទៀតទេ។ ប្រជាជនសូវៀតបានស្វាគមន៍ចំពោះការបោះឆ្នោតជ្រើសរើសលោកហ្គោបាឆេវ។ នៅក្នុងអាយុ 54 ឆ្នាំលោកគឺជាមេដឹកនាំសូវៀតក្មេងបំផុតចាប់តាំងពីលោកស្តាលីនមក។ លោកហ្គោបាឆេវគ្រាន់តែជាកុមារប៉ុណ្ណោះនៅអំឡុងពេលនៃការបោសសម្អាតយ៉ាងឃោរឃៅរបស់ស្តាលីនចំពោះសមាជិកបក្សដែលមានគំនិតឯករាជ្យ។ ខុសពីមេដឹកនាំសូវៀតផ្សេងទៀត លោកហ្គោបាឆេវបានសម្រេចចិត្តក្នុងការអនុវត្តគំនិតថ្មី។

ក្លាស់នូសត៍ជំរុញឱ្យមានការបើកចំហរ៖ មេដឹកនាំសូវៀតពីមុនបានគ្រប់គ្រងរដ្ឋបែបផ្តាច់ការ។ ពួកគេបានជម្រុញឱ្យមានភាពស្ងៀមស្ងាត់ និងបំបាក់ទឹកចិត្តប្រជាជនមិនឱ្យធ្វើសកម្មភាពដោយខ្លួនឯង។ ជាលទ្ធផល សង្គមសូវៀតហាក់ដូចជាមានការផ្លាស់ប្តូរតិចតួច ហើយសេដ្ឋកិច្ចសូវៀតនៅទ្រឹង។ លោកហ្គោបាឆេវបានដឹងថា កំណែទម្រង់សេដ្ឋកិច្ច និងសង្គមមិនអាចកើតឡើងបានទេ បើគ្មានលំហូរនៃគំនិត និងព័ត៌មានដោយសេរី។ នៅឆ្នាំ 1985 គាត់បានប្រកាសគោលនយោបាយដែលគេស្គាល់ថាក្លាស់នូសត៍ ឬបើកចំហ។ ក្លាស់នូសត៍បាននាំមកនូវការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ រដ្ឋាភិបាលបានអនុញ្ញាតឱ្យបើកព្រះវិហារ។ ពួកគេបានដោះលែងអ្នកប្រឆាំងចេញពីពន្ធនាគារ និងអនុញ្ញាតឱ្យបោះពុម្ពសៀវភៅដោយអ្នកនិពន្ធដែលត្រូវបានហាមឃាត់ពីមុនមក។ អ្នកយកព័ត៌មានបានស៊ើបអង្កេតបញ្ហា និងបានរិះគន់មន្ត្រីរដ្ឋាភិបាល។

## 2. កំណែទម្រង់សេដ្ឋកិច្ច និងនយោបាយ

ការបើកចំហថ្មីនេះបានអនុញ្ញាតឱ្យពលរដ្ឋសូវៀតអាចតិចតៀនអំពីបញ្ហាសេដ្ឋកិច្ច។ អ្នកប្រើប្រាស់តវ៉ាថាពួកគេត្រូវឈរតម្រង់ជួរដើម្បីទិញម្ហូបអាហារ និងសម្ភារៈប្រើប្រាស់ចំបាច់ផ្សេងៗទៀត។

ការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ច៖ លោកហ្គោបាឆេវបានស្តីបន្ទោសបញ្ហាទាំងនេះលើប្រព័ន្ធគ្មានប្រសិទ្ធភាពនៃផែនការកណ្តាលរបស់សហភាពសូវៀត។ នៅក្រោមផែនការកណ្តាល មន្ត្រីបក្សបានប្រាប់ពួកអ្នកគ្រប់គ្រងកសិដ្ឋាន និងរោងចក្រថាតើត្រូវផលិតក្នុងចំនួនប៉ុន្មាន។ ពួកមន្ត្រីទាំងនោះក៏បានប្រាប់ពួកអ្នកគ្រប់គ្រងថាតើប្រាក់ឈ្នួលប៉ុន្មានដែលត្រូវផ្តល់ឱ្យកម្មករ និងតម្លៃប៉ុន្មានដែលត្រូវលក់។ ដោយសារបុគ្គលម្នាក់ៗមិនអាចបង្កើនប្រាក់ឈ្នួលរបស់ពួកគេបាន ហើយផលិតកម្មកាន់តែច្រើន ពួកគេមានហេតុផលតិចតួចណាស់នៅក្នុងការបង្កើនប្រសិទ្ធភាព។ នៅឆ្នាំ 1985 លោកហ្គោបាឆេវបានណែនាំគំនិតប៉េរ៉េស្ត្រូយកា ឬការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ច។ នៅឆ្នាំ 1986 គាត់បានធ្វើកំណែទម្រង់ដើម្បីធ្វើឱ្យសេដ្ឋកិច្ចសូវៀតរស់ឡើងវិញ។ អ្នកគ្រប់គ្រងក្នុងតំបន់ទទួលបានសិទ្ធិអំណាចកាន់តែខ្លាំងលើកសិដ្ឋាន និងរោងចក្ររបស់ពួកគេ ហើយប្រជាជនត្រូវបានអនុញ្ញាតឱ្យបើកអាជីវកម្មឯកជនខ្នាតតូចៗ។ គោលដៅរបស់លោកហ្គោបាឆេវគឺមិនមែនដើម្បីបោះបង់ចោលលទ្ធិកុំម្មុយនីស្តទេ ប៉ុន្តែដើម្បីធ្វើឱ្យប្រព័ន្ធសេដ្ឋកិច្ចកាន់តែមានប្រសិទ្ធភាព និងផលិតភាព។

ប្រជាធិបតេយ្យនីយកម្មបើកចំហរប្រព័ន្ធនយោបាយ៖ លោកហ្គោបាឆេវក៏បានដឹងដែរថា ដើម្បីឱ្យសេដ្ឋកិច្ចប្រសើរឡើង បក្សកុំម្មុយនីស្តនឹងត្រូវបន្ធូរបន្លយការក្តាប់អំណាចរបស់ខ្លួនលើសង្គម និងនយោបាយសូវៀត។ នៅឆ្នាំ 1987 គាត់បានបង្ហាញពីគោលនយោបាយថ្មីទី 3 ដែលហៅថាប្រជាធិបតេយ្យនីយកម្ម។ វាគឺជាការបើកប្រព័ន្ធនយោបាយជាបណ្តើរៗ។ ផែនការនេះបានស្នើឱ្យមានការបោះឆ្នោតជ្រើសរើសស្ថាប័ននីតិប្បញ្ញត្តិថ្មី។ កាលពីមុនអ្នកបោះឆ្នោតជ្រើសរើសបានតែបេក្ខជនដែលត្រូវបានបក្សកុំម្មុយនីស្តជ្រើសរើសតែប៉ុណ្ណោះ។ ឥឡូវនេះ អ្នកបោះឆ្នោតអាចជ្រើសរើសបេក្ខជនពីបញ្ជីសម្រាប់ការិយាល័យនីមួយៗ។ ការបោះឆ្នោតបានធ្វើឱ្យមានការភ្ញាក់ផ្អើលជាច្រើន។ នៅកន្លែងជាច្រើន អ្នកបោះឆ្នោតជ្រើសរើសបេក្ខជនដែលមិនសូវស្គាល់ និងអ្នកកែទម្រង់ ជាជាងជ្រើសរើសមន្ត្រីបក្សដែលមានអំណាច។

គោលនយោបាយការបរទេស៖ គោលនយោបាយការបរទេសសូវៀតក៏បានផ្លាស់ប្តូរផងដែរ។ ដើម្បីប្រកួតប្រជែងផ្នែកយោធាជាមួយសហភាពសូវៀត ប្រធានាធិបតីរ៉ូណាល់ រីហ្គេនបានចាប់ផ្តើមការស្ថាបនាយោធាដែលមានតម្លៃថ្លៃបំផុតក្នុងប្រវត្តិសាស្ត្រសម័យសន្តិភាព ដែលមានតម្លៃជាង 2 ពាន់ពាន់លានដុល្លារ។ ក្រោមសម្ពាធពីការចំណាយយោធារបស់សហរដ្ឋអាមេរិក លោកហ្គោបាឆេវបានដឹងថាសេដ្ឋកិច្ចសូវៀតមិនអាចមានលទ្ធភាពទិញអាវុធថ្លៃៗបានទេ។ ការគ្រប់គ្រងលើអាវុធបានក្លាយជាអាទិភាពចម្បងមួយរបស់លោកហ្គោបាឆេវ។ នៅខែធ្នូ ឆ្នាំ 1987 លោក និងលោករីហ្គេនបានចុះហត្ថលេខាលើសន្ធិសញ្ញាកងកម្លាំងនុយក្លេអ៊ែរកម្រិតមធ្យម។ សន្ធិសញ្ញានេះបានហាមប្រាមកាំជ្រួចនុយក្លេអ៊ែរដែលមានរយៈចម្ងាយពី 300 ទៅ 3400 ម៉ាយ។

### 3. សហភាពសូវៀតប្រឈមមុខនឹងភាពចលាចល

គំនិតថ្មីរបស់លោកហ្គោបាឆេវ បាននាំឱ្យលោកគាំទ្រដល់ចលនានៃការធ្វើកំណែទម្រង់ទាំងប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយនៅក្នុងសហភាពសូវៀត។ កម្លាំងដ៏មានអំណាចសម្រាប់លទ្ធិប្រជាធិបតេយ្យកំពុងស្ថាបនានៅក្នុងប្រទេស ហើយលោកហ្គោបាឆេវបានសម្រេចចិត្តថាមិនប្រឆាំងនឹងការធ្វើកំណែទម្រង់ឡើយ។ ក្លាស់ណូសត៍, ប៉េរ៉េ

ស្ត្រួយកា, និងលទ្ធិប្រជាធិបតេយ្យគឺជាមធ្យោបាយដើម្បីធ្វើកំណែទម្រង់។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើកំណែទម្រង់ដើម្បីកែប្រែសហភាពសូវៀត នៅទីបំផុតបាននាំទៅដល់ការបែកបាក់គ្នា។ ជនជាតិផ្សេងៗនៅក្នុងសហភាពសូវៀតបានចាប់ផ្តើមស្នើឱ្យមានសេរីភាពសម្រាប់ពួកគេ។ មានក្រុមជនជាតិភាគតិចជាង 100 ក្រុមកំពុងរស់នៅក្នុងសហភាពសូវៀត។ ជនជាតិរុស្ស៊ីគឺជាក្រុមធំជាងគេ និងមានឥទ្ធិពលបំផុត។ ទោះយ៉ាងណាក៏ដោយ ប្រជាជនដែលមិនមែនជាជនជាតិរុស្ស៊ី គឺជាប្រជាជនភាគច្រើននៅក្នុងសាធារណរដ្ឋសូវៀតចំនួន 14 ។ ភាពតានតឹងជាតិសាសន៍បានផ្ទុះឡើងនៅក្នុងសង្គមសូវៀត។ នៅពេលដែលកំណែទម្រង់បានបន្ធូរបន្ថយការគ្រប់គ្រងអំណាចកណ្តាល ភាពចលាចលបានរីករាលដាលពាសពេញប្រទេស។ ក្រុមជាតិនិយមនៅហ្សកហ្ស៊ី, អ៊ុយក្រែន, និងម៉ុលដាវីបានទាមទារការគ្រប់គ្រងដោយខ្លួនឯង។ ប្រជាជនម៉ូស្លីមនៃអាស៊ីកណ្តាលរបស់សូវៀតបានស្នើឱ្យមានសេរីភាពខាងសាសនា។

លីទុយអានីសាកល្បងសមត្ថភាពហ្គោបាឆេវ៖ បញ្ហាប្រឈមដំបូងបានកើតមានឡើងនៅក្នុងប្រទេសនានានៅតំបន់បាល់ទិក ក្នុងនោះរួមមានប្រទេសលីទុយអានី, អេស្តូនី, និងឡាតវី។ សាធារណរដ្ឋទាំងនេះធ្លាប់ជារដ្ឋឯករាជ្យនៅចន្លោះសង្គ្រាមលោកទាំងពីរ រហូតដល់ពេលសូវៀតបានបញ្ចូលពួកគេជាឧបសម្ព័ន្ធក្នុងឆ្នាំ 1940 ។ 55 ឆ្នាំក្រោយមក នៅខែមីនា ឆ្នាំ 1990 លីទុយអានីបានប្រកាសឯករាជ្យរបស់ខ្លួន។ ដើម្បីព្យាយាមបង្ខំឱ្យប្រទេសនេះត្រឡប់ទៅក្នុងសហភាពសូវៀតវិញ លោកហ្គោបាឆេវបានបញ្ជាឱ្យហ៊ុំព័ទ្ធសេដ្ឋកិច្ចរបស់សាធារណរដ្ឋនេះ។ ទោះបីជាលោកហ្គោបាឆេវមានការស្ទាក់ស្ទើរក្នុងការប្រើប្រាស់វិធានការខ្លាំងជាងនេះក៏ដោយ ក៏លោកបារម្ភថាគំរូរបស់លីទុយអានីអាចនឹងលើកទឹកចិត្តឱ្យសាធារណរដ្ឋផ្សេងទៀតបំបែកខ្លួនចេញពីសូវៀត។ នៅខែមករា ឆ្នាំ 1991 កងទ័ពសូវៀតបានវាយប្រហារលើជនស៊ីវិលដែលគ្មានអាវុធនៅក្នុងរដ្ឋធានីរបស់ប្រទេសលីទុយអានី។ កងទ័ពបានសម្លាប់មនុស្ស 14 នាក់ និងរបួសរាប់រយនាក់។

លោកយ៉េលស៊ីនបានបរិហារលោកហ្គោបាឆេវ៖ ការវាយលុកនៅក្នុងប្រទេសលីទុយអានី និងកង្វះវឌ្ឍនភាពសេដ្ឋកិច្ចបានធ្វើឱ្យខូចប្រជាប្រិយភាពរបស់លោកហ្គោបាឆេវ។ ប្រជាជនបានស្វែងរកការដឹកនាំរបស់លោកបូរីសយ៉េលស៊ីន។ លោកគឺជាសមាជិកសភា និងជាអតីតអភិបាលក្រុងម៉ូស្គូ។ លោកយ៉េលស៊ីនបានរិះគន់ការបង្ក្រាបនៅក្នុងប្រទេសលីទុយអានី និងល្បឿនយឺតនៃការធ្វើកំណែទម្រង់។ នៅខែមិថុនា ឆ្នាំ 1991 ក្រុមអ្នកបោះឆ្នោតបានបោះឆ្នោតជ្រើសរើសលោកយ៉េលស៊ីនធ្វើជាប្រធានាធិបតីដំបូងគេរបស់សហព័ន្ធរុស្ស៊ី។ ទោះបីជាមានការប្រជែងគ្នារវាងលោកយ៉េលស៊ីន និងលោកហ្គោបាឆេវក៏ដោយ ពួកគេទាំងពីរបានប្រឈមមុខជាមួយនឹងមន្ត្រីកុំម្មុយនីស្តដូចគ្នា។ ក្រុមអ្នកអភិរក្សនិយមដែលប្រឆាំងនឹងកំណែទម្រង់ មានការខឹងសម្បារយ៉ាងខ្លាំងនៅពេលដែលលោកហ្គោបាឆេវបានបោះបង់តួនាទីរបស់សហភាពសូវៀតជាកម្លាំងលេចធ្លោនៅអឺរ៉ុបខាងកើត។ ពួកគេក៏ខ្លាចបាត់បង់អំណាច និងឯកសិទ្ធិរបស់ពួកគេផងដែរ។ មន្ត្រីទាំងនេះបានប្តេជ្ញាផ្តួលរំលំលោកហ្គោបាឆេវ និងលុបចោលការកែទម្រង់របស់លោក។

រដ្ឋប្រហារខែសីហា៖ ថ្ងៃទី 18 ខែសីហា ឆ្នាំ 1991 ពួកអ្នករឹងទទឹងបានឃុំខ្លួនលោកហ្គោបាឆេវនៅក្នុងផ្ទះវិស្សមកាលរបស់លោកនៅសមុទ្រខ្មៅ។ ពួកគេបានទាមទារឱ្យលោកលាលែងពីតំណែងជាប្រធានាធិបតីសូវៀត។ នៅព្រឹកព្រលឹមថ្ងៃបន្ទាប់ រថក្រោះ និងរថពាសដែករាប់រយគ្រឿងបានវិលចូលក្រុងម៉ូស្គូ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនសូវៀតបានបាត់បង់ការភ័យខ្លាចចំពោះគណបក្សកុំម្មុយនីស្ត។ ពួកគេមានឆន្ទៈការពារសេរីភាពរបស់ពួកគេ។ ក្រុមអ្នកតវ៉ាបានប្រមូលផ្តុំគ្នានៅអគារសភារុស្ស៊ី ជាកន្លែងដែលលោកយ៉េលស៊ីនធ្វើការ។ នៅពាក់កណ្តាលថ្ងៃត្រង់ លោកយ៉េលស៊ីនបានក្រោកឡើង ហើយបានឡើងលើរថក្រោះមួយ។ ខណៈដែលអ្នកគាំទ្ររបស់លោកបានអបអរសាទរ លោកយ៉េលស៊ីនបានប្រកាសថា "យើងប្រកាសថារាល់ការសម្រេចចិត្ត និងក្រឹត្យរបស់គណៈកម្មាធិការនេះគឺជាការខុសច្បាប់ ...យើងស្នើដល់ពលរដ្ឋនៃប្រទេសរុស្ស៊ី ...ទាមទារឱ្យប្រទេសនេះវិលទៅរកការបង្កើតធម្មនុញ្ញធម្មតាវិញ"។ នៅថ្ងៃទី 20 ខែសីហា ក្រុមអ្នករឹងទទឹងបានបញ្ជាឱ្យទាហានវាយប្រហារអគារសភា ប៉ុន្តែពួកគេបានបដិសេធ។ ការបដិសេធរបស់ពួកគេបានបង្វែរទិសដៅ។ នៅថ្ងៃទី 21 ខែសីហា យោធាបានដកកងកម្លាំងរបស់ខ្លួនចេញពីទីក្រុងម៉ូស្គូ។ នៅយប់នោះលោកហ្គោបាឆេវបានវិលត្រឡប់ទៅទីក្រុងម៉ូស្គូវិញ។

ការបញ្ចប់នៃសហភាពសូវៀត៖ ការប៉ុនប៉ងធ្វើរដ្ឋប្រហារបានបង្កឱ្យមានកំហឹងប្រឆាំងនឹងបក្សកុំម្មុយនីស្ត។ លោកហ្គោបាឆេវបានលាលែងពីតំណែងជាអគ្គលេខាធិការបក្សកុំម្មុយនីស្ត។ សភាសូវៀតបានបោះឆ្នោតបញ្ឈប់រាល់សកម្មភាពរបស់បក្សកុំម្មុយនីស្ត។ ដោយបានដណ្តើមអំណាចជាលើកដំបូងនៅឆ្នាំ 1917 ក្នុងរដ្ឋប្រហារដោគជ័យមួយ បក្សកុំម្មុយនីស្តឥឡូវនេះបានដួលរលំដោយសារតែរដ្ឋប្រហារបរាជ័យ។ រដ្ឋប្រហារក៏បានដើរតួនាទីយ៉ាងខ្លាំងមួយក្នុងការពន្លឿនការបែកបាក់នៃសហភាពសូវៀត។ អេស្តូនី និងឡាតវីបានប្រកាសឯករាជ្យរបស់ពួកគេភ្លាមៗ។ សាធារណរដ្ឋផ្សេងទៀតបានអនុវត្តតាមភ្លាមៗ។ ទោះបីជាលោកហ្គោបាឆេវបានអង្វរសុំឱ្យមានការរួបរួមក៏ដោយក៏គ្មាននរណាម្នាក់ស្តាប់លោកដែរ។ នៅដើមខែធ្នូ សាធារណរដ្ឋទាំង 15 បានប្រកាសឯករាជ្យ។ លោកយ៉េលស៊ីនបានជួបជាមួយមេដឹកនាំនៃសាធារណរដ្ឋផ្សេងទៀតដើម្បីធ្វើការសិក្សាជាថ្មីឡើងវិញ។ ពួកគេបានយល់ព្រមបង្កើត ខំមិនវែលនៃរដ្ឋឯករាជ្យ ដែលជាសហព័ន្ធធូរលុងមួយនៃអតីតទឹកដីសូវៀត។ មានតែសាធារណរដ្ឋបាល់ទិក និងហ្សកហ្ស៊ីប៉ុណ្ណោះដែលបដិសេធមិនចូលរួម។ ការបង្កើតខំមិនវែលនៃរដ្ឋឯករាជ្យបានឆ្លុះបញ្ចាំងពីការស្លាប់របស់សហភាពសូវៀត។ នៅថ្ងៃបុណ្យណូអែលឆ្នាំ 1991 លោកហ្គោបាឆេវបានប្រកាសលាលែងពីតំណែងជាប្រធានាធិបតីនៃសហភាពសូវៀតដោយសារវាត្រូវបានបញ្ចប់ ។

## 4. ប្រទេសរុស្ស៊ីក្រោមការដឹកនាំរបស់លោកបូរីស យ៉េលស៊ីន

ក្នុងនាមជាមេដឹកនាំសហព័ន្ធរុស្ស៊ីដ៏ធំមួយ លោកបូរីស យ៉េលស៊ីនឥឡូវនេះគឺជាឥស្សរជនដ៏មានឥទ្ធិពលបំផុតនៅក្នុងខំមិនវែលរដ្ឋឯករាជ្យ។ លោកប្រឈមមុខនឹងបញ្ហាជាច្រើន រួមទាំងសេដ្ឋកិច្ចដែលកំពុងបញ្ហា, ការប្រឆាំងផ្នែកខាងនយោបាយ, និងការធ្វើសង្គ្រាមដែលមិនមានប្រជាប្រិយភាព។

លោកយ៉េលស៊ីនប្រឈមមុខនឹងបញ្ហា៖ គោលដៅមួយរបស់លោកយ៉េលស៊ីនគឺការធ្វើកំណែទម្រង់សេដ្ឋកិច្ចរបស់រុស្ស៊ី។ លោកបានអនុវត្តផែនការមួយដែលគេស្គាល់ថាជា "ការដោះស្រាយដ៏តក់ស្លុត" ដែលជាការផ្លាស់ប្តូរ

សេដ្ឋកិច្ចភ្លាមៗទៅកាន់ទីផ្សារសេរី។ លោកយ៉េលស៊ីនបានកាត់បន្ថយរបាំងពាណិជ្ជកម្ម, ដកចេញនូវការគ្រប់គ្រងតម្លៃ, និងបញ្ចប់ការឧបត្ថម្ភធនដល់ឧស្សាហកម្មដែលគ្រប់គ្រងដោយរដ្ឋ។ ដំបូងឡើយ ផែនការនេះបានបន្តឱ្យមានការតក់ស្លុតជាជាងការដោះស្រាយ។ តម្លៃបានកើនឡើង ដោយចាប់ពីឆ្នាំ 1992 ដល់ឆ្នាំ 1994 អត្រាអតិផរណាជាមធ្យមមានចំនួន 800% ។ រោងចក្រជាច្រើនដែលពឹងផ្អែកលើប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលត្រូវកាត់បន្ថយផលិតកម្ម ឬបិទទាំងស្រុង។ បញ្ហានេះបានបណ្តាលឱ្យមនុស្សរាប់ពាន់នាក់បាត់បង់ការងារ។ នៅឆ្នាំ 1993 ប្រជាជនរុស្ស៊ីភាគច្រើនបានទទួលរងនូវការលំបាកផ្នែកសេដ្ឋកិច្ច។

បញ្ហាសេដ្ឋកិច្ចបានបញ្ឆេះវិបត្តិនយោបាយ៖ នៅខែតុលា ឆ្នាំ 1993 សមាជិកសភាបានប្រឆាំងនឹងគោលនយោបាយរបស់លោកយ៉េលស៊ីន បានបិទទ្វារឃុំខ្លួនឯងនៅក្នុងអគារសភា។ លោកយ៉េលស៊ីន បានបញ្ជាឱ្យកងទ័ពទម្លាក់គ្រាប់បែកលើអគារ ដោយបង្ខំឱ្យសមាជិកសភា និងក្រុមបះបោររាប់រយនាក់ចុះចាញ់។ មនុស្សជាច្រើនត្រូវបានសម្លាប់។ ក្រុមអ្នកប្រឆាំងបានចោទប្រកាន់លោកយ៉េលស៊ីថាបានអនុវត្តដូចជាជនផ្តាច់ការ។

ការបះបោរនៅឆេឈ្នា៖ បញ្ហារបស់លោកយ៉េលស៊ីនរួមមានសង្គ្រាមនៅតំបន់ឆេឈ្នា ជាតំបន់ដែលមានពួកម៉ូស្លីមរស់នៅភាគច្រើន ស្ថិតនៅភាគនិរតីនៃប្រទេសរុស្ស៊ី។ នៅឆ្នាំ 1991 ពួកឆេឈ្នាបានប្រកាសឯករាជ្យរបស់ខ្លួន ប៉ុន្តែលោកយ៉េលស៊ីនបានបដិសេធក្នុងការទទួលស្គាល់ការបំបែកខ្លួននេះ។ នៅឆ្នាំ 1994 លោកបានបញ្ជាឱ្យទាហានរុស្ស៊ីចំនួន 40,000 នាក់ចូលទៅក្នុងសាធារណរដ្ឋឆេឈ្នាដែលបានបំបែកខ្លួន។ កងកម្លាំងរុស្ស៊ីបានដុតកម្ទេចរដ្ឋធានីក្រូស្នីឱ្យរាបដល់ដី។ ដំណឹងអំពីការសម្លាប់ និងការបំផ្លិចបំផ្លាញបានបង្កឱ្យមានកំហឹងពេញប្រទេសរុស្ស៊ី។ ជាមួយនឹងការបោះឆ្នោតមកដល់ លោកយ៉េលស៊ីនបានព្យាយាមបញ្ចប់សង្គ្រាម។ នៅខែសីហា ឆ្នាំ 1996 ភាគីទាំង 2 បានចុះហត្ថលេខាលើបទឈប់បាញ់។ នៅឆ្នាំក្នុងនោះលោកយ៉េលស៊ីបានឈ្នះការបោះឆ្នោតឡើងវិញ។ ទោះយ៉ាងណាក៏ដោយ សង្គ្រាមបានផ្ទុះឡើងវិញម្តងទៀតរវាងរុស្ស៊ី និងឆេឈ្នា។ នៅឆ្នាំ 1999 នៅពេលដែលការប្រយុទ្ធគ្នាមានកាន់តែខ្លាំងឡើង លោកយ៉េលស៊ីនបានលាលែងពីតំណែង ហើយបានដាក់លោក វ្លាឌីមីរ ពូទីន ឱ្យធ្វើជាប្រធានាធិបតីស្តីទី។

## 5. ប្រទេសរុស្ស៊ីក្រោមការដឹកនាំរបស់លោកវ្លាឌីមៀរ ពូទីន

ការដោះស្រាយជាមួយនឹងការបះបោរនៅឆេឈ្នារបស់លោកពូទីន គឺជាសកម្មភាពដ៏ពេញនិយមមួយដែលបានជួយគាត់ឱ្យឈ្នះការបោះឆ្នោតប្រធានាធិបតីនៅក្នុងឆ្នាំ 2000 ។ យ៉ាងណាក៏ដោយ អំពើហិង្សានៅក្នុងតំបន់នៅតែបន្ត។

ពូទីនតស៊ូជាមួយពួកឆេឈ្នា៖ សង្គ្រាមរបស់លោកពូទីននៅឆេឈ្នា បានជម្រុញឱ្យពួកគេវេករចូលទៅក្នុងរដ្ឋធានីរបស់រុស្ស៊ី។ នៅខែតុលា ឆ្នាំ 2002 ឆេឈ្នាបានដណ្តើមកាន់កាប់រោងមហោស្រពនៅទីក្រុងម៉ូស្គូហើយមនុស្សជាង 150 នាក់បានស្លាប់នៅក្នុងប្រតិបត្តិការជួយសង្គ្រោះដោយកងកម្លាំងរុស្ស៊ី។ នៅពេលដែលសង្គ្រាមនៅឆេឈ្នាបានអូសបន្លាយ ការគាំទ្រដ៏ពេញនិយមរបស់ពលរដ្ឋរុស្ស៊ីចំពោះលោកពូទីនបានរសាត់ទៅ ហើយលោកពូទីន

បានងាកទៅគាបសង្កត់អ្នករិះគន់លោក។ ការបោះឆ្នោតនៅឆេឈ្នានៅក្នុងឆ្នាំ 2005 បានជួយស្តារសណ្តាប់ធ្នាប់ឡើងវិញ ហើយមកដល់ឆ្នាំ 2007 ការបះបោរមួយភាគធំបានស្ងប់ស្ងាត់។ ប៉ុន្តែការបះបោរនៅតែបន្ត។

បញ្ហាសេដ្ឋកិច្ច, នយោបាយ, និងសង្គម៖ ចាប់តាំងពីការដួលរលំនៃសហភាពសូវៀតមក ប្រទេសរុស្ស៊ីបានមើលឃើញពីការឡើងនៃភាពគ្មានផ្ទះសម្បែង, អំពើហិង្សាក្នុងគ្រួសារ, ភាពអត់ការងារធ្វើ, និងការថយចុះនៃអាយុសង្ឃឹមរស់។ អ្នកសង្កេតការណ៍មួយចំនួនបានងឿងឆ្ងល់ថា តើលទ្ធិប្រជាធិបតេយ្យរបស់រុស្ស៊ីអាចរស់បានដែរឬទេ? ប្រធានាធិបតីពូទីនមិនអាចឆ្លើយសំណួរនេះបានទេ។ ប្រទេសរុស្ស៊ីបាននិងកំពុងធ្វើដំណើរឆ្ពោះទៅរកការចូលរួមកាន់តែច្រើននៅក្នុងពាណិជ្ជកម្មពិភពលោក តាមរយៈការធ្វើទំនើបកម្មធនាគារ, ការធានារ៉ាប់រង, និង ច្បាប់ពន្ធដា។ ទន្ទឹមនឹងនេះ ការវាយប្រហារលើស្ថាប័នប្រជាធិបតេយ្យ ដូចជាសារព័ត៌មានសេរី មិនបានកសាងទំនុកចិត្តរបស់ពិភពលោកឡើយ។ ប្រវត្តិសាស្ត្ររុស្ស៊ី និងប្រទេសជិតខាងអឺរ៉ុបតែងតែមានទំនាក់ទំនងជាមួយគ្នា។ ភាពចលាចលនៅក្នុងសហភាពសូវៀតបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើតំបន់អឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត ដូចដែលអ្នកនឹងអាននៅមេរៀនបន្ទាប់។

# មេរៀនទី 4៖ ការផ្លាស់ប្តូរនៅអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត

## 1. កំណែទម្រង់នៅប៉ូឡូញ និងហុងគ្រី

មេដឹកនាំកុម្មុយនីស្តដែលចំណាស់ៗនៅអឺរ៉ុបបានទប់ទល់នឹងការធ្វើកំណែទម្រង់។ ទោះយ៉ាងណាក៏ដោយ កម្លាំងដ៏មានអំណាចសម្រាប់លទ្ធិប្រជាធិបតេយ្យត្រូវបានស្ថាបនាឡើងនៅក្នុងប្រទេសរបស់ពួកគេ។ កាលពីមុន ការគំរាមកំហែងពីអន្តរាគមន៍របស់សូវៀត បានរក្សាការគ្រប់គ្រងលើកម្លាំងបែបនេះ។ ឥឡូវនេះ លោកហ្គោបាឆេវ កំពុងនិយាយថាសហភាពសូវៀតនឹងមិនប្រឆាំងនឹងការកំណែទម្រង់ឡើយ។ ប៉ូឡូញ និងហុងគ្រីគឺជាប្រទេសដំបូងគេនៅអឺរ៉ុបខាងកើត ដែលទទួលយកស្មារតីនៃការធ្វើកំណែទម្រង់។ ក្នុងឆ្នាំ 1980 កម្មករប៉ូឡូញនៅរោងចក្រផលិតកប៉ាល់ដីដានស៍ បានធ្វើកូដកម្មទាមទារឱ្យរដ្ឋាភិបាលទទួលស្គាល់សហជីពរបស់ពួកគេ។ នៅពេលដែលប្រជាជនប៉ូឡូញរាប់លាននាក់គាំទ្រសកម្មភាពនេះ រដ្ឋាភិបាលបានយល់ព្រមតាមការទាមទាររបស់សហជីព។ មេដឹកនាំសហជីពលោកលេច វ៉ាឡេសាបានក្លាយជាវីរបុរសជាតិ។

សាមគ្គីភាពកម្ចាត់កុម្មុយនីស្ត៖ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំបន្ទាប់រដ្ឋាភិបាលប៉ូឡូញបានហាមឃាត់សហជីព ហើយបានប្រកាសច្បាប់អាជ្ញាសឹក។ បក្សកុម្មុយនីស្តបានមើលឃើញថា ការគ្រប់គ្រងដោយយោធាមិនអាចស្តារសេដ្ឋកិច្ចដែលបរាជ័យរបស់ប្រទេសប៉ូឡូញបានទេ។ នៅទសវត្សរ៍ឆ្នាំ 1980 ផលិតកម្មឧស្សាហកម្មបានធ្លាក់ចុះ ខណៈពេលដែលបំណុលបរទេសបានកើនឡើងដល់ជាង 40 ពាន់លានដុល្លារ។ ភាពមិនសប្បាយចិត្តរបស់សាធារណជនកាន់តែកើនឡើង ខណៈពេលដែលវិបត្តិសេដ្ឋកិច្ចកាន់តែអាក្រក់ទៅៗ។ នៅក្នុងខែសីហា ឆ្នាំ 1988 កម្មករដែលមានការមិនសប្បាយចិត្តបានឈប់ពីការងាររបស់ពួកគេ។ ពួកគេបានទាមទារឱ្យមានការលើកកម្ពស់ និងធ្វើឱ្យស្របច្បាប់នៃសហជីព។ មេដឹកនាំយោធា ឧត្តមសេនីយ៍ចារូហ្សេលស្គីបានយល់ព្រមជួបពិភាក្សាជាមួយមេដឹកនាំសហជីព។ នៅខែមេសា ឆ្នាំ 1989 លោកចារូហ្សេលស្គីបានធ្វើឱ្យស្របច្បាប់នូវសហជីព ហើយបានយល់ព្រមរៀបចំការបោះឆ្នោតដោយសេរីជាលើកដំបូងរបស់ប្រទេសប៉ូឡូញ ចាប់តាំងពីពួកកុម្មុយនីស្តឡើងកាន់អំណាច។ នៅក្នុងការបោះឆ្នោតអំឡុងឆ្នាំ 1989 និង 1990 ក្រុមអ្នកបោះឆ្នោតប៉ូឡូញបានបោះឆ្នោតប្រឆាំងនឹងពួកកុម្មុយនីស្ត ហើយបានជ្រើសរើសយ៉ាងលើសលប់នូវបេក្ខជនមកពីសហជីព។ ពួកគេបានបោះឆ្នោតជ្រើសរើសប្រធានាធិបតីលេច វ៉ាឡេសា។

ប៉ូឡូញបោះឆ្នោតទម្លាក់វ៉ាឡេសា៖ បន្ទាប់ពីក្លាយជាប្រធានាធិបតីនៅឆ្នាំ 1990 លោកលេច វ៉ាឡេសា បានព្យាយាមធ្វើឱ្យសេដ្ឋកិច្ចដែលក្ស័យធនរបស់ប្រទេសប៉ូឡូញមានជីវិតឡើងវិញ។ ក៏ដូចលោកបូរីស យ៉េលស៊ីនដែរ គាត់បានប្រើយុទ្ធសាស្ត្រនៃដំណោះស្រាយដ៏តក់ស្លុត ដើម្បីផ្លាស់ប្តូរប្រទេសប៉ូឡូញឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរី។ ក៏ដូចជានៅក្នុងប្រទេសរុស្ស៊ី អតិផរណា និងភាពអត់ការងារធ្វើបានកើនឡើង។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1990 សេដ្ឋកិច្ចកំពុងមានភាពប្រសើរឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនប៉ូឡូញជាច្រើននៅតែមិនសប្បាយចិត្តជាមួយនឹងល្បឿននៃវឌ្ឍនភាពសេដ្ឋកិច្ចនេះ។ នៅក្នុងការបោះឆ្នោតឆ្នាំ 1995 ពួកគេបានដកលោកវ៉ាឡេសាចេញពីតំណែង និងបានគាំទ្រអតីតមេដឹកនាំកុម្មុយនីស្តអាឡិចសាន់ឌឺ ក្វាស្នីវស្គី។

ប៉ូឡូញក្រោមការដឹកនាំរបស់លោកក្វាស្នីវស្គី៖ ប្រធានាធិបតីក្វាស្នីវស្គីបានដឹកនាំប្រទេសប៉ូឡូញក្នុងដំណើរការរបស់ខ្លួនដើម្បីជម្រុញឱ្យប្រទេសប៉ូឡូញក្លាយជាផ្នែកមួយនៃសហគមន៍អឺរ៉ុប។ នៅឆ្នាំ 1999 ប៉ូឡូញបានក្លាយជាសមាជិកពេញសិទ្ធិរបស់អង្គការណាតូ។ ក្នុងនាមជាសមាជិកអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (ណាតូ) ប្រទេសប៉ូឡូញបានផ្តល់ការគាំទ្រយ៉ាងខ្លាំងនៅក្នុងសង្គ្រាមប្រឆាំងនឹងអំពើភេរវកម្ម បន្ទាប់ពីការវាយប្រហារលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកនៅទីក្រុងញូវយ៉កកាលពីថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 2001។ នៅក្នុងឆ្នាំ 2005 លោកលេចកាហ្ស៊ីនស្គីសនៃគណបក្សអភិរក្សច្បាប់ និងយុត្តិធម៌បានឈ្នះតំណែងជាប្រធានាធិបតី។ នៅឆ្នាំបន្ទាប់ ប្អូនប្រុសភ្លោះរបស់លោកកាហ្ស៊ីនស្គីស គឺលោកចារ៉ូស្លាវបានក្លាយជានាយករដ្ឋមន្ត្រី។ លោកកាហ្ស៊ីនស្គីសបានប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដ៏ខ្លាំងក្លារបស់ប្រទេសប៉ូឡូញ, ប្រឆាំងនឹងការធ្វើកំណែទម្រង់យ៉ាងឆាប់រហ័សឆ្ពោះទៅរកទីផ្សារសេរី, និងបានគាំទ្រយុទ្ធនាការដឹកនាំដោយអាមេរិកនៅក្នុងប្រទេសអ៊ីរ៉ាក់។

ការរំលាយកុំម្មុយនីស្តនៅហុងគ្រី៖ បំផុសគំនិតដោយការផ្លាស់ប្តូរនៅក្នុងប្រទេសប៉ូឡូញ មេដឹកនាំហុងគ្រីបានចាប់ផ្តើមកម្មវិធីកំណែទម្រង់ដ៏ធំមួយ។ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្រុមអ្នកធ្វើកំណែទម្រង់បានលើកទឹកចិត្តសហគ្រាសឯកជន និងអនុញ្ញាតឱ្យមានទីផ្សារភាគហ៊ុនតូចមួយដំណើរការ។ រដ្ឋធម្មនុញ្ញថ្មីបានអនុញ្ញាតឱ្យមានប្រព័ន្ធពហុបក្សដែលមានការបោះឆ្នោតដោយសេរី។ ល្បឿននៃការផ្លាស់ប្តូរកាន់តែលឿននៅពេលដែលអ្នកកំណែទម្រង់ជ្រុលនិយមបានចូលកាន់សមាជបក្សកុំម្មុយនីស្តក្នុងខែតុលា ឆ្នាំ 1989 ។ ពួកជ្រុលនីយមបានទម្លាក់មេដឹកនាំគណបក្សកុំម្មុយនីស្ត ហើយបន្ទាប់មករំលាយគណបក្សខ្លួនឯងចោល។ នេះជាលើកដំបូងមួយ៖ បក្សកុំម្មុយនីស្តនៅអឺរ៉ុបមួយបានបោះឆ្នោតរំលាយខ្លួនឯង។ មួយឆ្នាំក្រោយមក នៅក្នុងការបោះឆ្នោតជាតិ ក្រុមអ្នកបោះឆ្នោតរបស់ប្រទេសនេះបានជ្រើសរើសរដ្ឋាភិបាលដែលមិនមែនកុំម្មុយនីស្តឡើងកាន់អំណាច។ នៅឆ្នាំ 1994 គណបក្សសង្គមនិយមមួយ ដែលភាគច្រើនបង្កើតឡើងដោយអតីតជនកុំម្មុយនីស្ត បានឈ្នះអាសនៈភាគច្រើននៅក្នុងសភានៃប្រទេសហុងគ្រី។ គណបក្សសង្គមនិយម និងគណបក្សប្រជាធិបតេយ្យបានបង្កើតសម្ព័ន្ធភាពជាមួយគ្នាដើម្បីគ្រប់គ្រងរដ្ឋាភិបាល។ នៅក្នុងការបោះឆ្នោតសភាក្នុងឆ្នាំ 1998 គណបក្សសេរីនិយមមួយបានទទួលអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា។ នៅឆ្នាំ 1999 ហុងគ្រីបានចូលរួមជាសមាជិកពេញសិទ្ធិក្នុងអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង។ នៅឆ្នាំ 2001 ភាគយឺតយ៉ាវនៃសេដ្ឋកិច្ចទូទៅមួយបានកើតមានឡើងនៅក្នុងប្រទេសហុងគ្រី។ បញ្ហានេះកើតមានឡើងដោយសារតែការនាំចេញមានភាពទន់ខ្សោយ, ការធ្លាក់ចុះនៃការវិនិយោគបរទេស, និងការចំណាយលើសលប់លើប្រាក់សោធនរដ្ឋ និងការបង្កើនប្រាក់ឈ្នួលអប្បបរមា។

## 2. អាល្លឺម៉ង់បង្រួបបង្រួមគ្នាឡើងវិញ

ខណៈពេលដែលប្រទេសប៉ូឡូញ និងហុងគ្រីកំពុងធ្វើដំណើរឆ្ពោះទៅរកការធ្វើកំណែទម្រង់ មេដឹកនាំគណបក្សអាល្លឺម៉ង់ខាងកើតដែលមានអាយុ 77 ឆ្នាំគឺលោកអេរិច ហូនេចគ័របានប្រានចោលការធ្វើកំណែទម្រង់ដែលលោកយល់ថាមានភាពមិនចាំបាច់។ បន្ទាប់មកនៅឆ្នាំ 1989 ប្រទេសហុងគ្រីបានអនុញ្ញាតឱ្យក្រុមអ្នកទេសចរវិស្សមកាលរបស់អាល្លឺម៉ង់ខាងកើតឆ្លងកាត់ព្រំដែនរបស់ខ្លួនចូលទៅកាន់ប្រទេសអូទ្រីស។ នៅទីនោះក្រុមអ្នកទេសចរអាចធ្វើ

ដំណើរបន្តទៅកាន់ប្រទេសអាល្លឺម៉ង់ខាងលិចបាន។ ជនជាតិអាល្លឺម៉ង់ខាងកើតរាប់ពាន់នាក់បានចាប់យកផ្លូវរត់គេចថ្មីនេះទៅកាន់អាឡឺម៉ង់ភាគខាងលិច។

ការដួលរលំនៃជញ្ជាំងប៊ែរឡាំង៖ ជាការឆ្លើយតបរដ្ឋាភិបាលអាល្លឺម៉ង់ខាងកើតបានបិទព្រំដែនរបស់ខ្លួនទាំងស្រុង។ នៅខែតុលា ឆ្នាំ 1989 បាតុកម្មដ៏ធំបានផ្ទុះឡើងនៅក្នុងទីក្រុងនានាទូទាំងប្រទេសអាល្លឺម៉ង់ខាងកើត។ ក្រុមអ្នកតវ៉ាទាមទារសិទ្ធិធ្វើដំណើរដោយសេរី ហើយក្រោយមកបានបន្ថែមការទាមទារឱ្យមានការបោះឆ្នោតដោយសេរី។ លោកហូនេចក័របានបាត់បង់សិទ្ធិអំណាចនៅក្នុងគណបក្ស ហើយលោកបានលាលែងពីតំណែងនៅថ្ងៃទី 18 ខែតុលា។ នៅខែមិថុនា ឆ្នាំ 1987 ប្រធានាធិបតីរីហ្គេនបានឈរនៅមុខជញ្ជាំងប៊ែរឡាំង ហើយបានទាមទារថា "លោកហ្គោបាឆេវសូមរុះជញ្ជាំងនេះចេញ!" 2 ឆ្នាំក្រោយមក ជញ្ជាំងខិតជិតទៅរកការដួលរលំ។ មេដឹកនាំអាល្លឺម៉ង់ខាងកើតថ្មីលោកអេហ្គូន ក្រេនស៍ បានលេងល្បែងយ៉ាងក្លាហានដោយអះអាងថាលោកអាចស្តារស្ថិរភាពឡើងវិញ ដោយអនុញ្ញាតឱ្យមនុស្សចាកចេញពីប្រទេសអាល្លឺម៉ង់ខាងកើត។ នៅថ្ងៃទី 9 ខែវិច្ឆិកា ឆ្នាំ 1989 គាត់បានបើកជញ្ជាំងប៊ែរឡាំង។ ទីក្រុងប៊ែរឡាំងដែលបែកគ្នាជាយូរមកហើយបានបើកឡើងវិញ ហើយប្រជាជនបានអបអរយ៉ាងសប្បាយរីករាយ។ ល្បែងដ៏អស្ចារ្យរបស់លោកក្រេនស៍ ដើម្បីជួយសង្គ្រោះលទ្ធិកុំម្មុយនីស្តនេះមិនដំណើរការឡើយ។ នៅចុងឆ្នាំ 1989 បក្សកុំម្មុយនីស្តអាល្លឺម៉ង់ខាងកើតរំលាយខ្លួន។

ការបង្រួបបង្រួម៖ ជាមួយនឹងការដួលរលំនៃលទ្ធិកុំម្មុយនីស្តនៅអាឡឺម៉ង់ខាងកើត ជនជាតិអាល្លឺម៉ង់ជាច្រើនបានចាប់ផ្តើមនិយាយអំពីការបង្រួបបង្រួមអាល្លឺម៉ង់ទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយ ចលនាសម្រាប់ការបង្រួបបង្រួមគ្នាបានធ្វើឱ្យមនុស្សជាច្រើនមានការព្រួយបារម្ភ ដោយមានការភ័យខ្លាចអំពីការបង្រួបបង្រួមអាល្លឺម៉ង់។ អធិការបតីអាល្លឺម៉ង់ខាងលិច លោកហេលមូត ខូល បានធានាដល់មេដឹកនាំពិភពលោកថា អាល្លឺម៉ង់បានរៀនសូត្រពីអតីតកាល។ ឥឡូវនេះពួកគេបានប្តេជ្ញាចិត្តចំពោះលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ ការធានារបស់លោកខូលបានជួយបញ្ចុះបញ្ចូលប្រជាជាតិអឺរ៉ុបផ្សេងទៀតឱ្យទទួលយកការបង្រួបបង្រួមអាល្លឺម៉ង់ឡើងវិញ។ ប្រទេសអាឡឺម៉ង់ត្រូវបានបង្រួបបង្រួមជាផ្លូវការនៅថ្ងៃទី 3 ខែតុលា ឆ្នាំ 1990 ។

បញ្ហាប្រឈមរបស់អាល្លឺម៉ង់៖ អាល្លឺម៉ង់ដែលទើបរួបរួមថ្មីបានប្រឈមមុខនឹងបញ្ហាដ៏ធ្ងន់ធ្ងរ។ ជាង 40 ឆ្នាំនៃការគ្រប់គ្រងរបស់ពួកកុំម្មុយនីស្តបានធ្វើឱ្យប្រទេសអាល្លឺម៉ង់ភាគខាងកើតមានការបំផ្លិចបំផ្លាញ។ ផ្លូវដែក, ផ្លូវហាយវេ, និងប្រព័ន្ធទូរស័ព្ទ មិនត្រូវបានធ្វើទំនើបកម្មឡើយចាប់តាំងពីសង្គ្រាមលោកលើកទី 2 មក។ ឧស្សាហកម្មអាឡឺម៉ង់ខាងកើតផលិតទំនិញដែលមិនអាចប្រកួតប្រជែងក្នុងទីផ្សារពិភពលោកបាន។ ការកសាងសេដ្ឋកិច្ចដែលក្សយធនរបស់អាល្លឺម៉ង់ភាគខាងកើតឡើងវិញនឹងក្លាយជាដំណើរការដ៏លំបាកមួយ និងចំណាយប្រាក់ច្រើន។ ដើម្បីបង់ថ្លៃលើការចំណាយទាំងនេះ លោកខូលបានដំឡើងពន្ធ។ ខណៈដែលអ្នកបង់ពន្ធកំពុងជាមួយភាពលំបាកពួកគេ កម្មករនៅអាល្លឺម៉ង់ខាងកើតបានប្រឈមមុខនឹងបញ្ហាមួយទៀតគឺភាពអត់ការងារធ្វើ។ រោងចក្រដែលគ្មានប្រសិទ្ធភាពបានបិទដែលធ្វើឱ្យកម្មកររាប់លាននាក់បាត់បង់ការងារ។

ការតស៊ូផ្នែកសេដ្ឋកិច្ច៖ ក្នុងឆ្នាំ 1998 ក្រុមអ្នកបោះឆ្នោតបានដកលោកខូលចេញពីតំណែង ហើយបានជ្រើសរើសអធិការបតីថ្មីគឺលោកហ្គ័រហាដ ស្រូលឌ័រមកពីគណបក្សសង្គមនិយមប្រជាធិបតេយ្យ។ លោកស្រូលឌ័របានចាប់ផ្តើមក្នុងនាមជាអ្នកធ្វើកំណែទម្រង់ទីផ្សារ ប៉ុន្តែដោយសារតែកំណើនសេដ្ឋកិច្ចមានភាពយឺតយ៉ាវ បានធ្វើឱ្យកិច្ចការកំណែទម្រង់មានភាពលំបាក។ ទោះបីជាប្រទេសអាឡឺម៉ង់មានសេដ្ឋកិច្ចធំជាងគេទី 3 របស់ពិភពលោកក៏ដោយក៏ប្រទេសនេះបានធ្លាក់ចុះមកនៅលេខ 5 វិញនៅឆ្នាំ 2005 ។ អត្រាអ្នកអត់ការងារធ្វើរបស់អាល្លឺម៉ង់គឺស្ថិតក្នុងចំណោមប្រទេសដែលមានអត្រាខ្ពស់បំផុតនៅអឺរ៉ុប ហើយការកើនឡើងអតិផរណាក៏ជាបញ្ហាផងដែរ។ ទោះយ៉ាងណាក៏ដោយ ក្នុងឆ្នាំ 2006 មួយឆ្នាំបន្ទាប់ពីលោកស្រីអេនជេឡា ម័រគេលមកពីគណបក្សប្រជាធិបតេយ្យគ្រីស្តសាសនាត្រូវបានជ្រើសរើសជាអធិការបតីអាឡឺម៉ង់ អត្រាភាពអត់ការងារធ្វើបានធ្លាក់ចុះក្រោម 4 លាននាក់ ហើយឱនភាពថវិការបស់អាល្លឺម៉ង់ត្រូវបានរក្សាឱ្យនៅក្រោមការកំណត់របស់សហភាពអឺរ៉ុប។ ការបង្រួបបង្រួមក៏បានបង្ខំប្រទេសអាល្លឺម៉ង់ ដែលជាប្រទេសធំជាងគេនៅអឺរ៉ុបកណ្តាល គិតឡើងវិញនូវតួនាទីរបស់ខ្លួនក្នុងកិច្ចការអន្តរជាតិ។

### 3. លទ្ធិប្រជាធិបតេយ្យរីករាលដាលនៅឆេកូស្លូវ៉ាគី

ការផ្លាស់ប្តូរនៅក្នុងប្រទេសអាឡឺម៉ង់ខាងកើតបានប៉ះពាល់ដល់ប្រទេសអឺរ៉ុបផ្សេងទៀត ក្នុងនោះរួមមានទាំងប្រទេសឆេកូស្លូវ៉ាគី និងរូម៉ានី។

កំណែទម្រង់ប្រទេសឆេកូស្លូវ៉ាគី៖ ខណៈពេលដែលហ្វូងមនុស្សយ៉ាងច្រើនកំពុងទាមទារលទ្ធិប្រជាធិបតេយ្យនៅអាឡឺម៉ង់ខាងកើត ប្រទេសជិតខាងឆេកូស្លូវ៉ាគីនៅតែស្ងប់ស្ងាត់។ រដ្ឋាភិបាលអភិរក្សនិយមដឹកនាំដោយលោកមីឡូស ចាគេសបានទប់ទល់នឹងការធ្វើកំណែទម្រង់ទាំងឡាយ។ នៅឆ្នាំ 1989 ប៉ូលីសបានចាប់ខ្លួនក្រុមអ្នកប្រឆាំងជាច្រើន។ ក្នុងចំណោមអ្នកទាំងនោះមានអ្នកនិពន្ធជនជាតិឆេកមួយរូបឈ្មោះវ៉ាក្លាវ ហាវេលដែលជាអ្នករិះគន់រដ្ឋាភិបាលដ៏មានប្រជាប្រិយភាព។ នៅថ្ងៃទី 28 ខែតុលាឆ្នាំ 1989 មនុស្សប្រហែល 10.000 នាក់បានប្រមូលផ្តុំគ្នានៅទីលានវេនសេស្លាស់ដែលស្ថិតនៅកណ្តាលក្រុងប្រាក។ ពួកគេទាមទារឱ្យមានលទ្ធិប្រជាធិបតេយ្យ និងសេរីភាព។ ពួកគេរាប់រយនាក់ត្រូវបានចាប់ខ្លួន។ 3 សប្តាហ៍ក្រោយមក សិស្សប្រមាន 25,000 នាក់ដែលត្រូវបានបំផុសគំនិតដោយការដួលរលំនៃទីក្រុងប៊ែរឡាំង បានប្រមូលផ្តុំគ្នានៅទីក្រុងប្រាកដើម្បីទាមទារឱ្យមានការធ្វើកំណែទម្រង់។ ក្រោយការបញ្ជាពីរដ្ឋាភិបាល ប៉ូលិសបានវាយប្រហារលើហ្វូងបាតុករយ៉ាងព្រៃផ្សៃ ហើយមនុស្សរាប់រយនាក់បានរងរបួស។ ការបង្ក្រាបរបស់រដ្ឋាភិបាលបានធ្វើឱ្យប្រជាជនឆេកមានការខឹងសម្បា។ ហ្វូងមនុស្សជាច្រើនបានប្រមូលផ្តុំគ្នានៅទីលានវេនសេស្លាស់។ ពួកគេបានទាមទារឱ្យបញ្ចប់ការគ្រប់គ្រងរបស់កុំម្មុយនីស្ត។ នៅថ្ងៃទី 25 ខែវិច្ឆិកា ក្រុមបាតុករប្រមាណ 500,000 នាក់បានប្រមូលផ្តុំគ្នានៅកណ្តាលទីក្រុងប្រាក។ ក្នុងរយៈពេលប៉ុន្មានម៉ោង លោកមីឡូស ចាគេស និងការិយាល័យនយោបាយទាំងមូលរបស់គាត់បានលាលែងចេញពីតំណែង។ មួយខែក្រោយមក សភាថ្មីបានបោះឆ្នោតជ្រើសរើសលោកវ៉ាក្លាវ ហាវេល ធ្វើជាប្រធានាធិបតីនៃប្រទេសឆេកូស្លូវ៉ាគី។

ឆេកូស្លូវ៉ាគីបែកបាក់គ្នា៖ នៅប្រទេសឆេកូស្លូវ៉ាគី ក្រុមអ្នកធ្វើកំណែទម្រង់ក៏បានបើកដំណើរការកម្មវិធីសេដ្ឋកិច្ចដោយផ្អែកលើគោលនយោបាយ "ដំណោះស្រាយដ៏តក់ស្លុត"។ កម្មវិធីនេះបណ្តាលឱ្យមានការកើនឡើងយ៉ាងខ្លាំង

នូវអត្រាអ្នកអត់ការងារធ្វើ។ ជាពិសេសវាធ្វើឱ្យប៉ះពាល់ដល់ប្រទេសស្លូវ៉ាគី ដែលជាសាធារណរដ្ឋមួយគ្រប់គ្រងនៅឆេកូស្លូវ៉ាគីភាគខាងកើត។ ដោយការមិនអាចយល់ស្របលើគោលនយោបាយសេដ្ឋកិច្ច ផ្នែកខ្លះនៃប្រទេសទាំង 2 (ស្លូវ៉ាគី និងសាធារណរដ្ឋឆេក) បានបែកចេញដាច់ពីគ្នា។ បើទោះបីជាមានការអង្វរករពីសំណាក់ ប្រធានាធិបតីវ៉ាក្លាវ ហាវេល ឱ្យមានការរួបរួមគ្នាក៏ដោយ ចលនាដើម្បីបំបែកប្រទេសទទួលបានការគាំទ្រក្នុងចំណោមមហាជន។ លោកហាវេលបានលាលែងពីតំណែងដោយសារតែបញ្ហានេះ។ ឆេកូស្លូវ៉ាគីបានបំបែកជា 2 ប្រទេសនៅថ្ងៃទី 1 ខែមករា ឆ្នាំ 1993 ។ លោកហាវែលត្រូវបានជ្រើសរើសជាប្រធានាធិបតីនៃសាធារណរដ្ឋឆេក។ គាត់បានឈ្នះការបោះឆ្នោតឡើងវិញក្នុងឆ្នាំ 1998 ។ បន្ទាប់មកនៅឆ្នាំ 2003 លោកហាវេលបានលាលែងពីតំណែងជាប្រធានាធិបតី ដោយមួយផ្នែកដោយសារតែបញ្ហាសុខភាព។ សភាឆេកបានជ្រើសរើសលោកវ៉ាក្លាវ ក្លៅស ដែលជាសេដ្ឋវិទូស្ដាំនិយម និងជាអតីតនាយករដ្ឋមន្ត្រីដើម្បីស្នងតំណែងបន្តពីលោក។ សេដ្ឋកិច្ចនៃសាធារណរដ្ឋឆេកមានភាពប្រសើរឡើងជាលំដាប់ បញ្ហាធ្ងន់ធ្ងរមួយចំនួនត្រូវបានជួយតាមរយៈការក្លាយជាសមាជិកពេញលេញនៃសហភាពអឺរ៉ុបក្នុងឆ្នាំ 2004 ។ ស្លូវ៉ាគីក៏បានធ្វើដំណើរលើមាគ៌ាកំណែទម្រង់ ដែលគាំទ្រដល់លោកខាងលិចផងដែរ។ ពួកគេបានជួបប្រទះនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតមួយនៅក្នុងតំបន់ក្នុងឆ្នាំ 2002។ នៅឆ្នាំ 2004 ពួកគេបានជ្រើសរើសលោកអ៊ីវ៉ាន់ ហ្គាស្ពារ៉ូវិចធ្វើជាប្រធានាធិបតី និងបានចូលរួមទាំងនៅក្នុងអង្គការណាតូ និងសហភាពអឺរ៉ុប។

### 4. ការជួលរលំនៅប្រទេសរ៉ូម៉ានី

នៅចុងឆ្នាំ 1989 មានតែប្រទេសរ៉ូម៉ានីមួយតែប៉ុណ្ណោះដែលហាក់ដូចជាមិនមានចលនាក្នុងការស្នើឱ្យមានការធ្វើកំណែទម្រង់។ មេដឹកនាំផ្ដាច់ការកុំម្មុយនីស្ដដ៏ឃោរឃៅរបស់រូម៉ានីលោកនីកូឡៃ សូសេស្គូបានរក្សាការកាន់កាប់អំណាចយ៉ាងរឹងមាំ។ ប៉ូលីសសម្ងាត់របស់លោកបានអនុវត្តយ៉ាងឃោរឃៅតាមការបញ្ជារបស់លោក។ យ៉ាងណាក៏ដោយ ប្រជាជនរ៉ូម៉ានីបានដឹងអំពីការធ្វើកំណែទម្រង់ក្នុងប្រទេសផ្សេងៗទៀត។ ពួកគេបានចាប់ផ្ដើមបង្កើតចលនាតវ៉ាមួយដោយខ្លួនឯង។

ការបះបោរដ៏ពេញនិយមមួយ៖ នៅក្នុងខែធ្នូ លោកសូសេស្គូបានបញ្ជាឱ្យកងទ័ពបាញ់ទៅលើហ្វូងបាតុករនៅក្នុងទីក្រុងទីមីសារ៉ា។ ពួកកងទ័ពបានធ្វើមនុស្សស្លាប់ និងរងរបួសរាប់រយនាក់។ ការសម្លាប់រង្គាលនៅទីមីសារ៉ាបានបញ្ឆេះឱ្យមានការបះបោរដ៏ខ្លាំងក្លាប្រឆាំងជាមួយនឹងលោកសូសេស្គូ។ ក្នុងរយៈពេលប៉ុន្មានថ្ងៃ កងទ័ពបានចូលរួមជាមួយប្រជាជន។ ដោយមានការភ័យព្រួយពីការដួលរលំនៃអំណាចរបស់លោក លោកសូសេស្គូ និងប្រពន្ធរបស់គាត់បានព្យាយាមក្នុងការរត់គេចខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ពួកគេត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបានកាត់ទោសប្រហារជីវិតនៅថ្ងៃបុណ្យណូអែល ឆ្នាំ 1989 ។ ការបោះឆ្នោតត្រូវបានធ្វើឡើងជាទៀងទាត់ចាប់តាំងពីពេលនោះមក។ នៅឆ្នាំ 2004 លោកត្រៃអាន បាសេស្គូត្រូវបានជ្រើសរើសជាប្រធានាធិបតី។

សេដ្ឋកិច្ចរ៉ូម៉ានី៖ ពេញមួយទសវត្សរ៍ឆ្នាំ 1990 រូម៉ានីបានតស៊ូជាមួយនឹងអំពើពុករលួយ និងឧក្រិដ្ឋកម្មនានាខណៈដែលពួកគេកំពុងព្យាយាមជួយសង្គ្រោះសេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងឆ្នាំ 2001 ផលិតកម្មទាំងមូលនៅតែមានត្រឹមតែ 75% នៃអ្វីដែលពួកគេធ្លាប់មានក្នុងឆ្នាំ 1989 ដែលជាឆ្នាំនៃការដួលរលំរបស់លោកសូសេស្គូ។ នៅក្នុងឆ្នាំ

ដំបូងនៃសតវត្សរ៍ទី 21, 2/3 នៃសេដ្ឋកិច្ចបន្តស្ថិតនៅជាកម្មសិទ្ធិរបស់រដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ចដើម្បីនាំមកនូវទម្រង់សេដ្ឋកិច្ចបែបមូលធននិយម។ រដ្ឋាភិបាលក៏ចាប់ផ្ដើមកាត់បន្ថយប្រព័ន្ធការិយាធិបតេយ្យ ដើម្បីលើកទឹកចិត្តដល់អ្នកវិនិយោគបរទេស។ នៅឆ្នាំ 2007 រូម៉ានីបានចូលរួមជាមួយសហភាពអឺរ៉ុប ខណៈដែលរដ្ឋាភិបាលរ៉ូម៉ានីបានចាប់ផ្ដើមចាកចេញពីសេដ្ឋកិច្ចដែលគ្រប់គ្រងដោយរដ្ឋ។

## 5. ការបែកបាក់នៃយូហ្គោស្លាវី

ជម្លោះជាតិសាសន៍បានញាំញីប្រទេសយូហ្គោស្លាវី។ ប្រទេសដែលបានបង្កើតឡើងនៅក្រោយសង្គ្រាមលោកលើកទី 1 នេះ មានក្រុមជនជាតិភាគតិចចំនួន 8 ក្រុមក្នុងនោះរួមមានជនជាតិស៊ែប, ក្រូអាត, ម៉ូស្លីម, ស្លូវេនី, ម៉ាសេដូនៀ, អាល់បានី, ហុងគ្រី, និងម៉ុងតេណេក្រូ។ ភាពខុសគ្នានៃជាតិសាសន៍ និងសាសនាដែលមានអាយុកាលរាប់សតវត្សរ៍មកហើយនេះ បានធ្វើឱ្យក្រុមទាំងនេះសម្លឹងគ្នាទៅវិញទៅមកដោយការមិនទុកចិត្ត។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 ប្រទេសយូហ្គោស្លាវីបានក្លាយជាសហព័ន្ធនៃសាធារណរដ្ឋចំនួន 6 ។ សាធារណរដ្ឋនីមួយៗមានប្រជាជនចម្រុះ។

ការបែកបាក់ដ៏បង្ហូរឈាម៖ លោកចូស៊ីប ទីតូដែលបានដឹកនាំប្រទេសយូហ្គោស្លាវីចាប់ពីឆ្នាំ 1945 ដល់ឆ្នាំ 1980 បានកាន់កាប់ប្រទេសទាំងនោះដោយរួបរួមគ្នា។ បន្ទាប់ពីការស្លាប់របស់លោកទីតូ ការអាក់អន់ចិត្តរបស់ជនជាតិនានាបានផ្ទុះឡើង។ មេដឹកនាំស៊ែប៊ីលោកស្លូបូដាន មីឡូសេវិកបានអះអាងពីភាពជាអ្នកដឹកនាំលើប្រទេសយូហ្គោស្លាវី។ ជនជាតិស៊ែប៊ីជាច្រើនបានប្រឆាំងជាមួយនឹងលោកស្លូបូដាន និងគោលនយោបាយរបស់លោក ហើយបានរត់គៀសខ្លួនចេញពីប្រទេស។ សាធារណរដ្ឋចំនួន 2 គឺស្លូវេនី និងក្រូអាត បានប្រកាសឯករាជ្យ។ នៅខែមិថុនា ឆ្នាំ 1991 កងទ័ពយូហ្គោស្លាវីដែលដឹកនាំដោយស៊ែប៊ីបានឈ្លានពានសាធារណរដ្ឋទាំង 2 ។ បន្ទាប់ពីការប្រយុទ្ធគ្នាដ៏បង្ហូរឈាមជាច្រើនខែ សាធារណរដ្ឋទាំង 2 បានរំដោះខ្លួនចេញពីការគ្រប់គ្រងរបស់ស៊ែប៊ី។ នៅដើមឆ្នាំ 1992 បូស្នៀ-ហឺហ្សេហ្គោវីណាបានចូលរួមជាមួយស្លូវេនី និងក្រូអាតក្នុងការប្រកាសឯករាជ្យ។ ក្នុងខែមេសា ស៊ែប៊ី និងម៉ុងតេណេក្រូបានបង្កើតយូហ្គោស្លាវីថ្មី។ ចំនួនប្រជាជននៅបូស្នៀ រួមមានអ្នកកាន់សាសនាឥស្លាម (44 ភាគរយ), ស៊ែប៊ី (31 ភាគរយ), និងក្រូអាត (17 ភាគរយ)។ ខណៈពេលដែលពួកម៉ូស្លីម-បូស្នៀ និងពួកក្រូអាត-បូស្នៀគាំទ្រឯករាជ្យភាព ពួកស៊ែប៊ី-បូស្នៀបានប្រឆាំងយ៉ាងខ្លាំង។ គាំទ្រដោយប្រទេសស៊ែប៊ី ពួកស៊ែប៊ី-បូស្នៀបានចាប់ផ្ដើមសង្គ្រាមនៅខែមីនា ឆ្នាំ 1992។ នៅអំឡុងពេលសង្គ្រាម កងកម្លាំងយោធាស៊ែប៊ី-បូស្នៀបានប្រើអំពើហិង្សា និងបានបង្ខំឱ្យពួកម៉ូស្លីម-បូស្នៀធ្វើចំណាកស្រុកចេញពីដែនដីដែលកាន់កាប់ដោយពួកស៊ែប៊ី-បូស្នៀ។ ត្រូវបានហៅថាការបោសសម្អាតជនជាតិភាគតិច គោលនយោបាយនេះមានគោលបំណងកម្ចាត់ឱ្យអស់នូវពួកម៉ូស្លីមចេញពីបូស្នៀ។ នៅឆ្នាំ 1995 យោធាស៊ែប៊ី-បូស្នៀបានគ្រប់គ្រង 70 ភាគរយនៃបូស្នៀ។ នៅខែធ្នូនៃឆ្នាំនោះ មេដឹកនាំនៃក្រុមទាំង 3 ដែលជាប់ពាក់ព័ន្ធក្នុងសង្គ្រាម បានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពដែលសម្របសម្រួលដោយអង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិក។ នៅខែកញ្ញា ឆ្នាំ 1996 ប្រជាជននៅបូស្នៀបានបោះឆ្នោតជ្រើសរើស

ប្រធានាធិបតីចំនួន 3 រូប មេដឹកនាំម្នាក់មកពីក្រុមជនជាតិនីមួយៗ។ នៅឆ្នាំ 2001 បូស្នៀ និងហឺហ្សេហ្គោវីណា បានចាប់ឯករាជ្យដោយខ្លួនឯង ដោយមិនចាំបាច់មានការត្រួតពិនិត្យពីសហគមន៍អន្តរជាតិបន្តទៀតឡើយ។

ការបះបោរនៅកូសូវ៉ូ៖ តំបន់បាល់កង់បានធ្លាក់ចូលទៅក្នុងអំពើហិង្សា និងការបង្ហូរឈាមម្តងទៀតនៅក្នុងឆ្នាំ 1998 លើកនេះគឺស្ថិតនៅតំបន់កូសូវ៉ូ ដែលជាខេត្តមួយស្ថិតនៅប្រទេសស៊ែប៊ីភាគខាងត្បូង បង្កើតឡើងដោយជនជាតិអាល់បានីស្ទើរតែទាំងស្រុង។ នៅពេលដែលចលនាឯករាជ្យនៅកូសូវ៉ូកាន់តែមានអំពើហិង្សា កងកម្លាំងយោធាស៊ែប៊ីបានលុកលុយខេត្តនេះ។ ជាការឆ្លើយតបទៅនឹងរបាយការណ៍ស្តីអំពីការកើនឡើងនៃអំពើឃោរឃៅ និងការបរាជ័យផ្នែកការទូតដើម្បីនាំមកនូវសន្តិភាព ណាតូបានចាប់ផ្តើមយុទ្ធនាការទម្លាក់គ្រាប់បែកប្រឆាំងនឹងប្រទេសយូហ្គោស្លាវីនៅនិទាឃរដូវឆ្នាំ 1999។ បន្ទាប់ពីបានស៊ូទ្រាំនឹងការទម្លាក់គ្រាប់បែកជាបន្តបន្ទាប់អស់រយៈពេលជាង 2 ខែ ទីបំផុតមេដឹកនាំយូហ្គោស្លាវីបានដកកងទ័ពរបស់ពួកគេចេញពីកូសូវ៉ូ។ នៅឆ្នាំ 2007 ការពិភាក្សាអំពីឋានៈរបស់កូសូវ៉ូនៅតែបន្ត។

ការប្រឈមមុខនឹងបញ្ហានៅក្នុងតំបន់៖ នៅដើមសតវត្សរ៍ទី 21 មានសញ្ញាពីការខ្វែងគំនិតគ្នានៅយូហ្គោស្លាវី។ លោកស្លូបូដាន មីឡូសេវិកត្រូវបានគេធ្វើបត្យាប័នដើម្បីចូលខ្លួនកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែលោកបានស្លាប់នៅឆ្នាំ 2006 ខណៈពេលដែលការកាត់ក្តីកំពុងដំណើរការ។ មួយផ្នែកធំនៃបំណុលបរទេសរបស់ប្រទេសនេះត្រូវបានលុបចោល។ ទោះបីជាមានចលនាទាមទារឯករាជ្យមួយនៅកូសូវ៉ូក៏ដោយ ការបោះឆ្នោតសភាក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ត្រូវបានធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ 2001 ដោយគ្មានអំពើហិង្សា។ នៅប្រទេសម៉ុងតេណេហ្គ្រូ (ដែលរួមគ្នាជាមួយស៊ែប៊ីបង្កើតជាប្រទេសយូហ្គោស្លាវី) ការធ្វើប្រជាមតិអំពីឯករាជ្យភាពនៅខែឧសភា ឆ្នាំ 2006 បានបង្ហាញថាអ្នកបោះឆ្នោតភាគច្រើនចង់បំបែកខ្លួនចេញពីស៊ែប៊ី។ នៅពេលដែលពួកម៉ុងតេណេហ្គ្រូបានប្រកាសឯករាជ្យនៅឆ្នាំ 2006 ស៊ែប៊ីបានទទួលយកស្ថានភាពថ្មីដោយសន្តិវិធី។ ក្នុងឆ្នាំ 2007 ប្រទេសស៊ែប៊ីបានរៀបចំការបោះឆ្នោតសភាមួយ ដោយគណបក្សជាតិនិយមជ្រុលទទួលបានគាំទ្រមួយចំនួន ប៉ុន្តែមិនអាចទទួលបានអាសនៈគ្រប់គ្រាន់ដើម្បីបង្កើតរដ្ឋាភិបាលថ្មីឡើយ។ ប្រជាជាតិនៃអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើតបានទទួលផលច្រើននៅដើមសតវត្សរ៍ទី 21 ។ ទោះយ៉ាងនេះក្តី ពួកគេនៅតែបន្តប្រឈមមុខជាមួយនឹងឧបសគ្គធ្ងន់ធ្ងរចំពោះលទ្ធិប្រជាធិបតេយ្យ។ ការដោះស្រាយជម្លោះជនជាតិភាគតិចនៅតែមានសារៈសំខាន់ដូចគ្នាទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ចផងដែរ។ ប្រសិនបើប្រជាជាតិនៃអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត និងអតីតសហភាពសូវៀតអាចកែលម្អកម្រិតជីវភាពរបស់ពួកគេ លទ្ធិប្រជាធិបតេយ្យអាចមានឱកាសកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ កំណែទម្រង់សេដ្ឋកិច្ចនៅក្នុងប្រទេសចិនកុំមុយនីស្តបានជំរុញឱ្យមានការទាមទារឱ្យមានការធ្វើកំណែទម្រង់នយោបាយ ដូចដែលអ្នកនឹងអាននៅមេរៀនបន្ទាប់។

# មេរៀនទី 5៖ ប្រទេសចិន, កំណែទម្រង់ និងប្រតិកម្ម

## 1. តើវិជំណែលរបស់ម៉ៅ

បន្ទាប់ពីពួកកុំម្មុយនីស្តបានឡើងកាន់អំណាចក្នុងប្រទេសចិននៅឆ្នាំ 1949 ម៉ៅ សេទុង បានកំណត់ក្នុងការផ្លាស់ប្តូរប្រទេសចិន។ លោកម៉ៅជឿថាសមភាពកសិករ, ស្មារតីបដិវត្ត, និងការខិតខំធ្វើការងារគឺសុទ្ធតែជាតម្រូវការចាំបាច់ដើម្បីកែលម្អសេដ្ឋកិច្ចចិន។ ទោះជាយ៉ាងណាក៏ដោយ កង្វះបច្ចេកវិទ្យាទំនើបបានរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់ចិនក្នុងការបង្កើនទិន្នផលកសិកម្ម និងឧស្សាហកម្ម។ លើសពីនេះ គោលនយោបាយរបស់លោកម៉ៅបានរារាំងដល់កំណើនសេដ្ឋកិច្ច។ លោកបានលុបបំបាត់ការជម្រុញឱ្យមានផលិតកម្មខ្ពស់។ លោកបានព្យាយាមជំនួសជីវិតរស់នៅជាលក្ខណៈគ្រួសារទៅជាលក្ខណៈសហករណ៍។ គោលនយោបាយទាំងនេះបានបញ្ឈប់គំនិតរបស់កសិករក្នុងការធ្វើការដើម្បីផលប្រយោជន៍ខ្លួនឯង និងគ្រួសារ។ ប្រឈមមុខនឹងគ្រោះមហន្តរាយសេដ្ឋកិច្ច ជនកុំម្មុយនីស្តចិនខ្លះបានពិភាក្សាអំពីការធ្វើទំនើបកម្មសេដ្ឋកិច្ច។ ដោយចោទប្រកាន់ពួកគេថា "ដើរតាមផ្លូវរបស់ពួកមូលធននិយម" ម៉ៅបានចាប់ផ្តើមបដិវត្តវប្បធម៌នៅឆ្នាំ 1966 ដើម្បីបោសសម្អាតឥទ្ធិពលប្រឆាំងបដិវត្តចេញពីប្រទេសចិន។ ទោះជាយ៉ាងណាក៏ដោយ ជំនួសឱ្យការរក្សាការពារលទ្ធិកុំម្មុយនីស្តជ្រុលនិយម បដិវត្តវប្បធម៌បានប្រែក្លាយមនុស្សជាច្រើនឱ្យប្រឆាំងនឹងវា។ នៅដើមទសវត្សរ៍ឆ្នាំ 1970 ប្រទេសចិនបានឈានចូលដំណាក់កាលកណ្តាលនិយមមួយដែលស្ថិតនៅក្រោមការដឹកនាំរបស់ជូ អេនឡាយ។ លោកជូ បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីតាំងពីឆ្នាំ 1949 មកម្លេះ។ នៅអំឡុងបដិវត្តវប្បធម៌ គាត់បានព្យាយាមទប់ស្កាត់ភាពជ្រុលនិយម។

## 2. ប្រទេសចិន និងលោកខាងលិច

នៅអំឡុងបដិវត្តវប្បធម៌ ប្រទេសចិនស្ទើរតែគ្មានតួនាទីនៅក្នុងកិច្ចការពិភពលោក។ នៅដើមទស្សវត្សរ៍ឆ្នាំ 1960 ប្រទេសចិនបានបែកបាក់ជាមួយសហភាពសូវៀតជុំវិញបញ្ហានៃការដឹកនាំកុំម្មុយនីស្តពិភពលោក។ លើសពីនេះ ចិនបានបង្ហាញអរិភាពចំពោះសហរដ្ឋអាមេរិក ដោយសារតែអាមេរិកគាំទ្ររដ្ឋាភិបាលលើកោះតៃវ៉ាន់។

ប្រទេសចិនបើកទ្វាររបស់ពួកគេ៖ លោកជូមានការព្រួយបារម្ភចំពោះភាពឯកោរបស់ចិន។ លោកបានចាប់ផ្តើមបង្ហាញសញ្ញាណថា លោកមានឆន្ទៈក្នុងការបង្កើតទំនាក់ទំនងជាមួយលោកខាងលិច។ នៅឆ្នាំ 1971 លោកជូបានធ្វើឱ្យពិភពលោកភ្ញាក់ផ្អើល តាមរយៈការអញ្ជើញក្រុមវាយកូនឃ្លីលើតុរបស់អាមេរិកឱ្យទៅទស្សនាប្រទេសចិន។ វាជាដំណើរទស្សនកិច្ចលើកដំបូងដោយក្រុមអាមេរិកទៅកាន់ប្រទេសចិនចាប់តាំងពីឆ្នាំ 1949 មក។ ដំណើរទស្សនកិច្ចនេះបានចាប់ផ្តើមសករាជថ្មីនៅក្នុងទំនាក់ទំនងចិន-អាមេរិក។ នៅឆ្នាំ 1971 សហរដ្ឋអាមេរិកបានផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន និងបានយល់ព្រមចំពោះសមាជិកភាពរបស់សាធារណៈរដ្ឋប្រជាមានិតចិននៅអង្គការសហប្រជាជាតិ។ នៅឆ្នាំបន្ទាប់ លោកប្រធានាធិបតីនិចសុនបានធ្វើទស្សនកិច្ចផ្លូវរដ្ឋទៅកាន់ប្រទេសចិន។ លោកបានជួបជាមួយលោកម៉ៅ និងលោកជូ។ មេដឹកនាំទាំង 3 បានព្រមព្រៀងគ្នាដើម្បីចាប់ផ្តើមការផ្លាស់ប្តូរវប្បធម៌ និងពាណិជ្ជកម្ម។ នៅឆ្នាំ 1979 សហរដ្ឋអាមេរិក និងចិនបានបង្កើតទំនាក់ទំនងការទូតជាមួយគ្នា។

កំណែទម្រង់សេដ្ឋកិច្ច៖ ទាំងលោកម៉ៅ និងលោកជូបានស្លាប់នៅឆ្នាំ 1976។ បន្តិចក្រោយមក អ្នកកណ្តាលនិយមបានកាន់កាប់បក្សកុំម្មុយនីស្ត។ ពួកគេបានចាប់ឃុំខ្លួនពួកជ្រុលនិយមមួយចំនួនដែលបានដឹកនាំបដិវត្តវប្បធម៌។ នៅឆ្នាំ 1980 តេង ស៊ាវពីង បានលេចឡើងជាមេដឹកនាំដ៏មានឥទ្ធិពលបំផុតនៅក្នុងប្រទេសចិន។ លោកគឺមនុស្សម្នាក់ចុងក្រោយក្នុងចំណោមជនបដិវត្តចាស់ដែលបានគ្រប់គ្រងប្រទេសចិនចាប់តាំងពីឆ្នាំ 1949 ។ ទោះបីជាលោកជាជនកុំម្មុយនីស្តស្ទើរពេញមួយជីវិតក៏ដោយ លោកតេងបានគាំទ្រនូវគោលនយោបាយសេដ្ឋកិច្ចបែបកណ្តាលនីយម។ ខុសពីលោកម៉ៅ លោកសុខចិត្តប្រើគំនិតមូលធននិយម ដើម្បីជួយដល់សេដ្ឋកិច្ចចិន។ លោកបានទទួលយកនូវគោលដៅមួយ ដែលគេស្គាល់ថាជា ទំនើបភាវូបនីយកម្មទាំងបួន។ ទំនើបភាវូបនីយកម្មទាំងនេះបានស្នើឱ្យមានការអភិវឌ្ឍក្នុងវិស័យកសិកម្ម, វិស័យឧស្សាហកម្ម, វិស័យការពារជាតិ, និងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ លោកតេងបានចាប់ផ្តើមកម្មវិធីកំណែទម្រង់សេដ្ឋកិច្ចប្រកបដោយមហិច្ឆតា។ ទីមួយ តេងបានលុបបំបាត់សហករណ៍របស់លោកម៉ៅ និងជួលដីទាំងនោះឱ្យកសិករម្នាក់ៗ។ កសិករបានបង់ថ្លៃជួលដីតាមរយៈការផ្តល់ទិន្នផលមួយភាគដល់រដ្ឋាភិបាល។ នៅពេលនោះពួកគេអាចដាំដំណាំនានាដើម្បីលក់យកប្រាក់ចំណេញ។ នៅក្រោមប្រព័ន្ធនេះ ផលិតកម្មស្បៀងបានកើនឡើង 50% ចន្លោះពីឆ្នាំ 1978 ដល់ឆ្នាំ 1984 ។ លោកតេងបានពង្រីកកម្មវិធីរបស់គាត់ទៅដល់ឧស្សាហកម្ម។ រដ្ឋាភិបាលបានអនុញ្ញាតឱ្យអាជីវករឯកជនធ្វើអាជីវកម្ម។ វាផ្តល់ឱ្យអ្នកគ្រប់គ្រងរោងចក្រឧស្សាហកម្មរបស់រដ្ឋមានសេរីភាពបន្ថែមទៀតក្នុងការកំណត់គោលដៅអំពីផលិតកម្ម។ លោកតេងក៏បានស្វាគមន៍ចំពោះបច្ចេកវិទ្យា និងការវិនិយោគពីបរទេសផងដែរ។ គោលនយោបាយសេដ្ឋកិច្ចរបស់លោកតេង បានបណ្តាលឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នូវជីវភាពរបស់ជនជាតិចិន។ នៅពេលដែលប្រាក់ចំណូលកើនឡើងមនុស្សចាប់ផ្តើមទិញឧបករណ៍ប្រើប្រាស់ និងទូរទស្សន៍។ យុវជនចិនឥឡូវស្លៀកសម្លៀកបំពាក់ទាន់សម័យ ហើយស្តាប់តន្ត្រីបស្ចិមប្រទេស។ សណ្ឋាគារដ៏ស្រស់ស្អាតពោរពេញទៅដោយភ្ញៀវទេសចរបរទេសជានិមិត្តរូបនៃគោលនយោបាយបើកចំហថ្មីរបស់ប្រទេសចិន។

### 3. ការសម្លាប់រង្គាលនៅទីលានធានអានមេន

កំណែទម្រង់សេដ្ឋកិច្ចរបស់លោកតេង បានបង្កើតបញ្ហាជាច្រើនដែលមិននឹកស្មានដល់។ នៅពេលដែលជីវភាពរស់នៅមានភាពប្រសើរឡើង គម្លាតរវាងអ្នកមាននិងអ្នកក្រកាន់តែរីកឡើង។ អ្វីដែលជាបញ្ហានោះគឺ មហាជនជាច្រើនជឿថា មន្ត្រីបក្សកុំម្មុយនីស្តទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីមុខតំណែង។ លើសពីនេះ គោលនយោបាយថ្មីបានទទួលមិនត្រឹមតែការវិនិយោគរបស់បស្ចិមប្រទេស និងអ្នកទេសចរប៉ុណ្ណោះទេ ប៉ុន្តែក៏មានទទួលគំនិតនយោបាយរបស់លោកខាងលិចផងដែរ។ ការកើនឡើងចំនួននិស្សិតចិនបានសិក្សានៅបរទេស និងស្វែងយល់អំពីលោកខាងលិច។ តាមទស្សនៈរបស់លោកតេង អត្ថប្រយោជន៍នៃការបើកសេដ្ឋកិច្ចលើសពីហានិភ័យទាំងនេះ។ យ៉ាងណាក៏ដោយ ខណៈនិស្សិតចិនបានរៀនកាន់តែច្រើនអំពីលទ្ធិប្រជាធិបតេយ្យ ពួកគេចាប់ផ្តើមចោទសួរពីកង្វះសេរីភាពនយោបាយរបស់ចិន។

និស្សិតទាមទារលទ្ធិប្រជាធិបតេយ្យ៖ នៅឆ្នាំ 1989 និស្សិតបានបង្កឱ្យមានការបះបោរដ៏មានប្រជាប្រិយមួយដែលធ្វើឱ្យមេដឹកនាំរបស់ប្រទេសចិនភ្ញាក់ផ្អើល។ ចាប់ពីខែមេសាឆ្នាំនោះ មានសិស្សជាង 10 ម៉ឺននាក់បានបានកាន់កាប់ទីលានធានអានមេន ដែលជាកន្លែងសាធារណៈដ៏ធំនៅចំកណ្ដាលទីក្រុងប៉េកាំង។ និស្សិតបានធ្វើបាតុកម្មទាមទារលទ្ធិប្រជាធិបតេយ្យ។ ការតវ៉ារបស់និស្សិតទទួលបានការគាំទ្រយ៉ាងទូលំទូលាយ។ នៅពេលដែលសិស្សរាប់ពាន់នាក់បានចាប់ផ្ដើមធ្វើកូដកម្មអត់អាហារដើម្បីបញ្ជាក់ពីបុព្វហេតុរបស់ពួកគេ ប្រជាជនបានចូលទៅក្នុងទីលានធានអានមេន ដើម្បីគាំទ្រពួកគេ។ និស្សិតជាច្រើនបានអំពាវនាវឱ្យតេង ស៊ាវពីងលាលែងចេញពីតំណែង។

លោកតេងបញ្ជាឱ្យបង្ក្រាប៖ ជាជាងពិចារណាលើការធ្វើកំណែទម្រង់នយោបាយ លោកតេងបានប្រកាសច្បាប់អាជ្ញាសឹក។ លោកបានបញ្ជាឱ្យទាហានប្រហែល 10 ម៉ឺននាក់ឡោមព័ទ្ធទីក្រុងប៉េកាំង។ ទោះបីជាសិស្សភាគច្រើននាក់បានចាកចេញពីទីលានបន្ទាប់ពីច្បាប់អាជ្ញាសឹកត្រូវបានប្រកាសក៏ដោយ ក៏មាននិស្សិតប្រហែល 5,000 នាក់បានជ្រើសរើសបន្តស្ថិតនៅ និងបន្តការតវ៉ារបស់ពួកគេ។ និស្សិតបានធ្វើឱ្យស្មារតីរបស់ពួកគេរស់ឡើងវិញតាមរយៈការសាងសង់រូបសំណាកកម្ពស់ 33 ហ្វីតដែលពួកគេបានដាក់ឈ្មោះថា "ព្រះនៃលទ្ធិប្រជាធិបតេយ្យ"។ នៅថ្ងៃទី 4 ខែមិថុនា ឆ្នាំ 1989 ការប្រឈមមុខដាក់គ្នាបានបញ្ចប់។ ទាហានប្រដាប់អាវុធរាប់ពាន់នាក់បានសម្រុកចូលទីលានធានអានមេន។ រថក្រោះបានវាយបំបែករបាំងការពារព្រះនៃលទ្ធិប្រជាធិបតេយ្យ។ ទាហានបានបាញ់កាំភ្លើងសំដៅទៅកាន់ហ្វូងនិស្សិតដែលកំពុងភ័យខ្លាច។ ពួកគេក៏បានវាយប្រហារលើហ្វូងបាតុករនៅទីកន្លែងផ្សេងៗទៀតក្នុងទីក្រុងប៉េកាំងផងដែរ។ ការវាយប្រហារនេះបានសម្លាប់មនុស្សរាប់រយនាក់ និងរាប់ពាន់នាក់ទៀតរងរបួស។ ការវាយប្រហារលើទីលាននិស្សិតនៅធានអានមេន គឺជាការចាប់ផ្ដើមយុទ្ធនាការដ៏ធំមួយរបស់រដ្ឋាភិបាលដើម្បីបញ្ឈប់ការតវ៉ា។ ប៉ូលីសបានចាប់ខ្លួនមនុស្សរាប់ពាន់នាក់។ រដ្ឋាភិបាលចិនបានប្រើប្រព័ន្ធផ្សព្វផ្សាយដើម្បីប្រកាសថារបាយការណ៍នៃការសម្លាប់រង្គាលនានាមានលក្ខណៈមិនត្រឹមត្រូវ។ ពួកមន្ត្រីបានអះអាងថា ឧក្រិដ្ឋជនមួយក្រុមតូចបានរៀបចំផែនការប្រឆាំងនឹងរដ្ឋាភិបាល។ យ៉ាងណាមិញ ទូរទស្សន៍បានផ្សាយការពិតដល់ពិភពលោករួចហើយ។

### 4. ប្រទេសចិនឈានចូលសហស្សវត្សរ៍ថ្មី

ការគាបសង្កត់យ៉ាងឃោរឃៅលើចលនាលទ្ធិប្រជាធិបតេយ្យ បាននាំលោកតេងឱ្យក្លាយជាអ្នកដឹកនាំដ៏មានអំណាចមួយរូបនៅក្នុងប្រទេសចិន។ នៅអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនៃជីវិតរបស់លោក លោកតេងបានបន្តកម្មវិធីកំណែទម្រង់សេដ្ឋកិច្ចរបស់លោក។ ទោះបីជាលោកតេងបានដកខ្លួនចេញពីអំណាចនៅក្នុងឆ្នាំ 1995 ក៏ដោយ ក៏លោកនៅតែជាមេដឹកនាំរបស់ប្រទេសចិន។ នៅខែកុម្ភៈ ឆ្នាំ 1997 បន្ទាប់ពីរស់នៅជាមួយជំងឺដ៏យូរអង្វែងមក លោកតេងបានទទួលមរណភាព។ អគ្គលេខាធិការបក្សកុំម្មុយនីស្ត លោកជាង ហ្ស៊ឺមីនបានចូលកាន់តំណែងជាប្រធានាធិបតី។

ប្រទេសចិនក្រោមការដឹកនាំរបស់ជាង៖ សំណួរជាច្រើនបានកើតឡើងបន្ទាប់ពីការស្លាប់របស់លោកតេង។ តើលោកជាងនឹងក្លាយជាអ្នកដឹកនាំបែបណា? តើគាត់អាចកាន់អំណាច និងធានាស្ថិរភាពនយោបាយបានទេ? ជាបុរសដែលមានភាពឆ្លាតវៃ និងមានការអប់រំខ្ពស់ លោកជាងបានធ្វើជាអភិបាលក្រុងសៀងហៃ។ លោកត្រូវបានគេ

ចាត់ទុកថាជាមនុស្សដែលមានជំនាញ, បត់បែន, និងអនុវត្តជាក់ស្តែង។ ទោះយ៉ាងណាក៏ដោយ លោកមិនមានបទពិសោធន៍យោធាទេ។ ដូច្នេះហើយ លោកជាងមានសម្ព័ន្ធមិត្តតិចតួចក្នុងចំណោមពួកមេទ័ព។ លោកក៏បានប្រឈមមុខជាមួយនឹងបញ្ហាពីសំណាក់គូប្រជែងនានា ដោយក្នុងនោះរួមមានទាំងមន្រ្តីដែលមានជួរមុខ ដែលចាប់អារម្មណ៍ជាមួយការធ្វើកំណែទម្រង់ហួសឆ្ងាយពីគោលនយោបាយសេដ្ឋកិច្ចរបស់លោកតេង។ សំណួរផ្សេងទៀតបន្ទាប់ពីការស្លាប់របស់លោកតេងគឺទាក់ទងនឹងកំណត់ត្រាសិទ្ធិមនុស្សមិនល្អរបស់ចិន, ការកាន់កាប់ទីបេ, និងទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1990 សហរដ្ឋអាមេរិកបានដាក់សម្ពាធលើប្រទេសចិនឱ្យដោះលែងអ្នកទោសនយោបាយ និងធានាសិទ្ធិជាមូលដ្ឋានសម្រាប់គូប្រជែងនយោបាយ។ ប្រទេសចិននៅតែប្រឆាំងជាមួយសម្ពាធទាំងអស់នេះ។ រដ្ឋាភិបាលបានបន្តគាបសង្កត់ចលនាប្រជាធិបតេយ្យ។ យ៉ាងណាក៏ដោយការចង់បានសេរីភាពនៅតែកើតមានឡើងពេញសង្គមចិន។ ប្រសិនបើចិននៅតែបើកចំហសេដ្ឋកិច្ច ប៉ុន្តែអនុវត្តនយោបាយបិទនោះ ភាពតានតឹងហាក់ដូចជានឹងនៅតែបន្ត។ នៅចុងឆ្នាំ 1997 លោកជាងបានធ្វើទស្សនកិច្ចផ្លូវរដ្ឋមួយទៅកាន់សហរដ្ឋអាមេរិក។ ក្នុងដំណើរទស្សនកិច្ចរបស់លោក បាតុករអាមេរិកបានទាមទារឱ្យមានលទ្ធិប្រជាធិបតេយ្យបន្ថែមទៀតក្នុងប្រទេសចិន។ លោកជាងបានសារភាពថា ប្រទេសចិនបានធ្វើកំហុសមួយចំនួន ប៉ុន្តែបានបដិសេធមិនសន្យាថាគោលនយោបាយរបស់ប្រទេសចិននឹងត្រូវផ្លាស់ប្តូរឡើយ។ ប្រធានាធិបតីជាង ហ្ស៊ឺមីន និងនាយករដ្ឋមន្រ្តីជូ យ៉ុងជីបានប្រកាសចូលនិវត្តន៍នៅចុងឆ្នាំ 2002 ។ អ្នកស្នងតំណែងរបស់ លោកជាងគឺលោកហ៊ូ ជិនតាវ។ ទោះជាយ៉ាងណាក៏ដោយ លោកជាងត្រូវបានគេរំពឹងថានឹងមានឥទ្ធិពលលើអ្នកស្នងតំណែងរបស់គាត់នៅពីក្រោយឆាក។ លោកហ៊ូបានក្លាយជាប្រធានាធិបតីរបស់ប្រទេសចិន និងជាអគ្គលេខាបក្សកុំម្មុយនីស្ត។ លោកជាងនៅតែជាមេដឹកនាំនយោបាយរបស់យោធា។ អ្នកទាំង 2 រូបបានគាំទ្រការផ្លាស់ប្តូររបស់ចិនទៅកាន់សេដ្ឋកិច្ចទីផ្សារសេរី។

ការផ្ទេរដែនដីហុងកុង៖ បញ្ហាសំខាន់មួយទៀតសម្រាប់ប្រទេសចិនគឺស្ថានភាពរបស់ហុងកុង។ ហុងកុងជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏រីកចម្រើនមួយ និងជាដែនដីអាណានិគមរបស់អង់គ្លេសដែលស្ថិតនៅឆ្នេរភាគអាគ្នេយ៍នៃប្រទេសចិន។ នៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1997 ចក្រភពអង់គ្លេសបានប្រគល់ដែនដីហុងកុងទៅឱ្យប្រទេសចិនវិញ ដោយបានបញ្ចប់ការគ្រប់គ្រងអាណានិគមរបស់ពួកគេលើដែនដីនេះរយៈពេល 155 ឆ្នាំ។ ជាផ្នែកមួយនៃការផ្ទេរនេះ ប្រទេសចិនបានសន្យាថានឹងគោរពប្រព័ន្ធសេដ្ឋកិច្ច និងសេរីភាពនយោបាយរបស់ហុងកុងសម្រាប់រយៈពេល 50 ឆ្នាំ។ ពលរដ្ឋហុងកុងជាច្រើនបារម្ភពីការគ្រប់គ្រងរបស់ចិន និងខ្លាចបាត់បង់សេរីភាពរបស់ពួកគេ។ យ៉ាងណាក៏ដោយ អ្នកខ្លះទៀតបានមើលឃើញថាការផ្ទេរនេះជាវិធីមួយក្នុងការភ្ជាប់មរតកចិនរបស់ពួកគេឡើងវិញ។ ក្នុងរយៈពេល 4 ឬ 5 ឆ្នាំដំបូងបន្ទាប់ពីការផ្ទេរ ការគ្រប់គ្រងរបស់ចិនដ៏គោកលើទីក្រុងហុងកុងត្រូវបានរឹតបន្តឹង។

**5. ប្រទេសចិនក្រោយឆ្នាំ 2000**

ករណីរបស់ប្រទេសចិនបង្ហាញថា ការបង្កើតលទ្ធិប្រជាធិបតេយ្យអាចជាដំណើរការយឺតមួយ, មិនជាប់លាប់, និងមិនពេញលេញ។ ការធ្វើកំណែទម្រង់បែបសេរីនិយមនៅក្នុងវិស័យមួយដូចជាសេដ្ឋកិច្ចជាដើម ប្រហែលជាមិនអាចនាំប្រទេសចិនឆ្ពោះទៅរកការធ្វើកំណែទម្រង់នយោបាយភ្លាមៗបាននោះឡើយ។

សេដ្ឋកិច្ច និងនយោបាយ៖ នៅក្នុងប្រទេសចិនភាពក្រីក្រមានការថយចុះយ៉ាងខ្លាំង។ ក្រុមអ្នកជំនាញខ្លះអះអាងថា ប្រទេសចិនអាចធ្វើកំណែទម្រង់សេដ្ឋកិច្ច និងអាចកាត់បន្ថយភាពក្រីក្របានគឺដោយសារតែពួកគេបានអនុវត្តវិធីសាស្ត្រក្នុងការលក់រោងចក្រឧស្សាហកម្មរបស់រដ្ឋ និងការធ្វើឯកជនភាវូបនីយកម្មសេដ្ឋកិច្ចបន្តិចម្តងៗជាជាងប្រើប្រាស់វិធីសាស្ត្រលឿនជាងនេះ។ យុទ្ធសាស្ត្ររបស់ប្រទេសចិនទទួលបានជោគជ័យ៖ នៅឆ្នាំ 2007 ប្រទេសនេះមានសេដ្ឋកិច្ចធំជាងគេលំដាប់ទី 4 របស់ពិភពលោក បន្ទាប់ពីសហរដ្ឋអាមេរិក, ជប៉ុន, និងអាល្លឺម៉ង់។ ទំនិញប្រើប្រាស់ថោកៗពីប្រទេសចិនកំពុងដាក់លក់នៅតាមហាង និងផ្សារទំនើបនានានៅទូទាំងពិភពលោក។ ប៉ុន្តែកម្លាំងសេដ្ឋកិច្ចរបស់ប្រទេសចិនបានមកជាមួយនឹងការចំណាយ។ គម្លាតទ្រព្យសម្បត្តិរវាងអ្នកទីក្រុង និងជនបទត្រូវបានពង្រីកដោយសារវិសមភាព ដែលនាំឱ្យមានភាពចលាចលក្នុងសង្គម។ លើសពីនេះ ឧស្សាហូបនីយកម្មយ៉ាងឆាប់រហ័សបានបង្កឱ្យមានការបំពុល និងបញ្ហាបរិស្ថានធ្ងន់ធ្ងរ។ ដោយសារប្រទេសនានាមានទំនាក់ទំនងកាន់តែខ្លាំងឡើងតាមរយៈបច្ចេកវិទ្យា និងពាណិជ្ជកម្ម ពួកគេនឹងមានឱកាសកាន់តែច្រើនដើម្បីមានឥទ្ធិពលលើគ្នាទៅវិញទៅមកផ្នែកខាងនយោបាយ។ នៅពេលដែលសភាសហរដ្ឋអាមេរិកបានបោះឆ្នោតដើម្បីធ្វើឱ្យវិស័យពាណិជ្ជកម្មរបស់មានភាពប្រក្រតីជាមួយប្រទេសចិន អ្នកគាំទ្រការផ្លាស់ប្តូរបែបនេះបានអះអាងថា មធ្យោបាយដ៏ល្អបំផុតដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរនយោបាយនៅក្នុងប្រទេសចិនគឺ តាមរយៈការចូលរួមកាន់តែច្រើនជាមួយប្រទេសចិនជាជាងទុកប្រទេសនេះឱ្យនៅឯកោ។ សញ្ញាណមួយទៀតនៃការបង្កើនការចូលរួមរបស់ប្រទេសចិនជាមួយពិភពលោក គឺយុទ្ធនាការដ៏ជោគជ័យរបស់ខ្លួនក្នុងការធ្វើជាម្ចាស់ផ្ទះកីឡាអូឡាំពិករដូវក្តៅឆ្នាំ 2008 នៅទីក្រុងប៉េកាំង។

# ឯកសារពិគ្រោះ

1. Douglas Carnine, Carlos Cortés, Kenneth Curtis, & Anita Robinson. (2009). *World History: Ancient Through Early Modern Times*. McDougal Littell, USA.

2. Roger B. Beck, Linda Black, Larry S. Krieger, Phillip C. Naylor, & Dahia Ibo Shabaka. (2009). *World History: Patterns of Interaction.* McDougal Littell, USA.

3. B. V. Rao. (2006). *World History: From Early Times to AD 2000*. 3rd edition, New Dawn Press, New Delhi, India.

4. *Charles Keith Maisels. (1999). EARLY CIVILIZATIONS OF THE OLD WORLD: The formative histories of Egypt, the Levant, Mesopotamia, India and China*. Routledge, NY, USA.

5. Merry E.Wiesner-Hanks. (2015). *A CONCISE HISTORY OF THE WORLD*. University Printing House, Cambridge, United Kingdom.

6. Howard Spodek. (2015). *The World's History*. Fifth Edition, Laurence King Publishing, Pearson Education, New Jersey.